# ការជំនុំជម្រះ

## ចាប់ផ្តើមពីដំណាក់របស់ព្រះជាម្ចាស់



ព្រះបន្ទូល

ព្រះបន្ទូល

កម្មសិទ្ធិ © ២០២២ ពួកជំនុំនៃព្រះដ៏មានគ្រប់ព្រះចេស្ដា

រក្សាសិទ្ធិគ្រប់យ៉ាង។
គ្មានផ្នែកទាំងមូល ឬផ្នែកណាមួយនៃសៀវភៅនេះត្រូវបាន
ផលិតឡើងវិញ ឬត្រូវបានប្រើប្រាស់ទោះតាមមធ្យោបាយណាមួយដោយ
គ្មានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិឡើយ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងអាសយដ្ឋាន៖
contact.km@kingdomsalvation.org

ខ្លឹមសារសៀវភៅនេះត្រូវបានប្រែសម្រួលទាំងស្រុងដោយអ្នកបកប្រែអាជីព។ យ៉ាងណាមិញ ដោយសារតែភាពខុសគ្នាផ្នែកភាសា និងកត្តាដទៃទៀត អសុក្រិតភាពមួយចំនួនគឺនៅតែមាន ចៀសមិនផុតឡើយ។ ប្រសិនបើអ្នករកឃើញអសុក្រិតភាពណាមួយ សូមយោងអត្ថបទដើម ជាភាសាចិន។ សូមកុំស្ទាក់ស្ទើរនឹងទំនាក់ទំនងយើងខ្ញុំ ដើម្បីឲ្យយើងខ្ញុំអាចធ្វើបច្ចុប្បន្នភាពសៀវភៅនេះនៅពេលបោះពុម្ពផ្សាយឡើងវិញ។

បោះពុម្ពលើកទី ២៖ ឆ្នាំ២០២២

https://km.godfootsteps.org

# អារម្ភកថា

ទោះបីមនុស្សជាច្រើនជឿលើព្រះជាម្ចាស់ក៏ដោយ ក៏មានមនុស្សតិចណាស់ដែលយល់អំពីអត្ថន័យនៃសេចក្ដីជំនឿលើព្រះជាម្ចាស់ និងអ្វីដែលពួកគេត្រូវធ្វើដើម្បីឲ្យស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។ នេះគឺដោយសារតែពួកគេមិនស្គាល់ព្រះជាម្ចាស់ ហើយនៅតែមិនដឹងអំពីកិច្ចការរបស់ទ្រង់ បើទោះបីជាពួកគេធ្លាប់ដឹងធ្លាប់ឮអំពីពាក្យថា «ព្រះជាម្ចាស់» និង «កិច្ចការរបស់ព្រះជាម្ចាស់» ក៏ដោយ។ ដូច្នេះ គ្មានអ្វីដែលត្រូវឆ្ងល់ឡើយថា អស់អ្នកដែលមិនស្គាល់ព្រះជាម្ចាស់ ប្រាកដជាមានជំនឿបែបច្របូកច្របល់អំពីទ្រង់ជាមិនខាន។ មនុស្សមិនមានជំនឿហ្មត់ចត់លើព្រះជាម្ចាស់ឡើយ ហើយនេះដោយសារតែការមានជំនឿលើព្រះជាម្ចាស់ដូចជារឿងចម្លែកពេក ឬជារឿងដែលពួកគេមិនធ្លាប់បានដឹងពីមុនមក។ នេះជាហេតុផលដែលនាំឲ្យពួកគេមិនអាចបំពេញតាមការទាមទាររបស់ព្រះជាម្ចាស់បាន។ នៅក្នុងន័យម្យ៉ាងទៀត បើមនុស្សមិនស្គាល់ព្រះជាម្ចាស់ ហើយមិនដឹងអំពីកិច្ចការរបស់ទ្រង់ នោះពួកគេមិនសក្ដិសមនឹងឲ្យព្រះជាម្ចាស់ប្រើនោះឡើយ បើដូច្នេះ ពួកគេនៅតែមិនអាចបំពេញតាមបំណងព្រះហឫទ័យរបស់ទ្រង់ដដែល។ «ជំនឿជឿលើព្រះជាម្ចាស់» គឺជាការជឿថាមានព្រះជាម្ចាស់ ហើយនេះគឺជាគោលគំនិតដ៏សាមញ្ញបំផុតដែលទាក់ទងនឹងការជឿលើព្រះជាម្ចាស់។ លើសពីនេះទៅទៀត ការជឿថាមានព្រះជាម្ចាស់ មិនដូចជាការជឿលើព្រះជាម្ចាស់យ៉ាងពិតប្រាកដឡើយ។ ផ្ទុយទៅវិញ វាជាប្រភេទនៃសេចក្ដីជំនឿដ៏សាមញ្ញមួយដែលពាក់ព័ន្ធនឹងជំនឿសាសនាដ៏ខ្លាំង។ សេចក្ដីជំនឿពិតប្រាកដលើព្រះជាម្ចាស់ មានន័យដូចខាងក្រោម៖ ឈរលើមូលដ្ឋាននៃការជឿថា ព្រះជាម្ចាស់ជាព្រះដែលគង់ជាអធិបតេយ្យភាពលើអ្វីៗទាំងអស់ មនុស្សម្នាក់ដកពិសោធន៍នូវព្រះបន្ទូល និងកិច្ចការរបស់ទ្រង់ កម្ចាត់ចោលនិស្ស័យពុករលួយរបស់គេ បំពេញតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងមកស្គាល់ព្រះជាម្ចាស់។ មានតែដំណើរផ្លូវបែបនេះទេ ទើបហៅថាជា «សេចក្ដីជំនឿលើព្រះជាម្ចាស់»។ ប៉ុន្តែ ជារឿយៗមនុស្សមើលឃើញការមានជំនឿលើព្រះជាម្ចាស់ ជារឿងដ៏សាមញ្ញ និងឥតបានការ។

មនុស្សដែលជឿលើព្រះជាម្ចាស់តាមរបៀបនេះ បានបាត់បង់នូវអត្ថន័យនៃការជឿលើព្រះជាម្ចាស់ហើយ ទោះបីពួកគេអាចបន្តជឿរហូតដល់ទីចុងបញ្ចប់ក៏ដោយ ក៏ពួកគេនឹងមិនដែលទទួលបានការយល់ព្រមពីព្រះជាម្ចាស់នោះឡើយ ដោយសារតែពួកគេដើរតាមផ្លូវខុស។ សព្វថ្ងៃនេះ នៅតែមានមនុស្សដែលជឿលើព្រះជាម្ចាស់ស្របតាមន័យពាក្យ និងគោលលទ្ធិឥតខ្លឹមសារក្នុងទៀត។ ពួកគេមិនដឹងថា ពួកគេខ្វះនូវសារជាតិនៃសេចក្តីជំនឿជឿលើព្រះជាម្ចាស់ ហើយពួកគេមិនអាចទទួលបាននូវការយល់ព្រមពីព្រះជាម្ចាស់ឡើយ។ ពួកគេនៅតែអធិស្ឋានទៅកាន់ព្រះជាម្ចាស់ដើម្បីឲ្យទ្រង់ប្រទានព្រះពរនៃសុវត្ថិភាព និងព្រះគុណដ៏គ្រប់គ្រាន់ទៀត។ ឥឡូវនេះ ចូរយើងឈប់បន្តិចសិន ធ្វើចិត្តឲ្យស្ងប់ ហើយសួរខ្លួនឯងថា៖ តើវាអាចទេថា ការជឿលើព្រះជាម្ចាស់ តាមពិតទៅជាកិច្ចការដ៏ងាយស្រួលបំផុតនៅលើផែនដី? តើវាអាចទេថា ការជឿលើព្រះជាម្ចាស់គ្មានន័យអ្វីសោះ ក្រៅពីការទទួលយកព្រះគុណឲ្យបានច្រើនពីព្រះជាម្ចាស់? តើមនុស្សដែលជឿលើព្រះជាម្ចាស់ ទាំងមិនស្គាល់ទ្រង់ ឬមិនជឿលើទ្រង់ ប៉ុន្តែបែរជាប្រឆាំងនឹងទ្រង់ ពិតជាអាចធ្វើឲ្យព្រះជាម្ចាស់គាប់ព្រះហឫទ័យឬ?

ព្រះជាម្ចាស់ និងមនុស្ស មិនអាចត្រូវបាននិយាយនៅកម្រិតស្មើគ្នាឡើយ។ សារជាតិ និងកិច្ចការរបស់ទ្រង់ ជាអ្វីមួយដែលមនុស្សមិនអាចវាស់ស្ទង់ និងយល់បានឡើយ។ ប្រសិនបើព្រះជាម្ចាស់មិនធ្វើកិច្ចការរបស់ទ្រង់ និងមានបន្ទូលដោយផ្ទាល់នៅក្នុងពិភពលោករបស់មនុស្សទេ នោះមនុស្សនឹងមិនអាចយល់អំពីព្រះហឫទ័យរបស់ព្រះជាម្ចាស់បានឡើយ។ ដូច្នេះសូម្បីតែអ្នកដែលបានដាក់ជីវិតរបស់គេទាំងស្រុងចំពោះព្រះជាម្ចាស់ ក៏នឹងមិនអាចទទួលបានការយល់ព្រមពីទ្រង់ដែរ។ ប្រសិនបើព្រះជាម្ចាស់មិនចាប់ផ្តើមធ្វើការទេ ទោះបីមនុស្សធ្វើការបានល្អយ៉ាងណា ក៏វានៅតែគ្មានតម្លៃអ្វីសោះឡើយ ព្រោះថាព្រះតម្រិះរបស់ព្រះជាម្ចាស់ នឹងតែងតែខ្ពង់ខ្ពស់ជាងគំនិតរបស់មនុស្ស ហើយព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់ តែងតែលើសហួសពីការយល់ដឹងរបស់មនុស្សជានិច្ច។ ហេតុនេះហើយបានជាខ្ញុំនិយាយថា អស់អ្នកដែលអះអាងថា «ខ្លួនយល់ទាំងស្រុង» អំពីព្រះជាម្ចាស់ និងកិច្ចការរបស់ទ្រង់ តាមពិតទៅជា

មនុស្សល្ងីល្ងើវិញទេ។ ពួកគេទាំងអស់គ្នា សុទ្ធតែជាមនុស្សដែលគិតតែពីខ្លួនឯង និង ល្ងង់ខ្លៅ។ មនុស្សមិនគួរកំណត់និយមន័យ អំពីកិច្ចការរបស់ព្រះជាម្ចាស់ឡើយ។ មួយវិញទៀត មនុស្សមិនអាចកំណត់និយមន័យអំពីកិច្ចការរបស់ព្រះជាម្ចាស់បាន ឡើយ។ នៅក្នុងព្រះនេត្ររបស់ព្រះជាម្ចាស់ មនុស្សគ្មានតម្លៃដូចជាសត្វស្រមោចដែរ។ តើមនុស្សអាចវាស់ស្ទង់អំពីកិច្ចការរបស់ព្រះជាម្ចាស់បានដោយរបៀបណា? អស់អ្នក ដែលចូលចិត្តនិយាយប៉ប៉ាច់ប៉ប៉ោចថា «ព្រះជាម្ចាស់មិនធ្វើការបែបនេះ ឬបែបនោះ» ឬ «ព្រះជាម្ចាស់មានលក្ខណៈបែបនេះ ឬបែបនោះ» តើពួកគេមិនមែនកំពុងនិយាយ ទាំងអួតក្អេងក្អាងទេឬអី? យើងទាំងអស់គ្នាគួរតែដឹងថា មនុស្សដែលរស់នៅខាង សាច់ឈាមបែបនេះ ត្រូវបានអារក្សសាតាំងធ្វើឲ្យពុករលួយរួចទៅហើយ។ និស្ស័យ ដើមរបស់មនុស្សជាតិ គឺប្រឆាំងទាស់នឹងព្រះជាម្ចាស់។ មនុស្សជាតិមិនអាចមាន ឋានៈស្មើនឹងព្រះជាម្ចាស់ឡើយ ហើយមនុស្សជាតិក៏គ្មានថ្ងៃសង្ឃឹមចង់ផ្ដល់ដំបូន្មាន ដល់កិច្ចការរបស់ព្រះជាម្ចាស់នោះដែរ។ ទាក់ទងនឹងរបៀបដែលព្រះជាម្ចាស់ដឹកនាំ មនុស្ស នោះជាកិច្ចការរបស់ព្រះជាម្ចាស់ផ្ទាល់។ វាជារឿងសក្តិសមដែលមនុស្ស គួរតែចុះចូលធ្វើតាម ដោយមិនចាំបាច់ហាមាត់និយាយអំពីទស្សនៈបែបនេះ ឬបែប នោះឡើយ ដ្បិតមនុស្សគ្មានអ្វីក្រៅពីជាធូលីដីឡើយ។ ដោយសារនេះជាចេតនា របស់យើងក្នុងការស្វែងរកព្រះជាម្ចាស់ ដូច្នេះ យើងមិនគួរដាក់សញ្ញាណរបស់យើង ពីលើកិច្ចការរបស់ទ្រង់ ដើម្បីឲ្យព្រះជាម្ចាស់យកទៅពិចារណាឡើយ ហើយជាង នេះទៅទៀត យើងមិនគួរប្រើនិស្ស័យពុករលួយរបស់យើងទាំងអស់ មកប្រឆាំងនឹង កិច្ចការរបស់ព្រះជាម្ចាស់នោះទេ។ តើការធ្វើបែបនេះមិនធ្វើឲ្យយើងក្លាយជាពួកទទឹង នឹងព្រះគ្រីស្ទទេឬអី? តើមនុស្សបែបនេះអាចជឿលើព្រះជាម្ចាស់បានយ៉ាងដូចម្ដេច? ដោយសារតែយើងជឿថា មានព្រះជាម្ចាស់ ហើយដោយសារតែយើងចង់បំពេញតាម ព្រះហឫទ័យរបស់ទ្រង់ និងចង់ឃើញទ្រង់ ដូច្នេះ យើងគួរតែស្វែងរកផ្លូវនៃសេចក្ដីពិត និងស្វែងរកផ្លូវ ដើម្បីស្របគ្នាជាមួយទ្រង់វិញ។ យើងមិនគួរប្រឆាំងនឹងទ្រង់ ដោយចិត្ត រឹងចចេសឡើយ។ តើទង្វើបែបនេះអាចនាំឲ្យមានផលល្អអ្វីទៅ?

សព្វថ្ងៃនេះ ព្រះជាម្ចាស់បានធ្វើកិច្ចការថ្មី។ អ្នកប្រហែលជាមិនទទួលយកពាក្យទាំងនេះឡើយ ហើយពាក្យទាំងនេះ ក៏ប្រហែលជាចម្លែកសម្រាប់អ្នកផងដែរ ប៉ុន្តែខ្ញុំសូមដាស់តឿនថា អ្នកមិនត្រូវបង្ហាញសារជាតិដើមរបស់អ្នកឡើយ ព្រោះថាមានតែអស់អ្នកដែលពិតជាស្រេកឃ្លាន និងចង់បានសេចក្ដីសុចរិតនៅចំពោះព្រះជាម្ចាស់ប៉ុណ្ណោះ ដែលអាចទទួលបានសេចក្ដីពិត ហើយមានតែអស់អ្នកដែលពិតជាប្ដូរផ្ដាច់ចំពោះទ្រង់ប៉ុណ្ណោះ ទើបអាចទទួលបានការបំភ្លឺ និងការដឹកនាំពីទ្រង់។ លទ្ធផលទទួលបានតាមរយៈការស្វែងរកសេចក្ដីពិត ដោយចិត្តស្ងប់សុខ មិនមែនដោយការឈ្លោះប្រកែក និងការទាស់ទែងនោះឡើយ។ នៅពេលដែលខ្ញុំមានបន្ទូលថា «សព្វថ្ងៃនេះ ព្រះជាម្ចាស់បានធ្វើកិច្ចការថ្មី» ខ្ញុំកំពុងតែសំដៅលើកិច្ចការនៃការយាងត្រឡប់មកជាសាច់ឈាមរបស់ព្រះជាម្ចាស់។ ប្រហែលពាក្យទាំងនេះ មិនធ្វើឲ្យអ្នកខ្វល់ចិត្តឡើយ។ ប្រហែលអ្នកស្អប់ខ្ពើមពាក្យទាំងនេះ ឬមួយក៏វាធ្វើឲ្យអ្នកចាប់អារម្មណ៍យ៉ាងខ្លាំង។ មិនថាក្នុងករណីណាមួយឡើយ ខ្ញុំសង្ឃឹមថា អស់អ្នកណាដែលពិតជាចង់ឲ្យព្រះជាម្ចាស់លេចមក គឺអាចទទួលយកការពិតនេះ ហើយពិចារណាយ៉ាងល្អិតល្អន់អំពីពាក្យទាំងនេះ ជាជាងឆាប់ធ្វើសេចក្ដីសន្និដ្ឋាន។ នេះហើយជាអ្វីដែលមនុស្សមានប្រាជ្ញាគួរតែធ្វើ។

វាមិនពិបាកឡើយក្នុងការសួរនាំរកចម្លើយ ប៉ុន្តែវាតម្រូវឲ្យយើងម្នាក់ៗដឹងអំពីសេចក្ដីពិតមួយនេះសិន៖ ព្រះដែលយកកំណើតជាមនុស្ស នឹងមានសារជាតិរបស់ព្រះជាម្ចាស់ ហើយព្រះដែលយកកំណើតជាមនុស្ស នឹងមានការសម្ដែងរបស់ព្រះជាម្ចាស់។ ដោយសារតែព្រះជាម្ចាស់បានត្រលប់ជាសាច់ឈាម ដូច្នេះ ទ្រង់នឹងសម្រេចកិច្ចការដែលទ្រង់ចង់ធ្វើ ហើយដោយសារតែព្រះជាម្ចាស់ បានត្រលប់ជាសាច់ឈាម ដូច្នេះទ្រង់នឹងសម្ដែងអំពីលក្ខណៈរបស់ទ្រង់ ហើយទ្រង់នឹងអាចនាំសេចក្ដីពិតទៅកាន់មនុស្ស ប្រទានជីវិតដល់គេ និងដឹកនាំផ្លូវគេ។ សាច់ឈាមដែលគ្មានសារជាតិរបស់ព្រះជាម្ចាស់ ច្បាស់ណាស់ថាមិនមែនជាព្រះដែលយកកំណើតជាមនុស្ស។ ដូច្នេះ វាគ្មានអ្វីដែលត្រូវសង្ស័យឡើយ។ ប្រសិនបើមនុស្សមានបំណង

ចង់សួរនាំថា តើវាជាសាច់ឈាមដែលយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់ ឬយ៉ាងណា នោះគេត្រូវតែបញ្ជាក់អះអាងការនេះ ដោយចេញពីនិស្ស័យដែលទ្រង់បង្ហាញចេញ និងព្រះបន្ទូលដែលទ្រង់មានបន្ទូល។ អាចនិយាយបានថា ដើម្បីបញ្ជាក់អះអាងថា តើវាជាសាច់ឈាមដែលយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់ និងថាតើវាជាផ្លូវដ៏ពិតឬអត់ នោះគេត្រូវតែធ្វើការវែកញែកវា ដោយឈរលើមូលដ្ឋាននៃសារជាតិរបស់ទ្រង់។ ហើយដើម្បីកំណត់ថា តើវាជាសាច់ឈាមរបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សឬយ៉ាងណា ចំណុចគន្លឹះស្ថិតនៅលើសារជាតិរបស់ទ្រង់ (កិច្ចការរបស់ទ្រង់ ព្រះបន្ទូលរបស់ទ្រង់ និស្ស័យរបស់ទ្រង់ និងទិដ្ឋភាពជាច្រើនផ្សេងទៀត) ជាជាងផ្អែកលើរូបរាងពីខាងក្រៅ។ បើមនុស្សពិនិត្យពិច័យទៅលើតែរូបរាងខាងក្រៅរបស់ទ្រង់ ហើយបែរជាមើលរំលងសារជាតិរបស់ទ្រង់ នោះវាបង្ហាញថាមនុស្សពិតជាងងឹតងងល់ និងល្ងង់ខ្លៅហើយ។ រូបរាងខាងក្រៅ មិនអាចកំណត់ពីសារជាតិបានឡើយ។ ជាងនេះទៅទៀត កិច្ចការរបស់ព្រះជាម្ចាស់មិនអាចស្របតាមសញ្ញាណរបស់មនុស្សបានទេ។ តើរូបរាងខាងក្រៅរបស់ព្រះយេស៊ូវ មិនផ្ទុយពីសញ្ញាណរបស់មនុស្សទេឬអី? តើទឹកមុខ និងសម្លៀកបំពាក់របស់ទ្រង់មិនអាចផ្ដល់ជាតម្រុយអំពីអត្តសញ្ញាណដ៏ពិតរបស់ទ្រង់ទេឬអី? តើពួកផារីស៊ីនៅគ្រាដំបូងមិនបានប្រឆាំងនឹងព្រះយេស៊ូវ ដោយសារតែពួកគេគ្រាន់តែមើលទៅកាន់រូបរាងខាងក្រៅរបស់ទ្រង់ និងមិនយកចិត្តទុកដាក់ចំពោះព្រះបន្ទូលដែលចេញពីព្រះឱស្ឋរបស់ទ្រង់ទេឬអី? ខ្ញុំសង្ឃឹមថា បងប្អូនប្រុសស្រីម្នាក់ៗដែលស្វែងរកការលេចមករបស់ព្រះជាម្ចាស់ នឹងមិនដើរជាន់ដានប្រវត្តិសាស្ត្រ ដែលពេញដោយសោកនាដកម្មនេះឡើយ។ អ្នកមិនត្រូវក្លាយជាពួកផារីស៊ីសម័យទំនើប ហើយដំដែកគោលព្រះជាម្ចាស់ទៅនឹងឈើឆ្កាងម្ដងទៀតឡើយ។ អ្នកគួរតែពិចារណាយ៉ាងយកចិត្តទុកដាក់អំពីរបៀបស្វាគមន៍ការយាងត្រឡប់មកវិញរបស់ព្រះជាម្ចាស់ ហើយអ្នកគួរតែមានគំនិតជ្រះថ្លាទាក់ទងនឹងរបៀបក្លាយជាមនុស្សម្នាក់ ដែលចុះចូលចំពោះសេចក្ដីពិតវិញ។ នេះជាទំនួលខុសត្រូវរបស់មនុស្សគ្រប់គ្នា ដែលកំពុងរង់ចាំការយាងត្រឡប់មកវិញរបស់ព្រះយេស៊ូវនៅលើ

ពពក។ យើងគួរតែញីភ្នែកខាងវិញ្ញាណរបស់យើង ដើម្បីឲ្យមើលឃើញច្បាស់ ហើយមិនផុងជ្រៅនៅក្នុងពាក្យនិយាយបំផ្លើសបែបរវើរវាយ។ យើងគួរតែគិតអំពីកិច្ចការជាក់ស្ដែងរបស់ព្រះជាម្ចាស់ និងមើលទៅកាន់ទិដ្ឋភាពជាក់ស្ដែងរបស់ព្រះជាម្ចាស់វិញ។ ចូរកុំបណ្ដោយខ្លួនឲ្យអណ្ដែតអណ្ដូង ឬវង្វេងនៅក្នុងការរវើរវាយឡើយ ប៉ុន្តែចូរទន្ទឹងរង់ចាំជានិច្ច នូវថ្ងៃដែលព្រះអម្ចាស់ព្រះយេស៊ូវយាងនៅលើពពក ចុះមកភ្លាមៗក្នុងចំណោមអ្នករាល់គ្នា ហើយនាំយកអ្នករាល់គ្នាដែលមិនធ្លាប់ស្គាល់ ឬធ្លាប់ឃើញទ្រង់ និងអស់អ្នកដែលមិនដឹងពីរបៀបធ្វើតាមព្រះហឫទ័យរបស់ទ្រង់។ ដូច្នេះ ការគិតអំពីកិច្ចការជាក់ស្ដែង គឺជារឿងដែលប្រសើរជាង!

អ្នកប្រហែលជាបើកសៀវភៅនេះ សម្រាប់គោលបំណងនៃការសិក្សាស្រាវជ្រាវ ឬក្នុងចេតនាចង់ទទួលយក។ មិនថាអ្នកមានអាកប្បកិរិយាបែបណានោះឡើយ ខ្ញុំសង្ឃឹមថា អ្នកនឹងអានវាដល់ចប់ ហើយនឹងមិនឆាប់ទុកសៀវភៅនេះចោលឡើយ។ ប្រហែលជាក្រោយពេលអានពាក្យទាំងនេះហើយ អាកប្បកិរិយារបស់អ្នកនឹងផ្លាស់ប្ដូរ ប៉ុន្តែការនេះអាស្រ័យលើការជំរុញចិត្ត និងកម្រិតនៃការយល់ដឹងរបស់អ្នកផងដែរ។ យ៉ាងណាមិញ មានរឿងមួយដែលអ្នកគួរតែដឹងគឺ៖ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ មិនអាចធ្វើឲ្យក្លាយជាពាក្យរបស់មនុស្សបានឡើយ ហើយពាក្យរបស់មនុស្ស ក៏មិនអាចធ្វើឲ្យក្លាយជាព្រះបន្ទូលរបស់ព្រះជាម្ចាស់បាននោះដែរ។ មនុស្សដែលព្រះជាម្ចាស់ប្រើ មិនមែនជាព្រះដែលយកកំណើតជាមនុស្សឡើយ ហើយព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស ក៏មិនមែនជាមនុស្សដែលព្រះជាម្ចាស់ប្រើដែរ។ នៅត្រង់ចំណុចនេះ វាមាននូវភាពខុសគ្នាដ៏សំខាន់មួយ។ ប្រហែលជាក្រោយពេលអានពាក្យទាំងនេះហើយ អ្នកមិនទទួលស្គាល់ពាក្យទាំងនេះថា ជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដូចជាការស្រាយបំភ្លឺដែលមនុស្សបានទទួលនោះឡើយ។ បើបែបនេះ អ្នកពិតជាខ្វាក់ភ្នែក ដោយភាពល្ងង់ខ្លៅហើយ។ តើព្រះបន្ទូលរបស់ព្រះជាម្ចាស់អាចដូចជាការស្រាយបំភ្លឺដែលមនុស្សបានទទួលដោយរបៀបណាទៅ? ព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស បើកឲ្យមានយុគសម័យមួយថ្មី ដឹកនាំមនុស្សជាតិ

ទាំងអស់ បើកសម្ដែងសេចក្ដីលាក់កំបាំង និងបង្ហាញដល់មនុស្សនូវទិសដៅដែលគេត្រូវដើរនៅក្នុងយុគសម័យថ្មីនេះ។ ការស្រាយបំភ្លឺដែលមនុស្សទទួលបាន គ្មានអ្វីក្រៅពីសេចក្ដីណែនាំដ៏សាមញ្ញ សម្រាប់ការប្រតិបត្តិ ឬទុកជាចំណេះដឹងនោះឡើយ។ វាមិនអាចដឹកនាំមនុស្សទាំងអស់ឲ្យចូលក្នុងយុគសម័យថ្មី ឬបើកសម្ដែងអំពីសេចក្ដីលាក់កំបាំងរបស់ព្រះជាម្ចាស់ផ្ទាល់បានឡើយ។ សរុបមក បើពិចារណាឱ្យគ្រប់ជ្រុងជ្រោយទៅព្រះជាម្ចាស់ គឺជាព្រះជាម្ចាស់ ហើយមនុស្ស គឺជាមនុស្ស។ ព្រះជាម្ចាស់មានសារជាតិជាព្រះជាម្ចាស់ ហើយមនុស្សមានសារជាតិជាមនុស្ស។ ប្រសិនបើមនុស្សចាត់ទុកពាក្យដែលព្រះជាម្ចាស់មានបន្ទូល ថាជាការស្រាយបំភ្លឺដ៏សាមញ្ញដោយព្រះវិញ្ញាណបរិសុទ្ធ ហើយយកពាក្យរបស់ពួកសាវ័ក និងពួកហោរា ជាពាក្យដែលព្រះជាម្ចាស់មានបន្ទូលដោយផ្ទាល់ នោះវាជាកំហុសរបស់មនុស្សហើយ។ ទោះបីជាយ៉ាងណា អ្នកមិនគួរច្របល់បញ្ចូលគ្នានូវអ្វីដែលត្រូវ និងអ្វីដែលខុស ឬយកខ្ពស់ជាទាប ឬយករាក់ទៅជាជ្រៅឡើយ។ យ៉ាងណាក៏ដោយ អ្នកមិនគួរបដិសេធនូវអ្វីដែលអ្នកដឹងថាជាសេចក្ដីពិតឡើយ។ មនុស្សគ្រប់គ្នាដែលជឿថាមានព្រះជាម្ចាស់ គួរតែសួរនាំរកបញ្ហា ដោយចេញពីទស្សនៈដ៏ត្រឹមត្រូវ ហើយទទួលយកកិច្ចការថ្មី និងព្រះបន្ទូលថ្មីរបស់ព្រះជាម្ចាស់ ដោយចេញពីទស្សនៈជាមនុស្សដែលទ្រង់បានបង្កើតមក បើមិនដូច្នោះទេ ពួកគេនឹងត្រូវព្រះជាម្ចាស់ផាត់ចោលជាមិនខាន។

ក្រោយកិច្ចការរបស់ព្រះយេហូវ៉ា ព្រះយេស៊ូវបានត្រឡប់ជាសាច់ឈាម ដើម្បីធ្វើកិច្ចការរបស់ទ្រង់នៅក្នុងចំណោមមនុស្ស។ កិច្ចការរបស់ទ្រង់មិនត្រូវបានអនុវត្តដាច់ដោយឡែកឡើយ ប៉ុន្តែត្រូវបានសង់ពីលើកិច្ចការរបស់ព្រះយេហូវ៉ា។ វាជាកិច្ចការសម្រាប់យុគសម័យថ្មីដែលព្រះជាម្ចាស់បានធ្វើ ក្រោយពេលទ្រង់បានបញ្ចប់យុគសម័យនៃក្រឹត្យវិន័យ។ ដូចគ្នាផងដែរ ក្រោយកិច្ចការរបស់ព្រះយេស៊ូវបានបញ្ចប់ ព្រះជាម្ចាស់បានបន្តធ្វើកិច្ចការរបស់ទ្រង់សម្រាប់យុគសម័យថ្មី ព្រោះថា ការគ្រប់គ្រងទាំងស្រុងរបស់ព្រះជាម្ចាស់តែងតែវិវឌ្ឍទៅមុខជានិច្ច។ ពេលដែលយុគសម័យចាស់កន្លងផុតទៅ វានឹងត្រូវជំនួសដោយយុគសម័យមួយថ្មី ហើយពេលដែលកិច្ចការចាស់

ត្រូវបានបញ្ចប់ វានឹងមានកិច្ចការថ្មីដែលត្រូវបន្តការគ្រប់គ្រងរបស់ព្រះជាម្ចាស់។ ការយកកំណើតជាមនុស្សនេះ គឺជាការយកកំណើតជាមនុស្សលើកទីពីររបស់ព្រះជាម្ចាស់ដែលកើតឡើងតាមក្រោយកិច្ចការរបស់ព្រះយេស៊ូវ។ ពិតមែនហើយ ការយកកំណើតជាមនុស្សនេះ មិនមែនកើតឡើងដោយឯករាជ្យឡើយ ប៉ុន្តែវាជាដំណាក់កាលទីបីនៃកិច្ចការ ក្រោយយុគសម័យនៃក្រឹត្យវិន័យ និងយុគសម័យនៃព្រះគុណ។ គ្រប់ពេលដែលព្រះជាម្ចាស់ ផ្តួចផ្តើមដំណាក់កាលថ្មីនៃកិច្ចការ គឺត្រូវតែមានទីចាប់ផ្តើមថ្មីជានិច្ច ហើយវាត្រូវតែនាំមកនូវយុគសម័យថ្មីផងដែរ។ ហើយវាក៏មាននូវការផ្លាស់ប្តូរស្របគ្នានៅក្នុងនិស្ស័យរបស់ព្រះជាម្ចាស់ នៅក្នុងឥរិយាបថនៃការធ្វើការរបស់ទ្រង់ នៅក្នុងទីតាំងនៃកិច្ចការរបស់ទ្រង់ និងនៅក្នុងព្រះនាមរបស់ទ្រង់ផងដែរ។ នេះហើយជាហេតុផលដែលមនុស្សមានការពិបាកក្នុងការទទួលយកកិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងយុគសម័យថ្មី។ ប៉ុន្តែ មិនថាមនុស្សប្រឆាំងនឹងទ្រង់យ៉ាងណាក៏ដោយ ក៏ព្រះជាម្ចាស់នៅតែធ្វើកិច្ចការរបស់ទ្រង់ និងដឹកនាំមនុស្សជាតិទាំងអស់ឆ្ពោះទៅមុខជានិច្ច។ ពេលព្រះយេស៊ូវបានយាងចូលក្នុងពិភពលោករបស់មនុស្ស ទ្រង់បាននាំមកនូវយុគសម័យនៃព្រះគុណ និងបានបញ្ចប់យុគសម័យនៃក្រឹត្យវិន័យ។ ក្នុងអំឡុងពេលនៃគ្រាចុងក្រោយ ព្រះជាម្ចាស់បានក្លាយជាសាច់ឈាមម្តងទៀត ហើយជាមួយការយកកំណើតជាមនុស្សនេះ ទ្រង់បានបិទបញ្ចប់យុគសម័យនៃព្រះគុណ ហើយបាននាំមកនូវយុគសម័យនៃនគរព្រះវិញ។ អស់អ្នកដែលអាចទទួលយកការយកកំណើតជាមនុស្សលើកទីពីររបស់ព្រះជាម្ចាស់ នឹងត្រូវបាននាំចូលទៅក្នុងយុគសម័យនៃនគរព្រះ ហើយលើសពីនេះទៀត គេនឹងអាចទទួលយកការដឹកនាំរបស់ព្រះជាម្ចាស់ដោយផ្ទាល់។ ទោះបីជាព្រះយេស៊ូវបានធ្វើកិច្ចការជាច្រើននៅក្នុងចំណោមមនុស្សក៏ដោយ ប៉ុន្តែទ្រង់គ្រាន់តែបញ្ចប់នូវកិច្ចការប្រោសលោះមនុស្សជាតិទាំងអស់ ហើយបានក្លាយជាតង្វាយលោះបាបរបស់មនុស្សប៉ុណ្ណោះ។ ទ្រង់មិនបានដកចោលនូវនិស្ស័យពុករលួយទាំងអស់ចេញពីមនុស្សឡើយ។ ការសង្គ្រោះមនុស្សយ៉ាងពេញលេញចេញពីឥទ្ធិពលរបស់អារក្សសាតាំង មិនគ្រាន់តែតម្រូវឲ្យព្រះយេស៊ូវក្លាយជា

តង្វាយលោះបាប និងទទួលយកអំពើបាបរបស់មនុស្សប៉ុណ្ណោះទេ ប៉ុន្តែវាក៏តម្រូវឲ្យព្រះជាម្ចាស់ធ្វើកិច្ចការកាន់តែខ្លាំង ដើម្បីដកចោលនិស្ស័យពុករលួយបែបសាតាំងទាំងអស់ចេញពីមនុស្សផងដែរ។ ដូច្នេះ ឥឡូវនេះមនុស្សត្រូវបានអត់ទោសពីអំពើបាបរបស់ខ្លួន ព្រះជាម្ចាស់បានត្រឡប់ជាសាច់ឈាម ដើម្បីដឹកនាំមនុស្សចូលទៅក្នុងយុគសម័យថ្មី ហើយចាប់ផ្ដើមកិច្ចការនៃការវាយផ្ចាល និងការជំនុំជម្រះ។ កិច្ចការនេះបាននាំមនុស្សចូលទៅក្នុងពិភពមួយកាន់តែខ្ពស់។ អស់អ្នកដែលចុះចូលក្រោមដែនគ្រប់គ្រងរបស់ទ្រង់ នឹងរីករាយចំពោះសេចក្ដីពិតកាន់តែខ្ពស់ ហើយទទួលព្រះពរកាន់តែធំ។ ពួកគេនឹងរស់នៅយ៉ាងពិតប្រាកដនៅក្នុងពន្លឺ ហើយគេនឹងទទួលបានសេចក្ដីពិត ផ្លូវ និងជីវិត។

ប្រសិនបើមនុស្ស បន្តជាប់នៅក្នុងយុគសម័យនៃព្រះគុណ នោះពួកគេនឹងមិនអាចត្រូវបានដកចោលនិស្ស័យពុករលួយរបស់គេបានឡើយ ដូច្នេះពួកគេគ្មានថ្ងៃនឹងស្គាល់និស្ស័យខាងក្នុងរបស់ព្រះជាម្ចាស់ឡើយ។ ប្រសិនបើមនុស្សតែងតែរស់នៅក្នុងព្រះគុណដ៏ពេញបរិបូណ៌ ប៉ុន្តែមិនមានផ្លូវនៃជីវិត ដែលអនុញ្ញាតឲ្យពួកគេស្គាល់ព្រះជាម្ចាស់ ឬបំពេញតាមព្រះហឫទ័យរបស់ទ្រង់ទេ នោះពួកគេនឹងមិនដែលទទួលបានទ្រង់យ៉ាងពិតប្រាកដនៅក្នុងជំនឿរបស់គេលើទ្រង់ឡើយ។ ជំនឿប្រភេទនេះ ពិតជាគួរឲ្យអាណិតណាស់។ នៅពេលដែលអ្នកបានអានចប់សៀវភៅនេះ នៅពេលដែលអ្នកបានដកពិសោធន៍ជំហាននីមួយៗ នៃកិច្ចការរបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សក្នុងយុគសម័យនៃនគរព្រះ នោះអ្នកនឹងមានអារម្មណ៍ថាបំណងប្រាថ្នាដែលអ្នកមានជាច្រើនឆ្នាំមកនេះ នៅចុងបញ្ចប់បានក្លាយជាការពិតហើយ។ អ្នកនឹងមានអារម្មណ៍ថា មានតែពេលនេះប៉ុណ្ណោះ ដែលអ្នកបានឃើញព្រះជាម្ចាស់មុខទល់នឹងមុខ។ មានតែពេលនេះប៉ុណ្ណោះ ដែលអ្នកបានឃើញទឹកព្រះភ័ក្ត្ររបស់ទ្រង់ បានឮព្រះសូរសៀងរបស់ទ្រង់ដោយផ្ទាល់ បានទទួលប្រាជ្ញាអំពីកិច្ចការរបស់ទ្រង់ និងពិតជាមានអារម្មណ៍យ៉ាងអស្ចារ្យអំពីព្រះចេស្ដារបស់ទ្រង់។ អ្នកនឹងមានអារម្មណ៍ថា អ្នកបានទទួលនូវរឿងជាច្រើនដែលមនុស្សនៅសម័យមុនមិនបានឃើញ

ក៏មិនធ្លាប់មានផងដែរ។ នៅពេលនេះ អ្នកនឹងដឹងយ៉ាងច្បាស់អំពីអត្ថន័យនៃការជឿលើព្រះជាម្ចាស់ និងអត្ថន័យនៃការធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ពិតប្រាកដណាស់ ប្រសិនបើអ្នកប្រកាន់ខ្ជាប់នឹងទស្សនៈអតីតកាល ហើយបដិសេធ ឬជំទាស់នឹងការពិតនៃការយកកំណើតជាមនុស្សលើកទីពីររបស់ព្រះជាម្ចាស់ នោះអ្នកនឹងនៅតែចាប់ខ្យល់ មិនទទួលបានអ្វីសោះឡើយ ហើយចុងបញ្ចប់ អ្នកនឹងត្រូវព្រះជាម្ចាស់ប្រកាសថា មានទោសប្រឆាំងនឹងទ្រង់។ អស់អ្នកដែលអាចស្ដាប់បង្គាប់តាមសេចក្ដីពិត និងចុះចូលចំពោះកិច្ចការរបស់ព្រះជាម្ចាស់ នឹងត្រូវបានអះអាងថា ខ្លួនស្ថិតនៅក្រោមព្រះនាមនៃព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សលើកទីពីរ ដែលជាព្រះដ៏ពេញដោយព្រះចេស្ដា។ ពួកគេនឹងអាចទទួលយកការដឹកនាំដោយផ្ទាល់របស់ព្រះជាម្ចាស់ ទទួលបានសេចក្ដីពិតកាន់តែច្រើន និងកាន់តែខ្ពស់ ក៏ដូចជាជីវិតដ៏ពិតផងដែរ។ ពួកគេនឹងមើលឃើញនិមិត្ត ដែលមនុស្សពីអតីតកាលមិនបានមើលឃើញ៖ «រួចខ្ញុំក៏បែរទៅរកសំឡេង ដែលបាននិយាយជាមួយខ្ញុំ។ ហើយកាលខ្ញុំ កំពុងបែរនោះ ខ្ញុំឃើញជើងទៀនមាសប្រាំពីរដើម ហើយចំកណ្ដាលជើងទៀនទាំងប្រាំពីរនោះ មានមួយអង្គដូចជាកូនមនុស្សគ្រងព្រះពស្ដ្រវែងដល់ព្រះបាទ ក៏មានគ្រងខ្សែមាសនៅនឹងដើមទ្រូង។ ព្រះសិរសា និងព្រះកេសាទ្រង់ សដូចជារោមចៀម គឺសដូចព្រិល ហើយព្រះនេត្រទ្រង់ប្រៀបដូចអណ្ដាតភ្លើង ព្រះបាទទ្រង់ដូចលង្ហិនរលីងដែលត្រូវស្ល នៅក្នុងឡ។ ចំណែកព្រះសូរសៀងទ្រង់ ប្រៀបដូចជាទឹកដ៏សន្ធឹក។ ទ្រង់កាន់ផ្កាយទាំងប្រាំពីរក្នុងព្រះហស្ដស្ដាំ ហើយមានដាវមុខពីរយ៉ាងមុត ចេញពីព្រះឱស្ឋទ្រង់ ចំណែកព្រះភក្ត្ររបស់ទ្រង់វិញ ភ្លឺដូចព្រះអាទិត្យរះពេញកម្ដៅ» (វិវរណៈ ១:១២-១៦)។ និមិត្តនេះគឺជាការសម្ដែងចេញនៃនិស្ស័យទាំងស្រុងរបស់ព្រះជាម្ចាស់ហើយការសម្ដែងចេញនៃនិស្ស័យទាំងស្រុងរបស់ទ្រង់ ក៏ជាការសម្ដែងចេញនៃកិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងការយកកំណើតជាមនុស្សនាពេលបច្ចុប្បន្នរបស់ទ្រង់ផងដែរ។ នៅក្នុងដំណើរការនៃការកាត់ទោស និងការជំនុំជម្រះ បុត្រមនុស្សសម្ដែងចេញនិស្ស័យខាងក្នុងរបស់ទ្រង់តាមរយៈការមានបន្ទូល ការអនុញ្ញាតឲ្យអស់អ្នកដែល

ទទួលយកការកាត់ទោសនិងការជំនុំជម្រះរបស់ទ្រង់ មើលឃើញពីព្រះភ័ក្ត្រពិតរបស់បុត្រមនុស្ស ដែលជាសេចក្ដីពណ៌នាដ៏ស្មោះ អំពីព្រះភ័ក្ត្ររបស់បុត្រមនុស្ស ដែលយ៉ូហានបានមើលឃើញ។ (ពិតប្រាកដណាស់ សម្រាប់មនុស្សដែលមិនទទួលយកកិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងយុគសម័យនៃនគរព្រះ នឹងមើលមិនឃើញរឿងទាំងអស់នេះឡើយ)។ ព្រះភ័ក្ត្រដ៏ពិតរបស់ព្រះជាម្ចាស់ មិនអាចត្រូវបានបរិយាយយ៉ាងពេញលេញ ដោយប្រើភាសាមនុស្សឡើយ ដូច្នេះព្រះជាម្ចាស់ប្រើមធ្យោបាយមួយដែលទ្រង់អាចសម្ដែងពីនិស្ស័យខាងក្នុងរបស់ទ្រង់ ដើម្បីបង្ហាញពីព្រះភ័ក្ត្រដ៏ពិតរបស់ទ្រង់ទៅកាន់មនុស្ស។ អាចនិយាយបានថា អស់អ្នកដែលបានយល់អំពីនិស្ស័យខាងក្នុងនៃបុត្រមនុស្ស បានឃើញព្រះភ័ក្ត្រដ៏ពិតរបស់បុត្រមនុស្ស ដ្បិតព្រះជាម្ចាស់មានឋានៈធំពេក ហើយមិនអាចបរិយាយយ៉ាងពេញលេញ ដោយប្រើភាសាមនុស្សបានឡើយ។ នៅពេលដែលមនុស្សបានដកពិសោធន៍ជំហាននីមួយៗនៃកិច្ចការរបស់ព្រះជាម្ចាស់ នៅក្នុងយុគសម័យនៃនគរព្រះរួចហើយ នោះគេនឹងដឹងអំពីអត្ថន័យដ៏ពិតនៃប្រសាសន៍របស់យ៉ូហាន នៅពេលដែលគាត់មានប្រសាសន៍អំពីបុត្រមនុស្សនៅក្នុងចំណោមជើងចង្កៀងថា៖ «ព្រះសិរសា និងព្រះកេសាទ្រង់ សដូចជារោមចៀម គឺសដូចព្រិល ហើយព្រះនេត្រទ្រង់ប្រៀបដូចអណ្ដាតភ្លើង ព្រះបាទទ្រង់ដូចលង្ហិនរលីង ដែលត្រូវស្លនៅក្នុងឡ។ ចំណែកព្រះសូរសៀងទ្រង់ ប្រៀបដូចជាទឹកដ៏សន្ធឹក។ ទ្រង់កាន់ផ្កាយទាំងប្រាំពីរក្នុងព្រះហស្តស្ដាំ ហើយមានដាវមុខពីរយ៉ាងមុត ចេញពីព្រះឱស្ឋទ្រង់ ចំណែកព្រះភក្ត្ររបស់ទ្រង់វិញ ភ្លឺដូចព្រះអាទិត្យរះពេញកម្ដៅ»។ នៅពេលនោះ អ្នកនឹងដឹងយ៉ាងពិតប្រាកដ ដោយមិនអាចប្រកែកបានថា សាច់ឈាមសាមញ្ញដែលបានមានបន្ទូលយ៉ាងច្រើននេះ គឺជាព្រះដែលយកកំណើតជាមនុស្សលើកទីពីរ។ លើសពីនេះទៅទៀត អ្នកនឹងយល់យ៉ាងពិតប្រាកដថា អ្នកពិតជាមានពរណាស់ និងមានអារម្មណ៍ថា អ្នកជាមនុស្សមានសំណាងបំផុតនៅក្នុងលោក។ តើអ្នកមិនព្រមទទួលយកព្រះពរនេះទេឬអី?

# តារាងមាតិកា


១. ជំពូកទី ១៖ ព្រះសូរសៀងរបស់ព្រះគ្រីស្ទ កាលពីដើមដំបូង ........................ ១
២. ជំពូកទី ២៖ ព្រះសូរសៀងរបស់ព្រះគ្រីស្ទ កាលពីដើមដំបូង ........................ ៣
៣. ជំពូកទី ៣៖ ព្រះសូរសៀងរបស់ព្រះគ្រីស្ទ កាលពីដើមដំបូង ........................ ៦
៤. ជំពូកទី ៥៖ ព្រះសូរសៀងរបស់ព្រះគ្រីស្ទ កាលពីដើមដំបូង ........................ ៨
៥. ជំពូកទី ១៥៖ ព្រះសូរសៀងរបស់ព្រះគ្រីស្ទ កាលពីដើមដំបូង ................... ១០
៦. ជំពូកទី ៨៨៖ ព្រះសូរសៀងរបស់ព្រះគ្រីស្ទ កាលពីដើមដំបូង ................... ១៥
៧. ជំពូកទី ១០៣៖ ព្រះសូរសៀងរបស់ព្រះគ្រីស្ទ កាលពីដើមដំបូង ................ ២១
៨. ជំពូកទី ៤៖ ព្រះបន្ទូលព្រះជាម្ចាស់ ថ្លែងទៅកាន់សកលលោកទាំងមូល ......... ២៨
៩. ជំពូកទី ៥៖ ព្រះបន្ទូលព្រះជាម្ចាស់ថ្លែងទៅកាន់សកលលោកទាំងមូល ......... ៣៤
១០. ជំពូកទី ៦៖ ព្រះបន្ទូលព្រះជាម្ចាស់ ថ្លែងទៅកាន់សកលលោកទាំងមូល ......... ៤០
១១. ជំពូកទី ៨៖ ព្រះបន្ទូលព្រះជាម្ចាស់ ថ្លែងទៅកាន់សកលលោកទាំងមូល ........ ៤៦
១២. ជំពូកទី ១០៖ ព្រះបន្ទូលព្រះជាម្ចាស់ ថ្លែងទៅកាន់សកលលោកទាំងមូល ...... ៥២
១៣. ចម្រៀងជ័យនៃនគរព្រះ ........................................................................ ៥៩
១៤. ជំពូកទី ១២៖ ព្រះបន្ទូលព្រះជាម្ចាស់ ថ្លែងទៅកាន់សកលលោកទាំងមូល ....... ៦២
១៥. ចូរអរសប្បាយ ម្នាលជនទាំងឡាយអើយ! .............................................. ៦៨
១៦. ជំពូកទី ២៦៖ ព្រះបន្ទូលព្រះជាម្ចាស់ ថ្លែងទៅកាន់សកលលោកទាំងមូល ...... ៧០
១៧. ជំពូកទី ២៩៖ ព្រះបន្ទូលព្រះជាម្ចាស់ ថ្លែងទៅកាន់សកលលោកទាំងមូល ...... ៧៦
១៨. តើអ្នកជឿ គួរប្រកាន់យកទស្សនៈអ្វី ........................................................ ៨២
១៩. មនុស្សពុករលួយ គ្មានសមត្ថភាពតំណាងឱ្យព្រះជាម្ចាស់ ......................... ៨៦
២០. ការបម្រើសាសនា ដាច់ខាតត្រូវតែលុបបំបាត់ ........................................ ៩០
២១. អ្នកគួរតែស្ដាប់បង្គាប់ព្រះជាម្ចាស់ នៅក្នុងជំនឿដែលអ្នកជឿដល់ទ្រង់ ......... ៩៥
២២. សេចក្ដីសន្យាចំពោះអស់អ្នកដែលត្រូវបានប្រោសឲ្យបានគ្រប់លក្ខណ៍ ....... ១០០
២៣. ពួកទុច្ចរិតនឹងត្រូវទទួលទោសយ៉ាងពិតប្រាកដ ...................................... ១០៨

២៤. របៀបបម្រើ ស្របគ្នាទៅនឹងបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ........ ១១៤
២៥. អំពីការដែលព្រះជាម្ចាស់ប្រើមនុស្ស ...................................................... ១២២
២៦. បញ្ញត្តិនៅក្នុងយុគសម័យថ្មី ................................................................ ១២៥
២៧. រាជ្យមួយពាន់ឆ្នាំបានមកដល់ហើយ ...................................................... ១៣២
២៨. អ្នកគួរដឹងថា ព្រះដ៏ជាក់ស្ដែង គឺជាព្រះជាម្ចាស់ .................................. ១៣៨
២៩. ការដឹងអំពីកិច្ចការរបស់ព្រះជាម្ចាស់នាពេលសព្វថ្ងៃ ............................. ១៤៧
៣០. តើកិច្ចការរបស់ព្រះជាម្ចាស់ សាមញ្ញដូចមនុស្សគិតដែរឬទេ? ................ ១៥៩
៣១. អ្នកត្រូវរស់នៅសម្រាប់សេចក្តីពិត ដ្បិតអ្នកជឿដល់ព្រះជាម្ចាស់ ............. ១៦៥
៣២. សំឡេងផ្គរលាន់ទាំងប្រាំពីរៈ ថ្លែងទំនាយថា ដំណឹងល្អ
នៃនគរព្រះ នឹងផ្សាយទៅពាសពេញទាំងសាកលលោក ........................ ១៧០
៣៣. ភាពខុសគ្នាដ៏សំខាន់រវាងព្រះដែលយកកំណើតជាមនុស្ស
និងមនុស្សដែលត្រូវបានព្រះជាម្ចាស់ត្រាស់បង្គាប់ ................................ ១៧៦
៣៤. មនុស្សត្រូវតែផ្ដោតលើភាពជាក់ស្ដែងនៅក្នុងសេចក្ដីជំនឿ
ពោលគឺការប្រណិប័តន៍តាមពិធីសាសនា មិនមែនជាជំនឿទេ ................ ១៨៩
៣៥. មានតែអ្នកដែលស្គាល់កិច្ចការរបស់ព្រះជាម្ចាស់ក្នុងពេល
បច្ចុប្បន្ននេះទេ ដែលអាចបម្រើព្រះជាម្ចាស់បាន .................................. ១៩៣
៣៦. ស្គាល់កិច្ចការថ្មីបំផុតរបស់ព្រះជាម្ចាស់
និងដើរតាមដានព្រះបាទារបស់ព្រះអង្គ .............................................. ២០២
៣៧. ព្រះជាម្ចាស់ប្រោសមនុស្សណា
ដែលស្របតាមព្រះហឫទ័យទ្រង់ឲ្យបានគ្រប់លក្ខណ៍ .......................... ២២០
៣៨. អស់អ្នកណាដែលស្ដាប់បង្គាប់ ព្រះជាម្ចាស់ដោយដួងចិត្តពិត
នឹងត្រូវព្រះជាម្ចាស់ទទួលយក ជាប្រាកដ ........................................... ២២៩
៣៩. យុគសម័យនៃនគរព្រះ គឺជាយុគសម័យនៃព្រះបន្ទូល ........................... ២៤០
៤០. គ្រប់យ៉ាងសម្រេចបានដោយព្រះបន្ទូលរបស់ព្រះជាម្ចាស់ ..................... ២៥៩

៤១. អស់អ្នកដែលនឹងត្រូវប្រោសឲ្យបានគ្រប់លក្ខណ៍
ត្រូវតែឆ្លងកាត់ការបន្សុទ្ធ ........................................................................ ២៧៨
៤២. មានតែតាមរយៈការឆ្លងកាត់ការល្បងលដ៏ឈឺចាប់ទេ
ទើបអ្នកអាចដឹងអំពីភាពគួរឲ្យស្រឡាញ់របស់ព្រះជាម្ចាស់ .................... ៣០៣
៤៣. មានតែការស្រលាញ់ព្រះជាម្ចាស់តែប៉ុណ្ណោះ
ទើបជាការជឿលើព្រះជាម្ចាស់ពិតប្រាកដ ......................................... ៣១៦
៤៤. ការជជែកដោយសង្ខេបអំពី «រាជ្យមួយពាន់ឆ្នាំបានមកដល់ហើយ» ........ ៣៣២
៤៥. មានតែអស់អ្នកដែលស្គាល់ព្រះជាម្ចាស់ប៉ុណ្ណោះ
ដែលអាចធ្វើទីបន្ទាល់អំពីព្រះជាម្ចាស់បាន ....................................... ៣៣៩
៤៦. របៀបដែលពេត្រុសចាប់ផ្តើមស្គាល់ព្រះយេស៊ូវ ................................. ៣៥២
៤៧. អស់អ្នកណាដែលស្រឡាញ់ព្រះជាម្ចាស់
នឹងរស់នៅក្នុងពន្លឺរបស់ទ្រង់អស់កល្បជានិច្ច ..................................... ៣៧០
៤៨. កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ និងកិច្ចការរបស់សាតាំង ..................... ៣៨៥
៤៩. ការព្រមានដល់អស់អ្នកដែលមិនអនុវត្តនូវសេចក្តីពិត .......................... ៣៩៦
៥០. តើអ្នកគឺជាមនុស្សម្នាក់ដែលចូលមកឯជីវិតឬ? ................................... ៤០៥
៥១. ការមាននិស្ស័យដែលមិនចេះផ្លាស់ប្តូរ
គឺជាការប្រឆាំងនឹងព្រះជាម្ចាស់ ........................................................ ៤១២
៥២. មនុស្សគ្រប់គ្នាដែលមិនស្គាល់ព្រះជាម្ចាស់
គឺជាមនុស្សដែលប្រឆាំងទាស់នឹងព្រះជាម្ចាស់ .................................... ៤២២
៥៣. និមិត្តអំពីកិច្ចការរបស់ព្រះជាម្ចាស់ (១) ............................................... ៤៣៣
៥៤. និមិត្តអំពីកិច្ចការរបស់ព្រះជាម្ចាស់ (២) ............................................. ៤៤៣
៥៥. និមិត្តអំពីកិច្ចការរបស់ព្រះជាម្ចាស់ (៣) .............................................. ៤៥៧
៥៦. អាថ៌កំបាំងនៃការយកកំណើតជាមនុស្ស (១) ........................................ ៤៨៩
៥៧. អាថ៌កំបាំងនៃការយកកំណើតជាមនុស្ស (២) ........................................ ៥១៤

៥៨. អាថ៌កំបាំងនៃការយកកំណើតជាមនុស្ស (៣) ........................................ ៥២៤
៥៩. អាថ៌កំបាំងនៃការយកកំណើតជាមនុស្ស (៤) ........................................ ៥៣៧
៦០. ការយកកំណើតជាមនុស្សទាំងពីរលើក
បំពេញនូវសារៈសំខាន់នៃការយកកំណើតជាមនុស្ស ............................ ៥៦៨
៦១. តើព្រះត្រៃឯកមានវត្តមានគង់នៅដែរឬទេ? ........................................ ៥៨៣
៦២. សេចក្តីពិតនៅខាងក្នុងអំពីកិច្ចការនៃការយកឈ្នះ (១) .......................... ៦០៣
៦៣. សេចក្តីពិតនៅខាងក្នុងអំពីកិច្ចការនៃការយកឈ្នះ (៣) .......................... ៦២២
៦៤. សេចក្តីពិតនៅខាងក្នុងអំពីកិច្ចការនៃការយកឈ្នះ (៤) .......................... ៦៣៨
៦៥. តើអ្នកគួរបម្រើបេសកកម្មនាពេលអនាគតរបស់អ្នកយ៉ាងដូចម្តេច? ......... ៦៤៩
៦៦. តើអ្នករាល់គ្នាមានការយល់ដឹងអ្វីខ្លះអំពីព្រះពរ? .................................... ៦៥១
៦៧. តើអ្នកមានការយល់ដឹងយ៉ាងដូចម្តេចអំពីព្រះជាម្ចាស់? ......................... ៦៥៦
៦៨. តើក្លាយជាមនុស្សពិតប្រាកដម្នាក់មានន័យដូចម្តេច ............................. ៦៦៦
៦៩. តើអ្នកដឹងអ្វីខ្លះអំពីសេចក្តីជំនឿ? ....................................................... ៦៧៦
៧០. នៅពេលស្លឹកឈើជ្រុះធ្លាក់ទៅគល់វិញ
នោះអ្នកនឹងសោកស្តាយនូវរាល់អំពើអាក្រក់ទាំងអស់ដែលអ្នកបានធ្វើ ....... ៦៨៦
៧១. គ្មាននរណាម្នាក់ដែលមានសាច់ឈាម
អាចគេចផុតពីថ្ងៃនៃសេចក្តីក្រោធបានឡើយ ........................................ ៦៩៥
៧២. ព្រះអង្គសង្គ្រោះបានយាងត្រឡប់មកវិញហើយ
នៅលើ «ពពកស» មួយដុំ ................................................................ ៧០៦
៧៣. កិច្ចការប្រកាសដំណឹងល្អ ក៏ជាកិច្ចការសង្គ្រោះមនុស្សដែរ ..................... ៧១៤
៧៤. កិច្ចការនៅក្នុងយុគសម័យនៃក្រឹត្យវិន័យ ............................................ ៧២១
៧៥. រឿងពិតពីក្រោយកិច្ចការនាយុគសម័យនៃការប្រោសលោះ .................. ៧២៩
៧៦. អ្នកគួរតែដឹងពីរបៀបដែលមនុស្សទាំងអស់បានវិវឌ្ឍ
មកដល់ពេលបច្ចុប្បន្ន ....................................................................... ៧៣៧

៧៧. អំពីងារ និងអត្តសញ្ញាណ ........................................................ ៧៦៦
៧៨. អ្នកគប្បីទុកព្រះពរនៃឋានៈចោលមួយឡែក
រួចឈ្វេងយល់ព្រះហឫទ័យព្រះជាម្ចាស់
ក្នុងការនាំសេចក្ដីសង្គ្រោះ មកឲ្យមនុស្សលោក ................................. ៧៩៦
៧៩. តើមនុស្សដែលបានដាក់កំហិតព្រះជាម្ចាស់
តាមសញ្ញាណរបស់ខ្លួន អាចទទួលការបើកសម្ដែង
ពីព្រះជាម្ចាស់យ៉ាងដូចម្ដេច? ........................................................ ៨១០
៨០. មានតែអស់អ្នកដែលស្គាល់ព្រះជាម្ចាស់
និងស្គាល់កិច្ចការរបស់ទ្រង់ប៉ុណ្ណោះ
ដែលអាចផ្គាប់ព្រះហឫទ័យព្រះជាម្ចាស់បាន ...................................... ៨១៩
៨១. ភាពខុសគ្នារវាងព័ន្ធកិច្ចរបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស
និងភារកិច្ចរបស់មនុស្ស ................................................................ ៨៣៤
៨២. ព្រះជាម្ចាស់ គឺជាព្រះអម្ចាស់នៃសព្វសារពើទាំងអស់ ........................... ៨៥១
៨៣. ជោគជ័យ ឬបរាជ័យ អាស្រ័យលើផ្លូវដែលមនុស្សដើរ .......................... ៨៦០
៨៤. កិច្ចការរបស់ព្រះជាម្ចាស់ និងកិច្ចការរបស់មនុស្ស .............................. ៨៨៩
៨៥. ការស្គាល់ដំណាក់កាលទាំងបីនៃកិច្ចការរបស់ព្រះជាម្ចាស់
គឺជាផ្លូវនាំទៅរកការស្គាល់ព្រះជាម្ចាស់ ............................................. ៩២៣
៨៦. មនុស្សជាតិដ៏ពុករលួយកាន់តែត្រូវការសេចក្ដីសង្គ្រោះ
របស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស .................................... ៩៥៣
៨៧. សារជាតិនៃសាច់ឈាមដែលព្រះជាម្ចាស់គង់សណ្ឋិត ........................... ៩៨៧
៨៨. កិច្ចការរបស់ព្រះជាម្ចាស់ និងការអនុវត្តរបស់មនុស្ស .......................... ១០១០
៨៩. សារជាតិរបស់ព្រះគ្រីស្ទ
គឺជាការស្ដាប់បង្គាប់តាមព្រះហឫទ័យរបស់ព្រះវរបិតា
ដែលគង់នៅស្ថានសួគ៌................................................................. ១០៤៥

៩០. ការស្រោចស្រង់ជីវិតធម្មតារបស់មនុស្សត្រឡប់មកវិញ
និងការនាំមនុស្សទៅកាន់ទិសដៅដ៏អស្ចារ្យមួយ ............................ ១០៦០
៩១. ព្រះជាម្ចាស់ និងមនុស្សលោក នឹងចូលទៅក្នុងសេចក្ដីសម្រាករួមគ្នា ...... ១០៩៦
៩២. ទម្រាំដល់ពេលដែលអ្នកបានឃើញព្រះកាយខាងវិញ្ញាណ
របស់ព្រះយេស៊ូវពីចម្ងាយ នោះព្រះជាម្ចាស់បានបង្កើតឋានសួគ៌
និងផែនដីថ្មីរួចស្រេចបាត់ទៅហើយ ............................................ ១១២៩
៩៣. មនុស្សដែលមិនចុះសម្រុងនឹងព្រះគ្រីស្ទ
គឺជាសត្រូវព្រះជាម្ចាស់ប្រាកដណាស់ ........................................ ១១៣៧
៩៤. មនុស្សជាច្រើនត្រូវបានត្រាស់ហៅ
តែមានមនុស្សតិចណាស់ដែលត្រូវបានជ្រើសរើស .......................... ១១៤៥
៩៥. អ្នកគួរតែស្វះស្វែងរកវិធីដែលស្របនឹងព្រះគ្រីស្ទ ............................ ១១៥១
៩៦. តើអ្នកជាអ្នកជឿលើព្រះជាម្ចាស់ដ៏ពិតប្រាកដមែនទេ? ..................... ១១៥៧
៩៧. ព្រះគ្រីស្ទធ្វើកិច្ចការជំនុំជម្រះ ដោយសេចក្ដីពិត .............................. ១១៦៥
៩៨. តើអ្នកដឹងទេ? ព្រះជាម្ចាស់បានធ្វើការដ៏អស្ចារ្យមួយ
នៅក្នុងចំណោមមនុស្សលោក .................................................... ១១៧២
៩៩. មានតែព្រះគ្រីស្ទនៃគ្រាចុងក្រោយទេ
ទើបអាចប្រទានមាគ៌ាជីវិតអស់កល្បជានិច្ចដល់មនុស្សបាន .............. ១១៨០
១០០. ចូរត្រៀមខ្លួនធ្វើអំពើល្អឲ្យបានគ្រប់គ្រាន់សម្រាប់ទិសដៅរបស់អ្នក ....... ១១៩០
១០១. តើអ្នកស្មោះត្រង់ចំពោះអ្នកណា? ................................................ ១១៩៦
១០២. អំពីទិសដៅ ................................................................................ ១២០៣
១០៣. សេចក្ដីដាស់តឿនទាំងបី ............................................................. ១២០៩
១០៤. អំពើរំលងនឹងនាំមនុស្សទៅកាន់ស្ថាននរក .................................... ១២១៦
១០៥. ការយល់ដឹងអំពីនិស្ស័យរបស់ព្រះជាម្ចាស់ ពិតជាសំខាន់ក្រៃលែង ....... ១២២៤
១០៦. វិធីស្គាល់ព្រះដែលគង់នៅលើផែនដី ........................................... ១២៣៣

១០៧. បញ្ហាដ៏ធ្ងន់ធ្ងរមួយ៖ អំពើក្បត់ (១) ................................................ ១២៤២
១០៨. បញ្ហាដ៏ធ្ងន់ធ្ងរមួយ៖ អំពើក្បត់ (២) ................................................ ១២៤៨
១០៩. អ្នករាល់គ្នាត្រូវតែពិចារណានូវទង្វើរបស់ខ្លួន .................................. ១២៥៥
១១០. ព្រះជាម្ចាស់ គឺជាប្រភពនៃជីវិតមនុស្ស ........................................ ១២៦២
១១១. ខ្យល់ដង្ហើមនៃព្រះដ៏មានគ្រប់ចេស្ដា ............................................ ១២៦៩
១១២. ការលេចមករបស់ព្រះជាម្ចាស់ បានចាប់ផ្ដើមក្នុងយុគសម័យថ្មីមួយ ....... ១២៧៥
១១៣. ព្រះជាម្ចាស់គ្រប់គ្រងលើវាសនារបស់មនុស្សលោកទាំងអស់ ............ ១២៨២
១១៤. ការស្គាល់ព្រះជាម្ចាស់ គឺជាផ្លូវឆ្ពោះទៅរកការកោតខ្លាចព្រះជាម្ចាស់
និងការគេចចេញពីសេចក្ដីអាក្រក់ ................................................ ១២៩២
១១៥. ការមើលឃើញការលេចមករបស់ព្រះជាម្ចាស់
នៅក្នុងការជំនុំជម្រះ និងការវាយផ្ចាលរបស់ទ្រង់ ............................ ១៣០៨

# ជំពូកទី ១៖ ព្រះសូរសៀងរបស់ព្រះគ្រីស្ទ កាលពីដើមដំបូង

ការសរសើរបានមកដល់ភ្នំស៊ីយ៉ូន ហើយព្រះដំណាក់របស់ព្រះជាម្ចាស់បានលេចមកដែរ។ ព្រះនាមដ៏បរិសុទ្ធពេញដោយសិរីល្អ ដែលមនុស្សទាំងអស់លើកសរសើរនោះរីកសាយភាយ។ ឱព្រះដ៏មានគ្រប់ព្រះចេស្ដាអើយ! ព្រះសិរសានៃចក្រវាឡ ព្រះគ្រីស្ទនៃគ្រាចុងក្រោយ ទ្រង់គឺជាព្រះអាទិត្យដ៏ចាំងចែង ដែលបានរះឡើងនៅលើភ្នំស៊ីយ៉ូន ដែលលេចត្រដែតឡើងដោយឫទ្ធានុភាព និងអំណាចដ៏ថ្កុំថ្កើងទៅលើចក្រវាឡទាំងមូល ...

ព្រះដ៏មានគ្រប់ព្រះចេស្ដាអើយ! ពួកយើងអំពាវនាវរកទ្រង់ក្នុងសេចក្ដីរីករាយយ៉ាងខ្លាំង ហើយពួកយើងរាំច្រៀង។ ទ្រង់ជាព្រះប្រោសលោះដ៏ពិតរបស់ពួកយើង ជាស្ដេចដ៏ធំធេងនៃចក្រវាឡ! ទ្រង់បានបង្កើតអ្នកមានជ័យជម្នះមួយក្រុម ហើយបានសម្រេចផែនការគ្រប់គ្រងរបស់ព្រះជាម្ចាស់។ មនុស្សទាំងអស់នឹងចូលហូរហែទៅរកភ្នំនេះ។ មនុស្សទាំងអស់នឹងលុតជង្គង់នៅមុខបល្ល័ង្ក! ទ្រង់ជាព្រះដ៏ពិតតែមួយប៉ុណ្ណោះ ហើយទ្រង់សក្ដិសមទទួលសិរីល្អ និងការលើកតម្កើង។ សូមថ្វាយគ្រប់ទាំងសិរីល្អ ការសរសើរតម្កើង និងសិទ្ធិអំណាចដល់បល្ល័ង្កនៃទ្រង់! ប្រភពទឹកនៃជីវិតហូរចេញមកពីបល្ល័ង្កទ្រង់ ស្រោចស្រព និងចម្អែតដល់ប្រជារាស្ដ្ររបស់ព្រះជាម្ចាស់ដ៏ច្រើនសន្ធឹកសន្ធាប់។ ជីវិតផ្លាស់ប្ដូរជារៀងរាល់ថ្ងៃ ហើយពន្លឺនិងការបើកសម្ដែងថ្មីតាមពីក្រោយពួកយើង ដែលតែងតែផ្ដល់ដល់ឱ្យពួកយើងនូវគតិជ្រៅជ្រះថ្មីៗ អំពីព្រះជាម្ចាស់។ នៅក្នុងបទពិសោធផ្សេងៗ ពួកយើងចាប់ផ្ដើមមានភាពច្បាស់លាស់ទាំងស្រុង អំពីព្រះជាម្ចាស់។ ព្រះបន្ទូលរបស់ទ្រង់ត្រូវបានស្ដែងចេញជានិច្ចនៅក្នុងចំណោមមនុស្សសុចរិត។ ពួកយើងពិតជាមានពរខ្លាំងណាស់! ដោយជួបជាមួយព្រះជាម្ចាស់មុខទល់នឹងមុខរាល់ថ្ងៃ ប្រាស្រ័យទាក់ទងជាមួយព្រះជាម្ចាស់នៅក្នុងរបស់សព្វសារពើ ហើយផ្ដល់ឲ្យព្រះជាម្ចាស់នូវអធិបតេយ្យភាពលើអ្វីៗទាំងអស់។ ពួកយើងសញ្ជឹងគិតលើព្រះបន្ទូលរបស់ព្រះជាម្ចាស់យ៉ាងប្រុងប្រយ័ត្ន ដួងចិត្តរបស់ពួកយើងសម្រាកយ៉ាង

ស្ងប់ស្ងាត់នៅក្នុងព្រះជាម្ចាស់ ហើយពួកយើងក៏មកចំពោះព្រះភ័ក្ត្ររបស់ព្រះជាម្ចាស់ដែរ ជាកន្លែងដែលយើងទទួលបានពន្លឺរបស់ទ្រង់។ រាល់ថ្ងៃ នៅក្នុងជីវិត ទង្វើ ពាក្យសម្ដី គំនិត និងយោបល់របស់យើង យើងរស់នៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយស្គាល់ខុស ស្គាល់ត្រូវគ្រប់ពេលវេលា។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដឹកនាំផ្លូវនៃជីវិត ហើយដោយមិនបានរំពឹងទុក រឿងលាក់កំបាំងខាងក្នុងចិត្តយើង ត្រូវបានលេចចេញមកនៅក្នុងពន្លឺម្ដងមួយៗ។ ការប្រកបគ្នាជាមួយព្រះជាម្ចាស់ ត្រូវធ្វើឡើងដោយគ្មានការពន្យារពេលឡើយ ហើយរាល់គំនិត និងយោបល់របស់យើងត្រូវបានព្រះជាម្ចាស់លាតត្រដាងឲ្យឃើញទាំងអស់។ យើងកំពុងតែរស់នៅមុខបល្ល័ង្ករបស់ព្រះគ្រីស្ទគ្រប់ពេលវេលា ដ្បិតនៅទីនោះ ជាកន្លែងដែលយើងត្រូវទទួលការជំនុំជម្រះ។ សាតាំងនៅបន្តកាន់កាប់គ្រប់កន្លែងនៅក្នុងរូបកាយរបស់យើង។ នៅថ្ងៃនេះ ដើម្បីស្ដារអធិបតេយ្យភាពរបស់ព្រះជាម្ចាស់ឡើងវិញ ព្រះវិហាររបស់ទ្រង់ត្រូវតែលាងជម្រះឲ្យស្អាតសិន។ ដើម្បីឲ្យព្រះជាម្ចាស់កាន់កាប់ទាំងស្រុង យើងត្រូវតែចូលរួមនៅក្នុងការប្រយុទ្ធស្លាប់រស់មួយនេះ។ មានតែនៅពេលដែលជីវិតចាស់របស់ពួកយើង ត្រូវបានជាប់ឆ្កាងប៉ុណ្ណោះ ទើបជីវិតដែលរស់ឡើងវិញរបស់ព្រះគ្រីស្ទ អាចសោយរាជ្យដល់កម្រិតខ្ពស់បំផុតបាន។

ឥឡូវនេះ ព្រះវិញ្ញាណបរិសុទ្ធកំពុងតែចាត់ចែងគ្រប់គ្រង លើគ្រប់ផ្នែកនៃជីវិតរបស់យើង ដើម្បីចូលរួមប្រយុទ្ធសម្រាប់ការស្ដារឡើងវិញរបស់យើង! ដរាបណាយើងត្រៀមខ្លួនជាស្រេច ដើម្បីបដិសេធខ្លួនឯង ហើយព្រមសហការជាមួយព្រះជាម្ចាស់ នោះព្រះជាម្ចាស់នឹងប្រាកដជាបំភ្លឺ និងបន្សុទ្ធចិត្តរបស់យើងគ្រប់ពេលវេលា ហើយទាមទារមកវិញនូវអ្វីដែលសាតាំងបានកាន់កាប់ ដើម្បីឲ្យយើងអាចត្រូវបានប្រោសឲ្យពេញខ្នាត ដោយព្រះជាម្ចាស់កាន់តែឆាប់តាមដែលអាចធ្វើទៅបាន។ ចូរកុំខ្ជះខ្ជាយពេលវេលាឡើយ។ ចូររស់នៅគ្រប់វិនាទីនៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ចូរស្អាងឡើងជាមួយពួកបរិសុទ្ធ ហើយត្រូវបាននាំចូលទៅក្នុងនគរព្រះ ព្រមទាំងចូលទៅក្នុងសិរីល្អជារួមជាមួយព្រះជាម្ចាស់។

# ជំពូកទី ២៖ ព្រះសូរសៀងរបស់ព្រះគ្រីស្ទ កាលពីដើមដំបូង

ពួកជំនុំនៅក្រុងភីឡាដិលភា បានកើតឡើងដោយសារតែព្រះគុណ ហើយនិងសេចក្ដីមេត្តាករុណារបស់ព្រះជាម្ចាស់ទាំងស្រុងតែម្ដង។ សេចក្ដីស្រឡាញ់ចំពោះព្រះជាម្ចាស់កើនឡើងនៅក្នុងដួងចិត្តរបស់ពួកបរិសុទ្ធដ៏ច្រើនអនេក ដែលមិនរារែកចិត្តនៅក្នុងដំណើរផ្លូវខាងវិញ្ញាណរបស់គេឡើយ។ ពួកគេបានប្រកាន់ខ្ជាប់ទៅនឹងជំនឿរបស់គេដែលជឿថា ព្រះដ៏ពិតតែមួយអង្គបានត្រលប់ជាសាច់ឈាម ជឿថាទ្រង់ជាព្រះសិរសានៃចក្រវាឡ ដែលបញ្ជាលើរបស់សព្វសារពើ៖ ជំនឿនេះត្រូវបានបញ្ជាក់ដោយព្រះវិញ្ញាណបរិសុទ្ធ ជាជំនឿមួយដ៏រឹងមាំដែលមិនអាចរើបានដូចជាភ្នំអ៊ីចឹង។ ហើយវានឹងមិនដែលផ្លាស់ប្ដូរឡើយ!

ឱព្រះដ៏មានគ្រប់ព្រះចេស្ដាអើយ! នៅថ្ងៃនេះ គឺជាទ្រង់ហើយដែលបានបើកភ្នែកខាងវិញ្ញាណរបស់ពួកយើង ដែលជួយឲ្យមនុស្សខ្វាក់មើលឃើញ ជួយឲ្យមនុស្សខ្វិនដើរបាន និងជួយឲ្យមនុស្សឃ្លង់បានជាស្អាត។ គឺជាទ្រង់ហើយដែលបានបើកទ្វារនៃស្ថានសួគ៌ ដើម្បីជួយឲ្យយើងយល់ពីសេចក្ដីលាក់កំបាំងនៃពិភពខាងវិញ្ញាណ។ ដោយត្រូវបានជ្រួតជ្រាបដោយព្រះបន្ទូលដ៏បរិសុទ្ធរបស់ទ្រង់ និងត្រូវបានសង្គ្រោះពីភាពជាមនុស្សរបស់ពួកយើង ដែលត្រូវបានសាតាំងធ្វើឱ្យពុករលួយ ពោលគឺទាំងអស់នេះជាកិច្ចការ និងសេចក្ដីមេត្តាករុណាដ៏ធំធេងលើសលប់របស់ទ្រង់។ ពួកយើងគឺជាស្មរបន្ទាល់របស់ទ្រង់!

ទ្រង់បានលាក់អង្គទ្រង់ជាយូរណាស់មកហើយ ដោយបន្ទាបព្រះអង្គទ្រង់ និងដោយស្ងប់ស្ងាត់។ ទ្រង់បានឆ្លងកាត់ការរស់ពីសុគតឡើងវិញ បានរងទុក្ខដោយការជាប់ឆ្កាង បានឆ្លងកាត់អំណរ និងទុក្ខព្រួយនៃជីវិតជាមនុស្ស ហើយបានជួបនូវការបៀតបៀន និងទុក្ខវេទនាជាច្រើន ទ្រង់បានដកពិសោធន៍ និងស្គាល់រសជាតិនៃការឈឺចាប់នៅក្នុងពិភពលោករបស់មនុស្ស ហើយទ្រង់ត្រូវបានមនុស្សជំនាន់នេះ

បោះបង់ចោល។ ព្រះដែលយកកំណើតជាមនុស្ស គឺជាព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ។ សម្រាប់ជាប្រយោជន៍ដល់បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ទ្រង់បានសង្គ្រោះពួកយើងពីគំនរលាមកសត្វ កាន់ពួកយើងដោយព្រះហស្តស្ដាំរបស់ទ្រង់ ហើយប្រទានព្រះគុណរបស់ទ្រង់ដល់យើងដោយឥតគិតថ្លៃ។ ដោយទទួលយករាល់ការឈឺចាប់គ្រប់យ៉ាង ទ្រង់បានលះបង់ព្រះជន្មទ្រង់ឲ្យយើង ហើយតម្លៃដែលទ្រង់បានបង់ដោយព្រះលោហិត ញើស និងទឹកព្រះនេត្រទ្រង់ ត្រូវបានស្ដែងចេញយ៉ាងច្បាស់នៅក្នុងពួកបរិសុទ្ធ។ ពួកយើងគឺជាលទ្ធផលចេញពី[ក] កិច្ចខិតខំប្រឹងប្រែងដ៏ប្រុងប្រយ័ត្នរបស់ទ្រង់ ហើយពួកយើងគឺជាតម្លៃដែលទ្រង់បានបង់។

ឱ ព្រះដ៏មានគ្រប់ព្រះចេស្ដាអើយ! គឺដោយសារតែព្រះទ័យសប្បុរសដែលពេញដោយសេចក្ដីស្រលាញ់ និងសេចក្ដីមេត្តាករុណារបស់ទ្រង់ សេចក្ដីសុចរិត និងឫទ្ធានុភាពរបស់ទ្រង់ ភាពបរិសុទ្ធ និងការបន្ទាបព្រះអង្គទ្រង់របស់ទ្រង់នេះហើយ ដែលនាំឲ្យមនុស្សទាំងអស់លុតជង្គង់នៅចំពោះព្រះភ័ក្ត្រទ្រង់ និងថ្វាយបង្គំទ្រង់អស់កល្បជានិច្ចនោះ។

នៅថ្ងៃនេះ ទ្រង់បានធ្វើឲ្យពួកជំនុំទាំងអស់ពេញខ្នាត ដូចជា ពួកជំនុំនៃក្រុងភីឡាដិលភា ហើយទ្រង់បានសម្រេចផែនការគ្រប់គ្រងរយៈពេល៦០០០ឆ្នាំរបស់ទ្រង់។ ពួកបរិសុទ្ធអាចចុះចូលដោយបន្ទាបខ្លួននៅចំពោះទ្រង់ ផ្សារភ្ជាប់ខាងវិញ្ញាណ និងការដើរតាមនៅក្នុងសេចក្ដីស្រឡាញ់ ដោយចូលរួមទៅនឹងប្រភពទឹក។ ទឹកដ៏រស់នៃជីវិតហូរឥតឈប់ ដោយលាងជម្រះ និងកម្ចាត់ចោលរាល់ភក់ជ្រាំ និងទឹកស្មោកគ្រោកដែលមាននៅក្នុងពួកជំនុំ ដើម្បីបន្សុទ្ធព្រះវិហាររបស់ទ្រង់ម្ដងទៀត។ យើងបានស្គាល់ព្រះដ៏ពិតជាក់ស្ដែង បានដើរនៅក្នុងព្រះបន្ទូលរបស់ទ្រង់ បានទទួលស្គាល់មុខងារ និងភារកិច្ចរបស់យើង ហើយបានធ្វើអ្វីៗគ្រប់យ៉ាងដែលយើងអាចធ្វើបាន ដើម្បីលះបង់ខ្លួនឯងសម្រាប់ជាប្រយោជន៍ដល់ពួកជំនុំ។ ដោយនៅស្ងប់ស្ងៀមចំពោះទ្រង់ យើង

លេខយោង៖

ក. អត្ថបទដើមមិនមានឃ្លា «លទ្ធផលចេញពី»។

ត្រូវតែយកចិត្តទុកដាក់មើលកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធ ដើម្បីកុំឲ្យព្រះហឫទ័យរបស់ទ្រង់ត្រូវបានរាំងស្ទះនៅក្នុងយើង។ នៅក្នុងចំណោមពួកបរិសុទ្ធនៅក្រុងនោះ ពួកគេមាននូវសេចក្ដីស្រឡាញ់ចំពោះគ្នា ហើយចំណុចខ្លាំងរបស់អ្នកខ្លះ នឹងជួយបំពេញបន្ថែមដល់ចំណុចខ្វះខាតរបស់អ្នកផ្សេងទៀត។ ពួកគេអាចដើរដោយវិញ្ញាណគ្រប់ពេល ដោយទទួលបានការស្រាយបំភ្លឺ និងការពន្យល់ពីព្រះវិញ្ញាណបរិសុទ្ធ។ ពួកគេអនុវត្តតាមសេចក្ដីពិតភ្លាមៗ នៅពេលដែលពួកគេយល់។ ពួកគេបន្តដើរតាមឲ្យទាន់ពន្លឺថ្មី និងដើរតាមជំហានព្រះបាទារបស់ព្រះជាម្ចាស់។

ចូរសហការជាមួយព្រះជាម្ចាស់យ៉ាងសកម្ម ហើយការអនុញ្ញាតឲ្យទ្រង់ត្រួតត្រា គឺជាការដើរជាមួយទ្រង់។ គ្រប់ទាំងគំនិត សញ្ញាណ យោបល់ និងការជាប់ជំពាក់ខាងលោកីយ៍ ត្រូវរលាយបាត់ទៅក្នុងខ្យល់ដូចជាផ្សែង។ យើងអនុញ្ញាតឲ្យព្រះជាម្ចាស់សោយរាជ្យដ៏ខ្ពង់ខ្ពស់នៅក្នុងវិញ្ញាណរបស់យើង ដើរជាមួយទ្រង់ និងទទួលបានភាពខ្ពង់ខ្ពស់ យកឈ្នះលើលោកីយ៍ ហើយវិញ្ញាណរបស់យើងមានសេរីភាពហោះហើរដោយសេរី និងទទួលបានការដោះលែង៖ នេះគឺជាលទ្ធផលនៅពេលដែលព្រះដ៏មានគ្រប់ព្រះចេស្ដាក្លាយជាស្ដេច។ តើយើងអាចមិនរាំច្រៀងនៅក្នុងការសរសើរតម្កើងដោយថ្វាយការសរសើរតម្កើងរបស់យើង និងច្រៀងបទទំនុកថ្មីយ៉ាងដូចម្ដេច?

មានផ្លូវដ៏ពិតជាច្រើន ដើម្បីសរសើរព្រះជាម្ចាស់៖ ការអំពាវនាវរកព្រះនាមទ្រង់ ការចូលទៅជិតទ្រង់ ការគិតអំពីទ្រង់ ការអានសេចក្ដីអធិស្ឋាន ការចូលរួមនៅក្នុងការប្រកបគ្នា ការសញ្ជឹងគិត ការអធិស្ឋាន និងបទចម្រៀងនៃការសរសើរតម្កើង។ នៅក្នុងប្រភេទនៃការសរសើរទាំងនេះ មាននូវសេចក្ដីរីករាយ និងមាននូវការចាក់ប្រេងតាំង ហើយមានអំណាចនៅក្នុងការសរសើរតម្កើង ហើយក៏មាននូវបន្ទុកមួយដែរ។ មាននូវសេចក្ដីជំនឿនៅក្នុងការសរសើរតម្កើង ហើយក៏មានគតិជ្រៅជ្រះថ្មីដែរ។

ចូរសហការជាមួយព្រះជាម្ចាស់យ៉ាងសកម្ម ហើយសម្របសម្រួលនៅក្នុងការបម្រើ និងមានចិត្តតែមួយ ចូរសម្រេចបំណងព្រះហឫទ័យរបស់ព្រះដ៏មានគ្រប់ព្រះចេស្ដា ចូរប្រញាប់ក្លាយជារូបកាយខាងវិញ្ញាណដ៏បរិសុទ្ធមួយ ចូរយកឈ្នះលើសាតាំង ហើយ

បញ្ចប់នូវវាសនារបស់សាតាំង។ ពួកជំនុំភីឡាដិលភា ត្រូវបានលើកឡើងទៅលើពពកចូលទៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់ ហើយត្រូវបានបង្ហាញចេញយ៉ាងច្បាស់នៅក្នុងសិរីល្អរបស់ទ្រង់។

## ជំពូកទី ៣៖ ព្រះសូរសៀងរបស់ព្រះគ្រីស្ទ កាលពីដើមដំបូង

ស្ដេចដ៏មានជ័យ គង់នៅលើបល្ល័ង្កដ៏ពេញដោយសិរីល្អរបស់ទ្រង់។ ទ្រង់បានសម្រេចនូវការប្រោសលោះ និងបានដឹកនាំប្រជារាស្ត្ររបស់ទ្រង់ទាំងអស់ ឲ្យលេចមកនៅក្នុងសិរីល្អ។ ទ្រង់ក្ដាប់ចក្រវាឡទាំងមូលនៅក្នុងព្រះហស្ដរបស់ទ្រង់ ហើយជាមួយព្រះប្រាជ្ញាញាណ និងឫទ្ធិអំណាចរបស់ទ្រង់ ទ្រង់បានសង់ និងបានបង្កើតទីក្រុងស៊ីយ៉ូនដ៏រឹងមាំ។ ដោយឫទ្ធានុភាពរបស់ទ្រង់ ទ្រង់ធ្វើការជំនុំជម្រះពិភពលោកដែលពោរពេញដោយបាប។ ទ្រង់បានទម្លាក់ការជំនុំជម្រះមកលើប្រជាជាតិនានា និងមនុស្សគ្រប់ជាតិសាសន៍ ផែនដី និងសមុទ្រ ព្រមទាំងគ្រប់ភាវៈមានជីវិតនៅក្នុងនោះ ក៏ដូចជាអស់អ្នកដែលងប់ងល់នឹងកាមគុណថោកទាបដែរ។ ព្រះជាម្ចាស់ច្បាស់ជានឹងជំនុំជម្រះពួកគេ ហើយទ្រង់ប្រាកដជានឹងក្រោធចំពោះពួកគេ ហើយជាលទ្ធផលឫទ្ធានុភាពរបស់ព្រះជាម្ចាស់នឹងត្រូវបើកសម្ដែង ហើយការជំនុំជម្រះរបស់ទ្រង់នឹងត្រូវធ្វើឡើងភ្លាមៗ ដោយគ្មានការពន្យារពេលឡើយ។ ភ្លើងនៃសេចក្ដីក្រោធរបស់ទ្រង់ប្រាកដជានឹងដុតរំលាយអំពើដ៏សាហាវយង់ឃ្នងរបស់ពួកគេ ហើយទុក្ខលំបាកនឹងធ្លាក់លើពួកគេគ្រប់ពេលវេលា។ ពួកគេនឹងមិនស្គាល់ផ្លូវដើម្បីឲ្យបានរួចខ្លួន ហើយក៏គ្មានកន្លែងដើម្បីលាក់ខ្លួនដែរ។ ពួកគេនឹងយំ ព្រមទាំងសង្កៀតធ្មេញ ហើយពួកគេនឹងនាំសេចក្ដីវិនាសមកដាក់លើខ្លួនឯង។

ពួកកូនប្រុសដ៏មានជ័យ និងជាស្ងួនភ្ងាររបស់ព្រះជាម្ចាស់ ប្រាកដជានឹងស្នាក់នៅក្នុងក្រុងស៊ីយ៉ូន ហើយមិនដែលចាកចេញពីទីក្រុងនេះឡើយ។ មនុស្សដ៏ច្រើនសន្ធឹក

សន្ទាប់ នឹងស្ដាប់ព្រះសូរសៀងរបស់ទ្រង់យ៉ាងយកចិត្តទុកដាក់ ពួកគេនឹងមើលសកម្មភាពរបស់ទ្រង់យ៉ាងយកចិត្តទុកដាក់ ហើយសំឡេងនៃការសរសើររបស់គេនឹងមិនដែលឈប់សោះឡើយ។ ព្រះដ៏ពិតតែមួយអង្គបានលេចមកហើយ! យើងនឹងស្គាល់ទ្រង់ច្បាស់នៅក្នុងវិញ្ញាណ ហើយដើរតាមទ្រង់យ៉ាងប្រកៀកប្រកិត។ យើងនឹងប្រញាប់ប្រញាល់ធ្វើដំណើរទៅមុខដោយអស់ពីកម្លាំងរបស់យើង និងលែងស្ទាក់ស្ទើរទៀតហើយ។ ចុងបញ្ចប់នៃពិភពលោកកំពុងតែលាតត្រដាងនៅមុខយើង ហើយជីវិតពួកជំនុំដ៏ត្រឹមត្រូវ ក៏ដូចជាមនុស្ស កិច្ចការ និងរឿងរ៉ាវដែលកើតឡើងជុំវិញយើង ក៏កំពុងតែបង្កើនកម្ដៅកាន់តែខ្លាំងដល់ការហ្វឹកហាត់របស់យើងដែរ។ ចូរយើងប្រញាប់យកដួងចិត្តរបស់យើងដែលស្រឡាញ់លោកីយ៍នោះ ត្រឡប់មកវិញ! ចូរយើងប្រញាប់យកនិមិត្តរបស់យើងដែលស្រអាប់ខ្លាំងនោះ ត្រឡប់មកវិញ! ចូរយើងបន្តនៅជាប់នឹងជំហានរបស់យើង ដើម្បីកុំឲ្យយើងដើរហួសព្រំដែន។ ចូរយើងទប់មាត់របស់យើង ដើម្បីឲ្យយើងអាចដើរនៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយលែងទាស់ទែងគ្នាអំពីរឿងផលប្រយោជន៍ និងការខាតបង់របស់យើងតទៅទៀត។ ចូរលះបង់ចោលចុះនូវភាពលោភលន់របស់អ្នកចំពោះលោកីយ៍ និងការស្រឡាញ់ទ្រព្យសម្បត្តិ! ចូរឲ្យខ្លួនអ្នកមានសេរីភាពពីចំណងដែលនៅស្អិតជាប់របស់អ្នកចំពោះស្វាមី និងកូនប្រុសស្រីរបស់អ្នក! ចូរបែរខ្នងទៅកាន់ទស្សនៈ និងបុរេវិនិច្ឆ័យរបស់អ្នកចុះ! ចូរភ្ញាក់ខ្លួនឡើង ដ្បិតពេលវេលាខ្លីណាស់! ចូរសម្លឹងទៅលើចុះ ចូរសម្លឹងទៅលើដោយចេញពីវិញ្ញាណ ហើយអនុញ្ញាតឲ្យព្រះជាម្ចាស់គ្រប់គ្រងចុះ។ មិនថាមានអ្វីៗកើតឡើងឡើយ ចូរកុំធ្វើដូចជាភរិយារបស់ឡុតនោះឡើយ។ វាពិតជាគួរឲ្យអាណិតណាស់ ដែលត្រូវគេបោះចោលទៅម្ខាង! វាពិតជាគួរឲ្យអាណិតណាស់! ចូរភ្ញាក់ខ្លួនឡើង!

# ជំពូកទី ៥៖ ព្រះសូរសៀងរបស់ព្រះគ្រីស្ទកាលពីដើមដំបូង

ភ្នំ និងទន្លេផ្លាស់ប្ដូរ ទឹកហូរទៅតាមចរន្តរបស់វា ហើយជីវិតរបស់មនុស្សមិនអាចឋិតថេរដូចផែនដី និងផ្ទៃមេឃនោះទេ។ មានតែព្រះដ៏មានគ្រប់ព្រះចេស្ដាប៉ុណ្ណោះ ដែលមានព្រះជន្មអស់កល្បជានិច្ច និងមានព្រះជន្មរស់ឡើងវិញ ដែលបន្តពីជំនាន់មួយទៅជំនាន់មួយជារៀងរហូត! របស់សព្វសារពើ និងហេតុការណ៍ទាំងអស់ស្ថិតនៅក្នុងព្រះហស្តរបស់ទ្រង់ ហើយសាតាំងស្ថិតនៅក្រោមព្រះបាទទ្រង់។

ថ្ងៃនេះ គឺដោយសារតែការជ្រើសរើសតាមការកំណត់របស់ព្រះជាម្ចាស់ ទើបទ្រង់រំដោះយើងចេញពីក្រញាំរបស់សាតាំង។ ទ្រង់ពិតជាព្រះដ៏ប្រោសលោះរបស់យើងប្រាកដមែន។ ព្រះជន្មដែលបានរស់ឡើងវិញ និងអស់កល្បជានិច្ចរបស់ព្រះគ្រីស្ទពិតជាបានធ្វើការនៅក្នុងយើង ដោយកំណត់ឲ្យយើងមានទំនាក់ទំនងជាមួយនឹងព្រះជន្មរបស់ព្រះជាម្ចាស់ ដែលយើងអាចមកជួបផ្ទាល់ជាមួយទ្រង់ ហូបទ្រង់ ផឹកទ្រង់ និងរីករាយនឹងទ្រង់។ នេះគឺជាតង្វាយដោយមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួន ដែលព្រះជាម្ចាស់បានប្រទាន ដោយថ្លៃលោហិតបេះដូងរបស់ទ្រង់។

រដូវកាលនានាចូលមកហើយទៅវិញ ដោយឆ្លងកាត់ខ្យល់ និងសន្សើម ជួបនឹងការឈឺចាប់ ការធ្វើទុក្ខបុកម្នេញ និងការរងទុក្ខជាច្រើនរបស់ជីវិត ជួបនឹងការមិនទទួលស្គាល់ និងការបង្កាច់បង្ខូចជាច្រើនរបស់លោកីយ៍ ជួបនឹងការចោទប្រកាន់ក្លែងក្លាយជាច្រើនរបស់រដ្ឋាភិបាល ប៉ុន្តែសេចក្ដីជំនឿរបស់ព្រះជាម្ចាស់ និងការប្ដេជ្ញារបស់ទ្រង់ មិនថមថយសូម្បីតែបន្តិច។ ទ្រង់ទុកព្រះជន្មផ្ទាល់របស់ទ្រង់មួយឡែក ដោយលះបង់ចំពោះបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងចំពោះផែនការព្រមទាំងការគ្រប់គ្រងរបស់ព្រះជាម្ចាស់ ដើម្បីឲ្យកិច្ចការទាំងនោះអាចសម្រេចបាន។ ទ្រង់មិនសំចៃចំពោះការឈឺចាប់នោះទេ ដើម្បីរាស្ត្រជាច្រើនរបស់ទ្រង់ ដោយការចិញ្ចឹមបីបាច់ និងស្រោចស្រពពួកគេយ៉ាងយកចិត្តទុកដាក់។ មិនថាយើងងងឹតងងល់

យ៉ាងណា ឬលំបាកយ៉ាងណានោះទេ យើងត្រូវតែចុះចូលចំពោះទ្រង់ ហើយព្រះជន្ម រស់ឡើងវិញរបស់ព្រះគ្រីស្ទ នឹងផ្លាស់ប្ដូរធម្មជាតិចាស់របស់យើង...។ ដើម្បីពួកកូនប្រុសច្បងទាំងអស់នេះ ទ្រង់ធ្វើការដោយមិននឿយហត់ ដោយមិនសោយអាហារ និងមិនសម្រាក។ ជាច្រើនថ្ងៃ និងច្រើនយប់ ដែលទ្រង់ទតមើលស៊ីយ៉ូនដោយអស់ពីព្រះទ័យ តាមរយៈកម្ដៅដ៏ក្ដៅហែង និងភាពត្រជាក់ស្ទើរកក។

លោកីយ៍ ផ្ទះសម្បែង កិច្ចការ និងគ្រប់យ៉ាងបានកន្លងផុតទៅទាំងស្រុងយ៉ាងរីករាយ និងស្ម័គ្រចិត្ត ហើយការសប្បាយតាមបែបលោកីយ៍ មិនជាប់ទាក់ទងនឹងទ្រង់ឡើយ...។ ព្រះបន្ទូលដែលចេញពីព្រះឱស្ឋរបស់ទ្រង់ វាយលុកចូលទៅក្នុងយើង ដោយបើកបង្ហាញអ្វីៗដែលលាក់ទុកយ៉ាងជ្រៅនៅក្នុងចិត្តរបស់យើង។ តើយើងអាចមិនជឿដូចម្ដេចកើត? ប្រយោគនីមួយៗដែលចេញពីព្រះឱស្ឋរបស់ទ្រង់ អាចក្លាយជាការពិតនៅក្នុងយើងគ្រប់ពេលវេលា។ អ្វីក៏ដោយដែលយើងធ្វើ ទោះនៅចំពោះទ្រង់ក្ដី ឬលាក់បាំងពីទ្រង់ក្ដី គឺគ្មានអ្វីដែលទ្រង់មិនជ្រាបនោះទេ គ្មានអ្វីដែលទ្រង់មិនយល់ឡើយ។ គ្រប់យ៉ាងនឹងបើកសម្ដែងនៅចំពោះទ្រង់យ៉ាងពិតប្រាកដ មិនថាផែនការ និងការរៀបចំផ្ទាល់ខ្លួនរបស់ពួកយើងនោះទេ។

ការអង្គុយនៅចំពោះទ្រង់ប្រកបដោយភាពស្រោកស្រាន្ត និងស្ងប់ស្ងាត់ ដោយមានអារម្មណ៍រីករាយនៅក្នុងវិញ្ញាណរបស់យើង ប៉ុន្តែអារម្មណ៍តែងតែទទេសូន្យ ហើយពិតជាជាប់ជំពាក់ជាមួយព្រះជាម្ចាស់៖ នេះគឺជាការអស្ចារ្យមួយដែលមិនអាចគិតដល់ និងមិនអាចសម្រេចបាន។ ព្រះវិញ្ញាណបរិសុទ្ធល្មមគ្រប់គ្រាន់ក្នុងការអះអាងថា ព្រះដ៏មានគ្រប់ព្រះចេស្ដា គឺជាព្រះជាម្ចាស់ដ៏ពិតមួយអង្គ! វាគឺជាអំណះអំណាងដែលមិនអាចប្រកែកបាន! យើងទាំងអស់គ្នាដែលនៅក្នុងក្រុមនេះពិតជាមានព្រះពរមិនអាចពណ៌នាបាន! ប្រសិនបើមិនមែនដោយសារព្រះគុណ និងសេចក្ដីមេត្តាករុណារបស់ព្រះជាម្ចាស់ទេ នោះយើងមានតែអាចត្រូវវិនាស និងដើរតាមសាតាំងប៉ុណ្ណោះ។ មានតែព្រះដ៏មានគ្រប់ព្រះចេស្ដាប៉ុណ្ណោះដែលអាចសង្គ្រោះយើងបាន!

ឱ! ព្រះដ៏មានគ្រប់ព្រះចេស្ដា ព្រះដ៏ជាក់ស្ដែងអើយ! គឺទ្រង់ហើយដែលបានបើក

ភ្នែកខាងវិញ្ញាណរបស់ពួកយើង ដោយអនុញ្ញាតឲ្យពួកយើងយល់ អំពីអាថ៌កំបាំងនៃពិភពខាងវិញ្ញាណ។ ទិដ្ឋភាពនៃនគរព្រះគ្មានព្រំដែនកំណត់នោះទេ។ ចូរយើងប្រុងប្រយ័ត្នខណៈដែលយើងកំពង់រង់ចាំ។ ពេលវេលាជិតមកដល់ហើយ។

អណ្ដាតភ្លើងនៃសង្គ្រាមកួចឡើង ផ្សែងកាំភ្លើងធំពេញផ្ទៃអាកាស ធាតុអាកាសប្រែជាក្ដៅឧណ្ហៗ អាកាសធាតុផ្លាស់ប្ដូរ គ្រោះចង្រៃនឹងលាតសន្ធឹង ហើយមនុស្សមិនអាចធ្វើអ្វីបានក្រៅពីស្លាប់ដោយគ្មានសង្ឃឹមរស់រានមានជីវិតនោះទេ។

ឱ! ព្រះដ៏មានគ្រប់ព្រះចេស្ដា ព្រះដ៏ជាក់ស្ដែងអើយ! គឺទ្រង់ហើយដែលជាបន្ទាយដ៏រឹងមាំរបស់ពួកយើង។ ទ្រង់គឺជាទីជម្រករបស់ពួកយើង។ ពួកយើងប្រមូលផ្ដុំគ្នានៅក្រោមស្លាបរបស់ទ្រង់ ហើយគ្រោះភ័យមិនអាចប៉ះពាល់យើងបានទេ។ នេះគឺជាការការពារ និងការថែរក្សានៃភាពជាព្រះរបស់ទ្រង់។

ពួកយើងទាំងអស់គ្នា បន្លឺសម្លេងឡើងជាបទចម្រៀង។ ពួកយើងច្រៀងដោយការសរសើរតម្កើង ហើយសម្លេងនៃការសរសើរតម្កើងរបស់ពួកយើង បន្លឺទូទាំងក្រុងស៊ីយ៉ូន! ព្រះដ៏មានគ្រប់ព្រះចេស្ដា ព្រះដ៏ជាក់ស្ដែង បានរៀបចំទិសដៅដ៏រុងរឿងនោះសម្រាប់ពួកយើង។ ចូរប្រុងប្រយ័ត្ន អូ! ចូរប្រយ័ត្នប្រយែង! មកដល់ពេលនេះពេលវេលាមិនទាន់ហួសនៅឡើយទេ។

# ជំពូកទី ១៥៖ ព្រះសូរសៀងរបស់ព្រះគ្រីស្ទកាលពីដើមដំបូង

ការលេចមករបស់ព្រះជាម្ចាស់ បានកើតឡើងនៅក្នុងក្រុមជំនុំទាំងអស់រួចហើយ។ គឺជាព្រះវិញ្ញាណដែលមានបន្ទូល ហើយទ្រង់គឺជាភ្លើងដ៏សន្ធោសន្ធៅ មានឫទ្ធានុភាព និងកំពុងជំនុំជម្រះ។ ទ្រង់គឺជាបុត្រមនុស្ស ទ្រង់គ្រងព្រះពស្ត្រវែងដល់ព្រះបាទា ហើយមានខ្សែមាសរឹតតឹងព្រះឧរា។ ព្រះសិរសា និងព្រះកេសារបស់ទ្រង់សដូចជារោមចៀម ហើយព្រះនេត្ររបស់ទ្រង់ដូចជាអណ្ដាតភ្លើង។ ព្រះបាទរបស់ទ្រង់ដូចជាលង្ហិនរលីង

ដែលភ្លឺផ្លេកៗដូចជាគេដុតក្នុងគុកភ្លើង ហើយព្រះសូរសៀងរបស់ទ្រង់ដូចជាសូរនៃទឹកជាច្រើន។ នៅព្រះហស្តស្ដាំទ្រង់កាន់ផ្កាយប្រាំពីរ ក៏មានដាវមុខពីរដ៏មុត ចេញពីព្រះឱស្ឋទ្រង់មក ហើយព្រះភក្ត្របញ្ចេញពន្លឺដូចជាថ្ងៃភ្លឺពេញអំណាច!

បុត្រមនុស្សត្រូវបានគេមើលឃើញ ហើយព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ ត្រូវបានបើកសម្ដែងយ៉ាងបើកចំហ។ សិរីល្អរបស់ព្រះជាម្ចាស់បានសាយភាយទៅ ដោយបញ្ចេញពន្លឺដូចជាថ្ងៃភ្លឺពេញអំណាច! ព្រះភក្ត្រដ៏មានសិរីល្អរបស់ទ្រង់ ភ្លឺត្រចះត្រចង់ដោយពន្លឺផ្លេកៗ។ តើភ្នែករបស់អ្នកណា ដែលហ៊ានសម្លឹងទ្រង់ដោយការទាស់ទទឹងនោះ? ការទាស់ទទឹងនាំទៅរកសេចក្ដីស្លាប់! គ្មានសេចក្ដីមេត្តាករុណាបន្តិចឡើយ ចំពោះអ្វីមួយដែលអ្នកគិតនៅក្នុងចិត្ត ចំពោះពាក្យពេចន៍ណាមួយដែលអ្នកនិយាយ ឬចំពោះអ្វីមួយដែលអ្នកធ្វើ។ អ្នករាល់គ្នានឹងយល់ ហើយមើលឃើញអ្វីដែលអ្នករាល់គ្នាបានទទួល គឺគ្មានអ្វីក្រៅពីការជំនុំជម្រះឡើយ! តើខ្ញុំអាចប្រកាន់ខ្ជាប់ការជំនុំជម្រះបានទេ នៅពេលដែលអ្នករាល់គ្នាមិនប្រឹងប្រែងហូប និងផឹកព្រះបន្ទូលរបស់ខ្ញុំ តែបែរជារំខានយ៉ាងបំពាន ហើយបំផ្លាញការកសាងរបស់ខ្ញុំនោះ? ខ្ញុំនឹងមិនប្រព្រឹត្តយ៉ាងទន់ភ្លន់ចំពោះបុគ្គលប្រភេទនេះទេ! ប្រសិនបើឥរិយាបថរបស់អ្នកកាន់តែធ្ងន់ធ្ងរទៅ នោះអ្នកនឹងត្រូវបានលេបត្របាក់ដោយអណ្ដាតភ្លើង! ព្រះដ៏មានគ្រប់ព្រះចេស្ដាបើកបង្ហាញនៅក្នុងរូបកាយខាងវិញ្ញាណមួយ ដោយគ្មានសាច់ឈាម ឬការតភ្ជាប់ពីក្បាលដល់ចុងជើងសូម្បីតែបន្តិចឡើយ។ ទ្រង់យាងឆ្លងកាត់ពិភពសាកលលោក ដោយគង់លើបល្ល័ង្កដ៏រុងរឿងនៅក្នុងស្ថានសួគ៌ជាន់ទីបី ទ្រង់គ្រប់គ្រងរបស់សព្វសារពើ។ សាកលលោក និងរបស់សព្វសារពើស្ថិតនៅក្នុងព្រះហស្តរបស់ខ្ញុំ។ ប្រសិនបើខ្ញុំមានបន្ទូលបែបណា នោះវានឹងក្លាយជាបែបនោះ។ ប្រសិនបើខ្ញុំបង្គាប់បែបណា នោះវានឹងទៅជាបែបនោះ។ សាតាំងនៅក្រោមព្រះបាទរបស់ខ្ញុំ វានៅក្នុងជង្ហុកដ៏ធំ! នៅពេលដែលសម្លេងរបស់ខ្ញុំបន្លឺឡើង នោះផ្ទៃមេឃ និងផែនដីនឹងកន្លងបាត់ទៅ ហើយក្លាយជាទទេសូន្យ! របស់សព្វសារពើនឹងត្រូវបានស្អាងឲ្យថ្មីឡើងវិញ នេះគឺជាសេចក្ដីពិតដែលមិនអាចផ្លាស់ប្ដូរបាន និងពិតជាត្រឹមត្រូវ។ ខ្ញុំបានយកឈ្នះពិភពលោក ក៏ដូចជាសភាវៈអាក្រក់

ទាំងអស់។ ខ្ញុំគង់នៅទីនេះ ដោយការនិយាយទៅកាន់អ្នករាល់គ្នា ហើយអស់អ្នកណាដែលមានត្រចៀក គួរតែស្ដាប់ ហើយអស់អ្នកណាដែលកំពុងតែរស់នៅគួរតែទទួលយក។

ពេលវេលានឹងចូលមកដល់ទីបញ្ចប់ របស់សព្វសារពើនៅក្នុងពិភពលោកនេះនឹងក្លាយជាទទេសូន្យ ហើយរបស់សព្វសារពើនឹងត្រូវបានកើតជាថ្មី។ ចូរចាំពីសេចក្ដីនេះ! ចូរកុំភ្លេចឲ្យសោះ! អាចមិនមានភាពស្រពេចស្រពិលឡើយ! ផ្ទៃមេឃ និងផែនដីនឹងកន្លងបាត់ទៅ តែព្រះបន្ទូលរបស់ខ្ញុំមិនដែលបាត់ឡើយ! ខ្ញុំសូមដាស់តឿនអ្នករាល់គ្នាម្ដងទៀត៖ ចូរកុំរត់ដោយអសារឥតការ! ចូរក្រោកឡើង! ចូរប្រែចិត្ត ការសង្គ្រោះនៅជិតបង្កើយ! ខ្ញុំបានលេចមករួចហើយនៅក្នុងចំណោមអ្នករាល់គ្នា ហើយព្រះសូរសៀងរបស់ខ្ញុំបានបន្លឺឡើង។ ព្រះសូរសៀងរបស់ខ្ញុំបានបន្លឺឡើងនៅចំពោះអ្នករាល់គ្នា។ ជារៀងរាល់ថ្ងៃ ព្រះសូរសៀងនេះនៅចំពោះមុខអ្នកដោយផ្ទាល់ ហើយរាល់ថ្ងៃគឺជាថ្ងៃដែលស្រស់ស្រាយ ហើយថ្មីជានិច្ច។ អ្នកមើលឃើញខ្ញុំ ហើយខ្ញុំមើលឃើញអ្នក។ ខ្ញុំនិយាយទៅកាន់អ្នកជានិច្ច ហើយខ្ញុំនៅចំពោះមុខអ្នក។ ទោះបីជាយ៉ាងណា អ្នកបដិសេធខ្ញុំ ហើយមិនស្គាល់ខ្ញុំទេ។ ចៀមខ្ញុំទាំងប៉ុន្មានវាស្ដាប់ខ្ញុំ ប៉ុន្តែអ្នករាល់គ្នាស្ទាក់ស្ទើរទៅវិញ! អ្នកស្ទាក់ស្ទើរ! ចិត្តរបស់អ្នកបានត្រឡប់ជាស្ពឹក ភ្នែករបស់អ្នកបានខ្វាក់ដោយសារសាតាំង ហើយអ្នកមិនអាចមើលឃើញផ្ទៃមុខដ៏មានសិរីរុងរឿងរបស់ខ្ញុំបានឡើយ អ្នកគួរឲ្យអាណិតណាស់! គួរឲ្យអាណិតមែន!

ព្រះវិញ្ញាណទាំងប្រាំពីរ នៅខាងមុខបល្ល័ង្ករបស់ខ្ញុំ ត្រូវបានបញ្ជូនទៅគ្រប់ច្រកល្ហកនៃផែនដី ហើយខ្ញុំនឹងបញ្ជូនអ្នកនាំសាររបស់ខ្ញុំ ដើម្បីនិយាយទៅកាន់ក្រុមជំនុំ។ ខ្ញុំសុចរិត និងស្មោះត្រង់ ខ្ញុំជាព្រះជាម្ចាស់ដែលត្រួតពិនិត្យផ្នែកដ៏ជ្រៅបំផុតនៃចិត្តរបស់មនុស្ស។ ព្រះវិញ្ញាណមានបន្ទូលដល់ពួកជំនុំទាំងប៉ុន្មាន ហើយនោះជាព្រះបន្ទូលរបស់ខ្ញុំដែលបន្លឺចេញពីខាងក្នុងបុត្រារបស់ខ្ញុំ។ អស់អ្នកណាដែលមានត្រចៀកគួរតែស្ដាប់! អស់អ្នកណាដែលកំពុងរស់នៅ គួរតែទទួលយក! ចូរហូប និងផឹកព្រះបន្ទូលទាំងនេះ ហើយចូរកុំសង្ស័យឡើយ។ អស់អ្នកណាដែលចុះចូល ហើយយកចិត្ត

ទុកដាក់ចំពោះព្រះបន្ទូលរបស់ខ្ញុំ នឹងទទួលបានព្រះពរដ៏អស្ចារ្យ! អស់អ្នកណាដែលស្វែងរកព្រះភ័ក្ត្រខ្ញុំដោយអស់ពីចិត្ត នឹងពិតជាមានពន្លឺថ្មី ការបំភ្លឺថ្មី និងការយល់ដឹងថ្មីៗ គ្រប់យ៉ាងនឹងស្រស់ ហើយថ្មីៗ ព្រះបន្ទូលរបស់ខ្ញុំនឹងលេចមកដល់វិញ្ញាណរបស់អ្នក ដើម្បីឲ្យអ្នកអាចមើលឃើញរាល់អាថ៌កំបាំងនៃពិភពខាងវិញ្ញាណទាំងឡាយ ហើយមើលឃើញថា នគរព្រះគឺស្ថិតនៅក្នុងចំណោមមនុស្ស។ ចូរចូលទៅក្នុងទីជម្រក ហើយព្រះគុណ និងព្រះពរទាំងអស់នឹងកើតមានដល់អ្នក។ គ្រោះទុរភិក្ស និងគ្រោះកាច នឹងមិនអាចប៉ះពាល់អ្នកបានឡើយ ហើយចចក ពស់ ខ្លា និងខ្លាដំបង នឹងមិនអាចបង្កគ្រោះថ្នាក់ដល់អ្នកបានឡើយ។ អ្នកនឹងទៅជាមួយខ្ញុំ ដើរជាមួយខ្ញុំ ហើយចូលទៅក្នុងសិរីល្អជាមួយខ្ញុំ។

ឱព្រះដ៏មានគ្រប់ព្រះចេស្ដាអើយ! រូបអង្គដ៏រុងរឿងរបស់ទ្រង់ លេចឡើងដោយចំហ រូបអង្គនៃព្រះវិញ្ញាណបរិសុទ្ធលេចឡើង ហើយទ្រង់គឺជាព្រះជាម្ចាស់ផ្ទាល់ព្រះអង្គដែលពេញលេញ! លោកីយ៍ និងសាច់ឈាមបានផ្លាស់ប្ដូរទាំងពីរ ហើយការផ្លាស់ប្រែរបស់ទ្រង់នៅលើភ្នំ គឺជារូបអង្គរបស់ព្រះជាម្ចាស់។ ទ្រង់ពាក់មកុដមាសនៅលើព្រះសិរសារបស់ទ្រង់ ព្រះពស្ត្ររបស់ទ្រង់សដូចរោមចៀម នៅជុំវិញព្រះឱរាមានខ្សែមាសព័ទ្ធជុំវិញ ហើយលោកីយ៍ និងរបស់សព្វសារពើ គឺជាទ្រនាប់ព្រះបាទរបស់ទ្រង់។ ព្រះនេត្ររបស់ទ្រង់ដូចជាអណ្ដាតភ្លើង មានដាវមុខពីរដ៏មុត ចេញពីព្រះឱស្ឋទ្រង់មក ហើយនៅព្រះហស្ដស្ដាំទ្រង់កាន់ផ្កាយប្រាំពីរ។ ផ្លូវទៅកាន់នគរព្រះគឺភ្លឺចែងចាំងគ្មានដែនកំណត់ ហើយសិរីរុងរឿងរបស់ទ្រង់លេចឡើង ព្រមទាំងបញ្ចេញពន្លឺ។ ភ្នំទាំងឡាយមានអំណរ ហើយទឹកសើចសប្បាយ ហើយព្រះអាទិត្យ ព្រះច័ន្ទ និងដួងតារាទាំងឡាយវិលត្រឡប់ទៅរកការរៀបចំដ៏មានសណ្ដាប់ធ្នាប់របស់ពួកវា ដោយទទួលស្វាគមន៍ព្រះជាម្ចាស់ដ៏ពិតតែមួយអង្គគត់ ដែលការយាងត្រឡប់មកប្រកបដោយជ័យជម្នះរបស់ទ្រង់ ប្រកាសអំពីការបញ្ចប់នៃផែនការគ្រប់គ្រងរយៈពេលប្រាំមួយពាន់ឆ្នាំរបស់ទ្រង់។ គ្រប់យ៉ាងលោតកញ្ឆេង និងរាំដោយក្ដីអំណរ! ចូរអបអរសាទរ! ព្រះដ៏មានគ្រប់ព្រះចេស្ដាគង់នៅលើបល្ល័ង្កដ៏រុងរឿងរបស់ទ្រង់! ចូរច្រៀង! ទង់ជ័យនៃព្រះចេស្ដាដ៏ខ្ពង់ខ្ពស់ ត្រូវ

បានលើកឡើងនៅលើភ្នំស៊ីយ៉ូនដ៏ប្រសើរ និងប្រកបដោយឫទ្ធានុភាព! ជាតិសាសន៍ទាំងអស់កំពុងតែអបអរសាទរ មនុស្សទាំងអស់កំពុងតែច្រៀង ភ្នំស៊ីយ៉ូនកំពុងតែសើចយ៉ាងក្អាកក្អាយ ហើយសិរីល្អរបស់ព្រះជាម្ចាស់បានកើតឡើង! ខ្ញុំមិនធ្លាប់ស្រមៃថា ខ្ញុំអាចមើលឃើញព្រះភក្ត្ររបស់ព្រះជាម្ចាស់នោះទេ ប៉ុន្តែថ្ងៃនេះ ខ្ញុំបានឃើញហើយ។ ដោយនៅផ្ទាល់ជាមួយទ្រង់ជារៀងរាល់ថ្ងៃ នោះខ្ញុំបានប្រគល់ចិត្តទាំងមូលដល់ទ្រង់។ ទ្រង់ប្រទានអាហារ និងភេសជ្ជៈយ៉ាងច្រើនក្រៃលែង។ ពន្លឺដ៏រុងរឿងរបស់ទ្រង់បំភ្លឺគ្រប់ទាំងជីវិត ពាក្យពេចន៍ សកម្មភាព គំនិត យោបល់។ ទ្រង់ដឹកនាំរាល់ជំហាននីមួយៗនៃវិធី ហើយការជំនុំជម្រះរបស់ទ្រង់កើតឡើងភ្លាមៗចំពោះចិត្តដ៏បះបោរ។

ការទទួលទាន ការស្នាក់នៅជាមួយគ្នា និងការរស់នៅជាមួយព្រះជាម្ចាស់ ការនៅរួមគ្នាជាមួយទ្រង់ ដើរជាមួយគ្នា រីករាយជាមួយគ្នា ទទួលបានសិរីល្អ និងព្រះពរជាមួយគ្នា ចែករំលែកភាពជាស្ដេចជាមួយទ្រង់ ហើយមានវត្តមានជាមួយគ្នានៅក្នុងនគរព្រះ ឱ! ពិតជារីករាយម្ល៉េះទេ! ឱ! ពិតជាផ្អែមល្ហែមម្ល៉េះទេ! យើងនៅផ្ទាល់ជាមួយទ្រង់មុខទល់នឹងមុខជារៀងរាល់ថ្ងៃ និយាយជាមួយទ្រង់ជារៀងរាល់ថ្ងៃ ហើយជជែកគ្នាជានិច្ច ព្រមទាំងទទួលបានការបំភ្លឺថ្មី និងគំនិតថ្មីជារៀងរាល់ថ្ងៃ។ ភ្នែកខាងវិញ្ញាណរបស់យើងបានបើក ហើយយើងមើលឃើញអ្វីៗគ្រប់យ៉ាង។ គ្រប់អាថ៌កំបាំងទាំងអស់នៃវិញ្ញាណត្រូវបានបើកសម្ដែងដល់យើង។ ជីវិតដ៏បរិសុទ្ធ គឺពិតជាគ្មានសេចក្ដីខ្វល់ខ្វាយឡើយ។ ចូររត់យ៉ាងលឿន និងកុំឈប់ឲ្យសោះ ព្រមទាំងបោះជំហានទៅមុខឥតឈប់ ព្រោះមានជីវិតដ៏អស្ចារ្យជាងនេះនៅខាងមុខ។ ចូរកុំពេញចិត្តត្រឹមតែរសជាតិផ្អែមឲ្យសោះ ចូរស្វែងរកឥតឈប់ឈរដើម្បីចូលទៅក្នុងព្រះជាម្ចាស់។ ទ្រង់គឺជាគ្រប់យ៉ាងដែលបរិបូរណ៍ និងច្រើនក្រៃលែង ហើយទ្រង់មានអ្វីៗគ្រប់ប្រភេទដែលយើងខ្វះខាត។ ចូរសហការយ៉ាងសកម្ម និងចូលទៅក្នុងទ្រង់ ហើយគ្មានអ្វីដែលនឹងដូចពីមុនម្ដងទៀតឡើយ។ ជីវិតរបស់យើង នឹងវិសេសវិសាល ហើយគ្មានបុគ្គលណា បញ្ហាណា ឬអ្វីមួយអាចនឹងរំខានយើងបានឡើយ។

ភាពវិសេសវិសាល! ភាពវិសាល! ភាពវិសេសវិសាលដ៏ពិត! ជីវិតដែលវិសេស

វិសាលរបស់ព្រះជាម្ចាស់ គឺនៅខាងក្នុង ហើយរបស់សព្វសារពើបានស្រាកស្រាន្ត យ៉ាងពិតប្រាកដ! យើងវិសេសលើសពិភពលោក និងវត្ថុនៃលោកីយ៍ ដោយគ្មានអារម្មណ៍ជាប់ជំពាក់ជាមួយស្វាមី ឬកូនៗឡើយ។ យើងវិសេស លើសការត្រួតត្រានៃជំងឺ និងបរិស្ថានទាំងឡាយ។ សាតាំងមិនហ៊ានរំខានយើងឡើយ។ យើងពិតជាវិសេស លើសគ្រោះមហន្តរាយទាំងស្រុង។ ការនេះកំពុងតែអនុញ្ញាតឲ្យព្រះជាម្ចាស់កាន់កាប់ភាពជាស្តេច! យើងជាន់ឈ្លីសាតាំងនៅក្រោមព្រះបាទ ឈរជាទីបន្ទាល់សម្រាប់ក្រុមជំនុំ ហើយបើកបង្ហាញយ៉ាងលម្អិតអំពីមុខមាត់ដ៏អាក្រក់របស់សាតាំង។ ការកសាងក្រុមជំនុំ គឺស្ថិតនៅក្នុងព្រះគ្រីស្ទ ហើយរូបកាយដ៏រុងរឿងបានលេចចេញមកនេះ គឺជាការរស់នៅក្នុងការលើកឡើង!

# ជំពូកទី ៤៨៖ ព្រះសូរសៀងរបស់ព្រះគ្រីស្ទ កាលពីដើមដំបូង

មនុស្សពិតជាមិនអាចស្រមៃគិត ដល់កម្រិតដែលល្បឿនរបស់ខ្ញុំបានពន្លឿននោះទេ៖ នេះគឺជាការអស្ចារ្យមួយដែលបានកើតឡើង ដែលមនុស្សមិនអាចវាស់ស្ទង់បាន។ ល្បឿនរបស់ខ្ញុំបានបន្តទៅមុខ ចាប់តាំងពីការបង្កើតពិភពលោកមកម្ល៉េះ ហើយកិច្ចការរបស់ខ្ញុំ មិនដែលបញ្ឈប់ឡើយ។ សាកលលោកទាំងមូលផ្លាស់ប្ដូរពីមួយថ្ងៃទៅមួយថ្ងៃ ហើយមនុស្សក៏ផ្លាស់ប្ដូរជានិច្ចដែរ។ ទាំងអស់នេះគឺជាផ្នែកនានានៃកិច្ចការរបស់ខ្ញុំ ទាំងអស់គឺជាផ្នែកនានានៃផែនការរបស់ខ្ញុំ ហើយជាងនេះទៅទៀត ពួកវាជាកម្មសិទ្ធិនៃការគ្រប់គ្រងរបស់ខ្ញុំ ហើយគ្មានមនុស្សណាដឹង ឬយល់រឿងរ៉ាវទាំងនេះទេ។ មានតែពេលដែលខ្ញុំផ្ទាល់ និយាយប្រាប់អ្នករាល់គ្នាប៉ុណ្ណោះ មានតែពេលដែលខ្ញុំទាក់ទងជាមួយអ្នករាល់គ្នាដោយផ្ទាល់ប៉ុណ្ណោះ ទើបអ្នករាល់គ្នាដឹងបានបន្តិច។ បើមិនដូច្នោះទេ ពិតជាគ្មាននរណាម្នាក់អាចមានយោបល់អំពីគម្រោងណាមួយ ចំពោះផែនការគ្រប់គ្រងរបស់ខ្ញុំឡើយ។ នេះគឺជាព្រះចេស្ដាដ៏អស្ចារ្យរបស់ខ្ញុំ

ហើយជាងនេះទៅទៀត នេះគឺជាសកម្មភាពដ៏អស្ចារ្យរបស់ខ្ញុំ។ ទាំងអស់នេះគឺជាអ្វីៗដែលគ្មាននរណាម្នាក់អាចផ្លាស់ប្តូរបានឡើយ។ ដូច្នេះហើយ អ្វីដែលខ្ញុំនិយាយថ្ងៃនេះក៏ចេញទៅ ហើយសេចក្តីនេះមិនអាចផ្លាស់ប្តូរដោយងាយៗឡើយ។ សញ្ញាណរបស់មនុស្សមិនមានផ្ទុកនូវចំណេះដឹងអំពីខ្ញុំសូម្បីតែបន្តិច សញ្ញាណរបស់មនុស្សទាំងអស់គ្មានអ្វីក្រៅពីសម្តីដែលមិនបានការនោះទេ! ចូរកុំគិតថា អ្នកមានគ្រប់គ្រាន់ ឬគិតថាអ្នកស្កប់ស្កល់ឲ្យសោះ! ខ្ញុំនិយាយប្រាប់អ្នកដូច្នេះថា៖ អ្នកនៅមានផ្លូវវែងឆ្ងាយទៀតដែលត្រូវទៅ! អ្នករាល់គ្នាដឹងតែបន្តិចបន្តួចប៉ុណ្ណោះ អំពីផែនការគ្រប់គ្រងទាំងមូលរបស់ខ្ញុំ ដូច្នេះ អ្នករាល់គ្នាត្រូវតែស្តាប់អ្វីដែលខ្ញុំនិយាយ ហើយធ្វើនូវអ្វីក៏ដោយដែលខ្ញុំនិយាយប្រាប់អ្នករាល់គ្នាឲ្យធ្វើ។ ចូរធ្វើសកម្មភាពឲ្យស្របទៅតាមបំណង របស់ខ្ញុំនៅក្នុងអ្វីៗគ្រប់យ៉ាង ហើយអ្នកប្រាកដជានឹងមានពររបស់ខ្ញុំជាមិនខាន។ នរណាក៏ដោយដែលជឿ នឹងត្រូវបានបំពេញចំពោះអ្វីដែលពួកគេបានគិតថា «ទទេ»។ នេះគឺជាសេចក្តីសុចរិតរបស់ខ្ញុំ ហើយជាងនេះទៅទៀត វាគឺជាឫទ្ធានុភាពរបស់ខ្ញុំ សេចក្តីក្រោធរបស់ខ្ញុំ និងការវាយផ្ចាលរបស់ខ្ញុំ។ ខ្ញុំនឹងមិនឲ្យនរណាម្នាក់យកគំនិត ឬសកម្មភាពសូម្បីតែមួយចេញទៅបាននោះឡើយ។

ដោយបានស្តាប់ព្រះបន្ទូលនានារបស់ខ្ញុំ នោះមនុស្សភាគច្រើនក៏ភ័យខ្លាច និងញាប់ញ័រ ផ្ទៃមុខរបស់ពួកគេជ្រីវជ្រួញដោយការចងចញ្ចើមប្រកបដោយក្តីទុក្ខព្រួយ។ តើខ្ញុំបានធ្វើឲ្យអ្នកមានកំហុសឬ? តើអាចទៅរួចទេ ដែលអ្នកមិនមែនជាកូនរបស់នាគដ៏ធំមានសម្បុរក្រហមនោះ? អ្នកថែមទាំងធ្វើពុតជាមនុស្សល្អទៀតផង! អ្នកថែមទាំងធ្វើពុតជាកូនប្រុសច្បងរបស់ខ្ញុំទៀតផង! តើអ្នកគិតថាខ្ញុំខ្វាក់ឬ? តើអ្នកគិតថាខ្ញុំមិនអាចញែកមនុស្សបានឬ? ខ្ញុំគឺជាព្រះជាម្ចាស់ដែលស្រាវជ្រាវដល់ចិត្តដ៏ជ្រៅរបស់មនុស្ស៖ នេះគឺជាអ្វីដែលខ្ញុំនិយាយប្រាប់ពួកកូនប្រុសរបស់ខ្ញុំ ហើយក៏ជាអ្វីដែលខ្ញុំនិយាយប្រាប់អ្នករាល់គ្នា ដែលជាកូនៗរបស់នាគដ៏ធំមានសម្បុរក្រហមដែរ។ ខ្ញុំមើលឃើញអ្វីៗគ្រប់យ៉ាងយ៉ាងច្បាស់ ដោយពុំមានការយល់ច្រឡំសូម្បីតែបន្តិច។ តើខ្ញុំអាចមិនដឹងពីអ្វីដែលខ្ញុំធ្វើបានយ៉ាងដូចម្តេច? ខ្ញុំជ្រាបច្បាស់អំពីអ្វីដែលខ្ញុំធ្វើ! ហេតុអ្វីបានជាខ្ញុំ

និយាយថា ខ្ញុំគឺជាព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ ជាព្រះអាទិករនៃសាកលលោក និងរបស់សព្វសារពើ? ហេតុអ្វីបានជាខ្ញុំនិយាយថា ខ្ញុំគឺជាព្រះជាម្ចាស់ដែលត្រួតពិនិត្យចិត្តខាងក្នុងបំផុតរបស់មនុស្ស? ខ្ញុំជ្រាបយ៉ាងច្បាស់អំពីស្ថានភាពរបស់មនុស្សម្នាក់ៗ។ តើអ្នករាល់គ្នាគិតថា ខ្ញុំមិនជ្រាបពីអ្វីដែលត្រូវធ្វើ ឬអ្វីដែលត្រូវនិយាយឬ? នេះមិនមែនជាក្ដីកង្វល់របស់អ្នកឡើយ។ ចូរប្រយ័ត្នដើម្បីកុំឲ្យត្រូវស្លាប់ដោយសារព្រះហស្តរបស់ខ្ញុំ ព្រោះអ្នកនឹងទទួលរងការបាត់បង់តាមវិធីនោះ។ បញ្ញត្តិរដ្ឋបាលរបស់ខ្ញុំ គឺមិនអត់ឱនឲ្យឡើយ។ តើអ្នកយល់ទេ? ទាំងអស់ខាងលើនេះ គឺជាផ្នែកនានានៃបញ្ញត្តិរដ្ឋបាលរបស់ខ្ញុំ។ ចាប់តាំងពីថ្ងៃដែលខ្ញុំនិយាយប្រាប់បញ្ញត្តិរដ្ឋបាលទាំងនេះទៅអ្នករាល់គ្នា ប្រសិនបើអ្នកប្រព្រឹត្តអំពើរំលងបន្ថែមណាមួយ នោះនឹងមានទោសទណ្ឌ ពីព្រោះពីមុនអ្នករាល់គ្នាមិនបានយល់ឡើយ។

ពេលនេះខ្ញុំប្រកាសឲ្យប្រើ បញ្ញត្តិរដ្ឋបាលរបស់ខ្ញុំចំពោះអ្នករាល់គ្នា (ដែលមានប្រសិទ្ធភាពចាប់ពីថ្ងៃនៃការប្រកាសឲ្យប្រើ ដោយការចាត់ចែងការវាយផ្ចាលផ្សេងៗទៅកាន់មនុស្សខុសៗគ្នា)៖

ខ្ញុំរក្សាសេចក្ដីសន្យារបស់ខ្ញុំ ហើយអ្វីៗគ្រប់យ៉ាងស្ថិតនៅក្នុងព្រះហស្តរបស់ខ្ញុំ៖ នរណាក៏ដោយដែលមានមន្ទិលសង្ស័យនឹងត្រូវបានសម្លាប់ជាក់ជាមិនខាន។ គ្មានកន្លែងត្រូវពិចារណាឡើយ។ ពួកគេនឹងត្រូវធ្វើឲ្យវិនាសមួយរំពេច ដូច្នេះ ព្រះទ័យរបស់ខ្ញុំពេញដោយសេចក្ដីស្អប់។ (សូមបញ្ជាក់ថា ចាប់ពីពេលនេះតទៅ នរណាក៏ដោយដែលត្រូវបានសម្លាប់ ច្បាស់ជាមិនមែនសមាជិកនៃនគររបស់ខ្ញុំឡើយ ហើយគេត្រូវតែជាកូនចៅរបស់សាតាំង។)

ក្នុងនាមជាពួកកូនប្រុសច្បង អ្នកគួរតែរក្សាតួនាទីរបស់ខ្លួន ហើយបំពេញភារកិច្ចរបស់ខ្លួន ព្រមទាំងមិនត្រូវចង់ដឹងចង់ឮរឿងរបស់អ្នកដទៃឡើយ។ អ្នកគួរតែថ្វាយខ្លួនចំពោះផែនការគ្រប់គ្រងរបស់ខ្ញុំ ហើយគ្រប់ទីកន្លែងដែលអ្នកទៅ អ្នកគួរតែធ្វើជាបន្ទាល់ដ៏ល្អអំពីខ្ញុំ និងសរសើរតម្កើងព្រះនាមរបស់ខ្ញុំ។ មិនត្រូវប្រព្រឹត្តសកម្មភាពដ៏អាម៉ាស់ឡើយ។ ចូរធ្វើជាគម្រូសម្រាប់ពួកកូនប្រុសរបស់ខ្ញុំ និងរាស្ត្ររបស់ខ្ញុំទាំងអស់។ មិន

ត្រូវប្រព្រឹត្តរំលងប្រពៃណី សូម្បីតែមួយភ្លែតក៏ដោយ៖ អ្នកត្រូវតែមានវត្តមានជានិច្ច នៅចំពោះមុខមនុស្សម្នាក់ៗ ដោយការនាំយកនូវអត្តសញ្ញាណនៃពួកកូនប្រុសច្បង មិនមែនជាអ្នកបម្រើនោះទេ។ ផ្ទុយទៅវិញ អ្នកគួរតែបោះជំហានទៅមុខដោយងើប ក្បាលខ្ពស់ឡើង។ ខ្ញុំកំពុងតែស្នើឲ្យអ្នករាល់គ្នាសរសើរតម្កើងព្រះនាមរបស់ខ្ញុំ មិនមែន ធ្វើឲ្យព្រះនាមរបស់ខ្ញុំ អាប់ឱននោះទេ។ អស់អ្នកណាដែលជាពួកកូនប្រុសច្បង គឺ ម្នាក់ៗមានតួនាទីផ្ទាល់ខ្លួនរបស់ពួកគេ ហើយមិនអាចធ្វើបានគ្រប់យ៉ាងឡើយ។ នេះ គឺជាទំនួលខុសត្រូវដែលខ្ញុំបានផ្ដល់ដល់អ្នករាល់គ្នា ហើយអ្នកមិនត្រូវគេចពីទំនួល ខុសត្រូវឡើយ។ អ្នកត្រូវតែលះបង់ខ្លួនអ្នកដោយអស់ពីចិត្ត អស់ពីគំនិត និងអស់ពី កម្លាំង ដើម្បីបំពេញអ្វីដែលខ្ញុំបានផ្ដល់ដល់អ្នករាល់គ្នា។

ចាប់ពីថ្ងៃនេះតទៅ ភារកិច្ចនៃការឃ្វាលពួកកូនប្រុសរបស់ខ្ញុំ និងរាស្ត្ររបស់ខ្ញុំ ទាំងអស់នៅទូទាំងពិភពសាកលលោក នឹងត្រូវបានប្រគល់ឲ្យពួកកូនប្រុសច្បងរបស់ខ្ញុំ បំពេញ ហើយខ្ញុំនឹងវាយផ្ចាលនរណាដែលមិនអាចថ្វាយចិត្ត និងគំនិតទាំងមូលរបស់ ពួកគេដើម្បីបំពេញភារកិច្ចនោះ។ នេះគឺជាសេចក្ដីសុចរិតរបស់ខ្ញុំ។ ខ្ញុំនឹងមិនប្រណី ហើយក៏មិនធូររលុង សូម្បីតែចំពោះពួកកូនប្រុសច្បងរបស់ខ្ញុំឡើយ។

ប្រសិនបើមាននរណាម្នាក់ ក្នុងចំណោមពួកកូនប្រុសរបស់ខ្ញុំ ឬក្នុងចំណោម រាស្ត្ររបស់ខ្ញុំ ដែលចំអក និងជេរប្រមាថពួកកូនប្រុសច្បងរបស់ខ្ញុំណាម្នាក់ នោះខ្ញុំ នឹងដាក់ទោសពួកគេយ៉ាងសាហាវ ព្រោះថាពួកកូនប្រុសច្បងរបស់ខ្ញុំតំណាងឲ្យខ្ញុំ ផ្ទាល់។ អ្វីដែលនរណាម្នាក់ធ្វើចំពោះពួកគេ ក៏ធ្វើចំពោះខ្ញុំដែរ។ នេះគឺជាភាពធ្ងន់ធ្ងរ បំផុតនៃបញ្ញត្តិរដ្ឋបាលរបស់ខ្ញុំ។ ដោយអាស្រ័យលើបំណងប្រាថ្នារបស់ពួកគេ នោះ ខ្ញុំនឹងអនុញ្ញាតឲ្យពួកកូនប្រុសច្បងរបស់ខ្ញុំ គ្រប់គ្រងសេចក្ដីសុចរិតរបស់ខ្ញុំប្រឆាំងនឹង ពួកកូនប្រុស ព្រមទាំងរាស្ត្ររបស់ខ្ញុំដែលបំពានលើបញ្ញត្តិនេះ។

ខ្ញុំនឹងបោះបង់ចោលបន្តិចម្ដងៗនូវអ្នកណាដែលប្រព្រឹត្តចំពោះខ្ញុំយ៉ាងឡេះឡោះ និងផ្ដោតតែទៅលើអាហារ សំលៀកបំពាក់ និងដំណេករបស់ខ្ញុំ ចូលរួមតែក្នុង កិច្ចការខាងក្រៅរបស់ខ្ញុំ ហើយមិនមានការពិចារណាចំពោះបន្ទុករបស់ខ្ញុំ ព្រមទាំង

មិនយកចិត្តទុកដាក់ ចំពោះការបំពេញតួនាទីផ្ទាល់ខ្លួនរបស់ពួកគេឲ្យបានសមរម្យ។ ការនេះ សំដៅលើអស់អ្នកណាដែលមានត្រចៀក។

នរណាក៏ដោយដែលបញ្ឈប់កិច្ចការបម្រើសម្រាប់ខ្ញុំ ត្រូវតែដកខ្លួនចេញទាំងស្ដាប់បង្គាប់ ដោយគ្មានការឈ្លោះប្រកែកឡើយ។ ចូរប្រយ័ត្ន បើមិនដូច្នោះទេ ខ្ញុំនឹងជម្រុះអ្នកចេញ។ (នេះគឺជាបញ្ញត្តិបន្ថែមមួយ។)

ពួកកូនប្រុសច្បងរបស់ខ្ញុំ ត្រូវតែចាប់កាន់ព្រនង់ដែកចាប់ពីពេលនេះតទៅ ហើយចាប់ផ្ដើមប្រតិបត្តិសិទ្ធិអំណាចរបស់ខ្ញុំដើម្បីគ្រប់គ្រងជាតិសាសន៍ និងប្រជាជនទាំងអស់ ដើម្បីដើរនៅក្នុងចំណោមជាតិសាសន៍ និងមនុស្សទាំងអស់ និងដើម្បីអនុវត្តការជំនុំជម្រះ សេចក្ដីសុចរិត និងឫទ្ធានុភាពរបស់ខ្ញុំនៅក្នុងចំណោមជាតិសាសន៍ និងមនុស្សទាំងអស់។ ពួកកូនប្រុស និងរាស្ត្ររបស់ខ្ញុំត្រូវតែកោតខ្លាចខ្ញុំ សរសើរតម្កើងខ្ញុំ អបអរខ្ញុំ និងថ្វាយសិរីល្អដល់ខ្ញុំឥតឈប់ឈរ ពីព្រោះផែនការគ្រប់គ្រងរបស់ខ្ញុំត្រូវបានសម្រេច ហើយពួកកូនប្រុសច្បងរបស់ខ្ញុំអាចសោយរាជ្យជាមួយខ្ញុំ។

នេះគឺជាផ្នែកមួយនៃបញ្ញត្តិរដ្ឋបាលរបស់ខ្ញុំ។ បន្ទាប់ពីនេះ ខ្ញុំនឹងនិយាយប្រាប់អ្នករាល់គ្នានូវបញ្ញត្តិរដ្ឋបាលទាំងនេះ នៅពេលដែលកិច្ចការដំណើរការទៅមុខ។ ចេញពីបញ្ញត្តិរដ្ឋបាលខាងលើ អ្នករាល់គ្នានឹងមើលឃើញអំពីជំហានដែលខ្ញុំធ្វើកិច្ចការរបស់ខ្ញុំក៏ដូចជាជំហានណាមួយដែលកិច្ចការរបស់ខ្ញុំបានទៅដល់។ នេះគួរតែជាការបញ្ជាក់មួយ។

ខ្ញុំបានជំនុំជម្រះសាតាំងរួចហើយ។ ដោយសារតែបំណង របស់ខ្ញុំមិនអាចរារាំងបាន ហើយដោយសារតែពួកកូនប្រុសច្បងរបស់ខ្ញុំបានទទួលសិរីល្អជាមួយនឹងខ្ញុំ នោះខ្ញុំបានប្រើប្រាស់សេចក្ដីសុចរិត និងឫទ្ធានុភាពរបស់ខ្ញុំរួចហើយ ចំពោះពិភពលោក និងរបស់សព្វសារពើដែលជាកម្មសិទ្ធិរបស់សាតាំង។ ខ្ញុំមិនលើកម្រាមដៃ ឬយកចិត្តទុកដាក់ចំពោះសាតាំងទាល់តែសោះ (ពីព្រោះវាមិនសមនឹងសន្ទនាជាមួយខ្ញុំឡើយ)។ ខ្ញុំគ្រាន់តែបន្តធ្វើនូវអ្វីដែលខ្ញុំចង់ធ្វើប៉ុណ្ណោះ។ កិច្ចការរបស់ខ្ញុំដំណើរការទៅមុខយ៉ាងរលូន មួយជំហានម្ដងៗ ហើយបំណងរបស់ខ្ញុំមិនអាចត្រូវបានរារាំងឡើយនៅទូទាំង

ផែនដីទាំងមូល។ ការនេះបានបំបាក់មុខសាតាំងក្នុងកម្រិតមួយ ហើយសាតាំងត្រូវបានបំផ្លាញទាំងស្រុង ប៉ុន្ដែការនេះមិនបានបំពេញបំណងរបស់ខ្ញុំឡើយ។ ខ្ញុំក៏អនុញ្ញាតឲ្យពួកកូនប្រុសច្បងរបស់ខ្ញុំ អនុវត្ដបញ្ញត្ដិរដ្ឋបាលរបស់ខ្ញុំចំពោះពួកគេដែរ។ មួយផ្នែក អ្វីដែលខ្ញុំឲ្យសាតាំងមើលឃើញ គឺជាសេចក្ដីក្រោធរបស់ខ្ញុំចំពោះវា។ មួយផ្នែកទៀត ខ្ញុំឲ្យសាតាំងមើលឃើញសិរីល្អរបស់ខ្ញុំ (មើលឃើញថា ពួកកូនប្រុសច្បងរបស់ខ្ញុំគឺជាទីបន្ទាល់ដែលខ្ទរខ្ទារបំផុតចំពោះភាពអាម៉ាស់របស់សាតាំង)។ ខ្ញុំមិនដាក់ទោសវាដោយផ្ទាល់នោះទេ ផ្ទុយទៅវិញ ខ្ញុំឲ្យពួកកូនប្រុសច្បងរបស់ខ្ញុំអនុវត្ដសេចក្ដីសុចរិត និងឫទ្ធានុភាពរបស់ខ្ញុំ។ ដោយសារតែសាតាំងធ្លាប់រំលោភបំពានពួកកូនប្រុសរបស់ខ្ញុំ ធ្វើទុក្ខបុកម្នេញពួកកូនប្រុសរបស់ខ្ញុំ និងសង្កត់សង្កិនពួកកូនប្រុសរបស់ខ្ញុំ ហើយនៅថ្ងៃនេះ បន្ទាប់ពីការបម្រើរបស់វាត្រូវបានបញ្ចប់ នោះខ្ញុំនឹងអនុញ្ញាតឲ្យកូនប្រុសច្បងដែលធំដឹងក្ដីរបស់ខ្ញុំ ជម្រុះវាចេញ។ សាតាំងមិនមានអំណាចទប់ទល់ការដួលរលំឡើយ។ ការជាប់គាំងរបស់ជាតិសាសន៍ទាំងអស់នៅក្នុងពិភពលោក គឺជាទីបន្ទាល់ដ៏ល្អបំផុត។ មនុស្សប្រយុទ្ធគ្នា ហើយប្រទេសនានាស្ថិតក្នុងសង្គ្រាម គឺជាការបង្ហាញឲ្យឃើញនូវការដួលរលំនៃនគររបស់សាតាំង។ មូលហេតុដែលខ្ញុំមិនបានបង្ហាញទីសម្គាល់ និងការអស្ចារ្យណាមួយនៅក្នុងអតីតកាល គឺដើម្បីនាំយកភាពអាម៉ាស់មកឲ្យសាតាំង និងដើម្បីលើកតម្កើងឈ្មោះរបស់ខ្ញុំមួយជំហានម្ដងៗ។ នៅពេលដែលសាតាំងត្រូវបានវិនាសទាំងស្រុង នោះខ្ញុំចាប់ផ្ដើមបង្ហាញព្រះចេស្ដារបស់ខ្ញុំ៖ អ្វីដែលខ្ញុំនិយាយ គឺកើតមានឡើង ហើយសេចក្ដីនានាដែលមានលក្ខណៈអធិធម្មជាតិ ដែលមិនស្របនឹងសញ្ញាណរបស់មនុស្ស នឹងត្រូវសម្រេច (ទាំងនេះ សំដៅទៅលើព្រះពរដែលនឹងមកក្នុងពេលដ៏ឆាប់ខាងមុខ)។ ដោយសារតែខ្ញុំគឺជាព្រះជាម្ចាស់ផ្ទាល់ព្រះអង្គដ៏ជាក់ស្ដែង ហើយខ្ញុំគ្មាននូវក្រឹត្យវិន័យ ហើយដោយសារតែខ្ញុំមានបន្ទូលអាស្រ័យលើការផ្លាស់ប្ដូរនៅក្នុងផែនការគ្រប់គ្រងរបស់ខ្ញុំ ដូច្នេះ អ្វីដែលខ្ញុំបានមានបន្ទូលកាលពីអតីតកាល គឺមិនអាចប្រើប្រាស់បានសម្រាប់បច្ចុប្បន្នឡើយ។ ចូរកុំប្រកាន់ខ្ជាប់ទៅនឹងសញ្ញាណផ្ទាល់ខ្លួនរបស់អ្នកឡើយ! ខ្ញុំមិនមែនជាព្រះជាម្ចាស់ដែលប្រកាន់ខ្ជាប់ដោយ

ក្រឹត្យវិន័យឡើយ។ ជាមួយខ្ញុំ អ្វីៗគ្រប់យ៉ាងគឺសេរី សំខាន់ និងរួចពីចំណងទាំងស្រុង។ ប្រហែលជាអ្វីដែលត្រូវបាននិយាយកាលពីម្សិលមិញ អាចហួសសម័យក្នុងថ្ងៃនេះ ឬប្រហែលជាវាអាចត្រូវបានបំភ្លេចនៅថ្ងៃនេះ (ទោះបីជាយ៉ាងណា បញ្ញត្តិរដ្ឋបាលរបស់ខ្ញុំ ចាប់តាំងពីត្រូវបានប្រកាសឲ្យប្រើប្រាស់មក នឹងមិនដែលផ្លាស់ប្ដូរឡើយ)។ ទាំងនេះ គឺជាជំហាននានានៅក្នុងផែនការគ្រប់គ្រងរបស់ខ្ញុំ។ ចូរកុំប្រកាន់ខ្ជាប់ទៅនឹងបទបញ្ញត្តិនានាឡើយ។ ជារៀងរាល់ថ្ងៃ មានពន្លឺថ្មីមួយ និងមានការបើកសម្ដែងថ្មីមួយ ហើយនោះគឺជាផែនការរបស់ខ្ញុំ។ ជារៀងរាល់ថ្ងៃ ពន្លឺរបស់ខ្ញុំនឹងត្រូវបានបើកសម្ដែងនៅក្នុងអ្នក ហើយព្រះសូរសៀងរបស់ខ្ញុំ នឹងត្រូវបានបើកសម្ដែងទៅកាន់ពិភពសាកលលោក។ តើអ្នកយល់ទេ? នេះគឺជាភារកិច្ចរបស់អ្នក ជាទំនួលខុសត្រូវដែលបានប្រគល់ដល់អ្នក។ អ្នកមិនត្រូវធ្វេសប្រហែសចំពោះវាឡើយ សូម្បីតែមួយភ្លែត។ ខ្ញុំនឹងប្រើប្រាស់មនុស្សដែលខ្ញុំព្រមទទួលរហូតដល់ទីបញ្ចប់ ហើយការនេះនឹងមិនដែលផ្លាស់ប្ដូរឡើយ។ ដោយសារតែខ្ញុំគឺជាព្រះដ៏មានគ្រប់ព្រះចេស្ដា នោះខ្ញុំជ្រាបអំពីប្រភេទមនុស្សដែលគួរធ្វើអ្វីមួយ ក៏ដូចជាប្រភេទមនុស្សដែលអាចធ្វើអ្វីមួយដែរ។ នេះគឺជាសព្វានុភាពរបស់ខ្ញុំ។

# ជំពូកទី ១០៣៖ ព្រះសូរសៀងរបស់ព្រះគ្រីស្ទ កាលពីដើមដំបូង

សម្លេងដូចផ្គរលាន់បានបន្លឺឡើង ដោយអង្រួនសាកលលោកទាំងមូល។ វាឮខ្លាំងណាស់ រហូតមនុស្សមិនអាចរត់គេចទាន់ពេលវេលានោះទេ។ មនុស្សខ្លះត្រូវបានសម្លាប់ មនុស្សខ្លះត្រូវបានបំផ្លាញ ហើយមនុស្សខ្លះទៀតត្រូវបានជំនុំជម្រះ។ វាពិតជាទស្សនីយភាពមួយ ដែលគ្មាននរណាម្នាក់ធ្លាប់បានឃើញឡើយ។ ចូរស្ដាប់ដោយយកចិត្តទុកដាក់៖ សម្លេងនៃផ្គរលាន់អមទៅដោយសម្លេងយំ ហើយសម្លេងនេះចេញមកពីស្ថានឃុំព្រលឹងមនុស្សស្លាប់ វាចេញមកពីឋាននរក។ វាជាសម្លេងដ៏ល្វីងជូរចត់

របស់កូនប្រុសរបស់អ្នកបះបោរទាំងនោះ ដែលខ្ញុំបានជំនុំជម្រះ។ អស់អ្នកណាដែលមិនបានស្ដាប់អ្វីដែលខ្ញុំមានបន្ទូល ហើយដែលមិនបានយកព្រះបន្ទូលរបស់ខ្ញុំទៅអនុវត្ត ត្រូវបានជំនុំជម្រះយ៉ាងធ្ងន់ធ្ងរ ហើយទទួលបណ្ដាសានៃសេចក្ដីក្រោធរបស់ខ្ញុំ។ ព្រះសូរសៀងរបស់ខ្ញុំ គឺជាការជំនុំជម្រះ និងសេចក្ដីក្រោធ។ ខ្ញុំមិនប្រព្រឹត្តចំពោះនរណាម្នាក់ដោយទន់ភ្លន់ ហើយក៏មិនបង្ហាញសេចក្ដីមេត្តាករុណាដល់នរណាម្នាក់ដែរ ព្រោះថាខ្ញុំគឺជាព្រះជាម្ចាស់ផ្ទាល់ព្រះអង្គដែលសុចរិត ហើយខ្ញុំមានសេចក្ដីក្រោធ ខ្ញុំមានចំហេះភ្លើង ខ្ញុំមានការបន្សុទ្ធ ហើយខ្ញុំមានការបំផ្លាញ។ នៅក្នុងខ្ញុំ គ្មានអ្វីដែលលាក់បាំង ឬប្រកបដោយមនោសញ្ចេតនាឡើយ ប៉ុន្ដែផ្ទុយទៅវិញ អ្វីៗគ្រប់យ៉ាងគឺបើកចំហរ សុចរិត និងមិនលម្អៀង។ ដោយសារតែពួកកូនប្រុសច្បងរបស់ខ្ញុំ នៅលើបល្ល័ង្កជាមួយខ្ញុំរួចហើយ ដោយគ្រួតត្រាលើជាតិសាសន៍ទាំងអស់ និងមនុស្សទាំងអស់នោះវត្ថុ និងមនុស្សដែលមិនស្អាតស្អំ ហើយមិនសុចរិតទាំងនោះ ចាប់ផ្ដើមទទួលការជំនុំជម្រះហើយនៅពេលនេះ។ ខ្ញុំនឹងស៊ើបអង្កេតម្នាក់ម្ដងៗ ដោយមិនរំលងអ្វីមួយឡើយ ហើយបើកឱ្យដឹងពីពួកគេទាំងស្រុង។ ដោយសារតែការជំនុំជម្រះរបស់ខ្ញុំត្រូវបានបើកសម្ដែងទាំងស្រុង និងបើកបង្ហាញយ៉ាងពេញលេញ ហើយខ្ញុំមិនបានរក្សាទុកអ្វីឡើយ នោះខ្ញុំនឹងបោះចោលអ្វីៗគ្រប់យ៉ាងដែលមិនស្របនឹងបំណងព្រះហឫទ័យរបស់ខ្ញុំ ហើយបណ្ដោយឲ្យវាវិនាសអស់កល្បជានិច្ចនៅក្នុងជង្ហុកធំ។ នៅទីនោះ ខ្ញុំនឹងអនុញ្ញាតឲ្យវាឆេះអស់កល្បជានិច្ច។ នេះគឺជាសេចក្ដីសុចរិតរបស់ខ្ញុំ ហើយនេះជាភាពទៀងត្រង់របស់ខ្ញុំ។ គ្មាននរណាម្នាក់អាចផ្លាស់ប្ដូរសេចក្ដីនេះបានទេ ហើយគ្រប់យ៉ាងត្រូវតែស្ថិតនៅក្រោមការបញ្ជារបស់ខ្ញុំ។

មនុស្សជាច្រើន ព្រងើយកន្ដើយចំពោះព្រះសូរសៀងរបស់ខ្ញុំ ដោយគិតថាព្រះបន្ទូលគ្រាន់តែជាពាក្យពេចន៍ ហើយថាការពិត ត្រឹមតែជាការពិតប៉ុណ្ណោះ។ ពួកគេងងឹតងងល់! តើពួកគេមិនដឹងថា ខ្ញុំគឺជាព្រះជាម្ចាស់ផ្ទាល់ព្រះអង្គដែលស្មោះត្រង់ឬ? ព្រះបន្ទូល និងការពិតរបស់ខ្ញុំកើតឡើងតំណាលគ្នា។ តើនេះមិនមែនជាករណីពិតដ៏ពិសេសទេឬ? មនុស្ស គ្រាន់តែមិនយល់ព្រះបន្ទូលរបស់ខ្ញុំប៉ុណ្ណោះ ហើយមាន

តែអស់អ្នកដែលត្រូវបានបំភ្លឺប៉ុណ្ណោះ ដែលអាចយល់យ៉ាងពិតប្រាកដ។ នេះជាការពិត។ នៅពេលដែលមនុស្សមើលឃើញព្រះបន្ទូលរបស់ខ្ញុំ ពួកគេភ័យខ្លាចលោះព្រលឹង ហើយរត់យ៉ាងប្រញាប់ប្រញាល់ទៅគ្រប់ទីកន្លែងដើម្បីលាក់ពួន។ ករណីនេះកើតឡើងកាន់តែច្រើន នៅពេលដែលការជំនុំជម្រះរបស់ខ្ញុំមកដល់។ នៅពេលដែលខ្ញុំបានបង្កើតរបស់សព្វសារពើ នៅពេលដែលខ្ញុំបំផ្លាញពិភពលោក ហើយនៅពេលដែលខ្ញុំធ្វើឲ្យពួកកូនប្រុសច្បងពេញខ្នាត គឺរឿងរ៉ាវទាំងអស់នេះ ត្រូវបានសម្រេចដោយព្រះបន្ទូលមួយម៉ាត់ចេញពីព្រះឱស្ឋរបស់ខ្ញុំ។ នេះគឺដោយសារតែព្រះបន្ទូលរបស់ខ្ញុំផ្ទាល់ គឺជាសិទ្ធិអំណាច វាគឺជាការជំនុំជម្រះ។ អាចនិយាយបានថា ខ្ញុំគឺជាការជំនុំជម្រះ និងជាឫទ្ធានុភាព នេះគឺជាការពិតដែលមិនអាចកែប្រែបាន។ នេះគឺជាទិដ្ឋភាពមួយនៃបញ្ញត្តិរដ្ឋបាលរបស់ខ្ញុំ នេះគឺជាមធ្យោបាយតែមួយដែលខ្ញុំជំនុំជម្រះមនុស្ស។ នៅក្នុងព្រះនេត្ររបស់ខ្ញុំ អ្វីៗគ្រប់យ៉ាង រួមទាំងមនុស្សទាំងអស់ កិច្ចការទាំងអស់ និងរបស់សព្វសារពើ ស្ថិតនៅក្នុងព្រះហស្តរបស់ខ្ញុំ និងស្ថិតនៅក្រោមការជំនុំជម្រះរបស់ខ្ញុំ។ គ្មាននរណាម្នាក់ ហើយគ្មានអ្វីមួយហ៊ានប្រព្រឹត្តយ៉ាងគគ្លើន ឬដោយចេតនាឡើយ ហើយគ្រប់យ៉ាងត្រូវតែបានសម្រេច ទៅតាមព្រះបន្ទូលដែលខ្ញុំថ្លែងចេញមក។ ម្នាក់ៗជឿលើព្រះបន្ទូលរបស់ខ្ញុំ ចេញពីសញ្ញាណមនុស្សដែលនៅខាងក្នុង។ នៅពេលដែលព្រះវិញ្ញាណរបស់ខ្ញុំបញ្ចេញព្រះសូរសៀង នោះម្នាក់ៗមានមន្ទិលសង្ស័យ។ មនុស្សគ្មានចំណេះដឹងអំពីសព្វានុភាពរបស់ខ្ញុំ សូម្បីតែបន្តិចហើយពួកគេថែមទាំងចោទប្រកាន់ ប្រឆាំងនឹងខ្ញុំថែមទៀតផង។ ខ្ញុំប្រាប់អ្នកឥឡូវនេះ អ្នកណាដែលមានមន្ទិលសង្ស័យចំពោះព្រះបន្ទូលរបស់ខ្ញុំ ហើយអ្នកណាដែលមើលងាយព្រះបន្ទូលរបស់ខ្ញុំ គឺអ្នកទាំងនេះហើយដែលនឹងត្រូវបានបំផ្លាញ។ ពួកគេគឺជាពួកកូនប្រុសនៃសេចក្ដីវិនាសដែលគ្មានទីបញ្ចប់។ ចេញពីចំណុចនេះ យើងអាចមើលឃើញថា មានមនុស្សតិចណាស់ដែលជាពួកកូនប្រុសច្បង ព្រោះថា នេះជាវិធីដែលខ្ញុំធ្វើការ។ ដូចដែលខ្ញុំបាននិយាយពីមុនមក ខ្ញុំសម្រេចអ្វីៗគ្រប់យ៉ាងដោយមិនកម្រើកម្រាមព្រះហស្តមួយផង ខ្ញុំគ្រាន់តែប្រើប្រាស់ព្រះបន្ទូលរបស់ខ្ញុំប៉ុណ្ណោះ។

បន្ទាប់មក នេះគឺជាទីកន្លែងដែលសព្វានុភាពរបស់ខ្ញុំស្ថិតនៅ។ នៅក្នុងព្រះបន្ទូលរបស់ខ្ញុំ គ្មាននរណាម្នាក់អាចស្វែងរកប្រភព និងគោលបំណងនៃអ្វីដែលខ្ញុំព្រះបន្ទូលនិយាយនោះទេ។ មនុស្សមិនអាចសម្រេចបានកិច្ចការនេះទេ ហើយពួកគេអាចធ្វើសកម្មភាព ខណៈពេលដែលដើរតាមការដឹកនាំរបស់ខ្ញុំប៉ុណ្ណោះ ហើយធ្វើអ្វីៗទៅតាមបំណង របស់ខ្ញុំ ដោយផ្អែកលើសេចក្ដីសុចរិតរបស់ខ្ញុំ ដែលបណ្ដាលឲ្យគ្រួសាររបស់ខ្ញុំមានសេចក្ដីសុចរិត និងសេចក្ដីស្ងប់សុខ បណ្ដាលឲ្យគ្រួសាររបស់ខ្ញុំរស់នៅជារៀងរហូត និងបណ្ដាលឲ្យគ្រួសាររបស់ខ្ញុំរឹងមាំ ព្រមទាំងមិនរង្គោះរង្គើជានិច្ចនិរន្តរ៍។

ការជំនុំជម្រះរបស់ខ្ញុំធ្លាក់មកកាន់មនុស្សរាល់គ្នា បញ្ញត្តិរដ្ឋបាលរបស់ខ្ញុំប៉ះពាល់មនុស្សរាល់គ្នា ហើយព្រះបន្ទូល និងអង្គរបស់ខ្ញុំ ត្រូវបានបើកសម្ដែងដល់មនុស្សគ្រប់គ្នា។ នេះគឺជាពេលវេលាសម្រាប់កិច្ចការដ៏អស្ចារ្យនៃព្រះវិញ្ញាណរបស់ខ្ញុំ (នៅពេលនេះ អស់អ្នកដែលនឹងទទួលបានព្រះពរ និងអស់អ្នកដែលនឹងទទួលរងនូវជោគវាសនាអាក្រក់ ត្រូវបានញែកចេញពីគ្នា)។ នៅពេលដែលព្រះបន្ទូលរបស់ខ្ញុំបញ្ចេញមក នោះខ្ញុំបានញែកអស់អ្នកដែលនឹងទទួលបានព្រះពរ ក៏ដូចជាអស់អ្នកដែលនឹងទទួលរងនូវជោគវាសនាអាក្រក់ហើយ។ ទាំងអស់នេះ គឺភ្លឺច្បាស់ដូចត្បូង ហើយខ្ញុំអាចមើលឃើញវាទាំងអស់ ក្នុងមួយប៉ព្រិចភ្នែក។ (ខ្ញុំកំពុងបញ្ចេញបន្ទូលបែបនេះទាក់ទងនឹងភាពជាមនុស្សរបស់ខ្ញុំ ដូច្នេះហើយ ព្រះបន្ទូលទាំងនេះមិនផ្ទុយពីការកំណត់ទុកជាមុន និងការជ្រើសរើសរបស់ខ្ញុំនោះទេ។) ខ្ញុំដើរឆ្លងកាត់ភ្នំ និងទន្លេ ហើយក្នុងចំណោមរបស់សព្វសារពើនៅទូទាំងលំហនៃសាកលលោក ដោយត្រួតពិនិត្យ និងបន្សុទ្ធទីកន្លែងនីមួយៗ ដើម្បីឲ្យទីកន្លែងដែលមិនស្អាត និងដែនដីដែលច្របូកច្របល់ទាំងអស់នោះលែងមានវត្តមានតទៅទៀត ហើយត្រូវបានដុតឲ្យវិនាសបាត់ទៅដោយសារព្រះបន្ទូលរបស់ខ្ញុំ។ ចំពោះខ្ញុំ អ្វីៗគ្រប់យ៉ាងគឺងាយស្រួលទេ។ ប្រសិនបើពេលនេះ គឺជាពេលវេលាដែលខ្ញុំបានកំណត់សម្រាប់ការបំផ្លាញពិភពលោក នោះខ្ញុំអាចលេបវាដោយបន្ទូលតែមួយម៉ាត់។ ទោះបីជាយ៉ាងណាឥឡូវនេះមិនទាន់ដល់ពេលនោះទេ។ គ្រប់យ៉ាងត្រូវតែរួចរាល់មុនពេលដែលខ្ញុំនឹងធ្វើ

កិច្ចការនេះ ដើម្បីកុំឲ្យផែនការ និងការគ្រប់គ្រងរបស់ខ្ញុំត្រូវបានរំខាន។ ខ្ញុំជ្រាបដឹងពីវិធីដើម្បីធ្វើកិច្ចការនេះយ៉ាងសមហេតុផល៖ ខ្ញុំមាន ប្រាជ្ញា របស់ខ្ញុំ ហើយខ្ញុំមានការគ្រប់គ្រងផ្ទាល់របស់ខ្ញុំ។ មនុស្សមិនត្រូវកម្រើកម្រាមដៃមួយឡើយ ចូរប្រយ័ត្នកុំឲ្យស្លាប់ដោយសារព្រះហស្តរបស់ខ្ញុំ។ ចំណុចនេះបានប៉ះពាល់បញ្ញត្តិរដ្ឋបាលរបស់ខ្ញុំរួចហើយ។ តាមរយៈការនេះ បុគ្គលម្នាក់អាចមើលឃើញភាពសាហាវ នៃបញ្ញត្តិរដ្ឋបាលរបស់ខ្ញុំ ក៏ដូចជាគោលការណ៍នៅពីក្រោយបញ្ញត្តិទាំងនេះ ដែលមានពីរផ្នែក៖ មួយផ្នែក គឺខ្ញុំសម្លាប់អស់អ្នកដែលមិនស្របនឹងបំណងរបស់ខ្ញុំ និងអ្នកដែលបំពាននឹងបញ្ញត្តិរដ្ឋបាលរបស់ខ្ញុំ។ មួយផ្នែកទៀត ក្នុងសេចក្តីក្រោធរបស់ខ្ញុំ ខ្ញុំដាក់បណ្តាសាអស់អ្នកដែលបំពានបញ្ញត្តិរដ្ឋបាលរបស់ខ្ញុំ។ ទិដ្ឋភាពទាំងពីរនេះ គឺមិនអាចជៀសវាងបានឡើយ ហើយជាគោលការណ៍ប្រតិបត្តិនៅពីក្រោយបញ្ញត្តិរដ្ឋបាលរបស់ខ្ញុំ។ មនុស្សម្នាក់ៗត្រូវបានដោះស្រាយទៅតាមគោលការណ៍ទាំងពីរនេះ ដោយគ្មានមនោសញ្ចេតនាឡើយ មិនថាបុគ្គលម្នាក់មានភក្តីភាពយ៉ាងណានោះទេ។ សេចក្តីនេះ គឺគ្រប់គ្រាន់ដើម្បីបង្ហាញពីសេចក្តីសុចរិតរបស់ខ្ញុំ ឫទ្ធានុភាពរបស់ខ្ញុំ និងសេចក្តីក្រោធរបស់ខ្ញុំ ដែលនឹងដុតបំផ្លាញវត្ថុនៃផែនដីទាំងអស់ វត្ថុនៃលោកិយទាំងអស់ និងរបស់សព្វសារពើដែលមិនស្របទៅតាមបំណងរបស់ខ្ញុំ។ នៅក្នុងព្រះបន្ទូលរបស់ខ្ញុំមានអាថ៌កំបាំងដែលនៅតែលាក់បាំងនៅឡើយ ហើយនៅក្នុងព្រះបន្ទូលរបស់ខ្ញុំ ក៏មានអាថ៌កំបាំងដែលត្រូវបានបើកសម្តែងដែរ។ ដូច្នេះ ដោយផ្អែកតាមសញ្ញាណរបស់មនុស្ស និងនៅក្នុងចិត្តរបស់មនុស្ស នោះព្រះបន្ទូលរបស់ខ្ញុំ គឺមិនអាចយល់បានជារៀងរហូត ហើយដួងព្រះទ័យរបស់ខ្ញុំគឺមិនអាចវាស់ស្ទង់បានជារៀងរហូត។ មានន័យថា ខ្ញុំត្រូវតែយកមនុស្សចេញពីសញ្ញាណ និងការគិតរបស់ពួកគេ។ នេះគឺជាចំណុចសំខាន់បំផុតនៃផែនការគ្រប់គ្រងរបស់ខ្ញុំ។ ខ្ញុំត្រូវតែធ្វើវាតាមវិធីនេះ ដើម្បីទទួលបានពួកកូនប្រុសច្បងរបស់ខ្ញុំ និងដើម្បីសម្រេចអ្វីៗដែលខ្ញុំសព្វព្រះហឫទ័យចង់ធ្វើ។

គ្រោះមហន្តរាយរបស់ពិភពលោក មានកំណើនកាន់តែច្រើនឡើងៗពីមួយថ្ងៃទៅមួយថ្ងៃ ហើយនៅក្នុងដំណាក់របស់ខ្ញុំ គ្រោះមហន្តរាយដ៏ចង្រៃមានកំណើនកាន់តែ

ខ្លាំងក្លាជាងមុន។ មនុស្សពិតជាគ្មានកន្លែងដើម្បីលាក់ពួន គ្មានកន្លែងដើម្បីលាក់ខ្លួនឡើយ។ ដោយសារការផ្លាស់ប្ដូរដែលកំពុងតែកើតឡើងនៅពេលនេះ នោះមនុស្សមិនស្គាល់ទីកន្លែង ដែលពួកគេនឹងឈានជំហានបន្ទាប់របស់គេឡើយ។ ហេតុការណ៍នេះនឹងក្លាយជាការពិតក្រោយពីការជំនុំជម្រះរបស់ខ្ញុំប៉ុណ្ណោះ។ ចូរចាំទុកចុះ! ទាំងអស់នេះគឺជាជំហាននៃកិច្ចការរបស់ខ្ញុំ ហើយវាគឺជាវិធីដែលខ្ញុំធ្វើការ។ ខ្ញុំនឹងកម្សាន្តចិត្តពួកកូនប្រុសច្បងរបស់ខ្ញុំទាំងអស់ម្នាក់ម្ដងៗ ហើយលើកពួកគេឡើងមួយជំហានទៀតក្នុងពេលតែមួយ។ ចំពោះអ្នកស៊ីឈ្នួលវិញ ខ្ញុំនឹងផាត់ចោល និងបោះបង់ពួកគេទាំងអស់ម្ដងម្នាក់ៗ។ នេះគឺជាផ្នែកមួយ នៃផែនការគ្រប់គ្រងរបស់ខ្ញុំ។ បន្ទាប់ពីអ្នកស៊ីឈ្នួលទាំងអស់ត្រូវបានបើកឱ្យដឹង នោះពួកកូនប្រុសច្បងរបស់ខ្ញុំ ក៏នឹងត្រូវបានបើកឱ្យដឹងដែរ។ (ចំពោះខ្ញុំ កិច្ចការនេះពិតជាងាយស្រួលខ្លាំងណាស់។ បន្ទាប់ពីពួកគេស្ដាប់ឮព្រះបន្ទូលរបស់ខ្ញុំ នោះអ្នកស៊ីឈ្នួលទាំងអស់នឹងដកចេញពីមុខការជំនុំជម្រះរបស់ខ្ញុំ និងការគម្រាមកំហែងនៃព្រះបន្ទូលរបស់ខ្ញុំ ហើយមានតែពួកកូនប្រុសច្បងរបស់ខ្ញុំប៉ុណ្ណោះដែលស្ថិតនៅ។ នេះមិនមែនជាអ្វីមួយដែលជាការស្ម័គ្រចិត្ត ឬជាអ្វីមួយដែលបំណងរបស់មនុស្សអាចផ្លាស់ប្ដូរបាននោះទេ។ ផ្ទុយទៅវិញ វាជាវិញ្ញាណរបស់ខ្ញុំដែលធ្វើការនៅក្នុងមនុស្ស។) នេះមិនមែនជាហេតុការណ៍ដែលនៅឆ្ងាយនោះទេ ហើយក្នុងកម្រិតណាមួយ អ្នករាល់គ្នាគួរតែអាចដឹងចេញពីដំណាក់កាលនៃកិច្ចការរបស់ខ្ញុំនេះ និងចេញពីព្រះបន្ទូលរបស់ខ្ញុំ។ ហេតុអ្វីបានជាខ្ញុំ និយាយច្រើនម្ល៉េះ ខណៈពេលដែលធម្មជាតិដែលមិនអាចប៉ាន់ប្រមាណបាននៃសម្លេងរបស់ខ្ញុំ មិនអាចវាស់ស្ទង់បានចំពោះមនុស្ស។ ខ្ញុំនិយាយទៅកាន់ពួកកូនប្រុសច្បងរបស់ខ្ញុំ ដោយសំឡេងលួងលោមសេចក្ដីមេត្តាករុណា និងសេចក្ដីស្រឡាញ់ (ដោយសារតែខ្ញុំតែងតែបំភ្លឺមនុស្សទាំងនេះ ហើយខ្ញុំនឹងមិនចាកចេញពីពួកគេឡើយ ព្រោះខ្ញុំបានកំណត់ពួកគេ ទុកជាមុនរួចហើយ) ខណៈពេលដែលខ្ញុំប្រព្រឹត្តចំពោះមនុស្សក្រៅពីពួកកូនប្រុសច្បងរបស់ខ្ញុំដោយការជំនុំជម្រះដ៏ធ្ងន់ធ្ងរ ដោយការគម្រាមកំហែង និងដោយការសម្លុត ដែលធ្វើឲ្យពួកគេមានអារម្មណ៍ភ័យខ្លាចជានិច្ច ដល់ចំណុចដែលសរសៃប្រសាទរបស់ពួកគេធ្វើការ

ឥតឈប់ឈរ។ នៅពេលដែលស្ថានភាពបានវិវឌ្ឍន៍ទៅដល់កម្រិតជាក់លាក់មួយ នោះពួកគេនឹងរត់គេចពីសភាពនេះ (នៅពេលដែលខ្ញុំបំផ្លាញពិភពលោក មនុស្ស ទាំងនេះនឹងនៅក្នុងជង្ហុកធំ) ប៉ុន្តែពួកគេនឹងមិនដែលរត់គេចផុតពីដៃនៃការជំនុំជម្រះ របស់ខ្ញុំ ឬរួចផុតពីស្ថានភាពនេះបានឡើយ។ ដូចនេះ នេះគឺជាការជំនុំជម្រះរបស់ ពួកគេ នេះគឺជាការវាយផ្ចាលរបស់ពួកគេ។ នៅថ្ងៃដែលសាសន៍ដទៃមកដល់ នោះខ្ញុំ នឹងបើកសម្តែងមនុស្សទាំងនេះម្នាក់ម្តងៗ។ ទាំងនេះគឺជាជំហាននៃកិច្ចការរបស់ខ្ញុំ។ ពេលនេះ តើអ្នករាល់គ្នាយល់ពីគោលបំណងនៅពីក្រោយព្រះសូរសៀងខាងដើមនៃ ព្រះបន្ទូលរបស់ខ្ញុំទាំងនោះឬទេ? តាមគំនិតរបស់ខ្ញុំ អ្វីមួយដែលមិនត្រូវបានបំពេញ សម្រេច គឺជាអ្វីមួយដែលត្រូវបានបំពេញសម្រេច ប៉ុន្តែអ្វីមួយដែលត្រូវបានបំពេញ សម្រេច មិនចាំបាច់តែជាអ្វីមួយដែលសម្រេចបាននោះទេ។ នេះដោយសារតែខ្ញុំ មានប្រាជ្ញា និងវិធីធ្វើការរបស់ខ្ញុំ ដែលមនុស្សគ្រាន់តែមិនយល់ប៉ុណ្ណោះ។ នៅពេល ដែលខ្ញុំសម្រេចបានលទ្ធផលជាមួយនឹងជំហាននេះ (នៅពេលដែលខ្ញុំបានបើកឱ្យ ដឹងពីមនុស្សអាក្រក់ទាំងអស់ ដែលទាស់ទទឹងនឹងខ្ញុំ) នោះខ្ញុំនឹងចាប់ផ្តើមជំហាន បន្ទាប់ ព្រោះថាបំណងព្រះហឫទ័យរបស់ខ្ញុំមិនត្រូវបានរារាំង និងគ្មាននរណាម្នាក់ ហ៊ានរំខានផែនការគ្រប់គ្រងរបស់ខ្ញុំ ហើយគ្មានអ្វីហ៊ានបង្កឧបសគ្គណាមួយបាន ឡើយ ពួកវាទាំងអស់ត្រូវតែបើកផ្លូវ! ឱកូនៗរបស់នាគដ៏ធំមានសម្បុរក្រហមអើយ ចូរ ស្តាប់ខ្ញុំ! ខ្ញុំដើរមកពីស៊ីយ៉ូន ហើយបានក្លាយជាសាច់ឈាមនៅក្នុងពិភពលោក ដើម្បី ទទួលយកពួកកូនប្រុសច្បងរបស់ខ្ញុំ ដើម្បីធ្វើឲ្យឪពុករបស់អ្នករាល់គ្នាអាម៉ាស់មុខ (ពាក្យពេចន៍ទាំងនេះ សំដៅចំពោះកូនចៅរបស់នាគដ៏ធំមានសម្បុរក្រហម) ដើម្បី គាំទ្រពួកកូនប្រុសច្បងរបស់ខ្ញុំ និងដើម្បីកែតម្រូវកំហុសឆ្គងដែលបានកើតឡើងចំពោះ ពួកកូនប្រុសច្បងរបស់ខ្ញុំ។ ដូច្នេះហើយ មិនត្រូវសាហាវម្តងទៀតឡើយ ខ្ញុំនឹងឲ្យពួក កូនប្រុសច្បងរបស់ខ្ញុំដោះស្រាយជាមួយអ្នករាល់គ្នា។ កាលពីអតីតកាល ពួកកូនប្រុស របស់ខ្ញុំត្រូវបានគេចំអក និងជិះជាន់ ហើយដោយសារតែព្រះវរបិតាកាន់កាប់ព្រះចេស្តា ជំនួសពួកកូនប្រុសរបស់ទ្រង់ នោះពួកកូនប្រុសរបស់ខ្ញុំត្រូវតែវិលត្រឡប់មករកការ

ឱបក្រសោបដ៏គួរឲ្យស្រឡាញ់របស់ខ្ញុំ លែងត្រូវបានគេចំអក និងលែងត្រូវបានគេជិះជាន់ តទៅទៀតហើយ។ ខ្ញុំសុចរិត ដែលនេះបង្ហាញអំពីភាពសុចរិតរបស់ខ្ញុំ ហើយសេចក្ដីសុចរិតនេះពិតជា «កំពុងតែស្រឡាញ់អស់អ្នកដែលខ្ញុំស្រឡាញ់ ហើយកំពុងតែស្អប់អស់អ្នកដែលខ្ញុំស្អប់។» ប្រសិនបើអ្នកនិយាយថា ខ្ញុំមិនសុចរិត នោះអ្នករាល់គ្នាគួរតែប្រញាប់ ហើយចាកចេញទៅ។ មិនត្រូវតតអៀនខ្មាស ហើយចាំតែជំហាមនៅក្នុងដំណាក់របស់ខ្ញុំឡើយ។ អ្នកគួរតែវិលត្រឡប់ទៅផ្ទះរបស់អ្នកជាប្រញាប់ ដើម្បីកុំឲ្យខ្ញុំឃើញមុខអ្នកតទៅទៀត។ ជង្ហុកដ៏ធំ គឺជាទិសដៅរបស់អ្នករាល់គ្នា ហើយជាកន្លែងដែលអ្នករាល់គ្នានឹងសម្រាក។ ប្រសិនបើអ្នកនៅក្នុងដំណាក់របស់ខ្ញុំ នោះនឹងគ្មានទីកន្លែងសម្រាប់អ្នករាល់គ្នាឡើយ ព្រោះថាអ្នករាល់គ្នា គឺជាសត្វតិរច្ឆាននៃបន្ទុក អ្នកគឺជាឧបករណ៍ដែលខ្ញុំប្រើប្រាស់។ នៅពេលដែលខ្ញុំលែងត្រូវការប្រើអ្នកតទៅទៀត នោះខ្ញុំត្រូវតែបោះអ្នករាល់គ្នាទៅក្នុងភ្លើងដើម្បីដុតបញ្ឆេះអ្នក។ នេះគឺជាបញ្ញត្តិរដ្ឋបាលរបស់ខ្ញុំ។ ខ្ញុំត្រូវតែធ្វើរបៀបនេះ ហើយមានតែតាមវិធីនេះទេ ដែលបង្ហាញអំពីវិធីដែលខ្ញុំធ្វើការ និងបើកសម្ដែងអំពីភាពសុចរិត និងឫទ្ធានុភាពរបស់ខ្ញុំ។ សំខាន់ជាងនេះទៅទៀត មានតែតាមវិធីនេះប៉ុណ្ណោះ ដែលពួកកូនប្រុសច្បងរបស់ខ្ញុំនឹងត្រូវបានអនុញ្ញាតឲ្យសោយរាជ្យដោយព្រះចេស្ដាជាមួយខ្ញុំ។

## ជំពូកទី ៤៖ ព្រះបន្ទូលព្រះជាម្ចាស់ ថ្លែងទៅកាន់សកលលោកទាំងមូល

រាស្ត្ររបស់ខ្ញុំទាំងអស់ដែលបម្រើនៅចំពោះខ្ញុំ គួរតែគិតត្រឡប់ក្រោយវិញអំពីអតីតកាល៖ តើសេចក្ដីស្រឡាញ់របស់អ្នកចំពោះខ្ញុំ ត្រូវបានធ្វើឱ្យខូចដោយសារភាពមិនបរិសុទ្ធដែរឬទេ? តើភក្ដីភាពរបស់អ្នកចំពោះខ្ញុំបរិសុទ្ធ និងអស់ពីចិត្តដែរឬទេ? តើចំណេះដឹងរបស់អ្នកអំពីខ្ញុំពិតប្រាកដដែរឬទេ? តើខ្ញុំបានកាន់កាប់កន្លែងធំប៉ុនណានៅក្នុងដួងចិត្តរបស់អ្នករាល់គ្នា? តើខ្ញុំបានបំពេញដួងចិត្តរបស់អ្នកទាំងស្រុងដែរឬទេ?

តើព្រះបន្ទូលរបស់ខ្ញុំទទួលជោគជ័យប៉ុនណា នៅក្នុងខ្លួនអ្នករាល់គ្នា? កុំស្មានថាខ្ញុំភ្លីភ្លើឲ្យសោះ! រឿងទាំងនេះខ្ញុំដឹងច្បាស់ខ្លាំងណាស់! សព្វថ្ងៃនេះ ពេលព្រះសូរសៀងអំពីសេចក្ដីសង្គ្រោះរបស់ខ្ញុំត្រូវបានបន្លឺឡើង តើមានការកើនឡើងនូវសេចក្ដីស្រឡាញ់របស់អ្នករាល់គ្នាចំពោះខ្ញុំខ្លះដែរឬទេ? តើចំណែកនៃភក្ដីភាពរបស់អ្នករាល់គ្នាចំពោះខ្ញុំក្លាយជាបរិសុទ្ធដែរឬទេ? តើអ្នករាល់គ្នាស្គាល់ខ្ញុំបានស៊ីជម្រៅហើយឬនៅ? តើការលើកសរសើរដែលបានធ្វើក្នុងអតីតកាល បានចាក់គ្រឹះយ៉ាងរឹងមាំសម្រាប់ការស្គាល់របស់អ្នករាល់គ្នានាពេលសព្វថ្ងៃនេះដែរឬទេ? តើព្រះវិញ្ញាណរបស់ខ្ញុំ កាន់កាប់អ្នករាល់គ្នាបានប៉ុន្មាន? តើរូបអង្គរបស់ខ្ញុំកាន់កាប់កន្លែងធំប៉ុនណានៅក្នុងខ្លួនរបស់អ្នករាល់គ្នា? តើព្រះសូរសៀងរបស់ខ្ញុំធ្វើឱ្យអ្នករាល់គ្នាភ្ញាក់ខ្លួនដែរឬទេ? តើអ្នករាល់គ្នាពិតជាមានអារម្មណ៍ថា អ្នករាល់គ្នាគ្មានកន្លែងសម្រាប់លាក់បាំងភាពអាម៉ាស់របស់ខ្លួនដែរឬទេ? តើអ្នករាល់គ្នាពិតជាជឿថា អ្នករាល់គ្នាគ្មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការធ្វើជារាស្ត្ររបស់ខ្ញុំដែរឬទេ? ប្រសិនបើអ្នករាល់គ្នាមិនចាប់ភ្លឹកសោះចំពោះសំណួរខាងលើនេះទេ នោះវាបង្ហាញថា អ្នករាល់គ្នាកំពុងនេសាទក្នុងទឹកដ៏កខ្វក់ ហើយអ្នករាល់គ្នាមានវត្តមានគ្រាន់តែដើម្បីបង្កើនតួលេខ លុះពេលដែលខ្ញុំបានកំណត់ទុកជាមុនបានមកដល់ អ្នករាល់គ្នាប្រាកដជានឹងត្រូវបានផាត់ចោល និងបោះចូលទៅក្នុងជង្ហុកធំជាលើកទីពីរ។ ទាំងនេះជាព្រះបន្ទូលព្រមានរបស់ខ្ញុំ ហើយអ្នកណាមើលស្រាលព្រះបន្ទូលទាំងនេះ នឹងត្រូវបានដាក់ទោសធ្ងន់ធ្ងរដោយការជំនុំជម្រះរបស់ខ្ញុំ ហើយនៅពេលដែលបានកំណត់នោះមកដល់ ពួកគេនឹងជួបគ្រោះមហន្តរាយ។ តើវាមិនដូច្នោះទេឬ? តើខ្ញុំនៅតែត្រូវផ្ដល់ឧទាហរណ៍ផ្សេងៗ ដើម្បីពន្យល់បង្ហាញពីរឿងនេះទៀតដែរឬទេ? តើខ្ញុំត្រូវតែមានព្រះបន្ទូលឲ្យច្បាស់ជាងមុន ដើម្បីផ្ដល់ជាឧទាហរណ៍គំរូដល់អ្នករាល់គ្នាទៀតដែរឬទេ? ចាប់តាំងពីពេលបង្កើត មករហូតដល់សព្វថ្ងៃនេះ មនុស្សជាច្រើនមិនបានស្ដាប់បង្គាប់ព្រះបន្ទូលរបស់ខ្ញុំទេ ម្ល៉ោះហើយពួកគេត្រូវបានបណ្ដេញ និងផាត់ចោលពីអូរនៃការស្ដារឡើងវិញរបស់ខ្ញុំ ហើយនៅទីបំផុត រូបកាយរបស់ពួកគេក៏វិនាស ឯវិញ្ញាណរបស់ពួកគេត្រូវបានបោះចូលទៅក្នុងស្ថានឃុំព្រលឹង

ហើយសូម្បីតែសព្វថ្ងៃនេះ ក៏ពួកគេនៅតែទទួលរងការដាក់ទោសយ៉ាងធ្ងន់ធ្ងរផងដែរ។ មនុស្សជាច្រើនបានធ្វើតាមព្រះបន្ទូលរបស់ខ្ញុំ ប៉ុន្តែពួកគេបានប្រឆាំងនឹងការបំភ្លឺ និងការស្រាយបំភ្លឺរបស់ខ្ញុំ ហេតុដូច្នេះហើយ ពួកគេក៏ត្រូវបានខ្ញុំទាត់ចោលផងដែរ ហើយក៏ធ្លាក់ក្រោមដែនត្រួតត្រារបស់សាតាំង និងក្លាយជាអ្នកដែលប្រឆាំងនឹងខ្ញុំ។ (សព្វថ្ងៃនេះ អស់អ្នកដែលប្រឆាំងនឹងខ្ញុំដោយផ្ទាល់ ស្ដាប់បង្គាប់តែសេចក្ដីរាក់កំផែលនៃព្រះបន្ទូលរបស់ខ្ញុំប៉ុណ្ណោះ ហើយមិនស្ដាប់បង្គាប់ទម្ងន់នៃព្រះបន្ទូលរបស់ខ្ញុំទេ។) ក៏មានមនុស្សជាច្រើនផងដែរ ដែលពួកគេគ្រាន់តែស្ដាប់ព្រះបន្ទូលដែលខ្ញុំបានថ្លែងកាលពីម្សិលមិញ និងពួកអ្នកដែលបានរក្សាទុក «សំណល់ឥតបានការ» ពីអតីតកាល ហើយមិនឲ្យតម្លៃ «ផល» នៃបច្ចុប្បន្នកាល។ មនុស្សទាំងនេះមិនត្រឹមតែត្រូវបានសាតាំងចាប់ឃុំខ្លួនប៉ុណ្ណោះទេ តែថែមទាំងបានក្លាយជាមនុស្សមានបាបអស់កល្បជានិច្ច និងក្លាយជាសត្រូវរបស់ខ្ញុំទៀតផង ហើយពួកគេប្រឆាំងនឹងខ្ញុំដោយផ្ទាល់។ មនុស្សបែបនេះជាកម្មវត្ថុនៃការជំនុំជម្រះរបស់ខ្ញុំ តាមទំហំនៃសេចក្ដីក្រោធរបស់ខ្ញុំ ហើយសព្វថ្ងៃនេះ ពួកគេនៅតែខ្វាក់ នៅតែស្ថិតក្នុងគុកងងឹតដដែល (និយាយឲ្យចំគឺថា មនុស្សបែបនេះគឺជាសាកសពដែលរលួយលែងដឹងអ្វី ដែលត្រូវបានគ្រប់គ្រងដោយសាតាំង ពីព្រោះភ្នែករបស់ពួកគេត្រូវបានខ្ញុំគ្របហើយ ខ្ញុំចង់មានន័យថា ពួកគេខ្វាក់ភ្នែក)។ វាជាការល្អក្នុងការផ្ដល់ឧទាហរណ៍ធ្វើជាសេចក្ដីសំអាងដល់អ្នករាល់គ្នា ដើម្បីឲ្យអ្នករាល់គ្នារៀនពីវា៖

តាមការលើកឡើងរបស់ប៉ូល អ្នករាល់គ្នានឹងគិតអំពីប្រវត្តិរបស់គាត់ និងរឿងរ៉ាវមួយចំនួនអំពីគាត់ ដែលមិនត្រឹមត្រូវ និងមិនសមស្របជាមួយការពិត។ គាត់ត្រូវបានឪពុកម្ដាយបង្រៀនតាំងតែពីតូច និងទទួលបានជីវិតរបស់ខ្ញុំ ហើយដោយសារការកំណត់ទុកជាមុនរបស់ខ្ញុំ គាត់មានគុណសម្បត្តិដែលខ្ញុំត្រូវការ។ នៅអាយុ ១៩ ឆ្នាំ គាត់បានអានសៀវភៅជាច្រើនអំពីជីវិត ម្ល៉ោះហើយខ្ញុំមិនចាំបាច់រៀបរាប់លម្អិតអំពីរបៀបអ្វីមួយឡើយ ព្រោះគាត់មានគុណសម្បត្តិរួចហើយ ឯខ្ញុំក៏បានបំភ្លឺ និងពន្យល់ហើយដែរ គាត់មិនត្រឹមតែអាចនិយាយ ដោយមានពន្លឺខាងក្នុងមួយចំនួន

អំពីបញ្ហាខាងវិញ្ញាណប៉ុណ្ណោះទេ តែគាត់ថែមទាំងអាចយល់ពីបំណងព្រះហឫទ័យរបស់ខ្ញុំទៀតផង។ ពិតមែនហើយ នេះមិនទាន់ដកចេញនូវកត្តាខាងក្នុង និងខាងក្រៅនៅឡើយទេ។ ទោះយ៉ាងណាក៏ដោយ គាត់មានភាពមិនគ្រប់លក្ខណ៍មួយ គឺថា ដោយសារតែទេពកោសល្យរបស់គាត់ ធ្វើឲ្យគាត់ប្រសប់និយាយ និងប្រសប់អួត។ ជាលទ្ធផល ដោយសារតែការមិនស្ដាប់បង្គាប់របស់គាត់ ដែលក្នុងនោះមានដូចជាការធ្វើជាតំណាង ឲ្យមហាទេវតាដោយផ្ទាល់ជាដើម នៅពេលខ្ញុំត្រលប់ជាសាច់ឈាមជាលើកដំបូង គាត់បានប្រឹងធ្វើសព្វបែបយ៉ាងដើម្បីផ្ដើនប្រឆាំងខ្ញុំ។ គាត់ជាមនុស្សម្នាក់ ក្នុងចំណោមពួកអ្នកដែលមិនស្គាល់ពីព្រះបន្ទូលរបស់ខ្ញុំ ហើយកន្លែងរបស់ខ្ញុំដែលនៅក្នុងដួងចិត្តរបស់គាត់បានបាត់អស់ហើយ។ មនុស្សបែបនេះប្រឆាំងនឹងភាពជាព្រះរបស់ខ្ញុំដោយផ្ទាល់ និងត្រូវបានខ្ញុំវាយទម្លាក់ ហើយនៅចុងបញ្ចប់ គេមានតែឱនក្បាល និងសារភាពពីបាបរបស់ពួកគេ។ ហេតុដូច្នេះហើយ បន្ទាប់ពីខ្ញុំបានប្រើចំណុចខ្លាំងរបស់គាត់ហើយ (និយាយឲ្យចំគឺថា ក្រោយពេលគាត់បានធ្វើការថ្វាយខ្ញុំមួយរយៈមក) គាត់ធ្លាក់ចូលក្នុងមាគ៌ាចាស់របស់គាត់ម្ដងទៀត ហើយទោះបីជាគាត់មិនបានស្ដាប់បង្គាប់ព្រះបន្ទូលរបស់ខ្ញុំដោយផ្ទាល់ក្ដី តែគាត់មិនបានស្ដាប់បង្គាប់ការណែនាំ និងការបំភ្លឺពីខាងក្នុងរបស់ខ្ញុំទេ ម្ល៉ោះហើយអ្វីគ្រប់យ៉ាងដែលគាត់បានធ្វើក្នុងអតីតកាលគឺឥតប្រយោជន៍ ឬនិយាយម្យ៉ាងទៀតថា មកុដនៃសិរីល្អដែលគាត់បាននិយាយនោះ បានក្លាយជាពាក្យឥតខ្លឹមសារ ដែលជាផលនៃការស្រមើលស្រមៃរបស់គាត់ផ្ទាល់ ដ្បិតសូម្បីតែសព្វថ្ងៃនេះ គាត់នៅតែត្រូវទទួលរងការជំនុំជម្រះរបស់ខ្ញុំ ដោយស្ថិតក្នុងភាពជាប់ឃុំដោយចំណងរបស់ខ្ញុំ។

តាមរយៈឧទាហរណ៍ខាងលើនេះ គេអាចមើលឃើញថា អស់អ្នកណាដែលប្រឆាំងនឹងខ្ញុំ (ដោយមិនមែនត្រឹមតែជាការប្រឆាំងនឹងភាពជាសាច់ឈាមរបស់ខ្ញុំប៉ុណ្ណោះទេ ប៉ុន្តែអ្វីដែលសំខាន់ជាងនេះទៅទៀតនោះគឺ ការប្រឆាំងនឹងព្រះបន្ទូលរបស់ខ្ញុំ និងព្រះវិញ្ញាណរបស់ខ្ញុំ និយាយឱ្យចំគឺថា ភាពជាព្រះរបស់ខ្ញុំ) ពួកគេត្រូវរងការជំនុំជម្រះរបស់ខ្ញុំនៅក្នុងសាច់ឈាមរបស់ពួកគេ ពេលព្រះវិញ្ញាណរបស់ខ្ញុំចាកចេញពីអ្នក ជា

ពេលដែលអ្នកធ្លាក់ចុះភ្លាមទៅក្រោម ដោយធ្លាក់ចូលទៅក្នុងស្ថានឃុំព្រលឹងដោយផ្ទាល់។ ហើយទោះបីជារូបកាយខាងសាច់ឈាមរបស់អ្នកនៅលើផែនដីក៏ដោយ ក៏អ្នកដូចជាមនុស្សម្នាក់ដែលរងទុក្ខដោយសារជំងឺផ្លូវចិត្តដែរ៖ អ្នកបានបាត់បង់ហេតុផលរបស់អ្នក ហើយភ្លាមៗនោះមានអារម្មណ៍ប្រៀបដូចជាសាកសពអីចឹង រហូតដល់ថ្នាក់អ្នកអង្វរខ្ញុំឲ្យបញ្ចប់សាច់ឈាមរបស់អ្នកដោយមិនបាច់បង្អង់។ អ្នករាល់គ្នាដែលមានវិញ្ញាណ ភាគច្រើនឲ្យតម្លៃខ្លាំងចំពោះកាលៈទេសៈទាំងនេះ ហើយខ្ញុំមិនចាំបាច់រៀបរាប់លម្អិតបន្ថែមទៀតទេ។ កាលពីមុន ពេលខ្ញុំធ្វើកិច្ចការក្នុងភាពជាមនុស្សធម្មតា មនុស្សភាគច្រើនបានវាស់ស្ទង់ខ្លួនគេធៀបនឹងសេចក្តីក្រោធ និងឫទ្ធានុភាពរបស់ខ្ញុំរួចហើយ ព្រមទាំងបានដឹងបន្តិចបន្តួចរួចហើយអំពីព្រះប្រាជ្ញាញាណ និងនិស្ស័យរបស់ខ្ញុំ។ សព្វថ្ងៃនេះ ខ្ញុំមានព្រះបន្ទូល និងធ្វើសកម្មភាពដោយផ្ទាល់ក្នុងភាពជាព្រះ ហើយនៅតែមានមនុស្សមួយចំនួនដែលនឹងមើលឃើញសេចក្តីក្រោធ និងការជំនុំជម្រះរបស់ខ្ញុំដោយផ្ទាល់ភ្នែករបស់ពួកគេ ជាងនេះទៅទៀត កិច្ចការចម្បងនៃផ្នែកទីពីរក្នុងយុគនៃការជំនុំជម្រះ គឺធ្វើឱ្យរាស្ត្ររបស់ខ្ញុំទាំងអស់ដឹងពីអំពើរបស់ខ្ញុំនៅក្នុងសាច់ឈាមដោយផ្ទាល់ ហើយធ្វើឱ្យអ្នកទាំងអស់គ្នាមើលឃើញនិស្ស័យរបស់ខ្ញុំដោយផ្ទាល់។ តែដោយសារខ្ញុំនៅក្នុងសាច់ឈាម នោះខ្ញុំបានព្រះតម្រិះមើលពីចំណុចខ្សោយរបស់អ្នករាល់គ្នា។ ខ្ញុំសង្ឃឹមថា អ្នករាល់គ្នាមិនចាត់ទុកវិញ្ញាណ ព្រលឹង និងរូបកាយរបស់អ្នករាល់គ្នាថាជារបស់លេងនោះទេ ដោយខ្វះការពិចារណាលះបង់ពួកវាទៅឲ្យសាតាំងឡើយ។ វាកាន់តែប្រសើរក្នុងការឲ្យតម្លៃខ្លាំងដល់អ្វីគ្រប់យ៉ាងដែលអ្នករាល់គ្នាមាន ហើយកុំចាត់ទុកវាដូចជាល្បែង ដ្បិតរបស់ទាំងនេះវាទាក់ទងដល់វាសនារបស់អ្នករាល់គ្នា។ តើអ្នករាល់គ្នាពិតជាអាចយល់ពីអត្ថន័យពិតនៃព្រះបន្ទូលរបស់ខ្ញុំឬទេ? តើអ្នករាល់គ្នាមានសមត្ថភាពក្នុងការយល់ពីអារម្មណ៍ពិតរបស់ខ្ញុំឬទេ?

តើអ្នករាល់គ្នាចង់បានព្រះពររបស់ខ្ញុំនៅលើផែនដី ដែលស្រដៀងនឹងព្រះពរនៅលើស្ថានសួគ៌ដែរឬទេ? តើអ្នករាល់គ្នាចង់ស្វែងរកនូវការយល់ដឹងអំពីខ្ញុំ ដែលជាការរីករាយនឹងព្រះបន្ទូលរបស់ខ្ញុំ និងការស្គាល់ខ្ញុំ ថាជារបស់ដែលមានតម្លៃ និងមានន័យ

បំផុតនៅក្នុងជីវិតរបស់អ្នករាល់គ្នាដែរឬទេ? តើអ្នករាល់គ្នាពិតជាអាចចុះចូលនឹងខ្ញុំយ៉ាងពេញលេញ ដោយមិនគិតពីក្ដីសង្ឃឹមផ្ទាល់ខ្លួនរបស់អ្នករាល់គ្នាដែរឬទេ? តើអ្នករាល់គ្នាពិតជាអាចឱ្យខ្លួនឯងរងការសម្លាប់ដោយខ្ញុំ និងនៅក្រោមការដឹកនាំរបស់ខ្ញុំដូចចៀមដែរឬទេ? តើមាននរណាម្នាក់ក្នុងចំណោមអ្នករាល់គ្នា ដែលមានសមត្ថភាពសម្រេចបានរបស់ទាំងនេះដែរឬទេ? តើវាអាចទៅរួចទេដែលថា អស់អ្នកដែលខ្ញុំព្រមទទួលយក ហើយទទួលបានការសន្យារបស់ខ្ញុំ គឺជាអ្នកដែលទទួលនូវព្រះពររបស់ខ្ញុំ? តើអ្នករាល់គ្នាបានយល់ដឹងពីព្រះបន្ទូលទាំងនេះហើយឬនៅ? ប្រសិនបើខ្ញុំល្បងលអ្នករាល់គ្នា តើអ្នករាល់គ្នាពិតជាអាចដាក់ខ្លួនឯងឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់ខ្ញុំទាំងស្រុង និងស្ថិតក្នុងការល្បងលទាំងនេះ ហើយស្វែងរកបំណងហឫទ័យរបស់ខ្ញុំ ព្រមទាំងស្គាល់ពីដួងព្រះហឫទ័យរបស់ខ្ញុំដែរឬទេ? ខ្ញុំមិនប្រាថ្នាឲ្យអ្នករាល់គ្នាអាចនិយាយនូវពាក្យសម្ដីដែលធ្វើឲ្យរំជួលចិត្តច្រើនទេ ឬក៏និទានរឿងដែលធ្វើឱ្យរំភើបច្រើនឡើយ ផ្ទុយទៅវិញខ្ញុំបង្គាប់ឲ្យអ្នកអាចធ្វើបន្ទាល់ល្អៗអំពីខ្ញុំ និងឲ្យអ្នកអាចចូលទៅក្នុងការពិតឲ្យបានពេញលេញ និងស៊ីជម្រៅ។ ប្រសិនបើខ្ញុំមិនបានមានព្រះបន្ទូលដោយផ្ទាល់ទេ តើអ្នកអាចលះបង់ចោលរាល់អ្វីៗដែលនៅជុំវិញអ្នក និងឱ្យខ្លួនអ្នកបម្រើខ្ញុំបានដែរឬទេ? តើនេះមិនមែនជាការពិតដែលខ្ញុំត្រូវការទេឬ? តើអ្នកណាអាចយល់ពីអត្ថន័យនៅក្នុងព្រះបន្ទូលរបស់ខ្ញុំបាន? ប៉ុន្តែខ្ញុំសុំឱ្យអ្នករាល់គ្នាឈប់ព្រួយបារម្ភពីសេចក្ដីសង្ស័យ និងសុំឱ្យមានបុរេសកម្ម នៅក្នុងការចូលរបស់អ្នករាល់គ្នា ហើយយល់ពីសារជាតិនៃព្រះបន្ទូលរបស់ខ្ញុំ។ ការនេះនឹងការពារអ្នករាល់គ្នាមិនឱ្យយល់ច្រឡំព្រះបន្ទូលរបស់ខ្ញុំ និងមិនឱ្យមានភាពមិនច្បាស់លាស់អំពីអត្ថន័យរបស់ខ្ញុំ ព្រមទាំងការបំពានលើបញ្ញត្តិរដ្ឋបាលរបស់ខ្ញុំ។ ខ្ញុំសង្ឃឹមថា អ្នករាល់គ្នាយល់ពីបំណងព្រះហឫទ័យរបស់ខ្ញុំចំពោះអ្នករាល់គ្នានៅក្នុងព្រះបន្ទូលរបស់ខ្ញុំ។ ចូរកុំគិតពីក្ដីសង្ឃឹមផ្ទាល់ខ្លួនតទៅទៀត ហើយចូរធ្វើដូចជាអ្នករាល់គ្នាបានតាំងចិត្តនៅចំពោះព្រះភក្ត្រខ្ញុំ ដើម្បីចុះចូលក្រោមការចាត់ចែងរបស់ព្រះជាម្ចាស់លើរបស់សព្វសារពើ។ អស់អ្នកដែលឈរក្នុងដំណាក់របស់ខ្ញុំ គួរតែធ្វើឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន ហើយ

អ្នកគួរតែផ្ដល់នូវអ្វីដែលល្អបំផុតអំពីខ្លួនឯង ទៅឲ្យផ្នែកចុងក្រោយនៃកិច្ចការរបស់ខ្ញុំនៅលើផែនដី។ តើអ្នកពិតជាចង់អនុវត្តការទាំងនេះមែនឬទេ?

ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៩២

# ជំពូកទី ៥៖ ព្រះបន្ទូលព្រះជាម្ចាស់ ថ្លែងទៅកាន់សកលលោកទាំងមូល

ព្រះសូរសៀងនៃព្រះវិញ្ញាណរបស់ខ្ញុំ គឺជាការបង្ហាញពីនិស្ស័យទាំងមូលរបស់ខ្ញុំ។ តើអ្នករាល់គ្នាយល់ឬទេ? ការមិនយល់ច្បាស់អំពីចំណុចនេះ គឺស្មើនឹងការរឹងទទឹងនឹងខ្ញុំដោយផ្ទាល់។ តើអ្នករាល់គ្នាពិតជាបានឃើញសារៈសំខាន់ ដែលមាននៅក្នុងនេះឬទេ? តើអ្នករាល់គ្នាដឹងថា ខ្ញុំខិតខំខ្លាំងយ៉ាងណា និងចំណាយថាមពលច្រើនយ៉ាងណាទៅលើអ្នករាល់គ្នាឬទេ? តើអ្នករាល់គ្នា ពិតជាហ៊ានលាតត្រដាងអ្វីៗដែលអ្នករាល់គ្នាបានធ្វើ និងបានប្រព្រឹត្តនៅចំពោះមុខឬទេ? ហើយអ្នករាល់គ្នាថ្លើមធំហ៊ានហៅខ្លួនឯងថា ជារាស្ដ្ររបស់ខ្ញុំនៅចំពោះមុខខ្ញុំ អ្នករាល់គ្នាមិនទាំងចេះខ្មាសអៀនផង កុំថាឡើយដល់ទៅមានញាណអ្វីនោះ! មិនយូរមិនឆាប់ មនុស្សដូចអ្នករាល់គ្នានឹងត្រូវបណ្ដេញចេញពីព្រះដំណាក់របស់ខ្ញុំ! ចូរកុំប្រើល្បិចទាហានចាស់ជាមួយខ្ញុំ ដោយស្មានថាអ្នករាល់គ្នាបានប្រកាន់ខ្ជាប់នូវទីបន្ទាល់សម្រាប់ខ្ញុំ! តើនេះជាអ្វីដែលមនុស្សជាតិមានសមត្ថភាពធ្វើបានឬ? ប្រសិនបើអ្នកនៅតែមានបំណង និងគោលដៅរបស់ខ្លួន នោះអ្នកបានចាប់ផ្ដើមថ្មីលើផ្លូវផ្សេងទៀតតាំងពីយូរមកហើយ។ តើអ្នកគិតថា ខ្ញុំមិនដឹងពីចំនួនដែលដួងចិត្តរបស់មនុស្សអាចផ្ទុកបានឬ? ចាប់ពីពេលនេះតទៅ នៅក្នុងរបស់សព្វសារពើ អ្នកត្រូវតែចូលទៅក្នុងភាពជាក់ស្ដែងនៃការអនុវត្ត បើគ្រាន់តែនិយាយខ្ជិលៗដូចដែលអ្នកបានធ្វើកាលពីមុន នោះអ្នកនឹងលែងទៅរួចទៀតហើយ។ កាលពីមុន អ្នករាល់គ្នាភាគច្រើនបានលៃលកកេងប្រវ័ញ្ចក្រោមដំបូលរបស់ខ្ញុំ ឯការពិតដែលថាអ្នកអាចឈរយ៉ាងរឹងមាំនៅថ្ងៃនេះ គឺសុទ្ធតែដោយសារភាព

ខ្លាំងនៃព្រះបន្ទូលរបស់ខ្ញុំទាំងអស់។ តើអ្នកគិតថា ខ្ញុំមានព្រះបន្ទូលដោយចៃដន្យ ដោយគ្មានគោលបំណងឬ? មិនអាចទៅរួចទេ! ខ្ញុំទតមកក្រោមឃើញរបស់សព្វសារពើពីស្ថានលើមក ហើយធ្វើការត្រួតត្រាលើរបស់សព្វសារពើពីស្ថានលើមក។ តាមរបៀបដូចគ្នានេះ ខ្ញុំបានដាក់សេចក្ដីសង្គ្រោះរបស់ខ្ញុំនៅលើផែនដីយ៉ាងត្រឹមត្រូវ។ មិនដែលមានពេលណាមួយដែលខ្ញុំមិនឃ្លាំមើលពីកន្លែងដ៏សម្ងាត់របស់ខ្ញុំនូវរាល់ចលនារបស់មនុស្ស និងរាល់អ្វីៗដែលពួកគេនិយាយ និងធ្វើនោះទេ។ ខ្ញុំស្គាល់មនុស្សដូចជាការបើកសៀវភៅមើលអ៊ីចឹង៖ ខ្ញុំឃើញ និងស្គាល់ពួកគេគ្រប់ៗគ្នា។ កន្លែងសម្ងាត់គឺជាទីលំនៅរបស់ខ្ញុំ ហើយផ្ទៃនៃស្ថានសួគ៌ទាំងមូល គឺជាគ្រែឡាបន្ទំរបស់ខ្ញុំ។ កម្លាំងរបស់សាតាំងមិនអាចទៅដល់ខ្ញុំបានទេ ដ្បិតខ្ញុំមានហូរហៀរទៅដោយឫទ្ធានុភាព សេចក្ដីសុចរិត និងការជំនុំជម្រះ។ អាថ៌កំបាំងដែលហួសនឹងថ្លែងបាន ស្ថិតនៅក្នុងព្រះបន្ទូលរបស់ខ្ញុំ។ នៅពេលខ្ញុំកំពុងមានបន្ទូល អ្នករាល់គ្នាក្លាយជាសត្វស្លាបដែលទើបតែត្រូវបានគេបោះចូលទៅក្នុងទឹក និងត្រូវបានសន្ធប់ដោយភាពច្របូកច្របល់ ឬជាទារកដែលទើបតែរងការភ័យរន្ធត់ ដែលហាក់ដូចជាមិនដឹងអ្វីទាំងអស់ ព្រោះវិញ្ញាណរបស់អ្នករាល់គ្នា បានធ្លាក់ទៅក្នុងសភាពភាំងស្មារតី។ ហេតុអ្វីបានជាខ្ញុំមានព្រះបន្ទូលថា កន្លែងអាថ៌កំបាំងគឺជាទីលំនៅរបស់ខ្ញុំ? តើអ្នកដឹងពីអត្ថន័យដ៏ជ្រាលជ្រៅនៃព្រះបន្ទូលរបស់ខ្ញុំឬទេ? តើមានមនុស្សណាម្នាក់ មានសមត្ថភាពស្គាល់ខ្ញុំឬទេ? តើមានអ្នកណាមានសមត្ថភាពស្គាល់ខ្ញុំ ដូចដែលគេស្គាល់ឪពុកម្ដាយរបស់គេឬទេ? ខ្ញុំសម្រាកក្នុងទីលំនៅរបស់ខ្ញុំ ហើយឃ្លាំមើលយ៉ាងដិតដល់៖ មនុស្សទាំងអស់នៅលើផែនដីញាប់ដៃញាប់ជើង «ធ្វើដំណើរជុំវិញពិភពលោក» និងប្រញាប់ប្រញាល់ទៅមក សុទ្ធតែសម្រាប់ជាប្រយោជន៍ដល់ជោគវាសនា និងអនាគតរបស់ពួកគេ។ តែទោះយ៉ាងនេះក្ដី គ្មានឡើយ សូម្បីតែមួយនាក់ដែលមានថាមពលអាចប្រើបានសម្រាប់កសាងនគររបស់ខ្ញុំ ហើយសូម្បីតែការប្រឹងប្រែងក្នុងការដកដង្ហើមក៏មិនមានស្មើដែរ។ ខ្ញុំបានបង្កើតមនុស្ស ហើយខ្ញុំបានរំដោះពួកគេពីការរងទុក្ខខ្លាំងជាច្រើនលើកច្រើនសា តែទោះយ៉ាងណា មនុស្សទាំងនេះសុទ្ធតែអកតញ្ញូ៖ គ្មាននរណាម្នាក់ឡើយ

ក្នុងចំណោមពួកគេដែលអាចរៀបរាប់បានអស់នូវឧទាហរណ៍ អំពីសេចក្តីសង្គ្រោះរបស់ខ្ញុំនោះទេ។ វាមានរយៈពេលច្រើនឆ្នាំ រហូតដល់ច្រើនសតវត្សរ៍ ចាប់តាំងពីពេលបង្កើតពិភពលោក រហូតមកដល់សព្វថ្ងៃនេះ ខ្ញុំបានបង្កើតការអស្ចារ្យជាច្រើន និងបានបង្ហាញព្រះប្រាជ្ញាញាណរបស់ខ្ញុំជាច្រើនដងមកហើយ។ តែទោះជាដូច្នេះក្តី មនុស្សហាក់ប្រែជាឆ្កួត និងស្ពឹកដូចមានរោគចិត្ត ហើយថែមទាំងពេលខ្លះដូចសត្វព្រៃដែលបោលចុះឡើងនៅក្នុងព្រៃ ដោយមិនចាប់អារម្មណ៍យកចិត្តទុកដាក់បន្តិចសោះចំពោះកិច្ចការរបស់ខ្ញុំ។ ជាច្រើនដងមកហើយ ខ្ញុំបានកាត់ទោសប្រហារជីវិតមនុស្ស និងបានផ្តន្ទាទោសពួកគេដល់ស្លាប់ ប៉ុន្តែផែនការគ្រប់គ្រងរបស់ខ្ញុំ មិនមាននរណាម្នាក់អាចផ្លាស់ប្តូរបានឡើយ។ ហេតុដូច្នេះហើយ នៅក្នុងព្រះហស្តរបស់ខ្ញុំ មនុស្សនៅតែបន្តបង្ហាញនូវរឿងចាស់ដែលពួកគេបានប្រកាន់ខ្ជាប់។ ព្រោះតែជំហាននៃកិច្ចការរបស់ខ្ញុំ ខ្ញុំបានរំដោះអ្នករាល់គ្នាម្តងទៀត ដែលជាអ្នកបានកើតនៅក្នុងគ្រួសារដ៏ធំមួយដែលអាក្រក់ គ្មានសីលធម៌ ស្មោកគ្រោក និងថោកទាប។

កិច្ចការដែលបានគ្រោងទុករបស់ខ្ញុំ នៅតែបន្តទៅមុខដោយគ្មានឈប់មួយខណៈណាឡើយ។ ដោយបានផ្លាស់ចូលទៅក្នុងយុគសម័យនៃនគរព្រះ និងដោយបានដឹកនាំអ្នករាល់គ្នាឲ្យចូលទៅក្នុងនគររបស់ខ្ញុំធ្វើជារាស្ត្ររបស់ខ្ញុំ នោះខ្ញុំនឹងមានការទាមទារផ្សេងទៀតដែលត្រូវធ្វើចំពោះអ្នករាល់គ្នា គឺថា ខ្ញុំនឹងចាប់ផ្តើមប្រកាសនៅចំពោះមុខអ្នករាល់គ្នាឲ្យប្រើធម្មនុញ្ញដែលខ្ញុំនឹងយកមកគ្រប់គ្រងយុគសម័យនេះ៖

ដោយហេតុថាអ្នករាល់គ្នាត្រូវបានហៅថាជារាស្ត្ររបស់ខ្ញុំ នោះអ្នករាល់គ្នាគួរតែអាចលើកតម្កើងព្រះនាមរបស់ខ្ញុំបាន ពោលគឺ ត្រូវប្រកាន់ខ្ជាប់នូវទីបន្ទាល់នៅក្នុងកណ្តាលសមុទ្រទុក្ខ។ ប្រសិនបើអ្នកណាម្នាក់ប៉ុនប៉ងបញ្ឆោតខ្ញុំ និងលាក់បាំងការពិតពីខ្ញុំ ឬចូលរួមក្នុងការប្រព្រឹត្តបង្ខូចព្រះកិត្តិនាមពីក្រោយខ្នងខ្ញុំ មនុស្សបែបនេះនឹងត្រូវបានដេញចេញ និងយកចេញពីផ្ទះរបស់ខ្ញុំ ឲ្យទៅរង់ចាំខ្ញុំដោះស្រាយជាមួយពួកគេ។ អស់អ្នកដែលផិតក្បត់ និងគ្មានលក្ខណៈជាកូនខ្ញុំកាលពីមុន និងអ្នកដែលក្រោកឡើងជាថ្មីនៅថ្ងៃនេះដើម្បីវិនិច្ឆ័យខ្ញុំជាចំហ ពួកគេក៏នឹងត្រូវដេញចេញពីផ្ទះ

របស់ខ្ញុំផងដែរ។ អស់អ្នកដែលជារាស្ត្ររបស់ខ្ញុំ ត្រូវតែបង្ហាញជានិច្ចនូវការចេះគិតគូរចំពោះបន្ទុករបស់ខ្ញុំ ព្រមទាំងប្រឹងប្រែងស្គាល់ព្រះបន្ទូលរបស់ខ្ញុំ។ មានតែមនុស្សដូចនេះទេ ទើបខ្ញុំនឹងបំភ្លឺពួកគេ ហើយពួកគេនឹងរស់នៅក្រោមការណែនាំ និងការបំភ្លឺរបស់ខ្ញុំ ដោយមិនជួបការវាយផ្ចាលសោះឡើយ។ អស់អ្នកដែលមិនបានបង្ហាញនូវការចេះគិតគូរចំពោះបន្ទុករបស់ខ្ញុំ ហើយផ្ដោតលើការធ្វើផែនការសម្រាប់អនាគតផ្ទាល់ខ្លួនពួកគេ (ពោលគឺ អស់អ្នកដែលមិនបានតម្រង់សកម្មភាពរបស់ពួកគេ ដើម្បីបំពេញបំណងព្រះហឫទ័យរបស់ខ្ញុំ ប៉ុន្តែបែរជាសម្លឹងរកអំណោយទៅវិញ) សត្វដូចអ្នកសុំទានទាំងនេះ ខ្ញុំបដិសេធមិនប្រើជាដាច់ខាត ព្រោះតាំងពីពេលពួកគេកើតមក ពួកគេគ្មានដឹងអ្វីបន្តិចសោះអំពីអត្ថន័យក្នុងការបង្ហាញនូវការចេះគិតគូរចំពោះបន្ទុករបស់ខ្ញុំ។ ពួកគេជាមនុស្សដែលខ្វះញាណធម្មតា មនុស្សបែបនេះរងផលប៉ះពាល់ពី «កង្វះអាហារូបត្ថម្ភ» ដល់ខួរក្បាល ហើយត្រូវការទៅផ្ទះរក «អាហាររូបត្ថម្ភ» បន្ថែមខ្លះទៀត។ ខ្ញុំមិនប្រើប្រាស់មនុស្សបែបនេះទេ។ ក្នុងចំណោមរាស្ត្ររបស់ខ្ញុំ មនុស្សគ្រប់គ្នានឹងត្រូវតម្រូវឲ្យចាត់ទុកការស្គាល់ខ្ញុំថាជាភារកិច្ចខានមិនបានដែលត្រូវធ្វើឲ្យគេឃើញរហូតដល់ទីបញ្ចប់ ឲ្យដូចការបរិភោគ ការស្លៀកពាក់ និងការដេក ដែលគ្រប់គ្នាមិនដែលភ្លេចមួយពេលណាសោះឡើយ ដើម្បីឲ្យនៅទីបញ្ចប់ ការស្គាល់ខ្ញុំនឹងក្លាយជាស៊ាំដូចជាការបរិភោគអ៊ីចឹងដែរ ដែលធ្វើបានដោយមិនបាច់ប្រឹងប្រែងដោយភាពស្ទាត់ជំនាញ។ ចំពោះព្រះបន្ទូលដែលខ្ញុំបញ្ចេញ អ្នករាល់គ្នាត្រូវតែទទួលយកដោយមានជំនឿបំផុត និងជ្រួតជ្រាបបានពេញលេញ ហើយវាអាចមិនមានសកម្មភាពពាក់កណ្ដាលទីបែបបង្គ្រប់កិច្ចនោះទេ។ អ្នកណាដែលមិនយកចិត្តទុកដាក់នឹងព្រះបន្ទូលរបស់ខ្ញុំ នឹងត្រូវបានចាត់ទុកថា រឹងទទឹងនឹងខ្ញុំដោយផ្ទាល់ រីឯអ្នកណាដែលមិនពិសាព្រះបន្ទូលរបស់ខ្ញុំ ឬមិនប្រឹងប្រែងស្គាល់ព្រះបន្ទូលរបស់ខ្ញុំ នឹងត្រូវបានចាត់ទុកថា មិនយកចិត្តទុកដាក់ចំពោះខ្ញុំ ហើយនឹងត្រូវបោសចេញពីមាត់ទ្វារនៃដំណាក់របស់ខ្ញុំដោយផ្ទាល់។ ដូចដែលខ្ញុំបានមានព្រះបន្ទូល កាលពីមុនអ៊ីចឹងនេះដោយសារតែអ្វីដែលខ្ញុំចង់បាន មិនមែនជាចំនួនមនុស្សដ៏ច្រើននោះទេ តែជា

ឧត្ដមភាព។ ក្នុងចំណោមមនុស្សមួយរយនាក់ ប្រសិនបើមានតែមនុស្សម្នាក់គត់ដែលអាចស្គាល់ខ្ញុំតាមរយៈព្រះបន្ទូលរបស់ខ្ញុំបាន នោះខ្ញុំនឹងសព្វព្រះហឫទ័យគ្រវែងចោលអ្នកផ្សេងទាំងអស់ដើម្បីផ្ដោតលើការបំភ្លឺ និងការពន្យល់ដល់មនុស្សតែម្នាក់នេះគត់។ តាមរយៈការនេះ អ្នករាល់គ្នាអាចឃើញថា វាមិនពិតទាំងស្រុងនោះទេដែលថា ចំនួនច្រើនតែអ្នកអាចបង្ហាញច្បាស់អំពីខ្ញុំ និងសម្ដែងអំពីខ្ញុំបាននោះ។ អ្វីដែលខ្ញុំចង់បានគឺស្រូវសាលី (ទោះបីជាវាអាចនឹងគ្មានសាច់គ្រាប់ពេញក៏ដោយ) មិនមែនស្រងែទេ (សូម្បីតែពេលវាមានសាច់គ្រាប់ពេញលេញគួរឲ្យកោតសរសើរក៏ដោយ)។ ចំណែកឯពួកអ្នកដែលមិនខ្វល់ពីការស្វះស្វែងរក តែផ្ទុយទៅវិញបែរជាប្រព្រឹត្តបែបខ្ជីខ្ជា ពួកគេគួរតែចាកចេញដោយខ្លួនឯង ព្រោះខ្ញុំមិនចង់ឃើញពួកគេទៀតនោះទេ ក្រែងលោពួកគេបន្ដធ្វើឲ្យខូចកិត្តិនាមរបស់ខ្ញុំ។ អំពីអ្វីៗដែលខ្ញុំទាមទារពីរាស្ត្ររបស់ខ្ញុំ ខ្ញុំនឹងឈប់ត្រឹមខប្រតិបត្តិទាំងនេះសម្រាប់ពេលបច្ចុប្បន្ន ហើយខ្ញុំនឹងរង់ចាំធ្វើការដាក់ទណ្ឌកម្មបន្ថែមទៀត អាស្រ័យលើការប្រែប្រួលកាលៈទេសៈ។

កាលពីថ្ងៃមុន មនុស្សភាគច្រើនលើសលុបគិតថា ខ្ញុំជាព្រះជាម្ចាស់ផ្ទាល់ព្រះអង្គដែលប្រកបដោយព្រះប្រាជ្ញាញាណ ហើយថាខ្ញុំចំជាព្រះជាម្ចាស់ដែលមើលឃើញជ្រៅទៅក្នុងដួងចិត្តមនុស្ស។ តែទោះយ៉ាងណា នេះគ្រាន់តែជាការនិយាយដ៏រាក់កំផែល។ ប្រសិនបើមនុស្សពិតជាបានស្គាល់ខ្ញុំមែន ពួកគេនឹងមិនសន្មតទុកមុនដើម្បីផ្ដោះទៅដល់ការសន្និដ្ឋាននោះទេ ផ្ទុយទៅវិញ ពួកគេនឹងនៅតែព្យាយាមស្គាល់ខ្ញុំតាមរយៈព្រះបន្ទូលរបស់ខ្ញុំ។ មានតែនៅពេលពួកគេបានឈានទៅដល់ដំណាក់កាលមួយដែលពួកគេពិតជាបានឃើញទង្វើរបស់ខ្ញុំមែន ទើបពួកគេមានតម្លៃសមនឹងនិយាយថា ខ្ញុំមានព្រះប្រាជ្ញាញាណ និងអស្ចារ្យ។ ចំណេះដឹងរបស់អ្នករាល់គ្នាចំពោះខ្ញុំមានលក្ខណៈរាក់កំផែលខ្លាំងណាស់។ ឆ្លងកាត់យុគសម័យនានា មនុស្សច្រើនខ្លាំងណាស់បានបម្រើខ្ញុំអស់រយៈពេលច្រើនឆ្នាំណាស់មកហើយ ដោយបានឃើញទង្វើរបស់ខ្ញុំក៏បានបែរមកស្គាល់ខ្ញុំយ៉ាងពិតប្រាកដខ្លះដែរ។ ដោយហេតុនេះហើយ ពួកគេធ្លាប់មានដួងចិត្តចុះចូលនឹងខ្ញុំជានិច្ច ដោយមិនហ៊ានលាក់ពួនបំណងប្រឆាំងនឹងខ្ញុំបន្ដិច

សោះឡើយ ទោះជាវាពិបាកក្នុងការស្វែងរកស្នាមព្រះបាទរបស់ខ្ញុំយ៉ាងណាក៏ដោយ។ ប្រសិនបើការណែនាំរបស់ខ្ញុំ មិនមាននៅក្នុងចំណោមមនុស្សទាំងនេះទេ នោះពួកគេនឹងមិនហ៊ានប្រព្រឹត្តទាំងប្រញាប់ប្រញាល់ឡើយ។ ហេតុដូច្នេះហើយ បន្ទាប់ពីរស់នៅឆ្លងកាត់បទពិសោធជាច្រើនឆ្នាំមក នៅទីបំផុត ពួកគេបានសរុបចំណេះដឹងមួយផ្នែកអំពីខ្ញុំ ដោយនិយាយថា ខ្ញុំមានព្រះប្រាជ្ញាញាណ អស្ចារ្យ និងជាអ្នកប្រៀនប្រដៅ ហើយថាព្រះបន្ទូលរបស់ខ្ញុំដូចដាវមុខពីរ ព្រមទាំងថាទង្វើរបស់ខ្ញុំល្អណាស់ ហួសនិស្ស័យ និងល្អវិសេស ថែមទាំងថាខ្ញុំស្ថិតស្ថាងដោយឫទ្ធានុភាព ហើយនិងថាព្រះប្រាជ្ញាញាណរបស់ខ្ញុំ ខ្ពស់ជាងមេឃា និងមានការយល់ដឹងជ្រៅជ្រះដទៃទៀត។ ទោះយ៉ាងណា សព្វថ្ងៃនេះ អ្នករាល់គ្នាស្គាល់ខ្ញុំគ្រាន់តែផ្នែកលើគ្រឹះដែលពួកគេបាននិយាយតែប៉ុណ្ណោះ ដូច្នេះអ្នករាល់គ្នាភាគច្រើនលើសលុប ពោលគឺដូចសេកអឺចឹងគ្រាន់តែត្រាប់តាមពាក្យសម្ដីដែលពួកគេបាននិយាយប៉ុណ្ណោះ។ ពោលគឺដោយសារតែខ្ញុំព្រះតម្រិះដល់កម្រិតរាក់កំផែលនៃរបៀបដែលអ្នករាល់គ្នាស្គាល់ខ្ញុំ និងកម្រិតអន់ថយនៃ «ការអប់រំ» របស់អ្នករាល់គ្នា ទើបខ្ញុំបានលើកលែងការវាយផ្ចាលច្រើនណាស់ដល់អ្នករាល់គ្នា។ ទោះបីជាយ៉ាងនេះក្ដី អ្នករាល់គ្នាភាគច្រើនលើសលុបនៅតែមិនស្គាល់ខ្លួនឯង ឬគិតថាអ្នករាល់គ្នាចង់បំពេញបំណងព្រះហឫទ័យរបស់ខ្ញុំយ៉ាងខ្លាំង តាមរយៈអំពើរបស់អ្នករាល់គ្នារួចហើយ ដោយហេតុនេះហើយអ្នកក៏បានរួចផុតពីការជំនុំជម្រះ ឬក៏គិតថា បន្ទាប់ពីខ្ញុំបានត្រលប់ជាសាច់ឈាមហើយ ខ្ញុំបានបាត់បង់ការតាមដានការប្រព្រឹត្តរបស់មនុស្សជាតិទាំងស្រុងអស់ហើយ ហេតុដូច្នេះហើយអ្នកក៏បានរួចផុតពីការវាយផ្ចាលផងដែរ ឬក៏ថា ព្រះជាម្ចាស់ដែលអ្នកជឿ មិនមាននៅក្នុងលំហរដ៏ធំល្វឹងល្វើយនៃសាកលលោកនេះទេ ដូច្នេះអ្នកបានចាត់ទុកការស្គាល់ព្រះជាម្ចាស់ជាកិច្ចការកំប៉ិចកំប៉ុកដែលត្រូវធ្វើនៅពេលទំនេរ មិនមែនជាការសំខាន់ដែលត្រូវទុកក្នុងដួងចិត្តរបស់អ្នក ជាភារកិច្ចដែលត្រូវតែបំពេញនោះទេ ដោយប្រើជំនឿលើព្រះជាម្ចាស់ជាវិធីមួយក្នុងការកេងចំណេញពេលវេលា ដែលបើមិនដូច្នេះទេនឹងត្រូវចំណាយពេលចោលឥតប្រយោជន៍។ ប្រសិនបើខ្ញុំមិនបានយោគយល់ដល់ការខ្វះ

លក្ខណៈសម្បត្តិ ហេតុផល និងការយល់ដឹងជ្រៅជ្រះរបស់អ្នករាល់គ្នាទេ នោះអ្នកទាំងអស់គ្នានឹងវិនាសនៅក្នុងការវាយផ្ចាលរបស់ខ្ញុំ ដោយត្រូវលប់ចេញពីអត្ថិភាពបាត់អស់ទៅហើយ។ ទោះយ៉ាងណាក៏ដោយ ខ្ញុំនឹងនៅតែអត់ឱនដល់មនុស្សជាតិរហូតដល់ពេលកិច្ចការរបស់ខ្ញុំនៅលើផែនដីត្រូវបានបញ្ចប់។ នេះជាអ្វីដែលអ្នករាល់គ្នាត្រូវតែដឹងទាំងអស់គ្នា និងឈប់ភាន់ច្រឡំរវាងការល្អ និងការអាក្រក់។

ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩២

# ជំពូកទី ៦៖ ព្រះបន្ទូលព្រះជាម្ចាស់ ថ្លែងទៅកាន់សកលលោកទាំងមូល

ចូរឆាប់យល់ដឹងចំពោះបញ្ហាខាងវិញ្ញាណ ចូរយកចិត្តទុកដាក់ចំពោះព្រះបន្ទូលរបស់ខ្ញុំ ហើយចូរមានសមត្ថភាពពិតប្រាកដ ក្នុងការគោរពព្រះវិញ្ញាណរបស់ខ្ញុំ និងលក្ខណៈរបស់ខ្ញុំ ក៏ដូចជាព្រះបន្ទូលរបស់ខ្ញុំ និងលក្ខណៈរបស់ខ្ញុំ ជាលក្ខណៈទាំងមូលដែលមិនអាចញែកចេញពីគ្នាបាន ដើម្បីឱ្យមនុស្សទាំងអស់ អាចបំពេញព្រះហឫទ័យរបស់ខ្ញុំនៅចំពោះព្រះភក្ត្ររបស់ខ្ញុំបាន។ ខ្ញុំបានដាក់ព្រះបាទលើរបស់សព្វសារពើដែលមាន ខ្ញុំបានឃ្លាំមើលទូទាំងសកលលោកដ៏ធំល្វឹងល្វើយនេះ ហើយខ្ញុំបានយាត្រានៅក្នុងចំណោមមនុស្សទាំងអស់ ដោយបានភ្លក់រសជាតិទាំងផ្អែម និងល្វីងនៅក្នុងចំណោមមនុស្ស ប៉ុន្តែគ្មានមនុស្សណាម្នាក់ បានស្គាល់ខ្ញុំពិតប្រាកដឡើយ ហើយក៏គ្មានអ្នកណាម្នាក់ចាប់អារម្មណ៍នឹងខ្ញុំ ក្នុងអំឡុងពេលខ្ញុំធ្វើដំណើរដែរ។ ព្រោះខ្ញុំស្ងៀមស្ងាត់ និងមិនដែលសម្ដែងឫទ្ធិអធិធម្មជាតិ ម្ល៉ោះហើយគ្មានអ្នកណាម្នាក់បានឃើញខ្ញុំពិតប្រាកដឡើយ។ សព្វថ្ងៃនេះមិនដូចអតីតកាលទេ៖ ខ្ញុំនឹងធ្វើរឿងដែលមិនធ្លាប់ឃើញតាំងពីពេលបង្កើតមក ខ្ញុំនឹងសម្ដែងនូវព្រះបន្ទូលដែលមិនធ្លាប់ឮនៅក្នុងយុគសម័យនានា ដ្បិតខ្ញុំសុំឱ្យ មនុស្សទាំងអស់បែរមកស្គាល់ខ្ញុំនៅក្នុងភាពជាសាច់ឈាម។ ទាំងនេះជាជំហាននៃការគ្រប់គ្រងរបស់ខ្ញុំ ប៉ុន្តែមនុស្សគ្មាន

គំនិតសង្ស័យអ្វីបន្តិចសោះទេ។ ថ្វីបើខ្ញុំបានមានព្រះបន្ទូលយ៉ាងច្បាស់លាស់ក្ដី ក៏មនុស្សនៅតែច្រឡំ ព្រោះវាពិបាកក្នុងការទាក់ទងទៅពួកគេបាន។ តើនេះមិនមែនជាភាពតូចទាបរបស់មនុស្សទេឬ? តើវាមិនមែនជាអ្វីពិតប្រាកដដែលខ្ញុំចង់ព្យាបាលទេឬ? ជាច្រើនឆ្នាំមកហើយ ខ្ញុំមិនបានធ្វើអ្វីទាំងអស់នៅក្នុងខ្លួនមនុស្ស ជាច្រើនឆ្នាំមកហើយ ទោះបីជាមានទំនាក់ទំនងដោយផ្ទាល់ ជាមួយសាច់ឈាមរបស់ខ្ញុំដែលយកកំណើតជាមនុស្សក៏ដោយ ក៏គ្មាននរណាម្នាក់ធ្លាប់ឮសំឡេងដែលចេញពីភាពជាព្រះរបស់ខ្ញុំដោយផ្ទាល់ដែរ។ ដូច្នេះ មនុស្សខ្វះនូវការស្គាល់ខ្ញុំដោយជៀសមិនរួច តែទោះយ៉ាងណា រឿងនេះមិនបានជះឥទ្ធិពលដល់សេចក្ដីស្រឡាញ់របស់ពួកគេចំពោះខ្ញុំ ដែលឆ្លងកាត់ច្រើនយុគសម័យមកហើយនោះទេ។ យ៉ាងណាមិញ សព្វថ្ងៃនេះ ខ្ញុំបានធ្វើនៅក្នុងខ្លួនអ្នករាល់គ្នានូវកិច្ចការដ៏មហស្ចារ្យ ជាកិច្ចការដែលមិនអាចវាស់ស្ទង់បាន និងគ្មានព្រំដែន ហើយខ្ញុំបានថ្លែងនូវព្រះបន្ទូលជាច្រើនមកហើយ។ ហើយទោះយ៉ាងណា ក្រោមស្ថានភាពបែបនេះ នៅតែមានមនុស្សជាច្រើនដែលរឹងទទឹងនឹងខ្ញុំដោយផ្ទាល់នៅចំពោះព្រះភក្ត្រខ្ញុំ។ ឥឡូវនេះ ខ្ញុំសូមលើកឧទាហរណ៍ពីរបីប្រាប់អ្នកឱ្យដឹងចុះ។

រាល់ថ្ងៃនេះ អ្នកអធិស្ឋានដល់ព្រះដ៏ស្រពេចស្រពិល ដោយព្យាយាមយល់ពីបំណងព្រះហឫទ័យរបស់ខ្ញុំ និងចង់បានការយល់ដឹងអំពីជីវិត។ ប៉ុន្តែនៅពេលប្រឈមមុខនឹងព្រះបន្ទូលរបស់ខ្ញុំ អ្នកយល់ឃើញបែបផ្សេងទៅវិញ អ្នកគោរពព្រះបន្ទូលខ្ញុំ និងព្រះវិញ្ញាណរបស់ខ្ញុំរួមជាមួយគ្នា តែទាត់ចោលលក្ខណៈរបស់ខ្ញុំ ដោយជឿលើបុគ្គលដែលជាមូលដ្ឋានគ្រឹះខ្ញុំមិនអាចបញ្ចេញព្រះបន្ទូលបែបនេះថា ព្រះបន្ទូលទាំងនោះត្រូវបានដឹកនាំដោយព្រះវិញ្ញាណរបស់ខ្ញុំ។ តើអ្នកស្គាល់អ្វីទៅនៅក្នុងស្ថានភាពបែបនេះ? អ្នកជឿលើព្រះបន្ទូលរបស់ខ្ញុំ ដល់ចំណុចមួយដែលមិនទាន់មានសញ្ញាណអំពីភាពខ្លាំងខុសប្លែកគ្នាចំពោះសាច់ឈាមដែលអង្គខ្ញុំសណ្ឋិតនៅ។ អ្នកចំណាយពេលរាល់ថ្ងៃសិក្សាពីបន្ទូលនោះ ហើយនិយាយថា «ហេតុអ្វីបានជាទ្រង់ធ្វើអ្វីៗតាមរបៀបនោះ? តើព្រះបន្ទូលទាំងនោះពិតជាមកពីព្រះជាម្ចាស់មែនឬទេ? មិនអាចទៅរួចទេ! ទ្រង់មិន

ខុសពីខ្ញុំប៉ុន្មានទេ ទ្រង់ក៏ជាមនុស្សធម្មតាផងដែរ។» តើគេអាចពន្យល់ពីស្ថានភាពបែបនេះយ៉ាងដូចម្ដេច?

ក្នុងចំណោមអ្នករាល់គ្នា តើនរណាទៅដែលគ្មានលក្ខណៈខាងលើនេះ? តើនរណាទៅដែលមិនត្រូវបានកាន់កាប់ដោយលក្ខណៈបែបនេះ? ពួកវាហាក់ដូចជាអ្វីៗដែលអ្នករក្សាទុកដូចរបស់ទ្រព្យផ្ទាល់ខ្លួន ដោយមិនដែលចង់ឱ្យពួកវាបាត់ទៅឡើយ។ កុំថាឡើយដល់ទៅថាអ្នកដេញតាមការខិតខំតាមគំនិតផ្ទាល់ខ្លួន តែផ្ទុយទៅវិញ អ្នករង់ចាំខ្ញុំធ្វើវាដោយអង្គខ្ញុំ។ ការពិតនឹងត្រូវបង្ហាញ គ្មានបុគ្គលណាម្នាក់ដែលមិនប្រឹងប្រែង ទៅជាស្គាល់ខ្ញុំដោយងាយនោះទេ។ ទាំងនេះមិនមែនជាព្រះបន្ទូលឥតបានការដែលខ្ញុំបង្រៀនដល់អ្នករាល់គ្នាឡើយ។ ខ្ញុំអាចផ្ដល់ឱ្យអ្នកនូវឧទាហរណ៍មួយទៀត ចេញពីទស្សនៈផ្សេងទៀតសម្រាប់ជាសេចក្ដីសំអាងរបស់អ្នក។

ពេលនិយាយដល់ពេត្រុស មនុស្សមានរឿងល្អមិនចេះអស់និយាយអំពីគាត់។ ពួកគេនឹកឃើញឡើងវិញនូវការដែលគាត់មិនទទួលស្គាល់ព្រះជាម្ចាស់ចំនួនបីដង នឹកឃើញពីការដែលគាត់សាកល្បងព្រះជាម្ចាស់តាមរយៈការបម្រើសាតាំង និងចុងក្រោយគាត់ត្រូវបានគេឆ្កាងក្បាលចុះក្រោមថ្វាយព្រះជាម្ចាស់ ។ល។ ឥឡូវនេះ ខ្ញុំនឹងផ្ដោតលើការពិពណ៌នាឱ្យអ្នករាល់គ្នាដឹងពីរបៀបដែលពេត្រុសស្គាល់ខ្ញុំ និងពីលទ្ធផលចុងក្រោយរបស់គាត់។ ពេត្រុសមានគុណសម្បត្តិល្អ ប៉ុន្តែស្ថានភាពរបស់គាត់មិនដូចប៉ុលទេ៖ ឪពុកម្ដាយរបស់គាត់បានធ្វើទុក្ខបុកម្នេញខ្ញុំ ពួកគេជាអារក្សដែលត្រូវបានកាន់កាប់ដោយសាតាំង ហេតុដូច្នេះហើយ ពួកគេមិនបានបង្រៀនពេត្រុសអំពីព្រះជាម្ចាស់សោះឡើយ។ ពេត្រុសឆ្លាតវៃ មានទេពកោសល្យ និងត្រូវបានឪពុកម្ដាយរបស់គាត់ស្រឡាញ់ក្រៃលែងតាំងតែពីតូចមកម្ល៉េះ។ ប៉ុន្តែពេលពេញវ័យ គាត់ក្លាយជាសត្រូវរបស់ពួកគេ ព្រោះគាត់មិនដែលឈប់តាមរកការស្គាល់ខ្ញុំ ហើយក្រោយមកក៏បែរខ្នងដាក់ពួកគេវិញ។ សំខាន់ជាងអ្វីផ្សេងទាំងអស់ នេះដោយសារតែគាត់ជឿថា ផ្ទៃមេឃ និងផែនដី ព្រមទាំងរបស់សព្វសារពើ គឺស្ថិតក្នុងព្រះហស្តនៃព្រះដ៏មានគ្រប់ចេស្ដា ហើយរឿងវិជ្ជមានទាំងអស់សុទ្ធតែមកពីព្រះជាម្ចាស់ ព្រមទាំង

ត្រូវបានចេញដោយផ្ទាល់ពីទ្រង់ ដែលមិនត្រូវបានកែច្នៃដោយសាតាំងឡើយ។ ការប្រឆាំងទាស់នឹងឪពុកម្ដាយរបស់ពេត្រុស បានធ្វើឱ្យគាត់ដឹងកាន់តែច្រើនអំពីក្ដីអាណិតស្រឡាញ់ និងសេចក្ដីមេត្តាករុណារបស់ខ្ញុំ ម្ល៉ោះហើយធ្វើឱ្យគាត់កើនឡើងនូវសេចក្ដីប្រាថ្នាក្នុងការស្វែងរកខ្ញុំ។ គាត់មិនត្រឹមតែបានផ្ដោតលើការហូប និងផឹកព្រះបន្ទូលរបស់ខ្ញុំប៉ុណ្ណោះទេ តែថែមទាំងផ្ដោតលើការយល់ពីបំណងព្រះហឫទ័យរបស់ខ្ញុំផងដែរ ហើយមានការប្រុងប្រយ័ត្នជានិច្ចនៅក្នុងដួងចិត្តរបស់គាត់។ ជាលទ្ធផល គាត់តែងតែឆាប់ញាប់ញ័រនៅក្នុងវិញ្ញាណរបស់គាត់ ហេតុដូចនេះហើយគាត់បានធ្វើតាមដួងព្រះហឫទ័យរបស់ខ្ញុំ នៅក្នុងអ្វីៗដែលគាត់បានធ្វើ។ គាត់បានរក្សាការផ្ដោតអារម្មណ៍ជាប្រចាំទៅលើការបរាជ័យរបស់មនុស្សនាពេលកន្លងមកដើម្បីជំរុញខ្លួនគាត់ឡើង ដោយភ័យខ្លាចថាក្លាយជាជាប់អន្ទាក់នៅក្នុងភាពបរាជ័យយ៉ាងខ្លាំង។ ដូច្នេះហើយគាត់ក៏បានផ្ចង់អារម្មណ៍ទៅលើការបញ្ជ្រាបជំនឿ និងសេចក្ដីស្រឡាញ់របស់អស់អ្នកដែលបានស្រឡាញ់ព្រះជាម្ចាស់ឆ្លងកាត់យុគសម័យនានា។ តាមរបៀបនេះ ពោលគឺមិនមានតែទស្សនៈអវិជ្ជមានប៉ុណ្ណោះទេ ប៉ុន្តែសំខាន់ជាងនេះទៅទៀតគឺទស្សនៈវិជ្ជមាន គាត់បានរីកចម្រើនយ៉ាងឆាប់រហ័ស រហូតដល់ថ្នាក់ចំណេះដឹងរបស់គាត់បានក្លាយជាចំណេះដឹងដ៏អស្ចារ្យបំផុតនៅចំពោះព្រះភក្ត្រខ្ញុំ។ ពេលនោះ វាមិនពិបាកក្នុងការស្រមៃទេ អំពីរបៀបដែលគាត់ដាក់អ្វីគ្រប់យ៉ាងដែលគាត់មាននៅក្នុងព្រះហស្តរបស់ខ្ញុំ របៀបដែលគាត់បានលះបង់សូម្បីតែការសម្រេចចិត្តអំពីម្ហូបអាហារ សម្លៀកបំពាក់ ការដេក និងកន្លែងដែលគាត់រស់នៅ ហើយបែរមករីករាយនឹងភោគទ្រព្យរបស់ខ្ញុំ អាស្រ័យតាមការសព្វព្រះហឫទ័យរបស់ខ្ញុំនៅក្នុងរបស់សព្វសារពើ។ ខ្ញុំបានដាក់គាត់ឱ្យស្ថិតក្រោមការល្បងលជាច្រើនរាប់មិនអស់ ពោលគឺជាការល្បងលដែលជាធម្មតាធ្វើឱ្យគាត់ស្ទើរតែស្លាប់ ប៉ុន្តែក្នុងចំណោមការល្បងលជាច្រើនរយនេះ គាត់មិនដែលបាត់បង់ជំនឿលើខ្ញុំ ឬមានអារម្មណ៍ខកចិត្តចំពោះខ្ញុំម្ដងណាឡើយ។ សូម្បីតែពេលខ្ញុំមានបន្ទូលថាខ្ញុំបានបោះបង់ចោលគាត់ក៏ដោយ ក៏គាត់នៅតែមិនធ្លាក់ទឹកចិត្ត ហើយនៅតែបន្តស្រឡាញ់ខ្ញុំតាមរបៀបជាក់ស្ដែង និង

ស្របតាមគោលការណ៍អនុវត្តពីមុន។ ខ្ញុំបានប្រាប់គាត់ថា ខ្ញុំនឹងមិនលើកសរសើរគាត់ទេ ទោះបីជាគាត់ស្រឡាញ់ខ្ញុំក៏ដោយ ហើយខ្ញុំនឹងបោះគាត់ចូលទៅក្នុងកណ្ដាប់ដៃរបស់សាតាំង។ ប៉ុន្តែក្រោមការល្បងលទាំងនេះ ដែលជាការល្បងលដែលមិនបានមកលើសាច់ឈាមរបស់គាត់ទេ តែជាពាក្យសម្ដីក្ដី គាត់នៅតែអធិស្ឋានដល់ខ្ញុំ ហើយនិយាយថា «ឱព្រះជាម្ចាស់អើយ! ក្នុងចំណោមស្ថានសួគ៌ និងផែនដី ព្រមទាំងរបស់សព្វសារពើ តើមានមនុស្សណាម្នាក់ ភាវៈណាមួយ ឬវត្ថុអ្វីមួយដែលមិនស្ថិតក្នុងព្រះហស្តរបស់ព្រះអង្គទេ ឱព្រះដ៏មានគ្រប់ចេស្ដាអើយ? នៅពេលព្រះអង្គពេញដោយសេចក្ដីមេត្តាករុណាចំពោះទូលបង្គំ ដួងចិត្តរបស់ទូលបង្គំត្រេកអរពន់ពេកណាស់ចំពោះសេចក្ដីមេត្តាករុណារបស់ព្រះអង្គ។ នៅពេលព្រះអង្គជំនុំជម្រះទូលបង្គំ ថ្វីបើទូលបង្គំអាចនឹងគ្មានតម្លៃក្ដី ក៏ទូលបង្គំដឹងកាន់តែច្បាស់ ពីការមិនអាចវាស់ស្ទង់បាននៃអំពើរបស់ព្រះអង្គដែរ ព្រោះព្រះអង្គពោរពេញទៅដោយសិទ្ធិអំណាច និងព្រះប្រាជ្ញាញាណ។ ថ្វីបើសាច់ឈាមរបស់ទូលបង្គំរងការលំបាកក្ដី ក៏វិញ្ញាណរបស់ទូលបង្គំធូរស្បើយដែរ។ តើធ្វើដូចម្ដេចឱ្យទូលបង្គំអាចនឹងមិនលើកសរសើរដល់ព្រះប្រាជ្ញាញាណ និងអំពើរបស់ព្រះអង្គបានទៅ? ទោះបីជាទូលបង្គំត្រូវស្លាប់បន្ទាប់ពីបានស្គាល់ព្រះអង្គក៏ដោយ តើធ្វើដូចម្ដេចទូលបង្គំអាចនឹងមិនធ្វើដូច្នោះដោយរីករាយ និងសប្បាយបានទៅ? ព្រះដ៏មានគ្រប់ចេស្ដាតែមួយអង្គគត់អើយ! តើព្រះអង្គពិតជាមិនសព្វព្រះហឫទ័យឱ្យទូលបង្គំឃើញព្រះអង្គទេឬ? តើទូលបង្គំពិតជាមិនសមនឹងទទួលការជំនុំជម្រះរបស់ព្រះអង្គទេឬ? តើវាអាចមានអ្វីមួយនៅក្នុងខ្លួនទូលបង្គំដែលព្រះអង្គមិនចង់ឃើញមែនទេ?» ក្នុងអំឡុងពេលល្បងលបែបនេះ សូម្បីតែពេត្រុសក៏មិនអាចយល់ពីបំណងព្រះហឫទ័យរបស់ខ្ញុំបានត្រឹមត្រូវដែរ នេះបានបញ្ជាក់ច្បាស់ថា គាត់មានមោទនភាព និងកិត្តិយសសមនឹងត្រូវបានខ្ញុំប្រើប្រាស់ (ទោះបីជាគាត់បានទទួលការជំនុំជម្រះរបស់ខ្ញុំ ដើម្បីឱ្យមនុស្សជាតិអាចមើលឃើញឫទ្ធានុភាព និងសេចក្ដីក្រោធរបស់ខ្ញុំក៏ដោយ) ព្រមទាំងបញ្ជាក់ច្បាស់ថា គាត់មិនបានឈឺចាប់ដោយសារទុក្ខលំបាកទាំងនេះឡើយ។ ដោយសារតែភក្ដីភាពរបស់គាត់នៅចំពោះ

ព្រះភក្ត្រខ្ញុំ និងដោយសារតែព្រះពររបស់ខ្ញុំដល់គាត់ គាត់បានធ្វើជាឧទាហរណ៍ និងជាគំរូដល់មនុស្សអស់ពេលច្រើនពាន់ឆ្នាំមកហើយ។ តើនេះមិនមែនជាអ្វីពិតប្រាកដដែលអ្នករាល់គ្នាគួរគ្រាប់តាមទេឬ? ចូរគិតឱ្យបានវែងឆ្ងាយអំពីមូលហេតុដែលខ្ញុំបានប្រាប់ពីរឿងរ៉ាវដ៏វែងអន្លាយបែបនេះអំពីពេត្រុស។ ទាំងនេះគួរតែជាគោលការណ៍ដែលអ្នករាល់គ្នាធ្វើតាម។

ទោះបីជាមានមនុស្សតិចតួចស្គាល់ខ្ញុំក៏ដោយ ក៏ខ្ញុំមិនបញ្ចេញសេចក្តីក្រោធរបស់ខ្ញុំទៅលើមនុស្សដែរ ព្រោះមនុស្សខ្វះខាតខ្លាំងណាស់ ហើយវាពិបាកសម្រាប់ពួកគេក្នុងការទទួលបានកម្រិតដែលខ្ញុំទាមទារពីពួកគេ។ ម្ល៉ោះហើយ ខ្ញុំបានត្រាប្រណីដល់មនុស្សអស់រយៈពេលច្រើនពាន់ឆ្នាំមកហើយ តាំងពីដើមរហូតដល់សព្វថ្ងៃនេះ ខ្ញុំសង្ឃឹមថាអ្នករាល់គ្នានឹងមិនបន្ធូរបន្ថយឱ្យខ្លួនឯង ព្រោះតែសេចក្តីត្រាប្រណីរបស់ខ្ញុំទេ។ តាមរយៈពេត្រុស អ្នកគួរតែបែរមកស្គាល់ខ្ញុំ និងប្រឹងប្រែងធ្វើតាមខ្ញុំ ហើយតាមរយៈការផ្សងព្រេងទាំងអស់របស់គាត់ អ្នកគួរតែទទួលបានការបំភ្លឺដែលមិនធ្លាប់មានពីមុនមក ហើយថែមទាំងទទួលបានពិភពដែលមិនធ្លាប់មានមនុស្សទៅដល់។ នៅទូទាំងចក្រវាល និងមេឃា ក្នុងចំណោមអ្វីគ្រប់យ៉ាងនៅក្នុងស្ថានសួគ៌ និងនៅលើផែនដី របស់សព្វសារពើនៅលើផែនដី និងនៅក្នុងស្ថានសួគ៌ថ្វាយការប្រឹងប្រែងគ្រប់យ៉ាងរបស់ពួកគេ ដល់ដំណាក់កាលចុងក្រោយនៃកិច្ចការរបស់ខ្ញុំ។ តើអ្នករាល់គ្នាប្រាកដជាមិនចង់ធ្វើជាអ្នកទស្សនា ដែលទទួលបញ្ជាទាំងបង្ខំពីសាតាំងមែនឬទេ? សាតាំងធ្លាប់បង្ហាញពីការបំផ្លាញការស្គាល់ខ្ញុំនៅក្នុងដួងចិត្តរបស់មនុស្ស ដោយសង្កៀតធ្មេញ និងបញ្ចេញក្រញ៉ាំរបស់វា នៅក្នុងការសម្លាប់ដ៏ឈឺផ្សាចុងក្រោយរបស់វា។ តើអ្នករាល់គ្នាចង់រងគ្រោះ ដោយសារគ្រោងការណ៍បោកបញ្ឆោតរបស់វានៅពេលនេះមែនឬទេ? តើអ្នករាល់គ្នាចង់បំផ្លាញជីវិតរបស់ខ្លួនឯង នៅពេលកិច្ចការរបស់ខ្ញុំត្រូវបានបញ្ចប់នៅទីបំផុតមែនឬទេ? តើអ្នករាល់គ្នា កំពុងរង់ចាំខ្ញុំបង្ហាញសេចក្តីត្រាប្រណីរបស់ខ្ញុំម្តងទៀតមែនឬទេ? ការតាមរកការស្គាល់ខ្ញុំគឺជាគន្លឹះ ប៉ុន្តែការផ្តោតលើការអនុវត្តគឺមិនអាចខ្វះបាន។ ព្រះបន្ទូលរបស់ខ្ញុំត្រូវបានបើកសម្តែងដល់អ្នករាល់គ្នាដោយផ្ទាល់

ហើយខ្ញុំសង្ឃឹមថា អ្នករាល់គ្នាអាចធ្វើតាមការណែនាំរបស់ខ្ញុំ និងលែងមានផែនការ និងមហិច្ឆតាសម្រាប់ខ្លួនឯងទៀត។

ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ១៩៩២

# ជំពូកទី ៨៖ ព្រះបន្ទូលព្រះជាម្ចាស់ ថ្លែងទៅកាន់សកលលោកទាំងមូល

នៅពេលការបើកសម្ដែងរបស់ខ្ញុំឈានដល់កម្រិតកំពូល និងនៅពេលការជំនុំជម្រះរបស់ខ្ញុំឈានដល់ទីបញ្ចប់ វានឹងដល់ពេលដែលរាស្ត្ររបស់ខ្ញុំទាំងអស់ត្រូវបានបើកសម្ដែង និងប្រទានឲ្យពេញខ្នាត។ ខ្ញុំយាត្រាទៅគ្រប់ជ្រុងជ្រោយនៃសកលលោកដើម្បីស្វែងរកម្ដងហើយម្ដងទៀតនូវអស់អ្នកដែលសម្របតាមបំណងព្រះហឫទ័យរបស់ខ្ញុំ ហើយសមនឹងឱ្យខ្ញុំប្រើប្រាស់។ តើអ្នកណាអាចក្រោកឡើង និងសហការជាមួយខ្ញុំបាន? សេចក្ដីស្រឡាញ់របស់មនុស្សចំពោះខ្ញុំ គឺតូចពេកក្រៃ ហើយសេចក្ដីជំនឿរបស់ពួកគេលើខ្ញុំក៏តូចបំផុតផងដែរ។ ប្រសិនបើខ្ញុំមិនបានតម្រង់ទម្ងន់នៃព្រះបន្ទូលរបស់ខ្ញុំទៅរកភាពទន់ខ្សោយរបស់មនុស្សទេ ពួកគេនឹងមានអំនួត ហើយបំផ្លើសដោយបូរបាច់ និងលើកឡើងនូវទ្រឹស្ដីបំប៉ោង ហាក់ដូចជាពួកគេចេះដឹងសព្វគ្រប់ និងដឹងរឿងគ្រប់យ៉ាងអំពីបញ្ហានៅផែនដី។ ក្នុងចំណោមអ្នកដែល «មានភក្ដីភាព» ចំពោះខ្ញុំកាលពីមុន និងក្នុងចំណោមអ្នកដែលសព្វថ្ងៃនេះ «ឈរយ៉ាងជាប់មាំ» នៅចំពោះព្រះភក្ត្រខ្ញុំ តើអ្នកណានៅតែហ៊ាននិយាយពេញដោយអំនួតទៀត? តើអ្នកណាដែលមិនរីករាយជាសម្ងាត់ ចំពោះក្ដីសង្ឃឹមផ្ទាល់ខ្លួនរបស់ពួកគេ? នៅពេលខ្ញុំមិនបានបើកបង្ហាញឲ្យមនុស្សយល់ដោយផ្ទាល់ទេ ពួកគេគ្មានកន្លែងលាក់បាំង ហើយត្រូវរងទារុណកម្មដោយភាពអាម៉ាស់។ បើខ្ញុំមានព្រះបន្ទូលតាមលក្ខណៈផ្សេង តើនឹងមានដូច្នោះច្រើនប៉ុន្មានទៀត? មនុស្សនឹងមានញាណដឹងបានកាន់តែប្រសើរ អំពីភាពជាប់បំណុល ដោយជឿថាគ្មានអ្វីដែលអាចព្យាបាលពួកគេបានទេ ហើយសុទ្ធតែ

នឹងត្រូវបានចងរឹតយ៉ាងតឹងណែន ដោយភាពអកម្មរបស់ពួកគេ។ នៅពេលមនុស្សអស់សង្ឃឹម ការគំនាប់របស់នគរព្រះបន្លឺសំឡេងជាផ្លូវការ ពោលគឺដូចដែលមនុស្សនិយាយថា «ជាពេលដែលព្រះវិញ្ញាណដ៏មានកម្លាំងខ្លាំងឡើងប្រាំពីរដង ចាប់ផ្ដើមធ្វើកិច្ចការ។» និយាយម្យ៉ាងទៀតគឺថា នេះជាពេលដែលជីវិតរបស់នគរព្រះចាប់ផ្ដើមជាផ្លូវការនៅលើផែនដី វាជាពេលដែលភាពជាព្រះរបស់ខ្ញុំ ចេញមកធ្វើការដោយផ្ទាល់ (ដោយគ្មាន «ដំណើរការ» ផ្លូវចិត្តឡើយ)។ មនុស្សទាំងអស់ប្រញាប់ប្រញាល់យ៉ាងមមាញឹក ប្រៀបដូចជាពួកគេត្រូវបានធ្វើឲ្យរស់ឡើងវិញ ឬដាស់ឲ្យភ្ញាក់ពីសុបិន ហើយនៅពេលភ្ញាក់ដឹងខ្លួន ពួកគេភ្ញាក់ផ្អើលដោយឃើញខ្លួនឯងស្ថិតក្នុងស្ថានភាពបែបនេះ។ កាលពីមុន ខ្ញុំបាននិយាយយ៉ាងច្រើនអំពីការកសាងក្រុមជំនុំ ខ្ញុំបានបើកឲ្យដឹងអាថ៌កំបាំងជាច្រើន ប៉ុន្តែនៅពេលកិច្ចការនោះឈានដល់កម្រិតកំពូល វាបានឈានដល់ទីបញ្ចប់យ៉ាងទាន់ហន់។ តែទោះយ៉ាងណា ការកសាងនគរព្រះគឺមានលក្ខណៈខុសគ្នា។ មានតែដល់ពេលដែលសង្គ្រាមនៅក្នុងពិភពខាងវិញ្ញាណឈានដល់ដំណាក់កាលចុងក្រោយរបស់វាទេ ទើបខ្ញុំចាប់ផ្ដើមកិច្ចការរបស់ខ្ញុំជាថ្មីនៅលើផែនដី។ និយាយឲ្យចំគឺថា ទាល់តែដល់ពេលដែលមនុស្សទាំងអស់ ស្ថិតនៅលើព្រំដែននៃការដកថយ ទើបខ្ញុំចាប់ផ្ដើម និងលើកឡើងកិច្ចការថ្មីរបស់ខ្ញុំជាផ្លូវការ។ ភាពខុសគ្នារវាងការកសាងនគរព្រះ និងការកសាងក្រុមជំនុំគឺថា ក្នុងការកសាងក្រុមជំនុំ ខ្ញុំបានធ្វើការតាមរយៈភាពជាមនុស្សដែលគ្រប់គ្រងដោយភាពជាព្រះ ខ្ញុំបានដោះស្រាយដោយផ្ទាល់ជាមួយធម្មជាតិដើមរបស់មនុស្ស ដោយបើកឲ្យដឹងពីខ្លួនដ៏អាក្រក់របស់ពួកគេដោយផ្ទាល់ និងបើកបង្ហាញពីលក្ខណៈរបស់ពួកគេ។ ជាលទ្ធផល ពួកគេបានបែរមកស្គាល់ខ្លួនឯងនៅលើមូលដ្ឋាននេះ ដូច្នេះហើយពួកគេមានភាពជឿជាក់នៅក្នុងដួងចិត្តរបស់ពួកគេ និងនៅក្នុងពាក្យសម្ដីរបស់ពួកគេ។ ឯការកសាងនគរព្រះវិញ ខ្ញុំធ្វើការដោយផ្ទាល់តាមរយៈភាពជាព្រះរបស់ខ្ញុំ ហើយអនុញ្ញាតឲ្យមនុស្សទាំងអស់ស្គាល់ពីកម្មសិទ្ធិ និងលក្ខណៈរបស់ខ្ញុំ នៅលើគ្រឹះនៃការចេះដឹងរបស់ពួកគេស្ដីពីព្រះបន្ទូលរបស់ខ្ញុំ ហើយនៅទីបញ្ចប់ អនុញ្ញាតឲ្យពួកគេស្គាល់ខ្ញុំដូចសាច់ឈាម

ដែលយកកំណើតជាមនុស្ស។ ម្ល៉ោះហើយ វាបញ្ចប់បាននូវការតាមរកព្រះដ៏ស្រពេចស្រពិលរបស់មនុស្ស ម្ល៉ោះហើយទើបពួកគេឈប់ទុកកន្លែងនៅក្នុងដួងចិត្តរបស់ពួកគេឲ្យព្រះជាម្ចាស់នៅក្នុងស្ថានសួគ៌ ពោលគឺ ខ្ញុំចង់ឲ្យមនុស្សជាតិដឹងពីទង្វើដែលខ្ញុំធ្វើនៅខណៈពេលខ្ញុំជាសាច់ឈាមដែលយកកំណើតជាមនុស្ស ដូច្នេះហើយខ្ញុំនឹងបញ្ចប់ពេលវេលារបស់ខ្ញុំនៅលើផែនដី។

ការកសាងនគរព្រះនេះ គឺសំដៅដោយផ្ទាល់ទៅរកពិភពខាងវិញ្ញាណ។ ពោលគឺ សភាពនៃការតយុទ្ធនៃពិភពខាងវិញ្ញាណ ត្រូវបានធ្វើឱ្យច្បាស់លាស់ដោយផ្ទាល់ក្នុងចំណោមរាស្ត្ររបស់ខ្ញុំទាំងអស់ ហើយនេះវាគ្រប់គ្រាន់ក្នុងការបង្ហាញថា មិនមែនមានតែនៅក្នុងក្រុមជំនុំប៉ុណ្ណោះទេ ប៉ុន្តែក៏មានច្រើនណាស់ដែរនៅក្នុងយុគសម័យនៃនគរព្រះ មនុស្សគ្រប់រូបមានការតយុទ្ធឥតឈប់ឈរ។ ទោះជាពួកគេមានរូបកាយយ៉ាងណាក៏ដោយ ក៏ពិភពខាងវិញ្ញាណត្រូវបានបើកឲ្យដឹងដោយផ្ទាល់ដែរ ហើយពួកគេមកទាក់ទងជាមួយជីវិតនៃពិភពខាងវិញ្ញាណ។ ម្ល៉ោះហើយនៅពេលអ្នករាល់គ្នាចាប់ផ្ដើមស្មោះត្រង់ អ្នករាល់គ្នាត្រូវតែរៀបចំខ្លួនឲ្យបានត្រឹមត្រូវសម្រាប់ផ្នែកបន្ទាប់នៃកិច្ចការរបស់ខ្ញុំ។ អ្នករាល់គ្នាគួរតែបញ្ឈប់បំណងក្នុងចិត្តរបស់ខ្លួនឲ្យអស់ មានតែបែបនោះទេ ទើបអ្នករាល់គ្នាអាចបំពេញដួងព្រះហឫទ័យរបស់ខ្ញុំបាន។ ខ្ញុំមិនខ្វល់ពីអ្វីៗដែលបានកើតឡើងនៅក្នុងក្រុមជំនុំកាលពីមុននោះទេ ឯសព្វថ្ងៃនេះ គឺនៅក្នុងសម័យកាលនៃនគរព្រះ។ តាំងតែពីដើមរៀងមក សាតាំងបាននិងកំពុងឈ្លបចាប់ពីក្រោយជំហាននីមួយៗនៅក្នុងផែនការរបស់ខ្ញុំ ហើយវាជាគ្រឿងបន្ទាប់បន្សំនៃព្រះប្រាជ្ញាញាណរបស់ខ្ញុំ វាតែងតែព្យាយាមរកផ្លូវ និងមធ្យោបាយដើម្បីបង្អាក់ផែនការដើមរបស់ខ្ញុំ។ ប៉ុន្តែ តើខ្ញុំអាចបង្អោនទៅតាមគ្រោងការបោកបញ្ឆោតរបស់វាបានឬទេ? អ្វីៗគ្រប់យ៉ាងនៅក្នុងស្ថានសួគ៌ និងនៅលើផែនដីសុទ្ធតែបម្រើខ្ញុំ តើគ្រោងការបោកបញ្ឆោតរបស់សាតាំងអាចខុសគ្នាដែរឬទេ? នេះច្បាស់ជាកន្លែងដែលព្រះប្រាជ្ញាញាណរបស់ខ្ញុំប្រសព្វគ្នា វាច្បាស់ណាស់ថា វាជាអ្វីដែលល្អអស្ចារ្យអំពីអំពើរបស់ខ្ញុំ ហើយវាជាគោលការណ៍ប្រតិបត្តិសម្រាប់ផែនការគ្រប់គ្រងទាំងមូលរបស់ខ្ញុំ។ នៅក្នុង

យុគនៃការកសាងនគរព្រះនេះ ខ្ញុំនៅតែមិនគេច ពីគ្រោងការបោកបញ្ឆោតរបស់សាតាំង ហើយខ្ញុំបន្តធ្វើកិច្ចការដែលខ្ញុំត្រូវធ្វើដដែល។ ក្នុងចំណោមសកលលោក និងរបស់សព្វសារពើ ខ្ញុំបានចាត់ទុកអំពើរបស់សាតាំងថាជាគ្រឿងបន្ទាប់បន្សំរបស់ខ្ញុំ។ តើនេះមិនមែនជាការបង្ហាញច្បាស់ អំពីព្រះប្រាជ្ញាញាណរបស់ខ្ញុំទេឬ? តើនេះមិនច្បាស់ថា ជាអ្វីដែលល្អអស្ចារ្យអំពីកិច្ចការរបស់ខ្ញុំទេឬ? ក្នុងឱកាសនៃការចូលទៅក្នុងយុគសម័យនៃនគរព្រះ របស់សព្វសារពើនៅក្នុងស្ថានសួគ៌ និងនៅលើផែនដីត្រូវបានផ្លាស់ប្រែខ្លាំងណាស់ ហើយពួកគេធ្វើការអបអរ និងត្រេកអរជាខ្លាំង។ តើអ្នករាល់គ្នាមិនដូចនេះទេឬ? តើនៅក្នុងដួងចិត្តរបស់អ្នកណាដែលមិនមានភាពផ្អែមនៃទឹកឃ្មុំ? តើអ្នកណាមិនត្រេកត្រអាលចំពោះសេចក្ដីអំណរ? តើអ្នកណាមិនរាំដោយក្ដីរីករាយ? តើអ្នកណាមិននិយាយពាក្យលើកសរសើរ?

តើអ្នករាល់គ្នាយល់ពីបំណងនិងដើមកំណើតនៃអ្វីៗទាំងអស់ដែលខ្ញុំបានថ្លែងប្រាប់ និងពិភាក្សាខាងលើនេះឬក៏អត់ទេ? ប្រសិនបើខ្ញុំមិនបានសួរបែបនេះទេ នោះមនុស្សភាគច្រើននឹងជឿថា ខ្ញុំគ្រាន់តែកំពុងមានព្រះបន្ទូលឥតបានការ ហើយពួកគេនឹងមិនអាចវាស់ស្ទង់ប្រភពនៃព្រះបន្ទូលរបស់ខ្ញុំបានទេ។ ប្រសិនបើអ្នករាល់គ្នាពិចារណាសេចក្ដីទាំងនោះដោយយកចិត្តទុកដាក់ នោះអ្នករាល់គ្នានឹងដឹងពីសារៈសំខាន់របស់ពួកវា។ យកល្អ អ្នកគួរតែអានសេចក្ដីទាំងនោះឲ្យបានដិតដល់៖ តើព្រះបន្ទូលរបស់ខ្ញុំមួយណាដែលមិនមានប្រយោជន៍ដល់អ្នក? តើមួយណាដែលគ្មានន័យក្នុងការធ្វើឲ្យជីវិតរបស់អ្នករីកចម្រើន? តើមួយណាដែលមិនថ្លែងអំពីការពិតនៃពិភពខាងវិញ្ញាណ? មនុស្សភាគច្រើនជឿថា ព្រះបន្ទូលរបស់ខ្ញុំ គ្មានហេតុផលជាក់ច្បាស់ និងថាព្រះបន្ទូលរបស់ខ្ញុំខ្វះនូវការពន្យល់ និងការបកស្រាយ។ តើព្រះបន្ទូលរបស់ខ្ញុំពិតជាអរូបី និងមិនអាចពន្យល់បានដូច្នោះមែនឬទេ? តើអ្នករាល់គ្នាពិតជាស្ដាប់បង្គាប់ព្រះបន្ទូលរបស់ខ្ញុំមែនឬទេ? តើអ្នករាល់គ្នាពិតជាព្រមទទួលព្រះបន្ទូលរបស់ខ្ញុំមែនឬទេ? តើអ្នករាល់គ្នាមិនចាត់ទុកព្រះបន្ទូលរបស់ខ្ញុំជារបស់លេងទេឬ? តើអ្នករាល់គ្នាមិនប្រើព្រះបន្ទូលរបស់ខ្ញុំ ធ្វើជាគ្រឿងបិទបាំងរូបរាងដ៏អាក្រក់របស់ខ្លួនទេឬ? នៅក្នុងពិភពលោកដ៏ធំធេង

នេះ តើអ្នកណាខ្លះត្រូវបានខ្ញុំពិនិត្យមើលដោយផ្ទាល់? តើអ្នកណាខ្លះបានឮព្រះបន្ទូលនៃព្រះវិញ្ញាណរបស់ខ្ញុំដោយផ្ទាល់? មនុស្សច្រើនណាស់រាវរក និងស្វែងរកនៅក្នុងភាពងងឹត មនុស្សច្រើនណាស់អធិស្ឋាននៅពេលមានគ្រោះកាច មនុស្សច្រើនណាស់អត់ឃ្លាន រងារ និងរង់ចាំក្នុងក្ដីសង្ឃឹម ហើយមនុស្សច្រើនណាស់បានជាប់ចំណងរបស់សាតាំង ក្រៅពីនេះ មនុស្សច្រើនណាស់មិនដឹងថាត្រូវបត់ទៅណាទេ មនុស្សច្រើនណាស់ក្បត់ខ្ញុំក្នុងពេលពួកគេមានសុភមង្គល មនុស្សច្រើនណាស់រមិលគុណ ហើយមនុស្សច្រើនណាស់ មានភក្ដីភាពនឹងគ្រោងការបោកបញ្ឆោតរបស់សាតាំង។ តើក្នុងចំណោមអ្នករាល់គ្នា អ្នកណាជាយ៉ូប? តើអ្នកណាជាពេត្រុស? ហេតុអ្វីបានជាខ្ញុំថ្លែងម្ដងហើយម្ដងទៀតអំពីយ៉ូប? ហេតុអ្វីបានជាខ្ញុំលើកឡើងអំពីពេត្រុសច្រើនដងខ្លាំងម្ល៉េះ? តើអ្នករាល់គ្នាធ្លាប់សម្គាល់ឃើញក្ដីសង្ឃឹមរបស់ខ្ញុំ សម្រាប់អ្នករាល់គ្នាឬទេ? អ្នករាល់គ្នាគួរតែចំណាយពេលពិចារណារឿងទាំងនេះបន្ថែមទៀត។

ពេត្រុសស្មោះត្រង់នឹងខ្ញុំអស់រយៈពេលជាច្រើនឆ្នាំ តែគាត់មិនដែលរអ៊ូរទាំ ឬត្អូញត្អែរអ្វីឡើយ សូម្បីតែយ៉ូបក៏មិនស្មើគាត់ដែរ ហើយឆ្លងកាត់ច្រើនយុគសម័យមកហើយ ពួកបរិសុទ្ធទាំងអស់អន់ជាងពេត្រុសឆ្ងាយណាស់។ គាត់មិនត្រឹមតែបានប្រឹងប្រែងស្គាល់ខ្ញុំប៉ុណ្ណោះទេ ប៉ុន្តែគាត់ថែមទាំងបានបែរមកស្គាល់ខ្ញុំក្នុងពេលដែលសាតាំងកំពុងអនុម័តគ្រោងការបោកបញ្ឆោតផងដែរ។ នេះបាននាំឲ្យពេត្រុសបម្រើខ្ញុំអស់រយៈពេលជាច្រើនឆ្នាំ ដោយតែងតែស្របតាមបំណងព្រះហឫទ័យរបស់ខ្ញុំ ដោយហេតុនេះហើយ គាត់មិនដែលត្រូវបានសាតាំងកេងប្រវ័ញ្ចបានឡើយ។ ពេត្រុសបានទាញយកមេរៀនពីសេចក្ដីជំនឿរបស់យ៉ូប ប៉ុន្តែក៏បានដឹងច្បាស់អំពីគុណវិបត្តិរបស់យ៉ូបផងដែរ។ ថ្វីដ្បិតយ៉ូបមានជំនឿដ៏មុតមាំក្តី តែគាត់ខ្វះចំណេះដឹងអំពីបញ្ហាក្នុងពិភពខាងវិញ្ញាណ ដូច្នេះគាត់បាននិយាយពាក្យសម្ដីជាច្រើនដែលមិនត្រូវនឹងការពិត នេះបង្ហាញថាចំណេះដឹងរបស់យ៉ូបគឺរាក់សេចក្ដី និងមិនអាចគ្រប់លក្ខណ៍បាន។ ហេតុដូច្នេះហើយ ពេត្រុសបានផ្ដោតលើការមានញាណដឹងអំពីវិញ្ញាណជានិច្ច ហើយតែងតែយកចិត្តទុកដាក់ក្នុងការសង្កេតមើលកម្លាំងចលនានៃពិភពខាងវិញ្ញាណ។ ជា

លទ្ធផល គាត់មិនត្រឹមតែអាចសម្គាល់ឃើញអ្វីម៉្យាងនៃបំណងប្រាថ្នារបស់ខ្ញុំប៉ុណ្ណោះទេ ប៉ុន្តែគាត់ថែមទាំងបានចំណេះដឹងបន្តិចបន្តួច អំពីគ្រោងការបោកបញ្ឆោតរបស់សាតាំងទៀតផង។ ដោយហេតុនេះ គាត់ស្គាល់ខ្ញុំបានកាន់តែប្រសើរឡើងជាងអ្នកដទៃឆ្លងកាត់ច្រើនយុគសម័យមកហើយ។

តាមបទពិសោធរបស់ពេត្រុសបង្ហាញថា វាមិនពិបាកទេក្នុងការមើលឃើញបែបនោះឲ្យតែមនុស្សចង់ស្គាល់ខ្ញុំមែន ពួកគេត្រូវតែផ្ដោតលើការពិចារណាយ៉ាងយកចិត្តទុកដាក់នៅក្នុងវិញ្ញាណរបស់ពួកគេ។ ខ្ញុំមិនសុំឲ្យអ្នក «ថ្វាយ» តង្វាយមួយចំនួនដល់ខ្ញុំក្រៅខ្លួននោះទេ នេះជាបញ្ហាបន្ទាប់បន្សំប៉ុណ្ណោះ។ ប្រសិនបើអ្នកមិនស្គាល់ខ្ញុំទេ នោះសេចក្ដីជំនឿ សេចក្ដីស្រឡាញ់ និងភក្ដីភាពទាំងអស់ដែលអ្នកនិយាយ គ្រាន់តែជាការបំភាន់ប៉ុណ្ណោះ វាជាការនិយាយផ្ដេសផ្ដាស ហើយអ្នកប្រាកដជាក្លាយជាមនុស្សដែលពូកែអួតនៅចំពោះព្រះភក្ត្រខ្ញុំ តែមិនស្គាល់ខ្លួនឯង។ ដូចនេះ អ្នកនឹងជាប់អន្ទាក់របស់សាតាំងម្ដងទៀត ហើយអ្នកមិនអាចដោះលែងខ្លួនឯងចេញបានទេ អ្នកនឹងក្លាយជាកូននៃសេចក្ដីវិនាស និងជាកម្មវត្ថុនៃការបំផ្លាញ។ យ៉ាងណាមិញ ប្រសិនបើអ្នកសោះអង្គើយ និងមិនយកចិត្តទុកដាក់ចំពោះព្រះបន្ទូលរបស់ខ្ញុំ នោះអ្នកមុខជាប្រឆាំងនឹងខ្ញុំដោយឥតសង្ស័យ។ នេះជាការពិត ហើយយកល្អ អ្នកគួរតែក្រឡេកមើលវិញ្ញាណដែលខុសប្លែកគ្នាជាច្រើនដែលត្រូវបានខ្ញុំវាយផ្ចាលតាមច្រកទ្វារនៃពិភពខាងវិញ្ញាណ។ តើវិញ្ញាណមួយណា ដែលប្រឈមមុខនឹងព្រះបន្ទូលរបស់ខ្ញុំ ដែលមិនអកម្ម ដែលមិនយកចិត្តទុកដាក់ និងដែលមិនព្រមទទួលយក? តើវិញ្ញាណមួយណាដែលមើលឃើញតែចំណុចអាក្រក់អំពីព្រះបន្ទូលរបស់ខ្ញុំ? តើវិញ្ញាណមួយណាដែលមិនបានព្យាយាមចាប់កំហុសនៃព្រះបន្ទូលរបស់ខ្ញុំ? តើវិញ្ញាណមួយណាដែលមិនបានប្រើព្រះបន្ទូលរបស់ខ្ញុំធ្វើជា «អាវុធទប់ទល់» ដើម្បី «ការពារ» ខ្លួនពួកគេ? ពួកគេមិនបានប្រើខ្លឹមសារនៃព្រះបន្ទូលរបស់ខ្ញុំធ្វើជាផ្លូវដើម្បីស្គាល់ខ្ញុំទេ ប៉ុន្តែធ្វើត្រឹមតែជារបស់លេងប៉ុណ្ណោះ។ បែបនេះ តើពួកគេមិនកំពុងប្រឆាំងនឹងខ្ញុំដោយផ្ទាល់ទេឬ? តើព្រះបន្ទូលរបស់ខ្ញុំជានរណា? តើព្រះវិញ្ញាណរបស់ខ្ញុំជានរណា? ខ្ញុំបានសួរអ្នករាល់គ្នា

នូវសំណួរបែបនេះច្រើនដងណាស់មកហើយ ក៏ប៉ុន្តែ តើអ្នករាល់គ្នាធ្លាប់ទទួលបានការយល់ដឹងជ្រៅជ្រះច្បាស់លាស់ជាងមុនអំពីសំណួរទាំងនេះឬទេ? តើអ្នករាល់គ្នាធ្លាប់បានឆ្លងកាត់បទពិសោធអំពីពួកវាឬទេ? ខ្ញុំរំលឹកអ្នករាល់គ្នាម្ដងទៀតថា៖ ប្រសិនបើអ្នករាល់គ្នាមិនស្គាល់ព្រះបន្ទូលរបស់ខ្ញុំ មិនព្រមទទួលព្រះបន្ទូលរបស់ខ្ញុំ ថែមទាំងមិនអនុវត្តព្រះបន្ទូលរបស់ខ្ញុំទេ នោះអ្នករាល់គ្នានឹងក្លាយជាកម្មវត្ថុនៃការវាយផ្ចាលរបស់ខ្ញុំដោយចៀសមិនរួច! អ្នករាល់គ្នាប្រាកដជានឹងក្លាយជាជនរងគ្រោះរបស់សាតាំង!

ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ១៩៩២

## ជំពូកទី ១០៖ ព្រះបន្ទូលព្រះជាម្ចាស់ ថ្លែងទៅកាន់សកលលោកទាំងមូល

យុគសម័យនៃនគរព្រះ គឺខុសគ្នាពីសម័យមុនៗទាំងអស់។ មិនខ្វល់ថាតើមនុស្សមានសកម្មភាពយ៉ាងណានោះទេ ផ្ទុយទៅវិញ ខ្ញុំបានយាងចុះមកលើផែនដីដើម្បីអនុវត្តកិច្ចការរបស់ខ្ញុំដោយផ្ទាល់ ជាកិច្ចការដែលមនុស្សជាតិអាចមិននឹកគិតដល់ ហើយក៏មិនសម្រេចបាន។ អស់រយៈពេលច្រើនឆ្នាំណាស់មកហើយ ចាប់តាំងពីពេលបង្កើតពិភពលោកមក កិច្ចការនេះមានត្រឹមតែការកសាងក្រុមជំនុំប៉ុណ្ណោះ ប៉ុន្តែគេមិនដែលឮអំពីការកសាងនគរព្រះទេ។ ទោះបីជាខ្ញុំមានព្រះបន្ទូលអំពីរឿងនេះដោយផ្ទាល់ព្រះឱស្ឋខ្ញុំក៏ដោយ តើមាននរណាម្នាក់ដែលដឹងពីលក្ខណៈរបស់វាឬទេ? ខ្ញុំធ្លាប់យាងចុះមកក្នុងពិភពមនុស្ស ហើយបានមានបទពិសោធ និងបានសង្កេតមើលការរងទុក្ខរបស់ពួកគេ ប៉ុន្តែខ្ញុំបានធ្វើដូច្នោះដោយមិនបានបំពេញគោលបំណងនៃការយកកំណើតជាមនុស្សរបស់ខ្ញុំទេ។ នៅពេលការកសាងនៃនគរព្រះបានចាប់ផ្ដើម នោះសាច់ឈាមដែលយកកំណើតជាមនុស្សរបស់ខ្ញុំ ក៏បានចាប់ផ្ដើមអនុវត្តកិច្ចការព័ន្ធកិច្ចរបស់ខ្ញុំជាផ្លូវការ ពោលគឺ ស្ដេចនៃនគរព្រះបានឡើងកាន់អំណាចគ្រប់គ្រងរបស់ទ្រង់ជាផ្លូវការ។ តាមរយៈសេចក្ដីនេះ វាបញ្ជាក់ច្បាស់ថា ការចុះមកនៃនគរព្រះចូលមកក្នុងពិភពមនុស្ស

ខុសឆ្ងាយពីការគ្រាន់តែជាការបង្ហាញឲ្យឃើញដែលគ្មានខ្លឹមសារ គឺជាការពិតជាក់ស្ដែងមួយ នេះជាចំណុចមួយនៃអត្ថន័យនៃ «ភាពជាក់ស្ដែងនៃការអនុវត្ត។» មនុស្សមិនដែលបានឃើញទង្វើណាមួយរបស់ខ្ញុំឡើយ ហើយក៏មិនដែលបានឮព្រះសូរសៀងណាមួយរបស់ខ្ញុំផងដែរ។ ទោះជាពួកគេបានឃើញទង្វើរបស់ខ្ញុំក្ដី តើពួកគេនឹងរកឃើញអ្វីខ្លះ? ហើយប្រសិនបើពួកគេបានឮខ្ញុំមានព្រះបន្ទូល តើពួកគេនឹងបានយល់អ្វីខ្លះ? នៅពាសពេញពិភពលោក មនុស្សគ្រប់រូបរស់នៅក្នុងសេចក្ដីមេត្តាករុណា និងសេចក្ដីសន្ដោសប្រណីរបស់ខ្ញុំ តែទោះដូច្នោះក្ដី មនុស្សជាតិទាំងអស់សុទ្ធតែស្ថិតនៅក្រោមការជំនុំជម្រះរបស់ខ្ញុំ និងដាក់ឲ្យស្ថិតក្រោមការល្បងលរបស់ខ្ញុំផងដែរ។ ខ្ញុំពោរពេញដោយសេចក្ដីមេត្តាករុណា និងការស្រឡាញ់ចំពោះមនុស្ស សូម្បីតែពេលពួកគេទាំងអស់បានក្លាយជាពុករលួយដល់កម្រិតណាក៏ដោយ។ ខ្ញុំបានធ្វើការវាយផ្ចាលពួកគេ សូម្បីតែពេលពួកគេទាំងអស់ បានចុះចូលនៅពីមុខរាជបល្ល័ង្ករបស់ខ្ញុំក៏ដោយ។ ទោះយ៉ាងណាក៏ដោយ តើមានមនុស្សណាម្នាក់ដែលមិនស្ថិតក្នុងការរងទុក្ខ និងការបន្សុទ្ធដែលខ្ញុំបានដាក់ចេញឬទេ? មនុស្សច្រើនណាស់ កំពុងរាវរកពន្លឺឆ្លងកាត់ភាពងងឹត ហើយមនុស្សច្រើនណាស់កំពុងតស៊ូយ៉ាងល្វីងជូចត់ ឆ្លងកាត់ការល្បងលរបស់ពួកគេ។ យ៉ូបមានជំនឿ ប៉ុន្តែតើគាត់មិនបានស្វែងរកផ្លូវចេញសម្រាប់ខ្លួនគាត់ទេឬ? ទោះបីជារាស្ត្ររបស់ខ្ញុំអាចឈរយ៉ាងរឹងមាំក្នុងការប្រឈមមុខនឹងការល្បងលក៏ដោយ តើមានអ្នកណាម្នាក់ដែលមិននិយាយរឿងនេះឮៗ បែរជាមានជំនឿក្នុងជម្រៅចិត្តដែរឬទេ? តើវាមិនសមទេឬដែលថា មនុស្សនិយាយពីជំនឿរបស់ខ្លួន ក្នុងពេលដែលពួកគេកំពុងតែលាក់ទុកការសង្ស័យនៅក្នុងដួងចិត្តរបស់ខ្លួននោះ? មិនមានមនុស្សណាម្នាក់ដែលបានឈរយ៉ាងជាប់មាំនៅក្នុងការល្បងល ឬដែលចុះចូលពិតប្រាកដនៅពេលទទួលការល្បងលនោះទេ។ ប្រសិនបើខ្ញុំមិនបានបាំងព្រះភក្ត្ររបស់ខ្ញុំដើម្បីគេចពីការក្រឡេកមើលពិភពលោកនេះទេ នោះមនុស្សជាតិទាំងមូលនឹងដួលរលំនៅក្រោមការសម្លឹងមើលទាំងក្ដៅក្រហាយរបស់ខ្ញុំ ដ្បិតខ្ញុំមិនសុំអ្វីពីមនុស្សឡើយ។

នៅពេលការគំនាប់ចំពោះនគរព្រះបន្លឺសំឡេងឡើង ពោលគឺក៏ជាពេលដែល

ផ្គរលាន់ទាំងប្រាំពីរបញ្ចេញសូរសព្ទ សំឡេងនេះធ្វើឲ្យញ័រញាក់ស្ថានសួគ៌ និងផែនដី ដែលធ្វើឲ្យរញ្ជួយអស់សួគ៌ាលៃ និងធ្វើឲ្យដួងចិត្តរបស់មនុស្សគ្រប់រូប ញាប់ញ័រ។ ចម្រៀងថ្វាយនគរព្រះក៏ធ្វើការប្រគំឡើងតាមពិធីការ នៅលើទឹកដីនាគដ៏ធំមានសម្បុរក្រហម ដោយបញ្ជាក់ថា ខ្ញុំបានបំផ្លាញប្រទេសនោះ ហើយបានបង្កើតព្រះនគររបស់ខ្ញុំ។ សំខាន់ជាងនេះទៅទៀតនោះគឺ នគររបស់ខ្ញុំត្រូវបានបង្កើតឡើងនៅលើផែនដី។ នៅពេលនេះ ខ្ញុំចាប់ផ្ដើមបញ្ជូនទេវតារបស់ខ្ញុំ ទៅគ្រប់ប្រទេសក្នុងពិភពលោកដើម្បីឲ្យពួកគេអាចឃ្វាលពួកកូនប្រុសរបស់ខ្ញុំ និងរាស្ត្ររបស់ខ្ញុំ នេះក៏ដើម្បីបំពេញតាមសេចក្ដីតម្រូវនៃជំហានបន្ទាប់នៃកិច្ចការរបស់ខ្ញុំ។ ទោះយ៉ាងណាក៏ដោយ ខ្ញុំផ្ទាល់ក៏យាងមកកន្លែងដែលនាគដ៏ធំមានសម្បុរក្រហមដេកពេន ហើយប្រកួតជាមួយវា។ នៅពេលមនុស្សជាតិទាំងអស់បែរមកស្គាល់ខ្ញុំក្នុងភាពជាសាច់ឈាម ហើយអាចមើលឃើញទង្វើរបស់ខ្ញុំក្នុងភាពជាសាច់ឈាម នោះជម្រករបស់នាគដ៏ធំមានសម្បុរក្រហមនឹងក្លាយទៅជាផេះ ហើយបាត់គ្មានសល់ដាន។ ដ្បិតអ្នកស្អប់នាគដ៏ធំមានសម្បុរក្រហមរហូតដល់ឆ្អឹង ក្នុងនាមជារាស្ត្រនៃនគររបស់ខ្ញុំ អ្នកត្រូវតែបំពេញតាមដួងព្រះហឫទ័យរបស់ខ្ញុំដោយប្រើសកម្មភាពរបស់អ្នក ហើយតាមរយៈវិធីនេះ អ្នកនាំភាពអាម៉ាស់ដល់នាគនេះ។ តើអ្នករាល់គ្នាពិតជាដឹងថា នាគដ៏ធំមានសម្បុរក្រហមគួរឲ្យស្អប់ឬទេ? តើអ្នករាល់គ្នាពិតជាមានអារម្មណ៍ថា វាជាសត្រូវរបស់ស្ដេចនៃនគរព្រះឬទេ? តើអ្នករាល់គ្នាពិតជាមានជំនឿថា អ្នកអាចធ្វើបន្ទាល់ដ៏អស្ចារ្យឲ្យខ្ញុំបានដែរឬទេ? តើអ្នករាល់គ្នាពិតជាជឿជាក់ថា អ្នកអាចយកឈ្នះនាគដ៏ធំមានសម្បុរក្រហមឬទេ? នេះហើយជាអ្វីដែលខ្ញុំសុំពីអ្នករាល់គ្នា។ អ្វីគ្រប់យ៉ាងដែលខ្ញុំត្រូវការ គឺដើម្បីឲ្យអ្នករាល់គ្នាអាចឈានដល់ជំហាននេះ។ តើអ្នករាល់គ្នានឹងអាចធ្វើការនេះបានឬទេ? តើអ្នករាល់គ្នាមានជំនឿថា អ្នកអាចសម្រេចការនេះបានឬទេ? តើមនុស្សមានសមត្ថភាពធ្វើអ្វីបានឲ្យពិតប្រាកដទៅ? តើវាមិនសមទេឬដែលថា ខ្ញុំធ្វើវាដោយអង្គឯង? ហេតុអ្វីបានជាខ្ញុំមានព្រះបន្ទូលថា ខ្ញុំយាងចុះមកដោយផ្ទាល់នៅទីតាំងដែលមានចម្បាំង? អ្វីដែលខ្ញុំចង់បាន គឺជាជំនឿរបស់អ្នករាល់គ្នា មិនមែនជាអំពើរបស់អ្នករាល់គ្នាទេ។ មនុស្ស

ទាំងអស់ សុទ្ធតែគ្មានសមត្ថភាពក្នុងការទទួលយកព្រះបន្ទូលរបស់ខ្ញុំដោយត្រង់នោះទេ ហើយផ្ទុយទៅវិញ គឺបានត្រឹមតែអាចក្រឡេកមើលមួយភ្លែតប៉ុណ្ណោះ។ តើការនេះបានជួយអ្នករាល់គ្នា ឲ្យសម្រេចគោលដៅរបស់ខ្លួនដែរឬទេ? តើអ្នករាល់គ្នាបែរមកស្គាល់ខ្ញុំតាមរបៀបនេះឬ? តាមពិត ក្នុងចំណោមមនុស្សនៅលើផែនដីនេះ គ្មាននរណាម្នាក់មានសមត្ថភាពមើលចំព្រះភក្ត្រខ្ញុំនោះទេ ហើយគ្មាននរណាម្នាក់អាចទទួលបានអត្ថន័យដ៏បរិសុទ្ធ និងអត្ថន័យដើមនៃព្រះបន្ទូលរបស់ខ្ញុំឡើយ។ ហេតុដូច្នេះហើយ ខ្ញុំបានដាក់ឲ្យដំណើរការនូវគម្រោងដែលមិនធ្លាប់មាននៅលើផែនដីពីមុនមក ដើម្បីសម្រេចគោលដៅរបស់ខ្ញុំ និងបង្កើតរូបអង្គរបស់ខ្ញុំ នៅក្នុងដួងចិត្តរបស់មនុស្ស។ តាមវិធីនេះ ខ្ញុំនឹងបញ្ចប់នូវយុគសម័យដែលសញ្ញាណមានអំណាចខ្លាំងលើមនុស្ស។

សព្វថ្ងៃនេះ ខ្ញុំមិនមែនត្រឹមតែយាងចុះមកលើប្រទេសរបស់នាគដ៏ធំមានសម្បុរក្រហមប៉ុណ្ណោះទេ ខ្ញុំក៏កំពុងងាកទៅប្រឈមមុខនឹងសកលលោកទាំងមូលផងដែរ ដែលធ្វើឲ្យសួគ៌ាលៃទាំងមូលរញ្ជួយញាប់ញ័រ។ តើមានកន្លែងណាមួយដែលមិនទទួលរងការជំនុំជម្រះរបស់ខ្ញុំឬទេ? តើមានកន្លែងណាមួយដែលមិននៅក្រោមភាពអន្តរាយដ៏ធំដែលខ្ញុំស្រោចពីលើវាដែរឬទេ? គ្រប់ទីកន្លែងដែលខ្ញុំយាងទៅ ខ្ញុំបានបាច «គ្រាប់ពូជនៃគ្រោះមហន្តរាយ» គ្រប់ប្រភេទ។ នេះជាវិធីធ្វើការមួយបែបរបស់ខ្ញុំ និងដោយគ្មានការសង្ស័យ ក៏ជាទង្វើនៃការសង្គ្រោះមនុស្សជាតិផងដែរ ហើយអ្វីដែលខ្ញុំពង្រីកទៅដល់ពួកគេ នៅតែជាប្រភេទនៃសេចក្ដីស្រឡាញ់។ ខ្ញុំចង់ឲ្យមនុស្សកាន់តែច្រើនបានស្គាល់ខ្ញុំ និងអាចមើលឃើញខ្ញុំ ហើយតាមរបៀបនេះ ពួកគេបែរមកគោរពព្រះជាម្ចាស់ដែលពួកគេមិនបានមើលឃើញ អស់រយៈពេលច្រើនឆ្នាំមកហើយ ប៉ុន្តែដែលពេលនេះពួកគេមើលឃើញថា ព្រះអង្គមានពិតប្រាកដមែន។ តើខ្ញុំបានបង្កើតពិភពលោកដោយសារមូលហេតុអ្វី? តើហេតុអ្វីបានជាខ្ញុំមិនកម្ទេចមនុស្សចោលឲ្យអស់រលីងទៅក្រោយពេលពួកគេបានក្លាយជាពុករលួយហើយ? តើមនុស្សជាតិទាំងមូលរស់នៅក្នុងគ្រោះមហន្តរាយដោយសារមូលហេតុអ្វី? តើអ្វីទៅជាគោលបំណងរបស់ខ្ញុំក្នុងការសណ្ឋិតក្នុងសាច់ឈាម? នៅពេលខ្ញុំអនុវត្តកិច្ចការរបស់ខ្ញុំ មនុស្សភ្លក់រសជាតិទាំង

ល្វីងជូរចត់ផង និងផ្អែមល្ហែមផង។ ក្នុងចំណោមមនុស្សទាំងអស់នៅក្នុងពិភពលោក តើអ្នកណាទៅដែលមិនរស់នៅក្នុងព្រះគុណរបស់ខ្ញុំ? ប្រសិនបើខ្ញុំមិនបានប្រទានឲ្យមនុស្សនូវព្រះពរផ្នែកសម្ភារៈទេ តើនៅលើលោកនេះ អ្នកណាទៅដែលនឹងអាចមានភាពសម្បូរសប្បាយបាន? តើវាអាចទៅរួចទេដែលថា ការអនុញ្ញាតឲ្យអ្នករាល់គ្នាមានឋានៈជារាស្ត្ររបស់ខ្ញុំ គឺជាព្រះពរ? បើអ្នករាល់គ្នាមិនមែនជារាស្ត្ររបស់ខ្ញុំទេ ប៉ុន្តែផ្ទុយទៅវិញជាអ្នកស៊ីឈ្នួល នោះអ្នករាល់គ្នានឹងមិនរស់នៅក្នុងព្រះពររបស់ខ្ញុំឡើយមែនទេ? ក្នុងចំណោមអ្នករាល់គ្នា គ្មានម្នាក់ណាឡើយដែលមានសមត្ថភាពក្នុងការវាស់ស្ទង់ពីដើមកំណើតនៃព្រះបន្ទូលរបស់ខ្ញុំ។ មនុស្សជាតិ នៅឆ្ងាយពីការមានតម្លៃស្មើងារដែលខ្ញុំបានប្រទានឲ្យពួកគេ ព្រោះតែងារជា «អ្នកស៊ីឈ្នួល» ពួកគេច្រើននាក់ណាស់រក្សាការថ្នាំងថ្នាក់នៅក្នុងដួងចិត្តរបស់ពួកគេ ហើយព្រោះតែងារជា «រាស្ត្ររបស់ខ្ញុំ» ពួកគេច្រើននាក់ណាស់ បង្កើតសេចក្ដីស្រឡាញ់ចំពោះខ្ញុំនៅក្នុងដួងចិត្តរបស់ពួកគេ។ ពួកគេមិនគួរព្យាយាមបន្លំខ្ញុំទេ ព្រះនេត្ររបស់ខ្ញុំមើលឃើញគ្រប់យ៉ាង! តើក្នុងចំណោមអ្នករាល់គ្នា នរណាទទួលយកដោយស្ម័គ្រចិត្ត ហើយតើក្នុងចំណោមអ្នករាល់គ្នា នរណាធ្វើការស្ដាប់បង្គាប់ទាំងស្រុង? បើសិនជាការគំនាប់ចំពោះនគរព្រះមិនបានបន្លឺសំឡេងឡើងទេ តើអ្នករាល់គ្នានឹងពិតជាអាចចុះចូលដល់ទីបញ្ចប់ឬទេ? អ្វីៗដែលមនុស្សមានសមត្ថភាពធ្វើ និងគិតបាន ព្រមទាំងចម្ងាយដែលពួកគេអាចទៅបាន សុទ្ធតែត្រូវបានខ្ញុំកំណត់ទុកជាមុនតាំងពីយូរយារណាស់មកហើយ។

មនុស្សដ៏ច្រើនលើសលុប ទទួលយកការឆេះឆួលរបស់ខ្ញុំនៅក្នុងពន្លឺនៃទឹកព្រះភក្ត្ររបស់ខ្ញុំ។ មនុស្សដ៏ច្រើនលើសលុប ដែលត្រូវបានជំរុញដោយការលើកទឹកចិត្តរបស់ខ្ញុំ ភ្ញាក់ឡើងឆ្ពោះទៅមុខស្វះស្វែងរក។ នៅពេលកម្លាំងរបស់សាតាំងវាយប្រហាររាស្ត្ររបស់ខ្ញុំ ខ្ញុំនៅទីនោះដើម្បីរារាំងពួកសាតាំង នៅពេលផែនការសម្ងាត់របស់សាតាំងធ្វើឲ្យអន្តរាយដល់ជីវិតរបស់ពួកគេ ខ្ញុំធ្វើឲ្យវារត់ត្របាញ់ជើងទៅតាមផ្លូវមួយទៅបាត់លែងវិលមកវិញតែម្ដង។ នៅលើផែនដី វិញ្ញាណអាក្រក់ៗគ្រប់បែបយ៉ាងតែងតែក្រវែលលបៗរកកន្លែងសម្រាក និងកំពុងស្វែងរកសាកសពមនុស្សដែលអាច

ស៊ីបានឥតឈប់ឈរ។ រាស្ត្រខ្ញុំអើយ! អ្នកត្រូវតែស្ថិតនៅក្នុងការថែទាំ និងការការពាររបស់ខ្ញុំជានិច្ច។ ចូរកុំប្រព្រឹត្តខុសគន្លងឡើយ! កុំប្រកាន់ឫកពាព្រហើន! អ្នករាល់គ្នាគួរតែថ្វាយភក្ដីភាពរបស់ខ្លួនទាំងអស់នៅក្នុងដំណាក់របស់ខ្ញុំ ហើយមានតែភក្ដីភាពប៉ុណ្ណោះ ដែលអ្នករាល់គ្នាអាចធ្វើការវាយលុកតបប្រឆាំងនឹងឧបាយកលរបស់អារក្សបាន។ ទោះស្ថិតក្នុងកាលៈទេសៈណាក៏ដោយ មិនគួរអ្នកប្រកាន់ឫកពាដូចដែលអ្នកបានធ្វើកាលពីមុនឡើយ ដោយធ្វើរឿងមួយនៅចំពោះព្រះភក្ត្រខ្ញុំ ហើយមួយទៀតនៅពីក្រោយខ្នងខ្ញុំ ប្រសិនបើអ្នកធ្វើបែបនេះ នោះអ្នកឃ្លាតឆ្ងាយពីការប្រោសលោះ។ តើខ្ញុំមិនបានថ្លែងនូវព្រះបន្ទូលទាំងនេះ លើសពីគ្រប់គ្រាន់ទេឬ? វាច្បាស់ណាស់ ពីព្រោះនិស្ស័យចាស់របស់មនុស្សមិនអាចកែបានទេ រហូតដល់ថ្នាក់ខ្ញុំត្រូវតែធ្វើការក្រើនរំលឹកមនុស្សម្ដងហើយម្ដងទៀត។ កុំធុញធ្វើអ្វី! អ្វីគ្រប់យ៉ាងដែលខ្ញុំមានព្រះបន្ទូល គឺសម្រាប់ជាប្រយោជន៍ដល់ការធានាវាសនារបស់អ្នករាល់គ្នា! កន្លែងស្អុយ និងស្មោកគ្រោក ជាអ្វីដែលសាតាំងត្រូវការយ៉ាងពិតប្រាកដ បើអ្នកកាន់តែអស់សង្ឃឹម ក្នុងការកែលម្អឡើងវិញបាន នោះអ្នកក៏កាន់តែប្រព្រឹត្តខុសគន្លង ដោយបដិសេធមិនចុះចូលនឹងការអត់ធ្មត់ បន្ទាប់មក ពួកវិញ្ញាណមិនស្អាតទាំងនោះកាន់តែច្រើននឹងរកប្រយោជន៍ឲ្យខ្លួនពួកវាពីឱកាសជ្រៀតចូលក្នុងខ្លួនឯង។ ប្រសិនបើអ្នកបានដល់ចំណុចនេះ នោះភក្ដីភាពរបស់អ្នករាល់គ្នា នឹងគ្មានអ្វីក្រៅតែពីការនិយាយលេងឥតបានការ ដោយគ្មានការពិតអ្វីបន្តិចសោះ ហើយពួកវិញ្ញាណមិនស្អាត នឹងលេបសេចក្ដីតាំងចិត្តរបស់អ្នករាល់គ្នា ហើយប្រែក្លាយវាទៅជាការមិនស្ដាប់បង្គាប់ និងទៅជាផែនការសម្ងាត់បែបសាតាំងដែលត្រូវបានប្រើដើម្បីរំខានដល់កិច្ចការរបស់ខ្ញុំ។ មកដល់ចំណុចនេះ អ្នកអាចត្រូវបានខ្ញុំផ្ចាញ់ពេលណាក៏បាន។ គ្មាននរណាម្នាក់យល់ពីទម្ងន់នៃស្ថានភាពនេះទេ មនុស្សទាំងអស់បានត្រឹមតែធ្វើគធ្វើថ្លង់ចំពោះអ្វីៗដែលពួកគេឮ និងគ្មានការប្រុងប្រយ័ត្នអ្វីបន្តិចសោះឡើយ។ ខ្ញុំចាំថា គ្មានអ្វីត្រូវបានធ្វើកាលពីមុនទេ តើអ្នកពិតជានៅតែកំពុងរង់ចាំឲ្យខ្ញុំអត់ឱនដល់អ្នកដោយ «ការបំភ្លេចចោល» ម្ដងទៀតឬ? ទោះបីជាមនុស្សបានប្រឆាំងខ្ញុំក្ដី ក៏ខ្ញុំនឹងមិនធ្វើការប្រឆាំងតបពួកគេវិញដែរ ដ្បិត

ពួកគេមានឋានៈតូចពេក ដូច្នេះហើយទើបខ្ញុំមិនបានធ្វើការទាមទារខ្ពស់ហួសហេតុពីពួកគេនោះទេ។ អ្វីគ្រប់យ៉ាងដែលខ្ញុំទាមទារ គឺឲ្យពួកគេឈប់ប្រព្រឹត្តខុសគន្លង និងឲ្យពួកគេស្ដាប់បង្គាប់ការទប់ស្កាត់។ ប្រាកដណាស់ថា វាមិនហួសពីសមត្ថភាពរបស់អ្នករាល់គ្នា ក្នុងការបំពេញតាមលក្ខខណ្ឌពិសេសមួយនេះនោះទេ មែនទេ? មនុស្សភាគច្រើន កំពុងតែរង់ចាំឲ្យខ្ញុំបើកសម្ដែងពីអាថ៌កំបាំងឲ្យច្រើនថែមទៀត ដើម្បីឲ្យពួកគេបានសប្បាយភ្នែកមើល។ ទោះយ៉ាងណាក៏ដោយ ថ្វីបើអ្នកបានងាកមកយល់ពីអាថ៌កំបាំងទាំងអស់នៃស្ថានសួគ៌ក៏ដោយ តែជាក់ស្ដែង តើអ្នកអាចធ្វើអ្វីបានជាមួយចំណេះដឹងទាំងនោះ? តើវានឹងបង្កើនក្ដីស្រឡាញ់របស់អ្នកចំពោះខ្ញុំបានទេ? តើវានឹងដាស់អារម្មណ៍ស្រឡាញ់របស់អ្នកចំពោះខ្ញុំដែរឬទេ? ខ្ញុំមិនមើលងាយមនុស្ស ហើយក៏មិនវិនិច្ឆ័យវអំពីពួកគេដោយងាយៗដែរ។ ប្រសិនបើទាំងនេះមិនមែនជាស្ថានភាពជាក់ស្ដែងរបស់មនុស្សទេ ខ្ញុំនឹងមិនពាក់លើក្បាលពួកគេនូវស្លាកបែបនេះយ៉ាងគាប់ជួនដូច្នេះសោះឡើយ។ ចូរគិតពីអតីតកាលឡើងវិញ៖ តើខ្ញុំធ្លាប់មួលបង្កាច់អ្នករាល់គ្នាប៉ុន្មានដងហើយ? តើខ្ញុំធ្លាប់បានមើលងាយអ្នករាល់គ្នាប៉ុន្មានដងហើយ? តើខ្ញុំធ្លាប់បានមើលមកអ្នករាល់គ្នាដោយមិនគិតពីស្ថានភាពជាក់ស្ដែងរបស់អ្នករាល់គ្នាប៉ុន្មានដងហើយ? តើព្រះសូរសៀងរបស់ខ្ញុំបានបរាជ័យក្នុងការយកឈ្នះអ្នករាល់គ្នាយ៉ាងអស់ពីចិត្តប៉ុន្មានដងហើយ? តើខ្ញុំបានមានព្រះបន្ទូលដោយគ្មានការបង្កើតសំឡេងត្រូវគ្នាដែលខ្ទរយ៉ាងជ្រៅនៅក្នុងខ្លួនអ្នករាល់គ្នាឬទេ? តើក្នុងចំណោមអ្នករាល់គ្នា អ្នកណាទៅដែលបានអានព្រះបន្ទូលរបស់ខ្ញុំដោយគ្មានការកោតខ្លាច និងញាប់ញ័រ ដោយភ័យខ្លាចយ៉ាងខ្លាំងថា ខ្ញុំនឹងវាយទម្លាក់ពួកអ្នកចូលទៅក្នុងជង្ហុកធំ? តើអ្នកណាទៅដែលមិនស៊ូទ្រាំនឹងការល្បងលមកពីព្រះបន្ទូលរបស់ខ្ញុំ? សិទ្ធិអំណាច មាននៅក្នុងព្រះសូរសៀងរបស់ខ្ញុំ ប៉ុន្តែនេះមិនមែនសម្រាប់កាត់សេចក្ដីតាមធម្មតាលើមនុស្សនោះទេ ផ្ទុយទៅវិញ ដោយគិតដល់ស្ថានភាពជាក់ស្ដែងរបស់ពួកគេ ខ្ញុំតែងតែបង្ហាញច្បាស់ដល់ពួកគេ អំពីអត្ថន័យដែលមាននៅក្នុងព្រះបន្ទូលរបស់ខ្ញុំ។ តាមពិតទៅ តើមានអ្នកណាម្នាក់ដែលមានសមត្ថភាពក្នុងការស្គាល់ព្រះចេស្ដាដ៏មានសព្វានុភាព នៅក្នុង

ព្រះបន្ទូលរបស់ខ្ញុំឬទេ? តើមានអ្នកណាម្នាក់ដែលអាចទទួលបានមាសសុទ្ធបំផុតដែលកើតពីព្រះបន្ទូលរបស់ខ្ញុំឬទេ? តើខ្ញុំបានសម្ដែងត្រឹមតែប៉ុន្មានព្រះបន្ទូលទេឬ? តើមានអ្នកណាម្នាក់ដែលធ្លាប់រក្សាទុកនូវព្រះបន្ទូលរបស់ខ្ញុំជាកំណប់ទ្រព្យឬទេ?

ថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៩២

# ចម្រៀងជ័យនៃនគរព្រះ

បណ្ដាជនសាទរខ្ញុំ ហើយសរសើរតម្កើងខ្ញុំ គ្រប់មាត់ទាំងអស់ថ្លែងពីព្រះដ៏ពិតតែមួយ ហើយមនុស្សគ្រប់គ្នាបើកភ្នែកងើយមើលស្នាព្រះហស្ដរបស់ខ្ញុំ។ នគរព្រះចុះមកលើពិភពមនុស្ស ហើយអង្គរបស់ខ្ញុំសម្បូរភោគទ្រព្យ និងភាពសម្បូរហូរហៀរ។ តើ នរណាដែលមិនត្រេកអរចំពោះការនេះ? តើនរណាដែលមិនរាំដោយអំណរ? ឱស៊ីយ៉ូនអើយ! ចូរលើកទង់ជ័យរបស់អ្នកឡើងដើម្បីអបអរខ្ញុំ! ចូរច្រៀងចម្រៀងជ័យឃោសរបស់អ្នកដើម្បីផ្សាយព្រះនាមដ៏បរិសុទ្ធរបស់ខ្ញុំ! ឱស្នាព្រះហស្ដទាំងអស់ រហូតដល់ចុងបំផុតនៃផែនដីអើយ! ចូររួសរាន់សម្អាតខ្លួនឯងឲ្យបានស្អាត ដើម្បីឲ្យអ្នកអាចធ្វើជាតង្វាយដល់ខ្ញុំ! ឱហ្វូងផ្កាយនៅលើស្ថានសួគ៌អើយ! ចូររួសរាន់ត្រឡប់ទៅកន្លែងរបស់អ្នកវិញចុះ ដើម្បីបង្ហាញពីព្រះចេស្ដាដ៏មានអនុភាពរបស់ខ្ញុំ នៅក្នុងលំហរអាកាស! ខ្ញុំផ្ទៀងព្រះកាណ៌របស់ខ្ញុំ ស្ដាប់សម្លេងមនុស្សនៅលើផែនដី គឺមនុស្សដែលបង្ហូរក្ដីស្រលាញ់ និងការគោរពគ្មានព្រំដែនចំពោះខ្ញុំតាមរយៈបទចម្រៀង! នៅថ្ងៃនេះ នៅពេលដែលស្នាព្រះហស្ដទាំងអស់មានជីវិតឡើងវិញ នោះខ្ញុំក៏យាងចុះមកក្នុងពិភពមនុស្ស។ នៅខណៈពេលនេះ គឺនៅខណៈពេលដ៏រីករាយនេះ ផ្កាទាំងអស់ក៏រីកស្គុសស្គាយ ហើយបក្សាបក្សីទាំងអស់ក៏ស្រែកច្រៀងត្រសង អ្វីៗទាំងអស់កក្រើកដោយអំណរ! នគររបស់សាតាំងក៏ដួលរលំដោយសារសម្លេងគំនាប់នៃនគរព្រះ គឺត្រូវបំផ្លាញដោយសម្លេងផ្គរលាន់នៃចម្រៀងជ័យរបស់នគរព្រះ ហើយមិនអាចងើបឡើងវិញបានទៀតឡើយ!

នៅលើផែនដី តើនរណាហ៊ានក្រោកឡើង ហើយតតាំង? នៅពេលខ្ញុំយាងចុះមកផែនដី ខ្ញុំនាំយកភ្លើង យកសេចក្ដីក្រោធ និងយកគ្រោះហមន្ដរាយគ្រប់បែបយ៉ាងមក។ ឥលូវនេះ នគរនៅលើផែនដី គឺជានគររបស់ខ្ញុំ! នៅលើមេឃ ពពកវិលចុះវិលឡើង ហើយនៅក្រោមមេឃ បឹងបួរ និងទន្លេក៏កញ្ជ្រោលឡើង ជាបទភ្លេងដ៏ពីរោះរណ្ដំ។ សត្វទាំងពួងដែលកំពុងសម្រាក ក៏ស្ទុះងើបចេញពីរូងរបស់ខ្លួនមក មនុស្សម្នាទាំងពួងក៏ងើបពីភាពលង់លក់របស់ខ្លួនដោយសារខ្ញុំ។ ទីបំផុត ថ្ងៃដែលមនុស្សដ៏ច្រើនលើសលប់បានទន្ទឹងរង់ចាំ ក៏មកដល់! ពួកគេក៏ច្រៀងបទចម្រៀងដ៏ពីរោះបំផុតថ្វាយដល់ខ្ញុំ!

នៅវេលាដ៏ស្រស់ត្រកាលនេះ គឺនៅវេលាដ៏រំភើបរីករាយនេះ

ការសរសើរតម្កើងក៏បន្លឺឡើងនៅគ្រប់ទីកន្លែង ទាំងនៅស្ថានសួគ៌ខាងលើ និងផែនដីខាងក្រោម។ តើនរណាដែលមិនរំភើបចំពោះរឿងនេះ?

តើដួងចិត្តរបស់នរណាដែលមិនធូរស្រាល? តើនរណាដែលមិនសម្រក់ទឹកភ្នែកពេលឃើញនូវ ទិដ្ឋភាពនេះ?

ផ្ទៃមេឃមិនមែនជាផ្ទៃមេឃចាស់ទេ ប៉ុន្តែឥលូវនេះ គឺជាផ្ទៃមេឃនៃនគរព្រះវិញ។

ផែនដីលែងជាផែនដីកាលពីមុនទៀតហើយ ប៉ុន្ដែឥលូវនេះ គឺជាទឹកដីដ៏បរិសុទ្ធវិញ។

ក្រោយភ្លៀងមួយមេធំបានកន្លងទៅ ពិភពលោកចាស់ដ៏ស្មោកគ្រោកក៏បានត្រលប់ជាពិភពលោកថ្មីទាំងស្រុង។

ភ្នំនានាកំពុងផ្លាស់ប្ដូរ ... ទឹកក៏កំពុងផ្លាស់ប្ដូរ ...

មនុស្សក៏កំពុងផ្លាស់ប្ដូរដែរ ... គឺអ្វីៗទាំងអស់កំពុងផ្លាស់ប្ដូរ...។

ឱភ្នំដ៏ស្ងាត់ជ្រងំអើយ! ចូរក្រោកឡើង ហើយរាំថ្វាយខ្ញុំ!

ឱទឹកដ៏នឹងថ្កល់អើយ! ចូរបន្ដហូរដោយសេរីចុះ!

អ្នករាល់គ្នាជាមនុស្សដែលកំពុងសុបិនអើយ! ចូរក្រោកឡើង ហើយដេញតាមក្ដីសុបិនទាំងនោះចុះ!

ខ្ញុំយាងមកហើយ ... ខ្ញុំគឺជាមហាក្សត្រ...។

មនុស្សជាតិទាំងអស់នឹងឃើញព្រះភ័ក្ត្ររបស់ខ្ញុំដោយភ្នែករបស់ពួកគេផ្ទាល់ ពួកគេ

នឹងស្ដាប់ឮព្រះសូរសៀងរបស់ខ្ញុំដោយត្រចៀករបស់ពួកគេផ្ទាល់
ហើយនឹងរស់ក្នុងជីវិតនៃនគរព្រះ សម្រាប់ខ្លួនឯង...។
ពិតជាផ្អែមល្ហែមណាស់ ... ពិតជាស្រស់ស្អាតណាស់...។
បំភ្លេចមិនបានទេ ... មិនអាចបំភ្លេចបានទេ...។

ក្នុងកំសួលនៃសេចក្ដីក្រោធរបស់ខ្ញុំ នាគដ៏ធំមានសម្បុរក្រហមជាប់គាំង។
អារក្សក៏បង្ហាញរូបពិតរបស់វានៅក្នុងការជំនុំជម្រះដ៏មានឫទ្ធានុភាពរបស់ខ្ញុំ។
មនុស្សទាំងអស់មានអារម្មណ៍ខ្មាស ពេលឮព្រះបន្ទូលដ៏ប្រឹតប្រៀនរបស់ខ្ញុំ និងគ្មានកន្លែងណាលាក់ខ្លួនឡើយ។
ពួកគេនឹកឃើញអតីតកាល នឹកឃើញពីរបៀបដែលពួកគេបានចំអក និងបានមើលងាយខ្ញុំ។
គ្មានពេលណាដែលពួកគេមិនបានសម្ដែងខ្លួនឯងឡើយ ហើយគ្មានពេលណាដែលពួកគេមិនបានបំពានលើខ្ញុំឡើយ។
ថ្ងៃនេះ តើនរណាមិនស្រក់ទឹកភ្នែក? តើនរណាមិនមានអារម្មណ៍ស្ដាយក្រោយ?
ពិភពចក្រវាឡទាំងមូលពោរពេញដោយទំនួញសោក ...
ពេញដោយសម្លេងត្រេកអរ ... និងសម្លេងសើចក្អាកក្អាយ...។
ឱក្ដីអំណរដែលគ្មានអ្វីប្រៀបបាន ... ឱក្ដីអំណរដែលគ្មានអ្វីប្រៀបស្មើ...។

ភ្លៀងកំពុងរលឹមតិចៗ ... ព្រិលក៏កំពុងធ្លាក់មកទាំងដុំៗយ៉ាងក្រាស់...។
នៅក្នុងខ្លួនមនុស្ស ទុក្ខព្រួយ និងអំណរ កំពុងលាយឡំគ្នា ... អ្នកខ្លះកំពុងសើចក្អាកក្អាយ ...
អ្នកខ្លះកំពុងយំខ្សឹកខ្សួល ... ហើយអ្នកខ្លះទៀតកំពុងអបអរ...។
មនុស្សគ្រប់គ្នាហាក់ដូចជាភ្លេចហើយថា ... នេះគឺជារដូវផ្ការីកដែលសម្បូរទឹកភ្លៀង និងពពក

ជារដូវក្ដៅដែលសម្បូរផ្ការីក ជាសរទរដូវដែលប្រមូលផលបានច្រើន

ឬជារដូវលំហើយដែលត្រជាក់ដូចជាកំណកសន្សើម និងទឹកកក គ្មាននរណាម្នាក់ដឹងឡើយ...។

នៅលើមេឃ ពពកកំពុងរសាត់ ហើយនៅលើផែនដី មហាសមុទ្រឡើងកករ។

ពួកកូនប្រុសគ្រវីដៃរបស់ពួកគេ ... បណ្ដាជនក៏កម្រើកជើងរបស់ខ្លួនរាំ...។

ទេវតាកំពុងធ្វើការ ... ទេវតាកំពុងឃ្វាលចៀម...។

មនុស្សនៅលើផែនដីទាំងអស់ញាប់ដៃញាប់ជើង ហើយអ្វីៗទាំងអស់នៅលើផែនដីក៏ពហុគុណឡើងដែរ។

# ជំពូកទី ១២៖ ព្រះបន្ទូលព្រះជាម្ចាស់ ថ្លែងទៅកាន់សកលលោកទាំងមូល

នៅពេលដែលពន្លឺចេញពីទិសខាងកើត ក៏ជាពេលវេលាដ៏ប្រាកដដែលខ្ញុំចាប់ផ្ដើមបញ្ចេញព្រះសូរសៀងរបស់ខ្ញុំផងដែរ។ នៅពេលដែលផ្លេកបន្ទោរបញ្ចេញពន្លឺ នោះសាកលលោកទាំងមូលនឹងត្រូវបំភ្លឺ ហើយការផ្លាស់ប្ដូរកើតឡើងនៅក្នុងគ្រប់តារានិករទាំងអស់។ ពូជសាសន៍មនុស្សទាំងមូល ប្រៀបដូចជាត្រូវបានរើសចេញអ៊ីចឹង។ នៅក្រោមរស្មីដែលរះមកពីទិសខាងកើត មនុស្សជាតិទាំងអស់ត្រូវបានបើកសម្ដែងនៅក្នុងសណ្ឋានដើមរបស់ពួកគេ ភ្នែករបស់ពួកគេស្រវាំងមិនដឹងថាត្រូវធ្វើអ្វីនោះទេ ហើយក៏មិនដឹងវិធី ដើម្បីលាក់បាំងសណ្ឋានដ៏កខ្វក់របស់ពួកគេនោះដែរ។ ពួកគេក៏ដូចទៅនឹងសត្វដែលរួចពីពន្លឺរបស់ខ្ញុំ ហើយជ្រកនៅក្នុងល្អាងភ្នំ ប៉ុន្តែគ្មាននរណាម្នាក់ក្នុងចំណោមពួកគេ អាចលាក់ខ្លួននៅក្នុងពន្លឺរបស់ខ្ញុំបានឡើយ។ មនុស្សទាំងអស់វង្វេងស្មារតី ដោយគ្រប់គ្នាកំពុងរង់ចាំ គ្រប់គ្នាកំពុងសម្លឹងមើល។ ជាមួយនឹងការមកដល់នៃពន្លឺរបស់ខ្ញុំ គ្រប់គ្នារីករាយនៅថ្ងៃកំណើតរបស់ពួកគេ ព្រមជាមួយគ្នានេះគ្រប់គ្នាក៏ដាក់បណ្ដាសាចំពោះថ្ងៃកំណើតរបស់ពួកគេដែរ។ អារម្មណ៍ច្របូកច្របល់

គឺមិនអាចបញ្ចេញបានទេ។ ទឹកភ្នែកនៃការធ្វើទណ្ឌកម្មខ្លួន បានបង្កើតទៅជាទន្លេ ហើយបានហូរទៅក្នុងទឹកភ្លៀងដែលកំពុងធ្លាក់ដោយបាត់ខ្លួនមួយរំពេច គ្មានស្នាមដាននោះទេ។ ជាថ្មីម្ដងទៀត ថ្ងៃរបស់ខ្ញុំកាន់តែចូលមកកៀកនឹងមនុស្សទាំងអស់ ដោយដាស់ពូជសាសន៍មនុស្សម្ដងទៀត ហើយប្រទានការចាប់ផ្ដើមថ្មីមួយផ្សេងទៀតដល់មនុស្សជាតិ។ បេះដូងរបស់ខ្ញុំលោត ហើយភ្នំទាំងឡាយលោតកញ្ឆេង ទឹករាំដោយរីករាយ ហើយរលកទឹកបក់ផ្ទប់នឹងផ្ទាំងថ្ម ទៅតាមចង្វាក់បេះដូងរបស់ខ្ញុំ។ វាពិបាកនឹងថ្លែងពីអ្វីដែលមាននៅក្នុងព្រះហឫទ័យរបស់ខ្ញុំណាស់។ ខ្ញុំចង់ធ្វើឲ្យរបស់គ្រប់យ៉ាងដែលកខ្វក់ ឆេះទៅជាផេះដោយការសម្លឹងរបស់ខ្ញុំ។ ខ្ញុំចង់ធ្វើឲ្យបុត្រនៃការមិនស្ដាប់បង្គាប់វិនាសចេញពីមុខព្រះនេត្ររបស់ខ្ញុំ ដោយមិនឲ្យមាននៅតទៅទៀតទេ។ ខ្ញុំមិនត្រឹមតែបង្កើតការចាប់ផ្ដើមថ្មីមួយនៅក្នុងកន្លែងដែលនាគដ៏ធំមានសម្បុរក្រហមរស់នៅនោះទេ ខ្ញុំថែមទាំងចាប់ផ្ដើមកិច្ចការថ្មីនៅលើសាកលលោកផងដែរ។ មិនយូរនោះទេ នគរនានានៃផែនដីនេះនឹងក្លាយជានគររបស់ខ្ញុំ។ មិនយូរនោះទេ នរគរនានានៃផែនដីនេះនឹងបាត់បង់ជារៀងរហូតព្រោះតែនគររបស់ខ្ញុំ ដោយសារតែខ្ញុំបានទទួលជ័យជម្នះរួចទៅហើយ ហើយដោយសារតែខ្ញុំបានត្រឡប់មកវិញដោយជ័យជម្នះ។ នាគដ៏ធំមានសម្បុរក្រហម ហត់នឿយក្នុងការប្រើមធ្យោបាយបោកប្រាស់ដើម្បីរំខានដល់ផែនការរបស់ខ្ញុំ ដោយរំពឹងថានឹងលុបបំបាត់កិច្ចការរបស់ខ្ញុំនៅលើផែនដី ប៉ុន្តែតើខ្ញុំអាចបាក់ទឹកចិត្តដោយសារតែយុទ្ធសាស្ត្របោកប្រាស់របស់វាឬទេ? តើខ្ញុំអាចភ័យខ្លាច រហូតដល់បាត់បង់ភាពជឿជាក់ដោយសារតែការគំរាមកំហែងរបស់វាឬទេ? មិនដែលមានភារៈណាមួយទាំងនៅលើស្ថានសួគ៌ ទាំងនៅលើផែនដី ដែលខ្ញុំមិនបានក្ដាប់នៅក្នុងបាតព្រះហស្តរបស់ខ្ញុំឡើយ។ តើពិតប៉ុនណាទៅ ដែលនាគដ៏ធំមានសម្បុរក្រហមប្រើស្នៀតនេះដើម្បីគ្រឿងបន្ទាប់បន្សំចំពោះខ្ញុំ? តើវាមិនមែនជាវត្ថុមួយដែលព្រះហស្តរបស់ខ្ញុំគ្រប់គ្រងទេឬអី?

អំឡុងពេល នៃការយកកំណើតជាមនុស្សរបស់ខ្ញុំនៅក្នុងពិភពមនុស្ស ក្រោមការដឹកនាំរបស់ខ្ញុំ នោះមនុស្សជាតិបានមកដល់ថ្ងៃនេះដោយមិនដឹងខ្លួន ហើយបាន

ស្គាល់ខ្ញុំដោយមិនដឹងខ្លួន។ ប៉ុន្តែ សម្រាប់វិធីដែលត្រូវដើរនៅលើផ្លូវដែលនៅខាងមុខ គ្មាននរណាម្នាក់មានតម្រុយ គ្មាននរណាម្នាក់ដឹង ហើយជាងនេះទៅទៀត គ្មាននរណាម្នាក់មានសញ្ញាដែលអាចប្រាប់ពីទិសដៅដែលពួកគេដើរនៅលើផ្លូវនោះទេ។ មានតែតាមរយៈព្រះដ៏មានគ្រប់ព្រះចេស្ដាដែលកំពុងឃ្លាំមើលពួកគេប៉ុណ្ណោះ ទើបមនុស្សម្នាក់អាចដើរនៅលើផ្លូវរហូតដល់ទីបញ្ចប់បាន។ មានតែតាមរយៈការដឹកនាំរបស់ផ្លេកបន្ទោរនៅទិសខាងកើតប៉ុណ្ណោះ ទើបមនុស្សនឹងអាចឆ្លងកាត់ទ្វារដែលនាំទៅរកនគររបស់ខ្ញុំបាន។ នៅក្នុងចំណោមមនុស្ស ដែលបានឃើញផ្លេកបន្ទោរនៅទិសខាងកើត មិនដែលមាននរណាម្នាក់បានឃើញព្រះភ័ក្ត្ររបស់ខ្ញុំនោះទេ។ តើអ្នកដែលបានឮព្រះសូរសៀងចេញពីបល្ល័ង្ករបស់ខ្ញុំតិចប៉ុនណា? តាមពិត តាំងពីសម័យបុរាណ គ្មានមនុស្សណាម្នាក់បានចូលមកទាក់ទងដោយផ្ទាល់ជាមួយរាងកាយរបស់ខ្ញុំនោះទេ។ មានតែបច្ចុប្បន្ននេះ ពេលនេះ ដែលខ្ញុំបានយាងមកក្នុងពិភពលោកទេ ទើបមនុស្សមានឱកាសបានឃើញខ្ញុំ។ ប៉ុន្តែទោះបីជាពេលនេះក៏ដោយ មនុស្សនៅតែមិនស្គាល់ខ្ញុំ គេបានត្រឹមតែសម្លឹងមើលព្រះភ័ក្ត្ររបស់ខ្ញុំ ហើយគេគ្រាន់តែឮព្រះសូរសៀងរបស់ខ្ញុំប៉ុណ្ណោះ ប៉ុន្តែគេមិនយល់ពីអត្ថន័យរបស់ខ្ញុំនោះទេ។ មនុស្សទាំងអស់គឺបែបនេះ។ ក្លាយជាមនុស្សម្នាក់ក្នុងចំណោមរាស្ត្ររបស់ខ្ញុំ តើអ្នករាល់គ្នាមិនមានមោទនភាពខ្លាំងទេឬ នៅពេលដែលអ្នកឃើញព្រះភ័ក្ត្ររបស់ខ្ញុំ? ហើយតើអ្នកមិនមានអារម្មណ៍អៀនខ្មាស ដោយសារតែអ្នកមិនស្គាល់ខ្ញុំទេឬអី? ខ្ញុំយាងនៅក្នុងចំណោមមនុស្ស ហើយខ្ញុំរស់នៅក្នុងចំណោមមនុស្ស ដោយសារខ្ញុំបានក្លាយជាសាច់ឈាម ហើយខ្ញុំបានយាងចុះមកពិភពរបស់មនុស្ស។ គោលបំណងរបស់ខ្ញុំ មិនមែនគ្រាន់តែធ្វើឲ្យមនុស្សអាចមើលសាច់ឈាមរបស់ខ្ញុំនោះទេ សំខាន់ជាងនេះ គឺដើម្បីឲ្យមនុស្សស្គាល់ខ្ញុំ។ ជាងនេះទៅទៀត តាមរយៈសាច់ឈាមជាមនុស្សរបស់ខ្ញុំ នោះខ្ញុំនឹងកាត់ទោសមនុស្សដោយសារបាបរបស់ពួកគេ។ តាមរយៈសាច់ឈាមជាមនុស្សរបស់ខ្ញុំ ខ្ញុំនឹងយកឈ្នះនាគដ៏ធំមានសម្បុរក្រហម ហើយបំផ្លាញជម្រករបស់វាឲ្យវិនាសសាបសូន្យ។

ទោះបីជាមនុស្សដែលរស់នៅលើផែនដី មានចំនួនច្រើនដូចជាផ្កាយក៏ដោយ ខ្ញុំស្គាល់ពួកគេទាំងអស់ច្បាស់ដូចបាតដៃរបស់ខ្ញុំដែរ។ ហើយទោះបីជាមនុស្សដែល «ស្រឡាញ់» ខ្ញុំ ច្រើនដូចជាខ្សាច់នៅក្នុងសមុទ្រក៏ដោយ ក៏មានតែមួយចំនួនប៉ុណ្ណោះដែលខ្ញុំជ្រើសរើស៖ មានតែអស់អ្នកដែលតាមរកពន្លឺដ៏ភ្លឺប៉ុណ្ណោះ ដោយមិនរាប់បញ្ចូលនឹងអស់អ្នកដែល «ស្រឡាញ់» ខ្ញុំនោះទេ។ ខ្ញុំមិនប៉ាន់ប្រមាណមនុស្សលើស ហើយខ្ញុំក៏មិនប៉ាន់ប្រមាណមនុស្សមិនដល់នោះដែរ។ ផ្ទុយទៅវិញ ខ្ញុំទាមទារពីមនុស្សដោយផ្អែកទៅលើបុគ្គលិកលក្ខណៈពីធម្មជាតិរបស់គេ ដូច្នេះ អ្វីដែលខ្ញុំត្រូវការគឺប្រភេទមនុស្សដែលស្វែងរកខ្ញុំដោយស្មោះអស់ពីចិត្ត ដែលខ្ញុំអាចសម្រេចគោលដៅរបស់ខ្ញុំក្នុងការជ្រើសរើសមនុស្សបាន។ មានសត្វព្រៃដ៏សាហាវជាច្រើនរាប់មិនអស់នៅលើភ្នំ ប៉ុន្តែនៅចំពោះព្រះភ័ក្ត្ររបស់ខ្ញុំពួកវាទាំងអស់ស្លូតដូចសត្វចៀម។ មានអាថ៌កំបាំងរាប់មិនអស់នៅក្រោមរលកទឹក ប៉ុន្តែពួកវាបង្ហាញខ្លួនរបស់វាដល់ខ្ញុំយ៉ាងច្បាស់ ដូចរបស់សព្វសារពើដែលមាននៅលើផែនដីដែរ។ នៅស្ថានសួគ៌ខាងលើ គឺជានគរដែលមនុស្សមិនអាចទៅដល់បាន ប៉ុន្តែខ្ញុំយាងនៅលើនគរដែលមិនអាចចូលទៅដល់ទាំងនោះបានដោយសេរី។ មនុស្សមិនដែលស្គាល់ខ្ញុំនៅក្នុងពន្លឺនោះទេ ប៉ុន្តែគេត្រឹមតែមើលឃើញខ្ញុំនៅពិភពនៃភាពងងឹតប៉ុណ្ណោះ។ តើសព្វថ្ងៃនេះអ្នករាល់គ្នាមិនស្ថិតក្នុងស្ថានភាពដូចនេះទេឬ? វាគឺជាពេលដែលការប្រព្រឹត្តរបស់នាគដ៏ធំមានសម្បុរក្រហមកំពុងមានកម្រោលខ្លាំងបំផុត ដែលខ្ញុំប្រើប្រាស់សាច់ឈាមដើម្បីធ្វើកិច្ចការរបស់ខ្ញុំ។ នៅពេលដែលនាគដ៏ធំមានសម្បុរក្រហមបង្ហាញសណ្ឋានពិតរបស់វាជាលើកដំបូង នោះខ្ញុំនាំទីបន្ទាល់ទៅកាន់ព្រះនាមរបស់ខ្ញុំ។ នៅពេលដែលខ្ញុំបានយាងនៅតាមផ្លូវរបស់មនុស្ស គ្មានភាវៈណាមួយ ឬមនុស្សណាម្នាក់បានភ្ញាក់ដឹងខ្លួននោះទេ ដូច្នេះហើយ នៅពេលដែលខ្ញុំយាងមកយកកំណើតជាមនុស្សនៅក្នុងពិភពមនុស្ស នោះគ្មាននរណាម្នាក់ដឹងនោះទេ។ ប៉ុន្តែនៅពេលខ្ញុំចាប់ផ្តើមធ្វើកិច្ចការរបស់ខ្ញុំនៅក្នុងសាច់ឈាមជាមនុស្សរបស់ខ្ញុំនោះ មនុស្សដឹងខ្លួន ហើយភ្ញាក់ពីការយល់សប្តិរបស់ពួកគេ ដោយព្រះសូរសៀងដែលឮដូចផ្គរលាន់បន្ទោររបស់ខ្ញុំ ហើយចាប់ពី

ពេលនេះ ពួកគេចាប់ផ្ដើមជីវិតរបស់ពួកគេនៅក្រោមការដឹកនាំរបស់ខ្ញុំ។ ក្នុងចំណោមរាស្ត្ររបស់ខ្ញុំ ខ្ញុំបានចាប់ផ្ដើមកិច្ចការថ្មីម្ដងទៀត។ តាមរយៈការនិយាយថា កិច្ចការរបស់ខ្ញុំនៅលើផែនដីមិនទាន់បញ្ចប់ គឺគ្រប់គ្រាន់ដើម្បីបង្ហាញថា រាស្ត្ររបស់ខ្ញុំដែលខ្ញុំបានមានព្រះបន្ទូលជាមួយ មិនមែនជាអស់អ្នកដែលខ្ញុំត្រូវការនៅក្នុងព្រះហឫទ័យរបស់ខ្ញុំនោះទេ ទោះបីជាយ៉ាងណាក៏ដោយ ខ្ញុំនៅតែជ្រើសរើសមួយចំនួនចេញពីពួកគេ។ ដោយសារភស្ដុតាងនេះ វាបញ្ជាក់យ៉ាងច្បាស់ថា ខ្ញុំមិនត្រឹមតែធ្វើឲ្យរាស្ត្ររបស់ខ្ញុំស្គាល់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សនោះទេ ខ្ញុំថែមទាំងលាងជម្រះពួកគេថែមទៀតផង។ ដោយសារតែភាពតឹងរឹងនៃបញ្ញត្តិរដ្ឋបាលរបស់ខ្ញុំ ទើបមនុស្សច្រើនណាស់នៅតែស្ថិតនៅក្នុងគ្រោះថ្នាក់នៃការដែលកំពុងត្រូវបានខ្ញុំផាត់ចោល។ លុះត្រាតែអ្នកព្យាយាមប្រឹងប្រែងដើម្បីដោះស្រាយបញ្ហាជាមួយខ្លួនឯង និងយកឈ្នះខ្លួនឯង។ លុះត្រាតែអ្នកធ្វើបែបនេះ បើមិនដូច្នោះទេ អ្នកនឹងប្រាកដជាក្លាយជាវត្ថុមួយដែលខ្ញុំស្អប់ និងបដិសេធ ដោយត្រូវបោះចូលទៅក្នុងស្ថាននរក ដែលជាកន្លែងមិនអាចរត់គេចបាន ដូចជាប៉ុលបានទទួលការវាយផ្ចាលដោយផ្ទាល់ពីព្រះហស្តរបស់ខ្ញុំអ៊ីចឹង។ តើអ្នករាល់គ្នារើសបានអ្វីពីព្រះបន្ទូលរបស់ខ្ញុំឬទេ? ដូចពីមុនអ៊ីចឹង វាគឺជាបំណងព្រះហឫទ័យរបស់ខ្ញុំដើម្បីលាងសម្អាតក្រុមជំនុំ ដើម្បីបន្តធ្វើការបន្សុទ្ធមនុស្សដែលខ្ញុំត្រូវការ ដោយសារខ្ញុំគឺជាព្រះជាម្ចាស់ ដែលស្អាត និងបរិសុទ្ធគ្រប់យ៉ាង។ ខ្ញុំនឹងធ្វើវិហាររបស់ខ្ញុំដោយមិនត្រឹមតែភ្លឺផ្លេកៗដោយពណ៌ឥន្ទធនូនោះទេ ថែមទាំងនៅផ្នែកខាងក្នុងស្អាតគ្មានស្នាមបន្ដិចឡើយ ដើម្បីឲ្យស៊ីនឹងផ្នែកខាងក្រៅ។ នៅក្នុងវត្តមានរបស់ខ្ញុំ អ្នករាល់គ្នាទាំងអស់ គួរតែគិតឡើងវិញអំពីអ្វីដែលអ្នកបានធ្វើនៅក្នុងអតីតកាល ហើយសម្រេចចិត្តថាតើសព្វថ្ងៃនេះ អ្នកអាចសម្រេចចិត្តថ្វាយសេចក្ដីពេញចិត្តដ៏ល្អឥតខ្ចោះនៅក្នុងព្រះហឫទ័យរបស់ខ្ញុំបានដែរឬទេ?

មនុស្សមិនគ្រាន់តែមិនស្គាល់ខ្ញុំនៅក្នុងសាច់ឈាមរបស់ខ្ញុំនោះទេ លើសពីនេះគេបរាជ័យក្នុងការយល់ខ្លួនឯង ដែលរស់នៅក្នុងរាងកាយបែបសាច់ឈាម។ អស់រយៈពេលជាច្រើនឆ្នាំ មនុស្សបាននិងកំពុងបោកបញ្ឆោតខ្ញុំ ដោយប្រព្រឹត្តចំពោះខ្ញុំ

ដូចជាភ្ញៀវម្នាក់មកពីក្រៅ។ ជាច្រើនលើកច្រើនសារណាស់ ពួកគេបានបិទទ្វារដោយទុកខ្ញុំនៅខាងក្រៅ «ទ្វារចូលទៅកាន់ផ្ទះរបស់គេ»។ ជាច្រើនលើកច្រើនសារណាស់ ដោយឈរនៅចំពោះព្រះភ័ក្ត្ររបស់ខ្ញុំ ពួកគេមិនបានគោរពខ្ញុំនោះទេ។ ជាច្រើនលើកច្រើនសារណាស់ ពួកគេបានបដិសេធមិនទទួលស្គាល់ខ្ញុំនៅក្នុងចំណោមមនុស្សដទៃទៀត។ ជាច្រើនលើកច្រើនសារណាស់ ពួកគេបានបដិសេធខ្ញុំនៅចំពោះមុខអារក្ស ហើយជាច្រើនលើកច្រើនសារណាស់ ពួកគេវាយប្រហារខ្ញុំ ដោយមាត់ដ៏បេះបួយរបស់ពួកគេ។ ទោះបីជាយ៉ាងណា ខ្ញុំមិនយកចិត្តទុកដាក់ចំពោះភាពទន់ខ្សោយរបស់មនុស្សនោះទេ ហើយខ្ញុំក៏មិនសួរដេញដោល ដោយសារតែការមិនស្ដាប់បង្គាប់របស់គេនោះដែរ។ គ្រប់យ៉ាងដែលខ្ញុំបានធ្វើ គឺប្រើថ្នាំចំពោះជំងឺរបស់គេ ដើម្បីព្យាបាលជំងឺរបស់គេដែលមិនអាចព្យាបាលបាន ដោយហេតុនោះ ទើបអាចធ្វើឲ្យគេទទួលបានសុខភាពឡើងវិញ ហើយទើបគេអាចស្គាល់ខ្ញុំបាន។ តើគ្រប់យ៉ាងដែលខ្ញុំបានធ្វើ មិនមែនដើម្បីផលប្រយោជន៍នៃការរស់រានមានជីវិតរបស់មនុស្ស និងមិនមែនដើម្បីផលប្រយោជន៍នៃការប្រទានឱកាសមួយក្នុងជីវិត ដល់មនុស្ស ទេឬអី? ជាច្រើនលើកច្រើនសារ ដែលខ្ញុំបានយាងមកកាន់ពិភពរបស់មនុស្ស ប៉ុន្ដែដោយសារតែខ្ញុំបានមកក្នុងទម្រង់ជាមនុស្សរបស់ខ្ញុំនៅលើផែនដី ទើបមនុស្សមិនបានយកចិត្តទុកដាក់ណាមួយចំពោះខ្ញុំនោះទេ។ ផ្ទុយទៅវិញ ម្នាក់ៗបានធ្វើសកម្មភាពទៅតាមអ្វីដែលគេគិតថាសមគួរ ហើយស្វែងរកច្រកចេញសម្រាប់ខ្លួនឯង។ ពួកគេដឹងតិចតួច ថាគ្រប់ផ្លូវនីមួយៗនៅខាងក្រោមស្ថានសួគ៌ គឺត្រូវស្ថិតនៅក្រោមការរៀបចំរបស់ខ្ញុំ! តើនរណាម្នាក់ក្នុងចំណោមអ្នករាល់គ្នា ហ៊ានទទួលយកការមិនសប្បាយចិត្តដាក់ក្នុងចិត្តរបស់ពួកគេនោះ? តើនរណាម្នាក់ក្នុងចំណោមអ្នកហ៊ានតែបន្ដិច ដើម្បីធ្វើឈានដល់កិច្ចព្រមព្រៀងមួយនោះ? ខ្ញុំគ្រាន់តែបាននិងកំពុងតែធ្វើកិច្ចការរបស់ខ្ញុំយ៉ាងស្ងាត់ស្ងៀមនៅក្នុងចំណោមមនុស្សប៉ុណ្ណោះ គឺតែប៉ុណ្ណឹងទេ។ ក្នុងអំឡុងពេលនៃការយកកំណើតជាមនុស្សរបស់ខ្ញុំ ប្រសិនបើខ្ញុំមិនបានអាណិតអាសូរចំពោះភាពទន់ខ្សោយរបស់មនុស្សនោះទេ នោះមនុស្សទាំងអស់នឹងភ័យខ្លាចលោះព្រលឹង ដោយសារតែការ

យកកំណើតជាមនុស្សរបស់ខ្ញុំ តែមួយមុខប៉ុណ្ណោះ។ ជាលទ្ធផល គេធ្លាក់ទៅក្នុងស្ថានឃុំព្រលឹង។ គឺដោយសារតែខ្ញុំបានបន្ទាបខ្លួន ហើយបានលាក់ខ្លួនប៉ុណ្ណោះ ទើបមនុស្សបានរត់គេចចេញពីមហន្តរាយ បានជួបការសង្គ្រោះពីការវាយផ្ចាលរបស់ខ្ញុំ ហើយដោយវិធីនេះ ទើបមនុស្សបានធ្វើដំណើរមកដល់សព្វថ្ងៃនេះ។ ដោយពិចារណាដល់ការលំបាកទម្រាំតែធ្វើដំណើរមកដល់សព្វថ្ងៃនោះ តើអ្នករាល់គ្នាមិនគួរស្រឡាញ់របស់ទាំងអស់នៅថ្ងៃស្អែកដែលនៅតែមកទៀត បានយ៉ាងដូចម្ដេច?

ថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩២

## ចូរអររសប្បាយ ម្នាលជនទាំងឡាយអើយ!

នៅក្នុងពន្លឺរបស់ខ្ញុំ មនុស្សមើលឃើញពន្លឺម្ដងទៀត។ នៅក្នុងព្រះបន្ទូលរបស់ខ្ញុំ មនុស្សស្វែងរកអ្វីៗដែលពួកគេរីករាយ។ ខ្ញុំបានយាងមកពីទិសខាងកើត ខ្ញុំចេញមកពីទិសខាងកើត។ នៅពេលដែលសិរីល្អរបស់ខ្ញុំបញ្ចេញពន្លឺឡើង នោះជាតិសាសន៍ទាំងអស់ត្រូវបានបំភ្លឺ គ្រប់យ៉ាងត្រូវបាននាំមកនៅក្នុងពន្លឺ មិនមែនអ្វីមួយនៅក្នុងភាពងងឹតឡើយ។ នៅក្នុងនគរព្រះ ជីវិតដែលរាស្ត្ររបស់ព្រះជាម្ចាស់រស់នៅជាមួយព្រះជាម្ចាស់ គឺមានសេចក្ដីសុខមិនអាចវាស់ស្ទង់បាន។ ទឹករាំដោយអំណរក្នុងជីវិតដ៏មានព្រះពររបស់មនុស្ស ភ្នំរីករាយជាមួយមនុស្សដែលជាភាពបរិបូរណ៍របស់ខ្ញុំ។ មនុស្សទាំងអស់តស៊ូ ធ្វើការយ៉ាងប្រឹងប្រែង ដោយបង្ហាញភក្ដីភាពរបស់ពួកគេនៅក្នុងនគររបស់ខ្ញុំ។ នៅក្នុងនគរព្រះ ការបះបោរលែងមានតទៅទៀតហើយ ការទាស់ទទឹងក៏លែងមានទៀតដែរ។ ស្ថានសួគ៌ និងផែនដីពឹងអាស្រ័យគ្នាទៅវិញទៅមក ខ្ញុំនិងមនុស្សចូលមកជិតគ្នាដោយអារម្មណ៍ដ៏ជ្រាលជ្រៅ ដោយផ្អែកខ្នងដាក់គ្នា តាមរយៈសុភមង្គលដ៏ផ្អែមល្ហែមរបស់ជីវិត...។ នៅពេលនេះ ខ្ញុំចាប់ផ្ដើមជីវិតរបស់ខ្ញុំនៅស្ថានសួគ៌ជាផ្លូវការ។ ការរំខានរបស់សាតាំងលែងមានតទៅទៀត ហើយមនុស្សចូលទៅក្នុងទីសម្រាក។ ទូទាំងសាកលលោកទាំងមូល រាស្ត្ររើសតាំងរបស់ខ្ញុំរស់នៅក្នុងសិរីល្អ

របស់ខ្ញុំ ដោយទទួលព្រះពរមិនអាចប្រៀបផ្ទឹមបាន មិនដូចជាមនុស្សដែលរស់នៅក្នុងចំណោមមនុស្សនោះទេ ប៉ុន្តែជាមនុស្សដែលរស់នៅជាមួយព្រះជាម្ចាស់។ មនុស្សទាំងអស់បានឆ្លងកាត់សេចក្ដីពុករលួយរបស់សាតាំង ហើយបានផឹកភាពល្វីងជូរចត់ និងភាពផ្អែមល្ហែមនៃជីវិតរហូតទាល់តែអស់។ ពេលនេះ តើបុគ្គលម្នាក់អាចមិនអរសប្បាយក្នុងការរស់នៅក្នុងពន្លឺរបស់ខ្ញុំ បានយ៉ាងដូចម្ដេចកើត? តើបុគ្គលម្នាក់អាចរំលងពេលវេលាដ៏ស្រស់បំព្រងនេះ ហើយបណ្ដោយឲ្យវាកន្លងទៅបានយ៉ាងដូចម្ដេចកើត? ម្នាលបណ្ដាជនទាំងឡាយអើយ! ចូរច្រៀងចម្រៀងនៅក្នុងចិត្តរបស់អ្នក ហើយរាំដោយក្ដីអំណរដើម្បីខ្ញុំ! ចូរលើកចិត្តដ៏ស្មោះស្ម័គ្ររបស់អ្នកឡើង ហើយថ្វាយវាមកខ្ញុំ! ចូរទូងស្គររបស់អ្នក ហើយលេងយ៉ាងរីករាយដើម្បីខ្ញុំ! ខ្ញុំបញ្ចេញសេចក្ដីអំណររបស់ខ្ញុំទៅទូទាំងសាកលលោកទាំងមូល! ខ្ញុំបើកសម្ដែងព្រះភ័ក្ត្រដ៏រុងរឿងរបស់ខ្ញុំចំពោះមនុស្ស! ខ្ញុំនឹងស្រែកដោយសម្លេងយ៉ាងឮ! ខ្ញុំនឹងទៅហួសពីសាកលលោក! ខ្ញុំសោយរាជ្យនៅក្នុងមនុស្សរួចហើយ! ខ្ញុំត្រូវបានមនុស្សលើកតម្កើង! ខ្ញុំរសាត់នៅក្នុងផ្ទៃមេឃពណ៌ខៀវនៅខាងលើ ហើយមនុស្សដើរជាមួយខ្ញុំ។ ខ្ញុំយាងក្នុងចំណោមមនុស្ស ហើយរាស្ត្ររបស់ខ្ញុំនៅជុំវិញខ្ញុំ! ចិត្តរបស់មនុស្សសប្បាយរីករាយ ចម្រៀងរបស់ពួកគេអង្រួនសាកលលោកដោយបន្ទរស្ថានសួគ៌! សាកលលោកលែងគ្របដណ្ដប់ដោយអ័ព្ទទៅទៀតហើយ លែងមានភក់ជ្រាំតទៅទៀត និងលែងមានគំនរសំរាមតទៅទៀត។ ឱមនុស្សបរិសុទ្ធនៃសាកលលោកអើយ! នៅក្រោមការត្រួតពិនិត្យរបស់ខ្ញុំ អ្នកបង្ហាញទឹកមុខពិតរបស់អ្នក។ អ្នកមិនមែនជាមនុស្សដែលគ្រប់ដណ្ដប់ដោយភាពកខ្វក់នោះទេ ប៉ុន្តែជាពួកបរិសុទ្ធដែលបរិសុទ្ធដូចកែវចរណៃ អ្នកទាំងអស់គ្នាជាមនុស្សជាទីស្រឡាញ់របស់ខ្ញុំ អ្នកទាំងអស់គ្នាជាក្ដីអំណររបស់ខ្ញុំ! របស់សព្វសារពើបានត្រឡប់ជាមានជីវិត! ពួកបរិសុទ្ធទាំងអស់បានត្រឡប់មកបម្រើខ្ញុំនៅស្ថានសួគ៌ ដោយចូលទៅក្នុងការឱបក្រសោបដ៏កក់ក្ដៅរបស់ខ្ញុំ លែងយំ លែងព្រួយបារម្ភតទៅទៀតហើយ ដោយថ្វាយខ្លួនចំពោះខ្ញុំ ត្រឡប់មកដំណាក់របស់ខ្ញុំ ហើយនៅក្នុងស្រុកកំណើតរបស់ពួកគេ ពួកគេនឹងស្រឡាញ់ខ្ញុំដោយគ្មានទីបញ្ចប់! ភាពអស់កល្បទាំងអស់មិនដែលផ្លាស់ប្ដូរឡើយ! ឯណាទៅក្ដីទុក្ខ

ព្រួយ! ឯណាទៅទឹកភ្នែក! ឯណាទៅសាច់ឈាម! ផែនដីកន្លងផុតទៅ ប៉ុន្តែស្ថានសួគ៌ស្ថិតនៅអស់កល្បជានិច្ច។ ខ្ញុំលេចមកចំពោះមនុស្សទាំងអស់ ហើយមនុស្សទាំងអស់សរសើរតម្កើងខ្ញុំ។ ជីវិតនេះ ភាពស្រស់បំព្រងនេះ ចាប់ពីពេលដែលមិនអាចបំភ្លេចបាននេះ រហូតដល់ចុងបញ្ចប់ នឹងមិនផ្លាស់ប្ដូរឡើយ។ នេះគឺជាជីវិតនៃនគរព្រះ។

# ជំពូកទី ២៦៖ ព្រះបន្ទូលព្រះជាម្ចាស់ ថ្លែងទៅកាន់សកលលោកទាំងមូល

តើនរណាបានរស់នៅក្នុងដំណាក់របស់ខ្ញុំ? តើនរណាបានក្រោកឈរឡើងដើម្បីខ្ញុំ? តើនរណាបានរងទុក្ខជំនួសខ្ញុំ? តើនរណាបានសន្យាដោយសម្ដីរបស់គេនៅចំពោះខ្ញុំ? តើនរណាបានដើរតាមខ្ញុំមកទល់បច្ចុប្បន្ន ហើយនៅតែមិនទាន់មានចិត្តអើពើ? ហេតុអ្វីក៏មនុស្សទាំងអស់សោះកក្រោះ និងគ្មានមេត្តាបែបនេះ? ហេតុអ្វីបានជាមនុស្សលោកបោះបង់ខ្ញុំ? ហេតុអ្វីបានជាមនុស្សលោកធុញទ្រាន់នឹងខ្ញុំ? ហេតុអ្វីបានជាគ្មានភាពកក់ក្ដៅនៅក្នុងពិភពមនុស្សដូច្នេះ? កាលនៅក្រុងស៊ីយ៉ូន ខ្ញុំបានភ្លក់ភាពកក់ក្ដៅដែលនៅឯស្ថានសួគ៌ ហើយកាលនៅស៊ីយ៉ូន ខ្ញុំបានរីករាយនឹងព្រះពរដែលនៅឯស្ថានសួគ៌។ ខ្ញុំបានរស់នៅក្នុងចំណោមមនុស្សលោកម្ដងទៀត ខ្ញុំបានភ្លក់ភាពល្វីងជូរចត់នៃពិភពលោក ហើយខ្ញុំបានឃើញសភាពខុសៗគ្នាដែលមានក្នុងចំណោមមនុស្សលោក ដោយផ្ទាល់ព្រះនេត្ររបស់ខ្ញុំ។ មនុស្សបានផ្លាស់ប្ដូរទាំងមិនដឹងខ្លួនដូចខ្ញុំបាន «ផ្លាស់ប្ដូរ» ដែរ ហើយមានតែតាមវិធីនេះទេ ទើបគេបានឈានមកដល់បច្ចុប្បន្ន។ ខ្ញុំមិនតម្រូវឲ្យមនុស្សអាចធ្វើអ្វីមួយសម្រាប់ជាប្រយោជន៍ដល់ខ្ញុំទេ ហើយខ្ញុំក៏មិនទាមទារឲ្យគេបង្កើនអ្វីមួយសម្រាប់ខ្ញុំដែរ។ ខ្ញុំគ្រាន់តែចង់ឲ្យគេអាចប្រព្រឹត្តតាមផែនការរបស់ខ្ញុំ មិនមែនមិនស្ដាប់បង្គាប់ខ្ញុំ ឬធ្វើជាសញ្ញាសម្គាល់នៃភាពអាម៉ាស់ដល់ខ្ញុំទេ តែធ្វើជាបន្ទាល់ខ្ទរខ្ទារឲ្យខ្ញុំវិញ។ ក្នុងចំណោមមនុស្សលោក ធ្លាប់មានមនុស្សដែលបានធ្វើបន្ទាល់ពីខ្ញុំ និងបានថ្វាយសិរីរុងរឿងដល់ព្រះនាមរបស់ខ្ញុំ ប៉ុន្តែ

តើការអនុវត្ត ឬ ចរិតមារយាទរបស់មនុស្ស អាចធ្វើឲ្យចិត្តខ្ញុំស្កប់យ៉ាងដូចម្ដេច? តើគេអាចសម្រួបនឹងចិត្តរបស់ខ្ញុំ ឬផ្គាប់ព្រះទ័យរបស់ខ្ញុំបានយ៉ាងដូចម្ដេច? ទាំងភ្នំ និងប្រភពទឹកនានានៅលើផែនដី ព្រមទាំងផ្កា ស្មៅ និងដើមឈើនានានៅលើផែនដីទាំងអស់នេះសុទ្ធតែបង្ហាញពីស្នាព្រះហស្តរបស់ខ្ញុំ គ្រប់យ៉ាងមានវត្តមានសម្រាប់ព្រះនាមរបស់ខ្ញុំ។ ប៉ុន្តែហេតុអ្វីក៏មនុស្សមិនអាចសម្រេចនូវបទដ្ឋាននៃសេចក្ដីបង្គាប់របស់ខ្ញុំបាន? តើនេះអាចមកពីភាពតូចតាចដ៏តោកយ៉ាករបស់គេដែរឬទេ? អាចមកពីការដែលខ្ញុំលើកតម្កើងគេដែរឬទេ? អាចមកពីខ្ញុំឃោរឃៅដាក់គេឬទេ? ហេតុអ្វីបានជាមនុស្សតែងតែភ័យខ្លាចសេចក្ដីបង្គាប់របស់ខ្ញុំ? សព្វថ្ងៃនេះ ក្នុងចំណោមបណ្ដាជនដែលនៅក្នុងនគរព្រះ ហេតុអ្វីបានជាអ្នកស្ដាប់តែសូរសៀងរបស់ខ្ញុំ តែមិនចង់ឃើញព្រះភ័ក្ត្ររបស់ខ្ញុំ? អ្នកសម្លឹងរកតែបន្ទូលរបស់ខ្ញុំដោយមិនផ្ទៀងផ្ទាត់បន្ទូលនោះទៅនឹងវិញ្ញាណរបស់ខ្ញុំ? ហេតុអ្វីក៏អ្នកញែកខ្ញុំទុកនៅឯស្ថានសួគ៌ខាងលើ និងនៅផែនដីខាងក្រោមដូច្នេះ? អាចមកពីកាលដែលខ្ញុំនៅផែនដី មិនដូចដែលខ្ញុំនៅស្ថានសួគ៌ឬ? អាចមកពីកាលនៅស្ថានសួគ៌ ខ្ញុំមិនអាចយាងចុះមកផែនដីឬ? អាចមកពីកាលនៅផែនដី ខ្ញុំមិនសមនឹងលើកឡើងទៅស្ថានសួគ៌ឬ? កាលនៅផែនដី ខ្ញុំដូចជាសត្តនិករដ៏តូចទាប កាលនៅស្ថានសួគ៌ ខ្ញុំប្រៀបដូចជាសភាវៈដែលត្រូវបានលើកតម្កើង ហើយហាក់ដូចជាមានអន្លង់ជ្រៅមួយនៅចន្លោះស្ថានសួគ៌ និងផែនដី ដែលមិនអាចឆ្លងកាត់បាន។ ដោយឡែក នៅក្នុងពិភពមនុស្ស ពួកគេហាក់មិនដឹងអំពីប្រភពដើមនៃរឿងទាំងនេះទេ ប៉ុន្តែពួកគេតែងតែរត់ទាស់នឹងខ្ញុំវិញ បន្ទូលរបស់ខ្ញុំហាក់មានតែសូរសៀង ហើយគ្មានន័យអ្វីឡើយ។ មនុស្សទាំងអស់ចំណាយការប្រឹងប្រែងរបស់គេលើព្រះបន្ទូលរបស់ខ្ញុំ ដោយដាក់ការសង្កេតរបស់គេផ្ទាល់លើអាការៈខាងក្រៅរបស់ខ្ញុំ ប៉ុន្តែពួកគេទាំងអស់គ្នាពើបប្រទះនឹងបរាជ័យ ការខិតខំរបស់គេគ្មានផលផ្លែសោះ ហើយផ្ទុយទៅវិញ ពួកគេត្រូវវាយឲ្យដួលដោយព្រះបន្ទូលរបស់ខ្ញុំ ហើយមិនហ៊ានក្រោកឡើងវិញម្ដងទៀតឡើយ។

ពេលខ្ញុំល្បងលសេចក្ដីជំនឿរបស់មនុស្សលោក គ្មានមនុស្សណាម្នាក់ធ្វើបន្ទាល់

ពិតទេ គ្មានមនុស្សណាម្នាក់អាចថ្វាយគ្រប់យ៉ាងដែលគេមានទេ ផ្ទុយទៅវិញ មនុស្ស នៅបន្តលាក់ខ្លួន ហើយបដិសេធមិនព្រមបើកចំហខ្លួនគេ ធ្វើហាក់ដូចជាខ្ញុំហៀបនឹង បំពានចិត្តរបស់គេអ៊ីចឹង។ សូម្បីតែយ៉ូប ក៏មិនធ្លាប់ឈរមាំនៅក្នុងការល្បងលរបស់ លោកដែរ ក៏មិនបានបញ្ចេញនូវភាពផ្អែមល្ហែម នៅក្នុងគ្រាដែលកំពុងរងទុក្ខលំបាក ដែរ។ មនុស្សទាំងអស់បង្កើតគន្លឹះកម្សោយនៃពណ៌បៃតង នៅក្នុងភាពកក់ក្ដៅនៃ និទាឃរដូវ ពួកគេមិនដែលនៅរក្សាពណ៌បៃតងនៅក្នុងខ្យល់ត្រជាក់នៃរដូវរងាទេ។ មនុស្សមិនអាចសម្រេចចេតនារបស់ខ្ញុំ ដោយប្រើកម្ពស់ដែលមានស្បែកដណ្ដប់ឆ្អឹង របស់គេបានទេ។ ក្នុងចំណោមមនុស្សលោក គ្មាននរណាម្នាក់អាចធ្វើជាគំរូដល់ អ្នកដទៃបានឡើយ ដ្បិតមនុស្សទាំងអស់ជាទូទៅគឺសុទ្ធតែដូចគ្នា និងមិនខុសគ្នានោះ ឡើយ ពួកគេមានលក្ខណៈខុសពីគ្នាតិចតួចណាស់។ ដោយព្រោះមូលហេតុនេះ សូម្បី មនុស្សសព្វថ្ងៃក៏នៅតែមិនអាចស្គាល់កិច្ចការរបស់ខ្ញុំទាំងអស់ដែរ។ លុះត្រាតែពេល ដែលការវាយផ្ចាលរបស់ខ្ញុំធ្លាក់មកលើមនុស្សទាំងអស់ទាំងមិនដឹងខ្លួន ទើបពួកគេ ស្គាល់កិច្ចការរបស់ខ្ញុំ ហើយមនុស្សក៏ចាប់ផ្ដើមធ្វើ បន្ទាល់ពីកិច្ចការរបស់ខ្ញុំដោយ គ្មានទង្វើរបស់ខ្ញុំ ឬបង្ខំនរណាម្នាក់សោះ។ នេះជាផែនការរបស់ខ្ញុំ វាជាចំណុចមួយ នៃកិច្ចការរបស់ខ្ញុំ គឺសម្ដែងចេញមកឲ្យច្បាស់ ហើយវាជាអ្វីដែលមនុស្សគួរតែដឹង។ នៅក្នុងនគរនេះ របស់សព្វសារពើជាច្រើននៃសត្តនិករ ចាប់ផ្ដើមមានជីវិតឡើងវិញ និងទទួលបានអនុភាពជីវិតរបស់គេមកវិញដែរ។ ដោយសារតែការប្រែប្រួលសភាព នៃផែនដី ព្រំដែនរវាងទឹកដីមួយ និងទឹកដីមួយទៀត ក៏ចាប់ផ្ដើមផ្លាស់ប្ដូរ។ ខ្ញុំបាន ថ្លែងទំនាយទុកថា នៅពេលដែនដីផ្ដាច់ចេញពីដែនដី ហើយដែនដីរួមគ្នាជាដែនដី នៅគ្រានោះខ្ញុំនឹងវាយកម្ទេចជាតិសាសន៍ទាំងអស់ឲ្យខ្ទេចខ្ទី។ នៅពេលនេះ ខ្ញុំនឹង ធ្វើឲ្យសត្តនិករទាំងអស់ បានជាថ្មីឡើងវិញ ហើយបែងចែកសកលលោកទាំងមូល ម្ដងទៀត ខ្ញុំធ្វើដូច្នេះ ដោយធ្វើឲ្យសកលលោកនេះមានសណ្ដាប់ធ្នាប់ និងផ្លាស់ប្ដូរអ្វីៗ ដែលចាស់ឲ្យក្លាយជាថ្មីវិញ នេះគឺជាផែនការរបស់ខ្ញុំ ហើយទាំងអស់នេះក៏ជាកិច្ចការ របស់ខ្ញុំដែរ។ នៅពេលជាតិសាសន៍ និងមនុស្សទាំងអស់លើផែនដី ត្រឡប់មកនៅ

ចំពោះបល្ល័ង្ករបស់ខ្ញុំ នោះខ្ញុំនឹងយកភាពសម្បូរសប្បាយនៃស្ថានសួគ៌ ហើយយកមកដាក់នៅលើពិភពរបស់មនុស្ស ដើម្បីឲ្យគេអរព្រះគុណដល់ខ្ញុំ ដែលពិភពលោកនេះបានពេញដោយភាពសម្បូរសប្បាយគ្មានគូរប្រៀប។ តែដរាបណាពិភពលោកចាស់នេះនៅតែបន្តមានវត្តមាន នោះខ្ញុំនឹងជះសេចក្តីក្រោធរបស់ខ្ញុំ មកលើជាតិសាសន៍ទាំងអម្បាលម៉ាន ខ្ញុំនឹងចេញបញ្ញត្តិរដ្ឋបាលរបស់ខ្ញុំពាសពេញសកលលោក ព្រមទាំងធ្វើការវាយផ្ចាលដល់មនុស្សណា ដែលល្មើសនឹងបញ្ញត្តិរដ្ឋបាលទាំងនេះ៖

ពេលខ្ញុំបែរព្រះភក្ត្ររបស់ខ្ញុំទៅកាន់សកលលោក ដើម្បីថ្លែងព្រះបន្ទូល មនុស្សទាំងអស់ស្តាប់ឮព្រះសូរសៀងរបស់ខ្ញុំ ហើយពេលនោះគេមើលឃើញកិច្ចការទាំងអស់ដែលខ្ញុំបានសាងនៅទូទាំងសកលលោក។ អស់អ្នកដែលបានតាំងខ្លួនទាស់ទទឹងនឹងបំណងព្រះហឫទ័យរបស់ខ្ញុំ ពោលគឺ មនុស្សដែលទាស់ទទឹងនឹងខ្ញុំដោយទង្វើរបស់មនុស្ស នឹងត្រូវនៅក្រោមការវាយផ្ចាលរបស់ខ្ញុំ។ ខ្ញុំនឹងយកផ្កាយជាច្រើននៅលើមេឃ រួចធ្វើវាឲ្យថ្មីវិញ ចូរអរព្រះគុណខ្ញុំ ដ្បិតព្រះអាទិត្យនិងព្រះចន្ទ នឹងត្រូវបានស្អាងឲ្យថ្មីឡើង ផ្ទៃមេឃលែងចាស់ដូចពីមុន ហើយរបស់សព្វសារពើជាច្រើនអនេកនៅលើផែនដី នឹងត្រូវបានស្អាងជាថ្មីឡើងវិញដែរ។ អ្វីគ្រប់យ៉ាងនឹងបានសម្រេចតាមរយៈព្រះបន្ទូលរបស់ខ្ញុំ។ ជាតិសាសន៍ជាច្រើន នៅក្នុងសកលលោកនឹងត្រូវបែងចែកជាថ្មីម្តងទៀត ហើយជំនួសដោយនគររបស់ខ្ញុំ ដើម្បីឲ្យប្រជាជាតិនានាលើផែនដីរលាយបាត់ទៅរហូត ហើយជាតិសាសន៍ទាំងអស់នឹងក្លាយទៅជានគរមួយដែលថ្វាយបង្គំខ្ញុំ ប្រជាជាតិទាំងអស់លើផែនដីនឹងត្រូវវិនាស ហើយលែងមានវត្តមានជារៀងរហូត។ មនុស្សទាំងអស់នៅក្នុងសកលលោក មនុស្សទាំងអស់ដែលជាកម្មសិទ្ធិរបស់អារក្សនឹងត្រូវវិនាសសាបសូន្យ នឹងត្រូវពិការដោយភ្លើងដ៏សន្ធោសន្ធៅរបស់ខ្ញុំ ពោលគឺ មនុស្សទាំងអស់នឹងត្រូវក្លាយទៅជាផេះ លើកលែងតែមនុស្សនៅក្នុងលំហូរនេះតែប៉ុណ្ណោះ។ ពេលខ្ញុំដាក់ទោសមនុស្សជាច្រើនតាមការប្រព្រឹត្តិខុសៗគ្នានោះ មនុស្សដែលនៅក្នុងចំណោមអ្នកកាន់សាសនា នឹងត្រឡប់មកឯនគររបស់ខ្ញុំ ត្រូវបានបង្ក្រាបដោយកិច្ចការរបស់ខ្ញុំ ដ្បិតពួកគេនឹងបានឃើញការមកដល់របស់ព្រះដ៏បរិសុទ្ធ

ដោយយោងគង់លើដុំពពកស។ មនុស្សគ្រប់គ្នា នឹងត្រូវញែកទៅតាមជំពូករបស់គេផ្ទាល់ ហើយគេនឹងទទួលការវាយផ្ចាលសមទៅនឹងទង្វើរបស់គេ។ អស់អ្នកដែលបានក្រោកឡើងប្រឆាំងនឹងខ្ញុំ គេនឹងវិនាស ចំណែកមនុស្សដែលពុំមានសកម្មភាពពាក់ព័ន្ធនឹងខ្ញុំ នោះគេនឹងបន្តមានវត្តមាននៅលើផែនដី ក្រោមការគ្រប់គ្រងរបស់ពួកកូនប្រុស និងរាស្ត្ររបស់ខ្ញុំ ដោយព្រោះតែរបៀបដែលគេបំពេញកាតព្វកិច្ចរបស់ខ្លួន។ ខ្ញុំនឹងបើកសម្ដែងព្រះកាយរបស់ខ្ញុំឲ្យមនុស្ស និងជាតិសាសន៍ជាច្រើនបានឃើញ រួចខ្ញុំនឹងបន្លឺព្រះសូរសៀងផ្ទាល់របស់ខ្ញុំលើផែនដី ទាំងប្រកាសពីការសម្រេចកិច្ចការដ៏អស្ចារ្យរបស់ខ្ញុំ ដើម្បីឲ្យមនុស្សជាតិទាំងអស់បានឃើញផ្ទាល់ភ្នែករបស់គេ។

នៅពេលដែលសូរសៀងរបស់ខ្ញុំលេចជ្រៅទៅក្នុងប្រពលភាព ខ្ញុំក៏សង្កេតមើលសភាពនៃសកលលោក។ សត្តនិករជាច្រើនអនេក ក៏ត្រូវបានបង្កើតជាថ្មី តាមរយៈបន្ទូលរបស់ខ្ញុំ។ ផ្ទៃមេឃផ្លាស់ប្ដូរ រីឯផែនដីក៏ផ្លាស់ប្ដូរដែរ។ មនុស្សក៏សម្ដែងចេញនូវសណ្ឋានដើមរបស់ខ្លួនសន្សឹមៗ រួចមនុស្សម្នាក់ៗត្រូវបានញែកទៅតាមជំពូករបស់គេ ហើយរកឃើញផ្លូវត្រឡប់ទៅក្នុងភាពជិតស្និទ្ធនឹងគ្រួសាររបស់គេវិញដោយមិនដឹងខ្លួន។ ការនេះធ្វើឲ្យខ្ញុំគាប់ព្រះហឫទ័យជាខ្លាំង។ ខ្ញុំមានសេរីភាពពីការរំខាន ចំណែកកិច្ចការដ៏អស្ចារ្យរបស់ខ្ញុំវិញ ក៏បានសម្រេចដោយមិនដឹងខ្លួនគ្រប់យ៉ាងក្នុងសត្តនិករទាំងអស់ក៏ត្រូវបានបំផ្លាស់បំប្រែដែរ។ ពេលដែលខ្ញុំបង្កើតពិភពលោកនេះមក ខ្ញុំបង្កើតគ្រប់យ៉ាងតាមប្រភេទរបស់វា ដោយដាក់គ្រប់យ៉ាងទៅតាមសណ្ឋានព្រមគ្នានឹងប្រភេទរបស់វា។ នៅពេលចុងបញ្ចប់នៃផែនការគ្រប់គ្រងរបស់ខ្ញុំ កាន់តែខិតមកជិត ខ្ញុំនឹងស្ដារសណ្ឋានដើមនៃការបង្កើត ខ្ញុំនឹងស្ដារគ្រប់យ៉ាងឱ្យដូចដើម ដោយផ្លាស់ប្ដូរគ្រប់យ៉ាងទាំងស្រុង ដើម្បីឱ្យគ្រប់យ៉ាងត្រឡប់ទៅជិតស្និទ្ធនឹងផែនការរបស់ខ្ញុំវិញ។ ពេលវេលាដល់ហើយ! ដំណាក់កាលចុងក្រោយនៃផែនការរបស់ខ្ញុំ ជិតនឹងសម្រេចហើយ។ ឱពិភពលោកដ៏ស្មោកគ្រោក ចាស់គំរិលអើយ! អ្នកនឹងធ្លាក់ទៅក្រោមបន្ទូលរបស់ខ្ញុំ! អ្នកប្រាកដជាក្លាយជាភាពទទេ ដោយសារផែនការរបស់ខ្ញុំ! អ្នកគ្រប់គ្នានឹងទទួលបាននូវជីវិតថ្មីនៅក្នុងព្រះបន្ទូលរបស់ខ្ញុំ អ្នកនឹងមានព្រះអម្ចាស់ដ៏មានអធិបតេយ្យ

ភាព! ឱពិភពលោកថ្មីដ៏បរិសុទ្ធ និងឥតសៅហ្មងអើយ! អ្នកនឹងបានរស់ឡើងវិញជាប្រាកដនៅក្នុងសិរីរុងរឿងរបស់ខ្ញុំ! ឱភ្នំស៊ីយ៉ូនអើយ! ចូរកុំស្ងប់ស្ងាត់ទៀតអី ខ្ញុំបានត្រឡប់មកវិញដោយជ័យជម្នះ! ខ្ញុំបានពិនិត្យពិច័យផែនដីទាំងមូល ពីក្នុងចំណោមសត្តនិករទាំងអស់។ នៅលើផែនដី មនុស្សលោកបានចាប់ផ្ដើមជីវិតថ្មីមួយ ហើយបានទទួលសេចក្ដីសង្ឃឹមថ្មី។ ឱរាស្ត្រខ្ញុំអើយ! ម្ដេចក៏អ្នកមិនត្រឡប់មកឯជីវិតនៅក្នុងពន្លឺរបស់ខ្ញុំ? ម្ដេចក៏អ្នកមិនលោតដោយអំណរ ក្រោមការដឹកនាំរបស់ខ្ញុំ? ដែនដីកំពុងតែស្រែកហ៊ោដោយភាពរីករាយ ទឹកខ្ជោលឡើងដោយសំណើចដ៏រីករាយ! ឱអ៊ីស្រាអែលដែលបានរស់ឡើងវិញអើយ! ម្ដេចក៏អ្នកមិនអាចមានអំនួតចំពោះរឿងរ៉ាវនៃការកំណត់ទុកជាមុនរបស់ខ្ញុំ? តើនរណាយំសោក? តើនរណាទ្រហោរយំ? អ៊ីស្រាអែលចាស់លែងមានទៀតហើយ ហើយអ៊ីស្រាអែលសព្វថ្ងៃក៏បានក្រោកឡើង លេចឡើង ហើយត្រដែតឡើងនៅក្នុងពិភពលោក និងបានឈរឡើងនៅក្នុងចិត្តរបស់មនុស្សទាំងអស់ផង។ អ៊ីស្រាអែលសព្វថ្ងៃ ច្បាស់ជាទទួលបាននូវប្រភពនៃអត្ថិភាពតាមរយៈរាស្ត្ររបស់ខ្ញុំ! ឱអេស៊ីព្ទដ៏គួរឱ្យស្អប់អើយ! អ្នកច្បាស់ជាមិននៅក្រោកឈរទាស់នឹងខ្ញុំទេមែនទេ? ម្ដេចក៏អ្នកអាចកេងចំណេញពីព្រះគុណរបស់ខ្ញុំ ហើយព្យាយាមគេចចេញពីការវាយផ្ចាលរបស់ខ្ញុំដូច្នេះ? ម្ដេចក៏អ្នកមិនអាចមានវត្តមាន នៅក្នុងការវាយផ្ចាលរបស់ខ្ញុំដូច្នេះ? អស់អ្នកណាដែលខ្ញុំស្រឡាញ់ នឹងរស់នៅអស់កល្បជានិច្ចជាប្រាកដ អស់អ្នកណាដែលឈរទាស់នឹងខ្ញុំនឹងត្រូវខ្ញុំវាយផ្ចាលអស់កល្បជានិច្ចយ៉ាងប្រាកដ។ ដ្បិតខ្ញុំគឺជាព្រះដែលប្រចណ្ឌ ហើយដោយព្រោះគ្រប់យ៉ាងដែលមនុស្សបានធ្វើ នោះខ្ញុំនឹងមិនលើកលែងឱ្យគេស្រួលៗឡើយ។ ខ្ញុំនឹងឃ្លាំមើលផែនដីទាំងមូល ហើយខ្ញុំនឹងបើកសម្ដែងពីអង្គខ្ញុំដល់មនុស្សជាច្រើន ដោយលេចមកនៅទិសខាងកើតនៃផែនដីដោយសេចក្ដីសុចរិត ឫទ្ធានុភាព សេចក្ដីក្រោធ និងការវាយផ្ចាល!

ថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៩២

# ជំពូកទី ២៩៖ ព្រះបន្ទូលព្រះជាម្ចាស់ ថ្លែងទៅកាន់សកលលោកទាំងមូល

នៅថ្ងៃ ដែលរបស់សព្វសារពើត្រូវបានរស់ឡើងវិញ ខ្ញុំបានយាងមកនៅក្នុងចំណោមមនុស្ស ហើយខ្ញុំបានចំណាយពេលទាំងថ្ងៃទាំងយប់ដ៏វិសេសវិសាលជាមួយគេ។ មានតែត្រង់ចំណុចនេះទេ ដែលមនុស្សអាចដឹងតិចតួចអំពីការដែលអាចចូលមកកាន់ខ្ញុំ ហើយនៅពេលដែលការប្រកបទាក់ទងរបស់គេជាមួយខ្ញុំកាន់តែញឹកញាប់ នោះគេនឹងមើលឃើញខ្លះៗអំពីកម្មសិទ្ធិ និងលក្ខណៈរបស់ខ្ញុំ ហើយជាលទ្ធផល គេទទួលបានចំណេះដឹងខ្លះពីខ្ញុំ។ ខ្ញុំងើបព្រះសិរសាររបស់ខ្ញុំ ទតមើលទៅក្នុងចំណោមមនុស្សទាំងអស់ ហើយពួកគេទាំងអស់គ្នាបានឃើញខ្ញុំ។ ប៉ុន្តែនៅពេលមានគ្រោះមហន្តរាយកើតឡើងដល់ពិភពលោក ពួកគេមានការថប់បារម្ភមួយរំពេច ហើយរូបអង្គរបស់ខ្ញុំក៏រសាត់បាត់ចេញពីចិត្តរបស់ពួកគេ។ ដោយការភ័យស្លន់ស្លោចំពោះការមកដល់នៃគ្រោះមហន្តរាយនេះ ពួកគេមិនយកចិត្តទុកដាក់ចំពោះការដាស់តឿនរបស់ខ្ញុំទេ។ ខ្ញុំបានចូលទៅកាន់មនុស្សជាច្រើនឆ្នាំមកហើយ ប៉ុន្តែគេនៅតែមិនដឹង ហើយមិនដែលស្គាល់ខ្ញុំសោះ។ ថ្ងៃនេះខ្ញុំមានបន្ទូលប្រាប់គេដោយព្រះឱស្ឋខ្ញុំផ្ទាល់ ហើយខ្ញុំធ្វើឲ្យមនុស្សទាំងអស់មកនៅចំពោះខ្ញុំ ដើម្បីទទួលអ្វីមួយពីខ្ញុំ ប៉ុន្តែពួកគេនៅតែរក្សាគម្លាតឆ្ងាយពីខ្ញុំដដែល ដូច្នេះហើយពួកគេមិនស្គាល់ខ្ញុំទេ។ នៅពេលដែលជំហានបាទារបស់ខ្ញុំជាន់លើសកលលោក និងដល់ចុងបំផុតនៃផែនដី មនុស្សនឹងចាប់ផ្ដើមឆ្លុះបញ្ចាំងអំពីខ្លួនឯង ហើយមនុស្សទាំងអស់នឹងចូលមករកខ្ញុំ និងក្រាបចុះនៅចំពោះខ្ញុំ ហើយថ្វាយបង្គំខ្ញុំ។ ថ្ងៃនេះនឹងក្លាយជាថ្ងៃដែលខ្ញុំទទួលបានសិរីល្អ ជាថ្ងៃយាងត្រលប់មកវិញរបស់ខ្ញុំ និងជាថ្ងៃចាកចេញរបស់ខ្ញុំដែរ។ ឥឡូវនេះ ខ្ញុំបានចាប់ផ្ដើមនូវកិច្ចការរបស់ខ្ញុំក្នុងចំណោមមនុស្សទាំងអស់ ហើយបានចេញដំណើរជាផ្លូវការនៅក្នុងសកលលោកទាំងមូល នៅពេលចុងបញ្ចប់នៃផែនការគ្រប់គ្រងរបស់ខ្ញុំ។ ចាប់ពីពេលនេះតទៅ អ្នកណាដែលមិនប្រយ័ត្នប្រយែង នឹងត្រូវទទួលខុសត្រូវចំពោះ

ការធ្លាក់ចូលទៅក្នុងការវាយផ្ចាលដោយគ្មានមេត្តា ហើយការនេះអាចកើតឡើងគ្រប់ពេលវេលា។ នេះមិនមែនដោយសារតែខ្ញុំគ្មានព្រះហឫទ័យនោះទេ ផ្ទុយទៅវិញ វាគឺជាជំហាននៃផែនការគ្រប់គ្រងរបស់ខ្ញុំ។ អ្វីៗទាំងអស់ត្រូវតែបន្តទៅតាមជំហាននៃផែនការរបស់ខ្ញុំ ហើយគ្មាននរណាម្នាក់អាចផ្លាស់ប្ដូរការនេះបានឡើយ។ នៅពេលដែលខ្ញុំចាប់ផ្ដើមកិច្ចការរបស់ខ្ញុំជាផ្លូវការ មនុស្សទាំងអស់ធ្វើចលនានៅពេលដែលខ្ញុំធ្វើចលនា មនុស្សនៅទូទាំងសកលលោកទាំងអស់នោះបោះជំហានទៅជាមួយខ្ញុំ នោះនឹងមាន «ភាពសប្បាយរីករាយ» នៅទូទាំងសកលលោក ហើយមនុស្សនឹងត្រូវជំរុញទៅមុខដោយខ្ញុំ។ ជាលទ្ធផល នាគដ៏ធំមានសម្បុរក្រហមនឹងត្រូវវាយឲ្យវង្វេងស្មារតី និងវល់គំនិតដោយសារខ្ញុំ ហើយវាបម្រើកិច្ចការរបស់ខ្ញុំ ហើយទោះបីជាវាមិនមានឆន្ទៈធ្វើក៏ដោយ ក៏វាមិនអាចធ្វើតាមបំណងផ្ទាល់ខ្លួនរបស់វាបានដែរ ប៉ុន្តែវាគ្មានសល់ជម្រើសអ្វីក្រៅពីការចុះចូលក្រោមគ្រប់គ្រងរបស់ខ្ញុំនោះទេ។ ក្នុងគ្រប់ផែនការទាំងអស់របស់ខ្ញុំ នាគដ៏ធំមានសម្បុរក្រហមគឺជាគ្រឿងបន្ទាប់បន្សំរបស់ខ្ញុំ ជាសត្រូវរបស់ខ្ញុំ និងជាអ្នកបម្រើរបស់ខ្ញុំដែរ ដូច្នោះហើយបានជាខ្ញុំមិនដែលបន្ធូរបន្ថយ «សេចក្ដីតម្រូវ» របស់ខ្ញុំពីវាទេ។ ដូច្នេះដំណាក់កាលចុងក្រោយ អំពីកិច្ចការនៃការយកកំណើតជាមនុស្សរបស់ខ្ញុំ គឺត្រូវបានបំពេញរួចហើយ គឺនៅក្នុងផ្ទះសម្បែងរបស់វាតែម្ដង។ តាមវិធីនេះ នាគដ៏ធំមានសម្បុរក្រហម អាចបម្រើដល់ខ្ញុំបានកាន់តែសមរម្យ ដែលតាមរយៈការនោះ ខ្ញុំនឹងយកឈ្នះលើវា ហើយបញ្ចប់ផែនការរបស់ខ្ញុំ។ នៅពេលដែលខ្ញុំធ្វើការ ទេវតាទាំងអស់ធ្វើសង្គ្រាមដ៏មុឺងម៉ាត់រួមជាមួយខ្ញុំ ហើយតាំងចិត្តដើម្បីបំពេញបំណងប្រាថ្នារបស់ខ្ញុំនៅដំណាក់កាលចុងក្រោយ ដើម្បីឱ្យមនុស្សនៅលើផែនដីក្រាបចុះនៅចំពោះខ្ញុំដូចពួកទេវតា និងមិនមានបំណងចិត្តទាស់នឹងខ្ញុំ ហើយមិនប្រព្រឹត្តអ្វីដែលបះបោរប្រឆាំងនឹងខ្ញុំទេ។ ទាំងនេះ គឺជាថាមពលនៃកិច្ចការរបស់ខ្ញុំនៅទូទាំងសកលលោក។

គោលបំណង និងសារៈសំខាន់នៃការយាងមកដល់របស់ខ្ញុំក្នុងចំណោមមនុស្ស គឺដើម្បីជួយសង្គ្រោះមនុស្សទាំងអស់ នាំមនុស្សទាំងអស់ឲ្យវិលត្រឡប់មកដំណាក់

របស់ខ្ញុំវិញ ដើម្បីបង្រួបបង្រួមស្ថានសួគ៌ជាមួយនឹងផែនដី និងដើម្បីឲ្យមនុស្សដឹងពី «ទីសម្គាល់» រវាងស្ថានសួគ៌និងផែនដី ដែលនេះគឺជាមុខងារដែលមានស្រាប់របស់មនុស្ស។ នៅពេលដែលខ្ញុំបង្កើតមនុស្សជាតិមក ខ្ញុំបានរៀបចំរបស់សព្វសារពើរួចជាស្រេចសម្រាប់មនុស្សជាតិ ហើយក្រោយមក ខ្ញុំបានអនុញ្ញាតឲ្យមនុស្សជាតិទទួលទៅតាមសេចក្ដីតម្រូវរបស់ខ្ញុំ ដែលជាទ្រព្យសម្បត្តិដែលខ្ញុំបានផ្ដល់ឲ្យគេ។ ដូច្នេះ ទើបខ្ញុំមានបន្ទូលថា ស្ថិតក្រោមការដឹកនាំរបស់ខ្ញុំនេះហើយ ដែលមនុស្សទាំងអស់បានឈានមកដល់សព្វថ្ងៃ។ ហើយនេះ គឺជាផែនការរបស់ខ្ញុំទាំងអស់។ ក្នុងចំណោមមនុស្សគ្រប់រូប មានមនុស្សជាច្រើនរាប់មិនអស់ រស់នៅក្រោមការការពារនៃសេចក្ដីស្រឡាញ់របស់ខ្ញុំ ហើយមានមនុស្សជាច្រើនរាប់មិនអស់ រស់នៅក្រោមការវាយផ្ចាលនៃសេចក្ដីសម្អប់របស់ខ្ញុំ។ ទោះបីជាមនុស្សទាំងអស់អធិស្ឋានដល់ខ្ញុំក៏ដោយ ក៏ពួកគេនៅតែមិនអាចផ្លាស់ប្ដូរកាលៈទេសៈបច្ចុប្បន្នរបស់ពួកគេបានឡើយ។ កាលណាពួកគេអស់សង្ឃឹមពួកគេ គ្រាន់តែទុកឲ្យវាកើតឡើងដោយឯកឯង ហើយលែងស្ដាប់បង្គាប់ខ្ញុំតទៅទៀត ដ្បិតអ្វីៗទាំងអស់នេះអាចសម្រេចបានតាមរយៈមនុស្ស។ នៅពេលនិយាយអំពីសណ្ឋាននៃជីវិតរបស់មនុស្ស គឺមនុស្សមិនទាន់រកឃើញនូវជីវិតដ៏ពិតនៅឡើយទេ គេនៅតែមិនទាន់ប្រទះឃើញនូវភាពអយុត្តិធម៌ ការបំផ្លិចបំផ្លាញ និងស្ថានភាពដ៏លំបាកនៃពិភពលោកនៅឡើយទេ ដូច្នេះហើយ តើវាមិនមែនជាការចូលមកដល់នៃគ្រោះមហន្តរាយទេឬអី ដោយមនុស្សភាគច្រើននៅតែប្រកាន់ខ្ជាប់ចំពោះធម្មជាតិ និងនៅតែទាញចំណាប់អារម្មណ៍ខ្លួនឯងទៅលើរសជាតិនៃ «ជីវិត» នៅឡើយ។ តើនេះមិនមែនជាសេចក្ដីពិតរបស់ពិភពលោកទេឬ? តើនេះមិនមែនជាសំឡេងនៃសេចក្ដីសង្គ្រោះ ដែលខ្ញុំបានមានបន្ទូលទៅកាន់មនុស្សទេឬ? ហេតុអ្វីក្នុងចំណោមមនុស្សជាតិ មិនមានអ្នកណាធ្លាប់ស្រឡាញ់ខ្ញុំដោយពិតប្រាកដ? ហេតុអ្វីបានជាមនុស្សស្រឡាញ់ខ្ញុំតែនៅពេលមានការវាយផ្ចាល និងជួបទុក្ខលំបាក ចុះពេលកំពុងស្ថិតក្រោមការការពាររបស់ខ្ញុំ ម្ដេចក៏គ្មាននរណាម្នាក់ស្រឡាញ់ខ្ញុំសោះអីចឹង? ខ្ញុំបានដាក់ការវាយផ្ចាលរបស់ខ្ញុំជាច្រើនដងមកលើមនុស្ស។ ពួកគេក្រឡេក

មើលវា ប៉ុន្តែក្រោយមកពួកគេព្រងើយកន្តើយនឹងវា ហើយពួកគេមិនបានសិក្សា និងសញ្ជឹងគិតពីវានៅពេលនេះទេ ដូច្នេះហើយ អ្វីទាំងអស់ដែលកើតឡើងលើមនុស្ស គឺជាការជំនុំជម្រះដោយគ្មានមេត្តា។ នេះគ្រាន់តែជាវិធីសាស្ត្រមួយនៃកិច្ចការរបស់ខ្ញុំប៉ុណ្ណោះ តែវានៅតែជាវិធីសាស្ត្រដើម្បីផ្លាស់ប្តូរមនុស្ស និងធ្វើឲ្យគេស្រលាញ់ខ្ញុំ។

ខ្ញុំគ្រងរាជ្យនៅក្នុងនគរព្រះ ហើយលើសពីនេះទៀត ខ្ញុំសោយរាជ្យនៅទូទាំងសកលលោកទាំងមូល។ ខ្ញុំជាស្ដេចនៃនគរព្រះ និងជាប្រមុខនៃសកលលោក។ ចាប់ពីពេលនេះតទៅ ខ្ញុំនឹងប្រមូលអស់អ្នកដែលខ្ញុំមិនបានជ្រើសរើស ហើយនឹងចាប់ផ្ដើមកិច្ចការរបស់ខ្ញុំក្នុងចំណោមសាសន៍ដទៃ ហើយខ្ញុំនឹងប្រកាសនូវបញ្ញត្តិរដ្ឋបាលរបស់ខ្ញុំដល់សកលលោកទាំងមូល ដើម្បីឲ្យខ្ញុំឈានទៅជំហានបន្ទាប់នៃកិច្ចការរបស់ខ្ញុំ។ ខ្ញុំនឹងប្រើការវាយផ្ចាល ដើម្បីផ្សព្វផ្សាយកិច្ចការរបស់ខ្ញុំក្នុងចំណោមសាសន៍ដទៃ ដែលមានន័យថា ខ្ញុំនឹងប្រើកម្លាំងប្រឆាំងនឹងអស់អ្នកដែលជាសាសន៍ដទៃ។ ជាធម្មតា កិច្ចការនេះនឹងត្រូវបានអនុវត្តនៅពេលដំណាលគ្នានឹងកិច្ចការរបស់ខ្ញុំ នៅក្នុងចំណោមអ្នករើសតាំង។ នៅពេលដែលប្រជារាស្ត្ររបស់ខ្ញុំគ្រប់គ្រង និងកាន់អំណាចនៅលើផែនដី នោះក៏នឹងជាថ្ងៃដែលមនុស្សទាំងអស់នៅលើផែនដីត្រូវបានយកឈ្នះ ហើយលើសពីនេះទៀត វានឹងជាពេលវេលាដែលខ្ញុំសម្រាក ហើយមានតែពេលនោះទេ ដែលខ្ញុំនឹងលេចមកចំពោះអស់អ្នកដែលត្រូវបានយកឈ្នះ។ ខ្ញុំលេចមកចំពោះនគរដ៏បរិសុទ្ធ ហើយលាក់ព្រះកាយខ្ញុំពីទឹកដីដ៏ស្មោកគ្រោក។ អស់អ្នកដែលត្រូវបានយកឈ្នះ ហើយស្ដាប់បង្គាប់នៅចំពោះខ្ញុំ គឺអាចមើលឃើញព្រះភ័ក្ត្ររបស់ខ្ញុំដោយផ្ទាល់ភ្នែក ហើយអាចស្ដាប់សំឡេងខ្ញុំដោយត្រចៀករបស់ពួកគេផ្ទាល់។ នេះគឺជាព្រះពរ ដល់អស់អ្នកដែលបានកើតនៅក្នុងអំឡុងពេលនៃគ្រាចុងក្រោយនេះ គឺជាព្រះពរដែលខ្ញុំបានកំណត់ទុកជាមុន ហើយនេះគឺជាអ្វីដែលមិនអាចកែប្រែបានដោយមនុស្សណាម្នាក់ឡើយ។ ថ្ងៃនេះ ខ្ញុំធ្វើកិច្ចការតាមរបៀបនេះ ដើម្បីជាប្រយោជន៍ដល់កិច្ចការនាពេលអនាគត។ រាល់កិច្ចការរបស់ខ្ញុំ គឺមានទំនាក់ទំនងគ្នាទៅវិញទៅមក នៅក្នុងនោះមានការអំពាវនាវ និងការឆ្លើយតប៖ មិនដែលមានជំហានណាមួយត្រូវ

បញ្ឈប់ភ្លាមៗ ហើយក៏មិនដែលមានជំហានណាមួយត្រូវបានអនុវត្តដោយឯករាជ្យពីជំហានផ្សេងទៀតឡើយ។ តើមិនមែនដូច្នេះទេឬ? តើកិច្ចការពីអតីតកាលមិនមែនជាគ្រឹះនៃកិច្ចការសព្វថ្ងៃទេឬ? តើព្រះបន្ទូលពីអតីតកាល មិនមែនជាព្រះបន្ទូលពីមុនដែលសម្រាប់ព្រះបន្ទូលសព្វថ្ងៃទេឬអី? តើជំហាននៃអតីតកាល មិនមែនជាដើមកំណើតនៃជំហាននៅសព្វថ្ងៃនេះទេឬ? នៅពេលដែលខ្ញុំបើកក្រាំងជាផ្លូវការ នោះគឺជាពេលដែលមនុស្សទូទាំងសកលលោកត្រូវទទួលការវាយផ្ចាល នៅពេលដែលមនុស្សនៅលើពិភពលោកត្រូវឆ្លងកាត់ការល្បងល ហើយវាជាចំណុចកំពូលនៃកិច្ចការរបស់ខ្ញុំ។ មនុស្សទាំងអស់រស់នៅក្នុងទឹកដីដែលគ្មានពន្លឺ ហើយមនុស្សទាំងអស់រស់នៅដោយមានការគំរាមកំហែងពីបរិស្ថានរបស់ពួកគេ។ អាចនិយាយម៉្យាងទៀតបានថា វាជាជីវិតដែលមនុស្សមិនធ្លាប់ជួបប្រទះ ចាប់តាំងពីសម័យកាលនៃការបង្កើតរហូតមកដល់បច្ចុប្បន្ន ហើយគ្មាននរណាម្នាក់ក្នុងមួយជីវិតគេ ធ្លាប់បាន «រីករាយ» នឹងជីវិតបែបនេះឡើយ ដូច្នេះហើយ បានជាខ្ញុំមានបន្ទូលថា ខ្ញុំបានធ្វើកិច្ចការដែលមិនមានអ្នកណាធ្លាប់បានធ្វើពីមុនមកឡើយ។ នេះគឺជាសណ្ឋានដ៏ពិតនៃកិច្ចការ ហើយនេះគឺជាអត្ថន័យនៅខាងក្នុងចិត្ត។ ដោយសារតែថ្ងៃរបស់ខ្ញុំខិតជិតមកដល់ សម្រាប់មនុស្សជាតិទាំងអស់ ហើយដោយសារតែវាមិនលេចមកនៅចម្ងាយឆ្ងាយទេ ប៉ុន្តែគឺនៅចំពីមុខភ្នែករបស់មនុស្សតែម្ដង ជាលទ្ធផល តើអ្នកណាមិនមានការខ្លាចរអាទៅ? ហើយតើអ្នកណាមិនអាចរីករាយខ្លាំងចំពោះរឿងនេះទៅ? ទីបំផុត ទីក្រុងបាប៊ីឡូនដ៏ស្មោកគ្រោកបានឈានដល់ទីបញ្ចប់ហើយ។ មនុស្សបានជួបនឹងពិភពដ៏ថ្មីស្រឡាងម្ដងទៀត ហើយផ្ទៃមេឃនិងផែនដីត្រូវបានផ្លាស់ប្ដូរ និងបង្កើតជាថ្មី។

នៅពេលដែលខ្ញុំលេចមកឯគ្រប់ជាតិសាសន៍ និងមនុស្សទាំងអស់ ពពកពណ៌សបក់បោកនៅលើមេឃ ហើយគ្របដណ្ដប់លើខ្ញុំ។ ដូច្នេះ សត្វស្លាបនៅលើផែនដីនឹងច្រៀង ហើយរាំដោយអំណរថ្វាយដល់ខ្ញុំ ដោយរំលេចឲ្យឃើញបរិយាកាសនៅលើផែនដី ហើយជាហេតុធ្វើឲ្យរបស់សព្វសារពើនៅលើផែនដី មានជីវិតរស់រវើកលែងមានការ «រសាត់ចុះក្រោមបន្តិចម្ដងៗ» ទៀតឡើយ ប៉ុន្តែជំនួសមកវិញដោយ

ការរស់នៅក្នុងបរិយាកាសមួយដែលប្រកបដោយថាមពល។ នៅពេលដែលខ្ញុំស្ថិតនៅក្នុងពពក នោះមនុស្សអាចមើលឃើញព្រះភក្ត្រ និងព្រះនេត្ររបស់ខ្ញុំយ៉ាងច្បាស់ ហើយនៅពេលនេះ គេមានអារម្មណ៍ភ័យខ្លាចបន្តិច។ កាលពីមុន គេបានឮកំណត់ត្រាប្រវត្តិសាស្ត្រអំពីខ្ញុំនៅក្នុងរឿងព្រេង ហើយជាលទ្ធផល គេមានជំនឿតែពាក់កណ្ដាលប៉ុណ្ណោះ ហើយមានការសង្ស័យចំពោះខ្ញុំពាក់កណ្ដាល។ គេមិនដឹងថាខ្ញុំនៅឯណា ឬព្រះភក្ត្ររបស់ខ្ញុំធំប៉ុនណានោះទេ តើព្រះភក្ត្ររបស់ខ្ញុំមិនធំទូលាយដូចសមុទ្រ ឬធំទូលាយគ្មានព្រំដែនដូចវាលស្មៅបៃតងទេឬអី? គ្មានអ្នកណាដឹងរឿងទាំងនេះទេ។ មានតែនៅពេលដែលមនុស្សបានឃើញព្រះភក្ត្ររបស់ខ្ញុំ នៅលើពពកនាពេលសព្វថ្ងៃនេះទេ ទើបមនុស្សមានអារម្មណ៍ថា ខ្ញុំដែលនៅក្នុងរឿងព្រេងនោះ គឺមានពិតប្រាកដ ដូច្នេះហើយ គេក៏ក្លាយជាមនុស្សដែលគាប់ព្រះហឫទ័យដល់ខ្ញុំ ហើយគឺដោយសារតែទង្វើរបស់ខ្ញុំប៉ុណ្ណោះ ទើបធ្វើឲ្យការកោតសរសើររបស់គេចំពោះខ្ញុំត្រឡប់ជាធំជាងនេះបន្តិច។ ប៉ុន្តែមនុស្សនៅតែមិនស្គាល់ខ្ញុំ ហើយគេឃើញតែផ្នែកមួយរបស់ខ្ញុំនៅក្នុងពពកប៉ុណ្ណោះ។ បន្ទាប់មក ខ្ញុំក៏លាតព្រះហស្តរបស់ខ្ញុំ ហើយបង្ហាញឲ្យមនុស្សឃើញ។ មនុស្សមានការងឿងឆ្ងល់ និងដាក់ដៃនៅលើមាត់របស់គេ ដោយភ័យខ្លាចយ៉ាងខ្លាំងថានឹងត្រូវវាយផ្ចាលដោយព្រះហស្តរបស់ខ្ញុំ ដូច្នេះហើយ គេក៏បន្ថែមការគោរពបន្តិចបន្តួចពីលើការកោតសរសើររបស់គេចំពោះខ្ញុំ។ មនុស្សសម្លឹងមើលគ្រប់សកម្មភាពរបស់ខ្ញុំដោយភ័យខ្លាចជាខ្លាំងថា គេនឹងត្រូវវាយផ្ចាលដោយសារខ្ញុំ នៅពេលដែលគេមិនយកចិត្តទុកដាក់ ប៉ុន្តែខ្ញុំមិន ត្រូវបានដាក់កម្រិតដោយសារតែការឃ្លាំមើលរបស់មនុស្សនោះឡើយ ហើយខ្ញុំនៅតែបន្តធ្វើកិច្ចការដោយព្រះហស្តរបស់ខ្ញុំ។ មានតែនៅក្នុងទង្វើទាំងអស់របស់ខ្ញុំនោះទេ ដែលអាចធ្វើឲ្យមនុស្សមានការពេញចិត្តចំពោះខ្ញុំបានខ្លះម៉្លោះហើយ គេក៏ចូលមកបន្តិចម្ដងៗនៅចំពោះខ្ញុំ ដើម្បីចូលរួមជាមួយខ្ញុំ។ នៅពេលដែលខ្ញុំត្រូវបានបើកសម្ដែងឲ្យមនុស្សឃើញអំពីលក្ខណៈទាំងស្រុងរបស់ខ្ញុំ នោះមនុស្សនឹងមើលឃើញព្រះភក្ត្ររបស់ខ្ញុំ ហើយចាប់ពីពេលនោះទៅ ខ្ញុំនឹងមិនលាក់ព្រះភក្ត្រ ឬលាក់បាំងព្រះកាយរបស់ខ្ញុំពីមនុស្សទៀតទេ។ នៅទូទាំងសកលលោក ខ្ញុំនឹង

លេចមកជាសាធារណៈនៅចំពោះមនុស្សទាំងអស់ ហើយអស់អ្នកដែលនៅជាប់សាច់ និងឈាម នឹងមើលឃើញទង្វើទាំងអស់របស់ខ្ញុំ។ អស់អ្នកដែលនៅជាប់នឹងវិញ្ញាណ នឹងរស់នៅដោយសុខសាន្តនៅក្នុងដំណាក់របស់ខ្ញុំ ហើយនឹងរីករាយចំពោះព្រះពរដ៏អស្ចារ្យទាំងអស់គ្នាជាមួយខ្ញុំ។ អស់អ្នកដែលខ្ញុំថែរក្សា ប្រាកដជានឹងគេចផុតពីការវាយផ្ចាល ហើយច្បាស់ជានឹងចៀសផុតពីការឈឺចាប់ខាងវិញ្ញាណ និងការឈឺចាប់ខាងសាច់ឈាម។ ខ្ញុំនឹងលេចមកជាសាធារណៈនៅចំពោះមនុស្សទាំងអស់ ហើយគ្រប់គ្រង និងប្រើអំណាចដើម្បីឲ្យក្លិនរបស់សាកសពលែងមាននៅលើសកលលោកទៀតផ្ទុយទៅវិញ ក្លិនក្រអូបឈ្ងុយឈ្ងប់របស់ខ្ញុំ នឹងសាយភាយពាសពេញពិភពលោកទាំងមូល ព្រោះថ្ងៃកំណត់របស់ខ្ញុំជិតមកដល់ហើយ មនុស្សនឹងដឹងខ្លួន អ្វីៗនៅលើផែនដីនឹងមានរបៀបរៀបរយ ហើយថ្ងៃនៃការរស់រានមានជីវិតនៅលើផែនដីនឹងមិនមានទៀតទេ ព្រោះខ្ញុំបានយាងមកដល់ហើយ!

ថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩២

# តើអ្នកជឿ គួរប្រកាន់យកទស្សនៈអ្វី

តើមនុស្សបានទទួលអ្វីចាប់តាំងពីពួកគេចាប់ផ្ដើមជឿលើព្រះជាម្ចាស់ជាលើកដំបូង? តើអ្នកបានដឹងអ្វីខ្លះពីព្រះជាម្ចាស់? ដោយសារជំនឿរបស់អ្នកលើព្រះជាម្ចាស់ តើអ្នកបានផ្លាស់ប្ដូរយ៉ាងណាខ្លះ? ថ្ងៃនេះ អ្នករាល់គ្នាដឹងថា ជំនឿរបស់មនុស្សលើព្រះជាម្ចាស់មិនមែនសម្រាប់តែការសង្គ្រោះព្រលឹង និងសុខុមាលភាពនៃសាច់ឈាមប៉ុណ្ណោះទេ ហើយវាក៏មិនមែនដើម្បីធ្វើឱ្យជីវិតរបស់ពួកគេមានភាពប្រសើរឡើងតាមរយៈការស្រឡាញ់ព្រះជាម្ចាស់ដែរ ។ល។ នៅក្នុងស្ថានភាពបច្ចុប្បន្ន ប្រសិនបើអ្នកស្រឡាញ់ព្រះជាម្ចាស់ដើម្បីជាប្រយោជន៍ដល់សុខុមាលភាពនៃសាច់ឈាម ឬការសប្បាយមួយភ្លែត ដូច្នេះ បើទោះបីជានៅទីបញ្ចប់ សេចក្ដីស្រឡាញ់របស់អ្នកចំពោះព្រះជាម្ចាស់ឈានដល់ចំណុចខ្ពស់បំផុត ហើយអ្នកមិនសុំអ្វីបន្ថែមទៀតក៏ដោយ ក៏

សេចក្តីស្រឡាញ់ដែលអ្នកស្វែងរកនេះ នៅតែជាសេចក្តីស្រឡាញ់មួយដែលមានភាពសៅហ្មង និងមិនសព្វព្រះហឫទ័យដល់ព្រះជាម្ចាស់ដែរ។ អ្នកដែលប្រើសេចក្តីស្រឡាញ់ចំពោះព្រះជាម្ចាស់ ដើម្បីធ្វើឱ្យជីវិតដ៏ស្រពោនរបស់ពួកគេប្រសើរឡើង និងដើម្បីបំពេញកន្លែងទទេស្អាតនៅក្នុងដួងចិត្តរបស់ពួកគេ គឺជាប្រភេទមនុស្សដែលលោភលន់ចង់បានជីវិតមួយងាយស្រួល មិនមែនជាអ្នកដែលស្វែងរកការស្រឡាញ់ព្រះជាម្ចាស់ពិតប្រាកដឡើយ។ នេះជាសេចក្តីស្រឡាញ់ដោយបង្ខំ វាគឺជាការស្វែងរកការស្កប់ស្កល់ចិត្ត ហើយព្រះជាម្ចាស់មិនត្រូវការវាឡើយ។ បើដូច្នោះមែន តើសេចក្តីស្រឡាញ់ប្រភេទអ្វីជារបស់អ្នក? តើអ្នកស្រឡាញ់ព្រះជាម្ចាស់ដើម្បីអ្វី? តើឥឡូវនេះនៅក្នុងអ្នកមានសេចក្តីស្រឡាញ់ពិតប្រាកដប៉ុនណាចំពោះព្រះជាម្ចាស់? សេចក្តីស្រឡាញ់របស់អ្នករាល់គ្នាភាគច្រើនគឺដូចជាប្រភេទដែលបានរៀបរាប់ខាងលើ។ សេចក្តីស្រឡាញ់បែបនេះគ្រាន់តែអាចរក្សាស្ថានភាពបច្ចុប្បន្នប៉ុណ្ណោះ។ វាមិនអាចសម្រេចបានភាពមិនចេះប្រែប្រួលនោះទេ ហើយវាក៏មិនអាចចាក់ឫសនៅក្នុងមនុស្សបានដែរ។ សេចក្តីស្រឡាញ់ប្រភេទនេះគឺគ្រាន់តែដូចផ្កាដែលរីក និងស្រពោនដោយគ្មានផ្លែប៉ុណ្ណោះ។ អាចនិយាយម្យ៉ាងទៀតបានថា ក្រោយពីអ្នកធ្លាប់បានស្រឡាញ់ព្រះជាម្ចាស់តាមរបៀបនេះហើយ ប្រសិនបើគ្មានអ្នកណាម្នាក់ដឹកនាំអ្នកទៅតាមផ្លូវដែលនៅខាងមុខ នោះអ្នកនឹងដួលមិនខាន។ ប្រសិនបើអ្នកគ្រាន់តែអាចស្រឡាញ់ព្រះជាម្ចាស់ តែក្នុងពេលដែលស្រឡាញ់ទ្រង់ ប៉ុន្តែក្រោយមកនិស្ស័យរបស់អ្នកនៅតែមិនផ្លាស់ប្តូរ នោះអ្នកនឹងនៅតែមិនអាចគេចខ្លួនចេញពីស្បែតទ្ធិពលនៃភាពងងឹត ហើយអ្នកនឹងនៅតែមិនអាចគេចខ្លួនចេញពីចំណងរបស់អារក្សសាតាំង និងឧបាយកលរបស់វាបានឡើយ។ ព្រះជាម្ចាស់មិនអាចទទួលយកមនុស្ស ដែលមានលក្ខណៈបែបនេះយ៉ាងពេញលេញទេ។ នៅទីបញ្ចប់ វិញ្ញាណ ព្រលឹង និងរាងកាយរបស់ពួកគេនឹងនៅតែជាកម្មសិទ្ធិរបស់អារក្សសាតាំងដដែល។ រឿងនេះមិនមានអ្វីគួរឱ្យសង្ស័យឡើយ។ អស់អ្នកដែលព្រះជាម្ចាស់មិនអាចទទួលយកយ៉ាងពេញលេញនឹងត្រលប់ទៅកាន់កន្លែងដើមរបស់ពួកគេវិញ គឺមានន័យថា ត្រលប់ទៅកាន់អារក្ស

សាតាំង ហើយពួកគេនឹងចុះទៅកាន់បឹងភ្លើង និងស្ពាន់ធ័រ ដើម្បីទទួលយកដំណាក់កាលបន្ទាប់នៃការដាក់ទោសពីព្រះជាម្ចាស់។ អស់អ្នកដែលព្រះជាម្ចាស់ទទួលយក គឺអស់អ្នកដែលបោះបង់ចោលអារក្សសាតាំង ហើយគេចខ្លួនចេញពីតំបន់ត្រួតត្រារបស់វា។ ពួកគេត្រូវបានដាក់លេខរៀងជាផ្លូវការ នៅក្នុងចំណោមមនុស្សនៃនគរនេះ។ មនុស្សរបស់នគរនេះ នឹងក្លាយជាបែបនេះ។ តើអ្នកសុខចិត្តក្លាយជាមនុស្សប្រភេទនេះឬទេ? តើអ្នកសុខចិត្តឱ្យព្រះជាម្ចាស់ទទួលយកអ្នកឬទេ? តើអ្នកសុខចិត្តគេចខ្លួនចេញពីតំបន់ត្រួតត្រារបស់អារក្សសាតាំង ហើយត្រលប់ទៅកាន់ព្រះជាម្ចាស់វិញឬទេ? តើពេលនេះអ្នកជាកម្មសិទ្ធិរបស់អារក្សសាតាំង ឬត្រូវបានដាក់លេខរៀងនៅក្នុងចំណោមមនុស្សរបស់នគរព្រះ? រឿងទាំងអស់នេះគួរតែច្បាស់លាស់រួចហើយ និងមិនត្រូវការការពន្យល់បន្ថែមទៀតទេ។

កាលពីមុន មានមនុស្សជាច្រើនស្វែងរក ដោយមហិច្ឆតាខ្លាំងក្លា និងគំនិតគ្មានមូលដ្ឋាន ពួកគេស្វែងរកទុកជាលទ្ធផលនៃសេចក្ដីសង្ឃឹមផ្ទាល់ខ្លួនរបស់ពួកគេ។ សូមយើងទុកបញ្ហាបែបនេះដោយឡែកមួយភ្លែតសិន។ អ្វីដែលសំខាន់នាពេលនេះ គឺត្រូវស្វែងរកវិធីនៃការប្រតិបត្តិដែលនឹងអាចឱ្យម្នាក់ៗក្នុងចំណោមអ្នករាល់គ្នា រក្សាលក្ខខណ្ឌសមស្របមួយនៅចំពោះព្រះជាម្ចាស់ ហើយផ្ដាច់ខ្លួនបន្តិចម្ដងៗចេញពីខ្នោះនៃឥទ្ធិពលរបស់អារក្សសាតាំង ដើម្បីឱ្យព្រះជាម្ចាស់អាចទទួលយកអ្នក និងរស់នៅលើផែនដីតាមអ្វីដែលព្រះជាម្ចាស់សព្វព្រះហឫទ័យចង់ឱ្យអ្នករស់នៅ។ មានតែតាមវិធីនេះប៉ុណ្ណោះ ទើបអ្នកអាចបំពេញតាមបំណងរបស់ព្រះជាម្ចាស់បាន។ មានមនុស្សជាច្រើនជឿលើព្រះជាម្ចាស់ ប៉ុន្តែមិនដឹងថាព្រះជាម្ចាស់សព្វព្រះហឫទ័យចង់បានអ្វី ឬអារក្សសាតាំងចង់បានអ្វីឡើយ។ ពួកគេមានជំនឿតាមរបៀបច្របូកច្របល់ ដោយគ្រាន់តែបណ្ដោយខ្លួនទៅតាមវាសនាប៉ុណ្ណោះ ហេតុនេះហើយបានជាពួកគេមិនមានជីវិតជាគ្រីស្ទបរិស័ទត្រឹមត្រូវ។ លើសពីនេះទៀត ពួកគេមិនមានទំនាក់ទំនងផ្ទាល់ខ្លួនត្រឹមត្រូវ និងរឹតតែមិនមានទំនាក់ទំនងដ៏ត្រឹមត្រូវជាមួយព្រះជាម្ចាស់ដែរ។ យោងតាមសេចក្ដីនេះ យើងអាចឃើញថា ភាពលំបាក និងគុណវិបត្តិរបស់មនុស្ស និង

កត្តាផ្សេងទៀតដែលអាចរារាំងបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ គឺមានច្រើន។ សេចក្ដីនេះគ្រប់គ្រាន់ដើម្បីបញ្ជាក់ថា មនុស្សមិនទាន់បានដើរនៅលើផ្លូវដ៏ត្រឹមត្រូវនៃជំនឿលើព្រះជាម្ចាស់នៅឡើយទេ ហើយពួកគេក៏មិនបានចូលទៅក្នុងបទពិសោធពិតប្រាកដនៃជីវិតរបស់មនុស្សដែរ។ ដូច្នេះ តើការដើរនៅលើផ្លូវត្រឹមត្រូវនៃជំនឿលើព្រះជាម្ចាស់មានន័យដូចម្ដេច? ការដើរនៅលើផ្លូវត្រឹមត្រូវមានន័យថា អ្នកអាចធ្វើឱ្យចិត្តរបស់អ្នកស្ងប់ស្ងាត់ នៅចំពោះព្រះជាម្ចាស់បានគ្រប់ពេល និងអរសប្បាយចំពោះទំនាក់ទំនងត្រឹមត្រូវជាមួយព្រះជាម្ចាស់ ហើយពួកគេនឹងដឹងពីអ្វីដែលខ្វះខាតនៅក្នុងមនុស្សបន្ដិចម្ដងៗ និងទទួលបានការយល់ដឹងដ៏ជ្រាលជ្រៅអំពីព្រះជាម្ចាស់ដោយយឺតៗ។ តាមរយៈការនេះ វិញ្ញាណរបស់អ្នកទទួលបានការយល់ដឹងថ្មី និងការបំភ្លឺថ្មីជារៀងរាល់ថ្ងៃ។ អ្នកចង់រីកចម្រើនឡើង ដោយអ្នកស្វះស្វែងដើម្បីចូលទៅក្នុងសេចក្ដីពិត ហើយជារៀងរាល់ថ្ងៃ មានពន្លឺថ្មី និងការយល់ដឹងថ្មី។ តាមរយៈផ្លូវនេះ អ្នកផ្ដាច់ខ្លួនបន្ដិចម្ដងៗចេញពីឥទ្ធិពលរបស់អារក្សសាតាំង និងរីកលូតលាស់ក្នុងជីវិតរបស់អ្នក។ មនុស្សបែបនេះបានចូលទៅតាមផ្លូវត្រឹមត្រូវហើយ។ ត្រូវវាយតម្លៃពីបទពិសោធពិតប្រាកដផ្ទាល់ខ្លួនរបស់អ្នក និងពិនិត្យមើលផ្លូវដែលអ្នកបានប្រកាន់យកនៅក្នុងជំនឿរបស់អ្នក៖ ពេលដែលអ្នកប្រកាន់ខ្ជាប់ផ្លូវទាំងអស់នេះ ធៀបនឹងអ្វីដែលបានរៀបរាប់ខាងលើ តើអ្នករកឃើញថា អ្នកកំពុងស្ថិតលើផ្លូវត្រូវដែរឬទេ? តើអ្នកបានផ្ដាច់ខ្លួនពីខ្នោះរបស់អារក្សសាតាំង និងឥទ្ធិពលរបស់អារក្សសាតាំងដោយបញ្ហាអ្វី? ប្រសិនបើអ្នកនៅមិនទាន់ស្ថិតនៅលើផ្លូវត្រឹមត្រូវនៅឡើយ នោះចំណងរបស់អ្នកជាមួយអារក្សសាតាំង នៅមិនទាន់បានកាត់ផ្ដាច់នោះទេ។ នៅក្នុងករណីនេះ តើការស្វះស្វែងដើម្បីស្រឡាញ់ព្រះជាម្ចាស់របស់អ្នក នាំអ្នកទៅកាន់សេចក្ដីស្រឡាញ់មួយដែលពិតប្រាកដ មិនប្រែប្រួល និងបរិសុទ្ធឬទេ? អ្នកនិយាយថាសេចក្ដីស្រឡាញ់របស់អ្នកចំពោះព្រះជាម្ចាស់ គឺមិនងាករេ និងស្មោះអស់ពីដួងចិត្ត ប៉ុន្តែអ្នកមិនបានផ្ដាច់ខ្លួនពីខ្នោះរបស់អារក្សសាតាំងទេ។ តើអ្នកមិនមែនកំពុងព្យាយាមបោកប្រាស់ព្រះជាម្ចាស់ទេឬ? ប្រសិនបើអ្នកចង់សម្រេចបានស្ថានភាពមួយដែលសេចក្ដីស្រឡាញ់របស់អ្នក

ចំពោះព្រះជាម្ចាស់គ្មានភាពសៅហ្មង ហើយអ្នកចង់ឱ្យព្រះជាម្ចាស់ទទួលយកអ្នកពេញលេញ និងត្រូវបានដាក់លេខរៀងនៅក្នុងចំណោមមនុស្សរបស់នគរនេះ នោះអ្នកត្រូវដាក់ខ្លួនឯងនៅលើផ្លូវត្រឹមត្រូវនៃជំនឿលើព្រះជាម្ចាស់ជាមុនសិន។

## មនុស្សពុករលួយ
## គ្មានសមត្ថភាពតំណាងឱ្យព្រះជាម្ចាស់

មនុស្សធ្លាប់រស់នៅក្រោមការគ្របបាំងដោយឥទ្ធិពលនៃសេចក្ដីងងឹត ជាប់ចំណងនៃឥទ្ធិពលរបស់អារក្សសាតាំង មិនអាចគេចបាន ហើយនិស្ស័យរបស់គេ ដែលកំពុងត្រូវបានត្រួតត្រាដោយអារក្សសាតាំងនោះ ក៏រឹតតែពុករលួយទៅៗ។ អាចនិយាយបានថា មនុស្សតែងតែរស់ក្នុងនិស្ស័យដ៏ពុករលួយរបស់អារក្សសាតាំង និងគ្មានសមត្ថភាពស្រឡាញ់ព្រះជាម្ចាស់ យ៉ាងពិតប្រាកដបាននោះឡើយ។ ដូច្នេះ ប្រសិនបើមនុស្សចង់ស្រឡាញ់ព្រះជាម្ចាស់ គេត្រូវតែលះបង់នូវការរាប់ខ្លួនឯងជាសុចរិត ការរាប់ខ្លួនឯងជាសំខាន់ ភាពក្រអឺតក្រទម ភាពអួតអាង និងនិស្ស័យគ្រប់យ៉ាងដែលដូចគ្នានឹងនិស្ស័យរបស់សាតាំង។ ពុំនោះទេ សេចក្ដីស្រឡាញ់របស់គេ គ្រាន់តែជាសេចក្ដីស្រឡាញ់ដ៏ស្មោកគ្រោក ជាក្ដីស្រឡាញ់បែបសាតាំង និងជាក្ដីសេចក្ដីស្រឡាញ់ដែលមិនអាចទទួលបានការអនុម័តពីព្រះជាម្ចាស់ដាច់ខាត។ ពុំមាននរណាម្នាក់ អាចស្រឡាញ់ព្រះជាម្ចាស់យ៉ាងពិតប្រាកដ ដោយមិនឆ្លងកាត់នូវការធ្វើឲ្យគ្រប់លក្ខណ៍ ប្រដៅតម្រង់ ការលួសកាត់ ការទូន្មាន ការវាយផ្ចាល ការបន្សុទ្ធសម្អាត និងការប្រោសឱ្យបានគ្រប់លក្ខណ៍ដោយព្រះវិញ្ញាណបរិសុទ្ធផ្ទាល់នោះឡើយ។ ប្រសិនបើអ្នកនិយាយថា ផ្នែកមួយនៃនិស្ស័យរបស់អ្នក តំណាងឱ្យព្រះជាម្ចាស់ ហើយអ្នកពិតជាអាចស្រឡាញ់ព្រះជាម្ចាស់បានយ៉ាងពិតប្រាកដ នោះអ្នកជាមនុស្សម្នាក់ ដែលមានសម្ដីអួតអាង ហើយល្ងីល្ងើ។ មនុស្សបែបនេះ ជាមហាទេវតាហើយ! ធម្មជាតិពីកំណើតរបស់មនុស្ស គឺគ្មានសមត្ថភាពនឹងតំណាងឱ្យព្រះជាម្ចាស់ឡើយ។ គេត្រូវតែលះបង់នូវ

ធម្មជាតិកំណើតរបស់ខ្លួន តាមរយៈភាពគ្រប់លក្ខណ៍របស់ព្រះជាម្ចាស់ ហើយមានតែតាមរយៈការយកចិត្តទុកដាក់លើបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ការបំពេញតាមព្រះហឫទ័យទ្រង់ និងឆ្លងកាត់នូវកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធប៉ុណ្ណោះ ទើបនិស្ស័យដែលស្ដែងចេញពីជីវិតគេ ទទួលបានការអនុម័តពីព្រះជាម្ចាស់។ អ្នកដែលរស់នៅក្នុងសាច់ឈាម គ្មាននរណាអាចតំណាងព្រះជាម្ចាស់ដោយផ្ទាល់បានឡើយ លុះត្រាតែគេជាមនុស្ស ដែលត្រូវបានព្រះវិញ្ញាណបរិសុទ្ធប្រើ។ យ៉ាងណាមិញ ទោះបីគេជាមនុស្សដែលមានលក្ខណៈបែបនេះក្ដី ក៏មិនអាចនិយាយបានថា និស្ស័យរបស់គេ និងលក្ខណៈដែលស្ដែងចេញពីជីវិតរបស់គេ តំណាងឱ្យព្រះជាម្ចាស់ទាំងស្រុងបាននោះដែរ។ អាចនិយាយបានត្រឹមថា ជីវិតរស់នៅរបស់គេ ត្រូវបានដឹកនាំ ដោយព្រះវិញ្ញាណបរិសុទ្ធប៉ុណ្ណោះ។ និស្ស័យរបស់មនុស្សបែបនេះ មិនអាចតំណាងឱ្យព្រះជាម្ចាស់បានទេ។

ទោះបីជានិស្ស័យរបស់មនុស្ស ត្រូវបានតាំងឡើងដោយព្រះជាម្ចាស់មែន តែវាត្រូវបានត្រួតត្រាដោយសាតាំង ដូច្នេះហើយនិស្ស័យរបស់មនុស្សទាំងមូល គឺជានិស្ស័យរបស់សាតាំង នេះជាការពិតមិនអាចប្រកែកបាន ហើយក៏អាចចាត់ទុកជារឿងវិជ្ជមានដែរ។ មនុស្សខ្លះនិយាយថា និស្ស័យរបស់ព្រះជាម្ចាស់ គឺការធ្វើអ្វីដោយត្រង់ៗ ហើយនិយាយទៀតថា និស្ស័យនេះក៏ស្ដែងឱ្យឃើញនៅក្នុងពួកគេ ដ្បិតចរិតរបស់ពួកគេក៏មានលក្ខណៈដូចគ្នាដែរ ហេតុនេះទើបពួកគេនិយាយថា និស្ស័យរបស់ពួកគេអាចតំណាងឱ្យព្រះជាម្ចាស់បាន។ តើមនុស្សទាំងនេះ គឺជាមនុស្សបែបណា? តើនិស្ស័យពុករលួយរបស់សាតាំង អាចតំណាងឱ្យព្រះជាម្ចាស់បានទេ? អ្នកណាដែលប្រកាសថានិស្ស័យរបស់ពួកគេជាអ្នកតំណាងរបស់ព្រះជាម្ចាស់ អ្នកនោះប្រមាថដល់ព្រះជាម្ចាស់ហើយ ក៏ប្រមាថដល់ព្រះវិញ្ញាណបរិសុទ្ធទៀតផង! វិធីសាស្ត្រដែលព្រះវិញ្ញាណបរិសុទ្ធធ្វើការ បង្ហាញថា កិច្ចការរបស់ព្រះជាម្ចាស់នៅលើផែនដី គឺជាកិច្ចការតែមួយគត់ដែលមានជ័យជម្នះ។ ហេតុនេះ និស្ស័យសាតាំងពុករលួយជាច្រើនដែលមនុស្សមាន ត្រូវតែលាងសម្អាត ឯលក្ខណៈដែលស្ដែងចេញពីជីវិតគេ ក៏នៅតែជារូបភាពរបស់អារក្ស

សាតាំងដែរ។ មនុស្សជឿថា វាគឺជានិស្ស័យល្អ ហើយវាតំណាងឱ្យការប្រព្រឹត្តខាងសាច់ឈាមរបស់មនុស្ស។ កាន់តែច្បាស់ជាងនេះទៀត គឺវាតំណាងឱ្យអារក្សសាតាំង ហើយប្រាកដជាមិនអាចតំណាងឱ្យព្រះជាម្ចាស់បានឡើយ។ បើទោះជាមាននរណាម្នាក់ បានស្រឡាញ់ព្រះជាម្ចាស់ រហូតដល់ថ្នាក់គេអាចរីករាយនឹងជីវិតស្ថានសួគ៌នៅលើផែនដីនេះ បានឈានដល់ពិភពដ៏ខ្ពង់ខ្ពស់បំផុត ហើយអាចប្រកាសថា៖ «ឱព្រះជាម្ចាស់អើយ! ទូលបង្គំស្រឡាញ់ទ្រង់យ៉ាងណា ក៏មិនល្មមដែរ» ក៏នៅតែមិនអាចនិយាយបានថា ពួកគេរស់នៅដូចព្រះជាម្ចាស់ ឬជាតំណាងព្រះជាម្ចាស់ឡើយ ដ្បិតសារជាតិពិតរបស់មនុស្ស មិនដូចព្រះជាម្ចាស់ទេ ហើយមនុស្សមិនអាចរស់នៅស្វែងចេញពីព្រះជាម្ចាស់បានឡើយ ក៏រឹតតែមិនអាចក្លាយជាព្រះជាម្ចាស់ដែរ។ អ្វីដែលព្រះវិញ្ញាណបរិសុទ្ធបានដឹកនាំមនុស្សឱ្យរស់តាម គឺឱ្យរស់នៅស្របទៅតាមអ្វីៗដែលព្រះជាម្ចាស់ទ្រង់តម្រូវពីមនុស្សប៉ុណ្ណោះ។

សកម្មភាព និងការប្រព្រឹត្តទាំងអស់របស់អារក្សសាតាំង ត្រូវបានស្ដែងឱ្យឃើញនៅក្នុងមនុស្ស។ សព្វថ្ងៃនេះ សកម្មភាព និងទង្វើទាំងអស់របស់មនុស្ស គឺជាការបង្ហាញពីសាតាំង ហេតុដូច្នេះហើយ ពួកគេមិនអាចតំណាងឱ្យព្រះជាម្ចាស់បានទេ។ មនុស្សជាសភាវៈតំណាងឱ្យសាតាំង ចំណែកនិស្ស័យរបស់មនុស្សមិនអាចតំណាងឱ្យនិស្ស័យរបស់ព្រះជាម្ចាស់បានទេ។ មនុស្សខ្លះមានចរិតល្អ ព្រះជាម្ចាស់អាចធ្វើការខ្លះតាមរយៈចរិតរបស់មនុស្សបែបនេះ ហើយកិច្ចការដែលពួកគេធ្វើ គឺត្រូវបានដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធ។ ប៉ុន្តែ និស្ស័យរបស់ពួកគេ មិនអាចតំណាងព្រះជាម្ចាស់បានទេ។ កិច្ចការដែលព្រះជាម្ចាស់ធ្វើលើពួកគេ គឺគ្មានអ្វីក្រៅពីសហការ និងពង្រីកអ្វីដែលមានស្រាប់នៅក្នុងជីវិតគេនោះទេ។ គ្មាននរណាម្នាក់អាចតំណាងព្រះជាម្ចាស់ដោយផ្ទាល់ ដូចហោរានៅជំនាន់មុន ឬដូចមនុស្សដែលព្រះជាម្ចាស់បានប្រើនោះឡើយ។ ទាល់តែស្ថិតក្នុងស្ថានភាពលំបាក ទើបមនុស្សស្រឡាញ់ព្រះជាម្ចាស់ ហើយមិនមាននរណាម្នាក់ខិតខំសហការ ដោយឆន្ទៈរបស់ពួកគេឡើយ។ តើអ្វីខ្លះជាកត្តាវិជ្ជមាន? អ្វីៗគ្រប់យ៉ាង ដែលមកពីព្រះជាម្ចាស់ដោយផ្ទាល់ សុទ្ធតែវិជ្ជមាន។ តែ

និស្ស័យរបស់មនុស្ស ត្រូវបានត្រួតត្រាដោយអារក្សសាតាំង និងមិនអាចតំណាងព្រះជាម្ចាស់បានឡើយ។ មានតែសេចក្ដីស្រឡាញ់ ឆន្ទៈក្នុងការរងទុក្ខ សេចក្ដីសុចរិត ការចុះចូល និងការបន្ទាបខ្លួន ព្រមទាំងការលាក់កំបាំងរបស់ព្រះជាម្ចាស់ដែលបានមកយកកំណើតជាមនុស្សប៉ុណ្ណោះ ទើបអាចតំណាងឲ្យព្រះជាម្ចាស់ ដោយផ្ទាល់បាន។ មូលហេតុគឺ នៅពេលដែលទ្រង់បានយាងមក គឺទ្រង់បានយាងមកដោយគ្មាននិស្ស័យបាប ហើយទ្រង់បានមកពីព្រះជាម្ចាស់ផ្ទាល់ ពុំមានការត្រួតត្រាដោយអារក្សសាតាំងនោះទេ។ ព្រះយេស៊ូវ គ្រាន់តែស្ថិតក្នុងសភាពដូចគ្នាទៅនឹងសាច់ឈាមដែលពេញដោយបាបប៉ុណ្ណោះ តែទ្រង់មិនតំណាងអំពើបាបទេ ហេតុនេះ ការប្រព្រឹត្ត ទង្វើ និងព្រះបន្ទូលរបស់ទ្រង់ រហូតដល់គ្រាមួយ មុនពេលការសម្រេចកិច្ចការរបស់ទ្រង់តាមរយៈការសុគតលើឈើឆ្កាង (រួមទាំងគ្រាដែលទ្រង់ត្រូវគេឆ្កាង) សុទ្ធតែតំណាងឱ្យព្រះជាម្ចាស់ផ្ទាល់។ គំរូរបស់ព្រះយេស៊ូវ គ្រប់គ្រាន់នឹងបញ្ជាក់ថា មនុស្សណាដែលមាននិស្ស័យបាប មិនអាចតំណាងព្រះជាម្ចាស់បានទេ ហើយបញ្ជាក់ទៀតថា អំពើបាបរបស់អ្នកនោះតំណាងឱ្យអារក្សសាតាំងវិញ។ ដូច្នេះ អាចនិយាយបានថា អំពើបាបមិនតំណាងឱ្យព្រះជាម្ចាស់ឡើយ ហើយព្រះជាម្ចាស់ក៏គ្មានបាបដែរ។ បើទោះបីជាកិច្ចការដែលព្រះវិញ្ញាណបរិសុទ្ធសម្រេចបាននៅក្នុងជីវិតមនុស្ស ត្រូវបានរាប់ថាជាកិច្ចការដែលត្រូវបានដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធក៏ដោយ ក៏មិនអាចនិយាយបានថា កិច្ចការដែលមនុស្សធ្វើ គឺជាកិច្ចការដែលគេធ្វើជំនួសឱ្យព្រះជាម្ចាស់នោះដែរ។ ដោយឡែក តាមអ្វីដែលមនុស្សគិត ទាំងអំពើបាប និងនិស្ស័យរបស់គេ មិនតំណាងឱ្យព្រះជាម្ចាស់ឡើយ។ មនុស្សអាចមើលឃើញផលផ្លែនៃជីវិត ដែលកើតចេញពីកិច្ចការដែលព្រះវិញ្ញាណបរិសុទ្ធបានធ្វើចំពោះគេ តាមរយៈការសម្លឹងមើលកិច្ចការដែលព្រះវិញ្ញាណបរិសុទ្ធបានធ្វើទៅលើគេ តាំងពីអតីតកាលរហូតមកដល់សព្វថ្ងៃនេះ។ មានមនុស្សតិចតួចណាស់ ដែលអាចរស់ស្ដែងចេញនូវសេចក្ដីពិត បន្ទាប់ពីត្រូវបានប្រដៅតម្រង់ និងលត់ដំដោយព្រះវិញ្ញាណបរិសុទ្ធ។ មានន័យថា ចំណែកនៃការសហការរបស់មនុស្សគ្មានវត្តមានទេ មានតែវត្តមានរបស់កិច្ចការនៃព្រះវិញ្ញាណ

បរិសុទ្ធតែប៉ុណ្ណោះ។ តើពេលនេះ អ្នកយល់ច្បាស់ទេ? ដូច្នេះ តើអ្នកនឹងសហការជាមួយទ្រង់ដល់ទីបំផុត ព្រមទាំងបំពេញភារកិច្ចរបស់ខ្លួនដូចម្ដេច នៅពេលដែលព្រះវិញ្ញាណបរិសុទ្ធកំពុងធ្វើការ?

# ការបម្រើសាសនា ដាច់ខាតត្រូវតែលុបបំបាត់

តាំងពីព្រះជាម្ចាស់បានចាប់ផ្ដើមបង្កើតសាកលលោកមក ទ្រង់ដៅមនុស្សជាច្រើនទុកជាមុន ដើម្បីបម្រើទ្រង់ រាប់ទាំងមនុស្សដែលមកពីគ្រប់សណ្ឋាននៃជីវិតផង។ គោលបំណងរបស់ទ្រង់ គឺដើម្បីបំពេញបំណងព្រះហឫទ័យរបស់ទ្រង់ និងដើម្បីធ្វើឲ្យកិច្ចការរបស់ទ្រង់នៅលើផែនដី បានសម្រេចយ៉ាងរលូន។ នេះហើយជាគោលបំណងរបស់ព្រះជាម្ចាស់ ក្នុងការជ្រើសរើសមនុស្សឲ្យបម្រើទ្រង់។ មនុស្សគ្រប់រូបដែលបម្រើព្រះជាម្ចាស់ ត្រូវតែយល់ពីបំណងព្រះហឫទ័យរបស់ទ្រង់។ កិច្ចការរបស់ទ្រង់នេះហើយ ដែលធ្វើឲ្យមនុស្សមើលឃើញព្រះប្រាជ្ញាញាណ និងសព្វានុភាពរបស់ព្រះជាម្ចាស់កាន់តែច្បាស់ ព្រមទាំងគោលការណ៍នៃកិច្ចការរបស់ទ្រង់នៅលើផែនដី។ តាមពិត ព្រះជាម្ចាស់បានយាងមកកាន់ផែនដី ដើម្បីធ្វើកិច្ចការរបស់ទ្រង់ ដើម្បីភ្ជាប់ទំនាក់ទំនងជាមួយមនុស្ស ដើម្បីឲ្យពួកគេអាចស្គាល់ពីកិច្ចការរបស់ទ្រង់កាន់តែច្បាស់។ ថ្ងៃនេះ អ្នករាល់គ្នា (ក្រុមមនុស្សនេះ) មានសំណាងណាស់ ដែលបានបម្រើព្រះដ៏ជាក់ស្ដែង។ នេះជាព្រះពរដ៏ច្រើនឥតគណនា សម្រាប់អ្នករាល់គ្នាដែលព្រះជាម្ចាស់បានរើសតាំងអ្នកឡើង។ ព្រះជាម្ចាស់ តែងតែមានគោលការណ៍របស់ទ្រង់នៅក្នុងការជ្រើសរើសមនុស្សឲ្យបម្រើទ្រង់។ ការបម្រើព្រះជាម្ចាស់ មិនដូចអ្វីដែលមនុស្សស្រមើស្រមៃថា ជារឿងដ៏រំភើបនោះឡើយ។ សព្វថ្ងៃនេះ អ្នករាល់គ្នាមើលឃើញថា មនុស្សទាំងអស់ ដែលបម្រើនៅចំពោះព្រះជាម្ចាស់ ធ្វើដូច្នេះ ដោយព្រោះពួកគេមានការណែនាំពីព្រះជាម្ចាស់ មានកិច្ចការពីព្រះវិញ្ញាណបរិសុទ្ធ និងដោយសារគេជាមនុស្ស ដែលស្វែងរកសេចក្ដីពិត។ ទាំងអស់នេះជាលក្ខខណ្ឌតិចតួច

បំផុតសម្រាប់អស់អ្នកណាដែលបម្រើព្រះជាម្ចាស់។

ការបម្រើព្រះជាម្ចាស់ មិនមែនជាកិច្ចការសាមញ្ញនោះឡើយ។ អស់អ្នកដែលមាននិស្ស័យពុករលួយ និងមិនផ្លាស់ប្រែ មិនអាចបម្រើព្រះជាម្ចាស់បានឡើយ។ ប្រសិនបើនិស្ស័យរបស់អ្នកមិនត្រូវបានវិនិច្ឆ័យ និងវាយប្រដៅដោយព្រះបន្ទូលរបស់ព្រះជាម្ចាស់ទេ នោះនិស្ស័យរបស់អ្នក នៅតែតំណាងឲ្យសាតាំងនៅឡើយ ហើយនេះបញ្ជាក់ថា អ្នកបម្រើព្រះជាម្ចាស់ ដោយចេញពីចេតនាល្អរបស់អ្នក និងបញ្ជាក់ថា ការបម្រើរបស់អ្នក ផ្អែកតាមនិស្ស័យដែលមកពីសាតាំងតែប៉ុណ្ណោះ។ អ្នកបម្រើព្រះជាម្ចាស់ដោយអត្តចរិតពីកំណើតរបស់អ្នក និងអាស្រ័យតាមចំណង់ចំណូលចិត្តផ្ទាល់ខ្លួនរបស់អ្នក។ លើសពីនេះទៀត អ្នកតែងតែគិតថា អ្វីដែលអ្នកព្រមធ្វើ គឺជាកិច្ចការដែលគាប់ព្រះហឫទ័យដល់ព្រះជាម្ចាស់ ហើយអ្វីដែលអ្នកមិនចង់ធ្វើ គឺជាកិច្ចការដែលព្រះជាម្ចាស់ស្អប់ ដូច្នេះ អ្នកធ្វើកិច្ចការគ្រប់យ៉ាង អាស្រ័យទៅតាមចំណង់ចំណូលចិត្តផ្ទាល់ខ្លួនរបស់អ្នកទេ។ តើការធ្វើដូចនេះ អាចរាប់ថាជាការបម្រើព្រះជាម្ចាស់បានដែរឬទេ? នៅទីបំផុត និស្ស័យរបស់អ្នកនឹងមិនមានការផ្លាស់ប្ដូរបន្តិចណាសោះឡើយ ផ្ទុយទៅវិញ ការបម្រើរបស់អ្នកនឹងធ្វើឲ្យអ្នកមានចិត្តរឹងរូសកាន់តែខ្លាំង ដូច្នេះ ការប្រកាន់ខ្ជាប់នូវនិស្ស័យពុករលួយរបស់អ្នកបែបនេះ នឹងបង្កើតឲ្យមានច្បាប់ អំពីការបម្រើព្រះជាម្ចាស់ដែលពឹងផ្អែកជាចម្បងលើចរិតផ្ទាល់ខ្លួនរបស់អ្នក និងអាងលើបទពិសោធដែលត្រូវបានដកចេញពីការបម្រើរបស់អ្នក ដោយផ្អែកលើនិស្ស័យផ្ទាល់ខ្លួនរបស់អ្នក។ ទាំងនេះជាបទពិសោធ និងជាមេរៀនរបស់មនុស្ស។ វាជាទស្សនៈវិជ្ជានៃការរស់នៅរបស់មនុស្សនៅលើពិភពលោក។ មនុស្សដែលចូលចិត្តបែបនេះ អាចត្រូវបានចាត់ថ្នាក់ជាពួកផារីស៊ី និងជាអ្នកដឹកនាំសាសនា។ ប្រសិនបើពួកគេមិនភ្ញាក់ខ្លួន ហើយប្រែចិត្តទេ នោះពួកគេនឹងប្រែក្លាយជាព្រះគ្រីស្ទក្លែងក្លាយ និងពួកទទឹងនឹងព្រះគ្រីស្ទ ដែលបោកបញ្ឆោតមនុស្សនៅគ្រាចុងក្រោយមិនខាន។ ព្រះគ្រីស្ទក្លែងក្លាយ និងពួកទទឹងនឹងព្រះគ្រីស្ទដែលគេនិយាយនោះ នឹងលេចចេញពីចំណោមមនុស្សបែបនេះ។ ប្រសិនបើអស់អ្នកដែលបម្រើព្រះជាម្ចាស់ ធ្វើតាម

អត្តចរិតផ្ទាល់របស់គេ និងប្រព្រឹត្តតាមឆន្ទៈរបស់គេផ្ទាល់ អ្នកទាំងនោះនឹងប្រឈមនឹងការបណ្ដេញចេញ នៅពេលណាមួយជាមិនខាន។ អស់អ្នកដែលប្រើបទពិសោធជាច្រើនឆ្នាំ ដែលខ្លួនទទួលបានពីការបម្រើព្រះជាម្ចាស់ ដើម្បីយកឈ្នះចិត្តមនុស្ស ដើម្បីបង្រៀន និងគ្រប់គ្រងមនុស្ស និងដើម្បីឲ្យបានខ្ពស់មុខខ្ពស់មាត់ តែមិនដែលកែប្រែចិត្ត មិនដែលលន់តួបាប និងមិនដែលលះបង់ប្រយោជន៍ពីមុខតំណែងរបស់ខ្លួន មនុស្សទាំងនេះនឹងត្រូវលុតជង្គង់នៅចំពោះព្រះជាម្ចាស់មិនខាន។ ដូចជាប៉ុលដែរ ពួកគេចូលចិត្តអួតអាង អំពីឋានៈ បុណ្យសក្តិដ៏ខ្ពង់ខ្ពស់របស់ខ្លួន និងសម្ដែងពីគុណសម្បត្តិរបស់ពួកគេ។ ព្រះជាម្ចាស់នឹងមិនធ្វើឲ្យមនុស្សបែបនេះបានគ្រប់លក្ខណ៍ឡើយ។ ការបម្រើបែបនេះ រំខានដល់កិច្ចការរបស់ព្រះជាម្ចាស់វិញទេ។ មនុស្សតែងតែប្រកាន់ខ្ជាប់ទៅនឹងរបៀបចាស់ៗ។ ពួកគេប្រកាន់ខ្ជាប់ទៅនឹងគំនិតចាស់ ទៅនឹងអ្វីៗគ្រប់យ៉ាងដែលកន្លងហួសទៅ។ នេះហើយជាឧបសគ្គដ៏ធំចំពោះការបម្រើព្រះជាម្ចាស់របស់ពួកគេ។ ប្រសិនបើអ្នកមិនអាចបោះវាចោលបានទេ របៀបចាស់ៗទាំងនេះ នឹងរួបរឹតជីវិតរបស់អ្នកទាំងមូលមិនខាន។ ព្រះជាម្ចាស់នឹងមិនសរសើរអ្នកឡើយ សូម្បីតែបន្តិច ទោះជាអ្នកបាក់ជើងពេលកំពុងរត់ ឬឈឺខ្នង ពេលកំពុងធ្វើការ ឬទោះត្រូវបានស្លាប់ដោយសារតែជំនឿរបស់អ្នកក្នុងការបម្រើទ្រង់ក៏ដោយ ក៏ទ្រង់មិនសរសើរដែរ។ ផ្ទុយទៅវិញ ទ្រង់នឹងមានបន្ទូលថា អ្នកជាមនុស្សដែលប្រព្រឹត្តអាក្រក់។

ចាប់ផ្ដើមពីថ្ងៃនេះទៅ ព្រះជាម្ចាស់នឹងធ្វើឲ្យបានគ្រប់លក្ខណ៍ជាផ្លូវការ ចំពោះអស់អ្នកដែលគ្មានគំនិតបែបសាសនា អស់អ្នកដែលព្រមទុកជីវិតចាស់របស់ខ្លួនដោយឡែក និងអស់អ្នកដែលស្ដាប់បង្គាប់ព្រះជាម្ចាស់ដោយចិត្តទៀងត្រង់។ ព្រះអង្គនឹងធ្វើឲ្យអស់អ្នកដែលស្រេកឃ្លានព្រះបន្ទូលរបស់ព្រះជាម្ចាស់ បានគ្រប់លក្ខណ៍។ មនុស្សទាំងអស់នោះគួរតែក្រោកឈរឡើង ហើយបម្រើព្រះជាម្ចាស់។ នៅក្នុងព្រះជាម្ចាស់ មានភាពពេញបរិបូរគ្មានទីបញ្ចប់ និងមានព្រះប្រាជ្ញាញាណ ដែលគ្មានដែនកំណត់។ មនុស្សកាន់តែច្រើនឡើងៗ កំពុងតែទន្ទឹងរង់ចាំចង់បានកិច្ចការដ៏អស្ចារ្យ និងព្រះបន្ទូលដ៏មានតម្លៃរបស់ទ្រង់ដោយចិត្តរីករាយ។ បច្ចុប្បន្ននេះ អស់អ្នកដែល

មានគំនិតសាសនា អស់អ្នកដែលអួតអាងពីឋានៈ និងអស់អ្នកដែលមិនអាចទុកខ្លួនពួកគេនៅដោយឡែក នឹងមានការពិបាកក្នុងការទទួលយកនូវរបៀបថ្មីៗទាំងនេះ។ ព្រះវិញ្ញាណបរិសុទ្ធគ្មានឱកាសធ្វើឲ្យមនុស្សទាំងនេះបានគ្រប់លក្ខណ៍នោះឡើយ។ ប្រសិនបើមនុស្សម្នាក់ មិនបានតាំងចិត្តក្នុងការស្ដាប់បង្គាប់ ហើយមិនស្រេកឃ្លានព្រះបន្ទូលរបស់ព្រះជាម្ចាស់ទេ នោះពួកគេគ្មានផ្លូវនឹងទទួលយករបៀបថ្មីទាំងនេះឡើយ។ ពួកគេនឹងក្លាយជាមនុស្សបះបោរកាន់តែខ្លាំង កាន់តែមានកលល្បិច ហើយចុងបញ្ចប់ ពួកគេនឹងដើរនៅលើផ្លូវខុស។ ដើម្បីសម្រេចកិច្ចការរបស់ទ្រង់ ពេលនេះព្រះជាម្ចាស់នឹងរើសមនុស្សថែមទៀត ជាអ្នកដែលស្រឡាញ់ទ្រង់ពិត និងអាចទទួលពន្លឺថ្មី ហើយទ្រង់នឹងកាត់បន្ថយទាំងស្រុងនូវអ្នកដឹកនាំសាសនាណា ដែលអួតអាងពីឋានៈរបស់ខ្លួន។ ចំពោះមនុស្សណាដែលក្បាលរឹង មិនចង់ផ្លាស់ប្រែ គឺទ្រង់មិនត្រូវការពួកគេសោះឡើយ សូម្បីតែម្នាក់ក៏ទ្រង់មិនចង់បានផង។ តើអ្នកចង់ក្លាយដូចជាមនុស្សទាំងនេះដែរឬទេ? តើអ្នកបម្រើព្រះជាម្ចាស់ ដោយចេញពីចំណង់ចំណូលចិត្តរបស់អ្នក ឬក៏តាមអ្វីដែលព្រះជាម្ចាស់តម្រូវដែរឬទេ? នេះជាអ្វីដែលអ្នកត្រូវតែដឹងដោយខ្លួនឯង។ តើអ្នកជាអ្នកដឹកនាំសាសនា ឬក៏ជាទារកកើតជាថ្មី ដែលព្រះជាម្ចាស់ធ្វើឲ្យបានគ្រប់លក្ខណ៍? តើមានការបម្រើរបស់នរណាខ្លះ ដែលទទួលបានការសរសើរពីព្រះវិញ្ញាណបរិសុទ្ធ? តើមានការបម្រើរបស់នរណាខ្លះទៀត ដែលព្រះជាម្ចាស់មិននឹកចាំ? តាមរយៈការបម្រើព្រះជាម្ចាស់ជាច្រើនឆ្នាំមកនេះ តើវាបានបំផ្លាស់បំប្រែជីវិតរបស់អ្នកយ៉ាងសម្បើមយ៉ាងណាទៅ? តើអ្នកយល់ច្បាស់ហើយឬនៅ អំពីការទាំងអស់? ប្រសិនបើអ្នកមានសេចក្ដីជំនឿពិតប្រាកដមែន នោះអ្នកនឹងបោះចោលគំនិតសាសនាចាស់ៗរបស់អ្នកកាលពីមុន ហើយអ្នកនឹងបម្រើព្រះជាម្ចាស់កាន់តែប្រសើរឡើង តាមរបៀបមួយថ្មីមិនខាន។ ឥឡូវនេះ ក្រោកឈរក៏មិនទាន់ហួសពេលដែរ។ គំនិតសាសនាចាស់ៗ អាចធ្វើឲ្យជីវិតទាំងមូលរបស់មនុស្សម្នាក់ បាត់បង់បាន។ បទពិសោធដែលមនុស្សម្នាក់ទទួលបាន អាចធ្វើឲ្យគេឃ្លាតឆ្ងាយពីព្រះជាម្ចាស់ ហើយធ្វើអ្វីតាមតែអំពើចិត្តរបស់គេ។ ប្រសិនបើអ្នកមិនបោះការទាំងនេះចោលទេ នោះវា

នឹងត្រឡប់ទៅជាថ្មជំពប់ដល់ការរីកចម្រើនក្នុងជីវិតរបស់អ្នកមិនខាន។ ព្រះជាម្ចាស់តែងតែធ្វើឲ្យអស់អ្នកដែលបម្រើទ្រង់ បានគ្រប់លក្ខណ៍ ហើយមិនងាយបោះបង់ពួកគេចោលឡើយ។ ប្រសិនបើអ្នកពិតជាទទួលយកការជំនុំជម្រះ និងការវាយផ្ចាលដោយព្រះបន្ទូលរបស់ព្រះជាម្ចាស់ ប្រសិនបើអ្នកអាចបោះចោលការអនុវត្ត និងច្បាប់សាសនាចាស់ៗរបស់អ្នក ហើយឈប់ប្រើគំនិតសាសនាចាស់គំរិល មកប្រៀបធៀបនឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅថ្ងៃនេះ នោះអ្នកនឹងមានអនាគតជាក់ជាមិនខាន។ ប៉ុន្តែ ប្រសិនបើអ្នកកាន់ខ្ជាប់តាមរបៀបចាស់ៗ ប្រសិនបើអ្នកនៅតែឱ្យតម្លៃវាខ្លាំង នោះអ្នកគ្មានផ្លូវទទួលបានសេចក្តីសង្គ្រោះឡើយ។ ព្រះជាម្ចាស់មិនឲ្យតម្លៃមនុស្សបែបនេះទេ។ ប្រសិនបើអ្នកពិតជាចង់ឲ្យព្រះជាម្ចាស់ធ្វើឲ្យអ្នកបានគ្រប់លក្ខណ៍ នោះអ្នកត្រូវតែសម្រេចចិត្តបោះចោលអ្វីៗទាំងអស់កាលពីមុន។ បើទោះបីជាអ្វី ដែលបានធ្វើកាលពីមុនត្រូវ ហើយទោះបីវាជាកិច្ចការរបស់ព្រះជាម្ចាស់ក៏ដោយ ក៏អ្នកត្រូវតែបោះវាចោល និងឈប់ប្រកាន់ខ្ជាប់តាមវាដែរ។ ទោះបីវាបានស្ដែងច្បាស់ថា ជាកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ដែលព្រះវិញ្ញាណបរិសុទ្ធធ្វើផ្ទាល់ក៏ដោយ ប៉ុន្តែនៅថ្ងៃនេះ អ្នកត្រូវតែបោះវាចោល។ ដាច់ខាត អ្នកមិនត្រូវពឹងផ្អែកលើវាទៀតឡើយ។ នេះជាអ្វីដែលព្រះជាម្ចាស់ទាមទារ។ អ្វីៗគ្រប់ យ៉ាងត្រូវតែផ្លាស់ជាថ្មីវិញ។ នៅក្នុងកិច្ចការ និងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ទ្រង់មិនមានបន្ទូលអំពីរបៀបចាស់ៗ ដែលទ្រង់បានធ្វើកាលពីមុន ហើយក៏ទ្រង់មិនជីកកកាយពីទិវាប្រវត្តិចាស់ដែរ ប៉ុន្តែព្រះជាម្ចាស់ជាព្រះដែលតែងតែថ្មីជានិច្ច មិនដែលចាស់ឡើយ ហើយក៏មិនប្រកាន់ខ្ជាប់ សូម្បីទៅនឹងព្រះបន្ទូលផ្ទាល់របស់ ទ្រង់ពីអតីតកាល។ ការនេះបង្ហាញថា ព្រះជាម្ចាស់មិនគោរពតាមច្បាប់ណាមួយឡើយ។ ដូច្នេះ ក្នុងនាមជាមនុស្សម្នាក់ ប្រសិនបើអ្នកតែងតែប្រកាន់ខ្ជាប់ទៅនឹងអ្វីដែលនៅអតីតកាល ប្រសិនបើអ្នកមិនព្រមប្រលែងវាចេញ ហើយអនុវត្តវាយ៉ាងតឹងរឹងទៅតាមក្បួនច្បាប់ ខណៈដែលព្រះជាម្ចាស់លែងធ្វើការដោយប្រើមធ្យោបាយដែលទ្រង់បានធ្វើពីមុនទៀត ដូច្នេះ តើពាក្យសម្ដី និងសកម្មភាពរបស់អ្នកមិនមានការរំខានទេឬអី? តើអ្នកមិនក្លាយជាសត្រូវរបស់ព្រះជាម្ចាស់ទេឬ? តើអ្នកព្រម

អនុញ្ញាតឲ្យជីវិតទាំងមូលរបស់អ្នកប្រែជាក្រឡាប់ចក្រ និងត្រូវបំផ្លាញ ដោយសារតែរបៀបចាស់ៗទាំងនេះឬអី? របៀបចាស់ៗទាំងអស់នេះ នឹងធ្វើឲ្យអ្នកក្លាយទៅជាមនុស្សម្នាក់ ដែលរារាំងកិច្ចការរបស់ព្រះជាម្ចាស់ តើអ្នកចង់ធ្វើជាមនុស្សប្រភេទនេះឬ? ប្រសិនបើអ្នកពិតជាមិនចង់ក្លាយជាមនុស្សប្រភេទនេះទេ ចូរប្រញាប់បញ្ឈប់អ្វីដែលកំពុងធ្វើនេះ ហើយបកក្រោយចាប់ផ្ដើមជីវិតសាជាថ្មីវិញ។ ព្រះជាម្ចាស់នឹងមិននឹកចាំការបម្រើរបស់អ្នកពីអតីតកាលឡើយ។

# អ្នកគួរតែស្ដាប់បង្គាប់ព្រះជាម្ចាស់ នៅក្នុងជំនឿដែលអ្នកជឿដល់ទ្រង់

ហេតុអ្វីបានជាអ្នកជឿលើព្រះជាម្ចាស់? មនុស្សភាគច្រើន ត្រូវស្រឡាំងកាំងដោយសារតែសំណួរនេះ។ ពួកគេតែងតែមានទស្សនៈពីរផ្ទុយគ្នាស្រឡះអំពីព្រះដ៏ជាក់ស្ដែង និងព្រះជាម្ចាស់ដែលគង់នៅស្ថានសួគ៌ ហើយការនេះបង្ហាញថា ពួកគេជឿទៅលើព្រះជាម្ចាស់ មិនមែនដើម្បីស្ដាប់បង្គាប់ទ្រង់ឡើយ ប៉ុន្តែដើម្បីទទួលបានផលប្រយោជន៍ណាមួយ ឬដើម្បីឲ្យបានរួចខ្លួនពីទុក្ខវេទនា ដែលកើតពីគ្រោះមហន្តរាយតែប៉ុណ្ណោះ។ ទាល់តែបែបនេះ ទើបពួកគេស្ដាប់បង្គាប់ខ្លះ។ ការស្ដាប់បង្គាប់របស់គេមានលក្ខខណ្ឌ ហើយគេធ្វើឡើងដោយបង្ខំចិត្ត ទាំងគិតដល់ប្រយោជន៍របស់គេ។ បើដូច្នេះ ហេតុអ្វីក៏អ្នកជឿលើព្រះជាម្ចាស់? ប្រសិនបើអ្នកជឿដើម្បីតែផលប្រយោជន៍ និងដើម្បីសម្រេចជោគវាសនារបស់ខ្លួន នោះកុំជឿព្រះអង្គល្អជាង។ សេចក្ដីជំនឿបែបនេះ គឺជាការបញ្ឆោតខ្លួនឯង ជាការធានាដល់ខ្លួនឯង និងជាការកោតសរសើរដល់ខ្លួនឯង។ ប្រសិនបើសេចក្ដីជំនឿរបស់អ្នក មិនត្រូវបានសង់ឡើងពីលើគ្រឹះនៃការស្ដាប់បង្គាប់ព្រះជាម្ចាស់ទេ នៅទីបំផុត អ្នកនឹងត្រូវដាក់ទោសចំពោះការទាស់ទទឹងនឹងទ្រង់វិញមិនខាន។ អស់អ្នកណាដែលមិនព្យាយាមស្ដាប់បង្គាប់ព្រះជាម្ចាស់ នៅក្នុងសេចក្ដីជំនឿរបស់គេ គឺទាស់ទទឹងនឹងទ្រង់ហើយ។ ព្រះជាម្ចាស់បង្គាប់ឲ្យ

មនុស្សស្វែងរកសេចក្ដីពិត ឲ្យគេស្រេកឃ្លានព្រះបន្ទូលរបស់ទ្រង់ ឲ្យគេហូប និងផឹកពីព្រះបន្ទូលទ្រង់ ហើយប្រតិបត្តិតាមព្រះបន្ទូលទាំងនោះ ដើម្បីឲ្យគេអាចសម្រេចបាននូវការស្ដាប់បង្គាប់តាមព្រះជាម្ចាស់។ ប្រសិនបើចំណុចទាំងនេះ គឺជាចេតនាដ៏ពិតរបស់អ្នក នោះព្រះជាម្ចាស់នឹងច្បាស់ជាលើកអ្នកឡើង ហើយទ្រង់នឹងសម្ដែងព្រះគុណរបស់ទ្រង់ដល់អ្នកជាប្រាកដ។ ការនេះគ្មានអ្វីដែលត្រូវសង្ស័យ និងប្រែប្រួលបានឡើយ។ ប្រសិនបើអ្នកគ្មានចេតនាស្ដាប់បង្គាប់ព្រះជាម្ចាស់ ហើយអ្នកមានគោលបំណងផ្សេង ដូច្នេះ គ្រប់យ៉ាងដែលអ្នកនិយាយនិងធ្វើ គឺទាំងពាក្យអធិស្ឋានរបស់អ្នកនៅចំពោះព្រះជាម្ចាស់ ព្រមទាំងគ្រប់ទង្វើរបស់អ្នក នឹងក្លាយជាការទាស់ទទឹងនឹងទ្រង់ជាក់ជាមិនខាន។ អ្នកប្រហែលជាមនុស្សម្នាក់ដែលនិយាយស្ដីទន់ភ្លន់ និងមានចរិតស្លូតបូត គ្រប់ទង្វើនិងកាយវិការរបស់អ្នកអាចមើលទៅមានភាពរម្យទម ហើយអ្នកអាចធ្វើខ្លួនដូចជាមនុស្សម្នាក់ដែលស្ដាប់បង្គាប់ ប៉ុន្តែពេលដែលនិយាយដល់ចេតនា និងទស្សនៈរបស់អ្នកចំពោះសេចក្ដីជំនឿលើព្រះជាម្ចាស់វិញ គ្រប់យ៉ាងដែលអ្នកធ្វើ សុទ្ធតែទាស់ទទឹងនឹងព្រះជាម្ចាស់ គ្រប់យ៉ាងដែលអ្នកធ្វើ សុទ្ធតែអាក្រក់ទាំងអស់។ មនុស្សដែលមើលទៅស្ដាប់បង្គាប់ដូចជាសត្វចៀម ប៉ុន្តែដួងចិត្តរបស់គេពេញដោយចេតនាអាក្រក់ គឺប្រៀបដូចជាសត្វចចកដែលពាក់ស្បែកចៀមដូច្នោះដែរ។ ពួកគេប្រមាថព្រះជាម្ចាស់ដោយផ្ទាល់ ហើយព្រះអង្គនឹងមិនត្រាប្រណីដល់ពួកគេណាម្នាក់ឡើយ។ ព្រះវិញ្ញាណបរិសុទ្ធនឹងបើកសម្ដែងពីពួកគេម្ដងម្នាក់ៗ ហើយបង្ហាញដល់មនុស្សគ្រប់គ្នាឲ្យឃើញថា ពួកមនុស្សកំពុត ច្បាស់ជាត្រូវព្រះវិញ្ញាណបរិសុទ្ធស្អប់ខ្ពើម និងបដិសេធជាមិនខាន។ ចូរកុំបារម្ភឡើយ៖ ព្រះជាម្ចាស់នឹងគិតបញ្ជី ហើយចាត់ការជាមួយនឹងពួកគេម្នាក់ៗវិញមិនខាន។

បើអ្នកមិនអាចទទួលយកពន្លឺថ្មីពីព្រះជាម្ចាស់និងមិនអាចយល់ ហើយមិនព្យាយាមស្វែងយល់គ្រប់ទាំងសេចក្ដីដែលទ្រង់ធ្វើនាពេលសព្វថ្ងៃ អ្នកប្រាកដជាដាក់ការរិះគន់ ឬពិនិត្យពិច័យ ហើយវិភាគទៅលើសេចក្ដីទាំងនោះជាមិនខាន ពុំនោះទេអ្នកច្បាស់ជាសង្ស័យ ដូច្នេះ អ្នកគ្មានគំនិតចង់ស្ដាប់បង្គាប់ព្រះជាម្ចាស់ឡើយ។ នៅពេលដែលពន្លឺ

បច្ចុប្បន្នលេចចេញមក ប្រសិនបើអ្នកនៅតែឲ្យតម្លៃទៅលើពន្លឺពីអតីតកាល ហើយប្រឆាំងនឹងកិច្ចការថ្មីរបស់ព្រះជាម្ចាស់ នោះអ្នកជាមនុស្សល្ងីល្ងើហើយ ដ្បិតអ្នកស្ថិតនៅក្នុងចំណោមមនុស្ស ដែលមានចេតនាទាស់ទទឹងនឹងព្រះជាម្ចាស់។ គន្លឹះក្នុងការស្ដាប់បង្គាប់ព្រះជាម្ចាស់ គឺការឲ្យតម្លៃពន្លឺថ្មី ហើយអាចទទួលយក និងប្រតិបត្តិតាមពន្លឺថ្មីនោះផងដែរ។ នេះហើយ គឺជាការស្ដាប់បង្គាប់ដ៏ពិត។ អស់អ្នកណាដែលមិនមានចិត្តស្រេកឃ្លានចង់បានព្រះជាម្ចាស់ គឺគ្មានបំណងចង់ចុះចូលនឹងទ្រង់ឡើយ ហើយដោយសារតែលទ្ធផលស្កប់ចិត្តជាមួយស្ថានភាពបច្ចុប្បន្នរបស់ខ្លួននេះ បានបណ្ដាលឲ្យពួកគេទាស់ទទឹងនឹងព្រះជាម្ចាស់។ មនុស្សបែបនេះ មិនអាចស្ដាប់បង្គាប់ព្រះជាម្ចាស់បានឡើយ ដោយសារតែគេបានងប់ងល់ជាមួយទិដ្ឋភាពពីអតីតកាល។ ទិដ្ឋភាពពីអតីតកាលទាំងនេះ បានផ្ដល់ឲ្យមនុស្សនូវការយល់ឃើញ និងការស្រមើស្រមៃគ្រប់យ៉ាងអំពីព្រះជាម្ចាស់ ហើយទាំងនេះបានក្លាយជារូបភាពរបស់ព្រះនៅក្នុងគំនិតរបស់គេ។ ដូច្នេះ អ្វីដែលពួកគេជឿ គឺជាសញ្ញាណរបស់ពួកគេផ្ទាល់ ហើយក្លាយជាបទដ្ឋាននៃការស្រមើស្រមៃរបស់ពួកគេ។ បើអ្នកប្រៀបធៀបព្រះជាម្ចាស់ ដែលធ្វើកិច្ចការជាក់ស្ដែងនាពេលបច្ចុប្បន្ន ជាមួយនឹងព្រះនៃការស្រមើស្រមៃរបស់អ្នក នោះសេចក្ដីជំនឿរបស់អ្នកចេញមកពីអារក្សសាតាំង ហើយវាត្រូវបង្ខូច ដោយសារសេចក្ដីលម្អៀងរបស់អ្នក។ ព្រះជាម្ចាស់មិនចង់បានសេចក្ដីជំនឿបែបនេះទេ មិនថា គុណសម្បត្តិនិងការតាំងចិត្តរបស់គេខ្ពស់ប៉ុនណា ហើយទោះជាពួកគេបានប្ដូរផ្ដាច់ប្រឹងប្រែងពេញមួយជីវិតចំពោះកិច្ចការរបស់ទ្រង់ ហើយត្រូវបានស្លាប់ដោយសារតែសេចក្ដីជំនឿរបស់ខ្លួនក៏ដោយ ក៏ព្រះជាម្ចាស់មិនសរសើរមនុស្ស ដែលមានសេចក្ដីជំនឿបែបនេះឡើយ។ ទ្រង់គ្រាន់តែប្រទានព្រះគុណបន្តិចបន្តួចដល់ពួកគេ ហើយអនុញ្ញាតឲ្យពួកគេរីករាយនឹងព្រះគុណនោះតែមួយដងប៉ុណ្ណោះ។ មនុស្សបែបនេះគ្មានសមត្ថភាពប្រតិបត្តិតាមសេចក្ដីពិតឡើយ។ ព្រះវិញ្ញាណបរិសុទ្ធមិនធ្វើការនៅក្នុងពួកគេទេ ហើយព្រះជាម្ចាស់នឹងផាត់ពួកគេម្ដងម្នាក់ៗចោលមិនខាន។ អស់អ្នកដែលមិនស្ដាប់បង្គាប់ព្រះជាម្ចាស់នៅក្នុងសេចក្ដីជំនឿរបស់គេ និងមានចេតនាអាក្រក់ មិនថាអ្នកទាំងនោះក្មេង ឬ

ចាស់ឡើយ ពួកគេសុទ្ធតែទាស់ទទឹង និងបង្អាក់ដល់កិច្ចការរបស់ព្រះជាម្ចាស់ ហើយមនុស្សបែបនេះនឹងត្រូវព្រះជាម្ចាស់ផាត់ចោល ដោយគ្មានអ្វីសង្ស័យឡើយ។ មនុស្សដែលមិនស្ដាប់បង្គាប់ព្រះជាម្ចាស់សូម្បីតែបន្តិច មនុស្សដែលគ្រាន់តែទទួលស្គាល់ព្រះនាមទ្រង់ ហើយមានការយល់ដឹងខ្លះអំពីព្រះហឫទ័យដ៏សប្បុរស និងព្រះទ័យស្រឡាញ់របស់ព្រះជាម្ចាស់ ប៉ុន្ដែដើរមិនទាន់លំអានព្រះបាទារបស់ព្រះវិញ្ញាណបរិសុទ្ធ ហើយមិនស្ដាប់បង្គាប់តាមកិច្ចការបច្ចុប្បន្ន និងមិនស្ដាប់តាមព្រះបន្ទូលនៃព្រះវិញ្ញាណបរិសុទ្ធ គឺជាមនុស្សដែលរស់នៅក្នុងចំណោមព្រះគុណនៃព្រះ ប៉ុន្ដែពួកគេនឹងមិនត្រូវបានទ្រង់ទទួលយក ឬប្រោសឲ្យបានគ្រប់លក្ខណ៍នោះទេ។ ព្រះជាម្ចាស់ប្រោសឲ្យមនុស្សទៅជាគ្រប់លក្ខណ៍ តាមរយៈការស្ដាប់បង្គាប់របស់គេ តាមរយៈការហូប ការផឹក និងការរីករាយជាមួយព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងតាមរយៈការរងទុក្ខ និងការបន្សុទ្ធនៅក្នុងជីវិតរបស់គេ។ មានតែតាមរយៈសេចក្ដីជំនឿបែបនេះទេ ទើបនិស្ស័យរបស់មនុស្សអាចត្រូវបានផ្លាស់ប្រែ ហើយពួកគេអាចមានចំណេះដឹងដ៏ពិតអំពីព្រះជាម្ចាស់។ ការមិនស្កប់ចិត្ត ជាមួយការរស់នៅក្នុងព្រះគុណនៃព្រះ ការខំស្វែងរក និងការស្រេកឃ្លានចង់បានសេចក្ដីពិតយ៉ាងខ្នះខ្នែង និងការព្យាយាមឲ្យព្រះជាម្ចាស់ទទួលយក នេះហើយជាអត្ថន័យនៃការស្ដាប់បង្គាប់តាមព្រះជាម្ចាស់ដោយបញ្ញាចិត្ត និងជាប្រភេទនៃសេចក្ដីជំនឿដែលព្រះអង្គចង់បាន។ មនុស្សដែលមិនធ្វើអ្វីសោះ ក្រៅពីរីករាយនឹងព្រះគុណនៃព្រះ មិនអាចត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍ ឬត្រូវបំផ្លាស់បំប្រែបានឡើយ។ រីឯការស្ដាប់បង្គាប់ ការគោរពប្រតិបត្តិដល់ព្រះ សេចក្ដីស្រឡាញ់ និងចិត្តអត់ធ្មត់របស់ពួកគេ សុទ្ធតែជាទង្វើលំៗទាំងអស់។ មនុស្សដែលគ្រាន់តែរីករាយនឹងព្រះគុណនៃព្រះមិនអាចស្គាល់ព្រះជាម្ចាស់យ៉ាងពិតប្រាកដឡើយ ហើយបើទោះបីជាពួកគេស្គាល់ព្រះជាម្ចាស់ក៏ដោយ ប៉ុន្ដែចំណេះដឹងរបស់គេនៅមានកម្រិតលំៗ ហើយគេនិយាយសេចក្ដីមួយចំនួនដូចជា «ព្រះជាម្ចាស់ស្រឡាញ់មនុស្ស» ឬ «ព្រះជាម្ចាស់ មានព្រះហឫទ័យអាណិតមេត្តាចំពោះមនុស្ស»។ កត្តានេះមិនតំណាងឲ្យជីវិតរបស់មនុស្ស ហើយក៏មិនបង្ហាញថា មនុស្សពិតជាស្គាល់ព្រះជាម្ចាស់

នោះឡើយ។ ប្រសិនបើមនុស្សមិនស្ដាប់បង្គាប់ព្រះជាម្ចាស់ទេ នោះព្រះបន្ទូលរបស់ព្រះជាម្ចាស់មិនអាចបន្សុទ្ធពួកគេ ហើយកាលណាសេចក្ដីល្បងលរបស់ទ្រង់មកដល់ពួកគេក៏មិនអាចស្ដាប់បង្គាប់ព្រះជាម្ចាស់ដែរ។ ផ្ទុយទៅវិញ បើពួកគេមានចិត្តសង្ស័យ និងជំពប់ដួល នោះពួកគេមិនមានការស្ដាប់បង្គាប់សោះឡើយ មានក្រឹត្យក្រម និងសេចក្ដីរឹតត្បិតជាច្រើន ទាក់ទងនឹងសេចក្ដីជំនឿជឿលើព្រះជាម្ចាស់នៅក្នុងពួកគេ ដូចជា បទពិសោធចាស់ៗដែលជាលទ្ធផលចេញពីសេចក្ដីជំនឿរយៈពេលជាច្រើនឆ្នាំ ឬពីគោលច្បាប់វិន័យផ្សេងៗដែលផ្អែកលើព្រះគម្ពីរ។ តើមនុស្សបែបនេះអាចស្ដាប់បង្គាប់ព្រះជាម្ចាស់បានដែរឬទេ? មនុស្សទាំងនេះ ពោរពេញដោយនិស្ស័យជាមនុស្ស។ តើពួកគេអាចស្ដាប់បង្គាប់ព្រះជាម្ចាស់ដោយរបៀបណា? «ការស្ដាប់បង្គាប់» របស់គេ គឺស្របតាមចំណង់ចំណូលចិត្តផ្ទាល់ខ្លួន។ តើព្រះជាម្ចាស់ចង់បានការស្ដាប់បង្គាប់បែបនេះដែរឬទេ? នេះមិនមែនជាការស្ដាប់បង្គាប់ព្រះជាម្ចាស់ឡើយ ប៉ុន្តែវាជាការប្រកាន់ខ្ជាប់តាមច្បាប់វិន័យនានា ជាការបំពេញចិត្ត និងជាការធ្វើឲ្យចិត្តរបស់ពួកគេបានស្ងប់ប៉ុណ្ណោះ។ ប្រសិនបើអ្នកនិយាយថា នេះជាការស្ដាប់បង្គាប់ដល់ព្រះជាម្ចាស់ តើអ្នកមិនប្រមាថទ្រង់ទៅហើយទេឬអី? អ្នកជាព្រះចៅផារ៉ោន ស្ដេចស្រុកអេស៊ីព្ទ។ អ្នកប្រព្រឹត្តអំពើអាក្រក់ និងបានចូលរួមនៅក្នុងកិច្ចការទាស់ទទឹងនឹងព្រះជាម្ចាស់ តើនេះជារបៀបដែលព្រះជាម្ចាស់ចង់ឲ្យអ្នកបម្រើទ្រង់មែនទេ? អ្នកគួរតែឆាប់ប្រែចិត្ត ហើយព្យាយាមស្គាល់ខ្លួនឯងឲ្យបានច្បាស់ជាងនេះវិញ។ បើមិនដូច្នោះទេ អ្នកគួរតែត្រលប់ទៅផ្ទះវិញទៅវាល្អជាង ដ្បិតការត្រលប់ទៅវិញនឹងផ្ដល់ប្រយោជន៍ល្អដល់អ្នក ជាងការបម្រើព្រះជាម្ចាស់ ត្រឹមតែបបូរមាត់។ អ្នកមុខជាមិនបង្អាក់ និងរំខានដល់កិច្ចការរបស់ទ្រង់ឡើយ។ អ្នកនឹងស្គាល់ឋានៈរបស់ខ្លួន ហើយរស់នៅយ៉ាងស្រួលដូច្នេះ តើការធ្វើបែបនេះនឹងមិនប្រសើរជាងទេឬអី? ហើយអ្នកនឹងមិនត្រូវទទួលទោសចំពោះការទាស់ទទឹងនឹងព្រះជាម្ចាស់ឡើយ!

# សេចក្តីសន្យាចំពោះអស់អ្នកដែល ត្រូវបានប្រោសឲ្យបានគ្រប់លក្ខណ៍

តើអ្វីទៅជាផ្លូវ ដែលព្រះជាម្ចាស់ប្រោសឲ្យមនុស្សក្លាយជាគ្រប់លក្ខណ៍? តើរាប់បញ្ចូលកត្តាអ្វីខ្លះ? តើអ្នកស្ម័គ្រចិត្តឲ្យព្រះជាម្ចាស់ប្រោសអ្នកឲ្យបានគ្រប់លក្ខណ៍ដែរឬទេ? តើអ្នកព្រមទទួលយកការជំនុំជម្រះ និងការដាក់ទោសពីទ្រង់ដែរឬទេ? តើអ្នករាល់គ្នាដឹងអ្វីខ្លះអំពីសំណួរទាំងនេះ? ប្រសិនបើអ្នកមិនដឹងថា និយាយដូចម្តេចទេ នេះគឺជាភស្តុតាងបញ្ជាក់ថា អ្នកនៅតែមិនស្គាល់ពីកិច្ចការរបស់ព្រះជាម្ចាស់បញ្ជាក់ថា អ្នកមិនបានទទួលការបំភ្លឺ ដោយព្រះវិញ្ញាណបរិសុទ្ធទាល់តែសោះ។ មនុស្សបែបនេះមិនអាចក្លាយជាមនុស្សគ្រប់លក្ខណ៍បានទេ។ ពួកគេនឹងត្រឹមតែទទួលបាននូវព្រះគុណតិចតួចប៉ុណ្ណោះ ដើម្បីរីករាយក្នុងរយៈពេលខ្លី ហើយនឹងមិនឋិតថេរឡើយ។ មនុស្សមិនអាចទទួលភាពគ្រប់លក្ខណ៍ពីព្រះជាម្ចាស់បានទេ ប្រសិនបើពួកគេគ្រាន់តែរីករាយ នឹងព្រះគុណរបស់ទ្រង់នោះ។ អ្នកខ្លះពេញចិត្ត នៅពេលសាច់ឈាមរបស់ពួកគេបានសុខសាន្ត និងភាពរីករីករាយ នៅពេលដែលជីវិតរបស់ពួកគេមានភាពងាយស្រួល និងគ្មានទុក្ខលំបាក ឬសំណាងអាក្រក់ នៅពេលដែលក្រុមគ្រួសារទាំងមូលរស់នៅដោយសុខដុម គ្មានការទាស់ទែងគ្នា មិនមានជម្លោះ ហើយពួកគេថែមទាំងជឿថា នេះគឺជាព្រះពរមកពីព្រះជាម្ចាស់ទៀតផង។ តាមពិតនេះគ្រាន់តែជាព្រះគុណរបស់ព្រះជាម្ចាស់ប៉ុណ្ណោះ។ អ្នករាល់គ្នាមិនត្រូវស្កប់ចិត្ត ដោយគ្រាន់តែរីករាយនឹងព្រះគុណរបស់ព្រះជាម្ចាស់នោះឡើយ។ ការគិតបែបនេះគឺពិតជាអន់ខ្លាំងណាស់។ ទោះបីជាអ្នកអានព្រះបន្ទូលរបស់ព្រះជាម្ចាស់រាល់ថ្ងៃ និងអធិស្ឋានរៀងរាល់ថ្ងៃ ហើយវិញ្ញាណរបស់អ្នកមានអារម្មណ៍រីករាយយ៉ាងខ្លាំង ហើយមានភាពសុខសាន្តជាពិសេស ប្រសិនបើនៅទីបំផុត អ្នកមិនមានអ្វីត្រូវនិយាយអំពីចំណេះដឹងរបស់ខ្លួនទាក់ទងនឹងព្រះជាម្ចាស់ និងកិច្ចការរបស់ទ្រង់ ហើយមិនធ្លាប់មានបទពិសោធអ្វីសោះ ហើយមិនខ្វល់ថា អ្នករាល់គ្នាបានហូប និងផឹកព្រះបន្ទូលព្រះជាម្ចាស់ច្រើន

ប៉ុនណាឡើយ ប្រសិនបើអ្នកគិតតែពីភាពសុខសាន្ត និងភាពរីករាយខាងវិញ្ញាណ ហើយគិតថា ព្រះបន្ទូលរបស់ព្រះជាម្ចាស់ផ្អែមល្ហែមគ្មានអ្វីប្រដូចបាន បើទោះជាអ្នកទទួលទានយ៉ាងណាក៏មិនគ្រប់ ប៉ុន្តែអ្នកមិនមានបទពិសោធជាក់ស្តែងអ្វីទាំងអស់ទាក់ទងនឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយគ្មានតថភាពនៃព្រះបន្ទូលទ្រង់សោះ ដូច្នេះ តើអ្នកអាចទទួលបានអ្វីខ្លះពីជំនឿចំពោះព្រះជាម្ចាស់បែបនេះ? ប្រសិនបើអ្នកមិនអាចរស់នៅស្របតាមសារជាតិនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ទេ នោះការហូប និងផឹកព្រះបន្ទូលទាំងនេះ ព្រមទាំងសេចក្តីអធិស្ឋានរបស់អ្នក គឺគ្មានអ្វីខុសពីជំនឿបែបសាសនាទេ។ មនុស្សបែបនេះ នឹងមិនអាចឲ្យព្រះជាម្ចាស់កែឲ្យគ្រប់លក្ខណ៍ និងមិនអាចឲ្យព្រះជាម្ចាស់ទទួលយកបានឡើយ។ មនុស្សដែលព្រះជាម្ចាស់អាចទទួលយកបាន គឺជាមនុស្សដែលដេញតាមសេចក្តីពិត។ អ្វីដែលព្រះជាម្ចាស់ទទួលយក មិនមែនជាសាច់ឈាមរបស់មនុស្សទេ ក៏មិនមែនជារបស់ដែលជាកម្មសិទ្ធិរបស់អ្នកនោះដែរ តែគឺជាចំណែកកម្មសិទ្ធិរបស់ព្រះជាម្ចាស់នៅក្នុងអ្នកនោះ។ ដូច្នេះ នៅពេលព្រះជាម្ចាស់ប្រោសមនុស្សឲ្យបានគ្រប់លក្ខណ៍ ព្រះអង្គមិនមែនប្រោសសាច់ឈាមរបស់ពួកគេឱ្យគ្រប់លក្ខណ៍ទេ តែប្រោសចិត្តរបស់ពួកឱ្យគ្រប់លក្ខណ៍គេវិញ ដោយអនុញ្ញាតឲ្យចិត្តរបស់ពួកគេត្រូវបានទ្រង់ទទួលយក និយាយឲ្យងាយយល់ស្រួលស្តាប់ ការដែលព្រះប្រោសមនុស្សឲ្យបានគ្រប់លក្ខណ៍ គឺទ្រង់ប្រោសចិត្តពួកគេឱ្យគ្រប់លក្ខណ៍ដើម្បីឲ្យចិត្តរបស់ពួកគេអាចបែរទៅរកទ្រង់វិញ ហើយអាចស្រឡាញ់ទ្រង់ផង។

សាច់ឈាមរបស់មនុស្ស គឺជាសាច់ឈាមដែលស្លាប់។ សាច់ឈាមនេះមិនបម្រើគោលបំណងឲ្យព្រះជាម្ចាស់ ដើម្បីឲ្យទទួលបានសាច់ឈាមមនុស្សទេ ពីព្រោះសាច់ឈាមរបស់មនុស្ស គឺជាសេចក្តីពុករលួយដែលជៀសមិនរួច ហើយមិនអាចទទួលមរតក ឬព្រះពរពីទ្រង់បានឡើយ។ ប្រសិនបើព្រះជាម្ចាស់ទទួលសាច់ឈាមរបស់មនុស្ស ហើយមានតែសាច់ឈាមរបស់មនុស្សប៉ុណ្ណោះ ដែលស្ថិតនៅក្នុងចរន្តនេះ នោះទោះបីជាមនុស្សស្ថិតនៅក្នុងចរន្តនោះ ក៏ចិត្តរបស់គេគង់ជាកម្មសិទ្ធិរបស់សាតាំងដែរ។ ករណីនេះ មិនត្រឹមតែមនុស្សមិនអាចក្លាយជាការសម្តែងការអស្ចារ្យ

របស់ព្រះជាម្ចាស់ប៉ុណ្ណោះទេ ប៉ុន្តែពួកគេគង់ក្លាយជាបន្ទុករបស់ទ្រង់ផងដែរ ហើយការជ្រើសរើសមនុស្សរបស់ព្រះជាម្ចាស់ នឹងក្លាយជារឿងគ្មានន័យ។ អស់អ្នកដែលព្រះជាម្ចាស់ មានព្រះទ័យចង់បំផ្លាស់បំប្រែឲ្យបានគ្រប់លក្ខណ៍នឹងទទួលបានព្រះពរ និងមរតករបស់ទ្រង់។ មានន័យថា ពួកគេទទួលយកកម្មសិទ្ធិ និងលក្ខណៈរបស់ព្រះជាម្ចាស់ ហើយសេចក្ដីទាំងពីរក៏ក្លាយជាលក្ខណៈដែលពួកគេមាននៅក្នុងជីវិតគេ។ ពួកគេមានព្រះបន្ទូលទាំងអស់របស់ព្រះជាម្ចាស់ ធ្វើការនៅក្នុងខ្លួនពួកគេ។ អ្នករាល់គ្នាអាចទទួលយកលក្ខណៈទាំងអស់របស់ព្រះជាម្ចាស់តាមសណ្ឋានពិតនៃលក្ខណៈនោះ ទោះជាលក្ខណៈអ្វីក៏ដោយ ហើយហេតុនេះ ទើបអ្នករស់នៅតាមសេចក្ដីពិតបាន។ នេះគឺជាជំពូកមនុស្សដែលព្រះជាម្ចាស់បានបំផ្លាស់បំប្រែឲ្យគ្រប់លក្ខណ៍ និងទទួលយក។ មានតែមនុស្សជំពូកនេះទេ ទើបអាចទទួលព្រះពរដែលព្រះជាម្ចាស់ប្រទានឲ្យបាន៖

១. ការទទួលបានសេចក្ដីស្រឡាញ់ទាំងស្រុងពីព្រះជាម្ចាស់។

២. ការប្រព្រឹត្តស្របតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ក្នុងគ្រប់ការទាំងអស់។

៣. ទទួលបានការណែនាំពីព្រះជាម្ចាស់ ដោយរស់នៅក្នុងពន្លឺរបស់ទ្រង់ ហើយទទួលបានការ បំភ្លឺពីព្រះអង្គ។

៤. រស់នៅជារូបភាពដែលព្រះជាម្ចាស់ស្រឡាញ់លើផែនដីនេះ ដោយស្រឡាញ់ព្រះជាម្ចាស់ប្រាកដ ដូចពេត្រុសដែរ ទាំងត្រូវគេឆ្កាងដើម្បីព្រះជាម្ចាស់ និងស័ក្ដិសមនឹងស្លាប់ ដើម្បីតបស្នងនឹងសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ហើយមានសិរីរុងរឿងដូចពេត្រុសដែរ។

៥. ទទួលបានការស្រឡាញ់ ការគោរព និងការកោតសសើរពីមនុស្សគ្រប់គ្នានៅលើផែនដីនេះ។

៦. ការជម្នះគ្រប់កត្តាទាំងអស់ក្នុងចំណងនៃសេចក្ដីស្លាប់ និងស្ថានឃុំព្រលឹង ដោយមិនផ្ដល់ឱកាសឲ្យដល់សាតាំងធ្វើកិច្ចការរបស់ខ្លួនបាន ដោយឲ្យព្រះជាម្ចាស់សណ្ឋិត និងរស់នៅក្នុងវិញ្ញាណមួយដ៏ស្រស់ថ្លា និងរស់រវើកហើយមិនដែលនឿយហត់ឡើយ។

៧. ការមានចិត្តត្រេកអរ និងរីករាយរកបរិយាយមិនបាន គ្រប់ពេលវេលាពេញមួយជីវិត ដូចជាមនុស្សម្នាក់ដែលបានមើលឃើញថ្ងៃនៃសិរីល្អរបស់ព្រះជាម្ចាស់បានមកដល់។

៨. ការទទួលបានសិរីរុងរឿងរួមគ្នាជាមួយព្រះជាម្ចាស់ និងមានទឹកមុខដូចគ្នានឹងពួកបរិសុទ្ធស្ងួនភ្ងាររបស់ព្រះជាម្ចាស់។

៩. ការក្លាយខ្លួនជាកូនស្ងួនភ្ងាររបស់ព្រះជាម្ចាស់ គឺជាអ្វីដែលទ្រង់ស្រឡាញ់នៅលើផែនដីនេះ។

១០. ការផ្លាស់ប្ដូរសណ្ឋាន និងការឡើងទៅស្ថានសួគ៌ជាន់ទីបីជាមួយព្រះជាម្ចាស់ និងការទៅហួសពីដែនកំណត់នៃសាច់ឈាម។

មានតែមនុស្សដែលអាចគ្រងព្រះពរនៃព្រះជាម្ចាស់ជាមរតកប៉ុណ្ណោះ ទើបត្រូវបានព្រះជាម្ចាស់ប្រោសឲ្យបានគ្រប់លក្ខណ៍ និងត្រូវបានទ្រង់ទទួលយក។ តើអ្នកទទួលបានអ្វីខ្លះ នៅពេលបច្ចុប្បន្ននេះ? តើព្រះជាម្ចាស់ បានកែឲ្យអ្នកបានគ្រប់លក្ខណ៍កម្រិតណា? ព្រះជាម្ចាស់ មិនមែនផ្លាស់ប្រែមនុស្សឲ្យគ្រប់លក្ខណ៍ដោយចៃដន្យនោះទេ ព្រះអង្គផ្លាស់ប្រែមនុស្សឲ្យគ្រប់លក្ខណ៍ដោយមានលក្ខខណ្ឌ ហើយមានលទ្ធផលច្បាស់លាស់ ដែលអាចមើលឃើញបាន។ វាមិនមែនដូចអ្វីដែលមនុស្សស្រមៃគិតថា ដរាបណាគាត់មានជំនឿលើព្រះជាម្ចាស់ គាត់អាចទទួលការប្រោសឲ្យបានគ្រប់លក្ខណ៍ ហើយត្រូវបានទទួលយកដោយព្រះជាម្ចាស់ ហើយគាត់អាចទទួលបានព្រះពរ និងមរតករបស់ព្រះអង្គនៅលើផែនដីឡើយ។ ការមិននិយាយអ្វីសោះអំពីការផ្លាស់ប្ដូរលក្ខណៈរបស់មនុស្សបែបនេះ គឺពិតជាពិបាកហួសប្រមាណ។ នាពេលបច្ចុប្បន្ននេះ អ្វីដែលអ្នករាល់គ្នាគួរតែស្វែងរកមុនគេ គឺការទុកឲ្យព្រះជាម្ចាស់ប្រោសអ្នករាល់គ្នា ឲ្យបានគ្រប់លក្ខណ៍នៅក្នុងគ្រប់ការទាំងអស់ និងឲ្យព្រះអង្គប្រោសអ្នកឲ្យបានគ្រប់លក្ខណ៍តាមរយៈមនុស្សទាំងអស់ បញ្ហាទាំងអស់ និងអ្វីៗទាំងអស់ដែលអ្នករាល់គ្នាបានជួបប្រទះ ដើម្បីឲ្យអ្វីដែលព្រះជាម្ចាស់ធ្វើការនៅក្នុងជីវិតអ្នករាល់គ្នាបានកាន់តែច្រើនឡើង។ ដំបូងអ្នករាល់គ្នាត្រូវតែទទួលមរតករបស់

ព្រះជាម្ចាស់នៅលើផែនដី ទាល់តែដល់ពេលនោះ ទើបអ្នកមានសិទ្ធិទទួលព្រះពរពីព្រះអង្គកាន់តែច្រើនឡើងៗបាន។ ទាំងនេះ គឺជាអ្វីដែលអ្នករាល់គ្នាគួរស្វែងរក ហើយអ្នករាល់គ្នាគួរស្វែងយល់មុនអ្វីៗទាំងអស់។ កាលណាអ្នករាល់គ្នារឹតតែព្យាយាមឲ្យបានគ្រប់លក្ខណ៍ដោយសារព្រះជាម្ចាស់នៅក្នុងគ្រប់ការទាំងអស់ នោះអ្នករាល់គ្នាក៏រឹតតែអាចមើលឃើញព្រះហស្តរបស់ព្រះជាម្ចាស់ក្នុងគ្រប់ការទាំងអស់ ជាលទ្ធផលអ្នករាល់គ្នានឹងព្យាយាមចូលក្នុងវត្តមាននៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងចូលទៅក្នុងតថភាពនៃព្រះបន្ទូលទ្រង់ តាមរយៈទស្សនៈផ្សេងៗពីគ្នា នៅក្នុងបញ្ហាផ្សេងៗពីគ្នា។ អ្នករាល់គ្នាមិនអាចស្កប់ចិត្តជាមួយនឹងស្ថានភាពអសកម្ម ដោយគ្រាន់តែមិនប្រព្រឹត្តអំពើបាប ឬគ្មានគំនិតគិតស្រមៃ គ្មានទស្សនវិជ្ជាសម្រាប់ការរស់នៅ និងគ្មានឆន្ទៈជាមនុស្សតែប៉ុណ្ណោះទេ។ ព្រះជាម្ចាស់ ធ្វើឱ្យមនុស្សគ្រប់លក្ខណ៍តាមរបៀបជាច្រើន។ ក្នុងគ្រប់បញ្ហាទាំងអស់ គឺសុទ្ធតែមានលទ្ធភាព នៃការប្រោសឲ្យបានគ្រប់លក្ខណ៍ ហើយទ្រង់មិនត្រឹមតែអាចធ្វើឱ្យអ្នកគ្រប់លក្ខណ៍នៅក្នុងលក្ខណៈវិជ្ជមានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងក្នុងន័យអវិជ្ជមានផងដែរ ដើម្បីឲ្យអ្នករាល់គ្នាទទួលបានកាន់តែច្រើន។ រៀងរាល់ថ្ងៃ ឱកាសត្រូវបានប្រោសឲ្យបានគ្រប់លក្ខណ៍ដោយព្រះជាម្ចាស់ និងឱកាសឲ្យព្រះជាម្ចាស់ទទួលយក គឺនៅតែមាន។ បន្ទាប់ពីបានឆ្លងកាត់បទពិសោធបែបនេះមួយរយៈ អ្នកនឹងត្រូវផ្លាស់ប្ដូរយ៉ាងខ្លាំង ហើយអ្នកនឹងយល់ពីរឿងជាច្រើនដែលអ្នកមិនធ្លាប់ដឹងពីមុន។ មិនចាំបាច់មានការណែនាំពីអ្នកដទៃទេ។ ព្រះជាម្ចាស់នឹងបំភ្លឺដល់អ្នក ទាំងមិនឲ្យអ្នកដឹងខ្លួន ដើម្បីឲ្យអ្នកទទួលបានការយល់ដឹងក្នុងគ្រប់រឿងទាំងអស់ ហើយបញ្ចូលបទពិសោធរបស់អ្នកឱ្យលម្អិត។ ព្រះជាម្ចាស់ប្រាកដជាដឹកនាំអ្នកដើម្បីកុំឲ្យអ្នកងាកទៅឆ្វេង ឬទៅស្ដាំឡើយ ដូច្នេះហើយអ្នកនឹងដើរលើមាគ៌ាឆ្ពោះទៅរកការត្រូវបានប្រោសឲ្យបានគ្រប់លក្ខណ៍ដោយទ្រង់។

ការដែលត្រូវបានប្រោសឲ្យបានគ្រប់លក្ខណ៍ដោយព្រះជាម្ចាស់មិនអាចកំណត់ត្រឹមភាពគ្រប់លក្ខណ៍ដែលបានមកពីការហូប និងផឹកព្រះបន្ទូលរបស់ព្រះជាម្ចាស់ឡើយ។ ការឆ្លងកាត់នូវបទពិសោធបែបនេះ អាចនឹងលម្អៀងជ្រុល វាអាចរួមបញ្ចូល

តិចតួចពេក ហើយអាចដាក់កំហិតមនុស្ស ឲ្យនៅក្នុងវិសាលភាពតូចតាចប៉ុណ្ណោះ។ ដូច្នេះ មនុស្សនឹងខ្វះខាតការចិញ្ចឹមបំប៉នខាងព្រលឹងវិញ្ញាណដែលពួកគេត្រូវការ។ ប្រសិនបើអ្នករាល់គ្នា ចង់ឲ្យបានគ្រប់លក្ខណ៍ដោយសារព្រះជាម្ចាស់ អ្នករាល់គ្នាត្រូវតែរៀនអំពីរបៀបពិសោធក្នុងគ្រប់បញ្ហាទាំងអស់ និងអាចទទួលបានការយល់ដឹងក្នុងអ្វីៗគ្រប់យ៉ាងដែលកើតឡើងចំពោះអ្នករាល់គ្នា។ ទោះជារឿងនោះល្អ ឬអាក្រក់ក៏ដោយ វាគួរតែនាំមកនូវផលប្រយោជន៍ដល់អ្នក ហើយវានឹងមិនធ្វើឲ្យអ្នកទៅជាអវិជ្ជមានឡើយ។ ទោះយ៉ាងណាក៏ដោយ អ្នកគួរតែអាចពិចារណាខណៈដែលអ្នកកំពុងឈរនៅខាងព្រះជាម្ចាស់ ហើយមិនវិភាគ ឬសិក្សារឿងនេះ តាមទស្សនៈរបស់មនុស្សទេ (ការនេះនឹងជាគម្លាតមួយនៅក្នុងបទពិសោធរបស់អ្នក)។ ប្រសិនបើអ្នកឆ្លងកាត់បទពិសោធបែបនេះនោះដួងចិត្តរបស់អ្នកនឹងបានពេញដោយបន្ទុកនៃជីវិតរបស់អ្នក។ អ្នកនឹងរស់នៅក្នុងពន្លឺនៃព្រះភ័ក្ត្ររបស់ព្រះជាម្ចាស់ជារៀងរហូត ដោយមិនងាយនឹងបែរចេញពីទ្រង់ងាយៗក្នុងការអនុវត្តរបស់អ្នកឡើយ។ មនុស្សបែបនេះមានអនាគតភ្លឺស្វាងនៅពីមុខពួកគេ។ ឱកាសត្រូវបានប្រោសឲ្យបានគ្រប់លក្ខណ៍ដោយព្រះជាម្ចាស់មានច្រើនណាស់។ វាអាស្រ័យត្រង់ថា អ្នករាល់គ្នាគឺជាមនុស្សដែលស្រឡាញ់ព្រះជាម្ចាស់ពិតមែន ឬមិនមែន ហើយអាស្រ័យត្រង់ថា អ្នករាល់គ្នាមាន ឬគ្មានការតាំងចិត្ត ដើម្បីឲ្យបានប្រោសឲ្យបានគ្រប់លក្ខណ៍ និងត្រូវបានទទួលយកដោយព្រះជាម្ចាស់ និងដើម្បីទទួលព្រះពរ និងមរតករបស់ទ្រង់។ ត្រឹមការតាំងចិត្ត គឺមិនទាន់គ្រប់គ្រាន់ទេ។ អ្នករាល់គ្នាត្រូវតែមានចំណេះដឹងច្រើន បើមិនដូច្នេះទេអ្នករាល់គ្នានឹងតែងតែងាកចេញពីការអនុវត្តរបស់អ្នករាល់គ្នាជាមិនខាន។ ព្រះជាម្ចាស់សព្វព្រះហឫទ័យធ្វើឲ្យអ្នករាល់គ្នាមានភាពគ្រប់លក្ខណ៍។ ជាក់ស្តែងបច្ចុប្បន្ននេះ ទោះបីជាមនុស្សភាគច្រើនបានទទួលកិច្ចការព្រះជាម្ចាស់អស់រយៈពេលយូរយ៉ាងណាក៏ដោយ ក៏ពួកគេបានកំណត់ខ្លួនឯងត្រឹមរស់នៅដោយពឹងផ្អែកតែនឹងព្រះគុណព្រះជាម្ចាស់ ហើយព្រមឱ្យព្រះអង្គកម្សាន្តសាច់ឈាមបន្តិចបន្តួចប៉ុណ្ណោះ ប៉ុន្តែពួកគេមិនព្រមទទួលការបើកសម្តែងបន្ថែម និងលើសពីនេះទេ។ ការនេះសរ

បញ្ជាក់ឲ្យឃើញថា ចិត្តរបស់មនុស្សនៅតែគិតពីរឿងក្រៅខ្លួនប៉ុណ្ណោះ។ ទោះបីកិច្ចការរបស់មនុស្ស ការបម្រើរបស់គេ និងដួងចិត្តនៃសេចក្ដីស្រឡាញ់របស់គេចំពោះព្រះជាម្ចាស់មានភាពសៅហ្មងតិចតួចក៏ដោយ បើយោងទៅតាមលក្ខណៈពិតក្នុងចិត្តរបស់គេ និងការគិតថយក្រោយរបស់គេ មនុស្សនៅតែស្វែងរកភាពសុខសាន្ត និងការរីករាយខាងសាច់ឈាមជានិច្ច ហើយមិនខ្វល់ពីលក្ខខណ្ឌ និងគោលបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ក្នុងការប្រោសពួកគេឲ្យបានគ្រប់លក្ខណ៍នឹងទៅជាយ៉ាងណានោះទេ។ ដូច្នេះហើយជីវិតរបស់មនុស្សភាគច្រើន នៅតែជាមនុស្សថោកទាប និងអាប់ឱនដដែល។ ជីវិតរបស់ពួកគេមិនបានផ្លាស់ប្ដូរបន្តិចបន្តួចឡើយ។ ពួកគេមិនចាត់ទុកជំនឿលើព្រះជាម្ចាស់ជារឿងសំខាន់នោះទេ វាហាក់ដូចជាពួកគេមានជំនឿសម្រាប់ជាប្រយោជន៍អ្នកដទៃ ដោយគ្រាន់តែបំពេញកិច្ច និងព្យាយាមសម្រេចអ្វីមួយដោយធ្វេសប្រហែស រសាត់អណ្ដែតក្នុងជីវិតដែលគ្មានគោលបំណង។ មនុស្សដែលអាចព្យាយាមចូលទៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ក្នុងគ្រប់ការទាំងអស់ ទាំងទទួលបានកាន់តែច្រើនឡើងៗ ហើយមានទ្រព្យសម្បត្តិកាន់តែច្រើន ក្នុងដំណាក់របស់ព្រះជាម្ចាស់សព្វថ្ងៃ និងទទួលបានព្រះពរពីព្រះជាម្ចាស់ថែមទៀតផងនោះ មានតិចណាស់។ ប្រសិនបើអ្នករាល់គ្នា ព្យាយាមឲ្យព្រះជាម្ចាស់ប្រោសអ្នករាល់គ្នា ឲ្យបានគ្រប់លក្ខណ៍ក្នុងគ្រប់ការទាំងអស់ ហើយអាចទទួលបាននូវអ្វីៗដែលទ្រង់សន្យានៅលើផែនដីនេះ ប្រសិនបើអ្នករាល់គ្នាព្យាយាមឲ្យព្រះជាម្ចាស់បំភ្លឺគំនិតអ្នកក្នុងគ្រប់ការទាំងអស់ និងមិនបណ្ដោយឲ្យពេលវេលា កន្លងទៅឥតប្រយោជន៍ នោះហើយជាផ្លូវត្រឹមត្រូវសម្រាប់ចូលទៅយ៉ាងសកម្ម។ ដូច្នេះទើបអ្នកមានតម្លៃ និងមានសិទ្ធិទទួលបាននូវភាពគ្រប់លក្ខណ៍អំពីព្រះជាម្ចាស់។ តើអ្នកពិតជាមនុស្សដែលព្យាយាមឲ្យព្រះប្រោសឲ្យបានគ្រប់លក្ខណ៍ដែរឬទេ? តើអ្នកពិតជាមនុស្សម្នាក់ដែលស្មោះត្រង់បំផុតក្នុងគ្រប់ការទាំងអស់មែនទេ? តើអ្នកមានដួងចិត្តស្រឡាញ់ព្រះជាម្ចាស់ដូចពេត្រុសដែរឬទេ? តើអ្នកមានឆន្ទៈស្រឡាញ់ព្រះជាម្ចាស់ដូចព្រះយេស៊ូវដែរឬទេ? អ្នកជឿលើព្រះយេស៊ូវអស់រយៈពេលជាច្រើនឆ្នាំហើយ តើអ្នកបានឃើញថាព្រះយេស៊ូវ

ស្រឡាញ់ព្រះជាម្ចាស់យ៉ាងណាទេ? តើអ្នកពិតជាជឿលើព្រះយេស៊ូវទេ? អ្នកជឿលើព្រះដ៏សកម្មនាពេលបច្ចុប្បន្ននេះ។ តើអ្នកបានឃើញថា ព្រះដ៏សកម្មក្នុងរូបកាយសាច់ឈាមនេះ ស្រឡាញ់ព្រះជាម្ចាស់ដែលគង់នៅឯស្ថានសួគ៌ខ្លាំងយ៉ាងណាទេ? អ្នកមានជំនឿលើព្រះអម្ចាស់យេស៊ូវគ្រីស្ទ ដោយសារការជាប់ឆ្កាងរបស់ទ្រង់ ដើម្បីសង្គ្រោះមនុស្សលោក និងការអស្ចារ្យដែលទ្រង់បានធ្វើ គឺជាហេតុការណ៍ដែលត្រូវបានទទួលយកដោយទូទៅ។ ប៉ុន្តែជំនឿរបស់មនុស្សមិនមែនកើតចេញពីការស្គាល់ និងការយល់ដឹងពិតអំពីព្រះយេស៊ូវគ្រីស្ទទេ។ អ្នកជឿលើព្រះនាមព្រះយេស៊ូវប៉ុណ្ណោះ តែអ្នកមិនជឿលើព្រះវិញ្ញាណរបស់ទ្រង់ទេ ពីព្រោះអ្នកមិនយកចិត្តទុកដាក់ថា ព្រះយេស៊ូវស្រឡាញ់ព្រះជាម្ចាស់យ៉ាងណានោះទេ។ សេចក្ដីជំនឿរបស់អ្នកលើព្រះជាម្ចាស់ ជាសេចក្ដីជំនឿឆោតពេក។ ទោះបីជាអ្នកជឿលើព្រះយេស៊ូវ អស់រយៈពេលជាច្រើនឆ្នាំក៏ដោយ ក៏អ្នកមិនដឹងពីរបៀបស្រឡាញ់ព្រះជាម្ចាស់ដែរ។ តើការនេះមិនធ្វើឱ្យអ្នកក្លាយជាមនុស្សល្ងីល្ងើបំផុតក្នុងលោកទេឬអី? នេះជាភស្តុតាងបញ្ជាក់ថាអស់រយៈពេលជាច្រើនឆ្នាំមកហើយ ដែលអ្នកបានបរិភោគអាហាររបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទដោយឥតប្រយោជន៍។ ខ្ញុំមិនត្រឹមតែមិនចូលចិត្តមនុស្សបែបនេះទេ តែខ្ញុំថែមទាំងជឿជាក់ថា ព្រះអម្ចាស់យេស៊ូវគ្រីស្ទដែលអ្នករាល់គ្នាគោរពបំផុតនោះ ក៏នឹងមិនចូលចិត្តពួកគេដែរ។ តើមនុស្សជំពូកនេះអាចទទួលភាពគ្រប់លក្ខណ៍ បានដោយរបៀបណា? តើអ្នករាល់គ្នាមិនមានភាពអាម៉ាស់ទេឬអី? តើអ្នករាល់គ្នាមិនមានអារម្មណ៍ខ្មាសអៀនទេឬអី? តើអ្នកនៅតែក្លាហានប្រឈមមុខនឹងព្រះអម្ចាស់យេស៊ូវគ្រីស្ទរបស់អ្នកដែរឬទេ? តើអ្នករាល់គ្នាយល់ពីខ្លឹមសារនៃសម្ដីដែលខ្ញុំបាននិយាយទេ?

# ពួកទុច្ចរិតនឹងត្រូវទទួលទោសយ៉ាងពិតប្រាកដ

ចូរសម្លឹងមើលខ្លួនឯង ដើម្បីឱ្យដឹងថាតើអ្នកអនុវត្តតាមសេចក្ដីសុចរិតនៅគ្រប់កិច្ចការដែលអ្នកធ្វើហើយឬនៅ ហើយថាតើគ្រប់ទង្វើរបស់អ្នក ត្រូវបានព្រះជាម្ចាស់ឃ្លាំមើលដែរឬទេ៖ នេះគឺជាគោលការណ៍ដែលអ្នកជឿលើព្រះជាម្ចាស់អនុវត្តកិច្ចការរបស់ពួកគេ។ អ្នកនឹងត្រូវហៅថាជាសុចរិត ដោយព្រោះអ្នករាល់គ្នាអាចធ្វើឱ្យព្រះជាម្ចាស់សព្វព្រះហឫទ័យបាន និងដោយព្រោះអ្នកទទួលយកការថែទាំ និងការការពារពីព្រះជាម្ចាស់។ នៅក្នុងព្រះនេត្ររបស់ព្រះជាម្ចាស់ អស់អ្នកដែលទទួលយកការថែទាំ ការការពារ និងភាពល្អឥតខ្ចោះ និងអស់អ្នកដែលទ្រង់បានទទួលយក គឺសុទ្ធតែជាមនុស្សសុចរិត ហើយទ្រង់ចាត់ទុកពួកគេរាល់គ្នាថាមានតម្លៃ។ កាលណាអ្នកទទួលយកព្រះបន្ទូលបច្ចុប្បន្នរបស់ព្រះជាម្ចាស់កាន់តែច្រើន នោះអ្នកនឹងកាន់តែអាចទទួលបាន និងយល់ដឹងអំពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ បានកាន់តែច្រើនដែរ ហើយអ្នកនឹងកាន់តែអាចរស់នៅតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងបំពេញតាមសេចក្ដីតម្រូវរបស់ទ្រង់ដែរ។ នេះគឺជាបញ្ញើបេសកកម្មរបស់ព្រះជាម្ចាស់ សម្រាប់អ្នករាល់គ្នា ហើយនេះគឺជាកិច្ចការដែលអ្នករាល់គ្នាគប្បីសម្រេចឱ្យបាន។ ប្រសិនបើអ្នកប្រើចិត្តគំនិតរបស់ខ្លួនដើម្បីវាស់វែង និងកំណត់ព្រំដែនព្រះជាម្ចាស់ ថាព្រះជាម្ចាស់ប្រៀបដូចជារូបចម្លាក់ដីឥដ្ឋដែលមិនចេះប្រែប្រួល ហើយប្រសិនបើអ្នកកំណត់ព្រំដែនព្រះជាម្ចាស់នៅក្នុងខ្នាតរង្វាស់នៃព្រះគម្ពីរ និងដាក់ទ្រង់នៅក្នុងទំហំកិច្ចការដែលមានដែនកំណត់ ទង្វើនេះសបញ្ជាក់ថា អ្នករាល់គ្នាបានដាក់ទោសចំពោះព្រះជាម្ចាស់ហើយ។ ដ្បិតពួកសាសន៍យូដានៅក្នុងសម័យសញ្ញាចាស់ ចាត់ទុកព្រះជាម្ចាស់ជារូបបដិមាករដែលមានរូបរាងមិនប្រែប្រួល ដែលពួកគេអាចចាំទុកក្នុងចិត្តរបស់ពួកគេបាន ហាក់បីដូចជាព្រះជាម្ចាស់អាចហៅបានត្រឹមតែជាព្រះមែស្ស៊ី ហើយមានតែទ្រង់ដែលគេហៅថាព្រះមែស្ស៊ីប៉ុណ្ណោះ ដែលអាចជាព្រះជាម្ចាស់បាន ហើយដោយព្រោះមនុស្សបានបម្រើ និងបានថ្វាយបង្គំព្រះជាម្ចាស់ ទុកទ្រង់ដូចជារូបចម្លាក់ដីឥដ្ឋ (ដែល

គ្មានជីវិត) ទើបបានជាពួកគេបោះដែកគោលឆ្កាងព្រះយេស៊ូវនៅក្នុងពេលនោះ ដោយកាត់ទោសប្រហារជីវិតទ្រង់ ពោលគឺព្រះយេស៊ូវដែលគ្មានកំហុសសោះត្រូវបានគេកាត់ទោសដល់ស្លាប់។ ព្រះជាម្ចាស់ពុំមានទោសអ្វីសោះឡើយ តែមនុស្សមិនព្រមទុកជីវិតឱ្យទ្រង់ ហើយទទូចកាត់ទោសប្រហារជីវិតទ្រង់ ដូច្នេះព្រះយេស៊ូវក៏ត្រូវបានគេឆ្កាងទៅ។ មនុស្សតែងជឿថា ព្រះជាម្ចាស់ពុំប្រែប្រួល ហើយកំណត់ទ្រង់ទៅតាមមូលដ្ឋាននៃសៀវភៅមួយក្បាល គឺព្រះគម្ពីរ ហាក់បីដូចជាមនុស្សមានការយល់ដឹងឥតខ្ចោះអំពីការគ្រប់គ្រងរបស់ព្រះជាម្ចាស់ និងហាក់បីដូចជាមនុស្សគ្រប់គ្រងអ្វីៗទាំងអស់ដែលព្រះជាម្ចាស់ធ្វើនៅក្នុងព្រះហស្តរបស់ទ្រង់ដូច្នេះដែរ។ មនុស្សល្ងង់ខ្លៅយ៉ាងខ្លាំង ក្រអឺតក្រទមយ៉ាងខ្លាំង ហើយពួកគេពូកែខាងការនិយាយបំផ្លើស។ មិនថាអ្នកមានចំណេះដឹងអំពីព្រះជាម្ចាស់ច្រើនប៉ុនណានោះទេ ខ្ញុំនៅតែមានបន្ទូលថា អ្នកពុំស្គាល់ព្រះជាម្ចាស់ឡើយ នៅតែថាអ្នកជាមនុស្សម្នាក់ដែលប្រឆាំងទាស់នឹងព្រះជាម្ចាស់ខ្លាំងបំផុត និងនៅតែថាអ្នកបានដាក់ទោសព្រះជាម្ចាស់ ដ្បិតអ្នកគ្មានសមត្ថភាពអនុវត្តតាមកិច្ចការរបស់ព្រះជាម្ចាស់ និងមិនអាចដើរក្នុងផ្លូវដែលព្រះជាម្ចាស់បានធ្វើឱ្យគ្រប់លក្ខណ៍បានឡើយ។ តើហេតុអ្វីបានជាព្រះជាម្ចាស់មិនដែលសព្វព្រះហឫទ័យនឹងទង្វើរបស់មនុស្ស? គឺដោយសារតែមនុស្សពុំស្គាល់ព្រះជាម្ចាស់ ដោយសារតែមនុស្សមានសញ្ញាណច្រើនហួសហេតុពេក និងដោយសារតែចំណេះដឹងរបស់ពួកគេអំពីព្រះជាម្ចាស់ មិនស្រេបទៅនឹងសេចក្ដីពិត តែផ្ទុយទៅវិញ និយាយពីរឿងរ៉ាវតែមួយដដែលៗដោយគ្មានអ្វីប្លែកសោះ ព្រមទាំងប្រើវិធីសាស្ត្រដូចៗគ្នានៅគ្រប់ស្ថានការណ៍ទាំងអស់។ ហេតុដូចនេះ ការយាងមកកាន់ផែនដីនាពេលសព្វថ្ងៃនេះ ព្រះជាម្ចាស់ត្រូវបានមនុស្សដំដែកគោលភ្ជាប់ទៅនឹងឈើឆ្កាងជាថ្មីម្ដងទៀត។ មនុស្សពិតជាឃោរឃៅណាស់! ការរួមគំនិតគ្នា និងល្បិចកលទុច្ចរិត ការលួចឆក់ និងការរឹបអូសពីអ្នកដទៃ ការដណ្ដើមកិត្តិយស និងលាភសក្ការៈ ការកាប់សម្លាប់គ្នាទៅវិញទៅមក តើដល់ពេលណាទើបអាចនឹងបញ្ចប់បាន? មិនថាព្រះជាម្ចាស់មានបន្ទូលច្រើនរាប់សិបពាន់ម៉ាត់ក៏ដោយ ក៏គ្មាននរណាម្នាក់ភ្ញាក់ស្មារតីវិញឡើយ។ មនុស្សធ្វើការដើម្បីជាប្រយោជន៍ដល់ក្រុម

គ្រួសារ និងកូនប្រុសស្រីរបស់ពួកគេ ជាប្រយោជន៍ដល់មុខរបរ ភាពជោគជ័យទៅថ្ងៃអនាគត តួនាទី អំនួតផ្ទាល់ខ្លួន និងប្រាក់កាសរបស់ពួកគេ ជាប្រយោជន៍ខាងចំណីអាហារ សម្លៀកបំពាក់ និងខាងសាច់ឈាម។ ប៉ុន្តែ តើមាននរណាម្នាក់ដែលបានធ្វើកិច្ចការដើម្បីជាប្រយោជន៍ដល់ព្រះជាម្ចាស់ពិតប្រាកដ? ទោះបីជាក្នុងចំណោមអស់អ្នកដែលធ្វើកិច្ចការដើម្បីជាប្រយោជន៍ដល់ព្រះជាម្ចាស់ក៏ដោយ ក៏មានមនុស្សតិចតួចណាស់ ដែលបានស្គាល់ព្រះជាម្ចាស់។ តើមានមនុស្សប៉ុន្មាននាក់ដែលមិនធ្វើការដើម្បីប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេនោះ? តើមានមនុស្សប៉ុន្មាននាក់ដែលមិនជិះជាន់ ឬបណ្ដេញអ្នកដទៃចេញដើម្បីការពារតំណែងរបស់ពួកគេ? ដូចនេះ ព្រះជាម្ចាស់ ត្រូវគេបង្ខំកាត់ទោសប្រហារជីវិតជាច្រើនលើកច្រើនសារ ហើយចៅក្រមឃោរឃៅច្រើនរាប់មិនអស់បានដាក់ទោសព្រះជាម្ចាស់ និងបានដំដែកគោលឆ្កាងទ្រង់ទៅលើឈើឆ្កាងជាថ្មីម្ដងទៀត។ តើមានមនុស្សប៉ុន្មាននាក់ដែលអាចត្រូវបានហៅថាសុចរិតបាន ដោយសារពួកគេធ្វើការដើម្បីជាប្រយោជន៍ដល់ព្រះជាម្ចាស់យ៉ាងពិតប្រាកដនោះ?

តើការដែលត្រូវប្រោសឱ្យបានគ្រប់លក្ខណ៍នៅចំពោះព្រះជាម្ចាស់ក្នុងនាមជាពួកបរិសុទ្ធ ឬបុគ្គលសុចរិតនោះ ងាយស្រួលដែរឬទេ? នេះគឺជាឃ្លាត្រឹមត្រូវដែលថា «ពុំមានសេចក្ដីសុចរិតនៅលើផែនដីនេះឡើយ សេចក្ដីសុចរិតមិនមាននៅក្នុងលោកិយនេះទេ។» នៅពេលអ្នករាល់គ្នាមកចំពោះព្រះជាម្ចាស់ ចូរគិតអំពីសម្លៀកបំពាក់ដែលអ្នករាល់គ្នាពាក់ ចូរគិតពីគ្រប់ទង្វើ និងពាក្យសម្ដីរបស់អ្នករាល់គ្នា ចូរគិតពីគំនិត និងយោបល់របស់អ្នករាល់គ្នា និងគិតសូម្បីតែការយល់សប្ដិដែលអ្នកសុបិនឃើញរាល់ថ្ងៃ ដោយគ្រប់ទាំងអស់នេះ គឺសម្រាប់តែជាប្រយោជន៍ផ្ទាល់ខ្លួនរបស់អ្នករាល់គ្នាប៉ុណ្ណោះ។ តើនេះមិនមែនជារឿងពិតទេឬអី? «សេចក្ដីសុចរិត» ពុំមានន័យថាជាការដាក់ទានដល់អ្នកដទៃនោះទេ ក៏ពុំមានន័យថាជាការស្រឡាញ់អ្នកជិតខាងរបស់អ្នកឱ្យដូចជាខ្លួនឯងដែរ ហើយក៏ពុំមានន័យថាជាការជៀសវាងការឈ្លោះប្រកែក និងការឈ្លោះទាស់ទែងគ្នា ឬពីការលួចឆក់ប្លន់ដែរ។ សេចក្ដីសុចរិតមានន័យថាជាការអនុវត្ត

បញ្ជាបេសកកម្មរបស់ព្រះជាម្ចាស់ តាមភារកិច្ចរបស់អ្នក និងគោរពតាមការចាត់ចែង និងការរៀបចំរបស់ព្រះជាម្ចាស់ ចាត់ទុកដូចជារបរចិញ្ចឹមជីវិតដែលស្ថានសួគ៌ប្រទានដល់អ្នក ដោយមិនគិតពីពេលវេលា ឬទីកន្លែងឡើយ គឺដូចជាគ្រប់កិច្ចការទាំងអស់ដែលព្រះអម្ចាស់យេស៊ូវបានធ្វើរួចរាល់មកហើយដែរ។ នេះគឺជាសេចក្ដីសុចរិតដែលព្រះជាម្ចាស់បានមានបន្ទូល។ ឡុតអាចត្រូវគេហៅថាសុចរិតបាន គឺដោយសារគាត់បានសង្គ្រោះជីវិតទេវតាពីរអង្គដែលព្រះជាម្ចាស់បានបញ្ជូនមក ដោយពុំបានគិតពីប្រយោជន៍ ឬការខាតបង់របស់ខ្លួនឡើយ។ គេអាចត្រឹមនិយាយថា អ្វីដែលគាត់បានធ្វើនៅពេលនោះ គឺអាចហៅថាសុចរិតបាន ប៉ុន្តែគាត់មិនអាចឱ្យគេហៅថាជាមនុស្សសុចរិតបានទេ។ គឺដោយសារតែឡុតបានឃើញព្រះជាម្ចាស់ ហើយក៏បានប្រគល់កូនស្រីពីរនាក់របស់គាត់ដើម្បីដូរនឹងទេវតាពីរអង្គ ដែលអាចហៅថាជាទង្វើសុចរិតបាន ប៉ុន្តែឥរិយាបថទាំងអស់របស់គាត់កាលពីមុន មិនសុទ្ធតែតំណាងឱ្យសេចក្ដីសុចរិតនោះទេ។ ដូច្នេះ ខ្ញុំមានបន្ទូលថា «ពុំមានមនុស្សសុចរិតនៅលើផែនដីនេះឡើយ»។ សូម្បីតែអស់អ្នកដែលនៅក្នុងនិកាយ ដំណើរនៃការជាសះស្បើយ (Stream of Recovery) ក៏គ្មាននរណាម្នាក់អាចហៅថាសុចរិតបានដែរ។ មិនថាទង្វើរបស់អ្នកល្អយ៉ាងណា មិនថាអ្នកចេញមកសរសើរតម្កើងព្រះនាមរបស់ព្រះជាម្ចាស់យ៉ាងណា មិនថាអ្នកមិនដែលវាយតប់ និងដាក់បណ្ដាសាអ្នកដទៃ មិនថាអ្នកមិនលួចឆក់ប្លន់ពីអ្នកដទៃនោះទេ ក៏អ្នកនៅតែមិនអាចហៅថាសុចរិតបានដែរ ដ្បិតទង្វើនេះ គឺមនុស្សធម្មតាសុទ្ធតែអាចធ្វើបាន។ ចំណុចសំខាន់នៅក្នុងពេលនេះគឺថា អ្នកពុំស្គាល់ព្រះជាម្ចាស់។ គេអាចត្រឹមនិយាយបានថា នៅពេលបច្ចុប្បន្ននេះ អ្នកមានភាពជាមនុស្សធម្មតាតែបន្តិចបន្តួចប៉ុណ្ណោះ ប៉ុន្តែគ្មានធាតុនៃសេចក្ដីសុចរិតដែលព្រះទ្រង់មានបន្ទូលឡើយ ដូច្នេះហើយ គ្មានអ្វីដែលអ្នកធ្វើអាចបញ្ជាក់បានថាអ្នកស្គាល់ព្រះជាម្ចាស់ឡើយ។

កាលគ្រាមុន នៅពេលព្រះជាម្ចាស់គង់នៅឯស្ថានសួគ៌ មនុស្សលោកបានធ្វើទង្វើក្នុងរបៀបមួយដែលបោកបញ្ឆោតចំពោះព្រះជាម្ចាស់។ សព្វថ្ងៃនេះ ព្រះជាម្ចាស់

បាន និងកំពុងគង់ក្នុងចំណោមមនុស្សជាតិ ពោលគឺគ្មាននរណាម្នាក់បានដឹងថា អស់រយៈពេលប៉ុន្មានឆ្នាំមកហើយនោះទេ ប៉ុន្តែនៅក្នុងការប្រព្រឹត្តរបស់ខ្លួន មនុស្ស នៅតែបន្តរបៀបរបស់ពួកគេ និងព្យាយាមបញ្ឆោតទ្រង់។ តើការគិតរបស់មនុស្សមិន អន់ថយពេកទេឬអី? គឺវាដូចគ្នានឹងយូដាសដែរ៖ នៅមុនពេលព្រះយេស៊ូវយាងមក យូដាសនិយាយកុហក ដើម្បីបោកបញ្ឆោតបងប្អូនប្រុសស្រីរបស់ខ្លួន ហើយសូម្បីតែ ក្រោយពេលដែលព្រះយេស៊ូវយាងមកហើយក្ដី ក៏នៅតែមិនព្រមកែប្រែដែរ។ គាត់ មិនបានស្គាល់ព្រះយេស៊ូវសូម្បីតែបន្តិច ហើយចុងក្រោយក៏ក្បត់នឹងព្រះយេស៊ូវ។ តើ នេះមិនមែនមកពីគាត់មិនស្គាល់ព្រះជាម្ចាស់ទេឬអី? សព្វថ្ងៃនេះ ប្រសិនបើអ្នករាល់គ្នា នៅមិនទាន់ស្គាល់ព្រះជាម្ចាស់ នោះអាចថាអ្នករាល់គ្នានឹងក្លាយជាយូដាសម្នាក់ទៀត សោកនាដកម្មនៃការឆ្កាងព្រះយេស៊ូវនៅក្នុងសម័យនៃព្រះគុណកាលពីពីរពាន់ឆ្នាំមុន នឹងកើតមានឡើងសារជាថ្មី។ តើអ្នករាល់គ្នា មិនជឿលើរឿងនេះទេឬ? នេះគឺជា ការពិត! បច្ចុប្បន្ននេះ មនុស្សភាគច្រើនសុទ្ធតែស្ថិតក្នុងស្ថានភាពមួយស្រដៀងគ្នា ហើយមនុស្សប្រភេទនេះកំពុងដើរតួជាយូដាសគ្រប់ៗគ្នា។ ខ្ញុំប្រហែលជាមានបន្ទូល ដូច្នេះឆាប់បន្តិចពេកហើយ ប៉ុន្តែខ្ញុំមិនមែនមានបន្ទូលអត់ប្រយោជន៍នោះទេ តែគឺ សំអាងទៅលើការពិត ហើយអ្នកមិនអាចធ្វើអ្វីក្រៅពីត្រូវជឿលើរឿងនេះឡើយ។ បើ ទោះបីជាមនុស្សជាច្រើនបានធ្វើពុតជាដាក់ខ្លួនក្ដី ក៏នៅក្នុងចិត្តរបស់ពួកគេគ្មានអ្វី ក្រៅតែពីស្រះទឹកមរណៈ ដែលជារណ្ដៅទឹកស្អុយនោះឡើយ។ សព្វថ្ងៃនេះ មាន មនុស្សបែបនេះច្រើនណាស់នៅក្នុងព្រះវិហារ ហើយអ្នករាល់គ្នាគិតថា ខ្ញុំពុំបានដឹង អំពីរឿងនេះសោះឡើយ។ បច្ចុប្បន្ននេះ ព្រះវិញ្ញាណរបស់ខ្ញុំ សម្រេចចិត្តជំនួសខ្ញុំ និង ធ្វើបន្ទាល់ជំនួសខ្ញុំ។ តើអ្នកគិតថាខ្ញុំមិនដឹងអ្វីសោះមែនទេ? តើអ្នកគិតថា ខ្ញុំមិនដឹងអំពី គំនិតវៀចវេរនៅក្នុងចិត្តរបស់អ្នករាល់គ្នា និងរឿងរ៉ាវដែលអ្នករាល់គ្នាទុកនៅក្នុងចិត្ត មែនទេ? តើការយល់ដឹងឱ្យបានច្រើនអំពីព្រះជាម្ចាស់ ងាយស្រួលដល់ម្ល៉េះមែនទេ? តើអ្នកគិតថា អ្នកអាចចាត់ទុកទ្រង់បែបណាក៏បានស្រេចតែចិត្តមែនទេ? កាលពីមុន ខ្ញុំមានការព្រួយបារម្ភក្រែងអ្នករាល់គ្នាមានអារម្មណ៍ដូចជាប់ឃុំ ដូចនេះ ខ្ញុំក៏បានបន្ត

ផ្ដល់សេរីភាពដល់អ្នករាល់គ្នា ប៉ុន្តែមនុស្សមិនអាចប្រាប់បានថាខ្ញុំកំពុងតែធ្វើល្អដាក់ពួកគេនោះទេ ហើយនៅពេលដែលខ្ញុំប្រទានឱ្យគេត្រឹមមួយតឹក ពួកគេបែរជាយកដល់ទៅមួយម៉ែត្រ។ ចូរសួរមនុស្សជុំវិញខ្លួនអ្នករាល់គ្នាមើល៖ ខ្ញុំស្ទើរតែមិនដែលមានបន្ទូលជាមួយនរណាម្នាក់ និងសឹងតែមិនដែលព្រមាននរណាម្នាក់សូម្បីបន្តិច ប៉ុន្តែខ្ញុំនៅតែជ្រាបយ៉ាងច្បាស់អំពីការជំរុញទឹកចិត្ត និងចិត្តគំនិតរបស់មនុស្ស។ តើអ្នកគិតថាព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ ដែលទ្រង់ធ្វើបន្ទាល់ពីព្រះអង្គនោះ តើទ្រង់ល្ងីល្ងើឬ? ក្នុងករណីនេះ ខ្ញុំមានបន្ទូលថា អ្នកពិតជាខ្វាក់ពេកហើយ! ខ្ញុំនឹងមិនលាតត្រដាងអំពើរបស់អ្នកឡើយ ប៉ុន្តែចូរចាំមើលចុះ ថាតើអ្នកនឹងអាចក្លាយជាពុករលួយយ៉ាងណា។ ចូរចាំមើលចុះ ថាតើកលល្បិចឆ្លាតវៃបន្តិចបន្តួចរបស់អ្នកនេះ អាចរក្សាជីវិតរបស់អ្នកបាន ឬក៏ការព្យាយាមអស់ពីចិត្តរបស់អ្នកដើម្បីស្រឡាញ់ព្រះជាម្ចាស់ អាចរក្សាជីវិតរបស់អ្នកបានទេ។ ថ្ងៃនេះ ខ្ញុំមិនដាក់ទោសអ្នកឡើយ។ ចូរចាំរហូតដល់វេលារបស់ព្រះជាម្ចាស់ ដើម្បីមើលថាតើទ្រង់ដាក់ទោសអ្នកដោយបែបណា។ ក្នុងពេលនេះ ខ្ញុំគ្មានពេលជជែកលេង ឥតបានការជាមួយអ្នកឡើយ ហើយខ្ញុំមិនអាចពន្យារពេលកិច្ចការដ៏មហិមារបស់ខ្ញុំ ដោយសារតែរឿងរ៉ាវរបស់អ្នកនោះទេ។ សត្វដង្កូវដូចជារូបអ្នក គ្មានតម្លៃអ្វីឱ្យព្រះជាម្ចាស់ចំណាយពេលមកមានបន្ទូលជាមួយនោះទេ ដូច្នេះចូរចាំមើលថា តើអ្នកនឹងត្រូវវិលាយសាបសូន្យទៅដោយរបៀបណា។ មនុស្សបែបនេះមិនបន្តស្វែងរកការស្គាល់ព្រះជាម្ចាស់ សូម្បីតែបន្តិចសោះឡើយ ពួកគេក៏មិនមានសេចក្ដីស្រឡាញ់ចំពោះទ្រង់សូម្បីបន្តិច ហើយពួកគេនៅតែចង់ឱ្យព្រះជាម្ចាស់ហៅពួកគេថាជាសុចរិត តើនេះមិនគួរឱ្យចង់សើចទេឬអី? ដោយសារតែមានមនុស្សតិចតួចដែលមានសេចក្ដីស្មោះត្រង់ដោយពិតប្រាកដ នោះខ្ញុំនឹងផ្ដោតតែទៅលើការបន្តផ្ដល់ជីវិតដល់មនុស្សលោកតែប៉ុណ្ណោះ។ ខ្ញុំនឹងធ្វើកិច្ចការណាដែលខ្ញុំត្រូវធ្វើឱ្យចប់សព្វគ្រប់នៅក្នុងពេលនេះ ប៉ុន្តែនៅពេលអនាគត ខ្ញុំនឹងដាក់ទោសចំពោះមនុស្សម្នាក់ៗទៅតាមអ្វីដែលពួកគេបានធ្វើ។ ខ្ញុំបានមានបន្ទូលអំពីអ្វីដែលត្រូវនិយាយ ដ្បិតនេះគឺជាកិច្ចការដ៏ពិតប្រាកដដែលខ្ញុំត្រូវធ្វើ។ ខ្ញុំធ្វើតែកិច្ចការណាដែលខ្ញុំត្រូវធ្វើប៉ុណ្ណោះ

ហើយខ្ញុំមិនធ្វើកិច្ចការណាដែលខ្ញុំមិនគប្បីធ្វើឡើយ។ ក៏ប៉ុន្ដែ ខ្ញុំសង្ឃឹមថា អ្នករាល់គ្នាចំណាយពេលឱ្យបានច្រើន ដើម្បីឆ្លុះបញ្ចាំងអំពីចំណុចនេះ៖ តើចំណេះដឹងរបស់អ្នកចំពោះព្រះជាម្ចាស់ មានពិតប្រាកដដល់កម្រិតណា? តើអ្នកជាមនុស្សម្នាក់ដែលដំដែកគោលព្រះជាម្ចាស់ទៅនឹងឈើឆ្កាងម្ដងទៀតមែនទេ? ពាក្យចុងក្រោយរបស់ខ្ញុំគឺ៖ សេចក្ដីវេទនានឹងមានដល់អស់អ្នកដែលឆ្កាងព្រះជាម្ចាស់។

# របៀបបម្រើ ស្របគ្នាទៅនឹង បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់

នៅពេលមនុស្សម្នាក់ជឿលើព្រះជាម្ចាស់ តើគេគួរបម្រើទ្រង់ដោយរបៀបណាឱ្យពិតប្រាកដទៅ? តើមានលក្ខខណ្ឌអ្វីដែលត្រូវបំពេញ ហើយមានសេចក្ដីពិតអ្វីខ្លះដែលអ្នកដែលបម្រើព្រះជាម្ចាស់គួរយល់? ហើយតើអ្នកអាចវង្វេងនៅក្នុងការបម្រើរបស់អ្នកនៅត្រង់កន្លែងណាខ្លះ? អ្នករាល់គ្នាគួរតែដឹងពីចម្លើយនៃរឿងទាំងអស់នេះ។ បញ្ហាទាំងនេះ ប៉ះពាល់ដល់របៀបដែលអ្នករាល់គ្នាជឿលើព្រះជាម្ចាស់ និងរបៀបដែលអ្នកដើរលើផ្លូវដែលដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធ ហើយចុះចូលនឹងការចាត់ចែងយ៉ាងហ្មត់ចត់របស់ព្រះជាម្ចាស់ក្នុងគ្រប់ការទាំងអស់ ដែលអាចឱ្យអ្នករាល់គ្នាយល់គ្រប់ជំហាននៃកិច្ចការរបស់ព្រះជាម្ចាស់ នៅក្នុងអ្នករាល់គ្នា។ នៅពេលអ្នកឈានដល់ចំណុចនោះ អ្នករាល់គ្នានឹងពេញចិត្តចំពោះអ្វីដែលជាសេចក្ដីជំនឿលើព្រះជាម្ចាស់ពេញចិត្ត នឹងរបៀបជឿលើព្រះជាម្ចាស់យ៉ាងត្រឹមត្រូវ ហើយពេញចិត្តនឹងអ្វីដែលអ្នកគួរធ្វើ ដើម្បីប្រព្រឹត្តឲ្យត្រូវតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ការនេះនឹងធ្វើឱ្យអ្នករាល់គ្នាចុះចូលចំពោះកិច្ចការរបស់ព្រះជាម្ចាស់យ៉ាងពេញលេញ និងពេញទំហឹង។ អ្នករាល់គ្នានឹងមិនមានការត្អូញត្អែរ ហើយអ្នកនឹងមិនវិនិច្ឆ័យ ឬវិភាគអ្វីសោះ និងរឹតតែមិនសិក្សាស្រាវជ្រាវកិច្ចការរបស់ព្រះជាម្ចាស់។ ហេតុនេះ អ្នករាល់គ្នានឹងអាចស្ដាប់បង្គាប់ចំពោះព្រះជាម្ចាស់រហូតដល់ស្លាប់ ដោយទុកឱ្យព្រះជាម្ចាស់

ដឹកនាំអ្នក និងដកយកជីវិតរបស់អ្នកដូចជាសត្វចៀម ដើម្បីឱ្យអ្នករាល់គ្នាអាចក្លាយជាពេត្រុសនៃទសវត្សឆ្នាំ១៩៩០ ហើយអាចស្រឡាញ់ព្រះជាម្ចាស់ខ្លាំងបំផុត ដល់ថ្នាក់ហ៊ានជាប់ឆ្កាងដោយគ្មានការត្អូញត្អែរសូម្បីតែបន្តិច។ មានតែពេលនោះទេ ទើបអ្នកនឹងអាចរស់នៅដូចជាពេត្រុសនៃទសវត្សឆ្នាំ១៩៩០បាន។

មនុស្សគ្រប់រូបដែលមានការតាំងចិត្ត អាចបម្រើព្រះជាម្ចាស់បាន ក៏ប៉ុន្តែមានតែអ្នកដែលយកចិត្តទុកដាក់បំផុត ចំពោះបំណងព្រះទ័យរបស់ព្រះជាម្ចាស់ និងយល់ពីព្រះហឫទ័យរបស់ព្រះជាម្ចាស់ប៉ុណ្ណោះ ទើបមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងមានសិទ្ធិបម្រើព្រះជាម្ចាស់បាន។ ខ្ញុំបានរកឃើញចំណុចមួយនេះ ក្នុងចំណោមអ្នករាល់គ្នាគឺ៖ មនុស្សជាច្រើនជឿថា ដរាបណាពួកគេខ្នះខ្នែងផ្សាយដំណឹងល្អសម្រាប់ព្រះជាម្ចាស់ ដើរប្រាប់គេអំពីព្រះជាម្ចាស់ ថ្វាយខ្លួន និងលះបង់អ្វីៗទាំងអស់សម្រាប់ព្រះជាម្ចាស់ ។ល។ នេះហើយ គឺជាការបម្រើព្រះជាម្ចាស់។ សូម្បីតែអ្នកកាន់សាសនាជាច្រើនបានជឿថា ការបម្រើព្រះជាម្ចាស់ គឺជាការដើរកាន់ព្រះគម្ពីរក្នុងដៃ ដោយផ្សព្វផ្សាយដំណឹងល្អអំពីនគរស្ថានសួគ៌ និងសង្គ្រោះមនុស្ស ដោយឱ្យពួកគេប្រែចិត្ត និងលន់តួបាប។ ក៏មានអ្នកដឹកនាំសាសនាជាច្រើនគិតថា ការបម្រើព្រះជាម្ចាស់មានដូចជា ការអធិប្បាយនៅក្នុងវិហារ បន្ទាប់ពីបានទទួលការសិក្សា និងការបណ្ដុះបណ្ដាលជ្រៅជ្រះនៅក្នុងសាលាព្រះគម្ពីរ និងការបង្រៀនមនុស្សតាមរយៈការអានអត្ថបទគម្ពីរ។ លើសពីនេះ មានមនុស្សនៅតំបន់ក្រីក្រដែលជឿថា ការបម្រើព្រះជាម្ចាស់ គឺជាការប្រោសជំងឺ និងដេញអារក្សចេញពីបងប្អូនប្រុសស្រីរបស់ពួកគេ ឬជាការអធិស្ឋានសម្រាប់ពួកគេ ឬបម្រើពួកគេ។ ក្នុងចំណោមអ្នករាល់គ្នា មានមនុស្សជាច្រើនដែលជឿថា ការបម្រើព្រះជាម្ចាស់ គឺជាការហូប និងផឹកព្រះបន្ទូលរបស់ព្រះជាម្ចាស់ អធិស្ឋានទៅព្រះជាម្ចាស់ជារៀងរាល់ថ្ងៃ ក៏ដូចជាការទៅសួរសុខទុក្ខ និងធ្វើកិច្ចការនៅតាមក្រុមជំនុំគ្រប់ទីកន្លែង។ មានបងប្អូនប្រុសស្រីផ្សេងទៀតដែលជឿថា ការបម្រើព្រះជាម្ចាស់ គឺជាការដែលមិនរៀបអាពាហ៍ពិពាហ៍ ឬចិញ្ចឹមគ្រួសារ ហើយថ្វាយខ្លួនទាំងស្រុងទៅព្រះជាម្ចាស់។ ប៉ុន្តែមានមនុស្សតិចណាស់ ដែលដឹង

ថា ការបម្រើព្រះជាម្ចាស់ តាមការពិតគឺជាអ្វីនោះ។ ទោះបីជាមានមនុស្សជាច្រើនដែលបម្រើព្រះជាម្ចាស់ ប្រៀបដូចជាផ្កាយនៅលើមេឃក៏ដោយ ក៏ចំនួនអ្នកដែលអាចបម្រើដោយផ្ទាល់ និងចំនួនអ្នកដែលអាចបម្រើស្របទៅនឹងបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ គឺមានចំនួនតិចតួចបំផុត។ ហេតុអ្វីខ្ញុំនិយាយដូច្នេះ? ខ្ញុំនិយាយដូច្នេះពីព្រោះអ្នករាល់គ្នាមិនយល់ពីសារជាតិនៃឃ្លាដែលថា «ការបម្រើព្រះជាម្ចាស់» ហើយអ្នកយល់តិចតួចបំផុតអំពីរបៀបបម្រើ ស្របទៅនឹងបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ វាមាននូវតម្រូវការបន្ទាន់ ដែលតម្រូវឱ្យមនុស្សយល់ដឹងឱ្យប្រាកដពីប្រភេទនៃការបម្រើចំពោះព្រះជាម្ចាស់ ប្រកបដោយសុខដុមរមនានឹងបំណងព្រះហឫទ័យរបស់ទ្រង់។

ប្រសិនបើអ្នករាល់គ្នាចង់បម្រើ ស្របតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ជាដំបូងអ្នកត្រូវយល់ពីជំពូកមនុស្សដែលព្រះជាម្ចាស់គាប់ព្រះហឫទ័យ ជំពូកមនុស្សដែលព្រះជាម្ចាស់មិនសព្វព្រះទ័យ ជំពូកមនុស្សដែលត្រូវបានព្រះជាម្ចាស់ប្រោសឱ្យគ្រប់លក្ខណ៍ និងមនុស្សដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីបម្រើព្រះជាម្ចាស់។ យ៉ាងហោចណាស់ អ្នករាល់គ្នាគួរតែមានចំណេះដឹងនេះ។ ម្យ៉ាងវិញទៀត អ្នករាល់គ្នាគួរតែដឹងពីគោលបំណងនៃកិច្ចការរបស់ព្រះជាម្ចាស់ និងកិច្ចការដែលព្រះជាម្ចាស់ត្រូវធ្វើនៅទីនេះ និងឥឡូវនេះ។ បន្ទាប់ពីបានយល់អំពីចំណុចនេះ និងតាមរយៈការដឹកនាំនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ ជាដំបូងអ្នករាល់គ្នាគួរតែបានចូលទៅឯទ្រង់ និងបានទទួលបញ្ញាបេសកកម្ម របស់ព្រះជាម្ចាស់ជាមុនសិន។ នៅពេលដែលអ្នករាល់គ្នាពិតជាបានស្គាល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយនៅពេលដែលអ្នកពិតជាស្គាល់កិច្ចការរបស់ព្រះជាម្ចាស់ អ្នករាល់គ្នានឹងមានលក្ខណៈគ្រប់គ្រាន់ ដើម្បីបម្រើព្រះជាម្ចាស់។ ហើយកាលណាអ្នករាល់គ្នាបម្រើទ្រង់ នោះព្រះជាម្ចាស់នឹងបើកភ្នែកខាងឯព្រលឹងវិញ្ញាណរបស់អ្នករាល់គ្នា ហើយឱ្យអ្នករាល់គ្នាយល់ដឹងអំពីកិច្ចការរបស់ទ្រង់កាន់តែខ្លាំង និងមើលឃើញកិច្ចការនោះកាន់តែច្បាស់ជាងមុន។ នៅពេលដែលអ្នកចូលទៅកាន់ភាពពិតនេះ បទពិសោធរបស់អ្នកនឹងកាន់តែជ្រាលជ្រៅ និងពិតប្រាកដ

ហើយអ្នករាល់គ្នាដែលមានបទពិសោធបែបនេះ នឹងអាចដើរនៅក្នុងក្រុមជំនុំនានា និងផ្ដល់ការផ្គត់ផ្គង់ដល់បងប្អូនប្រុសស្រីរបស់អ្នក ដើម្បីឱ្យអ្នករាល់គ្នាអាចជួយចម្រើនកម្លាំងគ្នាទៅវិញទៅមក ដើម្បីបំពេញនូវភាពខ្វះខាតរបស់ខ្លួនផ្ទាល់ និងទទួលបានចំណេះដឹងកាន់តែច្រើនខាងព្រលឹងវិញ្ញាណរបស់អ្នករាល់គ្នា។ លុះត្រាតែអ្នករាល់គ្នាសម្រេចបានលទ្ធផលនេះ ទើបអ្នករាល់គ្នាអាចបម្រើស្របតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ហើយត្រូវបានព្រះជាម្ចាស់ប្រោសឱ្យគ្រប់លក្ខណ៍ នៅក្នុងការបម្រើព្រះរបស់អ្នក។

អស់អ្នកដែលបម្រើព្រះជាម្ចាស់ គួរតែជាអ្នកជិតស្និទ្ធរបស់ព្រះជាម្ចាស់ ពួកគេគួរតែផ្គាប់ព្រះហឫទ័យព្រះជាម្ចាស់ ហើយមានភាពស្មោះត្រង់បំផុតចំពោះព្រះជាម្ចាស់។ មិនថាអ្នកធ្វើសកម្មភាពជាឯកជន ឬនៅទីសាធារណៈ អ្នកអាចទទួលបានសេចក្ដីអំណររបស់ព្រះជាម្ចាស់នៅចំពោះព្រះជាម្ចាស់ អ្នកអាចឈរមាំនៅចំពោះព្រះជាម្ចាស់ ហើយទោះបីមនុស្សដទៃប្រព្រឹត្តនឹងអ្នកយ៉ាងណា ក៏អ្នកតែងតែដើរតាមផ្លូវដែលអ្នកគួរតែដើរជានិច្ច ហើយយកចិត្តទុកដាក់ដល់បន្ទុករបស់ព្រះជាម្ចាស់យ៉ាងល្អិតល្អន់។ មានតែមនុស្សជំពូកនេះទេ ទើបជាមិត្តសម្លាញ់របស់ព្រះជាម្ចាស់។ មិត្តសម្លាញ់របស់ព្រះជាម្ចាស់ទាំងអស់នោះ អាចបម្រើទ្រង់ដោយផ្ទាល់ ព្រោះពួកគេត្រូវបានប្រគល់នូវបញ្ជាបេសកកម្មដ៏អស្ចារ្យ និងបន្ទុករបស់ព្រះជាម្ចាស់ ពួកគេអាចយកព្រះហឫទ័យរបស់ព្រះជាម្ចាស់ដាក់នៅក្នុងដួងចិត្តរបស់ពួកគេ ហើយយក បន្ទុករបស់ព្រះជាម្ចាស់ធ្វើជាបន្ទុករបស់ពួកគេផ្ទាល់ ហើយពួកគេមិនគិតពីអនាគតរបស់ពួកគេឡើយ៖ សូម្បីតែនៅពេលដែលពួកគេមិនមានការរំពឹងទុក ហើយពួកគេឈរមាំទាំងមិនបានទទួលអ្វីសោះ ក៏ពួកគេនៅតែជឿលើព្រះជាម្ចាស់ដោយចិត្តស្រឡាញ់។ ហេតុដូច្នេះ មនុស្សជំពូកនេះគឺជាមិត្តសម្លាញ់របស់ព្រះជាម្ចាស់។ មិត្តសម្លាញ់របស់ព្រះជាម្ចាស់ ក៏ជាអ្នកជិតស្និទ្ធរបស់ទ្រង់ដែរ។ មានតែអ្នកជិតស្និទ្ធរបស់ព្រះជាម្ចាស់ប៉ុណ្ណោះ ទើបអាចចែករំលែកនូវភាពល្ងើយរបស់ទ្រង់ និងព្រះតម្រិះរបស់ទ្រង់ ហើយទោះបីសាច់ឈាមរបស់ពួកគេឈឺចាប់ និងខ្សោយក៏ដោយ ក៏ពួកគេអាចស៊ូទ្រាំនឹងការឈឺចាប់ និងលះបង់អ្វីដែលពួកគេចូលចិត្ត ដើម្បីផ្គាប់ព្រះហឫទ័យព្រះជាម្ចាស់។

ព្រះជាម្ចាស់ដាក់បន្ទុកកាន់តែច្រើនដល់មនុស្សជំពូកនេះ ហើយអ្វីដែលព្រះជាម្ចាស់សព្វព្រះហឫទ័យ ត្រូវបានស្ដែងចេញ តាមរយៈទីបន្ទាល់របស់មនុស្សជំពូកនេះ។ ដូច្នេះ មនុស្សទាំងនេះគាប់ព្រះហឫទ័យព្រះជាម្ចាស់ ពួកគេជាអ្នកបម្រើរបស់ព្រះជាម្ចាស់ ដែលដើរតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ហើយមានតែមនុស្សជំពូកនេះប៉ុណ្ណោះ ដែលអាចគ្រងរាជ្យជាមួយព្រះជាម្ចាស់បាន។ នៅពេលដែលអ្នកបានក្លាយជាមិត្តសម្លាញ់របស់ព្រះជាម្ចាស់ ពិតប្រាកដណាស់ ជាពេលដែលអ្នកនឹងគ្រងរាជ្យជាមួយនឹងព្រះជាម្ចាស់។

ព្រះយេស៊ូវអាចបំពេញបញ្ជាបេសកកម្មរបស់ព្រះជាម្ចាស់ ដែលជាកិច្ចការនៃការប្រោសលោះមនុស្សទាំងអស់ ពីព្រោះទ្រង់បានយកចិត្តទុកដាក់ចំពោះបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ដោយមិនចាំបាច់មានផែនការ ឬការរៀបចំណាមួយ សម្រាប់អង្គទ្រង់ឡើយ។ ដូច្នេះ ទ្រង់គឺជាមិត្តសម្លាញ់របស់ព្រះជាម្ចាស់ គឺជាព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ ជាព្រះជាម្ចាស់ដែលអ្នករាល់គ្នាយល់ច្បាស់។ (តាមពិត ទ្រង់គឺជាព្រះជាម្ចាស់ផ្ទាល់ព្រះអង្គដែលត្រូវបានធ្វើបន្ទាល់ដោយព្រះជាម្ចាស់។ ខ្ញុំនិយាយអំពីរឿងនេះនៅទីនេះ ដើម្បីប្រើអង្គហេតុពីព្រះយេស៊ូវមកបង្ហាញពីបញ្ហានេះ។) ទ្រង់អាចដាក់ផែនការគ្រប់គ្រងរបស់ព្រះជាម្ចាស់នៅកណ្ដាល ហើយទ្រង់តែងតែអធិស្ឋានដល់ព្រះវរបិតាដែលគង់នៅស្ថានសួគ៌ និងបានស្វែងរកបំណងព្រះហឫទ័យរបស់ព្រះវរបិតា ដែលគង់នៅស្ថានសួគ៌។ ទ្រង់បានអធិស្ឋាន និងមានបន្ទូលថា៖ «ឱព្រះដ៏ជាព្រះវរបិតា! សូមសម្រេចទៅតាមបំណងព្រះហឫទ័យរបស់ទ្រង់ចុះ កុំតាមចិត្តទូលបង្គំឡើយ ប៉ុន្តែសូមសម្រេចតាមផែនការរបស់ទ្រង់វិញ។ មនុស្សអាចនឹងខ្សោយ ប៉ុន្តែហេតុអ្វីទ្រង់យកព្រះទ័យទុកដាក់នឹងគេ? តើមនុស្សដែលប្រៀបដូចជាស្រមោច នៅក្នុងព្រះហស្តរបស់ទ្រង់ មានតម្លៃអ្វីដែលទ្រង់ត្រូវយកព្រះទ័យទុកដាក់? នៅក្នុងដួងចិត្តទូលបង្គំ ទូលបង្គំគ្រាន់តែចង់សម្រេចតាមបំណងព្រះហឫទ័យរបស់ទ្រង់ ហើយទូលបង្គំចង់ឲ្យទ្រង់ធ្វើអ្វីដែលទ្រង់ចង់ធ្វើនៅក្នុងទូលបង្គំ តាមបំណងព្រះហឫទ័យរបស់ទ្រង់។» តាមផ្លូវទៅក្រុងយេរូសាឡិម ព្រះយេស៊ូវមានព្រះទ័យក្រៀមក្រំជាខ្លាំង ដូចជាកាំបិត

កំពុងចាក់ចូលទៅក្នុងបេះដូងរបស់ទ្រង់ តែទ្រង់មិនមានបំណងងាកបែរពីព្រះបន្ទូលរបស់ទ្រង់សូម្បីតែបន្តិច ពោលគឺតែងតែមានកម្លាំងដ៏មានអានុភាព ដែលបង្ខំឲ្យទ្រង់ឆ្ពោះទៅកន្លែងដែលទ្រង់នឹងត្រូវគេឆ្កាង។ នៅទីបំផុត ទ្រង់ត្រូវបានគេដំដែកគោលជាប់នឹងឈើឆ្កាង ហើយត្រឡប់ដូចជាសាច់ឈាមមានបាបដែលបំពេញកិច្ចការនៃការប្រោសលោះរបស់មនុស្ស។ ទ្រង់បានផ្ដាច់ច្រវាក់នៃសេចក្ដីស្លាប់ និងស្ថានឃុំព្រលឹង។ នៅចំពោះទ្រង់ សេចក្ដីស្លាប់ ស្ថាននរក និងស្ថានឃុំព្រលឹង បានបាត់បង់អំណាចរបស់វា ហើយត្រូវបានទ្រង់យកឈ្នះរួចទៅហើយ។ ទ្រង់បានរស់នៅអស់រយៈពេលសាមសិបបីឆ្នាំ ជារយៈពេលដែលទ្រង់តែងតែខិតខំអស់ពីសមត្ថភាព ដើម្បីបំពេញតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ស្របតាមកិច្ចការរបស់ព្រះជាម្ចាស់នៅពេលនោះ ទាំងមិនដែលគិតពីផលប្រយោជន៍ ឬការខាតបង់ផ្ទាល់ខ្លួនឡើយ ហើយតែងតែគិតពីបំណងព្រះហឫទ័យរបស់ព្រះវរបិតា។ ដូច្នេះ បន្ទាប់ពីទ្រង់បានទទួលពិធីជ្រមុជទឹក ព្រះជាម្ចាស់ក៏មានបន្ទូលថា៖ «នេះគឺជាបុត្រស្ងួនភ្ងារបស់ខ្ញុំ ខ្ញុំសព្វព្រះទ័យនឹងទ្រង់ណាស់។» ដោយសារតែការបម្រើរបស់ទ្រង់នៅចំពោះព្រះជាម្ចាស់ ស្របនឹងបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ទើបបានជាព្រះជាម្ចាស់ដាក់បន្ទុកដ៏ធ្ងន់នៃការប្រោសលោះមនុស្សទាំងអស់លើស្មារបស់ទ្រង់ និងធ្វើឲ្យទ្រង់សម្រេចកិច្ចការនោះបាន ហើយទ្រង់មានលក្ខណសម្បត្តិគ្រប់គ្រាន់ និងមានសិទ្ធិបំពេញកិច្ចការដ៏សំខាន់នេះ។ ពេញមួយជីវិតរបស់ទ្រង់ ទ្រង់បានស៊ូទ្រាំនឹងការរងទុក្ខដែលមិនអាចវាស់បានសម្រាប់ព្រះជាម្ចាស់ ហើយទ្រង់ត្រូវបានសាតាំងល្បួងជាច្រើនដងរាប់មិនអស់ ប៉ុន្តែទ្រង់មិនដែលខូចព្រះទ័យឡើយ។ ព្រះជាម្ចាស់បានប្រគល់កិច្ចការដ៏ធំសម្បើមដល់ទ្រង់ ពីព្រោះព្រះជាម្ចាស់បានទុកចិត្តលើទ្រង់ ហើយស្រឡាញ់ទ្រង់ ដូច្នេះព្រះជាម្ចាស់បានមានបន្ទូលដោយផ្ទាល់ថា «នេះគឺជាបុត្រស្ងួនភ្ងារបស់ខ្ញុំ ខ្ញុំសព្វព្រះទ័យនឹងទ្រង់ណាស់។» នៅពេលនោះ មានតែព្រះយេស៊ូវទេ ដែលអាចសម្រេចបញ្ញាបេសកកម្មនេះបាន ហើយនេះគឺជាទិដ្ឋភាពជាក់ស្ដែងមួយ នៃការបញ្ចប់កិច្ចការប្រោសលោះមនុស្សលោកទាំងអស់របស់ព្រះជាម្ចាស់ នៅក្នុងយុគសម័យនៃព្រះគុណ។

ប្រសិនបើអ្នករាល់គ្នាអាចផ្ដោតការយកចិត្តទុកដាក់ចំពោះបន្ទុករបស់ព្រះជាម្ចាស់ ហើយបោះបង់ចោលសាច់ឈាមរបស់អ្នករាល់គ្នាដូចជាព្រះយេស៊ូវ នោះព្រះជាម្ចាស់នឹងប្រគល់កិច្ចការសំខាន់ៗដល់អ្នករាល់គ្នា ដើម្បីឱ្យអ្នករាល់គ្នានឹងបំពេញទៅតាមលក្ខខណ្ឌតម្រូវ ដើម្បីបម្រើព្រះជាម្ចាស់។ មានតែនៅក្នុងកាលៈទេសៈបែបនេះទេ ទើបអ្នករាល់គ្នាអាចនិយាយបានថា អ្នករាល់គ្នាកំពុងធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ហើយបំពេញបញ្ញាបេសកកម្មរបស់ទ្រង់ ហើយមានតែពេលនោះទេ ទើបអ្នកហ៊ាននិយាយថា អ្នកពិតជាកំពុងបម្រើព្រះជាម្ចាស់។ បើប្រៀបធៀបនឹងគំរូរបស់ព្រះយេស៊ូវ តើអ្នកហ៊ាននិយាយទេថា អ្នកគឺជាមិត្តសម្លាញ់របស់ព្រះជាម្ចាស់? តើអ្នកហ៊ាននិយាយទេថា អ្នកកំពុងធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់? តើអ្នកហ៊ាននិយាយទេថា អ្នកពិតជាកំពុងបម្រើព្រះជាម្ចាស់? សព្វថ្ងៃនេះ អ្នកមិនយល់ពីរបៀបបម្រើព្រះជាម្ចាស់ឡើយ។ តើអ្នកហ៊ាននិយាយទេថា អ្នកគឺជាមិត្តសម្លាញ់របស់ព្រះជាម្ចាស់? បើអ្នកនិយាយថា អ្នកបម្រើព្រះជាម្ចាស់ តើអ្នកមិនប្រមាថដល់ទ្រង់ទេឬអី? សូមគិតមើលថា៖ តើអ្នកកំពុងបម្រើព្រះជាម្ចាស់ ឬកំពុងបម្រើខ្លួនឯង? អ្នកបម្រើសាតាំង តែអ្នកនិយាយដោយចចេសថា អ្នកកំពុងបម្រើព្រះជាម្ចាស់។ នៅក្នុងន័យនេះ តើអ្នកមិនប្រមាថព្រះជាម្ចាស់ទេឬអី? មនុស្សជាច្រើនលោភលន់ចង់បានផលប្រយោជន៍ ជាបុណ្យសក្តិនៅពីក្រោយខ្នងរបស់ខ្ញុំ ពួកគេល្មោភស៊ី ពួកគេល្មោភដេក និងយកចិត្តទុកដាក់ចំពោះសាច់ឈាម គេតែងតែបារម្ភខ្លាចគ្មានវិធីបំប៉នសាច់ឈាម។ ពួកគេ មិនបំពេញតាមតួនាទីត្រឹមត្រូវរបស់ពួកគេនៅក្នុងក្រុមជំនុំទេ តែពួកគេទទួលប្រយោជន៍ពីក្រុមជំនុំ ពុំនោះសោត ពួកគេក៏យកបន្ទូលរបស់ខ្ញុំទៅដាស់តឿនបងប្អូនប្រុសស្រី ដោយតាំងខ្លួនជាចៅហ្វាយលើអ្នកដទៃតាមរយៈសិទ្ធិអំណាចជាអ្នកគ្រប់គ្រង។ មនុស្សជំពូកនេះ នៅតែនិយាយថា ពួកគេកំពុងធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងតែងតែនិយាយថា ពួកគេជាមិត្តសម្លាញ់របស់ព្រះជាម្ចាស់។ តើនេះមិនចម្លែកទេឬអី? ប្រសិនបើអ្នកមានបំណងដ៏ត្រឹមត្រូវ ប៉ុន្តែមិនអាចបម្រើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ទេនោះ អ្នកនឹងក្លាយជា

មនុស្សល្ងីល្ងើ។ ប៉ុន្តែប្រសិនបើបំណងរបស់អ្នកមិនត្រឹមត្រូវ ហើយអ្នកនៅតែនិយាយថា អ្នកជាអ្នកបម្រើព្រះជាម្ចាស់ នោះអ្នកគឺជាមនុស្សដែលទាស់ទទឹងនឹងព្រះជាម្ចាស់ ហើយអ្នកសមនឹងទទួលទណ្ឌកម្មពីព្រះជាម្ចាស់! ខ្ញុំគ្មានការអាណិតអាសូរចំពោះមនុស្សបែបនេះទេ! នៅក្នុងព្រះដំណាក់របស់ព្រះជាម្ចាស់ ពួកគេតែងតែជំហមលោភលន់ចង់បានភាពស្រណុកខាងសាច់ឈាម ហើយមិនគិតពីផលប្រយោជន៍របស់ព្រះជាម្ចាស់ឡើយ។ ពួកគេតែងតែស្វែងរកអ្វីដែលល្អសម្រាប់ពួកគេ ហើយពួកគេមិនបានយកចិត្តទុកដាក់ចំពោះបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ឡើយ។ ពួកគេមិនទទួលយកការត្រួតពិនិត្យនៃព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ នៅក្នុងអ្វីដែលពួកគេធ្វើឡើយ។ ពួកគេតែងតែប្រើកលល្បិច និងបោកបញ្ឆោតបងប្អូនប្រុសស្រីរបស់ពួកគេ និងធ្វើជាមនុស្សមុខពីរ ដូចជាកញ្ជ្រោងនៅក្នុងចម្ការទំពាំងបាយជូរដែលតែងតែលួចយកផ្លែទំពាំងបាយជូរ ហើយជាន់កម្ទេចដើមនៅក្នុងចម្ការ។ តើមនុស្សជំពូកនេះអាចជាមិត្តសម្លាញ់របស់ព្រះជាម្ចាស់ដែរឬទេ? តើអ្នកសមនឹងទទួលព្រះពរពីព្រះជាម្ចាស់ដែរឬទេ? អ្នកមិនមានបន្ទុកសម្រាប់ជីវិតរបស់អ្នក និងក្រុមជំនុំសោះ តើអ្នកសមនឹងទទួលបញ្ជាបេសកកម្មរបស់ព្រះជាម្ចាស់ដែរឬទេ? តើនរណានឹងហ៊ានទុកចិត្តមនុស្សដូចជាអ្នក? នៅពេលដែលអ្នកបម្រើព្រះជាម្ចាស់ដូចនេះ តើព្រះជាម្ចាស់អាចនឹងហ៊ានប្រគល់កិច្ចការសំខាន់ជាងនេះដល់អ្នកដែរឬទេ? តើនេះនឹងមិនធ្វើឲ្យកិច្ចការមានភាពយឺតយ៉ាវទេឬអី?

ខ្ញុំនិយាយដូច្នេះ ដើម្បីឲ្យអ្នករាល់គ្នាដឹងអំពីលក្ខខណ្ឌដែលត្រូវបំពេញដើម្បីបម្រើស្របតាមបំណងព្រះឫទ័យរបស់ព្រះជាម្ចាស់។ ប្រសិនបើអ្នករាល់គ្នា មិនប្រគល់ដួងចិត្តរបស់អ្នកដល់ព្រះជាម្ចាស់ ប្រសិនបើអ្នកមិនផ្ដោតការយកចិត្តទុកដាក់ចំពោះបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដូចជាព្រះយេស៊ូវទេនោះ ព្រះជាម្ចាស់មិនអាចជឿជាក់លើអ្នករាល់គ្នាបានឡើយ ហើយនឹងបញ្ចប់ដោយត្រូវជំនុំជម្រះដោយព្រះជាម្ចាស់។ ប្រហែលជាសព្វថ្ងៃនេះ អ្នកតែងតែមានចេតនាបញ្ឆោតព្រះជាម្ចាស់ក្នុងការបម្រើទ្រង់ ហើយតែងតែដោះស្រាយជាមួយព្រះអង្គ ក្នុងឥរិយាបថដែល

ជាក់ច្បាស់។ សរុបសេចក្ដីមក ប្រសិនបើអ្នកបោកបញ្ឆោតព្រះជាម្ចាស់ ការជំនុំជម្រះដ៏ឥតមេត្តានឹងធ្លាក់មកលើអ្នក ដោយមិនគិតពីអ្វីទាំងអស់ផ្សេងទៀត។ អ្នករាល់គ្នាគួរតែទាញយកប្រយោជន៍ពីការចូលទៅក្នុងផ្លូវដ៏ត្រឹមត្រូវក្នុងការបម្រើព្រះជាម្ចាស់ ដើម្បីប្រគល់ដួងចិត្តដល់ព្រះជាម្ចាស់ជាមុន ដោយមានភក្ដីភាពចំពោះព្រះជាម្ចាស់តែមួយគត់។ មិនថាអ្នកនៅចំពោះព្រះជាម្ចាស់ ឬនៅមុខមនុស្សដទៃទៀត ដួងចិត្តរបស់អ្នកគួរតែផ្ដោតទៅរកព្រះជាម្ចាស់ជានិច្ច ហើយអ្នកគួរតែតាំងចិត្តស្រឡាញ់ព្រះជាម្ចាស់ ដូចព្រះយេស៊ូវដែរ។ តាមវិធីនេះ ព្រះជាម្ចាស់នឹងប្រោសឲ្យអ្នកបានគ្រប់លក្ខណ៍ ដើម្បីឲ្យអ្នកក្លាយជាអ្នកបម្រើដែលព្រះជាម្ចាស់សព្វព្រះហឫទ័យ។ ប្រសិនបើអ្នកពិតជាចង់ឱ្យព្រះជាម្ចាស់ប្រោសឱ្យគ្រប់លក្ខណ៍មែន ហើយឲ្យកិច្ចការបម្រើរបស់អ្នកស្របតាមបំណងព្រះហឫទ័យរបស់ទ្រង់ នោះអ្នកគួរតែផ្លាស់ប្ដូរទស្សនៈពីមុនរបស់អ្នក ចំពោះសេចក្ដីជំនឿលើព្រះជាម្ចាស់ និងផ្លាស់ប្ដូររបៀបចាស់របស់អ្នកដែលអ្នកបានប្រើដើម្បីបម្រើព្រះជាម្ចាស់ ទើបអ្នកកាន់តែត្រូវបានព្រះជាម្ចាស់ប្រោសឱ្យគ្រប់លក្ខណ៍។ តាមវិធីនេះ ព្រះជាម្ចាស់នឹងមិនបោះបង់ចោលអ្នកឡើយ ហើយអ្នកនឹងនាំមុខនៃអស់អ្នកដែលស្រឡាញ់ព្រះជាម្ចាស់ ដូចជាពេត្រុស។ ប្រសិនបើអ្នកនៅតែមិនប្រែចិត្ត នោះចុងក្រោយ អ្នកនឹងជួបរឿងដូចជាយូដាស។ មនុស្សគ្រប់គ្នាដែលជឿដល់ព្រះជាម្ចាស់ គួរតែយល់អំពីរឿងនេះ។

# អំពីការដែលព្រះជាម្ចាស់ប្រើមនុស្ស

គ្មាននរណាម្នាក់មានសមត្ថភាពរស់នៅដោយឯករាជ្យបាននោះឡើយ លើកលែងតែអស់អ្នកដែលត្រូវបានផ្ដល់ទិសដៅ និងការដឹកនាំដ៏ពិសេសពីព្រះវិញ្ញាណបរិសុទ្ធប៉ុណ្ណោះ ដោយសារតែពួកគេត្រូវការការធ្វើព័ន្ធកិច្ច និងការឃ្វាលពីអស់អ្នកដែលព្រះជាម្ចាស់បានប្រើប្រាស់។ ដូច្នេះក្នុងយុគសម័យនីមួយៗ ព្រះជាម្ចាស់លើកមនុស្សផ្សេងៗដែលរួសរាន់ មមាញឹកឃ្វាលពួកជំនុំ ដើម្បីជាប្រយោជន៍ដល់កិច្ចការទ្រង់។

កិច្ចការរបស់ព្រះជាម្ចាស់ ត្រូវធ្វើឡើងតាមរយៈមនុស្សដែលទ្រង់គាប់ព្រះហឫទ័យ និងសរសើរ ពោលគឺព្រះវិញ្ញាណបរិសុទ្ធ ត្រូវប្រើប្រាស់ឥរិយាបទខាងក្នុងរបស់ពួកគេ ដែលមានតម្លៃសមនឹងប្រើការ ដើម្បីឱ្យព្រះវិញ្ញាណបរិសុទ្ធធ្វើការ ហើយពួកគេនឹងត្រូវច្នៃតម្រូវឱ្យព្រះជាម្ចាស់ប្រើតាមរយៈការប្រោសឱ្យគ្រប់លក្ខណ៍ដោយព្រះវិញ្ញាណបរិសុទ្ធ។ ដោយសារមនុស្សគ្មានសមត្ថភាពយល់ដឹងសោះ បានជាគេត្រូវឃ្វាលដោយមនុស្សដែលព្រះជាម្ចាស់ប្រើ ពោលគឺវាដូចគ្នា នឹងការដែលព្រះជាម្ចាស់ប្រើលោកម៉ូសេ ជាមនុស្សដែលទ្រង់យល់ថាស័ក្តិសមប្រើនៅពេលនោះ ហើយជាមនុស្សដែលទ្រង់ប្រើឱ្យធ្វើកិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងដំណាក់កាលនោះ។ ក្នុងដំណាក់កាលនេះ ព្រះជាម្ចាស់ប្រើមនុស្ស ហើយក៏ទាញយកប្រយោជន៍ខ្លះពីចំណែករបស់គេដែលអាចប្រើការបាន ដោយព្រះវិញ្ញាណបរិសុទ្ធ ដើម្បីធ្វើការ ហើយព្រះវិញ្ញាណបរិសុទ្ធក៏ដឹកនាំ និងកែប្រែនូវចំណែកសេសសល់ គឺជាចំណែកដែលមិនអាចប្រើការបាន ឱ្យបានគ្រប់លក្ខណ៍ព្រមគ្នាតែម្តង។

កិច្ចការដែលត្រូវបានអនុវត្តដោយមនុស្សដែលព្រះជាម្ចាស់ប្រើ គឺធ្វើឡើងដើម្បីសហការជាមួយកិច្ចការរបស់ព្រះគ្រីស្ទ ឬព្រះវិញ្ញាណបរិសុទ្ធ។ ព្រះជាម្ចាស់លើកមនុស្សនេះឡើង នៅក្នុងចំណោមមនុស្សដទៃទៀត គេនៅទីនោះដើម្បីដឹកនាំមនុស្សដែលព្រះជាម្ចាស់បានជ្រើសរើស ហើយព្រះជាម្ចាស់ក៏លើកគេឡើង ដើម្បីធ្វើកិច្ចការទំនាក់ទំនងរបស់មនុស្ស។ ដោយមានមនុស្សដែលអាចធ្វើការទំនាក់ទំនងជាមួយមនុស្ស នៅជាមួយបែបនេះ នោះសេចក្តីតម្រូវដែលព្រះជាម្ចាស់តម្រូវពីមនុស្ស និងកិច្ចការដែលព្រះវិញ្ញាណបរិសុទ្ធត្រូវធ្វើនៅក្នុងចំណោមមនុស្ស អាចនឹងសម្រេចបានកាន់តែច្រើន ដោយសារបុគ្គលម្នាក់នេះ។ និយាយមួយបែបទៀតគឺថា បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ក្នុងការប្រើមនុស្ស គឺដើម្បីឱ្យមនុស្សដែលដើរតាមព្រះជាម្ចាស់ អាចយល់ពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់កាន់តែប្រសើរ ហើយអាចសម្រេចបាន នូវសេចក្តីដែលទ្រង់តម្រូវបានកាន់តែច្រើន។ ដោយសារមនុស្សគ្មានសមត្ថភាពយល់ដឹងពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ ឬបំណងព្រះហឫទ័យរបស់

ព្រះជាម្ចាស់ដោយផ្ទាល់ ទើបព្រះជាម្ចាស់បានលើកមនុស្សម្នាក់ឡើងមកប្រើ ដើម្បីអនុវត្តកិច្ចការបែបនេះ។ មនុស្សដែលព្រះជាម្ចាស់ប្រើនេះ ក៏អាចចាត់ទុកថាជាមនុស្សដែលព្រះជាម្ចាស់ប្រើសម្រាប់ណែនាំមនុស្សដូចគ្នា និងជា «អ្នកបកប្រែ» សម្រាប់សម្របសម្រួលការទំនាក់ទំនងរវាងព្រះជាម្ចាស់ និងមនុស្សផងដែរ។ ដូច្នេះមនុស្សប្រភេទនេះមិនដូចមនុស្សផ្សេងទៀត ដែលធ្វើកិច្ចការក្នុងដំណាក់របស់ព្រះជាម្ចាស់ ឬសាវ័កទ្រង់ឡើយ។ មនុស្សដូចជាពួកគាត់ គេអាចចាត់ទុកជាអ្នកដែលបម្រើព្រះជាម្ចាស់ ប៉ុន្តែនៅក្នុងខ្លឹមសារការងាររបស់គាត់ និងប្រវត្តិនៃការដែលព្រះជាម្ចាស់ប្រើគាត់ គឺគាត់ខុសពីអ្នកធ្វើកិច្ចការផ្សេង និងសាវ័កដទៃទៀតឆ្ងាយណាស់។ ចំពោះខ្លឹមសារការងារ និងប្រវត្តិនៃការដែលព្រះជាម្ចាស់ប្រើប្រាស់គាត់ មនុស្សដែលព្រះជាម្ចាស់ប្រើ គឺទ្រង់ជាអ្នកលើកគាត់ឡើង ក៏បម្រុងគាត់ទុកសម្រាប់កិច្ចការរបស់ព្រះអង្គ ហើយគេសហការក្នុងកិច្ចការរបស់ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ។ គ្មាននរណាម្នាក់អាចធ្វើកិច្ចការរបស់គាត់ជំនួសគាត់បានឡើយ នេះគឺជាការសហការរបស់មនុស្សដែលសំខាន់ចំពោះកិច្ចការរបស់ព្រះ។ ជាមួយគ្នានេះ កិច្ចការដែលអនុវត្តដោយអ្នកបម្រើការ ឬសាវ័កដទៃៗទៀតគឺគ្រាន់តែជាការផ្ទេរ និងអនុវត្តចំណុចជាច្រើននៃការរៀបចំសម្រាប់ពួកជំនុំក្នុងសម័យកាលនីមួយៗ ពុំនោះទេ កិច្ចការនោះគ្រាន់តែជាកិច្ចការនៃការផ្ដល់ជីវិតយ៉ាងសាមញ្ញដើម្បីរក្សាជីវិតពួកជំនុំប៉ុណ្ណោះ។ អ្នកបម្រើការ និងពួកសាវ័កទាំងនេះមិនត្រូវបានចាក់ប្រេងតាំងដោយព្រះជាម្ចាស់ឡើយ រឹតតែមិនអាចហៅពួកគេថាជាមនុស្ស ដែលព្រះវិញ្ញាណបរិសុទ្ធប្រើនោះឡើយ។ ពួកគេត្រូវបានជ្រើសរើសចេញពីក្នុងចំណោមពួកជំនុំ ហើយបន្ទាប់ពីពួកគេទទួលបានការអប់រំ និងបណ្ដុះបណ្ដាលក្នុងរយៈពេលណាមួយហើយ មនុស្សដែលស័ក្តិសមនឹងត្រូវរក្សាទុក រីឯមនុស្សដែលមិនស័ក្តិសមនឹងត្រូវបញ្ជូនត្រឡប់ទៅវិញ។ ដោយសារមនុស្សទាំងនេះត្រូវបានជ្រើសរើសចេញពីពួកជំនុំ អ្នកខ្លះបានបង្ហាញធាតុពិតរបស់ខ្លួន ក្រោយពីក្លាយជាអ្នកដឹកនាំ ហើយអ្នកខ្លះទៀតថែមទាំងបានធ្វើការអាក្រក់ៗជាច្រើន ហើយចុងក្រោយក៏ត្រូវបានបណ្ដេញចេញ។ ម៉្យាងវិញទៀត មនុស្សដែលព្រះជាម្ចាស់

ប្រើ គឺជាមនុស្សដែលព្រះជាម្ចាស់រៀបចំ ហើយជាមនុស្សដែលមានគុណសម្បត្តិជាក់លាក់ និងមានភាពជាមនុស្ស។ គាត់ត្រូវបានរៀបចំ និងប្រោសឱ្យគ្រប់លក្ខណ៍ជាមុន ដោយព្រះវិញ្ញាណបរិសុទ្ធ ហើយត្រូវបានដឹកនាំទាំងស្រុងដោយព្រះវិញ្ញាណបរិសុទ្ធ ជាពិសេស នៅពេលកិច្ចការរបស់គាត់មកដល់ គាត់ត្រូវបានដឹកនាំ និងបង្គាប់ដោយព្រះវិញ្ញាណបរិសុទ្ធ។ ជាលទ្ធផលនៃកិច្ចការនេះ នៅលើផ្លូវនៃការដឹកនាំរបស់មនុស្សដែលព្រះជាម្ចាស់ជ្រើសរើស គ្មានការងាករេបែរចេញឡើយ ដ្បិតព្រះជាម្ចាស់ទ្រង់ពិតជាទទួលខុសត្រូវចំពោះកិច្ចការរបស់ទ្រង់ផ្ទាល់ ហើយព្រះជាម្ចាស់ធ្វើកិច្ចការរបស់ទ្រង់ផ្ទាល់គ្រប់ពេលវេលា។

# បញ្ញត្តិនៅក្នុងយុគសម័យថ្មី

ចំពោះការមានបទពិសោធពីកិច្ចការរបស់ព្រះជាម្ចាស់ អ្នករាល់គ្នាត្រូវតែអានព្រះបន្ទូលរបស់ទ្រង់ដោយយកចិត្តទុកដាក់ និងប្រដាប់ខ្លួនដោយសេចក្ដីពិត។ ប៉ុន្តែពាក់ព័ន្ធនឹងអ្វីដែលអ្នករាល់គ្នាចង់ធ្វើ ឬរបៀបដែលអ្នកចង់ធ្វើវា មិនចាំបាច់មានសេចក្ដីអធិស្ឋានដ៏អស់ពីចិត្ត ឬការអង្វរសុំនោះទេ ហើយតាមពិតទៅការទាំងនេះ គឺគ្មានប្រយោជន៍អ្វីទេ។ ប៉ុន្តែ នាពេលបច្ចុប្បន្ននេះ បញ្ហាដែលអ្នករាល់គ្នាកំពុងតែប្រឈមមុខគឺថាអ្នកមិនដឹងពីរបៀបដកបទពិសោធពីកិច្ចការរបស់ព្រះ ហើយថានៅក្នុងអ្នក គឺមាននូវលក្ខណៈអកម្មជាច្រើន។ អ្នករាល់គ្នាស្គាល់នូវគោលលទ្ធិជាច្រើន តែអ្នកមិនមានភាពជាក់ស្ដែងច្រើននោះទេ។ តើនេះមិនមែនជាសញ្ញា នៃភាពក្លែងក្លាយទេឬ? មានភាពក្លែងក្លាយច្រើនអាចត្រូវបានមើលឃើញនៅក្នុងអ្នករាល់គ្នា ដែលជាមនុស្សមួយក្រុមនេះ។ ថ្ងៃនេះ អ្នករាល់គ្នាពុំអាចមានលទ្ធភាពសម្រេចបាននូវការល្បងល ដូចជា «អ្នកស៊ីឈ្នួលទាំងឡាយ» បានទេ ហើយអ្នកក៏ពុំអាចមានលទ្ធភាពស្រមៃ ឬសម្រេចការល្បងលផ្សេងទៀត និងការបន្សុទ្ធដែលទាក់ទងនឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់បានដែរ។ អ្នករាល់គ្នាត្រូវតែប្រកាន់ខ្ជាប់នូវចំណុចជាច្រើន ដែលអ្នករាល់គ្នាគួរតែ

យកទៅអនុវត្ត។ នេះមានន័យថា មនុស្សត្រូវតែប្រកាន់ខ្ជាប់នូវកាតព្វកិច្ចជាច្រើន ដែលពួកគេគួរតែបំពេញ។ នេះហើយជាអ្វីដែលមនុស្សគួរតែប្រកាន់ខ្ជាប់ ហើយ នេះក៏ជាអ្វីដែលពួកគេត្រូវតែប្រតិបត្តិដែរ។ ចូរអនុញ្ញាតឲ្យព្រះវិញ្ញាណបរិសុទ្ធ ធ្វើអ្វី ដែលព្រះវិញ្ញាណបរិសុទ្ធត្រូវតែធ្វើ មនុស្សមិនអាចជួយអ្វីបានឡើយ នៅក្នុងរឿង នេះ។ មនុស្សគួរប្រកាន់ខ្ជាប់នូវអ្វីដែលមនុស្សគួរតែធ្វើ ដោយមិនជាប់ពាក់ព័ន្ធនឹង ព្រះវិញ្ញាណបរិសុទ្ធ។ វាគ្មានអ្វីក្រៅពីអ្វីដែលគួរតែត្រូវបានធ្វើដោយមនុស្សនោះទេ ហើយវាក៏គួរតែត្រូវបានប្រកាន់ខ្ជាប់ជាបញ្ញត្តិ ដូចទៅនឹងការធ្វើតាមច្បាប់នៅក្នុងគម្ពីរ សញ្ញាចាស់ដែរ។ ទោះបីជាឥឡូវនេះមិនមែនជាយុគសម័យនៃក្រឹត្យវិន័យក្តី ក៏នៅតែ មានព្រះបន្ទូលជាច្រើន ដែលគួរតែត្រូវបានប្រកាន់ខ្ជាប់ ដូចទៅនឹងព្រះបន្ទូលដែល បានថ្លែងនៅក្នុងយុគសម័យនៃក្រឹត្យវិន័យដែរ។ ព្រះបន្ទូលទាំងនេះ មិនត្រូវបាន អនុវត្ត ដោយគ្រាន់តែពឹងអាងលើការប៉ះពាល់ពីព្រះវិញ្ញាណបរិសុទ្ធប៉ុណ្ណោះទេ ប៉ុន្តែ ផ្ទុយទៅវិញ ព្រះបន្ទូលទាំងនេះគឺជាអ្វីដែលមនុស្សគួរតែប្រកាន់ខ្ជាប់។ ឧទាហរណ៍ អ្នក មិនត្រូវដាក់ការវិនិច្ឆ័យចំពោះកិច្ចការរបស់ព្រះដ៏ជាក់ស្តែងឡើយ។ អ្នកមិនត្រូវប្រឆាំង ទាស់នឹងមនុស្សដែលព្រះជាម្ចាស់បានធ្វើបន្ទាល់បញ្ជាក់ឡើយ។ នៅចំពោះព្រះភ័ក្ត្រ ព្រះជាម្ចាស់ អ្នកត្រូវស្គាល់ឋានៈរបស់ខ្លួន ហើយមិនត្រូវអសីលធម៌ឡើយ។ អ្នកគួរតែ ចេះប្រមាណខ្លួនក្នុងការនិយាយស្តី ហើយពាក្យសម្តី និងសកម្មភាពរបស់អ្នក ត្រូវតែ ធ្វើទៅតាមរបៀបរៀបចំរបស់មនុស្ស ដែលត្រូវបានធ្វើបន្ទាល់ដោយព្រះជាម្ចាស់។ អ្នកគួរតែគោរពទីបន្ទាល់នៃព្រះជាម្ចាស់។ អ្នកមិនត្រូវធ្វើជាមិនដឹងមិនឮចំពោះកិច្ចការ របស់ព្រះជាម្ចាស់ ហើយនិងព្រះបន្ទូល ដែលចេញពីព្រះឱស្ឋរបស់ទ្រង់ឡើយ។ អ្នកមិនត្រូវធ្វើត្រាប់តាមសំឡេង និងចង់ត្រាប់តាមព្រះសូរសៀងរបស់ព្រះជាម្ចាស់ ឡើយ។ នៅខាងក្រៅ អ្នកមិនត្រូវធ្វើអ្វីដែលប្រឆាំងទាស់នឹងមនុស្សដែលត្រូវបាន ធ្វើបន្ទាល់ដោយព្រះជាម្ចាស់ឡើយ ។ល។ ទាំងនេះ ជាអ្វីដែលមនុស្សម្នាក់ៗគួរតែ ប្រកាន់ខ្ជាប់។ នៅក្នុងយុគសម័យនីមួយៗ ព្រះជាម្ចាស់បញ្ជាក់ពីក្បួនច្បាប់ជាច្រើន ដែលស្រដៀងនឹងក្រឹត្យវិន័យ ហើយត្រូវតែប្រកាន់ខ្ជាប់ដោយមនុស្ស។ តាមរយៈ

ការនេះ ទ្រង់ដាក់រឹតបន្តឹងនិស្ស័យរបស់មនុស្ស និងរកឃើញពីភាពស្មោះត្រង់របស់គេ។ ឧទាហរណ៍ ចូរពិចារណាអំពីព្រះបន្ទូលដែលថា៖ «ចូរគោរពប្រណិប័តន៍ដល់ឪពុកម្ដាយរបស់អ្នក» នៅក្នុងសម័យគម្ពីរសញ្ញាចាស់។ ព្រះបន្ទូលទាំងនេះ មិនបានយកមកអនុវត្តនៅសព្វថ្ងៃនេះទេ នៅគ្រានោះ គេគ្រាន់តែរឹតបន្តឹងនិស្ស័យខាងក្រៅរបស់មនុស្សមួយចំនួនដែលត្រូវបានប្រើ ដើម្បីបង្ហាញសេចក្តីស្មោះត្រង់នៃជំនឿរបស់មនុស្សចំពោះព្រះជាម្ចាស់ និងក៏ជាសញ្ញាសម្គាល់មួយរបស់អស់អ្នកដែលបានជឿលើព្រះជាម្ចាស់ដែរ។ ទោះបីជាឥឡូវនេះជាយុគសម័យនៃនគរព្រះក៏ដោយ ក៏នៅតែមានក្រឹត្យវិន័យជាច្រើន ដែលមនុស្សត្រូវតែកាន់តាមដែរ។ ច្បាប់វិន័យពីអតីតកាល មិនត្រូវបានយកមកអនុវត្តនោះទេ ហើយសព្វថ្ងៃនេះ មានការអនុវត្តសមស្របជាច្រើនថែមទៀតសម្រាប់ឲ្យមនុស្សប្រតិបត្តិ និងការអនុវត្តដែលជាការចាំបាច់។ ច្បាប់វិន័យទាំងនេះ មិនទាក់ទងនឹងកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធទេ ហើយត្រូវតែត្រូវបានអនុវត្តដោយមនុស្ស។

នៅក្នុងយុគសម័យនៃព្រះគុណ ការអនុវត្តជាច្រើននៅក្នុងយុគសម័យនៃក្រឹត្យវិន័យ ត្រូវបានគេបោះបង់ចោល ដោយសារតែក្រឹត្យវិន័យទាំងនេះគ្មានប្រសិទ្ធភាពជាពិសេស សម្រាប់កិច្ចការនៅពេលនោះ។ ក្រោយពីក្រឹត្យវិន័យទាំងនេះត្រូវបានបោះបង់ចោល ការអនុវត្តជាច្រើនត្រូវបានដាក់ចេញដែលសមស្របសម្រាប់សម័យនោះ ហើយបានក្លាយទៅជាច្បាប់វិន័យជាច្រើននៅសព្វថ្ងៃនេះ។ នៅពេលដែលព្រះជាម្ចាស់នៃបច្ចុប្បន្នកាលបានយាងមក ច្បាប់វិន័យទាំងនេះ ត្រូវបានចែកចាយ ហើយវាលែងត្រូវបានតម្រូវឲ្យកាន់តាមទៀតហើយ រីឯការអនុវត្តជាច្រើនត្រូវបានដាក់ចេញដែលសមស្របសម្រាប់កិច្ចការនៅសព្វថ្ងៃនេះ។ សព្វថ្ងៃនេះ ការអនុវត្តទាំងនេះមិនមែនជាច្បាប់វិន័យនោះទេ ប៉ុន្តែផ្ទុយទៅវិញ គឺដើម្បីសម្រេចឲ្យបានប្រសិទ្ធភាព។ ការអនុវត្តទាំងនេះសមស្របសម្រាប់ថ្ងៃនេះ ហើយថ្ងៃស្អែក ប្រហែលពួកវានឹងក្លាយជាច្បាប់វិន័យ។ សរុបសេចក្តីមក អ្នកគួរតែប្រកាន់ខ្ជាប់នូវអ្វីដែលជាផ្លែផ្កាសម្រាប់កិច្ចការនៅថ្ងៃនេះ។ កុំយកចិត្តទុកដាក់នឹងថ្ងៃស្អែក៖ អ្វីដែលត្រូវបានធ្វើ

នៅថ្ងៃនេះ គឺសម្រាប់ជាប្រយោជន៍នៅថ្ងៃនេះ។ ប្រហែលជានៅពេលដែលថ្ងៃស្អែកមកដល់ នឹងមានការអនុវត្តប្រសើរជាងមុន ដែលអ្នកនឹងត្រូវបានតម្រូវឲ្យអនុវត្តតាម ប៉ុន្តែកុំយកចិត្តទុកដាក់នឹងការនោះខ្លាំងពេក។ ផ្ទុយទៅវិញ ត្រូវប្រកាន់ខ្ជាប់នូវអ្វីដែលគួរតែត្រូវបានកាន់តាមនៅថ្ងៃនេះ ដើម្បីចៀសវាងការប្រឆាំងទាស់នឹងព្រះជាម្ចាស់។ សព្វថ្ងៃនេះ គ្មានអ្វីដែលសំខាន់សម្រាប់មនុស្សក្នុងការប្រកាន់ខ្ជាប់ ជាងអ្វីដូចតទៅនេះឡើយ៖ អ្នកដាច់ខាតមិនត្រូវព្យាយាមបញ្ឆោតព្រះជាម្ចាស់ ដែលឈរនៅនឹងភ្នែកអ្នក ឬបិទបាំងអ្វីពីទ្រង់ឡើយ។ អ្នកមិនត្រូវពោលពាក្យស្មោកគ្រោក ឬនិយាយក្រអឺតក្រទមនៅចំពោះព្រះជាម្ចាស់ ដែលនៅចំពោះមុខអ្នកឡើយ។ អ្នកមិនត្រូវបោកបញ្ឆោតព្រះជាម្ចាស់ ដែលនៅពីមុខភ្នែករបស់អ្នក ដោយពាក្យសម្ដីផ្អែមល្ហែម និងដោយសម្ដីត្រឹមត្រូវ ដើម្បីទទួលបានការជឿទុកចិត្តពីទ្រង់ឡើយ។ អ្នកមិនត្រូវប្រព្រឹត្ត ដោយគ្មានការគោរពកោតខ្លាចនៅចំពោះព្រះជាម្ចាស់ឡើយ។ អ្នកត្រូវតែស្ដាប់បង្គាប់តាមសេចក្ដីទាំងអស់ ដែលព្រះជាម្ចាស់មានបន្ទូលចេញពីព្រះឱស្ឋរបស់ទ្រង់ ហើយមិនត្រូវរឹងទទឹង ប្រឆាំងទាស់ ឬប្រកែកតវ៉ានឹងព្រះបន្ទូលរបស់ទ្រង់ឡើយ។ អ្នកមិនត្រូវបកស្រាយព្រះបន្ទូល ដែលព្រះជាម្ចាស់មានបន្ទូលចេញពីព្រះឱស្ឋរបស់ទ្រង់ តាមដែលអ្នកឃើញថាសមនោះឡើយ។ អ្នកគួរតែប្រុងប្រយ័ត្នចំពោះអណ្ដាតរបស់អ្នក ដើម្បីចៀសវាងកុំឲ្យវាធ្វើឲ្យអ្នកធ្លាក់ខ្លួនក្លាយជាចំណីឧបាយកលបោកបញ្ឆោតរបស់ពួកកំណាច។ អ្នកគួរតែការពារជំហានរបស់អ្នក ដើម្បីចៀសវាងការបំពានដែនកំណត់ដែលព្រះជាម្ចាស់បានកំណត់ឲ្យអ្នក។ ប្រសិនបើអ្នកបំពាន នោះវានឹងបណ្ដាលឲ្យអ្នកឈរនៅទីតាំងរបស់ព្រះជាម្ចាស់ និងនិយាយពាក្យសម្ដីក្រអឺតក្រទម និងអួតបំប៉ោង ដូច្នេះ អ្នកនឹងក្លាយជាទីសម្អប់របស់ព្រះជាម្ចាស់។ អ្នកមិនត្រូវផ្សាយព្រះបន្ទូលដែលចេញពីព្រះឱស្ឋរបស់ព្រះជាម្ចាស់ ដោយធ្វេសប្រហែសឡើយ ក្រែងអ្នកដទៃសើចចំអកមើលងាយអ្នក ហើយពួកអារក្សធ្វើឲ្យអ្នកទៅជាល្ងីល្ងើ។ អ្នកត្រូវស្ដាប់បង្គាប់កិច្ចការទាំងអស់ របស់ព្រះជាម្ចាស់នៃបច្ចុប្បន្នកាល។ បើទោះបីជាអ្នកមិនយល់ពីវាក៏ដោយ ក៏អ្នកមិនត្រូវរិះគន់លើវាដែរ អ្វីដែលអ្នកអាចធ្វើបាន គឺគ្មានអ្វី

ក្រៅតែពីការស្វែងរក និងការប្រកបគ្នាប៉ុណ្ណោះ។ គ្មាននរណាម្នាក់អាចបំពានកន្លែងដើមរបស់ព្រះជាម្ចាស់បានឡើយ។ អ្នកមិនអាចធ្វើអ្វីបាន ក្រៅតែពីបម្រើព្រះជាម្ចាស់នៃបច្ចុប្បន្នកាលក្នុងឋានៈជាមនុស្សទេ។ អ្នកមិនអាចបង្រៀនព្រះជាម្ចាស់នៃបច្ចុប្បន្នកាលក្នុងឋានៈជាមនុស្សបានទេ ព្រោះការដែលធ្វើដូច្នេះ ត្រូវបានហៅថាមានកំហុស។ គ្មាននរណាម្នាក់អាចឈរជំនួសមនុស្ស ដែលព្រះជាម្ចាស់បានធ្វើបន្ទាល់ឡើយ អ្នកឈរក្នុងនាមជាមនុស្សទាំងខាងពាក្យសម្ដី ការប្រព្រឹត្ត និងគំនិតដ៏ជ្រាលជ្រៅបំផុតរបស់អ្នក។ ត្រូវគោរពតាមការនេះ ព្រោះវាជាទំនួសខុសត្រូវរបស់មនុស្ស ហើយគ្មាននរណាម្នាក់អាចកែប្រែវាដោយប៉ុនប៉ងបំពានលើបញ្ញត្តិរដ្ឋបាលបានឡើយ។ ចំណុចនេះគួរតែត្រូវបានចងចាំដោយមនុស្សគ្រប់គ្នា។

រយៈកាលដ៏យូរអង្វែងដែលព្រះជាម្ចាស់បានចំណាយពេលមានបន្ទូល និងបន្លឺព្រះសូរសៀង បានបណ្ដាលឲ្យមនុស្សចាត់ទុកការអាន និងការចងចាំព្រះបន្ទូលរបស់ព្រះជាម្ចាស់ ជាកាតព្វកិច្ចចម្បងរបស់គេ។ គ្មាននរណាម្នាក់យកចិត្តទុកលើការអនុវត្តទេ ហើយសូម្បីតែអ្វីដែលអ្នកគួរតែគោរពតាម ក៏អ្នកមិនធ្វើដែរ។ ទង្វើបែបនេះបាននាំមកនូវការលំបាក និងបញ្ហាជាច្រើន ដល់ការបម្រើរបស់អ្នករាល់គ្នា។ ប្រសិនបើមុនពេលនៃការអនុវត្តនូវព្រះបន្ទូលរបស់ព្រះជាម្ចាស់ អ្នកមិនបានប្រកាន់ខ្ជាប់ទៅនឹង អ្វីដែលអ្នកគួរតែកាន់តាម នោះអ្នកជាមនុស្សម្នាក់ក្នុងចំណោមមនុស្សដែលត្រូវបានស្អប់ខ្ពើម និងបដិសេធដោយព្រះជាម្ចាស់ហើយ។ ក្នុងការប្រកាន់ខ្ជាប់នូវការអនុវត្តទាំងនេះ អ្នកគួរតែមានភាពហ្មត់ចត់ និងស្មោះត្រង់។ អ្នកមិនគួរចាត់ទុកការអនុវត្តទាំងនេះ ជាខ្មោះច្រវ៉ាក់ទេ ប៉ុន្តែគួរតែប្រកាន់ខ្ជាប់ដូចជាបទបញ្ញត្តិវិញ។ ថ្ងៃនេះ អ្នកមិនគួរតែខ្វល់ខ្វាយនឹងខ្លួនឯងថា តើលទ្ធផលអ្វីខ្លះ ដែលត្រូវតែសម្រេចនោះទេ។ សរុបសេចក្ដីមក នេះហើយជារបៀបដែលព្រះវិញ្ញាណបរិសុទ្ធធ្វើការ ហើយអ្នកណាដែលប្រព្រឹត្តបំពាន ត្រូវតែទទួលទោស។ ព្រះវិញ្ញាណបរិសុទ្ធមិនមានមនោសញ្ចេតនា និងការយកព្រះទ័យទុកដាក់ចំពោះការយល់ដឹងបច្ចុប្បន្នរបស់អ្នកឡើយ។ ប្រសិនបើអ្នកប្រព្រឹត្តខុសនឹងទ្រង់នៅថ្ងៃនេះ នោះទ្រង់នឹងដាក់ទោសអ្នក។

ប្រសិនបើអ្នកប្រព្រឹត្តខុសនឹងទ្រង់នៅក្នុងដែននៃអធិបតេយ្យភាពរបស់ទ្រង់ នោះទ្រង់នឹងមិនលើកលែងឲ្យអ្នកឡើយ។ ទ្រង់មិនខ្វល់ថា អ្នកម៉ឺងម៉ាត់យ៉ាងណានៅក្នុងការប្រកាន់ខ្ជាប់របស់អ្នកចំពោះព្រះបន្ទូលរបស់ព្រះយេស៊ូវនោះទេ។ ប្រសិនបើអ្នកបំពានបញ្ញត្តិរបស់ព្រះជាម្ចាស់នៃបច្ចុប្បន្នកាល ទ្រង់នឹងដាក់ទោសអ្នក ហើយផ្ដន្ទាទោសអ្នកដល់ស្លាប់។ តើអាចឲ្យអ្នកទទួលយកវាបានដោយរបៀបណាទៅ ប្រសិនបើអ្នកមិនប្រកាន់ខ្ជាប់តាមក្រឹត្យវិន័យទាំងនេះ? អ្នកត្រូវតែកាន់តាម បើទោះបីជាវាមានការរងទុក្ខឈឺចាប់បន្តិចបន្តួចក៏ដោយ! មិនថាជាសាសនា វិស័យ ជាតិសាសន៍ ឬនិកាយអ្វីនោះទេ នាពេលអនាគត ពួកគេត្រូវតែប្រកាន់ខ្ជាប់តាមការអនុវត្តនេះទាំងអស់។ គ្មាននរណាម្នាក់ត្រូវបានលើកលែង ហើយក៏គ្មាននរណាម្នាក់នឹងត្រូវបានសំចៃដែរ! ដ្បិតការអនុវត្តទាំងនេះ ជាអ្វីដែលព្រះវិញ្ញាណបរិសុទ្ធនឹងធ្វើនៅថ្ងៃនេះ ហើយគ្មាននរណាម្នាក់អាចបំពានវាបានឡើយ។ ទោះបីសេចក្ដីទាំងនេះ មិនមែនជាអ្វីដែលអស្ចារ្យក្ដី ក៏មនុស្សគ្រប់គ្នាត្រូវតែធ្វើតាមការអនុវត្តទាំងនេះដែរ ហើយវាក៏ជាបញ្ញត្តិដែលព្រះយេស៊ូវឲ្យ ជាព្រះដែលត្រូវបានប្រោសឲ្យរស់ឡើងវិញ និងយាងឡើងទៅកាន់ឋានសួគ៌ បានកំណត់ឲ្យមនុស្ស។ តើ «ផ្លូវ ... (៧)» មិននិយាយទេឬថា និយមន័យរបស់ព្រះយេស៊ូវគឺ អ្នកជាមនុស្សសុចរិត ឬមានបាប គឺអាស្រ័យទៅលើអាកប្បកិរិយារបស់អ្នក ចំពោះព្រះជាម្ចាស់នៅថ្ងៃនេះ? គ្មាននរណាម្នាក់អាចមើលរំលងចំណុចនេះបានទេ។ នៅក្នុងយុគសម័យនៃក្រឹត្យវិន័យ ពួកផារិស៊ីពីជំនាន់មួយទៅជំនាន់មួយ បានជឿលើព្រះជាម្ចាស់ ប៉ុន្តែចំពោះការមកដល់របស់យុគសម័យនៃព្រះគុណ ពួកគេមិនបានស្គាល់ព្រះយេស៊ូវទេ ហើយបានប្រឆាំងទាស់នឹងទ្រង់ថែមទៀតផង។ ដូច្នេះ អ្វីៗទាំងអស់ដែលពួកគេបានធ្វើ គឺសុទ្ធតែគ្មានប្រយោជន៍ និងឥតបានការ ហើយព្រះជាម្ចាស់មិនបានទទួលយកការប្រព្រឹត្តិរបស់ពួកគេទេ។ ប្រសិនបើអ្នកអាចមើលធ្លុះពីរឿងនេះ នោះអ្នកនឹងមិនងាយប្រព្រឹត្តអំពើបាបឡើយ។ មនុស្សជាច្រើនប្រហែលជាបានប្រៀបធៀបខ្លួនឯងទៅនឹងព្រះជាម្ចាស់។ តើការប្រឆាំងទាស់នឹងព្រះជាម្ចាស់មានរសជាតិដូចម្ដេច? តើវាជូរចត់ ឬផ្អែម? អ្នកគួរតែយល់អំពីរឿង

នេះ កុំធ្វើពើថា អ្នកមិនដឹងឲ្យសោះ។ នៅក្នុងចិត្តរបស់មនុស្សមួយចំនួនប្រហែលជាពួកគេនៅតែមិនទុកចិត្ត។ ប៉ុន្តែ ខ្ញុំសូមណែនាំអ្នកឲ្យសាកល្បងវា ហើយមើលថា វាមានរសជាតិបែបណា។ បែបនេះ នឹងការពារមនុស្សជាច្រើនពីការដែលតែងតែមានមន្ទិលសង្ស័យអំពីវា។ មនុស្សជាច្រើនអានព្រះបន្ទូលរបស់ព្រះជាម្ចាស់ ប៉ុន្តែប្រឆាំងទាស់នឹងទ្រង់ដោយសម្ងាត់នៅក្នុងចិត្តរបស់ពួកគេ។ បន្ទាប់ពីប្រឆាំងទាស់នឹងទ្រង់បែបនេះ តើអ្នកមិនមានអារម្មណ៍ដូចមានកាំបិតមួយចាក់ដោតនៅក្នុងចិត្តរបស់អ្នកទេឬអី? ប្រសិនបើវាមិនមែនជាភាពមិនស៊ីចង្វាក់គ្នាក្នុងគ្រួសារទេ វាក៏ជាភាពមិនស្រួលខាងរាងកាយ ឬការឈឺចាប់ដល់កូនប្រុស និងកូនស្រីដែរ។ ទោះបីជាសាច់ឈាមរបស់អ្នក ត្រូវបានរួចផុតពីសេចក្តីស្លាប់ ក៏ព្រះហស្តរបស់ព្រះជាម្ចាស់មិនដែលចាកចេញពីអ្នកឡើយ។ តើអ្នកគិតថា វាអាចងាយស្រួលបែបនោះឬ? ជាពិសេស វារឹតតែចាំបាច់ថែមទៀតសម្រាប់មនុស្សជាច្រើន ដែលនៅជិតព្រះជាម្ចាស់ ក្នុងការផ្តោតការយកចិត្តទុកដាក់លើការនេះ។ ពេលវេលាកន្លងផុតទៅ អ្នកនឹងភ្លេចវាទាំងមិនដឹងខ្លួន អ្នកនឹងត្រូវធ្លាក់ចូលទៅក្នុងសេចក្តីល្បួង រួចធ្វេសប្រហែសនឹងអ្វីគ្រប់យ៉ាង ហើយការនេះនឹងបានជាដើមចមនៃអំពើបាបរបស់អ្នក។ តើនេះហាក់ដូចជារឿងតូចតាចសម្រាប់អ្នកដែរទេ? ប្រសិនបើអ្នកអាចធ្វើការនេះបានល្អ នោះអ្នកនឹងមានឱកាសត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍ ដើម្បីចូលមកចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់ ហើយទទួលសេចក្តីណែនាំពីព្រះឱស្ឋរបស់ទ្រង់ផ្ទាល់។ ប្រសិនបើអ្នកធ្វេសប្រហែស នោះបញ្ហានឹងកើតមានដល់អ្នក ហើយអ្នកនឹងជាទីរឹងទទឹងដល់ព្រះជាម្ចាស់ ពាក្យសម្តី និងសកម្មភាពរបស់អ្នកនឹងប្រែខុសគន្លងធម៌ ហើយមិនយូរមិនឆាប់ អ្នកនឹងត្រូវបោកបក់ទៅតាមខ្យល់ដ៏ខ្លាំង និងព្យុះរលកដ៏ធំសម្បើម។ ម្នាក់ៗនៅក្នុងចំណោមអ្នក គួរតែកត់ចំណាំពីបញ្ញត្តិទាំងនេះ។ ប្រសិនបើអ្នកបំពានទៅលើវានោះ បើទោះជាមនុស្សដែលត្រូវបានធ្វើទីបន្ទាល់ដោយព្រះជាម្ចាស់មិនថ្កោលទោសអ្នកក៏ដោយ ក៏ព្រះវិញ្ញាណនៃព្រះជាម្ចាស់នឹងមានកិច្ចការមិនទាន់បញ្ចប់ជាមួយអ្នក ហើយទ្រង់នឹងមិនសំចៃអ្នកឡើយ។ តើអ្នកអាចទ្រាំទ្រនឹងផលវិបាកនៃការបំពានរបស់អ្នកបានដែរឬទេ? ដូចនេះ មិនថាអ្វីដែលព្រះជាម្ចាស់មាន

ព្រះបន្ទូលនោះទេ អ្នកត្រូវតែយកព្រះបន្ទូលរបស់ទ្រង់ទៅអនុវត្ត ហើយត្រូវតែប្រកាន់ខ្ជាប់តាមគ្រប់មធ្យោបាយណាដែលអ្នកអាចធ្វើបាន។ នេះមិនមែនជារឿងសាមញ្ញទេ!

## រាជ្យមួយពាន់ឆ្នាំបានមកដល់ហើយ

តើអ្នករាល់គ្នាធ្លាប់បានឃើញកិច្ចការអ្វីខ្លះដែលព្រះជាម្ចាស់នឹងសម្រេចនៅក្នុងក្រុមមនុស្សនេះទេ? ព្រះជាម្ចាស់បានមានបន្ទូលថា ទោះនៅក្នុងរាជ្យមួយពាន់ឆ្នាំក៏ដោយ ក៏មនុស្សត្រូវបន្តដើរតាមព្រះសូរសៀងរបស់ទ្រង់ជាដរាបតទៅ ហើយនៅពេលអនាគត ព្រះសូរសៀងរបស់ព្រះជាម្ចាស់នឹងនៅតែដឹកនាំជីវិតមនុស្សដោយផ្ទាល់នៅក្នុងទឹកដីដ៏មានជីជាតិនៃស្រុកកាណានដដែល។ នៅពេលម៉ូសេស្ថិតនៅទីរហោស្ថាន ព្រះជាម្ចាស់បានណែនាំ និងមានព្រះបន្ទូលទៅកាន់គាត់ដោយផ្ទាល់។ ព្រះជាម្ចាស់បានប្រទានអាហារ ទឹក និងនំម៉ាណាមកពីស្ថានសួគ៌ឱ្យមនុស្សបានបរិភោគ ហើយសព្វថ្ងៃនេះ ក៏នៅតែបែបនេះដដែល៖ ព្រះជាម្ចាស់បានប្រទានគ្រឿងបរិភោគ និងភេសជ្ជៈដល់មនុស្សឱ្យបានទទួលទាន ហើយទ្រង់បានដាក់បណ្ដាសាដោយផ្ទាល់ ដើម្បីវាយផ្ចាលមនុស្ស។ ហេតុនេះ គ្រប់ជំហាននៃកិច្ចការរបស់ទ្រង់ គឺព្រះជាម្ចាស់ ជាអ្នកបំពេញដោយផ្ទាល់។ សព្វថ្ងៃនេះ មនុស្សស្វែងរកហេតុការណ៍ដដែលៗ ពួកគេស្វែងរកទីសម្គាល់ និងការអស្ចារ្យ ហើយមនុស្សបែបនេះទំនងជានឹងត្រូវបានបោះបង់ចោល ដ្បិតកិច្ចការរបស់ព្រះជាម្ចាស់កាន់តែជាក់ស្ដែងឡើងៗ។ គ្មាននរណាម្នាក់បានដឹងថា ព្រះជាម្ចាស់បានយាងចុះមកពីស្ថានសួគ៌ឡើយ ហើយពួកគេក៏ពុំបានដឹងថា ព្រះជាម្ចាស់បានប្រទានអាហារ និងថ្នាំប៉ូវពីស្ថានសួគ៌ដែរ។ តែព្រះជាម្ចាស់មានពិតប្រាកដ ហើយទិដ្ឋភាពដ៏រំភើបនៃរាជ្យមួយពាន់ឆ្នាំដែលមនុស្សស្រមើស្រមៃនោះ ក៏ជាព្រះសូរសៀងផ្ទាល់របស់ព្រះជាម្ចាស់ដែរ។ នេះគឺជាការពិត ហើយមានតែការពិតនេះទេ ដែលត្រូវបានហៅថាការសោយរាជ្យជាមួយព្រះជាម្ចាស់នៅលើផែនដី។ ការសោយរាជ្យជាមួយព្រះជាម្ចាស់នៅលើផែនដី សំដៅ

ទៅលើសាច់ឈាម។ សាច់ឈាមនោះ គឺមិនមែនជាសាច់ឈាមដែលគ្មានវត្ថុមាននៅលើផែនដីទេ ហើយហេតុនេះអស់អ្នកដែលគិតតែចង់ទៅឋានសួគ៌ជាន់ទីបីនោះ ក៏ធ្វើបែបនេះជាអសារឥតការ។ ថ្ងៃមួយ នៅពេលដែលសកលលោកទាំងមូលត្រឡប់ទៅរកព្រះជាម្ចាស់វិញ កិច្ចការស្នូលរបស់ទ្រង់នៅក្នុងចក្រវាឡនេះ នឹងដើរតាមព្រះសូរសៀងរបស់ទ្រង់។ នៅទីកន្លែងផ្សេងទៀត អ្នកខ្លះនឹងប្រើទូរសព្ទ អ្នកខ្លះនឹងជិះយន្តហោះ អ្នកខ្លះនឹងជិះទូកឆ្លងសមុទ្រ ហើយអ្នកខ្លះទៀតនឹងប្រើកាំរស្មីឡាស៊ែរដើម្បីទទួលបានព្រះសូរសៀងរបស់ព្រះជាម្ចាស់។ មនុស្សគ្រប់គ្នានឹងគោរពសរសើរ និងស្រេកឃ្លានចង់បានទ្រង់ ពួកគេគ្រប់គ្នានឹងមកជិតព្រះជាម្ចាស់ រួចប្រមូលផ្ដុំគ្នាទៅរកព្រះជាម្ចាស់ ហើយគ្រប់គ្នានឹងថ្វាយបង្គំព្រះជាម្ចាស់។ ទាំងអស់នេះនឹងក្លាយជាស្នាព្រះហស្ដរបស់ព្រះជាម្ចាស់។ ចូរចងចាំរឿងនេះ! ព្រះជាម្ចាស់ច្បាស់ជានឹងមិនចាប់ផ្ដើមជាថ្មីនៅទីកន្លែងផ្សេងទៀតឡើយ។ ព្រះជាម្ចាស់នឹងសម្រេចការពិតនេះ៖ ទ្រង់នឹងធ្វើឱ្យមនុស្សទាំងអស់ នៅទូទាំងសកលលោកនេះមកនៅចំពោះទ្រង់ និងថ្វាយបង្គំព្រះជាម្ចាស់នៅលើផែនដី ហើយកិច្ចការរបស់ទ្រង់នៅទីកន្លែងផ្សេងទៀតនឹងត្រូវបញ្ឈប់ ហើយមនុស្សនឹងត្រូវបានបង្ខំឱ្យស្វែងរកផ្លូវពិត។ រឿងនេះនឹងដូចជាយ៉ូសែបដែរ៖ មនុស្សគ្រប់គ្នាបានមករកគាត់ដើម្បីទទួលបានអាហារ ហើយឱនក្បាលគោរពគាត់ ដ្បិតគាត់មានគ្រឿងបរិភោគ។ ដើម្បីជៀសវាងពីការអត់ឃ្លាន មនុស្សនឹងត្រូវបង្ខំចិត្តមកស្វែងរកផ្លូវពិត។ សហគមន៍សាសនាទាំងមូល នឹងរងទុក្ខដោយសារគ្រោះអត់ឃ្លានយ៉ាងធ្ងន់ធ្ងរ ហើយមានតែព្រះជាម្ចាស់ក្នុងពេលសព្វថ្ងៃនេះប៉ុណ្ណោះ ជាប្រភពទឹករស់ ដែលមានប្រភពទឹកមិនចេះរីងស្ងួត ដែលផ្ដល់ឱ្យមនុស្សបានប្រើប្រាស់ទទួលទាន ហើយមនុស្សនឹងមករក[ទ្រង់] និងពឹងផ្អែកលើទ្រង់។ ពេលនោះនឹងក្លាយជាពេលវេលាដែលស្នាព្រះហស្ដរបស់ព្រះជាម្ចាស់ ត្រូវបានបង្ហាញឱ្យឃើញ ហើយព្រះជាម្ចាស់ទទួលបានសិរីរុងរឿង។ មនុស្សគ្រប់គ្នានៅទូទាំងសកលលោកទាំងមូល នឹងថ្វាយបង្គំ «មនុស្ស» សាមញ្ញនេះ។ តើនេះនឹងមិនមែនជាថ្ងៃនៃសិរីល្អរបស់ព្រះជាម្ចាស់ទេឬ? ថ្ងៃមួយ គ្រូគង្វាលចាស់ៗ នឹងផ្ញើទូរសារមកសុំទឹកពីប្រភពទឹក

រស់។ ពួកគេនឹងក្លាយជាចាស់ជរា ប៉ុន្តែពួកគេនឹងមកថ្វាយបង្គំបុគ្គលរូបនេះ ជាមនុស្ស ដែលពួកគេមើលងាយ។ ពួកគេនឹងទទួលស្គាល់ទ្រង់ដោយមាត់របស់ពួកគេ ហើយ ពួកគេនឹងជឿទ្រង់អស់ពីដួងចិត្តរបស់ពួកគេ។ តើនេះមិនមែនជាទីសម្គាល់ និងការ អស្ចារ្យទេឬអី? នៅពេលដែលនគរទាំងមូលត្រេកអរសប្បាយ នោះគឺជាថ្ងៃនៃសិរីល្អ របស់ព្រះជាម្ចាស់ ហើយអស់អ្នកដែលមករកអ្នករាល់គ្នា ហើយទទួលបានដំណឹងល្អ នៃព្រះជាម្ចាស់ នឹងទទួលបានព្រះពរពីព្រះជាម្ចាស់ ហើយប្រទេស និងប្រជាជនដែល ធ្វើបែបនេះ នឹងទទួលបានព្រះពរ និងព្រះទ័យទុកដាក់របស់ព្រះជាម្ចាស់។ ទិសដៅ ទៅអនាគតនឹងមានលក្ខណៈដូចនេះ៖ អស់អ្នកដែលទទួលបានព្រះសូរសៀងពីព្រះ ឱស្ឋរបស់ព្រះជាម្ចាស់ នឹងមានផ្លូវដើរនៅលើផែនដី ហើយមិនថាពួកគេជាអ្នកជំនួញ ឬអ្នកវិទ្យាសាស្ត្រ ឬអ្នកអប់រំ ឬឧស្សាហករទេ អ្នកដែលមិនទទួលបានព្រះបន្ទូលរបស់ ព្រះជាម្ចាស់នឹងជួបការលំបាកក្នុងដំណើរ សូម្បីតែមួយជំហានក៏ដោយ ហើយនឹងត្រូវ បង្ខំឱ្យស្វែងរកផ្លូវពិត។ នេះគឺជាអត្ថន័យដែលថា «បើមានសេចក្ដីពិត អ្នកនឹងដើរបាន ពេញពិភពលោក បើគ្មានសេចក្ដីពិត អ្នកនឹងទៅណាមិនបានឡើយ»។ សេចក្ដីពិត គឺបែបនេះ៖ ព្រះជាម្ចាស់នឹងប្រើផ្លូវ (សំដៅលើព្រះបន្ទូលទាំងអស់របស់ទ្រង់) ដើម្បី បង្គាប់សកលលោកទាំងមូល និងគ្រប់គ្រង ព្រមទាំងយកឈ្នះមនុស្ស។ មនុស្ស តែងតែសង្ឃឹមទទួលបាននូវប្រយោជន៍យ៉ាងច្រើន តាមរយៈកិច្ចការដែលព្រះជាម្ចាស់ បំពេញ។ និយាយឱ្យងាយយល់ គឺតាមរយៈព្រះបន្ទូលនេះហើយ ដែលព្រះជាម្ចាស់ គ្រប់គ្រងលើមនុស្ស ហើយអ្នកត្រូវធ្វើតាមអ្វីដែលទ្រង់មានព្រះបន្ទូល ទោះបីជាអ្នក មិនចង់ក៏ដោយ។ នេះគឺជាការពិតឥតលម្អៀង ហើយមនុស្សគ្រប់គ្នាត្រូវគោរពតាម ហើយក៏ជាការពិតឥតប្រែប្រួល ហើយមនុស្សគ្រប់គ្នាក៏ត្រូវដឹងដែរ។

ព្រះវិញ្ញាណបរិសុទ្ធប្រទានអារម្មណ៍ដល់មនុស្ស។ បន្ទាប់ពីអានព្រះបន្ទូលរបស់ ព្រះជាម្ចាស់ នៅក្នុងចិត្តរបស់មនុស្ស ពួកគេមានអារម្មណ៍ខ្ជាប់ខ្ជួន និងស្ងប់សុខ ហើយ អស់អ្នកដែលមិនទទួលបានព្រះបន្ទូលរបស់ព្រះជាម្ចាស់ មានអារម្មណ៍ទទេសូន្យ។ នេះគឺជាឫទ្ធានុភាពនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់។ មនុស្សត្រូវអានព្រះបន្ទូល ហើយ

បន្ទាប់ពីអានរួច ពួកគេនឹងធំធាត់ ហើយពួកគេមិនអាចអត់ព្រះបន្ទូលបានទេ។ នេះគឺដូចជាពេលដែលមនុស្សជក់អាភៀនដែរ៖ វាជួយឱ្យពួកគេមានកម្លាំង ហើយពេលគ្មានវា ទើបពួកគេដឹងថា កម្លាំងអូសទាញរបស់វាខ្លាំងណាស់ ហើយគេគ្មានកម្លាំងកំហែងតតាំងឡើយ។ នេះគឺជាទំនោររបស់ហ្វូងមនុស្សបច្ចុប្បន្ននេះ។ ការអានព្រះបន្ទូលរបស់ព្រះជាម្ចាស់ ធ្វើឱ្យមនុស្សមានកម្លាំង។ ប្រសិនបើពួកគេពុំអានព្រះបន្ទូលទេ ពួកគេមានអារម្មណ៍ថា គ្មានកម្លាំងកំហែង ប៉ុន្តែបន្ទាប់ពីបានអានព្រះបន្ទូលរួច ពួកគេក៏ក្រោកចេញពី «គ្រែសម្រាប់អ្នកជំងឺ» ភ្លាមៗ។ នេះជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលមានអំណាចលើផែនដី និងជាការគ្រប់គ្រងរបស់ព្រះជាម្ចាស់នៅលើផែនដី។ មនុស្សខ្លះចង់ចាកចេញ ឬមានអារម្មណ៍ហត់នឿយនឹងកិច្ចការរបស់ព្រះជាម្ចាស់។ ទោះបីបែបនេះក្ដី ពួកគេមិនអាចផ្ដាច់ខ្លួនចេញពីព្រះបន្ទូលរបស់ព្រះជាម្ចាស់បានឡើយ។ មិនថាពួកគេខ្សោយកម្រិតណានោះទេ ពួកគេនៅតែត្រូវពឹងផ្អែកលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីអាចរស់បាន ហើយមិនថាពួកគេរឹងទទឹងប៉ុនណានោះទេ ពួកគេនៅតែមិនហ៊ានបោះបង់ចោល នូវព្រះបន្ទូលរបស់ព្រះជាម្ចាស់ដដែល។ នៅពេលដែលព្រះបន្ទូលរបស់ព្រះជាម្ចាស់បង្ហាញឥទ្ធិឫទ្ធិដ៏ពិតប្រាកដហើយ គឺជាពេលដែលព្រះជាម្ចាស់គ្រប់គ្រង និងប្រើប្រាស់ឫទ្ធានុភាព។ នេះគឺជារបៀបដែលទ្រង់បំពេញកិច្ចការ។ ចុងក្រោយទៅ នេះគឺជាមធ្យោបាយ ដែលព្រះជាម្ចាស់បំពេញកិច្ចការ ហើយគ្មានអ្នកណាអាចចាកចេញបានទេ។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ នឹងផ្សាយទៅក្នុងចំណោមផ្ទះជាច្រើនរាប់មិនអស់ ព្រះបន្ទូលនឹងត្រូវអ្នករាល់គ្នាដឹង ដល់ពេលនោះ ទើបកិច្ចការរបស់ទ្រង់ត្រូវផ្សាយទៅទូទាំងសកលលោក។ អាចនិយាយបានថា ប្រសិនបើកិច្ចការរបស់ព្រះជាម្ចាស់ត្រូវផ្សាយទៅទូទាំងសកលលោក នោះព្រះបន្ទូលរបស់ទ្រង់ក៏ត្រូវផ្សាយទៅដែរ។ នៅថ្ងៃនៃសិរីល្អរបស់ព្រះជាម្ចាស់ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ នឹងបង្ហាញឫទ្ធានុភាព និងសិទ្ធិអំណាច។ គ្រប់ព្រះបន្ទូលរបស់ទ្រង់តាំងពីដើមរហូតរៀងមក នឹងត្រូវសម្រេចបាន ហើយនឹងកើតមានឡើងដោយពិតប្រាកដ។ ក្នុងលក្ខណៈនេះ សិរីល្អនឹងត្រូវមកដល់ព្រះជាម្ចាស់នៅលើផែនដី ដែលអាចនិយាយ

ថា ព្រះបន្ទូលរបស់ទ្រង់នឹងគ្រងគ្រងលើផែនដី។ ពួកមនុស្សអាក្រក់ នឹងត្រូវវាយផ្ចាល ដោយព្រះបន្ទូលដែលចេញពីព្រះឱស្ឋរបស់ព្រះជាម្ចាស់ អ្នកអស់ដែលសុចរិត នឹងត្រូវទទួលបានព្រះពរពីព្រះបន្ទូលដែលចេញពីព្រះឱស្ឋរបស់ទ្រង់ ហើយអ្នករាល់គ្នានឹងត្រូវស្អាងចិត្តឡើងជាថ្មី និងបានគ្រប់លក្ខណ៍ ដោយព្រះបន្ទូលដែលចេញពីព្រះឱស្ឋរបស់ទ្រង់។ ទ្រង់នឹងមិនបញ្ចេញនូវទីសម្គាល់ ឬការអស្ចារ្យអ្វីឡើយ។ គ្រប់ការទាំងអស់នឹងត្រូវបានសម្រេច ដោយព្រះបន្ទូលរបស់ទ្រង់ ហើយព្រះបន្ទូលរបស់ទ្រង់នឹងបង្កើតជាការពិត។ មនុស្សគ្រប់គ្នានៅលើផែនដី នឹងអបអរចំពោះព្រះបន្ទូលរបស់ព្រះជាម្ចាស់ មិនថាពួកគេជាមនុស្សចាស់ ឬក្មេង ជាប្រុស ស្រី ចាស់ ឬក្មេងឡើយ មនុស្សគ្រប់គ្នានឹងចុះចូលចំពោះព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់លេចឡើងខាងសាច់ឈាម ដែលអាចឱ្យមនុស្សមើលឃើញព្រះបន្ទូលនៅលើផែនដី បានរស់រវើក និងដូចមានជីវិតពិតៗ។ នេះហើយគឺជាអត្ថន័យដែលថា ព្រះបន្ទូលក្លាយជាសាច់ឈាម។ ព្រះជាម្ចាស់បានយាងចុះមកផែនដី ក្នុងគោលបំណងចម្បង ដើម្បីសម្រេចការពិតថា «ព្រះបន្ទូលក្លាយជាសាច់ឈាម» ដែលចង់បានន័យថា ទ្រង់បានយាងចុះមក ដើម្បីឱ្យព្រះបន្ទូលរបស់ទ្រង់អាចចេញពីខាងសាច់ឈាម (មិនដូចជំនាន់ម៉ូសេនៅក្នុងព្រះគម្ពីរសញ្ញាចាស់ឡើយ ដែលព្រះសូរសៀងរបស់ព្រះជាម្ចាស់បានចេញមកពីលើមេឃ)។ បន្ទាប់ពីគ្រានោះមក ព្រះបន្ទូលទាំងស្រុងរបស់ទ្រង់នឹងត្រូវសម្រេច ក្នុងយុគសម័យនៃរាជ្យមួយពាន់ឆ្នាំ ព្រះបន្ទូលនឹងក្លាយជាការពិតដែលអាចមើលឃើញផ្ទាល់ភ្នែករបស់មនុស្ស ហើយមនុស្សនឹងមើលឃើញព្រះបន្ទូលដោយភ្នែកផ្ទាល់របស់ពួកគេ ដោយពុំមានភាពខុសគ្នា សូម្បីបន្តិចសោះឡើយ។ នេះគឺជាអត្ថន័យដ៏ឧត្តមនៃការយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់។ នេះមានន័យថា កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ គឺសម្រេចទៅបានតាមរយៈសាច់ឈាម និងតាមរយៈព្រះបន្ទូល។ នេះគឺអត្ថន័យពិតប្រាកដនៃ «ព្រះបន្ទូលបានត្រឡប់ជាសាច់ឈាម» និង «ការលេចមកជាសាច់ឈាមរបស់ព្រះបន្ទូល»។ មានតែព្រះជាម្ចាស់ប៉ុណ្ណោះ ដែលអាចមានបន្ទូលអំពីព្រះហឫទ័យរបស់ព្រះវិញ្ញាណបរិសុទ្ធបាន ហើយមានតែព្រះជាម្ចាស់នៅក្នុង

សាច់ឈាមប៉ុណ្ណោះ ដែលអាចមានព្រះបន្ទូលជំនួសឱ្យព្រះវិញ្ញាណបរិសុទ្ធបាន។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅក្នុងការយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់ នោះគឺងាយយល់ ហើយអ្នកផ្សេងទៀត ទទួលបានការណែនាំដោយព្រះបន្ទូលទាំងនេះ។ គ្មាននរណាម្នាក់គេចផុតនោះទេ ពួកគេនឹងរស់នៅក្នុងទំហំនៃកិច្ចការនេះ។ មានតែតាមព្រះសូរសៀងទាំងនេះប៉ុណ្ណោះ ដែលមនុស្សអាចដឹងបាន។ ប្រសិនបើអស់អ្នកដែលគិតថាមិនអាចទទួលបានព្រះសូរសៀងដោយបែបនេះ ហើយគិតថាពួកគេអាចទទួលបានព្រះសូរសៀងពីស្ថានសួគ៌វិញ នោះពួកគេកំពុងស្រមើស្រមៃហើយ។ នេះគឺជាសិទ្ធិអំណាចដែលបង្ហាញនៅក្នុងការយកកំណើតក្នុងសាច់ឈាមរបស់ព្រះជាម្ចាស់ ដែលនាំឱ្យអ្នករាល់គ្នាជឿស៊ប់។ សូម្បីតែអ្នកជំនាញ និងអ្នកដឹកនាំសាសនាដ៏គួរឱ្យគោរព ក៏មិនអាចនិយាយព្រះបន្ទូលទាំងនេះបានដែរ។ ពួកគេត្រូវចុះចូលចំពោះព្រះបន្ទូល ហើយគ្មាននរណាម្នាក់អាចចាប់ផ្ដើមជាថ្មីបានឡើយ។ ព្រះជាម្ចាស់នឹងប្រើព្រះបន្ទូល ដើម្បីបង្ក្រាបសាកលលោកនេះ។ ទ្រង់នឹងធ្វើបែបនេះ មិនមែនតាមការយកកំណើតខាងសាច់ឈាមរបស់ទ្រង់នោះទេ ប៉ុន្តែតាមរយៈការប្រើព្រះសូរសៀងពីព្រះឱស្ឋរបស់ព្រះជាម្ចាស់ដែលក្លាយជាសាច់ឈាម ដើម្បីយកឈ្នះមនុស្សទាំងអស់នៅក្នុងសកលលោកទាំងមូលនេះ។ នេះទើបជាការដែលព្រះបន្ទូលបានត្រឡប់ជាសាច់ឈាម ហើយការដែលព្រះបន្ទូលលេចមកជាសាច់ឈាម ក៏មានតែមួយនេះដែរ។ ចំពោះមនុស្ស ប្រហែលជាវាហាក់ដូចជាព្រះជាម្ចាស់មិនបានធ្វើកិច្ចការអ្វីច្រើននោះទេ ប៉ុន្តែព្រះជាម្ចាស់ទ្រង់បានបន្លឺនូវព្រះបន្ទូលរបស់ទ្រង់ ហើយព្រះបន្ទូលនេះនឹងត្រូវគេជឿ និងកោតស្ញប់ស្ញែង។ បើគ្មានការពិតទាំងនេះទេ មនុស្សនឹងស្រែកទ្រហោយំ។ បើមានព្រះបន្ទូលរបស់ព្រះជាម្ចាស់ ពួកគេនឹងនៅស្ងៀមស្ងាត់។ ព្រះជាម្ចាស់ប្រាកដជានឹងសម្រេចបាននូវសេចក្ដីពិតនេះ ដ្បិតនេះ គឺជាផែនការដែលព្រះបានបង្កើតជាយូរមកហើយ ពោលគឺសម្រេចបាននូវសេចក្ដីពិតនៃការមកដល់នៃព្រះបន្ទូលនៅលើផែនដី។ តាមពិត ពុំមានការចាំបាច់ឱ្យខ្ញុំពន្យល់នោះទេ ការមកដល់នៃរាជ្យមួយពាន់ឆ្នាំនៅលើផែនដី គឺជាការមកដល់នៃព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅលើផែនដី។ ការចុះមក

នៃទីក្រុងយេរូសាឡឹមថ្មីពីស្ថានសួគ៌ គឺជាការមកដល់នៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីមកគង់នៅក្នុងចំណោមមនុស្ស ដើម្បីមករួមប្រកបជាមួយមនុស្ស ធ្វើរាល់កិច្ចការសព្វគ្រប់បែបយ៉ាង និងនៅក្នុងគំនិតដ៏ជ្រាលជ្រៅរបស់គេ។ នេះក៏ជាការពិតដែលព្រះជាម្ចាស់នឹងសម្រេចបានដែរ។ នេះគឺជាសម្រស់ដ៏ស្រស់បំព្រង នៃរាជ្យមួយពាន់ឆ្នាំ។ នេះគឺជាផែនការដែលព្រះជាម្ចាស់បានកំណត់៖ ព្រះបន្ទូលរបស់ទ្រង់នឹងលេចមកលើផែនដីមួយពាន់ឆ្នាំ ហើយបន្ទូលទាំងនេះនឹងបើកសម្ដែងឱ្យឃើញនូវស្នាព្រះហស្តរបស់ទ្រង់ និងបញ្ចប់ទៅនូវរាល់កិច្ចការរបស់ទ្រង់នៅលើផែនដី ដែលក្រោយពីនេះមកដំណាក់កាលរបស់មនុស្សនឹងត្រូវចូលដល់ទីបញ្ចប់។

# អ្នកគួរដឹងថា ព្រះដ៏ជាក់ស្ដែង គឺជាព្រះជាម្ចាស់

តើអ្នកគួរស្គាល់អ្វីខ្លះអំពីព្រះដ៏ជាក់ស្ដែង? ព្រះវិញ្ញាណព្រះក្នុងភាពជាមនុស្ស និងព្រះបន្ទូល ផ្សំឡើងបានជាព្រះដ៏ជាក់ស្ដែងផ្ទាល់ ហើយនេះជាអត្ថន័យពិតប្រាកដរបស់ព្រះដ៏ជាក់ស្ដែង។ ប្រសិនបើអ្នកស្គាល់តែព្រះក្នុងភាពជាមនុស្ស ប្រសិនបើអ្នកស្គាល់តែទម្លាប់ និងបុគ្គលិកលក្ខណៈរបស់ទ្រង់ តែមិនស្គាល់ពីកិច្ចការរបស់ព្រះវិញ្ញាណ ឬមិនដឹងពីអ្វីដែលព្រះវិញ្ញាណបានធ្វើនៅក្នុងសាច់ឈាម ហើយប្រសិនបើអ្នកគ្រាន់តែចាប់អារម្មណ៍លើព្រះវិញ្ញាណ និងព្រះបន្ទូល ហើយគ្រាន់តែអធិស្ឋាននៅចំពោះព្រះវិញ្ញាណ តែមិនបានស្គាល់ពីកិច្ចការនៃព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ នៅក្នុងព្រះដ៏ជាក់ស្ដែង នោះសេចក្ដីនេះបានបង្ហាញថា អ្នកមិនបានស្គាល់ព្រះដ៏ជាក់ស្ដែងឡើយ។ ចំណេះដឹងស្ដីពីព្រះដ៏ជាក់ស្ដែង រាប់បញ្ចូលទាំងការស្គាល់ និងការមានបទពិសោធជាមួយព្រះបន្ទូលទ្រង់ ព្រមទាំងការចាប់យកច្បាប់វិន័យ និងគោលការណ៍នៃកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ហើយនិងរបៀបដែលព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះជាម្ចាស់ធ្វើការនៅក្នុងសាច់ឈាម។ វាក៏រាប់បញ្ចូលទាំងការដឹងថា គ្រប់ទាំងសកម្មភាពរបស់ព្រះជាម្ចាស់នៅក្នុងសាច់ឈាម គឺមានព្រះវិញ្ញាណជាអ្នកគ្រប់គ្រង ហើយព្រះបន្ទូល

ដែលព្រះអង្គថ្លែងមក ជាការបង្ហាញឲ្យឃើញផ្ទាល់អំពីព្រះវិញ្ញាណ។ ដូចនេះ ដើម្បីស្គាល់ព្រះដ៏ជាក់ស្តែង វាជាការប្រសើរខ្លាំងណាស់ ដែលត្រូវដឹងពីរបៀបដែលព្រះជាម្ចាស់ធ្វើការនៅក្នុងលក្ខណៈជាមនុស្ស និងក្នុងភាពជាព្រះ ហើយជាលទ្ធផល វាទាក់ទិននឹងការបើកសម្តែងឲ្យឃើញពីព្រះវិញ្ញាណ ដែលមនុស្សគ្រប់គ្នាចូលរួម។

តើការបើកសម្តែងអំពីព្រះវិញ្ញាណ មានលក្ខណៈដូចម្តេចខ្លះ? ជួនកាលព្រះជាម្ចាស់ធ្វើការក្នុងលក្ខណៈជាមនុស្ស ហើយពេលខ្លះ ក៏ធ្វើការក្នុងភាពជាព្រះ ប៉ុន្តែចំពោះករណីទាំងពីរនេះ គឺព្រះវិញ្ញាណបរិសុទ្ធជាអ្នកបញ្ជា។ មិនថាវិញ្ញាណនៅក្នុងមនុស្ស ជាអ្វីឡើយ នោះជាការបើកសម្តែងពីលក្ខណៈខាងក្រៅរបស់គេ។ ព្រះវិញ្ញាណធ្វើការជាធម្មតា ប៉ុន្តែការដឹកនាំរបស់ទ្រង់ដោយព្រះវិញ្ញាណមានពីរផ្នែកគឺ៖ មួយផ្នែកជាកិច្ចការរបស់ទ្រង់នៅក្នុងលក្ខណៈជាមនុស្ស ហើយមួយផ្នែកទៀត គឺជាកិច្ចការរបស់ទ្រង់តាមរយៈភាពជាព្រះ។ អ្នកគួរដឹងអំពីការនេះឲ្យបានច្បាស់។ កិច្ចការរបស់ព្រះវិញ្ញាណមានលក្ខណៈផ្សេងៗគ្នាទៅតាមកាលៈទេសៈផ្សេងៗ៖ នៅពេលដែលតម្រូវឲ្យមានកិច្ចការក្នុងលក្ខណៈជាមនុស្សរបស់ទ្រង់ នោះព្រះវិញ្ញាណក៏បានដឹកនាំកិច្ចការក្នុងលក្ខណៈមនុស្សនេះ ហើយនៅពេលដែលតម្រូវឲ្យមានកិច្ចការក្នុងភាពជាព្រះ នោះភាពជាព្រះក៏លេចមកដើម្បីធ្វើកិច្ចការនោះ។ ដ្បិតព្រះជាម្ចាស់ធ្វើការក្នុងសាច់ឈាម និងលេចមកជាសាច់ឈាម ព្រះអង្គធ្វើការនៅក្នុងលក្ខណៈជាមនុស្សផង និងលក្ខណៈជាព្រះផង។ ព្រះវិញ្ញាណ ជាអ្នកដឹកនាំកិច្ចការរបស់ទ្រង់ក្នុងលក្ខណៈជាមនុស្ស ហើយកិច្ចការទាំងនេះ គឺធ្វើឡើងសម្រាប់បំពេញតម្រូវការមនុស្សខាងផ្នែកសាច់ឈាម ដើម្បីសម្រួលដល់ការចូលរួមជាមួយទ្រង់ ដើម្បីអនុញ្ញាតឲ្យពួកគេមើលឃើញនូវលក្ខណៈពិត និងលក្ខណៈធម្មតារបស់ព្រះជាម្ចាស់ និងដើម្បីជួយឲ្យពួកគេមើលឃើញថា ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ បានលេចមកជាសាច់ឈាម ហើយនៅក្នុងចំណោមមនុស្ស រស់នៅជាមួយមនុស្ស និងផ្សារភ្ជាប់ជាមួយមនុស្សផង។ កិច្ចការរបស់ទ្រង់ក្នុងភាពជាព្រះបានធ្វើឡើងដើម្បីផ្គត់ផ្គង់ដល់ជីវិតរបស់មនុស្ស និងដើម្បីដឹកនាំមនុស្សក្នុងគ្រប់អ្វីៗទាំងអស់ ចាប់ពីចំណុចវិជ្ជមាន ការផ្លាស់ប្តូរនិស្ស័យ

មនុស្ស និងការអនុញ្ញាតឲ្យពួកគេបានឃើញយ៉ាងពិតប្រាកដ អំពីការលេចឡើងរបស់ព្រះវិញ្ញាណនៅក្នុងសាច់ឈាម។ អ្វីដែលសំខាន់នោះ គឺការរីកចម្រើនលូតលាស់នៅក្នុងជីវិតរបស់មនុស្ស សម្រេចបានដោយផ្ទាល់តាមរយៈកិច្ចការ និងព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅក្នុងភាពជាព្រះ។ មានតែមនុស្សទទួលយកកិច្ចការរបស់ព្រះវិញ្ញាណប៉ុណ្ណោះ ទើបពួកគេអាចសម្រេចការផ្លាស់ប្ដូរនិស្ស័យរបស់ខ្លួន ហើយទាល់តែបែបនេះ ទើបពួកគេអាចត្រូវបានចាក់បំពេញឱ្យពេញលេញនៅក្នុងវិញ្ញាណរបស់ពួកគេបាន។ លើសពីនេះ មានតែកិច្ចការក្នុងលក្ខណៈជាមនុស្ស ដូចជា ការឃ្វាលរបស់ព្រះជាម្ចាស់ ការគាំទ្រ និងការទំនុកបម្រុងក្នុងលក្ខណៈជាមនុស្សប៉ុណ្ណោះ ទើបលទ្ធផលនៃកិច្ចការរបស់ព្រះជាម្ចាស់ អាចសម្រេចបានយ៉ាងពេញលេញ។ ព្រះដ៏ជាក់ស្ដែង គឺជាព្រះដែលមានបន្ទូលអំពីកិច្ចការថ្ងៃនេះ ទាំងក្នុងលក្ខណៈជាមនុស្ស និងក្នុងភាពជាព្រះ។ តាមរយៈការលេចមកនៃព្រះដ៏ជាក់ស្ដែង កិច្ចការ និងជីវិតជាមនុស្សធម្មតារបស់ទ្រង់ ព្រមទាំងកិច្ចការក្នុងលក្ខណៈជាព្រះទាំងស្រុងរបស់ព្រះអង្គ ក៏បានសម្រេច។ លក្ខណៈជាមនុស្ស និងភាពជាព្រះរបស់ព្រះអង្គ បានរួមបញ្ចូលគ្នាមកតែមួយ ហើយកិច្ចការទាំងពីរនេះ ក៏សម្រេចបានតាមរយៈព្រះបន្ទូល មិនថាក្នុងលក្ខណៈជាមនុស្ស ឬជាព្រះឡើយ ទ្រង់ក៏ថ្លែងព្រះបន្ទូល។ នៅពេលព្រះជាម្ចាស់ធ្វើការក្នុងលក្ខណៈជាមនុស្ស ព្រះអង្គមានបន្ទូលជាភាសាមនុស្ស ដូចនេះមនុស្សអាចចូលរួម និងស្វែងយល់បាន។ ព្រះបន្ទូលរបស់ទ្រង់ ត្រូវបានថ្លែងមកដោយច្បាស់លាស់ និងងាយយល់ទៀតផង ដូចនេះ ទើបមនុស្សទាំងអស់អាចទទួលយកព្រះបន្ទូលទាំងនេះបាន មិនថាមនុស្សមានចំណេះដឹងខ្ពស់ ឬជាមនុស្សមិនសូវមានការអប់រំខ្ពស់ឡើយ ពួកគេគ្រប់គ្នាអាចទទួលយកនូវព្រះបន្ទូលរបស់ព្រះជាម្ចាស់បាន។ កិច្ចការរបស់ព្រះជាម្ចាស់ក្នុងលក្ខណៈជាព្រះ ក៏បានសម្ដែងចេញមកតាមព្រះបន្ទូលដែរ ប៉ុន្តែវាពោរពេញដោយការទំនុកបម្រុង ពោរពេញដោយជីវិត ហើយកិច្ចការនេះមិនបានសៅហ្មងដោយគំនិតរបស់មនុស្សឡើយ វាមិនជាប់ពាក់ព័ន្ធនឹងការពេញចិត្តរបស់មនុស្សឡើយ ហើយវាមិនស្ថិតក្រោមដែនកំណត់របស់មនុស្សឡើយ វាស្ថិតនៅក្រៅដែនកំណត់នៃលក្ខណៈជា

មនុស្សធម្មតា វាត្រូវបានយកមកអនុវត្តនៅក្នុងសាច់ឈាម ប៉ុន្តែវាជាការបើកសម្ដែងឲ្យឃើញដោយផ្ទាល់ពីព្រះវិញ្ញាណ។ ប្រសិនបើមនុស្សគ្រាន់តែទទួលស្គាល់កិច្ចការរបស់ព្រះជាម្ចាស់ក្នុងលក្ខណៈជាមនុស្ស នោះគេនឹងកំណត់ដែនរបស់ខ្លួន ត្រឹមវិសាលភាពជាក់លាក់ណាមួយ ហើយនឹងតម្រូវឲ្យមានដំណោះស្រាយក្នុងរយៈពេលយូរអង្វែង ការកាត់ចេញ និងវិន័យ ដើម្បីឲ្យមានការផ្លាស់ប្ដូរបន្តិចបន្តួចនៅក្នុងពួកគេ។ បើគ្មានកិច្ចការ ឬព្រះវត្តមាននៃព្រះវិញ្ញាណបរិសុទ្ធទេនោះ ពួកគេនឹងងាកទៅរកផ្លូវចាស់របស់គេវិញជាក់ជាមិនខាន ហើយមានតែតាមរយៈកិច្ចការក្នុងលក្ខណៈជាព្រះប៉ុណ្ណោះ ទើបការវក់វី និងកង្វះខាតទាំងនេះអាចនឹងត្រូវបានកែតម្រូវ ហើយមានតែពេលនោះទេ ទើបមនុស្សអាចមានភាពពេញលេញឡើង។ ជំនួសឲ្យដំណោះស្រាយ និងការកាត់ចេញឥតឈប់ឈរ អ្វីដែលចាំបាច់នោះគឺ ការផ្គត់ផ្គង់បែបវិជ្ជមាន ការប្រើប្រាស់ព្រះបន្ទូលដើម្បីបំពេញភាពខ្វះចន្លោះទាំងអស់ ការប្រើប្រាស់ព្រះបន្ទូលដើម្បីបើកសម្ដែងគ្រប់សភាពទាំងអស់របស់មនុស្ស ការប្រើប្រាស់ព្រះបន្ទូលដើម្បីដឹកនាំជីវិតរបស់ពួកគេ ពាក្យសម្ដីគ្រប់ម៉ាត់របស់ពួកគេ និងសកម្មភាពនីមួយៗរបស់ពួកគេ ដើម្បីបង្ហាញនូវចេតនា និងការជម្រុញទឹកចិត្តរបស់ពួកគេ។ នេះជាកិច្ចការពិតប្រាកដរបស់ព្រះដ៏ជាក់ស្ដែង។ ដូចនេះ នៅក្នុងអាកប្បកិរិយារបស់អ្នកចំពោះព្រះដ៏ជាក់ស្ដែង ចុះចូលចំពោះលក្ខណៈជាមនុស្សរបស់ទ្រង់ ដោយទទួលស្គាល់ទ្រង់ ហើយលើសពីនេះ អ្នកត្រូវទទួលយក និងគោរពដល់កិច្ចការ និងព្រះបន្ទូលក្នុងលក្ខណៈជាព្រះរបស់ព្រះអង្គ។ ការលេចមកជាសាច់ឈាមរបស់ព្រះជាម្ចាស់មានន័យថា គ្រប់កិច្ចការ និងព្រះបន្ទូលទាំងអស់របស់ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ ត្រូវបានធ្វើឡើងតាមរយៈលក្ខណៈជាមនុស្សធម្មតារបស់ព្រះអង្គ និងតាមរយៈការយកកំណើតជាសាច់ឈាមរបស់ទ្រង់។ម្យ៉ាងទៀត ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់បានដឹកនាំកិច្ចការក្នុងលក្ខណៈជាមនុស្សរបស់ទ្រង់ និងអនុវត្តកិច្ចការនៃភាពជាព្រះនៅក្នុងលក្ខណៈសាច់ឈាម ហើយនៅក្នុងព្រះជាម្ចាស់ដែលបានយកកំណើតជាមនុស្ស អ្នកអាចមើលឃើញទាំងកិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងលក្ខណៈជាមនុស្សផង និងកិច្ចការរបស់ទ្រង់

ទាំងស្រុងក្នុងលក្ខណៈជាព្រះផង។ នេះជាសារៈសំខាន់យ៉ាងពិតប្រាកដ នៃការលេចមកជាសាច់ឈាមរបស់ព្រះដ៏ជាក់ស្ដែង។ ប្រសិនបើអ្នកអាចមើលឃើញសេចក្ដីនេះយ៉ាងច្បាស់ នោះអ្នកនឹងអាចដាក់ផ្នែកផ្សេងៗគ្នារបស់ព្រះជាម្ចាស់បញ្ចូលគ្នាតែមួយបាន អ្នកនឹងឈប់យកចិត្តទុកដាក់លើកិច្ចការរបស់ទ្រង់ ក្នុងលក្ខណៈជាព្រះទៀតជាមិនខាន ហើយអ្នកនឹងឈប់ចាត់ទុកកិច្ចការរបស់ទ្រង់ក្នុងលក្ខណៈជាមនុស្សដោយការបដិសេធហួសហេតុពេកឡើយ ហើយអ្នកនឹងមិនសម្លឹងមើលហួសប្រមាណ ឬមិនដើរលើផ្លូវផ្សេងឡើយ។ សរុបមក អត្ថន័យនៃព្រះដ៏ជាក់ស្ដែង គឺជាកិច្ចការនៃលក្ខណៈជាមនុស្ស និងលក្ខណៈជាព្រះរបស់ព្រះអង្គ ដោយមានព្រះវិញ្ញាណជាអ្នកដឹកនាំ ដែលកិច្ចការនេះត្រូវបានបើកសម្ដែងតាមរយៈផ្នែកសាច់ឈាមរបស់ទ្រង់ ដើម្បីឲ្យមនុស្សអាចមើលឃើញថា ព្រះអង្គច្បាស់លាស់ និងមានភាពរស់រវើក ដោយមានលក្ខណៈជាក់ស្ដែង និងពិតប្រាកដផង។

កិច្ចការនៃព្រះវិញ្ញាណរបស់ព្រះជាម្ចាស់នៅក្នុងលក្ខណៈជាមនុស្សកំពុងស្ថិតក្នុងដំណាក់កាលអន្តរកាល។ ព្រះអង្គបានធ្វើឲ្យលក្ខណៈជាមនុស្សរបស់ទ្រង់អាចទទួលនូវការណែនាំពីព្រះវិញ្ញាណបរិសុទ្ធ ដោយការធ្វើឲ្យលក្ខណៈជាមនុស្សរបស់ព្រះអង្គមានភាពគ្រប់លក្ខណ៍ ហើយបន្ទាប់ពីនេះ លក្ខណៈជាមនុស្សរបស់ទ្រង់ក៏អាចផ្គត់ផ្គង់ និងឃ្វាលក្រុមជំនុំបាន។ នេះគឺជាការបើកសម្ដែងមួយនៃកិច្ចការធម្មតារបស់ព្រះជាម្ចាស់។ ដូចនេះ ប្រសិនបើអ្នកអាចមើលឃើញច្បាស់ អំពីគោលការណ៍នៃកិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងលក្ខណៈជាមនុស្ស នោះអ្នកទំនងជាមិនអាចបង្ហាញនូវគំនិតអំពីកិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងលក្ខណៈជាមនុស្សឡើយ។ ទាក់ទិននឹងអ្វីផ្សេងទៀតនោះ គឺព្រះវិញ្ញាណរបស់ព្រះជាម្ចាស់មិនអាចធ្វើខុសឡើយ។ ព្រះអង្គសុចរិត និងមិនដែលធ្វើខុសឡើយ ទ្រង់មិនដែលប្រព្រឹត្តអ្វីដែលមិនត្រូវឡើយ។ កិច្ចការដែលមកពីព្រះ គឺជាការបើកសម្ដែងដោយផ្ទាល់ពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដោយគ្មានការជ្រៀតជ្រែកពីលក្ខណៈជាមនុស្សឡើយ។ កិច្ចការនេះកើតឡើងពីព្រះវិញ្ញាញដោយផ្ទាល់ គឺវាមិនបានឆ្លងកាត់នូវភាពគ្រប់លក្ខណ៍ឡើយ។

ទោះយ៉ាងណាក្ដី ចំពោះរឿងដែលថាទ្រង់អាចធ្វើការនៅក្នុងលក្ខណៈជាព្រះនោះ គឺមិនស្ថិតលើលក្ខណៈអធិធម្មជាតិតិចបំផុតនោះឡើយ ហើយវាហាក់ដូចជាត្រូវបានអនុវត្តដោយបុគ្គលធម្មតា។ ព្រះជាម្ចាស់យាងចុះពីស្ថានសួគ៌មកផែនដី ដើម្បីបើកសម្ដែងព្រះបន្ទូលរបស់ព្រះជាម្ចាស់តាមរយៈសាច់ឈាម ដើម្បីបំពេញកិច្ចការរបស់ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ តាមរយៈរបៀបនៃសាច់ឈាម។

សព្វថ្ងៃនេះ ចំណេះដឹងមនុស្សស្ដីពីព្រះដ៏ជាក់ស្ដែង មានតែការយល់ឃើញមួយផ្នែកតែប៉ុណ្ណោះ ហើយការយល់ដឹងរបស់ពួកគេអំពីសារៈសំខាន់នៃការយកកំណើតជាមនុស្ស ក៏នៅតែមានស្ដួចស្ដើងនៅឡើយ។ តាមរយៈសាច់ឈាមរបស់ព្រះជាម្ចាស់ មនុស្សមើលឃើញថាព្រះអង្គមានភាពពេញបរិបូរណ៍តាមរយៈកិច្ចការ និងព្រះបន្ទូលរបស់ទ្រង់ ដែលព្រះវិញ្ញាណរបស់ព្រះជាម្ចាស់បានរួមបញ្ចូលយ៉ាងច្រើន។ ប៉ុន្ដែមិនថាយ៉ាងណានោះទេ ទីបន្ទាល់របស់ព្រះជាម្ចាស់ គឺចេញមកពីព្រះវិញ្ញាណរបស់ព្រះជាម្ចាស់៖ ជាអ្វីដែលព្រះជាម្ចាស់បានធ្វើនៅក្នុងលក្ខណៈជាសាច់ឈាម ជាគោលការណ៍ដែលទ្រង់បានបំពេញកិច្ចការ ជាអ្វីដែលទ្រង់បានធ្វើក្នុងលក្ខណៈជាមនុស្ស និងជាអ្វីដែលទ្រង់បានធ្វើនៅក្នុងលក្ខណៈជាព្រះ។ មនុស្សត្រូវតែមានការយល់ដឹងអំពីសេចក្ដីនេះ។ សព្វថ្ងៃនេះ អ្នកអាចថ្វាយបង្គំបុគ្គលនេះបាន ខណៈពេលដែលអ្នកកំពុងថ្វាយបង្គំព្រះវិញ្ញាណ ហើយនេះជាចំនួនស្ដួចស្ដើងបំផុត ដែលមនុស្សគួរទទួលបាននៅក្នុងចំណេះដឹងពីព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស៖ ការស្គាល់ពីសារៈសំខាន់នៃព្រះវិញ្ញាណតាមរយៈសាច់ឈាម ការស្គាល់កិច្ចការក្នុងលក្ខណៈជាព្រះរបស់ព្រះវិញ្ញាណនៅក្នុងសាច់ឈាម និងកិច្ចការក្នុងលក្ខណៈជាមនុស្សនៅក្នុងសាច់ឈាម ដោយទទួលយកនូវព្រះបន្ទូល និងពាក្យថ្លែងមកទាំងអស់របស់ព្រះវិញ្ញាណ ព្រមទាំងមើលឃើញពីរបៀបដែលព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ដឹកនាំផ្នែកសាច់ឈាម និងបើកសម្ដែងអំពីព្រះចេស្ដារបស់ទ្រង់នៅក្នុងសាច់ឈាម។ នេះអាចនិយាយបានថា មនុស្សស្គាល់ព្រះវិញ្ញាណនៅស្ថានសួគ៌តាមរយៈសាច់ឈាម ការលេចមករបស់ព្រះដ៏ជាក់ស្ដែងដោយផ្ទាល់ព្រះអង្គក្នុងចំណោមមនុស្ស ដែលបាន

បណ្ដេញព្រះដែលឥតជាក់លាក់នៅក្នុងគំនិតរបស់មនុស្ស។ ការថ្វាយបង្គំរបស់មនុស្ស ចំពោះព្រះដ៏ជាក់ស្ដែងផ្ទាល់ បានធ្វើឲ្យការស្ដាប់បង្គាប់របស់គេចំពោះព្រះជាម្ចាស់ មានការកើនឡើង ហើយតាមរយៈកិច្ចការក្នុងលក្ខណៈជាព្រះនៃព្រះវិញ្ញាណរបស់ព្រះជាម្ចាស់នៅក្នុងសាច់ឈាម កិច្ចការរបស់ព្រះចំពោះផ្នែកសាច់ឈាម និងកិច្ចការក្នុងលក្ខណៈជាមនុស្សរបស់ទ្រង់នៅក្នុងសាច់ឈាម មនុស្សទទួលបានការបើកសម្ដែងឲ្យឃើញ និងត្រូវបានបានឃ្វាល ហើយនិស្ស័យរបស់មនុស្ស ក៏មានការផ្លាស់ប្ដូរដែរ។ នេះជាអត្ថន័យពិតប្រាកដ នៃការយាងមកដល់របស់ព្រះវិញ្ញាណនៅក្នុងសាច់ឈាម គោលបំណងចម្បងដែលមនុស្សអាចផ្សារភ្ជាប់ជាមួយព្រះជាម្ចាស់ ពឹងផ្អែកលើព្រះជាម្ចាស់ និងមានចំណេះដឹងអំពីព្រះជាម្ចាស់។

ជាបឋម តើមនុស្សគួរមានអាកប្បកិរិយាអ្វីខ្លះចំពោះព្រះដ៏ជាក់ស្ដែង? តើអ្នកបានស្គាល់អ្វីខ្លះអំពីការយកកំណើតជាមនុស្ស ការលេចមកជាសាច់ឈាមរបស់ព្រះបន្ទូល ការលេចមកជាសាច់ឈាមរបស់ព្រះជាម្ចាស់ និងទង្វើរបស់ព្រះដ៏ជាក់ស្ដែង? តើមានប្រធានបទអ្វីដែលសំខាន់ជាងគេ សម្រាប់យកមកពិភាក្សានៅថ្ងៃនេះ? នៅក្នុងការយកកំណើតជាមនុស្ស ការមកដល់របស់ព្រះបន្ទូលក្នុងសាច់ឈាម និងការលេចមកជាសាច់ឈាមរបស់ព្រះជាម្ចាស់ គឺជាបញ្ហាដែលត្រូវតែធ្វើការស្វែងយល់។ អ្នករាល់គ្នាត្រូវតែមកធ្វើការស្វែងយល់នូវបញ្ហាទាំងនេះជាបន្តបន្ទាប់ និងត្រូវមានចំណេះដឹងច្បាស់លាស់អំពីបញ្ហាទាំងនេះ នៅក្នុងបទពិសោធជីវិតរបស់អ្នករាល់គ្នា ដោយអាស្រ័យលើជំហរ និងអាស្រ័យលើយុគសម័យរបស់អ្នករាល់គ្នា។ ដំណើរការដែលមនុស្សមានបទពិសោធអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ គឺដូចនឹងដំណើរការដែលពួកគេស្គាល់ពីការលេចមកជាសាច់ឈាមនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់។ កាលណាមនុស្សមានបទពិសោធអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់កាន់តែខ្លាំង នោះគេក៏បានស្គាល់ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់កាន់តែច្រើនដែរ តាមរយៈការមានបទពិសោធអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ មនុស្សក៏មានការយល់ដឹងពីគោលការណ៍នៃកិច្ចការរបស់ព្រះវិញ្ញាណ និងបានស្គាល់ព្រះដ៏ជាក់ស្ដែងផ្ទាល់ព្រះអង្គ។ តាមពិតទៅ នៅពេល

ដែលព្រះជាម្ចាស់ធ្វើឲ្យមនុស្សគ្រប់លក្ខណ៍ និងទទួលបានពួកគេ នោះទ្រង់កំពុងតែអនុញ្ញាតឲ្យពួកគេស្គាល់ពីទង្វើនៃព្រះដ៏ជាក់ស្តែង។ ព្រះអង្គកំពុងប្រើប្រាស់កិច្ចការនៃព្រះដ៏ជាក់ស្តែងដើម្បីបង្ហាញមនុស្សពីសារៈសំខាន់នៃការយកកំណើតជាមនុស្ស ដើម្បីបង្ហាញពួកគេថា ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់បានលេចមកនៅចំពោះមុខមនុស្សយ៉ាងពិតប្រាកដ។ នៅពេលដែលព្រះជាម្ចាស់ទទួលយកមនុស្ស និងប្រោសឲ្យមនុស្សបានគ្រប់លក្ខណ៍ នោះការបើកសម្តែងអំពីព្រះដ៏ជាក់ស្តែង បានយកឈ្នះលើពួកគេ ព្រះបន្ទូលនៃព្រះដ៏ជាក់ស្តែងបានផ្លាស់ប្តូរពួកគេ ហើយជីវិតរបស់ព្រះអង្គផ្ទាល់ បានធ្វើការនៅក្នុងពួកគេ ដោយចាក់បំពេញពួកគេជាមួយនឹងលក្ខណៈរបស់ទ្រង់ (មិនថាជាលក្ខណៈរបស់ព្រះអង្គក្នុងភាពជាមនុស្ស ឬលក្ខណៈរបស់ទ្រង់ក្នុងភាពជាព្រះនោះទេ) ធ្វើការចាក់បំពេញពួកគេជាមួយនឹងធាតុផ្សំនៃព្រះបន្ទូលរបស់ទ្រង់ ព្រមទាំងការធ្វើឲ្យមនុស្សរស់នៅតាមព្រះបន្ទូលរបស់ទ្រង់។ នៅពេលដែលព្រះជាម្ចាស់ទទួលបានមនុស្សមក ព្រះអង្គបានធ្វើកិច្ចការមុនគេដោយការប្រើប្រាស់ព្រះបន្ទូល និងការថ្លែងអំពីព្រះដ៏ជាក់ស្តែង ដែលជារបៀបមួយដើម្បីដោះស្រាយជាមួយនឹងភាពខ្វះខាតរបស់មនុស្ស និងដើម្បីជំនុំជម្រះ និងបើកសម្តែងនូវនិស្ស័យរបស់ពួកគេដែលចូលចិត្តប្រឆាំងទាស់នឹងទ្រង់ ដែលបណ្តាលឲ្យពួកគេទទួលបានអ្វីដែលខ្លួនត្រូវការ និងបង្ហាញប្រាប់ពួកគេថា ព្រះជាម្ចាស់បានយាងមកក្នុងចំណោមពួកគេហើយ។ អ្វីដែលសំខាន់ជាងគេ ជាកិច្ចការដែលព្រះដ៏ជាក់ស្តែងបានធ្វើនោះ គឺការសង្គ្រោះមនុស្សម្នាក់ៗចេញពីឥទ្ធិពលរបស់សាតាំង ដោយយកពួកគេចេញពីទឹកដីដែលខូចកខ្វក់ និងបណ្តេញចោលនូវនិស្ស័យពុករលួយរបស់ពួកគេ។ សារៈសំខាន់ដ៏ជ្រាលជ្រៅបំផុតដែលព្រះដ៏ជាក់ស្តែងទទួលបាន គឺការអាចរស់នៅក្នុងភាពជាមនុស្សធម្មតាជាមួយនឹងព្រះដ៏ជាក់ស្តែង ដែលធ្វើជាឧទាហរណ៍ និងជាគំរូ និងជាការដែលអាចអនុវត្តស្របតាមព្រះបន្ទូល និង សេចក្តីតម្រូវរបស់ព្រះដ៏ជាក់ស្តែង ដោយគ្មានគម្លាតសូម្បីតែបន្តិច ឬការចាកចេញ ជាការអនុវត្តតាមរបៀបគ្រប់យ៉ាងដែលព្រះអង្គមានបន្ទូល ព្រមទាំងការអាចសម្រេចបាននូវអ្វីគ្រប់យ៉ាងដែលព្រះអង្គបង្គាប់។ តាមរបៀបនេះ ព្រះជាម្ចាស់នឹង

ទទួលបានអ្នក។ នៅពេលដែលព្រះជាម្ចាស់ទទួលបានអ្នក នោះអ្នកមិនត្រឹមតែមាននូវកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធទេ បើតាមគោលការណ៍ គឺអ្នកអាចរស់នៅតាមសេចក្ដីតម្រូវនៃព្រះដ៏ជាក់ស្ដែងទៀតផង។ ការមានកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ មិនមែនមានន័យថាអ្នកមានជីវិតទេ។ អ្វីដែលសំខាន់បំផុតនោះ គឺអ្នកអាចប្រព្រឹត្តស្របតាមសេចក្ដីតម្រូវរបស់ព្រះដ៏ជាក់ស្ដែង ដែលទ្រង់ចង់ឲ្យអ្នកធ្វើ ដែលកិច្ចការទាំងនេះទាក់ទងនឹងការដែលព្រះជាម្ចាស់អាចទទួលបានអ្នក។ ទាំងនេះ គឺជាអត្ថន័យដ៏អស្ចារ្យបំផុតនៃកិច្ចការរបស់ព្រះដ៏ជាក់ស្ដែងនៅក្នុងលក្ខណៈសាច់ឈាម។ នេះអាចនិយាយបានថា ព្រះជាម្ចាស់ទទួលបានមនុស្សមួយក្រុមតាមរយៈការលេចមកជាសាច់ឈាមយ៉ាងពិតប្រាកដ និងជាក់លាក់ ហើយមានភាពច្បាស់លាស់ និងរស់រវើក ការឲ្យមនុស្សមើលឃើញ ការធ្វើកិច្ចការនៃព្រះវិញ្ញាណនៅក្នុងសាច់ឈាម និងការធ្វើជាឧទាហរណ៍សម្រាប់មនុស្សនៅក្នុងសាច់ឈាម។ ការមកដល់របស់ព្រះជាម្ចាស់ជាសាច់ឈាម គឺដើម្បីជួយមនុស្សឲ្យមើលឃើញទង្វើពិតប្រាកដរបស់ព្រះជាម្ចាស់ ដើម្បីផ្ដល់ជារូបរាងនៃសាច់ឈាមទៅដល់ព្រះវិញ្ញាណដែលគ្មានរូបរាង និងដើម្បីអនុញ្ញាតឲ្យមនុស្សមើលឃើញ និងបានប៉ះពាល់ទ្រង់ផង។ តាមរយៈសេចក្ដីនេះ អស់អ្នកណាដែលទ្រង់បានចាក់បំពេញ នឹងរស់នៅបង្ហាញទ្រង់ ទ្រង់នឹងទទួលបានពួកគេ ហើយគេនឹងដើរតាមព្រះហឫទ័យរបស់ទ្រង់។ ប្រសិនបើព្រះជាម្ចាស់ មានព្រះបន្ទូលតែក្នុងស្ថានសួគ៌ ហើយមិនបានយាងមកផែនដីពិតប្រាកដទេ នោះមនុស្សនឹងមិនអាចស្គាល់ព្រះជាម្ចាស់ឡើយ ពួកគេនឹងបានត្រឹមតែអាចអធិប្បាយពីការប្រព្រឹត្តរបស់ព្រះជាម្ចាស់ ដោយការប្រើប្រាស់ទ្រឹស្ដីទទេសូន្យ និងមិនអាចមានព្រះបន្ទូលរបស់ព្រះជាម្ចាស់ពិតប្រាកដឡើយ។ ការសំខាន់ដែលព្រះជាម្ចាស់បានយាងមកផែនដីនេះ គឺ ដើម្បីធ្វើជាឧទាហរណ៍ និងជាគំរូសម្រាប់អស់អ្នកដែលទ្រង់ទទួលបាន។ មានតែបែបនេះទេ ទើបមនុស្សអាចស្គាល់ព្រះជាម្ចាស់បានពិតប្រាកដ ប៉ះព្រះជាម្ចាស់បាន និងមើលឃើញទ្រង់ ហើយមានតែបែបនេះទេ ទើបព្រះជាម្ចាស់អាចទទួលបានពួកគេយ៉ាងពិតប្រាកដ។

# ការដឹងអំពីកិច្ចការរបស់ព្រះជាម្ចាស់នាពេលសព្វថ្ងៃ

សម្រាប់ផ្នែកភាគច្រើន ដើម្បីដឹងអំពីកិច្ចការរបស់ព្រះជាម្ចាស់នាពេលសព្វថ្ងៃ គឺជាការត្រូវដឹងអំពីអ្វីដែលជាព័ន្ធកិច្ចដ៏សំខាន់ របស់ព្រះយកកំណើតជាមនុស្សនៅគ្រាចុងក្រោយ និងអ្វីដែលទ្រង់បានយាងមកធ្វើនៅលើផែនដី។ ខ្ញុំបានលើកឡើងរួចហើយនៅក្នុងព្រះបន្ទូលរបស់ខ្ញុំថា ព្រះជាម្ចាស់បានយាងមកកាន់ផែនដី (ក្នុងអំឡុងគ្រាចុងក្រោយ) ដើម្បីធ្វើជាគំរូ មុនពេលទ្រង់ចាកចេញទៅ។ តើព្រះជាម្ចាស់ធ្វើជាគំរូនេះដោយរបៀបណា? ទ្រង់ធ្វើជាគំរូតាមរយៈការមានបន្ទូល និងតាមរយៈការធ្វើការ និងការប្រកាសព្រះបន្ទូលនៅទូទាំងប្រទេស។ នេះជាកិច្ចការរបស់ព្រះជាម្ចាស់ ក្នុងអំឡុងគ្រាចុងក្រោយ។ ដើម្បីធ្វើឲ្យផែនដីក្លាយជាពិភពលោកនៃព្រះបន្ទូល ទ្រង់គ្រាន់តែមានបន្ទូល ដើម្បីឲ្យមនុស្សគ្រប់គ្នាទទួលបានព្រះបន្ទូល និងការស្រាយបំភ្លឺពីព្រះបន្ទូលរបស់ទ្រង់ ព្រមទាំងដាស់វិញ្ញាណរបស់មនុស្សឲ្យភ្ញាក់ឡើង ដើម្បីឲ្យគេទទួលបានភាពច្បាស់លាស់អំពីនិមិត្ត។ ក្នុងអំឡុងនៃគ្រាចុងក្រោយ ព្រះដែលយកកំណើតជាមនុស្សបានយាងមកកាន់ផែនដី ក្នុងគោលបំណងជាចម្បង ដើម្បីថ្លែងព្រះបន្ទូល។ នៅពេលដែលព្រះយេស៊ូវបានយាងមក ទ្រង់បានផ្សាយដំណឹងល្អអំពីនគរស្ថានសួគ៌ ហើយទ្រង់បានសម្រេចកិច្ចការប្រោសលោះនៃការជាប់ឆ្កាង។ ទ្រង់បាននាំមកនូវការបញ្ចប់យុគសម័យនៃក្រឹត្យវិន័យ ហើយលុបបំបាត់រាល់អ្វីៗដែលចាស់។ ការយាងមកដល់របស់ព្រះយេស៊ូវបានបញ្ចប់យុគសម័យនៃក្រឹត្យវិន័យ និងបាននាំមកនូវយុគសម័យនៃព្រះគុណ ហើយការយាងមករបស់ព្រះដែលយកកំណើតជាមនុស្សនៅគ្រាចុងក្រោយ បានបញ្ចប់នូវយុគសម័យនៃព្រះគុណ។ ទ្រង់បានយាងមក ក្នុងគោលបំណងជាចម្បង ដើម្បីថ្លែងបន្ទូលរបស់ទ្រង់ ដើម្បីប្រើព្រះបន្ទូលធ្វើឲ្យមនុស្សក្លាយជាគ្រប់លក្ខណ៍ ដើម្បីបំភ្លឺ និងស្រាយពន្យល់ដល់មនុស្ស និងដើម្បីដកចោលនូវកន្លែងនៃព្រះដ៏ស្រពេចស្រពិលដែលមាននៅក្នុងដួងចិត្តរបស់មនុស្ស។ នេះមិនមែនជាដំណាក់កាលនៃកិច្ចការដែលព្រះយេស៊ូវបានធ្វើ នៅពេលដែលទ្រង់

បានយាងមកនោះឡើយ។ នៅពេលដែលព្រះយេស៊ូវបានយាងមក ទ្រង់បានធ្វើការអស្ចារ្យជាច្រើន ទ្រង់បានប្រោសអ្នកជំងឺឲ្យជា និងបណ្ដេញពួកអារក្ស ហើយទ្រង់បានធ្វើកិច្ចការប្រោសលោះនៃការជាប់ឆ្កាង។ ជាលទ្ធផល នៅក្នុងសញ្ញាណរបស់មនុស្ស ពួកគេជឿថា នេះជារបៀបដែលព្រះជាម្ចាស់គួរតែក្លាយជា។ ដ្បិតពេលដែលព្រះយេស៊ូវបានយាងមក ទ្រង់មិនបានធ្វើកិច្ចការនៃការកម្ចាត់ចោលនូវរូបអង្គអំពីព្រះដ៏ស្រពេចស្រពិលចេញពីដួងចិត្តរបស់មនុស្សឡើយ។ នៅពេលដែលទ្រង់បានយាងមក ទ្រង់បានជាប់ឆ្កាង ទ្រង់បានប្រោសអ្នកជំងឺឲ្យជា និងបណ្ដេញអារក្ស ហើយទ្រង់បានផ្សាយដំណឹងល្អអំពីនគរស្ថានសួគ៌។ នៅក្នុងន័យម៉្យាង ការយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់ ក្នុងអំឡុងគ្រាចុងក្រោយ កម្ចាត់ចោលកន្លែងដែលមានផ្ទុកនូវព្រះដ៏ស្រពេចស្រពិលនៅក្នុងសញ្ញាណរបស់មនុស្ស ដូច្នេះ វានឹងលែងគ្មានរូបអង្គអំពីព្រះដ៏ស្រពេចស្រពិលនៅក្នុងដួងចិត្តរបស់មនុស្សទៀតហើយ។ តាមរយៈព្រះបន្ទូល និងកិច្ចការដ៏ពិតរបស់ទ្រង់ ចលនារបស់ទ្រង់នៅទូទាំងទឹកដី និងកិច្ចការដ៏ពិតអស្ចារ្យ និងធម្មតា ដែលទ្រង់ធ្វើនៅក្នុងចំណោមមនុស្ស ទ្រង់ធ្វើឲ្យមនុស្សស្គាល់ពីការពិតរបស់ព្រះជាម្ចាស់ ហើយកម្ចាត់ចោលកន្លែងរបស់ព្រះដ៏ស្រពេចស្រពិលដែលមាននៅក្នុងដួងចិត្តមនុស្ស។ នៅក្នុងន័យម៉្យាងទៀត ព្រះជាម្ចាស់ប្រើព្រះបន្ទូលដែលថ្លែងចេញពីសាច់ឈាមរបស់ទ្រង់ ដើម្បីធ្វើឲ្យមនុស្សបានពេញខ្នាត និងសម្រេចគ្រប់កិច្ចការទាំងអស់។ នេះជាកិច្ចការដែលព្រះជាម្ចាស់នឹងសម្រេច ក្នុងអំឡុងគ្រាចុងក្រោយ។

អ្វីដែលអ្នករាល់គ្នាត្រូវដឹង៖

១. កិច្ចការរបស់ព្រះជាម្ចាស់មិនមែនជារឿងអធិធម្មជាតិឡើយ ហើយអ្នកមិនគួរមានសញ្ញាណអំពីវាឡើយ។

២. អ្នករាល់គ្នាត្រូវតែយល់អំពីកិច្ចការចម្បងដែលព្រះយកកំណើតជាមនុស្សបានយាងមកធ្វើនៅពេលនេះ។

ទ្រង់មិនបានយាងមក ដើម្បីប្រោសអ្នកជំងឺឲ្យជា បណ្ដេញអារក្ស ឬធ្វើការអស្ចារ្យឡើយ ហើយទ្រង់ក៏មិនបានយាងមក ដើម្បីផ្សាយដំណឹងល្អអំពីការប្រែចិត្ត ឬប្រទាន

ឲ្យមនុស្សនូវការប្រោសលោះដែរ។ នោះគឺដោយសារតែព្រះយេស៊ូវបានធ្វើកិច្ចការទាំងនេះរួចហើយ ហើយព្រះជាម្ចាស់នឹងមិនធ្វើកិច្ចការទាំងនេះម្ដងទៀតឡើយ។ សព្វថ្ងៃនេះ ព្រះជាម្ចាស់បានយាងមក ដើម្បីបិទបញ្ចប់យុគសម័យនៃព្រះគុណ និងកម្ចាត់ចោលរាល់ការអនុវត្តទាំងប៉ុន្មាន អំពីយុគសម័យនៃព្រះគុណ។ ព្រះជាម្ចាស់ដ៏សកម្មបានយាងមក ក្នុងគោលបំណងចម្បងដើម្បីបង្ហាញថា ទ្រង់ពិតប្រាកដ។ នៅពេលដែលព្រះយេស៊ូវបានយាងមក ទ្រង់បានមានបន្ទូលតិចតួចណាស់ ប៉ុន្តែទ្រង់បានធ្វើកិច្ចការជាចម្បង ដោយទ្រង់បានធ្វើការអស្ចារ្យ សម្ដែងទីសម្គាល់ និងឫទ្ធិបារមី ហើយប្រោសអ្នកជំងឺឲ្យជា និងបណ្ដេញអារក្ស បើមិនដូច្នោះទេ ទ្រង់បានថ្លែងទំនាយ ដើម្បីបញ្ចុះបញ្ចូលឲ្យមនុស្សជឿ និងធ្វើឲ្យពួកគេមើលឃើញថា ទ្រង់ជាព្រះជាម្ចាស់ និងថា ទ្រង់ជាព្រះដែលគ្មានព្រះទ័យក្ដួលអាណិត។ ចុងបញ្ចប់ ទ្រង់បានបញ្ចប់កិច្ចការនៃការជាប់ឆ្កាង។ ព្រះជាម្ចាស់នាពេលសព្វថ្ងៃមិនសម្ដែងទីសម្គាល់ និងឫទ្ធិបារមីឡើយ ហើយក៏មិនប្រោសអ្នកជំងឺឲ្យជា និងបណ្ដេញអារក្សដែរ។ នៅពេលដែលព្រះយេស៊ូវបានយាងមក កិច្ចការដែលទ្រង់បានធ្វើ តំណាងឲ្យផ្នែកមួយរបស់ព្រះជាម្ចាស់ ប៉ុន្តែលើកនេះ ព្រះជាម្ចាស់បានយាងមកដើម្បីធ្វើដំណាក់កាលនៃកិច្ចការដែលត្រូវបានរំពឹងទុក ព្រោះថាព្រះជាម្ចាស់មិនធ្វើកិច្ចការដដែលម្ដងទៀតឡើយ។ ទ្រង់ជាព្រះដែលតែងតែថ្មីជានិច្ច និងមិនដែលចាស់ឡើយ ដូច្នេះ អ្វីគ្រប់យ៉ាងដែលអ្នកមើលឃើញនាពេលបច្ចុប្បន្ន គឺជាព្រះបន្ទូល និងកិច្ចការរបស់ព្រះដ៏ពិត។

ព្រះដែលយកកំណើតជាមនុស្សនៅគ្រាចុងក្រោយ បានយាងមកក្នុងគោលបំណងចម្បង ដើម្បីថ្លែងនូវព្រះបន្ទូលរបស់ទ្រង់ ដើម្បីពន្យល់អំពីសេចក្ដីគ្រប់យ៉ាងដែលចាំបាច់ចំពោះជីវិតរបស់មនុស្ស ដើម្បីបង្ហាញថាមនុស្សណាគួរតែចូលទៅ ដើម្បីបង្ហាញដល់មនុស្ស អំពីទង្វើរបស់ព្រះជាម្ចាស់ និងដើម្បីបង្ហាញដល់មនុស្សអំពីព្រះប្រាជ្ញាញាណ សព្វានុភាព និងភាពអស្ចារ្យរបស់ព្រះជាម្ចាស់។ តាមរយៈរបៀបជាច្រើនដែលព្រះជាម្ចាស់មានបន្ទូល មនុស្សមើលឃើញអំពីភាពខ្ពង់ខ្ពស់ និងភាពមហិមារបស់ព្រះជាម្ចាស់ ហើយលើសពីនេះទៅទៀត ពួកគេក៏មើលឃើញពីការ

បន្ទាបខ្លួន និងការលាក់កំបាំងរបស់ព្រះជាម្ចាស់ផងដែរ។ មនុស្សមើលឃើញថា ព្រះជាម្ចាស់មានឋានៈខ្ពង់ខ្ពស់ ប៉ុន្តែក៏ឃើញដែរថា ទ្រង់បន្ទាបខ្លួន និងលាក់កំបាំង ហើយទ្រង់អាចក្លាយជាបុគ្គលទន់ទាបបំផុតផងដែរ។ ព្រះបន្ទូលខ្លះរបស់ទ្រង់ត្រូវបានថ្លែងដោយផ្ទាល់ចេញពីការយល់ឃើញនៃព្រះវិញ្ញាណ ខ្លះទៀតថ្លែងដោយផ្ទាល់ចេញពីការយល់ឃើញរបស់មនុស្ស ហើយខ្លះផ្សេងទៀតចេញពីទិដ្ឋភាពបុគ្គលទីបី។ នៅក្នុងការនេះ វាអាចត្រូវបានមើលឃើញថា ឥរិយាបថនៃកិច្ចការរបស់ព្រះជាម្ចាស់មានលក្ខណៈខុសគ្នាយ៉ាងខ្លាំង ហើយភាពខុសគ្នានោះគឺតាមរយៈព្រះបន្ទូលដែល ទ្រង់អនុញ្ញាតឲ្យមនុស្សមើលឃើញ។ កិច្ចការរបស់ព្រះជាម្ចាស់ ក្នុងអំឡុងគ្រាចុងក្រោយ គឺមានទាំងភាពសាមញ្ញផង និងភាពពិតផង ដូច្នេះ ក្រុមមនុស្សនៅគ្រាចុងក្រោយ ត្រូវទទួលសេចក្ដីល្បងលដ៏ធំបំផុតគ្រប់យ៉ាង។ ដោយសារតែភាពសាមញ្ញ និងភាពពិតរបស់ព្រះជាម្ចាស់ មនុស្សទាំងអស់បានធ្លាក់ចូលទៅក្នុងសេចក្ដីល្បងលបែបនេះ ហើយការដែលមនុស្សបានធ្លាក់ចូលទៅក្នុងសេចក្ដីល្បងលរបស់ព្រះជាម្ចាស់ នោះគឺដោយសារតែភាពសាមញ្ញ និងភាពពិតរបស់ព្រះជាម្ចាស់។ ក្នុងអំឡុងយុគសម័យរបស់ព្រះយេស៊ូវ គ្មាននូវសញ្ញាណ ឬសេចក្ដីល្បងលឡើយ។ ដោយសារតែកិច្ចការភាគច្រើនដែលព្រះយេស៊ូវបានធ្វើ ស្របជាមួយសញ្ញាណរបស់មនុស្ស មនុស្សដើរតាមទ្រង់ ហើយពួកគេគ្មានសញ្ញាណអំពីទ្រង់ឡើយ។ សេចក្ដីល្បងលនាពេលបច្ចុប្បន្ន គឺជាសេចក្ដីល្បងលដ៏ខ្លាំងបំផុតដែលមនុស្សនឹងត្រូវជួប ហើយនៅពេលដែលគេនិយាយថា មនុស្សទាំងនេះបានចេញពីទុក្ខវេទនាដ៏ធំ នេះជាទុក្ខវេទនាដែលគេចង់សំដៅលើការនោះហើយ។ បច្ចុប្បន្ននេះ ព្រះជាម្ចាស់មានបន្ទូលដើម្បីបង្កើតឲ្យមានសេចក្ដីជំនឿ សេចក្ដីស្រឡាញ់ ការទទួលយកទុក្ខវេទនា និងការស្ដាប់បង្គាប់នៅក្នុងមនុស្សទាំងនេះ។ ព្រះបន្ទូលដែលត្រូវបានថ្លែងចេញពីព្រះដែលយកកំណើតជាមនុស្សនៅគ្រាចុងក្រោយ ត្រូវបានថ្លែងមកដោយស្របតាមសារជាតិនៃនិស្ស័យរបស់មនុស្ស ឥរិយាបថរបស់មនុស្ស ហើយនោះជាអ្វីដែលមនុស្សគួរតែចូលទៅក្នុងនាពេលសព្វថ្ងៃ។ ព្រះបន្ទូលរបស់ទ្រង់មានទាំងសាមញ្ញផង និងភាព

ពិតផង៖ ទ្រង់មិនមានបន្ទូលពីថ្ងៃស្អែក ហើយទ្រង់ក៏មិនមើលពីថ្ងៃម្សិលមិញដែរ។ ព្រះអង្គមានបន្ទូលតែអ្វីដែលគួរចូលទៅរក អ្វីដែលគួរអនុវត្ត និងអ្វីដែលគួរស្វែងយល់នៅថ្ងៃនេះប៉ុណ្ណោះ។ ក្នុងអំឡុងពេលបច្ចុប្បន្ននេះ ប្រសិនបើមានការលេចឡើងនូវមនុស្សម្នាក់ដែលអាចសម្ដែងទីសម្គាល់ និងឫទ្ធិបារមី បណ្ដេញអារក្ស ប្រោសអ្នកជំងឺឲ្យជា និងធ្វើការអស្ចារ្យជាច្រើនផ្សេងទៀត ហើយប្រសិនបើបុគ្គលនោះអះអាងថា ខ្លួនជាព្រះយេស៊ូវដែលបានយាងមក នោះវាជាការក្លែងបន្លំ ដែលពួកវិញ្ញាណអាក្រក់បានធ្វើ ដើម្បីក្លែងខ្លួនជាព្រះយេស៊ូវហើយ។ សូមចងចាំអំពីការនេះ! ព្រះជាម្ចាស់ទ្រង់មិនធ្វើកិច្ចការដដែលម្ដងទៀតឡើយ។ ដំណាក់កាលនៃកិច្ចការរបស់ព្រះយេស៊ូវបានបញ្ចប់ទាំងស្រុងរួចហើយ ហើយព្រះជាម្ចាស់នឹងមិនធ្វើដំណាក់កាលនៃកិច្ចការនោះម្ដងទៀតឡើយ។ កិច្ចការរបស់ព្រះជាម្ចាស់ខុសស្រឡះ ពីសញ្ញាណរបស់មនុស្ស។ ឧទាហរណ៍ ព្រះគម្ពីរសញ្ញាចាស់បានថ្លែងទំនាយទស្សន៍ទាយអំពីការយាងមករបស់ព្រះមែស្ស៊ី ហើយលទ្ធផលនៃសេចក្ដីទំនាយនេះ គឺជាការយាងមករបស់ព្រះយេស៊ូវ។ ការនេះបានកើតឡើងរួចហើយ ដូច្នេះ វាជារឿងខុសឆ្គងដែលមានព្រះមេស៊ីមួយទៀតបានយាងមកម្ដងទៀត។ ព្រះយេស៊ូវបានយាងមករួចហើយ ហើយវាជារឿងខុសឆ្គងប្រសិនបើព្រះយេស៊ូវត្រូវយាងមកម្ដងទៀតនាពេលបច្ចុប្បន្ន។ មានព្រះនាមសម្រាប់គ្រប់យុគសម័យ ហើយព្រះនាមនីមួយៗ មានផ្ទុកនូវចរិតលក្ខណៈនៃយុគសម័យនោះ។ នៅក្នុងសញ្ញាណរបស់មនុស្ស ព្រះជាម្ចាស់ត្រូវតែសម្ដែងទីសម្គាល់ និងឫទ្ធិបារមីជានិច្ច ទ្រង់ត្រូវតែប្រោសអ្នកជំងឺឲ្យជា និងបណ្ដេញអារក្ស ហើយទ្រង់ត្រូវតែដូចជាព្រះយេស៊ូវជានិច្ច។ ប៉ុន្តែ លើកនេះ ព្រះជាម្ចាស់មិនដូចជាពេលនោះឡើយ។ ក្នុងអំឡុងនៃគ្រាចុងក្រោយ ប្រសិនបើព្រះជាម្ចាស់នៅតែបង្ហាញទីសម្គាល់ និងឫទ្ធិបារមី ហើយនៅតែបណ្ដេញអារក្ស និងប្រោសអ្នកជំងឺឲ្យជា ប្រសិនបើទ្រង់បានធ្វើដូចដែលព្រះយេស៊ូវបានធ្វើ នោះព្រះជាម្ចាស់នឹងធ្វើកិច្ចការដដែលម្ដងទៀតហើយ បើដូច្នេះ កិច្ចការរបស់ព្រះយេស៊ូវនឹងគ្មានតម្លៃ ឬសំខាន់នោះឡើយ។ ដូច្នេះ ព្រះជាម្ចាស់អនុវត្តដំណាក់កាលនៃកិច្ចការមួយនៅគ្រប់យុគសម័យ។ នៅពេលដែល

ដំណាក់កាលនីមួយៗនៃកិច្ចការរបស់ទ្រង់ត្រូវបានបញ្ចប់ នោះពួកវិញ្ញាណអាក្រក់នឹងយកតម្រាប់តាមភ្លាមៗមិនខាន ហើយក្រោយពេលអារក្សសាតាំងចាប់ផ្ដើមចម្លងកិច្ចការរបស់ព្រះជាម្ចាស់ នោះព្រះជាម្ចាស់នឹងផ្លាស់ប្ដូរទៅប្រើប្រាស់វិធីសាស្ត្រផ្សេងវិញ។ នៅពេលដែលព្រះជាម្ចាស់បានបញ្ចប់ដំណាក់កាលនៃកិច្ចការរបស់ទ្រង់ ពួកវិញ្ញាណអាក្រក់ក៏ចម្លងតាមកិច្ចការរបស់ទ្រង់។ អ្នករាល់គ្នាត្រូវតែប្រាកដច្បាស់ពីរឿងនេះ។ ហេតុអ្វីបានជាកិច្ចការរបស់ព្រះជាម្ចាស់នាពេលសព្វថ្ងៃ ខុសប្លែកអំពីកិច្ចការរបស់ព្រះយេស៊ូវ? ហេតុអ្វីបានជាព្រះជាម្ចាស់នាពេលសព្វថ្ងៃមិនសម្ដែងទីសម្គាល់ និងឫទ្ធិបារមី មិនបណ្ដេញអារក្ស និងប្រោសអ្នកជំងឺឲ្យជា? ប្រសិនបើកិច្ចការរបស់ព្រះយេស៊ូវជាកិច្ចការដែលបានធ្វើរួចហើយនៅក្នុងអំឡុងយុគសម័យនៃក្រឹត្យវិន័យ តើទ្រង់អាចតំណាងឲ្យព្រះជាម្ចាស់នៅយុគសម័យនៃព្រះគុណបានដែរឬទេ? តើទ្រង់អាចបញ្ចប់កិច្ចការនៃការជាប់ឆ្កាងបានដែរឬទេ? ដូចនៅក្នុងយុគសម័យនៃក្រឹត្យវិន័យដែរ ប្រសិនបើព្រះយេស៊ូវបានចូលទៅក្នុងព្រះវិហារ និងកាន់តាមថ្ងៃសប្ប័ទ នោះវានឹងគ្មាននរណាម្នាក់បៀតបៀនទ្រង់ ហើយមនុស្សគ្រប់គ្នានឹងស្វាគមន៍ទទួលយកទ្រង់មិនខាន។ បើដូច្នេះ តើទ្រង់អាចត្រូវបានគេឆ្កាងដែរឬទេ? តើទ្រង់អាចបញ្ចប់កិច្ចការប្រោសលោះបានដែរឬទេ? តើអ្វីជាកិច្ចការដ៏ចម្បងទៅ ប្រសិនបើព្រះដែលយកកំណើតជាមនុស្សនៃគ្រាចុងក្រោយ បានសម្ដែងទីសម្គាល់ និងឫទ្ធិបារមី ដូចជាព្រះយេស៊ូវបានធ្វើនោះ? លុះត្រាតែព្រះជាម្ចាស់ធ្វើផ្នែកមួយទៀតនៃកិច្ចការរបស់ទ្រង់ក្នុងអំឡុងនៃគ្រាចុងក្រោយ ជាផ្នែកមួយដែលតំណាងឲ្យផ្នែកនៃផែនការគ្រប់គ្រងរបស់ទ្រង់ ទើបមនុស្សអាចទទួលបានចំណេះដឹងកាន់តែស៊ីជម្រៅអំពីព្រះជាម្ចាស់ ហើយមានតែធ្វើបែបនេះទេ ទើបផែនការគ្រប់គ្រងរបស់ព្រះជាម្ចាស់អាចត្រូវបានបញ្ចប់។

ក្នុងអំឡុងនៃគ្រាចុងក្រោយ ព្រះជាម្ចាស់បានយាងមក ក្នុងគោលបំណងចម្បងដើម្បីមានបន្ទូលរបស់ទ្រង់។ ទ្រង់មានបន្ទូល ចេញពីការយល់ឃើញរបស់ទិដ្ឋភាពព្រះវិញ្ញាណ ការយល់ឃើញរបស់មនុស្ស និងការយល់ឃើញរបស់បុគ្គលទីបី។ ទ្រង់មានបន្ទូលនៅក្នុងរបៀបផ្សេងៗគ្នា ដោយប្រើរបៀបមួយសម្រាប់អំឡុងពេលមួយ

ហើយទ្រង់ប្រើវិធីសាស្រ្តនៃការមានបន្ទូល ដើម្បីផ្លាស់ប្ដូរសញ្ញាណរបស់មនុស្ស និងកម្ចាត់ចោលរូបអង្គ នៃព្រះដ៏ស្រពេចស្រពិលចេញពីដួងចិត្តរបស់មនុស្ស។ នេះជាកិច្ចការដ៏ចម្បងដែលព្រះជាម្ចាស់ធ្វើ។ ដោយសារតែមនុស្សជឿថា ព្រះជាម្ចាស់បានយាងមក ដើម្បីប្រោសអ្នកជំងឺឲ្យជា បណ្ដេញអារក្ស ធ្វើការអស្ចារ្យ និងប្រទានព្រះពរផ្នែកសម្ភារៈដល់មនុស្ស នោះព្រះជាម្ចាស់អនុវត្តដំណាក់កាលនៃកិច្ចការនេះ ដែលជាកិច្ចការនៃការកាត់ទោស និងការជំនុំជម្រះ ដើម្បីកម្ចាត់ចោលអ្វីៗទាំងនេះចេញពីសញ្ញាណរបស់មនុស្ស ដើម្បីឱ្យមនុស្សអាចដឹងអំពីការពិត និងភាពសាមញ្ញរបស់ព្រះជាម្ចាស់ និងដើម្បីឲ្យរូបអង្គរបស់ព្រះយេស៊ូវត្រូវបានកម្ចាត់ចោលចេញពីដួងចិត្តរបស់គេ ហើយជំនួសមកវិញដោយរូបអង្គថ្មីអំពីព្រះជាម្ចាស់។ ពេលណាដែលរូបអង្គអំពីព្រះជាម្ចាស់ដែលមាននៅក្នុងចិត្តរបស់មនុស្សក្លាយជាចាស់ នោះវាក្លាយជារូបព្រះហើយ។ នៅពេលដែលព្រះយេស៊ូវបានយាងមក ហើយអនុវត្តដំណាក់កាលនៃកិច្ចការនោះ ទ្រង់មិនតំណាងឲ្យផ្នែកទាំងស្រុងរបស់ព្រះជាម្ចាស់ឡើយ។ ទ្រង់បានធ្វើទីសម្គាល់ និងឫទ្ធិបារមីខ្លះ បានមានបន្ទូលខ្លះ ហើយចុងបញ្ចប់ ត្រូវបានជាប់ឆ្កាង។ ទ្រង់បានតំណាងឲ្យផ្នែកមួយរបស់ព្រះជាម្ចាស់។ ទ្រង់មិនអាចតំណាងឲ្យអ្វីគ្រប់យ៉ាងដែលមកពីព្រះជាម្ចាស់ឡើយ ប៉ុន្តែផ្ទុយទៅវិញ ទ្រង់បានតំណាងឲ្យព្រះជាម្ចាស់នៅក្នុងការធ្វើផ្នែកមួយនៃកិច្ចការរបស់ព្រះជាម្ចាស់។ នេះគឺដោយសារតែព្រះជាម្ចាស់ធំមហិមា និងសែនអស្ចារ្យ ហើយទ្រង់មិនអាចវាស់ស្ទង់បាន និងដោយសារតែព្រះជាម្ចាស់គ្រាន់តែធ្វើផ្នែកមួយនៃកិច្ចការរបស់ទ្រង់នៅក្នុងគ្រប់យុគសម័យ។ គោលបំណងចម្បងនៃកិច្ចការដែលព្រះជាម្ចាស់ធ្វើនៅជំនាន់នេះគឺ ដើម្បីផ្គត់ផ្គង់ព្រះបន្ទូលសម្រាប់ជីវិតរបស់មនុស្ស ដើម្បីលាតត្រដាងនូវធម្មជាតិ និងសារជាតិរបស់មនុស្ស ហើយនិងនិស្ស័យដ៏ពុករលួយរបស់គេ និងការផាត់ចោលសញ្ញាណសាសនា គំនិតសក្តិភូមិ និងគំនិតចាស់គំរឹល ចំណេះដឹង និងវប្បធម៌របស់មនុស្ស ដែលត្រូវតែលាងជម្រះឲ្យស្អាត តាមរយៈការនៅជាប់ជាមួយព្រះបន្ទូលរបស់ព្រះជាម្ចាស់។ នៅគ្រាចុងក្រោយ ព្រះជាម្ចាស់ប្រើប្រាស់ព្រះបន្ទូល មិនមែនទីសម្គាល់ និងឫទ្ធិបារមីឡើយ ដើម្បីប្រោស

មនុស្សឲ្យបានគ្រប់លក្ខណ៍។ ទ្រង់ប្រើព្រះបន្ទូលរបស់ទ្រង់ ដើម្បីលាតត្រដាងមនុស្ស ជំនុំជម្រះមនុស្ស កាត់ទោសមនុស្ស និងធ្វើឲ្យមនុស្សគ្រប់បានលក្ខណ៍ ដូច្នេះ នៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ មនុស្សចាប់ផ្ដើមមើលឃើញពីព្រះប្រាជ្ញាញាណ និងភាពគួរឲ្យស្រឡាញ់របស់ព្រះជាម្ចាស់ និងចាប់ផ្ដើមយល់ដឹងពីនិស្ស័យរបស់ព្រះជាម្ចាស់ ហើយតាមរយៈព្រះបន្ទូលរបស់ព្រះជាម្ចាស់ មនុស្សមើលឃើញពីទង្វើរបស់ទ្រង់។ នៅក្នុងអំឡុងយុគសម័យនៃក្រឹត្យវិន័យ ព្រះយេហូវ៉ាបានដឹកនាំម៉ូសេចេញពីស្រុកអេស៊ីព្ទ ជាមួយព្រះបន្ទូលរបស់ទ្រង់ ហើយមានបន្ទូលមួយចំនួនទៅកាន់សាសន៍អ៊ីស្រាអែល។ នាពេលនោះ ផ្នែកខ្លះនៃទង្វើរបស់ព្រះជាម្ចាស់ ត្រូវបានសម្ដែងឲ្យឃើញច្បាស់ ប៉ុន្តែដោយសារតែគុណសម្បត្តិរបស់មនុស្សនៅមានកម្រិត ហើយគ្មានអ្វីមួយអាចធ្វើឲ្យចំណេះដឹងរបស់គេបានពេញខ្នាត ដូច្នេះ ព្រះជាម្ចាស់នៅតែបន្តមានបន្ទូល និងបន្តធ្វើការ។ នៅក្នុងយុគសម័យនៃព្រះគុណ មនុស្សបានឃើញផ្នែកខ្លះនៃទង្វើរបស់ព្រះជាម្ចាស់ជាថ្មីម្ដងទៀត។ ព្រះយេស៊ូវអាចបង្ហាញទីសម្គាល់ និងឫទ្ធិបារមី ប្រោសអ្នកជំងឺឲ្យជា និងបណ្ដេញអារក្ស និងជាប់ឆ្កាង បីថ្ងៃក្រោយមកទ្រង់បានមានព្រះជន្មរស់ឡើងវិញ ហើយបានបង្ហាញអង្គទ្រង់ឲ្យមនុស្សមើលឃើញនៅក្នុងសណ្ឋានជាសាច់ឈាម។ មនុស្សគ្មានចំណេះដឹងអ្វីក្រៅពីនេះឡើយ អំពីព្រះជាម្ចាស់។ មនុស្សដឹងតែអ្វីដែលព្រះជាម្ចាស់បង្ហាញឲ្យគេឃើញប៉ុណ្ណោះ ហើយប្រសិនបើព្រះជាម្ចាស់មិនបង្ហាញអ្វីផ្សេងទៅកាន់មនុស្សទេ នោះមនុស្សមានចំណេះដឹងតែប៉ុណ្ណឹងអំពីព្រះជាម្ចាស់។ ដូច្នេះ ព្រះជាម្ចាស់បន្តធ្វើការ ដើម្បីឲ្យចំណេះដឹងរបស់មនុស្សស្ដីពីទ្រង់មានកាន់តែស៊ីជម្រៅ និងដើម្បីឲ្យមនុស្សអាចស្គាល់បន្តិចម្ដងៗ អំពីសារជាតិរបស់ព្រះជាម្ចាស់។ នៅគ្រាចុងក្រោយ ព្រះជាម្ចាស់ប្រើព្រះបន្ទូលរបស់ទ្រង់ ដើម្បីធ្វើឲ្យមនុស្សក្លាយជាគ្រប់លក្ខណ៍។ និស្ស័យដ៏ពុករលួយរបស់អ្នកត្រូវបានលាតត្រដាងចេញ ដោយព្រះបន្ទូលរបស់ព្រះ ហើយសញ្ញាណខាងសាសនារបស់អ្នក ក៏ត្រូវបានជំនួសដោយការពិតរបស់ព្រះជាម្ចាស់ដែរ។ ព្រះដែលយកកំណើតជាមនុស្សនៅគ្រាចុងក្រោយបានយាងមកក្នុងគោលបំណងចម្បង ដើម្បីសម្រេចតាម

ព្រះបន្ទូលដែលថែងថា «ព្រះបន្ទូលក្លាយជាសាច់ឈាម ព្រះបន្ទូលយាងមកនៅក្នុងសាច់ឈាម ហើយព្រះបន្ទូលលេចចេញមកនៅក្នុងសាច់ឈាម»។ ហើយប្រសិនបើអ្នកមិនមានចំណេះដឹងយ៉ាងហ្មត់ចត់អំពីការនេះទេ នោះអ្នកនឹងមិនអាចឈររឹងមាំបានឡើយ។ ក្នុងអំឡុងនៃគ្រាចុងក្រោយ ព្រះជាម្ចាស់មានគោលបំណងជាចម្បង ដើម្បីសម្រេចដំណាក់កាលនៃកិច្ចការនៅក្នុងព្រះបន្ទូលលេចចេញមកក្នុងសាច់ឈាម ហើយនេះជាផ្នែកមួយ នៃផែនការគ្រប់គ្រងរបស់ព្រះជាម្ចាស់។ ដូច្នេះ អ្នករាល់គ្នាត្រូវតែមានចំណេះដឹងឲ្យបានច្បាស់លាស់។ មិនថាព្រះជាម្ចាស់ធ្វើការតាមរបៀបណាទេ ព្រះជាម្ចាស់ មិនអនុញ្ញាតឲ្យមនុស្សមកដាក់កម្រិតលើទ្រង់នោះឡើយ។ ប្រសិនបើព្រះជាម្ចាស់មិនបានធ្វើកិច្ចការនេះ ក្នុងអំឡុងពេលនៃគ្រាចុងក្រោយទេ នោះចំណេះដឹងរបស់មនុស្សអំពីទ្រង់មិនអាចទៅណាបានឆ្ងាយឡើយ។ អ្នកនឹងគ្រាន់តែដឹងថា ព្រះជាម្ចាស់អាចជាប់ឆ្កាង និងដឹងថា ព្រះជាម្ចាស់អាចបំផ្លាញក្រុងសូដុម និងដឹងទៀតថា ព្រះយេស៊ូវអាចមានព្រះជន្មរស់ពីសុគតឡើងវិញ ហើយបង្ហាញអង្គទ្រង់ឲ្យពេត្រុសបានឃើញប៉ុណ្ណោះ...។ ប៉ុន្តែ អ្នកនឹងមិនដែលនិយាយថា ព្រះបន្ទូលរបស់ព្រះជាម្ចាស់អាចសម្រេចការទាំងអស់ និងអាចយកឈ្នះមនុស្សនោះឡើយ។ មានតែតាមរយៈការដកពិសោធន៍ព្រះបន្ទូលរបស់ព្រះជាម្ចាស់ប៉ុណ្ណោះ ទើបអ្នកអាចនិយាយចេញនូវចំណេះដឹងបែបនេះ ហើយបើអ្នកដកពិសោធន៍អំពីកិច្ចការរបស់ព្រះបានកាន់តែច្រើន នោះអ្នកនឹងមានចំណេះដឹងអំពីទ្រង់កាន់តែហ្មត់ចត់។ មានតែបែបនេះទេ ទើបអ្នកនឹងឈប់ដាក់កម្រិតលើព្រះជាម្ចាស់ ចេញពីសញ្ញាណរបស់អ្នកផ្ទាល់។ មនុស្សស្គាល់ព្រះជាម្ចាស់ តាមរយៈការដកពិសោធន៍នូវកិច្ចការរបស់ទ្រង់ ហើយវាគ្មានផ្លូវណាផ្សេងដែលត្រឹមត្រូវក្នុងការស្គាល់ព្រះជាម្ចាស់ឡើយ។ បច្ចុប្បន្ននេះ មានមនុស្សជាច្រើនដែលមិនធ្វើអ្វីសោះ ក្រៅពីអង្គុយរង់ចាំមើលទីសម្គាល់ និងឫទ្ធិបារមី និងពេលនៃគ្រោះមហន្តរាយដ៏ធំមកដល់ប៉ុណ្ណោះ។ តើអ្នកជឿលើព្រះជាម្ចាស់ ឬក៏អ្នកជឿលើគ្រោះមហន្តរាយដ៏ធំ? នៅពេលដែលគ្រោះមហន្តរាយដ៏ធំមកដល់ នោះវានឹងយឺតពេលហើយ ហើយប្រសិនបើព្រះជាម្ចាស់មិនបញ្ជូនគ្រោះមហន្តរាយដ៏ធំចុះ

មកទេ តើទ្រង់មិនមែនជាព្រះជាម្ចាស់ទេឬអី? តើអ្នកជឿលើទីសម្គាល់ និងឫទ្ធិបារមី ឬក៏អ្នកជឿលើព្រះជាម្ចាស់ផ្ទាល់? ព្រះយេស៊ូវមិនបានសម្ដែងទីសម្គាល់ និងឫទ្ធិបារមី នៅពេលដែលមនុស្សសើចចំអកដាក់ទ្រង់ឡើយ ប៉ុន្តែតើទ្រង់មិនមែនជាព្រះជាម្ចាស់ទេឬអី? តើអ្នកជឿលើទីសម្គាល់ និងឫទ្ធិបារមី ឬក៏ជឿលើសារជាតិរបស់ព្រះជាម្ចាស់ឬទេ? ទស្សនៈរបស់មនុស្សអំពីជំនឿលើព្រះជាម្ចាស់ គឺខុសហើយ! ព្រះយេហូវ៉ាបានមានបន្ទូលជាច្រើន ក្នុងអំឡុងយុគសម័យនៃក្រឹត្យវិន័យ ប៉ុន្តែសូម្បីតែសព្វថ្ងៃនេះ ព្រះបន្ទូលមួយចំនួននៅមិនទាន់បានសម្រេចនៅឡើយទេ។ តើអ្នកអាចនិយាយថា ព្រះយេហូវ៉ាមិនមែនជាព្រះជាម្ចាស់ទេឬអី?

ថ្ងៃនេះ អ្នករាល់គ្នាគួរតែយល់ច្បាស់ហើយថា នៅគ្រាចុងក្រោយ វាជាការពិតដែល «ព្រះបន្ទូលក្លាយជាសាច់ឈាម» គឺត្រូវបានសម្រេចដោយព្រះជាម្ចាស់។ តាមរយៈកិច្ចការដ៏ពិតរបស់ទ្រង់នៅលើផែនដី ទ្រង់ធ្វើឲ្យមនុស្សស្គាល់ទ្រង់ មានទំនាក់ទំនងជាមួយទ្រង់ និងមើលឃើញពីទង្វើដ៏ពិតរបស់ទ្រង់។ ទ្រង់ធ្វើឲ្យមនុស្សមើលឃើញយ៉ាងច្បាស់ថា ទ្រង់អាចសម្ដែងទីសម្គាល់ នងឫទ្ធិបារមី និងឃើញថា វាក៏មានពេលដែលទ្រង់មិនអាចធ្វើបែបនេះផងដែរ ហើយវាអាស្រ័យទៅលើយុគសម័យប៉ុណ្ណោះ។ សម្រាប់សេចក្ដីនេះ អ្នកអាចមើលឃើញថា ព្រះជាម្ចាស់មិនមែនគ្មានសមត្ថភាពក្នុងការសម្ដែងទីសម្គាល់ និងឫទ្ធិបារមីឡើយ ប៉ុន្តែផ្ទុយទៅវិញ ទ្រង់ផ្លាស់ប្ដូររបៀបនៃការធ្វើការរបស់ទ្រង់ឲ្យស្របតាមកិច្ចការដែលត្រូវសម្រេច និងស្របតាមសម័យកាលវិញទេ។ នៅក្នុងដំណាក់កាលបច្ចុប្បន្ននៃកិច្ចការ ទ្រង់មិនបង្ហាញទីសម្គាល់ និងឫទ្ធិបារមីឡើយ ហើយការដែលទ្រង់បានបង្ហាញទីសម្គាល់ និងឫទ្ធិបារមីខ្លះនៅក្នុងយុគសម័យរបស់ព្រះយេស៊ូវ គឺដោយសារតែកិច្ចការរបស់ទ្រង់នៅក្នុងយុគសម័យនោះ ខុសប្លែកពីសម័យនេះ។ ព្រះជាម្ចាស់ មិនធ្វើកិច្ចការនោះនៅពេលបច្ចុប្បន្នឡើយ ហើយមនុស្សខ្លះជឿថា ទ្រង់គ្មានសមត្ថភាពសម្ដែងទីសម្គាល់ និងឫទ្ធិបារមី ឬមួយពួកគេគិតថា ប្រសិនបើទ្រង់មិនសម្ដែងទីសម្គាល់ និងឫទ្ធិបារមីទេ ដូច្នេះ ទ្រង់មិនមែនជាព្រះជាម្ចាស់ឡើយ។ តើនេះមិនមែនជាជំនឿខុសឆ្គងទេឬអី? ព្រះជាម្ចាស់អាចសម្ដែង

ទីសម្គាល់ និងឫទ្ធិបារមីបាន ប៉ុន្តែទ្រង់កំពុងតែធ្វើការនៅក្នុងយុគសម័យមួយផ្សេង ដូច្នេះហើយបានជាទ្រង់មិនធ្វើកិច្ចការបែបនោះ។ ដោយសារតែនេះជាយុគសម័យមួយផ្សេង ហើយដោយសារតែនេះជាដំណាក់កាលផ្សេងនៃកិច្ចការរបស់ព្រះជាម្ចាស់ ដូច្នេះ ទង្វើដែលព្រះជាម្ចាស់ធ្វើក៏មានលក្ខណៈខុសគ្នាផងដែរ។ ជំនឿរបស់មនុស្សទៅលើព្រះជាម្ចាស់ មិនមែនជាជំនឿលើទីសម្គាល់ និងឫទ្ធិបារមី ក៏មិនមែនជាជំនឿលើការអស្ចារ្យដែរ ប៉ុន្តែជាជំនឿលើកិច្ចការដ៏ពិតរបស់ទ្រង់ នៅក្នុងអំឡុងយុគសម័យថ្មី។ មនុស្សចាប់ផ្ដើមស្គាល់ព្រះជាម្ចាស់ តាមរយៈឥរិយាបថដែលព្រះជាម្ចាស់ធ្វើការ ហើយចំណេះដឹងនេះបង្កើតមនុស្សឲ្យមានជំនឿលើព្រះជាម្ចាស់ ដែលអាចនិយាយបានថា ជាជំនឿលើកិច្ចការ និងទង្វើរបស់ព្រះជាម្ចាស់។ នៅក្នុងដំណាក់កាលនៃកិច្ចការនេះ ព្រះជាម្ចាស់មានបន្ទូលជាចម្បង។ កុំរង់ចាំចង់ឃើញទីសម្គាល់ និងឫទ្ធិបារមីនោះឡើយ ព្រោះថាអ្នកនឹងមើលលែងឃើញទៀតហើយ! នេះគឺដោយសារតែអ្នកមិនបានកើតមក ក្នុងអំឡុងយុគសម័យនៃព្រះគុណឡើយ។ ប្រសិនបើអ្នកបានកើតមកក្នុងគ្រានោះ នោះអ្នកអាចមើលឃើញទីសម្គាល់ និងឫទ្ធិបារមី ប៉ុន្តែអ្នកបានកើតមកក្នុងគ្រាចុងក្រោយ ដូច្នេះ អ្នកអាចមើលឃើញតែការពិត និងភាពសាមញ្ញរបស់ព្រះជាម្ចាស់ប៉ុណ្ណោះ។ កុំរំពឹងចង់ឃើញព្រះយេស៊ូវដែលពេញដោយអធិធម្មជាតិនៅក្នុងអំឡុងគ្រាចុងក្រោយនោះឡើយ។ អ្នកអាចមើលឃើញតែព្រះដ៏សកម្មដែលយកកំណើតជាមនុស្ស ដែលគ្មានលក្ខណៈអ្វីខុសប្លែកពីមនុស្សសាមញ្ញនោះឡើយ។ នៅក្នុងសម័យដំណាក់កាលនីមួយៗ ព្រះជាម្ចាស់ទ្រង់ធ្វើឲ្យឃើញជាក់ច្បាស់អំពីទង្វើខុសៗគ្នា។ នៅក្នុងសម័យដំណាក់កាលនីមួយៗ ទ្រង់ធ្វើឲ្យឃើញច្បាស់អំពីផ្នែកនៃទង្វើរបស់ព្រះជាម្ចាស់ ហើយកិច្ចការនៃយុគសម័យនីមួយៗតំណាងឲ្យផ្នែកមួយនៃនិស្ស័យរបស់ព្រះជាម្ចាស់ និងផ្នែកមួយនៃទង្វើរបស់ព្រះជាម្ចាស់។ ទង្វើដែលទ្រង់ធ្វើឲ្យឃើញច្បាស់ មានលក្ខណៈខុសគ្នាទៅតាមយុគសម័យដែលទ្រង់ធ្វើការ ប៉ុន្តែវាផ្ដល់ឲ្យមនុស្សនូវចំណេះដឹងកាន់តែស៊ីជម្រៅអំពីព្រះជាម្ចាស់ មានជំនឿលើព្រះកាន់តែពិតប្រាកដ និងកាន់តែជាក់ច្បាស់។ មនុស្សជឿលើព្រះជាម្ចាស់ ដោយសារតែ

គ្រប់ទង្វើរបស់ព្រះជាម្ចាស់ ដោយសារទ្រង់ជាព្រះដ៏សែនអស្ចារ្យ ធំមហិមា ពេញដោយព្រះចេស្ដា និងមិនអាចវាស់ស្ទង់បាន។ ប្រសិនបើអ្នកជឿលើព្រះជាម្ចាស់ ដោយសារតែទ្រង់អាចធ្វើទីសម្គាល់ និងឫទ្ធិបារមី និងអាចប្រោសអ្នកជំងឺឲ្យជា និងបណ្ដេញអារក្ស នោះទស្សនៈរបស់អ្នកគឺខុសហើយ ហើយមនុស្សខ្លះនឹងនិយាយទៅកាន់អ្នកថា «តើពួកវិញ្ញាណអាក្រក់មិនចេះធ្វើរឿងទាំងនេះដែរទេឬអី?» តើនេះមិនមែនជាធាតុផ្សំដែលធ្វើឲ្យរូបអង្គនៃព្រះជាម្ចាស់ ច្រឡំជាមួយរូបភាពរបស់សាតាំងទេឬអី? សព្វថ្ងៃនេះ ជំនឿរបស់មនុស្សលើព្រះជាម្ចាស់ គឺដោយសារតែទង្វើជាច្រើនរបស់ទ្រង់ និងចំនួនដ៏ច្រើនសន្ធឹកសន្ធាប់នៃកិច្ចការដែលទ្រង់ធ្វើ និងរបៀបជាច្រើនដែលទ្រង់មានបន្ទូល។ ព្រះជាម្ចាស់ប្រើព្រះសូរសៀងរបស់ទ្រង់ ដើម្បីយកឈ្នះមនុស្ស និងធ្វើឲ្យមនុស្សក្លាយជាគ្រប់លក្ខណ៍។ មនុស្សជឿលើព្រះជាម្ចាស់ ដោយសារតែទង្វើជាច្រើនរបស់ទ្រង់ មិនមែនដោយសារតែទ្រង់អាចបង្ហាញទីសម្គាល់ និងឫទ្ធិបារមីនោះឡើយ ដូច្នេះ មនុស្សអាចស្គាល់ព្រះជាម្ចាស់បាន មានតែតាមរយៈការធ្វើបន្ទាល់ពីទង្វើរបស់ទ្រង់ប៉ុណ្ណោះ។ មានតែតាមរយៈការដឹងអំពីទង្វើដ៏ពិតរបស់ព្រះជាម្ចាស់ របៀបដែលទ្រង់ធ្វើការ វិធីសាស្រ្តដែលប្រកបដោយព្រះបញ្ញាញាណដែលទ្រង់ប្រើ របៀបដែលទ្រង់មានបន្ទូល និងរបៀបដែលទ្រង់ធ្វើឲ្យមនុស្សក្លាយជាគ្រប់លក្ខណ៍ គឺមានតែដឹងអំពីទិដ្ឋភាពទាំងនេះប៉ុណ្ណោះ ទើបអ្នកអាចយល់អំពីការពិតរបស់ព្រះជាម្ចាស់ និងយល់អំពីនិស្ស័យរបស់ទ្រង់ ដឹងនូវអ្វីដែលទ្រង់ចូលចិត្ត អ្វីដែលទ្រង់ស្អប់ និងរបៀបដែលទ្រង់ធ្វើការទៅលើមនុស្ស។ តាមរយៈការយល់ដឹងអំពីអ្វីដែលព្រះជាម្ចាស់សព្វព្រះហឫទ័យ និងមិនសព្វព្រះហឫទ័យ អ្នកអាចធ្វើការវែកញែករវាងអ្វីដែលវិជ្ជមាន និងអ្វីដែលអវិជ្ជមាន ហើយតាមរយៈចំណេះដឹងរបស់អ្នកអំពីព្រះជាម្ចាស់ នោះជីវិតរបស់អ្នកនឹងមានវឌ្ឍនភាពជាមិនខាន។ សរុបមក អ្នកត្រូវតែទទួលបានចំណេះដឹងអំពីកិច្ចការរបស់ព្រះជាម្ចាស់ ហើយអ្នកត្រូវតែកែតម្រូវទស្សនៈរបស់អ្នក អំពីការជឿលើព្រះជាម្ចាស់។

# តើកិច្ចការរបស់ព្រះជាម្ចាស់ សាមញ្ញដូចមនុស្សគិតដែរឬទេ?

ក្នុងនាមជាអ្នកជឿលើព្រះជាម្ចាស់ ម្នាក់ៗក្នុងចំណោមអ្នករាល់គ្នា គួរតែលើកសរសើរ អំពីរបៀបដែលអ្នករាល់គ្នាបានទទួលការលើកតម្កើង និងការសង្គ្រោះដ៏អស្ចារ្យបំផុត តាមរយៈការទទួលយកកិច្ចការរបស់ព្រះជាម្ចាស់នៅគ្រាចុងក្រោយ និងកិច្ចការនៃផែនការដែលទ្រង់ធ្វើនៅក្នុងអ្នក នាពេលសព្វថ្ងៃនេះ។ ព្រះជាម្ចាស់បានធ្វើឱ្យមនុស្សមួយក្រុមនេះ ផ្ដោតតែទៅលើកិច្ចការរបស់ទ្រង់នៅទូទាំងសាកលលោក។ ទ្រង់បានលះបង់ព្រះលោហិតទាំងអស់ នៃដួងព្រះហឫទ័យរបស់ទ្រង់សម្រាប់អ្នករាល់គ្នា ហើយទ្រង់បានទាមទារមកវិញ និងបានប្រទានកិច្ចការរបស់ព្រះវិញ្ញាណដល់អ្នករាល់គ្នា នៅទូទាំងសាកលលោក។ ដូច្នេះហើយ អ្នករាល់គ្នាគឺជាមនុស្សដែលមានសំណាង។ លើសពីនេះទៅទៀត ទ្រង់បានបង្វែរសិរីល្អរបស់ទ្រង់ពីអ៊ីស្រាអែល ដែលជារាស្ត្ររើសតាំងរបស់ទ្រង់ ទៅឱ្យអ្នករាល់គ្នា ហើយទ្រង់នឹងធ្វើឱ្យគោលបំណងនៃផែនការរបស់ទ្រង់ ស្ដែងចេញឱ្យឃើញយ៉ាងជាក់ច្បាស់តាមរយៈមនុស្សមួយក្រុមនេះ។ ដូច្នេះ អ្នករាល់គ្នាជាមនុស្សដែលនឹងទទួលបានមរតករបស់ព្រះជាម្ចាស់ ហើយលើសពីនេះទៅទៀត អ្នកគឺជាទាយាទនៃសិរីល្អរបស់ព្រះជាម្ចាស់។ ប្រហែលជាអ្នករាល់គ្នានឹកចាំអំពីពាក្យទាំងអស់នេះហើយថា៖ «ដ្បិតទុក្ខលំបាកដ៏ស្រាលរបស់យើង គឺតែមួយភ្លែតទេ តែវានឹងធ្វើឲ្យយើងមានសិរីរុងរឿងយ៉ាងច្រើនលើសលុប អស់កល្បជានិច្ច។» អ្នករាល់គ្នាធ្លាប់ស្ដាប់ឮពាក្យទាំងអស់នេះពីមុនមកហើយ ប៉ុន្តែក្នុងចំណោមអ្នករាល់គ្នា គ្មាននរណាម្នាក់យល់ពីអត្ថន័យពិតប្រាកដនៃពាក្យទាំងនេះទេ។ ថ្ងៃនេះ អ្នករាល់គ្នាដឹងយ៉ាងច្បាស់អំពីសារៈសំខាន់ពិតប្រាកដនៃពាក្យទាំងនេះហើយ។ ពាក្យទាំងនេះ នឹងបានសម្រេចដោយព្រះជាម្ចាស់នៅគ្រាចុងក្រោយ ហើយវានឹងបានសម្រេចនៅក្នុងអស់អ្នកដែលទទួលរងការបៀតបៀនយ៉ាងឃោរឃៅពីសំណាក់នាគដ៏ធំមានសម្បុរក្រហមនៅក្នុងទឹកដីដែលវាបានរុំព័ទ្ធ

ជុំជិត។ នាគដ៏ធំមានសម្បុរក្រហមនេះ បៀតបៀនព្រះជាម្ចាស់ និងជាខ្មាំងសត្រូវរបស់ព្រះជាម្ចាស់ ដូច្នេះហើយបានជានៅក្នុងទឹកដីនេះ អ្នកណាដែលជឿលើព្រះជាម្ចាស់ត្រូវរងការអាម៉ាស់ និងការជិះជាន់ ហើយជាលទ្ធផល ពាក្យទាំងនេះនឹងសម្រេចនៅក្នុងអ្នករាល់គ្នាដែលជាមនុស្សមួយក្រុមនេះ។ កិច្ចការទាំងអស់របស់ព្រះជាម្ចាស់ ត្រូវជួបឧបសគ្គធំៗជាច្រើន ហើយការសម្រេចកិច្ចការជាច្រើនតាមព្រះបន្ទូលរបស់ទ្រង់ ក៏ត្រូវចំណាយពេលវេលាយ៉ាងយូរ ដោយសារតែកិច្ចការនេះបានចាប់ផ្ដើមនៅក្នុងទឹកដីមួយដែលប្រឆាំងនឹងព្រះជាម្ចាស់។ ដូច្នេះ មនុស្សត្រូវបានបន្សុទ្ធដោយសារផលនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលជាផ្នែកមួយនៃការរងទុក្ខផងដែរ។ វាពិតជាពិបាកខ្លាំងណាស់សម្រាប់ព្រះជាម្ចាស់ ក្នុងការបំពេញកិច្ចការរបស់ទ្រង់នៅក្នុងទឹកដីរបស់នាគដ៏ធំមានសម្បុរក្រហម ប៉ុន្តែគឺតាមរយៈការលំបាកនេះហើយ ដែលព្រះជាម្ចាស់សម្រេចកិច្ចការរបស់ទ្រង់បានមួយដំណាក់កាល ដោយបង្ហាញឱ្យឃើញច្បាស់នូវព្រះប្រាជ្ញាញាណ និងស្នាព្រះហស្តដ៏អស្ចារ្យរបស់ទ្រង់ ព្រមទាំងប្រើប្រាស់ឱកាសនេះ ដើម្បីធ្វើឱ្យមនុស្សមួយក្រុមនេះបានពេញលេញ។ គឺតាមរយៈការរងទុក្ខរបស់មនុស្ស តាមរយៈគុណសម្បត្តិរបស់ពួកគេ និងតាមរយៈនិស្ស័យជាសាតាំងរបស់មនុស្សនៅក្នុងទឹកដីដ៏គួរឱ្យស្អប់ខ្ពើមនេះហើយ ដែលព្រះជាម្ចាស់ធ្វើកិច្ចការបន្សុទ្ធ និងការយកឈ្នះរបស់ទ្រង់ ប្រយោជន៍ឱ្យទ្រង់បានទទួលសិរីល្អតាមរយៈកិច្ចការនេះ និងដើម្បីឱ្យទ្រង់អាចទទួលបានអស់អ្នកដែលនឹងធ្វើបន្ទាល់ពីស្នាព្រះហស្តរបស់ទ្រង់។ នេះគឺជាចំណុចសំខាន់ទាំងស្រុងនៃការលះបង់ទាំងអស់ដែលព្រះជាម្ចាស់បានធ្វើសម្រាប់មនុស្សមួយក្រុមនេះ។ ពោលគឺតាមរយៈ អ្នកដែលប្រឆាំងនឹងទ្រង់ទាំងអស់នោះហើយ ដែលព្រះជាម្ចាស់ធ្វើការយកឈ្នះ ហើយមានតែតាមរយៈការនេះប៉ុណ្ណោះ ដែលអំណាចចេស្ដាដ៏អស្ចារ្យរបស់ព្រះជាម្ចាស់បានបង្ហាញឱ្យឃើញច្បាស់។ អាចនិយាយម្យ៉ាងទៀតបានថា មានតែអស់អ្នកដែលនៅក្នុងទឹកដីដ៏ស្មោកគ្រោកនេះប៉ុណ្ណោះ ដែលសមនឹងទទួលបានសិរីល្អរបស់ព្រះជាម្ចាស់ទុកជាមរតក ហើយមានតែការនេះប៉ុណ្ណោះ ដែលអាចរំលេចឱ្យឃើញនូវអំណាចចេស្ដាដ៏អស្ចារ្យរបស់

ព្រះជាម្ចាស់។ ហេតុដូច្នេះហើយ បានជាតាមរយៈទឹកដីដ៏កខ្វក់ និងតាមរយៈអស់អ្នកដែលរស់នៅក្នុងទឹកដីដ៏កខ្វក់នេះហើយ ដែលព្រះជាម្ចាស់បានទទួលសិរីល្អ។ នេះហើយជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ដំណាក់កាលនៃកិច្ចការរបស់ព្រះយេស៊ូវ ក៏ដូចគ្នាដែរ៖ ទ្រង់អាចត្រឹមតែទទួលបានសិរីល្អ តែពីក្នុងចំណោមពួកផារិស៊ីដែលបានបៀតបៀនទ្រង់ប៉ុណ្ណោះ។ ប្រសិនបើមិនមែនដោយសារការបៀតបៀនរបស់ពួកផារិស៊ី និងការក្បត់របស់យូដាសទេ ម៉្លេះព្រះយេស៊ូវនឹងមិនត្រូវគេចំអក ឬក៏ និយាយបង្ខូចបង្កាច់ ក៏រឹតតែមិនត្រូវគេឆ្កាង និងមិនអាចទទួលបានសិរីល្អដែរ។ កន្លែងណាដែលព្រះជាម្ចាស់ធ្វើការក្នុងសម័យកាលនីមួយៗ និងកន្លែងណាដែលទ្រង់ធ្វើកិច្ចការរបស់ទ្រង់ខាងសាច់ឈាម គឺជាកន្លែងដែលទ្រង់ទទួលបានសិរីល្អ និងជាកន្លែងដែលទ្រង់ទទួលបានអស់អ្នកដែលទ្រង់សព្វព្រះហឫទ័យចង់ទទួល។ នេះហើយជាផែនការនៃកិច្ចការរបស់ព្រះជាម្ចាស់ និងជាការគ្រប់គ្រងរបស់ទ្រង់។

នៅក្នុងផែនការរាប់ពាន់ឆ្នាំរបស់ព្រះជាម្ចាស់ មានកិច្ចការពីរផ្នែកដែលបានសម្រេចតាមរយៈសាច់ឈាម៖ ទីមួយ គឺកិច្ចការជាប់ឆ្កាង ដែលទ្រង់បានទទួលសិរីល្អ ហើយមួយទៀតគឺកិច្ចការនៃការយកឈ្នះ និងភាពគ្រប់លក្ខណ៍នៅគ្រាចុងក្រោយ ដែលទ្រង់ទទួលសិរីល្អ។ នេះហើយជាការគ្រប់គ្រងរបស់ព្រះជាម្ចាស់។ ដូច្នេះ ចូរកុំចាត់ទុកថាកិច្ចការរបស់ព្រះជាម្ចាស់ ឬក៏បញ្ញាបេសកកម្មរបស់ព្រះជាម្ចាស់សម្រាប់អ្នករាល់គ្នាគឺជារឿងធម្មតានោះឡើយ។ អ្នករាល់គ្នា គឺជាទាយាទដែលត្រូវទទួលបានសិរីល្អដ៏លើសលប់ និងជាសិរីល្អដ៏នៅអស់កល្បជានិច្ចរបស់ព្រះជាម្ចាស់ ហើយឋានៈត្រូវបានតែងតាំងជាពិសេសដោយព្រះជាម្ចាស់។ ក្នុងចំណោមផ្នែកទាំងពីរនៃសិរីល្អរបស់ទ្រង់ គឺទីមួយបានបង្ហាញឱ្យឃើញយ៉ាងច្បាស់នៅក្នុងអ្នករាល់គ្នា ហើយភាពពេញលេញនៃផ្នែកទីមួយនៃសិរីល្អរបស់ព្រះជាម្ចាស់នេះ បានប្រទានមកអ្នករាល់គ្នាទុកជាមរតក។ នេះជាការលើកតម្កើងរបស់ព្រះជាម្ចាស់ចំពោះអ្នក ហើយវាក៏ជាផែនការដែលទ្រង់បានកំណត់ទុកជាយូរមកហើយដែរ។ តាមភាពអស្ចារ្យនៃកិច្ចការដែលព្រះជាម្ចាស់បានធ្វើនៅក្នុងទឹកដីដែលនាគដ៏ធំមានសម្បុរក្រហមរស់នៅ គឺច្បាស់ជាបានទទួល

ផ្លែផ្កាជាយូរមកហើយ ហើយមនុស្សក៏បានត្រៀមជាស្រេចដើម្បីនឹងទទួលយកដែរ ប្រសិនបើកិច្ចការនេះ ត្រូវបានផ្លាស់ទៅធ្វើនៅកន្លែងផ្សេង។ លើសពីនេះទៅទៀត កិច្ចការនេះនឹងកាន់តែងាយទទួលយកសម្រាប់បុព្វជិតទាំងអស់នៅភាគខាងលិច ដែលជឿលើព្រះជាម្ចាស់ ព្រោះដំណាក់កាលនៃកិច្ចការរបស់ព្រះយេស៊ូវ ដើរតួជាគំរូមួយ។ នេះហើយជាមូលហេតុដែលព្រះជាម្ចាស់មិនអាចសម្រេចបាននូវដំណាក់កាលនៃការទទួលសិរីល្អនៅកន្លែងផ្សេងទៀត ដ្បិតសិរីល្អរបស់ព្រះជាម្ចាស់មិនអាចនៅទ្រឹងនៅពេលកិច្ចការនេះមានការគាំទ្រពីមនុស្ស និងត្រូវបានទទួលស្គាល់ពីជាតិសាសន៍នានានោះទេ។ ប្រាកដណាស់ នេះហើយជាចំណុចដ៏សំខាន់បំផុត ដែលធ្វើឱ្យកិច្ចការនៅដំណាក់កាលនេះ នៅទ្រឹងក្នុងទឹកដីនេះ។ ក្នុងចំណោមអ្នករាល់គ្នាគ្មាននរណាម្នាក់ដែលត្រូវបានការពារដោយសារក្រឹត្យវិន័យនោះទេ ផ្ទុយទៅវិញ អ្នកមានតែត្រូវដាក់ទោសចោទប្រកាន់ ដោយសារតែក្រឹត្យវិន័យ។ អ្វីដែលកាន់តែជាបញ្ហានោះគឺ មនុស្សមិនយល់ពីអ្នករាល់គ្នា៖ សូម្បីតែសាច់ញាតិ ឪពុកម្ដាយ មិត្តភក្តិ ឬក៏សហការីរបស់អ្នករាល់គ្នា ក៏គ្មាននរណាម្នាក់យល់ពីអ្នករាល់គ្នាដែរ។ នៅពេលដែលព្រះជាម្ចាស់ «បានបោះបង់» អ្នករាល់គ្នា នោះអ្នករាល់គ្នាមិនអាចបន្តរស់នៅលើផែនដីបានទៀតឡើយ ប៉ុន្តែទោះបីជាបែបនេះក៏ដោយ ក៏មនុស្សមិនអាចទ្រាំនៅឆ្ងាយពីព្រះជាម្ចាស់បានដែរ ដែលនេះហើយជាចំណុចសំខាន់នៃការយកឈ្នះរបស់ព្រះជាម្ចាស់លើមនុស្ស និងជាសិរីល្អរបស់ព្រះជាម្ចាស់។ អ្វីដែលអ្នករាល់គ្នាបានទទួលជាមរតកនៅថ្ងៃនេះ លើសពីអ្វីដែលពួកសាវ័ក និងពួកហោរានៅគ្រប់សម័យកាលបានទទួលទៅទៀត ហើយក៏អស្ចារ្យជាងអ្វីដែលម៉ូសេ និងពេត្រុសបានទទួលដែរ។ ព្រះពរមិនអាចទទួលបានក្នុងរយៈពេលតែមួយថ្ងៃ ឬក៏ពីរថ្ងៃនោះទេ គឺត្រូវតែទទួលតាមរយៈការលះបង់ដ៏ធំធេង។ អាចនិយាយបានថា អ្នករាល់គ្នាត្រូវតែមានសេចក្ដីស្រលាញ់មួយដែលបានឆ្លងកាត់ការបន្សុទ្ធ អ្នកត្រូវតែមានសេចក្ដីជំនឿយ៉ាងមាំ ហើយអ្នកត្រូវមានសេចក្ដីពិតជាច្រើន ដែលព្រះជាម្ចាស់តម្រូវឱ្យអ្នកមាន។ លើសពីនោះទៅទៀត អ្នកត្រូវតែបែរទៅរកសេចក្ដីយុត្តិធម៌ ដោយមិនត្រូវភ័យខ្លាច ឬក៏គេចវេស

ឡើយ ហើយអ្នកត្រូវតែមានសេចក្តីស្រលាញ់ចំពោះព្រះជាម្ចាស់ ដែលខ្ជាប់ខ្ជួនរហូតអស់ជីវិត។ អ្នកត្រូវតែមានការតាំងចិត្ត ហើយការផ្លាស់ប្តូរត្រូវតែកើតឡើងនៅក្នុងនិស្ស័យជីវិតរបស់អ្នករាល់គ្នា ភាពពុករលួយរបស់អ្នករាល់គ្នាត្រូវតែសះស្បើយ អ្នកត្រូវតែទទួលយកការរៀបចំទាំងអស់របស់ព្រះជាម្ចាស់ដោយគ្មានការត្អូញត្អែរ ហើយអ្នកត្រូវស្តាប់បង្គាប់ទ្រង់រហូតដល់ទីមរណា។ នេះហើយជាអ្វីដែលអ្នករាល់គ្នាត្រូវទទួល នេះហើយជាគោលដៅចុងក្រោយនៃកិច្ចការរបស់ព្រះជាម្ចាស់ និងជាអ្វីដែលព្រះជាម្ចាស់ទាមទារពីមនុស្សមួយក្រុមនេះ។ ដោយព្រោះទ្រង់ប្រទានដល់អ្នករាល់គ្នា នោះទ្រង់ប្រាកដជាទារសំណងពីអ្នករាល់គ្នាវិញ ហើយទ្រង់ប្រាកដជានឹងទាមទារនូវអ្វីដែលស័ក្តិសមពីអ្នករាល់គ្នាជាមិនខាន។ ដូច្នេះ កិច្ចការទាំងអស់ដែលព្រះជាម្ចាស់ធ្វើ សុទ្ធតែមានហេតុផល ដែលបង្ហាញឱ្យឃើញម្តងហើយម្តងទៀតថា ព្រះជាម្ចាស់ធ្វើកិច្ចការដែលមានបទដ្ឋានខ្ពង់ខ្ពស់ និងសេចក្តីតម្រូវតឹងតែង។ ដោយសារចំណុចនេះហើយ ទើបអ្នករាល់គ្នាគួរតែពេញដោយសេចក្តីជំនឿលើព្រះជាម្ចាស់។ សរុបមក កិច្ចការទាំងអស់របស់ព្រះជាម្ចាស់ សុទ្ធតែធ្វើឡើងសម្រាប់ជាប្រយោជន៍ដល់អ្នករាល់គ្នា ដើម្បីឱ្យអ្នករាល់គ្នាស័ក្តិសមនឹងទទួលមរតករបស់ទ្រង់។ កិច្ចការនេះមិនមែនសម្រាប់ជាប្រយោជន៍ដល់សិរីល្អផ្ទាល់របស់ព្រះជាម្ចាស់ទេ តែសម្រាប់ជាប្រយោជន៍ដល់សេចក្តីសង្គ្រោះរបស់អ្នករាល់គ្នា និងដើម្បីធ្វើឱ្យមនុស្សមួយក្រុមដែលបានរងទុក្ខវេទនាយ៉ាងខ្លាំងនៅក្នុងទឹកដីដ៏ស្មោកគ្រោកនេះ បានគ្រប់លក្ខណ៍វិញ។ អ្នករាល់គ្នាគួរតែយល់ពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ដូច្នេះហើយ ខ្ញុំសូមដាស់តឿនដល់មនុស្សល្ងង់ខ្លៅជាច្រើនដែលគ្មានការយល់ដឹង ឬគ្មានបញ្ញាញាណថា៖ ចូរកុំល្បងលព្រះជាម្ចាស់ឡើយ ហើយក៏កុំតតាំងតទៅទៀត។ ព្រះជាម្ចាស់បានឆ្លងកាត់ការរងទុក្ខវេទនា ដែលគ្មានមនុស្សណាម្នាក់អាចទ្រាំទ្របានឡើយ ហើយទ្រង់ក៏បានទ្រាំទ្រចំពោះការអាម៉ាស់យ៉ាងខ្លាំងជំនួសមនុស្សជាយូរមកហើយដែរ។ តើមានអ្វីទៀតទៅដែលអ្នកមិនអាចបោះបង់ចោលបាន? តើមានអ្វីទៀតទៅដែលសំខាន់ជាងបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់? តើអ្វីទៅដែលអាចឧត្តុង្គឧត្តម

ជាងសេចក្ដីស្រលាញ់របស់ព្រះជាម្ចាស់ទៀតនោះ? វាពិបាកណាស់ទៅហើយសម្រាប់ព្រះជាម្ចាស់ដែលត្រូវបំពេញកិច្ចការរបស់ទ្រង់នៅក្នុងទឹកដីដ៏ស្មោកគ្រោកនេះ។ បន្ថែមលើនេះទៀត មនុស្សបានបំពានទាំងដឹងច្បាស់ និងដោយចេតនា ដោយធ្វើឱ្យកិច្ចការរបស់ព្រះជាម្ចាស់ត្រូវអូសបន្លាយពេលវេលាជាយូរ។ សរុបមក នេះមិនមែនជាឧត្ដមប្រយោជន៍របស់អ្នកណាម្នាក់ឡើយ ក៏មិនផ្ដល់ផលប្រយោជន៍អ្វីដល់អ្នកណាដែរ។ ព្រះជាម្ចាស់មិនជាប់ក្នុងចំណងពេលវេលាទេ កិច្ចការ និងសិរីល្អរបស់ទ្រង់ គឺជាអាទិភាពចម្បង។ ដូច្នេះហើយ ដើម្បីសម្រេចកិច្ចការរបស់ទ្រង់ ទោះថ្លៃយ៉ាងណាក៏ទ្រង់ហ៊ានចំណាយ មិនថាត្រូវចំណាយពេលយូរប៉ុនណានោះទេ។ នេះហើយជានិស្ស័យរបស់ព្រះជាម្ចាស់៖ ទ្រង់នឹងមិនសម្រាកឡើយ រហូតទាល់តែកិច្ចការរបស់ទ្រង់បានសម្រេច។ កិច្ចការរបស់ទ្រង់នឹងបញ្ចប់នៅពេលដែលទ្រង់ទទួលបានផ្នែកទីពីរនៃសិរីល្អរបស់ទ្រង់។ នៅក្នុងសកលលោកទាំងមូល ប្រសិនបើព្រះជាម្ចាស់មិនបញ្ចប់ផ្នែកទីពីរនៃកិច្ចការនៃការទទួលបានសិរីល្អរបស់ទ្រង់ទេ ថ្ងៃរបស់ទ្រង់គ្មានផ្លូវមកដល់ទេ ព្រះហស្ដរបស់ទ្រង់នឹងមិនចាកចោលរាស្ដ្ររើសតាំងរបស់ទ្រង់ សិរីល្អរបស់ទ្រង់ក៏នឹងមិនធ្លាក់ចុះមកលើអ៊ីស្រាអែល ហើយផែនការរបស់ទ្រង់ក៏មិនបញ្ចប់ដែរ។ អ្នករាល់គ្នាគួរតែអាចមើលឃើញបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ហើយគួរតែមើលឃើញថា កិច្ចការរបស់ព្រះជាម្ចាស់មិនមែនងាយ ដូចជាការបង្កើតផ្ទៃមេឃ និងផែនដី ព្រមទាំងរបស់សព្វសារពើឡើយ។ នោះគឺដោយសារតែកិច្ចការសព្វថ្ងៃនេះ គឺជាការបំផ្លាស់បំប្រែអស់អ្នកដែលត្រូវបានធ្វើឱ្យពុករលួយ អ្នកដែលស្ពឹកស្រពន់ដល់កម្រិតអតិបរមា ជាកិច្ចការបន្សុទ្ធអស់អ្នកដែលទ្រង់បានបង្កើតមក ប៉ុន្តែត្រូវចាញ់បញ្ឆោតសាតាំង។ នេះមិនមែនជាការបង្កើតអ័ដាម ឬក៏នាងអេវ៉ាទេ ក៏មិនមែនជាការបង្កើតពន្លឺ ឬក៏បង្កើតរុក្ខជាតិ និងសត្វទាំងពួងដែរ។ ព្រះជាម្ចាស់ធ្វើឱ្យអ្វីៗទាំងអស់ដែលត្រូវសាតាំងធ្វើឱ្យពុករលួយ ឱ្យទៅជាបរិសុទ្ធវិញ ហើយទ្រង់នឹងទទួលយករបស់ទាំងអស់សាជាថ្មី របស់ទាំងអស់នោះនឹងក្លាយទៅជាកម្មសិទ្ធិ និងជាសិរីល្អរបស់ទ្រង់។ រឿងនេះមិនដូចជាការស្រមៃរបស់មនុស្សទេ ហើយក៏មិនមែនងាយស្រួល

ដូចជាការបង្កើតផ្ទៃមេឃ និងផែនដី ព្រមទាំងអ្វីៗនៅក្រោមមេឃលើដីនេះ ឬក៏ងាយដូចការដាក់បណ្ដាសាអារក្សសាតាំងឱ្យធ្លាក់ទៅក្នុងជង្ហុកជ្រៅនោះដែរ ផ្ទុយទៅវិញ វាជាកិច្ចការបំផ្លាស់បំប្រែមនុស្ស ផ្លាស់ប្ដូរអ្វីៗដែលអវិជ្ជមាន និងមិនមែនជាកម្មសិទ្ធិទ្រង់ឱ្យត្រលប់ជាវិជ្ជមាន និងជាកម្មសិទ្ធិទ្រង់វិញ។ នេះគឺជាសេចក្ដីពិតដែលនៅពីក្រោយកិច្ចការរបស់ព្រះជាម្ចាស់នៅដំណាក់កាលនេះ។ អ្នករាល់គ្នាត្រូវតែយល់ពីបញ្ហានេះ ហើយជៀសវាងពីគំនិតដែលគិតថា រឿងនេះងាយស្រួលណាស់។ កិច្ចការរបស់ព្រះជាម្ចាស់ មិនដូចជាកិច្ចការធម្មតានោះទេ។ ភាពអស្ចារ្យ និងប្រាជ្ញានៃកិច្ចការនេះលើសពីគំនិតរបស់មនុស្សឆ្ងាយណាស់។ ព្រះជាម្ចាស់មិនបង្កើតរបស់សព្វសារពើរក្នុងដំណាក់កាលនៃកិច្ចការនេះទេ តែទ្រង់ក៏មិនបំផ្លាញវាដែរ។ ផ្ទុយទៅវិញ ទ្រង់បំផ្លាស់បំប្រែសព្វសារពើដែលទ្រង់បានបង្កើត ហើយបន្សុទ្ធសព្វសារពើដែលសាតាំងបានបង្ខូចវិញ។ ដូច្នេះ ព្រះជាម្ចាស់ចាប់ផ្ដើមគម្រោងមួយដ៏មហិមា ដែលជាសារៈសំខាន់ទាំងស្រុងនៃកិច្ចការរបស់ព្រះជាម្ចាស់។ តើអ្នកមើលឃើញតាមរយៈពាក្យសម្ដីនេះថា កិច្ចការរបស់ព្រះជាម្ចាស់ពិតជាសាមញ្ញណាស់មែនទេ?

# អ្នកត្រូវរស់នៅសម្រាប់សេចក្តីពិត ដ្បិតអ្នកជឿដល់ព្រះជាម្ចាស់

បញ្ហាទូទៅដែលមានក្នុងជីវិតមនុស្សគ្រប់គ្នាគឺថា ពួកគេយល់អំពីសេចក្ដីពិតហើយ ប៉ុន្តែពួកគេមិនបានយកសេចក្ដីពិតនេះទៅអនុវត្តទេ។ ម្យ៉ាង ដោយសារពួកគេមិនចង់លះបង់អ្វីសោះ ម្យ៉ាងទៀតដោយសារតែការយល់ដឹងរបស់ពួកគេនៅស្ទើរ ពួកគេមិនអាចមើលឃើញលក្ខណៈពិតនៃភាពលំបាកប្រចាំថ្ងៃ ហើយពួកគេមិនចេះពីវិធីអនុវត្តសេចក្ដីពិតនេះ ឱ្យបានត្រឹមត្រូវនោះឡើយ។ ដោយសារតែបទពិសោធរបស់ពួកគេនៅស្ទើរ លក្ខណសម្បត្តិរបស់គេក៏ខ្សោយ ហើយកម្រិតនៃការយល់ដឹងរបស់គេក៏តិចដែរនោះ ទើបពួកគេគ្មានវិធីណាសម្រាប់ដោះស្រាយបញ្ហាលំបាក ដែលខ្លួនជួបប្រទះក្នុង

ជីវិតប្រចាំថ្ងៃឡើយ។ ពួកគេជឿព្រះជាម្ចាស់តែបបូរមាត់ប៉ុណ្ណោះ ប៉ុន្តែមិនអាចយាងព្រះជាម្ចាស់មកគង់ក្នុងជីវិតប្រចាំថ្ងៃរបស់ខ្លួននោះឡើយ។ មានន័យថា ព្រះជាម្ចាស់គឺព្រះជាម្ចាស់ ឯជីវិតគឺជីវិត ហាក់បីដូចជា មនុស្សគ្មានសម្ពន្ធភាពជាមួយព្រះជាម្ចាស់នៅក្នុងជីវិតរបស់ពួកគេសោះឡើយ។ នេះគឺជាអ្វីដែលមនុស្សគ្រប់គ្នាគិត។ ពិតណាស់ ការជឿព្រះជាម្ចាស់បែបនេះ ទ្រង់នឹងមិនទទួលយក និងប្រោសឱ្យមនុស្សបានគ្រប់លក្ខណ៍ឡើយ។ ជាក់ស្ដែង មិនមែនព្រះបន្ទូលរបស់ព្រះជាម្ចាស់មិនមានការបើកសម្ដែងពេញលេញនោះទេ តែមនុស្សវិញទេ ដែលពុំមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីទទួលយកព្រះបន្ទូលនោះ។ អាចនិយាយបានថា ស្ទើរតែពុំមាននរណាម្នាក់ធ្វើតាមបំណងព្រះហឫទ័យដើមរបស់ព្រះជាម្ចាស់បានឡើយ ផ្ទុយទៅវិញ សេចក្ដីជំនឿរបស់ពួកគេចំពោះព្រះជាម្ចាស់ ធ្វើតាមតែចេតនាផ្ទាល់របស់គេ ស្របនឹងសញ្ញាណ សាសនាដែលគេគោរពនាពេលកន្លងមក និងការប្រព្រឹត្តទៅតាមវិធីផ្ទាល់ខ្លួនរបស់ពួកគេវិញ។ មានមនុស្សតិចតួចដែលឆ្លងកាត់ការបំផ្លាស់បំប្រែ តាមរយៈការទទួលយកព្រះបន្ទូលរបស់ព្រះជាម្ចាស់ រួចចាប់ផ្ដើមប្រព្រឹត្តតាមបំណងព្រះទ័យរបស់ទ្រង់។ ផ្ទុយទៅវិញ ពួកគេនៅតែតស៊ូ ក្នុងជំនឿខុសឆ្គងរបស់គេដដែល។ ពេលមនុស្សចាប់ផ្ដើមជឿព្រះជាម្ចាស់ ពួកគេជឿដោយផ្អែកលើក្រឹត្យក្រមពីបុរាណខាងសាសនា ហើយពួកគេរស់នៅ និងប្រាស្រ័យជាមួយអ្នកដទៃ ដោយផ្អែកទាំងស្រុងលើទស្សនវិជ្ជាសម្រាប់ការរស់នៅរបស់ពួកគេផ្ទាល់។ អាចនិយាយបានថា ករណីនេះកើតឡើងចំពោះមនុស្សប្រាំបួននាក់នៅក្នុងចំណោមរាល់មនុស្សដប់នាក់។ មានមនុស្សតិចតួចណាស់ដែលច្នៃចេញជាផែនការថ្មី រួចដុះពន្លកចេញជាត្រួយថ្មី បន្ទាប់ពីចាប់ផ្ដើមជឿព្រះជាម្ចាស់។ មនុស្សលោកមិនបានទទួលយកព្រះបន្ទូលរបស់ព្រះជាម្ចាស់ ទុកជាសេចក្ដីពិត ឬក៏ចាត់ទុកជាសេចក្ដីពិត ដើម្បីអនុវត្តតាមព្រះបន្ទូលនេះឡើយ។

ជាឧទាហរណ៍ ចូរមានសេចក្ដីជំនឿលើព្រះយេស៊ូវ។ ទោះបីជានរណាម្នាក់ទើបចាប់ផ្ដើមជឿ ឬក៏បានទទួលជឿយូរមកហើយក្ដី ពួកគេទាំងអស់នោះ គ្រាន់តែប្រើទេពកោសល្យ និងជំនាញដែលពួកគេមានតែប៉ុណ្ណោះ។ មនុស្សគ្រាន់តែបានបន្ថែម

ពាក្យប៉ុន្មានម៉ាត់ថា «សេចក្ដីជំនឿជឿលើព្រះជាម្ចាស់» ទៅក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ ប៉ុន្តែពួកគេមិនបានផ្លាស់ប្រែនិស្ស័យរបស់ខ្លួនសោះ ហើយសេចក្ដីជំនឿលើព្រះជាម្ចាស់របស់គេ ក៏មិនបានលូតលាស់សូម្បីបន្តិច។ ការស្វះស្វែងរកព្រះជាម្ចាស់របស់ពួកគេ គឺក្ដៅមិនក្ដៅ ត្រជាក់ក៏មិនត្រជាក់។ ពួកគេមិនបាននិយាយថា ពួកគេនឹងបោះបង់សេចក្ដីជំនឿរបស់ខ្លួននោះទេ ប៉ុន្តែពួកគេក៏មិនថ្វាយគ្រប់យ៉ាងដល់ព្រះជាម្ចាស់ដែរ។ ពួកគេមិនដែលស្រឡាញ់ព្រះជាម្ចាស់ឱ្យពិតប្រាកដ ឬស្ដាប់បង្គាប់ទ្រង់សោះ។ សេចក្ដីជំនឿលើព្រះជាម្ចាស់របស់ពួកគេ គឺជាការបញ្ចូលគ្នារវាងភាពពិត និងភាពក្លែងក្លាយ ដោយពួកគេចូលទៅកាន់សេចក្ដីនេះដោយបើកភ្នែកម្ខាង ហើយបិទភ្នែកម្ខាង និងគ្មានមានចិត្តស្មោះត្រង់ក្នុងការអនុវត្តសេចក្ដីជំនឿរបស់ពួកគេឡើយ។ ពួកគេបន្តរស់នៅក្នុងស្ថានភាពវង្វេង ហើយនៅទីបញ្ចប់ ពួកគេក៏ស្លាប់ក្នុងស្ថានភាពវង្វេងនេះ។ តើទាំងអស់នេះមានន័យអ្វី? ពេលនេះ ដើម្បីជឿលើព្រះជាម្ចាស់ដ៏ជាក់ស្ដែង អ្នកត្រូវតែដើរតាមវិថីត្រឹមត្រូវ។ ប្រសិនបើអ្នកជឿលើព្រះជាម្ចាស់ អ្នកមិនត្រូវស្វែងរកព្រះពរតែមួយមុខនោះទេ ប៉ុន្តែអ្នកត្រូវតែស្រឡាញ់ព្រះជាម្ចាស់ និងស្គាល់ព្រះជាម្ចាស់ផង។ តាមរយៈការបំភ្លឺរបស់ទ្រង់ និងការស្វែងរករបស់អ្នកផ្ទាល់ អ្នកអាចហូប និងផឹកព្រះបន្ទូលរបស់ទ្រង់ អាចបង្កើតការយល់ដឹងច្បាស់លាស់អំពីព្រះជាម្ចាស់ ព្រមទាំងមានក្ដីស្រឡាញ់ពិតចំពោះព្រះជាម្ចាស់ ដោយចេញពីចិត្តរបស់ខ្លួន។ ពោលគឺនៅពេលក្ដីស្រឡាញ់របស់អ្នកចំពោះព្រះជាម្ចាស់ គឺជាសេចក្ដីស្រឡាញ់ពិតប្រាកដបំផុត គ្មាននរណាអាចបំផ្លាញ និងរារាំងសេចក្ដីស្រឡាញ់របស់អ្នកចំពោះព្រះអង្គបានឡើយ ពេលនេះហើយ អ្នកស្ថិតនៅលើវិថីត្រឹមត្រូវខាងឯជំនឿលើព្រះជាម្ចាស់ហើយ។ ការនេះបញ្ជាក់ថា អ្នកក្លាយជាកម្មសិទ្ធិរបស់ព្រះជាម្ចាស់ ដ្បិតព្រះអង្គទទួលបាននូវចិត្តរបស់អ្នក ជាកម្មសិទ្ធិព្រះជាម្ចាស់ហើយ ក៏គ្មានអ្វីមួយអាចយកអ្នកធ្វើជាកម្មសិទ្ធិបានដែរ។ តាមរយៈបទពិសោធ និងការលះបង់របស់អ្នក និងតាមរយៈកិច្ចការរបស់ព្រះជាម្ចាស់ អ្នកអាចបង្កើតបានសេចក្ដីស្រឡាញ់ឥតព្រៀងនៅចំពោះព្រះជាម្ចាស់ ហើយពេលអ្នកមានសេចក្ដីស្រឡាញ់នេះ អ្នកនឹងរួចពីឥទ្ធិពលរបស់សាតាំង ហើយ

ចូលមករស់នៅក្នុងពន្លឺនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់វិញ។ ទាល់តែអ្នកបានរួចចេញពីឥទ្ធិពលនៃភាពងងឹត ទើបអាចនិយាយបានថា អ្នកបានទទួលព្រះជាម្ចាស់ហើយ។ តាមសេចក្ដីជំនឿដែលអ្នកមានក្នុងព្រះជាម្ចាស់ អ្នកត្រូវតែព្យាយាមស្វែងរកគោលដៅនេះ។ នេះជាភារកិច្ចរបស់អ្នករាល់គ្នាម្នាក់ៗ។ អ្នកទាំងអស់គ្នាមិនត្រូវស្កប់ស្កល់ជាមួយស្ថានភាពបច្ចុប្បន្ននេះទេ។ អ្នកមិនអាចមានចិត្តពីរ ចំពោះកិច្ចការរបស់ព្រះជាម្ចាស់នោះទេ ហើយអ្នកក៏មិនអាចមើលស្រាលលើកិច្ចការនេះបានដែរ។ អ្នកគួរតែគិតពីព្រះជាម្ចាស់ក្នុងគ្រប់កិច្ចការ និងគ្រប់ពេលវេលាទាំងអស់ ហើយធ្វើរាល់កិច្ចការទាំងអស់សម្រាប់ទ្រង់។ ហើយរាល់ពេលដែលអ្នកនិយាយ ឬប្រព្រឹត្ត អ្នកគួរតែគិតដល់ផលប្រយោជន៍នៃដំណាក់ព្រះជាម្ចាស់ជាមុនសិន។ ធ្វើបែបនេះ ទើបអ្នកអាចក្លាយជាទីគាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់បាន។

កំហុសដ៏ធំបំផុតរបស់មនុស្សនៅក្នុងសេចក្ដីជំនឿរបស់គេចំពោះព្រះជាម្ចាស់ គឺពួកគេជឿត្រឹមតែពាក្យសំដីប៉ុណ្ណោះ តែមែនទែនទៅ ព្រះជាម្ចាស់គ្មានវត្តមានក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេទេ។ ពិតណាស់ មនុស្សទាំងអស់ជឿថាមានព្រះជាម្ចាស់ ប៉ុន្តែព្រះជាម្ចាស់មិនមានចំណែកនៅក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេឡើយ។ មាត់មនុស្សលើកសេចក្ដីអធិស្ឋានជាច្រើនទៅកាន់ព្រះជាម្ចាស់ ប៉ុន្តែក្នុងចិត្តគេ មានព្រះជាម្ចាស់តិចតួចណាស់ ហេតុនេះ ទើបព្រះជាម្ចាស់បានល្បងលគេម្ដងហើយម្ដងទៀត។ នេះដោយសារពួកគេមានចិត្តមិនស្អាត ទើបព្រះជាម្ចាស់មិនមានជម្រើសផ្សេងក្រៅពីល្បងលគេ ដើម្បីឲ្យពួកគេខ្មាស ហើយដឹងខ្លួនតាមរយៈការល្បងលទាំងអស់នេះ។ ពុំនោះទេ មនុស្សលោកនឹងក្លាយទៅជាកូនចៅរបស់ពួកមហាទេវតា ហើយរឹតតែអាក្រក់ឡើងៗ។ នៅក្នុងដំណើរវិវឌ្ឍនៃសេចក្ដីជំនឿរបស់ពួកគេចំពោះព្រះជាម្ចាស់ មនុស្សម្នាក់ៗលះបង់ចេតនា និងគោលបំណងផ្ទាល់ខ្លួនរបស់គេ ក្រោមការសម្អាតដោយឥតឈប់ឈររបស់ព្រះជាម្ចាស់។ ពុំនោះទេ ព្រះជាម្ចាស់គ្មានវិធីណាមកប្រើមនុស្សណាម្នាក់ ក៏គ្មានវិធីណាមកអនុវត្តកិច្ចការដែលទ្រង់ត្រូវធ្វើនៅក្នុងពួកគេដែរ។ ដំបូងព្រះជាម្ចាស់សម្អាតមនុស្សជាមុនសិន ហើយតាមដំណើរការនេះ អ្នកទាំងនោះ

អាចស្គាល់ខ្លួនឯង រួចព្រះជាម្ចាស់ក៏អាចបំផ្លាស់បំប្រែពួកគេបាន។ បន្ទាប់មក ទើបព្រះជាម្ចាស់ដាក់ព្រះជន្មទ្រង់ឲ្យគង់ក្នុងពួកគេ ទាល់តែបែបនេះ ទើបពួកគេប្រែចិត្តទាំងស្រុងចំពោះព្រះជាម្ចាស់។ ដូច្នេះហើយ ទើបខ្ញុំនិយាយថា ការជឿព្រះជាម្ចាស់មិនមែនងាយស្រួលដូចគេនិយាយនោះឡើយ។ ប្រសិនបើអ្នកមានតែចំណេះដឹងមួយមុខ ប៉ុន្តែគ្មានព្រះបន្ទូលរបស់ទ្រង់ជាជីវិត ដូចដែលព្រះជាម្ចាស់ទតឃើញ ហើយប្រសិនបើចំណេះរបស់អ្នក មានកម្រិតទៅតាមសមត្ថភាពរបស់អ្នក ប៉ុន្តែមិនអាចអនុវត្តនូវសេចក្ដីពិត ឬរស់នៅតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់បាន នេះសបញ្ជាក់ថាអ្នកមិនទាន់មានចិត្តស្រឡាញ់ព្រះជាម្ចាស់នៅឡើយទេ ហើយបង្ហាញថា ចិត្តរបស់អ្នកមិនមែនជាកម្មសិទ្ធិរបស់ព្រះជាម្ចាស់នោះឡើយ។ មនុស្សអាចស្គាល់ព្រះជាម្ចាស់តាមរយៈការទទួលជឿលើទ្រង់៖ នេះគឺជាគោលដៅចុងក្រោយ ហើយជាគោលដៅដែលមនុស្សស្វះស្វែងរក។ អ្នកត្រូវខិតខំរស់នៅតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ដើម្បីឱ្យព្រះបន្ទូលនោះបង្កើតផលផ្លែនៅក្នុងការអនុវត្តរបស់អ្នក។ ប្រសិនបើអ្នកមានតែចំណេះដឹងខាងគោលលទ្ធិ នោះសេចក្ដីជំនឿរបស់អ្នកចំពោះព្រះជាម្ចាស់ ក៏ពុំមានប្រយោជន៍អ្វីដែរ។ លុះត្រាតែអ្នកអនុវត្ត ហើយរស់នៅតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ ទើបសេចក្ដីជំនឿរបស់អ្នកត្រូវបានរាប់ថាបានពេញខ្នាត និងស្របតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ នៅលើវិថីនេះ មានមនុស្សជាច្រើនអាចនិយាយពីចំណេះដឹងបានយ៉ាងច្រើន ប៉ុន្តែពេលដែលសេចក្ដីស្លាប់មកដល់ គេស្រក់ទឹកភ្នែក ហើយស្អប់ខ្លួនឯងដែលខ្ជះខ្ជាយជីវិត និងរស់យ៉ាងយូរដោយឥតប្រយោជន៍។ ពួកគេគ្រាន់តែយល់ពីគោលលទ្ធិប៉ុណ្ណោះ ប៉ុន្តែមិនអាចអនុវត្តសេចក្ដីពិត ឬធ្វើជាទីបន្ទាល់ពីព្រះជាម្ចាស់បានឡើយ ផ្ទុយទៅវិញ គេរវល់ទៅនេះទៅនោះ ដូចសត្វឃ្មុំ ហើយនៅពេលសេចក្ដីស្លាប់ជិតមកដល់ ទីបំផុតទើបពួកគេយល់ថា ពួកគេខ្វះទីបន្ទាល់ពិតប្រាកដ ដោយពួកគេមិនស្គាល់ព្រះជាម្ចាស់ទាល់តែសោះ។ តើរឿងនេះមិនយឺតពេលទៅហើយទេឬ? ហេតុអ្វីក៏អ្នកមិនឆក់ឱកាស ហើយដេញតាមសេចក្ដីពិតដែលអ្នកស្រឡាញ់? ហេតុអ្វីក៏រង់ចាំដល់ថ្ងៃស្អែក? ប្រសិននៅក្នុងជីវិត អ្នកមិនទទួលរងនូវ

ទុក្ខលំបាកដើម្បីសេចក្ដីពិត ឬស្វែងរក និងទទួលបានសេចក្ដីពិតនេះ តើអ្នកអាចថាមកពីអ្នកចង់មានវិប្បដិសារី ពេលដែលអ្នកជិតស្លាប់មែនទេ? ប្រសិនបើដូច្នេះមែន ហេតុអ្វីត្រូវជឿព្រះជាម្ចាស់? តាមការពិត មានកត្តាជាច្រើន ដែលមនុស្សអាចយកសេចក្ដីពិតមកអនុវត្ត និងអាចផ្គាប់ព្រះហឫទ័យព្រះជាម្ចាស់បាន ប្រសិនបើគេព្យាយាមតែបន្តិចបន្តួច។ តែដោយសារចិត្តរបស់ពួកគេត្រូវវិញ្ញាណអាក្រក់សណ្ឋិត រហូតពួកគេមិនអាចធ្វើអ្វីសម្រាប់ប្រយោជន៍ដល់ព្រះជាម្ចាស់បាន ហើយគេរវល់ជានិច្ចចំពោះរឿងសាច់ឈាម ដោយនៅទីបញ្ចប់ មិនបានសម្រេចអ្វីសោះឡើយ។ ដូច្នេះហើយ មនុស្សតែងទទួលរងនូវបញ្ហា និងការលំបាកជាច្រើន។ តើទាំងនេះមិនមែនជាការធ្វើទុក្ខរបស់សាតាំងទេឬអី? តើនេះមិនមែនជាភាពពុករលួយនៃនិស្ស័យសាច់ឈាមទេឬអី? អ្នកមិនត្រូវបន្លំព្រះជាម្ចាស់ ដោយបបូរមាត់បោកបញ្ឆោតរបស់អ្នកនោះទេ? ប៉ុន្តែ អ្នកត្រូវមានសកម្មភាពជាក់ស្ដែង។ ចូរកុំបញ្ឆោតខ្លួនឯងឱ្យសោះ តើមានប្រយោជន៍អ្វី? តើអ្នកអាចទទួលបានផលអ្វីខ្លះ តាមរយៈការរស់នៅដើម្បីប្រយោជន៍សាច់ឈាម និងការខំប្រឹងលំបាក ដើម្បីរិះរកឲ្យបាននូវប្រាក់ចំណេញ និងកិត្តិនាមនោះ?

## សំឡេងផ្គរលាន់ទាំងប្រាំពីរ៖ ថ្លែងទំនាយថា ដំណឹងល្អនៃនគរព្រះ នឹងផ្សាយទៅពាសពេញទាំងសាកលលោក

ខ្ញុំកំពុងពង្រីកកិច្ចការរបស់ខ្ញុំ ក្នុងចំណោមជាតិសាសន៍ដទៃ។ សិរីល្អរបស់ខ្ញុំ ចាំងចែងពេញទាំងសកលលោក។ មនុស្សផ្កាយ-ផ្កាយ-ចំណុច-ចំណុចទាំងអស់ ស្ពាយនូវបំណងព្រះហឫទ័យរបស់ខ្ញុំនៅជាប់នឹងខ្លួន ហើយពួកគេត្រូវបានដឹកនាំដោយព្រះហស្តរបស់ខ្ញុំ និងត្រៀមធ្វើកិច្ចការដែលខ្ញុំបានចាត់ចែងឲ្យ។ ចាប់ពីពេលនេះទៅ ខ្ញុំបានចូលទៅយុគសម័យថ្មីមួយ ដោយនាំយកមនុស្សទាំងអស់ទៅក្នុងពិភពថ្មីមួយ។ នៅពេលដែលខ្ញុំយាងត្រឡប់ទៅ «ទឹកដីកំណើត» របស់ខ្ញុំវិញ ខ្ញុំបានចាប់ផ្ដើម

ធ្វើកិច្ចការមួយចំណែកទៀត នៅក្នុងផែនការដើមរបស់ខ្ញុំ ដើម្បីឲ្យមនុស្សស្គាល់ខ្ញុំកាន់ជ្រាលជ្រៅជាងមុន។ ខ្ញុំយកព្រះហឫទ័យទុកដាក់ចំពោះសកលលោកទាំងមូលនេះណាស់ ហើយខ្ញុំយល់ឃើញថា[ក] វាជាឱកាសមួយដ៏ល្អ សម្រាប់កិច្ចការរបស់ខ្ញុំ ហេតុនេះបានជាខ្ញុំប្រញាប់ប្រញាល់យាងទៅមកចុះឡើង ដោយបំពេញកិច្ចការថ្មីរបស់ខ្ញុំចំពោះមនុស្ស។ ទីបំផុត នេះគឺជាយុគសម័យថ្មីមួយ ហើយខ្ញុំបាននាំកិច្ចការថ្មីមក ដើម្បីនាំយកមនុស្សថ្មីៗបន្ថែមទៀតទៅក្នុងសម័យថ្មីនេះ ហើយទុកមនុស្សដែលខ្ញុំត្រូវតែកម្ចាត់ចោលមួយឡែកសិន។ ខ្ញុំបានអនុវត្តដំណាក់កាលមួយនៃកិច្ចការដែលមនុស្សពុំអាចយល់បាននៅក្នុងជាតិសាសន៍នៃនាគដ៏ធំមានសម្បុរក្រហម ដោយធ្វើឲ្យពួកគេឃោលឃោគទៅមកនៅក្នុងខ្យល់ ហើយក្រោយមក មនុស្សជាច្រើនត្រូវរសាត់បាត់ទៅយ៉ាងស្ងៀមស្ងាត់ ដោយសារខ្យល់បក់។ ពិតណាស់ នេះគឺជា «លានបោកស្រូវ» ដែលខ្ញុំនឹងត្រូវជម្រះឲ្យស្អាត។ វាជាអ្វីដែលខ្ញុំទន្ទឹងជាខ្លាំង ហើយជាផែនការរបស់ខ្ញុំផងដែរ។ ដ្បិតមនុស្សអាក្រក់ជាច្រើនបានលបលួចចូលមក ពេលខ្ញុំកំពុងធ្វើការ ប៉ុន្តែខ្ញុំមិនប្រញាប់បណ្ដេញពួកគេឲ្យចេញនោះទេ។ ផ្ទុយទៅវិញ ខ្ញុំនឹងកម្ចាត់ពួកគេចោលនៅពេលមានឱកាសល្អ។ ទាល់តែកិច្ចការនេះរួចរាល់ ទើបខ្ញុំនឹងក្លាយជារន្ធទឹកនៃជីវិត ដែលអាចឲ្យអស់អ្នកដែលស្រឡាញ់ខ្ញុំពិតប្រាកដ មកទទួលផ្លែល្វា និងគន្ធាក្រអូបសាយនៃផ្កាកំភ្លឹងបាន។ នៅក្នុងទឹកដីដែលសាតាំងស្នាក់នៅគឺជាទឹកដីដែលមានសុទ្ធតែធូលី នៅទីនោះគ្មានសល់មាសសុទ្ធទេ សល់តែដីខ្សាច់ប៉ុណ្ណោះ ហេតុនេះ ខ្ញុំក៏បំពេញនូវកិច្ចការមួយដំណាក់កាល តម្រូវទៅតាមកាលៈទេសៈទាំងនេះសិន។ អ្នកគប្បីដឹងថា អ្វីដែលខ្ញុំទទួលបានគឺមាសសុទ្ធ ជាមាសដែលបន្សុទ្ធរួច មិនមែនជាខ្សាច់ទេ។ តើមនុស្សអាក្រក់អាចស្ថិតនៅក្នុងដំណាក់របស់ខ្ញុំបានដោយវិធីណា? តើខ្ញុំអាចអនុញ្ញាតឲ្យពពួកសត្វកញ្ជ្រោង ក្លាយជាបញ្ញើក្អែកនៅក្នុងឋានសួគ៌ខ្ញុំ

---

លេខយោង៖

ក. អត្ថបទដើមមិនមានឃ្លា «ឃើញថា»។

បានដោយវិធីណា? ខ្ញុំប្រើវិធីសាស្ត្រទាំងអស់ដែលអាចគិតដល់ ដើម្បីបណ្ដេញរបស់ទាំងអស់នេះចេញ។ មុនពេលដែលបំណងព្រះហឫទ័យរបស់ខ្ញុំត្រូវបញ្ចេញប្រាប់ឲ្យគេបានដឹង គ្មាននរណាម្នាក់ដឹងអំពីអ្វីដែលខ្ញុំហៀបនឹងធ្វើនោះទេ។ ខ្ញុំក៏នឹងចាប់យកឱកាសនេះ ដើម្បីបណ្ដេញមនុស្សអាក្រក់ចេញ ហើយពួកគេនឹងត្រូវបង្ខំឲ្យចេញពីព្រះវត្តមានរបស់ខ្ញុំ។ នេះជាអ្វីដែលខ្ញុំធ្វើចំពោះពួកមនុស្សអាក្រក់ ប៉ុន្តែគង់មានថ្ងៃមួយដែលពួកគេអាចបម្រើខ្ញុំបាន។ ចំណង់ដែលមនុស្សចង់បានការប្រទានពរ គឺខ្លាំងក្លាណាស់។ ហេតុនេះ ខ្ញុំនឹងបង្វែរព្រះកាយខ្ញុំ ហើយបង្ហាញព្រះភក្ត្រប្រកបដោយសិរីល្អរបស់ខ្ញុំទៅដល់សាសន៍ដទៃ ដើម្បីឲ្យមនុស្សទាំងអស់ អាចរស់នៅក្នុងពិភពលោកមួយជាកម្មសិទ្ធផ្ទាល់ខ្លួន និងវិនិច្ឆ័យខ្លួនឯងបាន ចំណែកឯខ្ញុំវិញ ខ្ញុំនឹងនៅតែបន្តថ្លែងព្រះបន្ទូលដែលខ្ញុំគួរថ្លែង ហើយផ្គត់ផ្គង់ឲ្យមនុស្សនូវអ្វីដែលពួកគេត្រូវការ។ ទម្រាំមនុស្សបានភ្ញាក់ដឹងខ្លួនវិញ គឺខ្ញុំបានបន្សាយកិច្ចការរបស់ខ្ញុំរួចជាយូរមកហើយ។ បន្ទាប់មក ខ្ញុំនឹងបញ្ជាក់អំពីបំណងរបស់ខ្ញុំឲ្យមនុស្សបានដឹង និងចាប់ផ្ដើមចំណែកទីពីរនៃកិច្ចការរបស់ខ្ញុំចំពោះមនុស្ស ដោយអនុញ្ញាតឲ្យមនុស្សទាំងអស់ ដើរតាមខ្ញុំយ៉ាងប្រកៀកដើម្បីសម្រួលកិច្ចការរបស់ខ្ញុំ និងអាចឲ្យមនុស្សធ្វើអ្វី តាមសមត្ថភាពរបស់ពួកគេ ដើម្បីរួមគ្នាជាមួយខ្ញុំបំពេញកិច្ចការដែលខ្ញុំចាំបាច់ត្រូវធ្វើ។

គ្មាននរណាម្នាក់ជឿថា ពួកគេនឹងមើលឃើញសិរីល្អរបស់ខ្ញុំទេ ហើយខ្ញុំមិនបង្ខិតបង្ខំពួកគេឡើយ ផ្ទុយទៅវិញ ខ្ញុំនឹងដកយកសិរីល្អរបស់ខ្ញុំចេញពីក្នុងចំណោមមនុស្សជាតិ និងនាំយកសិរីល្អនោះទៅកាន់ពិភពមួយទៀត។ ពេលមនុស្សប្រែចិត្តសាជាថ្មី នោះខ្ញុំនឹងយកសិរីល្អរបស់ខ្ញុំ ទៅបង្ហាញដល់អ្នកដែលមានជំនឿវិញ។ នេះគឺជាគោលការណ៍ ដែលខ្ញុំអនុវត្តកិច្ចការ។ ដ្បិតមានពេលមួយដែលសិរីល្អរបស់ខ្ញុំបាត់ចេញពីស្រុកកាណាន ហើយក៏មានពេលមួយដែលសិរីល្អខ្ញុំនឹងចាកចេញពីមនុស្សដែលខ្ញុំបានជ្រើសរើសផងដែរ។ លើសពីនេះទៅទៀត មានពេលមួយដែលសិរីល្អរបស់ខ្ញុំចាកចេញពីផែនដីទាំងមូល ដែលធ្វើឲ្យវាប្រែជាងងឹត ហើយធ្លាក់ចូលទៅក្នុងភាពអន្ធិការ។ សូម្បីទឹកដីស្រុកកាណាន ក៏នឹងមើលមិនឃើញពន្លឺព្រះអាទិត្យ

ដែរ។ មនុស្សគ្រប់គ្នានឹងបាត់បង់ជំនឿរបស់ពួកគេ ប៉ុន្តែគ្មាននរណាម្នាក់អាចទ្រាំចាកចេញពីគន្ធាក្រអូបសាយនៃទឹកដីកាណានបានឡើយ។ ទាល់តែខ្ញុំបានឆ្លងទៅកាន់ផ្ទៃមេឃ និងផែនដីថ្មី ទើបខ្ញុំអាចយកចំណែកផ្សេងទៀតក្នុងសិរីល្អរបស់ខ្ញុំបាន និងសម្តែងសិរីល្អនោះនៅក្នុងស្រុកកាណានសិន ដែលនាំឲ្យមានពន្លឺព្រឹមៗចាំងឡើងលើផែនដីទាំងមូល ដែលលិចចូលក្នុងភាពងងឹតស្លុងនៃរាត្រីកាល ដែលផែនដីទាំងមូលអាចត្រឡប់មកជាមានពន្លឺវិញ ដោយមនុស្សទាំងអស់នៅលើផែនដី អាចមកស្រូបយកកម្លាំងពីអានុភាពពន្លឺនេះ ដើម្បីឲ្យសិរីល្អរបស់ខ្ញុំកើនកាន់តែច្រើន និងលេចឡើងជាថ្មីដល់គ្រប់ជាតិសាសន៍ ហើយដោយឱ្យមនុស្សទាំងអស់អាចដឹងថា ខ្ញុំបានមកកាន់ពិភពលោកនេះជាយូរមកហើយ រួចខ្ញុំបាននាំសិរីល្អរបស់ខ្ញុំពីអ៊ីស្រាអែលទៅឯទិសខាងកើតទៀត ដ្បិតសិរីល្អរបស់ខ្ញុំរះចាំងចែងពីទិសខាងកើត ហើយសិរីល្អនេះត្រូវបាននាំចេញមកពីយុគសម័យនៃព្រះគុណ។ ប៉ុន្តែគឺជាអ៊ីស្រាអែល ជាទីដែលខ្ញុំបានចាកចេញមក ហើយខ្ញុំក៏មកដល់ទិសខាងកើត។ ទាល់តែពន្លឺនៅទិសខាងកើតចាប់ផ្តើមឡើងសបន្តិចម្តងៗ ទើបភាពអន្ធិកានៅទូទាំងផែនដីនឹងចាប់ផ្តើមត្រឡប់ជាមានពន្លឺវិញ ដល់ពេលនោះទើបមនុស្សដឹងថា ខ្ញុំបានចាកចេញពីអ៊ីស្រាអែលជាយូរមកហើយ ហើយខ្ញុំកំពុងតែរះឡើងជាថ្មីនៅទិសខាងកើត។ ខ្ញុំមិនអាចមកយកកំណើតជាថ្មីក្នុងសាសន៍អ៊ីស្រាអែលបានទេ ដ្បិតខ្ញុំបានយាងចុះមកអ៊ីស្រាអែលម្តងរួចហើយ ក្រោយមក ខ្ញុំក៏បានចាកចេញពីទីនោះ ដ្បិតកិច្ចការរបស់ខ្ញុំ គឺដឹកនាំសកលលោកទាំងមូល រួចលើសពីនេះ ផ្លេកបន្ទោរនឹងជះពន្លឺត្រង់ពីទិសខាងកើតទៅទិសខាងលិច។ ដែលខ្ញុំបានចុះមកទិសខាងកើត រួចយកស្រុកកាណានមកឲ្យមនុស្សនៅទិសខាងកើត គឺដោយព្រោះហេតុផលនេះហើយ។ ខ្ញុំនឹងនាំយកមនុស្សមកពីជុំវិញផែនដីនេះទៅកាន់ទឹកដីកាណាន ដូច្នេះ ខ្ញុំបន្តបញ្ចេញនូវព្រះសូរសៀងនៅស្រុកកាណាន ដើម្បីគ្រប់គ្រងសកលលោកទាំងមូល។ ពេលនេះ នៅលើផែនដី កន្លែងណាក៏គ្មានពន្លឺដែរ ក្រៅតែពីស្រុកកាណាន ហើយមនុស្សទាំងអស់នឹងរងគ្រោះដោយសារការស្រេកឃ្លាន និងរងាត្រជាក់។ ខ្ញុំបានប្រទានសិរីល្អដល់សាសន៍អ៊ីស្រាអែល

ដោយហេតុនេះ ខ្ញុំក៏នាំសាសន៍អ៊ីស្រាអែលទៅឯទិសខាងកើត និងឲ្យដល់មនុស្សទាំងអស់នៅទិសខាងកើតដែរ។ ខ្ញុំបាននាំពួកគេគ្រប់គ្នាទៅរកពន្លឺ ដើម្បីឲ្យពួកគេអាចរួបរួមគ្នាជាថ្មីនឹងពន្លឺនោះ ហើយភពប្រសព្វជាមួយគ្នា និងមិនចាំបាច់ស្វែងរកពន្លឺនោះទៀតឡើយ។ ខ្ញុំនឹងឲ្យមនុស្សដែលស្វែងរកពន្លឺនោះ បានមើលឃើញពន្លឺនោះម្ដងទៀត និងមើលឃើញសិរីល្អដែលខ្ញុំមាននៅស្រុកអ៊ីស្រាអែលផង។ ខ្ញុំនឹងឲ្យពួកគេឃើញថា ខ្ញុំបានចុះមកនៅលើដុំពពកស នៅក្នុងចំណោមមនុស្សជាតិជាយូរមកហើយ ឲ្យពួកគេឃើញដុំពពកស និងផ្លែឈើជាចង្កោមច្រើនរាប់មិនអស់ ហើយលើសពីនោះ គឺឲ្យពួកគេឃើញព្រះយេហូវ៉ា គឺជាព្រះនៃសាសន៍អ៊ីស្រាអែល។ ខ្ញុំនឹងឲ្យពួកគេសម្លឹងទៅឯចៅហ្វាយសាសន៍យូដា ជាព្រះមែស្ស៊ីដែលគេទន្ទឹងរង់ចាំជាយូរ និងការលេចមកដ៏ពេញលេញរបស់ខ្ញុំ ដែលត្រូវស្ដេចជាច្រើនអង្គធ្វើទុក្ខបុកម្នេញក្នុងគ្រប់យុគសម័យទាំងអស់។ ខ្ញុំនឹងសម្រេចកិច្ចការរបស់ខ្ញុំដើម្បីសកលលោកទាំងមូល ហើយខ្ញុំនឹងបំពេញកិច្ចការអស្ចារ្យ ដោយបង្ហាញសិរីល្អទាំងអស់ ព្រមទាំងស្នាព្រះហស្តរបស់ខ្ញុំដល់មនុស្សនៅគ្រាចុងក្រោយ។ ខ្ញុំនឹងបង្ហាញព្រះភក្ត្រ ដែលប្រកបដោយសិរីល្អរបស់ខ្ញុំទាំងស្រុង នៅចំពោះមុខមនុស្សដែលបានរង់ចាំខ្ញុំអស់ជាច្រើនឆ្នាំ គឺដល់អស់អ្នកដែលទន្ទឹងរង់ចាំខ្ញុំយាងមកលើដុំពពក ដល់សាសន៍អ៊ីស្រាអែលដែលបានទន្ទឹងចាំខ្ញុំយាងមកជាថ្មី និងដល់មនុស្សគ្រប់ៗគ្នាដែលបៀតបៀនខ្ញុំ ដើម្បីឲ្យមនុស្សទាំងអស់គ្នាដឹងថា ខ្ញុំបានដកសិរីល្អរបស់ខ្ញុំជាយូរមកហើយ និងបាននាំយកវាត្រឡប់មកទិសខាងកើត ដើម្បីឲ្យសិរីល្អនោះលែងស្ថិតនៅស្រុកយូដាទៀត។ ដ្បិតគ្រាចុងក្រោយបានចូលមកដល់ហើយ!

ខ្ញុំកំពុងបំពេញកិច្ចការរបស់ខ្ញុំក្នុងសកលលោកទាំងមូល ហើយនៅទិសខាងកើតក៏មានសូរផ្គរលាន់គ្រាំងៗឥតដាច់ បណ្ដាលឲ្យជាតិសាសន៍ ហើយនិងគណៈនិកាយទាំងអស់ញាប់ញ័រ។ គឺសូរសៀងរបស់ខ្ញុំនេះហើយ ដែលបានដឹកនាំមនុស្សទាំងអស់មកក្នុងពេលបច្ចុប្បន្ននេះ។ ខ្ញុំធ្វើឲ្យមនុស្សទាំងអស់ ត្រូវយកឈ្នះដោយព្រោះសូរសៀងរបស់ខ្ញុំ ឲ្យគេធ្លាក់ទៅក្នុងផ្លូវទឹកហូរ រួចចុះចូលនឹងខ្ញុំ ពីព្រោះខ្ញុំបានយក

សិរីល្អរបស់ខ្ញុំពីផែនដីមកវិញជាយូរមកហើយ និងបានបញ្ចេញសិរីល្អជាថ្មី នៅឯទិសខាងកើត។ តើនរណាខ្លះមិនចង់ឃើញសិរីល្អរបស់ខ្ញុំ? តើនរណាខ្លះមិនរង់ចាំការយាងត្រឡប់មកវិញរបស់ខ្ញុំដោយអន្ទះសា? តើនរណាខ្លះមិនស្រេកឃ្លានចង់ឃើញការលេចមករបស់ខ្ញុំ? តើនរណាខ្លះ មិនប្រាថ្នាចង់បានសេចក្ដីស្រឡាញ់របស់ខ្ញុំ? តើនរណាខ្លះមិនអាចមករកពន្លឺបាន? តើនរណាខ្លះមើលមិនឃើញភាពសម្បូរសប្បាយនៃទឹកដីកាណាន? តើនរណាខ្លះមិនទន្ទឹងចាំការយាងត្រឡប់មកវិញ នៃព្រះដ៏ប្រោសលោះ? តើនរណាខ្លះមិនដែលមិនស្រលាញ់ព្រះអង្គដែលមានព្រះចេស្ដាដ៏អស្ចារ្យ? ព្រះសូរសៀងរបស់ខ្ញុំ នឹងត្រូវផ្សាយទៅពេញទាំងផែនដី។ ខ្ញុំបែរព្រះភ័ក្ត្ររបស់ខ្ញុំទៅរាស្ត្ររើសតាំងរបស់ខ្ញុំ ហើយមានបន្ទូលជាច្រើនទៀតទៅកាន់ពួកគេ។ ខ្ញុំថ្លែងព្រះបន្ទូលរបស់ខ្ញុំទៅកាន់សកលលោក និងមនុស្សជាតិទាំងមូល ដូចផ្គរលាន់សូរសន្ធឹក ដែលអង្រួនទាំងភ្នំ និងទន្លេ។ អំណឹះតទៅ ព្រះបន្ទូលនៅក្នុងព្រះឱស្ឋរបស់ខ្ញុំបានក្លាយជាកំណប់ទ្រព្យរបស់មនុស្ស ហើយមនុស្សគ្រប់គ្នាក៏ត្រេកអរសប្បាយនឹងព្រះបន្ទូលរបស់ខ្ញុំដែរ។ ផ្លេកបន្ទោរ ជះពន្លឺពីទិសខាងកើតទៅដល់ទិសខាងលិច។ ព្រះបន្ទូលរបស់ខ្ញុំ គឺជាព្រះបន្ទូលដែលមនុស្សរារែកមិនចង់បោះបង់ចោល ហើយក្នុងពេលជាមួយគ្នា គេក៏រកយល់មិនបានដែរ ប៉ុន្ដែគេត្រេកអរសប្បាយនឹងព្រះបន្ទូលកាន់ច្រើនឡើងៗ។ មនុស្សគ្រប់ៗគ្នា ត្រេកអរសប្បាយ ហើយសាទរចំពោះការយាងមកដល់របស់ខ្ញុំ គឺប្រៀបដូចជាទារកដែលទើបនឹងកើត។ តាមរយៈព្រះសូរសៀងរបស់ខ្ញុំ ខ្ញុំនឹងនាំមនុស្សគ្រប់គ្នាមកចំពោះខ្ញុំ។ ហេតុនេះ ខ្ញុំនឹងចូលទៅក្នុងចំណោមមនុស្សជាផ្លូវការ ដើម្បីឲ្យពួកគេថ្វាយបង្គំខ្ញុំ។ ខ្ញុំនឹងធ្វើយ៉ាងណាឲ្យមនុស្សគ្រប់ៗគ្នាមកនៅចំពោះព្រះភក្ត្រខ្ញុំ និងមើលឃើញផ្លេកបន្ទោរជះពន្លឺពីទិសខាងកើត ហើយឃើញខ្ញុំយាងចុះមកលើ «ភ្នំដើមអូលីវ» ដែលនៅទិសខាងកើត ដោយសិរីរុងរឿងដែលខ្ញុំបានបញ្ចេញ និងដោយព្រះបន្ទូលនៅក្នុងព្រះឱស្ឋរបស់ខ្ញុំ។ ពួកគេនឹងឃើញថា ខ្ញុំបានមកដល់ផែនដីជាយូរមកហើយ ក៏មិនមែនជាកូនសាសន៍យូដាទៀតដែរ ប៉ុន្ដែជាផ្លេកបន្ទោរនៅទិសខាងកើត។ ដ្បិតខ្ញុំត្រូវប្រោសឲ្យរស់ឡើងវិញ និងបានចាកចេញ

ពីក្នុងចំណោមមនុស្សជាតិជាយូរមកហើយ ហើយក្រោយមក ខ្ញុំក៏លេចមកជាថ្មីជាមួយនឹងសិរីល្អ នៅក្នុងចំណោមមនុស្ស។ ខ្ញុំជាព្រះដែលទទួលបានការថ្វាយបង្គំច្រើនសម័យកាលរាប់មិនអស់តាំងពីមុនមក ហើយខ្ញុំក៏ជាទារកដែលពួកសាសន៍អ៊ីស្រាអែលបានបោះបង់ចោលជាច្រើនសម័យកាលរាប់មិនអស់តាំងពីមុនមកដែរ។ លើសពីនេះ ខ្ញុំគឺជាព្រះដ៏មានគ្រប់ព្រះចេស្ដា ពោរពេញដោយសិរីល្អក្នុងសម័យបច្ចុប្បន្ននេះ! ចូរឲ្យមនុស្សទាំងអស់គ្នាចូលមកចំពោះបល្ល័ង្ករបស់ខ្ញុំ ហើយមើលឃើញព្រះភក្ត្រដ៏មានសិរីល្អរបស់ខ្ញុំ ស្ដាប់ព្រះសូរសៀងរបស់ខ្ញុំ និងសម្លឹងមើលទៅឯស្នាព្រះហស្ដរបស់ខ្ញុំ។ នេះគឺជាបំណងព្រះហឫទ័យទាំងស្រុងរបស់ខ្ញុំ វាជាទីបញ្ចប់ និងជាចំណុចកំពូលនៃផែនការរបស់ខ្ញុំ ហើយក៏ជាគោលបំណងនៃការគ្រប់គ្រងរបស់ខ្ញុំ ដើម្បីឲ្យមនុស្សគ្រប់ជាតិសាសន៍ថ្វាយបង្គំខ្ញុំ ឲ្យមនុស្សគ្រប់ភាសាទទួលស្គាល់ខ្ញុំ ឲ្យមនុស្សគ្រប់ៗគ្នាដាក់សេចក្ដីជំនឿរបស់គេមកលើខ្ញុំ ហើយឲ្យមនុស្សគ្រប់ៗគ្នាស្ថិតក្រោមការគ្រប់គ្រងរបស់ខ្ញុំ!

# ភាពខុសគ្នាដ៏សំខាន់
# រវាងព្រះដែលយកកំណើតជាមនុស្ស
# និងមនុស្សដែលត្រូវបានព្រះជាម្ចាស់ត្រាស់បង្គាប់

ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់បានកំពុងតែស្វែងរកអស់រយៈពេលជាច្រើនឆ្នាំកាលដែលទ្រង់ធ្វើការនៅលើផែនដី ហើយព្រះជាម្ចាស់ក៏បានប្រើមនុស្សជាច្រើនផងដែរ ដើម្បីធ្វើកិច្ចការរបស់ទ្រង់នៅគ្រប់យុគសម័យកាល។ ប៉ុន្តែ សម្រាប់អ្វីទាំងអស់នៅក្នុងគ្រានេះវិញ ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់មិនបានរកឃើញកន្លែងសម្រាកដ៏សមគួរមួយនោះឡើយ ជាហេតុនាំឲ្យព្រះជាម្ចាស់ទ្រង់ ផ្លាស់ប្ដូរមនុស្សផ្សេងៗនៅក្នុងចំណោមពួកគេ ដើម្បីធ្វើកិច្ចការរបស់ទ្រង់។ សរុបមក កិច្ចការរបស់ទ្រង់ត្រូវបានសម្រេចតាមរយៈមនុស្ស។ អាចនិយាយបានថា សម្រាប់ប៉ុន្មានឆ្នាំមកនោះ

កិច្ចការរបស់ព្រះជាម្ចាស់មិនដែលឈប់សោះឡើយ ប៉ុន្តែកិច្ចការរបស់ទ្រង់ត្រូវបានអនុវត្តបន្តនៅក្នុងមនុស្ស រហូតមកដល់ពេលសព្វថ្ងៃ។ ទោះបីព្រះជាម្ចាស់បានមានបន្ទូលជាច្រើន និងបានធ្វើកិច្ចការជាច្រើនក៏ដោយ ក៏មនុស្សនៅតែមិនស្គាល់ទ្រង់ដដែល ហើយទាំងអស់នេះគឺដោយសារតែព្រះជាម្ចាស់មិនដែលបង្ហាញអង្គទ្រង់ឲ្យមនុស្សបានឃើញ ហើយក៏ដោយសារតែទ្រង់គ្មានទម្រង់មួយដែលពិតជាក់ស្ដែងផងដែរ។ ដូច្នេះហើយបានជាព្រះជាម្ចាស់ត្រូវតែសម្រេចកិច្ចការនេះ ដែលជាកិច្ចការនៃការនាំមនុស្សទាំងអស់ឲ្យស្គាល់ពីភាពសំខាន់ជាក់ស្ដែងអំពីព្រះជាម្ចាស់ដ៏ពិត។ ដើម្បីសម្រេចកិច្ចការនេះបាន ព្រះជាម្ចាស់ត្រូវតែបើកសម្ដែងព្រះវិញ្ញាណរបស់ទ្រង់នៅក្នុងភាពជាមនុស្សពិតៗ និងធ្វើកិច្ចការរបស់ទ្រង់នៅកណ្ដាលចំណោមពួកគេ។ មានតែពេលដែលព្រះវិញ្ញាណរបស់ព្រះជាម្ចាស់យកទម្រង់ជាមនុស្ស ដោយពាក់សាច់ និងឆ្អឹង ហើយដើរនៅក្នុងចំណោមមនុស្ស រួមដំណើរជាមួយពួកគេនៅក្នុងជីវិតរបស់គេ ពេលខ្លះបង្ហាញខ្លួន ហើយពេលខ្លះទៀតព្រះអង្គធ្វើការលាក់អង្គទ្រង់ទេ ទើបមនុស្សអាចមានការយល់ដឹងកាន់តែស៊ីជម្រៅអំពីទ្រង់។ ប្រសិនបើព្រះជាម្ចាស់បន្តនៅក្នុងសាច់ឈាម នោះទ្រង់នឹងមិនអាចសម្រេចកិច្ចការរបស់ទ្រង់បានទាំងស្រុងឡើយ។ ក្រោយពេលធ្វើការនៅក្នុងសាច់ឈាមអស់ពេលមួយរយៈ ដើម្បីធ្វើព័ន្ធកិច្ចដែលត្រូវសម្រេចនៅក្នុងសាច់ឈាមរួច ព្រះជាម្ចាស់នឹងត្រូវចាកចេញពីសាច់ឈាម ហើយធ្វើការនៅក្នុងពិភពខាងវិញ្ញាណក្នុងរូបភាពនៃសាច់ឈាម ដូចដែលព្រះយេស៊ូវបានធ្វើក្រោយពេលទ្រង់បានធ្វើការមួយរយៈនៅក្នុងភាពជាមនុស្សសាមញ្ញ ហើយបានបញ្ចប់គ្រប់កិច្ចការដែលទ្រង់ត្រូវសម្រេច។ អ្នករាល់គ្នាប្រហែលចងចាំអំពីបទគម្ពីរនេះដែលដកស្រង់ចេញពី «ផ្លូវ ... (៥)»៖ «ទូលបង្គំនឹកចាំអំពីព្រះវរបិតានៃទូលបង្គំដែលមានបន្ទូលមកទូលបង្គំថា 'នៅលើផែនដី ចូរស្វះស្វែងធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះវរបិតារបស់អ្នក និងបំពេញបញ្ជាបេសកកម្មរបស់ទ្រង់ទៅ។ គ្មានអ្វីផ្សេងទៀតដែលអ្នកត្រូវខ្វល់នោះទេ។'» តើអ្នកមើលឃើញអ្វីខ្លះនៅក្នុងបទគម្ពីរនេះ? នៅពេលដែលព្រះជាម្ចាស់យាងមកកាន់ផែនដី ទ្រង់ធ្វើតែកិច្ចការណាដែលស្ថិតនៅក្នុងភាពជា

ព្រះប៉ុណ្ណោះ ហើយនោះជាអ្វីដែលព្រះវិញ្ញាណនៃស្ថានសួគ៌បានផ្ទុកផ្ដាក់ដល់ព្រះដែលយកកំណើតជាមនុស្ស។ នៅពេលដែលទ្រង់យាងមក ទ្រង់គ្រាន់តែប្រកាសព្រះបន្ទូលនៅទូទាំងទឹកដី ដើម្បីថ្លែងព្រះសូរសៀងរបស់ទ្រង់ តាមរយៈមធ្យោបាយផ្សេងៗ និងចេញពីទិដ្ឋភាពផ្សេងៗប៉ុណ្ណោះ។ ទ្រង់យកការផ្គត់ផ្គង់តម្រូវការរបស់មនុស្ស និងការបង្រៀនមនុស្សជាគោលដៅ និងជាគោលការណ៍ការងាររបស់ទ្រង់ ហើយទ្រង់មិនខ្វល់ជាមួយកិច្ចការផ្សេងទៀត ដូចជាទំនាក់ទំនងអន្តរបុគ្គល ឬសេចក្ដីលម្អិតនៃជីវិតរបស់មនុស្សឡើយ។ ព័ន្ធកិច្ចចម្បងរបស់ទ្រង់ គឺជាការប្រកាសព្រះបន្ទូល ជំនួសឲ្យព្រះវិញ្ញាណ។ នៅពេលដែលព្រះវិញ្ញាណរបស់ព្រះជាម្ចាស់បង្ហាញអង្គទ្រង់នៅក្នុងសាច់ឈាម ទ្រង់គ្រាន់តែបំពេញដល់តម្រូវការនៃជីវិតរបស់មនុស្ស និងប្រកាសនូវសេចក្ដីពិតប៉ុណ្ណោះ។ ទ្រង់មិនបានពាក់ព័ន្ធនៅក្នុងកិច្ចការរបស់មនុស្សឡើយ គឺអាចនិយាយបានថា ទ្រង់មិនចូលរួមនៅក្នុងកិច្ចការក្នុងភាពជាមនុស្សទេទេ។ មនុស្សមិនអាចធ្វើកិច្ចការរបស់ព្រះ ហើយព្រះជាម្ចាស់មិនពាក់ព័ន្ធក្នុងកិច្ចការរបស់មនុស្ស។ ប៉ុន្មានឆ្នាំដោយចាប់តាំងពីព្រះជាម្ចាស់បានយាងមកផែនដី ដើម្បីធ្វើនូវកិច្ចការរបស់ទ្រង់ ព្រះអង្គតែងតែធ្វើវាតាមរយៈមនុស្ស។ យ៉ាងណាមិញ មនុស្សទាំងនេះមិនអាចត្រូវបានចាត់ទុកដូចជាព្រះដែលយកកំណើតជាមនុស្សឡើយ គឺគ្រាន់តែជាមនុស្សដែលត្រូវបានព្រះជាម្ចាស់ត្រាស់បង្គាប់ប៉ុណ្ណោះ។ នៅគ្រាដដែលនោះ ព្រះជាម្ចាស់នាពេលបច្ចុប្បន្ន អាចមានបន្ទូលដោយផ្ទាល់ចេញពីទិដ្ឋភាពនៃភាពជាព្រះ ដោយប្រកាសអំពីព្រះសូរសៀង និងការធ្វើការជំនួសឲ្យព្រះវិញ្ញាណ។ អស់អ្នកដែលព្រះជាម្ចាស់បានត្រាស់បង្គាប់នៅទូទាំងយុគសម័យកាល គឺដូចជាឧទាហរណ៍នៃព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ដែលកំពុងតែធ្វើការនៅក្នុងរូបកាយខាងសាច់ឈាមដូច្នេះដែរ។ ហេតុអ្វីបានជាពួកគេមិនអាចត្រូវបានហៅថាជាព្រះជាម្ចាស់ទៅ? ប៉ុន្តែព្រះជាម្ចាស់នាពេលបច្ចុប្បន្នក៏ជាព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ដែលកំពុងធ្វើការដោយផ្ទាល់នៅក្នុងសាច់ឈាមផងដែរ ហើយព្រះយេស៊ូវក៏ជាព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ដែលកំពុងធ្វើការនៅក្នុងសាច់ឈាមផងដែរ ដូច្នេះ ព្រះអង្គទាំងពីរក៏ត្រូវ

បានហៅថាជាព្រះជាម្ចាស់ផងដែរ។ តើវាមានលក្ខណៈខុសគ្នាយ៉ាងដូចម្ដេចទៅ? មនុស្សដែលព្រះជាម្ចាស់បានត្រាស់បង្គាប់នៅទូទាំងយុគសម័យកាល សុទ្ធតែមានសមត្ថភាពចេះគិត និងត្រិះរិះពិចារណាតាមធម្មតា។ ពួកគេទាំងអស់គ្នាបានយល់អំពីគោលការណ៍នៃការប្រព្រឹត្តរបស់មនុស្ស។ ពួកគេមានគំនិតជាមនុស្សសាមញ្ញ ហើយក៏មានអ្វីៗគ្រប់យ៉ាងដែលមនុស្សសាមញ្ញគួរតែមានផងដែរ។ ពួកគេភាគច្រើនមាននូវទេពកោសល្យ និងបញ្ញាវាងវៃអស្ចារ្យ។ ដើម្បីធ្វើឲ្យមនុស្សទាំងនេះគ្រប់លក្ខណ៍ ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ ប្រើប្រាស់នូវទេពកោសល្យរបស់គេ ដែលជាព្រះអំណោយទានដែលព្រះជាម្ចាស់ប្រទានឲ្យ។ ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ប្រើប្រាស់ទេពកោសល្យរបស់គេ ប្រើប្រាស់ចំណុចខ្លាំងរបស់គេ ដើម្បីបម្រើព្រះជាម្ចាស់។ ប៉ុន្ដែសារជាតិរបស់ព្រះជាម្ចាស់មិនមាននូវគំនិត ឬយោបល់នោះទេ ដោយមិនមានលាយឡំនូវចេតនារបស់មនុស្ស ហើយថែមទាំងខ្វះនូវអ្វីដែលមនុស្សសាមញ្ញមានទៀតផង។ គឺអាចនិយាយបានថា ទ្រង់មិនធ្លាប់ស្គាល់គោលការណ៍នៃការប្រព្រឹត្តិរបស់មនុស្សឡើយ។ នេះជាលក្ខណៈរបស់ទ្រង់ នៅពេលដែលព្រះជាម្ចាស់នាពេលបច្ចុប្បន្នយាងមកកាន់ផែនដី។ កិច្ចការ និងព្រះបន្ទូលរបស់ទ្រង់មិនមានលាយឡំជាមួយចេតនា ឬគំនិតរបស់មនុស្សទេ ប៉ុន្ដែវាជាការស្ដែងចេញដោយផ្ទាល់អំពីចេតនារបស់ព្រះវិញ្ញាណ ហើយទ្រង់ធ្វើការដោយផ្ទាល់ ជំនួសឲ្យព្រះជាម្ចាស់។ នេះមានន័យថា ព្រះវិញ្ញាណមានបន្ទូលដោយផ្ទាល់ និងមានន័យថា ភាពជាព្រះធ្វើកិច្ចការដោយផ្ទាល់ ដោយគ្មានលាយឡំជាមួយចេតនារបស់មនុស្ស សូម្បីតែបន្ដិចនោះឡើយ។ ម្យ៉ាងទៀត ព្រះដែលយកកំណើតជាមនុស្សតំណាងដោយផ្ទាល់នូវភាពជាព្រះ ដោយគ្មានគំនិត ឬយោបល់របស់មនុស្សឡើយ ហើយក៏គ្មានការយល់ដឹងអំពីគោលការណ៍នៃការប្រព្រឹត្តរបស់មនុស្សផងដែរ។ បើសិនជាមានតែភាពជាព្រះជាអ្នកធ្វើការ (មានន័យថា បើសិនជាមានតែព្រះជាម្ចាស់ផ្ទាល់ជាអ្នកធ្វើការ) នោះវានឹងគ្មានផ្លូវឲ្យកិច្ចការរបស់ព្រះជាម្ចាស់ត្រូវបានអនុវត្តនៅលើផែនដីនោះឡើយ។ ដូច្នេះ នៅពេលដែលព្រះជាម្ចាស់យាងមកកាន់ផែនដី ទ្រង់ត្រូវតែមានមនុស្សមួយក្រុមតូចដែលទ្រង់អាចត្រាស់បង្គាប់ ដើម្បី

ធ្វើការនៅក្នុងភាពជាមនុស្ស ទន្ទឹមជាមួយកិច្ចការដែលព្រះជាម្ចាស់ធ្វើនៅក្នុងភាពជាព្រះ។ ម្យ៉ាងទៀត ទ្រង់ប្រើប្រាស់កិច្ចការរបស់មនុស្ស ដើម្បីគាំទ្រដល់កិច្ចការជាព្រះរបស់ទ្រង់។ បើមិនដូច្នេះទេ វានឹងគ្មានផ្លូវដែលមនុស្សអាចធ្វើកិច្ចការរបស់ព្រះដោយផ្ទាល់បានឡើយ។ នេះជាលក្ខណៈនៃការធ្វើការរបស់ព្រះយេស៊ូវ និងពួកសិស្សរបស់ទ្រង់។ ក្នុងពេលដែលទ្រង់គង់នៅក្នុងពិភពលោក ព្រះយេស៊ូវបានលុបបំបាត់ចោលក្រឹត្យវិន័យចាស់ៗ ហើយបង្កើតនូវបទបញ្ញត្តិថ្មីៗ។ ទ្រង់ក៏មានបន្ទូលជាច្រើនផងដែរ។ គ្រប់កិច្ចការទាំងអស់នេះត្រូវបានសម្រេចនៅក្នុងភាពជាព្រះ។ ឯមនុស្សផ្សេងទៀតដូចជា ពេត្រុស ប៉ុល និងយ៉ូហាន សុទ្ធតែសង់កិច្ចការជាបន្តបន្ទាប់របស់ពួកគេពីលើគ្រឹះនៃព្រះបន្ទូលរបស់ព្រះយេស៊ូវប៉ុណ្ណោះ។ គឺអាចនិយាយបានថា ព្រះជាម្ចាស់បានចាប់ផ្ដើមនូវកិច្ចការរបស់ទ្រង់នៅក្នុងយុគសម័យនោះ ដោយបង្ហាញនូវទីចាប់ផ្ដើមនៃយុគសម័យនៃព្រះគុណ។ ទ្រង់បាននាំមកនូវយុគសម័យមួយថ្មី លុបបំបាត់អ្វីដែលចាស់ ហើយក៏សម្រេចតាមព្រះបន្ទូលដែលថែងថា «ព្រះជាម្ចាស់ជាដើមដំបូង និងជាទីបញ្ចប់»។ ម្យ៉ាងទៀត មនុស្សត្រូវតែធ្វើកិច្ចការរបស់មនុស្សនៅពីលើគ្រឹះនៃកិច្ចការដែលមកពីព្រះ។ នៅពេលដែលព្រះយេស៊ូវបានមានបន្ទូលគ្រប់យ៉ាងដែលទ្រង់ត្រូវមានបន្ទូល និងបានបង្ហើយកិច្ចការរបស់ទ្រង់នៅលើផែនដីរួចហើយ ទ្រង់ក៏បានចាកចេញពីមនុស្ស។ ក្រោយមក មនុស្សទាំងអស់ធ្វើការស្របតាមគោលការណ៍ដែលបានបង្ហាញនៅក្នុងព្រះបន្ទូលរបស់ទ្រង់ និងបានអនុវត្តស្របទៅតាមសេចក្ដីពិតដែលទ្រង់បានមានបន្ទូល។ មនុស្សទាំងអស់នេះបានធ្វើការសម្រាប់ព្រះយេស៊ូវ។ ប្រសិនបើព្រះយេស៊ូវធ្វើការនេះតែអង្គទ្រង់ នោះទោះបីទ្រង់មានបន្ទូលច្រើនប៉ុនណាក៏មនុស្សគ្មានផ្លូវនឹងយល់អំពីព្រះបន្ទូលរបស់ទ្រង់នោះដែរ ដោយសារតែទ្រង់កំពុងតែធ្វើការនៅក្នុងភាពជាព្រះ ហើយអាចមានបន្ទូលនៃភាពជាព្រះប៉ុណ្ណោះ ហើយទ្រង់មិនអាចពន្យល់ដល់ចំណុចមួយដែលមនុស្សសាមញ្ញអាចយល់ព្រះបន្ទូលរបស់ទ្រង់បានឡើយ។ ដូច្នេះហើយបានជាទ្រង់ត្រូវមានពួកសាវ័ក និងពួកហោរា ដែលបានមកតាមក្រោយទ្រង់ ដើម្បីជួយបំពេញបន្ថែមដល់កិច្ចការរបស់ទ្រង់។ នេះជាគោល

ការណ៍អំពីរបៀបដែលព្រះដែលយកកំណើតជាមនុស្សធ្វើកិច្ចការរបស់ទ្រង់ ដោយប្រើប្រាស់សាច់ឈាមជាមនុស្ស ដើម្បីមានបន្ទូល និងធ្វើការឲ្យសម្រេចកិច្ចការនៃភាពជាព្រះ ហើយបន្ទាប់មក ប្រើប្រាស់មនុស្សពីរបីនាក់ ឬប្រហែលច្រើននាក់ ដែលជាមនុស្សដែលស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ដើម្បីបំពេញបន្ថែមដល់កិច្ចការរបស់ទ្រង់។ ព្រះជាម្ចាស់ត្រាស់បង្គាប់មនុស្សដែលស្របតាមព្រះហឫទ័យរបស់ទ្រង់ ដើម្បីធ្វើកិច្ចការនៃការគង្វាល និងការផ្ដល់ទឹកនៅក្នុងភាពជាមនុស្ស ដើម្បីឲ្យពួកជ្រើសតាំងរបស់ព្រះជាម្ចាស់អាចយល់អំពីតថភាពនៃសេចក្ដីពិត។

នៅពេលដែលទ្រង់បានយាងមកក្លាយជាសាច់ឈាម ប្រសិនបើព្រះជាម្ចាស់ធ្វើតែកិច្ចការនៃភាពជាព្រះ ហើយគ្មានមនុស្សដែលស្របតាមព្រះហឫទ័យរបស់ទ្រង់ធ្វើការរួមជាមួយទ្រង់ទេ នោះមនុស្សនឹងគ្មានសមត្ថភាពយល់អំពីព្រះហឫទ័យរបស់ព្រះជាម្ចាស់ ឬផ្សារភ្ជាប់ជាមួយនឹងព្រះជាម្ចាស់នោះឡើយ។ ព្រះជាម្ចាស់ត្រូវតែប្រើប្រាស់មនុស្សសាមញ្ញ ដែលស្របតាមព្រះហឫទ័យរបស់ទ្រង់ក្នុងការសម្រេចកិច្ចការនេះ ដែលជាមើលថែ និងឃ្វាលដល់ពួកជំនុំ ដើម្បីឲ្យកម្រិតនៃការយល់ដឹងរបស់មនុស្សអាចស្រមើស្រមៃឃើញ ហើយខួរក្បាលរបស់គេអាចយល់បាន។ នៅក្នុងន័យម៉្យាងទៀត ព្រះជាម្ចាស់ប្រើប្រាស់មនុស្សមួយក្រុមតូច ដែលស្របតាមព្រះហឫទ័យរបស់ទ្រង់ ដើម្បី «បកស្រាយ» កិច្ចការដែលទ្រង់ធ្វើនៅក្នុងភាពជាព្រះរបស់ទ្រង់ ដើម្បីឲ្យមនុស្សអាចយល់អំពីកិច្ចការរបស់ទ្រង់ ដើម្បីបំផ្លាស់បំប្រែភាសារបស់ព្រះឲ្យក្លាយជាភាសារបស់មនុស្ស ដើម្បីឲ្យមនុស្សអាចស្វែងយល់ និងយល់ដឹងពីកិច្ចការរបស់ទ្រង់បាន។ បើព្រះជាម្ចាស់មិនធ្វើបែបនេះទេ នោះនឹងគ្មាននរណាម្នាក់យល់ភាសារបស់ព្រះជាម្ចាស់ឡើយ ដោយសារតែមនុស្សដែលស្របតាមព្រះហឫទ័យរបស់ព្រះ គឺជាចំនួនមនុស្សមួយក្រុមតូច ហើយសមត្ថភាពរបស់មនុស្សក្នុងការយល់ភាសារបស់ព្រះ ក៏នៅខ្សោយទៀត។ នោះជាហេតុផលដែលព្រះជាម្ចាស់ជ្រើសរើសវិធីសាស្ត្រនេះ នៅពេលដែលទ្រង់ធ្វើការនៅក្នុងសាច់ឈាមជាមនុស្សតែប៉ុណ្ណោះ។ បើមានតែកិច្ចការនៃព្រះ នោះវានឹងគ្មានផ្លូវដែលមនុស្សអាចដឹង ឬផ្សារភ្ជាប់ជាមួយនឹង

ព្រះជាម្ចាស់បានឡើយ ដោយសារតែមនុស្សមិនយល់ភាសារបស់ព្រះជាម្ចាស់ឡើយ។ មនុស្សអាចយល់ភាសានេះបាន លុះត្រាតែតាមរយៈភ្នាក់ងារនៃមនុស្សដែលស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដែលធ្វើការបកស្រាយបញ្ជាក់ពីព្រះបន្ទូលរបស់ទ្រង់។ យ៉ាងណាមិញ បើមានតែមនុស្សបែបនេះធ្វើការនៅក្នុងភាពជាមនុស្ស វាអាចបន្តនៅក្នុងជីវិតសាមញ្ញរបស់មនុស្សតែប៉ុណ្ណោះ ប៉ុន្តែវាមិនអាចបំផ្លាស់បំប្រែនិស្ស័យរបស់មនុស្សបានឡើយ។ កិច្ចការរបស់ព្រះជាម្ចាស់ មិនអាចមានទីចាប់ផ្ដើមថ្មីទេ ហើយវានឹងមានតែរបៀបចាស់ៗដដែលៗ គួរឲ្យធុញទ្រាន់ប៉ុណ្ណោះ។ មានតែតាមរយៈភ្នាក់ងារនៃព្រះដែលយកកំណើតជាមនុស្ស ដែលមានបន្ទូលនូវអ្វីៗគ្រប់យ៉ាងដែលត្រូវថ្លែង និងធ្វើអ្វីៗគ្រប់យ៉ាងដែលត្រូវធ្វើ ក្នុងអំឡុងពេលនៃការយកកំណើតជាមនុស្សរបស់ទ្រង់ ហើយក្រោយមក មនុស្សធ្វើការ និងដកពិសោធន៍ ស្របតាមព្រះបន្ទូលរបស់ទ្រង់ប៉ុណ្ណោះ ទើបនិស្ស័យរបស់ពួកគេនឹងអាចផ្លាស់ប្រែ និងអាចហូរទៅតាមពេលវេលា។ ព្រះអង្គដែលធ្វើការនៅក្នុងភាពជាព្រះ តំណាងឲ្យព្រះជាម្ចាស់ ចំណែកឯអ្នកដែលធ្វើការនៅក្នុងភាពជាមនុស្ស គឺជាមនុស្សដែលព្រះជាម្ចាស់ត្រាស់បង្គាប់។ គឺអាចនិយាយបានថា ព្រះដែលយកកំណើតជាមនុស្សមានលក្ខណៈខុសគ្នាយ៉ាងខ្លាំងពីមនុស្សដែលព្រះជាម្ចាស់បានត្រាស់បង្គាប់។ ព្រះដែលយកកំណើតជាមនុស្សអាចធ្វើកិច្ចការនៃភាពជាព្រះ ខណៈមនុស្សដែលត្រូវបានព្រះជាម្ចាស់ត្រាស់បង្គាប់ មិនអាចធ្វើកិច្ចការនេះបានឡើយ។ នៅដើមដំបូងនៃយុគសម័យនីមួយៗ ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់មានបន្ទូលដោយផ្ទាល់ ហើយផ្ដើមឡើងនូវយុគសម័យថ្មី ដើម្បីនាំមនុស្សចូលទៅក្នុងទីចាប់ផ្ដើមមួយថ្មី។ នៅពេលដែលទ្រង់បានមានបន្ទូលចប់ហើយ ការនេះជាសញ្ញាបញ្ជាក់ថា កិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងភាពជាព្រះក៏ត្រូវបានបញ្ចប់ផងដែរ។ ក្រោយមក មនុស្សទាំងអស់ដែលដើរតាមបុគ្គលដែលព្រះជាម្ចាស់បានប្រើប្រាស់ ក៏ទទួលបានបទពិសោធជីវិតរបស់គេផងដែរ។ ដូចគ្នាផងដែរ ការនេះក៏ជាដំណាក់កាលមួយដែលព្រះជាម្ចាស់នាំមនុស្សចូលទៅក្នុងយុគសម័យថ្មី និងប្រទានឲ្យមនុស្សនូវទីចាប់ផ្ដើមថ្មីផងដែរ ដ្បិតនេះជាពេលមួយដែលកិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងសាច់ឈាមត្រូវបានបិទបញ្ចប់។

ព្រះជាម្ចាស់មិនយាងមកផែនដី ដើម្បីធ្វើឲ្យភាពជាមនុស្សសាមញ្ញរបស់ទ្រង់ទៅជាគ្រប់លក្ខណ៍ឡើយ ហើយទ្រង់ក៏មិនធ្វើកិច្ចការនៃភាពជាមនុស្សសាមញ្ញនោះដែរ។ ទ្រង់យាងមក ដើម្បីធ្វើកិច្ចការនៃភាពជាព្រះនៅក្នុងភាពជាមនុស្សសាមញ្ញប៉ុណ្ណោះ។ អ្វីដែលព្រះជាម្ចាស់មានបន្ទូលចេញពីភាពជាមនុស្សសាមញ្ញ មិនដូចជាអ្វីដែលមនុស្សស្រមៃនោះឡើយ។ មនុស្សបានដាក់និយមន័យពាក្យ «ភាពជាមនុស្សសាមញ្ញ» ថាជាការមានប្រពន្ធ ឬប្ដី និងមានកូនប្រុសកូនស្រី។ នេះគឺជាភស្តុតាងដែលបង្ហាញថា មនុស្សម្នាក់ជាមនុស្សសាមញ្ញ។ យ៉ាងណាមិញ ព្រះជាម្ចាស់មិនទតឃើញបែបនេះឡើយ។ ទ្រង់ទតឃើញភាពជាមនុស្សសាមញ្ញ ជាការមានគំនិតជាមនុស្សសាមញ្ញ ជាការមានជីវិតជាមនុស្សសាមញ្ញ ហើយនិងជាការកើតចេញពីមនុស្សសាមញ្ញ។ ប៉ុន្តែ ភាពសាមញ្ញរបស់ទ្រង់មិនរួមបញ្ចូលការមានប្រពន្ធ ឬប្ដី និងការមានកូន ដោយស្របទៅតាមរបៀបដែលមនុស្សនិយាយអំពីភាពសាមញ្ញនោះឡើយ។ ចំពោះមនុស្ស អ្វីដែលព្រះជាម្ចាស់មានបន្ទូលអំពីភាពជាមនុស្សសាមញ្ញនេះ គឺជាអ្វីដែលមនុស្សចាត់ទុកថានៅខ្វះភាពជាមនុស្សនៅឡើយ សឹងតែខ្វះនូវអារម្មណ៍ និងហាក់ដូចជាគ្មានតម្រូវការខាងសាច់ឈាម ដូចជាព្រះយេស៊ូវដែលមានសំបកក្រៅជាមនុស្សសាមញ្ញ និងយករូបរាងជាមនុស្សសាមញ្ញ ប៉ុន្តែនៅក្នុងសារជាតិទ្រង់វិញ គ្មានសោះឡើយនូវអ្វីដែលមនុស្សសាមញ្ញគួរតែមាន។ ចេញពីទស្សនៈនេះ មនុស្សមើលឃើញថា សារជាតិរបស់ព្រះដែលយកកំណើតជាមនុស្សមិនមានភាពទាំងស្រុងនៃភាពជាមនុស្សសាមញ្ញឡើយ ប៉ុន្តែគ្រាន់តែមាននូវផ្នែកមួយនៃអ្វីៗដែលមនុស្សគួរតែមានប៉ុណ្ណោះ ដើម្បីគាំទ្រដល់ជីវិតប្រចាំថ្ងៃរបស់មនុស្សសាមញ្ញ និងទ្រទ្រង់ដល់អំណាចនៃការត្រិះរិះពិចារណារបស់មនុស្សសាមញ្ញ។ ប៉ុន្តែ ចំណុចទាំងនេះគ្មានពាក់ព័ន្ធជាមួយអ្វីដែលមនុស្សចាត់ទុកជាភាពជាមនុស្សសាមញ្ញនោះឡើយ។ វាជាអ្វីដែលព្រះដែលយកកំណើតជាមនុស្សគួរតែមាន។ យ៉ាងណាមិញ មនុស្សនៅតែបន្តនិយាយថា ព្រះដែលយកកំណើតជាមនុស្សអាចមានភាពជាមនុស្សសាមញ្ញបានលុះត្រាតែទ្រង់មានប្រពន្ធ មានកូនប្រុសស្រី និងមានក្រុមគ្រួសារ ហើយបើទ្រង់គ្មាន

អ្វីៗទាំងនេះទេ ពួកគេនិយាយថា ទ្រង់មិនមែនជាមនុស្សសាមញ្ញឡើយ។ ខ្ញុំចង់សួរអ្នកថា «តើព្រះជាម្ចាស់មានប្រពន្ធទេ? តើព្រះជាម្ចាស់អាចមានប្ដីទេ? តើព្រះជាម្ចាស់អាចមានកូនដែរឬទេ?» តើទាំងនេះមិនមែនជាជំនឿខុសឆ្គងទេឬអី? ប៉ុន្តែ ព្រះដែលយកកំណើតជាមនុស្សមិនអាចយាងចេញពីក្រហែងថ្ម ឬធ្លាក់ចុះពីលើមេឃទេ។ ទ្រង់អាចប្រសូតមក ចូលក្នុងគ្រួសារមនុស្សសាមញ្ញប៉ុណ្ណោះ។ នោះជាហេតុផលដែលទ្រង់មានឪពុកម្ដាយ និងប្អូនស្រីៗ។ នេះជាចំណុចដែលភាពជាមនុស្សសាមញ្ញរបស់ព្រះដែលយកកំណើតជាមនុស្សគួរតែមាន។ ហើយនេះ ជាករណីរបស់ព្រះយេស៊ូវ ដ្បិតទ្រង់មានឪពុកម្ដាយ ប្អូនស្រី និងប្អូនប្រុស ហើយអ្វីៗទាំងអស់នេះ គឺជាភាពសាមញ្ញ។ ប៉ុន្តែ បើទ្រង់មានប្រពន្ធ និងកូនប្រុសស្រី នោះទ្រង់នឹងមិនមានភាពជាមនុស្សសាមញ្ញដែលព្រះជាម្ចាស់មានគោលបំណងសម្រាប់ព្រះដែលយកកំណើតជាមនុស្ស ឲ្យមាននោះឡើយ។ បើបែបនេះមែន នោះទ្រង់នឹងមិនអាចធ្វើការជំនួសឲ្យភាពជាព្រះបានឡើយ។ ប៉ុន្តែ ជាក់ស្ដែង ដោយសារតែទ្រង់គ្មានប្រពន្ធ ឬកូន ហើយកើតចេញពីមនុស្សសាមញ្ញ ចូលក្នុងគ្រួសារសាមញ្ញ ដូច្នេះ ទ្រង់អាចធ្វើកិច្ចការនៃភាពជាព្រះបាន។ ដើម្បីបញ្ជាក់ការនេះឲ្យកាន់តែច្បាស់ អ្វីដែលព្រះជាម្ចាស់ចាត់ទុកជាមនុស្សសាមញ្ញ គឺជាមនុស្សដែលកើតចូលក្នុងគ្រួសារសាមញ្ញមួយ។ មានតែមនុស្សបែបនេះទេ ទើបមានគុណសម្បត្តិគ្រប់គ្រាន់ ដើម្បីធ្វើកិច្ចការរបស់ព្រះ។ នៅក្នុងន័យម្យ៉ាងទៀត បើមនុស្សមានប្រពន្ធ កូន ឬប្ដី មនុស្សនោះនឹងមិនអាចធ្វើកិច្ចការនៃព្រះបានឡើយ ព្រោះថាពួកគេនឹងមានតែភាពជាមនុស្សសាមញ្ញដែលមនុស្សទាមទារ ប៉ុន្តែមែនមែនជាភាពជានៃមនុស្សសាមញ្ញដែលព្រះជាម្ចាស់ទាមទារនោះឡើយ។ ការនោះត្រូវបានតម្រូវទុកដោយព្រះជាម្ចាស់ ហើយអ្វីដែលមនុស្សយល់ ជារឿយៗ គឺមានលក្ខណៈខុសគ្នាស្រឡះ។ នៅក្នុងដំណាក់កាលនៃកិច្ចការរបស់ព្រះជាម្ចាស់នេះ មាននូវរឿងជាច្រើនដែលផ្ទុយ និងខុសគ្នាយ៉ាងខ្លាំងពីសញ្ញាណរបស់មនុស្ស។ អាចនិយាយបានថា ដំណាក់កាលនៃកិច្ចការរបស់ព្រះជាម្ចាស់នេះ ផ្សំឡើងទាំងស្រុងចេញពីភាពជាព្រះកំពុងតែធ្វើការដោយផ្ទាល់ ដោយមានភាពជាមនុស្សដើរតួជំនួយ។ ដោយសារតែ

ព្រះជាម្ចាស់យាងមកផែនដី ដើម្បីធ្វើកិច្ចការរបស់ទ្រង់ដោយផ្ទាល់ ជាជាងអនុញ្ញាតឲ្យមនុស្សលូកដៃធ្វើវា នោះទ្រង់យកកំណើតជាមនុស្សនៅក្នុងសាច់ឈាមដោយផ្ទាល់ (នៅក្នុងមនុស្សសាមញ្ញមិនពេញលេញ) ដើម្បីធ្វើកិច្ចការរបស់ទ្រង់។ ទ្រង់ប្រើប្រាស់ការយកកំណើតជាមនុស្សនេះ ដើម្បីបង្ហាញទៅកាន់មនុស្សជាតិនូវយុគសម័យមួយថ្មី ដើម្បីប្រាប់ដល់មនុស្សជាតិអំពីជំហានបន្ទាប់នៅក្នុងកិច្ចការរបស់ទ្រង់ និងដើម្បីសុំឲ្យមនុស្សអនុវត្តតាមមាគ៌ាដែលបានពណ៌នានៅក្នុងព្រះបន្ទូលរបស់ទ្រង់។ ជារួមមក នេះជាកិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងសាច់ឈាម។ ទ្រង់រៀបនឹងចាកចេញពីមនុស្សជាតិ លែងគង់នៅក្នុងសាច់ឈាមនៃភាពជាមនុស្សសាមញ្ញទៀតហើយ ប៉ុន្តែផ្ទុយទៅវិញ ទ្រង់ចាកចេញពីមនុស្ស ដើម្បីចាប់ផ្ដើមផ្នែកមួយទៀតនៃកិច្ចការរបស់ទ្រង់។ បន្ទាប់មក ទ្រង់ប្រើប្រាស់មនុស្ស ដែលស្របតាមព្រះហឫទ័យរបស់ទ្រង់ក្នុងចំណោមមនុស្សមួយក្រុមនេះ ដើម្បីបន្តកិច្ចការរបស់ទ្រង់នៅលើផែនដី ប៉ុន្តែនៅក្នុងភាពជាមនុស្សរបស់គេ។

ព្រះដែលយកកំណើតជាមនុស្សមិនអាចបន្តនៅជាមួយមនុស្សជារៀងរហូតឡើយ ដោយសារតែព្រះជាម្ចាស់មានកិច្ចការជាច្រើនទៀតដែលត្រូវធ្វើ។ ទ្រង់មិនអាចជាប់ជំពាក់ជាមួយសាច់ឈាមឡើយ។ ទ្រង់ត្រូវតែលះបង់សាច់ឈាមចោល ដើម្បីធ្វើកិច្ចការដែលទ្រង់ត្រូវធ្វើ ទោះបីជាទ្រង់ត្រូវធ្វើកិច្ចការនោះនៅក្នុងរូបភាពជាសាច់ឈាមក៏ដោយ។ នៅពេលដែលព្រះជាម្ចាស់យាងមកផែនដី ទ្រង់មិនរង់ចាំរហូតដល់ទ្រង់បានដល់ទម្រង់មួយដែលមនុស្សសាមញ្ញគួរតែមានមុនពេលការសុគតនិងការចាកចេញពីមនុស្សជាតិនោះឡើយ។ មិនថាសាច់ឈាមរបស់ទ្រង់មានវ័យប៉ុនណានោះទេ នៅពេលដែលកិច្ចការរបស់ទ្រង់ត្រូវបានបញ្ចប់ នោះទ្រង់ត្រូវតែយាងចាកចេញពីមនុស្ស។ សម្រាប់ទ្រង់ វាគ្មានឡើយការមានវ័យចាស់នោះ ទ្រង់មិនបានរាប់ចំនួនថ្ងៃរបស់ទ្រង់ ស្របតាមអាយុកាលរបស់មនុស្សឡើយ ផ្ទុយទៅវិញ ទ្រង់បញ្ចប់ព្រះជន្មរបស់ទ្រង់នៅក្នុងសាច់ឈាម ស្របតាមជំហាននៃកិច្ចការរបស់ទ្រង់។ ប្រហែលមានមនុស្សខ្លះមានអារម្មណ៍ថា ការដែលយាងចូលក្នុងសាច់ឈាម

បែបនេះ ព្រះជាម្ចាស់ត្រូវតែមានព្រះជន្មដល់កម្រិតមួយ ត្រូវតែធំធាត់ឡើងរហូតដល់ពេញវ័យ ចូលដល់វ័យចំណាស់ ហើយចាកចេញទៅនៅពេលដែលរូបកាយនោះលែងដំណើរការប៉ុណ្ណោះ។ នេះជាការស្រមើស្រមៃរបស់មនុស្ស ប៉ុន្តែព្រះជាម្ចាស់មិនធ្វើការបែបនេះឡើយ។ ទ្រង់យាងចូលក្នុងសាច់ឈាម ដើម្បីធ្វើកិច្ចការដែលទ្រង់គួរតែធ្វើប៉ុណ្ណោះ ហើយទ្រង់មិនរស់នៅតាមបែបជាមនុស្សសាមញ្ញ ដែលកើតមកមានឪពុកម្ដាយ ធំធាត់ឡើង បង្កើតជាគ្រួសារ និងចាប់ផ្ដើមធ្វើការ មានកូន និងចិញ្ចឹមកូន ឬមានបទពិសោធនូវការឡើងចុះនៃជីវិតនោះឡើយ។ ទាំងអស់នេះគឺជាសកម្មភាពរបស់មនុស្សសាមញ្ញ។ នៅពេលដែលព្រះជាម្ចាស់យាងមកផែនដី នេះជាព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ដែលពាក់រូបកាយជាសាច់ឈាម យាងចូលក្នុងសាច់ឈាម ប៉ុន្តែព្រះជាម្ចាស់មិនរស់នៅជីវិតតាមបែបមនុស្សសាមញ្ញឡើយ។ ទ្រង់គ្រាន់តែយាងមក ដើម្បីសម្រេចផ្នែកមួយនៅក្នុងផែនការគ្រប់គ្រងរបស់ទ្រង់ប៉ុណ្ណោះ។ បន្ទាប់ពីនេះ ទ្រង់នឹងត្រូវចាកចេញពីមនុស្សជាតិ។ នៅពេលដែលទ្រង់យាងចូលទៅក្នុងសាច់ឈាម ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់មិនបានធ្វើឲ្យភាពជាមនុស្សសាមញ្ញខាងសាច់ឈាមនោះ បានគ្រប់លក្ខណ៍ឡើយ។ ផ្ទុយទៅវិញ នៅពេលកំណត់មួយដែលព្រះជាម្ចាស់បានតម្រូវទុកជាមុន ភាពជាព្រះត្រូវបន្តធ្វើការដោយផ្ទាល់វិញ។ ក្រោយពេលធ្វើគ្រប់កិច្ចការដែលទ្រង់ត្រូវធ្វើ និងបញ្ចប់ព័ន្ធកិច្ចរបស់ទ្រង់បានទាំងស្រុងហើយ ទើបកិច្ចការនៃព្រះវិញ្ញាណរបស់ព្រះជាម្ចាស់នៅក្នុងដំណាក់កាលនេះត្រូវបានបញ្ចប់ ហើយវាក៏ជាចំណុចដែលព្រះជន្មរបស់ព្រះដែលយកកំណើតជាមនុស្ស ត្រូវបានបញ្ចប់ផងដែរ មិនថារូបកាយខាងសាច់ឈាមរបស់ទ្រង់បានរស់នៅដល់អាយុកាលយូរប៉ុនណានោះឡើយ។ គឺអាចនិយាយបានថា មិនថារូបកាយខាងសាច់ឈាមចូលដល់ដំណាក់កាលអ្វីនៃជីវិត មិនថាវារស់នៅលើផែនដីបានយូរប៉ុនណានោះឡើយ ប៉ុន្តែអ្វីៗគ្រប់យ៉ាងត្រូវបានសម្រេចព្រះទ័យ ដោយកិច្ចការនៃព្រះវិញ្ញាណ។ វាគ្មានទាក់ទងជាមួយនឹងអ្វីដែលមនុស្សចាត់ទុកថាជាភាពជាមនុស្សសាមញ្ញនោះឡើយ។ ចូរយកព្រះយេស៊ូវជាឧទាហរណ៍ទៅចុះ។ ទ្រង់បានរស់នៅក្នុងសាច់ឈាមរយៈពេល

សាមសិបបីឆ្នាំកន្លះ។ ទាក់ទងនឹងអាយុកាលនៃរូបកាយជាមនុស្ស ទ្រង់មិនគួរសុគត នៅវ័យនេះឡើយ ហើយទ្រង់ក៏មិនគួរលាចាកលោកទៅបែបនេះនោះដែរ។ ប៉ុន្តែការនេះមិនប៉ះពាល់ដល់ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ឡើយ។ កិច្ចការរបស់ទ្រង់ត្រូវបានបញ្ចប់ នៅចំណុចដែលរូបកាយត្រូវបានដកបាត់ទៅ គឺបាត់រួមជាមួយព្រះវិញ្ញាណតែម្ដង។ នេះគឺជាគោលការណ៍ ដែលព្រះជាម្ចាស់ធ្វើការនៅក្នុងសាច់ឈាម។ បើនិយាយឲ្យចំ ភាពជាមនុស្សរបស់ព្រះដែលយកកំណើតជាមនុស្ស មិនមានភាពសំខាន់ជាចម្បងឡើយ។ សូមបញ្ជាក់ម្ដងទៀតថា ទ្រង់យាងមកផែនដី មិនមែនដើម្បីរស់នៅជីវិតជាមនុស្សសាមញ្ញម្នាក់នោះឡើយ។ ជាដំបូង ទ្រង់មិនបានចាប់ផ្ដើមជីវិតជាមនុស្សសាមញ្ញ ហើយបន្ទាប់មក ចាប់ផ្ដើមធ្វើការនោះឡើយ។ ផ្ទុយទៅវិញ ពេលដែលទ្រង់ប្រសូតចូលក្នុងគ្រួសារមនុស្សសាមញ្ញភ្លាម ទ្រង់អាចធ្វើកិច្ចការនៃព្រះបានភ្លាម ហើយកិច្ចការនៃព្រះនេះ ជាកិច្ចការមួយដែលមិនប្រឡាក់ប្រឡូកជាមួយចេតនារបស់មនុស្ស មិនមែនជាកិច្ចការខាងសាច់ឈាម មិនស្របតាមផ្លូវនៃសង្គម ឬមិនពាក់ព័ន្ធនឹងគំនិត ឬសញ្ញាណរបស់មនុស្សឡើយ ហើយលើសពីនេះទៅទៀត វាមិនពាក់ព័ន្ធនឹងទស្សនវិជ្ជានៃការរស់នៅរបស់មនុស្សនោះឡើយ។ នេះគឺជាកិច្ចការដែលព្រះយកកំណើតជាមនុស្សមានគោលបំណងចង់ធ្វើ ហើយវាក៏ជាភាពសំខាន់ជាក់ស្ដែងនៃការយកកំណើតជាមនុស្សរបស់ទ្រង់ផងដែរ។ ព្រះជាម្ចាស់យាងចូលក្នុងសាច់ឈាមជាចម្បង ដើម្បីធ្វើដំណាក់កាលមួយនៃកិច្ចការដែលត្រូវសម្រេចនៅក្នុងសាច់ឈាម ដោយមិនចាំបាច់ឆ្លងកាត់ដំណើរការមិនសំខាន់ផ្សេងទៀត ហើយសម្រាប់បទពិសោធរបស់មនុស្សសាមញ្ញ ទ្រង់មិនមាននោះឡើយ។ កិច្ចការដែលព្រះយកកំណើតជាមនុស្សត្រូវធ្វើ មិនរួមបញ្ចូលបទពិសោធរបស់មនុស្សសាមញ្ញនោះទេ។ ដូច្នេះ ព្រះជាម្ចាស់យាងចូលក្នុងសាច់ឈាមសម្រាប់ជាប្រយោជន៍នៃការសម្រេចកិច្ចការដែលទ្រង់ត្រូវសម្រេចនៅក្នុងសាច់ឈាមប៉ុណ្ណោះ។ អ្វីៗផ្សេងទៀតគ្មានពាក់ព័ន្ធជាមួយទ្រង់ឡើយ។ ទ្រង់មិនចាំបាច់ឆ្លងកាត់ដំណើរការជាច្រើនដែលមិនសំខាន់នោះទេ។ ពេលដែលកិច្ចការរបស់ទ្រង់ត្រូវបានបញ្ចប់ នោះភាពសំខាន់នៃការ

យកកំណើតជាមនុស្សរបស់ទ្រង់ ក៏ត្រូវបានបញ្ចប់ផងដែរ។ ការបញ្ចប់ដំណាក់កាលនេះ មានន័យថា កិច្ចការដែលទ្រង់ត្រូវធ្វើនៅក្នុងសាច់ឈាមបានបិទបញ្ចប់ ហើយព័ន្ធកិច្ចនៃសាច់ឈាមរបស់ទ្រង់ក៏បានបញ្ចប់ផងដែរ។ ប៉ុន្តែ ទ្រង់មិនអាចបន្តធ្វើការនៅក្នុងសាច់ឈាមជារៀងរហូតនោះឡើយ។ ទ្រង់ត្រូវតែបន្តទៅកាន់កន្លែងមួយទៀត ដើម្បីធ្វើការ ជាកន្លែងមួយនៅខាងក្រៅសាច់ឈាម។ មានតែបែបនេះទេ ទើបកិច្ចការរបស់ទ្រង់អាចត្រូវបានសម្រេចយ៉ាងពេញលេញ និងរីកចម្រើនបានលទ្ធផលកាន់តែខ្លាំង។ ព្រះជាម្ចាស់ធ្វើការស្របតាមផែនការដើមរបស់ទ្រង់។ កិច្ចការអ្វីដែលទ្រង់ត្រូវធ្វើ និងកិច្ចការអ្វីដែលទ្រង់បានបញ្ចប់ ទ្រង់ជ្រាបដឹងយ៉ាងច្បាស់តែម្ដង។ ព្រះជាម្ចាស់ដឹកនាំមនុស្សម្នាក់ៗឲ្យដើរតាមផ្លូវមួយដែលទ្រង់បានតម្រូវទុករួចជាស្រេច។ គ្មាននរណាម្នាក់ អាចរួចផុតនោះឡើយ។ គឺមានតែមនុស្សដែលដើរតាមការដឹកនាំនៃព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ប៉ុណ្ណោះ ទើបគេអាចចូលសម្រាកបាន។ នៅក្នុងកិច្ចការបន្ទាប់ វាអាចនឹងគ្មានព្រះជាម្ចាស់ដែលមានបន្ទូលនៅក្នុងសាច់ឈាម ដើម្បីដឹកនាំមនុស្សទៀតឡើយ ប៉ុន្តែអាចជាព្រះវិញ្ញាណនៅក្នុងទម្រង់ជាក់ស្ដែង ធ្វើការដឹកនាំជីវិតរបស់មនុស្សវិញម្ដង។ មានតែបែបនេះទេ ទើបមនុស្សអាចប៉ះពាល់ព្រះជាម្ចាស់យ៉ាងច្បាស់ សម្លឹងទៅកាន់ព្រះជាម្ចាស់ និងយល់កាន់តែច្បាស់អំពីការពិតដែលព្រះជាម្ចាស់តម្រូវទុក ហើយត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍ដោយព្រះជាម្ចាស់ដ៏ពិត។ នេះគឺជាកិច្ចការដែលព្រះជាម្ចាស់មានគោលបំណងចង់សម្រេច និងជាអ្វីដែលទ្រង់បានគ្រោងទុកជាយូរឆ្នាំមកហើយ។ ចាប់ពីពេលនេះតទៅ អ្នករាល់គ្នាគួរតែមើលឃើញផ្លូវដែលអ្នករាល់គ្នាគួរតែដើរហើយ!

# មនុស្សត្រូវតែផ្ដោតលើភាពជាក់ស្ដែង នៅក្នុងសេចក្ដីជំនឿ ពោលគឺការប្រណិប័តន៍តាម ពិធីសាសនា មិនមែនជាជំនឿទេ

តើអ្នកប្រណិប័តន៍តាមទំនៀមសាសនាចំនួនប៉ុន្មាន? តើប៉ុន្មានលើកហើយ ដែលអ្នកបានបះបោរប្រឆាំងនឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយដើរតាមផ្លូវរបស់ខ្លួនឯង? តើប៉ុន្មានលើកមកហើយ ដែលអ្នកអនុវត្តតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយព្រោះតែអ្នកពិតជាគិតពិចារណាពីបន្ទុករបស់ទ្រង់ ហើយព្យាយាមបំពេញតាមបំណងព្រះហឫទ័យព្រះអង្គ? អ្នកគួរយល់នូវព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយអនុវត្តទៅតាមព្រះបន្ទូល។ ចូរមានគោលការណ៍ចំពោះគ្រប់សកម្មភាព និងការប្រព្រឹត្តរបស់អ្នក ទោះគោលការណ៍នេះមិនមែនសំដៅលើការប្រកាន់ខ្ជាប់តាមច្បាប់ទម្លាប់ ឬធ្វើអ្វីមួយដោយទើសទាល់ ដើម្បីបង្ហាញឲ្យគេឃើញនោះឡើយ ផ្ទុយទៅវិញ វាសំដៅលើការអនុវត្តតាមសេចក្ដីពិត និងរស់នៅដោយព្រះបន្ទូលរបស់ព្រះជាម្ចាស់។ មានតែការអនុវត្តបែបនេះប៉ុណ្ណោះ ទើបផ្គាប់ព្រះហឫទ័យព្រះជាម្ចាស់បាន។ សកម្មភាពទាំងឡាយណា ដែលផ្គាប់ព្រះហឫទ័យព្រះជាម្ចាស់ គឺមិនមែនជាច្បាប់ទម្លាប់ទេ ប៉ុន្តែជាការអនុវត្តនូវសេចក្ដីពិត។ មនុស្សមួយចំនួនចូលចិត្តទាក់ទាញចំណាប់អារម្មណ៍មកលើខ្លួនឯង។ នៅចំពោះមុខបងប្អូនប្រុសស្រីរបស់ខ្លួន ពួកគេប្រហែលជានិយាយថាខ្លួនជំពាក់ព្រះជាម្ចាស់ ប៉ុន្តែនៅក្រោយខ្នងអ្នកទាំងនោះ ពួកគេមិនអនុវត្តនូវសេចក្ដីពិតទេ ហើយប្រព្រឹត្តខុសគ្នាស្រឡះ។ តើការទាំងនេះមិនមែនជាពួកផារិស៊ី ដែលកាន់សាសនាទេមែនទេ? មនុស្សម្នាក់ដែលពិតជាស្រលាញ់ព្រះជាម្ចាស់មែន ហើយមាននូវសេចក្ដីពិត គេជាមនុស្សដែលស្មោះត្រង់នឹងព្រះជាម្ចាស់ ប៉ុន្តែមិនបញ្ចេញឫកពារបែបនេះទេ។ បុគ្គលបែបនេះសុខចិត្តអនុវត្តសេចក្ដីពិត នៅពេលមានស្ថានការណ៍កើតឡើង ហើយមិនស្រដី ឬប្រព្រឹត្តទង្វើដែលប្រឆាំងនឹងមនសិការរបស់គេឡើយ។ បុគ្គលបែបនេះបង្ហាញនូវប្រាជ្ញា នៅពេលដែលបញ្ហាកើតមានឡើង ហើយមានគោល

ការណ៍នៅក្នុងការប្រព្រឹត្តរបស់ខ្លួន មិនថាមានស្ថានការណ៍អ្វីក៏ដោយ។ បុគ្គលបែបនេះ អាចផ្ដល់នូវការបម្រើយ៉ាងពិតប្រាកដ។ ជាញឹកញាប់ មានមនុស្សមួយចំនួននិយាយបានត្រឹមតែបបូរមាត់ អំពីការដែលគេជំពាក់គុណព្រះជាម្ចាស់ ពួកគេចំណាយពេលក្នុងជីវិតរបស់គេដោយបង្ហាញទឹកមុខខ្វល់ខ្វាយ បង្ហាញឥរិយាបថថា ខ្លួនដូចជារងការប៉ះពាល់ ហើយធ្វើពុតគួរឲ្យអាណិត។ ពិតជាគួរឲ្យស្អប់ខ្ពើមណាស់! ប្រសិនបើអ្នកសួរគេថា «តើអ្នកអាចប្រាប់ខ្ញុំបានទេថា អ្នកជំពាក់គុណព្រះជាម្ចាស់យ៉ាងណាដែរ?» នោះគេនឹងគាំងសម្ដី និយាយអ្វីមិនចេញ។ ប្រសិនបើអ្នកស្មោះត្រង់នឹងព្រះជាម្ចាស់មែន ចូរកុំដើរនិយាយពីការនេះ ផ្ទុយទៅវិញ ចូរបង្ហាញសេចក្ដីស្រលាញ់របស់អ្នកចំពោះព្រះជាម្ចាស់ ដោយវិធីអនុវត្តជាក់ស្ដែង ហើយអធិស្ឋានទៅកាន់ទ្រង់ដោយដួងចិត្តពិតប្រាកដវិញ។ អស់អ្នកដែលគ្រាន់តែប្រព្រឹត្តចំពោះព្រះជាម្ចាស់ ត្រឹមតែបបូរមាត់ និងគ្រាន់តែដើម្បីបង្គ្រប់កិច្ច គឺសុទ្ធតែជាមនុស្សពុតត្បុត! មានមនុស្សមួយចំនួននិយាយពីការជំពាក់គុណព្រះជាម្ចាស់នៅរាល់លើកដែលគេអធិស្ឋាន ហើយចាប់ផ្ដើមយំនៅរាល់លើកដែលគេអធិស្ឋាន ទោះបីជាមិនទទួលបានការប៉ះពាល់ចិត្តពីព្រះវិញ្ញាណបរិសុទ្ធក្ដី។ មនុស្សបែបនេះត្រូវបានគ្រប់គ្រងដោយទំនៀម និងសញ្ញាណផ្នែកសាសនា ពួកគេរស់នៅដោយទំនៀម និងសញ្ញាណសាសនា ពួកគេរស់នៅកាន់តាមទំនៀម និងសញ្ញាណបែបនេះ ដោយជឿជាក់ជានិច្ចថា សកម្មភាពទាំងនោះគាប់ព្រះហឫទ័យព្រះ ហើយជឿថា ទ្រង់សព្វព្រះហឫទ័យនឹងការគោរពប្រតិបត្តិតាមព្រះបែបលំៗ ឬទឹកភ្នែកសោកសៅ។ តើមានអ្វីល្អចេញពីមនុស្សមិនសមហេតុផលបែបនេះ? ដើម្បីបង្ហាញនូវការបន្ទាបខ្លួន មនុស្សមួយចំនួនធ្វើពុតជាប្រកបដោយព្រះគុណ នៅពេលខ្លួននិយាយចំពោះមុខអ្នកដទៃ។ អ្នកខ្លះក្រាបលូនដោយចេតនានៅចំពោះមុខអ្នកដទៃ ធ្វើខ្លួនដូចជាកូនចៀមដែលគ្មានកម្លាំងកំហែងបន្តិចសោះ។ តើនេះឬជាឫកពារដ៏សក្ដិសមរបស់ប្រជារាស្ដ្រនៃនគរព្រះ? ប្រជារាស្ដ្រនៅក្នុងនគរព្រះគួរតែរស់រវើក និងមានសេរីភាព គ្មានទោស និងបើកចំហ ស្មោះត្រង់ និងគួរឲ្យស្រលាញ់ ហើយរស់នៅក្នុងស្ថានភាពមួយប្រកបដោយសេរីភាព។ ពួកគេគួរមាន

សច្ចភាព និងភាពថ្លៃថ្នូរ ហើយអាចឈរជាស្មរបន្ទាល់នៅគ្រប់ទីកន្លែងដែលគេទៅ ទាំងព្រះជាម្ចាស់ ទាំងមនុស្សផងទាំងពួង សុទ្ធតែស្រឡាញ់មនុស្សបែបនេះ។ មនុស្សក្មេងខ្ចីខាងឯសេចក្ដីជំនឿ មានការអនុវត្តខាងក្រៅច្រើនពេក ពួកគេត្រូវឆ្លងកាត់រយៈពេលដែលត្រូវលាងជម្រះ និងបំបាក់បំបកជាមុនសិន។ មនុស្សដែលមានសេចក្ដីជំនឿលើព្រះជាម្ចាស់យ៉ាងជ្រាលជ្រៅ គឺមិនអាចសម្គាល់ខុសពីអ្នកដទៃដោយមើលពីសំបកក្រៅទេ ប៉ុន្តែសកម្មភាពនិងការប្រព្រឹត្តរបស់គេគឺគួរឲ្យសរសើរវិញ។ មានតែមនុស្សបែបនេះប៉ុណ្ណោះ ទើបអាចរាប់ទុកថារស់នៅតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ប្រសិនបើអ្នកប្រកាសដំណឹងល្អរាល់ថ្ងៃ ទៅកាន់មនុស្សជាច្រើន ដើម្បីខិតខំនាំគេចូលមកកាន់ការសង្គ្រោះ ប៉ុន្តែនៅទីបញ្ចប់ អ្នកនៅតែរស់នៅតាមច្បាប់ទម្លាប់ និងគោលលទ្ធិផ្សេងៗ នោះអ្នកមិនអាចថ្វាយសិរីល្អដល់ព្រះបានឡើយ។ មនុស្សបែបនេះ គឺជាអ្នកកាន់សាសនា ហើយក៏ជាមនុស្សកំពុតដែរ។ នៅពេលដែលអ្នកកាន់សាសនាទាំងនោះជួបជុំគ្នា ពួកគេប្រហែលជាសួរថា «បងស្រី បងសុខសប្បាយឬទេសព្វថ្ងៃនេះ?» នាងប្រហែលជាតបថា «ខ្ញុំមានអារម្មណ៍ថា ខ្ញុំជំពាក់ព្រះជាម្ចាស់ ហើយខ្ញុំគិតថា ខ្ញុំមិនអាចផ្គាប់ព្រះហឫទ័យទ្រង់ទេ»។ ម្នាក់ទៀតក៏ប្រហែលជានិយាយថា «ខ្ញុំក៏មានអារម្មណ៍ជំពាក់ព្រះជាម្ចាស់ដែរ ហើយខ្ញុំមិនអាចផ្គាប់ព្រះហឫទ័យទ្រង់ទេ»។ ត្រឹមតែប្រយោគ និងពាក្យសម្ដីមួយចំនួននេះ គឺវា បញ្ជាក់ពីសេចក្ដីគួរខ្ពើមក្នុងជម្រៅចិត្តគេស្រេចហើយ ពាក្យសម្ដីបែបនេះគឺគួរឲ្យស្អប់ និងគួរឲ្យខ្ពើមជាពន់ពេក។ និស្ស័យរបស់មនុស្សបែបនេះគឺប្រឆាំងនឹងព្រះជាម្ចាស់។ មនុស្សដែលផ្ដោតលើការពិត អ្វីៗដែលមានក្នុងចិត្តគំនិតរបស់គេ គឺគេនិយាយចេញអស់ ហើយបើកចិត្តរបស់គេនៅក្នុងការប្រកបគ្នា។ ពួកគេមិនចូលរួមនៅក្នុងការអនុវត្តខុសឆ្គងណាមួយ ហើយក៏មិនបង្ហាញសេចក្ដីគួរសម ឬភាពរីករាយដែលគ្មានន័យបែបនេះទេ។ ពួកគេតែងនិយាយត្រង់ៗ ហើយមិនអនុវត្តច្បាប់របស់លោកិយនោះឡើយ។ មនុស្សមួយចំនួនចូលចិត្តការសម្ដែងអាការៈខាងក្រៅ រហូតដល់លែងគិតពិចារណាអ្វីសោះ។ នៅពេលដែលនរណាម្នាក់ច្រៀង ពួកគេចាប់ផ្ដើមរាំ មិនទាំងដឹងផងថា

បាយនៅក្នុងឆ្នាំងរបស់គេខ្លោច។ មនុស្សបែបនេះ មិនគោរពដល់ព្រះជាម្ចាស់ ក៏មិនសមនឹងទទួលកិត្តិយស និងរឹតតែផ្ដេសផ្ដាសទៅទៀត។ សេចក្ដីទាំងប៉ុន្មាននេះ គឺជាការស្ដែងឲ្យឃើញអំពីកង្វះភាពជាកស្ដែង។ ពេលដែលមនុស្សមួយចំនួ ប្រកបគ្នាអំពីបញ្ហាជីវិតខាងវិញ្ញាណ ទោះបីជាពួកគេមិននិយាយអំពីការជំពាក់អ្វីនឹងព្រះជាម្ចាស់ ក៏ពួកគេនៅតែរក្សាសេចក្ដីស្រលាញ់ដ៏ពិតប្រាកដសម្រាប់ទ្រង់ នៅក្នុងជម្រៅចិត្តគេដែរ។ អារម្មណ៍ដែលអ្នកគិតថាជំពាក់គុណព្រះជាម្ចាស់ មិនពាក់ព័ន្ធនឹងអ្នកដទៃទេ អ្នកជំពាក់ព្រះជាម្ចាស់ មិនមែនមនុស្សលោកទាងអស់ទេ។ បើអ្នកចេះតែនិយាយពីការនេះប្រាប់អ្នកដទៃ តើមានប្រយោជន៍អ្វីដល់អ្នក? អ្នកត្រូវឲ្យតម្លៃលើការចូលទៅក្នុងភាពជាក់ស្ដែង មិនមែនលើភាពមោះមុត ឬការសម្ដែងអការៈខាងក្រៅនោះទេ។ តើទង្វើល្អដ៏រាក់កំផែលរបស់មនុស្ស តំណាងឲ្យអ្វី? ការទាំងនោះតំណាងឲ្យសាច់ឈាម ហើយសូម្បីតែការអនុវត្តខាងក្រៅដ៏ល្អបំផុត ក៏មិនតំណាងឲ្យជីវិតដែរ ការទាំងនោះអាចគ្រាន់តែបង្ហាញពីលក្ខណៈជាបុគ្គលផ្ទាល់ខ្លួនរបស់អ្នកប៉ុណ្ណោះ។ ការអនុវត្តពីខាងក្រៅរបស់មនុស្ស គឺមិនអាចបំពេញបំណងព្រះហឫទ័យចង់បានរបស់ព្រះជាម្ចាស់បានទេ។ អ្នកនិយាយអំពីការជំពាក់ព្រះជាម្ចាស់ជាប់ជានិច្ច ប៉ុន្ដែអ្នកមិនអាចផ្គត់ផ្គង់ជីវិតរបស់អ្នកដទៃ ឬលើកទឹកចិត្តពួកគេឲ្យស្រលាញ់ព្រះជាម្ចាស់បានឡើយ។ តើអ្នកជឿថា សកម្មភាពនានាដែលអ្នកប្រព្រឹត្តនោះ នឹងផ្គាប់ព្រះហឫទ័យព្រះជាម្ចាស់ដែរឬទេ? អ្នកគិតថា ទង្វើរបស់អ្នកសមស្របតាមបំណងព្រះហឫទ័យព្រះ ហើយសកម្មភាពទាំងនោះកើតចេញពីព្រះវិញ្ញាណ ប៉ុន្ដែតាមការពិត គំនិតនេះសុទ្ធតែជាគំនិតលេលា! អ្នកជឿថា អ្វីដែលគាប់ចិត្តអ្នក និងអ្វីដែលអ្នកសុខចិត្តធ្វើ គឺច្បាស់ជាអ្វីដែលព្រះជាម្ចាស់សព្វព្រះហឫទ័យ។ តើអ្វីដែលអ្នកចូលចិត្ត អាចតំណាងឲ្យព្រះជាម្ចាស់បានទេ? តើអត្តចរិតរបស់បុគ្គលម្នាក់ អាចតំណាងឲ្យព្រះជាម្ចាស់បានទេ? ច្បាស់ណាស់ អ្វីដែលគាប់ចិត្តអ្នក គឺជាអ្វីដែលព្រះជាម្ចាស់ស្អប់ខ្ពើម ហើយទម្លាប់របស់អ្នក គឺជាអ្វីដែលព្រះមិនគាប់ព្រះហឫទ័យ ហើយបដិសេធ។ ប្រសិនបើអ្នកមានអារម្មណ៍ជំពាក់ព្រះជាម្ចាស់ ចូរទៅអធិស្ឋាននៅចំពោះព្រះជាម្ចាស់ចុះ មិន

ចាំបាច់និយាយពីរឿងនេះប្រាប់អ្នកដទៃទេ។ ប្រសិនបើអ្នកមិនអធិស្ឋាននៅចំពោះព្រះជាម្ចាស់ទេ ហើយផ្ទុយទៅវិញ អ្នកចេះតែបង្ហេវចំណាប់អារម្មណ៍មកលើខ្លួនឯងនៅចំពោះមុខអ្នកដទៃ តើទង្វើនេះអាចផ្គាប់ព្រះហឫទ័យព្រះជាម្ចាស់បានដែរឬទេ? ប្រសិនបើសកម្មភាពរបស់អ្នក មានតែក្នុងអាការៈសម្ដែងខាងក្រៅ នោះមានន័យថាអ្នកទៅជាឥតប្រយោជន៍ ដោយព្រោះទង្វើជ្រុលនិយមនេះហើយ។ តើចរិតបែបណាខ្លះជាចរិតមនុស្ស ដែលគ្រាន់តែប្រព្រឹត្តអំពើល្អបែបរាក់កំផែល ហើយគ្មានការពិត? មនុស្សបែបនេះ គ្រាន់តែជាពួកផារិស៊ីដ៏កំពុត និងជាអ្នកកាន់សាសនាប៉ុណ្ណោះ! ប្រសិនបើអ្នករាល់គ្នាមិនបោះបង់ចោលនូវការប្រព្រឹត្តតែសំបកក្រៅរបស់ខ្លួន ហើយមិនអាចធ្វើការផ្លាស់ប្ដូរបានទេ នោះចរិតពុតត្បុតនៅក្នុងអ្នករាល់គ្នានឹងចម្រើនឡើងថែមទៀត។ បើចរិតពុតត្បុតរបស់អ្នកកាន់តែធំ នោះការទាស់ទទឹងនឹងព្រះជាម្ចាស់ក៏មានកាន់តែច្រើនដែរ។ នៅទីបញ្ចប់ មនុស្សបែបនេះនឹងត្រូវផាត់ចោលជាប្រាកដ!

# មានតែអ្នកដែលស្គាល់កិច្ចការ
# របស់ព្រះជាម្ចាស់ក្នុងពេលបច្ចុប្បន្ននេះទេ
# ដែលអាចបម្រើព្រះជាម្ចាស់បាន

ដើម្បីធ្វើទីបន្ទាល់ថ្វាយដល់ព្រះជាម្ចាស់ និងដើម្បីធ្វើឱ្យនាគដ៏ធំមានសម្បុរក្រហមអាម៉ាស់មុខ អ្នកត្រូវតែមានគោលការណ៍ ហើយអ្នកត្រូវតែបំពេញទៅតាមលក្ខខណ្ឌមួយ៖ អ្នកត្រូវស្រលាញ់ព្រះជាម្ចាស់នៅក្នុងចិត្តរបស់អ្នក ហើយចូលមករកព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ប្រសិនបើអ្នក មិនចូលមករកព្រះបន្ទូលរបស់ព្រះជាម្ចាស់ទេ នោះអ្នកនឹងគ្មានផ្លូវណាដើម្បីធ្វើឱ្យសាតាំងអាម៉ាស់មុខបានឡើយ។ តាមរយៈការលូតលាស់ក្នុងជីវិតរបស់អ្នក អ្នកបោះបង់នាគដ៏ធំមានសម្បុរក្រហមនោះ ហើយធ្វើឱ្យវាអាម៉ាស់មុខពេកក្រៃ។ មានតែពេលនោះទេដែលនាគដ៏ធំមានសម្បុរក្រហម ត្រូវអាម៉ាស់មុខដោយពិតប្រាកដ។ កាលណាអ្នកអាចអនុវត្តតាមព្រះបន្ទូលព្រះជាម្ចាស់ឱ្យ

បានកាន់តែច្រើន ពេលនោះភស្តុងតាងដែលអ្នកស្រលាញ់ព្រះជាម្ចាស់ និងស្អប់ខ្មៅម នាគដ៏ធំមានសម្បុរក្រហម ក៏កាន់តែច្រើនដែរ។ កាលណាអ្នកធ្វើតាមព្រះបន្ទូល របស់ព្រះជាម្ចាស់កាន់តែច្រើន ពេលនោះភស្តុតាងដែលអ្នកស្រេកឃ្លានចង់បាន សេចក្តីពិតក៏កាន់តែច្រើនដែរ។ មនុស្សដែលមិនស្រេកឃ្លានចង់បានព្រះបន្ទូលរបស់ ព្រះជាម្ចាស់ គឺជាមនុស្សគ្មានជីវិត។ មនុស្សរបៀបនេះ គឺជាមនុស្សស្ថិតនៅក្រៅ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយជាកម្មសិទ្ធិរបស់សាសនា។ មនុស្សដែលជឿលើ ព្រះជាម្ចាស់ពិតប្រាកដ មានចំណេះដឹងជ្រាលជ្រៅអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ តាមរយៈការហូប និងការផឹកព្រះបន្ទូលរបស់ទ្រង់។ ប្រសិនបើអ្នកមិនស្រេកឃ្លាន ចង់បានព្រះបន្ទូលរបស់ព្រះជាម្ចាស់ទេ នោះអ្នកមិនអាចហូប និងផឹកព្រះបន្ទូលរបស់ ព្រះជាម្ចាស់បានឡើយ ហើយប្រសិនបើអ្នកមិនស្គាល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ទេនោះ អ្នកនឹងគ្មានមធ្យោបាយណាដើម្បីធ្វើទីបន្ទាល់ថ្វាយដល់ព្រះជាម្ចាស់ ឬគាប់ ព្រះហឫទ័យរបស់ព្រះជាម្ចាស់បានឡើយ។

នៅក្នុងការជឿលើព្រះជាម្ចាស់ តើមនុស្សម្នាក់ គួរស្គាល់ព្រះជាម្ចាស់យ៉ាងដូច ម្ដេច? គេគួរស្គាល់ព្រះជាម្ចាស់ដោយផ្អែកលើព្រះបន្ទូល និងកិច្ចការរបស់ព្រះជាម្ចាស់ ក្នុងពេលបច្ចុប្បន្ន ដោយគ្មានងាករេ ឬដោយគ្មានជំនឿខុសឆ្គងឡើយ ហើយគេត្រូវ ស្គាល់កិច្ចការរបស់ព្រះជាម្ចាស់មុននឹងស្គាល់កិច្ចការដទៃផ្សេងទៀតទាំងអស់។ នេះគឺជាមូលដ្ឋានគ្រឹះនៃការស្គាល់ព្រះជាម្ចាស់។ ជំនឿខុសឆ្គងទាំងអស់ដែលខ្វះ ការទទួលយកព្រះបន្ទូលរបស់ព្រះជាម្ចាស់ដោយចិត្តស្មោះ គឺគ្រាន់តែជាសញ្ញាណ សាសនាប៉ុណ្ណោះ។ សញ្ញាណទាំងនេះ គឺជាការទទួលយកដោយខុសឆ្គង និងមិន ត្រឹមត្រូវ។ ជំនាញដ៏ពូកែរបស់អ្នកកាន់សាសនា គឺយកព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលគេទទួលយកនាពេលអតីតកាល ទៅផ្ទៀងផ្ទាត់ជាមួយនឹងព្រះបន្ទូលបច្ចុប្បន្ន ដើម្បីប្រឆាំងទាស់នឹងព្រះបន្ទូលទាំងនោះ។ ប្រសិនបើក្នុងពេលបម្រើព្រះម្ចាស់នា ពេលបច្ចុប្បន្ននេះ អ្នកប្រកាន់ខ្ជាប់ជាមួយរឿងរ៉ាវនៃការបើកសម្ដែងដោយការបំភ្លឺ របស់ព្រះវិញ្ញាណបរិសុទ្ធនាពេលកន្លងមក នោះការបម្រើរបស់អ្នកនឹងបង្កឱ្យមានការ

រំខាន ហើយការអនុវត្តរបស់អ្នកនឹងហួសសម័យ ហើយក៏មិនខុសអ្វីពីពិធីសាសនាដែរ។ ប្រសិនបើអ្នកជឿថា អស់អ្នកណាដែលបម្រើព្រះជាម្ចាស់ត្រូវបន្ទាបខ្លួន ត្រូវមានភាពអត់ធ្មត់ និងត្រូវមានអ្វីៗផ្សេងទៀតតែសំបកក្រៅនោះ ហើយប្រសិនបើអ្នកយកចំណេះដឹងបែបនេះទៅអនុវត្តនាពេលបច្ចុប្បន្ន នោះចំណេះដឹងបែបនេះគ្រាន់តែជាសញ្ញាណសាសនាប៉ុណ្ណោះ ហើយការអនុវត្តបែបនេះបានក្លាយទៅជាការប្រតិបត្តិដោយពុតត្បុត។ ពាក្យថា «សញ្ញាណសាសនា» សំដៅទៅលើអ្វីៗដែលហួសសម័យ និងចាស់គំរឹល (រួមទាំងការទទួលយកនូវព្រះបន្ទូលទាំងឡាយ ដែលព្រះជាម្ចាស់មានបន្ទូលពីមុនៗមក និងពន្លឺដែលបើកសម្ដែងដោយផ្ទាល់ពីព្រះវិញ្ញាណបរិសុទ្ធដែរ) ប្រសិនបើយកសញ្ញាណទាំងនេះទៅអនុវត្តនាពេលបច្ចុប្បន្ន នោះវានឹងរំខានដល់កិច្ចការរបស់ព្រះជាម្ចាស់ ហើយមិនផ្ដល់ប្រយោជន៍អ្វីដល់មនុស្សសោះឡើយ។ ប្រសិនបើមនុស្សមិនអាចដកចេញនូវសញ្ញាណពីក្នុងខ្លួនពួកគេ ដែលជាសញ្ញាណសាសនានេះទេ នោះសញ្ញាណទាំងអស់នេះ នឹងក្លាយជាឧបសគ្គយ៉ាងធំសម្រាប់មនុស្សក្នុងការបម្រើព្រះជាម្ចាស់។ មនុស្សដែលមានសញ្ញាណសាសនា មិនមានវិធីណាដើម្បីដើរតាមឲ្យទាន់ជំហាននៃកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធបានឡើយ។ ពួកគេដើរយឺតជាងមួយជំហាន បន្ទាប់មកពីរជំហាន ហើយនេះគឺដោយសារតែសញ្ញាណសាសនាទាំងនេះ ធ្វើឱ្យមនុស្សរាប់ខ្លួនឯងជាសុចរិត និងក្រអឺតក្រទមហួសហេតុ។ ព្រះជាម្ចាស់មិនមានព្រះហឫទ័យអាឡោះអាល័យ ចំពោះអ្វីដែលទ្រង់បានមានព្រះបន្ទូល និងបានធ្វើកន្លងមកឡើយ។ ប្រសិនបើការនោះហួសសម័យទៅហើយ ទ្រង់នឹងលុបវាចោល។ ពិតណាស់ តើអ្នកអាចបោះបង់ចោលសញ្ញាណរបស់អ្នកបានដែរទេ? ប្រសិនបើអ្នកប្រកាន់ខ្ជាប់ទៅនឹងព្រះបន្ទូល ដែលព្រះជាម្ចាស់បានមានព្រះបន្ទូលកាលពីអតីតកាល តើនេះអាចបញ្ជាក់ថាអ្នកស្គាល់កិច្ចការរបស់ព្រះជាម្ចាស់ដែរឬទេ? ប្រសិនបើអ្នកមិនអាចទទួលយកពន្លឺរបស់ព្រះវិញ្ញាណបរិសុទ្ធនាពេលបច្ចុប្បន្ននេះបានទេ ផ្ទុយទៅវិញ បែរជាប្រកាន់ខ្ជាប់ទៅនឹងពន្លឺពីអតីតកាល តើនេះអាចបញ្ជាក់ថា អ្នកដើរតាមលំអានរបស់ព្រះជាម្ចាស់បានដែរឬទេ? តើអ្នកនៅតែ

មិនទាន់អាចបោះបង់ចោលសញ្ញាណសាសនាបានមែនទេ? បើដូច្នេះមែន នោះអ្នកនឹងក្លាយជាមនុស្សម្នាក់ដែលប្រឆាំងទាស់នឹងព្រះជាម្ចាស់ជាមិនខាន។

ប្រសិនបើមនុស្សអាចលះបង់នូវសញ្ញាណសាសនាបាន នោះពួកគេមិនចាំបាច់ប្រើគំនិតរបស់ពួកគេទៅវាស់ស្ទង់ព្រះបន្ទូល និងកិច្ចការរបស់ព្រះជាម្ចាស់ក្នុងពេលបច្ចុប្បន្ននេះឡើយ ហើយផ្ទុយទៅវិញ ពួកគេនឹងស្ដាប់បង្គាប់ដោយត្រង់តែម្ដង។ ទោះបីកិច្ចការរបស់ព្រះជាម្ចាស់ក្នុងពេលបច្ចុប្បន្ននេះ ខុសគ្នាស្រឡះពីកិច្ចការរបស់ព្រះជាម្ចាស់នាពេលអតីតកាលក៏ដោយ ក៏អ្នកអាចលះបង់នូវទស្សនពីអតីតកាលចោលបានដែរ ហើយស្ដាប់បង្គាប់តាមកិច្ចការរបស់ព្រះជាម្ចាស់ក្នុងពេលបច្ចុប្បន្ននេះដោយត្រង់តែម្ដង។ មិនថាព្រះជាម្ចាស់បានធ្វើការយ៉ាងណាកាលពីអតីតកាលនោះទេ ប្រសិនបើអ្នកអាចយល់ពីកិច្ចការនោះបាន អ្នកត្រូវផ្ដល់តម្លៃអាទិភាពដល់កិច្ចការរបស់ព្រះជាម្ចាស់ក្នុងពេលបច្ចុប្បន្ននេះ ដូច្នេះ អ្នកនឹងក្លាយជាមនុស្សម្នាក់ដែលបានលះបង់សញ្ញាណរបស់ខ្លួន ជាមនុស្សម្នាក់ដែលស្ដាប់បង្គាប់ព្រះជាម្ចាស់ និងជាមនុស្សម្នាក់ដែលអាចស្ដាប់បង្គាប់តាមកិច្ចការ និងព្រះបន្ទូលរបស់ព្រះជាម្ចាស់បាន ព្រមទាំងដើរតាមលំអានរបស់ទ្រង់ទៀតផង។ នៅក្នុងលក្ខណៈនេះ អ្នកនឹងក្លាយទៅជាមនុស្សម្នាក់ ដែលស្ដាប់បង្គាប់ព្រះជាម្ចាស់ដ៏ពិតប្រាកដ។ អ្នកនឹងមិនវិភាគ ឬពិនិត្យពិច័យកិច្ចការរបស់ព្រះជាម្ចាស់ទៀតឡើយ។ ការនេះហាក់បីដូចជាព្រះជាម្ចាស់បានបំភ្លេចកិច្ចការពីមុនរបស់ទ្រង់ចោល ហើយអ្នកក៏បានបំភ្លេចកិច្ចការនេះដែរ។ បច្ចុប្បន្នគឺបច្ចុប្បន្ន អតីតកាលគឺអតីតកាល ហើយដោយសារព្រះជាម្ចាស់ឈប់អើពើពីនឹងកិច្ចការដែលទ្រង់បានបំពេញកាលពីអតីតកាលទៅហើយ អ្នកក៏មិនគួរគិតគូរដល់កិច្ចការទាំងនោះទៀតដែរ។ លុះត្រាតែអ្នកអាចធ្វើបែបនេះបាន ទើបអ្នកនឹងអាចក្លាយជាមនុស្សម្នាក់ដែលស្ដាប់បង្គាប់ព្រះជាម្ចាស់បានទាំងស្រុង និងអាចលះបង់នូវសញ្ញាណសាសនាបានទាំងស្រុង។

ពីព្រោះជានិច្ចកាល មានការអភិវឌ្ឍន៍ថ្មីៗនៅក្នុងកិច្ចការរបស់ព្រះជាម្ចាស់ ដូច្នេះមានកិច្ចការថ្មី ហើយក៏មានកិច្ចការដែលចាស់ហួសសម័យដែរ។ ប្រភេទកិច្ចការផ្សេងៗ

គ្នានេះ ទាំងថ្មី ទាំងចាស់ មិនប្រឆាំងគ្នាទេ ប៉ុន្តែបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក ព្រោះជំហាននីមួយៗបន្តគ្នាពីជំហានមុនៗមក។ ជាការពិតណាស់ ដោយសារមានកិច្ចការថ្មី ដូច្នេះកិច្ចការចាស់ត្រូវតែផាត់ចោល។ ឧទាហរណ៍ ការអនុវត្ត និងពាក្យទំនៀមដែលត្រូវបានបង្កើតឡើងជាយូរមកហើយ គួបផ្សំនឹងបទពិសោធ និងការបង្រៀនជាច្រើនឆ្នាំរបស់មនុស្ស បានបង្កើតជាសញ្ញាណគ្រប់បែបយ៉ាងនៅក្នុងចិត្តរបស់មនុស្ស។ ប៉ុន្តែ អ្វីដែលកាន់តែផ្ដល់ផលល្អដល់ការបង្កើតសញ្ញាណ ដែលមនុស្សបង្កើតឡើង ហើយរួមផ្សំនឹងការផ្សព្វផ្សាយទ្រឹស្ដីប្រពៃណីពីបុរាណក្នុងរយៈពេលជាច្រើនឆ្នាំនេះ គឺដោយសារព្រះជាម្ចាស់មិនទាន់បើកសម្ដែងព្រះភ័ក្ត្រ និងនិស្ស័យពិតប្រាកដរបស់ទ្រង់ឲ្យមនុស្សបានឃើញពេញលេញនៅឡើយ។ អាចនិយាយបានថា នៅក្នុងអំឡុងពេលនៃជំនឿរបស់មនុស្សចំពោះព្រះជាម្ចាស់ ឥទ្ធិពលនៃសញ្ញាណនានា បាននាំឱ្យមានការបង្កើត និងវិវឌ្ឍន៍ ជាបន្តបន្ទាប់នូវចំណេះដឹងរបស់មនុស្ស ដែលពួកគេមានសញ្ញាណគ្រប់បែបយ៉ាងអំពីព្រះជាម្ចាស់ ទើបធ្វើឱ្យអ្នកកាន់សាសនាជាច្រើនដែលបម្រើព្រះជាម្ចាស់ បានក្លាយទៅជាសត្រូវរបស់ទ្រង់ទៅវិញ។ ដូច្នេះ កាលណាមនុស្សមានសញ្ញាណសាសនាកាន់តែច្រើន ពេលនោះពួកគេកាន់តែប្រឆាំងទាស់នឹងព្រះជាម្ចាស់ ហើយពួកគេនឹងក្លាយជាសត្រូវរបស់ព្រះជាម្ចាស់កាន់តែច្រើនឡើងដែរ។ កិច្ចការរបស់ព្រះជាម្ចាស់តែងតែថ្មីជានិច្ច មិនដែលចាស់សោះឡើយ កិច្ចការនោះមិនដែលក្លាយជាគោលលទ្ធិទេ ហើយផ្ទុយទៅវិញ កិច្ចការនោះមានការផ្លាស់ប្ដូរ និងផ្លាស់ថ្មីជានិច្ច មានតិចមានច្រើន។ កិច្ចការនេះ ជាការបើកសម្ដែងនូវនិស្ស័យរបស់ព្រះជាម្ចាស់ដោយផ្ទាល់។ វាក៏ជាគោលការណ៍ ជាប់ពាក់ព័ន្ធទៅនឹងកិច្ចការរបស់ព្រះជាម្ចាស់ដែរ និងជាមធ្យោបាយមួយក្នុងចំណោមមធ្យោបាយនានា ដែលព្រះជាម្ចាស់សម្រេចការគ្រប់គ្រងរបស់ទ្រង់។ ប្រសិនបើព្រះជាម្ចាស់មិនបានបំពេញកិច្ចការតាមវិធីនេះទេ មនុស្សនឹងមិនផ្លាស់ប្រែ ឬមិនអាចស្គាល់ព្រះជាម្ចាស់បានឡើយ ហើយសាតាំងក៏នឹងមិនអាចបង្ក្រាបបានដែរ។ ដូច្នេះហើយ នៅក្នុងកិច្ចការរបស់ទ្រង់ តែងមានការផ្លាស់ប្ដូរជាបន្តបន្ទាប់ ដែលមើលទៅដូចជាមិនស្ថិតស្ថេរ ប៉ុន្តែតាមពិតទៅ

កើតមានតាមពេលវេលាកំណត់។ ប៉ុន្ដែមនុស្សជឿលើព្រះជាម្ចាស់តាមរបៀបផ្សេងៗពីគ្នា។ មនុស្សប្រកាន់ខ្ជាប់ទៅនឹងគោលលទ្ធិ និងប្រព័ន្ធចាស់ដែលគេធ្លាប់ស្គាល់ ហើយនៅពេលគោលលទ្ធិ និងប្រព័ន្ធនោះកាន់តែយូរកាលទៅ មនុស្សកាន់តែងាយនឹងទទួលយកវា។ តើគំនិតដ៏ល្ងីល្ងើរបស់មនុស្ស ដែលចចេសរឹងរូសដូចជាដុំថ្ម អាចទទួលយកកិច្ចការថ្មី និងព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលមិនអាចវាស់ស្ទង់បានដូចម្ដេចទៅ? មនុស្សស្អប់ព្រះជាម្ចាស់ដែលមានលក្ខណៈថ្មីជានិច្ច និងមិនដែលចាស់សោះនោះ។ មនុស្សចូលចិត្តតែព្រះជាម្ចាស់ចាស់បុរាណ មានព្រះទន្តវែង មានសក់ស្កូវ នៅនឹងថ្កល់។ ដូច្នេះ ដោយសារព្រះជាម្ចាស់ និងមនុស្សមានចំណូលចិត្តរៀងៗខ្លួន ទើបមនុស្សក្លាយជាសត្រូវរបស់ព្រះជាម្ចាស់។ ភាពផ្ទុយគ្នាជាច្រើននេះ នៅតែកើតមាននាពេលបច្ចុប្បន្ននេះដដែល គឺនៅពេលដែលព្រះជាម្ចាស់បានបំពេញកិច្ចការអស់ពេលជិតប្រាំមួយពាន់ឆ្នាំកន្លងមកហើយ។ ដូច្នេះ ពួកគេទាំងនោះគ្មានអ្វីអាចជួយបានទេ។ ប្រហែលនេះមកពីភាពចចេសរឹងរូសរបស់មនុស្ស ឬមកពីភាពដែលមនុស្សមិនអាចបំពានបានលើបញ្ញត្តិរដ្ឋបាលរបស់ព្រះជាម្ចាស់ ប៉ុន្ដែបុព្វជិតប្រុសស្រីទាំងនោះ នៅតែប្រកាន់ខ្ជាប់ទៅនឹងក្រដាសសៀវភៅចាស់ៗដុះផ្សិតដដែល នៅពេលដែលព្រះជាម្ចាស់បន្ដកិច្ចការនៃការគ្រប់គ្រង ដែលមិនទាន់ចប់សព្វគ្រប់របស់ទ្រង់ ហាក់ដូចជាគ្មាននរណាម្នាក់នៅខាងទ្រង់សោះឡើយ។ បើទោះបីជាភាពផ្ទុយគ្នានេះធ្វើឱ្យមនុស្ស និងព្រះជាម្ចាស់ក្លាយជាសត្រូវនឹងគ្នា និងមិនអាចផ្សះផ្សាគ្នាបានក៏ដោយ ក៏ព្រះជាម្ចាស់ មិនបានយកព្រះហឫទ័យទុកដាក់ចំពោះភាពផ្ទុយគ្នាទាំងនេះឡើយ ហាក់ដូចជាមាន ឬគ្មានភាពផ្ទុយគ្នាទាល់តែសោះ។ ទោះជាយ៉ាងណាក្ដី មនុស្សនៅតែប្រកាន់ខ្ជាប់នូវជំនឿ និងសញ្ញាណរបស់ខ្លួន និងមិនដែលលះបង់វាចោលឡើយ។ ប៉ុន្ដែរឿងមួយដែលបង្ហាញឱ្យឃើញដោយខ្លួនឯងនោះគឺថា ទោះបីមនុស្សមិនងាកចេញពីជំហររបស់ខ្លួនក្ដី ក៏ព្រះបាទារបស់ព្រះជាម្ចាស់នៅតែបោះជំហានទៅមុខជានិច្ច ហើយទ្រង់តែងតែផ្លាស់ប្ដូរជំហររបស់ទ្រង់ទៅតាមមជ្ឈដ្ឋានជុំវិញ។ នៅទីបញ្ចប់ គឺមនុស្សទេដែលនឹងត្រូវចុះចាញ់ ដោយមិនចាំបាច់ច្បាំង។ ក្នុងពេលជាមួយគ្នានេះ ព្រះជាម្ចាស់

គឺជាសត្រូវដ៏ធំជាងគេបំផុត របស់សត្រូវទាំងអស់ដែលត្រូវបានបង្ក្រាប ហើយក៏ជាជើងឯកក្នុងចំណោមមនុស្សដែលត្រូវបានបង្ក្រាប និងក្នុងចំណោមអ្នកដែលមិនទាន់បានបង្ក្រាបដែរ។ តើនរណាអាចប្រកួតជាមួយព្រះជាម្ចាស់ ហើយទទួលបានជោគជ័យនោះ? សញ្ញាណរបស់មនុស្សហាក់ដូចជាមកអំពីព្រះជាម្ចាស់ ដ្បិតសញ្ញាណភាគច្រើនបានកើតចេញពីកិច្ចការរបស់ព្រះជាម្ចាស់។ ប៉ុន្តែ ព្រះជាម្ចាស់មិនអត់ទោសឱ្យមនុស្សដោយព្រោះការនេះទេ ហើយលើសពីនេះទៀត ទ្រង់ក៏មិនសរសើរមនុស្សដែលបង្កើតផលិតផលមួយហើយមួយទៀត «សម្រាប់ព្រះជាម្ចាស់» ដែលខុសពីកិច្ចការរបស់ព្រះជាម្ចាស់ ក្រោយពីកិច្ចការរបស់ព្រះជាម្ចាស់បញ្ចប់ហើយដែរ។ ផ្ទុយទៅវិញ ទ្រង់ស្អប់ខ្ពើមយ៉ាងខ្លាំងចំពោះសញ្ញាណរបស់មនុស្ស និងជំនឿស៊ប់ ព្រមទាំងចាស់គំរឹល ហើយទ្រង់ក៏មិនមានបំណងព្រះហឫទ័យទទួលស្គាល់សូម្បីតែថ្ងៃដែលសញ្ញាណទាំងនោះលេចឡើងជាលើកដំបូងដែរ។ ទ្រង់មិនទទួលយកសោះឡើយថាសញ្ញាណទាំងនេះកើតចេញពីកិច្ចការរបស់ទ្រង់ ដ្បិតសញ្ញាណរបស់មនុស្ស ត្រូវបានផ្សាយដោយមនុស្ស។ ប្រភពនៃសញ្ញាណទាំងនេះ គឺចិត្ត និងគំនិតរបស់មនុស្ស និងមិនមែនមកអំពីព្រះជាម្ចាស់នោះទេ គឺមកពីសាតាំង។ ព្រះហឫទ័យរបស់ព្រះជាម្ចាស់ គឺចង់ឱ្យកិច្ចការរបស់ទ្រង់ក្លាយជាថ្មី និងរស់រវើក មិនមែនចាស់ និងគ្មានជីវិតនោះទេ ហើយតាមរយៈកិច្ចការនេះ ទ្រង់ធ្វើឱ្យមនុស្សប្រកាន់យ៉ាងខ្ជាប់ខ្ជួនទៅនឹងភាពខុសគ្នាទៅតាមសម័យកាល និងពេលវេលា មិនស្ថិតស្ថេរ និងអាចប្រែប្រួលបាន។ នោះដោយសារទ្រង់គឺជាព្រះជាម្ចាស់ដែលធ្វើឱ្យមនុស្សមានជីវិត និងក្លាយជាមនុស្សថ្មី ផ្ទុយទៅវិញ អារក្សធ្វើឱ្យមនុស្សស្លាប់ និងក្លាយជាមនុស្សចាស់។ តើអ្នករាល់គ្នានៅតែមិនយល់ទៀតឬអី? អ្នកមានសញ្ញាណអំពីព្រះជាម្ចាស់ ហើយមិនអាចលះបង់សញ្ញាណទាំងនោះបានទេ ដ្បិតអ្នកមិនព្រមបើកចិត្ត។ វាមិនមែនដោយសារកិច្ចការរបស់ព្រះជាម្ចាស់មានអត្ថន័យតិចតួចពេក ឬដោយសារកិច្ចការរបស់ព្រះជាម្ចាស់មិនស្របតាមបំណងប្រាថ្នារបស់មនុស្សនោះទេ ហើយក៏មិនមែនដោយសារព្រះជាម្ចាស់តែងតែធ្វេសប្រហែសក្នុងភារកិច្ចរបស់ទ្រង់នោះដែរ។ ការដែលអ្នកមិនអាចលះបង់

ចោលនូវសញ្ញាណរបស់អ្នកបាន គឺដោយសារតែអ្នកខ្វះការស្ដាប់បង្គាប់ ហើយដោយសារតែអ្នកមិនមានលក្ខណៈដូចជាសត្តនិកររបស់ព្រះជាម្ចាស់សូម្បីបន្តិចសោះឡើយ។ វាមិនមែនដោយសារព្រះជាម្ចាស់ ធ្វើឱ្យមានការលំបាកដល់អ្នកនោះទេ។ គ្រប់អ្វីៗទាំងអស់នេះកើតចេញពីអ្នក ហើយគ្មានជាប់ទាក់ទងជាមួយព្រះជាម្ចាស់សោះឡើយ។ រាល់ទុក្ខវេទនា និងសំណាងអាក្រក់ គឺបង្កឡើងដោយមនុស្ស។ ព្រះហឫទ័យរបស់ព្រះជាម្ចាស់ គឺល្អជានិច្ច។ ទ្រង់គ្មានបំណងព្រះហឫទ័យចង់ឱ្យអ្នកបង្កើតសញ្ញាណណាមួយនោះទេ ផ្ទុយទៅវិញទ្រង់សព្វព្រះហឫទ័យចង់ឱ្យអ្នកផ្លាស់ប្រែ និងប្ដូរយុគសម័យដែលកន្លងផុតទៅ។ ប៉ុន្តែ អ្នកមិនអាចប្រាប់ពីភាពខុសគ្នារវាងវត្ថុពីរបានឡើយ ហើយតែងតែពិនិត្យពិច័យ ឬក៏វិភាគលើវត្ថុនោះជានិច្ច។ មិនមែនដោយសារព្រះជាម្ចាស់ធ្វើឲ្យរឿងលំបាកសម្រាប់អ្នកនោះទេ ប៉ុន្តែគឺដោយសារអ្នកមិនមានការគោរពព្រះជាម្ចាស់ ហើយការមិនស្ដាប់បង្គាប់របស់អ្នកនោះ គឺច្រើនលើសលប់ណាស់។ សត្តនិករដ៏តូច ដែលហ៊ានយកចំណែកបន្តិចបន្តួចដែលព្រះជាម្ចាស់បានប្រទាននាពេលកន្លងមក ហើយបែរជាងាកមកវាយប្រហារព្រះជាម្ចាស់វិញ តើនេះមិនមែនជាការមិនស្ដាប់បង្គាប់របស់មនុស្សទេឬអី? អាចនិយាយដោយត្រង់បានថា មនុស្សមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការបញ្ចេញទស្សនៈរបស់គេ នៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់ឡើយ ហើយពួកគេកាន់តែគ្មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការប្រើពាក្យពេចន៍ថ្លែងចេញនូវភាសារោយរាយ ដែលឥតប្រយោជន៍ ធំក្លិនស្អុយគគ្រុក និងស្អុយរលួយ តាមតែចិត្តប្រាថ្នា ពោកគឺដើម្បីនិយាយតែអំពីសញ្ញាណដែលជុះផ្សិតនោះ។ តើពួកគេមិនរឹតតែឥតប្រយោជន៍ទេឬអី?

អ្នកដែលបម្រើព្រះជាម្ចាស់ដោយពិតប្រាកដគឺជាមនុស្សម្នាក់ដែលធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ជាអ្នកស័ក្តិសមឱ្យព្រះជាម្ចាស់ប្រើ និងជាអ្នកដែលអាចលះបង់នូវសញ្ញាណសាសនារបស់ពួកគេបាន។ ប្រសិនបើអ្នកចង់ហូប និងផឹកព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីឱ្យទទួលបានផលផ្លែនោះ ដូច្នេះ អ្នកត្រូវតែលះបង់សញ្ញាណសាសនារបស់អ្នក។ ប្រសិនបើអ្នកមានបំណងចង់បម្រើព្រះជាម្ចាស់ នោះ

វារឹតតែចាំបាច់ក្នុងការបោះបង់សញ្ញាណសាសនាជាមុនសិន ហើយស្ដាប់បង្គាប់តាមព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅគ្រប់ការទាំងអស់ដែលអ្នកធ្វើ។ នេះជាអ្វីដែលអ្នកបម្រើព្រះជាម្ចាស់គួរមាន។ ប្រសិនបើអ្នកខ្វះចំណេះដឹងនេះ នោះនៅពេលអ្នកបម្រើព្រះជាម្ចាស់ អ្នកនឹងបង្កការរំខាន និងភាពរឹករវ ហើយប្រសិនបើអ្នកនៅប្រកាន់ខ្ជាប់ទៅនឹងសញ្ញាណរបស់អ្នកទៀត នោះអ្នកនឹងចៀសមិនផុតពីត្រូវព្រះជាម្ចាស់វាយផ្ដួល និងមិនអាចក្រោកឈរឡើងវិញបានឡើយ។ ចូរយកពេលបច្ចុប្បន្ននេះធ្វើជាឧទាហរណ៍ស្រាប់។ ព្រះសូរសៀង និងកិច្ចការបច្ចុប្បន្នជាច្រើន មិនស៊ីគ្នាទៅនឹងព្រះគម្ពីរ និងកិច្ចការដែលព្រះជាម្ចាស់បានបំពេញនាពេលកន្លងមកទេ ហើយប្រសិនបើអ្នកមិនចង់ស្ដាប់បង្គាប់ទេ នោះអ្នកអាចនឹងដួលគ្រប់ពេលទាំងអស់បាន។ ប្រសិនបើអ្នកចង់បម្រើឱ្យស្របទៅតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ នោះអ្នកត្រូវលះបង់សញ្ញាណសាសនារបស់អ្នក ហើយកែតម្រូវទស្សនផ្ទាល់ខ្លួនរបស់អ្នកជាមុនសិន។ ភាគច្រើន អ្វីដែលគេនិយាយនាពេលអនាគត នឹងមិនដូចគ្នានឹងអ្វីដែលគេបាននិយាយកាលពីពេលអតីតកាលឡើយ ហើយបច្ចុប្បន្ននេះ ប្រសិនបើអ្នកខ្វះឆន្ទៈក្នុងការស្ដាប់បង្គាប់ អ្នកនឹងមិនអាចដើរលើមាគ៌ានៅខាងមុខបានឡើយ។ ប្រសិនបើវិធីសាស្ត្របំពេញកិច្ចការណាមួយរបស់ព្រះជាម្ចាស់ បានចាក់ឫសក្នុងខ្លួនអ្នក ហើយអ្នកមិនដែលបោះបង់វិធីសាស្ត្រនោះចោលទេ ដូច្នេះ វិធីសាស្ត្រនោះនឹងក្លាយជាសញ្ញាណសាសនារបស់អ្នក។ ប្រសិនបើលក្ខណៈរបស់ព្រះជាម្ចាស់ បានចាក់ឫសនៅក្នុងខ្លួនអ្នក នោះអ្នកបានទទួលសេចក្ដីពិត ហើយប្រសិនបើព្រះបន្ទូល និងសេចក្ដីពិតរបស់ព្រះជាម្ចាស់ អាចក្លាយជាជីវិតរបស់អ្នកបាន នោះអ្នកនឹងលែងមានសញ្ញាណអំពីព្រះជាម្ចាស់ទៀតហើយ។ អ្នកដែលមានចំណេះដឹងពិតប្រាកដអំពីព្រះជាម្ចាស់ នឹងគ្មានសញ្ញាណអ្វីឡើយ ហើយនឹងមិនកាន់តាមគោលលទ្ធិណាមួយដែរ។

ចូរដាស់ខ្លួនអ្នកឱ្យភ្ញាក់ឡើង ដោយសួរសំណួរខាងក្រោមនេះ៖

១. តើចំណេះដឹងនៅក្នុងខ្លួនអ្នករំខានដល់ការបម្រើព្រះជាម្ចាស់ដែរឬទេ?

២. នៅក្នុងជីវិតប្រចាំថ្ងៃរបស់អ្នក តើអ្នកគោរពប្រតិបត្តិសាសនាប៉ុន្មានដែរ? ប្រសិន

បើអ្នកបង្ហាញការគោរពសាសនាតែសម្បកខាងក្រៅ តើនេះមានន័យថា ជីវិតរបស់អ្នកលូតលាស់ធំធាត់ និងចាស់ទុំហើយឬនៅ?

៣. នៅពេលដែលអ្នកហូប និងផឹកព្រះបន្ទូលរបស់ព្រះជាម្ចាស់ តើអ្នកអាចលះបង់សញ្ញាណសាសនារបស់អ្នកបានដែរឬទេ?

៤. នៅពេលអ្នកអធិដ្ឋាន តើអ្នកអាចលះបង់ចោលពិធីសាសនាបានដែរឬទេ?

៥. តើអ្នកជាមនុស្សម្នាក់ដែលស័ក្ដិសមឱ្យព្រះជាម្ចាស់ប្រើដែរឬទេ?

៦. តើចំណេះដឹងរបស់អ្នកអំពីព្រះជាម្ចាស់ មានសញ្ញាណសាសនាច្រើនកម្រិតណា?

# ស្គាល់កិច្ចការថ្មីបំផុតរបស់ព្រះជាម្ចាស់ និងដើរតាមដានព្រះបាទារបស់ព្រះអង្គ

ឥឡូវនេះ អ្នករាល់គ្នាត្រូវស្វែងរកឲ្យបានក្លាយជារាស្ត្ររបស់ព្រះជាម្ចាស់ ហើយត្រូវចាប់ផ្ដើមចូលទៅក្នុងផ្លូវដ៏ត្រឹមត្រូវទាំងស្រុង។ ដើម្បីធ្វើជារាស្ត្ររបស់ព្រះជាម្ចាស់ មានន័យថា គឺជាការចូលក្នុងយុគសម័យនៃនគរព្រះ។ សព្វថ្ងៃនេះ អ្នកចាប់ផ្ដើមចូលទៅក្នុងការបង្ហឹកបង្ហឺននៃនគរព្រះជាផ្លូវការ ហើយជីវិតរបស់អ្នកនៅថ្ងៃអនាគតត្រូវតែឈប់ខ្ជីខ្ជា និងធ្វេសប្រហែលដូចកាលពីមុនទៀត។ ការរស់នៅរបៀបនេះ មិនអាចទទួលបាននូវបទដ្ឋាន ដែលព្រះជាម្ចាស់តម្រូវនោះឡើយ។ ប្រសិនបើអ្នកមិនមានអារម្មណ៍ថាជារឿងបន្ទាន់ខ្លាំងទេ នោះវាបង្ហាញឲ្យឃើញថា អ្នកគ្មានបំណងចិត្តចង់ឲ្យខ្លួនឯងរីកចម្រើនឡើងទេ ហើយថាការស្វែងរករបស់អ្នកគឺឥតបានការ និងភាន់ច្រឡំ ហើយអ្នកមិនអាចបំពេញតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់បានឡើយ។ ការចូលក្នុងការបង្ហឹកបង្ហឺននៃនគរព្រះមានន័យថា ជាការចាប់ផ្ដើមជីវិតជារាស្ត្ររបស់ព្រះជាម្ចាស់ តើអ្នកសុខចិត្តទទួលយកការបង្ហឹកបង្ហឺននេះដែរឬទេ? តើអ្នកសុខចិត្តស្ថិតក្រោមការបង្គាប់បញ្ជាដែរឬទេ? តើអ្នកសុខចិត្តរស់នៅ ក្រោមការវាយផ្ចាលពីព្រះជាម្ចាស់ដែរឬទេ? តើអ្នកសុខចិត្តរស់នៅក្រោមការវាយផ្ចាលរបស់ព្រះជាម្ចាស់ដែរ

ឬទេ? នៅពេលព្រះបន្ទូលរបស់ព្រះជាម្ចាស់ចាក់បង្ហូរលើអ្នក និងល្បងលអ្នក តើអ្នកនឹងប្រតិបត្តិបែបណាដែរ? ហើយនៅពេលដែលអ្នកប្រឈមមុខនឹងការពិតគ្រប់បែបគ្រប់សណ្ឋាន តើអ្នកនឹងធ្វើអ្វី? កាលពីដើមឡើយ អ្នកមិនបានផ្ចង់ចិត្តលើជីវិតឡើយ ថ្ងៃនេះអ្នកត្រូវចូលក្នុងភាពពិតប្រាកដនៃជីវិត ហើយស្វែងរកការផ្លាស់ប្ដូរនៅក្នុងនិស្ស័យនៃជីវិតរបស់អ្នក។ នេះជាអ្វីដែលរាស្ត្រនៃនគរព្រះត្រូវតែទទួលបាន។ អស់អ្នកណាដែលជារាស្ត្ររបស់ព្រះជាម្ចាស់ ត្រូវតែមាននូវជីវិត ពួកគេត្រូវតែទទួលយកការបង្ហឹកបង្ហឺននៃនគរព្រះ ហើយស្វែងរកនូវការផ្លាស់ប្ដូរនិស្ស័យនៃជីវិតរបស់ខ្លួន។ នេះជាអ្វីដែលព្រះជាម្ចាស់តម្រូវសម្រាប់រាស្ត្រនៃនគរព្រះ។

សេចក្ដីបង្គាប់របស់ព្រះជាម្ចាស់សម្រាប់រាស្ត្រនៃនគរព្រះមានដូចខាងក្រោម៖

១. ពួកគេត្រូវតែទទួលយកនូវបញ្ញើបេសកកម្មរបស់ព្រះជាម្ចាស់។ គឺមានន័យថា ពួកគេត្រូវតែទទួលយកនូវព្រះបន្ទូលទាំងអស់ ដែលបានថ្លែងនៅក្នុងកិច្ចការរបស់ព្រះជាម្ចាស់នៅគ្រាចុងក្រោយ។

២. ពួកគេត្រូវតែចូលទៅកាន់ការបង្ហឹកបង្ហឺននៃនគរព្រះ។

៣. ពួកគេត្រូវតែស្វែងរកនូវដួងចិត្តរបស់គេ ដែលព្រះជាម្ចាស់បានប៉ះពាល់។ នៅពេលដែលដួងចិត្តរបស់អ្នកបែរទៅរកព្រះជាម្ចាស់ទាំងស្រុង ហើយអ្នកមានជីវិតខាងព្រលឹងវិញ្ញាណមួយដែលធម្មតា នោះអ្នកនឹងរស់នៅក្នុងអាណាចក្រដែលមានសេរីភាព មានន័យថា អ្នកនឹងរស់នៅក្រោមការថែរក្សា និងការការពារនៃក្ដីស្រលាញ់របស់ព្រះជាម្ចាស់។ មានតែពេលដែលអ្នករស់នៅក្រោមការថែរក្សា និងការការពាររបស់ព្រះជាម្ចាស់ទេ ទើបអ្នកនឹងក្លាយជាកម្មសិទ្ធិរបស់ទ្រង់។

៤. ពួកគេត្រូវតែត្រូវបានព្រះជាម្ចាស់ទទួលយក។

៥. ពួកគេត្រូវតែក្លាយជាការសម្ដែងចេញនូវសិរីល្អរបស់ព្រះជាម្ចាស់នៅលើផែនដី។

ចំណុចទាំង៥នេះ គឺជាបញ្ញើបេសកកម្មរបស់ខ្ញុំសម្រាប់អ្នករាល់គ្នា។ ព្រះបន្ទូលរបស់ខ្ញុំថ្លែងមកចំពោះរាស្ត្ររបស់ព្រះជាម្ចាស់ ហើយប្រសិនជាអ្នក មិនចង់ទទួលយកបញ្ញើបេសកកម្មទាំងនេះទេ ខ្ញុំក៏មិនបង្ខំអ្នកដែរ ប៉ុន្តែប្រសិនបើអ្នកទទួលយក

បញ្ញាបេសកកម្មទាំងនេះ ដោយពិតប្រាកដ នោះអ្នកនឹងអាចធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ សព្វថ្ងៃនេះ អ្នករាល់គ្នាចាប់ផ្ដើមទទួលយកបញ្ញាបេសកកម្មរបស់ព្រះជាម្ចាស់ ហើយចង់ឲ្យក្លាយខ្លួនជារាស្ត្រនៃនគរព្រះ និងទទួលបាននូវបទដ្ឋាន ដែលតម្រូវឲ្យក្លាយជារាស្ត្រនៃនគរព្រះ។ ជាជំហានដំបូងនៃការចូលទៅរកការបង្វឹកបង្វឺន។ ប្រសិនបើអ្នក ចង់ធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ឲ្យបានពេញលេញ នោះអ្នកត្រូវតែទទួលយកបញ្ញាបេសកកម្មទាំងប្រាំនេះ ហើយប្រសិនបើអ្នក អាចសម្រេចបញ្ញាបេសកកម្មទាំងនេះបាន នោះអ្នកនឹងបានថ្វាយដួងចិត្តទៅកាន់ព្រះជាម្ចាស់ ហើយព្រះជាម្ចាស់ប្រាកដជានឹងប្រើប្រាស់អ្នកយ៉ាងល្អបំផុត។ អ្វីដែលសំខាន់សម្រាប់ថ្ងៃនេះ គឺជាការចូលទៅក្នុងការបង្វឹកបង្វឺននៃនគរព្រះ។ ការចូលទៅក្នុងការបង្វឹកបង្វឺននៃនគរព្រះ គឺពាក់ព័ន្ធទៅនឹងជីវិតផ្នែកព្រលឹងវិញ្ញាណ។ កាលពីមុន មិនមានការនិយាយអំពីជីវិតផ្នែកព្រលឹងវិញ្ញាណទេ ប៉ុន្តែសព្វថ្ងៃនេះនៅពេលដែលអ្នកចាប់ផ្ដើមចូលទៅក្នុងការបង្វឹកបង្វឺននៃនគរព្រះ នោះអ្នកបានចូលក្នុងជីវិតផ្នែកព្រលឹងវិញ្ញាណជាផ្លូវការហើយ។

តើជីវិតផ្នែកព្រលឹងវិញ្ញាណ គឺជាជីវិតបែបណា? ជីវិតផ្នែកព្រលឹងវិញ្ញាណ គឺជាជីវិតដែលដួងចិត្តរបស់អ្នកបានបែរទៅរកព្រះជាម្ចាស់ទាំងស្រុង និងអាចយកចិត្តទុកដាក់ចំពោះសេចក្ដីស្រលាញ់របស់ព្រះជាម្ចាស់។ វាជាជីវិតដែលអ្នករស់នៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយចិត្តរបស់អ្នកគ្មានអ្វីផ្សេងទៀតឡើយ អ្នកអាចយល់ដឹងពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់នៅសព្វថ្ងៃនេះ និងជាជីវិតដែលដឹកនាំដោយពន្លឺនៃព្រះវិញ្ញាណបរិសុទ្ធនៅសព្វថ្ងៃនេះ ដើម្បីបំពេញភារកិច្ចរបស់អ្នក។ ជីវិតរវាងមនុស្សនិងព្រះជាម្ចាស់ គឺជាជីវិតផ្នែកព្រលឹងវិញ្ញាណ។ ប្រសិនបើអ្នកមិនអាចដើរតាមពន្លឺនៅថ្ងៃនេះទេ នោះទំនាក់ទំនងរបស់អ្នកជាមួយនឹងព្រះជាម្ចាស់ មាននូវគំលាតមួយកើតឡើង វាថែមទាំងអាចមានលក្ខណៈធ្ងន់ធ្ងរ ហើយអ្នកមិនមានជីវិតផ្នែកព្រលឹងវិញ្ញាណទេ។ ទំនាក់ទំនងធម្មតាជាមួយព្រះជាម្ចាស់ត្រូវបានសង់ឡើងនៅលើគ្រឹះនៃការទទួលយកព្រះបន្ទូលរបស់ព្រះជាម្ចាស់នាពេលបច្ចុប្បន្ន។ តើអ្នកមានជីវិត

ធម្មតាផ្នែកព្រលឹងវិញ្ញាណដែរឬទេ? តើអ្នកមានទំនាក់ទំនងធម្មតាជាមួយព្រះជាម្ចាស់ដែរឬទេ? តើអ្នកជាមនុស្សម្នាក់ ដែលធ្វើតាមកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធដែរឬទេ? ប្រសិនបើអ្នក អាចដើរតាមពន្លឺរបស់ព្រះវិញ្ញាណបរិសុទ្ធនាពេលបច្ចុប្បន្ន ហើយអាចយល់ដឹងពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់នៅក្នុងព្រះបន្ទូលរបស់ទ្រង់ ព្រមទាំងចូលក្នុងព្រះបន្ទូលទាំងនោះ នោះអ្នកជាមនុស្សម្នាក់ដែលដើរតាមចរន្តនៃព្រះវិញ្ញាណបរិសុទ្ធ។ ប្រសិនបើអ្នកមិនដើរតាមចរន្តនៃព្រះវិញ្ញាណបរិសុទ្ធទេ នោះប្រាកដណាស់ថាអ្នកជាមនុស្សម្នាក់ដែលមិនស្វែងរកសេចក្តីពិត។ ព្រះវិញ្ញាណបរិសុទ្ធមិនមានឱកាសធ្វើការនៅក្នុងអស់អ្នកដែលគ្មានបំណងចិត្តចង់ឲ្យខ្លួនឯងរីកចម្រើននោះទេ ហើយជាលទ្ធផល មនុស្សបែបនេះមិនអាចប្រមូលកម្លាំងរបស់ខ្លួនទេ ហើយតែងតែអកម្មជានិច្ច។ ថ្ងៃនេះ តើអ្នកដើរតាមចរន្តនៃព្រះវិញ្ញាណបរិសុទ្ធដែរឬទេ? តើអ្នកស្ថិតក្នុងចរន្តនៃព្រះវិញ្ញាណបរិសុទ្ធដែរឬទេ? តើអ្នកបានចេញពីសភាវអកម្មហើយ ឬនៅ? អស់អ្នកដែលជឿលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ អ្នកដែលយកកិច្ចការរបស់ព្រះជាម្ចាស់ធ្វើជាគ្រឹះ និងដើរតាមពន្លឺនៃព្រះវិញ្ញាណបរិសុទ្ធនាពេលបច្ចុប្បន្ន ពួកគេសុទ្ធតែស្ថិតនៅក្នុងចរន្តនៃព្រះវិញ្ញាណបរិសុទ្ធ។ ប្រសិនបើអ្នកជឿថាព្រះបន្ទូលរបស់ព្រះជាម្ចាស់មានលក្ខណៈពិតប្រាកដ និងត្រឹមត្រូវយ៉ាងច្បាស់លាស់ ហើយប្រសិនបើអ្នកជឿលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ មិនថាទ្រង់មានបន្ទូលពីអ្វីនោះអ្នកជាមនុស្សម្នាក់ដែលស្វែងរកការចូលទៅក្នុងកិច្ចការរបស់ព្រះជាម្ចាស់ ហើយតាមរយៈវិធីនេះ អ្នកបានបំពេញបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ហើយ។

ដើម្បីចូលទៅក្នុងចរន្តនៃព្រះវិញ្ញាណបរិសុទ្ធ អ្នកត្រូវតែមានទំនាក់ទំនងធម្មតាជាមួយព្រះជាម្ចាស់ ហើយអ្នកត្រូវកំចាត់ចោលនូវសភាវៈអកម្មរបស់អ្នក ជាមុនសិន។ មនុស្សមួយចំនួនតែងតែធ្វើតាមហ្វូងមនុស្ស ហើយដួងចិត្តរបស់គេវង្វេងចេញឆ្ងាយពីព្រះជាម្ចាស់។ មនុស្សបែបនេះ គ្មានបំណងចិត្តធ្វើឲ្យខ្លួនឯងបានរីកចម្រើនទេ ហើយបទដ្ឋានដែលពួកគេស្វែងរកក៏ស្ថិតក្នុងកម្រិតទាបពេកដែរ។ មានតែការស្វែងរកការស្រលាញ់ព្រះជាម្ចាស់ និងការទទួលបានដោយព្រះជាម្ចាស់ប៉ុណ្ណោះ

ទើបជាបំណងព្រះហឫទ័យរបស់ទ្រង់។ មានមនុស្សជាច្រើន ដែលប្រើប្រាស់តែមនសិការរបស់ខ្លួនដើម្បីតបស្នងសេចក្ដីស្រលាញ់របស់ព្រះជាម្ចាស់ ប៉ុន្តែការនេះមិនអាចឈានទៅដល់ បំណងព្រះហឫទ័យរបស់ព្រះអង្គឡើយ។ កាលណាអ្នកស្វែងរកបទដ្ឋានកាន់តែខ្ពស់ នោះអ្នកនឹងមានភាពរីករាយនឹងបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់កាន់តែខ្លាំង។ ក្នុងនាមជាមនុស្សម្នាក់មានភាពធម្មតា និងជាអ្នកស្វែងរកការស្រលាញ់ព្រះជាម្ចាស់ នោះការចូលទៅក្នុងនគរព្រះដើម្បីក្លាយជាម្នាក់ក្នុងចំណោមរាស្ត្ររបស់ព្រះជាម្ចាស់ គឺជាអនាគតពិតប្រាកដរបស់អ្នករាល់គ្នា និងជាជីវិតមួយដែលមានតម្លៃខ្ពស់បំផុត និងមានសារៈសំខាន់ ហើយគ្មានអ្នកណាម្នាក់មានពរជាងអ្នករាល់គ្នាឡើយ។ ហេតុអ្វីបានជាខ្ញុំមានបន្ទូលបែបនេះ? ដ្បិតអស់អ្នកដែលមិនជឿលើព្រះជាម្ចាស់រស់នៅសម្រាប់តែសាច់ឈាម និងរស់នៅសម្រាប់សាតាំង ប៉ុន្តែសព្វថ្ងៃនេះ អ្នករាល់គ្នារស់នៅសម្រាប់ព្រះជាម្ចាស់ និងរស់នៅធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ហេតុនេះទើបខ្ញុំមានបន្ទូលថា ជីវិតរបស់អ្នករាល់គ្នាមានសារៈសំខាន់បំផុត។ មានតែមនុស្សមួយក្រុមដែលត្រូវបានព្រះជាម្ចាស់ជ្រើសរើសនេះទេ ទើបអាចរស់នៅក្នុងជីវិតដែលមានសារៈសំខាន់បំផុតបាន៖ គ្មាននរណាម្នាក់ផ្សេងទៀតនៅលើផែនដី អាចរស់នៅក្នុងជីវិតមួយដែលមានតម្លៃ និងមានន័យបែបនេះឡើយ។ ដោយសារតែព្រះជាម្ចាស់ជ្រើសរើសអ្នក និងលើកអ្នកឲ្យខ្ពស់ឡើងហើយជាងនេះទៅទៀត ដោយសារតែសេចក្ដីស្រលាញ់របស់ព្រះជាម្ចាស់ចំពោះអ្នកទើបអ្នករាល់គ្នាមានការយល់ដឹងពីជីវិតពិត និងស្គាល់ពីរបៀបរស់នៅក្នុងជីវិតមួយដែលមានតម្លៃបំផុត។ នេះមិនមែនដោយសារតែអ្នករាល់គ្នាស្វែងរកសេចក្ដីល្អនោះទេ ប៉ុន្តែគឺដោយសារតែព្រះគុណរបស់ព្រះជាម្ចាស់វិញ។ គឺព្រះជាម្ចាស់ជាអ្នកដែលបើកភ្នែកនៃព្រលឹងវិញ្ញាណរបស់អ្នករាល់គ្នា ហើយគឺជាព្រះវិញ្ញាណបរិសុទ្ធដែលបានប៉ះពាល់ដួងចិត្តរបស់អ្នករាល់គ្នា ដែលបានប្រទាននូវជោគវាសនាល្អដល់អ្នករាល់គ្នាដើម្បីចូលមកនៅចំពោះព្រះភ័ក្ត្ររបស់ព្រះអង្គ។ ប្រសិនបើព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះជាម្ចាស់មិនបានបំភ្លឺអ្នករាល់គ្នាទេ នោះអ្នករាល់គ្នានឹងមិនអាចមើលឃើញពីអ្វី

ដែលគួរឲ្យស្រលាញ់អំពីព្រះជាម្ចាស់ ហើយវាក៏មិនអាចឲ្យអ្នកស្រលាញ់ព្រះជាម្ចាស់បានដែរ។ ទាំងអស់នេះគឺដោយសារតែព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះជាម្ចាស់បានប៉ះពាល់ដួងចិត្តរបស់មនុស្ស ដែលធ្វើឲ្យដួងចិត្តរបស់គេ បែរមករកព្រះជាម្ចាស់ ហើយជួនកាលនៅពេលដែលអ្នកកំពុងតែរីករាយនឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ក៏មានការប៉ះពាល់វិញ្ញាណរបស់អ្នក ហើយអ្នកមានអារម្មណ៍ថា អ្នកគ្មានជម្រើសអ្វីក្រៅពីស្រលាញ់ព្រះជាម្ចាស់ឡើយ ពោលគឺមានកម្លាំងដ៏អស្ចារ្យមួយនៅក្នុងអ្នក ហើយគ្មានអ្វីមួយដែលអ្នកមិនអាចទុកមួយឡែកសិនបាននោះឡើយ។ ប្រសិនបើអ្នកមានអារម្មណ៍បែបនេះ នោះអ្នកត្រូវបានប៉ះពាល់ដោយព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះជាម្ចាស់ហើយ ហើយដួងចិត្តរបស់អ្នកបានបែរទៅរកព្រះជាម្ចាស់ទាំងស្រុង ហើយអ្នកនឹងអធិស្ឋានទៅកាន់ព្រះជាម្ចាស់ រួចពោលថា «ព្រះជាម្ចាស់អើយ! ព្រះអង្គបានកំណត់ និងជ្រើសរើសពួកយើងទុកជាមុន។ សិរីរុងរឿងរបស់ព្រះអង្គផ្តល់ឲ្យទូលបង្គំមានអំនួត ហើយវាធ្វើឲ្យទូលបង្គំមានអារម្មណ៍បរិបូរណ៍ក្នុងការក្លាយជារាស្ត្រម្នាក់របស់ព្រះអង្គ។ ទូលបង្គំនឹងចំណាយ ព្រមទាំងថ្វាយគ្រប់យ៉ាងដើម្បីធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះអង្គ ហើយនិងថ្វាយនូវពេលវេលារបស់ទូលបង្គំជាច្រើនឆ្នាំ ព្រមទាំងខិតខំប្រឹងប្រែង ពេញមួយជីវិតសម្រាប់ព្រះអង្គ។» នៅពេលអ្នកអធិស្ឋានបែបនេះ នឹងមានសេចក្តីស្រលាញ់ឥតឈប់ឈរ និងការស្តាប់បង្គាប់ពិតប្រាកដនៅក្នុងចិត្តរបស់អ្នកចំពោះព្រះជាម្ចាស់។ តើអ្នកធ្លាប់មានបទពិសោធបែបនេះដែរឬទេ? ប្រសិនបើព្រះវិញ្ញាណបរិសុទ្ធតែងតែប៉ះពាល់មនុស្ស នោះពួកគេចង់ថ្វាយខ្លួនទៅកាន់ព្រះជាម្ចាស់ដោយសេចក្តីអធិស្ឋានថា៖ «ឱព្រះជាម្ចាស់អើយ! ទូលបង្គំចង់ឃើញថ្ងៃនៃសិរីល្អរបស់ទ្រង់ ហើយទូលបង្គំចង់រស់នៅសម្រាប់ព្រះអង្គ គ្មានអ្វីមានតម្លៃ ឬមានន័យជាងការរស់នៅសម្រាប់ព្រះអង្គទេ ហើយទូលបង្គំគ្មានចិត្តចង់រស់សម្រាប់សាតាំង និងសាច់ឈាមបន្តិចសោះឡើយ។ សូមព្រះអង្គលើកទូលបង្គំឡើងដោយការជួយឲ្យទូលបង្គំអាចរស់នៅសម្រាប់ព្រះអង្គនាពេលបច្ចុប្បន្ន។» នៅពេលដែលអ្នកបានអធិស្ឋានរបៀបនេះ អ្នកនឹងមានអារម្មណ៍ថា អ្នកគ្មានអ្វីផ្សេងក្រៅពីថ្វាយដួងចិត្ត

របស់អ្នកទៅកាន់ព្រះជាម្ចាស់ឡើយ ដោយអ្នកត្រូវតែទទួលបានព្រះជាម្ចាស់ ហើយអ្នកមិនចង់បាត់បង់ជីវិតដោយមិនទទួលបានព្រះជាម្ចាស់ក្នុងពេលដែលអ្នកនៅរស់នោះទេ។ ការបាននិយាយបែបនេះនៅក្នុងសេចក្ដីអធិស្ឋាន អ្នកនឹងមានកម្លាំងដែលមិនចេះរីងស្ងួតនៅក្នុងខ្លួន ហើយអ្នកនឹងមិនដឹងថាកម្លាំងនេះចេញមកពីណាឡើយ ក៏នឹងមាននូវអំណាចឥតដែនកំណត់ នៅក្នុងដួងចិត្តរបស់អ្នក ហើយអ្នកនឹងដឹងថាព្រះជាម្ចាស់គួរឲ្យស្រលាញ់ណាស់ ហើយព្រះអង្គស័ក្ដិសមនឹងឲ្យយើងស្រលាញ់។ ការណ៍នេះកើតឡើងនៅពេលដែលព្រះជាម្ចាស់ប៉ះពាល់អ្នក។ អស់អ្នកដែលមានបទពិសោធបែបនេះ ត្រូវបានប៉ះពាល់ដោយព្រះជាម្ចាស់។ សម្រាប់អស់អ្នកដែលតែងតែត្រូវបានប៉ះពាល់ដោយព្រះជាម្ចាស់ ការផ្លាស់ប្ដូរកើតឡើងក្នុងជីវិតរបស់ពួកគេ នោះគេអាចធ្វើការតាំងចិត្ត និងសុខចិត្តទទួលយកព្រះជាម្ចាស់ទាំងស្រុង សេចក្ដីស្រលាញ់សម្រាប់ព្រះជាម្ចាស់នៅក្នុងដួងចិត្តរបស់គេមានកាន់តែខ្លាំងឡើង ហើយដួងចិត្តរបស់គេបានបែរទៅរកព្រះជាម្ចាស់ទាំងស្រុង ពួកគេមិនខ្វល់ពីគ្រួសារ លោកិយ មិនមានការពាក់ព័ន្ធ ឬមិនខ្វល់ខ្វាយពីអនាគតឡើយ ហើយពួកគេសុខចិត្តលះបង់ការប្រឹងប្រែងអស់មួយជីវិតថ្វាយទៅកាន់ព្រះជាម្ចាស់។ អស់អ្នកដែលត្រូវបានប៉ះពាល់ដោយព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះជាម្ចាស់ គឺជាមនុស្សដែលស្វែងរកសេចក្ដីពិត និងជាអ្នកដែលមានក្ដីសង្ឃឹមថាព្រះជាម្ចាស់ប្រទានឲ្យគេបានគ្រប់លក្ខណ៍។

តើអ្នកបានបែរចិត្តទៅរកព្រះជាម្ចាស់ហើយឬនៅ? តើព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះជាម្ចាស់បានប៉ះពាល់ចិត្តរបស់អ្នកឬនៅ? ប្រសិនបើអ្នកមិនដែលមានបទពិសោធបែបនេះ ហើយប្រសិនបើអ្នកមិនដែលអធិស្ឋានបែបនេះទេ នោះការនេះបង្ហាញថាព្រះជាម្ចាស់មិនគង់នៅក្នុងចិត្តរបស់អ្នកឡើយ។ អស់អ្នកដែលព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ដឹកនាំ ហើយអស់អ្នកដែលព្រះវិញ្ញាណរបស់ព្រះជាម្ចាស់បានប៉ះពាល់ មាននូវកិច្ចការរបស់ព្រះជាម្ចាស់ ដែលបង្ហាញថាព្រះបន្ទូល និងសេចក្ដីស្រលាញ់របស់ព្រះជាម្ចាស់បានចាក់ឫសនៅក្នុងពួកគេ។ មនុស្សមួយចំនួនពោលថា៖ «ទូលបង្គំមិនស្មោះត្រង់ដូចនៅក្នុងសេចក្ដីអធិស្ឋានរបស់ទូលបង្គំ ហើយទូលបង្គំក៏មិនសូវមានការ

ប៉ះពាល់ពីព្រះជាម្ចាស់ដែរ។ ជួនកាល នៅពេលដែលទូលបង្គំសញ្ជឹងគិត ហើយអធិស្ឋាន ទូលបង្គំមានអារម្មណ៍ថា ព្រះជាម្ចាស់គួរឲ្យស្រលាញ់ ហើយដួងចិត្តរបស់ទូលបង្គំក៏ទទួលបានការប៉ះពាល់ពីព្រះអង្គ។» គ្មានអ្វីសំខាន់ជាងដួងចិត្តរបស់មនុស្សឡើយ។ នៅពេលដួងចិត្តរបស់អ្នកបែរទៅរកព្រះជាម្ចាស់ នោះលក្ខណៈរបស់អ្នកទាំងមូលនឹងបែរទៅរកព្រះជាម្ចាស់វិញ ហើយនៅគ្រានោះ ដួងចិត្តរបស់អ្នកនឹងត្រូវបានប៉ះពាល់ដោយព្រះវិញ្ញាណរបស់ព្រះជាម្ចាស់។ អ្នករាល់គ្នាភាគច្រើនទទួលបានបទពិសោធបែបនេះ វាគ្រាន់តែជម្រៅនៃបទពិសោធរបស់អ្នកមិនដូចគ្នាតែប៉ុណ្ណោះ។ មនុស្សមួយចំនួនពោលថា៖ «ទូលបង្គំមិននិយាយច្រើន នៅក្នុងពាក្យអធិស្ឋានទេ ទូលបង្គំគ្រាន់តែស្ដាប់អំពីការរួបរួមរបស់អ្នកដទៃ និងកម្លាំងដែលកើតឡើងនៅក្នុងទូលបង្គំប៉ុណ្ណោះ។» ការនេះបង្ហាញថាអ្នកមានការប៉ះពាល់ផ្នែកខាងក្នុងដោយព្រះជាម្ចាស់។ ព្រះជាម្ចាស់បានប៉ះពាល់មនុស្សនៅផ្នែកខាងក្នុង ដោយពួកគេមានការជំរុញចិត្តនៅពេលបានឮអំពីការរួបរួមរបស់អ្នកដទៃ។ ប្រសិនបើដួងចិត្តរបស់មនុស្សម្នាក់នៅដដែលឥតកម្រើកនៅពេលពួកគេបានឮព្រះបន្ទូលដែលជំរុញទឹកចិត្ត នោះបញ្ជាក់ថា កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធមិនស្ថិតនៅក្នុងពួកគេទេ។ នៅក្នុងខ្លួនរបស់ពួកគេគឺមិនចង់បានអ្វីឡើយ វាបញ្ជាក់ថាពួកគេគ្មានការតាំងចិត្តទេ ហើយដូចនេះពួកគេមិនមានកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធឡើយ។ ប្រសិនបើមនុស្សម្នាក់មានការប៉ះពាល់ពីព្រះជាម្ចាស់ ពួកគេនឹងមានប្រតិកម្មនៅពេលដែលបានឮព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ប្រសិនបើពួកគេមិនមានការប៉ះពាល់ពីព្រះជាម្ចាស់ទេ នោះពួកគេមិនមានការផ្សារភ្ជាប់ជាមួយព្រះបន្ទូលរបស់ព្រះជាម្ចាស់ ពួកគេមិនមានទំនាក់ទំនងជាមួយព្រះបន្ទូលទាំងនេះ ហើយពួកគេមិនអាចទទួលការបំភ្លឺឡើយ។ អស់អ្នកដែលបានឮព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយគ្មានប្រតិកម្មអ្វីសោះ គឺជាមនុស្សដែលមិនមានការប៉ះពាល់ពីព្រះជាម្ចាស់ ពួកគេជាមនុស្សដែលមិនមានកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ។ អស់អ្នកដែលអាចទទួលយកនូវការបំភ្លឺថ្មីមាននូវការប៉ះពាល់ ព្រមទាំងមានកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធនៅជាមួយផង។

ការវាស់វែងខ្លួនឯង៖

១. តើអ្នកកំពុងស្ថិតនៅចំកណ្ដាលនៃកិច្ចការបច្ចុប្បន្ន របស់ព្រះវិញ្ញាណបរិសុទ្ធឬទេ?

២. តើដួងចិត្តរបស់អ្នកបានបែរទៅរកព្រះជាម្ចាស់ ហើយឬនៅ? តើអ្នកមានការប៉ះពាល់ដោយព្រះជាម្ចាស់ហើយឬនៅ?

៣. តើព្រះបន្ទូលរបស់ព្រះជាម្ចាស់បានចាក់ឫសនៅក្នុងអ្នកហើយឬនៅ?

៤. តើការអនុវត្តរបស់អ្នក ធ្វើឡើងដោយផ្អែកលើគ្រឹះនៃសេចក្ដីតម្រូវ របស់ព្រះ ជាម្ចាស់ឬទេ?

៥. តើអ្នករស់នៅក្រោមការណែនាំនៃពន្លឺបច្ចុប្បន្នរបស់ព្រះវិញ្ញាណបរិសុទ្ធ ដែរឬទេ?

៦. តើដួងចិត្តរបស់អ្នក ត្រូវបានគ្រប់គ្រងដោយការយល់ឃើញ ចាស់គំរឹល ឬក៏គ្រប់គ្រងដោយព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅពេលបច្ចុប្បន្ននេះ?

តាមរយៈការស្ដាប់ឮអំពីព្រះបន្ទូលទាំងនេះ តើអ្នករាល់គ្នា មានប្រតិកម្មអ្វីខ្លះ? តាមជំនឿដែលអ្នកបានជឿប៉ុន្មានឆ្នាំនេះ តើអ្នកមានព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់អ្នកដែរឬទេ? តើមានការផ្លាស់ប្រែនៅក្នុងនិស្ស័យពុករលួយរបស់អ្នកកាលពីមុនដែរ ឬទេ? ស្របតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់នាពេលបច្ចុប្បន្ន តើអ្នកដឹងថាការមានជីវិតគឺជាអ្វី? ហើយការមិនមានជីវិតគឺជាអ្វី? តើការនេះច្បាស់លាស់សម្រាប់អ្នករាល់គ្នាដែរឬទេ? ទាក់ទិននឹងភាពសំខាន់បំផុតក្នុងការដើរតាមព្រះជាម្ចាស់គ្រប់យ៉ាង គួរតែអាស្រ័យលើព្រះបន្ទូលរបស់ព្រះជាម្ចាស់នាពេលបច្ចុប្បន្ន៖ មិនថាអ្នកកំពុងស្វែងរកការចូលទៅក្នុងជីវិត ឬការបំពេញតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់នោះទេ គ្រប់យ៉ាង គួរតែនៅចំណុចកណ្ដាលរង្វង់នៃព្រះបន្ទូលរបស់ព្រះជាម្ចាស់នាពេលបច្ចុប្បន្ន។ ប្រសិនបើអ្វីដែលអ្នកទំនាក់ទំនង និងស្វែងរកមិនស្ថិតនៅកណ្ដាលរង្វង់នៃព្រះបន្ទូលរបស់ព្រះជាម្ចាស់នាពេលបច្ចុប្បន្នទេ នោះអ្នកជាមនុស្សចម្លែកនៅចំពោះព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយគ្មានសេសសល់នូវកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធឡើយ។ អ្វីដែលព្រះជាម្ចាស់សព្វព្រះហឫទ័យចង់បានគឺមនុស្សដែលដើរតាមដានព្រះបាទរបស់ព្រះអង្គ។ មិនថាអ្វីដែលអ្នកបានយល់ដឹង

ពីមុនមានលក្ខណៈអស្ចារ្យ ឬបរិសុទ្ធប៉ុនណានោះទេ ព្រះជាម្ចាស់មិនចង់បានឡើយ ហើយប្រសិនបើអ្នកមិនអាចដករបស់អស់ទាំងនោះចេញទេ នោះរបស់អស់ទាំងនោះនឹងក្លាយជាឧបសគ្គយ៉ាងធំចំពោះការចូលទៅក្នុងអនាគត។ មានពរហើយអស់អ្នកណាដែលអាចដើរតាមពន្លឺនាពេលបច្ចុប្បន្នរបស់ព្រះវិញ្ញាណបរិសុទ្ធ។ មនុស្សដែលមានអាយុច្រើនមកហើយក៏បានដើរតាមដានព្រះបាទារបស់ព្រះជាម្ចាស់ដែរ ប៉ុន្តែពួកគេមិនអាចដើរតាមព្រះអង្គរហូតមកដល់ថ្ងៃនេះទេ នេះគឺជាព្រះពររបស់មនុស្សនៅគ្រាចុងក្រោយ។ អស់អ្នកដែលបានដើរតាមកិច្ចការបច្ចុប្បន្នរបស់ព្រះវិញ្ញាណបរិសុទ្ធ និងអស់អ្នកណាដែលអាចដើរតាមដានព្រះបាទារបស់ព្រះជាម្ចាស់ គឺពួកគេដើរតាមព្រះជាម្ចាស់ទៅគ្រប់ទីកន្លែងដែលព្រះអង្គដឹកនាំពួកគេទៅ មនុស្សទាំងអស់នេះជាអ្នកដែលព្រះអង្គប្រទានពរ។ អស់អ្នកណាដែលមិនដើរតាមកិច្ចការបច្ចុប្បន្នរបស់ព្រះវិញ្ញាណបរិសុទ្ធ មិនបានចូលទៅក្នុងកិច្ចការនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ឡើយ មិនថាពួកគេប្រឹងប្រែងប៉ុនណា ឬមិនថាពួកគេរងទុក្ខប៉ុនណា ឬពួកគេប្រឹងរត់ទៅមុខយ៉ាងណានោះទេ គឺគ្មានអ្វីមួយដែលមានន័យសម្រាប់ព្រះជាម្ចាស់ឡើយ ហើយព្រះអង្គនឹងមិនស្ងើចសរសើរពួកគេឡើយ។ ថ្ងៃនេះ អស់អ្នកណាដែលដើរតាមព្រះបន្ទូលបច្ចុប្បន្នរបស់ព្រះជាម្ចាស់ គឺស្ថិតនៅក្នុងចរន្តនៃព្រះវិញ្ញាណបរិសុទ្ធ អស់អ្នកណាដែលជាជនចម្លែកចំពោះព្រះបន្ទូលរបស់ព្រះជាម្ចាស់នាពេលបច្ចុបន្ន គឺស្ថិតនៅក្រៅចរន្តនៃព្រះវិញ្ញាណបរិសុទ្ធ ហើយមនុស្សប្រភេទនេះ មិនមានការស្ងើចសរសើរពីព្រះជាម្ចាស់ឡើយ។ ការបម្រើដែលមានការបែកចេញពីព្រះសូរសៀងបច្ចុប្បន្នរបស់ព្រះវិញ្ញាណបរិសុទ្ធ គឺជាការបម្រើនៃសាច់ឈាម និងសញ្ញាណ ហើយវាមិនអាចស្របនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់ឡើយ។ ប្រសិនបើមនុស្សរស់នៅក្នុងសញ្ញាណសាសនា នោះពួកគេមិនអាចធ្វើអ្វីដែលសមនឹងបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ឡើយ ហើយទោះបីជាពួកគេបម្រើព្រះជាម្ចាស់ក្តី ក៏ពួកគេបម្រើនៅក្នុងការស្រមើស្រមៃ និងសញ្ញាណដែរ ហើយមិនមានលក្ខណៈគ្រប់គ្រាន់ក្នុងការបម្រើស្របតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ឡើយ។ អស់អ្នកដែលមិនអាចដើរតាមកិច្ចការរបស់

ព្រះវិញ្ញាណបរិសុទ្ធ មិនយល់ពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ឡើយ ហើយអស់អ្នកណាដែលមិនយល់ពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ក៏មិនអាចបម្រើព្រះជាម្ចាស់បានដែរ។ ព្រះជាម្ចាស់ចង់បានការបម្រើ ដែលស្របតាមព្រះហឫទ័យរបស់ព្រះអង្គ ទ្រង់មិនចង់បានការបម្រើដែលចេញពីសញ្ញាណ និងសាច់ឈាមឡើយ។ ប្រសិនបើមនុស្សមិនអាចដើរតាមជំហាននៃកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធទេ នោះពួកគេរស់នៅក្នុងសញ្ញាណហើយ។ ការបម្រើរបស់មនុស្សបែបនេះកាត់ផ្ដាច់ និងមានការរំខាន ហើយការបម្រើបែបនេះ ធ្វើឡើងដោយផ្ទុយនឹងព្រះជាម្ចាស់។ ដូចនេះ អស់អ្នកណាដែលមិនអាចដើរតាមដានព្រះបាទារបស់ព្រះជាម្ចាស់ មិនអាចបម្រើព្រះជាម្ចាស់បានទេ ហើយអស់អ្នក ដែលមិនអាចដើរតាមដានព្រះបាទរបស់ព្រះជាម្ចាស់ ភាគច្រើនប្រឆាំងទាស់នឹងព្រះជាម្ចាស់ ហើយមិនអាចស្របនឹងព្រះជាម្ចាស់ឡើយ។ «ការដើរតាមកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធ» មានន័យថា ជាការស្វែងយល់ពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់នាពេលបច្ចុប្បន្ន ជាការដែលអាចប្រព្រឹត្តស្របនឹងតម្រូវការបច្ចុប្បន្នរបស់ព្រះជាម្ចាស់ ជាការដែលអាចស្ដាប់បង្គាប់ និងដើរតាមព្រះជាម្ចាស់នាពេលបច្ចុប្បន្ន និងជាការចូលទៅដែលស្របតាមព្រះសូរសៀងថ្មីបំផុតរបស់ព្រះជាម្ចាស់។ នេះទើបជាមនុស្សដែលដើរតាមកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ និងនៅក្នុងចរន្តនៃព្រះវិញ្ញាណបរិសុទ្ធ។ មនុស្សបែបនេះ គឺមិនត្រឹមតែអាចទទួលនូវការសរសើរពីព្រះជាម្ចាស់ប៉ុណ្ណោះទេ តែថែមទាំងអាចស្គាល់នូវនិស្ស័យរបស់ព្រះជាម្ចាស់ដែលមាននៅក្នុងកិច្ចការចុងក្រោយរបស់ព្រះអង្គ និងអាចស្គាល់នូវសញ្ញាណ និងការមិនស្ដាប់បង្គាប់របស់មនុស្ស ព្រមទាំងធម្មជាតិរបស់មនុស្ស និងលក្ខណៈផ្សំរបស់គេផង តាមរយៈកិច្ចការចុងក្រោយបំផុតរបស់ព្រះអង្គ។ លើសពីនេះទៅទៀត ពួកគេអាចសម្រេចបាននូវការផ្លាស់ប្ដូរនិស្ស័យរបស់ពួកគេបន្តិចម្ដងៗនៅក្នុងអំឡុងពេលដែលគេបម្រើដល់ទ្រង់។ មានតែមនុស្សបែបនេះប៉ុណ្ណោះ ទើបជាអ្នកដែលអាចទទួលបានព្រះជាម្ចាស់ និងជាអ្នកដែលបានរកឃើញផ្លូវដ៏ពិតយ៉ាងប្រាកដ។ អស់អ្នកណាដែលត្រូវផាត់ចោលដោយកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ គឺជាមនុស្ស

ដែលមិនអាចដើរតាមកិច្ចការចុងក្រោយរបស់ព្រះជាម្ចាស់ និងជាអ្នកដែលប្រឆាំងទាស់នឹងកិច្ចការចុងក្រោយរបស់ទ្រង់។ មនុស្សបែបនេះប្រឆាំងទាស់នឹងព្រះជាម្ចាស់ដោយបើកចំហរ ពីព្រោះព្រះជាម្ចាស់បានធ្វើកិច្ចការថ្មី ហើយដោយសារតែរូបអង្គនៃព្រះមិនដូចជាសញ្ញាណរបស់ពួកគេ ជាលទ្ធផល ពួកគេប្រឆាំងទាស់នឹងព្រះជាម្ចាស់ដោយបើកចំហរ និងបានយកការជំនុំជម្រះមកទម្លាក់លើព្រះអង្គ ដែលនាំឲ្យព្រះជាម្ចាស់ស្អប់ខ្ពើម និងបដិសេធពួកគេ។ ការមានចំណេះដឹងអំពីកិច្ចការចុងក្រោយបំផុតរបស់ព្រះជាម្ចាស់មិនមែនជារឿងងាយស្រួលទេ ប៉ុន្តែប្រសិនបើមនុស្សមានគំនិតស្ដាប់បង្គាប់កិច្ចការរបស់ព្រះជាម្ចាស់ នោះពួកគេនឹងមានឱកាសមើលឃើញព្រះអង្គ ហើយនិងមានឱកាសទទួលបានការដឹកនាំថ្មីបំផុតរបស់ព្រះវិញ្ញាណបរិសុទ្ធផង។ អស់អ្នកណាដែលប្រឆាំងនឹងកិច្ចការរបស់ព្រះជាម្ចាស់ដោយចេតនា មិនអាចទទួលបានការបំភ្លឺពីព្រះវិញ្ញាណបរិសុទ្ធ ឬការណែនាំពីព្រះជាម្ចាស់ឡើយ។ ដូចនេះ មិនថាមនុស្សអាចទទួលនូវកិច្ចការចុងក្រោយរបស់ព្រះជាម្ចាស់ ឬអត់នោះទេ គឺអាស្រ័យលើព្រះគុណរបស់ព្រះជាម្ចាស់ ហើយវាគឺអាស្រ័យលើការស្វែងរករបស់ពួកគេ ព្រមទាំងអាស្រ័យលើចេតនារបស់ពួកគេដែរ។

មានពរហើយអស់អ្នកដែលអាចស្ដាប់បង្គាប់តាមព្រះសូរសៀងនាពេលបច្ចុប្បន្ននៃរបស់ព្រះវិញ្ញាណបរិសុទ្ធ។ មិនថាពួកគេធ្លាប់ធ្វើយ៉ាងណា ឬមួយថាព្រះវិញ្ញាណបរិសុទ្ធធ្លាប់ធ្វើការនៅក្នុងពួកគេបែបណានោះទេ អស់អ្នកដែលទទួលបានកិច្ចការចុងក្រោយរបស់ព្រះជាម្ចាស់ គឺជាអ្នកដែលទទួលបានព្រះពរខ្លាំងបំផុតហើយ ហើយអស់អ្នក ដែលមិនអាចដើរតាមកិច្ចការចុងក្រោយនាពេលបច្ចុប្បន្នទេ គឺត្រូវបានផាត់ចោល។ ព្រះជាម្ចាស់ ចង់បានអស់អ្នកដែលអាចទទួលបាននូវពន្លឺថ្មី ហើយព្រះអង្គចង់បានអ្នកដែលទទួលយក និងស្គាល់នូវកិច្ចការចុងក្រោយបំផុត របស់ព្រះអង្គ។ ហេតុអ្វីបានជាពោលថា អ្នកត្រូវតែជាក្រមុំព្រហ្មចារី? ក្រមុំព្រហ្មចារីអាចស្វែងរកនូវកិច្ចការរបស់ព្រះជាម្ចាស់ និងស្វែងយល់នូវអ្វីដែលថ្មី ហើយលើសពីនេះទៅទៀត គេអាចដកចេញនូវសញ្ញាណចាស់ៗ និងគោរពតាមកិច្ចការរបស់

ព្រះជាម្ចាស់នាពេលបច្ចុប្បន្ន។ ក្រុមមនុស្សប្រភេទនេះ ជាក្រុមមនុស្សដែលទទួលនូវកិច្ចការថ្មីបំផុតនាពេលបច្ចុប្បន្ន គឺជាអ្នកដែលព្រះជាម្ចាស់បានកំណត់ទុកជាមុនតាំងពីមុនយុគសម័យនានាទៅទៀត ហើយពួកគេជាមនុស្សដែលមានពរបំផុត។ អ្នករាល់គ្នាស្ដាប់ឮនូវព្រះសូរសៀងរបស់ព្រះជាម្ចាស់ ដូចនេះ នៅទូទាំងស្ថានសួគ៌ និងផែនដី ព្រមទាំងនៅគ្រប់ជំនាន់ទាំងអស់ គ្មាននរណាម្នាក់មានពរជាងអ្នករាល់គ្នាដែលជាក្រុមមនុស្សប្រភេទនេះឡើយ។ ទាំងអស់នេះ គឺដោយសារតែកិច្ចការរបស់ព្រះជាម្ចាស់ ដោយសារតែការកំណត់ទុកជាមុន និងការជ្រើសរើសរបស់ទ្រង់ ព្រមទាំងដោយសារតែព្រះគុណរបស់ព្រះជាម្ចាស់។ ប្រសិនបើព្រះជាម្ចាស់មិនបានមានបន្ទូល និងថ្លែងព្រះបន្ទូលចេញមកទេ តើអ្នករាល់គ្នាបានស្ថិតក្នុងលក្ខខណ្ឌដូចសព្វថ្ងៃនេះដែរឬទេ? ដូច្នេះ សូមឲ្យព្រះជាម្ចាស់ទទួលបានសិរីល្អ និងការសរសើរតម្កើង ដ្បិតការទាំងអស់នេះកើតឡើងដោយសារព្រះជាម្ចាស់បានលើកអ្នកឡើង។ ដោយមានចំណុចទាំងអស់នេះនៅក្នុងគំនិតរបស់អ្នក តើអ្នកអាចនៅតែអកម្មទៀតទេ? តើកម្លាំងរបស់អ្នកនៅតែមិនអាចកើនឡើងមែនឬ?

ដែលអ្នកអាចទទួលយកនូវការជំនុំជម្រះ ការវាយផ្ចាល ការវាយផ្ចួល និងការបន្សុទ្ធនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយលើសពីនេះទៅទៀត អាចទទួលយកនូវបញ្ញាបេសកកម្មរបស់ព្រះជាម្ចាស់បាន គឺព្រះជាម្ចាស់បានកំណត់ទុកជាមុនតាំងពីមុនយុគសម័យនានាទៅទៀត ហើយដូចនេះ អ្នកមិនត្រូវមានទុក្ខព្រួយពេកនៅពេលអ្នកត្រូវវាយផ្ចាលឡើយ។ គ្មាននរណាម្នាក់អាចដកយកចេញ នូវកិច្ចការដែលបានធ្វើនៅក្នុងអ្នករាល់គ្នា និងព្រះពរដែលបានចាក់បង្ហូរមកលើអ្នកឡើយ ហើយក៏គ្មាននរណាម្នាក់អាចដកយកចេញនូវអ្វីទាំងអស់ដែលបានប្រទានឲ្យអ្នករាល់គ្នាដែរ។ មនុស្សដែលកាន់សាសនាមិនអាចអត់ទ្រាំការមិនប្រៀបធៀបនឹងអ្នករាល់គ្នាបានឡើយ។ អ្នករាល់គ្នាមិនមានជំនាញអស្ចារ្យនៅក្នុងព្រះគម្ពីរឡើយ ហើយក៏មិនបានទទួលការបំពាក់បំប៉ននូវទ្រឹស្ដីផ្នែកសាសនាដែរ ប៉ុន្ដែដោយសារតែព្រះជាម្ចាស់បានធ្វើការនៅក្នុងអ្នករាល់គ្នា នោះអ្នករាល់គ្នាទទួលបានកាន់តែច្រើន គឺច្រើនជាងនរណា

ទាំងអស់នៅគ្រប់សម័យកាល ហើយនេះជាព្រះពរដ៏អស្ចារ្យបំផុតរបស់អ្នករាល់គ្នា។ ដោយសារតែការនេះ អ្នករាល់គ្នាត្រូវតែមានការលះបង់សម្រាប់ព្រះជាម្ចាស់កាន់តែខ្លាំង ព្រមទាំងមានភាពស្មោះត្រង់ចំពោះព្រះជាម្ចាស់កាន់តែខ្លាំងជាងនេះដែរ។ ដ្បិតព្រះជាម្ចាស់បានលើកអ្នកឡើង អ្នកត្រូវតែជំរុញការប្រឹងប្រែងរបស់ខ្លួន ហើយត្រូវត្រៀមលក្ខណៈដើម្បីទទួលយកនូវបញ្ញាបេសកកម្មរបស់ព្រះជាម្ចាស់។ អ្នកត្រូវតែឈរយ៉ាងរឹងមាំនៅទីកន្លែងដែលព្រះជាម្ចាស់បានប្រទានឲ្យអ្នក ស្វែងរកការក្លាយជាមនុស្សម្នាក់ក្នុងចំណោមប្រជារាស្ត្ររបស់ទ្រង់ ទទួលយកការបង្ហឹកបង្ហឺនអំពីនគរព្រះ ត្រូវព្រះជាម្ចាស់ទទួលយក និងត្រូវក្លាយជាទីបន្ទាល់ដែលពេញដោយសិរីល្អចំពោះព្រះជាម្ចាស់។ តើអ្នកមាននូវការតាំងចិត្តទាំងនេះដែរឬទេ? ប្រសិនបើអ្នកមានការតាំងចិត្តទាំងនេះ នោះប្រាកដថាព្រះជាម្ចាស់ទទួលយកអ្នកជាមិនខាន ព្រមទាំងក្លាយជាបន្ទាល់ដែលពេញដោយសិរីល្អសម្រាប់ព្រះជាម្ចាស់ផង។ អ្នកគួរតែយល់ថាបញ្ញាបេសកកម្មដ៏សំខាន់នេះកំពុងត្រូវបានព្រះជាម្ចាស់ទទួលយក និងក្លាយជាបន្ទាល់ដែលពេញដោយសេរីល្អចំពោះព្រះជាម្ចាស់។ នេះជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។

ព្រះបន្ទូលរបស់ព្រះវិញ្ញាណបរិសុទ្ធនាពេលបច្ចុប្បន្ន គឺជាថាមវន្តនៃកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ និងការបំភ្លឺ ជាបន្តបន្ទាប់ពីព្រះវិញ្ញាណបរិសុទ្ធចំពោះមនុស្សក្នុងអំឡុងពេលនេះ គឺជាទំនោរនៃកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ។ ហើយតើអ្វីដែលជាទំនោរនៅក្នុងកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធនាពេលបច្ចុប្បន្ន? វាគឺជាការដឹកនាំមនុស្សចូលទៅក្នុងកិច្ចការរបស់ព្រះជាម្ចាស់នាពេលបច្ចុប្បន្ន និងចូលទៅក្នុងជីវិតធម្មតាផ្នែកព្រលឹងវិញ្ញាណ។ មានជំហានមួយចំនួនដើម្បីចូលទៅក្នុងជីវិតធម្មតាផ្នែកព្រលឹងវិញ្ញាណ៖

១. ទីមួយ អ្នកត្រូវចាក់បង្ហូរដួងចិត្តរបស់អ្នក ចូលទៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់។ អ្នកមិនត្រូវស្វែងរកព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅក្នុងអតីតកាល ហើយមិនត្រូវសិក្សាពីព្រះបន្ទូលនោះ ហើយក៏មិនត្រូវប្រៀបធៀប ទៅនឹងព្រះបន្ទូលនាពេល

បច្ចុប្បន្នដែរ។ ផ្ទុយទៅវិញ អ្នកត្រូវចាក់បង្ហូរនូវដួងចិត្តរបស់អ្នកទាំងស្រុងចូលទៅក្នុងព្រះបន្ទូលបច្ចុប្បន្នរបស់ព្រះជាម្ចាស់។ ប្រសិនបើមានមនុស្សដែលចង់អានព្រះបន្ទូលរបស់ព្រះជាម្ចាស់ សៀវភៅផ្នែកព្រលឹងវិញ្ញាណ ឬអ្វីដែលជាការបង្រៀននៅក្នុងអតីតកាល ហើយនរណាដែលមិនដើរតាមព្រះបន្ទូលរបស់ព្រះវិញ្ញាណបរិសុទ្ធនាពេលបច្ចុប្បន្ន នោះពួកគេគឺជាមនុស្សល្ងង់បំផុតហើយ។ ព្រះជាម្ចាស់ស្អប់មនុស្សបែបនេះណាស់។ ប្រសិនបើអ្នកចង់ទទួលយកនូវពន្លឺនៃព្រះវិញ្ញាណបរិសុទ្ធនាពេលបច្ចុប្បន្ន នោះចូរចាក់បង្ហូរដួងចិត្តរបស់អ្នកទាំងស្រុង ចូលទៅក្នុងបន្ទូលរបស់ព្រះវិញ្ញាណបរិសុទ្ធនាពេលបច្ចុប្បន្ន។ នេះជារឿងទីមួយដែលអ្នកត្រូវធ្វើឲ្យបាន។

២. អ្នកត្រូវតែអធិស្ឋានដោយផ្អែកលើមូលដ្ឋាននៃព្រះបន្ទូលដែលព្រះជាម្ចាស់មានបន្ទូលនាពេលបច្ចុប្បន្ន ចូលទៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងទំនាក់ទំនងជាមួយព្រះអង្គ ព្រមទាំងធ្វើការតាំងចិត្តនៅចំពោះព្រះជាម្ចាស់ បង្កើតនូវបទដ្ឋានដែលអ្នកចង់ស្វែងរកការសម្រេចបាននូវការតាំងចិត្តនោះ។

៣. អ្នកត្រូវតែស្វែងរកការចូលទៅក្នុងសេចក្ដីពិតយ៉ាងជ្រៅនៅលើមូលដ្ឋាននៃកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធនាពេលបច្ចុប្បន្ន។ ចូរកុំប្រកាន់យកព្រះសូរសៀង និងទ្រឹស្ដីពីអតីតកាល។

៤. អ្នកត្រូវតែស្វែងរកការប៉ះពាល់មកពីព្រះវិញ្ញាណបរិសុទ្ធ និងចូលក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់។

៥. អ្នកត្រូវតែស្វែងរកការចូលទៅក្នុងមាគ៌ាដែលព្រះវិញ្ញាណបរិសុទ្ធនាពេលបច្ចុប្បន្នបានយាងកាត់។

តើអ្នកស្វែងរកការប៉ះពាល់ដោយព្រះវិញ្ញាណបរិសុទ្ធ ដោយរបៀបណា? រឿងសំខាន់បំផុត គឺត្រូវរស់នៅក្នុងព្រះបន្ទូលនាពេលបច្ចុប្បន្នរបស់ព្រះជាម្ចាស់ និងអធិស្ឋានដោយផ្អែកទៅលើ មូលដ្ឋាននៃសេចក្ដីតម្រូវរបស់ព្រះជាម្ចាស់។ តាមរយៈការអធិស្ឋានដោយរបៀបនេះ នោះព្រះវិញ្ញាណបរិសុទ្ធប្រាកដជានឹងប៉ះពាល់អ្នក។ ប្រសិនបើអ្នកមិនស្វែងរកមូលដ្ឋាននៃព្រះបន្ទូល ដែលព្រះជាម្ចាស់បានថ្លែងទេ នោះ

ការនេះគ្មានផលផ្លែអ្វីនោះឡើយ។ អ្នកគួរអធិស្ឋានដោយពោលថា៖ «ឱ ព្រះជាម្ចាស់អើយ! ទូលបង្គំប្រឆាំងនឹងព្រអង្គ ហើយទូលបង្គំជំពាក់ព្រះអង្គច្រើនណាស់។ ទូលបង្គំពិតជាមិនស្ដាប់បង្គាប់មែន ហើយមិនអាចផ្គាប់ព្រះហឫទ័យរបស់ព្រះអង្គឡើយ។ ឱ ព្រះអង្គអើយ ទូលបង្គំចង់ឲ្យព្រះអង្គសង្គ្រោះទូលបង្គំ ទូលបង្គំចង់បម្រើព្រះអង្គរហូតដល់ថ្ងៃចុងក្រោយ ទូលបង្គំចង់លះបង់ជីវិតសម្រាប់ព្រះអង្គ។ ព្រះអង្គជំនុំជម្រះ និងវាយផ្ចាលទូលបង្គំ ហើយទូលបង្គំសមតែស្លាប់ ដើម្បីឲ្យមនុស្សទាំងអស់អាចប្រកាន់ខ្ជាប់នូវនិស្ស័យសុចរិតរបស់ព្រះអង្គ ដោយតាមរយៈការស្លាប់របស់ទូលបង្គំ។» នៅពេលដែលអ្នកអធិស្ឋានតាមរបៀបនេះចេញពីចិត្តរបស់អ្នក នោះព្រះជាម្ចាស់នឹងស្ដាប់ឮអ្នក ហើយទ្រង់នឹងដឹកនាំអ្នក។ ប្រសិនបើអ្នកមិនអធិស្ឋានដោយផ្អែកលើមូលដ្ឋាននៃព្រះបន្ទូលរបស់ព្រះវិញ្ញាណបរិសុទ្ធនាពេលបច្ចុប្បន្នទេ នោះមិនមាននូវការប៉ះពាល់ពីព្រះវិញ្ញាណបរិសុទ្ធមកលើអ្នកឡើយ។ ប្រសិនបើអ្នកអធិស្ឋានផ្អែកតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងស្របតាមអ្វីដែលព្រះជាម្ចាស់សព្វព្រះហឫទ័យនឹងធ្វើនៅពេលនេះ នោះអ្នកពោលថា «ឱព្រះជាម្ចាស់អើយ! ទូលបង្គំចង់ទទួលយកបញ្ញើបេសកកម្មរបស់ព្រះអង្គ ហើយទូលបង្គំសុខចិត្តបូជាជីវិតរបស់ទូលបង្គំទាំងមូលសម្រាប់សិរីល្អរបស់ព្រះអង្គ ដើម្បីឲ្យអ្វីទាំងអស់ដែលទូលបង្គំបានធ្វើអាចឈានទៅដល់បទដ្ឋាននៃប្រជារាស្ត្ររបស់ព្រះជាម្ចាស់។ សូមឲ្យព្រះអង្គបានប៉ះពាល់ដួងចិត្តរបស់ទូលបង្គំ។ ទូលបង្គំចង់ឲ្យព្រះវិញ្ញាណរបស់ព្រះអង្គ បានបំភ្លឺទូលបង្គំ ដើម្បីធ្វើឲ្យអ្វីទាំងអស់ដែលទូលបង្គំធ្វើបាន នាំនូវភាពអាម៉ាស់មកទម្លាក់លើសាតាំង ដើម្បីឲ្យនៅទីបំផុត ព្រះអង្គនឹងទទួលយកទូលបង្គំ។» ប្រសិនបើអ្នកអធិស្ឋានរបៀបនេះ អធិស្ឋានក្នុងរបៀបមួយដែលផ្ដោតជុំវិញបំណងព្រះឫទ័យរបស់ព្រះជាម្ចាស់ នោះព្រះវិញ្ញាណបរិសុទ្ធ នឹងធ្វើការនៅក្នុងអ្នកដោយចៀសមិនផុតឡើយ។ អ្វីដែលសំខាន់នោះមិនអាស្រ័យលើថា តើអ្នកអធិស្ឋានបានប៉ុន្មានពាក្យទេ អ្វីដែលសំខាន់នោះគឺថា តើអ្នកយល់ពីបំណងបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែរឬអត់។ អ្នករាល់គ្នាប្រហែលជាសុទ្ធតែមាននូវបទពិសោធដូចខាងក្រោមនេះហើយ៖

ជួនកាល ក្នុងពេលអធិស្ឋាននៅពេលជួបជុំគ្នា សក្ដានុពលនៃកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធក៏ឈានដល់ចំណុចខ្ពស់បំផុត ដែលបណ្ដាលឲ្យកម្លាំងរបស់មនុស្សគ្រប់គ្នាបានកើនឡើង។ មនុស្សមួយចំនួនយំដោយជូរចត់ និងបង្ហូរទឹកភ្នែកក្នុងពេលអធិស្ឋាននោះ ពួកគេយកឈ្នះលើវិប្បដិសារីនៅចំពោះព្រះជាម្ចាស់ ហើយមនុស្សមួយចំនួនទៀតបង្ហាញនូវការតាំងចិត្ត និងធ្វើការស្បថ។ នេះគឺជាឥទ្ធិពលដែលកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធសម្រេចបាន។ ថ្ងៃនេះ វាជាការសំខាន់ដែលមនុស្សទាំងអស់ចាក់បង្ហូរដួងចិត្តរបស់គេទាំងស្រុងចូលទៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ចូរកុំផ្ដោតលើព្រះបន្ទូលដែលបានថ្លែងពីមុន ហើយប្រសិនបើអ្នកនៅតែប្រកាន់ខ្ជាប់នូវអ្វីដែលចែងមកពីមុន នោះព្រះវិញ្ញាណបរិសុទ្ធនឹងមិនធ្វើការនៅក្នុងអ្នកឡើយ។ តើអ្នកមើលឃើញថា តើការនេះសំខាន់ប៉ុនណាដែរឬទេ?

តើអ្នករាល់គ្នាស្គាល់មាគ៌ាដែលព្រះវិញ្ញាណបរិសុទ្ធនាពេលបច្ចុប្បន្នបានយាងលើដែរឬទេ? ចំណុចមួយចំនួនខាងលើ គឺជាអ្វីដែលព្រះវិញ្ញាណបរិសុទ្ធនាពេលបច្ចុប្បន្ន និងអនាគតត្រូវសម្រេច។ ចំណុចទាំងនេះ គឺជាមាគ៌ាដែលព្រះវិញ្ញាណបរិសុទ្ធបានជ្រើសយក ហើយច្រកចូលទៅរកផ្លូវនោះត្រូវតែឲ្យមនុស្សស្វែងរក។ ចំពោះច្រកចូលក្នុងជីវិតរបស់អ្នក យ៉ាងហោចណាស់អ្នកត្រូវចាក់បង្ហូរដួងចិត្តរបស់អ្នកចូលទៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយអាចទទួលយកនូវការជំនុំជម្រះ និងការវាយវាយផ្ចាលនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយដួងចិត្តរបស់អ្នកត្រូវតែប្រាថ្នាចង់បានព្រះជាម្ចាស់ អ្នកត្រូវតែស្វែងរកការចូលទៅក្នុងសេចក្ដីពិតដ៏ជ្រាលជ្រៅ ព្រមទាំងគោលបំណងដែលព្រះជាម្ចាស់តម្រូវ។ នៅពេលដែលអ្នកមាននូវកម្លាំងនេះ នោះវាបង្ហាញថា ព្រះជាម្ចាស់បានប៉ះពាល់អ្នក ហើយដួងចិត្តរបស់អ្នកបានចាប់ផ្ដើមបែរទៅរកព្រះជាម្ចាស់វិញ។

ជំហានដំបូងនៃច្រកចូលទៅកាន់ជីវិត គឺត្រូវចាក់បង្ហូរដួងចិត្តរបស់អ្នកទាំងស្រុងចូលទៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយជំហានទីពីរគឺត្រូវទទួលការប៉ះពាល់ពីព្រះវិញ្ញាណបរិសុទ្ធ។ តើអ្វីខ្លះជាឥទ្ធិពលដែលទទួលបានដោយការទទួលយកការ

ប៉ះពាល់ពីព្រះវិញ្ញាណបរិសុទ្ធ? វាជាការដែលអាចប្រាថ្នាចង់បាន ចង់ស្វែងរកនិងរុករកនូវសេចក្ដីពិតមួយដែលកាន់តែជ្រាលជ្រៅ និងអាចសហការជាមួយព្រះជាម្ចាស់ក្នុងឥរិយាបថវិជ្ជមាន។ ថ្ងៃនេះ ការសហការរបស់អ្នកជាមួយព្រះជាម្ចាស់ដែលអាចនិយាយបានថាមានគោលបំណងមួយចំពោះការដេញតាមរបស់អ្នក ចំពោះសេចក្ដីអធិស្ឋានរបស់អ្នក និងចំពោះការប្រកបរបស់អ្នកជាមួយព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយអ្នកបំពេញភារកិច្ចរបស់អ្នក ស្របតាមសេចក្ដីតម្រូវរបស់ព្រះជាម្ចាស់ ដែលការនេះហើយគឺជាការសហការជាមួយព្រះជាម្ចាស់។ ប្រសិនបើអ្នកគ្រាន់តែនិយាយថាអនុញ្ញាតឲ្យព្រះជាម្ចាស់ធ្វើការ ប៉ុន្តែខ្លួនឯងមិនបានធ្វើអ្វីទាល់តែសោះ សូម្បីតែការអធិស្ឋាន ឬការស្វែងរកក៏មិនធ្វើផង នោះតើការនេះអាចហៅថាជាការសហការដែរឬទេ? ប្រសិនបើអ្នកមិនមានដាននៃការសហការនៅក្នុងអ្នកទេ ហើយមិនមានការបង្ហឹកបង្ហឺន សម្រាប់ការចូលទៅដែលមាននូវគោលបំណងទេ នោះអ្នកមិនមែនកំពុងសហការឡើយ។ មនុស្សមួយចំនួនពោលថា៖ «អ្វីៗទាំងអស់គឺអាស្រ័យលើការកំណត់ទុកជាមុនរបស់ព្រះជាម្ចាស់ គ្រប់យ៉ាងសុទ្ធតែព្រះអង្គជាអ្នកធ្វើដោយផ្ទាល់។ ប្រសិនបើព្រះជាម្ចាស់មិនធ្វើវាទេ នោះតើឲ្យមនុស្ស អាចនឹងធ្វើដូចម្ដេចកើតទៅ?» កិច្ចការរបស់ព្រះជាម្ចាស់គឺធម្មតា និងមិនមានលក្ខណៈអធិធម្មជាតិបន្តិចសោះឡើយ ហើយព្រះវិញ្ញាណបរិសុទ្ធធ្វើការតែតាមរយៈការស្វែងរកដ៏សកម្មរបស់អ្នកប៉ុណ្ណោះ ដ្បិតព្រះជាម្ចាស់មិនបានបង្ខំមនុស្សឡើយ អ្នកត្រូវតែផ្ដល់ឱកាសដល់ព្រះជាម្ចាស់ឲ្យធ្វើការ ហើយប្រសិនបើអ្នកមិនស្វែងរក ឬចូលទៅទេ ហើយប្រសិនបើចិត្តអ្នកមិនចង់បានសូម្បីតែបន្តិច នោះព្រះជាម្ចាស់មិនមានឱកាសធ្វើការឡើយ។ តើអ្នកអាចស្វែងរកការប៉ះពាល់ពីព្រះជាម្ចាស់តាមផ្លូវណា? គឺតាមរយៈការអធិស្ឋាន និងការចូលមកជិតព្រះជាម្ចាស់។ ប៉ុន្តែសំខាន់បំផុតនោះគឺ ចូរចាំថា វាគឺត្រូវស្ថិតលើមូលដ្ឋាននៃព្រះបន្ទូលដែលព្រះជាម្ចាស់បានថ្លែង។ នៅពេលដែលអ្នកមានការប៉ះពាល់ពីព្រះជាម្ចាស់ជាញឹកញាប់ នោះអ្នកមិននៅជាប់ជាទាសករនៃសាច់ឈាមទៀតទេ៖ ស្វាមី ភរិយា កូន និងប្រាក់ សុទ្ធតែមិនអាចបង្អាក់អ្នកបានទេ ហើយអ្នក

ប្រាថ្នាចង់តែស្វែងរកសេចក្ដីពិត និងរស់នៅចំពោះព្រះជាម្ចាស់ប៉ុណ្ណោះ។ ពេលនេះ អ្នកនឹងក្លាយជាមនុស្សម្នាក់ដែលរស់នៅក្នុងពិភពនៃសេរីភាព។

# ព្រះជាម្ចាស់ប្រោសមនុស្សណា ដែលស្របតាមព្រះហឫទ័យទ្រង់ឲ្យបានគ្រប់លក្ខណ៍

ឥឡូវនេះ ព្រះជាម្ចាស់សព្វព្រះទ័យនឹងប្រមូលមនុស្សមួយក្រុម ដែលផ្ដុំដោយមនុស្សខិតខំរួបរួមជាមួយនឹងទ្រង់ មនុស្សដែលអាចស្ដាប់តាមកិច្ចការរបស់ទ្រង់ មនុស្សដែលជឿថា ព្រះបន្ទូលដែលទ្រង់ថ្លែងជាព្រះបន្ទូលពិត និងជាមនុស្សដែលអាចយកសេចក្ដីតម្រូវនានារបស់ព្រះជាម្ចាស់ទៅអនុវត្ត ពួកគេគឺជាមនុស្សដែលមានការយល់ដឹងច្បាស់នៅក្នុងដួងចិត្ត ជាមនុស្សដែលអាចត្រូវប្រោសឲ្យគ្រប់លក្ខណ៍ ហើយពួកគេគង់នឹងអាចដើរនៅលើមាគ៌ា នៃភាពគ្រប់លក្ខណ៍បានមិនខានឡើយ។ អស់អ្នកណាដែលពុំអាចធ្វើឲ្យបានគ្រប់លក្ខណ៍ គឺជាមនុស្សដែលពុំមានការយល់ដឹងពិតប្រាកដអំពីកិច្ចការរបស់ព្រះជាម្ចាស់ ជាមនុស្សដែលពុំហូប និងផឹកព្រះបន្ទូលរបស់ព្រះជាម្ចាស់ មនុស្សដែលពុំយកចិត្តទុកដាក់លើព្រះបន្ទូលរបស់ទ្រង់ និងជាមនុស្សដែលគ្មានសេចក្ដីស្រឡាញ់ចំពោះព្រះជាម្ចាស់នៅក្នុងដួងចិត្តរបស់គេ។ អស់អ្នកដែលមានចិត្តសង្ស័យចំពោះព្រះដែលយកកំណើតជាមនុស្ស ដែលតែងមិនប្រាកដប្រជាចំពោះព្រះអង្គ មិនដែលមានភាពហ្មត់ចត់ចំពោះព្រះបន្ទូលរបស់ទ្រង់ ហើយតែងតែក្បត់ទ្រង់ ពួកគេជាមនុស្សដែលប្រឆាំងនឹងព្រះជាម្ចាស់ និងជាកម្មសិទ្ធិរបស់សាតាំង។ គ្មានមធ្យោបាយណាដែលអាចធ្វើឲ្យមនុស្សជំពូកទាំងនេះ អាចគ្រប់លក្ខណ៍បានឡើយ។

ប្រសិនបើអ្នកប្រាថ្នាឲ្យបានគ្រប់លក្ខណ៍នោះ ដំបូងអ្នកត្រូវតែធ្វើឲ្យព្រះជាម្ចាស់សព្វព្រះហឫទ័យអ្នកសិន ដ្បិតទ្រង់ធ្វើឲ្យមនុស្សដែលទ្រង់សព្វព្រះហឫទ័យ និងស្របតាមព្រះហឫទ័យរបស់ទ្រង់បានគ្រប់លក្ខណ៍។ ប្រសិនបើអ្នកចង់ស្របនឹងព្រះហឫទ័យរបស់ទ្រង់ នោះអ្នកត្រូវតែមានដួងចិត្តមួយដែលស្ដាប់បង្គាប់តាមកិច្ចការ

របស់ទ្រង់ អ្នកត្រូវតែប្រឹងប្រែងស្វែងរកសេចក្តីពិត ហើយអ្នកត្រូវតែទទួលយកការពិនិត្យពិច័យរបស់ព្រះជាម្ចាស់ លើគ្រប់កិច្ចការទាំងអស់។ តើរាល់ទង្វើដែលអ្នកទាំងអស់គ្នាបានប្រព្រឹត្ត បានឆ្លងកាត់ការពិនិត្យពិច័យរបស់ព្រះជាម្ចាស់ហើយឬនៅ? តើចេតនារបស់អ្នក ត្រឹមត្រូវហើយឬនៅ? ប្រសិនបើចេតនារបស់អ្នកត្រឹមត្រូវហើយ នោះព្រះជាម្ចាស់នឹងសរសើរអ្នក ប្រសិនបើចេតនារបស់អ្នកមិនត្រឹមត្រូវវិញ នោះបង្ហាញឲ្យឃើញថា អ្វីដែលអ្នកស្រឡាញ់ពេញចិត្ត គឺសាច់ឈាម និងសាតាំង មិនមែនព្រះជាម្ចាស់ទេ។ ហេតុដូច្នេះហើយ អ្នកត្រូវតែប្រើនូវសេចក្តីអធិស្ឋាន ទុកជាវិធីទទួលយកការពិនិត្យពិច័យរបស់ព្រះជាម្ចាស់ ក្នុងគ្រប់កិច្ចការទាំងអស់។ ទោះបីជាខ្ញុំមិនមែនកំពុងឈរនៅចំពោះអ្នកផ្ទាល់ក៏ដោយ នៅពេលអ្នកអធិស្ឋាន ព្រះវិញ្ញាណបរិសុទ្ធគង់ជាមួយអ្នក ហើយទាំងខ្ញុំ និងព្រះវិញ្ញាណនៃព្រះជាម្ចាស់ សុទ្ធសឹងជាព្រះជាម្ចាស់ដែលអ្នកកំពុងអធិស្ឋានរក។ តើអ្នកនឹងជឿលើមនុស្សនេះឬទេ ប្រសិនបើទ្រង់ពុំមានព្រះវិញ្ញាណនៃព្រះជាម្ចាស់គង់នៅជាមួយទេនោះ? នៅពេលអ្នកទាំងអស់គ្នាជឿលើមនុស្សនេះ នោះអ្នកជឿលើព្រះវិញ្ញាណនៃព្រះជាម្ចាស់ហើយ។ នៅពេលអ្នកទាំងអស់គ្នាកោតខ្លាចមនុស្សនេះ អ្នកក៏កោតខ្លាចព្រះវិញ្ញាណនៃព្រះជាម្ចាស់ដែរ។ សេចក្តីជំនឿលើព្រះវិញ្ញាណនៃព្រះជាម្ចាស់ គឺជាសេចក្តីជំនឿលើមនុស្សម្នាក់នេះ ហើយសេចក្តីជំនឿលើមនុស្សម្នាក់នេះ គឺជាសេចក្តីជំនឿលើព្រះវិញ្ញាណនៃព្រះជាម្ចាស់។ នៅពេលអ្នកអធិស្ឋាន អ្នកទទួលអារម្មណ៍ថា ព្រះវិញ្ញាណគង់ជាមួយ ហើយមានអារម្មណ៍ថា ព្រះជាម្ចាស់នៅចំពោះមុខអ្នក ហេតុដូច្នេះហើយ អ្នកក៏អធិស្ឋានទៅកាន់ព្រះវិញ្ញាណទ្រង់។ សព្វថ្ងៃនេះ មនុស្សភាគច្រើនភ័យខ្លាចក្នុងការនាំយកទង្វើរបស់ខ្លួនមកចំពោះព្រះជាម្ចាស់ពេក ដ្បិតខណៈពេលដែលអ្នកបំភាន់សាច់ឈាមរបស់ទ្រង់ នោះអ្នកមិនអាចបំភាន់ព្រះវិញ្ញាណរបស់ទ្រង់បានឡើយ។ គ្រប់បញ្ហាដែលមិនអាចទ្រាំទ្រនឹងការពិនិត្យពិច័យរបស់ព្រះជាម្ចាស់បានទេ នោះទាស់ទទឹងនឹងសេចក្តីពិត ហើយក៏គួរតែត្រូវបោះចោលទៅម្ខាងដែរ ទង្វើផ្ទុយពីនេះ គឺជាអំពើបាបទាស់នឹងព្រះជាម្ចាស់ហើយ។ ដូច្នេះ អ្នកត្រូវតែថ្វាយដួងចិត្ត

របស់អ្នកនៅចំពោះព្រះជាម្ចាស់ គ្រប់ពេលទាំងអស់ ទាំងពេលអធិស្ឋាន ពេលនិយាយស្ដី និងពេលប្រកបគ្នាជាមួយបងប្អូនប្រុសស្រីរបស់អ្នក និងពេលអ្នកបំពេញភារកិច្ច និងប្រកបរបរចិញ្ចឹមជីវិតរបស់អ្នក។ នៅពេលដែលអ្នកបំពេញតួនាទីរបស់ខ្លួន នោះព្រះជាម្ចាស់គង់នៅជាមួយអ្នក ហើយដរាបណាចេតនារបស់អ្នកត្រឹមត្រូវ និងជាចេតនាសម្រាប់កិច្ចការនៅក្នុងដំណាក់របស់ព្រះជាម្ចាស់ នោះទ្រង់នឹងទទួលយករាល់កិច្ចការដែលអ្នកធ្វើ អ្នកគួរតែលះបង់ខ្លួនដោយចិត្តស្មោះស ដើម្បីបំពេញមុខងាររបស់ខ្លួន។ នៅពេលអ្នកអធិស្ឋាន ប្រសិនបើអ្នកមានសេចក្ដីស្រឡាញ់ចំពោះព្រះជាម្ចាស់នៅក្នុងចិត្ត ហើយស្វែងរកការថែរក្សា ការការពារ និងការពិនិត្យពិច័យពីព្រះជាម្ចាស់ ប្រសិនបើកិច្ចការទាំងអស់នេះគឺជាចេតនារបស់អ្នក នោះសេចក្ដីអធិស្ឋានរបស់អ្នកច្បាស់ជាមានប្រសិទ្ធភាព។ ឧទាហរណ៍ នៅពេលអ្នកអធិស្ឋាននៅក្នុងអង្គប្រជុំនានា ប្រសិនបើអ្នកបើកដួងចិត្ត រួចអធិស្ឋានទៅកាន់ព្រះជាម្ចាស់ ហើយទូលទ្រង់នូវអ្វីដែលមាននៅក្នុងចិត្តដោយមិនពោលពាក្យកុហក នោះសេចក្ដីអធិស្ឋានរបស់អ្នកនឹងមានប្រសិទ្ធភាពយ៉ាងពិតប្រាកដ។ ប្រសិនបើអ្នកមានដួងចិត្តស្រឡាញ់ព្រះ ដោយស្មោះអស់ពីចិត្ត នោះចូរស្បថចំពោះព្រះជាម្ចាស់ដូចនេះថា៖ «ឱព្រះជាម្ចាស់ដែលគង់នៅស្ថានសួគ៌ និងលើផែនដី និងក្នុងចំណោមសព្វសារពើអើយ! ទូលបង្គំសូមស្បថនឹងទ្រង់ថា៖ សូមឲ្យព្រះវិញ្ញាណរបស់ទ្រង់ពិនិត្យពិច័យអស់ទាំងទង្វើដែលទូលបង្គំធ្វើ ហើយការពារ និងថែរក្សាទូលបង្គំគ្រប់ពេលវេលា ព្រមទាំងធ្វើឲ្យគ្រប់កិច្ចការទាំងអស់ដែលទូលបង្គំធ្វើ អាចស្ថិតនៅក្នុងវត្តមានរបស់ទ្រង់ផង។ ប្រសិនបើដួងចិត្តទូលបង្គំឈប់ស្រឡាញ់ទ្រង់ ឬក្បត់ទ្រង់ នោះសូមដាក់ទោស និងដាក់បណ្ដាសាយ៉ាងធ្ងន់ធ្ងរចំពោះទូលបង្គំចុះ។ សូមកុំអត់ទោសឲ្យទូលបង្គំឡើយ ទោះក្នុងជីវិតនេះ និងនៅបរលោកក្ដី!» តើអ្នកហ៊ានស្បថដូចនេះដែរឬទេ? ប្រសិនបើអ្នកទាំងអស់គ្នាមិនហ៊ានទេ នោះបង្ហាញថាអ្នកជាមនុស្សកំសាក ហើយអ្នកនៅតែស្រឡាញ់ខ្លួនឯង។ តើអ្នកមានការតាំងចិត្តបែបនេះដែរឬទេ? ប្រសិនបើនេះគឺពិតជាការតាំងចិត្តរបស់អ្នកមែន អ្នកគួរតែស្បថបែបនេះ ប្រសិនបើអ្នកមានការតាំងចិត្តស្បថបែបនេះ នោះព្រះជាម្ចាស់

នឹងសម្រេចការតាំងចិត្តរបស់អ្នក។ នៅពេលអ្នកទាំងអស់គ្នាស្បថចំពោះព្រះជាម្ចាស់ នោះទ្រង់ព្រះសណ្ដាប់។ ព្រះជាម្ចាស់កំណត់ថា តើអ្នកគឺជាមនុស្សមានបាប ឬមនុស្សសុចរិត តាមរយៈការវាស់ស្ទង់សេចក្ដីអធិស្ឋាន និងការអនុវត្តរបស់អ្នក។ ឥឡូវនេះគឺជាដំណើរការនៃការប្រោសឲ្យអ្នកបានគ្រប់លក្ខណ៍ ហើយប្រសិនបើអ្នកពិតជាមានសេចក្ដីជំនឿលើការប្រោសឲ្យគ្រប់លក្ខណ៍មែន នោះអ្នកនឹងនាំយកទង្វើទាំងអស់ដែលអ្នកធ្វើ មកចំពោះព្រះជាម្ចាស់ ហើយទទួលយកការពិនិត្យពិច័យរបស់ទ្រង់ ដ្បិតបើអ្នកប្រព្រឹត្តការបះបោរទាំងងងើល ឬប្រសិនបើអ្នកក្បត់ព្រះជាម្ចាស់ នោះទ្រង់នឹងឲ្យសម្បថរបស់អ្នកកើតផល ដូច្នេះ អ្វីក៏ដោយដែលកើតឡើងចំពោះអ្នក ទោះជាក្ដីវិនាសអន្តរាយឬការវាយផ្ចាល នោះជាទង្វើរបស់អ្នកផ្ទាល់ទេ។ អ្នកបានស្បថហើយ ដូច្នេះ អ្នកគួរតែប្រកាន់តាមសម្បថនេះឲ្យជាប់។ ប្រសិនបើអ្នកស្បថហើយ ប៉ុន្តែមិនប្រកាន់តាមទេ អ្នកនឹងរងនូវក្ដីវិនាសអន្តរាយ។ ដោយសារសម្បថនោះជាសម្បថរបស់អ្នក នោះព្រះជាម្ចាស់នឹងឲ្យផលដល់សម្បថនោះ។ មនុស្សខ្លះភ័យខ្លាចបន្ទាប់ពីបានអធិស្ឋាន និងទួញសោកថា «ចប់អស់ហើយ! ឱកាសប្រព្រឹត្តរឿងឧបាយមុខរបស់ខ្ញុំចប់ហើយ។ ឱកាសប្រព្រឹត្តនូវការអាក្រក់របស់ខ្ញុំចប់ហើយ។ ឱកាសផ្ដេកផ្ដួលតាមចំណង់ខាងលោកិយរបស់ខ្ញុំចប់ហើយ!» មនុស្សទាំងអស់នេះ នៅតែស្រឡាញ់លោកិយ និងអំពើបាប ហើយរងនូវក្ដីវិនាសអន្តរាយប្រាកដណាស់។

ដើម្បីក្លាយជាអ្នកជឿលើព្រះជាម្ចាស់ មានន័យថា រាល់អ្វីទាំងអស់ដែលអ្នកធ្វើត្រូវតែនាំមកចំពោះទ្រង់ ហើយឆ្លងកាត់ការពិនិត្យពិច័យរបស់ទ្រង់។ ប្រសិនបើអ្វីដែលអ្នកធ្វើ អាចយកមកដាក់ចំពោះព្រះភក្ត្រព្រះវិញ្ញាណនៃព្រះជាម្ចាស់បាន ប៉ុន្តែមិនអាចយកមកដាក់ចំពោះរូបកាយសាច់ឈាមរបស់ព្រះជាម្ចាស់ទេ នោះវាបង្ហាញឲ្យឃើញថា អ្នកមិនទាន់បានឆ្លងកាត់ការពិនិត្យពិច័យដោយព្រះវិញ្ញាណរបស់ទ្រង់នៅឡើយទេ។ តើព្រះវិញ្ញាណនៃព្រះជាម្ចាស់ គឺជានរណា? តើបុគ្គលដែលព្រះជាម្ចាស់ធ្វើបន្ទាល់ពីគេនោះ គឺជានរណា? តើទ្រង់ទាំងពីរអង្គនេះ មិនមែនជាព្រះជាម្ចាស់តែមួយ ហើយដូចគ្នាទេឬអី? មនុស្សភាគច្រើនចាត់ទុកទ្រង់ទាំងពីរថាជាអង្គពីរ

ផ្សេងគ្នា ដោយជឿថា ព្រះវិញ្ញាណព្រះជាម្ចាស់ គឺជាព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ ហើយបុគ្គល ដែលព្រះជាម្ចាស់ធ្វើបន្ទាល់ពីគេនោះ គ្រាន់តែជាមនុស្សលោកម្នាក់ប៉ុណ្ណោះ។ ប៉ុន្តែ តើអ្នកមិនមែនគិតខុសទេឬអី? តើបុគ្គលម្នាក់នេះ ធ្វើការជួសមុខឲ្យអ្នកណា? មនុស្សណាដែលមិនស្គាល់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស អ្នកទាំងនោះពុំមានការយល់ដឹងខាងវិញ្ញាណឡើយ។ ព្រះវិញ្ញាណនៃព្រះជាម្ចាស់ និងការត្រលប់ជាសាច់ឈាមរបស់ទ្រង់ គឺជាអង្គតែមួយ ព្រោះវិញ្ញាណរបស់ព្រះជាម្ចាស់បានគង់នៅក្នុងសាច់ឈាម។ ប្រសិនបើបុគ្គលម្នាក់នេះពុំមានចិត្តសណ្ដោសចំពោះអ្នកទេ តើវិញ្ញាណរបស់ព្រះជាម្ចាស់នឹងមានសេចក្ដីសន្ដោសដែរឬទេ? តើអ្នកមិនច្រឡំទេឬអី? សព្វថ្ងៃនេះ មនុស្សណាដែលពុំអាចទទួលយកការពិនិត្យពិច័យរបស់ព្រះជាម្ចាស់ នោះពុំអាចទទួលបានការយល់ព្រមពីទ្រង់ឡើយ ហើយមនុស្សណាដែលពុំស្គាល់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សទេ នោះពុំអាចត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍បានឡើយ។ ចូរមើលទង្វើទាំងអស់ដែលអ្នកធ្វើចុះ ក្រែងអាចយកកិច្ចការនោះ មកដាក់ចំពោះព្រះភក្ត្រព្រះជាម្ចាស់បាន។ ប្រសិនបើអ្នកពុំអាចនាំយកទង្វើទាំងអស់ដែលអ្នកធ្វើមកដាក់ចំពោះព្រះភក្ត្រព្រះជាម្ចាស់ទេ ការនោះបង្ហាញថា អ្នកគឺជាមនុស្សអាក្រក់ហើយ។ តើមនុស្សអាក្រក់អាចត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍ដែរឬទេ? រាល់ទង្វើដែលអ្នកប្រព្រឹត្ត រាល់សកម្មភាព រាល់ចេតនា និងរាល់ប្រតិកម្មទាំងអស់របស់អ្នក គួរតែត្រូវបានយកមកចំពោះព្រះភក្ត្រព្រះជាម្ចាស់។ សូម្បីតែជីវិតខាងវិញ្ញាណប្រចាំថ្ងៃរបស់អ្នក រួមមានការអធិស្ឋានរបស់អ្នក ភាពជិតស្និទ្ធរបស់អ្នកចំពោះព្រះជាម្ចាស់ របៀបដែលអ្នកហូប និងផឹកព្រះបន្ទូលព្រះជាម្ចាស់ ការប្រកបគ្នារបស់អ្នកជាមួយបងប្អូនប្រុសស្រីរបស់អ្នក និងជីវិតរបស់អ្នកនៅក្នុងពួកជំនុំ រួមទាំងការបម្រើជាដៃគូរបស់អ្នក ក៏អាចត្រូវបានយកមកចំពោះព្រះភក្ត្រព្រះជាម្ចាស់ ដើម្បីធ្វើការពិនិត្យពិច័យផងដែរ។ ការអនុវត្តបែបនេះហើយដែលនឹងជួយអ្នកឲ្យសម្រេចបានភាពរីកចម្រើននៅក្នុងជីវិត។ ដំណើរការនៃការទទួលយកការពិនិត្យពិច័យរបស់ព្រះជាម្ចាស់ គឺជាដំណើរការនៃការបន្សុទ្ធ។ កាលណាអ្នកទទួលយកការពិនិត្យពិច័យ

របស់ព្រះជាម្ចាស់កាន់តែច្រើន នោះអ្នកត្រូវបានបន្សុទ្ធ ហើយអ្នកកាន់តែស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ប្រយោជន៍កុំឲ្យអ្នកត្រូវនាំទៅរកឧបាយមុខ ហើយឲ្យដួងចិត្តរបស់អ្នក ស្ថិតនៅក្នុងព្រះវត្តមានរបស់ទ្រង់។ កាលណាអ្នកទទួលយកការពិនិត្យពិច័យ របស់ព្រះជាម្ចាស់កាន់តែច្រើន នោះសាតាំងក៏អាប់មុខកាន់តែខ្លាំង ហើយសមត្ថភាពរបស់អ្នកក្នុងការបង់បោះចោលសាច់ឈាម ក៏កាន់តែប្រសើរឡើងដែរ។ ដូច្នេះ ការទទួលយកការពិនិត្យពិច័យរបស់ព្រះជាម្ចាស់ គឺជាមាគ៌ាមួយនៃការប្រព្រឹត្តដែលមនុស្សលោកគួរតែដើរតាម។ ទោះបីជាអ្នកប្រព្រឹត្តអ្វីក៏ដោយ ក៏អ្នកអាចនាំយកការប្រព្រឹត្តរបស់អ្នកមកចំពោះព្រះភក្ត្រព្រះជាម្ចាស់ ហើយស្វែងរកការពិនិត្យពិច័យរបស់ទ្រង់ និងព្យាយាមធ្វើតាមព្រះជាម្ចាស់បានដែរ សូម្បីតែពេលដែលអ្នកប្រាស្រ័យទាក់ទងជាមួយបងប្អូនប្រុសស្រីរបស់អ្នកក្តី ដ្បិតការនេះនឹងធ្វើឲ្យការអនុវត្តរបស់អ្នកកាន់តែត្រឹមត្រូវ។ មានតែតាមរយៈការនាំយករាល់ទង្វើរបស់អ្នកមកចំពោះព្រះភក្ត្រព្រះជាម្ចាស់ ហើយទទួលយកការពិនិត្យពិច័យរបស់ព្រះជាម្ចាស់ទេ ទើបអ្នកអាចក្លាយទៅជាមនុស្សម្នាក់ ដែលអាចរស់នៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់បាន។

មនុស្សដែលគ្មានការយល់ដឹងអំពីព្រះជាម្ចាស់ គ្មានថ្ងៃអាចស្តាប់តាមព្រះជាម្ចាស់បានយ៉ាងពេញលេញឡើយ។ មនុស្សប្រភេទនេះ គឺជាកូននៃសេចក្តីរឹងចចេស។ ពួកគេមានមហិច្ឆតាខ្លាំងជ្រុល ថែមទាំងមាន សេចក្តីបះបោរខ្លាំងនៅក្នុងពួកគេដូច្នេះហើយ ពួកគេធ្វើឲ្យខ្លួនគេឃ្លាតឆ្ងាយពីព្រះជាម្ចាស់ ហើយគ្មានឆន្ទៈនឹងទទួលយកការពិនិត្យពិច័យរបស់ទ្រង់ឡើយ។ មនុស្សបែបនេះមិនងាយនឹងត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍ឡើយ។ មនុស្សខ្លះទំរើសក្នុងការដែលពួកគេហូប និងផឹកព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងទទួលយកព្រះបន្ទូលរបស់ទ្រង់។ ពួកគេទទួលយកព្រះបន្ទូលរបស់ព្រះជាម្ចាស់តែប៉ុន្មានចំណែកដែលត្រូវទៅនឹងការយល់ឃើញរបស់ពួកគេប៉ុណ្ណោះ ហើយបដិសេធព្រះបន្ទូលដែលមិនត្រូវទៅនឹងការយល់ឃើញរបស់ពួកគេទៅវិញ។ តើនេះមិនមែនជាការបះបោរ និងការជំទាស់យ៉ាងកំរោល ចំពោះ

ព្រះជាម្ចាស់ទេឬអី? ប្រសិនបើមនុស្សម្នាក់ ជឿលើព្រះជាម្ចាស់អស់ច្រើនឆ្នាំហើយ ប៉ុន្តែមិនបានបង្កើនការយល់ដឹងអំពីទ្រង់សូម្បីតែបន្តិច នោះពួកគេមិនមែនជាអ្នកជឿឡើយ។ មនុស្សណាដែលមានឆន្ទៈទទួលយកការពិនិត្យពិច័យរបស់ព្រះជាម្ចាស់ គឺជាមនុស្សដែលព្យាយាមយល់ដឹងអំពីទ្រង់ ជាមនុស្សដែលមានឆន្ទៈទទួលយកការងាររបស់ទ្រង់។ ពួកគេគឺជាមនុស្សដែលនឹងទទួលបានកេរមរតក និងព្រះពរពីព្រះជាម្ចាស់ ហើយជាមនុស្សដែលមានពរច្រើនជាងគេ។ ព្រះជាម្ចាស់ដាក់បណ្ដាសាដល់មនុស្សដែលគ្មានទ្រង់នៅក្នុងចិត្តរបស់ពួកគេ ហើយទ្រង់វាយផ្ចាល និងបោះបង់មនុស្សបែបនេះចោល។ ប្រសិនបើអ្នកមិនស្រឡាញ់ព្រះជាម្ចាស់ទេ នោះទ្រង់នឹងបោះបង់អ្នកចោល ហើយប្រសិនបើអ្នក ពុំស្ដាប់តាមអ្វីដែលខ្ញុំថ្លែងនេះទេ នោះខ្ញុំសន្យាថា ព្រះវិញ្ញាណនៃព្រះនឹងបោះបង់អ្នកចោល។ ប្រសិនបើអ្នកមិនជឿទេ នោះអ្នកអាចសាកល្បងបាន។ ថ្ងៃនេះ ខ្ញុំសូមបញ្ជាក់ប្រាប់អ្នកអំពីមាគ៌ានៃការប្រព្រឹត្តមួយ ប៉ុន្តែអ្នកអនុវត្តតាម ឬអត់នោះ គឺអាស្រ័យទៅលើអ្នក។ ប្រសិនបើអ្នកមិនជឿទេ ប្រសិនបើអ្នកមិនអនុវត្តតាមទេ នោះអ្នកនឹងឃើញដោយខ្លួនឯងថា ព្រះវិញ្ញាណបរិសុទ្ធធ្វើការជាមួយអ្នក ឬអត់! ប្រសិនបើអ្នកមិនព្យាយាមយល់អំពីព្រះជាម្ចាស់ទេ នោះព្រះវិញ្ញាណបរិសុទ្ធនឹងមិនធ្វើការជាមួយអ្នកឡើយ។ ព្រះជាម្ចាស់ធ្វើការនៅក្នុងមនុស្សដែលស្វះស្វែង ហើយឲ្យតម្លៃលើព្រះបន្ទូលរបស់ទ្រង់។ ដរាបណាអ្នកឲ្យតម្លៃលើព្រះបន្ទូលរបស់ព្រះជាម្ចាស់កាន់តែខ្លាំង នោះព្រះវិញ្ញាណរបស់ទ្រង់ធ្វើការនៅក្នុងអ្នក។ កាលណាមនុស្សម្នាក់ឲ្យតម្លៃព្រះបន្ទូលរបស់ព្រះជាម្ចាស់កាន់តែខ្លាំង នោះឱកាសដែលពួកគេត្រូវបានព្រះជាម្ចាស់ប្រោសឲ្យគ្រប់លក្ខណ៍ ក៏កាន់តែកើនឡើងដែរ។ ព្រះជាម្ចាស់ប្រោសមនុស្សដែលស្រឡាញ់ទ្រង់ពិតឲ្យបានគ្រប់លក្ខណ៍ ហើយទ្រង់ប្រោសមនុស្សដែលមានចិត្តស្ងប់នៅចំពោះទ្រង់ឲ្យបានគ្រប់លក្ខណ៍។ ដើម្បីឲ្យតម្លៃលើរាល់កិច្ចការទាំងអស់របស់ព្រះជាម្ចាស់ លើការបំភ្លឺរបស់ព្រះជាម្ចាស់ លើព្រះវត្តមានរបស់ព្រះជាម្ចាស់ លើព្រះទ័យទុកដាក់និងការថែរក្សារបស់ព្រះជាម្ចាស់ លើរបៀបដែលព្រះបន្ទូលរបស់ព្រះជាម្ចាស់ក្លាយទៅជាតថភាពរបស់អ្នក និងផ្គត់ផ្គង់

ដល់ជីវិតអ្នក គឺសុទ្ធតែស្របទៅនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ មានន័យថា ប្រសិនបើអ្នក ឲ្យតម្លៃលើកិច្ចការរបស់ព្រះជាម្ចាស់ ប្រសិនបើអ្នកឲ្យតម្លៃលើរាល់កិច្ចការទាំងអស់ ដែលទ្រង់បានធ្វើមកលើអ្នក នោះទ្រង់នឹងប្រទានពរដល់អ្នក ហើយធ្វើឲ្យអ្វីទាំងអស់ដែលជារបស់អ្នក ចម្រើនឡើង។ ប្រសិនបើអ្នកពុំឲ្យតម្លៃលើព្រះបន្ទូលព្រះជាម្ចាស់ទេ ទ្រង់នឹងពុំធ្វើការនៅក្នុងអ្នកឡើយ ប៉ុន្តែទ្រង់នឹងប្រទានព្រះគុណទ្រង់តែបន្តិចបន្តួចប៉ុណ្ណោះ សម្រាប់ជំនឿរបស់អ្នក ឬប្រទានពរជាទ្រព្យធនស្ដួចស្ដើងឲ្យអ្នក និងប្រទាននូវសុវត្ថិភាពតែបន្តិចដល់គ្រួសារអ្នកវិញ។ អ្នកគួរតែខិតខំធ្វើឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់ក្លាយជាតថភាពរបស់អ្នក និងអាចធ្វើឲ្យទ្រង់គាប់ព្រះទ័យ ហើយស្របតាមព្រះហឫទ័យរបស់ទ្រង់ អ្នកពុំគួរព្យាយាមអាស្រ័យតែផលនៃព្រះគុណរបស់ទ្រង់ឡើយ។ សម្រាប់ពួកអ្នកជឿ គ្មានអ្វីដែលសំខាន់ជាងការទទួលយកកិច្ចការរបស់ព្រះជាម្ចាស់ ការទទួលបានភាពគ្រប់លក្ខណ៍ ហើយក្លាយជាមនុស្សដែលធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ឡើយ។ ការនេះគួរតែជាគោលដៅដែលអ្នកគួរតែស្វះស្វែងរកឲ្យបាន។

អ្វីទាំងអស់ដែលមនុស្សស្វះស្វែងរកក្នុងយុគសម័យនៃព្រះគុណ គឺហួសសម័យទៅហើយ ព្រោះបច្ចុប្បន្ននេះ ការស្វះស្វែងមានបទដ្ឋានមួយខ្ពស់ជាងមុន អ្វីដែលគេស្វះស្វែងនោះ មានទាំងភាពឧត្តុង្គឧត្តមជាងមុន និងជាក់ស្ដែងជាងមុន អ្វីដែលគេស្វះស្វែងរកនោះ អាចធ្វើឲ្យអ្វីដែលមនុស្សលោកចង់បាននៅខាងក្នុងស្កប់ចិត្ត។ កាលពីសម័យមុនៗ ព្រះជាម្ចាស់ពុំបានធ្វើការទៅលើមនុស្សលោក ដូចជាទ្រង់ធ្វើនាពេលបច្ចុប្បន្ននេះទេ ដ្បិតទ្រង់ពុំបានមានព្រះបន្ទូលទៅកាន់ពួកគេច្រើន ដូចសព្វថ្ងៃនេះទេ រីឯសេចក្ដីតម្រូវរបស់ទ្រង់ក៏មិនខ្ពស់ ដូចជាសេចក្ដីតម្រូវនាពេលសព្វថ្ងៃនេះដែរ។ ការដែលព្រះជាម្ចាស់មានបន្ទូលអំពីសេចក្ដីទាំងនេះទៅកាន់មនុស្សលោកនាពេលបច្ចុប្បន្ន បង្ហាញឲ្យឃើញថា ព្រះជាម្ចាស់មានចេតនាដ៏ខ្ពង់ខ្ពស់ផ្ដោតសំខាន់ទៅលើអ្នក គឺទៅលើមនុស្សមួយក្រុមនេះ។ ប្រសិនបើអ្នក ពិតជាប្រាថ្នាឲ្យព្រះជាម្ចាស់ប្រោសឱ្យគ្រប់លក្ខណ៍មែន នោះចូរព្យាយាមឲ្យបានការនេះទុកជាគោលដៅសំខាន់

របស់អ្នកចុះ។ ដើម្បីសម្រេចគោលដៅទាំងនេះបាន ទោះជាអ្នករត់ចុះឡើងដោយចំណាយកម្លាំងរបស់ខ្លួន ដោយបម្រើតួនាទីមួយ ឬទោះជាអ្នកបានទទួលបញ្ជាបេសកកម្មរបស់ព្រះជាម្ចាស់ក៏ដោយ ក៏គោលបំណងសំខាន់ នៅតែជាការដែលត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍ និងផ្គាប់តាមបំណងព្រះហឫទ័យរបស់ព្រះជានិច្ចដែរ។ ប្រសិនបើមាននរណាម្នាក់និយាយថា គេពុំព្យាយាមឲ្យបានភាពគ្រប់លក្ខណ៍ដោយសារព្រះជាម្ចាស់ ឬចូលទៅក្នុងជីវិតទេ ប៉ុន្តែបែរជាព្យាយាមឲ្យបានភាពសុខសាន្ត និងអំណរខាងសាច់ឈាមទៅវិញនោះ គេគឺជាមនុស្សងងឹតងងល់។ មនុស្សដែលពុំព្យាយាមឲ្យបានតថភាពនៃជីវិត ប៉ុន្តែបែរជាព្យាយាមឲ្យបានជីវិតអស់កល្បនៅឯបរលោកនាយ និងព្យាយាមឲ្យបានសុវត្ថិភាពនៅលោកិយនេះ គឺជាមនុស្សងងឹតងងល់ខ្លាំងបំផុត។ ដូច្នេះ អ្វីៗទាំងអស់ដែលអ្នកធ្វើ គួរតែត្រូវបានធ្វើឡើងក្នុងគោលបំណងឲ្យព្រះជាម្ចាស់ប្រោសឲ្យគ្រប់លក្ខណ៍ និងឲ្យទ្រង់ទទួលយក។

កិច្ចការដែលព្រះធ្វើនៅក្នុងមនុស្សលោក គឺដើម្បីផ្គត់ផ្គង់ពួកគេ ស្របទៅតាមតម្រូវការផ្សេងៗរបស់ពួកគេ។ បើជីវិតរបស់មនុស្សម្នាក់មានតម្រូវការកាន់តែធំ នោះពួកគេទាមទារកាន់តែច្រើន និងព្យាយាមឲ្យបានកាន់តែខ្លាំង។ ប្រសិនបើក្នុងដំណាក់កាលនេះ អ្នកមិនព្យាយាមឲ្យបានទេ នោះបង្ហាញថា ព្រះវិញ្ញាណបរិសុទ្ធបានបោះបង់អ្នកចោលហើយ។ មនុស្សណាដែលស្វះស្វែងរកជីវិត នឹងមិនត្រូវព្រះវិញ្ញាណបរិសុទ្ធបោះបង់ចោលឡើយ ដ្បិតមនុស្សប្រភេទនេះរមែងព្យាយាមខ្នះខ្នែង និងមានបំណងប្រាថ្នាខ្ពស់ក្នុងចិត្តជានិច្ច។ មនុស្សប្រភេទនេះមិនដែលរីករាយនឹងអ្វីដែលពួកគេមានក្នុងពេលនេះឡើយ។ ដំណាក់កាលនីមួយៗនៃកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធមានគោលបំណងសម្រេចបានប្រពលភាពនៅក្នុងអ្នក ប៉ុន្តែប្រសិនបើអ្នកបង្កើនក្តីកង្វល់ ប្រសិនបើអ្នក លែងមានសេចក្តីត្រូវការតទៅទៀត ប្រសិនបើអ្នកលែងទទួលយកកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធតទៅទៀត នោះទ្រង់នឹងបោះបង់អ្នកចោល។ មនុស្សត្រូវការការពិនិត្យពិច័យ របស់ព្រះជាម្ចាស់រៀងរាល់ថ្ងៃ ពួកគេត្រូវការការផ្គត់ផ្គង់ដ៏បរិបូរ ពីព្រះជាម្ចាស់ជារៀងរាល់ថ្ងៃ។ តើមនុស្សអាចរស់ដោយមិនហូប និងផឹក

ព្រះបន្ទូលរបស់ព្រះជាម្ចាស់ជារៀងរាល់ថ្ងៃបានដែរឬទេ? ប្រសិនបើមនុស្សម្នាក់មានអារម្មណ៍ថា គេមិនអាចហូប និងផឹកព្រះបន្ទូលព្រះជាម្ចាស់គ្រប់គ្រាន់ទេ ប្រសិនបើគេស្វែងរកព្រះបន្ទូល ហើយស្រេកឃ្លានព្រះបន្ទូលជានិច្ច នោះព្រះវិញ្ញាណបរិសុទ្ធនឹងធ្វើការនៅក្នុងពួកគេជានិច្ច។ នៅពេលមនុស្សម្នាក់កាន់តែចង់បាន នោះលទ្ធផលដែលកើតចេញពីការប្រកបគ្នារបស់គេ គឺកាន់តែជាក់ស្ដែង។ នៅពេលមនុស្សម្នាក់ស្វែងរកសេចក្ដីពិតកាន់តែខ្លាំង នោះពួកគេសម្រេចបានភាពរីកចម្រើនក្នុងជីវិតរបស់ខ្លួនកាន់តែឆាប់ ដោយធ្វើឲ្យពួកគេសម្បូរទាំងបទពិសោធ ហើយមានទ្រព្យធនកាន់តែច្រើនសន្ធឹក នៅក្នុងដំណាក់របស់ព្រះជាម្ចាស់។

# អស់អ្នកណាដែលស្ដាប់បង្គាប់ ព្រះជាម្ចាស់ដោយដួងចិត្តពិត នឹងត្រូវព្រះជាម្ចាស់ទទួលយក ជាប្រាកដ

កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ផ្លាស់ប្ដូរពីមួយថ្ងៃទៅមួយថ្ងៃ។ កិច្ចការនេះកាន់តែខ្ពស់ឡើងៗរាល់ជំហាន ការបើកសម្ដែងនៅថ្ងៃស្អែកខ្ពស់ជាងការបើកសម្ដែងនៅថ្ងៃនេះ ដោយឡើងខ្ពស់ទៅៗពីមួយជំហានទៅមួយជំហាន។ ការងារនោះគឺជាការងារដែលព្រះជាម្ចាស់ធ្វើឲ្យមនុស្សបានគ្រប់លក្ខណ៍។ ប្រសិនបើមនុស្សមិនអាចដើរឲ្យទាន់ទេ នោះពួកគេនឹងត្រូវបណ្ដេញចេញគ្រប់ពេលវេលា។ ប្រសិនបើពួកគេគ្មានចិត្តស្ដាប់បង្គាប់ទេ ពួកគេនឹងមិនអាចដើរតាមរហូតដល់ទីបញ្ចប់បានឡើយ។ យុគសម័យមុនបានកន្លងផុតទៅហើយ។ នេះគឺជាយុគសម័យថ្មី។ ហើយនៅក្នុងសម័យថ្មី កិច្ចការថ្មីក៏ត្រូវបានធ្វើឡើង។ ជាពិសេស នៅក្នុងយុគសម័យចុងក្រោយដែលមនុស្សត្រូវធ្វើឲ្យបានគ្រប់លក្ខណ៍ ព្រះជាម្ចាស់ នឹងបំពេញកិច្ចការកាន់តែថ្មីកាន់តែឆាប់ ដូច្នេះ បើក្នុងចិត្តពួកគេគ្មានការស្ដាប់បង្គាប់ទេ មនុស្សនឹងពិបាកដើរតាមលំអានរបស់ព្រះជាម្ចាស់។ ព្រះជាម្ចាស់ ពុំគោរពតាមខ្នាតតម្រាណាមួយឡើយ

ហើយទ្រង់ក៏មិនចាត់ទុកដំណាក់កាលណាមួយនៃកិច្ចការរបស់ទ្រង់ថាមិនមានការប្រែប្រួលដែរ។ ផ្ទុយទៅវិញ កិច្ចការដែលព្រះជាម្ចាស់ធ្វើ គឺកាន់តែថ្មីឡើង និងកាន់តែខ្ពស់ឡើងរហូត។ ក្នុងដំណាក់កាលនីមួយៗ កិច្ចការរបស់ទ្រង់កាន់តែជាក់ស្ដែង និងកាន់តែស្របគ្នាទៅនឹងតម្រូវការជាក់ស្ដែងរបស់មនុស្សលោក។ មានតែក្រោយពេលដែលមនុស្សជួបប្រទះកិច្ចការបែបនោះប៉ុណ្ណោះ ទើបពួកគេ អាចសម្រេចបាននូវការបំផ្លាស់បំប្រែនិស្ស័យរបស់ពួកគេជាចុងក្រោយបាន។ ចំណេះដឹងស្ដីពីជីវិតរបស់មនុស្សឈានដល់កម្រិតកាន់តែខ្ពស់ឡើងៗ ដូច្នេះហើយកិច្ចការរបស់ព្រះជាម្ចាស់ក៏ឈានដល់កម្រិតកាន់តែខ្ពស់ជាងមុនដូចគ្នា។ មានតែដូច្នេះទេ ទើបមនុស្សអាចធ្វើឲ្យគ្រប់លក្ខណ៍បាន និងស័ក្ដិសមឲ្យព្រះជាម្ចាស់ប្រើ។ ព្រះហស្តម្ខាង ព្រះជាម្ចាស់ធ្វើកិច្ចការដោយបែបនេះដើម្បីតទល់និងផ្លាស់ប្រែសញ្ញាណរបស់មនុស្ស ហើយព្រះហស្តម្ខាងទៀតទ្រង់ដឹកនាំមនុស្សទៅកាន់ស្ថានភាពរឹតតែជាក់ស្ដែង និងខ្ពស់ជាងមុន គឺចូលទៅក្នុងពិភពដ៏ខ្ពស់បំផុតនៃសេចក្តីជំនឿចំពោះព្រះ ដើម្បីឲ្យបំណងព្រះហឫទ័យនៃព្រះអាចសម្រេចបាននៅទីបំផុត។ អស់អ្នកណាដែលមានចរិតមិនស្ដាប់បង្គាប់ ដែលមានចេតនាប្រឆាំងទាស់នឹងទ្រង់ នឹងត្រូវបណ្ដេញចេញនៅដំណាក់កាលនៃកិច្ចការជឿនលឿនទៅមុខដ៏ឆាប់រហ័ស និងពេញទំហឹងរបស់ព្រះជាម្ចាស់។ មានតែអស់អ្នកណាដែលព្រមស្ដាប់បង្គាប់ និងអ្នកដែលបន្ទាបខ្លួនពួកគេដោយអរសប្បាយប៉ុណ្ណោះ ដែលអាចរីកចម្រើនទៅមុខរហូតដល់ចុងបញ្ចប់នៃផ្លូវបាន។ នៅក្នុងកិច្ចការប្រភេទនេះ អ្នករាល់គ្នាគប្បីរៀនពីវិធីចុះចូល និងវិធីទុកដាក់សញ្ញាណរបស់ខ្លួនមួយឡែក។ អ្នកគប្បីមានការប្រុងប្រយ័ត្ននៅគ្រប់ជំហានដែលអ្នកដើរ។ ប្រសិនបើអ្នកធ្វេសប្រហែស អ្នកប្រាកដជានឹងក្លាយជាមនុស្សម្នាក់ ដែលត្រូវព្រះវិញ្ញាណបរិសុទ្ធបោះបង់ចោល ជាមនុស្សម្នាក់ ដែលរំខានដល់កិច្ចការរបស់ព្រះជាម្ចាស់។ នៅមុនពេលឆ្លងកាត់ដំណាក់កាលនៃកិច្ចការនេះ ខ្នាតតម្រា និងក្រឹត្យវិន័យរបស់មនុស្សពីមុន មានច្រើនខ្លាំងរហូតដល់មនុស្សអរសប្បាយនឹងសេចក្ដីទាំងនោះជ្រុល ហើយជាលទ្ធផល មនុស្សត្រូវគេបោកបញ្ឆោត និងភ្លេចថា ខ្លួនជានរណា។ ទាំងនេះគឺជាឧបសគ្គដែលរារាំងមិនឲ្យ

មនុស្សទទួលយកកិច្ចការថ្មីរបស់ព្រះជាម្ចាស់បាន។ ឧបសគ្គទាំងនេះគឺជាសត្រូវនៃចំណេះដឹងរបស់មនុស្សអំពីព្រះជាម្ចាស់។ វាមានគ្រោះថ្នាក់សម្រាប់មនុស្សដែលមិនមានការស្ដាប់បង្គាប់នៅក្នុងចិត្តរបស់ពួកគេ និងមិនមានការស្រេកឃ្លានចង់បានសេចក្ដីពិត។ ប្រសិនបើអ្នកចុះចូលតែចំពោះកិច្ចការ និងព្រះបន្ទូលងាយៗរបស់ព្រះជាម្ចាស់ ហើយមិនអាចយល់សេចក្ដីដែលស៊ីជម្រៅជាងនេះ នោះអ្នកគឺជាមនុស្សម្នាក់ ដែលប្រកាន់ខ្ជាប់ទៅនឹងវិធីចាស់ៗ និងមិនអាចដើរឲ្យទាន់ នូវកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធបានឡើយ។ កិច្ចការដែលព្រះជាម្ចាស់ធ្វើ ខុសគ្នាពីពេលមួយទៅពេលមួយ។ ប្រសិនបើអ្នកស្ដាប់បង្គាប់តាមកិច្ចការរបស់ព្រះជាម្ចាស់បានល្អនៅដំណាក់កាលមួយ តែការស្ដាប់បង្គាប់របស់អ្នកចំពោះកិច្ចការរបស់ទ្រង់បែរជាមិនបានល្អនៅដំណាក់កាលមួយទៀត ឬក៏អ្នកមិនអាចស្ដាប់បង្គាប់បាន នោះព្រះជាម្ចាស់នឹងបោះបង់អ្នកចោល។ ប្រសិនបើអ្នកដើរទាន់ព្រះជាម្ចាស់ នៅពេលទ្រង់បោះជំហាននេះ នោះអ្នកត្រូវបន្តដើរឲ្យទាន់នៅពេលទ្រង់បោះជំហានបន្ទាប់ទៀត។ គឺមានតែពេលនោះទេ ទើបអ្នកនឹងអាចក្លាយទៅជាមនុស្សម្នាក់ ដែលស្ដាប់បង្គាប់ព្រះវិញ្ញាណបរិសុទ្ធ។ ដោយសារតែអ្នកជឿលើព្រះជាម្ចាស់ អ្នកត្រូវរក្សាការស្ដាប់បង្គាប់របស់អ្នកឲ្យបានឋិតថេរ។ អ្នកមិនអាចគ្រាន់តែស្ដាប់បង្គាប់នៅពេលអ្នកសប្បាយចិត្ត ហើយមិនស្ដាប់បង្គាប់នៅពេលអ្នកមិនសប្បាយចិត្តនោះទេ។ ការស្ដាប់បង្គាប់បែបនេះ ព្រះជាម្ចាស់មិនសរសើរឡើយ។ ប្រសិនបើអ្នកមិនអាចដើរតាមជំហាននៃកិច្ចការថ្មីដែលខ្ញុំបានរៀបចំ និងបន្តប្រកាន់ខ្ជាប់តាមសុភាសិតចាស់ពីមុនមកទេនោះ តើអាចមានការរីកចម្រើននៅក្នុងជីវិតរបស់អ្នកដោយរបៀបណា? កិច្ចការរបស់ព្រះជាម្ចាស់ គឺដើម្បីទំនុកបម្រុងដល់អ្នកតាមរយៈព្រះបន្ទូលរបស់ទ្រង់។ នៅពេលអ្នកស្ដាប់បង្គាប់ និងទទួលយកព្រះបន្ទូលរបស់ទ្រង់ នោះព្រះវិញ្ញាណបរិសុទ្ធនឹងធ្វើការនៅក្នុងខ្លួនឯងជាប្រាកដ។ ព្រះវិញ្ញាណបរិសុទ្ធធ្វើកិច្ចការដូចគ្នាបេះបិទនឹងអ្វីដែលខ្ញុំមានបន្ទូល។ ចូរធ្វើដូចអ្វីដែលខ្ញុំបានមានបន្ទូលចុះ នោះព្រះវិញ្ញាណបរិសុទ្ធនឹងធ្វើការនៅក្នុងខ្លួនអ្នកជាប្រាកដ។ ខ្ញុំបានបញ្ចេញនូវពន្លឺថ្មីមួយសម្រាប់ឲ្យអ្នករាល់គ្នាបានឃើញ ដោយនាំយកអ្នករាល់គ្នាទៅក្នុងពន្លឺបច្ចុប្បន្ន

ហើយនៅពេលដែលអ្នកដើរទៅក្នុងពន្លឺនេះ ព្រះវិញ្ញាណបរិសុទ្ធនឹងធ្វើការនៅក្នុងអ្នកភ្លាមៗ។ មានមនុស្សមួយចំនួនដែលចចេសរឹងរូស និយាយថា «ខ្ញុំនឹងមិនធ្វើតាមអ្វីដែលអ្នកនិយាយទ្បើយ»។ នៅក្នុងករណីនេះ ខ្ញុំប្រាប់អ្នកចុះថា អ្នកបានមកដល់ចុងបញ្ចប់នៃផ្លូវហើយ។ អ្នកត្រូវក្រៀមស្វិត និងគ្មានជីវិតទៀតទ្បើយ។ ហេតុដូចនេះ នៅក្នុងបទពិសោធនៃការបំផ្លាស់បំប្រែនិស្ស័យរបស់អ្នក គ្មានអ្វីសំខាន់ជាងការរក្សាជំហានឲ្យទាន់នឹងពន្លឺបច្ចុប្បន្ននេះទ្បើយ។ ព្រះវិញ្ញាណបរិសុទ្ធមិនត្រឹមតែធ្វើការក្នុងខ្លួនមនុស្សណាម្នាក់ ដែលព្រះជាម្ចាស់ប្រើការនោះទេ ប៉ុន្តែក៏ធ្វើការនៅក្នុងពួកជំនុំផងដែរ។ ទ្រង់អាចធ្វើការនៅក្នុងមនុស្សគ្រប់គ្នាបាន។ ទ្រង់អាចនឹងកំពុងធ្វើការក្នុងខ្លួនអ្នកក្នុងអំឡុងពេលបច្ចុប្បន្ន ហើយអ្នកនឹងបានស្គាល់កិច្ចការនេះ។ នៅក្នុងអំឡុងពេលបន្ទាប់ទៀត ទ្រង់អាចនឹងធ្វើការក្នុងខ្លួនមនុស្សផ្សេងទៀត ដែលក្នុងករណីនេះ អ្នកត្រូវតែប្រញាប់ដើរតាម។ នៅពេលអ្នកដើរតាមពន្លឺបច្ចុប្បន្នកាន់តែកៀក នោះជីវិតរបស់អ្នកនឹងកាន់តែរីកចម្រើនទ្បើង។ មិនថាចរិតលក្ខណៈរបស់មនុស្សម្នាក់បែបណានោះទេ ប្រសិនបើព្រះវិញ្ញាណបរិសុទ្ធធ្វើការក្នុងពួកគេ នោះអ្នកត្រូវតែដើរតាម។ ចូរថ្លឹងថ្លែងបទពិសោធរបស់ពួកគេ តាមរយៈបទពិសោធរបស់អ្នកផ្ទាល់ នោះអ្នកនឹងទទួលបានអ្វីកាន់តែខ្ពស់។ ការធ្វើបែបនេះ នោះអ្នកនឹងរីកចម្រើនកាន់តែឆាប់។ នេះគឺជាផ្លូវនៃភាពគ្រប់លក្ខណ៍សម្រាប់មនុស្ស និងជាមធ្យោបាយ ដែលជីវិតបានរីកចម្រើនធំធាត់។ ផ្លូវដែលនាំឲ្យគ្រប់លក្ខណ៍គឺអាចសម្រេចបាន តាមរយៈការស្ដាប់បង្គាប់របស់អ្នក ចំពោះកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ។ អ្នកពុំដឹងថា ព្រះជាម្ចាស់នឹងធ្វើឲ្យអ្នកបានគ្រប់លក្ខណ៍តាមរយៈមនុស្សប្រភេទណានោះទេ ក៏មិនដឹងថា ទ្រង់អនុញ្ញាតឲ្យអ្នកទទួលបាន ឬមើលឃើញអស់ទាំងសេចក្ដីតាមរយៈមនុស្ស តាមព្រឹត្តិការណ៍ ឬតាមវត្ថុអ្វីទ្បើយ។ ប្រសិនបើអ្នកអាចដាក់ជើងនៅលើគន្លងផ្លូវដ៏ត្រឹមត្រូវ នោះអាចបង្ហាញថា អ្នកមានក្ដីសង្ឃឹមដ៏ធំធេងដើម្បីឲ្យព្រះជាម្ចាស់ធ្វើឲ្យគ្រប់លក្ខណ៍។ ប្រសិនបើអ្នកមិនអាចធ្វើបានទេ នោះបង្ហាញថាអនាគតរបស់អ្នកងងឹតសូន្យឈឹង គ្មានពន្លឺអ្វីទ្បើយ។ នៅពេលអ្នកចាប់ផ្ដើមដើរនៅលើផ្លូវត្រូវ អ្នកនឹង

ទទួលការបើកសម្ដែងក្នុងគ្រប់ការទាំងអស់។ មិនថាព្រះវិញ្ញាណបរិសុទ្ធបើកសម្ដែងអ្វីខ្លះចំពោះអ្នកដទៃនោះទេ ប្រសិនបើអ្នកបន្តឋិតនៅលើមូលដ្ឋានចំណេះដឹងរបស់ពួកគេដើម្បីទទួលបានបទពិសោធលើអ្វីៗដោយខ្លួនឯង នោះបទពិសោធនេះ នឹងក្លាយជាចំណែកមួយនៃជីវិតរបស់អ្នក ហើយអ្នកនឹងអាចផ្គត់ផ្គង់ដល់អ្នកដទៃបានតាមរយៈបទពិសោធនេះ។ អស់អ្នកណាដែលផ្គត់ផ្គង់អ្នកដទៃ ដោយពាក្យសម្ដីដូចជាសត្វសេក ជាមនុស្សដែលមិនធ្លាប់មានបទពិសោធអ្វីសោះឡើយ។ អ្នកត្រូវស្វែងយល់ដើម្បីរកវិធីអនុវត្តមួយ នៅមុនពេលដែលអ្នកអាចចាប់ផ្ដើមនិយាយអំពីបទពិសោធ និងចំណេះដឹងជាក់ស្ដែងរបស់អ្នក តាមរយៈការបំភ្លឺ និងការបង្ហាញរបស់អ្នកដទៃ។ ការនេះនឹងមានប្រយោជន៍យ៉ាងច្រើនសម្រាប់ជីវិតផ្ទាល់ខ្លួនរបស់អ្នក។ អ្នកគប្បីឆ្លងកាត់បទពិសោធបែបនេះ ដោយស្ដាប់បង្គាប់តាមគ្រប់អ្វីដែលមកពីព្រះជាម្ចាស់។ អ្នកគប្បីព្យាយាមស្វែងយល់ ពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ក្នុងគ្រប់ការទាំងអស់ និងរៀនសូត្រមេរៀននានាក្នុងគ្រប់ការទាំងអស់ ដើម្បីឲ្យជីវិតរបស់អ្នកចម្រើនឡើង។ ការអនុវត្តបែបនេះ ជួយឲ្យមានការរីកចម្រើនយ៉ាងឆាប់រហ័ស។

ព្រះវិញ្ញាណបរិសុទ្ធ បំភ្លឺដល់អ្នកតាមរយៈបទពិសោធជាក់ស្ដែង និងធ្វើឲ្យអ្នកគ្រប់លក្ខណ៍តាមរយៈសេចក្ដីជំនឿរបស់អ្នក។ តើអ្នកពិតជាសុខចិត្តឲ្យខ្លួនបានគ្រប់លក្ខណ៍ដែរឬទេ? ប្រសិនបើអ្នកត្រូវបានព្រះជាម្ចាស់ប្រោសឲ្យគ្រប់លក្ខណ៍ នោះអ្នកនឹងមានសេចក្ដីក្លាហានក្នុងការលះបង់ខាងសាច់ឈាមរបស់អ្នក អ្នកនឹងអាចប្រតិបត្តិតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយអ្នកនឹងមិនអសកម្ម ឬទន់ខ្សោយឡើយ។ អ្នកនឹងអាចស្ដាប់បង្គាប់តាមគ្រប់អ្វីៗដែលមកអំពីព្រះជាម្ចាស់ ហើយគ្រប់សកម្មភាពរបស់អ្នក មិនថាសកម្មភាពដែលត្រូវបានធ្វើជាសាធារណៈ ឬដោយឯកជននោះទេ គឺនឹងត្រូវព្រះជាម្ចាស់ទតឃើញ។ ប្រសិនបើអ្នកជាមនុស្សស្មោះត្រង់ ហើយអនុវត្តតាមសេចក្ដីពិតក្នុងគ្រប់ការទាំងអស់ នោះអ្នកនឹងត្រូវធ្វើឲ្យគ្រប់លក្ខណ៍។ មនុស្សបោកបញ្ឆោតដែលធ្វើបែបនេះនៅមុខមនុស្សម្នា ហើយធ្វើបែបផ្សេងនៅក្រោយខ្នងពួកគេទាំងនោះ មិនស្ម័គ្រចិត្តឱ្យខ្លួនត្រូវបានធ្វើឲ្យគ្រប់លក្ខណ៍ឡើយ។ ពួកគេជាកូន

នៃសេចក្ដីបាក់បែក និងជាកូននៃសេចក្ដីវិនាស។ ពួកគេមិនមែនជាកម្មសិទ្ធិរបស់ព្រះជាម្ចាស់ឡើយ តែជាកម្មសិទ្ធិរបស់សាតាំង។ ពួកគេមិនមែនជាមនុស្សដែលព្រះជាម្ចាស់ជ្រើសរើសនោះឡើយ! ប្រសិនបើទង្វើ និងឥរិយាបថរបស់អ្នកមិនបានបង្ហាញនៅចំពោះព្រះជាម្ចាស់ ឬមិនបានទតមើលដោយព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ទេ នេះគឺជាភស្តុតាងបញ្ជាក់ថា អ្នកមានអ្វីមិនត្រឹមត្រូវហើយ។ ទាល់តែអ្នកទទួលយកការជំនុំជម្រះ និងការដាក់ទោសរបស់ព្រះជាម្ចាស់ ហើយយកចិត្តទុកដល់ការបំផ្លាស់បំប្រែនិស្ស័យរបស់អ្នកប៉ុណ្ណោះ ទើបអ្នកអាចបោះជំហាននៅលើផ្លូវដែលធ្វើឲ្យគ្រប់លក្ខណ៍។ ប្រសិនបើអ្នក ពិតជាចង់ឲ្យបានគ្រប់លក្ខណ៍ដោយព្រះជាម្ចាស់ និងចង់ធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់មែន នោះអ្នកគប្បី ស្ដាប់បង្គាប់តាមកិច្ចការទាំងអស់របស់ព្រះជាម្ចាស់ដោយពុំមានការរអ៊ូរទាំសូម្បីតែមួយម៉ាត់ ដោយគ្មានការសន្និដ្ឋាន វាយតម្លៃ ឬក៏វិនិច្ឆ័យកិច្ចការរបស់ព្រះជាម្ចាស់ឡើយ។ ទាំងអស់នេះជាលក្ខខណ្ឌបន្តិចបន្តួច សម្រាប់ឲ្យព្រះជាម្ចាស់ធ្វើឲ្យបានគ្រប់លក្ខណ៍។ លក្ខខណ្ឌចាំបាច់សម្រាប់អស់អ្នកណាដែលចង់បានគ្រប់លក្ខណ៍ដោយព្រះជាម្ចាស់គឺបែបនេះ៖ ធ្វើកិច្ចការដោយចិត្តស្រឡាញ់ព្រះជាម្ចាស់ក្នុងគ្រប់ការទាំងអស់។ តើការធ្វើកិច្ចការដោយចិត្តស្រឡាញ់ព្រះជាម្ចាស់ មានន័យដូចម្ដេច? មានន័យថា គ្រប់ទង្វើ និងអាកប្បកិរិយាទាំងអស់របស់អ្នក អាចបង្ហាញនៅចំពោះព្រះជាម្ចាស់បាន។ ហើយដោយសារអ្នកមានបំណងត្រឹមត្រូវ មិនថាទង្វើរបស់អ្នកត្រឹមត្រូវ ឬក៏ខុសនោះទេ អ្នកមិនខ្លាចនឹងបង្ហាញទង្វើនោះនៅចំពោះព្រះជាម្ចាស់ ឬនៅចំពោះបងប្អូនប្រុសស្រីរបស់អ្នកឡើយ ហើយអ្នកក៏ហ៊ានស្បថនៅចំពោះព្រះជាម្ចាស់ដែរ។ អ្នកត្រូវបង្ហាញគ្រប់ចេតនា គំនិត និងទស្សនៈរបស់អ្នក នៅចំពោះព្រះជាម្ចាស់ ដើម្បីឲ្យទ្រង់ពិនិត្យពិច័យ។ ប្រសិនបើអ្នកប្រតិបត្តិ និងចូលទៅរកទ្រង់ដោយវិធីនេះ នោះការរីកចម្រើននៅក្នុងជីវិតរបស់អ្នកប្រាកដជាឆាប់រហ័សមិនខាន។

ដោយសារអ្នកជឿលើព្រះជាម្ចាស់ អ្នកត្រូវដាក់សេចក្ដីជំនឿរបស់អ្នក ក្នុងគ្រប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងក្នុងគ្រប់កិច្ចការទាំងអស់របស់ទ្រង់។ មានន័យថា

ដោយសារអ្នកជឿលើព្រះជាម្ចាស់ អ្នកត្រូវតែស្ដាប់បង្គាប់ទ្រង់។ ប្រសិនបើអ្នកមិនអាចធ្វើបែបនេះបានទេ មិនថាអ្នកជឿ ឬក៏មិនជឿលើព្រះជាម្ចាស់នោះទេ គឺគ្មានបានការអ្វីនោះឡើយ។ ប្រសិនបើអ្នកបានជឿលើព្រះជាម្ចាស់អស់រយៈពេលជាច្រើនឆ្នាំមកហើយ ប៉ុន្ដែមិនដែលស្ដាប់បង្គាប់ទ្រង់ ហើយមិនទទួលយកលក្ខណៈពេញលេញនៃព្រះបន្ទូលរបស់ទ្រង់ ហើយផ្ទុយទៅវិញ បែរជាសុំឲ្យព្រះជាម្ចាស់ចុះចូលនឹងអ្នក និងធ្វើតាមគំនិតរបស់អ្នក ដូច្នេះ អ្នកជាមនុស្សបះបោរប្រឆាំងនឹងទ្រង់ខ្លាំងជាងគេបំផុត អ្នកជាមនុស្សមិនជឿលើព្រះជាម្ចាស់ទេ។ តើមនុស្សបែបនេះអាចស្ដាប់បង្គាប់ព្រះបន្ទូល និងកិច្ចការរបស់ព្រះជាម្ចាស់ដែលមិនស្របទៅនឹងគំនិតរបស់មនុស្សដូចម្ដេចបាន? មនុស្សដែលមិនគោរព ហើយទាស់ទទឹងនឹងព្រះជាម្ចាស់ដោយចេតនាអ្នកទាំងនោះហើយជាមនុស្សដែលបះបោរខ្លាំងជាងគេបំផុត។ ពួកគេជាសត្រូវរបស់ព្រះជាម្ចាស់ ជាពួកទទឹងនឹងព្រះគ្រីស្ទ។ ដួងចិត្តរបស់ពួកគេតែងប្រទូសទាស់នឹងកិច្ចការថ្មីរបស់ព្រះជាម្ចាស់។ ពួកគេមិនដែលមានទំនោរចិត្តចង់ចុះចូលឡើយ ហើយពួកគេក៏មិនធ្លាប់បានចុះចូលដោយអរសប្បាយ ឬក៏បន្ទាបខ្លួនពួកគេដែរ។ ពួកគេលើកតម្កើងពីខ្លួនឯងនៅចំពោះមុខអ្នកដទៃ និងមិនដែលចុះចូលនឹងនរណាម្នាក់ឡើយ។ នៅមុខព្រះជាម្ចាស់ ពួកគេចាត់ទុកខ្លួនឯងជាមនុស្សពូកែអធិប្បាយព្រះបន្ទូល និងជាមនុស្សដែលមានជំនាញជាងគេក្នុងការបំពេញកិច្ចការកែប្រែអ្នកដទៃ។ ពួកគេមិនដែលលះបង់ចោល «រតនសម្បត្តិ» ដែលពួកគេមាននោះទេ ប៉ុន្ដែចាត់ទុកវាជាមរតកគ្រួសារសម្រាប់ថ្វាយបង្គំ សម្រាប់អធិប្បាយប្រាប់អ្នកដទៃ ហើយពួកគេប្រើវាដើម្បីប្រៀនប្រដៅដល់ពួកល្ងង់ខ្លៅ ដែលគោរពស្រឡាញ់របស់ទ្រព្យទាំងនោះទុកជាព្រះជាម្ចាស់។ ជាការពិត នៅក្នុងពួកជំនុំមានមនុស្សបែបនេះច្រើនណាស់។ អាចនិយាយបានថា ពួកគេជា «វីរជនដែលគ្មាននរណាអាចយកឈ្នះបាន» ដែលស្នាក់នៅក្នុងដំណាក់របស់ព្រះជាម្ចាស់ពីមួយជំនាន់ទៅមួយជំនាន់។ ពួកគេយកការអធិប្បាយព្រះបន្ទូល (គោលលទ្ធិ) ទុកជាកាតព្វកិច្ចដ៏ឧត្ដុង្គឧត្ដមរបស់ពួកគេ។ ពីមួយឆ្នាំទៅមួយឆ្នាំ ពីមួយជំនាន់ទៅមួយជំនាន់ ពួកគេចាប់ផ្ដើមអនុវត្តភារកិច្ច «ពិសិដ្ឋ និងមិនអាច

បំពានបាន» យ៉ាងស្វាហាប់។ គ្មាននរណាម្នាក់ហ៊ានប៉ះពួកគេឡើយ។ គ្មានមនុស្ស ណាម្នាក់ហ៊ានស្ដីបន្ទោសពួកគេ ដោយបើកចំហឡើយ។ ពួកគេក្លាយជា «ស្ដេច» នៅក្នុងដំណាក់របស់ព្រះជាម្ចាស់ដោយធ្វើខ្លួនជាមនុស្សអាក្រក់ឃោរឃៅ នៅពេល ពួកគេសង្កត់សង្កិនអ្នកដទៃពីមួយជំនាន់ទៅមួយជំនាន់។ ពួកវិញ្ញាណអាក្រក់ទាំងនេះ ចង់ពួតដៃគ្នា និងបំផ្លាញកិច្ចការរបស់ខ្ញុំ តើខ្ញុំអាចឲ្យពួកអារក្សមានជីវិតទាំងអស់នេះ កើតមាននៅចំពោះព្រះនេត្ររបស់ខ្ញុំដូចម្ដេចបាន? សូម្បីតែអស់អ្នកដែលស្ដាប់បង្គាប់ តែពាក់កណ្ដាល ក៏មិនអាចបន្តរហូតដល់ចុងបញ្ចប់បានដែរ ហើយស្ដេចផ្ដាច់ការ ដែលមិនមានការស្ដាប់បង្គាប់សូម្បីតែបន្តិចនៅក្នុងដួងចិត្តរបស់ពួកគេរឹតតែមិនអាច បន្តទៅដល់ចុងបញ្ចប់បាន! មនុស្សមិនងាយនឹងយល់ពីកិច្ចការរបស់ព្រះជាម្ចាស់ បានឡើយ។ សូម្បីតែមួយចំណែកតូចនៃកិច្ចការដែលចុងក្រោយធ្វើឲ្យពួកគេទៅជា គ្រប់លក្ខណ៍ ក៏មនុស្សមិនអាចទទួលយកបានដែរ ទោះបីជាគេប្រើអស់ទាំងកម្លាំង ដែលពួកគេមានក៏ដោយ។ ដូច្នេះ តើកូនចៅនៃមហាទេវតាដែលព្យាយាមចង់បំផ្លាញ កិច្ចការរបស់ព្រះជាម្ចាស់នោះជាអ្វី? តើពួកគេមិនមានក្ដីសង្ឃឹមថាព្រះជាម្ចាស់នឹង ទទួលយកសូម្បីតែបន្តិចឬ? គោលបំណងរបស់ខ្ញុំក្នុងការយកឈ្នះ គឺមិនមែនគ្រាន់តែ យកឈ្នះដើម្បីឲ្យតែឈ្នះនោះឡើយ ប៉ុន្តែគឺឈ្នះដើម្បីបើកសម្ដែងពីសេចក្ដីសុចរិត និងសេចក្ដីទុច្ចរិត ដើម្បីទទួលបានភស្ដុតាងសម្រាប់ការដាក់ទោសមនុស្ស ដើម្បី ថ្កោលទោសមនុស្សអាក្រក់ ហើយលើសពីនេះ គឺឈ្នះដើម្បីជាប្រយោជន៍ដល់ការ កែប្រែអស់អ្នកដែលព្រមស្ដាប់បង្គាប់ឲ្យបានគ្រប់លក្ខណ៍។ នៅចុងបំផុត មនុស្សនឹង ត្រូវបែងចែកទៅតាមជំពូក ហើយមនុស្សដែលត្រូវធ្វើឲ្យគ្រប់លក្ខណ៍ គឺជាមនុស្ស ដែលមានចិត្តគំនិតពោរពេញទៅដោយការស្ដាប់បង្គាប់។ នេះគឺជាកិច្ចការដែលត្រូវ សម្រេចឲ្យបាននៅទីបំផុត។ ហើយខណៈនោះ អស់អ្នកណាដែលគ្រប់ទង្វើរបស់គេ មានលក្ខណៈបះបោរ នឹងត្រូវដាក់ទោស រួចបញ្ជូនទៅដុតនៅក្នុងភ្លើង ពួកគេជារបស់ ដែលត្រូវបណ្ដាសាអស់កល្បជានិច្ច។ នៅពេលនោះមកដល់ «វីរជនដ៏អស្ចារ្យដែល គ្មាននរណាអាចយកឈ្នះបាន» នៅក្នុងសម័យអតីតកាល នឹងក្លាយជា «មនុស្សកំសាក

ទន់ខ្សោយ និងគ្មានអំណាច» ដែលទាបបំផុត និងត្រូវគេគេចចេញ។ មានតែ ចំណុចនេះទេ ដែលបង្ហាញពីគ្រប់ទិដ្ឋភាពនៃសេចក្ដីសុចរិតរបស់ព្រះជាម្ចាស់បាន ហើយនិស្ស័យរបស់ទ្រង់មិនអាចឲ្យមនុស្សប្រមាថបានឡើយ ហើយមានតែចំណុចនេះទេ ដែលអាចធ្វើឲ្យសេចក្ដីសម្អប់នៅក្នុងចិត្តខ្ញុំបានស្ងប់ទៅវិញ។ តើអ្នករាល់គ្នាមិនយល់ស្របទេឬអីថា កិច្ចការនេះសមហេតុផលទាំងស្រុង?

មិនមែនមនុស្សទាំងអស់គ្នាសុទ្ធតែស្គាល់កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធឡើយ ហើយមនុស្សដែលកំពុងបម្រើព័ន្ធកិច្ច គឺសុទ្ធតែអាចទទួលបានជីវិតនោះដែរ។ ជីវិតគឺមិនមែនជារបស់ទ្រព្យរួមដែលមនុស្សជាតិចែករំលែកគ្នាឡើយ ហើយការបំផ្លាស់បំប្រែនិស្ស័យ មិនងាយឲ្យមនុស្សសម្រេចបានទេ។ ការចុះចូលនឹងកិច្ចការរបស់ព្រះជាម្ចាស់ ត្រូវតែពិត និងជាក់ស្ដែង ហើយត្រូវស្ដែងចេញតាមការរស់នៅ។ ការចុះចូលបែបលំៗតែមួយមុខ មិនអាចទទួលបានការសរសើរតម្កើងពីព្រះជាម្ចាស់ឡើយ ហើយការស្ដាប់បង្គាប់ កត្តាមិនសំខាន់នៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយគ្មានការព្យាយាមផ្លាស់ប្ដូរនិស្ស័យរបស់មនុស្សណាម្នាក់ នោះក៏មិនត្រូវនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែរ។ ការស្ដាប់បង្គាប់ព្រះជាម្ចាស់ និងការចុះចូលចំពោះកិច្ចការរបស់ព្រះជាម្ចាស់ គឺជារឿងតែមួយ និងដូចគ្នា។ អស់អ្នកណាដែលគ្រាន់តែចុះចូលនឹងព្រះជាម្ចាស់ តែមិនចុះចូលនឹងកិច្ចការរបស់ទ្រង់ មិនអាចចាត់ទុកថា ស្ដាប់បង្គាប់បានឡើយ ហើយអ្នកដែលមិនចុះចូលដោយពិតប្រាកដ តែគ្រាន់តែបញ្ចើចបញ្ចើតែពីខាងក្រៅ កាន់តែមិនអាចចាត់ទុកថា ស្ដាប់បង្គាប់បានដែរ។ អស់អ្នកណាដែលចុះចូលចំពោះព្រះជាម្ចាស់ពិតប្រាកដ សុទ្ធតែអាចទទួលបានផលពីកិច្ចការរបស់ព្រះជាម្ចាស់ និងសម្រេចនូវការយល់ដឹងអំពីនិស្ស័យ និងកិច្ចការរបស់ព្រះជាម្ចាស់បាន។ មានតែមនុស្សប្រភេទនេះទេទើបអាចចុះចូលនឹងព្រះជាម្ចាស់បាន។ មនុស្សបែបនេះអាចទទួលបានចំណេះដឹងថ្មី និងធ្វើការបំផ្លាស់បំប្រែជាថ្មីពីកិច្ចការថ្មី។ មានតែមនុស្សបែបនេះទេ ដែលព្រះជាម្ចាស់លើកសរសើរ មានតែមនុស្សបែបនេះទេ ដែលត្រូវប្រោសឲ្យបានគ្រប់លក្ខណ៍ ហើយមានតែមនុស្សទាំងអស់នេះទេដែលជាអ្នកដែល

អាចឲ្យនិស្ស័យរបស់ពួកគេបំផ្លាស់បំប្រែបាន។ អស់អ្នកណាដែលព្រះជាម្ចាស់សរសើរតម្កើង គឺជាមនុស្សដែលចុះចូលនឹងព្រះជាម្ចាស់ដោយអរសប្បាយ និងចុះចូលចំពោះព្រះបន្ទូល និងកិច្ចការរបស់ទ្រង់។ មានតែមនុស្សបែបនេះទេ ដែលជាមនុស្សត្រឹមត្រូវ មានតែមនុស្សបែបនេះទេ ដែលចង់បានព្រះជាម្ចាស់ និងស្វែងរកព្រះជាម្ចាស់ដោយស្មោះត្រង់។ សម្រាប់អស់អ្នកណាដែលគ្រាន់តែនិយាយអំពីជំនឿរបស់ពួកគេចំពោះព្រះជាម្ចាស់ត្រឹមតែបបូរមាត់របស់ពួកគេ ប៉ុន្តែតាមពិតទៅ គេបែជាជេរដាក់បណ្ដាសាទ្រង់ ពួកគេជាមនុស្សដែលពាក់ក្បាំងមុខ ជាមនុស្សដែលមានពិសដូចសត្វពស់ ពួកគេជាមនុស្សបោកប្រាស់ខ្លាំងជាងគេបំផុត។ មិនយូរមិនឆាប់ទេ ពួកមនុស្សអាក្រក់ទាំងនេះ នឹងត្រូវគេដោះក្បាំងមុខដ៏អប្រិយនេះចេញ។ តើនេះមិនមែនជាកិច្ចការដែលកំពុងធ្វើ ក្នុងពេលបច្ចុប្បន្នទេឬអី? មនុស្សទុច្ចរិតនឹងនៅតែទុច្ចរិតជានិច្ច ហើយនឹងមិនអាចគេចចេញពីការដាក់ទោសបានឡើយ។ មនុស្សល្អនឹងនៅតែជាមនុស្សល្អជានិច្ច ហើយនឹងត្រូវបានបើកសម្ដែង នៅពេលកិច្ចការរបស់ព្រះចូលដល់ទីបញ្ចប់។ គ្មានមនុស្សទុច្ចរិតណាម្នាក់ត្រូវបានចាត់ទុកជាសុចរិតបានឡើយ ហើយគ្មានមនុស្សសុចរិតណាម្នាក់ដែលត្រូវចាត់ទុកថាទុច្ចរិត ឡើយ។ តើខ្ញុំអាចឲ្យមនុស្សណាម្នាក់ រងការចោទប្រកាន់មិនត្រឹមត្រូវដូចម្ដេចបាន?

នៅពេលជីវិតរបស់អ្នករីកចម្រើនទៅមុខ អ្នកត្រូវតែមានច្រកចូលថ្មី និងគំនិតស៊ីជម្រៅថ្មី និងខ្ពស់ជាងមុន ដែលកាន់តែស៊ីជម្រៅនៅគ្រប់ជំហាន។ នេះគឺជាអ្វីដែលមនុស្សជាតិគប្បីត្រាប់តាម។ តាមរយៈការទំនាក់ទំនងការស្ដាប់បទអធិប្បាយ ការអានព្រះបន្ទូលរបស់ព្រះជាម្ចាស់ ឬការដោះស្រាយបញ្ហាមួយចំនួន អ្នកនឹងទទួលបានការយល់ដឹងស៊ីជម្រៅ និងការបំភ្លឺថ្មី ហើយនឹងមិនរស់នៅក្នុងតម្រាពីបុរាណ និងសម័យបុរណានោះទេ។ អ្នកតែងរស់នៅក្នុងពន្លឺថ្មីជានិច្ច ហើយនឹងមិនឃ្លាតឆ្ងាយពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ឡើយ។ នេះគឺជាអត្ថន័យនៃការចាប់ផ្ដើមការដើរនៅលើផ្លូវត្រឹមត្រូវ។ ពីមួយថ្ងៃទៅមួយថ្ងៃ ការចំណាយតម្លៃមួយសម្រាប់កម្រិតសើៗ នឹងមិនជោគជ័យឡើយ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ឈានចូលក្នុងពិភពកាន់តែខ្ពស់ជាងមុន ហើយអ្វី

ថ្មីៗកើតមានជារៀងរាល់ថ្ងៃ ហើយមនុស្សក៏ត្រូវទទួលយកនូវអ្វីថ្មីជារៀងរាល់ថ្ងៃដូចគ្នាដែរ។ ដូច្នេះ ព្រះជាម្ចាស់នាំផលផ្លែដល់ព្រះបន្ទូលដែលទ្រង់ថ្លែង ដូចទ្រង់មានបន្ទូល ហើយប្រសិនបើអ្នកមិនអាចដើរទាន់ទេ នោះអ្នកនឹងត្រូវថយទៅនៅពីខាងក្រោយ។ អ្នកត្រូវអធិដ្ឋានឲ្យបានស៊ីជម្រៅជាងមុន។ ការហូប និងការផឹកព្រះបន្ទូលរបស់ព្រះជាម្ចាស់ មិនអាចអាក់ខានបានឡើយ។ ចូរធ្វើឲ្យការបំភ្លឺ និងការបើកសម្ដែងដែលអ្នកទទួលបានកាន់តែស៊ីជម្រៅជាងមុន ហើយឲ្យគំនិត និងការស្រមើស្រមៃរបស់អ្នករសាយបាត់ទៅបន្តិចម្ដងៗ។ អ្នកក៏ត្រូវពង្រឹងការវិនិច្ឆ័យរបស់អ្នក ហើយអ្វីៗដែលអ្នកជួបប្រទះ អ្នកត្រូវមានគំនិតផ្ទាល់ខ្លួន ហើយត្រូវមានទស្សនៈផ្ទាល់ខ្លួនចំពោះរឿងរ៉ាវទាំងអស់នេះ។ តាមរយៈការយល់ដឹងរឿងរ៉ាវខ្លះៗខាងព្រលឹងវិញ្ញាណ អ្នកត្រូវមានការយល់ដឹងស៊ីជម្រៅអំពីអ្វីដែលមាននៅខាងក្រៅ ហើយស្វែងយល់អំពីសារជាតិស្នូលនៃបញ្ហានោះ។ ប្រសិនបើអ្នកមិនប្រដាប់កាយដោយចំណុចទាំងនេះទេ តើអ្នកអាចដឹកនាំពួកជំនុំបានដោយរបៀបណាទៅ? ប្រសិនបើអ្នកគ្រាន់តែនិយាយអំពីន័យពាក្យ និងគោលលទ្ធិដោយគ្មានការពិត និងដោយគ្មានវិធី អនុវត្ត អ្នកអាចត្រឹមដោះស្រាយបញ្ហាមួយពេលខ្លីប៉ុណ្ណោះ។ ពេលនិយាយចំពោះអ្នកជឿថ្មី ការនេះអាចទទួលយកបានខ្លះដែរ ប៉ុន្តែក្រោយមក នៅពេលអ្នកជឿថ្មីមានបទពិសោធជាក់ស្ដែងខ្លះ អ្នកនឹងលែងអាចទំនុកបម្រុងដល់ពួកគេបានទៀតហើយ។ ដូច្នេះ តើអ្នកស័ក្ដិសមនឹងឲ្យព្រះជាម្ចាស់ប្រើបានដោយរបៀបណា? ដោយគ្មានការបំភ្លឺថ្មីៗ អ្នកមិនអាចធ្វើការបានឡើយ។ អស់អ្នកណាដែលគ្មានការបំភ្លឺថ្មី គឺជាអស់អ្នកណាដែលមិនដឹងថាត្រូវដកបទពិសោធដោយរបៀបណា ហើយមនុស្សបែបនេះមិនទទួលបានចំណេះដឹង ឬបទពិសោធថ្មីៗឡើយ។ ហើយក្នុងបញ្ហានៃការផ្ដល់ជីវិត ពួកគេមិនអាចបំពេញមុខងាររបស់ពួកគេបាននោះឡើយ ហើយពួកគេក៏មិនស័ក្ដិសមឲ្យព្រះជាម្ចាស់ប្រើដែរ។ មនុស្សប្រភេទនេះគឺល្អតែខាងឥតប្រយោជន៍ គ្រាន់តែជាមនុស្សឥតបានការប៉ុណ្ណោះ។ ការពិត មនុស្សបែបនេះមិនអាចបំពេញមុខងាររបស់ខ្លួននៅក្នុងការងាររបស់ពួកគេ ពួកគេសុទ្ធតែគ្មានបានការអ្វីនោះទេ។ ពួកគេមិនត្រឹមតែមិនអាចបំពេញមុខងាររបស់ខ្លួនបានទេ ប៉ុន្តែ

តាមពិតទៅ ពួកគេបានដាក់សម្ពាធដែលមិនចាំបាច់យ៉ាងច្រើនទៅលើពួកជំនុំ។ ខ្ញុំសូមដាស់តឿន «មនុស្សចាស់គួរឲ្យគោរព» ទាំងអស់ នេះ ចូរប្រញាប់ចាកចេញពីពួកជំនុំ ដើម្បីកុំឲ្យមនុស្សឯទៀតស៊ើចសរសើរដល់អ្នក។ មនុស្សបែបនេះគ្មានការយល់ដឹងអំពីកិច្ចការថ្មីឡើយ និងសម្បូរទៅដោយសញ្ញាណមិនចេះចប់មិនចេះហើយ។ ពួកគេមិនបំពេញមុខងារអ្វីទាំងអស់នៅក្នុងពួកជំនុំ។ តែផ្ទុយទៅវិញ ពួកគេនិយាយបំបាក់ទឹកចិត្តអ្នកដទៃ និងផ្សាយអំពើអាក្រក់នៅគ្រប់ទីកន្លែង ដល់ថ្នាក់ហ៊ានចូលរួមក្នុងការប្រព្រឹត្តខុស និងចូលរួមក្នុងការរំខានគ្រប់បែបយ៉ាងដល់ពួកជំនុំដោយរុញច្រាន អ្នកដែលគ្មានការបែងចែកត្រឹមត្រូវទៅក្នុងការភ័ន្តច្រឡំ និងភាពច្របូកច្របល់។ ពួកអារក្សដែលមានជីវិតទាំងអស់នេះ ពួកវិញ្ញាណអាក្រក់ទាំងអស់នេះ ត្រូវចាកចេញពីពួកជំនុំឲ្យបានឆាប់ មិនត្រូវឲ្យពួកជំនុំវិនាសហិនហោចដោយសាររឿងរបស់អ្នកឡើយ។ អ្នកប្រហែលជាមិនខ្លាចកិច្ចការបច្ចុប្បន្ននេះទេ ប៉ុន្តែតើអ្នកមិនខ្លាចការដាក់ទោសដ៏សុចរិតនៅថ្ងៃស្អែកទេឬអី? មានមនុស្សមួយចំនួនធំនៅក្នុងពួកជំនុំជាមនុស្សកេងប្រវ័ញ្ចហើយមានឆ្កែចចកជាច្រើនដែលព្យាយាមរំខានដល់កិច្ចការជាប្រក្រតីរបស់ព្រះជាម្ចាស់។ ពួកគេទាំងអស់នេះគឺជាអារក្សដែលបញ្ជូនមកដោយស្ដេចអារក្ស ជាសត្វចចកកំណាចដែលព្យាយាមចង់ស៊ីកូនចៀមដែលមិនដឹងខ្លួន។ ប្រសិនបើមនុស្សបែបនេះមិនត្រូវគេបណ្ដេញចេញទេ ពួកគេនឹងក្លាយជាបញ្ញើក្អែកនៅក្នុងពួកជំនុំ ជាសត្វក្នុតដែលស៊ីតង្វាយ។ មិនយូរមិនឆាប់ទេ ថ្ងៃមួយនឹងមកដល់ នៅពេលសត្វដង្កូវគួរឲ្យខ្ពើម រអើមល្ងង់ខ្លៅ ទាបថោក និងគួរឲ្យស្អប់នេះ ត្រូវដាក់ទោស។

## យុគសម័យនៃនគរព្រះ គឺជាយុគសម័យនៃព្រះបន្ទូល

នៅក្នុងយុគសម័យនៃនគរព្រះ ព្រះជាម្ចាស់ប្រើប្រាស់ព្រះបន្ទូល ដើម្បីចូលទៅក្នុងយុគសម័យថ្មី ដើម្បីផ្លាស់ប្ដូររបៀបដែលទ្រង់ធ្វើការ និងដើម្បីធ្វើកិច្ចការនៃយុគសម័យទាំងមូល។ នេះហើយជាគោលការណ៍ដែលព្រះជាម្ចាស់ធ្វើការនៅក្នុងយុគសម័យនៃ

ព្រះបន្ទូល។ ទ្រង់បានត្រឡប់ជាសាច់ឈាម ដើម្បីមានបន្ទូលចេញពីទិដ្ឋភាពខុសៗគ្នា ដូច្នេះ មនុស្សអាចមើលឃើញព្រះជាម្ចាស់យ៉ាងពិតប្រាកដ ដែលជាព្រះបន្ទូលកំពុងតែលេចមកនៅក្នុងសាច់ឈាម និងអាចមើលឃើញព្រះប្រាជ្ញាញាណ និងភាពអស្ចារ្យរបស់ទ្រង់។ កិច្ចការបែបនេះត្រូវបានធ្វើឡើង ដើម្បីឲ្យកាន់តែមានប្រសិទ្ធភាពក្នុងការសម្រេចគោលដៅនៃការយកឈ្នះមនុស្ស ការប្រោសមនុស្សឲ្យគ្រប់លក្ខណ៍ និងការផាត់មនុស្សចោល ដែលជាអត្ថន័យដ៏ពិតនៃការប្រើប្រាស់ព្រះបន្ទូលដើម្បីធ្វើការនៅក្នុងយុគសម័យនៃព្រះបន្ទូល។ តាមរយៈព្រះបន្ទូលទាំងនេះ មនុស្សចាប់ផ្ដើមដឹងអំពីកិច្ចការរបស់ព្រះជាម្ចាស់ និស្ស័យរបស់ព្រះជាម្ចាស់ លក្ខណៈរបស់មនុស្ស និងអ្វីដែលមនុស្សគួរតែចូលទៅក្នុង។ តាមរយៈព្រះបន្ទូល កិច្ចការដែលព្រះជាម្ចាស់ចង់ធ្វើនៅក្នុងយុគសម័យនៃព្រះបន្ទូល បានបង្កើតផលផ្លែទាំងអស់។ តាមរយៈព្រះបន្ទូលទាំងនេះ មនុស្សត្រូវបានលាតត្រដាង ផាត់ចោល និងសាកល្បង។ មនុស្សបានឃើញព្រះបន្ទូលរបស់ព្រះជាម្ចាស់ បានឮព្រះបន្ទូលទាំងនេះ និងបានទទួលស្គាល់ពីអត្ថិភាពនៃព្រះបន្ទូលទាំងនេះ។ ជាលទ្ធផល ពួកគេបានចាប់ផ្ដើមជឿលើអត្ថិភាពរបស់ព្រះជាម្ចាស់ ជឿលើសព្វានុភាព និងព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់ ក៏ដូចជាជឿលើសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះមនុស្ស និងបំណងព្រះហឫទ័យទ្រង់ក្នុងការសង្គ្រោះមនុស្ស។ ពាក្យថា «ព្រះបន្ទូល» អាចមានលក្ខណៈសាមញ្ញ និងធម្មតា ប៉ុន្តែព្រះបន្ទូលដែលចេញពីព្រះឱស្ឋរបស់ព្រះដែលយកកំណើតជាមនុស្ស ធ្វើឲ្យអង្រួនដល់ចក្រវាឡ បំផ្លាស់បំប្រែដួងចិត្តរបស់មនុស្ស បំផ្លាស់បំប្រែសញ្ញាណ និងនិស្ស័យចាស់របស់គេ ព្រមទាំងបំផ្លាស់បំប្រែរបៀបដែលពិភពលោកទាំងមូលធ្លាប់សម្ដែងចេញ។ នៅក្នុងយុគសម័យនានា មានតែព្រះជាម្ចាស់នាពេលបច្ចុប្បន្នទេ ដែលបានធ្វើការតាមរបៀបនេះ និងមានតែទ្រង់ប៉ុណ្ណោះ ដែលមានបន្ទូល ហើយយាងមកសង្គ្រោះមនុស្ស។ ចាប់ពីពេលនេះតទៅ មនុស្សរស់នៅក្រោមការចង្អុលបង្ហាញនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ ត្រូវបានឃ្វាល និងផ្គត់ផ្គង់ដោយព្រះបន្ទូលរបស់ទ្រង់។ មនុស្សរស់នៅក្នុងពិភពនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ ក្នុងចំណោមបណ្ដាសា និង

ព្រះពររបស់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយមានមនុស្សកាន់តែច្រើនថែមទៀត ដែលចូលមករស់នៅក្រោមការជំនុំជម្រះ និងការវាយផ្ចាលនៃព្រះបន្ទូលរបស់ទ្រង់។ ព្រះបន្ទូលទាំងនេះ និងកិច្ចការនេះ គឺសម្រាប់ជាប្រយោជន៍ដល់សេចក្ដីសង្គ្រោះរបស់មនុស្ស សម្រាប់ជាប្រយោជន៍ដល់ការបំពេញតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងសម្រាប់ជាប្រយោជន៍ដល់ការបំផ្លាស់បំប្រែរូបរាងដើមនៃពិភពលោកចាស់។ ព្រះជាម្ចាស់បានបង្កើតពិភពលោក ដោយប្រើព្រះបន្ទូលរបស់ទ្រង់ដឹកនាំមនុស្សនៅទូទាំងសកលលោក ដោយប្រើព្រះបន្ទូល ហើយទ្រង់យកឈ្នះ និងសង្គ្រោះពួកគេដោយប្រើព្រះបន្ទូល។ ចុងក្រោយនេះ ទ្រង់នឹងប្រើព្រះបន្ទូលដើម្បីនាំពិភពលោកចាស់មកដល់ទីបញ្ចប់ ក្នុងគោលបំណងសម្រេចផែនការនៃការគ្រប់គ្រងទាំងអស់របស់ទ្រង់។ នៅក្នុងយុគសម័យទាំងមូលនៃនគរព្រះ ព្រះជាម្ចាស់ប្រើព្រះបន្ទូលដើម្បីធ្វើ និងសម្រេចកិច្ចការរបស់ទ្រង់។ ទ្រង់មិនសម្ដែងឫទ្ធិបារមី ឬការអស្ចារ្យឡើយ ប៉ុន្តែទ្រង់គ្រាន់តែធ្វើកិច្ចការទ្រង់ តាមរយៈព្រះបន្ទូលតែប៉ុណ្ណោះ។ ដោយសារតែព្រះបន្ទូលទាំងនេះ មនុស្សត្រូវបានចិញ្ចឹមបីបាច់និងផ្គត់ផ្គង់ ព្រមទាំងទទួលបានចំណេះដឹង និងបទពិសោធដ៏ពិតផងដែរ។ នៅក្នុងយុគសម័យនៃព្រះបន្ទូល មនុស្សបានទទួលព្រះពរយ៉ាងពិសេស។ គេលែងរងការឈឺចាប់ខាងរូបកាយទៀតហើយ គឺគេគ្រាន់តែរីករាយនឹងការផ្គត់ផ្គង់ដ៏ហូរហៀរនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ប៉ុណ្ណោះ ដោយមិនចាំបាច់ត្រូវចេញទៅស្វែងរក ឬធ្វើដំណើរទាំងងងឹតងងល់ និងលែងមានទុក្ខវេទនា គេមើលឃើញការលេចមករបស់ព្រះជាម្ចាស់ ស្ដាប់ឮទ្រង់មានបន្ទូលចេញពីព្រះឱស្ឋរបស់ទ្រង់ផ្ទាល់ ទទួលយកអ្វីដែលទ្រង់ផ្គត់ផ្គង់ និងមើលឃើញទ្រង់ធ្វើកិច្ចការ ដោយអង្គទ្រង់ផ្ទាល់តែម្ដង។ ទាំងនេះគឺជាកិច្ចការដែលមនុស្សកាលពីអតីតកាលមិនអាចរីករាយបានឡើយ ហើយវាជាព្រះពរដែលពួកគេមិនដែលធ្លាប់បានទទួល។

ព្រះជាម្ចាស់បានតាំងព្រះទ័យប្រោសឲ្យមនុស្សគ្រប់លក្ខណ៍ ហើយមិនថាទ្រង់មានបន្ទូលចេញពីទិដ្ឋភាពបែបណាឡើយ គ្រប់យ៉ាងដែលទ្រង់មានបន្ទូល នោះគឺសម្រាប់ជាប្រយោជន៍ដល់ការប្រោសមនុស្សឲ្យគ្រប់លក្ខណ៍ប៉ុណ្ណោះ។ ព្រះបន្ទូល

ដែលចេញពីទិដ្ឋភាពនៃព្រះវិញ្ញាណ មនុស្សពិបាកយល់ណាស់ ហើយពួកគេក៏គ្មានផ្លូវក្នុងការអនុវត្តតាមដែរ ដោយសារតែសមត្ថភាពយល់ដឹងរបស់គេនៅមានកម្រិត។ កិច្ចការរបស់ព្រះជាម្ចាស់សម្រេចបានប្រសិទ្ធភាពខុសៗគ្នា ហើយក៏ជួយទៅសម្រេចជំហាននីមួយៗនៃកិច្ចការដែលទ្រង់មានសម្រាប់គោលបំណងរបស់ទ្រង់ផងដែរ។ លើសពីនេះទៅទៀត វាពិតជាសំខាន់ណាស់ ដែលទ្រង់ត្រូវមានបន្ទូលចេញពីទិដ្ឋភាពខុសៗគ្នា ព្រោះថាមានតែធ្វើបែបនេះទេ ទើបទ្រង់អាចប្រោសឲ្យមនុស្សបានគ្រប់លក្ខណ៍។ បើទ្រង់បន្លឺព្រះសូរសៀងរបស់ទ្រង់ចេញពីទិដ្ឋភាពនៃព្រះវិញ្ញាណតែមួយ នោះវានឹងគ្មានផ្លូវដើម្បីបញ្ចប់ដំណាក់កាលនៃកិច្ចការរបស់ព្រះជាម្ចាស់នេះឡើយ។ ចេញពីតុងសំឡេងដែលទ្រង់មានបន្ទូល អ្នកអាចមើលឃើញអំពីការតាំងព្រះហឫទ័យរបស់ទ្រង់ក្នុងការប្រោសមនុស្សមួយក្រុមនេះឲ្យបានគ្រប់លក្ខណ៍។ ដូច្នេះ តើអ្វីទៅគួរតែជាជំហានដំបូងសម្រាប់មនុស្សម្នាក់ៗ ដែលចង់ឲ្យទ្រង់ប្រោសឲ្យបានគ្រប់លក្ខណ៍? អ្វីដែលសំខាន់បំផុតនោះ គឺថាអ្នកត្រូវដឹងអំពីកិច្ចការរបស់ព្រះជាម្ចាស់។ នាពេលបច្ចុប្បន្ននេះ ព្រះជាម្ចាស់បានប្រើវិធីសាស្ត្រមួយថ្មី នៅក្នុងកិច្ចការរបស់ទ្រង់។ ដោយសារតែយុគសម័យបានផ្លាស់ប្ដូរ ដូច្នេះ របៀបដែលព្រះជាម្ចាស់ធ្វើការក៏ត្រូវផ្លាស់ប្ដូរ ហើយវិធីសាស្ត្រដែលទ្រង់មានបន្ទូល ក៏មានលក្ខណៈខុសពីមុនផងដែរ។ សព្វថ្ងៃនេះ មិនត្រឹមតែវិធីសាស្ត្រនៃកិច្ចការរបស់ទ្រង់ បានផ្លាស់ប្ដូរប៉ុណ្ណោះទេ ប៉ុន្តែយុគសម័យក៏បានផ្លាស់ប្ដូរផងដែរ។ ឥឡូវនេះ គឺជាយុគសម័យនៃនគរព្រះ ហើយវាក៏ជាយុគសម័យរបស់ព្រះជាម្ចាស់ ដ៏ជាសេចក្ដីស្រឡាញ់ផងដែរ។ វាជាគំរូនៃយុគសម័យរាជ្យមួយពាន់ឆ្នាំ ដែលជាយុគសម័យនៃព្រះបន្ទូល ហើយនៅក្នុងយុគសម័យនេះ ព្រះជាម្ចាស់នឹងមានបន្ទូលទៅតាមមធ្យោបាយជាច្រើន ដើម្បីប្រោសមនុស្សឲ្យគ្រប់លក្ខណ៍ ហើយទ្រង់ក៏មានបន្ទូល ចេញពីទិដ្ឋភាពខុសៗគ្នា ដើម្បីផ្គត់ផ្គង់ដល់មនុស្សផងដែរ។ ពេលចូលទៅក្នុងយុគសម័យនៃរាជ្យមួយពាន់ឆ្នាំ ព្រះជាម្ចាស់នឹងចាប់ផ្ដើមប្រើព្រះបន្ទូល ដើម្បីប្រោសមនុស្សឲ្យគ្រប់លក្ខណ៍ អនុញ្ញាតឲ្យមនុស្សចូលទៅក្នុងតថភាពជីវិត និងដឹកនាំមនុស្សឲ្យដើរតាមផ្លូវដ៏ត្រឹមត្រូវ។ តាម

រយៈការដកពិសោធន៍ ចេញពីជំហានជាច្រើននៃកិច្ចការរបស់ព្រះជាម្ចាស់ មនុស្ស បានមើលឃើញថា កិច្ចការរបស់ព្រះជាម្ចាស់មិននៅតែដដែលនោះឡើយ ប៉ុន្ដែវា កំពុងតែវិវឌ្ឍទៅមុខ និងកាន់តែស៊ីជម្រៅ ឥតស្រាកស្រាន្តឡើយ។ ក្រោយពេល មនុស្សបានដកពិសោធន៍អស់ពេលយ៉ាងយូរមក កិច្ចការបានផ្លាស់ប្ដូរវិលវល់ដដែលៗ ម្ដងហើយម្ដងទៀត។ ទោះបីផ្លាស់ប្ដូរជាច្រើនយ៉ាងណាក៏ដោយ ក៏វាមិនដែលឃ្លាត ចេញពីគោលបំណងរបស់ព្រះជាម្ចាស់ ក្នុងការនាំសេចក្ដីសង្គ្រោះទៅកាន់មនុស្សជាតិ ដែរ។ ទោះត្រូវឆ្លងកាត់ការផ្លាស់ប្ដូររាប់ម៉ឺនដងក៏ដោយ ក៏វាមិនដែលបែរចេញពី គោលបំណងដើមរបស់វាដែរ។ មិនថាវិធីសាស្ត្រនៃកិច្ចការរបស់ព្រះជាម្ចាស់ផ្លាស់ប្ដូរ យ៉ាងណាក៏ដោយ ក៏កិច្ចការនេះមិនដែលចាកចេញ ពីសេចក្ដីពិត ឬពីជីវិតនោះដែរ។ ការផ្លាស់ប្ដូរនៅក្នុងវិធីសាស្ត្រនៃការសម្រេចកិច្ចការ គឺគ្រាន់តែជាការផ្លាស់ប្ដូរនៅក្នុង ទម្រង់នៃកិច្ចការ និងទិដ្ឋភាពដែលព្រះជាម្ចាស់មានបន្ទូលប៉ុណ្ណោះ។ វាគ្មានការផ្លាស់ប្ដូរ នៅក្នុងកម្មវត្ថុស្នូលនៃកិច្ចការរបស់ព្រះជាម្ចាស់ឡើយ។ ការផ្លាស់ប្ដូរនៅក្នុងតុងនៃ ព្រះសូរសៀងរបស់ព្រះជាម្ចាស់ និងវិធីសាស្ត្រនៃកិច្ចការរបស់ទ្រង់ត្រូវបានធ្វើឡើង ដើម្បីសម្រេចផលឲ្យកាន់តែមានប្រសិទ្ធភាព។ ការផ្លាស់ប្ដូរនៅក្នុងតុងនៃព្រះសូរសៀង មិនមានន័យជាការផ្លាស់ប្ដូរនៅក្នុងគោលបំណង ឬគោលការណ៍នៅពីក្រោយកិច្ចការ នោះឡើយ។ មនុស្សជឿលើព្រះជាម្ចាស់ជាចម្បង ដើម្បីស្វែងរកជីវិត។ ប្រសិនបើ អ្នកជឿលើព្រះជាម្ចាស់ ប៉ុន្ដែមិនស្វែងរកជីវិត ឬដេញតាមសេចក្ដីពិត ឬចំណេះដឹង អំពីព្រះជាម្ចាស់ទេ នោះវាមិនមែនជាសេចក្ដីជំនឿលើព្រះជាម្ចាស់ឡើយ! ហើយតើការ បន្ដព្យាយាមចូលទៅក្នុងនគរមួយ ដើម្បីក្លាយជាស្ដេច ជារឿងដ៏ពិតប្រាកដដែរឬទេ? ការទទួលបានសេចក្ដីស្រឡាញ់ដ៏ពិតសម្រាប់ព្រះជាម្ចាស់តាមរយៈការស្វែងរកជីវិត គឺជាការពិត ហើយការដេញតាម និងការប្រតិបត្តិតាមសេចក្ដីពិត ពោលគឺទាំងនេះគឺ ការពិត។ តាមរយៈការអានព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងការដកពិសោធន៍ជាមួយ ព្រះបន្ទូលទាំងនេះ អ្នកនឹងចាប់ផ្ដើមមានចំណេះដឹងអំពីព្រះជាម្ចាស់នៅក្នុងចំណោម បទពិសោធពិតៗ ហើយនេះជាអត្ថន័យនៃការដេញតាមដ៏ពិត។

ឥឡូវនេះ គឺជាយុគសម័យនៃនគរព្រះ។ ការដែលអ្នកបានចូលទៅក្នុងយុគសម័យថ្មីនេះ គឺអាស្រ័យលើថា តើអ្នកបានចូលទៅក្នុងការពិតនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ ឬថាតើព្រះបន្ទូលរបស់ទ្រង់ បានក្លាយជាតថភាពជីវិតរបស់អ្នកហើយឬនៅ។ មនុស្សគ្រប់គ្នាបានស្គាល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់រួចហើយ ដូច្នេះនៅចុងបញ្ចប់ មនុស្សទាំងអស់នឹងរស់នៅក្នុងពិភពនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ហើយព្រះបន្ទូលរបស់ទ្រង់នឹងបំភ្លឺ ហើយបកស្រាយដល់មនុស្សម្នាក់ៗចេញពីខាងក្នុងចិត្ត។ ក្នុងអំឡុងពេលនេះ ប្រសិនបើអ្នកមិនយកចិត្តទុកដាក់ក្នុងការអានព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយមិនចាប់អារម្មណ៍លើព្រះបន្ទូលរបស់ទ្រង់ទេ នោះវាបង្ហាញឲ្យឃើញថា អ្នកមានសភាពខុសហើយ។ ប្រសិនបើអ្នកមិនអាចចូលក្នុងយុគសម័យនៃព្រះបន្ទូលបានទេ នោះព្រះវិញ្ញាណបរិសុទ្ធនឹងមិនធ្វើការនៅក្នុងអ្នកឡើយ ប៉ុន្តែប្រសិនបើអ្នកបានចូលក្នុងយុគសម័យនេះ នោះទ្រង់នឹងធ្វើកិច្ចការរបស់ទ្រង់។ នៅដើមយុគសម័យនៃព្រះបន្ទូល តើអ្នកអាចធ្វើអ្វីខ្លះ ដើម្បីទទួលបានកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធ? ព្រះជាម្ចាស់នឹងសម្រេចកិច្ចការដូចខាងក្រោមនៅក្នុងយុគសម័យនេះ និងនៅក្នុងចំណោមអ្នករាល់គ្នា៖ មនុស្សគ្រប់គ្នានឹងរស់នៅតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ គេនឹងយកសេចក្ដីពិតទៅអនុវត្ត ហើយគេនឹងស្រឡាញ់ព្រះជាម្ចាស់យ៉ាងអស់ពីចិត្ត។ មនុស្សទាំងអស់នឹងប្រើព្រះបន្ទូលរបស់ព្រះជាម្ចាស់ ជាគ្រឹះមូលដ្ឋាន និងជាការពិតរបស់គេ ហើយគេនឹងមានដួងចិត្តដែលគោរពកោតខ្លាចព្រះជាម្ចាស់។ ហើយតាមរយៈការអនុវត្តតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ មនុស្សនឹងកាន់អំណាចជាព្រះមហាក្សត្ររួមជាមួយព្រះជាម្ចាស់។ នេះជាកិច្ចការដែលព្រះជាម្ចាស់ត្រូវសម្រេច។ តើអ្នកអាចរស់នៅដោយគ្មានការអានព្រះបន្ទូលរបស់ព្រះជាម្ចាស់បានដែរឬទេ? សព្វថ្ងៃនេះ មានមនុស្សជាច្រើនដែលមានអារម្មណ៍ថា ពួកគេមិនអាចរស់នៅបាន សូម្បីតែមួយថ្ងៃ ឬពីរថ្ងៃ ដោយមិនបានអានព្រះបន្ទូលរបស់ព្រះជាម្ចាស់នោះឡើយ។ ពួកគេត្រូវតែអានព្រះបន្ទូលរបស់ទ្រង់ជារៀងរាល់ថ្ងៃ ហើយប្រសិនបើពេលវេលាមិនអំណោយផលសម្រាប់ការអាន ពួកគេនឹងស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ជំនួសវិញ។ នេះជាអារម្មណ៍ដែលព្រះវិញ្ញាណ

បរិសុទ្ធប្រទានដល់មនុស្ស ហើយវាក៏ជារបៀបមួយដែលទ្រង់ចាប់ផ្ដើមធ្វើចលនានៅក្នុងពួកគេផងដែរ។ ទ្រង់គ្រប់គ្រងមនុស្សតាមរយៈព្រះបន្ទូល ដើម្បីឲ្យពួកគេអាចចូលទៅក្នុងការពិតនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់។ បន្ទាប់ពីខកខានមិនបានហូប និងផឹកព្រះបន្ទូលរបស់ព្រះជាម្ចាស់តែមួយថ្ងៃ ប្រសិនបើអ្នកមានអារម្មណ៍អាប់អួរស្រេកទឹក និងមិនអាចឈរបាន នេះបង្ហាញឲ្យឃើញថា អ្នកបានទទួលការប៉ះពាល់ពីព្រះវិញ្ញាណបរិសុទ្ធ និងបង្ហាញទៀតថា ទ្រង់មិនបានបែរចេញពីអ្នកឡើយ។ ដូច្នេះ អ្នកជាបុគ្គលម្នាក់ដែលស្ថិតនៅក្នុងចរន្តនេះហើយ។ យ៉ាងណាមិញ ក្រោយពេលមួយ ឬពីរថ្ងៃ ដោយមិនហូប និងផឹកព្រះបន្ទូលរបស់ព្រះជាម្ចាស់ ប្រសិនបើអ្នកមិនមានអារម្មណ៍ឃ្លានស្រេកទឹក ឬទទួលការប៉ះពាល់អ្វីទេ នោះវាបង្ហាញឲ្យឃើញថា ព្រះវិញ្ញាណបរិសុទ្ធបានបែរចេញពីអ្នកហើយ។ ការនេះមានន័យថា វាមានបញ្ហាអ្វីមួយជាមួយសភាពនៅខាងក្នុងរបស់អ្នកហើយ។ អ្នកមិនបានចូលក្នុងយុគសម័យនៃព្រះបន្ទូល ហើយអ្នកជាបុគ្គលម្នាក់ក្នុងចំណោមមនុស្សជាច្រើនផ្សេងទៀត ដែលបានបរាជ័យ។ ព្រះជាម្ចាស់ប្រើព្រះបន្ទូលដើម្បីគ្រប់គ្រងលើមនុស្ស។ អ្នកមានអារម្មណ៍ល្អ ប្រសិនបើអ្នកហូបនិងផឹកព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយប្រសិនបើអ្នកមិនបានធ្វើទេ នោះអ្នកនឹងគ្មានផ្លូវដើរឡើយ។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ក្លាយជាអាហាររបស់មនុស្ស និងជាកម្លាំងជំរុញចិត្តពួកគេ។ ព្រះគម្ពីរចែងថា៖ «មនុស្សមិនមែនរស់ដោយសារតែនំបុ័ងប៉ុណ្ណោះទេ ប៉ុន្តែរស់ដោយសារគ្រប់ទាំងព្រះបន្ទូលដែលចេញពីព្រះឱស្ឋរបស់ព្រះជាម្ចាស់វិញ»។ សព្វថ្ងៃនេះ ព្រះជាម្ចាស់នឹងបង្ហើយកិច្ចការនេះ ហើយទ្រង់នឹងសម្រេចការពិតនេះនៅក្នុងអ្នករាល់គ្នា។ តើមនុស្សកាលពីអតីតកាលអាចរស់នៅបានជាច្រើនថ្ងៃយ៉ាងដូចម្ដេច ដោយមិនអានព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយនៅតែអាចបរិភោគ និងធ្វើការបានធម្មតា ប៉ុន្តែនេះមិនមែនជាករណីនៅសព្វថ្ងៃនេះទេ? នៅក្នុងយុគសម័យនេះ ព្រះជាម្ចាស់ប្រើប្រាស់ព្រះបន្ទូលជាចម្បង ដើម្បីគ្រប់គ្រងមនុស្សទាំងអស់។ តាមរយៈព្រះបន្ទូលរបស់ព្រះជាម្ចាស់ មនុស្សត្រូវទទួលការជំនុំជម្រះ និងការប្រោសឲ្យគ្រប់លក្ខណ៍ បន្ទាប់មក ពួកគេបានចូលទៅក្នុង

នគរព្រះនាពេលចុងបញ្ចប់។ មានតែព្រះបន្ទូលរបស់ព្រះជាម្ចាស់មួយប៉ុណ្ណោះ ដែលអាចប្រទានជីវិតដល់មនុស្ស ហើយមានតែព្រះបន្ទូលរបស់ព្រះជាម្ចាស់តែមួយគត់ ដែលអាចប្រទានដល់មនុស្សនូវពន្លឺ និងផ្លូវសម្រាប់ការអនុវត្ត ជាពិសេសនៅក្នុងយុគសម័យនៃនគរព្រះ។ ដរាបណា អ្នកមិនបែរចេញពីការពិតនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយហូបនិងផឹកព្រះបន្ទូលរបស់ទ្រង់ជារៀងរាល់ថ្ងៃ នោះព្រះជាម្ចាស់នឹងអាចប្រោសអ្នកឲ្យបានគ្រប់លក្ខណ៍ជាក់ជាមិនខាន។

ការដេញតាមជីវិត មិនមែនជាអ្វីមួយដែលត្រូវធ្វើទាំងប្រញាប់ប្រញាល់ នោះឡើយ។ ការរីកចម្រើននៃជីវិត មិនអាចកើតឡើងក្នុងពេលតែមួយថ្ងៃឬពីរថ្ងៃនោះឡើយ។ កិច្ចការរបស់ព្រះជាម្ចាស់ គឺសាមញ្ញនិងជាក់ស្ដែង ហើយវាមានដំណើរការមួយដែលចាំបាច់ត្រូវឆ្លងកាត់។ វាត្រូវការឲ្យព្រះយេស៊ូវ ដែលយកកំណើតជាមនុស្ស ចំណាយពេលសាមសិបបីឆ្នាំកន្លះ ដើម្បីបញ្ចប់កិច្ចការនៃការជាប់ឆ្កាងរបស់ទ្រង់ បើដូច្នេះ តើការធ្វើឲ្យមនុស្សក្លាយជាបរិសុទ្ធ និងការបំផ្លាស់បំប្រែជីវិតរបស់គេ គឺជាកិច្ចការដែលពិបាកបំផុតឬ? វាមិនមែនជាកិច្ចការដ៏ងាយស្រួល ដើម្បីធ្វើឲ្យមនុស្សសាមញ្ញក្លាយជាមនុស្សដែលស្ដែងចេញអំពីព្រះជាម្ចាស់នោះឡើយ។ ជាពិសេស គឺសម្រាប់មនុស្សដែលកើតមកនៅក្នុងប្រជាជាតិនៃនាគដ៏ធំមានសម្បុរក្រហម ជាអ្នកដែលមានគុណសម្បត្តិទន់ខ្សោយ ដូច្នេះ វាតម្រូវឲ្យព្រះជាម្ចាស់ប្រើរយៈពេលយូរ ដើម្បីមានបន្ទូល និងធ្វើកិច្ចការរបស់ទ្រង់។ ដូច្នេះ មិនត្រូវខ្វះចិត្តអត់ធ្មត់ក្នុងការនៅចាំមើលពីលទ្ធផលឡើយ។ អ្នកត្រូវតែប្រុងប្រៀបខ្លួនជាស្រេច ក្នុងការហូប និងផឹកព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយដាក់កិច្ចខិតខំប្រឹងប្រែងកាន់តែខ្លាំង ចូលទៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់។ នៅពេលដែលអ្នកអានព្រះបន្ទូលរបស់ទ្រង់ចប់ អ្នកត្រូវតែចេះយកព្រះបន្ទូលទាំងនោះទៅអនុវត្តជាក់ស្ដែង ដោយរីកចម្រើនឡើងនៅក្នុងចំណេះដឹង ការយល់ដឹងជ្រៅជ្រះ ការដឹងខុសត្រូវ និងប្រាជ្ញានៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់។ តាមរយៈដំណើរការនេះ ជីវិតរបស់អ្នកនឹងទទួលនូវការផ្លាស់ប្រែទាំងមិនដឹងខ្លួនមិនខាន។ ប្រសិនបើអ្នកអាចយកការហូប និងការផឹកព្រះបន្ទូលរបស់

ព្រះជាម្ចាស់ ការអានព្រះបន្ទូល ការស្គាល់ព្រះបន្ទូល ការដកពិសោធន៍ពីព្រះបន្ទូល និងការអនុវត្តតាមព្រះបន្ទូល មកធ្វើជាគោលការណ៍ប្រចាំជីវិតរបស់អ្នក នោះអ្នកនឹងមានភាពចាស់ទុំ ដោយមិនដឹងខ្លួនមិនខាន។ មានមនុស្សមួយចំនួននិយាយថា ពួកគេមិនអាចយកព្រះបន្ទូលរបស់ព្រះជាម្ចាស់មកអនុវត្តបានឡើយ ទោះបីក្រោយពេលដែលពួកគេបានអានរួចក៏ដោយ។ តើអ្នកប្រញាប់ប្រញាល់ធ្វើអ្វី? នៅពេលដែលអ្នកឡើងទៅដល់កម្រិតមួយ នោះអ្នកនឹងអាចយកព្រះបន្ទូលរបស់ទ្រង់ទៅអនុវត្តបានមិនខាន។ តើក្មេងអាយុបួន ឬប្រាំឆ្នាំនឹងនិយាយថា ពួកគេមិនអាចជួយ ឬផ្ដល់កិត្តិយសដល់ឪពុកម្ដាយរបស់គេដែរឬទេ? អ្នកគួរតែដឹងអំពីកម្រិតសមត្ថភាពរបស់អ្នកនាពេលបច្ចុប្បន្ន។ ចូរអនុវត្តនូវអ្វីដែលអ្នកអាចអនុវត្តបាន ហើយចៀសវាងក្លាយជាមនុស្សម្នាក់ដែលបង្អាក់ដល់ការគ្រប់គ្រងរបស់ព្រះជាម្ចាស់។ ចូរគ្រាន់តែហូប និងផឹកព្រះបន្ទូលរបស់ព្រះជាម្ចាស់ចុះ ហើយយកវាជាគោលការណ៍ប្រចាំជីវិតរបស់អ្នក ចាប់ពីពេលនេះតទៅ។ ក្នុងពេលបច្ចុប្បន្ន ចូរកុំបារម្ភឡើយថា តើព្រះជាម្ចាស់អាចប្រោសឲ្យអ្នកបានគ្រប់លក្ខណ៍ ឬយ៉ាងណានោះ។ ចូរកុំទាន់ជីកឫស ជីកគល់ឡើយ។ សូមគ្រាន់តែហូប និងផឹកព្រះបន្ទូលរបស់ព្រះជាម្ចាស់ នៅពេលដែលព្រះបន្ទូលទាំងនោះមករកអ្នក នោះព្រះជាម្ចាស់នឹងប្រាកដជាធ្វើឲ្យអ្នកបានពេញខ្នាតមិនខាន។ ទោះបីជាយ៉ាងណាក៏ដោយ មានគោលការណ៍មួយដែលអ្នកត្រូវប្រកាន់ខ្ជាប់ នៅពេលដែលអ្នកត្រូវហូប និងផឹកព្រះបន្ទូលរបស់ទ្រង់។ ចូរកុំធ្វើវាទាំងងងឹតងងល់ឡើយ។ នៅក្នុងការហូប និងផឹកព្រះបន្ទូលរបស់ព្រះជាម្ចាស់ តាមន័យម្យ៉ាង ចូរស្វែងរកព្រះបន្ទូលដែលអ្នកគួរតែដឹង ហើយនោះជាព្រះបន្ទូលដែលទាក់ទងនឹងនិមិត្ត ហើយតាមន័យម្យ៉ាងទៀត ចូរស្វែងរករបៀបដែលអ្នកគួរតែយកព្រះបន្ទូលទៅអនុវត្ត ហើយនោះជាអ្វីដែលអ្នកគួរតែចូលទៅក្នុង។ មួយផ្នែកពាក់ព័ន្ធនឹងចំណេះដឹង ហើយមួយផ្នែកទៀតពាក់ព័ន្ធនឹងការចូលទៅក្នុង។ នៅពេលដែលអ្នកយល់អំពីផ្នែកទាំងពីរនេះ ហើយយល់អំពីអ្វីដែលអ្នកគួរតែដឹង និងអ្វីដែលអ្នកគួរតែអនុវត្ត នោះអ្នកនឹងដឹងពីរបៀបត្រូវហូប និងផឹកពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាក់ជាមិនខាន។

បន្តទៅមុខទៀត ការនិយាយអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ គួរតែជាគោលការណ៍មួយដែលអ្នកត្រូវនិយាយ។ តាមធម្មតា នៅពេលដែលអ្នករាល់គ្នាជួបជុំគ្នា អ្នកគួរតែប្រកបគ្នានៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ យកព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាខ្លឹមសារនៃអន្តរកម្មរបស់អ្នក និយាយអំពីអ្វីដែលអ្នកដឹងអំពីព្រះបន្ទូលទាំងនេះ របៀបដែលអ្នកយកព្រះបន្ទូលទៅអនុវត្ត និងរបៀបដែលព្រះវិញ្ញាណបរិសុទ្ធធ្វើការ។ ដរាបណាអ្នករួមប្រកបនៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ នោះព្រះវិញ្ញាណបរិសុទ្ធនឹងស្រាយបំភ្លឺដល់អ្នកមិនខាន។ ដើម្បីឲ្យពិភពលោក ទទួលយកព្រះបន្ទូលរបស់ព្រះជាម្ចាស់ វាតម្រូវឲ្យមនុស្សមានកិច្ចសហការជាមួយគ្នា។ ប្រសិនបើអ្នកមិនចូលក្នុងការនេះទេ នោះព្រះជាម្ចាស់នឹងគ្មានផ្លូវអាចធ្វើការនោះឡើយ។ ប្រសិនបើអ្នកបន្តបិទមាត់របស់អ្នក ហើយមិននិយាយអំពីព្រះបន្ទូលរបស់ទ្រង់ នោះទ្រង់នឹងគ្មានផ្លូវស្រាយបំភ្លឺដល់អ្នកឡើយ។ គ្រប់ពេលដែលអ្នកមិនរវល់ក្នុងព្រះបន្ទូល ឬនិយាយអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ទេ ចូរកុំចូលរួមនៅក្នុងការជជែកគ្នាលេងដែលឥតបានការនោះឡើយ! ចូរឲ្យជីវិតរបស់អ្នកពោរពេញដោយព្រះបន្ទូលរបស់ព្រះជាម្ចាស់ចុះ ហើយពេលនោះ នោះអ្នកនឹងក្លាយជាអ្នកជឿយ៉ាងពិតប្រាកដមិនខាន។ វាមិនសំខាន់ឡើយ បើការរួមប្រកបរបស់អ្នកមានកម្រិតសើៗនោះ។ បើគ្មានទឹករាក់ នោះក៏គ្មានទឹកជ្រៅដែរ។ វាជាដំណើរការមួយ។ តាមរយៈការបណ្ដុះបណ្ដាលរបស់អ្នក អ្នកនឹងយល់អំពីការស្រាយបំភ្លឺរបស់ព្រះវិញ្ញាណបរិសុទ្ធដែលមានចំពោះអ្នក និងរបៀបហូប និងផឹកកាន់តែមានប្រសិទ្ធភាព ពីព្រះបន្ទូលរបស់ព្រះជាម្ចាស់។ បន្ទាប់ពីរយៈពេលនៃការស្វែងយល់នេះចប់ទៅ អ្នកនឹងចូលទៅក្នុងការពិតនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់មិនខាន។ ប្រសិនបើអ្នកមានការតាំងចិត្តចង់សហការ នោះអ្នកនឹងអាចទទួលបានកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធមិនខាន។

ចេញពីគោលការណ៍នៃការហូប និងផឹកព្រះបន្ទូលរបស់ព្រះជាម្ចាស់ មានគោលការណ៍មួយទាក់ទងនឹងចំណេះដឹង ហើយគោលការណ៍មួយទៀត ទាក់ទងនឹងការចូលទៅក្នុង។ តើព្រះបន្ទូលណាខ្លះដែលអ្នកគួរតែដឹង? អ្នកគួរតែដឹងអំពីព្រះបន្ទូល

ដែលទាក់ទងនឹងនិមិត្ត (ដូចជាព្រះបន្ទូលទាក់ទងនឹងយុគសម័យណាដែលកិច្ចការរបស់ព្រះជាម្ចាស់បានចូលរួចហើយ អ្វីដែលព្រះជាម្ចាស់ចង់សម្រេចឥឡូវ និងអ្វីជាការយកកំណើតជាមនុស្សជាដើម ហើយការទាំងអស់នេះ គឺសុទ្ធតែពាក់ព័ន្ធជាមួយនិមិត្ត)។ តើផ្លូវដែលមនុស្សគួរតែចូលទៅក្នុង មានន័យដូចម្ដេច? ការនេះសំដៅទៅលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលមនុស្សគួរតែអនុវត្ត និងចូលទៅក្នុង។ ខាងលើ គឺជាទិដ្ឋភាពចំនួនពីរនៃការហូប និងផឹកព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ចាប់ពីពេលនេះតទៅ ចូរហូប និងផឹកព្រះបន្ទូលរបស់ព្រះជាម្ចាស់តាមរបៀបនេះចុះ។ ប្រសិនបើអ្នកមានការយល់ដឹងច្បាស់លាស់ អំពីព្រះបន្ទូលរបស់ទ្រង់ទាក់ទងនឹងនិមិត្ត នោះមិនចាំបាច់បន្តអានគ្រប់ពេលនោះឡើយ។ កិច្ចការដ៏សំខាន់ គឺត្រូវហូប និងផឹកកាន់តែច្រើន ពីព្រះបន្ទូលអំពីការចូលទៅក្នុង ដូចជារបៀបបែរចិត្តរបស់អ្នកបែរទៅរកព្រះជាម្ចាស់ របៀបធ្វើឲ្យចិត្តរបស់អ្នកនៅស្ងប់ចំពោះព្រះជាម្ចាស់ និងរបៀបលះបង់ចោលសាច់ឈាម។ ទាំងនេះ គឺជាកិច្ចការដែលអ្នកគួរតែយកទៅអនុវត្ត។ ប្រសិនបើមិនដឹងអំពីរបៀបហូប និងផឹកព្រះបន្ទូលរបស់ព្រះជាម្ចាស់ទេ នោះការប្រកបដ៏ពិតនឹងមិនអាចទៅរួចឡើយ។ នៅពេលដែលអ្នកដឹងអំពីរបៀបហូប និងផឹកព្រះបន្ទូលរបស់ទ្រង់ ព្រមទាំងយល់អំពីចំណុចគន្លឹះហើយ នោះការប្រកបនឹងដំណើរការយ៉ាងរលូន ហើយទោះបីជាមានបញ្ហាអ្វីក៏ដោយ ក៏អ្នកនឹងអាចប្រកប និងយល់ពីការពិតដដែល។ នៅពេលដែលប្រកបនៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ប្រសិនបើអ្នកគ្មានការពិតទេ នោះអ្នកមិនបានយល់អំពីចំណុចគន្លឹះឡើយ ហើយនេះបង្ហាញថា អ្នកមិនបានដឹងអំពីរបៀបហូប និងផឹកព្រះបន្ទូលរបស់ព្រះជាម្ចាស់ឡើយ។ មនុស្សខ្លះយល់ថា ការអានព្រះបន្ទូលរបស់ព្រះជាម្ចាស់ជារឿងគួរឲ្យធុញទ្រាន់ ហើយនេះមិនមែនជាសភាពធម្មតាឡើយ។ អ្វីដែលធម្មតាគឺជាការមិនចេះនឿយហត់ក្នុងការអានព្រះបន្ទូលរបស់ព្រះជាម្ចាស់ តែងតែស្រេកឃ្លានចង់បានព្រះបន្ទូល និងតែងតែមើលឃើញព្រះបន្ទូលរបស់ព្រះជាម្ចាស់ថាជាការល្អជានិច្ច។ នេះជារបៀបដែលមនុស្សចូលទៅហូប និងផឹកព្រះបន្ទូលរបស់ព្រះជាម្ចាស់យ៉ាងពិតប្រាកដ។ នៅពេលដែលអ្នកមាន

អារម្មណ៍ថា ព្រះបន្ទូលរបស់ព្រះជាម្ចាស់មានភាពជាក់ស្ដែងច្បាស់ៗ និងជាអ្វីដែលមនុស្សគួរតែចូលទៅកាន់ ហើយនៅពេលដែលអ្នកមានអារម្មណ៍ថា ព្រះបន្ទូលរបស់ព្រះជាម្ចាស់គឺជាជំនួយ និងមានប្រយោជន៍ខ្លាំងចំពោះមនុស្ស ហើយថាព្រះបន្ទូលគឺជាការផ្គត់ផ្គង់ដល់ជីវិតរបស់មនុស្ស នោះជាព្រះវិញ្ញាណបរិសុទ្ធទេ ដែលប្រទានឲ្យអ្នកនូវអារម្មណ៍បែបនេះ ហើយក៏ជាព្រះវិញ្ញាណបរិសុទ្ធផងដែរ ដែលប៉ះពាល់ចិត្តរបស់អ្នក។ ការនេះបញ្ជាក់ថា ព្រះវិញ្ញាណបរិសុទ្ធកំពុងតែធ្វើការនៅខាងក្នុងអ្នក និងបញ្ជាក់ទៀតថា ព្រះជាម្ចាស់មិនបានបែរចេញពីអ្នកឡើយ។ ដោយមើលឃើញថា ព្រះជាម្ចាស់តែងតែមានបន្ទូលជានិច្ចនោះមនុស្សមួយចំនួន បែរជាធុញទ្រាន់នឹងព្រះបន្ទូលរបស់ទ្រង់ទៅវិញ ហើយគេបែរជាគិតថា ទោះបីគេអាន ឬមិនអានព្រះបន្ទូលក៏ដោយ ក៏វាគ្មានប្រយោជន៍អ្វីដែរ ហើយការមានគំនិតបែបនេះ មិនមែនជាសភាពធម្មតាឡើយ។ ពួកគេខ្វះនូវដួងចិត្តដែលស្រេកឃ្លានចង់ចូលទៅក្នុងការពិត ហើយមនុស្សបែបនេះមិនដែលស្រេកឃ្លាន ឬក៏ឲ្យតម្លៃសំខាន់ទៅលើការប្រោសឲ្យគ្រប់លក្ខណ៍នោះឡើយ។ គ្រប់ពេលដែលអ្នករកឃើញថា អ្នកមិនស្រេកឃ្លាននូវព្រះបន្ទូលរបស់ព្រះជាម្ចាស់ នេះបង្ហាញឲ្យឃើញថា អ្នកមិនស្ថិតនៅក្នុងសភាពធម្មតាឡើយ។ កាលពីអតីតកាល ដើម្បីកំណត់ថាតើព្រះជាម្ចាស់បានបែរចេញ ឬមិនបានបែរចេញពីអ្នក គឺត្រូវបានកំណត់ឡើងដោយមើលថាតើអ្នកមានសន្តិភាពផ្លូវចិត្តឬក៏អត់ ហើយថាតើអ្នកមានអារម្មណ៍រីករាយឬយ៉ាងណា។ បច្ចុប្បន្ននេះ គន្លឹះនៃការកំណត់គឺថាតើអ្នកស្រេកឃ្លានចង់បានព្រះបន្ទូលរបស់ព្រះជាម្ចាស់ ថាតើព្រះបន្ទូលរបស់ទ្រង់ក្លាយជាការពិតរបស់អ្នក ថាតើអ្នកស្មោះត្រង់ និងថាតើអ្នកអាចធ្វើគ្រប់កិច្ចការដែលអ្នកអាចធ្វើបានសម្រាប់ព្រះជាម្ចាស់ឬយ៉ាងណា។ នៅក្នុងន័យម្យ៉ាងទៀត មនុស្សត្រូវទទួលការជំនុំជម្រះ ដោយការពិតនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ព្រះជាម្ចាស់ចង្អុលបង្ហាញព្រះបន្ទូលរបស់ទ្រង់ ទៅកាន់មនុស្សជាតិទាំងអស់។ ប្រសិនបើអ្នកស្ម័គ្រចិត្តអានព្រះបន្ទូល នោះទ្រង់នឹងបំភ្លឺដល់អ្នក ប៉ុន្តែប្រសិនបើអ្នកមិនស្ម័គ្រចិត្តទេ នោះទ្រង់នឹងមិនបំភ្លឺឡើយ។ ព្រះជាម្ចាស់ស្រាយបំភ្លឺ ដល់អស់អ្នកណាដែលស្រេកឃ្លាន

ចង់បានសេចក្ដីសុចរិត ហើយទ្រង់ស្រោយបំភ្លឺដល់អស់អ្នកណាដែលស្វែងរកទ្រង់។ មនុស្សមួយចំនួននិយាយថា ព្រះជាម្ចាស់មិនស្រោយបំភ្លឺដល់ពួកគេឡើយ ទោះបីក្រោយពេលដែលពួកគេអានព្រះបន្ទូលរបស់ទ្រង់ក៏ដោយ។ ប៉ុន្ដែ តើអ្នកបានអានព្រះបន្ទូលទាំងនេះដោយរបៀបណាខ្លះទៅ? ប្រសិនបើអ្នកអានព្រះបន្ទូលរបស់ទ្រង់នៅក្នុងរបៀបមួយដែលមានការយល់ដឹងសើរៗ ហើយមិនឲ្យតម្លៃទៅលើការពិត តើព្រះជាម្ចាស់អាចស្រោយបំភ្លឺដល់អ្នកបានដោយរបៀបណាទៅ? តើមនុស្សម្នាក់ដែលមិនឲ្យតម្លៃលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ អាចឲ្យទ្រង់ប្រោសគេឲ្យបានគ្រប់លក្ខណ៍យ៉ាងដូចម្ដេចទៅ? ប្រសិនបើអ្នកមិនឲ្យតម្លៃលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ទេ នោះអ្នកនឹងគ្មានសេចក្ដីពិត ឬការពិតឡើយ។ ប្រសិនបើអ្នកឲ្យតម្លៃលើព្រះបន្ទូលរបស់ទ្រង់ នោះអ្នកនឹងអាចយកសេចក្ដីពិតនោះទៅអនុវត្ត ហើយមានតែបែបនេះទេ ទើបអ្នកនឹងមានការពិត។ នេះហើយជាហេតុផលដែលអ្នកត្រូវហូប និងផឹកព្រះបន្ទូលរបស់ព្រះជាម្ចាស់គ្រប់ពេលវេលា មិនថាអ្នករវល់ ឬមិនរវល់ មិនថាកាលៈទេសៈរបស់អ្នកអំណោយផល ឬមិនអំណោយផល និងមិនថាអ្នកកំពុងត្រូវបានល្បងល ឬអត់នោះឡើយ។ សរុបមក ព្រះបន្ទូលរបស់ព្រះជាម្ចាស់គឺជាគ្រឹះមូលដ្ឋាននៃវត្តមានរបស់មនុស្ស។ គ្មាននរណាម្នាក់ អាចបែរចេញពីព្រះបន្ទូលរបស់ទ្រង់បានឡើយ តែត្រូវបរិភោគព្រះបន្ទូលទ្រង់ ដូចជាគេបរិភោគអាហារបីពេលក្នុងមួយថ្ងៃយ៉ាងនោះដែរ។ តើការប្រោសឲ្យគ្រប់លក្ខណ៍ និងការត្រូវបានព្រះទទួលយក អាចជារឿងងាយស្រួលឬទេ? មិនថាអ្នកយល់ ឬមិនយល់ក្នុងពេលបច្ចុប្បន្ន ហើយមិនថាអ្នកមានការយល់ដឹងជ្រៅជ្រះអំពីកិច្ចការរបស់ព្រះជាម្ចាស់នោះឡើយ អ្នកត្រូវតែហូប និងផឹកព្រះបន្ទូលរបស់ព្រះជាម្ចាស់ ឲ្យបានច្រើនតាមតែអាចធ្វើទៅបាន។ នេះគឺជាការចូលនៅក្នុងរបៀបប្រុងប្រៀបខ្លួនជាមុន។ ក្រោយពេលអានព្រះបន្ទូលរបស់ព្រះជាម្ចាស់ហើយ ចូរប្រញាប់អនុវត្តតាមអ្វីដែលអ្នកអាចយល់ ហើយទុកអ្វីដែលអ្នកមិនទាន់យល់នៅមុំសិន។ ប្រហែលមានព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាច្រើនដែលអ្នកមិនទាន់យល់ពីពេលដំបូងនៅឡើយ ប៉ុន្ដែក្រោយពេលពីរបីខែ ឬក៏មួយឆ្នាំមក អ្នកនឹងអាចយល់

មិនខាន។ តើការនេះអាចកើតឡើងយ៉ាងដូចម្ដេច? វាដោយសារតែព្រះជាម្ចាស់មិនអាចប្រាសមនុស្សឲ្យបានគ្រប់លក្ខណ៍ក្នុងពេលមួយថ្ងៃ ឬក៏ពីរថ្ងៃបានឡើយ។ ភាគច្រើន នៅពេលដែលអ្នកអានព្រះបន្ទូលរបស់ទ្រង់ អ្នកប្រហែលជាមិនយល់ក្នុងពេលភ្លាមៗឡើយ។ នៅពេលនោះ ព្រះបន្ទូលរបស់ទ្រង់ហាក់ដូចជាគ្មានន័យអ្វីក្រៅពីអត្ថបទធម្មតាប៉ុណ្ណោះ។ អ្នកច្បាស់ជាមានបទពិសោធបែបនេះ មុនពេលដែលអ្នកអាចយល់អំពីព្រះបន្ទូលទាំងនោះ។ ព្រះជាម្ចាស់បានមានបន្ទូលយ៉ាងច្រើន ហើយអ្នកគួរតែខំប្រឹងហូប និងផឹកព្រះបន្ទូលរបស់ទ្រង់ យ៉ាងនោះអ្នកនឹងយល់ដោយមិនដឹងខ្លួន ហើយព្រះវិញ្ញាណបរិសុទ្ធនឹងស្រាយបំភ្លឺឲ្យអ្នកយល់មិនខាន។ នៅពេលដែលព្រះវិញ្ញាណបរិសុទ្ធស្រាយបំភ្លឺដល់មនុស្ស ជារឿយៗទ្រង់ធ្វើឡើងដោយមនុស្សមិនបានដឹងឡើយ។ ទ្រង់ស្រាយបំភ្លឺ និងដឹកនាំអ្នក នៅពេលដែលអ្នកស្រេកឃ្លាន និងស្វែងរក។ គោលការណ៍ដែលព្រះវិញ្ញាណបរិសុទ្ធធ្វើការ គឺផ្ដោតសំខាន់ជុំវិញកិច្ចការរបស់ព្រះជាម្ចាស់ ដែលអ្នកហូប និងផឹក។ អស់អ្នកណាដែលមិនឲ្យតម្លៃទៅលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយតែងតែមានអាកប្បកិរិយាផ្សេងចំពោះព្រះបន្ទូលរបស់ទ្រង់ មិនមានការពិតនោះឡើយ ព្រោះថានៅក្នុងគំនិតអល់អែករបស់គេ ពួកគេជឿថា វាជារឿងមិនសំខាន់អ្វីឡើយ ទោះបីគេអានព្រះបន្ទូលរបស់ទ្រង់ឬមិនបានអានក៏ដោយ។ ចំពោះមនុស្សបែបនេះ កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ឬការស្រាយបំភ្លឺរបស់ទ្រង់ មិនអាចត្រូវបានមើលឃើញនៅក្នុងពួកគេឡើយ។ មនុស្សប្រភេទនេះ គឺជាអ្នកមានពុត ដែលធ្វើពើដូចជាខ្លួនខំប្រឹងណាស់ ប៉ុន្តែតាមពិតគ្មានគុណសម្បត្តិពិតប្រាកដឡើយ គឺដូចជាប្រស្នារបស់[ក] ណានគូ យ៉ាងនោះដែរ។

បើគ្មានព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាការពិតរបស់អ្នកទេ នោះអ្នកគ្មានសមត្ថភាពពិតប្រាកដឡើយ។ នៅពេលដែលវេលានត្រូវល្បងលមកដល់ អ្នកប្រាកដជានឹងត្រូវ

លេខយោង៖

ក. អត្ថបទដើមមិនមានឃ្លា «ប្រស្នារបស់»។

ដួលហើយបន្ទាប់មក សមត្ថភាពដ៏ពិតរបស់អ្នកនឹងត្រូវបើកសម្ដែងឲ្យឃើញមិនខាន។ ប៉ុន្តែអស់អ្នកណាដែលបន្តស្វែងរកដើម្បីចូលទៅក្នុងការពិត នោះប្រាកដជានឹងយល់ពីគោលបំណងនៃកិច្ចការរបស់ព្រះជាម្ចាស់មិនខាន នៅពេលដែលគេហ៊ុមព័ទ្ធដោយសេចក្ដីល្បួងល។ មនុស្សដែលមានមនសិការ និងស្រេកឃ្លានព្រះជាម្ចាស់ គួរតែធ្វើសកម្មភាពជាក់ស្ដែង ដើម្បីសងគុណដល់ព្រះជាម្ចាស់សម្រាប់សេចក្ដីស្រឡាញ់របស់ទ្រង់។ អស់អ្នកណាដែលគ្មានភាពជាក់ស្ដែង មិនអាចឈរមាំបានឡើយ នៅពេលដែលគេជួបសូម្បីតែបញ្ហាដ៏កំប៉ិកកំប៉ុក។ នេះហើយជាភាពខុសគ្នារវាងមនុស្សដែលមានសមត្ថភាពពិត និងអ្នកដែលគ្មានសមត្ថភាពពិត។ ទោះបីមនុស្សទាំងពីរប្រភេទនេះហូប និងផឹកព្រះបន្ទូលរបស់ព្រះជាម្ចាស់ដូចគ្នាក៏ដោយ ចុះហេតុអ្វីបានជាអ្នកខ្លះអាចឈរមាំនឹងសេចក្ដីល្បួងល ឯអ្នកខ្លះទៀតបែរជារត់គេចខ្លួនដូច្នេះ? ភាពខុសគ្នាយ៉ាងជាក់ស្ដែងគឺថា អ្នកខ្លះខ្វះនូវសមត្ថភាពពិតប្រាកដ។ ពួកគេមិនមានព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីបម្រើជាការពិតរបស់ខ្លួន ហើយព្រះបន្ទូលរបស់ទ្រង់មិនបានចាក់ឫសជ្រៅនៅក្នុងពួកគេ។ នៅពេលដែលពួកគេជួបសេចក្ដីល្បួងលភ្លាម ពួកគេក៏ចាប់ផ្ដើមទ័លច្រក។ ហេតុអ្វីបានជាមនុស្សមួយចំនួនអាចឈរមាំនៅក្នុងសេចក្ដីល្បួងល? នោះគឺដោយសារតែពួកគេយល់អំពីសេចក្ដីពិត និងមាននិមិត្ត ហើយពួកគេយល់អំពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងលក្ខខណ្ឌតម្រូវរបស់ទ្រង់ ដូច្នេះហើយបានជាពួកគេ អាចឈរយ៉ាងមាំឆ្លងផុតសេចក្ដីល្បួងលបាន។ នេះជាសមត្ថភាពពិតប្រាកដ ហើយនេះក៏ជាជីវិតផងដែរ។ អ្នកខ្លះក៏អានព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែរ ប៉ុន្តែពួកគេមិនបានយកព្រះបន្ទូលរបស់ទ្រង់ទៅអនុវត្ត ហើយក៏គ្មានភាពហ្មត់ចត់ជាមួយនឹងព្រះបន្ទូលដែរ។ មនុស្សដែលគ្មានភាពហ្មត់ចត់នឹងព្រះបន្ទូល មិនឲ្យតម្លៃទៅលើការអនុវត្តឡើយ។ មនុស្សដែលមិនមានព្រះបន្ទូលរបស់ព្រះជាម្ចាស់បម្រើជាភាពជាក់ស្ដែងរបស់គេ គឺគ្មានសមត្ថភាពពិតឡើយ ហើយមនុស្សប្រភេទនេះនឹងមិនអាចឈរមាំ ដើម្បីឆ្លងផុតសេចក្ដីល្បួងលនោះឡើយ។

នៅពេលដែលព្រះបន្ទូលរបស់ព្រះជាម្ចាស់ប្រទានមក នោះអ្នកគួរតែទទួលយក

ភ្លាមៗ ព្រមទាំងហូប និងផឹកព្រះបន្ទូលទាំងនោះ។ មិនថាអ្នកមានការយល់ដឹងកម្រិតណាឡើយ ប៉ុន្តែមានទស្សនៈមួយ ដែលអ្នកត្រូវប្រកាន់ខ្ជាប់ គឺត្រូវហូបនិងផឹក ដឹង និងអនុវត្តតាមព្រះបន្ទូលរបស់ទ្រង់។ នេះជាអ្វីមួយដែលអ្នកគួរតែអាចធ្វើបាន។ ចូរកុំខ្វល់ឡើយថាតើអ្នកមានសមត្ថភាពខ្ពស់ប៉ុនណានោះ។ ចូរគ្រាន់តែផ្ដោតទៅលើការហូបនិងផឹកព្រះបន្ទូលរបស់ទ្រង់ទៅបានហើយ។ នេះជាអ្វីដែលមនុស្សគួរតែសហការ។ ជីវិតខាងវិញ្ញាណរបស់អ្នក គឺជាការព្យាយាមចូលទៅក្នុងការពិតនៃការហូប និងផឹកព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយយកព្រះបន្ទូលទៅអនុវត្តតាម។ វាមិនមែនជាភារកិច្ចរបស់អ្នកឡើយ ក្នុងការផ្ដោតទៅលើអ្វីផ្សេងនោះ។ អ្នកដឹកនាំពួកជំនុំ គួរតែអាចដឹកនាំបងប្អូនប្រុសស្រីទាំងប៉ុន្មានរបស់គេ ដើម្បីឲ្យពួកគេដឹងអំពីរបៀបហូបនិងផឹកព្រះបន្ទូលរបស់ព្រះជាម្ចាស់។ នេះជាទំនួលខុសត្រូវរបស់អ្នកដឹកនាំពួកជំនុំម្នាក់ៗ។ មិនថាគេក្មេង ឬចាស់ឡើយ មនុស្សគ្រប់គ្នាគួរតែចាត់ទុកការហូប និងផឹកព្រះបន្ទូលរបស់ទ្រង់ ជាកិច្ចការដ៏សំខាន់បំផុត និងគួរតែមានព្រះបន្ទូលរបស់ទ្រង់នៅក្នុងដួងចិត្តរបស់ពួកគេ។ ការចូលទៅក្នុងភាពជាក់ស្ដែងនេះ មានន័យថាជាការចូលទៅក្នុងយុគសម័យនៃនគរព្រះ។ សព្វថ្ងៃនេះ មនុស្សភាគច្រើនមានអារម្មណ៍ថាពួកគេមិនអាចរស់នៅដោយគ្មានការហូប និងផឹកព្រះបន្ទូលរបស់ព្រះជាម្ចាស់បានឡើយ និងមានអារម្មណ៍ថា ព្រះបន្ទូលរបស់ទ្រង់គឺនៅថ្មីៗ មិនថាវាស្ថិតនៅពេលណានោះឡើយ។ ការនេះមានន័យថា ពួកគេកំពុងតែចាប់ផ្ដើមដើរនៅលើផ្លូវដ៏ត្រឹមត្រូវហើយ។ ព្រះជាម្ចាស់ប្រើប្រាស់ព្រះបន្ទូលដើម្បីធ្វើកិច្ចការរបស់ទ្រង់ និងដើម្បីផ្គត់ផ្គង់ដល់មនុស្ស។ នៅពេលដែលមនុស្សគ្រប់គ្នាស្រេកឃ្លាន ចង់បានព្រះបន្ទូលរបស់ព្រះជាម្ចាស់ នោះមនុស្សជាតិនឹងចូលទៅក្នុងពិភពនៃព្រះបន្ទូលរបស់ទ្រង់មិនខាន។

ព្រះជាម្ចាស់បានមានបន្ទូលយ៉ាងច្រើន។ តើអ្នកបានយល់ដឹងប៉ុនណាហើយ? តើអ្នកបានចូលទៅដល់កម្រិតណាហើយ? ប្រសិនបើអ្នកដឹកនាំពួកជំនុំមិនបានដឹកនាំបងប្អូនប្រុសស្រីរបស់ពួកគេឲ្យចូលទៅក្នុងការពិតនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ទេ នោះពួកគេនឹងត្រូវដកសិទ្ធិជាអ្នកដឹកនាំនៅក្នុងភារកិច្ចរបស់គេមិនខាន ហើយពួកគេ

នឹងមិនបានបំពេញតាមទំនួលខុសត្រូវរបស់ខ្លួនឡើយ! មិនថាអ្នកមានការយល់ដឹងជ្រៅជ្រះ ឬរាក់កំផែលឡើយ ទោះបីជាអ្នកមានការរយល់ដឹងកម្រិតណាក៏ដោយ ក៏អ្នកត្រូវតែដឹងអំពីរបៀបហូប និងផឹកព្រះបន្ទូលរបស់ទ្រង់ អ្នកត្រូវតែយកចិត្តទុកដាក់ខ្លាំងទៅលើព្រះបន្ទូលរបស់ទ្រង់ ហើយស្វែងយល់អំពីសារៈសំខាន់ និងភាពចាំបាច់នៃការហូប និងផឹកព្រះបន្ទូលទាំងនោះ។ ព្រះជាម្ចាស់បានកំពុងតែមានបន្ទូលយ៉ាងច្រើនណាស់ ប្រសិនបើអ្នកមិនហូប និងផឹកព្រះបន្ទូលរបស់ទ្រង់ ឬមិនព្យាយាមស្វែងរក ឬអនុវត្តតាមព្រះបន្ទូលរបស់ទ្រង់ទេ នោះមិនអាចរាប់ថាជាការជឿលើព្រះជាម្ចាស់នោះឡើយ។ ដោយសារតែអ្នកជឿលើព្រះជាម្ចាស់យ៉ាងពិតប្រាកដ នោះអ្នកត្រូវតែហូប និងផឹកព្រះបន្ទូលរបស់ទ្រង់ ដកពិសោធន៍ពីព្រះបន្ទូលរបស់ទ្រង់ ហើយរស់នៅតាមព្រះបន្ទូលរបស់ទ្រង់។ មានតែធ្វើបែបនេះទេ ទើបអាចរាប់ថាជាការជឿលើព្រះជាម្ចាស់! ប្រសិនបើអ្នកនិយាយថា អ្នកជឿលើព្រះជាម្ចាស់ចេញពីមាត់របស់អ្នក ប៉ុន្តែមិនយកព្រះបន្ទូលរបស់ទ្រង់ណាមួយទៅអនុវត្ត ឬបង្កើតឲ្យចេញជាការពិតទេ នោះវាមិនអាចនិយាយថា ជាការជឿលើព្រះជាម្ចាស់នោះឡើយ។ ផ្ទុយទៅវិញ វាជា «ការស្វែងរកនំបុ័ង ដើម្បីចម្អែតអ្នកស្រេកឃ្លាន» ប៉ុណ្ណោះ។ ដោយនិយាយតែទីបន្ទាល់ធម្មតាៗ និយាយតែរឿងគ្មានប្រយោជន៍ និងកិច្ចការរាក់កំផែល ដោយគ្មានការពិតសូម្បីតែបន្តិចៈ ទាំងនេះគ្មាននូវធាតុផ្សំអំពីជំនឿលើព្រះជាម្ចាស់ឡើយ ហើយអ្នកមិនបានយល់អំពីផ្លូវដ៏ត្រឹមត្រូវនៃការជឿលើព្រះជាម្ចាស់នោះទេ។ ហេតុអ្វីបានជាអ្នកត្រូវហូប និងផឹកព្រះបន្ទូល របស់ព្រះជាម្ចាស់ឲ្យបានកាន់តែច្រើនកាន់តែល្អ? ប្រសិនបើអ្នកមិនហូប និងផឹកព្រះបន្ទូលរបស់ទ្រង់ ប៉ុន្តែស្វែងរកតែការឡើងស្ថានសួគ៌ តើនេះជាការជឿលើព្រះជាម្ចាស់ឬទេ? តើអ្វីទៅជាជំហានដំបូងដែលអ្នកជឿលើព្រះជាម្ចាស់គួរតែធ្វើ? តើព្រះជាម្ចាស់ប្រោសមនុស្សម្នាក់ឲ្យបានគ្រប់លក្ខណ៍តាមរបៀបណាទៅ? តើអ្នកអាចត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍ ដោយគ្មានការហូប និងផឹកព្រះបន្ទូលរបស់ព្រះជាម្ចាស់បានដែរឬទេ? តើអ្នកអាចត្រូវបានចាត់ទុកជាមនុស្សម្នាក់នៃនគរព្រះ ដោយគ្មានព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីបម្រើជាការពិតរបស់អ្នកបានដែរឬអី?

តើសេចក្តីជំនឿលើព្រះជាម្ចាស់មានន័យដូចម្តេចទៅ? យ៉ាងហោចណាស់ អ្នកជឿលើព្រះជាម្ចាស់គួរតែមានឥរិយាបថល្អនៅខាងក្រៅ ហើយអ្វីដែលសំខាន់បំផុតគឺ គេត្រូវមានព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកមិនអាចគេចចេញពីព្រះបន្ទូលរបស់ទ្រង់បានឡើយ។ ការស្គាល់ព្រះជាម្ចាស់ និងការបំពេញតាមព្រះហឫទ័យរបស់ទ្រង់ អាចសម្រេចទៅបាន មានតែតាមរយៈព្រះបន្ទូលរបស់ទ្រង់ប៉ុណ្ណោះ។ នៅក្នុងពេលអនាគត គ្រប់ប្រជាជាតិ គ្រប់និកាយ គ្រប់សាសនា និងគ្រប់វិស័យ នឹងត្រូវយកឈ្នះ តាមរយៈព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ព្រះជាម្ចាស់នឹងមានបន្ទូលដោយផ្ទាល់ ហើយមនុស្សទាំងអស់នឹងកាន់ព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅក្នុងដៃរបស់គេ ហើយតាមមធ្យោបាយបែបនេះ មនុស្សជាតិនឹងត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍។ ទាំងខាងក្នុងនិងខាងក្រៅ ព្រះបន្ទូលរបស់ព្រះជាម្ចាស់នឹងជ្រួតជ្រាបចូលទាំងអស់៖ មនុស្សជាតិនឹងនិយាយព្រះបន្ទូលរបស់ព្រះជាម្ចាស់ចេញពីមាត់របស់គេ អនុវត្តតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងរក្សាទុកព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅខាងក្នុងចិត្តគេ ហើយជ្រួតជ្រាបពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ ទាំងខាងក្នុងនិងខាងក្រៅ។ មានតែបែបនេះទេ ទើបមនុស្សជាតិនឹងត្រូវបានប្រោសឲ្យបានគ្រប់លក្ខណ៍។ អស់អ្នកដែលបំពេញតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ហើយអាចធ្វើបន្ទាល់ពីទ្រង់បាន អ្នកទាំងនោះគឺជាអ្នកដែលមានព្រះបន្ទូលរបស់ព្រះជាម្ចាស់ ជាការពិតរបស់គេ។

ការចូលទៅក្នុងយុគសម័យនៃព្រះបន្ទូល ឬយុគសម័យនៃរាជ្យមួយពាន់ឆ្នាំ គឺជាកិច្ចការដែលកំពុងតែត្រូវបានសម្រេចនាពេលសព្វថ្ងៃ។ ចាប់ពីពេលនេះតទៅ ចូរអនុវត្តការរួមប្រកបនៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ចុះ។ មានតែតាមរយៈការហូបនិងផឹក ព្រមទាំងការដកពិសោធន៍ពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ទេ ទើបអ្នកអាចនឹងរស់នៅតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់បាន។ អ្នកត្រូវតែបង្កើតឲ្យមានបទពិសោធជាក់ស្តែងមួយចំនួន ដើម្បីធ្វើឲ្យអ្នកដទៃជឿ។ ប្រសិនបើអ្នកមិនអាចរស់នៅតាមភាពជាក់ស្តែងនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ទេ នោះគ្មាននរណាម្នាក់នឹងជឿ

ឡើយ! មនុស្សទាំងអស់ ដែលត្រូវបានព្រះជាម្ចាស់ប្រើប្រាស់ សុទ្ធតែអាចរស់នៅតាមភាព ជាក់ស្ដែងនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ប្រសិនបើអ្នកមិនអាចបង្កើតការពិតនេះ និងធ្វើបន្ទាល់ពីព្រះជាម្ចាស់ទេ នោះវាបង្ហាញឲ្យឃើញថា ព្រះវិញ្ញាណបរិសុទ្ធមិនបានធ្វើការនៅខាងក្នុងអ្នកឡើយ និងបង្ហាញទៀតថា អ្នកមិនត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍នោះទេ។ នេះជាសារៈសំខាន់នៃព្រះបន្ទូលរបស់ព្រះជាម្ចាស់។ តើអ្នកមានដួងចិត្តដែលស្រេកឃ្លានព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែរឬទេ? មនុស្សដែលស្រេកឃ្លានចង់បានព្រះបន្ទូលរបស់ព្រះជាម្ចាស់ ក៏ស្រេកឃ្លានចង់បានសេចក្ដីពិតផងដែរ ហើយមានតែមនុស្សបែបនេះទេ ទើបព្រះជាម្ចាស់ប្រទានពរ។ នៅពេលអនាគត ព្រះជាម្ចាស់នឹងមានបន្ទូលកាន់តែច្រើនថែមទៀតទៅកាន់គ្រប់សាសនា និងគ្រប់និកាយ។ ជាដំបូងទ្រង់មានបន្ទូល និងបន្លឺព្រះសូរសៀងទ្រង់នៅក្នុងចំណោមអ្នករាល់គ្នា ដើម្បីប្រោសអ្នករាល់គ្នាឲ្យបានពេញខ្នាត មុនពេលទ្រង់បន្តទៅមានបន្ទូល និងបន្លឺព្រះសូរសៀងទ្រង់នៅក្នុងចំណោមសាសន៍ដទៃ ដើម្បីយកឈ្នះលើពួកគេ។ តាមរយៈព្រះបន្ទូលរបស់ទ្រង់ មនុស្សទាំងអស់នឹងជឿយ៉ាងស្មោះអស់ពីចិត្តតែម្ដង។ តាមរយៈព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងការបើកសម្ដែងរបស់ទ្រង់ នឹងធ្វើឲ្យនិស្ស័យដ៏ពុករលួយរបស់មនុស្សរសាយបាត់ទៅបន្តិចម្ដងៗ គេទទួលបានរូបរាងជាមនុស្ស ហើយនិស្ស័យបះបោររបស់គេប្រែជាចុះខ្សោយ។ ព្រះបន្ទូលធ្វើការទៅលើមនុស្សដោយសិទ្ធិអំណាច ហើយយកឈ្នះលើមនុស្សដោយពន្លឺរបស់ព្រះជាម្ចាស់។ កិច្ចការដែលព្រះជាម្ចាស់ធ្វើនៅក្នុងយុគសម័យបច្ចុប្បន្ន ក៏ដូចជាចំណុចកំពូលនៃកិច្ចការរបស់ទ្រង់ អាចត្រូវបានរកឃើញនៅក្នុងព្រះបន្ទូលរបស់ទ្រង់។ ប្រសិនបើអ្នកមិនអានព្រះបន្ទូលរបស់ទ្រង់ទេ នោះអ្នកនឹងមិនយល់អ្វីឡើយ។ តាមរយៈការដែលអ្នកហូបនិងផឹកព្រះបន្ទូលរបស់ទ្រង់ និងតាមរយៈការចូលរួមប្រកបជាមួយបងប្អូនប្រុសស្រីរបស់អ្នក និងជាមួយបទពិសោធពិតជាក់ស្ដែងរបស់អ្នក នោះអ្នកនឹងទទួលបានចំណេះដឹងដ៏ពេញលេញអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់មិនខាន។ មានតែបែបនេះទេ ទើបអ្នកអាចរស់នៅតាមការពិតនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់បាន។

# គ្រប់យ៉ាងសម្រេចបានដោយព្រះបន្ទូលរបស់ព្រះជាម្ចាស់

ព្រះជាម្ចាស់ថ្លែងព្រះបន្ទូលរបស់ទ្រង់ ហើយធ្វើកិច្ចការរបស់ទ្រង់ ស្របទៅតាមយុគសម័យខុសៗគ្នា ហើយទ្រង់ថ្លែងព្រះបន្ទូលខុសៗគ្នា នៅក្នុងយុគសម័យផ្សេងៗគ្នា។ ព្រះជាម្ចាស់ មិនប្រកាន់ខ្ជាប់តាមក្រឹត្យក្រមណាមួយ ក៏មិនធ្វើកិច្ចការដដែលៗ ឬមានព្រះហឫទ័យអាឡោះអាល័យចំពោះរឿងរ៉ាវពីអតីតកាលនោះឡើយ។ ទ្រង់ជាព្រះដែលតែងតែថ្មីជានិច្ច និងមិនដែលចាស់គំរិលឡើយ ហើយទ្រង់ថ្លែងព្រះបន្ទូលថ្មីៗរៀងរាល់ថ្ងៃ។ អ្នកគួរតែប្រកាន់ខ្ជាប់ តាមអ្វីដែលគួរប្រកាន់ឲ្យខ្ជាប់នៅពេលបច្ចុប្បន្ន។ នេះហើយគឺជាទំនួលខុសត្រូវ និងជាភារកិច្ចរបស់មនុស្ស។ ការអនុវត្តដែលផ្តោតសំខាន់ទៅលើពន្លឺ និងព្រះបន្ទូលរបស់ព្រះជាម្ចាស់នាពេលបច្ចុប្បន្ន គឺពិតជាសំខាន់ខ្លាំងណាស់។ ព្រះជាម្ចាស់មិនប្រកាន់ខ្ជាប់តាមក្រឹត្យក្រមអ្វីទាំងអស់ ហើយទ្រង់អាចថ្លែងព្រះបន្ទូលតាមទស្សនៈផ្សេៗគ្នា ដើម្បីស្តែងពីប្រាជ្ញាញាណ និងសព្វានុភាពរបស់ទ្រង់ឲ្យបានច្បាស់។ ទោះយ៉ាងណា ព្រះជាម្ចាស់នៅតែជាព្រះជាម្ចាស់ដដែល បើទោះបីជាទ្រង់ថ្លែងព្រះបន្ទូលតាមទស្សនៈព្រះវិញ្ញាណ ឬទស្សនៈរបស់មនុស្ស ឬបុគ្គលទីបីក្តី ក៏មិនជាបញ្ហាដែរ ហើយអ្នកមិនអាចនិយាយថា ទ្រង់ជាព្រះដោយសារទ្រង់ថ្លែងព្រះបន្ទូលតាមទស្សនៈរបស់មនុស្សនោះឡើយ។ ដោយសារតែព្រះជាម្ចាស់ថ្លែងព្រះបន្ទូលតាមទស្សនៈផ្សេងៗគ្នា ទើបបានជាមានការយល់ឃើញជាច្រើនបានផុសឡើងក្នុងចំណោមមនុស្សមួយចំនួន។ មនុស្សបែបនេះ មិនស្គាល់ព្រះជាម្ចាស់ទេ ហើយក៏មិនស្គាល់កិច្ចការរបស់ទ្រង់ដែរ។ ប្រសិនបើព្រះជាម្ចាស់ថ្លែងព្រះបន្ទូលពីទស្សនៈតែមួយ តើមនុស្សព្រមបោះបង់ចោលក្រឹត្យក្រម ដែលទាក់ទងនឹងព្រះជាម្ចាស់ទេ? តើព្រះជាម្ចាស់ អាចបណ្តោយឲ្យមនុស្សប្រព្រឹត្តទង្វើបែបនេះទេ? បើទោះបីព្រះជាម្ចាស់ថ្លែងព្រះបន្ទូលតាមទស្សនៈណាក៏ដោយ ក៏ព្រះអង្គមានគោលបំណងចំពោះការធ្វើបែបនេះដែរ។ ប្រសិនបើព្រះជាម្ចាស់ត្រូវថ្លែងព្រះបន្ទូលតាមទស្សនៈព្រះវិញ្ញាណរហូត តើអ្នកអាចផ្សារភ្ជាប់ទំនាក់ទំនងជាមួយទ្រង់បានដែរទេ? ហេតុនេះ

បានជាពេលខ្លះទ្រង់ថ្លែងព្រះបន្ទូលតាមរយៈបុគ្គលទីបី ដើម្បីប្រទានព្រះបន្ទូលរបស់ទ្រង់ដល់អ្នក ហើយដឹកនាំអ្នកចូលក្នុងតថភាពជាក់ស្ដែង។ គ្រប់យ៉ាងដែលព្រះជាម្ចាស់ធ្វើសុទ្ធតែត្រឹមត្រូវ។ និយាយឲ្យខ្លី កិច្ចការគ្រប់យ៉ាង គឺព្រះជាម្ចាស់ជាអ្នកធ្វើទាំងអស់ ហើយអ្នកមិនគួរសង្ស័យចំពោះរឿងនេះឡើយ។ ព្រះអង្គគឺជាព្រះជាម្ចាស់ ដូច្នេះ ទោះបីជាទ្រង់ថ្លែងព្រះបន្ទូលតាមទស្សនៈបែបណា ក៏ព្រះអង្គនៅតែជាព្រះជាម្ចាស់ដដែល។ នេះជាសេចក្ដីពិតមួយ ដែលមិនអាចផ្លាស់ប្ដូរបានឡើយ។ ទោះបីជាទ្រង់ធ្វើកិច្ចការតាមវិធីណា ក៏ទ្រង់នៅតែជាព្រះជាម្ចាស់ ហើយលក្ខណៈពិតរបស់ទ្រង់នឹងមិនប្រែប្រួលឡើយ! ពេត្រុសស្រឡាញ់ព្រះជាម្ចាស់ណាស់ ហើយគាត់ក៏ធ្លាប់ជាមនុស្សម្នាក់ដែលព្រះជាម្ចាស់សព្វព្រះហឫទ័យដែរ ប៉ុន្តែព្រះជាម្ចាស់មិនបានធ្វើបន្ទាល់បញ្ជាក់ថាគាត់គឺជាព្រះអម្ចាស់ ឬជាព្រះគ្រីស្ទឡើយ ដ្បិតសភាវៈបែបណា គឺមានលក្ខណៈពិតយ៉ាងនោះអ្នក និងមិនអាចផ្លាស់ប្ដូរបានឡើយ។ ក្នុងកិច្ចការរបស់ព្រះជាម្ចាស់ ទ្រង់មិនប្រកាន់ខ្ជាប់តាមក្រឹត្យក្រមអ្វីទាំងអស់ ប៉ុន្តែទ្រង់ប្រើវិធីសាស្ត្រផ្សេងៗពីគ្នា ដើម្បីធ្វើឲ្យកិច្ចការរបស់ទ្រង់មានប្រសិទ្ធភាព និងធ្វើឲ្យមនុស្សស្គាល់ទ្រង់កាន់តែជ្រាលជ្រៅ។ គ្រប់វិធីសាស្ត្រនៃការអនុវត្តកិច្ចការរបស់ទ្រង់ សុទ្ធតែជួយឲ្យមនុស្សស្គាល់ព្រះអង្គ ហើយក៏ដើម្បីកែប្រែមនុស្សឲ្យបានគ្រប់លក្ខណ៍ដែរ។ ទោះបីជាព្រះអង្គប្រើប្រាស់វិធីសាស្ត្រមួយណាដើម្បីអនុវត្តកិច្ចការក៏ដោយ ក៏វិធីសាស្ត្រនីមួយៗសុទ្ធតែត្រូវបានធ្វើឡើងដើម្បីស្អាងមនុស្ស និងធ្វើឲ្យមនុស្សបានគ្រប់លក្ខណ៍ដែរ។ ថ្វីបើវិធីសាស្ត្រណាមួយរបស់ទ្រង់អាចនឹងអូសបន្លាយរយៈពេលយូរក៏ដោយ ក៏វិធីសាស្ត្រនេះត្រូវបានធ្វើឡើងដើម្បីសម្រួលដល់សេចក្ដីជំនឿដែលមនុស្សមានចំពោះព្រះអង្គដែរ។ ហេតុនេះ គប្បីកុំឲ្យមានក្ដីមន្ទិលសង្ស័យនៅក្នុងចិត្តអ្នករាល់គ្នាឡើយ។ ទាំងអស់នេះសុទ្ធតែជាជំហាននៃកិច្ចការរបស់ព្រះជាម្ចាស់ ហើយអ្នករាល់គ្នាត្រូវតែស្ដាប់តាមជំហានទាំងអស់នេះ។

អ្វីដែលត្រូវបានលើកឡើងនៅថ្ងៃនេះ ជាច្រកចូលទៅកាន់តថភាព មិនមែនការឡើងស្ថានសួគ៌ ឬការគ្រងរាជ្យជាស្ដេចនោះទេ អ្វីៗទាំងអស់ដែលត្រូវបានលើកឡើងគឺជាការស្វែងរកច្រកចូលទៅកាន់តថភាព។ ពុំមានការស្វែងរកណាដែលជាក់ស្ដែង

ជាងនេះឡើយ ហើយការជជែកអំពីការគ្រងរាជ្យជាស្ដេច ក៏មិនជាក់ស្ដែងដែរ។ មនុស្សមានចម្ងល់ច្រើនណាស់ ហើយសព្វថ្ងៃនេះ គេក៏នៅតែវាស់ស្ទង់កិច្ចការរបស់ព្រះជាម្ចាស់ ដោយការយល់ដឹងខាងសាសនារបស់ពួកគេដដែលដែរ។ ទោះបីជាមនុស្សបានស្គាល់វិធីសាស្ត្រអនុវត្តកិច្ចការរបស់ព្រះជាម្ចាស់ច្រើនហើយក៏ដោយ តែមនុស្សនៅតែមិនស្គាល់កិច្ចការរបស់ទ្រង់ នៅតែស្វែងរកទីសម្គាល់ និងការអស្ចារ្យ ហើយក៏នៅតែរកមើលថា ព្រះបន្ទូលរបស់ព្រះជាម្ចាស់ បានសម្រេចហើយឬនៅដែរ។ តើនោះមិនមែនជាភាពល្ងង់ខ្លៅដ៏សម្បើមទេឬអី? ប្រសិនបើគ្មានផលសម្រេចនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ទេ តើនឹងជឿថាទ្រង់ជាព្រះជាម្ចាស់ទេ? សព្វថ្ងៃនេះ នៅក្នុងក្រុមជំនុំមានមនុស្សបែបនេះជាច្រើន កំពុងតែរង់ចាំមើលទីសម្គាល់ និងការអស្ចារ្យ។ ពួកគេពោលថា ប្រសិនបើព្រះបន្ទូលរបស់ព្រះជាម្ចាស់បានសម្រេចនោះព្រះអង្គ គឺជាព្រះជាម្ចាស់ហើយ។ ប្រសិនបើព្រះបន្ទូលរបស់ព្រះជាម្ចាស់មិនទាន់បានសម្រេច នោះព្រះអង្គមិនមែនជាព្រះជាម្ចាស់ទេ។ ដូច្នេះ តើអ្នកជឿលើព្រះជាម្ចាស់ ដោយព្រោះតែផលសម្រេចនៃព្រះបន្ទូលរបស់ទ្រង់ ឬដោយសារព្រះអង្គផ្ទាល់គឺជាព្រះជាម្ចាស់? ទស្សនៈនៃជំនឿរបស់មនុស្សចំពោះព្រះជាម្ចាស់ គឺត្រូវតែមានលក្ខណៈត្រឹមត្រូវ! កាលណាអ្នកយល់ឃើញថា ព្រះបន្ទូលរបស់ព្រះជាម្ចាស់មិនទាន់បានសម្រេច ហើយអ្នកក៏ប្រញាប់រត់គេច តើនេះជាជំនឿលើព្រះជាម្ចាស់ដែរឬទេ? កាលណាអ្នកជឿលើព្រះជាម្ចាស់ អ្នកត្រូវតែលះបង់អ្វីៗគ្រប់យ៉ាង ដើម្បីឲ្យបានសេចក្ដីមេត្តាករុណារបស់ព្រះជាម្ចាស់ ហើយស្ដាប់បង្គាប់តាមកិច្ចការទាំងអស់របស់ទ្រង់។ ព្រះជាម្ចាស់បានថ្លែងព្រះបន្ទូលច្រើនណាស់នៅក្នុងព្រះគម្ពីរសញ្ញាចាស់ តើមានព្រះបន្ទូលណាមួយ ដែលអ្នកបានឃើញផ្ទាល់នឹងភ្នែករបស់អ្នកថាបានសម្រេចហើយ? តើអ្នកអាចនិយាយថា ព្រះយេហូវ៉ាមិនមែនជាព្រះពិត ដោយសារតែអ្នកមិនបានឃើញការនោះឬ? ទោះបីជាមានព្រះបន្ទូលជាច្រើនប្រហែលជាបានសម្រេចហើយក៏ដោយ ក៏មនុស្សមិនអាចមើលឃើញការនោះបានច្បាស់ដែរ ព្រោះមនុស្សមិនមានសេចក្ដីពិត និងមិនយល់អ្វីសោះ។ មនុស្សខ្លះចង់រត់គេច នៅពេលដែលពួកគេ

មានអារម្មណ៍ថា ព្រះបន្ទូលរបស់ព្រះជាម្ចាស់មិនទាន់បានសម្រេច។ អ្នកណាដែលចង់ទៅ គួរទៅឲ្យហើយ គ្មាននរណាឃាត់គេឡើយ! សាកមើលទៅ ក្រែងលោអ្នកអាចគេចរួច។ ទោះបីជាគេចរួច ក៏អ្នកគង់តែនឹងវិលមកវិញដែរ។ ព្រះជាម្ចាស់គ្រប់គ្រងអ្នកដោយព្រះបន្ទូលរបស់ទ្រង់ ហើយប្រសិនបើអ្នកចាកចេញពីក្រុមជំនុំ និងពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ ក៏អ្នកគង់តែគ្មានផ្លូវរស់បន្តទៅទៀតដែរ។ ប្រសិនបើអ្នកមិនជឿរឿងនេះទេ សាកមើលខ្លួនឯងក៏បាន តើអ្នកគិតថា អ្នកអាចចាកចេញទៅស្រួលៗមែនទេ? ព្រះវិញ្ញាណនៃព្រះជាម្ចាស់ គ្រប់គ្រងអ្នក។ អ្នកមិនអាចចាកចេញបានទេ។ នេះជាបញ្ញត្តិរដ្ឋបាលរបស់ព្រះជាម្ចាស់! ប្រសិនបើមនុស្សណាចង់សាកមើល ពួកគេអាចសាកបាន! អ្នកពោលថា បុគ្គលម្នាក់នេះមិនមែនជាព្រះជាម្ចាស់ទេ ដូច្នេះ ចូរប្រព្រឹត្តបាបទាស់នឹងទ្រង់ចុះ ហើយចាំមើលទ្រង់ធ្វើអ្វីខ្លះ។ រូបកាយសាច់ឈាមរបស់អ្នកអាចនឹងមិនស្លាប់ទេ ហើយអ្នកក៏នៅតែអាចចិញ្ចឹមជីវិត និងស្លៀកពាក់ឲ្យខ្លួនឯងបានដដែល ប៉ុន្តែក្នុងចិត្តវិញ អ្នកមិនអាចទ្រាំបានទេ។ អ្នកនឹងមានអារម្មណ៍តានតឹង និងអារម្មណ៍រងទារុណ ព្រោះគ្មានអ្វីឈឺចាប់ជាងនេះទៀតទេ។ មនុស្សមិនអាចស៊ូទ្រាំរងទារុណ និងភាពអន្តរាយខាងផ្លូវចិត្តបានឡើយ អ្នកប្រហែលជាអាចធន់ទ្រាំនឹងទុក្ខលំបាកនៃសាច់ឈាមបាន ប៉ុន្តែអ្នកច្បាស់ជាមិនអាចស៊ូទ្រាំជាមួយនឹងភាពតានតឹង និងទុក្ខទារុណខាងផ្លូវចិត្តដ៏យូរអង្វែងបានឡើយ។ សព្វថ្ងៃនេះ អ្នកមិនអាចមើលឃើញទីសម្គាល់ និងការអស្ចារ្យទេ តែក៏គ្មាននរណាម្នាក់ហ៊ានរត់គេចឡើយ មិនថាពួកគេមានភាពអវិជ្ជមានយ៉ាងណាក៏ដោយ ដ្បិតព្រះជាម្ចាស់គ្រប់គ្រងមនុស្សដោយព្រះបន្ទូលរបស់ទ្រង់។ ទោះបីជាគ្មានការមកដល់នៃការពិតក៏ដោយ ក៏គ្មាននរណាម្នាក់អាចគេចរួចបានដែរ។ តើទាំងអស់នេះមិនមែនជាសកម្មភាពរបស់ព្រះជាម្ចាស់ទេឬអី? សព្វថ្ងៃនេះ ព្រះជាម្ចាស់បានយាងមកផែនដីហើយ ដើម្បីប្រទានជីវិតដល់មនុស្ស។ ទ្រង់មិនមែនប្រលោមលួងលោមអ្នកដោយបង្ហាញទីសម្គាល់ និងការអស្ចារ្យជាច្រើន ដើម្បីធានាឲ្យបាននូវសម្ពន្ធភាពដ៏សុខសាន្តរវាងព្រះជាម្ចាស់ និងមនុស្ស ដូចដែលមនុស្សស្រមើស្រមៃនោះឡើយ។ មនុស្សណាដែលមិនផ្ដោត

ការយកចិត្តទុកដាក់លើជីវិត ប៉ុន្តែបែរជាផ្ដោតការយកចិត្តទុកដាក់លើការធ្វើឲ្យព្រះជាម្ចាស់បង្ហាញនូវទីសម្គាល់ និងការអស្ចារ្យ អ្នកទាំងនោះគឺជាពួកផារិស៊ី! គឺពួកផារិស៊ីនេះហើយដែលបោះព្រះយេស៊ូវភ្ជាប់លើឈើឆ្កាង។ ប្រសិនបើអ្នកវាស់ស្ទង់ព្រះជាម្ចាស់ ដោយយោងតាមទស្សនៈនៃជំនឿខ្លួនឯងផ្ទាល់ចំពោះព្រះជាម្ចាស់ ទាំងជឿដល់ទ្រង់ ប្រសិនបើព្រះបន្ទូលទ្រង់បានសម្រេច ហើយថែមទាំងមានមន្ទិល និងប្រមាថដល់ទ្រង់ ប្រសិនបើព្រះបន្ទូលរបស់ទ្រង់មិនបានសម្រេច ដូច្នេះ តើអ្នកមិនបោះព្រះយេស៊ូវភ្ជាប់លើឈើឆ្កាងទេឬអី? មនុស្សបែបនេះគឺជាមនុស្សប្រហែសនឹងកាតព្វកិច្ចរបស់ខ្លួន ហើយរីករាយនឹងភាពស្រណុកសុខស្រួលទាំងចិត្តលោភលន់!

ម្យ៉ាងវិញទៀត បញ្ហាដ៏ធំបំផុតរបស់មនុស្សគឺ គេមិនស្គាល់កិច្ចការរបស់ព្រះជាម្ចាស់។ ទោះបីជាឥរិយាបថរបស់មនុស្ស មិនមែនជាឥរិយាបថមានះរឹងរូសក៏ដោយ តែវាជាឥរិយាបថមន្ទិលសង្ស័យ។ គេមិនបដិសេធមែន តែគេក៏មិនទទួលស្គាល់ទាំងស្រុងដែរ។ ប្រសិនបើមនុស្សស្គាល់កិច្ចការរបស់ព្រះជាម្ចាស់ច្បាស់ ពួកគេនឹងមិនរត់គេចទេ។ បញ្ហាមួយទៀតរបស់មនុស្ស គឺគេមិនស្គាល់តថភាព។ សព្វថ្ងៃនេះ បុគ្គលម្នាក់ៗសុទ្ធតែបានផ្សារភ្ជាប់ជាមួយនឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ប្រាកដណាស់ នៅថ្ងៃអនាគត អ្នកមិនគួរគិតពីការមើលឃើញទីសម្គាល់ និងការអស្ចារ្យទេ។ ខ្ញុំប្រាប់អ្នកតាមត្រង់ចុះ៖ នៅក្នុងដំណាក់កាលបច្ចុប្បន្ន គ្រប់យ៉ាងដែលអ្នកអាចមើលឃើញ គឺព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយបើទោះបីជាគ្មានការពិតក៏ដោយ ក៏ជីវិតរបស់ព្រះជាម្ចាស់នៅតែអាចចាក់ជាប់នៅក្នុងមនុស្សដែរ។ កិច្ចការនេះហើយគឺជាកិច្ចការដ៏សំខាន់នៅក្នុងរាជ្យមួយពាន់ឆ្នាំ ហើយប្រសិនបើអ្នកមិនអាចគិតយល់ពីកិច្ចការនេះទេ នោះអ្នកនឹងទៅជាខ្សោយ ហើយរលំដួលជាមិនខាន។ អ្នកនឹងធ្លាក់ទៅក្នុងសេចក្ដីវេទនា ហើយជាប់ចំណងរបស់សាតាំងធ្ងន់ធ្ងរជាងមុនមិនខាន។ ព្រះជាម្ចាស់បានយាងមកផែនដីនេះ គឺដើម្បីមកថ្លែងព្រះបន្ទូលទ្រង់ជាពិសេស។ អ្វីដែលអ្នកផ្សារភ្ជាប់ជាមួយគឺព្រះបន្ទូលរបស់ព្រះជាម្ចាស់ អ្វីដែលអ្នកមើលឃើញគឺព្រះបន្ទូលរបស់ព្រះជាម្ចាស់ អ្វីដែលអ្នកស្គាល់គឺព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយការយកកំណើតជាមនុស្សរបស់

ព្រះជាម្ចាស់នេះ ប្រើប្រាស់ព្រះបន្ទូលជាពិសេស ដើម្បីធ្វើឲ្យមនុស្សបានគ្រប់លក្ខណ៍។ ព្រះអង្គមិនបង្ហាញនូវទីសម្គាល់ និងការអស្ចារ្យទេ ហើយជាពិសេស ព្រះអង្គក៏មិនធ្វើកិច្ចការដែលព្រះយេស៊ូវបានធ្វើពីអតីតកាលដែរ។ ថ្វីបើទាំងពីរអង្គនេះគឺជាព្រះ ហើយក៏ជាសាច់ឈាមក៏ពិតមែន ប៉ុន្តែព័ន្ធកិច្ចរបស់ទ្រង់មិនដូចគ្នាទេ។ នៅគ្រាដែលព្រះយេស៊ូវបានយាងមកផែនដី ទ្រង់ក៏បានធ្វើកិច្ចការរបស់ព្រះជាម្ចាស់មួយចំណែក ហើយថ្លែងព្រះបន្ទូលខ្លះដែរ ប៉ុន្តែ តើអ្វីជាកិច្ចការចម្បងដែលទ្រង់សម្រេចបាន? កិច្ចការដែលទ្រង់សម្រេចបានជាចម្បង គឺកិច្ចការជាប់ឆ្កាង។ ព្រះអង្គបានត្រលប់ជាមានលក្ខណៈដូចជាសាច់ឈាមដែលមានបាប ដើម្បីសម្រេចកិច្ចការជាប់ឆ្កាង ហើយប្រោសលោះមនុស្សជាតិទាំងអស់ ហើយដោយព្រោះតែអំពើបាបរបស់មនុស្សជាតិទាំងអស់ ទើបទ្រង់បំពេញតួនាទីជាតង្វាយធួននឹងបាប។ នេះជាកិច្ចការចម្បង ដែលទ្រង់សម្រេចបាន។ ជាចុងក្រោយ ទ្រង់ក៏បានប្រទានផ្លូវនៃឈើឆ្កាង ដើម្បីដឹកនាំមនុស្សណាដែលមកតាមពីក្រោយ។ កាលព្រះយេស៊ូវយាងមក គោលដៅចម្បងគឺដើម្បីសម្រេចកិច្ចការប្រោសលោះ។ ទ្រង់បានប្រោសលោះមនុស្សជាតិទាំងអស់ ព្រមទាំងបាននាំយកដំណឹងល្អអំពីនគរស្ថានសួគ៌ មកឲ្យមនុស្សលោក ហើយលើសពីនេះទៀត ទ្រង់បាននាំយកផ្លូវទៅឯនគរស្ថានសួគ៌ទៅកាន់មនុស្សផងដែរ។ ជាលទ្ធផល អស់អ្នកណាមកតាមក្រោយក៏ពោលថា «យើងគួរដើរតាមផ្លូវនៃឈើឆ្កាង ហើយលះបង់ខ្លួនឯងដើម្បីឈើឆ្កាង»។ ពិតណាស់ កាលដើមដំបូងឡើយ ព្រះយេស៊ូវក៏បានធ្វើកិច្ចការផ្សេងខ្លះទៀត និងបានថ្លែងព្រះបន្ទូលខ្លះ ដើម្បីធ្វើឲ្យមនុស្សប្រែចិត្ត និងលន់តួបាបរបស់ខ្លួនដែរ។ ប៉ុន្តែ ព័ន្ធកិច្ចរបស់ទ្រង់ គឺនៅតែជាការជាប់ឆ្កាងដដែល ហើយរយៈពេលបីឆ្នាំកន្លះ ដែលទ្រង់បានចំណាយក្នុងការប្រកាសអំពីផ្លូវនេះ គឺជាការរៀបចំសម្រាប់ការជាប់ឆ្កាងដែលមកដល់តាមក្រោយ។ ច្រើនលើកដែលព្រះយេស៊ូវបានអធិស្ឋានក៏ដើម្បីតែការជាប់ឆ្កាងនេះដែរ។ ជីវិតរបស់មនុស្សធម្មតាម្នាក់ ដែលទ្រង់បានដឹកនាំ និងរយៈពេល៣៣ឆ្នាំកន្លះដែលព្រះអង្គបានគង់នៅលើផែនដី គឺដើម្បីសម្រេចកិច្ចការនៃការជាប់ឆ្កាងជាចម្បង។ ចុះព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សសព្វថ្ងៃ នឹង

សម្រេចកិច្ចការអ្វីវិញ? សព្វថ្ងៃនេះ ព្រះជាម្ចាស់បានត្រលប់ជាសាច់ឈាម ដើម្បីសម្រេចកិច្ចការជាពិសេសមួយគឺ «ព្រះបន្ទូលដែលលេចមកជាសាច់ឈាម» ដើម្បីប្រើប្រាស់ព្រះបន្ទូលធ្វើឲ្យមនុស្សបានគ្រប់លក្ខណ៍ និងធ្វើឲ្យមនុស្សទទួលយកនូវការប្រឈមនឹងព្រះបន្ទូល និងការបន្សុទ្ធដោយព្រះបន្ទូល។ ទ្រង់ធ្វើឲ្យអ្នកទទួលបានការផ្គត់ផ្គង់ និងទទួលបានជីវិតនៅក្នុងព្រះបន្ទូលទ្រង់។ អ្នកមើលឃើញកិច្ចការ និងស្នាព្រះហស្តទ្រង់នៅក្នុងព្រះបន្ទូលទ្រង់។ ព្រះជាម្ចាស់ប្រើប្រាស់ព្រះបន្ទូល ដើម្បីវាយផ្ចាល និងបន្សុទ្ធអ្នក ហេតុនេះហើយ ប្រសិនបើអ្នករងទុក្ខលំបាក នោះក៏ដោយសារព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែរ។ សព្វថ្ងៃនេះ ព្រះជាម្ចាស់មិនធ្វើកិច្ចការរបស់ទ្រង់ ដោយប្រើការពិតឡើង គឺដោយប្រើព្រះបន្ទូលវិញ។ ទាល់តែព្រះបន្ទូលទ្រង់បានយាងមកសណ្ឋិតលើអ្នក ទើបព្រះវិញ្ញាណបរិសុទ្ធអាចធ្វើការនៅក្នុងអ្នក ហើយធ្វើឲ្យអ្នករងនូវការឈឺចាប់ ឬស្គាល់ភាពផ្អែមល្ហែមបាន។ មានតែព្រះបន្ទូលរបស់ព្រះជាម្ចាស់ទេ ទើបអាចនាំអ្នកមកក្នុងតថភាព ហើយក៏មានតែព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែរ ទើបអាចធ្វើឲ្យអ្នកបានគ្រប់លក្ខណ៍។ ដូច្នេះ យ៉ាងហោចណាស់ អ្នកត្រូវតែយល់ដូច្នេះថា កិច្ចការដ៏ពិសេសដែលព្រះជាម្ចាស់ធ្វើនៅគ្រាចុងក្រោយ គឺការប្រើប្រាស់ព្រះបន្ទូលទ្រង់ ដើម្បីធ្វើឲ្យបុគ្គលគ្រប់គ្នាបានគ្រប់លក្ខណ៍ និងដើម្បីដឹកនាំមនុស្ស។ គ្រប់កិច្ចការទាំងអស់ដែលទ្រង់ធ្វើ គឺសុទ្ធតែតាមរយៈព្រះបន្ទូល។ ព្រះអង្គមិនប្រើការពិតមកវាយផ្ចាលអ្នកទេ។ ជាច្រើនលើកច្រើនសារ ដែលមនុស្សខ្លះទាស់ទទឹងនឹងព្រះជាម្ចាស់។ ព្រះជាម្ចាស់មិនធ្វើឲ្យអ្នកកើតទុក្ខខ្លាំងពេកទេ សាច់ឈាមរបស់អ្នកមិនត្រូវបានដាក់ទោសទេ ហើយអ្នកក៏មិនត្រូវរងទុក្ខលំបាកដែរ ប៉ុន្តែកាលណាព្រះបន្ទូលទ្រង់មកសណ្ឋិតលើអ្នក ហើយបន្សុទ្ធអ្នក នោះអ្នកមិនអាចទ្រាំបានឡើយ។ តើវាមិនមែនដូច្នេះទេឬអី? នៅក្នុងអំឡុងសម័យពួកអ្នកបម្រើ ព្រះជាម្ចាស់បានមានបន្ទូលថា ទ្រង់នឹងបោះមនុស្សទៅក្នុងជង្ហុកធំ។ តើមនុស្សពិតជាទៅដល់បាតជង្ហុកធំនេះដែរឬទេ? គ្រាន់តែតាមរយៈការប្រើព្រះបន្ទូល ដើម្បីបន្សុទ្ធមនុស្ស នោះមនុស្សបានចូលទៅក្នុងជង្ហុកធំបាត់ទៅហើយ។ ហេតុនេះ នៅគ្រាចុងក្រោយ កាលណាព្រះជាម្ចាស់ត្រលប់

ជាសាច់ឈាម ទ្រង់ប្រើព្រះបន្ទូលជាចម្បង ដើម្បីសម្រេចកិច្ចការទាំងអស់ ហើយធ្វើឲ្យកិច្ចការទាំងអស់ស្ដែងចេញយ៉ាងច្បាស់។ មានតែនៅក្នុងព្រះបន្ទូលរបស់ទ្រង់ទេ ទើបអ្នកអាចមើលឃើញលក្ខណៈរបស់ទ្រង់ មានតែនៅក្នុងព្រះបន្ទូលរបស់ទ្រង់ទេ ទើបអ្នកអាចមើលឃើញថា ទ្រង់គឺជាអង្គព្រះជាម្ចាស់ផ្ទាល់ពិតមែន។ កាលណាព្រះជាម្ចាស់ យាងមកយកកំណើតជាមនុស្សនៅលើផែនដី គឺទ្រង់មិនធ្វើកិច្ចការផ្សេងទៀតឡើយ ក្រៅតែពីថ្លែងព្រះបន្ទូល ដូច្នេះ មិនចាំបាច់ត្រូវការការពិតអ្វីទេ ត្រឹមព្រះបន្ទូលគឺគ្រប់គ្រាន់ហើយ។ នោះគឺដោយសារទ្រង់បានយាងមកជាពិសេសដើម្បីធ្វើកិច្ចការនេះ ដើម្បីឲ្យមនុស្សមើលឃើញព្រះចេស្ដា និងឧត្ដមភាពនៅក្នុងព្រះបន្ទូលរបស់ទ្រង់ ដើម្បីឲ្យមនុស្សមើលឃើញថា ទ្រង់លាក់ព្រះកាយដោយបន្ទាបព្រះអង្គទ្រង់យ៉ាងណានៅក្នុងព្រះបន្ទូលរបស់ទ្រង់ និងដើម្បីឲ្យមនុស្សស្គាល់ភាពបរិបូររបស់ទ្រង់នៅក្នុងព្រះបន្ទូលរបស់ទ្រង់។ កម្មសិទ្ធិ និងលក្ខណៈទាំងអស់របស់ព្រះអង្គសុទ្ធតែមាននៅក្នុងព្រះបន្ទូលរបស់ទ្រង់។ ប្រាជ្ញាញាណ និងភាពមហស្ចារ្យរបស់ទ្រង់សុទ្ធតែមាននៅក្នុងព្រះបន្ទូលរបស់ទ្រង់។ ដោយសារព្រះបន្ទូលនេះ អ្នកត្រូវបានបង្កើតមកឲ្យមើលឃើញវិធីសាស្ត្រនានាដែលព្រះជាម្ចាស់ប្រើប្រាស់ សម្រាប់ថ្លែងព្រះបន្ទូលទ្រង់។ កិច្ចការភាគច្រើនរបស់ព្រះជាម្ចាស់នៅក្នុងអំឡុងពេលនេះ គឺជាការផ្គត់ផ្គង់ ការបើកសម្ដែង និងការដោះស្រាយជាមួយមនុស្ស។ ទ្រង់មិនដាក់បណ្ដាសារលេងៗនោះឡើយ ហើយសូម្បីតែពេលទ្រង់ដាក់បណ្ដាសា ក៏ទ្រង់ដាក់បណ្ដាសាដោយព្រះបន្ទូលដែរ។ ដូច្នេះហើយ ក្នុងយុគសម័យដែលព្រះជាម្ចាស់បានត្រលប់ជាសាច់ឈាមនេះ ចូរកុំព្យាយាមមើលព្រះជាម្ចាស់ប្រោសជំងឺ និងបណ្ដេញវិញ្ញាណអាក្រក់ទៀត ហើយឈប់តាមរកទីសម្គាល់ទៀតទៅ គ្មានប្រយោជន៍ទេ! ទីសម្គាល់ទាំងនោះមិនអាចធ្វើឲ្យមនុស្សបានគ្រប់លក្ខណ៍ទេ! និយាយឲ្យត្រង់ទៅ៖ សព្វថ្ងៃនេះ ព្រះដ៏ពិតផ្ទាល់ព្រះអង្គដែលមានរូបកាយសាច់ឈាម ទ្រង់មិនធ្វើសកម្មភាពទេ ទ្រង់ថ្លែងតែព្រះបន្ទូលប៉ុណ្ណោះ។ នេះជាសេចក្ដីពិត! ទ្រង់ប្រើព្រះបន្ទូលដើម្បីធ្វើឲ្យអ្នកបានគ្រប់លក្ខណ៍ ហើយប្រើព្រះបន្ទូលដើម្បីប្រទាននូវអាហារ និងផ្ដល់ទឹកដល់អ្នក។ ទ្រង់ក៏ប្រើព្រះបន្ទូល

ដើម្បីធ្វើកិច្ចការ ហើយទ្រង់ក៏ប្រើព្រះបន្ទូលនៅក្នុងការពិត ដើម្បីឲ្យអ្នកស្គាល់ពីភាពជាក់ស្ដែងរបស់ទ្រង់ដែរ។ ប្រសិនបើអ្នកមិនអាចគិតយល់ពីលក្ខណៈនៃកិច្ចការរបស់ព្រះជាម្ចាស់មួយនេះទេ នោះក៏ពិបាកនឹងមានគំនិតអវិជ្ជមានដែរ អ្នកគួរផ្ដោតតែលើអ្វីដែលវិជ្ជមាន ពោលគឺទោះបីជាព្រះបន្ទូលរបស់ព្រះជាម្ចាស់មិនបានសម្រេចក៏ដោយ ឬទោះបីជាគ្មានការមកដល់នៃការពិតក៏ដោយ ក៏ព្រះជាម្ចាស់ធ្វើឲ្យមនុស្សទទួលបាននូវជីវិតពីព្រះបន្ទូលទ្រង់ដែរ ហើយនេះគឺជាទីសម្គាល់ដ៏ធំបំផុត ហើយជាងនេះទៅទៀត នេះគឺជាសេចក្ដីពិតដែលមិនអាចប្រកែកបាន។ នេះគឺជាភ័ស្តុតាងដ៏ល្អបំផុតដែលនាំឲ្យបានស្គាល់ព្រះជាម្ចាស់ ហើយជាទីសម្គាល់ដ៏ធំជាងទីសម្គាល់ណាទាំងអស់។ មានតែព្រះបន្ទូលនេះទេ ទើបអាចធ្វើឲ្យមនុស្សបានគ្រប់លក្ខណ៍។

កាលណាយុគសម័យនៃនគរព្រះបានចាប់ផ្ដើមហើយ នោះព្រះជាម្ចាស់ក៏ចាប់ផ្ដើមបញ្ចេញព្រះបន្ទូលរបស់ទ្រង់ដែរ។ នាថ្ងៃអនាគត ព្រះបន្ទូលទាំងអស់នេះនឹងបានសម្រេចបន្តិចម្ដងៗ លុះដល់ពេលនោះ ជីវិតមនុស្សនឹងបានចម្រើនឡើង។ ការប្រើប្រាស់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីសម្ដែងពីនិស្ស័យពុករលួយរបស់មនុស្សគឺរឹតតែជាក់ស្ដែង និងរឹតតែចាំបាច់ ហើយទ្រង់មិនប្រើអ្វីផ្សេងឡើយក្រៅតែពីព្រះបន្ទូលមកធ្វើកិច្ចការរបស់ព្រះអង្គ ដើម្បីធ្វើឲ្យសេចក្ដីជំនឿរបស់មនុស្សបានគ្រប់លក្ខណ៍ ដ្បិតសព្វថ្ងៃនេះជាយុគសម័យនៃព្រះបន្ទូល ហើយយុគសម័យនេះទាមទារនូវសេចក្ដីជំនឿ ការតាំងចិត្ត និងការសហការរបស់មនុស្ស។ កិច្ចការរបស់ព្រះជាម្ចាស់ដែលបានត្រលប់ជាសាច់ឈាមនៅគ្រាចុងក្រោយ គឺប្រើប្រាស់ព្រះបន្ទូលទ្រង់ ដើម្បីបម្រើ និងផ្គត់ផ្គង់មនុស្ស។ ទាល់តែព្រះជាម្ចាស់ដែលបានត្រលប់ជាសាច់ឈាមបញ្ចប់នូវការថ្លែងព្រះបន្ទូលទ្រង់ ទើបព្រះបន្ទូលនោះនឹងចាប់ផ្ដើមសម្រេច។ កាលព្រះអង្គកំពុងថ្លែងព្រះបន្ទូល ព្រះបន្ទូលទ្រង់មិនបានសម្រេចឡើយ ដ្បិតព្រះបន្ទូលរបស់ទ្រង់មិនអាចសម្រេច ពេលដែលទ្រង់ស្ថិតក្នុងដំណាក់កាលសាច់ឈាមនៅឡើយ នោះទេ។ នេះគឺដើម្បីឲ្យមនុស្សអាចមើលឃើញថា ព្រះជាម្ចាស់គឺជាសាច់ឈាម មិនមែនជាវិញ្ញាណទេ ដូច្នេះ មនុស្សអាចមើលឃើញនូវភាពជាក់ស្ដែងរបស់ព្រះជាម្ចាស់

បានដោយភ្នែករបស់គេផ្ទាល់។ នៅថ្ងៃដែលកិច្ចការរបស់ទ្រង់ចប់សព្វគ្រប់ នៅពេលដែលព្រះបន្ទូលទាំងអស់ដែលទ្រង់ត្រូវថ្លែងបានថ្លែងរួចហើយ នោះព្រះបន្ទូលរបស់ទ្រង់នឹងចាប់ផ្ដើមសម្រេច។ ពេលនេះ មិនមែនយុគសម័យនៃការសម្រេចព្រះបន្ទូលរបស់ព្រះជាម្ចាស់ទេ ដ្បិតទ្រង់មិនទាន់បញ្ចប់ការថ្លែងព្រះបន្ទូលរបស់ទ្រង់ទេ។ ដូច្នេះ កាលណាអ្នកឃើញថា ព្រះជាម្ចាស់នៅកំពុងថ្លែងព្រះបន្ទូលរបស់ទ្រង់នៅលើផែនដីនៅឡើយ ចូរកុំទន្ទឹងផលសម្រេចនៃព្រះបន្ទូលទ្រង់អី។ កាលណាព្រះជាម្ចាស់ឈប់ថ្លែងព្រះបន្ទូលទ្រង់ ហើយកាលណាកិច្ចការរបស់ព្រះអង្គនៅលើផែនដីបានសម្រេច នោះទើបជាពេលដែលព្រះបន្ទូលទ្រង់ចាប់ផ្ដើមសម្រេច។ ក្នុងព្រះបន្ទូលទ្រង់ នៅក្នុងកាលៈទេសៈខ្លះក៏មានការប្រទានជីវិត ហើយនៅក្នុងកាលៈទេសៈខ្លះទៀតក៏មានជាសេចក្ដីទំនាយដែរ ជាសេចក្ដីទំនាយអំពីរឿងរ៉ាវដែលនឹងមកដល់ កិច្ចការដែលនឹងត្រូវសម្រេច និងកិច្ចការដែលពុំទាន់បានសម្រេច។ នៅក្នុងព្រះបន្ទូលរបស់ព្រះយេស៊ូវក៏ធ្លាប់មានសេចក្ដីទំនាយដែរ។ ក្នុងន័យមួយ គឺទ្រង់បានប្រទាននូវជីវិត និងក្នុងន័យមួយទៀត គឺទ្រង់មានបន្ទូលជាសេចក្ដីទំនាយ។ សព្វថ្ងៃនេះ ពុំមានការជជែកអំពីការអនុវត្តព្រះបន្ទូល និងការពិតក្នុងពេលជាមួយគ្នាទៀតទេ ពីព្រោះភាពខុសគ្នារវាងកត្តាដែលអាចមើលឃើញដោយភ្នែកមនុស្សផ្ទាល់ និងកិច្ចការដែលត្រូវបានធ្វើឡើងដោយព្រះជាម្ចាស់ គឺធំធេងខ្លាំងណាស់។ អាចនិយាយបានតែម្យ៉ាងគត់ថា កាលណាកិច្ចការរបស់ព្រះជាម្ចាស់បានសម្រេចហើយ នោះព្រះបន្ទូលរបស់ទ្រង់ក៏បានសម្រេចដែរ ចំណែកការពិតនឹងកើតតាមក្រោយព្រះបន្ទូលវិញ។ នៅក្នុងគ្រាចុងក្រោយ ព្រះដែលយកកំណើតជាមនុស្សក៏ធ្វើព័ន្ធកិច្ចនៃព្រះបន្ទូលនៅលើផែនដីដែរ ហើយនៅក្នុងការធ្វើព័ន្ធកិច្ចនៃព្រះបន្ទូល ទ្រង់ថ្លែងតែព្រះបន្ទូលប៉ុណ្ណោះ ទ្រង់មិនខ្វល់អំពីបញ្ហាដទៃទៀតទេ។ កាលណាកិច្ចការរបស់ព្រះជាម្ចាស់ប្រែប្រួល នោះព្រះបន្ទូលទ្រង់នឹងចាប់ផ្ដើមចេញជាផលសម្រេច។ សព្វថ្ងៃនេះ ព្រះបន្ទូលត្រូវបានប្រើប្រាស់មុនគេដើម្បីធ្វើឲ្យអ្នកបានគ្រប់លក្ខណ៍។ កាលណាព្រះអង្គទទួលបានសិរីរុងរឿងនៅទូទាំងសកលលោកទាំងមូល នោះកិច្ចការរបស់ទ្រង់ក៏នឹងចប់សព្វគ្រប់ ព្រះបន្ទូលដែលគួរ

ថ្លែងនឹងត្រូវបានថ្លែង រួចព្រះបន្ទូលទាំងអស់នឹងក្លាយជាការពិត។ ព្រះជាម្ចាស់បានយាងមកផែនដីនៅគ្រាចុងក្រោយ ដើម្បីធ្វើព័ន្ធកិច្ចនៃព្រះបន្ទូល ដើម្បីឲ្យមនុស្សជាតិស្គាល់ព្រះអង្គ និងដើម្បីឲ្យមនុស្សជាតិអាចមើលឃើញព្រះប្រាជ្ញាញាណរបស់ទ្រង់ និងសកម្មភាពដ៏មហស្ចារ្យទាំងអស់ដែលកើតពីព្រះបន្ទូលរបស់ទ្រង់។ ក្នុងយុគសម័យនៃនគរព្រះ ព្រះជាម្ចាស់ប្រើព្រះបន្ទូលជាចម្បង ដើម្បីយកឈ្នះមនុស្សជាតិទាំងអស់។ នាថ្ងៃអនាគត ព្រះបន្ទូលរបស់ទ្រង់នឹងយាងមកសណ្ឋិតលើគ្រប់សាសនា គ្រប់វិស័យ គ្រប់ប្រជាជាតិ និងគ្រប់និកាយ។ ព្រះជាម្ចាស់ប្រើព្រះបន្ទូលទ្រង់ ដើម្បីយកឈ្នះ ដើម្បីធ្វើឲ្យមនុស្សទាំងអស់មើលឃើញថា ព្រះបន្ទូលទ្រង់មានទាំងសិទ្ធិអំណាច និងឫទ្ធានុភាព ដូច្នេះបានជាសព្វថ្ងៃនេះ អ្នករាល់គ្នាមើលឃើញតែព្រះបន្ទូលរបស់ព្រះជាម្ចាស់ប៉ុណ្ណោះ។

ព្រះបន្ទូលដែលព្រះជាម្ចាស់បានថ្លែងនៅក្នុងយុគសម័យនេះ ខុសគ្នាពីព្រះបន្ទូលដែលត្រូវបានថ្លែងនៅក្នុងយុគសម័យនៃក្រឹត្យវិន័យ ដូច្នេះហើយ ព្រះបន្ទូលក្នុងយុគសម័យទាំងពីរនេះ ក៏ខុសពីព្រះបន្ទូលដែលត្រូវបានថ្លែងក្នុងយុគសម័យនៃព្រះគុណដែរ។ ក្នុងយុគសម័យនៃព្រះគុណ ព្រះជាម្ចាស់មិនធ្វើកិច្ចការនៃព្រះបន្ទូលទេ ប៉ុន្តែទ្រង់គ្រាន់តែថ្លែងអំពីការជាប់ឆ្កាង ដើម្បីប្រោសលោះមនុស្សជាតិទាំងអស់។ ព្រះគម្ពីរគ្រាន់តែរៀបរាប់ពីមូលហេតុ ដែលព្រះយេស៊ូវត្រូវបានគេឆ្កាង ហើយភាពវេទនាដែលទ្រង់បានទទួលនៅលើឈើឆ្កាង ព្រមទាំងរៀបរាប់ពីរបៀបដែលមនុស្សគួរត្រូវជាប់ឆ្កាងសម្រាប់ព្រះជាម្ចាស់។ នៅក្នុងយុគសម័យនោះ កិច្ចការគ្រប់យ៉ាងដែលត្រូវបានធ្វើដោយព្រះជាម្ចាស់ គឺផ្ដោតជាសំខាន់លើការជាប់ឆ្កាង។ នៅក្នុងយុគសម័យនៃនគរព្រះ ព្រះជាម្ចាស់ដែលបានយកកំណើតជាមនុស្ស ថ្លែងព្រះបន្ទូលដើម្បីយកឈ្នះមនុស្សទាំងអស់ដែលជឿដល់ទ្រង់។ នេះហើយជា «ព្រះបន្ទូលដែលកំពុងលេចមកជាសាច់ឈាម»។ ព្រះជាម្ចាស់បានយាងមកនៅក្នុងគ្រាចុងក្រោយ ដើម្បីធ្វើកិច្ចការនេះ ពោលគឺទ្រង់បានយាងមកដើម្បីសម្រេចនូវសារៈសំខាន់ពិត នៃព្រះបន្ទូលដែលកំពុងលេចមកជាសាច់ឈាម។ ព្រះអង្គគ្រាន់តែថ្លែងព្រះបន្ទូលប៉ុណ្ណោះ ហើយការ

មកដល់នៃការពិតក៏កម្រមានដែរ។ នេះគឺជាលក្ខណៈពិតបំផុតនៃព្រះបន្ទូល ដែលកំពុងលេចមកជាសាច់ឈាម រួចកាលណាព្រះជាម្ចាស់ដែលយកកំណើត ថ្លែងព្រះបន្ទូលរបស់ទ្រង់ នេះគឺជាការលេចមកនៃព្រះបន្ទូលនៅក្នុងសាច់ឈាម និងជាព្រះបន្ទូលដែលយាងមកសណ្ឋិតនៅក្នុងសាច់ឈាម។ «ដើមឡើយ មានព្រះបន្ទូល ព្រះបន្ទូលក៏គង់នៅជាមួយព្រះជាម្ចាស់ ព្រះបន្ទូលជាព្រះជាម្ចាស់ ហើយព្រះបន្ទូលក៏បានក្លាយជាសាច់ឈាម»។ ការនេះ (កិច្ចការនៃការលេចមកជាសាច់ឈាម) ជាកិច្ចការ ដែលព្រះជាម្ចាស់នឹងសម្រេចឲ្យបាននៅគ្រាចុងក្រោយ ហើយក៏ជាជំពូកចុងក្រោយនៃផែនការគ្រប់គ្រងរបស់ទ្រង់ទាំងមូលដែរ ដូច្នេះហើយ ព្រះជាម្ចាស់ត្រូវតែយាងមកផែនដី ហើយសម្ដែងព្រះបន្ទូលរបស់ទ្រង់ក្នុងសាច់ឈាម។ កិច្ចការដែលត្រូវធ្វើឲ្យរួចនៅថ្ងៃនេះ កិច្ចការដែលនឹងត្រូវធ្វើឲ្យរួចនៅថ្ងៃអនាគត កិច្ចការដែលព្រះជាម្ចាស់នឹងត្រូវសម្រេចឲ្យបាន ទិសដៅចុងក្រោយរបស់មនុស្ស មនុស្សដែលនឹងត្រូវបានសង្គ្រោះ មនុស្សដែលនឹងត្រូវបំផ្លាញ ។ល។ កិច្ចការទាំងអស់ដែលគួរតែត្រូវសម្រេចឲ្យបាននៅទីបញ្ចប់ គឺត្រូវបានថ្លែងបញ្ជាក់យ៉ាងច្បាស់អស់ហើយ ហើយគ្រប់យ៉ាងក៏ដើម្បីសម្រេចឲ្យបាននូវសារៈសំខាន់ពិតនៃព្រះបន្ទូលដែលកំពុងលេចមកជាសាច់ឈាមដែរ។ បញ្ញត្តិរដ្ឋបាល និងក្រឹត្យវិន័យដែលត្រូវបានបញ្ចេញកាលពីគ្រាមុន មនុស្សដែលនឹងត្រូវបំផ្លាញ មនុស្សដែលនឹងត្រូវចូលទៅសម្រាក គឺព្រះបន្ទូលទាំងអស់នេះត្រូវតែសម្រេច។ នេះជាកិច្ចការដែលត្រូវសម្រេចឲ្យបានជាពិសេសដោយព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សនៅគ្រាចុងក្រោយ។ ព្រះអង្គធ្វើឲ្យមនុស្សដឹងថា អស់អ្នកដែលព្រះជាម្ចាស់បានកំណត់ទុកជាមុននៅកន្លែងណា ហើយមនុស្សដែលព្រះជាម្ចាស់មិនបានកំណត់ទុកជាមុននៅកន្លែងណា ដឹងពីវិធីបែងចែករាស្ត្ររបស់ទ្រង់ និងពួកកូនប្រុសទាំងឡាយរបស់ទ្រង់តាមប្រភេទ ដឹងអំពីអ្វីដែលនឹងត្រូវកើតឡើងចំពោះប្រទេសអ៊ីស្រាអែល និងដឹងអំពីអ្វីដែលនឹងត្រូវកើតឡើងចំពោះស្រុកអេស៊ីព្ទ ពោលគឺព្រះបន្ទូលគ្រប់ម៉ាត់នឹងត្រូវបានសម្រេចនាថ្ងៃអនាគត។ ល្បឿននៃកិច្ចការរបស់ព្រះជាម្ចាស់កំពុងតែស្ទុះឡើង។ ព្រះជាម្ចាស់ប្រើប្រាស់ព្រះបន្ទូល

ជាមធ្យោបាយសម្រាប់បើកសម្ដែងប្រាប់មនុស្សអំពីកិច្ចការដែលត្រូវធ្វើឲ្យរួចនៅក្នុងយុគសម័យនីមួយៗ កិច្ចការដែលត្រូវធ្វើដោយព្រះជាម្ចាស់ដែលយកកំណើតជាសាច់ឈាម និងព័ន្ធកិច្ចដែលទ្រង់ត្រូវធ្វើ ហើយព្រះបន្ទូលទាំងអស់នេះ គឺសុទ្ធតែដើម្បីសម្រេចឲ្យបាននូវសារៈសំខាន់ពិតនៃព្រះបន្ទូលដែលកំពុងលេចមកជាសាច់ឈាម។

ខ្ញុំបានមានបន្ទូលពីខាងដើមរួចហើយថា «អស់អ្នកណាដែលផ្ដោតលើការមើលឃើញទីសម្គាល់ និងការអស្ចារ្យនឹងត្រូវបោះបង់ចោល។ ពួកគេមិនមែនជាមនុស្សដែលត្រូវធ្វើឲ្យបានគ្រប់លក្ខណ៍ឡើយ»។ ខ្ញុំបានថ្លែងព្រះបន្ទូលច្រើនណាស់ ប៉ុន្តែមនុស្សមិនស្គាល់កិច្ចការនេះសូម្បីបន្តិចសោះ ហើយមកដល់ពេលនេះហើយ មនុស្សទាំងនោះនៅតែទូលសុំទីសម្គាល់ និងការអស្ចារ្យដដែល។ តើសេចក្ដីជំនឿរបស់អ្នកចំពោះព្រះជាម្ចាស់ គ្មានអ្វីផ្សេងក្រៅពីចង់បានទីសម្គាល់ និងការអស្ចារ្យ ឬមួយដើម្បីទទួលបានជីវិត? ព្រះយេស៊ូវក៏បានមានបន្ទូលជាច្រើនដែរ ហើយព្រះបន្ទូលខ្លះ គឺនៅមិនទាន់សម្រេចនៅឡើយទេ។ តើអ្នកអាចនិយាយថា ព្រះយេស៊ូវមិនមែនជាព្រះជាម្ចាស់បានដែរឬទេ? ព្រះជាម្ចាស់បានធ្វើបន្ទាល់បញ្ជាក់ថា ទ្រង់គឺជាព្រះគ្រីស្ទ ហើយជាព្រះរាជបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះជាម្ចាស់។ តើអ្នកអាចបដិសេធរឿងនេះទេ? សព្វថ្ងៃនេះ ព្រះជាម្ចាស់ថ្លែងតែព្រះបន្ទូល ហើយប្រសិនបើអ្នកមិនដឹងរឿងនេះឲ្យពិស្ដារទេ គឺអ្នកមិនអាចឈរជាប់បានឡើយ។ តើអ្នកជឿលើទ្រង់ ដោយសារទ្រង់ជាព្រះជាម្ចាស់ ឬក៏អ្នកជឿលើទ្រង់ ដោយផ្អែកលើការសម្រេច ឬមិនសម្រេចតាមព្រះបន្ទូលរបស់ព្រះអង្គ? តើអ្នកជឿលើទីសម្គាល់ និងការអស្ចារ្យ ឬមួយអ្នកជឿលើព្រះជាម្ចាស់? សព្វថ្ងៃនេះ ទ្រង់មិនធ្វើទីសម្គាល់ និងការអស្ចារ្យទេ តើព្រះអង្គពិតជាព្រះជាម្ចាស់ដែរឬទេ? ប្រសិនបើព្រះបន្ទូលដែលទ្រង់ថ្លែង មិនត្រូវបានសម្រេច តើព្រះអង្គពិតជាព្រះជាម្ចាស់ដែរឬទេ? តើលក្ខណៈពិតរបស់ព្រះជាម្ចាស់ ត្រូវបានកំណត់ដោយការសម្រេច ឬមិនសម្រេចតាមព្រះបន្ទូលដែលទ្រង់ថ្លែងមែនទេ? ហេតុអ្វីក៏មនុស្សមួយចំនួនតែងតែរង់ចាំនូវផលសម្រេចនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ មុនពេលដែលគេជឿដល់ទ្រង់ដូច្នេះ? តើនេះមិនមែនមានន័យថា ពួកគេមិនស្គាល់ទ្រង់

ទេឬអី? មនុស្សទាំងអស់ដែលមានការយល់ដឹងបែបនេះ គឺជាមនុស្សដែលបដិសេធព្រះជាម្ចាស់។ គេប្រើការយល់ដឹងមកវាស់ស្ទង់ព្រះជាម្ចាស់ ប្រសិនបើព្រះបន្ទូលរបស់ព្រះជាម្ចាស់បានសម្រេច គេក៏ជឿដល់ទ្រង់ ហើយប្រសិនមិនបានសម្រេចវិញ គេក៏មិនជឿដល់ទ្រង់ ហើយពួកគេរមែងដេញតាមទីសម្គាល់ និងការអស្ចារ្យ។ តើអ្នកទាំងនេះមិនមែនជាពួកផារិស៊ីសម័យទំនើបទេឬអី? អ្នកអាចឈរមាំឬមិនមាំ គឺអាស្រ័យត្រង់ថាអ្នកស្គាល់ឬមិនស្គាល់ព្រះពិត ពោលគឺ កត្តានេះពិតជាសំខាន់ណាស់! តថភាពនៃព្រះបន្ទូលរឹតតែវិសេសវិសាលនៅក្នុងអ្នក នោះការដែលអ្នកស្គាល់ពីតថភាពរបស់ព្រះជាម្ចាស់ ក៏រឹតតែអស្ចារ្យ ហើយអ្នកក៏រឹតតែអាចឈរមាំពេលត្រូវល្បងល។ កាលណាអ្នករឹតតែផ្ដោតលើទីសម្គាល់ និងការអស្ចារ្យ នោះអ្នករឹតតែមិនអាចឈរមាំបាន ហើយអ្នកនឹងដួលចុះពេលត្រូវល្បងល។ ទីសម្គាល់ និងការអស្ចារ្យមិនមែនជាគ្រឹះទេ មានតែតថភាពនៃព្រះជាម្ចាស់ទេទើបជាជីវិត។ មនុស្សមួយចំនួនមិនដឹងពីលទ្ធផលដែលត្រូវបានសម្រេចដោយកិច្ចការរបស់ព្រះជាម្ចាស់ផង។ ពួកគេចំណាយជីវិតរបស់គេក្នុងភាពវង្វេងវង្វាន់ មិនមែនព្យាយាមស្គាល់ពីកិច្ចការរបស់ព្រះជាម្ចាស់នោះឡើយ។ គោលបំណងនៃការដេញតាមរបស់គេ នោះគឺគ្រាន់តែធ្វើឲ្យព្រះជាម្ចាស់បំពេញនូវសេចក្ដីប៉ងប្រាថ្នារបស់គេប៉ុណ្ណោះ។ ពួកគេនិយាយថា ពួកគេនឹងតាមរកជីវិត ប្រសិនបើព្រះបន្ទូលរបស់ព្រះជាម្ចាស់ត្រូវបានសម្រេច ប៉ុន្តែប្រសិនបើព្រះបន្ទូលទ្រង់មិនបានសម្រេចទេ នោះលទ្ធភាពនៃការតាមរកជីវិតក៏គ្មានដែរ។ មនុស្សគិតថាជំនឿលើព្រះជាម្ចាស់ គឺជាការតាមរក ការមើលឃើញទីសម្គាល់និងការអស្ចារ្យ និងការដេញតាមការឡើងទៅស្ថានសួគ៌និងស្ថានសួគ៌ជាន់ទីបី។ ក្នុងចំណោមពួកគេ គ្មាននរណាម្នាក់ពោលថា ជំនឿគឺជាការតាមរកច្រកចូលទៅក្នុងតថភាពជាក់ស្ដែង ការតាមរកជីវិត និងការតាមរកការដែលត្រូវបានព្រះជាម្ចាស់ទទួលយកទេ។ តើអ្វីទៅជាតម្លៃនៃការតាមរកបែបនេះ? មនុស្សដែលមិនតាមរកចំណេះដឹងអំពីព្រះជាម្ចាស់ និងសេចក្ដីគាប់ព្រះហឫទ័យរបស់ព្រះអង្គ អ្នកទាំងនោះគឺជាមនុស្សដែលមិនជឿលើព្រះជាម្ចាស់ ហើយជាមនុស្សដែលប្រមាថព្រះជាម្ចាស់ផង!

ពេលនេះ តើអ្នករាល់គ្នាយល់ហើយឬនៅថា ជំនឿលើព្រះជាម្ចាស់គឺជាអ្វី? តើជំនឿលើព្រះជាម្ចាស់គឺជាការមើលឃើញទីសម្គាល់ និងការអស្ចារ្យមែនទេ? តើជំនឿនេះគឺជាការឡើងទៅស្ថានសួគ៌មែនទេ? ការជឿលើព្រះជាម្ចាស់ មិនមែនងាយស្រួលបន្តិចណាឡើយ។ ទម្លាប់សាសនាទាំងអស់នោះគួរតែបោះចោលទៅ ការដេញតាមការប្រោសជំងឺ និងការបណ្ដេញវិញ្ញាណអាក្រក់ ការផ្ដោតសំខាន់លើទីសម្គាល់ និងការអស្ចារ្យ ការលោភចង់បានព្រះគុណរបស់ព្រះជាម្ចាស់ ភាពសុខសាន្ត និងក្ដីអំណរថែមទៀត ការដេញតាមក្ដីរំពឹងសម្រាប់អនាគត និងសេចក្ដីសុខខាងសាច់ឈាមទាំងអស់នេះ គឺសុទ្ធតែជាទម្លាប់សាសនា ហើយទម្លាប់សាសនាទាំងអស់នេះ គឺជាជំនឿស្រពេចស្រពិល។ សព្វថ្ងៃនេះ តើអ្វីគឺជាជំនឿពិតលើព្រះជាម្ចាស់? នោះគឺជាទទួលយកព្រះបន្ទូលព្រះជាម្ចាស់ធ្វើជាតថភាពនៃជីវិតរបស់អ្នក និងការស្គាល់ព្រះជាម្ចាស់តាមរយៈព្រះបន្ទូលរបស់ទ្រង់ ដើម្បីសម្រេចឲ្យបាននូវសេចក្ដីស្រឡាញ់ពិតរបស់ទ្រង់។ ដើម្បីឲ្យកាន់តែច្បាស់៖ ជំនឿលើព្រះជាម្ចាស់ គឺដើម្បីឲ្យអ្នកស្ដាប់បង្គាប់ទ្រង់ ស្រឡាញ់ទ្រង់ និងបំពេញភារកិច្ចដែលគួរតែត្រូវបានបំពេញដោយសត្តនិកររបស់ព្រះជាម្ចាស់។ នេះហើយគឺជាគោលបំណងនៃការជឿលើព្រះជាម្ចាស់។ អ្នកត្រូវសម្រេចឲ្យបាននូវចំណេះដឹងអំពី ភាពគួរឲ្យស្រឡាញ់របស់ព្រះជាម្ចាស់ ទំហំនៃភាពស័ក្តិសមនឹងទទួលនូវការគោរពកោតខ្លាចរបស់ព្រះជាម្ចាស់ ស្គាល់អំពីរបៀបដែលទ្រង់ធ្វើកិច្ចការនៃសេចក្ដីសង្គ្រោះ និងធ្វើឲ្យពួកគេបានគ្រប់លក្ខណ៍ នៅក្នុងសត្តនិករដែលទ្រង់បង្កើត។ ទាំងអស់នេះ គឺសុទ្ធតែជាសារៈសំខាន់នៃជំនឿរបស់អ្នកលើព្រះជាម្ចាស់។ ជំនឿលើព្រះជាម្ចាស់សំខាន់បំផុត គឺជាការផ្លាស់ប្ដូរពីជីវិតខាងសាច់ឈាម ទៅកាន់ជីវិតដែលស្រឡាញ់ព្រះជាម្ចាស់ ពីការរស់នៅក្នុងសេចក្ដីពុករលួយ ទៅកាន់ការរស់នៅក្នុងជីវិតនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់។ វាគឺជាការចាកចេញពីអំណាចគ្រប់គ្រងរបស់សាតាំង ហើយមករស់នៅក្រោមការថែរក្សា និងការការពាររបស់ព្រះជាម្ចាស់វិញ។ វាជាលទ្ធភាពដែលអាចស្ដាប់បង្គាប់ព្រះជាម្ចាស់ និងមិនមែនជាការស្ដាប់បង្គាប់សាច់ឈាមនោះទេ។ វាជាការទុកឱកាសឲ្យព្រះជាម្ចាស់

ទទួលបានដួងចិត្តរបស់អ្នកទាំងមូល ទុកឲ្យព្រះជាម្ចាស់ធ្វើឲ្យអ្នកបានគ្រប់លក្ខណ៍ និងរំដោះអ្នកឲ្យរួចពីនិស្ស័យពុករលួយបែបសាតាំង។ ជំនឿលើព្រះជាម្ចាស់ គឺច្រើនតែបែបនេះ ដើម្បីឲ្យព្រះចេស្ដា និងសិរីរុងរឿងរបស់ព្រះជាម្ចាស់ អាចនឹងត្រូវបានស្ដែងនៅក្នុងអ្នក ដើម្បីឲ្យអ្នកអាចធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ហើយសម្រេចផែនការរបស់ព្រះជាម្ចាស់ និងអាចធ្វើបន្ទាល់អំពីព្រះជាម្ចាស់នៅចំពោះមុខសាតាំង។ ជំនឿលើព្រះជាម្ចាស់មិនគួរផ្ដោតសំខាន់លើចិត្តប្រាថ្នាចង់ឃើញទីសម្គាល់ និងការអស្ចារ្យឡើយ ក៏មិនគួរផ្ដោតលើប្រយោជន៍នៃសាច់ឈាមផ្ទាល់ខ្លួនរបស់អ្នកដែរ។ ជំនឿគួរតែជាការដេញតាមឲ្យបានស្គាល់ព្រះជាម្ចាស់ និងជាការដែលអាចស្ដាប់បង្គាប់ព្រះជាម្ចាស់ គឺស្ដាប់បង្គាប់រហូតដល់អស់ជីវិត ដូចជាពេត្រុស។ ទាំងអស់នេះ គឺជាគោលបំណងសំខាន់ៗនៃការជឿលើព្រះជាម្ចាស់។ មនុស្សហូប និងផឹកព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីស្គាល់ព្រះអង្គ និងផ្គាប់ព្រះហឫទ័យទ្រង់។ ការហូប និងផឹកព្រះបន្ទូលរបស់ព្រះជាម្ចាស់ ធ្វើឲ្យអ្នកស្គាល់ព្រះអង្គកាន់តែច្បាស់ ហើយទាល់តែអាចបានស្គាល់ទ្រង់ច្បាស់ ទើបអ្នកអាចស្ដាប់បង្គាប់ទ្រង់បាន។ ទាល់តែអ្នកស្គាល់ព្រះជាម្ចាស់ ទើបអ្នកអាចស្រឡាញ់ទ្រង់បាន ហើយនេះគឺជាគោលដៅដែលមនុស្សគួរមាននៅក្នុងជំនឿរបស់គេចំពោះព្រះជាម្ចាស់។ ប្រសិនបើអ្នកនៅតែព្យាយាមរកមើលទីសម្គាល់ និងការអស្ចារ្យនៅក្នុងជំនឿរបស់អ្នកចំពោះព្រះជាម្ចាស់ ទស្សនៈនៃជំនឿចំពោះព្រះជាម្ចាស់បែបនេះ គឺពិតជាខុសហើយ។ ជំនឿលើព្រះជាម្ចាស់ផ្ដោតសំខាន់លើការទទួលព្រះបន្ទូលរបស់ព្រះជាម្ចាស់ធ្វើជាតថភាពនៃជីវិត។ គោលបំណងរបស់ព្រះជាម្ចាស់ អាចនឹងត្រូវគេទទួលបានតាមរយៈការអនុវត្តព្រះបន្ទូលដែលចេញពីព្រះឱស្ឋរបស់ព្រះជាម្ចាស់ ហើយយកមកអនុវត្ត នៅក្នុងជីវិតរបស់អ្នកផ្ទាល់។ នៅក្នុងជំនឿលើព្រះជាម្ចាស់ មនុស្សគួរព្យាយាមទុកឲ្យព្រះជាម្ចាស់កែច្នៃគេឲ្យបានគ្រប់លក្ខណ៍ ឲ្យគេអាចចុះចូលចំពោះព្រះជាម្ចាស់ និងដើម្បីស្ដាប់បង្គាប់ព្រះជាម្ចាស់ទាំងស្រុង។ ប្រសិនបើអ្នកអាចស្ដាប់បង្គាប់ព្រះជាម្ចាស់ដោយគ្មានការរអ៊ូរទាំ ចូរប្រយ័ត្នចំពោះបំណងប្រថ្នារបស់ព្រះជាម្ចាស់ ចូរសម្រេចឲ្យបាននូវកេរ្តិ៍ឈ្មោះដូច

ពេត្រុស ហើយទទួលបានព្រះបន្ទូលសរសើរពីព្រះជាម្ចាស់ដូចពេត្រុសផង ដល់ពេលនោះទើបអ្នកសម្រេចបានជោគជ័យនៅក្នុងជំនឿ ដែលអ្នកមានចំពោះព្រះជាម្ចាស់ ហើយជំនឿនេះនឹងប្រាប់ឲ្យដឹងថា ព្រះជាម្ចាស់ទទួលបានអ្នកហើយ។

ព្រះជាម្ចាស់ធ្វើកិច្ចការរបស់ទ្រង់ នៅទូទាំងសកលលោកទាំងមូល។ មនុស្សណាដែលជឿដល់ទ្រង់ គឺត្រូវតែទទួលព្រះបន្ទូលទ្រង់ ហើយហូប និងផឹកព្រះបន្ទូលរបស់ទ្រង់។ គ្មាននរណាម្នាក់ដែលព្រះជាម្ចាស់ទទួលយកតាមរយៈការមើលឃើញទីសម្គាល់ និងការអស្ចារ្យ ដែលព្រះជាម្ចាស់បានបង្ហាញនោះឡើយ។ ក្នុងគ្រប់យុគសម័យទាំងអស់ ព្រះជាម្ចាស់តែងតែប្រើព្រះបន្ទូល ដើម្បីធ្វើឲ្យមនុស្សបានគ្រប់លក្ខណ៍។ ហេតុនេះ អ្នករាល់គ្នាមិនគប្បីដាក់ការយកចិត្តទុកដាក់ទាំងស្រុងទៅលើទីសម្គាល់ និងការអស្ចារ្យនោះឡើយ ប៉ុន្តែគួរព្យាយាមឲ្យបានគ្រប់លក្ខណ៍ដោយសារព្រះជាម្ចាស់វិញ។ នៅក្នុងយុគសម័យ នៃក្រឹត្យវិន័យរបស់ព្រះគម្ពីរសញ្ញាចាស់ ព្រះជាម្ចាស់បានថ្លែងព្រះបន្ទូលខ្លះ ហើយក្នុងយុគសម័យនៃព្រះគុណព្រះយេស៊ូវក៏បានថ្លែងព្រះបន្ទូលជាច្រើនដែរ។ បន្ទាប់ពីព្រះយេស៊ូវ បានថ្លែងនូវព្រះបន្ទូលជាច្រើនរួចហើយ នោះពួកសិស្ស និងពួកសាវ័កក៏បាននាំមនុស្សអនុវត្តតាមបញ្ញត្តិដែលព្រះយេស៊ូវបានប្រទានឲ្យ ហើយមានបទពិសោធស្របតាមព្រះបន្ទូល និងគោលការណ៍នានាដែលព្រះយេស៊ូវបានថ្លែងប្រាប់។ នៅគ្រាចុងក្រោយ ព្រះជាម្ចាស់ប្រើព្រះបន្ទូលរបស់ទ្រង់ជាចម្បង ដើម្បីធ្វើឲ្យមនុស្សបានគ្រប់លក្ខណ៍។ ព្រះអង្គមិនប្រើទីសម្គាល់ និងការអស្ចារ្យដើម្បីសង្កត់សង្កិន ឬមួយបញ្ចុះបញ្ចូលឲ្យមនុស្សជឿនោះទេ ទង្វើនេះមិនអាចធ្វើឲ្យគេស្គាល់ព្រះចេស្ដារបស់ព្រះជាម្ចាស់ឡើយ។ ប្រសិនបើព្រះជាម្ចាស់បង្ហាញទីសម្គាល់ និងការអស្ចារ្យ នោះក៏មិនអាចស្ដែងឲ្យគេស្គាល់ពីតថភាពរបស់ព្រះជាម្ចាស់ដែរ ព្រមទាំងមិនអាចធ្វើឲ្យមនុស្សគ្រប់លក្ខណ៍បានដែរ។ ព្រះជាម្ចាស់មិនធ្វើឲ្យមនុស្សបានគ្រប់លក្ខណ៍ដោយសារទីសម្គាល់ និងការអស្ចារ្យឡើយ តែទ្រង់ប្រើព្រះបន្ទូល ដើម្បីស្រោចស្រព និងឃ្វាលមនុស្ស បន្ទាប់មកទ្រង់ក៏ទទួលបាននូវការស្ដាប់បង្គាប់របស់មនុស្ស និងឲ្យគេបានស្គាល់ព្រះអង្គ។ នេះគឺជា

គោលដៅនៃកិច្ចការដែលទ្រង់ធ្វើ និងជាគោលដៅនៃព្រះបន្ទូលដែលទ្រង់ថ្លែង។ ព្រះជាម្ចាស់មិនប្រើវិធីសាស្ត្រនៃការបង្ហាញទីសម្គាល់ និងការអស្ចារ្យ ដើម្បីធ្វើឲ្យមនុស្សបានគ្រប់លក្ខណ៍ឡើយ តែទ្រង់ប្រើព្រះបន្ទូល និងប្រើវិធីសាស្ត្រអនុវត្តខុសៗគ្នា ដើម្បីធ្វើឲ្យមនុស្សបានគ្រប់លក្ខណ៍។ ព្រះជាម្ចាស់ ថ្លែងព្រះបន្ទូលតាមទស្សនៈផ្សេងៗគ្នាជាច្រើន ដើម្បីធ្វើឲ្យមនុស្សបានគ្រប់លក្ខណ៍ និងដើម្បីប្រទានឲ្យមនុស្សស្គាល់ពីកិច្ចការ ព្រះប្រាជ្ញាញាណ និងស្នាព្រះហស្តដ៏មហស្ចារ្យរបស់ទ្រង់កាន់តែច្បាស់ មិនថាតាមរយៈការបន្សុទ្ធ ការដោះស្រាយ ការលួសកាត់ ឬការប្រទាននូវព្រះបន្ទូលនោះឡើយ។ នៅពេលមនុស្សបានពេញខ្នាតនៅចំពេលដែលព្រះជាម្ចាស់បញ្ចប់យុគសម័យនៅគ្រាចុងក្រោយ នោះគេនឹងមានគ្រប់លក្ខណៈសម្បត្តិដើម្បីគិតដល់ទីសម្គាល់ និងការអស្ចារ្យ។ កាលណាអ្នកស្គាល់ព្រះជាម្ចាស់ ហើយអាចស្ដាប់បង្គាប់ព្រះជាម្ចាស់ បើទោះបីជាទ្រង់ធ្វើកិច្ចការអ្វីក៏ដោយ នោះអ្នកនឹងលែងមានសញ្ញាណអំពីទ្រង់ នៅពេលដែលអ្នកមើលឃើញទីសម្គាល់ និងការអស្ចារ្យ។ ក្នុងខណៈពេលនេះ អ្នកពុករលួយ និងមិនអាចស្ដាប់បង្គាប់ព្រះជាម្ចាស់ពេញលេញឡើយ តើអ្នកគិតថា អ្នកមានគ្រប់លក្ខណៈសម្បតិនឹងមើលឃើញទីសម្គាល់ និងការអស្ចារ្យហើយឬនៅ ក្នុងសភាពបែបនេះ? កាលណាព្រះជាម្ចាស់បង្ហាញទីសម្គាល់ និងការអស្ចារ្យ ពេលនោះ គឺជាពេលដែលព្រះជាម្ចាស់ដាក់ទោសមនុស្ស ហើយក៏ជាពេលផ្លាស់ប្ដូរយុគសម័យដែរ ហើយលើសពីនេះទៀត គឺជាពេលវេលាដែលត្រូវបញ្ចប់យុគសម័យនេះ។ កាលណាកិច្ចការរបស់ព្រះជាម្ចាស់ កំពុងត្រូវបានអនុវត្តជាធម្មតា ទ្រង់មិនបង្ហាញទីសម្គាល់ និងការអស្ចារ្យទេ។ ការបង្ហាញទីសម្គាល់ និងការអស្ចារ្យ គឺជារឿងងាយបំផុតហើយសម្រាប់ទ្រង់ ប៉ុន្តែនោះមិនមែនជាគោលការណ៍នៃការអនុវត្តកិច្ចការរបស់ទ្រង់ឡើយ ហើយក៏មិនមែនជាគោលបំណងនៃកិច្ចការគ្រប់គ្រងមនុស្សរបស់ទ្រង់ដែរ។ ប្រសិនបើមនុស្សបានឃើញទីសម្គាល់ និងការអស្ចារ្យ ហើយប្រសិនបើព្រះកាយខាងព្រលឹងវិញ្ញាណរបស់ព្រះជាម្ចាស់ បានលេចមកឲ្យមនុស្សឃើញហើយ នោះពួកគេគ្រប់គ្នាមុខជាលែងជឿលើព្រះជាម្ចាស់

ហើយមែនទេ? ខ្ញុំបាននិយាយពីខាងដើមរួចហើយថា អ្នកមានជ័យជម្នះមួយក្រុមត្រូវបានទទួលពីទិសខាងកើតមក គេគឺជាអ្នកមានជ័យជម្នះដែលកើតចេញមកពីគ្រាមហាវេទនា។ តើពាក្យទាំងអស់នេះមានន័យដូចម្ដេច? ពាក្យទាំងអស់នេះមានន័យថា មនុស្សដែលទើបតែទទួលបាន ទាល់តែគេបានឆ្លងកាត់ការជំនុំជម្រះ និងការវាយផ្ចាល ការប្រឈមដោះស្រាយ និងការកាត់ចេញ ហើយនិងការបន្សុទ្ធគ្រប់យ៉ាង ទើបគេស្ដាប់បង្គាប់ពិតប្រាកដ។ ជំនឿរបស់មនុស្សទាំងអស់នេះមិនមែនស្រពេចស្រពិល និងអរូបីទេ តែជាជំនឿពិត។ ពួកគេមិនធ្លាប់ឃើញទីសម្គាល់ និងការអស្ចារ្យ ឬការឫទ្ធិបារមីអ្វីទាំងអស់ ពួកគេក៏មិននិយាយអំពីន័យពាក្យ និងសេចក្ដីបង្រៀនដែលពិបាកយល់ ឬគំនិតជ្រាលជ្រៅអ្វីដែរ ផ្ទុយទៅវិញ ពួកគេមានតថភាព និងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយពិតជាស្គាល់តថភាពរបស់ព្រះជាម្ចាស់ពិតប្រាកដមែន។ តើក្រុមមនុស្សបែបនេះ គ្មានសមត្ថភាពពន្យល់ពីព្រះចេស្ដារបស់ព្រះជាម្ចាស់ឲ្យងាយជាងនេះទេមែនទេ? កិច្ចការរបស់ព្រះជាម្ចាស់នៅគ្រាចុងក្រោយជាកិច្ចការពិត។ នៅក្នុងយុគសម័យព្រះយេស៊ូវ ព្រះអង្គមិនបានយាងមក ដើម្បីធ្វើឲ្យមនុស្សបានគ្រប់លក្ខណ៍នោះទេ ប៉ុន្តែទ្រង់យាងមកប្រោសលោះមនុស្ស ហេតុនេះហើយទើបទ្រង់បង្ហាញនូវការអស្ចារ្យមួយចំនួន ដើម្បីធ្វើឲ្យមនុស្សដើរតាមទ្រង់។ ដ្បិតព្រះអង្គយាងមកជាពិសេស ដើម្បីបំពេញកិច្ចការនៃការជាប់ឆ្កាង ចំណែកឯការបង្ហាញទីសម្គាល់ មិនមែនជាចំណែកព័ន្ធកិច្ចរបស់ទ្រង់ឡើយ។ ទីសម្គាល់ និងការអស្ចារ្យគឺជាកិច្ចការដែលត្រូវធ្វើ ដើម្បីធ្វើឲ្យកិច្ចការរបស់ទ្រង់មានប្រសិទ្ធភាព ហើយទាំងនេះគឺជាកិច្ចការបន្ថែម ហើយមិនមែនតំណាងឲ្យកិច្ចការនៃយុគសម័យទាំងមូលនោះឡើយ។ នៅក្នុងយុគសម័យក្រឹត្យវិន័យនៃព្រះគម្ពីរសញ្ញាចាស់ ព្រះជាម្ចាស់ក៏បង្ហាញនូវទីសម្គាល់ និងការអស្ចារ្យដែរ ប៉ុន្តែកិច្ចការដែលព្រះជាម្ចាស់ធ្វើនាពេលសព្វថ្ងៃ គឺជាកិច្ចការពិត ហើយទ្រង់ច្បាស់ជាមិនបង្ហាញទីសម្គាល់ និងការអស្ចារ្យនាពេលនេះទេ។ ប្រសិនបើទ្រង់បង្ហាញទីសម្គាល់ និងការអស្ចារ្យ នោះកិច្ចការរបស់ទ្រង់នឹងត្រូវបោះបង់ចោល លែងមានលំដាប់លំដោយ ហើយទ្រង់មុខជាមិនអាចធ្វើ

នូវកិច្ចការដទៃទៀតនោះឡើយ។ ប្រសិនបើព្រះជាម្ចាស់មានព្រះបន្ទូល ដើម្បីប្រើព្រះបន្ទូលដើម្បីធ្វើឲ្យមនុស្សគ្រប់លក្ខណ៍ ប៉ុន្តែព្រះអង្គក៏បង្ហាញទីសម្គាល់ និងការអស្ចារ្យ នោះតើអាចពន្យល់បានទេថា មនុស្សជឿដល់ព្រះអង្គប្រាកដមែន ឬមិនមែន? ហេតុនេះហើយ ទើបព្រះជាម្ចាស់មិនធ្វើកិច្ចការបែបនេះទេ។ នៅក្នុងមនុស្សមានគំនិតសាសនាច្រើនណាស់ ហើយព្រះជាម្ចាស់យាងមកនៅគ្រាចុងក្រោយ គឺដើម្បីបណ្តេញគំនិតសាសនា និងជំនឿហួសវិស័យធម្មជាតិក្នុងជីវិតមនុស្សចេញ រួចធ្វើឲ្យគេស្គាល់នូវតថភាពរបស់ព្រះជាម្ចាស់។ ទ្រង់បានយាងមកដើម្បីលុបរូបអង្គរបស់ព្រះជាម្ចាស់ដែលមើលមិនឃើញ ហើយពោរពេញដោយភាពរវើរវាយ ម្យ៉ាងទៀតនោះគឺជារូបអង្គនៃព្រះជាម្ចាស់ដែលពុំមានវត្តមានគង់នៅនេះចោល។ ហេតុនេះ នៅពេលនេះ សេចក្តីដែលមានតម្លៃបំផុតចំពោះអ្នកនោះ គឺជាការស្គាល់តថភាព! សេចក្តីពិត គ្របបាំងអ្វីៗគ្រប់យ៉ាង។ សព្វថ្ងៃនេះ តើអ្នកមានសេចក្តីពិតច្រើនប៉ុនណា? តើសេចក្តីពិតទាំងអស់នេះបង្ហាញទីសម្គាល់ និងការអស្ចារ្យរបស់ព្រះជាម្ចាស់ដែរឬទេ? វិញ្ញាណអាក្រក់ក៏អាចបង្ហាញឲ្យឃើញទីសម្គាល់ និងការអស្ចារ្យដែរ តើវិញ្ញាណទាំងអស់នោះគឺជាព្រះដែរឬទេ? នៅក្នុងជំនឿដែលមនុស្សមានចំពោះព្រះជាម្ចាស់ អ្វីដែលមនុស្សស្វែងរកនៅក្នុងសេចក្តីពិត និងអ្វីៗដែលគេចង់បានគឺជីវិត មិនមែនទីសម្គាល់ និងការអស្ចារ្យទេ។ នេះគួរតែជាគោលដៅរបស់មនុស្សដែលជឿដល់ព្រះជាម្ចាស់។

# អស់អ្នកដែលនឹងត្រូវប្រោសឲ្យបានគ្រប់លក្ខណ៍ ត្រូវតែឆ្លងកាត់ការបន្សុទ្ធ

ប្រសិនបើអ្នកជឿលើព្រះជាម្ចាស់ នោះអ្នកត្រូវតែស្តាប់បង្គាប់ព្រះជាម្ចាស់ យកសេចក្តីពិតទៅអនុវត្ត ហើយបំពេញគ្រប់ទាំងកាតព្វកិច្ចរបស់អ្នក។ លើសពីនេះទៀតអ្នកត្រូវតែយល់ពីរឿងរ៉ាវដែលអ្នកគួរមានបទពិសោធ។ ប្រសិនបើអ្នកគ្រាន់តែមានបទពិសោធក្នុងការដែលអ្នកកំពុងត្រូវបានដោះស្រាយ កំពុងត្រូវបានប្រៀនប្រដៅ និង

កំពុងត្រូវបានជំនុំជម្រះ ប្រសិនបើអ្នកគ្រាន់តែអាចរីករាយនឹងព្រះជាម្ចាស់ ប៉ុន្តែនៅតែមិនអាចទទួលបាននូវអារម្មណ៍នៅពេលព្រះជាម្ចាស់ប្រៀនប្រដៅអ្នក ឬដោះស្រាយជាមួយនឹងអ្នក ការនេះ គឺមិនអាចទទួលយកបាននោះទេ។ ប្រហែលជានៅក្នុងឧទាហរណ៍នៃការបន្សុទ្ធនេះ អ្នកអាចឈរជើងនៅកន្លែងរបស់អ្នក ប៉ុន្តែការនេះនៅតែមិនទាន់គ្រប់គ្រាន់នៅឡើយទេ។ អ្នកនៅតែត្រូវដើរទៅមុខជានិច្ច។ មេរៀននៃការស្រឡាញ់ព្រះជាម្ចាស់មិនដែលចប់ ហើយគ្មានទីបញ្ចប់ឡើយ។ មនុស្សយល់ឃើញថា ការជឿលើព្រះជាម្ចាស់ជាអ្វីដែលសាមញ្ញបំផុត ប៉ុន្តែនៅពេលដែលពួកគេទទួលបានបទពិសោធជាក់ស្តែង នោះពួកគេនឹងដឹងថាជំនឿលើព្រះជាម្ចាស់មិនសាមញ្ញដូចអ្វីដែលមនុស្សស្រមៃគិតនោះទេ។ នៅពេលដែលព្រះជាម្ចាស់ ទ្រង់ធ្វើកិច្ចការដើម្បីបន្សុទ្ធមនុស្ស នោះគឺមនុស្សរងទុក្ខ។ នៅពេលមនុស្សទទួលការបន្សុទ្ធកាន់តែច្រើន នោះពួកគេនឹងស្រឡាញ់ព្រះជាម្ចាស់កាន់តែខ្លាំងឡើង ហើយព្រះចេស្ដារបស់ព្រះជាម្ចាស់ដែលនឹងត្រូវបើកសម្ដែងដល់ពួកគេកាន់តែច្រើនដែរ។ ផ្ទុយទៅវិញ បើមនុស្សទទួលការបន្សុទ្ធតិចតួច នោះសេចក្តីស្រឡាញ់របស់ពួកគេចំពោះព្រះជាម្ចាស់នឹងមានការលូតលាស់កាន់តែតិចទៅៗ ហើយព្រះចេស្ដារបស់ព្រះជាម្ចាស់ដែលនឹងត្រូវបើកសម្ដែងដល់ពួកគេ ក៏កាន់តែតិចដែរ។ នៅពេលការបន្សុទ្ធ និងការរងទុក្ខរបស់មនុស្សបែបនេះកាន់តែច្រើនឡើងៗ ហើយការរងទារុណកម្មដែលពួកគេជួបប្រទះកាន់តែច្រើន នោះពួកគេនឹងកាន់តែស្រឡាញ់ព្រះជាម្ចាស់កាន់តែខ្លាំងឡើង ជំនឿដ៏ពិតប្រាកដរបស់ពួកគេចំពោះព្រះជាម្ចាស់កាន់តែខ្លាំងឡើង ហើយចំណេះដឹងដ៏ជ្រាលជ្រៅរបស់ពួកគេអំពីព្រះជាម្ចាស់ក៏កាន់តែច្រើនឡើងដែរ។ នៅក្នុងបទពិសោធរបស់អ្នក អ្នកនឹងឃើញមនុស្សដែលរងទុក្ខយ៉ាងខ្លាំង នៅពេលពួកគេទទួលនូវការបន្សុទ្ធ ជាអ្នកដែលត្រូវបានដោះស្រាយ និងត្រូវបានប្រៀនប្រដៅច្រើន ហើយអ្នកនឹងឃើញថា ទាំងនោះគឺជាអស់អ្នកដែលមានសេចក្តីស្រឡាញ់យ៉ាងខ្លាំង ចំពោះព្រះជាម្ចាស់ និងមានចំណេះដឹងអំពីព្រះជាម្ចាស់បានជ្រៅជ្រះ និងជ្រាលជ្រៅជាងមុន។ អ្នកដែលមិនមានបទពិសោធក្នុងការទទួលបានការដោះស្រាយ នឹងមានចំណេះ

ដឹង ប៉ុន្តែមានសើៗ ហើយពួកគេអាចនិយាយថា៖ «ព្រះជាម្ចាស់ល្អណាស់ ទ្រង់ផ្តល់នូវព្រះគុណដល់មនុស្ស ដើម្បីឲ្យពួកគេអាចរីករាយនឹងទ្រង់»។ ប្រសិនបើមនុស្សបានឆ្លងកាត់បទពិសោធក្នុងការទទួលបានការដោះស្រាយ និងត្រូវបានប្រៀនប្រដៅ នោះពួកគេអាចនិយាយអំពីចំណេះដឹងដ៏ពិតអំពីព្រះជាម្ចាស់បាន។ ដូច្នេះបើកិច្ចការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់កាន់តែច្រើននៅចំពោះមនុស្ស នោះតម្លៃ និងភាពសំខាន់ក៏កាន់តែមានច្រើន។ បើមានការពិបាកក្នុងការចូលទៅកាន់អ្នកកាន់តែច្រើន ហើយភាពមិនស៊ីគ្នាទៅនឹងសញ្ញាណរបស់អ្នកកាន់តែច្រើន នោះកិច្ចការរបស់ព្រះជាម្ចាស់គឺអាចយកឈ្នះលើអ្នក ទទួលយកអ្នក និងប្រោសឲ្យអ្នកបានគ្រប់លក្ខណ៍។ ភាពសំខាន់នៃកិច្ចការរបស់ព្រះជាម្ចាស់មានការអស្ចារ្យខ្លាំងណាស់! ប្រសិនបើព្រះជាម្ចាស់មិនបានបន្សុទ្ធមនុស្សតាមរបៀបនេះទេ ប្រសិនបើទ្រង់មិនបានធ្វើកិច្ចការទៅតាមវិធីសាស្ត្រនេះទេ នោះកិច្ចការរបស់ទ្រង់នឹងគ្មានប្រសិទ្ធភាព ហើយគ្មានភាពសំខាន់អ្វីឡើយ។ នៅក្នុងពេលកន្លងមក ធ្លាប់មានការនិយាយថា ព្រះជាម្ចាស់នឹងជ្រើសរើស ហើយទទួលបានក្រុមនេះ ហើយទ្រង់ប្រោសឲ្យពួកគេបានគ្រប់លក្ខណ៍ នៅគ្រាចុងក្រោយ។ ត្រង់ចំណុចនេះ គឺមានភាពសំខាន់ដ៏អស្ចារ្យ។ បើកិច្ចការដែលទ្រង់អនុវត្តនៅក្នុងអ្នករាល់គ្នាកាន់តែច្រើន នោះសេចក្តីស្រឡាញ់របស់អ្នករាល់គ្នាចំពោះព្រះជាម្ចាស់ គឺកាន់តែជ្រាលជ្រៅ និងបរិសុទ្ធឡើង។ បើកិច្ចការរបស់ព្រះជាម្ចាស់កាន់តែច្រើន មនុស្សកាន់តែអាចយល់ពីព្រះប្រាជ្ញាញាណរបស់ទ្រង់កាន់តែច្រើន ហើយចំណេះដឹងរបស់មនុស្សអំពីទ្រង់ ក៏កាន់តែជ្រាលជ្រៅទៅទៀត។ នៅថ្ងៃចុងក្រោយ ផែនការប្រាំមួយពាន់ឆ្នាំរបស់ព្រះជាម្ចាស់សម្រាប់ការគ្រប់គ្រង នឹងត្រូវបញ្ចប់។ តើវាពិតជាអាចបញ្ចប់ដោយងាយទេ? នៅពេលដែលទ្រង់យកឈ្នះមនុស្ស តើកិច្ចការរបស់ទ្រង់នឹងត្រូវបញ្ចប់ឬ? តើវាសាមញ្ញអ្វីចឹងពេកទេ? មនុស្សពិតជាស្រមៃគិតថា វាសាមញ្ញដូចនេះមែន ប៉ុន្តែអ្វីដែលព្រះជាម្ចាស់ធ្វើ គឺមិនសាមញ្ញអ៊ីចឹងទេ។ មិនថាកិច្ចការរបស់ព្រះជាម្ចាស់ណាមួយនោះទេ គឺមនុស្សមិនអាចយល់បានឡើយ។ ប្រសិនបើអ្នកអាចយល់ពីវាបាន នោះកិច្ចការរបស់ព្រះជាម្ចាស់នឹងគ្មានភាពសំខាន់ ឬ

គ្មានតម្លៃអ្វីទេ។ កិច្ចការដែលព្រះជាម្ចាស់បានធ្វើ គឺមនុស្សមិនអាចយល់បានឡើយ។ វាផ្ទុយពីសញ្ញាណរបស់អ្នកទាំងស្រុង ហើយបើការដែលមិនអាចត្រូវគ្នាជាមួយនឹងសញ្ញាណរបស់អ្នកមានកាន់តែច្រើន នោះបង្ហាញថា កិច្ចការរបស់ព្រះជាម្ចាស់ពិតជាមានន័យមែន។ ប្រសិនបើវាត្រូវគ្នានឹងសញ្ញាណរបស់អ្នក នោះវានឹងគ្មានន័យទេ។ សព្វថ្ងៃនេះ អ្នកមានអារម្មណ៍ថាកិច្ចការរបស់ព្រះជាម្ចាស់ពិតជាអស្ចារ្យណាស់ ហើយបើអ្នកកាន់តែមានអារម្មណ៍ថាវាកាន់តែអស្ចារ្យ នោះអ្នកកាន់តែមានអារម្មណ៍ថាព្រះជាម្ចាស់ជាព្រះដែលយើងមិនអាចយល់បាន ហើយអ្នកនឹងឃើញថាការប្រព្រឹត្តិរបស់ព្រះជាម្ចាស់អស្ចារ្យយ៉ាងណា។ ប្រសិនបើទ្រង់គ្រាន់តែធ្វើការសើៗអោយតែរួចដើម្បីយកឈ្នះលើមនុស្ស ហើយក្រោយមកទៀតមិនធ្វើអ្វីសោះ មនុស្សនឹងមិនអាចមើលឃើញពីភាពសំខាន់ នៃកិច្ចការរបស់ព្រះជាម្ចាស់បានឡើយ។ ថ្វីបើឥឡូវនេះ អ្នកកំពុងទទួលនូវការបន្សុទ្ធបន្តិចបន្តួចក្ដី តែវាមានអត្ថប្រយោជន៍ដ៏ច្រើនចំពោះការរីកលូតលាស់នៅក្នុងជីវិតរបស់អ្នក។ ដូច្នេះវាគឺជាតម្រូវការចាំបាច់បំផុតសម្រាប់អ្នករាល់គ្នាដែលត្រូវឆ្លងកាត់ការលំបាកបែបនេះ។ ថ្ងៃនេះ អ្នកទទួលបានការបន្សុទ្ធបន្តិចបន្តួច ប៉ុន្តែនៅពេលក្រោយ អ្នកនឹងអាចមើលឃើញយ៉ាងពិតប្រាកដអំពីការប្រព្រឹត្តិរបស់ព្រះជាម្ចាស់ ហើយទីបំផុតអ្នកនឹងនិយាយថា៖ «ការប្រព្រឹត្តិរបស់ព្រះជាម្ចាស់ គឺអស្ចារ្យខ្លាំងណាស់!» ទាំងនេះគឺជាព្រះបន្ទូលនៅក្នុងចិត្តរបស់អ្នក។ ដោយមានបទពិសោធនៃការបន្សុទ្ធ ពីព្រះជាម្ចាស់មួយរយៈ (ទុក្ខលំបាករបស់អ្នកដែលបម្រើ និងពេលវេលានៃការវាយផ្ចាល) ទីបំផុត មនុស្សមួយចំនួនបាននិយាយថា «ការជឿលើព្រះជាម្ចាស់ គឺពិតជាពិបាកខ្លាំងណាស់!» ការដែលពួកគេបានប្រើពាក្យថា «ពិតជាពិបាកខ្លាំងណាស់» បង្ហាញឲ្យឃើញថា ការប្រព្រឹត្តិរបស់ព្រះជាម្ចាស់ គឺមិនអាចយល់បានឡើយ ដោយកិច្ចការរបស់ព្រះជាម្ចាស់មានភាពសំខាន់ និងមានគុណតម្លៃយ៉ាងខ្លាំង ហើយកិច្ចការរបស់ទ្រង់ គឺសក្ដិសមនឹងទទួលបានការឲ្យតម្លៃយ៉ាងខ្ពស់ពីមនុស្ស។ បន្ទាប់ពីខ្ញុំបានធ្វើកិច្ចការយ៉ាងច្រើន ប្រសិនបើអ្នកមិនមានចំណេះដឹងបន្តិចសោះ ពេលនោះតើកិច្ចការរបស់ខ្ញុំនឹងនៅតែមានតម្លៃដែរឬទេ? វានឹងធ្វើឲ្យ

អ្នកនិយាយថា៖ «ការបម្រើព្រះជាម្ចាស់ គឺពិតជាពិបាកខ្លាំងណាស់ ការប្រព្រឹត្ត របស់ព្រះជាម្ចាស់គឺអស្ចារ្យណាស់ ហើយព្រះជាម្ចាស់ពិតជាមានព្រះប្រាជ្ញាញាណ មែន! ព្រះជាម្ចាស់គួរឲ្យស្រឡាញ់ណាស់!» បន្ទាប់ពីឆ្លងកាត់បទពិសោធមួយរយៈ មក ប្រសិនបើអ្នកអាចនិយាយពាក្យបែបនេះ នោះការនេះសរបញ្ជាក់ថាអ្នកទទួល បានកិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងអ្នកហើយ។ ថ្ងៃមួយ នៅពេលដែលអ្នកកំពុង ផ្សាយដំណឹងល្អនៅបរទេស ហើយមានគេសួរអ្នកថា៖ តើសេចក្ដីជំនឿរបស់អ្នកលើ ព្រះជាម្ចាស់ទៅជាយ៉ាងណាហើយ? អ្នកនឹងអាចនិយាយថា «សកម្មភាពរបស់ព្រះ ជាម្ចាស់គឺគួរឲ្យស្ញប់ស្ញែង!» ពួកគេនឹងមានអារម្មណ៍ថា ពាក្យរបស់អ្នក និយាយពីបទ ពិសោធជាក់ស្ដែង។ នេះគឺជាការធ្វើបន្ទាល់ដ៏ពិត។ អ្នកនឹងនិយាយថា កិច្ចការរបស់ ព្រះជាម្ចាស់គឺពោរពេញទៅដោយប្រាជ្ញា ហើយកិច្ចការរបស់ទ្រង់ដែលមាននៅក្នុង អ្នក ពិតជាបានធ្វើឲ្យអ្នកជឿជាក់ ហើយយកឈ្នះលើដួងចិត្តរបស់អ្នកបាន។ អ្នកនឹង ស្រឡាញ់ទ្រង់ជានិច្ច ពីព្រោះទ្រង់វិសេសជាងសេចក្ដីស្រឡាញ់របស់មនុស្សទៅទៀត! ប្រសិនបើអ្នកអាចនិយាយរឿងទាំងនេះបាន នោះអ្នកអាចផ្លាស់ប្រែចិត្តមនុស្សបាន ហើយ។ ទាំងអស់នេះ គឺជាការធ្វើបន្ទាល់។ ប្រសិនបើអ្នកអាចធ្វើបន្ទាល់ដោយសូររំពង ដើម្បីឲ្យមនុស្សស្រក់ទឹកភ្នែក នោះបង្ហាញថាអ្នកជាមនុស្សម្នាក់ដែលពិតជាស្រឡាញ់ ព្រះជាម្ចាស់ ដ្បិតអ្នកអាចថ្លែងទីបន្ទាល់ថាស្រឡាញ់ព្រះជាម្ចាស់ ហើយតាមរយៈអ្នក សកម្មភាពរបស់ព្រះជាម្ចាស់ អាចយកជាធ្វើទីបន្ទាល់បាន។ តាមរយៈទីបន្ទាល់របស់ អ្នក អ្នកដទៃត្រូវបានបង្កើតឡើងដើម្បីស្វែងរកកិច្ចការរបស់ព្រះជាម្ចាស់ ដើម្បីទទួល បានបទពិសោធពីកិច្ចការរបស់ព្រះជាម្ចាស់ និងទោះនៅក្នុងបរិស្ថានណាក៏ដោយ ដែលពួកគេភប់ប្រសព្វ ពួកគេនឹងអាចឈរយ៉ាងរឹងមាំបាន។ នេះគឺជាមធ្យោបាយ ដ៏ពិតតែមួយគត់នៃការធ្វើបន្ទាល់ ហើយនេះប្រាកដណាស់ថាជាអ្វីដែលជាសេចក្ដី តម្រូវចំពោះអ្នកឥឡូវនេះ។ អ្នកគប្បីឃើញថា កិច្ចការរបស់ព្រះជាម្ចាស់មានតម្លៃខ្លាំង ណាស់ ហើយសក្ដិសមនឹងទទួលបានការឲ្យតម្លៃយ៉ាងខ្ពស់ពីមនុស្សថា ព្រះជាម្ចាស់ មានតម្លៃខ្លាំងណាស់ ហើយមានបរិបូរក្រៃលែង។ ទ្រង់មិនត្រឹមតែអាចមានព្រះបន្ទូល

នោះទេ ប៉ុន្តែថែមទាំងជំនុំជម្រះមនុស្ស បន្សុទ្ធចិត្តពួកគេ នាំឲ្យពួកគេរីករាយ ទទួលបានពួកគេ ឈ្នះពួកគេ និងប្រោសឲ្យពួកគេបានគ្រប់លក្ខណ៍។ តាមបទពិសោធរបស់អ្នក អ្នកនឹងឃើញថាព្រះជាម្ចាស់គួរឲ្យស្រឡាញ់ខ្លាំងណាស់។ ដូច្នេះតើអ្នកស្រឡាញ់ព្រះជាម្ចាស់ខ្លាំងប៉ុនណាឥឡូវនេះ? តើអ្នកពិតជាអាចនិយាយរឿងទាំងនេះចេញពីបេះដូងអ្នកបានទេ? នៅពេលដែលអ្នកអាចបង្ហាញនូវពាក្យទាំងនេះ ចេញពីជម្រៅចិត្តអ្នក ពេលនោះអ្នកនឹងអាចធ្វើបន្ទាល់បាន។ នៅពេលដែលបទពិសោធរបស់អ្នកឈានដល់កម្រិតនេះ អ្នកនឹងអាចមានសមត្ថភាពធ្វើបន្ទាល់សម្រាប់ព្រះជាម្ចាស់ ហើយអ្នកនឹងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។ ប្រសិនបើបទពិសោធរបស់អ្នកមិនឈានដល់កម្រិតនេះទេ នោះអ្នកនឹងនៅកាន់តែឆ្ងាយ។ វាជារឿងធម្មតាទេដែលមនុស្សបើកបង្ហាញពីភាពទន់ខ្សោយក្នុងកំឡុងពេលដំណើរការបន្សុទ្ធ ប៉ុន្តែបន្ទាប់ពីការបន្សុទ្ធរួចរាល់ហើយ អ្នកគប្បីអាចនិយាយបានថា៖ «ព្រះជាម្ចាស់ពិតជាឈ្លាសវៃណាស់ក្នុងកិច្ចការរបស់ទ្រង់!» ប្រសិនបើអ្នកពិតជាអាចទទួលបាននូវការយល់ដឹងជាក់ស្ដែងនៃពាក្យទាំងនេះ នោះវានឹងត្រឡប់ជាអ្វីដែលអ្នកស្រឡាញ់ខ្លាំងបំផុត ហើយបទពិសោធរបស់អ្នកនឹងមានតម្លៃ។

តើអ្នកគួរស្វែងរកអ្វីឥឡូវនេះ? ទោះបីជាអ្នកអាចមានសមត្ថភាពក្នុងការធ្វើបន្ទាល់ចំពោះកិច្ចការរបស់ព្រះជាម្ចាស់បានឬអត់ ទោះបីជាអ្នកអាចធ្វើអោយមានជាទីបន្ទាល់ និងការជាក់ស្ដែងរបស់ព្រះជាម្ចាស់ឬអត់ ហើយបើទោះជាអ្នកសមនឹងប្រើប្រាស់ដោយទ្រង់ឬអត់ក៏ដោយ ទាំងនេះគឺជាអ្វីដែលអ្នកគប្បីស្វែងរក។ តើព្រះជាម្ចាស់ពិតជាបានធ្វើកិច្ចការច្រើនប៉ុនណានៅក្នុងអ្នក? តើអ្នកបានឃើញប៉ុន្មាន? តើអ្នកបានប៉ះប៉ុន្មាន? តើអ្នកមានបទពិសោធ និងភ្លក្សរសជាតិបានប៉ុន្មានហើយ? មិនថាព្រះជាម្ចាស់បានល្បងលអ្នក ដោះស្រាយជាមួយអ្នក ឬប្រៀនប្រដៅអ្នកនោះទេ សកម្មភាព និងកិច្ចការរបស់ទ្រង់ត្រូវបានធ្វើឡើងសម្រាប់អ្នក។ ប៉ុន្តែក្នុងនាមជាអ្នកជឿលើព្រះជាម្ចាស់ និងជាមនុស្សម្នាក់ដែលមានឆន្ទៈចង់ស្វែងរកឲ្យបានគ្រប់លក្ខណ៍ដោយសារទ្រង់ តើអ្នកអាចធ្វើបន្ទាល់ចំពោះកិច្ចការរបស់ព្រះជាម្ចាស់ ដោយផ្អែកលើបទពិសោធជាក់ស្ដែង

របស់អ្នកឬទេ? តើអ្នកអាចរស់នៅស្របតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ តាមរយៈបទពិសោធជាក់ស្ដែងរបស់អ្នកឬទេ? តើអ្នកអាចផ្ដល់ឲ្យអ្នកដទៃតាមរយៈបទពិសោធជាក់ស្ដែងផ្ទាល់ខ្លួនរបស់អ្នក ហើយលះបង់ពេលពេញមួយជីវិតរបស់អ្នក ដើម្បីធ្វើបន្ទាល់ ចំពោះកិច្ចការរបស់ព្រះជាម្ចាស់ដែរឬទេ? ដើម្បីធ្វើបន្ទាល់អំពីកិច្ចការរបស់ព្រះជាម្ចាស់ អ្នកត្រូវតែពឹងផ្អែកលើបទពិសោធ ចំណេះដឹង និងតម្លៃដែលអ្នកបានបង់។ មានតែធ្វើដូច្នេះទេ ទើបអ្នកអាចផ្គាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់បាន។ តើអ្នកជាមនុស្សម្នាក់ដែលធ្វើបន្ទាល់អំពីកិច្ចការរបស់ព្រះជាម្ចាស់ឬទេ? តើអ្នកមានសេចក្ដីប្រាថ្នានេះទេ? ប្រសិនបើអ្នកអាចធ្វើបន្ទាល់អំពីព្រះនាមទ្រង់ ហើយលើសពីនេះទៅទៀត ធ្វើបន្ទាល់អំពីកិច្ចការរបស់ទ្រង់ ហើយប្រសិនបើអ្នកអាចរស់នៅតាមរូបភាពដែលទ្រង់តម្រូវពីរាស្ត្ររបស់ទ្រង់ នោះអ្នកគឺជាស្មរបន្ទាល់សម្រាប់ព្រះជាម្ចាស់។ តើអ្នកពិតជាធ្វើបន្ទាល់អំពីព្រះជាម្ចាស់យ៉ាងដូចម្ដេច? អ្នកធ្វើវាដោយស្វែងរក និងចង់រស់នៅស្របតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយដោយធ្វើ បន្ទាល់ជាមួយនឹងពាក្យរបស់អ្នក នោះគឺអនុញ្ញាតឲ្យមនុស្សដឹងពីកិច្ចការរបស់ទ្រង់ និងមើលឃើញសកម្មភាពរបស់ទ្រង់។ ប្រសិនបើអ្នកពិតជាស្វែងរករបស់ទាំងនេះមែន នោះព្រះជាម្ចាស់នឹងប្រោសឲ្យអ្នកបានគ្រប់លក្ខណ៍។ ប្រសិនបើអ្វីទាំងអស់ដែលអ្នកស្វែងរក គឺដើម្បីឲ្យបានការប្រោសឲ្យគ្រប់លក្ខណ៍ពីព្រះជាម្ចាស់ ហើយទទួលបានព្រះពរនៅចុងបញ្ចប់ នោះទស្សនៈនៃសេចក្ដីជំនឿរបស់អ្នកលើព្រះជាម្ចាស់ គឺមិនសុទ្ធទេ។ អ្នកគប្បីស្វែងរកវិធីដើម្បីមើលឃើញ ការប្រព្រឹត្តិរបស់ព្រះជាម្ចាស់នៅក្នុងជីវិតពិត របៀបក្នុងការផ្គាប់ព្រះហឫទ័យទ្រង់នៅពេលដែលទ្រង់បើកសម្ដែងពីបំណងព្រះហឫទ័យរបស់ទ្រង់មកកាន់អ្នក និងស្វែងរកវិធីដែលអ្នកគួរធ្វើបន្ទាល់អំពីភាពអស្ចារ្យ និងអំពីព្រះប្រាជ្ញាញាណរបស់ទ្រង់ ហើយនិងរបៀបធ្វើបន្ទាល់អំពីការដែលទ្រង់ប្រៀនប្រដៅ និងដោះស្រាយជាមួយអ្នក។ ទាំងអស់នេះគឺជារឿងដែលអ្នកគប្បីពិចារណា។ ប្រសិនបើសេចក្ដីស្រឡាញ់របស់អ្នកចំពោះព្រះជាម្ចាស់ គឺសម្រាប់តែការដែលអ្នកអាចចែកចាយនូវសិរីរុងរឿងរបស់ព្រះជាម្ចាស់ បន្ទាប់ពីទ្រង់ប្រោសឲ្យអ្នកបានគ្រប់លក្ខណ៍ នោះវា

នៅតែមិនទាន់គ្រប់គ្រាន់ ហើយមិនអាចបំពេញតាមសេចក្ដីតម្រូវរបស់ព្រះជាម្ចាស់នៅឡើយទេ។ អ្នកត្រូវតែអាចធ្វើបន្ទាល់អំពីកិច្ចការរបស់ព្រះជាម្ចាស់ បំពេញតាមការទាមទាររបស់ទ្រង់ និងទទួលយកបទពិសោធអំពីកិច្ចការដែលទ្រង់បានធ្វើចំពោះមនុស្ស តាមរបៀបជាក់ស្ដែង។ មិនថាការឈឺចាប់ ការស្រក់ទឹកភ្នែក ឬការសោកសៅទេ អ្នកត្រូវតែទទួលនូវបទពិសោធនៃរឿងរ៉ាវទាំងអស់នេះ នៅក្នុងការអនុវត្តរបស់អ្នក។ រឿងរ៉ាវទាំងអស់នេះ នឹងនាំឲ្យអ្នកបានគ្រប់លក្ខណ៍ ជាមនុស្សម្នាក់ដែលធ្វើបន្ទាល់អំពីព្រះជាម្ចាស់។ តើឥឡូវនេះ ជាអ្វីឱ្យប្រាកដដែលបង្ខំអ្នកឲ្យរងទុក្ខ ហើយស្វែងរកភាពគ្រប់លក្ខណ៍នោះ? តើការរងទុក្ខបច្ចុប្បន្នរបស់អ្នក ពិតជាដើម្បីប្រយោជន៍ក្នុងការស្រឡាញ់ព្រះជាម្ចាស់ និងធ្វើបន្ទាល់សម្រាប់ទ្រង់មែនទេ? ឬក៏សម្រាប់ជាប្រយោជន៍នៃព្រះពរខាងសាច់ឈាម សម្រាប់សេចក្ដីសង្ឃឹម និងវាសនាអនាគតរបស់អ្នក? គ្រប់ទាំងចេតនា ការលើកទឹកចិត្ត និងគោលដៅទាំងអស់របស់អ្នក ដែលអ្នកខំស្វែងរក ត្រូវតែទទួលបានការកែតម្រូវ ហើយមិនអាចដឹកនាំដោយឆន្ទៈផ្ទាល់ខ្លួនរបស់អ្នកបានឡើយ។ ប្រសិនបើមនុស្សម្នាក់ស្វែងរកភាពគ្រប់លក្ខណ៍ដើម្បីទទួលបានព្រះពរ និងគ្រប់គ្រងអំណាច ខណៈមនុស្សម្នាក់ទៀតស្វែងរកភាពគ្រប់លក្ខណ៍ដើម្បីផ្គាប់ព្រះហឫទ័យព្រះជាម្ចាស់ ដើម្បីធ្វើបន្ទាល់ជាក់ស្ដែងចំពោះកិច្ចការរបស់ព្រះជាម្ចាស់ តើមធ្យោបាយនៃការស្វះស្វែងរកមួយណា ក្នុងចំណោមមធ្យោបាយទាំងពីរ ដែលអ្នកនឹងជ្រើសយក? ប្រសិនបើអ្នកជ្រើសយកទីមួយ នោះអ្នកនឹងនៅឆ្ងាយខ្លាំងណាស់ពីបទដ្ឋានរបស់ព្រះជាម្ចាស់។ ខ្ញុំធ្លាប់មានព្រះបន្ទូលថា សកម្មភាពរបស់ខ្ញុំនឹងត្រូវបានគេដឹងជាចំហនៅទូទាំងសកលលោក ហើយខ្ញុំនឹងសោយរាជ្យជាស្ដេចក្នុងសកលលោក។ ម្យ៉ាងវិញទៀត អ្វីដែលអ្នករាល់គ្នាត្រូវបានប្រគល់សេចក្ដីទុកចិត្តឲ្យធ្វើ នោះគឺត្រូវចេញទៅធ្វើបន្ទាល់ពីកិច្ចការរបស់ព្រះជាម្ចាស់ មិនមែនដើម្បីក្លាយជាស្ដេច ហើយលេចមុខនៅលើសកលលោកទាំងមូលនោះទេ។ ចូរឲ្យការប្រព្រឹត្តិរបស់ព្រះជាម្ចាស់បានបំពេញលោកធាតុ និងលំហអាកាស។ ចូរឲ្យមនុស្សគ្រប់គ្នាបានឃើញការប្រព្រឹត្តទាំងនោះ ហើយទទួលស្គាល់ការប្រព្រឹត្តទាំងនោះ។ ព្រះបន្ទូល

ទាំងនេះ គឺទាក់ទងនឹងព្រះជាម្ចាស់អង្គទ្រង់ផ្ទាល់ ហើយអ្វីដែលមនុស្សគប្បីធ្វើ គឺធ្វើបន្ទាល់អំពីព្រះជាម្ចាស់។ តើឥឡូវនេះ អ្នកស្គាល់ព្រះជាម្ចាស់បានប៉ុនណាហើយ? តើអ្នកអាចធ្វើបន្ទាល់អំពីព្រះជាម្ចាស់បានប៉ុនណា? តើអ្វីទៅជាគោលបំណងរបស់ព្រះជាម្ចាស់ក្នុងការប្រោសឲ្យមនុស្សមានភាពគ្រប់លក្ខណ៍? នៅពេលដែលអ្នកយល់អំពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ តើអ្នកគប្បីបង្ហាញពីការពិចារណាចំពោះបំណងព្រះហឫទ័យរបស់ទ្រង់យ៉ាងដូចម្ដេច? ប្រសិនបើអ្នកមានឆន្ទៈទទួលបានការប្រោសឲ្យបានគ្រប់លក្ខណ៍ និងធ្វើបន្ទាល់អំពីកិច្ចការរបស់ព្រះជាម្ចាស់តាមរយៈអ្វីដែលអ្នករស់នៅ ប្រសិនបើអ្នកមានកំលាំងជំរុញនេះ នោះគ្មានអ្វីដែលពិបាកខ្លាំងនោះទេ។ អ្វីដែលមនុស្សត្រូវការនៅពេលនេះ គឺសេចក្ដីជំនឿ។ ប្រសិនបើអ្នកមានកំលាំងជំរុញនេះ នោះវានឹងមានភាពងាយស្រួលក្នុងការបោះបង់ចោលនូវភាពអវិជ្ជមាន ភាពអកម្ម ភាពខ្ជិលច្រអូស និងសញ្ញាណនៃសាច់ឈាម ទស្សនវិជ្ជានៃការរស់នៅ និស្ស័យបះបោរ អារម្មណ៍ និងអ្វីៗផ្សេងទៀត។

នៅពេលឆ្លងកាត់ការល្បងល វាជារឿងធម្មតាទេដែលមនុស្សនឹងទន់ខ្សោយ ឬមានភាពអវិជ្ជមាននៅក្នុងខ្លួនពួកគេ ឬខ្វះភាពច្បាស់លាស់ ទាក់ទងនឹងបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ឬខ្វះផ្លូវសម្រាប់ការអនុវត្តរបស់ពួកគេ។ ប៉ុន្តែក្នុងករណីណាក៏ដោយ អ្នកត្រូវតែមានសេចក្ដីជំនឿលើកិច្ចការរបស់ព្រះជាម្ចាស់ ហើយមិនត្រូវបដិសេធព្រះជាម្ចាស់ឡើយ គឺដូចជាយ៉ូបដែរ។ ទោះបីជាយ៉ូបខ្សោយ ហើយពោលពាក្យប្រទេចផ្ដាសា ដល់ថ្ងៃកំណើតរបស់ខ្លួនក៏ដោយ ក៏គាត់មិនបានប្រកែកទេថា គ្រប់អ្វីទាំងអស់នៅក្នុងជីវិតមនុស្ស គឺត្រូវបានប្រទានអោយដោយព្រះយេហូវ៉ា ហើយថាព្រះយេហូវ៉ា ក៏ជាអ្នកដែលយករបស់ទាំងនោះចេញទៅវិញដែរ។ មិនថាគាត់ត្រូវបានល្បងលយ៉ាងដូចម្ដេចក៏ដោយ ក៏គាត់នៅតែរក្សាជំនឿនេះដដែល។ នៅក្នុងបទពិសោធរបស់អ្នក មិនថាការបន្សុទ្ធអ្វីក៏ដោយដែលអ្នកឆ្លងកាត់ តាមរយៈព្រះបន្ទូលរបស់ព្រះជាម្ចាស់ អ្វីដែលព្រះជាម្ចាស់តម្រូវពីមនុស្ស ទាក់ទងនឹងជំនឿនោះគឺជាសេចក្ដីជំនឿរបស់ពួកគេ និងសេចក្ដីស្រឡាញ់របស់ពួកគេចំពោះទ្រង់។ អ្វី

ដែលទ្រង់ប្រោសឲ្យមានភាពគ្រប់លក្ខណ៍ដោយធ្វើកិច្ចការតាមរបៀបនេះ គឺជំនឿ សេចក្តីស្រឡាញ់ និងសេចក្តីប្រាថ្នារបស់មនុស្ស។ ព្រះជាម្ចាស់ធ្វើកិច្ចការនៃភាពគ្រប់លក្ខណ៍ដល់មនុស្ស ហើយពួកគេមិនអាចមើលឃើញអំពីកិច្ចការនេះ និងមិនអាចមានអារម្មណ៍អំពីកិច្ចការនេះទេ។ ក្នុងកាលៈទេសៈបែបនេះ អ្នកត្រូវតម្រូវឲ្យមានសេចក្តីជំនឿ។ សេចក្តីជំនឿរបស់មនុស្សត្រូវបានតម្រូវទុក នៅពេលដែលអ្វីមួយមិនអាចមើលឃើញដោយភ្នែកទទេបាន ហើយអ្នកត្រូវតម្រូវឲ្យមានសេចក្តីជំនឿ នៅពេលដែលអ្នកមិនអាចបំបាត់ចោលនូវសញ្ញាណផ្ទាល់ខ្លួនរបស់អ្នកបាន។ នៅពេលដែលអ្នកមិនមានភាពច្បាស់លាស់អំពីកិច្ចការរបស់ព្រះជាម្ចាស់ អ្វីដែលអ្នកត្រូវធ្វើ គឺត្រូវមានសេចក្តីជំនឿ និងប្រកាន់ជំហររឹងមាំ និងធ្វើបន្ទាល់។ នៅពេលដែលយ៉ូបឈានដល់ចំណុចនេះ ព្រះជាម្ចាស់បានលេចមកចំពោះគាត់ ហើយបានមានព្រះបន្ទូលទៅកាន់គាត់។ នោះគឺមានតែចេញពីសេចក្តីជំនឿរបស់អ្នកប៉ុណ្ណោះ ដែលអ្នកនឹងអាចឃើញព្រះជាម្ចាស់ ហើយនៅពេលអ្នកមានសេចក្តីជំនឿ នោះព្រះជាម្ចាស់នឹងប្រោសឲ្យអ្នកបានគ្រប់លក្ខណ៍។ បើគ្មានសេចក្តីជំនឿទេ ទ្រង់មិនអាចធ្វើការនេះបានទេ។ ព្រះជាម្ចាស់នឹងប្រទានដល់អ្នក នូវអ្វីដែលអ្នកសង្ឃឹមថានឹងទទួលបាន។ ប្រសិនបើអ្នកមិនមានសេចក្តីជំនឿទេ នោះអ្នកមិនអាចទទួលបានភាពគ្រប់លក្ខណ៍ទេ ហើយអ្នកនឹងមិនអាចមើលឃើញពីសកម្មភាពរបស់ព្រះជាម្ចាស់ឡើយ ហើយថែមទាំងមិនអាចឃើញ នូវព្រះចេស្ដារបស់ព្រះជាម្ចាស់ទៀតផង។ នៅពេលដែលអ្នកមានសេចក្តីជំនឿថាអ្នកនឹងឃើញសកម្មភាពរបស់ទ្រង់នៅក្នុងបទពិសោធជាក់ស្តែងរបស់អ្នក ពេលនោះព្រះជាម្ចាស់នឹងលេចមកចំពោះអ្នក ហើយទ្រង់នឹងបំភ្លឺ និងដឹកនាំអ្នកពីក្នុងជម្រៅចិត្ត។ បើគ្មានសេចក្តីជំនឿនោះទេ ព្រះជាម្ចាស់នឹងមិនអាចធ្វើការនោះបានឡើយ។ ប្រសិនបើអ្នកបាត់បង់សេចក្តីសង្ឃឹមលើព្រះជាម្ចាស់ តើអ្នកនឹងមានបទពិសោធក្នុងកិច្ចការរបស់ទ្រង់យ៉ាងដូចម្តេចបាន? ដូច្នេះ មានតែនៅពេលដែលអ្នកមានសេចក្តីជំនឿ ហើយអ្នកមិនមានការមន្ទិលសង្ស័យចំពោះព្រះជាម្ចាស់ មានតែនៅពេលអ្នកមានសេចក្តីជំនឿពិតលើទ្រង់ មិនថាទ្រង់ធ្វើអ្វីក៏ដោយ នោះទ្រង់នឹងបំភ្លឺ និងធ្វើឲ្យ

អ្នកយល់ជាក់ តាមរយៈបទពិសោធរបស់អ្នក ហើយមានតែពេលនោះទេ ដែលអ្នកអាចមើលឃើញសកម្មភាពរបស់ទ្រង់។ រឿងទាំងនេះ ត្រូវបានសម្រេចគ្រប់ទាំងអស់តាមរយៈសេចក្ដីជំនឿ។ សេចក្ដីជំនឿកើតឡើងតែតាមរយៈការបន្សុទ្ធប៉ុណ្ណោះ ហើយក្នុងករណីដែលគ្មានការបន្សុទ្ធ នោះសេចក្ដីជំនឿមិនអាចរីកលូតលាស់បានទេ។ តើពាក្យថា «សេចក្ដីជំនឿ» សំដៅទៅលើអ្វី? សេចក្ដីជំនឿ គឺជាការជឿដ៏ពិតប្រាកដ និងចិត្តស្មោះត្រង់ ដែលមនុស្សគប្បីមាន នៅពេលដែលពួកគេមិនអាចមើលឃើញ ឬប៉ះអ្វីមួយ នៅពេលដែលកិច្ចការរបស់ព្រះជាម្ចាស់មិនស្របនឹងសញ្ញាណរបស់មនុស្ស នៅពេលដែលវាហួសពីសមត្ថភាពរបស់មនុស្ស។ នេះហើយគឺជាសេចក្ដីជំនឿដែលខ្ញុំបានមានព្រះបន្ទូលនោះ។ មនុស្សត្រូវការនូវសេចក្ដីជំនឿ ក្នុងអំឡុងពេលមានការលំបាក និងការបន្សុទ្ធ ហើយសេចក្ដីជំនឿ គឺជាអ្វីមួយដែលត្រូវនៅជាប់តាមដោយការបន្សុទ្ធ។ ការបន្សុទ្ធ និងសេចក្ដីជំនឿ មិនអាចដាច់ចេញពីគ្នាបានឡើយ។ មិនថាព្រះជាម្ចាស់ធ្វើកិច្ចការយ៉ាងដូចម្ដេច និងមិនថាបរិយាកាសរបស់អ្នកយ៉ាងណានោះទេ អ្នកអាចស្វែងរកជីវិត និងស្វែងរកសេចក្ដីពិត ហើយស្វែងរកចំណេះដឹងអំពីកិច្ចការរបស់ព្រះជាម្ចាស់ ព្រមទាំងមានការយល់ដឹងអំពីសកម្មភាពរបស់ទ្រង់ ហើយអ្នកអាចធ្វើទៅតាមសេចក្ដីពិត។ ការធ្វើដូច្នេះ គឺជាអ្វីដែលត្រូវមានសេចក្ដីជំនឿដ៏ពិត ហើយការធ្វើដូច្នេះបង្ហាញថា អ្នកមិនបានបាត់បង់សេចក្ដីជំនឿលើព្រះជាម្ចាស់ទេ។ អ្នកអាចមានសេចក្ដីជំនឿដ៏ពិតលើព្រះជាម្ចាស់ ប្រសិនបើអ្នកអាចតស៊ូនៅក្នុងការស្វែងរកសេចក្ដីពិតតាមរយៈការបន្សុទ្ធ ប្រសិនបើអ្នក អាចស្រឡាញ់ព្រះជាម្ចាស់យ៉ាងពិតប្រាកដ ហើយមិនមានការសង្ស័យអំពីទ្រង់ទេ នោះទោះបីជាទ្រង់ធ្វើអ្វីក៏ដោយ ក៏អ្នកនៅតែអនុវត្តនូវសេចក្ដីពិតដើម្បីផ្គាប់ព្រះហឫទ័យទ្រង់ ហើយអ្នកអាចស្វែងរកនូវជម្រៅនៃបំណងព្រះហឫទ័យរបស់ទ្រង់ និងគិតពិចារណា អំពីបំណងព្រះហឫទ័យរបស់ទ្រង់។ កាលពីមុន នៅពេលដែលព្រះជាម្ចាស់មានព្រះបន្ទូលថា អ្នកនឹងសោយរាជ្យជាស្ដេច អ្នកបានស្រឡាញ់ទ្រង់ ហើយនៅពេលដែលទ្រង់ បង្ហាញអង្គទ្រង់ផ្ទាល់ចំពោះអ្នកដោយចំហ អ្នកបានស្វែងរកទ្រង់។ ប៉ុន្តែឥឡូវនេះ ព្រះជាម្ចាស់បានលាក់បាំងអ្នកមិនឲ្យ

មើលឃើញទ្រង់បាន ហើយបញ្ហាបានកើតមានដល់អ្នក តើពេលនោះអ្នកនឹងបាត់បង់នូវសេចក្ដីសង្ឃឹមលើព្រះជាម្ចាស់ឬទេ? ដូច្នេះអ្នកត្រូវតែស្វែងរកជីវិត ហើយព្យាយាមផ្គាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់គ្រប់ពេលវេលា។ នេះហៅថាសេចក្ដីជំនឿដ៏ពិតប្រាកដ ហើយនេះជាប្រភេទនៃសេចក្ដីស្រឡាញ់ដ៏ពិត និងស្រស់ស្អាតបំផុត។

កាលពីអតីតកាល មនុស្សទាំងអស់មករកព្រះជាម្ចាស់ដើម្បីធ្វើការប្ដេជ្ញាចិត្តរបស់ពួកគេ ហើយពួកគេនិយាយថា៖ «ទោះបីគ្មានអ្នកណាផ្សេងស្រឡាញ់ព្រះជាម្ចាស់ក៏ដោយ ក៏ទូលបង្គំត្រូវតែស្រឡាញ់ទ្រង់ដែរ»។ តែឥឡូវនេះ ការបន្សុទ្ធកើតឡើងលើអ្នក ហើយដោយសារការនេះមិនត្រូវនឹងសញ្ញាណរបស់អ្នក នោះអ្នកក៏បាត់បង់សេចក្ដីជំនឿលើព្រះជាម្ចាស់។ តើសេចក្ដីស្រឡាញ់នេះពិតឬអត់? អ្នកបានអានជាច្រើនដងហើយអំពីការប្រព្រឹត្តិរបស់យ៉ូប តើអ្នកបានភ្លេចអំពីការប្រព្រឹត្តិទាំងនោះទេឬ? សេចក្ដីស្រឡាញ់ពិតអាចលេចចេញជារូបរាងបានពីសេចក្ដីជំនឿ។ អ្នកបណ្ដុះសេចក្ដីស្រឡាញ់ដ៏ពិតសម្រាប់ព្រះជាម្ចាស់ តាមរយៈការបន្សុទ្ធដែលអ្នកបានឆ្លងកាត់ ហើយតាមរយៈជំនឿរបស់អ្នក អ្នកអាចគិតពិចារណាដល់បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ នៅក្នុងបទពិសោធជាក់ស្ដែងរបស់អ្នក ហើយវាក៏តាមរយៈសេចក្ដីជំនឿ ដែលអ្នកបោះបង់ចោលសាច់ឈាមរបស់អ្នកផ្ទាល់ ហើយស្វែងរកជីវិត។ នេះគឺជាអ្វីដែលមនុស្សគប្បីធ្វើ។ ប្រសិនបើអ្នកធ្វើការនេះ ពេលនោះអ្នកនឹងអាចឃើញសកម្មភាពរបស់ព្រះជាម្ចាស់ ប៉ុន្តែប្រសិនបើអ្នកខ្វះសេចក្ដីជំនឿ នោះអ្នកនឹងមិនអាចមើលឃើញពីសកម្មភាពរបស់ព្រះជាម្ចាស់ ឬទទួលបទពិសោធពីកិច្ចការរបស់ទ្រង់ឡើយ។ ប្រសិនបើអ្នកចង់ត្រូវបានប្រើ និងត្រូវបានប្រោសឲ្យបានគ្រប់លក្ខណ៍ដោយព្រះជាម្ចាស់ នោះអ្នកត្រូវតែមានអ្វីៗទាំងអស់ដូចជា៖ ឆន្ទៈក្នុងការរងទុក្ខ សេចក្ដីជំនឿ ការស៊ូទ្រាំ ការស្ដាប់បង្គាប់ និងសមត្ថភាពក្នុងការទទួលពិសោធកិច្ចការរបស់ព្រះជាម្ចាស់ យល់ពីព្រះហឫទ័យរបស់ទ្រង់ ពិចារណាពីទុក្ខព្រួយរបស់ទ្រង់ជាដើម។ ការធ្វើឲ្យមនុស្សបានគ្រប់លក្ខណ៍ គឺមិនងាយស្រួលនោះទេ ហើយរាល់ការបន្សុទ្ធនីមួយៗដែលអ្នកជួបប្រទះ តម្រូវឲ្យមានជំនឿ និងសេចក្ដីស្រឡាញ់។ ប្រសិនបើអ្នក

ចង់ទទួលបានភាពគ្រប់លក្ខណ៍ពីព្រះជាម្ចាស់ វាមិនគ្រប់គ្រាន់ទេក្នុងការដែលគ្រាន់តែឆ្ពោះទៅមុខនៅលើផ្លូវ ហើយវាមិនគ្រប់គ្រាន់ដែរ ក្នុងការដែលគ្រាន់តែលះបង់ខ្លួនឯងសម្រាប់ព្រះជាម្ចាស់នោះ។ អ្នកត្រូវតែមានរបស់ជាច្រើនដើម្បីអាចក្លាយជាមនុស្សម្នាក់ដែលត្រូវបានធ្វើឲ្យគ្រប់លក្ខណ៍ដោយព្រះជាម្ចាស់។ នៅពេលដែលអ្នកប្រឈមមុខនឹងការរងទុក្ខ អ្នកត្រូវតែអាចទុកនូវកង្វល់ខាងសាច់ឈាមមួយឡែក ហើយកុំត្អូញត្អែរប្រឆាំងនឹងព្រះជាម្ចាស់។ នៅពេលដែលព្រះជាម្ចាស់លាក់អង្គទ្រង់ពីអ្នក អ្នកត្រូវតែអាចមានជំនឿ ដើម្បីដើរតាមទ្រង់ ដើម្បីរក្សាសេចក្ដីស្រឡាញ់ពីមុនរបស់អ្នកដោយមិនឲ្យវារសាត់ចេញ ឬរលាយបាត់ឡើយ។ មិនថាព្រះជាម្ចាស់ធ្វើយ៉ាងដូចម្ដេចទេ អ្នកត្រូវតែចុះចូលនឹងការរចនារបស់ទ្រង់ ហើយត្រៀមដាក់បណ្ដាសាសាច់ឈាមរបស់អ្នកផ្ទាល់ ជាជាងការត្អូញត្អែរទាស់ប្រឆាំងនឹងទ្រង់។ នៅពេលដែលអ្នកប្រឈមនឹងការល្បងល អ្នកត្រូវតែផ្គាប់ព្រះហឫទ័យព្រះជាម្ចាស់ ទោះបីអ្នកអាចនឹងយំយ៉ាងជូរចត់ ឬមានអារម្មណ៍ស្ទាក់ស្ទើរ ក្នុងការផ្ដាច់ខ្លួនចេញពីវត្ថុដែលជាទីស្រឡាញ់ខ្លះក៏ដោយ។ មានតែការនេះទេ ដែលជាសេចក្ដីស្រឡាញ់ និងសេចក្ដីជំនឿដ៏ពិត។ មិនថាកម្ពស់ជាក់ស្ដែងរបស់អ្នកប៉ុនណានោះទេ ជាដំបូងអ្នកត្រូវតែមានទាំងឆន្ទៈដើម្បីរងទុក្ខលំបាក និងសេចក្ដីជំនឿដ៏ពិត ហើយអ្នកក៏ត្រូវមានឆន្ទៈក្នុងការលះបង់នូវសាច់ឈាមផងដែរ។ អ្នកគប្បីមានឆន្ទៈស៊ូទ្រាំការលំបាកផ្ទាល់ខ្លួន ហើយទទួលរងនូវការខាតបង់ចំពោះផលប្រយោជន៍ផ្ទាល់ខ្លួនរបស់អ្នក ដើម្បីផ្គាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់។ អ្នកក៏ត្រូវតែមានសមត្ថភាពក្នុងការមានអារម្មណ៍សោកស្ដាយចំពោះខ្លួនឯងនៅក្នុងចិត្តផងដែរ៖ កាលពីអតីតកាល អ្នកមិនអាចផ្គាប់ព្រះហឫទ័យព្រះជាម្ចាស់ ហើយឥឡូវនេះអ្នកអាចសោកស្ដាយខ្លួនឯងបាន។ អ្នកមិនត្រូវខ្វះខាតក្នុងការទាំងនោះណាមួយទេ វាគឺតាមរយៈការទាំងនេះ ដែលព្រះជាម្ចាស់នឹងធ្វើឲ្យអ្នកបានគ្រប់លក្ខណ៍។ ប្រសិនបើអ្នកមិនអាចបំពេញតាមលក្ខខណ្ឌទាំងនេះទេ នោះអ្នកមិនអាចទទួលបានភាពគ្រប់លក្ខណ៍នោះឡើយ។

នរណាដែលបម្រើព្រះជាម្ចាស់ មិនត្រឹមតែដឹងពីរបៀបនៃការរងទុក្ខសម្រាប់ទ្រង់

ប៉ុណ្ណោះទេ។ លើសពីនេះទៅទៀត ពួកគេគប្បីយល់ថា គោលបំណងនៃការជឿលើព្រះជាម្ចាស់ គឺដើម្បីស្វែងរកសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់។ ព្រះជាម្ចាស់ប្រើអ្នក មិនត្រឹមតែដើម្បីបន្សុទ្ធអ្នក ឬដើម្បីជាប្រយោជន៍ដើម្បីឲ្យអ្នករងទុក្ខនោះទេ ប៉ុន្តែព្រះជាម្ចាស់ប្រើអ្នកដើម្បីឲ្យអ្នកដឹងពីសកម្មភាពរបស់ទ្រង់ ដឹងពីភាពសំខាន់ដ៏ពិតអំពីជីវិតមនុស្ស ហើយជាពិសេស ដើម្បីឲ្យអ្នកអាចដឹងថាការបម្រើព្រះជាម្ចាស់មិនមែនជាកិច្ចការងាយស្រួលទេ។ ការទទួលពិសោធន៍អំពីកិច្ចការរបស់ព្រះជាម្ចាស់ មិនមែនដើម្បីរីករាយនឹងព្រះគុណទេ តែជាការរងទុក្ខចំពោះសេចក្ដីស្រឡាញ់របស់អ្នកចំពោះទ្រង់។ ដោយព្រោះអ្នករីករាយនឹងព្រះគុណរបស់ព្រះជាម្ចាស់ អ្នកក៏ត្រូវរីករាយនឹងការវាយផ្ចាលរបស់ទ្រង់ផងដែរ។ អ្នកត្រូវតែមានបទពិសោធអំពីការទាំងអស់នេះ។ អ្នកអាចទទួលបាននូវបទពិសោធអំពីការបំភ្លឺរបស់ព្រះជាម្ចាស់នៅក្នុងអ្នក ហើយអ្នកក៏អាចមានបទពិសោធពីរបៀបដែលទ្រង់ដោះស្រាយជាមួយអ្នក និងជំនុំជម្រះអ្នកផងដែរ។ តាមវិធីនេះ បទពិសោធរបស់អ្នកនឹងមានលក្ខណៈទូលំទូលាយ។ ព្រះជាម្ចាស់បានអនុវត្តនូវកិច្ចការរបស់ទ្រង់អំពីការជំនុំជម្រះ និងការវាយផ្ចាល់មកលើអ្នក។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់បានដោះស្រាយជាមួយអ្នក ប៉ុន្តែមិនត្រឹមតែប៉ុណ្ណោះទេ ព្រះបន្ទូលក៏បានបំភ្លឺ និងធ្វើឲ្យអ្នកយល់ច្បាស់ផងដែរ។ នៅពេលដែលអ្នកមានភាពអវិជ្ជមាន និងខ្សោយ ព្រះជាម្ចាស់បារម្ភពីអ្នក។ គ្រប់កិច្ចការទាំងអស់នេះ គឺដើម្បីឲ្យអ្នកដឹងថាអ្វីៗទាំងអស់អំពីមនុស្ស គឺស្ថិតនៅក្នុងផែនការដែលព្រះជាម្ចាស់បានរៀបចំ។ អ្នកប្រហែលជាគិតថា ការជឿលើព្រះជាម្ចាស់ គឺជាការរងទុក្ខ ឬការធ្វើអ្វីៗគ្រប់យ៉ាងសម្រាប់ទ្រង់។ អ្នកអាចគិតថា គោលបំណងនៃការជឿលើព្រះជាម្ចាស់ គឺដើម្បីឲ្យសាច់ឈាមរបស់អ្នកមានសេចក្ដីសុខសាន្ត ឬដើម្បីឲ្យអ្វីៗនៅក្នុងជីវិតរបស់អ្នកដំណើរការទៅដោយរលូន ឬដើម្បីឲ្យអ្នកមានផាសុកភាព និងមានភាពងាយស្រួលក្នុងគ្រប់រឿងទាំងអស់។ ទោះយ៉ាងណាក៏ដោយ គោលបំណងទាំងនេះ គ្មានគោលបំណងណាដែលមនុស្សគប្បីភ្ជាប់ទៅនឹងជំនឿរបស់ពួកគេលើព្រះជាម្ចាស់នោះឡើយ។ ប្រសិនបើអ្នកជឿលើគោលបំណងទាំងនេះ នោះទស្សនៈ

របស់អ្នកមិនត្រឹមត្រូវទេ ហើយវាមិនអាចទៅរួចទេដែលអ្នកអាចទទួលបាននូវភាពគ្រប់លក្ខណ៍នោះ។ សកម្មភាពរបស់ព្រះជាម្ចាស់ និស្ស័យដ៏សុចរិតរបស់ព្រះជាម្ចាស់ ប្រាជ្ញារបស់ទ្រង់ ព្រះបន្ទូលរបស់ទ្រង់ និងភាពអស្ចារ្យរបស់ទ្រង់ និងភាពដែលមិនអាចវាស់ស្ទង់បានរបស់ទ្រង់ គឺជាអ្វីទាំងអស់ដែលមនុស្សគួរតែយល់។ ដោយយល់ពីការនេះហើយ អ្នកគប្បីប្រើវាដើម្បីឲ្យចិត្តអ្នកផ្ដាច់ចេញពីការទាមទារ ពីក្ដីសង្ឃឹម និងពីសញ្ញាណផ្ទាល់ខ្លួនទាំងអស់។ មានតែការផាត់ចោលនូវការទាំងអស់នេះទេ ទើបអ្នកអាចបំពេញទៅតាមលក្ខខណ្ឌដែលតម្រូវដោយព្រះជាម្ចាស់ ហើយមានតែការធ្វើបែបនេះទេ ដែលអ្នកអាចមានជីវិត និងផ្គាប់ព្រះហឫទ័យព្រះជាម្ចាស់បាន។ គោលបំណងនៃការជឿលើព្រះជាម្ចាស់ គឺដើម្បីផ្គាប់ព្រះហឫទ័យដល់ទ្រង់ និងដើម្បីរស់នៅស្របទៅតាមនិស្ស័យដែលទ្រង់តម្រូវ ដើម្បីឲ្យសកម្មភាព និងសិរីល្អរបស់ទ្រង់ ត្រូវបានសម្ដែងចេញតាមរយៈក្រុមមនុស្សមិនសក្តិសមនឹងទទួលនេះ។ នេះគឺជាទស្សនវិស័យដ៏ត្រឹមត្រូវ ចំពោះការជឿលើព្រះជាម្ចាស់ ហើយនេះក៏ជាគោលដៅដែលអ្នកគប្បីស្វែងរកផងដែរ។ អ្នកគប្បីមានទស្សនៈត្រឹមត្រូវអំពីការជឿលើព្រះជាម្ចាស់ ហើយអ្នកគប្បីស្វែងរកដើម្បីទទួលបានព្រះបន្ទូលរបស់ព្រះជាម្ចាស់។ អ្នកត្រូវតែហូប និងផឹកព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយអ្នកត្រូវតែអាចរស់នៅទៅតាមសេចក្ដីពិត ហើយជាពិសេស អ្នកត្រូវតែអាចមើលឃើញការជាក់ស្ដែងរបស់ទ្រង់ ការដ៏អស្ចារ្យរបស់ទ្រង់នៅពាសពេញសកលលោក ក៏ដូចជាកិច្ចការជាក់ស្ដែងដែលទ្រង់ធ្វើនៅក្នុងភាពជាសាច់ឈាម។ តាមរយៈបទពិសោធជាក់ស្ដែងរបស់ពួកគេ មនុស្សអាចកោតសរសើរចំពោះរបៀបដែលព្រះជាម្ចាស់ធ្វើកិច្ចការរបស់ទ្រង់ចំពោះពួកគេ និងអ្វីដែលជាបំណងព្រះហឫទ័យរបស់ទ្រង់ចំពោះពួកគេ។ គោលបំណងនៃការទាំងអស់នេះ គឺដើម្បីផាត់ចោលនូវនិស្ស័យរបស់មនុស្សដែលពុករលួយបែបសាតាំង។ ដោយបានបោះចោលនូវភាពស្មោកគ្រោក និងអំពើទុច្ចរិតទាំងប៉ុន្មាននៅខាងក្នុងអ្នក ហើយបោះចោលចេតនាដែលមិនត្រឹមត្រូវរបស់អ្នក និងបានលូតលាស់នូវសេចក្ដីជំនឿដ៏ពិតលើព្រះជាម្ចាស់ មានតែសេចក្ដីជំនឿដ៏ពិតប៉ុណ្ណោះ ទើបអ្នកអាចស្រឡាញ់ព្រះជាម្ចាស់

ដ៏ពិតប្រាកដបាន។ អ្នកអាចស្រឡាញ់ព្រះជាម្ចាស់ពិតប្រាកដលើគ្រឹះនៃជំនឿរបស់អ្នកនៅក្នុងទ្រង់។ តើអ្នកអាចសម្រេចបានសេចក្ដីស្រឡាញ់ចំពោះព្រះជាម្ចាស់ ដោយមិនជឿលើទ្រង់ដែរទេ? ដោយសារអ្នកជឿលើព្រះជាម្ចាស់ អ្នកមិនអាចភ័ន្តច្រឡំអំពីរឿងនេះបានទេ។ មនុស្សខ្លះមានកម្លាំងពេញលេញ នៅពេលពួកគេឃើញថាសេចក្ដីជំនឿលើព្រះជាម្ចាស់នឹងនាំមកនូវព្រះពរដល់ពួកគេ ប៉ុន្តែបន្ទាប់មកពួកគេបាត់បង់ថាមពលទាំងអស់ នៅពេលពួកគេឃើញថាពួកគេត្រូវរងទុក្ខនូវការបន្សុទ្ធ។ តើនោះជាការជឿលើព្រះជាម្ចាស់ទេ? នៅទីបំផុត អ្នកត្រូវតែទទួលបានការស្ដាប់បង្គាប់ពេញលេញ និងទាំងស្រុង នៅចំពោះព្រះជាម្ចាស់ដោយជំនឿរបស់អ្នក។ អ្នកជឿលើព្រះជាម្ចាស់ ប៉ុន្តែអ្នកនៅតែមានការទាមទារពីទ្រង់ មានសញ្ញាណខាងសាសនាជាច្រើនដែលអ្នកមិនអាចផ្ដាច់ខ្លួនចេញ ផលប្រយោជន៍ផ្ទាល់ខ្លួនដែលអ្នកមិនអាចបោះបង់ចោល ហើយអ្នកនៅតែស្វែងរកព្រះពរខាងសាច់ឈាម ហើយចង់ឲ្យព្រះជាម្ចាស់ជួយសង្គ្រោះសាច់ឈាមអ្នក ដើម្បីសង្គ្រោះព្រលឹងអ្នក ទាំងនេះគឺជាឥរិយាបថរបស់មនុស្សដែលមានទស្សនៈខុសឆ្គង។ ទោះបីជាមនុស្សដែលមានជំនឿលើសាសនា មានជំនឿលើព្រះជាម្ចាស់ក៏ដោយ ពួកគេមិនស្វែងរកការផ្លាស់ប្ដូរនូវនិស្ស័យរបស់ពួកគេ ហើយមិនស្វែងរកចំណេះដឹងអំពីព្រះជាម្ចាស់ទេ ផ្ទុយទៅវិញ ពួកគេស្វែងរកតែផលប្រយោជន៍ខាងសាច់ឈាមរបស់ពួកគេប៉ុណ្ណោះ។ មនុស្សជាច្រើនក្នុងចំណោមអ្នករាល់គ្នា មានសេចក្ដីជំនឿដែលជាផ្នែកនៃជំនឿសាសនា។ នេះមិនមែនជាសេចក្ដីជំនឿដ៏ពិតចំពោះព្រះជាម្ចាស់នោះទេ។ ដើម្បីជឿលើព្រះជាម្ចាស់ មនុស្សត្រូវតែមានដួងចិត្តដែលត្រៀមរងទុក្ខលំបាកសម្រាប់ទ្រង់ និងមានឆន្ទៈលះបង់ខ្លួនឯង។ ដរាបណាមនុស្សមិនបំពេញនូវលក្ខខណ្ឌទាំងពីរនេះ នោះជំនឿរបស់ពួកគេលើព្រះជាម្ចាស់ មិនមានសុពលភាពទេ ហើយពួកគេនឹងមិនអាចសម្រេចបានការផ្លាស់ប្ដូរនិស្ស័យរបស់ពួកគេឡើយ។ មានតែមនុស្សដែលស្វែងរកសេចក្ដីពិតដ៏ពិតប្រាកដ ស្វែងរកចំណេះដឹងពីព្រះជាម្ចាស់ ហើយស្វែងរកជីវិតនោះទេ ទើបជាអ្នកដែលជឿលើព្រះជាម្ចាស់ដ៏ពិត។

នៅពេលមានការល្បួងលកើតឡើងចំពោះអ្នក តើអ្នកនឹងអនុវត្តកិច្ចការរបស់ព្រះជា

ម្ចាស់ ក្នុងការចាត់ចែងការល្បងលទាំងនោះយ៉ាងដូចម្តេច? តើអ្នកនឹងមានភាពអវិជ្ជមាន ឬតើអ្នកនឹងយល់ពីការល្បងល និងការបន្សុទ្ធរបស់ព្រះជាម្ចាស់អំពីមនុស្ស ដែលចេញពីភាពវិជ្ជមានឬទេ? តើអ្នកនឹងទទួលបានអ្វីខ្លះ តាមរយៈការល្បងល និងការបន្សុទ្ធរបស់ព្រះជាម្ចាស់? តើសេចក្តីស្រឡាញ់របស់អ្នកចំពោះព្រះជាម្ចាស់ នឹងរីកលូតលាស់ឬទេ? នៅពេលដែលអ្នកត្រូវទទួលការបន្សុទ្ធ តើអ្នកនឹងអាចអនុវត្តការល្បងលរបស់យ៉ូប ហើយចូលរួមដោយស្មោះអស់ពីចិត្ត ជាមួយនឹងកិច្ចការដែលព្រះជាម្ចាស់បានធ្វើនៅក្នុងអ្នកដែរឬទេ? តើអ្នកអាចមើលឃើញពីរបៀបដែលព្រះជាម្ចាស់សាកល្បងមនុស្ស តាមរយៈការល្បងលចំពោះយ៉ូបឬទេ? តើការជម្រុញទឹកចិត្តប្រភេទណា ដែលអាចធ្វើឲ្យការល្បងលរបស់យ៉ូប មានចំពោះអ្នក? តើអ្នកនឹងសុខចិត្តឈរធ្វើបន្ទាល់អំពីព្រះជាម្ចាស់ នៅក្នុងការការបន្សុទ្ធរបស់អ្នក ឬតើអ្នកចង់ផ្គាប់ចិត្តខាងសាច់ឈាមនៅក្នុងបរិយាកាសសុខស្រួលឬ? តើទស្សនៈរបស់អ្នកលើជំនឿចំពោះព្រះជាម្ចាស់ជាអ្វី? តើវាពិតប្រាកដសម្រាប់ទ្រង់ ហើយមិនមែនសម្រាប់សាច់ឈាមទេឬ? តើអ្នកពិតជាមានទីដៅមួយដែលអ្នកស្វែងរក នៅក្នុងការស្វែងរករបស់អ្នកឬទេ? តើអ្នកមានបំណងចង់ឆ្លងកាត់ការបន្សុទ្ធ ដើម្បីឲ្យអ្នកមានភាពគ្រប់លក្ខណ៍ពីព្រះជាម្ចាស់ ឬតើអ្នកចង់បានការវាយផ្ចាល និងការដាក់បណ្តាសាពីព្រះជាម្ចាស់? តើអ្វីជាទស្សនៈពិតរបស់អ្នក ទាក់ទងនឹងការធ្វើបន្ទាល់អំពីព្រះជាម្ចាស់? តើមនុស្សគប្បីប្រព្រឹត្តអ្វីខ្លះ នៅក្នុងមជ្ឈដ្ឋានជាក់លាក់មួយ ដើម្បីធ្វើបន្ទាល់ដ៏ពិតអំពីព្រះជាម្ចាស់? ចាប់តាំងពីព្រះជាម្ចាស់ដ៏ជាក់ស្តែង បានបើកសម្តែងយ៉ាងច្រើននៅក្នុងកិច្ចការជាក់ស្តែងរបស់ទ្រង់នៅក្នុងអ្នក ហេតុអ្វីបានជាអ្នកតែងតែមានគំនិតចង់ចាកចេញ? តើជំនឿរបស់អ្នកលើព្រះជាម្ចាស់ គឺសម្រាប់ព្រះជាម្ចាស់ឬទេ? សម្រាប់អ្នករាល់គ្នាភាគច្រើន ជំនឿរបស់អ្នក គឺជាផ្នែកមួយនៃការគណនា ដែលអ្នកធ្វើឡើងក្នុងនាមខ្លួនអ្នក ដើម្បីស្វែងរកនូវផលប្រយោជន៍ផ្ទាល់ខ្លួនរបស់អ្នក។ មានមនុស្សតិចតួចណាស់ដែលជឿលើព្រះជាម្ចាស់ សម្រាប់ព្រះជាម្ចាស់។ តើនេះមិនមែនជាការបះបោរទេឬ?

គោលបំណងចម្បងចំពោះកិច្ចការនៃការបន្សុទ្ធ គឺដើម្បីប្រោសឲ្យសេចក្តីជំនឿ

របស់មនុស្សបានគ្រប់លក្ខណ៍។ នៅចុងបញ្ចប់ អ្វីដែលសម្រេចបាន គឺថាអ្នកចង់ចាកចេញ ប៉ុន្តែក្នុងពេលជាមួយគ្នានេះ អ្នកមិនអាចទេ។ មនុស្សខ្លះនៅតែអាចមានសេចក្តីជំនឿ ទោះបីនៅពេលដែលពួកគេឥតមានសេចក្តីសង្ឃឹមសូម្បីតែបន្តិច។ ហើយមនុស្សលែងមានសង្ឃឹមទាល់តែសោះ ទាក់ទងនឹងលទ្ធភាពដែលអាចធ្វើបាននៃអនាគតរបស់ពួកគេផ្ទាល់។ មានតែពេលនេះទេដែលការបន្សុទ្ធរបស់ព្រះជាម្ចាស់ត្រូវបានបញ្ចប់។ មនុស្សនៅតែមិនទាន់ឈានដល់ដំណាក់កាលនៃការរិលរល់ រវាងជីវិត និងសេចក្តីស្លាប់ ហើយពួកគេមិនបានភ្លក់សេចក្តីស្លាប់ទេ ដូច្នេះដំណើរការនៃការបន្សុទ្ធ មិនទាន់ត្រូវបានបញ្ចប់នៅឡើយ។ ទោះបីអ្នកទាំងនោះស្ថិតនៅក្នុងជំហាននៃអ្នកស៊ីឈ្នួលក៏ដោយ ក៏មិនត្រូវបានបន្សុទ្ធឲ្យប្រសើរបំផុតដែរ។ យ៉ូបបានឆ្លងកាត់ការបន្សុទ្ធដ៏ធំធេង ហើយគាត់មិនមានអ្វីដែលត្រូវពឹងផ្អែកនោះទេ។ មនុស្សត្រូវឆ្លងកាត់ការបន្សុទ្ធ រហូតដល់ចំណុចមួយដែលពួកគេមិនមានសេចក្តីសង្ឃឹម និងគ្មានអ្វីត្រូវពឹងផ្អែកលើ មានតែការធ្វើដូចនេះទេ ទើបជាការបន្សុទ្ធដ៏ពិតប្រាកដ។ ក្នុងអំឡុងពេលនៃអ្នកស៊ីឈ្នួល ប្រសិនបើចិត្តរបស់អ្នកតែងតែស្ងប់ នៅចំពោះព្រះជាម្ចាស់ជានិច្ច ហើយបើទោះបីជាទ្រង់បានធ្វើអ្វី និងមិនថាជាបំណងព្រះហឫទ័យរបស់ទ្រង់ចំពោះអ្នកយ៉ាងណាក៏ដោយ អ្នកតែងតែគោរពតាមការរៀបចំរបស់ទ្រង់ជានិច្ច ពេលនោះ នៅចុងបញ្ចប់នៃផ្លូវ អ្នកនឹងយល់អ្វីៗទាំងអស់ដែលព្រះជាម្ចាស់បានធ្វើ។ អ្នកបានឆ្លងកាត់ការល្បងលរបស់យ៉ូប ហើយនៅពេលដំណាលគ្នា អ្នកត្រូវឆ្លងកាត់ការល្បងលរបស់ពេត្រុស។ ពេលយ៉ូបត្រូវល្បងល គាត់បានធ្វើបន្ទាល់ ហើយនៅទីបំផុត ព្រះយេហូវ៉ាបានបើកសម្ដែងដល់គាត់។ មានតែបន្ទាប់ពីគាត់បានធ្វើបន្ទាល់ប៉ុណ្ណោះ នោះទើបគាត់សមនឹងឃើញព្រះភក្ត្ររបស់ព្រះជាម្ចាស់។ ហេតុអ្វីបានមានព្រះបន្ទូលថា៖ «ខ្ញុំលាក់ខ្លួនពីទឹកដីដ៏ស្មោកគ្រោក តែបង្ហាញអង្គខ្ញុំដល់នគរដ៏បរិសុទ្ធ?» នោះមានន័យថា មានតែពេលដែលអ្នកបរិសុទ្ធ ហើយឈរធ្វើបន្ទាល់នោះទេ ទើបអ្នកអាចមានកិត្តិយសក្នុងការមើលឃើញព្រះភក្ត្ររបស់ព្រះជាម្ចាស់បាន។ ប្រសិនបើអ្នក មិនអាចឈរធ្វើបន្ទាល់អំពីទ្រង់បានទេ អ្នកមិនមានកិត្តិយសក្នុងការមើលឃើញព្រះភក្ត្រទ្រង់

បានទេ។ ប្រសិនបើអ្នកដកថយ ឬតវ៉ាប្រឆាំងនឹងព្រះជាម្ចាស់នៅពេលធ្វើការបន្សុទ្ធ បរាជ័យក្នុងការឈរធ្វើបន្ទាល់អំពីទ្រង់ ហើយក្លាយជាមនុស្សល្ងីល្ងើរបស់សាតាំង នោះអ្នកនឹងមិនអាចទទួលបាននូវការលេចមករបស់ព្រះជាម្ចាស់ឡើយ។ ប្រសិនបើអ្នកដូចជាយ៉ូបដែលស្ថិតក្នុងការល្បងល ដោយបានដាក់បណ្ដាសាចំពោះសាច់ឈាមរបស់ខ្លួនគាត់ផ្ទាល់ ហើយមិនបានត្អូញត្អែរទាស់ប្រឆាំងនឹងព្រះជាម្ចាស់ ហើយអាចស្អប់សាច់ឈាមរបស់គាត់ផ្ទាល់ ដោយមិនត្អូញត្អែរ ឬប្រព្រឹត្តបាបតាមរយៈពាក្យសម្ដីរបស់គាត់ នោះអ្នកនឹងអាចឈរធ្វើបន្ទាល់បាន។ នៅពេលដែលអ្នកឆ្លងកាត់ការបន្សុទ្ធក្នុងកម្រិតមួយ ហើយនៅតែអាចដូចយ៉ូប ដោយស្ដាប់បង្គាប់ទាំងស្រុងនៅចំពោះព្រះជាម្ចាស់ និងដោយគ្មានសេចក្ដីតម្រូវផ្សេងទៀតពីទ្រង់ ឬពីសញ្ញាណផ្ទាល់ខ្លួនរបស់អ្នកទេ នោះព្រះជាម្ចាស់នឹងលេចមកឯអ្នក។ ឥឡូវព្រះជាម្ចាស់មិនលេចមករកអ្នកទេ ពីព្រោះអ្នកមានទស្សនៈផ្ទាល់ខ្លួនច្រើនមែនទែន មានការរើសអើងផ្ទាល់ខ្លួន មានគំនិតអាត្មានិយម មានសេចក្ដីតម្រូវផ្ទាល់ខ្លួន និងមានផលប្រយោជន៍ខាងសាច់ឈាម ហើយអ្នកមិនសមនឹងឃើញព្រះភ័ក្ត្ររបស់ទ្រង់ទេ។ បើអ្នកនឹងបានឃើញព្រះជាម្ចាស់ អ្នកនឹងវាស់ស្ទង់ទ្រង់តាមសញ្ញាណផ្ទាល់ខ្លួនរបស់អ្នក ហើយដោយការធ្វើដូច្នេះ ទ្រង់នឹងត្រូវឆ្កាងនៅលើឈើឆ្កាងដោយអ្នក។ ប្រសិនបើមានរឿងជាច្រើនកើតឡើងមកលើអ្នក ដែលមិនត្រូវនឹងសញ្ញាណរបស់អ្នក ប៉ុន្តែអ្នកអាចដាក់ទុកវាមួយឡែក និងទទួលបានចំណេះដឹងអំពីសកម្មភាពរបស់ព្រះជាម្ចាស់ពីការទាំងនេះ ហើយប្រសិនបើនៅកណ្ដាលការបន្សុទ្ធ អ្នកបង្ហាញដួងចិត្តនៃសេចក្ដីស្រឡាញ់របស់អ្នក ចំពោះព្រះជាម្ចាស់ នោះការនេះគឺជាការធ្វើបន្ទាល់។ ប្រសិនបើផ្ទះរបស់អ្នកមានសេចក្ដីសុខសាន្ត អ្នករីករាយនឹងភាពសុខដុមខាងសាច់ឈាម គ្មាននរណាម្នាក់បៀតបៀនអ្នក ហើយបងប្អូនប្រុសស្រីរបស់អ្នកនៅក្នុងពួកជំនុំស្ដាប់បង្គាប់អ្នក តើអ្នកអាចបង្ហាញនូវចិត្តនៃក្ដីស្រឡាញ់របស់អ្នកចំពោះព្រះជាម្ចាស់បានទេ? តើស្ថានភាពនេះអាចបន្សុទ្ធអ្នកបានទេ? វាគ្រាន់តែតាមរយៈការបន្សុទ្ធ ដែលសេចក្ដីស្រឡាញ់របស់អ្នកចំពោះព្រះជាម្ចាស់ អាចត្រូវបានបង្ហាញចេញ ហើយមានតែតាមរយៈអ្វីៗ

ដែលកើតឡើង ដែលមិនត្រូវនឹងសញ្ញាណរបស់អ្នកទេ ដែលអ្នកអាចទទួលបានភាពគ្រប់លក្ខណ៍។ ជាមួយនឹងការបម្រើនូវអ្វីដែលផ្ទុយ និងអវិជ្ជមានជាច្រើន ហើយដោយប្រើគ្រប់ទាំងប្រភេទនៃការបើកបង្ហាញទាំងអស់របស់សាតាំង ដែលជាសកម្មភាពរបស់វា ការចោទប្រកាន់របស់វា ការរំខាន និងការបំភាន់របស់វា ព្រះជាម្ចាស់បង្ហាញចេញដល់អ្នកនូវមុខមាត់ដ៏អាក្រក់របស់សាតាំងយ៉ាងច្បាស់ ហើយដោយហេតុនេះ ធ្វើឲ្យសមត្ថភាពរបស់អ្នកបានគ្រប់លក្ខណ៍ ដោយមើលឃើញសាតាំងច្បាស់ ដែលអ្នកអាចស្អប់សាតាំង ហើយបោះបង់វាចោល។

បទពិសោធជាច្រើននៃការបរាជ័យ ភាពខ្សោយ ពេលវេលាអវិជ្ជមានរបស់អ្នក ការទាំងអស់នោះអាចនិយាយបានថាជាការល្បងលរបស់ព្រះជាម្ចាស់។ នេះគឺ ដោយសារតែអ្វីគ្រប់យ៉ាងមកពីព្រះជាម្ចាស់ ហើយអ្វីៗ និងព្រឹត្តិការណ៍ទាំងអស់ស្ថិតនៅក្នុងព្រះហស្តរបស់ទ្រង់។ មិនថាអ្នកបរាជ័យ ឬអ្នកខ្សោយ ហើយអ្នកជំពប់ដួល ការទាំងអស់អាស្រ័យលើព្រះជាម្ចាស់ ហើយស្ថិតនៅក្នុងការយល់បានរបស់ទ្រង់។ តាមទស្សនៈរបស់ព្រះជាម្ចាស់ នេះគឺជាការល្បងលចំពោះអ្នក ហើយប្រសិនបើអ្នកមិនអាចស្គាល់វាបាន វានឹងក្លាយទៅជាការល្បួង។ មានសណ្ឋានពីរប្រភេទដែលមនុស្សគប្បីស្គាល់៖ មួយមកពីព្រះវិញ្ញាណបរិសុទ្ធ ហើយប្រភពនៃសណ្ឋានមួយទៀតទំនងជាមកពីសាតាំង។ សណ្ឋានមួយ គឺជាសណ្ឋានដែលព្រះវិញ្ញាណបរិសុទ្ធបំភ្លឺអ្នក ហើយអនុញ្ញាតឲ្យអ្នកស្គាល់ខ្លួនឯង ស្អប់ខ្ពើម និងមានអារម្មណ៍សោកស្ដាយចំពោះខ្លួនឯង និងអាចមានសេចក្តីស្រឡាញ់ដ៏ពិតប្រាកដចំពោះព្រះជាម្ចាស់ ដើម្បីកំណត់ចិត្តរបស់អ្នកចំពោះការផ្គាប់ព្រះហឫទ័យទ្រង់។ សណ្ឋានមួយទៀត គឺជាសណ្ឋានដែលអ្នកស្គាល់ខ្លួនឯង ប៉ុន្តែអ្នកមានភាពអវិជ្ជមាន និងខ្សោយ។ គេអាចនិយាយបានថាសណ្ឋាននេះ គឺជាការការបន្សុទ្ធរបស់ព្រះជាម្ចាស់ ហើយវាក៏ជាការល្បួងរបស់សាតាំងផងដែរ។ ប្រសិនបើអ្នកទទួលស្គាល់ការនោះ នេះហើយគឺជាសេចក្តីសង្គ្រោះរបស់ព្រះជាម្ចាស់ចំពោះអ្នក ហើយប្រសិនបើអ្នកមានអារម្មណ៍ថាអ្នកជាប់បំណុលរបស់ទ្រង់យ៉ាងច្រើនឥឡូវនេះ ហើយប្រសិនបើចាប់ពីពេលនេះតទៅ អ្នកព្យាយាមសងទៅកាន់

ទ្រង់វិញ ហើយលែងធ្លាក់ចូលក្នុងភាពគ្មានគុណធម៌បែបនេះ ប្រសិនបើអ្នកដាក់ការខិតខំរបស់អ្នកទៅក្នុងការហូប និងផឹកព្រះបន្ទូលរបស់ទ្រង់ ហើយប្រសិនបើអ្នកតែងតែគិតថាខ្លួនឯងខ្វះ ហើយមានចិត្តចង់បាន ការនេះហើយគឺជាការល្បងលរបស់ព្រះជាម្ចាស់។ បន្ទាប់ពីការរងទុក្ខវេទនាបានបញ្ចប់ ហើយអ្នកកំពុងឈានទៅមុខម្ដងទៀត ព្រះជាម្ចាស់នៅតែដឹកនាំ ធ្វើឲ្យយល់ច្បាស់ បំភ្លឺ និងចិញ្ចឹមអ្នក។ ប៉ុន្តែប្រសិនបើអ្នកមិនទទួលស្គាល់វា ហើយអ្នកមានភាពអវិជ្ជមាន ចូរអ្នកគ្រាន់តែបោះបង់ចោលនូវភាពអស់សង្ឃឹម ប្រសិនបើអ្នកគិតតាមរបៀបនេះ នោះការល្បួងរបស់សាតាំងនឹងកើតមានដល់អ្នក។ ពេលយ៉ូបបានឆ្លងកាត់ការល្បងល ព្រះជាម្ចាស់ និងសាតាំងបានភ្នាល់គ្នា ហើយព្រះជាម្ចាស់បានអនុញ្ញាតឲ្យសាតាំងធ្វើទុក្ខដល់យ៉ូប។ ទោះបីជាព្រះជាម្ចាស់កំពុងល្បងលយ៉ូបក៏ដោយ តាមពិតវាជាសាតាំងទេ ដែលបានធ្វើមកលើគាត់។ ចំពោះសាតាំង វាបានល្បួងយ៉ូប ប៉ុន្តែយ៉ូបនៅខាងព្រះជាម្ចាស់។ ប្រសិនបើមិនដូច្នោះទេ នោះយ៉ូបនឹងធ្លាក់ក្នុងការល្បួង។ ដរាបណាមនុស្សធ្លាក់ក្នុងការល្បួង ពួកគេនឹងជួបគ្រោះថ្នាក់។ ការឆ្លងកាត់នូវការបន្សុទ្ធ អាចនិយាយបានថាជាការល្បងលពីព្រះជាម្ចាស់ ប៉ុន្តែប្រសិនបើអ្នកមិនស្ថិតក្នុងសណ្ឋានល្អ វាអាចនិយាយបានថាជាការល្បួងពីសាតាំង។ ប្រសិនបើអ្នកមិនច្បាស់អំពីនិមិត្ត សាតាំងនឹងចោទប្រកាន់អ្នក ហើយធ្វើឲ្យអ្នកមើលឃើញមិនច្បាស់ពីទិដ្ឋភាពនៃនិមិត្ត។ ទម្រាំតែអ្នកដឹងអំពីវា អ្នកនឹងធ្លាក់ក្នុងការល្បួងបាត់ទៅហើយ។

ប្រសិនបើអ្នកមិនមានបទពិសោធអំពីកិច្ចការរបស់ព្រះជាម្ចាស់ទេនោះ អ្នកនឹងមិនអាចទទួលបាននូវភាពគ្រប់លក្ខណ៍ឡើយ។ នៅក្នុងបទពិសោធរបស់អ្នក អ្នកក៏ត្រូវតែចូលឲ្យបានស៊ីជម្រៅផងដែរ។ ឧទាហរណ៍ តើមានរឿងអ្វីខ្លះដែលនាំអ្នកឲ្យបង្កើតសញ្ញាណ និងចំណង់ដ៏លើសលប់ ហើយតើការអនុវត្តបែបណាដែលសមរម្យ ដែលអ្នកត្រូវដោះស្រាយបញ្ហាទាំងនេះ? ប្រសិនបើអ្នកអាចមានបទពិសោធនូវកិច្ចការរបស់ព្រះជាម្ចាស់ នេះមានន័យថាអ្នកមានកម្ពស់ហើយ។ ប្រសិនបើអ្នកគ្រាន់តែបង្ហាញថាមានភាពរឹងមាំ នេះមិនមែនជាកម្ពស់ដ៏ពិតទេ ហើយអ្នកប្រាកដជាមិនអាចឈររឹងមាំ

បានឡើយ។ នៅពេលដែលអ្នកមានបទពិសោធក្នុងកិច្ចការរបស់ព្រះជាម្ចាស់ ហើយអ្នកអាចមានបទពិសោធ និងពិចារណាវានៅពេលណាមួយ និងកន្លែងណាមួយដែលអ្នករាល់គ្នាអាចចាកចេញពីពួកគង្វាល ហើយរស់នៅឯករាជ្យ ដោយពឹងផ្អែកលើព្រះជាម្ចាស់ ហើយអ្នកអាច មើលឃើញសកម្មភាពជាក់ស្ដែងរបស់ព្រះជាម្ចាស់បាន មានតែបែបនេះនោះទេ ដែលបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់នឹងបានសម្រេច។ ឥឡូវនេះមនុស្សភាគច្រើនមិនដឹងពីរបៀបក្នុងការទទួលបានបទពិសោធ ហើយនៅពេលពួកគេជួបប្រទះនូវបញ្ហា ពួកគេមិនដឹងពីរបៀបថែរក្សាវាទេ។ ពួកគេមិនមានសមត្ថភាពទទួលបានបទពិសោធក្នុងកិច្ចការរបស់ព្រះជាម្ចាស់ទេ ហើយពួកគេមិនអាចដឹកនាំជីវិតខាងវិញ្ញាណបានដែរ។ អ្នកត្រូវតែយកព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងធ្វើកិច្ចការនៅក្នុងជីវិតជាក់ស្ដែងរបស់អ្នក។

ពេលខ្លះព្រះជាម្ចាស់ប្រទានឲ្យអ្នកនូវប្រភេទអារម្មណ៍មួយ ដែលជាអារម្មណ៍ធ្វើឲ្យអ្នកបាត់បង់ការរីករាយខាងក្នុង និងបាត់បង់វត្តមានរបស់ព្រះជាម្ចាស់ដូចជាអ្នកកំពុងធ្លាក់ក្នុងភាពងងឹត។ នេះគឺជាប្រភេទនៃការបន្សុទ្ធ។ រាល់ពេលដែលអ្នកធ្វើអ្វីៗ វាតែងតែមានភាពរអាក់រអួល ឬអ្នកនឹងទាល់ច្រក។ នេះជាការប្រៀនប្រដៅរបស់ព្រះជាម្ចាស់។ ជួនកាល នៅពេលដែលអ្នកធ្វើអ្វីមួយដែលមិនស្ដាប់បង្គាប់ និងបះបោរប្រឆាំងនឹងព្រះជាម្ចាស់ គ្មាននរណាទៀតអាចដឹងអំពីរឿងនេះបានទេ មានតែព្រះជាម្ចាស់ទេដែលជ្រាបដឹង។ ទ្រង់នឹងដាក់ទោសអ្នក ហើយទ្រង់នឹងប្រៀនប្រដៅអ្នក។ កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ គឺលម្អិតខ្លាំងណាស់។ ទ្រង់សង្កេតដោយយកព្រះទ័យទុកដាក់បំផុតចំពោះរាល់ព្រះបន្ទូល និងសកម្មភាព រាល់អំពើ និងចលនារបស់ពួកគេ ហើយរាល់ការគិត និងគំនិតរបស់ពួកគេ ដើម្បីឲ្យមនុស្សអាចទទួលបានការយល់ដឹងខាងក្នុងចិត្តអំពីរឿងទាំងអស់នេះ។ អ្នកធ្វើរឿងមួយម្ដង វាចាប់ផ្ដើមខុស អ្នកធ្វើរឿងមួយម្ដងទៀត ហើយវានៅតែខុសដដែល ហើយអ្នកនឹងចាប់ផ្ដើមយល់ពីកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធបន្តិចម្ដងៗ។ ឆ្លងកាត់ការប្រៀនប្រដៅជាច្រើនដង អ្នកនឹងដឹងពីអ្វីដែលត្រូវធ្វើ ដើម្បីស្របតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់

និងអ្វីដែលមិនស្របតាមបំណងព្រះហឫទ័យរបស់ព្រះទ្រង់។ នៅចុងបញ្ចប់ អ្នកនឹងមានការឆ្លើយតបដ៏ត្រឹមត្រូវ ចំពោះការណែនាំពីព្រះវិញ្ញាណបរិសុទ្ធពីក្នុងចិត្តអ្នក។ ពេលខ្លះអ្នកនឹងបះបោរ ហើយព្រះជាម្ចាស់នឹងស្ដីបន្ទោសអ្នកពីខាងក្នុងចិត្ត។ ការទាំងអស់នេះ មកពីការប្រៀនប្រដៅរបស់ព្រះជាម្ចាស់។ ប្រសិនបើអ្នកមិនមិនឲ្យតម្លៃចំពោះព្រះបន្ទូលរបស់ព្រះជាម្ចាស់ទេ ប្រសិនបើអ្នកធ្វើកិច្ចការរបស់ទ្រង់បន្តិចបន្តួច នោះទ្រង់នឹងមិនអើពើនឹងអ្នកឡើយ។ បើអ្នកយកព្រះបន្ទូលរបស់ព្រះជាម្ចាស់ឲ្យប្រាកដប្រជា នោះទ្រង់នឹងបំភ្លឺអ្នកកាន់តែច្រើន។ ឥឡូវនេះ មានមនុស្សខ្លះនៅក្នុងពួកជំនុំដែលមានជំនឿច្របូកច្របល់ ហើយភាន់ច្រលំ ហើយពួកគេធ្វើរឿងមិនសមរម្យជាច្រើន ហើយប្រព្រឹត្តដោយគ្មានការប្រៀនប្រដៅ ដូច្នេះហើយ ពួកគេមិនអាចមើលឃើញបានច្បាស់អំពីកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធទេ។ មនុស្សខ្លះទុកកាតព្វកិច្ចរបស់ពួកគេចោល ដើម្បីជាប្រយោជន៍ក្នុងការរកប្រាក់ ចេញទៅធ្វើជំនួញដោយមិនមានការប្រៀនប្រដៅ។ មនុស្សប្រភេទនោះ ស្ថិតក្នុងភាពគ្រោះថ្នាក់កាន់តែខ្លាំង។ មិនត្រឹមតែបច្ចុប្បន្ននេះ ពួកគេមិនមានកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធប៉ុណ្ណោះទេ ប៉ុន្ដែនៅពេលអនាគត ពួកគេនឹងពិបាកក្នុងការទទួលបានភាពគ្រប់លក្ខណ៍ណាស់។ មានមនុស្សជាច្រើនដែលគេមិនអាចមើលឃើញកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ហើយគេមិនអាចមើលឃើញការប្រៀនប្រដៅរបស់ព្រះជាម្ចាស់បានឡើយ។ ពួកគេគឺជាអ្នកដែលមិនយល់ច្បាស់ អំពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ហើយជាអ្នកដែលមិនដឹងពីកិច្ចការរបស់ទ្រង់។ អ្នកដែលអាចឈរនៅមាំបាននៅចំណោមការបន្សុទ្ធ អ្នកដែលដើរតាមព្រះជាម្ចាស់មិនថាទ្រង់ធ្វើអ្វីក៏ដោយ ហើយយ៉ាងហោចណាស់ក៏មិនអាចចាកចេញបានដែរ ឬក៏សម្រេចបាន០.១% នៃអ្វីដែលពេត្រុសបានសម្រេចនោះគឺល្អទេ ប៉ុន្ដែពួកគេគ្មានតម្លៃចំពោះព្រះជាម្ចាស់ ក្នុងការប្រើប្រាស់ពួកគេនោះឡើយ។ មនុស្សជាច្រើនយល់អ្វីៗបានយ៉ាងឆាប់រហ័ស មានសេចក្ដីស្រឡាញ់ដ៏ពិតចំពោះព្រះជាម្ចាស់ ហើយអាចលើសពីកម្រិតរបស់ពេត្រុស ហើយព្រះជាម្ចាស់ធ្វើកិច្ចការនៃភាពគ្រប់លក្ខណ៍ចំពោះពួកគេ។ ការប្រៀនប្រដៅ និងការបំភ្លឺ បានទៅដល់

មនុស្សបែបនេះ ហើយប្រសិនបើមានអ្វីមួយនៅក្នុងពួកគេដែលមិនស្របតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ នោះពួកគេអាចបណ្ដេញវាចេញភ្លាមៗ។ មនុស្សបែបនេះ គឺជាមាស ប្រាក់ និងត្បូងមានតម្លៃ គុណតម្លៃរបស់ពួកគេ គឺខ្ពង់ខ្ពស់ខ្លាំងណាស់។ ប្រសិនបើព្រះជាម្ចាស់បានធ្វើកិច្ចការជាច្រើនប្រភេទ ប៉ុន្តែអ្នកនៅតែដូចជាខ្សាច់ ឬថ្ម នោះអ្នកគ្មានតម្លៃទេ!

កិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងប្រទេសនៃនាគដ៏ធំមានសម្បុរក្រហម គឺអស្ចារ្យ និងហួសពីការអាចយល់បាន។ ទ្រង់នឹងប្រោសមនុស្សមួយក្រុមឲ្យបានគ្រប់លក្ខណ៍ ហើយផាត់ចោលក្រុមខ្លះទៀត ព្រោះមានមនុស្សគ្រប់ប្រភេទនៅក្នុងពួកជំនុំ មានអ្នកដែលស្រឡាញ់សេចក្ដីពិត និងអ្នកដែលមិនស្រលាញ់សេចក្ដីពិត។ មានអស់អ្នកដែលមានបទពិសោធអំពីកិច្ចការរបស់ព្រះជាម្ចាស់ ហើយអ្នកដែលមិនមានបទពិសោធអំពីកិច្ចការរបស់ព្រះជាម្ចាស់ មានអ្នកដែលបំពេញកាតព្វកិច្ចរបស់ខ្លួន ហើយអ្នកដែលមិនធ្វើតាមកាតព្វកិច្ចរបស់ខ្លួន។ មានអ្នកដែលធ្វើបន្ទាល់អំពីព្រះជាម្ចាស់ ហើយអ្នកដែលមិនធ្វើបន្ទាល់អំពីព្រះជាម្ចាស់ ហើយមួយផ្នែកនៃពួកគេ គឺជាអ្នកមិនជឿ និងជាមនុស្សអាក្រក់ ហើយពួកគេនឹងត្រូវបានផាត់ចោល។ ប្រសិនបើអ្នកមិនបានដឹងច្បាស់ពីកិច្ចការរបស់ព្រះជាម្ចាស់ទេ នោះអ្នកនឹងមានភាពអវិជ្ជមាន។ នេះគឺដោយសារតែកិច្ចការរបស់ព្រះជាម្ចាស់អាចត្រូវបានគេមើលឃើញតែនៅក្នុងមនុស្សមួយចំនួនតូចប៉ុណ្ណោះ។ នៅពេលនេះវានឹងកាន់តែច្បាស់ថា អ្នកណាដែលស្រឡាញ់ព្រះជាម្ចាស់ពិតប្រាកដ ហើយអ្នកណាមិនស្រឡាញ់ព្រះជាម្ចាស់ពិតប្រាកដ។ អ្នកដែលស្រឡាញ់ព្រះជាម្ចាស់ពិតប្រាកដ មានកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ រីឯអ្នកដែលមិនស្រឡាញ់ទ្រង់ពិតប្រាកដ នឹងត្រូវបានបើកសម្ដែងតាមរយៈជំហាននីមួយៗនៃកិច្ចការរបស់ទ្រង់។ ពួកគេនឹងក្លាយជាវត្ថុ នៃការផាត់ចោល។ មនុស្សទាំងនេះនឹងត្រូវបានបើកសម្ដែងឲ្យដឹងក្នុងរយៈពេលនៃកិច្ចការនៃការយកឈ្នះ ហើយពួកគេគឺជាមនុស្សដែលមិនមានតម្លៃក្នុងការទទួលបាននូវភាពគ្រប់លក្ខណ៍នោះឡើយ។ អស់អ្នកដែលទទួលបានភាពគ្រប់លក្ខណ៍ ត្រូវបានទទួលដោយព្រះជាម្ចាស់នៅក្នុង

ភាពទាំងស្រុងរបស់ពួកគេ ហើយអាចមានសមត្ថភាពស្រឡាញ់ព្រះជាម្ចាស់ ដូចជាពេត្រុសបានធ្វើអ៊ីចឹង។ អ្នកដែលត្រូវបានយកឈ្នះ គេមិនមានសេចក្ដីស្រឡាញ់ដោយឯកឯងទេ មានតែសេចក្ដីស្រឡាញ់ដែលអកម្ម ហើយពួកគេត្រូវបង្ខំចិត្តស្រឡាញ់ព្រះជាម្ចាស់។ សេចក្ដីស្រឡាញ់ដោយឯកឯង ត្រូវបានលូតលាស់ឡើងតាមរយៈការយល់ដឹង ដែលទទួលបានតាមរយៈបទពិសោធជាក់ស្ដែង។ សេចក្ដីស្រឡាញ់នេះ មាននៅក្នុងចិត្តរបស់មនុស្ស ហើយធ្វើឲ្យពួកគេលះបង់ដោយស្ម័គ្រចិត្តចំពោះព្រះជាម្ចាស់។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ក្លាយជាគ្រឹះរបស់ពួកគេ ហើយពួកគេអាចរងទុក្ខសម្រាប់ព្រះជាម្ចាស់។ ជាការពិត ទាំងនេះគឺជារឿងរ៉ាវដែលនរណាម្នាក់មាន ដែលត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍ដោយព្រះជាម្ចាស់។ ប្រសិនបើអ្នកគ្រាន់តែព្យាយាមដើម្បីយកឈ្នះនោះ អ្នកមិនអាចធ្វើបន្ទាល់ អំពីព្រះជាម្ចាស់បានឡើយ។ ប្រសិនបើព្រះជាម្ចាស់គ្រាន់តែសម្រេចបាននូវគោលដៅនៃសេចក្ដីសង្គ្រោះតាមរយៈការយកឈ្នះមនុស្ស នោះជំហាននៃអ្នកស៊ីឈ្នួល នឹងបញ្ចប់កិច្ចការ។ ទោះយ៉ាងណាក៏ដោយ ការយកឈ្នះមនុស្ស មិនមែនជាគោលដៅចុងក្រោយរបស់ព្រះជាម្ចាស់ក្នុងការប្រោសឲ្យមនុស្សបានគ្រប់លក្ខណ៍នោះទេ។ ដូច្នេះជាជាងការនិយាយថា ដំណាក់កាលនេះគឺជាកិច្ចការនៃការយកឈ្នះ ជាជាងថាវាគឺជាកិច្ចការនៃការប្រោសឲ្យបានគ្រប់លក្ខណ៍ និងការផាត់ចោល មនុស្សមួយចំនួនមិនទាន់ត្រូវយកឈ្នះបានពេញលេញនៅឡើយទេ ហើយនៅក្នុងដំណើរការនៃការយកឈ្នះពួកគេ ក្រុមមនុស្សមួយក្រុមនឹងត្រូវប្រោសឲ្យបានគ្រប់លក្ខណ៍។ កិច្ចការទាំងពីរផ្នែកនេះ ត្រូវបានអនុវត្តដោយឯកច្ឆន្ទ។ មនុស្សមិនបានចាកចេញ សូម្បីតែក្នុងរយៈពេលដ៏យូរនៃកិច្ចការបែបនេះ ហើយការនេះបង្ហាញថា គោលដៅនៃការយកឈ្នះត្រូវបានសម្រេច នេះគឺជាសេចក្ដីពិតនៃការយកឈ្នះបាន។ ការបន្សុទ្ធមិនមែនសម្រាប់ជាប្រយោជន៍នៃការយកឈ្នះបានទេ ប៉ុន្តែសម្រាប់ជាប្រយោជន៍នៃការធ្វើឲ្យគ្រប់លក្ខណ៍។ បើគ្មានការការបន្សុទ្ធទេ មនុស្សមិនអាចទទួលបានការគ្រប់លក្ខណ៍ឡើយ។ ដូច្នេះការការបន្សុទ្ធពិតជាមានតម្លៃណាស់! សព្វថ្ងៃនេះ មនុស្សមួយក្រុមកំពុងត្រូវបានធ្វើឲ្យបាន

គ្រប់លក្ខណ៍ និងទទួលបាន។ ព្រះពរទាំងដប់ដែលបានរៀបរាប់ពីមុន គឺសំដៅទៅលើអ្នកដែលត្រូវបានប្រោសឲ្យបានគ្រប់លក្ខណ៍។ អ្វីគ្រប់យ៉ាងអំពីការផ្លាស់ប្ដូររូបភាពរបស់ពួកគេនៅលើផែនដី គឺសំដៅទៅលើអ្នកដែលបានប្រោសឲ្យបានគ្រប់លក្ខណ៍។ អ្នកដែលមិនទាន់ត្រូវបានប្រោសឱ្យគ្រប់លក្ខណ៍ មិនមានលក្ខណៈគ្រប់គ្រាន់ដើម្បីទទួលបានសេចក្ដីសន្យារបស់ព្រះជាម្ចាស់ឡើយ។

# មានតែតាមរយៈការឆ្លងកាត់ ការល្បងលដ៏ឈឺចាប់ទេ ទើបអ្នកអាចដឹងអំពី ភាពគួរឲ្យស្រឡាញ់របស់ព្រះជាម្ចាស់

តើសព្វថ្ងៃនេះ អ្នកស្រឡាញ់ព្រះជាម្ចាស់ខ្លាំងកម្រិតណាទៅ? តើអ្នកដឹងច្រើនកម្រិតណាអំពីគ្រប់កិច្ចការដែលព្រះជាម្ចាស់បានធ្វើនៅក្នុងអ្នក? ទាំងនេះគឺជារឿងដែលអ្នកគួរតែរៀនសូត្រ។ នៅពេលដែលព្រះជាម្ចាស់យាងមកដល់ផែនដី គ្រប់យ៉ាងដែលទ្រង់បានធ្វើនៅក្នុងមនុស្ស និងបានអនុញ្ញាតឲ្យមនុស្សមើលឃើញ គឺដើម្បីឲ្យមនុស្សនឹងស្រឡាញ់ទ្រង់ ព្រមទាំងស្គាល់ទ្រង់យ៉ាងពិតប្រាកដ។ ការដែលមនុស្សអាចរងទុក្ខសម្រាប់ព្រះជាម្ចាស់ និងអាចមកដល់ឆ្ងាយកម្រិតនេះ នៅក្នុងទិដ្ឋភាពមួយ គឺដោយសារតែសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ហើយនៅក្នុងទិដ្ឋភាពមួយទៀត គឺដោយសារតែសេចក្ដីសង្គ្រោះរបស់ព្រះជាម្ចាស់។ ជាងនេះទៅទៀត វាក៏ដោយសារតែការជំនុំជម្រះ និងកិច្ចការនៃការវាយផ្ចាលដែលព្រះជាម្ចាស់បានអនុវត្តនៅក្នុងមនុស្សដែរ។ ប្រសិនបើអ្នកគ្មានការជំនុំជម្រះ ការវាយផ្ចាល និងការល្បងលរបស់ព្រះជាម្ចាស់ទេ ហើយប្រសិនបើព្រះជាម្ចាស់មិនបានធ្វើឲ្យអ្នករាល់គ្នារងទុក្ខទេ នោះនិយាយឲ្យចំទៅ អ្នករាល់គ្នាមិនស្រឡាញ់ព្រះជាម្ចាស់យ៉ាងពិតប្រាកដឡើយ។ បើកិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងមនុស្សមានកាន់តែធំ ហើយបើសិនទុក្ខលំបាករបស់មនុស្សមានកាន់តែខ្លាំង នោះវាស្តែងចេញឲ្យឃើញកាន់តែច្បាស់ថា កិច្ចការរបស់ព្រះជាម្ចាស់

កាន់តែមានអត្ថន័យ ហើយដួងចិត្តរបស់មនុស្សកាន់តែអាចស្រឡាញ់ព្រះជាម្ចាស់យ៉ាងពិតប្រាកដ។ តើអ្នករៀនពីរបៀបស្រឡាញ់ព្រះជាម្ចាស់យ៉ាងដូចម្ដេចទៅ? បើគ្មានការដាក់ទោស និងការបន្សុទ្ធ បើគ្មានការល្បងលដ៏ឈឺចាប់ទេ ហើយលើសពីនេះទៅទៀត បើគ្រប់កិច្ចការដែលព្រះជាម្ចាស់បានប្រទានមកដល់មនុស្សមានត្រឹមតែជាព្រះគុណ សេចក្ដីស្រឡាញ់ និងសេចក្ដីមេត្តាករុណា តើអ្នកនឹងអាចឡើងទៅដល់កម្រិតមួយ នៃការស្រឡាញ់ព្រះជាម្ចាស់យ៉ាងពិតប្រាកដ ដោយរបៀបណាទៅ? នៅក្នុងន័យម្យ៉ាង ក្នុងអំឡុងពេលនៃការល្បងលរបស់ព្រះជាម្ចាស់ មនុស្សចាប់ផ្ដើមដឹងអំពីសេចក្ដីកម្សោយរបស់ខ្លួន និងមើលឃើញថា គេជាមនុស្សមិនសំខាន់ គួរឲ្យស្អប់ខ្ពើម និងទន់ទាប និងមើលឃើញទៀតថា គេមិនមានអ្វី គឺគ្មានអ្វីសោះតែម្ដង។ នៅក្នុងន័យម្យ៉ាងទៀត ក្នុងអំឡុងពេលនៃការល្បងលរបស់ទ្រង់ ព្រះជាម្ចាស់បង្កើតនូវបរិយាកាសខុសៗគ្នាសម្រាប់មនុស្ស ដើម្បីឲ្យគេកាន់តែអាចមានបទពិសោធអំពីភាពគួរឲ្យស្រឡាញ់របស់ព្រះជាម្ចាស់។ ទោះបីជាការឈឺចាប់មានកម្រិតខ្លាំងហើយពេលខ្លះ ពុំអាចជម្នះបាន ឬអាចដល់កម្រិតនៃភាពតានតឹងចិត្តខ្លាំងចេញពីការល្បងលនោះក៏ដោយ ក៏មនុស្សមើលឃើញពីភាពគួរឲ្យស្រឡាញ់នៃកិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងមនុស្សដែរ ហើយមានតែតាមរយៈការឈរលើគ្រឹះនេះទេ ទើបមនុស្សកើតមានចិត្តស្រឡាញ់ដ៏ពិតប្រាកដចំពោះព្រះជាម្ចាស់។ សព្វថ្ងៃនេះ មនុស្សមើលឃើញថា ដោយមានព្រះគុណ សេចក្ដីស្រឡាញ់ និងសេចក្ដីមេត្តាករុណារបស់ព្រះជាម្ចាស់តែម្យ៉ាង គេគ្មានសមត្ថភាពស្គាល់ខ្លួនឯងយ៉ាងពិតប្រាកដ ហើយក៏មិនអាចស្គាល់ពីលក្ខណៈរបស់មនុស្សដែរ។ មានតែតាមរយៈការបន្សុទ្ធ និងការជំនុំជម្រះរបស់ព្រះជាម្ចាស់ ព្រមទាំងស្ថិតក្នុងអំឡុងពេលនៃដំណើរការបន្សុទ្ធដោយផ្ទាល់ទេ ទើបមនុស្សអាចដឹងអំពីសេចក្ដីកម្សោយរបស់ខ្លួន ហើយដឹងទៀតថា គេគ្មានអ្វីសោះឡើយ។ ហេតុដូចនេះ សេចក្ដីស្រឡាញ់របស់មនុស្សចំពោះព្រះជាម្ចាស់ត្រូវបានសង់ពីលើគ្រឹះនៃការបន្សុទ្ធ និងការជំនុំជម្រះរបស់ព្រះជាម្ចាស់។ ប្រសិនបើអ្នកគ្រាន់តែរីករាយនឹងព្រះគុណរបស់ព្រះជាម្ចាស់ គ្រាន់តែមានជីវិតគ្រួសារដ៏សុខសប្បាយ ឬ

គ្រាន់តែមានព្រះពរខាងសម្ភារៈ នោះអ្នកមិនទទួលបានព្រះជាម្ចាស់ឡើយ ហើយជំនឿរបស់អ្នកលើព្រះជាម្ចាស់ក៏មិនអាចត្រូវបានចាត់ទុកថាបានជោគជ័យនោះដែរ។ ព្រះជាម្ចាស់បានអនុវត្តរួចហើយនូវដំណាក់កាលមួយនៃកិច្ចការអំពីព្រះគុណនៅក្នុងសាច់ឈាម ហើយព្រះអង្គក៏បានប្រទានព្រះពរខាងសម្ភារៈដល់មនុស្សរួចហើយដែរ ប៉ុន្តែមនុស្សមិនអាចត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍ជាមួយព្រះគុណ សេចក្តីស្រឡាញ់ និងសេចក្តីមេត្តាករុណាតែម្យ៉ាងនោះឡើយ។ នៅក្នុងបទពិសោធរបស់មនុស្ស គេមានបទពិសោធខ្លះ អំពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ហើយក៏មើលឃើញសេចក្តីស្រឡាញ់ និងសេចក្តីមេត្តាករុណារបស់ព្រះជាម្ចាស់ដែរ ប៉ុន្តែដោយបានមានបទពិសោធក្នុងរយៈពេលមួយ ដូច្នេះ គេមើលឃើញថា ព្រះគុណ សេចក្តីស្រឡាញ់ និងសេចក្តីមេត្តាករុណារបស់ព្រះជាម្ចាស់មិនអាចធ្វើឲ្យមនុស្សបានគ្រប់លក្ខណ៍ មិនអាចបើកសម្តែងអំពីសេចក្តីពុករលួយដែលមាននៅខាងក្នុងមនុស្ស និងមិនអាចជួយឲ្យមនុស្សយកឈ្នះលើនិស្ស័យដ៏ពុករលួយរបស់គេ ព្រមទាំងធ្វើឲ្យសេចក្តីស្រឡាញ់ និងសេចក្តីជំនឿរបស់គេបានគ្រប់លក្ខណ៍នោះឡើយ។ កិច្ចការនៃព្រះគុណរបស់ព្រះជាម្ចាស់ គឺជាកិច្ចការនៃអំឡុងពេលមួយ ហើយមនុស្សមិនអាចពឹងអាងលើការរីករាយនឹងព្រះគុណរបស់ព្រះជាម្ចាស់ ដើម្បីស្គាល់ព្រះជាម្ចាស់បានឡើយ។

តើព្រះជាម្ចាស់ប្រោសមនុស្សឲ្យគ្រប់លក្ខណ៍ តាមមធ្យោបាយណាខ្លះទៅ? វាអាចសម្រេចបាន តាមរយៈមធ្យោបាយនៃនិស្ស័យដ៏សុចរិតរបស់ទ្រង់។ និស្ស័យដ៏សុចរិតរបស់ព្រះជាម្ចាស់មាននូវធាតុផ្សំជាចម្បង ដូចជាសេចក្តីសុចរិត សេចក្តីក្រោធ ឫទ្ធានុភាព ការជំនុំជម្រះ និងការដាក់បណ្តាសា ហើយទ្រង់ប្រោសមនុស្សឲ្យគ្រប់លក្ខណ៍ជាចម្បងតាមរយៈមធ្យោបាយនៃការជំនុំជម្រះរបស់ទ្រង់។ មនុស្សមួយចំនួនមិនយល់ បែរជាសួរអំពីហេតុផល ដែលនាំឲ្យព្រះជាម្ចាស់អាចប្រោសមនុស្សឲ្យគ្រប់លក្ខណ៍ តាមរយៈការជំនុំជម្រះ និងការដាក់បណ្តាសា។ ពួកគេនិយាយថា «ប្រសិនបើព្រះជាម្ចាស់ត្រូវដាក់បណ្តាសាមនុស្ស តើមនុស្សនឹងមិនស្លាប់ទេឬអី? ប្រសិនបើព្រះជាម្ចាស់ត្រូវជំនុំជម្រះមនុស្ស នោះតើមនុស្សនឹងមិនត្រូវមានទោសទេ

ឬអី? បើដូច្នេះ តើគេអាចនៅតែត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍យ៉ាងដូចម្ដេចកើតទៅ?» ទាំងនេះគឺជាពាក្យរបស់មនុស្សដែលមិនស្គាល់ពីកិច្ចការរបស់ព្រះជាម្ចាស់ប៉ុណ្ណោះ។ អ្វីដែលព្រះជាម្ចាស់ដាក់បណ្ដាសា គឺជាការមិនស្ដាប់បង្គាប់របស់មនុស្ស ហើយអ្វីដែលទ្រង់ជំនុំជម្រះ គឺជាបាបរបស់មនុស្ស។ ទោះបីជាព្រះអង្គមានបន្ទូលគំរោះគំរើយ និងគ្មានក្ដីមេត្ដាក៏ដោយ ក៏ទ្រង់បើកសម្ដែងនូវអ្វីៗគ្រប់យ៉ាងដែលមាននៅក្នុងមនុស្ស ដោយបើកសម្ដែងតាមរយៈព្រះបន្ទូលដ៏ប្រិតប្រៀនទាំងនេះ ដែលមានសារៈសំខាន់នៅក្នុងមនុស្សដែរ ប៉ុន្ដែតាមរយៈការជំនុំជម្រះបែបនេះ ទ្រង់ប្រទានដល់មនុស្សនូវចំណេះដឹងដ៏ជ្រាលជ្រៅអំពីលក្ខណៈនៃសាច់ឈាម ហើយជាលទ្ធផលមនុស្សក៏ចុះចូលចំពោះព្រះជាម្ចាស់។ សាច់ឈាមរបស់មនុស្សគឺចេញពីអំពើបាប និងពីសាតាំង វាជាការមិនស្ដាប់បង្គាប់ ហើយវាក៏ជាកម្មវត្ថុនៃការវាយផ្ចាលរបស់ព្រះជាម្ចាស់ដែរ។ ហេតុដូចនេះ ដើម្បីជួយឲ្យមនុស្សស្គាល់ខ្លួនឯង ព្រះបន្ទូលនៃការជំនុំជម្រះរបស់ព្រះជាម្ចាស់ត្រូវតែថ្លែងទៅកាន់គេ ហើយទ្រង់ត្រូវតែប្រើវិធីសាស្ត្រគ្រប់យ៉ាងនៃការបន្សុទ្ធ ពោលគឺមានតែបែបនេះទេ ទើបកិច្ចការរបស់ព្រះជាម្ចាស់អាចមានប្រសិទ្ធភាព។

តាមរយៈព្រះបន្ទូលដែលព្រះជាម្ចាស់បានថ្លែង គេអាចមើលឃើញថា ទ្រង់បានដាក់ទោសរួចហើយ ដល់សាច់ឈាមរបស់មនុស្ស។ តើព្រះបន្ទូលទាំងនេះមិនមែនជាព្រះបន្ទូលនៃការដាក់បណ្ដាសាទេឬ? ព្រះបន្ទូលដែលព្រះជាម្ចាស់បានថ្លែង បើកសម្ដែងពីពណ៌សម្បុរដ៏ពិតរបស់មនុស្ស ហើយតាមរយៈការបើកសម្ដែងបែបនេះ មនុស្សត្រូវបានជំនុំជម្រះ ហើយនៅពេលដែលគេមើលឃើញថា ខ្លួនមិនអាចបំពេញតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់បាន គេមានអារម្មណ៍សោកសៅ និងវិប្បដិសារីនៅក្នុងចិត្ត មានអារម្មណ៍ថា គេបានជំពាក់គុណព្រះជាម្ចាស់យ៉ាងខ្លាំង ហើយគេមិនអាចទទួលបាន បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ឡើយ។ មានពេលខ្លះ ព្រះវិញ្ញាណបរិសុទ្ធប្រៀនប្រដៅអ្នកពីខាងក្នុង ហើយការប្រៀនប្រដៅនេះចេញមកពីការជំនុំជម្រះរបស់ព្រះជាម្ចាស់។ មានពេលខ្លះទៀត ព្រះជាម្ចាស់

ស្ដីបន្ទោសអ្នក និងលាក់ព្រះភ័ក្ត្ររបស់ទ្រង់ពីអ្នក នៅពេលដែលទ្រង់មិនយកព្រះទ័យទុកដាក់ចំពោះអ្នក និងមិនធ្វើការនៅក្នុងអ្នក នោះហើយ ជាពេលដែលទ្រង់វាយផ្ចាលអ្នកដោយស្ងាត់ៗ ដើម្បីបន្សុទ្ធអ្នក។ កិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងមនុស្សត្រូវបានធ្វើឡើងជាចម្បង ដើម្បីជួយឲ្យគេមើលឃើញយ៉ាងច្បាស់អំពីនិស្ស័យដ៏សុចរិតរបស់ទ្រង់។ នៅទីបំផុត តើមនុស្សត្រូវធ្វើបន្ទាល់អ្វីខ្លះអំពីព្រះជាម្ចាស់? មនុស្សត្រូវធ្វើបន្ទាល់ថា ព្រះជាម្ចាស់ជាព្រះដ៏សុចរិត ថានិស្ស័យរបស់ទ្រង់គឺជាសេចក្ដីសុចរិត សេចក្ដីក្រោធ ការវាយផ្ចាល និងការជំនុំជម្រះ ដូច្នេះ មនុស្សត្រូវធ្វើបន្ទាល់អំពីនិស្ស័យដ៏សុចរិតរបស់ព្រះជាម្ចាស់។ ព្រះជាម្ចាស់ប្រើប្រាស់ការជំនុំជម្រះរបស់ទ្រង់ ដើម្បីប្រោសមនុស្សឲ្យគ្រប់លក្ខណ៍ ទ្រង់បានស្រឡាញ់មនុស្ស ហើយបានសង្គ្រោះមនុស្ស ប៉ុន្តែ តើសេចក្ដីស្រឡាញ់របស់ទ្រង់មានផ្ទុកនូវធាតុផ្សំអ្វីខ្លះទៅ? សេចក្ដីស្រឡាញ់របស់ទ្រង់មាននូវការជំនុំជម្រះ ឫទ្ធានុភាព សេចក្ដីក្រោធ និងការដាក់បណ្ដាសា។ ទោះបីជាព្រះជាម្ចាស់បានដាក់បណ្ដាសាមនុស្សកាលពីអតីតកាលក៏ដោយ ក៏ទ្រង់មិនបានបោះមនុស្សឲ្យធ្លាក់ជង្ហុកធំទាំងស្រុងឡើយ ផ្ទុយទៅវិញ ទ្រង់បានប្រើមធ្យោបាយនោះ ដើម្បីបន្សុទ្ធសេចក្ដីជំនឿរបស់មនុស្សវិញទេ។ ព្រះអង្គមិនបានសម្លាប់មនុស្សឡើយ ប៉ុន្តែទ្រង់បានធ្វើបែបនេះ ដើម្បីប្រោសឲ្យមនុស្សបានគ្រប់លក្ខណ៍។ លក្ខណៈនៃសាច់ឈាម គឺជាសារជាតិមួយមកពីសាតាំង ហើយព្រះជាម្ចាស់ពិតជាមានបន្ទូលត្រឹមត្រូវមែន ប៉ុន្តែការពិតដែលត្រូវបានអនុវត្តដោយព្រះជាម្ចាស់ មិនត្រូវបានសម្រេចស្របតាមព្រះបន្ទូលរបស់ទ្រង់ឡើយ។ ព្រះអង្គដាក់បណ្ដាសាអ្នក ដើម្បីឲ្យអ្នកអាចស្រឡាញ់ទ្រង់ និងដើម្បីឲ្យអ្នកអាចស្គាល់ពីលក្ខណៈនៃសាច់ឈាម។ ព្រះអង្គវាយផ្ចាលអ្នក ដើម្បីឲ្យអ្នកអាចភ្ញាក់ខ្លួន ជួយឲ្យអ្នកដឹងអំពីសេចក្ដីកម្សោយដែលមានខាងក្នុងអ្នក និងដឹងអំពីភាពគ្មានតម្លៃទាល់តែសោះរបស់មនុស្ស។ ហេតុដូចនេះ ការដាក់បណ្ដាសា ការជំនុំជម្រះ ឫទ្ធានុភាព និងសេចក្ដីក្រោធរបស់ព្រះជាម្ចាស់សុទ្ធតែត្រូវបានប្រើ ដើម្បីធ្វើប្រោសឱ្យមនុស្សបានគ្រប់លក្ខណ៍ទេ។ គ្រប់យ៉ាងដែលព្រះជាម្ចាស់ធ្វើនាពេលសព្វថ្ងៃ ហើយនិស្ស័យដ៏សុចរិតដែលទ្រង់បើកសម្ដែងឲ្យអ្នករាល់គ្នាយល់

យ៉ាងច្បាស់នោះ គឺដើម្បីប្រោសឲ្យមនុស្សបានគ្រប់លក្ខណ៍ទេ។ នេះហើយជាសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់។

នៅក្នុងសញ្ញាណបែបប្រពៃណីរបស់មនុស្ស គេជឿថា សេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់គឺជាព្រះគុណ សេចក្ដីមេត្តាករុណា និងសេចក្ដីអាណិតអាសូររបស់ទ្រង់ចំពោះសេចក្ដីកម្សោយរបស់មនុស្ស។ ទោះបីសេចក្ដីទាំងនេះជាសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ក៏ដោយ ក៏សេចក្ដីទាំងនេះជាជ្រុងមួយប៉ុណ្ណោះ ហើយវាមិនមែនជាមធ្យោបាយចម្បងដែលព្រះជាម្ចាស់ប្រើ ដើម្បីប្រោសមនុស្សឲ្យបានគ្រប់លក្ខណ៍នោះឡើយ។ មនុស្សមួយចំនួនចាប់ផ្ដើមជឿលើព្រះជាម្ចាស់ដោយសារតែជំងឺ។ ជំងឺនេះគឺជាព្រះគុណរបស់ព្រះជាម្ចាស់សម្រាប់អ្នក ព្រោះថាបើគ្មានវាទេ នោះអ្នកក៏នឹងមិនជឿលើព្រះជាម្ចាស់ដែរ ហើយប្រសិនបើអ្នកមិនបានជឿលើព្រះជាម្ចាស់ នោះអ្នកក៏នឹងមិនបានមកដល់កម្រិតនេះដែរ។ ដូច្នេះ សូម្បីតែព្រះគុណបែបនេះក៏ជាសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ដែរ។ នៅក្នុងគ្រានៃការជឿលើព្រះយេស៊ូវ មនុស្សបានធ្វើនូវកិច្ចការជាច្រើនដែលមិនស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដោយសារតែពួកគេមិនបានយល់អំពីសេចក្ដីពិត តែព្រះជាម្ចាស់មានសេចក្ដីស្រឡាញ់ និងសេចក្ដីមេត្តាករុណា ដោយបាននាំមនុស្សឲ្យមកដល់កម្រិតនេះ ហើយទោះបីជាមនុស្សមិនដឹងខ្យល់អ្វីសោះក៏ដោយ ក៏ព្រះជាម្ចាស់នៅតែអនុញ្ញាតឲ្យគេដើរតាមទ្រង់ដែរ ហើយលើសពីនេះទៅទៀត ទ្រង់បានដឹកនាំមនុស្សឲ្យចូលមកក្នុងគ្រាសព្វថ្ងៃ។ តើនេះមិនមែនជាសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ទេឬ? សេចក្ដីដែលត្រូវបានបើកបង្ហាញនៅក្នុងនិស្ស័យរបស់ព្រះជាម្ចាស់ គឺជាសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ហើយនេះជារឿងត្រឹមត្រូវទាំងស្រុង! នៅពេលដែលការសាងសង់ពួកជំនុំបានឡើងដល់កម្រិតកំពូល ព្រះជាម្ចាស់បានធ្វើជំហាននៃកិច្ចការរបស់ពួកអ្នកស៊ីឈ្នួល ហើយបានបោះមនុស្សឲ្យធ្លាក់ទៅក្នុងជង្ហុកធំ។ ព្រះបន្ទូលនាសម័យរបស់ពួកអ្នកស៊ីឈ្នួលសុទ្ធតែជាការដាក់បណ្ដាសា៖ ការដាក់បណ្ដាសាលើសាច់ឈាមរបស់អ្នក ការដាក់បណ្ដាសាលើនិស្ស័យបែបសាតាំងដ៏ពុករលួយរបស់អ្នក និងការដាក់បណ្ដាសា

លើអ្វីៗអំពីអ្នក ដែលមិនបំពេញតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ កិច្ចការដែលព្រះជាម្ចាស់បានធ្វើនៅក្នុងជំហាននោះត្រូវបានសម្ដែងចេញជាឫទ្ធានុភាព បន្ទិចក្រោយពេលព្រះជាម្ចាស់បានអនុវត្តជំហាននៃកិច្ចការវាយផ្ចាល ហើយនៅទីនោះ ក៏មកដល់ការល្បងលនៃសេចក្ដីស្លាប់ដែរ។ នៅក្នុងកិច្ចការបែបនេះ មនុស្សបានឃើញសេចក្ដីក្រោធ ឫទ្ធានុភាព ការជំនុំជម្រះ និងការវាយផ្ចាលរបស់ព្រះជាម្ចាស់ ប៉ុន្តែគេក៏បានឃើញព្រះគុណ សេចក្ដីស្រឡាញ់ និងសេចក្ដីមេត្តាករុណារបស់ព្រះជាម្ចាស់ដែរ។ គ្រប់កិច្ចការដែលព្រះជាម្ចាស់បានធ្វើ និងគ្រប់សេចក្ដីដែលត្រូវបានសម្ដែងចេញជានិស្ស័យរបស់ទ្រង់ គឺជាសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះមនុស្ស ហើយគ្រប់កិច្ចការដែលព្រះជាម្ចាស់បានធ្វើ គឺសុទ្ធសឹងតែដើម្បីបំពេញសេចក្ដីត្រូវការរបស់មនុស្ស។ ព្រះអង្គបានធ្វើកិច្ចការនេះ ដើម្បីធ្វើឲ្យមនុស្សបានគ្រប់លក្ខណ៍ ហើយទ្រង់បានផ្គត់ផ្គង់ដល់មនុស្សស្របតាមកម្ពស់របស់គេ។ ប្រសិនបើព្រះជាម្ចាស់មិនធ្វើបែបនេះទេ នោះមនុស្សនឹងគ្មានសមត្ថភាពចូលមកចំពោះព្រះភ័ក្ត្ររបស់ព្រះជាម្ចាស់ឡើយ ហើយគេក៏គ្មានផ្លូវស្គាល់ព្រះភ័ក្ត្រដ៏ពិតរបស់ព្រះជាម្ចាស់នោះដែរ។ ចាប់តាំងពីពេលដែលមនុស្សបានចាប់ផ្ដើមជឿលើព្រះជាម្ចាស់ជាលើកដំបូង រហូតដល់សព្វថ្ងៃនេះ ព្រះជាម្ចាស់បានផ្គត់ផ្គង់ដល់មនុស្សបន្តិចម្ដងៗស្របតាមកម្ពស់របស់គេ ដើម្បីឲ្យគេស្គាល់ទ្រង់ពីក្នុងជម្រៅចិត្តបន្តិចម្ដងៗ។ មានតែតាមរយៈការបានមកដល់សព្វថ្ងៃនេះទេ ទើបមនុស្សទទួលស្គាល់ថា ការជំនុំជម្រះរបស់ព្រះជាម្ចាស់ពិតជាអស្ចារ្យ។ ជំហាននៃកិច្ចការរបស់ពួកអ្នកស៊ីឈ្នួល គឺជាហេតុការណ៍លើកដំបូង នៃកិច្ចការដាក់បណ្ដាសា ចាប់តាំងពីកំណើតពិភពលោក រហូតមកដល់ពេលបច្ចុប្បន្ននេះ។ មនុស្សបានត្រូវបណ្ដាសាឲ្យធ្លាក់ទៅក្នុងជង្ហុកធំ។ ប្រសិនបើព្រះជាម្ចាស់មិនបានធ្វើកិច្ចការនោះទេ ម្ល៉េះសព្វថ្ងៃនេះ មនុស្សនឹងគ្មានចំណេះដឹងដ៏ពិតអំពីព្រះជាម្ចាស់ឡើយ ហើយមានតែតាមរយៈការដាក់បណ្ដាសារបស់ព្រះជាម្ចាស់ទេ ទើបមនុស្សបានជួបជាផ្លូវការនូវនិស្ស័យរបស់ទ្រង់។ មនុស្សត្រូវបានបើកសម្ដែងតាមរយៈការល្បងលរបស់ពួកអ្នកស៊ីឈ្នួល។ គេបានឃើញថា ចិត្តស្វាមីភក្ដិរបស់គេមិនត្រូវបាន

ទទួលយក ឃើញថាកម្ពស់របស់គេនៅទាបពេក ឃើញថាគេគ្មានសមត្ថភាពបំពេញតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងឃើញទៀតថា ការអះអាងរបស់គេអំពីការបំពេញតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់នៅគ្រប់ពេលនោះ គឺគ្រាន់តែជាសម្ដីខ្យល់ប៉ុណ្ណោះ។ ទោះបីជាព្រះជាម្ចាស់បានដាក់បណ្ដាសាមនុស្សនៅក្នុងជំហាននៃកិច្ចការរបស់ពួកអ្នកស៊ីឈ្នួលក៏ដោយ ក៏ជំហាននៃកិច្ចការរបស់ព្រះជាម្ចាស់នោះជារឿងអស្ចារ្យដដែល នេះបើក្រឡេកមើលក្រោយពីពេលនេះ៖ ដ្បិតកិច្ចការនេះបាននាំឲ្យមានចំណុចបកក្រោយដ៏សំខាន់មួយសម្រាប់មនុស្ស ហើយក៏បាននាំឲ្យមានការផ្លាស់ប្ដូរដ៏ធំមួយនៅក្នុងនិស្ស័យជីវិតរបស់គេដែរ។ មុនសម័យកាលរបស់ពួកអ្នកស៊ីឈ្នួល មនុស្សមិនបានដឹងអ្វីសោះឡើយអំពីការស្វះស្វែងរកជីវិត អំពីអត្ថន័យនៃការជឿលើព្រះជាម្ចាស់ ឬអំពីព្រះប្រាជ្ញាញាណនៃកិច្ចការរបស់ព្រះជាម្ចាស់នោះឡើយ ហើយគេក៏មិនបានយល់ថា កិច្ចការរបស់ព្រះជាម្ចាស់អាចល្បងលមនុស្សបាននោះដែរ។ ចាប់តាំងពីសម័យកាលរបស់ពួកអ្នកស៊ីឈ្នួល រហូតដល់សម័យកាលសព្វថ្ងៃ មនុស្សមើលឃើញថា កិច្ចការរបស់ព្រះជាម្ចាស់ពិតជាអស្ចារ្យណាស់ ហើយកិច្ចការរបស់ទ្រង់ទៀតសោត មនុស្សមិនអាចវាស់ស្ទង់បានឡើយ។ មនុស្សមិនអាចស្រមៃឃើញអំពីរបៀបដែលព្រះជាម្ចាស់ធ្វើការ ដោយប្រើខួរក្បាលរបស់ខ្លួនឡើយ ហើយគេមើលឃើញពីកម្ពស់ដ៏តូចទាបរបស់ខ្លួន ព្រមទាំងមើលឃើញទៀតថា ភាគច្រើននៃជីវិតរបស់គេគឺជាការមិនស្ដាប់បង្គាប់។ នៅពេលដែលព្រះជាម្ចាស់បានដាក់បណ្ដាសាមនុស្ស ទ្រង់ធ្វើបែបនេះ ដើម្បីចង់សម្រេចឲ្យបានប្រសិទ្ធភាព ហើយទ្រង់មិនបានកាត់ទោសប្រហារជីវិតមនុស្សឡើយ។ ទោះបីជាព្រះអង្គបានដាក់បណ្ដាសាមនុស្សក៏ដោយ ក៏ទ្រង់បានធ្វើតាមរយៈព្រះបន្ទូលប៉ុណ្ណោះ ហើយការដាក់បណ្ដាសារបស់ទ្រង់នោះទៀតសោត តាមពិតទៅមិនបានធ្លាក់ទៅលើមនុស្សឡើយ ដ្បិតអ្វីដែលព្រះជាម្ចាស់បានដាក់បណ្ដាសានោះ គឺជាការមិនស្ដាប់បង្គាប់របស់មនុស្សទេ ដូច្នេះ ព្រះបន្ទូលនៃការដាក់បណ្ដាសារបស់ទ្រង់ក៏ត្រូវបានថ្លែងឡើងដើម្បីប្រោសឲ្យមនុស្សបានគ្រប់លក្ខណ៍ដែរ។ មិនថាព្រះជាម្ចាស់ជំនុំជម្រះមនុស្ស

ឬក៏ដាក់បណ្ដាសាមនុស្សឡើយ កិច្ចការទាំងពីរនេះត្រូវបានធ្វើឡើង ដើម្បីប្រោសឲ្យមនុស្សបានគ្រប់លក្ខណ៍ប៉ុណ្ណោះ៖ កិច្ចការទាំងពីរនេះត្រូវបានធ្វើ ដើម្បីប្រោសឲ្យគ្រប់លក្ខណ៍នូវផ្នែកមិនបរិសុទ្ធដែលមាននៅខាងក្នុងមនុស្ស។ តាមរយៈមធ្យោបាយនេះ មនុស្សត្រូវបានបន្សុទ្ធ ហើយអ្វីដែលកំពុងតែខ្វះខាតនៅក្នុងមនុស្ស ត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍ តាមរយៈព្រះបន្ទូល និងកិច្ចការរបស់ទ្រង់។ គ្រប់ជំហាននៃកិច្ចការរបស់ព្រះជាម្ចាស់ មិនថាជាការថ្លែងព្រះបន្ទូលដ៏គំរោះគំរើយ មិនថាជាការជំនុំជម្រះ ឬការវាយផ្ចាលនោះឡើយ សុទ្ធតែត្រូវបានធ្វើឡើងក្នុងគោលបំណងប្រោសឲ្យមនុស្សបានគ្រប់លក្ខណ៍ប៉ុណ្ណោះ ហើយនេះជាកិច្ចការដ៏ត្រឹមត្រូវបំផុត។ នៅគ្រប់យុគសម័យ ព្រះជាម្ចាស់មិនដែលធ្វើកិច្ចការបែបនេះពីមុនមកឡើយ គឺមានតែពេលសព្វថ្ងៃនេះប៉ុណ្ណោះ ដែលព្រះអង្គបានធ្វើការនៅក្នុងអ្នករាល់គ្នា ដើម្បីឲ្យអ្នកយល់អំពីព្រះប្រាជ្ញាញាណរបស់ទ្រង់។ ទោះបីជាអ្នកបានរងការឈឺចាប់មួយចំនួននៅក្នុងអ្នករាល់គ្នាក៏ដោយ ក៏ដួងចិត្តរបស់អ្នកមានភាពខ្ជាប់ខ្ជួន និងមានសន្តិភាពដែរ។ គឺព្រះពររបស់អ្នកនេះហើយដែលអាចរីករាយបាននៅក្នុងដំណាក់កាលនៃកិច្ចការរបស់ព្រះជាម្ចាស់មួយនេះ។ មិនថាអ្នកអាចទទួលបានបែបណានៅពេលអនាគតឡើយ គ្រប់យ៉ាងដែលអ្នកមើលឃើញអំពីកិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងអ្នករាល់គ្នានាពេលសព្វថ្ងៃនេះ គឺជាសេចក្ដីស្រឡាញ់។ ប្រសិនបើមនុស្សមិនមានបទពិសោធអំពីការជំនុំជម្រះ និងការបន្សុទ្ធរបស់ព្រះជាម្ចាស់ទេ នោះសកម្មភាព និងសេចក្ដីក្លៀវក្លារបស់គេនឹងបន្តនៅកម្រិតសើៗជានិច្ច ហើយនិស្ស័យរបស់គេក៏នឹងបន្តមិនផ្លាស់ប្ដូរដដែល។ តើការនេះរាប់ថាត្រូវបានព្រះជាម្ចាស់ទទួលយកដែរឬ? សព្វថ្ងៃនេះ ទោះបីជាមានភាពក្រអឺតក្រទម និងភាពក្អេងក្អាងជាច្រើនទៀតនៅក្នុងដួងចិត្តរបស់មនុស្សក៏ដោយ ក៏និស្ស័យរបស់មនុស្ស នៅមានស្ថិរភាពខ្លាំងជាងពេលមុនៗដែរ។ ការដោះស្រាយរបស់ព្រះជាម្ចាស់ជាមួយអ្នកត្រូវបានធ្វើឡើង ដើម្បីសង្គ្រោះដល់អ្នក ហើយទោះបីជាពេលខ្លះ អ្នកអាចមានអារម្មណ៍ឈឺចាប់ខ្លះក៏ដោយ ក៏ថ្ងៃមួយនឹងមកដល់ដែរ ជាថ្ងៃដែលមានការផ្លាស់ប្ដូរមួយនៅក្នុងនិស្ស័យរបស់អ្នក។ នៅពេលនោះ អ្នកនឹងក្រឡេក

ក្រោយ ហើយមើលឃើញពីភាពប្រកបដោយព្រះប្រាជ្ញាញាណ នៃកិច្ចការរបស់ព្រះជាម្ចាស់ ហើយនៅពេលនោះ អ្នកនឹងអាចយល់អំពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់យ៉ាងពិតប្រាកដ។ សព្វថ្ងៃនេះ មានមនុស្សមួយចំនួនដែលនិយាយថា ពួកគេយល់អំពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ហើយ ប៉ុន្ដែគ្មាននរណាម្នាក់យល់យ៉ាងច្បាស់ឡើយ។ តាមពិតទៅ ពួកគេកំពុងតែនិយាយអំពីសេចក្ដីក្លែងក្លាយទេ ដោយសារតែនៅពេលបច្ចុប្បន្ន ពួកគេមិនទាន់បានយល់នៅឡើយទេថា បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ គឺជាការសង្គ្រោះមនុស្ស ឬក៏ជាការដាក់បណ្ដាសាមនុស្ស។ ប្រហែលឥឡូវនេះ អ្នកមិនអាចមើលឃើញយ៉ាងច្បាស់ឡើយ ប៉ុន្ដែថ្ងៃមួយនឹងមកដល់ ជាថ្ងៃដែលអ្នកមើលឃើញថា ថ្ងៃដែលព្រះជាម្ចាស់ទទួលបានសិរីល្អបានមកដល់ហើយ ហើយអ្នកនឹងមើលឃើញអំពីអត្ថន័យនៃការស្រឡាញ់ព្រះជាម្ចាស់ អ្នកនឹងចាប់ផ្ដើមស្គាល់ពីជីវិតជាមនុស្ស សាច់ឈាមរបស់អ្នកនឹងរស់នៅក្នុងពិភពលោកនៃការស្រឡាញ់ព្រះជាម្ចាស់ វិញ្ញាណរបស់អ្នកនឹងត្រូវបានរំដោះឲ្យមានសេរីភាព ជីវិតរបស់អ្នកនឹងពេញដោយសេចក្ដីអំណរ ហើយអ្នកនឹងតែងតែនៅជិតព្រះជាម្ចាស់ និងសម្លឹងមើលទ្រង់ជានិច្ច។ នៅពេលនោះ អ្នកនឹងដឹងថា កិច្ចការរបស់ព្រះជាម្ចាស់នាពេលសព្វថ្ងៃពិតជាមានតម្លៃខ្លាំងណាស់។

សព្វថ្ងៃនេះ មនុស្សភាគច្រើនមិនមានចំណេះដឹងនេះឡើយ។ ពួកគេជឿថា ទុក្ខវេទនាគ្មានតម្លៃ ពួកគេត្រូវបានលោកីយ៍បោះបង់ចោល ជីវិតគ្រួសាររបស់ពួកគេជួបនូវបញ្ហា ពួកគេមិនត្រូវបានព្រះជាម្ចាស់ស្រឡាញ់ ហើយអនាគតរបស់ពួកគេមានភាពស្រពេចស្រពិល។ ទុក្ខវេទនារបស់មនុស្សមួយចំនួនឡើងដល់កម្រិតកំពូល ហើយគំនិតរបស់ពួកគេបែរទៅរកសេចក្ដីស្លាប់។ នេះមិនមែនជាសេចក្ដីស្រឡាញ់ដ៏ពិតចំពោះព្រះជាម្ចាស់ឡើយ។ មនុស្សបែបនេះគឺជាមនុស្សកំសាកវិញទេ ព្រោះពួកគេគ្មានការតស៊ូព្យាយាម ទន់ជ្រាយ និងគ្មានកម្លាំងសោះ! ព្រះជាម្ចាស់មានព្រះទ័យចង់ឲ្យមនុស្សស្រឡាញ់ទ្រង់ ប៉ុន្ដែបើមនុស្សស្រឡាញ់ទ្រង់កាន់តែខ្លាំង នោះមនុស្សនឹងជួបទុក្ខវេទនាកាន់តែខ្លាំង ហើយបើមនុស្សស្រឡាញ់ទ្រង់កាន់តែខ្លាំង នោះ

មនុស្សនឹងជួបការល្បងលកាន់តែខ្លាំងដែរ។ ប្រសិនបើអ្នកស្រឡាញ់ទ្រង់ នោះទុក្ខវេទនាសព្វបែបយ៉ាងនឹងធ្លាក់មកលើអ្នក ហើយប្រសិនបើអ្នកមិនស្រឡាញ់ទេ នោះអ្វីៗគ្រប់យ៉ាងនឹងប្រហែលជាដំណើរការយ៉ាងរលូនសម្រាប់អ្នក ហើយគ្រប់យ៉ាងដែលនៅជុំវិញអ្នកនឹងមានសុខសន្តិភាព។ នៅពេលដែលអ្នកស្រឡាញ់ព្រះជាម្ចាស់ អ្នកនឹងមានអារម្មណ៍ថា មានរឿងជាច្រើននៅជុំវិញអ្នកដែលអ្នកមិនអាចយកឈ្នះបានឡើយ ហើយដោយសារតែកម្ពស់របស់អ្នកនៅទាបពេក ដូច្នេះ អ្នកនឹងត្រូវតែទទួលការបន្សុទ្ធ។ ជាងនេះទៅទៀត អ្នកនឹងគ្មានសមត្ថភាពបំពេញតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ឡើយ ហើយអ្នកនឹងតែងតែមានអារម្មណ៍ថា បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់មានភាពខ្ពង់ខ្ពស់ពេក ដែលហួសពីការឈោងចាប់របស់មនុស្ស។ ដោយព្រោះតែការទាំងអស់នេះ អ្នកនឹងត្រូវបានបន្សុទ្ធ ដ្បិតមានសេចក្ដីកម្សោយយ៉ាងច្រើននៅខាងក្នុងអ្នក ជាសេចក្ដីកម្សោយដែលគ្មានសមត្ថភាពបំពេញតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ឡើយ ដូច្នេះ អ្នកនឹងត្រូវបានបន្សុទ្ធនៅផ្នែកខាងក្នុង។ ប៉ុន្តែ អ្នករាល់គ្នាត្រូវតែមើលឃើញឲ្យច្បាស់ថា ការញែកជាបរិសុទ្ធនេះអាចសម្រេចបានតាមរយៈការបន្សុទ្ធតែប៉ុណ្ណោះ។ ដូច្នេះ ក្នុងអំឡុងពេលនៃគ្រាចុងក្រោយទាំងនេះ អ្នករាល់គ្នា ត្រូវតែធ្វើបន្ទាល់អំពីព្រះជាម្ចាស់។ មិនថាទុក្ខវេទនារបស់អ្នកធំធេងប៉ុនណាឡើយ អ្នកគួរតែដើររហូតដល់ទីបំផុត ហើយទោះបីជាដល់ដង្ហើមចុងក្រោយរបស់អ្នកក៏ដោយ ក៏អ្នកត្រូវតែបន្តស្មោះត្រង់ចំពោះព្រះជាម្ចាស់ ហើយចុះចូលចំពោះការចាត់ចែងរបស់ព្រះជាម្ចាស់ដដែល ពោលគឺមានតែបែបនេះទេ ទើបជាការស្រឡាញ់ព្រះជាម្ចាស់យ៉ាងពិតប្រាកដ ហើយមានតែបែបនេះទេ ទើបជាការធ្វើបន្ទាល់ដ៏រឹងមាំ និងលាន់កងរំពង។ នៅពេលដែលអ្នកត្រូវបានសាតាំងល្បួង អ្នកគួរតែនិយាយថា៖ «ដួងចិត្តរបស់ខ្ញុំជាកម្មសិទ្ធិរបស់ព្រះជាម្ចាស់ ហើយព្រះជាម្ចាស់បានទទួលយកខ្ញុំរួចហើយ។ ខ្ញុំមិនអាចបំពេញតាមចិត្តរបស់អ្នកឡើយ ព្រោះថាខ្ញុំត្រូវតែថ្វាយនូវអ្វីៗទាំងអស់របស់ខ្ញុំដើម្បីបំពេញតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់»។ ប្រសិនបើអ្នកបំពេញតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់កាន់តែច្រើន នោះព្រះជាម្ចាស់ប្រទាន

ព្រះពរដល់អ្នកកាន់តែច្រើន ហើយកម្លាំងនៃសេចក្ដីស្រឡាញ់របស់អ្នកចំពោះព្រះជាម្ចាស់ក៏កាន់តែខ្លាំងដែរ។ ជាមួយគ្នានេះដែរ អ្នកនឹងមានសេចក្ដីជំនឿ និងការតាំងចិត្ត ហើយអ្នកនឹងមានអារម្មណ៍ថា គ្មានអ្វីមួយមានតម្លៃ ឬសំខាន់ជាងការលះបង់ជីវិតស្រឡាញ់ព្រះជាម្ចាស់ឡើយ។ គេអាចនិយាយបានថា ប្រសិនបើមនុស្សស្រឡាញ់ព្រះជាម្ចាស់ នោះគេនឹងគ្មានភាពសោកសៅឡើយ។ ទោះបីជាពេលខ្លះសាច់ឈាមរបស់អ្នកមានភាពទន់ខ្សោយ ហើយអ្នកជួបនូវបញ្ហាជាក់ស្ដែងជាច្រើនក៏ដោយ ក៏ក្នុងអំឡុងពេលទាំងនេះ អ្នកនឹងពឹងអាងលើព្រះជាម្ចាស់យ៉ាងពិតប្រាកដដែរ ហើយនៅក្នុងវិញ្ញាណរបស់អ្នក អ្នកនឹងទទួលបានការលួងលោម ព្រមទាំងមានអារម្មណ៍ជឿជាក់ថា អ្នកមានអ្វីមួយជាទីពំនាក់។ តាមរបៀបនេះ អ្នកនឹងអាចយកឈ្នះលើបរិយាកាសជាច្រើន ហើយអ្នកក៏នឹងមិនរអ៊ូរទាំអំពីព្រះជាម្ចាស់ ដោយសារតែការថប់បារម្ភដែលអ្នកមាននោះដែរ។ ផ្ទុយទៅវិញ អ្នកនឹងចង់ស្រែកច្រៀង រាំ និងអធិស្ឋាន ចង់ជួបជុំ និងប្រាស្រ័យទាក់ទង ចង់ទូលគំនិតរបស់អ្នកប្រាប់ដល់ព្រះជាម្ចាស់ ហើយអ្នកនឹងមានអារម្មណ៍ថា មនុស្ស រឿងរ៉ាវ និងអ្វីៗគ្រប់យ៉ាងដែលបានកើតឡើងជុំវិញអ្នក ដែលព្រះជាម្ចាស់បានរៀបចំទុកទាំងអំបាលម៉ាននេះ ពិតជាសក្ដិសមមែន។ ប្រសិនបើអ្នកមិនស្រឡាញ់ព្រះជាម្ចាស់ទេ នោះអ្វីៗគ្រប់យ៉ាងដែលអ្នកសម្លឹងមើលនឹងក្លាយជារឿងគួរឲ្យធុញទ្រាន់ចំពោះអ្នក ហើយគ្មានអ្វីមួយនឹងក្លាយជាទីគាប់ភ្នែករបស់អ្នកឡើយ។ នៅក្នុងដួងចិត្តរបស់អ្នក អ្នកនឹងគ្មានសេរីភាពឡើយ គឺមានតែការសង្កត់សង្កិនប៉ុណ្ណោះ ដួងចិត្តរបស់អ្នកនឹងតែងតែរអ៊ូរទាំអំពីព្រះជាម្ចាស់ ហើយអ្នកនឹងតែងតែមានអារម្មណ៍ថា អ្នករងទារុណកម្មច្រើនពេកហើយ ព្រមទាំងមានអារម្មណ៍ទៀតថា នេះជារឿងអយុត្តិធម៌ណាស់។ ប្រសិនបើអ្នកមិនដេញតាមដើម្បីជាប្រយោជន៍ឱ្យបានសេចក្ដីសុខ ហើយបែរជាស្វះស្វែងបំពេញតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងមិនឲ្យសាតាំងចោទប្រកាន់ នោះការស្វះស្វែងបែបនេះនឹងផ្ដល់ឲ្យអ្នកមានកម្លាំងដ៏ខ្លាំងក្លាក្នុងការស្រឡាញ់ព្រះជាម្ចាស់មិនខាន។ មនុស្សអាចអនុវត្តតាមគ្រប់ទាំងសេចក្ដីដែលព្រះជាម្ចាស់បានថ្លែង ហើយគ្រប់យ៉ាងដែលគេធ្វើ គឺដើម្បី

អាចបំពេញតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ នេះហើយជាអត្ថន័យនៃការមានភាពពិតជាក់ស្ដែងនោះ។ ការស្វះស្វែងបំពេញតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ គឺជាការប្រើសេចក្ដីស្រឡាញ់របស់អ្នកចំពោះព្រះជាម្ចាស់ ដោយអនុវត្តតាមព្រះបន្ទូលរបស់ទ្រង់ ហើយមិនថាក្នុងពេលណាឡើយ ទោះបីជាពេលដែលអ្នកដទៃគ្មានកម្លាំងចង់ធ្វើក៏ដោយ ក៏នៅខាងក្នុងអ្នកនៅតែមានដួងចិត្តដែលស្រឡាញ់ព្រះជាម្ចាស់ ជាដួងចិត្តមួយដែលស្រេកឃ្លានយ៉ាងជ្រាលជ្រៅចង់បានព្រះជាម្ចាស់ ព្រមទាំងនឹករឭកទ្រង់យ៉ាងខ្លាំង។ នេះហើយជាកម្ពស់ដ៏ពិតប្រាកដនោះ។ កម្ពស់របស់អ្នកឡើងខ្ពស់បាន គឺអាស្រ័យលើទំហំនៃសេចក្ដីស្រឡាញ់របស់អ្នកដែលមានចំពោះព្រះជាម្ចាស់ អាស្រ័យលើថាតើអ្នកអាចបន្ដឈររឹងមាំឬអត់ នៅពេលដែលជួបការល្បងល អាស្រ័យលើថាតើអ្នកទន់ខ្សោយឬអត់ នៅពេលដែលជួបបរិយាកាសជាក់លាក់មួយ និងអាស្រ័យលើថាតើអ្នកអាចប្រកាន់ជំហររឹងប៉ឹងឬអត់ នៅពេលដែលបងប្អូនប្រុសស្រីរបស់អ្នកបដិសេធអ្នក។ ការពិតនឹងស្ដែងចេញឲ្យឃើញច្បាស់អំពីលក្ខណៈនៃសេចក្ដីស្រឡាញ់របស់អ្នកចំពោះព្រះជាម្ចាស់។ តាមរយៈកិច្ចការភាគច្រើនរបស់ព្រះជាម្ចាស់ គេអាចមើលឃើញបានថា ព្រះជាម្ចាស់ពិតជាស្រឡាញ់មនុស្ស ទោះបីជាភ្នែកខាងវិញ្ញាណរបស់មនុស្សមិនទាន់បានបើកចំហទាំងស្រុង ហើយគេមិនអាចមើលឃើញយ៉ាងច្បាស់អំពីកិច្ចការភាគច្រើនរបស់ព្រះជាម្ចាស់ និងបំណងព្រះហឫទ័យរបស់ទ្រង់ ព្រមទាំងភាពគួរឲ្យស្រឡាញ់ជាច្រើនទៀតអំពីព្រះជាម្ចាស់។ មនុស្សមានសេចក្ដីស្រឡាញ់ដ៏ពិតតិចតួចពេកហើយចំពោះព្រះជាម្ចាស់។ អ្នកបានជឿលើព្រះជាម្ចាស់ពេញមួយជីវិត ហើយនៅសព្វថ្ងៃនេះ ព្រះជាម្ចាស់បានកាត់ផ្ដាច់ផ្លូវទាំងអស់នៃការរត់គេច។ បើនិយាយឲ្យចំ អ្នកគ្មានជម្រើសអ្វីផ្សេងក្រៅពីដើរតាមមាគ៌ាត្រឹមត្រូវ ជាមាគ៌ាត្រឹមត្រូវដែលអ្នកត្រូវបានដឹកនាំឲ្យដើរ តាមរយៈការជំនុំជម្រះដ៏ឃោរឃៅ និងសេចក្ដីសង្គ្រោះដ៏ខ្ពស់បំផុតរបស់ព្រះជាម្ចាស់នោះឡើយ។ មានតែក្រោយពេលដែលជួបទុក្ខលំបាក និងការបន្សុទ្ធទេ ទើបមនុស្សដឹងថា ព្រះជាម្ចាស់គួរឲ្យស្រឡាញ់។ តាមរយៈការមានបទពិសោធរហូតដល់ពេលសព្វថ្ងៃ គេអាចនិយាយបានថា មនុស្សបានចាប់ផ្ដើមស្គាល់អំពីផ្នែក

ដ៏គួរឲ្យស្រឡាញ់របស់ព្រះជាម្ចាស់ហើយ ប៉ុន្តែការនេះនៅមិនទាន់គ្រប់គ្រាន់ឡើយ ដោយសារតែមនុស្សនៅខ្វះចំណុចជាច្រើនទៀត។ មនុស្សត្រូវតែមានបទពិសោធអំពីកិច្ចការដ៏អស្ចារ្យជាច្រើនទៀតរបស់ព្រះជាម្ចាស់ ព្រមទាំងមានបទពិសោធជាច្រើនទៀតអំពីគ្រប់ទាំងការបន្សុទ្ធចេញពីទុក្ខវេទនា ដែលត្រូវបានព្រះជាម្ចាស់រៀបចំទុក។ មានតែបែបនេះទេ ទើបនិស្ស័យជីវិតរបស់មនុស្សត្រូវបានផ្លាស់ប្ដូរ។

# មានតែការស្រលាញ់ព្រះជាម្ចាស់តែប៉ុណ្ណោះ ទើបជាការជឿលើព្រះជាម្ចាស់ពិតប្រាកដ

សព្វថ្ងៃនេះ ដោយសារអ្នករាល់គ្នាព្យាយាមស្រលាញ់ និងស្គាល់ព្រះជាម្ចាស់ អ្នករាល់គ្នាត្រូវតែស៊ូទ្រាំនឹងការលំបាក និងការបន្សុទ្ធតាមផ្នែកមួយ ហើយមួយទៀត អ្នករាល់គ្នាត្រូវតែបង់ថ្លៃ។ គ្មានមេរៀនណាដែលជ្រាលជ្រៅ ជាងមេរៀនអំពីការស្រឡាញ់ព្រះជាម្ចាស់នោះទេ ហើយអាចនិយាយបានថា មេរៀនដែលមនុស្សរៀនអំពីជំនឿក្នុងមួយជីវិត គឺរៀនអំពីរបៀបស្រឡាញ់ព្រះជាម្ចាស់នេះឯង។ និយាយឲ្យចំគឺថា ប្រសិនបើអ្នកជឿលើព្រះជាម្ចាស់ អ្នកត្រូវតែស្រឡាញ់ព្រះជាម្ចាស់។ ប្រសិនបើអ្នកគ្រាន់តែជឿលើព្រះជាម្ចាស់ ប៉ុន្តែមិនស្រឡាញ់ទ្រង់ និងមិនបានស្គាល់ព្រះអង្គ ហើយមិនដែលស្រឡាញ់ព្រះអង្គដោយសេចក្ដីស្រឡាញ់ពិតប្រាកដដែលចេញពីក្នុងចិត្តរបស់អ្នកទេ នោះជំនឿរបស់អ្នកលើព្រះជាម្ចាស់ គឺឥតប្រយោជន៍ឡើយ។ ប្រសិនបើអ្នកគ្មានសេចក្ដីស្រឡាញ់ចំពោះព្រះជាម្ចាស់នៅក្នុងជំនឿរបស់អ្នកលើព្រះជាម្ចាស់ទេ នោះអ្នករស់នៅដោយអសារឥតការ ហើយជីវិតទាំងមូលរបស់អ្នកគឺទាបបំផុតក្នុងចំណោមជីវិតទាំងអស់។ ប្រសិនបើពេញមួយជីវិតរបស់អ្នក អ្នកមិនដែលស្រឡាញ់ និងបំពេញព្រះហឫទ័យព្រះជាម្ចាស់សោះ នោះតើអ្វីទៅជាប្រយោជន៍នៃការរស់នៅរបស់អ្នក? ហើយតើអ្វីទៅជាប្រយោជន៍នៃជំនឿរបស់អ្នកលើព្រះជាម្ចាស់? តើនោះមិនមែនជាការខ្ជះខ្ជាយនូវការខិតខំទេឬអី? និយាយឲ្យចំគឺថា

ប្រសិនបើមនុស្សជឿ និងស្រឡាញ់ព្រះជាម្ចាស់ នោះពួកគេត្រូវតែបង់ថ្លៃ។ ជាជាងការព្យាយាមធ្វើសកម្មភាពតាមរបៀបមួយចំនួននៅខាងក្រៅ ពួកគេគួរតែស្វះស្វែងរកពន្លឺពិតប្រាកដនៅខាងក្នុងជម្រៅនៃដួងចិត្តរបស់ពួកគេ។ ប្រសិនបើអ្នកសាទរចំពោះការច្រៀងរាំ ប៉ុន្តែគ្មានសមត្ថភាពអនុវត្តនូវសេចក្តីពិត តើអ្នកអាចនិយាយថាស្រឡាញ់ព្រះជាម្ចាស់បានយ៉ាងដូចម្តេចទៅ? ការស្រឡាញ់ព្រះជាម្ចាស់ តម្រូវឲ្យមានការស្វះស្វែងរកបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ក្នុងគ្រប់ការទាំងអស់ និងតម្រូវឲ្យអ្នកស្ទង់មើលជ្រៅទៅខាងក្នុង នៅពេលមានរឿងអ្វីមួយកើតឡើងចំពោះអ្នក ការព្យាយាមយល់ពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងការព្យាយាមដឹងនូវអ្វីៗ ដែលជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ នោះហើយទើបជាកិច្ចការដែលទ្រង់ប្រាប់ឲ្យអ្នកសម្រេចឲ្យបាន និងជារបៀបដែលអ្នកគួរតែយកចិត្តទុកដាក់ចំពោះបំណងព្រះហឫទ័យរបស់ទ្រង់។ ឧទាហរណ៍៖ មានរឿងអ្វីមួយកើតឡើងដែលតម្រូវឲ្យអ្នកស៊ូទ្រាំនឹងការលំបាក នៅពេលនោះអ្នកគួរតែយល់អំពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងរបៀបដែលអ្នកគួរតែយកចិត្តទុកដាក់ ចំពោះបំណងព្រះហឫទ័យរបស់ទ្រង់។ អ្នកមិនត្រូវបំពេញចិត្តខ្លួនឯងទេ៖ ជាដំបូង ត្រូវទុកចោលខ្លួនឯងទៅម្ខាងសិន។ គ្មានអ្វីដែលអន់ជាងសាច់ឈាមទៅទៀតនោះទេ។ អ្នកត្រូវតែប្រឹងប្រែងបំពេញបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ហើយអ្នកត្រូវតែបំពេញករណីយកិច្ចរបស់អ្នក។ ដោយមានគំនិតបែបនេះ ព្រះជាម្ចាស់នឹងនាំមកឲ្យអ្នកនូវការបំភ្លឺយ៉ាងពិសេសនៅក្នុងរឿងនេះ ហើយចិត្តរបស់អ្នកក៏នឹងបានសុខស្រួលផងដែរ។ មិនថារឿងធំ ឬតូចនោះទេ នៅពេលដែលវាកើតឡើងចំពោះអ្នក ជាដំបូង អ្នកត្រូវទុកចោលខ្លួនឯងទៅម្ខាងសិន ហើយចាត់ទុកសាច់ឈាមថាជារបស់ដែលអន់បំផុតក្នុងចំណោមរបស់ទាំងអស់។ កាលណាអ្នកកាន់តែបំពេញចិត្តខាងសាច់ឈាម នោះវាកាន់តែយកសេរីភាពទៅបាត់កាន់តែច្រើន។ ប្រសិនបើអ្នកបំពេញចិត្តវានៅពេលនេះ ពេលក្រោយវានឹងសុំច្រើនបន្ថែមទៀត។ នៅពេលរឿងនេះចេះតែបន្ត មនុស្សនឹងបែរមកស្រឡាញ់សាច់ឈាមកាន់តែខ្លាំងឡើងៗ។ សាច់ឈាមតែងតែមានសេចក្តីប្រាថ្នាហួសហេតុ ហើយវា

តែងតែសុំឲ្យអ្នកបំពេញចិត្តវា និងឲ្យអ្នកចម្អែតវា មិនថាវាស្ថិតនៅក្នុងរបស់ដែលអ្នកបរិភោគ អ្វីៗដែលអ្នកស្លៀកពាក់ ឬនៅក្នុងកំហឹងរបស់អ្នក ឬការផ្គាប់ផ្គុនចំពោះភាពទន់ខ្សោយ និងភាពខ្ជិលច្រអូសរបស់អ្នកនោះទេ...។ កាលណាអ្នកបំពេញចិត្តសាច់ឈាមកាន់តែច្រើន នោះសេចក្ដីប្រាថ្នារបស់វានឹងកាន់តែខ្លាំងឡើង ហើយសាច់ឈាមក៏កាន់តែពុករលួយខ្លាំងឡើងៗ រហូតដល់ថ្នាក់សាច់ឈាមរបស់មនុស្សលាក់ពួនសូម្បីតែសញ្ញាណដែលកាន់តែជ្រៅទៅៗ ហើយមិនស្ដាប់បង្គាប់ព្រះជាម្ចាស់ និងលើកតម្កើងខ្លួនឯង ព្រមទាំងសង្ស័យអំពីកិច្ចការរបស់ព្រះជាម្ចាស់។ កាលណាអ្នកបំពេញចិត្តសាច់ឈាមកាន់តែច្រើន នោះភាពទន់ខ្សោយរបស់សាច់ឈាមនឹងកាន់តែខ្លាំងឡើង។ អ្នកនឹងមានអារម្មណ៍ថា គ្មាននរណាម្នាក់អាណិតអាសូរចំពោះភាពទន់ខ្សោយរបស់អ្នកទេ អ្នកនឹងជឿជានិច្ចថា ព្រះជាម្ចាស់បានទៅឆ្ងាយសែនឆ្ងាយ ហើយអ្នកនឹងនិយាយថា៖ «ព្រះជាម្ចាស់អីក៏គ្រោតគ្រាតយ៉ាងនេះ? ហេតុអ្វីបានជាទ្រង់មិនឲ្យមនុស្សឈប់សម្រាកខ្លះផងដូច្នេះ?» នៅពេលមនុស្សបំពេញចិត្តសាច់ឈាម ហើយស្រលាញ់បីបាច់វាខ្លាំងពេក នោះពួកគេបំផ្លាញខ្លួនឯងហើយ។ ប្រសិនបើអ្នកពិតជាស្រឡាញ់ព្រះជាម្ចាស់ ហើយមិនបំពេញចិត្តសាច់ឈាមមែន នោះអ្នកនឹងឃើញថា គ្រប់យ៉ាងដែលព្រះជាម្ចាស់ធ្វើ គឺសុទ្ធតែត្រឹមត្រូវ និងល្អខ្លាំងណាស់ ហើយឃើញថា ការដាក់បណ្ដាសារបស់ទ្រង់ចំពោះការបះបោររបស់អ្នក និងការជំនុំជម្រះរបស់ទ្រង់ចំពោះភាពទុច្ចរិតរបស់អ្នកគឺជារឿងត្រឹមត្រូវ។ មានពេលខ្លះ ព្រះជាម្ចាស់នឹងវាយផ្ចាល ហើយដាក់ពិន័យអ្នក និងបង្កើនបរិយាកាសដើម្បីលត់ដំអ្នក ដោយបង្ខំអ្នកឲ្យមករកទ្រង់ ហើយអ្នកនឹងមានអារម្មណ៍ជានិច្ចថា អ្វីដែលព្រះជាម្ចាស់កំពុងធ្វើគឺអស្ចារ្យមែន។ ដូច្នេះ អ្នកនឹងមានអារម្មណ៍ហាក់ដូចជាគ្មានការឈឺចាប់ខ្លាំងនោះទេ ហើយយល់ឃើញថា ព្រះជាម្ចាស់គួរឲ្យស្រឡាញ់ខ្លាំងណាស់។ ប្រសិនបើអ្នកផ្គាប់ផ្គុនដល់ភាពទន់ខ្សោយខាងសាច់ឈាម ហើយនិយាយថា ព្រះជាម្ចាស់ទៅឆ្ងាយសែនឆ្ងាយ នោះអ្នកនឹងមានអារម្មណ៍ឈឺចាប់ជានិច្ច ហើយអ្នកនឹងធ្លាក់ទឹកចិត្តជានិច្ច អ្នកនឹងមិនយល់ច្បាស់អំពីកិច្ចការទាំងអស់របស់ព្រះជាម្ចាស់ឡើយ ហើយវានឹង

ហាក់ដូចជាព្រះជាម្ចាស់មិនចេះអាណិតអាសូរចំពោះភាពទន់ខ្សោយរបស់មនុស្សអ្វីបន្តិចសោះ ថែមទាំងមិនដឹងពីការលំបាករបស់មនុស្សទៀតផង។ ដូច្នេះហើយ អ្នកនឹងមានអារម្មណ៍កម្សត់ និងឯកោជានិច្ច ប្រៀបដូចជាអ្នកបានរងនូវភាពអយុត្តិធម៌យ៉ាងខ្លាំង ហើយនៅពេលនេះអ្នកនឹងចាប់ផ្ដើមត្អូញត្អែរ។ កាលណាអ្នកផ្គាប់ផ្គុនដល់ភាពទន់ខ្សោយខាងសាច់ឈាមកាន់តែច្រើនបែបនេះ នោះអ្នកនឹងមានអារម្មណ៍ថាព្រះជាម្ចាស់ទៅកាន់តែឆ្ងាយទៅៗ រហូតដល់ថ្នាក់អាក្រក់យ៉ាងខ្លាំង ដោយអ្នកបដិសេធកិច្ចការរបស់ព្រះជាម្ចាស់ ហើយចាប់ផ្ដើមប្រឆាំងនឹងព្រះជាម្ចាស់ ថែមទាំងមិនស្ដាប់បង្គាប់អ្វីគ្រប់យ៉ាងផង។ ដូច្នេះ អ្នកត្រូវតែបះបោរទាស់នឹងសាច់ឈាម ហើយកុំផ្គាប់ផ្គុនដល់វាទៀត៖ «ប្ដី (ប្រពន្ធ) កូនៗ ក្ដីសង្ឃឹម អាពាហ៍ពិពាហ៍ គ្រួសាររបស់ខ្ញុំ គ្មាននរណាម្នាក់មានបញ្ហានោះទេ! ក្នុងចិត្តខ្ញុំមានតែព្រះជាម្ចាស់ប៉ុណ្ណោះ ហើយខ្ញុំត្រូវតែព្យាយាមឲ្យអស់ពីសមត្ថភាពដើម្បីបំពេញទៅតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងមិនបំពេញចិត្តសាច់ឈាមឡើយ»។ អ្នកត្រូវតែមានការតាំងចិត្តបែបនេះ។ ប្រសិនបើអ្នកមានការតាំងចិត្តបែបនេះជាប់ជានិច្ច នោះនៅពេលអ្នកអនុវត្តនូវសេចក្ដីពិត ហើយទុកចោលខ្លួនឯងទៅម្ខាង អ្នកនឹងអាចធ្វើបានដូច្នោះដោយការខិតខំដ៏តិចតួចប៉ុណ្ណោះ។ គេនិយាយថា កាលពីមុនមានកសិករម្នាក់បានឃើញពស់មួយកករឹងនៅលើផ្លូវ។ កសិករនោះបានយកវាឡើង ហើយឱបវាជាប់នឹងទ្រូងរបស់គាត់ ហើយបន្ទាប់ពីពស់នោះបានរស់ឡើងវិញ វាក៏បានចឹកកសិកររហូតដល់ស្លាប់។ សាច់ឈាមរបស់មនុស្សគឺដូចជាពស់ដែរ៖ លក្ខណៈរបស់វាគឺបង្កអន្ដរាយដល់អាយុជីវិតរបស់ពួកគេ ហើយនៅពេលវាទទួលបានលក្ខណៈផ្ទាល់ខ្លួនរបស់វាពេញលេញ នោះជីវិតរបស់អ្នកក៏ត្រូវបាត់បង់។ សាច់ឈាមគឺជារបស់សាតាំង។ នៅក្នុងសាច់ឈាមនេះវគឺជាសេចក្ដីប្រាថ្នាដ៏ហួសហេតុ វាគិតតែអំពីខ្លួនឯងប៉ុណ្ណោះ វាចង់បានភាពសុខស្រួល ហើយរីករាយនឹងការកម្សាន្ត ដោយលង់ក្នុងសេចក្ដីខ្ជិលច្រអូស និងភាពទំនេរ ហើយពេលបំពេញចិត្តវាដល់ចំណុចមួយ នោះនៅទីបំផុត អ្នកនឹងត្រូវវាស៊ីអស់រលីង។ និយាយឲ្យចំគឺថា ប្រសិនបើអ្នកបំពេញចិត្តវានៅពេលនេះ ពេលក្រោយ

វានឹងមកសុំច្រើនបន្ថែមទៀត។ វាមានសេចក្ដីប្រាថ្នាហួសហេតុ និងតម្រូវការថ្មីៗជានិច្ច ហើយកេងចំណេញពីការផ្គាប់ផ្គុនរបស់អ្នកចំពោះសាច់ឈាម ដើម្បីធ្វើឲ្យអ្នកស្រឡាញ់បីបាច់វាកាន់តែខ្លាំងឡើង និងរស់នៅក្នុងភាពសុខស្រួលរបស់វា ហើយប្រសិនបើអ្នកមិនយកឈ្នះវាទេ នោះនៅទីបំផុត អ្នកនឹងបំផ្លាញខ្លួនឯង។ មិនថាអ្នកអាចទទួលបានជីវិតនៅចំពោះព្រះជាម្ចាស់ឬអត់ ហើយទីបញ្ចប់របស់អ្នកនឹងទៅជាយ៉ាងណានោះទេ គឺអាស្រ័យលើរបៀបដែលអ្នកធ្វើការបះបោរទាស់នឹងសាច់ឈាមយ៉ាងដូចម្ដេចប៉ុណ្ណោះ។ ព្រះជាម្ចាស់បានសង្គ្រោះអ្នក និងជ្រើសរើសអ្នក ហើយបានកំណត់អ្នកទុកជាមុន ប៉ុន្តែប្រសិនបើអ្នកមិនសុខចិត្តបំពេញតាមព្រះហឫទ័យរបស់ទ្រង់ទេ អ្នកមិនសុខចិត្តអនុវត្តនូវសេចក្ដីពិតទេ ហើយអ្នកមិនសុខចិត្តបះបោរទាស់នឹងសាច់ឈាមផ្ទាល់របស់អ្នកដោយប្រើដួងចិត្តដែលពិតជាស្រឡាញ់ព្រះជាម្ចាស់ទេ នោះនៅទីបំផុតអ្នកនឹងបំផ្លាញខ្លួនឯង ហេតុដូច្នេះហើយ អ្នកនឹងត្រូវស៊ូទ្រាំចំពោះការឈឺចាប់យ៉ាងខ្លាំងមហិមា។ ប្រសិនបើអ្នកជានិច្ចកាលផ្គាប់ផ្គុនដល់សាច់ឈាម នោះសាតាំងនឹងលេបអ្នកបន្តិចម្ដងៗរហូតដល់អស់ ហើយមិនទុកឲ្យអ្នកមានជីវិត ឬទាក់ទងនឹងព្រះវិញ្ញាណឡើយ រហូតដល់ថ្ងៃដែលអ្នកងងឹតនៅខាងក្នុងទាំងស្រុង។ នៅពេលអ្នករស់នៅក្នុងភាពងងឹត អ្នកនឹងត្រូវសាតាំងចាប់ឃុំខ្លួន អ្នកនឹងលែងមានព្រះជាម្ចាស់នៅក្នុងចិត្តរបស់អ្នកទៀតហើយ នៅពេលនោះ អ្នកនឹងបដិសេធថាគ្មានព្រះជាម្ចាស់ទេ រួចហើយអ្នកនឹងចាកចេញពីទ្រង់។ ដូច្នេះ ប្រសិនបើមនុស្សចង់ស្រឡាញ់ព្រះជាម្ចាស់ ពួកគេត្រូវតែបង់ថ្លៃនៃការឈឺចាប់ ហើយស៊ូទ្រាំនឹងការលំបាក។ មិនចាំបាច់មានជំនឿស៊ប់ និងការលំបាកពីខាងក្រៅ ក៏ដូចជាការអានច្រើន និងការរវល់ខ្លាំងច្រើននោះទេ ផ្ទុយទៅវិញពួកគេគួរតែទុកចោលរបស់ដែលនៅជាមួយពួកគេទាំងនេះដូចជា៖ ការគិតហួសប្រមាណ ផលប្រយោជន៍ផ្ទាល់ខ្លួន និងការពិចារណាផ្ទាល់ខ្លួន សញ្ញាណ និងបំណងរបស់ពួកគេ។ នេះហើយជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។

ការដោះស្រាយរបស់ព្រះជាម្ចាស់ចំពោះនិស្ស័យខាងក្រៅរបស់មនុស្សក៏ជាផ្នែក

មួយនៃកិច្ចការរបស់ព្រះអង្គផងដែរ ឧទាហរណ៍ដូចជា ការដោះស្រាយចំពោះភាពជាមនុស្សដែលមិនត្រឹមត្រូវពីខាងក្រៅរបស់មនុស្ស ឬក៏របៀបរស់នៅ និងទម្លាប់របស់ពួកគេ មធ្យោបាយ និងទំនៀមទម្លាប់របស់ពួកគេ ក៏ដូចជាការអនុវត្តខាងក្រៅរបស់ពួកគេ និងជំនឿមុតមាំរបស់ពួកគេ។ ប៉ុន្តែនៅពេលទ្រង់ប្រាប់ឲ្យមនុស្សអនុវត្តនូវសេចក្ដីពិត ហើយផ្លាស់ប្ដូរនិស្ស័យរបស់ពួកគេ នោះអ្វីដែលត្រូវដោះស្រាយជាចម្បង គឺ បំណង និងសញ្ញាណនៅក្នុងពួកគេ។ បើគ្រាន់តែដោះស្រាយចំពោះនិស្ស័យខាងក្រៅរបស់អ្នកនោះ គឺមិនពិបាកទេ វាប្រៀបដូចជាការប្រាប់អ្នកកុំឲ្យបរិភោគនូវអ្វីដែលអ្នកចូលចិត្តជាដើម គឺស្រួលទេ។ តែទោះជាយ៉ាងនេះក្ដី ចំពោះអ្វីៗដែលប៉ះជាប់នឹងសញ្ញាណខាងក្នុងខ្លួនឯង គឺមិនងាយកម្ចាត់ចេញនោះទេ។ វាតម្រូវឲ្យមនុស្សបះបោរទាស់នឹងសាច់ឈាម ហើយបង់ថ្លៃ និងរងទុក្ខនៅចំពោះព្រះភ័ក្ត្ររបស់ព្រះជាម្ចាស់។ ជាពិសេស វាគឺដូច្នេះឯងចំពោះបំណងរបស់មនុស្ស។ ចាប់តាំងពីពេលមនុស្សចាប់ផ្ដើមជឿលើព្រះជាម្ចាស់ ពួកគេបានលាក់ពួនបំណងដែលមិនត្រឹមត្រូវជាច្រើន។ នៅពេលអ្នកមិនអនុវត្តនូវសេចក្ដីពិត អ្នកមានអារម្មណ៍ថា បំណងរបស់អ្នកទាំងអស់គឺសុទ្ធតែត្រឹមត្រូវ ប៉ុន្តែនៅពេលមានរឿងអ្វីមួយកើតឡើងចំពោះអ្នក អ្នកនឹងឃើញថា នៅក្នុងខ្លួនអ្នកមានបំណងមិនត្រឹមត្រូវជាច្រើន។ ដូច្នេះ នៅពេលព្រះជាម្ចាស់ប្រោសឲ្យមនុស្សគ្រប់លក្ខណ៍ ទ្រង់ធ្វើឲ្យពួកគេដឹងថា មានសញ្ញាណជាច្រើននៅក្នុងខ្លួនពួកគេ ដែលរារាំងពួកគេមិនឲ្យស្គាល់ព្រះជាម្ចាស់។ នៅពេលអ្នកដឹងថា បំណងរបស់អ្នកសុទ្ធតែខុស ហើយប្រសិនបើអ្នកអាចឈប់អនុវត្តតាមសញ្ញាណ និងបំណងរបស់អ្នក ហើយអាចធ្វើទីបន្ទាល់ពីព្រះជាម្ចាស់ និងប្រកាន់ខ្ជាប់នូវជំហររបស់អ្នកទោះមានរឿងអ្វីកើតឡើងចំពោះអ្នកក៏ដោយ នេះទើបបញ្ជាក់ថា អ្នកបានបះបោរទាស់នឹងសាច់ឈាម។ នៅពេលអ្នកបះបោរទាស់នឹងសាច់ឈាម នោះនឹងមានការតយុទ្ធនៅក្នុងខ្លួនអ្នកដោយចៀសមិនរួចឡើយ។ សាតាំងនឹងព្យាយាមធ្វើឲ្យមនុស្សធ្វើតាមវា វានឹងព្យាយាមធ្វើឲ្យពួកគេធ្វើតាមសញ្ញាណខាងសាច់ឈាម ហើយប្រកាន់យកផលប្រយោជន៍ខាងសាច់ឈាម ប៉ុន្តែព្រះបន្ទូលរបស់ព្រះជាម្ចាស់នឹងបំភ្លឺ

ហើយពន្យល់មនុស្សពីខាងក្នុង ហើយនៅពេលនេះ វាអាស្រ័យលើអ្នក ថាតើអ្នកធ្វើតាមព្រះជាម្ចាស់ ឬធ្វើតាមសាតាំង។ ព្រះជាម្ចាស់សុំឲ្យមនុស្សអនុវត្តនូវសេចក្ដីពិតជាចម្បង ដើម្បីដោះស្រាយជាមួយរឿងរ៉ាវនានានៅក្នុងខ្លួនពួកគេ ដើម្បីដោះស្រាយជាមួយគំនិត និងសញ្ញាណរបស់ពួកគេ ដែលមិនស្របទៅតាម ព្រះហឫទ័យព្រះជាម្ចាស់។ ព្រះវិញ្ញាណបរិសុទ្ធប៉ះពាល់ចិត្តមនុស្ស ហើយបំភ្លឺ និងពន្យល់ពួកគេ។ ដូច្នេះការតយុទ្ធនៅពីក្រោយរឿងរ៉ាវគ្រប់យ៉ាងដែលកើតឡើង៖ នៅរាល់ពេលដែលមនុស្សអនុវត្តនូវសេចក្ដីពិត ឬអនុវត្តនូវសេចក្ដីស្រឡាញ់ចំពោះព្រះជាម្ចាស់ វាមានការតយុទ្ធយ៉ាងខ្លាំងក្លាមួយ ហើយទោះបីជាគ្រប់យ៉ាងអាចមើលទៅហាក់ដូចជាល្អជាមួយសាច់ឈាមរបស់ពួកគេក៏ដោយ ក៏តាមពិតទៅនៅក្នុងជម្រៅចិត្តរបស់ពួកគេ នឹងមានការតយុទ្ធស្លាប់រស់មួយកើតមានជាដរាប ហើយមានតែក្រោយពេលការតយុទ្ធដ៏ខ្លាំងក្លានេះចប់ និងក្រោយពេលលទ្ធផលដ៏ច្រើនមហិមាចេញមកប៉ុណ្ណោះ ទើបអាចកំណត់ការឈ្នះចាញ់បាន។ គេមិនដឹងថាតើត្រូវសើច ឬយំនោះទេ។ ព្រោះបំណងជាច្រើននៅក្នុងខ្លួនមនុស្សគឺសុទ្ធតែខុសឆ្គង ឬដោយសារតែកិច្ចការរបស់ព្រះជាម្ចាស់ភាគច្រើនមានលក្ខណៈផ្ទុយពីសញ្ញាណរបស់ពួកគេ នៅពេលមនុស្សអនុវត្តនូវសេចក្ដីពិត ការតយុទ្ធដ៏មហិមាមួយបានកើតឡើងនៅពីក្រោយឆាក។ ដោយបានអនុវត្តនូវសេចក្ដីពិតនេះ នៅពីក្រោយឆាក មនុស្សនឹងស្រក់ទឹកភ្នែកសោកសៅយ៉ាងច្រើនរាប់មិនអស់ មុនពេលដែលពួកគេរៀបចំចិត្តរបស់ខ្លួនដើម្បីបំពេញតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់នៅទីបំផុត។ ដោយសារតែការតយុទ្ធនេះ មនុស្សត្រូវស៊ូទ្រាំនឹងការរងទុក្ខ និងការបន្សុទ្ធ ហើយនេះគឺជាការរងទុក្ខពិតប្រាកដ។ នៅពេលការតយុទ្ធនេះកើតមានមកលើអ្នក ហើយប្រសិនបើអ្នកពិតជាអាចឈរនៅខាងព្រះជាម្ចាស់មែន នោះអ្នកនឹងអាចបំពេញតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់បាន។ ខណៈពេលកំពុងអនុវត្តនូវសេចក្ដីពិត វាចៀសមិនរួចទេថា គេនឹងរងទុក្ខនៅខាងក្នុង ហើយប្រសិនបើនៅពេលដែលពួកគេអនុវត្តនូវសេចក្ដីពិត អ្វីគ្រប់យ៉ាងនៅក្នុងខ្លួនមនុស្ស សុទ្ធតែត្រឹមត្រូវមែន នោះពួកគេនឹងមិនត្រូវការព្រះជាម្ចាស់ប្រោសឲ្យពួកគេគ្រប់លក្ខណ៍

នោះទេ ឯការតយុទ្ធនឹងមិនមានឡើយ ហើយពួកគេនឹងមិនរងទុក្ខដែរ។ ដោយសារតែមានរឿងរ៉ាវជាច្រើននៅក្នុងខ្លួនមនុស្សដែលមិនសមស្របនឹងឲ្យព្រះជាម្ចាស់ប្រើការ ហើយដោយសារតែមាននិស្ស័យបះបោរយ៉ាងច្រើនរបស់សាច់ឈាមបែបនេះ ទើបមនុស្សត្រូវរៀនមេរៀនអំពីការបះបោរទាស់នឹងសាច់ឈាមឲ្យបានកាន់តែជ្រៅជ្រះ។ នេះគឺជាអ្វីដែលព្រះជាម្ចាស់ហៅថា ការរងទុក្ខ ដែលទ្រង់បានមានបន្ទូលប្រាប់មនុស្សឲ្យទទួលរងជាមួយទ្រង់។ ពេលអ្នកជួបការលំបាក សូមប្រញាប់អធិស្ឋានដល់ព្រះជាម្ចាស់ថា៖ «ឱ ព្រះអង្គអើយ! ទូលបង្គំចង់បំពេញតាមព្រះហឫទ័យរបស់ទ្រង់ ទូលបង្គំចង់ស៊ូទ្រាំនឹងការលំបាកចុងក្រោយ ដើម្បីបំពេញតាមព្រះហឫទ័យរបស់ព្រះអង្គ ហើយមិនខ្វល់ថាទូលបង្គំជួបប្រទះឧបសគ្គខ្លាំងយ៉ាងណានោះទេ ទូលបង្គំនៅតែបំពេញតាមព្រះហឫទ័យរបស់ទ្រង់ជានិច្ច។ ទោះបីជាទូលបង្គំត្រូវលះបង់ជីវិតរបស់ទូលបង្គំទាំងស្រុងក្ដី ក៏កូននៅតែត្រូវបំពេញតាមព្រះហឫទ័យរបស់ទ្រង់ជានិច្ច!» ដោយមានការតាំងចិត្តបែបនេះ នៅពេលអ្នកអធិស្ឋានដូច្នេះ អ្នកនឹងអាចប្រកាន់ខ្ជាប់នូវទីបន្ទាល់របស់អ្នក។ រាល់ពេលដែលពួកគេអនុវត្តនូវសេចក្ដីពិត រាល់ពេលដែលពួកគេទទួលរងនូវការបន្សុទ្ធ រាល់ពេលដែលពួកគេត្រូវបានល្បងល ហើយរាល់ពេលដែលកិច្ចការរបស់ព្រះជាម្ចាស់មកដល់ពួកគេ មនុស្សត្រូវតែស៊ូទ្រាំនឹងការឈឺចាប់ដ៏សែនខ្លាំង។ ទាំងអស់នេះគឺជាការសាកល្បងសម្រាប់មនុស្ស ដូច្នេះហើយបានជាមានការតយុទ្ធនៅក្នុងខ្លួនពួកគេទាំងអស់គ្នា។ នេះគឺជាតម្លៃជាក់ស្ដែងដែលពួកគេត្រូវបង់។ ការអានព្រះបន្ទូលឲ្យបានច្រើន និងការរវល់ខ្លាំងច្រើនគឺជាចំណែកមួយនៃតម្លៃនោះ។ វាជាអ្វីដែលមនុស្សគួរតែធ្វើ វាជាករណីយកិច្ចរបស់ពួកគេ និងជាការទទួលខុសត្រូវដែលពួកគេគួរតែបំពេញ ប៉ុន្តែមនុស្សត្រូវតែទុកចោលនូវអ្វីៗនៅក្នុងខ្លួនពួកគេដែលចាំបាច់ត្រូវទុកចោល។ ប្រសិនបើអ្នកមិនធ្វើដូច្នេះទេ នោះទោះជាអ្នករងទុក្ខវេទនាខាងក្រៅខ្លាំងយ៉ាងណាក៏ដោយ ទោះជាអ្នករវល់ខ្លាំងយ៉ាងណាក៏ដោយ ទាំងអស់នោះនឹងគ្មានប្រយោជន៍អ្វីឡើយ! និយាយឲ្យចំទៅគឺថា មានតែការផ្លាស់ប្ដូរនៅក្នុងខ្លួនអ្នកតែប៉ុណ្ណោះទើបអាចកំណត់ ថាតើការលំបាកខាងក្រៅរបស់អ្នកមាន

តម្លៃឬអត់។ នៅពេលនិស្ស័យខាងក្នុងរបស់អ្នកបានផ្លាស់ប្ដូររួចហើយ ហើយអ្នកបានអនុវត្តនូវសេចក្ដីពិត នោះការរងទុក្ខខាងក្រៅរបស់អ្នកទាំងអស់ នឹងទទួលបានការអនុម័តពីព្រះជាម្ចាស់ តែប្រសិនបើនិស្ស័យខាងក្នុងរបស់អ្នកគ្មានការផ្លាស់ប្ដូរទេ នោះទោះបីជាអ្នកស៊ូទ្រាំនឹងការរងទុក្ខយ៉ាងណា ឬទោះជាអ្នករវល់ខ្លាំងនៅខាងក្រៅយ៉ាងណាក៏ដោយ ក៏នឹងគ្មានការអនុម័តពីព្រះជាម្ចាស់ឡើយ ហើយការលំបាកដែលគ្មានការបញ្ជាក់ពីព្រះជាម្ចាស់គឺឥតប្រយោជន៍នោះទេ។ ដូច្នេះ មិនថាតម្លៃដែលអ្នកបានបង់ត្រូវបានព្រះជាម្ចាស់អនុម័ត ឬអត់ គឺវាត្រូវបានកំណត់ដោយថាតើមានការផ្លាស់ប្ដូរនៅក្នុងខ្លួនអ្នក ឬអត់ និងដោយថាតើអ្នកអនុវត្តនូវសេចក្ដីពិតហើយបះបោរទាស់នឹងបំណង និងសញ្ញាណផ្ទាល់ខ្លួនរបស់អ្នកឬអត់ ដើម្បីបំពេញបានតាមបំណងព្រះហឫទ័យព្រះជាម្ចាស់ ស្គាល់ព្រះជាម្ចាស់ និងមានភក្ដីភាពចំពោះព្រះជាម្ចាស់។ មិនថាអ្នករវល់ខ្លាំងយ៉ាងណានោះទេ ប្រសិនបើអ្នកមិនដែលចេះធ្វើការបះបោរទាស់នឹងបំណងផ្ទាល់ខ្លួនរបស់អ្នកទេ ប៉ុន្តែចេះតែធ្វើការស្វះស្វែងរកសកម្មភាព និងជំនឿមុតមាំខាងក្រៅ ហើយមិនដែលយកចិត្តទុកដាក់ចំពោះជីវិតរបស់អ្នកទេ នោះការលំបាករបស់អ្នកនឹងគ្មានប្រយោជន៍អ្វីឡើយ។ នៅក្នុងស្ថានភាពមួយចំនួន ប្រសិនបើអ្នកមានអ្វីមួយចង់និយាយ ប៉ុន្តែអ្នកមានអារម្មណ៍ក្នុងខ្លួនថា ការនិយាយនេះមិនត្រឹមត្រូវ ការនិយាយនេះមិនផ្ដល់ប្រយោជន៍ដល់បងប្អូនប្រុសស្រីរបស់អ្នកទេ ហើយអាចធ្វើឲ្យពួកគេឈឺចាប់ទៅទៀត ពេលនោះអ្នកនឹងមិននិយាយចេញមកទេ ដោយសុខចិត្តឈឺចាប់នៅខាងក្នុងវិញ ដ្បិតពាក្យសម្ដីទាំងនេះមិនអាចបំពេញតាមបំណងព្រះហឫទ័យព្រះជាម្ចាស់ឡើយ។ នៅពេលនេះ នឹងមានការតយុទ្ធមួយនៅក្នុងអ្នក តែអ្នកនឹងសុខចិត្តរងការឈឺចាប់ ហើយលះបង់នូវអ្វីដែលអ្នកស្រលាញ់។ អ្នកនឹងសុខចិត្តស៊ូទ្រាំរងការលំបាកនេះ ដើម្បីបំពេញនូវព្រះហឫទ័យព្រះជាម្ចាស់ ហើយទោះបីជាអ្នកនឹងរងការឈឺចាប់នៅក្នុងខ្លួនក៏ដោយ ក៏អ្នកនឹងមិនផ្គាប់ផ្គុនដល់សាច់ឈាមដែរ ហើយនៅតែបំពេញតាមព្រះហឫទ័យព្រះជាម្ចាស់ដដែល ដូច្នេះហើយ អ្នកក៏នឹងទទួលបានភាពសុខស្រួលនៅក្នុងខ្លួនវិញផងដែរ។ នេះទើបពិតជាការបង់ថ្លៃ

ហើយជាតម្លៃ ដែលព្រះជាម្ចាស់សព្វព្រះហឫទ័យចង់បាន។ ប្រសិនបើអ្នកអនុវត្តតាមរបៀបនេះ ព្រះជាម្ចាស់ប្រាកដជាប្រទានពរដល់អ្នក ប្រសិនបើអ្នកមិនអាចធ្វើបែបនេះបានទេ នោះមិនថាអ្នកយល់ដឹងច្រើនប៉ុនណា ឬអ្នកចេះនិយាយបានល្អប៉ុនណាទេ វានឹងគ្មានបានការអ្វីឡើយ! នៅលើផ្លូវឆ្ពោះទៅរកការស្រឡាញ់ព្រះជាម្ចាស់ ប្រសិនបើអ្នកអាចឈរនៅខាងព្រះជាម្ចាស់នៅពេលទ្រង់ច្បាំងជាមួយសាតាំង ហើយអ្នកមិនត្រឡប់ទៅរកសាតាំងវិញទេ នោះអ្នកនឹងសម្រេចបាននូវសេចក្តីស្រឡាញ់ចំពោះព្រះជាម្ចាស់ ហើយអ្នកនឹងបានប្រកាន់ខ្ជាប់នូវទីបន្ទាល់របស់ខ្លួន។

នៅគ្រប់ជំហាននៃកិច្ចការដែលព្រះជាម្ចាស់ធ្វើនៅក្នុងខ្លួនមនុស្ស ពីខាងក្រៅទំនងជាអន្តរកម្មរវាងមនុស្ស ដែលហាក់ដូចជាកើតចេញពីការរៀបចំរបស់មនុស្ស ឬពីការជ្រៀតជ្រែករបស់មនុស្ស។ ប៉ុន្តែនៅពីក្រោយឆាក គ្រប់ជំហាននៃកិច្ចការ និងអ្វីគ្រប់យ៉ាងដែលកើតឡើង គឺសុទ្ធតែជាការភ្នាល់ ដែលសាតាំងធ្វើឡើងនៅចំពោះព្រះជាម្ចាស់ ហើយទាមទារឲ្យមនុស្សប្រកាន់ខ្ជាប់នូវទីបន្ទាល់របស់ខ្លួនអំពីព្រះជាម្ចាស់។ ចូរយករឿងរបស់យ៉ូប នៅពេលដែលគាត់ត្រូវបានសាកល្បងមកធ្វើជាឧទាហរណ៍៖ នៅពីក្រោយឆាក សាតាំងកំពុងតែភ្នាល់ជាមួយព្រះជាម្ចាស់ ហើយអ្វីដែលបានកើតឡើងដល់យ៉ូបគឺជាទង្វើរបស់មនុស្ស និងការជ្រៀតជ្រែករបស់មនុស្ស។ នៅពីក្រោយជំហាននីមួយៗនៃកិច្ចការដែលព្រះជាម្ចាស់ធ្វើនៅក្នុងអ្នក អ្នករាល់គ្នាគឺជាការភ្នាល់របស់សាតាំងជាមួយព្រះជាម្ចាស់ និយាយរួម នៅពីក្រោយអ្វីគ្រប់យ៉ាង គឺជាចម្បាំងមួយ។ ឧទាហរណ៍ថា ប្រសិនបើអ្នករើសអើងចំពោះបងប្អូនប្រុសស្រីរបស់អ្នក នោះអ្នកនឹងបញ្ចេញពាក្យសម្ដីដែលអ្នកចង់និយាយ ជាពាក្យសម្ដីដែលអ្នកមានអារម្មណ៍ថា អាចនឹងមិនគាប់ព្រះហឫទ័យព្រះជាម្ចាស់ ប៉ុន្តែប្រសិនបើអ្នកមិននិយាយចេញមកទេ នោះអ្នកនឹងមានអារម្មណ៍មិនស្រួលចិត្ត ហើយនៅខណៈនោះ ការតយុទ្ធមួយនឹងចាប់ផ្ដើមនៅក្នុងខ្លួនអ្នក៖ «តើខ្ញុំនិយាយ ឬអត់?» នេះហើយជាចម្បាំង។ ដូច្នេះ វាមានការតយុទ្ធនៅក្នុងអ្វីគ្រប់យ៉ាងដែលអ្នកជួបប្រទះ ហើយនៅពេលមានការតយុទ្ធនៅក្នុងខ្លួនអ្នក ដោយសារតែអ្នកសហការពិតប្រាកដ និងរងទុក្ខពិតប្រាកដ នោះ

ព្រះជាម្ចាស់ធ្វើការនៅក្នុងខ្លួនឯង។ នៅទីបំផុត អ្នកអាចទុកចោលបញ្ហានេះនៅក្នុងខ្លួនឯង ហើយកំហឹងក៏រលត់បាត់ជាធម្មតា។ នេះជាឥទ្ធិពលនៃការសហការរបស់អ្នកជាមួយព្រះជាម្ចាស់។ អ្វីគ្រប់យ៉ាងដែលមនុស្សធ្វើ តម្រូវឲ្យពួកគេបង់ថ្លៃជាក់លាក់មួយនៅក្នុងការខិតខំប្រឹងប្រែងរបស់ពួកគេ។ បើគ្មានការលំបាកពិតប្រាកដទេ ពួកគេមិនអាចបំពេញព្រះហឫទ័យព្រះជាម្ចាស់បានឡើយ ពួកគេសូម្បីតែឈានជិតដល់កម្រិតនៃការបំពេញព្រះហឫទ័យព្រះជាម្ចាស់ក៏អត់ដែរ ហើយពួកគេគ្រាន់តែកំពុងព្រោកប្រាជ្ញពីពាក្យស្លោកឥតខ្លឹមសារតែប៉ុណ្ណោះ! តើពាក្យស្លោកឥតខ្លឹមសារទាំងនេះអាចបំពេញព្រះហឫទ័យព្រះជាម្ចាស់បានឬទេ? នៅពេលព្រះជាម្ចាស់ និងសាតាំង ច្បាំងគ្នានៅក្នុងពិភពខាងវិញ្ញាណ តើអ្នកគួរតែបំពេញព្រះហឫទ័យព្រះជាម្ចាស់យ៉ាងដូចម្ដេច ហើយតើអ្នកគួរតែប្រកាន់ខ្ជាប់នូវទីបន្ទាល់របស់ខ្លួនអំពីទ្រង់យ៉ាងដូចម្ដេច? អ្នកគួរតែដឹងថា អ្វីគ្រប់យ៉ាងដែលកើតឡើងចំពោះអ្នក គឺជាការល្បងលដ៏ធំ និងជាពេលដែលព្រះជាម្ចាស់ត្រូវការឲ្យអ្នកធ្វើនូវបន្ទាល់។ ថ្វីបើមើលពីខាងក្រៅវាហាក់ដូចជាមិនសំខាន់ក៏ដោយ ក៏នៅពេលរឿងទាំងនេះកើតឡើង វាបង្ហាញឲ្យដឹងថាតើអ្នកស្រលាញ់ព្រះជាម្ចាស់ ឬអត់។ ប្រសិនបើអ្នកធ្វើបាន នោះអ្នកនឹងអាចប្រកាន់ខ្ជាប់នូវទីបន្ទាល់របស់ខ្លួនអំពីទ្រង់បាន ហើយប្រសិនបើអ្នកមិនបានអនុវត្តនូវសេចក្ដីស្រឡាញ់ដល់ទ្រង់ទេ នេះបង្ហាញឲ្យដឹងថា អ្នកមិនមែនជាមនុស្សដែលអនុវត្តនូវសេចក្ដីពិតនោះទេ ហើយអ្នកគឺគ្មានការពិត និងគ្មានជីវិតដែរ អ្នកគឺជាអង្កាម! អ្វីគ្រប់យ៉ាងដែលកើតឡើងចំពោះមនុស្ស គឺកើតឡើងនៅពេលដែលព្រះជាម្ចាស់ត្រូវការឲ្យពួកគេប្រកាន់ខ្ជាប់នូវទីបន្ទាល់របស់ពួកគេអំពីទ្រង់។ ថ្វីបើគ្មានបញ្ហាធំដុំកើតឡើងចំពោះអ្នកនៅពេលនេះក្ដី ហើយអ្នកក៏មិនធ្វើបន្ទាល់ឲ្យបានអស្ចារ្យក្ដី ក៏រាល់សេចក្ដីលម្អិតនៃជីវិតប្រចាំថ្ងៃរបស់អ្នកនៅតែជាបញ្ហាក្នុងការធ្វើបន្ទាល់ពីព្រះជាម្ចាស់ដដែល។ ប្រសិនបើអ្នកអាចឈ្នះការកោតសរសើរពីបងប្អូនប្រុសស្រីរបស់អ្នក ពីសមាជិកគ្រួសាររបស់អ្នក និងពីមនុស្សគ្រប់គ្នាជុំវិញអ្នក ហើយប្រសិនបើថ្ងៃណាមួយ អ្នកមិនជឿមកកោតសរសើរនូវអ្វីគ្រប់យ៉ាងដែលអ្នកធ្វើ និងឃើញថាអ្វីគ្រប់យ៉ាងដែលព្រះជាម្ចាស់ធ្វើគឺអស្ចារ្យ នោះមានន័យថាអ្នក

បានធ្វើបន្ទាល់ហើយ។ ទោះបីអ្នកគ្មានពន្លឺខាងក្នុង និងមានគុណសម្បត្តិអន់ក៏ដោយ តាមរយៈការដែលព្រះជាម្ចាស់ជាម្ចាស់ប្រោសឱ្យអ្នកគ្រប់លក្ខណ៍ នោះអ្នកអាចបំពេញព្រះហឫទ័យរបស់ទ្រង់ ហើយយកចិត្តទុកដាក់ចំពោះបំណងព្រះហឫទ័យរបស់ទ្រង់ ដោយការបង្ហាញអ្នកដទៃអំពីកិច្ចការដ៏អស្ចារ្យដែលទ្រង់បានធ្វើនៅក្នុងមនុស្សដែលមានគុណសម្បត្តិអន់បំផុត។ នៅពេលមនុស្សភ្ញាក់ខ្លួនស្គាល់ព្រះជាម្ចាស់វិញ ហើយក្លាយជាអ្នកមានជ័យជម្នះនៅចំពោះមុខសាតាំង និងមានភក្ដីភាពចំពោះព្រះជាម្ចាស់បំផុត នោះគ្មាននរណាម្នាក់ដែលមានបង្អែករឹងមាំជាងក្រុមមនុស្សនេះឡើយ ហើយនេះជាទីបន្ទាល់ដ៏អស្ចារ្យបំផុត។ ទោះបីជាអ្នកគ្មានសមត្ថភាពធ្វើកិច្ចការអស្ចារ្យបានក៏ដោយ ក៏អ្នកអាចបំពេញព្រះហឫទ័យព្រះជាម្ចាស់បានដែរ។ អ្នកដទៃមិនអាចទុកចោលសញ្ញាណរបស់ពួកគេបានទេ ប៉ុន្តែអ្នកអាចធ្វើបាន អ្នកដទៃមិនអាចធ្វើបន្ទាល់ពីព្រះជាម្ចាស់ក្នុងបទពិសោធជាក់ស្ដែងរបស់ពួកគេបានទេ ប៉ុន្តែអ្នកអាចប្រើសកម្មភាព និងកម្ពស់ជាក់ស្ដែងរបស់អ្នកដើម្បីតបស្នងសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ និងធ្វើបន្ទាល់ពីទ្រង់យ៉ាងខ្ទរខ្ទារ។ នេះទើបរាប់ជាការស្រឡាញ់ព្រះជាម្ចាស់ពិតប្រាកដមែន។ ប្រសិនបើអ្នកគ្មានសម្ថភាពនេះទេ នោះអ្នកមិនធ្វើបន្ទាល់នៅក្នុងចំណោមសមាជិកគ្រួសាររបស់អ្នក នៅក្នុងចំណោមបងប្អូនប្រុសស្រីរបស់អ្នក ឬនៅចំពោះមុខមនុស្សឡើយ។ ប្រសិនបើអ្នកមិនអាចធ្វើបន្ទាប់នៅចំពោះមុខសាតាំងបានទេ សាតាំងនឹងសើចចំអកដាក់អ្នក វានឹងចាត់ទុកអ្នកជាមនុស្សឆ្កួត ជារបស់លេង ហើយជារឿយៗវានឹងធ្វើឲ្យអ្នកវង្វេងវង្វាន់ និងនាំឲ្យអ្នកវិកលចរិត។ នាពេលអនាគត ការល្បងលដ៏ធំអាចនឹងកើតមានដល់អ្នក ប៉ុន្តែថ្ងៃនេះ បើសិនជាអ្នកស្រឡាញ់ព្រះជាម្ចាស់ដោយដួងចិត្តពិតមែន ហើយដោយមិនខ្វល់ថាការល្បងលនៅខាងមុខធំប៉ុនណា និងដោយមិនគិតពីអ្វីដែលកើតឡើងចំពោះអ្នក ប្រសិនបើអ្នកប្រកាន់ខ្ជាប់នូវទីបន្ទាល់របស់ខ្លួន ហើយអាចបំពេញព្រះហឫទ័យព្រះជាម្ចាស់បាន នោះចិត្តអ្នកនឹងបានសុខស្រួល ហើយអ្នកនឹងមិនភ័យខ្លាចអ្វីឡើយ មិនថាការល្បងលដែលអ្នកជួបប្រទះ នាពេលអនាគតធំប៉ុនណាក៏ដោយ។ អ្នករាល់គ្នាមិនអាចមើលឃើញនូវអ្វីដែលនឹងកើតឡើង

នាពេលអនាគតឡើយ។ អ្នករាល់គ្នាគ្រាន់តែអាចបំពេញព្រះហឫទ័យព្រះជាម្ចាស់ក្នុងស្ថានភាពថ្ងៃនេះបាន។ អ្នករាល់គ្នាគ្មានសមត្ថភាពធ្វើកិច្ចការដ៏អស្ចារ្យណាមួយទេ ហើយគួរតែផ្ដោតលើការបំពេញព្រះហឫទ័យព្រះជាម្ចាស់ តាមរយៈការដកបទពិសោធព្រះបន្ទូលរបស់ទ្រង់នៅក្នុងជីវិតពិត ហើយធ្វើបន្ទាល់ដ៏រឹងមាំ និងខ្លួរខ្លារ ដែលធ្វើឲ្យសាតាំងអាម៉ាស់មុខ។ ទោះបីជាសាច់ឈាមរបស់អ្នកនឹងនៅតែមិនទាន់ពេញចិត្ត ហើយនឹងរងទុក្ខក៏ដោយ ក៏អ្នកនឹងបំពេញព្រះហឫទ័យព្រះជាម្ចាស់បាន ហើយធ្វើឲ្យសាតាំងអាម៉ាស់មុខដែរ។ ប្រសិនបើអ្នកអនុវត្តតាមរបៀបនេះជានិច្ច នោះព្រះជាម្ចាស់នឹងបើកផ្លូវមួយនៅចំពោះមុខអ្នក។ នៅថ្ងៃមួយ ពេលដែលការល្បងលដ៏ធំមកដល់ អ្នកដទៃនឹងធ្លាក់ចុះ ប៉ុន្តែអ្នកនឹងនៅតែអាចឈរយ៉ាងរឹងមាំ៖ ដោយសារតែតម្លៃដែលអ្នកបានបង់នោះ ព្រះជាម្ចាស់នឹងការពារអ្នក ដូច្នេះអ្នកអាចឈរយ៉ាងរឹងមាំ និងមិនធ្លាក់ចុះឡើយ។ បើជាធម្មតាអ្នកអាចអនុវត្តនូវសេចក្ដីពិតបាន និងបំពេញព្រះហឫទ័យព្រះជាម្ចាស់ដោយដួងចិត្តដែលពិតជាស្រឡាញ់ទ្រង់មែន នោះព្រះជាម្ចាស់នឹងការពារអ្នកជាប្រាកដក្នុងអំឡុងពេលល្បងលនាពេលអនាគត។ ថ្វីបើអ្នកជាមនុស្សឆោតល្ងង់ មានកម្ពស់តូចទាប និងមានគុណសម្បត្តិអន់ក៏ដោយ ក៏ព្រះជាម្ចាស់នឹងមិនរើសអើងអ្នកដែរ។ វាអាស្រ័យលើថាតើបំណងរបស់អ្នកត្រឹមត្រូវ ឬអត់។ សព្វថ្ងៃនេះ អ្នកអាចបំពេញព្រះហឫទ័យព្រះជាម្ចាស់ ដោយអ្នកយកចិត្តទុកដាក់ តាំងពីចំណុចតូចល្អិតបំផុត អ្នកបំពេញព្រះហឫទ័យព្រះជាម្ចាស់ក្នុងគ្រប់ការទាំងអស់ អ្នកមានបេះដូងមួយដែលពិតជាស្រឡាញ់ព្រះជាម្ចាស់មែន អ្នកថ្វាយបេះដូងពិតរបស់អ្នកដល់ព្រះជាម្ចាស់ ហើយទោះបីជាមានរឿងខ្លះ ដែលអ្នកមិនអាចយល់បានក៏ដោយ ក៏អ្នកអាចមកនៅមុខព្រះជាម្ចាស់ដើម្បីកែតម្រង់បំណងរបស់អ្នកបានដែរ ហើយស្វះស្វែងរកបំណងព្រះហឫទ័យព្រះជាម្ចាស់ ព្រមទាំងធ្វើអ្វីគ្រប់យ៉ាងដែលត្រូវការដើម្បីបំពេញព្រះហឫទ័យព្រះជាម្ចាស់។ ប្រហែលជាបងប្អូនប្រុសស្រីរបស់អ្នកនឹងបោះបង់ចោលអ្នក ប៉ុន្តែដួងចិត្តរបស់អ្នកនឹងនៅតែបំពេញព្រះហឫទ័យព្រះជាម្ចាស់ ហើយអ្នកនឹងមិនលោភលន់ចង់បានការសប្បាយខាងសាច់ឈាមនោះទេ។ ប្រសិនបើអ្នកអនុវត្ត

តាមរបៀបនេះជានិច្ច នោះអ្នកនឹងត្រូវបានការពារនៅពេលការល្បងល ដ៏ធំចូលមកដល់អ្នក។

តើការល្បងលសំដៅទៅរកស្ថានភាពខាងក្នុងអ្វីខ្លះនៅក្នុងមនុស្ស? ពួកវាតម្រង់ទៅរកនិស្ស័យបះបោរនៅក្នុងមនុស្សដែលគ្មានសមត្ថភាពបំពេញព្រះហឫទ័យព្រះជាម្ចាស់បាន។ មានភាពមិនបរិសុទ្ធយ៉ាងច្រើននៅក្នុងខ្លួនមនុស្ស ព្រមទាំងមានការលាក់ពុតយ៉ាងច្រើនផងដែរ ដូច្នេះហើយព្រះជាម្ចាស់ដាក់មនុស្សឲ្យស្ថិតក្រោមការល្បងល ដើម្បីញែកខ្លួនពួកគេជាបរិសុទ្ធ។ ប៉ុន្តែ ប្រសិនបើសព្វថ្ងៃនេះអ្នកអាចបំពេញព្រះហឫទ័យព្រះជាម្ចាស់បាន នោះការល្បងលនាពេលអនាគតនឹងក្លាយជាភាពគ្រប់លក្ខណ៍សម្រាប់អ្នក។ ប្រសិនបើសព្វថ្ងៃនេះអ្នកមិនអាចបំពេញព្រះហឫទ័យព្រះជាម្ចាស់បានទេ នោះការល្បងលនាពេលអនាគតនឹងល្បងអ្នក ហើយអ្នកនឹងធ្លាក់ចុះទាំងមិនដឹងខ្លួន ហើយនៅពេលនោះអ្នកនឹងមិនអាចជួយខ្លួនឯងបានទេ ដ្បិតអ្នកមិនអាចតាមទាន់ កិច្ចការរបស់ព្រះជាម្ចាស់បាន និងគ្មានកម្ពស់ពិតនោះទេ។ ដូច្នេះហើយ ប្រសិនបើអ្នកចង់ឲ្យអាចឈរយ៉ាងរឹងមាំនាពេលអនាគត ចង់បំពេញព្រះហឫទ័យព្រះជាម្ចាស់ឲ្យបានប្រសើរឡើង និងចង់ធ្វើតាមទ្រង់រហូតដល់ចុងបំផុត អ្នកត្រូវតែកសាងគ្រឹះឲ្យរឹងមាំនៅថ្ងៃនេះ។ អ្នកត្រូវតែបំពេញព្រះហឫទ័យព្រះជាម្ចាស់តាមរយៈការអនុវត្តនូវសេចក្ដីពិតក្នុងគ្រប់ការទាំងអស់ និងយកចិត្តទុកដាក់ចំពោះបំណងហឫទ័យរបស់ទ្រង់។ ប្រសិនបើអ្នកអនុវត្តតាមរបៀបនេះជានិច្ច នោះនឹងមានគ្រឹះមួយនៅក្នុងអ្នក ហើយព្រះជាម្ចាស់នឹងជំរុញចិត្តដែលស្រឡាញ់ទ្រង់នៅក្នុងខ្លួនឯង ហើយទ្រង់នឹងផ្ដល់ទំនុកចិត្តដល់អ្នក។ នៅថ្ងៃមួយ ពេលដែលការល្បងលកើតមានដល់អ្នកពិតមែន នោះអ្នកអាចនឹងរងការឈឺចាប់មួយចំនួន ហើយមានអារម្មណ៍សោកសៅដល់កម្រិតជាក់លាក់មួយ ព្រមទាំងរងនូវទុក្ខព្រួយយ៉ាងធ្ងន់ធ្ងរ ប្រៀបដូចជាអ្នកបានស្លាប់ដូច្នោះដែរ ប៉ុន្តែសេចក្ដីស្រឡាញ់របស់អ្នកចំពោះព្រះជាម្ចាស់ នឹងមិនប្រែប្រួលឡើយ ហើយថែមទាំងកាន់តែជ្រាលជ្រៅខ្លាំងឡើង។ នេះហើយគឺជាព្រះពររបស់ព្រះជាម្ចាស់។ បើសិនជាអ្នកអាចទទួលយកគ្រប់យ៉ាង ដែលជាព្រះជាម្ចាស់

មានបន្ទូល និងអំពើរបស់ព្រះជាម្ចាស់នៅថ្ងៃនេះដោយចិត្តព្រមស្ដាប់បង្គាប់ នោះអ្នកប្រាកដជានឹងទទួលបានព្រះពរពីព្រះជាម្ចាស់ ដូច្នេះហើយអ្នកនឹងក្លាយជាមនុស្សដែលព្រះជាម្ចាស់ប្រទានពរឲ្យ និងទទួលបានការសន្យារបស់ទ្រង់។ បើសិនជាថ្ងៃនេះអ្នកមិនអនុវត្តទេ នៅពេលការល្បងលកើតមានដល់អ្នកនៅថ្ងៃណាមួយ នោះអ្នកនឹងមិនមានសេចក្ដីជំនឿ ឬចិត្តដែលស្រឡាញ់នោះទេ ហើយនៅពេលនោះការល្បងលនឹងក្លាយជាសេចក្ដីល្បួង។ អ្នកនឹងធ្លាក់ចូលក្នុងសេចក្ដីល្បួងរបស់សាតាំង ហើយនឹងគ្មានផ្លូវគេចចេញបានឡើយ។ សព្វថ្ងៃនេះ អ្នកប្រហែលជាអាចឈរយ៉ាងរឹងមាំនៅពេលដែលការល្បងលតូចមួយកើតមានដល់អ្នក ប៉ុន្តែដោយចៀសមិនរួច អ្នកនឹងមិនអាចឈរយ៉ាងរឹងមាំបានទៀតទេនៅពេលដែលការល្បងលដ៏សម្បើមមួយកើតមានដល់អ្នកនៅថ្ងៃណាមួយ។ មនុស្សមួយចំនួនបញ្ឆោតខ្លួនឯង ហើយគិតថាពួកគេជិតបានគ្រប់លក្ខណ៍រួចទៅហើយ។ បើសិនជាអ្នកមិនចូលឲ្យជ្រៅជាងនេះនៅពេលទាំងនោះទេ ហើយនៅតែឥតខ្វល់ខ្វាយ នោះអ្នកនឹងស្ថិតក្នុងគ្រោះថ្នាក់។ សព្វថ្ងៃនេះ ព្រះជាម្ចាស់មិនធ្វើកិច្ចការដែលល្បងលធំដុំជាងនេះទេ ហើយអ្វីគ្រប់យ៉ាងហាក់ដូចជាមិនអីនោះទេ ប៉ុន្តែនៅពេលព្រះជាម្ចាស់ល្បងលអ្នក នោះអ្នកនឹងឃើញថា អ្នកមានការខ្វះខាតច្រើនណាស់ កម្ពស់របស់អ្នកតូចណាស់ ហើយអ្នកគ្មានសមត្ថភាពក្នុងការស៊ូទ្រាំនឹងការល្បងលដ៏ធំបានឡើយ។ បើសិនជាអ្នកនៅតែបែបនេះ និងនៅក្នុងសភាពនិចល នោះនៅពេលដែលការល្បងលមកដល់ អ្នកនឹងដួល។ អ្នករាល់គ្នាគួរតែឧស្សាហ៍មើលទៅកម្ពស់របស់អ្នកថាតើវាតូចប៉ុនណា មានតែវិធីនេះទេទើបធ្វើឲ្យអ្នករីកចម្រើនបាន។ បើសិនជាទាល់តែស្ថិតក្នុងពេលល្បងលទើបអ្នកឃើញថា កម្ពស់របស់អ្នកតូចទាបខ្លាំង អំណាចចិត្តរបស់អ្នកខ្សោយណាស់ ការពិតនៅក្នុងខ្លួនអ្នកតិចណាស់ ហើយឃើញថា អ្នកគ្មានលក្ខណៈគ្រប់គ្រាន់សម្រាប់ព្រះហឫទ័យព្រះជាម្ចាស់ទេ បើសិនជាដល់ពេលនោះទើបអ្នកដឹងរឿងទាំងនេះ នោះវានឹងយឺតពេលហើយ។

បើសិនជាអ្នក មិនដឹងពីនិស្ស័យរបស់ព្រះជាម្ចាស់ទេ នោះអ្នកនឹងដួលដោយ

ចៀសមិនរួចក្នុងពេលល្បងល ពីព្រោះអ្នកមិនដឹងពីវិធីដែលព្រះជាម្ចាស់ប្រោសឲ្យមនុស្សបានគ្រប់លក្ខណ៍ និងមធ្យោបាយ ដែលទ្រង់ធ្វើឲ្យពួកគេបានគ្រប់លក្ខណ៍ ហើយនៅពេលការល្បងលរបស់ព្រះជាម្ចាស់មកដល់អ្នក ហើយពួកវាមិនត្រូវនឹងសញ្ញាណរបស់អ្នក នោះអ្នកនឹងមិនអាចឈរយ៉ាងរឹងមាំបានទេ។ សេចក្តីស្រឡាញ់ពិតប្រាកដរបស់ព្រះជាម្ចាស់គឺជានិស្ស័យទាំងអស់របស់ទ្រង់ ហើយនៅពេលនិស្ស័យទាំងអស់របស់ទ្រង់ត្រូវបានបង្ហាញដល់មនុស្ស តើការនេះនាំយកអ្វីខ្លះដល់សាច់ឈាមរបស់អ្នក? នៅពេលដែលនិស្ស័យសុចរិតរបស់ព្រះជាម្ចាស់ ត្រូវបានបង្ហាញដល់មនុស្ស សាច់ឈាមរបស់ពួកគេនឹងរងការឈឺចាប់ខ្លាំង ដោយចៀសមិនរួចឡើយ។ បើសិនជាអ្នកមិនរងការឈឺចាប់នេះទេ នោះអ្នកមិនអាចត្រូវបានព្រះជាម្ចាស់ធ្វើឲ្យគ្រប់លក្ខណ៍ឡើយ ហើយអ្នកក៏នឹងមិនអាចបូជាសេចក្តីស្រឡាញ់ពិតប្រាកដថ្វាយដល់ព្រះជាម្ចាស់បានដែរ។ បើព្រះជាម្ចាស់ធ្វើឲ្យអ្នកបានគ្រប់លក្ខណ៍ ទ្រង់ប្រាកដជានឹងបង្ហាញនូវនិស្ស័យទាំងអស់របស់ទ្រង់ដល់អ្នកមិនខានឡើយ។ ចាប់តាំងពីពេលបង្កើតរហូតមកដល់សព្វថ្ងៃនេះ ព្រះជាម្ចាស់ មិនដែលបង្ហាញពីនិស្ស័យទាំងអស់របស់ទ្រង់ដល់មនុស្សទេ ប៉ុន្តែក្នុងអំឡុងគ្រាចុងក្រោយនេះ ទ្រង់បើកសម្តែងឲ្យដឹងអំពីនិស្ស័យទាំងនេះដល់ក្រុមមនុស្សដែលទ្រង់បានជ្រើសរើស និងកំណត់ទុកជាមុន ហើយតាមរយៈការប្រោសឲ្យមនុស្សបានគ្រប់លក្ខណ៍ ទ្រង់លាតត្រដាងនិស្ស័យរបស់ទ្រង់ ដែលតាមរយៈនេះ ទ្រង់ធ្វើឲ្យមនុស្សមួយក្រុមបានពេញខ្នាត។ នេះហើយជាសេចក្តីស្រឡាញ់ពិតប្រាកដរបស់ព្រះជាម្ចាស់ចំពោះមនុស្ស។ ការពិសោធសេចក្តីស្រឡាញ់ពិតប្រាកដរបស់ព្រះជាម្ចាស់ ទាមទារឲ្យមនុស្សបង់ថ្លៃខ្ពស់ ហើយស៊ូទ្រាំនឹងការឈឺចាប់ដ៏សែនខ្លាំង។ មានតែបន្ទាប់ពីនេះទេ ទើបពួកគេត្រូវបានព្រះជាម្ចាស់ទទួលយក និងអាចថ្វាយសេចក្តីស្រឡាញ់ពិតប្រាកដរបស់ពួកគេដល់ព្រះជាម្ចាស់វិញ ហើយមានតែពេលនោះទេទើបសព្វព្រះហឫទ័យរបស់ព្រះជាម្ចាស់។ បើសិនជាមនុស្សចង់ឲ្យព្រះជាម្ចាស់ប្រោសឲ្យគ្រប់លក្ខណ៍ ហើយបើសិនជាពួកគេចង់ធ្វើតាមបំណងព្រះហឫទ័យរបស់ទ្រង់ និងថ្វាយសេចក្តីស្រឡាញ់ពិតប្រាកដយ៉ាងពេញលេញ

ដល់ព្រះជាម្ចាស់ នោះពួកគេត្រូវតែពិសោធនូវការរងទុក្ខខ្លាំង និងទារុណកម្មយ៉ាងច្រើន ពីស្ថានភាពរបស់ពួកគេ ដើម្បីរងការឈឺចាប់ដែលអាក្រក់ជាងការស្លាប់ទៅទៀត។ នៅទីបំផុត ពួកគេនឹងត្រូវបានបង្ខំឲ្យថ្វាយចិត្តពិតប្រាកដជូនដល់ព្រះជាម្ចាស់វិញ។ មិនថាអ្នកស្រឡាញ់ព្រះជាម្ចាស់ពិតប្រាកដ ឬអត់នោះទេ វានឹងត្រូវបានបើកឲ្យដឹង ក្នុងអំឡុងពេលនៃការលំបាក និងការបន្សុទ្ធ។ ព្រះជាម្ចាស់ញែកសេចក្ដីស្រឡាញ់របស់មនុស្សជាបរិសុទ្ធ ហើយការនេះក៏សម្រេចបានតែនៅក្នុងពេលដែលមានការលំបាក និងការបន្សុទ្ធប៉ុណ្ណោះ។

## ការជជែកដោយសង្ខេបអំពី «រាជ្យមួយពាន់ឆ្នាំបានមកដល់ហើយ»

តើអ្នករាល់គ្នាគិតអ្វីខ្លះអំពីនិមិត្តនៃរាជ្យមួយពាន់ឆ្នាំ? មនុស្សខ្លះគិតពីវាខ្លាំងណាស់ ហើយពួកគេនិយាយថា «រាជ្យមួយពាន់ឆ្នាំនឹងគង់វង្សមួយពាន់ឆ្នាំនៅលើផែនដី ដូច្នេះ បើសមាជិកចាស់ៗ របស់ក្រុមជំនុំដែលមិនទាន់រៀបការ តើពួកគេត្រូវរៀបការឬ? គ្រួសាររបស់ខ្ញុំមិនមានប្រាក់ តើខ្ញុំគួរចាប់ផ្ដើមរកប្រាក់ឬ? ...» អ្វីទៅជារាជ្យមួយពាន់ឆ្នាំ? តើអ្នករាល់គ្នាដឹងឬទេ? មនុស្សមានភាពឆោតល្ងង់ ហើយរងនូវការឈឺចាប់យ៉ាងខ្លាំង។ ការពិតទៅ រាជ្យមួយពាន់ឆ្នាំ មិនទាន់បានមកដល់ជាផ្លូវការនៅឡើយទេ។ អំឡុងពេលនៃដំណាក់កាលដែលប្រោសឲ្យមនុស្សបានគ្រប់លក្ខណ៍ រាជ្យមួយពាន់ឆ្នាំ គឺគ្រាន់តែជាកូនបក្សីទើបរៀនហើរប៉ុណ្ណោះ ហើយនៅវេលាដែលរាជ្យមួយពាន់ឆ្នាំត្រូវបានប្រកាសដោយព្រះជាម្ចាស់ មនុស្សនឹងត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍។ ពីមុនមក មានការលើកឡើងថា មនុស្សនឹងបានដូចជាពួកបរិសុទ្ធ ហើយឈរយ៉ាងរឹងមាំក្នុងស្រុកស៊ីនីម។ ទាល់តែពេលដែលមនុស្សត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍ (ពេលដែលពួកគេបានក្លាយជាពួកបរិសុទ្ធ ដែលត្រូវបានប្រកាសដោយព្រះជាម្ចាស់) ទើបរាជ្យមួយពាន់ឆ្នាំមកដល់។ នៅពេលដែលព្រះជាម្ចាស់ប្រោសឲ្យមនុស្សបានគ្រប់លក្ខណ៍

ទ្រង់ធ្វើឲ្យពួកគេបានបរិសុទ្ធ ហើយកាលណាពួកគេបានបរិសុទ្ធប៉ុនណា នោះពួកគេក៏ត្រូវបានព្រះជាម្ចាស់ ប្រោសឲ្យគ្រប់លក្ខណ៍ច្រើនប៉ុណ្ណោះដែរ។ ពេលភាពមិនបរិសុទ្ធ ការបះបោរ ការប្រឆាំង និងរឿងនានាខាងសាច់ឈាមក្នុងខ្លួនអ្នករាល់គ្នាត្រូវបានបណ្ដេញចេញអស់ទៅ ពេលនោះអ្នកត្រូវបានប្រោសឲ្យបរិសុទ្ធហើយ នោះអ្នករាល់គ្នានឹងទទួលបានសេចក្ដីស្រឡាញ់ពីព្រះជាម្ចាស់ (ម្យ៉ាងទៀត អ្នកនឹងក្លាយជាពួកបរិសុទ្ធ) នៅពេលដែលព្រះជាម្ចាស់ប្រោសឲ្យអ្នកបានបរិសុទ្ធ និងក្លាយជាមនុស្សបរិសុទ្ធម្នាក់ នោះអ្នកនឹងបានឋិតនៅក្នុងរាជ្យមួយពាន់ឆ្នាំ។ ឥឡូវនេះ ជាយុគសម័យនៃនគរព្រះ។ ក្នុងយុគសម័យនៃរាជ្យមួយពាន់ឆ្នាំ មនុស្សនឹងអាស្រ័យលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ដើម្បីមានជីវិតរស់នៅ ហើយសាសន៍ទាំងអស់នឹងមកនៅក្រោមព្រះនាមរបស់ព្រះជាម្ចាស់ ហើយមនុស្សទាំងអស់នឹងចូលមកអានព្រះបន្ទូលរបស់ព្រះជាម្ចាស់។ នៅគ្រានោះ មនុស្សខ្លះនឹងទូរស័ព្ទ ខ្លះនឹងផ្ញើទូរសារ... ពួកគេនឹងប្រើមធ្យោបាយគ្រប់បែបយ៉ាងដើម្បីទទួលបានព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយអ្នករាល់គ្នាក៏អ៊ីចឹងដែរ នឹងមកក្រោមបន្ទូលរបស់ព្រះជាម្ចាស់។ ទាំងអស់នេះ ជាអ្វីដែលកើតឡើង បន្ទាប់ពីមនុស្សត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍។ នៅសព្វថ្ងៃនេះ មនុស្សត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍ បន្សុទ្ធ បំភ្លឺ និងបង្ហាញផ្លូវតាមរយៈព្រះបន្ទូល នេះជាយុគសម័យនៃនគរព្រះ ជាដំណាក់កាលនៃមនុស្សដែលត្រូវបានប្រោសឲ្យបរិសុទ្ធ ហើយវាមិនជាប់ទាក់ទងនឹងសម័យរាជ្យមួយពាន់ឆ្នាំទេ។ កំឡុងពេលនៃរាជ្យមួយពាន់ឆ្នាំ មនុស្សនឹងត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍រួចជាស្រេច ហើយនិស្ស័យពុករលួយនានានៅក្នុងខ្លួនពួកគេនឹងត្រូវបានបន្សុទ្ធ។ នៅគ្រានោះ ព្រះបន្ទូលដែលចេញមកពីព្រះជាម្ចាស់ នឹងបង្ហាញផ្លូវមនុស្សមួយជំហានម្ដងៗ ហើយនឹងបើកឲ្យឃើញនូវអាថ៌កំបាំងនៃកិច្ចការរបស់ព្រះជាម្ចាស់ ពីគ្រានៃការបង្កបង្កើតរហូតមកដល់សព្វថ្ងៃ ហើយព្រះបន្ទូលទាំងឡាយរបស់ទ្រង់ នឹងប្រាប់មនុស្សពីកិច្ចការរបស់ព្រះជាម្ចាស់ក្នុងគ្រប់សម័យនិងរៀងរាល់ថ្ងៃអំពីរបៀបដែលទ្រង់បង្ហាញផ្លូវមនុស្ស ពីកិច្ចការដែលទ្រង់ធ្វើក្នុងពិភពខាងវិញ្ញាណ ហើយនឹងប្រាប់ពួកគេពីថាមវន្តនៃពិភព

ខាងឯវិញ្ញាណ។ ទាល់តែបែបនេះ ទើបវានឹងក្លាយជាយុគសម័យនៃព្រះបន្ទូលពិតៗ ឥឡូវនេះវាត្រឹមតែឋិតនៅក្នុងសភាពជាកូនបក្សីទើបរៀនហើរប៉ុណ្ណោះ។ បើមនុស្សមិនត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍ និងបរិសុទ្ធទេ នោះពួកគេនឹងគ្មានផ្លូវអាចរស់នៅបានមួយពាន់ឆ្នាំនៅលើផែនដីដែរ ហើយសាច់ឈាមពួកគេនឹងរលួយទៅដោយជៀសមិនផុត តែបើមនុស្សត្រូវបានបន្សុទ្ធផ្នែកខាងក្នុង ហើយពួកគេលែងជារបស់សាតាំង និងរបស់សាច់ឈាម នោះពួកគេនឹងបន្តរស់នៅលើផែនដីតទៅទៀត។ ក្នុងដំណាក់កាលនេះ អ្នកនៅតែឆោតល្ងង់ ហើយរឿងទាំងអស់ដែលអ្នករាល់គ្នាជួប នោះគឺការស្រឡាញ់ព្រះជាម្ចាស់ និងការធ្វើទីបន្ទាល់ពីទ្រង់ នៅរាល់ថ្ងៃដែលអ្នករស់នៅលើផែនដីនោះ។

«រាជ្យមួយពាន់ឆ្នាំបានមកដល់ហើយ» គឺជាទំនាយមួយ ហើយវាស្រដៀងទៅនឹងការទាយទុកជាមុនរបស់ហោរា ជាការដែលព្រះជាម្ចាស់ទាយទុកមុនពីអ្វីដែលនឹងកើតឡើងនាពេលអនាគត។ ព្រះបន្ទូលនានា ដែលព្រះជាម្ចាស់មានបន្ទូលក្នុងពេលអនាគត និងព្រះបន្ទូលនានាដែលទ្រង់មានបន្ទូលនៅសព្វថ្ងៃនេះ មិនដូចគ្នាទេ៖ ព្រះបន្ទូលក្នុងពេលអនាគត នឹងបង្ហាញផ្លូវពីយុគសម័យនោះ ខណៈដែលព្រះបន្ទូលនានាដែលទ្រង់មានបន្ទូលនៅសព្វថ្ងៃ ធ្វើឲ្យមនុស្សបានគ្រប់លក្ខណ៍ បន្សុទ្ធពួកគេ និងប្រាស្រ័យទាក់ទងនឹងពួកគេ។ យុគសម័យនៃព្រះបន្ទូលក្នុងពេលអនាគត មានភាពខុសគ្នានឹងយុគសម័យព្រះបន្ទូលនាពេលសព្វថ្ងៃ។ សព្វថ្ងៃនេះ ព្រះបន្ទូលទាំងអស់របស់ព្រះជាម្ចាស់ (មិនថាតាមវិធីណាដែលទ្រង់មានបន្ទូលនោះទេ) គឺសុទ្ធតែដើម្បីធ្វើឲ្យមនុស្សបានគ្រប់លក្ខណ៍ ដើម្បីបន្សុទ្ធនូវអ្វីដែលកខ្វក់ក្នុងខ្លួនពួកគេ ដើម្បីធ្វើឲ្យពួកគេបានបរិសុទ្ធ ហើយធ្វើឲ្យពួកគេបានសុចរិត នៅចំពោះព្រះភ័ក្ត្ររបស់ព្រះជាម្ចាស់។ ព្រះបន្ទូលនៅសព្វថ្ងៃនេះ និងព្រះបន្ទូលនៅពេលអនាគត ជារឿងពីរផ្សេងគ្នា។ ព្រះបន្ទូលក្នុងយុគសម័យនៃនគរព្រះ គឺដើម្បីធ្វើឲ្យមនុស្សចូលទៅក្នុងការហ្វឹកហាត់ទាំងឡាយ ដើម្បីនាំមនុស្សទៅកាន់គន្លងត្រឹមត្រូវក្នុងរឿងគ្រប់យ៉ាង ដើម្បីបណ្ដេញនូវអ្វីទាំងអស់ដែលមិនបរិសុទ្ធក្នុងខ្លួនពួកគេ។ នេះជាអ្វីដែលព្រះជាម្ចាស់ធ្វើក្នុងសម័យនេះ។ ទ្រង់បង្កើតមូលដ្ឋានមួយនៃព្រះបន្ទូលរបស់ទ្រង់ក្នុងមនុស្សគ្រប់រូប

ទ្រង់ធ្វើឲ្យព្រះបន្ទូលទ្រង់ក្លាយជាជីវិតនៃមនុស្សគ្រប់រូប ហើយទ្រង់ប្រើព្រះបន្ទូលរបស់ទ្រង់ ដើម្បីបំភ្លឺនិងបង្ហាញផ្លូវពីខាងក្នុងដល់ពួកគេជាប់ជានិច្ច។ ហើយពេលដែលពួកគេមិនខ្វាយខ្វល់នឹងបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ព្រះបន្ទូលរបស់ទ្រង់នឹងនៅក្នុងខ្លួនរបស់ពួកគេ ដើម្បីស្ដីបន្ទោស និងប្រៀនប្រដៅពួកគេ។ ព្រះបន្ទូលនានានៅពេលសព្វថ្ងៃ គួរតែជាជីវិតរបស់មនុស្ស ព្រះបន្ទូលទាំងនោះផ្ដល់ដោយផ្ទាល់នូវអ្វីៗគ្រប់យ៉ាងដែលមនុស្សត្រូវការ គ្រប់យ៉ាងដែលអ្នកខ្វះនៅក្នុងខ្លួន ត្រូវបានផ្ដល់មកដោយព្រះបន្ទូល ហើយអស់អ្នកដែលទទួលយកព្រះបន្ទូល ទទួលបានការបំភ្លឺដោយការហូប និងផឹកបន្ទូលរបស់ទ្រង់។ ព្រះបន្ទូលនានាក្នុងពេលអនាគត បង្ហាញផ្លូវដល់មនុស្សទូទាំងសកលលោកនេះ ហើយសព្វថ្ងៃ ពាក្យទាំងនេះត្រូវបាននិយាយឡើងតែក្នុងប្រទេសចិនប៉ុណ្ណោះ ហើយពួកវាមិនតំណាងឲ្យពាក្យទាំងឡាយ ដែលត្រូវបាននិយាយទៅទូទាំងសកលលោកនោះទេ។ ព្រះជាម្ចាស់នឹងមានបន្ទូលទៅកាន់សកលលោកទាំងមូល នៅពេលដែលរាជ្យមួយពាន់ឆ្នាំមកដល់ប៉ុណ្ណោះ។ ចូរដឹងថាព្រះបន្ទូលនាពេលសព្វថ្ងៃ គឺសុទ្ធតែដើម្បីធ្វើឲ្យមនុស្សបានគ្រប់លក្ខណ៍ ព្រះបន្ទូលដែលព្រះជាម្ចាស់បានមានបន្ទូលក្នុងអំឡុងពេលនៃដំណាក់កាលនេះ គឺសុទ្ធតែដើម្បីបំពេញតម្រូវការរបស់មនុស្ស មិនមែនដើម្បីអនុញ្ញាតឲ្យអ្នកដឹងពីរឿងអាថ៌កំបាំងនានា ឬពីការអស្ចារ្យនានារបស់ព្រះជាម្ចាស់នោះទេ។ ការដែលទ្រង់មានបន្ទូលតាមរយៈមធ្យោបាយជាច្រើននោះ គឺដើម្បីផ្គត់ផ្គង់តាមតម្រូវការរបស់មនុស្ស។ សម័យរាជ្យមួយពាន់ឆ្នាំ មិនទាន់មកដល់នៅឡើយទេ (រាជ្យមួយពាន់ឆ្នាំ ដែលត្រូវបាននិយាយមកនេះ ជាថ្ងៃនៃសិរីល្អរបស់ព្រះជាម្ចាស់)។ បន្ទាប់ពីកិច្ចការរបស់ព្រះយេស៊ូវក្នុងស្រុកយូដាត្រូវបានបញ្ចប់ ព្រះជាម្ចាស់បានផ្លាស់ប្ដូរកិច្ចការរបស់ទ្រង់មកកាន់ចិនដីគោកវិញ ហើយបានបង្កើតផែនការមួយទៀត។ ទ្រង់ធ្វើការមួយផ្នែកទៀតនៃកិច្ចការរបស់ទ្រង់ក្នុងខ្លួនអ្នករាល់គ្នា ទ្រង់ធ្វើកិច្ចការនៃការប្រោសឲ្យមនុស្សបានគ្រប់លក្ខណ៍ដោយប្រើព្រះបន្ទូល ហើយទ្រង់ប្រើព្រះបន្ទូលនានាដើម្បីធ្វើឲ្យមនុស្សទទួលរងនូវការឈឺចាប់យ៉ាងខ្លាំង ក៏ដូចជាទទួលបាននូវព្រះគុណយ៉ាងច្រើនដូចគ្នាដែរ។ ដំណាក់កាលនៃ

កិច្ចការនេះ នឹងបង្កើតនូវអ្នកមានជ័យជម្នះមួយក្រុមនេះ ពួកគេនឹងមានលទ្ធភាពធ្វើទីបន្ទាល់ពីសកម្មភាពរបស់ទ្រង់ ពួកគេនឹងមានលទ្ធភាពរស់នៅតាមភាពជាក់ស្ដែង ហើយតាមការពិតទៅ ពួកគេនឹងធ្វើឲ្យទ្រង់សព្វព្រះហឫទ័យ ហើយមានភក្ដីភាពចំពោះទ្រង់រហូតដល់ស្លាប់ ហើយតាមរយៈវិធីនេះ ព្រះជាម្ចាស់នឹងទទួលបានសិរីល្អ។ ពេលព្រះជាម្ចាស់ទទួលបានសិរីល្អ ដែលមានន័យថា ពេលទ្រង់ប្រោសឲ្យមនុស្សមួយក្រុមនេះបានគ្រប់លក្ខណ៍រួចហើយ នោះនឹងដល់យុគសម័យរាជ្យមួយពាន់ឆ្នាំហើយ។

ព្រះយេស៊ូវបានគង់នៅលើផែនដីអស់រយៈពេលសាមសិបបីឆ្នាំកន្លះ ទ្រង់បានយាងមកធ្វើកិច្ចការនៃការជាប់ឆ្កាង ហើយតាមរយៈការជាប់ឆ្កាង ព្រះជាម្ចាស់បានទទួលនូវសិរីល្អមួយចំណែករបស់ទ្រង់។ នៅពេលដែលព្រះជាម្ចាស់បានត្រលប់មកជាសាច់ឈាម ទ្រង់អាចបន្ទាបព្រះអង្គទ្រង់ និងលាក់កំបាំង ហើយអាចទ្រាំទ្រនឹងការរងទុក្ខយ៉ាងធ្ងន់ធ្ងរ។ បើទោះជាទ្រង់ជាព្រះជាម្ចាស់ ក៏ទ្រង់នៅតែអត់ទ្រាំនឹងការសើចចំអក និងការប្រមាថទាំងឡាយ ហើយទ្រង់បានអត់ទ្រាំនឹងការឈឺចាប់យ៉ាងខ្លាំងក្លាក្នុងការដែលត្រូវគេដំដោយដែកគោលភ្ជាប់នឹងឈើឆ្កាង ដើម្បីបំពេញកិច្ចការនៃការប្រោសលោះ។ បន្ទាប់ពីដំណាក់កាលនៃកិច្ចការនេះត្រូវបញ្ចប់ បើទោះជាមនុស្សបានឃើញថាព្រះជាម្ចាស់ បានទទួលនូវសិរីល្អដ៏អស្ចារ្យរបស់ទ្រង់ រឿងនេះមិនមែនជាសិរីល្អទាំងស្រុងរបស់ទ្រង់ទេ វាគ្រាន់តែជាសិរីល្អមួយចំណែករបស់ទ្រង់ដែលទ្រង់បានទទួលពីព្រះយេស៊ូវប៉ុណ្ណោះ។ បើទោះជាព្រះយេស៊ូវអាចទ្រាំទ្រនឹងការលំបាកទាំងឡាយ អាចបន្ទាបព្រះអង្គទ្រង់ និងអាចត្រូវបានលាក់កំបាំង អាចត្រូវបានគេឆ្កាងដើម្បីព្រះជាម្ចាស់ ក៏ព្រះជាម្ចាស់ទទួលបានត្រឹមសិរីល្អមួយផ្នែករបស់ទ្រង់ប៉ុណ្ណោះ ហើយសិរីល្អរបស់ទ្រង់ ត្រូវបានទទួលនៅក្នុងប្រទេសអ៊ីស្រាអែល។ ព្រះជាម្ចាស់នៅមានសិរីល្អមួយផ្នែកផ្សេងទៀតគឺៈ ការយាងមកផែនដី ដើម្បីធ្វើកិច្ចការជាក់ស្ដែង និងប្រោសឲ្យមនុស្សមួយក្រុមបានគ្រប់លក្ខណ៍។ អំឡុងដំណាក់កាលនៃកិច្ចការរបស់ព្រះយេស៊ូវ ទ្រង់បានធ្វើរឿងអព្ភូតហេតុមួយចំនួន តែដំណាក់កាលនៃកិច្ចការនោះ មិនមែនដើម្បីតែសម្ដែងទីសម្គាល់ និងការអស្ចារ្យនោះទេ។ ជាបឋម គឺ

ដើម្បីបង្ហាញថា ព្រះយេស៊ូវអាចរងទុក្ខ ហើយត្រូវបានឆ្កាងដើម្បីព្រះជាម្ចាស់ ដែលបង្ហាញថា ព្រះយេស៊ូវអាចរងនូវការឈឺចាប់យ៉ាងធ្ងន់ធ្ងរ ព្រោះទ្រង់បានស្រឡាញ់ព្រះជាម្ចាស់ និងបង្ហាញថា បើទោះជាព្រះជាម្ចាស់បានបោះបង់ទ្រង់ ក៏ទ្រង់នៅតែស្ម័គ្រលះបង់ព្រះជន្មរបស់ទ្រង់ទៅតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែរ។ បន្ទាប់ពីព្រះជាម្ចាស់បានបំពេញកិច្ចការរបស់ទ្រង់នៅក្នុងប្រទេសអ៊ីស្រាអែល ហើយព្រះយេស៊ូវត្រូវបានដំនឹងដែកគោលភ្ជាប់ឈើឆ្កាង ព្រះជាម្ចាស់ក៏បានទទួលសិរីល្អ ហើយព្រះអង្គបានធ្វើទីបន្ទាល់នៅចំពោះមុខសាតាំង។ អ្នករាល់គ្នាមិនដឹង ហើយក៏មិនបានឃើញថាព្រះជាម្ចាស់បានត្រលប់ជាសាច់ឈាមក្នុងប្រទេសចិនដោយរបៀបណា ដូច្នេះ តើអ្នករាល់គ្នាអាចមើលឃើញថា ព្រះជាម្ចាស់បានទទួលសិរីល្អដោយរបៀបណា? នៅពេលដែលព្រះជាម្ចាស់ ធ្វើកិច្ចការជាច្រើននៃការយកឈ្នះនៅក្នុងអ្នករាល់គ្នា ហើយអ្នករាល់គ្នាឈរយ៉ាងរឹងមាំ ពេលនោះដំណាក់កាលនៃកិច្ចការរបស់ព្រះជាម្ចាស់នេះ បានជោគជ័យហើយ ហើយនេះជាផ្នែកមួយនៃសិរីល្អរបស់ព្រះជាម្ចាស់។ អ្នករាល់គ្នាមើលឃើញត្រឹមរឿងនេះប៉ុណ្ណោះ ហើយអ្នករាល់គ្នាមិនទាន់ត្រូវបានព្រះជាម្ចាស់ប្រោសឲ្យគ្រប់លក្ខណ៍នៅឡើយទេ ហើយក៏មិនទាន់ថ្វាយដួងចិត្តរបស់អ្នកទាំងស្រុងទៅកាន់ព្រះជាម្ចាស់ដែរ។ អ្នករាល់គ្នាមិនទាន់បានឃើញទាំងស្រុងនូវសិរីល្អនេះ អ្នកត្រឹមមើលឃើញថា ព្រះជាម្ចាស់បានយកឈ្នះដួងចិត្តរបស់អ្នករាល់គ្នា ឃើញថាអ្នករាល់គ្នាមិនអាចចាកចេញពីទ្រង់ ហើយនឹងដើរតាមព្រះជាម្ចាស់រហូតដល់ចុងបញ្ចប់ឡើយ ហើយដួងចិត្តរបស់អ្នកនឹងមិនផ្លាស់ប្ដូរ ហើយមើលឃើញថា នេះជាសិរីល្អរបស់ព្រះជាម្ចាស់ទេ។ តើអ្នកមើលឃើញសិរីល្អរបស់ព្រះជាម្ចាស់នៅក្នុងអ្វីខ្លះ? គឺក្នុងឥទ្ធិពលនានានៃកិច្ចការរបស់ទ្រង់ក្នុងខ្លួនមនុស្ស។ មនុស្សមើលឃើញថា ព្រះជាម្ចាស់គួរឲ្យស្រឡាញ់យ៉ាងខ្លាំង ពួកគេមានព្រះជាម្ចាស់ក្នុងដួងចិត្តពួកគេ ហើយមិនចង់ចាកចេញពីទ្រង់ទេ ហើយនេះជាសិរីល្អរបស់ព្រះជាម្ចាស់។ ពេលភាពរឹងមាំ នៃបងប្អូនប្រុសស្រីក្នុងក្រុមជំនុំនានាកើតមានឡើង ហើយពួកគេអាចស្រឡាញ់ព្រះជាម្ចាស់ចេញពីដួងចិត្តរបស់ពួកគេ

មើលឃើញព្រះចេស្ដាដ៏ខ្ពង់ខ្ពស់នៃកិច្ចការដែលព្រះជាម្ចាស់បានធ្វើ ព្រះចេស្ដាដែលគ្មានអ្វីប្រៀបបាននៃព្រះបន្ទូលរបស់ទ្រង់ ពេលពួកគេបានឃើញថា ព្រះបន្ទូលរបស់ទ្រង់មានសិទ្ធិអំណាច និងថាទ្រង់អាចចាប់ផ្ដើមកិច្ចការរបស់ទ្រង់ក្នុងទីក្រុងដែលត្រូវគេបោះបង់ចោលក្នុងប្រទេសចិនដីគោក បើទោះជាមនុស្សមានភាពទន់ខ្សោយ ពេលដួងចិត្តពួកគេឱនក្រាប ចំពោះព្រះភ័ក្ត្ររបស់ព្រះជាម្ចាស់ ហើយពួកគេព្រមទទួលព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយបើទោះជាពួកគេទន់ខ្សោយ និងគ្មានតម្លៃស័ក្ដិសម ពេលពួកគេអាចមើលឃើញថា ព្រះបន្ទូលរបស់ព្រះជាម្ចាស់ គួរឲ្យស្រឡាញ់យ៉ាងខ្លាំង ហើយមានតម្លៃស័ក្តិសមនឹងការថែរក្សារបស់ពួកគេ នោះរឿងនេះគឺជាសិរីល្អរបស់ព្រះជាម្ចាស់ហើយ។ ពេលថ្ងៃនោះមកដល់ ជាពេលដែលព្រះជាម្ចាស់ប្រោសឲ្យមនុស្សបានគ្រប់លក្ខណ៍ ហើយអាចចុះចូលនៅចំពោះព្រះភ័ក្ត្រទ្រង់ ហើយអាចស្ដាប់តាមព្រះជាម្ចាស់ទាំងស្រុង និងដាក់នូវជោគវាសនារបស់ពួកគេទៅក្នុងព្រះហស្តនៃព្រះជាម្ចាស់ នោះផ្នែកទីពីរនៃសិរីល្អរបស់ព្រះជាម្ចាស់នឹងត្រូវទទួលបានមកយ៉ាងពេញលេញ។ អាចនិយាយបានថា នៅពេលដែលកិច្ចការនៃព្រះដ៏ជាក់ស្ដែងបានបញ្ចប់ទាំងស្រុង នោះកិច្ចការរបស់ទ្រង់ក្នុងទឹកដីចិនដីគោកនឹងដល់ទីបញ្ចប់។ ម្យ៉ាងទៀត ពេលអស់អ្នកដែលត្រូវបានកំណត់ទុកជាមុន និងត្រូវបានព្រះជាម្ចាស់ជ្រើសរើស ត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍រួចហើយ នោះព្រះជាម្ចាស់នឹងបានទទួលសិរីល្អ។ ព្រះជាម្ចាស់មានបន្ទូលថា ទ្រង់បាននាំមកនូវផ្នែកទីពីរនៃសិរីល្អរបស់ទ្រង់មកកាន់ប៉ែកខាងកើត ប៉ុន្តែវាមិនអាចឲ្យគេមើលឃើញដោយភ្នែកទទេបានទេ។ ព្រះជាម្ចាស់ បាននាំយកកិច្ចការរបស់ទ្រង់មកប៉ែកខាងកើត៖ ទ្រង់បានមកដល់ខាងកើតរួចហើយ ហើយនេះជាសិរីល្អរបស់ព្រះជាម្ចាស់។ នៅសព្វថ្ងៃនេះ បើទោះជាកិច្ចការរបស់ទ្រង់មិនទាន់បានបញ្ចប់ក្ដី ព្រោះព្រះជាម្ចាស់បានសម្រេចព្រះហឫទ័យថានឹងធ្វើវា នោះវានឹងប្រាកដជាបានសម្រេច។ ព្រះជាម្ចាស់បានសម្រេចព្រះហឫទ័យថាទ្រង់នឹងបំពេញកិច្ចការក្នុងប្រទេសចិន ហើយទ្រង់បានតាំងចិត្តនឹងធ្វើឲ្យអ្នករាល់គ្នាបានពេញខ្នាត។ ដូច្នេះ ទ្រង់មិនឲ្យអ្នករាល់គ្នាទៅណារួចទេ គឺទ្រង់បានយកឈ្នះ

ដួងចិត្តអ្នករាល់គ្នារួចទៅហើយ ហើយអ្នកត្រូវបន្តដំណើរទៅមុខ មិនថាអ្នកចង់ ឬអត់នោះទេ ហើយពេលព្រះជាម្ចាស់យកឈ្នះលើអ្នករាល់គ្នារួចហើយ ព្រះជាម្ចាស់ក៏ទទួលបានសិរីល្អ។ សព្វថ្ងៃនេះ ព្រះជាម្ចាស់មិនទាន់ទទួលបានសិរីល្អពេញលេញនៅឡើយទេ ព្រោះអ្នករាល់គ្នាមិនទាន់ត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍នៅឡើយ។ បើទោះជាដួងចិត្តរបស់អ្នកបានត្រឡប់រកព្រះជាម្ចាស់ក្តី ក៏នៅមានភាពទន់ខ្សោយជាច្រើនក្នុងសាច់ឈាមរបស់អ្នកដែរ ហើយអ្នកមិនមានលទ្ធភាពធ្វើឲ្យព្រះជាម្ចាស់សព្វព្រះហឫទ័យទេ អ្នកមិនអាចនឹកចាំពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ហើយអ្នកនៅមានរឿងអវិជ្ជមានជាច្រើនដែលអ្នករាល់គ្នាត្រូវជម្រុះចេញពីខ្លួន ហើយអ្នកត្រូវឆ្លងកាត់ការល្បងល និងការបន្សុទ្ធជាច្រើនទៀត។ មានតែបែបនេះទេ ទើបនិស្ស័យជីវិតរបស់អ្នកអាចផ្លាស់ប្តូរ ហើយអ្នកអាចនឹងត្រូវបានព្រះជាម្ចាស់យកឈ្នះ។

# មានតែអស់អ្នកដែលស្គាល់ព្រះជាម្ចាស់ប៉ុណ្ណោះ ដែលអាចធ្វើទីបន្ទាល់អំពីព្រះជាម្ចាស់បាន

វាជាការចាត់តាំងរបស់ស្ថានសួគ៌ និងត្រូវទទួលស្គាល់ដោយផែនដីក្នុងការជឿលើព្រះជាម្ចាស់ និងស្គាល់ព្រះជាម្ចាស់ ហើយសព្វថ្ងៃនេះ ក្នុងអំឡុងសម័យដែលព្រះជាម្ចាស់យកកំណើតជាមនុស្សកំពុងបំពេញកិច្ចការរបស់ទ្រង់ដោយផ្ទាល់ គឺពេលវេលាដ៏ល្អជាពិសេសក្នុងការស្គាល់ព្រះជាម្ចាស់។ ការផ្គាប់ព្រះហឫទ័យព្រះជាម្ចាស់ គឺជាអ្វីដែលអាចសម្រេចទៅបានដោយការកសាងមូលដ្ឋានគ្រឹះ នៃការស្វែងយល់ពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ហើយដើម្បីស្វែងយល់ពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់បាន ចាំបាច់ត្រូវមានចំណេះដឹងខ្លះៗអំពីព្រះជាម្ចាស់។ ចំណេះដឹងអំពីព្រះជាម្ចាស់នេះ គឺជានិមិត្តដែលមនុស្សម្នាក់ជឿលើព្រះជាម្ចាស់ត្រូវតែមាន។ វាគឺជាមូលដ្ឋានគ្រឹះនៃជំនឿរបស់មនុស្សចំពោះព្រះជាម្ចាស់។ បើសិនគ្មានចំណេះដឹងនេះទេ ជំនឿរបស់មនុស្សចំពោះព្រះជាម្ចាស់ នឹងមានដោយស្រពេច

ស្រពិល នៅក្នុងចំណោមទ្រឹស្ដីទទេសូន្យ។ បើទោះបីវាជាការតាំងចិត្តរបស់មនុស្ស បែបនេះ ដើម្បីដើរតាមព្រះជាម្ចាស់ក៏ពិតមែន ក៏ពួកគេនឹងមិនទទួលបានអ្វីសោះឡើយ។ អស់អ្នកដែលមិនទទួលបានអ្វីសោះនៅក្នុងអូរនេះ គឺជាអ្នកដែលនឹងត្រូវផាត់ចោល ពោលគឺពួកគេគឺជាមនុស្សកេងប្រវ័ញ្ច។ មិនថាឯងមានបទពិសោធនៅក្នុងដំណាក់កាលណាមួយនៃកិច្ចការរបស់ព្រះជាម្ចាស់នោះទេ អ្នកគប្បីមាននិមិត្តដ៏អស្ចារ្យមួយអមមកជាមួយ។ បើពុំដូចនេះទេ អ្នកមុខជានឹងជួបការលំបាកក្នុងការទទួលយកជំហាននីមួយៗនៃកិច្ចការថ្មីនេះ ដ្បិតកិច្ចការថ្មីរបស់ព្រះជាម្ចាស់ លើសពីសមត្ថភាពរបស់មនុស្សដែលអាចនឹងស្រមៃដល់ ហើយនៅក្រៅព្រំដែននៃការយល់ដឹងរបស់គេ។ ដូច្នេះ បើគ្មានអ្នកគង្វាលដើម្បីមើលថែមនុស្ស បើគ្មានអ្នកគង្វាលចូលរួមក្នុងការប្រកបអំពីនិមិត្តទេ មនុស្សមិនអាចទទួលបានកិច្ចការថ្មីនេះឡើយ។ ប្រសិនបើមនុស្សពុំអាចទទួលបាននិមិត្តទេ នោះពួកគេមិនអាចទទួលបានកិច្ចការថ្មីរបស់ព្រះជាម្ចាស់ឡើយ ហើយប្រសិនបើមនុស្សមិនអាចស្ដាប់បង្គាប់តាមកិច្ចការថ្មីរបស់ព្រះជាម្ចាស់ទេ នោះមនុស្សនឹងមិនអាចយល់ពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់បានឡើយ ហើយដូចនេះ ចំណេះដឹងអំពីព្រះជាម្ចាស់នឹងក្លាយជាគ្មានបានការអ្វីទាំងអស់។ នៅមុនពេលមនុស្សអនុវត្តតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់បាន គេត្រូវស្គាល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់សិន ពោលគឺគេត្រូវយល់ពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ មានតែបែបនេះទេ ទើបអាចអនុវត្តតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់បានសុក្រិតល្អ និងស្របតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ នេះគឺជាអ្វីដែលអ្នកស្វែងរកសេចក្ដីពិតគ្រប់គ្នាត្រូវមាន ហើយវាក៏ជាដំណើរការដែលមនុស្សគ្រប់គ្នាព្យាយាមចង់ស្គាល់ព្រះជាម្ចាស់ត្រូវឆ្លងកាត់ផងដែរ។ ដំណើរការនៃការស្គាល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ គឺជាដំណើរការនៃការស្គាល់ព្រះជាម្ចាស់ និងកិច្ចការរបស់ព្រះជាម្ចាស់។ ដូចនេះការស្គាល់និមិត្ត មិនគ្រាន់តែ សំដៅលើការស្គាល់សភាពជាមនុស្សរបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សនោះទេ ប៉ុន្តែក៏រាប់បញ្ចូលទាំងការស្គាល់ព្រះបន្ទូល និងកិច្ចការរបស់ព្រះជាម្ចាស់ផងដែរ។ មនុស្សស្វែងយល់ពីបំណងព្រះហឫទ័យរបស់

ព្រះជាម្ចាស់តាមរយៈព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយពួកគេស្គាល់ពីនិស្ស័យរបស់ព្រះជាម្ចាស់ និងស្គាល់ថាព្រះជាម្ចាស់ជានរណាតាមរយៈកិច្ចការរបស់ព្រះជាម្ចាស់។ ជំនឿលើព្រះជាម្ចាស់ គឺជាជំហានដំបូងក្នុងការស្គាល់ព្រះជាម្ចាស់។ ដំណើរការនៃការវិវឌ្ឍទៅមុខ ដោយចាប់ពីជំនឿដំបូងលើព្រះជាម្ចាស់ រហូតដល់ជំនឿដ៏ជ្រាលជ្រៅលើទ្រង់ គឺជាដំណើរការនៃការស្គាល់ព្រះជាម្ចាស់ ជាដំណើរការនៃការឆ្លងកាត់បទពិសោធ នៅក្នុងកិច្ចការរបស់ព្រះជាម្ចាស់។ ប្រសិនបើអ្នកគ្រាន់តែជឿលើព្រះជាម្ចាស់ដើម្បីគ្រាន់តែជឿលើព្រះជាម្ចាស់ប៉ុណ្ណោះ និងមិនមែនដើម្បីស្គាល់ទ្រង់ទេ នោះពុំមានសេចក្ដីពិតនៅក្នុងសេចក្ដីជំនឿរបស់អ្នកឡើយ ហើយសេចក្ដីជំនឿរបស់អ្នកមិនអាចក្លាយជាបរិសុទ្ធបានឡើយ និងគ្មានអ្វីដែលត្រូវឆ្ងល់អំពីរឿងនេះនោះទេ។ ក្នុងអំឡុងពេលដែលមនុស្សឆ្លងកាត់បទពិសោធក្នុងកិច្ចការរបស់ព្រះជាម្ចាស់ ប្រសិនបើគេស្គាល់ព្រះជាម្ចាស់បន្តិចម្ដងៗ នោះនិស្ស័យរបស់គេនឹងត្រូវផ្លាស់ប្រែបន្តិចម្ដងៗ ហើយជំនឿរបស់ពួកគេនឹងកាន់តែពិតឡើងៗ។ តាមរបៀបនេះ នៅពេលដែលមនុស្សសម្រេចបាននូវជំនឿរបស់គេលើព្រះជាម្ចាស់ គេនឹងត្រូវព្រះជាម្ចាស់ទទួលយកទាំងស្រុង។ មូលហេតុដែលព្រះជាម្ចាស់បានចំណាយពេលយ៉ាងយូរដើម្បីត្រលប់ជាសាច់ឈាមជាលើកទីពីរដើម្បីបំពេញកិច្ចការរបស់ទ្រង់ដោយផ្ទាល់ គឺដើម្បីឲ្យមនុស្សអាចស្គាល់ទ្រង់ និងអាចឃើញទ្រង់បាន។ ការស្គាល់ព្រះជាម្ចាស់[ក] គឺជាលទ្ធផលចុងក្រោយដែលត្រូវសម្រេចឲ្យបាននៅទីបញ្ចប់នៃកិច្ចការរបស់ព្រះជាម្ចាស់។ វាគឺជាលក្ខខណ្ឌចុងក្រោយដែលព្រះជាម្ចាស់បានបង្កើតមនុស្សលោក។ មូលហេតុដែលទ្រង់ធ្វើបែបនេះ គឺដើម្បីធ្វើទីបន្ទាល់ចុងក្រោយរបស់ទ្រង់។ ទ្រង់បំពេញកិច្ចការនេះដើម្បីឲ្យទីបំផុត មនុស្សអាចត្រឡប់មករកទ្រង់វិញដោយពេញលេញ។ មនុស្សអាចមកស្រឡាញ់ព្រះជាម្ចាស់វិញបានដោយសារការស្គាល់ព្រះជាម្ចាស់ ហើយដើម្បីស្រឡាញ់

លេខយោង៖

ក. អត្ថបទដើមសរសេរថា «កិច្ចការនៃការស្គាល់ព្រះជាម្ចាស់»។

ព្រះជាម្ចាស់បាន គេត្រូវស្គាល់ព្រះជាម្ចាស់។ មិនថាគេស្វែងរកដោយបែបណា ឬគេស្វែងរកចង់បានអ្វីនោះទេ គេត្រូវតែសម្រេចបាននូវចំណេះដឹងអំពីព្រះជាម្ចាស់។ មានតែរបៀបនេះទេ ទើបមនុស្សអាចផ្គាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់បាន។ មានតែការស្គាល់ព្រះជាម្ចាស់ប៉ុណ្ណោះ ដែលអាចឲ្យមនុស្សមានសេចក្ដីជំនឿពិតលើព្រះជាម្ចាស់ ហើយមានតែការស្គាល់ព្រះជាម្ចាស់ប៉ុណ្ណោះដែលអាចឲ្យគេគោរពកោតខ្លាច និងស្ដាប់បង្គាប់ព្រះជាម្ចាស់ដោយពិតប្រាកដ។ អស់អ្នកដែលពុំស្គាល់ព្រះជាម្ចាស់ នឹងមិនអាចស្ដាប់បង្គាប់ និងគោរពកោតខ្លាចព្រះជាម្ចាស់ដោយពិតប្រាកដបានឡើយ។ ការស្គាល់ព្រះជាម្ចាស់ រួមបញ្ចូលនូវការស្គាល់និស្ស័យរបស់ទ្រង់ ការយល់ដឹងអំពីបំណងព្រះហឫទ័យរបស់ទ្រង់ និងការស្គាល់ពីលក្ខណៈរបស់ទ្រង់។ ប៉ុន្តែ មិនថានរណាម្នាក់ស្គាល់អំពីទិដ្ឋភាពណាមួយនោះទេ គឺចំណុចនីមួយៗតម្រូវឲ្យមនុស្សឲ្យតម្លៃខ្ពស់ និងត្រូវមានឆន្ទៈស្ដាប់បង្គាប់ បើគ្មានចំណុចណាមួយទេ គ្មាននរណាម្នាក់អាចបន្តស្ដាប់បង្គាប់បានរហូតដល់ទីបញ្ចប់ឡើយ។ កិច្ចការរបស់ព្រះជាម្ចាស់ មិនស្របគ្នាជាមួយនឹងសញ្ញាណរបស់មនុស្សឡើយ។ និស្ស័យរបស់ព្រះជាម្ចាស់ និងលក្ខណៈរបស់ទ្រង់ជា គឺពិបាកឲ្យមនុស្សលោកដឹងបានខ្លាំងណាស់ ហើយអ្វីគ្រប់យ៉ាងដែលព្រះមានបន្ទូល និងធ្វើ គឺមិនអាចឲ្យមនុស្សលោកយល់បានឡើយ។ ប្រសិនបើមនុស្សចង់ស្ដាប់បង្គាប់ព្រះជាម្ចាស់ ក៏ប៉ុន្តែមិនអាចស្ដាប់បង្គាប់ទ្រង់បាន ដូច្នេះ មនុស្សលោកមិនទទួលបានអ្វីសោះឡើយ។ គិតចាប់ពីការបង្កើតពិភពលោក រហូតដល់បច្ចុប្បន្ននេះ ព្រះជាម្ចាស់បានបំពេញកិច្ចការយ៉ាងច្រើន ដែលមនុស្សមិនអាចយល់បាន ហើយមនុស្សពិបាកនឹងទទួលយកបាន ហើយព្រះជាម្ចាស់បានមានបន្ទូលជាច្រើនដែលធ្វើឲ្យសញ្ញាណរបស់មនុស្សពិបាកនឹងផ្សះផ្សាបាន។ ប៉ុន្តែ ទ្រង់មិនដែលបញ្ឈប់កិច្ចការរបស់ទ្រង់ដោយសារមនុស្សមានការលំបាកខ្លាំងនោះទេ។ ផ្ទុយទៅវិញ ទ្រង់បន្តបំពេញកិច្ចការ និងបន្តមានព្រះបន្ទូល ហើយបើទោះបីជា «អ្នកចម្បាំង» ជាច្រើន មិនអាចសម្រេចកិច្ចការបាន ក៏ទ្រង់នៅតែបន្តបំពេញកិច្ចការរបស់ទ្រង់ដដែល និងបន្តជ្រើសរើសមនុស្សមួយក្រុមហើយមួយក្រុម

ទៀត ដែលសុខចិត្តចុះចូលចំពោះកិច្ចការថ្មីរបស់ទ្រង់ដោយគ្មានពេលសម្រាក។ ទ្រង់គ្មានសេចក្ដីអាណិតអាសូរចំពោះ «វីរៈជន» ដែលបាត់បង់អំណាចនោះទេ ហើយផ្ទុយទៅវិញ ទ្រង់យកព្រះហឫទ័យទុកដាក់ចំពោះអស់អ្នកដែលទទួលយកកិច្ចការ និងព្រះបន្ទូលថ្មីរបស់ព្រះជាម្ចាស់។ ប៉ុន្តែ តើទ្រង់បំពេញកិច្ចការដោយបែបនេះ ពីមួយជំហានទៅមួយជំហានទៀតរហូតដល់ទីបញ្ចប់ ដោយបែបណា? តើហេតុអ្វីបានជាទ្រង់តែងតែជម្រុះចោលមនុស្សខ្លះ និងជ្រើសរើសមនុស្សផ្សេងទៀត? តើហេតុអ្វីបានជាទ្រង់តែងតែជ្រើសរើសវិធីបែបនេះ? គោលបំណងនៃកិច្ចការរបស់ទ្រង់ គឺដើម្បីឲ្យមនុស្សស្គាល់ទ្រង់ និងដើម្បីឲ្យទ្រង់អាចទទួលយកគេបាន។ គោលការណ៍នៃកិច្ចការរបស់ទ្រង់ គឺដើម្បីគិតគូរដល់អស់អ្នកដែលអាចចុះចូលនឹងកិច្ចការដែលទ្រង់កំពុងធ្វើក្នុងពេលបច្ចុប្បន្ននេះ និងមិនគិតគូរដល់អស់អ្នកដែលចុះចូលនឹងកិច្ចការដែលបានធ្វើរួចរាល់កាលពីអតីតកាល ដោយប្រឆាំងទាស់នឹងកិច្ចការដែលទ្រង់បំពេញ ក្នុងពេលសព្វថ្ងៃនេះឡើយ។ ខាងក្រោមនេះ គឺជាមូលហេតុដែលទ្រង់បានជម្រុះចោលមនុស្សជាច្រើននាក់។

ឥទ្ធិពលនៃមេរៀនក្នុងការស្គាល់ព្រះជាម្ចាស់ មិនអាចសម្រេចទៅបានក្នុងពេលមួយថ្ងៃឬពីរថ្ងៃនោះទេ៖ មនុស្សត្រូវប្រមូលយកបទពិសោធ ឆ្លងកាត់ទុក្ខវេទនា និងសម្រេចនូវការចុះចូលដោយពិតប្រាកដ។ ដំបូងបង្អស់ ត្រូវចាប់ផ្ដើមពីកិច្ចការ និងព្រះបន្ទូលរបស់ព្រះជាម្ចាស់។ វាជាការចាំបាច់ដែលអ្នកត្រូវយល់ដឹងថា ចំណេះដឹងអំពីព្រះជាម្ចាស់ ត្រូវរួមបញ្ចូលអ្វីខ្លះ ថាតើត្រូវទទួលបានចំណេះដឹងនេះដោយរបៀបណា និងថាតើត្រូវមើលឃើញព្រះជាម្ចាស់ នៅក្នុងបទពិសោធរបស់អ្នកដោយបែបណា។ នេះគឺអ្វីដែលមនុស្សគ្រប់គ្នាត្រូវធ្វើ នៅពេលដែលពួកគេមិនទាន់ស្គាល់ទ្រង់នៅឡើយ។ គ្មាននរណាម្នាក់អាចយល់ពីកិច្ចការ និងព្រះបន្ទូលរបស់ព្រះជាម្ចាស់ក្នុងពេលតែមួយជាមួយគ្នានោះទេ ហើយគ្មាននរណាម្នាក់អាចសម្រេចការយល់ដឹងអំពីលក្ខណៈទាំងស្រុងរបស់ព្រះជាម្ចាស់ បានក្នុងពេលដ៏ខ្លីឡើយ។ ក្នុងការទទួលបានបទពិសោធនេះ មានដំណើរការចាំបាច់មួយ បើគ្មានដំណើរការនេះទេ គ្មាននរណាម្នាក់

អាចស្គាល់ព្រះជាម្ចាស់ ឬដើរតាមទ្រង់ដោយស្មោះត្រង់បាននោះឡើយ។ កាលណាព្រះជាម្ចាស់បំពេញកិច្ចការកាន់តែច្រើន ពេលនោះមនុស្សក៏ស្គាល់ទ្រង់កាន់តែច្រើនដែរ។ កាលណាកិច្ចការរបស់ព្រះជាម្ចាស់ កាន់តែខុសគ្នាពីសញ្ញាណរបស់មនុស្ស ពេលនោះចំណេះដឹងរបស់មនុស្សអំពីទ្រង់ក៏កាន់តែផ្លាស់ជាថ្មី និងជ្រាលជ្រៅជាងមុនដែរ។ ប្រសិនបើកិច្ចការរបស់ព្រះជាម្ចាស់ នៅតែដដែលជារៀងរហូត និងគ្មានការប្រែប្រួល នោះចំណេះដឹងរបស់មនុស្សចំពោះទ្រង់ ក៏នឹងមិនមានច្រើនដែរ។ អ្នករាល់គ្នាគប្បីត្រូវដឹងឲ្យបានច្បាស់អំពីនិមិត្តទាំងនេះនៅចន្លោះពេលនៃការបង្កើត និងពេលបច្ចុប្បន្ន អ្វីដែលព្រះជាម្ចាស់បានធ្វើក្នុងសម័យក្រឹត្យវិន័យ អ្វីដែលទ្រង់បានធ្វើក្នុងសម័យព្រះគុណ និងអ្វីដែលទ្រង់ធ្វើក្នុងសម័យនៃនគរព្រះ។ ឯងរាល់គ្នាត្រូវតែស្គាល់នូវកិច្ចការរបស់ព្រះជាម្ចាស់។ ក្រោយពេលដែលពេត្រុស បានដើរតាមព្រះយេស៊ូវ ទើបគាត់ចាប់ផ្ដើមស្គាល់បន្តិចម្ដងៗអំពីកិច្ចការដែលព្រះវិញ្ញាណបានធ្វើនៅក្នុងព្រះយេស៊ូវគ្រីស្ទ។ គាត់បាននិយាយថា៖ «ការពឹងផ្អែកលើបទពិសោធមនុស្ស មិនគ្រប់គ្រាន់ដើម្បីទទួលបានចំណេះដឹងពេញលេញនោះទេ។ ត្រូវមានអ្វីថ្មីៗជាច្រើនចេញពីកិច្ចការរបស់ព្រះជាម្ចាស់ ដើម្បីជួយឲ្យយើងស្គាល់ទ្រង់បាន»។ កាលពីដំបូងឡើយ ពេត្រុសបានជឿថា ព្រះយេស៊ូវគឺជាមនុស្សម្នាក់ដែលព្រះជាម្ចាស់បញ្ជូនមក ដូចជាសាវ័កម្នាក់ដែរ ហើយគាត់មិនបានគិតថាព្រះយេស៊ូវជាព្រះគ្រីស្ទនោះទេ។ នៅពេលនោះ ពេលគាត់ចាប់ផ្ដើមដើរតាមព្រះយេស៊ូវ ព្រះយេស៊ូវបានមានបន្ទូលសួរគាត់ថា៖ «ស៊ីម៉ូន កូនយ៉ូណាសអើយ តើអ្នកនឹងដើរតាមខ្ញុំដែរឬទេ?» ពេត្រុសបានទូលតបថា៖ «ខ្ញុំត្រូវដើរតាមលោក ដែលព្រះវរបិតានៅឯស្ថានសួគ៌បានបញ្ជូនមក។ ខ្ញុំត្រូវទទួលស្គាល់លោក ដែលព្រះវិញ្ញាណបរិសុទ្ធបានជ្រើសរើស។ ខ្ញុំនឹងដើរតាមលោក»។ តាមពាក្យសម្ដីរបស់គាត់ អាចមើលឃើញថា ពេត្រុសគ្មានចំណេះដឹងអ្វីសោះអំពីព្រះយេស៊ូវ។ គាត់ធ្លាប់មានបទពិសោធអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ ធ្លាប់ដោះស្រាយនឹងខ្លួនឯង និងធ្លាប់រងទុក្ខលំបាកដើម្បីព្រះជាម្ចាស់ ប៉ុន្តែ គាត់គ្មានចំណេះដឹងអំពីកិច្ចការរបស់ព្រះជាម្ចាស់ឡើយ។ បន្ទាប់ពីដកបទ

ពិសោធមួយរយៈពេលមក ពេត្រុសបានឃើញ នូវទង្វើជាច្រើនរបស់ព្រះជាម្ចាស់ នៅក្នុងព្រះយេស៊ូវ គាត់បានឃើញពីសេចក្ដីគួរឲ្យស្រឡាញ់របស់ព្រះជាម្ចាស់ ហើយគាត់បានឃើញអំពីលក្ខណៈរបស់ព្រះជាម្ចាស់យ៉ាងច្រើននៅក្នុងព្រះយេស៊ូវ។ ដូចគ្នានេះដែរ គាត់ក៏បានឃើញថា ព្រះបន្ទូលដែលព្រះយេស៊ូវមានបន្ទូល មិនធ្លាប់មានមនុស្សណាម្នាក់និយាយពីមុនមកឡើយ ហើយកិច្ចការដែលព្រះយេស៊ូវបានបំពេញ មិនធ្លាប់មានមនុស្សណាម្នាក់ធ្វើពីមុនមកឡើយ។ បន្ថែមលើនេះ តាមរយៈបន្ទូល និងសកម្មភាពរបស់ព្រះយេស៊ូវ ពេត្រុសបានមើលឃើញនូវព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់យ៉ាងច្រើន និងកិច្ចការជាច្រើនដែលមានលក្ខណៈជាព្រះ។ នៅក្នុងបទពិសោធរបស់គាត់ គាត់មិនត្រឹមតែបានស្គាល់ខ្លួនគាត់ប៉ុណ្ណោះទេ ប៉ុន្តែក៏បានយកចិត្តទុកដាក់យ៉ាងខ្លាំងលើគ្រប់សកម្មភាពរបស់ព្រះយេស៊ូវផងដែរ ដែលតាមរយៈនោះ គាត់បានរកឃើញនូវលក្ខណៈថ្មីៗជាច្រើនដូចជា ការបើកសម្ដែងជាច្រើនអំពីព្រះដ៏ពិតប្រាកដនៅក្នុងកិច្ចការដែលព្រះជាម្ចាស់បានធ្វើតាមរយៈព្រះយេស៊ូវ និងឃើញថា ព្រះយេស៊ូវខុសពីមនុស្សធម្មតាតាមរយៈព្រះបន្ទូលដែលទ្រង់ថ្លែងមក និងសកម្មភាពដែលទ្រង់ធ្វើ ក៏ដូចជាវិធីដែលទ្រង់ការពារពួកជំនុំ និងកិច្ចការដែលទ្រង់បានបំពេញផងដែរ។ ដូចនេះ ពេត្រុសបានរៀនអំពីព្រះយេស៊ូវនូវមេរៀនជាច្រើនដែលគាត់គប្បីត្រូវរៀន ហើយទម្រាំដល់ពេលដែលព្រះយេស៊ូវត្រូវឆ្កាងទៅនឹងឈើឆ្កាង គាត់បានទទួលនូវចំណេះដឹងពិតប្រាកដជាច្រើនអំពីព្រះយេស៊ូវ ជាចំណេះដឹងដែលបានក្លាយជាមូលដ្ឋាននៃសេចក្ដីស្មោះត្រង់ពេញមួយជីវិតរបស់គាត់ចំពោះព្រះយេស៊ូវ និងអំពីការជាប់ឆ្កាងជើងឡើងលើ ដែលគាត់បានទទួលរងដើម្បីជាប្រយោជន៍ដល់កិច្ចការរបស់ព្រះអម្ចាស់។ បើទោះបីជាគាត់មានសញ្ញាណខ្លះ និងពុំមានចំណេះដឹងច្បាស់លាស់អំពីព្រះយេស៊ូវពីដំបូងក៏ពិតមែន ក៏ប៉ុន្តែចំណុចទាំងនេះ គឺជាចំណែកពុករលួយដែលមិនអាចជៀសផុតបានរបស់មនុស្ស។ នៅពេលដែលព្រះយេស៊ូវជិតចាកចេញ ទ្រង់បានប្រាប់ពេត្រុសថា ការជាប់ឆ្កាងរបស់ទ្រង់ គឺជាកិច្ចការដែលទ្រង់ត្រូវចុះមកបំពេញ៖ វាជាការចាំបាច់ដែលទ្រង់ត្រូវគេបោះបង់ចោលក្នុងយុគសម័យនេះ ហើយ

ភាពមិនបរិសុទ្ធ និងយុគសម័យចាស់នេះ ត្រូវឆ្កាងទ្រង់ទៅនឹងឈើឆ្កាង។ ទ្រង់បានយាងមកដើម្បីបញ្ចប់កិច្ចការនៃការប្រោសលោះ ហើយនៅពេលបញ្ចប់កិច្ចការរបស់ទ្រង់ នោះព័ន្ធកិច្ចរបស់ទ្រង់ក៏នឹងដល់ទីបញ្ចប់ដែរ។ ដោយស្ដាប់ឮបែបនេះ ពេត្រុសកើតទុក្ខសោកសៅ និងកាន់តែជក់ជាប់នឹងព្រះយេស៊ូវកាន់តែខ្លាំងឡើង។ នៅពេលព្រះយេស៊ូវត្រូវឆ្កាងទៅនឹងឈើឆ្កាង ពេត្រុសសម្ងំយំតែម្នាក់ឯង។ នៅមុនពេលនោះ គាត់បានសួរព្រះយេស៊ូវថា៖ «ព្រះអម្ចាស់! ទ្រង់មានបន្ទូលថា ទ្រង់នឹងត្រូវគេឆ្កាង។ ក្រោយពេលដែលទ្រង់យាងទៅបាត់ តើយើងនឹងឃើញទ្រង់ម្ដងទៀត នៅពេលណា?» តើគ្មានធាតុផ្សំនៃការផិតក្បត់នៅក្នុងពាក្យសម្ដីដែលគាត់និយាយទេឬអី? តើគ្មានសញ្ញាណណាមួយនៅលាយឡំក្នុងពាក្យសម្ដីទាំងនោះទេឬអី? នៅក្នុងចិត្តរបស់គាត់ គាត់ដឹងថា ព្រះយេស៊ូវបានក្លាយជាផ្នែកពេញលេញនៃកិច្ចការរបស់ព្រះជាម្ចាស់ ហើយបន្ទាប់ពីព្រះយេស៊ូវបានចាកចេញទៅបាត់ ព្រះវិញ្ញាណនឹងសណ្ឋិតនៅក្នុងខ្លួនគាត់។ បើទោះបីជាទ្រង់នឹងត្រូវគេឆ្កាងទៅនឹងឈើឆ្កាង រួចយាងឡើងទៅស្ថានសួគ៌ក្ដី ក៏ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់នឹងសណ្ឋិតនៅក្នុងខ្លួនគាត់ដដែល។ នៅពេលនោះ ពេត្រុសមានចំណេះដឹងខ្លះៗអំពីព្រះយេស៊ូវ៖ គាត់ដឹងថា ព្រះយេស៊ូវត្រូវបានព្រះវិញ្ញាណនៃព្រះជាម្ចាស់បញ្ជូនមក ដឹងថាព្រះវិញ្ញាណនៃព្រះជាម្ចាស់គង់សណ្ឋិតនៅក្នុងទ្រង់ ហើយថាព្រះយេស៊ូវគឺជាព្រះជាម្ចាស់ផ្ទាល់តែម្ដង និងដឹងថាទ្រង់ជាព្រះគ្រីស្ទ។ ក៏ប៉ុន្តែ ដោយសារសេចក្ដីស្រឡាញ់របស់គាត់ចំពោះព្រះយេស៊ូវ ហើយដោយសារភាពទន់ខ្សោយក្នុងភាពជាមនុស្សលោករបស់គាត់ ទើបពេត្រុសពោលពាក្យបែបនេះ។ នៅគ្រប់ជំហាននៃកិច្ចការរបស់ព្រះជាម្ចាស់ ប្រសិនបើនរណាម្នាក់អាចប្រតិបត្តិតាម និងដកពិសោធន៍យ៉ាងយកចិត្តទុកដាក់ នោះមនុស្សម្នាក់នោះនឹងអាចរកឃើញនូវភាពគួរឲ្យស្រឡាញ់របស់ព្រះជាម្ចាស់បន្តិចម្ដងៗ។ ហើយ តើប៉ុលបានធ្វើអ្វីសម្រាប់និមិត្តរបស់គាត់? នៅពេលព្រះយេស៊ូវយាងមកជិតគាត់ ប៉ុលបានទូលឆ្លើយថា៖ «ឱព្រះអម្ចាស់អើយ! តើទ្រង់គឺជានរណា?» ព្រះយេស៊ូវតបថា «ខ្ញុំឈ្មោះយេស៊ូវ ជាជនដែលអ្នកបៀតបៀន»។ នេះគឺជានិមិត្តរបស់ប៉ុល។ ពេត្រុស

ទទួលយកនិមិត្តរបស់គាត់អំពីការរស់ឡើងវិញរបស់ព្រះយេស៊ូវ ការលេចមករបស់ទ្រង់ក្នុងពេល៤០ថ្ងៃ និងការបង្រៀនអំពីពេលវេលាក្នុងឆាកជីវិតរបស់ព្រះយេស៊ូវរហូតដល់ចុងបញ្ចប់នៃដំណើររបស់ទ្រង់។

មនុស្សជួបប្រទះបទពិសោធក្នុងកិច្ចការរបស់ព្រះជាម្ចាស់ បានស្គាល់ខ្លួនឯង និងកម្ចាត់ចោលនូវនិស្ស័យពុករលួយ និងស្វែងរកការរីកចម្រើនធំធាត់នៅក្នុងជីវិត ដែលការទាំងអស់នេះ គឺដើម្បីស្គាល់ព្រះជាម្ចាស់។ ប្រសិនបើអ្នកគ្រាន់តែស្វែងរកចង់ស្គាល់ខ្លួនឯង និងដើម្បីកម្ចាត់និស្ស័យពុករលួយផ្ទាល់ខ្លួនរបស់អ្នក ប៉ុន្តែគ្មានចំណេះដឹងអំពីកិច្ចការដែលព្រះជាម្ចាស់ធ្វើមកលើមនុស្ស គ្មានចំណេះដឹងអំពីភាពអស្ចារ្យនៃសេចក្ដីសង្គ្រោះរបស់ទ្រង់ ឬថាតើអ្នកត្រូវដកពិសោធន៍ក្នុងកិច្ចការរបស់ព្រះជាម្ចាស់ និងធ្វើជាទីបន្ទាល់អំពីទង្វើរបស់ទ្រង់ទេ ដូច្នេះ បទពិសោធរបស់អ្នក គឺភ្លីភ្លើចោលម្សៀត។ ប្រសិនបើអ្នកគិតថា ជីវិតរបស់មនុស្សម្នាក់បានទទួលភាពចាស់ទុំដោយគ្រាន់តែមនុស្សម្នាក់អាចដាក់បញ្ចូលសេចក្ដីពិតទៅក្នុងការអនុវត្តរបស់ខ្លួន និងធ្វើការតស៊ូ នេះមានន័យថា អ្នកនៅតែមិនទាន់ចាប់បាននូវខ្លឹមសារពិតរបស់ជីវិត ឬគោលបំណងរបស់ព្រះជាម្ចាស់ក្នុងការធ្វើឲ្យមនុស្សបានគ្រប់លក្ខណ៍ឡើយ។ នៅថ្ងៃមួយ ពេលដែលអ្នកស្ថិតក្នុងចំណោមពួកជំនុំសាសនា ក្នុងចំណោមសមាជិកនៃពួកជំនុំនៃការកែប្រែចិត្ត ឬសមាជិកនៃពួកជំនុំជីវិត អ្នកនឹងជួបមនុស្សដែលប្តូរផ្តាច់ ដែលការអធិស្ឋានរបស់ពួកគេ មាន «និមិត្ត» នៅក្នុងនោះ ហើយនៅក្នុងការស្វែងរកជីវិតរបស់ពួកគេ ពួកគេមានអារម្មណ៍ប៉ះពាល់ចិត្ត និងទទួលបានការណែនាំដោយព្រះបន្ទូល។ បន្ថែមលើនេះ ពួកគេអាចតស៊ូជម្នះបញ្ហាជាច្រើន និងលះបង់ខ្លួនឯងបាន និងមិនត្រូវដឹកនាំដោយសាច់ឈាមឡើយ។ នៅពេលនោះ អ្នកនឹងមិនអាចនិយាយពីភាពខុសគ្នាបានឡើយ៖ អ្នកនឹងជឿថា អ្វីគ្រប់យ៉ាងដែលពួកគេធ្វើគឺសុទ្ធតែត្រឹមត្រូវ គឺជាការបើកសម្ដែងពីធម្មជាតិនៃជីវិត ហើយនោះគឺជាសេចក្ដីអាណិតអាសូរជាពន់ពេក ដែលពួកគេជឿលើនាមដែលមិនត្រឹមត្រូវ។ តើទស្សនៈបែបនេះ មិនឆ្កួតលីលាពេកទេឬអី? តើហេតុអ្វីបានជាគេនិយាយថា មនុស្សជាច្រើនពុំមានជីវិត? ដោយសារពួកគេពុំស្គាល់

ព្រះជាម្ចាស់ ហេតុនេះហើយ គេនិយាយថាពួកគេពុំមានព្រះជាម្ចាស់នៅក្នុងចិត្ត និងគ្មានជីវិតសោះឡើយ។ ប្រសិនបើសេចក្ដីជំនឿរបស់អ្នកលើព្រះជាម្ចាស់បានឈានដល់កម្រិតមួយដែលអ្នកអាចយល់បានយ៉ាងជ្រាលជ្រៅអំពីទង្វើរបស់ព្រះជាម្ចាស់ សេចក្ដីពិតអំពីព្រះជាម្ចាស់ និងគ្រប់ដំណាក់កាលនៃកិច្ចការរបស់ព្រះជាម្ចាស់ នោះមានន័យថាអ្នកកំពុងមានសេចក្ដីពិតនៅក្នុងខ្លួន។ ប្រសិនបើអ្នកមិនស្គាល់កិច្ចការ និងនិស្ស័យរបស់ព្រះជាម្ចាស់ទេ នោះមានន័យថាអ្នកនៅតែមានចំណុចខ្វះខាតនៅក្នុងបទពិសោធរបស់អ្នកនៅឡើយ។ របៀបដែលព្រះយេស៊ូវបានអនុវត្តដំណាក់កាលនៃកិច្ចការរបស់ទ្រង់ របៀបដែលត្រូវអនុវត្តកិច្ចការនៅដំណាក់កាលនេះ និងរបៀបដែលព្រះជាម្ចាស់បានបំពេញកិច្ចការរបស់ទ្រង់នៅក្នុងសម័យព្រះគុណ កិច្ចការដែលកំពុងធ្វើនៅដំណាក់កាលនេះ ប្រសិនបើអ្នកគ្មានចំណេះដឹងហ្មត់ចត់អំពីចំណុចទាំងអស់នេះទេ នោះអ្នកនឹងមិនមានអារម្មណ៍ច្បាស់ក្នុងចិត្តនោះទេ ហើយអ្នកនឹងមិនស្ងប់ក្នុងចិត្តឡើយ។ បន្ទាប់ពីបទពិសោធមួយរយៈមក ប្រសិនបើអ្នកមិនអាចស្គាល់ការដែលព្រះជាម្ចាស់បានបំពេញ និងគ្រប់ជំហាននៃកិច្ចការរបស់ទ្រង់ទេ ហើយប្រសិនបើអ្នកបានទទួលចំណេះដឹងជ្រាលជ្រៅអំពីគោលបំណងរបស់ព្រះជាម្ចាស់ក្នុងការថ្លែងព្រះបន្ទូលរបស់ទ្រង់ និងមូលហេតុដែលព្រះបន្ទូលយ៉ាងច្រើនដែលទ្រង់បានថ្លែងនោះមិនទាន់សម្រេចបាន នោះអ្នកអាចក្លាហាន និងគ្មានការរួញរាក្នុងការបន្ដដើរលើផ្លូវខាងមុខ ដោយគ្មានការព្រួយបារម្ភ និងការបន្សុទ្ធ។ អ្នករាល់គ្នាគប្បីមើលថាតើព្រះជាម្ចាស់សម្រេចបានកិច្ចការរបស់ទ្រង់យ៉ាងច្រើនដោយមធ្យោបាយបែបណា។ ទ្រង់ប្រើព្រះបន្ទូលដែលទ្រង់បានមានបន្ទូល ដោយបន្សុទ្ធមនុស្ស និងបំផ្លាស់បំប្រែសញ្ញាណរបស់គេដោយមធ្យោបាយនៃព្រះបន្ទូលជាច្រើនបែបខុសៗគ្នា។ រាល់ទុក្ខវេទនាដែលអ្នករាល់គ្នាបានស៊ូទ្រាំ រាល់ការបន្សុទ្ធដែលអ្នកបានឆ្លងកាត់ ការដោះស្រាយ ដែលអ្នកបានទទួលយកនៅក្នុងខ្លួនអ្នក និងការបំភ្លឺដែលអ្នកបានឆ្លងកាត់ ទាំងអស់នេះអាចសម្រេចទៅបានតាមរយៈព្រះបន្ទូលដែលព្រះជាម្ចាស់បានមានបន្ទូល។ តើមនុស្សដើរតាមព្រះជាម្ចាស់ដោយសារមូលហេតុអ្វី? មនុស្សដើរតាម

ដោយសារព្រះបន្ទូលរបស់ព្រះជាម្ចាស់! ព្រះបន្ទូលរបស់ព្រះជាម្ចាស់ គឺមានអាថ៌កំបាំងយ៉ាងជ្រៅ ហើយថែមទាំងអាចបណ្ដាលចិត្តមនុស្ស បើកសម្ដែងពីរឿងរ៉ាវដែលកប់ជ្រៅនៅក្នុងនោះ ធ្វើឲ្យគេដឹងពីរឿងរ៉ាវដែលបានកើតឡើងពីអតីតកាល និងអាចឲ្យគេយល់ធ្លុះទៅក្នុងអនាគតបាន។ ដូចនេះ មនុស្សបានឆ្លងកាត់ទុក្ខវេទនា ដោយសារព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយក៏ត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍ដោយសារព្រះបន្ទូលរបស់ព្រះជាម្ចាស់ផងដែរ៖ មានតែពេលនេះទេដែលមនុស្សដើរតាមព្រះជាម្ចាស់។ អ្វីដែលមនុស្សគប្បីធ្វើនៅក្នុងដំណាក់កាលនេះ គឺទទួលយកព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយមិនថាគេត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍ ឬស្ថិតក្រោមការបន្សុទ្ធនោះទេ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ គឺជាកូនសោ។ នេះគឺជាកិច្ចការរបស់ព្រះជាម្ចាស់ ហើយនេះគឺជានិមិត្តដែលមនុស្សត្រូវដឹងក្នុងពេលសព្វថ្ងៃនេះ។

តើព្រះជាម្ចាស់ប្រោសឲ្យមនុស្សបានគ្រប់លក្ខណ៍ដោយរបៀបណា? តើនិស្ស័យរបស់ព្រះជាម្ចាស់ គឺជាអ្វីដែរ? តើមានអ្វីខ្លះនៅក្នុងនិស្ស័យរបស់ទ្រង់? ដើម្បីបញ្ជាក់អំពីចំណុចនេះ៖ មនុស្សហៅវាថាជាការផ្សាយព្រះនាមរបស់ព្រះជាម្ចាស់ មនុស្សហៅវាថាជាការធ្វើបន្ទាល់អំពីព្រះជាម្ចាស់ ហើយមនុស្សហៅវាថាជាការអួតសរសើរអំពីព្រះជាម្ចាស់។ ផ្អែកតាមមូលដ្ឋានគ្រឹះនៃការស្គាល់ព្រះជាម្ចាស់ មនុស្សនឹងត្រូវបានបំផ្លាស់បំប្រែ នៅក្នុងនិស្ស័យជីវិតរបស់ពួកគេនៅពេលចុងក្រោយ។ កាលណាមនុស្សឆ្លងកាត់ការប្រឈមនឹងការដោះស្រាយបញ្ហា និងការបន្សុទ្ធ ពេលនោះមនុស្សនឹងកាន់តែរឹងមាំ។ នៅពេលណាដែលកិច្ចការរបស់ព្រះជាម្ចាស់កាន់តែមានច្រើនជំហានទៅៗ ពេលនោះមនុស្សនឹងត្រូវប្រោសឲ្យបានគ្រប់លក្ខណ៍កាន់តែច្រើនទៅៗ។ សព្វថ្ងៃនេះ តាមបទពិសោធរបស់មនុស្ស គ្រប់ជំហាននីមួយៗនៃកិច្ចការរបស់ព្រះជាម្ចាស់ វាយប្រហារទៅលើសញ្ញាណរបស់គេ ហើយលើសពីប្រាជ្ញារបស់មនុស្ស និងហួសពីការរំពឹងទុករបស់គេផង។ ព្រះជាម្ចាស់ប្រទានអ្វីគ្រប់យ៉ាងដែលមនុស្សត្រូវការ និងគ្រប់ទិដ្ឋភាពដែលមានលក្ខណៈខុសគ្នាជាមួយសញ្ញាណនេះ។ ព្រះជាម្ចាស់ថ្លែងព្រះបន្ទូលរបស់ទ្រង់ នៅពេលដែលអ្នកចុះខ្សោយ។ មានតែរបៀប

នេះទេដែលទ្រង់អាចទំនុកបម្រុងជីវិតរបស់អ្នកបាន។ តាមរយៈការវាយប្រហារលើសញ្ញាណរបស់អ្នក ទ្រង់ធ្វើឲ្យអ្នកទទួលយកនូវការដោះស្រាយរបស់ព្រះជាម្ចាស់។ មានតែតាមរបៀបនេះទេ ដែលអ្នកអាចឲ្យខ្លួនឯងចាកផុតពីសេចក្ដីពុករលួយរបស់ខ្លួនបាន។ សព្វថ្ងៃនេះ ក្នុងទិដ្ឋភាពមួយ ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស ធ្វើការនៅក្នុងលក្ខណៈជាព្រះ ហើយក្នុងទិដ្ឋភាពមួយទៀត ទ្រង់បំពេញកិច្ចការក្នុងលក្ខណៈជាមនុស្សធម្មតា។ នៅពេលអ្នកមិនអាចបដិសេធកិច្ចការណាមួយរបស់ព្រះជាម្ចាស់ នៅពេលអ្នកអាចចុះចូលបានមិនថាព្រះជាម្ចាស់មានបន្ទូលពីអ្វី ឬធ្វើអ្វីនៅក្នុងលក្ខណៈជាមនុស្សនៅពេលអ្នកអាចចុះចូល និងអាចយល់បាន មិនថាលក្ខណៈធម្មតាបែបណាដែលទ្រង់មានជាក់ស្ដែងនោះទេ ហើយនៅពេលដែលអ្នកបានទទួលបទពិសោធជាក់ស្ដែង នៅពេលនោះអ្នកនឹងអាចប្រាកដថា ទ្រង់គឺជាព្រះជាម្ចាស់ ពេលនោះអ្នកនឹងឈប់បង្កើតសញ្ញាណផ្សេងៗ ហើយពេលនោះអ្នកនឹងអាចដើរតាមទ្រង់រហូតដល់ទីបញ្ចប់បាន។ កិច្ចការរបស់ព្រះជាម្ចាស់ គឺមានប្រាជ្ញាញាណ ហើយទ្រង់ជ្រាបថាមនុស្សអាចប្រកាន់បានខ្ជាប់ខ្ជួនក្នុងការធ្វើបន្ទាល់អំពីទ្រង់បានដោយរបៀបណា។ ទ្រង់ជ្រាបថាចំណុចខ្សោយរបស់មនុស្សនៅត្រង់ណា ហើយព្រះបន្ទូលដែលទ្រង់ថ្លែងនោះ នឹងវាយប្រហារចំចំណុចខ្សោយរបស់គេ ប៉ុន្តែទ្រង់ក៏ប្រើបន្ទូលដ៏អស្ចារ្យ និងប្រកបដោយប្រាជ្ញារបស់ទ្រង់ ដើម្បីរក្សាជំហរក្នុងការធ្វើទីបន្ទាល់អំពីទ្រង់។ ទាំងអស់នេះ គឺជាការការអស្ចាររបស់ព្រះជាម្ចាស់។ កិច្ចការដែលព្រះជាម្ចាស់ធ្វើ គឺហួសពីប្រាជ្ញារបស់មនុស្សអាចនឹកស្រមៃដល់។ ក្នុងលក្ខណៈជាសាច់ឈាម អ្វីដែលធ្វើឲ្យមនុស្សពុករលួយ និងអ្វីដែលបង្ករឲ្យទៅជាលក្ខណៈនៃមនុស្ស អ្វីទាំងអស់នេះ ត្រូវបើកសម្ដែងដោយការជំនុំជម្រះរបស់ព្រះជាម្ចាស់ ដែលមនុស្សគ្មានកន្លែងណាត្រូវលាក់បាំងពីសេចក្ដីអាម៉ាស់របស់គេឡើយ។

ព្រះជាម្ចាស់ធ្វើកិច្ចការជំនុំជម្រះ និងការកាត់ទោស ដើម្បីឲ្យមនុស្សអាចទទួលបានចំណេះដឹងអំពីទ្រង់ និងដើម្បីជាប្រយោជន៍ដល់ការធ្វើទីបន្ទាល់របស់ទ្រង់។ បើគ្មានការជំនុំជម្រះរបស់ទ្រង់ចំពោះនិស្ស័យពុករលួយរបស់មនុស្សទេ មនុស្សអាចនឹង

មិនដឹងអំពីនិស្ស័យសុចរិតរបស់ទ្រង់ដែលមិនលើកលែងចំពោះការរំលងនោះឡើយ ហើយមនុស្សក៏មិនអាចកែប្រែចំណេះដឹងរបស់គេអំពីព្រះជាម្ចាស់ឲ្យទៅជាថ្មីបានដែរ។ សម្រាប់ជាប្រយោជន៍ដល់ការធ្វើទីបន្ទាល់របស់ទ្រង់ និងការគ្រប់គ្រងរបស់ទ្រង់ ទ្រង់ធ្វើឲ្យភាពទាំងស្រុងរបស់ទ្រង់ដឹងសុះសាយជាសាធារណៈ ដើម្បីឲ្យមនុស្សអាចមានចំណេះដឹងអំពីព្រះជាម្ចាស់តាមរយៈការលេចមករបស់ទ្រង់ជាសាធារណៈ ដើម្បីឲ្យគេទទួលបានការបំផ្លាស់បំប្រែនិស្ស័យរបស់គេ និងដើម្បីធ្វើទីបន្ទាល់អំពីទ្រង់ឲ្យលាន់ឮកងរំពង។ ការបំផ្លាស់បំប្រែនិស្ស័យរបស់មនុស្ស គឺសម្រេចទៅបានតាមរយៈកិច្ចការជាច្រើនប្រភេទខុសៗគ្នា។ បើគ្មានការផ្លាស់ប្រែនិស្ស័យរបស់គេទេ មនុស្សនឹងមិនអាចធ្វើទីបន្ទាល់អំពីព្រះជាម្ចាស់ និងធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់បានឡើយ។ ការបំផ្លាស់បំប្រែនិស្ស័យរបស់មនុស្ស បញ្ជាក់ថា មនុស្សត្រូវបានដោះលែងឲ្យមានសេរីភាពពីបាវបម្រើរបស់សាតាំង និងពីឥទ្ធិពលនៃភាពងងឹត និងបានក្លាយជាគំរូ និងជាសំណាកដ៏ពិតប្រាកដនៃកិច្ចការរបស់ព្រះជាម្ចាស់ ជាស្មរបន្ទាល់របស់ព្រះជាម្ចាស់ និងជាមនុស្សម្នាក់ដែលធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។ សព្វថ្ងៃនេះ ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស បានមកបំពេញកិច្ចការរបស់ទ្រង់នៅលើផែនដី ហើយទ្រង់តម្រូវឲ្យមនុស្សមានចំណេះដឹងអំពីទ្រង់ ស្ដាប់បង្គាប់ទ្រង់ ធ្វើទីបន្ទាល់អំពីទ្រង់ ស្គាល់ពីកិច្ចការជាក់ស្ដែង និងកិច្ចការធម្មតារបស់ទ្រង់ ស្ដាប់តាមគ្រប់ព្រះបន្ទូល និងកិច្ចការរបស់ទ្រង់ ដែលមិនដូចគ្នាទៅនឹងសញ្ញាណរបស់មនុស្សឡើយ និងដើម្បីធ្វើទីបន្ទាល់អំពីកិច្ចការដែលទ្រង់ធ្វើដើម្បីប្រោសលោះមនុស្ស ក៏ដូចជាទង្វើដែលទ្រង់បានធ្វើដើម្បីបង្ក្រាបមនុស្ស។ អស់អ្នកណាដែលធ្វើទីបន្ទាល់អំពីព្រះជាម្ចាស់ ត្រូវមានចំណេះដឹងអំពីព្រះជាម្ចាស់។ មានតែទីបន្ទាល់បែបនេះទេដែលមានលក្ខណៈសុក្រឹត និងពិតប្រាកដ ហើយមានតែការធ្វើទីបន្ទាល់បែបនេះទេ ដែលអាចធ្វើឲ្យសាតាំងអាម៉ាស់មុខបាន។ ព្រះជាម្ចាស់ប្រើអស់អ្នកណាដែលបានមកស្គាល់ទ្រង់ តាមរយៈការឆ្លងកាត់ការជំនុំជម្រះ និងការកាត់ទោសរបស់ទ្រង់ ដោយត្រូវប្រឈមមុខ និងត្រូវកាត់ចេញ ដើម្បីធ្វើទីបន្ទាល់អំពី

ទ្រង់បាន។ ទ្រង់ប្រើអស់អ្នកណាដែលត្រូវសាតាំងធ្វើឲ្យពុករលួយ ធ្វើទីបន្ទាល់អំពីទ្រង់ ហើយទ្រង់ក៏ប្រើអស់អ្នកណាដែលត្រូវបានបំផ្លាស់បំប្រែនិស្ស័យ និងអ្នកដែលទទួលបានព្រះពររបស់ទ្រង់ ដើម្បីធ្វើទីបន្ទាល់អំពីទ្រង់។ ទ្រង់មិនត្រូវការឲ្យមនុស្សសរសើរទ្រង់ដោយបបូរមាត់របស់ពួកគេឡើយ ហើយទ្រង់ក៏មិនត្រូវការការសរសើរតម្កើង និងទីបន្ទាល់របស់មនុស្សដែលមានលក្ខណៈដូចសាតាំងដែរ ដែលមនុស្សទាំងនេះមិនត្រូវបានទ្រង់ប្រោសលោះឡើយ។ មានតែអ្នកដែលស្គាល់ព្រះជាម្ចាស់ប៉ុណ្ណោះ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការធ្វើទីបន្ទាល់អំពីទ្រង់បាន ហើយមានតែអស់អ្នកណាដែលត្រូវបានបំផ្លាស់បំប្រែនិស្ស័យរបស់ពួកគេប៉ុណ្ណោះ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការធ្វើទីបន្ទាល់អំពីទ្រង់។ ព្រះជាម្ចាស់ នឹងមិនអនុញ្ញាតឲ្យមនុស្សនាំយកសេចក្ដីអាម៉ាស់មកដាក់លើព្រះនាមទ្រង់ដោយចេតនាបានឡើយ។

## របៀបដែលពេត្រុសចាប់ផ្ដើមស្គាល់ព្រះយេស៊ូវ

ក្នុងអំឡុងពេលដែលពេត្រុសបានចំណាយពេលជាមួយព្រះយេស៊ូវ គាត់បានឃើញចរិតលក្ខណៈ ដ៏គួរឲ្យស្រឡាញ់ជាច្រើននៅក្នុងព្រះយេស៊ូវ បានឃើញនូវចំណុចជាច្រើនដែលសក្ដិសមនឹងយកតម្រាប់តាម និងបានឃើញចំណុចជាច្រើនដែលបានប្រទានដល់គាត់។ ទោះបីជាពេត្រុសបានឃើញតួអង្គនៃព្រះជាម្ចាស់ នៅក្នុងព្រះយេស៊ូវតាមរបៀបជាច្រើន និងបានឃើញគុណសម្បត្តិដ៏គួរឲ្យស្រឡាញ់ជាច្រើនរបស់ទ្រង់ក៏ដោយ ក៏ដំបូងឡើយ គាត់មិនបានស្គាល់ព្រះយេស៊ូវដែរ។ ពេត្រុសបានចាប់ផ្ដើមដើរតាមព្រះយេស៊ូវ នៅពេលដែលគាត់មានវ័យ២០ឆ្នាំ ហើយគាត់បានបន្ដដើរតាមទ្រង់អស់រយៈពេលប្រាំមួយឆ្នាំ។ ក្នុងអំឡុងពេលនោះ គាត់មិនដែលបានស្គាល់ព្រះយេស៊ូវឡើយ ប៉ុន្ដែពេត្រុសព្រមដើរតាមព្រះយេស៊ូវ ដោយសារតែភាពស្ងប់ស្ងែងដែលគាត់មានចំពោះទ្រង់សុទ្ធសាធ។ ដំបូងឡើយ នៅពេលដែលព្រះយេស៊ូវបានត្រាស់ហៅគាត់នៅឆ្នេរសមុទ្រកាលីឡេ ទ្រង់បានសួរថា៖ «ស៊ីម៉ូន កូន

យ៉ូណាសអើយ! តើអ្នកនឹងដើរតាមខ្ញុំឬទេ?» ពេត្រុសបានតបវិញថា៖ «ខ្ញុំត្រូវដើរតាមព្រះដែលព្រះវរបិតាគង់នៅស្ថានសួគ៌ចាត់ឲ្យមក។ ខ្ញុំត្រូវតែទទួលស្គាល់ព្រះអង្គដែលត្រូវបានជ្រើសរើសដោយព្រះវិញ្ញាណបរិសុទ្ធ។ ខ្ញុំនឹងដើរតាមទ្រង់»។ នៅពេលនោះ ពេត្រុសបានឮអំពីបុរសម្នាក់ដែលមានឈ្មោះថា យេស៊ូវ ដែលជាហោរាដ៏ខ្ពង់ខ្ពស់បំផុត និងជាបុត្រាសំណព្វរបស់ព្រះជាម្ចាស់រួចទៅហើយ ហើយពេត្រុសចេះតែសង្ឃឹមថា នឹងរកឃើញទ្រង់ ហើយសង្ឃឹមថានឹងមានឱកាសមើលឃើញទ្រង់ (ព្រោះថា នេះជារបៀបដែលគាត់ត្រូវបានដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធ)។ ទោះបីពេត្រុសមិនធ្លាប់បានឃើញទ្រង់ និងបានឮតែពាក្យចចាមអារ៉ាមអំពីទ្រង់ក៏ដោយ ប៉ុន្តែការចង់បាន និងស្ញប់ស្ញែងចំពោះព្រះយេស៊ូវ ក៏ដុះឡើងនៅក្នុងដួងចិត្តរបស់គាត់បន្ដិចម្ដងៗ ហើយជារឿយៗ គាត់បានទន្ទឹងចង់ឃើញព្រះយេស៊ូវនៅថ្ងៃមួយ។ តើព្រះយេស៊ូវបានត្រាស់ហៅពេត្រុសដោយរបៀបណា? ទ្រង់ក៏បានឮអំពីបុរសម្នាក់ឈ្មោះពេត្រុសដែរ ប៉ុន្តែព្រះវិញ្ញាណបរិសុទ្ធមិនមែនជាអ្នកណែនាំទ្រង់ថា៖ «ចូរយាងទៅសមុទ្រកាលីឡេ ជាកន្លែងដែលមានបុរសម្នាក់ឈ្មោះថា ស៊ីម៉ូន កូនយ៉ូណាស» នោះឡើយ។ ព្រះយេស៊ូវបានឮពីមនុស្សម្នាក់និយាយថា មានបុរសម្នាក់ឈ្មោះ ស៊ីម៉ូន កូនយ៉ូណាស ហើយទ្រង់ឮថា មនុស្សបានឮអំពីមេរៀនអធិប្បាយរបស់គាត់ឮថា គាត់ក៏បានប្រកាសដំណឹងល្អអំពីនគរស្ថានសួគ៌ និងឮថា មនុស្សដែលបានឮគាត់អធិប្បាយ សុទ្ធតែមានអារម្មណ៍រំជួលចិត្តរហូតស្រក់ទឹកភ្នែក។ ក្រោយពេលបានឮបែបនេះ ព្រះយេស៊ូវបានដើរតាមបុរសម្នាក់នោះទៅកាន់សមុទ្រកាលីឡេ ហើយពេលដែលពេត្រុសបានទទួលការត្រាស់ហៅរបស់ព្រះយេស៊ូវ នោះគាត់ក៏បានដើរតាមទ្រង់។

ក្នុងអំឡុងពេលដែលគាត់ដើរតាមព្រះយេស៊ូវ ពេត្រុសបានបង្កើតទស្សនៈជាច្រើនអំពីទ្រង់ ហើយតែងតែវិនិច្ឆ័យទ្រង់តាមទស្សនៈរបស់គាត់ផ្ទាល់។ ទោះបីពេត្រុសមានកម្រិតការយល់ដឹងខ្លះអំពីព្រះវិញ្ញាណក៏ដោយ ក៏ការយល់ដឹងរបស់គាត់មិនសូវជាច្បាស់លាស់ឡើយ ដែលជាហេតុនាំឲ្យគាត់និយាយថា៖ «ខ្ញុំត្រូវដើរតាមព្រះដែលព្រះវរបិតាដែលគង់នៅស្ថានសួគ៌ចាត់ឲ្យមក។ ខ្ញុំត្រូវតែទទួលស្គាល់ព្រះអង្គដែល

ត្រូវបានជ្រើសរើសដោយព្រះវិញ្ញាណបរិសុទ្ធ»។ គាត់មិនបានយល់អំពីកិច្ចការដែលព្រះយេស៊ូវបានធ្វើ ហើយក៏ខ្វះនូវភាពច្បាស់លាស់អំពីកិច្ចការទាំងនោះផងដែរ។ ក្រោយពេលដើរតាមទ្រង់បានមួយរយៈ ពេត្រុសកាន់តែចាប់អារម្មណ៍នឹងអ្វីដែលទ្រង់បានធ្វើ និងមានបន្ទូល ហើយក៏ចាប់អារម្មណ៍ខ្លាំងលើព្រះយេស៊ូវផ្ទាល់ផងដែរ។ គាត់ចាប់ផ្ដើមមានអារម្មណ៍ថា ព្រះយេស៊ូវ បានបណ្ដាលឲ្យមានសេចក្ដីស្រឡាញ់ និងការគោរពបែបនេះ។ គាត់ចូលចិត្តចំណាយពេលជាមួយទ្រង់ និងនៅជិតទ្រង់ ហើយការស្ដាប់ព្រះបន្ទូលរបស់ព្រះយេស៊ូវបានផ្ដល់ជាការគាំទ្រ និងជំនួយដល់គាត់ទៀតផង។ ក្នុងអំឡុងពេលដែលគាត់ដើរតាមព្រះយេស៊ូវ ពេត្រុសបានសង្កេត និងរៀនសូត្រនូវអ្វីៗគ្រប់យ៉ាងអំពីព្រះជន្មរបស់ទ្រង់ដូចជា សកម្មភាព ពាក្យសម្ដី ចលនា និងការសម្ដែងចេញរបស់ទ្រង់។ គាត់បានទទួលនូវការយល់ដឹងដ៏ស៊ីជម្រៅថា ព្រះយេស៊ូវមិនដូចជាបុរសទូទៅនោះឡើយ។ ទោះបីរូបរាងជាមនុស្សរបស់ទ្រង់លើសពីធម្មតាក៏ដោយ ប៉ុន្តែ ទ្រង់ពេញដោយសេចក្ដីស្រឡាញ់ ចិត្តអាណិតអាសូរ និងការអត់ឱនចំពោះមនុស្សលោក។ គ្រប់យ៉ាងដែលទ្រង់ធ្វើ ឬមានបន្ទូល គឺជាជំនួយដ៏ធំចំពោះអ្នកដទៃ ហើយពេត្រុសបានឃើញ និងបានទទួលពីព្រះយេស៊ូវនូវសេចក្ដីដែលគាត់មិនធ្លាប់បានឃើញ ឬធ្លាប់មានកាលពីមុនឡើយ។ គាត់បានឃើញថា ទោះបីព្រះយេស៊ូវមិនមានឋានៈខ្ពង់ខ្ពស់ ឬគ្មានភាពជាមនុស្សប្លែកពីគេក៏ដោយ ក៏ទ្រង់ពិតជាមានលក្ខណសម្បត្តិដ៏អស្ចារ្យ និងខុសប្លែកពីធម្មតា។ ទោះបីពេត្រុសមិនអាចពន្យល់បានទាំងស្រុងក្ដី ក៏គាត់អាចមើលឃើញថា ព្រះយេស៊ូវមានកិរិយាខុសប្លែកពីអ្នកឯទៀត ព្រោះថា កិច្ចការដែលទ្រង់បានធ្វើ ខុសប្លែកពីកិច្ចការដែលមនុស្សធម្មតាធ្វើប្រាកដមែន។ ចាប់តាំងពីពេល ដែលគាត់មានទំនាក់ទំនងជាមួយព្រះយេស៊ូវ ពេត្រុសក៏បានឃើញដែរថា អត្តចរិតរបស់ទ្រង់ខុសប្លែកពីអត្តចរិតរបស់មនុស្សទូទៅដែរ។ ទ្រង់តែងតែប្រព្រឹត្តដោយចរិតនឹងធឹង មិនតក់ក្រហល់ មិននិយាយបំផ្លើស ឬមិនមើលស្រាលប្រធានបទអ្វីមួយទេ ហើយទ្រង់បានបញ្ចេញកិរិយាមាយាទក្នុងជីវិតរបស់ទ្រង់ តាមរបៀបមួយដែលសម្ដែងពីអត្តចរិតមួយដែលសាមញ្ញផង និង

គួរឲ្យស្ងើចសរសើរផង។ នៅក្នុងការសន្ទនា ព្រះយេស៊ូវបានមានបន្ទូលត្រង់ៗ និងប្រកបដោយព្រះគុណ តែងតែប្រាស្រ័យទាក់ទងដោយឫកពាររីករាយ តែស្ងប់ស្ងាត់ ហើយទ្រង់មិនដែលបាត់បង់សេចក្តីថ្លៃថ្នូររបស់ទ្រង់ឡើយ ក្នុងពេលដែលកំពុងតែធ្វើកិច្ចការរបស់ទ្រង់។ ពេត្រុសបានឃើញថា ពេលខ្លះព្រះយេស៊ូវមិនសូវមាត់ក ប៉ុន្តែពេលខ្លះទៀត ទ្រង់មានបន្ទូលឥតឈប់។ ពេលខ្លះ ទ្រង់មានព្រះទ័យរីករាយយ៉ាងខ្លាំង ដូចជាសត្វព្រាបដែលអរកញ្ឆេង និងប្រលែងលេង ហើយមានពេលខ្លះទៀត ទ្រង់កើតទុក្ខយ៉ាងខ្លាំងដោយមិនមានបន្ទូលអ្វីសោះ ហើយមើលទៅដូចជា ទ្រង់មានពេញដោយទុក្ខព្រួយ ដូចជាអ្នកម្តាយម្នាក់ដែលស្គមស្គាំង និងល្វិតល្វៃ។ ពេលខ្លះទ្រង់ពេញដោយកំហឹង ដូចជាទាហានដ៏អង់អាចដែលសម្រុកទៅសម្លាប់ខ្មាំង ហើយពេលខ្លះទៀត ទ្រង់ដូចជាសត្វសិង្ហដែលកំពុងគ្រហឹម។ ពេលខ្លះ ទ្រង់សើច ហើយពេលខ្លះទៀត ទ្រង់បានអធិស្ឋាន ហើយយំសោកផង។ ទោះបីជាព្រះយេស៊ូវប្រព្រឹត្តយ៉ាងណាក៏ដោយ ក៏ពេត្រុសកាន់តែមានចិត្តស្រឡាញ់ និងការគោរពចំពោះទ្រង់ឥតដែនកំណត់។ សំណើចរបស់ព្រះយេស៊ូវបានធ្វើឲ្យគាត់ពេញដោយសេចក្តីសុខ ទុក្ខសោករបស់ទ្រង់បានធ្វើឲ្យគាត់លិចលង់ក្នុងទុក្ខព្រួយ កំហឹងទ្រង់បានធ្វើឲ្យគាត់ខ្លាច ខណៈពេលដែលព្រះទ័យមេត្តា ការអត់ទោស និងការទាមទារដ៏តឹងរ៉ឹងដែលទ្រង់ចង់បានពីមនុស្ស បានធ្វើឲ្យគាត់ស្រឡាញ់ព្រះយេស៊ូវ និងបង្កើតជាការគោរព និងការស្រេកឃ្លានចង់បានទ្រង់យ៉ាងពិតប្រាកដ។ ពិតណាស់ ក្រោយពេលពេត្រុសបានរស់នៅជាមួយព្រះយេស៊ូវ អស់រយៈពេលជាច្រើនឆ្នាំ ទើបគាត់ចាប់ផ្តើមទទួលស្គាល់ការទាំងអស់នេះបន្តិចម្តងៗ។

ពេត្រុសគឺជាមនុស្សម្នាក់ដែលមានហេតុផល ហើយគាត់កើតមក ដោយមានភាពវៃឆ្លាតពីកំណើត ប៉ុន្តែគាត់បានធ្វើកិច្ចការល្ងីល្ងើជាច្រើន ពេលដើរតាមព្រះយេស៊ូវ។ កាលគ្រាដំបូងៗ គាត់មានសញ្ញាណមួយចំនួនអំពីព្រះយេស៊ូវ។ គាត់បានសួរថា៖ «បណ្តាជននិយាយថា ទ្រង់ជាហោរា ដូច្នេះ ពេលទ្រង់មានព្រះជន្មប្រាំបីវស្សា ហើយចាប់ផ្តើមដឹងក្តី តើទ្រង់ដឹងទេថា ទ្រង់គឺជាព្រះជាម្ចាស់? តើទ្រង់បានដឹងទេថា ទ្រង់

ចាប់បដិសន្ធិដោយព្រះវិញ្ញាណបរិសុទ្ធ?» ព្រះយេស៊ូវបានតបវិញថា៖ «អត់ទេ ខ្ញុំមិនបានដឹងឡើយ។ តើខ្ញុំមើលទៅមិនដូចជាមនុស្សធម្មតាចំពោះអ្នកទេឬអី? ខ្ញុំជាមនុស្សដូចអ្នកឯទៀតដែរ។ បុគ្គលដែលព្រះវរបិតាចាត់ឲ្យមកមក គឺជាមនុស្សធម្មតាម្នាក់ មិនមែនជាបុគ្គលអស្ចារ្យឡើយ។ ហើយទោះបីកិច្ចការដែលខ្ញុំធ្វើ តំណាងឲ្យព្រះវរបិតាខ្ញុំដែលគង់នៅស្ថានសួគ៌ក៏ដោយ ក៏រូបរាងរបស់ខ្ញុំ បុគ្គលិកលក្ខណៈរបស់ខ្ញុំ និងរូបកាយសាច់ឈាមនេះ មិនអាចតំណាងព្រះវរបិតារបស់ខ្ញុំដែលគង់នៅស្ថានសួគ៌បានពេញលេញឡើយ គឺបានតែផ្នែកមួយរបស់ទ្រង់ប៉ុណ្ណោះ។ ទោះបីខ្ញុំកើតពីព្រះវិញ្ញាណក៏ដោយ ក៏ខ្ញុំនៅតែជាមនុស្សសាមញ្ញម្នាក់ ហើយព្រះវរបិតាខ្ញុំបានចាត់ខ្ញុំឲ្យមកកាន់ផែនដីនេះ ក្នុងនាមជាមនុស្សសាមញ្ញម្នាក់ មិនមែនជាបុគ្គលអស្ចារ្យនោះឡើយ»។ ទាល់តែពេត្រុសបានឮការនេះ ទើបគាត់ទទួលបានការយល់ដឹងដ៏តិចតួចអំពីព្រះយេស៊ូវ។ ទាល់តែគាត់បានចំណាយពេលពេលរាប់ម៉ោងសិក្សា ពីកិច្ចការរបស់ព្រះយេស៊ូវ សិក្សាសេចក្ដីបង្រៀនរបស់ទ្រង់ សិក្សាពីការមើលថែហ្វូងចៀមរបស់ទ្រង់ និងសិក្សាពីការធ្វើការសម្រេចចិត្តរបស់ទ្រង់ ទើបគាត់ទទួលបានការយល់ដឹងកាន់តែស៊ីជម្រៅបែបនេះ។ ពេលព្រះយេស៊ូវមានព្រះជន្ម៣០ព្រះវស្សា ទ្រង់បានប្រាប់ពេត្រុសអំពីការជាប់ឆ្កាងដែលហៀបនឹងកើតឡើង និងប្រាប់ទៀតថា ទ្រង់បានយាងមក ដើម្បីអនុវត្តកិច្ចការមួយដំណាក់កាល គឺការជាប់ឆ្កាង ដើម្បីប្រោសលោះមនុស្សលោកទាំងអស់។ ព្រះយេស៊ូវក៏បានប្រាប់ដល់ពេត្រុសថា បីថ្ងៃក្រោយពីការជាប់ឆ្កាង បុត្រមនុស្សនឹងមានព្រះជន្មរស់ឡើងវិញ ហើយប្រាប់ថា បន្ទាប់ពីមានព្រះជន្មរស់ឡើងវិញ ទ្រង់នឹងបង្ហាញអង្គទ្រង់ឲ្យបណ្ដាជនឃើញរយៈពេល៤០ថ្ងៃ។ ពេលបានឮពាក្យទាំងនេះហើយ ពេត្រុសមានអារម្មណ៍សោកសៅ និងចងចាំពាក្យទាំងនេះនៅក្នុងចិត្ត។ ចាប់ពីពេលនោះមក គាត់កាន់តែមានទំនាក់ទំនងស្និទ្ធស្នាលជាមួយព្រះយេស៊ូវ។ ក្រោយពេលមានបទពិសោធបានមួយរយៈ ពេត្រុសក៏ចាប់ផ្ដើមទទួលស្គាល់ថា អ្វីៗគ្រប់យ៉ាងដែលព្រះយេស៊ូវបានធ្វើ គឺទ្រង់បានធ្វើក្នុងឋានៈជាព្រះជាម្ចាស់ ហើយគាត់ក៏ចាប់ផ្ដើមគិតថា ព្រះយេស៊ូវ គឺពិតជាគួរឲ្យស្រឡាញ់

ឥតឧបមា។ ទាល់តែគាត់មានការយល់ដឹងបែបនេះទេ ទើបព្រះវិញ្ញាណបរិសុទ្ធស្រាយបំភ្លឺដល់គាត់ចេញពីខាងក្នុងចិត្ត។ ក្រោយមកទៀត ព្រះយេស៊ូវបានត្រឡប់ទៅរកពួកសិស្ស និងអ្នកដើរតាមទ្រង់ផ្សេងទៀត ហើយសួរថា៖ «យ៉ូហាន តើអ្នកគិតថា ខ្ញុំជានរណា?» យ៉ូហានបានតបថា៖ «ទ្រង់ជាម៉ូសេ»។ បន្ទាប់មក ទ្រង់បានបែរទៅលូកា៖ «ចុះអ្នកវិញ លូកា តើអ្នកគិតថា ខ្ញុំជានរណា?» លូកាបានតបថា៖ «ទ្រង់ជាហោរាដ៏អស្ចារ្យជាងគេ»។ បន្ទាប់មក ទ្រង់បានសួរប្អូនស្រីម្នាក់ ហើយនាងបានតបថា៖ «ទ្រង់ជាហោរាម្នាក់ដ៏អស្ចារ្យជាងគេ ដែលមានបន្ទូលជាច្រើន ពីអស់កល្បជានិច្ចដល់អស់កល្បជានិច្ច។ គ្មានទំនាយណា ដែលអស្ចារ្យដូចជាសេចក្ដីទំនាយរបស់ទ្រង់ ហើយក៏គ្មានបុគ្គលណាដែលមានចំណេះដឹងខ្ពស់ខ្ពស់លើសទ្រង់នោះដែរ ដ្បិតទ្រង់ជាហោរាម្នាក់»។ បន្ទាប់មក ព្រះយេស៊ូវបានបែរទៅពេត្រុស ហើយសួរថា៖ «ពេត្រុស តើអ្នកគិតថា ខ្ញុំជានរណា?» ពេត្រុសបានតបវិញថា៖ «ទ្រង់ជាព្រះគ្រីស្ទ ជាបុត្ររបស់ព្រះជាម្ចាស់ដ៏មានព្រះជន្មរស់។ ទ្រង់យាងមកពីស្ថានសួគ៌។ ទ្រង់មិនមែនមកពីផែនដីឡើយ។ ទ្រង់មិនដូចសត្តនិកររបស់ព្រះជាម្ចាស់ឡើយ។ យើងនៅលើផែនដី ហើយទ្រង់គង់នៅទីនេះជាមួយយើង ប៉ុន្តែទ្រង់មកពីស្ថានសួគ៌ មិនមែនមកពីលោកីយ៍ឡើយ ហើយទ្រង់មិនមែនមកពីផែនដីឡើយ»។ គឺតាមរយៈបទពិសោធរបស់គាត់នេះហើយ ដែលព្រះវិញ្ញាណបរិសុទ្ធបានស្រាយបំភ្លឺដល់គាត់ ទើបគាត់អាចមានការយល់ដឹងបែបនេះ។ ក្រោយការស្រាយបំភ្លឺនេះ គាត់កាន់តែស្ញើចសរសើរពីអ្វីៗគ្រប់យ៉ាងដែលព្រះយេស៊ូវធ្វើ កាន់តែនឹកគិតថា ទ្រង់ជាបុគ្គលដ៏គួរឲ្យស្រឡាញ់ និងមានចិត្តស្ទាក់ស្ទើរ មិនចង់នៅឆ្ងាយពីព្រះយេស៊ូវ។ ដូច្នេះ ពេលព្រះយេស៊ូវបានសម្ដែងអង្គទ្រង់ជាលើកដំបូងឲ្យពេត្រុសឃើញ ក្រោយពេលដែលទ្រង់ត្រូវជាប់ឆ្កាង និងរស់ឡើងវិញ ពេត្រុសបានស្រែកដោយក្ដីរីករាយឥតឧបមាថា៖ «ព្រះអម្ចាស់អើយ! ទ្រង់មានព្រះជន្មរស់ឡើងវិញហើយ!» បន្ទាប់មក ពេត្រុសចាប់បានត្រីដ៏ធំមួយក្បាល រួចចម្អិនវាទាំងយំ ថ្វាយព្រះយេស៊ូវសោយ។ ព្រះយេស៊ូវក៏ញញឹម ប៉ុន្តែមិនបានមានបន្ទូលអ្វីឡើយ។ ទោះបីពេត្រុសបានដឹងថា ព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ

ក៏ដោយ ក៏គាត់មិនបានយល់ អំពីសេចក្ដីអាថ៌កំបាំងនៃហេតុការណ៍នេះឡើយ។ នៅពេលដែលគាត់បានថ្វាយត្រីឲ្យព្រះយេស៊ូវសោយ ព្រះយេស៊ូវមិនបានបដិសេធទេ តែក៏ទ្រង់មិនបានមានបន្ទូល ឬអង្គុយសោយអាហារនោះដែរ។ ផ្ទុយទៅវិញ ទ្រង់បានបាត់ព្រះកាយមួយរំពេច។ ហេតុការណ៍នេះបានធ្វើឲ្យពេត្រុសតក់ស្លុតយ៉ាងខ្លាំង ហើយទាល់តែបែបនេះ ទើបពេត្រុសបានយល់ថា ព្រះយេស៊ូវដែលបានរស់ឡើងវិញ ខុសពីព្រះយេស៊ូវកាលពីមុន។ ពេលដែលពេត្រុសយល់អំពីការនេះហើយ គាត់បានទួញសោក ប៉ុន្តែគាត់ក៏ទទួលបានការកម្សាន្តចិត្តដោយដឹងថា ព្រះអម្ចាស់បានបញ្ចប់កិច្ចការរបស់ទ្រង់ហើយ។ គាត់ដឹងថា ព្រះយេស៊ូវបានបញ្ចប់កិច្ចការរបស់ទ្រង់រួចហើយ ព្រមទាំងដឹងថា ពេលវេលាដែលទ្រង់នៅជាមួយមនុស្សលោកបានមកដល់ទីបញ្ចប់ និងដឹងទៀតថា មនុស្សនឹងត្រូវដើរតាមផ្លូវរបស់ខ្លួន ចាប់ពីពេលនេះតទៅ។ ព្រះយេស៊ូវធ្លាប់ប្រាប់គាត់ថា៖ «អ្នកក៏ត្រូវផឹកពីពែងដ៏ល្វីងជូរចត់ដែលខ្ញុំបានផឹកនេះផងដែរ (នេះជាអ្វីដែលទ្រង់បានមានបន្ទូល បន្ទាប់ពីទ្រង់មានព្រះជន្មរស់ឡើងវិញ)។ អ្នកក៏ត្រូវដើរតាមផ្លូវដែលខ្ញុំបានដើរផងដែរ។ អ្នកត្រូវតែលះបង់ជីវិតរបស់អ្នកសម្រាប់ខ្ញុំ»។ កិច្ចការនាពេលនោះ មិនមានទម្រង់ជាការសន្ទនាមុខទល់នឹងមុខឡើយ ខុសពីពេលសព្វថ្ងៃ។ ក្នុងអំឡុងយុគសម័យនៃព្រះគុណ កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធត្រូវបានលាក់កំបាំងជាពិសេស ហើយពេត្រុសបានឆ្លងកាត់ទុក្ខលំបាកជាច្រើន។ ពេលខ្លះពេត្រុសដល់ថ្នាក់ឧទានថា៖ «ឱព្រះជាម្ចាស់អើយ! ទូលបង្គំគ្មានអ្វីសល់ ក្រៅពីជីវិតនេះឡើយ។ ទោះបីវាគ្មានតម្លៃច្រើនចំពោះទ្រង់ក៏ដោយ ក៏ទូលបង្គំចង់ថ្វាយជីវិតនេះដល់ទ្រង់។ ទោះបីមនុស្សមិនសក្ដិសមនឹងស្រឡាញ់ទ្រង់ ហើយសេចក្ដីស្រឡាញ់និងដួងចិត្តរបស់គេគ្មានតម្លៃសោះក៏ដោយ ក៏ទូលបង្គំជឿថា ទ្រង់ជ្រាបពីបំណងចិត្តរបស់មនុស្ស។ ហើយទោះបីរូបកាយរបស់មនុស្សមិនសមឲ្យទ្រង់ទទួលយកក៏ដោយ ក៏ទូលបង្គំចង់ឲ្យទ្រង់ទទួលយកដួងចិត្តរបស់ទូលបង្គំចុះ»។ ការបន្លឺសំឡេងអធិស្ឋានបែបនេះបានផ្ដល់ជាកម្លាំងចិត្តដល់គាត់ ជាពិសេស នៅពេលដែលគាត់អធិស្ឋានថា៖ «ទូលបង្គំព្រមថ្វាយដួងចិត្តរបស់ទូលបង្គំទាំងស្រុង ដល់ព្រះជាម្ចាស់ហើយ។

ទោះបីទូលបង្គំមិនអាចធ្វើអ្វីសម្រាប់ថ្វាយព្រះជាម្ចាស់ក៏ដោយ ក៏ទូលបង្គំព្រមបំពេញព្រះហឫទ័យព្រះជាម្ចាស់យ៉ាងស្មោះត្រង់ និងថ្វាយខ្លួនរបស់ទូលបង្គំដល់ទ្រង់ដោយអស់ពីចិត្ត។ ទូលបង្គំជឿថា ព្រះជាម្ចាស់នឹងទតមើលដួងចិត្តរបស់ទូលបង្គំមិនខាន»។ គាត់បាននិយាយថា៖ «នៅក្នុងជីវិតរបស់ទូលបង្គំ ទូលបង្គំមិនសុំអ្វីឡើយ ក្រៅពីសុំឲ្យគំនិតដែលទូលបង្គំគិតស្រឡាញ់ព្រះជាម្ចាស់ និងបំណងចិត្តរបស់ទូលបង្គំ ត្រូវបានព្រះជាម្ចាស់ព្រមទទួលយក។ ទូលបង្គំបាននៅជាមួយព្រះអម្ចាស់យេស៊ូវអស់រយៈពេលយ៉ាងយូរ ប៉ុន្តែទូលបង្គំមិនដែលស្រឡាញ់ទ្រង់ឡើយ ហើយនេះជាបំណុលដ៏ធំបំផុតរបស់ទូលបង្គំ។ ទោះបីទូលបង្គំបាននៅជាមួយទ្រង់ ក៏ទូលបង្គំមិនបានស្គាល់ទ្រង់ ហើយទូលបង្គំថែមទាំងនិយាយពាក្យសម្ដីមិនសមរម្យ នៅពីក្រោយខ្នងរបស់ទ្រង់ទៀតផង។ ពេលគិតដល់រឿងទាំងអស់នេះ វាធ្វើឲ្យទូលបង្គំមានអារម្មណ៍កាន់តែជំពាក់ព្រះអម្ចាស់យេស៊ូវ»។ គាត់តែងតែអធិស្ឋាន ដោយតវិយាបថបែបនេះ។ គាត់បាននិយាយថា៖ «ខ្ញុំអន់ជាងធូលីដីទៅទៀត។ ខ្ញុំមិនអាចធ្វើអ្វីបានសោះឡើយ ក្រៅតែពីថ្វាយដួងចិត្តដ៏ស្មោះត្រង់នេះដល់ព្រះជាម្ចាស់»។

បទពិសោធរបស់ពេត្រុសបានឡើងដល់កម្រិតកំពូល នៅពេលដែលរូបកាយរបស់គាត់សឹងតែត្រូវបានខ្ទេចខ្ទាំទាំងស្រុង ប៉ុន្តែព្រះយេស៊ូវនៅតែប្រទានការលើកទឹកចិត្តដល់គាត់ពីក្នុងមកវិញ។ ហើយមានពេលមួយនោះ ព្រះយេស៊ូវបានបង្ហាញអង្គទ្រង់ឲ្យពេត្រុសឃើញ។ ពេលពេត្រុសស្ថិតក្នុងទុក្ខវេទនាយ៉ាងខ្លាំង និងមានអារម្មណ៍ថាដួងចិត្តរបស់គាត់បានខ្ទេចខ្ទាំ ព្រះយេស៊ូវបានបង្គាប់គាត់ថា៖ «អ្នកបាននៅជាមួយខ្ញុំនៅលើផែនដី ហើយខ្ញុំបាននៅទីនេះជាមួយអ្នក។ មែនហើយ ពីមុនយើងនៅជាមួយគ្នាឯស្ថានសួគ៌ ពិតណាស់ ស្ថានសួគ៌ជាពិភពខាងវិញ្ញាណ ឥឡូវនេះ ខ្ញុំត្រូវត្រឡប់ទៅកាន់ពិភពខាងវិញ្ញាណវិញ ហើយអ្នកនៅលើផែនដីនេះ ដោយព្រោះខ្ញុំមិនមែនមកពីផែនដីនេះឡើយ ដូច្នេះ អ្នកក៏មិនមកពីផែនដីដែរ អ្នកត្រូវតែសម្រេចមុខងាររបស់អ្នកនៅលើផែនដី។ ក្នុងនាមអ្នកជាអ្នកបម្រើម្នាក់ អ្នកត្រូវតែសម្រេចភារកិច្ចរបស់ខ្លួន»។ ការឮថា គាត់នឹងអាចត្រឡប់ទៅនៅក្បែរព្រះជាម្ចាស់វិញ បានផ្ដល់នូវការកម្សាន្តចិត្ត

ដល់ពេត្រុស។ នាគ្រានោះ ពេត្រុសឈឺចាប់ខ្លាំង សឹងតែដេកឈឺមួយកន្លែងនៅលើគ្រែ។ គាត់មានវិប្បដិសារីដល់ថ្នាក់និយាយថា៖ «ខ្ញុំពុករលួយខ្លាំងណាស់ នោះខ្ញុំមិនអាចផ្គាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់បានឡើយ»។ ព្រះយេស៊ូវបានបង្ហាញអង្គទ្រង់ឲ្យគាត់បានឃើញ ហើយមានបន្ទូលថា៖ «ពេត្រុសអើយ តើអាចទេថា អ្នកភ្លេចការតាំងចិត្តដែលអ្នកធ្លាប់មានចំពោះខ្ញុំទៅហើយនោះ? តើអ្នកពិតជាភ្លេចអ្វីៗគ្រប់យ៉ាងដែលខ្ញុំបាននិយាយហើយឬ?» ដោយឃើញថា នោះជាព្រះយេស៊ូវ ពេត្រុសក៏បានក្រោកចេញពីគ្រែរបស់គាត់ ហើយព្រះយេស៊ូវក៏បានកម្សាន្តចិត្តគាត់ថា៖ «ដូចខ្ញុំបានប្រាប់អ្នករួចហើយថា ខ្ញុំមិនមែនមកពីផែនដីនេះឡើយ។ អ្នកត្រូវតែយល់អំពីការនេះ ប៉ុន្តែតើអ្នកបានភ្លេចអ្វីផ្សេងទៀតដែលខ្ញុំបានប្រាប់អ្នកហើយឬ? 'អ្នកក៏មិនមែនមកពីផែនដី ឬលោកីយ៍នេះដែរ។' ឥឡូវនេះ មានកិច្ចការដែលអ្នកត្រូវតែធ្វើ អ្នកមិនអាចទួញសោកបែបនេះឡើយ។ អ្នកមិនអាចរងទុក្ខបែបនេះទេ។ មនុស្ស និងព្រះជាម្ចាស់មិនអាចរួមរស់នៅជាមួយគ្នាក្នុងពិភពតែមួយនោះទេ ដូច្នេះ ខ្ញុំមានកិច្ចការរបស់ខ្ញុំ ហើយអ្នកក៏មានកិច្ចការរបស់អ្នកដែរ ហើយថ្ងៃមួយ ពេលដែលកិច្ចការរបស់អ្នកត្រូវបានបញ្ចប់ យើងនឹងជួបជុំគ្នានៅក្នុងពិភពតែមួយ ហើយខ្ញុំនឹងដឹកនាំអ្នកឲ្យនៅជាមួយខ្ញុំជារៀងរហូត»។ ពេត្រុសបានទទួលការកម្សាន្តចិត្ត និងការធានាជាថ្មី ក្រោយពេលឮពាក្យទាំងនេះ។ គាត់បានដឹងថា ទុក្ខវេទនានេះគឺជាអ្វីមួយដែលគាត់ត្រូវតែស៊ូទ្រាំ និងត្រូវជួប ហើយគាត់ក៏បានទទួលការជំរុញចិត្ត ចាប់ពីពេលនោះមក។ ព្រះយេស៊ូវបានបង្ហាញអង្គទ្រង់ឲ្យគាត់ឃើញជាពិសេស នៅក្នុងពេលវេលាមួយដ៏សំខាន់ ដោយប្រទានឲ្យគាត់នូវការស្រាយបំភ្លឺ និងការដឹកនាំជាពិសេស ហើយទ្រង់បានធ្វើកិច្ចការជាច្រើនទៅលើជីវិតរបស់គាត់។ តើពេត្រុសមានវិប្បដិសារីបំផុតចំពោះអ្វីខ្លះ? ក្រោយពេលពេត្រុសបាននិយាយថា៖ «ទ្រង់ជាបុត្រារបស់ព្រះជាម្ចាស់ដ៏មានព្រះជន្មរស់» មិនបានប៉ុន្មាន ព្រះយេស៊ូវក៏សួរសំណួរមួយទៀតដល់ពេត្រុស (ទោះបីវាមិនត្រូវបានកត់ត្រានៅក្នុងព្រះគម្ពីរតាមរបៀបនេះក៏ដោយ)។ ព្រះយេស៊ូវបានសួរគាត់ថា៖ «ពេត្រុសអើយ! តើអ្នកធ្លាប់ស្រឡាញ់ខ្ញុំទេ?» ពេត្រុសបានយល់ពីអត្ថន័យនៃព្រះបន្ទូលរបស់

ទ្រង់ ហើយបាននិយាយថា៖ «ឱ ព្រះអម្ចាស់អើយ! ទូលបង្គំធ្លាប់ស្រឡាញ់ព្រះវរបិតាដែលគង់នៅស្ថានសួគ៌ ប៉ុន្តែទូលបង្គំសូមសារភាពថា ទូលបង្គំមិនដែលស្រឡាញ់ទ្រង់ឡើយ»។ បន្ទាប់មក ព្រះយេស៊ូវមានបន្ទូលថា៖ «បើមនុស្សមិនស្រឡាញ់ព្រះវរបិតាដែលគង់នៅស្ថានសួគ៌ផង ធ្វើម្ដេចពួកគេអាចស្រឡាញ់ព្រះរាជបុត្រាទ្រង់ដែលនៅលើផែនដីនេះបាន? ហើយប្រសិនបើមនុស្សមិនស្រឡាញ់ព្រះរាជបុត្រាដែលព្រះដ៏ជាព្រះវរបិតាចាត់មកផង ធ្វើម្ដេចពួកគេអាចស្រឡាញ់ព្រះវរបិតាដែលគង់នៅស្ថានសួគ៌បាន? ប្រសិនបើមនុស្សពិតជាស្រឡាញ់ព្រះរាជបុត្រាដែលគង់នៅលើផែនដី នោះពួកគេក៏ពិតជាស្រឡាញ់ព្រះវរបិតាដែលគង់នៅស្ថានសួគ៌ដែរ»។ ពេលពេត្រុសបានឮពាក្យទាំងនេះ គាត់ក៏បានដឹងពីអ្វីដែលគាត់គ្មាន។ គាត់តែងមានវិប្បដិសារី រហូតដល់ស្រក់ទឹកភ្នែក ស្ដាយពាក្យសម្ដី ដែលគាត់បាននិយាយថា៖ «ទូលបង្គំធ្លាប់ស្រឡាញ់ព្រះវរបិតាដែលគង់នៅស្ថានសួគ៌ ប៉ុន្តែទូលបង្គំមិនធ្លាប់ស្រឡាញ់ទ្រង់ឡើយ»។ ក្រោយពេលព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ និងក្រោយពេលដែលទ្រង់យាងឡើងស្ថានសួគ៌ គាត់កាន់តែមានវិប្បដិសារី និងស្ដាយក្រោយចំពោះពាក្យទាំងនេះ។ ដោយនឹកចាំអំពីកិច្ចការពីអតីតកាល និងកម្ពស់បច្ចុប្បន្នរបស់គាត់ ជារឿយៗ គាត់នឹងចូលមកចំពោះព្រះយេស៊ូវដោយសេចក្ដីអធិស្ឋាន ទាំងមានអារម្មណ៍ស្ដាយក្រោយ និងជំពាក់ទ្រង់រហូត ដោយសារតែគាត់ មិនបានបំពេញតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងមិនបានបំពេញតាមបទដ្ឋានរបស់ព្រះជាម្ចាស់។ រឿងទាំងនេះបានក្លាយជាបន្ទុកដ៏ធំបំផុតរបស់គាត់។ គាត់បាននិយាយថា៖ «នៅថ្ងៃមួយ ទូលបង្គំនឹងថ្វាយដល់ទ្រង់នូវអ្វីៗគ្រប់យ៉ាងដែលទូលបង្គំមាន និងអ្វីគ្រប់យ៉ាងដែលជាជីវិតទូលបង្គំ ហើយទូលបង្គំនឹងថ្វាយដល់ទ្រង់នូវរបស់ដែលមានតម្លៃបំផុត»។ គាត់បាននិយាយថា៖ «ឱព្រះជាម្ចាស់អើយ! ទូលបង្គំមានតែសេចក្ដីជំនឿមួយ និងសេចក្ដីស្រឡាញ់មួយប៉ុណ្ណោះ។ ជីវិតរបស់ទូលបង្គំគ្មានតម្លៃអ្វីឡើយ ឯរូបកាយទូលបង្គំទៀតសោត ក៏គ្មានតម្លៃដែរ។ ទូលបង្គំមានតែសេចក្ដីជំនឿមួយ និងសេចក្ដីស្រឡាញ់មួយប៉ុណ្ណោះ។ ក្នុងគំនិតរបស់ទូលបង្គំមានតែសេចក្ដីជំនឿលើទ្រង់ប៉ុណ្ណោះ ចំណែក

ក្នុងចិត្តទូលបង្គំ ក៏មានតែសេចក្ដីស្រឡាញ់ចំពោះទ្រង់ដែរ។ ទូលបង្គំមានតែរបស់ពីរនេះប៉ុណ្ណោះ ដែលទូលបង្គំអាចថ្វាយដល់ទ្រង់ គឺគ្មានអ្វីផ្សេងឡើយ»។ ពេត្រុសបានទទួលការលើកទឹកចិត្ត ដោយសារព្រះបន្ទូលរបស់ព្រះយេស៊ូវ ព្រោះមុនពេលព្រះយេស៊ូវត្រូវគេឆ្កាង ទ្រង់បានប្រាប់ពេត្រុសថា៖ «ខ្ញុំមិនមែនមកពីលោកីយ៍នេះឡើយ ហើយអ្នកក៏មិនមែនមកពីលោកីយ៍នេះដែរ»។ ក្រោយមក ពេលពេត្រុសមានការឈឺចាប់ខ្លាំងពេក ព្រះយេស៊ូវក៏បានរំឭកដល់គាត់ថា៖ «ពេត្រុសអើយ តើអ្នកបានភ្លេចហើយឬ? ខ្ញុំមិនមែនមកពីលោកីយ៍នេះឡើយ ហើយដែលខ្ញុំបានចាកចេញមុននេះ ក៏ដោយសារតែកិច្ចការរបស់ខ្ញុំដែរ។ អ្នកក៏មិនមែនមកពីលោកីយ៍នេះដែរ តើអ្នកពិតជាភ្លេចហើយមែនទេ? ខ្ញុំបានប្រាប់អ្នកពីរដងហើយ តើអ្នកមិនចាំទេឬអី?» ពេលឮព្រះបន្ទូលទាំងនេះ ពេត្រុសក៏បានឆ្លើយថា៖ «ទូលបង្គំមិនបានភ្លេចនោះឡើយ!» បន្ទាប់មក ព្រះយេស៊ូវបានមានព្រះបន្ទូលថា៖ «អ្នកធ្លាប់បានចំណាយពេលដ៏រីករាយជាមួយខ្ញុំនៅស្ថានសួគ៌ និងបានចំណាយពេលមួយរយៈនៅក្បែរខ្ញុំ។ អ្នកនឹកខ្ញុំ ហើយខ្ញុំក៏នឹកអ្នកដែរ។ ទោះបីជាសត្តនិករទាំងអស់គ្មានតម្លៃនឹងលើកយកមកនិយាយនៅចំពោះព្រះនេត្ររបស់ខ្ញុំក៏ដោយ តើខ្ញុំមិនអាចស្រឡាញ់មនុស្សស្លូតត្រង់ និងគួរឲ្យស្រឡាញ់ដូចម្ដេចបាន? តើអ្នកបានភ្លេចព្រះបន្ទូលសន្យារបស់ខ្ញុំហើយឬ? អ្នកត្រូវតែទទួលយកបញ្ញើបេសកកម្មរបស់ខ្ញុំនៅលើផែនដី ហើយអ្នកត្រូវតែសម្រេចភារកិច្ចដែលខ្ញុំបានផ្ទុកផ្ដាក់ឲ្យអ្នកធ្វើ។ ថ្ងៃមួយ ខ្ញុំច្បាស់ជាដឹកនាំអ្នកឲ្យមកនៅក្បែរខ្ញុំវិញ»។ ក្រោយពេលឮពាក្យនេះ ពេត្រុសកាន់តែមានទឹកចិត្ត និងទទួលបាននូវការជំរុញចិត្តកាន់តែខ្លាំង ដល់ថ្នាក់ពេលដែលគាត់ជាប់នៅលើឈើឆ្កាង គាត់អាចនិយាយថា៖ «ឱព្រះជាម្ចាស់អើយ! ទូលបង្គំមិនអាចស្រឡាញ់ទ្រង់បានសមល្មមឡើយ! ទោះបីជាទ្រង់បង្គាប់ឲ្យទូលបង្គំស្លាប់ក៏ដោយ ក៏ទូលបង្គំនៅតែមិនស្រឡាញ់ទ្រង់ឲ្យល្មមដែរ។ ទោះបីជាទ្រង់បញ្ជូនព្រលឹងរបស់ទូលបង្គំទៅកន្លែងណា ទោះបីជាទ្រង់មិនបំពេញតាមព្រះបន្ទូលសន្យាពីអតីតកាលរបស់ទ្រង់ ហើយទោះបីជាទ្រង់នឹងធ្វើអ្វីនៅពេលខាងមុខនោះឡើយ ក៏ទូលបង្គំនៅតែស្រឡាញ់ និងជឿលើទ្រង់ជានិច្ច»។ អ្វីដែលគាត់

បានប្រកាន់ខ្ជាប់ គឺជាសេចក្តីជំនឿ និងសេចក្តីស្រឡាញ់ដ៏ពិតរបស់គាត់។

នាល្ងាចមួយ មានពួកសិស្សប៉ុន្មាននាក់ រួមទាំងពេត្រុសផង កំពុងតែជិះទូកនេសាទជាមួយព្រះយេស៊ូវ ហើយពេត្រុស ក៏បានសួរទៅកាន់ព្រះយេស៊ូវត្រង់ៗថា៖ «ព្រះអម្ចាស់! ទូលបង្គំចង់សួរទ្រង់សំណួរមួយដែលទូលបង្គំមាននៅក្នុងចិត្តជាយូរណាស់មកហើយ»។ ព្រះយេស៊ូវបានតបថា៖ «សូមអញ្ជើញសួរមកចុះ!» ហើយពេត្រុសបានសួរថា៖ «តើកិច្ចការដែលបានធ្វើ ក្នុងអំឡុងពេលយុគសម័យនៃក្រឹត្យវិន័យ ជាទង្វើរបស់ទ្រង់មែនទេ?» ព្រះយេស៊ូវបានញញឹម ហាក់មានបន្ទូលថា៖ «ក្មេងនេះ ពិតជានិយាយត្រង់មែន!» បន្ទាប់មក ទ្រង់មានបន្ទូលបន្តប្រកបដោយគោលបំណងថា៖ «មិនមែនជាទង្វើរបស់ខ្ញុំឡើយ។ វាគឺជាទង្វើរបស់ព្រះយេហូវ៉ា និងម៉ូសេ»។ ពេត្រុសបានឮដូច្នេះ ហើយក៏ឧទានថា៖ «អូហ៍! ដូច្នេះ កិច្ចការនោះមិនមែនជាទង្វើរបស់ទ្រង់ទេ»។ ពេលពេត្រុសបាននិយាយពាក្យទាំងនេះហើយ ព្រះយេស៊ូវមិនបានមានបន្ទូលទៀតឡើយ។ ពេត្រុសបានគិតក្នុងចិត្តថា៖ «មិនមែនជាទ្រង់ឡើយដែលបានធ្វើកិច្ចការនេះ ដូច្នេះ ទ្រង់បានយាងមកបំផ្លាញក្រឹត្យវិន័យ គ្មានអ្វីចម្លែកទេ ព្រោះវាមិនមែនជាកិច្ចការរបស់ទ្រង់ផងនោះ»។ ដួងចិត្តរបស់គាត់បានធូរស្រាល។ ក្រោយមក ព្រះយេស៊ូវបានជ្រាបថា ពេត្រុសនិយាយត្រង់ៗ ប៉ុន្តែដោយសារតែពេលនោះ គាត់គ្មានការយល់ដឹង ដូច្នេះ ព្រះយេស៊ូវមិនបានមានបន្ទូលអ្វីផ្សេង ឬក៏ជំទាស់គាត់ដោយផ្ទាល់ឡើយ។ មានម្តងនោះ ព្រះយេស៊ូវបានអធិប្បាយនៅក្នុងសាលាប្រជុំមួយដែលមានមនុស្សជាច្រើនចូលរួម រួមទាំងពេត្រុសផងដែរ។ នៅក្នុងបទអធិប្បាយរបស់ទ្រង់ ព្រះយេស៊ូវបានមានបន្ទូលថា៖ «ឯព្រះដែលនឹងមកពីភាពអស់កល្ប ទៅភាពអស់កល្ប ទ្រង់នឹងធ្វើកិច្ចការនៃការប្រោសលោះ ក្នុងអំឡុងយុគសម័យនៃព្រះគុណ ដើម្បីប្រោសលោះមនុស្សលោកទាំងអស់ពីបាប ប៉ុន្តែទ្រង់នឹងមិនត្រូវកំហិតដោយបទបញ្ញត្តិណាមួយ នៅក្នុងការដឹកនាំមនុស្សចេញពីអំពើបាបឡើយ។ ទ្រង់នឹងយាងចេញពីក្រឹត្យវិន័យ ហើយយាងចូលទៅក្នុងយុគសម័យនៃព្រះគុណ។ ទ្រង់នឹងប្រោសលោះមនុស្សលោកទាំងអស់។ ទ្រង់នឹងបោះជំហានទៅមុខ ចេញពី

យុគសម័យនៃក្រឹត្យវិន័យ ចូលទៅកាន់យុគសម័យនៃព្រះគុណ ប៉ុន្តែគ្មាននរណាម្នាក់ស្គាល់ព្រះអង្គ ដែលយាងមកពីព្រះយេហូវ៉ានោះឡើយ។ កិច្ចការដែលម៉ូសេបានធ្វើត្រូវបានប្រទានមកពីព្រះយេហូវ៉ា ហើយម៉ូសេបានព្រាងក្រឹត្យវិន័យ ដោយសារតែកិច្ចការដែលព្រះយេហូវ៉ាបានធ្វើ»។ នៅពេលមានបន្ទូលបែបនេះរួចហើយ ទ្រង់បានបន្តទៀតថា៖ «អស់អ្នកដែលលុបចោលបទបញ្ញត្តិនៅយុគសម័យនៃព្រះគុណ ក្នុងអំឡុងយុគសម័យនៃព្រះគុណ នឹងជួបសេចក្ដីភិតភ័យមិនខាន។ ពួកគេត្រូវតែឈរនៅក្នុងព្រះវិហារ ហើយទទួលសេចក្ដីវិនាសពីព្រះជាម្ចាស់ រួចភ្លើងនឹងធ្លាក់មកលើពួកគេ»។ ការស្ដាប់ឮពាក្យទាំងប៉ុន្មាននេះ បានជះឥទ្ធិពលខ្លះដល់ពេត្រុស ហើយក្នុងរយៈពេលទាំងអស់ នៃបទពិសោធរបស់គាត់ ព្រះយេស៊ូវបានមើលថែ និងជួយការពារពេត្រុស មានបន្ទូលជាមួយគាត់ដោយឥតលាក់កំបាំងទាល់តែសោះ ធ្វើឲ្យពេត្រុសមានការយល់ដឹងកាន់តែប្រសើរថែមទៀតអំពីព្រះយេស៊ូវ។ ពេលពេត្រុសគិតអំពីអ្វីដែលព្រះយេស៊ូវបានបង្រៀននៅថ្ងៃនោះ និងសំណួរដែលគាត់បានសួរព្រះយេស៊ូវនៅពេលដែលពួកគេនៅលើទូកនេសាទ ចម្លើយដែលព្រះយេស៊ូវបានប្រទាន ក៏ដូចជារបៀបដែលទ្រង់បានញញឹម ទីបំផុត ក៏បានធ្វើឲ្យពេត្រុសមានការយល់ដឹងអំពីរឿងរ៉ាវទាំងអស់នេះ។ ក្រោយមក ព្រះវិញ្ញាណបរិសុទ្ធបានស្រាយបំភ្លឺឲ្យពេត្រុសយល់ ទាល់តែពេលនោះទើបគាត់បានដឹងថា ព្រះយេស៊ូវគឺជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់ដ៏មានព្រះជន្មរស់។ ការយល់ដឹងរបស់ពេត្រុសបានមកពីការស្រាយបំភ្លឺរបស់ព្រះវិញ្ញាណបរិសុទ្ធ ប៉ុន្តែការយល់ដឹងរបស់គាត់នេះឆ្លងកាត់នូវដំណើរការមួយ។ ដំណើរការនោះគឺតាមរយៈការសួរសំណួរ ការស្ដាប់ឮព្រះយេស៊ូវបង្រៀន បន្ទាប់មកគឺតាមរយៈការទទួលបានការប្រកបគ្នាយ៉ាងពិសេសរបស់ព្រះយេស៊ូវ និងការគង្វាលដ៏ពិសេសរបស់ទ្រង់ដែលនាំឲ្យពេត្រុសចាប់ផ្ដើមទទួលស្គាល់ថា ព្រះយេស៊ូវជាព្រះបុត្រារបស់ព្រះជាម្ចាស់ដ៏មានព្រះជន្មរស់។ ការយល់ដឹងនេះ មិនមែនសម្រេចបានតែក្នុងពេលមួយយប់ឡើយ វាជាដំណើរការមួយ ហើយការនេះបានក្លាយជាជំនួយមួយដល់គាត់ នៅក្នុងបទពិសោធក្រោយៗរបស់គាត់។ ហេតុអ្វីបានជាព្រះយេស៊ូវមិន

ធ្វើកិច្ចការនៃការប្រោសឲ្យបានគ្រប់លក្ខណ៍ នៅក្នុងអ្នកដទៃផ្សេងទៀត ប៉ុន្តែបែរជាធ្វើតែជាមួយនឹងពេត្រុសម្នាក់ដូច្នេះ? នោះគឺដោយសារមានតែពេត្រុសម្នាក់ប៉ុណ្ណោះដែលដឹងថា ព្រះយេស៊ូវជាព្រះបុត្រារបស់ព្រះជាម្ចាស់ដ៏មានព្រះជន្មរស់ ហើយអ្នកផ្សេងទៀតមិនបានដឹងអំពីការនេះឡើយ។ ថ្វីបើមានពួកសិស្សជាច្រើនបានចេះដឹងនូវរឿងយ៉ាងច្រើន ក្នុងពេលដែលពួកគេដើរតាមទ្រង់ក៏ដោយ ក៏ចំណេះដឹងរបស់គេស្ទើរណាស់។ នេះជាហេតុផលដែលពេត្រុសត្រូវបានព្រះយេស៊ូវជ្រើសរើស ជាបុគ្គលគំរូម្នាក់នៃការដែលត្រូវប្រោសឲ្យបានគ្រប់លក្ខណ៍។ អ្វីដែលព្រះយេស៊ូវបានមានបន្ទូលទៅកាន់ពេត្រុសនៅគ្រានោះ គឺជាអ្វីដែលទ្រង់មានបន្ទូលមកកាន់មនុស្សនាពេលសព្វថ្ងៃនេះ ដ្បិតចំណេះដឹង និងការចូលទៅកាន់ជីវិតរបស់ពួកគេត្រូវតែឈានឲ្យកម្រិតដូចជាពេត្រុស។ ទាល់តែស្របតាមលក្ខខណ្ឌ និងផ្លូវនេះ ទើបព្រះជាម្ចាស់នឹងប្រោសមនុស្សគ្រប់គ្នាឲ្យបានគ្រប់លក្ខណ៍។ ហេតុអ្វីបានជាមនុស្សសព្វថ្ងៃត្រូវបានតម្រូវឲ្យមានសេចក្ដីជំនឿ និងសេចក្ដីស្រឡាញ់ដ៏ពិត? អ្នករាល់គ្នាក៏ត្រូវដកពិសោធន៍នូវអ្វីដែលពេត្រុសបានដកពិសោធន៍ដែរ។ ផលផ្លែដែលពេត្រុសបានទទួលពីបទពិសោធរបស់គាត់ ក៏ត្រូវបង្ហាញចេញនៅក្នុងអ្នករាល់គ្នា ហើយអ្នករាល់គ្នាក៏ត្រូវជួបការឈឺចាប់ដែលពេត្រុសបានជួបដែរ។ ផ្លូវដែលអ្នករាល់គ្នាត្រូវដើរ គឺជាផ្លូវដូចគ្នាដែលពេត្រុសបានដើរ។ ការឈឺចាប់ដែលអ្នករាល់គ្នាមាន គឺជាការឈឺចាប់ដែលពេត្រុសធ្លាប់មាន។ នៅពេលដែលអ្នករាល់គ្នាបានទទួលសិរីរុងរឿង ហើយនៅពេលដែលអ្នករាល់គ្នាស្ដែងចេញនូវជីវិតពិតក្នុងការរស់នៅរបស់អ្នក នោះអ្នកក៏ស្ដែងចេញនូវរូបភាពរបស់ពេត្រុស នៅក្នុងការរស់នៅរបស់អ្នកដែរ។ ផ្លូវដែលត្រូវដើរ គឺជាផ្លូវដូចគ្នា ហើយមនុស្សម្នាក់ត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍ តាមរយៈការដើរតាមផ្លូវនោះឯង។ យ៉ាងណាមិញ គុណសម្បត្តិរបស់អ្នករាល់គ្នាគឺនៅខ្វះខាតខ្លះទៀត បើប្រៀបធៀបជាមួយពេត្រុស ដោយសារតែពេលវេលាបានផ្លាស់ប្ដូរ ដូច្នេះ កម្រិតនៃសេចក្ដីពុករលួយរបស់មនុស្សក៏ផ្លាស់ប្ដូរដែរ និងដោយសារតែស្រុកយូដាជានគរមួយដែលមានវត្តមានយូរលង់ និងមានវប្បធម៌ដ៏ចំណាស់។ ដូច្នេះ អ្នករាល់គ្នាត្រូវតែធ្វើអ្វីៗគ្រប់យ៉ាងដែល

អ្នកអាចធ្វើបាន ដើម្បីកែលម្អគុណសម្បត្តិរបស់អ្នកឲ្យបានប្រសើរឡើង។

ពេត្រុសជាមនុស្សម្នាក់មានសុភវិនិច្ឆ័យណាស់ មានប្រាជ្ញានៅក្នុងគ្រប់កិច្ចការដែលគាត់បានធ្វើ ហើយគាត់ក៏ជាមនុស្សទៀងត្រង់បំផុតដែរ។ គាត់បានជួបនូវឧបសគ្គជាច្រើន។ គាត់ចាប់ផ្ដើមមានទំនាក់ទំនងលើកដំបូងជាមួយសង្គមនៅវ័យ ១៤ឆ្នាំ ជាពេលដែលគាត់បានចូលរៀន និងទៅសាលាប្រជុំផងដែរ។ គាត់មានសេចក្ដីសោមនស្សរីករាយយ៉ាងខ្លាំង ហើយក៏ព្រមចូលរួមការប្រជុំគ្រប់ពេលផងដែរ។ នាពេលនោះ ព្រះយេស៊ូវមិនទាន់បានចាប់ផ្ដើមកិច្ចការរបស់ទ្រង់ជាផ្លូវការនៅឡើយទេ ហើយនេះ គ្រាន់តែជាការចាប់ផ្ដើមយុគសម័យនៃព្រះគុណប៉ុណ្ណោះ។ ពេត្រុសបានចាប់ផ្ដើមមានទំនាក់ទំនងជាមួយអ្នកដឹកនាំសាសនាផ្សេងៗ ពេលដែលគាត់មានវ័យ១៤ឆ្នាំ។ លុះដល់ពេលគាត់មានអាយុ១៨ឆ្នាំ គាត់ចាប់ផ្ដើមមានទំនាក់ទំនងជាមួយថ្នាក់ដឹកនាំកំពូលៗខាងសាសនា ប៉ុន្តែបន្ទាប់ពីគាត់បានឃើញពីភាពចលាចលដែលនៅពីក្រោយរូបភាពសាសនាមក គាត់ក៏ដកថយពីការនោះវិញ។ ដោយឃើញថាមនុស្សទាំងនេះពេញដោយឧបាយកល ប៉ិនប្រសប់ប្រើល្បិច និងផែនការអាក្រក់ គាត់ចាប់ផ្ដើមមានចិត្តស្អប់ខ្ពើមយ៉ាងខ្លាំង (នេះជារបៀបដែលព្រះវិញ្ញាណបរិសុទ្ធបានធ្វើការនៅគ្រានោះ ដើម្បីធ្វើឲ្យគាត់បានគ្រប់លក្ខណ៍។ ទ្រង់បានប៉ះពាល់ចិត្តគាត់យ៉ាងពិសេស ហើយបានធ្វើកិច្ចការដ៏ពិសេសទៅលើគាត់) ជាលទ្ធផល គាត់ក៏បានដកខ្លួនចេញពីសាលាប្រជុំនៅក្នុងវ័យ១៨ឆ្នាំ។ ឪពុកម្ដាយរបស់គាត់បានបៀតបៀនគាត់ ហើយពួកគេនឹងមិនបណ្ដោយឲ្យគាត់ជឿឡើយ (ពួកគេជាអារក្ស និងអ្នកមិនជឿ)។ ទីបំផុត ពេត្រុសក៏បានចាកចេញពីផ្ទះ ហើយបានធ្វើដំណើរទៅគ្រប់ទិសទីដើម្បីនេសាទត្រី និងប្រកាសអំពីព្រះបន្ទូលរបស់ព្រះអស់រយៈពេលពីរឆ្នាំ ហើយក្នុងអំឡុងពេលនោះ គាត់ក៏បានដឹកនាំមនុស្សមួយចំនួនផងដែរ។ ឥឡូវនេះ អ្នកគួរតែអាចមើលឃើញផ្លូវដ៏ហ្មត់ចត់ដែលពេត្រុសបានដើរ យ៉ាងច្បាស់ហើយ។ ប្រសិនបើអ្នកអាចមើលឃើញផ្លូវរបស់ពេត្រុសច្បាស់ នោះអ្នកក៏នឹងដឹងច្បាស់អំពីកិច្ចការដែលកំពុងត្រូវបានធ្វើសព្វថ្ងៃផងដែរ ដូច្នេះ អ្នកនឹងមិនរអ៊ូរទាំ មិនអសកម្ម ឬចង់បានអ្វីមួយនោះ

ឡើយ។ អ្នកគួរតែយល់ពីអារម្មណ៍របស់ពេត្រុសនៅពេលនោះថា៖ គាត់ស្រឡាំងកាំងដោយសារទុក្ខព្រួយ។ គាត់លែងអធិស្ឋានសុំអនាគតល្អ ឬព្រះពរទៀតហើយ។ គាត់មិនបានស្វែងរកប្រយោជន៍ សេចក្ដីសុខ កិត្តិនាមល្បីល្បាញ ឬទ្រព្យសម្បត្តិនៅក្នុងលោកីយ៍នេះឡើយ។ គាត់គ្រាន់តែព្យាយាមរស់នៅក្នុងជីវិតមួយ ដែលមានន័យខ្លឹមសារបំផុត ជាជីវិតមួយដែលតបស្នងចំពោះសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ហើយថ្វាយវត្ថុដ៏មានតម្លៃបំផុតដែលគាត់មានដល់ព្រះជាម្ចាស់។ ក្រោយមក គាត់ក៏មានអារម្មណ៍ស្កប់ចិត្ត។ ជារឿយៗ គាត់បានអធិស្ឋានទៅកាន់ព្រះយេស៊ូវដោយពាក្យថា៖ «ឱព្រះអម្ចាស់យេស៊ូវគ្រីស្ទអើយ ទូលបង្គំធ្លាប់ស្រឡាញ់ទ្រង់ ប៉ុន្តែទូលបង្គំមិនដែលស្រឡាញ់ទ្រង់យ៉ាងពិតប្រាកដឡើយ។ ទោះបីទូលបង្គំ បាននិយាយថាទូលបង្គំមានជំនឿលើទ្រង់ក៏ដោយ ក៏ទូលបង្គំមិនដែលស្រឡាញ់ទ្រង់ ដោយដួងចិត្តពិតប្រាកដឡើយ។ ទូលបង្គំគ្រាន់តែសម្លឹងទៅកាន់ទ្រង់ កោតសរសើរទ្រង់ និងនឹករឭកអំពីទ្រង់ ប៉ុន្តែទូលបង្គំមិនដែលស្រឡាញ់ទ្រង់ ហើយក៏មិនដែលមានជំនឿដ៏ពិតលើទ្រង់នោះដែរ»។ គាត់តែងតែអធិស្ឋាន ដើម្បីធ្វើការតាំងចិត្តរបស់គាត់ ហើយគាត់តែងតែទទួលការលើកទឹកចិត្តពីព្រះបន្ទូលរបស់ព្រះយេស៊ូវ និងទាញបាននូវការជំរុញចិត្តចេញពីព្រះបន្ទូលទាំងនោះ។ ក្រោយមក បន្ទាប់ពីឆ្លងកាត់បទពិសោធមួយរយៈ ព្រះយេស៊ូវក៏បានល្បងលគាត់ ដោយជំរុញគាត់ឲ្យកាន់តែស្រេកឃ្លានចង់បានទ្រង់ថែមទៀត។ គាត់បាននិយាយថា៖ «ឱព្រះអម្ចាស់យេស៊ូវគ្រីស្ទអើយ! ទូលបង្គំពិតជានឹកទ្រង់ ហើយទន្ទឹងចង់ឃើញទ្រង់ខ្លាំងណាស់។ ទូលបង្គំនៅខ្វះចន្លោះច្រើនណាស់ ហើយទូលបង្គំមិនសក្ដិសមសម្រាប់សេចក្ដីស្រឡាញ់របស់ទ្រង់ឡើយ។ ទូលបង្គំសូមអង្វរឲ្យទ្រង់យកទូលបង្គំចេញក្នុងពេលឆាប់ៗនេះទៅ។ តើទ្រង់នឹងត្រូវការទូលបង្គំនៅពេលណា? តើទ្រង់នឹងយកទូលបង្គំទៅនៅពេលណា? តើទូលបង្គំសម្លឹង មើលព្រះភ័ក្ត្ររបស់ទ្រង់ម្ដងទៀតនៅពេលណា? ទូលបង្គំលែងចង់មានជីវិតរស់ក្នុងរូបកាយនេះ ដើម្បីបន្តនិស្ស័យពុករលួយ ហើយក៏មិនចង់បះបោរតទៅទៀតនោះដែរ។ ទូលបង្គំត្រៀមខ្លួនជាស្រេច ដើម្បីថ្វាយអ្វីៗគ្រប់យ៉ាងដែលទូលបង្គំមានដល់ទ្រង់កាន់តែឆាប់

តាមតែទូលបង្គំអាចធ្វើបាន ហើយទូលបង្គំមិនចង់ធ្វើឲ្យទ្រង់ព្រួយព្រះទ័យតទៅទៀតឡើយ»។ នេះជារបៀបដែលគាត់បានអធិស្ឋាន ប៉ុន្តែនៅពេលនោះ គាត់មិនបានដឹងអំពីអ្វីដែលព្រះយេស៊ូវនឹងធ្វើឲ្យគ្រប់លក្ខណ៍នៅក្នុងគាត់ឡើយ។ ក្នុងអំឡុងពេលដែលគាត់ព្រួយចិត្ត ដោយសារតែការល្បងលរបស់គាត់ ព្រះយេស៊ូវបានបង្ហាញអង្គទ្រង់ឲ្យគាត់ឃើញម្ដងទៀត ហើយមានបន្ទូលថា៖ «ពេត្រុស ខ្ញុំចង់ធ្វើឲ្យអ្នកបានគ្រប់លក្ខណ៍ ដើម្បីឲ្យអ្នកក្លាយជាផលផ្លែមួយ ដែលស្ដែងឲ្យឃើញ ពីភាពគ្រប់លក្ខណ៍របស់ខ្ញុំតាមរយៈអ្នក ហើយជាផលផ្លែដែលនាំឲ្យខ្ញុំមានចិត្តរីករាយ។ តើអ្នកអាចធ្វើបន្ទាល់ពីខ្ញុំយ៉ាងពិតប្រាកដដែរឬទេ? តើអ្នកបានធ្វើតាមអ្វីដែលខ្ញុំបានសុំឲ្យអ្នកធ្វើដែរឬទេ? តើអ្នកបានរស់នៅតាមពាក្យដែលខ្ញុំបាននិយាយហើយឬនៅ? អ្នកធ្លាប់ស្រឡាញ់ខ្ញុំ ប៉ុន្តែទោះបីជាអ្នកបានស្រឡាញ់ខ្ញុំ តើអ្នកបានរស់នៅតាមពាក្យរបស់ខ្ញុំហើយឬនៅ? តើអ្នកបានធ្វើអ្វីខ្លះសម្រាប់ខ្ញុំ? អ្នកទទួលស្គាល់ថា អ្នកមិនសក្ដិសមនឹងទទួលសេចក្ដីស្រឡាញ់របស់ខ្ញុំឡើយ ប៉ុន្តែតើអ្នកបានធ្វើអ្វីខ្លះសម្រាប់ខ្ញុំ?» ពេត្រុសបានឃើញថា គាត់មិនបានធ្វើអ្វីសោះសម្រាប់ព្រះយេស៊ូវ ហើយគាត់បាននឹកចាំអំពីពាក្យសម្បថដែលគាត់ស្បថថ្វាយជីវិតរបស់គាត់ដល់ព្រះជាម្ចាស់កាលពីមុន។ ដូច្នេះ គាត់ក៏លែងរអ៊ូរទាំ ហើយចាប់ពីពេលនោះមក ពាក្យអធិស្ឋានរបស់គាត់កាន់តែប្រសើរឡើង។ គាត់បានអធិស្ឋានដោយពោលថា៖ «ឱព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ! ទូលបង្គំធ្លាប់ចាកចោលទ្រង់ ហើយទ្រង់ក៏ធ្លាប់ចាកចោលទូលបង្គំម្ដងផងដែរ។ យើងបានចំណាយទាំងពេលនៅដាច់ពីគ្នា និងពេលនៅជាមួយគ្នា។ ប៉ុន្តែ ទ្រង់ស្រឡាញ់ទូលបង្គំខ្លាំងជាងអ្នកណាទាំងអស់។ ទូលបង្គំបានបះបោរទាស់នឹងទ្រង់ដដែលៗ និងបានធ្វើឲ្យទ្រង់ព្រួយព្រះហឫទ័យម្ដងហើយម្ដងទៀត។ តើទូលបង្គំអាចបំភ្លេចរឿងទាំងនេះបានដោយរបៀបណា? ទូលបង្គំតែងតែនឹកចាំជានិច្ច ហើយមិនភ្លេចកិច្ចការដែលទ្រង់បានធ្វើចំពោះទូលបង្គំ និងអ្វីដែលទ្រង់បានប្រទានដល់ទូលបង្គំនោះឡើយ។ ទូលបង្គំបានធ្វើអ្វីគ្រប់យ៉ាងដែលទូលបង្គំអាចធ្វើបាន សម្រាប់កិច្ចការដែលទ្រង់បានធ្វើចំពោះទូលបង្គំ។ ទ្រង់ជ្រាបដឹងអំពីអ្វីដែលទូលបង្គំអាចធ្វើបាន ហើយទ្រង់ថែមទាំងជ្រាប

អំពីតួនាទីដែលទូលបង្គំអាចធ្វើបានដែរ។ ទូលបង្គំចង់ចុះចូលចំពោះការរៀបចំរបស់ទ្រង់ ហើយទូលបង្គំនឹងថ្វាយអ្វីៗទាំងអស់ដែលទូលបង្គំមានដល់ទ្រង់។ មានតែទ្រង់មួយប៉ុណ្ណោះដែលជ្រាបដឹងអំពីអ្វីដែលទូលបង្គំអាចធ្វើសម្រាប់ទ្រង់។ ទោះបីអារក្សសាតាំងបានបោកបញ្ឆោតទូលបង្គំយ៉ាងច្រើន ហើយទូលបង្គំបានបះបោរទាស់នឹងទ្រង់ក៏ដោយ ក៏ទូលបង្គំជឿថា ទ្រង់មិននឹកនាពីសេចក្ដីរំលងដែលទូលបង្គំបានធ្វើទាំងនោះ ហើយក៏ជឿថា ទ្រង់មិនប្រព្រឹត្តចំពោះទូលបង្គំ ដោយផ្អែកលើសេចក្ដីរំលងទាំងនោះផងដែរ។ ទូលបង្គំចង់ថ្វាយជីវិតរបស់ទូលបង្គំទាំងស្រុងដល់ទ្រង់។ ទូលបង្គំមិនសុំអ្វីឡើយ ហើយក៏គ្មានសេចក្ដីសង្ឃឹម ឬផែនការអ្វីផ្សេងនោះដែរ។ ទូលបង្គំគ្រាន់តែចង់ធ្វើតាមបំណង និងព្រះហឫទ័យរបស់ទ្រង់តែមួយប៉ុណ្ណោះ។ ទូលបង្គំនឹងផឹកពីពែងដ៏ល្វីងជូរចត់របស់ទ្រង់ ហើយទូលបង្គំនឹងធ្វើតាមបង្គាប់របស់ទ្រង់ជានិច្ច»។

អ្នករាល់គ្នាត្រូវតែស្គាល់ឲ្យច្បាស់ អំពីផ្លូវដែលអ្នករាល់គ្នាត្រូវដើរ។ អ្នករាល់គ្នាត្រូវតែដឹងឲ្យច្បាស់ អំពីផ្លូវដែលអ្នករាល់គ្នានឹងដើរនៅពេលអនាគត ដឹងថាអ្វីទៅដែលព្រះជាម្ចាស់នឹងធ្វើឲ្យគ្រប់លក្ខណ៍ និងអ្វីខ្លះទៅ ដែលទ្រង់បានផ្ទុកផ្ដាក់ដល់អ្នករាល់គ្នា។ នៅថ្ងៃមួយ ប្រហែលជាអ្នករាល់គ្នានឹងជួបការល្បងល ហើយពេលដែលគ្រានោះមកដល់ បើអ្នករាល់គ្នាអាចទាញការជំរុញចិត្តចេញពីបទពិសោធរបស់ពេត្រុសបាន នោះវានឹងបង្ហាញថា អ្នករាល់គ្នាកំពុងតែដើរតាមផ្លូវរបស់ពេត្រុសយ៉ាងពិតប្រាកដហើយ។ ពេត្រុសបានទទួលការសរសើរពីព្រះជាម្ចាស់ ដោយព្រោះសេចក្ដីជំនឿ សេចក្ដីស្រឡាញ់ដ៏ពិត និងចិត្តភក្ដីភាពដែលគាត់មានចំពោះព្រះជាម្ចាស់។ ហើយដោយសារតែភាពទៀងត្រង់ និងការចង់បានព្រះជាម្ចាស់ នៅក្នុងដួងចិត្តរបស់គាត់នេះហើយ ដែលនាំឲ្យព្រះជាម្ចាស់ប្រោសគាត់ឲ្យបានគ្រប់លក្ខណ៍នោះ។ បើអ្នកពិតជាមានសេចក្ដីស្រឡាញ់ និងសេចក្ដីជំនឿដ៏ពិត ដូចជាពេត្រុសមែន នោះព្រះយេស៊ូវប្រាកដជានឹងប្រោសឲ្យអ្នកបានគ្រប់លក្ខណ៍ជាក់ជាមិនខាន។

# អស់អ្នកណាដែលស្រឡាញ់ព្រះជាម្ចាស់ នឹងរស់នៅក្នុងពន្លឺរបស់ទ្រង់អស់កល្បជានិច្ច

ធាតុផ្សំនៃជំនឿរបស់មនុស្សភាគច្រើនដែលមានចំពោះព្រះជាម្ចាស់ គឺជាជំនឿបែបសាសនា៖ ពួកគេមិនអាចស្រឡាញ់ព្រះជាម្ចាស់ ហើយអាចត្រឹមតែ ដើរតាមព្រះជាម្ចាស់ ដូចជាមនុស្សយន្ត ពួកគេមិនអាចចង់បាន ឬស្រឡាញ់ព្រះជាម្ចាស់ឲ្យពិតប្រាកដនោះឡើយ។ ពួកគេគ្រាន់តែដើរតាមព្រះអង្គយ៉ាងស្ងៀមស្ងាត់ប៉ុណ្ណោះ។ មនុស្សច្រើនណាស់ ជឿលើព្រះជាម្ចាស់ ប៉ុន្តែមានមនុស្សតិចណាស់ដែលស្រឡាញ់ព្រះជាម្ចាស់ ពួកគេគ្រាន់តែ «គោរព» ព្រះជាម្ចាស់ ដ្បិតពួកគេខ្លាចវិនាស ឬពុំនោះទេ ពួកគេ «ស្ញប់ស្ញែង» ព្រះជាម្ចាស់ ដ្បិតទ្រង់ឧត្ដុង្គឧត្ដម និងមានឫទ្ធានុភាព ប៉ុន្តែនៅក្នុងការគោរព និងការស្ញប់ស្ញែងរបស់គេ ពុំមាននូវសេចក្ដីស្រឡាញ់ ហើយនិងការចង់បានដ៏ពិតប្រាកដនោះទេ។ នៅក្នុងបទពិសោធរបស់ពួកគេ ពួកគេស្វែងរកតែរឿងអសារឥតការនៃសេចក្ដីពិត ពុំនោះទេ គឺស្វែងរកតែ សេចក្ដីអាថ៌កំបាំងមួយចំនួនដែលពុំមានសារៈសំខាន់។ មនុស្សភាគច្រើន គ្រាន់តែដើរតាមដោយស្ទូចយកព្រះពរនៅក្នុងទឹកដែលល្អក់កករ ពួកគេមិនស្វែងរកសេចក្ដីពិត ក៏មិនស្ដាប់បង្គាប់ព្រះជាម្ចាស់ដោយពិតប្រាកដ ដើម្បីទទួលព្រះពររបស់ទ្រង់ដែរ។ ជីវិតនៃជំនឿ របស់មនុស្សទាំងអស់ ចំពោះព្រះជាម្ចាស់ គឺគ្មានន័យអ្វីសោះ គ្មានទាំងតម្លៃ និងមានតែការគិតគូរ និងការចង់បានរបស់ពួកគេផ្ទាល់។ ពួកគេមិនមែនជឿព្រះជាម្ចាស់ដើម្បីស្រឡាញ់ទ្រង់ទេ តែដើម្បីបានទទួលព្រះពរវិញ។ មនុស្សជាច្រើនធ្វើអ្វីៗទៅតាមទំនើងចិត្ត ពួកគេធ្វើអ្វីដែលខ្លួនចង់ធ្វើ ហើយមិនដែលពិចារណាដល់ប្រយោជន៍របស់ព្រះជាម្ចាស់ ឬពិចារណាថា អ្វីដែលគេធ្វើនោះស្រប ឬពុំស្របនឹងព្រះហឫទ័យព្រះជាម្ចាស់ទេ។ មនុស្សបែបនេះ សូម្បីត្រឹមឲ្យមានជំនឿពិត គេមិនអាចធ្វើបានផង ទម្រាំឲ្យគេស្រឡាញ់ព្រះជាម្ចាស់ទៀត គឺកាន់តែមិនអាចទៅរួច។ ជាងនេះទៅទៀត លក្ខណៈពិតរបស់ព្រះជាម្ចាស់ គឺមិនត្រឹមតែឲ្យមនុស្សជឿលើទ្រង់ប៉ុណ្ណោះទេ គឺឲ្យ

គេស្រឡាញ់ទ្រង់។ ប៉ុន្តែ មនុស្សជាច្រើនក្នុងចំណោមអ្នកដែលជឿលើព្រះជាម្ចាស់ គឺសុទ្ធតែអសមត្ថភាព រកមិនឃើញ «អាថ៌កំបាំង» នេះ។ មនុស្សមិនហ៊ានស្រឡាញ់ព្រះជាម្ចាស់ ហើយក៏មិនព្យាយាមស្រឡាញ់ទ្រង់ដែរ។ ពួកគេពុំដែលធ្លាប់រកឃើញសោះថា ព្រះជាម្ចាស់មានលក្ខណៈគួរឲ្យស្រឡាញ់ច្រើនណាស់។ ពួកគេពុំធ្លាប់រកឃើញសោះថា ព្រះជាម្ចាស់ គឺជាព្រះដែលស្រឡាញ់មនុស្ស និងជាព្រះដ៏គង់នៅដើម្បីឲ្យមនុស្សស្រឡាញ់។ សោភ័ណភាពរបស់ព្រះជាម្ចាស់ ត្រូវបានស្តែងចេញមកតាមរយៈកិច្ចការរបស់ទ្រង់៖ លុះត្រាតែ មនុស្សមានបទពិសោធពីកិច្ចការរបស់ទ្រង់ ទើបពួកគេអាចរកឃើញសោភ័ណភាពរបស់ទ្រង់។ មានតែតាមរយៈបទពិសោធជាក់ស្តែងរបស់គេទេ ទើបគេអាចស្ញើចសរសើរពី សោភ័ណភាពរបស់ព្រះជាម្ចាស់បាន ហើយប្រសិនបើមិនមានការកត់សម្គាល់ពីបទពិសោធនេះនៅក្នុងជីវិតពិតទេ ក៏គ្មាននរណាម្នាក់អាចរកឃើញសោភណភាពរបស់ព្រះជាម្ចាស់ដែរ។ ព្រះជាម្ចាស់មានលក្ខណៈគួរឲ្យស្រឡាញ់ច្រើនណាស់ ប៉ុន្តែប្រសិនបើគ្មានចំណងទំនាក់ទំនងពិតជាមួយនឹងទ្រង់ទេ មនុស្សក៏មិនអាចរកឃើញលក្ខណៈដ៏គួរឲ្យស្រឡាញ់ទាំងនេះដែរ។ មានន័យថា ប្រសិនបើព្រះជាម្ចាស់មិនបានក្លាយជាសាច់ឈាមទេ មនុស្សច្បាស់ជាមិនអាចមានចំណងទំនាក់ទំនងពិតជាមួយនឹងព្រះជាម្ចាស់ឡើយ ហើយប្រសិនបើពួកគេមិនអាចមានចំណងទំនាក់ទំនងពិតជាមួយទ្រង់ទេ នោះពួកគេច្បាស់ជាមិនអាចស្គាល់កិច្ចការរបស់ទ្រង់ឡើយ ហើយសេចក្តីស្រឡាញ់របស់គេចំពោះព្រះអង្គ ក៏ច្បាស់ជាត្រូវសៅហ្មង ដោយភាពក្លែងក្លាយជា និងការស្រមើស្រមៃជាច្រើន។ សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ នៅឯស្ថានសួគ៌ មិនជាក់ស្តែងដូចជាសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់នៅផែនដីនេះទេ ដ្បិតការដែលមនុស្សស្គាល់ព្រះជាម្ចាស់ ដែលគង់នៅស្ថានសួគ៌ គឺផ្អែកទៅលើការស្រមើស្រមៃរបស់គេ មិនមែនផ្អែកលើអ្វីដែលគេមើលឃើញផ្ទាល់នឹងភ្នែក និងផ្អែកលើអ្វីដែលគេបានពិសោធដោយខ្លួនឯង។ ពេលព្រះជាម្ចាស់យាងមកផែនដី មនុស្សអាចមើលឃើញសោភ័ណភាព និងទង្វើរបស់ទ្រង់ផ្ទាល់ ហើយពួកគេក៏អាចមើលឃើញ គ្រប់យ៉ាងទាក់ទងទៅនឹងនិស្ស័យជាក់ស្តែង

និងនិស្ស័យធម្មតារបស់ទ្រង់ ដែលសេចក្ដីទាំងអស់នេះ មានលក្ខណៈជាក់ស្ដែងលើសពីការដែលគេស្គាល់ព្រះជាម្ចាស់ដែលគង់នៅឯស្ថានសួគ៌ រាប់ពាន់ដង។ បើទោះបីមនុស្សស្រឡាញ់ព្រះជាម្ចាស់ដែលគង់នៅឯស្ថានសួគ៌ខ្លាំងប៉ុនណា ក៏សេចក្ដីស្រឡាញ់នេះគ្មានអ្វីជាក់ស្ដែងដែរ ហើយពោរពេញទៅដោយគំនិតរបស់មនុស្ស។ បើទោះបីជាសេចក្ដីស្រឡាញ់របស់មនុស្ស ចំពោះព្រះដែលគង់នៅលើផែនដីនេះ មានតិចតួចស្ដួចស្ដើងម្ដេចក្ដី ក៏សេចក្ដីស្រឡាញ់នេះ ជាសេចក្ដីស្រឡាញ់ជាក់ស្ដែងដែរ បើទោះបីជាមានតិចតួចប៉ុនណាក្ដី ក៏សេចក្ដីស្រឡាញ់នេះ នៅតែជាសេចក្ដីស្រឡាញ់ពិត។ ព្រះជាម្ចាស់ធ្វើឲ្យមនុស្សស្គាល់ទ្រង់ តាមរយៈកិច្ចការជាក់ស្ដែង ហើយទ្រង់ទទួលបាននូវសេចក្ដីស្រឡាញ់របស់គេ តាមរយៈចំណេះដឹងនេះហើយ។ គឺដូចជាពេត្រុសដែរ៖ ប្រសិនបើគាត់មិនធ្លាប់រស់នៅ ជាមួយព្រះយេស៊ូវ នោះគាត់មុខជាមិនអាចស្រឡាញ់ព្រះយេស៊ូវឡើយ។ ដូច្នេះ ភក្ដីភាពដែលគាត់មាន ចំពោះព្រះយេស៊ូវ ក៏ផ្អែកលើចំណងទំនាក់ទំនងរបស់គាត់ជាមួយនឹងព្រះយេស៊ូវដែរ។ ដើម្បីឲ្យមនុស្សស្រឡាញ់ព្រះជាម្ចាស់ ទ្រង់បានយាងមកក្នុងចំណោមមនុស្សលោក ហើយរស់នៅជាមួយពួកគេ ហើយអស់ទាំងសេចក្ដីដែលព្រះអង្គបើកសម្ដែងឲ្យមនុស្សបានឃើញ និងមានបទពិសោធ សុទ្ធតែជាតថភាពរបស់ព្រះជាម្ចាស់។

ព្រះជាម្ចាស់ប្រើភាពជាក់ស្ដែង និងដំណើរមកដល់នៃហេតុការណ៍ ដើម្បីប្រោសមនុស្សឲ្យគ្រប់លក្ខណ៍។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ សម្រេចចំណែកកិច្ចការរបស់ទ្រង់ ក្នុងការប្រោសមនុស្សឲ្យគ្រប់លក្ខណ៍ ហើយនេះគឺជាកិច្ចការនៃការដឹកនាំ និងការបើកផ្លូវ។ មានន័យថា អ្នកត្រូវរកឃើញវិធីអនុវត្ត និងស្គាល់និមិត្តទាំងនេះ ក្នុងព្រះបន្ទូលទ្រង់។ មនុស្សនឹងមានផ្លូវ និងនិមិត្តនៅក្នុងការអនុវត្តជាក់ស្ដែងរបស់គេ តាមរយៈការយល់ដឹងសេចក្ដីទាំងនេះ ហើយគេនឹងអាចទទួលបាននូវការស្រាយបំភ្លឺ តាមរយៈព្រះបន្ទូលរបស់ព្រះជាម្ចាស់។ គេនឹងអាចយល់ដឹងថា សេចក្ដីទាំងនេះ មកពីព្រះជាម្ចាស់ ហើយអាចយល់ឃើញយ៉ាងជាក់។ បន្ទាប់ពីមានការយល់ដឹងហើយ មនុស្សត្រូវចូលទៅក្នុងតថភាពនេះភ្លាម ហើយត្រូវប្រើព្រះបន្ទូលព្រះជាម្ចាស់ ដើម្បី

ផ្គាប់ព្រះទ័យរបស់ទ្រង់ នៅក្នុងជីវិតជាក់ស្ដែងរបស់គេ។ ព្រះជាម្ចាស់ នឹងដឹកនាំអ្នកក្នុងគ្រប់ការទាំងអស់ រួចទ្រង់នឹងប្រទានឲ្យអ្នកនូវវិធីអនុវត្ត ហើយធ្វើឲ្យអ្នកមានអារម្មណ៍ថា ទ្រង់គួរឲ្យស្រឡាញ់យ៉ាងពិសេស ព្រមទាំងអនុញ្ញាតិឲ្យអ្នកមើលឃើញថា គ្រប់ជំហាននៃកិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងអ្នក ធ្វើឡើងដើម្បីធ្វើឲ្យអ្នកបានគ្រប់លក្ខណ៍។ ប្រសិនបើ អ្នកចង់ឃើញសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ប្រសិនបើអ្នកចង់ស្គាល់សេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ យ៉ាង ពិតប្រាកដ នោះអ្នកត្រូវតែចូលឲ្យជ្រៅក្នុងភាពជាក់ស្ដែង អ្នកត្រូវតែចូលជ្រៅទៅក្នុងជីវិតពិត និងមើលឃើញថា គ្រប់យ៉ាងដែលព្រះជាម្ចាស់ធ្វើ គឺជាសេចក្ដីស្រឡាញ់ និងការសង្គ្រោះមើលឃើញថា គ្រប់យ៉ាងដែលទ្រង់ធ្វើ គឺដើម្បីឲ្យមនុស្សអាចលះបង់រឿងសៅហ្មង ហើយបន្សុទ្ធលក្ខណៈដែលមានក្នុងមនុស្ស ជាសេចក្ដីដែលមិនអាចឲ្យគេផ្គាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់បាន។ ព្រះជាម្ចាស់ប្រើព្រះបន្ទូល ដើម្បីផ្គត់ផ្គង់មនុស្សលោក ទ្រង់ចាត់ចែងស្ថានការណ៍នៃ ជីវិតពិតសម្រាប់ឲ្យមនុស្សមានបទពិសោធ ហើយប្រសិនបើមនុស្សហូប និងផឹកព្រះបន្ទូលព្រះជាម្ចាស់ច្រើន នោះពេលគេយកព្រះបន្ទូលនោះទៅអនុវត្ត នោះពួកគេក៏អាចដោះស្រាយការលំបាកទាំងអស់ក្នុងជីវិតរបស់គេ ដោយប្រើព្រះបន្ទូលរបស់ព្រះជាម្ចាស់។ មានន័យថា អ្នកតែមានព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីចូលឲ្យជ្រៅក្នុងភាពជាក់ស្ដែង។ ប្រសិនបើអ្នកមិនហូប និងផឹកព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយមិនមាននូវកិច្ចការរបស់ព្រះអង្គ នោះអ្នកនឹងមិនមានមាគ៌ាចូលទៅឯជីវិតឡើយ។ ប្រសិនបើអ្នកមិនដែលហូប និងផឹកព្រះបន្ទូលព្រះជាម្ចាស់ នោះអ្នកនឹងទាល់ប្រាជ្ញា នៅពេលមានរឿងកើតឡើងចំពោះអ្នក។ អ្នកគ្រាន់តែដឹងថា ខ្លួនគប្បីស្រឡាញ់ព្រះជាម្ចាស់ ប៉ុន្តែអ្នកមិនអាចបែងចែកភាពខុសគ្នា និងគ្មានវិធីអនុវត្តសោះ។ អ្នកច្របូកច្របល់ និងវង្វេងវង្វាន់ ហើយពេលខ្លះ អ្នកថែមទាំងជឿថា តាមរយៈការបំពេញតាមសាច់ឈាម អ្នកក៏ផ្គាប់ព្រះទ័យព្រះជាម្ចាស់ដែរ ទាំងអស់នេះ គឺជាលទ្ធផលនៃការមិនហូប និងមិនផឹកព្រះបន្ទូលរបស់ព្រះជាម្ចាស់។ មានន័យថា ប្រសិនបើ អ្នកគ្មានជំនួយមកពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយចេះតែរអ៊ូរទាំ

នៅក្នុងភាពជាក់ស្ដែង នោះអ្នកអសមត្ថភាពជាមូលដ្ឋានក្នុងការស្វែងរកវិធីអនុវត្ត ហើយ។ មនុស្សបែបនេះ មិនយល់ពីអត្ថន័យនៃការជឿលើព្រះជាម្ចាស់តែម្ដង ហើយរឹតតែមិនយល់អំពីអត្ថន័យនៃការស្រឡាញ់ព្រះជាម្ចាស់ទៅទៀត។ ប្រសិនបើអ្នកឧស្សាហ៍អធិស្ឋាន ស្រាវជ្រាវ ហើយស្វែងរក ដោយប្រើការស្រាយបំភ្លឺ និងការដឹកនាំដោយព្រះបន្ទូលរបស់ព្រះជាម្ចាស់ តាមរយៈការនេះ អ្នកនឹងរកឃើញថា អ្នកគួរយកព្រះបន្ទូលមកអនុវត្ត គួររិះរកឱកាសសម្រាប់កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ សហការជាមួយព្រះជាម្ចាស់យ៉ាងពិតប្រាកដ ហើយអ្នកលែងច្រឡូកច្របល់ និងវង្វេងវង្វាន់ដែរ បន្ទាប់មក អ្នកនឹងមានផ្លូវមួយក្នុងជីវិតពិត ហើយអ្នកនឹងផ្គាប់ព្រះជាម្ចាស់បានយ៉ាងពិតប្រាកដ។ ពេលដែលអ្នកបានផ្គាប់ព្រះទ័យព្រះជាម្ចាស់ហើយ នោះនឹងមានការដឹកនាំរបស់ព្រះជាម្ចាស់ នៅក្នុងជីវិតរបស់អ្នក ហើយអ្នកនឹងមានការប្រទានព្រះពរជាពិសេសពីព្រះជាម្ចាស់ គឺជាព្រះពរដែលនឹងផ្ដល់ឲ្យអ្នកមានទឹកចិត្តរីករាយ៖ អ្នកនឹងមានអារម្មណ៍ថាមានកិត្តិយសជាពិសេស ដ្បិតអ្នកបានផ្គាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ អ្នកមានអាម្មណ៍ស្រស់ស្រាយពីខាងក្នុងជាពិសេស ហើយក្នុងដួងចិត្តរបស់អ្នក អ្នកនឹងបានជ្រះស្រឡះ ហើយស្ងប់សុខផង។ សម្បជញ្ញៈរបស់អ្នកនឹងបានស្រាកស្រាន្ត ព្រមទាំងបានរួចពីចោទប្រកាន់ទាំងអម្បាលម៉ាន ហើយអ្នកនឹងមានអារម្មណ៍រីករាយក្នុងចិត្ត នៅពេលជួបបងប្អូន ប្រុសស្រីរបស់ខ្លួន។ នេះហើយជាអត្ថន័យនៃការត្រេកអរ នឹងសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ហើយមានតែវិធីនេះទេ ទើបជាការអរសប្បាយនឹងព្រះជាម្ចាស់យ៉ាងពិតប្រាកដ។ ភាពអរសប្បាយរបស់មនុស្សនឹងក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ អាចទទួលបានតាមរយៈបទពិសោធមួយគឺ៖ តាមរយៈការឆ្លងកាត់នូវការលំបាក និងបទពិសោធនៃការយកសេចក្ដីពិតទៅអនុវត្ត។ ប្រសិនបើអ្នកគ្រាន់តែពោលថា ព្រះជាម្ចាស់ពិតជាស្រឡាញ់អ្នក ដោយពោលថា ព្រះជាម្ចាស់បានបង់ថ្លៃលោះដ៏ធ្ងន់ធ្ងរដើម្បីមនុស្សលោក ដល់ថ្នាក់ទ្រង់ថ្លែងព្រះបន្ទូលជាច្រើនដោយអត់ធ្មត់ និងដោយសប្បុរស ហើយតែងសង្គ្រោះមនុស្សលោករហូត នោះការពោលពាក្យសម្ដីរបស់អ្នក វាបានត្រឹមតែជាការអរសប្បាយតែម្ខាងរបស់

ព្រះជាម្ចាស់ទេ។ ប៉ុន្តែ ការអរសប្បាយដ៏អស្ចារ្យជាងនេះ ដែលជាការអរសប្បាយពិត គឺពេលដែលមនុស្សយកសេចក្ដីពិតទៅអនុវត្តនៅក្នុងជីវិតពិតរបស់ពួកគេ បន្ទាប់ពីពួកគេបានជ្រះថ្លា និងបានសុខសាន្តនៅក្នុងចិត្តហើយ។ ពួកគេមានអារម្មណ៍ថាត្រូវបានបណ្ដាលចិត្តជាខ្លាំងនៅក្នុងចិត្ត និងមានអារម្មណ៍ថា ព្រះជាម្ចាស់គួរឲ្យស្រឡាញ់បំផុត។ អ្នកនឹងមានអារម្មណ៍ថា តម្លៃដែលអ្នកបានបង់ គឺលើសពីសមរម្យទៅហើយ។ ដោយបានបង់តម្លៃដ៏លើសលប់ តាមរយៈការប្រឹងប្រែង របស់អ្នក នោះអ្នកនឹងបានភ្លឺថ្លាក្នុងចិត្តជាពិសេស៖ អ្នកនឹងមានអារម្មណ៍ថា អ្នកកំពុងតែរីករាយនឹងក្ដីស្រឡាញ់យ៉ាងពិតប្រាកដ ហើយអ្នកនឹងយល់ថា ព្រះជាម្ចាស់បានធ្វើកិច្ចការនៃសេចក្ដីសង្គ្រោះនៅក្នុងមនុស្សលោកយល់ថា ការដែលទ្រង់រំលែងមនុស្សលោក គឺដើម្បីបន្សុទ្ធពួកគេ ហើយយល់ថា ព្រះជាម្ចាស់ល្បងលមនុស្ស ដើម្បីពិសោធមើលថា ពួកគេស្រឡាញ់ពិតប្រាកដដែរឬទេ។ ប្រសិនបើអ្នកយកសេចក្ដីពិតមកអនុវត្តបែបនេះរហូត នោះអ្នកនឹងបង្កើតបានការចេះដឹងដ៏ច្បាស់លាស់អំពីកិច្ចការជាច្រើនរបស់ព្រះជាម្ចាស់ ហើយពេលនោះអ្នកនឹងមានអារម្មណ៍ថា ព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅចំពោះមុខអ្នក ច្បាស់ដូចថ្ងៃ។ ប្រសិនបើអ្នកអាចយល់ច្បាស់អំពីសេចក្ដីពិតជាច្រើន អ្នកនឹងមានអារម្មណ៍ថា គ្រប់សេចក្ដីទាំងអស់សុទ្ធ តែងាយយកមកអនុវត្ត ដែលនឹងប្រោសឲ្យអ្នកមានសេរីដ៏ធំធេង និងប្រោសអ្នកឲ្យរួច រហូតអ្នកអាចយកឈ្នះបញ្ហា និងការល្បួងនានា ហើយអ្នកនឹងឃើញថា គ្មានអ្វីជាបញ្ហា ចំពោះអ្នកឡើយ។ នៅពេលនោះអ្នកកំពុងតែអរសប្បាយនឹងក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ហើយសេចក្ដីស្រឡាញ់ពិតរបស់ព្រះជាម្ចាស់នឹងមកសណ្ឋិតលើអ្នកជាមិនខាន។ ព្រះជាម្ចាស់ប្រទានពរដល់មនុស្សដែលមាននិមិត្ត មនុស្សដែលមានសេចក្ដីពិត មានចំណេះដឹង និងស្រឡាញ់ទ្រង់ពិតប្រាកដ។ ប្រសិនបើមនុស្សចង់មើលឃើញនូវសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ពួកគេត្រូវតែយកសេចក្ដីពិតមកអនុវត្តក្នុងជីវិតជាក់ស្ដែង ពួកគេត្រូវតែព្រមស៊ូទ្រាំនឹងការឈឺចាប់ និងបោះបង់អ្វីៗដែលគេស្រឡាញ់ ដើម្បីផ្គាប់ព្រះហឫទ័យព្រះជាម្ចាស់។ ព្រះជាម្ចាស់ច្បាស់ជាប្រទានពរដល់អ្នកតាមវិធីនេះ ហើយប្រសិនបើអ្នកស៊ូទ្រាំនឹងការលំបាកបែបនេះ

បាន បន្ទាប់មក កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធនឹងកើតមានដល់អ្នក។ មនុស្សអាចមើលឃើញលក្ខណៈគួរឲ្យស្រឡាញ់របស់ព្រះជាម្ចាស់ តាមរយៈជីវិតជាក់ស្ដែង និងបទពិសោធព្រះបន្ទូលព្រះជាម្ចាស់ ហើយទាល់តែគេបានភ្លក់នូវសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ទើបគេអាចស្រឡាញ់ទ្រង់ យ៉ាងពិតប្រាកដបាន។

កាលណាអ្នកកាន់តែយកសេចក្ដីពិតមកអនុវត្ត អ្នកក៏មានសេចក្ដីពិតកាន់តែច្រើនដែរ។ កាលណាអ្នកកាន់តែយកសេចក្ដីពិតមកអនុវត្ត អ្នកមានសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់កាន់តែច្រើនដែរ ហើយកាលណាអ្នកកាន់តែយកសេចក្ដីពិតមកអនុវត្ត អ្នកទទួលបានព្រះពរកាន់តែច្រើនពីព្រះជាម្ចាស់ដែរ។ ប្រសិនបើអ្នកអនុវត្តបែបនេះបានរហូត នោះសេចក្ដីស្រឡាញ់ដែលព្រះជាម្ចាស់មានចំពោះអ្នក នឹងជួយឲ្យអ្នកមើលឃើញបន្តិចម្ដងៗ ដូចជា ពេត្រុសចាប់ផ្ដើមស្គាល់ព្រះជាម្ចាស់៖ លោកបាននិយាយថា ព្រះជាម្ចាស់មិនត្រឹមតែមានប្រាជ្ញាញាណ បង្កើតនូវផ្ទៃមេឃ ផែនដី និងរបស់សព្វសារពើនោះទេ តែលើសពីនេះទៀត ទ្រង់ក៏មានប្រាជ្ញាញាណ ក្នុងការអនុវត្តកិច្ចការជាក់ស្ដែង ក្នុងមនុស្សផងដែរ។ ពេត្រុសបាននិយាយថា ទ្រង់មិនត្រឹមតែស័ក្ដិសមឲ្យមនុស្សស្រឡាញ់ ដោយព្រោះការដែលព្រះអង្គបង្កើតផ្ទៃមេឃ ផែនដី និងរបស់សព្វសារពើនោះទេ តែលើសពីនេះ គឺដោយព្រោះភាពវាងវៃក្នុងការបង្កើតមនុស្សលោក សង្គ្រោះមនុស្សលោក និងប្រោសឲ្យ មនុស្សលោកបានគ្រប់លក្ខណ៍ និងដើម្បីបន្សល់ទុកសេចក្ដីស្រឡាញ់ឲ្យពួកគេ។ ពេត្រុសបាននិយាយទៀតថា នៅក្នុងព្រះអង្គមានលក្ខណៈជាច្រើនដែលស័ក្ដិសមឲ្យ មនុស្សស្រឡាញ់។ ពេត្រុសទូលទៅព្រះយេស៊ូវថា «តើការបង្កើតផ្ទៃមេឃ ផែនដី និងរបស់សព្វសារពើ គឺជាហេតុផលតែមួយដែលធ្វើឲ្យទ្រង់ស័ក្ដិសមនឹងទទួលសេចក្ដីស្រឡាញ់ពីមនុស្សលោកមែនទេ? នៅក្នុងព្រះអង្គមានលក្ខណៈច្រើនទៀតដែលគួរឲ្យស្រឡាញ់។ ព្រះអង្គធ្វើការ និងមានចលនាក្នុងជីវិតជាក់ស្ដែង ព្រះវិញ្ញាណរបស់ទ្រង់ពាល់ទូលបង្គំពីខាងក្នុង ទ្រង់លត់ដំទូលបង្គំ ទ្រង់ទិតៀនទូលបង្គំ សេចក្ដីទាំងអស់នេះ រឹតតែសមឲ្យទ្រង់ទទួលនូវសេចក្ដីស្រឡាញ់ពីមនុស្សលោកថែមទៀតផង»។ ប្រសិនបើអ្នកចង់ឃើញ និងស្គាល់

សេចក្ដីស្រឡាញ់ព្រះជាម្ចាស់ នោះអ្នកត្រូវតែស្រាវជ្រាវ និងស្វែងរកក្នុងជីវិតជាក់ស្ដែង ហើយត្រូវព្រមលះបង់សាច់ឈាមរបស់ខ្លួនដោយឡែក។ អ្នកត្រូវតែធ្វើការតាំងចិត្ត បែបនេះ។ អ្នកត្រូវធ្វើជាមនុស្សម្នាក់ដែលមានការតាំងចិត្ត ជាមនុស្សដែលអាចផ្គាប់ព្រះហឫទ័យព្រះជាម្ចាស់ ក្នុងគ្រប់ការទាំងអស់ដោយមិនខ្ជិលច្រអូស ឬលោភនឹងការអាស្រ័យផលនៃសាច់ឈាម ក៏មិនរស់ដើម្បីសាច់ឈាម តែរស់ដើម្បីព្រះជាម្ចាស់។ ក៏មានពេលខ្លះ អ្នកក៏មិនបានផ្គាប់ព្រះហឫទ័យព្រះជាម្ចាស់បានដែរ។ មូលហេតុមកពីអ្នកមិនយល់ព្រះហឫទ័យទ្រង់ ដូច្នេះពេលក្រោយ អ្នកត្រូវផ្គាប់ព្រះហឫទ័យទ្រង់ឲ្យបាន មិនត្រូវផ្គាប់សាច់ឈាម ឡើយ ទោះបីជាត្រូវខំប្រឹងប្រែងជាងមុនក៏ដោយ។ កាលណាអ្នកមានបទពិសោធដូច្នេះហើយ អ្នកនឹងបានស្គាល់ ព្រះជាម្ចាស់។ អ្នកត្រូវតែមើលឃើញថា ព្រះជាម្ចាស់អាចបង្កើតផ្ទៃមេឃ ផែនដី និងរបស់សព្វសារពើ ឃើញថា ទ្រង់បានយកកំណើតជាសាច់ឈាម ដើម្បីឲ្យមនុស្សអាចនឹងមើលឃើញទ្រង់ ហើយមានចំណងទាក់ទងជាមួយទ្រង់យ៉ាងពិតប្រាកដ។ អ្នកនឹងមើលឃើញថាទ្រង់អាចដើរក្នុងចំណោមមនុស្សលោក ហើយឃើញថា ព្រះវិញ្ញាណរបស់ទ្រង់អាចប្រោសមនុស្សឲ្យបានគ្រប់លក្ខណ៍ នៅក្នុងជីវិតជាក់ស្ដែង ដោយអនុញ្ញាតិឲ្យពួកគេមើលឃើញនូវលក្ខណៈគួរឲ្យស្រឡាញ់របស់ទ្រង់ និងស្គាល់ការលត់ដំ ការវាយផ្ចាល និងស្គាល់ព្រះពររបស់ព្រះអង្គ។ ប្រសិនបើអ្នកមានបទពិសោធបែបនេះរហូត នោះអ្នកនឹងមិនអាចដាច់ចេញពីព្រះជាម្ចាស់ក្នុងជីវិតជាក់ស្ដែងបានឡើយ ហើយប្រសិនបើថ្ងៃមួយសម្ពន្ធភាពរបស់អ្នកជាមួយនឹងព្រះជាម្ចាស់លែងប្រក្រតី នោះអ្នកនឹងអាចរងនូវការស្ដីបន្ទោស និងមានវិប្បដិសារី។ នៅពេលដែលអ្នកមានសម្ពន្ធភាពប្រក្រតីមួយជាមួយព្រះជាម្ចាស់ នោះអ្នកនឹងមិនចង់ទៅឆ្ងាយពីព្រះជាម្ចាស់ទេ ហើយប្រសិនបើថ្ងៃមួយព្រះជាម្ចាស់មានបន្ទូលថា ទ្រង់នឹងទៅឆ្ងាយពីអ្នក នោះអ្នកនឹងភ័យខ្លាច រួចនិយាយថា អ្នកស៊ូស្លាប់ ប្រសើរជាងឲ្យព្រះជាម្ចាស់ចេញឆ្ងាយពីអ្នក។ កាលណាអ្នកមាន អារម្មណ៍បែបនេះ នោះអ្នកគិតថា អ្នកមិនអាចចាកចេញឆ្ងាយពីព្រះជាម្ចាស់ឡើយ អ្នកនឹងមានមូលដ្ឋានគ្រឹះមួយ ហើយអ្នកនឹងត្រេកអរសប្បាយនឹងសេចក្ដី

ស្រឡាញ់របស់ព្រះជាម្ចាស់ យ៉ាងពិតប្រាកដ តាមវិធីនេះ។

មនុស្សនិយាយអំពីការដែលគេយកព្រះជាម្ចាស់ ធ្វើជាជីវិតរបស់គេជារឿយៗ ប៉ុន្ដែបទពិសោធរបស់គេ គឺមិនទាន់ដល់ចំណុចនោះនៅឡើយទេ។ អ្នកគ្រាន់តែនិយាយថា ព្រះជាម្ចាស់ជាជីវិតអ្នក អ្នកនិយាយថា ព្រះអង្គដឹកនាំអ្នករាល់ថ្ងៃ ដោយអ្នកហូប និង ផឹកព្រះបន្ទូលរបស់ទ្រង់រាល់ថ្ងៃ ហេតុនេះ ទ្រង់បានក្លាយទៅជាជីវិតរបស់អ្នកហើយ។ ការចេះដឹងរបស់មនុស្សដែលនិយាយដូច្នេះ រាក់កំផែលណាស់។ មនុស្សជាច្រើន គ្មានមូលដ្ឋានគ្រឹះនៅក្នុងខ្លួនទេ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ត្រូវបានដាក់ដាំនៅក្នុងពួកគេ ប៉ុន្ដែព្រះបន្ទូលនោះមិនទាន់ដុះពន្លកឡើងទេ ក៏រឹតតែមិនទាន់កើតមានជាផលផ្លែផង។ បច្ចុប្បន្ននេះ តើអ្នកមានបទពិសោធដល់កម្រិតណាហើយ? ទើបតែពេលនេះ គឺបន្ទាប់ពីព្រះជាម្ចាស់បានជំរុញអ្នកមកដល់កម្រិតនេះ ទើបអ្នកមានអារម្មណ៍ថា អ្នកមិនអាចចាកចេញពីព្រះជាម្ចាស់រួច។ លុះថ្ងៃមួយ នៅពេលដែលបទពិសោធរបស់អ្នកបានឈានដល់ចំណុចជាក់លាក់មួយ ប្រសិនបើព្រះជាម្ចាស់បង្ខំឲ្យអ្នកចេញទៅឆ្ងាយ អ្នកច្បាស់ជាមិនអាចធ្វើបានឡើយ។ អ្នកនឹងគិតជានិច្ចថា អ្នកមិនអាចរស់ដោយគ្មានព្រះជាម្ចាស់សណ្ឋិតក្នុងអ្នកឡើយ។ អ្នកអាចរស់នៅដោយគ្មានប្ដី គ្មានប្រពន្ធ ឬកូន គ្មានគ្រួសារ គ្មានឪពុក ឬម្ដាយ គ្មានការអាស្រ័យផលផ្នែកសាច់ឈាម ប៉ុន្ដែអ្នកមិនអាចរស់ ដោយគ្មានព្រះជាម្ចាស់បានឡើយ។ ជីវិតរស់នៅដោយគ្មានព្រះជាម្ចាស់ ប្រៀបបានទៅនឹងការបាត់បង់ ជីវិតរបស់អ្នកដូច្នោះដែរ អ្នកច្បាស់ជាមិនអាចរស់ដោយគ្មានព្រះជាម្ចាស់ឡើយ។ កាលណាអ្នកមានបទពិសោធដល់ចំណុចនេះហើយ អ្នកនឹងសម្រេចគោលដៅ នៅក្នុងជំនឿរបស់អ្នកចំពោះព្រះជាម្ចាស់ ហើយតាមរយៈវិធីនេះ ព្រះជាម្ចាស់នឹងក្លាយជាជីវិតរបស់អ្នក គឺទ្រង់ក្លាយជាគ្រឹះនៃវត្តមានជីវិតរបស់អ្នក។ អ្នកនឹងមិនអាចចេញទៅឆ្ងាយ ពីព្រះជាម្ចាស់ឡើយ។ នៅពេលដែលអ្នកមានបទពិសោធដល់កម្រិតនេះ អ្នកនឹងអរសប្បាយនឹងសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់យ៉ាងពិតប្រាកដ ហើយពេលដែលអ្នកមានសម្ពន្ធភាពជិតស្និទនឹងព្រះជាម្ចាស់គ្រប់គ្រាន់ហើយ ព្រះអង្គនឹងក្លាយជាជីវិតរបស់អ្នក ជាក្ដីស្រឡាញ់របស់

អ្នក ហើយនៅពេលនោះ អ្នកនឹងអធិស្ឋានទៅព្រះអង្គ ហើយទូលថា៖ «ឱព្រះជាម្ចាស់អើយ! ទូលបង្គំមិនអាចចេញឆ្ងាយពីព្រះអង្គឡើយ។ ទ្រង់ជាជីវិតទូលបង្គំ។ ទូលបង្គំអាចបន្តរស់ដោយគ្មានអ្វីៗទាំងអស់បាន ប៉ុន្តែទូលបង្គំមិនអាចបន្តរស់ដោយគ្មានព្រះអង្គបានឡើយ»។ នេះជាស្ថានការណ៍ពិតរបស់មនុស្ស វាគឺជាជីវិតពិតរបស់គេ។ មនុស្សខ្លះធ្លាប់ត្រូវគេបង្ខំឲ្យឈានមកដល់ស្ថានការណ៍ជីវិតដែលគេមានសព្វថ្ងៃ៖ ពួកគេត្រូវបន្តទៅមុខ បើទោះជាពួកគេមិនចង់ក៏ដោយ ហើយពួកគេតែមានអារម្មណ៍ថា ពួកគេហាក់កំពុងនៅជាប់នឹងកន្លៀតថ្ម ឬកន្លែងដ៏លំបាកមួយ។ អ្នកត្រូវតែមានបទពិសោធដែលថា ព្រះជាម្ចាស់គឺជាជីវិតរបស់អ្នក បទពិសោធដែលថា ប្រសិនបើព្រះជាម្ចាស់ត្រូវដកចេញពីដួងចិត្តរបស់អ្នក ការនេះវាប្រៀបបានទៅនឹងការបាត់បង់ជីវិតរបស់អ្នក។ ព្រះជាម្ចាស់ត្រូវតែជាជីវិតរបស់អ្នក ហើយអ្នកច្បាស់ជាមិនអាចចេញឆ្ងាយពីទ្រង់ឡើយ។ តាមរយៈវិធីនេះ អ្នកនឹងមានបទពិសោធពិតពីព្រះជាម្ចាស់ ហើយនៅពេលនេះ ពេលដែលអ្នកស្រឡាញ់ព្រះជាម្ចាស់ គឺអ្នកនឹងស្រឡាញ់ទ្រង់ពិតប្រាកដ ហើយក្តីស្រឡាញ់នោះ ក៏ក្លាយជាក្តីស្រឡាញ់ដ៏បរិសុទ្ធអស្ចារ្យ។ ថ្ងៃមួយ នៅពេលដែលបទពិសោធរបស់អ្នកបង្ហាញថា ជីវិតរបស់អ្នកបានឈានដល់ចំណុចជាក់លាក់មួយ នៅពេលអ្នកអធិស្ឋានដល់ព្រះជាម្ចាស់ រួចហូប និងផឹកព្រះបន្ទូលព្រះជាម្ចាស់ នោះអ្នកនឹងមិនអាចទុកព្រះជាម្ចាស់ចោលនៅខាងក្នុងបានឡើយ ហើយអ្នកក៏មិនអាចបំភ្លេចទ្រង់បានដែរ ទោះបីជាអ្នកចង់ធ្វើបែបនេះក៏ដោយ។ ព្រះជាម្ចាស់នឹងក្លាយជាជីវិតរបស់អ្នក អ្នកអាចបំភ្លេចលោកិយចោល អ្នកអាចបំភ្លេចភរិយា ស្វាមី ឬកូនៗរបស់អ្នកបាន ប៉ុន្តែអ្នកនឹងពិបាកបំភ្លេចព្រះជាម្ចាស់ណាស់ ការធ្វើបែបនេះ គឺច្បាស់ជាមិនអាចទៅរួច នេះជាជីវិតពិត និងជាក្តីស្រឡាញ់ពិតដែលអ្នកមានចំពោះព្រះជាម្ចាស់។ កាលណាសេចក្តីស្រឡាញ់ដែលមនុស្សមានចំពោះព្រះជាម្ចាស់ បានឈានដល់ចំណុចមួយជាក់លាក់ នោះក្តីស្រឡាញ់ដែលគេមានចំពោះអ្វីៗដទៃទៀត គឺមិនអាចប្រៀបស្មើនឹងក្តីស្រឡាញ់របស់គេចំពោះព្រះជាម្ចាស់ឡើយ។ ក្តីស្រឡាញ់ដែលគេមានចំពោះព្រះជាម្ចាស់ គឺជាអាទិភាពទីមួយ។ តាមរយៈវិធីនេះ អ្នកអាច

លះបង់ចោលអ្វីៗផ្សេងគ្រប់យ៉ាង ហើយក៏ព្រមទទួលការដោះស្រាយ និងការលួសកាត់ពីសំណាក់ព្រះជាម្ចាស់ផង។ កាលណាអ្នកសម្រេចបានក្តីស្រឡាញ់ ដែលល្អលើសអ្វីៗទាំងអស់របស់ព្រះជាម្ចាស់ នោះអ្នកនឹងរស់ក្នុងតថភាព និងក្នុងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់បាន។

នៅពេលដែលព្រះជាម្ចាស់ ក្លាយជាជីវិតនៅក្នុងមនុស្សហើយ មនុស្សមិនអាចចេញឆ្ងាយពីព្រះជាម្ចាស់ឡើយ។ តើនេះមិនមែនជាទង្វើរបស់ព្រះជាម្ចាស់ទេឬអី? គ្មានទីបន្ទាល់ណាអស្ចារ្យជាងនេះទៀតទេ! ព្រះជាម្ចាស់បានធ្វើកិច្ចការ ដល់ចំណុចជាក់លាក់មួយហើយ ព្រះអង្គបានបង្គាប់ឲ្យមនុស្សធ្វើកិច្ចការបម្រើឲ្យគេត្រូវទទួលទោស ឬឲ្យគេស្លាប់ ហើយមនុស្សក៏មិនបានរាថយដែរ នេះគឺបង្ហាញថា ពួកគេត្រូវព្រះជាម្ចាស់យកឈ្នះហើយ។ មនុស្សដែលមានសេចក្តីពិតក្នុងបទពិសោធពិតរបស់គេ គឺជាមនុស្សដែលអាចឈរមាំនៅក្នុងទីបន្ទាល់របស់គេ អាចឈរមាំនៅក្នុងតួនាទីរបស់គេ អាចឈរនៅខាងព្រះជាម្ចាស់ដោយមិនរាថយ ហើយគឺជាមនុស្សដែលអាចមានសម្ពន្ធភាពសាមញ្ញមួយ ជាមួយនឹងមនុស្សដែលស្រឡាញ់ព្រះជាម្ចាស់ ជាមនុស្សដែលអាចស្តាប់បង្គាប់ព្រះជាម្ចាស់ទាំងស្រុង ពេលដែលមានរឿងរ៉ាវកើតឡើងចំពោះពួកគេ ហើយអាចស្តាប់បង្គាប់រហូតដល់ទីមរណាផង។ ការអនុវត្តរបស់អ្នក និងការបើកសម្តែង ក្នុងជីវិតជាក់ស្តែងរបស់អ្នក គឺជាទីបន្ទាល់របស់ព្រះជាម្ចាស់ សេចក្តីទាំងនេះគឺជាការរស់ជាទីបន្ទាល់ និងជាបន្ទាល់របស់ព្រះជាម្ចាស់ ហើយនេះជាការអាស្រ័យ ផលពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ដែរ។ នៅពេល អ្នកបានដកពិសោធន៍ដល់ចំណុចនេះហើយ ផលដែលនឹងត្រូវកើតមាន នឹងសម្រេចបាន។ អ្នកមានជីវិតជាទីបន្ទាល់ពិត ហើយគ្រប់ទាំងសកម្មភាពរបស់អ្នក នឹងត្រូវអ្នកដទៃមើលឃើញទាំងស្ញើចសរសើរ។ ការស្លៀកពាក់ និងកិរិយាខាងក្រៅរបស់អ្នក គ្មានអ្វីគួរឲ្យកត់សម្គាល់ទេ ប៉ុន្តែជីវិតរបស់អ្នកគឺជាការរស់ជាទីបន្ទាល់ពីការគោរពកោតខ្លាចព្រះជាទីបំផុត ហើយពេលដែលអ្នកផ្សាយព្រះបន្ទូលព្រះជាម្ចាស់ នោះអ្នកក៏ត្រូវដឹកនាំ និងស្រាយបំភ្លឺដោយព្រះអង្គ។ អ្នកអាចថ្លែងពីព្រះហឫទ័យ របស់ព្រះជាម្ចាស់

តាមរយៈពាក្យសម្ដីរបស់អ្នកអាចផ្សាយអំពី តថភាព ហើយអ្នកអាចយល់ច្រើនអំពីការបម្រើខាងឯវិញ្ញាណ។ អ្នកអាចនិយាយស្ដីដោយស្មោះត្រង់ អ្នកជាមនុស្សត្រឹមត្រូវ និងទៀងត្រង់ ចេះទុកមុខ ហើយថ្លៃថ្នូរ អ្នកអាចស្ដាប់តាមការចាត់ចែងរបស់ព្រះជាម្ចាស់ និងឈរមាំក្នុងទីបន្ទាល់របស់ខ្លួន នៅពេលដែលមានរឿងរ៉ាវកើតឡើងចំពោះអ្នក ហើយអ្នកក៏មានភាពនឹងធឹង និងស្រគត់ស្រគំ ទោះបីអ្នកកំពុងដោះស្រាយបញ្ហាអ្វីក៏ដោយ។ បុគ្គលបែបនេះ គឺពិតជាធ្លាប់បានឃើញសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់មែន។ មនុស្សខ្លះនៅវ័យក្មេង ប៉ុន្តែពួកគេប្រព្រឹត្តខ្លួនដូចជាមនុស្សវ័យកណ្ដាល ពួកគេមានភាពចាស់ទុំគេមានសេចក្ដីពិត ហើយមានគេស្ងើចសរសើរផង ហើយអ្នកទាំងអស់នេះ ជាមនុស្សដែលមានទីបន្ទាល់ និងជាទីសម្គាល់ពីព្រះជាម្ចាស់។ មានន័យថា ពេលដែលពួកគេមានបទពិសោធដល់ចំណុចមួយជាក់លាក់ នោះពួកគេនឹងមានការយល់ដឹងដ៏ជ្រាលជ្រៅចំពោះព្រះជាម្ចាស់ នៅក្នុងពួកគេ ហើយកិរិយាខាងក្រៅរបស់ពួកគេ នឹងបាននឹងធឹងទៀតផង។ មនុស្សជាច្រើន គេមិនយកសេចក្ដីពិតទៅអនុវត្ត ហើយក៏មិនឈរមាំនៅក្នុងទីបន្ទាល់របស់គេដែរ។ នៅក្នុងមនុស្សបែបនេះ គ្មានទេសេចក្ដីស្រឡាញ់សម្រាប់ព្រះជាម្ចាស់ ឬបន្ទាល់អំពីព្រះជាម្ចាស់ ហើយពួកគេទាំងអស់នេះ គឺជាមនុស្សដែលព្រះជាម្ចាស់ស្អប់ជាទីបំផុត។ ពួកគេអានព្រះបន្ទូលរបស់ព្រះជាម្ចាស់ក្នុងទីជំនុំ ប៉ុន្តែសាតាំងទើបជាទីបន្ទាល់ជីវិតរបស់គេវិញ ហើយនេះជាការបន្ទាបបន្ថោកព្រះជាម្ចាស់ ជាការបំពានព្រះជាម្ចាស់ និងជាការប្រមាថព្រះជាម្ចាស់។ នៅក្នុងមនុស្សជំពូកនេះ គ្មានទេទីសម្គាល់នៃសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ពួកគេគ្មានកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធទាល់តែសោះ ដូច្នេះ សម្ដី និងសកម្មភាពរបស់មនុស្ស សុទ្ធតែតំណាងឲ្យសាតាំង។ ប្រសិនបើដួងចិត្តរបស់អ្នកបានមេត្រីជានិច្ចនៅចំពោះព្រះភក្ត្រព្រះជាម្ចាស់ ហើយអ្នកក៏យកចិត្តទុកដាក់ចំពោះមនុស្ស និងរឿងរ៉ាវ ព្រមទាំងហេតុការណ៍ដែលកំពុងតែកើតឡើងជុំវិញខ្លួនឯងជាប់ជានិច្ច ហើយប្រសិនបើអ្នកចេះគិតដល់បន្ទុករបស់ព្រះជាម្ចាស់ និងមានចិត្តគោរពកោតខ្លាចដល់ទ្រង់ នោះព្រះអង្គនឹងស្រាយបំភ្លឺពីក្នុងចិត្តអ្នកជារឿយៗ។ នៅក្នុង

ពួកជំនុំ មានមនុស្សដែលជា «អ្នកត្រួតត្រា» ជាច្រើន៖ ពួកគេត្រៀមឃ្លាំមើលភាពកម្សោយរបស់អ្នកដទៃ បន្ទាប់មកក៏ចម្លង និងប្រព្រឹត្តតាមពួកគេ។ ពួកគេអសមត្ថភាពក្នុងការបែងចែកភាពខុសគ្នា ពួកគេមិនស្អប់អំពើបាប មិនខ្ពើមកិច្ចការរបស់សាតាំង ហើយនៅទីបំផុត ពួកគេនឹងត្រូវព្រះជាម្ចាស់បោះបង់ចោលទាំងស្រុង។ ដួងចិត្តរបស់អ្នកត្រូវតែជាដួងចិត្តដែលចេះគោរពកោតខ្លាច នៅចំពោះព្រះជាម្ចាស់ជានិច្ច ពាក្យសម្ដី និងសកម្មភាពរបស់អ្នក ក៏មិនត្រូវស្ទើរក្ដៅស្ទើរត្រជាក់ ហើយមិនត្រូវមានចិត្តចង់ប្រឆាំង ទាស់នឹងព្រះជាម្ចាស់ ឬធ្វើឲ្យទ្រង់ព្រួយព្រះទ័យឡើយ។ អ្នកមិនគប្បីព្រមឲ្យកិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងអ្នក ក្លាយជាអសារឥតការ ឬបណ្ដោយឲ្យការលំបាកដែលអ្នកបានស៊ូទ្រាំ និងគ្រប់យ៉ាងដែលអ្នកយកមកអនុវត្ត ទៅជាឥតប្រយោជន៍នោះឡើយ។ អ្នកត្រូវតែព្រមធ្វើការឲ្យខ្លាំងជាងមុន និងស្រឡាញ់ព្រះជាម្ចាស់ជាងមុននៅលើផ្លូវខាងមុខ។ មនុស្សទាំងនេះ គឺជាមនុស្សដែលមាននិមិត្តទុកជា មូលដ្ឋានគ្រឹះរបស់ពួកគេ។ ពួកគេគឺជាមនុស្សដែលស្វែងរកវឌ្ឍនភាព។

ប្រសិនបើមនុស្សជឿលើព្រះជាម្ចាស់ ហើយមានបទពិសោធពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយដួងចិត្តគោរពដល់ព្រះជាម្ចាស់ នោះសេចក្ដីសង្គ្រោះ និងសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ អាចនឹងឃើញមាននៅក្នុងមនុស្សបែបនេះ។ មនុស្សទាំងនេះអាចធ្វើបន្ទាល់ពីព្រះជាម្ចាស់បាន ពួកគេអាចរស់ជាទីបន្ទាល់ពីសេចក្ដីពិតពីលក្ខណៈ និងនិស្ស័យរបស់ព្រះជាម្ចាស់បាន។ ប្រសិនបើមនុស្សចង់ស្រឡាញ់ព្រះជាម្ចាស់ ពួកគេត្រូវតែបានភ្លក់ និងមើលឃើញលក្ខណៈដ៏គួរឲ្យស្រឡាញ់របស់ព្រះ។ ទាល់តែដល់ពេលនោះ ទើបដួងចិត្តដែលស្រឡាញ់ព្រះ ដួងចិត្តដែលជំរុញចិត្តអ្នកដទៃឲ្យថ្វាយខ្លួន ដោយភក្ដីភាពដល់ព្រះជាម្ចាស់ អាចត្រូវបណ្ដុះឡើងនៅក្នុងពួកគេ។ ព្រះជាម្ចាស់មិនបង្ខំមនុស្សលោក ឲ្យស្រឡាញ់ទ្រង់ដោយពាក្យសម្ដី និងការសម្ដែងទឹកមុខ ឬដោយការស្រមើស្រមៃរបស់ពួកគេឡើយ ហើយព្រះអង្គក៏មិនបង្ខំពួកគេឲ្យស្រឡាញ់ទ្រង់ដែរ។ ផ្ទុយទៅវិញ ទ្រង់ទុកឲ្យគេស្រឡាញ់ទ្រង់ដោយឆន្ទៈរបស់គេផ្ទាល់ ហើយទ្រង់ទុកឲ្យគេមើលឃើញពីលក្ខណៈគួរឲ្យស្រឡាញ់របស់

ទ្រង់ នៅក្នុងកិច្ចការ និងព្រះសូរសៀងទ្រង់វិញ បន្ទាប់មក ក៏មានការនឹកចាំពីសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់នៅក្នុងពួកគេ។ មានតែតាមវិធីនេះទេ ទើបមនុស្សអាចធ្វើជាបន្ទាល់ពីព្រះជាម្ចាស់យ៉ាងពិតប្រាកដបាន។ មនុស្សមិនស្រឡាញ់ព្រះជាម្ចាស់ ដោយសារតែអ្នកដទៃជំរុញឲ្យពួក គេធ្វើដូច្នេះ ហើយវាក៏មិនមែនជាសន្ទុះអារម្មណ៍តែមួយពេលនោះដែរ។ ពួកគេស្រឡាញ់ព្រះជាម្ចាស់ ដោយសារពួកគេបានឃើញពីលក្ខណៈគួរឲ្យស្រឡាញ់របស់ព្រះអង្គ ពួកគេបានឃើញថា ព្រះអង្គមានលក្ខណៈច្រើន ស័ក្ដិសមនឹងឲ្យមនុស្សស្រឡាញ់ ដោយសារពួកគេបានឃើញការសង្គ្រោះ ព្រះប្រាជ្ញាញាណ និងស្នាព្រះហស្ដដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ ហើយជាលទ្ធផល ពួកគេក៏ស្ញើចសរសើរ និងចង់បានព្រះជាម្ចាស់ពិតប្រាកដ ហើយក៏កើតមានចំណង់ចិត្ត ដែលធ្វើឲ្យគេមិនអាចរស់នៅដោយគ្មានព្រះជាម្ចាស់បាន។ ហេតុផលដែលមនុស្សដែលធ្វើបន្ទាល់ពិតពីព្រះជាម្ចាស់ អាចធ្វើបន្ទាល់ខ្ទរខ្ទារពីទ្រង់បាន គឺមកពីទីបន្ទាល់របស់ពួកគេចាក់គ្រឹះនៅលើការដឹងឮ និងការចង់បានព្រះជាម្ចាស់ពិតប្រាកដ។ ទីបន្ទាល់បែបនេះ មិនមែនត្រូវបានប្រទានមកស្របទៅនឹងសន្ទុះចិត្តឡើយ តែស្របទៅនឹងការស្គាល់ព្រះជាម្ចាស់ និងនិស្ស័យរបស់ទ្រង់វិញ។ ដោយសារតែពួកគេចាប់ផ្ដើមស្គាល់ព្រះជាម្ចាស់ ពួកគេគិតថា ពួកគេប្រាកដជាត្រូវធ្វើបន្ទាល់ពីព្រះអង្គ និងត្រូវធ្វើឲ្យពួកមនុស្សដែលចង់បានព្រះជាម្ចាស់ បានស្គាល់ទ្រង់ ហើយត្រូវដឹងពីលក្ខណៈគួរឲ្យស្រឡាញ់ និងភាពជាក់លាក់របស់ទ្រង់។ ទីបន្ទាល់របស់គេ កើតពីឆន្ទៈស្ម័គ្រចិត្ត ដូចគ្នានឹងសេចក្ដីស្រឡាញ់ដែលគេមានចំពោះព្រះជាម្ចាស់ដែរ។ ទីបន្ទាល់នេះ គឺជាទីបន្ទាល់ពិត ហើយមានសារៈសំខាន់ និងតម្លៃពិត។ ទីបន្ទាល់នេះ មិនមែនជាទីបន្ទាល់អសកម្ម ឬល្អតែខាងក្រៅ និងគ្មានន័យនោះទេ។ ហេតុផលមានតម្លៃ និងមានន័យបំផុត ដែលមានតែមនុស្សដែលពិតជាស្រឡាញ់ព្រះជាម្ចាស់ អាចមាននៅក្នុងជីវិតគេ ក៏ជាហេតុផលដែល ធ្វើឲ្យពួកគេជឿលើព្រះជាម្ចាស់ពិតប្រាកដ នោះគឺមនុស្សទាំងនេះ អាចរស់នៅក្នុងពន្លឺរបស់ព្រះជាម្ចាស់ ហើយអាចរស់នៅដើម្បីកិច្ចការ និងការគ្រប់គ្រងរបស់ព្រះអង្គបាន។ ដោយសារតែពួកគេរស់នៅក្នុងពន្លឺ មិនរស់នៅក្នុងសេចក្ដីងងឹត

ទើបពួកគេមិនរស់ក្នុងជីវិតឥតន័យ តែរស់ក្នុងជីវិតដែលប្រកបដោយព្រះពរដែលមកពីព្រះជាម្ចាស់វិញ។ មានតែមនុស្សដែលស្រឡាញ់ព្រះជាម្ចាស់ទេ ទើបអាចធ្វើបន្ទាល់អំពីព្រះជាម្ចាស់ មានតែពួកគេទេ ទើបជាស្មរបន្ទាល់របស់ព្រះជាម្ចាស់ មានតែពួកគេទេ ទើបអាចទទួលបានព្រះពរពីព្រះជាម្ចាស់ ហើយមានតែពួកគេទេ ទើបអាចទទួលនូវសេចក្តីសន្យារបស់ព្រះជាម្ចាស់។ មនុស្សដែលស្រឡាញ់ព្រះជាម្ចាស់ គឺជាមិត្តសម្លាញ់របស់ព្រះជាម្ចាស់ ពួកគេជាមនុស្សដែលព្រះជាម្ចាស់សព្វព្រះទ័យ ហើយពួកគេអាចអាស្រ័យផលនៃព្រះពរជាមួយគ្នានឹងព្រះជាម្ចាស់។ មានតែមនុស្សបែបនេះទេ ទើបរស់នៅអស់កល្បជានិច្ច ហើយមានតែពួកគេទេ ទើបអាចរស់នៅក្រោមការថែរក្សា និងការការពាររបស់ព្រះជាម្ចាស់បាន។ ព្រះជាម្ចាស់ គឺជាព្រះសម្រាប់ឲ្យមនុស្សស្រឡាញ់ ហើយទ្រង់ក៏ស័ក្តិសម នឹងឲ្យមនុស្សគ្រប់គ្នាស្រឡាញ់ ប៉ុន្តែមិនមែនមនុស្សគ្រប់គ្នាសុទ្ធតែអាចស្រឡាញ់ទ្រង់បាននោះទេ ហើយមិនមែនមនុស្សគ្រប់គ្នាសុទ្ធតែអាចធ្វើបន្ទាល់ពីព្រះជាម្ចាស់ ហើយទទួលព្រះចេស្តាជាមួយនឹងព្រះជាម្ចាស់ដែរ។ ពួកមនុស្សដែលស្រឡាញ់ព្រះជាម្ចាស់ពិតប្រាកដ គេអាចដើរគ្រប់ទីកន្លែងនៅក្រោមមេឃ ដោយគ្មាននរណាហ៊ានប្រឆាំងទាស់នឹងពួកគេឡើយ ហើយពួកគេពួកគេអាចប្រើអនុភាពនៅលើផែនដី ហើយគ្រប់គ្រងរាស្ត្រទាំងអស់របស់ព្រះជាម្ចាស់ ដោយសារពួកគេអាចធ្វើបន្ទាល់ពីព្រះជាម្ចាស់ និងអាចថ្វាយការប្រឹងប្រែងទាំងអស់របស់គេ សម្រាប់កិច្ចការរបស់ព្រះអង្គបាន។ មនុស្សទាំងនេះ មកជុំគ្នាពីគ្រប់ទីកន្លែង ក្នុងពិភពលោក។ ពួកគេនិយាយភាសាខុសៗគ្នា ហើយមានសម្បុរស្បែកខុសៗគ្នា តែវត្តមានជីវិតរបស់ពួកគេមានអត្ថន័យដូចៗគ្នា។ ពួកគេសុទ្ធតែមានដួងចិត្តដែលស្រឡាញ់ព្រះជាម្ចាស់ ពួកគេមានទីបន្ទាល់ដូចគ្នា និងមានការតាំងចិត្តដូចគ្នា ហើយមានសេចក្តីប្រាថ្នាដូចគ្នាផង។ មនុស្សដែលស្រឡាញ់ព្រះជាម្ចាស់ គេអាចដើរពេញពិភពលោកដោយសេរី ចំណែកឯមនុស្សដែលធ្វើបន្ទាល់ពីព្រះជាម្ចាស់ អាចធ្វើដំណើរទៅទូទាំងសកលលោកទៀតផង។ មនុស្សទាំងនេះ ជាមនុស្សដែលព្រះជាម្ចាស់សព្វព្រះហឫទ័យ ពួកគេទទួលបានព្រះពរពីព្រះជាម្ចាស់ ហើយពួកគេនឹងរស់នៅក្នុងពន្លឺរបស់ទ្រង់អស់កល្បជានិច្ច។

# កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ និងកិច្ចការរបស់សាតាំង

តើមនុស្សម្នាក់យល់ពីសេចក្ដីលម្អិតខាងឯវិញ្ញាណ បានដោយរបៀបណា? តើព្រះវិញ្ញាណបរិសុទ្ធ បំពេញកិច្ចការលើមនុស្សដោយរបៀបណា? តើសាតាំងធ្វើកិច្ចការលើមនុស្សដោយរបៀបណា? តើវិញ្ញាណអាក្រក់ធ្វើកិច្ចការលើមនុស្សដោយរបៀបណា? តើមានការសម្ដែងឲ្យឃើញអ្វីខ្លះ? នៅពេលមានអ្វីមួយកើតឡើងចំពោះអ្នក តើវាកើតចេញពីព្រះវិញ្ញាណបរិសុទ្ធមែនទេ ហើយតើអ្នកគួរស្ដាប់បង្គាប់តាម ឬបដិសេធវា? នៅក្នុងការអនុវត្តជាក់ស្ដែងរបស់មនុស្ស រឿងភាគច្រើនកើតចេញពីបំណងរបស់មនុស្ស ដែលមនុស្សជៀសមិនផុតពីជឿថាវាមកពីព្រះវិញ្ញាណបរិសុទ្ធ។ រឿងខ្លះកើតមកពីវិញ្ញាណអាក្រក់ ប៉ុន្ដែមនុស្សនៅតែគិតថា រឿងទាំងនោះកើតមកអំពីព្រះវិញ្ញាណបរិសុទ្ធ ហើយពេលខ្លះ ព្រះវិញ្ញាណបរិសុទ្ធជួយណែនាំមនុស្សពីខាងក្នុង ប៉ុន្ដែមនុស្សមានការភ័យខ្លាចថា ការណែនាំនោះមកអំពីសាតាំង ហេតុដូច្នេះហើយ ក៏មិនហ៊ានស្ដាប់បង្គាប់តាម នៅពេលការពិតនោះគឺ ការណែនាំនោះជាការបំភ្លឺពីព្រះវិញ្ញាណបរិសុទ្ធ។ ហេតុនេះ បើមនុស្សម្នាក់មិនអនុវត្តការបែងចែកភាពខុសគ្នាទេ នោះនឹងគ្មានផ្លូវណាដើម្បីដកពិសោធន៍ពីក្នុងបទពិសោធជាក់ស្ដែងរបស់មនុស្សឡើយ។ បើគ្មានការបែងចែកភាពខុសគ្នាទេ គ្មានផ្លូវណាដែលអាចទទួលបានជីវិតឡើយ។ តើព្រះវិញ្ញាណបរិសុទ្ធបំពេញកិច្ចការដោយរបៀបណា? តើវិញ្ញាណអាក្រក់ធ្វើការដោយរបៀបណា? តើមានអ្វីខ្លះដែលចេញមកពីបំណងរបស់មនុស្ស? ហើយតើមានអ្វីខ្លះដែលកើតចេញពីការណែនាំ និងការបំភ្លឺរបស់ព្រះវិញ្ញាណបរិសុទ្ធ? ប្រសិនបើអ្នកយល់ពីទម្រង់នៃកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធនៅខាងក្នុងខ្លួនមនុស្ស នោះនៅក្នុងជីវិតប្រចាំថ្ងៃរបស់អ្នក និងក្នុងអំឡុងបទពិសោធជាក់ស្ដែងរបស់អ្នក អ្នកនឹងអាចពង្រីកចំណេះដឹងរបស់ខ្លួនបាន និងអាចបែងចែកភាពខុសគ្នាបាន។ អ្នកនឹងមកស្គាល់ព្រះជាម្ចាស់ អ្នកនឹងអាចយល់ និងដឹងអំពីសាតាំង។ អ្នកនឹងឈប់ភ័ន្ដច្រឡំពីការស្ដាប់បង្គាប់ ឬការស្វែងរករបស់អ្នកទៀត ហើយអ្នកនឹងក្លាយជាមនុស្សម្នាក់ដែល

មានគំនិតច្បាស់លាស់ ជាមនុស្សដែលស្ដាប់បង្គាប់កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ។

កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ គឺជាទម្រង់មួយនៃការណែនាំយ៉ាងសកម្ម និងជាការបំភ្លឺបែបវិជ្ជមាន។ កិច្ចការនេះ មិនឲ្យមនុស្សក្លាយជាអកម្មឡើយ។ វានាំមកនូវការស្រាកស្រាន្តដល់ពួកគេ ផ្ដល់សេចក្ដីជំនឿ និងការតាំងចិត្តដល់ពួកគេ និងអាចឲ្យពួកគេស្វែងរក ការប្រោសឲ្យបានគ្រប់លក្ខណ៍ពីព្រះជាម្ចាស់។ នៅពេលដែលព្រះវិញ្ញាណបរិសុទ្ធបំពេញកិច្ចការ មនុស្សអាចចូលរួមបានដោយសកម្ម។ ពួកគេមិនមែនអកម្ម ឬក៏ត្រូវបង្ខំឡើយ តែត្រូវធ្វើការដោយគំនិតផ្ដួចផ្ដើមផ្ទាល់ខ្លួនរបស់ពួកគេ។ នៅពេលព្រះវិញ្ញាណបរិសុទ្ធបំពេញកិច្ចការ មនុស្សមានក្ដីត្រេកអរ និងសុខចិត្តស្ដាប់បង្គាប់តាម និងរីករាយនឹងបន្ទាបខ្លួនរបស់ពួកគេ។ បើទោះបីជាពួកគេមានការឈឺចាប់ និងប្រេះស្រាំក្នុងចិត្តក្ដី ក៏ពួកគេនៅតែមានការតាំងចិត្តដើម្បីពួតដៃគ្នាដែរ។ ពួកគេរងទុក្ខយ៉ាងខ្លាំង ពួកគេអាចស្ដាប់បង្គាប់តាម ហើយពួកគេមិនជាប់ប្រឡាក់ទៅដោយបំណងរបស់មនុស្សឡើយ មិនប្រឡាក់ទៅគំនិតរបស់មនុស្សឡើយ ហើយច្បាស់ណាស់ ពួកគេមិនជាប់ប្រឡាក់ទៅដោយចំណង់ និងការជំរុញចិត្តរបស់មនុស្សឡើយ។ នៅពេលមនុស្សជួបប្រទះបទពិសោធនៃកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ពួកគេមានលក្ខណៈបរិសុទ្ធជាពិសេសពីខាងក្នុង។ អ្នកណាដែលមានកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ស្ដែងចេញនូវសេចក្ដីស្រឡាញ់ចំពោះព្រះជាម្ចាស់ ហើយសេចក្ដីស្រឡាញ់ចំពោះបងប្អូនប្រុសស្រីរបស់ពួកគេ។ ពួកគេមានក្ដីរីករាយចំពោះអ្វីៗដែលធ្វើឲ្យព្រះជាម្ចាស់សប្បាយព្រះទ័យ និងស្អប់ខ្ពើម ចំពោះអ្វីដែលព្រះជាម្ចាស់ស្អប់ខ្ពើម។ មនុស្សដែលត្រូវបានបណ្ដាលចិត្តដោយកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធមានភាពជាមនុស្សធម្មតា ហើយពួកគេនៅបន្តស្វែងរកសេចក្ដីពិតឥតឈប់ និងមាននូវភាពជាមនុស្ស។ នៅពេលព្រះវិញ្ញាណបរិសុទ្ធបំពេញកិច្ចការក្នុងខ្លួនមនុស្ស ស្ថានភាពរបស់ពួកគេកាន់តែប្រសើរឡើងៗ ហើយភាពជាមនុស្សរបស់ពួកគេ កាន់តែធម្មតាទៅៗ ហើយទោះបីជាការពួតដៃគ្នារបស់ពួកគេមួយចំនួនអាចល្ងង់ខ្លៅខ្លះក៏ពិតមែន ក៏ការជំរុញចិត្តរបស់ពួកគេត្រឹមត្រូវ ច្រកចូលរបស់ពួកគេវិជ្ជមាន ពួកគេមិនបានព្យាយាម

បង្កការបង្អាក់អ្វីឡើយ ហើយនៅក្នុងខ្លួនពួកគេ គ្មានការព្យាបាទអ្វីឡើយ។ កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ គឺធម្មតា និងពិតប្រាកដ ហើយព្រះវិញ្ញាណបរិសុទ្ធបំពេញកិច្ចការលើមនុស្ស ស្របទៅតាមក្រឹត្យក្រមនៃជីវិតមនុស្សធម្មតា ហើយទ្រង់អនុវត្តការបំភ្លឺ និងការណែនាំនៅក្នុងខ្លួនមនុស្ស ស្របទៅតាមការស្វែងរកជាក់ស្ដែងរបស់មនុស្សធម្មតា។ នៅពេលព្រះវិញ្ញាណបរិសុទ្ធបំពេញកិច្ចការលើមនុស្ស ទ្រង់ណែនាំ និងបំភ្លឺពួកគេស្របទៅតាមតម្រូវការរបស់មនុស្សធម្មតា។ ទ្រង់ប្រទានដល់ពួកគេ ស្របទៅតាមតម្រូវការរបស់ពួកគេ ហើយទ្រង់ណែនាំ និងបំភ្លឺពួកគេដោយសកម្ម ស្របទៅតាមអ្វីដែលពួកគេខ្វះខាត និងស្របទៅតាមភាពខ្វះខាតរបស់ពួកគេ។ កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ គឺដើម្បីបំភ្លឺ និងណែនាំមនុស្សនៅក្នុងជីវិតជាក់ស្ដែង។ លុះត្រាណាតែពួកគេជួបប្រទះនូវព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅក្នុងជីវិតជាក់ស្ដែងរបស់ពួកគេ ទើបពួកគេអាចមើលឃើញ កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធបាន។ នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេ ប្រសិនបើមនុស្សស្ថិតក្នុងស្ថានភាពវិជ្ជមាន និងមានជីវិតខាងវិញ្ញាណធម្មតា នោះពួកគេនឹងមានកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ។ ក្នុងស្ថានភាពបែបនេះ នៅពេលដែលពួកគេហូប និងផឹកព្រះបន្ទូលរបស់ព្រះជាម្ចាស់ ពួកគេក៏មានសេចក្ដីជំនឿ។ នៅពេលពួកគេអធិស្ឋាន ពួកគេមានការបណ្ដាលចិត្ត។ នៅពេលពួកគេក្រោកឡើងប្រឆាំងនឹងអ្វីមួយ ពួកគេមិនអសកម្មឡើយ។ ហើយនៅពេលដែលមានអ្វីមួយកើតឡើង ពួកគេអាចមើលឃើញនូវមេរៀននានានៅក្នុងរឿងទាំងនោះបាន ដែលព្រះជាម្ចាស់តម្រូវឲ្យពួកគេរៀនសូត្រ។ ពួកគេមិនមែនអសកម្ម ឬទន់ខ្សោយឡើយ ហើយបើទោះបីជាពួកគេមានការលំបាកជាក់ស្ដែងក្ដី ក៏ពួកគេនឹងអាចស្ដាប់បង្គាប់តាមគ្រប់ការរៀបចំរបស់ព្រះជាម្ចាស់ដែរ។

តើកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ អាចសម្រេចបានឥទ្ធិពលអ្វីខ្លះ? អ្នកអាចល្ងង់ខ្លៅ ហើយអ្នកអាចខ្វះការយល់ដឹង ប៉ុន្តែព្រះវិញ្ញាណបរិសុទ្ធ គឺត្រូវបំពេញកិច្ចការឲ្យខានតែបាន ដូច្នេះហើយ នឹងមានសេចក្ដីជំនឿនៅក្នុងខ្លួនអ្នក ហើយអ្នកនឹងតែងមានអារម្មណ៍ថា អ្នកមិនអាចស្រឡាញ់ព្រះជាម្ចាស់បានគ្រប់គ្រាន់ជានិច្ច។ អ្នកនឹង

សុខចិត្តពួតដៃគ្នា មិនថាមានការលំបាកខ្លាំងប៉ុនណានៅខាងមុខនោះទេ។ នឹងកើតមានរឿងខ្លះចំពោះអ្នក ហើយអ្នកនឹងមិនច្បាស់ថា រឿងណាមកអំពីព្រះជាម្ចាស់ ឬរឿងណាមកអំពីសាតាំងឡើយ ប៉ុន្តែអ្នកអាចរង់ចាំមើលបាន ហើយអ្នកនឹងមិនអកម្ម ឬខ្ជិលខ្ជាឡើយ។ នេះគឺជាកិច្ចការធម្មតារបស់ព្រះវិញ្ញាណបរិសុទ្ធ។ នៅពេលដែលព្រះវិញ្ញាណបរិសុទ្ធធ្វើការនៅក្នុងខ្លួនអ្នក នោះអ្នកនឹងនៅតែជួបប្រទះការលំបាកជាក់ស្ដែងដដែល៖ ពេលខ្លះអ្នកនឹងត្រូវយំសោក ហើយពេលខ្លះនឹងមានរឿងមួយចំនួនដែលអ្នកមិនអាចយកឈ្នះបាន ប៉ុន្តែនេះគ្រាន់តែជាដំណាក់កាលនៃកិច្ចការធម្មតារបស់ព្រះវិញ្ញាណបរិសុទ្ធតែប៉ុណ្ណោះ។ បើទោះបីជាអ្នកមិនបានយកឈ្នះលើការលំបាកទាំងអស់នោះក្ដី ហើយបើទោះបីជានៅពេលនោះ អ្នកទន់ខ្សោយ និងពោរពេញដោយការរអ៊ូរទាំក្ដី ក៏ក្រោយមកទៀត អ្នកនឹងនៅតែអាចស្រឡាញ់ព្រះជាម្ចាស់ដោយសេចក្ដីជំនឿខ្លាំងក្លាដដែល។ ភាពអកម្មរបស់អ្នកមិនអាចរារាំងអ្នកពីការមានបទពិសោធធម្មតាបានឡើយ ហើយមិនថាអ្នកដទៃនិយាយបែបណានោះទេ មិនថាអ្នកដទៃវាយប្រហារអ្នកបែបណានោះទេ អ្នកនៅតែអាចស្រឡាញ់ព្រះជាម្ចាស់បានដដែល។ ក្នុងអំឡុងពេលអធិស្ឋាន អ្នកតែងមានអារម្មណ៍ថា អ្នកពិតជាជាប់ជំពាក់ព្រះជាម្ចាស់យ៉ាងខ្លាំងកាលពីអតីតកាល ហើយអ្នកតាំងចិត្តគាប់ព្រះហឫទ័យព្រះជាម្ចាស់ និងបដិសេធខាងសាច់ឈាម នៅពេលណាដែលអ្នកជួបប្រទះនូវរឿងបែបនោះជាថ្មីម្ដងទៀត។ កម្លាំងនេះបង្ហាញថា កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ គឺសណ្ឋិតនៅខាងក្នុងខ្លួនអ្នក។ នេះគឺជាលក្ខណៈធម្មតានៃកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ។

តើអ្វីទៅជាកិច្ចការដែលមកអំពីសាតាំង? ចំពោះកិច្ចការ ដែលមកអំពីសាតាំងនិមិត្តនៅក្នុងខ្លួនមនុស្ស គឺពេចស្រពិល។ មនុស្សគ្មានភាពជាមនុស្សធម្មតា ការជំរុញចិត្តពីខាងក្រោយទង្វើរបស់ពួកគេមិនត្រឹមត្រូវ ហើយបើទោះបីជាពួកគេចង់ស្រឡាញ់ព្រះជាម្ចាស់ ក៏តែងតែមានការចោទប្រកាន់នៅខាងក្នុងខ្លួនគេជានិច្ច ហើយការចោទប្រកាន់ និងគំនិតទាំងអស់នោះ មានការជ្រៀតជ្រែកនៅខាងក្នុងខ្លួនពួកគេឥតឈប់ ដោយរារាំងការធំធាត់នៅក្នុងជីវិតរបស់ពួកគេ និងរារាំងពួកគេមិនឲ្យមករ

កព្រះជាម្ចាស់ក្នុងស្ថានភាពធម្មតា។ នេះចង់និយាយថា ឲ្យតែមានកិច្ចការរបស់សាតាំងនៅខាងក្នុងខ្លួនមនុស្ស ដួងចិត្តរបស់គេ មិនអាចស្ងប់នៅចំពោះព្រះជាម្ចាស់បានឡើយ។ មនុស្សបែបនេះមិនដឹងថាពួកគេត្រូវធ្វើអ្វីចំពោះខ្លួនគេឡើយ គឺនៅពេលដែលពួកគេឃើញមនុស្សប្រមូលផ្ដុំគ្នាជុំៗ ពួកគេចង់រត់គេចចេញ ហើយពួកគេមិនអាចបិទភ្នែករបស់ពួកគេបានទេ នៅពេលអ្នកដទៃអធិស្ឋានបាន។ កិច្ចការរបស់វិញ្ញាណអាក្រក់ ធ្វើឲ្យទំនាក់ទំនងធម្មតារវាងមនុស្សនិងព្រះជាម្ចាស់ខូចបង់ និងធ្វើឲ្យនិមិត្តពីមុនរបស់មនុស្ស ឬធ្វើឲ្យផ្លូវនៃច្រកចូលទៅក្នុងជីវិតពីមុនរបស់ពួកគេប្រែជាស្រអាប់។ នៅក្នុងដួងចិត្តរបស់ពួកគេ ពួកគេមិនអាចស្និតនឹងព្រះជាម្ចាស់បានឡើយ ហើយរឿងជាច្រើនតែងកើតមានឡើង ដែលបង្កការរំខានចំពោះពួកគេ និងដាក់ច្រវាក់ពួកគេជាប់។ ដួងចិត្តរបស់ពួកគេ មិនអាចស្វែងរកសេចក្ដីស្ងប់បានឡើយ ហើយពួកគេគ្មានសល់កម្លាំងអ្វីដើម្បីស្រឡាញ់ព្រះជាម្ចាស់ឡើយ ហើយវិញ្ញាញរបស់ពួកគេបានលិចចុះទៅបាត់។ ទាំងអស់នោះ គឺជាការបង្ហាញនៃកិច្ចការរបស់សាតាំង។ ការបង្ហាញនៃកិច្ចការរបស់សាតាំង មានដូចជា៖ ការមិនអាចឈរនៅលើទីតាំងរបស់អ្នកបាន និងមិនអាចធ្វើទីបន្ទាល់បាន ដែលធ្វើឲ្យអ្នកក្លាយជាមនុស្សម្នាក់ដែលមានកំហុសនៅចំពោះព្រះជាម្ចាស់ និងជាអ្នកដែលគ្មានភាពស្មោះត្រង់ចំពោះព្រះជាម្ចាស់ឡើយ។ នៅពេលដែលសាតាំងជ្រៀតជ្រែក អ្នកនឹងបាត់បង់នូវសេចក្ដីស្រឡាញ់ និងភាពស្មោះត្រង់ចំពោះព្រះជាម្ចាស់នៅក្នុងខ្លួនអ្នក អ្នកនឹងត្រូវបាត់បង់ទំនាក់ទំនងធម្មតាជាមួយព្រះជាម្ចាស់ អ្នកមិនបន្តស្វែងរកសេចក្ដីពិត ឬការកែលម្អខ្លួនឯងឡើយ។ អ្នកដើរថយក្រោយ និងក្លាយជាអកម្ម អ្នកផ្ដេកផ្ដួលទៅតាមខ្លួនឯង អ្នកបើកដៃដល់ការផ្សាយអំពើបាប និងមិនស្អប់ខ្ពើមអំពើបាបឡើយ។ បន្ថែមលើនេះ ការជ្រៀតជ្រែករបស់សាតាំង ធ្វើឲ្យអ្នករលាយសាបសូន្យ។ វាធ្វើឲ្យការប៉ះពាល់ពីព្រះជាម្ចាស់ រលាយបាត់បង់ពីក្នុងខ្លួនអ្នក និងធ្វើឲ្យអ្នករអ៊ូរទាំអំពីព្រះជាម្ចាស់ និងទទឹងទាស់នឹងទ្រង់ ដែលនាំឲ្យអ្នកចោទសួរដល់ព្រះជាម្ចាស់។ ហើយក៏មាននូវលទ្ធភាពដែលអ្នកនឹងត្រូវបោះបង់ចោលព្រះជាម្ចាស់ផងដែរ។ អ្វីគ្រប់យ៉ាងនេះ មកអំពីសាតាំង។

នៅក្នុងជីវិតប្រចាំថ្ងៃរបស់អ្នក បើមានអ្វីមួយកើតឡើងចំពោះអ្នក តើអ្នកគប្បីបែងចែកភាពខុសគ្នារវាងថាតើវាមកអំពីកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ឬមកអំពីកិច្ចការរបស់សាតាំងដោយរបៀបណា? នៅពេលដែល ស្ថានភាពរបស់មនុស្សគឺធម្មតា នោះជីវិតខាងវិញ្ញាណរបស់ពួកគេ និងជីវិតខាងសាច់ឈាមរបស់ពួកគេក៏ធម្មតាដែរ ហើយហេតុផលរបស់ពួកគេក៏ធម្មតា និងមានរបៀបរៀបរយល្អដែរ។ នៅពេលដែលពួកគេនៅក្នុងស្ថានភាពបែបនេះ អ្វីដែលពួកគេជួបប្រទះ និងបានស្គាល់នៅក្នុងខ្លួនពួកគេ អាចនិយាយបានជាទូទៅថា មកអំពីការបណ្ដាលចិត្តដោយព្រះវិញ្ញាណបរិសុទ្ធ (មានការយល់ដឹងផ្ទះជ្រៅ ឬមានចំណេះដឹងធម្មតានៅពេលដែលពួកគេហូប និងផឹកព្រះបន្ទូលរបស់ព្រះជាម្ចាស់ ឬមានភាពស្មោះត្រង់ចំពោះអ្វីមួយ ឬចំពោះរឿងមួយចំនួន មានកម្លាំងស្រឡាញ់ព្រះជាម្ចាស់ ដែលអ្វីទាំងអស់នេះ មកអំពីព្រះវិញ្ញាណបរិសុទ្ធ)។ កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធនៅក្នុងខ្លួនមនុស្ស គឺធម្មតាខ្លាំងណាស់។ មនុស្សមិនអាចដឹងអំពីកិច្ចការនេះបានឡើយ ហើយកិច្ចការនេះ គឺហាក់ដូចជាមកតាមរយៈមនុស្សខ្លួនឯង បើទោះបីជាតាមពិតទៅ វាជាកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធក្ដី។ នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ ព្រះវិញ្ញាណបរិសុទ្ធ បំពេញកិច្ចការទាំងធំ ទាំងតូចជាមួយមនុស្សគ្រប់គ្នា ហើយអ្វីដែលខុសគ្នានោះ គឺគ្រាន់តែជាទំហំនៃកិច្ចការនេះប៉ុណ្ណោះ។ មនុស្សមួយចំនួនមានលក្ខណៈសម្បត្តិល្អ ហើយពួកគេយល់ដឹងពីរឿងរ៉ាវមួយចំនួនបានឆាប់រហ័ស ហើយនៅក្នុងចំណោមពួកគេ ការបំភ្លឺពីព្រះវិញ្ញាណបរិសុទ្ធគឺអស្ចារ្យយ៉ាងខ្លាំង។ ចំណែកឯមនុស្សមួយចំនួនទៀត មានគុណសម្បត្តិអន់ខ្សោយ ហើយពួកគេត្រូវការពេលយូរ ដើម្បីយល់ដឹងពីរឿងមួយចំនួនបាន ប៉ុន្តែព្រះវិញ្ញាណបរិសុទ្ធពាល់ពួកគេពីខាងក្នុង ហើយពួកគេក៏អាចសម្រេចបាននូវសេចក្ដីស្មោះត្រង់ចំពោះព្រះជាម្ចាស់វិញដែរគឺព្រះវិញ្ញាណបរិសុទ្ធបំពេញកិច្ចការនៅក្នុងចំណោមអ្នកទាំងឡាយណាដែលស្វែងរកព្រះជាម្ចាស់។ នៅក្នុងជីវិតប្រចាំថ្ងៃ នៅពេលដែលមនុស្សមិនទទឹងទាស់ ឬបះបោរប្រឆាំងនឹងព្រះជាម្ចាស់ មិនធ្វើរឿងដែលមិនស្របគ្នានឹងការគ្រប់គ្រងរបស់ព្រះជាម្ចាស់ និងមិនត្រូវជ្រៀតជ្រែកក្នុងកិច្ចការរបស់ព្រះជាម្ចាស់

នោះព្រះវិញ្ញាណបរិសុទ្ធនឹងបំពេញកិច្ចការច្រើន ឬតិចក្នុងចំណោមពួកគេម្នាក់ៗ។ ទ្រង់ពាល់ពួកគេ បំភ្លឺពួកគេ និងប្រទានសេចក្ដីជំនឿដល់ពួកគេ ប្រទានកម្លាំងដល់ពួកគេ និងផ្លាស់ពួកគេឲ្យមានភាពសកម្ម លែងខ្ជិលច្រអូស ឬលោភលន់នឹងការអរសប្បាយខាងសាច់ឈាម ដោយសុខចិត្តអនុវត្តតាមសេចក្ដីពិត និងស្រេកឃ្លានចង់បានព្រះបន្ទូលរបស់ព្រះជាម្ចាស់។ គ្រប់ការទាំងអស់នេះ គឺជាកិច្ចការដែលមកអំពីព្រះវិញ្ញាណបរិសុទ្ធ។

នៅពេលស្ថានភាពរបស់មនុស្សមិនធម្មតា ពួកគេត្រូវបានព្រះវិញ្ញាណបរិសុទ្ធបោះបង់ចោល។ នៅក្នុងដួងចិត្តរបស់ពួកគេ ពួកគេចូលចិត្តរអ៊ូរទាំ ការជំរុញចិត្តរបស់ពួកគេមិនត្រឹមត្រូវ ពួកគេខ្ជិលច្រអូស ពួកគេផ្ដេកផ្ដួលទៅខាងសាច់ឈាម ហើយដួងចិត្តរបស់ពួកគេបះបោរទាស់នឹងសេចក្ដីពិត។ អ្វីគ្រប់យ៉ាងនេះ គឺមកអំពីសាតាំង។ នៅពេលស្ថានភាពរបស់មនុស្សមិនធម្មតា នៅពេលពួកគេមានភាពងងឹតនៅខាងក្នុង និងបានវង្វេងក្នុងហេតុផលផ្ទាល់ខ្លួនរបស់ពួកគេ ដោយត្រូវព្រះវិញ្ញាណបរិសុទ្ធបោះបង់ចោល និងមិនអាចដឹងថាមានព្រះជាម្ចាស់នៅខាងក្នុងខ្លួនពួកគេ នេះគឺជាពេលដែលសាតាំងកំពុងធ្វើការ នៅក្នុងខ្លួនពួកគេហើយ។ ប្រសិនបើមនុស្សតែងតែមានកម្លាំងនៅក្នុងខ្លួនពួកគេ និងតែងមានសេចក្ដីស្រឡាញ់ចំពោះព្រះជាម្ចាស់ ជាទូទៅ នៅពេលរឿងរ៉ាវកើតមានចំពោះពួកគេ រឿងទាំងអស់នោះមកអំពីព្រះវិញ្ញាណបរិសុទ្ធ ហើយនរណាក៏ដោយដែលពួកគេជួប នោះការជួបគ្នានោះ គឺកើតចេញពីការរៀបចំរបស់ព្រះជាម្ចាស់។ នេះចង់បានន័យថា នៅពេលអ្នកស្ថិតនៅក្នុងស្ថានភាពធម្មតា នៅពេលដែលអ្នកស្ថិតនៅក្នុងកិច្ចការដ៏អស្ចារ្យរបស់ព្រះវិញ្ញាណបរិសុទ្ធ នោះមិនអាចឲ្យសាតាំងធ្វើឲ្យអ្នកចុះខ្សោយបានឡើយ។ នៅលើមូលដ្ឋាននេះ អាចនិយាយបានថា អ្វីគ្រប់យ៉ាងមកអំពីព្រះវិញ្ញាណបរិសុទ្ធ ហើយបើទោះបីជាអ្នកមានគំនិតមិនត្រឹមត្រូវក្ដី ក៏អ្នកអាចបដិសេធគំនិតនោះបាន ហើយអ្នកមិនដើរតាមគំនិតនោះឡើយ។ អ្វីគ្រប់យ៉ាងនេះ មកអំពីកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ។ តើសាតាំងជ្រៀតជ្រែកនៅក្នុងស្ថានភាពអ្វីខ្លះ? សាតាំងងាយនឹងធ្វើការនៅក្នុងខ្លួនអ្នក

ណាស់ នៅពេលស្ថានភាពរបស់អ្នកមិនធម្មតា នៅពេលអ្នកមិនត្រូវបានព្រះជាម្ចាស់ពាល់ និងគ្មានកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ នៅពេលខាងក្នុងខ្លួនអ្នកស្ងួតនិងសោះកក្រោះ នៅពេលអ្នកអធិស្ឋានចំពោះព្រះជាម្ចាស់ ប៉ុន្តែមិនយល់អ្វីសោះ ហើយនៅពេលអ្នកហូប និងផឹកព្រះបន្ទូលរបស់ព្រះជាម្ចាស់ ប៉ុន្តែមិនត្រូវបានបំភ្លឺ និងស្រាយបំភ្លឺ។ និយាយមួយបែបទៀត នៅពេលដែលព្រះវិញ្ញាណបរិសុទ្ធបោះបង់អ្នកចោល ហើយអ្នកគ្មានអារម្មណ៍ដឹងអំពីព្រះជាម្ចាស់ នោះរឿងដែលកើតឡើងចំពោះអ្នក មកអំពីសេចក្ដីល្បួងរបស់សាតាំង។ នៅពេលព្រះវិញ្ញាណបរិសុទ្ធបំពេញកិច្ចការ សាតាំងក៏កំពុងធ្វើការក្នុងពេលជាមួយគ្នានោះដែរ។ ព្រះវិញ្ញាណបរិសុទ្ធពាល់ពីខាងក្នុងនៃមនុស្ស ហើយពេលជាមួយគ្នានោះ សាតាំងក៏ជ្រៀតជ្រែកនៅខាងក្នុងខ្លួនអ្នកផងដែរ។ ក៏ប៉ុន្តែ កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ជាកិច្ចការឈានមុខគេ ហើយមនុស្សដែលមានស្ថានភាពធម្មតា អាចយកជ័យជម្នះបាន។ នេះគឺជាជ័យជម្នះនៃកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ លើកិច្ចការរបស់សាតាំង។ នៅពេលដែលព្រះវិញ្ញាណបរិសុទ្ធបំពេញនូវកិច្ចការ និស្ស័យពុករលួយនៅតែបន្តកើតមាននៅខាងក្នុងខ្លួនមនុស្សដដែល។ ប៉ុន្តែក្នុងអំឡុងពេលនៃកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធនេះ មនុស្សងាយនឹងរកឃើញ និងស្គាល់នូវការបះបោរ ការជំរុញចិត្ត និងសេចក្ដីកំផិតរបស់ពួកគេណាស់។ មានតែពេលនោះប៉ុណ្ណោះ ទើបមនុស្សមានអារម្មណ៍ស្ដាយក្រោយ និងដុះចេញនូវចេតនាក្នុងការប្រែចិត្ត។ ដោយបែបនេះ និស្ស័យបះបោរ និងនិស្ស័យពុករលួយរបស់ពួកគេ ចុងក្រោយនឹងត្រូវបំបាត់ចោលនៅខាងក្នុងកិច្ចការរបស់ព្រះជាម្ចាស់។ កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ គឺធម្មតាខ្លាំងណាស់។ នៅពេលទ្រង់បំពេញកិច្ចការលើមនុស្ស ពួកគេនៅតែបន្តមានបញ្ហាដដែល ពួកគេនៅតែទួញសោក ពួកគេនៅតែរងទុក្ខ ពួកគេនៅតែទន់ខ្សោយ ហើយមានរឿងជាច្រើនដែលពួកគេនៅតែមិនច្បាស់ដដែល ក៏ប៉ុន្តែនៅក្នុងស្ថានភាពនេះ ពួកគេអាចបញ្ឈប់ខ្លួនពួកគេពីការដើរថយក្រោយបាន ហើយពួកគេអាចស្រឡាញ់ព្រះជាម្ចាស់បាន ហើយបើទោះបីជាពួកគេទួញសោក និងមានទុក្ខព្រួយក្ដី ក៏ពួកគេនៅតែអាចសរសើរតម្កើងដល់ព្រះជាម្ចាស់បានដដែល។

កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ គឺធម្មតាណាស់ និងមិនហួសពីនិស្ស័យធម្មជាតិអ្វីឡើយ។ មនុស្សភាគច្រើនជឿថា ឲ្យតែព្រះវិញ្ញាណបរិសុទ្ធចាប់ផ្ដើមបំពេញកិច្ចការនោះការផ្លាស់ប្ដូរនឹងកើតមានឡើងចំពោះស្ថានភាពរបស់មនុស្ស ហើយរឿងដែលសំខាន់ចំពោះពួកគេ នឹងត្រូវកម្ចាត់ចេញ។ ជំនឿបែបនេះ គឺជាការបំភាន់បោកប្រាស់។ នៅពេលព្រះវិញ្ញាណបរិសុទ្ធបំពេញកិច្ចការលើមនុស្ស អ្វីដែលជាភាពអសកម្មរបស់មនុស្ស នៅតែមានដដែល ហើយកម្ពស់របស់ពួកគេ នៅដូចដើមដដែល ប៉ុន្តែគេទទួលបានការស្រាយបំភ្លឺ និងការបំភ្លឺពីព្រះវិញ្ញាណបរិសុទ្ធ ដូច្នេះហើយ ស្ថានភាពរបស់ពួកគេ ក្លាយជាសកម្មជាងមុន ស្ថានភាពនៅក្នុងខ្លួនពួកគេ ក្លាយជាធម្មតា ហើយគេផ្លាស់ប្ដូរបន្តិចម្ដងៗ។ នៅក្នុងបទពិសោធរបស់មនុស្ស ពួកគេមានបទពិសោធសំខាន់នៅក្នុងកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ឬកិច្ចការរបស់សាតាំង ហើយប្រសិនបើពួកគេមិនអាចយល់អំពីស្ថានភាពទាំងអស់នេះបានទេ និងមិនអាចបែងចែកភាពខុសគ្នានេះបានទេ នោះច្រកចូលទៅក្នុងបទពិសោធជាក់ស្ដែងរបស់ពួកគេ គឺហួសពីការអនុវត្តបាន ហើយមិនចាំបាច់អ្វីទៅនិយាយដល់ការបំផ្លាស់បំប្រែនិស្ស័យរបស់ពួកគេឡើយ។ ហេតុនេះ គន្លឹះដើម្បីដកបទពិសោធពីកិច្ចការរបស់ព្រះជាម្ចាស់ គឺការដែលអាចយល់បានតាមរយៈរឿងរ៉ាវបែបនេះ។ ក្នុងលក្ខណៈនេះ ពួកគេនឹងកាន់តែងាយស្រួលដកបទពិសោធពីកិច្ចការនេះ។

កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ គឺជាការចម្រើនទៅមុខដោយវិជ្ជមាន ចំណែកឯកិច្ចការរបស់សាតាំង គឺជាការថយក្រោយ ជាភាពអវិជ្ជមាន ជាការបះបោរ ជាការទទឹងទាស់នឹងព្រះជាម្ចាស់ ជាការបាត់សេចក្ដីជំនឿលើព្រះជាម្ចាស់ ជាការមិនអាចសូម្បីតែច្រៀងទំនុកតម្កើង និងជាការទន់ខ្សោយខ្លាំងក្នុងការបំពេញភារកិច្ចរបស់មនុស្សម្នាក់។ អ្វីគ្រប់យ៉ាងដែលកើតចេញពីការបំភ្លឺរបស់ព្រះវិញ្ញាណបរិសុទ្ធ គឺមានកើតមកដោយឯកឯង គ្មានការបង្ខិតបង្ខំចំពោះអ្នកឡើយ។ ប្រសិនបើអ្នកអនុវត្តតាមកិច្ចការនេះ នោះអ្នកនឹងមានសេចក្ដីសុខសាន្ត។ ប្រសិនបើអ្នកមិនអនុវត្តតាមទេ នោះអ្នកនឹងត្រូវស្ដីបន្ទោសនៅពេលក្រោយ។ បើមានការបំភ្លឺពីព្រះវិញ្ញាណបរិសុទ្ធ នោះ

គ្មានអ្វីដែលអ្នកធ្វើ នឹងត្រូវជ្រៀតជ្រែក ឬរឹតត្បិតឡើយ។ អ្នកនឹងត្រូវដោះលែងឲ្យមានសេរីភាព នឹងមានផ្លូវមួយដើម្បីអនុវត្តនូវទង្វើរបស់អ្នក ហើយអ្នកនឹងមិនត្រូវស្ថិតក្រោមការចាប់ចងណាមួយឡើយ ប៉ុន្តែអាចធ្វើការបានស្របតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ កិច្ចការរបស់សាតាំងធ្វើឲ្យអ្នកជ្រៀតជ្រែកនៅក្នុងរឿងជាច្រើន។ វាធ្វើឲ្យអ្នកមិនអាចអធិស្ឋានបាន ខ្ជិលច្រអូសខ្លាំងក្នុងការហូប និងផឹកព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងមិនសូវពេញចិត្តនឹងរស់នៅក្នុងជីវិតជាក្រុមជំនុំឡើយ ហើយវាធ្វើឲ្យអ្នកឃ្លាតចេញពីជីវិតខាងវិញ្ញាណ។ កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ពុំប៉ះពាល់ដល់ជីវិតរបស់ចាំថ្ងៃរបស់អ្នក និងពុំប៉ះពាល់ដល់ជីវិតខាងវិញ្ញាណធម្មតារបស់អ្នកឡើយ។ អ្នកមិនអាចយល់ដឹងពីរឿងរ៉ាវជាច្រើននៅពេលដែលវាកើតឡើងភ្លាមៗនោះទេ ប៉ុន្តែក្រោយពេលប៉ុន្មានថ្ងៃរួចមក ដួងចិត្តរបស់អ្នកនឹងបានភ្លឺត្រចះត្រចង់ ហើយគំនិតរបស់អ្នកនឹងច្បាស់ជាងមុន។ អ្នកមកជាមានការញាណដឹងអំពីរឿងរ៉ាវខាងវិញ្ញាណ ហើយអ្នកអាចយល់បានបន្តិចម្តងៗ ថាតើគំនិតនោះមកអំពីព្រះជាម្ចាស់ ឬមកអំពីសាតាំង។ រឿងខ្លះច្បាស់ជាធ្វើឲ្យអ្នកទទឹងទាស់នឹងព្រះជាម្ចាស់ និងបះបោរនឹងព្រះជាម្ចាស់ ឬរាំងអ្នកឲ្យអនុវត្តតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់។ អ្វីទាំងអស់នេះ សុទ្ធតែមកអំពីសាតាំង។ ពេលខ្លះ រឿងមិនច្បាស់ក្រឡែតនោះទេ ហើយអ្នកមិនអាចប្រាប់បានថារឿងនោះជារឿងអ្វីឡើយ។ ក្រោយមកទៀត អ្នកអាចមើលឃើញនូវការបង្ហាញនៃរឿងនោះ រួចក៏គិតឲ្យយល់។ ប្រសិនបើអ្នកអាចយល់ដឹងបានច្បាស់ថាតើរឿងណាមកអំពីសាតាំង និងថាតើរឿងណាដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធ នោះអ្នកនឹងមិនងាយនឹងត្រូវដឹកនាំក្នុងផ្លូវខុសតាមបទពិសោធរបស់អ្នកឡើយ។ ពេលខ្លះ នៅពេលស្ថានភាពរបស់អ្នកមិនល្អ នោះអ្នកមានគំនិតមួយចំនួនដែលនាំឲ្យអ្នកចេញពីស្ថានភាពអសកម្មរបស់អ្នកបាន។ នេះបង្ហាញថា បើទោះបីជាស្ថានភាពរបស់អ្នក មិនសមប្រកបក្តី គំនិតរបស់អ្នកខ្លះ នៅតែអាចមកអំពីព្រះវិញ្ញាណបរិសុទ្ធដដែល។ វាមិនមែនជាករណីថា នៅពេលដែលអ្នកអសកម្ម គំនិតទាំងអស់របស់អ្នក ត្រូវសាតាំងបញ្ជូនមកទេ។ ប្រសិនបើពិតអីចឹងមែន ដូច្នេះ តើអ្នកនឹងអាចផ្លាស់ប្តូរទៅក្នុងស្ថានភាពវិជ្ជមានបាន

ដែរឬទេ? ការដែលអកម្មក្នុងមួយរយៈពេល នោះព្រះវិញ្ញាណបរិសុទ្ធប្រទានឱកាសដល់អ្នកដើម្បីប្រោសឲ្យបានគ្រប់លក្ខណ៍។ ទ្រង់ពាល់អ្នក និងនាំអ្នកចេញពីស្ថានភាពអសកម្មរបស់អ្នក។

បើដឹងថាអ្វីជាកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ និងអ្វីជាកិច្ចការរបស់សាតាំង នោះអ្នកអាចប្រៀបធៀបកិច្ចការនេះបានដោយខ្លួនឯង ក្នុងអំឡុងពេលនៃបទពិសោធរបស់អ្នក និងតាមរយៈបទពិសោធផ្ទាល់ខ្លួនរបស់អ្នក ហើយក្នុងលក្ខណៈបែបនេះ នឹងមានសេចក្ដីពិតកាន់តែច្រើនដែលពាក់ព័ន្ធនឹងគោលការណ៍នៅក្នុងបទពិសោធរបស់អ្នក។ បើអាចយល់ពីសេចក្ដីពិតនៃគោលការណ៍នេះបាន អ្នកនឹងអាចគ្រប់គ្រងលើស្ថានភាពជាក់ស្ដែងរបស់អ្នកបាន អ្នកនឹងអាចបែងចែកភាពខុសគ្នាក្នុងចំណោមមនុស្ស និងព្រឹត្តិការណ៍បាន ហើយអ្នកនឹងមិនលះបង់អ្វីច្រើនដើម្បីទទួលបានកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធឡើយ។ ជាការពិតណាស់ នេះគឺអាស្រ័យលើការជំរុញចិត្តរបស់អ្នកដែលត្រឹមត្រូវ និងអាស្រ័យលើឆន្ទៈរបស់អ្នកក្នុងការស្វែងរក និងអនុវត្ត។ ភាសាបែបនេះ (ភាសាដែលពាក់ព័ន្ធនឹងគោលការណ៍) គប្បីបង្ហាញពីបទពិសោធរបស់អ្នក។ បើគ្មានភាសានេះទេ បទពិសោធរបស់អ្នក នឹងពោរពេញទៅដោយការជ្រៀតជ្រែកពីសាតាំង និងពោរពេញទៅដោយចំណេះដឹងឆ្កួតលីលា។ ប្រសិនបើអ្នកមិនយល់ថាព្រះវិញ្ញាណបរិសុទ្ធបំពេញកិច្ចការដោយបែបណានោះទេ នោះអ្នកមិនយល់ថាតើអ្នកត្រូវចូលទៅដោយរបៀបណាឡើយ ហើយប្រសិនបើអ្នកមិនយល់ថាតើសាតាំងធ្វើការដោយបែបណានោះ នោះអ្នកមិនយល់ថាតើអ្នកត្រូវប្រុងប្រយ័ត្ននៅគ្រប់ជំហានដែលអ្នកត្រូវដើរដោយរបៀបណានោះទេ។ មនុស្សគប្បីយល់ពីរបៀបដែលព្រះវិញ្ញាណបរិសុទ្ធបំពេញកិច្ចការផង និងយល់អំពីរបៀបដែលសាតាំងធ្វើការផង។ កិច្ចការទាំងពីរនេះ គឺជាផ្នែកដ៏សំខាន់នៃបទពិសោធរបស់មនុស្ស។

# ការព្រមានដល់អស់អ្នកដែលមិនអនុវត្តនូវសេចក្ដីពិត

អស់អ្នកនៅក្នុងចំណោមបងប្អូនប្រុសស្រីដែលតែងតែបង្ហាញនូវភាពអវិជ្ជមានរបស់ខ្លួន គឺជាកញ្ជះរបស់សាតាំង ហើយពួកគេរំខានដល់ពួកជំនុំ។ មនុស្សបែបនេះនឹងត្រូវបណ្ដេញ និងផាត់ចោលនៅថ្ងៃណាមួយជាមិនខាន។ នៅក្នុងជំនឿរបស់ពួកគេលើព្រះជាម្ចាស់ ប្រសិនបើមនុស្សមិនមានដួងចិត្តគោរពចំពោះព្រះជាម្ចាស់ ប្រសិនបើពួកគេមិនមានដួងចិត្តនៃការស្ដាប់បង្គាប់ចំពោះព្រះជាម្ចាស់នោះទេ នោះពួកគេមិនត្រឹមតែមិនអាចធ្វើកិច្ចការណាមួយសម្រាប់ទ្រង់ប៉ុណ្ណោះទេ តែផ្ទុយទៅវិញ ពួកគេនឹងក្លាយជាអ្នកដែលរំខានដល់កិច្ចការរបស់ទ្រង់ ហើយជាអ្នកដែលបំពានលើទ្រង់។ ការជឿលើព្រះជាម្ចាស់តែមិនស្ដាប់បង្គាប់ ឬគោរពចំពោះទ្រង់ ហើយបែរជាទាស់ប្រឆាំងនឹងទ្រង់ទៅវិញ នោះគឺជាការបង្ខូចព្រះកិត្តិនាមយ៉ាងខ្លាំងចំពោះអ្នកជឿ។ ប្រសិនបើអ្នកជឿទាំងឡាយ គ្រាន់តែជាមនុស្សធម្មតា និងមិនចេះទប់ការនិយាយរបស់ខ្លួន ហើយប្រព្រឹត្តដូចជាអ្នកមិនជឿ នោះពួកគេគឺអាក្រក់ជាងអ្នកមិនជឿទៅទៀត។ ពួកគេគឺជាអារក្សពីបុរាណ។ អស់អ្នកដែលបញ្ចេញសម្ដីពិសពុល និងរបិលរប៉ូចនៅក្នុងក្រុមជំនុំ ជាអ្នកផ្សាយពាក្យចចាមអារាម បង្កជាភាពមិនចុះសម្រុងគ្នា និងបង្កជាបក្សពួកមនុស្សខូចក្នុងចំណោមបងប្អូនប្រុសស្រី គឺពួកគេគួរត្រូវបណ្ដេញចេញពីក្រុមជំនុំ។ ប៉ុន្តែដោយសារតែឡូវនេះជាយុគសម័យនៃកិច្ចការរបស់ព្រះជាម្ចាស់ដែលខុសពីមុន មនុស្សទាំងនេះត្រូវបានដាក់កម្រិត ដ្បិតពួកគេប្រឈមមុខនឹងការផាត់ចោលយ៉ាងជាក់។ អស់អ្នកដែលត្រូវបានធ្វើឲ្យពុករលួយដោយសាតាំង គឺមាននិស្ស័យពុករលួយ។ អ្នកខ្លះមិនមានអ្វីក្រៅពីនិស្ស័យពុករលួយឡើយ ខណៈពេលដែលអ្នកខ្លះទៀតមានភាពខុសប្លែកគ្នា៖ ពួកគេមិនត្រឹមតែមាននិស្ស័យរបស់សាតាំងដែលពុករលួយប៉ុណ្ណោះទេ ប៉ុន្តែធម្មជាតិរបស់ពួកគេក៏មានលក្ខណៈព្យាបាទផងដែរ។ មិនត្រឹមតែពាក្យសម្ដី និងសកម្មភាពរបស់ពួកគេ បង្ហាញពីការពុករលួយ និងនិស្ស័យសាតាំងរបស់ពួកគេប៉ុណ្ណោះទេ លើសពីនេះទៅទៀត មនុស្សទាំងនេះជាអារក្សសាតាំងដ៏ពិតប្រាកដ។ ឥរិយាបថរបស់ពួកគេ

កាត់ផ្ដាច់ និងរំខានដល់កិច្ចការរបស់ព្រះជាម្ចាស់ វារារាំងដល់ការចូលរបស់បងប្អូនប្រុសស្រីទៅក្នុងជីវិត ហើយវាធ្វើឲ្យខូចខាតដល់ជីវិតធម្មតារបស់ពួកជំនុំ។ មិនយូរមិនឆាប់ ចចកដែលពាក់រោមចៀមទាំងនេះ នឹងត្រូវបានកំចាត់ចោល។ អាកប្បកិរិយាដែលឥតមេត្តា និងអាកប្បកិរិយាដែលបដិសេធ គួរត្រូវបានទទួលយកដោយកញ្ចុះរបស់សាតាំងទាំងនេះ។ មានតែការធ្វើដូច្នេះទេ ទើបអាចឈរនៅខាងព្រះជាម្ចាស់បាន ហើយអស់អ្នកដែលខកខានមិនបានធ្វើដូច្នេះ គឺនឹងផុងទៅយ៉ាងជ្រៅជាមួយសាតាំង។ មនុស្សដែលជឿលើព្រះជាម្ចាស់ដ៏ពិតប្រាកដ តែងតែមានទ្រង់នៅក្នុងដួងចិត្តរបស់ខ្លួនជានិច្ច ហើយពួកគេតែងតែផ្ទុកនៅក្នុងខ្លួនគេនូវដួងចិត្តដែលគោរពដល់ព្រះជាម្ចាស់ និងដួងចិត្តដែលស្រឡាញ់ដល់ព្រះជាម្ចាស់។ អស់អ្នកដែលជឿលើព្រះជាម្ចាស់ គប្បីធ្វើអ្វីៗដោយប្រយ័ត្នប្រយែង និងដោយប្រុងប្រយ័ត្ន ហើយគ្រប់អ្វីដែលពួកគេធ្វើ គប្បីស្របតាមសេចក្ដីតម្រូវរបស់ព្រះជាម្ចាស់ ហើយអាចផ្គាប់ព្រះហឫទ័យរបស់ទ្រង់បាន។ ពួកគេមិនគួររឹងចចេស និងធ្វើអ្វីដែលពួកគេពេញចិត្ត ដែលមិនសមនឹងបែបបទរបស់ពួកបរិសុទ្ធឡើយ។ មនុស្សមិនត្រូវប្រព្រឹត្តអ្វីដែលមិនសមរម្យ លើកព្រះនាមព្រះជាម្ចាស់គ្រប់ទីកន្លែងដោយភាពក្រអឺតក្រទម និងបោកប្រាស់គ្រប់ទីកន្លែងនោះឡើយ។ នេះគឺជាប្រភេទនៃការប្រព្រឹត្តិដែលបះបោរខ្លាំងបំផុត។ គ្រួសារមានច្បាប់ទម្លាប់របស់ខ្លួន ហើយប្រជាជាតិនានាមានច្បាប់របស់ខ្លួន ហើយតើនៅក្នុងដំណាក់របស់ព្រះជាម្ចាស់មិនមានច្បាប់ទម្លាប់ច្រើនជាងនេះទេឬអី? តើបទដ្ឋានទាំងនោះមិនតឹងរ៉ឹងជាងនេះទេឬអី? តើមិនមានបញ្ញត្តិរដ្ឋបាលច្រើនជាងនេះទេឬអី? មនុស្សមានសេរីភាពធ្វើអ្វីដែលពួកគេចង់ធ្វើ ប៉ុន្តែបញ្ញត្តិរដ្ឋបាលរបស់ព្រះជាម្ចាស់មិនអាចធ្វើការផ្លាស់ប្ដូរតាមតែចិត្តនោះឡើយ។ ព្រះជាម្ចាស់គឺជាព្រះដែលមិនអត់ឱនចំពោះការប្រព្រឹត្តខុសរបស់មនុស្សឡើយ ទ្រង់គឺជាព្រះជាម្ចាស់ដែលប្រហារជីវិតមនុស្ស។ តើមនុស្សពិតជាមិនបានដឹងពីរឿងនេះហើយទេឬ?

គ្រប់ក្រុមជំនុំទាំងអស់ សុទ្ធតែមានមនុស្សដែលបង្កបញ្ហាដល់ក្រុមជំនុំ ឬជ្រៀតជ្រែកក្នុងកិច្ចការរបស់ព្រះជាម្ចាស់។ ពួកគេទាំងអស់ជាសាតាំង ដែលបានបន្លំខ្លួន

ជ្រៀតចូលក្នុងដំណាក់របស់ព្រះជាម្ចាស់។ មនុស្សបែបនេះ ពូកែសំដែងណាស់៖ ពួកគេមកនៅចំពោះខ្ញុំដោយការគោរពដ៏ខ្ពង់ខ្ពស់ ដោយឱនក្រាបថ្វាយបង្គំ រស់នៅដូចឆ្កែអង្វែស៊ី និងលះបង់ «អ្វីៗទាំងអស់» របស់ពួកគេ ដើម្បីសម្រេចគោលបំណងផ្ទាល់ខ្លួនរបស់ពួកគេ ប៉ុន្ដែនៅចំពោះមុខបងប្អូនប្រុសស្រី ពួកគេបង្ហាញផ្នែកអាក្រក់របស់ពួកគេ។ នៅពេលពួកគេឃើញមនុស្សដែលអនុវត្តនូវសេចក្ដីពិត ពួកគេវាយវាយប្រហារមនុស្សទាំងនោះ ហើយដាក់មនុស្សទាំងនោះមួយឡែក។ នៅពេលដែលពួកគេឃើញមនុស្សដែលអស្ចារ្យជាងខ្លួន ពួកគេបញ្ចើចបញ្ចើ និងលែបខាយចំពោះមនុស្សទាំងនោះ។ ពួកគេធ្វើអ្វីតាមចិត្តនៅក្នុងក្រុមជំនុំ។ អាចនិយាយបានថា «មនុស្សរករឿងគេក្នុងក្រុមជំនុំ» បែបនេះ និង «មនុស្សចាំតែធ្វើតាមគេប្រាប់» បែបនេះ មាននៅក្នុងក្រុមជំនុំភាគច្រើន។ ពួកគេដើរចុះឡើងជាមួយគ្នា ព្រិចភ្នែក និងឲ្យសញ្ញាសម្ងាត់គ្នាទៅវិញទៅមក ហើយគ្មាននរណាម្នាក់ក្នុងចំណោមពួកគេអនុវត្តនូវសេចក្ដីពិតទេ។ អ្នកណាដែលពិសពុលខ្លាំងជាងគេ គឺជា «មេអារក្ស» ហើយអ្នកណាមានកិត្យានុភាពខ្ពស់បំផុតនឹងដឹកនាំពួកគេ ដោយលើកទង់របស់គេខ្ពស់ឡើង។ មនុស្សទាំងនេះទាស់ទែងគ្នានៅក្នុងក្រុមជំនុំ ដោយផ្សាយពីភាពអវិជ្ជមានរបស់ពួកគេ បង្ហាញពីការស្លាប់ ធ្វើអ្វីតាមដែលពួកគេពេញចិត្ត និយាយតាមដែលពួកគេពេញចិត្ត ហើយគ្មាននរណាម្នាក់ហ៊ានបញ្ឈប់ពួកគេទេ។ ពួកគេពោរពេញទៅដោយនិស្ស័យរបស់សាតាំង។ មិនយូរប៉ុន្មាន ពួកគេបណ្ដាលឲ្យមានការរំខានជាងខ្យល់នៃសេចក្ដីស្លាប់ចូលក្រុមជំនុំទៅទៀត។ អស់អ្នកដែលនៅក្នុងក្រុមជំនុំ ដែលអនុវត្តនូវសេចក្ដីពិត ត្រូវបានបណ្ដេញចេញ មិនអាចធ្វើអ្វីបានទាំងអស់ ខណៈអ្នកដែលរំខានដល់ពួកជំនុំ ហើយលាតត្រដាងពីសេចក្ដីស្លាប់ដោយភាពក្រេវក្រោធ ហើយមានច្រើនទៀត បែរជាមានមនុស្សភាគច្រើនដើរតាមពួកគេទៅវិញ។ ជាការពិត ពួកជំនុំបែបនេះគ្រប់គ្រងដោយសាតាំង ហើយអារក្សគឺជាស្ដេចរបស់ពួកគេ។ ប្រសិនបើពួកជំនុំមិនក្រោកឡើង ហើយបដិសេធនឹងមេអារក្សនោះទេ នោះពួកគេមិនយូរមិនឆាប់នឹងត្រូវវិនាសអន្ដរាយដែរ។ ចាប់ពីពេលនេះទៅ ចំណាត់ការត្រូវធ្វើឡើងទាស់ប្រឆាំង

នឹងពួកជំនុំបែបនេះ។ ប្រសិនបើអស់អ្នកដែលមានសមត្ថភាព តែមិនអនុវត្តស្វែងរកនូវសេចក្ដីពិតបន្តិចបន្តួចនោះទេ ពេលនោះពួកជំនុំនោះនឹងត្រូវបណ្ដេញចេញ។ ប្រសិនបើពួកជំនុំមិនមាននរណាម្នាក់ដែលមានឆន្ទៈអនុវត្តនូវសេចក្ដីពិត ហើយគ្មាននរណាម្នាក់ដែលអាចធ្វើបន្ទាល់សម្រាប់ព្រះជាម្ចាស់បានទេ នោះពួកជំនុំនោះគប្បីនៅដាច់ឆ្ងាយពីគេទាំងស្រុង ហើយទំនាក់ទំនងរបស់ពួកជំនុំនោះជាមួយពួកជំនុំផ្សេងទៀត ត្រូវតែកាត់ផ្ដាច់។ នេះគេហៅថា «ការបញ្ចុះសព»។ នេះជាអត្ថន័យនៃការបណ្ដេញអារក្សចេញ។ ប្រសិនបើពួកជំនុំមួយ មានក្រុមមនុស្សរករឿងគេច្រើន ហើយពួកគេត្រូវបានដើរតាមដោយ «ពួកពលបរិវារ» ដែលខ្វះនូវយោបល់ទាំងស្រុង ហើយប្រសិនបើពួកជំនុំដែលសូម្បីតែបន្ទាប់ពីបានឃើញនូវសេចក្ដីពិតហើយ នៅតែមិនអាចបដិសេធបានចំពោះការចងភ្ជាប់ និងឧបាយកលនៃក្រុមមនុស្សដែលរករឿងទាំងនេះបានទេ នោះមនុស្សល្ងីល្ងើទាំងអស់នោះ នឹងត្រូវផាត់ចោលនៅទីបំផុត។ ពួកពលបរិវារទាំងនេះប្រហែលជាមិនបានធ្វើអ្វីមួយដែលអាក្រក់នោះទេ ប៉ុន្តែពួកគេកាន់តែមានភាពបោកបញ្ឆោត កាន់តែវង្វេង ហើយមនុស្សគ្រប់រូបដែលបែបនេះនឹងត្រូវផាត់ចោល។ មិនមាននរណាម្នាក់ឡើយដែលនឹងនៅសល់! អស់អ្នកដែលជាកម្មសិទ្ធិរបស់សាតាំងនឹងត្រូវត្រឡប់ទៅសាតាំងវិញ រីឯអស់អ្នកដែលជារបស់ព្រះជាម្ចាស់ប្រាកដជាស្វែងរកនូវសេចក្ដីពិត។ ការនេះ គឺសម្រេចដោយធម្មជាតិរបស់ពួកគេ។ អស់អ្នកដែលដើរតាមសាតាំងទាំងអស់នឹងត្រូវវិនាស! គ្មានការអាណិតអាសូរណានឹងត្រូវបានបង្ហាញដល់មនុស្សបែបនេះឡើយ។ ចូរឲ្យអ្នកដែលស្វែងរកសេចក្ដីពិតនឹងត្រូវបានប្រទានឲ្យ ហើយចូរឲ្យពួកគេអាចរីករាយនឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅក្នុងដួងចិត្តដែលស្ដាប់របស់ពួកគេ។ ព្រះជាម្ចាស់ទ្រង់សុចរិត។ ទ្រង់នឹងមិនបង្ហាញការសព្វព្រះទ័យដោយលំអៀង ចំពោះនរណាម្នាក់ឡើយ។ ប្រសិនបើអ្នកជាអារក្ស នោះអ្នកមិនអាចអនុវត្តនូវសេចក្ដីពិតបានឡើយ។ ប្រសិនបើអ្នកជាមនុស្សម្នាក់ដែលស្វែងរកសេចក្ដីពិត នោះវាប្រាកដច្បាស់ថា អ្នកនឹងមិនត្រូវបានចាប់ជាឈ្លើយដោយសាតាំងឡើយ។ ការនេះគឺហួសពីការសង្ស័យទាំងអស់។

មនុស្សដែលមិនខិតខំប្រឹងប្រែងដើម្បីមានការលូតលាស់ តែងតែប្រាថ្នាឲ្យអ្នកដទៃមានភាពអវិជ្ជមាន និងសោះអង្គើយដូចខ្លួនឯងជានិច្ច។ អ្នកដែលមិនអនុវត្តនូវសេចក្ដីពិត គឺច្រណែននឹងអ្នកដែលអនុវត្ត ហើយតែងតែព្យាយាមបោកបញ្ឆោតដល់អស់អ្នកដែលល្ងីល្ងើ និងខ្វះនូវយោបល់។ អ្វីៗដែលមនុស្សទាំងនេះធ្វើឲ្យកើតមាន អាចបណ្ដាលឲ្យអ្នកទន់ខ្សោយ ធ្លាក់ចុះ លូតលាស់នូវភាពមិនធម្មតា និងពោរពេញទៅដោយភាពងងឹត។ វាធ្វើឲ្យអ្នកឃ្លាតឆ្ងាយពីព្រះជាម្ចាស់ ហើយស្រឡាញ់សាច់ឈាម និងបណ្ដោយខ្លួនឯង។ មនុស្សដែលមិនស្រឡាញ់សេចក្ដីពិត ហើយតែងតែគោរពចំពោះព្រះជាម្ចាស់ គឺគ្មានការដឹងខ្លួនដោយខ្លួនឯង ហើយនិស្ស័យរបស់មនុស្សបែបនេះ បានទាក់ទាញអ្នកដទៃឲ្យប្រព្រឹត្តបាប និងប្រឆាំងនឹងព្រះជាម្ចាស់។ ពួកគេមិនអនុវត្តនូវសេចក្ដីពិត ហើយក៏មិនអនុញ្ញាតឲ្យអ្នកដទៃអនុវត្តនូវសេចក្ដីពិតដែរ។ ពួកគេស្រឡាញ់អំពើបាប ហើយមិនស្អប់ខ្ពើមនឹងខ្លួនឯងទេ។ ពួកគេមិនស្គាល់ពីខ្លួនឯង ហើយពួកគេបញ្ឈប់អ្នកដទៃមិនឲ្យស្គាល់ពីខ្លួនឯងផងដែរ។ ពួកគេក៏បញ្ឈប់អ្នកដទៃពីការចង់បានសេចក្ដីពិតដែរ។ អ្នកដែលពួកគេបោកបញ្ឆោត មិនអាចមើលឃើញពន្លឺបានទេ។ ពួកគេធ្លាក់ក្នុងភាពងងឹត មិនស្គាល់ខ្លួនឯង ពួកគេមិនច្បាស់អំពីសេចក្ដីពិត ហើយកាន់តែឃ្លាតឆ្ងាយទៅៗពីព្រះជាម្ចាស់។ ពួកគេមិនអនុវត្តនូវសេចក្ដីពិត ហើយពួកគេបញ្ឈប់អ្នកដទៃមិនឲ្យអនុវត្តនូវសេចក្ដីពិត ដោយនាំមនុស្សល្ងីល្ងើទាំងនោះមករកពួកគេ។ ជាជាងការនិយាយថាពួកគេជឿលើព្រះជាម្ចាស់ វាជាការប្រសើរជាងក្នុងការនិយាយថា ពួកគេជឿលើបុព្វបុរសរបស់ពួកគេ ឬថាអ្វីដែលពួកគេជឿ គឺជារូបព្រះនៅក្នុងដួងចិត្តរបស់ពួកគេ។ វាជាការល្អបំផុតសម្រាប់មនុស្សទាំងនោះដែលអះអាងថាដើរតាមព្រះជាម្ចាស់ដើម្បីបើកភ្នែកពួកគេ ហើយមើលឲ្យបានជាក់ដើម្បីឃើញច្បាស់ថានរណាដែលពួកគេគួរជឿ៖ តើពិតជាព្រះជាម្ចាស់ ឬសាតាំង ដែលអ្នកជឿ? ប្រសិនបើអ្នកដឹងថាអ្វីដែលអ្នកជឿមិនមែនជាព្រះជាម្ចាស់ទេ តែជារូបព្រះផ្ទាល់ខ្លួនរបស់អ្នក នោះវាជាការល្អបំផុតប្រសិនបើអ្នកមិនបានអះអាងថាជាអ្នកជឿ។ ប្រសិនបើអ្នកពិតជាមិនដឹងថាអ្នកជឿលើអ្នកណាទេ ដូច្នេះជាថ្មីម្ដងទៀត វាជាការល្អ

បំផុតប្រសិនបើអ្នកមិនបានអះអាងថាជាអ្នកជឿ។ ការនិយាយអ៊ីចឹងគឺជាការប្រមាថ! គ្មាននរណាម្នាក់បង្ខំអ្នកឲ្យជឿលើព្រះជាម្ចាស់នោះទេ។ កុំនិយាយថាអ្នករាល់គ្នាជឿលើខ្ញុំឡើយ។ ខ្ញុំមានព្រះបន្ទូលបែបនេះគ្រប់គ្រាន់ហើយ ហើយខ្ញុំមិនចង់ឮវាម្តងទៀតទេ ពីព្រោះអ្វីដែលអ្នករាល់គ្នាជឿ គឺរូបព្រះនៅក្នុងដួងចិត្តរបស់អ្នករាល់គ្នា និងពួកអ្នកដែលរករឿងនៅក្នុងពួកជំនុំរបស់អ្នករាល់គ្នា។ អស់អ្នកដែលគ្រវីក្បាលនៅពេលពួកគេឮពីសេចក្តីពិត ដែលញញឹមពេលដែលពួកគេឮអំពីការជជែកពីសេចក្តីស្លាប់ គឺជាអ្នកដែលកើតចេញពីសាតាំង ហើយពួកគេគឺជាអ្នកដែលនឹងត្រូវបានផាត់ចោល។ មនុស្សជាច្រើននៅក្នុងពួកជំនុំគ្មានយោបល់ទេ។ នៅពេលមានអ្វីដែលបោកបញ្ឆោតកើតឡើង ពួកគេស្រាប់តែឈរនៅខាងសាតាំង។ ពួកគេថែមទាំងអាក់អន់ចិត្តចំពោះការដែលត្រូវហៅថាជាកញ្ជះរបស់សាតាំង។ ទោះបីជាមនុស្សអាចនិយាយថាពួកគេគ្មានយោបល់ ពួកគេតែងតែឈរនៅម្ខាងដោយគ្មានសេចក្តីពិត ពួកគេមិនដែលឈរនៅម្ខាងនៃសេចក្តីពិត នៅចំពេលដែលសំខាន់នោះទេ ពួកគេមិនដែលក្រោកឈរ និងប្រកែកតវ៉ាចំពោះសេចក្តីពិតឡើយ។ តើពួកគេពិតជាខ្វះ នូវយោបល់មែនទេ? ហេតុអ្វីបានជាពួកគេ ស្រាប់តែយកខាងសាតាំង? ហេតុអ្វីបានជាពួកគេមិនដែលនិយាយពាក្យមួយម៉ាត់ដែលសមរម្យ និងសមហេតុផល ក្នុងការគាំទ្រសេចក្តីពិត? តើស្ថានភាពនេះកើតឡើងយ៉ាងពិតប្រាកដ ដោយសារតែការភាន់ច្រលំមួយពេលរបស់ពួកគេឬទេ? មនុស្សដែលមានយោបល់កាន់តែតិច នោះពួកគេកាន់តែមិនអាចឈរនៅខាងសេចក្តីពិតបាន។ តើនេះបង្ហាញពីអ្វី? តើវាមិនបង្ហាញថាមនុស្សដែលគ្មានយោបល់ គឺស្រលាញ់ការអាក្រក់ទេឬ? តើវាមិនបានបង្ហាញថាពួកគេជាមនុស្សដ៏ស្មោះត្រង់របស់សាតាំងទេឬ? ហេតុអ្វីពួកគេអាចឈរនៅខាងសាតាំង ហើយនិយាយភាសារបស់វា? រាល់ពាក្យសម្តី និងការប្រព្រឹត្តរបស់ពួកគេ ការបង្ហាញចេញនៅលើផ្ទៃមុខរបស់ពួកគេ គឺគ្រប់គ្រាន់ដើម្បីបញ្ជាក់ថា ពួកគេមិនមែនជាអ្នកដែលស្រឡាញ់សេចក្តីពិតទេ។ ផ្ទុយទៅវិញ ពួកគេគឺជាមនុស្សដែលស្អប់សេចក្តីពិត។ ការដែលពួកគេអាចឈរនៅខាងសាតាំង គឺគ្រប់គ្រាន់ដើម្បីបញ្ជាក់ថាសាតាំងពិតជាស្រឡាញ់អារក្ស

តូចៗទាំងនេះ ដែលបានលះបង់ជីវិតរបស់ពួកគេដើម្បីជាប្រយោជន៍ដល់សាតាំង។ តើហេតុការណ៍ទាំងអស់នេះមិនច្បាស់ពេញលេញទេឬអី? ប្រសិនបើអ្នកពិតជាមនុស្សដែលស្រឡាញ់សេចក្ដីពិត ហេតុអ្វីបានជាអ្នកមិនយកចិត្តទុកដាក់ចំពោះអ្នកដែលអនុវត្តនូវសេចក្ដីពិត ហើយហេតុអ្វីបានជាអ្នកធ្វើតាមអ្នកដែលមិនអនុវត្តសេចក្ដីពិតភ្លាមៗដូច្នេះ? តើនេះជាបញ្ហាប្រភេទអ្វី? ខ្ញុំមិនខ្វល់ថាអ្នកមានយោបល់ឬអត់។ ខ្ញុំមិនខ្វល់ថាអ្នកបានបង់ថ្លៃប៉ុន្មាននោះទេ។ ខ្ញុំមិនខ្វល់ថាតើកងកម្លាំងរបស់អ្នកធំប៉ុនណាហើយខ្ញុំមិនខ្វល់ថាអ្នកគឺជាមនុស្សដែលរករឿងគេក្នុងពួកជំនុំ ឬជាអ្នកដឹកនាំដែលកាន់ទង់នោះទេ។ ប្រសិនបើកងកម្លាំងរបស់អ្នកគឺអស្ចារ្យ នោះគ្រាន់តែជាជំនួយពីកម្លាំងរបស់សាតាំងប៉ុណ្ណោះ។ ប្រសិនបើកិត្យានុភាពរបស់អ្នកខ្ពស់ ដូច្នេះនោះគឺគ្រាន់តែដោយសារតែមានមនុស្សជាច្រើននៅជុំវិញខ្លួនអ្នកដែលមិនអនុវត្តនូវសេចក្ដីពិតប៉ុណ្ណោះ។ ប្រសិនបើអ្នកមិនត្រូវបានបណ្ដេញចេញទេ នោះគឺដោយសារតែពេលនេះមិនមែនជាពេលវេលាសម្រាប់កិច្ចការនៃការបណ្ដេញចេញ។ ផ្ទុយទៅវិញវាដល់ពេលកិច្ចការនៃការផាត់ចោលហើយ។ មិនមានការប្រញាប់ក្នុងការបណ្ដេញអ្នកឥឡូវនេះទេ។ ខ្ញុំគ្រាន់តែរង់ចាំថ្ងៃដែលខ្ញុំនឹងដាក់ទោសអ្នកបន្ទាប់ពីអ្នកត្រូវបានផាត់ចោល។ អស់អ្នកណាដែលមិនអនុវត្តនូវសេចក្ដីពិត នឹងត្រូវផាត់ចោល!

មនុស្សដែលជឿលើព្រះជាម្ចាស់ពិតប្រាកដ គឺជាអ្នកដែលមានឆន្ទៈអនុវត្តតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយមានឆន្ទៈអនុវត្តនូវសេចក្ដីពិត។ មនុស្សដែលពិតជាអាចឈររឹងមាំក្នុងការធ្វើបន្ទាល់របស់ពួកគេអំពីព្រះជាម្ចាស់ ក៏ជាអ្នកដែលមានឆន្ទៈអនុវត្តតាមព្រះបន្ទូលរបស់ទ្រង់ ហើយអាចឈរយ៉ាងពិតប្រាកដនៅខាងសេចក្ដីពិតបានដែរ។ មនុស្សដែលចូលចិត្តប្រើកលល្បិច និងភាពអយុត្តិធម៌ ពួកគេទាំងអស់នោះខ្វះនូវសេចក្ដីពិត ហើយពួកគេទាំងអស់នាំនូវភាពអាម៉ាស់ទៅកាន់ព្រះជាម្ចាស់។ អ្នកដែលបង្កជម្លោះនៅក្នុងក្រុមជំនុំ គឺជាកញ្ជះរបស់សាតាំង ពួកគេជាតំណាងរបស់សាតាំង។ មនុស្សបែបនេះគឺរបិលរប៉ូចណាស់។ អស់អ្នកដែលគ្មានយោបល់ហើយមិនអាចឈរនៅខាងសេចក្ដីពិត អ្នកទាំងអស់នោះមានបំណងអាក្រក់ ហើយ

ធ្វើឲ្យខូចដល់សេចក្តីពិត។ លើសពីនេះទៅទៀត ពួកគេគឺជាអ្នកតំណាងពីបុរាណរបស់សាតាំង។ ពួកគេគឺលើសហួសពីការប្រោសលោះ ហើយនឹងត្រូវផាត់ចោលដោយធម្មជាតិ។ គ្រួសាររបស់ព្រះជាម្ចាស់ មិនអនុញ្ញាតឲ្យអស់អ្នកដែលមិនអនុវត្តនូវសេចក្តីពិត នៅសល់នោះឡើយ ហើយក៏មិនអនុញ្ញាតឲ្យនៅតែសល់ អស់អ្នកដែលជាអ្នកដែលមានចិត្តចង់រុះរើពួកជំនុំនោះដែរ។ ទោះយ៉ាងណា ពេលនេះមិនមែនជាពេលវេលាដើម្បីធ្វើកិច្ចការបណ្តេញចេញនោះទេ។ មនុស្សបែបនេះនឹងត្រូវបានលាតត្រដាង និងផាត់ចោលនៅទីបំផុត។ គ្មានកិច្ចការដែលគ្មានប្រយោជន៍ទៀតដែលត្រូវលះបង់សម្រាប់មនុស្សទាំងនេះទេ។ អស់អ្នកដែលជាកម្មសិទ្ធិរបស់សាតាំងមិនអាចឈរនៅខាងសេចក្តីពិតបានឡើយ រីឯអស់អ្នកដែលស្វែងរកនូវសេចក្តីពិត គឺអាចឈរនៅខាងសេចក្តីពិតបាន។ មនុស្សដែលមិនអនុវត្តនូវសេចក្តីពិត គឺមិនសមនឹងស្តាប់ព្ធផ្លូវនៃសេចក្តីពិត និងមិនសក្តិសមក្នុងការធ្វើបន្ទាល់ពីសេចក្តីពិតឡើយ។ សេចក្តីពិតគឺមិនមែនសម្រាប់ត្រចៀករបស់ពួកគេទេ។ ផ្ទុយទៅវិញ វាត្រូវត្រឡប់ឆ្ពោះទៅឯអ្នកដែលអនុវត្តនូវសេចក្តីពិត។ មុនពេលចុងបញ្ចប់របស់មនុស្សគ្រប់រូបត្រូវបានបើកសម្តែង អស់អ្នកដែលយាយីដល់ពួកជំនុំ ហើយរំខានដល់កិច្ចការរបស់ព្រះជាម្ចាស់ នឹងត្រូវទុកចោលជាមុនសិនសម្រាប់ពេលឥឡូវនេះ ដើម្បីដោះស្រាយនៅពេលក្រោយ។ នៅពេលដែលកិច្ចការត្រូវបានបញ្ចប់ មនុស្សទាំងនេះនឹងត្រូវបានលាតត្រដាង ហើយបន្ទាប់មកពួកគេនឹងត្រូវផាត់ចោល។ សម្រាប់ពេលបច្ចុប្បន្ននេះ ខណៈពេលដែលសេចក្តីពិតកំពុងត្រូវបានប្រទានឲ្យ សេចក្តីពិតនឹងត្រូវគេមិនអើពើ។ នៅពេលដែលសេចក្តីពិតទាំងមូលត្រូវបានបើកសម្តែងដល់មនុស្ស មនុស្សទាំងនោះនឹងត្រូវផាត់ចោល។ នោះគឺជាពេលវេលាដែលមនុស្សទាំងអស់នឹងត្រូវបានចាត់ថ្នាក់តាមប្រភេទរបស់ពួកគេ។ ឧបាយកលតូចតាចរបស់អ្នកដែលមិនមានយោបល់ នឹងនាំទៅដល់ការបំផ្លាញពួកគេ ដោយដៃរបស់មនុស្សអាក្រក់ ហើយពួកគេនឹងត្រូវល្បួងដោយការទាំងនោះ ដោយមិនវិលត្រឡប់មកវិញឡើយ។ ហើយការប្រព្រឹត្តបែបនេះគឺជាអ្វីដែលពួកគេសមនឹងទទួល ព្រោះពួកគេមិនស្រឡាញ់សេចក្តីពិត ព្រោះពួកគេ

មិនអាចឈរនៅខាងនៃសេចក្ដីពិតបាន ពីព្រោះពួកគេដើរតាមមនុស្សអាក្រក់ ហើយឈរនៅខាងមនុស្សអាក្រក់ ហើយដោយសារតែពួកគេឃុបឃិតជាមួយមនុស្សអាក្រក់ និងប្រឆាំងព្រះជាម្ចាស់។ ពួកគេដឹងយ៉ាងច្បាស់ថាអ្វីដែលមនុស្សអាក្រក់បញ្ចេញគឺជាអំពើអាក្រក់ ប៉ុន្តែពួកគេមានចិត្តរឹងរូស ហើយបែរខ្នងដាក់សេចក្ដីពិតដើម្បីដើរតាមពួកគេវិញ។ តើមនុស្សទាំងនេះដែលមិនអនុវត្តនូវសេចក្ដីពិត ប៉ុន្តែជាអ្នកដែលបំផ្លាញ និងគួរឲ្យស្អប់ខ្ពើម មិនមែនសុទ្ធតែប្រព្រឹត្តអំពើអាក្រក់ទេឬអី? ទោះបីមានអ្នកខ្លះក្នុងចំណោមពួកគេដែលធ្វើខ្លួនគេថាជាស្ដេច និងជាអ្នកដទៃទៀតដែលដើរតាមពួកគេក៏ដោយ តើធម្មជាតិដែលប្រឆាំងនឹងព្រះជាម្ចាស់របស់ពួកគេ មិនដូចគ្នាទាំងអស់ទេឬ? តើមានលេសអ្វីដែលពួកគេអាចអះអាងថាព្រះជាម្ចាស់មិនជួយសង្គ្រោះពួកគេនោះ? តើមានលេសអ្វីដែលពួកគេអាចអះអាងថាព្រះជាម្ចាស់មិនសុចរិត? តើវាមិនមែនជាអំពើអាក្រក់របស់ពួកគេដែលកំពុងតែបំផ្លាញពួកគេទេឬ? តើវាមិនមែនជាការបះបោររបស់ពួកគេដែលកំពុងទាញពួកគេធ្លាក់ចូលក្នុងនរកទេឬ? នៅទីបំផុតមនុស្សដែលអនុវត្តនូវសេចក្ដីពិត នឹងត្រូវបានសង្គ្រោះ និងធ្វើឲ្យបានគ្រប់លក្ខណ៍ ដោយសារតែសេចក្ដីពិត។ នៅទីបំផុត អស់អ្នកដែលមិនអនុវត្តនូវសេចក្ដីពិត នឹងនាំសេចក្ដីអន្តរាយដល់ខ្លួនគេដោយសារតែសេចក្ដីពិត។ ទាំងនេះ គឺជាការបញ្ចប់ដែលរង់ចាំអ្នកដែលអនុវត្តនូវសេចក្ដីពិត និងអ្នកដែលមិនអនុវត្តនូវសេចក្ដីពិត។ ខ្ញុំសូមណែនាំដល់អ្នកដែលមិនមានគម្រោងអនុវត្តនូវសេចក្ដីពិត ឲ្យចាកចេញពីពួកជំនុំឲ្យបានឆាប់តាមដែលអាចធ្វើបាន ដើម្បីចៀសវាងប្រព្រឹត្តអំពើបាបកាន់តែច្រើន។ នៅពេលដែលពេលវេលាមកដល់ វានឹងយឺតពេលសម្រាប់ការសោកស្ដាយ។ ជាពិសេសអ្នកដែលបង្កើតក្រុមមនុស្សខូច និងបង្កើតក្រុមបក្សពួក និងអ្នកដែលរករឿងក្នុងពួកជំនុំ ត្រូវតែចាកចេញឲ្យបានឆាប់។ មនុស្សបែបនេះ ដែលមានធម្មជាតិនៃចចកអាក្រក់ គឺមិនអាចផ្លាស់ប្ដូរបានទេ។ វាជាការប្រសើរ ប្រសិនបើពួកគេចាកចេញពីពួកជំនុំ ឲ្យបានកាន់តែឆាប់បំផុត ដោយមិនត្រឡប់មកម្ដងទៀតដើម្បីរំខានដល់ជីវិតធម្មតារបស់បងប្អូនប្រុសស្រី ហើយដោយហេតុនេះ ជៀសវាងការដាក់ទោសរបស់ព្រះជាម្ចាស់។ អស់អ្នកដែលបាន

ទៅជាមួយពួកគេ គប្បីប្រើឱកាសនេះដើម្បីផ្ដាច់ខ្លួនចេញពីខ្លួនអ្នក។ តើអ្នកនឹងចាកចេញពីពួកជំនុំទៅរួមជាមួយមនុស្សអាក្រក់ ឬនៅជាប់ ហើយដើរតាមដោយស្ដាប់បង្គាប់? អ្នកត្រូវតែពិចារណាពីបញ្ហានេះដោយយកចិត្តទុកដាក់។ ខ្ញុំផ្ដល់ឲ្យអ្នករាល់គ្នានូវឱកាសមួយបន្ថែមទៀតដើម្បីជ្រើសរើស ហើយខ្ញុំរង់ចាំចម្លើយរបស់អ្នករាល់គ្នា។

## តើអ្នកគឺជាមនុស្សម្នាក់ដែលចូលមកឯជីវិតឬ?

ទាល់តែពេលដែលអ្នកយកនិស្ស័យដ៏ពុករលួយរបស់អ្នកចេញ និងសម្រេចបានការស្ដែងចេញភាពជាមនុស្សសាមញ្ញ តាមរយៈការរស់នៅប៉ុណ្ណោះ ទើបអ្នកនឹងអាចត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍បាន។ ទោះបីជាអ្នកនឹងមិនអាចថ្លែងបទទំនាយ ឬនិយាយពីអាថ៌កំបាំងណាមួយក៏ដោយ អ្នកនឹងរស់នៅ និងបើកសម្ដែងនូវរូបភាពរបស់មនុស្ស។ ព្រះជាម្ចាស់បានបង្កើតមនុស្ស ប៉ុន្ដែក្រោយមក មនុស្សត្រូវបានសាតាំងធ្វើឲ្យពុករលួយ ដូច្នេះហើយទើបមនុស្សក្លាយជា «មនុស្សស្លាប់»។ ដូច្នេះ បន្ទាប់ពីអ្នកបានផ្លាស់ប្ដូរ អ្នកនឹងលែងដូច «មនុស្សស្លាប់» ទាំងនេះតទៅទៀតហើយ។ គឺជាព្រះបន្ទូលរបស់ព្រះជាម្ចាស់នេះហើយ ដែលធ្វើឲ្យវិញ្ញាណរបស់មនុស្សបានភ្លឺឡើង និងបណ្ដាលឲ្យពួកគេកើតសាជាថ្មី ហើយនៅពេលដែលវិញ្ញាណរបស់មនុស្សកើតសាជាថ្មី នោះពួកគេនឹងមានជីវិត។ នៅពេលដែលខ្ញុំនិយាយអំពី «មនុស្សស្លាប់» ខ្ញុំកំពុងសំដៅទៅលើសាកសពដែលគ្មានវិញ្ញាណ សំដៅលើមនុស្សដែលវិញ្ញាណរបស់ពួកគេបានស្លាប់នៅក្នុងពួកគេបាត់ទៅហើយ។ នៅពេលដែលវិញ្ញាណរបស់មនុស្សរស់ឡើងវិញ នោះមនុស្សនឹងបានចូលមកឯជីវិត។ ពួកបរិសុទ្ធដែលត្រូវបាននិយាយពីមុនសំដៅលើមនុស្សដែលចូលមកឯជីវិត គឺអស់អ្នកដែលធ្លាប់ស្ថិតនៅក្រោមឥទ្ធិពលរបស់សាតាំង ប៉ុន្ដែបានយកឈ្នះសាតាំង។ រាស្ដ្ររើសតាំងរបស់ប្រទេសចិន បានអត់ទ្រាំនឹងការបៀតបៀន និងល្បិចបោកបញ្ឆោតដ៏សាហាវយង់ឃ្នងរបស់នាគដ៏ធំមានសម្បុរក្រហម ដែលបន្សល់ទុកឲ្យពួកគេត្រូវខ្ទេចខ្ទាំខាងផ្លូវចិត្ត និងគ្មានភាពក្លាហានដើម្បី

រស់នៅសូម្បីតែបន្តិច។ ដូច្នេះ ការភ្ញាក់រឭកនៃវិញ្ញាណរបស់ពួកគេ ត្រូវតែចាប់ផ្ដើមដោយលក្ខណៈសំខាន់របស់ពួកគេ៖ នៅក្នុងលក្ខណៈសំខាន់របស់ពួកគេ វិញ្ញាណរបស់ពួកគេត្រូវតែបានដាស់ឲ្យភ្ញាក់រឭកបន្តិចម្ដងៗ។ នៅថ្ងៃមួយ ពេលដែលពួកគេចូលមកឯជីវិត នោះនឹងគ្មានឧបសគ្គតទៅទៀតទេ ហើយគ្រប់យ៉ាងនឹងដំណើរការយ៉ាងរលូន។ នៅពេលបច្ចុប្បន្ន រឿងនេះនៅតែមិនអាចសម្រេចបានដដែល។ មនុស្សភាគច្រើនរស់នៅក្នុងផ្លូវដែលនាំមកនូវគំនិតគ្រោះថ្នាក់ជាច្រើន ពួកគេត្រូវបានគ្របដណ្ដប់ដោយអាការៈនៃសេចក្ដីស្លាប់ ហើយពួកគេខ្វះខាតច្រើនណាស់។ ពាក្យពេចន៍របស់មនុស្សមួយចំនួន បង្កប់ទៅដោយសេចក្ដីស្លាប់ សកម្មភាពរបស់ពួកគេបង្កប់ក៏ទៅដោយសេចក្ដីស្លាប់ ហើយសឹងតែគ្រប់យ៉ាងដែលពួកគេនាំយកមកនៅក្នុងរបៀបដែលពួកគេរស់នៅ គឺសុទ្ធតែមានសេចក្ដីស្លាប់។ សព្វថ្ងៃនេះ ប្រសិនបើមនុស្សធ្វើទីបន្ទាល់ថ្វាយព្រះជាម្ចាស់ជាសាធារណៈ នោះពួកគេនឹងបរាជ័យក្នុងកិច្ចការនេះ ដោយសារតែពួកគេមិនទាន់មកឯជីវិតពេញលេញនៅឡើយ ហើយមានមនុស្សស្លាប់ជាច្រើននៅក្នុងចំណោមអ្នករាល់គ្នា។ សព្វថ្ងៃនេះ មនុស្សមួយចំនួនសួរមូលហេតុដែលព្រះជាម្ចាស់មិនបង្ហាញទីសម្គាល់ និងការអស្ចារ្យ ដើម្បីឲ្យទ្រង់អាចផ្សព្វផ្សាយកិច្ចការរបស់ទ្រង់បានយ៉ាងលឿននៅក្នុងចំណោមសាសន៍ដទៃ។ មនុស្សស្លាប់មិនអាចធ្វើទីបន្ទាល់ថ្វាយព្រះជាម្ចាស់បានទេ ដែលវាគឺជាកិច្ចការដែលមានតែមនុស្សមានជីវិតប៉ុណ្ណោះ ទើបអាចធ្វើបាន ប៉ុន្ដែមនុស្សភាគច្រើនសព្វថ្ងៃនេះ គឺសុទ្ធតែជា «មនុស្សស្លាប់»។ មនុស្សជាច្រើនណាស់រស់នៅក្រោមការគ្របដណ្ដប់របស់សេចក្ដីស្លាប់ នៅក្រោមឥទ្ធិពលរបស់សាតាំង និងមិនអាចទទួលបានជ័យជម្នះ។ ដូច្នេះ ធ្វើដូចម្ដេចទើបពួកគេអាចធ្វើទីបន្ទាល់ថ្វាយព្រះជាម្ចាស់បាន? ធ្វើដូចម្ដេចទើបពួកគេអាចផ្សព្វផ្សាយកិច្ចការនៃដំណឹងល្អបាន?

អស់អ្នកដែលរស់នៅក្រោមឥទ្ធិពលនៃភាពងងឹត គឺជាមនុស្សដែលរស់នៅក្នុងសេចក្ដីស្លាប់ គឺជាអស់អ្នកដែលជាកម្មសិទ្ធិរបស់សាតាំង។ បើគ្មានការសង្គ្រោះពីព្រះជាម្ចាស់ និងត្រូវបានព្រះជាម្ចាស់ជំនុំជម្រះ ព្រមទាំងវាយផ្ចាលនោះទេ នោះមនុស្ស

មិនអាចគេចផុតពីឥទ្ធិពលរបស់សេចក្ដីស្លាប់បានឡើយ។ ពួកគេមិនអាចក្លាយជាមនុស្សមានជីវិតបានទេ។ «មនុស្សស្លាប់» ទាំងនេះ មិនអាចធ្វើទីបន្ទាល់ថ្វាយព្រះជាម្ចាស់បានទេ ហើយព្រះជាម្ចាស់ក៏មិនអាចប្រើពួកគេដែរ ជាងនេះទៅទៀត ពួកគេរឹតតែមិនអាចចូលទៅក្នុងនគរព្រះបានទៀតផង។ ព្រះជាម្ចាស់សព្វព្រះហឫទ័យចង់បានទីបន្ទាល់របស់មនុស្សដែលចូលមកឯជីវិត មិនមែនមនុស្សស្លាប់នោះទេ ហើយទ្រង់ស្នើឲ្យមនុស្សមានជីវិតធ្វើការសម្រាប់ទ្រង់ មិនមែនមនុស្សស្លាប់នោះទេ។ «មនុស្សស្លាប់» គឺអស់អ្នកដែលទាស់ទទឹង ហើយបះបោរប្រឆាំងនឹងព្រះជាម្ចាស់។ ពួកគេគឺជាអស់អ្នកដែលស្ពឹកស្រពន់ខាងវិញ្ញាណ ហើយមិនយល់ដឹងអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ពួកគេគឺជាអស់អ្នកដែលមិនយកសេចក្ដីពិតទៅអនុវត្ត ហើយមិនមានភាពស្មោះត្រង់ចំពោះព្រះជាម្ចាស់សូម្បីតែបន្ដិច ហើយពួកគេគឺជាមនុស្សដែលរស់នៅក្រោមការត្រួតត្រារបស់សាតាំង និងត្រូវបានសាតាំងកេងប្រវ័ញ្ច។ មនុស្សស្លាប់ស្ដែងពីខ្លួនរបស់គេតាមរយៈការក្រោកឈរប្រឆាំងនឹងសេចក្ដីពិត តាមរយៈការបះបោរប្រឆាំងនឹងព្រះជាម្ចាស់ និងតាមរយៈភាពតូចទាប ភាពថោកទាប ភាពអាក្រក់ ភាពសាហាវឃោរឃៅ ការបោកប្រាស់ និងកលល្បិច។ ទោះបីជាមនុស្សបែបនេះបរិភោគ និងផឹកព្រះបន្ទូលរបស់ព្រះជាម្ចាស់ក៏ដោយ ក៏ពួកគេមិនអាចស្ដែងពីព្រះបន្ទូលរបស់ព្រះជាម្ចាស់តាមរយៈការរស់នៅបានដែរ។ ទោះបីជាពួកគេមានជីវិតក៏ដោយ ក៏ពួកគេគ្រាន់តែជាសាកសពដែលដកដង្ហើម និងសាកសពដែលដើរប៉ុណ្ណោះ។ មនុស្សស្លាប់ពិតជាមិនអាចធ្វើឲ្យព្រះជាម្ចាស់សព្វព្រះហឫទ័យបានឡើយ ជាងនេះទៅទៀត ពួកគេក៏កាន់តែមិនស្ដាប់បង្គាប់ទ្រង់យ៉ាងពិតប្រាកដទៀតផង។ ពួកគេគ្រាន់តែអាចបោកបញ្ឆោតទ្រង់ ប្រមាថប្រឆាំងនឹងទ្រង់ និងក្បត់ទ្រង់ប៉ុណ្ណោះ ហើយគ្រប់យ៉ាងដែលពួកគេនាំមកតាមរយៈរបៀបដែលពួកគេរស់នៅ គឺសុទ្ធតែបើកសម្ដែងពីធម្មជាតិរបស់សាតាំង។ ប្រសិនបើមនុស្សចង់ក្លាយជាភាវៈមានជីវិត និងចង់ធ្វើទីបន្ទាល់ថ្វាយព្រះជាម្ចាស់ ហើយត្រូវបានអនុញ្ញាតពីព្រះជាម្ចាស់ នោះពួកគេត្រូវតែទទួលយកការសង្គ្រោះរបស់ព្រះជាម្ចាស់។ ពួកគេត្រូវតែចុះចូលចំពោះការជំនុំជម្រះ និងការវាយផ្ចាលរបស់

ទ្រង់យ៉ាងរីករាយ ហើយត្រូវតែទទួលយកនូវការលួសកាត់ និងការដោះស្រាយពីព្រះជាម្ចាស់ដោយរីករាយដែរ។ ទាល់តែពេលនោះ ទើបពួកគេនឹងអាចយកសេចក្ដីពិតទាំងអស់ដែលព្រះជាម្ចាស់បានតម្រូវទៅអនុវត្តបាន ហើយទាល់តែពេលនោះ ទើបពួកគេនឹងទទួលបានការសង្គ្រោះរបស់ព្រះជាម្ចាស់ ហើយក្លាយជាភាវៈមានជីវិតយ៉ាងពិតប្រាកដ។ មនុស្សមានជីវិតត្រូវបានសង្គ្រោះដោយព្រះជាម្ចាស់។ ពួកគេត្រូវបានជំនុំជម្រះ និងវាយផ្ចាលដោយព្រះជាម្ចាស់ ពួកគេចង់ថ្វាយខ្លួន និងរីករាយក្នុងការថ្វាយជីវិតរបស់ពួកសម្រាប់ព្រះជាម្ចាស់ ហើយពួកគេនឹងបូជាជីវិតរបស់ពួកគេទាំងមូលថ្វាយព្រះជាម្ចាស់យ៉ាងរីករាយ។ ទាល់តែពេលដែលមនុស្សមានជីវិតធ្វើបន្ទាល់ថ្វាយព្រះជាម្ចាស់ ទើបសាតាំងត្រូវអាម៉ាស់មុខ។ ទាល់តែមនុស្សមានជីវិតទើបអាចផ្សព្វផ្សាយកិច្ចការដំណឹងល្អរបស់ព្រះជាម្ចាស់បាន ទាល់តែមនុស្សមានជីវិតទើបត្រូវនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ហើយទាល់តែមនុស្សមានជីវិត ទើបជាមនុស្សពិត។ ដំបូងឡើយ មនុស្សដែលព្រះជាម្ចាស់បានបង្កើត គឺនៅមានជីវិត ប៉ុន្តែដោយសារតែសេចក្ដីពុករលួយរបស់សាតាំង នោះមនុស្សរស់នៅក្នុងសេចក្ដីស្លាប់ ហើយរស់នៅក្រោមឥទ្ធិពលរបស់សាតាំង ហើយដោយសារតែបែបនេះ ទើបមនុស្សបានក្លាយជាមនុស្សស្លាប់គ្មានវិញ្ញាណ ពួកគេបានក្លាយជាសត្រូវដែលទាស់ទទឹងនឹងព្រះជាម្ចាស់ ពួកគេបានក្លាយជាឧបករណ៍របស់សាតាំង ហើយពួកគេបានក្លាយជាចំណាប់ខ្មាំងរបស់សាតាំងទៀតផង។ មនុស្សមានជីវិតទាំងអស់ដែលព្រះជាម្ចាស់បានបង្កើត បានក្លាយជាមនុស្សស្លាប់ ដូច្នេះ ព្រះជាម្ចាស់បានបាត់បង់ទីបន្ទាល់របស់ទ្រង់ ហើយទ្រង់បានបាត់បង់មនុស្សជាតិដែលទ្រង់បានបង្កើត និងដែលជាវត្ថុតែមួយគត់ដែលមានខ្យល់ដង្ហើមរបស់ទ្រង់។ ប្រសិនបើព្រះជាម្ចាស់នឹងត្រូវយកទីបន្ទាល់របស់ទ្រង់ត្រឡប់មកវិញ ហើយយកអស់អ្នកដែលទ្រង់បានបង្កើតដោយព្រះហស្តរបស់ទ្រង់ផ្ទាល់ ប៉ុន្តែដែលត្រូវបានសាតាំងចាប់ជាចំណាប់ខ្មាំងត្រឡប់មកវិញ នោះទ្រង់ត្រូវតែប្រោសឲ្យពួកគេរស់ឡើងវិញ ដើម្បីឲ្យពួកគេក្លាយជាភាវៈមានជីវិត ហើយទ្រង់ត្រូវតែទទួលយកពួកគេមកវិញ ដើម្បីឲ្យពួកគេរស់នៅក្នុងពន្លឺរបស់ទ្រង់។ មនុស្ស

ស្លាប់ គឺជាមនុស្សដែលគ្មានវិញ្ញាណ មនុស្សស្ពឹកស្រពន់បំផុត និងជាមនុស្សដែលទាស់ទទឹងនឹងព្រះជាម្ចាស់។ ពួកគេនៅខាងមុខបង្អស់ក្នុងចំណោមអ្នកដែលមិនស្គាល់ព្រះជាម្ចាស់។ មនុស្សទាំងនេះ គ្មានបំណងស្ដាប់បង្គាប់ព្រះជាម្ចាស់សូម្បីតែបន្តិចឡើយ។ ពួកគេមានតែបះបោរប្រឆាំងនឹងទ្រង់ ហើយទាស់ទទឹងនឹងទ្រង់ ព្រមទាំងគ្មានភាពស្មោះត្រង់សូម្បីតែបន្តិច។ មនុស្សមានជីវិតជាមនុស្ស ដែលមានវិញ្ញាណកើតជាថ្មី ជាមនុស្សដែលចេះស្ដាប់បង្គាប់ព្រះជាម្ចាស់ និងជាមនុស្សស្មោះត្រង់ចំពោះព្រះជាម្ចាស់។ ពួកគេមានសេចក្ដីពិត និងទីបន្ទាល់ ហើយមានតែមនុស្សទាំងនេះទេ ទើបគាប់ព្រះហឫទ័យព្រះជាម្ចាស់នៅក្នុងដំណាក់របស់ទ្រង់។ ព្រះជាម្ចាស់សង្គ្រោះមនុស្សដែលអាចមកឯជីវិត ជាមនុស្សដែលអាចមើលឃើញការសង្គ្រោះរបស់ព្រះជាម្ចាស់ ជាមនុស្សដែលអាចស្មោះត្រង់ចំពោះព្រះជាម្ចាស់ និងជាមនុស្សសុខចិត្តស្វះស្វែងរកព្រះជាម្ចាស់។ ទ្រង់សង្គ្រោះអស់អ្នកដែលជឿ លើការយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់ និងជឿលើការលេចមករបស់ទ្រង់។ មនុស្សមួយចំនួនអាចចូលមកឯជីវិត ហើយមនុស្សមួយចំនួនមិនអាច។ រឿងនេះអាស្រ័យលើថា តើធម្មជាតិរបស់ពួកគេអាចត្រូវបានសង្គ្រោះ ឬអត់។ មនុស្សជាច្រើនបានឮព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាច្រើន ប៉ុន្តែពួកគេមិនយល់អំពីបំណងព្រះហឫទ័យរបស់ទ្រង់ឡើយ ហើយពួកគេនៅតែមិនអាចយកព្រះបន្ទូលទាំងនោះ ទៅអនុវត្តដដែល។ មនុស្សបែបនេះ មិនអាចស្វែងចេញនូវសេចក្ដីពិតណាមួយតាមរយៈការរស់នៅ ហើយក៏ជ្រៀតជ្រែកនូវកិច្ចការរបស់ព្រះជាម្ចាស់ដោយចេតនាដែរ។ ពួកគេមិនអាចធ្វើកិច្ចការណាមួយសម្រាប់ព្រះជាម្ចាស់ឡើយ ពួកគេមិនអាចថ្វាយអ្វីមួយទៅទ្រង់ឡើយ ហើយពួកគេក៏ចំណាយលុយរបស់ក្រុមជំនុំជាសម្ងាត់ ព្រមទាំងទទួលទាននៅក្នុងដំណាក់របស់ព្រះជាម្ចាស់ដោយមិនបង់ថ្លៃផង។ មនុស្សទាំងនេះ គឺជាមនុស្សស្លាប់ ហើយពួកគេនឹងមិនត្រូវបានសង្គ្រោះឡើយ។ ព្រះជាម្ចាស់សង្គ្រោះអស់អ្នកដែលនៅក្នុងកិច្ចការរបស់ទ្រង់ ប៉ុន្តែមានមនុស្សមួយចំនួនដែលមិនអាចទទួលបានការសង្គ្រោះរបស់ទ្រង់។ មានតែមនុស្សមួយចំនួនតូចប៉ុណ្ណោះ ដែលអាចទទួលបានការសង្គ្រោះ

របស់ទ្រង់។ នេះដោយសារតែមនុស្សភាគច្រើន ត្រូវបានធ្វើឱ្យពុករលួយយ៉ាងខ្លាំង និងបានក្លាយជាមនុស្សស្លាប់ ហើយពួកគេនៅហួសពីការសង្គ្រោះ។ ពួកគេត្រូវបានកេងប្រវ័ញ្ចដោយសាតាំងទាំងស្រុង ហើយធម្មជាតិរបស់ពួកគេអាក្រក់ខ្លាំងពេក។ មនុស្សមួយចំនួនតូចនោះ ក៏មិនអាចស្ដាប់បង្គាប់ព្រះជាម្ចាស់យ៉ាងពេញលេញដែរ។ ពួកគេមិនមែនជាមនុស្សដែលស្មោះត្រង់បំផុតចំពោះព្រះជាម្ចាស់តាំងពីដើមរៀងមក ឬជាមនុស្សដែលមានសេចក្ដីស្រឡាញបំផុតសម្រាប់ព្រះជាម្ចាស់តាំងពីដំបូងនោះទេ។ ផ្ទុយទៅវិញ ដោយសារតែកិច្ចការនៃការគ្រប់គ្រងរបស់ទ្រង់ ទើបពួកគេបានស្ដាប់បង្គាប់ព្រះជាម្ចាស់ ដោយសារតែសេចក្ដីស្រឡាញ់ដ៏ឧត្ដុង្គឧត្ដមរបស់ទ្រង់ ទើបពួកគេមើលឃើញព្រះជាម្ចាស់ ដោយសារតែនិស្ស័យសុចរិតរបស់ព្រះជាម្ចាស់ ទើបពួកគេមានការផ្លាស់ប្ដូរនិស្ស័យរបស់ពួកគេ ហើយដោយសារតែកិច្ចការរបស់ទ្រង់ ជាកិច្ចការដែលជាក់ស្ដែង និងសាមញ្ញផង ទើបពួកគេចាប់ផ្ដើមស្គាល់ព្រះជាម្ចាស់។ បើគ្មានកិច្ចការរបស់ព្រះជាម្ចាស់នេះទេ នោះមិនថាមនុស្សទាំងនេះល្អប៉ុនណានោះទេ ពួកគេនឹងនៅតែជាកម្មសិទ្ធិរបស់សាតាំង ពួកគេនឹងនៅតែជាកម្មសិទ្ធិរបស់សេចក្ដីស្លាប់ ហើយពួកគេនឹងនៅតែស្លាប់ដដែល។ ការពិតដែលថា សព្វថ្ងៃនេះ មនុស្សទាំងនេះអាចទទួលបានការសង្គ្រោះរបស់ព្រះជាម្ចាស់បាន គឺដោយសារតែពួកគេព្រមសហការជាមួយព្រះជាម្ចាស់។

ដោយសារតែភាពស្មោះត្រង់របស់ពួកគេចំពោះព្រះជាម្ចាស់ ទើបមនុស្សរស់នឹងត្រូវបានព្រះជាម្ចាស់ទទួលយក និងរស់នៅក្នុងសេចក្ដីសន្យារបស់ទ្រង់ ហើយដោយសារតែការប្រឆាំងជំទាស់របស់ពួកគេចំពោះព្រះជាម្ចាស់ ទើបមនុស្សស្លាប់នឹងត្រូវព្រះជាម្ចាស់ស្អប់ ព្រមទាំងបដិសេធ ហើយរស់នៅក្នុងការដាក់ទោស និងការដាក់បណ្ដាសារបស់ទ្រង់។ នេះហើយជានិស្ស័យសុចរិតរបស់ព្រះជាម្ចាស់ ដែលមនុស្សមិនអាចផ្លាស់ប្ដូរបានទេ។ ដោយសារតែការស្វះស្វែងរកផ្ទាល់ខ្លួនរបស់ពួកគេ ទើបមនុស្សទទួលបានការអនុញ្ញាតរបស់ព្រះជាម្ចាស់ ហើយរស់នៅក្នុងពន្លឺ។ ដោយសារតែការបោកបញ្ឆោតប្រកបដោយល្បិចកលរបស់ពួកគេ នោះទើបមនុស្សត្រូវបានព្រះជា

ម្ចាស់ដាក់បណ្ដាសា ហើយធ្លាក់ចូលទៅក្នុងការដាក់ទោស។ ដោយសារតែទង្វើអាក្រក់របស់ពួកគេ ទើបមនុស្សត្រូវបានព្រះជាម្ចាស់ដាក់ទោស ហើយដោយសារតែការចង់បាន និងភាពស្មោះត្រង់របស់ពួកគេ ទើបមនុស្សទទួលបានព្រះពររបស់ព្រះជាម្ចាស់។ ព្រះជាម្ចាស់ទ្រង់សុចរិតៈ ទ្រង់ប្រទានពរចំពោះមនុស្សមានជីវិត ហើយដាក់បណ្ដាសាមនុស្សស្លាប់ ដូច្នេះហើយទើបពួកគេតែងតែនៅក្នុងសេចក្ដីស្លាប់ ហើយមិនដែលរស់នៅក្នុងពន្លឺរបស់ទ្រង់ឡើយ។ ព្រះជាម្ចាស់នឹងនាំយកមនុស្សមានជីវិតទៅក្នុងនគររបស់ទ្រង់ និងចូលទៅក្នុងព្រះពររបស់ទ្រង់ ដើម្បីនៅជាមួយទ្រង់ជារៀងរហូត។ ប៉ុន្តែសម្រាប់មនុស្សស្លាប់វិញ ទ្រង់នឹងប្រហារពួកគេ ហើយប្រគល់ពួកគេទៅក្នុងសេចក្ដីស្លាប់អស់កល្បជានិច្ច។ ពួកគេគឺជាកម្មវត្ថុនៃការបំផ្លាញរបស់ទ្រង់ ហើយគេនឹងនៅតែជាកម្មសិទ្ធិរបស់សាតាំងជានិរន្តន៍។ ព្រះជាម្ចាស់មិនប្រព្រឹត្តចំពោះមនុស្សណាម្នាក់ដោយអយុត្តិធម៌ឡើយ។ អស់អ្នកដែលពិតជាស្វះស្វែងរកព្រះជាម្ចាស់ នឹងនៅតែនៅក្នុងដំណាក់របស់ព្រះជាម្ចាស់យ៉ាងជាក់ច្បាស់ ហើយអស់អ្នកដែលមិនស្ដាប់បង្គាប់ព្រះជាម្ចាស់ ព្រមទាំងមិនចុះសម្រុងជាមួយទ្រង់ នឹងរស់នៅក្នុងការដាក់ទោសរបស់ទ្រង់យ៉ាងជាក់ច្បាស់។ ប្រហែលជាអ្នកមិនប្រាកដអំពីកិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងសាច់ឈាមទេ ប៉ុន្តែថ្ងៃមួយ សាច់ឈាមរបស់ព្រះជាម្ចាស់នឹងមិនរៀបចំចាត់ចែងទីបញ្ចប់របស់មនុស្សដោយផ្ទាល់នោះទេ។ ផ្ទុយទៅវិញ វិញ្ញាណរបស់ទ្រង់នឹងរៀបចំចាត់ចែងទិសដៅរបស់មនុស្ស ហើយនៅពេលនោះ មនុស្សនឹងដឹងថា សាច់ឈាមរបស់ព្រះជាម្ចាស់ និងវិញ្ញាណរបស់ទ្រង់គឺតែមួយ ដឹងថា សាច់ឈាមរបស់ទ្រង់មិនអាចប្រព្រឹត្តកំហុសបាន ហើយដឹងថា វិញ្ញាណរបស់ទ្រង់កាន់តែមិនអាចមានកំហុសបានទៀតផង។ ចុងបញ្ចប់ ទ្រង់នឹងទទួលយកអស់អ្នកដែលចូលមកឯជីវិតទៅក្នុងព្រះរាជ្យរបស់ទ្រង់ជាប្រាកដ មិនឲ្យលើស ហើយក៏មិនឲ្យខ្វះម្នាក់ណាឡើយ។ ចំពោះមនុស្សស្លាប់វិញ ដែលមិនបានចូលមកឯជីវិត នោះពួកគេនឹងត្រូវបោះទៅក្នុងទីជម្រករបស់សាតាំង។

# ការមាននិស្ស័យដែលមិនចេះផ្លាស់ប្ដូរ គឺជាការប្រឆាំងនឹងព្រះជាម្ចាស់

ក្រោយពីមានការធ្លាក់ចូលក្នុងសេចក្ដីពុករលួយជាច្រើនពាន់ឆ្នាំមក មនុស្សលោកមានភាពស្ពឹកស្រពន់ និងល្ងិតល្ងង់ ដ្បិតគេបានក្លាយជាអារក្សដែលបានទាស់ប្រឆាំងនឹងព្រះជាម្ចាស់ រហូតដល់ការបះបោររបស់មនុស្សចំពោះព្រះជាម្ចាស់ត្រូវបានចងក្រងក្នុងសៀវភៅប្រវត្តិសាស្ត្រ ហើយមនុស្សលោកខ្លួនឯងទៀតសោត ក៏មិនអាចរៀបរាប់អស់អំពីទង្វើបះបោររបស់ខ្លួនបានពេញលេញដែរ ដ្បិតមនុស្សត្រូវបានសាតាំងបណ្ដាលឲ្យក្លាយជាពុករលួយអស់ ហើយសាតាំងក៏បាននាំឲ្យមនុស្សវង្វេង រហូតដល់មិនដឹងថា តើត្រូវងាកមកវិញនៅត្រង់ណាដែរ។ សូម្បីសព្វថ្ងៃនេះក្ដី មនុស្សលោកនៅតែក្បត់នឹងព្រះជាម្ចាស់ដដែល ដ្បិតនៅពេលមនុស្សបានមើលឃើញព្រះជាម្ចាស់ហើយ ក៏គេនៅតែក្បត់នឹងទ្រង់ ហើយនៅពេលដែលគេមិនអាចឃើញព្រះអង្គ នោះក៏គេនៅតែក្បត់នឹងព្រះអង្គដដែល។ ជាងនេះទៀត សូម្បីតែអ្នកដែលបានធ្វើជាសក្ខីភាពនៃបណ្ដាសា និងសេចក្ដីក្រោធរបស់ព្រះជាម្ចាស់ហើយក៏ដោយ ក៏នៅតែក្បត់នឹងព្រះអង្គទៀត។ ដូច្នេះ ខ្ញុំសូមប្រាប់ថា វិចារណញ្ញាណរបស់មនុស្សបានបាត់បង់មុខងារដើមហើយ រីឯមនសិការរបស់មនុស្សក៏ដូចគ្នាដែរ។ មនុស្សលោកដែលខ្ញុំរៀបរាប់នេះ គឺជាសត្វសាហាវនៅក្នុងសណ្ឋានជាមនុស្ស គេជាសត្វពស់ដែលមានពិស ហើយមិនថាគេព្យាយាមសម្ដែងជាគួរឲ្យអាណិតយ៉ាងណានៅចំពោះមុខខ្ញុំ ក៏ខ្ញុំគ្មានក្ដីអាណិតចំពោះគេដែរ ដ្បិតមនុស្សលោកមិនចេះបែងចែកខ្មៅ និងស មិនចេះបែងចែកសេចក្ដីពិត និងសេចក្ដីមិនពិត។ វិចារណញ្ញាណរបស់មនុស្សមានភាពស្រពន់ណាស់ ប៉ុន្តែគេនៅតែប្រាថ្នាចង់បានព្រះពរថែមទៀត ភាពជាមនុស្សរបស់គេមានភាពអាប់ឱនខ្លាំងណាស់ ប៉ុន្តែគេក៏នៅតែប្រាថ្នាចង់បានអធិបតេយ្យភាពរបស់អង្គក្សត្រា។ តើមនុស្សដែលមានការយល់ឃើញបែបនេះ ត្រូវធ្វើជាស្ដេចរបស់នរណាទៅ? តើមនុស្សដែលមានសារជាតិជាមនុស្សបែបនេះ អាចអង្គុយលើបល្ល័ង្ក

បានយ៉ាងដូចម្ដេចទៅ? មនុស្សលោកពិតជាគ្មានការអៀនខ្មាសទាល់តែសោះ! គេជាមនុស្សមានអំនួត! ចំពោះអ្នករាល់គ្នាដែលប្រាថ្នាចង់ទទួលបានព្រះពរ នោះខ្ញុំសូមប្រាប់អ្នករាល់គ្នាថា ដំបូង ត្រូវរកកញ្ចក់ឆ្លុះជាមុនសិន រួចក្រឡេកមើលពីភាពអាក្រក់របស់ខ្លួនឯង ហើយសួរថា តើអ្នករាល់គ្នាមានមុខមាត់ជាមនុស្សម្នាក់ ដែលអាចទទួលបានព្រះពរដែរឬទេ? គឺអ្នករាល់គ្នាមិនមានការផ្លាស់ប្ដូរនិស្ស័យបន្តិចណាសោះ ហើយអ្នករាល់គ្នាក៏មិនទាន់បានយកសេចក្ដីពិតទៅអនុវត្តតាមដែរ តែអ្នករាល់គ្នានៅតែប្រាថ្នាចង់បានសេចក្ដីអស្ចារ្យ នៅថ្ងៃបន្ទាប់ដដែល។ អ្នករាល់គ្នាកំពុងតែបោកបញ្ឆោតខ្លួនឯងហើយ! មនុស្សដែលកើតមកក្នុងទឹកដីកខ្វក់បែបនេះ បានរងការខូចខាតពីសង្គមយ៉ាងខ្លាំង បានរងឥទ្ធិពលពីក្រមសីលធម៌សក្ដិភូមិ ហើយក៏ទទួលបានការបង្រៀននៅ «វិទ្យាស្ថានឧត្ដមសិក្សា» ទៀតផង។ ការគិតថយក្រោយ ការអាក្រក់ខូចផ្នែកសីលធម៌ ការយល់ឃើញតូចទាបពីជីវិត ទស្សនៈវិទ្យាសម្រាប់ការរស់នៅដ៏គួរឲ្យស្អប់ខ្ពើម ជីវិតរស់នៅដែលគ្មានតម្លៃទាល់តែសោះ ព្រមទាំងរបៀបរស់នៅ និងទំនៀមទម្លាប់ដ៏ថោកទាប ដែលទាំងអស់នេះបានឈ្លានពានដួងចិត្តរបស់មនុស្សយ៉ាងខ្លាំងក្លា ព្រមទាំងបានធ្វើឲ្យចុះខ្សោយ និងវាយប្រហារមនសិការរបស់ពួកគេផងដែរ។ ជាលទ្ធផល មនុស្សលោកកាន់តែស្ថិតនៅឆ្ងាយពីព្រះជាម្ចាស់ខ្លាំងណាស់ ហើយកាន់តែទាស់ប្រឆាំងនឹងព្រះជាម្ចាស់ច្រើនទៀតផង។ បន្តិចម្ដងៗ និស្ស័យរបស់មនុស្សក៏កាន់តែសាហាវទៅៗដែរ ហើយមិនមាននរណាម្នាក់ដែលសុខចិត្តបោះបង់គ្រប់យ៉ាងដើម្បីព្រះជាម្ចាស់ឡើយ គ្មាននរណាម្នាក់ដែលនឹងស្ដាប់បង្គាប់ព្រះជាម្ចាស់ចេញពីចិត្ត ហើយលើសពីនេះទៅទៀតនោះ ក៏គ្មានបុគ្គលណាម្នាក់ដែលនឹងស្វែងរកការបង្ហាញព្រះកាយរបស់ព្រះជាម្ចាស់អស់ពីចិត្តដែរ។ ផ្ទុយទៅវិញ ដោយស្ថិតក្រោមដែនត្រួតត្រារបស់សាតាំង មនុស្សលោកមិនបានធ្វើអ្វីទាល់តែសោះ ក្រៅពីចង់បានការសប្បាយដោយយល់ព្រមឲ្យភាពពុករលួយនៃសាច់ឈាមនៅក្នុងទឹកដីដែលពេញដោយភក់ជ្រាំនេះ។ សូម្បីពេលដែលពួកគេបានឮអំពីសេចក្ដីពិតហើយក្ដី អស់អ្នកដែលរស់នៅក្នុងភាពងងឹតមិនបានគិតដល់ការយកសេចក្ដីពិតទៅអនុវត្តទេ ហើយពួកគេក៏

មិនមានទំនោរក្នុងការស្វែងរកព្រះជាម្ចាស់ដែរ ទោះបីជាពួកគេបានឃើញការបង្ហាញព្រះកាយរបស់ព្រះជាម្ចាស់ហើយក្ដី។ តើមនុស្សលោកដែលគួរឲ្យស្អប់ខ្ពើមយ៉ាងនេះ អាចមានឱកាសទទួលបានការសង្គ្រោះបានយ៉ាងដូចម្ដេច? តើមនុស្សលោកដែលអាប់ឱនខ្លាំងយ៉ាងនេះ អាចរស់នៅក្នុងពន្លឺបានយ៉ាងដូចម្ដេច?

ការផ្លាស់ប្ដូរនិស្ស័យរបស់មនុស្សចាប់ផ្ដើមជាមួយនឹងការយល់ដឹងពីសារជាតិគេ និងតាមរយៈការផ្លាស់ប្ដូរការគិត លក្ខណៈធម្មជាតិ និងទស្សនៈវិស័យផ្លូវចិត្ត និងតាមរយៈការផ្លាស់ប្ដូរជាមូលដ្ឋាន។ មានតែតាមរយៈរបៀបនេះទេ ទើបការផ្លាស់ប្ដូរពិតប្រាកដ អាចសម្រេចបាននៅក្នុងនិស្ស័យរបស់មនុស្ស។ និស្ស័យពុករលួយរបស់មនុស្ស កើតឡើងដោយសារសាតាំងបានបំពុល និងជាន់ឈ្លីពួកគេ និងដោយសារតែមហន្តរាយដ៏អាក្រក់ ដែលសាតាំងបានធ្វើដាក់មកលើការគិត សីលធម៌ ការយល់ដឹង និងវិចារណញ្ញាណរបស់គេ។ វាច្បាស់ណាស់ថា គឺដោយសារតែមូលដ្ឋានសំខាន់របស់មនុស្សត្រូវបានសាតាំងធ្វើឲ្យពុករលួយអស់ និងខុសគ្នាទាំងស្រុងពីអ្វីដែលព្រះជាម្ចាស់បានបង្កើតពួកវា ពីដំបូងមក ទើបធ្វើឲ្យមនុស្សទាស់ប្រឆាំងនឹងព្រះជាម្ចាស់ និងមិនយល់អំពីសេចក្ដីពិត។ ដូចនេះ ការផ្លាស់ប្ដូរនិស្ស័យរបស់មនុស្សគួរតែចាប់ផ្ដើមជាមួយនឹងការផ្លាស់ប្ដូរការគិត ការយល់ដឹង និងវិចារណញ្ញាណរបស់មនុស្ស ដែលនឹងធ្វើការផ្លាស់ប្ដូរការយល់ដឹងរបស់គេអំពីព្រះជាម្ចាស់ ព្រមទាំងការយល់ដឹងអំពីសេចក្ដីពិត។ អស់អ្នកណាដែលកើតមកនៅលើទឹកដី ដែលពេញដោយសេចក្ដីពុករលួយបំផុតនោះ រឹតតែមិនដឹងអ្វីសោះពីព្រះជាម្ចាស់ ឬមិនដឹងចំពោះអត្ថន័យនៃការជឿលើព្រះជាម្ចាស់។ នៅពេលមនុស្សដែលកាន់តែពុករលួយពួកគេកាន់តែមិនសូវដឹងថា ព្រះជាម្ចាស់មានពិតប្រាកដមែន ហើយវិចារណញ្ញាណ និងការចេះដឹងរបស់គេ ក៏កាន់តែខ្សោយទៅៗដែរ។ ប្រភពនៃការជំទាស់ និងការបះបោររបស់មនុស្សប្រឆាំងនឹងព្រះជាម្ចាស់ គឺជាសេចក្ដីពុករលួយរបស់គេដែលបង្កដោយសាតាំង។ ដោយសារតែសេចក្ដីពុករលួយរបស់សាតាំង មនសិការរបស់មនុស្សក៏បានក្លាយជាស្ពឹកអស់ ដ្បិតគេគ្មានសីលធម៌ គំនិតរបស់គេចុះខ្សោយទៅៗ ហើយ

ទស្សនៈវិស័យផ្លូវចិត្តរបស់គេក៏ឈានថយក្រោយដែរ។ មុនពេលមនុស្សត្រូវសាតាំងបណ្ដាលឲ្យក្លាយជាពុករលួយ មនុស្សបានដើរតាមព្រះជាម្ចាស់ និងស្ដាប់បង្គាប់ព្រះបន្ទូលរបស់ទ្រង់ បន្ទាប់ពីបានស្ដាប់ឮពួកវាដោយឯកឯង។ គេជាមនុស្សដែលមានវិចារណញ្ញាណ និងមនសិការល្អ ហើយជាមនុស្សជាតិធម្មតាម្នាក់។ ក្រោយពីសាតាំងធ្វើឲ្យគេធ្លាក់ក្នុងសេចក្ដីអាក្រក់មក វិចារណញ្ញាណ មនសិការ និងភាពជាមនុស្សរបស់គេក៏បានក្លាយជាអន់ថយ ហើយក៏ត្រូវខូចអស់ដោយសារសាតាំង។ ដូចនេះ គេក៏បានបាត់បង់ការស្ដាប់បង្គាប់ និងសេចក្ដីស្រលាញ់ចំពោះព្រះជាម្ចាស់។ វិចារណញ្ញាណរបស់មនុស្សបានខុសពីធម្មតា និស្ស័យរបស់គេក៏បានក្លាយដូចជាសត្វ ហើយការបះបោរប្រឆាំងនឹងព្រះជាម្ចាស់របស់គេក៏មានកាន់តែញឹកញាប់ និងកាន់តែធ្ងន់ធ្ងរ។ ប៉ុន្ដែមនុស្សលោកនៅតែមិនដឹង និងមិនទទួលស្គាល់រឿងនេះ ហើយក៏បានជំទាស់ប្រឆាំង និងបះបោរទាំងងងឹតងងល់។ និស្ស័យពិតរបស់មនុស្សត្រូវបានលាតត្រដាងឡើង នៅក្នុងការបង្ហាញអំពីវិចារណញ្ញាណ ការយល់ដឹង និងមនសិការរបស់គេ ដ្បិតវិចារណញ្ញាណ និងការយល់ដឹងរបស់គេមិនសមហេតុផល ហើយមនសិការរបស់គេក៏បានក្លាយជាស្រអាប់យ៉ាងខ្លាំង ដូចនេះ និស្ស័យរបស់គេមានការបះបោរប្រឆាំងនឹងព្រះជាម្ចាស់។ ប្រសិនបើវិចារណញ្ញាណ និងការយល់ដឹងរបស់មនុស្សមិនអាចផ្លាស់ប្ដូរ នោះការផ្លាស់ប្ដូរនិស្ស័យរបស់គេ គឺមិនអាចទៅរួចនោះទេ ដូចជាការគោរពតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែរ។ ប្រសិនបើវិចារណញ្ញាណរបស់មនុស្សមិនត្រឹមត្រូវទេ នោះគេមិនអាចបម្រើព្រះជាម្ចាស់ និងមិនសក្ដិសមឲ្យព្រះជាម្ចាស់ប្រើប្រាស់ឡើយ។ «វិចារណញ្ញាណធម្មតា» សំដៅលើការស្ដាប់បង្គាប់ និងការស្មោះត្រង់ចំពោះព្រះជាម្ចាស់ ការចង់បានព្រះជាម្ចាស់ជាខ្លាំង និងការមិនមានចិត្តងាករេចំពោះព្រះជាម្ចាស់ផង។ វាសំដៅលើការមានចិត្តមួយថ្លើមមួយ ចំពោះព្រះជាម្ចាស់ ព្រមទាំងមិនមានបំណងប្រឆាំងនឹងព្រះជាម្ចាស់ឡើយ។ ការមានវិចារណញ្ញាខុសពីធម្មតា គឺមិនដូច្នេះឡើយ។ ដោយសារតែសាតាំងបានធ្វើឲ្យមនុស្សទៅជាពុករលួយ មនុស្សក៏មានសញ្ញាណផ្សេងៗអំពីព្រះជាម្ចាស់ ហើយ

គេគ្មានភាពស្មោះត្រង់ចំពោះទ្រង់ ឬប្រាថ្នាចង់បានទ្រង់ឡើយ។ គេក៏មិននិយាយអ្វីចេញពីមនសិការ ចំពោះព្រះជាម្ចាស់ឡើយ។ មនុស្សមានបំណងទាស់ប្រឆាំងនឹងព្រះជាម្ចាស់ និងបានធ្វើការវិនិច្ឆ័យទ្រង់ ហើយលើសពីនេះទៅទៀត ថែមទាំងប្រមាថទ្រង់នៅពីក្រោយខ្នងព្រះអង្គទៀតផង។ មនុស្សបានធ្វើការវិនិច្ឆ័យព្រះជាម្ចាស់ ទាំងដែលដឹងច្បាស់ថាព្រះអង្គ គឺជាព្រះជាម្ចាស់ ដ្បិតមនុស្សគ្មានបំណងស្ដាប់បង្គាប់ព្រះជាម្ចាស់ឡើយ ហើយគ្រាន់តែទាមទារនេះទាមទារនោះពីទ្រង់ ទាំងងងឹតងងល់ប៉ុណ្ណោះ។ មនុស្សបែបនេះ គឺមនុស្សដែលមានវិចារណញ្ញាណមិនសមស្រប មិនអាចស្គាល់ពីអាកប្បកិរិយាដ៏គួរឲ្យស្អប់ខ្ពើមរបស់ខ្លួន ឬមានការសោកស្ដាយអំពីការបះបោររបស់ខ្លួនទេ។ ប្រសិនបើមនុស្សអាចស្គាល់ពីខ្លួនឯងបាន នោះពួកគេបានទទួលនូវវិចារណញ្ញាណបន្តិចបន្តួចរបស់ពួកគេឡើងវិញហើយ ដ្បិតនៅពេលមនុស្សដែលមិនអាចស្គាល់ខ្លួនឯង កាន់តែបះបោរជំទាស់នឹងព្រះជាម្ចាស់ នោះវិចារណញ្ញាណរបស់ពួកគេ ក៏កាន់តែគ្មានហេតុផលដែរ។

ការបើកសម្ដែង ឲ្យឃើញអំពីនិស្ស័យពុករលួយរបស់មនុស្ស គ្មានប្រភពមកពីណាក្រៅពីមនសិការដែលអន់ថយ សន្ដានព្យាបាទ ព្រមទាំងវិចារណញ្ញាណដែលមិនសមរម្យរបស់គេ។ ប្រសិនបើមនសិការ និងវិចារណញ្ញាណរបស់មនុស្ស អាចប្រែក្លាយទៅជាធម្មតាម្ដងទៀតបាន នោះគេនឹងក្លាយជាមនុស្សម្នាក់ដែលសក្ដិសមនឹងប្រើប្រាស់ នៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់។ វាជារឿងធម្មតាទៅហើយ ដោយសារមនសិការរបស់មនុស្សតែងតែស្ពឹកស្រពន់ជានិច្ច ហើយដោយសារតែវិចារណញ្ញាណរបស់មនុស្ស ដែលមិនធ្លាប់មានភាពសមរម្យផងនោះ ក៏កាន់តែអន់ថយទៅៗ ទើបមនុស្សលោកបះបោរប្រឆាំងនឹងព្រះជាម្ចាស់កាន់តែខ្លាំង គេថែមទាំងដល់ថ្នាក់ឆ្កាងព្រះយេស៊ូវនៅលើឈើឆ្កាង ព្រមទាំងបដិសេធចំពោះការយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់ នៅគ្រាចុងក្រោយដែលទ្រង់យាងចូលក្នុងដំណាក់របស់ព្រះអង្គ ហើយគេក៏បានថ្កោលទោសសាច់ឈាមរបស់ព្រះជាម្ចាស់ និងមើលងាយបន្ទាបបន្ថោកសាច់ឈាមរបស់ព្រះអង្គផង។ ប្រសិនបើមនុស្សមាននូវភាពជាមនុស្សតែបន្តិចនោះ

គេនឹងមិនប្រព្រឹត្តយ៉ាងឃោរឃៅ ចំពោះសាច់ឈាមរបស់ព្រះជាម្ចាស់ដែលបានចាប់បដិសន្ធិមកនោះឡើយ។ ប្រសិនបើគេមានវិចារណញ្ញាណតែបន្តិច នោះគេនឹងមិនប្រព្រឹត្តយ៉ាងព្រៃផ្សៃ ចំពោះសាច់ឈាមដែលព្រះជាម្ចាស់បានចាប់បដិសន្ធិនោះឡើយ។ ប្រសិនបើគេមានមនិសការតែបន្តិច នោះគេនឹងមិន «អរព្រះគុណ» ចំពោះព្រះជាម្ចាស់ដែលបានចាប់បដិសន្ធិមក តាមរបៀបនេះឡើយ។ មនុស្សរស់នៅក្នុងយុគសម័យដែលព្រះជាម្ចាស់បានក្លាយជាសាច់ឈាម ប៉ុន្ដែ គេមិនអាចអរព្រះគុណព្រះជាម្ចាស់ សម្រាប់ការប្រទាននូវឱកាសល្អដល់ខ្លួនឡើយ ហើយផ្ទុយទៅវិញ គេក៏បានដាក់បណ្ដាសាចំពោះការយាងមករបស់ព្រះជាម្ចាស់ ឬបានព្រងើយកន្តើយ ចំពោះសេចក្ដីពិតនៃការការយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់ទាំងស្រុង ហើយក៏ហាក់ដូចជាប្រឆាំង និងនឿយណាយ ចំពោះការចាប់បដិសន្ធិនេះផងដែរ។ សរុបមក បើទោះបីជាមនុស្សប្រព្រឹត្តចំពោះការយាងមកវិញរបស់ព្រះជាម្ចាស់យ៉ាងណាក៏ដោយ ក៏ព្រះជាម្ចាស់តែងតែអនុវត្តកិច្ចការរបស់ទ្រង់ ដោយអត់ធ្មត់ ទោះបីជាមនុស្សមិនបានស្វាគមន៍ព្រះអង្គសូម្បីតែបន្តិច និងតែងទូលសុំពីព្រះអង្គទាំងងងឹតងងល់ក្ដី។ និស្ស័យរបស់មនុស្ស បានប្រែក្លាយទៅជាឃោឃៅយ៉ាងខ្លាំង វិចារណញ្ញាណរបស់គេក៏កាន់តែស្ពឹកស្រពន់ខ្លាំងដែរ ហើយមនសិការរបស់គេក៏ត្រូវបានអារក្សជាន់ឈ្លីទាំងស្រុង ហើយលែងជាមនសិការដើមរបស់មនុស្សជាយូរមកហើយ។ មនុស្សមិនត្រឹមតែមិនដឹងគុណដល់ព្រះដែលក្លាយជាសាច់ឈាមចំពោះការដែលទ្រង់ប្រទាននូវជីវិត និងព្រះគុណយ៉ាងច្រើនដល់មនុស្សជាតិទេ តែគេបែរជាតូចចិត្តនឹងព្រះជាម្ចាស់ដែលបានប្រទាននូវសេចក្ដីពិតដល់ខ្លួនទៅវិញ នេះគឺដោយសារមនុស្សមិនមានចំណាប់អារម្មណ៍ចំពោះសេចក្ដីពិតសូម្បីតែបន្តិច ទើបគេតូចចិត្តចំពោះព្រះជាម្ចាស់បែបនេះ។ មនុស្សមិនត្រឹមតែមិនអាចលះបង់ជីវិតរបស់ខ្លួន សម្រាប់ព្រះជាម្ចាស់ដែលបានយកកំណើតជាមនុស្សនោះទេ ប៉ុន្ដែគេថែមទាំងបានព្យាយាមទាញយកព្រះហឫទ័យអធ្យាស្រ័យពីទ្រង់ ហើយទាមទារផលប្រយោជន៍លើសពីអ្វីដែលមនុស្សបានថ្វាយចំពោះព្រះជាម្ចាស់រាប់សិបដងទៅទៀត។ មនុស្ស

ដែលមានមនសិការ និងវិចារណញ្ញាណបែបនេះ គិតថា នេះមិនមែនជាបញ្ហាធំដុំនោះទេ ហើយក៏នៅតែជឿថា ពួកគេបានលះបង់យ៉ាងច្រើនសម្រាប់ព្រះជាម្ចាស់ និងគិតថា ព្រះជាម្ចាស់បានប្រទានពរដល់ពួកគេបន្តិចបន្តួចប៉ុណ្ណោះ។ មានមនុស្សលាដៃទារឲ្យខ្ញុំសងទឹកដោះគោគេវិញពីរចាន ដ្បិតពួកគេបានឲ្យទឹកខ្ញុំមួយចាន ឬទារឲ្យខ្ញុំចេញថ្លៃបន្ទប់សំណាក់ឲ្យគេបីបួនយប់ ដោយសារតែគេចេញថ្លៃបន្ទប់សំណាក់ ឲ្យខ្ញុំមួយយប់។ តើអ្នកនៅតែចង់បានជីវិត ទាំងមានលក្ខណៈជាមនុស្ស និងមនសិការបែបនេះ ដូចម្ដេចបាន? អ្នកពិតជាមនុស្សទុរគតគួរឲ្យមើលងាយមែន! លក្ខណៈជាមនុស្ស និងមនសិការបែបនេះនៅក្នុងខ្លួនគេ គឺជាដើមហេតុដែលបណ្ដាលឲ្យព្រះជាម្ចាស់ដែលចាប់បដិសន្ធិជាមនុស្ស យាងមកត្រាច់ចរពេញផែនដី ដោយគ្មានកន្លែងណាធ្វើជាទីជម្រកឡើយ។ មនុស្សដែលមានមនសិការ និងលក្ខណៈជាមនុស្សពិតប្រាកដ គួរតែថ្វាយបង្គំ និងបម្រើព្រះជាម្ចាស់ ដែលបានយកកំណើតជាមនុស្សដោយអស់ពីចិត្ត មិនមែនធ្វើដោយព្រោះតែព្រះអង្គបានធ្វើកិច្ចការជាច្រើនឡើយ តែត្រូវបម្រើព្រះអង្គ បើទោះបីជាទ្រង់មិនបានធ្វើការសោះក្ដី។ កិច្ចការនេះគួរតែត្រូវបានធ្វើឡើង ដោយបុគ្គលដែលមានវិចារណញ្ញាណត្រឹមត្រូវ ហើយវាគឺជាកាតព្វកិច្ចរបស់មនុស្ស។ មនុស្សភាគច្រើនហ៊ានទាំងនិយាយលក្ខខណ្ឌជាច្រើន ចំពោះការបម្រើព្រះជាម្ចាស់ទៀតផង៖ ពួកគេមិនខ្វល់ទេថា ទ្រង់ជាព្រះជាម្ចាស់ ឬជាមនុស្ស ហើយពួកគេគ្រាន់តែនិយាយអំពីលក្ខខណ្ឌរបស់ខ្លួនឯង ហើយគេព្យាយាមសម្រេចសេចក្ដីប្រាថ្នារបស់ខ្លួនតែប៉ុណ្ណោះ។ នៅពេលអ្នករាល់គ្នាចម្អិនអាហារឲ្យខ្ញុំ អ្នករាល់គ្នាទាមទារថ្លៃឈ្នួលចុងភៅ នៅពេលអ្នករត់ឲ្យខ្ញុំ អ្នកក៏សុំថ្លៃរត់ នៅពេលអ្នកធ្វើការឲ្យខ្ញុំ អ្នកក៏ទាមទារថ្លៃធ្វើការដែរ នៅពេលអ្នកបោកគក់សម្លៀកបំពាក់របស់ខ្ញុំ អ្នកទាមទារថ្លៃបោកគក់ នៅពេលអ្នកផ្គត់ផ្គង់ដល់ក្រុមជំនុំ អ្នកក៏ទាមទារសំណងថ្លៃចំណាយមកវិញ នៅពេលអ្នកអធិប្បាយ អ្នកក៏ទាមទារថ្លៃអធិប្បាយ នៅពេលអ្នកចែកចាយសៀវភៅ អ្នកក៏ទាមទារថ្លៃឈ្នួលចែកចាយសៀវភៅនោះ ហើយនៅពេលដែលអ្នកសរសេរ អ្នកក៏ទាមទារថ្លៃនិពន្ធដែរ។ អស់អ្នកដែលខ្ញុំបានដោះស្រាយរួច ថែមទាំងបានទាមទារ

ការតបស្នងពីខ្ញុំទៀត រីឯអស់អ្នកដែលត្រូវបានបញ្ជូនទៅផ្ទះ ក៏ទាមទារនូវសំណង សម្រាប់ការខូចខាតកេរ្តិ៍ឈ្មោះរបស់គេ អស់អ្នកដែលមិនទាន់បានរៀបការ ក៏ទាមទារថ្លៃបណ្ណាការ ឬការទូទាត់សំណងសម្រាប់ការបាត់បង់ភាពជាយុវវ័យរបស់គេ អស់អ្នកដែលបានសម្លាប់សត្វមាន់ ក៏បានទាមទារថ្លៃសម្លាប់សត្វ អស់អ្នកដែលចៀនអាហារ ក៏ទាមទារថ្លៃឈ្នួលចៀន ហើយអស់អ្នកដែលស្លសម្ល ក៏ទាមទារថ្លៃស្លនោះដែរ...។ នេះហើយជាលក្ខណៈមនុស្សជាតិដ៏ខ្ពង់ខ្ពស់ និងអស្ចារ្យរបស់អ្នករាល់គ្នានោះ ហើយទង្វើទាំងនេះហើយដែលមនសិការដ៏កក់ក្ដៅរបស់អ្នករាល់គ្នាយកតម្រាប់តាម។ តើវិចារណញាណរបស់អ្នករាល់គ្នានៅឯណា? តើលក្ខណៈជាមនុស្សរបស់អ្នកនៅឯណា? ខ្ញុំប្រាប់អ្នករាល់គ្នាចុះ! ប្រសិនបើអ្នករាល់គ្នានៅតែបន្តបែបនេះ នោះខ្ញុំនឹងឈប់ធ្វើការក្នុងអ្នករាល់គ្នាជាមិនខាន។ ខ្ញុំនឹងមិនធ្វើការក្នុងចំណោមហ្វូងសត្វតិរច្ឆាន ដែលពាក់ស្បែកជាមនុស្សឡើយ ខ្ញុំនឹងមិនរងទុក្ខជំនួសក្រុមមនុស្សដែលយកទឹកមុខទន់ភ្លន់មកលាក់បាំងចិត្តព្រៃផ្សៃឡើយ ខ្ញុំនឹងមិនស៊ូទ្រាំជួសហ្វូងសត្វមួយក្ដាប់ ដែលមិនអាចទទួលបានការសង្គ្រោះ សូម្បីតែបន្តិចនោះឡើយ។ នៅថ្ងៃដែលខ្ញុំយាងត្រលប់មករកអ្នករាល់គ្នាវិញ គឺជាថ្ងៃដែលអ្នករាល់គ្នាស្លាប់ជាមិនខាន វាជាថ្ងៃដែលភាពងងឹតចូលមកដល់អ្នករាល់គ្នា ហើយជាថ្ងៃដែលពន្លឺបោះបង់ចោលអ្នករាល់គ្នាផងដែរ។ ខ្ញុំប្រាប់អ្នករាល់គ្នាចុះ! ខ្ញុំនឹងមិនដែលមានចិត្តសប្បុរស ចំពោះក្រុមមនុស្សដូចជាអ្នករាល់គ្នាជាក្រុមមួយដែលអន់ជាងសត្វតិរច្ឆានទៅទៀតនោះឡើយ! ព្រះបន្ទូល និងសកម្មភាពរបស់ខ្ញុំមានដែនកំណត់ តាមភាពជាមនុស្សជាតិ និងមនសិការរបស់អ្នករាល់គ្នា នៅពេលនេះ ខ្ញុំនឹងមិនធ្វើការទៀតឡើយ ដ្បិតអ្នករាល់គ្នាខ្វះខាតមនសិការយ៉ាងខ្លាំង អ្នករាល់គ្នាបណ្ដាលឲ្យខ្ញុំមានការឈឺចាប់ក្រៃលែង ហើយឥរិយាបថដ៏គួរឲ្យស្អប់ខ្ពើមរបស់អ្នករាល់គ្នា ក៏ធ្វើឲ្យខ្ញុំខ្ពើមរអើមខ្លាំងណាស់ដែរ។ មនុស្សណាដែលខ្វះខាតនូវភាពជាមនុស្ស និងមនសិការខ្លាំងពេក នោះនឹងមិនអាចមានឱកាសទទួលបានការសង្គ្រោះឡើយ។ ខ្ញុំនឹងមិនសង្គ្រោះមនុស្សដែលគ្មានចិត្ត និងរមិលគុណឡើយ។ លុះវេលាកំណត់របស់ខ្ញុំមកដល់ ខ្ញុំនឹងបង្អុរភ្លើងដ៏សន្ធោសន្ធៅអស់កល្បជានិច្ចមកលើ

កូនចៅនៃសេចក្តីរឹងចចេស ដែលធ្លាប់ពន្យុះឲ្យខ្ញុំពិរោធយ៉ាងខ្លាំង ខ្ញុំនឹងដាក់ទណ្ឌកម្មជាដរាប ដល់សត្វលោកណាដែលធ្លាប់គ្រវែងខ្ញុំចោល ដោយគ្មានសន្តានចិត្ត និងបានបោះបង់ចោលខ្ញុំ ខ្ញុំនឹងយកភ្លើងនៃសេចក្តីក្រោធរបស់ខ្ញុំ មកដុតកូននៃសេចក្តីរឹងចចេស ដែលធ្លាប់បានរួមអាហារ និងរស់នៅជាមួយខ្ញុំ តែមិនបានជឿលើខ្ញុំ គឺមនុស្សដែលបានជេរប្រមាថ និងក្បត់ខ្ញុំ។ អស់អ្នកណាដែលពន្យុះឲ្យខ្ញុំមានសេចក្តីក្រោធ ខ្ញុំនឹងដាក់ទណ្ឌកម្មអ្នកនោះ ខ្ញុំនឹងបង្ហុរសេចក្តីក្រោធទាំងអស់របស់ខ្ញុំមកលើពួកតិរិច្ឆានដែលធ្លាប់ចង់នៅក្បែរខ្ញុំ ចង់បានឋានៈស្មើនឹងខ្ញុំ តែមិនបានថ្វាយបង្គំ ឬស្តាប់បង្គាប់ខ្ញុំទេ។ រំពាត់ដែលខ្ញុំយកមកវាយមនុស្ស នឹងត្រូវធ្លាក់ទៅលើពពួកសត្វដែលធ្លាប់តែរីករាយចំពោះការមើលថែរបស់ខ្ញុំ ហើយធ្លាប់រីករាយនឹងអាថ៌កំបាំងដែលខ្ញុំមានបន្ទូលប្រាប់ផង ព្រមទាំងអស់អ្នកណាដែលធ្លាប់ព្យាយាមយកការសប្បាយនឹងទ្រព្យសម្បត្តិដែលខ្ញុំប្រទានឲ្យ។ ខ្ញុំនឹងមិនអត់ទោសចំពោះនរណាដែលព្យាយាមដណ្តើមតំណែងរបស់ខ្ញុំទេ ខ្ញុំនឹងមិនទុកជីវិតឲ្យនរណាម្នាក់ដែលព្យាយាមដណ្តើមយកអាហារ និងសម្លៀកបំពាក់ពីខ្ញុំឡើយ។ ដ្បិតពេលនេះ អ្នករាល់គ្នាបានគេចផុតពីគ្រោះថ្នាក់ និងបន្តទាមទារពីខ្ញុំហួសហេតុ។ ពេលថ្ងៃនៃសេចក្តីក្រោធមកដល់ នោះអ្នករាល់គ្នានឹងមិនទាមទារអ្វីពីខ្ញុំទៀតឡើយ នៅគ្រានោះ ខ្ញុំនឹងឲ្យអ្នករាល់គ្នា «រីករាយ» នឹងភាពស្កប់ស្កល់នៃដួងចិត្តរបស់ខ្លួនឯង ខ្ញុំនឹងបង្ខំអ្នករាល់គ្នាផ្កាប់មុខទៅនឹងដី ហើយអ្នករាល់គ្នានឹងមិនអាចក្រោកឡើងម្តងទៀតបានឡើយ! មិនយូរប៉ុន្មាន ខ្ញុំនឹង «សង» បំណុលនេះទៅអ្នករាល់គ្នាវិញ ហើយខ្ញុំសង្ឃឹមថា អ្នករាល់គ្នានឹងរង់ចាំថ្ងៃនោះមកដល់ដោយសេចក្តីអត់ធ្មត់។

ប្រសិនបើមនុស្សដែលគួរឲ្យមើលងាយនេះ ពិតជាអាចបោះបង់បំណងប្រាថ្នាដ៏ហួសហេតុនេះចោលបាន រួចវិលត្រលប់ទៅរកព្រះជាម្ចាស់វិញ នោះគេនៅតែមានឱកាសទទួលបានការសង្គ្រោះដដែល។ ប្រសិនបើមនុស្ស មានដួងចិត្តដែលពិតជាចង់បានព្រះជាម្ចាស់មែន នោះព្រះជាម្ចាស់នឹងមិនបោះបង់គេចោលឡើយ។ មនុស្សបរាជ័យមិនបានព្រះជាម្ចាស់ គឺមិនមែនដោយសារតែ ព្រះជាម្ចាស់រញ្ជួយ

ព្រះទ័យ ឬដោយសារតែព្រះជាម្ចាស់មិនមានបំណងឲ្យមនុស្សទទួលបានទ្រង់ដែរ ប៉ុន្តែ មនុស្សទៅវិញទេដែលមិនចង់បានព្រះជាម្ចាស់ ហើយដោយសារតែមនុស្សមិនប្រញាប់ប្រញាល់ស្វែងរកព្រះជាម្ចាស់។ តើព្រះជាម្ចាស់អាចដាក់បណ្តាសាមនុស្សណាម្នាក់ នៅក្នុងចំណោមមនុស្សដែលស្វែងរកទ្រង់ពិតប្រាកដ ដូចម្តេចបាន? តើវិចារណញ្ញាណដ៏ត្រឹមត្រូវ និងមនសិការដែលប្រកបដោយវិចារណញ្ញាណ ត្រូវព្រះជាម្ចាស់ដាក់បណ្តាសាបានយ៉ាងដូចម្តេច? តើមនុស្សម្នាក់ដែលបានថ្វាយបង្គំ និងបម្រើព្រះជាម្ចាស់ពិតប្រាកដ ត្រូវឆេះបន្សុសដោយភ្លើងនៃព្រះពិរោធរបស់ទ្រង់ដូចម្តេចបាន? តើមនុស្សម្នាក់ដែលរីករាយនឹងស្តាប់បង្គាប់ព្រះជាម្ចាស់ ត្រូវបណ្តេញចេញពីព្រះដំណាក់របស់ព្រះជាម្ចាស់ ដូចម្តេចបាន? តើមនុស្សម្នាក់ដែលមិនអាចស្រលាញ់ព្រះជាម្ចាស់សមល្មម អាចរស់នៅក្នុងការដាក់ទោសរបស់ព្រះជាម្ចាស់ យ៉ាងដូចម្តេច? តើមនុស្សម្នាក់ដែលរីករាយនឹងលះបង់គ្រប់យ៉ាងសម្រាប់ព្រះជាម្ចាស់ ត្រូវទុកចោលដោយគ្មានអ្វីសោះ យ៉ាងដូចម្តេច? មនុស្សគ្មានឆន្ទៈនឹងព្យាយាមឲ្យបានព្រះជាម្ចាស់ គ្មានឆន្ទៈនឹងលះបង់ទ្រព្យរបស់ខ្លួនសម្រាប់ព្រះជាម្ចាស់ ហើយគ្មានឆន្ទៈនឹងលះបង់ការខិតខំក្នុងមួយជីវិតរបស់ខ្លួន ដើម្បីព្រះជាម្ចាស់ ផ្ទុយទៅវិញ គេពោលថា ព្រះជាម្ចាស់ជ្រុលពេក ដោយលក្ខណៈរបស់ព្រះជាម្ចាស់ ខុសឆ្ងាយពីការយល់ឃើញរបស់មនុស្សខ្លាំងពេក។ ដោយមានភាពជាមនុស្សបែបនេះ បើទោះបីជាអ្នករាល់គ្នាមិនកំណត់ការប្រឹងប្រែងរបស់ខ្លួន ក៏អ្នកនៅតែមិនអាចទទួលបានការយល់ព្រមពីព្រះជាម្ចាស់ ដោយមិនបាច់និយាយដល់ការពិតដែលថា អ្នកមិនស្វែងរកព្រះជាម្ចាស់ផង។ តើអ្នករាល់គ្នាមិនដឹងទេអីឬថា អ្នករាល់គ្នា គឺជាទំនិញខូចគុណភាពរបស់មនុស្សលោក? តើអ្នកមិនដឹងទេឬអីថា គ្មានភាពជាមនុស្សណា ដែលទាបជាងភាពជាមនុស្សរបស់អ្នករាល់គ្នាទេ? តើអ្នករាល់គ្នាមិនដឹងពីងារដែលអ្នកដទៃហៅអ្នក ដើម្បីផ្តល់កិត្តិយសដល់អ្នករាល់គ្នាទេឬអី? អស់អ្នកដែលស្រលាញ់ព្រះជាម្ចាស់ពិតប្រាកដ ហៅអ្នករាល់គ្នាថាជាឪពុកចចក ជាម្តាយចចក ជាកូនចចក និងជាចៅចចក។ អ្នករាល់គ្នាជាពូជពង្សចចក ហើយអ្នករាល់គ្នាគួរតែស្គាល់ពីអត្តសញ្ញាណរបស់ខ្លួន

ហើយមិនត្រូវភ្លេចឡើយ។ ចូរកុំគិតថាខ្លួនជាបុគ្គលដ៏ខ្ពង់ខ្ពស់នោះឡើយ៖ អ្នករាល់គ្នាគឺជាសត្វតិរិច្ឆានដ៏សាហាវនៅក្នុងចំណោមមនុស្សជាតិ។ តើអ្នករាល់គ្នាមិនដឹងរឿងនេះសោះមែនទេ? តើអ្នករាល់គ្នាដឹងថា ខ្ញុំបានប្រថុយគ្រោះថ្នាក់ខ្លាំងប៉ុនណាទេ ក្នុងការមកធ្វើការក្នុងចំណោមអ្នករាល់គ្នានេះ? ប្រសិនបើវិចារណញ្ញាណរបស់អ្នករាល់គ្នាមិនអាចដូចធម្មតាឡើងវិញបាន ហើយមនសិការរបស់អ្នករាល់គ្នា មិនអាចដំណើរការដូចធម្មតាទេនោះ អ្នករាល់គ្នានឹងមិនអាចបោះបង់ងារជា «ចចក» នោះចោលបានទេ អ្នករាល់គ្នានឹងមិនអាចគេចផុតថ្ងៃនៃបណ្ដាសា និងថ្ងៃនៃការដាក់ទោសរបស់អ្នករាល់គ្នាដែរ។ អ្នករាល់គ្នាបានកើតមកក្នុងឋានៈតូចទាប ជាជីវិតមួយដែលគ្មានតម្លៃទាល់តែសោះ។ តាមសន្ដានអ្នករាល់គ្នាពីកំណើត អ្នកគឺចចកស្រេកឃ្លានមួយហ្វូង ជាគំនរកម្ទេចកម្ទី និងជាគំនរសំរាម ហើយខ្ញុំខុសពីអ្នករាល់គ្នា គឺខ្ញុំមិនធ្វើការក្នុងចំណោមអ្នករាល់គ្នា ដើម្បីទទួលបានការពេញចិត្តឡើយ តែដោយសារតែតម្រូវការការងារដែលត្រូវបំពេញវិញ។ ប្រសិនបើអ្នករាល់គ្នានៅបន្តបះបោររបៀបនេះទៀត នោះខ្ញុំនឹងបញ្ឈប់កិច្ចការរបស់ខ្ញុំ ហើយនឹងមិនធ្វើការក្នុងចំណោមអ្នករាល់គ្នាជាថ្មីម្ដងទៀតឡើយ។ ផ្ទុយទៅវិញ ខ្ញុំនឹងផ្ទេរកិច្ចការរបស់ខ្ញុំ ទៅឲ្យមនុស្សមួយក្រុមផ្សេងទៀតដែលខ្ញុំសព្វព្រះទ័យ ហើយខ្ញុំនឹងចាកចេញពីអ្នករាល់គ្នារបៀបនេះ ជារៀងរហូត ដ្បិតខ្ញុំមិនចង់លើកតម្កើងអ្នកណាដែលជាសត្រូវនឹងខ្ញុំឡើយ។ ដូចនេះ តើអ្នករាល់គ្នានៅតែចង់ចុះសម្រុងជាមួយខ្ញុំ ឬចង់ធ្វើជាសត្រូវប្រឆាំងនឹងខ្ញុំ?

# មនុស្សគ្រប់គ្នាដែលមិនស្គាល់ព្រះជាម្ចាស់ គឺជាមនុស្សដែលប្រឆាំងទាស់នឹងព្រះជាម្ចាស់

ដើម្បីយល់ពីគោលបំណងនៃកិច្ចការរបស់ព្រះជាម្ចាស់ យល់ពីឥទ្ធិពលដែលកិច្ចការរបស់ទ្រង់មានមកលើមនុស្ស និងយល់ច្បាស់ពីបំណងព្រះហឫទ័យដ៏ពិតប្រាកដរបស់ទ្រង់ចំពោះមនុស្សលោក៖ នេះគឺជាអ្វីដែលមនុស្សគ្រប់គ្នាដែលដើរតាម

ព្រះជាម្ចាស់ គប្បីសម្រេចឲ្យបាន។ សព្វថ្ងៃនេះ ការយល់ដឹងអំពីកិច្ចការរបស់ព្រះជាម្ចាស់ គឺជាអ្វីដែលមនុស្សរាល់គ្នាខ្វះខាត។ ទង្វើដែលព្រះជាម្ចាស់បានធ្វើមកលើមនុស្ស កិច្ចការទាំងមូលរបស់ព្រះជាម្ចាស់ និងបំណងព្រះហឫទ័យដ៏ពិតប្រាកដរបស់ព្រះជាម្ចាស់ចំពោះមនុស្សលោក រាប់តាំងពីការបង្កើតភពផែនដីរហូតដល់បច្ចុប្បន្ន ទាំងអស់នេះគឺជារឿងដែលមនុស្សមិនដឹង និងមិនយល់។ ភាពខ្វះចន្លោះនេះ មិនមែនត្រឹមតែមើលមិនឃើញ នៅក្នុងចំណោមអ្នកកាន់សាសនាទាំងមូលប៉ុណ្ណោះទេ ប៉ុន្តែសូម្បីតែ ក្នុងចំណោមអ្នកដែលជឿលើព្រះជាម្ចាស់ក៏គ្មានដែរ។ នៅពេលគ្រានោះមកដល់ នោះអ្នកនឹងមើលឃើញព្រះជាម្ចាស់យ៉ាងពិតប្រាកដ នៅពេលដែលអ្នកគិតយល់ពីព្រះប្រាជ្ញាញាណរបស់ទ្រង់ នៅពេលដែលអ្នកមើលឃើញទង្វើទាំងអស់ដែលព្រះជាម្ចាស់បានធ្វើ នៅពេលដែលអ្នកដឹងថាព្រះជាម្ចាស់ជានរណា និងមានអ្វីខ្លះ ពោលគឺជាពេលដែលអ្នកបានឃើញព្រះទ័យយល់អធ្យាស្រ័យ ព្រះប្រាជ្ញាញាណ ភាពអស្ចារ្យរបស់ទ្រង់ និងគ្រប់អ្វីៗទាំងអស់ដែលទ្រង់បានធ្វើមកលើមនុស្ស គឺពេលនោះហើយដែលអ្នកនឹងសម្រេចបានជោគជ័យនៅក្នុងសេចក្តីជំនឿរបស់អ្នកចំពោះព្រះជាម្ចាស់។ នៅពេលគេនិយាយថា ព្រះជាម្ចាស់មានអ្វីៗគ្រប់យ៉ាង និងជាព្រះដ៏ពេញបរិបូរណ៍ តើទ្រង់មានអ្វីគ្រប់យ៉ាងតាមវិធីណាឲ្យប្រាកដ ហើយទ្រង់ពេញបរិបូរណ៍តាមវិធីណាឲ្យប្រាកដ? ប្រសិនបើអ្នករាល់គ្នាមិនយល់ពីចំណុចនេះទេ នោះអ្នកមិនអាចចាត់ទុកថាមានជំនឿលើព្រះជាម្ចាស់បានឡើយ។ ហេតុអ្វីក៏ខ្ញុំនិយាយថា មនុស្សដែលនៅក្នុងចំណោមអ្នកកាន់សាសនា មិនមែនជាអ្នកជឿលើព្រះជាម្ចាស់ តែជាអ្នកប្រព្រឹត្តអាក្រក់ ជាជំពូកមនុស្សដូចគ្នានឹងមារសាតាំង? នៅពេលខ្ញុំនិយាយថា ពួកគេជាមនុស្សអាក្រក់ នោះគឺដោយសារតែពួកគេមិនយល់ពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងមិនអាចមើលឃើញប្រាជ្ញាញាណរបស់ទ្រង់។ គ្មានពេលណាដែលព្រះជាម្ចាស់បង្ហាញកិច្ចការរបស់ទ្រង់ដល់ពួកគេឡើយ។ ពួកគេជាមនុស្សខ្វាក់ ពួកគេមិនអាចមើលឃើញទង្វើរបស់ព្រះជាម្ចាស់នោះទេ ពួកគេត្រូវបានព្រះជាម្ចាស់បោះបង់ចោល ហើយពួកគេខ្វះការយកចិត្តទុកដាក់ និងការការពារទាំងស្រុងពី

ព្រះជាម្ចាស់ ដោយមិនចាំបាច់និយាយដល់កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធនោះទេ។ អស់អ្នកណាដែលគ្មានកិច្ចការរបស់ព្រះជាម្ចាស់ អ្នកនោះសុទ្ធតែជាអ្នកប្រព្រឹត្តអាក្រក់ និងជាអ្នកប្រឆាំងទាស់នឹងព្រះជាម្ចាស់។ អ្នកប្រឆាំងទាស់នឹងព្រះជាម្ចាស់ដែលខ្ញុំនិយាយដល់នេះ សំដៅលើអស់អ្នកណាដែលមិនស្គាល់ព្រះជាម្ចាស់ អស់អ្នកណាដែលស្គាល់ព្រះជាម្ចាស់ត្រឹមតែតាមបបូរមាត់របស់ពួកគេ តែពុំបានស្គាល់ទ្រង់ពិតប្រាកដ អស់អ្នកណាដែលដើរតាមព្រះជាម្ចាស់ តែមិនស្ដាប់បង្គាប់ទ្រង់ និងអស់អ្នកណាដែលអាស្រ័យផលពីព្រះគុណរបស់ព្រះជាម្ចាស់ តែមិនអាចប្រកាន់ខ្ជាប់នូវទីបន្ទាល់របស់ខ្លួនចំពោះទ្រង់។ បើគ្មានការយល់ដឹងអំពីគោលបំណងនៃកិច្ចការរបស់ព្រះជាម្ចាស់ ឬគ្មានការយល់ដឹងអំពីកិច្ចការដែលព្រះជាម្ចាស់ធ្វើចំពោះមនុស្សលោកទេ នោះមនុស្សមិនអាចបំពេញតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់បានឡើយ ហើយក៏មិនអាចប្រកាន់ខ្ជាប់នូវទីបន្ទាល់របស់ខ្លួនចំពោះព្រះជាម្ចាស់បានដែរ។ មូលហេតុដែលមនុស្សប្រឆាំងទាស់នឹងព្រះជាម្ចាស់គឺ ទីមួយកើតចេញពីនិស្ស័យពុករលួយរបស់ពួកគេ និងមួយទៀតកើតចេញពីភាពល្ងង់ខ្លៅមិនស្គាល់ព្រះជាម្ចាស់ និងកង្វះការយល់ដឹងអំពីគោលការណ៍ដែលព្រះជាម្ចាស់បំពេញកិច្ចការ និងអំពីបំណងព្រះហឫទ័យរបស់ទ្រង់ចំពោះមនុស្ស។ ទិដ្ឋភាពទាំងពីរនេះរួមគ្នាបង្កើតបានជាប្រវត្តិនៃការប្រឆាំងទាស់របស់មនុស្ស ចំពោះព្រះជាម្ចាស់។ មនុស្សដែលទើបតែជឿថ្មី ទាស់ទទឹងនឹងព្រះជាម្ចាស់ ដោយសារតែការទាស់ទទឹងនេះ មានក្នុងចរិតពីកំណើតរបស់គេ រីឯមនុស្សដែលជឿយូរហើយ គេទាស់ទទឹងនឹងព្រះជាម្ចាស់ ដោយសារតែចរិតព្រងើយកន្តើយដែលគេមានចំពោះព្រះជាម្ចាស់ បន្ថែមលើនិស្ស័យពុករលួយរបស់គេ។ នៅមុនពេលដែលព្រះជាម្ចាស់បានក្លាយជាសាច់ឈាម ខ្នាតរង្វាស់ថាតើមនុស្សម្នាក់ប្រឆាំងទាស់នឹងព្រះជាម្ចាស់ដែរឬអត់នោះ គឺអាស្រ័យថា តើបុគ្គលនោះគោរពតាមបញ្ញត្តិដែលព្រះជាម្ចាស់បានចែង នៅស្ថានសួគ៌ដែរ ឬយ៉ាងណា។ ឧទាហរណ៍ នៅក្នុងសម័យក្រឹត្យវិន័យ ជនណាដែលមិនគោរពតាមក្រឹត្យវិន័យរបស់ព្រះយេហូវ៉ា ត្រូវបានគេចាត់ទុកជាមនុស្សដែលប្រឆាំងទាស់នឹងព្រះជាម្ចាស់។ ជនណាដែលលួចយក

តង្វាយថ្វាយព្រះយេហូវ៉ា ឬជនដែលប្រឆាំងទាស់នឹងមនុស្ស ដែលព្រះយេហូវ៉ាគាប់ព្រះហឫទ័យ ត្រូវចាត់ទុកជាអ្នកប្រឆាំងទាស់នឹងព្រះជាម្ចាស់ ហើយត្រូវកាត់ទោសដោយគប់សម្លាប់នឹងដុំថ្ម។ ជនណាដែលមិនគោរពឪពុកម្ដាយខ្លួន ជនណាដែលបានវាយដំ ឬដាក់បណ្ដាសាអ្នកដទៃ ត្រូវចាត់ទុកជាមនុស្សម្នាក់ដែលមិនគោរពតាមក្រឹត្យវិន័យ។ ហើយអស់អ្នកណាដែលមិនកាន់តាមក្រឹត្យវិន័យរបស់ព្រះយេហូវ៉ា ត្រូវចាត់ទុកជាមនុស្សដែលប្រឆាំងទាស់នឹងទ្រង់។ រឿងនេះគ្មានទៀតទេក្នុងយុគសម័យនៃព្រះគុណ ពេលនោះជនណាដែលប្រឆាំងទាស់នឹងព្រះយេស៊ូវ ត្រូវចាត់ទុកជាអ្នកដែលប្រឆាំងនឹងព្រះជាម្ចាស់ ហើយជនណាដែលមិនស្ដាប់បង្គាប់តាមព្រះសូរសៀងរបស់ព្រះយេស៊ូវ ត្រូវចាត់ទុកជាអ្នកដែលប្រឆាំងទាស់នឹងព្រះជាម្ចាស់។ នៅពេលនេះលក្ខណៈនៃការប្រឆាំងទាស់នឹងព្រះជាម្ចាស់ ត្រូវបានកំណត់កាន់តែសុក្រឹត និងជាក់ស្ដែងជាងមុន។ នៅពេលដែលព្រះជាម្ចាស់មិនទាន់ក្លាយសាច់ឈាមនៅឡើយ ខ្នាតរង្វាស់ថាតើមនុស្សម្នាក់ប្រឆាំងទាស់នឹងព្រះជាម្ចាស់ឬអត់នោះ គឺអាស្រ័យលើថាតើបុគ្គលនោះបានថ្វាយបង្គំ និងគោរពបូជាដល់ព្រះជាម្ចាស់ដ៏មើលមិនឃើញ ដែលគង់នៅស្ថានសួគ៌ដែរ ឬយ៉ាងណា។ លក្ខណៈនៃការប្រឆាំងទាស់នឹងព្រះជាម្ចាស់ដែលបានកំណត់នៅគ្រានោះ មិនមែនសុទ្ធតែជាក់ស្ដែងទាំងអស់នោះទេ ដ្បិតមនុស្សមិនអាចមើលឃើញព្រះជាម្ចាស់នោះឡើយ ហើយពួកគេក៏មិនដឹងថា រូបអង្គរបស់ព្រះជាម្ចាស់មានលក្ខណៈបែបណាដែរ ឬថា ទ្រង់បានធ្វើកិច្ចការ និងមានព្រះបន្ទូលអ្វីខ្លះដែរ។ មនុស្សគ្មានសញ្ញាណអ្វីសោះអំពីព្រះជាម្ចាស់ ហើយគេបានជឿលើព្រះជាម្ចាស់ដោយស្រពេចស្រពិល ព្រោះព្រះជាម្ចាស់មិនទាន់បានបង្ហាញខ្លួនឲ្យមនុស្សបានឃើញនៅឡើយទេ។ ដូច្នេះ មិនថាមនុស្សបានជឿលើព្រះជាម្ចាស់តាមការស្រមើស្រមៃរបស់ពួកគេ ឬយ៉ាងណានោះទេ ក៏ព្រះជាម្ចាស់មិនបានថ្កោលទោសមនុស្ស ឬទាមទារអ្វីច្រើនពេកពីមនុស្សនោះទេ ដ្បិតមនុស្សមិនអាចមើលឃើញព្រះជាម្ចាស់បានឡើយ។ នៅពេលដែលព្រះជាម្ចាស់បានក្លាយជាសាច់ឈាម និងមកបំពេញកិច្ចការក្នុងចំណោមមនុស្សផងទាំងពួង គ្រប់គ្នាមើលឃើញទ្រង់ និងស្ដាប់ព្

ព្រះបន្ទូលរបស់ទ្រង់ ហើយគ្រប់គ្នាបានឃើញពីទង្វើដែលព្រះជាម្ចាស់ធ្វើ តាមរូបកាយខាងសាច់ឈាមរបស់ទ្រង់។ នៅពេលនេះ សញ្ញាណទាំងអស់របស់មនុស្សក៏រលាយបាត់។ ចំពោះអស់អ្នកណាដែលបានឃើញព្រះជាម្ចាស់លេចមកជាសាច់ឈាម ពួកគេនឹងមិនត្រូវទទួលទោសទេបើពួកគេព្រមស្ដាប់បង្គាប់ទ្រង់ ចំណែកអស់អ្នកណាដែលមានចេតនាតតាំងជាមួយទ្រង់ នឹងត្រូវចាត់ទុកជាអ្នកប្រឆាំងទាស់នឹងព្រះជាម្ចាស់។ មនុស្សបែបនេះ គឺជាពួកទទឹងនឹងព្រះគ្រីស្ទ ជាសត្រូវដែលមានចេតនាប្រឆាំងទាស់នឹងព្រះជាម្ចាស់។ អ្នកដែលមានសញ្ញាណអំពីព្រះជាម្ចាស់ ចាក់ឫសក្នុងគំនិតរបស់គេ ប៉ុន្ដែក៏នៅតែត្រៀមខ្លួនជាស្រេច ហើយព្រមស្ដាប់បង្គាប់ទ្រង់ គេនឹងមិនទទួលបានការថ្កោលទោសឡើយ។ ព្រះជាម្ចាស់ថ្កោលទោសមនុស្ស ដោយផ្អែកលើបំណង និងទង្វើរបស់ពួកគេ មិនមែនថ្កោលទោស ដោយផ្អែកលើគំនិត និងយោបល់របស់ពួកគេឡើយ។ បើទ្រង់ថ្កោលទោសមនុស្ស ដោយផ្អែកលើគំនិត និងយោបល់របស់ពួកគេ នោះនឹងគ្មានមនុស្សណាម្នាក់ អាចគេចផុតពីព្រះហស្ដនៃសេចក្ដីក្រោធរបស់ព្រះជាម្ចាស់បានឡើយ។ អស់អ្នកណាដែលមានចេតនាប្រឆាំងទាស់នឹងព្រះជាម្ចាស់ដែលយកកំណើតជាសាច់ឈាម នឹងត្រូវទទួលទណ្ឌកម្មដោយសារការមិនស្ដាប់បង្គាប់របស់ពួកគេ។ ទាក់ទងនឹងមនុស្សដែលប្រឆាំងនឹងព្រះជាម្ចាស់ដោយចេតនាទាំងអស់នេះ ការប្រឆាំងទាស់របស់ពួកគេ កើតចេញពីការពិតដែលថាពួកគេមានសញ្ញាណចាក់ឫសអំពីព្រះជាម្ចាស់ ដែលនាំពួកគេផុងខ្លួនទៅក្នុងសកម្មភាពដែលរំខានដល់កិច្ចការរបស់ព្រះជាម្ចាស់ជាបន្ដបន្ទាប់។ មនុស្សទាំងអស់នេះ មានចេតនាតតាំង និងបំផ្លាញកិច្ចការរបស់ព្រះជាម្ចាស់។ ពួកគេមិនត្រឹមតែមានសញ្ញាណអំពីព្រះជាម្ចាស់ប៉ុណ្ណោះទេ ប៉ុន្ដែពួកគេថែមទាំងបានចូលរួមក្នុងសកម្មភាពនានា ដែលរំខានដល់កិច្ចការរបស់ទ្រង់ទៀតផង ហើយដោយហេតុនេះ មនុស្សប្រភេទនេះនឹងត្រូវថ្កោលទោស។ អ្នកដែលគ្មានចេតនាធ្វើឱ្យរំខានដល់កិច្ចការរបស់ព្រះជាម្ចាស់ នឹងមិនទទួលនូវការថ្កោលទោសថាជាមនុស្សមានបាបនោះទេ ព្រោះពួកគេអាចស្ដាប់បង្គាប់ដោយសុទ្ធចិត្ត និងមិនចូលរួមក្នុងសកម្មភាពនានា ដែលបង្កឱ្យមានការរំខាន និងភាពរឹករវរនោះទេ។ មនុស្ស

បែបនេះនឹងមិនទទួលបានការថ្កោលទោសឡើយ។ ក៏ប៉ុន្តែ នៅពេលមនុស្សឆ្លងកាត់កិច្ចការរបស់ព្រះជាម្ចាស់ អស់រយៈពេលជាច្រើនឆ្នាំ ប្រសិនបើពួកគេនៅបន្តមានសញ្ញាណចាក់ឫសអំពីព្រះជាម្ចាស់ ហើយនៅតែមិនអាចយល់ដឹងពីកិច្ចការរបស់ព្រះជាម្ចាស់ដែលយកកំណើតជាសាច់ឈាម ហើយប្រសិនបើពួកគេនៅតែបន្តមានសញ្ញាណអំពីព្រះជាម្ចាស់ មិនថាពួកគេបានឆ្លងកាត់កិច្ចការរបស់ទ្រង់ច្រើនឆ្នាំប៉ុនណា ហើយនៅតែមិនអាចស្គាល់ទ្រង់បាន ដូច្នេះ ទោះបីជាពួកគេមិនបានចូលរួមក្នុងសកម្មភាពរំខាននានាក្តី ក៏ចិត្តរបស់ពួកគេបានជិតជាមទៅដោយសញ្ញាណយ៉ាងច្រើនអំពីព្រះជាម្ចាស់ ហើយទោះបីជាសញ្ញាណទាំងនេះមិនសម្តែងចេញមកច្បាស់ក្តី ក៏មនុស្សបែបនេះគ្មានប្រយោជន៍អ្វីចំពោះកិច្ចការរបស់ព្រះជាម្ចាស់ដែរ។ ពួកគេមិនអាចផ្សាយដំណឹងល្អសម្រាប់ព្រះជាម្ចាស់ ឬប្រកាន់ខ្ជាប់នូវទីបន្ទាល់របស់ខ្លួនចំពោះទ្រង់បានឡើយ។ មនុស្សបែបនេះ គឺជាមនុស្សដែលគ្មានបានការ និងជាមនុស្សល្ងង់ខ្លៅ។ ដោយសារតែពួកគេមិនស្គាល់ព្រះជាម្ចាស់ ហើយលើសពីនេះទៅទៀត ពួកគេមិនអាចបោះចោលសញ្ញាណរបស់ពួកគេអំពីទ្រង់បានទាំងស្រុង នោះពួកគេត្រូវទទួលការថ្កោលទោស។ គេអាចនិយាយដូចនេះថា៖ ចំពោះអ្នកជឿថ្មី រឿងមានសញ្ញាណអំពីព្រះជាម្ចាស់ ឬមិនដឹងអ្វីសោះអំពីទ្រង់ វាជារឿងធម្មតាទេ តែចំពោះអ្នកដែលបានជឿព្រះជាម្ចាស់អស់រយៈពេលជាច្រើន ហើយឆ្លងកាត់បទពិសោធក្នុងកិច្ចការជាច្រើនរបស់ទ្រង់ ការដែលនៅមានសញ្ញាណបែបនេះ វាមិនមែនជារឿងធម្មតាទេ រីឯការដែលមិនដឹងអ្វីសោះអំពីព្រះជាម្ចាស់ គឺកាន់តែមិនធម្មតា ចំពោះមនុស្សបែបនេះទៀតផង។ ពួកគេត្រូវទទួលការថ្កោលទោស ក៏មិនមែនដោយសារតែស្ថានភាពធម្មតានេះដែរ។ មនុស្សមិនធម្មតាទាំងនេះ គឺសុទ្ធតែជាសំរាម។ ពួកគេគឺជាអ្នកដែលប្រឆាំងទាស់នឹងព្រះជាម្ចាស់ខ្លាំងជាងគេ និងជាអ្នកដែលទទួលបានព្រះគុណរបស់ព្រះជាម្ចាស់ទាំងមិនដឹងគុណ។ មនុស្សបែបនេះ នឹងត្រូវផាត់ចោលនៅទីចុងបំផុត!

អ្នកណាដែលមិនយល់ ពីគោលបំណងនៃកិច្ចការរបស់ព្រះជាម្ចាស់ គឺជាអ្នកដែលប្រឆាំងទាស់នឹងទ្រង់ ហើយអ្នកដែលបានយល់ពីគោលបំណងនៃកិច្ចការរបស់

ព្រះជាម្ចាស់ ប៉ុន្ដែនៅតែមិនខំប្រឹងស្ដាប់ព្រះហឫទ័យព្រះជាម្ចាស់ អ្នកនោះកាន់តែត្រូវបានចាត់ទុកថាជាអ្នកប្រឆាំងនឹងព្រះជាម្ចាស់។ មានអ្នកដែលអានព្រះគម្ពីរនៅក្នុងព្រះវិហារធំៗ ហើយសូត្រខគម្ពីរពេញមួយថ្ងៃ ប៉ុន្ដែគ្មាននរណាម្នាក់ក្នុងចំណោមពួកគេ យល់ពីគោលបំណងនៃកិច្ចការរបស់ព្រះជាម្ចាស់ឡើយ។ ក្នុងចំណោមពួកគេគ្មាននរណាម្នាក់អាចស្គាល់ព្រះជាម្ចាស់ឡើយ ក្នុងចំណោមពួកគេ ក៏រឹតតែគ្មាននរណាម្នាក់អាចធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះបានឡើយ។ ពួកគេទាំងអស់សុទ្ធតែជាមនុស្សអប្រិយ គ្មានតម្លៃ ហើយម្នាក់ៗឈរនៅទីដ៏ខ្ពស់ដើម្បីបង្រៀនព្រះជាម្ចាស់។ ពួកគេប្រឆាំងទាស់នឹងព្រះជាម្ចាស់ដោយចេតនា ទាំងដែលពួកគេកំពុងកាន់ទង់របស់ព្រះជាម្ចាស់ ពួកគេនៅតែស៊ីសាច់ និងហុតឈាមមនុស្ស ខណៈដែលគេកំពុងប្រកាសអំពីជំនឿរបស់ខ្លួនចំពោះព្រះជាម្ចាស់។ មនុស្សទាំងអស់នេះសុទ្ធតែជាអារក្សដែលលេបត្របាក់ព្រលឹងមនុស្ស ជាវិញ្ញាណអាក្រក់ដែលមានចេតនាដើរចូលក្នុងផ្លូវរបស់អស់អ្នកណាដែលព្យាយាមដើរលើផ្លូវត្រូវ ហើយជាថ្មជំពប់ដែលបង្អាក់ដល់អ្នកដែលស្វែងរកព្រះជាម្ចាស់ផង។ ពួកគេអាចមាននូវ «អត្តភាពត្រឹមត្រូវ» ប៉ុន្ដែធ្វើដូចម្ដេចឲ្យអ្នកដែលដើរតាមពួកគេដឹងថា ពួកគេគ្រាន់តែជាពួកទទឹងនឹងព្រះគ្រីស្ទ ដែលដឹកនាំមនុស្សឲ្យទាស់ទទឹងនឹងព្រះជាម្ចាស់? តើធ្វើម្ដេចឲ្យអ្នកដែលដើរតាមពួកគេដឹងថាពួកគេជាវិញ្ញាណអាក្រក់ដ៏មានជីវិតដែលតាំងចិត្តលេបត្របាក់ព្រលឹងមនុស្ស? អ្នកដែលលើកស្ទួយខ្លួនឯងឲ្យខ្ពង់ខ្ពស់ នៅចំពោះវត្តមានរបស់ព្រះជាម្ចាស់ គឺជាមនុស្សទាបថោកបំផុត ចំណែកអ្នកដែលគិតថាខ្លួនឯងទាបវិញ គឺជាអ្នកដែលមានកិត្តិយសបំផុត។ ហើយជាងនេះទៀត អ្នកដែលគិតថាពួកគេស្គាល់កិច្ចការរបស់ព្រះជាម្ចាស់ និងអ្នកដែលមានសមត្ថភាព ក្នុងការប្រកាសប្រាប់ពីកិច្ចការរបស់ព្រះជាម្ចាស់ដល់អ្នកដទៃ ដោយសំឡេងឮៗ ទាំងក្នុងខណៈដែលពួកគេសម្លឹងមើលទៅទ្រង់ដោយផ្ទាល់ អ្នកទាំងនេះគឺជាមនុស្សល្ងង់ខ្លៅបំផុត។ មនុស្សបែបនេះ គេគ្មានទីបន្ទាល់ពីព្រះជាម្ចាស់ទេ តែក្រអឺតក្រទម និងពោរពេញដោយអំនួត។ អស់អ្នកណាដែលជឿថា ពួកគេមានចំណេះដឹងតិចតួចអំពីព្រះជាម្ចាស់ ទោះបីជាគេមានបទពិសោធ និង

ចំណេះដឹងជាក់ស្ដែងអំពីទ្រង់ច្រើនក្ដី គឺជាមនុស្សដែលទ្រង់សព្វព្រះទ័យបំផុត។ មានតែមនុស្សបែបនេះទេ ទើបមានទីបន្ទាល់ដ៏ពិតប្រាកដ ហើយពិតជាអាចត្រូវបានប្រោសឲ្យបានគ្រប់លក្ខណ៍ពីសំណាក់ព្រះជាម្ចាស់។ អស់អ្នកណាដែលមិនយល់អំពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ នោះគឺជាអ្នកប្រឆាំងទាស់នឹងព្រះជាម្ចាស់។ អស់អ្នកណាដែលយល់ពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ តែពុំបានអនុវត្តតាមសេចក្ដីពិត គឺជាអ្នកប្រឆាំងទាស់នឹងព្រះជាម្ចាស់។ អស់អ្នកណាដែលហូប និងផឹកព្រះបន្ទូលរបស់ព្រះជាម្ចាស់ តែប្រឆាំងទាស់នឹងសារជាតិនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ គឺជាអ្នកប្រឆាំងទាស់នឹងព្រះជាម្ចាស់។ អស់អ្នកណាដែលមានសញ្ញាណអំពីព្រះជាម្ចាស់ដែលយកកំណើតជាសាច់ឈាម ហើយមានគំនិតចូលរួមក្នុងការបះបោរ គឺជាអ្នកប្រឆាំងទាស់នឹងព្រះជាម្ចាស់។ អស់អ្នកណាដែលតិះទៀនព្រះជាម្ចាស់ គឺជាអ្នកប្រឆាំងទាស់នឹងព្រះជាម្ចាស់។ ហើយអស់អ្នកណាដែលមិនអាចស្គាល់ព្រះជាម្ចាស់បាន ឬមិនអាចធ្វើជាទីបន្ទាល់សម្រាប់ទ្រង់បាន គឺជាអ្នកប្រឆាំងទាស់នឹងព្រះជាម្ចាស់។ ដូច្នេះ ខ្ញុំសុំលើកទឹកចិត្តអ្នករាល់គ្នា៖ ប្រសិនបើអ្នករាល់គ្នាពិតជាមានសេចក្ដីជំនឿថា អ្នករាល់គ្នាអាចដើរតាមផ្លូវនេះបាន ចូរបន្តដើរតាមផ្លូវនេះចុះ។ ប៉ុន្តែ ប្រសិនបើអ្នករាល់គ្នាមិនអាចហាមខ្លួនឯងមិនឲ្យប្រឆាំងនឹងព្រះជាម្ចាស់បានទេ នោះអ្នកត្រូវតែដើរចេញឲ្យឆ្ងាយ មុនហួសពេល។ បើមិនដូច្នោះទេ ឱកាសដែលរឿងអាក្រក់ធ្លាក់មកលើអ្នក គឺមានខ្ពស់ណាស់ ពីព្រោះចរិតពីកំណើតរបស់អ្នករាល់គ្នាពិតជាពុករលួយខ្លាំងណាស់។ អ្នកគ្មានភាពស្មោះត្រង់ ឬការស្ដាប់បង្គាប់ ឬចិត្តដែលស្រេកឃ្លានសេចក្ដីសុចរិត និងសេចក្ដីពិត ឬសេចក្ដីស្រឡាញ់ចំពោះព្រះជាម្ចាស់ សូម្បីតែបន្តិចសោះ។ គេអាចនិយាយបានថា ស្ថានភាពរបស់អ្នករាល់គ្នានៅចំពោះព្រះជាម្ចាស់ គឺពិតជាច្របូកច្របល់ខ្លាំងណាស់។ អ្នកមិនអាចគោរពតាមអ្វីដែលអ្នកគួរគោរពតាម និងមិនអាចនិយាយអ្វីដែលអ្នកគួរនិយាយ។ អ្វីដែលអ្នកគួរយកទៅអនុវត្ត អ្នកបែរជាមិនអាចអនុវត្តបាន។ ហើយមុខងារដែលអ្នកគួរតែបំពេញ អ្នកបែរជាមិនអាចបំពេញបាន។ អ្នកគ្មានភាពស្មោះត្រង់ គ្មានមនសិការ គ្មានការ

ស្ដាប់បង្គាប់ ឬការសម្រេចចិត្តដែលអ្នកគួរធ្វើនោះទេ។ អ្នកមិនបានស៊ូទ្រាំនឹងការរងទុក្ខដែលតម្រូវឲ្យឱ្យអ្នកស៊ូទ្រាំនោះឡើយ ហើយអ្នកគ្មានសេចក្ដីជំនឿដែលអ្នកគួរតែមាន។ និយាយឲ្យចំទៅ អ្នករាល់គ្នាគ្មានគុណសម្បត្តិអ្វីទាំងអស់៖ តើអ្នករាល់គ្នាមិនខ្មាសអៀននឹងបន្តរស់នៅទេឬអី? ខ្ញុំសូមបញ្ជាក់ប្រាប់អ្នករាល់គ្នាថា យកល្អអ្នកគួរបិទភ្នែករបស់អ្នកគេងឲ្យលក់ជារៀងរហូតទៅ ធ្វើដូច្នេះកុំឲ្យព្រះជាម្ចាស់ទ្រង់ព្រួយព្រះទ័យពីបញ្ហា និងទុក្ខវេទនារបស់អ្នករាល់គ្នា ដើម្បីជាប្រយោជន៍ដល់អ្នករាល់គ្នា។ អ្នករាល់គ្នាជឿលើព្រះជាម្ចាស់ តែមិនស្គាល់ពីព្រះហឫទ័យរបស់ព្រះជាម្ចាស់។ អ្នកហូប និងផឹកព្រះបន្ទូលរបស់ព្រះជាម្ចាស់ តែមិនអាចគោរពតាមអ្វីដែលព្រះជាម្ចាស់ចង់បានពីមនុស្សឡើយ។ អ្នកជឿលើព្រះជាម្ចាស់ តែបែរជាមិនស្គាល់ទ្រង់ ហើយអ្នកបន្តរស់នៅដោយគ្មានគោលដៅ ដើម្បីតស៊ូសម្រេចឲ្យបាន គ្មានតម្លៃ និងគ្មានន័យអ្វីសោះឡើយ។ អ្នករស់នៅជាមនុស្ស តែបែរជាគ្មានសតិសម្បជញ្ញៈ គ្មានសុចរិតភាព ឬគ្មានភាពគួរឱ្យជឿជាក់សូម្បីតែបន្តិច តើអ្នករាល់គ្នានៅអាចហៅខ្លួនឯងថាជាមនុស្សបានទៀតឬអី? អ្នកជឿលើព្រះជាម្ចាស់ តែបែរជាបោកបញ្ឆោតទ្រង់។ លើសពីនេះទៅទៀត អ្នកយកប្រាក់កាសរបស់ព្រះជាម្ចាស់ និងតង្វាយដែលត្រូវបានថ្វាយដល់ទ្រង់។ តែនៅទីបញ្ចប់ អ្នកនៅតែមិនបានបង្ហាញនូវការគិតពិចារណាអំពីទឹកព្រះទ័យរបស់ព្រះជាម្ចាស់ ឬមានមនសិការចំពោះទ្រង់សូម្បីបន្តិច។ សូម្បីតែការចង់បានតិចតួចបំផុតរបស់ព្រះជាម្ចាស់ ក៏អ្នកមិនអាចធ្វើបានផង។ តើអ្នករាល់គ្នានៅអាចហៅខ្លួនឯងថាជាមនុស្សទៀតឬអី? ការបរិភោគអាហារដែលព្រះជាម្ចាស់ប្រទានដល់អ្នក និងការស្រូបយកអុកស៊ីហ្សែនដែលទ្រង់បានប្រទានដល់អ្នករាល់គ្នាដោយក្ដីអំណរ និងព្រះគុណរបស់ទ្រង់ តែចុងក្រោយ សូម្បីបន្តិចក៏អ្នកមិនស្គាល់ទ្រង់ផង។ ផ្ទុយទៅវិញ អ្នកបានក្លាយជាមនុស្សឥតបានការ ដែលប្រឆាំងទាស់នឹងព្រះជាម្ចាស់។ តើការនេះមិនធ្វើឱ្យអ្នកក្លាយជាសត្វ ដែលទាបថោកជាងសត្វឆ្កែទេឬអី? ក្នុងចំណោមសត្វនានា តើមានសត្វណាមួយដែលសាហាវជាងអ្នករាល់គ្នាទៀតនោះ?

គ្រូគង្វាល និងមនុស្សចាស់ទុំ ដែលឈរនៅលើទីអាសនាខ្ពស់ៗដើម្បីបង្រៀន

ទៅដល់អ្នកដទៃ គឺជាអ្នកប្រឆាំងទាស់នឹងព្រះជាម្ចាស់ និងជាសម្ព័ន្ធមិត្តរបស់សាតាំង។ តើអ្នករាល់គ្នាដែលមិនឈរនៅលើទីអាសនាខ្ពស់ៗ ដើម្បីបង្រៀនដល់អ្នកដទៃ មិនមែនជាអ្នកប្រឆាំងទាស់នឹងព្រះជាម្ចាស់ខ្លាំងជាងគេទេឬអី? តើអ្នករាល់គ្នាមិនរួមគំនិតជាមួយសាតាំង ច្រើនជាងពួកគេទេឬអី? អ្នកដែលមិនយល់ពីគោលបំណងនៃកិច្ចការរបស់ព្រះជាម្ចាស់ មិនដឹងពីរបៀបប្រតិបត្តិតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ឡើយ។ ប្រាកដណាស់ អ្នកដែលយល់ច្បាស់ពីគោលបំណងនៃកិច្ចការរបស់ទ្រង់ មិនអាចមិនដឹងពីរបៀបប្រតិបត្តិតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់នោះទេ។ កិច្ចការរបស់ព្រះជាម្ចាស់ មិនដែលមានកំហុសទេ មានតែសកម្មភាពរបស់មនុស្សប៉ុណ្ណោះដែលមានកំហុស។ តើមនុស្សអគុណធម៌ដែលប្រឆាំងទាស់នឹងព្រះជាម្ចាស់ដោយចេតនា ពួកគេមិនអាក្រក់ ហើយសាហាវជាងពួកគ្រូគង្វាល និងពួកចាស់ទុំទាំងនោះទេឬអី? មានមនុស្សជាច្រើនដែលប្រឆាំងទាស់នឹងព្រះជាម្ចាស់ ប៉ុន្តែក្នុងចំណោមពួកគេ ក៏មានវិធីខុសគ្នាជាច្រើន ដែលពួកគេប្រឆាំងទាស់នឹងព្រះជាម្ចាស់ផងដែរ។ ដោយសារតែអ្នកជឿព្រះជាម្ចាស់មានគ្រប់សណ្ឋាន ហេតុដូច្នេះ អ្នកប្រឆាំងទាស់នឹងព្រះជាម្ចាស់ ក៏មានគ្រប់សណ្ឋានដែរ មនុស្សម្នាក់ខុសពីមនុស្សម្នាក់ទៀត។ មនុស្សដែលមិនស្គាល់ច្បាស់ពីគោលបំណងនៃកិច្ចការរបស់ព្រះជាម្ចាស់ គ្មាននរណាម្នាក់អាចបានសង្គ្រោះឡើយ។ កាលពីមុន មិនថាមនុស្សធ្លាប់បានប្រឆាំងទាស់នឹងព្រះជាម្ចាស់បែបណានោះទេ នៅពេលដែលមនុស្សចាប់ផ្ដើមយល់អំពីគោលបំណងនៃកិច្ចការរបស់ព្រះជាម្ចាស់ ហើយលះបង់ការខិតខំរបស់ខ្លួនដើម្បីផ្គាប់ព្រះហឫទ័យព្រះជាម្ចាស់ នោះព្រះជាម្ចាស់នឹងលាងសម្អាតបាបរបស់ពួកគេពីមុនមកទាំងអស់។ ដរាបណាមនុស្សស្វែងរកសេចក្ដីពិត និងអនុវត្តតាមសេចក្ដីពិត ពេលនោះ ព្រះជាម្ចាស់នឹងមិនចងចាំអ្វីដែលពួកគេបានប្រព្រឹត្តឡើយ។ លើសពីនេះទៅទៀត ព្រះជាម្ចាស់រាប់មនុស្សជាសុចរិត ដោយផ្អែកលើមូលដ្ឋាននៃការអនុវត្តតាមសេចក្ដីពិតរបស់ពួកគេ។ នេះហើយគឺជាសេចក្ដីសុចរិតរបស់ព្រះជាម្ចាស់។ មុនពេលដែលមនុស្សបានឃើញព្រះជាម្ចាស់ ឬឆ្លងកាត់កិច្ចការរបស់ទ្រង់ មិនថាមនុស្សធ្វើបែបណាចំពោះព្រះជាម្ចាស់

ទេ ទ្រង់មិនទុកវានៅក្នុងព្រះទ័យទ្រង់ឡើយ។ ទោះយ៉ាងណាក៏ដោយ នៅពេលមនុស្សបានឃើញព្រះជាម្ចាស់ និងឆ្លងកាត់កិច្ចការរបស់ទ្រង់ ពេលនោះរាល់ទង្វើ និងសកម្មភាពរបស់មនុស្ស នឹងត្រូវបានព្រះជាម្ចាស់កត់ត្រាបញ្ចូលទៅក្នុង «ក្រាំង» ដ្បិតមនុស្សបានឃើញព្រះជាម្ចាស់ និងបានរស់នៅក្នុងកិច្ចការរបស់ទ្រង់។

នៅពេលដែលមនុស្សបានឃើញច្បាស់ថា ព្រះជាម្ចាស់ជានរណា និងមានអ្វីខ្លះ នៅពេលដែលពួកគេបានឃើញភាពឧត្ដុង្គឧត្ដមរបស់ទ្រង់ ហើយនៅពេលដែលពួកគេបានដឹងច្បាស់ពីកិច្ចការរបស់ព្រះជាម្ចាស់ ហើយលើសពីនេះទៀត នៅពេលដែលនិស្ស័យចាស់របស់មនុស្ស ត្រូវបានបំផ្លាស់បំប្រែ នោះមនុស្សនឹងបោះបង់ចោលទាំងស្រុងនូវនិស្ស័យបះបោររបស់គេដែលប្រឆាំងទាស់នឹងព្រះជាម្ចាស់។ អាចនិយាយបានថា មនុស្សគ្រប់រូប មានពេលខ្លះប្រឆាំងទាស់នឹងព្រះជាម្ចាស់ ហើយនៅពេលខ្លះមនុស្សគ្រប់រូប បានបះបោរប្រឆាំងនឹងព្រះជាម្ចាស់។ ទោះបីជាយ៉ាងណា ប្រសិនបើអ្នកមានចេតនាស្ដាប់បង្គាប់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស ហើយផ្គាប់ព្រះទ័យរបស់ព្រះជាម្ចាស់ចាប់ពីពេលនេះទៅ ដោយភាពស្មោះត្រង់របស់អ្នក ចូរអនុវត្តតាមសេចក្ដីពិតដែលអ្នកគួរអនុវត្ត បំពេញភារកិច្ចដែលអ្នករាល់គ្នាគួរបំពេញ និងប្រព្រឹត្តតាមបទបញ្ញាដែលអ្នកគួរប្រព្រឹត្តតាម ពេលនោះអ្នកគឺជាមនុស្សម្នាក់ដែលសុខចិត្តលះបង់ចោលការបះបោររបស់អ្នក ដើម្បីផ្គាប់ព្រះហឫទ័យព្រះជាម្ចាស់ និងជាមនុស្សម្នាក់ដែលព្រះជាម្ចាស់ប្រោសឲ្យគ្រប់លក្ខណ៍បាន។ ប្រសិនបើអ្នករាល់គ្នាចចេសរឹងរូស មិនព្រមមើលឃើញកំហុសរបស់ខ្លួន និងគ្មានបំណងកែប្រែខ្លួន ប្រសិនបើអ្នកនៅតែជម្នះ ចង់បន្តការបះបោររបស់អ្នក ដោយគ្មានបំណងចង់ប្រកបជាមួយព្រះជាម្ចាស់ និងផ្គាប់ព្រះហឫទ័យរបស់ទ្រង់ ដូច្នេះមនុស្សដែលមានចិត្តរឹងត្បឹង និងមិនចេះប្រែចិត្តដូចជាអ្នក ពិតជានឹងត្រូវទទួលទណ្ឌកម្មជាក់ជាមិនខាន ហើយក៏នឹងមិនដែលក្លាយជាមនុស្សដែលព្រះជាម្ចាស់ប្រោសឲ្យបានគ្រប់លក្ខណ៍ឡើយ។ ដូច្នេះអ្នកគឺជាសត្រូវរបស់ព្រះជាម្ចាស់នៅថ្ងៃនេះ ហើយថ្ងៃស្អែក អ្នកនឹងក្លាយជាសត្រូវរបស់ព្រះជាម្ចាស់ដែរ ហើយអ្នកនឹងនៅតែបន្តក្លាយជាសត្រូវរបស់ព្រះជាម្ចាស់នៅថ្ងៃក្រោយ

ទៀតដែរ។ អ្នករាល់គ្នានឹងក្លាយជាអ្នកប្រឆាំងទាស់ និងជាសត្រូវរបស់ព្រះជាម្ចាស់ ជារៀងរហូត។ ក្នុងករណីនេះ តើព្រះជាម្ចាស់អាចលើកលែងទោសដល់អ្នករាល់គ្នា ដូចម្ដេចបាន? ការប្រឆាំងទាស់នឹងព្រះជាម្ចាស់ ជាចរិតរបស់មនុស្សតាំងពីកំណើត ប៉ុន្តែមនុស្សមិនបាច់មានចេតនាស្វែងយល់ពី «អាថ៌កំបាំង» នៃការប្រឆាំងទាស់នឹង ព្រះជាម្ចាស់នោះទេ ដ្បិតការផ្លាស់ប្ដូរចរិតលក្ខណៈរបស់មនុស្ស គឺជាកិច្ចការដែល ពិបាកបំផុត។ ប្រសិនបើដូច្នោះមែន នោះអ្នកគួរតែដើរចេញឱ្យឆ្ងាយ មុនហួសពេល ក្រែងលោការវាយផ្ចាលរបស់អ្នកនាពេលអនាគត កាន់តែធ្ងន់ធ្ងរ ហើយក្រែងលោ ចរិតធម្មជាតិដ៏កាចសាហាវរបស់អ្នករាល់គ្នាផ្ទុះឡើង និងមិនអាចគ្រប់គ្រងបាន រហូត រាងកាយខាងសាច់ឈាមរបស់អ្នក ត្រូវព្រះជាម្ចាស់កម្ចាត់ចោលនៅទីចុងបំផុតទៅ។ អ្នកជឿលើព្រះជាម្ចាស់ដើម្បីទទួលបានព្រះពរ។ ប៉ុន្តែ ប្រសិនបើនៅទីបំផុត មានតែ សំណាងអាក្រក់ដែលកើតឡើងចំពោះអ្នក តើនោះមិនមែនជាការអាម៉ាស់ទេឬអី? ខ្ញុំ សុំលើកទឹកចិត្តអ្នករាល់គ្នាចុះ យកល្អ អ្នកត្រូវរៀបចំផែនការមួយទៀត។ អ្វីក៏ដោយ ដែលអ្នកអាចធ្វើបាន មុខជាល្អប្រសើរជាងការជឿលើព្រះជាម្ចាស់៖ ប្រាកដណាស់ ផ្លូវមិនមែនមានតែមួយនេះទេ។ ប្រសិនបើអ្នកមិនបានស្វែងរកសេចក្ដីពិត តើអ្នកអាច បន្តរួចជីវិតបានទេ? ហេតុអ្វីបានជាអ្នកត្រូវតែប្រឆាំងនឹងព្រះជាម្ចាស់យ៉ាងដូច្នេះ?

# និមិត្តអំពីកិច្ចការរបស់ព្រះជាម្ចាស់ (១)

យ៉ូហានបានធ្វើកិច្ចការសម្រាប់ព្រះយេស៊ូវ អស់រយៈពេលប្រាំពីរឆ្នាំ និងបាន រៀបចំផ្លូវរួចរាល់ មុនពេលព្រះយេស៊ូវបានយាងមកដល់។ មុនការនេះ ដំណឹងល្អ អំពីនគរស្ថានសួគ៌ ដែលយ៉ូហានបានប្រកាសប្រាប់ ត្រូវបានឮខ្ចរខ្ចាយនៅពេញក្នុង ស្រុក ដូច្នេះហើយដំណឹងល្អបានផ្សព្វផ្សាយពាសពេញស្រុកយូដា ហើយគ្រប់គ្នា ហៅគាត់ថាជាហោរា។ នៅពេលនោះ ស្ដេចហេរ៉ូឌមានបំណងចង់សម្លាប់យ៉ូហាន ប៉ុន្តែទ្រង់មិនហ៊ានទេ ដ្បិតមនុស្សគោរពយ៉ូហានយ៉ាងខ្លាំង ហើយស្ដេចហេរ៉ូឌខ្លាច

ថា បើទ្រង់សម្លាប់យ៉ូហាន នោះពួកគេនឹងបះបោរប្រឆាំងនឹងទ្រង់។ កិច្ចការដែលបានធ្វើដោយយ៉ូហាន គឺផ្ដើមចេញពីក្នុងចំណោមមនុស្សសាមញ្ញ ហើយគាត់បានផ្សព្វផ្សាយឲ្យមានអ្នកជឿចេញពីជនជាតិយូដា។ អស់រយៈពេលប្រាំពីរឆ្នាំ គាត់បានរៀបចំផ្លូវថ្វាយព្រះយេស៊ូវ រហូតដល់ពេលដែលព្រះយេស៊ូវចាប់ផ្ដើមបំពេញព័ន្ធកិច្ចរបស់ទ្រង់។ ដោយសារមូលហេតុនេះហើយ ទើបយ៉ូហានគឺជាហោរាដ៏អស្ចារ្យបំផុតក្នុងចំណោមហោរាទាំងអស់។ ពេលនោះ បន្ទាប់ពីយ៉ូហានត្រូវបានគេចាប់ដាក់គុក ព្រះយេស៊ូវបានចាប់ផ្ដើមកិច្ចការជាផ្លូវការរបស់ទ្រង់។ មុនយ៉ូហាន មិនដែលមានហោរាណាម្នាក់ដែលបានរៀបចំផ្លូវថ្វាយព្រះជាម្ចាស់នោះទេ ពីព្រោះមុនព្រះយេស៊ូវ ព្រះជាម្ចាស់មិនដែលត្រឡប់ជាសាច់ឈាមពីមុនមកនោះឡើយ។ ដូច្នេះក្នុងចំណោមហោរាទាំងអស់រហូតដល់យ៉ូហាន គាត់គឺជាមនុស្សតែម្នាក់គត់ដែលបានរៀបចំផ្លូវថ្វាយព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស ហើយតាមរយៈការនេះ យ៉ូហានបានក្លាយជាហោរាដ៏អស្ចារ្យបំផុតនៃគម្ពីរសញ្ញាចាស់ និងគម្ពីរសញ្ញាថ្មី។ យ៉ូហានបានចាប់ផ្ដើមផ្សាយដំណឹងល្អអំពីនគរស្ថានសួគ៌រយៈពេលប្រាំពីរឆ្នាំ មុនពេលការធ្វើបុណ្យជ្រមុជទឹករបស់ព្រះយេស៊ូវ។ ចំពោះមនុស្ស កិច្ចការដែលគាត់បានធ្វើហាក់ដូចជាខ្ពស់ជាងកិច្ចការដែលព្រះយេស៊ូវត្រូវធ្វើបន្ទាប់ ប៉ុន្ដែយ៉ាងណាក៏ដោយ គាត់គ្រាន់តែជាហោរាម្នាក់ប៉ុណ្ណោះ។ គាត់មិនបានធ្វើកិច្ចការ និងនិយាយនៅក្នុងព្រះវិហារទេ ប៉ុន្ដែនៅតាមទីប្រជុំជន និងភូមិនានានៅខាងក្រៅព្រះវិហារវិញ។ ជាការពិត គាត់បានធ្វើកិច្ចការនេះក្នុងចំណោមមនុស្សដែលជាជនជាតិយូដា ជាពិសេសអ្នកដែលក្រីក្រ។ កម្រណាស់ដែលយ៉ូហានបានទាក់ទងជាមួយនឹងមនុស្សមកពីសង្គមថ្នាក់ខ្ពស់ ហើយគាត់គ្រាន់តែផ្សាយដំណឹងល្អក្នុងចំណោមមនុស្សសាមញ្ញនៅស្រុកយូដាប៉ុណ្ណោះ។ ការនេះ គឺដើម្បីរៀបចំឲ្យត្រូវមនុស្ស សម្រាប់ព្រះអម្ចាស់យេស៊ូវ និងរៀបចំកន្លែងសមរម្យថ្វាយទ្រង់ ដើម្បីធ្វើកិច្ចការ។ តាមរយៈហោរាម្នាក់ដូចជាយ៉ូហាន ដើម្បីរៀបចំផ្លូវ ព្រះអម្ចាស់យេស៊ូវអាចចេញដំណើរទៅតាមផ្លូវរបស់ទ្រង់អំពីឈើឆ្កាងភ្លាមៗបន្ទាប់ពីទ្រង់បានយាងមកដល់។ នៅពេលដែលព្រះជាម្ចាស់បានត្រឡប់ជា

សាច់ឈាមដើម្បីធ្វើកិច្ចការរបស់ទ្រង់ ទ្រង់មិនចាំបាច់ធ្វើកិច្ចការជ្រើសរើសមនុស្ស ហើយទ្រង់ក៏មិនចាំបាច់ស្វែងរកមនុស្ស ឬទីកន្លែងដើម្បីធ្វើកិច្ចការដោយផ្ទាល់នោះទេ។ ទ្រង់មិនបានធ្វើកិច្ចការបែបនេះទេ នៅពេលដែលទ្រង់បានយាងមក។ មនុស្សត្រឹមត្រូវ ត្រូវបានរៀបចំរួចជាស្រេចអស់ហើយដើម្បីថ្វាយទ្រង់ មុនពេលដែលទ្រង់បានយាងមកដល់។ យ៉ូហានបានបញ្ចប់កិច្ចការនេះរួចហើយ គឺមុនពេលដែលព្រះយេស៊ូវបានចាប់ផ្ដើមកិច្ចការរបស់ទ្រង់ ដ្បិតនៅពេលដែលព្រះជាម្ចាស់ដែលបានយកកំណើតជាមនុស្សបានយាងមកដល់ដើម្បីធ្វើកិច្ចការរបស់ទ្រង់ នោះទ្រង់ធ្វើការដោយឥតបត់បែនលើអស់អ្នកដែលបានរង់ចាំទ្រង់ជាយូរមកហើយ។ ព្រះយេស៊ូវមិនបានយាងមកដើម្បីធ្វើកិច្ចការនៃការកែតម្រូវរបស់មនុស្សនោះទេ។ ទ្រង់គ្រាន់តែយាងមកដើម្បីបំពេញនូវព័ន្ធកិច្ចរបស់ទ្រង់ដែលត្រូវបំពេញប៉ុណ្ណោះ អ្វីៗផ្សេងទៀតមិនទាក់ទងនឹងទ្រង់ឡើយ។ នៅពេលដែលយ៉ូហានបានមក គាត់មិនបានធ្វើអ្វីក្រៅពីការនាំមនុស្សចេញពីព្រះវិហារ និងមនុស្សក្នុងចំណោមជនជាតិយូដា ជាមនុស្សមួយក្រុមដែលបានទទួលដំណឹងល្អអំពីនគរស្ថានសួគ៌ ដើម្បីឲ្យពួកគេអាចក្លាយជាកម្មវត្ថុនៃកិច្ចការរបស់ព្រះអម្ចាស់យេស៊ូវ។ យ៉ូហានបានធ្វើការអស់រយៈពេលប្រាំពីរឆ្នាំ ដែលមានន័យថាគាត់បានផ្សព្វផ្សាយដំណឹងល្អអស់រយៈពេលប្រាំពីរឆ្នាំ។ ក្នុងកំឡុងពេលកិច្ចការរបស់គាត់ យ៉ូហានមិនបានសម្ដែងការឫទ្ធិបារមីច្រើនទេ ដ្បិតកិច្ចការរបស់គាត់ គឺដើម្បីរៀបចំផ្លូវ។ កិច្ចការរបស់គាត់គឺជាកិច្ចការត្រួសត្រាយ។ កិច្ចការផ្សេងទៀត ជាកិច្ចការដែលព្រះយេស៊ូវនឹងធ្វើ គឺមិនទាក់ទងនឹងគាត់ទេ។ គាត់គ្រាន់តែស្នើឲ្យមនុស្សសារភាពនូវអំពើបាបរបស់ខ្លួន ហើយប្រែចិត្ត និងធ្វើបុណ្យជ្រមុជទឹកឲ្យមនុស្ស ដើម្បីឲ្យពួកគេបានសង្គ្រោះប៉ុណ្ណោះ។ ទោះបីជាគាត់បានធ្វើកិច្ចការថ្មី ហើយបានបើកផ្លូវដែលមនុស្សមិនធ្លាប់ដើរឆ្លងកាត់ពីមុនក៏ដោយ ក៏គាត់គ្រាន់តែរៀបចំផ្លូវសម្រាប់ព្រះយេស៊ូវប៉ុណ្ណោះ។ គាត់គ្រាន់តែជាហោរាម្នាក់ដែលបានធ្វើនូវកិច្ចការត្រួសត្រាយ ហើយគាត់មិនមានសមត្ថភាពធ្វើកិច្ចការរបស់ព្រះយេស៊ូវទេ។ ទោះបីជាព្រះយេស៊ូវមិនមែនជាអ្នកទីមួយដែលប្រកាសដំណឹងល្អអំពីនគរស្ថានសួគ៌ក៏ដោយ

ហើយទោះបីជាទ្រង់បានបន្តតាមផ្លូវដែលយ៉ូហានបានដើរក៏ដោយ ក៏គ្មាននរណាផ្សេងទៀតដែលអាចធ្វើកិច្ចការរបស់ទ្រង់បានឡើយ ហើយកិច្ចការរបស់ទ្រង់គឺខ្ពស់ជាងកិច្ចការរបស់យ៉ូហាន។ ព្រះយេស៊ូវ មិនអាចរៀបចំផ្លូវផ្ទាល់ខ្លួនរបស់ទ្រង់ទេ។ កិច្ចការរបស់ទ្រង់ត្រូវបានអនុវត្តដោយផ្ទាល់ជំនួសឱ្យព្រះជាម្ចាស់។ ដូច្នេះហើយ មិនថាយ៉ូហានបានធ្វើកិច្ចការប៉ុន្មានឆ្នាំនោះទេ ក៏គាត់នៅតែជាហោរាម្នាក់ ហើយនៅតែជាអ្នកដែលត្រួសត្រាយផ្លូវដដែល។ កិច្ចការរយៈពេលបីឆ្នាំដែលព្រះយេស៊ូវបានធ្វើ គឺលើសពីរយៈពេលប្រាំពីរឆ្នាំនៃកិច្ចការរបស់យ៉ូហាន ដ្បិតសារជាតិនៃកិច្ចការរបស់ទ្រង់គឺមិនដូចគ្នាទេ។ នៅពេលដែលព្រះយេស៊ូវចាប់ផ្ដើមបំពេញព័ន្ធកិច្ចរបស់ទ្រង់ ក៏ជាពេលដែលកិច្ចការរបស់យ៉ូហានត្រូវបញ្ចប់ដែរ យ៉ូហានបានរៀបចំមនុស្ស និងកន្លែងគ្រប់គ្រាន់សម្រាប់ព្រះអម្ចាស់យេស៊ូវប្រើ ហើយទាំងនេះគឺគ្រប់គ្រាន់សម្រាប់ព្រះអម្ចាស់យេស៊ូវចាប់ផ្ដើមកិច្ចការរយៈពេលបីឆ្នាំ។ ដូច្នេះហើយ នៅពេលណាដែលកិច្ចការរបស់យ៉ូហានត្រូវបានបញ្ចប់ភ្លាម ព្រះអម្ចាស់យេស៊ូវក៏បានចាប់ផ្ដើមកិច្ចការផ្ទាល់ខ្លួនរបស់ទ្រង់ជាផ្លូវការ ហើយពាក្យដែលយ៉ូហានបាននិយាយចេញ ក៏ត្រូវបានបោះបង់ចោល។ នោះគឺដោយសារតែកិច្ចការដែលយ៉ូហានបានធ្វើ គឺសម្រាប់តែជាប្រយោជន៍ក្នុងការផ្លាស់ប្ដូរ ហើយពាក្យសំដីរបស់គាត់មិនមែនជាពាក្យសម្រាប់ជីវិតដែលនាំឲ្យមនុស្សឈានទៅរកការលូតលាស់ថ្មីទេ។ ទីបំផុត ពាក្យសំដីរបស់គាត់គ្រាន់តែជាការប្រើប្រាស់បណ្ដោះអាសន្នប៉ុណ្ណោះ។

កិច្ចការដែលព្រះយេស៊ូវបានធ្វើ មិនមែនមានលក្ខណៈអធិធម្មជាតិនោះទេ។ មានដំណើរការមួយចំពោះកិច្ចការនេះ ហើយកិច្ចការនេះបានរីកចម្រើនទៅតាមក្រឹត្យក្រមជាធម្មតារបស់វាទាំងអស់។ ក្នុងរយៈពេលប្រាំមួយខែចុងក្រោយនៃជីវិតរបស់ទ្រង់ ព្រះយេស៊ូវបានជ្រាបជាក់ច្បាស់ថាទ្រង់បានយាងមកដើម្បីធ្វើកិច្ចការនេះ ហើយទ្រង់បានជ្រាបថា ទ្រង់បានយាងមកដើម្បីត្រូវគេបោះដែកគោលភ្ជាប់នៅលើឈើឆ្កាង។ មុនពេលដែលទ្រង់ត្រូវគេឆ្កាង ព្រះយេស៊ូវបានអធិដ្ឋានជាប់ជានិច្ចទៅកាន់ព្រះដ៏ជាព្រះវរបិតា ដូចដែលទ្រង់បានអធិដ្ឋានបីដងនៅក្នុងសួនច្បារគែតសេម៉ានីអ៊ីចឹង។

បន្ទាប់ពីទ្រង់បានទទួលពិធីបុណ្យជ្រមុជទឹក ព្រះយេស៊ូវបានបំពេញព័ន្ធកិច្ចរបស់ទ្រង់រយៈពេលបីឆ្នាំកន្លះ ហើយកិច្ចការជាផ្លូវការរបស់ទ្រង់មានរយៈពេលពីរឆ្នាំកន្លះ។ ក្នុងឆ្នាំទីមួយ ទ្រង់ត្រូវបានសាតាំងចោទប្រកាន់ ធ្វើទុក្ខបុកម្នេញដោយមនុស្ស និងស្ថិតក្រោមសេចក្ដីល្បួងរបស់មនុស្ស។ ទ្រង់បានឈ្នះលើការល្បួងជាច្រើននៅពេលដែលទ្រង់អនុវត្តកិច្ចការរបស់ទ្រង់។ ក្នុងរយៈពេលប្រាំមួយខែចុងក្រោយ នៅពេលដែលព្រះយេស៊ូវហៀបនឹងត្រូវគេយកទៅឆ្កាងក្នុងពេលឆាប់ៗ នោះពេត្រុសបាននិយាយពាក្យសំដីចេញពីមាត់របស់គាត់ថា ទ្រង់ជាព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់ ថាទ្រង់គឺជាព្រះគ្រីស្ទ។ ហើយមានតែបែបនេះទេ ដែលកិច្ចការរបស់ទ្រង់ត្រូវបានគេស្គាល់គ្រប់គ្នា ហើយមានតែបែបនេះទេ ដែលអត្តសញ្ញាណរបស់ទ្រង់ត្រូវបានបើកសម្ដែងជាសាធារណៈ។ បន្ទាប់មក ព្រះយេស៊ូវបានមានបន្ទូលប្រាប់ពួកសិស្សរបស់ទ្រង់ថា ទ្រង់នឹងត្រូវគេឆ្កាងដើម្បីជាប្រយោជន៍ដល់មនុស្ស ហើយថា បីថ្ងៃក្រោយមកទ្រង់នឹងមានព្រះជន្មរស់ឡើងវិញ ថាទ្រង់បានយាងមកដើម្បីបំពេញកិច្ចការនៃការប្រោសលោះ ហើយទ្រង់ជាព្រះអង្គសង្គ្រោះ។ ទាល់តែក្នុងរយៈពេលប្រាំមួយខែចុងក្រោយ ទើបទ្រង់បានបើកសម្ដែងនូវអត្តសញ្ញាណរបស់ទ្រង់ និងកិច្ចការដែលទ្រង់មានបំណងព្រះហឫទ័យចង់ធ្វើ។ នេះក៏ជាពេលវេលារបស់ព្រះជាម្ចាស់ដែរ ហើយនេះជារបៀបដែលទ្រង់អនុវត្តកិច្ចការ។ នៅពេលនោះ ផ្នែកមួយចំនួននៃកិច្ចការរបស់ព្រះយេស៊ូវ គឺស្របទៅតាមគម្ពីរសញ្ញាចាស់ ទៅតាមក្រឹត្យវិន័យរបស់ម៉ូសេដែរ និងទៅតាមព្រះបន្ទូលរបស់ព្រះយេហូវ៉ាក្នុងយុគសម័យនៃក្រឹត្យវិន័យ។ ការទាំងអស់នេះព្រះយេស៊ូវបានប្រើដើម្បីធ្វើផ្នែកនៃកិច្ចការរបស់ទ្រង់។ ទ្រង់បានប្រកាសប្រាប់ដល់មនុស្ស និងបង្រៀនពួកគេក្នុងសាលាប្រជុំ ហើយទ្រង់បានប្រើសេចក្ដីទំនាយរបស់ពួកហោរានៅក្នុងគម្ពីរសញ្ញាចាស់ ដើម្បីស្ដីបន្ទោសពួកផារិស៊ីដែលស្អប់ខ្ពើមទ្រង់ ហើយបានប្រើព្រះបន្ទូលចេញពីបទគម្ពីរ ដើម្បីបើកសម្ដែងពីការមិនស្ដាប់បង្គាប់របស់ពួកគេ និងដើម្បីថ្កោលទោសពួកគេ។ ដ្បិតពួកគេបានមើលងាយចំពោះអ្វីដែលព្រះយេស៊ូវបានធ្វើ ជាពិសេសកិច្ចការភាគច្រើនរបស់ព្រះយេស៊ូវ ដែលមិនត្រូវបានធ្វើទៅតាម

ក្រឹត្យវិន័យនៅក្នុងបទគម្ពីរ ហើយលើសពីនេះទៅទៀត អ្វីដែលទ្រង់បានបង្រៀន គឺខ្ពស់ជាងពាក្យសំដីរបស់ពួកគេ ហើយខ្ពស់ជាងអ្វីដែលបានទាយដោយពួកហោរាក្នុងបទគម្ពីរទៅទៀត។ កិច្ចការរបស់ព្រះយេស៊ូវ គឺសម្រាប់តែប្រយោជន៍ដល់ការប្រោសលោះរបស់មនុស្ស និងដើម្បីការជាប់ឆ្កាងប៉ុណ្ណោះ ដូច្នេះហើយ មិនចាំបាច់ឲ្យទ្រង់មានបន្ទូលថែមទៀត ដើម្បីយកឈ្នះលើមនុស្សណាទេ។ អ្វីជាច្រើនដែលទ្រង់បានបង្រៀនមនុស្ស គឺត្រូវបានដកស្រង់ចេញពីព្រះបន្ទូលនៅក្នុងបទគម្ពីរ ហើយទោះបីជាកិច្ចការរបស់ទ្រង់មិនលើសពីបទគម្ពីរក៏ដោយ ក៏ទ្រង់នៅតែអាចសម្រេចកិច្ចការនៃការជាប់ឆ្កាងបានដែរ។ កិច្ចការរបស់ទ្រង់ មិនមែនជាកិច្ចការនៃព្រះបន្ទូលទេ ក៏មិនមែនកិច្ចការធ្វើសម្រាប់ជាប្រយោជន៍ដល់ការយកឈ្នះលើមនុស្សដែរ ប៉ុន្តែកិច្ចការត្រូវបានធ្វើឡើងក្នុងគោលបំណងដើម្បីប្រោសលោះមនុស្ស។ ទ្រង់គ្រាន់តែដើរតួជាតង្វាយលោះបាបសម្រាប់មនុស្ស ហើយមិនបានធ្វើជាប្រភពនៃព្រះបន្ទូលសម្រាប់មនុស្សនោះទេ។ ទ្រង់មិនបានធ្វើកិច្ចការរបស់សាសន៍ដទៃ ដែលជាកិច្ចការនៃការយកឈ្នះលើមនុស្សនោះទេ តែកិច្ចការនៃការជាប់ឆ្កាង ជាកិច្ចការដែលបានធ្វើនៅក្នុងចំណោមអ្នកដែលជឿថាមានព្រះជាម្ចាស់។ ទោះបីជាកិច្ចការរបស់ទ្រង់ត្រូវបានអនុវត្តនៅលើគ្រឹះនៃបទគម្ពីរ ហើយទោះបីជាទ្រង់បានប្រើអ្វីដែលបានថ្លែងទំនាយដោយពួកហោរាពីបុរាណ ដើម្បីថ្កោលទោសពួកផារិស៊ីក៏ដោយ នេះគឺគ្រប់គ្រាន់ហើយដើម្បីបញ្ចប់កិច្ចការនៃការជាប់ឆ្កាង។ ប្រសិនបើកិច្ចការនាពេលសព្វថ្ងៃនេះ នៅតែត្រូវបានអនុវត្តដោយផ្អែកលើគ្រឹះនៃការថ្លែងទំនាយរបស់ហោរាពីបុរាណនៅក្នុងបទគម្ពីរ នោះវាមិនអាចទៅរួចទេក្នុងការយកឈ្នះលើអ្នករាល់គ្នានោះ ដ្បិតគម្ពីរសញ្ញាចាស់មិនមានកំណត់ត្រាអំពីការមិនស្ដាប់បង្គាប់ និងអំពើបាបរបស់អ្នករាល់គ្នាជាជនជាតិចិន ហើយនិងប្រវត្តិនៃអំពើបាបរបស់អ្នករាល់គ្នាទេ។ ដូច្នេះ ប្រសិនបើកិច្ចការនេះនៅតែជាប់មានក្នុងព្រះគម្ពីរ នោះអ្នករាល់គ្នានឹងមិនដែលបានសម្រេចផលនោះឡើយ។ ព្រះគម្ពីរកត់ទុកតែប្រវត្តិសាស្ត្រដែលមានកំណត់អំពីជនជាតិអ៊ីស្រាអែល ដែលជាជនជាតិមួយមិនមានសមត្ថភាពក្នុងការបង្កើតឲ្យមានថាតើអ្នករាល់គ្នាជាមនុស្សអាក្រក់ ឬល្អ ឬនៅក្នុងការជំនុំជម្រះ

អ្នករាល់គ្នានោះឡើយ។ សូមស្រមៃគិតថា ខ្ញុំនឹងត្រូវជំនុំជម្រះអ្នករាល់គ្នា យោងទៅតាមប្រវត្តិសាស្ត្ររបស់ជនជាតិអ៊ីស្រាអែល តើអ្នករាល់គ្នានៅតែដើរតាមខ្ញុំដូចដែលអ្នកធ្វើនៅសព្វថ្ងៃនេះទេ? តើអ្នករាល់គ្នាដឹងទេថា តើអ្នករាល់គ្នាពិបាកប៉ុនណា? ប្រសិនបើគ្មានព្រះបន្ទូលណាមួយត្រូវបានថ្លែងចេញមកនៅក្នុងដំណាក់កាលនេះទេ នោះវាមិនអាចទៅរួចទេ ក្នុងការបញ្ចប់នូវកិច្ចការនៃការយកឈ្នះ។ ដោយសារតែខ្ញុំមិនបានយាងមកដើម្បីឲ្យគេបោះដែកគោលភ្ជាប់នឹងឈើឆ្កាងនោះទេ ប៉ុន្តែខ្ញុំត្រូវតែថ្លែងពីព្រះបន្ទូលដែលដាច់ដោយឡែកពីព្រះគម្ពីរ ដើម្បីឲ្យអ្នករាល់គ្នាអាចត្រូវបានយកឈ្នះ។ កិច្ចការដែលព្រះយេស៊ូវបានធ្វើ គឺគ្រាន់តែជាដំណាក់កាលខ្ពស់ជាងគម្ពីរសញ្ញាចាស់ប៉ុណ្ណោះ។ វាត្រូវបានប្រើដើម្បីចាប់ផ្ដើមនូវយុគសម័យមួយ និងដើម្បីដឹកនាំយុគសម័យនោះ។ ហេតុអ្វីបានជាទ្រង់មានបន្ទូលថា «ខ្ញុំមិនបានយាងមកដើម្បីបំផ្លាញក្រឹត្យវិន័យទេ ប៉ុន្តែដើម្បីបំពេញក្រឹត្យវិន័យវិញ?» ប៉ុន្តែនៅក្នុងកិច្ចការរបស់ទ្រង់ មានកិច្ចការជាច្រើនដែលខុសប្លែកពីក្រឹត្យវិន័យដែលបានអនុវត្ត និងបទបញ្ញត្តិ ដែលជនជាតិអ៊ីស្រាអែលដើរតាមនៅក្នុងគម្ពីរសញ្ញាចាស់ ដ្បិតទ្រង់មិនបានយាងមកធ្វើតាមក្រឹត្យវិន័យទេ ប៉ុន្តែដើម្បីបំពេញនូវក្រឹត្យវិន័យវិញ។ ដំណើរការនៃការបំពេញក្រឹត្យវិន័យ រួមបញ្ចូលនូវការអនុវត្តជាក់ស្ដែងជាច្រើន៖ កិច្ចការរបស់ទ្រង់កាន់តែមានភាពជាក់ស្ដែង និងពិតប្រាកដ ហើយលើសពីនេះទៅទៀត វាកាន់តែមានជីវិត និងមិនមែនធ្វើតាមតែច្បាប់ដោយងងឹតងងល់នោះទេ។ តើជនជាតិអ៊ីស្រាអែលមិនបានរក្សាថ្ងៃឈប់សម្រាកទេឬ? នៅពេលដែលព្រះយេស៊ូវបានយាងមក នោះទ្រង់មិនសមនឹងបានថ្ងៃឈប់សម្រាកទេ ដ្បិតទ្រង់បានមានបន្ទូលថា កូនមនុស្សគឺជាម្ចាស់នៃថ្ងៃឈប់សម្រាក ហើយនៅពេលដែលម្ចាស់នៃថ្ងៃឈប់សម្រាកយាងមកដល់ គឺទ្រង់អាចធ្វើអ្វីតាមតែទ្រង់សព្វព្រះហឫទ័យនឹងធ្វើ។ ទ្រង់បានមកដើម្បីបំពេញក្រឹត្យវិន័យនៃគម្ពីរសញ្ញាចាស់ ហើយផ្លាស់ប្ដូរក្រឹត្យវិន័យ។ អ្វីទាំងអស់ដែលបានធ្វើនៅថ្ងៃនេះ គឺផ្អែកលើពេលបច្ចុប្បន្ន តែវានៅតែពឹងផ្អែកលើគ្រឹះនៃកិច្ចការរបស់ព្រះយេហូវ៉ានៅក្នុងយុគសម័យនៃក្រឹត្យវិន័យដដែល ហើយវាមិនបំពានលើវិសាលភាពនេះបានឡើយ។

ឧទាហរណ៍ដូចជា ការប្រយ័ត្នប្រយែងចំពោះពាក្យសំដីរបស់អ្នក ហើយមិនប្រព្រឹត្តអំពើផិតក្បត់ជាដើម តើទាំងនេះមិនមែនជាក្រឹត្យវិន័យនៃគម្ពីរសញ្ញាចាស់ទេឬអី? សព្វថ្ងៃនេះ អ្វីដែលជាការតម្រូវពីអ្នករាល់គ្នា មិនមែនកំណត់ត្រឹមតែអ្វីដែលមានចែងនៅក្នុងក្រឹត្យវិន័យដប់ប្រការប៉ុណ្ណោះទេ ប៉ុន្តែរួមមានបទបញ្ញត្តិ និងច្បាប់ដែលមានបទបញ្ជាខ្ពង់ខ្ពស់ជាងបទបញ្ញត្តិមុនៗជាច្រើន។ តែនេះមិនមែនមានន័យថា អ្វីៗដែលបានកើតឡើងពីមុនត្រូវបានរំលាយចោលនោះទេ ដ្បិតដំណាក់កាលនីមួយៗនៃកិច្ចការរបស់ព្រះជាម្ចាស់ត្រូវបានធ្វើឡើងនៅលើគ្រឹះនៃដំណាក់កាលមុន។ ចំពោះកិច្ចការដែលព្រះយេហូវ៉ាបានធ្វើនៅក្នុងប្រទេសអ៊ីស្រាអែលនាពេលនោះ ដូចជាការតម្រូវឲ្យមនុស្សថ្វាយយញ្ញបូជា គោរពឪពុកម្ដាយខ្លួន មិនថ្វាយបង្គំរូបព្រះ មិនធ្វើបាប ឬជេរប្រមាថអ្នកដទៃ មិនប្រព្រឹត្តអំពើផិតក្បត់ មិនជក់បារី ឬផឹកសុរា និងមិនបរិភោគរបស់ដែលស្លាប់ ឬផឹកឈាម តើនេះមិនជាគ្រឹះសម្រាប់អ្នករាល់គ្នាអនុវត្តរហូតដល់សព្វថ្ងៃនេះទេឬអី? គឺស្ថិតនៅលើគ្រឹះនៃអតីតកាលនេះហើយ ដែលកិច្ចការនេះត្រូវបានអនុវត្តរហូតមកដល់សព្វថ្ងៃនេះ។ ទោះបីជាក្រឹត្យវិន័យពីអតីតកាលលែងត្រូវបានលើកឡើង ហើយអ្នកមានការតម្រូវថ្មីក៏ដោយ ក៏ក្រឹត្យវិន័យទាំងនេះ ដែលនៅឆ្ងាយពីការលុបបំបាត់ចោល ត្រូវបានលើកតម្កើងខ្ពស់ឡើងវិញ។ ចំពោះការនិយាយថា ក្រឹត្យវិន័យត្រូវបានលុបបំបាត់ចោល មានន័យថាយុគសម័យពីមុន គឺហួសសម័យ តែមានបញ្ញត្តិខ្លះដែលអ្នកត្រូវគោរពជារៀងរហូត។ បទបញ្ញត្តិពីអតីតកាលត្រូវបានយកមកអនុវត្ត ហើយបានក្លាយជាការអនុវត្តរបស់មនុស្សរួចទៅហើយ និងមិនចាំបាច់ដាក់ការបញ្ជាក់ជាពិសេសទៅលើបទបញ្ញត្តិដូចជា «កុំជក់បារី» និង «កុំផឹកសុរា» ជាដើមនោះទេ។ នៅលើគ្រឹះនេះ បទបញ្ញត្តិថ្មីត្រូវបានដាក់ចេញទៅនោះទេតាមតម្រូវការរបស់អ្នករាល់គ្នានាពេលបច្ចុប្បន្ន ទៅតាមកម្ពស់របស់អ្នករាល់គ្នា ហើយទៅតាមកិច្ចការនាពេលបច្ចុប្បន្ន។ ការដាក់បទបញ្ញត្តិសម្រាប់យុគសម័យថ្មី មិនមានន័យថា លុបបំបាត់បទបញ្ញត្តិនៃយុគសម័យពីមុនទេ ប៉ុន្តែជាការលើកបទបញ្ញត្តិខ្ពស់ឡើងនៅលើគ្រឹះនេះ ដើម្បីធ្វើឲ្យសកម្មភាពរបស់មនុស្សកាន់តែពេញលេញ និងស្របទៅតាម

ការពិតជាក់ស្តែង។ ប្រសិនបើសព្វថ្ងៃនេះ អ្នករាល់គ្នាត្រូវបានតម្រូវអោយធ្វើតាមបទបញ្ញត្តិ ហើយគោរពតាមក្រឹត្យវិន័យនៃគម្ពីរសញ្ញាចាស់ ដូចគ្នាទៅនឹងជនជាតិអ៊ីស្រាអែល ហើយប្រសិនបើអ្នករាល់គ្នាត្រូវបានតម្រូវឲ្យទន្ទេញចាំក្រឹត្យវិន័យដែលបានដាក់ចេញដោយព្រះយេហូវ៉ា នោះគ្មានលទ្ធភាពណាដែលអ្នករាល់គ្នាអាចផ្លាស់ប្តូរបានឡើយ។ ប្រសិនបើអ្នករាល់គ្នា គ្រាន់តែធ្វើតាមបទបញ្ញត្តិដែលមានកម្រិតមួយចំនួន ឬទន្ទេញចាំនូវក្រឹត្យវិន័យរាប់មិនអស់ទាំងនោះ នោះនិស្ស័យពីមុនរបស់អ្នករាល់គ្នានឹងនៅជាប់យ៉ាងជ្រាលជ្រៅ ហើយគ្មានផ្លូវណា អាចដកវាចេញបានឡើយ។ ដូច្នេះ អ្នករាល់គ្នានឹងក្លាយជាមនុស្សគ្មានគុណធម៌កាន់តែខ្លាំង ហើយគ្មាននរណាម្នាក់ក្នុងចំណោមអ្នករាល់គ្នា នឹងក្លាយជាអ្នកស្តាប់បង្គាប់នោះទេ។ នេះគឺមានន័យថាបទបញ្ញត្តិសាមញ្ញមួយចំនួន ឬក្រឹត្យវិន័យរាប់មិនអស់ គឺមិនអាចជួយអ្នករាល់គ្នា ឲ្យដឹងអំពីទង្វើរបស់ព្រះយេហូវ៉ាឡើយ។ អ្នករាល់គ្នាមិនដូចជនជាតិអ៊ីស្រាអែលទេ៖ តាមរយៈការធ្វើតាមក្រឹត្យវិន័យ និងទន្ទេញចាំបទបញ្ញត្តិទាំងនោះ ពួកគេអាចធ្វើបន្ទាល់ពីទង្វើរបស់ព្រះយេហូវ៉ា ហើយថ្វាយនូវភក្តីភាពរបស់ពួកគេទៅចំពោះទ្រង់តែមួយអង្គប៉ុណ្ណោះ។ តែអ្នករាល់គ្នាមិនអាចសម្រេចការនេះបានទេ ហើយបទបញ្ញត្តិមួយចំនួននៃយុគសម័យគម្ពីរសញ្ញាចាស់ មិនត្រឹមតែមិនអាចធ្វើឲ្យអ្នករាល់គ្នាថ្វាយនូវដួងចិត្តរបស់អ្នក ឬការពារអ្នករាល់គ្នាប៉ុណ្ណោះទេ ប៉ុន្តែផ្ទុយទៅវិញ នឹងធ្វើឲ្យអ្នករាល់គ្នាធូររលុង ហើយនឹងធ្វើឲ្យអ្នកធ្លាក់ទៅនរក។ ដ្បិតកិច្ចការរបស់ខ្ញុំ គឺជាកិច្ចការនៃការយកឈ្នះ ហើយវាផ្តោតលើការមិនស្តាប់បង្គាប់ និងនិស្ស័យពីមុនរបស់អ្នក។ ព្រះបន្ទូលដ៏សប្បុរសរបស់ព្រះយេហូវ៉ា និងព្រះយេស៊ូវ នៅតិចជាងព្រះបន្ទូលដ៏ធ្ងន់ធ្ងរអំពីការជំនុំជម្រះនៅសព្វថ្ងៃនេះទេ។ បើគ្មានព្រះបន្ទូលដ៏ធ្ងន់ធ្ងរបែបនេះទេ នោះមិនអាចយកឈ្នះលើអ្នករាល់គ្នាដែលជា «អ្នកជំនាញ» ជាអ្នកដែលមិនស្តាប់បង្គាប់អស់រយៈពេលរាប់ពាន់ឆ្នាំមកហើយនោះឡើយ។ ក្រឹត្យវិន័យនៃគម្ពីរសញ្ញាចាស់ បានបាត់អំណាចរបស់ខ្លួនលើអ្នករាល់គ្នាតាំងពីយូរយារណាស់មកហើយ ហើយការជំនុំជម្រះនាពេលសព្វថ្ងៃនេះ គឺគួរអោយខ្លាចជាងក្រឹត្យវិន័យចាស់ទៅទៀត។ អ្វីដែល

សមនឹងអ្នកបំផុតនោះ គឺការជំនុំជម្រះ ហើយមិនដាក់កម្រិតចំពោះរឿងដែលមិនសំខាន់អំពីក្រឹត្យវិន័យឡើយ ដ្បិតអីអ្នកមិនមែនជាមនុស្សពីដើមដំបូងឡើយ ប៉ុន្ដែជាមនុស្សដែលបានធ្វើឲ្យពុករលួយអស់រាប់ពាន់ឆ្នាំមកហើយ។ អ្វីដែលមនុស្សត្រូវតែសម្រេចបាននៅពេលនេះ គឺស្របតាមសណ្ឋានដ៏ពិតរបស់មនុស្សនាពេលសព្វថ្ងៃនេះ តាមរយៈកម្រិតគុណភាព និងកម្ពស់ជាក់ស្ដែងរបស់មនុស្សបច្ចុប្បន្ន ហើយវាមិនតម្រូវឲ្យអ្នកធ្វើតាមច្បាប់នេះទេ។ ការនេះ គឺដើម្បីឲ្យការផ្លាស់ប្ដូរអាចត្រូវសម្រេចនៅក្នុងនិស្ស័យពីមុនរបស់អ្នក ហើយដើម្បីឲ្យអ្នកអាចបោះចោលនូវសញ្ញាណរបស់អ្នកចេញ។ តើអ្នកគិតថា បទបញ្ញត្តិជាច្បាប់ដែរឬទេ? អាចនិយាយបានថា វាជាសេចក្ដីតម្រូវជាធម្មតាចំពោះមនុស្ស។ ក្រឹត្យវិន័យមិនមែនជាច្បាប់ដែលអ្នកត្រូវតែធ្វើតាមនោះទេ ឧទាហរណ៍ដូចជាការហាមជក់បារី តើវាជាច្បាប់ឬ? វាមិនមែនជាច្បាប់ទេ! ប៉ុន្ដែវាត្រូវបានតម្រូវពីភាពជាមនុស្សធម្មតា វាមិនមែនជាច្បាប់ទេ ប៉ុន្ដែជាអ្វីដែលមានចែងសម្រាប់មនុស្សជាតិទាំងមូល។ សព្វថ្ងៃនេះ មានបទបញ្ញត្តិជាច្រើនត្រូវបានបង្កើតឡើង នោះក៏មិនមែនជាច្បាប់ដែរ។ បទបញ្ញត្តិទាំងនោះគឺជាសេចក្ដីតម្រូវ ដើម្បីសម្រេចបាននូវភាពជាមនុស្សធម្មតា។ មនុស្សមិនមាន ឬដឹងអំពីរឿងរ៉ាវបែបនេះពីអតីតកាលទេ ដូច្នេះមនុស្ស ត្រូវបានតម្រូវឲ្យសម្រេចវាបាននៅពេលសព្វថ្ងៃនេះ ហើយរឿងរ៉ាវទាំងនោះមិនចាត់ទុកថាជាច្បាប់ទេ។ ក្រឹត្យវិន័យ គឺមិនដូចគ្នាទៅនឹងច្បាប់ទេ។ ច្បាប់ដែលខ្ញុំមានបន្ទូល គឺយោងទៅលើពិធី ភាពផ្លូវការ ឬការប្រព្រឹត្តខុសឆ្គង និងភាពមិនត្រឹមត្រូវរបស់មនុស្ស។ ពួកវាជាបទបញ្ញត្តិដែលមិនអាចជួយអ្វីដល់មនុស្សបានទេ វាមិនមានប្រយោជន៍ចំពោះគេទេ។ ពួកវាបង្កើតផ្លូវប្រតិបត្តិដែលមិនមានន័យអ្វីឡើយ។ នេះជាសេចក្ដីសង្ខេបនៃច្បាប់ ហើយច្បាប់ទាំងនេះត្រូវតែបោះបង់ចោល ដ្បិតច្បាប់ទាំងនេះ មិនបានផ្ដល់ផលប្រយោជន៍ដល់មនុស្សទេ។ មានតែអ្វីដែលផ្ដល់ផលប្រយោជន៍ដល់មនុស្សទេ ទើបត្រូវយកទៅអនុវត្ត។

# និមិត្តអំពីកិច្ចការរបស់ព្រះជាម្ចាស់ (២)

ដំណឹងល្អនៃការប្រែចិត្ត ត្រូវបានអធិប្បាយនៅក្នុងយុគសម័យនៃព្រះគុណ ហើយបើមនុស្សបានជឿ នោះគេនឹងត្រូវបានសង្គ្រោះ។ សព្វថ្ងៃនេះ ជំនួសឲ្យសេចក្ដីសង្គ្រោះ មានតែការនិយាយអំពីការយកឈ្នះ និងភាពគ្រប់លក្ខណ៍តែប៉ុណ្ណោះ។ មិនធ្លាប់មានការនិយាយថា ប្រសិនបើមនុស្សម្នាក់ជឿ នោះគ្រួសាររបស់ពួកគេទាំងមូលនឹងត្រូវទទួលបានព្រះពរឡើយ ឬថានៅពេលត្រូវបានសង្គ្រោះហើយ គឺតែងតែត្រូវបានសង្គ្រោះជានិច្ចនោះទេ។ សព្វថ្ងៃនេះ គ្មាននរណាម្នាក់និយាយពាក្យទាំងអស់នេះទៀតទេ ហើយរឿងបែបនេះហួសសម័យហើយ។ នៅពេលនោះ កិច្ចការរបស់ព្រះយេស៊ូវគឺជាកិច្ចការប្រោសលោះគ្រប់មនុស្សជាតិទាំងអស់។ បាបរបស់អស់អ្នកដែលបានជឿលើទ្រង់ ត្រូវបានអត់ទោសឲ្យ។ ឲ្យតែអ្នកបានជឿលើទ្រង់ នោះទ្រង់នឹងប្រោសលោះអ្នក។ ប្រសិនបើអ្នកបានជឿលើទ្រង់ នោះអ្នកលែងមានបាបទៀតហើយ អ្នកត្រូវរួចផុតពីបាបរបស់អ្នក។ នេះគឺជាអត្ថន័យ នៃការដែលទទួលបានសេចក្ដីសង្គ្រោះ និងការដែលត្រូវទទួលបានយុត្តិធម៌តាមរយៈសេចក្ដីជំនឿ។ ក៏ប៉ុន្តែនៅក្នុងអស់អ្នកដែលបានជឿ នៅតែមានការបះបោរ និងបានទទឹងទាស់នឹងព្រះជាម្ចាស់ដដែល ហើយសារជាតិទាំងនេះត្រូវដកចេញបន្តិចម្ដងៗ។ សេចក្ដីសង្គ្រោះពុំមានន័យថា មនុស្សត្រូវបានព្រះយេស៊ូវទទួលបានទាំងស្រុងនោះទេ ប៉ុន្តែមនុស្សលែងមានបាបទៀតហើយ ពោលគឺមានន័យថាអំពើបាបរបស់គេត្រូវបានអត់ទោសឲ្យ។ ប្រសិនបើអ្នកបានជឿ នោះអ្នកនឹងលែងមានបាបទៀតហើយ។ នៅពេលនោះ ព្រះយេស៊ូវបានធ្វើកិច្ចការយ៉ាងច្រើនដែលសិស្សរបស់ទ្រង់មិនអាចយល់បាន និងបានមានព្រះបន្ទូលជាច្រើនដែលមនុស្សពុំយល់សោះឡើយ។ នេះគឺដោយសារនៅពេលនោះ ទ្រង់មិនបានប្រទានការពន្យល់ណាមួយឡើយ។ ហេតុនេះ ជាច្រើនឆ្នាំបន្ទាប់ពីទ្រង់បានយាងចាកចេញទៅ ម៉ាថាយបានបង្កើតពង្សាវតារមួយសម្រាប់ព្រះយេស៊ូវ ហើយអ្នកដទៃក៏បានធ្វើកិច្ចការជាច្រើនដែលចេញពីបំណងរបស់មនុស្ស។ ព្រះយេស៊ូវមិនបានយាងមកដើម្បី

ប្រោសមនុស្សឲ្យបានគ្រប់លក្ខណ៍ និងដើម្បីទទួលបានមនុស្សឡើយ ប៉ុន្តែដើម្បីបំពេញកិច្ចការមួយដំណាក់កាលនៃកិច្ចការនេះ ពោលគឺការនាំមកនូវដំណឹងល្អអំពីនគរស្ថានសួគ៌ និងការបញ្ចប់កិច្ចការនៃការជាប់ឆ្កាង។ ហេតុដូច្នេះ នៅពេលដែលព្រះយេស៊ូវត្រូវបានគេឆ្កាង នោះកិច្ចការរបស់ទ្រង់បានចូលដល់ទីបញ្ចប់។ ប៉ុន្តែនៅក្នុងដំណាក់កាលបច្ចុប្បន្ន ដែលជាកិច្ចការនៃការយកឈ្នះ នោះត្រូវតែមានព្រះបន្ទូលជាច្រើនថ្លែងចេញមក ត្រូវធ្វើកិច្ចការកាន់តែច្រើន និងត្រូវមានដំណាក់កាលជាច្រើន។ ដូច្នេះ អាថ៌កំបាំងជាច្រើននៃកិច្ចការរបស់ព្រះយេស៊ូវ និងព្រះយេហូវ៉ា ចាំបាច់ត្រូវតែបើកសម្ដែង ដើម្បីឲ្យមនុស្សទាំងអស់អាចមានការយល់ដឹង និងមានភាពច្បាស់លាស់នៅក្នុងជំនឿរបស់ពួកគេ ដ្បិតនេះគឺជាកិច្ចការនៃគ្រាចុងក្រោយ ហើយគ្រាចុងក្រោយគឺជាចុងបញ្ចប់នៃកិច្ចការរបស់ព្រះជាម្ចាស់ ជាពេលវេលានៃការបញ្ចប់កិច្ចការនេះ។ ដំណាក់កាលនៃកិច្ចការនេះនឹងបំភ្លឺដល់អ្នកអំពីក្រឹត្យវិន័យរបស់ព្រះយេហូវ៉ា និងការប្រោសលោះរបស់ព្រះយេស៊ូវ ហើយជាគោលការណ៍ គឺដើម្បីឲ្យអ្នកអាចយល់ពីកិច្ចការទាំងស្រុងនៃផែនការគ្រប់គ្រងរយៈពេលប្រាំមួយពាន់ឆ្នាំរបស់ព្រះជាម្ចាស់ និងលើកសរសើរអំពីសារៈសំខាន់ និងលក្ខណៈសំខាន់នៃផែនការគ្រប់គ្រងរយៈពេលប្រាំមួយពាន់ឆ្នាំនេះ ព្រមទាំងយល់អំពីគោលបំណងនៃគ្រប់កិច្ចការទាំងអស់ដែលព្រះយេស៊ូវបានបំពេញ និងព្រះបន្ទូលដែលទ្រង់បានមានព្រះបន្ទូល ហើយសូម្បីតែជំនឿផ្កាប់មុខរបស់អ្នក និងការស្រឡាញ់ពេញចិត្តចំពោះព្រះគម្ពីរក៏ដោយ។ គ្រប់ការទាំងអស់នេះ សុទ្ធតែនឹងអនុញ្ញាតឲ្យអ្នកយល់ដឹងបានយ៉ាងពិស្ដារ។ អ្នកនឹងត្រូវយល់ដឹងទាំងអំពីកិច្ចការដែលព្រះយេស៊ូវបានបំពេញ និងកិច្ចការរបស់ព្រះជាម្ចាស់ក្នុងពេលសព្វថ្ងៃនេះ ហើយអ្នកនឹងយល់ដឹង និងបានឃើញអំពីសេចក្ដីពិត អំពីជីវិត និងអំពីផ្លូវ។ នៅក្នុងដំណាក់កាលនៃកិច្ចការដែលព្រះយេស៊ូវបានបំពេញ តើហេតុអ្វីបានជាព្រះយេស៊ូវយាងចាកចេញដោយមិនបានបញ្ចប់កិច្ចការនេះ? ដោយសារដំណាក់កាលនៃកិច្ចការរបស់ព្រះយេស៊ូវ គឺមិនមែនជាកិច្ចការនៃការបញ្ចប់សម័យកាលឡើយ។ នៅពេលដែលទ្រង់ត្រូវគេឆ្កាងទៅនឹងឈើឆ្កាង ព្រះបន្ទូលរបស់ទ្រង់ ក៏បានដល់ទី

បញ្ចប់ដែរ។ ក្រោយការឆ្កាងរបស់ទ្រង់ កិច្ចការរបស់ទ្រង់ត្រូវបានបញ្ចប់ទាំងស្រុង។ ដំណាក់កាលបច្ចុប្បន្ននេះ គឺមានភាពខុសគ្នា៖ មានតែបន្ទាប់ពីព្រះបន្ទូលត្រូវបានសម្ដែងដល់ចុងបញ្ចប់នៃកិច្ចការទាំងស្រុងរបស់ព្រះជាម្ចាស់ប៉ុណ្ណោះ ទើបកិច្ចការរបស់ទ្រង់នឹងត្រូវបានបញ្ចប់។ ក្នុងអំឡុងដំណាក់កាលនៃកិច្ចការរបស់ព្រះយេស៊ូវ មានព្រះបន្ទូលជាច្រើនដែលមិនទាន់បានមានព្រះបន្ទូល ឬមិនទាន់បានបញ្ចេញព្រះសូរសៀងដោយពេញលេញនៅឡើយ។ ក៏ប៉ុន្តែ ព្រះយេស៊ូវមិនយកព្រះទ័យទុកដាក់ចំពោះអ្វីដែលទ្រង់បានមានព្រះបន្ទូល និងមិនបានមានព្រះបន្ទូលនោះទេ ដ្បិតព័ន្ធកិច្ចរបស់ទ្រង់ គឺមិនមែនជាព័ន្ធកិច្ចនៃព្រះបន្ទូលទេ ដូច្នេះហើយ ក្រោយពីទ្រង់ត្រូវបានគេឆ្កាងទៅនឹងឈើឆ្កាង ទ្រង់ក៏បានយាងចាកចេញទៅ។ ដំណាក់កាលនៃកិច្ចការនោះសំខាន់គឺដើម្បីជាប្រយោជន៍ដល់ការជាប់ឆ្កាង និងមិនដូចជាដំណាក់កាលបច្ចុប្បន្ននេះឡើយ។ ជាគោលការណ៍ ដំណាក់កាលនៃកិច្ចការបច្ចុប្បន្ននេះ គឺដើម្បីជាប្រយោជន៍ដល់ការបញ្ចប់ ការសម្អាត និងការនាំកិច្ចការទាំងអស់នោះទៅរកទីបញ្ចប់។ ប្រសិនបើព្រះបន្ទូលមិនបានសម្ដែងរហូតដល់ចុងបំផុតទេ នោះនឹងគ្មានផ្លូវណាដែលអាចបញ្ចប់កិច្ចការនេះបានឡើយ ដ្បិតនៅក្នុងដំណាក់កាលនៃកិច្ចការនេះ គ្រប់កិច្ចការទាំងអស់ត្រូវចូលដល់ទីបញ្ចប់ និងត្រូវសម្រេចបានដោយប្រើព្រះបន្ទូល។ នៅពេលនោះព្រះយេស៊ូវបានបំពេញកិច្ចការជាច្រើនដែលមនុស្សមិនអាចយល់បាន។ ទ្រង់បានយាងចាកចេញទៅដោយស្ងៀមស្ងាត់ ហើយសព្វថ្ងៃនេះ នៅតែមានមនុស្សជាច្រើនដែលមិនយល់ពីព្រះបន្ទូលរបស់ទ្រង់ ដែលការយល់ដឹងរបស់ពួកគេគឺជាការខុសឆ្គងក៏ប៉ុន្តែពួកគេនៅតែជឿថា វាជាការត្រឹមត្រូវ និងមិនដឹងថា ពួកគេខុសឆ្គងនោះទេ។ ដំណាក់កាលចុងក្រោយនឹងនាំកិច្ចការរបស់ព្រះជាម្ចាស់ទៅរកទីបញ្ចប់ ហើយនឹងសម្រេចនូវការបញ្ចប់កិច្ចការនោះ។ មនុស្សទាំងអស់នឹងយល់ និងដឹងអំពីផែនការគ្រប់គ្រងរបស់ព្រះជាម្ចាស់។ សញ្ញាណនៅខាងក្នុងខ្លួនមនុស្ស បំណងរបស់គេ ការយល់ដឹងខុស និងមិនសមហេតុផលរបស់គេ សញ្ញាណរបស់គេអំពីកិច្ចការរបស់ព្រះយេហូវ៉ា និងកិច្ចការរបស់ព្រះយេស៊ូវ ទស្សនៈរបស់គេអំពីពួកសាសន៍ដទៃ និង

ភាពវៀចវេរ និងកំហុសដទៃទៀត នឹងត្រូវបានកែតម្រូវ។ ហើយមនុស្សនឹងយល់ពីមាគ៌ាជីវិតដែលត្រឹមត្រូវ និងគ្រប់កិច្ចការទាំងអស់ដែលព្រះជាម្ចាស់បានធ្វើ ព្រមទាំងសេចក្ដីពិតទាំងស្រុងផង។ នៅពេលដែលរឿងនេះកើតឡើង ដំណាក់កាលនៃកិច្ចការនេះនឹងត្រូវចូលដល់ទីបញ្ចប់។ កិច្ចការរបស់ព្រះយេហូវ៉ា គឺជាការបង្កើតពិភពលោកនេះ ដែលវាគឺជាការចាប់ផ្ដើមដំបូង។ ដំណាក់កាលនៃកិច្ចការនេះ គឺជាចុងបញ្ចប់នៃកិច្ចការ ហើយវាក៏ជាការបិទបញ្ចប់ដែរ។ កាលពីដើមដំបូង កិច្ចការរបស់ព្រះជាម្ចាស់ត្រូវបានអនុវត្ត ក្នុងចំណោមរាស្ត្ររើសតាំងនៃស្រុកអ៊ីស្រាអែល ហើយវាគឺជាការចាប់ផ្ដើមនៃយុគសម័យថ្មីមួយ នៅកន្លែងដែលបរិសុទ្ធបំផុតនៃគ្រប់ទីកន្លែង។ ដំណាក់កាលចុងក្រោយនៃកិច្ចនេះ គឺត្រូវធ្វើឡើងនៅក្នុងប្រទេសដែលមិនបរិសុទ្ធជាងគេបំផុតក្នុងចំណោមប្រទេសទាំងអស់ ដើម្បីជំនុំជម្រះលោកិយនេះ និងនាំយុគសម័យនេះទៅដល់ទីចុងបញ្ចប់។ នៅក្នុងដំណាក់កាលដំបូង កិច្ចការរបស់ព្រះជាម្ចាស់ត្រូវធ្វើឡើងនៅកន្លែងដែលមានពន្លឺខ្លាំងបំផុត ហើយដំណាក់កាលចុងក្រោយត្រូវអនុវត្តនៅក្នុងកន្លែងងងឹតបំផុត ហើយភាពងងឹតនេះនឹងត្រូវបណ្ដេញចេញ រួចពន្លឺនឹងមកជំនួសវិញ ហើយមនុស្សទាំងអស់នឹងត្រូវបានយកឈ្នះ។ នៅពេលដែលមនុស្សនៃកន្លែងមិនបរិសុទ្ធ និងងងឹតជាងគេត្រូវបានយកឈ្នះ ហើយប្រជាជនទាំងអស់បានទទួលស្គាល់ថា មានព្រះជាម្ចាស់ពិតប្រាកដមែន ដឹងថានរណាជាព្រះជាម្ចាស់ដ៏ពិតប្រាកដ ហើយមនុស្សគ្រប់គ្នាបានជឿជាក់ទាំងស្រុង នោះការពិតនេះនឹងត្រូវប្រើដើម្បីអនុវត្តកិច្ចការនៃការយកឈ្នះនៅទូទាំងសាកលលោកទាំងមូល។ ដំណាក់កាលនៃកិច្ចការនេះ គឺជានិមិត្តសញ្ញា៖ នៅពេលដែលកិច្ចការនៃយុគសម័នេះត្រូវបានបញ្ចប់ នោះកិច្ចការនៃការគ្រប់គ្រងរយៈពេលប្រាំមួយពាន់ឆ្នាំនេះនឹងត្រូវចូលមកដល់ទីបញ្ចប់ទាំងស្រុង។ នៅពេលអស់អ្នកដែលស្ថិតនៅក្នុងកន្លែងងងឹតជាងគេបំផុត ត្រូវបានយកឈ្នះ នោះច្បាស់ណាស់ថា គ្រប់កន្លែងដទៃផ្សេងទៀតក៏នឹងត្រូវបានយកឈ្នះដែរ។ ហេតុដូច្នេះ មានតែកិច្ចការនៃការយកឈ្នះនៅក្នុងប្រទេសចិនប៉ុណ្ណោះ ដែលមាននិមិត្តសញ្ញាដ៏មានអត្ថន័យខ្លឹមសារ។ ប្រទេសចិនតំណាងឲ្យគ្រប់កម្លាំងនៃសេចក្ដី

ងងឹតទាំងអស់ ហើយប្រជាជនចិនតំណាងឲ្យអស់អ្នកដែលនៅខាងសាច់ឈាមរបស់សាតាំង និងខាងសាច់ និងឈាម។ គឺជនជាតិចិននេះហើយដែលត្រូវបាននាគដ៏ធំមានសម្បុរក្រហមធ្វើឲ្យពុករលួយយ៉ាងខ្លាំង ជាអ្នកដែលមានការទទឹងទាស់នឹងព្រះជាម្ចាស់ខ្លាំងជាងគេបំផុត ហើយភាពជាមនុស្សរបស់ពួកគេ គឺថោកទាប និងមិនបរិសុទ្ធឡើយ ដូច្នេះហើយ ពួកគេគឺជាប្រភេទគំរូនៃភាពជាមនុស្សដែលពុករលួយទាំងអស់។ នេះមិនមែនចង់និយាយថា ប្រទេសដទៃទៀតគ្មានបញ្ហាអ្វីនោះទេ។ សញ្ញាណរបស់មនុស្ស គឺសុទ្ធតែដូចគ្នាទាំងអស់ ហើយបើទោះបីជាប្រជាជននៃប្រទេសទាំងអស់នោះអាចមានគុណសម្បត្តិល្អក្តី ប្រសិនបើពួកគេមិនស្គាល់ព្រះជាម្ចាស់ទេ នោះច្បាស់ជាដោយសារតែពួកគេទាស់ទទឹងនឹងទ្រង់ហើយ។ តើហេតុអ្វីបានជាសាសន៍យូដាក៏ទាស់ទទឹង និងបដិសេធព្រះជាម្ចាស់ដែរនោះ? តើហេតុអ្វីបានជាពួកផារិស៊ីក៏ទទឹងទាស់នឹងទ្រង់ដែរនោះ? តើហេតុអ្វីបានយូដាសក្បត់ព្រះយេស៊ូវដែរ? នៅពេលនោះសិស្សជាច្រើនមិនបានស្គាល់ព្រះយេស៊ូវឡើយ។ បន្ទាប់ពីព្រះយេស៊ូវត្រូវបានគេឆ្កាង និងមានព្រះជន្មរស់ឡើងវិញ តើមូលហេតុអ្វី បានជាមនុស្សនៅតែមិនជឿលើទ្រង់ដដែល? តើការមិនស្តាប់បង្គាប់របស់មនុស្ស មិនសុទ្ធតែដូចគ្នាទេឬអី? គឺគ្រាន់តែថាប្រជាជនចិនត្រូវបានធ្វើជាឧទាហរណ៍អំពីការយកឈ្នះប៉ុណ្ណោះ ហើយនៅពេលដែលពួកគេត្រូវបានយកឈ្នះ ពួកគេនឹងក្លាយជាពុម្ព និងជាគំរូ ហើយនឹងក្លាយជាទីសម្អាងសម្រាប់អ្នកដទៃ។ តើហេតុអ្វីបានជាខ្ញុំតែងតែមានព្រះបន្ទូលថា អ្នករាល់គ្នាគឺជាមនុស្សបន្ទាប់បន្សំ នៅក្នុងផែនការនៃការគ្រប់គ្រងរបស់ខ្ញុំ? គឺប្រជាជនចិននេះហើយដែលបើកបង្ហាញអំពីសេចក្តីពុករលួយ ភាពមិនបរិសុទ្ធ ភាពទុច្ចរិត ការទាស់ទទឹង និងការបះបោរទាំងស្រុង និងបើកសម្តែងឲ្យឃើញនៅក្នុងទម្រង់ខុសៗគ្នា។ ចំណុចម្ខាង ពួកគេមានលក្ខណៈសម្បត្តិអន់ខ្សោយ ហើយចំណុចម្ខាងទៀត ជីវិត និងផ្នត់គំនិតរបស់ពួកគេគឺអន់ខ្សោយ ហើយទម្លាប់ មជ្ឈដ្ឋាន គ្រួសារកំណើតរបស់ពួកគេគ្រប់សព្វបែបយ៉ាងទាំងអស់ គឺសុទ្ធតែអន់ខ្សោយខ្លាំងណាស់ និងអន់ថយជាងគេបំផុត។ ឋានៈរបស់ពួកគេក៏តូចទាបខ្លាំងណាស់ដែរ។ កិច្ចការនៅក្នុងកន្លែងនេះ គឺជា

និមិត្តសញ្ញា ហើយបន្ទាប់ពីការសាកល្បងនេះត្រូវបានអនុវត្តចប់ទាំងស្រុង នោះកិច្ចការបន្ទាប់របស់ព្រះជាម្ចាស់នឹងកាន់តែងាយស្រួលជាងនេះ។ ប្រសិនបើដំណាក់កាលនៃកិច្ចការនេះអាចបញ្ចប់ទៅបាន នោះកិច្ចការបន្ទាប់ក៏នឹងអាចបញ្ចប់ទៅបានដូចគ្នាដែរ។ នៅពេលដែលដំណាក់កាលនៃកិច្ចការនេះត្រូវបានបញ្ចប់ នោះជោគជ័យដ៏អស្ចារ្យនឹងត្រូវសម្រេចបានដោយពេញលេញ ហើយកិច្ចការនៃការយកឈ្នះនៅទូទាំងសាកលលោកទាំងមូល នឹងឈានចូលដល់ទីបញ្ចប់។ តាមពិតទៅ នៅពេលដែលកិច្ចការក្នុងចំណោមអ្នករាល់គ្នាសម្រេចបានជោគជ័យ នោះកិច្ចការនេះ គឺមិនខុសអ្វីពីជោគជ័យនៅទូទាំងសាកលលោកទាំងមូលឡើយ។ នេះគឺជាសារៈសំខាន់នៃមូលហេតុដែលខ្ញុំឲ្យអ្នករាល់គ្នាធ្វើជាពុម្ព និងជាគំរូ។ ការបះបោរ ការទាស់ទទឹង ភាពមិនបរិសុទ្ធ សេចក្ដីទុច្ចរិត ទាំងអស់នេះសុទ្ធតែមាននៅក្នុងខ្លួនមនុស្សទាំងអស់នេះ ហើយនៅក្នុងពួកគេ គឺសុទ្ធតែតំណាងឲ្យការបះបោររបស់មនុស្សជាតិ។ ពួកគេមានអ្វីដែលអាចប្រើការបាន។ ហេតុនេះ ពួកគេត្រូវបានចាត់ទុកជាគំរូល្អបំផុតនៃការយកឈ្នះ ហើយនៅពេលដែលពួកគេត្រូវបានយកឈ្នះរួចហើយ ពួកគេនឹងក្លាយជាពុម្ព និងជាគំរូសម្រាប់មនុស្សដទៃទៀតដោយឯកឯង។ គ្មានអ្វីដែលជានិមិត្តសញ្ញាជាងដំណាក់កាលដំបូងដែលត្រូវអនុវត្តនៅក្នុងស្រុកអ៊ីស្រាអែលឡើយ។ ពួកសាសន៍អ៊ីស្រាអែល គឺជាពួកបរិសុទ្ធជាងគេបំផុត និងជាមនុស្សពុករលួយតិចជាងគេបំផុត ដូច្នេះហើយ ការចាប់ផ្ដើមនៃយុគសម័យថ្មីនៅក្នុងទឹកដីនេះ គឺមានសារៈសំខាន់ខ្លាំងជាងគេបំផុត។ អាចនិយាយបានថា បុព្វបុរសរបស់មនុស្សជាតិបានចេញមកពីស្រុកអ៊ីស្រាអែល ហើយស្រុកអ៊ីស្រាអែល គឺជាទីកន្លែងកំណើតនៃកិច្ចការរបស់ព្រះជាម្ចាស់។ កាលពីដើមដំបូងឡើយ មនុស្សទាំងអស់នេះ គឺជាមនុស្សបរិសុទ្ធជាងគេបំផុត ហើយពួកគេទាំងអស់សុទ្ធតែថ្វាយបង្គំព្រះយេហូវ៉ា ហើយកិច្ចការរបស់ព្រះជាម្ចាស់ចំពោះពួកគេ គឺអាចសម្រេចផលផ្លែបានយ៉ាងច្រើនបំផុត។ ព្រះគម្ពីរទាំងមូលកត់ត្រាអំពីកិច្ចការក្នុងសម័យកាលពីរ៖ ទីមួយ គឺកិច្ចការនៅក្នុងយុគសម័យនៃក្រឹត្យវិន័យ ហើយមួយទៀត គឺកិច្ចការនៅក្នុងយុគសម័យនៃព្រះគុណ។ ព្រះគម្ពីរសញ្ញាចាស់

កត់ត្រាពីព្រះបន្ទូលរបស់ព្រះយេហូវ៉ាទៅកាន់ពួកសាសន៍អ៊ីស្រាអែល និងកិច្ចការរបស់ទ្រង់នៅស្រុកអ៊ីស្រាអែល។ ព្រះគម្ពីរសញ្ញាថ្មីកត់ត្រាពីកិច្ចការរបស់ព្រះយេស៊ូវនៅស្រុកយូដា។ ប៉ុន្តែ តើហេតុអ្វីបានជាព្រះគម្ពីរមិនមានឈ្មោះចិន? ដោយសារកិច្ចការរបស់ព្រះជាម្ចាស់ពីរផ្នែកដំបូង ត្រូវធ្វើឡើងនៅស្រុកអ៊ីស្រាអែល ដោយសាររាស្ត្រនៃស្រុកអ៊ីស្រាអែល គឺជារាស្ត្ររើសតាំង នោះមានន័យថា ពួកគេគឺជាមនុស្សដំបូងដែលត្រូវទទួលស្គាល់កិច្ចការរបស់ព្រះយេហូវ៉ា។ ពួកគេជាមនុស្សដែលពុករលួយតិចតួចបំផុតក្នុងចំណោមមនុស្សជាតិទាំងអស់ ហើយកាលដើមដំបូងឡើយ ពួកគេមានគំនិតសរសើរតម្កើងដល់ព្រះជាម្ចាស់ និងគោរពទ្រង់។ ពួកគេបានស្ដាប់បង្គាប់តាមព្រះបន្ទូលរបស់ព្រះយេហូវ៉ា ហើយតែងបម្រើការនៅក្នុងព្រះវិហារ និងស្លៀកសម្លៀកបំពាក់ជាពួកសង្ឃ ឬពាក់មកុដ។ ពួកគេគឺជាមនុស្សដំបូងគេបង្អស់ដែលថ្វាយបង្គំព្រះជាម្ចាស់ ហើយជាកម្មវត្ថុដំបូងគេបំផុតនៅក្នុងកិច្ចការរបស់ទ្រង់។ មនុស្សទាំងអស់នេះគឺជាពុម្ព និងជាគំរូសម្រាប់មនុស្សជាតិទាំងមូល។ ពួកគេគឺជាពុម្ព និងជាគំរូនៃភាពបរិសុទ្ធនៃមនុស្សសុចរិត។ មនុស្សដូចជាយ៉ូប អ័ប្រាហាំ ឡុត ឬពេត្រុស និងធីម៉ូថេ គឺសុទ្ធតែជាពួកសាសន៍អ៊ីស្រាអែល ជាពុម្ព និងជាគំរូនៃមនុស្សបរិសុទ្ធជាងគេបំផុត។ ក្នុងចំណោមមនុស្សជាតិ អ៊ីស្រាអែលគឺជាប្រទេសដំបូងគេបង្អស់ដែលថ្វាយបង្គំព្រះជាម្ចាស់ ហើយមនុស្សសុចរិតជាច្រើនចេញមកពីទីនេះច្រើនជាងកន្លែងដទៃផ្សេងទៀត។ ព្រះជាម្ចាស់ បានធ្វើការក្នុងចំណោមពួកគេដើម្បីឲ្យទ្រង់អាចធ្វើការគ្រប់គ្រងមនុស្សជាតិបានល្អប្រសើរនៅទូទាំងដែនដីទាំងមូលនៅពេលអនាគត។ សមិទ្ធផល និងទង្វើសុចរិតរបស់ពួកគេក្នុងការថ្វាយបង្គំព្រះយេហូវ៉ា ត្រូវបានកត់ត្រាទុក ដើម្បីឲ្យពួកគេអាចធ្វើជាពុម្ព និងជាគំរូដល់មនុស្សនៅក្រៅស្រុកអ៊ីស្រាអែលក្នុងអំឡុងយុគសម័យនៃព្រះគុណ ហើយសកម្មភាពរបស់ពួកគេត្រូវបានអនុវត្តក្នុងកិច្ចការរយៈពេលរាប់ពាន់ឆ្នាំរហូតមកទល់នឹងពេលសព្វថ្ងៃនេះ។

បន្ទាប់ពីការបង្កើតពិភពលោកនេះ ដំណាក់កាលដំបូងនៃកិច្ចការរបស់ព្រះជាម្ចាស់ គឺត្រូវធ្វើឡើងនៅក្រៅស្រុកអ៊ីស្រាអែល ដូច្នេះហើយ ស្រុកអ៊ីស្រាអែលគឺជាទីកន្លែង

កំណើតនៃកិច្ចការរបស់ព្រះជាម្ចាស់នៅលើផែនដី និងជាមូលដ្ឋាននៃកិច្ចការរបស់ព្រះជាម្ចាស់នៅលើផែនដីនេះ។ ទំហំនៃកិច្ចការរបស់ព្រះយេស៊ូវ គ្រប់ដណ្ដប់លើស្រុកយូដាទាំងមូល។ ក្នុងអំឡុងពេលនៃកិច្ចការរបស់ទ្រង់ មានមនុស្សតិចតួចប៉ុណ្ណោះនៅស្រុកយូដាដែលបានដឹងអំពីកិច្ចការនេះ ដ្បិតទ្រង់ មិនបានធ្វើកិច្ចការណាមួយក្រៅស្រុកយូដាឡើយ។ សព្វថ្ងៃនេះ កិច្ចការរបស់ព្រះជាម្ចាស់ត្រូវបាននាំយកទៅកាន់ប្រទេសចិន ហើយត្រូវបានអនុវត្តទាំងស្រុង តែនៅក្នុងទំហំកិច្ចការនេះប៉ុណ្ណោះ។ ក្នុងអំឡុងពេលនៃជំហាននេះ គ្មានកិច្ចការណាដែលត្រូវធ្វើឡើងនៅក្រៅប្រទេសចិនឡើយ។ ការពង្រីកកិច្ចការនេះនៅក្រៅប្រទេសចិន គឺជាកិច្ចការដែលនឹងត្រូវធ្វើឡើងនៅពេលក្រោយទៀត។ ដំណាក់កាលនៃកិច្ចការនេះ គឺកើតមានបន្ទាប់ពីដំណាក់កាលនៃកិច្ចការរបស់ព្រះយេស៊ូវ។ ព្រះយេស៊ូវបានបំពេញកិច្ចការនៃការប្រោសលោះ ហើយដំណាក់កាលនេះ គឺជាកិច្ចការដែលកើតមានបន្ទាប់ពីកិច្ចការនោះ។ កិច្ចការនៃការប្រោសលោះ ត្រូវបានបញ្ចប់ ហើយនៅក្នុងដំណាក់កាលនេះ ពុំត្រូវការឲ្យមានការយកកំណើតជាមនុស្ស ពីព្រះវិញ្ញាណបរិសុទ្ធឡើយ ដោយសារដំណាក់កាលនៃកិច្ចការនេះ គឺមិនដូចដំណាក់កាលចុងក្រោយឡើយ ហើយបន្ថែមលើនេះ ដោយសារប្រទេសចិន គឺមិនដូចគ្នានឹងប្រទេសអ៊ីស្រាអែលឡើយ។ ព្រះយេស៊ូវបានធ្វើកិច្ចការមួយដំណាក់កាល ដែលជាកិច្ចការនៃការប្រោសលោះ។ មនុស្សបានមើលឃើញព្រះយេស៊ូវ ហើយមិនយូរប៉ុន្មាន កិច្ចការរបស់ទ្រង់ក៏បានចាប់ផ្ដើមផ្សាយទៅកាន់ពួកសាសន៍ដទៃ។ សព្វថ្ងៃនេះ មានមនុស្សជាច្រើនដែលជឿលើព្រះជាម្ចាស់នៅអាមេរិក នៅចក្រភពអង់គ្លេស និងរុស្ស៊ី ហេតុដូច្នេះហើយ តើហេតុអ្វីបានជាមានមនុស្សតិចតួចដែលជឿថាមានព្រះជាម្ចាស់នៅប្រទេសចិន? ដោយសារប្រទេសចិន គឺជាជាតិសាសន៍ដែលរឹតត្បិតជាងគេ។ បែបនេះ ប្រទេសចិនគឺជាប្រទេសចុងក្រោយគេដែលទទួលយកផ្លូវរបស់ព្រះជាម្ចាស់ ហើយសូម្បីតែនៅពេលនេះក្ដី គឺមានរយៈពេលតិចជាងមួយរយឆ្នាំទៅទៀតរាប់ចាប់តាំងពីប្រទេសនេះជឿលើព្រះ គឺនៅនៅក្រោយសហរដ្ឋអាមេរិក និងចក្រភពអង់គ្លេសឆ្ងាយណាស់។ ដំណាក់កាលចុងក្រោយនៃ

កិច្ចការរបស់ព្រះជាម្ចាស់ គឺត្រូវធ្វើឡើងនៅក្នុងទឹកដីប្រទេសចិន ដើម្បីនាំយកកិច្ចការរបស់ទ្រង់ទៅដល់ទីបញ្ចប់ និងដើម្បីឲ្យកិច្ចការរបស់ទ្រង់អាចសម្រេចជោគជ័យបាន។ ប្រជាជននៅក្នុងស្រុកអ៊ីស្រាអែល សុទ្ធតែហៅព្រះយេហូវ៉ាថាព្រះអម្ចាស់។ នៅពេលនោះ ពួកគេបានចាត់ទុកទ្រង់ថាជាមេគ្រួសារ ហើយស្រុកអ៊ីស្រាអែលទាំងមូលបានក្លាយជាគ្រួសារដ៏ធំមួយ ដែលមនុស្សគ្រប់គ្នាថ្វាយបង្គំព្រះអម្ចាស់យេហូវ៉ា។ ព្រះវិញ្ញាណរបស់ព្រះយេហូវ៉ា តែងលេចមកនៅចំពោះមុខពួកគេ ហើយទ្រង់បានមានព្រះបន្ទូល និងបញ្ចេញព្រះសូរសៀងរបស់ទ្រង់ទៅកាន់ពួកគេ និងបានប្រើបង្គោលពពក និងសំឡេងដើម្បីណែនាំជីវិតរបស់ពួកគេ។ នៅពេលនោះ ព្រះវិញ្ញាណបានប្រទាននូវការណែនាំរបស់ទ្រង់នៅស្រុកអ៊ីស្រាអែលដោយផ្ទាល់ ដោយមានព្រះបន្ទូល និងបញ្ចេញព្រះសូរសៀងរបស់ទ្រង់ទៅកាន់មនុស្ស ហើយពួកគេបានឃើញពពក និងបានស្ដាប់ឮសំឡេងផ្គរលាន់ ហើយតាមរបៀបនេះ ទ្រង់ក៏បានណែនាំជីវិតរបស់ពួកគេអស់ពេលជាច្រើនពាន់ឆ្នាំ។ ហេតុនេះ មានតែរាស្ត្រនៃស្រុកអ៊ីស្រាអែលប៉ុណ្ណោះ ដែលតែងតែថ្វាយបង្គំព្រះយេហូវ៉ា។ ពួកគេជឿថា ព្រះយេហូវ៉ាគឺជាព្រះជាម្ចាស់របស់ពួកគេ ហើយថាទ្រង់មិនមែនជាព្រះជាម្ចាស់របស់សាសន៍ដទៃឡើយ។ នេះគឺគ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលឡើយ៖ ក្រោយមក ព្រះយេហូវ៉ាបានបំពេញកិច្ចការក្នុងចំណោមពួកគេអស់រយៈពេលជិតបួនពាន់ឆ្នាំ។ នៅក្នុងទឹកដីនៃប្រទេសចិននេះ ក្រោយពេលដេកលង់លក់ស្ពឹកស្ពឹងអស់រយៈពេលរាប់ពាន់ឆ្នាំមក មានតែពេលនេះប៉ុណ្ណោះដែលពួកមនុស្សគ្មានគុណធម៌ ចាប់ផ្ដើមដឹងថាស្ថានសួគ៌ និងផែនដី ព្រមទាំងរបស់សព្វសារពើទាំងអស់ មិនបានកើតឡើងដោយឯកឯងឡើយ ប៉ុន្តែត្រូវព្រះអាទិករជាអ្នកបង្កើតឡើងមក។ ដោយសារដំណឹងល្អនេះចេញមកពីស្រុកក្រៅ អស់អ្នកដែលមានគំនិតសក្តិភូមិ និងប្រតិកិរិយា ជឿថាអស់អ្នកដែលទទួលយកដំណឹងល្អនេះ គឺជាពួកក្បត់ ពួកគេគឺជាសត្វឆ្កែដែលបានក្បត់ព្រះពុទ្ធដែលជាដូនតារបស់ពួកគេ។ បន្ថែមលើនេះ ពួកអ្នកដែលមានគំនិតសក្តិភូមិទាំងអស់នេះសួរថា៖ «តើប្រជាជនចិនអាចជឿលើព្រះជាម្ចាស់នៃសាសន៍បរទេសបានដោយរបៀបណាទៅ? តើពួកគេមិនក្បត់នឹងដូនតារបស់ពួកគេ

ទេឬអី? តើពួកគេមិនមែនកំពុងប្រព្រឹត្តអំពើអាក្រក់ទេឬអី?» សព្វថ្ងៃនេះ មនុស្សបានភ្លេចថាព្រះយេហូវ៉ាជាព្រះជាម្ចាស់របស់ពួកគេជាយូរណាស់មកហើយ។ ពួកគេមិនសូវបានគិតគូរដល់ព្រះអាទិករជាយូរណាស់មកហើយ ហើយពួកគេបែរជាជឿលើការវិវឌ្ឍន៍ មានន័យថា មនុស្សវិវឌ្ឍន៍ចេញពីស្វាឌី ហើយថាពិភពធម្មជាតិកើតឡើងមកដោយឯកឯង។ គ្រប់អាហារល្អៗដែលមនុស្សបរិភោគសុទ្ធតែបានមកពីធម្មជាតិ មនុស្សមានកើត និងមានស្លាប់ ហើយគ្មានព្រះជាម្ចាស់អង្គណាមួយដែលគ្រប់គ្រងលើរបស់សព្វសារពើទាំងអស់នេះទេ។ បន្ថែមលើនេះ មានពួកមិនជឿលើព្រះជាម្ចាស់ជាច្រើនដែលជឿថា ព្រះជាម្ចាស់ដែលគ្រប់គ្រងលើសព្វសារពើទាំងអស់ គឺជាអបិយជំនឿ និងមិនមែនជាវិទ្យាសាស្ត្រឡើយ។ ប៉ុន្តែ តើវិទ្យាសាស្ត្រអាចជំនួសកិច្ចការរបស់ព្រះជាម្ចាស់បានដែរឬទេ? តើវិទ្យាសាស្ត្រ អាចគ្រប់គ្រងលើមនុស្សបានដែរឬទេ? ការផ្សាយដំណឹងល្អនៅក្នុងប្រទេសដែលដឹកនាំដោយពួកមិនជឿលើព្រះជាម្ចាស់ គឺមិនមែនជារឿងងាយទេ ហើយវាមានឧបសគ្គជាច្រើន។ សព្វថ្ងៃនេះ តើមិនមានមនុស្សច្រើនទេឬដែលទាស់ទទឹងនឹងព្រះជាម្ចាស់តាមរបៀបនេះ?

នៅពេលដែលព្រះយេស៊ូវបានយាងមកបំពេញកិច្ចការរបស់ទ្រង់ មានមនុស្សជាច្រើនបានប្រៀបធៀបកិច្ចការរបស់ទ្រង់ជាមួយនឹងកិច្ចការរបស់ព្រះយេហូវ៉ា និងបានឃើញថា កិច្ចការទាំងនោះមិនដូចគ្នាទេ រួចពួកគេក៏ឆ្កាងព្រះយេស៊ូវទៅនឹងឈើឆ្កាង។ តើហេតុអ្វី បានជាពួកគេរកមិនឃើញនូវភាពដូចគ្នា រវាងកិច្ចការរបស់ទ្រង់? រឿងខ្លះ គឺដោយសារព្រះយេស៊ូវបានបំពេញកិច្ចការថ្មី ហើយក៏ដោយសារនៅមុនពេលដែលព្រះយេស៊ូវបានចាប់ផ្ដើមកិច្ចការរបស់ទ្រង់ គ្មាននរណាម្នាក់បានសរសេរទុកពង្សាវតាររបស់ទ្រង់ឡើយ។ វាប្រាកដជាល្អប្រសិនបើមាននរណាម្នាក់បានកត់ត្រាទុកថាតើនរណានឹងត្រូវឆ្កាងព្រះយេស៊ូវទៅនឹងឈើឆ្កាងនោះ? ប្រសិនបើម៉ាថាយបានសរសេរពង្សាវតាររបស់ព្រះយេស៊ូវជាច្រើនទស្សវត្សរ៍មុននោះ ប្រហែលជាព្រះយេស៊ូវនឹងមិនត្រូវរងទុក្ខវេទនាពីការធ្វើទុក្ខបុកម្នេញយ៉ាងខ្លាំងបែបនេះឡើយ។ តើវាមិនមែនបែបនេះទេឬអី? ឲ្យតែមនុស្សបានអានអំពីពង្សាវតាររបស់ព្រះយេស៊ូវ

ដែលថាទ្រង់គឺជាកូនរបស់អ័ប្រាហាំ និងជាពូជពង្សរបស់ស្ដេចដាវីឌ នោះពួកគេនឹងបញ្ឈប់ការធ្វើទុក្ខបុកម្នេញរបស់ពួកគេលើទ្រង់។ តើវាមិនគួរឲ្យអាណិតទេឬដែលពង្សាវតាររបស់ទ្រង់ត្រូវបានសរសេរយឺតពេលពេកនោះ? ហើយអ្វីដែលគួរឲ្យអាណិតនោះគឺ ព្រះគម្ពីរគ្រាន់តែកត់ត្រាពីដំណាក់កាលនៃកិច្ចការរបស់ព្រះជាម្ចាស់ចំនួនពីរប៉ុណ្ណោះ៖ ដំណាក់កាលមួយគឺជាកិច្ចការនៃយុគសម័យនៃនគរព្រះ និងជាកិច្ចការនៃយុគសម័យនៃព្រះគុណ ដំណាក់កាលមួយទៀត គឺជាកិច្ចការរបស់ព្រះយេហូវ៉ា និងជាកិច្ចការរបស់ព្រះយេស៊ូវ។ តើវានឹងប្រសើរយ៉ាងណា ប្រសិនបើហោរាអស្ចារ្យណាម្នាក់បានទស្សន៍ទាយពីកិច្ចការនៅក្នុងពេលសព្វថ្ងៃនេះ។ នោះនឹងមានផ្នែកបន្ថែមនៅលើព្រះគម្ពីរដែលមានចំណងជើងថា «កិច្ចការនៃគ្រាចុងក្រោយ» តើនោះនឹងមិនប្រសើរជាងនេះទេឬអី? តើហេតុអ្វីបានជាមនុស្សត្រូវរងទុក្ខវេទាយ៉ាងខ្លាំងនៅពេលសព្វថ្ងៃនេះ? អ្នករាល់គ្នាបានជួបប្រទះនឹងពេលវេលាដ៏សែនលំបាក! ប្រសិនបើរាល់គ្នាស័ក្តិសមនឹងឲ្យគេស្អប់មែន នោះគឺមកពីអេសាយ និងដានីយ៉ែល មិនបានទស្សន៍ទាយអំពីកិច្ចការនៃគ្រាចុងក្រោយ ហើយប្រសិនបើមនុស្សគ្រប់គ្នាត្រូវទទួលការស្ដីបន្ទោសមែន នោះគឺដោយសារពួកសាវ័កនៅក្នុងព្រះគម្ពីរសញ្ញាថ្មីមិនបានកត់ត្រាពង្សាវតាររបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស ឲ្យបានមុននេះ។ នេះពិតជាគួរឲ្យអាម៉ាស់ខ្លាំងណាស់! អ្នករាល់គ្នាត្រូវស្វែងរកភស្ដុតាងទាំងអស់ ហើយបើទោះបីជារកឃើញចំណែកតិចតួចនៃព្រះបន្ទូលទាំងនោះក្ដី ក៏អ្នកនៅតែមិនអាចនិយាយថាតើអ្វីដែលរកឃើញនោះ ជាភស្ដុតាង ឬមិនមែនដែរ។ ពិតជាគួរឲ្យខ្មាសគេខ្លាំងណាស់! តើហេតុអ្វីបានជានៅក្នុងកិច្ចការរបស់ទ្រង់ ព្រះជាម្ចាស់មានអាថ៌កំបាំងអ្វីម្ល៉េះ? ថ្ងៃនេះមនុស្សជាច្រើនមិនទាន់បានស្វែងរកភស្ដុតាងដាច់ស្រេចនៅឡើយទេ ក៏ប៉ុន្តែពួកគេក៏មិនអាចបដិសេធវាបានឡើយ។ ដូច្នេះ តើពួកគេគប្បីត្រូវធ្វើដូចម្ដេច? ពួកគេមិនអាចតាំងចិត្តដើរតាមព្រះជាម្ចាស់បានឡើយ ក៏ប៉ុន្តែពួកគេក៏មិនអាចបោះជំហានទៅមុខទាំងមានមន្ទិលសង្ស័យបែបនេះបានដែរ។ ហេតុដូច្នេះហើយ «បញ្ញាវន្តឈ្លៀសវៃ និងមានអំណោយទាន» ប្រកាន់ខ្ជាប់ទៅតាមអាកប្បកិរិយាមួយនៃ «ការសាកល្បង

ហើយនិងឃើញច្បាស់» នៅពេលដែលពួកគេដើរតាមព្រះជាម្ចាស់។ នេះគឺជាបញ្ហាច្រើនខ្លាំងណាស់! តើរឿងរ៉ាវនឹងមិនងាយស្រួលទេឬ ប្រសិនបើម៉ាថាយ ម៉ាកុស លូកា និងយ៉ូហាន បានធ្វើការទស្សន៍ទាយពីអនាគតនោះ? វានឹងកាន់តែប្រសើរជាងនេះ ប្រសិនបើយ៉ូហានបានឃើញសេចក្តីពិតដ៏ជ្រាលជ្រៅនៃជីវិតនៅក្នុងនគរព្រះ ប៉ុន្តែគួរឲ្យស្តាយណាស់ដែលគាត់បានឃើញត្រឹមតែនិមិត្ត និងមិនបានឃើញពីកិច្ចការនៅលើផែនដីដែលជាក់ស្តែង និងពិតប្រាកដ។ វាពិតជារឿងគួរឲ្យអាម៉ាស់ណាស់! តើព្រះជាម្ចាស់មានបញ្ហាអ្វី? ក្រោយពេលដែលកិច្ចការរបស់ទ្រង់ ធ្វើបានយ៉ាងល្អនៅស្រុកអ៊ីស្រាអែល តើហេតុអ្វីបានជាពេលនេះទ្រង់យាងទៅប្រទេសចិនវិញ ហើយតើហេតុអ្វីបានជាទ្រង់ត្រូវយកកំណើតជាមនុស្ស និងត្រូវបំពេញកិច្ចការដោយផ្ទាល់ និងត្រូវរស់នៅក្នុងចំណោមមនុស្ស? ព្រះជាម្ចាស់ពិតជាយកព្រះទ័យទុកដាក់ចំពោះមនុស្សខ្លាំងណាស់។ ទ្រង់មិនត្រឹមតែមិនបានមានបន្ទូលប្រាប់មនុស្សជាមុននោះទេ ប៉ុន្តែទ្រង់បាននាំយកការវាយផ្ចាល និងការជំនុំជម្រះរបស់ទ្រង់មកភ្លាមៗ។ វាពិតជាគ្មានអត្ថន័យអ្វីទាល់តែសោះ! លើកដំបូងដែលព្រះជាម្ចាស់បានយកកំណើតជាមនុស្ស ទ្រង់បានរងទុក្ខវេទនាយ៉ាងខ្លាំងដោយសារការមិនបានមានបន្ទូលប្រាប់មនុស្សជាមុនអំពីសេចក្តីពិតដ៏ជ្រាលជ្រៅទាំងអស់។ ច្បាស់ណាស់ ទ្រង់មិនអាចបំភ្លេចកិច្ចការនេះបានឡើយ? ហេតុដូច្នេះ តើហេតុអ្វីបានជាទ្រង់នៅមិនបានមានបន្ទូលប្រាប់មនុស្សអំពីរឿងនេះ? សព្វថ្ងៃនេះ ពិតជាសំណាងអាក្រក់ណាស់ដែលនៅក្នុងព្រះគម្ពីរមានកណ្ឌគម្ពីរត្រឹមតែហុកសិបប្រាំមួយកណ្ឌប៉ុណ្ណោះ។ គ្រាន់តែត្រូវការឲ្យមានការទស្សន៍ទាយបន្ថែមមួយទៀតអំពីកិច្ចការនៃគ្រាចុងក្រោយប៉ុណ្ណោះ! តើអ្នកមិនគិតអ៊ីចឹងទេមែនទេ? សូម្បីតែព្រះយេហូវ៉ា អេសាយ និងស្តេចដាវីឌ ក៏ពុំបានមានព្រះបន្ទូល និងនិយាយអំពីកិច្ចការសព្វថ្ងៃនេះដែរ។ ពួកគេក៏ត្រូវបានគេដកចេញ ពីពេលបច្ចុប្បន្ននេះដែរ ដោយបំបែកចេញពីគ្នាក្នុងរយៈពេលច្រើនជាងបួនពាន់ឆ្នាំ។ ព្រះយេស៊ូវក៏មិនបានទស្សន៍ទាយពីកិច្ចការសព្វថ្ងៃនេះឲ្យបានពេញលេញដែរ ដោយគ្រាន់តែមានព្រះបន្ទូលបន្តិចបន្តួចអំពីរឿងនេះប៉ុណ្ណោះ ហើយមនុស្សនៅតែរកភស្តុតាងមិនទាន់គ្រប់គ្រាន់

នៅឡើយ។ ប្រសិនបើអ្នកប្រៀបធៀបកិច្ចការសព្វថ្ងៃនេះ នឹងកិច្ចការកាលពីមុន តើកិច្ចការទាំងពីរនេះអាចរួមបញ្ចូលគ្នាបានដោយរបៀបណា? ដំណាក់កាលនៃកិច្ចការរបស់ព្រះយេហូវ៉ា ត្រូវបានដឹកនាំនៅស្រុកអ៊ីស្រាអែល ដូច្នេះ ប្រសិនបើអ្នកប្រៀបធៀបកិច្ចការនាពេលសព្វថ្ងៃនេះជាមួយនឹងកិច្ចការនោះ នឹងមានភាពខុសគ្នាកាន់តែច្រើន។ កិច្ចការទាំងពីរនេះមិនអាចប្រៀបធៀបគ្នាបានឡើយ។ អ្នកមិនមែនជារាស្ត្រនៃស្រុកអ៊ីស្រាអែល ហើយអ្នកក៏មិនមែនជាសាសន៍យូដាដែរ។ គុណសម្បត្តិរបស់អ្នក និងអ្វីៗគ្រប់បែបយ៉ាងអំពីអ្នក គឺនៅខ្វះខាតណាស់ តើអ្នកអាចប្រៀបធៀបខ្លួនឯងជាមួយនឹងពួកគេបានដោយរបៀបណាទៅ? តើវាអាចទៅរួចដែរឬទេ? ត្រូវដឹងថា កិច្ចការនាពេលសព្វថ្ងៃនេះ គឺជាយុគសម័យនៃនគរព្រះ ហើយវាគឺខុសគ្នាពីយុគសម័យនៃក្រឹត្យវិន័យ និងយុគសម័យនៃព្រះគុណ។ ក្នុងករណីណាក៏ដោយ មិនត្រូវសាកល្បង និងប្រើរូបមន្តណាមួយឡើយ។ ព្រះជាម្ចាស់មិនអាចស្វែងរកឃើញតាមរូបមន្តណាមួយឡើយ។

តើព្រះយេស៊ូវរស់នៅរយៈពេល ២៩ឆ្នាំ ក្រោយកំណើតរបស់ទ្រង់យ៉ាងដូចម្ដេច? ព្រះគម្ពីរគ្មានកត់ត្រាអ្វីពីកុមារភាព និងយុវភាពរបស់ទ្រង់ឡើយ។ តើអ្នកដឹងថារឿងនោះបែបណាដែរឬទេ? តើវាអាចថា ទ្រង់គ្មានកុមារភាព ឬយុវភាព ហើយថានៅពេលដែលទ្រង់បានប្រសូតមក ទ្រង់មានព្រះជន្ម ៣០ឆ្នាំរួចទៅហើយមែនទេ? អ្នកដឹងតិចតួចខ្លាំងណាស់ ដូច្នេះ មិនត្រូវធ្វេសប្រហែសក្នុងការបញ្ចេញទស្សនៈរបស់អ្នកឡើយ។ វាគ្មានអ្វីល្អចំពោះអ្នកនោះទេ! ព្រះគម្ពីរកត់ត្រាត្រឹមថា ព្រះយេស៊ូវមានព្រះជន្ម ៣០ឆ្នាំ ទ្រង់ត្រូវបានជ្រមុជទឹក ហើយត្រូវដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធទៅក្នុងទីរហោស្ថាន ដើម្បីឆ្លងកាត់ការល្បួងរបស់អារក្ស។ ហើយដំណឹងល្អទាំងបួន កត់ត្រាអំពីកិច្ចការរបស់ទ្រង់រយៈពេលបីឆ្នាំកន្លះប៉ុណ្ណោះ។ គ្មានកំណត់ត្រាពីកុមារភាពនិងយុវភាពរបស់ទ្រង់ឡើយ ប៉ុន្តែនេះពុំបញ្ជាក់ថា ទ្រង់គ្មានកុមារភាព និងយុវភាពនោះទេ។ គឺគ្រាន់តែថា កាលដើមដំបូងឡើយ ទ្រង់មិនបានធ្វើកិច្ចការណាមួយទេ ហើយទ្រង់គឺជាមនុស្សធម្មតាម្នាក់។ ដូច្នេះ តើអ្នកអាចនិយាយថា ព្រះយេស៊ូវបានរស់នៅអស់រយៈពេល ៣៣ឆ្នាំ ដោយគ្មានយុវភាព និងកុមារភាពបានដោយរបៀបណា? តើ

ទ្រង់អាចយាងចូលដល់ព្រះជន្ម ៣៣ឆ្នាំកន្លះ បានដោយរបៀបណា? មនុស្សទាំងអស់សុទ្ធតែគិតថាទ្រង់មានលក្ខណៈអធិធម្មជាតិ និងមិនពិតប្រាកដ។ គ្មានអ្វីត្រូវឆ្ងល់នោះទេថា ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស គឺមានភាពជាមនុស្សសាមញ្ញ និងធម្មតា ប៉ុន្តែនៅពេលដែលទ្រង់បានអនុវត្តកិច្ចការរបស់ទ្រង់ គឺទ្រង់បានធ្វើវាដោយភាពជាមនុស្សមិនពេញខ្នាត និងក្នុងភាពជាព្រះពេញលេញ។ គឺដោយសារបញ្ហានេះហើយទើបមនុស្សមានមន្ទិលសង្ស័យអំពីកិច្ចការនៅក្នុងពេលសព្វថ្ងៃនេះ និងសង្ស័យសូម្បីតែកិច្ចការរបស់ព្រះយេស៊ូវ។ បើទោះបីជាកិច្ចការរបស់ព្រះជាម្ចាស់ ខុសគ្នាពីសម័យកាលពីរដែលទ្រង់បានយកកំណើតជាមនុស្សក្ដី ក៏លក្ខណៈសំខាន់របស់ទ្រង់មិនដូច្នេះដែរ។ ពិតណាស់ ប្រសិនបើអ្នកអានកំណត់ត្រានៃដំណឹងល្អទាំងបួន នោះមានភាពខុសគ្នាច្រើនខ្លាំងណាស់។ តើអ្នកអាចត្រឡប់ទៅកាន់ជីវិតរបស់ព្រះយេស៊ូវក្នុងអំឡុងកុមារភាព និងយុវភាពរបស់ទ្រង់បានដោយរបៀបណា? តើអ្នកអាចយល់ដឹងពីភាពជាមនុស្សធម្មតារបស់ព្រះយេស៊ូវបានដោយរបៀបណា? ប្រហែលជាអ្នកមានការយល់ដឹងខ្លាំង អំពីភាពជាមនុស្សរបស់ព្រះជាម្ចាស់ក្នុងពេលបច្ចុប្បន្ន ក៏ប៉ុន្តែអ្នកគ្មានយល់ពីភាពជាមនុស្សរបស់ព្រះយេស៊ូវឡើយ ហើយអ្នកកាន់តែមិនយល់អំពីរឿងនេះទៅទៀត។ ប្រសិនបើម៉ាថាយមិនបានកត់ត្រាទុកទេ អ្នកក៏នឹងគ្មានចំណេះដឹងអ្វីអំពីភាពជាមនុស្សរបស់ព្រះយេស៊ូវដែរ។ ប្រហែលជានៅពេលដែលខ្ញុំប្រាប់សាច់រឿងរបស់ព្រះយេស៊ូវក្នុងអំឡុងជីវិតរបស់ទ្រង់ និងប្រាប់អ្នកអំពីសេចក្ដីពិតដ៏ជ្រាលជ្រៅអំពីកុមារភាព និងយុវភាពរបស់ព្រះយេស៊ូវ អ្នកនឹងគ្រវីក្បាល ហើយនិយាយថា «មិនពិតទេ! ទ្រង់មិនអាចធ្វើបែបនេះបានឡើយ។ ទ្រង់មិនអាចមានចំណុចខ្សោយនោះទេ ហើយទ្រង់កាន់តែគ្មានភាពជាមនុស្សសោះឡើយ!» អ្នកនឹងស្រែកឮខ្លាំងៗថែមទៀត។ គឺដោយសារអ្នកមិនស្គាល់ព្រះយេស៊ូវ ទើបអ្នកគ្មានសញ្ញាណអំពីខ្ញុំ។ អ្នកជឿថាព្រះយេស៊ូវ មានលក្ខណៈជាព្រះខ្លាំងពេក គឺគ្មានអ្វីខាងឯសាច់ឈាមអំពីទ្រង់ឡើយ។ ប៉ុន្តែ ការពិតនៅតែជាការពិត។ គ្មាននរណាម្នាក់ចង់និយាយអ្វីផ្ទុយនឹងសេចក្ដីពិតនៃសច្ចភាពនេះឡើយ ដ្បិតនៅពេលដែលខ្ញុំមានព្រះបន្ទូលពាក់ព័ន្ធនឹង

សេចក្ដីពិត គឺមិនមែនជាការប្រមើលមើល ហើយក៏មិនមែនជាការព្យាករនោះដែរ។ ត្រូវដឹងថា ព្រះជាម្ចាស់អាចយាងឡើងទៅទីដ៏សែនខ្ពស់ ហើយជាងនេះទៅទៀត ទ្រង់អាចពួននៅក្នុងទីដ៏សែនជ្រៅ។ ព្រះអង្គមិនមែនជាអ្វីមួយដែលអ្នកចេះតែប្រឌិតចេញពីគំនិតរបស់ខ្លួនទេ ទ្រង់គឺជាព្រះជាម្ចាស់នៃគ្រប់សត្តនិករទាំងអស់ ពោលគឺមិនមែនជាព្រះជាម្ចាស់ផ្ទាល់ខ្លួនរបស់បុគ្គលណាមួយឡើយ។

# និមិត្តអំពីកិច្ចការរបស់ព្រះជាម្ចាស់ (៣)

លើកដំបូងដែលព្រះជាម្ចាស់ បានយកកំណើតជាមនុស្ស គឺតាមរយៈការចាប់កំណើតដោយព្រះវិញ្ញាណបរិសុទ្ធ ហើយរឿងនេះគឺមានជាប់ពាក់ព័ន្ធទៅនឹងកិច្ចការដែលទ្រង់មានសព្វព្រះហឫទ័យចង់ធ្វើ។ យុគសម័យនៃព្រះគុណ បានចាប់ផ្ដើមដោយព្រះនាមរបស់ព្រះយេស៊ូវ។ នៅពេលព្រះយេស៊ូវបានចាប់ផ្ដើមបំពេញព័ន្ធកិច្ចរបស់ទ្រង់ ព្រះវិញ្ញាណបរិសុទ្ធបានចាប់ផ្ដើមធ្វើទីបន្ទាល់អំពីព្រះនាមរបស់ព្រះយេស៊ូវ ហើយព្រះនាមរបស់ព្រះយេហូវ៉ា លែងត្រូវបានគេនិយាយទៀតហើយ។ ផ្ទុយទៅវិញ ព្រះវិញ្ញាណបរិសុទ្ធបានបំពេញនូវកិច្ចការថ្មីនេះ ដែលជាគោលការណ៍ក្រោមព្រះនាមព្រះយេស៊ូវ។ ការធ្វើទីបន្ទាល់របស់អ្នកដែលបានជឿលើទ្រង់ កើតចេញពីព្រះយេស៊ូវគ្រីស្ទ ហើយកិច្ចការដែលពួកគេបានធ្វើ ក៏ដើម្បីព្រះយេស៊ូវគ្រីស្ទដែរ។ ការបិទបញ្ចប់យុគសម័យនៃក្រឹត្យវិន័យនៅក្នុងព្រះគម្ពីរសញ្ញាចាស់ មានន័យថាកិច្ចការដែលធ្វើឡើងជាគោលការណ៍ក្រោមព្រះនាមរបស់ព្រះយេហូវ៉ា បានមកដល់ទីបញ្ចប់ហើយ។ ហេតុដូច្នេះ ព្រះនាមរបស់ព្រះជាម្ចាស់ លែងហៅថាជា ព្រះយេហូវ៉ាទៀតហើយ។ ផ្ទុយទៅវិញ ទ្រង់ត្រូវបានហៅថា ព្រះយេស៊ូវ ហើយចាប់ពីចំណុចនេះតទៅ ព្រះវិញ្ញាណបរិសុទ្ធបានចាប់ផ្ដើមកិច្ចការជាគោលការណ៍នៅក្រោមព្រះនាមព្រះយេស៊ូវ។ ដូច្នេះ មនុស្សនៅតែហូប និងផឹកព្រះបន្ទូលរបស់ព្រះយេហូវ៉ាដដែលនាពេលសព្វថ្ងៃនេះ ហើយនៅតែធ្វើគ្រប់យ៉ាងទៅតាមកិច្ចការនៃយុគសម័យនៃក្រឹត្យវិន័យដដែល តើ

អ្នកមិនមែនកំពុងអនុវត្តតាមក្រឹត្យវិន័យទាំងងងឹតងងល់ទេឬអី? តើអ្នកមិនមែនកំពុងជាប់គាំងនៅក្នុងអតីតកាលទេឬ? អ្នករាល់គ្នាដឹងថា គ្រាចុងក្រោយបានចូលមកដល់ហើយ។ តើវាអាចទេថា នៅពេលដែលព្រះយេស៊ូវយាងមក ទ្រង់នឹងនៅតែត្រូវគេហៅថាព្រះយេស៊ូវដដែល? ព្រះយេហូវ៉ាបានមានបន្ទូលប្រាប់រាស្ត្រអ៊ីស្រាអែលថា ព្រះមែស្ស៊ីនឹងយាងមក ក៏ប៉ុន្តែនៅពេលដែលទ្រង់យាងមកនោះ ទ្រង់មិនត្រូវគេហៅថាព្រះមែស្ស៊ីទេ ប៉ុន្តែត្រូវគេហៅថា ព្រះយេស៊ូវ វិញ។ ព្រះយេស៊ូវបានមានព្រះបន្ទូលថា ទ្រង់នឹងយាងមកម្ដងទៀត ហើយថាទ្រង់នឹងយាងមក ដោយសារទ្រង់បានយាងចាកចេញទៅ។ ទាំងអស់នេះគឺជាព្រះបន្ទូលរបស់ព្រះយេស៊ូវ ប៉ុន្តែតើអ្នកឃើញផ្លូវដែលព្រះយេស៊ូវបានយាងចាកចេញទៅដែរឬទេ? ព្រះយេស៊ូវបានយាងចាកចេញទៅដោយគង់នៅលើដុំពពកស ប៉ុន្តែតើអាចថាទ្រង់នឹងយាងត្រឡប់មកវិញនៅលើដុំពពកសដោយផ្ទាល់ព្រះអង្គក្នុងចំណោមមនុស្សដែរឬទេ? ប្រសិនបើដូច្នេះមែន តើទ្រង់នឹងមិននៅតែត្រូវគេហៅថា ព្រះយេស៊ូវដដែលទេឬអី? នៅពេលដែលព្រះយេស៊ូវយាងមកម្ដងទៀត យុគសម័យនេះ នឹងបានផ្លាស់ប្ដូររួចជាស្រេច ដូច្នេះ តើទ្រង់នៅតែអាចឲ្យគេហៅថា ព្រះយេស៊ូវ បានដែរឬទេ? តើអាចថាព្រះជាម្ចាស់អាចត្រឹមត្រូវបានស្គាល់ដោយព្រះនាមថា ព្រះយេស៊ូវ មែនទេ? តើទ្រង់អាចមិនត្រូវគេហៅដោយព្រះនាមថ្មីនៅក្នុងយុគសម័យថ្មីនេះមែនទេ? តើរូបភាពរបស់មនុស្សម្នាក់ និងឈ្មោះជាក់លាក់ណាមួយ អាចតំណាងឲ្យព្រះជាម្ចាស់បានទាំងស្រុងដែរឬទេ? នៅក្នុងយុគសម័យនីមួយៗ ព្រះជាម្ចាស់បំពេញកិច្ចការថ្មី ហើយទ្រង់ត្រូវគេហៅដោយព្រះនាមថ្មីមួយ។ តើទ្រង់អាចបំពេញកិច្ចការតែមួយនៅក្នុងយុគសម័យផ្សេងគ្នាម្ដេចបាន? តើទ្រង់អាចជិតជាប់ទៅនឹងរឿងចាស់បានដោយរបៀបណា? ព្រះនាមរបស់ព្រះយេស៊ូវ ត្រូវបានប្រើដើម្បីជាប្រយោជន៍ដល់កិច្ចការនៃការប្រោសលោះ ដូច្នេះ តើទ្រង់នៅតែត្រូវគេហៅដោយព្រះនាមដដែល នៅពេលដែលទ្រង់យាងត្រឡប់មកវិញនៅគ្រាចុងក្រោយដែរឬទេ? តើទ្រង់នឹងត្រូវនៅបន្តបំពេញកិច្ចការ នៃការប្រោសលោះដែរឬទេ? តើហេតុអ្វីបានជាថាព្រះយេហូវ៉ា និងព្រះយេស៊ូវ ជាព្រះជាម្ចាស់តែមួយ ប៉ុន្តែទ្រង់ទាំងពីរ

ត្រូវគេហៅដោយព្រះនាមខុសគ្នានៅក្នុងយុគសម័យផ្សេងគ្នាទៅវិញ? តើនេះមិនមែនដោយសារយុគសម័យនៃកិច្ចការរបស់ទ្រង់ខុសគ្នាទេមែនទេ? តើព្រះនាមតែមួយអាចតំណាងឲ្យព្រះជាម្ចាស់បានទាំងស្រុងដែរឬទេ? បើបែបនេះមែន ព្រះជាម្ចាស់ត្រូវហៅដោយព្រះនាមខុសគ្នានៅយុគសម័យផ្សេងគ្នា ហើយទ្រង់ត្រូវតែប្រើព្រះនាមនេះដើម្បីផ្លាស់ប្ដូរយុគសម័យនេះ និងដើម្បីតំណាងយុគសម័យនេះ។ ដ្បិតគ្មានព្រះនាមណាមួយដែលអាចតំណាងឲ្យព្រះជាម្ចាស់ផ្ទាល់ព្រះអង្គពេញលេញនោះឡើយ ហើយព្រះនាមនីមួយៗ គឺអាចត្រឹមតែតំណាងឲ្យទិដ្ឋភាពបណ្ដោះអាសន្ននៃនិស្ស័យរបស់ព្រះជាម្ចាស់នៅក្នុងយុគសម័យណាមួយប៉ុណ្ណោះ។ អ្វីដែលព្រះនាមអាចធ្វើបាន គឺតំណាងដល់កិច្ចការរបស់ទ្រង់។ ហេតុនេះ ព្រះជាម្ចាស់អាចជ្រើសរើសព្រះនាមណាមួយក៏បាន ដែលជាអត្ថប្រយោជន៍ដល់និស្ស័យរបស់ទ្រង់ ដើម្បីតំណាងដល់យុគសម័យទាំងមូល។ មិនខ្វល់ថាតើវាគឺជាយុគសម័យនៃព្រះយេហូវ៉ា ឬជាយុគសម័យនៃព្រះយេស៊ូវទេ យុគសម័យនីមួយៗ គឺត្រូវមានព្រះនាមតំណាងមួយ។ នៅចុងបញ្ចប់យុគសម័យនៃព្រះគុណ យុគសម័យចុងក្រោយបានចូលមកដល់ ហើយព្រះយេស៊ូវ ក៏បានយាងមកដល់ហើយដែរ។ តើទ្រង់នៅតែអាចត្រូវគេហៅថាព្រះយេស៊ូវបានដោយរបៀបណា? តើទ្រង់នៅតែអាចមានទម្រង់ជាព្រះយេស៊ូវដែលគង់ក្នុងចំណោមមនុស្សដូចម្ដេចបាន? តើអ្នកបានភ្លេចថាព្រះយេស៊ូវ គឺគ្មានអ្វីផ្សេងក្រៅពីរូបអង្គរបស់អ្នកស្រុកណាសារ៉ែតទេឬអី? តើអ្នកបានភ្លេចថាព្រះយេស៊ូវ គឺជាព្រះដ៏ប្រោសលោះរបស់មនុស្សជាតិហើយមែនទេ? តើទ្រង់អាចទទួលយកកិច្ចការនៃការយកឈ្នះ និងការប្រោសឲ្យមនុស្សបានគ្រប់លក្ខណ៍នៅគ្រាចុងក្រោយ បានដោយរបៀបណា? ព្រះយេស៊ូវបានយាងចាកចេញទៅដោយគង់នៅលើដុំពពកស (នេះគឺជាការពិត) ប៉ុន្តែតើទ្រង់អាចយាងត្រឡប់មកវិញដោយគង់នៅលើដុំពពកសក្នុងចំណោមមនុស្ស និងនៅតែត្រូវហៅថាព្រះយេស៊ូវបានដោយរបៀបណា? ប្រសិនបើទ្រង់ពិតជាបានយាងមកនៅលើដុំពពកមែននោះ តើមនុស្សអាចមិនស្គាល់ទ្រង់បានដោយរបៀបណា? តើមនុស្សនៅលើពិភពលោកនេះមិនសុទ្ធតែស្គាល់ទ្រង់ទេឬអី? នៅក្នុងករណី

នោះ តើព្រះយេស៊ូវតែមួយអង្គឯងមិនមែនជាព្រះជាម្ចាស់ទេឬអី? នៅក្នុងករណីនោះ រូបអង្គរបស់ព្រះជាម្ចាស់ គួរតែជារូបរាងនៃជាតិសាសន៍យូដាម្នាក់ ហើយលើសពីនេះទៀត រូបរាងនេះនឹងនៅដដែលជារៀងរហូត។ ព្រះយេស៊ូវបានមានព្រះបន្ទូលថា ទ្រង់នឹងយាងមកដោយសារទ្រង់បានយាងចាកចេញទៅ ប៉ុន្តែតើអ្នកដឹងពីអត្ថន័យពិតនៃព្រះបន្ទូលរបស់ទ្រង់ដែរឬទេ? តើអាចដោយសារថា ទ្រង់បានមានបន្ទូលប្រាប់ក្រុមអ្នករាល់គ្នានេះមែនទេ? អ្វីគ្រប់យ៉ាងដែលអ្នកដឹងគឺថា ទ្រង់នឹងយាងមកដោយសារទ្រង់បានយាងចាកចេញទៅ ដោយគង់នៅលើដុំពពក ប៉ុន្តែតើអ្នកដឹងច្បាស់ថា ព្រះជាម្ចាស់បំពេញកិច្ចការរបស់ទ្រង់ដោយផ្ទាល់ព្រះអង្គដោយរបៀបណាដែរឬទេ? ប្រសិនបើអ្នកពិតជាអាចមើលឃើញមែន នោះតើព្រះបន្ទូលដែលព្រះយេស៊ូវបានសម្ដែងមកនោះ អាចពន្យល់បានដោយរបៀបណា? ទ្រង់បានមានព្រះបន្ទូលថា៖ នៅពេលដែលកូនមនុស្សមកដល់នៅគ្រាចុងក្រោយ ទ្រង់ផ្ទាល់ព្រះអង្គនឹងមិនជ្រាបពីការនេះទេ ពួកទេវតានឹងមិនដឹង អ្នកនាំសារនៅស្ថានសួគ៌នឹងមិនដឹង ហើយមនុស្សទាំងអស់ក៏នឹងមិនដឹងដែរ។ មានតែព្រះវរបិតាប៉ុណ្ណោះដែលនឹងជ្រាបពីការនេះ ពោលគឺមានតែព្រះវិញ្ញាណប៉ុណ្ណោះដែលនឹងជ្រាបពីការនេះ។ សូម្បីតែបុត្រមនុស្សផ្ទាល់ព្រះអង្គក៏មិនជ្រាបដែរ ក៏ប៉ុន្តែ តើអ្នកអាចមើលឃើញ និងអាចដឹងបានដែរឬទេ? ប្រសិនបើអ្នកអាចដឹងនិងឃើញដោយភ្នែកផ្ទាល់របស់អ្នកបាន តើព្រះបន្ទូលទាំងអស់នេះ មិនត្រូវបានសម្ដែងមកដោយអសារឥតការទេឬអី? ហើយតើព្រះយេស៊ូវបានមានព្រះបន្ទូលអ្វីខ្លះនៅពេលនោះ? «ប៉ុន្តែ ចំពោះថ្ងៃ និងពេលកំណត់នោះ គឺគ្មានមនុស្សណាម្នាក់ដឹងឡើយ សូម្បីតែពួកទេវតានៃស្ថានសួគ៌ និងព្រះរាជបុត្រាក៏មិនជ្រាបផង គឺមានតែព្រះវរបិតារបស់ខ្ញុំមួយប៉ុណ្ណោះដែលជ្រាប។ តែដូចសម័យរបស់លោកណូអេយ៉ាងណា បុត្រមនុស្សក៏នឹងយាងមកយ៉ាងនោះដែរ។ ... ចូរឲ្យអ្នកបានត្រៀមខ្លួនជាស្រេច ដ្បិតក្នុងវេលាមួយដែលអ្នកគិតមិនដល់ បុត្រមនុស្សក៏យាងមកដល់»។ នៅពេលថ្ងៃនោះមកដល់ បុត្រមនុស្សផ្ទាល់ព្រះអង្គ ក៏នឹងមិនជ្រាបដឹងដែរ។ បុត្រមនុស្សសំដៅលើសាច់ឈាមរបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស ដែលជាមនុស្សសាមញ្ញ និង

ធម្មតាម្នាក់។ សូម្បីតែបុត្រមនុស្សផ្ទាល់ព្រះអង្គ ក៏មិនជ្រាបដឹងដែរ ដូច្នេះ តើអ្នកអាចដឹងបានរបៀបណា? ព្រះយេស៊ូវបានមានព្រះបន្ទូលថា ទ្រង់នឹងយាងមកដោយសារទ្រង់បានយាងចាកចេញទៅ។ នៅពេលដែលទ្រង់យាងមក សូម្បីតែទ្រង់ផ្ទាល់ព្រះអង្គក៏មិនជ្រាបដែរ ដូច្នេះ តើទ្រង់អាចមានបន្ទូលប្រាប់ដល់អ្នកជាមុនបានដោយរបៀបណា? តើអ្នកអាចមើលឃើញការយាងមកដល់របស់ទ្រង់ដែរឬទេ? តើនោះមិនមែនជាការកំប្លែងទេឬអី? រៀងរាល់ពេលដែលព្រះជាម្ចាស់យាងមកកាន់ផែនដី ទ្រង់ផ្លាស់ប្ដូរព្រះនាមរបស់ទ្រង់ ផ្លាស់ប្ដូរភេទរបស់ទ្រង់ ផ្លាស់ប្ដូររូបអង្គរបស់ទ្រង់ និងផ្លាស់ប្ដូរកិច្ចការរបស់ទ្រង់។ ទ្រង់មិនដែលបំពេញកិច្ចការដដែលៗនោះទេ។ ទ្រង់គឺជាព្រះជាម្ចាស់ដែលតែងតែថ្មីជានិច្ច និងមិនដែលចាស់ឡើយ។ នៅពេលដែលទ្រង់យាងមកកាលពីមុន ទ្រង់ត្រូវគេហៅថាព្រះយេស៊ូវ។ តើទ្រង់ នៅតែអាចត្រូវគេហៅថាព្រះយេស៊ូវម្ដងទៀតទេ នៅពេលដែលទ្រង់យាងមកម្ដងទៀតនោះ? នៅពេលដែលទ្រង់បានយាងមកកាលពីលើកមុន ទ្រង់គឺជាមនុស្សប្រុស។ តើនៅពេលនេះ ទ្រង់អាចជាមនុស្សប្រុសម្ដងទៀតដែរឬទេ? កិច្ចការរបស់ទ្រង់នៅពេលដែលទ្រង់បានយាងមកក្នុងអំឡុងយុគសម័យនៃព្រះគុណ គឺដើម្បីឲ្យគេឆ្កាងទៅនឹងឈើឆ្កាង។ នៅពេលដែលទ្រង់យាងមកម្ដងទៀត តើទ្រង់នៅតែអាចប្រោសលោះមនុស្សជាតិឲ្យរួចពីបាបដែរឬទេ? តើទ្រង់អាចត្រូវគេឆ្កាងទៅនឹងឈើឆ្កាងម្ដងទៀតដែរឬទេ? តើនោះនឹងមិនមែនធ្វើឲ្យកិច្ចការរបស់ទ្រង់ទៅជាច្រំដែលទេឬអី? តើអ្នកមិនដឹងថាព្រះជាម្ចាស់គឺតែងតែថ្មីជានិច្ច និងមិនដែលចាស់ទេឬអី? មានអ្នកខ្លះនិយាយថា ព្រះជាម្ចាស់មិនប្រែប្រួលទេ។ នោះគឺត្រឹមត្រូវហើយ ប៉ុន្តែវាសំដៅលើភាពមិនប្រែប្រួលនៃនិស្ស័យរបស់ព្រះជាម្ចាស់ និងលក្ខណៈសំខាន់របស់ទ្រង់ប៉ុណ្ណោះ។ ការផ្លាស់ប្ដូរព្រះនាម និងកិច្ចការរបស់ទ្រង់មិនបានបញ្ជាក់ថា លក្ខណៈសំខាន់របស់ទ្រង់បានផ្លាស់ប្ដូរនោះទេ។ ម្យ៉ាងវិញទៀត ព្រះជាម្ចាស់នឹងតែងតែជាព្រះជាម្ចាស់ជានិច្ច ហើយចំណុចនេះនឹងមិនដែលផ្លាស់ប្ដូរឡើយ។ ប្រសិនបើអ្នកនិយាយថា កិច្ចការរបស់ព្រះជាម្ចាស់គឺមិនប្រែប្រួល នោះតើទ្រង់នឹងអាចបញ្ចប់ផែនការគ្រប់គ្រងរយៈពេលប្រាំមួយពាន់ឆ្នាំរបស់ទ្រង់បានដោយ

របៀបណា? អ្នកគ្រាន់តែដឹងថា ព្រះជាម្ចាស់មិនប្រែប្រួលជារៀងរហូត ប៉ុន្តែតើអ្នកដឹងថាព្រះជាម្ចាស់គឺតែងតែថ្មីជានិច្ច និងមិនដែលចាស់ដែរឬទេ? ប្រសិនបើកិច្ចការរបស់ព្រះជាម្ចាស់គឺមិនប្រែប្រួល តើទ្រង់អាចដឹកនាំមនុស្សជាតិទាំងអស់រហូតមកទល់នឹងបច្ចុប្បន្ននេះបានដែរឬទេ? ប្រសិនបើព្រះជាម្ចាស់គឺមិនប្រែប្រួល តើហេតុអ្វីបានជាទ្រង់បានបញ្ចប់កិច្ចការរបស់ទ្រង់ក្នុងយុគសម័យចំនួនពីរ? កិច្ចការរបស់ទ្រង់មិនដែលឈប់បោះជំហានទៅមុខឡើយ ដែលមានន័យថា និស្ស័យរបស់ទ្រង់ គឺត្រូវបើកសម្ដែងឲ្យមនុស្សបានឃើញបន្តិចម្ដងៗ ហើយអ្វីដែលត្រូវបើកសម្ដែងនោះ គឺនិស្ស័យរបស់ទ្រង់។ កាលដើមដំបូងឡើយ និស្ស័យរបស់ព្រះជាម្ចាស់ត្រូវបានលាក់បាំង មិនឲ្យមនុស្សដឹងទេ ទ្រង់មិនដែលបើកសម្ដែងនិស្ស័យរបស់ទ្រង់ឲ្យមនុស្សបានឃើញដោយបើកចំហឡើយ ហើយមនុស្សគ្មានចំណេះដឹងអ្វីអំពីទ្រង់នោះទេ។ ដោយសារចំណុចនេះហើយទើបទ្រង់ប្រើកិច្ចការរបស់ទ្រង់ដើម្បីបើកសម្ដែងនិស្ស័យរបស់ទ្រង់ឲ្យមនុស្សបានឃើញបន្តិចម្ដងៗ ប៉ុន្តែការបំពេញកិច្ចការដោយបែបនេះ ពុំមានន័យថា និស្ស័យរបស់ព្រះជាម្ចាស់ផ្លាស់ប្ដូរ នៅគ្រប់យុគសម័យឡើយ។ មិនមែនថានិស្ស័យរបស់ព្រះជាម្ចាស់ប្រែប្រួលឥតឈប់ ដោយសារបំណងព្រះហឫទ័យរបស់ទ្រង់ តែងតែផ្លាស់ប្ដូរជានិច្ចនោះឡើយ។ ផ្ទុយទៅវិញ គឺដោយសារយុគសម័យនៃកិច្ចការរបស់ទ្រង់ខុសៗគ្នា ទើបព្រះជាម្ចាស់ទ្រង់យកនិស្ស័យរបស់ទ្រង់ឲ្យបានទាំងស្រុង ដោយបើកសម្ដែងឲ្យមនុស្សឃើញមួយជំហានម្ដងៗ ដើម្បីឲ្យមនុស្សអាចស្គាល់ទ្រង់បាន។ ប៉ុន្តែនេះពុំមែនជាសេចក្ដីសម្អាងដែលថាព្រះជាម្ចាស់មិនមាននិស្ស័យជាក់លាក់ណាមួយពីដើមមកនោះទេ ឬថានិស្ស័យរបស់ទ្រង់បានផ្លាស់ប្ដូរបន្តិចម្ដងៗនៅពេលដែលយុគសម័យនីមួយៗបានកន្លងផុតទៅនោះទេ ការយល់ដឹងបែបនេះ នឹងក្លាយទៅជាការយល់ដឹងដែលមិនត្រឹមត្រូវ។ ព្រះជាម្ចាស់បើកសម្ដែងនិស្ស័យដែលមានតាំងពីដើមមក និងនិស្ស័យជាក់លាក់របស់ទ្រង់ឲ្យមនុស្សបានឃើញ (លក្ខណៈរបស់ទ្រង់) ស្របទៅតាមយុគសម័យនីមួយៗដែលបានកន្លងផុតទៅ។ កិច្ចការនៃយុគសម័យមួយមិនអាចសម្ដែងចេញនូវនិស្ស័យទាំងស្រុងរបស់ព្រះជាម្ចាស់បានឡើយ។ ហេតុដូច្នេះ

ហើយ ពាក្យថា «ព្រះជាម្ចាស់តែងតែថ្មីជានិច្ច និងមិនដែលចាស់» សំដៅលើកិច្ចការរបស់ទ្រង់ ហើយពាក្យថា «ព្រះជាម្ចាស់មិនប្រែប្រួល» សំដៅលើកម្មសិទ្ធិ និងលក្ខណៈរបស់ទ្រង់។ បើមិនគិតបែបនេះទេ អ្នកមិនអាចធ្វើឲ្យកិច្ចការរយៈពេលប្រាំមួយពាន់ឆ្នាំភ្ជាប់គ្នានឹងចំណុចតែមួយបានទេ ឬវិលវល់ចុះឡើង ជាមួយព្រះបន្ទូលដែលស្លាប់ប៉ុណ្ណោះ។ បែបនេះ គឺជាភាពល្ងង់ខ្លៅរបស់មនុស្ស។ ព្រះជាម្ចាស់គឺមិនធម្មតាដូចជាមនុស្សស្រមៃនោះទេ ហើយកិច្ចការរបស់ទ្រង់ មិនអាចបង្អែរបង្អង់ក្នុងយុគសម័យណាមួយបានឡើយ។ ឧទាហរណ៍ ព្រះយេហូវ៉ាមិនអាចតែងតែតំណាងឲ្យព្រះនាមរបស់ព្រះជាម្ចាស់ឡើយ។ ព្រះជាម្ចាស់ ក៏អាចបំពេញកិច្ចការរបស់ទ្រង់នៅក្រោមព្រះនាមរបស់ព្រះយេស៊ូវបានដែរ។ នេះគឺជាទីសម្គាល់ដែលថា កិច្ចការរបស់ព្រះជាម្ចាស់ តែងតែចម្រើនទៅមុខជានិច្ច។

ព្រះជាម្ចាស់ គឺតែងតែជាព្រះជាម្ចាស់ជានិច្ច ហើយទ្រង់នឹងមិនអាចក្លាយទៅជាសាតាំងជាដាច់ខាត។ សាតាំងនៅតែជាសាតាំង ហើយវានឹងមិនអាចក្លាយជាព្រះជាម្ចាស់បានឡើយ។ ព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់ ការអស្ចារ្យរបស់ព្រះជាម្ចាស់ សេចក្ដីសុចរិតរបស់ព្រះជាម្ចាស់ ឬឫទ្ធានុភាពរបស់ព្រះជាម្ចាស់នឹងមិនផ្លាស់ប្ដូរឡើយ។ សារជាតិរបស់ទ្រង់ និងកម្មសិទ្ធិ ព្រមទាំងលក្ខណៈរបស់ទ្រង់ នឹងមិនដែលផ្លាស់ប្ដូរឡើយ។ ក៏ប៉ុន្តែ ចំពោះកិច្ចការរបស់ទ្រង់វិញ គឺវាតែងតែចម្រើនទៅមុខជានិច្ច តែងតែចូលជ្រៅទៅមុខ ដ្បិតទ្រង់តែងតែថ្មីជានិច្ច និងមិនដែលចាស់ឡើយ។ នៅក្នុងយុគសម័យនីមួយៗ ព្រះជាម្ចាស់តែងយកព្រះនាមថ្មីមួយ នៅក្នុងយុគសម័យនីមួយៗ ទ្រង់បំពេញកិច្ចការថ្មី ហើយនៅក្នុងយុគសម័យនីមួយៗ ទ្រង់អនុញ្ញាតឲ្យអ្វីដែលទ្រង់បានបង្កើតមក មើលឃើញពីបំណងព្រះហឫទ័យថ្មី និងនិស្ស័យថ្មីរបស់ទ្រង់។ នៅក្នុងយុគសម័យថ្មី ប្រសិនបើមនុស្សមិនអាចមើលឃើញការបើកសម្ដែងអំពីនិស្ស័យថ្មីរបស់ព្រះជាម្ចាស់ទេ តើពួកគេអាចនឹងមិនឆ្កាងទ្រង់ទៅនឹងឈើឆ្កាងជារៀងរហូតដែរឬទេ? ហើយការធ្វើបែបនេះ តើពួកគេនឹងមិនកំណត់និយមន័យឲ្យព្រះជាម្ចាស់ទេឬអី? ប្រសិនបើព្រះជាម្ចាស់យកកំណើតជាមនុស្ស តែជាបុរស នោះមនុស្សនឹងកំណត់ថា

ទ្រង់ គឺជាបុរស ជាព្រះជាម្ចាស់ដែលជាមនុស្សប្រុស ហើយនឹងមិនដែលជឿថាទ្រង់អាចក្លាយជាព្រះជាម្ចាស់ដែលជាមនុស្សស្រីឡើយ។ បន្ទាប់មកទៀត មនុស្សនឹងគិតថាព្រះជាម្ចាស់គឺមានភេទដូចមុន គឺជាបុរស ថាព្រះជាម្ចាស់គឺជាមេនៃមនុស្សប្រុស ប៉ុន្ដែ ចុះចំណែកមនុស្សស្រីវិញ? រឿងនេះគឺមិនយុត្តិធម៌ទេ។ តើនេះមិនមែនជាការកំណត់តាមការនិយមចូលចិត្តទេឬអី? ប្រសិនបើនេះគឺជាការពិតមែន នោះអស់អ្នកណាដែលព្រះជាម្ចាស់បានសង្គ្រោះ នឹងក្លាយជាមនុស្សប្រុសដូចជាទ្រង់ដែរ ហើយគ្មានមនុស្សស្រីណាម្នាក់ដែលនឹងត្រូវសង្គ្រោះនោះទេ។ នៅពេលដែលព្រះជាម្ចាស់បានបង្កើតមនុស្សជាតិមក ទ្រង់បានបង្កើតអ័ដាម រួចទ្រង់បានបង្កើតអេវ៉ា។ ទ្រង់មិនត្រឹមតែបានបង្កើតអ័ដាមប៉ុណ្ណោះទេ ប៉ុន្ដែទ្រង់ក៏បានបង្កើតទាំងមនុស្សប្រុស និងមនុស្សស្រីឲ្យដូចរូបអង្គរបស់ទ្រង់ដែរ។ ព្រះជាម្ចាស់មិនគ្រាន់តែជាព្រះជាម្ចាស់របស់មនុស្សប្រុសទេ ប៉ុន្ដែទ្រង់ក៏ជាព្រះជាម្ចាស់របស់មនុស្សស្រីដែរ។ ព្រះជាម្ចាស់យាងចូលមកក្នុងយុគសម័យនៃកិច្ចការថ្មីនៅគ្រាចុងក្រោយ។ ទ្រង់នឹងបើកសម្ដែងនិស្ស័យរបស់ទ្រង់កាន់តែច្រើន ហើយនិស្ស័យនោះនឹងមិនមែនជាចិត្តក្ដួលអាណិត និងសេចក្ដីស្រឡាញ់ ដូចនៅក្នុងសម័យរបស់ព្រះយេស៊ូវឡើយ។ ដោយសារទ្រង់មានកិច្ចការថ្មីនៅក្នុងព្រះហស្តរបស់ទ្រង់ កិច្ចការថ្មីនេះ នឹងត្រូវមានមកជាមួយនិស្ស័យថ្មីដែរ។ ដូច្នេះ ប្រសិនបើកិច្ចការនេះត្រូវព្រះវិញ្ញាណបំពេញ ប្រសិនបើព្រះជាម្ចាស់មិនបានយកកំណើតជាមនុស្សទេ តែផ្ទុយទៅវិញ ព្រះវិញ្ញាណបានមានព្រះបន្ទូលដោយផ្ទាល់តាមរយៈសំឡេងផ្គរលាន់ ដើម្បីឲ្យមនុស្សគ្មានផ្លូវណាអាចទាក់ទងជាមួយទ្រង់បាន តើមនុស្សអាចស្គាល់ពីនិស្ស័យរបស់ទ្រង់ដែរឬទេ? ប្រសិនបើព្រះវិញ្ញាណបំពេញកិច្ចការតែមួយព្រះអង្គឯង នោះមនុស្សនឹងគ្មានផ្លូវដែលអាចស្គាល់ពីនិស្ស័យរបស់ព្រះជាម្ចាស់បានឡើយ។ មនុស្សអាចត្រឹមតែឃើញពីនិស្ស័យរបស់ព្រះជាម្ចាស់ដោយភ្នែករបស់ពួកគេ នៅពេលដែលទ្រង់យកកំណើតជាមនុស្ស នៅពេលដែលព្រះបន្ទូលលេចមកជាសាច់ឈាម ហើយទ្រង់បើកសម្ដែងពីនិស្ស័យរបស់ទ្រង់ទាំងស្រុងតាមរយៈសាច់ឈាមប៉ុណ្ណោះ។ ព្រះជាម្ចាស់ពិតជារស់នៅក្នុងចំណោមមនុស្ស

ពិតប្រាកដមែន។ ទ្រង់គឺរូបី មនុស្សអាចបន្ស៊ីគ្នាជាមួយនិស្ស័យរបស់ទ្រង់បានដោយផ្ទាល់ អាចពាក់ព័ន្ធនឹងកម្មសិទ្ធិ និងលក្ខណៈរបស់ទ្រង់បាន។ មានតែបែបនេះទេ ទើបមនុស្សអាចស្គាល់ទ្រង់បានដោយពិតប្រាកដ។ នៅពេលជាមួយគ្នានោះដែរ ព្រះជាម្ចាស់ក៏បានបញ្ចប់កិច្ចការដែល «ព្រះជាម្ចាស់ គឺជាព្រះជាម្ចាស់របស់មនុស្សប្រុស និងជាព្រះជាម្ចាស់របស់មនុស្សស្រី» និងបានបញ្ចប់កិច្ចការរបស់ទ្រង់ទាំងស្រុងនៅខាងសាច់ឈាមដែរ។ ទ្រង់មិនដែលបំពេញកិច្ចការជាន់គ្នា នៅក្នុងយុគសម័យណាមួយឡើយ។ ដោយសារគ្រាចុងក្រោយបានចូលមកដល់ហើយ ទ្រង់នឹងបំពេញកិច្ចការដែលទ្រង់ត្រូវបំពេញនៅគ្រាចុងក្រោយ រួចបើកសម្ដែងពីនិស្ស័យរបស់ទ្រង់ទាំងស្រុងនៅគ្រាចុងក្រោយ។ និយាយពីគ្រាចុងក្រោយនេះ គឺសំដៅលើយុគសម័យខុសគ្នា ពោលគឺជាយុគសម័យមួយដែលព្រះយេស៊ូវបានមានព្រះបន្ទូលថា អ្នករាល់គ្នានឹងជួបគ្រោះមហន្តរាយជាប្រាកដ និងជួបគ្រោះរញ្ជួយដី គ្រោះទុរភិក្ស និងរោគពិស ដែលទាំងនេះនឹងបង្ហាញថា នេះគឺជាយុគសម័យថ្មីមួយ គឺលែងជាយុគសម័យនៃព្រះគុណពីមុនទៀតហើយ។ ឧបមាដូចជាមនុស្សនិយាយថា ព្រះជាម្ចាស់មិនប្រែប្រួលជារៀងរហូត និស្ស័យរបស់ទ្រង់គឺតែងតែមានចិត្តក្តួលអាណិត និងគួរឲ្យស្រឡាញ់ ថាទ្រង់ស្រឡាញ់មនុស្សដូចជារូបអង្គទ្រង់ ហើយទ្រង់ប្រទានសេចក្តីសង្គ្រោះដល់មនុស្ស និងមិនដែលស្អប់មនុស្សឡើយ តើកិច្ចការរបស់ទ្រង់នឹងអាចចូលដល់ទីបញ្ចប់បានដែរឬទេ? នៅពេលដែលព្រះយេស៊ូវបានយាងមក និងត្រូវគេបោះភ្ជាប់ទៅនឹងឈើឆ្កាង ដោយបានលះបង់អង្គទ្រង់សម្រាប់អ្នកមានបាបទាំងអស់ និងបូជាអង្គទ្រង់ថ្វាយនៅលើអាសនា នោះទ្រង់បានបញ្ចប់កិច្ចការនៃការប្រោសលោះរួចស្រេចហើយ និងបាននាំយុគសម័យនៃព្រះគុណទៅរកទីចុងបញ្ចប់។ ដូច្នេះ តើការធ្វើកិច្ចការនេះម្តងទៀតនៅយុគសម័យនៃគ្រាចុងក្រោយនេះ នឹងមានប្រយោជន៍អ្វី? តើការធ្វើរឿងដដែលៗមិនមែនជាការបដិសេធកិច្ចការរបស់ព្រះយេស៊ូវទេឬអី? ប្រសិនបើព្រះជាម្ចាស់មិនបានបំពេញកិច្ចការនៃការជាប់ឆ្កាងនៅពេលដែលទ្រង់យាងមកនៅក្នុងដំណាក់កាលនេះទេ ប៉ុន្តែបែរជាបន្តស្រឡាញ់ និងមានព្រះហឫទ័យក្តួលអាណិត នោះតើទ្រង់

អាចនឹងនាំយុគសម័យនោះ ទៅរកទីបញ្ចប់បានដោយរបៀបណា? តើព្រះជាម្ចាស់ដែលគួរឲ្យស្រឡាញ់ និងមានព្រះហឫទ័យក្ដួលអាណិត នឹងអាចនាំយុគសម័យនេះទៅរកទីបញ្ចប់បានដែរឬទេ? នៅចុងបញ្ចប់ នៃកិច្ចការបិទបញ្ចប់យុគសម័យរបស់ទ្រង់ និស្ស័យរបស់ព្រះជាម្ចាស់ គឺជាការវាយផ្ចាល និងការជំនុំជម្រះ ដែលទ្រង់បើកសម្ដែងពីគ្រប់ការទាំងអស់ដែលមិនសុចរិត គឺដើម្បីធ្វើការជំនុំជម្រះមនុស្សទាំងអស់ជាសាធារណៈ និងដើម្បីប្រោសអ្នកដែលស្រឡាញ់ទ្រង់ដែលមានដួងចិត្តស្មោះឲ្យបានគ្រប់លក្ខណ៍។ មានតែនិស្ស័យបែបនេះទេទើបអាចនាំយុគសម័យនេះទៅរកទីបញ្ចប់បាន។ គ្រាចុងក្រោយបានចូលមកដល់ហើយ។ របស់សព្វសារពើដែលបានបង្កើតមក នឹងត្រូវញែកដាច់ពីគ្នាទៅតាមប្រភេទរបស់វា ហើយត្រូវបែងចែងទៅតាមប្រភេទខុសគ្នាផ្អែកតាមលក្ខណៈរបស់ពួកគេ។ នេះគឺជាពេលវេលាដែលព្រះជាម្ចាស់បើកសម្ដែងពីលទ្ធផលរបស់មនុស្ស និងទិសដៅរបស់ពួកគេ។ ប្រសិនបើមនុស្សមិនបានឆ្លងកាត់ការវាយផ្ចាល និងការជំនុំជម្រះទេ នោះនឹងគ្មានផ្លូវដែលអាចសម្ដែងឲ្យយល់ពីការមិនស្ដាប់បង្គាប់ និងសេចក្ដីទុច្ចរិតរបស់ពួកគេបានឡើយ។ មានតែតាមរយៈការវាយផ្ចាល និងការជំនុំជម្រះប៉ុណ្ណោះទើបលទ្ធផលនៃរបស់សព្វសារពើដែលបានបង្កើតមក អាចត្រូវបើកសម្ដែងឲ្យឃើញបាន។ នៅពេលដែលត្រូវវាយផ្ចាល និងជំនុំជម្រះ មនុស្សគ្រាន់តែបង្ហាញពីពណ៌ពិតប្រាកដរបស់គេប៉ុណ្ណោះ។ មនុស្សអាក្រក់ ត្រូវដាក់ជាមួយមនុស្សអាក្រក់ មនុស្សល្អត្រូវដាក់ជាមួយមនុស្សល្អ ហើយមនុស្សទាំងអស់ត្រូវញែកដាច់ចេញពីគ្នាទៅតាមប្រភេទរបស់ពួកគេ។ តាមរយៈការវាយផ្ចាល និងការជំនុំជម្រះ លទ្ធផលនៃរបស់សព្វសារពើដែលបានបង្កើតមក នឹងត្រូវបើកសម្ដែងឲ្យឃើញ ដើម្បីឲ្យមនុស្សអាក្រក់អាចត្រូវដាក់ទោស ហើយមនុស្សល្អអាចទទួលបានរង្វាន់ ហើយគ្រប់មនុស្សទាំងអស់សុទ្ធតែស្ថិតក្រោមអំណាចត្រួតត្រារបស់ព្រះជាម្ចាស់។ គ្រប់កិច្ចការទាំងអស់នេះ ត្រូវតែសម្រេចឲ្យបានតាមរយៈការវាយផ្ចាល និងការជំនុំជម្រះដោយសុចរិត។ ដោយសារសេចក្ដីពុករលួយរបស់មនុស្សបានឈានដល់កម្រិតកំពូល ហើយការមិនស្ដាប់បង្គាប់របស់ពួកគេកាន់តែខ្លាំងឡើងៗ

នោះមានតែនិស្ស័យសុចរិតរបស់ព្រះជាម្ចាស់ប៉ុណ្ណោះ ដែលជានិស្ស័យមួយ ដែលបូកផ្សំជាគោលការណ៍នៃការវាយផ្ចាល និងការជំនុំជម្រះ និងជានិស្ស័យដែលត្រូវបើកបង្ហាញក្នុងអំឡុងគ្រាចុងក្រោយប៉ុណ្ណោះ ទើបអាចបំផ្លាស់បំប្រែ និងធ្វើឲ្យមនុស្សបានពេញខ្នាតទាំងស្រុង។ មានតែនិស្ស័យបែបនេះទេ ដែលអាចសម្ដែងឲ្យយល់ពីអំពើអាក្រក់ និងដាក់ទោសយ៉ាងធ្ងន់ធ្ងរលើមនុស្សទុច្ចរិតទាំងអស់បាន។ ហេតុនេះនិស្ស័យបែបនេះជ្រួតជ្រាបទៅដោយខ្លឹមសារសំខាន់នៃយុគសម័យនេះ ហើយការបើកសម្ដែង និងការបង្ហាញពីនិស្ស័យរបស់ទ្រង់ គឺធ្វើឡើងដើម្បីតែជាប្រយោជន៍នៃកិច្ចការនៅក្នុងយុគសម័យថ្មីនីមួយៗប៉ុណ្ណោះ។ ព្រះជាម្ចាស់មិនបើកសម្ដែងនិស្ស័យរបស់ទ្រង់តាមតែអំពើចិត្ត និងដោយគ្មានខ្លឹមសារនោះទេ។ ឧបមាថា ក្នុងការបើកសម្ដែង ពីលទ្ធផលរបស់មនុស្សក្នុងអំឡុងគ្រាចុងក្រោយ ព្រះជាម្ចាស់នៅតែត្រូវប្រទានដល់មនុស្សនូវព្រះហឫទ័យក្តួលអាណិត និងសេចក្តីស្រឡាញ់ឥតគណនា និងបន្តសេចក្តីស្រឡាញ់ដល់មនុស្ស និងមិនឲ្យមនុស្សស្ថិតក្រោមការជំនុំជម្រះដោយសុចរិត ប៉ុន្តែបែរជាបង្ហាញដល់ពួកគេនូវការអត់ឱន ការអត់ទ្រាំ និងការអត់ទោស និងការលើកលែងទោសដល់មនុស្សទៅវិញ មិនថាពួកគេមានបាបខ្លាំងយ៉ាងណានោះទេ គឺគ្មានការជំនុំជម្រះសុចរិតណាមួយឡើយ៖ ដូច្នេះ តើពេលណាដែលការគ្រប់គ្រងទាំងអស់របស់ព្រះជាម្ចាស់ នឹងអាចចូលដល់ទីបញ្ចប់បានទៅ? តើនៅពេលណាដែលនិស្ស័យបែបនេះ នឹងអាចដឹកនាំមនុស្សទៅរកទិសដៅសមស្របរបស់មនុស្សជាតិបាន? ឧទាហរណ៍ ចៅក្រមម្នាក់ដែលគួរឲ្យស្រឡាញ់ ជាចៅក្រមដែលមានទឹកមុខសប្បុរស និងមានសណ្ដានចិត្តល្អ។ គាត់ស្រឡាញ់មនុស្ស មិនខ្វល់ថាពួកគេបានប្រព្រឹត្តទោសកំហុសអ្វីឡើយ ហើយគាត់ស្រឡាញ់ និងអត់ឱនដល់ពួកគេមិនថាពួកគេជានរណានោះទេ។ នៅក្នុងករណីនោះ តើពេលណាដែលគាត់អាចកាត់ក្ដីដោយយុត្តិធម៌បានទៅ? ក្នុងអំឡុងគ្រាចុងក្រោយ មានតែការជំនុំជម្រះដោយសុចរិតប៉ុណ្ណោះដែលអាចញែកមនុស្សស្របទៅតាមប្រភេទរបស់ពួកគេបាន និងនាំមនុស្សទៅកាន់ពិភពថ្មីមួយ។ តាមរបៀបនេះ យុគសម័យទាំងមូល ត្រូវបាននាំទៅរកទីបញ្ចប់

តាមរយៈនិស្ស័យសុចរិតរបស់ព្រះជាម្ចាស់នៅក្នុងការជំនុំជម្រះ និងការវាយផ្ចាល។

កិច្ចការរបស់ព្រះជាម្ចាស់ក្នុងការគ្រប់គ្រងរបស់ទ្រង់ទាំងមូល គឺច្បាស់លាស់ខ្លាំងណាស់៖ យុគសម័យនៃព្រះគុណ គឺជាយុគសម័យនៃព្រះគុណ ហើយគ្រាចុងក្រោយ គឺជាគ្រាចុងក្រោយ។ មានភាពខុសគ្នាដាច់ស្រឡះរវាងយុគសម័យនីមួយៗ ដ្បិតក្នុងយុគសម័យនីមួយៗ ព្រះជាម្ចាស់បំពេញកិច្ចការដែលជាតំណាងឲ្យយុគសម័យនោះ។ សម្រាប់កិច្ចការនៃគ្រាចុងក្រោយដែលត្រូវបំពេញ គឺត្រូវមានការដុតដោយភ្លើង ការជំនុំជម្រះ ការវាយផ្ចាល សេចក្ដីក្រោធ និងការបំផ្លាញ ដើម្បីនាំយុគសម័យនោះទៅរកទីបញ្ចប់។ គ្រាចុងក្រោយសំដៅលើយុគសម័យចុងក្រោយ។ ក្នុងអំឡុងយុគសម័យចុងក្រោយនេះ តើព្រះជាម្ចាស់នឹងនាំយុគសម័យនោះទៅរកទីបញ្ចប់ដែរឬទេ? ដើម្បីបញ្ចប់យុគសម័យនេះ ព្រះជាម្ចាស់ត្រូវនាំការវាយផ្ចាល និងការជំនុំជម្រះមកជាមួយទ្រង់។ មានតែបែបនេះទេ ទើបអាចនាំយុគសម័យនេះទៅរកទីបញ្ចប់បាន។ គោលបំណងរបស់ព្រះយេស៊ូវ គឺដើម្បីឲ្យមនុស្សអាចបន្តជីវិតបាន ដើម្បីបន្តរស់នៅ និងដើម្បីឲ្យគេអាចមានជីវិតនៅក្នុងផ្លូវដែលល្អប្រសើរ។ ទ្រង់បានសង្គ្រោះមនុស្សឲ្យរួចពីអំពើបាបដើម្បីឲ្យគេអាចឈប់ធ្លាក់ទៅក្នុងអំពើគ្មានគុណធម៌ និងលែងរស់នៅក្នុងស្ថានឃុំព្រលឹង និងស្ថាននរក ហើយតាមរយៈការសង្គ្រោះមនុស្សពីស្ថានឃុំព្រលឹង និងស្ថាននរកនេះ ព្រះយេស៊ូវបានអនុញ្ញាតឲ្យគេបន្តរស់នៅតទៅទៀត។ បច្ចុប្បន្ននេះ គ្រាចុងក្រោយបានចូលមកដល់ហើយ។ ព្រះជាម្ចាស់នឹងធ្វើឲ្យមនុស្សវិនាសហិនហោច និងបំផ្លាញពូជមនុស្សទាំងស្រុង ពោលគឺទ្រង់នឹងបំផ្លាស់បំប្រែការបះបោររបស់មនុស្សជាតិ។ ដោយព្រោះមូលហេតុនេះ និងតាមរយៈនិស្ស័យនៃចិត្តក្ដួលអាណិត និងគួរឲ្យស្រឡាញ់ពីអតីតកាល វានឹងមិនអាចទៅរួចនោះទេ ដែលព្រះជាម្ចាស់ត្រូវបញ្ចប់យុគសម័យនេះ ឬនាំផែនការគ្រប់គ្រងរយៈពេលប្រាំមួយពាន់ឆ្នាំរបស់ទ្រង់ឲ្យចេញផលផ្លែ។ នៅគ្រប់យុគសម័យទាំងអស់ មានការតំណាងជាពិសេសអំពីនិស្ស័យរបស់ព្រះជាម្ចាស់ ហើយគ្រប់យុគសម័យទាំងអស់ សុទ្ធតែមានកិច្ចការដែលព្រះជាម្ចាស់គប្បីត្រូវបំពេញ។ ដូច្នេះ កិច្ចការដែលព្រះជាម្ចាស់ផ្ទាល់ព្រះអង្គបាន

បំពេញនៅក្នុងយុគសម័យនីមួយៗ មានការបើកសម្ដែងពីនិស្ស័យពិតប្រាកដរបស់ទ្រង់ ហើយព្រះនាមទាំងពីររបស់ទ្រង់ និងកិច្ចការដែលទ្រង់បំពេញ បានផ្លាស់ប្ដូរជាមួយនឹងយុគសម័យនេះ ពោលគឺកិច្ចការទាំងអស់នេះ សុទ្ធតែថ្មីទាំងអស់។ ក្នុងអំឡុងយុគសម័យនៃក្រឹត្យវិន័យ កិច្ចការនៃការដឹកនាំមនុស្សជាតិ ត្រូវធ្វើឡើងនៅក្រោមព្រះនាមរបស់ព្រះយេហូវ៉ា ហើយដំណាក់កាលដំបូងនៃកិច្ចការនេះ ត្រូវធ្វើឡើងនៅលើផែនដី។ នៅក្នុងដំណាក់កាលនេះ កិច្ចការនេះបានរួមបញ្ចូលនូវសាងសង់ព្រះវិហារ និងអាសនា និងប្រើក្រឹត្យវិន័យដើម្បីដឹកនាំរាស្ត្រអ៊ីស្រាអែល ព្រមទាំងដើម្បីបំពេញកិច្ចការក្នុងចំណោមពួកគេ។ តាមរយៈការដឹកនាំរាស្ត្រអ៊ីស្រាអែល ទ្រង់បានចាប់ផ្ដើមមូលដ្ឋានគ្រឹះនៃកិច្ចការរបស់ទ្រង់នៅលើផែនដី។ ចេញពីមូលដ្ឋានគ្រឹះនេះ ទ្រង់បានពង្រីកកិច្ចការរបស់ទ្រង់នៅក្រៅស្រុកអ៊ីស្រាអែល ដែលនេះចង់និយាយថា ទ្រង់បានពង្រីកកិច្ចការរបស់ទ្រង់ទៅក្រៅចាប់ពីស្រុកអ៊ីស្រាអែលទៅ ដើម្បីឲ្យកូនចៅជំនាន់ក្រោយបានដឹងថាព្រះយេហូវ៉ាថាជាព្រះជាម្ចាស់ន្ដិចម្ដងៗ និងដឹងថាគឺព្រះយេហូវ៉ានេះហើយដែលបានបង្កើតផ្ទៃមេឃ និងផែនដី ព្រមទាំងរបស់សព្វសារពើទាំងអស់ ហើយគឺព្រះយេហូវ៉ានេះហើយ ដែលបានបង្កើតគ្រប់សត្តនិករទាំងអស់មក។ ទ្រង់បានពង្រីកកិច្ចការរបស់ទ្រង់ តាមរយៈរាស្ត្រអ៊ីស្រាអែលទៅដល់រាស្ត្រដទៃផ្សេងទៀត។ ដែនដីស្រុកអ៊ីស្រាអែល គឺជាកន្លែងបរិសុទ្ធដំបូងគេនៃកិច្ចការរបស់ព្រះយេហូវ៉ានៅលើផែនដី ហើយគឺដែនដីអ៊ីស្រាអែលនេះហើយ ដែលព្រះជាម្ចាស់បានយាងទៅបំពេញកិច្ចការនៅលើផែនដី។ នោះគឺជាកិច្ចការ នៅយុគសម័យនៃក្រឹត្យវិន័យ។ ក្នុងអំឡុងយុគសម័យនៃព្រះគុណ ព្រះយេស៊ូវគឺជាព្រះជាម្ចាស់ដែលបានសង្គ្រោះមនុស្ស។ កម្មសិទ្ធិ និងលក្ខណៈរបស់ទ្រង់ គឺព្រះគុណ សេចក្ដីស្រឡាញ់ ព្រះទ័យក្ដួលអាណិត ការអត់ទ្រាំ ការអត់ធ្មត់ ការបន្ទាបខ្លួន ការយកព្រះទ័យទុកដាក់ និងការអត់ឱន ហើយកិច្ចការយ៉ាងច្រើនដែលទ្រង់បានបំពេញ គឺដើម្បីតែជាប្រយោជន៍ដល់ការប្រោសលោះមនុស្សតែប៉ុណ្ណោះ។ និស្ស័យរបស់ទ្រង់ គឺជានិស្ស័យមួយដែលមានចិត្តក្ដួលអាណិត និងសេចក្ដីស្រឡាញ់ ហើយដោយសារទ្រង់មានព្រះហឫទ័យ

ក្ដួលអាណិត និងគួរឲ្យស្រឡាញ់នេះហើយ ទើបទ្រង់ត្រូវគេបោះភ្ជាប់ទៅនឹងឈើឆ្កាងជំនួសមនុស្ស ដើម្បីបង្ហាញថា ព្រះជាម្ចាស់បានស្រឡាញ់មនុស្សដូចជាអង្គទ្រង់ដែរ គឺស្រឡាញ់ខ្លាំង រហូតដល់ទ្រង់បានលះបង់អង្គទ្រង់ទាំងស្រុង។ ក្នុងអំឡុងយុគសម័យនៃព្រះគុណ ព្រះនាមរបស់ព្រះជាម្ចាស់ គឺព្រះយេស៊ូវ នេះគឺចង់បានន័យថា ព្រះជាម្ចាស់គឺជាព្រះជាម្ចាស់មួយអង្គដែលបានសង្គ្រោះមនុស្ស ហើយទ្រង់គឺជាព្រះជាម្ចាស់ដែលមានព្រះហឫទ័យក្ដួលអាណិត និងគួរឲ្យស្រឡាញ់។ ព្រះជាម្ចាស់គង់នៅជាមួយមនុស្ស។ សេចក្ដីស្រឡាញ់របស់ទ្រង់ ព្រះហឫទ័យក្ដួលអាណិតរបស់ទ្រង់ និងសេចក្ដីសង្គ្រោះរបស់ទ្រង់ បានមកជាមួយមនុស្សគ្រប់គ្នាទាំងអស់។ មានតែតាមរយៈការទទួលយកព្រះនាមរបស់ព្រះយេស៊ូវ និងព្រះវត្តមានរបស់ទ្រង់ប៉ុណ្ណោះ ទើបមនុស្សអាចទទួលបានសន្តិភាព និងអំណរ ដើម្បីទួលបានព្រះពររបស់ទ្រង់ ព្រះគុណដ៏ធំធេង និងច្រើនឥតគណនារបស់ទ្រង់ និងសេចក្ដីសង្គ្រោះរបស់ទ្រង់បាន។ តាមរយៈការជាប់ឆ្កាងរបស់ព្រះយេស៊ូវ អស់អ្នកដែលបានដើរតាមទ្រង់ទទួលបាននូវសេចក្ដីសង្គ្រោះ ហើយបាបរបស់ពួកគេត្រូវបានអត់ទោសឲ្យ។ ក្នុងអំឡុងយុគសម័យនៃព្រះគុណ ព្រះយេស៊ូវ គឺជាព្រះនាមរបស់ព្រះជាម្ចាស់។ អាចនិយាយម្យ៉ាងទៀតបានថា កិច្ចការនៅយុគសម័យនៃព្រះគុណត្រូវធ្វើឡើងជាគោលការណ៍នៅក្រោមព្រះនាមព្រះយេស៊ូវ។ ក្នុងអំឡុងយុគសម័យនៃព្រះគុណ ព្រះជាម្ចាស់ត្រូវគេហៅថា ព្រះយេស៊ូវ។ ទ្រង់បានបំពេញកិច្ចការនៅដំណាក់កាលនៃកិច្ចការថ្មីលើសពីព្រះគម្ពីរសញ្ញាចាស់ ហើយកិច្ចការរបស់ទ្រង់បានបញ្ចប់ទៅដោយការជាប់ឆ្កាង។ នេះគឺជាកិច្ចការទាំងស្រុងរបស់ទ្រង់។ ហេតុនេះ ក្នុងអំឡុងយុគសម័យនៃក្រឹត្យវិន័យ ព្រះយេហូវ៉ាគឺជាព្រះនាមរបស់ព្រះជាម្ចាស់ ហើយនៅក្នុងយុគសម័យនៃព្រះគុណ ព្រះនាមព្រះយេស៊ូវ គឺបានតំណាងឲ្យព្រះជាម្ចាស់។ ក្នុងអំឡុងពេលនៃគ្រាចុងក្រោយ ព្រះនាមរបស់ទ្រង់គឺ ព្រះដ៏មានគ្រប់ព្រះចេស្ដា ជាព្រះដ៏មានគ្រប់ចេស្ដា ដែលប្រើព្រះចេស្ដារបស់ទ្រង់ដើម្បីដឹកនាំមនុស្ស យកឈ្នះលើមនុស្ស និងទទួលបានមនុស្ស ហើយចុងក្រោយ នាំយុគសម័យនោះទៅរកទីបញ្ចប់។ នៅគ្រប់ដំណាក់កាលទាំងអស់

នៅគ្រប់ដំណាក់កាលនៃកិច្ចការរបស់ទ្រង់ និស្ស័យរបស់ព្រះជាម្ចាស់ គឺជាភស្តុតាង។

កាលដើមដំបូងឡើយ ការដឹកនាំមនុស្ស ក្នុងអំឡុងយុគសម័យនៃក្រឹត្យវិន័យនៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺដូចជាការដឹកនាំជីវិតរបស់កូនម្នាក់ដែរ។ មនុស្សជាតិកាលដើមដំបូងឡើយ គឺជាកូនដែលទើបកើតរបស់ព្រះយេហូវ៉ា។ ពួកគេ គឺជាពួកសាសន៍អ៊ីស្រាអែល។ ពួកគេគ្មានការយល់ដឹងថាតើត្រូវគោរពព្រះជាម្ចាស់ ឬថាតើត្រូវរស់នៅលើផែនដីនេះដោយរបៀបណានោះទេ។ នេះចង់មានន័យថា ព្រះយេហូវ៉ាបានបង្កើតមនុស្សជាតិមក ពោលគឺទ្រង់បានបង្កើតអ័ដាម និងអេវ៉ា ប៉ុន្តែទ្រង់មិនបានប្រទានសមត្ថភាពដល់ពួកគេឲ្យយល់ថាតើត្រូវគោរពព្រះយេហូវ៉ា ឬដើរតាមក្រឹត្យវិន័យរបស់ព្រះយេហូវ៉ានៅលើផែនដីនេះ ដោយរបៀបណានោះទេ។ បើគ្មានការណែនាំដោយផ្ទាល់ពីព្រះយេហូវ៉ាទេ គ្មាននរណាម្នាក់ អាចដឹងរឿងនេះដោយផ្ទាល់បានទេ ដ្បិតកាលដើមដំបូងឡើយ មនុស្សមិនមានសមត្ថភាពបែបនោះទេ។ មនុស្សគ្រាន់តែដឹងថា ព្រះយេហូវ៉ាគឺជាព្រះជាម្ចាស់ ប៉ុន្តែថាតើត្រូវគោរពទ្រង់ដោយរបៀបណានោះ ថាការប្រព្រឹត្តបែបណាជាការគោរពទ្រង់នោះ ថាចិត្តបែបណាដែលមនុស្សម្នាក់រាប់ថាគោរពទ្រង់ ឬអ្វីដែលត្រូវលះបង់នៅក្នុងការគោរពទ្រង់នោះ គឺមនុស្សគ្មានដឹងអ្វីទាល់តែសោះ។ មនុស្សគ្រាន់តែដឹងថា ត្រូវអរសប្បាយនឹងរបស់សព្វសារពើដែលព្រះយេហូវ៉ាបានបង្កើតមកប៉ុណ្ណោះ ប៉ុន្តែតើជីវិតនៅលើផែនដីបែបណាដែលមានតម្លៃសម្រាប់សត្តនិកររបស់ព្រះជាម្ចាស់នោះ គឺមនុស្សគ្មានដឹងអ្វីទាល់តែសោះ។ បើគ្មាននរណាម្នាក់ណែនាំពួកគេទេ បើគ្មាននរណាម្នាក់ដឹកនាំផ្លូវពួកគេដោយផ្ទាល់ទេ មនុស្សជាតិនឹងមិនអាចដឹកនាំជីវិតបានត្រឹមត្រូវឲ្យសមនឹងភាពមនុស្សឡើយ ប៉ុន្តែគ្រាន់តែត្រូវបានសាតាំងចាប់ជាចំណាប់ខ្មាំង ដោយលាក់លៀមតែប៉ុណ្ណោះ។ ព្រះយេហូវ៉ាបានបង្កើតមនុស្សជាតិមក ពោលគឺទ្រង់បានបង្កើតដូនតារបស់មនុស្សជាតិ គឺអ័ដាម និងអេវ៉ា ប៉ុន្តែទ្រង់មិនបានប្រទានប្រាជ្ញា និងភាពឈ្លៀសវៃដល់ពួកគេបន្ថែមទៀតឡើយ។ ថ្វីបីពួកគេបានរស់នៅលើផែនដីនេះរួចហើយក៏ពិតមែន ប៉ុន្តែពួកគេមិនបានយល់ដឹងអ្វីទាល់តែសោះ។ ហេតុដូច្នេះហើយ កិច្ចការរបស់ព្រះយេហូវ៉ាក្នុង

ការបង្កើតមនុស្សជាតិ គឺបានបញ្ចប់ត្រឹមពាក់កណ្ដាលប៉ុណ្ណោះ ហើយនៅឆ្ងាយពីទីបញ្ចប់នៅឡើយ។ ទ្រង់គ្រាន់តែបានសូនរូបមនុស្សចេញពីដីឥដ្ឋ និងបានប្រទានខ្យល់ដង្ហើមជីវិត ប៉ុន្តែ មិនបានប្រទានចេតនាគោរពព្រះជាម្ចាស់ឲ្យបានគ្រប់គ្រាន់នោះទេ។ កាលដើមដំបូងឡើយ មនុស្សគ្មានគំនិតគោរពទ្រង់ ឬកោតខ្លាចទ្រង់ឡើយ។ មនុស្សដឹងត្រឹមថាត្រូវស្ដាប់ព្រះបន្ទូលរបស់ទ្រង់ប៉ុណ្ណោះ ប៉ុន្តែល្ងង់ខ្លៅគ្មានចំណេះដឹងជាមូលដ្ឋានសម្រាប់ជីវិតនៅលើផែនដី និងច្បាប់ធម្មតានៃជីវិតរបស់មនុស្សឡើយ។ ហេតុដូច្នេះហើយ បើទោះបីជាព្រះយេហូវ៉ាបានបង្កើតមនុស្សប្រុស និងមនុស្សស្រី និងបានបញ្ចប់កិច្ចការក្នុងពេលប្រាំពីរថ្ងៃក្ដី ក៏ពុំមានន័យថា ទ្រង់បានបញ្ចប់កិច្ចការនៃការបង្កើតមនុស្សដែរ ដ្បិតមនុស្សមានតែសំបក និងខ្វះខាតភាពពិតនៃការធ្វើជាមនុស្ស។ មនុស្សគ្រាន់តែដឹងថា គឺព្រះយេហូវ៉ានេះហើយដែលបានបង្កើតមនុស្សជាតិមក ប៉ុន្តែគេមិនដឹងថាតើត្រូវគោរពតាមព្រះបន្ទូល ឬក្រឹត្យវិន័យរបស់ព្រះយេហូវ៉ាដោយរបៀបណានោះទេ។ ដូច្នេះហើយក្រោយពីមនុស្សជាតិមានជីវិត កិច្ចការរបស់ព្រះយេហូវ៉ានៅឆ្ងាយពីទីបញ្ចប់នៅឡើយទេ។ ទ្រង់នៅតែដឹកនាំមនុស្សជាតិដោយពេញលេញដើម្បីឲ្យគេមកចំពោះទ្រង់ ដើម្បីឲ្យពួកគេអាចរស់នៅរួមគ្នានៅលើផែនដី និងគោរពទ្រង់ និងដើម្បីឲ្យពួកគេអាចចូលទៅក្នុងផ្លូវដែលត្រឹមត្រូវនៃជីវិតជាមនុស្សធម្មតានៅលើផែនដីតាមរយៈការណែនាំរបស់ទ្រង់។ មានតែបែបនេះទេទើបកិច្ចការដែលត្រូវធ្វើឡើងជាគោលការណ៍ក្រោមព្រះនាមរបស់ព្រះយេហូវ៉ាអាចបញ្ចប់ទៅបានទាំងស្រុង ពោលគឺមានតែបែបនេះទេ ទើបកិច្ចការរបស់ព្រះយេហូវ៉ាក្នុងការបង្កើតពិភពលោកនេះបានបញ្ចប់ទាំងស្រុង។ ដូច្នេះហើយ បន្ទាប់ពីបានបង្កើតមនុស្សជាតិមក ទ្រង់ត្រូវដឹកនាំជីវិតមនុស្សជាតិនៅលើផែនដី អស់រយៈពេលជាច្រើនពាន់ឆ្នាំ ដើម្បីឲ្យមនុស្សជាតិអាចគោរពតាមបញ្ញត្តិ និងក្រឹត្យវិន័យ ហើយចូលរួមនៅក្នុងគ្រប់សកម្មភាពទាំងអស់នៃជីវិតជាមនុស្សធម្មតានៅលើផែនដី។ មានតែពេលនោះទេដែលកិច្ចការរបស់ព្រះយេហូវ៉ា ត្រូវបានបញ្ចប់ទាំងស្រុង។ ទ្រង់បានបំពេញកិច្ចការនេះក្រោយពេលបង្កើតមនុស្សជាតិមក និងបានបន្តកិច្ចការនេះរហូតដល់សម័យយ៉ាកុប

នៅពេលនោះទ្រង់បានធ្វើឲ្យកូនប្រុសទាំងដប់ពីរនាក់របស់យ៉ាកុបក្លាយទៅជាកុលសម្ព័ន្ធទាំងដប់ពីររបស់អ៊ីស្រាអែល។ ចាប់ពីនោះមក រាស្ត្រអ៊ីស្រាអែលទាំងអស់សុទ្ធតែក្លាយជាពូជមនុស្សដែលត្រូវទ្រង់ដឹកនាំជាផ្លូវការនៅលើផែនដី ហើយស្រុកអ៊ីស្រាអែលបានក្លាយជាទីតាំងជាក់លាក់មួយនៅលើផែនដីដែលទ្រង់បានបំពេញកិច្ចការរបស់ទ្រង់។ ព្រះយេហូវ៉ាបានធ្វើឲ្យមនុស្សទាំងនេះក្លាយជាក្រុមមនុស្សដំបូងគេដែលទ្រង់បានបំពេញកិច្ចការរបស់ទ្រង់ជាផ្លូវការនៅលើផែនដី ហើយទ្រង់នឹងធ្វើឲ្យដែនដីអ៊ីស្រាអែលទាំងមូលក្លាយជាប្រភពដើមសម្រាប់កិច្ចការរបស់ទ្រង់ ដោយប្រើពួកគេជាចំណុចចាប់ផ្ដើមនៃកិច្ចការកាន់តែធំ ដើម្បីឲ្យមនុស្សទាំងអស់ដែលកើតចេញពីទ្រង់នៅលើផែនដី នឹងដឹងថាតើត្រូវគោរព និងត្រូវរស់នៅលើផែនដីនេះ ដោយរបៀបណា។ ដូច្នេះហើយទង្វើរបស់ពួកសាសន៍អ៊ីស្រាអែល បានក្លាយជាឧទាហរណ៍សម្រាប់ឲ្យរាស្ត្រនៃជាតិសាសន៍ដទៃយកគំរូតាមបាន ហើយព្រះបន្ទូលដែលបានសម្ដែងឡើងក្នុងចំណោមរាស្ត្រអ៊ីស្រាអែល បានក្លាយជាព្រះបន្ទូលដែលត្រូវរាស្ត្រនៃជាតិសាសន៍ដទៃស្ដាប់តាម។ ដ្បិតពួកគេគឺជាមនុស្សដំបូងគេ ដែលត្រូវទទួលក្រឹត្យវិន័យ និងបញ្ញត្តិរបស់ព្រះយេហូវ៉ា ហើយពួកគេក៏ជាមនុស្សដំបូងគេដែលដឹងថាត្រូវគោរពផ្លូវ របស់ព្រះយេហូវ៉ាដោយរបៀបណា។ ពួកគេគឺជាដូនតារបស់ពូជមនុស្ស ដែលបានដឹងពីផ្លូវរបស់ព្រះយេហូវ៉ា ក៏ជាតំណាងរបស់ពូជមនុស្សរើសតាំងដោយព្រះយេហូវ៉ាដែរ។ នៅពេលដែលយុគសម័យនៃព្រះគុណ បានចូលមកដល់ព្រះយេហូវ៉ាលែងដឹកនាំមនុស្សដោយបែបនេះទៀតហើយ។ មនុស្សមានអំពើបាប ហើយបានលះបង់ខ្លួនគេក្នុងអំពើបាប ដូច្នេះហើយ ទ្រង់បានចាប់ផ្ដើមស្រោចស្រង់មនុស្សឲ្យរួចពីអំពើបាប។ តាមរបៀបនេះ ទ្រង់បានស្ដីបន្ទោសមនុស្សរហូតដល់មនុស្សត្រូវបានរំដោះពីអំពើបាបទាំងស្រុង។ នៅគ្រាចុងក្រោយ មនុស្សបានលេចចូលក្នុងភាពគ្មានសីលធម៌យ៉ាងខ្លាំង ដែលកិច្ចការនៅក្នុងដំណាក់កាលនេះ អាចអនុវត្តបានតាមរយៈការជំនុំជម្រះ និងការវាយផ្ចាលតែប៉ុណ្ណោះ។ មានតែបែបនេះទេទើបកិច្ចការនេះអាចសម្រេចជោគជ័យបាន។ នេះគឺជាកិច្ចការនៅក្នុងយុគសម័យជាច្រើន។

អាចនិយាយម៉្យាងទៀតបានថា ព្រះជាម្ចាស់ប្រើព្រះនាមរបស់ទ្រង់ កិច្ចការរបស់ទ្រង់ និងរូបអង្គរបស់ព្រះជាម្ចាស់ខុសៗគ្នា ដើម្បីញែកយុគសម័យមួយចេញពីយុគសម័យមួយទៀត និងធ្វើការផ្លាស់ប្ដូរវាក្នុងយុគសម័យទាំងអស់នោះ។ ព្រះនាមរបស់ព្រះជាម្ចាស់ និងកិច្ចការទ្រង់ តំណាងឲ្យយុគសម័យរបស់ទ្រង់ និងតំណាងឲ្យកិច្ចការរបស់ទ្រង់នៅគ្រប់យុគសម័យទាំងអស់។ ឧបមាថា កិច្ចការរបស់ព្រះជាម្ចាស់នៅគ្រប់យុគសម័យនេះ គឺតែងតែដូចគ្នា ហើយទ្រង់គឺតែងតែត្រូវគេហៅដោយព្រះនាមដូចគ្នា តើមនុស្សអាចនឹងស្គាល់ទ្រង់បានដោយរបៀបណា? ព្រះជាម្ចាស់ត្រូវគេហៅថាព្រះយេហូវ៉ា ហើយក្រៅពីព្រះជាម្ចាស់ដែលត្រូវគេហៅថាព្រះយេហូវ៉ានោះ នរណាក៏ដោយដែលត្រូវគេហៅដោយឈ្មោះទីទៃពីនេះ មិនមែនជាព្រះជាម្ចាស់ឡើយ។ ឬបើពុំដូច្នោះទេ ព្រះជាម្ចាស់អាចត្រឹមជាព្រះយេស៊ូវ ហើយក្រៅពីព្រះនាមរបស់ព្រះយេស៊ូវ ទ្រង់មិនអាចមិនត្រូវបានគេហៅ ដោយព្រះនាមដទៃទៀតឡើយ។ ក្រៅពីព្រះយេស៊ូវ ព្រះយេហូវ៉ា គឺមិនមែនជាព្រះជាម្ចាស់ឡើយ ហើយព្រះដ៏មានគ្រប់ព្រះចេស្ដាក៏មិនមែនជាព្រះជាម្ចាស់ដែរ។ មនុស្សជឿថា វាពិតប្រាកដហើយដែលព្រះជាម្ចាស់មានគ្រប់ព្រះចេស្ដានោះ ប៉ុន្ដែព្រះជាម្ចាស់ គឺជាព្រះជាម្ចាស់ដែលគង់នៅក្នុងចំណោមមនុស្ស ហើយទ្រង់ត្រូវគេហៅថាព្រះយេស៊ូវ ដ្បិតព្រះជាម្ចាស់គឺគង់នៅជាមួយមនុស្ស។ ការគិតបែបនេះ គឺស្របទៅតាមគោលលទ្ធិ និងបានកំណត់ព្រះជាម្ចាស់ក្នុងកម្រិតជាក់លាក់មួយ។ ដូច្នេះ នៅគ្រប់ដំណាក់កាលទាំងអស់ កិច្ចការដែលព្រះជាម្ចាស់បំពេញ ព្រះនាមដែលគេហៅទ្រង់ និងរូបអង្គដែលទ្រង់ប្រើ កិច្ចការដែលទ្រង់បំពេញនៅគ្រប់ដំណាក់កាលតាំងពីដើមរហូតដល់បច្ចុប្បន្ន គឺចំណុចទាំងអស់នេះមិនអនុវត្តតាមបញ្ញត្តិតែមួយ និងមិនស្ថិតនៅក្រោមដែនកំណត់ណាមួយឡើយ។ ទ្រង់គឺជាព្រះយេហូវ៉ា ប៉ុន្ដែទ្រង់ក៏ជាព្រះយេស៊ូវដែរ ហើយក៏ជាព្រះមែស៊ី និងជាព្រះដ៏មានគ្រប់ព្រះចេស្ដាដែរ។ កិច្ចការរបស់ទ្រង់អាចឆ្លងកាត់ការបំផ្លាស់បំប្រែបន្ដិចម្ដងៗ ដោយមានការផ្លាស់ប្ដូរទៅតាមព្រះនាមរបស់ទ្រង់។ គ្មានព្រះនាមណាមួយដែលអាចតំណាងដល់ទ្រង់ដោយពេញលេញបានឡើយ ប៉ុន្ដែគ្រប់ព្រះនាមទាំងអស់ដែលគេហៅទ្រង់ សុទ្ធតែអាចតំណាងឲ្យ

ទ្រង់បាន ហើយកិច្ចការដែលទ្រង់បំពេញនៅគ្រប់ដំណាក់កាល សុទ្ធតែតំណាងឲ្យនិស្ស័យរបស់ទ្រង់។ ឧបមាថា នៅពេលដែលគ្រាចុងក្រោយមកដល់ ព្រះជាម្ចាស់ដែលអ្នកមើលឃើញ គឺនៅតែជាព្រះយេស៊ូវដដែល ហើយបន្ថែមលើនេះ ទ្រង់កំពុងគង់លើដុំពពកស ហើយទ្រង់នៅតែលេចមកក្នុងរូបអង្គរបស់ព្រះយេស៊ូវដដែល ហើយព្រះបន្ទូលដែលទ្រង់ថ្លែង គឺនៅតែជាព្រះបន្ទូលរបស់ព្រះយេស៊ូវដដែល៖ «អ្នករាល់គ្នាគប្បីស្រឡាញ់អ្នកជិតខាងខ្លួនឲ្យដូចជាខ្លួនអ្នក អ្នកគប្បីត្រូវតមអាហារ និងអធិស្ឋានស្រឡាញ់ខ្មាំងសត្រូវរបស់អ្នកឲ្យដូចជាអ្នកអរសប្បាយនឹងជីវិតផ្ទាល់ខ្លួនរបស់អ្នក អត់ទ្រាំជាមួយអ្នកដទៃ និងចេះអត់ធ្មត់ ហើយបន្ទាបខ្លួន។ អ្នករាល់គ្នាត្រូវតែធ្វើរឿងទាំងអស់នេះនៅមុនពេលដែលអ្នកអាចក្លាយជាសិស្សរបស់ខ្ញុំ។ ហើយតាមរយៈការធ្វើបែបនេះ ទើបអ្នកអាចចូលទៅក្នុងនគររបស់ខ្ញុំបាន»។ តើនេះនឹងក្លាយជាកម្មសិទ្ធិនៃកិច្ចការ នៅក្នុងយុគសម័យនៃព្រះគុណមែនទេ? តើអ្វីដែលទ្រង់មានព្រះបន្ទូលនឹងមិនមែនជាផ្លូវនៃយុគសម័យនៃព្រះគុណទេឬអី? តើអ្នកនឹងមានអារម្មណ៍បែបណា ប្រសិនបើអ្នករាល់គ្នាស្ដាប់ឮព្រះបន្ទូលទាំងអស់នេះ? តើអ្នកនឹងមិនមានអារម្មណ៍ថា នេះនៅតែជាកិច្ចការរបស់ព្រះយេស៊ូវមែនទេ? តើនេះនឹងមិនមែនជាការបំពេញកិច្ចការជាន់គ្នាទេមែនទេ? តើមនុស្សអាចស្វែងរកសេចក្ដីអរសប្បាយនៅក្នុងនេះបានដែរឬទេ? អ្នករាល់គ្នានឹងមានអារម្មណ៍ថា កិច្ចការរបស់ព្រះជាម្ចាស់អាចបន្តទៅបានតែនៅក្នុងពេលនេះប៉ុណ្ណោះ និងគ្មានការចម្រើនទៅមុខឡើយ។ ទ្រង់មានព្រះចេស្ដាយ៉ាងខ្លាំង ហើយគ្មានកិច្ចការថ្មីណាត្រូវបំពេញនោះទេ ហើយទ្រង់បានប្រើព្រះចេស្ដារបស់ទ្រង់ដល់កំណត់របស់វាហើយ។ ពីរបាន់ឆ្នាំមុនពេលនេះ គឺជាយុគសម័យនៃព្រះគុណ ហើយពីរពាន់ឆ្នាំក្រោយ ទ្រង់គឺនៅតែប្រៀនប្រដៅអំពីផ្លូវនៃយុគសម័យនៃព្រះគុណ និងនៅតែត្រូវធ្វើឲ្យមនុស្សមានការប្រែចិត្តដដែល។ មនុស្សនឹងនិយាយថា៖ «ឱ ព្រះជាម្ចាស់អើយ! ទ្រង់មានព្រះចេស្ដាខ្លាំងដល់ម្ល៉េះ។ ទូលបង្គំជឿថាទ្រង់មានព្រះប្រាជ្ញាញាណខ្លាំងណាស់ ក៏ប៉ុន្តែទ្រង់ជ្រាបត្រឹមការអត់ទ្រាំ និងខ្វល់ខ្វាយត្រឹមតែការអត់ធ្មត់ប៉ុណ្ណោះ។ ទ្រង់គ្រាន់តែជ្រាបថាត្រូវស្រឡាញ់សត្រូវរបស់ទ្រង់ដោយបែបណាប៉ុណ្ណោះ

ហើយទ្រង់មិនជ្រាបពីអ្វីផ្សេងទៀតឡើយ»។ នៅក្នុងគំនិតរបស់មនុស្ស ព្រះជាម្ចាស់នឹងមានលក្ខណៈដូចកាលនៅក្នុងយុគសម័យនៃព្រះគុណជារៀងរហូត ហើយមនុស្សនឹងតែងតែជឿថា ព្រះជាម្ចាស់គឺគួរឲ្យស្រឡាញ់ និងមានព្រះហឫទ័យក្តួលអាណិត។ តើអ្នកគិតថាកិច្ចការរបស់ព្រះជាម្ចាស់ នឹងតែងតែច្រំដែលជានិច្ចមែនទេ? ដូច្នេះហើយនៅក្នុងដំណាក់កាលនៃកិច្ចការរបស់ទ្រង់ ទ្រង់នឹងមិនត្រូវគេឆ្កាងឡើយ ហើយគ្រប់ការទាំងអស់ដែលអ្នករាល់គ្នាឃើញ និងប៉ះពាល់ នឹងមិនដូចជាអ្វីៗគ្រប់យ៉ាងដែលអ្នករាល់គ្នាបានស្រមៃ ឬបានស្ដាប់ឮគេនិយាយនោះទេ។ សព្វថ្ងៃនេះ ព្រះជាម្ចាស់មិនបានពាក់ព័ន្ធនឹងពួកផារីស៊ីឡើយ ហើយទ្រង់ក៏មិនបានឲ្យពិភពលោកដឹងដែរ ហើយអស់អ្នកដែលស្គាល់ទ្រង់ គឺជាអ្នករាល់គ្នាដែលដើរតាមទ្រង់នេះហើយ ដ្បិតទ្រង់នឹងមិនត្រូវគេឆ្កាងជាថ្មីម្ដងទៀតឡើយ។ ក្នុងអំឡុងយុគសម័យនៃព្រះគុណ ព្រះយេស៊ូវបានបង្រៀនដោយបើកចំហនៅទូទាំងដែនដីទាំងមូល ដើម្បីជាប្រយោជន៍ដល់កិច្ចការផ្សាយដំណឹងល្អរបស់ទ្រង់។ ទ្រង់បានពាក់ព័ន្ធនឹងពួកផារីស៊ីដើម្បីជាប្រយោជន៍ដល់កិច្ចការនៃការជាប់ឆ្កាង។ ប្រសិនបើទ្រង់មិនបានពាក់ព័ន្ធនឹងពួកផារីស៊ី និងអ្នកកាន់អំណាចដែលមិនបានស្គាល់ទ្រង់ទេ តើទ្រង់អាចត្រូវបានគេថ្កោលទោស ហើយបន្ទាប់មក ត្រូវគេក្បត់ និងបោះទ្រង់ភ្ជាប់ទៅនឹងឈើឆ្កាង យ៉ាងដូចម្ដេចកើតទៅ? ដូច្នេះហើយ ទ្រង់បានពាក់ព័ន្ធនឹងពួកផារីស៊ី ដើម្បីជាប្រយោជន៍ដល់កិច្ចការនៃការជាប់ឆ្កាងនេះ។ សព្វថ្ងៃនេះ ទ្រង់បំពេញកិច្ចការរបស់ទ្រង់ដោយសម្ងាត់ ដើម្បីជៀសវាងពីសេចក្តីល្បួង។ នៅក្នុងការយកកំណើតជាមនុស្សចំនួនពីរដងរបស់ព្រះជាម្ចាស់ កិច្ចការ និងសារៈសំខាន់គឺខុសគ្នា ហើយកាលអាកាសក៏ខុសគ្នាដែរ ដូច្នេះ តើកិច្ចការដែលទ្រង់បំពេញអាចដូចគ្នាទាំងស្រុងបានដោយរបៀបណា?

តើព្រះនាមរបស់ព្រះយេស៊ូវ ដែលថា «ព្រះអង្គគង់ជាមួយនឹងយើងខ្ញុំ» តំណាងឲ្យនិស្ស័យរបស់ព្រះជាម្ចាស់ទាំងស្រុងមែនទេ? តើវាអាចបង្ហាញពីព្រះជាម្ចាស់បានទាំងស្រុងដែរឬទេ? ប្រសិនបើមនុស្សនិយាយថា ព្រះជាម្ចាស់អាចត្រឹមហៅថាព្រះយេស៊ូវ និងមិនមានព្រះនាមអ្វីផ្សេង ដោយសារព្រះជាម្ចាស់មិនអាចផ្លាស់ប្ដូរនិស្ស័យ

របស់ទ្រង់បាន ព្រះបន្ទូលទាំងអស់នេះ គឺជាការប្រមាថដ៏ធ្ងន់ធ្ងរខ្លាំងណាស់! តើអ្នកជឿថា ព្រះនាមព្រះយេស៊ូវ គឺព្រះអង្គគង់ជាមួយនឹងយើងខ្ញុំ តែមួយមុខនេះអាចតំណាងឲ្យព្រះជាម្ចាស់ទាំងស្រុងបានដែរឬទេ? ព្រះជាម្ចាស់អាចត្រូវបានគេហៅដោយព្រះនាមជាច្រើន ប៉ុន្តែក្នុងចំណោមព្រះនាមទាំងអស់នេះ គ្មានព្រះនាមណាមួយដែលអាចគេចផុតពីព្រះជាម្ចាស់ឡើយ គ្មានព្រះនាមណាមួយ អាចតំណាងឲ្យព្រះជាម្ចាស់ដោយពេញលេញនោះទេ។ ដូច្នេះហើយ ព្រះជាម្ចាស់មានព្រះនាមជាច្រើន ប៉ុន្តែព្រះនាមទាំងអស់នេះ មិនអាចសម្ដែងចេញពីនិស្ស័យរបស់ព្រះជាម្ចាស់ដោយពេញលេញឡើយ ដ្បិតនិស្ស័យរបស់ព្រះជាម្ចាស់ គឺសម្បូរបែបលើសពីសមត្ថភាពដែលមនុស្សអាចស្គាល់ទ្រង់បាន។ ការប្រើភាសារបស់មនុស្សជាតិ មិនគ្រប់គ្រាន់ដើម្បីបង្ហាញពីព្រះជាម្ចាស់ឲ្យបានពេញលេញនោះទេ។ មនុស្សជាតិគ្មានអ្វីក្រៅពីពាក្យសម្ដីបន្តិចបន្តួចដើម្បីបង្ហាញពីអ្វីទាំងអស់ ដែលពួកគេដឹងអំពីនិស្ស័យរបស់ព្រះជាម្ចាស់នោះឡើយ ដូចជាពាក្យថា៖ មហិមា កិត្តិយស អស្ចារ្យ មិនអាចយល់បាន ឧត្តុង្គឧត្តម បរិសុទ្ធ សុចរិត ឈ្លាសវៃ និងពាក្យដទៃផ្សេងទៀត។ មានពាក្យជាច្រើនខ្លាំងណាស់! ពាក្យបន្តិចបន្តួចនេះ មិនអាចរៀបរាប់សូម្បីតែនិស្ស័យរបស់ព្រះជាម្ចាស់ដែលមនុស្សបានដឹងដ៏តិចតួចក្តី។ ពេលកន្លងមក អ្នកដទៃទៀតបានបន្ថែមពាក្យពេចន៍ដែលពួកគេបានគិតថា អាចរៀបរាប់បានកាន់តែប្រសើរអំពីភាពឆេះឆួលដែលនៅក្នុងដួងចិត្តរបស់ពួកគេដូចជាពាក្យដែលថា៖ ព្រះជាម្ចាស់មហិមាខ្លាំងណាស់! ព្រះជាម្ចាស់បរិសុទ្ធខ្លាំងណាស់! ព្រះជាម្ចាស់គួរឲ្យស្រឡាញ់ខ្លាំងណាស់! សព្វថ្ងៃ ការនិយាយរបស់មនុស្សបែបនេះបានដល់កម្រិតកំពូលហើយ ក៏ប៉ុន្តែមនុស្សនៅតែមិនអាចសម្ដែងពីខ្លួនអ្នកឲ្យបានច្បាស់នៅឡើយ។ ដូច្នេះហើយ សម្រាប់មនុស្ស ព្រះជាម្ចាស់មានព្រះនាមជាច្រើន ទ្រង់មិនមែនមានតែព្រះនាមមួយទេ នេះគឺដោយសារសភាវៈរបស់ព្រះជាម្ចាស់ គឺសម្បូរបែបខ្លាំងណាស់ ហើយភាសារបស់មនុស្ស គឺមិនទាន់គ្រប់គ្រាន់នៅឡើយទេ។ ពាក្យមួយម៉ាត់ ឬព្រះនាមមួយពុំអាចតំណាងឲ្យព្រះជាម្ចាស់ទាំងស្រុងបានទេ ដូច្នេះ តើអ្នកគិតថាព្រះនាមរបស់ទ្រង់អាចមិនប្រែប្រួលដែរទេ? ព្រះជាម្ចាស់

មហិមា និងបរិសុទ្ធខ្លាំងណាស់ ក៏ប៉ុន្តែតើអ្នកនឹងមិនអនុញ្ញាតឲ្យទ្រង់ផ្លាស់ប្ដូរព្រះនាមរបស់ទ្រង់នៅក្នុងយុគសម័យថ្មីទេឬ? ហេតុនេះ នៅគ្រប់យុគសម័យដែលព្រះជាម្ចាស់បំពេញនូវកិច្ចការរបស់ទ្រង់ដោយផ្ទាល់ព្រះអង្គ គឺទ្រង់ប្រើព្រះនាមមួយ ដែលស័ក្តិសមនឹងយុគសម័យនោះ ដើម្បីបង្ហាញពីកិច្ចការដែលទ្រង់សព្វព្រះហឫទ័យចង់ធ្វើ។ ទ្រង់ប្រើព្រះនាមនេះ ជាព្រះនាមមួយដែលមានលក្ខណៈសំខាន់បណ្ដោះអាសន្ន ដើម្បីតំណាងឲ្យនិស្ស័យរបស់ទ្រង់នៅក្នុងយុគសម័យនោះ។ នេះគឺជាព្រះជាម្ចាស់ដែលប្រើភាសាមនុស្សជាតិដើម្បីបើកសម្ដែងពីនិស្ស័យផ្ទាល់របស់ទ្រង់។ បើទោះបីជាដូច្នេះក្ដី មនុស្សជាច្រើនដែលធ្លាប់មានបទពិសោធខាងវិញ្ញាណ និងធ្លាប់បានឃើញព្រះជាម្ចាស់ដោយផ្ទាល់ក្ដី ក៏នៅតែមានអារម្មណ៍ថា ព្រះនាមមួយនេះមិនអាចតំណាងឲ្យព្រះជាម្ចាស់បានទាំងស្រុងទេ។ វរហើយ! រឿងនេះមិនអាចជួយបានទេ ដូច្នេះមនុស្សលែងហៅព្រះជាម្ចាស់ដោយព្រះនាមរបស់ទ្រង់តទៅទៀតហើយ ប៉ុន្តែហៅទ្រង់ត្រឹមថា «ព្រះជាម្ចាស់» ប៉ុណ្ណោះ។ ដួងចិត្តរបស់មនុស្ស ហាក់ដូចជាពោរពេញដោយសេចក្តីស្រឡាញ់ ក៏ប៉ុន្តែក៏មានជាប់ពាក់ព័ន្ធនឹងការជំទាស់ដែរ ដ្បិតមនុស្សពុំបានដឹងថាតើត្រូវពន្យល់អំពីព្រះជាម្ចាស់ដោយរបៀបណានោះទេ។ លក្ខណៈរបស់ព្រះជាម្ចាស់សម្បូរបែបខ្លាំងរហូតដល់គ្មានវិធីណាដែលអាចរៀបរាប់បានឡើយ។ គ្មានព្រះនាមណាមួយដែលអាចសង្ខេបពីនិស្ស័យរបស់ព្រះជាម្ចាស់បាននោះឡើយ ហើយគ្មានព្រះនាមណាមួយដែលអាចរៀបរាប់ពីគ្រប់កម្មសិទ្ធិ និងលក្ខណៈរបស់ព្រះជាម្ចាស់បានឡើយ។ ប្រសិនបើនរណាម្នាក់សួរខ្ញុំថា៖ «តើទ្រង់ប្រើព្រះនាមអ្វីឲ្យប្រាកដ?» ខ្ញុំនឹងនិយាយប្រាប់ពួកគេថា៖ «ព្រះជាម្ចាស់ គឺជាព្រះជាម្ចាស់!» តើនេះមិនមែនជាព្រះនាមដ៏ល្អបំផុតសម្រាប់ព្រះជាម្ចាស់ទេឬអី? តើនេះមិនមែនជាការបង្ហាញពីនិស្ស័យរបស់ព្រះជាម្ចាស់ទេឬអី? រឿងគឺបែបនេះហើយ តើហេតុអ្វីបានជាអ្នករាល់គ្នាខំប្រឹងស្វែងរកព្រះនាមរបស់ព្រះជាម្ចាស់ខ្លាំងយ៉ាងនេះ? តើហេតុអ្វីអ្នកត្រូវប្រើខួរក្បាលរបស់អ្នក ដោយគ្មានបានហូបចុក និងដេកពួន ដើម្បីតែជាប្រយោជន៍ដល់ព្រះនាមមួយបែបនេះ? ថ្ងៃនោះនឹងចូលមកដល់ នៅពេលដែលព្រះជាម្ចាស់លែងត្រូវ

បានគេហៅថា ព្រះយេហូវ៉ា ព្រះយេស៊ូវ ឬព្រះមែស៊ីតទៅទៀត គឺទ្រង់នឹងត្រូវគេហៅត្រឹមថា ព្រះអាទិករ។ នៅពេលនោះ គ្រប់ព្រះនាមទាំងអស់ដែលទ្រង់បានដាក់នៅលើផែនដី នឹងត្រូវចូលដល់ទីបញ្ចប់ ដ្បិតកិច្ចការរបស់ទ្រង់នៅលើផែនដីនឹងត្រូវចូលដល់ទីបញ្ចប់ ក្រោយពេលដែលព្រះនាមរបស់ទ្រង់លែងមានទៀត។ នៅពេលដែលគ្រប់យ៉ាងទាំងអស់មកនៅក្រោមអំណាចត្រួតត្រារបស់ព្រះអាទិករ តើចាំបាច់អ្វីដែលទ្រង់ត្រូវការព្រះនាម សមស្របតែមិនពេញលេញបែបនេះធ្វើអ្វី? តើអ្នកនឹងនៅតែបន្តស្វែងរកព្រះនាមរបស់ព្រះជាម្ចាស់ក្នុងពេលនេះទៀតដែរឬទេ? តើអ្នកនៅតែហ៊ាននិយាយថា ព្រះជាម្ចាស់គឺនៅតែត្រូវបានហៅថា ព្រះយេហូវ៉ា តែមួយប៉ុណ្ណោះទៀតមែនទេ? តើអ្នកនៅតែហ៊ាននិយាយថា ព្រះជាម្ចាស់អាចត្រូវហៅត្រឹម ព្រះយេស៊ូវ តែមួយប៉ុណ្ណោះមែនទេ? តើអ្នកអាចទូលរ៉ែកបាបនៃការប្រមាថចំពោះព្រះជាម្ចាស់បានដែរឬទេ? អ្នកគប្បីដឹងថា កាលពីដើមដំបូង ព្រះជាម្ចាស់គ្មានព្រះនាមអ្វីទេ។ ទ្រង់គ្រាន់តែមានព្រះនាមមួយ ឬពីរ ឬច្រើន ដោយសារតែទ្រង់មានកិច្ចការត្រូវបំពេញ និងត្រូវគ្រប់គ្រងមនុស្សជាតិប៉ុណ្ណោះ។ មិនថាគេហៅព្រះនាមទ្រង់បែបណានោះទេ តើទ្រង់មិនជ្រើសយកព្រះនាមនោះ ដោយផ្ទាល់ព្រះអង្គទេមែនទេ? តើទ្រង់ត្រូវការឲ្យអ្នកដែលជាសត្តនិករមួយ ដែលទ្រង់បានបង្កើតមកនោះ រៀបរាប់អំពីព្រះនាមនោះដែរឬទេ? ព្រះនាមដែលគេហៅព្រះជាម្ចាស់ គឺជាព្រះនាមមួយដែលស្របនឹងអ្វីដែលមនុស្សអាចយល់ដឹងបាន ស្របតាមភាសារបស់មនុស្សជាតិ ប៉ុន្តែព្រះនាមនេះ គឺមិនមែនជាព្រះនាមដែលមនុស្សអាចសង្ខេបរួមបានទេ។ អ្នកអាចនិយាយបានត្រឹមថា មានព្រះជាម្ចាស់គង់នៅលើស្ថានសួគ៌ ថាទ្រង់ត្រូវគេហៅថា ព្រះជាម្ចាស់ ថាទ្រង់គឺជាព្រះជាម្ចាស់ផ្ទាល់ព្រះអង្គដែលមានព្រះចេស្ដាខ្លាំងពូកែ ដែលមានព្រះប្រាជ្ញាញាណអស្ចារ្យ ខ្ពង់ខ្ពស់ អស្ចារ្យ និងអាថ៌កំបាំងយ៉ាងខ្លាំង និងមានព្រះចេស្ដាអស្ចារ្យ ហេតុដូច្នេះហើយ អ្នកមិនអាចនិយាយអ្វីបានឡើយ ហើយអ្នកទាំងគ្នាអាចដឹងបាន តែបន្តិចបន្តួចនេះប៉ុណ្ណោះ។ រឿងគឺបែបនេះហើយ តើព្រះនាមព្រះយេស៊ូវអាចតំណាងឲ្យព្រះជាម្ចាស់ផ្ទាល់ព្រះអង្គមែនទេ? នៅពេលដែលគ្រាចុងក្រោយមកដល់ បើទោះបីជាព្រះជាម្ចាស់គឺជាអ្នកដែល

នៅបន្តបំពេញកិច្ចការរបស់ទ្រង់ក្ដី ក៏ព្រះនាមរបស់ទ្រង់ត្រូវតែផ្លាស់ប្ដូរដែរ ដ្បិតវាគឺជាយុគសម័យមួយខុសគ្នា។

ព្រះជាម្ចាស់ដែលអស្ចារ្យបំផុតនៅទូទាំងសាកលលោក និងនៅពិភពខាងលើ តើទ្រង់អាចពន្យល់ពីព្រះអង្គទ្រង់ ដោយប្រើរូបអង្គខាងសាច់ឈាមបានដែរឬទេ? ព្រះជាម្ចាស់យកសាច់ឈាមមកគ្រងពីលើទ្រង់ ដើម្បីបំពេញកិច្ចការនៅក្នុងដំណាក់កាលមួយនៃកិច្ចការរបស់ទ្រង់។ គ្មានសារៈសំខាន់ជាក់លាក់ណាមួយ ចំពោះរូបអង្គខាងឯសាច់ឈាមនេះទេ វាគ្មានទំនាក់ទំនងអ្វី ក្នុងការឆ្លងកាត់យុគសម័យឡើយ ហើយវាក៏គ្មានអ្វីត្រូវពាក់ព័ន្ធ នឹងនិស្ស័យរបស់ព្រះជាម្ចាស់ដែរ។ តើហេតុអ្វីបានជាព្រះយេស៊ូវ អនុញ្ញាតឲ្យរូបអង្គទ្រង់នៅរក្សាដូចដើម? តើហេតុអ្វីបានជាមិនព្រមឲ្យមនុស្សគូរគំនូររូបអង្គទ្រង់ ដើម្បីឲ្យរូបអង្គនេះអាចផ្សាយបន្តទៅកាន់ជំនាន់ក្រោយៗទៀត? តើហេតុអ្វីបានជាទ្រង់មិនអនុញ្ញាតឲ្យមនុស្សទទួលស្គាល់ថា រូបអង្គរបស់ទ្រង់គឺជារូបអង្គរបស់ព្រះជាម្ចាស់? បើទោះបីជារូបកាយរបស់មនុស្សត្រូវបានបង្កើតឡើងជារូបអង្គរបស់ព្រះជាម្ចាស់ តើវាអាចទេដែលឲ្យរូបកាយខាងក្រៅរបស់មនុស្សតំណាងឲ្យរូបអង្គដ៏ខ្ពង់ខ្ពស់របស់ព្រះជាម្ចាស់នោះ? នៅពេលដែលព្រះជាម្ចាស់យកកំណើតជាមនុស្ស ទ្រង់គ្រាន់តែយាងចុះពីស្ថានសួគ៌ទៅកើតជាមនុស្សណាមួយប៉ុណ្ណោះ។ គឺព្រះវិញ្ញាណរបស់ទ្រង់នេះហើយដែលយាងចុះមកកើតជាមនុស្ស ហើយតាមរយៈការយកកំណើតនេះហើយដែលទ្រង់បំពេញកិច្ចការរបស់ព្រះវិញ្ញាណ។ គឺព្រះវិញ្ញាណនេះហើយ ដែលបើកសម្ដែងនៅខាងសាច់ឈាម ហើយគឺព្រះវិញ្ញាណនេះហើយដែលបំពេញកិច្ចការរបស់ទ្រង់ខាងឯសាច់ឈាម។ កិច្ចការដែលត្រូវបានធ្វើខាងឯសាច់ឈាមតំណាងឲ្យព្រះវិញ្ញាណទាំងស្រុង ហើយសាច់ឈាមនោះ គឺសម្រាប់តែជាប្រយោជន៍ដល់កិច្ចការនេះប៉ុណ្ណោះ ប៉ុន្តែនោះពុំមានន័យថា រូបអង្គខាងឯសាច់ឈាមជំនួសរូបអង្គពិតរបស់ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គនោះឡើយ។ នេះគឺមិនមែនជាគោលបំណង ឬជាខ្លឹមសារសំខាន់របស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សឡើយ។ ទ្រង់បានយកកំណើតជាមនុស្សតែដើម្បីឲ្យព្រះវិញ្ញាណអាចស្វែងរកកន្លែងមួយដើម្បី

ស្នាក់នៅ ដែលសមស្របនឹងកិច្ចការរបស់ទ្រង់ប៉ុណ្ណោះ ដើម្បីសម្រេចកិច្ចការរបស់ទ្រង់ខាងឯសាច់ឈាមបានកាន់តែប្រសើរ ដើម្បីឲ្យមនុស្សអាចមើលឃើញទង្វើរបស់ទ្រង់ យល់ពីនិស្ស័យរបស់ទ្រង់ ស្ដាប់ឮព្រះបន្ទូលរបស់ទ្រង់ និងស្គាល់ពីការអស្ចារ្យនៃកិច្ចការរបស់ទ្រង់។ ព្រះនាមរបស់ទ្រង់តំណាងឲ្យនិស្ស័យរបស់ទ្រង់ កិច្ចការរបស់ទ្រង់តំណាងឲ្យអត្តសញ្ញាណរបស់ទ្រង់ ប៉ុន្ដែទ្រង់មិនដែលបានមានព្រះបន្ទូលថា ការលេចមករបស់ទ្រង់ខាងសាច់ឈាមតំណាងឲ្យរូបអង្គរបស់ទ្រង់ឡើយ។ នោះគ្រាន់តែជាសញ្ញាណរបស់មនុស្សប៉ុណ្ណោះ។ ហេតុដូច្នេះហើយ ទិដ្ឋភាពសំខាន់នៃការយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់ គឺព្រះនាមរបស់ទ្រង់ កិច្ចការរបស់ទ្រង់ និស្ស័យរបស់ទ្រង់ និងភេទរបស់ទ្រង់។ ទាំងអស់នេះ គឺប្រើដើម្បីតំណាងឲ្យការគ្រប់គ្រងរបស់ទ្រង់នៅក្នុងយុគសម័យនេះ។ ការលេចមករបស់ទ្រង់ខាងឯសាច់ឈាមនេះ មិនជាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងរបស់ទ្រង់ឡើយ គឺគ្រាន់តែដើម្បីជាប្រយោជន៍ដល់កិច្ចការរបស់ទ្រង់នៅពេលនោះប៉ុណ្ណោះ។ ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សមិនអាចនឹងមានរូបរាងជាក់លាក់ណាមួយឡើយ ដូច្នេះហើយ ទ្រង់ជ្រើសរើសគ្រួសារដែលសមស្របមួយ ដើម្បីកំណត់ពីរូបអង្គរបស់ទ្រង់។ ប្រសិនបើរូបរាងខាងក្រៅរបស់ព្រះជាម្ចាស់ មានសារៈសំខាន់ដែលអាចធ្វើជាតំណាងបាន នោះអស់អ្នកដែលមានទម្រង់មុខស្រដៀងនឹងទ្រង់ ក៏នឹងអាចតំណាងឲ្យព្រះជាម្ចាស់បានដែរ។ តើនោះនឹងមិនក្លាយជាកំហុសដ៏ធ្ងន់ទេឬអី? រូបគំនូររបស់ព្រះយេស៊ូវត្រូវបានមនុស្សគូរដើម្បីឲ្យមនុស្សអាចថ្វាយបង្គំទ្រង់បាន។ នៅពេលនោះ ព្រះវិញ្ញាណបរិសុទ្ធគ្មានការណែនាំអ្វីពិសេសទេ ដូច្នេះហើយ មនុស្សបានចែកចាយរូបគំនូរដែលគេស្រមៃ គូរនោះបន្តគ្នារហូតមកទល់សព្វថ្ងៃនេះ។ តាមពិតទៅ តាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ មនុស្សមិនគួរធ្វើបែបនេះឡើយ។ គឺសទ្ធាដ៏មុតមាំរបស់មនុស្សនេះហើយដែលបង្កើតជារូបគំនូររបស់ព្រះយេស៊ូវឲ្យនៅសល់រហូតដល់សព្វថ្ងៃនេះ។ ព្រះជាម្ចាស់ គឺជាព្រះវិញ្ញាណ ហើយមនុស្សមិនអាចទាញជារួមថារូបអង្គរបស់ទ្រង់បែបណានៅក្នុងការវិភាគចុងក្រោយនោះទេ។ រូបអង្គរបស់ទ្រង់ គឺអាចតំណាងបានត្រឹមនិស្ស័យរបស់

ទ្រង់តែប៉ុណ្ណោះ។ សម្រាប់ទម្រង់នៃព្រះនាសាររបស់ទ្រង់ ព្រះឱស្ឋរបស់ទ្រង់ ព្រះនេត្ររបស់ទ្រង់ និងព្រះកេសារបស់ទ្រង់ ទាំងអស់នេះគឺមិនអាចឲ្យអ្នករៀបរាប់បាននោះទេ។ នៅពេលដែលការបើកសម្ដែងបានមកដល់យូហាន គាត់បានឃើញរូបអង្គនៃបុត្រមនុស្ស៖ ចេញពីព្រះឱស្ឋរបស់ទ្រង់គឺជាដាវមុខពីរ ព្រះនេត្ររបស់ទ្រង់គឺដូចជាអណ្ដាតភ្លើង ព្រះសិរសានិងព្រះកេសារបស់ទ្រង់ពណ៌សដូចជារោមចៀម ព្រះបាទារបស់ទ្រង់ដូចជាលង្ហិនខាត់រលោងស្រិល ហើយនៅឱរារបស់ទ្រង់ មានក្រវាត់ឈៀងពណ៌មាស។ បើទោះបីជាពាក្យរបស់គាត់ច្បាស់ៗក្ដី ក៏រូបអង្គរបស់ព្រះជាម្ចាស់ដែលគាត់បានរៀបរាប់ មិនមែនជារូបអង្គនៃសត្តនិករដែលបានបង្កើតមកនោះដែរ។ អ្វីដែលគាត់បានឃើញ គឺគ្រាន់តែជានិមិត្តប៉ុណ្ណោះ និងមិនមែនជារូបអង្គនៃមនុស្សមកពីពិភពពិតនោះទេ។ យូហានបានឃើញនិមិត្តមួយ ប៉ុន្តែគាត់មិនបានឃើញរូបរាងខាងក្រៅពិតប្រាកដរបស់ព្រះជាម្ចាស់ឡើយ។ រូបអង្គនៃសាច់ឈាមដែលយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់ ដែលជារូបអង្គនៃសត្តនិករដែលបានបង្កើតមក គឺមិនអាចតំណាងឲ្យនិស្ស័យរបស់ព្រះជាម្ចាស់ទាំងស្រុងនោះទេ។ នៅពេលដែលព្រះយេហូវ៉ាបានបង្កើតមនុស្សជាតិមក ទ្រង់បានមានព្រះបន្ទូលថា ទ្រង់បានបង្កើតមនុស្សឲ្យដូចជារូបអង្គទ្រង់ និងបានបង្កើតមនុស្សប្រុស និងមនុស្សស្រីមក។ នៅពេលនោះទ្រង់បានមានព្រះបន្ទូលថា ទ្រង់បានបង្កើតមនុស្សប្រុស និងមនុស្សស្រីឲ្យដូចរូបអង្គរបស់ព្រះជាម្ចាស់។ បើទោះបីជាលក្ខណៈរូបរបស់មនុស្សស្រដៀងគ្នានឹងរូបអង្គរបស់ព្រះជាម្ចាស់ក្ដី ក៏នេះមិនអាចបកស្រាយថា រូបរាងខាងក្រៅរបស់មនុស្ស គឺជារូបអង្គរបស់ព្រះជាម្ចាស់បានដែរ។ អ្នកក៏មិនអាចប្រើភាសារបស់មនុស្សជាតិដើម្បីធ្វើជាគំរូពេញលេញអំពីរូបអង្គរបស់ព្រះជាម្ចាស់បានដែរ ដ្បិតព្រះជាម្ចាស់ខ្ពង់ខ្ពស់ណាស់មហិមាណាស់ អស្ចារ្យណាស់ និងមិនអាចយល់បានឡើយ!

នៅពេលដែលព្រះយេស៊ូវយាងមកបំពេញកិច្ចការរបស់ទ្រង់ គឺកិច្ចការនោះស្ថិតនៅក្រោមការណែនាំរបស់ព្រះវិញ្ញាណបរិសុទ្ធ។ ទ្រង់បានបំពេញកិច្ចការដែលទ្រង់ចង់បំពេញ និងមិនមែនទៅតាមយុគសម័យនៃក្រឹត្យវិន័យក្នុងព្រះគម្ពីរសញ្ញាចាស់ ឬទៅ

តាមកិច្ចការរបស់ព្រះយេហូវ៉ាឡើយ។ បើទោះបីជាកិច្ចការដែលព្រះយេស៊ូវយាងមកបំពេញនោះ គឺមិនស្របទៅតាមក្រឹត្យវិន័យរបស់ព្រះយេហូវ៉ា ឬបញ្ញត្តិរបស់ព្រះយេហូវ៉ាក្ដី ក៏ប្រភពរបស់ទ្រង់ គឺតែមួយ និងដូចគ្នាដែរ។ កិច្ចការដែលព្រះយេស៊ូវបានធ្វើតំណាងឲ្យព្រះនាមរបស់ព្រះយេស៊ូវ ហើយវាតំណាងឲ្យយុគសម័យនៃព្រះគុណ។ សម្រាប់កិច្ចការដែលព្រះយេហូវ៉ាបំពេញ គឺតំណាងឲ្យព្រះយេហូវ៉ា ហើយវាតំណាងឲ្យយុគសម័យនៃក្រឹត្យវិន័យ។ កិច្ចការរបស់ទ្រង់ គឺជាកិច្ចការរបស់ព្រះវិញ្ញាណតែមួយនៅក្នុងយុគសម័យពីរផ្សេងគ្នា។ កិច្ចការដែលព្រះយេស៊ូវបានបំពេញអាចតំណាងត្រឹមយុគសម័យនៃព្រះគុណប៉ុណ្ណោះ ហើយកិច្ចការដែលព្រះយេហូវ៉ាបានបំពេញ តំណាងត្រឹមយុគសម័យនៃក្រឹត្យវិន័យក្នុងព្រះគម្ពីរសញ្ញាចាស់ប៉ុណ្ណោះ។ ព្រះយេហូវ៉ាបានណែនាំត្រឹមរាស្ត្រអ៊ីស្រាអែល និងរាស្ត្រអេហ្ស៊ីប និងគ្រប់ជាតិសាសន៍ទាំងអស់នៅក្រៅស្រុកអ៊ីស្រាអែលប៉ុណ្ណោះ។ កិច្ចការរបស់ព្រះយេស៊ូវនៅក្នុងយុគសម័យនៃព្រះគុណក្នុងព្រះគម្ពីរសញ្ញាថ្មី គឺជាកិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងព្រះនាមរបស់ព្រះយេស៊ូវនៅពេលដែលទ្រង់បានដឹកនាំយុគសម័យនោះ។ ប្រសិនបើអ្នកនិយាយថា កិច្ចការរបស់ព្រះយេស៊ូវផ្អែកលើកិច្ចការរបស់ព្រះយេហូវ៉ា ថាទ្រង់មិនបានបង្កើតកិច្ចការថ្មីណាមួយ ហើយថាគ្រប់ការដែលទ្រង់បានបំពេញ គឺស្របទៅតាមព្រះបន្ទូលរបស់ព្រះយេហូវ៉ា និងសេចក្ដីទំនាយរបស់អេសាយ នោះព្រះយេស៊ូវនឹងមិនមែនជាព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សឡើយ។ ប្រសិនបើទ្រង់បានបំពេញកិច្ចការរបស់ទ្រង់ដោយបែបនេះមែន ទ្រង់នឹងអាចក្លាយត្រឹមជាសាវ័កមួយរូប ឬជាអ្នកធ្វើការនៅក្នុងយុគសម័យនៃក្រឹត្យវិន័យប៉ុណ្ណោះ។ ប្រសិនបើដូចជាអ្នកនិយាយមែន នោះព្រះយេស៊ូវមិនអាចចាប់ផ្ដើមយុគសម័យមួយបានឡើយ ហើយទ្រង់ក៏មិនអាចបំពេញកិច្ចការដទៃផ្សេងទៀតបានដែរ។ ដូចគ្នានេះដែរ ព្រះវិញ្ញាណបរិសុទ្ធ ត្រូវបំពេញកិច្ចការរបស់ទ្រង់ជាគោលការណ៍តាមរយៈព្រះយេហូវ៉ា ហើយព្រះវិញ្ញាណបរិសុទ្ធមិនអាចបំពេញកិច្ចការថ្មីបានឡើយលើកលែងតែតាមរយៈព្រះយេហូវ៉ាប៉ុណ្ណោះ។ វាជារឿងខុសសម្រាប់មនុស្ស ដែលយល់ពីកិច្ចការរបស់ព្រះយេស៊ូវថាបែបនេះ។ ប្រសិនបើ

មនុស្សជឿថា កិច្ចការដែលព្រះយេស៊ូវ បានធ្វើស្របទៅតាមព្រះបន្ទូលរបស់ព្រះយេហូវ៉ា និងតាមសេចក្ដីទំនាយរបស់អេសាយ នោះតើព្រះយេស៊ូវគឺជាព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សមែនទេ ឬតើទ្រង់គឺជាហោរាម្នាក់មែនទេ? តាមទស្សនៈនេះ នឹងគ្មានយុគសម័យនៃព្រះគុណទេ ហើយព្រះយេស៊ូវនឹងមិនក្លាយជាព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សឡើយ ដ្បិតកិច្ចការដែលទ្រង់បានបំពេញ មិនអាចតំណាងឲ្យយុគសម័យនៃព្រះគុណបាន និងអាចតំណាងត្រឹមតែយុគសម័យនៃក្រឹត្យវិន័យនៅក្នុងព្រះគម្ពីរសញ្ញាចាស់ប៉ុណ្ណោះ។ អាចនឹងមាននូវយុគសម័យថ្មីមួយនៅពេលដែលព្រះយេស៊ូវយាងមកបំពេញកិច្ចការថ្មី ដើម្បីបើកយុគសម័យថ្មីមួយ ដើម្បីឆ្លងកាត់កិច្ចការដែលបានបំពេញពីមុននៅស្រុកអ៊ីស្រាអែល និងដើម្បីបំពេញកិច្ចការរបស់ទ្រង់មិនឲ្យស្របទៅតាមកិច្ចការ ដែលព្រះយេហូវ៉ាបានធ្វើនៅស្រុកអ៊ីស្រាអែល ឬស្របតាមក្រឹត្យវិន័យចាស់របស់ទ្រង់ ឬស្របទៅតាមបទបញ្ញត្តិណាមួយឡើយ ប៉ុន្តែផ្ទុយទៅវិញគឺដើម្បីបំពេញកិច្ចការថ្មីដែលទ្រង់គប្បីបំពេញ។ ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គយាងមកដើម្បីបើកយុគសម័យនោះ ហើយព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ ក៏យាងមកដើម្បីនាំយុគសម័យនោះទៅរកទីបញ្ចប់ដែរ។ មនុស្សមិនអាចធ្វើកិច្ចការនៃការចាប់ផ្ដើមយុគសម័យមួយ និងបញ្ចប់យុគសម័យនោះបានទេ។ ប្រសិនបើព្រះយេស៊ូវមិនបាននាំយកកិច្ចការរបស់ព្រះយេហូវ៉ាទៅរកទីបញ្ចប់ ក្រោយពីទ្រង់បានយាងមកទេ នោះនឹងក្លាយជាភស្តុតាងបញ្ជាក់ថា ទ្រង់គឺគ្រាន់តែជាមនុស្សម្នាក់ប៉ុណ្ណោះ និងមិនអាចតំណាងឲ្យព្រះជាម្ចាស់បានឡើយ។ ច្បាស់ណាស់ថា ដោយសារព្រះយេស៊ូវបានយាងមក និងបានបញ្ចប់កិច្ចការរបស់ព្រះយេហូវ៉ា បានបន្តកិច្ចរបស់ព្រះយេហូវ៉ា និងបន្តកិច្ចការរបស់ព្រះអង្គផ្ទាល់ ដែលជាកិច្ចការថ្មីមួយទៀត នោះបញ្ជាក់ថា នេះគឺជាយុគសម័យថ្មីមួយ ហើយថាព្រះយេស៊ូវគឺជាព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ។ ទ្រង់បានបំពេញនូវកិច្ចការនៅដំណាក់កាលពីរផ្សេងគ្នា។ ដំណាក់កាលមួយត្រូវធ្វើឡើងនៅក្នុងព្រះវិហារ ហើយដំណាក់កាលមួយត្រូវធ្វើឡើងនៅក្រៅព្រះវិហារ។ ដំណាក់កាលមួយ ត្រូវដឹកនាំមនុស្សស្របទៅតាមក្រឹត្យវិន័យ ហើយដំណាក់កាលមួយទៀត ត្រូវលះបង់ធ្វើជា

តង្វាយលោះបាប។ ដំណាក់កាលនៃកិច្ចការទាំងពីរនេះ គឺមានភាពខុសគ្នាយ៉ាងខ្លាំង។ ការនេះបែងចែកយុគសម័យថ្មីចេញពីយុគសម័យចាស់ ហើយវាត្រឹមត្រូវណាស់ដែលនិយាយថា ដំណាក់កាលទាំងពីរ គឺជាយុគសម័យពីរផ្សេងគ្នា។ ទីតាំងនៃកិច្ចការរបស់ទ្រង់គឺខុសគ្នា ខ្លឹមសារនៃកិច្ចការរបស់ទ្រង់ក៏ខុសគ្នា ហើយគោលបំណងនៃកិច្ចការរបស់ទ្រង់ក៏ខុសគ្នាដែរ។ ដូច្នេះ ដំណាក់កាលនៃកិច្ចការនេះអាចបែងចែកជាពីរយុគសម័យ៖ ព្រះគម្ពីរសញ្ញាថ្មី និងព្រះគម្ពីរសញ្ញាចាស់ យុគសម័យសញ្ញាថ្មី និងយុគសម័យសញ្ញាចាស់។ នៅពេលដែលព្រះយេស៊ូវបានយាងមក ទ្រង់មិនបានយាងទៅក្នុងព្រះវិហារទេហើយនេះបញ្ជាក់ថា យុគសម័យរបស់ព្រះយេហូវ៉ាបានបញ្ចប់រួចហើយ។ ទ្រង់មិនបានយាងចូលទៅក្នុងព្រះវិហារទេ ដោយសារកិច្ចការរបស់ព្រះយេហូវ៉ានៅក្នុងព្រះវិហារបានបញ្ចប់រួចហើយ និងមិនចាំបាច់ត្រូវការធ្វើវាម្តងទៀតឡើយ ហើយបើធ្វើម្តងទៀតនឹងជាន់គ្នាមិនខាន។ មានតែតាមរយៈការចាកចេញពីព្រះវិហារ ការចាប់ផ្តើមកិច្ចការថ្មី និងការចាប់ផ្តើមមាគ៌ាថ្មីនៅក្រៅព្រះវិហារទេ ទើបទ្រង់អាចនាំកិច្ចការរបស់ព្រះជាម្ចាស់ទៅដល់ចំណុចកំពូលរបស់វាបាន។ ប្រសិនបើទ្រង់មិនបានចាកចេញពីព្រះវិហារដើម្បីបំពេញកិច្ចការរបស់ទ្រង់ទេ នោះកិច្ចការរបស់ព្រះជាម្ចាស់នឹងត្រូវជាប់គាំង នៅលើមូលដ្ឋានគ្រឹះនៃព្រះវិហារដដែល ហើយនឹងមិនមានការផ្លាស់ប្តូរថ្មីណាមួយទេ។ ហេតុដូច្នេះហើយ នៅពេលដែលព្រះយេស៊ូវយាងមក ទ្រង់មិនបានចូលទៅក្នុងព្រះវិហារឡើយ និងមិនបានបំពេញកិច្ចការរបស់ទ្រង់នៅក្នុងព្រះវិហារទេ។ ទ្រង់បានបំពេញកិច្ចការរបស់ទ្រង់នៅក្រៅព្រះវិហារ និងបានដឹកនាំពួកសិស្ស ព្រមទាំងបានបំពេញកិច្ចការរបស់ទ្រង់ដោយសេរី។ ការយាងចាកចេញរបស់ព្រះជាម្ចាស់ពីព្រះវិហារដើម្បីបំពេញកិច្ចការរបស់ទ្រង់ មានន័យថា ព្រះជាម្ចាស់មានផែនការថ្មីមួយ។ កិច្ចការរបស់ទ្រង់ គឺត្រូវបំពេញនៅក្រៅព្រះវិហារ ហើយវាគឺជាកិច្ចការថ្មីដែលមិនជាប់ជំពាក់ នឹងការអនុវត្តកិច្ចការនេះក្នុងលក្ខណៈណាមួយឡើយ។ នៅពេលដែលព្រះយេស៊ូវបានយាងមកដល់ ទ្រង់បាននាំកិច្ចការរបស់ព្រះយេហូវ៉ាក្នុងអំឡុងយុគសម័យនៃព្រះគម្ពីរសញ្ញាចាស់ទៅរកទីបញ្ចប់។ បើទោះបីជាទ្រង់ត្រូវហៅ

ដោយព្រះនាមពីរផ្សេងគ្នាក៏ដោយ ក៏ជាព្រះវិញ្ញាណតែមួយដែរ ដែលបានសម្រេចកិច្ចការនៅដំណាក់កាលទាំងពីរនេះ ហើយកិច្ចការដែលបានធ្វើរួចហើយ ក៏បានបន្ត។ ដោយសារព្រះនាមខុសគ្នា ហើយខ្លឹមសារនៃកិច្ចការខុសគ្នា យុគសម័យនោះក៏ខុសគ្នាដែរ។ នៅពេលដែលព្រះយេហូវ៉ាបានយាងមក នោះគឺជាយុគសម័យរបស់ព្រះយេហូវ៉ា ហើយនៅពេលដែលព្រះយេស៊ូវ ទ្រង់បានយាងមក នោះគឺជាយុគសម័យរបស់ព្រះយេស៊ូវ។ ដូច្នេះហើយ នៅពេលដែលយាងមកម្ដងៗ ព្រះជាម្ចាស់ត្រូវគេហៅដោយព្រះនាមមួយ ទ្រង់ណែនាំយុគសម័យមួយ ហើយទ្រង់ចាប់ផ្ដើមមាគ៌ាថ្មីមួយ ហើយនៅលើមាគ៌ាថ្មីនីមួយៗ ទ្រង់ប្រើព្រះនាមថ្មីមួយ ដែលបង្ហាញថា ព្រះជាម្ចាស់គឺតែងតែថ្មីជានិច្ច និងមិនដែលចាស់ឡើយ ហើយនោះគឺជាកិច្ចការរបស់ទ្រង់ ដែលមិនដែលឈប់ចម្រើនទៅមុខឡើយ។ ប្រវត្តិសាស្រ្តតែងរំកិលទៅមុខ ហើយកិច្ចការរបស់ព្រះជាម្ចាស់ក៏តែងផ្លាស់ប្ដូរទៅមុខជានិច្ចដែរ។ ដើម្បីឲ្យផែនការគ្រប់គ្រងរយៈពេលប្រាំមួយពាន់ឆ្នាំឈានចូលដល់ទីបញ្ចប់បាន វាត្រូវតែបន្តចម្រើនទៅមុខជានិច្ច។ ទ្រង់ត្រូវតែបំពេញកិច្ចការថ្មីជារៀងរាល់ថ្ងៃ ហើយជារៀងរាល់ឆ្នាំ ទ្រង់ត្រូវតែបំពេញនូវកិច្ចការថ្មីជានិច្ច។ ទ្រង់ត្រូវតែចាប់ផ្ដើមមាគ៌ាថ្មីៗ ចាប់ផ្ដើមសម័យកាលថ្មីៗ ចាប់ផ្ដើមកិច្ចការថ្មី និងកាន់តែអស្ចារ្យ ហើយជាមួយគ្នានោះដែរ ត្រូវនាំព្រះនាមថ្មី និងកិច្ចការថ្មីមកជាមួយ។ ពីពេលមួយទៅពេលមួយ ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់កំពុងបំពេញកិច្ចការថ្មី ហើយមិនដែលនៅជាប់នឹងវិធីសាស្រ្តចាស់ ឬច្បាប់ចាស់ឡើយ។ ហើយកិច្ចការរបស់ទ្រង់ក៏មិនដែលឈប់ដែរ គឺឆ្លងកាត់ពីពេលមួយទៅពេលមួយឥតដាច់ឡើយ។ ប្រសិនបើអ្នកនិយាយថា កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធមិនប្រែប្រួល តើហេតុអ្វីបានជាព្រះយេហូវ៉ាសុំពួកសង្ឃឲ្យបម្រើទ្រង់នៅក្នុងព្រះវិហារ ប៉ុន្ដែព្រះយេស៊ូវវិញ បែរជាមិនបានយាងចូលទៅក្នុងព្រះវិហារនៅពេលដែលទ្រង់យាងមក បើទោះបីជាមនុស្សបាននិយាយថា ទ្រង់គឺជាសង្ឃមានឋានៈខ្ពស់ជាងគេ ហើយថាទ្រង់ចេញមកពីដំណាក់របស់ដាវីឌ ហើយក៏ជាសង្ឃខ្ពស់ជាងគេ និងជាក្សត្រដ៏ធំជាងគេ? ហើយតើហេតុអ្វីបានទ្រង់មិនថ្វាយយញ្ញបូជា? ការចូលទៅក្នុងព្រះវិហារ ឬការមិនចូលទៅក្នុងព្រះវិហារ តើការ

ទាំងអស់នេះ មិនមែនជាកិច្ចការរបស់ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គទេឬអី? ដូចដែលមនុស្សនឹកស្រមៃ ប្រសិនបើព្រះយេស៊ូវនឹងយាងមកម្ដងទៀតនៅគ្រាចុងក្រោយ ហើយនៅតែត្រូវហៅថាព្រះយេស៊ូវ និងនៅតែយាងមកលើដុំពពកស ដោយយាងចុះមកក្នុងចំណោមមនុស្សជារូបអង្គរបស់ព្រះយេស៊ូវ៖ តើនោះមិនមែនជាកិច្ចការដដែលៗរបស់ទ្រង់ទេឬអី? តើព្រះវិញ្ញាណបរិសុទ្ធអាចនៅជាប់នឹងរឿងចាស់បានទេ? អ្វីដែលមនុស្សជឿ គឺជាសញ្ញាណ ហើយអ្វីៗដែលមនុស្សយល់ គឺស្របទៅតាមន័យត្រង់ ហើយក៏ស្របទៅតាមការស្រមៃរបស់ពួកគេដែរ។ អ្វីទាំងនោះ មិនស្របគ្នាជាមួយនឹងគោលការណ៍ នៃកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធឡើយ ហើយក៏មិនស្របទៅតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែរ។ ព្រះជាម្ចាស់នឹងមិនបំពេញកិច្ចការដោយបែបនេះទេ។ ព្រះជាម្ចាស់មិនល្ងង់ខ្លៅ និងល្ងីល្ងើនោះទេ ហើយកិច្ចការរបស់ទ្រង់ គឺមិនធម្មតាដូចជាអ្នកនឹកស្រមៃឡើយ។ ផ្អែកតាមគ្រប់យ៉ាងដែលមនុស្សនឹកស្រមៃ ព្រះយេស៊ូវនឹងយាងមកនៅលើដុំពពក និងយាងចុះមកក្នុងចំណោមពួកអ្នករាល់គ្នា។ អ្នករាល់គ្នានឹងឃើញទ្រង់គង់នៅលើដុំពពក ហើយទ្រង់នឹងមានបន្ទូលប្រាប់អ្នករាល់គ្នាថា ទ្រង់គឺជាព្រះយេស៊ូវ។ អ្នករាល់គ្នាក៏នឹងឃើញស្នាមដែកគោលនៅលើព្រះហស្ដរបស់ទ្រង់ ហើយនឹងស្គាល់ទ្រង់ថាជា ព្រះយេស៊ូវ។ ហើយទ្រង់នឹងសង្គ្រោះអ្នករាល់គ្នាម្ដងទៀត ហើយនិងធ្វើជាព្រះដ៏មានគ្រប់ចេស្ដារបស់អ្នករាល់គ្នា។ ទ្រង់នឹងសង្គ្រោះអ្នករាល់គ្នា ប្រទានឈ្មោះថ្មីដល់អ្នករាល់គ្នា និងប្រទានដុំថ្មសដល់អ្នករាល់គ្នាម្នាក់មួយដុំ ដែលបន្ទាប់ពីនោះមក អ្នករាល់គ្នានឹងត្រូវអនុញ្ញាតឲ្យចូលទៅក្នុងនគរស្ថានសួគ៌ ហើយនឹងត្រូវទទួលយកទៅស្ថានសួគ៌។ តើជំនឿបែបនេះ មិនមែនជាសញ្ញាណរបស់មនុស្សទេឬអី? តើព្រះជាម្ចាស់បំពេញកិច្ចការស្របតាមសញ្ញាណរបស់មនុស្សមែនទេ ឬតើទ្រង់បំពេញកិច្ចការទាស់នឹងសញ្ញាណរបស់មនុស្សមែនទេ? តើសញ្ញាណរបស់មនុស្សសុទ្ធតែមកអំពីសាតាំងមែនទេ? តើមនុស្សទាំងអស់មិនសុទ្ធតែត្រូវសាតាំងធ្វើឲ្យពុករលួយទេឬអី? ប្រសិនបើព្រះជាម្ចាស់ បានបំពេញកិច្ចការស្របទៅតាមសញ្ញាណរបស់មនុស្ស តើទ្រង់មិនក្លាយជាសាតាំងទៅមែនទេ? តើទ្រង់នឹងមិនមែនជា

ប្រភេទតែមួយនឹងសត្តនិករ ដែលទ្រង់បង្កើតមកទេឬអី? ដោយសារសព្វសារពើដែលទ្រង់បង្កើតមកត្រូវបានសាតាំងធ្វើឲ្យពុករលួយយ៉ាងខ្លាំងក្នុងពេលនេះ ទើបមនុស្សបានក្លាយទៅជារូបតំណាងរបស់សាតាំង ប្រសិនបើព្រះជាម្ចាស់ត្រូវធ្វើការស្របទៅតាមអ្វីជារបស់សាតាំង តើទ្រង់នឹងមិនឃុបឃិតគ្នាជាមួយនឹងសាតាំងទេឬអី? តើមនុស្សអាចយល់ពីកិច្ចការរបស់ព្រះជាម្ចាស់ បានដោយរបៀបណា? ហេតុដូច្នេះព្រះជាម្ចាស់ នឹងមិនធ្វើការស្របទៅតាមសញ្ញាណរបស់មនុស្សឡើយ ហើយនឹងមិនដែលធ្វើកិច្ចការដូចដែលអ្នកនឹកស្រមៃនោះទេ។ មានមនុស្សដែលនិយាយថាព្រះជាម្ចាស់ផ្ទាល់ព្រះអង្គបានមានព្រះបន្ទូលថា ទ្រង់នឹងយាងមកនៅលើដុំពពក។ តើវាពិតទេថា ព្រះជាម្ចាស់បានមានព្រះបន្ទូលបែបនេះដោយផ្ទាល់ព្រះអង្គទ្រង់នោះ ប៉ុន្តែតើអ្នកមិនដឹងថា គ្មានមនុស្សណាម្នាក់អាចយល់ពីអាថ៌កំបាំងរបស់ព្រះជាម្ចាស់បានទេឬ? តើអ្នកមិនដឹងទេថា គ្មានមនុស្សណាម្នាក់អាចពន្យល់ពីព្រះបន្ទូលរបស់ព្រះជាម្ចាស់បាន? ក្រៅពីស្រមោលនៃការសង្ស័យ តើអ្នកច្បាស់ទេថា អ្នកត្រូវបានបំភ្លឺ និងស្រាយបំភ្លឺដោយព្រះវិញ្ញាណបរិសុទ្ធនោះ? ច្បាស់ណាស់ គឺមិនមែនព្រះវិញ្ញាណបរិសុទ្ធទេដែលបានបង្ហាញអ្នកតាមរបៀបមួយដោយផ្ទាល់បែបនេះនោះ? តើព្រះវិញ្ញាណបរិសុទ្ធមែនទេដែលបានណែនាំអ្នក ឬជាសញ្ញាណរបស់អ្នកបានដឹកនាំអ្នកឲ្យគិតបែបនេះ? អ្នកនិយាយថា «ព្រះជាម្ចាស់ទ្រង់មានព្រះបន្ទូលបែបនេះ»។ ប៉ុន្តែ យើងមិនអាចប្រើសញ្ញាណ និងគំនិតផ្ទាល់របស់យើងដើម្បីវាស់ស្ទង់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ឡើយ។ សម្រាប់ពាក្យដែលអេសាយបាននិយាយ តើអ្នកអាចពន្យល់ពាក្យរបស់គាត់ឲ្យបានច្បាស់លាស់ដែរឬទេ? តើអ្នកហ៊ានពន្យល់ពាក្យរបស់គាត់ដែរឬទេ? ដោយសារអ្នកមិនហ៊ានពន្យល់សម្ដីរបស់អេសាយ តើហេតុអ្វីបានជាអ្នកហ៊ានពន្យល់ពីព្រះបន្ទូលរបស់ព្រះយេស៊ូវ? តើនរណាខ្ពង់ខ្ពស់ជាង ព្រះយេស៊ូវ ឬអេសាយ? ដោយសារចម្លើយ គឺព្រះយេស៊ូវខ្ពង់ខ្ពស់ជាង តើហេតុអ្វីបានជាអ្នកពន្យល់ព្រះបន្ទូលដែលព្រះយេស៊ូវបានថ្លែងមក? តើព្រះជាម្ចាស់នឹងមានបន្ទូលប្រាប់អ្នកអំពីកិច្ចការរបស់ទ្រង់ជាមុនដែរឬទេ? គ្មានសត្តនិករណាមួយដែលអាចដឹងបានទេ គ្មានអ្នកនាំសារស្ថានសួគ៌ណាមួយដឹង

ឡើយ ហើយកូនមនុស្សក៏មិនដែរ ដូច្នេះ តើអ្នកអាចដឹងបានដោយរបៀបណា? មនុស្ស នៅមានការខ្វះខាតខ្លាំងណាស់។ អ្វីដែលសំខាន់សម្រាប់អ្នករាល់គ្នាក្នុងពេលនេះ គឺ ត្រូវដឹងអំពីដំណាក់កាលទាំងបីនៃកិច្ចការនេះ។ ចាប់តាំងពីកិច្ចការរបស់ព្រះយេហូវ៉ា ទៅដល់កិច្ចការរបស់ព្រះយេស៊ូវ និងពីកិច្ចការរបស់ព្រះយេស៊ូវទៅដល់ដំណាក់កាល បច្ចុប្បន្ននេះ ដំណាក់កាលទាំងបីនេះ គ្របដណ្ដប់លើការគ្រប់គ្រងសព្វគ្រប់បែបយ៉ាង ទាំងអស់របស់ព្រះជាម្ចាស់ ហើយកិច្ចការទាំងអស់ គឺសុទ្ធតែជាកិច្ចការរបស់ព្រះ វិញ្ញាណតែមួយ។ ចាប់តាំងពីការបង្កើតពិភពលោកនេះមក ព្រះជាម្ចាស់តែងបំពេញ កិច្ចការនៃការគ្រប់គ្រងមនុស្សជាតិ។ ទ្រង់គឺជាការចាប់ផ្ដើម និងជាទីបញ្ចប់ ទ្រង់គឺជា ព្រះជាម្ចាស់ដំបូងគេ និងចុងក្រោយគេ ហើយទ្រង់គឺជាព្រះជាម្ចាស់មួយអង្គដែល ចាប់ផ្ដើមយុគសម័យមួយ និងជាព្រះជាម្ចាស់ដែលនាំយុគសម័យនោះទៅរកទីបញ្ចប់។ ដំណាក់កាលទាំងបីនៃកិច្ចការនេះ ដែលស្ថិតក្នុងយុគសម័យខុសគ្នា និងទីតាំងខុសគ្នា គឺជាកិច្ចការរបស់ព្រះវិញ្ញាណតែមួយ។ អស់អ្នកដែលញែកដំណាក់កាលទាំងបីនេះ ពីគ្នា នោះឈរទទឹងនឹងព្រះជាម្ចាស់ហើយ។ បច្ចុប្បន្ននេះ វាបញ្ជាក់អ្នកឲ្យយល់ថា គ្រប់កិច្ចការទាំងអស់ គឺចាប់តាំងពីដំណាក់កាលដំបូង រហូតដល់សព្វថ្ងៃនេះ គឺជា កិច្ចការរបស់ព្រះជាម្ចាស់តែមួយព្រះអង្គ ជាកិច្ចការរបស់ព្រះវិញ្ញាណតែមួយ។ គ្មានអ្វី ត្រូវឆ្ងល់ចំពោះចំណុចនេះទេ។

# អាថ៌កំបាំងនៃការយកកំណើតជាមនុស្ស (១)

យ៉ូហានបានត្រួសត្រាយផ្លូវសម្រាប់ព្រះយេស៊ូវ ក្នុងយុគសម័យនៃព្រះគុណ។ យ៉ូហាន មិនអាចធ្វើកិច្ចការរបស់ព្រះជាម្ចាស់ផ្ទាល់បានទេ ប៉ុន្តែបានត្រឹមតែអាច បំពេញភារកិច្ចរបស់មនុស្សតែប៉ុណ្ណោះ។ ទោះបីយ៉ូហាន គឺជាអ្នកដើរមុនព្រះអម្ចាស់ ក៏គាត់មិនអាចតំណាងឱ្យព្រះជាម្ចាស់បានដែរ។ គាត់គ្រាន់តែជាមនុស្សម្នាក់ដែល ត្រូវបានព្រះវិញ្ញាណបរិសុទ្ធប្រើប្រាស់តែប៉ុណ្ណោះ។ បន្ទាប់ពីព្រះយេស៊ូវបានទទួល

ពិធីជ្រមុជទឹករួច ព្រះវិញ្ញាណបរិសុទ្ធក៏បានយាងចុះមកសណ្ឋិតលើទ្រង់ ក្នុងសណ្ឋានដូចជាសត្វព្រាប។ បន្ទាប់មក ទ្រង់ក៏បានចាប់ផ្ដើមកិច្ចការរបស់ទ្រង់ គឺទ្រង់បានចាប់ផ្ដើមបំពេញព័ន្ធកិច្ចរបស់ព្រះគ្រីស្ទ។ នោះហើយ ជាហេតុផលដែលព្រះអង្គចាប់ផ្ដើមមានអត្តសញ្ញាណជាព្រះជាម្ចាស់ ដ្បិតទ្រង់យាងមកពីព្រះជាម្ចាស់។ ទោះបីកាលពីមុន សេចក្ដីជំនឿរបស់ទ្រង់មានលក្ខណៈបែបណាក៏ដោយ អាចថា ពេលខ្លះខ្សោយ ឬពេលខ្លះរឹងមាំ ក៏សេចក្ដីជំនឿទាំងអស់នោះ សុទ្ធតែជាកម្មសិទ្ធិនៃជីវិតដែលទ្រង់ជាមនុស្សធម្មតា មុនពេលទ្រង់បំពេញព័ន្ធកិច្ចរបស់ទ្រង់។ បន្ទាប់ពីទ្រង់បានទទួលពិធីជ្រមុជទឹក (គឺបន្ទាប់ពីត្រូវបានចាក់ប្រេងតាំង) ព្រះចេស្ដា និងសិរីរុងរឿងរបស់ព្រះជាម្ចាស់ ក៏មកសណ្ឋិតនឹងទ្រង់ភ្លាម ហើយព្រះអង្គក៏បានចាប់ផ្ដើមបំពេញព័ន្ធកិច្ចរបស់ទ្រង់ដែរ។ ព្រះអង្គអាចធ្វើទីសម្គាល់ និងការអស្ចារ្យ ទាំងសម្ដែងឫទ្ធិបារមីនានា ហើយទ្រង់មានទាំងព្រះចេស្ដា និងសិទ្ធិអំណាច ដ្បិតទ្រង់កំពុងធ្វើការជំនួសមុខឲ្យព្រះជាម្ចាស់ដោយផ្ទាល់។ ព្រះអង្គកំពុងធ្វើកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធជំនួសទ្រង់ ព្រមទាំងបញ្ចេញព្រះសូរសៀងរបស់ព្រះវិញ្ញាណផង។ ដូច្នេះ ព្រះអង្គគឺជាព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ នេះគឺជារឿងដែលមិនអាចប្រកែកបាន។ យ៉ូហាន គឺជាមនុស្សម្នាក់ដែលព្រះវិញ្ញាណបរិសុទ្ធប្រើប្រាស់។ គាត់មិនអាចតំណាងឲ្យព្រះជាម្ចាស់បានទេ ហើយការតំណាងឲ្យព្រះជាម្ចាស់ ក៏ជារឿងដែលមិនអាចទៅរួចសម្រាប់គាត់ដែរ។ ប្រសិនបើគាត់ចង់ធ្វើបែបនេះ ព្រះវិញ្ញាណបរិសុទ្ធ ក៏មុខជាមិនអនុញ្ញាតដែរ ដ្បិតគាត់មិនអាចធ្វើកិច្ចការដែលព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ ចង់សម្រេចបាននោះដែរ។ ប្រហែលជានៅក្នុងគាត់ មាននូវឆន្ទៈរបស់មនុស្សច្រើនពេក ឬមានអ្វីម៉្យាងដែលខុសឆ្គង។ ក្នុងកាលៈទេសៈណាក៏ដោយ ក៏គាត់មិនអាចតំណាងឲ្យព្រះជាម្ចាស់ដោយផ្ទាល់បានដែរ។ កំហុស និងភាពឆ្គាំឆ្គងរបស់គាត់ តំណាងឲ្យតែខ្លួនគាត់ផ្ទាល់ប៉ុណ្ណោះ តែកិច្ចការរបស់គាត់ គឺជាតំណាងឲ្យព្រះវិញ្ញាណបរិសុទ្ធ។ ដោយឡែក អ្នកមិនអាចនិយាយថា ជីវិតរបស់គាត់ទាំងមូល តំណាងឲ្យព្រះជាម្ចាស់នោះទេ។ តើគម្លាត និងភាពឆ្គាំឆ្គងរបស់ទ្រង់ អាចតំណាងឲ្យព្រះជាម្ចាស់បានដែរឬទេ? សេចក្ដីឆ្គាំឆ្គងក្នុង

ការតំណាងឲ្យមនុស្ស គឺជារឿងធម្មតាទេ ប៉ុន្តែប្រសិនបើមនុស្សខុសឆ្គងក្នុងការតំណាងឲ្យព្រះជាម្ចាស់ តើនោះមិនបន្ថោកដល់ព្រះជាម្ចាស់ទេឬអី? តើនោះមិនមែនជាការប្រមាថដល់ព្រះវិញ្ញាណបរិសុទ្ធទេឬអី? ព្រះវិញ្ញាណបរិសុទ្ធ មិនអនុញ្ញាតឲ្យមនុស្សជំនួសតំណែងរបស់ព្រះជាម្ចាស់ ដោយធ្វេសប្រហែសឡើយ បើទោះបីគេត្រូវបានអ្នកដទៃលើកសរសើរក៏ដោយ។ ប្រសិនបើគេពុំមែនជាព្រះជាម្ចាស់ គេមុខជាមិនអាចឈរមាំនៅទីបញ្ចប់ឡើយ។ ព្រះវិញ្ញាណបរិសុទ្ធមិនអនុញ្ញាតឲ្យមនុស្សតំណាងឲ្យព្រះជាម្ចាស់ ស្រេចតែមនុស្សចង់ធ្វើនោះឡើយ! ឧទាហរណ៍ គឺព្រះវិញ្ញាណបរិសុទ្ធហើយដែលបានធ្វើបន្ទាល់ពីយ៉ូហាន ហើយព្រះវិញ្ញាណក៏ជាអ្នកបើកសម្ដែងថា គាត់គឺជាមនុស្សម្នាក់ដែលត្រួសត្រាយផ្លូវថ្វាយព្រះយេស៊ូវ ប៉ុន្តែកិច្ចការដែលព្រះវិញ្ញាណបរិសុទ្ធធ្វើចំពោះគាត់ ត្រូវបានវាស់ស្ទង់យ៉ាងច្បាស់លាស់។ អស់ទាំងសេចក្ដីដែលត្រូវបានបង្គាប់ពីយ៉ូហាន គឺឲ្យគាត់ធ្វើជាអ្នកត្រួសត្រាយផ្លូវសម្រាប់ព្រះយេស៊ូវ គឺដើម្បីរៀបចំផ្លូវថ្វាយទ្រង់។ មានន័យថា ព្រះវិញ្ញាណបរិសុទ្ធរក្សាតែកិច្ចការរបស់គាត់ ក្នុងការត្រួសត្រាយផ្លូវ និងអនុញ្ញាតឲ្យគាត់ធ្វើតែកិច្ចការនេះប៉ុណ្ណោះ គឺគាត់មិនត្រូវបានអនុញ្ញាតឲ្យធ្វើកិច្ចការផ្សេងពីនេះឡើយ។ យ៉ូហានតំណាងឲ្យអេលីយ៉ា ហើយគាត់តំណាងឲ្យហោរាម្នាក់ដែលត្រួសត្រាយផ្លូវ។ ព្រះវិញ្ញាណបរិសុទ្ធបានរក្សាគាត់ទុកក្នុងរឿងនេះ ដរាបណាកិច្ចការរបស់គាត់ គឺជាការត្រួសត្រាយផ្លូវ នោះព្រះវិញ្ញាណបរិសុទ្ធនឹងរក្សាគាត់រហូត។ យ៉ាងណាមិញ ប្រសិនបើគាត់អះអាងថា គាត់ជាព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ ហើយនិយាយថា គាត់មកនេះដើម្បីបង្ហើយកិច្ចការនៃការប្រោសលោះនោះព្រះវិញ្ញាណបរិសុទ្ធ មុខជាត្រូវដាក់វិន័យគាត់មិនខាន។ ទោះបីកិច្ចការរបស់យ៉ូហានអស្ចារ្យយ៉ាងណា ហើយទោះបីជាកិច្ចការរបស់គាត់ ត្រូវបានព្រះវិញ្ញាណបរិសុទ្ធរក្សាទុក ក៏កិច្ចការនោះពុំមែនជាកិច្ចការដែលគ្មានព្រំដែនកំណត់នោះដែរ។ ដោយសំអាងថា ព្រះវិញ្ញាណបរិសុទ្ធ ពិតជារក្សាកិច្ចការរបស់គាត់មែន ក៏អំណាចដែលត្រូវបានប្រទានឲ្យគាត់នៅពេលនោះ គឺកំណត់ត្រឹមតែការត្រួសត្រាយផ្លូវរបស់គាត់ប៉ុណ្ណោះ។ គាត់មិនអាចធ្វើកិច្ចការណាផ្សេងទាល់តែសោះ ដ្បិតគាត់គ្រាន់តែជា

យ៉ូហាន ដែលត្រួសត្រាយផ្លូវតែប៉ុណ្ណោះ គឺពុំមែនជាព្រះយេស៊ូវទេ។ ដូច្នេះ ទីបន្ទាល់ព្រះវិញ្ញាណបរិសុទ្ធ គឺជាគន្លឹះសំខាន់ ប៉ុន្តែកិច្ចការដែលព្រះវិញ្ញាណបរិសុទ្ធអនុញ្ញាតឲ្យមនុស្សធ្វើ គឺរឹតតែសំខាន់ជាងទៅទៀត។ តើយ៉ូហានមិនបានទទួលនូវសក្ខីភាពដ៏ល្បីរន្ទឺនៅពេលនោះទេឬអី? តើកិច្ចការរបស់គាត់ មិនអស្ចារ្យដែរទេឬអី? ប៉ុន្តែ កិច្ចការដែលគាត់បានធ្វើ មិនអាចលើសកិច្ចការរបស់ព្រះយេស៊ូវឡើយ ដ្បិតគាត់គ្រាន់តែជាមនុស្សម្នាក់ដែលព្រះវិញ្ញាណបរិសុទ្ធប្រើប្រាស់ និងមិនអាចតំណាងឲ្យព្រះជាម្ចាស់ដោយផ្ទាល់បានឡើយ ដូច្នេះហើយ កិច្ចការដែលគាត់បានធ្វើក៏មានកម្រិត។ បន្ទាប់ពីគាត់បានបញ្ចប់កិច្ចការត្រួសត្រាយផ្លូវរួចហើយ ព្រះវិញ្ញាណបរិសុទ្ធលែងរក្សាទីបន្ទាល់របស់គាត់ទៀតហើយ ក្រោយមកទៀត គាត់ក៏គ្មានកិច្ចការអ្វីថ្មីដែរ ហើយគាត់បានចាកចេញទៅ នៅពេលដែលកិច្ចការរបស់ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ បានចាប់ផ្ដើម។

មានមនុស្សខ្លះត្រូវវិញ្ញាណអាក្រក់សណ្ឋិត ហើយស្រែកយ៉ាងកងរំពងថា «ខ្ញុំគឺជាព្រះជាម្ចាស់!» ប៉ុន្តែនៅទីបញ្ចប់ ពួកគេក៏ត្រូវបានបើកបង្ហាញ ដ្បិតពួកគេខុសពីអ្វីដែលគេតំណាង។ ពួកគេតំណាងឲ្យមារសាតាំង ហើយព្រះវិញ្ញាណបរិសុទ្ធមិនយកព្រះទ័យទុកដាក់នឹងពួកគេទេ។ ទោះបីអ្នកលើកតម្កើងខ្លួនឯងខ្ពស់យ៉ាងណា ឬទោះបីអ្នកស្រែកខ្លាំងយ៉ាងណា ក៏អ្នកនៅតែជាមនុស្ស ហើយជាមនុស្សដែលជាកម្មសិទ្ធិរបស់សាតាំងផង។ ខ្ញុំមិនដែលស្រែកថា «ខ្ញុំគឺជាព្រះជាម្ចាស់ ខ្ញុំគឺជាព្រះរាជបុត្រាស្ងួនភ្ញារបស់ព្រះជាម្ចាស់!» ឡើយ ប៉ុន្តែកិច្ចការដែលខ្ញុំធ្វើ គឺជាកិច្ចការរបស់ព្រះជាម្ចាស់។ តើខ្ញុំចាំបាច់អីត្រូវស្រែកដែរឬទេ? មិនចាំបាច់មានការលើកតម្កើងទេ។ ព្រះជាម្ចាស់ធ្វើកិច្ចការរបស់ទ្រង់ផ្ទាល់ដោយអង្គអ្នក ហើយមិនត្រូវការឲ្យមនុស្សថ្វាយឋានៈដល់ទ្រង់ ឬថ្វាយគោរមងារជាកិត្តិយសដល់ទ្រង់ឡើយៈ កិច្ចការរបស់ទ្រង់បង្ហាញឲ្យឃើញពីអត្តសញ្ញាណ និងឋានៈរបស់ទ្រង់។ មុនពេលព្រះយេស៊ូវធ្វើពិធីជ្រមុជទឹក តើព្រះអង្គមិនមែនជាព្រះជាម្ចាស់ផ្ទាល់ព្រះអង្គទេឬអី? តើព្រះអង្គមិនមែនជាសាច់ឈាមជាមនុស្សរបស់ព្រះជាម្ចាស់ទេឬអី? ប្រាកដណាស់ មិនអាចនិយាយបានថា ទាល់តែក្រោយពេលដែលទ្រង់បានទទួលសក្ខីភាព ទើបទ្រង់បានក្លាយជាព្រះរាជបុត្រាតែមួយ

របស់ព្រះជាម្ចាស់នោះឡើយ មែនទេ? មុនពេលដែលព្រះអង្គបានចាប់ផ្ដើមកិច្ចការរបស់ព្រះអង្គជាយូរមកហើយនោះ តើពុំមានមនុស្សម្នាក់ ដែលមានឈ្មោះថា យេស៊ូវ ស្រេចទៅហើយទេឬអី? អ្នកមិនអាចនាំមកនូវផ្លូវថ្មី ឬបង្ហាញឲ្យឃើញព្រះវិញ្ញាណបានឡើយ។ អ្នកមិនអាចបង្ហាញពីកិច្ចការរបស់ព្រះវិញ្ញាណ ឬព្រះបន្ទូលដែលទ្រង់ថ្លែងបានឡើយ។ អ្នកមិនអាចធ្វើកិច្ចការរបស់ព្រះជាម្ចាស់ផ្ទាល់បានឡើយ ហើយអ្នកក៏មិនអាចធ្វើកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធដែរ។ ព្រះប្រាជ្ញាញាណ ការអស្ចារ្យ និងភាពយល់មិនបានរបស់ព្រះជាម្ចាស់ ព្រមទាំងនិស្ស័យទាំងអស់របស់ព្រះជាម្ចាស់ដែលទ្រង់ប្រើមកវាយផ្ចាលមនុស្ស ទាំងអស់នេះសុទ្ធតែលើសពីសមត្ថភាពដែលអ្នកអាចបង្ហាញឲ្យឃើញបាន។ ដូច្នេះ ការព្យាយាមអះអាងខ្លួនឯងជាព្រះជាម្ចាស់ គឺមុខជាឥតប្រយោជន៍ទទេ។ អ្នកមានតែត្រឹមឈ្មោះ ហើយចំណែកឯលក្ខណៈវិញ គឺគ្មានសោះ។ ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គបានយាងមកហើយ ប៉ុន្តែគ្មាននរណាម្នាក់ទទួលស្គាល់ព្រះអង្គឡើយ ដោយឡែក ទ្រង់បន្តធ្វើកិច្ចការរបស់ព្រះអង្គ ហើយធ្វើកិច្ចការនោះក្នុងការសម្ដែងឲ្យឃើញពីព្រះវិញ្ញាណបរិសុទ្ធ។ ទោះបីជាអ្នកហៅទ្រង់ថា មនុស្ស ឬព្រះជាម្ចាស់ ព្រះអម្ចាស់ ឬព្រះគ្រីស្ទ ឬហៅទ្រង់ថា បងស្រី ក៏គ្មានបញ្ហាអ្វីដែរ។ ប៉ុន្តែ កិច្ចការដែលទ្រង់ធ្វើ គឺជាកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ និងតំណាងឲ្យកិច្ចការរបស់ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ។ ទ្រង់មិនខ្វល់ពីឈ្មោះដែលមនុស្សហៅទ្រង់នោះឡើយ។ តើឈ្មោះនោះអាចកំណត់កិច្ចការរបស់ទ្រង់ដែរឬទេ? ទោះបីជាអ្នកហៅទ្រង់តាមព្រះនាមអ្វីក៏ដោយ តាមព្រះតម្រិះព្រះជាម្ចាស់ ទ្រង់នៅតែជាសាច់ឈាមជាមនុស្សនៃព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ដដែល។ ប្រសិនបើអ្នកមិនអាចរៀបចំផ្លូវសម្រាប់យុគសម័យថ្មីមួយ ឬមិនអាចបញ្ចប់យុគសម័យចាស់ ឬមិនអាចចាប់ផ្ដើមយុគសម័យថ្មីមួយ ឬមិនអាចធ្វើកិច្ចការថ្មី នោះអ្នកមិនអាចឲ្យគេហៅថាជាព្រះជាម្ចាស់បានឡើយ!

សូម្បីតែមនុស្សម្នាក់ ដែលត្រូវបានព្រះវិញ្ញាណបរិសុទ្ធប្រើប្រាស់ ក៏មិនអាចតំណាងឲ្យព្រះជាម្ចាស់ផ្ទាល់បានដែរ។ នេះមិនមែនមានន័យត្រឹមថា មនុស្សបែបនេះ

មិនអាចតំណាងឲ្យព្រះជាម្ចាស់នោះទេ តែក៏មានន័យដែរថា កិច្ចការដែលគេធ្វើ មិនអាចតំណាងឲ្យព្រះជាម្ចាស់ដោយផ្ទាល់បានឡើយ។ ម្យ៉ាងទៀត បទពិសោធរបស់មនុស្ស មិនអាចដាក់ចូលដោយផ្ទាល់ ទៅក្នុងការគ្រប់គ្រងរបស់ព្រះជាម្ចាស់បានឡើយ ហើយបទពិសោធនោះ ក៏មិនអាចតំណាងឲ្យការគ្រប់គ្រងរបស់ព្រះជាម្ចាស់ដែរ។ កិច្ចការដែលព្រះជាម្ចាស់ធ្វើដោយផ្ទាល់ព្រះអង្គ គឺសុទ្ធតែជាកិច្ចការដែលទ្រង់ចង់ធ្វើនៅក្នុងផែនការគ្រប់គ្រងរបស់ព្រះអង្គផ្ទាល់ ហើយជាកិច្ចការដែលមានចំណែកដល់ការគ្រប់គ្រងដ៏ធំអស្ចារ្យ។ កិច្ចការដែលមនុស្សបានធ្វើ បន្សំឡើងដោយការផ្ដល់បទពិសោធរបស់ពួកគេរៀងខ្លួន។ វាបន្សំឡើង ពីការរកឃើញផ្លូវនៃបទពិសោធថ្មីមួយ ដែលលើសបទពិសោធមនុស្សសម័យមុនធ្លាប់ឆ្លងកាត់ និងជាផ្លូវនៃការដឹកនាំបងប្អូនប្រុសស្រីរបស់គេ ទាំងកំពុងស្ថិតក្រោមការដឹកនាំរបស់ព្រះវិញ្ញាណបរិសុទ្ធ។ អ្វីដែលមនុស្សទាំងអស់នេះផ្ដល់ឲ្យ គឺជាបទពិសោធរៀងៗខ្លួនរបស់គេ ឬជាសំណេរខាងព្រលឹងវិញ្ញាណរបស់មនុស្សខាងព្រលឹងវិញ្ញាណ។ ទោះបីមនុស្សទាំងនេះ ត្រូវបានព្រះវិញ្ញាណបរិសុទ្ធប្រើ ក៏កិច្ចការដែលពួកគេធ្វើ មិនមានពាក់ព័ន្ធនឹងកិច្ចការនៃការគ្រប់គ្រងដ៏ធំអស្ចារ្យ នៅក្នុងផែនការប្រាំមួយពាន់ឆ្នាំដែរ។ ពួកគេគ្រាន់តែជាមនុស្សដែលត្រូវបានបីបាច់ដោយព្រះវិញ្ញាណបរិសុទ្ធ នៅក្នុងសម័យកាលផ្សេងពីគ្នា ឲ្យដឹកនាំមនុស្សដែលនៅក្នុងលំហូររបស់ព្រះវិញ្ញាណបរិសុទ្ធ រហូតទាល់តែមុខងារដែលគេអាចបំពេញ ឈានដល់ទីបញ្ចប់ ឬរហូតទាល់តែជីវិតរបស់គេត្រូវបញ្ចប់។ កិច្ចការដែលពួកគេធ្វើ គ្រាន់តែជារៀបចំផ្លូវដ៏ត្រឹមត្រូវមួយ សម្រាប់ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ ឬបន្តនូវចំណុចជាក់លាក់មួយនៃការគ្រប់គ្រងរបស់ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គនៅលើផែនដី។ នៅក្នុងពួកគេផ្ទាល់ មនុស្សទាំងនេះមិនអាចធ្វើកិច្ចការដែលធំជាងការគ្រប់គ្រងរបស់ព្រះអង្គបានឡើយ ពួកគេក៏មិនអាចបើកបង្ហាញពីផ្លូវថ្មីៗ ហើយក្នុងចំណោមពួកគេ ក៏រឹតតែគ្មាននរណាអាចបញ្ចប់កិច្ចការទាំងអស់របស់ព្រះជាម្ចាស់តាំងពីយុគសម័យដើមបានឡើយ។ ដូច្នេះ កិច្ចការដែលពួកគេធ្វើ តំណាងត្រឹមមនុស្សម្នាក់ដែលកំពុងបំពេញមុខងាររបស់គេ និងមិនអាចតំណាងឲ្យព្រះជាម្ចាស់

ផ្ទាល់ព្រះអង្គ ដែលកំពុងបំពេញព័ន្ធកិច្ចរបស់ទ្រង់បានឡើយ។ នេះគឺដោយសារតែកិច្ចការដែលពួកគេធ្វើមិនដូចនឹងកិច្ចការដែលព្រះជាម្ចាស់ផ្ទាល់ព្រះអង្គធ្វើឡើយ។ កិច្ចការនៃការចាប់ផ្ដើមយុគសម័យថ្មី មិនមែនជាកិច្ចការដែលមនុស្សអាចធ្វើជំនួសព្រះជាម្ចាស់បានឡើយ។ កិច្ចការនេះគ្មាននរណាអាចធ្វើបាន ក្រៅតែពីព្រះជាម្ចាស់ផ្ទាល់ព្រះអង្គឡើយ។ កិច្ចការដែលមនុស្សបានធ្វើឡើង បន្សំឡើងដោយការបំពេញកាតព្វកិច្ចរបស់គេក្នុងនាមជាមនុស្ស និងត្រូវបានធ្វើឡើង ពេលដែលគេត្រូវបានបណ្ដាលចិត្ត ឬត្រូវបានស្រាយបំភ្លឺដោយព្រះវិញ្ញាណបរិសុទ្ធ។ ការដឹកនាំដែលមនុស្សទាំងអស់នេះផ្ដល់ជូន សុទ្ធតែបន្សំឡើងដោយការបង្ហាញឲ្យមនុស្សឃើញផ្លូវនៃការអនុវត្តក្នុងជីវិតប្រចាំថ្ងៃ និងបង្ហាញពីវិធីដែលគេគួរប្រព្រឹត្តស្របទៅតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់សុទ្ធសាធ។ កិច្ចការរបស់មនុស្ស ពុំមានពាក់ព័ន្ធនឹងការគ្រប់គ្រងរបស់ព្រះជាម្ចាស់ ហើយក៏មិនតំណាងឲ្យកិច្ចការរបស់ព្រះវិញ្ញាណដែរ។ ឧទាហរណ៍ កិច្ចការរបស់ស្មរបន្ទាល់ លី និង វ៉ចមែន នី គឺដើម្បីនាំផ្លូវ។ ទោះជាផ្លូវថ្មី ឬផ្លូវចាស់ ក៏កិច្ចការនេះសំអាងលើគោលការណ៍សេសសល់ក្នុងព្រះគម្ពីរ។ ទោះបីកិច្ចការរបស់គេ ជាការស្ដារពួកជំនុំក្នុងតំបន់ ឬជាការកសាងពួកជំនុំក្នុងតំបន់ ក៏កិច្ចការនោះមានការពាក់ព័ន្ធនឹងការស្ថាបនាពួកជំនុំដែរ។ កិច្ចការដែលពួកគេធ្វើ ត្រូវបានអនុវត្តលើកិច្ចការដែលព្រះយេស៊ូវនិងពួកសិស្សរបស់ទ្រង់មិនទាន់បានបង្ហើយ ឬមិនបានវិវឌ្ឍទៅមុខទៀត នៅក្នុងយុគសម័យនៃព្រះគុណ។ អ្វីដែលពួកគេធ្វើនៅក្នុងកិច្ចការរបស់គេ គឺស្ដារនូវអ្វី ដែលព្រះយេស៊ូវបានបង្គាប់ពីមនុស្សជំនាន់ក្រោយៗបន្ទាប់ពីទ្រង់ នៅក្នុងកិច្ចការដើមរបស់ទ្រង់ ដូចជា ការគ្របក្បាលរបស់គេឲ្យជាប់ ការទទួលពិធីជ្រមុជទឹក ការកាច់នំបុ័ង ឬការផឹកស្រាជាដើម។ អាចនិយាយបានថា កិច្ចការដែលគេធ្វើ គឺកាន់ខ្ជាប់តាមព្រះគម្ពីរ និងស្វះស្វែងរកមាគ៌ានៅក្នុងព្រះគម្ពីរ។ ពួកគេមិនបានបង្កើតការវិវឌ្ឍថ្មីអ្វីទាល់តែសោះ។ ដូច្នេះ មនុស្សម្នាក់អាចមើលឃើញតែត្រឹមការរកឃើញផ្លូវថ្មីៗ នៅក្នុងព្រះគម្ពីរ ក៏ដូចជាការអនុវត្តនានាដែលល្អប្រសើរ និងមានភាពប្រាកដប្រជាជាងនេះ នៅក្នុងកិច្ចការរបស់គេ។ តែនៅក្នុងកិច្ចការរបស់

ខ្លួន មនុស្សម្នាក់មិនអាចរកឃើញបំណងព្រះហឫទ័យបច្ចុប្បន្នរបស់ព្រះជាម្ចាស់បានឡើយ ហើយរឹតតែមិនអាចរកឃើញកិច្ចការថ្មីដែលព្រះជាម្ចាស់ក្នុងគ្រាចុងក្រោយនេះ គ្រោងនឹងធ្វើបានដែរ។ នេះមកពីផ្លូវដែលគេដើរ នៅតែជាផ្លូវចាស់ គឺគ្មានការកែប្រែថ្មី និងគ្មានការវិវឌ្ឍអ្វីសោះ។ ពួកគេបន្តប្រកាន់ខ្ជាប់នូវការពិតអំពីការជាប់ឆ្កាងរបស់ព្រះយេស៊ូវ ដើម្បីរក្សាទម្លាប់នៃការបង្គាប់ឲ្យមនុស្សកែប្រែចិត្ត និងលន់តួបាបរបស់គេ ដើម្បីប្រកាន់ខ្ជាប់នូវពំនោលថា អស់អ្នកដែលទ្រាំទ្រដល់ទីបញ្ចប់នឹងបានសង្គ្រោះ និងពំនោលថា បុរសគឺជាប្រមុខរបស់ស្ត្រី ហើយស្ត្រីត្រូវតែស្ដាប់តាមស្វាមីរបស់នាង និងប្រកាន់ខ្ជាប់រឹតតែខ្លាំង តាមសញ្ញាណពីបុរាណថា បងប្អូនស្រីៗ មិនអាចអធិប្បាយព្រះបន្ទូលឡើយ បានត្រឹមស្ដាប់បង្គាប់តែប៉ុណ្ណោះ។ ប្រសិនបើគេនៅបន្តប្រកាន់ខ្ជាប់ តាមលក្ខណៈនៃភាពជាអ្នកដឹកនាំបែបនេះ នោះព្រះវិញ្ញាណបរិសុទ្ធនឹងមិនអាចអនុវត្តកិច្ចការថ្មី មិនអាចប្រោសមនុស្សឲ្យរួចពីគោលលទ្ធិ ឬមិនអាចដឹកនាំពួកគេទៅក្នុងពិភពមួយដែលមានតែសេរីភាព និងសម្រស់ស្រស់ត្រកាលបានឡើយ។ ហេតុនេះ ដំណាក់កាលកិច្ចការនេះ គឺជាដំណាក់កាលដែលផ្លាស់ប្ដូរយុគសម័យ ត្រូវតែធ្វើឡើង និងត្រូវថ្លែងចេញដោយព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ ពុំនោះទេ គ្មាននរណាម្នាក់អាចធ្វើកិច្ចការនេះជំនួសទ្រង់បានឡើយ។ រហូតមកទល់បច្ចុប្បន្ននេះ កិច្ចការទាំងអស់របស់ព្រះវិញ្ញាណបរិសុទ្ធដែលស្ថិតនៅក្រៅលំហូរនេះគឺនៅទ្រឹង ហើយអស់អ្នកដែលព្រះវិញ្ញាណបរិសុទ្ធប្រើ ក៏បានបាត់បង់ការស៊ូទ្រាំរបស់ពួកគេដែរ។ ដូច្នេះ ដោយសារតែកិច្ចការរបស់មនុស្សដែលព្រះវិញ្ញាណបរិសុទ្ធប្រើ មិនដូចនឹងកិច្ចការដែលធ្វើឡើងដោយព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ នោះអត្តសញ្ញាណរបស់គេ និងប្រធានបទដែលគេប្រព្រឹត្តជំនួសនោះ ក៏ខុសគ្នាទៅតាមនោះដែរ។ នេះគឺមកពីកិច្ចការដែលព្រះវិញ្ញាណមានបំណងចង់ធ្វើ មានលក្ខណៈខុសគ្នា ហើយចំពោះរឿងនេះ អស់អ្នកណាដែលធ្វើកិច្ចការដូចគ្នា ត្រូវបានសម្រេចតាមអត្តសញ្ញាណ និងឋានៈផ្សេងៗគ្នារបស់ពួកគេ។ មនុស្សដែលត្រូវបានព្រះវិញ្ញាណបរិសុទ្ធប្រើប្រាស់ ក៏អាចធ្វើកិច្ចការខ្លះដែលជាកិច្ចការថ្មី និងអាចផាត់ចោលកិច្ចការខ្លះ ដែលត្រូវបាន

ធ្វើនៅក្នុងយុគសម័យចាស់ផងដែរ ប៉ុន្តែអ្វីដែលពួកគេធ្វើ មិនអាចបង្ហាញឲ្យឃើញពីនិស្ស័យ និងបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់នៅក្នុងយុគសម័យថ្មីបានឡើយ។ ពួកគេធ្វើការ ដើម្បីបញ្ចប់កិច្ចការក្នុងយុគសម័យចាស់តែប៉ុណ្ណោះ មិនមែនដើម្បីធ្វើកិច្ចការថ្មី ក្នុងគោលបំណងបង្ហាញឲ្យឃើញផ្ទាល់នូវនិស្ស័យរបស់ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គនោះឡើយ។ ដូច្នេះ ទោះបីជាពួកគេលុបបំបាត់នូវទំនៀមទម្លាប់ហួសសម័យច្រើនយ៉ាងណា ឬឧទ្ទេសនាមនូវទំនៀមទម្លាប់ថ្មីច្រើនប៉ុនណា ក៏ពួកគេនៅតែតំណាងឲ្យមនុស្ស និងសភាវៈដែលព្រះជាម្ចាស់បង្កើតមកដដែល។ យ៉ាងណាមិញ កាលណាព្រះជាម្ចាស់ផ្ទាល់ព្រះអង្គអនុវត្តកិច្ចការ នោះទ្រង់មិនប្រកាសពីការលុបបំបាត់ទំនៀមទម្លាប់នានាក្នុងយុគសម័យចាស់ ឬប្រកាសពីការចាប់ផ្តើមយុគសម័យថ្មីដោយផ្ទាល់នោះទេ។ ទ្រង់ធ្វើកិច្ចការរបស់ទ្រង់ត្រង់ៗ និងចំៗ។ ក្នុងការបំពេញកិច្ចការដែលទ្រង់ចង់ធ្វើ គឺទ្រង់ឥតលាក់លៀមសោះ ពោលគឺទ្រង់បង្ហាញចេញមកត្រង់ៗនូវកិច្ចការដែលទ្រង់បាននាំមក ក៏ធ្វើកិច្ចការរបស់ទ្រង់ចំៗ ដូចដែលទ្រង់ចង់បានកាលពីដើមទាំងបង្ហាញនូវអត្ថិភាព និងនិស្ស័យរបស់ទ្រង់ផង។ និស្ស័យរបស់ទ្រង់ និងកិច្ចការរបស់ទ្រង់ ក៏ខុសគ្នាពីអ្វីដែលមានក្នុងយុគសម័យចាស់ដែរ ដូចមនុស្សឃើញស្រាប់ហើយ។ យ៉ាងណាមិញ តាមទស្សនៈរបស់ព្រះជាម្ចាស់ផ្ទាល់ នេះគ្រាន់តែជាការបន្ត និងជាវិវឌ្ឍន៍បន្ថែមនៃកិច្ចការរបស់ទ្រង់ប៉ុណ្ណោះ។ កាលណាព្រះជាម្ចាស់ផ្ទាល់ទ្រង់ធ្វើការ ទ្រង់ក៏បង្ហាញព្រះបន្ទូលរបស់ទ្រង់ និងនាំយកកិច្ចការថ្មីមកដោយផ្ទាល់តែម្តង។ ផ្ទុយទៅវិញ ពេលមនុស្សធ្វើការ កិច្ចការថ្មីបានមកតាមរយៈការពិភាក្សា និងការសិក្សា ឬវាជាការពង្រីកចំណេះដឹង និងជាការរៀបចំទំនៀមទម្លាប់ជាប្រព័ន្ធ ដោយចាក់គ្រឹះលើកិច្ចការរបស់អ្នកដទៃ។ មានន័យថា សារជាតិនៃកិច្ចការដែលមនុស្សបានធ្វើឡើង គឺអនុវត្តតាមលំដាប់លំដោយដែលត្រូវបានស្ថាបនាឡើងជាស្រេច ហើយ «ដើរលើផ្លូវចាស់ ដោយពាក់ស្បែកជើងថ្មី»។ នេះមានន័យថា សូម្បីផ្លូវដែលដើរដោយមនុស្សដែលព្រះវិញ្ញាណបរិសុទ្ធប្រើប្រាស់ ក៏ត្រូវបានកសាងលើគ្រឹះដែលព្រះជាម្ចាស់ផ្ទាល់ ជាអ្នកចាប់ផ្តើមដែរ។ ដូច្នេះ កាលណាគ្រប់យ៉ាងត្រូវបានពោល និងធ្វើរួចហើយ

មនុស្ស គឺនៅតែជាមនុស្ស ហើយព្រះជាម្ចាស់ គឺនៅតែជាព្រះជាម្ចាស់ដដែល។

យ៉ូហានបានកើតមកតាមសេចក្ដីសន្យា ដូចគ្នានឹងអ៊ីសាក ដែលកើតមកជាកូនអ័ប្រាហាំដែរ។ គាត់បានត្រួសត្រាយផ្លូវថ្វាយព្រះយេស៊ូវ និងបានធ្វើកិច្ចការជាច្រើន ប៉ុន្តែគាត់មិនមែនជាព្រះជាម្ចាស់ទេ។ ផ្ទុយទៅវិញ គាត់គឺជាម្នាក់ក្នុងចំណោមពួកហោរា ដ្បិតគាត់គ្រាន់តែត្រួសត្រាយផ្លូវថ្វាយព្រះយេស៊ូវប៉ុណ្ណោះ។ កិច្ចការរបស់គាត់ក៏អស្ចារ្យដែរ ហើយទាល់តែពេលដែលគាត់បានត្រួសត្រាយផ្លូវរួច ទើបព្រះយេស៊ូវចាប់ផ្ដើមធ្វើកិច្ចការរបស់ទ្រង់ជាផ្លូវការ។ ក្នុងន័យនេះ គាត់គ្រាន់តែពលីកម្លាំងថ្វាយព្រះយេស៊ូវ ហើយកិច្ចការដែលគាត់ធ្វើ គឺជាការបម្រើដល់កិច្ចការរបស់ព្រះយេស៊ូវ។ បន្ទាប់ពីគាត់បានបញ្ចប់ការត្រួសត្រាយផ្លូវរួច ព្រះយេស៊ូវក៏ចាប់ផ្ដើមកិច្ចការរបស់ទ្រង់ ជាកិច្ចការដែលថ្មីជាង ច្បាស់លាស់ជាង និងពិស្ដារជាង។ យ៉ូហានបានធ្វើតែត្រឹមចំណែកនៃការចាប់ផ្ដើមកិច្ចការតែប៉ុណ្ណោះ រីឯចំណែកដ៏ធំនៃកិច្ចការថ្មី ត្រូវបានធ្វើឡើងដោយព្រះយេស៊ូវវិញ។ យ៉ូហានក៏បានធ្វើកិច្ចការថ្មីដែរ ប៉ុន្តែគាត់គ្រាន់តែជាមនុស្សម្នាក់ដែលបានចាប់ផ្ដើមយុគសម័យថ្មីមួយប៉ុណ្ណោះ។ យ៉ូហានបានកើតមកតាមសេចក្ដីសន្យា ហើយឈ្មោះរបស់គាត់ ក៏ទេវតាជាអ្នកដាក់ឲ្យដែរ។ នៅគ្រានោះ មានមនុស្សខ្លះចង់ដាក់ឈ្មោះគាត់តាមឈ្មោះរបស់ឪពុកគាត់ គឺសាការី ប៉ុន្តែម្ដាយគាត់ក៏បន្លឺសំឡេងឡើង ដោយនិយាយថា «កូននេះមិនអាចហៅតាមឈ្មោះរបស់ឪពុកវាឡើយ។ គួរហៅវាថា យ៉ូហាន វិញ»។ ការណ៍នេះគឺជាការបង្គាប់របស់ព្រះវិញ្ញាណបរិសុទ្ធសុទ្ធសាធ។ ព្រះយេស៊ូវក៏ត្រូវបានថ្វាយព្រះនាម តាមការបង្គាប់របស់ព្រះវិញ្ញាណបរិសុទ្ធដែរ ទ្រង់ប្រសូតពីព្រះវិញ្ញាណបរិសុទ្ធ ហើយទ្រង់ក៏ត្រូវបានសន្យាដោយព្រះវិញ្ញាណបរិសុទ្ធដែរ។ ព្រះយេស៊ូវ គឺជាព្រះជាម្ចាស់ ជាព្រះគ្រីស្ទ និងជាកូនមនុស្ស។ កិច្ចការរបស់យ៉ូហាន ក៏ជាកិច្ចការដ៏អស្ចារ្យដែរ ចុះហេតុអ្វីបានជាគេមិនហៅគាត់ថា ព្រះជាម្ចាស់? មែនទែនទៅ តើអ្វីជាភាពខុសគ្នារវាងកិច្ចការដែលត្រូវបានធ្វើឡើងដោយព្រះយេស៊ូវ និងកិច្ចការដែលត្រូវបានធ្វើឡើងដោយយ៉ូហាន? ហេតុផលតែមួយគត់នោះ គឺមកពីយ៉ូហានជាអ្នកដែលត្រួសត្រាយផ្លូវថ្វាយព្រះយេស៊ូវ មែនទេ? ឬមកពីការណ៍នេះត្រូវ

បានព្រះជាម្ចាស់កំណត់ទុក? ទោះបីជាយ៉ូហានធ្លាប់និយាយថា «ចូរអ្នករាល់គ្នាប្រែចិត្ត ដ្បិតនគរព្រះនៅជិតបង្កើយ» ហើយគាត់ធ្លាប់ផ្សាយដំណឹងល្អអំពីនគរស្ថានសួគ៌ដែរក៏ដោយ ក៏កិច្ចការរបស់គាត់ មិនរីវឌ្ឍន៍បន្ថែម និងគ្រាន់តែតាក់តែងឲ្យមានការចាប់ផ្ដើមមួយប៉ុណ្ណោះ។ ផ្ទុយទៅវិញ ព្រះយេស៊ូវបានចាប់ផ្ដើមយុគសម័យថ្មី និងបានបញ្ចប់យុគសម័យទៀតផង តែទ្រង់ក៏បានសម្រេចក្រឹត្យវិន័យក្នុងគម្ពីរសញ្ញាចាស់ផងដែរ។ កិច្ចការដែលទ្រង់ធ្វើ ជាកិច្ចការដែលអស្ចារ្យជាងកិច្ចការរបស់យ៉ូហាន ហើយសំខាន់ជាងនេះ គឺទ្រង់យាងមកប្រោសលោះមនុស្សជាតិទាំងអស់ ទ្រង់បានសម្រេចដំណាក់កាលនៃកិច្ចការនោះរួចហើយ។ ចំណែកយ៉ូហានវិញ គាត់គ្រាន់តែរៀបចំផ្លូវប៉ុណ្ណោះ។ ទោះបីកិច្ចការរបស់គាត់ ជាកិច្ចការអស្ចារ្យ ពាក្យសម្ដីដែលគាត់បង្រៀនមានច្រើន ហើយសិស្សដែលដើរតាមគាត់ក៏មានច្រើនដែរនោះ ក៏កិច្ចការដែលគាត់ធ្វើវាមិនលើសពីការនាំយកការចាប់ផ្ដើមថ្មីមួយ មកឲ្យមនុស្សដែរ។ មនុស្សពុំដែលទទួលបានជីវិត ទទួលបានផ្លូវ ឬទទួលបានសេចក្ដីពិតស៊ីជម្រៅជាងមុនពីគាត់ដែរ ហើយគេក៏មិនទទួលបាននូវការយល់ដឹងពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ដោយសារគាត់នោះដែរ។ យ៉ូហានគឺជាហោរដ៏អស្ចារ្យម្នាក់ (អេលីយ៉ា) ដែលបានបើកបង្ហាញនូវមូលបទថ្មី សម្រាប់កិច្ចការរបស់ព្រះយេស៊ូវ និងបានរៀបចំសម្រាប់មនុស្សជ្រើសតាំង។ គាត់ជាអ្នកនាំមុខនៃយុគសម័យនៃព្រះគុណ។ រឿងរ៉ាវបែបនេះ មិនអាចមើលដឹងដោយគ្រាន់តែសង្កេតមើលសំបកកាយជាមនុស្សរបស់ពួកគេឡើយ។ រឿងនេះកាន់តែសមទាំងអស់ ដ្បិតយ៉ូហានក៏បានធ្វើកិច្ចការច្រើនគួរសម ហើយជាងនេះទៀត គាត់ក៏ត្រូវបានសន្យាដោយព្រះវិញ្ញាណបរិសុទ្ធដែរ ហើយកិច្ចការរបស់គាត់ត្រូវបានរក្សាដោយព្រះវិញ្ញាណបរិសុទ្ធទៀតផង។ ហេតុដូច្នេះហើយ គឺមានតែតាមរយៈកិច្ចការដែលពួកគេធ្វើនេះទេ ទើបគេអាចបែងចែកអត្តសញ្ញាណរៀងៗខ្លួន របស់ពួកគេបាន ដ្បិតគ្មានផ្លូវអាចឲ្យមនុស្សប្រាប់ពីសារជាតិរបស់មនុស្ស ដោយសំអាងលើរូបរាងខាងក្រៅរបស់គេបានឡើយ ហើយក៏គ្មានផ្លូវណាអាចឲ្យមនុស្សប្រាកដច្បាស់ថា ទីបន្ទាល់របស់ព្រះវិញ្ញាណបរិសុទ្ធ គឺជាអ្វីនោះឡើយ។ កិច្ចការដែលត្រូវបានធ្វើ

ដោយយ៉ូហាន និងកិច្ចការដែលត្រូវបានធ្វើដោយព្រះយេស៊ូវ គឺមិនដូចគ្នាទេ ហើយក៏មានលក្ខណៈខុសគ្នាដែរ។ គឺដោយសារលក្ខណៈនេះហើយ ទើបមនុស្សអាចកំណត់បានថា យ៉ូហានគឺជាព្រះជាម្ចាស់ ឬក៏មិនមែន។ កិច្ចការរបស់ព្រះយេស៊ូវគឺចាប់ផ្ដើម បន្ត បង្ហើយ និងនាំមកនូវការបង្កើតផលផ្លែ។ ទ្រង់អនុវត្តកិច្ចការជំហាននីមួយៗក្នុងចំណោមជំហានទាំងអស់នេះ ខណៈដែលកិច្ចការរបស់យ៉ូហាន គ្មានអ្វីក្រៅតែពីការបង្កើតនូវការចាប់ផ្ដើមមួយប៉ុណ្ណោះ។ ដំបូងឡើយ ព្រះយេស៊ូវផ្សាយដំណឹងល្អ និងផ្សាយប្រាប់ពីផ្លូវនៃការប្រែចិត្ត រួចបន្តទៅធ្វើបុណ្យជ្រមុជទឹកឲ្យមនុស្ស ប្រោសមនុស្សឈឺ និងបណ្ដេញវិញ្ញាណអាក្រក់។ ចុងក្រោយ ទ្រង់ក៏ប្រោសលោះមនុស្សជាតិទាំងអស់ពីអំពើបាប រួចបង្ហើយកិច្ចការរបស់ទ្រង់សម្រាប់យុគសម័យទាំងមូល។ ទ្រង់ក៏បានយាងទៅគ្រប់ទីកន្លែង ទាំងផ្សាយប្រាប់មនុស្ស និងផ្សាយដំណឹងល្អអំពីនគរស្ថានសួគ៌ទៀតផង។ ចំពោះរឿងនេះ ព្រះអង្គ និងយ៉ូហាន មានដូចគ្នា ចំណែកភាពខុសគ្នាវិញគឺ ព្រះយេស៊ូវបានចាប់ផ្ដើមយុគសម័យថ្មីមួយ ហើយនាំយកយុគសម័យនៃព្រះគុណមកឲ្យមនុស្សលោក។ ព្រះបន្ទូលស្ដីពីអ្វីដែលមនុស្សគួរអនុវត្ត និងអ្វីដែលមនុស្សគួរប្រព្រឹត្តតាម នៅក្នុងយុគសម័យនៃក្រឹត្យវិន័យ ក៏ចេញមកពីព្រះឱស្ឋរបស់ទ្រង់ដែរ ហើយនៅទីបញ្ចប់ ទ្រង់ក៏បញ្ចប់កិច្ចការនៃការប្រោសលោះ។ យ៉ូហានពុំដែលធ្លាប់អនុវត្តកិច្ចការនេះបានសោះ។ ដូច្នេះហើយ គឺមានតែព្រះយេស៊ូវទេដែលបានធ្វើកិច្ចការរបស់ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គបាន ហើយព្រះអង្គគឺជាព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ ព្រមទាំងតំណាងឲ្យព្រះជាម្ចាស់ដោយផ្ទាល់ផង។ សញ្ញាណរបស់មនុស្សពោលថា អស់អ្នកណាដែលកើតមកដោយសេចក្ដីសន្យា កើតពីព្រះវិញ្ញាណ ថែរក្សាដោយព្រះវិញ្ញាណបរិសុទ្ធ និងអស់អ្នកដែលបើកផ្លូវថ្មីៗ គឺជាព្រះ។ យោងតាមការលើកហេតុផលបែបនេះ យ៉ូហានគឺច្បាស់ជាព្រះជាម្ចាស់ ហើយម៉ូសេ អ័ប្រាហាំ និងដាវីឌ ... តើពួកគេមិនមែនជាព្រះជាម្ចាស់ គ្រប់តែគ្នាទេឬអី? តើនេះមិនមែនជារឿងកំប្លែងទាំងស្រុងទេឬអី?

មុនពេលបំពេញព័ន្ធកិច្ចរបស់ទ្រង់ ព្រះយេស៊ូវ គ្រាន់តែជាមនុស្សធម្មតាម្នាក់

ដែលបានប្រព្រឹត្តស្របតាមអ្វីៗគ្រប់យ៉ាងដែលព្រះវិញ្ញាណបរិសុទ្ធធ្វើប៉ុណ្ណោះ។ បើទោះបីជាពេលនោះ ទ្រង់មិនស្គាល់អត្តសញ្ញាណរបស់ទ្រង់ផ្ទាល់ ក៏ទ្រង់ស្ដាប់តាមគ្រប់យ៉ាងដែលមកពីព្រះជាម្ចាស់ដែរ។ ព្រះវិញ្ញាណបរិសុទ្ធ មិនដែលសម្ដែងប្រាប់ពីអត្តសញ្ញាណរបស់ទ្រង់ មុនពេលដែលព័ន្ធកិច្ចរបស់ទ្រង់ចាប់ផ្ដើមនោះទេ។ មានតែក្រោយពេល ដែលទ្រង់បានចាប់ផ្ដើមព័ន្ធកិច្ចរបស់ទ្រង់ប៉ុណ្ណោះទេ ទើបទ្រង់បានលុបបំបាត់ច្បាប់ និងក្រឹត្យក្រមទាំងអស់នោះ ហើយទាល់តែដល់ពេលដែលទ្រង់បានចាប់ផ្ដើមបំពេញព័ន្ធកិច្ចរបស់ទ្រង់ជាផ្លូវការ ទើបព្រះបន្ទូលរបស់ទ្រង់បានជ្រួតជ្រាបដោយសិទ្ធិអំណាច និងព្រះចេស្ដា។ លុះក្រោយពេល ដែលទ្រង់បានចាប់ផ្ដើមព័ន្ធកិច្ចរបស់ទ្រង់ ទើបកិច្ចការរបស់ទ្រង់នាំយុគសម័យថ្មីមួយឲ្យចាប់ផ្ដើមឡើង។ មុនពេលនេះ ព្រះវិញ្ញាណបរិសុទ្ធបាននៅលាក់កំបាំងនៅក្នុងព្រះអង្គ អស់រយៈពេល២៩ឆ្នាំ ជាពេលដែលទ្រង់បានបង្ហាញឲ្យឃើញតែមនុស្សម្នាក់ និងគ្មានអត្តសញ្ញាណជាព្រះជាម្ចាស់ទេ។ កិច្ចការរបស់ព្រះជាម្ចាស់ បានចាប់ផ្ដើមជាមួយទ្រង់ក្នុងពេលកំពុងធ្វើការ និងកំពុងបំពេញព័ន្ធកិច្ចរបស់ទ្រង់ ទ្រង់បានចាប់ផ្ដើមធ្វើកិច្ចការស្របទៅតាមផែនការដែលមាននៅក្នុងព្រះអង្គ ដោយមិនខ្វល់ថា មនុស្សស្គាល់ពីទ្រង់ប៉ុនណានោះឡើយ ហើយកិច្ចការដែលទ្រង់ធ្វើ ក៏ជាការបង្ហាញឲ្យឃើញផ្ទាល់ពីព្រះជាម្ចាស់ផ្ទាល់ព្រះអង្គដែរ។ នៅវេលានោះ ព្រះយេស៊ូវបានសួរទៅមនុស្សដែលនៅជុំវិញព្រះអង្គថា «តើអ្នករាល់គ្នាថា ខ្ញុំជានរណា?» ពួកគេទូលតបថា «ព្រះអង្គជាហោរាដ៏ធំឧត្ដមជាងគេ ហើយជាគ្រូពេទ្យដ៏ពូកែរបស់យើងរាល់គ្នា»។ ហើយអ្នកខ្លះទៀតតបថា «ទ្រង់ជាមហាបូជាចារ្យរបស់យើង» ។ល។ គេក៏បានផ្ដល់ចម្លើយគ្រប់ប្រភេទ មានអ្នកខ្លះទៀតថែមទាំងពោលថា ទ្រង់ជាយ៉ូហាន ជាអេលីយ៉ា ជាដើម។ រួចព្រះយេស៊ូវក៏បែរទៅស៊ីម៉ូនពេត្រុស ហើយសួរថា «តើអ្នកថា ខ្ញុំជានរណា?» ពេត្រុសក៏ទូលឆ្លើយថា «ទ្រង់គឺជាព្រះគ្រីស្ទ ជាព្រះរាជបុត្រា នៃព្រះដ៏មានព្រះជន្មគង់នៅ»។ តាំងពីពេលនោះមក មនុស្សក៏ចាប់ផ្ដើមដឹងថា ទ្រង់គឺជាព្រះជាម្ចាស់។ ពេលដែលអត្តសញ្ញាណរបស់ទ្រង់ ត្រូវបានសម្ដែងឲ្យគេស្គាល់ គឺពេត្រុសនេះហើយជាអ្នកដែលដឹងរឿងនេះមុនគេ ហើយរឿងនេះក៏ត្រូវបាន

ថ្លែងចេញពីមាត់របស់គាត់ដែរ។ ក្រោយមក ព្រះយេស៊ូវក៏ថ្លែងថា «អ្វីដែលអ្នកបានពោលនេះ មិនមែនចេញពីសាច់ឈាមទេ តែចេញមកពីព្រះវរបិតារបស់ខ្ញុំទេតើ»។ បន្ទាប់ពីពិធីជ្រមុជទឹករបស់ទ្រង់រួច ទោះបីជាអ្នកដទៃមិនដឹងរឿងនេះក៏ដោយ ក៏កិច្ចការដែលទ្រង់ធ្វើ គឺជាកិច្ចការដែលទ្រង់ធ្វើជំនួសមុខឲ្យព្រះជាម្ចាស់ដែរ។ ទ្រង់បានយាងមកដើម្បីអនុវត្តកិច្ចការរបស់ទ្រង់ មិនមែនដើម្បីសម្ដែងពីអត្តសញ្ញាណរបស់ទ្រង់ឡើយ។ លុះក្រោយពេលដែលពេត្រុសបាននិយាយអំពីរឿងនេះ ទើបអត្តសញ្ញាណរបស់ទ្រង់ត្រូវបានបង្ហាញឲ្យគេដឹងដោយបើកចំហ។ ទោះបីជាអ្នកមិនដឹងថា ទ្រង់គឺជាព្រះជាម្ចាស់ផ្ទាល់ក៏ដោយ លុះដល់ពេលកំណត់ ក៏ទ្រង់ចាប់ផ្ដើមកិច្ចការរបស់ទ្រង់ដែរ។ ហើយទោះបីជាអ្នកមិនដឹងពីរឿងនោះ ក៏ទ្រង់នៅតែបន្តធ្វើកិច្ចការរបស់ទ្រង់ដូចពីមុនដែរ។ បើទោះបីជាអ្នកបដិសេធរឿងនេះ ក៏ទ្រង់នឹងនៅតែបំពេញកិច្ចការរបស់ទ្រង់ ហើយនិងអនុវត្តកិច្ចការនោះ តាមពេលវេលាដែលត្រូវធ្វើដែរ។ ទ្រង់បានយាងមកដើម្បីធ្វើកិច្ចការរបស់ទ្រង់ និងបំពេញព័ន្ធកិច្ចរបស់ទ្រង់ មិនមែនមកដើម្បីឲ្យមនុស្សស្គាល់សាច់ឈាមរបស់ទ្រង់ឡើយ តែដើម្បីឲ្យមនុស្សទទួលកិច្ចការរបស់ទ្រង់វិញ។ ប្រសិនបើអ្នកបរាជ័យក្នុងការទទួលស្គាល់ថា កិច្ចការដំណាក់កាលបច្ចុប្បន្ននេះ គឺជាកិច្ចការរបស់ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ នោះគឺមកពីអ្នកខ្វះនូវនិមិត្ត។ តែយ៉ាងណាក៏ដោយ អ្នកមិនអាចបដិសេធកិច្ចការក្នុងដំណាក់កាលនេះបានទេ ការខកខានរបស់អ្នក ក្នុងការទទួលស្គាល់កិច្ចការនេះ មិនបញ្ជាក់ថា ព្រះវិញ្ញាណបរិសុទ្ធមិនមែនកំពុងធ្វើការ ឬបញ្ជាក់ថា កិច្ចការរបស់ទ្រង់ ជាកិច្ចការខុសឆ្គងនោះដែរ។ មានអ្នកខ្លះទៀតថែមទាំងយកកិច្ចការបច្ចុប្បន្ន ទៅផ្ទៀងផ្ទាត់នឹងកិច្ចការរបស់ព្រះយេស៊ូវនៅក្នុងព្រះគម្ពីរ ហើយប្រើភាពខុសប្រក្រតីណាមួយ មកបដិសេធកិច្ចការក្នុងដំណាក់កាលនេះទៀតផង។ តើនេះមិនមែនជាសកម្មភាពរបស់មនុស្សមោហ៍បាំងទេឬអី? សេចក្ដីនានាដែលត្រូវបានកត់ត្រាក្នុងព្រះគម្ពីរ មានកម្រិត សេចក្ដីទាំងនោះមិនអាចបង្ហាញពីកិច្ចការរបស់ព្រះជាម្ចាស់ទាំងស្រុងបានឡើយ។ ដំណឹងល្អទាំងបួនរួមគ្នាទាំងអស់ មានមិនដល់មួយរយចំពូកផង ក្នុងនោះមានសរសេរតែព្រឹត្តិការណ៍មួយចំនួន

តូចប៉ុណ្ណោះ ដូចជា ព្រះយេស៊ូវដាក់បណ្ដាសាដើមឧទុម្ពរ ពេត្រុសបដិសេធបីដងថាមិនស្គាល់ព្រះអម្ចាស់ ព្រះយេស៊ូវលេចមកឲ្យពួកសិស្សឃើញបន្ទាប់ពីការជាប់ឆ្កាង និងការរស់ឡើងវិញរបស់ទ្រង់ សេចក្ដីបង្រៀនអំពីការតមអាហារ សេចក្ដីបង្រៀនអំពីការអធិដ្ឋាន សេចក្ដីបង្រៀនអំពីការលែងលះ ការប្រសូត និងពង្សាវតារបស់ព្រះយេស៊ូវ ការជ្រើសតាំងពួកសិស្សរបស់ព្រះយេស៊ូវ ។ល។ យ៉ាងណាមិញ មនុស្សឲ្យតម្លៃសេចក្ដីទាំងនេះដូចកំណប់ ថែមទាំងយកកិច្ចការបច្ចុប្បន្នទៅប្រៀបធៀបនឹងសេចក្ដីទាំងនោះផង។ ពួកគេថែមទាំងជឿទៀតថា កិច្ចការទាំងអស់ដែលព្រះយេស៊ូវបានធ្វើក្នុងគ្រាដែលទ្រង់រស់នៅលើផែនដី គឺមានតែត្រឹមប៉ុណ្ណឹង ហាក់ដូចជាព្រះជាម្ចាស់មានសមត្ថភាពធ្វើការត្រឹមប៉ុណ្ណឹង និងគ្មានអ្វីលើសពីនេះទេ។ តើនេះមិនមែនជារឿងលេលាទេឬអី?

ពេលវេលាដែលព្រះយេស៊ូវមាននៅលើផែនដី គឺសាមសិបបីឆ្នាំកន្លះ ពោលគឺទ្រង់មានព្រះជន្មគង់នៅលើផែនដី សាមសិបបីឆ្នាំកន្លះ។ មានតែពេលវេលាបីឆ្នាំកន្លះប៉ុណ្ណោះ ដែលត្រូវបានចំណាយក្នុងការបំពេញព័ន្ធកិច្ចរបស់ទ្រង់ ពេលវេលាដែលនៅសេសសល់ គឺទ្រង់រស់នៅជាមនុស្សធម្មតាម្នាក់ប៉ុណ្ណោះ។ ដំបូងឡើយ ទ្រង់ចូលរួមកម្មវិធីនានានៅក្នុងសាលាប្រជុំ ហើយទ្រង់បានស្ដាប់ការបកស្រាយបទគម្ពីរពីពួកបូជាចារ្យ និងស្ដាប់សេចក្ដីបង្រៀនរបស់មនុស្សផ្សេងទៀតនៅទីនោះ។ ទ្រង់បានទទួលចំណេះដឹងជាច្រើនអំពីព្រះគម្ពីរ៖ ទ្រង់មិនមែនប្រសូតមកទាំងមានចំណេះដឹងស្រាប់មកជាមួយទេ ទ្រង់បានទទួលចំណេះដឹងនោះ តាមរយៈការអាន និងការស្ដាប់។ ក្នុងព្រះគម្ពីរបានកត់ត្រាយ៉ាងច្បាស់ថា ទ្រង់បានសួរសំណួរដល់គ្រូៗក្នុងសាលាប្រជុំ ពេលទ្រង់មានព្រះជន្មដប់ពីរឆ្នាំថា៖ តើអ្វីខ្លះជាបទទំនាយរបស់ពួកហោរាពីបុរាណ? តើក្រឹត្យវិន័យរបស់ម៉ូសេមានអ្វីខ្លះ? ចុះគម្ពីរសញ្ញាចាស់? តើមនុស្សដែលកំពុងបម្រើព្រះជាម្ចាស់ ដោយស្លៀកសម្លៀកបំពាក់ជាបូជាចារ្យនៅក្នុងព្រះវិហារ មានតួនាទីអ្វី? ... ទ្រង់បានសួរសំណួរជាច្រើន ដ្បិតទ្រង់ក៏គ្មានចំណេះ ឬការយល់ដឹងពីរឿងអស់ទាំងនេះដែរ។ ទោះបីជាទ្រង់ត្រូវបានចាប់បដិសន្ធិដោយព្រះវិញ្ញាណបរិសុទ្ធ ក៏ទ្រង់ប្រសូត

មកជាមនុស្សធម្មតាសុទ្ធសាធដែរ។ ថ្វីបើទ្រង់មានលក្ខណៈពិសេសខ្លះ ក៏ព្រះអង្គនៅតែជាមនុស្សធម្មតាម្នាក់ដដែល។ ព្រះប្រាជ្ញាញាណរបស់ទ្រង់ លូតលាស់ជាបន្តបន្ទាប់ ស្របទៅតាមកម្ពស់ និងព្រះជន្មរបស់ទ្រង់ ហើយទ្រង់ក៏បានឆ្លងកាត់ដំណាក់នានានៅក្នុងជីវិតជាមនុស្សធម្មតាម្នាក់ដែរ។ នៅក្នុងការស្រមើស្រមៃរបស់មនុស្ស ព្រះយេស៊ូវមិនបានឆ្លងកាត់កុមារភាព ឬវ័យជំទង់នោះឡើយ។ ទ្រង់បានចាប់ផ្ដើមរស់ក្នុងជីវិតជាមនុស្សម្នាក់ដែលមានវ័យសាមសិបបីឆ្នាំ ពេលទ្រង់ប្រសូតមកភ្លាមតែម្ដង ហើយទ្រង់ត្រូវគេឆ្កាងពេលបញ្ចប់កិច្ចការរបស់ទ្រង់។ ទ្រង់មុខជាមិនបានឆ្លងកាត់ដំណាក់កាលនានាក្នុងជីវិតជាមនុស្សធម្មតាឡើយ។ ទ្រង់ក៏មិនបានបរិភោគ ឬសេពគប់ជាមួយនឹងមនុស្សដទៃទៀត ហើយពួកគេមិនងាយនឹងជួបទ្រង់ទេ សូម្បីមួយភ្លែតក៏ដោយ។ ទ្រង់មុខជាមនុស្សខុសប្រក្រតី ដែលបំភិតបំភ័យអស់អ្នកណាដែលបានឃើញទ្រង់ ដ្បិតទ្រង់គឺជាព្រះជាម្ចាស់។ មនុស្សជឿថា ព្រះជាម្ចាស់ដែលយាងមកក្នុងសាច់ឈាម ប្រាកដជាមិនរស់ដូចមនុស្សធម្មតាម្នាក់នោះទេ។ ពួកគេជឿថា ទ្រង់ស្អាតដោយមិនចាំបាច់ដុះធ្មេញរបស់ទ្រង់ ឬលុបលាងព្រះភក្ត្ររបស់ទ្រង់ឡើយ ដ្បិតទ្រង់គឺជាបុគ្គលបរិសុទ្ធ។ តើទាំងអស់នេះមិនមែនជាសញ្ញាណរបស់មនុស្សសុទ្ធសាធទេឬអី? ព្រះគម្ពីរពុំមានកត់ត្រាពីជីវិតរបស់ព្រះយេស៊ូវ ក្នុងមានជាមនុស្សឡើយ មានតែកត់ត្រាពីកិច្ចការរបស់ទ្រង់ប៉ុណ្ណោះ ប៉ុន្តែនេះក៏មិនមែនបញ្ជាក់ថា ទ្រង់គ្មានភាពជាមនុស្សធម្មតា ឬបញ្ជាក់ថា ទ្រង់មិនបានរស់ក្នុងជីវិតជាមនុស្សធម្មតាម្នាក់ មុនពេលទ្រង់មានព្រះជន្មសាមសិបឆ្នាំនោះដែរ។ ទ្រង់បានចាប់ផ្ដើមកិច្ចការរបស់ទ្រង់ជាផ្លូវការពេលគ្រប់ព្រះជន្ម២៩ឆ្នាំ ប៉ុន្តែអ្នកមិនអាចសរសេររៀបរាប់ពីជីវិតជាមនុស្សរបស់ទ្រង់ទាំងមូលអស់ មុនវ័យនេះបានឡើយ។ ព្រះគម្ពីរ គ្រាន់តែមិនរៀបរាប់ពីគ្រាទាំងអស់នោះនៅក្នុងការកត់ត្រាប៉ុណ្ណោះ។ ដោយសារតែវេលាទាំងនោះ គឺជាគ្រាដែលទ្រង់មានព្រះជន្មរស់ជាមនុស្សធម្មតា និងពុំមែនជាគ្រាដែលទ្រង់ធ្វើកិច្ចការក្នុងភាពជាព្រះរបស់ទ្រង់ ទើបវាមិនចាំបាច់ត្រូវកត់ត្រារឿងនេះទុក។ មុនពេលព្រះយេស៊ូវទទួលបុណ្យជ្រមុជទឹក ព្រះវិញ្ញាណបរិសុទ្ធមិនបានធ្វើការដោយផ្ទាល់ទេ គឺគ្រាន់តែរក្សា

ព្រះអង្គនៅក្នុងជីវិតរបស់ទ្រង់ ក្នុងនាមជាមនុស្សធម្មតាម្នាក់ រហូតដល់ថ្ងៃកំណត់ដែលព្រះយេស៊ូវត្រូវបំពេញព័ន្ធកិច្ចរបស់ទ្រង់។ ទោះបីទ្រង់ គឺជាព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស ក៏ទ្រង់ឆ្លងកាត់ដំណើរការនៃភាពចាស់ចិត្តចាស់គំនិត ដូចមនុស្សធម្មតាម្នាក់ដែរ។ ដំណើរការនៃភាពចាស់ចិត្តចាស់គំនិតនេះ មិនត្រូវបានបញ្ចូលក្នុងព្រះគម្ពីរឡើយ។ រឿងនេះមិនត្រូវបានបញ្ចូល ដ្បិតវាមិនជួយផ្ដល់នូវជំនួយអ្វីធំដុំដល់ការលូតលាស់ក្នុងជីវិតរបស់មនុស្សឡើយ។ វេលាមុនពេលដែលទ្រង់បានទទួលបុណ្យជ្រមុជទឹក គឺជាវេលាលាក់កំបាំង ជាវេលាដែលទ្រង់មិនបានធ្វើទីសម្គាល់ និងការអស្ចារ្យអ្វីសោះ។ លុះក្រោយពេលដែលព្រះយេស៊ូវបានទទួលពិធីជ្រមុជទឹក ទើបទ្រង់កិច្ចការប្រោសលោះមនុស្សទាំងអស់ ជាកិច្ចការដែលសម្បូរ និងពោរពេញដោយព្រះគុណ សេចក្ដីពិត សេចក្ដីស្រឡាញ់ និងសេចក្ដីមេត្តាករុណា។ ប្រាកដណាស់ ការចាប់ផ្ដើមកិច្ចការនេះ ក៏ជាការចាប់ផ្ដើមយុគសម័យនៃព្រះគុណដែរ ដោយព្រោះមូលហេតុនេះ ទើបកិច្ចការនេះត្រូវបានកត់ទុក និងផ្ទេរបន្តរហូតដល់បច្ចុប្បន្ន។ កិច្ចការនេះគឺដើម្បីបើកច្រកចេញ និងនាំមនុស្សគ្រប់គ្នាទៅកាន់ផលសម្រេច ឲ្យអស់អ្នកដែលស្ថិតក្នុងយុគសម័យនៃព្រះគុណ ដើម្បីឲ្យគេដើរលើមាគ៌ានៃយុគសម័យនៃព្រះគុណ និងមាគ៌ានៃឈើឆ្កាង។ គ្រប់យ៉ាងសុទ្ធតែជាការពិត ទោះបីជាវាចេញមកពីការកត់ត្រាដែលសរសេរដោយមនុស្សក៏ដោយ លើកលែងតែកំហុសតូចតាចមួយចំនួន ដែលត្រូវបានគេរកឃើញក្នុងកន្លែងខុសៗគ្នាប៉ុណ្ណោះ។ ទោះបីជាដូច្នេះក៏ដោយ កំណត់ត្រាទាំងនេះ មិនអាចនិយាយបានថា មិនពិតនោះទេ។ រឿងដែលត្រូវបានកត់ត្រា គឺជារឿងពិតសុទ្ធសាធ ដែលមានខុសនោះ គឺខុសត្រង់សំណេរដែលមនុស្សសរសេរប៉ុណ្ណោះ។ មានមនុស្សខ្លះនឹងនិយាយថា ប្រសិនបើព្រះយេស៊ូវជាបុគ្គលដែលមានភាពជាមនុស្សធម្មតា និងសាមញ្ញ តើទ្រង់អាចធ្វើទីសម្គាល់ និងការអស្ចារ្យបានដោយរបៀបណា? រយៈពេលសែសិបថ្ងៃនៃការល្បួងដែលព្រះយេស៊ូវបានឆ្លងកាត់ គឺជាទីសម្គាល់ដ៏អស្ចារ្យ ជាការណ៍មួយដែលមនុស្សធម្មតាម្នាក់ មុខជាមិនអាចនឹងសម្រេចបាន។ រយៈពេលសែសិបថ្ងៃនៃការល្បួងរបស់ទ្រង់ ស្ថិតក្នុងធម្មជាតិនៃការបំពេញកិច្ចការ

របស់ព្រះវិញ្ញាណបរិសុទ្ធ ចុះតើគេអាចនិយាយថា នៅក្នុងទ្រង់គ្មានលក្ខណៈអធិធម្មជាតិបន្តិចសោះបានដោយរបៀបណា? សមត្ថភាពរបស់ទ្រង់ ក្នុងការធ្វើទីសម្គាល់ និងការអស្ចារ្យ មិនបញ្ជាក់ថា ទ្រង់គឺជាមនុស្សមហស្ចារ្យម្នាក់ និងពុំមែនជាមនុស្សធម្មតានោះឡើយ។ គ្រាន់តែថា ព្រះវិញ្ញាណបរិសុទ្ធធ្វើការក្នុងមនុស្សធម្មតាម្នាក់ដូចជាទ្រង់ប៉ុណ្ណោះ ទើបធ្វើឲ្យទ្រង់អាចធ្វើការអស្ចារ្យ ហើយថែមទាំងធ្វើការអស្ចារ្យជាងនេះទៀតផង។ មុនពេលព្រះយេស៊ូវបំពេញព័ន្ធកិច្ចរបស់ទ្រង់ ឬតាមព្រះគម្ពីរបានរ៉ាយរ៉ាប់ថា មុនពេលព្រះវិញ្ញាណបរិសុទ្ធយាងចុះមកសណ្ឋិតលើទ្រង់ ព្រះយេស៊ូវគ្រាន់តែជាមនុស្សធម្មតាម្នាក់ និងគ្មានលក្ខណៈអធិធម្មជាតិសោះឡើយ។ ពេលដែលព្រះវិញ្ញាណបរិសុទ្ធ យាងចុះមកសណ្ឋិតលើទ្រង់ ពោលគឺពេលដែលទ្រង់បានចាប់ផ្ដើមបំពេញព័ន្ធកិច្ចរបស់ទ្រង់ ទ្រង់ក៏បានពេញដោយលក្ខណៈអធិធម្មជាតិ។ ដោយសារតែបែបនេះ ទើបមនុស្សចាប់ផ្ដើមជឿថា សាច់ឈាមជាមនុស្សរបស់ព្រះជាម្ចាស់គឺគ្មានភាពជាមនុស្សធម្មតានោះទេ។ ជាងនេះទៀត គេច្រឡំគិតថា ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស មានតែភាពជាព្រះ គ្មានភាពជាមនុស្សទេ។ ប្រាកដណាស់ កាលព្រះជាម្ចាស់យាងមកផែនដី ដើម្បីធ្វើកិច្ចការរបស់ទ្រង់ មនុស្សទាំងអស់មើលឃើញព្រឹត្តិការណ៍អធិធម្មជាតិ។ អ្វីដែលពួកគេមើលឃើញនឹងភ្នែករបស់គេផ្ទាល់ និងអ្វីដែលពួកគេស្ដាប់ឮនឹងត្រចៀករបស់គេផ្ទាល់ សុទ្ធតែមានលក្ខណៈអធិធម្មជាតិ ដ្បិតកិច្ចការ និងព្រះបន្ទូលរបស់ទ្រង់ គឺសុទ្ធតែមិនអាចយល់បាន និងមិនអាចទទួលយកបានសម្រាប់ពួកគេ។ ប្រសិនបើមានរបស់អ្វីពីស្ថានសួគ៌ ត្រូវបានយកមកផែនដី តើអាចជារបស់អ្វីផ្សេង ក្រៅតែពីរបស់ដែលមានលក្ខណៈអធិធម្មជាតិបានដែរឬទេ? ពេលដែលសេចក្ដីអាថ៌កំបាំងនៃនគរស្ថានសួគ៌ត្រូវបាននាំយកមកផែនដី សេចក្ដីអាថ៌កំបាំងដែលមនុស្សគិតមិនដល់ ហើយយល់មិនបាន ជាអាថ៌កំបាំងដែលចម្លែកដល់ចិត្ត និងប្រកបដោយភាពវាងវៃ តើសេចក្ដីទាំងនោះសុទ្ធតែមិនមែនជាអធិធម្មជាតិទៀតមែនទេ? ដោយឡែក អ្នកគួរដឹងថា ទោះបីជាសេចក្ដីនោះមានលក្ខណៈអធិធម្មជាតិយ៉ាងណា ក៏គ្រប់យ៉ាងត្រូវបានអនុវត្តនៅក្នុងភាពជាមនុស្សធម្មតា របស់

ព្រះអង្គដដែលដែរ។ ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស មានពេញដោយភាពជាមនុស្ស។ ប្រសិនបើទ្រង់ពុំមានភាពជាមនុស្សទេ នោះទ្រង់មុខជាពុំមែនជាសាច់ឈាមជាមនុស្សរបស់ព្រះជាម្ចាស់ឡើយ។ ព្រះយេស៊ូវបានធ្វើការអស្ចារ្យធំៗជាច្រើន កាលទ្រង់គង់នៅលើផែនដី។ អ្វីដែលសាសន៍អ៊ីស្រាអែលបានឃើញនៅពេលនោះ គឺពោរពេញដោយរឿងរ៉ាវអធិធម្មជាតិ។ ពួកគេបានមើលឃើញទាំងទេវតា និងទេវទូត ហើយពួកគេបានស្តាប់ឮព្រះសូរសៀងរបស់ព្រះយេហូវ៉ាទៀតផង។ តើទាំងនេះមិនមែនជារឿងអធិធម្មជាតិទេឬអី? ប្រាកដណាស់ សព្វថ្ងៃនេះ មានវិញ្ញាណអាក្រក់ខ្លះបោកបញ្ឆោតមនុស្ស ដោយប្រើប្រាស់ទង្វើអធិធម្មជាតិ ពោលគឺគ្មានអ្វីក្រៅតែពីការយកតម្រាប់របស់ពួកវា ដើម្បីបោកបញ្ឆោតមនុស្ស តាមរយៈកិច្ចការដែលមិនមែនត្រូវបានធ្វើឡើង ដោយព្រះវិញ្ញាណបរិសុទ្ធនាពេលបច្ចុប្បន្ន។ មនុស្សជាច្រើនធ្វើការអស្ចារ្យ និងប្រោសមនុស្សឈឺ ព្រមទាំងបណ្តេញអារក្សផង ទាំងអស់នេះមិនជាអ្វីទាំងអស់ ក្រៅតែពីកិច្ចការរបស់វិញ្ញាណអាក្រក់ ដ្បិតព្រះវិញ្ញាណបរិសុទ្ធលែងធ្វើការបែបនេះនាពេលបច្ចុប្បន្នទៀតហើយ ហើយអស់អ្នកណាដែលត្រាប់តាមកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ តាំងពីសម័យនោះមក គឺជាវិញ្ញាណអាក្រក់ប្រាកដណាស់។ កិច្ចការទាំងអស់ដែលត្រូវបានអនុវត្តនៅអ៊ីស្រាអែលសម័យនោះ គឺជាកិច្ចការមួយដែលមានលក្ខណៈអធិធម្មជាតិ ទោះបីពេលនេះព្រះវិញ្ញាណបរិសុទ្ធមិនធ្វើការក្នុងលក្ខណៈបែបនេះក៏ដោយ ហើយពេលនេះកិច្ចការបែបនេះ គឺជាតម្រាប់ និងជាការក្លែងកាយរបស់សាតាំង និងជាការបង្កចលាចលរបស់វាផង។ ដោយឡែក អ្នកមិនអាចនិយាយថា គ្រប់យ៉ាងដែលមានលក្ខណៈអធិធម្មជាតិ សុទ្ធតែមកពីវិញ្ញាណអាក្រក់នោះឡើយ ការនេះអាស្រ័យលើយុគសម័យនៃកិច្ចការរបស់ព្រះជាម្ចាស់។ ចូរពិចារណាអំពីកិច្ចការដែលត្រូវបានធ្វើឡើងដោយព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សនាពេលបច្ចុប្បន្ន៖ តើចំណុចណាខ្លះ ដែលគ្មានលក្ខណៈអធិធម្មជាតិ? ព្រះបន្ទូលរបស់ទ្រង់ គឺយល់មិនដល់ និងមិនអាចទទួលយកបានសម្រាប់អ្នក ហើយកិច្ចការដែលទ្រង់ធ្វើ គឺគ្មានមនុស្សណាម្នាក់អាចធ្វើបានឡើយ។ អ្វីដែលទ្រង់យល់

មនុស្សគ្មានផ្លូវយល់បានឡើយ ចំណែកឯចំណេះដឹងរបស់ទ្រង់វិញ មនុស្សក៏មិនដឹងជាមានតាំងពីពេលណាមកដែរ។ មានមនុស្សខ្លះនិយាយថា «ទូលបង្គំក៏ជាមនុស្សធម្មតាដូចទ្រង់ដែរ ប៉ុន្តែចុះម្ដេចបានជាទូលបង្គំមិនដឹងអ្វីដែលទ្រង់ដឹងដូច្នេះ? ទូលបង្គំចាស់ជាង និងមានបទពិសោធច្រើនជាង ប៉ុន្តែម្ដេចបានជាទ្រង់ដឹងពីអ្វីដែលទូលបង្គំមិនដឹង?» តាមទស្សនៈរបស់មនុស្ស អ្វីៗទាំងអស់នេះគឺជារឿងដែលមនុស្សគ្មានផ្លូវនឹងទទួលបានឡើយ។ ហេតុនេះ មានមនុស្សខ្លះនិយាយថា «គ្មាននរណាដឹងពីកិច្ចការដែលត្រូវបានអនុវត្តនៅអ៊ីស្រាអែលនោះឡើយ ហើយសូម្បីតែអ្នកបកស្រាយព្រះគម្ពីរក៏មិនអាចផ្ដល់នូវការបកស្រាយបានដែរ ចុះម្ដេចបានជាអ្នកដឹង?» តើទាំងអស់នេះមិនមែនជារឿងអធិធម្មជាតិទេឬអី? ព្រះអង្គពុំមានបទពិសោធអំពីការអស្ចារ្យទេ ប៉ុន្តែទ្រង់ជ្រាបគ្រប់យ៉ាង ទ្រង់មានបន្ទូល និងបង្ហាញឲ្យឃើញពីសេចក្ដីពិតយ៉ាងងាយស្រួលបំផុត។ តើនេះមិនមែនជារឿងអធិធម្មជាតិទៀតមែនទេ? កិច្ចការរបស់ទ្រង់លើសលប់ពេកនឹងឲ្យមនុស្សអាចទទួលបាន។ កិច្ចការនោះ គំនិតរបស់មនុស្សដែលមានសាច់ឈាម មិនអាចទទួលបានទេ ហើយការលើកហេតុផលនៃគំនិតរបស់មនុស្សក៏មិនអាចយល់ពីកិច្ចការនេះបានដែរ។ ទោះបីជាទ្រង់មិនធ្លាប់បានអានព្រះគម្ពីរ ក៏ទ្រង់យល់ពីកិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងស្រុកអ៊ីស្រាអែលដែរ។ ហើយទោះបីជាទ្រង់ឈរលើផែនដី ពេលទ្រង់ថ្លែងព្រះបន្ទូល ក៏ទ្រង់ថ្លែងពីសេចក្ដីអាថ៌កំបាំងដែលនៅឯស្ថានសួគ៌ជាន់ទីបីដែរ។ កាលណាមនុស្សអានព្រះបន្ទូលទាំងនេះ អារម្មណ៍នេះនឹងយកឈ្នះលើគេ៖ «តើនេះមិនមែនជាសម្ដីពីស្ថានសួគ៌ ជាន់ទីបីទេឬអី? តើការទាំងអស់នេះ មិនលើសពីអ្វីដែលមនុស្សធម្មតាអាចសម្រេចបានទេឬអី? នៅពេលនោះ កាលព្រះយេស៊ូវឆ្លងកាត់ការតមអាហាររយៈពេលសែសិបថ្ងៃ តើនោះមិនមែនជារឿងអធិធម្មជាតិទៀតមែនទេ?» ប្រសិនបើអ្នកនិយាយថា ការតមអាហាររយៈពេលសែសិបថ្ងៃ គឺជាករណីអធិធម្មជាតិសុទ្ធសាធ ជាទង្វើរបស់វិញ្ញាណអាក្រក់ នោះតើអ្នកមិនថ្កោលទោសព្រះយេស៊ូវទេឬអី? មុនពេលព្រះយេស៊ូវបំពេញព័ន្ធកិច្ចរបស់ទ្រង់ ព្រះអង្គមានលក្ខណៈដូចមនុស្សធម្មតាម្នាក់។ ទ្រង់ទៅសាលារៀនទៀតផង តើទ្រង់បានរៀន

អាន និងរៀនសរសេរ តាមរបៀបណាទៀត? កាលព្រះជាម្ចាស់បានត្រឡប់ជាសាច់ឈាម ព្រះវិញ្ញាណបរិសុទ្ធនៅលាក់កំបាំងក្នុងសាច់ឈាមនោះ។ ដូច្នេះ ការធ្វើជាមនុស្សធម្មតាម្នាក់ ទ្រង់ចាំបាច់ត្រូវឆ្លងកាត់ដំណើរការលូតលាស់ និងភាពចាស់ចិត្តចាស់គំនិត ហើយមិនមែនទាល់តែសមត្ថភាពវិនិច្ឆ័យរបស់ទ្រង់បានចម្រើនឡើងហើយទ្រង់យល់ដឹងការណ៍នានា ទើបអាចរាប់ថា ទ្រង់ជាមនុស្សធម្មតាម្នាក់នោះទេ។ លុះក្រោយពេលដែលភាពជាមនុស្សរបស់ទ្រង់ បានចាស់ចិត្តចាស់គំនិត ទើបទ្រង់អាចបំពេញព័ន្ធកិច្ចរបស់ទ្រង់បាន។ តើទ្រង់អាចបំពេញព័ន្ធកិច្ចរបស់ទ្រង់ ខណៈដែលភាពជាមនុស្សធម្មតារបស់ទ្រង់ មិនទាន់ចាស់ចិត្តចាស់គំនិត ហើយការលើកហេតុផលរបស់ទ្រង់ នៅមិនទាន់ត្រឹមត្រូវបានដែរឬទេ? ប្រាកដណាស់ មិនអាចរំពឹងឲ្យទ្រង់បំពេញព័ន្ធកិច្ចរបស់ទ្រង់ ពេលទ្រង់មានព្រះជន្មប្រាំមួយ ឬប្រាំពីរឆ្នាំនោះទេ! ហេតុអ្វីបានជាព្រះជាម្ចាស់ មិនសម្ដែងអង្គទ្រង់ដោយបើកចំហ ពេលទ្រង់បានក្លាយជាសាច់ឈាមភ្លាម? នោះគឺមកពីភាពជាមនុស្សនៃសាច់ឈាមរបស់ទ្រង់ នៅមិនទាន់ចាស់ចិត្តចាស់គំនិត ដំណើរការវិនិច្ឆ័យនៃភាពជាមនុស្សធម្មតារបស់ទ្រង់ ក៏ដូចជាភាពជាមនុស្សធម្មតានៃសាច់ឈាមនេះ មិនទាន់ជាកម្មសិទ្ធិដ៏ពេញលេញរបស់ព្រះអង្គនៅឡើយទេ។ ដោយព្រោះមូលហេតុនេះ ទ្រង់ចាំបាច់ត្រូវមានភាពជាមនុស្សធម្មតា និងមានសុភវិនិច្ឆ័យជាមនុស្សធម្មតាម្នាក់ដាច់ខាត រហូតទាល់តែបានប្រដាប់កាយគ្រប់គ្រាន់ ក្នុងការរ៉ាប់រងកិច្ចការរបស់ទ្រង់ នៅក្នុងសាច់ឈាមបាន គឺមុនពេលទ្រង់អាចចាប់ផ្ដើមកិច្ចការរបស់ទ្រង់បាន។ ប្រសិនបើទ្រង់មិនទាន់បានស្មើនឹងភារកិច្ចនេះទេ នោះទ្រង់ចាំបាច់ត្រូវបន្តចម្រើនវ័យ និងចាស់ចិត្តចាស់គំនិតផង។ ប្រសិនបើព្រះយេស៊ូវបានចាប់ផ្ដើមកិច្ចការរបស់ទ្រង់ក្នុងវ័យប្រាំពីរ ឬប្រាំបីឆ្នាំ តើមនុស្សមិនចាត់ទុកទ្រង់ជាមនុស្សអច្ឆរិយទៅហើយទេឬអី? តើមនុស្សទាំងអស់មិនគិតថា ព្រះអង្គជាកុមារម្នាក់ទេមែនទេ? តើមាននរណាខ្លះយល់ឃើញថា ទ្រង់ជាមនុស្សគួរឲ្យទុកចិត្ត? កុមារម្នាក់ដែលមានវ័យប្រាំពីរ ឬប្រាំបីឆ្នាំ មិនខ្ពស់ជាងវេទិកាដែលគេឈរពីក្រោយនោះទេ តើគេសមនឹងអធិប្បាយព្រះបន្ទូលដែរឬទេ? មុនពេលភាពជាមនុស្សធម្មតា

របស់ទ្រង់ចាស់ចិត្តចាស់គំនិត ទ្រង់រ៉ាប់រងភារកិច្ចនោះមិនបានទេ។ មើលទៅដរាបណាភាពជាមនុស្សរបស់ទ្រង់នៅមិនទាន់ចាស់ចិត្តចាស់គំនិត ចំណែកជាច្រើននៃកិច្ចការនេះ គឺមិនអាចទទួលបានតែម្ដង។ កិច្ចការរបស់ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់នៅក្នុងសាច់ឈាម ក៏ត្រូវបានត្រួតត្រាដោយគោលការណ៍នៃកិច្ចការនោះផ្ទាល់ដែរ។ ទាល់តែដល់ពេលដែលទ្រង់បានប្រដាប់កាយដោយភាពជាមនុស្សធម្មតា ទើបទ្រង់អាចរ៉ាប់រងកិច្ចការ និងទទួលបន្ទុកការងាររបស់ព្រះវរបិតាបាន។ លុះដល់ពេលនោះទើបទ្រង់អាចចាប់ផ្ដើមកិច្ចការរបស់ទ្រង់បាន។ ក្នុងកុមារភាពរបស់ទ្រង់ ព្រះយេស៊ូវមិនអាចយល់រឿងរ៉ាវជាច្រើនដែលបានកើតឡើងក្នុងសម័យបុរាណនោះទេ ហើយទ្រង់ក៏ចាប់ផ្ដើមយល់ ដោយសារតែការសួរសំណួរដល់គ្រូបង្រៀននៅតាមសាលាប្រជុំតែប៉ុណ្ណោះ។ ប្រសិនបើទ្រង់បានចាប់ផ្ដើមធ្វើកិច្ចការរបស់ទ្រង់ភ្លាម ពេលទ្រង់ចេះនិយាយ តើធ្វើម្ដេចអាចឲ្យទ្រង់មិនប្រព្រឹត្តកំហុសបាន? តើព្រះជាម្ចាស់អាចប្រព្រឹត្តនូវកំហុសឆ្គងផ្ដាសទៅរួចទេ? ហេតុនេះ លុះក្រោយពេលដែលទ្រង់អាចធ្វើការបាន ទើបទ្រង់ចាប់ផ្ដើមកិច្ចការរបស់ទ្រង់។ ទ្រង់មិនបានអនុវត្តកិច្ចការអ្វីសោះ រហូតទាល់តែទ្រង់មានសមត្ថភាពពេញលេញនឹងរ៉ាប់រងការងារនេះបាន។ ពេលចម្រើនវ័យ២៩ឆ្នាំ ព្រះយេស៊ូវបានចាស់ចិត្តគំនិតច្រើនហើយ ហើយភាពជាមនុស្សរបស់ទ្រង់ ក៏ល្មមនឹងរ៉ាប់រ៉ងកិច្ចការដែលទ្រង់ត្រូវធ្វើនោះដែរ។ លុះដល់ពេលនោះ ទើបព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ចាប់ផ្ដើមធ្វើការក្នុងទ្រង់ជាផ្លូវការ។ នៅពេលនោះ យ៉ូហានបានប្រុងប្រៀបអស់រយៈពេលប្រាំពីរឆ្នាំ ដើម្បីបើកផ្លូវថ្វាយទ្រង់ ហើយពេលកិច្ចការរបស់គាត់បញ្ចប់ទៅគាត់ត្រូវបានបញ្ជូនទៅក្នុងមន្ទីរឃុំឃាំង។ អម្រែកនេះក៏ធ្លាក់លើព្រះយេស៊ូវទាំងស្រុង។ ប្រសិនបើទ្រង់រ៉ាប់រងកិច្ចការនេះក្នុងវ័យ២១ឆ្នាំ ឬ ២២ឆ្នាំ ពេលនោះជាពេលដែលភាពជាមនុស្សរបស់ទ្រង់ នៅខ្វះខាតច្រើន ជាពេលដែលទ្រង់ទើបតែឈានចូលក្នុងយុវភាពក្មេងខ្ចី ហើយមានកិច្ចការជាច្រើនដែលទ្រង់មិនដឹង ហើយទ្រង់មុខជាមិនអាចទទួលរ៉ាប់រងការងារបានឡើយ។ នៅពេលនោះ យ៉ូហានបានអនុវត្តកិច្ចការរបស់គាត់បានខ្លះ មុនពេលដែលព្រះយេស៊ូវចាប់ផ្ដើមកិច្ចការរបស់ទ្រង់ ដោយកាលនោះ ទ្រង់

ឈានដល់មជ្ឈិមវ័យទៅហើយ។ ស្ថិតក្នុងវ័យនោះ ភាពជាមនុស្សធម្មតារបស់ទ្រង់ គឺល្មមនឹងរ៉ាប់រងកិច្ចការដែលទ្រង់ធ្វើហើយ។ ពេលនេះ ព្រះដែលយកកំណើតជាមនុស្សក៏មានភាពជាមនុស្សធម្មតា ទោះបីជាភាពជាមនុស្សនេះ មានភាពចាស់ទុំខ្លាំងធៀបទៅនឹងមនុស្សវ័យចំណាស់ក្នុងចំណោមអ្នករាល់គ្នា ក៏ភាពជាមនុស្សនេះល្មមគ្រប់គ្រាន់នឹងរ៉ាប់រងកិច្ចការរបស់ទ្រង់ស្រេចទៅហើយ។ កាលៈទេសៈដែលនៅជុំវិញកិច្ចការសព្វថ្ងៃ គឺមិនដូចគ្នាទាំងស្រុងនឹងកាលៈទេសៈក្នុងសម័យព្រះយេស៊ូវនោះទេ។ ហេតុអ្វីបានជាព្រះយេស៊ូវជ្រើសរើសសាវ័កដប់ពីរនាក់? នោះគឺដើម្បីជ្រោមជ្រែងដល់កិច្ចការរបស់ទ្រង់សុទ្ធសាធ និងឲ្យគេរួមចំណែកក្នុងកិច្ចការនោះ។ ក្នុងន័យម្យ៉ាង គឺដើម្បីចាក់គ្រឹះសម្រាប់កិច្ចការរបស់ទ្រង់នៅសម័យនោះ ក្នុងន័យម្យ៉ាងទៀត គឺដើម្បីចាក់គ្រឹះសម្រាប់កិច្ចការរបស់ទ្រង់នៅសម័យក្រោយៗមកទៀត។ ការជ្រើសរើសយកសាវ័កទាំងដប់ពីរនាក់ គឺជាបំណងព្រះហឫទ័យរបស់ព្រះយេស៊ូវ ស្របទៅតាមកិច្ចការនៅពេលនោះ ដ្បិតនោះគឺជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ផ្ទាល់។ ទ្រង់ជឿថាទ្រង់គួរជ្រើសរើសសាវ័កដប់ពីរនាក់ រួចហើយដឹកនាំពួកគេឲ្យផ្សាយព្រះបន្ទូលគ្រប់ទីកន្លែង។ ប៉ុន្តែសព្វថ្ងៃនេះ ការនេះពុំចាំបាច់មាននៅក្នុងចំណោមអ្នករាល់គ្នានោះទេ! កាលព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស ធ្វើការនៅក្នុងសាច់ឈាម មានគោលការណ៍ជាច្រើន និងមានរឿងរ៉ាវជាច្រើនដែលមនុស្សមិនយល់តែម្ដង។ មនុស្សរមែងប្រើសញ្ញាណរបស់គេផ្ទាល់មកវាយតម្លៃព្រះអង្គ ឬមកធ្វើការទាមទារហួសហេតុពីព្រះជាម្ចាស់។ ប៉ុន្តែមកទល់សព្វថ្ងៃនេះ មនុស្សជាច្រើនមិនដឹងសោះថា ចំណេះដឹងរបស់ពួកគេ សុទ្ធតែជាការបន្សំឡើងពីសញ្ញាណរបស់ពួកគេផ្ទាល់សុទ្ធសាធ។ ទោះបីព្រះជាម្ចាស់យកកំណើតជាមនុស្សក្នុងយុគសម័យ ឬទីកន្លែងណាក៏ដោយ ក៏គោលការណ៍សម្រាប់កិច្ចការរបស់ទ្រង់នៅក្នុងសាច់ឈាម នៅតែមិនផ្លាស់ប្ដូរដដែល។ ទ្រង់មិនអាចក្លាយជាសាច់ឈាម ហើយលើកសាច់ឈាមឲ្យខ្ពស់នៅក្នុងកិច្ចការរបស់ទ្រង់នោះឡើយ និងរឹតតែមិនអាចក្លាយជាសាច់ឈាម ហើយមិនធ្វើការក្នុងភាពជាមនុស្សធម្មតានៃសាច់ឈាមទៅទៀត។ ពុំនោះទេ សារៈសំខាន់នៃការយកកំណើតជាមនុស្ស

របស់ព្រះជាម្ចាស់ នឹងរលាយជាអសារឥតការ ហើយព្រះបន្ទូលដែលបានត្រឡប់ជាសាច់ឈាម នឹងក្លាយជារឿងឥតន័យទាំងស្រុង។ ជាងនេះទៅទៀត មានតែព្រះវរបិតាដែលគង់នៅឯស្ថានសួគ៌ប៉ុណ្ណោះ (ព្រះវិញ្ញាណ) ជ្រាបពីការយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់ ហើយគ្មាននរណាផ្សេងដឹងឡើយ សូម្បីតែសាច់ឈាមរបស់ព្រះជាម្ចាស់ផ្ទាល់ ឬទេវទូតពីស្ថានសួគ៌ក្ដី។ ហេតុនេះទើបកិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងសាច់ឈាម នោះរឹតតែធម្មតា និងរឹតតែប្រសើរ ក្នុងការបង្ហាញឲ្យឃើញថា ព្រះបន្ទូលពិតជាបានត្រឡប់ជាសាច់ឈាមមែន ហើយសាច់ឈាមនោះ គឺជាមនុស្សសាមញ្ញ និងធម្មតាម្នាក់។

អ្នកខ្លះប្រហែលជាឆ្ងល់ថា «ហេតុអ្វីក៏យុគសម័យនេះ ត្រូវចាប់ផ្ដើមឡើងដោយព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ? តើមនុស្សមិនអាចធ្វើជំនួសទ្រង់បានទេមែនទេ?» អ្នករាល់គ្នាសុទ្ធតែដឹងថា ព្រះជាម្ចាស់បានត្រឡប់ជាសាច់ឈាម សម្រាប់ការបើកបង្ហាញនូវគោលបំណងដ៏ជាក់លាក់មួយ ចាប់យុគសម័យថ្មីមួយ ហើយពិតណាស់ ពេលទ្រង់ចាប់ផ្ដើមយុគសម័យថ្មី ទ្រង់នឹងបញ្ចប់យុគសម័យចាស់ ក្នុងពេលជាមួយគ្នាតែម្ដង។ ព្រះជាម្ចាស់ គឺជាទីចាប់ផ្ដើម និងជាទីបញ្ចប់។ ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ គឺជាអ្នកធ្វើឲ្យកិច្ចការរបស់ទ្រង់ចាប់ផ្ដើមដំណើរការ ដូច្នេះហើយ អ្នកដែលបញ្ចប់យុគសម័យចាស់ក៏ត្រូវតែជាព្រះជាម្ចាស់ផ្ទាល់ព្រះអង្គដែរ។ នោះគឺជាភ័ស្តុតាងពីការដែលទ្រង់យកឈ្នះសាតាំង និងការដែលទ្រង់យកឈ្នះលោកីយ៍។ រាល់ពេលដែលព្រះជាម្ចាស់ផ្ទាល់ធ្វើការនៅក្នុងចំណោមមនុស្សលោក នោះហើយគឺជាចាប់ផ្ដើមសង្គ្រាមមួយថ្មី។ គ្មានការចាប់ផ្ដើមកិច្ចការថ្មី តាមធម្មតាក៏គ្មានការបញ្ចប់សង្គ្រាមចាស់ដែរ។ ហើយកាលណាគ្មានការបញ្ចប់សង្គ្រាមចាស់ នេះក៏ជាភស្តុតាងបញ្ជាក់ថា សង្គ្រាមជាមួយសាតាំង ក៏មិនទាន់ដល់ទីបញ្ចប់ដែរ។ លុះត្រាតែព្រះជាម្ចាស់ផ្ទាល់ព្រអង្គយាងមក ហើយអនុវត្តកិច្ចការថ្មីក្នុងចំណោមមនុស្សលោក ទើបមនុស្សអាចរួចខ្លួនទាំងស្រុងពីការគ្រប់គ្រងរបស់សាតាំង ហើយទទួលបាននូវជីវិតថ្មី និងការចាប់ផ្ដើមថ្មីមួយ។ ពុំនោះទេ មនុស្សនឹងរស់នៅក្នុងយុគសម័យចាស់ជានិរន្ត ហើយរស់នៅក្រោមឥទ្ធិពលចាស់ របស់

សាតាំងជារៀងរហូត។ ក្នុងគ្រប់យុគសម័យដែលត្រូវបានដឹកនាំដោយព្រះជាម្ចាស់ មនុស្សបានរួចខ្លួនមួយចំណែក ដូច្នេះហើយ មនុស្សអាចវិវឌ្ឍទៅមុខព្រមជាមួយនឹងកិច្ចការរបស់ព្រះជាម្ចាស់ ឈានទៅរកយុគសម័យថ្មី។ ជ័យជម្នះរបស់ព្រះជាម្ចាស់គឺជាជ័យជម្នះរបស់មនុស្សទាំងអស់ដែលដើរតាមទ្រង់។ ប្រសិនបើការរត់ប្រណាំងរបស់មនុស្ស ត្រូវបានដាក់បន្ទុកដោយសារបញ្ចប់យុគសម័យ នោះទោះបីជាតាមទស្សនៈរបស់មនុស្ស ឬសាតាំង ក៏ការរត់ប្រណាំងនេះ គ្មានអ្វីក្រៅតែពីទង្វើទាស់ប្រឆាំង ឬក្បត់ព្រះជាម្ចាស់តែប៉ុណ្ណោះ មិនមែនជាការស្ដាប់បង្គាប់ព្រះជាម្ចាស់ឡើយ ហើយកិច្ចការរបស់មនុស្សនឹងក្លាយជាឧបករណ៍ប្រើប្រាស់សម្រាប់សាតាំងវិញ។ ទាល់តែមនុស្សស្ដាប់បង្គាប់ និងធ្វើតាមព្រះជាម្ចាស់ នៅក្នុងយុគសម័យដែលចាប់ផ្ដើមឡើងដោយព្រះជាម្ចាស់ទាំងស្រុង ទើបសាតាំងអាចជឿទាំងស្រុងបាន ដ្បិតនោះហើយគឺជាភារកិច្ចរបស់មនុស្ស។ ហេតុនេះ ខ្ញុំនិយាយថា អ្នករាល់គ្នាត្រូវតែធ្វើតាម និងស្ដាប់បង្គាប់ប៉ុណ្ណោះគឺបានហើយ គ្មានអ្វីតម្រូវពីអ្នករាល់គ្នាទៀតទេ។ នេះហើយគឺជាអត្ថន័យថាឲ្យមនុស្សម្នាក់ៗប្រកាន់ខ្ជាប់នូវកាតព្វកិច្ចរបស់ខ្លួន ហើយឲ្យម្នាក់ៗបំពេញមុខងាររបស់ខ្លួនឯងរៀងៗខ្លួន។ ព្រះជាម្ចាស់ធ្វើកិច្ចការរបស់ទ្រង់ផ្ទាល់ ហើយមនុស្សពុំចាំបាច់មកធ្វើកិច្ចការជំនួសទ្រង់ទេ ហើយទ្រង់ក៏មិនរួមចំណែកក្នុងកិច្ចការរបស់មនុស្សលោកដែរ។ មនុស្សបំពេញភារកិច្ចរបស់គេ ហើយក៏មិនរួមចំណែកក្នុងកិច្ចការរបស់ព្រះជាម្ចាស់ដែរ។ នេះទើបជាការស្ដាប់បង្គាប់ និងជាភស្ដុតាងបញ្ជាក់ពីភាពបរាជ័យរបស់សាតាំង។ បន្ទាប់ពីព្រះជាម្ចាស់ផ្ទាល់ បានបញ្ចប់ការចាប់ផ្ដើមយុគសម័យថ្មី ទ្រង់លែងយាងចុះមកធ្វើកិច្ចការនៅក្នុងចំណោមមនុស្សជាតិ ដោយអង្គអ្នកទៀតហើយ។ លុះត្រាតែបែបនោះ ទើបមនុស្សឈានចូលទៅក្នុងយុគសម័យថ្មីជាផ្លូវការ ដើម្បីបំពេញភារកិច្ចរបស់គេ និងអនុវត្តបេសកកម្មរបស់គេ ក្នុងភាពជាមនុស្សលោក។ ទាំងអស់នេះ គឺជាគោលការណ៍ដែលព្រះជាម្ចាស់ធ្វើការ ជាគោលការណ៍ដែលគ្មាននរណាម្នាក់អាចប្រព្រឹត្តរំលងបាន។ ទាល់តែធ្វើការតាមរបៀបនេះ ទើបមានសុភវិនិច្ឆ័យ និងសមហេតុផល។ កិច្ចការរបស់ព្រះជាម្ចាស់ គឺត្រូវតែធ្វើឡើង

ដោយព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ។ គឺព្រះអង្គហើយដែលជាអ្នកធ្វើឲ្យកិច្ចការរបស់ទ្រង់ដំណើរការទៅបាន ហើយព្រះអង្គក៏ជាអ្នកបង្ហើយកិច្ចការរបស់ទ្រង់ដែរ។ ព្រះអង្គជាអ្នករៀបចំផែនការអំពីកិច្ចការនេះ ហើយព្រះអង្គក៏ជាអ្នកចាត់ចែងកិច្ចការនេះដែរ ជាងនេះទៅទៀត ព្រះអង្គក៏ជាអ្នកនាំកិច្ចការនេះឲ្យឈានទៅរកផលសម្រេចដែរ។ ដូចមានចែងក្នុងព្រះគម្ពីរថា «ខ្ញុំជាដើម ហើយជាចុង ខ្ញុំជាអ្នកព្រោះពូជ និងជាអ្នកច្រូតផល»។ គ្រប់យ៉ាងដែលពាក់ព័ន្ធនឹងការគ្រប់គ្រងរបស់ព្រះអង្គ សុទ្ធតែត្រូវបានធ្វើឡើងដោយព្រះជាម្ចាស់ផ្ទាល់។ ទ្រង់គឺជាអ្នកគ្រប់គ្រងផែនការគ្រប់គ្រងរយៈពេលប្រាំមួយពាន់ឆ្នាំ គ្មាននរណាអាចធ្វើកិច្ចការរបស់ទ្រង់ ជំនួសទ្រង់បានឡើយ ហើយក៏គ្មាននរណាអាចបិទបញ្ចប់កិច្ចការរបស់ទ្រង់ដែរ ដ្បិតគឺទ្រង់ហើយជាអ្នកក្ដោបក្ដាប់អ្វីៗគ្រប់យ៉ាង ក្នុងព្រះហស្តរបស់ព្រះអង្គ។ បន្ទាប់ពីបានបង្កើតលោកីយ៍នេះរួច ទ្រង់នឹងដឹកនាំលោកីយ៍ទាំងមូល ទៅរស់ក្នុងពន្លឺរបស់ព្រះអង្គ ហើយទ្រង់នឹងបញ្ចប់យុគសម័យនេះទាំងមូលផងដែរ ដោយនាំផែនការទាំងមូលរបស់ព្រះអង្គ ឈានទៅរកផលសម្រេច!

# អាថ៌កំបាំងនៃការយកកំណើតជាមនុស្ស (២)

នៅគ្រាដែលព្រះយេស៊ូវធ្វើការនៅក្នុងស្រុកយូដា ទ្រង់បានធ្វើកិច្ចការនោះដោយបើកចំហ ប៉ុន្ដែពេលនេះ ខ្ញុំធ្វើការ និងមានបន្ទូលក្នុងចំណោមអ្នករាល់គ្នាជាសម្ងាត់វិញ។ អ្នកជឿជាច្រើនសុទ្ធតែមិនដឹងរឿងនេះសោះ។ កិច្ចការរបស់ខ្ញុំក្នុងចំណោមអ្នករាល់គ្នា គឺបិទមិនឲ្យអ្នកក្រៅដឹងទេ។ ព្រះបន្ទូលទាំងអស់នេះ ការវាយផ្ចាល និងការជំនុំជម្រះទាំងនេះ គឺឲ្យដឹងត្រឹមអ្នករាល់គ្នាប៉ុណ្ណោះ និងគ្មាននរណាផ្សេងឡើយ។ កិច្ចការទាំងអស់នេះ ត្រូវបានអនុវត្តនៅក្នុងចំណោមអ្នករាល់គ្នា និងបើកសម្ដែងប្រាប់តែអ្នករាល់គ្នាប៉ុណ្ណោះ ក្នុងចំណោមអ្នកមិនជឿ គ្មាននរណាដឹងរឿងនេះទេ ដ្បិតវេលាកំណត់ នៅមិនទាន់មកដល់នៅឡើយទេ។ មនុស្សដែលនៅទីនេះទាំងអស់ហៀបនឹងត្រូវបានប្រោសឲ្យបានពេញខ្នាតហើយ បន្ទាប់ពីបានទ្រាំទ្រនឹងការវាយ

ផ្ទាល ប៉ុន្តែអស់អ្នកដែលនៅខាងក្រៅវិញ គេមិនដឹងអ្វីសោះអំពីរឿងនេះ។ កិច្ចការនេះលាក់កំបាំងណាស់! ចំពោះពួកគេ ព្រះជាម្ចាស់ដែលបានត្រឡប់ជាសាច់ឈាមបានបំពួនព្រះកាយ ប៉ុន្តែចំពោះអ្នកដែលនៅក្នុងចង្កោមនេះវិញ គេអាចនិយាយបានថា ទ្រង់បើកចំហ។ ថ្វីបើនៅក្នុងព្រះជាម្ចាស់ គ្រប់យ៉ាងសុទ្ធតែបើកចំហ គ្រប់យ៉ាងត្រូវបានបើកសម្ដែង ហើយគ្រប់យ៉ាងត្រូវបានដោះឲ្យរួច ក៏រឿងនេះជាការពិត ចំពោះតែអស់អ្នកដែលជឿលើព្រះអង្គប៉ុណ្ណោះ ចំណែកអ្នកដែលនៅសេសសល់ គឺអ្នកមិនជឿវិញនោះ គ្មានអ្វីត្រូវបានបង្ហាញឲ្យគេដឹងឡើយ។ កិច្ចការដែលកំពុងត្រូវបានធ្វើឡើងសព្វថ្ងៃក្នុងចំណោមអ្នករាល់គ្នា និងនៅក្នុងប្រទេសចិន គឺត្រូវបានបិទបាំងយ៉ាងតឹងរ៉ឹង ដើម្បីកុំឲ្យពួកគេដឹង។ ប្រសិនបើគេដឹងពីកិច្ចការនេះ ម្ល៉េះគ្រប់យ៉ាងដែលគេធ្វើ គឺជំទាស់នឹងរឿងនេះ ហើយដាក់វាទៅក្នុងការបៀតបៀនជាមិនខាន។ ពួកគេមុខជាមិនជឿរឿងនេះទេ។ ដើម្បីធ្វើកិច្ចការនៅក្នុងជាតិសាសន៍របស់នាគដ៏ធំមានសម្បុរក្រហម ដែលជាកន្លែងអន់ជាងគេបង្អស់នេះ មិនមែនជាភារកិច្ចងាយស្រួលនោះទេ។ ប្រសិនបើកិច្ចការនេះ ត្រូវយកទៅដាក់កណ្ដាលចំណោមសាធារណជន នោះវាមុខជាមិនអាចបន្តទៀតបានទេ។ កិច្ចការដំណាក់កាលនេះ មិនអាចយកទៅអនុវត្តកណ្ដាលចំណោមសាធារណជនបានតែម្ដង។ ប្រសិនបើកិច្ចការនេះត្រូវយកទៅអនុវត្តកណ្ដាលចំណោមសាធារណជន តើពួកគេអាចអនុញ្ញាតឲ្យកិច្ចការនេះវិវឌ្ឍទៅមុខបានដោយរបៀបណា? តើទង្វើបែបនេះ មិនធ្វើឲ្យកិច្ចការនេះមានហានិភ័យកាន់តែខ្លាំងទេឬអី? ប្រសិនបើកិច្ចការនេះមិនត្រូវលាក់បំបាំង តែផ្ទុយទៅវិញ ត្រូវបានអនុវត្តដូចនៅក្នុងសម័យព្រះយេស៊ូវ លុះកាលទ្រង់ប្រោសមនុស្សឈឺ និងដេញអារក្សយ៉ាងអស្ចារ្យ តើការនោះមិនក្លាយជា «រឹបអូស» ដែលត្រូវវិញ្ញាណអាក្រក់ចាប់យកទៅជាយូរហើយទេឬអី? តើពួកគេអាចបណ្ដោយឲ្យព្រះជាម្ចាស់មានវត្តមានគង់នៅបានទេ? ប្រសិនបើពេលនេះ ខ្ញុំចូលទៅក្នុងសាលាប្រជុំ ដើម្បីប្រកាសព្រះបន្ទូល និងបង្រៀនមនុស្ស នោះខ្ញុំមិនត្រូវគេវាយដំ ក្លាយទៅជាបំណែកៗជាយូរហើយទេឬអី? ហើយប្រសិនបើរឿងនេះបានកើតឡើង តើឲ្យកិច្ចការរបស់ខ្ញុំអាចបន្តអនុវត្តទៅមុខទៀត

បានដោយរបៀបណា? ហេតុផលដែលគ្មានទីសម្គាល់ និងការអស្ចារ្យត្រូវបានសម្ដែងចេញដោយបើកចំហនោះ គឺដើម្បីការលាក់បំបាំងនេះហើយ។ ដូច្នេះ ចំពោះអ្នកមិនជឿ កិច្ចការរបស់ខ្ញុំមិនអាចត្រូវបានមើលឃើញ ស្គាល់ ឬរកឃើញនោះឡើយ។ ប្រសិនបើកិច្ចការដំណាក់កាលនេះ ត្រូវធ្វើឡើងក្នុងលក្ខណៈដូចគ្នានឹងកិច្ចការរបស់ព្រះយេស៊ូវក្នុងយុគសម័យនៃព្រះគុណ កិច្ចការនេះមិនអាចនៅជាប់លាប់ដូចសព្វថ្ងៃនេះទេ។ ដូច្នេះ ការធ្វើការជាសម្ងាត់បែបនេះ គឺជាប្រយោជន៍ដល់អ្នករាល់គ្នា និងដល់កិច្ចការទាំងមូល។ កាលណាកិច្ចការរបស់ព្រះជាម្ចាស់នៅលើផែនដីនេះ មកដល់ទីបញ្ចប់ពេលគឺពេលដែលកិច្ចការសម្ងាត់នេះបញ្ចប់ទៅ នោះដំណាក់កាលកិច្ចការនេះនឹងបែកធ្លាយដល់សាធារណជនទូទៅ។ គ្រប់គ្នានឹងដឹងថា មានអ្នកមានជ័យជម្នះមួយក្រុមនៅក្នុងប្រទេសចិន។ គ្រប់គ្នានឹងដឹងថា ព្រះជាម្ចាស់បានក្លាយជាសាច់ឈាមនៅក្នុងប្រទេសចិន និងដឹងថា កិច្ចការរបស់ទ្រង់ឈានដល់ទីបញ្ចប់ហើយ។ លុះដល់ពេលនោះទើបមនុស្សភ្ញាក់នឹកឃើញថា៖ ហេតុអ្វីបានជាប្រទេសចិនពុំទាន់បង្ហាញនូវឱនភាព ឬការដួលរលំដូច្នេះ? វាបញ្ជាក់ថា ព្រះជាម្ចាស់កំពុងអនុវត្តកិច្ចការរបស់ទ្រង់ដោយផ្ទាល់នៅក្នុងប្រទេសចិន ហើយបានប្រោសមនុស្សមួយក្រុមឲ្យបានគ្រប់លក្ខណ៍ក្លាយជាអ្នកមានជ័យជម្នះ។

ព្រះជាម្ចាស់បានក្លាយជាសាច់ឈាម ដើម្បីបង្ហាញអង្គទ្រង់ដល់មនុស្សមួយក្រុមដែលដើរតាមទ្រង់ ក្នុងគ្រាដែលទ្រង់អនុវត្តកិច្ចការរបស់ទ្រង់ដោយផ្ទាល់ប៉ុណ្ណោះ មិនមែនដល់សត្តនិករទាំងអស់ឡើយ។ ទ្រង់បានក្លាយជាសាច់ឈាម ដើម្បីបង្ហើយដំណាក់កាលមួយនៃកិច្ចការរបស់ទ្រង់ និងមិនមែនដើម្បីបង្ហាញរូបអង្គរបស់ទ្រង់ដល់មនុស្សនោះឡើយ។ យ៉ាងណាមិញ កិច្ចការរបស់ទ្រង់គឺទ្រង់ត្រូវតែយកទៅអនុវត្តដោយអង្គឯង ដូច្នេះទ្រង់ចាំបាច់ត្រូវធ្វើកិច្ចការនេះក្នុងសាច់ឈាម។ កាលណាកិច្ចការនេះបញ្ចប់ទៅ នោះទ្រង់នឹងចាកចេញពីពិភពមនុស្ស ទ្រង់មិនអាចគង់នៅយូរក្នុងចំណោមមនុស្សជាតិបានឡើយ ខ្លាចក្រែងមានឧបសគ្គរាំងស្ទះដល់កិច្ចការនេះកើតមានឡើង។ អ្វីដែលទ្រង់សម្ដែងដល់ហ្វូងបណ្ដាជន គ្រាន់តែជានិស្ស័យសុចរិត

របស់ទ្រង់ និងស្នាព្រះហស្តទាំងអស់របស់ទ្រង់ប៉ុណ្ណោះ ពុំមែនជារូបអង្គពីគ្រាដែលទ្រង់ក្លាយជាសាច់ឈាមទាំងពីរលើកនោះទេ ដ្បិតរូបអង្គរបស់ព្រះជាម្ចាស់ អាចសម្ដែងឲ្យឃើញតែតាមរយៈនិស្ស័យរបស់ទ្រង់ប៉ុណ្ណោះ និងមិនអាចជំនួសដោយរូបអង្គនៃសាច់ឈាមជាមនុស្សរបស់ទ្រង់នោះឡើយ។ រូបអង្គនៃសាច់ឈាមរបស់ទ្រង់ត្រូវបានបើកបង្ហាញដើម្បីកំណត់ចំនួនមនុស្ស គឺមានតែអស់អ្នកដែលដើរតាមទ្រង់ប៉ុណ្ណោះ ដ្បិតទ្រង់ធ្វើការនៅក្នុងសាច់ឈាម។ នេះហើយជាហេតុផលដែលកិច្ចការដែលកំពុងត្រូវបានអនុវត្តនៅពេលនេះ ត្រូវបានធ្វើឡើងដោយសម្ងាត់។ ព្រះយេស៊ូវក៏បង្ហាញអង្គទ្រង់ដល់តែសាសន៍យូដា ក្នុងគ្រាដែលទ្រង់ធ្វើកិច្ចការរបស់ទ្រង់តាមរបៀបដូចគ្នានេះដែរ ហើយទ្រង់ពុំដែលបង្ហាញអង្គទ្រង់ជាសាធារណៈ ដល់ជាតិសាសន៍ដទៃទៀតឡើយ។ ដូច្នេះ កាលណាទ្រង់បានបង្ហើយកិច្ចការរបស់ទ្រង់ នោះទ្រង់នឹងចាកចេញពីពិភពរបស់មនុស្សភ្លាម មិននៅយូរទេ។ ក្រោយមកទៀត គឺមិនមែនទ្រង់ (រូបភាពមនុស្សម្នាក់នេះ) ទេ ដែលបង្ហាញអង្គទ្រង់ដល់មនុស្ស តែគឺព្រះវិញ្ញាណបរិសុទ្ធវិញ ដែលអនុវត្តកិច្ចការនេះដោយផ្ទាល់។ កាលណាកិច្ចការរបស់ព្រះជាម្ចាស់ដែលត្រឡប់ជាសាច់ឈាម ត្រូវបានបញ្ចប់ទៅទាំងស្រុង នោះទ្រង់នឹងចាកចេញពីពិភពមនុស្សដែលតែងតែស្លាប់នេះ ហើយមិនយាងត្រឡប់មកធ្វើកិច្ចការណាមួយ ដូចគ្នាទៅនឹងកិច្ចការដែលទ្រង់ធ្វើកាលទ្រង់នៅជាសាច់ឈាមម្ដងទៀតឡើយ។ បន្ទាប់ពីនេះ កិច្ចការនេះនឹងត្រូវធ្វើឡើងទាំងអស់ដោយព្រះវិញ្ញាណបរិសុទ្ធផ្ទាល់។ ក្នុងគ្រានេះ មនុស្សកម្រនឹងអាចមើលឃើញរូបអង្គនៃរូបកាយសាច់ឈាមរបស់ទ្រង់ណាស់ ទ្រង់មិនបង្ហាញអង្គទ្រង់ដល់មនុស្សទាល់តែសោះ តែទ្រង់នៅលាក់ព្រះកាយជានិរន្តរ៍វិញ។ ពេលវេលាសម្រាប់កិច្ចការរបស់ព្រះជាម្ចាស់បានត្រឡប់ជាសាច់ឈាមមានកំណត់។ កិច្ចការនេះត្រូវបានអនុវត្តនៅក្នុងយុគសម័យ កាលសម័យ ជាតិសាសន៍ និងក្នុងចំណោមក្រុមមនុស្សជាក់លាក់។ កិច្ចការនេះបង្ហាញឲ្យឃើញតែកិច្ចការក្នុងសម័យកាលនៃការយកកំណើតរបស់ព្រះជាម្ចាស់ វាតំណាងឲ្យយុគសម័យ ហើយវាតំណាងឲ្យកិច្ចការរបស់ព្រះវិញ្ញាណនៃព្រះជាម្ចាស់ នៅក្នុង

យុគសម័យមួយដោយឡែកប៉ុណ្ណោះ ហើយមិនមែនកិច្ចការទាំងស្រុងរបស់ព្រះអង្គឡើយ។ ដូច្នេះ រូបអង្គរបស់ព្រះជាម្ចាស់ដែលក្លាយជាសាច់ឈាម នឹងមិនត្រូវបានបង្ហាញដល់មនុស្សទាំងអស់ឡើយ។ អ្វីដែលត្រូវបានបង្ហាញដល់បណ្ដាជន គឺភាពសុចរិតរបស់ព្រះជាម្ចាស់ និងនិស្ស័យទាំងអស់របស់ព្រះអង្គ មិនមែនរូបអង្គរបស់ទ្រង់ក្នុងគ្រាដែលទ្រង់ក្លាយជាសាច់ឈាមទាំងពីរលើកនោះទេ។ រូបអង្គដែលបង្ហាញឲ្យមនុស្សឃើញនោះ មិនមែនជារូបអង្គតែអង្គឯង ក៏មិនមែនជារូបអង្គទាំងពីរអង្គរួមគ្នាដែរ។ ដូច្នេះ វាជារឿងចាំបាច់ ដែលសាច់ឈាមជាមនុស្សរបស់ព្រះជាម្ចាស់ ត្រូវចាកចេញពីផែនដីពេលបញ្ចប់កិច្ចការដែលទ្រង់ត្រូវធ្វើ ដ្បិតទ្រង់យាងមកដើម្បីធ្វើតែកិច្ចការដែលទ្រង់គួរធ្វើ និងមិនមែនមកបង្ហាញរូបអង្គរបស់ទ្រង់ដល់មនុស្សឡើយ។ ទោះបីជាសារៈសំខាន់នៃការយកកំណើតជាមនុស្សនេះ ត្រូវបានសម្រេចរួចរាល់ដោយព្រះជាម្ចាស់បានត្រឡប់ជាសាច់ឈាមដល់ទៅពីរលើក ក៏ទ្រង់នឹងមិនបង្ហាញអង្គទ្រង់ជាចំហ ដល់ជាតិសាសន៍ណាផ្សេងដែលមិនធ្លាប់បានឃើញទ្រង់ពីមុនសោះនោះឡើយ។ ព្រះយេស៊ូវនឹងមិនសម្ដែងអង្គទ្រង់ផ្ទាល់ ជាព្រះអាទិត្យនៃសេចក្ដីសុចរិតដល់សាសន៍យូដាម្ដងទៀតឡើយ ទ្រង់ក៏មិនឈរនៅលើភ្នំដើមអូលីវ ហើយលេចមកឲ្យមនុស្សទាំងអស់ឃើញដែរ។ គ្រប់យ៉ាងដែលសាសន៍យូដាបានឃើញ គឺរូបអង្គរបស់ព្រះយេស៊ូវ ក្នុងគ្រាដែលទ្រង់មានព្រះជន្មគង់នៅក្នុងស្រុកយូដា។ នេះគឺមកពីកិច្ចការរបស់ព្រះយេស៊ូវ ក្នុងការដែលទ្រង់យកកំណើតជាមនុស្ស បានបញ្ចប់ទៅកាលពីពីរពាន់ឆ្នាំមុន។ ទ្រង់នឹងមិនត្រឡប់មកស្រុកយូដា ក្នុងរូបភាពជាសាសន៍យូដា ក៏រឹតតែមិនបង្ហាញអង្គទ្រង់ក្នុងរូបភាពជាសាសន៍យូដា ដល់ជាតិសាសន៍ដទៃណាផ្សេងទៀតដែរ ដ្បិតរូបអង្គព្រះយេស៊ូវដែលបានត្រឡប់ជាសាច់ឈាម គ្រាន់តែជារូបភាពជាសាសន៍យូដាម្នាក់ប៉ុណ្ណោះ និងមិនមែនជារូបអង្គជាបុត្រមនុស្សដែលយ៉ូហានបានឃើញនោះទេ។ ទោះបីជាព្រះយេស៊ូវ បានសន្យានឹងអ្នកដែលដើរតាមទ្រង់ថា ទ្រង់នឹងយាងត្រឡប់មកវិញ ក៏ទ្រង់នឹងមិនបង្ហាញអង្គទ្រង់ក្នុងរូបភាពជាសាសន៍យូដា ដល់មនុស្សដែលនៅក្នុងជាតិសាសន៍ដទៃទៀតដែរ។ អ្នករាល់គ្នាគួរដឹងថា កិច្ចការរបស់ព្រះជាម្ចាស់

ដែលត្រឡប់ជាសាច់ឈាម គឺដើម្បីបើកយុគសម័យមួយ។ កិច្ចការនេះ ត្រូវបានកំណត់តែក្នុងរយៈពេលពីរបីឆ្នាំប៉ុណ្ណោះ ហើយទ្រង់មិនអាចអាចបង្ហើយកិច្ចការទាំងអស់របស់ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ ដូចដែលរូបអង្គរបស់ព្រះយេស៊ូវក្នុងនាមជាសាសន៍យូដា អាចតំណាងត្រឹមតែរូបអង្គរបស់ព្រះជាម្ចាស់ កាលទ្រង់ធ្វើការក្នុងស្រុកយូដា ហើយទ្រង់អាចធ្វើតែកិច្ចការនៃការជាប់ឆ្កាងតែប៉ុណ្ណោះ។ ក្នុងគ្រាដែលព្រះយេស៊ូវគង់ក្នុងសាច់ឈាមនៅឡើយ ទ្រង់មិនអាចធ្វើកិច្ចការនៃការបញ្ចប់យុគសម័យ ឬបំផ្លាញមនុស្សជាតិបានឡើយ។ ដូច្នេះ បន្ទាប់ពីទ្រង់ត្រូវគេឆ្កាង និងបានបង្ហើយកិច្ចការរបស់ទ្រង់នោះទ្រង់ក៏យាងឡើងទៅស្ថានខ្ពស់ ហើយបំបាំងព្រះកាយទ្រង់ពីមនុស្សលោកទៅ។ តាំងពីពេលនោះមក ពួកអ្នកជឿដ៏ស្មោះត្រង់ដែលមកពីជាតិសាសន៍ដទៃទាំងអស់នេះ មិនអាចមើលឃើញការបើកសម្ដែងរបស់ព្រះអម្ចាស់យេស៊ូវទេ តែអាចត្រឹមមើលឃើញរូបភាពរបស់ទ្រង់ ដែលពួកគេបិទភ្ជាប់ទៅនឹងជញ្ជាំងតែប៉ុណ្ណោះ។ រូបភាពនេះ គ្រាន់តែជារូបភាពដែលមនុស្សគូរប៉ុណ្ណោះ មិនមែនជារូបអង្គនៃព្រះជាម្ចាស់ ដូចដែលទ្រង់បើកបង្ហាញអង្គទ្រង់ឲ្យមនុស្សបានឃើញនោះឡើយ។ ព្រះជាម្ចាស់នឹងមិនបង្ហាញអង្គទ្រង់ដោយចំហដល់បណ្ដាជនក្នុងរូបភាពកាលពីគ្រាដែលទ្រង់ក្លាយជាសាច់ឈាមទាំងពីរលើកនោះឡើយ។ កិច្ចការដែលទ្រង់ធ្វើក្នុងចំណោមមនុស្សជាតិ គឺដើម្បីអនុញ្ញាតឲ្យគេយល់ពីនិស្ស័យរបស់ទ្រង់។ ទាំងអស់នេះ ត្រូវបានបង្ហាញដល់មនុស្ស ដោយមធ្យោបាយនៃកិច្ចការក្នុងយុគសម័យខុសៗគ្នា ការនេះត្រូវបានសម្រេចឡើងតាមរយៈនិស្ស័យដែលទ្រង់បានសម្ដែងឲ្យមនុស្សឃើញ និងកិច្ចការដែលទ្រង់បានធ្វើ មិនមែនតាមរយៈការបើកសម្ដែងរបស់ព្រះយេស៊ូវឡើយ។ មានន័យថា រូបអង្គរបស់ព្រះជាម្ចាស់ត្រូវបានសម្ដែងឲ្យមនុស្សស្គាល់ មិនមែនតាមរយៈរូបអង្គនៃការយកកំណើតជាមនុស្សនេះឡើយ តែគឺតាមរយៈកិច្ចការដែលត្រូវបានអនុវត្តដោយព្រះដែលយកកំណើតជាមនុស្សដែលមានទាំងរូបអង្គ និងសណ្ឋានទាំងពីរ ចំណែករូបអង្គរបស់ទ្រង់ក៏ត្រូវបានបង្ហាញឲ្យគេឃើញ ហើយនិស្ស័យរបស់ទ្រង់ក៏ត្រូវបានសម្ដែងឲ្យគេស្គាល់ តាមរយៈកិច្ចការរបស់ទ្រង់ដែរ។ នេះហើយគឺជាសារៈសំខាន់នៃកិច្ចការដែលទ្រង់ចង់ធ្វើនៅក្នុងសាច់ឈាម។

កាលណាកិច្ចការរបស់សាច់ឈាមជាមនុស្សរបស់ព្រះជាម្ចាស់ទាំងពីរអង្គ ឈានដល់ទីបញ្ចប់ នោះទ្រង់នឹងចាប់ផ្ដើមបង្ហាញនិស្ស័យសុចរិតរបស់ទ្រង់ ដល់គ្រប់ជាតិសាសន៍នៃអ្នកមិនជឿទាំងអស់ ដោយអនុញ្ញាតឲ្យពួកបណ្ដាជនគ្រប់គ្នាមើលឃើញរូបអង្គរបស់ទ្រង់។ ទ្រង់នឹងបើកសម្ដែងពីនិស្ស័យរបស់ទ្រង់ ហើយទ្រង់នឹងបង្ហាញយ៉ាងច្បាស់ពីចុងបញ្ចប់នៃជំពូកមនុស្សខុសៗគ្នា តាមរយៈមធ្យោបាយនេះ ទាំងធ្វើឲ្យយុគសម័យចាស់ ឈានដល់ទីបញ្ចប់ទាំងស្រុងផង។ ហេតុផលដែលកិច្ចការរបស់ទ្រង់នៅក្នុងសាច់ឈាម មិនលាតសន្ធឹងកាន់តែធំទូលាយ (ដូចកាលព្រះយេស៊ូវធ្វើការតែក្នុងស្រុកយូដា ហើយសព្វថ្ងៃខ្ញុំធ្វើការតែក្នុងចំណោមអ្នករាល់គ្នា) គឺមកពីកិច្ចការរបស់ទ្រង់នៅក្នុងសាច់ឈាមមានដែនកំណត់ និងមានកំហិត។ ទ្រង់គ្រាន់តែកំពុងអនុវត្តកិច្ចការរបស់ទ្រង់មួយរយៈពេលខ្លី ក្នុងរូបភាពសាច់ឈាមជាមនុស្សសាមញ្ញ និងធម្មតាម្នាក់ប៉ុណ្ណោះ។ ទ្រង់មិនមែនកំពុងប្រើសាច់ឈាមនេះ មកធ្វើកិច្ចការដ៏អស់កល្បជានិច្ច ឬកិច្ចការនៃការបង្ហាញអង្គទ្រង់ដល់បណ្ដាជន ក្នុងជាតិសាសន៍អ្នកមិនជឿនោះឡើយ។ កិច្ចការនៅក្នុងសាច់ឈាមនេះ អាចកំណត់បានត្រឹមវិសាលភាព (ដូចជា ការធ្វើការតែក្នុងស្រុកយូដា ឬក្នុងចំណោមអ្នករាល់គ្នា) ហើយតាមមធ្យោបាយនៃកិច្ចការដែលត្រូវបានអនុវត្តនៅក្នុងដែនកំណត់នេះ នោះវិសាលភាពនៃកិច្ចការនេះអាចលាតសន្ធឹងទៅបាន។ ពិតណាស់ កិច្ចការលាតសន្ធឹងនេះ ត្រូវតែអនុវត្តផ្ទាល់ដោយព្រះវិញ្ញាណបរិសុទ្ធ និងលែងជាកិច្ចការរបស់សាច់ឈាមជាមនុស្សរបស់ទ្រង់ទៀតហើយ។ ដោយព្រោះកិច្ចការក្នុងសាច់ឈាមនេះ មានដែនកំណត់ និងមិនលាតសន្ធឹងដល់គ្រប់ទិសទីទាំងអស់ក្នុងសកលលោក កិច្ចការនេះមិនអាចសម្រេចបានឡើយ។ ព្រះវិញ្ញាណបរិសុទ្ធអនុវត្តកិច្ចការបន្តបន្ទាប់មកទៀត តាមរយៈកិច្ចការក្នុងសាច់ឈាមនេះ។ ដូច្នេះ កិច្ចការដែលត្រូវបានធ្វើឡើងក្នុងសាច់ឈាម ជាកិច្ចការដែលមានលក្ខណៈនាំមុខ ជាកិច្ចការដែលត្រូវបានអនុវត្តនៅក្នុងដែនកំណត់ជាក់លាក់។ បន្ទាប់ពីនេះ គឺព្រះវិញ្ញាណរបស់ទ្រង់ហើយដែលអនុវត្តកិច្ចការនេះបន្តទៀត ហើយជាងនេះទៀត ទ្រង់ធ្វើការនេះក្នុងវិសាលភាពដែលធំជាងមុនផង។

ព្រះជាម្ចាស់យាងមកដើម្បីធ្វើកិច្ចការនៅលើផែនដីប៉ុណ្ណោះដើម្បីដឹកនាំយុគសម័យ។ ទ្រង់មានន័យថាបើកយុគសម័យមួយថ្មី និងបញ្ចប់យុគសម័យចាស់ប៉ុណ្ណោះ។ ទ្រង់មិនបានយាងមករស់ជាគំរូពីដំណើរជីវិតរបស់មនុស្សម្នាក់នៅលើផែនដី មកឲ្យព្រះអង្គផ្ទាល់បានស្គាល់ពីអំណរ និងទុក្ខនៃជីវិតនៅក្នុងពិភពរបស់មនុស្សលោក ឬមកប្រោសបុគ្គលម្នាក់ជាក់លាក់ឲ្យបានគ្រប់លក្ខណ៍ ដោយព្រះហស្តទ្រង់ ឬមកទតមើលបុគ្គលម្នាក់ជាក់លាក់ចម្រើនលូតលាស់។ នេះមិនមែនជាកិច្ចការរបស់ទ្រង់ទេ កិច្ចការរបស់ទ្រង់ គឺគ្រាន់តែមកចាប់ផ្ដើមយុគសម័យថ្មី និងបញ្ចប់យុគសម័យចាស់។ ពោលគឺទ្រង់នឹងចាប់ផ្ដើមយុគសម័យមួយដោយផ្ទាល់ បញ្ចប់យុគសម័យមួយទៀតដោយផ្ទាល់ និងយកឈ្នះសាតាំង តាមរយៈការអនុវត្តកិច្ចការរបស់ទ្រង់ដោយផ្ទាល់ដែរ។ រាល់ពេលដែលទ្រង់អនុវត្តកិច្ចការរបស់ទ្រង់ដោយផ្ទាល់ គឺប្រៀបដូចជាទ្រង់ឈានជើងចូលទៅក្នុងសមរភូមិ។ ដំបូង ទ្រង់ឈ្នះលោកីយ៍ រួចហើយយកឈ្នះលើសាតាំង ទាំងនៅក្នុងសាច់ឈាមនៅឡើយ។ ទ្រង់យកសិរីរុងរឿងទាំងអស់ជាកម្មសិទ្ធិរបស់ទ្រង់ ហើយបើកវាំងនននៃកិច្ចការរយៈពេលពីរពាន់ឆ្នាំនេះទាំងស្រុង ធ្វើដូច្នេះ ដើម្បីឲ្យមនុស្សទាំងអស់លើផែនដី មានផ្លូវត្រឹមត្រូវមួយសម្រាប់ដើរ និងមានជីវិតសុខសាន្ត និងរីករាយមួយ សម្រាប់រស់នៅដែរ។ យ៉ាងណាមិញ ព្រះជាម្ចាស់មិនអាចគង់នៅជាមួយមនុស្សលោកលើផែនដីបានយូរទេ ដ្បិតព្រះជាម្ចាស់គឺជាព្រះ ហើយសំខាន់បំផុត គឺទ្រង់មិនដូចគ្នានឹងមនុស្សលោកទេ។ ទ្រង់មិនអាចរស់ក្នុងអាយុកាលនៃមនុស្សធម្មតាម្នាក់ ពោលគឺទ្រង់មិនអាចគង់នៅលើផែនដីនេះ ដូចមនុស្សម្នាក់ដែលគ្មានអ្វីសោះ ក្រៅពីភាពសាមញ្ញឡើយ ដ្បិតទ្រង់មានចំណែកជាមនុស្សធម្មតារបស់បុគ្គលធម្មតាម្នាក់ តិចតួចណាស់ សម្រាប់រក្សាជីវិតជាមនុស្សរបស់ទ្រង់។ ក្នុងន័យមួយទៀត គឺ តើព្រះជាម្ចាស់អាចបង្កើតគ្រួសារ ចាប់អាជីពការងារ និងបីបាច់កូនចៅលើផែនដីនេះ ដោយរបៀបណា? តើនេះមិនមែនជាក្ដីអាម៉ាស់ដល់ទ្រង់ទេឬអី? ដែលទ្រង់ត្រូវបានផ្ដល់នូវភាពជាមនុស្សធម្មតានោះ គឺសម្រាប់តែគោលបំណងអនុវត្តកិច្ចការក្នុងលក្ខណៈធម្មតាមួយ មិនមែនឲ្យទ្រង់អាចមានគ្រួសារ និងអាជីពការងារ ដូចមនុស្ស

ធម្មតាម្នាក់នោះទេ។ ញាណធម្មតារបស់ទ្រង់ គំនិតធម្មតារបស់ទ្រង់ ព្រមទាំងការចិញ្ចឹមជីវិត និងការស្លៀកពាក់ធម្មតានៃសាច់ឈាមរបស់ទ្រង់ គឺល្មមនឹងបញ្ជាក់ថា ទ្រង់មានភាពជាមនុស្សធម្មតាហើយ។ ពុំចាំបាច់ឲ្យទ្រង់មានគ្រួសារ ឬអាជីវការងារដើម្បីមកបញ្ជាក់ថា ទ្រង់មានភាពជាមនុស្សសាមញ្ញនោះឡើយ។ រឿងនេះគឺមុខជាមិនចាំបាច់សោះតែម្ដង! ការយាងមកផែនដីរបស់ព្រះជាម្ចាស់ គឺព្រះបន្ទូលដែលបានត្រឡប់ជាសាច់ឈាម ទ្រង់គ្រាន់តែអនុញ្ញាតឲ្យមនុស្សយល់ព្រះបន្ទូលរបស់ទ្រង់ និងមើលឃើញព្រះបន្ទូលរបស់ទ្រង់ ពោលគឺ ទ្រង់អនុញ្ញាតឲ្យមនុស្សមើលឃើញកិច្ចការដែលត្រូវបានអនុវត្តដោយសាច់ឈាមរបស់ទ្រង់។ ចេតនារបស់ទ្រង់ គឺមិនមែនឲ្យមនុស្សប្រព្រឹត្តចំពោះសាច់ឈាមរបស់ទ្រង់ ដោយវិធីពិសេសអ្វីឡើយ តែឲ្យមនុស្សចេះស្ដាប់បង្គាប់ដល់ទីបញ្ចប់ប៉ុណ្ណោះ ពោលគឺ ស្ដាប់បង្គាប់គ្រប់ទាំងព្រះបន្ទូលដែលចេញពីព្រះឱស្ឋរបស់ទ្រង់មក ហើយចុះចូលនឹងគ្រប់កិច្ចការដែលទ្រង់ធ្វើ។ ទ្រង់គ្រាន់តែធ្វើការក្នុងសាច់ឈាមប៉ុណ្ណោះ ទ្រង់គ្មានចេតនាបង្គាប់ឲ្យមនុស្សលើកតម្កើងភាពមហិមា និងភាពបរិសុទ្ធនៃសាច់ឈាមរបស់ទ្រង់ឡើយ តែផ្ទុយទៅវិញ ទ្រង់កំពុងបង្ហាញឲ្យមនុស្សឃើញប្រាជ្ញានៃកិច្ចការរបស់ទ្រង់ និងសិទ្ធិអំណាចទាំងអស់ដែលទ្រង់មានវិញ។ ដូច្នេះហើយ ទោះបីជាទ្រង់មានភាពជាមនុស្សដ៏អស្ចារ្យ ក៏ទ្រង់មិនធ្វើសេចក្ដីប្រកាសដែរ ហើយផ្ដោតតែលើកិច្ចការដែលទ្រង់គួរធ្វើតែប៉ុណ្ណោះ។ អ្នករាល់គ្នាគប្បីដឹងថា ហេតុអ្វីបានជាព្រះជាម្ចាស់ក្លាយជាសាច់ឈាម តែមិនប្រកាស ឬធ្វើបន្ទាល់ពីភាពជាមនុស្សធម្មតារបស់ទ្រង់ ផ្ទុយទៅវិញ ទ្រង់គ្រាន់តែអនុវត្តកិច្ចការដែលទ្រង់ចង់ធ្វើប៉ុណ្ណោះ។ ដូច្នេះ គ្រប់យ៉ាងដែលអ្នករាល់គ្នាអាចមើលឃើញ តាមរយៈព្រះដែលយកកំណើតជាមនុស្ស គឺលក្ខណៈជាព្រះរបស់ទ្រង់ នេះគឺមកពីទ្រង់មិនដែលប្រកាសពីលក្ខណៈជាមនុស្សរបស់ទ្រង់ ឲ្យមនុស្សយកតម្រាប់តាម។ លុះដល់ពេលដែលមនុស្សដឹកនាំមនុស្សដទៃទៀត ទើបគេនិយាយពីលក្ខណៈជាមនុស្សរបស់ទ្រង់ ដើម្បីទទួលបានការសរសើរ និងការជឿជាក់កាន់តែច្រើន ហើយទទួលបាននូវភាពជាអ្នកដឹកនាំពីមនុស្សដទៃផង។ ផ្ទុយទៅវិញ ព្រះជាម្ចាស់បានយកឈ្មោះមនុស្សលោក

តាមរយៈកិច្ចការរបស់ទ្រង់តែម្យ៉ាងគត់ (ពោលគឺ ជាកិច្ចការដែលមនុស្សទទួលមិនបាន)។ វាជារឿងមិនសំខាន់ មិនថាទ្រង់ត្រូវបានលើកសរសើរដោយមនុស្ស ឬធ្វើឱ្យមនុស្សគោរពទ្រង់នោះទេ។ គ្រប់យ៉ាងដែលទ្រង់ធ្វើ គឺដើម្បីបណ្ដុះទឹកចិត្តគោរពកោតខ្លាចចំពោះទ្រង់ នៅក្នុងចិត្តរបស់មនុស្ស។ គ្រប់យ៉ាងដែលទ្រង់ត្រូវការ គឺឲ្យអ្នកគោរពកោតខ្លាចទ្រង់ នៅពេលដែលអ្នកបានឃើញនិស្ស័យរបស់ទ្រង់ ផ្ទាល់នឹងភ្នែក។ កិច្ចការដែលព្រះជាម្ចាស់ធ្វើ គឺជាកិច្ចការរបស់ព្រះអង្គផ្ទាល់ មិនមានមនុស្សណាធ្វើកិច្ចការនេះជំនួសទ្រង់បានឡើយ ក៏គ្មានមនុស្សណាអាចទទួលយកកិច្ចការនេះបានដែរ។ មានតែព្រះជាម្ចាស់ផ្ទាល់ទេ ទើបអាចធ្វើកិច្ចការរបស់ទ្រង់ផ្ទាល់ និងចាប់ផ្ដើមយុគសម័យមួយថ្មី សម្រាប់ដឹកនាំមនុស្សទៅក្នុងការរស់នៅបែបថ្មី។ កិច្ចការដែលទ្រង់ធ្វើ គឺដើម្បីឲ្យមនុស្សអាចចាប់ផ្ដើមមានជីវិតថ្មីជាកម្មសិទ្ធ និងចូលទៅក្នុងយុគសម័យថ្មីមួយ។ កិច្ចការដែលនៅសេសសល់ ត្រូវបានប្រគល់ទៅឲ្យអស់អ្នកណាដែលមានភាពជាមនុស្សធម្មតា ដែលត្រូវបានអ្នកដទៃលើកសរសើរ។ ដូច្នេះ ទ្រង់បានបង្ហើយកិច្ចការរយៈពេលពីរពាន់ឆ្នាំ តែក្នុងរយៈពេលបីឆ្នាំកន្លះ ក្នុងថេរវេលាសាមបីឆ្នាំដែលទ្រង់សណ្ឋិតក្នុងសាច់ឈាមក្នុងយុគសម័យនៃព្រះគុណ។ កាលព្រះជាម្ចាស់យាងមកដើម្បីអនុវត្តកិច្ចការរបស់ទ្រង់ ទ្រង់តែងតែបង្ហើយកិច្ចការរយៈពេលពីរពាន់ឆ្នាំរបស់ទ្រង់ ឬកិច្ចការក្នុងយុគសម័យមួយទាំងមូលក្នុងថេរវេលាខ្លីបំផុត គឺពីរបីឆ្នាំប៉ុណ្ណោះ។ ទ្រង់មិនបានបង្អង់ ហើយទ្រង់ក៏មិនពន្យាពេលដែរ ទ្រង់គ្រាន់តែបង្រួមកិច្ចការរយៈពេលជាច្រើនឆ្នាំ ដើម្បីឲ្យវាសម្រេចទៅបានតែក្នុងរយៈពេលពីរបីឆ្នាំយ៉ាងខ្លី។ នេះគឺមកពីកិច្ចការដែលទ្រង់ធ្វើផ្ទាល់នោះ គឺដើម្បីជាប្រយោជន៍ដល់ការបើកច្រកផ្លូវថ្មីមួយ និងការដឹកនាំយុគសម័យថ្មីមួយទាំងស្រុង។

# អាថ៌កំបាំងនៃការយកកំណើតជាមនុស្ស (៣)

នៅគ្រាដែលព្រះជាម្ចាស់អនុវត្តកិច្ចការរបស់ទ្រង់ ទ្រង់យាងមកមិនមែនដើម្បីចូលរួមក្នុងការស្ថាបនា ឬចូលរួមក្នុងចលនាណាមួយឡើយ តែមកសម្រេចព័ន្ធកិច្ចរបស់ទ្រង់វិញ។ រាល់ពេលដែលទ្រង់ក្លាយជាសាច់ឈាម នោះគឺដើម្បីសម្រេចដំណាក់កាលកិច្ចការមួយ និងដើម្បីចាប់ផ្ដើមយុគសម័យថ្មីមួយប៉ុណ្ណោះ។ ពេលនេះយុគសម័យនៃនគរព្រះបានមកដល់ហើយ ហើយការបង្ហាត់បង្រៀននៃនគរព្រះ ក៏មកដល់ដែរ។ កិច្ចការដំណាក់កាលនេះ មិនមែនជាកិច្ចការរបស់មនុស្សទេ ហើយក៏មិនមែនសម្រាប់កែខៃមនុស្សឲ្យឈានទៅដល់កម្រិតជាក់លាក់មួយដែរ ប៉ុន្តែដើម្បីសម្រេចចំណែកមួយនៃកិច្ចការរបស់ព្រះជាម្ចាស់ប៉ុណ្ណោះ។ អ្វីដែលទ្រង់ធ្វើ មិនមែនជាកិច្ចការរបស់មនុស្សទេ ក៏មិនមែនដើម្បីសម្រេចនូវលទ្ធផលជាក់លាក់មួយ ក្នុងការកែខៃមនុស្ស មុនពេលគេចាកចេញពីផែនដីនេះដែរ។ វាជាការសម្រេចព័ន្ធកិច្ចរបស់ទ្រង់ និងបញ្ចប់កិច្ចការដែលទ្រង់គួរធ្វើ នោះគឺធ្វើការរៀបចំដ៏ត្រឹមត្រូវសម្រាប់កិច្ចការរបស់ទ្រង់នៅលើផែនដី និងទទួលបាននូវសិរីល្អ។ កិច្ចការរបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស គឺមិនដូចនឹងកិច្ចការរបស់មនុស្សដែលព្រះវិញ្ញាណបរិសុទ្ធប្រើនោះទេ។ កាលព្រះជាម្ចាស់យាងមកធ្វើកិច្ចការរបស់ទ្រង់នៅលើផែនដី ទ្រង់មានព្រះទ័យខ្វល់ខ្វាយ ចំពោះតែការសម្រេចព័ន្ធកិច្ចរបស់ទ្រង់ប៉ុណ្ណោះ។ ចំពោះរឿងដទៃផ្សេងទៀតដែលមិនពាក់ព័ន្ធនឹងព័ន្ធកិច្ចរបស់ទ្រង់ គឺទ្រង់សឹងតែមិនចូលរួមសោះ សូម្បីតែយកព្រះនេត្រមើល ក៏មិនមើលផង។ ទ្រង់អនុវត្តតែកិច្ចការដែលទ្រង់គួរធ្វើប៉ុណ្ណោះ ទ្រង់មិនខ្វល់ខ្វាយនឹងកិច្ចការដែលមនុស្សគួរធ្វើ សូម្បីតែបន្តិច។ កិច្ចការដែលទ្រង់ធ្វើ ជាកិច្ចការដែលពាក់ព័ន្ធនឹងយុគសម័យដែលទ្រង់គង់នៅ ហើយពាក់ព័ន្ធនឹងព័ន្ធកិច្ចដែលទ្រង់ត្រូវបំពេញសុទ្ធសាធ ហាក់ដូចជា រឿងរ៉ាវដទៃផ្សេងទៀត ស្ថិតនៅក្រៅវិសាលភាពរបស់ទ្រង់ដូច្នោះដែរ។ ទ្រង់មិនប្រដាប់អង្គទ្រង់ដោយចំណេះដឹងមូលដ្ឋានបន្ថែម ស្ដីអំពីការរស់នៅជាមនុស្សក្នុងចំណោមមនុស្សជាតិទេ ហើយទ្រង់ក៏មិនរៀនបំនិនសង្គមបន្ថែមទៀត ឬប្រដាប់

អង្គទ្រង់ដោយសេចក្ដីណាផ្សេងដែលមនុស្សយល់ដឹងនោះឡើយ។ គ្រប់យ៉ាងដែលមនុស្សគួរមាន មិនបានធ្វើឲ្យទ្រង់ខ្វល់ខ្វាយអ្វីសោះ ហើយទ្រង់ធ្វើតែកិច្ចការណាដែលជាកាតព្វកិច្ចរបស់ទ្រង់តែប៉ុណ្ណោះ។ ដូច្នេះហើយ តាមការមើលឃើញរបស់មនុស្ស ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស មានចំណុចខ្វះខាតច្រើន ដល់ថ្នាក់ទ្រង់មិនទាំងអាចយកព្រះទ័យទុកដាក់នឹងសេចក្ដីជាច្រើនដែលមនុសគួរមាន ហើយទ្រង់ពុំមានការយល់ដឹងអំពីរឿងទាំងនោះទាល់តែសោះ។ រឿងទាំងអស់នោះ ដូចជាចំណេះដឹងទូទៅអំពីការរស់នៅ ក៏ដូចជាគោលការណ៍គ្រប់គ្រងកិរិយារបស់បុគ្គល និងការធ្វើអន្តរកម្មជាមួយអ្នកដទៃ ហាក់ដូចជាគ្មានការទាក់ទងនឹងទ្រង់ទាល់តែសោះ។ ប៉ុន្តែ អ្នកមិនអាចដឹងពីគន្លឹះនៃភាពមិនប្រក្រតី តាមរយៈព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស សូម្បីតែបន្តិចសោះ។ មានន័យថា ភាពជាមនុស្សរបស់ទ្រង់ រក្សាតែការរស់នៅរបស់ទ្រង់ ក្នុងនាមជាមនុស្សធម្មតាម្នាក់ និងរក្សាការលើកហេតុផលនៃព្រះតម្រិះរបស់ទ្រង់ ទាំងផ្ដល់ឲ្យទ្រង់នូវសមត្ថភាពក្នុងការបែងចែកអ្វីដែលត្រូវ និងអ្វីដែលខុស។ យ៉ាងណាមិញ ទ្រង់មិនត្រូវបានប្រដាប់កាយដោយអ្វីផ្សេងពីនេះ ជាអ្វីៗគ្រប់យ៉ាងដែលមនុស្ស (សភាវៈដែលត្រូវបានបង្កើតមក) គួរមាននោះទេ។ ព្រះជាម្ចាស់ក្លាយជាសាច់ឈាម ដើម្បីសម្រេចព័ន្ធកិច្ចរបស់ទ្រង់ប៉ុណ្ណោះ។ កិច្ចការរបស់ទ្រង់ ត្រូវបានតម្រង់ទៅរកយុគសម័យមួយទាំងមូល មិនមែនតម្រង់ទៅរកមនុស្សណាម្នាក់ ឬទីកន្លែងណាមួយឡើយ គឺតម្រង់ទៅរកសកលលោកទាំងមូល។ នេះគឺជាទិសដៅនៃកិច្ចការរបស់ទ្រង់ និងជាគោលការណ៍ដែលទ្រង់ធ្វើការ។ គ្មាននរណាម្នាក់អាចបង្វែរទិសដៅនេះបានឡើយ ហើយមនុស្សក៏គ្មានផ្លូវពាក់ព័ន្ធនឹងកិច្ចការនេះដែរ។ រាល់ពេលដែលព្រះជាម្ចាស់ត្រឡប់ជាសាច់ឈាម ទ្រង់នាំយកកិច្ចការក្នុងយុគសម័យនោះ មកជាមួយនឹងទ្រង់ដែរ ហើយទ្រង់គ្មានចេតនារស់នៅជាមួយនឹងមនុស្សយូរដល់ម្ភៃឆ្នាំ សាមសិបឆ្នាំ សែសិបឆ្នាំ ចិតសិបឆ្នាំ ឬប៉ែតសិបឆ្នាំ ដើម្បីឲ្យទ្រង់អាចមានការយល់ដឹងកាន់តែច្បាស់ និងទទួលបានចំណេះដឹងក្នុងទ្រង់កាន់តែច្រើននោះឡើយ។ គ្មានអ្វីចាំបាច់ដល់ម្លឹងទេ! ធ្វើបែបនេះ គឺគ្មានផ្លូវធ្វើឲ្យចំណេះដឹងដែលមនុស្សមាន

ចំពោះនិស្ស័យធម្មជាតិរបស់ព្រះជាម្ចាស់ មុជជ្រៅទៅឆ្ងាយបានឡើយ ផ្ទុយទៅវិញ វាមានតែបន្ថែមនូវសញ្ញាណ និងធ្វើឲ្យសញ្ញាណ និងគំនិតរបស់គេ ទៅជារឹងដូចថ្ម។ ដូច្នេះ ការនេះវាផ្ដល់ប្រយោជន៍ឲ្យអ្នករាល់គ្នាបានយល់ច្បាស់ថា អ្វីជាកិច្ចការរបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស។ ប្រាកដណាស់ថា អ្នករាល់គ្នាមិនបានយល់ពាក្យសម្ដីដែលខ្ញុំថ្លែងទៅកាន់អ្នករាល់គ្នា៖ «គឺមិនមែនដើម្បីមានពិសោធន៍នូវភាពជាមនុស្សដែលខ្ញុំមាននេះទេមែនទេ?» តើអ្នករាល់គ្នាភ្លេចពាក្យថា៖ «ព្រះជាម្ចាស់យាងមកផែនដី មិនមែនដើម្បីមករស់ក្នុងជីវិតជាមនុស្សធម្មតាម្នាក់» ហើយមែនទេ? អ្នករាល់គ្នាមិនយល់ពីគោលបំណងរបស់ព្រះជាម្ចាស់ ក្នុងការត្រឡប់ជាសាច់ឈាមនេះទេ អ្នករាល់គ្នាក៏ដឹងពីអត្ថន័យសំណួរថា «តើព្រះជាម្ចាស់អាចយាងមកផែនដី ក្នុងចេតនាពិសោធឲ្យស្គាល់ជីវិតជាមនុស្សម្នាក់ ដោយរបៀបណា?» ព្រះជាម្ចាស់យាងមកផែនដី ដើម្បីមកបង្ហើយកិច្ចការរបស់ទ្រង់ទាំងស្រុង ដូច្នេះហើយទើបកិច្ចការរបស់ទ្រង់នៅលើផែនដីនេះ នៅមិនបានយូរទេ។ ទ្រង់យាងមកផែនដីនេះ មិនមែនមកឲ្យព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ បង្រៀនរូបកាយសាច់ឈាមរបស់ទ្រង់ ឲ្យក្លាយជាមនុស្សមានឋានៈខ្ពស់ ជាអ្នកដឹកនាំពួកជំនុំនោះឡើយ។ កាលព្រះជាម្ចាស់យាងមកផែនដី គឺព្រះបន្ទូលដែលត្រឡប់ជាសាច់ឈាម យ៉ាងណាមិញ មនុស្សមិនដឹងពីកិច្ចការរបស់ទ្រង់ ហើយដាក់បន្ទុកកិច្ចការនានាលើទ្រង់ដោយបង្ខំ។ ប៉ុន្តែអ្នករាល់គ្នាគួរដឹងថា ព្រះជាម្ចាស់គឺជាព្រះបន្ទូលដែលត្រឡប់ជាសាច់ឈាម មិនមែនជារូបកាយសាច់ឈាមដែលត្រូវបានបង្រៀនដោយព្រះវិញ្ញាណនៃព្រះ សម្រាប់ទទួលរ៉ាប់រងនូវតួនាទីរបស់ព្រះជាម្ចាស់ សម្រាប់វេលានោះទេ។ ព្រះជាម្ចាស់ផ្ទាល់ ក៏មិនមែនជាផលដែលបានមកពីការបង្ហាត់បង្រៀនដែរ ប៉ុន្តែជាព្រះបន្ទូលដែលត្រឡប់ជាសាច់ឈាម ហើយសព្វថ្ងៃនេះ ទ្រង់អនុវត្តកិច្ចការរបស់ទ្រង់ជាផ្លូវការ ក្នុងចំណោមអ្នករាល់គ្នាទាំងអស់ផង។ អ្នករាល់គ្នាសុទ្ធតែដឹង និងទទួលស្គាល់ថា ការយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់ គឺជាសេចក្ដីពិតដ៏ប្រាកដប្រជា ប៉ុន្តែអ្នករាល់គ្នាធ្វើដូចជាអ្នករាល់គ្នាដឹងពីរឿងនេះដូច្នោះដែរ។ ចាប់តាំងពី កិច្ចការរបស់ព្រះជាម្ចាស់ដែលយកកំណើត

ជាមនុស្ស រហូតដល់សារៈសំខាន់ និងសារជាតិរបស់ការយកកំណើតរបស់ទ្រង់ អ្នករាល់គ្នាអាចយល់បានតិចតួចណាស់ ហើយអ្នកគ្រាន់តែអនុវត្តតាមអ្នកដទៃ ដោយទន្ទេញពាក្យសម្ដីដ៏ឆាប់រហ័សតាមការចងចាំតែប៉ុណ្ណោះ។ តើអ្នកជឿថា ព្រះដែលយកកំណើតជាមនុស្ស ជាមនុស្សដូចដែលអ្នកស្រមៃមែនទេ?

ព្រះជាម្ចាស់ក្លាយជាសាច់ឈាម ដើម្បីដឹកនាំយុគសម័យនេះទាំងស្រុង និងដើម្បីឲ្យកិច្ចការថ្មីដំណើរការ។ អ្នករាល់គ្នាចាំបាច់ត្រូវតែយល់ដឹងអំពីចំណុចនេះ។ មុខងារនេះខុសគ្នាខ្លាំងពីមុខងាររបស់មនុស្ស ហើយមុខងារទាំងពីរនេះ មិនអាចលើកឡើងក្នុងខ្យល់ដង្ហើមដូចតែមួយនោះទេ។ មនុស្សត្រូវទទួលនូវការបង្ហាត់បង្រៀន និងប្រោសឲ្យបានគ្រប់លក្ខណ៍ជាយូរ មុនពេលដែលគេអាចត្រូវយកទៅប្រើប្រាស់ ដើម្បីអនុវត្តកិច្ចការ ហើយចំពោះភាពជាមនុស្សដែលគេត្រូវការ គឺជាចំពូកមនុស្សពិសេសលំដាប់ខ្ពស់។ មនុស្សមិនត្រឹមតែអាចរក្សាស្មារតីនៃភាពជាមនុស្សធម្មតាប៉ុណ្ណោះទេ ប៉ុន្តែគេក៏ត្រូវតែយល់ដឹងបន្ថែមអំពីគោលការណ៍ និងច្បាប់នានាជាច្រើន ដែលកំពុងគ្រប់គ្រងកិរិយារបស់គេ នៅក្នុងទំនាក់ទំនងជាមួយអ្នកដទៃ ហើយជាងនេះទៅទៀត គេត្រូវតែតាំងចិត្តរៀនសូត្របន្ថែមអំពីប្រាជ្ញាញាណ និងចំណេះដឹងដ៏ត្រឹមត្រូវតាមសីលធម៌របស់មនុស្ស។ នេះគឺជាអ្វីដែលមនុស្ស គួរប្រដាប់ជាប់ខ្លួន។ ដោយឡែក ចំពោះព្រះជាម្ចាស់ដែលត្រឡប់ជាសាច់ឈាម គឺមិនមែនដូច្នេះទេ ដ្បិតកិច្ចការរបស់ទ្រង់មិនតំណាងឲ្យមនុស្ស ហើយក៏មិនមែនជាកិច្ចការរបស់មនុស្សដែរ ផ្ទុយទៅវិញ កិច្ចការនោះគឺជាការបង្ហាញឲ្យឃើញផ្ទាល់ពីព្រះវត្តមានរបស់ទ្រង់ និងជាការអនុវត្តផ្ទាល់នៃកិច្ចការដែលទ្រង់គួរតែធ្វើ។ (តាមធម្មតា កិច្ចការរបស់ទ្រង់ត្រូវបានអនុវត្តក្នុងពេលវេលាមួយដ៏ត្រឹមត្រូវ មិនមែនធ្វើឡើងម្ដងម្កាល ឬធ្វើដោយភាពព្រាវៗនោះទេ ហើយកិច្ចការនេះត្រូវបានចាប់ផ្ដើមពេលវេលាកំណត់ក្នុងការសម្រេចព័ន្ធកិច្ចរបស់ទ្រង់មកដល់)។ ទ្រង់មិនរួមចំណែក នៅក្នុងជីវិតរបស់មនុស្សលោក ឬកិច្ចការរបស់មនុស្សលោកនោះទេ ពោលគឺ ភាពជាមនុស្សរបស់ទ្រង់ មិនត្រូវបានប្រដាប់ដោយសេចក្ដីណាមួយ ក្នុងចំណោមសេចក្ដីទាំងនេះទេ (ទោះបីជាសេចក្ដី

នេះមិនប៉ះពាល់ដល់កិច្ចការរបស់ទ្រង់ក៏ដោយ)។ ទ្រង់គ្រាន់តែបំពេញព័ន្ធកិច្ចរបស់ទ្រង់ តាមវេលាកំណត់សម្រាប់ឲ្យទ្រង់ធ្វើកិច្ចការនេះតែប៉ុណ្ណោះ ទោះទ្រង់មានឋានៈអ្វីក៏ទ្រង់បន្តកិច្ចការដែលទ្រង់ធ្វើតាមធម្មតាដែរ។ គ្រប់អ្វីៗដែលមនុស្សដឹងពីទ្រង់ និងគ្រប់អ្វីៗដែលគំនិតរបស់មនុស្សគិតចំពោះទ្រង់ មិនប៉ះពាល់ដល់កិច្ចការរបស់ទ្រង់ទាំងស្រុងឡើយ។ ឧទាហរណ៍ កាលព្រះយេស៊ូវអនុវត្តកិច្ចការរបស់ទ្រង់ គ្មាននរណាដឹងទេថា ទ្រង់ជានរណាឲ្យប្រាកដ ប៉ុន្តែទ្រង់ក៏បន្តធ្វើកិច្ចការរបស់ទ្រង់តាមធម្មតា។ កត្តានេះគ្មានរាំងស្ទះដល់ការអនុវត្តកិច្ចការដែលទ្រង់គួរធ្វើឡើយ។ ដូច្នេះ ជាដំបូងទ្រង់មិនបានថ្លែង ឬប្រកាសប្រាប់ពីអត្តសញ្ញាណរបស់ទ្រង់ផ្ទាល់នោះទេ ហើយទ្រង់គ្រាន់តែឲ្យមនុស្សដើរតាមទ្រង់ប៉ុណ្ណោះ។ តាមធម្មតា រឿងនេះមិនត្រឹមតែជាការបន្ទាបខ្លួនរបស់ព្រះជាម្ចាស់ទេ តែក៏ជាវិធីដែលព្រះជាម្ចាស់ធ្វើការក្នុងសាច់ឈាមដែរ។ ទ្រង់បានត្រឹមតែធ្វើតាមរបៀបនេះប៉ុណ្ណោះ ដ្បិតមនុស្សគ្មានផ្លូវមើលទ្រង់ស្គាល់ដោយភ្នែកទទេរបស់គេឡើយ។ ហើយបើទោះបីជាមនុស្សបានទទួលស្គាល់ទ្រង់ ក៏គេមុខជាមិនអាចជួយកិច្ចការរបស់ទ្រង់ដែរ។ ជាងនេះទៅទៀត ទ្រង់មិនបានក្លាយជាសាច់ឈាម ដើម្បីឲ្យមនុស្សចាប់ផ្ដើមស្គាល់សាច់ឈាមរបស់ទ្រង់ដែរ ទ្រង់ក្លាយជាសាច់ឈាម ដើម្បីមកអនុវត្តកិច្ចការ និងបំពេញព័ន្ធកិច្ចរបស់ទ្រង់។ ដោយព្រោះមូលហេតុនេះ ទ្រង់មិនបានផ្ដល់សារៈសំខាន់ដល់ការបង្ហាញអត្តសញ្ញាណរបស់ទ្រង់ជាសាធារណៈនោះទេ។ កាលទ្រង់បានបង្ហើយកិច្ចការទាំងអស់ដែលទ្រង់គួរធ្វើនោះហើយ អត្តសញ្ញាណ និងឋានៈទាំងអស់របស់ទ្រង់ នឹងបង្ហាញឲ្យមនុស្សឃើញច្បាស់ដោយឯកឯង។ ព្រះជាម្ចាស់ដែលបានត្រឡប់ជាសាច់ឈាមរក្សានូវភាពស្ងៀមស្ងាត់ និងមិនដែលធ្វើសេចក្ដីប្រកាសអ្វីទាំងអស់។ ទ្រង់មិនអើពើចំពោះមនុស្ស ក៏មិនអើពើចំពោះរបៀបដែលមនុស្សវិវឌ្ឍយ៉ាងណានៅក្នុងការដើរតាមទ្រង់នោះដែរ ទ្រង់គ្រាន់តែបន្តធ្វើការបំពេញព័ន្ធកិច្ចរបស់ទ្រង់ និងអនុវត្តកិច្ចការដែលទ្រង់គួរធ្វើប៉ុណ្ណោះ។ គ្មាននរណាម្នាក់អាចរាំរាំងកិច្ចការរបស់ទ្រង់បានឡើយ។ លុះដល់វេលាកំណត់ដែលទ្រង់ត្រូវបង្ហើយកិច្ចការរបស់ទ្រង់ កិច្ចការនោះនឹងត្រូវបង្ហើយ ព្រមទាំងត្រូវបញ្ចប់ទៅជាក់ជា

មិនខាន ហើយគ្មាននរណាម្នាក់អាចបង្អាប់ផ្សេងពីនេះបានឡើយ។ លុះក្រោយពេលដែលទ្រង់ចាកចេញពីមនុស្ស ពេលទ្រង់បង្ហើយកិច្ចការរបស់ទ្រង់រួច ទើបមនុស្សយល់ពីកិច្ចការដែលទ្រង់ធ្វើ តែក៏នៅមិនទាន់យល់ច្បាស់ទាំងស្រុងដែរ។ ហើយមនុស្សនឹងត្រូវការពេលវេលាយូរ ដើម្បីយល់ឲ្យច្បាស់ពីចេតនាដែលទ្រង់អនុវត្តកិច្ចការរបស់ទ្រង់ជាលើកទីមួយ។ និយាយម្យ៉ាងទៀតគឺ កិច្ចការក្នុងយុគសម័យរបស់ព្រះដែលយកកំណើតជាមនុស្ស ត្រូវបានបែងចែកជាពីរផ្នែក។ ផ្នែកទីមួយបន្សំឡើងដោយកិច្ចការដែលព្រះជាម្ចាស់ដែលបានយកកំណើតជាសាច់ឈាមធ្វើដោយផ្ទាល់ព្រះអង្គ និងព្រះបន្ទូលដែលសាច់ឈាមជាមនុស្សរបស់ព្រះជាម្ចាស់ថ្លែងចេញមក។ កាលណាព័ន្ធកិច្ចនៃសាច់ឈាមរបស់ទ្រង់ត្រូវសម្រេចបានទាំងស្រុង នោះចំណែកមួយទៀតនៃកិច្ចការដែលនៅសេសសល់ នឹងត្រូវអនុវត្តដោយមនុស្សដែលព្រះវិញ្ញាណបរិសុទ្ធប្រើ។ វេលានេះហើយជាវេលាដែលមនុស្សគួរបំពេញមុខងាររបស់គេ ដ្បិតព្រះជាម្ចាស់បានបើកផ្លូវរួចជាស្រេចហើយ ហើយមនុស្សចាំបាច់ត្រូវដើរដោយខ្លួនឯង។ មានន័យថា ព្រះជាម្ចាស់ដែលត្រឡប់ជាសាច់ឈាម អនុវត្តកិច្ចការមួយចំណែក ហើយបន្ទាប់មកព្រះវិញ្ញាណបរិសុទ្ធ និងមនុស្សដែលព្រះវិញ្ញាណបរិសុទ្ធប្រើប្រាស់ នឹងធ្វើកិច្ចការនេះបន្តទៀត។ ដូច្នេះ មនុស្សគួរដឹងថា កិច្ចការដែលត្រូវបានអនុវត្តជាចម្បងដោយព្រះជាម្ចាស់ ដែលត្រឡប់ជាសាច់ឈាមក្នុងដំណាក់កាលនេះ ត្រូវតម្រូវឲ្យមានអ្វីខ្លះ ហើយគេត្រូវយល់ឲ្យច្បាស់ពីសារៈសំខាន់ របស់ព្រះជាម្ចាស់ដែលត្រឡប់ជាសាច់ឈាម និងពីកិច្ចការដែលទ្រង់គួរធ្វើ ហើយមិនត្រូវទាមទារពីព្រះជាម្ចាស់ តាមការទាមទារពីមនុស្សនោះឡើយ។ ក្នុងនេះមានរៀបរាប់ពីកំហុសរបស់មនុស្ស សញ្ញាណរបស់គេ ហើយជាងនេះទៅទៀតគឺ ការមិនស្ដាប់បង្គាប់របស់គេ។

ព្រះជាម្ចាស់ដែលត្រឡប់ជាសាច់ឈាម គ្មានចេតនាឲ្យមនុស្សស្គាល់សាច់ឈាមរបស់ទ្រង់ ឬឲ្យមនុស្សបែងចែកភាពខុសគ្នារវាងសាច់ឈាមរបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស និងសាច់ឈាមរបស់មនុស្សនោះឡើយ ព្រះជាម្ចាស់ដែលត្រឡប់ជាសាច់ឈាម ក៏មិនបណ្ដុះសមត្ថភាពនៃការដឹងខុសត្រូវរបស់មនុស្ស ហើយ

ទ្រង់រឹតតែមិនធ្វើដូច្នេះ ក្នុងចេតនាឲ្យមនុស្សថ្វាយបង្គំសាច់ឈាមជាមនុស្សរបស់ព្រះជាម្ចាស់ ដើម្បីទទួលបានការថ្វាយសិរីល្អយ៉ាងអស្ចារ្យនោះដែរ។ ក្នុងចំណោមសេចក្ដីទាំងនេះ គ្មានអ្វីជាចេតនារបស់ព្រះជាម្ចាស់ក្នុងការក្លាយជាសាច់ឈាមនេះទេ។ ព្រះជាម្ចាស់ក៏មិនមែនក្លាយជាសាច់ឈាម ដើម្បីថ្កោលទោសមនុស្ស ឬបើកសម្ដែងដល់មនុស្សដោយចេតនា និងបង្កនូវការលំបាកដល់គេនោះឡើយ។ ក្នុងចំណោមសេចក្ដីទាំងនេះ គ្មានអ្វីជាចេតនារបស់ព្រះជាម្ចាស់ក្នុងការក្លាយជាសាច់ឈាមនេះទេ។ គ្រប់ពេលដែលព្រះជាម្ចាស់ក្លាយជាសាច់ឈាម គឺទម្រង់កិច្ចការនេះហើយ ដែលជារឿងចៀសមិនរួច។ ដែលទ្រង់ប្រព្រឹត្តដូចដែលទ្រង់ធ្វើនេះ គឺដើម្បីកិច្ចការដែលធំជាងនេះ និងការគ្រប់គ្រងដែលធំជាងនេះរបស់ទ្រង់ និងមិនមែនសម្រាប់មូលហេតុដែលមនុស្សស្រមើស្រមៃនោះឡើយ។ ព្រះជាម្ចាស់យាងមកផែនដីក៏ដោយសារតែកិច្ចការរបស់ទ្រង់តម្រូវ និងតាមភាពចាំបាច់ប៉ុណ្ណោះ។ ទ្រង់មិនមែនយាងមកផែនដីនេះដោយចេតនាទតសម្លឹងមើលជុំវិញប៉ុណ្ណោះទេ តែមកអនុវត្តកិច្ចការដែលទ្រង់គួរធ្វើវិញ។ តើមានហេតុផលអ្វីទៀតបានជាទ្រង់ត្រូវរ៉ាប់រងអម្រែកដ៏ធ្ងន់ធ្ងរបែបនេះ ហើយទទួលយកហានិភ័យធំៗបែបនេះ ដើម្បីអនុវត្តកិច្ចការនេះ? ព្រះជាម្ចាស់ត្រឡប់ជាសាច់ឈាមតែពេលណាដែលទ្រង់ចាំបាច់ត្រូវធ្វើប៉ុណ្ណោះ ហើយទ្រង់តែងមានសារៈសំខាន់ពិសេសមកជាមួយជានិច្ច។ ប្រសិនបើកិច្ចការនេះ គឺដើម្បីអនុញ្ញាតឲ្យតែមនុស្សសម្លឹងមើលមកទ្រង់ និងដើម្បីពង្រីកវិសាលភាពនៃចំណេះដឹងរបស់គេនោះទ្រង់ប្រាកដជាមិនយាងមក ក្នុងចំណោមមនុស្សដោយធ្វេសប្រហែសជាដាច់ខាត។ ទ្រង់យាងមកផែនដីនេះ ដើម្បីជាប្រយោជន៍ដល់ការគ្រប់គ្រងរបស់ទ្រង់ និងកិច្ចការដ៏ធំជាងមុនរបស់ទ្រង់ដែរ ហើយដើម្បីឲ្យទ្រង់ អាចទទួលបានមនុស្សជាតិបន្ថែមទៀត។ ទ្រង់យាងមកដើម្បីបង្ហាញឲ្យឃើញពីយុគសម័យនេះ ទ្រង់យាងមកដើម្បីយកឈ្នះសាតាំង ហើយទ្រង់គ្រងអង្គអ្នកដោយសាច់ឈាម ដើម្បីយកឈ្នះសាតាំង។ ជាងនេះទៀត ទ្រង់យាងមកដើម្បីដឹកនាំមនុស្សលោកទាំងមូល នៅក្នុងការរស់នៅតាមបែបបទជីវិតរបស់គេ។ ទាំងអស់នេះ សុទ្ធតែពាក់ព័ន្ធនឹងការគ្រប់គ្រង

របស់ទ្រង់ ហើយពាក់ព័ន្ធនឹងកិច្ចការនៃសកលលោកទាំងមូល។ ប្រសិនបើព្រះជាម្ចាស់ក្លាយជាសាច់ឈាម ដើម្បីអនុញ្ញាតឲ្យមនុស្សចាប់ផ្ដើមស្គាល់សាច់ឈាមរបស់ទ្រង់ និងដើម្បីបើកភ្នែកមនុស្ស នោះហេតុអ្វីបានជាទ្រង់មិនធ្វើដំណើរទៅគ្រប់ជាតិសាសន៍? តើកិច្ចការនេះមិនក្លាយជារឿងងាយស្រួលខ្លាំងពេកទេឬអី? ប៉ុន្ដែ ទ្រង់មិនធ្វើដូច្នេះទេ ផ្ទុយទៅវិញ ទ្រង់ជ្រើសរើសយកកន្លែងដ៏ស័ក្តិសមមួយ ដើម្បីបញ្ចប់ និងចាប់ផ្ដើមកិច្ចការដែលទ្រង់គួរធ្វើ។ ត្រឹមសាច់ឈាមមួយនេះ គឺសំខាន់ខ្លាំងណាស់ទៅហើយ។ ទ្រង់បង្ហាញឲ្យឃើញពីយុគសម័យមួយទាំងមូល ហើយក៏អនុវត្តកិច្ចការនៃយុគសម័យមួយទាំងមូលដែរ។ ទ្រង់បានបញ្ចប់យុគសម័យចាស់ ហើយចាប់ផ្ដើមយុគសម័យថ្មី។ ទាំងអស់នេះ សុទ្ធតែជារឿងសំខាន់ពាក់ព័ន្ធនឹងការគ្រប់គ្រងរបស់ព្រះជាម្ចាស់ ហើយទាំងអស់នេះ សុទ្ធតែជាសារៈសំខាន់នៃកិច្ចការមួយដំណាក់កាល ដែលព្រះជាម្ចាស់យាងមកផែនដី ដើម្បីអនុវត្ត។ កាលព្រះយេស៊ូវយាងមកផែនដី ទ្រង់ថ្លែងព្រះបន្ទូលខ្លះ និងអនុវត្តកិច្ចការមួយចំនួនតែប៉ុណ្ណោះ។ ព្រះអង្គមិនដាក់ព្រះកាយទៅខ្វល់នឹងជីវិតរបស់មនុស្សលោកឡើយ រួចទ្រង់ក៏ចាកចេញទៅ ពេលទ្រង់បង្ហើយកិច្ចការរបស់ទ្រង់រួចហើយភ្លាម។ សព្វថ្ងៃនេះ កាលណាខ្ញុំបញ្ចប់ការថ្លែងព្រះបន្ទូល និងផ្ទេរព្រះបន្ទូលរបស់ខ្ញុំដល់អ្នករាល់គ្នា ហើយកាលណាអ្នករាល់គ្នាបានយល់អស់ហើយ ជំហាននៃកិច្ចការរបស់ខ្ញុំនេះ ក៏នឹងបញ្ចប់ទៅដែរ ទោះបីជាជីវិតរបស់អ្នករាល់គ្នាទៅជាយ៉ាងណាក៏ដោយ។ នៅថ្ងៃអនាគត នឹងមានមនុស្សមកបន្តជំហាននៃកិច្ចការរបស់ខ្ញុំ ហើយបន្តធ្វើកិច្ចការនៅលើផែនដី ស្របតាមព្រះបន្ទូលទាំងនេះទៀតផង នៅពេលនោះ កិច្ចការរបស់មនុស្ស និងការស្ថាបនារបស់មនុស្សនឹងចាប់ផ្ដើមឡើង។ ប៉ុន្ដែ បច្ចុប្បន្ននេះ ព្រះជាម្ចាស់ធ្វើតែកិច្ចការរបស់ទ្រង់ប៉ុណ្ណោះ ដើម្បីសម្រេចព័ន្ធកិច្ចរបស់ទ្រង់ និងដើម្បីបង្ហើយជំហានមួយក្នុងកិច្ចការរបស់ទ្រង់។ ព្រះជាម្ចាស់ធ្វើការក្នុងលក្ខណៈមួយខុសពីមនុស្ស។ មនុស្សចូលចិត្តជំនួប និងការប្រមូលផ្ដុំជាវេទិកា ហើយផ្ដល់សារៈសំខាន់ចំពោះពិធីអធិកអធម ចំណែកអ្វីដែលព្រះជាម្ចាស់ស្អប់បំផុតនោះ គឺជំនួប និងការប្រមូលផ្ដុំរបស់មនុស្សនេះហើយ។ ព្រះជាម្ចាស់ សន្ទនា និងជជែកជាមួយមនុស្ស

ក្នុងលក្ខណៈមិនផ្លូវការ នេះគឺជាកិច្ចការរបស់ព្រះជាម្ចាស់ ជាកិច្ចការដែលត្រូវបានដោះលែងជាពិសេស ហើយដោះអ្នករាល់គ្នាឲ្យដែរ។ យ៉ាងណាមិញ ខ្ញុំស្អប់បំផុតការជួបជុំជាមួយអ្នករាល់គ្នា ហើយខ្ញុំមិនអាចស៊ាំនឹងជីវិតដ៏តឹងរ៉ឹង ដូចជាជីវិតរបស់អ្នករាល់គ្នានោះឡើយ។ ខ្ញុំស្អប់ជាងគេគឺក្រឹត្យក្រម។ ក្រឹត្យក្រមទាំងនេះដាក់កំហិតឲ្យមនុស្សដល់ថ្នាក់ធ្វើឲ្យគេខ្លាច លែងហ៊ានកម្រើក លែងហ៊ាននិយាយស្ដី និងលែងហ៊ានច្រៀង ភ្នែករបស់គេសម្លឹងមកចំអ្នកតែម្ដង។ ខ្ញុំស្អប់ណាស់ លក្ខណៈនៃការជួបជុំរបស់អ្នករាល់គ្នា ហើយខ្ញុំស្អប់ណាស់ការជួបជុំធំៗ។ ខ្ញុំបដិសេធមិនជួបជុំជាមួយនឹងអ្នករាល់គ្នា តាមវិធីបែបនេះតែម្ដង ដ្បិតលក្ខណៈនៃការរស់នបែបនេះ ធ្វើឲ្យមនុស្សមានអារម្មណ៍ដូចជាប់ចំណង ហើយអ្នករាល់គ្នាកាន់ខ្ជាប់តាមពិធីបុណ្យ និងក្រឹត្យក្រមច្រើនពេក។ ប្រសិនបើអ្នករាល់គ្នាត្រូវបានអនុញ្ញាតឲ្យដឹកនាំ អ្នកនឹងដឹកនាំមនុស្សទាំងអស់ទៅក្នុងអំណាចគ្រប់គ្រងនៃក្រឹត្យក្រម ហើយពួកគេនឹងគ្មានផ្លូវយកក្រឹត្យក្រមទុកមួយឡែក នៅក្នុងការដឹកនាំរបស់អ្នករាល់គ្នានោះឡើយ។ ផ្ទុយទៅវិញ មជ្ឈដ្ឋានសាសនានឹងរឹតតែមានភាពតឹងតែងកាន់តែខ្លាំង ហើយទំនៀមទម្លាប់របស់មនុស្សនឹងនៅតែបន្តកើនឡើងដែរ។ មនុស្សខ្លះក៏បន្តប្រកាស និងថ្លែងព្រះបន្ទូល ពេលដែលពួកគេជួបជុំគ្នា ហើយពួកគេមិនដែលមានអារម្មណ៍ខ្វល់ខ្វាយទេ ចំណែកអ្នកខ្លះក៏អាចបន្តប្រកាសព្រះបន្ទូលបានរាប់សិបថ្ងៃ ដោយមិនសម្រាក។ ទាំងអស់នេះរាប់ជាការជួបជុំធំៗ និងជាការជួបជុំរបស់មនុស្ស។ ពិធីទាំងនេះគ្មានអ្វីពាក់ព័ន្ធនឹងរបៀបរបបនៃការហូប និងផឹក របៀបរបបនៃអំណរសប្បាយ ឬរបៀបរបបនៃការដែលវិញ្ញាណត្រូវបានប្រោសឲ្យរួចនោះឡើយ។ ទាំងអស់នេះ គឺសុទ្ធតែជាការជួបជុំ! ការប្រជុំសហការីរបស់អ្នករាល់គ្នា ក៏ដូចជាការជួបជុំពួកជំនុំ ទាំងតូចទាំងធំ សុទ្ធតែជាទីស្អប់ខ្ពើមចំពោះខ្ញុំ ហើយខ្ញុំក៏មិនដែលចាប់អារម្មណ៍នឹងពិធីទាំងអស់នេះទេ។ នេះគឺជាគោលការណ៍ដែលខ្ញុំធ្វើការ៖ ខ្ញុំមិនព្រមប្រកាសព្រះបន្ទូលក្នុងពួកជំនុំឡើយ ខ្ញុំក៏មិនចង់ប្រកាសអ្វីនៅក្នុងចំណោមជំនុំសាធារណជនធំៗដែរ ហើយខ្ញុំរឹតតែមិនចង់ប្រជុំជាមួយអ្នករាល់គ្នាពីរបីថ្ងៃ ក្នុងកម្មវិធីសន្និសីទពិសេសមួយផង។ ខ្ញុំយល់ថាមិនពេញចិត្តដែលអ្នករាល់គ្នា

ត្រូវអង្គុយ រៀបឬករៀបពារនៅក្នុងការប្រជុំគ្នានោះឡើយ។ ខ្ញុំស្អប់នឹងឃើញអ្នករាល់គ្នារស់នៅក្នុងកំហិតនៃពិធីណាមួយ ហើយជាងនេះទៅទៀត ខ្ញុំមិនព្រមរួមចំណែកនៅក្នុងពិធីណាមួយរបស់អ្នករាល់គ្នាទេ។ អ្នករាល់គ្នាកាន់តែធ្វើរឿងនេះ ខ្ញុំរឹតតែយល់ថា វាគួរឲ្យស្អប់។ ខ្ញុំគ្មានចំណាប់អារម្មណ៍នឹងពិធី និងក្រឹត្យក្រមរបស់អ្នករាល់គ្នានេះ សូម្បីបន្តិចសោះ។ ទោះបីជាអ្នករាល់គ្នាប្រារព្ធពិធីនេះបានល្អយ៉ាងណា ក៏ខ្ញុំយល់ថា ពិធីទាំងអស់នេះសុទ្ធតែគួរឲ្យស្អប់។ មិនមែនមកពីការរៀបចំរបស់អ្នករាល់គ្នាមិនសម ឬមកពីអ្នករាល់គ្នាអន់ពេកនោះទេ គឺមកពីខ្ញុំស្អប់លក្ខណៈនៃការរស់នៅរបស់អ្នករាល់គ្នា ហើយជាងនេះទៀត ខ្ញុំមិនអាចស៊ាំនឹងការរស់នៅបែបនេះ។ អ្នករាល់គ្នាមិនយល់កិច្ចការដែលខ្ញុំចង់ធ្វើសូម្បីបន្តិច។ កាលព្រះយេស៊ូវធ្វើកិច្ចការរបស់ទ្រង់នាសម័យនោះ បន្ទាប់ពីអធិប្បាយព្រះបន្ទូលនៅតាមកន្លែងខ្លះរួច ទ្រង់នឹងដឹកនាំពួកសិស្សរបស់ទ្រង់ចេញពីក្រុង រួចជជែកជាមួយពួកគេពីរបៀបដែលព្រះបន្ទូលនោះ ដែលបណ្ដាលឲ្យពួកគេយល់។ ទ្រង់ធ្វើការក្នុងលក្ខណៈបែបនេះជារឿយៗ។ កិច្ចការរបស់ទ្រង់នៅក្នុងចំណោមបណ្ដាជន មានតិច និងនៅចន្លោះឆ្ងាយពីគ្នា។ តាមអ្វីដែលអ្នករាល់គ្នាទូលសុំពីទ្រង់ ព្រះជាម្ចាស់ដែលត្រឡប់ជាសាច់ឈាម មិនគួរមានជីវិតជាមនុស្សធម្មតាម្នាក់នោះទេ។ ទ្រង់ត្រូវតែអនុវត្តកិច្ចការរបស់ទ្រង់ ហើយទោះបីជាទ្រង់គង់ ឈរ ឬយាងដើរ ទ្រង់ត្រូវតែថ្លែងព្រះបន្ទូល។ ទ្រង់ត្រូវតែធ្វើកិច្ចការគ្រប់ពេលវេលា ហើយមិនអាចបញ្ឈប់ «ប្រតិបត្តិការ» របស់ទ្រង់បានឡើយ ពុំនោះទេ គឺទ្រង់កំពុងតែធ្វេសនឹងកាតព្វកិច្ចរបស់ទ្រង់ហើយ។ តើការទាមទាររបស់មនុស្សទាំងនេះ សមទៅនឹងញាណជាមនុស្សដែរឬទេ? ឯណាទៅសច្ចភាពរបស់អ្នករាល់គ្នា? តើអ្នករាល់គ្នាមិនសុំច្រើនពេកហើយមែនទេ? តើខ្ញុំចាំបាច់ត្រូវឲ្យអ្នកមកពិនិត្យពិច័យខ្ញុំ ពេលខ្ញុំធ្វើការដែរមែនទេ? តើខ្ញុំចាំបាច់ត្រូវឲ្យអ្នកកត្រួតពិនិត្យ ពេលខ្ញុំបំពេញព័ន្ធកិច្ចរបស់ខ្ញុំដែរមែនទេ? ខ្ញុំដឹងច្បាស់ថា កិច្ចការណាដែលខ្ញុំគួរធ្វើ ហើយគួរធ្វើនៅពេលណា មិនចាំបាច់ឲ្យអ្នកដទៃមកលូកដៃទេ។ ប្រហែលជាអ្នកមើលឃើញថា ខ្ញុំមិនបានធ្វើអ្វីច្រើនទេ ប៉ុន្តែមកទល់នឹងពេលនោះ កិច្ចការរបស់ខ្ញុំ ជិតនឹងចប់ទៅហើយ។ ចូរយកព្រះបន្ទូលរបស់

ព្រះយេស៊ូវនៅក្នុងដំណឹងល្អទាំងបួនមកធ្វើជាឧទាហរណ៍៖ តើព្រះបន្ទូលនេះមិនត្រូវបានកំហិតដែរទេឬអី? នៅគ្រានោះ កាលព្រះយេស៊ូវយាងចូលសាលាប្រជុំ និងបង្រៀនព្រះបន្ទូល ភាគច្រើនគឺទ្រង់ធ្វើចប់ក្នុងរយៈពេលតែពីរបីនាទីប៉ុណ្ណោះ ហើយកាលណាទ្រង់មានបន្ទូលចប់ ទ្រង់ក៏នាំសិស្សរបស់ទ្រង់ទៅលើទូក ហើយចាកចេញទៅដោយគ្មានការបកស្រាយអ្វីសោះ។ ភាគច្រើន អស់អ្នកដែលនៅក្នុងសាលាប្រជុំនោះ ពិភាក្សាតែក្នុងចំណោមគ្នាគេនោះទៅ តែព្រះយេស៊ូវមិនចូលរួមនឹងការពិភាក្សានេះទេ។ ព្រះជាម្ចាស់ធ្វើតែកិច្ចការដែលទ្រង់គួរធ្វើប៉ុណ្ណោះ ហើយគ្មានអ្វីលើស ឬគ្មានអ្វីក្រៅពីកិច្ចការនេះឡើយ។ ពេលនេះ មនុស្សជាច្រើនចង់ឲ្យខ្ញុំថ្លែងព្រះបន្ទូលច្រើនជាងនេះ និងមានបន្ទូលច្រើនជាងនេះ យ៉ាងហោចណាស់ក៏មួយថ្ងៃបីបួនម៉ោងដែរ។ ដូចអ្នករាល់គ្នាឃើញហើយ ព្រះជាម្ចាស់លែងក្លាយជាព្រះជាម្ចាស់ហើយ ទាល់តែទ្រង់ថ្លែងព្រះបន្ទូល ហើយមានតែអស់អ្នកដែលថ្លែងព្រះបន្ទូលទេ ទើបជាព្រះជាម្ចាស់។ អ្នករាល់គ្នាសុទ្ធតែងងឹតងងល់! ទាំងអស់គ្នាសុទ្ធតែគ្មានវិចារណញាណ! អ្នករាល់គ្នាសុទ្ធតែជាសភាវៈល្ងង់ខ្លៅ ហើយមិនដឹងអ្វីឡើយ! អ្នករាល់គ្នាមានសញ្ញាណច្រើនហួសប្រមាណ! អ្នករាល់គ្នាទាមទារហួសហេតុ! អ្នករាល់គ្នាគ្មានមនុស្សធម៌! អ្នករាល់គ្នាមិនបន្តិចសោះថា ព្រះជាម្ចាស់គឺជាអ្វី! អ្នករាល់គ្នាជឿថា អ្នកថ្លែងព្រះបន្ទូល និងអ្នកពូកែអធិប្បាយ សុទ្ធតែជាព្រះជាម្ចាស់ និងយល់ថា មនុស្សណាដែលព្រមផ្ដល់ព្រះបន្ទូលដល់អ្នករាល់គ្នា អ្នកនោះហើយគឺជាឪពុករបស់អ្នករាល់គ្នា។ ចូរប្រាប់ខ្ញុំមកមើល តើអ្នករាល់គ្នានៅដឹងអំពីលក្ខណៈដែលត្រឹមត្រូវ និងរូបរាងដែលមិនធម្មតារបស់អ្នករាល់គ្នាបន្តិចដែរទេ? ប៉ុន្តែ អ្នកពិតជាស្គាល់ព្រះអាទិត្យពីស្ថានសួគ៌! អ្នករាល់គ្នាម្នាក់ៗ ប្រៀបដូចជាមន្ត្រីលោភលន់ និងពុករលួយ ដូច្នេះ តើអ្នកអាចមើលឃើញញាណដោយវិធីណា? តើអ្នកអាចបែងចែកត្រូវ និងខុសបានទេ? ខ្ញុំបានប្រទានឲ្យអ្នករាល់គ្នាច្រើនណាស់ ប៉ុន្តែក្នុងចំណោមអ្នករាល់គ្នា តើមានមនុស្សប៉ុន្មាននាក់ឲ្យតម្លៃដល់អ្វីដែលខ្ញុំប្រទានឲ្យ? តើនរណាយកសេចក្ដីនេះជាកម្មសិទ្ធិពេញលេញ? អ្នករាល់គ្នាមិនដឹងថា នរណាជាអ្នកបើកផ្លូវដែលអ្នករាល់គ្នាដើររហូតដល់សព្វថ្ងៃនេះទេ ដូច្នេះ អ្នករាល់គ្នាក៏

បន្តធ្វើការទាមទារពីខ្ញុំ ដោយធ្វើការទាមទារដ៏គួរឲ្យអស់សំណើច ហើយលេលាផង។ តើអ្នករាល់គ្នាមិនដិតដៅដោយសារសេចក្ដីខ្មាសទេឬអី? តើខ្ញុំនិយាយមិនទាន់គ្រប់ទៀតមែនទេ? តើខ្ញុំធ្វើមិនទាន់គ្រប់ទៀតមែនទេ? ក្នុងចំណោមអ្នករាល់គ្នា តើមាននរណាដែលអាចចាត់ទុកព្រះបន្ទូលរបស់ខ្ញុំ ជាកំណប់យ៉ាងពិតប្រាកដ? អ្នកនិយាយអួតពីខ្ញុំនៅនឹងមុខខ្ញុំ ប៉ុន្តែអ្នកនិយាយកុហក និងបោកប្រាស់នៅពីក្រោយខ្នងវិញ! សកម្មភាពរបស់អ្នករាល់គ្នាគួរឲ្យស្អប់ណាស់ ហើយវាធ្វើឲ្យខ្ញុំក្ដៅក្រហាយ! ខ្ញុំដឹងថា អ្នករាល់គ្នាសុំឲ្យខ្ញុំនិយាយ និងមិនឲ្យខ្ញុំធ្វើការសម្រាប់ហេតុផលណាផ្សេង ក្រៅតែពីចម្អែតក្រសៃភ្នែករបស់អ្នករាល់គ្នា និងពង្រីកវិសាលភាពចំណេះដឹងរបស់អ្នករាល់គ្នាផង មិនមែនដើម្បីជាប្រយោជន៍ដល់ការបំផ្លាស់បំប្រែជីវិតរបស់អ្នករាល់គ្នានោះឡើយ។ ខ្ញុំបាននិយាយនឹងអ្នករាល់គ្នាច្រើនណាស់ហើយ។ ជីវិតរបស់អ្នករាល់គ្នា គួរតែបានផ្លាស់ប្ដូរជាយូរណាស់មកហើយ ដូច្នេះ ហេតុអ្វីបានជាអ្នករាល់គ្នា នៅតែត្រឡប់ទៅរកសភាពរបស់ខ្លួនឯង សូម្បីតែក្នុងពេលបច្ចុប្បន្នដូច្នេះ? តើអាចមកពីព្រះបន្ទូលរបស់ខ្ញុំត្រូវគេដណ្ដើមពីអ្នករាល់គ្នាទៅ ហើយអ្នករាល់គ្នាមិនបានទទួលព្រះបន្ទូលទាំងនេះមែនទេ? និយាយតាមត្រង់ទៅ ខ្ញុំមិនចង់និយាយអ្វីលើសពីនេះ ទៅកាន់មនុស្សអន់ដូចជាអ្នករាល់គ្នាទេ និយាយទៅ គឺឥតប្រយោជន៍ទទេ! ខ្ញុំមិនចង់ធ្វើកិច្ចការឥតប្រយោជន៍ច្រើនពេកទេ! អ្នករាល់គ្នាគ្រាន់តែចង់ពង្រីកវិសាលភាពនៃចំណេះដឹងរបស់ខ្លួន ឬចម្អែតក្រសៃភ្នែករបស់ខ្លួន និងមិនមែនឲ្យបានជីវិតនោះឡើយ! អ្នករាល់គ្នាសុទ្ធតែកំពុងបោកប្រាស់ខ្លួនឯង! ខ្ញុំសួរអ្នករាល់គ្នាទៅចុះថា តើអ្នករាល់គ្នាបានយកអ្វីដែលខ្ញុំមានបន្ទូលទៅកាន់អ្នករាល់គ្នា មុខទល់នឹងមុខ ទៅអនុវត្តបានច្រើនប៉ុនណាហើយ? គ្រប់យ៉ាងដែលអ្នករាល់គ្នាធ្វើ គឺលេងល្បិចបោកប្រាស់អ្នកដទៃ! ក្នុងចំណោមអ្នករាល់គ្នា ខ្ញុំស្អប់ណាស់មនុស្សដែលរីករាយនឹងសម្លឹងមើល ក្នុងនាមជាទស្សនិកជន ហើយខ្ញុំយល់ថា ចម្ងល់របស់អ្នករាល់គ្នា គឺពិតជាគួរឲ្យស្អប់ខ្លាំងណាស់។ ប្រសិនបើអ្នករាល់គ្នាមិនមកទីនេះដើម្បីស្វះស្វែងរកផ្លូវពិត ឬស្រេកឃ្លានសេចក្ដីពិត នោះអ្នករាល់គ្នាគឺជាកម្មវត្ថុនៃសេចក្ដីសម្អប់របស់ខ្ញុំហើយ! ខ្ញុំដឹងថា អ្នករាល់គ្នាស្ដាប់ខ្ញុំនិយាយ

ទាំងអស់ ដើម្បីបំពេញចម្ងល់របស់អ្នករាល់គ្នា ឬដើម្បីបំពេញចំណង់ចិត្តដ៏លោភលន់មួយហើយមួយទៀតរបស់អ្នករាល់គ្នា។ អ្នករាល់គ្នាមិនគិតស្វែងរកវត្តមាននៃសេចក្ដីពិតឡើយ ក៏មិនស្វែងរកផ្លូវត្រូវ សម្រាប់ការចូលទៅឯជីវិតនោះដែរ។ ការទាមទារទាំងអស់នេះ មិនមែនមានស្រាប់នៅក្នុងអ្នករាល់គ្នាតែម្ដងនោះទេ។ គ្រប់យ៉ាងដែលអ្នករាល់គ្នាធ្វើ គឺប្រព្រឹត្តចំពោះព្រះជាម្ចាស់ដូចជារបស់លេង ដែលអ្នករាល់គ្នាស្រាវជ្រាវ និងសរសើរ។ អ្នករាល់គ្នាមានបំណងចិត្តតិចតួចណាស់ក្នុងការស្វះស្វែងរកជីវិត ប៉ុន្តែមានបំណងចិត្តចង់ដឹងចង់ឮច្រើន! ការបកស្រាយអំពីផ្លូវនៃជីវិត ដល់មនុស្សបែបនេះ គឺប្រៀបដូចជាចាក់ទឹកលើក្បាលទា។ ខ្ញុំក៏ប្រហែលជាមិននិយាយអ្វីសោះតែម្ដង! ខ្ញុំប្រាប់អ្នករាល់គ្នាទៅចុះ៖ ប្រសិនបើអ្នករាល់គ្នា គ្រាន់តែព្យាយាមបំពេញចន្លោះក្នុងដួងចិត្តរបស់អ្នករាល់គ្នា នោះអ្នករាល់គ្នាមិនបានខំប្រឹងមករកខ្ញុំអស់ពីលទ្ធភាពទេ! អ្នករាល់គ្នាគួរតែផ្ដល់សារៈសំខាន់ ចំពោះការទទួលបាននូវជីវិត! ចូរកុំបញ្ឆោតខ្លួនឯងឡើយ! អ្នករាល់គ្នា មិនទាន់បានយកការចង់ដឹងចង់ឮរបស់អ្នករាល់គ្នា មកធ្វើជាមូលដ្ឋានសម្រាប់ការស្វះស្វែងឲ្យបានជីវិតរបស់អ្នករាល់គ្នា ឬប្រើវាជាលេស សម្រាប់ការសុំឲ្យខ្ញុំនិយាយមកកាន់អ្នករាល់គ្នានោះឡើយ។ ទាំងអស់នេះសុទ្ធតែជាល្បិចដែលអ្នករាល់គ្នាស្ទាត់ជំនាញខ្លាំងណាស់! ខ្ញុំសុំសួរអ្នករាល់គ្នាម្ដងទៀតថា៖ អ្វីដែលខ្ញុំមានបន្ទូលប្រាប់ឲ្យអ្នកចូលទៅក្នុងនោះ តើអ្នកប្រកាន់ខ្ជាប់ពិតប្រាកដបានច្រើនប៉ុនណាហើយ? តើអ្នកយល់ពីអ្វីៗគ្រប់យ៉ាងដែលខ្ញុំនិយាយទៅកាន់អ្នកទេ? តើអ្នករាល់គ្នាព្យាយាមយកអ្វីៗគ្រប់យ៉ាងដែលខ្ញុំនិយាយទៅកាន់អ្នករាល់គ្នានេះ ទៅអនុវត្តទេ?

កិច្ចការគ្រប់យុគសម័យទាំងអស់ សុទ្ធតែផ្ដួចផ្ដើមឡើងដោយព្រះជាម្ចាស់ផ្ទាល់ ប៉ុន្តែអ្នកគប្បីដឹងថា ទោះបីជាព្រះជាម្ចាស់ធ្វើកិច្ចការតាមវិធីណាក៏ដោយ ក៏ទ្រង់មិនមែនយាងមកដើម្បីចាប់ផ្ដើមចលនាមួយ ឬធ្វើសន្និសីទពិសេស ឬបង្កើតស្ថាប័នណាមួយ ជំនួសមុខឲ្យអ្នករាល់គ្នានោះឡើយ។ ទ្រង់យាងមក ដើម្បីអនុវត្តកិច្ចការដែលទ្រង់គួរធ្វើទាំងស្រុង។ កិច្ចការរបស់ទ្រង់ មិនទទួលរងនូវកំហិតពីមនុស្សណាម្នាក់ឡើយ។ ទ្រង់ធ្វើកិច្ចការរបស់ទ្រង់ តាមវិធីដែលទ្រង់សព្វព្រះទ័យ ទោះបីជាមនុស្ស

គិតអ្វី ឬដឹងអ្វីពីរឿងនេះក៏ដោយ ក៏ទ្រង់យកព្រះទ័យទុកដាក់តែពីការអនុវត្តកិច្ចការរបស់ទ្រង់ប៉ុណ្ណោះ។ ចាប់តាំងពីកំណើតផែនដីរហូតមកទល់នឹងបច្ចុប្បន្ន មានកិច្ចការបីដំណាក់កាលហើយ ពីព្រះយេហូវ៉ា ដល់ព្រះយេស៊ូវ និងពីយុគសម័យនៃក្រឹត្យវិន័យ ដល់យុគសម័យនៃព្រះគុណ ព្រះជាម្ចាស់ពុំដែលចូលរួមក្នុងសន្និសីទពិសេសណាមួយរបស់មនុស្សឡើយ ហើយទ្រង់ក៏មិនបានប្រមូលផ្ដុំមនុស្សទាំងអស់ឲ្យមូលគ្នា ដើម្បីឲ្យចូលរួមក្នុងសន្និសីទការងារជាសកលពិសេសណាមួយ ក្នុងគោលបំណងពង្រីកវិសាលភាពនៃកិច្ចការរបស់ទ្រង់ដែរ។ គ្រប់យ៉ាងដែលទ្រង់ធ្វើ គឺអនុវត្តកិច្ចការផ្ដួចផ្ដើមយុគសម័យមួយទាំងមូល ក្នុងពេលវេលាសមស្របមួយ និងក្នុងទីកន្លែងដ៏ត្រឹមត្រូវមួយ ពោលគឺការចាប់ផ្ដើមយុគសម័យ និងការដឹកនាំមនុស្សមនុស្សលោក ឲ្យរស់នៅតាមបែបផែននៃជីវិតរបស់គេ។ សន្និសីទពិសេសៗ គឺជាការជួបជុំរបស់មនុស្ស ការប្រមូលផ្ដុំមនុស្សឲ្យមូលគ្នា ដើម្បីអបអរថ្ងៃសម្រាកនានា គឺជាកិច្ចការរបស់មនុស្ស។ ព្រះជាម្ចាស់មិនកាន់តាមថ្ងៃសម្រាកទេ ហើយជាងនេះទៀត ទ្រង់យល់ឃើញថា ពិធីទាំងអស់នេះ គួរឲ្យស្អប់ណាស់។ ទ្រង់មិនចូលរួមក្នុងសន្និសីទពិសេសណាឡើយ ហើយលើសពីនេះ ទ្រង់យល់ថា សន្និសីទទាំងនេះគួរឲ្យស្អប់ណាស់។ ពេលនេះ អ្នកគួរយល់ច្បាស់ថា អ្វីទៅជាកិច្ចការដែលត្រូវបានធ្វើឡើងដោយព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សហើយ!

# អាថ៌កំបាំងនៃការយកកំណើតជាមនុស្ស (៤)

អ្នករាល់គ្នាគួរតែដឹងអំពីសាច់រឿងបង្កប់ពីក្រោយព្រះគម្ពីរ និងសាច់រឿងនៃការបង្កើតព្រះគម្ពីររួចហើយ។ មនុស្សដែលមិនទទួលយកកិច្ចការថ្មីរបស់ព្រះជាម្ចាស់ មិនមានចំណេះដឹងនេះឡើយ គឺពួកគេមិនដឹងទេ។ ប្រសិនបើអ្នកត្រូវនិយាយត្រង់ៗ អំពីចំណេះដឹងទាំងនេះទៅកាន់ពួកគេ នោះគេនឹងលែងក្លាយជាមនុស្សប្រកាន់ខ្ជាប់នឹងព្រះគម្ពីរជាមួយអ្នកទៀតហើយ។ ជានិច្ចកាល ពួកគេកំពុងតែសិក្សាស៊ីជម្រៅ

ទៅលើសេចក្ដីទំនាយដែលត្រូវបានថ្លែង៖ តើសេចក្ដីទំនាយនេះបានក្លាយជាការពិតហើយឬនៅ? តើសេចក្ដីទំនាយនោះ បានក្លាយជាការពិតហើយឬនៅ? ការទទួលដំណឹងល្អរបស់ពួកគេគឺស្របតាមព្រះគម្ពីរ ហើយពួកគេប្រកាសដំណឹងល្អដែលស្របតាមព្រះគម្ពីរ។ ជំនឿរបស់គេលើព្រះជាម្ចាស់ ពឹងអាងលើព្រះបន្ទូលចេញពីព្រះគម្ពីរ ហើយបើគ្មានព្រះគម្ពីរទេ នោះពួកគេនឹងមិនជឿលើព្រះជាម្ចាស់ឡើយ។ នេះជារបៀបដែលពួកគេរស់នៅ គឺដោយពិនិត្យពិច័យលើព្រះគម្ពីរ។ នៅពេលដែលពួកគេសិក្សាព្រះគម្ពីរម្ដងទៀត ហើយសុំឲ្យអ្នកពន្យល់ អ្នកនិយាយថា៖ «ជាដំបូង ចូរយើងកុំផ្ទៀងផ្ទាត់ប្រយោគនីមួយៗឡើយ។ ផ្ទុយទៅវិញ ចូរយើងមើលពីរបៀបដែលព្រះវិញ្ញាណបរិសុទ្ធធ្វើការវិញ។ ចូរយើងដើរតាមផ្លូវដែលយើងដើរ ហើយប្រៀបធៀបវាជាមួយសេចក្ដីពិត ដើម្បីចង់ដឹងថាតើផ្លូវនេះពិតជាកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធឬអត់ ហើយចូរយើងប្រើកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធ ដើម្បីពិនិត្យមើលថាតើផ្លូវមួយនេះត្រឹមត្រូវឬក៏អត់។ ចំពោះថាតើសេចក្ដីនេះ ឬសេចក្ដីនោះបានក្លាយជាការពិតដូចបានថ្លែងទុកឬអត់ ក្នុងនាមជាមនុស្ស យើងមិនគួរខ្វល់អំពីវាឡើយ។ សម្រាប់យើងវាប្រសើរជាងក្នុងការនិយាយអំពីកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធ និងកិច្ចការថ្មីៗបំផុតដែលព្រះជាម្ចាស់បានកំពុងតែធ្វើ»។ សេចក្ដីទំនាយនៅក្នុងព្រះគម្ពីរ គឺជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលត្រូវបានបញ្ជូនមក តាមរយៈពួកហោរានៅគ្រានោះ ហើយព្រះបន្ទូលត្រូវបានសរសេរឡើង ដោយមនុស្សដែលព្រះជាម្ចាស់បានប្រើប្រាស់ និងទទួលបានការបណ្ដាលឲ្យតាក់តែងឡើង។ មានតែព្រះជាម្ចាស់ផ្ទាល់ព្រះអង្គប៉ុណ្ណោះដែលអាចពន្យល់អំពីព្រះបន្ទូលទាំងនោះ មានតែព្រះវិញ្ញាណបរិសុទ្ធប៉ុណ្ណោះដែលអាចបកស្រាយអត្ថន័យនៃព្រះបន្ទូលទាំងនោះ ហើយមានតែព្រះជាម្ចាស់ផ្ទាល់ព្រះអង្គប៉ុណ្ណោះដែលអាចបកត្រាទាំងប្រាំពីរ និងបើកក្រាំងបាន។ អ្នកនិយាយថា៖ «អ្នកមិនមែនជាព្រះជាម្ចាស់ឡើយ ហើយខ្ញុំក៏មិនមែនជាព្រះជាម្ចាស់ដែរ ដូច្នេះ តើនរណាហ៊ានពន្យល់អំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ទៅ? តើអ្នកហ៊ានពន្យល់អំពីព្រះបន្ទូលទាំងនោះឬ? ទោះបីជាហោរាយេរេមា យ៉ូហាន និងអេលីយ៉ា មកក៏ដោយ ក៏ពួកគេ

មិនហ៊ានពន្យល់ អំពីព្រះបន្ទូលទាំងនោះដែរ ព្រោះថាពួកគេមិនមែនជាកូនចៀមឡើយ។ មានតែកូនចៀមប៉ុណ្ណោះដែលអាចបកត្រាទាំងប្រាំពីរ និងបើកក្រាំងបាន ហើយគ្មានអ្នកផ្សេងទៀត អាចពន្យល់អំពីព្រះបន្ទូលរបស់ទ្រង់បានឡើយ។ ខ្ញុំមិនហ៊ានដណ្ដើមព្រះនាមរបស់ព្រះជាម្ចាស់ឡើយ ហើយក៏គ្មានបំណង ចង់ពន្យល់អំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែរ។ ខ្ញុំចង់ក្លាយជាមនុស្សម្នាក់ ដែលស្ដាប់បង្គាប់ព្រះជាម្ចាស់តែប៉ុណ្ណោះ។ តើអ្នកជាព្រះជាម្ចាស់ឬ? គ្មានសត្តនិកររបស់ព្រះជាម្ចាស់ណាម្នាក់ហ៊ានបើកក្រាំង ឬពន្យល់អំពីព្រះបន្ទូលទាំងនោះឡើយ ហើយខ្ញុំក៏មិនហ៊ានពន្យល់ដែរ។ យកល្អ អ្នកមិនគួរព្យាយាមចង់ពន្យល់ពីព្រះបន្ទូលទាំងនោះឡើយ។ មិនគួរមាននរណាម្នាក់ ព្យាយាមពន្យល់ព្រះបន្ទូលទាំងនោះទេ។ ចូរយើងនិយាយអំពីកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធវិញ ព្រោះថានេះជាអ្វីដែលមនុស្សអាចធ្វើបាន។ ខ្ញុំមានចំណេះដឹងតិចតួចប៉ុណ្ណោះ អំពីកិច្ចការរបស់ព្រះយេហូវ៉ា និងកិច្ចការរបស់ព្រះយេស៊ូវ ហើយខ្ញុំក៏គ្មានបទពិសោធផ្ទាល់ខ្លួនអំពីកិច្ចការបែបនេះដែរ ដូច្នេះ ខ្ញុំអាចនិយាយអំពីកិច្ចការនេះបានតែបន្តិចបន្តួចប៉ុណ្ណោះ។ ចំពោះអត្ថន័យនៃព្រះបន្ទូលដែលអេសាយ ឬព្រះយេស៊ូវបានថ្លែងនៅក្នុងសម័យរបស់ពួកគេ ខ្ញុំនឹងមិនពន្យល់ឡើយ។ ខ្ញុំមិនសិក្សាព្រះគម្ពីរឡើយ ប៉ុន្តែផ្ទុយទៅវិញ ខ្ញុំដើរតាមកិច្ចការនាពេលបច្ចុប្បន្នរបស់ព្រះជាម្ចាស់។ ជាការពិត អ្នកចាត់ទុកព្រះគម្ពីរជាក្រាំងតូចមួយ ប៉ុន្តែតើនេះមិនមែនជាសៀវភៅមួយ ដែលមានតែកូនចៀមប៉ុណ្ណោះដែលអាចបើកបានទេឬអី? ក្រៅពីកូនចៀម តើនរណាទៅដែលអាចបើកវាបាន? អ្នកមិនមែនជាកូនចៀមឡើយ ហើយខ្ញុំក៏មិនហ៊ានតាំងខ្លួនជាព្រះជាម្ចាស់ផ្ទាល់ព្រះអង្គដែរ ដូច្នេះ ចូរយើងកុំវិភាគអំពីព្រះគម្ពីរ ឬពិនិត្យពិច័យព្រះគម្ពីរឡើយ។ អ្វីដែលប្រសើរជាងក្នុងការពិភាក្សានោះ គឺជាកិច្ចការដែលត្រូវបានធ្វើដោយព្រះវិញ្ញាណបរិសុទ្ធ ព្រោះថានេះជាកិច្ចការនាពេលបច្ចុប្បន្នដែលត្រូវបានធ្វើដោយព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ។ ចូរយើងមើលអំពីគោលការណ៍ដែលព្រះជាម្ចាស់ធ្វើការ និងលក្ខណៈសំខាន់នៃកិច្ចការរបស់ទ្រង់វិញ ហើយប្រើប្រាស់ចំណុចទាំងនេះ ដើម្បីផ្ទៀងផ្ទាត់មើលថាតើផ្លូវដែលយើងដើរនាពេលសព្វថ្ងៃ គឺជាផ្លូវ

ដែលត្រឹមត្រូវឬអត់ ហើយដោយធ្វើបែបនេះ វានឹងជួយឲ្យយើងប្រាកដច្បាស់អំពីផ្លូវមួយនោះ»។ ប្រសិនបើអ្នករាល់គ្នាចង់ប្រកាសដំណឹងល្អ ជាពិសេសទៅកាន់មនុស្សដែលស្ថិតនៅក្នុងពិភពខាងសាសនា អ្នកត្រូវតែយល់អំពីព្រះគម្ពីរ និងមានសមត្ថភាពប៉ិនប្រសប់អំពីសាច់រឿងខាងក្នុងនៃព្រះគម្ពីរ បើមិនដូច្នោះទេ អ្នកគ្មានផ្លូវអាចប្រកាសដំណឹងល្អបានឡើយ។ នៅពេលដែលអ្នកបានយល់អំពីរូបភាពធំ ហើយឈប់ពិនិត្យពិច័យលើព្រះបន្ទូលដែលគ្មានជីវិតនៃព្រះគម្ពីរតាមរបៀបមិនសំខាន់ ប៉ុន្តែបែរជានិយាយតែអំពីកិច្ចការរបស់ព្រះជាម្ចាស់ និងសេចក្ដីពិតជីវិត នោះអ្នកនឹងអាចទទួលបានមនុស្សដែលស្វែងរកចេញពីដួងចិត្តដ៏ពិតមិនខាន។

កិច្ចការរបស់ព្រះយេហូវ៉ា ក្រឹត្យវិន័យដែលទ្រង់បានបង្កើតឡើង និងគោលការណ៍ដែលទ្រង់បានចង្អុលបង្ហាញដល់មនុស្សនៅក្នុងការរស់នៅរបស់ពួកគេ មាតិកានៃកិច្ចការដែលទ្រង់បានធ្វើនៅក្នុងយុគសម័យនៃក្រឹត្យវិន័យ ភាពសំខាន់នៃការដែលទ្រង់ដាក់ឲ្យប្រើប្រាស់ក្រឹត្យវិន័យរបស់ទ្រង់ ភាពសំខាន់នៃកិច្ចការរបស់ទ្រង់ចំពោះយុគសម័យនៃព្រះគុណ និងកិច្ចការដែលព្រះជាម្ចាស់ធ្វើ នៅក្នុងដំណាក់កាលចុងក្រោយនេះ៖ ទាំងអស់នេះហើយ គឺជាចំណុចដែលអ្នករាល់គ្នាគួរយល់ដឹង។ ដំណាក់កាលដំបូង គឺជាកិច្ចការនៅយុគសម័យនៃក្រឹត្យវិន័យ។ ដំណាក់កាលទីពីរ គឺជាកិច្ចការនៅយុគសម័យនៃព្រះគុណ។ ហើយដំណាក់កាលទីបី គឺជាកិច្ចការនៃគ្រាចុងក្រោយ។ អ្នករាល់គ្នាត្រូវតែយល់ឲ្យបានច្បាស់ អំពីដំណាក់កាលទាំងបីនៃកិច្ចការរបស់ព្រះជាម្ចាស់។ ចាប់តាំងពីដើមដំបូង រហូតដល់ទីបញ្ចប់ ទាំងអស់មាននូវបីដំណាក់កាល។ តើអ្វីទៅជាលក្ខណៈសំខាន់នៃកិច្ចការនៅដំណាក់កាលនីមួយៗ? តើនៅក្នុងកិច្ចការនៃផែនការគ្រប់គ្រងរយៈពេលប្រាំមួយពាន់ឆ្នាំមានដំណាក់កាលចំនួនប៉ុន្មានដែលត្រូវអនុវត្ត? តើដំណាក់កាលទាំងនេះត្រូវបានអនុវត្តយ៉ាងដូចម្ដេច? ហេតុអ្វីបានជាដំណាក់កាលនីមួយៗត្រូវបានអនុវត្តតាមរបៀបនោះ? ទាំងនេះសុទ្ធតែជាសំណួរដ៏សំខាន់។ កិច្ចការនៅយុគសម័យនីមួយៗមាននូវគុណតម្លៃតំណាងរបស់វា។ តើកិច្ចការអ្វីទៅ ដែលព្រះយេហូវ៉ាបានអនុវត្ត? ហេតុអ្វីបានជាទ្រង់ធ្វើវាតាម

របៀបនោះ? ហេតុអ្វីទ្រង់ត្រូវបានហៅថាជាព្រះយេហូវ៉ា? ជាថ្មីម្ដងទៀត តើកិច្ចការអ្វីដែលព្រះយេស៊ូវបានអនុវត្តនៅក្នុងយុគសម័យនៃព្រះគុណ? តើទ្រង់បានធ្វើកិច្ចការនោះដោយរបៀបណា? តើផ្នែកណាខ្លះនៃនិស្ស័យរបស់ព្រះជាម្ចាស់ តំណាងឲ្យដំណាក់កាលនីមួយៗនៃកិច្ចការ និងយុគសម័យនីមួយៗ? តើផ្នែកណាខ្លះនៃនិស្ស័យរបស់ទ្រង់ដែលត្រូវបានបង្ហាញចេញនៅក្នុងយុគសម័យនៃក្រឹត្យវិន័យ? តើមានផ្នែកណាខ្លះនៅក្នុងយុគសម័យនៃព្រះគុណ? តើមានផ្នែកណាខ្លះនៅក្នុងយុគសម័យចុងក្រោយ? ទាំងនេះគឺជាសំណួរដ៏សំខាន់ ដែលអ្នករាល់គ្នាត្រូវយល់ឲ្យបានច្បាស់។ និស្ស័យទាំងអស់របស់ព្រះជាម្ចាស់ត្រូវបានបើកសម្ដែងនៅក្នុងដំណើរផ្លូវនៃផែនការគ្រប់គ្រង រយៈពេលប្រាំមួយពាន់ឆ្នាំ។ និស្ស័យទាំងនេះ មិនត្រូវបានបើកសម្ដែងតែនៅក្នុងយុគសម័យនៃព្រះគុណ យុគសម័យនៃក្រឹត្យវិន័យ ឬតែក្នុងអំឡុងពេលនៃគ្រាចុងក្រោយប៉ុណ្ណោះនោះឡើយ។ កិច្ចការដែលត្រូវអនុវត្តនៅគ្រាចុងក្រោយតំណាងដោយការជំនុំជម្រះ សេចក្ដីក្រោធ និងការវាយផ្ចាល។ កិច្ចការដែលត្រូវអនុវត្តនៅគ្រាចុងក្រោយ មិនអាចជំនួសឲ្យកិច្ចការនៅយុគសម័យនៃក្រឹត្យវិន័យ ឬយុគសម័យនៃព្រះគុណឡើយ។ យ៉ាងណាមិញ ដំណាក់កាលទាំងបីដែលមានភាពជាប់ទាក់ទងគ្នានេះ បង្កើតបានជាស្ថាប័នមួយ ហើយដំណាក់កាលទាំងបីនេះ សុទ្ធតែជាកិច្ចការរបស់ព្រះជាម្ចាស់តែមួយ។ តាមធម្មតា ការអនុវត្តនៃកិច្ចការនេះ ត្រូវបានបែងចែកជាយុគសម័យខុសៗគ្នា។ កិច្ចការដែលត្រូវបានធ្វើនៅគ្រាចុងក្រោយនាំមកនូវការបិទបញ្ចប់ចំពោះអ្វីៗគ្រប់យ៉ាង ហើយការដែលត្រូវបានធ្វើនៅក្នុងយុគសម័យនៃក្រឹត្យវិន័យ គឺជាកិច្ចការនៃការចាប់ផ្ដើម ឯកិច្ចការដែលត្រូវបានធ្វើនៅក្នុងយុគសម័យនៃព្រះគុណ គឺជាកិច្ចការនៃការប្រោសលោះ។ ចំពោះនិមិត្តអំពីកិច្ចការនៅក្នុងផែនការគ្រប់គ្រងរយៈពេលប្រាំមួយពាន់ឆ្នាំនេះ គ្មាននរណាម្នាក់អាចទទួលបានគតិជ្រៅជ្រះ ឬការយល់ដឹងឡើយ ហើយនិមិត្តទាំងនេះ នៅបន្តជាពាក្យប្រដៅដដែល។ នៅគ្រាចុងក្រោយ មានតែកិច្ចការនៃព្រះបន្ទូលប៉ុណ្ណោះដែលត្រូវបានអនុវត្ត ដើម្បីនាំចូលទៅក្នុងយុគសម័យនៃនគរព្រះ ប៉ុន្តែវាមិនតំណាងឲ្យយុគសម័យទាំងអស់ឡើយ។

គ្រាចុងក្រោយគ្មានអ្វីលើសពីគ្រាចុងក្រោយទេ ហើយហើយមិនលើសពីយុគសម័យនៃនគរព្រះឡើយ ហើយវាមិនតំណាងឲ្យយុគសម័យនៃព្រះគុណ ឬយុគសម័យនៃក្រឹត្យវិន័យឡើយ។ ក្នុងអំឡុងនៃគ្រាចុងក្រោយ វាគ្រាន់តែគ្រប់កិច្ចការទាំងអស់នៅក្នុងផែនការរយៈពេលប្រាំមួយពាន់ឆ្នាំ ត្រូវបានបើកសម្ដែង ឲ្យអ្នករាល់គ្នាបានឃើញប៉ុណ្ណោះ។ នេះគឺជាការបើកសម្ដែងនូវសេចក្ដីអាថ៌កំបាំង។ សេចក្ដីអាថ៌កំបាំងប្រភេទនេះ គឺជាអ្វីមួយដែលគ្មានមនុស្សណាម្នាក់អាចបើកសម្ដែងបានឡើយ។ មិនថាមនុស្សនោះមានការយល់ដឹងអំពីព្រះគម្ពីរអស្ចារ្យប៉ុនណាឡើយ ប៉ុន្តែវានៅតែជាព្រះបន្ទូលដ្បិតមនុស្សមិនយល់អំពីលក្ខណៈសំខាន់នៃព្រះគម្ពីរឡើយ។ នៅក្នុងការអានព្រះគម្ពីរ មនុស្សអាចយល់អំពីសេចក្ដីពិតខ្លះ គេអាចពន្យល់ព្រះបន្ទូលបានខ្លះ ឬពិនិត្យពិច័យលើបទគម្ពីរ និងជំពូកដ៏ល្បីៗមួយចំនួនបាន ប៉ុន្តែ គេនឹងមិនអាចចម្រាញ់យកអត្ថន័យដែលមាននៅក្នុងព្រះបន្ទូលទាំងនោះបានឡើយ ព្រោះថាអ្វីៗទាំងអស់ដែលមនុស្សមើលឃើញ គឺជាព្រះបន្ទូលដែលស្លាប់ មិនមែនជាឈុតឆាកនៃកិច្ចការរបស់ព្រះយេហូវ៉ា និងរបស់ព្រះយេស៊ូវឡើយ ហើយមនុស្សគ្មានផ្លូវអាចបកស្រាយសេចក្ដីអាថ៌កំបាំងនៃកិច្ចការនេះបានឡើយ។ ដូច្នេះ សេចក្ដីអាថ៌កំបាំងអំពីផែនការគ្រប់គ្រងរយៈពេលប្រាំមួយពាន់ឆ្នាំ គឺជាសេចក្ដីអាថ៌កំបាំងដ៏ធំបំផុត ដ៏លាក់កំបាំងបំផុត ហើយមនុស្សមិនអាចវាស់ស្ទង់បានឡើយ។ គ្មាននរណាម្នាក់ អាចយល់ដោយផ្ទាល់អំពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ឡើយ លុះត្រាតែព្រះជាម្ចាស់ផ្ទាល់ព្រះអង្គពន្យល់ និងបើកសម្ដែងការនោះដល់មនុស្ស បើមិនដូច្នោះទេ សេចក្ដីទាំងនេះនឹងនៅតែជាពាក្យប្រដៅចំពោះមនុស្សជារៀងរហូត នៅតែបន្តជាសេចក្ដីអាថ៌កំបាំងជារៀងរហូត។ អ្នកមិនបាច់ខ្វល់អំពីសេចក្ដីនៅក្នុងពិភពខាងសាសនាឡើយ ហើយនៅថ្ងៃនេះ ប្រសិនបើខ្ញុំមិនមានបន្ទូលប្រាប់ដល់អ្នករាល់គ្នាទេ នោះអ្នកនឹងមិនយល់អំពីវាឡើយ។ កិច្ចការរយៈពេលប្រាំមួយពាន់ឆ្នាំនេះ គឺជាសេចក្ដីមួយដែលមានលក្ខណៈអាថ៌កំបាំងខ្លាំងជាងសេចក្ដីទំនាយទាំងអស់របស់ពួកហោរាទៅទៀត។ វាជាសេចក្ដីអាថ៌កំបាំងដ៏ធំបំផុត ចាប់តាំងពីកំណើតពិភពលោក រហូតមកដល់ពេលបច្ចុប្បន្ន

ហើយគ្មានហោរាណាម្នាក់នៅក្នុងយុគសម័យទាំងអស់អាចវាស់ស្ទង់បានឡើយ ព្រោះសេចក្ដីអាថ៌កំបាំងនេះត្រូវបានបើកសម្ដែងតែនៅក្នុងយុគសម័យចុងក្រោយប៉ុណ្ណោះ ហើយវាមិនធ្លាប់ត្រូវបានបើកសម្ដែងកាលពីមុនឡើយ។ ប្រសិនបើអ្នករាល់គ្នាអាចយល់អំពីសេចក្ដីអាថ៌កំបាំងនេះ ហើយប្រសិនបើអ្នកអាចទទួលយកវាបានទាំងស្រុង នោះគ្រប់បុគ្គលសាសនាទាំងអស់នឹងត្រូវចាញ់ក្រោមសេចក្ដីអាថ៌កំបាំងនេះមិនខាន។ មានតែសេចក្ដីនេះទេ ដែលជានិមិត្តដ៏អស្ចារ្យបំផុត និងជាសេចក្ដីដែលមនុស្សចង់យល់បំផុត ប៉ុន្តែវាក៏ជាអ្វីមួយដែលគេមិនយល់ច្បាស់បំផុតដែរ។ នៅពេលដែលអ្នករាល់គ្នាស្ថិតនៅក្នុងយុគសម័យនៃព្រះគុណ អ្នកមិនដឹងអំពីកិច្ចការ ដែលត្រូវបានធ្វើដោយព្រះយេស៊ូវ ឬកិច្ចការដែលត្រូវបានធ្វើដោយព្រះយេហូវ៉ាឡើយ។ មនុស្សមិនយល់អំពីហេតុផលដែលព្រះយេហូវ៉ាបានបង្កើតក្រឹត្យវិន័យ ហេតុផលដែលទ្រង់សុំឲ្យបណ្ដាជនកាន់តាមក្រឹត្យវិន័យ ឬហេតុផលដែលព្រះវិហារត្រូវបានសង់ ហើយក៏មិនយល់អំពីហេតុផលដែលប្រជាជនអ៊ីស្រាអែលត្រូវបានដឹកនាំចេញពីស្រុកអេស៊ីព្ទ ចូលទៅក្នុងវាលរហោស្ថាន បន្ទាប់មក ចូលទៅក្នុងទឹកដីកាណានឡើយ។ សេចក្ដីទាំងនេះនៅមិនទាន់បើកសម្ដែង រហូតមកដល់ពេលបច្ចុប្បន្ន។

កិច្ចការនៅគ្រាចុងក្រោយ គឺជាដំណាក់កាលចុងក្រោយនៃដំណាក់កាលទាំងបី។ វាជាកិច្ចការនៃយុគសម័យថ្មីមួយទៀត ហើយវាមិនតំណាងឲ្យកិច្ចការគ្រប់គ្រងទាំងអស់ឡើយ។ ផែនការគ្រប់គ្រងរយៈពេលប្រាំមួយពាន់ឆ្នាំ ត្រូវបានបែងចែកជាបីដំណាក់កាលនៃកិច្ចការ។ គ្មានដំណាក់កាលណាមួយ អាចតំណាងឲ្យកិច្ចការនៃយុគសម័យទាំងបីនោះឡើយ ប៉ុន្តែតំណាងតែផ្នែកមួយ នៃដំណាក់កាលទាំងមូលប៉ុណ្ណោះ។ ព្រះនាមព្រះយេហូវ៉ា មិនអាចតំណាងឲ្យនិស្ស័យទាំងស្រុងរបស់ព្រះជាម្ចាស់ឡើយ។ ការដែលទ្រង់បានអនុវត្តកិច្ចការរបស់ទ្រង់នៅក្នុងយុគសម័យនៃក្រឹត្យវិន័យ មិនបញ្ជាក់ថា ព្រះជាម្ចាស់អាចក្លាយជាព្រះនៅក្រោមក្រឹត្យវិន័យតែប៉ុណ្ណោះឡើយ។ ព្រះយេហូវ៉ាបានបង្កើតក្រឹត្យវិន័យសម្រាប់មនុស្ស ហើយបានប្រទានបទបញ្ញត្តិដល់ពួកគេ ដោយសុំឲ្យមនុស្សកសាងព្រះវិហារ និងអាសនា ដូច្នេះ កិច្ចការដែល

ទ្រង់បានធ្វើ តំណាងឲ្យយុគសម័យនៃក្រឹត្យវិន័យតែប៉ុណ្ណោះ។ កិច្ចការដែលទ្រង់បានធ្វើនេះ មិនបញ្ជាក់ថា ព្រះជាម្ចាស់ជាព្រះមួយអង្គដែលសុំឲ្យមនុស្សកាន់តាមក្រឹត្យវិន័យ ឬទ្រង់ជាព្រះជាម្ចាស់នៅក្នុងព្រះវិហារ ឬទ្រង់ជាព្រះជាម្ចាស់នៅមុខអាសនាប៉ុណ្ណោះឡើយ។ ការនិយាយបែបនេះមិនមែនជាការពិតឡើយ។ កិច្ចការដែលត្រូវបានធ្វើនៅក្រោមក្រឹត្យវិន័យ អាចតំណាងឲ្យយុគសម័យមួយតែប៉ុណ្ណោះ។ ដូច្នេះ ប្រសិនបើព្រះជាម្ចាស់ បានធ្វើកិច្ចការតែនៅក្នុងយុគសម័យនៃក្រឹត្យវិន័យ នោះមនុស្សនឹងកំណត់អត្ថន័យព្រះជាម្ចាស់ ទៅតាមនិយមន័យខាងក្រោមថា «ព្រះជាម្ចាស់ជាព្រះដែលគង់នៅក្នុងព្រះវិហារ ហើយដើម្បីបម្រើព្រះជាម្ចាស់ យើងត្រូវតែស្លៀកពាក់ជាសង្ឃ ហើយចូលទៅក្នុងព្រះវិហារ»។ ប្រសិនបើកិច្ចការនៅក្នុងយុគសម័យនៃព្រះគុណមិនត្រូវបានអនុវត្ត ហើយយុគសម័យនៃក្រឹត្យវិន័យបានបន្ត រហូតមកដល់ពេលបច្ចុប្បន្ន នោះមនុស្សនឹងមិនដឹងថា ព្រះជាម្ចាស់ជាព្រះ ដែលពេញដោយសេចក្ដីមេត្តាករុណា និងសេចក្ដីស្រឡាញ់ដែរនោះឡើយ។ ប្រសិនបើកិច្ចការនៅក្នុងយុគសម័យនៃក្រឹត្យវិន័យមិនត្រូវបានធ្វើ ហើយមានតែកិច្ចការ នៅក្នុងយុគសម័យនៃព្រះគុណ នោះអ្វីៗគ្រប់យ៉ាងដែលមនុស្សនឹងដឹងគឺថា ព្រះជាម្ចាស់អាចប្រោសលោះមនុស្ស និងអត់ទោសដល់បាបរបស់មនុស្សតែប៉ុណ្ណោះ។ អ្វីដែលមនុស្សដឹងគឺ ទ្រង់បរិសុទ្ធ និងស្លូតត្រង់ និងដឹងទៀតថា ទ្រង់អាចលះបង់អង្គទ្រង់ដោយការជាប់ឆ្កាងដើម្បីជាប្រយោជន៍ដល់មនុស្ស។ មនុស្សនឹងដឹងតែរឿងទាំងនេះប៉ុណ្ណោះ ប៉ុន្តែគេគ្មានការយល់ដឹងអំពីរឿងផ្សេងឡើយ។ ដូច្នេះ យុគសម័យនីមួយៗតំណាងឲ្យផ្នែកមួយនៃនិស្ស័យរបស់ព្រះជាម្ចាស់។ ចំពោះផ្នែកណានៃនិស្ស័យរបស់ព្រះជាម្ចាស់ដែលត្រូវបានតំណាងនៅក្នុងយុគសម័យនៃក្រឹត្យវិន័យ ផ្នែកណានៅក្នុងយុគសម័យនៃព្រះគុណ និងផ្នែកណានៅក្នុងដំណាក់កាលនាពេលបច្ចុប្បន្ននេះ គឺមានតែនៅពេលដែលដំណាក់កាលទាំងបី ត្រូវបានដាក់បញ្ចូលគ្នាប៉ុណ្ណោះ ទើបវាអាចបើកសម្ដែងអំពីនិស្ស័យទាំងអស់របស់ព្រះជាម្ចាស់។ មានតែនៅពេលដែលមនុស្សចាប់ផ្ដើមដឹងអំពីដំណាក់កាលទាំងបីប៉ុណ្ណោះ ទើបគេអាចយល់អំពីវាបានទាំងស្រុង។ គ្មានដំណាក់

កាលណាមួយក្នុងដំណាក់កាលទាំងបីអាចត្រូវបានលុបចោលនោះឡើយ។ អ្នករាល់គ្នានឹងមើលឃើញពីនិស្ស័យរបស់ព្រះជាម្ចាស់យ៉ាងពេញលេញបាន គឺក្រោយពេលដែលអ្នកដឹង អំពីដំណាក់កាលទាំងបីនៃកិច្ចការទាំងនេះតែប៉ុណ្ណោះ។ ការដែលព្រះជាម្ចាស់សម្រេចកិច្ចការរបស់ទ្រង់ នៅក្នុងយុគសម័យនៃក្រឹត្យវិន័យ មិនបញ្ជាក់ថាទ្រង់ជាព្រះជាម្ចាស់នៅក្រោមក្រឹត្យវិន័យតែមួយឡើយ ហើយការដែលទ្រង់បានបញ្ចប់កិច្ចការប្រោសលោះរបស់ទ្រង់ ក៏មិនមែនមានន័យថា ព្រះជាម្ចាស់នឹងប្រោសលោះមនុស្សជាតិជារៀងរហូតនោះដែរ។ ទាំងនេះ គឺជាការធ្វើសេចក្ដីសន្និដ្ឋានរបស់មនុស្សតែប៉ុណ្ណោះ។ យុគសម័យនៃព្រះគុណបានមកដល់ទីបញ្ចប់ហើយ ដូច្នេះ អ្នកមិនអាចនិយាយថា ព្រះជាម្ចាស់ជាកម្មសិទ្ធិចំពោះឈើឆ្កាងតែមួយគត់ ហើយនិយាយទៀតថាឈើឆ្កាងតំណាងឲ្យសេចក្ដីសង្គ្រោះរបស់ព្រះជាម្ចាស់តែមួយនោះឡើយ ព្រោះការនិយាយបែបនេះ នឹងដាក់ព្រំដែនកំណត់ព្រះជាម្ចាស់មិនខាន។ នៅក្នុងដំណាក់កាលបច្ចុប្បន្ន ព្រះជាម្ចាស់កំពុងតែផ្ដោតធ្វើកិច្ចការនៃព្រះបន្ទូល ប៉ុន្តែអ្នកមិនអាចនិយាយថាព្រះជាម្ចាស់មិនដែលមានសេចក្ដីមេត្តាករុណាចំពោះមនុស្ស ហើយនិយាយទៀតថា អ្វីគ្រប់យ៉ាងដែលទ្រង់បាននាំមក គឺជាការវាយផ្ចាល និងការជំនុំជម្រះនោះឡើយ។ កិច្ចការនៅគ្រាចុងក្រោយ លាតត្រដាងពីកិច្ចការរបស់ព្រះយេហូវ៉ា និងព្រះយេស៊ូវព្រមទាំងគ្រប់ទាំងសេចក្ដីអាថ៌កំបាំងដែលមនុស្សមិនបានយល់ ហើយក៏បើកសម្ដែងពីទិសដៅ និងទីចុងបញ្ចប់នៃមនុស្សជាតិ និងបិទបញ្ចប់គ្រប់ទាំងកិច្ចការនៃសេចក្ដីសង្គ្រោះនៅក្នុងចំណោមមនុស្សជាតិដែរ។ ដំណាក់កាលនៃកិច្ចការនៅគ្រាចុងក្រោយនេះ នាំមកនូវការបិទបញ្ចប់ដល់អ្វីៗទាំងអស់។ គ្រប់សេចក្ដីអាថ៌កំបាំងដែលមនុស្សមិនយល់ ត្រូវបានលាតត្រដាង ដើម្បីជួយឲ្យមនុស្សយល់ដល់ជម្រៅចិត្តរបស់គេ និងមានការយល់ដឹងច្បាស់លាស់ទាំងស្រុងនៅក្នុងដួងចិត្តរបស់គេ។ មានតែបែបនេះទេទើបពូជសាសន៍មនុស្សអាចត្រូវបានចាត់ថ្នាក់ទៅតាមប្រភេទរបស់គេ។ មានតែក្រោយពេលដែលផែនការគ្រប់គ្រងរយៈពេលប្រាំមួយពាន់ឆ្នាំត្រូវបានបញ្ចប់ប៉ុណ្ណោះទើបមនុស្សនឹងចាប់ផ្ដើមយល់អំពីនិស្ស័យទាំងស្រុងរបស់ព្រះជាម្ចាស់ ដ្បិតពេលនោះ

ផែនការរបស់ទ្រង់នឹងបានមកដល់ទីបញ្ចប់។ ឥឡូវនេះ អ្នករាល់គ្នាបានដកពិសោធន៍អំពីកិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងយុគសម័យចុងក្រោយរួចហើយ តើនិស្ស័យរបស់ព្រះជាម្ចាស់គឺជាអ្វីទៅ? តើអ្នកហ៊ាននិយាយថា ព្រះជាម្ចាស់ជាព្រះដែលគ្រាន់តែមានបន្ទូលតែម្យ៉ាងឬ? អ្នកនឹងមិនហ៊ានធ្វើសេចក្ដីសន្និដ្ឋានបែបនេះឡើយ។ អ្នកខ្លះនឹងនិយាយថា ព្រះជាម្ចាស់ជាព្រះដែលលាតត្រដាងសេចក្ដីអាថ៌កំបាំង ហើយនិយាយទៀតថា ព្រះជាម្ចាស់គឺជាកូនចៀម និងជាព្រះដែលបកត្រាទាំងប្រាំពីរ។ ប៉ុន្តែ គ្មាននរណាម្នាក់ហ៊ានធ្វើសេចក្ដីសន្និដ្ឋានបែបនេះឡើយ។ អ្នកផ្សេងទៀតនឹងនិយាយថា ព្រះជាម្ចាស់ជាសាច់ឈាមដែលយកកំណើតជាមនុស្ស ប៉ុន្តែ នេះនៅតែមិនទាន់ត្រឹមត្រូវនៅឡើយទេ។ អ្នកផ្សេងទៀតអាចនិយាយថា ព្រះដែលយកកំណើតជាមនុស្សយាងមក ដើម្បីមានបន្ទូលតែប៉ុណ្ណោះ ហើយទ្រង់មិនធ្វើទីសម្គាល់ និងការអស្ចារ្យអ្វីឡើយ។ ការនិយាយបែបនេះមិនត្រូវឡើយ ព្រោះព្រះយេស៊ូវបានត្រលប់ជាសាច់ឈាម ហើយបានធ្វើទីសម្គាល់ និងការអស្ចារ្យជាច្រើន ដូច្នេះ អ្នកនឹងមិនហ៊ានកំណត់អត្ថន័យព្រះជាម្ចាស់ស្រាលៗបែបនេះឡើយ។ គ្រប់កិច្ចការដែលត្រូវបានធ្វើនៅក្នុងផែនការគ្រប់គ្រងរយៈពេលប្រាំមួយពាន់ឆ្នាំនេះ ឥឡូវបានមកដល់ទីបញ្ចប់ហើយ។ មានតែក្រោយពេលដែលកិច្ចការទាំងអស់នេះត្រូវបានបើកសម្ដែងឲ្យមនុស្សបានឃើញ និងត្រូវបានអនុវត្តនៅក្នុងចំណោមមនុស្សជាតិប៉ុណ្ណោះ ទើបមនុស្សជាតិនឹងដឹងអំពីនិស្ស័យទាំងអស់របស់ព្រះជាម្ចាស់ និងដឹងពីកម្មសិទ្ធិ និងលក្ខណៈរបស់ទ្រង់។ នៅពេលដែលកិច្ចការនៃដំណាក់កាលនេះត្រូវបានបញ្ចប់ទាំងស្រុង នោះគ្រប់ទាំងសេចក្ដីអាថ៌កំបាំងដែលមនុស្សមិនយល់ នឹងត្រូវបានបើកសម្ដែង គ្រប់ទាំងសេចក្ដីពិតដែលមិនបានយល់កាលពីមុន នឹងត្រូវបានបង្ហាញឲ្យយល់ច្បាស់ ហើយពូជសាសន៍មនុស្សនឹងបានដឹងអំពីផ្លូវ និងទិសដៅទៅថ្ងៃអនាគតរបស់គេ។ នេះគឺជាកិច្ចការទាំងស្រុងដែលត្រូវធ្វើនៅក្នុងដំណាក់កាលបច្ចុប្បន្ន។ ទោះបីផ្លូវដែលមនុស្សដើរនាពេលសព្វថ្ងៃ ជាផ្លូវនៃឈើឆ្កាង និងផ្លូវនៃទុក្ខវេទនាក៏ដោយ ក៏អ្វីដែលមនុស្សត្រូវអនុវត្ត អ្វីដែលគេហូប ផឹក និងរីករាយនៅថ្ងៃនេះ មានលក្ខណៈខុសគ្នាយ៉ាងខ្លាំងពីអ្វី

ដែលមនុស្សបានធ្វើនៅក្រោមក្រឹត្យវិន័យ និងយុគសម័យនៃព្រះគុណ។ អ្វីដែលត្រូវបានស្នើសុំពីមនុស្សនាពេលសព្វថ្ងៃ ខុសពីអ្វីដែលត្រូវបានស្នើសុំកាលពីអតីតកាល ហើយក៏កាន់តែខុសពីអ្វីដែលត្រូវបានស្នើសុំនៅក្នុងយុគសម័យនៃក្រឹត្យវិន័យដែរ។ ដូច្នេះ តើអ្វីទៅ ដែលត្រូវបានស្នើសុំពីមនុស្សនៅក្រោមក្រឹត្យវិន័យ នៅពេលដែលព្រះជាម្ចាស់កំពុងតែធ្វើកិច្ចការរបស់ទ្រង់ នៅក្នុងស្រុកអ៊ីស្រាអែល? វាជាការដែលមនុស្សត្រូវតែកាន់តាមថ្ងៃសប្ប័ទ និងក្រឹត្យវិន័យរបស់ព្រះយេហូវ៉ាប៉ុណ្ណោះ។ គ្មាននរណាម្នាក់ធ្វើការនៅថ្ងៃសប្ប័ទ ឬបំពានក្រឹត្យវិន័យរបស់ព្រះយេហូវ៉ាឡើយ។ ប៉ុន្តែសព្វថ្ងៃនេះ វាមិននៅបែបនេះទៀតទេ។ នៅថ្ងៃសប្ប័ទ មនុស្សធ្វើការ ជួបជុំគ្នា និងអធិស្ឋានតាមធម្មតា ហើយគ្មានបម្រាមណាមួយ ត្រូវបានដាក់ទៅលើពួកគេទេ។ អស់អ្នកដែលនៅក្នុងយុគសម័យនៃព្រះគុណត្រូវទទួលបុណ្យជ្រមុជទឹក ហើយពួកគេក៏ត្រូវបានស្នើសុំឲ្យតមអាហារ កាច់នំបុ័ង ផឹកស្រាទំពាំងបាយជូរ គ្របក្បាល និងលាងជើងរបស់អ្នកដទៃ។ សព្វថ្ងៃនេះ ច្បាប់ទាំងនេះត្រូវបានលុបបំបាត់ចោល ប៉ុន្តែមនុស្សទទួលបានការទាមទារកាន់តែធំ ដ្បិតកិច្ចការរបស់ព្រះជាម្ចាស់ចម្រើនឡើងកាន់តែស៊ីជម្រៅ ហើយច្រកចូលរបស់មនុស្សក៏ឡើងកាន់តែខ្ពស់ដែរ។ កាលពីអតីតកាល ព្រះយេស៊ូវបានដាក់ព្រះហស្តរបស់ទ្រង់លើមនុស្ស ហើយអធិស្ឋានសម្រាប់ពួកគេ ប៉ុន្តែឥឡូវនេះ ចំពោះគ្រប់ទាំងសេចក្ដីដែលត្រូវបានថ្លែង តើអ្វីទៅជាអត្ថប្រយោជន៍នៃការអធិស្ឋានដាក់ដៃពីលើ? គឺមានតែព្រះបន្ទូលមួយគត់ ដែលអាចសម្រេចជាលទ្ធផលបាន។ នៅពេលដែលទ្រង់ បានដាក់ព្រះហស្តរបស់ទ្រង់ទៅលើមនុស្ស កាលពីអតីតកាល វាជាការប្រទានពរដល់មនុស្ស ហើយវាក៏ជាការប្រោសមនុស្សឲ្យជាពីជំងឺរបស់គេដែរ។ នេះគឺជារបៀបដែលព្រះវិញ្ញាណបរិសុទ្ធបានធ្វើការនៅគ្រានោះ ប៉ុន្តែសព្វថ្ងៃនេះ វាមិននៅបែបនោះទៀតឡើយ។ ឥឡូវនេះ ព្រះវិញ្ញាណបរិសុទ្ធប្រើប្រាស់ព្រះបន្ទូល ដើម្បីធ្វើការ និងសម្រេចជាលទ្ធផល។ ព្រះបន្ទូលរបស់ទ្រង់ត្រូវបានស្ដែងចេញយ៉ាងច្បាស់ដល់អ្នករាល់គ្នា ហើយអ្នកគួរតែអនុវត្តតាមព្រះបន្ទូលដែលអ្នកបានទទួល។ ព្រះបន្ទូលរបស់ទ្រង់ គឺជាបំណងព្រះហឫទ័យរបស់ទ្រង់ ហើយព្រះបន្ទូល

ទាំងនោះ គឺជាកិច្ចការដែលទ្រង់សព្វព្រះហឫទ័យចង់ធ្វើ។ តាមរយៈព្រះបន្ទូលរបស់ទ្រង់ អ្នកនឹងយល់អំពីបំណងព្រះហឫទ័យរបស់ទ្រង់ ហើយចំពោះការដែលទ្រង់សុំឲ្យអ្នកទទួលបាន អ្នកគ្រាន់តែអនុវត្តតាមព្រះបន្ទូលរបស់ទ្រង់ដោយផ្ទាល់ទៅ ដោយមិនចាំបាច់មានការដាក់ដៃពីលើនោះឡើយ។ អ្នកខ្លះនិយាយថា៖ «សូមទ្រង់ដាក់ព្រះហស្តលើទូលបង្គំមក! សូមទ្រង់ដាក់ព្រះហស្តលើទូលបង្គំមក ដើម្បីឲ្យទូលបង្គំអាចទទួលបានព្រះពររបស់ទ្រង់ និងដើម្បីឲ្យទូលបង្គំអាចចូលរួមចំណែកជាមួយទ្រង់»។ ទាំងនេះជាការអនុវត្តពីអតីតកាលដែលហួសសម័យ ឥឡូវនេះ វាប្រើការលែងបានទៀតហើយ ព្រោះថាយុគសម័យបានផ្លាស់ប្ដូរហើយ។ ព្រះវិញ្ញាណបរិសុទ្ធធ្វើការស្របតាមយុគសម័យ ដោយមិនធ្វើការបែបព្រាវៗ ឬស្របតាមក្បួនច្បាប់នោះឡើយ។ យុគសម័យបានផ្លាស់ប្ដូរ ហើយយុគសម័យថ្មីក៏នាំមកនូវកិច្ចការថ្មីដែរ។ នេះជាការពិតនៅគ្រប់ដំណាក់កាលនៃកិច្ចការ ដូច្នេះ កិច្ចការរបស់ទ្រង់មិនដែលជាន់ដានដដែលៗឡើយ។ នៅក្នុងយុគសម័យនៃព្រះគុណ ព្រះយេស៊ូវបានធ្វើកិច្ចការជាច្រើនដូចជា ការប្រោសជំងឺឲ្យជា ការបណ្ដេញអារក្ស ការដាក់ដៃអធិស្ឋានលើមនុស្ស និងការប្រទានពរដល់មនុស្ស។ យ៉ាងណាមិញ ការធ្វើបែបនេះនៅក្នុងសម័យបច្ចុប្បន្ន នឹងក្លាយជារឿងគ្មានន័យឡើយ។ ព្រះវិញ្ញាណបរិសុទ្ធបានធ្វើការតាមរបៀបនោះកាលនៅគ្រានោះ ដោយសារតែវាជាយុគសម័យនៃព្រះគុណ ហើយវាមានព្រះគុណគ្រប់គ្រាន់សម្រាប់មនុស្សដើម្បីរីករាយ។ មនុស្សមិនត្រូវបានស្នើសុំឲ្យបង់ថ្លៃអ្វីឡើយ ហើយដរាបណាគេមានសេចក្ដីជំនឿ នោះគេនឹងទទួលបានព្រះគុណមិនខាន។ អ្វីៗគ្រប់យ៉ាងត្រូវបានប្រព្រឹត្តចំពោះដោយប្រកបដោយព្រះគុណ។ ឥឡូវនេះ យុគសម័យបានផ្លាស់ប្ដូរ ហើយកិច្ចការរបស់ព្រះជាម្ចាស់ក៏បានវិវឌ្ឍទៅមុខដែរ។ គឺមានតែតាមរយៈការវាយផ្ចាល និងការជំនុំជម្រះប៉ុណ្ណោះ ទើបការបះបោររបស់មនុស្ស និងអ្វីៗដែលមិនបរិសុទ្ធនៅក្នុងមនុស្ស នឹងត្រូវជម្រះចោល។ នៅដំណាក់កាលនៃការប្រោសលោះនោះ វាជារឿងចាំបាច់ ដែលព្រះជាម្ចាស់ធ្វើការតាមរបៀបនោះ គឺជាការបង្ហាញព្រះគុណគ្រប់គ្រាន់ ដើម្បីឲ្យមនុស្សរីករាយ ដូច្នេះ មនុស្សអាចត្រូវបានប្រោសលោះពីបាប

ហើយតាមរយៈមធ្យោបាយនៃព្រះគុណ បាបរបស់គេត្រូវបានអត់ទោសឲ្យ។ ដំណាក់កាលបច្ចុប្បន្ននេះ គឺជាការលាតត្រដាងសេចក្តីទុច្ចរិតដែលមាននៅខាងក្នុងមនុស្ស តាមរយៈមធ្យោបាយនៃការវាយផ្ចាល ការជំនុំជម្រះ និងការផ្ចាញ់ដោយព្រះបន្ទូល ក៏ដូចជាការប្រៀនប្រដៅ និងការបើកសម្តែងនៃព្រះបន្ទូល ដើម្បីឲ្យមនុស្សជាតិនៅជំនាន់ក្រោយៗត្រូវបានសង្គ្រោះ។ នេះគឺជាកិច្ចការមួយដែលស៊ីជម្រៅជាងការប្រោសលោះ។ ព្រះគុណនៅក្នុងយុគសម័យនៃព្រះគុណ គឺគ្រប់គ្រាន់សម្រាប់ការរីករាយរបស់មនុស្ស ប៉ុន្តែឥឡូវនេះ មនុស្សបានដកពិសោធន៍ព្រះគុណនេះរួចហើយ ដូច្នេះ គេលែងរីករាយនឹងវាទៀតហើយ។ ឥឡូវ កិច្ចការនេះក្លាយជាអតីតកាល ហើយវាលែងត្រូវបានធ្វើទៀតហើយ។ ឥឡូវនេះ មនុស្សត្រូវបានសង្គ្រោះ តាមរយៈការជំនុំជម្រះនៃព្រះបន្ទូល។ ក្រោយពេលដែលមនុស្សត្រូវបានជំនុំជម្រះ ត្រូវបានវាយផ្ចាល និងត្រូវបានបន្សុទ្ធ នោះនិស្ស័យរបស់គេនឹងត្រូវបានផ្លាស់ប្តូរ។ ចំពោះព្រះបន្ទូលដែលខ្ញុំបានថ្លែង តើវាមិនទាន់គ្រប់គ្រាន់ទៀតឬ? ដំណាក់កាលនីមួយៗត្រូវបានធ្វើស្របតាមការវិវឌ្ឍនៃពូជសាសន៍មនុស្សទាំងមូល ហើយក៏ស្របតាមយុគសម័យដែរ។ កិច្ចការទាំងអស់សុទ្ធតែសំខាន់ ហើយកិច្ចការទាំងអស់ត្រូវបានធ្វើសម្រាប់ជាប្រយោជន៍នៃសេចក្តីសង្គ្រោះចុងក្រោយ ដើម្បីឲ្យមនុស្សជាតិអាចមានទិសដៅល្អនៅថ្ងៃអនាគត និងដើម្បីឲ្យមនុស្សជាតិអាចត្រូវបានចាត់ថ្នាក់ស្របតាមប្រភេទរបស់គេនៅចុងបញ្ចប់។

កិច្ចការនៃគ្រាចុងក្រោយ គឺជាការមានបន្ទូល។ ការផ្លាស់ប្តូរធំៗអាចត្រូវបានកើតឡើងនៅក្នុងមនុស្ស តាមរយៈមធ្យោបាយនានានៃព្រះបន្ទូល។ ឥឡូវនេះ ការផ្លាស់ប្តូរដែលកើតឡើងនៅក្នុងមនុស្សទាំងនេះ ក្រោយពេលដែលទទួលយកព្រះបន្ទូលទាំងនេះ មានកម្រិតខ្លាំងជាងការផ្លាស់ប្តូរដែលកើតឡើងនៅក្នុងមនុស្ស ក្រោយពេលដែលពួកគេទទួលបាននូវទីសម្គាល់ព្រមទាំងការអស្ចារ្យនៅយុគសម័យនៃព្រះគុណទៅទៀត។ ព្រោះថានៅក្នុងយុគសម័យនៃព្រះគុណ អារក្សត្រូវបានបណ្តេញចេញពីមនុស្ស ដោយការអធិស្ឋានដាក់ដៃពីលើមែន ប៉ុន្តែនិស្ស័យដ៏ពុករលួយដែលមាននៅក្នុងមនុស្សនៅតែមានដដែល។ មនុស្សត្រូវបានប្រោសឲ្យជាពីជំងឺរបស់គេ និងត្រូវ

បានអត់ទោសពីបាបរបស់គេមែន ប៉ុន្តែចំពោះរបៀបដែលមនុស្សត្រូវបានលាងជម្រះពីនិស្ស័យដ៏ពុករលួយរបស់សាតាំងដែលមាននៅក្នុងគេ កិច្ចការនេះមិនទាន់ត្រូវបានធ្វើនៅឡើយទេ។ មនុស្សគ្រាន់តែទទួលបានសេចក្ដីសង្គ្រោះ និងការអត់ទោសពីបាបរបស់ពួកគេសម្រាប់សេចក្ដីជំនឿរបស់គេប៉ុណ្ណោះ ប៉ុន្តែនិស្ស័យបាបរបស់មនុស្ស មិនត្រូវបានរំលើងចោលឡើយ ហើយនិស្ស័យទាំងនោះមាននៅក្នុងពួកគេដដែល។ បាបរបស់មនុស្សត្រូវបានអត់ទោស តាមរយៈព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស ប៉ុន្តែការនេះមិនមែនមានន័យថា មនុស្សលែងមានបាបនៅក្នុងគេនោះឡើយ។ បាបរបស់មនុស្ស អាចត្រូវបានអត់ទោសឲ្យតាមរយៈតង្វាយលោះបាបមែន ប៉ុន្តែចំពោះរបៀបដែលមនុស្សអាចត្រូវបានប្រោសកុំឲ្យប្រព្រឹត្តបាបតទៅទៀត និងរបៀបដែលនិស្ស័យបាបរបស់គេអាចត្រូវបានរំលើងចោលទាំងស្រុង និងបំផ្លាស់បំប្រែនោះ គេគ្មានផ្លូវដោះស្រាយបញ្ហានេះឡើយ។ បាបរបស់មនុស្សត្រូវបានអត់ទោសឲ្យ ហើយនោះគឺដោយសារតែកិច្ចការនៃការជាប់ឆ្កាងរបស់ព្រះជាម្ចាស់ ប៉ុន្តែមនុស្សបានបន្តរស់នៅក្នុងនិស្ស័យសាតាំងដ៏ពុករលួយបែបចាស់របស់គេតទៅទៀត។ ដូច្នេះ មនុស្សត្រូវតែទទួលបានសេចក្ដីសង្គ្រោះទាំងស្រុងពីនិស្ស័យសាតាំងដ៏ពុករលួយរបស់គេ ដើម្បីឲ្យនិស្ស័យបាបរបស់គេអាចត្រូវបានរំលើងចោលទាំងស្រុង មិនឲ្យវិវឌ្ឍម្ដងទៀត និងឲ្យនិស្ស័យរបស់មនុស្សត្រូវបានបំផ្លាស់បំប្រែ។ ការនេះនឹងតម្រូវឲ្យមនុស្សយល់អំពីផ្លូវនៃការលូតលាស់នៅក្នុងជីវិត យល់អំពីមាគ៌ាជីវិត និងយល់អំពីផ្លូវក្នុងការផ្លាស់ប្ដូរនិស្ស័យរបស់គេ។ លើសពីនេះទៅទៀត វានឹងតម្រូវឲ្យមនុស្សប្រព្រឹត្តស្របតាមផ្លូវនេះ ដើម្បីឲ្យនិស្ស័យរបស់គេអាចទទួលបានការផ្លាស់ប្ដូរបន្តិចម្ដងៗ ហើយគេអាចរស់នៅក្រោមការជះពន្លឺ ដើម្បីឲ្យអ្វីៗទាំងអស់ដែលគេធ្វើ អាចស្របតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដើម្បីឲ្យគេអាចកម្ចាត់ចោល និស្ស័យសាតាំងដ៏ពុករលួយរបស់គេ និងដើម្បីឲ្យគេអាចផ្ដាច់ខ្លួនមានសេរីភាព ពីឥទ្ធិពលនៃសេចក្ដីងងឹតរបស់សាតាំង ហើយជាលទ្ធផល ពួកគេអាចងើបខ្លួនផុតពីបាបបានទាំងស្រុង។ មានតែបែបនេះទេ ទើបមនុស្សនឹងទទួលបានសេចក្ដីសង្គ្រោះទាំងស្រុង។ នៅពេលដែលព្រះយេស៊ូវ

កំពុងតែធ្វើកិច្ចការរបស់ទ្រង់ ចំណេះដឹងរបស់មនុស្សអំពីទ្រង់នៅតែមិនច្បាស់លាស់ និងនៅស្រពេចស្រពិល។ មនុស្សតែងតែជឿថា ទ្រង់ជាបុត្ររបស់ព្រះបាទដាវីឌ និងប្រកាសថា ទ្រង់ជាហោរាដ៏ធំ ជាព្រះអម្ចាស់ដ៏មានព្រះហឫទ័យមេត្តាដែលបានប្រោសលោះបាបរបស់មនុស្ស។ ដោយសារតែភាពរឹងមាំនៃសេចក្ដីជំនឿរបស់ពួកគេ អ្នកខ្លះត្រូវបានប្រោសឲ្យជាតាមរយៈការពាល់ជាយព្រះពស្ត្ររបស់ទ្រង់ ហើយមនុស្សខ្វាក់អាចមើលឃើញ និងសូម្បីតែមនុស្សស្លាប់ក៏អាចរស់ឡើងវិញដែរ។ យ៉ាងណាមិញ មនុស្សមិនអាចឈ្វេងយល់ពីនិស្ស័យសាតាំងដ៏ពុករលួយដែលចាក់ឫសយ៉ាងជ្រៅនៅក្នុងគេឡើយ ហើយគេក៏មិនដឹងអំពីរបៀបកម្ចាត់វាចោលនោះដែរ។ មនុស្សបានទទួលព្រះគុណយ៉ាងច្រើនដូចជា សន្តិភាព និងសុភមង្គលខាងសាច់ឈាម សេចក្ដីជំនឿរបស់សមាជិកម្នាក់ នាំមកនូវព្រះពរដល់សមាជិកគ្រួសារទាំងមូល និងការប្រោសជំងឺឲ្យជាជាដើម។ ផ្នែកផ្សេងទៀតគឺជាអំពើល្អរបស់មនុស្ស និងជាការបង្ហាញកិរិយាគោរពកោតខ្លាចព្រះរបស់គេ ហើយបើមនុស្សម្នាក់អាចរស់នៅលើមូលដ្ឋានទាំងនេះ នោះពួកគេត្រូវបានចាត់ទុកជាអ្នកជឿដែលសមគួរហើយ។ មានតែអ្នកជឿបែបនេះប៉ុណ្ណោះ ទើបអាចទៅស្ថានសួគ៌ ក្រោយពេលស្លាប់ទៅ ហើយនេះមានន័យថា ពួកគេត្រូវបានសង្គ្រោះ។ ប៉ុន្តែ នៅក្នុងជីវិតរបស់ពួកគេ មនុស្សទាំងនេះមិនបានយល់ទាល់តែសោះអំពីមាគ៌ាជីវិត។ គ្រប់យ៉ាងដែលពួកគេបានធ្វើ គឺជាការប្រព្រឹត្តអំពើបាប ហើយបន្ទាប់មក សារភាពពីបាបរបស់ពួកគេនៅក្នុងវដ្តដដែលៗ ដោយគ្មានមាគ៌ាណាមួយដើម្បីផ្លាស់ប្ដូរនិស្ស័យរបស់ពួកគេឡើយ។ នេះគឺជាលក្ខខណ្ឌរបស់មនុស្សនៅក្នុងយុគសម័យនៃព្រះគុណ។ តើមនុស្ស បានទទួលសេចក្ដីសង្គ្រោះទាំងស្រុងហើយឬនៅ? អត់ទេ! ដូច្នេះ ក្រោយដំណាក់កាលនៃកិច្ចការនោះបានបញ្ចប់ទៅ នៅមានកិច្ចការនៃការជំនុំជម្រះ និងការវាយផ្ចាលទៀត។ ដំណាក់កាលនេះ គឺដើម្បីធ្វើឲ្យមនុស្សក្លាយជាបរិសុទ្ធ ដោយមធ្យោបាយនៃព្រះបន្ទូល ហើយក៏ផ្ដល់ឲ្យគេមានមាគ៌ា ដើម្បីដើរតាមដែរ។ ដំណាក់កាលនេះនឹងមិនមានផលផ្លែ ឬមានន័យឡើយ ប្រសិនបើវាបន្តជាមួយការបណ្ដេញអារក្សនោះ ព្រោះវានឹងមិនអាចរំលើងនិស្ស័យ

បាបរបស់មនុស្ស ហើយមនុស្សនឹងនៅជាប់គាំងត្រឹមការអត់ទោសអំពើបាបរបស់គេ។ តាមរយៈតង្វាយលោះបាប មនុស្សត្រូវបានអត់ទោសពីបាបរបស់គេ ដ្បិតកិច្ចការនៃការជាប់ឆ្កាងបានមកដល់ទីបញ្ចប់ ហើយព្រះជាម្ចាស់បានយកឈ្នះលើសាតាំងរួចហើយ។ ប៉ុន្តែ និស្ស័យដ៏ពុករលួយរបស់មនុស្ស នៅតែបន្តមាននៅខាងក្នុងគេ មនុស្សនៅតែអាចប្រព្រឹត្តបាប និងប្រឆាំងជាមួយព្រះជាម្ចាស់ ហើយព្រះជាម្ចាស់មិនទទួលបានមនុស្សជាតិឡើយ។ នេះជាហេតុផលដែលនៅក្នុងដំណាក់កាលនៃកិច្ចការនេះ ព្រះជាម្ចាស់ប្រើប្រាស់ព្រះបន្ទូល ដើម្បីលាតត្រដាងនិស្ស័យដ៏ពុករលួយរបស់មនុស្ស ធ្វើឲ្យគេអនុវត្តស្របតាមមាគ៌ាត្រឹមត្រូវ។ ដំណាក់កាលនេះមានអត្ថន័យខ្លាំងជាងដំណាក់កាលមុន ហើយក៏មានផលផ្លែជាងដែរ ព្រោះថាឥឡូវនេះ គឺជាព្រះបន្ទូលដែលផ្គត់ផ្គង់ដោយផ្ទាល់ដល់ជីវិតរបស់មនុស្ស និងជួយបំផ្លាស់និស្ស័យរបស់មនុស្សជាថ្មីទាំងស្រុង ហើយវាជាដំណាក់កាលនៃកិច្ចការមួយដែលមានលក្ខណៈហ្មត់ចត់ជាង។ ដូច្នេះ ការយកកំណើតជាមនុស្សនៅក្នុងគ្រាចុងក្រោយបានបំពេញនូវភាពសំខាន់នៃការយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់ និងបានសម្រេចទាំងស្រុងនូវផែនការគ្រប់គ្រងរបស់ព្រះជាម្ចាស់សម្រាប់សេចក្ដីសង្គ្រោះរបស់មនុស្ស។

កិច្ចការសង្គ្រោះមនុស្សរបស់ព្រះជាម្ចាស់មិនត្រូវបានធ្វើឡើងដោយផ្ទាល់ ដោយប្រើប្រាស់វិធីសាស្ត្ររបស់ព្រះវិញ្ញាណ និងអត្តសញ្ញាណ របស់ព្រះវិញ្ញាណឡើយ ព្រោះថាមនុស្សមិនអាចប៉ះពាល់ ឬមើលឃើញព្រះវិញ្ញាណរបស់ទ្រង់ឡើយ ហើយក៏មិនអាចចូលជិតទ្រង់បានដែរ។ ប្រសិនបើទ្រង់ព្យាយាមសង្គ្រោះមនុស្សដោយផ្ទាល់ ដោយប្រើប្រាស់វិធីសាស្ត្ររបស់ព្រះវិញ្ញាណ នោះមនុស្សនឹងមិនអាចទទួលបានសេចក្ដីសង្គ្រោះរបស់ទ្រង់ឡើយ។ ប្រសិនបើព្រះជាម្ចាស់មិនពាក់សំបកខាងក្រៅជាមនុស្សទេ នោះមនុស្សនឹងគ្មានផ្លូវទទួលបានសេចក្ដីសង្គ្រោះនេះឡើយ។ ព្រោះថាមនុស្សគ្មានផ្លូវចូលទៅរកទ្រង់ ហើយក៏គ្មាននរណាម្នាក់ អាចចូលជិតពពករបស់ព្រះយេហូវ៉ាបាននោះដែរ។ មានតែតាមរយៈការក្លាយជាមនុស្ស ពោលគឺមានតែតាមរយៈការយកព្រះបន្ទូលរបស់ទ្រង់ដាក់ចូលទៅក្នុងរូបកាយ ដែលទ្រង់រៀបនឹង

ត្រលប់ជាសាច់ឈាមប៉ុណ្ណោះ ទើបទ្រង់អាចធ្វើការដោយផ្ទាល់ ដោយធ្វើឲ្យព្រះបន្ទូលចូលទៅក្នុងអស់អ្នកដែលដើរតាមទ្រង់។ មានតែបែបនេះទេ ទើបមនុស្សអាចមើលឃើញ និងស្ដាប់ឮព្រះបន្ទូលរបស់ទ្រង់ដោយផ្ទាល់បាន ហើយលើសពីនេះ គេអាចចូលកាន់កាប់ព្រះបន្ទូលរបស់ទ្រង់ គឺមានតែតាមមធ្យោបាយនេះប៉ុណ្ណោះ ទើបគេអាចទទួលបានសេចក្ដីសង្គ្រោះយ៉ាងពេញលេញ។ ប្រសិនបើព្រះជាម្ចាស់មិនត្រលប់ជាសាច់ឈាមទេ នោះគ្មានសាច់ និងឈាមណាមួយនឹងអាចទទួលបានសេចក្ដីសង្គ្រោះដ៏ធំបែបនេះ ហើយក៏គ្មានមនុស្សណាម្នាក់ ទទួលបានសេចក្ដីសង្គ្រោះនោះដែរ។ ប្រសិនព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ បានធ្វើការដោយផ្ទាល់នៅក្នុងចំណោមមនុស្សជាតិ នោះមនុស្សជាតិទាំងអស់នឹងត្រូវវាយផ្ដួលមិនខាន បើមិនដូច្នោះទេ ពួកគេគ្មានផ្លូវចូលទៅជិតព្រះជាម្ចាស់បាននោះឡើយ ហើយពួកគេនឹងត្រូវជាប់ជាឈ្លើយសឹករបស់សាតាំងទាំងស្រុងមិនខាន។ ការយកកំណើតលើកទីមួយ គឺជាការប្រោសលោះមនុស្សពីបាប ដើម្បីប្រោសលោះមនុស្ស តាមរយៈរូបកាយជាសាច់ឈាមរបស់ព្រះយេស៊ូវគឺថា ទ្រង់បានសង្គ្រោះមនុស្សពីឈើឆ្កាង ប៉ុន្តែនិស្ស័យសាតាំងដ៏ពុករលួយនៅតែបន្តមាននៅខាងក្នុងមនុស្សដដែល។ ការយកកំណើតជាមនុស្សលើកទីពីរ លែងបម្រើជាតង្វាយលោះបាបទៀតហើយ ប៉ុន្តែដើម្បីសង្គ្រោះអស់អ្នកដែលត្រូវបានប្រោសលោះពីបាបយ៉ាងពេញលេញវិញ។ ការនេះត្រូវបានធ្វើឡើង ដើម្បីឲ្យមនុស្សដែលត្រូវបានអត់ទោស អាចទទួលបានការប្រោសលោះពីបាបរបស់ពួកគេ និងត្រូវបានញែកជាបរិសុទ្ធទាំងស្រុង ហើយតាមរយៈការមាននិស្ស័យដែលផ្លាស់ប្រែ ពួកគេអាចរំដោះខ្លួនឲ្យមានសេរីភាពពីឥទ្ធិពលនៃសេចក្ដីងងឹតរបស់សាតាំង និងត្រលប់ទៅមុខបល្ល័ង្ករបស់ព្រះជាម្ចាស់វិញ។ មានតែបែបនេះទេ ទើបមនុស្សអាចត្រូវបានញែកជាបរិសុទ្ធទាំងស្រុង។ ក្រោយពេលដែលយុគសម័យនៃក្រឹត្យវិន័យបានបញ្ចប់ ហើយបន្តជាមួយយុគសម័យនៃព្រះគុណ ព្រះជាម្ចាស់បានចាប់ផ្ដើមកិច្ចការនៃសេចក្ដីសង្គ្រោះ ដែលបន្តរហូតមកដល់គ្រាចុងក្រោយ ជាពេលដែលទ្រង់ជំនុំជម្រះ និងវាយផ្ចាលដល់ពូជសាសន៍មនុស្សសម្រាប់ការបះបោររបស់ពួកគេ ហើយទ្រង់នឹងបន្សុទ្ធមនុស្សជាតិទាំង

ស្រុង។ មានតែបែបនេះទេ ទើបព្រះជាម្ចាស់នឹងបញ្ចប់កិច្ចការសង្គ្រោះរបស់ទ្រង់ ហើយចូលសម្រាកបាន។ ដូច្នេះ នៅក្នុងដំណាក់កាលទាំងបីនៃកិច្ចការ ព្រះជាម្ចាស់បានត្រលប់ជាសាច់ឈាមតែពីរដងប៉ុណ្ណោះ ដើម្បីអនុវត្តកិច្ចការរបស់ទ្រង់នៅក្នុងចំណោមមនុស្សដោយផ្ទាល់ព្រះអង្គ។ នោះគឺដោយសារតែមានដំណាក់កាលតែមួយប៉ុណ្ណោះនៅក្នុងចំណោមដំណាក់កាលទាំងបីនៃកិច្ចការ ដែលចង្អុលបង្ហាញមនុស្សនៅក្នុងការដឹកនាំជីវិតរបស់ខ្លួន ខណៈពេលដែលដំណាក់កាលពីរផ្សេងទៀត មាននូវកិច្ចការនៃសេចក្តីសង្គ្រោះ។ មានតែតាមរយៈការត្រលប់ជាសាច់ឈាមប៉ុណ្ណោះ ទើបព្រះជាម្ចាស់អាចគង់នៅរួមជាមួយមនុស្ស ដកពិសោធន៍ការឈឺចាប់របស់ពិភពលោក ហើយរស់នៅក្នុងរូបកាយខាងសាច់ឈាមដ៏សាមញ្ញ។ មានតែបែបនេះទេ ទើបទ្រង់អាចផ្គត់ផ្គង់ដល់មនុស្សនូវផ្លូវពិតជាក់ស្តែង ដែលពួកគេត្រូវការក្នុងនាមជាមនុស្ស។ គឺតាមរយៈការយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់នេះហើយ ដែលមនុស្សទទួលបាននូវសេចក្តីសង្គ្រោះដ៏ពេញលេញពីព្រះជាម្ចាស់ និងមិនជាការឆ្លើយតបដោយផ្ទាល់ពីស្ថានសួគ៌ចំពោះសេចក្តីអធិស្ឋានរបស់គេ។ ព្រោះថាបើមនុស្សស្ថិតក្នុងសាច់ និងឈាម គេគ្មានផ្លូវមើលឃើញព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ ហើយក៏មិនអាចចូលទៅជិតព្រះវិញ្ញាណរបស់ទ្រង់បានដែរ។ គ្រប់យ៉ាងដែលមនុស្សអាចមានទំនាក់ទំនងជាមួយ គឺជាសាច់ឈាមដែលយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់ ហើយមានតែមធ្យោបាយបែបនេះទេ ទើបមនុស្សអាចយល់ទាំងស្រុងអំពីផ្លូវ និងសេចក្តីពិត ហើយទទួលបានសេចក្តីសង្គ្រោះយ៉ាងពេញលេញ។ ការយកកំណើតជាមនុស្សលើកទីពីរនឹងមានលក្ខណៈគ្រប់គ្រាន់ ដើម្បីលាងជម្រះបាបរបស់មនុស្ស ហើយប្រោសឲ្យគេបានបរិសុទ្ធយ៉ាងពេញលេញ។ ដូច្នេះ តាមរយៈការយកកំណើតជាមនុស្សលើកទីពីរ កិច្ចការទាំងស្រុងរបស់ព្រះជាម្ចាស់នៅក្នុងសាច់ឈាម នឹងត្រូវនាំទៅរកការបិទបញ្ចប់ ហើយភាពសំខាន់នៃការយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់ ក៏បានបញ្ចប់ដែរ។ ដូច្នេះ កិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងសាច់ឈាម នឹងបានមកដល់ទីបញ្ចប់ទាំងស្រុង។ ក្រោយការយកកំណើតជាមនុស្សលើកទីពីរ ទ្រង់នឹងមិនត្រលប់ជាសាច់ឈាម

ជាលើកទីបីសម្រាប់កិច្ចការរបស់ទ្រង់ឡើយ។ ព្រោះការគ្រប់គ្រងទាំងស្រុងរបស់ទ្រង់ នឹងបានមកដល់ទីបញ្ចប់។ ការយកកំណើតជាមនុស្សនៅគ្រាចុងក្រោយ នឹងទទួលបានទាំងស្រុងនូវពួករាស្ត្ររើសតាំងរបស់ទ្រង់ ហើយមនុស្សជាតិនៅក្នុងគ្រាចុងក្រោយ នឹងត្រូវបានចាត់ថ្នាក់ទៅតាមប្រភេទរបស់ពួកគេ។ ទ្រង់នឹងលែងធ្វើកិច្ចការនៃការសង្គ្រោះ ហើយក៏មិនយាងត្រលប់ជាសាច់ឈាម ដើម្បីអនុវត្តកិច្ចការណាមួយទៀតដែរ។ នៅក្នុងកិច្ចការនៃគ្រាចុងក្រោយ ព្រះបន្ទូលមានអំណាចខ្លាំងជាងការបង្ហាញទីសម្គាល់ និងការអស្ចារ្យទៅទៀត ហើយសិទ្ធិអំណាចនៃព្រះបន្ទូល ក៏ខ្ពស់លើសសិទ្ធិអំណាចនៃទីសម្គាល់ និងការអស្ចារ្យដែរ។ ព្រះបន្ទូលលាតត្រដាងគ្រប់ទាំងនិស្ស័យដ៏ពុករលួយដែលកប់ជ្រៅនៅក្នុងដួងចិត្តរបស់មនុស្ស។ អ្នកគ្មានផ្លូវណា ដើម្បីដឹងអំពីនិស្ស័យទាំងនោះដោយខ្លួនឯងឡើយ។ នៅពេលដែលនិស្ស័យទាំងនោះត្រូវបានលាតត្រដាងនៅមុខអ្នកតាមរយៈព្រះបន្ទូល នោះអ្នកនឹងឈ្វេងយល់ពីនិស្ស័យទាំងនោះដោយឯកឯង អ្នកនឹងមិនអាចបដិសេធវាបានឡើយ ហើយអ្នកនឹងជឿជាក់ទាំងស្រុងមិនខាន។ តើនេះមិនមែនជាសិទ្ធិអំណាចនៃព្រះបន្ទូលទេឬ? នេះគឺជាលទ្ធផលដែលសម្រេចបាន តាមរយៈកិច្ចការនៃព្រះបន្ទូលនាពេលសព្វថ្ងៃ។ ដូច្នេះ មិនមែនតាមរយៈការប្រោសជំងឺឲ្យជា និងការបណ្ដេញអារក្សនោះទេ ដែលនាំឲ្យមនុស្សអាចបានសង្គ្រោះយ៉ាងពេញលេញពីបាបរបស់ខ្លួន ហើយគេក៏មិនអាចបានពេញខ្នាត ដោយការបង្ហាញទីសម្គាល់ និងការអស្ចារ្យនោះដែរ។ សិទ្ធិអំណាចក្នុងការប្រោសជំងឺឲ្យជា និងការបណ្ដេញអារក្ស ផ្ដល់ឲ្យមនុស្សតែព្រះគុណប៉ុណ្ណោះ ប៉ុន្តែសាច់ឈាមរបស់មនុស្សនៅតែជាកម្មសិទ្ធិរបស់សាតាំងដដែល ហើយនិស្ស័យសាតាំងដ៏ពុករលួយ នៅតែមាននៅខាងក្នុងមនុស្សដដែល។ អាចនិយាយម្យ៉ាងទៀតបានថា អ្វីដែលមិនទាន់ត្រូវបានប្រោសឲ្យបរិសុទ្ធ នៅតែជាប់ទាក់ទងនឹងបាប និងសេចក្ដីស្មោកគ្រោកដដែល។ មានតែក្រោយពេលដែលគេត្រូវបានប្រោសឲ្យបរិសុទ្ធតាមរយៈព្រះបន្ទូលប៉ុណ្ណោះ ទើបព្រះជាម្ចាស់អាចទទួលបានមនុស្ស ហើយគេអាចត្រូវបានញែកជាបរិសុទ្ធ។ នៅពេលដែលអារក្សត្រូវបានបណ្ដេញចេញពីមនុស្ស ហើយគេត្រូវបានប្រោសលោះ នេះ

មានន័យថា គេបានរើបម្រះចេញពីកណ្ដាប់ដៃរបស់សាតាំង ហើយត្រលប់ទៅរកព្រះជាម្ចាស់វិញ។ យ៉ាងណាមិញ បើគ្មានការប្រោសឲ្យបរិសុទ្ធ ឬការផ្លាស់ប្រែដោយព្រះជាម្ចាស់ទេ នោះគេនៅតែជាមនុស្សដ៏ពុករលួយដដែល។ នៅក្នុងមនុស្សនៅតែមានសេចក្ដីស្មោកគ្រោក ការប្រឆាំង និងការបះបោរដដែល ហើយមនុស្សនៅតែត្រលប់ទៅរកព្រះជាម្ចាស់តាមរយៈការប្រោសលោះរបស់ទ្រង់ ប៉ុន្តែគេគ្មានចំណេះដឹងសូម្បីតែបន្តិចអំពីព្រះជាម្ចាស់ ហើយគេនៅតែមានសមត្ថភាពប្រឆាំង និងក្បត់ទ្រង់ដដែល។ មុនពេលដែលមនុស្សត្រូវបានប្រោសលោះ សារជាតិពុលជាច្រើនរបស់សាតាំងត្រូវបានដាក់នៅក្នុងគេរួចទៅហើយ ហើយក្រោយពេលដែលសាតាំងបានធ្វើឲ្យមនុស្សពុករលួយអស់រយៈពេលរាប់ពាន់ឆ្នាំរួចមក នៅខាងក្នុងមនុស្សមាននូវនិស្ស័យដែលប្រឆាំងនឹងព្រះជាម្ចាស់រួចទៅហើយ។ ដូច្នេះ នៅពេលដែលមនុស្សត្រូវបានប្រោសលោះ វាជាករណីនៃការប្រោសលោះដែលមនុស្សត្រូវបានទិញនៅក្នុងតម្លៃដ៏ខ្ពស់ ប៉ុន្តែធម្មជាតិដែលមានជាតិពុលដែលមាននៅខាងក្នុងគេ មិនត្រូវបានផាត់ចោលឡើយ។ មនុស្សដែលត្រូវបានកខ្វក់យ៉ាងខ្លាំង ត្រូវតែឆ្លងកាត់ការផ្លាស់ប្ដូរមួយសិន មុននឹងក្លាយជាបុគ្គលដ៏សក្ដិសម ដើម្បីបម្រើព្រះជាម្ចាស់។ តាមរយៈមធ្យោបាយនៃកិច្ចការជំនុំជម្រះ និងការវាយផ្ចាលនេះ មនុស្សនឹងចាប់ផ្ដើមស្គាល់ទាំងស្រុងពីសេចក្ដីស្មោកគ្រោក និងលក្ខណៈសំខាន់ដ៏ពុករលួយដែលមាននៅខាងក្នុងគេ ហើយគេនឹងអាចផ្លាស់ប្ដូរបានទាំងស្រុង និងត្រលប់ជាបរិសុទ្ធផង។ មានតែបែបនេះទេ ទើបមនុស្សអាចសក្ដិសមត្រលប់ទៅមុខបល្ល័ង្ករបស់ព្រះជាម្ចាស់វិញ។ គ្រប់កិច្ចការដែលបានធ្វើនាពេលសព្វថ្ងៃនេះ គឺដើម្បីឲ្យមនុស្សអាចត្រូវបានសម្អាតឲ្យស្អាត និងបានផ្លាស់ប្ដូរ ហើយតាមរយៈការជំនុំជម្រះ និងការវាយផ្ចាលដោយព្រះបន្ទូល ក៏ដូចជាតាមរយៈការបន្សុទ្ធ នោះមនុស្សអាចលាងជម្រះសេចក្ដីពុករលួយរបស់ខ្លួន ហើយត្រូវបានប្រោសឲ្យបានបរិសុទ្ធ។ ជាជាងគិតថាដំណាក់កាលនៃកិច្ចការនេះជាកិច្ចការនៃសេចក្ដីសង្គ្រោះ នោះវាសមរម្យជាងដែលនិយាយថា វាជាកិច្ចការនៃការប្រោសឲ្យបរិសុទ្ធ។ នៅក្នុងសេចក្ដីពិត ដំណាក់កាលនេះគឺជាដំណាក់កាលនៃការយកឈ្នះ

ក៏ដូចជាដំណាក់កាលទីពីរនៅក្នុងកិច្ចការនៃសេចក្ដីសង្គ្រោះដែរ។ គឺតាមរយៈការជំនុំជម្រះ និងការវាយផ្ចាលដោយព្រះបន្ទូលនេះហើយ ទើបព្រះជាម្ចាស់ទទួលបានមនុស្ស ហើយតាមរយៈការប្រើប្រាស់ព្រះបន្ទូល ដើម្បីបន្សុទ្ធ ជំនុំជម្រះ និងលាតត្រដាងនេះហើយ ទើបគ្រប់ទាំងភាពមិនបរិសុទ្ធ សញ្ញាណ ចេតនា និងសេចក្ដីប្រាថ្នាផ្ទាល់ខ្លួនដែលមាននៅក្នុងដួងចិត្តរបស់មនុស្ស ត្រូវបានបើកសម្ដែងទាំងស្រុង។ សម្រាប់អ្វីៗគ្រប់យ៉ាងដែលមនុស្សអាចត្រូវបានប្រោសលោះ និងត្រូវបានអត់ទោសឲ្យចំពោះបាបរបស់ខ្លួន វាអាចត្រូវបានគេចាត់ទុកថា ព្រះជាម្ចាស់មិននឹកនាពីសេចក្ដីរំលងរបស់មនុស្ស ហើយមិនប្រព្រឹត្តចំពោះមនុស្សស្របតាមសេចក្ដីរំលងរបស់គេ។ យ៉ាងណាមិញ នៅពេលដែលមនុស្សរស់នៅក្នុងរូបរាងកាយនៃសាច់ឈាម មិនត្រូវបានប្រោសឲ្យមានសេរីភាពពីបាប នោះគេនៅតែបន្តប្រព្រឹត្តអំពើបាប ហើយបើកសម្ដែងពីនិស្ស័យសាតាំងដ៏ពុករលួយរបស់គេ គ្មានថ្ងៃបញ្ចប់ឡើយ។ នេះគឺជាជីវិតរបស់មនុស្ស ដែលដើរនៅក្នុងវដ្តនៃការប្រព្រឹត្តអំពើបាប និងការទទួលបានការអត់ទោស ដោយគ្មានទីបញ្ចប់។ មនុស្សភាគច្រើនប្រព្រឹត្តអំពើបាបនៅពេលថ្ងៃ ហើយលន់តួបាបនៅពេលយប់។ ទោះបីតង្វាយលោះបាប មានប្រសិទ្ធភាពជារៀងរហូតសម្រាប់មនុស្សក៏ដោយ ក៏ការធ្វើបែបនេះ នឹងមិនអាចសង្គ្រោះមនុស្សពីបាបបានឡើយ។ មានតែពាក់កណ្ដាលនៃកិច្ចការសង្គ្រោះប៉ុណ្ណោះ ដែលត្រូវបានសម្រេច ព្រោះថាមនុស្សនៅតែមាននិស្ស័យដ៏ពុករលួយ។ ឧទាហរណ៍ នៅពេលដែលមនុស្សបានដឹងថា ពួកគេជាពូជពង្សចេញពីម៉ូអាប់ ពួកគេបានចាប់ផ្ដើមរអ៊ូរទាំ ឈប់ដេញតាមជីវិត ហើយក្លាយជាមនុស្សអវិជ្ជមានទាំងស្រុងតែម្ដង។ តើនេះមិនបង្ហាញថា មនុស្សនៅតែមិនអាចចុះចូលទាំងស្រុងក្រោមការត្រួតត្រារបស់ព្រះជាម្ចាស់ទេឬអី? តើនេះមិនមែនជានិស្ស័យបែបសាតាំងដ៏ពុករលួយរបស់ពួកគេទេឬ? នៅពេលដែលអ្នកមិនចុះចូលចំពោះការវាលផ្ចាល នោះដៃរបស់អ្នកត្រូវបានលើកឡើងខ្ពស់ជាងដៃរបស់អ្នកឯទៀត រួមទាំងព្រះយេស៊ូវដែរ។ ហើយអ្នកបានស្រែកខ្លាំងៗថា៖ «ចូរក្លាយជាបុត្រស្ងួនភ្ងារបស់ព្រះជាម្ចាស់! ចូរក្លាយជាមនុស្សជំនិតរបស់ព្រះជាម្ចាស់! យើងសុខចិត្ត

ស្លាប់ ជាជាងក្រាបថ្វាយបង្គំសាតាំង! ចូរប្រឆាំងនឹងសាតាំងដ៏កញ្ចាស់! ចូរប្រឆាំងនឹងនាគដ៏ធំមានសម្បុរក្រហម! សូមឲ្យនាគដ៏ធំមានសម្បុរក្រហម ដួលរលំពីអំណាច! សូមឲ្យព្រះជាម្ចាស់ប្រោសឲ្យយើងបានពេញខ្នាត!» សម្រែករបស់អ្នកលាន់ឮខ្លាំងជាងអ្នកឯទៀតៗ។ ប៉ុន្ដែ នៅពេលដែលការវាយផ្ចាលមកដល់ និស្ស័យដ៏ពុករលួយរបស់មនុស្សត្រូវបានបើកបង្ហាញម្ដងទៀត។ បន្ទាប់មក សម្រែករបស់គេក៏បានឈប់ ហើយការតាំងចិត្តរបស់គេ ក៏បរាជ័យ។ នេះជាសេចក្ដីពុករលួយរបស់មនុស្ស ដែលស៊ីជម្រៅជាងអំពើបាបទៅទៀត ព្រោះវាជាអ្វីមួយដែលត្រូវបានដាំជាប់ដោយសាតាំង និងត្រូវបានចាក់ឫសយ៉ាងជ្រៅនៅក្នុងមនុស្ស។ មនុស្សមិនងាយដឹងពីបាបរបស់គេឡើយ។ គេគ្មានផ្លូវនឹងទទួលស្គាល់និស្ស័យដែលចាក់ឫសយ៉ាងជ្រៅរបស់ខ្លួនឡើយ ហើយគេត្រូវតែពឹងអាងលើការជំនុំជម្រះដោយព្រះបន្ទូល ដើម្បីសម្រេចលទ្ធផលនេះ។ មានតែបែបនេះទេ ទើបមនុស្សអាចត្រូវបានផ្លាស់ប្ដូរបន្ដិចម្ដងៗចាប់ពីចំណុចនេះតទៅ។ មនុស្សបានស្រែកបែបនេះកាលពីអតីតកាល ដោយសារតែគេគ្មានការយល់ដឹងអំពីនិស្ស័យពីកំណើតដ៏ពុករលួយរបស់គេ។ ទាំងនេះគឺជាភាពមិនបរិសុទ្ធដែលមាននៅក្នុងមនុស្ស។ នៅក្នុងអំឡុងពេលដ៏យូរនៃការជំនុំជម្រះ និងការវាយផ្ចាល មនុស្សបានរស់នៅក្នុងបរិយាកាសដ៏តានតឹងមួយ។ តើការនេះមិនត្រូវបានសម្រេច តាមរយៈព្រះបន្ទូលទេឬ? តើអ្នកមិនបានស្រែកខ្លាំងដែរទេឬ មុនពេលដែលមានការល្បងលដល់ពួកអ្នកស៊ីឈ្នួល? «ចូរចូលក្នុងនគរព្រះ! អស់អ្នកដែលទទួលយកព្រះនាមនេះ នឹងចូលទៅក្នុងនគរព្រះ! មនុស្សទាំងអស់ នឹងចូលរួមទទួលចំណែកពីព្រះជាម្ចាស់!» នៅពេលដែលការល្បងលនៃពួកអ្នកស៊ីឈ្នួលបានមកដល់ នោះអ្នកលែងស្រែកឡើងទៀតហើយ។ កាលពីដើមដំបូង មនុស្សទាំងអស់បានស្រែកឡើងថា «ឱ ព្រះជាម្ចាស់អើយ! នៅគ្រប់ទីកន្លែងដែលទ្រង់ដាក់ទូលបង្គំ នោះទូលបង្គំនឹងចុះចូលឲ្យទ្រង់ដឹកនាំ»។ នៅពេលដែលបានអានព្រះបន្ទូលរបស់ព្រះជាម្ចាស់ «តើនរណាខ្លះនឹងក្លាយដូចជាប៉ុលរបស់ខ្ញុំ?» មនុស្សបាននិយាយថា «ទូលបង្គំព្រម!» បន្ទាប់មក ពួកគេបានឃើញឃ្លាថា «ចុះចំណែកសេចក្ដីជំនឿរបស់យ៉ូប?» និងបាននិយាយថា «ទូលបង្គំ

ព្រមមានសេចក្ដីជំនឿរបស់យ៉ូប។ ឱ ព្រះជាម្ចាស់អើយ សូមទ្រង់ល្បងលទូលបង្គំមកចុះ!» នៅពេលដែលការល្បងលពួកអ្នកស៊ីឈ្នួលបានមកដល់ ពួកគេបានដួលរលំតែម្ដង ហើយមិនអាចក្រោកឈរបានម្ដងទៀតឡើយ។ ក្រោយមកទៀត ភាពមិនបរិសុទ្ធនៅក្នុងដួងចិត្តរបស់គេចាប់ផ្ដើមរលាយបាត់ទៅបន្តិចម្ដងៗ។ តើការនេះមិនត្រូវបានសម្រេច តាមរយៈព្រះបន្ទូលទេឬ? ដូច្នេះ អ្វីដែលអ្នករាល់គ្នាបានដកពិសោធន៍នៅថ្ងៃនេះ គឺជាលទ្ធផលដែលត្រូវបានសម្រេចតាមរយៈព្រះបន្ទូល ហើយវាមានកម្រិតធំធេងជាងលទ្ធផលដែលត្រូវបានសម្រេចតាមរយៈការធ្វើទីសម្គាល់ និងការអស្ចារ្យរបស់ព្រះយេស៊ូវទៅទៀត។ សិរីល្អរបស់ព្រះជាម្ចាស់ដែលអ្នកមើលឃើញ ហើយសិទ្ធិអំណាច របស់ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គដែលអ្នកមើលឃើញ មិនត្រឹមតែត្រូវបានមើលឃើញតាមរយៈមធ្យោបាយនៃការជាប់ឆ្កាង ការប្រោសជំងឺឲ្យជា និងការបណ្ដេញអារក្សប៉ុណ្ណោះទេ ប៉ុន្តែលើសពីនេះទៅទៀត ក៏តាមរយៈមធ្យោបាយនៃការជំនុំជម្រះនៃព្រះបន្ទូលរបស់ទ្រង់ដែរ។ ការនេះបង្ហាញដល់អ្នកថា សិទ្ធិអំណាច និងព្រះចេស្ដារបស់ព្រះជាម្ចាស់មិនកើតឡើងតាមរយៈតែការធ្វើទីសម្គាល់ ការប្រោសជំងឺឲ្យជា និងការបណ្ដេញអារក្សប៉ុណ្ណោះទេ ប៉ុន្តែក៏បង្ហាញថា ការជំនុំជម្រះចេញពីព្រះបន្ទូលរបស់ព្រះជាម្ចាស់កាន់តែអាចតំណាងឲ្យសិទ្ធិអំណាចរបស់ព្រះជាម្ចាស់ និងបើកសម្ដែងពីភាពពេញដោយព្រះចេស្ដារបស់ទ្រង់ដែរ។

អ្វីដែលមនុស្សទទួលបានសព្វថ្ងៃនេះ ដូចជា កម្ពស់បច្ចុប្បន្ន ចំណេះដឹង សេចក្ដីស្រឡាញ់ ស្វាមីភក្ដិ ការស្ដាប់បង្គាប់ និងគតិជ្រៅជ្រះរបស់គេ ទាំងអស់នេះគឺជាលទ្ធផលដែលទទួលបានតាមរយៈការជំនុំជម្រះនៃព្រះបន្ទូល។ ការដែលអ្នកអាចមានស្វាមីភក្ដិ និងបន្តឈរមាំរហូតមកដល់ថ្ងៃនេះ គឺទទួលបានតាមរយៈព្រះបន្ទូល។ ឥឡូវ មនុស្សមើលឃើញថា កិច្ចការរបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សពិតជាអស្ចារ្យមែន ហើយមានរឿងជាច្រើនទៀតនៅក្នុងកិច្ចការនេះ ដែលមនុស្សមិនអាចទទួលបាន ដោយព្រោះវាជាសេចក្ដីអាថ៌កំបាំង និងភាពអច្ឆរិយៈ។ ដូចនេះ មនុស្សជាច្រើនបានចុះចូល។ អ្នកខ្លះមិនធ្លាប់ចុះចូលចំពោះមនុស្សណាម្នាក់ឡើយ

តាំងពីកើតមក ប៉ុន្តែ នៅពេលដែលពួកគេមើលឃើញព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅថ្ងៃនេះ ពួកគេក៏ព្រមចុះចូលទាំងស្រុង ទាំងមិនបានចាប់អារម្មណ៍ ហើយពួកគេមិនហ៊ានពិនិត្យពិច័យ ឬនិយាយអ្វីផ្សេងឡើយ។ មនុស្សបានលុតជង្គង់នៅក្រោមព្រះបន្ទូល ហើយត្រូវបានដួល នៅក្រោមការជំនុំជម្រះនៃព្រះបន្ទូល។ ប្រសិនបើព្រះវិញ្ញាណរបស់ព្រះជាម្ចាស់បានមានព្រះបន្ទូលដោយផ្ទាល់ទៅកាន់មនុស្ស នោះមនុស្សជាតិទាំងអស់នឹងចុះចូលចំពោះព្រះសូរសៀង ក្រាបចុះ ដោយគ្មានពាក្យនៃការបើកសម្ដែងឡើយ គឺដូចជារបៀបដែលប៉ុលបានធ្លាក់ដួលទៅលើដី ដោយសារតែពន្លឺដ៏ចាំងនៅតាមផ្លូវទៅកាន់ទីក្រុងដាម៉ាសអ៊ីចឹងដែរ។ ប្រសិនបើព្រះជាម្ចាស់បានបន្តធ្វើកិច្ចការតាមរបៀបនេះ នោះមនុស្សនឹងមិនអាចស្គាល់ពីនិស្ស័យដ៏ពុករលួយរបស់គេតាមរយៈការជំនុំជម្រះនៃព្រះបន្ទូល និងទទួលបានសេចក្ដីសង្គ្រោះឡើយ។ មានតែតាមរយៈការត្រលប់ជាសាច់ឈាមទេ ទើបព្រះជាម្ចាស់អាចមានបន្ទូលដោយផ្ទាល់ទៅកាន់ត្រចៀករបស់មនុស្សម្នាក់ៗ ដើម្បីឲ្យមនុស្សទាំងអស់ដែលមានត្រចៀកអាចស្ដាប់ឮព្រះបន្ទូលរបស់ទ្រង់ ហើយទទួលយកកិច្ចការនៃការជំនុំជម្រះរបស់ទ្រង់តាមរយៈព្រះបន្ទូល។ មានតែបែបនេះទេ ទើបលទ្ធផលអាចសម្រេចបានតាមរយៈព្រះបន្ទូលរបស់ទ្រង់ ជាជាងឲ្យព្រះវិញ្ញាណស្ដែងចេញ ដើម្បីធ្វើឲ្យមនុស្សចុះចូលទាំងភ័យខ្លាច។ មានតែតាមរយៈកិច្ចការដ៏ជាក់ស្ដែង តែអស្ចារ្យនេះប៉ុណ្ណោះ ទើបនិស្ស័យចាស់របស់មនុស្សដែលកប់យ៉ាងជ្រៅអស់រយៈពេលជាច្រើនឆ្នាំ អាចត្រូវបានលាតត្រដាងយ៉ាងពេញលេញ ដើម្បីឲ្យមនុស្សអាចស្គាល់វា និងឲ្យទ្រង់ផ្លាស់ប្ដូរវា។ ទាំងនេះគឺជាកិច្ចការជាក់ស្ដែងរបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស ហើយមានតែតាមរយៈការមានបន្ទូល និងការអនុវត្តការជំនុំជម្រះនៅក្នុងលក្ខណៈជាក់ស្ដែងនេះទេ ទើបទ្រង់សម្រេចបានលទ្ធផលនៃការជំនុំជម្រះ ទៅលើមនុស្សតាមរយៈព្រះបន្ទូល។ នេះគឺជាសិទ្ធិអំណាច របស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស និងភាពសំខាន់ នៃការយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់។ វាត្រូវបានធ្វើឡើងដើម្បីធ្វើឲ្យមនុស្សបានស្គាល់ ពីសិទ្ធិអំណាចរបស់ព្រះជាម្ចាស់ដែលយកកំណើតជា

មនុស្ស ដើម្បីឲ្យដឹងអំពីលទ្ធផលដែលត្រូវបានសម្រេច តាមរយៈកិច្ចការនៃព្រះបន្ទូល និងដើម្បីឲ្យដឹងថា ព្រះវិញ្ញាណបានយាងមកនៅក្នុងសាច់ឈាម ហើយបង្ហាញសិទ្ធិអំណាចរបស់ទ្រង់តាមរយៈការជំនុំជម្រះមនុស្សដោយព្រះបន្ទូល។ ទោះបីជាសាច់ឈាមរបស់ទ្រង់មានទម្រង់ខាងក្រៅនៃភាពជាមនុស្សសាមញ្ញ និងធម្មតាក៏ដោយ ប៉ុន្តែលទ្ធផលដែលព្រះបន្ទូលរបស់ទ្រង់សម្រេចបាននោះ បង្ហាញដល់មនុស្សថា ទ្រង់ពេញដោយសិទ្ធិអំណាច ថាទ្រង់ជាព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ និងថាព្រះបន្ទូលរបស់ទ្រង់ គឺជាការស្តែងចេញអំពីព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ។ តាមរយៈមធ្យោបាយនេះ មនុស្សជាតិទាំងអស់បានមើលឃើញថា ទ្រង់គឺជាព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ ឃើញថា ទ្រង់គឺជាព្រះជាម្ចាស់ផ្ទាល់ព្រះអង្គដែលបានត្រលប់ជាសាច់ឈាម ដែលគ្មាននរណាម្នាក់អាចប្រមាថទ្រង់បានឡើយ និងមើលឃើញទៀតថា គ្មាននរណាម្នាក់អាចខ្ពស់ហួសពីការជំនុំជម្រះរបស់ទ្រង់ដោយព្រះបន្ទូល ហើយក៏គ្មានកម្លាំងនៃសេចក្ដីងងឹតណាមួយអាចយកឈ្នះលើសិទ្ធិអំណាចរបស់ទ្រង់បានដែរ។ មនុស្សចុះចូលចំពោះទ្រង់ទាំងស្រុង ដោយសារតែទ្រង់ជាព្រះបន្ទូល ដែលត្រលប់ជាសាច់ឈាម ដោយសារតែសិទ្ធិអំណាចរបស់ទ្រង់ និងដោយសារតែការជំនុំជម្រះរបស់ទ្រង់ដោយព្រះបន្ទូល។ កិច្ចការដែលត្រូវបាននាំមកដោយសាច់ឈាម ដែលយកកំណើតជាមនុស្សរបស់ទ្រង់ គឺជាសិទ្ធិអំណាចមួយដែលទ្រង់មាន។ ហេតុផលដែលទ្រង់ត្រលប់ជាសាច់ឈាម គឺដោយសារតែសាច់ឈាមក៏អាចមានសិទ្ធិអំណាចដែរ ហើយទ្រង់អាចអនុវត្តកិច្ចការតាមរបៀបជាក់ស្តែងមួយនៅក្នុងចំណោមមនុស្សជាតិ គឺតាមរបៀបមួយដែលមនុស្សអាចមើលឃើញ និងពាល់បាន។ កិច្ចការនេះមានលក្ខណៈប្រាកដប្រជាជាងកិច្ចការដែលត្រូវបានធ្វើដោយផ្ទាល់ ដោយព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ ដែលមានគ្រប់ទាំងសិទ្ធិអំណាច ហើយលទ្ធផលរបស់វាក៏ស្តែងចេញឲ្យឃើញច្បាស់ដែរ។ នេះគឺដោយសារតែសាច់ឈាមដែលយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់ អាចមានបន្ទូល និងធ្វើការនៅតាមរបៀបជាក់ស្តែង។ ទម្រង់ខាងក្រៅនៃសាច់ឈាមរបស់ទ្រង់គ្មានសិទ្ធិអំណាចអ្វីឡើយ ហើយមនុស្សអាចចូលទៅជិតបាន ខណៈដែល

លក្ខណៈសំខាន់របស់ទ្រង់មានសិទ្ធិអំណាច ប៉ុន្តែចំពោះសិទ្ធិអំណាចរបស់ទ្រង់ គ្មាននរណាម្នាក់អាចមើលឃើញឡើយ។ នៅពេលដែលទ្រង់មានបន្ទូល និងធ្វើការ មនុស្សមិនអាចដឹងពីអត្ថិភាពនៃសិទ្ធិអំណាចរបស់ទ្រង់ឡើយ ហើយការនេះជួយឲ្យទ្រង់ធ្វើកិច្ចការចេញពីលក្ខណៈជាក់ស្ដែង។ គ្រប់ទាំងកិច្ចការជាក់ស្ដែងនេះ អាចសម្រេចបានលទ្ធផល។ ទោះបីជាគ្មានមនុស្សណាម្នាក់ដឹងថា ទ្រង់មានសិទ្ធិអំណាច ឬមើលឃើញថា ទ្រង់មិនអាចត្រូវបានប្រមាថ ឬមើលឃើញពីសេចក្ដីក្រោធរបស់ទ្រង់ក៏ដោយ ក៏ទ្រង់សម្រេចបានលទ្ធផលគ្រោងទុកនៃព្រះបន្ទូលរបស់ទ្រង់តាមរយៈសិទ្ធិអំណាចដ៏លាក់កំបាំងរបស់ទ្រង់ សេចក្ដីក្រោធដ៏លាក់កំបាំងរបស់ទ្រង់ និងព្រះបន្ទូលដែលទ្រង់មានបន្ទូលដោយចំហ។ អាចនិយាយម្យ៉ាងទៀតបានថា តាមរយៈព្រះសូរសៀងរបស់ទ្រង់ ភាពប្រាកដប្រជានៃព្រះបន្ទូលរបស់ទ្រង់ និងគ្រប់ទាំងព្រះប្រាជ្ញាញាណចេញពីព្រះបន្ទូលរបស់ទ្រង់ នោះមនុស្សនឹងជឿទាំងស្រុងតែម្ដង។ តាមរបៀបនេះ មនុស្សចុះចូលចំពោះព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស ដែលមើលទៅហាក់ដូចជាគ្មានសិទ្ធិអំណាច ប៉ុន្តែបែរជាអាចសម្រេចបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ក្នុងការសង្គ្រោះមនុស្សបានទៅវិញ។ នេះគឺជាទិដ្ឋភាពមួយទៀតនៃភាពសំខាន់អំពីការយកកំណើតជាមនុស្សរបស់ទ្រង់ គឺជាការមានបន្ទូលកាន់តែប្រាកដប្រជា និងអនុញ្ញាតឲ្យតថភាពជាក់ស្ដែងនៃព្រះបន្ទូលរបស់ទ្រង់មានឥទ្ធិពលទៅលើមនុស្ស ដើម្បីឲ្យមនុស្សធ្វើបន្ទាល់ពីព្រះចេស្ដានៃព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ដូច្នេះ បើកិច្ចការនេះមិនត្រូវបានធ្វើឡើង តាមរយៈមធ្យោបាយនៃការយកកំណើតជាមនុស្សទេ នោះវានឹងមិនអាចសម្រេចបានលទ្ធផលអ្វីឡើយ ហើយវានឹងមិនអាចសង្គ្រោះមនុស្សដែលពេញដោយអំពើបាបបានយ៉ាងពេញលេញឡើយ។ ប្រសិនបើព្រះជាម្ចាស់មិនត្រលប់ជាសាច់ឈាមទេ នោះទ្រង់នឹងបន្តជាព្រះវិញ្ញាណដែលមនុស្សមិនអាចមើលឃើញ និងពាល់បាន។ មនុស្សជាសត្តនិករនៃសាច់ឈាម ដូច្នេះ គេនិងព្រះជាម្ចាស់មានពិភពពីរផ្សេងគ្នា និងមានធម្មជាតិខុសគ្នាដែរ។ ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់មិនអាចចុះសម្រុងជាមួយមនុស្ស ដែលមកពីសាច់ឈាមឡើយ ហើយវាក៏

គ្មានផ្លូវនៃការបង្កើតនូវទំនាក់ទំនងរវាងពួកគេបានដែរ បើដូច្នេះ មនុស្សគ្មានសមត្ថភាពទទួលបានការបំផ្លាស់ប្រែខាងវិញ្ញាណឡើយ។ ដោយសារតែហេតុផលនេះហើយបានជាព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ត្រូវតែត្រលប់ជាមនុស្ស ដើម្បីធ្វើកិច្ចការដើមរបស់ទ្រង់។ ព្រះជាម្ចាស់អាចយាងឡើងទៅទីដ៏ខ្ពង់ខ្ពស់បំផុត និងបន្ទាបអង្គទ្រង់ត្រលប់ជាមនុស្ស ដើម្បីធ្វើការនៅក្នុងចំណោមមនុស្សជាតិ និងរស់នៅកណ្តាលចំណោមពួកគេបាន ប៉ុន្តែមនុស្សមិនអាចឡើងទៅកាន់ទីដ៏ខ្ពស់បំផុត និងក្លាយជាវិញ្ញាណបានទេ ហើយលើសពីនេះ គេក៏មិនអាចចុះទៅកាន់ទីដ៏ទាបបំផុតនោះដែរ។ នេះជាហេតុផលដែលព្រះជាម្ចាស់ត្រូវតែត្រលប់ជាសាច់ឈាម ដើម្បីអនុវត្តកិច្ចការរបស់ទ្រង់។ ដោយសារហេតុផលដដែលនេះហើយ បានជាក្នុងអំឡុងនៃការយកកំណើតជាមនុស្សលើកទីមួយ មានតែសាច់ឈាមរបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សប៉ុណ្ណោះ ទើបអាចប្រោសលោះមនុស្សតាមរយៈការជាប់ឆ្កាង ប៉ុន្តែវាគ្មានផ្លូវណាដែលព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ត្រូវបានជាប់ឆ្កាង ជាតង្វាយលោះបាបសម្រាប់មនុស្សឡើយ។ ព្រះជាម្ចាស់អាចត្រលប់ជាសាច់ឈាមដោយផ្ទាល់ ដើម្បីធ្វើជាតង្វាយលោះបាបសម្រាប់មនុស្ស ប៉ុន្តែមនុស្សមិនអាចឡើងទៅស្ថានសួគ៌ដោយផ្ទាល់ ដើម្បីទទួលតង្វាយលោះបាបដែលព្រះជាម្ចាស់បានរៀបចំទុកសម្រាប់គេឡើយ។ ដោយសារហេតុផលនេះ អ្វីគ្រប់យ៉ាងដែលអាចធ្វើបាន គឺសុំឲ្យព្រះជាម្ចាស់រត់ចុះឡើងពីរបីដងនៅចន្លោះស្ថានសួគ៌និងផែនដី ដោយមិនចាំបាច់ឲ្យមនុស្សត្រូវឡើងទៅស្ថានសួគ៌ ដើម្បីទទួលយកសេចក្តីសង្គ្រោះនេះទេ ព្រោះមនុស្សបានធ្លាក់ចុះ ហើយលើសពីនេះទៅទៀត មនុស្សក៏មិនអាចឡើងទៅស្ថានសួគ៌បានដែរ ថែមទាំងមិនអាចទទួលយកតង្វាយលោះបានទៀតផង។ ដូច្នេះ វាចាំបាច់ណាស់ដែលព្រះយេស៊ូវត្រូវយាងមកកណ្តាលចំណោមមនុស្សជាតិ ហើយធ្វើកិច្ចការដែលមនុស្សមិនអាចសម្រេចបានដោយព្រះអង្គទ្រង់ផ្ទាល់។ គ្រប់ពេលដែលព្រះជាម្ចាស់ត្រលប់ជាសាច់ឈាម គឺសុទ្ធតែជាពេលដ៏ចាំបាច់បំផុត។ បើមានដំណាក់កាលណាមួយ ដែលអាចត្រូវបានអនុវត្តដោយផ្ទាល់ដោយព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ នោះទ្រង់នឹងមិនចាំបាច់ត្រូវចុះចូល

រហូតដល់រងភាពអាម៉ាស់នៃការយកកំណើតជាមនុស្សនោះឡើយ។

នៅក្នុងដំណាក់កាលចុងក្រោយនៃកិច្ចការ លទ្ធផលត្រូវបានសម្រេចតាមរយៈព្រះបន្ទូល។ តាមរយៈព្រះបន្ទូល មនុស្សចាប់ផ្ដើមយល់ដឹងអំពីសេចក្ដីអាថ៌កំបាំងជាច្រើន និងកិច្ចការដែលព្រះជាម្ចាស់បានធ្វើតាមរយៈមនុស្សជំនាន់មុន។ តាមរយៈព្រះបន្ទូល មនុស្សបានទទួលការបំភ្លឺពីព្រះវិញ្ញាណបរិសុទ្ធ។ តាមរយៈព្រះបន្ទូល មនុស្សចាប់ផ្ដើមយល់អំពីសេចក្ដីអាថ៌កំបាំង ដែលមិនធ្លាប់ត្រូវបានបើកសម្ដែងពីមនុស្សជំនាន់មុន ក៏ដូចជាកិច្ចការរបស់ពួកហោរា និងពួកសាវ័កកាលពីគ្រាមុន និងគោលការណ៍ដែលពួកគេបានធ្វើការដែរ។ តាមរយៈព្រះបន្ទូល មនុស្សក៏ចាប់ផ្ដើមយល់អំពីនិស្ស័យរបស់ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ ក៏ដូចជាយល់អំពីការបះបោរ និងការប្រឆាំងរបស់មនុស្ស ហើយគេក៏ចាប់ផ្ដើមដឹងអំពីលក្ខណៈសំខាន់របស់គេផងដែរ។ តាមរយៈជំហាននៃកិច្ចការទាំងនេះ និងតាមរយៈគ្រប់ទាំងព្រះបន្ទូលដែលបានថ្លែងមក មនុស្សចាប់ផ្ដើមដឹងអំពីកិច្ចការរបស់ព្រះវិញ្ញាណ កិច្ចការរបស់សាច់ឈាមដែលយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់ ហើយលើសពីនេះ ក៏ដឹងអំពីនិស្ស័យទាំងស្រុងរបស់ទ្រង់ដែរ។ ចំណេះដឹងរបស់អ្នកអំពីកិច្ចការគ្រប់គ្រងរយៈពេលប្រាំមួយពាន់ឆ្នាំរបស់ព្រះជាម្ចាស់ក៏ទទួលបានតាមរយៈព្រះបន្ទូលដែរ។ តើការបោះបង់ចោលនូវចំណេះដឹងអំពីសញ្ញាណចាស់ និងភាពជោគជ័យរបស់អ្នក ក៏មិនត្រូវបានទទួលតាមរយៈព្រះបន្ទូលដែរទេឬអី? នៅក្នុងដំណាក់កាលមុន ព្រះយេស៊ូវបានធ្វើទីសម្គាល់ និងការអស្ចារ្យជាច្រើន ប៉ុន្តែនៅក្នុងដំណាក់កាលនេះ វាគ្មានទីសម្គាល់ និងការអស្ចារ្យឡើយ។ តើការដែលអ្នកទទួលបានការយល់ដឹងអំពីហេតុផលដែលព្រះជាម្ចាស់មិនបើកសម្ដែងនូវទីសម្គាល់ និងការអស្ចារ្យ ក៏មិនបានមកតាមរយៈព្រះបន្ទូលដែរទេឬអី? ដូច្នេះ ព្រះបន្ទូលដែលបានថ្លែងនៅក្នុងដំណាក់កាលនេះ គឺខ្ពស់ហួសពីកិច្ចការដែលត្រូវបានធ្វើដោយពួកសាវ័ក និងពួកហោរាកាលពីជំនាន់មុនទៅទៀត។ សូម្បីតែសេចក្ដីទំនាយដែលពួកហោរាបានថ្លែង ក៏មិនអាចសម្រេចបានលទ្ធផលនេះដែរ។ ពួកហោរាបានថ្លែងតែសេចក្ដីទំនាយប៉ុណ្ណោះ ពួកគេបាននិយាយអំពីអ្វីដែលនឹងកើត

ឡើងនៅថ្ងៃអនាគត ប៉ុន្តែមិនបាននិយាយអំពីកិច្ចការដែលព្រះជាម្ចាស់ចង់ធ្វើនាពេលបច្ចុប្បន្នឡើយ។ ពួកគេក៏មិនបានថ្លែង ដើម្បីដឹកនាំមនុស្សជាតិនៅក្នុងជីវិតរបស់ពួកគេ ឬក៏ផ្ដល់នូវសេចក្ដីពិតចំពោះមនុស្សជាតិ ឬបើកសម្ដែងពីសេចក្ដីអាថ៌កំបាំងដល់ពួកគេឡើយ រីតតែមិនបានផ្ដល់នូវជីវិតទៅទៀត។ ចេញពីព្រះបន្ទូលដែលបានថ្លែងនៅក្នុងដំណាក់កាលនេះ មានសេចក្ដីទំនាយ និងសេចក្ដីពិត ប៉ុន្តែព្រះបន្ទូលទាំងនេះបម្រើជាចម្បង ដើម្បីប្រទានជីវិតដល់មនុស្សប៉ុណ្ណោះ។ ព្រះបន្ទូលនាពេលបច្ចុប្បន្នខុសពីសេចក្ដីទំនាយរបស់ពួកហោរា។ នេះគឺជាដំណាក់កាលនៃកិច្ចការមួយសម្រាប់ជីវិតរបស់មនុស្ស ដើម្បីផ្លាស់ប្ដូរនិស្ស័យនៃជីវិតរបស់មនុស្ស និងមិនមែនសម្រាប់ជាប្រយោជន៍នៃការថ្លែងទំនាយឡើយ។ ដំណាក់កាលទីមួយ គឺជាកិច្ចការរបស់ព្រះយេហូវ៉ា។ កិច្ចការរបស់ទ្រង់ គឺរៀបចំផ្លូវមួយសម្រាប់មនុស្ស ដើម្បីថ្វាយបង្គំព្រះជាម្ចាស់នៅលើផែនដី។ វាជាកិច្ចការនៃទីចាប់ផ្ដើម ដើម្បីស្វែងរកប្រភពដើមសម្រាប់កិច្ចការនៅលើផែនដី។ នៅគ្រានោះ ព្រះយេហូវ៉ាបានបង្រៀនដល់ប្រជាជនអ៊ីស្រាអែលឲ្យកាន់តាមថ្ងៃសប្ប័ទ គោរពឪពុកម្ដាយរបស់ខ្លួន និងរស់នៅចុះសម្រុងគ្នា។ នេះគឺដោយសារតែមនុស្សនៅគ្រានោះ មិនបានយល់អំពីអ្វីដែលបានរួមផ្សំជាមនុស្ស ហើយក៏មិនយល់ពីរបៀបរស់នៅលើផែនដីដែរ។ នៅក្នុងដំណាក់កាលទីមួយនៃកិច្ចការ វាចាំបាច់ណាស់ដែលទ្រង់ត្រូវចង្អុលបង្ហាញមនុស្សជាតិឲ្យចេះដឹកនាំជីវិតរបស់ពួកគេ។ រាល់សេចក្ដីដែលព្រះយេហូវ៉ាបានមានបន្ទូលទៅកាន់ពួកគេ មនុស្សជាតិមិនធ្លាប់ដឹងឮ ឬមានចំណេះបែបនោះពីមុនមកឡើយ។ នៅគ្រានោះ ព្រះជាម្ចាស់បានរើសតាំងពួកហោរាជាច្រើននាក់ ដើម្បីថ្លែងទំនាយ ហើយពួកគេទាំងអស់បានធ្វើការនេះ ក្រោមការចង្អុលបង្ហាញរបស់ព្រះយេហូវ៉ា។ នេះគ្រាន់តែជាចំណុចមួយនៅក្នុងកិច្ចការរបស់ព្រះជាម្ចាស់ប៉ុណ្ណោះ។ នៅក្នុងដំណាក់កាលទីមួយ ព្រះជាម្ចាស់មិនបានត្រលប់ជាសាច់ឈាមឡើយ ដូច្នេះ ទ្រង់បានបង្គាប់ដល់គ្រប់ពូជអំបូរ និងគ្រប់ប្រជាជាតិតាមរយៈពួកហោរា។ នៅពេលដែលព្រះយេស៊ូវបានធ្វើការនៅក្នុងសម័យរបស់ទ្រង់ ទ្រង់មិនបានមានបន្ទូលជាច្រើន ដូចនៅក្នុងសម័យបច្ចុប្បន្នឡើយ។ ដំណាក់កាលនៃ

កិច្ចការរបស់ព្រះបន្ទូលនៅក្នុងគ្រាចុងក្រោយនេះ មិនធ្លាប់បានធ្វើនៅក្នុងយុគសម័យ និងជំនាន់មុនៗឡើយ។ ទោះបីអេសាយ ដានីយ៉ែល និងយ៉ូហានបានថ្លែងនូវសេចក្ដីទំនាយជាច្រើនក៏ដោយ ក៏សេចក្ដីទំនាយរបស់គេខុសគ្នាស្រឡះពីព្រះបន្ទូលដែលត្រូវបានថ្លែងនាពេលសព្វថ្ងៃនេះដែរ។ អ្វីដែលពួកគេបានមានប្រសាសន៍ គឺគ្រាន់តែជាសេចក្ដីទំនាយប៉ុណ្ណោះ ប៉ុន្តែព្រះបន្ទូលដែលត្រូវបានថ្លែងនាពេលសព្វថ្ងៃនេះ មិនមែនជាសេចក្ដីទំនាយឡើយ។ ប្រសិនបើខ្ញុំប្រែក្លាយគ្រប់ទាំងសេចក្ដីដែលខ្ញុំមានបន្ទូលនាពេលនេះឲ្យក្លាយជាសេចក្ដីទំនាយ តើអ្នករាល់គ្នានឹងអាចយល់ដែរឬទេ? ឧបមាថា អ្វីដែលខ្ញុំបានមានបន្ទូលនោះ គឺជាកិច្ចការនានាក្រោយពេលដែលខ្ញុំបានចេញទៅផុត តើអ្នកអាចទទួលបានការយល់ដឹងយ៉ាងដូចម្ដេចទៅ? កិច្ចការនៃព្រះបន្ទូល មិនត្រូវបានធ្វើនៅក្នុងសម័យរបស់ព្រះយេស៊ូវ ឬនៅក្នុងយុគសម័យនៃក្រឹត្យវិន័យឡើយ។ ប្រហែលជាអ្នកខ្លះនឹងនិយាយថា «តើព្រះយេហូវ៉ា មិនបានមានបន្ទូលនៅក្នុងពេលដែលទ្រង់ធ្វើការដែរទេឬអី? បន្ថែមពីលើការប្រោសជំងឺឲ្យជា ការបណ្ដេញអារក្ស និងការធ្វើទីសម្គាល់ និងការអស្ចារ្យ តើព្រះយេស៊ូវមិនបានមានបន្ទូលនៅគ្រាដែលទ្រង់កំពុងតែធ្វើការដែរទេឬអី?» វាមានភាពខុសគ្នារវាងរឿងរ៉ាវនានាដែលត្រូវបានថ្លែង។ តើអ្វីទៅជាលក្ខណៈសំខាន់ នៃព្រះបន្ទូលដែលព្រះយេហូវ៉ាបានថ្លែង? ទ្រង់កំពុងតែចង្អុលបង្ហាញមនុស្សជាតិឲ្យចេះដឹកនាំជីវិតរបស់ពួកគេនៅលើផែនដី ហើយវាមិនបានប៉ះពាល់ដល់កិច្ចការនៅក្នុងជីវិតខាងវិញ្ញាណឡើយ។ ហេតុអ្វីបានជាគេនិយាយថា នៅពេលដែលព្រះយេហូវ៉ាបានមានបន្ទូល ទ្រង់បានបង្គាប់ទៅកាន់មនុស្សនៅគ្រប់ទីកន្លែង? ពាក្យថា «បង្គាប់» មានន័យថា ប្រាប់យ៉ាងជាក់ច្បាស់ និងបញ្ជាដោយត្រង់។ ទ្រង់មិនបានប្រទានជីវិតដល់មនុស្សឡើយ ផ្ទុយទៅវិញ ទ្រង់គ្រាន់តែកាន់ដៃមនុស្ស ហើយបង្រៀនពួកគេពីរបៀបគោរពស្រឡាញ់ទ្រង់ ដោយមិនបានផ្ដល់ជាប្រស្នាជាច្រើនឡើយ។ កិច្ចការដែលព្រះយេហូវ៉ាបានធ្វើនៅក្នុងស្រុកអ៊ីស្រាអែល គឺមិនទាក់ទងនឹងការដោះស្រាយ ការប្រៀនប្រដៅមនុស្ស ឬការប្រទានការជំនុំជម្រះ និងការវាយផ្ចាលឡើយ ប៉ុន្តែវាជាការចង្អុលបង្ហាញពួកគេវិញ។ ព្រះយេហូវ៉ាបានបញ្ជាទៅកាន់ម៉ូសេឲ្យ

ប្រាប់ប្រជារាស្ត្ររបស់ទ្រង់ ឲ្យដើរប្រមូលនំម៉ាណានៅឯវាលរហោស្ថាន។ រៀងរាល់ព្រឹកមុនពេលថ្ងៃរះ ពួកគេត្រូវចេញទៅប្រមូលនំម៉ាណា គឺមួយគ្រប់ល្មមសម្រាប់ពួកគេក្នុងការបរិភោគសម្រាប់ថ្ងៃនោះប៉ុណ្ណោះ។ នំម៉ាណា មិនអាចរក្សាទុករហូតដល់ថ្ងៃស្អែកបានឡើយ ព្រោះវានឹងដុះផ្សិតមិនខាន។ ទ្រង់មិនបានបង្រៀនមនុស្ស ឬលាតត្រដាងពីធម្មជាតិរបស់ពួកគេ ហើយក៏មិនបានបង្ហាញគំនិត និងយោបល់របស់ពួកគេដែរ។ ទ្រង់មិនបានផ្លាស់ប្តូរមនុស្សឡើយ ផ្ទុយទៅវិញ ទ្រង់បានចង្អុលបង្ហាញដល់ពួកគេនៅក្នុងការដឹកនាំជីវិតរបស់ខ្លួនវិញ។ មនុស្សនៅគ្រានោះ ដូចជាកូនក្មេងអ៊ីចឹង ហើយពួកគេគ្មានយល់អ្វីឡើយ ក្រៅពីការដេកដើរឈរអង្គុយ ដូច្នេះ ព្រះយេហូវ៉ាគ្រាន់តែចេញក្រឹត្យវិន័យ ដើម្បីចង្អុលបង្ហាញដល់បណ្តាជនប៉ុណ្ណោះ។

ដើម្បីផ្សាយដំណឹងល្អឲ្យមនុស្សទាំងអស់ដែលស្វែងរកដោយដួងចិត្តដ៏ពិត អាចទទួលបានចំណេះដឹង អំពីកិច្ចការដែលត្រូវបានធ្វើនៅថ្ងៃនេះ និងជឿជាក់យ៉ាងមុតមាំ អ្នកត្រូវតែមានការយល់ដឹងដ៏ច្បាស់លាស់អំពីសាច់រឿងនៅខាងក្នុង យល់អំពីលក្ខណៈសំខាន់ និងភាពសំខាន់នៃកិច្ចការ ដែលត្រូវបានធ្វើនៅក្នុងដំណាក់កាលនីមួយៗ។ ដោយស្តាប់ឮការប្រកបគ្នារបស់អ្នក អ្នកផ្សេងទៀតអាចយល់អំពីកិច្ចការរបស់ព្រះយេហូវ៉ា កិច្ចការរបស់ព្រះយេស៊ូវ ហើយកាន់តែសំខាន់ជាងនេះទៀតនោះ គឺគេអាចយល់អំពីគ្រប់ទាំងកិច្ចការរបស់ព្រះជាម្ចាស់នាពេលសព្វថ្ងៃ ក៏ដូចជាទំនាក់ទំនង និងភាពខុសគ្នារវាងដំណាក់កាលទាំងបីនៃកិច្ចការនេះដែរ។ ដូច្នេះក្រោយពេលដែលពួកគេបានបញ្ចប់ការស្តាប់ហើយ អ្នកផ្សេងទៀតនឹងមើលឃើញថាដំណាក់កាលទាំងបីមិនបានបង្អាក់ដល់គ្នាឡើយ ប៉ុន្តែមើលឃើញថា ដំណាក់កាលទាំងអស់គឺជាកិច្ចការរបស់ព្រះវិញ្ញាណតែមួយ។ ទោះបីជាពួកទ្រង់ ធ្វើការនៅក្នុងយុគសម័យផ្សេងគ្នា មាតិកានៃកិច្ចការដែលពួកទ្រង់អនុវត្តខុសគ្នា ហើយព្រះបន្ទូលដែលពួកទ្រង់មានបន្ទូលខុសគ្នាក៏ដោយ ក៏គោលការណ៍ដែលពួកទ្រង់ធ្វើ គឺតែមួយនិងដូចគ្នាដែរ។ ទាំងនេះគឺជានិមិត្តដ៏ធំបំផុតដែលអ្នកដើរតាមព្រះជាម្ចាស់ទាំងអស់គួរតែយល់។

# ការយកកំណើតជាមនុស្សទាំងពីរលើក បំពេញនូវសារៈសំខាន់នៃការយកកំណើតជាមនុស្ស

ដំណាក់កាលនីមួយៗនៃកិច្ចការដែលព្រះជាម្ចាស់បានធ្វើ សុទ្ធតែមានសារៈសំខាន់ជាក់ស្ដែងរបស់វាផ្ទាល់។ កាលពីមុន គ្រាដែលព្រះយេស៊ូវបានយាងមក ទ្រង់បានយាងមកក្នុងទម្រង់ជាភេទបុរស ហើយនៅពេលដែលព្រះជាម្ចាស់យាងមកនាពេលនេះ ទម្រង់របស់ទ្រង់ជាភេទស្រ្តី។ តាមរយៈការនេះ អ្នកអាចមើលឃើញថា ការបង្កើតរបស់ព្រះជាម្ចាស់ទាំងបុរស និងស្រ្តី អាចសម្រាប់ជាប្រយោជន៍ដល់កិច្ចការរបស់ទ្រង់ ហើយចំពោះទ្រង់ គឺគ្មានការបែងចែកភេទនោះឡើយ។ នៅពេលដែលព្រះវិញ្ញាណរបស់ទ្រង់យាងមក ទ្រង់អាចយកទម្រង់ជាសាច់ឈាម ណាក៏បានតាមតែទ្រង់សព្វព្រះទ័យ ហើយសាច់ឈាមនោះអាចតំណាងឲ្យទ្រង់បាន។ មិនថាសាច់ឈាមនោះជាបុរស ឬស្ត្រីឡើយ ដរាបណាវាជាសាច់ឈាមដែលយកកំណើតជាមនុស្សរបស់ទ្រង់ នោះវាអាចតំណាងឲ្យព្រះជាម្ចាស់បានហើយ។ ប្រសិនបើព្រះយេស៊ូវបានបង្ហាញអង្គទ្រង់ជាស្ត្រី នៅពេលដែលទ្រង់បានយាងមក ម៉្យាងទៀត ប្រសិនបើទ្រង់ជាទារិកា ហើយមិនមែនជាទារកដែលត្រូវបានចាប់កំណើតដោយព្រះវិញ្ញាណបរិសុទ្ធ ដំណាក់កាលនៃកិច្ចការនោះ ក៏នឹងត្រូវបានបញ្ចប់ដូចគ្នាបានផងដែរ។ ប្រសិនបើវាបែបនេះ នោះកិច្ចការដំណាក់កាលបច្ចុប្បន្ននឹងត្រូវបានបញ្ចប់ដោយបុរសភេទវិញ ប៉ុន្តែកិច្ចការនឹងត្រូវបានបញ្ចប់ដូចគ្នា។ កិច្ចការដែលត្រូវបានសម្រេចនៅក្នុងដំណាក់កាលនីមួយៗ មានសារៈសំខាន់របស់វារៀងៗខ្លួន ហើយកិច្ចការដំណាក់កាលនោះនឹងមិនកើតឡើងម្ដងទៀតឡើយ ហើយវានឹងមិនជាន់ជាមួយនឹងដំណាក់កាលផ្សេងទៀតឡើយ។ នៅពេលនោះ កាលព្រះយេស៊ូវកំពុងធ្វើកិច្ចការរបស់ទ្រង់ គេហៅទ្រង់ថាព្រះរាជបុត្រាតែមួយ ហើយ «ព្រះរាជបុត្រា» នេះ គឺសំដៅទៅលើបុរសភេទ។ ហេតុអ្វីបានជាព្រះរាជបុត្រាតែមួយ មិនត្រូវបានលើកមកនិយាយនៅក្នុងដំណាក់កាលបច្ចុប្បន្ន? គឺដោយសារតែលក្ខខណ្ឌតម្រូវនៃកិច្ចការ ចាំបាច់ត្រូវមានការផ្លាស់ប្ដូរភេទ ឲ្យខុសពី

ព្រះយេស៊ូវ។ ចំពោះព្រះជាម្ចាស់ គឺគ្មានភាពខុសគ្នានៃភេទនោះឡើយ។ ទ្រង់ធ្វើកិច្ចការរបស់ទ្រង់តាមតែទ្រង់ចង់ធ្វើ ហើយនៅក្នុងការធ្វើកិច្ចការរបស់ទ្រង់ ទ្រង់មិនចំណុះនៅក្រោមសេចក្ដីរឹតត្បិតណាមួយឡើយ ប៉ុន្តែទ្រង់មានសេរីភាពជាពិសេសតែម្ដង។ ដោយឡែក គ្រប់ដំណាក់កាលនៃកិច្ចការទាំងអស់ សុទ្ធតែមានសារៈសំខាន់ជាក់ស្ដែងរបស់វា។ ព្រះជាម្ចាស់បានត្រលប់ជាសាច់ឈាមចំនួនពីរលើក ហើយការនេះជាភ័ស្ដុតាងស្រាប់បញ្ជាក់ថា ការយកកំណើតជាមនុស្សរបស់ទ្រង់នៅគ្រាចុងក្រោយ គឺជាលើកចុងក្រោយ។ ទ្រង់បានយាងមក ដើម្បីធ្វើឲ្យមនុស្សលោកដឹងអំពីគ្រប់ទាំងទង្វើរបស់ទ្រង់។ ប្រសិនបើនៅក្នុងដំណាក់កាលនេះ ទ្រង់មិនបានត្រលប់ជាសាច់ឈាម ដើម្បីធ្វើកិច្ចការដោយផ្ទាល់ ឲ្យមនុស្សមើលឃើញផ្ទាល់ភ្នែក នោះមនុស្សនឹងប្រកាន់ខ្ជាប់ជារៀងរហូត នូវសញ្ញាណដែលគិតថា ព្រះជាម្ចាស់ គឺជាបុរសតែប៉ុណ្ណោះ មិនមែនជាមនុស្សស្រីនោះឡើយ។ មុនពេលនេះ មនុស្សជាតិទាំងអស់បានជឿថា ព្រះជាម្ចាស់អាចក្លាយជាបុរសភេទតែប៉ុណ្ណោះ និងជឿទៀតថា នារីភេទមិនអាចត្រូវបានហៅថាជាព្រះជាម្ចាស់បានឡើយ ដ្បិតមនុស្សជាតិទាំងអស់បានចាត់ទុកបុរសថា មានសិទ្ធិអំណាចខ្ពស់ជាងស្ត្រី។ ពួកគេបានជឿថា គ្មានស្ត្រីណាម្នាក់ដែលអាច ប្រើសិទ្ធិអំណាចបានឡើយ គឺមានតែបុរសប៉ុណ្ណោះ។ លើសពីនេះទៅទៀត ពួកគេថែមទាំងនិយាយថា បុរសជាក្បាលរបស់ស្ត្រី និងនិយាយថាស្ត្រីត្រូវតែស្ដាប់បង្គាប់បុរស ហើយគេមិនអាចប្រសើរជាងបុរសបានឡើយ។ កាលពីអតីតកាល ពេលគេនិយាយថា បុរសគឺជាក្បាលរបស់ស្ត្រី គេកំពុងតែសំដៅទៅលើអ័ដាម និងអេវ៉ា ដែលត្រូវបានចាញ់បញ្ឆោតសត្វពស់ មិនមែនសំដៅលើបុរស និងស្ត្រី ដែលត្រូវបានបង្កើតឡើងដោយព្រះយេហូវ៉ា កាលពីដើមដំបូង។ ពិតប្រាកដណាស់ ស្ត្រីត្រូវតែស្ដាប់បង្គាប់ និងស្រឡាញ់ស្វាមីរបស់នាង ហើយស្វាមីត្រូវតែរៀនចិញ្ចឹម និងផ្គត់ផ្គង់ដល់ក្រុមគ្រួសាររបស់គាត់។ ទាំងនេះគឺជាច្បាប់ និងជាក្រឹត្យក្រមដែលត្រូវបានកំណត់ទុកដោយព្រះយេហូវ៉ា សម្រាប់ឲ្យមនុស្សជាតិត្រូវប្រកាន់ខ្ជាប់នៅក្នុងជីវិតរបស់គេនៅលើផែនដី។ ព្រះយេហូវ៉ាបានមានបន្ទូលទៅកាន់ស្ត្រីថា «ចិត្តអ្នកក៏ប្រាថ្នាចង់បានប្ដី ហើយ

គេនឹងត្រួតលើអ្នក»។ ទ្រង់បានមានបន្ទូលបែបនេះ គឺដើម្បីឲ្យមនុស្សជាតិ (ទាំងបុរស និងស្រ្ដី) អាចរស់នៅជីវិតបែបសាមញ្ញ ក្រោមការគ្រប់គ្រងរបស់ព្រះយេហូវ៉ា និង ដើម្បីឲ្យជីវិតរបស់មនុស្សជាតិមានរចនាសម្ព័ន្ធ ហើយមិនធ្វើខុសពីសណ្ដាប់ធ្នាប់ដ៏ត្រឹមត្រូវរបស់គេប៉ុណ្ណោះ។ ដូច្នេះហើយ ព្រះយេហូវ៉ាបានបង្កើតនូវច្បាប់ដ៏សមរម្យស្ដីអំពីរបៀបដែលបុរស និងស្រ្ដីគួរតែប្រព្រឹត្ត ទោះបីជាការនេះពាក់ព័ន្ធជាមួយសត្តនិករទាំងអស់ដែលកំពុងតែរស់នៅលើផែនដី ហើយគ្មានទំនាក់ទំនងជាមួយព្រះដែលយកកំណើតជាមនុស្សរបស់ទ្រង់ក៏ដោយ។ តើព្រះជាម្ចាស់អាចមានលក្ខណៈដូចគ្នានឹងសត្តនិករដែលទ្រង់បានបង្កើតឡើងដោយរបៀបណា? ព្រះបន្ទូលរបស់ទ្រង់ត្រូវបានថ្លែងទៅកាន់តែមនុស្សជាតិដែលជាសត្តនិកររបស់ទ្រង់ប៉ុណ្ណោះ ហើយទ្រង់មានបន្ទូលបែបនេះ ដើម្បីឲ្យមនុស្សលោករស់នៅជីវិតបែបសាមញ្ញ ស្របតាមច្បាប់ដែលទ្រង់បានបង្កើតឡើងសម្រាប់បុរស និងស្រ្ដី។ កាលពីដើមដំបូង នៅពេលដែលព្រះយេហូវ៉ាបានបង្កើតមនុស្សជាតិ ទ្រង់បានបង្កើតមនុស្សមកមានពីរប្រភេទ គឺបុរស និងស្រ្ដី។ ដូច្នេះ វាត្រូវមានផ្នែកជាបុរស និងផ្នែកជាស្រ្ដី នៅក្នុងសាច់ឈាមដែលយកកំណើតជាមនុស្សរបស់ទ្រង់។ ទ្រង់មិនបានសម្រេចព្រះទ័យធ្វើកិច្ចការរបស់ទ្រង់ដោយផ្អែកលើព្រះបន្ទូលដែលទ្រង់បានថ្លែងទៅកាន់អ័ដាម និងអេវ៉ាឡើយ។ ទាំងពីរលើកដែលទ្រង់បានក្លាយជាសាច់ឈាមត្រូវបានកំណត់ទាំងស្រុង ស្របតាមព្រះតម្រិះរបស់ទ្រង់ នៅពេលដែលទ្រង់បានបង្កើតមនុស្សលោកជាលើកដំបូង ដូច្នេះ ទ្រង់បានបញ្ចប់កិច្ចការនៃការយកកំណើតជាមនុស្សទាំងពីរលើករបស់ទ្រង់ ដោយផ្អែកលើបុរស និងស្រ្ដី មុនពេលពួកគេក្លាយជាពុលរលួយ។ ប្រសិនបើមនុស្សជាតិយកព្រះបន្ទូលដែលព្រះយេហូវ៉ាបានថ្លែងទៅកាន់អ័ដាម និងអេវ៉ា ដែលត្រូវបានចាញ់បញ្ឆោតសត្វពស់ ហើយប្រើប្រាស់ព្រះបន្ទូលទាំងនោះនៅក្នុងកិច្ចការនៃការយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់ តើព្រះយេស៊ូវមិនត្រូវស្រឡាញ់ភរិយារបស់ទ្រង់តាមការគួរទេឬអី? បើបែបនេះ តើព្រះជាម្ចាស់នឹងនៅតែជាព្រះជាម្ចាស់ឬ? ហើយបើវាដូច្នេះ តើទ្រង់នៅតែអាចសម្រេចកិច្ចការរបស់ទ្រង់ដែរឬទេ? ប្រសិនបើការដែលព្រះយកកំណើត ជា

មនុស្សស្រី គឺជារឿងខុស ដូច្នេះតើការដែលព្រះជាម្ចាស់បានបង្កើតឲ្យមានស្ត្រីមកនោះ វាមិនមែនជាកំហុសដ៏ធំបំផុតទេឬអី? ប្រសិនបើមនុស្សនៅតែជឿថា ការដែលព្រះយកកំណើតជាស្ត្រី គឺជារឿងខុស ដូច្នេះ តើព្រះយេស៊ូវដែលមិនបានរៀបការ ហើយមិនអាចស្រឡាញ់ភរិយារបស់ទ្រង់បាននោះ មិនមានកំហុសជាច្រើន ដូចជាការយកកំណើតជាមនុស្សនាពេលបច្ចុប្បន្នដែរទេឬអី? ដោយសារតែអ្នកប្រើព្រះបន្ទូលដែលព្រះយេហូវ៉ាបានថ្លែងទៅកាន់នាងអេវ៉ា ដើម្បីវាស់ស្ទង់សេចក្ដីពិតនៃការយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់នៅក្នុងពេលបច្ចុប្បន្ន ដូច្នេះ អ្នកត្រូវប្រើព្រះបន្ទូលរបស់ព្រះយេហូវ៉ាទៅកាន់អ័ដាម មកវិនិច្ឆ័យព្រះអម្ចាស់យេស៊ូវ ដែលបានក្លាយជាសាច់ឈាមនៅក្នុងយុគសម័យនៃព្រះគុណដែរ។ តើការទាំងនេះមិនមែនតែមួយ និងដូចគ្នាទេឬអី? ដោយសារតែអ្នកយកខ្នាតរង្វាស់របស់ព្រះអម្ចាស់យេស៊ូវ ស្របតាមបុរសភេទដែលមិនត្រូវបានចាញ់បញ្ឆោតដោយសត្វពស់ ដូច្នេះ អ្នកមិនអាចវិនិច្ឆ័យសេចក្ដីពិតនៃការយកកំណើតជាមនុស្សនាពេលសព្វថ្ងៃ ស្របតាមស្ត្រីដែលត្រូវបានចាញ់បញ្ឆោតសត្វពស់ឡើយ។ ការធ្វើបែបនេះ គឺវាមិនយុត្តិធម៌ឡើយ! ការវាស់ស្ទង់ព្រះជាម្ចាស់តាមរបៀបនេះបញ្ជាក់ឲ្យឃើញថា អ្នកខ្វះនូវវិចារណញ្ញាណហើយ។ នៅពេលដែលព្រះយេហូវ៉ា បានក្លាយជាសាច់ឈាមចំនួនពីរដង ភេទនៃសាច់ឈាមរបស់ទ្រង់ពាក់ព័ន្ធនឹងភេទបុរសនិងភេទស្រី ដែលមិនត្រូវបានចាញ់បញ្ឆោតសត្វពស់ ហើយវាស្របតាមបុរស និងស្ត្រី ដែលមិនត្រូវបានចាញ់បញ្ឆោតសត្វពស់ នាំឲ្យទ្រង់បានក្លាយជាសាច់ឈាមចំនួនពីរដង។ សូមកុំគិតថា ភេទជាបុរសរបស់ព្រះយេស៊ូវ មានលក្ខណៈដូចជាបុរសភេទរបស់អ័ដាម ដែលត្រូវបានចាញ់បញ្ឆោតសត្វពស់នោះឡើយ។ អ្នកទាំងពីរមានលក្ខណៈខុសគ្នាស្រឡះ ព្រោះអ្នកទាំងពីរមានបុរសភេទចេញពីនិស្ស័យពីរខុសគ្នា។ ច្បាស់ណាស់ បុរសភេទរបស់ព្រះយេស៊ូវមិនអាចបញ្ជាក់បានថា ទ្រង់ជាក្បាលរបស់ស្ត្រីទាំងអស់ឡើយ ប៉ុន្តែមិនមែនជាក្បាលរបស់បុរសទាំងអស់? តើទ្រង់មិនមែនជាស្ដេចរបស់សាសន៍យូដាគ្រប់រូប (រួមទាំងបុរសនិងស្ត្រី) ទេឬអី? ទ្រង់ជាព្រះជាម្ចាស់ផ្ទាល់ មិនមែនគ្រាន់តែជាក្បាលរបស់ស្ត្រីទេ ប៉ុន្តែក៏ជា

ក្បាលរបស់បុរសផងដែរ។ ទ្រង់ជាព្រះអម្ចាស់នៃគ្រប់សត្តនិករ និងជាក្បាលនៃគ្រប់សត្តនិករ។ តើអ្នកអាចកំណត់ភាពជាបុរសរបស់ព្រះយេស៊ូវ ឲ្យក្លាយជានិមិត្តសញ្ញានៃក្បាលរបស់ស្ត្រី បានដោយរបៀបណា? តើការនេះមិនប្រមាថព្រះជាម្ចាស់ទេឬអី? ព្រះយេស៊ូវជាបុរសម្នាក់ដែលមិនត្រូវបានពុករលួយឡើយ។ ទ្រង់ជាព្រះជាម្ចាស់។ ទ្រង់ជាព្រះគ្រីស្ទ។ ទ្រង់ជាព្រះអម្ចាស់។ តើទ្រង់អាចធ្វើជាបុរស ដូចអ័ដាមដែលត្រូវបានពុករលួយដោយរបៀបណា? ព្រះយេស៊ូវគឺជាសាច់ឈាម ដែលត្រូវបានគ្រងដោយព្រះវិញ្ញាណដ៏បរិសុទ្ធបំផុតរបស់ព្រះជាម្ចាស់។ តើអ្នកអាចនិយាយថា ទ្រង់ជាព្រះជាម្ចាស់ ដែលមានភាពជាបុរសរបស់អ័ដាមបានដោយរបៀបណា? នៅក្នុងករណីនេះ តើគ្រប់កិច្ចការទាំងអស់របស់ព្រះជាម្ចាស់ មិនក្លាយជាខុសទេឬអី? តើព្រះយេហូវ៉ាបានដាក់បញ្ចូលភាពជាបុរសរបស់អ័ដាម ដែលត្រូវបានចាញ់បញ្ឆោតសត្វពស់ មកក្នុងព្រះយេស៊ូវបានដែរឬទេ? តើការយកកំណើតជាមនុស្សនាពេលបច្ចុប្បន្ន មិនមែនជាឧទាហរណ៍មួយទៀតអំពីកិច្ចការរបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស ដែលមានភេទខុសគ្នាពីព្រះយេស៊ូវ ប៉ុន្តែមាននិស្ស័យដូចទ្រង់ទេឬអី? តើអ្នកនៅតែហ៊ាននិយាយថា ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស មិនអាចក្លាយជាស្ត្រីដោយសារតែស្ត្រី គឺជាមនុស្សដំបូងគេដែលត្រូវបានចាញ់បញ្ឆោតសត្វពស់ឬ? តើអ្នកនៅតែហ៊ាននិយាយថា ព្រះជាម្ចាស់មិនអាចក្លាយជាសាច់ឈាមជាស្ត្រី ដោយសារតែស្ត្រីមានភាពស្មោកគ្រោកបំផុត និងជាប្រភពនៃសេចក្តីពុករលួយរបស់មនុស្សជាតិឬ? តើអ្នកនៅតែហ៊ានទទូចក្នុងការនិយាយថា «ស្ត្រីនឹងត្រូវស្តាប់បង្គាប់បុរសជានិច្ច ហើយគេមិនអាចស្តែងចេញ ឬតំណាងឲ្យព្រះជាម្ចាស់ដោយផ្ទាល់» បានទេឬ? កាលពីអតីតកាល អ្នកមិនបានយល់ឡើយ ប៉ុន្តែឥឡូវនេះ តើអ្នកអាចបន្តប្រមាថកិច្ចការរបស់ព្រះជាម្ចាស់ ជាពិសេសសាច់ឈាម ដែលយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់ទៀតឬ? ប្រសិនបើអ្នកនៅមិនទាន់ច្បាស់អំពីការនេះ យកល្អអ្នកគួរតែប្រយ័ត្នអណ្តាតរបស់អ្នកទៅ ក្រែងលោភាពល្ងីល្ងើ និងភាពអវិជ្ជារបស់អ្នកត្រូវបង្ហាញចេញមក ហើយភាពស្មោកគ្រោករបស់អ្នកត្រូវលាតត្រដាង។ សូមកុំគិតថា អ្នកយល់គ្រប់ទាំងសេចក្តី

នោះឡើយ។ ខ្ញុំសូមប្រាប់អ្នកថា រាល់អ្វីៗដែលអ្នកបានមើលឃើញ និងបានឆ្លងកាត់នៅមិនទាន់គ្រប់គ្រាន់ឲ្យអ្នកយល់បានឡើយ សូម្បីតែមួយភាគមួយពាន់នៃផែនការគ្រប់គ្រងរបស់ខ្ញុំក៏មិនបានផង។ ដូច្នេះ ហេតុអ្វីបានជាអ្នកធ្វើខ្លួនដូចជាក្រអឺតក្រទមម្ល៉េះ? ទេពកោសល្យដ៏ស្តួចស្តើង និងចំណេះដឹងបន្តិចបន្តួចដែលអ្នកមាននោះ មិនល្មមនឹងឲ្យព្រះយេស៊ូវប្រើនៅក្នុងកិច្ចការរបស់ទ្រង់បានឡើយ សូម្បីតែក្នុងពេលមួយវិនាទីក៏មិនបានផង! តើអ្នកមានបទពិសោធច្រើនប៉ុនណាទៅ? អ្វីដែលអ្នកបានឃើញ និងគ្រប់ទាំងសេចក្តីដែលអ្នកបានស្តាប់ឮនៅក្នុងជីវិតរបស់អ្នក និងអ្វីដែលអ្នកបានស្រមើស្រមៃមានកម្រិតតិចជាងកិច្ចការដែលខ្ញុំធ្វើក្នុងពេលមួយភ្លែតទៅទៀត! អ្នកពូកែតែខាងរកមើល និងពូកែខាងចាប់កំហុសរបស់គេប៉ុណ្ណោះ។ អ្នកអាចក្រអឺតក្រទមតាមតែអ្នកចង់ធ្វើទៅចុះ ប៉ុន្តែអ្នកគ្មានតម្លៃអ្វីក្រៅពីជាសត្វមួយក្បាលដែលមិនស្មើនឹងសត្វស្រមោចមួយផង! អ្វីៗដែលអ្នកមាននៅក្នុងពោះរបស់អ្នក គឺអន់ជាងអ្វីដែលមាននៅក្នុងពោះរបស់សត្វស្រមោចទៅទៀត! កុំដោយសារតែអ្នកបានទទួលបទពិសោធនិងអតីតភាពខ្លះ ធ្វើឲ្យអ្នកគិតថា អ្នកមានសិទ្ធិឆ្កាដៃឆ្កាជើង ហើយនិយាយទាំងក្អេងក្អាងនោះ។ តើបទពិសោធ និងអតីតភាពរបស់អ្នក មិនមែនជាលទ្ធផលកើតចេញពីព្រះបន្ទូលដែលខ្ញុំបានថ្លែងទេឬអី? តើអ្នកជឿថា អ្នកទទួលបានការទាំងនេះ ដោយចេញពីកម្លាំង និងសេចក្តីព្យាយាមរបស់អ្នកមែនទេ? សព្វថ្ងៃនេះ អ្នកមើលឃើញថា ខ្ញុំបានត្រលប់ជាសាច់ឈាម ហើយជាលទ្ធផលតាំងពីពេលនោះ នៅក្នុងអ្នកក៏កើតមាននូវគោលគំនិតដ៏ច្រើនហួសប្រមាណ ហើយមានសញ្ញាណមិនចេះចប់ឡើយ។ បើមិនមែនសម្រាប់ការយកកំណើតជាមនុស្សរបស់ខ្ញុំទេ បើទោះជាអ្នកមានទេពកោសល្យដ៏អស្ចារ្យយ៉ាងណាក៏ដោយ ក៏អ្នកនឹងគ្មានគោលគំនិតដ៏ច្រើនបែបនេះដែរ។ តើសញ្ញាណរបស់អ្នកមិនមែនកើតចេញមកពីទេពកោសល្យទាំងនេះទេឬអី? ប្រសិនបើព្រះយេស៊ូវមិនបានក្លាយជាសាច់ឈាមជាលើកដំបូងទេ តើអ្នកនឹងដឹងអំពីការយកកំណើតជាមនុស្សដែរឬទេ? តើមិនមែនដោយសារតែការយកកំណើតជាមនុស្សលើកទីមួយបានផ្តល់ឲ្យអ្នកមានចំណេះដឹងថា អ្នកព្យាយាមវិនិច្ឆ័យការយកកំណើតជាមនុស្សលើក

ទីពីររបស់ទ្រង់ ដោយឥតអៀនខ្មាសទេឬអី? ហេតុអ្វីបានជាអ្នកព្រមដាក់ខ្លួនរៀនសូត្រពីការនេះ តែមិនព្រមធ្វើខ្លួនជាអ្នកដើរតាមដែលស្ដាប់បង្គាប់ម្នាក់ដូច្នេះ? នៅពេលដែលអ្នកបានចូលទៅក្នុងចរន្តនេះ ហើយចូលមកនៅចំពោះព្រះដែលយកកំណើតជាមនុស្ស តើទ្រង់នឹងអនុញ្ញាតឲ្យអ្នកស្រាវជ្រាវអំពីទ្រង់ដែរឬទេ? អ្នកអាចស្រាវជ្រាវអំពីប្រវត្តិសាស្ត្រគ្រួសាររបស់អ្នកបាន ប៉ុន្តែប្រសិនបើអ្នកព្យាយាមស្រាវជ្រាវអំពី «ប្រវត្តិគ្រួសារ» របស់ព្រះជាម្ចាស់ តើព្រះជាម្ចាស់នាពេលសព្វថ្ងៃ នឹងអនុញ្ញាតឲ្យអ្នកធ្វើការសិក្សាបែបនេះដែរឬទេ? តើអ្នកមិនខ្វាក់ភ្នែកទេឬអី? តើអ្នកមិនយកការមាក់ងាយមកដាក់ខ្លួនអ្នកទេឬអី?

ប្រសិនបើកិច្ចការរបស់ព្រះយេស៊ូវត្រូវបានសម្រេច ហើយមិនត្រូវបានបំពេញបន្ថែម ដោយកិច្ចការនៅក្នុងដំណាក់កាលនៃគ្រាចុងក្រោយនេះ នោះមនុស្សនឹងប្រកាន់ខ្ជាប់ជារៀងរហូតនូវសញ្ញាណថា មានតែព្រះយេស៊ូវមួយប៉ុណ្ណោះ ទើបជាព្រះរាជបុត្រាតែមួយរបស់ព្រះជាម្ចាស់ ពោលគឺ មនុស្សគិតថា ព្រះជាម្ចាស់មានព្រះរាជបុត្រាតែមួយគត់ និងគិតទៀតថា មនុស្សផ្សេងទៀតដែលមកតាមក្រោយដោយមាននាមផ្សេងនឹងមិនមែនជាព្រះរាជបុត្រាតែមួយរបស់ព្រះជាម្ចាស់ ក៏រឹតតែមិនមែនជាព្រះជាម្ចាស់ផ្ទាល់នោះឡើយ។ មនុស្សមានសញ្ញាណថា អស់អ្នកណាដើរតួជាតង្វាយលោះបាប ឬដែលមានឫទ្ធានុភាពជំនួសឲ្យព្រះជាម្ចាស់ និងប្រោសលោះមនុស្សជាតិទាំងអស់ គឺជាព្រះរាជបុត្រាតែមួយគត់របស់ព្រះជាម្ចាស់។ មានអ្នកខ្លះដែលជឿថា លុះត្រាតែព្រះដែលយាងមកនោះជាបុរស ទើបទ្រង់អាចត្រូវបានចាត់ទុកជាព្រះរាជបុត្រាតែមួយរបស់ព្រះជាម្ចាស់ និងជាអ្នកតំណាងរបស់ព្រះជាម្ចាស់។ មនុស្សខ្លះទៀតថែមទាំងនិយាយថា ព្រះយេស៊ូវជាព្រះរាជបុត្រារបស់ព្រះយេហូវ៉ា ជាបុត្រាតែមួយគត់របស់ទ្រង់ទៀតផង។ តើសញ្ញាណបែបនេះមិនមែនជាការបំផ្លើសពេកទេឬអី? ប្រសិនបើដំណាក់កាលនៃកិច្ចការនេះមិនត្រូវបានសម្រេចនៅក្នុងដំណាក់កាលចុងក្រោយទេ នោះមនុស្សជាតិទាំងមូលនឹងត្រូវគ្របបាំងក្រោមស្រមោលអន្ធការចំពោះព្រះជាម្ចាស់មិនខាន។ ប្រសិនបើវាបែបនេះ នោះមនុស្ស

ប្រុសនឹងគិតថា ខ្លួនមានឋានៈខ្ពស់ជាងស្ត្រី ហើយស្ត្រីនឹងមិនអាចងើបក្បាលឡើងបានឡើយ ដូច្នេះ វានឹងគ្មានស្ត្រីណាម្នាក់អាចទទួលបានការសង្គ្រោះនោះឡើយ។ មនុស្សតែងតែជឿថា ព្រះជាម្ចាស់ជាបុរស ហើយលើសពីនេះទៅទៀត គេជឿថា ទ្រង់តែងតែស្អប់ខ្ពើមស្ត្រី ហើយមិនប្រទានសេចក្ដីសង្គ្រោះដល់នាងឡើយ។ ប្រសិនបើបែបនេះមែន តើវាមិនមែនជាការពិតទេឬអីថា គ្រប់ស្ត្រីទាំងអស់ដែលត្រូវបានបង្កើតមក ដោយព្រះយេហូវ៉ា និងដែលត្រូវបានពុកខូចផងនោះ នឹងមិនមានឱកាសទទួលបាននូវការសង្គ្រោះ? បើដូច្នេះ តើការដែលព្រះយេហូវ៉ាបានបង្កើតស្ត្រីមក ពោលគឺបានបង្កើតនាងអេវ៉ាមក មិនទៅជាឥតប្រយោជន៍ទេឬអី? ហើយតើស្ត្រីនឹងមិនត្រូវវិនាសអស់កល្បជានិច្ចទេឬអី? ព្រោះតែហេតុផលនេះ ដំណាក់កាលនៃកិច្ចការនៅគ្រាចុងក្រោយ គឺត្រូវធ្វើឡើងដើម្បីសង្គ្រោះមនុស្សជាតិទាំងអស់ គឺមិនមែនសម្រាប់តែស្ត្រីប៉ុណ្ណោះឡើយ។ ប្រសិនបើនរណាម្នាក់គិតថា បើព្រះជាម្ចាស់ត្រូវតែយកកំណើតជាមនុស្សជាស្ត្រី ហើយការនេះ ធ្វើឡើងសម្រាប់ជាប្រយោជន៍ដល់ការសង្គ្រោះស្ត្រីប៉ុណ្ណោះ នោះបុគ្គលនោះនឹងប្រាកដជាមនុស្សល្ងីល្ងើមិនខាន!

កិច្ចការសព្វថ្ងៃបានរុញច្រានកិច្ចការនាយុគសម័យនៃព្រះគុណឲ្យឆ្ពោះទៅមុខ មានន័យថា កិច្ចការដែលស្ថិតនៅក្រោមផែនការគ្រប់គ្រងរយៈពេលប្រាំមួយពាន់ឆ្នាំទាំងមូល ក៏បានបន្តទៅមុខទៀតហើយ។ ទោះបីជាយុគសម័យនៃព្រះគុណបានបញ្ចប់ក៏ដោយ ប៉ុន្តែវឌ្ឍនភាពនៅក្នុងកិច្ចការរបស់ព្រះជាម្ចាស់ ក៏នៅតែមានដែរ។ ហេតុអ្វីបានជាខ្ញុំនិយាយម្ដងទៀតថា ដំណាក់កាលនៃកិច្ចការនេះ សង់ឡើងនៅលើយុគសម័យនៃព្រះគុណ និងយុគសម័យនៃក្រឹត្យវិន័យ? នោះគឺដោយសារតែកិច្ចការនាពេលសព្វថ្ងៃ គឺជាការបន្តនូវកិច្ចការដែលបានធ្វើរួចហើយ នៅក្នុងយុគសម័យនៃព្រះគុណ និងជាវឌ្ឍនភាពលើកិច្ចការដែលបានធ្វើរួច នៅក្នុងយុគសម័យនៃក្រឹត្យវិន័យ។ ដំណាក់កាលទាំងបីនេះ មានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមកយ៉ាងស្អិតរមួត គឺដូចជាតំណមួយៗនៅក្នុងច្រវាក់ដែលប្រទាក់គ្នាយ៉ាងណែនដូច្នោះដែរ។ ហេតុអ្វីបានជាខ្ញុំនិយាយថា ដំណាក់កាលនៃកិច្ចការនេះសង់ឡើងនៅលើកិច្ចការដែលព្រះយេស៊ូវ

បានធ្វើដែរ? ឧបមាថា ដំណាក់កាលនេះមិនត្រូវបានសាងលើកិច្ចការដែលព្រះយេស៊ូវបានធ្វើ នោះការជាប់ឆ្កាងមួយទៀតនឹងត្រូវកើតឡើងនៅក្នុងដំណាក់កាលនេះ ហើយកិច្ចការប្រោសលោះនៃដំណាក់កាលមុននឹងត្រូវធ្វើឡើងម្តងទៀតមិនខាន។ ការនេះនឹងទៅជាគ្មានន័យ។ ដូច្នេះ មិនមែនថា កិច្ចការនោះត្រូវបានបញ្ចប់ទាំងស្រុងឡើយ ប៉ុន្តែយុគសម័យនោះបានបន្តទៅមុខ ហើយកម្រិតនៃកិច្ចការនោះ ក៏ត្រូវលើកឡើងកាន់តែខ្ពស់ ជាងពេលមុនទៅទៀត។ អាចនិយាយបានថា ដំណាក់កាលនៃកិច្ចការនេះត្រូវបានសង់ឡើងនៅលើគ្រឹះមូលដ្ឋាននាយុគសម័យនៃក្រឹត្យវិន័យ និងលើថ្មដានៃកិច្ចការរបស់ព្រះយេស៊ូវ។ កិច្ចការរបស់ព្រះជាម្ចាស់ ត្រូវបានសាងឡើង ពីមួយដំណាក់កាលទៅមួយដំណាក់កាល ហើយដំណាក់កាលនេះមិនមែនជាការចាប់ផ្តើមថ្មីនោះឡើយ។ មានតែបន្សំគ្នានៃដំណាក់កាលនៃកិច្ចការទាំងបីប៉ុណ្ណោះ ទើបអាចត្រូវបានចាត់ទុកជាផែនការគ្រប់គ្រងរយៈពេលប្រាំមួយពាន់ឆ្នាំបាន។ កិច្ចការនៃដំណាក់កាលនេះ ត្រូវបានធ្វើឡើងលើគ្រឹះមូលដ្ឋាននៃកិច្ចការក្នុងយុគសម័យនៃព្រះគុណ។ ប្រសិនបើដំណាក់កាលនៃកិច្ចការទាំងពីរនេះមិនទាក់ទងគ្នាទេ ចុះហេតុអ្វីបានជាការជាប់ឆ្កាង មិនកើតឡើងម្តងទៀតនៅក្នុងដំណាក់កាលនេះទៅ? ហេតុអ្វីបានជាខ្ញុំមិនទទួលយកបាបរបស់មនុស្ស ប៉ុន្តែបែរជាយាងមកជំនុំជម្រះ និងកាត់ទោសមនុស្សដោយផ្ទាល់ទៅវិញ? ប្រសិនបើកិច្ចការជំនុំជម្រះ និងវាយផ្ចាលមនុស្សរបស់ខ្ញុំ មិនបានធ្វើតាមការជាប់ឆ្កាង ដោយរួមជាមួយការយាងមករបស់ខ្ញុំក្នុងពេលបច្ចុប្បន្ន មិនមែនចាប់កំណើតដោយព្រះវិញ្ញាណបរិសុទ្ធទេ នោះខ្ញុំនឹងគ្មានគុណសម្បត្តិគ្រប់គ្រាន់ដើម្បីជំនុំជម្រះ និងវាយផ្ចាលមនុស្សឡើយ។ ប្រាកដណាស់ ដោយសារតែខ្ញុំគឺជាអង្គតែមួយជាមួយព្រះយេស៊ូវ ទើបខ្ញុំចុះមកដោយផ្ទាល់ ដើម្បីវាយផ្ចាល និងជំនុំជម្រះមនុស្ស។ កិច្ចការនៅដំណាក់កាលនេះត្រូវបានសាងឡើងទាំងស្រុងពីលើកិច្ចការនៅដំណាក់កាលមុន។ នេះគឺជាហេតុផលដែលបញ្ជាក់ថា មានតែកិច្ចការប្រភេទនេះប៉ុណ្ណោះដែលអាចនាំមនុស្សទៅរកសេចក្តីសង្គ្រោះ មួយជំហានម្តងៗបាន។ ព្រះយេស៊ូវហើយនិងខ្ញុំ ចេញមកពីព្រះវិញ្ញាណតែមួយ។ ទោះបីយើងដាច់ឡែកនៅក្នុងសាច់

ឈាមរបស់យើងក៏ដោយ ក៏ព្រះវិញ្ញាណរបស់យើងតែមួយដដែល។ ទោះបីខ្លឹមសារនៃអ្វីដែលយើងធ្វើ ហើយកិច្ចការដែលយើងរ៉ាប់រង មិនដូចគ្នាក៏ដោយ ប៉ុន្តែយើងមានសារជាតិដូចគ្នា។ សាច់ឈាមរបស់យើងមានទម្រង់ខុសគ្នា នេះដោយសារតែការផ្លាស់ប្ដូរនៅក្នុងសម័យកាល និងលក្ខខណ្ឌតម្រូវខុសគ្នានៃកិច្ចការយើងប៉ុណ្ណោះ។ ព័ន្ធកិច្ចរបស់យើងក៏មិនដូចគ្នាដែរ ដូច្នេះកិច្ចការដែលយើងនាំមក ហើយនិស្ស័យដែលយើងបើកសម្ដែងទៅកាន់មនុស្សក៏ខុសគ្នាដែរ។ នោះជាហេតុផលដែលនាំឲ្យអ្វីដែលមនុស្សមើលឃើញ និងយល់នៅសម័យនេះ មានលក្ខណៈខុសពីអតីតកាល គឺដោយសារតែការផ្លាស់ប្ដូរនៅក្នុងយុគសម័យនេះហើយ។ ដ្បិតពួកទ្រង់មានលក្ខណៈខុសគ្នាទាំងភេទ និងទម្រង់នៃសាច់ឈាមរបស់ពួកទ្រង់ ហើយពួកទ្រង់ក៏មិនកើតចេញពីគ្រួសារដូចគ្នាដែរ ចំណែកឯអំឡុងពេលវិញ ក៏ខុសគ្នាទៀតនោះ តែយ៉ាងណាក៏ពួកទ្រង់មានព្រះវិញ្ញាណតែមួយដែរ។ ទោះបីជាសាច់ឈាមរបស់ពួកទ្រង់មិនមានឈាមជ័រតែមួយឬជាសាច់ញាតិបងប្អូនដូចគ្នាក៏ដោយ ក៏មិនអាចបដិសេធថា ពួកទ្រង់មិនមែនជាសាច់ឈាមដែលយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់ នៅក្នុងសម័យកាលពេលពីរផ្សេងគ្នានោះឡើយ។ ការដែលពួកទ្រង់ជាសាច់ឈាមដែលយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់ គឺជាសេចក្តីពិតដែលមិនអាចប្រកែកបាន។ យ៉ាំងណាក្តីពួកទ្រង់មិនមានពង្សាវតារដូចគ្នា និងមិនមានភាសាមនុស្សតែមួយដូចគ្នាក៏ដោយ (ម្នាក់ជាបុរសដែលនិយាយភាសាសាសន៍យូដា ហើយម្នាក់ទៀតជាស្ត្រីដែលនិយាយតែភាសាចិនប៉ុណ្ណោះ)។ គឺដោយសារតែហេតុផលទាំងនេះហើយ ទើបពួកទ្រង់បានរស់នៅក្នុងប្រទេសខុសគ្នា ដើម្បីធ្វើកិច្ចការដ៏សមគួរដែលអង្គនីមួយៗត្រូវធ្វើ និងនៅក្នុងសម័យកាលខុសគ្នាផងដែរ។ ទោះបីជាការពិត ពួកទ្រង់មានព្រះវិញ្ញាណតែមួយ ព្រមទាំងមានសារជាតិដូចគ្នាក៏ដោយ ក៏ភាពដូចគ្នាទាំងស្រុងរវាងសំបកក្រៅនៃសាច់ឈាមរបស់ពួកទ្រង់ គឺពុំមាននោះឡើយ។ គ្រប់យ៉ាងដែលពួកទ្រង់ដូចគ្នា គឺជាភាពជាមនុស្សដូចគ្នា ប៉ុន្តែបើនិយាយដល់រូបរាងខាងក្រៅនៃសាច់ឈាមរបស់ពួកទ្រង់ និងកាលៈទេសៈ នៃការចាប់កំណើតរបស់ពួកទ្រង់វិញ គឺមិនដូចគ្នានោះឡើយ។

ចំណុចទាំងនេះ គ្មានឥទ្ធិពលអ្វីទៅលើកិច្ចការរបស់ពួកទ្រង់ ឬទៅលើចំណេះដឹងដែលមនុស្សមានអំពីពួកទ្រង់ឡើយ ដ្បិតនៅក្នុងការវិភាគចុងក្រោយ ពួកទ្រង់ជាព្រះវិញ្ញាណដូចគ្នា ហើយគ្មាននរណាម្នាក់អាចបំបែកពួកទ្រង់ចេញពីគ្នាបានឡើយ។ ទោះបីជាពួកទ្រង់មិនមានឈាមជ័រដូចគ្នាក៏ដោយ ក៏អត្ថិភាពទាំងស្រុងរបស់ពួកទ្រង់ គ្រប់គ្រងព្រះវិញ្ញាណរបស់ពួកទ្រង់ ជាព្រះវិញ្ញាណដែលបែងចែកកិច្ចការផ្សេងៗទៅកាន់ពួកទ្រង់នៅក្នុងសម័យកាលខុសគ្នា និងសាច់ឈាមរបស់ពួកទ្រង់ក៏មានទៅតាមពង្សាវតារនៃឈាមជ័រខុសគ្នាដែរ។ ព្រះវិញ្ញាណរបស់ព្រះយេហូវ៉ា មិនមែនជាបិតានៃព្រះវិញ្ញាណរបស់ព្រះយេស៊ូវឡើយ ហើយព្រះវិញ្ញាណរបស់ព្រះយេស៊ូវ ក៏មិនមែនជាបុត្រារបស់ព្រះវិញ្ញាណនៃព្រះយេហូវ៉ានោះដែរ៖ ពួកទ្រង់ជាព្រះវិញ្ញាណតែមួយ និងដូចគ្នា។ ដូចគ្នាដែរ ព្រះដែលយកកំណើតជាមនុស្សសព្វថ្ងៃ និងព្រះយេស៊ូវ មិនមានឈាមជ័រដូចគ្នាឡើយ ប៉ុន្តែពួកទ្រង់គឺតែមួយ នោះគឺដោយសារតែព្រះវិញ្ញាណរបស់ពួកទ្រង់តែមួយ។ ព្រះជាម្ចាស់អាចធ្វើកិច្ចការនៃសេចក្តីមេត្តាករុណា និងសេចក្តីស្រឡាញ់ដ៏សប្បុរស ក៏ដូចជាធ្វើកិច្ចការនៃការជំនុំជម្រះ និងការកាត់ទោសដ៏សុចរិតចំពោះមនុស្ស និងកិច្ចការនៃការដាក់បណ្ដាសាមនុស្ស។ ហើយនៅចុងបញ្ចប់ ទ្រង់អាចធ្វើកិច្ចការបំផ្លាញពិភពលោក និងកិច្ចការដាក់ទោសមនុស្សទុច្ចរិតផងដែរ។ តើទ្រង់មិនធ្វើកិច្ចការទាំងអស់នេះដោយអង្គឯងទេឬអី? តើនេះមិនមែនជាព្រះដ៏មានសព្វានុភាពទេឬអី? ទ្រង់អាចប្រកាសឲ្យមនុស្សប្រើច្បាប់ និងចេញជាសេចក្តីបង្គាប់ទៅកាន់គេ ហើយទ្រង់ក៏អាចដឹកនាំអ៊ីស្រាអែលជំនាន់មុន ឲ្យរស់នៅជីវិតរបស់គេនៅលើផែនដី និងដឹកនាំពួកគេនៅក្នុងការសាងសង់ព្រះវិហារ និងទីអាសនា ព្រមទាំងដាក់ពួកអ៊ីស្រាអែលទាំងអស់ ឲ្យនៅក្រោមអំណាចគ្រប់គ្រងរបស់ទ្រង់ផងដែរ។ ដោយសារតែសិទ្ធិអំណាចរបស់ទ្រង់ ព្រះអង្គបានរស់នៅលើផែនដីជាមួយប្រជាជនអ៊ីស្រាអែល អស់រយៈពេលពីរពាន់ឆ្នាំ។ ពួកអ៊ីស្រាអែលមិនហ៊ានបះបោរប្រឆាំងនឹងទ្រង់ឡើយ គ្រប់គ្នាបានគោរពកោតខ្លាចព្រះយេហូវ៉ា និងកាន់តាមបទបញ្ញត្តិរបស់ទ្រង់។ នេះគឺជាកិច្ចការដែលត្រូវបានធ្វើឡើង ដោយគុណធម៌នៃសិទ្ធិអំណាចរបស់ទ្រង់ និងសព្វានុភាពរបស់ទ្រង់។

បន្ទាប់មក ក្នុងអំឡុងយុគសម័យនៃព្រះគុណ ព្រះយេស៊ូវបានយាងមក ដើម្បីប្រោសលោះមនុស្សជាតិដែលធ្លាក់ចុះទាំងអស់ (មិនមែនគ្រាន់តែ ប្រជាជនអ៊ីស្រាអែលប៉ុណ្ណោះទេ)។ ទ្រង់បានបង្ហាញសេចក្ដីមេត្តាករុណា និងសេចក្ដីស្រឡាញ់ដ៏សប្បុរសទៅកាន់មនុស្ស។ ព្រះយេស៊ូវ ដែលមនុស្សបានឃើញនៅក្នុងយុគសម័យនៃព្រះគុណបានពេញដោយ សេចក្ដីស្រឡាញ់ដ៏សប្បុរស និងតែងតែស្រឡាញ់មនុស្សជានិច្ច ព្រោះថាទ្រង់បានយាងមកដើម្បីសង្គ្រោះមនុស្សជាតិឲ្យរួចពីបាប។ ទ្រង់អាចអត់ទោសមនុស្សឲ្យរួចពីបាបរបស់គេបាន លុះត្រាតែការជាប់ឆ្កាងរបស់ទ្រង់ បានប្រោសលោះមនុស្សជាតិពីអំពើបាបទាំងស្រុង។ ក្នុងអំឡុងពេលនេះ ព្រះជាម្ចាស់បានបង្ហាញអង្គទ្រង់ នៅមុខមនុស្សជាមួយសេចក្ដីមេត្តាករុណា និងសេចក្ដីស្រឡាញ់ដ៏សប្បុរស មានន័យថា ទ្រង់បានក្លាយជាតង្វាយលោះបាបសម្រាប់មនុស្ស និងត្រូវបានជាប់ឆ្កាងដោយព្រោះអំពើបាបរបស់មនុស្ស ដើម្បីឲ្យពួកគេទទួលបានការអត់ទោសជារៀងរហូត។ ទ្រង់ពេញដោយសេចក្ដីមេត្តាករុណា សេចក្ដីអាណិតអាសូរ ព្រះទ័យអត់ធ្មត់ និងព្រះទ័យស្រឡាញ់។ ហើយអស់អ្នកណា ដែលបានដើរតាមព្រះយេស៊ូវនៅក្នុងយុគសម័យនៃព្រះគុណ ក៏គួរតែមានចិត្តអត់ធ្មត់ និងសេចក្ដីស្រឡាញ់ក្នុងគ្រប់កិច្ចការទាំងអស់ផងដែរ។ ពួកគេមានចិត្តអំណត់ ហើយមិនដែលប្រយុទ្ធតបតវិញឡើយ ទោះបីពេលត្រូវគេវាយដំ ជេរប្រមាថ ឬគប់ដុំថ្មក៏ដោយ។ ប៉ុន្តែ ក្នុងអំឡុងពេលនៃដំណាក់កាលចុងក្រោយ វាលែងមានរឿងបែបនេះទៀតហើយ។ កិច្ចការរបស់ព្រះយេស៊ូវ និងព្រះយេហូវ៉ា មិនដូចគ្នាទាំងអស់នោះទេ ទោះបីជាពួកទ្រង់មានព្រះវិញ្ញាណតែមួយក៏ដោយ។ កិច្ចការរបស់ព្រះយេហូវ៉ា មិនបាននាំឲ្យយុគសម័យត្រូវបញ្ចប់ឡើយ ប៉ុន្តែទ្រង់បានដឹកនាំយុគសម័យ នាំផ្លូវជីវិតរបស់មនុស្សលោកនៅលើផែនដី ចំណែកឯកិច្ចការសព្វថ្ងៃវិញ គឺជាការយកឈ្នះមនុស្សនៅក្នុងប្រជាជាតិនៃសាសន៍ដទៃ ដែលត្រូវបានពុករលួយយ៉ាងជ្រៅ ហើយមិនគ្រាន់តែដឹកនាំពួកអ្នករើសតាំងរបស់ព្រះជាម្ចាស់ នៅក្នុងប្រទេសចិនប៉ុណ្ណោះទេ ប៉ុន្តែដឹកនាំចក្រវាលទាំងមូល និងមនុស្សជាតិទាំងអស់ផងដែរ។ អ្នកប្រហែលជាមើលឃើញថា កិច្ចការនេះកំពុងតែ

ត្រូវបានធ្វើតែនៅក្នុងប្រទេសចិនប៉ុណ្ណោះ ប៉ុន្តែតាមពិតទៅ វាបានចាប់ផ្ដើមរីកសាយទៅក្រៅប្រទេសចិនរួចស្រេចទៅហើយ។ ហេតុអ្វីបានជាមនុស្សនៅក្រៅប្រទេសចិនត្រូវស្វែងរកផ្លូវពិតជាថ្មីម្ដងទៀត? នោះគឺដោយសារតែព្រះវិញ្ញាណ បានចាប់ផ្ដើមធ្វើការរួចហើយ ហើយព្រះបន្ទូលដែលថ្លែងចេញនាពេលសព្វថ្ងៃ ត្រូវបានតម្រង់ឆ្ពោះទៅកាន់មនុស្សនៅទូទាំងសកលលោក។ ជាមួយការនេះ កិច្ចការពាក់កណ្ដាលបានកំពុងតែដំណើរការហើយ។ ចាប់តាំងពីកំណើតពិភពលោក រហូតមកដល់ពេលបច្ចុប្បន្ន ព្រះវិញ្ញាណនៃព្រះបានធ្វើឲ្យកិច្ចការដ៏អស្ចារ្យនេះ ដំណើរការហើយ ហើយលើសពីនេះទៅទៀត ទ្រង់បានធ្វើកិច្ចការផ្សេងៗនៅក្នុងយុគសម័យខុសៗគ្នា និងនៅក្នុងចំណោមប្រជាជាតិខុសៗគ្នាផងដែរ។ មនុស្សនៅតាមយុគសម័យនីមួយៗមើលឃើញពីនិស្ស័យខុសគ្នារបស់ទ្រង់ ដែលត្រូវបានបើកសម្ដែងដោយឯកឯង តាមរយៈកិច្ចការខុសគ្នាដែលទ្រង់ធ្វើ។ ទ្រង់ជាព្រះជាម្ចាស់ ដែលពេញដោយសេចក្ដីមេត្តាករុណា និងសេចក្ដីស្រឡាញ់ដ៏សប្បុរស។ ទ្រង់ជាតង្វាយលោះបាបសម្រាប់មនុស្ស និងជាអ្នកគង្វាលរបស់មនុស្ស។ ប៉ុន្តែ ទ្រង់ក៏ជាការជំនុំជម្រះ ការវាយផ្ចាល និងជាបណ្ដាសារបស់មនុស្សផងដែរ។ ទ្រង់អាចនាំមនុស្សឲ្យរស់នៅលើផែនដីអស់រយៈពេលពីរពាន់ឆ្នាំ ហើយទ្រង់ក៏អាចប្រោសលោះមនុស្សជាតិដែលពុករលួយចេញពីបាបបានផងដែរ។ សព្វថ្ងៃនេះ ទ្រង់ក៏អាចយកឈ្នះមនុស្សជាតិដែលមិនស្គាល់ទ្រង់ ហើយបង្ក្រាបពួកគេឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទ្រង់ផងដែរ ដើម្បីឱ្យមនុស្សទាំងអស់នឹងចុះចូលចំពោះទ្រង់ទាំងស្រុងមិនខាន។ ចុងបញ្ចប់ ទ្រង់នឹងដុតចោលរាល់អ្វីៗដែលមិនបរិសុទ្ធ និងមិនសុចរិតនៅក្នុងមនុស្សទូទាំងសកលលោក ដើម្បីបង្ហាញពួកគេថា ទ្រង់មិនគ្រាន់តែជាព្រះដ៏ពេញដោយសេចក្ដីមេត្តាករុណា និងគួរឲ្យស្រឡាញ់ មិនគ្រាន់តែជាព្រះនៃព្រះប្រាជ្ញាញាណ និងឫទ្ធិបារមី និងមិនគ្រាន់តែជាព្រះដ៏បរិសុទ្ធប៉ុណ្ណោះទេ ប៉ុន្តែលើសពីនេះ ទ្រង់ក៏ជាព្រះដែលជំនុំជម្រះមនុស្សផងដែរ។ ចំពោះមនុស្សទុច្ចរិតនៅក្នុងចំណោមមនុស្សជាតិ ទ្រង់កំពុងតែដុត ជំនុំជម្រះ និងដាក់ទោសចំពោះមនុស្សដែលត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍វិញ ទ្រង់ជាទុក្ខលំបាក ជាការ

បន្សុទ្ធ និងជាសេចក្ដីល្បងល ក៏ដូចជាការកម្សាន្តចិត្ត ការជួយទ្រទ្រង់ ការផ្ដត់ផ្ដង់នៃព្រះបន្ទូល ការដោះស្រាយ និងការកាត់តម្រឹមផងដែរ។ ហើយចំពោះមនុស្សដែលត្រូវបានផាត់ចោល ទ្រង់ជាការដាក់ទោស និងការសងសឹក។ សូមប្រាប់ខ្ញុំមើល៍ តើព្រះជាម្ចាស់មិនមែនជាព្រះដ៏ពេញដោយព្រះចេស្ដាទេឬអី? ទ្រង់មានសមត្ថភាពធ្វើគ្រប់កិច្ចការទាំងអស់ មិនមែនត្រឹមតែកិច្ចការជាប់ឆ្កាង ដូចដែលអ្នកស្រមៃនោះឡើយ។ អ្នកគិតថា ព្រះជាម្ចាស់អន់ដល់ម្ល៉ឹង! តើអ្នកជឿថា ទ្រង់អាចធ្វើបានត្រឹមការប្រោសលោះមនុស្សជាតិទាំងមូល តាមរយៈការជាប់ឆ្កាងរបស់ទ្រង់ប៉ុណ្ណឹងមែនទេ? ហើយក្រោយមកទៀត អ្នកនឹងដើរតាមទ្រង់ឡើងទៅស្ថានសួគ៌ ដើម្បីបរិភោគផលផ្លែពីដើមឈើនៃជីវិត និងផឹកទឹកពីទន្លេនៃជីវិតមែនទេ? ... តើវាអាចងាយស្រួលម្ល៉ឹងទេ? សូមប្រាប់ខ្ញុំមើល៍ តើអ្នកបានសម្រេចអ្វីខ្លះហើយ? តើអ្នកមានជីវិតរបស់ព្រះយេស៊ូវដែរឬទេ? ពិតណាស់ អ្នកត្រូវបានទ្រង់ប្រោសលោះមែន ប៉ុន្តែការជាប់ឆ្កាង គឺជាកិច្ចការរបស់ព្រះយេស៊ូវផ្ទាល់ព្រះអង្គទេ។ តើអ្នកបានសម្រេចភារកិច្ចអ្វីខ្លះហើយក្នុងនាមជាមនុស្សលោក? អ្នកគោរពកោតខ្លាចព្រះតែសំបកក្រៅប៉ុណ្ណោះ ប៉ុន្តែអ្នកមិនយល់អំពីផ្លូវរបស់ទ្រង់ឡើយ។ តើនេះជារបៀបដែលអ្នកស្ដែងឲ្យគេឃើញពីទ្រង់មែនទេ? ប្រសិនបើអ្នកមិនបានទទួលជីវិតរបស់ព្រះជាម្ចាស់ ឬមិនបានឃើញភាពពេញលេញ នៃនិស្ស័យសុចរិតរបស់ទ្រង់ទេ ដូច្នេះ អ្នកមិនអាចអះអាងថា ខ្លួនជាមនុស្សម្នាក់ដែលមានជីវិតបានឡើយ ហើយអ្នកក៏មិនសក្ដិសមនឹងដើរឆ្លងតាមទ្វារនៃនគរស្ថានសួគ៌នោះដែរ។

ព្រះជាម្ចាស់មិនគ្រាន់តែជាព្រះវិញ្ញាណប៉ុណ្ណោះទេ ទ្រង់ក៏អាចត្រលប់ជាសាច់ឈាមបានដែរ។ លើសពីនេះទៅទៀត ទ្រង់ជារូបកាយនៃសិរីល្អមួយ។ ព្រះយេស៊ូវត្រូវបានប្រជាជនអ៊ីស្រាអែល ដែលជាសាសន៍យូដានាសម័យនោះឃើញផ្ទាល់នឹងភ្នែករបស់គេ ទោះបីជាអ្នករាល់គ្នាមិនធ្លាប់បានឃើញទ្រង់ក៏ដោយ។ ជាដំបូង ទ្រង់ជារូបកាយខាងសាច់ឈាម ប៉ុន្តែក្រោយពេលទ្រង់បានជាប់ឆ្កាង ទ្រង់បានក្លាយជារូប កាយនៃសិរីល្អ។ ទ្រង់ជាព្រះវិញ្ញាណ ដែលគង់នៅគ្រប់ទិសទី ហើយអាចធ្វើការ

នៅគ្រប់ទីកន្លែងបាន។ ទ្រង់អាចជាព្រះយេហូវ៉ា អាចជាព្រះយេស៊ូវ ឬក៏អាចជាព្រះមែស៊ី។ នៅចុងបញ្ចប់ ទ្រង់ក៏អាចក្លាយជាព្រះដ៏មានគ្រប់ព្រះចេស្តាបានផងដែរ។ ទ្រង់គឺជាសេចក្តីសុចរិត ជាការជំនុំជម្រះ និងជាការវាយផ្ចាល។ ទ្រង់ជាបណ្តាសា និងជាព្រះពិរោធ ប៉ុន្តែទ្រង់ក៏ជាសេចក្តីមេត្តាករុណា ហើយជាសេចក្តីស្រឡាញ់ដ៏សប្បុរសផងដែរ។ គ្រប់កិច្ចការដែលទ្រង់បានធ្វើ សុទ្ធតែអាចតំណាងឲ្យទ្រង់បានទាំងអស់។ តើអ្នកនិយាយថា ព្រះជាម្ចាស់មានឥរិយាបថបែបណា? អ្នកមិនអាចពន្យល់បានឡើយ។ ប្រសិនបើអ្នកមិនអាចពន្យល់បានផង អ្នកមិនគួរសន្និដ្ឋានអំពីព្រះជាម្ចាស់នោះឡើយ។ ចូរកុំសន្និដ្ឋានថា ព្រះជាម្ចាស់ជាព្រះនៃសេចក្តីមេត្តាករុណា និងសេចក្តីស្រឡាញ់ដ៏សប្បុរសជារៀងរហូត ដោយសារតែទ្រង់បានធ្វើកិច្ចការនៃការប្រោសលោះ នៅក្នុងដំណាក់កាលមួយនោះឡើយ។ តើអ្នកអាចប្រាកដច្បាស់ទេថា ទ្រង់ជាព្រះដ៏ពេញដោយសេចក្តីមេត្តាករុណា និងសេចក្តីស្រឡាញ់តែមួយនោះ? ប្រសិនបើទ្រង់គ្រាន់តែជាព្រះនៃសេចក្តីមេត្តាករុណា និងសេចក្តីស្រឡាញ់នោះ ចុះហេតុអ្វីបានជាទ្រង់នឹងត្រូវបញ្ចប់យុគសម័យនៅគ្រាចុងក្រោយ? ហេតុអ្វីបានជាទ្រង់នឹងបញ្ជូនគ្រោះមហន្តរាយយ៉ាងច្រើនបែបនេះ? យោងតាមសញ្ញាណ និងគំនិតរបស់មនុស្ស ព្រះជាម្ចាស់គួរតែមានព្រះទ័យមេត្តាករុណា និងព្រះទ័យស្រឡាញ់ដល់ទីបញ្ចប់ ដើម្បីឲ្យសមាជិកចុងក្រោយគ្រប់ៗរូប របស់មនុស្សជាតិ អាចទទួលបានការសង្គ្រោះ។ ប៉ុន្តែ នៅគ្រាចុងក្រោយ ហេតុអ្វីបានជាទ្រង់បញ្ជូនគ្រោះមហន្តរាយធំៗ ដូចជា គ្រោះរញ្ជួយដី គ្រោះកាចចង្រៃ និងគ្រោះទុរ្ភិក្ស មកបំផ្លាញមនុស្សជាតិដ៏អាក្រក់ ដែលចាត់ទុកព្រះជាម្ចាស់ ជាសត្រូវរបស់គេដូច្នេះ? ហេតុអ្វីបានជាទ្រង់អនុញ្ញាតឲ្យមនុស្សរងគ្រោះមហន្តរាយទាំងនេះ? ចំពោះរឿងថា ព្រះជាម្ចាស់មានឥរិយាបថបែបណានោះ នៅក្នុងចំណោមអ្នករាល់គ្នា គ្មាននរណាម្នាក់ហ៊ាននិយាយបានឡើយ ហើយក៏គ្មាននរណាម្នាក់អាចពន្យល់បានដែរ។ តើអ្នកអាចប្រាកដច្បាស់ទេថា ទ្រង់ជាព្រះវិញ្ញាណ? តើអ្នកហ៊ាននិយាយថា ទ្រង់មិនមែនជានរណាឡើយ ក្រៅពីជាសាច់ឈាមរបស់ព្រះយេស៊ូវនោះ? ហើយតើអ្នកហ៊ាននិយាយទេថា ទ្រង់

គឺជាព្រះជាម្ចាស់ ដែលនឹងត្រូវជាប់ឆ្កាងជារៀងរហូត សម្រាប់ជាប្រយោជន៍របស់មនុស្សលោក?

## តើព្រះត្រៃឯកមានវត្តមានគង់នៅដែរឬទេ?

បន្ទាប់ពីសេចក្ដីពិតអំពីព្រះយេស៊ូវត្រឡប់មកជាសាច់ឈាមបានលេចចេញមក មនុស្សក៏ជឿថា នៅក្នុងស្ថានសួគ៌ មិនមែនមានតែព្រះវរបិតាទេ សូម្បីតែព្រះរាជបុត្រា ហើយនិងព្រះវិញ្ញាណបរិសុទ្ធក៏គង់នៅទីនោះដែរ។ នេះជាសញ្ញាណទូទៅមួយដែលមនុស្សប្រកាន់ខ្ជាប់ថា មានព្រះមួយអង្គបែបនេះគង់នៅស្ថានសួគ៌៖ ជាព្រះត្រៃឯកអង្គដែលមាន ព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ។ មនុស្សទាំងអស់សុទ្ធតែមានសញ្ញាណទាំងនេះថា៖ ព្រះជាម្ចាស់គឺជាព្រះតែមួយ ប៉ុន្តែមានបីអង្គជាជំនឿដែលអ្នកទាំងអស់នោះជឿស៊ប់ ក្នុងសញ្ញាណទូទៅរបស់គេ មានដូចជា ព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ។ មានតែបីអង្គនេះទេ ទើបរួបរួមគ្នាមកជាព្រះតែមួយបាន។ ប្រសិនបើគ្មានព្រះវរបិតាដ៏បរិសុទ្ធ ព្រះជាម្ចាស់មិនអាចពេញជាព្រះដែរ។ ដូចគ្នាដែរ ព្រះជាម្ចាស់មុខជាមិនអាចពេញជាព្រះទេ ប្រសិនបើគ្មានព្រះរាជបុត្រា ឬព្រះវិញ្ញាណដ៏បរិសុទ្ធ។ នៅក្នុងសញ្ញាណរបស់គេ ពួកគេជឿថា ព្រះវរបិតាតែអង្គឯង ឬព្រះរាជបុត្រាតែអង្គឯង មិនអាចរាប់ជាព្រះបានឡើយ។ ទាល់តែព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធរួមគ្នា ទើបរាប់ជាព្រះជាម្ចាស់បាន។ ពេលនេះ អ្នកជឿលើសាសនាទាំងអស់ ហើយសូម្បីតែពួកបរិស័ទនៅក្នុងចំណោមអ្នករាល់គ្នា សុទ្ធតែប្រកាន់ខ្ជាប់ជំនឿនេះ។ ប៉ុន្តែត្រង់ថា ជំនឿនេះត្រូវ ឬមិនត្រូវ គ្មាននរណាអាចពន្យល់បានឡើយ ដ្បិតអ្នករាល់គ្នាតែងតែមានភាពស្រពេចស្រពិលយល់ច្រឡំ ចំពោះរឿងដែលទាក់ទងនឹងព្រះជាម្ចាស់ផ្ទាល់។ ទោះបីជាសេចក្ដីទាំងនេះ គ្រាន់តែជាសញ្ញាណ ក៏អ្នករាល់គ្នាមិនដឹងដែរថា សេចក្ដីនេះត្រូវ ឬខុសឡើយ ដ្បិតអ្នករាល់គ្នារងនូវឥទ្ធិពលពីសញ្ញាណសាសនាខ្លាំងពេក។ អ្នករាល់គ្នាបានទទួលសញ្ញាណសាសនា

ទូទៅនេះជ្រាលជ្រៅពេក ហើយជាតិពុលនេះបានជ្រាបចូលក្នុងខ្លួនឯងជ្រៅពេក។ ហេតុនេះ អ្នករាល់គ្នាក៏បានចុះចូលចំពោះឥទ្ធិពលដ៏សាហាវ នៅក្នុងបញ្ហានេះដែរ ដ្បិតព្រះត្រៃឯកអង្គ គ្មានវត្ដមានគង់នៅតែម្ដង។ ពោលគឺ ត្រៃឯកភាពនៃព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណដ៏បរិសុទ្ធ គ្មានវត្តមាន គង់នៅតែម្ដង។ ទាំងអស់នេះ គឺជាសញ្ញាណទូទៅ ទាំងអស់របស់មនុស្ស និងជាជំនឿក្លែងក្លាយរបស់មនុស្សផង។ ជាច្រើនសតវត្សកន្លងមកនេះ មនុស្សបានជឿលើព្រះត្រៃឯក ជំនឿនេះបានវងនូវឥទ្ធិពលពីសញ្ញាណនៅក្នុងគំនិតរបស់មនុស្ស ប្រឌិតឡើងដោយមនុស្ស ហើយក៏មិនធ្លាប់មានមនុស្សណាម្នាក់ធ្លាប់បានឃើញពីមុនមកដែរ។ ជាច្រើនឆ្នាំកន្លងមកនេះ មានអ្នកបកស្រាយព្រះគម្ពីរជាច្រើន ធ្លាប់បានពន្យល់អំពី «អត្ថន័យពិត» នៃព្រះត្រៃឯក ប៉ុន្តែការពន្យល់អំពី ព្រះត្រៃឯកអង្គថាជាព្រះបីអង្គខុសគ្នាដែលមានលក្ខណៈដូចៗគ្នា មានសភាពស្រពេចស្រពិល និងមិនច្បាស់លាស់ មនុស្សទាំងអស់ក៏វង្វេងដោយសារ «ការកាត់ស្រាយ» អំពីព្រះជាម្ចាស់។ គ្មានមនុស្សអស្ចារ្យណាម្នាក់អាចផ្ដល់ការពន្យល់ក្បោះក្បាយមួយបានឡើយ។ ការពន្យល់ភាគច្រើនទទួលយកបាន ដោយព្រោះការលើកហេតុផល និងជាសំណេរ ប៉ុន្តែគ្មានមនុស្សណាម្នាក់មានការយល់ដឹងពេញលេញច្បាស់លាស់ ពីអត្ថន័យនៃសេចក្ដីពន្យល់នោះឡើយ។ មូលហេតុគឺមកពីត្រៃឯកដ៏អស្ចារ្យ ដែលមនុស្សជឿក្នុងចិត្តនេះ គឺគ្មានវត្តមានតែម្ដង។ ដ្បិតពុំមាននរណាម្នាក់ធ្លាប់បានឃើញព្រះភក្ត្រពិតរបស់ព្រះជាម្ចាស់ ក៏ពុំមាននរណាមានភ័ព្វសំណាងបានឡើងទៅលេងដំណាក់របស់ព្រះជាម្ចាស់ ដើម្បីពិនិត្យថា មានវត្ថុអ្វីខ្លះមានវត្តមាននៅកន្លែងដែលព្រះជាម្ចាស់គង់នៅ ដើម្បីពិនិត្យឲ្យច្បាស់ថា មានមនុស្សប៉ុន្មានម៉ឺន ឬប៉ុន្មានរយលានជំនាន់នៅក្នុង «ដំណាក់របស់ព្រះជាម្ចាស់» ឬដើម្បីសង្កេតមើលថា ទ្រង់ទ្រាយដែលព្រះជាម្ចាស់មានជាយូរមកហើយនោះ ផ្គុំឡើងប៉ុន្មានផ្នែកនោះឡើយ។ អ្វីដែលត្រូវយកមកពិនិត្យ គឺដូច្នេះ៖ យុគសម័យរបស់ព្រះវរបិតា និងព្រះរាជបុត្រា ព្រមទាំងព្រះវិញ្ញាណបរិសុទ្ធ ការលេចមករៀងខ្លួនរបស់អង្គព្រះនីមួយៗ វិធីជាក់ស្ដែងដែលទ្រង់ទាំងបីនៅទីទៃពីគ្នា និងវិធីដែលទ្រង់ទាំងបីរួមគ្នាមកតែមួយ។ គួរឲ្យស្ដាយ ក្នុងរយៈ

ពេលជាច្រើនឆ្នាំមកនេះ ពុំមាននរណាម្នាក់អាចកំណត់នូវសេចក្ដីពិត ទាក់ទងនឹងបញ្ហាទាំងនេះទេ។ ពួកគេបានត្រឹមតែស្មានប៉ុណ្ណោះ ដ្បិតពុំមាននរណាម្នាក់ ធ្លាប់ឡើងទៅលេងស្ថានសួគ៌ រួចត្រឡប់មកវិញទាំងយក «របាយការណ៍ស៊ើបអង្កេត» មកឲ្យមនុស្សជាតិគ្រប់ៗគ្នា ដើម្បីរាយការណ៍ពីសេចក្ដីពិតទាក់ទងនឹងបញ្ហានេះ ប្រាប់ដល់ពួកបរិស័ទដែលឆេះឆួល និងជឿស៊ប់លើជំនឿព្រះត្រៃឯកនេះ។ ពិតណាស់ ការបង្កើតឲ្យមាននូវសញ្ញាណបែបនេះ បើដាក់ការបន្ទោសមកលើមនុស្សក៏មិនកើតដែរ ដ្បិតហេតុអ្វីក៏ព្រះយេហូវ៉ាដ៏ជាព្រះវរបិតា ពុំមានព្រះយេស៊ូវដ៏ជាព្រះរាជបុត្រានៅជាមួយទ្រង់ ពេលទ្រង់បង្កើតមនុស្សលោក? កាលដើមដំបូង ប្រសិនបើគ្រប់យ៉ាងប្រើតែព្រះនាមព្រះយេហូវ៉ា នោះគឺមុខជាល្អជាងនេះមិនខាន។ ប្រសិនបើត្រូវបន្ទោសលើពេលវេលាដ៏ខ្លីដែលកន្លងផុតរបស់ព្រះយេហូវ៉ាដ៏ជាព្រះដែលទ្រង់មិនបានហៅព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ មកចំពោះទ្រង់ក្នុងគ្រាបង្កើតសត្តនិករទាំងអស់ ប៉ុន្តែផ្ទុយទៅវិញ ទ្រង់អនុវត្តកិច្ចការនេះតែមួយអង្គឯង។ ប្រសិនបើទ្រង់ទាំងបីអង្គធ្វើកិច្ចការទាំងអស់នេះព្រមគ្នា តើទ្រង់ទាំងបីព្រះអង្គមិនក្លាយជាព្រះតែមួយទេឬអី? តាំងពីដើមដំបូងរហូតមកដល់ទីបញ្ចប់ ប្រសិនបើមានតែព្រះនាមព្រះយេហូវ៉ា ហើយគ្មានព្រះនាមព្រះយេស៊ូវ ពីយុគសម័យនៃព្រះគុណ ឬប្រសិនបើទ្រង់នៅតែប្រើព្រះនាមថា ព្រះយេហូវ៉ា តើព្រះជាម្ចាស់មិនត្រូវមនុស្សទុកជីវិត មិនឲ្យរងទុក្ខលំបាកពីការបែងចែកនេះទេឬអី? និយាយឲ្យចំទៅ រឿងទាំងអស់មិនអាចបន្ទោសព្រះយេហូវ៉ាបានទេ ប្រសិនបើត្រូវបន្ទោស គឺបន្ទោសព្រះវិញ្ញាណបរិសុទ្ធ ដ្បិតរយៈពេលរាប់ពាន់ឆ្នាំមកនេះ ព្រះអង្គបានបន្តកិច្ចការរបស់ទ្រង់ ដោយប្រើព្រះនាមព្រះយេហូវ៉ា និងព្រះយេស៊ូវ ព្រមទាំងព្រះនាមព្រះវិញ្ញាណបរិសុទ្ធផងធ្វើឲ្យមនុស្សវង្វេង ហើយភ័ន្តច្រឡំ ដល់ថ្នាក់មិនអាចដឹងច្បាស់ថា ព្រះអង្គណាមួយជាព្រះជាម្ចាស់។ ប្រសិនបើព្រះវិញ្ញាណបរិសុទ្ធផ្ទាល់បានធ្វើកិច្ចការដោយគ្មានទ្រង់ទ្រាយ ឬរូបអង្គ ហើយជាងនេះទៅទៀត គឺដោយមិនប្រើព្រះនាមព្រះយេស៊ូវ ហើយមនុស្សក៏មិនអាចពាល់ទ្រង់ ឬមើលឃើញទ្រង់បានត្រឹមតែស្ដាប់ឮតែសំឡេងផ្គរលាន់ តើកិច្ចការបែបនេះមិនមានប្រយោជន៍ដល់មនុស្ស

ច្រើនជាងទេឬអី? ដូច្នេះ តើពេលនេះគួរធ្វើអ្វីវិញ? សញ្ញាណរបស់មនុស្សបង្គរឡើងខ្ពស់ដូចភ្នំ ហើយល្ហល្ហាចដូចផ្ទៃសមុទ្រ ដល់ថ្នាក់ព្រះជាម្ចាស់នាពេលបច្ចុប្បន្នលែងអាចទ្រាំនឹងសញ្ញាណទាំងនេះបាន ហើយមិនដឹងជាត្រូវធ្វើយ៉ាងណានោះឡើយ។ កាលពីមុន ពេលដែលមានតែព្រះយេហូវ៉ា ព្រះយេស៊ូវ និងព្រះវិញ្ញាណបរិសុទ្ធ មនុស្សមិនដឹងជាត្រូវប្រឈមយ៉ាងណាទៅហើយ ពេលនេះមានព្រះដ៏មានគ្រប់ព្រះចេស្ដាថែមមួយទៀត ដែលមានបន្ទូលថាជាអង្គមួយរបស់ព្រះជាម្ចាស់ដែរ។ តើនរណាដឹងថាទ្រង់ជានរណា ហើយតើទ្រង់ជាអង្គណាមួយក្នុងព្រះត្រៃឯក ដែលទ្រង់គង់បង្កប់ជាមួយឬលាក់ព្រះកាយក្នុងអង្គណាមួយ ក្នុងរយៈពេលជាច្រើនឆ្នាំមកនេះ? តើមនុស្សអាចទ្រាំនឹងសេចក្ដីនេះបានយ៉ាងដូចម្ដេច? ត្រឹមព្រះត្រៃឯកអង្គប៉ុណ្ណឹង ល្មមឲ្យមនុស្សចំណាយពេលមួយជីវិតមកពន្យល់ទៅហើយ តែពេលនេះមាន «ព្រះតែមួយមានបួនអង្គ» ទៀត។ តើគួរពន្យល់រឿងនេះដោយរបៀបណា? តើអ្នកអាចពន្យល់បានទេ? បងប្អូនប្រុសស្រីអើយ! តើអ្នករាល់គ្នាបានជឿដល់ព្រះបែបនេះ មកទល់សព្វថ្ងៃនេះដែរឬទេ? ខ្ញុំសូមសរសើរអ្នករាល់គ្នាទៅចុះ។ ព្រះត្រៃឯកអង្គ គឺល្មមនឹងទ្រាំទ្រស្រេចទៅហើយ ចុះម្ដេចក៏អ្នករាល់គ្នាបន្តមានជំនឿតរង្គើ លើព្រះមួយដែលមានដល់ទៅបួនអង្គទៀតនោះ? អ្នករាល់គ្នាត្រូវបានជំរុញឲ្យចេញទៅ តែអ្នករាល់គ្នាបដិសេធ។ ពិតជាស្មានមិនដល់មែន! អ្នករាល់គ្នាពិតជាហ៊ានមែន! មនុស្សម្នាក់ពិតជាអាចដល់ថ្នាក់ជឿលើព្រះដល់ទៅបួនអង្គ ហើយមិនរាប់ជំនឿនោះគឺជាជំនឿសំខាន់ទៀត តើអ្នករាល់គ្នាមិនគិតថា វាជារឿងអស្ចារ្យទេឬអី? មើលទៅអ្នក គ្មាននរណាអាចដឹងថា អ្នករាល់គ្នាអាចធ្វើការអស្ចារ្យបានទេ! ខ្ញុំប្រាប់អ្នករាល់គ្នាទៅចុះ តាមពិត ព្រះត្រៃឯកអង្គ គ្មានវត្តមាននៅទីកន្លែងណាមួយនៅក្នុងសកលលោកនេះទេ។ ព្រះពុំមានព្រះវរបិតា ក៏ពុំមានព្រះរាជបុត្រា ហើយរឹតតែគ្មានគំនិតគិតថា ព្រះវរបិតា និងព្រះរាជបុត្រាសហការគ្នាប្រើព្រះវិញ្ញាណបរិសុទ្ធជាឧបករណ៍ដែរ។ ទាំងអស់នេះសុទ្ធតែជាជំនឿខុសឆ្គងដ៏ធំបំផុតនៅក្នុងលោកិយនេះ ហើយគ្មានវត្តមាននោះឡើយ! ប៉ុន្តែបើទោះបីជាជំនឿខុសឆ្គងនេះមានប្រភពដើម ហើយប្រភពដើមនោះមិនមែនគ្មានមូលដ្ឋានទាំងស្រុងដែរ ដ្បិតគំនិត

របស់អ្នករាល់គ្នាមិនមែនសាមញ្ញ ហើយតម្រិះរបស់អ្នករាល់គ្នាក៏ពុំមែនឥតហេតុផលដែរ។ ផ្ទុយទៅវិញ គំនិត និងតម្រិះទាំងអស់នោះ គឺសុទ្ធតែត្រឹមត្រូវ និងប៉ិនប្រសប់រហូតដល់ថ្នាក់សូម្បីសាតាំង ក៏មិនអាចដណ្ដើមបានផង។ រឿងគួរឲ្យអាណិតគឺ គំនិតទាំងនេះ សុទ្ធតែជាគំនិតខុសឆ្គង ហើយគ្មានវត្តមានតែម្ដង! អ្នករាល់គ្នាពុំបានឃើញសេចក្ដីពិតដ៏ពិតប្រាកដទាល់តែសោះ។ អ្នករាល់គ្នាគ្រាន់តែធ្វើការស្មាន និងស្រមើស្រមៃ បន្ទាប់មកបញ្ចូលគ្រប់យ៉ាងដោយប្រឌិតចេញជារឿងមួយ ដើម្បីទទួលបានការទុកចិត្តរបស់អ្នកដទៃដោយការបោកបញ្ឆោត និងដើម្បីទទួលបាននូវអំណាចគ្រប់គ្រងលើមនុស្សដែលល្ងីល្ងើបំផុត ក្នុងចំណោមមនុស្សឥតគំនិត ឬហេតុផល ដើម្បីឲ្យពួកគេជឿលើ «សេចក្ដីបង្រៀនដ៏ជំនាញ» ដែលអស្ចារ្យ និងល្បីល្បាញរបស់អ្នករាល់គ្នាវិញ។ តើនេះជាការពិតទេ? តើនេះជាផ្លូវជីវិត ដែលមនុស្សគួរតែទទួលមែនទេ? សុទ្ធតែចោលម្សៀតទាំងអស់! សូម្បីសម្ដីមួយម៉ាត់ក៏មិនត្រូវផង! ក្នុងរយៈពេលជាច្រើនឆ្នាំមកនេះ ព្រះជាម្ចាស់ត្រូវអ្នករាល់គ្នាញែកចេញមកបែបនេះ ដោយត្រូវញែកចេញទៅជាតូចទៅៗ ពីមួយជំនាន់ទៅមួយជំនាន់ រហូតដល់ថ្នាក់ព្រះមួយអង្គត្រូវបែងចែកជាចំហឲ្យទៅជាព្រះបីអង្គ។ ហើយពេលនេះ មនុស្សមិនអាចបង្រួមព្រះឲ្យមកជាព្រះតែមួយវិញបានយ៉ាងងាយឡើយ ដ្បិតអ្នករាល់គ្នាបានបែងចែកទ្រង់ឲ្យទៅជាតូចពេកទៅហើយ! ប្រសិនបើមិនមែនដោយសារតែកិច្ចការដ៏រហ័សរបស់ខ្ញុំ មុនពេលវាយឺតពេល គឺពិបាកនិយាយថា អ្នកនឹងបន្តនៅតែបែបនេះ ដោយពុំមានភាពខ្មាសអៀនយូរប៉ុនណាណាស់! បើនៅតែបន្តចែកព្រះជាម្ចាស់បែបនេះ តើទ្រង់នៅអាចធ្វើជាព្រះជាម្ចាស់របស់អ្នករាល់គ្នាដូចម្ដេចទៅ? តើអ្នករាល់គ្នានឹងនៅតែស្គាល់ព្រះជាម្ចាស់ដែរឬទេ? តើអ្នករាល់គ្នា នឹងនៅតែស្វែងរកដើមកំណើតរបស់ខ្លួនដែរឬទេ? តើអ្នករាល់គ្នានៅតែទទួលស្គាល់ថា ទ្រង់ជាឪពុករបស់អ្នករាល់គ្នា ហើយត្រឡប់ទៅរកទ្រង់វិញ ដូចម្ដេចទៅ? ប្រសិនបើខ្ញុំមកដល់យឺតជាងនេះ នោះអ្នកច្បាស់ជាបញ្ជូន «ព្រះវរបិតា និងព្រះរាជបុត្រា» គឺព្រះយេហូវ៉ា និងព្រះយេស៊ូវឲ្យត្រឡប់ទៅអ៊ីស្រាអែលវិញ ហើយប្រកាសថា អ្នករាល់គ្នាផ្ទាល់ក៏ជាផ្នែកមួយរបស់ព្រះជាម្ចាស់ជាមិនខាន។ សំណាងល្អ

ហើយដែលគ្រានេះជាគ្រាចុងក្រោយ។ ទីបំផុត ថ្ងៃដែលខ្ញុំទន្ទឹងជាយូរមកហើយនេះ ក៏បានមកដល់ ហើយទាល់តែខ្ញុំបានអនុវត្តកិច្ចការដំណាក់កាលនេះឲ្យហើយ ដោយព្រះហស្តខ្ញុំផ្ទាល់ទើបការបែងចែកព្រះជាម្ចាស់ផ្ទាល់ ពីសំណាក់អ្នករាល់គ្នា ត្រូវបានបញ្ឈប់។ ប្រសិនបើមិនមែនដោយព្រោះរឿងនេះទេ អ្នករាល់គ្នាមុខជាតម្កើងខ្លួនឯងថែមទាំងលើកតម្កើងពួកសាតាំងក្នុងចំណោមអ្នករាល់គ្នាដាក់លើតុរបស់អ្នករាល់គ្នា រួចថ្វាយបង្គំផង។ នេះហើយជាវិធីដែលអ្នករាល់គ្នាបែងចែកព្រះជាម្ចាស់! តើអ្នករាល់គ្នានឹងបន្តធ្វើបែបនេះ ដល់ពេលនេះមែនទេ? ខ្ញុំសួរអ្នករាល់គ្នាទៅចុះ៖ តើមានព្រះចំនួនប៉ុន្មាន? តើព្រះណាមួយដែលនាំយកសេចក្ដីសង្គ្រោះមកអ្នករាល់គ្នា? តើព្រះដែលអ្នករាល់គ្នាតែងតែអធិស្ឋានរក គឺជាព្រះទីមួយ ទីពីរ ឬទីបី? តើអ្នករាល់គ្នាតែងតែជឿលើព្រះអង្គណា? ព្រះវរបិតា? ព្រះរាជបុត្រា? ឬក៏ព្រះវិញ្ញាណ? ចូរប្រាប់ខ្ញុំមកថា អ្នកជឿលើព្រះណាមួយ។ ទោះបីជាអ្នកនិយាយពាក្យ គ្រប់ម៉ាត់ថា អ្នកជឿលើព្រះ តែអ្វីដែលអ្នករាល់គ្នាជឿពិតប្រាកដ គឺខួរក្បាលរបស់អ្នករាល់គ្នាផ្ទាល់! អ្នកគ្មានព្រះជាម្ចាស់ក្នុងចិត្តរបស់អ្នករាល់គ្នាតែម្ដង! ដោយឡែក នៅក្នុងគំនិតរបស់អ្នករាល់គ្នា មានព្រះត្រៃឯកបែបនេះច្រើនណាស់! តើអ្នករាល់គ្នាមិនយល់ស្របទេឬអី?

ប្រសិនបើកិច្ចការទាំងបីដំណាក់កាល ត្រូវបានវាយតម្លៃតាមជំនឿលើព្រះត្រៃឯកនេះ នោះត្រូវតែមានព្រះទាំងបីអង្គព្រោះកិច្ចការត្រូវបានអនុវត្តដោយព្រះនីមួយៗគឺមិនដូចគ្នាឡើយ។ ប្រសិនបើនរណាម្នាក់ក្នុងចំណោមអ្នករាល់គ្នានិយាយថា ព្រះត្រៃឯកពិតជាមានមែនជាប្រាកដមែន នោះចូរពន្យល់ថា នៅក្នុងអង្គទាំងបីនេះ ព្រះណាមួយគឺជាអ្វីឲ្យប្រាកដ។ តើព្រះវរបិតាដ៏បរិសុទ្ធ គឺជាអ្វី? តើព្រះរាជបុត្រា គឺជាអ្វី? តើព្រះវិញ្ញាណបរិសុទ្ធ គឺជាអ្វី? តើព្រះយេហូវ៉ា គឺជាព្រះវរបិតាដ៏បរិសុទ្ធ? តើព្រះយេស៊ូវគឺជាព្រះរាជបុត្រា? ចុះចំណែកព្រះវិញ្ញាណបរិសុទ្ធ គឺជាអ្វី? តើព្រះវរបិតាមិនមែនជាវិញ្ញាណទេឬអី? តើលក្ខណៈពិតរបស់ព្រះរាជបុត្រា គឺមិនមែនជាវិញ្ញាណដែរទេឬអី? តើកិច្ចការរបស់ព្រះយេស៊ូវ គឺមិនមែនជាកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធទេឬអី? តើកិច្ចការរបស់ព្រះយេហូវ៉ា ក្នុងគ្រាដែលត្រូវបានអនុវត្តដោយព្រះវិញ្ញាណ នោះមិន

ដូចជាកិច្ចការរបស់ព្រះយេស៊ូវទេឬអី? តើព្រះជាម្ចាស់មានវិញ្ញាណប៉ុន្មាន? យោងតាមការពន្យល់របស់អ្នក អង្គទាំងបីរបស់ព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ គឺតែមួយ បើដូច្នេះមែន គឺមានព្រះវិញ្ញាណបី ប៉ុន្តែដើម្បីមាននូវព្រះវិញ្ញាណបី មានន័យថា ត្រូវតែមានព្រះបីអង្គ។ ដូច្នេះមានន័យថា គ្មាននូវព្រះដ៏ពិតតែមួយទេ។ ធ្វើម្ដេចឲ្យព្រះបែបនេះ នៅតែមានលក្ខណៈដើមជាព្រះជាម្ចាស់បាន? ប្រសិនបើអ្នកទទួលស្គាល់ថា មានព្រះតែមួយ នោះធ្វើម្ដេចអាចឲ្យទ្រង់មានបុត្រាម្នាក់ ហើយធ្វើជាឪពុកម្នាក់បាន? តើទាំងអស់នេះ មិនមែនត្រឹមតែជាសញ្ញាណរបស់អ្នករាល់គ្នាទេឬអី? មានព្រះតែមួយប៉ុណ្ណោះនៅក្នុងព្រះនេះ មានតែមួយអង្គ ហើយក៏មានវិញ្ញាណនៃព្រះតែមួយ ដូចដែលមានចែងក្នុងព្រះគម្ពីរថា «មានព្រះវិញ្ញាណបរិសុទ្ធតែមួយ ហើយមានព្រះតែមួយគត់»។ មិនថាព្រះវរបិតា ឬព្រះរាជបុត្រាដែលអ្នកនិយាយនេះមាន ឬគ្មានព្រះវត្តមានក៏ដោយ ទីបំផុត ក៏មានតែព្រះជាម្ចាស់តែមួយគត់ ហើយលក្ខណៈពិតរបស់ព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធដែលអ្នករាល់គ្នាជឿនេះជាលក្ខណៈពិតរបស់ព្រះវិញ្ញាណបរិសុទ្ធ។ ន័យមួយទៀតគឺ ព្រះគឺជាវិញ្ញាណ ប៉ុន្តែទ្រង់ក៏អាចក្លាយជាសាច់ឈាម ហើយរស់នៅក្នុងចំណោមមនុស្សលោក ព្រមទាំងខ្ពស់ឧត្តមលើសអ្វីៗទាំងអស់ផង។ វិញ្ញាណរបស់ទ្រង់ក៏រួមបញ្ចូលទាំងអស់ ហើយមានវត្តមានគ្រប់ទីកន្លែងក្នុងពេលតែមួយ។ ទ្រង់អាចជាសាច់ឈាម ហើយនៅខ្ពស់ក្រៅចក្រវាឡនេះព្រមគ្នាក៏បាន។ ដ្បិតមនុស្សទាំងអស់និយាយថា ព្រះជាម្ចាស់ គឺជាព្រះដ៏ពិតតែមួយ រួចមានព្រះតែមួយអង្គ ហើយមានតែមួយអង្គគត់ ពុំមាននរណាម្នាក់អាចបែងចែកតាមចិត្តបានឡើយ! ព្រះជាម្ចាស់ជាព្រះវិញ្ញាណតែមួយ ហើយមានតែមួយអង្គគត់ព្រមទាំងនិយាយថា នោះគឺជាព្រះវិញ្ញាណនៃព្រះ។ ប្រសិនបើដូចអ្វីដែលអ្នកនិយាយមែន ព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ តើទាំងបីអង្គនេះ មិនមែនជាព្រះបីអង្គពីគ្នាទេឬអី? ព្រះវិញ្ញាណបរិសុទ្ធ គឺជារឿងមួយ ព្រះរាជបុត្រា គឺជារឿងមួយ ហើយព្រះវរបិតា គឺជារឿងមួយដោយឡែក។ អង្គទាំងបីអង្គខុសគ្នា ហើយលក្ខណៈរបស់ព្រះទាំងបីអង្គក៏ខុសគ្នាដែរ ដូច្នេះតើព្រះទាំងបីអង្គអាចជាចំណែកនីមួយៗនៃព្រះ

តែមួយបានយ៉ាងដូចម្ដេច? ព្រះវិញ្ញាណបរិសុទ្ធ គឺជាវិញ្ញាណមួយ ចំណុចនេះមនុស្សងាយយល់ទេ។ ប្រសិនបើដូច្នេះមែន នោះព្រះវរបិតា ក៏រឹតតែជាវិញ្ញាណមួយទៅទៀត។ ទ្រង់មិនធ្លាប់យាងចុះមកផែនដី និងមិនធ្លាប់បានក្លាយជាសាច់ឈាមផង ទ្រង់ជាព្រះយេហូវ៉ាដ៏ជាព្រះនៅក្នុងដួងចិត្តរបស់មនុស្ស ហើយទ្រង់ក៏ជាវិញ្ញាណមួយយ៉ាងពិតប្រាកដដែរ។ ចុះតើអ្វីជាសម្ពន្ធភាពរវាងព្រះអង្គ និងព្រះវិញ្ញាណបរិសុទ្ធ? តើនោះជាសម្ពន្ធភាពរវាងព្រះវរបិតា និងព្រះរាជបុត្រា? ឬជាសម្ពន្ធភាពរវាងព្រះវិញ្ញាណបរិសុទ្ធ និងព្រះវិញ្ញាណរបស់ព្រះវរបិតា? តើលក្ខណៈពិតនៃវិញ្ញាណនីមួយៗ ដូចគ្នាដែរឬទេ? ឬក៏ ព្រះវិញ្ញាណបរិសុទ្ធ គឺជាភាជនៈរបស់ព្រះវរបិតា? តើរឿងនេះត្រូវពន្យល់យ៉ាងដូចម្ដេចវិញ? ចុះតើសម្ពន្ធភាពរវាងព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ គឺជាអ្វី? តើជាសម្ពន្ធភាពរវាងវិញ្ញាណពីរ ឬក៏ជាសម្ពន្ធភាពរវាងមនុស្ស និងវិញ្ញាណ? ទាំងអស់នេះគឺសុទ្ធតែជាបញ្ហាដែលគ្មានការបកស្រាយ! ប្រសិនបើព្រះទាំងបីអង្គ សុទ្ធតែជាវិញ្ញាណ នោះគ្មានអ្វីត្រូវជជែកអំពីព្រះទាំងបីអង្គទៀតទេ ដ្បិតទាំងបីអង្គសុទ្ធតែមានវិញ្ញាណមួយ។ ប្រសិនបើទាំងបីអង្គនេះ គឺជាព្រះដោយឡែកពីគ្នា នោះវិញ្ញាណរបស់ព្រះទាំងបីមុខជាមានអានុភាពខុសគ្នា ហើយព្រះទាំងបីអង្គ មិនអាចជាវិញ្ញាណតែមួយបានទេ។ ជំនឿបែបនេះអំពីព្រះវរបិតាព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ គឺលេលាបំផុត! កត្តានេះញែកព្រះជាម្ចាស់ និងបែងចែកទ្រង់ចេញជាបីអង្គ អង្គនីមួយៗមានទាំងឋានៈ និងមានទាំងវិញ្ញាណ តើទ្រង់នៅតែអាចជាវិញ្ញាណតែមួយ និងជាព្រះតែមួយបានយ៉ាងដូចម្ដេច? ចូរប្រាប់ខ្ញុំមកមើលថា តើផ្ទៃមេឃ ផែនដី និងរបស់សព្វសារពើត្រូវបានបង្កើតឡើងដោយព្រះវរបិតា ព្រះរាជបុត្រា ឬក៏ព្រះវិញ្ញាណដ៏បរិសុទ្ធឬ? អ្នកខ្លះក៏និយាយថា ព្រះទាំងបីអង្គបានបង្កើតរបស់សព្វសារពើ រួមជាមួយគ្នា។ តើព្រះអង្គណាជាអ្នកសង្គ្រោះមនុស្សជាតិ? ព្រះវិញ្ញាណបរិសុទ្ធ ព្រះរាជបុត្រា ឬព្រះវរបិតា? មានអ្នកខ្លះថា ព្រះរាជបុត្រា គឺជាព្រះដែលបានសង្គ្រោះមនុស្សជាតិ។ ចុះ តើព្រះរាជបុត្រាមានលក្ខណៈពិតជាព្រះបែបណា? តើព្រះអង្គមិនមែនជារូបកាយសាច់ឈាមរបស់ព្រះវិញ្ញាណនៃព្រះទេឬអី? សាច់ឈាមដែលជារូបកាយរបស់ព្រះវិញ្ញាណនៃព្រះ ហៅ

ព្រះជាម្ចាស់ដែលគង់នៅស្ថានសួគ៌ដោយព្រះនាមថា ព្រះវរបិតា តាមទស្សនៈជាមនុស្សដែលព្រះបានបង្កើត។ តើអ្នកមិនដឹងទេថា ព្រះយេស៊ូវបានប្រសូតមកដោយការចាប់បដិសន្ធិរបស់ព្រះវិញ្ញាណបរិសុទ្ធ? នៅក្នុងទ្រង់ គឺព្រះវិញ្ញាណបរិសុទ្ធ ទោះបីជាអ្នកនិយាយអ្វី ក៏ទ្រង់នៅតែជាព្រះដែលគង់នៅជាមួយនឹងព្រះជាម្ចាស់នៅស្ថានសួគ៌ដែរ ដ្បិតទ្រង់ជារូបកាយសាច់ឈាមរបស់ព្រះវិញ្ញាណនៃព្រះ។ គំនិតគិតបែបនេះចំពោះព្រះរាជបុត្រា គឺមិនពិតតែម្ដង។ គឺជាវិញ្ញាណតែមួយ ដែលអនុវត្តកិច្ចការទាំងអស់ គឺមានតែព្រះជាម្ចាស់ផ្ទាល់ព្រះអង្គទេ ទើបជាវិញ្ញាណនៃព្រះដែលអនុវត្តកិច្ចការរបស់ទ្រង់។ តើព្រះវិញ្ញាណនៃព្រះនេះជាអ្នកណា? តើពុំមែនជាព្រះវិញ្ញាណបរិសុទ្ធទេឬអី? តើពុំមែនជាព្រះវិញ្ញាណបរិសុទ្ធដែលធ្វើការជាមួយព្រះយេស៊ូវទេឬអី? ប្រសិនបើកិច្ចការនេះ មិនត្រូវបានអនុវត្តដោយព្រះវិញ្ញាណបរិសុទ្ធ (ដែលជាព្រះវិញ្ញាណនៃព្រះ) តើកិច្ចការរបស់ទ្រង់ អាចតំណាងឲ្យព្រះជាម្ចាស់ផ្ទាល់យ៉ាងដូចម្ដេច? នៅពេលព្រះយេស៊ូវហៅព្រះជាម្ចាស់ដែលនៅស្ថានសួគ៌ដោយព្រះនាមព្រះវរបិតា នៅពេលទ្រង់អធិដ្ឋាន គឺទ្រង់ធ្វើបែបនេះ តាមទស្សនៈជាមនុស្សដែលព្រះបានបង្កើតតែប៉ុណ្ណោះ ហេតុផលមួយគត់ គឺមកពីព្រះវិញ្ញាណនៃព្រះគ្រងរូបកាយសាច់ឈាមធម្មតា ហើយមានសម្បកកាយជាភាវៈដែលត្រូវបានបង្កើតមក។ បើទោះបីជានៅក្នុងទ្រង់មានព្រះវិញ្ញាណនៃព្រះ សម្បកកាយរបស់ទ្រង់ នៅតែជាមនុស្សធម្មតា ពោលគឺទ្រង់បានក្លាយជា «កូនបុត្រមនុស្ស» ដែលមនុស្សទាំងអស់បានលើកយកមកនិយាយរួមទាំងព្រះយេស៊ូវផ្ទាល់ផង។ ដែលទ្រង់ត្រូវបានគេហៅថា បុត្រមនុស្ស ព្រោះទ្រង់ជាបុគ្គលម្នាក់ (មិនដឹងជាបុរស ឬស្ត្រីទេ តែយ៉ាងណាក៏ទ្រង់មានសម្បកកាយជាមនុស្សដែរ) ដែលកើតក្នុងគ្រួសារធម្មតានៃមនុស្សទូទៅមួយ។ ដូច្នេះ ព្រះយេស៊ូវហៅព្រះដែលគង់នៅស្ថានសួគ៌ ដោយព្រះនាមព្រះវរបិតា គឺដូចដែលអ្នករាល់គ្នាហៅទ្រង់ថាព្រះវរបិតាពីដំបូងដែរ។ ទ្រង់ធ្វើបែបនេះ តាមទស្សនៈជាមនុស្ស។ តើអ្នករាល់គ្នានៅចាំសេចក្ដីអធិដ្ឋាននៃព្រះអម្ចាស់ដែលព្រះយេស៊ូវ បានបង្រៀនអ្នករាល់គ្នាឲ្យទន្ទេញទេ? «ព្រះវរបិតានៃយើងខ្ញុំដែលគង់នៅស្ថានសួគ៌...។» ទ្រង់បានបង្គាប់ឲ្យមនុស្សទាំងអស់

ហៅព្រះដែលគង់នៅស្ថានសួគ៌ ដោយព្រះនាមថាព្រះវរបិតា។ ដ្បិតព្រះអង្គហៅព្រះដែលគង់ស្ថានសួគ៌ថាព្រះវរបិតាដែរ ហើយទ្រង់ធ្វើដូច្នេះ តាមទស្សនៈជាមនុស្សម្នាក់ដែលមានឋានៈស្មើនឹងអ្នករាល់គ្នា។ ដោយព្រោះអ្នករាល់គ្នា ហៅព្រះដែលគង់នៅស្ថានសួគ៌ដោយព្រះនាមព្រះវរបិតាដែរ ព្រះយេស៊ូវបានរាប់អង្គទ្រង់ផ្ទាល់ក្នុងឋានៈស្មើនឹងអ្នករាល់គ្នា ហើយជាមនុស្សម្នាក់ដែឡត្រូវបានព្រះជ្រើសរើសនៅលើផែនដី (ពោលគឺជាព្រះរាជបុត្រានៃព្រះ)។ ប្រសិនបើអ្នករាល់គ្នាហៅព្រះជាម្ចាស់ថា ព្រះវរបិតា តើនេះមិនមែនដោយសារអ្នករាល់គ្នា គឺជាមនុស្សទេឬអី? ទោះបីជាសិទ្ធិអំណាចរបស់ព្រះយេស៊ូវនៅលើផែនដីធំប៉ុនណាមុនពេលដែលទ្រង់ត្រូវជាប់ឆ្កាង ទ្រង់គ្រាន់តែជាកូនមនុស្សម្នាក់ ដែលឃុំគ្រងដោយព្រះវិញ្ញាណបរិសុទ្ធ (ពោលគឺជាព្រះជាម្ចាស់) ហើយជាមនុស្សម្នាក់នៅក្នុងចំណោមមនុស្សដែលព្រះបានបង្កើតនៅលើផែនដី ដ្បិតព្រះអង្គមិនទាន់សម្រេចកិច្ចការរបស់ទ្រង់នៅឡើយ។ ដូច្នេះ ការដែលទ្រង់ហៅព្រះដែលគង់ស្ថានសួគ៌ថា ព្រះវរបិតា គឺជាការបន្ទាបខ្លួន និងជាការស្ដាប់បង្គាប់របស់ទ្រង់ទាំងស្រុង។ យ៉ាងណាមិញ ការដែលព្រះអង្គហៅព្រះជាម្ចាស់ (ព្រះវិញ្ញាណនៃព្រះដែលគង់នៅស្ថានសួគ៌) ដោយកិរិយាបែបនេះមិនបញ្ជាក់ថា ទ្រង់ជាព្រះបុត្រារបស់ព្រះវិញ្ញាណព្រះដែលគង់នៅស្ថានសួគ៌នោះទេ។ ផ្ទុយទៅវិញ នោះមកពីទស្សនៈរបស់ទ្រង់ខុសគេ មិនមែនមកពីទ្រង់ជាមនុស្សខុសគេទេ។ វត្តមាននៃអង្គខុសគ្នារបស់ព្រះជាជំនឿខុសឆ្គង! មុនពេលព្រះយេស៊ូវត្រូវគេឆ្កាង ទ្រង់គ្រាន់តែជាកូនមនុស្សម្នាក់ដែលជាប់ចំណងកំហិតនៃសាច់ឈាម ហើយទ្រង់គ្មានសិទ្ធិអំណាចពេញលេញរបស់ព្រះវិញ្ញាណបរិសុទ្ធឡើយ។ ហេតុនេះទើបទ្រង់អាចស្វែងរកព្រះហឫទ័យនៃព្រះដ៏ជាព្រះវរបិតា តាមតែត្រឹមទស្សនៈជាមនុស្សប៉ុណ្ណោះ។ ពេលព្រះអង្គអធិស្ឋានលើកទីបីនៅសួនកេតសេម៉ានី ទ្រង់អធិស្ឋានថា «សូមកុំតាមចិត្តទូលបង្គំឡើយ តែសូមតាមបំណងព្រះហឫទ័យរបស់ទ្រង់វិញ»។ មុនពេលទ្រង់ត្រូវជាប់ឆ្កាង ទ្រង់ត្រឹមតែជាស្ដេចនៃសាសន៍យូដា ទ្រង់ជាព្រះគ្រីស្ទ ជាបុត្រមនុស្ស ហើយក៏មិនមែនជារូបកាយ ដែលពេញដោយសិរីល្អដែរ។ ហេតុនេះ តាមទស្សនៈនៃភាវៈដែលត្រូវបានបង្កើតមក ទ្រង់

ហៅព្រះជាម្ចាស់ថា ព្រះវរបិតា។ ពេលនេះ អ្នកមិនអាចពោលថា អ្នកដែលហៅព្រះជាម្ចាស់ថា ព្រះវរបិតាជាព្រះបុត្រានោះទេ។ ប្រសិនបើដូច្នេះមែន តើអ្នករាល់គ្នានឹងមិនក្លាយទៅជាព្រះបុត្រា នៅពេលដែលព្រះយេស៊ូវបានបង្រៀនអ្នករាល់គ្នា អំពីសេចក្តីអធិស្ឋានរបស់ព្រះអម្ចាស់ហើយទេឬអី? ប្រសិនបើអ្នករាល់គ្នានៅតែមិនទាន់ជឿ ចូរប្រាប់ខ្ញុំមកមើលថា តើអ្នកដែលអ្នករាល់គ្នាហៅថា ព្រះវរបិតា គឺជាអ្នកណា? ប្រសិនបើអ្នកសំដៅលើព្រះយេស៊ូវ ចុះព្រះវរបិតារបស់ព្រះយេស៊ូវជាអ្នកណាចំពោះអ្នករាល់គ្នាវិញ? ក្រោយពេលដែលព្រះយេស៊ូវយាងចេញទៅបាត់ គំនិតបែបនេះអំពីព្រះវរបិតា និងព្រះបុត្រា ក៏លែងមានតទៅទៀត។ គំនិតបែបនេះ ត្រឹមត្រូវតែក្នុងគ្រាដែលព្រះយេស៊ូវ បានត្រឡប់ជាសាច់ឈាមតែប៉ុណ្ណោះ នៅក្នុងកាលៈទេសៈផ្សេងទៀត ពេលដែលអ្នករាល់គ្នាហៅព្រះថាព្រះវរបិតា សម្ពន្ធភាពនេះ គឺគ្រាន់តែជាសម្ពន្ធភាពរវាងព្រះអម្ចាស់នៃសត្តនិករ និងមនុស្សដែលព្រះអង្គបានបង្កើតតែប៉ុណ្ណោះ។ ពុំមានវេលាដែលគំនិតអំពីត្រៃឯកភាពនៃព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធនេះអាចឈរនៅបានឡើយ។ វាជាជំនឿខុសឆ្គងមួយ ដែលកម្រមានគេឃើញក្នុងយុគសម័យទាំងអស់ណាស់ ហើយក៏មិនមាននៅផង!

កត្តានេះធ្វើឲ្យមនុស្សភាគច្រើននឹកឃើញដល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ពីក្នុងគម្ពីរលោកុប្បត្តិថា «ចូរយើងបង្កើតមនុស្សឲ្យដូចរូបយើង ឲ្យមានលក្ខណៈដូចយើង»។ ព្រះបន្ទូលដែលព្រះមានបន្ទូលថា «ចូរយើងធ្វើមនុស្សឲ្យដូចរូបយើង» សំដៅលើអង្គព្រះពីរអង្គ ឬច្រើនជាងនេះ ដ្បិតទ្រង់បានប្រើព្រះបន្ទូលថា «យើង» ដូច្នេះ មិនមែនមានព្រះតែមួយអង្គទេ។ ដោយសារតែការបង្ហាញរបៀបនេះ មនុស្សចាប់ផ្តើមគិតតាមគំនិតអរូបីរបស់អង្គនៃព្រះផ្សេងៗពីគ្នា ហើយពាក្យទាំងនេះផុសចេញពីគំនិតផ្តោតលើព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ។ រួចចុះព្រះវរបិតាមានលក្ខណៈដូចម្តេច? តើព្រះបុត្រាមានលក្ខណៈដូចម្តេច? ហើយព្រះវិញ្ញាណបរិសុទ្ធ មានលក្ខណៈដូចម្តេច? តើអាចទេថា មនុស្សសព្វថ្ងៃត្រូវបានបង្កើតមកតាមរូបអង្គរបស់ព្រះទាំងបីរួមគ្នា? នោះតើរូបកាយរបស់មនុស្សមានលក្ខណៈដូចទៅនឹងព្រះវរបិតា ព្រះរាជបុត្រា

ឬក៏ព្រះវិញ្ញាណបរិសុទ្ធ? តើមនុស្ស មានលក្ខណៈដូចគ្នាទៅនឹងព្រះអង្គណាមួយ? គំនិតរបស់មនុស្សបែបនេះ គឺមិនត្រឹមត្រូវ ហើយចោលម្សៀតទៀតផង! វាអាចត្រឹម បែងចែកព្រះមួយអង្គ ឲ្យក្លាយជាព្រះជាច្រើនអង្គតែប៉ុណ្ណោះ។ ក្នុងគ្រាដែលម៉ូសេ សរសេរបទគម្ពីរលោកុប្បត្តិ មនុស្សជាតិត្រូវបានបង្កើតនៅក្រោយពេលដែលបង្កើត ភពផែនដីនេះរួច។ នៅគ្រាដំបូងបង្អស់ ពេលដែលផែនដីនេះចាប់ផ្ដើមឡើង ម៉ូសេ មិនទាន់មានវត្តមានទេ។ ហើយម៉ូសេក៏បានសរសេរកណ្ឌគម្ពីរនេះ ក្នុងគ្រាក្រោយ ពេលដែលការបង្កើតផែនដីនេះកើតឡើងយ៉ាងយូរ ដូច្នេះ ម្ដេចបានជាគាត់អាចដឹងពី អ្វី ដែលព្រះដែលគង់នៅឯស្ថានសួគ៌មានព្រះបន្ទូល? លោកពុំមានតឹកតាងអ្វីបន្តិចអំពី របៀបដែលព្រះជាម្ចាស់បង្កើតលោកិយនេះឡើងនោះទេ។ នៅក្នុងគម្ពីរសញ្ញាចាស់ ពុំមាននិយាយអំពីព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណទេ គឺមានតែព្រះដ៏ពិតតែ មួយគឺ ព្រះយេហូវ៉ាដែលកំពុងតែអនុវត្តកិច្ចការរបស់ទ្រង់ ក្នុងស្រុកអ៊ីស្រាអែល តែប៉ុណ្ណោះ។ ទ្រង់ត្រូវបានគេហៅដោយព្រះនាមផ្សេងៗពីគ្នា ពេលយុគសម័យ មានការផ្លាស់ប្ដូរ ប៉ុន្តែកត្តានេះមិនអាចបញ្ជាក់ថា ព្រះនាមនីមួយៗសំដៅលើអង្គព្រះ ខុសគ្នានោះដែរ។ ប្រសិនបើដូច្នោះមែន នោះអង្គព្រះដែលនៅក្នុងព្រះជាម្ចាស់មិន ច្រើនឥតគណនាទៅហើយទេឬអី? អ្វីដែលមានចែងនៅក្នុងគម្ពីរសញ្ញាចាស់ គឺជា កិច្ចការរបស់ព្រះយេហូវ៉ា ជាដំណាក់កាលមួយនៃកិច្ចការរបស់ព្រះជាម្ចាស់ផ្ទាល់ សម្រាប់ការផ្ដើមយុគសម័យនៃក្រឹត្យវិន័យ។ គឺកិច្ចការរបស់ព្រះជាម្ចាស់នេះហើយ ដែលនៅពេលទ្រង់មានបន្ទូលនោះវាក៏មានឡើង ពេលទ្រង់បង្គាប់ នោះវាក៏លេច មក។ ពុំមានគ្រាណាមួយដែលព្រះយេហូវ៉ាមានបន្ទូលថា ទ្រង់ជាព្រះវរបិតាដែល យាងមកអនុវត្តកិច្ចការនេះ ហើយទ្រង់ក៏មិនធ្លាប់ថ្លែងទំនាយថា ព្រះរាជបុត្រានឹង យាងប្រោសលោះមនុស្សជាតិដែរ។ នោះមកដល់សម័យព្រះយេស៊ូវ ក៏មានតែត្រឹម ពាក្យថា ព្រះជាម្ចាស់បានត្រឡប់ជាសាច់ឈាម ដើម្បីសង្គ្រោះមនុស្សជាតិ មិនមាន ពាក្យថា ព្រះរាជបុត្រាត្រូវយាងមកនោះទេ។ ដោយសារយុគសម័យទាំងនោះមិន ដូចគ្នា ហើយកិច្ចការដែលព្រះធ្វើដោយផ្ទាល់ក៏ខុសគ្នា ទ្រង់ក៏ត្រូវអនុវត្តកិច្ចការរបស់

ទ្រង់នៅក្នុងភពខុសគ្នា។ អត្តសញ្ញាណដែលទ្រង់តំណាង ក៏ខុសគ្នាទៅតាមរបៀបនេះដែរ។ មនុស្សជឿថា ព្រះយេហូវ៉ាគឺជាព្រះវរបិតារបស់ព្រះយេស៊ូវ តែតាមពិតរឿងនេះមិនត្រូវបានព្រះយេស៊ូវទទួលស្គាល់ទេ ទ្រង់មានព្រះបន្ទូលថា «យើងពុំដែលត្រូវបានបែងចែកជាព្រះវរបិតា និងព្រះរាជបុត្រាឡើយ។ ខ្ញុំនិងព្រះវរបិតាដែលគង់នៅស្ថានសួគ៌ គឺតែមួយ។ ព្រះវរបិតាគង់ក្នុងខ្ញុំ ហើយខ្ញុំក៏នៅក្នុងព្រះវរបិតាខ្ញុំដែរ។ កាលណាមនុស្សមើលឃើញព្រះបុត្រា ពួកគេក៏កំពុងមើលឃើញព្រះវរបិតាដែលគង់នៅស្ថានសួគ៌ដែរ»។ នៅពេលព្រះបន្ទូលទាំងអស់នេះត្រូវបានថ្លែង ទោះជាព្រះវរបិតា ឬព្រះបុត្រាក៏ដោយ ព្រះទាំងពីរអង្គជាវិញ្ញាណតែមួយ មិនមែនព្រះដែលត្រូវបានបែងចែង ក្លាយជាអង្គព្រះដោយឡែកពីគ្នានោះឡើយ។ នៅពេលមនុស្សព្យាយាមពន្យល់បញ្ហាទាំងនោះក៏ចាក់ស្រេះជាមួយនឹងគំនិតថាមានព្រះជាច្រើនអង្គ ហើយក៏មានសម្ព័ន្ធភាពរវាងព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ។ ពេលមនុស្សនិយាយអំពីអង្គព្រះដោយឡែកពីគ្នា តើសម្ដីបែបនេះមិនកំណត់រូបរាងរបស់ព្រះជាម្ចាស់ទេឬអី? មនុស្សថែមទាំងចាត់ថ្នាក់អង្គទាំងបីរបស់ព្រះ ជាព្រះទីមួយ ទីពីរ និងទីបីទៀតផង។ ទាំងអស់នេះ សុទ្ធតែជាការស្រមើស្រមៃរបស់មនុស្ស ពុំសមយកធ្វើជាឯកសារយោង និងមិនប្រាកដប្រជាទាល់តែសោះ! ប្រសិនបើអ្នកសួរបន្ថែមទៀតថា «តើព្រះមានប៉ុន្មាន?» នោះគេ ប្រាកដជាឆ្លើយថា ព្រះជាម្ចាស់ គឺជាព្រះត្រៃឯករួមមានព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ ជាព្រះពិតតែមួយ។ ប្រសិនបើអ្នកសួរគេម្ដងទៀតថា «តើព្រះវរបិតាជាអ្នកណា?» នោះគេនឹង ឆ្លើយថា «ព្រះវរបិតាគឺជាវិញ្ញាណនៃព្រះដែលគង់នៅស្ថានសួគ៌»។ «ទ្រង់គ្រប់គ្រងលើទាំងអស់ ហើយក៏ជាម្ចាស់ឋានសួគ៌ទៀតផង»។ «ចុះព្រះយេហូវ៉ា គឺជាវិញ្ញាណដែរឬទេ?» នោះគេនឹងឆ្លើយ «មែនហើយ!» ប្រសិនបើអ្នកសួរគេថា «តើព្រះរាជបុត្រាគឺជាអ្នកណា?» គេនឹងឆ្លើយថា ពិតណាស់ ព្រះយេស៊ូវ គឺជាព្រះរាជបុត្រា។ ចុះតើអ្វីជាដំណើររឿងព្រះយេស៊ូវ? តើទ្រង់យាងមកពីកន្លែងណា? គេមុខជាឆ្លើយថា «ព្រះយេស៊ូវប្រសូតពីនាងម៉ារា ដោយសារការចាប់បដិសន្ធិរបស់ព្រះវិញ្ញាណបរិសុទ្ធ»។ ចុះតើលក្ខណៈពិតរបស់ទ្រង់ មិនមែន

ជាវិញ្ញាណដែរទេឬអី? តើកិច្ចការរបស់ទ្រង់មិនតំណាងឲ្យកិច្ចការរបស់ទ្រង់ មិនតំណាងកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធទេឬអី? ព្រះយេហូវ៉ាជាវិញ្ញាណ ដូច្នេះហើយលក្ខណៈពិតរបស់ព្រះយេស៊ូវក៏ជាវិញ្ញាណដែរ។ គ្រានេះគឺជាគ្រាចុងក្រោយ នោះមិនចាំបាច់និយាយច្រើនទេថា ទ្រង់នៅតែជាព្រះវិញ្ញាណ តើព្រះទាំងបីអង្គ គឺជាអង្គព្រះខុសគ្នាដោយរបៀបណា? ដូច្នេះ ព្រះទាំងបីអង្គគ្មានអ្វីខុសគ្នាទេ។ ព្រះយេស៊ូវត្រូវបានចាប់បដិសន្ធិដោយព្រះវិញ្ញាណបរិសុទ្ធ ហើយគ្មានអ្វីគួរឲ្យសង្ស័យទេថា កិច្ចការរបស់ទ្រង់គឺពិតជាកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ។ នៅក្នុងដំណាក់កាលទីមួយនៃ កិច្ចការដែលត្រូវបានអនុវត្តដោយព្រះយេហូវ៉ា ទ្រង់បានត្រឡប់ជាសាច់ឈាម និងមិនបានលេចមកឲ្យមនុស្សឃើញដែរ។ ហេតុនេះ មនុស្សមិនធ្លាប់ឃើញការលេចមករបស់ទ្រង់ឡើយ។ ទោះបីទ្រង់អស្ចារ្យ និងខ្ពង់ខ្ពស់យ៉ាងណា ក៏ទ្រង់នៅតែជាវិញ្ញាណដដែលដែរ ជាព្រះជាម្ចាស់ផ្ទាល់ ដែលជាអ្នកបង្កើតមនុស្សមកនៅដើមដំបូងបង្អស់។ មានន័យថា ទ្រង់គឺជាវិញ្ញាណរបស់ព្រះជាម្ចាស់។ ព្រះអង្គមានបន្ទូលមកកាន់មនុស្សពីលើពពក ដែលត្រឹមតែជាវិញ្ញាណមួយប៉ុណ្ណោះ ហើយគ្មាននរណាម្នាក់បានឃើញការលេចមករបស់ទ្រង់ ដោយផ្ទាល់ភ្នែកនោះឡើយ។ មានតែក្នុងយុគសម័យនៃព្រះគុណ នៅពេលដែលវិញ្ញាណនៃព្រះបានត្រឡប់ជាសាច់ឈាម ហើយបានយកកំណើតជាសាច់ឈាមក្នុងស្រុកយូដា ទើបមនុស្សមើលឃើញរូបអង្គព្រះដែលយកកំណើតជាមនុស្សជាលើកទីមួយ ជាសាសន៍យូដាម្នាក់។ គឺគ្មានឃើញអ្វីនៃព្រះយេហូវ៉ាស្ដីពីទ្រង់ឡើយ។ យ៉ាងណាមិញ ទ្រង់បានចាប់បដិសន្ធិដោយវិញ្ញាណនៃព្រះយេហូវ៉ាផ្ទាល់ ហើយព្រះយេស៊ូវនៅតែប្រសូតក្នុងឋានៈជាតំណាងព្រះវិញ្ញាណរបស់ព្រះជាម្ចាស់។ អ្វីដែលមនុស្សមើលឃើញដំបូង គឺព្រះវិញ្ញាណបរិសុទ្ធយាងចុះមកសណ្ឋិតលើព្រះយេស៊ូវ ដូចជាសត្វព្រាប។ ព្រះវិញ្ញាណនេះមិនមែនជាវិញ្ញាណដែលរួមក្នុងព្រះយេស៊ូវទេ តែជាព្រះវិញ្ញាណបរិសុទ្ធវិញ។ ចុះតើវិញ្ញាណរបស់ព្រះយេស៊ូវដោយឡែកពីព្រះវិញ្ញាណបរិសុទ្ធមែនទេ? ប្រសិនបើព្រះយេស៊ូវ គឺជាព្រះយេស៊ូវដ៏ជាព្រះរាជបុត្រា ហើយព្រះវិញ្ញាណបរិសុទ្ធ គឺជាព្រះវិញ្ញាណបរិសុទ្ធ តើព្រះអង្គទាំងពីរ

ជាព្រះតែមួយយ៉ាងដូចម្ដេច? ប្រសិនបើដូច្នេះមែន កិច្ចការនេះមិនអាចអនុវត្តបានឡើយ។ ព្រះវិញ្ញាណដែលនៅក្នុងព្រះយេស៊ូវ ព្រះវិញ្ញាណដែលនៅឯស្ថានសួគ៌ និងព្រះវិញ្ញាណនៃព្រះយេហូវ៉ា គឺជាព្រះវិញ្ញាណតែមួយ។ ព្រះវិញ្ញាណត្រូវបានហៅថាព្រះវិញ្ញាណដ៏បរិសុទ្ធ ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ ព្រះវិញ្ញាណទាំងប្រាំពីរ និងព្រះវិញ្ញាណដែលរួមបញ្ចូលគ្រប់ទាំងអស់។ ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់អាចអនុវត្តនូវកិច្ចការច្រើនណាស់។ ទ្រង់អាចបង្កើតពិភពលោក ហើយទ្រង់ក៏បំផ្លាញពិភពលោកនេះ ដោយបង្កជំនន់ពន្លិចផែនដីនេះក៏បាន។ ទ្រង់អាចប្រោសលោះមនុស្សជាតិ ហើយជាងនេះទៅទៀត ទ្រង់ក៏អាចយកឈ្នះ និងបំផ្លាញមនុស្សជាតិផងដែរ។ កិច្ចការនេះសុទ្ធតែត្រូវបានអនុវត្តដោយព្រះជាម្ចាស់ផ្ទាល់ ហើយមិនអាចត្រូវបានធ្វើឡើងដោយភាពជាអង្គព្រះណាមួយជំនួសទ្រង់បានឡើយ។ ព្រះវិញ្ញាណរបស់ទ្រង់អាចត្រូវហៅចំព្រះនាមថា ព្រះយេហូវ៉ា និងព្រះយេស៊ូវ ក៏ដូចជាព្រះដ៏មានគ្រប់ព្រះចេស្ដា។ ព្រះអង្គគឺជាព្រះអម្ចាស់ និងព្រះគ្រីស្ទ។ ទ្រង់ក៏អាចក្លាយជាកូនមនុស្សដែរ។ ទ្រង់គង់នៅស្ថានសួគ៌ ហើយក៏គង់លើផែនដីនេះផងដែរ ទ្រង់ខ្ពង់ខ្ពស់លើសចក្រវាលទាំងមូល និងក្នុងចំណោមបណ្ដាជនផង។ ទ្រង់គឺជាម្ចាស់តែមួយគត់របស់ផ្ទៃមេឃ និងផែនដី! តាំងតែពីគ្រាបង្កើតផែនដី រហូតមកទល់ពេលនេះ កិច្ចការនេះត្រូវបានអនុវត្តដោយព្រះវិញ្ញាណនៃព្រះដោយផ្ទាល់។ ទាំងកិច្ចការនៅស្ថានសួគ៌ ឬក៏ជាកិច្ចការខាងសាច់ឈាម សុទ្ធតែត្រូវបានអនុវត្តដោយព្រះវិញ្ញាណរបស់ទ្រង់ផ្ទាល់។ សត្តនិករទាំងអស់ ទោះបីជានៅលើមេឃ ឬនៅលើផែនដី សុទ្ធតែនៅក្នុងកណ្ដាប់ព្រះហស្តដ៏មានឫទ្ធានុភាពរបស់ទ្រង់។ ទាំងអស់នេះ គឺសុទ្ធតែជាកិច្ចការរបស់ព្រះជាម្ចាស់ ហើយគ្មាននរណា អាចធ្វើកិច្ចការនេះជំនួសទ្រង់បានឡើយ។ នៅឯស្ថានសួគ៌ ទ្រង់ជាព្រះវិញ្ញាណ ប៉ុន្តែក៏ជាព្រះជាម្ចាស់ផ្ទាល់ដែរ។ នៅក្នុងចំណោមមនុស្សលោក ទ្រង់គឺមនុស្សដែលមានសាច់ឈាម ប៉ុន្តែក៏នៅតែជាព្រះជាម្ចាស់ផ្ទាល់ដែរ។ ទោះបីជាទ្រង់អាចនឹងត្រូវគេហៅដោយព្រះនាមរាប់ពាន់ផ្សេងទៀត ក៏ទ្រង់នៅតែជាព្រះផ្ទាល់ព្រះអង្គដែរ ដែលជាការបង្ហាញឲ្យឃើញផ្ទាល់របស់ព្រះវិញ្ញាណបរិសុទ្ធ ហើយក៏ជា

ការប្រកាសប្រាប់ដល់ជាតិសាសន៍ និងប្រទេសទាំងអស់នៅគ្រាចុងក្រោយផងដែរ។ ព្រះជាម្ចាស់ អាចត្រូវបានហៅថាជាព្រះដ៏មានគ្រប់ព្រះចេស្ដា និងព្រះដ៏ពិតតែមួយ ជាព្រះជាម្ចាស់ផ្ទាល់ ដែលរួមបញ្ចូលគ្រប់ទាំងអស់ នោះទើបជាព្រះនាមដែលអាចហៅបានគ្រប់ពេលវេលា។ អង្គព្រះខុសគ្នានោះ គឺគ្មានទេ ហើយរឹតតែគ្មានជំនឿអំពីព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធផង។ នៅស្ថានសួគ៌ និងផែនដីនេះ គឺមានព្រះតែមួយគត់!

ផែនការគ្រប់គ្រងរបស់ព្រះជាម្ចាស់លាតសន្ធឹងប្រាំមួយពាន់ឆ្នាំ ហើយត្រូវបានបែងចែងជាបីយុគសម័យ ផ្អែកតាមភាពខុសគ្នានៃកិច្ចការរបស់ទ្រង់៖ យុគសម័យទីមួយ ជាយុគសម័យនៃក្រឹត្យវិន័យក្នុងសញ្ញាចាស់។ យុគសម័យទីពីរ គឺជាយុគសម័យនៃព្រះគុណ។ ឯយុគសម័យទីបីជាគ្រាចុងក្រោយ ពោលគឺយុគសម័យនៃនគរព្រះ។ ក្នុងយុគសម័យនីមួយៗ អត្តសញ្ញាណប្លែកមួយត្រូវបានបង្ហាញចេញមក។ នេះក៏ព្រោះតែភាពខុសគ្នាក្នុងកិច្ចការនេះប៉ុណ្ណោះ ពោលគឺ លក្ខខណ្ឌតម្រូវនៃកិច្ចការនេះ។ ដំណាក់កាលទីមួយនៃកិច្ចការក្នុងសម័យនៃក្រឹត្យវិន័យ ត្រូវបានអនុវត្តនៅក្នុងស្រុកអ៊ីស្រាអែល ហើយដំណាក់កាលទីពីរនៃការបញ្ចប់កិច្ចការប្រោសលោះ ត្រូវបានអនុវត្តនៅក្នុងស្រុកយូដា។ សម្រាប់កិច្ចការនៃការប្រោសលោះ ព្រះយេស៊ូវបានមក ប្រសូតតាមរយៈការចាប់បដិសន្ធិដោយព្រះវិញ្ញាណបរិសុទ្ធ និងធ្វើជាព្រះបុត្រាតែមួយគត់។ ទាំងអស់នេះ គឺសុទ្ធតែមកពីលក្ខខណ្ឌតម្រូវនៃកិច្ចការនេះ។ នៅគ្រាចុងក្រោយ ព្រះជាម្ចាស់ចង់បន្សាយកិច្ចការរបស់ទ្រង់ដល់សាសន៍ដទៃ រួចក៏យកឈ្នះមនុស្សនៅទីនោះ ដើម្បីឲ្យព្រះនាមទ្រង់ល្បីរន្ទឺក្នុងចំណោមពួកគេ។ ទ្រង់ចង់ដឹកនាំមនុស្ស ទាំងក្នុងការយល់ដឹង និងការចូលទៅក្នុងសេចក្ដីពិតគ្រប់យ៉ាង។ កិច្ចការទាំងអស់នេះ ត្រូវបានអនុវត្តដោយព្រះវិញ្ញាណតែមួយ។ បើទោះបីជាទ្រង់ប្រហែលជាធ្វើដូច្នេះ តាមទស្សនៈខុសគ្នា តែសណ្ឋាន និងគោលការណ៍នៃកិច្ចការនេះ គឺនៅដូចគ្នាដដែល។ កាលណាអ្នកប្រកាន់ខ្ជាប់តាមគោលការណ៍ និងសណ្ឋានកិច្ចការ ដែលព្រះអង្គបានអនុវត្ត នោះអ្នកនឹងដឹងថា កិច្ចការនេះ គឺសុទ្ធតែត្រូវបាន

ធ្វើឡើងដោយព្រះវិញ្ញាណតែមួយ។ នៅតែមានមនុស្សខ្លះនិយាយថា «ព្រះវរបិតាជាព្រះវរបិតា ព្រះរាជបុត្រាជាព្រះរាជបុត្រាព្រះវិញ្ញាណបរិសុទ្ធជាព្រះវិញ្ញាណបរិសុទ្ធ ហើយនៅទីបំផុត ទាំងបីព្រះអង្គនឹងរួមគ្នាមកតែមួយ»។ តើអ្នកនឹងធ្វើឲ្យព្រះទាំងបីអង្គ រួមគ្នាមកតែមួយដោយវិធីណា? តើព្រះវរបិតា និងព្រះវិញ្ញាណបរិសុទ្ធ រួមគ្នាមកតែមួយដោយវិធីណា? ប្រសិនបើព្រះទាំងពីរអង្គ គឺជាព្រះពីរអង្គរហូតមក ទោះបីជាព្រះទាំងពីរអង្គរួមគ្នាយ៉ាងណា តើទ្រង់ទាំងពីរ មិននៅតែជាព្រះពីរអង្គ ដោយឡែកពីគ្នាទេឬអី? កាលណាអ្នកនិយាយ អំពីការបង្រួមព្រះទាំងពីរអង្គមកតែមួយ តើនោះមិនត្រឹមតែជាការបង្រួមចំណែកពីរ ដើម្បីឲ្យក្លាយជាចំណែកមួយទាំងមូលទេឬអី? ប៉ុន្តែ តើព្រះអង្គទាំងពីរពុំមែនជាចំណែកពីរ មុនពេលរួមគ្នាមកតែមួយទេឬអី? ព្រះវិញ្ញាណនីមួយៗ ទ្រង់មានលក្ខណៈពិតខុសគ្នាហើយព្រះវិញ្ញាណទាំងពីរ មិនអាចបង្រួមគ្នាមកតែមួយបាននោះទេ។ វិញ្ញាណមិនមែនជាវត្ថុធាតុ ហើយក៏មិនដូចនឹងវត្ថុផ្សេងទៀតក្នុងពិភពលោកនេះឡើយ។ ព្រះវរបិតា ជាព្រះវិញ្ញាណមួយ ព្រះរាជបុត្រាជាព្រះវិញ្ញាណមួយ ចំណែកព្រះវិញ្ញាណបរិសុទ្ធជាព្រះវិញ្ញាណមួយផ្សេងទៀត ហើយព្រះវិញ្ញាណទាំងបីរួមគ្នា ដូចជាទឹកបីកែវរួមគ្នាមកតែមួយទាំងមូល។ តើនោះ មិនមែនជាព្រះបីអង្គរួមគ្នាមកតែមួយទេឬអី? នេះជាពន្យល់ដែលខុសសុទ្ធសាធ និងមិនសមហេតុផលទាំងស្រុង! តើនេះមិនមែនជាការបែងចែកព្រះទេឬអី? តើធ្វើយ៉ាងណាអាចឲ្យព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ បង្រួមគ្នាមកតែមួយបាន? តើព្រះទាំងបីអង្គមិនមែនជាចំណែកបី ដែលមានលក្ខណៈខុសគ្នាទេឬអី? នៅតែមានអ្នកផ្សេងទៀតដែលនិយាយថា «តើព្រះជាម្ចាស់មិនបានបញ្ជាក់យ៉ាងច្បាស់ថា ព្រះយេស៊ូវជាព្រះរាជបុត្រស្ងួនភ្ញារបស់ទ្រង់ទេឬអី?» ព្រះយេស៊ូវ គឺជាបុត្រាស្ងួនភ្ញារបស់ព្រះជាម្ចាស់ ជាបុត្រដែលទ្រង់សព្វព្រះហឫទ័យណាស់ ព្រះបន្ទូលនេះ គឺព្រះជាម្ចាស់ផ្ទាល់ជាអ្នកថ្លែងមែន។ គឺព្រះជាម្ចាស់ជាអ្នកធ្វើបន្ទាល់ពីអង្គទ្រង់ផ្ទាល់ តែធ្វើតាមទស្សនៈខុសពីគ្នាប៉ុណ្ណោះ នោះជាព្រះវិញ្ញាណនៅស្ថានសួគ៌ ធ្វើបន្ទាល់ពីរូបកាយសាច់ឈាមរបស់ទ្រង់ផ្ទាល់។ ព្រះយេស៊ូវ គឺជារូបកាយសាច់ឈាមរបស់ទ្រង់ ពុំមែន

ជាព្រះបុត្រារបស់ទ្រង់ដែលនៅស្ថានសួគ៌ទេ។ តើអ្នកយល់ដែរឬទេ? តើព្រះបន្ទូលរបស់ព្រះយេស៊ូវថា «ខ្ញុំសណ្ឋិតក្នុងព្រះវរបិតា ហើយព្រះវរបិតាក៏សណ្ឋិតក្នុងខ្ញុំដែរ» មិនបង្ហាញថា ព្រះអង្គទាំងបី ជាព្រះវិញ្ញាណតែមួយទេឬអី? តើមិនមែនដោយសារតែការយកកំណើតជាសាច់ឈាមទេឬអី ដែលព្រះទាំងបីអង្គត្រូវបានញែកចេញរវាងស្ថានសួគ៌ និងផែនដី? ក្នុងភាពជាក់ស្ដែង ព្រះអង្គទាំងបី គឺនៅតែជាព្រះវិញ្ញាណតែមួយ តែទោះយ៉ាងណាក៏ដោយ នោះគ្រាន់តែជាព្រះ ដែលកំពុងតែធ្វើបន្ទាល់ពីអង្គទ្រង់ផ្ទាល់តែប៉ុណ្ណោះ។ ដោយសារតែការប្រែប្រួលយុគសម័យ លក្ខខណ្ឌតម្រូវនៃកិច្ចការ ហើយនិងដំណាក់កាលខុសៗគ្នានៃផែនការគ្រប់គ្រងរបស់ទ្រង់ ព្រះនាមដែលមនុស្សហៅទ្រង់ក៏ខុសៗគ្នាដែរ។ កាលទ្រង់យាងមកអនុវត្តដំណាក់កាលទីមួយនៃកិច្ចការនេះ ទ្រង់ត្រូវបានគេហៅដោយព្រះនាមថា ព្រះយេហូវ៉ាដែលជាអ្នកគង្វាលនៃសាសន៍អ៊ីស្រាអែល។ នៅក្នុងដំណាក់កាលទីពីរ ព្រះដែលយកកំណើតជាសាច់ឈាមហៅបានត្រឹមថា ព្រះអម្ចាស់ និងព្រះគ្រីស្ទ។ តែនៅពេលនោះ ព្រះវិញ្ញាណដែលគង់នៅស្ថានសួគ៌ បានប្រកាសត្រឹមថា ទ្រង់ជាព្រះរាជបុត្រាស្ងួនភ្ងាររបស់ព្រះជាម្ចាស់ ហើយពុំមានការលើកឡើងអំពីអត្ថិភាពរបស់ទ្រង់ថាជាព្រះរាជបុត្រាតែមួយរបស់ព្រះជាម្ចាស់នោះឡើយ។ រឿងនេះមិនអាចកើតឡើងងាយដូច្នេះទេ។ ម្ដេចបានជាព្រះមានបុត្រតែមួយនោះ? តើព្រះមិនបានក្លាយជាមនុស្សទេឬអី? ដោយសារទ្រង់ជារូបកាយសាច់ឈាម ទើបទ្រង់ត្រូវបានហៅថា ព្រះរាជបុត្រាស្ងួនភ្ងាររបស់ព្រះជាម្ចាស់ ហើយតាំងពីពេលនោះមក សម្ពន្ធភាពរវាងព្រះវរបិតា និងព្រះរាជបុត្រាក៏ចាប់ផ្ដើមមាន។ សម្ពន្ធភាពនេះកើតឡើង ដោយសារការបែងចែករវាងស្ថានសួគ៌ និងផែនដី។ ព្រះយេស៊ូវបានអធិស្ឋានតាមទស្សនៈជាមនុស្សខាងសាច់ឈាម។ ដោយសារតែទ្រង់គ្រងរូបកាយសាច់ឈាមរបស់មនុស្សសាមញ្ញៗ បែបនេះ ទ្រង់មានបន្ទូលតាមទស្សនៈជាមនុស្សថា «សម្បកកាយរបស់ខ្ញុំ គឺជាសម្បកកាយមនុស្ស។ ដោយសារខ្ញុំគ្រងរូបកាយផ្នែកសាច់ឈាមរបស់មនុស្ស ដើម្បីយាងមកផែនដីនេះ ពេលនេះខ្ញុំនៅឆ្ងាយពីស្ថានសួគ៌ណាស់»។ ដោយព្រោះហេតុនេះ ទើបទ្រង់បានត្រឹមតែអាចអធិដ្ឋាន

ទៅឯព្រះដ៏ជាព្រះវរបិតា តាមទស្សនៈជាមនុស្សខាងសាច់ឈាម។ នេះគឺជាកាតព្វកិច្ចរបស់ព្រះអង្គ ហើយវាជាកាតព្វកិច្ចដែលព្រះវិញ្ញាណនៃព្រះដែលយកកំណើតជាមនុស្ស គួរផ្ដល់ជូន។ មិនអាចនិយាយថា ទ្រង់មិនមែនជាព្រះជាម្ចាស់ ដោយសារតែទ្រង់បានអធិស្ឋានទៅរកព្រះវរបិតា តាមទស្សនៈជាមនុស្សខាងសាច់ឈាម។ ទោះបីទ្រង់ត្រូវបានហៅថាជាព្រះរាជបុត្រាស្ងួនភ្ងារបស់ព្រះជាម្ចាស់ ប៉ុន្ដែទ្រង់ក៏នៅតែជាព្រះជាម្ចាស់ផ្ទាល់ដដែល ដ្បិតទ្រង់ជារូបកាយសាច់ឈាមរបស់ព្រះវិញ្ញាណ ហើយលក្ខណៈពិតរបស់ទ្រង់ គឺនៅតែជាវិញ្ញាណ។ មនុស្សឆ្ងល់ពីហេតុផលដែលទ្រង់អធិស្ឋាន ហាក់ដូចទ្រង់ជាព្រះជាម្ចាស់ផ្ទាល់។ មូលហេតុមកពីទ្រង់គឺជាព្រះដែលយកកំណើតជាមនុស្ស ជាព្រះជាម្ចាស់ដែលកំពុងគង់ក្នុងសាច់ឈាម ហើយមិនមែនជាព្រះវិញ្ញាណដែលនៅឯស្ថានសួគ៌នោះឡើយ។ ព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ សុទ្ធតែជាព្រះ។ ទាល់តែព្រះទាំងបីអង្គ រួមគ្នាមកតែមួយ ទើបអាចរាប់ថាជាព្រះពិតតែមួយបានហើយព្រះចេស្ដារបស់ទ្រង់ ក៏អស្ចារ្យខុសពីធម្មតាដោយសារវិធីនេះដែរ។ មានមនុស្សដែលនិយាយថា គឺមានតែវិធីនេះទេទើបទ្រង់អាចធ្វើជាព្រះវិញ្ញាណទាំងប្រាំពីរបាន។ ពេលដែលព្រះរាជបុត្រាអធិស្ឋាន បន្ទាប់ពីទ្រង់យាងមកនោះ ព្រះដែលទ្រង់អធិស្ឋានរក គឺព្រះវិញ្ញាណ។ នៅក្នុងភាពជាក់ស្ដែងទ្រង់កំពុងអធិស្ឋានតាមទស្សនៈជាមនុស្ស។ ទ្រង់មិនពេញលេញ ដោយសារតែសាច់ឈាមមិនពេញលេញ ហើយទ្រង់មាននូវសេចក្ដីកម្សោយជាច្រើន ពេលដែលព្រះអង្គយាងមកក្នុងសាច់ឈាម ហើយទ្រង់ជួបនូវបញ្ហាជាច្រើន នៅពេលដែលទ្រង់អនុវត្តកិច្ចការរបស់ទ្រង់ នៅក្នុងសាច់ឈាម។ ហេតុនេះបានជាទ្រង់អធិស្ឋានបីដងទៅកាន់ព្រះវរបិតា មុនពេលទ្រង់ត្រូវគេឆ្កាង និងជាច្រើនលើកទៀត មុនពេលទ្រង់ជាប់ឆ្កាងផងដែរ។ ទ្រង់បានអធិស្ឋាននៅក្នុងចំណោមពួកសិស្សទ្រង់ ទ្រង់បានអធិស្ឋានម្នាក់អ្នកនៅលើភ្នំ ទ្រង់ក៏បានអធិស្ឋាននៅលើទូកនេសាទ រួចទ្រង់ក៏បានអធិស្ឋាននៅក្នុងចំណោមបណ្ដាជន ទ្រង់ក៏បានអធិស្ឋានទាំងពេលកំពុងកាច់នំបុ័ង ហើយទ្រង់ក៏អធិស្ឋានពេលកំពុងឲ្យពរអ្នកដទៃទៀតផង។ ហេតុអ្វីបានជាទ្រង់ធ្វើដូច្នេះ? ទ្រង់អធិស្ឋានទៅកាន់

ព្រះវិញ្ញាណព្រះអង្គ កំពុងអធិស្ឋានទៅកាន់ព្រះវិញ្ញាណ គឺទៅកាន់ព្រះដែលនៅឯស្ថានសួគ៌ តាមទស្សនៈជាមនុស្សខាងសាច់ឈាម។ ដូច្នេះតាមទស្សនៈរបស់មនុស្ស ព្រះយេស៊ូវ បានក្លាយជាព្រះរាជបុត្រានៅក្នុងដំណាក់កាលនោះ។ យ៉ាងណាមិញ នៅក្នុងដំណាក់កាលនេះ ព្រះអង្គមិនអធិស្ឋានទេ។ ហេតុអ្វីក៏បែបនេះ? នេះគឺមកពីអ្វីដែលទ្រង់នាំយកនោះ គឺជាកិច្ចការនៃព្រះបន្ទូល ព្រមទាំងការជំនុំជម្រះ និងការវាយផ្ចាល។ ទ្រង់មិនត្រូវការនូវការអធិស្ឋាន ហើយព័ន្ធកិច្ចរបស់ទ្រង់ គឺត្រូវថ្លែងព្រះបន្ទូល។ ទ្រង់ពុំមែនត្រូវគេឆ្កាង ហើយទ្រង់ក៏មិនត្រូវមនុស្សចាប់យកទៅឲ្យពួកអ្នកមានអំណាចដែរ។ ទ្រង់គ្រាន់តែអនុវត្តកិច្ចការរបស់ទ្រង់ប៉ុណ្ណោះ។ នៅគ្រាដែលព្រះយេស៊ូវអធិស្ឋាន ទ្រង់កំពុងអធិស្ឋានទៅកាន់ព្រះដ៏ជាព្រះវរបិតា ដើម្បីឲ្យនគរស្ថានសួគ៌មកដល់ ដើម្បីឲ្យព្រះហឫទ័យព្រះវរបិតាបានសម្រេច និងសម្រាប់កិច្ចការដែលនឹងត្រូវមកដល់។ នៅក្នុងដំណាក់កាលនេះ នគរស្ថានសួគ៌បានចុះមកដល់ហើយ តើទ្រង់នៅតែត្រូវការអធិស្ឋានបែបនេះទៀតមែនទេ? កិច្ចការរបស់ទ្រង់ គឺបញ្ចប់យុគសម័យនេះ ហើយពុំមានយុគសម័យថ្មីទៀតទេ ហេតុនេះ ចាំបាច់អ្វីត្រូវអធិស្ឋានសម្រាប់ដំណាក់កាលបន្ទាប់ទៀតនោះ? ខ្ញុំខ្លាចតែគ្មានទេ!

ក្នុងការបកស្រាយរបស់មនុស្ស គឺមាននូវសម្ដីផ្ទុយគ្នាជាច្រើន។ ពិតណាស់ទាំងអស់នេះជាសញ្ញាណរបស់មនុស្ស ប្រសិនបើគ្មានការពិនិត្យពិច័យទេ អ្នករាល់គ្នាមុខជាជឿថា ការពន្យល់របស់ពួកគេសុទ្ធតែត្រឹមត្រូវទាំងអស់។ តើអ្នកមិនដឹងទេឬថា គំនិតបែបនេះដែលថា ព្រះត្រៃឯក គ្មានអ្វីក្រៅពីសញ្ញាណនានារបស់មនុស្សទេឬអី? ចំណេះដឹងរបស់មនុស្ស ពុំមានចំណេះដឹងណាពេញលេញ ឬម៉ត់ចត់នោះទេ។ ភាពស្មោកគ្រោកក៏ចេះតែមាន ហើយមនុស្សក៏មានគំនិតច្រើនដែរ។ នេះបង្ហាញថា មនុស្សម្នាក់មិនអាចត្រឹមតែពន្យល់អំពីកិច្ចការរបស់ព្រះជាម្ចាស់ប៉ុណ្ណោះទេ។ មានរឿងច្រើនណាស់នៅក្នុងគំនិតរបស់មនុស្សទាំងអស់ គឺសុទ្ធតែចេញមកពីហេតុផល និងតម្រិះរបស់គេ ដែលផ្ទុយអំពីសេចក្ដីពិត។ តើហេតុផលរបស់អ្នក អាចកាត់ញែកកិច្ចការរបស់ព្រះជាម្ចាស់ ឲ្យម៉ត់ចត់ដែរឬទេ? តើអ្នកអាចទទួលបានតម្រិះស៊ីជម្រៅ

ក្នុងគ្រប់កិច្ចការទាំងអស់របស់ព្រះយេហូវ៉ាដែរឬទេ? ក្នុងឋានៈជាមនុស្ស តើអ្នកអាចមើលឃើញកិច្ចការទាំងអស់នេះទេ ឬក៏ព្រះជាម្ចាស់ផ្ទាល់ ទើបអាចមើលឃើញពីអស់កល្បជានិច្ចដល់អស់កល្បជានិច្ចបាន។ តើគឺអ្នកមែនទេ ដែលអាចមើលឃើញអតីតកាលពីអស់កល្បជានិច្ច ដល់អនាគតកាលដ៏អស់កល្បជានិច្ច ឬទាល់តែព្រះជាម្ចាស់ ទើបអាចធ្វើបែបនេះបាន? តើអ្នកនិយាយអ្វីខ្លះ? តើអ្នកអាចស័ក្ដិសមនឹងពន្យល់ព្រះជាម្ចាស់ទេ? តើការពន្យល់របស់អ្នកផ្អែកលើអ្វី? តើអ្នកគឺជាព្រះមែនទេ? ស្ថានសួគ៌ និងផែនដីព្រមទាំងរបស់សព្វសារពើ ត្រូវបានបង្កើតដោយព្រះជាម្ចាស់ផ្ទាល់។ អ្នកដែលធ្វើកិច្ចការនេះ គឺមិនមែនជាអ្នកទេ ដូច្នេះ ហេតុអ្វីទើបអ្នកផ្ដល់នូវការពន្យល់មិនត្រឹមត្រូវបែបនេះ? ពេលនេះ តើអ្នកបន្ដជឿលើព្រះត្រៃឯកទៀតដែរឬទេ? តើអ្នកមិនគិតទេថា វិធីនេះគឺជាបន្ទុកខ្លាំងពេកទេឬអី? ល្អបំផុត គឺអ្នកត្រូវជឿលើព្រះតែមួយបាន ហើយ មិនចាំបាច់ជឿព្រះបីអង្គទេ។ ស្រាលខ្លួន គឺជារឿងល្អបំផុត ដ្បិតបន្ទុករបស់ព្រះអម្ចាស់ស្រាលទេ។

# សេចក្ដីពិតនៅខាងក្នុងអំពីកិច្ចការនៃការយកឈ្នះ (១)

មនុស្សជាតិ ដែលត្រូវសាតាំងធ្វើឲ្យពុករលួយជាខ្លាំងនោះ មិនដឹងទេថា មានព្រះជាម្ចាស់មួយអង្គ ហើយបានឈប់ថ្វាយបង្គំព្រះជាម្ចាស់ផង។ កាលដើមដំបូង ពេលដែលអ័ដាម និងអេវ៉ាត្រូវបានបង្កើតមក សិរីល្អ និងទីបន្ទាល់របស់ព្រះយេហូវ៉ា គឺមានវត្តមានជាប់មករហូត។ តែបន្ទាប់ពីត្រូវបានធ្វើឲ្យទៅជាពុករលួយ មនុស្សបានបាត់បង់សិរីល្អ និងទីបន្ទាល់របស់ព្រះជាម្ចាស់ ដ្បិតគ្រប់គ្នាបានបះបោរប្រឆាំងនឹងព្រះជាម្ចាស់ និងលែងកោតខ្លាចទ្រង់ទាំងអស់គ្នា។ កិច្ចការនៃការយកឈ្នះនាពេលសព្វថ្ងៃ គឺដើម្បីស្ដារទីបន្ទាល់ទាំងអស់ និងសិរីល្អទាំងអស់ឡើងវិញ និងដើម្បីឲ្យមនុស្សទាំងអស់ថ្វាយបង្គំព្រះជាម្ចាស់ ប្រយោជន៍ឲ្យមានទីបន្ទាល់នៅក្នុងចំណោមសត្តនិករ នេះហើយជាកិច្ចការ ដែលត្រូវបានធ្វើនៅក្នុងដំណាក់កាលនេះ។ ពិត

ណាស់ តើមនុស្សជាតិត្រូវបានយកឈ្នះដោយរបៀបណា? ដោយការប្រើកិច្ចការនៃព្រះបន្ទូលក្នុងដំណាក់កាលនេះ ដើម្បីឲ្យមនុស្សជឿទាំងស្រុង តាមរយៈការប្រើនូវការលាតត្រដាង ការជំនុំជម្រះ ការវាយផ្ចាល និងការដាក់បណ្ដាសាឥតអាសូរ ដើម្បីបញ្ចុះបញ្ចូលគេទាំងស្រុង តាមរយៈការលាតត្រដាងនូវការបះបោររបស់មនុស្ស និងការជំនុំជម្រះការតតាំងរបស់គេ ដើម្បីឲ្យគេអាចស្គាល់ភាពទុច្ចរិត និងភាពស្មោកគ្រោករបស់មនុស្សជាតិ ហើយប្រើនូវសេចក្ដីទាំងនេះ ជាគ្រឿងបន្ទាប់បន្សំចំពោះនិស្ស័យដ៏សុចរិតរបស់ព្រះជាម្ចាស់។ មនុស្សត្រូវបានយកឈ្នះ និងត្រូវបានជំរុញឲ្យជឿទាំងស្រុងភាគច្រើនគឺតាមរយៈព្រះបន្ទូលទាំងនេះហើយ។ ព្រះបន្ទូលគឺជាមធ្យោបាយនាំទៅរកការយកឈ្នះមនុស្សជាតិចុងក្រោយបំផុត ហើយអស់អ្នកណាដែលទទួលយកការយកឈ្នះរបស់ព្រះជាម្ចាស់ ត្រូវតែទទួលយកការវាយផ្ចួល និងការជំនុំជម្រះនៃព្រះបន្ទូលរបសប់ទ្រង់។ ដំណើរការនៃការថ្លែងព្រះបន្ទូលនៅថ្ងៃនេះ ពិតប្រាកដជាដំណើរការនៃការយកឈ្នះច្បាស់ណាស់។ ចុះមនុស្សគួរសហការដោយវិធីណា? គឺតាមរយៈការហូប និងផឹកព្រះបន្ទូលទាំងនេះ ហើយសម្រេចបាននូវការយល់ដឹងអំពីព្រះបន្ទូលទាំងអស់នេះ។ ចំពោះរឿងថា មនុស្សត្រូវបានយកឈ្នះយ៉ាងណានោះ នេះគឺរឿងដែលពួកគេផ្ទាល់មិនអាចធ្វើបានដោយខ្លួនឯងឡើយ។ តាមរយៈការហូប និងផឹកព្រះបន្ទូលទាំងនេះ គ្រប់យ៉ាងដែលអ្នកអាចធ្វើបានគឺ ត្រូវចាប់ផ្ដើមស្គាល់ពីសេចក្ដីពុករលួយ និងភាពស្មោកគ្រោករបស់អ្នក ស្គាល់ការបះបោរ និងភាពទុច្ចរិតរបស់អ្នក រួចលុតក្រាបនៅចំពោះព្រះជាម្ចាស់។ បន្ទាប់ពីយល់បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ហើយ ប្រសិនបើអ្នកអាចយកការយល់ដឹងនេះទៅអនុវត្ត ហើយប្រសិនបើអ្នកមាននិមិត្ត និងអាចចុះចូលទាំងស្រុងចំពោះព្រះបន្ទូលទាំងនេះ ព្រមទាំងមិនធ្វើការជ្រើសរើសណាមួយដោយខ្លួនឯង នោះអ្នកនឹងត្រូវបានយកឈ្នះហើយ ហើយរឿងទាំងអស់នេះកើតឡើងដោយសារតែព្រះបន្ទូលទាំងអស់នេះ។ ហេតុអ្វីបានជាមនុស្សបាត់បង់ទីបន្ទាល់នេះ? ពីព្រោះគ្មាននរណាម្នាក់មានជំនឿលើព្រះជាម្ចាស់សោះ ដ្បិតព្រះជាម្ចាស់គ្មានកន្លែងគង់ក្នុងចិត្តរបស់មនុស្សទេ។ ការយកឈ្នះមនុស្ស គឺជាការ

ស្ដារសេចក្ដីជំនឿរបស់មនុស្សជាតិឡើងវិញ។ មនុស្សតែងចង់រត់ទៅក្នុងលោកិយដ៏សាមញ្ញនេះទាំងឥតបានគិត ហើយពួកគេបណ្ដុះនូវសេចក្ដីសង្ឃឹមច្រើនជ្រុល ចង់បានច្រើនពេកសម្រាប់អនាគតរបស់គេ ហើយមានការទាមទារច្រើនហួសហេតុ។ ពួកគេតែងតែគិតគូរពីសាច់ឈាមជាប់ជានិច្ច ទាំងត្រៀមផែនការសម្រាប់សាច់ឈាម និងគ្មានចំណាប់អារម្មណ៍ ក្នុងការស្វែងរកផ្លូវនៃជំនឿលើព្រះជាម្ចាស់សោះ។ ដួងចិត្តរបស់គេត្រូវបានសាតាំងឆក់យកបាត់ ពួកគេបានបាត់បង់ការគោរពចំពោះព្រះជាម្ចាស់ ហើយពួកគេក៏ជាប់ជំពាក់តែនឹងសាតាំងដែរ។ តែមនុស្សត្រូវបានព្រះជាម្ចាស់បង្កើតមក។ ដូច្នេះ មនុស្សបានបាត់បង់ទីបន្ទាល់នោះទៅហើយ មានន័យថា គេបានបាត់បង់សិរីល្អរបស់ព្រះជាម្ចាស់ទៅហើយ។ គោលបំណងនៃការយកឈ្នះមនុស្សជាតិ គឺដើម្បីទាមទារមកវិញនូវសិរីល្អនៃការគោរពរបស់មនុស្សចំពោះព្រះជាម្ចាស់។ គេនិយាយបែបនេះថា៖ មានមនុស្សជាច្រើនដែលមិនព្យាយាមឲ្យបានជីវិត ប្រសិនបើមានមនុស្សមួយចំនួនដែលព្យាយាមឲ្យបានជីវិត ពួកគេក៏មានតែក្នុងចំនួនតិចតួចដែរ។ មនុស្សអំពល់នឹងរឿងអនាគតរបស់គេ ហើយមិនយកចិត្តទុកដាក់នឹងជីវិតទេ។ មនុស្សខ្លះបះបោរនឹងព្រះជាម្ចាស់ វិនិច្ឆ័យព្រះអង្គពីក្រោយខ្នង ហើយមិនអនុវត្តសេចក្ដីពិតទេ។ មនុស្សទាំងនេះត្រូវបានព្រងើយកន្តើយនៅពេលនេះ។ ឥឡូវនេះ ពុំមានកិច្ចការអ្វីត្រូវបានធ្វើឡើងចំពោះពួកកូនប្រុសនៃសេចក្ដីបះបោរទាំងអស់នេះទេ តែនៅពេលអនាគត អ្នកនឹងរស់នៅក្នុងសេចក្ដីងងឹតទាំងយំ និងសង្កៀតធ្មេញផង។ អ្នកមិនស្គាល់ពីតម្លៃនៃពន្លឺនោះទេ ពេលដែលអ្នកកំពុងរស់នៅក្នុងពន្លឺ តែអ្នកនឹងស្គាល់ពីតម្លៃនោះពេលដែលអ្នកកំពុងរស់នៅក្នុងយប់ងងឹត ហើយពេលនោះអ្នកនឹងស្ដាយក្រោយ។ ពេលនេះអ្នកមានអារម្មណ៍ធម្មតា តែគង់មានថ្ងៃមួយអ្នកនឹងស្ដាយក្រោយ។ នៅពេលដែលថ្ងៃនោះមកដល់ សេចក្ដីងងឹតនឹងចុះមកដល់ ហើយពន្លឺនឹងលែងមានតទៅទៀត ពេលនោះ ស្ដាយក្រោយក៏ហួសពេលទៅហើយដែរ។ ដោយសារតែអ្នកមិនយល់អំពីកិច្ចការសព្វថ្ងៃ ទើបអ្នកមិនអរសប្បាយនឹងពេលវេលាដែលអ្នកកំពុងមានសព្វថ្ងៃ។ កាលណាកិច្ចការនៃសកលលោកទាំងមូលនេះចាប់ផ្ដើម មានន័យថា ពេលដែល

គ្រប់យ៉ាងដែលខ្ញុំកំពុងថ្លែងនេះក្លាយជាការពិត មនុស្សជាច្រើននឹងទូលដៃឡើង ហើយទ្រហោរយំដោយការឈឺចាប់នៅក្នុងចិត្ត។ ហើយតាមរយៈទង្វើនេះ តើពួកគេនឹងមិនត្រូវធ្លាក់ទៅក្នុងសេចក្ដីងងឹតទាំងយំ និងសង្កៀតធ្មេញទេឬអី? មនុស្សទាំងអស់ដែលព្យាយមឲ្យបានជីវិត និងត្រូវបានប្រោសឲ្យបានពេញខ្នាត អាចនឹងត្រូវបានប្រើ ខណៈដែលពួកកូនប្រុសនៃសេចក្ដីបះបោរ ដែលមិនសមនឹងយកទៅប្រើ នឹងត្រូវធ្លាក់ទៅក្នុងសេចក្ដីងងឹត។ ពួកគេនឹងគ្មានកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ និងមិនអាចធ្វើអ្វីមួយឲ្យមានប្រយោជន៍បានឡើយ។ ដូច្នេះ ពួកគេនឹងត្រូវទ្រុឌទ្រោមដោយសារការទួញសោក ដ្បិតគេត្រូវធ្លាក់ចូលទៅក្នុងការដាក់ទោស។ ប្រសិនបើអ្នកបានទទួលការបំពាក់បំប៉នយ៉ាងល្អ នៅក្នុងដំណាក់កាលនៃកិច្ចការនេះ ហើយអ្នកបានចម្រើនឡើងក្នុងជីវិតរបស់អ្នក នោះអ្នកស័ក្ដិសមនឹងយកទៅប្រើហើយ។ ប្រសិនបើអ្នកមិនបានទទួលការបំពាក់បំប៉នយ៉ាងល្អទេ ទោះបីជាអ្នកត្រូវបានហៅឲ្យទៅធ្វើកិច្ចការដំណាក់កាលបន្ទាប់ ក៏អ្នកមិនស័ក្ដិសមនឹងប្រើការបានដែរ នៅពេលនេះ អ្នកនឹងគ្មានឱកាសម្ដងទៀតឡើយ បើទោះបីជាអ្នកចង់បំពាក់បំប៉នខ្លួនឯងក៏ដោយ។ ព្រះជាម្ចាស់នឹងចាកចេញទៅបាត់ តើអ្នកអាចទៅរកឱកាសនៅចំពោះមុខអ្នកបែបនេះឯណាទៀតនៅពេលនេះ? តើអ្នកអាចទៅទទួលការហ្វឹកហាត់ដែលព្រះជាម្ចាស់ផ្ទាល់ជាអ្នកប្រទានឲ្យនៅឯណាបាន? ពេលនោះ ព្រះជាម្ចាស់នឹងមិនថ្លែងព្រះបន្ទូល ឬបញ្ចេញព្រះសូរសៀងរបស់ទ្រង់ផ្ទាល់ទៀតទេ គ្រប់យ៉ាងដែលអ្នកនឹងអាចធ្វើបានគឺ សង្កេតមើលសេចក្ដីដែលកំពុងត្រូវបានថ្លែងចេញមកនាពេលសព្វថ្ងៃ ពេលនោះ តើការយល់ដឹងនឹងកើតមានយ៉ាងងាយស្រួល ដោយរបៀបណា? តើជីវិតនាថ្ងៃអនាគត អាចនឹងល្អប្រសើរជាងជីវិតសព្វថ្ងៃកម្រិតណា? នៅពេលនោះ តើអ្នកនឹងមិនកំពុងទទួលរងនូវសេចក្ដីស្លាប់ទាំងរស់ ខណៈដែលអ្នកយំ និងសង្កៀតធ្មេញរបស់អ្នកទេឬអី? ពេលនេះ ព្រះពរកំពុងត្រូវបានប្រទានឲ្យអ្នកស្រេចហើយ ប៉ុន្តែអ្នកមិនដឹងពីរបៀបអាស្រ័យផលព្រះពរទាំងនេះទេ។ អ្នកកំពុងតែរស់នៅក្នុងព្រះពរស្រេចហើយ តែអ្នកនៅតែមិនដឹង។ នេះបង្ហាញថា អ្នកត្រូវបានកំណត់ឲ្យវិនាសរងទុក្ខវេទនាហើយ! សព្វថ្ងៃនេះ មនុស្សខ្លះតតាំង មនុស្សខ្លះ

បះបោរ មនុស្សខ្លះធ្វើនេះឬធ្វើនោះ ហើយខ្ញុំគ្រាន់តែព្រងើយកន្តើយ ប៉ុន្តែកុំគិតឲ្យសោះថា ខ្ញុំមិនដឹងថាអ្នកកំពុងធ្វើអ្វី ឬគិតអ្វី។ តើខ្ញុំមិនយល់ពីសារជាតិរបស់អ្នកមែនទេ? ហេតុអ្វីបានជានៅតែរករឿងឈ្លោះនឹងខ្ញុំ? តើអ្នកមិនជឿលើព្រះជាម្ចាស់ ដើម្បីព្យាយាមឲ្យបានជីវិតនិងព្រះពរ ដើម្បីប្រយោជន៍ខ្លួនឯងផ្ទាល់ទេឬអី? ដែលអ្នកមានសេចក្ដីជំនឿនោះតើមិនមែនដើម្បីប្រយោជន៍ផ្ទាល់របស់អ្នកទេឬអី? នាពេលបច្ចុប្បន្ននេះ ខ្ញុំកំពុងធ្វើកិច្ចការយកឈ្នះ តាមរយៈការថ្លែងព្រះបន្ទូលប៉ុណ្ណោះ ហើយកាលណាកិច្ចការនៃការយកឈ្នះនេះឈានដល់ទីបញ្ចប់ នោះទីបញ្ចប់របស់អ្នកនឹងស្ដែងចេញមកយ៉ាងច្បាស់។ តើខ្ញុំរ៉ាយរ៉ាប់ប្រាប់អ្នកយ៉ាងក្បោះក្បាយដែរឬទេ?

កិច្ចការនៃការយកឈ្នះនាពេលសព្វថ្ងៃនេះ ធ្វើឡើងដើម្បីបញ្ជាក់ឲ្យច្បាស់ថាទីបញ្ចប់របស់មនុស្ស នឹងទៅជាយ៉ាងណា។ ហេតុអ្វីបានជាមានការលើកឡើងថាការវាយផ្ចាលនិងការជំនុំជម្រះនាពេលសព្វថ្ងៃនេះ គឺជាការជំនុំជម្រះនៅមុខបល្ល័ង្កសនៅគ្រាចុងក្រោយ? តើអ្នកមើលឃើញការនេះទេ? ហេតុអ្វីបានជាកិច្ចការនៃការយកឈ្នះ គឺជាកិច្ចការដំណាក់កាលចុងក្រោយ? តើការបង្ហាញឲ្យដឹងពីប្រភេទទីបញ្ចប់ដែលជំពូកមនុស្សនីមួយៗនឹងត្រូវជួប នៅមិនច្បាស់ទៀតមែនទេ? នៅក្នុងដំណើរការនៃកិច្ចការនៃការយកឈ្នះ ការវាយផ្ចាល និងការជំនុំជម្រះ តើការនេះមិនអនុញ្ញាតឲ្យមនុស្សគ្រប់គ្នាបង្ហាញពីចរិតពិតរបស់ខ្លួន ហើយបន្ទាប់មក ក៏ត្រូវបែងចែងទៅតាមជំពូក របស់គេទេឬអី? ជំនួសឲ្យការនិយាយថា នេះគឺជាការយកឈ្នះមនុស្សជាតិ ហើយយកល្អគួរតែនិយាយថា នេះគឺជាការបង្ហាញពីប្រភេទទីបញ្ចប់ដែលនឹងមានសម្រាប់ជំពូកមនុស្សនីមួយៗវិញ។ ការនេះ គឺជាការជំនុំជម្រះបាបរបស់មនុស្ស រួចហើយក៏បើកសម្ដែងពីជំពូកមនុស្សផ្សេងៗ ហើយសម្រេចថា ពួកគេជាមនុស្សអាក្រក់ ឬជាមនុស្សសុចរិត។ បន្ទាប់ពីកិច្ចការនៃការយកឈ្នះ កិច្ចការប្រទានរង្វាន់ដល់មនុស្សល្អ និងដាក់ទោសមនុស្សអាក្រក់ ក៏មកដល់។ មនុស្សដែលស្ដាប់បង្គាប់ទាំងស្រុង ពោលគឺមនុស្សដែលត្រូវបានយកឈ្នះទាំងស្រុង នឹងត្រូវដាក់នៅក្នុងជំហានបន្ទាប់នៃការផ្សព្វផ្សាយកិច្ចការរបស់ព្រះជាម្ចាស់ទៅដល់សកលលោក

ទាំងមូល ហើយមនុស្សដែលត្រូវបានយកឈ្នះ នឹងត្រូវដាក់ទៅក្នុងសេចក្ដីងងឹត ហើយនឹងត្រូវជួបទុក្ខលំបាក។ ដូច្នេះ មនុស្សនឹងត្រូវបែងចែកទៅតាមជំពូក គឺមនុស្សដែលប្រព្រឹត្តអំពើអាក្រក់ នឹងត្រូវដាក់ឲ្យនៅជាមួយមនុស្សអាក្រក់ ដោយគ្មានពន្លឺព្រះអាទិត្យម្ដងទៀតឡើយ ហើយមនុស្សសុចរិតនឹងត្រូវដាក់ឲ្យនៅជាមួយមនុស្សល្អ ឲ្យបានទទួលពន្លឺ និងរស់នៅក្នុងពន្លឺអស់កល្បជានិច្ច។ ទីបញ្ចប់សម្រាប់របស់សព្វសារពើ ជិតមកដល់ហើយ។ ទីបញ្ចប់របស់មនុស្ស ត្រូវបានបង្ហាញចេញយ៉ាងច្បាស់ផ្ទាល់ភ្នែករបស់គេ ហើយរបស់សព្វសារពើនឹងត្រូវបែងចែកទៅតាមជំពូករបស់គេ។ ដូច្នេះ តើមនុស្សអាចគេចពីក្ដីបារម្ភរបស់មនុស្សម្នាក់ៗ ដែលត្រូវបែងចែកតាមជំពូករបស់គេយ៉ាងដូចម្ដេច? ទីបញ្ចប់នៃជំពូកនីមួយៗរបស់មនុស្ស ត្រូវបានបង្ហាញចេញនៅពេលដែលទីបញ្ចប់នៃរបស់សព្វសារពើជិតចូលមកដល់ ហើយការនេះនឹងត្រូវបានធ្វើឡើង ខណៈដែលកិច្ចការនៃការយកឈ្នះសកលលោកទាំងមូល កំពុងដំណើរការ (បូករួមទាំងកិច្ចការនៃការយកឈ្នះ ដោយចាប់ផ្ដើមពីកិច្ចការបច្ចុប្បន្ន)។ ការបើកសម្ដែងអំពីទីបញ្ចប់នៃមនុស្សជាតិទាំងអស់ ត្រូវបានធ្វើឡើងនៅមុខបល្ល័ង្កនៃការជំនុំជម្រះ ខណៈដែលកិច្ចការនៃការវាយផ្ចាល និងកិច្ចការនៃការយកឈ្នះនៅគ្រាចុងក្រោយ កំពុងដំណើរការ។ ការបែងចែកមនុស្សទៅតាមជំពូក មិនមែនជាការដាក់មនុស្សឲ្យត្រឡប់ទៅរកជំពូកដើមរបស់គេនោះទេ ដ្បិតកាលដែលមនុស្សត្រូវបានបង្កើតឡើងនៅពេលដែលបង្កើតផែនដី គឺមានមនុស្សតែមួយជំពូកប៉ុណ្ណោះ ការបែងចែកក៏មានតែមួយគត់ដែរ គឺរវាងមនុស្សប្រុស និងមនុស្សស្រី។ មិនមានជំពូកមនុស្សខុសគ្នាច្រើននោះទេ។ គឺក្រោយរយៈពេលរាប់ពាន់ឆ្នាំ នៃសេចក្ដីពុករលួយទើបមានជំពូកមនុស្សខុសៗគ្នាលេចឡើងមក ដោយមានអ្នកខ្លះស្ថិតក្រោមអំណាចគ្រប់គ្រងរបស់វិញ្ញាណស្មោកគ្រោក អ្នកខ្លះស្ថិតក្រោមអំណាចគ្រប់គ្រងរបស់វិញ្ញាណឃោរឃៅ ឯអស់អ្នកដែលព្យាយាមឲ្យបានជីវិត ស្ថិតក្រោមអំណាចគ្រប់គ្រងរបស់ព្រះដ៏មានគ្រប់ព្រះចេស្ដា។ មានតែតាមវិធីនេះទេ ទើបការបែងចែកជាក្រុម កើតមានឡើងក្នុងចំណោមមនុស្ស ហើយមានតែតាមវិធីនេះទេ ទើបមនុស្សចែកគ្នាជាក្រុមៗ នៅក្នុង

គ្រួសារដ៏ធំរបស់មនុស្សបាន។ មនុស្សទាំងអស់កើតមកមាន «ឪពុក» ខុសៗគ្នា ហើយវាមិនមែនជាករណីដែលថា គ្រប់ៗគ្នាសុទ្ធតែស្ថិតនៅក្រោមអំណាចត្រួតត្រារបស់ព្រះដ៏មានគ្រប់ព្រះចេស្ដានោះដែរ ដ្បិតមនុស្សបះបោរខ្លាំងពេក។ ការជំនុំជម្រះដ៏សុចរិតលាតត្រដាងនូវសភាពអត្ថិភាពពិតនៃជំពូកមនុស្សនីមួយៗ គ្មាននៅសល់អ្វីបន្ដិចត្រូវលាក់កំបាំងឡើយ។ គ្រប់គ្នាបង្ហាញមុខមាត់ពិតរបស់ខ្លួននៅក្នុងពន្លឺ។ នៅពេលនេះមនុស្សលែងមានសភាពដូចដើមទៀតហើយ ភាពដូចគ្នាពីដើមនៃបុព្វបុរសរបស់គេបានរលាយបាត់ជាយូរមកហើយ ពីព្រោះកូនចៅរបស់អ័ដាម និងអេវ៉ារាប់មិនអស់ត្រូវសាតាំងចាប់យកជាយូរមកហើយ ក៏មិនបានស្គាល់ពន្លឺស្ថានសួគ៌ម្ដងទៀតឡើយ ហើយក៏ដោយសារតែមនុស្សមានពេញដោយចរិតពិសពុលគ្រប់យ៉ាងរបស់សាតាំងដែរ។ ដូច្នេះ មនុស្សមានទិសដៅដ៏ត្រឹមត្រូវរបស់ខ្លួនហើយ។ ជាងនេះទៅទៀត ពួកគេត្រូវបានបែងចែកទៅតាមជំពូក ដោយផ្អែកលើភាពពិសពុលខុសៗគ្នារបស់ពួកគេ មានន័យថា ពួកគេត្រូវបានបែងចែកទៅតាមកម្រិត ដែលពួកគេត្រូវបានយកឈ្នះនៅថ្ងៃនេះ។ ទីបញ្ចប់របស់មនុស្សមិនមែនកត្ដាដែលត្រូវកំណត់ទុកជាមុនតាំងពីគ្រាកំណើតផែនដីនោះទេ។ នោះគឺមកពីកាលដើមឡើយ មនុស្សមានតែមួយក្រុមគត់ដែលហៅជារួមថា «មនុស្សជាតិ» ហើយដំបូងឡើង មនុស្សក៏មិនត្រូវសាតាំងធ្វើឲ្យពុករលួយដែរ ពួកគេទាំងអស់សុទ្ធតែរស់នៅក្នុងពន្លឺរបស់ព្រះជាម្ចាស់ ដោយគ្មានសេចក្ដីងងឹត ធ្លាក់មកលើពួកគេនោះឡើយ។ តែបន្ទាប់ពីមនុស្សត្រូវសាតាំងធ្វើឲ្យពុករលួយ មនុស្សគ្រប់ប្រភេទ គ្រប់ជំពូក ក៏ខ្ចាត់ខ្ចាយទៅពេញផែនដី គឺមនុស្សគ្រប់ប្រភេទ គ្រប់ជំពូក ដែលកើតចេញពីគ្រួសារមួយដែលគេហៅជារួមថា «មនុស្សជាតិ» ដែលប្រមូលផ្ដុំដោយមនុស្សទាំងប្រុសទាំងស្រី។ ពួកគេទាំងអស់ត្រូវបានបុព្វបុរសរបស់គេដឹកនាំឲ្យវង្វេងចេញពីបុព្វបុរសដើមបង្អស់របស់គេ គឺមនុស្សជាតិដែលមានមនុស្សប្រុស និងមនុស្សស្រី (ពោលគឺ អ័ដាម និងអេវ៉ានៅពេលដើមដំបូងបង្អស់ ដែលជាបុព្វបុរសដ៏ចំណាស់បំផុតរបស់ពួកគេ)។ នៅពេលនោះ ជនជាតិអ៊ីស្រាអែលជាមនុស្សមួយក្រុមគត់នៅលើផែនដី ដែលមានជីវិតដឹកនាំដោយព្រះយេហូវ៉ា។ មនុស្ស

ជំនាន់ដើមទាំងអស់នេះ ព្រងើយកន្ដើយនឹងបញ្ហានានាក្នុងពិភពមនុស្សទាំងស្រុង តែក្រោយមកគេក៏ដើរតាមគន្លងបុព្វបុរសរបស់គេ ទៅរស់នៅក្នុងដែនដីដែលពួកគេប្រកាសថាជារបស់ខ្លួន បន្តរហូតមកទល់សម័យបច្ចុប្បន្ន។ ដូច្នេះ ពួកគេក៏នៅតែព្រងើយកន្ដើយចំពោះការដែលពួកគេវង្វេងចេញពីព្រះយេហូវ៉ា និងចំពោះការដែលពួកគេត្រូវធ្វើឲ្យពុករលួយដោយវិញ្ញាណស្មោកគ្រោក និងវិញ្ញាណអាក្រក់គ្រប់យ៉ាងរហូតដល់សព្វថ្ងៃនេះ។ អស់អ្នកដែលត្រូវបានធ្វើឲ្យពុករលួយ និងត្រូវបំពុលខ្លាំងរហូតមកទល់សព្វថ្ងៃនេះ គឺអស់អ្នកដែលមិនអាចនឹងត្រូវបានសង្គ្រោះនៅចុងបំផុតនោះ នឹងគ្មានជម្រើសអ្វីក្រៅតែពីដើរទៅជាមួយបុព្វបុរសរបស់គេ គឺជាវិញ្ញាណស្មោកគ្រោកដែលធ្វើឲ្យពួកគេពុករលួយនោះឡើយ។ អស់អ្នកដែលអាចបានសង្គ្រោះនៅទីបំផុតនោះ នឹងឆ្ពោះទៅរកទិសដៅដ៏ត្រឹមត្រូវរបស់មនុស្សជាតិ ជាទីបញ្ចប់ដែលត្រូវបានរក្សាទុក សម្រាប់មនុស្សដែលត្រូវបានសង្គ្រោះ និងត្រូវបានយកឈ្នះ។ គ្រប់យ៉ាងនឹងត្រូវធ្វើឡើងដើម្បីសង្គ្រោះអស់អ្នកដែលអាចត្រូវបានសង្គ្រោះ ប៉ុន្ដែសម្រាប់មនុស្សដែលគ្មានស្មារតី និងមិនអាចព្យាបាលបាន ជម្រើសតែមួយគត់របស់គេ គឺត្រូវដើរតាមបុព្វបុរសរបស់គេទៅក្នុងជង្ហុកធំនៃការវាយផ្ចាល។ សូមកុំគិតថា ទីបញ្ចប់របស់អ្នកត្រូវបានកំណត់ទុកតាំងតែពីដើមដំបូង ហើយពេលនេះទើបត្រូវបានបើកសម្ដែងឲ្យដឹងនោះឡើយ។ ប្រសិនបើអ្នកគិតដូច្នេះមែន តើអ្នកភ្លេចហើយមែនទេថា ក្នុងគ្រាដំបូងដែលមនុស្សត្រូវបង្កើតមក ពុំមានក្រុមមនុស្សអាក្រក់ត្រូវបានបង្កើតមកទេឬអី? តើអ្នកភ្លេចហើយមែនទេថា មានតែមនុស្សជាតិមួយក្រុមគត់ដែលប្រមូលផ្ដុំឡើងដោយអ័ដាម និងអេវ៉ាដែលត្រូវបានបង្កើតមក (មានន័យថា មានតែមនុស្សប្រុស និងមនុស្សស្រីប៉ុណ្ណោះត្រូវបានបង្កើតឡើង)? ប្រសិនបើអ្នកគឺជាពូជរបស់សាតាំងតាំងពីដើមមក តើនេះមិនមែនមានន័យថា កាលដែលព្រះយេហូវ៉ាបានបង្កើតមនុស្សមក ទ្រង់បានបញ្ចូលក្រុមមនុស្សអាក្រក់ នៅក្នុងសត្តនិកររបស់ទ្រង់ដែរមែនទេ? តើទ្រង់អាចធ្វើកិច្ចការដូច្នេះដែរឬទេ? ព្រះអង្គបានបង្កើតមនុស្សមកសម្រាប់ជាប្រយោជន៍ដល់ទីបន្ទាល់របស់ទ្រង់ ព្រះអង្គបានបង្កើតមនុស្សសម្រាប់ជាប្រយោជន៍ដល់សិរីល្អរបស់

ទ្រង់។ ហេតុអ្វីក៏ទ្រង់បង្កើតក្រុមកូនចៅរបស់សាតាំងដោយចេតនាឲ្យមកតតាំងនឹងទ្រង់ខ្លាំងដល់ម្លឹង? ម្ដេចបានជាព្រះយេហូវ៉ាធ្វើដល់ម្លឹង? ប្រសិនបើទ្រង់ធ្វើដូច្នេះមែន តើនរណានឹងនិយាយថា ព្រះអង្គគឺជាព្រះជាម្ចាស់ដ៏សុចរិត? ពេលនេះ នៅពេលដែលខ្ញុំនិយាយថា នៅទីបញ្ចប់ អ្នកខ្លះនៅក្នុងចំណោមអ្នករាល់គ្នា នឹងទៅជាមួយសាតាំង មិនមែនមានន័យថា អ្នកនៅជាមួយសាតាំង តាំងតែពីដើមមកទេ ផ្ទុយទៅវិញ វាមានន័យថា អ្នកបានផុងលង់យ៉ាងជ្រៅ ដល់ថ្នាក់សូម្បីតែព្រះជាម្ចាស់ព្យាយាមសង្គ្រោះអ្នក ក៏អ្នកនៅតែមិនទទួលបានសេចក្ដីសង្គ្រោះនោះដែរ។ គ្មានជម្រើសអ្វីផ្សេងឡើយ ក្រៅតែពីដាក់អ្នកឲ្យនៅក្នុងក្រុមជាមួយសាតាំង។ នេះគឺមកពីអ្នកនៅហួសពីសេចក្ដីសង្គ្រោះ មិនមែនមកពីព្រះជាម្ចាស់ទុច្ចរិតចំពោះអ្នក និងមានចេតនាកំណត់វាសនារបស់អ្នកឲ្យធ្វើជាតំណាងរបស់សាតាំង បន្ទាប់មកក៏ដាក់អ្នកក្នុងក្រុមជាមួយសាតាំង និងមានគោលបំណងចង់ឲ្យអ្នករងទុក្ខវេទនានោះទេ។ នោះមិនមែនជារឿងពិតដ៏ពិស្ដារនៃកិច្ចការយកឈ្នះនោះឡើយ។ ប្រសិនបើនោះគឺជាអ្វីដែលអ្នកជឿ នោះការយល់ដឹងរបស់អ្នកលម្អៀងជ្រុលពេកហើយ! ដំណាក់កាលចុងក្រោយនៃការយកឈ្នះ ធ្វើឡើងដើម្បីសង្គ្រោះមនុស្ស និងដើម្បីបង្ហាញពីទីបញ្ចប់របស់គេដែរ។ កិច្ចការនេះធ្វើឡើង ដើម្បីលាតត្រដាងពីឱនភាពរបស់មនុស្ស តាមរយៈការជំនុំជម្រះ និងធ្វើឲ្យគេប្រែចិត្ត ឲ្យគេក្រោកឡើងនិងឲ្យគេព្យាយាមឲ្យបានជីវិត និងផ្លូវត្រូវនៃជីវិតមនុស្ស។ ការនេះគឺដើម្បីដាស់ចិត្តរបស់មនុស្សស្ពឹកស្រពន់ និងមនុស្សល្ងង់ខ្លៅ និងដើម្បីបង្ហាញការបះបោរក្នុងជម្រៅចិត្តរបស់គេ តាមរយៈការជំនុំជម្រះ។ យ៉ាងណាមិញ ប្រសិនបើមនុស្សនៅតែមិនអាចប្រែចិត្ត នៅតែមិនអាចព្យាយាមឲ្យបានផ្លូវនៃជីវិតមនុស្ស និងមិនអាចបោះបង់សេចក្ដីពុករលួយទាំងអស់នេះ នោះពួកគេអាក្រក់ហួសដែលអាចបានសង្គ្រោះ និងត្រូវលេបត្របាក់ដោយសាតាំងជាមិនខាន។ នេះហើយជាសារៈសំខាន់នៃការយកឈ្នះរបស់ព្រះជាម្ចាស់៖ គឺដើម្បីសង្គ្រោះមនុស្ស និងដើម្បីបង្ហាញពីទីបញ្ចប់របស់ពួកគេ។ ទីបញ្ចប់ដ៏ល្អ និងទីបញ្ចប់អាក្រក់ទាំងអស់នេះ សុទ្ធតែត្រូវបានបើកសម្ដែងឲ្យឃើញតាមរយៈកិច្ចការនៃការយកឈ្នះ។ មិនថា

មនុស្សនឹងត្រូវបានសង្គ្រោះ ឬក៏ត្រូវបណ្ដាសានោះទេ គឺសុទ្ធតែត្រូវបានបើកសម្ដែងឱ្យឃើញក្នុងអំឡុងពេលកិច្ចការនៃការយកឈ្នះ។

គ្រាចុងក្រោយ គឺជាគ្រាដែលរបស់សព្វសារពើ នឹងត្រូវបែងចែកជាក្រុមតាមប្រភេទ តាមរយៈការយកឈ្នះ។ ការយកឈ្នះ គឺជាកិច្ចការនៅគ្រាចុងក្រោយ ហើយអាចនិយាយម្យ៉ាងទៀតបានថា ការជំនុំជម្រះបាបរបស់បុគ្គលម្នាក់ៗ គឺជាកិច្ចការនៅគ្រាចុងក្រោយ។ បើមិនដូច្នោះ តើធ្វើយ៉ាងទើបអាចបែងចែកមនុស្សជាក្រុមបាន? កិច្ចការនៃការបែងចែកក្រុម ដែលត្រូវបានធ្វើឡើងក្នុងចំណោមអ្នករាល់គ្នា គឺជាការចាប់ផ្ដើមកិច្ចការនេះនៅក្នុងសកលលោកទាំងមូល។ បន្ទាប់ពីនេះមក គ្រប់ទឹកដីនិងគ្រប់មនុស្សទាំងអស់ ក៏នឹងត្រូវដាក់ឲ្យនៅក្រោមកិច្ចការនៃការយកឈ្នះដែរ។ នេះមានន័យថា មនុស្សគ្រប់គ្នានៅក្នុងការបង្កើត នឹងត្រូវបែងចែកជាក្រុមតាមប្រភេទ ដោយចុះចូលនៅចំពោះបល្ល័ង្កនៃការជំនុំជម្រះ ដើម្បីទទួលការជំនុំជម្រះ។ គ្មានមនុស្សណាម្នាក់ ឬមានអ្វីមួយអាចគេចផុតពីការទទួលរងនូវការវាយផ្ចាល និងការជំនុំជម្រះ ក៏គ្មានមនុស្សណាម្នាក់ ឬគ្មានអ្វីមួយ ដែលមិនត្រូវបានបែងចែកទៅតាមប្រភេទនោះដែរ។ មនុស្សគ្រប់រូប នឹងត្រូវបែងចែកជាក្រុម ដ្បិតទីបញ្ចប់នៃរបស់សព្វសារពើចូលមកកាន់តែកៀក ហើយស្ថានសួគ៌និងផែនដី បានឈានដល់ទីបញ្ចប់របស់ខ្លួនហើយ។ តើមនុស្សអាចគេចផុតពីគ្រាចុងក្រោយ នៃអត្ថិភាពរបស់មនុស្សយ៉ាងដូចម្ដេច? ដូច្នេះហើយ តើទង្វើរឹងចចេសរបស់អ្នករាល់គ្នា អាចនៅបន្តបានយូរប៉ុនណាទៀត? តើអ្នកមើលមិនឃើញទេថា គ្រាចុងក្រោយរបស់អ្នកកំពុងខិតមកកាន់តែជិត? តើម្ដេចបានជាមនុស្សដែលគោរពកោតខ្លាចព្រះជាម្ចាស់ និងចង់ឲ្យព្រះអង្គលេចមក មិនអាចមើលឃើញគ្រាដែលសេចក្ដីសុចរិតរបស់ព្រះជាម្ចាស់លេចមក? តើម្ដេចបានជាពួកគេមិនអាចទទួលរង្វាន់ជាចុងក្រោយ សម្រាប់សេចក្ដីល្អបាន? តើអ្នកគឺជាមនុស្សដែលប្រព្រឹត្តអំពើល្អ ឬជាមនុស្សដែលប្រព្រឹត្តអំពើអាក្រក់? តើអ្នកជាមនុស្សដែលទទួលយកការជំនុំជម្រះដ៏សុចរិត រួចស្ដាប់តាមបង្គាប់ ឬក៏អ្នកជាមនុស្សដែលទទួលយកការជំនុំជម្រះដ៏សុចរិត រួចហើយត្រូវបណ្ដាសា? តើអ្នករស់នៅមុខបល្ល័ង្ក

នៃការជំនុំជម្រះក្នុងពន្លឺ ឬអ្នករស់នៅក្នុងស្ថានឃុំព្រលឹងមនុស្សស្លាប់ ក្នុងសេចក្ដីងងឹត? តើអ្នកផ្ទាល់ មិនមែនជាមនុស្សម្នាក់ដែលដឹងច្បាស់ជាងគេថា ទីបញ្ចប់របស់អ្នកជាទីបញ្ចប់នៃរង្វាន់ ឬទីបញ្ចប់នៃការដាក់ទោសទេឬអី? តើអ្នកមិនមែនជាមនុស្សម្នាក់ដែលដឹង និងយល់ច្បាស់ជាងគេបំផុត ថាព្រះជាម្ចាស់ ទ្រង់សុចរិតទេឬ អី? ដូច្នេះ តើការប្រព្រឹត្ត និងដួងចិត្តរបស់អ្នក ប្រៀបបានទៅនឹងអ្វី? នៅពេលដែលខ្ញុំយកឈ្នះអ្នកនៅថ្ងៃនេះ តើអ្នកពិតជាត្រូវការឲ្យខ្ញុំប្រាប់អ្នកទេថា ឥរិយាបថរបស់អ្នក ល្អ ឬអាក្រក់? តើអ្នកបានលះបង់សម្រាប់ខ្ញុំច្រើនប៉ុនណាហើយ? តើអ្នកថ្វាយបង្គំខ្ញុំជ្រាលជ្រៅកម្រិតណា? តើអ្នកផ្ទាល់មិនដឹងច្បាស់ទេថា អ្នកមានអាកប្បកិរិយាយ៉ាងណាចំពោះខ្ញុំ? អ្នកគួរតែដឹងច្បាស់ជាងនរណាទាំងអស់ថា ទីបញ្ចប់ចុងក្រោយបំផុតរបស់អ្នកនឹងទៅជាយ៉ាងណា! ខ្ញុំប្រាប់អ្នកជាប្រាកដថា៖ ខ្ញុំបានបង្កើតតែមនុស្សមកទេ ហើយខ្ញុំបានបង្កើតអ្នកមក ប៉ុន្តែខ្ញុំមិនបានប្រគល់អ្នកទៅឲ្យសាតាំងទេ ខ្ញុំក៏គ្មានចេតនាបង្ខំឲ្យអ្នករាល់គ្នាប្រឆាំង ឬតតាំងនឹងខ្ញុំ ហើយឲ្យអ្នកត្រូវទទួលទោសពីខ្ញុំដែរ។ តើសេចក្ដីទុក្ខលំបាក និងការរងទុក្ខវេទនាទាំងអស់នេះ មិនមែនដោយសារតែ ដួងចិត្តរបស់អ្នករាល់គ្នារឹងរូសពេក ហើយកិរិយាប្រព្រឹត្តរបស់អ្នករាល់គ្នា គួរឲ្យស្អប់ពេកទេឬអី? ដូច្នេះ តើទីបញ្ចប់ដែលអ្នករាល់គ្នានឹងជួបប្រទះ មិនត្រូវបានកំណត់ដោយខ្លួនអ្នករាល់គ្នាផ្ទាល់ទេឬអី? តើអ្នករាល់គ្នាមិនដឹងច្បាស់ក្នុងចិត្តខ្លួនឯងជាងនរណាទាំងអស់ទេថា ទីបញ្ចប់របស់អ្នកនឹងទៅជាយ៉ាងណា? ហេតុផលដែលខ្ញុំយកឈ្នះមនុស្ស គឺដើម្បីបង្ហាញឲ្យគេឃើញកាន់តែច្បាស់ និងនាំយកសេចក្ដីសង្គ្រោះមកឲ្យអ្នក។ មិនមែនមកបង្ខំឲ្យអ្នកប្រព្រឹត្តការអាក្រក់ ក៏មិនមែនមានចេតនាបង្ខំឲ្យអ្នកដើរទៅរកស្ថាននរកនៃសេចក្ដីហិនវិនាសដែរ។ លុះដល់វេលាកំណត់ ទុក្ខវេទនាដ៏ធំធេងរបស់អ្នកទាំងអស់គ្នា ការទ្រហោយំ និងការសង្កៀតធ្មេញរបស់អ្នក តើមិនមែនសុទ្ធតែដោយសារបាបរបស់អ្នកទេឬអី? ដូច្នេះ តើមិនមែនជាសេចក្ដីល្អ ឬសេចក្ដីអាក្រក់របស់អ្នកទេឬអី ដែលជាការជំនុំជម្រះដ៏ប្រសើបំផុតរបស់អ្នករាល់គ្នានោះ? តើវាមិនមែនជាភ័ស្ដុតាងបញ្ជាក់យ៉ាងច្បាស់អំពីទីបញ្ចប់របស់អ្នកទេឬអី?

សព្វថ្ងៃនេះ ខ្ញុំធ្វើការនៅក្នុងចំណោមរាស្ត្ររើសតាំងរបស់ព្រះជាម្ចាស់ នៅក្នុងប្រទេសចិន ដើម្បីបើកសម្ដែងពីនិស្ស័យបះបោរទាំងអស់របស់គេ ព្រមទាំងបកអាក្រាតពីសេចក្ដីអាក្រក់ទាំងអស់របស់គេ ហើយការនេះផ្ដល់នូវបរិបទសម្រាប់ការនិយាយអ្វីៗគ្រប់យ៉ាង ដែលខ្ញុំត្រូវនិយាយ។ បន្ទាប់មកទៀត នៅពេលដែលខ្ញុំអនុវត្តជំហានបន្ទាប់នៃកិច្ចការយកឈ្នះសកលលោកទាំងមូល ខ្ញុំនឹងប្រើការជំនុំជម្រះរបស់ខ្ញុំចំពោះអ្នករាល់គ្នា មកជំនុំជម្រះភាពទុច្ចរិតរបស់មនុស្សគ្រប់គ្នានៅក្នុងសកលលោកទាំងមូល ដ្បិតអ្នករាល់គ្នាជាតំណាងរបស់ពួកបះបោរក្នុងចំណោមមនុស្សជាតិ។ អស់អ្នកដែលមិនអាចឈានឡើងទៅមុខ នឹងបានត្រឹមក្លាយទៅជាគ្រឿងបន្ទាប់បន្សំ និងជាវត្ថុសម្រាប់បម្រើតែប៉ុណ្ណោះ ចំណែកមនុស្សដែលអាចឈានឡើងទៅមុខ នឹងត្រូវយកទៅប្រើការ។ ហេតុអ្វីបានជាខ្ញុំនិយាយថា មនុស្សដែលមិនអាចឈានឡើងទៅមុខបានត្រឹមដើរតួជាមនុស្សបន្ទាប់បន្សំ? មកពីព្រះបន្ទូល និងកិច្ចការរបស់ខ្ញុំនាពេលបច្ចុប្បន្នសុទ្ធតែតម្រង់ទៅរកសាវតាររបស់អ្នករាល់គ្នា និងដោយសារតែអ្នករាល់គ្នាបានក្លាយជាតំណាង និងជាគំរូនៃពួកបះបោរក្នុងចំណោមមនុស្សជាតិទាំងអស់។ ក្រោយមក ខ្ញុំនឹងយកព្រះបន្ទូលដែលយកឈ្នះអ្នករាល់គ្នានេះ ទៅកាន់បណ្ដាប្រទេសដទៃទៀត ហើយប្រើព្រះបន្ទូលនេះ ដើម្បីយកឈ្នះមនុស្សនៅទីនោះ ប៉ុន្តែអ្នកនឹងមិនទទួលបានព្រះបន្ទូលនោះឡើយ។ តើការនេះមិនបានធ្វើឲ្យអ្នកក្លាយជាមនុស្សបន្ទាប់បន្សំទេឬអី? និស្ស័យពុករលួយរបស់មនុស្សជាតិទាំងអស់ ទង្វើបះបោររបស់មនុស្ស ព្រមទាំងរូបភាព និងទឹកមុខដ៏អាក្រក់របស់មនុស្សទាំងអស់នេះ គឺសុទ្ធតែត្រូវបានកត់ត្រានៅថ្ងៃនេះ នៅក្នុងព្រះបន្ទូលដែលបានប្រើសម្រាប់យកឈ្នះអ្នករាល់គ្នា។ បន្ទាប់មក ខ្ញុំនឹងប្រើព្រះបន្ទូលនេះ មកយកឈ្នះមនុស្សពីគ្រប់ប្រជាជាតិ និងគ្រប់គណៈនិកាយ ពីព្រោះអ្នករាល់គ្នាគឺជាគំរូ ជាឧទាហរណ៍ស្រាប់។ យ៉ាងណាមិញ ខ្ញុំមិនបានប្រកាសបោះបង់អ្នករាល់គ្នា ដោយចេតនានោះឡើយ ប្រសិនបើអ្នកធ្វើមិនបានល្អនៅក្នុងការព្យាយាមឲ្យបានរបស់អ្នករាល់គ្នា ដូច្នេះ បញ្ជាក់ថា អ្នកគឺជាមនុស្សដែលមើលមិនជាឡើយ តើអ្នកមិនមែនកំពុងដើរតួជាវត្ថុបម្រើ និងជាគ្រឿងបន្ទាប់បន្សំទេឬអី?

ខ្ញុំធ្លាប់និយាយថា ប្រាជ្ញារបស់ខ្ញុំត្រូវបានប្រើប្រាស់ដោយផ្អែកលើគ្រោងការណ៍របស់សាតាំង។ ហេតុអ្វីបានជាខ្ញុំនិយាយដូច្នេះ? តើនោះមិនមែនជាសេចក្ដីពិតពីក្រោយអ្វីដែលខ្ញុំកំពុងនិយាយ និងកំពុងធ្វើទេឬអី? ប្រសិនបើអ្នកមិនអាចឈានឡើងទៅមុខ ប្រសិនបើអ្នកមិនត្រូវបានប្រោសឲ្យបានគ្រប់លក្ខណ៍ តែបែជាត្រូវទទួលទោសវិញនោះ តើអ្នកមិនក្លាយជាមនុស្សបន្ទាប់បន្សំទេឬអី? ប្រហែលជាអ្នកធ្លាប់បានរងទុក្ខច្រើនគួរសមនៅក្នុងជីវិតរបស់អ្នក ប៉ុន្តែអ្នកនៅតែមិនយល់អ្វីសោះអ្នកនៅតែកន្តើយនឹងរឿងគ្រប់យ៉ាងក្នុងជីវិត។ ទោះបីជាអ្នកធ្លាប់បានវាយផ្ចាល និងជំនុំជម្រះ ក៏អ្នកមិនធ្លាប់បានផ្លាស់ប្រែទាល់តែសោះ ហើយក្នុងជម្រៅចិត្តរបស់អ្នកគឺអ្នកមិនទទួលបានជីវិតឡើយ។ លុះពេលវេលាដែលត្រូវល្បងលកិច្ចការរបស់អ្នកមកដល់ អ្នកនឹងឆ្លងកាត់នូវការល្បងលដ៏សន្ធោសន្ធៅដូចអណ្ដាតភ្លើង និងទុក្ខវេទនាដែលខ្លាំងក្លាជាងមុនទៅទៀត។ អណ្ដាតភ្លើងនេះ នឹងឆេះបន្សុសលក្ខណៈទាំងមូលរបស់អ្នកឲ្យក្លាយទៅជាផេះផង់។ ពេលមនុស្សម្នាក់ដែលគ្មានជីវិត មនុស្សម្នាក់ដែលគ្មានមាសសុទ្ធក្នុងខ្លួនសូម្បីតែបន្តិច មនុស្សម្នាក់ដែលស្អិតជាប់នឹងនិស្ស័យពុករលួយដ៏ចាស់គំរិល និងមនុស្សម្នាក់ដែលសូម្បីត្រឹមធ្វើជាមនុស្សបន្ទាប់បន្សំក៏មិនអាចធ្វើបានល្អផងនោះ តើធ្វើយ៉ាងណាទើបមិនអាចឲ្យអ្នកត្រូវផាត់ចោល? តើកិច្ចការនៃការយកឈ្នះមានប្រយោជន៍អ្វីខ្លះ ចំពោះមនុស្សដែលមានតម្លៃមិនបានមួយកាក់មួយសេន គឺមនុស្សម្នាក់ដែលគ្មានជីវិតផងនោះ? លុះវេលានោះមកដល់ សម័យកាលដែលអ្នករស់នៅ នឹងលំបាកជាងសម័យរបស់ណូអេ និងក្រុងសូដុមទៅទៀត! ពេលនោះការអធិដ្ឋាននឹងគ្មានប្រយោជន៍សម្រាប់អ្នកទៀតឡើយ។ តើធ្វើយ៉ាងណា ទើបអ្នកអាចត្រឡប់មកវិញនៅពេលក្រោយ ហើយចាប់ផ្ដើមប្រែចិត្តសាជាថ្មី នៅពេលដែលកិច្ចការនៃការសង្គ្រោះបានបញ្ចប់ទៅហើយនោះ? នៅពេលដែលកិច្ចការទាំងអស់នៃសេចក្ដីសង្គ្រោះត្រូវបានធ្វើរួច នោះនឹងគ្មានកិច្ចការនេះទៀតឡើយ។ កិច្ចការដែលនឹងត្រូវមានគឺជាការចាប់ផ្ដើមកិច្ចការនៃការដាក់ទោសអស់អ្នកដែលជាមនុស្សអាក្រក់វិញ។ តើអ្នកមិនមែនជាគោលដៅនៃការដាក់ទោសដ៏ធ្ងន់ធ្ងរទេឬអី? ថ្ងៃនេះ ខ្ញុំកំពុងពន្យល់ប្រាប់អ្នក

អំពីរឿងនេះយ៉ាងល្អិតល្អន់។ ប្រសិនបើអ្នកសម្រេចចិត្តថាមិនស្ដាប់ ប្រសិនបើអ្នកទើបតែចាប់ផ្ដើមមានអារម្មណ៍ស្ដាយក្រោយ និងចាប់ផ្ដើមជឿ នៅពេលដែលសេចក្ដីអន្តរាយធ្លាក់មកលើអ្នកនៅពេលក្រោយ តើវាមិនយឺតពេលទៅហើយទេឬអី? ខ្ញុំកំពុងផ្ដល់ឱកាសមួយឲ្យអ្នកបានប្រែចិត្តនៅថ្ងៃនេះ ប៉ុន្តែអ្នកមិនព្រមធ្វើដូច្នេះសោះ។ តើអ្នកចង់នៅចាំដល់កាលណាទៀត? ចាំរហូតដល់ថ្ងៃដាក់ទោសមែនទេ? ថ្ងៃនេះ ខ្ញុំមិននឹកចាំអំពីសេចក្ដីរំលងរបស់អ្នកពីអតីតកាលនោះទេ។ ខ្ញុំអត់ទោសឲ្យអ្នករាល់គ្នាម្ដងហើយម្ដងទៀត ទាំងបែរចេញពីចំណុចអវិជ្ជមានរបស់អ្នក ដើម្បីសម្លឹងមើលតែភាពវិជ្ជមានរបស់អ្នក ដ្បិតព្រះបន្ទូល និងកិច្ចការបច្ចុប្បន្នរបស់ខ្ញុំ គឺធ្វើឡើងដើម្បីសង្គ្រោះអ្នក ហើយខ្ញុំក៏គ្មានចេតនាអាក្រក់ចំពោះអ្នកដែរ។ ប៉ុន្តែ អ្នកបដិសេធមិនព្រមចូលសោះ អ្នកមិនអាចបែងចែកការល្អពីការអាក្រក់ ហើយមិនដឹងថាត្រូវឲ្យតម្លៃសេចក្ដីសប្បុរសយ៉ាងណាផង។ តើមនុស្សបែបនេះ មិនរង់ចាំតែការមកដល់នៃទណ្ឌកម្ម និងការដាក់ទោសដ៏សុចរិតទេឬទី?

នៅពេលដែលម៉ូសេវាយថ្ម នោះទឹកដែលព្រះយេហូវ៉ាបានប្រទានឲ្យក៏ហូរចេញមក នេះគឺដោយសារសេចក្ដីជំនឿរបស់គាត់។ នៅពេលដែល ដាវីឌលេងស៊ុងដើម្បីសរសើរតម្កើងខ្ញុំ ដែលជាព្រះយេហូវ៉ា ដោយដួងចិត្តគាត់ពោរពេញដោយសេចក្ដីអរសប្បាយ នេះគឺដោយសារសេចក្ដីជំនឿរបស់គាត់។ នៅពេលដែលយ៉ូបបាត់បង់សត្វចិញ្ចឹមរបស់គាត់ដែលនៅពេញភ្នំ និងទ្រព្យសម្បត្តិយ៉ាងច្រើនសម្បើម ហើយរាងកាយរបស់គាត់ដែលពេញដោយដំបៅខ្ទុះ នេះគឺដោយសារសេចក្ដីជំនឿរបស់គាត់។ នៅពេលដែលគាត់អាចស្ដាប់ឮព្រះសូរសៀងរបស់ខ្ញុំ ដែលជាព្រះយេហូវ៉ា និងឃើញសិរីល្អរបស់ខ្ញុំដែលជាព្រះយេហូវ៉ា នេះគឺដោយសារសេចក្ដីជំនឿរបស់គាត់។ ការដែលពេត្រុសអាចស្ដាប់បង្គាប់ព្រះយេស៊ូវគ្រីស្ទ គឺដោយសារសេចក្ដីជំនឿរបស់គាត់។ ការដែលគាត់អាចឲ្យគេដំដែកគោលទៅនឹងឈើឆ្កាងក៏ព្រោះតែនាមខ្ញុំ និងធ្វើទីបន្ទាល់ដែលមានសិរីល្អ គឺដោយសារសេចក្ដីជំនឿរបស់គាត់ដែរ។ នៅពេលដែលយ៉ូហាន បានឃើញពីរូបអង្គដ៏អស្ចារ្យនៃកូនមនុស្ស នេះគឺដោយសារសេចក្ដីជំនឿ

របស់គាត់។ នៅពេលដែលគាត់បានឃើញពីនិមិត្តហេតុនៅគ្រាចុងក្រោយបង្អស់ នេះគឺដោយសារសេចក្តីជំនឿរបស់គាត់។ មូលហេតុដែលពួកហ្វូងមនុស្សនៅក្នុងប្រទេសនៃពួកជាតិសាសន៍ដទៃ បានទទួលនូវការបើកសម្តែងរបស់ខ្ញុំ និងបានដឹងថា ខ្ញុំបានត្រឡប់មកជាសាច់ឈាម ដើម្បីបំពេញកិច្ចការរបស់ខ្ញុំក្នុងចំណោមមនុស្ស ក៏ដោយសារសេចក្តីជំនឿរបស់ពួកគេដែរ។ អស់អ្នកណាដែលលត់ដំដោយសារបន្ទូលមិនពិរោះស្តាប់របស់ខ្ញុំ ប៉ុន្តែត្រូវបានធូរស្បើយចិត្ត និងបានសង្គ្រោះដោយបន្ទូលទាំងនោះ តើពួកគេមិនបានធ្វើបែបនេះ ដោយសារសេចក្តីជំនឿរបស់ពួកគេទេឬអី? មនុស្សបានទទួលសេចក្តីជាច្រើន ដោយសារតែសេចក្តីជំនឿរបស់ពួកគេ ហើយនោះមិនមែនជាព្រះពររហូតទេ។ ពួកគេប្រហែលជាមិនបានទទួលនូវប្រភេទសុភមង្គល និងអំណរដែលដាវីឌបានបន្សល់ទុក ឬទទួលបានទឹកដែលព្រះយេហូវ៉ាប្រទានមក ដូចម៉ូសេឡើយ។ ឧទាហរណ៍ យ៉ូបត្រូវបានព្រះយេហូវ៉ាប្រទានពរ ដោយសារតែសេចក្តីជំនឿរបស់គាត់ ប៉ុន្តែលោកក៏បានទទួលរងនូវសេចក្តីអន្តរាយដែរ។ ទោះបីជាអ្នកត្រូវបានប្រទានពរ ឬទទួលរងនូវសេចក្តីអន្តរាយ ក៏ព្រឹត្តការណ៍ទាំងពីរនេះសុទ្ធតែជាព្រឹត្តិការណ៍ប្រកបដោយព្រះពរដែរ។ គ្មានសេចក្តីជំនឿ អ្នកនឹងមិនអាចទទួលកិច្ចការនៃការយកឈ្នះបានឡើយ ក៏រឹតតែមើលមិនឃើញស្នាព្រះហស្តរបស់ព្រះយេហូវ៉ា ដែលត្រូវបានបង្ហាញឲ្យអ្នកឃើញ ដោយផ្ទាល់ភ្នែកនៅថ្ងៃនេះផង។ ទុក្ខទោសនៅថ្ងៃនេះ ទុក្ខភ័យនៅថ្ងៃនេះ និងការជំនុំជម្រះទាំងអស់ ប្រសិនបើការទាំងអស់នេះមិនបានធ្លាក់មកលើអ្នកទេ តើអ្នកនឹងអាចមើលឃើញពីស្នាព្រះហស្តរបស់ព្រះយេហូវ៉ានៅថ្ងៃនេះទេ? ថ្ងៃនេះ គឺសេចក្តីជំនឿនេះហើយដែលអនុញ្ញាតឲ្យអ្នកត្រូវបានយកឈ្នះ ហើយគឺការដែលត្រូវបានយកឈ្នះនេះហើយដែលអនុញ្ញាតឱ្យអ្នកជឿលើគ្រប់ស្នាព្រះហស្តរបស់ព្រះយេហូវ៉ា។ គឺដោយសារសេចក្តីជំនឿតែប៉ុណ្ណោះដែលអ្នកបានទទួលនូវការវាយផ្ចាល និងការជំនុំជម្រះបែបនេះ។ តាមរយៈការវាយផ្ចាល និងការជំនុំជម្រះនេះ អ្នកត្រូវបានយកឈ្នះ និងត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍។ បើគ្មានការដាក់ទោស និងការជំនុំជម្រះ ដែលអ្នកកំពុងតែទទួលសព្វថ្ងៃនេះទេ សេចក្តីជំនឿរបស់អ្នកនឹងទៅជា

អសារឥតការ ដ្បិតអ្នកមិនស្គាល់ព្រះជាម្ចាស់។ ទោះបីជាអ្នកជឿលើព្រះអង្គកម្រិតណា ក៏សេចក្ដីជំនឿរបស់អ្នកនៅតែជាការសម្ដែងឥតន័យ គ្មានមូលដ្ឋានលើភាពជាក់ស្ដែងដដែល។ គឺទាល់តែអ្នកទទួលកិច្ចការនៃការយកឈ្នះ កិច្ចការដែលធ្វើឲ្យអ្នកស្ដាប់បង្គាប់ទាំងស្រុង ទើបសេចក្ដីជំនឿរបស់អ្នកក្លាយជាការពិត និងជឿជាក់បាន ហើយដួងចិត្តរបស់អ្នកក៏បែរទៅរកព្រះជាម្ចាស់ដែរ។ បើទោះបីជាអ្នកទទួលរងនូវការជំនុំជម្រះ និងបណ្ដាសាដ៏ធំដោយសារតែពាក្យថា «សេចក្ដីជំនឿ» នេះ នោះអ្នកមានសេចក្ដីជំនឿពិត ហើយអ្នកក៏ទទួលបានរបស់ដ៏ពិតបំផុត ជាក់ស្ដែងបំផុត និងមានតម្លៃបំផុតដែរ។ ឯមូលហេតុវិញគឺមានតែនៅក្នុងដំណើរនៃការជំនុំជម្រះទេ ទើបអ្នកមើលឃើញទិសដៅចុងក្រោយ នៃការបង្កើតរបស់ព្រះជាម្ចាស់បាន។ គឺតាមរយៈការជំនុំជម្រះនេះហើយ ទើបអ្នកមើលឃើញថា ព្រះអាទិករជាព្រះដែលត្រូវស្រឡាញ់។ គឺដោយសារតែកិច្ចការនៃការយកឈ្នះនេះហើយ ដែលអ្នកមើលឃើញព្រះហស្តរបស់ព្រះជាម្ចាស់។ គឺដោយសារតែកិច្ចការនៃការយកឈ្នះនេះហើយ ទើបអ្នកយល់អំពីជីវិតរបស់មនុស្សទាំងស្រុង។ គឺដោយសារតែកិច្ចការនៃការយកឈ្នះនេះហើយទើបអ្នកទទួលបានមាគ៌ាត្រឹមត្រូវនៃជីវិតមនុស្ស និងចាប់ផ្ដើមយល់អំពីអត្ថន័យពិតរបស់ «មនុស្ស» គឺតាមរយៈការយកឈ្នះនេះហើយ ទើបអ្នកមើលឃើញនិស្ស័យសុចរិតរបស់ព្រះដ៏មានគ្រប់ព្រះចេស្ដា និងព្រះភក្ត្រដ៏ស្រស់ស្អាត និងពេញដោយសិរីល្អរបស់ទ្រង់។ គឺដោយសារតែការយកឈ្នះរបស់ទ្រង់នេះហើយ ទើបអ្នកដឹងអំពីប្រភពដើមរបស់មនុស្ស និងយល់ពី «ប្រវត្តិអមតៈ» របស់មនុស្សជាតិទាំងអស់។ គឺដោយសារតែការយកឈ្នះនេះហើយ ទើបអ្នកចាប់ផ្ដើមយល់ពីបុព្វបុរសរបស់មនុស្សជាតិ និងប្រភពដើមនៃសេចក្ដីពុករលួយរបស់មនុស្សជាតិ។ គឺដោយសារតែការយកឈ្នះនេះហើយ ទើបអ្នកទទួលនូវសេចក្ដីអំណរ និងការកម្សាន្តចិត្ត ក៏ដូចជាការវាយផ្ចាល ការដាក់វិន័យ និងព្រះបន្ទូលស្ដីបន្ទោសឥតទីបញ្ចប់ពីព្រះអាទិករ ចំពោះមនុស្សជាតិដែលទ្រង់បានបង្កើត។ គឺដោយសារតែការយកឈ្នះនេះហើយ ទើបអ្នកទទួលនូវព្រះពរ ក៏ដូចជាទុក្ខភ័យដែលមនុស្សត្រូវទទួល...។ តើនេះមិនមែនដោយសារតែអ្នកទាំងអស់គ្នាមាន

សេចក្ដីជំនឿតិចពេកទេឬអី? ហើយតើសេចក្ដីជំនឿរបស់អ្នក មិនចម្រើនឡើង បន្ទាប់ពីអ្នកបានទទួលសេចក្ដីទាំងអស់នេះទេឬអី? តើអ្នកមិនទទួលបាននូវចំនួនច្រើនលើសលប់ទេឬអី? អ្នកមិនត្រឹមតែបានឮព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងបានឃើញព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់ទេ តែអ្នកក៏បានឆ្លងកាត់ដំណាក់កាលនីមួយៗនៃកិច្ចការរបស់ព្រះអង្គដោយផ្ទាល់ដែរ។ ប្រហែលជាអ្នកមុខជានិយាយថា ប្រសិនបើអ្នកគ្មានសេចក្ដីជំនឿ នោះអ្នកនឹងមិនទទួលរងនូវការវាយផ្ចាលបែបនេះ ឬការជំនុំជម្រះបែបនេះទេ។ ដោយឡែក អ្នកគប្បីដឹងថាគ្មានសេចក្ដីជំនឿ អ្នកមិនត្រឹមតែមិនអាចទទួលនូវការវិនិច្ឆ័យបែបនេះ ឬការថែរក្សាបែបនេះពីសំណាក់ព្រះដ៏មានគ្រប់ព្រះចេស្ដាឡើយ តែអ្នកក៏មុខជាត្រូវបាត់បង់ឱកាសជួបនឹងព្រះអាទិករ អស់កល្បជានិច្ចដែរ។ អ្នកមុខជាមិនធ្លាប់ដឹងពីប្រភពដើមរបស់មនុស្សជាតិ និងមិនធ្លាប់យល់ពីសារៈសំខាន់នៃជីវិតមនុស្សដែរ។ បើទោះបីជារូបកាយរបស់អ្នកស្លាប់បាត់ ហើយព្រលឹងរបស់អ្នកចាកចេញពីខ្លួនបាត់ ក៏អ្នកនៅតែមិនយល់ពីស្នាព្រះហស្ដទាំងអស់របស់ព្រះអាទិករ ហើយអ្នកក៏រឹតតែមិនដឹងថា ព្រះអាទិករបានធ្វើកិច្ចការអស្ចារ្យដល់ម្ល៉ឹងនៅលើផែនដី បន្ទាប់ពីទ្រង់បានបង្កើតមនុស្សជាតិរួចមកដែរ។ ក្នុងនាមជាសមាជិកម្នាក់ក្នុងចំណោមមនុស្សជាតិដែលទ្រង់បានបង្កើតមកនេះ តើអ្នកមិនព្រមធ្លាក់ទៅក្នុងសេចក្ដីងងឹត និងទទួលរងនូវការដាក់ទោសដ៏អស់កល្បជានិច្ច ទាំងមិនដឹងអីបែបនេះដែរឬទេ? ប្រសិនបើអ្នកផ្ដាច់ខ្លួនពីការវាយផ្ចាល និងការជំនុំជម្រះសព្វថ្ងៃ តើអ្នកនឹងជួបប្រទះអ្វីខ្លះ? តើអ្នកគិតថា កាលណាអ្នកបានផ្ដាច់ខ្លួនពីការជំនុំជម្រះបច្ចុប្បន្ននេះហើយ អ្នកនឹងអាចគេចផុតពីជីវិតដ៏លំបាកនេះដែរឬទេ? តើវាមិនមែនជាការពិតទេមែនទេដែលថា ប្រសិនបើអ្នកចាកចេញពី «កន្លែងនេះ» អ្វីដែលអ្នកនឹងពើបប្រទះ គឺទណ្ឌកម្មដ៏ឈឺចាប់ ឬការធ្វើទុក្ខដ៏សាហាវដែលបង្កឡើងដោយអាកំណាច? តើអ្នកអាចនឹងជួបប្រទះ ពេលវេលាដែលមិនអាចទ្រាំទ្របានទាំងយប់ទាំងថ្ងៃដែរឬទេ? តើអ្នកគិតថា ដោយសារតែអ្នកគេចចេញពីការជំនុំជម្រះនេះនៅថ្ងៃនេះ អ្នកអាចគេចផុតពីទណ្ឌកម្ម នាពេលអនាគតដែរមែនទេ? តើនឹងមានអ្វីកើតឡើងចំពោះអ្នក? តើពិតទេ

ដែលថា វាអាចជាស្ថានសួគ៌លើផែនដីដែលអ្នកស្រមៃនោះ? តើអ្នកគិតថា អ្នកគេចផុតពីការវាយផ្ចាលនាអនាគតកាល ដោយគ្រាន់តែរត់ចេញពីភាពជាក់ស្ដែង ដូចដែលអ្នកធ្វើពេលនេះបានមែនទេ? បន្ទាប់ពីថ្ងៃនេះទៅ តើអ្នកនឹងអាចរកឃើញឱកាសបែបនេះ និងព្រះពរបែបនេះម្ដងទៀតបានដែរឬទេ? តើអ្នកនឹងអាចរកឃើញឱកាស និងព្រះពរនេះនៅពេលដែលក្ដីអន្តរាយកើតមានដល់អ្នកដែរឬទេ? តើអ្នកនឹងអាចរកឃើញឱកាស និងព្រះពរនេះ នៅពេលដែលមនុស្សជាតិទាំងអស់ ចូលទៅក្នុងសេចក្ដីសម្រាកដែរឬទេ? ជីវិតដ៏រីករាយរបស់អ្នកនាពេលបច្ចុប្បន្ន និងគ្រួសារសុខដុមដ៏តូចមួយរបស់អ្នកនេះ តើអាចជំនួសទិសដៅដ៏អស់កល្បជានិច្ចនាពេលអនាគតរបស់អ្នកបានដែរឬទេ? ប្រសិនបើអ្នកមានសេចក្ដីជំនឿពិត ហើយប្រសិនបើអ្នកបានទទួលនូវសេចក្ដីជាច្រើន ដោយសារតែសេចក្ដីជំនឿរបស់អ្នក ទាំងអស់នោះហើយ គឺជាអ្វីដែលអ្នកគួរបានទទួល និងជាអ្វីដែលអ្នកគួរតែមានតាំងតែពីដំបូងនៅក្នុងជីវិតជាមនុស្ស។ គ្មានអ្វីមានប្រយោជន៍ដល់សេចក្ដីជំនឿនិងជីវិតរបស់អ្នកជាងការយកឈ្នះនេះទៀតឡើយ។

ថ្ងៃនេះ អ្នកត្រូវយល់ពីអ្វីដែលព្រះជាម្ចាស់បង្គាប់ពីមនុស្សដែលត្រូវបានយកឈ្នះ យល់ពីអាកប្បកិរិយាដែលទ្រង់មានចំពោះមនុស្សដែលត្រូវប្រោសឲ្យបានគ្រប់លក្ខណ៍ និងយល់ ពីអ្វីដែលអ្នកគួរប្រកាន់ខ្ជាប់ក្នុងពេលបច្ចុប្បន្ននេះ។ មានរឿងខ្លះ អ្នកត្រូវយល់ត្រឹមតិចតួចប៉ុណ្ណោះ។ អ្នកមិនចាំបាច់ត្រូវពិនិត្យពិច័យ ពាក្យអាថ៌កំបាំងមួយចំនួនឡើយ។ សេចក្ដីទាំងនោះមិនមានប្រយោជន៍ច្រើនដល់ជីវិតទេ ហើយវាគ្រាន់តែតម្រូវឲ្យមានការសម្លឹងមើលត្រួសៗតែប៉ុណ្ណោះ។ អ្នកអាចមើលដឹងសេចក្ដីអាថ៌កំបាំងនានាដូចជា អាថ៌កំបាំងរបស់អ័ដាម និងអេវ៉ា៖ អ្វីៗគ្រប់យ៉ាងទាក់ទងនឹងអ័ដាម និងអេវ៉ានាសម័យនោះ និងកិច្ចការដែលព្រះជាម្ចាស់សព្វព្រះហឫទ័យចង់ធ្វើនាពេលបច្ចុប្បន្ន។ អ្នកត្រូវតែយល់ថា ក្នុងការយកឈ្នះ និងការប្រោសមនុស្សឲ្យបានគ្រប់លក្ខណ៍ ព្រះជាម្ចាស់សព្វព្រះហឫទ័យចង់ឲ្យមនុស្សត្រឡប់ទៅរកសភាពដើមដូចអ័ដាមនិងអេវ៉ាដែរ។ នៅក្នុងចិត្តរបស់អ្នក អ្នកគួរតែមានគំនិតល្អមួយស្ដីអំពីកម្រិតនៃភាពគ្រប់លក្ខណ៍ដែលត្រូវតែទទួលឲ្យបានដើម្បីបំពេញទៅតាមខ្នាតគំរូរបស់

ព្រះជាម្ចាស់ ហើយពេលនោះ អ្នកត្រូវតែព្យាយាមសម្រេចការនេះឲ្យបាន។ ការនេះពាក់ព័ន្ធនឹងការអនុវត្តរបស់អ្នក ហើយនេះជាសេចក្ដីដែលអ្នកគួរយល់។ ការព្យាយាមចូលទៅក្នុងបញ្ហាទាំងអស់នេះ ស្របតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ គឺល្អមសម្រាប់អ្នករាល់គ្នាហើយ។ នៅពេលដែលអ្នកអានពាក្យមួយឃ្លាថា «វាបានចំណាយពេលអស់មួយម៉ឺនឆ្នាំនៅក្នុងប្រវត្តិសាស្ត្រសម្រាប់មនុស្សជាតិ ដើម្បីទៅដល់កន្លែងដែលបានមកដល់សព្វថ្ងៃនេះ» អ្នកនឹងឆ្ងល់ ដូច្នេះហើយ អ្នកក៏ព្យាយាមស្វែងរកចម្លើយជាមួយបងប្អូនប្រុសស្រី។ «ព្រះជាម្ចាស់មានបន្ទូលថា ការវិវត្តរបស់មនុស្សជាតិ សន្ធឹងទៅក្រោយប្រាំមួយពាន់ឆ្នាំ មែនទេ? ចុះមួយម៉ឺនឆ្នាំនេះជាអ្វីទៅវិញ?» តើការព្យាយាមស្វែងរកចម្លើយចំពោះសំណួរនេះ មានប្រយោជន៍អ្វី? ទោះបីព្រះជាម្ចាស់ផ្ទាល់ព្រះអង្គធ្វើការអស់រយៈពេលរាប់ម៉ឺនឆ្នាំ ឬរាប់រយលានឆ្នាំ តើព្រះអង្គពិតជាត្រូវឲ្យអ្នកដឹងពីរឿងនេះដែរមែនទេ? ក្នុងនាមជាមនុស្ស នេះមិនមែនជារឿងដែលអ្នកត្រូវដឹងឡើយ។ ចូរអនុញ្ញាតឲ្យខ្លួនអ្នកពិចារណាបន្តិចអំពីសម្ដីបែបនេះ ហើយចូរកុំព្យាយាមយល់ពីសេចក្ដីនេះ ដូចទៅនឹងនិមិត្តមួយឲ្យសោះ។ អ្នកត្រូវដឹងពីអ្វីដែលអ្នកគួរចូលទៅក្នុង និងយល់នៅថ្ងៃនេះ បន្ទាប់មក អ្នកត្រូវមានការយល់ដឹងឲ្យបានច្បាស់អំពីរឿងនេះ។ ពេលនោះទើបអ្នកនឹងត្រូវបានយកឈ្នះ។ បន្ទាប់ពីអានពាក្យខាងលើនេះរួច ក្នុងខ្លួនរបស់អ្នកគួរតែមានតែប្រតិកម្មធម្មតាមួយគឺ៖ ព្រះជាម្ចាស់កំពុងឆេះឆួលដោយក្ដីអន្ទះសា ទ្រង់សព្វព្រះហឫទ័យចង់យកឈ្នះយើងរាល់គ្នា ហើយទទួលបានសិរីរុងរឿង និងទីបន្ទាល់ ដូច្នេះ តើយើងគួរសហការនឹងទ្រង់ដោយរបៀបណា? តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីឲ្យទ្រង់យកឈ្នះបានទាំងស្រុង ហើយក្លាយជាទីបន្ទាល់របស់ទ្រង់? តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីឲ្យព្រះជាម្ចាស់អាចទទួលបានសិរីល្អ? តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីឲ្យខ្លួនយើងអាចរស់នៅក្នុងអំណាចត្រួតត្រារបស់ព្រះជាម្ចាស់ និងមិនមែននៅក្រោមអំណាចត្រួតត្រារបស់សាតាំង? នេះគឺជាអ្វីដែលមនុស្សគួរគិតគូរ។ គ្រប់ៗគ្នាក្នុងចំណោមអ្នករាល់គ្នា គួរដឹងច្បាស់អំពីសារៈសំខាន់នៃការយកឈ្នះរបស់ព្រះជាម្ចាស់។ នេះហើយជាទំនួលខុសត្រូវរបស់អ្នករាល់គ្នា។ ទាល់តែទទួលបានភាពច្បាស់លាស់នេះ

សិន ទើបអ្នកនឹងមានច្រកចូល ទើបអ្នកស្គាល់កិច្ចការក្នុងដំណាក់កាលនេះ ហើយក្លាយជាមនុស្សស្ដាប់បង្គាប់ទាំងស្រុងបាន។ ពុំនោះទេ អ្នករាល់គ្នានឹងមិនសម្រេចបាននូវការស្ដាប់បង្គាប់ពិតប្រាកដទេ។

## សេចក្ដីពិតនៅខាងក្នុងអំពីកិច្ចការនៃការយកឈ្នះ (៣)

លទ្ធផលចង់បានអំពីកិច្ចការនៃការយកឈ្នះ សំខាន់គឺ ដើម្បីឱ្យផ្នែកសាច់ឈាមរបស់មនុស្សឈប់ធ្វើការបះបោរ គឺដើម្បីឱ្យគំនិតរបស់មនុស្សទទួលបាននូវចំណេះដឹងថ្មីអំពីព្រះជាម្ចាស់ ដើម្បីឱ្យដួងចិត្តរបស់គេ បានស្ដាប់បង្គាប់ព្រះជាម្ចាស់យ៉ាងហ្មត់ចត់ និងដើម្បីឱ្យមនុស្ស មានចិត្តប្រាថ្នាចង់ធ្វើថ្វាយព្រះជាម្ចាស់។ មនុស្សមិនបានរាប់ថាត្រូវបានយកឈ្នះ នៅពេលដែលចរិតដើម ឬសាច់ឈាមរបស់ពួកគេបានផ្លាស់ប្ដូរទេ ហើយនៅពេលដែលការគិត មនសិការ និងញាណរបស់មនុស្សផ្លាស់ប្ដូរ ពោលគឺនៅពេលដែលអាកប្បកិរិយាផ្នែកចិត្តគំនិតរបស់អ្នកផ្លាស់ប្ដូរ នោះគឺជាពេលដែលព្រះជាម្ចាស់បានយកឈ្នះលើអ្នកហើយ។ នៅពេលដែលអ្នកបានតាំងចិត្តស្ដាប់បង្គាប់ និងបានទទួលយកនូវចិត្តគំនិតថ្មី នៅពេលដែលអ្នកលែងនាំយកនូវសញ្ញាណ ឬចេតនាផ្ទាល់ខ្លួនចំពោះព្រះបន្ទូល និងកិច្ចការរបស់ព្រះជាម្ចាស់តទៅទៀតហើយ នៅពេលដែលខួរក្បាលរបស់អ្នកអាចគិតបានជាធម្មតា ពោលគឺនៅពេលដែលអ្នកអាចថ្វាយខ្លួនឯងសម្រាប់ព្រះជាម្ចាស់ដោយស្មោះអស់ពីចិត្ត នោះអ្នកជាប្រភេទមនុស្សដែលព្រះជាម្ចាស់បានយកឈ្នះទាំងស្រុងហើយ។ នៅក្នុងសាសនា មនុស្សជាច្រើនរងទុក្ខយ៉ាងខ្លាំងពេញមួយជីវិតរបស់ពួកគេៈ ពួកគេលត់ដំរូបកាយរបស់ខ្លួន និងផ្ទុកឈើឆ្កាងរបស់ខ្លួន ហើយពួកគេថែមទាំងបន្តរងទុក្ខ ព្រមទាំងស៊ូទ្រាំនៅពេលដែលពួកគេហៀបនឹងស្លាប់! មនុស្សមួយចំនួននៅតែធ្វើការតមអាហារនៅថ្ងៃនៃសេចក្ដីស្លាប់របស់ខ្លួនចូលមកដល់។ ពួកគេបានបដិសេធខ្លួនឯងពេញមួយជីវិត គឺបដិសេធនូវម្ហូបអាហារឆ្ងាញ់ៗ និងសម្លៀកបំពាក់ល្អៗ ដោយផ្ដោតលើការរងទុក្ខតែប៉ុណ្ណោះ។ ពួកគេ

អាចលត់ដំរូបកាយរបស់ខ្លួន និងបោះបង់ចោលនូវផ្នែកខាងសាច់ឈាមរបស់គេ។ ស្មារតីសម្រាប់ការស៊ូទ្រាំរបស់ពួកគេ ពិតជាគួរឱ្យសរសើរ។ ប៉ុន្តែការគិត បំណង និងឥរិយាបថផ្នែកចិត្តគំនិត ព្រមទាំងធម្មជាតិដើមរបស់ពួកគេមិនទាន់ត្រូវបានដោះស្រាយសូម្បីតែបន្តិចនៅឡើយ។ ពួកគេខ្វះនូវចំណេះដឹង ដ៏ពិតប្រាកដអំពីខ្លួនឯង។ រូបភាពនៅក្នុងចិត្តរបស់ពួកគេអំពីព្រះជាម្ចាស់គឺទ្រង់ជាព្រះពីបុរាណ ជាព្រះដ៏ស្រពេចស្រពិល។ ការតាំងចិត្តរបស់គេក្នុងការរងទុក្ខសម្រាប់ព្រះជាម្ចាស់កើតចេញពីការខ្នះខ្នែង និងលក្ខណៈវិជ្ជមានរបស់ពួកគេ។ ទោះបីជាពួកគេជឿលើព្រះជាម្ចាស់ក្ដី ក៏ពួកគេមិនយល់ពីទ្រង់ និងមិនស្គាល់ពីបំណងព្រះហឫទ័យរបស់ទ្រង់ឡើយ។ ពួកគេខំធ្វើការ ហើយនិងរងទុក្ខសម្រាប់ព្រះជាម្ចាស់ទាំងងងឹតងងល់។ ពួកគេមិនឱ្យតម្លៃលើអ្វីទាំងអស់ លើការយល់ឃើញ ខ្វល់ខ្វាយបន្តិចបន្តួចអំពីរបៀបដែលធានាឱ្យបានថាការបម្រើរបស់ពួកគេពិតជាបានបំពេញបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ហើយពួកគេក៏មិនសូវដឹងពីរបៀបទទួលបានចំណេះដឹងអំពីព្រះជាម្ចាស់។ ព្រះជាម្ចាស់ដែលពួកគេបម្រើ មិនមែនជាព្រះនៅក្នុងរូបអង្គពីដើមរបស់ទ្រង់ឡើយ ប៉ុន្តែជាព្រះដែលពួកគេបានស្រមើស្រមៃ ជាព្រះដែលពួកគេបានត្រឹមតែឮ ឬត្រឹមតែបានអាននៅក្នុងសំណេររឿងព្រេងតែប៉ុណ្ណោះ។ បន្ទាប់មក ពួកគេក៏ប្រើប្រាស់ការស្រមើស្រមៃចេញជារូបរាង និងជំនឿស៊ប់ ដើម្បីរងទុក្ខសម្រាប់ព្រះជាម្ចាស់ និងទទួលយកកិច្ចការរបស់ព្រះជាម្ចាស់ ដែលព្រះជាម្ចាស់សព្វព្រះហឫទ័យចង់ឱ្យធ្វើ។ ការបម្រើរបស់ពួកគេគឺមិនត្រឹមត្រូវឡើយ ជាក់ស្ដែង គឺគ្មាននរណាម្នាក់ក្នុងចំណោមពួកគេពិតជាអាចបម្រើស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់បានឡើយ។ មិនថាពួកគេរងទុក្ខវេទនាដោយអំណរយ៉ាងណា ការយល់ឃើញរបស់ពួកគេកាលពីមុនចំពោះការបម្រើ និងចិត្តគំនិតរបស់ពួកគេចំពោះលក្ខណៈរបស់ព្រះជាម្ចាស់ គឺនៅតែដដែល ដ្បិតពួកគេមិនបានឆ្លងកាត់ការជំនុំជម្រះ ការវាយផ្ចាល ការបន្សុទ្ធ និងការប្រទានឱ្យគ្រប់លក្ខណ៍របស់ព្រះជាម្ចាស់ឡើយ ហើយក៏មិនមាននរណាបានណែនាំពួកគេឱ្យប្រើប្រាស់សេចក្ដីពិតដែរ។ សូម្បីតែពេលដែលពួកគេជឿលើព្រះយេស៊ូវគ្រីស្ទ ជាព្រះសង្គ្រោះក៏គ្មាននរណា

ម្នាក់ក្នុងចំណោមពួកគេធ្លាប់បានឃើញព្រះសង្គ្រោះដែរ។ ពួកគេបានត្រឹមតែស្គាល់ទ្រង់តាមរយៈការនិទានប្រាប់ និងការឮតៗគ្នាតែប៉ុណ្ណោះ។ ជាលទ្ធផលការបម្រើរបស់ពួកគេ មានចំនួនមិនលើសពីការបម្រើម្ដងម្កាលដោយធ្វើទាំងបិទភ្នែក ដូចជាមនុស្សខ្វាក់បម្រើឪពុកឡើយ។ តើការបម្រើបែបនេះអាចទទួលបានអ្វី? ហើយតើនរណាយល់ព្រមឱ្យធ្វើវា? ចាប់តាំងពីដើមដំបូងរហូតមកដល់ចុងបំផុត ការបម្រើរបស់ពួកគេនៅតែដដែលជារហូតមក។ ពួកគេទទួលតែមេរៀនដែលមនុស្សបានរៀបចំ ហើយយកការបម្រើរបស់ពួកគេដោយផ្អែកលើលក្ខណៈធម្មជាតិរបស់គេ និងធ្វើតាមការពេញចិត្តរបស់ខ្លួនតែប៉ុណ្ណោះ។ តើការធ្វើបែបនេះ អាចនាំឱ្យមានរង្វាន់អ្វីដែរ? សូម្បីតែពេត្រុសដែលជាអ្នកបានឃើញព្រះយេស៊ូវគ្រីស្ទ ក៏មិនបានដឹងពីរបៀបបម្រើដែលស្របតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែរ គឺលោកបានដឹងអំពីការនេះក្នុងពេលចុងក្រោយ នៅពេលដែលលោកមានវ័យចំណាស់ទៅហើយ។ តើសេចក្ដីនេះបាននិយាយអ្វីខ្លះអំពីមនុស្សខ្វាក់ទាំងនោះ ដែលមិនមានបទពិសោធក្នុងការដោះស្រាយ ឬការទទួលការលួសកាត់សូម្បីតែបន្តិច និងអស់អ្នកដែលមិនមាននរណាដឹកនាំនោះ? តើការបម្រើរបស់មនុស្សនៅក្នុងចំណោមអ្នករាល់គ្នានាពេលនេះមិនដូចជាមនុស្សខ្វាក់ទាំងនោះទេឬអី? មនុស្សអស់ទាំងនោះដែលមិនបានទទួលការជំនុំជម្រះ មិនបានទទួលការលួសកាត់ និងការដោះស្រាយ និងអស់អ្នកដែលមិនមានការផ្លាស់ប្ដូរ តើពួកគេមិនត្រូវបានយកឈ្នះទាំងស្រុងទេឬ? តើមនុស្សបែបនេះមានប្រយោជន៍អ្វី? ប្រសិនបើការគិតរបស់អ្នក ចំណេះដឹងរបស់អ្នកអំពីជីវិត និងចំណេះដឹងរបស់អ្នកអំពីព្រះជាម្ចាស់ បង្ហាញពីការមិនមានការផ្លាស់ប្ដូរ ហើយអ្នកមិនទទួលបានអ្វីទាំងអស់ នោះអ្នកនឹងមិនទទួលបានអ្វីគួរឱ្យកត់សម្គាល់នៅក្នុងការបម្រើរបស់អ្នកឡើយ! បើគ្មាននិមិត្ត និងចំណេះដឹងថ្មីអំពីកិច្ចការរបស់ព្រះជាម្ចាស់ទេ នោះអ្នកនឹងមិនទទួលបានការយកឈ្នះឡើយ។ វិធីរបស់អ្នកក្នុងការដើរតាមព្រះជាម្ចាស់នឹងដូចជាមនុស្សដែលរងទុក្ខ និងតមអាហារៈ គឺមានតម្លៃតិចណាស់! វាច្បាស់ណាស់ ដ្បិតមានទីបន្ទាល់តិចតួចប៉ុណ្ណោះនៅក្នុងអ្វីដែលគេធ្វើ បានជាខ្ញុំមានបន្ទូល

ថាការបម្រើរបស់គេ គឺឥតប្រយោជន៍សោះឡើយ! ពេញមួយជីវិតរបស់ពួកគេ មនុស្ស ទាំងនោះរងទុក្ខលំបាក និងចំណាយពេលនៅក្នុងមន្ទីរឃុំឃាំង។ ពួកគេប្រឹងអត់ទ្រាំជានិច្ច ស្រលាញ់ជានិច្ច ហើយពួកគេផ្ទុកឈើឆ្កាងជានិច្ច ពួកគេត្រូវបានលោកិយមើលងាយ និងបដិសេធ ពួកគេជួបប្រទះការលំបាកគ្រប់យ៉ាង ហើយទោះបីជាពួកគេស្ដាប់បង្គាប់រហូតដល់ទីបញ្ចប់ក៏ដោយ ក៏ពួកគេនៅតែមិនត្រូវបានយកឈ្នះដែរ ព្រមទាំងមិនអាចធ្វើទីបន្ទាល់អំពីការដែលត្រូវបានយកឈ្នះឡើយ។ ពួកគេបានរងទុក្ខយ៉ាងខ្លាំង ប៉ុន្តែនៅខាងក្នុងវិញ ពួកគេមិនបានស្គាល់ព្រះជាម្ចាស់ទាល់តែសោះ។ គ្មានគំនិត សញ្ញាណចាស់ៗ ការអនុវត្តផ្នែកសាសនា ចំណេះដឹងដែលមនុស្សបង្កើត និងគំនិតជាមនុស្សណាមួយរបស់ពួកគេដែលត្រូវបានដោះស្រាយនោះឡើយ។ គ្មានតម្រុយអំពីគំនិតថ្មីនៅក្នុងពួកគេឡើយ សូម្បីតែបន្តិច។ គ្មានចំណេះដឹងណាមួយរបស់ពួកគេស្ដីពីព្រះជាម្ចាស់ដែលពិត និងសុក្រឹតនោះឡើយ។ ពួកគេបានយល់ច្រឡំចំពោះបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ តើការនេះបម្រើដល់ព្រះជាម្ចាស់ដែរឬទេ? មិនថាចំណេះដឹងរបស់អ្នកកាលពីមុន ស្ដីពីព្រះជាម្ចាស់បែបណានោះទេ ប្រសិនបើថ្ងៃនេះនៅតែដដែល ហើយអ្នកនៅតែបន្តយកចំណេះដឹងរបស់អ្នកអំពីព្រះជាម្ចាស់ទៅធ្វើជាមូលដ្ឋាន តាមសញ្ញាណ និងគំនិតផ្ទាល់ខ្លួនរបស់អ្នក ដោយមិនខ្វល់ថាព្រះជាម្ចាស់ធ្វើអ្វីនោះ ពោលគឺ ប្រសិនបើអ្នកមិនមានចំណេះដឹងថ្មី និងពិតប្រាកដ ហើយបើសិនជាអ្នកមិនអាចដឹងអំពីរូបអង្គ និងនិស្ស័យពិតរបស់ព្រះជាម្ចាស់ទេនោះ ប្រសិនបើចំណេះដឹងរបស់អ្នកអំពីព្រះជាម្ចាស់នៅតែទទួលការដឹកមុខពីគំនិតបែបសក្តិភូមិ និងបែបអបិយជំនឿ ហើយនៅតែកើតឡើងពីការស្រមើស្រមៃ និងសញ្ញាណរបស់មនុស្ស នោះអ្នកមិនទាន់ត្រូវបានយកឈ្នះឡើយ។ គ្រប់ទាំងព្រះបន្ទូលជាច្រើនដែលខ្ញុំបានថ្លែងទៅកាន់អ្នកឥឡូវនេះ គឺដើម្បីឱ្យអ្នកដឹង មានចំណេះដឹងនេះដើម្បីដឹកនាំអ្នកទៅកាន់ចំណេះដឹងដែលថ្មីជាងមុន និងមានភាពសុក្រឹតផង។ ព្រះបន្ទូលទាំងនេះ ក៏មានន័យផងដែរដើម្បីលុបបំបាត់នូវសញ្ញាណចាស់ៗ និងចំណេះដឹងចាស់ៗនៅក្នុងអ្នក ដើម្បីឱ្យអ្នកអាចមានចំណេះដឹងថ្មី។ ប្រសិនបើអ្នកហូប និងផឹក

ព្រះបន្ទូលរបស់ខ្ញុំ នោះចំណេះដឹងរបស់អ្នកនឹងផ្លាស់ប្ដូរគួរឱ្យកត់សម្គាល់។ ដរាបណាដែលអ្នកហូប និងផឹកព្រះបន្ទូលរបស់ព្រះជាម្ចាស់ដោយដួងចិត្តដែលស្ដាប់បង្គាប់ នោះការយល់ឃើញរបស់អ្នក នឹងមានលក្ខណៈខុសពីមុនស្រឡះ។ ដរាបណាអ្នកអាចទទួលយកនូវការវាយផ្ចាលម្ដងហើយម្ដងទៀតបាន នោះចិត្តគំនិតចាស់របស់អ្នកនឹងផ្លាស់ប្រែជាបន្តបន្ទាប់។ ដរាបណាចិត្តគំនិរបស់អ្នកត្រូវបានជំនួសដោយអ្វីដែលថ្មី នោះការប្រព្រឹត្តរបស់អ្នកក៏នឹងផ្លាស់ប្ដូរតាមនោះដែរ។ តាមវិធីនេះ ការបម្រើរបស់អ្នកនឹងកាន់តែឆាប់ដល់គោលដៅ គឺកាន់តែអាចបំពេញតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ប្រសិនបើអ្នកអាចផ្លាស់ប្ដូរជីវិតរបស់អ្នក ចំណេះដឹងរបស់អ្នកអំពីជីវិតមនុស្ស និងសញ្ញាណរបស់អ្នកអំពីព្រះជាម្ចាស់ នោះលក្ខណៈធម្មជាតិរបស់អ្នកក៏នឹងថមថយបន្តិចម្ដងៗដែរ។ នេះគឺជាផលប៉ះពាល់នៅពេលដែលព្រះជាម្ចាស់យកឈ្នះលើមនុស្ស វាជាការផ្លាស់ប្ដូរដែលកើតឡើងចំពោះមនុស្ស ហើយគ្មានអ្វីក្រៅពីនេះឡើយ។ នៅក្នុងសេចក្ដីជំនឿរបស់អ្នកលើព្រះជាម្ចាស់ ប្រសិនបើអ្វីទាំងអស់ដែលអ្នកដឹងគឺជាការលត់ដំរូបកាយ ការស៊ូទ្រាំ និងការរងទុក្ខ ហើយអ្នកមិនដឹងថាតើវាជាការត្រឹមត្រូវ ឬមិនត្រឹមត្រូវ រឹតតែមិនដឹងថាតើការនេះធ្វើដើម្បីជាប្រយោជន៍របស់នរណា នោះតើឱ្យការអនុវត្តន៍បែបនេះដឹកនាំទៅរកការផ្លាស់ប្ដូរម្ដេចបាន?

ត្រូវយល់ថា អ្វីដែលខ្ញុំសុំពីអ្នករាល់គ្នា គឺមិនមែនសម្រាប់ឱ្យអ្នករាល់គ្នាចងសាច់ឈាមរបស់ខ្លួនឱ្យនៅជាប់នឹងចំណង ឬបញ្ឈប់ខួរក្បាលរបស់អ្នករាល់គ្នាមិនឱ្យគិតដល់គំនិតផ្សេងៗតាមតែអំពើចិត្តនោះឡើយ។ នេះមិនមែនជាគោលដៅនៃកិច្ចការទេ ហើយក៏មិនមែនជាកិច្ចការដែលត្រូវបង្ហើយនៅពេលនេះដែរ។ ពេលនេះអ្នករាល់គ្នាត្រូវតែមានចំណេះដឹងដែលកើតឡើងពីចំណុចវិជ្ជមាន ដើម្បីឱ្យអ្នកអាចផ្លាស់ប្ដូរខ្លួនឯងបាន។ សកម្មភាពដែលចាំបាច់បំផុតគឺថា អ្នកត្រូវបំពាក់បំប៉នខ្លួនឯងជាមួយនឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់ មានន័យថា ត្រូវបំពាក់បំប៉នខ្លួនឯងជាមួយនឹងសេចក្ដីពិត និងនិមិត្តនាពេលបច្ចុប្បន្ន ហើយបន្ទាប់មកត្រូវចេញទៅ និងយកវាទៅអនុវត្តចុះ។ នេះជាទំនួលខុសត្រូវរបស់អ្នករាល់គ្នា។ ខ្ញុំមិនបានសុំឱ្យអ្នករាល់គ្នាស្វែងរក និង

ទទួលបានការបំភ្លឺច្រើនជាងនេះទេ។ បច្ចុប្បន្ននេះ អ្នករាល់គ្នាមិនមានកម្ពស់សម្រាប់ការនេះឡើយ។ អ្វីដែលតម្រូវឱ្យអ្នករាល់គ្នាមាននោះ គឺត្រូវធ្វើគ្រប់យ៉ាងតាមតែអាចធ្វើបាន ដើម្បីហូប និងផឹកព្រះបន្ទូលរបស់ព្រះជាម្ចាស់។ អ្នករាល់គ្នាត្រូវតែយល់ពីកិច្ចការរបស់ព្រះជាម្ចាស់ និងស្គាល់ពីធម្មជាតិរបស់អ្នករាល់គ្នា សារជាតិរបស់អ្នករាល់គ្នា និងស្គាល់ពីជីវិតចាស់របស់អ្នករាល់គ្នាផង។ ជាពិសេស អ្នកត្រូវតែស្គាល់នូវការអនុវត្តន៍ដែលឆ្គាំឆ្គង និងមិនសមហេតុផលកាលពីមុន និងការព្រឹត្តរបស់មនុស្សដែលអ្នកបានចូលរួមជាមួយ។ ដើម្បីផ្លាស់ប្ដូរ អ្នកត្រូវតែចាប់ផ្ដើមដោយការផ្លាស់ប្ដូរការគិតរបស់អ្នក។ ដំបូងឡើយ ចូរជំនួសការគិតចាស់គំរិលរបស់អ្នកដោយគំនិតថ្មី និងអនុញ្ញាតឱ្យគំនិតថ្មីរបស់អ្នករាល់គ្នាគ្រប់គ្រងពាក្យសម្ដី និងសកម្មភាព ព្រមទាំងជីវិតរបស់អ្នករាល់គ្នាដែរ។ នេះជាអ្វីដែលតម្រូវឱ្យអ្នករាល់គ្នាធ្វើនៅថ្ងៃនេះ។ មិនត្រូវអនុវត្តដោយងងឹតងងល់ និងដើរតាមដោយងងឹតងងល់ឡើយ។ អ្នកគួរមានមូលដ្ឋានគ្រឹះ និងគោលដៅមួយ។ មិនត្រូវបោកបញ្ឆោតខ្លួនឯងទេ។ អ្នករាល់គ្នាត្រូវដឹងថាតើសេចក្ដីជំនឿរបស់អ្នករាល់គ្នាលើព្រះអង្គគឺសម្រាប់អ្វី តើគួរទទួលបានអ្វីខ្លះពីសេចក្ដីជំនឿនេះ ហើយតើអ្នកគួរចូលទៅក្នុងអ្វីក្នុងពេលឥលូវនេះ។ វាជាការចាំបាច់ដែលអ្នកត្រូវដឹងពីការទាំងអស់នេះ។

អ្វីដែលអ្នករាល់គ្នាគួរចូលទៅក្នុងនាពេលបច្ចុប្បន្នគឺ ជាការលើកស្ទួយជីវិតរបស់អ្នករាល់គ្នា និងការបង្កើននូវភាពសុក្រឹតរបស់អ្នករាល់គ្នា។ លើសពីនេះ អ្នកត្រូវតែផ្លាស់ប្ដូរនូវការយល់ឃើញចាស់គំរិលរបស់អ្នករាល់គ្នាកាលពីមុន ផ្លាស់ប្ដូរការគិតរបស់អ្នក និងផ្លាស់ប្ដូរសញ្ញាណរបស់អ្នក។ ជីវិតទាំងមូលរបស់អ្នករាល់គ្នាត្រូវការស្ដារឱ្យថ្មីឡើងវិញ។ នៅពេលដែលចំណេះដឹងរបស់អ្នកស្ដីពីទង្វើរបស់ព្រះជាម្ចាស់បានផ្លាស់ប្ដូរហើយ នៅពេលដែលមានការចេះដឹងជាថ្មីអំពីសេចក្ដីពិតនៃអ្វីៗដែលព្រះជាម្ចាស់មានព្រះបន្ទូល ហើយនៅពេលដែលចំណេះដឹងដែលនៅក្នុងអ្នកមានការលើកស្ទួយឡើង នោះជីវិតរបស់អ្នកនឹងត្រលប់ទៅជាប្រសើរវិញជាមិនខាន។ អ្វីគ្រប់យ៉ាងដែលមនុស្សធ្វើ និងនិយាយចេញមកនៅពេលនេះ គឺជាក់ស្ដែងណាស់។ ទាំងនេះមិនមែន

ជាគោលលទ្ធិឡើយ តែជាអ្វីដែលមនុស្សត្រូវការសម្រាប់ជីវិតរបស់ពួកគេ ហើយជាអ្វីដែលខ្លួនគួរមាន។ នេះគឺជាការផ្លាស់ប្ដូរដែលកើតមកនៅក្នុងមនុស្ស ក្នុងអំឡុងពេលកិច្ចការនៃការយកឈ្នះ ជាការផ្លាស់ប្ដូរដែលគេគួរឆ្លងកាត់ ហើយវាជាលទ្ធផលក្រោយពួកគេត្រូវបានយកឈ្នះ។ នៅពេលដែលអ្នកបានផ្លាស់ប្ដូរការគិតរបស់អ្នក ដោយបានទទួលយកនូវអាកប្បកិរិយានៃចិត្តគំនិតថ្មី បានបដិសេធសញ្ញាណ និងចេតនា ព្រមទាំងការនិយាយហេតុផលសមរម្យពីមុនរបស់ខ្លួន ដោយអ្នកបានបោះចោលនូវអ្វីដែលបានចាក់ឫសយ៉ាងជ្រៅនៅក្នុងអ្នក ហើយទទួលបាននូវចំណេះដឹងថ្មីអំពីសេចក្ដីជំនឿលើព្រះជាម្ចាស់ នោះទីបន្ទាល់ដែលអ្នកបានធ្វើនឹងត្រូវបានកើនឡើង ហើយលក្ខណៈរបស់អ្នកទាំងមូល នឹងត្រូវបានផ្លាស់ប្ដូរយ៉ាងពិតប្រាកដ។ ចំណុចទាំងអស់នេះគឺពិតជាក់ស្ដែងបំផុត មានភាពពិតប្រាកដបំផុត និងជាគ្រឹះសំខាន់បំផុតនៃអ្វីៗទាំងអស់ ពោលគឺអ្វីដែលមនុស្សមិនអាចនឹងយល់នៅក្នុងអតីតកាល និងជាអ្វីដែលពួកគេមិនអាចផ្សារភ្ជាប់បាន។ ទាំងនេះជាកិច្ចការពិតប្រាកដរបស់ព្រះវិញ្ញាណ។ តើអ្នកយល់ច្បាស់ពីព្រះគម្ពីរ កាលពីអតីតកាលយ៉ាងដូចម្ដេចដែរ? យករឿងនេះមកប្រៀបធៀបថ្ងៃនេះ អ្នកនឹងដឹង។ កាលពីមុន ចិត្តគំនិតរបស់អ្នកលើកស្ទួយដល់ ម៉ូសេ ពេត្រុស និង ប៉ុល ឬជាការថ្លែង និងទស្សនៈនៅក្នុងព្រះគម្ពីរទាំងអស់នោះ ព្រមទាំងបានដាក់នៅលើជើងទម្រផង។ ពេលនេះ ប្រសិនបើត្រូវតម្រូវឱ្យអ្នកដាក់ព្រះគម្ពីរ នៅលើជើងទម្រ តើអ្នកនឹងធ្វើទេ? អ្នកបានឃើញហើយថា ព្រះគម្ពីរមានការកត់ត្រាច្រើនពេកហើយដែលសរសេរឡើងដោយមនុស្ស ហើយថាព្រះគម្ពីរ គ្រាន់តែជាកំណត់ហេតុរបស់មនុស្ស អំពីកិច្ចការពីរដំណាក់កាលរបស់ព្រះជាម្ចាស់ប៉ុណ្ណោះ។ វាជាសៀវភៅប្រវត្តិសាស្ត្រមួយ។ តើវាមិនមែនមានន័យថា ចំណេះដឹងរបស់អ្នកស្ដីពីព្រះគម្ពីរនេះបានផ្លាស់ប្ដូរទេឬ? ប្រសិនបើអ្នកក្រឡេកមើលពីពង្សាវតាររបស់ព្រះយេស៊ូវដែលមានចែងនៅក្នុងគម្ពីរម៉ាថាយ នោះអ្នកនឹងពោលថា «ពង្សាវតារ របស់ព្រះយេស៊ូវបែបហ្នឹង? យ៉ាប់មែន! នេះជាពូជពង្សរបស់ យ៉ូសែបទេតើ មិនមែនព្រះយេស៊ូវទេ។ រវាងព្រះយេស៊ូវ និង យ៉ូសែប គ្មានទំនាក់ទំនងអ្វីនឹងគ្នាឡើយ»។ នៅពេលដែលអ្នកក្រឡេកមើលព្រះគម្ពីរនៅពេល

ឥលូវនេះ នោះចំណេះដឹងរបស់អ្នកស្តីពីចំណុចនេះមានភាពខុសប្លែក គឺមានន័យថា ទស្សនៈរបស់អ្នកមានការផ្លាស់ប្តូរ ហើយអ្នកបានធ្វើឱ្យចំណេះដឹងរបស់អ្នកកើនឡើងបានមួយកម្រិតទៀត គឺចេះជាងពួកអ្នកប្រាជ្ញកម្រិតខ្ពស់ខាងសាសនាទៅទៀត។ នៅពេលដែលមានបុគ្គលណាម្នាក់ ពោលថាមានអ្វីមួយនៅក្នុងពង្សាវតារនេះ អ្នកនឹងឆ្លើយតបថា «តើមានអ្វីពាក់ព័ន្ធពីណាមក? ចូរចេញទៅពន្យល់ចុះ។ ព្រះយេស៊ូវ និងយ៉ូសែបមិនមានអ្វីពាក់ព័ន្ធគ្នាឡើយ។ តើអ្នកមិនដឹងទេឬ? តើព្រះយេស៊ូវអាចមានពង្សាវតារដែរឬទេ? តើព្រះយេស៊ូវអាចមានដូនតាបានយ៉ាងដូចម្តេច? តើទ្រង់អាចក្លាយជាពូជពង្សរបស់មនុស្សដូចម្តេចបាន? សាច់ឈាមរបស់ទ្រង់បានកើតចេញពីនាងម៉ារី វិញ្ញាណរបស់ទ្រង់គឺជាព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ មិនមែនជាវិញ្ញាណមនុស្សឡើយ។ ព្រះយេស៊ូវគឺជាព្រះរាជបុត្រាស្ងួនភ្ងារបស់ព្រះជាម្ចាស់ ហេតុដូចនេះ តើព្រះអង្គ អាចមានពង្សាវតារបានយ៉ាងដូចម្តេច? ក្នុងពេលដែលទ្រង់គង់នៅលើផែនដី ទ្រង់មិនមែនជាសមាជិកនៃមនុស្សជាតិទេ ដូចនេះ តើឱ្យទ្រង់មានពូជពង្សបានយ៉ាងដូចម្តេចទៅ?» នៅពេលដែលអ្នកវិភាគពីពង្សាវតារ និងពន្យល់ពីសេចក្តីពិតខាងក្នុងយ៉ាងច្បាស់លាស់ ដោយចែកចាយនូវអ្វីដែលអ្នកបានយល់ បុគ្គលនោះនឹងគាំងគំនិតនិយាយមិនចេញ។ មនុស្សមួយចំនួននឹងយកព្រះគម្ពីរធ្វើជាឯកសារសំអាង ហើយសួរអ្នកថា «ព្រះយេស៊ូវមានពង្សាវតារ។ តើព្រះជាម្ចាស់របស់អ្នកនាពេលបច្ចុប្បន្ន មានពង្សាវតារដែរឬទេ?» នោះអ្នកនឹងត្រូវប្រាប់គេតាមការចេះដឹងរបស់អ្នក ដែលការចេះដឹងនេះគឺជាការពិតទាំងអស់ ហើយតាមរបៀបនេះ ចំណេះដឹងរបស់អ្នកនឹងទទួលបាននូវឥទ្ធិពលមួយហើយ។ នៅក្នុងសេចក្តីពិត ព្រះយេស៊ូវមិនជាប់ពាក់ព័ន្ធនឹងយ៉ូសែបទេ រឹតតែមិនជាប់ពាក់ព័ន្ធនឹងអ័ប្រាហាំទៅទៀត ទ្រង់គ្រាន់តែប្រសូត្រនៅស្រុកអ៊ីស្រាអែលប៉ុណ្ណោះ។ យ៉ាងណាក្តី ព្រះជាម្ចាស់មិនមែនជាជនជាតិអ៊ីស្រាអែល ឬជាសែស្រឡាយរបស់ពួកអ៊ីស្រាអែលទេ។ ការដែលបានប្រសូត្រនៅអ៊ីស្រាអែល មិនមែនមានន័យច្បាស់ថា ព្រះជាម្ចាស់គឺជាព្រះរបស់អ៊ីស្រាអែលតែមួយនោះទេ។ ការនេះគឺសម្រាប់តែជាប្រយោជន៍ដល់កិច្ចការរបស់ព្រះអង្គ ដែល

ទ្រង់ត្រូវអនុវត្ត នូវកិច្ចការនៃការយកកំណើតជាមនុស្សប៉ុណ្ណោះ។ ព្រះជាម្ចាស់គឺជាព្រះនៃរបស់សព្វសារពើដែលបានបង្កើតមកនៅលើចក្រវាលនេះ។ ព្រះអង្គគ្រាន់តែអនុវត្តនូវដំណាក់កាលមួយនៃកិច្ចការរបស់ព្រះអង្គនៅក្នុងទឹកដីអីស្រាអែលមុនគេប៉ុណ្ណោះ បន្ទាប់មក ទ្រង់ក៏បានចាប់ផ្ដើមធ្វើការនៅក្នុងចំណោមពួកជាតិសាសន៍ដទៃ។ យ៉ាងណាក្ដី មនុស្សបានចាត់ទុកព្រះយេស៊ូវជាព្រះរបស់ពួកអ៊ីស្រាអែល ហើយលើសពីនេះទៅទៀត ពួកគេក៏បានទុកព្រះអង្គនៅក្នុងចំណោមជាតិសាសន៍អ៊ីស្រាអែល និងក្នុងចំណោមពូជពង្សរបស់ស្ដេចដាវីឌដែរ។ ព្រះគម្ពីរបានចែងថា នៅគ្រាចុងក្រោយ ព្រះនាមព្រះយេហូវ៉ានឹងក្លាយជានាមដ៏អស្ចារ្យក្នុងចំណោមសាសន៍ដទៃ គឺមានន័យថា ព្រះជាម្ចាស់នឹងធ្វើការក្នុងចំណោមសាសន៍ដទៃ ក្នុងអំឡុងពេលនៃគ្រាចុងក្រោយ។ ការដែលព្រះជាម្ចាស់បានយកកំណើតជាមនុស្សនៅស្រុកយូដា មិនមែនបង្ហាញថា ព្រះជាម្ចាស់ ស្រលាញ់តែពួកសាសន៍យូដាប៉ុណ្ណោះទេ។ ការនោះបានកើតឡើងដោយព្រោះតែសេចក្ដីតម្រូវប៉ុណ្ណោះ មិនមែនដោយសារតែ ព្រះជាម្ចាស់អាចយកកំណើតជាមនុស្សបានតែនៅក្នុងប្រទេសអ៊ីស្រាអែលតែមួយនោះទេ (ដោយសារតែអ៊ីស្រាអែលជារាស្ត្រដែលព្រះជាម្ចាស់បានជ្រើសតាំង)។ តើរាស្ត្រដែលព្រះជាម្ចាស់បានជ្រើសតាំងមិនមាននៅក្នុងចំណោមពួកសាសន៍ដទៃទេឬ? គឺក្រោយពេលដែលព្រះយេស៊ូវបានធ្វើការនៅស្រុកយូដាចប់ កិច្ចការនោះក៏បានពង្រីកដល់សាសន៍ដទៃ។ (ពួកអ៊ីស្រាអែលហៅជាតិសាសន៍ទាំងអស់ ក្រៅពីអ៊ីស្រាអែលថាជា «សាសន៍ដទៃ»)។ តាមពិតមានមនុស្សដែលព្រះជាម្ចាស់បានជ្រើសតាំងនៅក្នុងសាសន៍ដទៃទាំងនោះផងដែរ គឺគ្រាន់តែថា នៅគ្រានោះមិនទាន់មានកិច្ចការដែលត្រូវបំពេញនៅទីនោះនៅឡើយ។ មនុស្សបានធ្វើការផ្ដោតសំខាន់ទៅលើអ៊ីស្រាអែល ពីព្រោះតែកិច្ចការពីរជំហានដំបូងបានកើតឡើងនៅក្នុងប្រទេសអ៊ីស្រាអែល ខណៈពេលដែលគ្មានកិច្ចការណាសោះបានកើតឡើងនៅក្នុងសាសន៍ដទៃ។ កិច្ចការក្នុងចំណោមសាសន៍ដទៃ គឺទើបតែចាប់ផ្ដើមនៅពេលបច្ចុប្បន្ននេះប៉ុណ្ណោះ ហេតុនេះហើយទើបមនុស្សពិបាកនឹងទទួលយកវា។ ប្រសិនបើអ្នកអាចយល់ច្បាស់ពីការទាំងអស់នេះ ប្រសិនបើអ្នកអាច

ជ្រួតជ្រាប និងចាត់ទុកការនេះបានត្រឹមត្រូវ នោះអ្នកនឹងមានចំណេះដឹងត្រឹមត្រូវអំពីព្រះជាម្ចាស់នាពេលបច្ចុប្បន្ននេះ និងក្នុងពេលអតីកាល ហើយចំណេះដឹងថ្មីនេះនឹងមានកម្រិតខ្ពស់ជាងចំណេះដឹងអំពីព្រះជាម្ចាស់ដែលពួកបរិសុទ្ធនៅក្នុងប្រវត្តិសាស្រ្តមានទៅទៀត។ ប្រសិនបើអ្នកមានបទពិសោធអំពីកិច្ចការនៅថ្ងៃនេះ និងបានស្ដាប់ឮពីព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅពេលបច្ចុប្បន្ននេះ ប៉ុន្តែមិនមានចំណេះដឹងអំពីលក្ខណៈទាំងស្រុងរបស់ព្រះជាម្ចាស់ ហើយការស្វះស្វែងរករបស់អ្នកនៅតែដូចដើមជានិច្ច ហើយមិនបានជំនួសនូវអ្វីដែលថ្មី ជាពិសេស ប្រសិនបើអ្នកមានបទពិសោធពីកិច្ចការនៃការការយកឈ្នះទាំងអស់នេះ ប៉ុន្តែបែរជាមិនមានការផ្លាស់ប្ដូរសោះ នូវអ្វីដែលមាននៅក្នុងអ្នក នោះតើជំនឿរបស់អ្នកមិនដូចជាមនុស្សដែលស្វែងរកតែនំប៉័ងដើម្បីចម្អែតសេចក្ដីស្រេកឃ្លានទេឬ? ចំពោះរឿងនេះ កិច្ចការនៃការយកឈ្នះ នឹងមិនមានទទួលបាននូវឥទ្ធិពលណាសោះនៅក្នុងអ្នក។ នោះតើអ្នកនឹងមិនក្លាយជាម្នាក់ក្នុងចំណោមមនុស្សដែលត្រូវផាត់ចោលទេឬ?

នៅពេលដែលកិច្ចការទាំងអស់នៃការយកឈ្នះបានមកដល់ទីបញ្ចប់ហើយ វាជាការសំខាន់ណាស់ដែលអ្នករាល់គ្នាបានឈ្វេងយល់ថា ព្រះជាម្ចាស់មិនត្រឹមតែជាព្រះរបស់អ៊ីស្រាអែលប៉ុណ្ណោះទេ តែទ្រង់ជាព្រះលើសត្តនិករទាំងអស់។ ទ្រង់បានបង្កើតមនុស្សជាតិទាំងអស់ មិនត្រឹមតែជនជាតិអ៊ីស្រាអែលប៉ុណ្ណោះទេ។ ប្រសិនបើអ្នកពោលថា ព្រះជាម្ចាស់គឺជាព្រះរបស់សាសន៍អ៊ីស្រាអែលតែម្នាក់ ឬថា ការដែលព្រះជាម្ចាស់យកកំណើតជាមនុស្សនៅសាសន៍ណាមួយក្រៅពីអ៊ីស្រាអែលជាការដែលមិនអាចទៅរួច នោះអ្នកមិនទាន់មានការយល់ដឹងក្នុងអំឡុងពេលនៃដំណើរការនៃកិច្ចការដែលព្រះជាម្ចាស់យកឈ្នះលើអ្នកនេះឡើយ ហើយអ្នកមិនទទួលស្គាល់សូម្បីតែបន្តិចដែលថាព្រះជាម្ចាស់គឺជាព្រះរបស់អ្នក គឺអ្នកគ្រាន់តែស្គាល់ថាព្រះជាម្ចាស់ប្ដូរពីប្រទេសអ៊ីស្រាអែលទៅប្រទេសចិន ហើយកំពុងតែត្រូវបង្ខំឱ្យធ្វើជាព្រះរបស់អ្នក។ ប្រសិនបើការនេះនៅតែជារបៀបដែលអ្នកយល់ឃើញអំពីអ្វីៗ នោះកិច្ចការរបស់ខ្ញុំនៅក្នុងអ្នកគ្មានផលផ្លែឡើយ ហើយអ្នកមិនបានយល់អំពីអ្វីដែលខ្ញុំបានមានបន្ទូលសូម្បីតែមួយ

ចំណុច។ ប្រសិនបើចុងក្រោយអ្នកសរសេរពីពង្សាវតារមួយទៀតសម្រាប់ខ្ញុំដូចអ្វីដែលម៉ាថាយបានធ្វើ ដោយរកឃើញឰយុកោមួយដែលស័ក្តិសមសម្រាប់ខ្ញុំ ដោយស្វែងរកបុរេកថាត្រឹមត្រូវរបស់ខ្ញុំ ដូចជា ព្រះជាម្ចាស់មានពង្សាវតារពីរសម្រាប់ការយកកំណើតជាមនុស្សទាំងពីរលើករបស់ទ្រង់វិញ តើនោះនឹងមិនមែនជារឿងកំប្លែងធំបំផុតនៅលើពិភពលោកទេឬ? តើអ្នកមិនមែនជា «បុគ្គលដែលមានបំណងល្អ» ដែលបានរកពង្សាវតារមួយឱ្យខ្ញុំ ដែលធ្វើឱ្យខ្ញុំក្លាយទៅជាម្នាក់ដែលបានបែងចែកព្រះជាម្ចាស់ជាពីរទេឬ? តើអ្នកអាចទទួលយកបន្ទុក នៃបាបនេះបានដែរឬទេ? បន្ទាប់ពីកិច្ចការនៃការយកឈ្នះទាំងអស់នេះ ប្រសិនបើអ្នកនៅតែមិនជឿថា ព្រះជាម្ចាស់គឺជាព្រះជាម្ចាស់នៃរបស់សព្វសារពើទេ ប្រសិនបើអ្នកនៅតែគិតថាព្រះជាម្ចាស់គឺជាព្រះនៃជនជាតិអ៊ីស្រាអែលតែម្នាក់ តើអ្នកមិនមែនជាម្នាក់ដែលទាស់នឹងព្រះជាម្ចាស់ដោយបើកចំហរទេឬ? គោលបំណងនៃការយកឈ្នះលើអ្នកនៅថ្ងៃនេះគឺដើម្បីឱ្យអ្នកទទួលស្គាល់ថាព្រះជាម្ចាស់គឺជាព្រះរបស់អ្នក និងជាព្រះរបស់អ្នកដទៃទៀតដែរ ហើយអ្វីដែលសំខាន់ជាងគេនោះគឺ ទ្រង់ជាព្រះជាម្ចាស់របស់មនុស្សគ្រប់គ្នាដែលស្រលាញ់ទ្រង់ និងជាព្រះនៃរបស់សព្វសារពើទាំងអស់។ ព្រះអង្គជាព្រះជាម្ចាស់ នៃជនជាតិអ៊ីស្រាអែល និងជាព្រះជាម្ចាស់នៃប្រជាជនអេស៊ីព្ទ។ ព្រះអង្គជាព្រះជាម្ចាស់នៃចក្រភពអង់គ្លេស និងជាព្រះជាម្ចាស់នៃជនជាតិអាមេរិកផងដែរ។ ព្រះអង្គមិនត្រឹមតែជាព្រះរបស់អ័ដាម និងនាងអេវ៉ាតែប៉ុណ្ណោះទេ ប៉ុន្តែក៏ជាព្រះជាម្ចាស់នៃពូជពង្សទាំងអស់របស់ពួកគេដែរ។ ព្រះអង្គជាព្រះជាម្ចាស់នៃអ្វីៗនៅក្នុងស្ថានសួគ៌ និងអ្វីៗនៅលើផែនដី។ គ្រួសារទាំងអស់ មិនថាពួកគេជាសាសន៍អ៊ីស្រាអែល ឬសាសន៍ដទៃនោះទេ គឺសុទ្ធតែស្ថិតនៅក្នុងព្រះហស្តនៃព្រះជាម្ចាស់តែមួយអង្គ។ ព្រះអង្គ មិនត្រឹមតែធ្វើការនៅក្នុងប្រទេសអ៊ីស្រាអែលអស់ពេលរាប់ពាន់ឆ្នាំ និងបានប្រសូត្រនៅស្រុកយូដាប៉ុណ្ណោះទេ ប៉ុន្តែពេលនេះ ព្រះអង្គបានយាងចុះមកប្រទេសចិន ដែលកន្លែងនេះជាទីដែលនាគដ៏ធំមានសម្បុរក្រហមឆ្វាយរង្វេល។ ប្រសិនបើការដែលបានប្រសូត្រនៅស្រុកយូដាធ្វើឱ្យទ្រង់អាចក្លាយជាស្ដេចនៃសាសន៍យូដា នោះតើការដែលទ្រង់យាងចុះមកក្នុងចំណោម

អ្នករាល់គ្នានៅពេលបច្ចុប្បន្ននេះ មិនមែនធ្វើឱ្យទ្រង់ក្លាយជាព្រះរបស់អ្នករាល់គ្នាទេឬអី? ព្រះអង្គបានដឹកនាំជនជាតិអ៊ីស្រាអែល និងបានប្រសូត្រនៅស្រុកយូដា ហើយព្រះអង្គក៏បានប្រសូត្រនៅក្នុងទឹកដីនៃសាសន៍ដទៃដែរ។ តើកិច្ចការទាំងអស់របស់ទ្រង់ មិនមែនត្រូវបានធ្វើឡើងសម្រាប់មនុស្សជាតិដែលទ្រង់បានបង្កើតទេឬ? តើព្រះអង្គស្រលាញ់សាសន៍អ៊ីស្រាអែលមួយរយដង ហើយស្អប់ខ្ពើមសាសន៍ដទៃមួយពាន់ដងឬ? តើនោះមិនមែនជាសញ្ញាណរបស់អ្នកទេឬ? មិនមែនព្រះជាម្ចាស់មិនធ្លាប់ធ្វើជាព្រះរបស់អ្នករាល់គ្នានោះទេ ប៉ុន្តែផ្ទុយទៅវិញ គឺអ្នករាល់គ្នាទេដែលមិនបានទទួលស្គាល់ទ្រង់ ហើយមិនមែនព្រះជាម្ចាស់មិនចង់ធ្វើជាព្រះរបស់អ្នករាល់គ្នាទេ ប៉ុន្តែគឺគឺអ្នករាល់គ្នាទេដែលបដិសេធព្រះអង្គ។ នៅក្នុងចំណោមអ្នកដែលព្រះជាម្ចាស់បានបង្កើតមក តើនរណាដែលមិនស្ថិតនៅក្នុងព្រះហស្តនៃព្រះដ៏មានគ្រប់ចេស្ដា? ក្នុងការយកឈ្នះលើអ្នករាល់គ្នានៅពេលបច្ចុប្បន្ននេះ តើគោលដៅគឺមិនមែនដើម្បីឱ្យអ្នករាល់គ្នាបានទទួលស្គាល់ថា ព្រះជាម្ចាស់ មិនមែនជាអ្វីក្រៅពីព្រះជាម្ចាស់របស់អ្នករាល់គ្នាទេឬ? ប្រសិនបើអ្នករាល់គ្នានៅតែប្រកាន់ថា ព្រះជាម្ចាស់គឺជាព្រះរបស់ជនជាតិអ៊ីស្រាអែលតែម្នាក់ ហើយនៅតែប្រកាន់ថា ដំណាក់របស់ស្ដេចដាវីឌដែលនៅក្នុងប្រទេសអ៊ីស្រាអែល គឺជាកន្លែងកំណើតរបស់ព្រះជាម្ចាស់ ហើយថាគ្មានជាតិសាសន៍ណាក្រៅពីអ៊ីស្រាអែល ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បី «បង្កើត» ព្រះជាម្ចាស់ រឹតតែថាគ្មានគ្រួសារសាសន៍ដទៃណាមិនអាចទទួលនូវកិច្ចការរបស់ព្រះយេហូវ៉ាដោយផ្ទាល់ ប្រសិនបើអ្នកនៅតែគិតរបៀបនេះ នោះតើវាមិនធ្វើឱ្យអ្នកមានជំហររឹងចចេសទេឬ? មិនត្រូវប្រកាន់ជំហរតែអ៊ីស្រាអែលរហូតពេកនោះទេ។ ព្រះជាម្ចាស់កំពុងនៅទីនេះក្នុងចំណោមអ្នករាល់គ្នានៅពេលបច្ចុប្បន្ន។ អ្នកក៏មិនគួរសម្លឹងមើលទៅលើមេឃដែរ។ ចូរឈប់សន្មតថាព្រះជាម្ចាស់របស់អ្នកនៅឯស្ថានសួគ៌ទៅ! ព្រះជាម្ចាស់បានយាងមកក្នុងកណ្ដាលអ្នករាល់គ្នាហើយ ដូចនេះតើទ្រង់អាចគង់នៅស្ថានសួគ៌ដូចម្ដេចនឹងបាន? អ្នកមិនបានជឿលើព្រះជាម្ចាស់អស់រយៈពេលជាយូរណាស់មកហើយ ប៉ុន្តែអ្នកមានសញ្ញាណជាច្រើនអំពីទ្រង់ រហូតដល់ចំណុចមួយ

ដែលអ្នកមិនហ៊ានគិតជាលើកទីពីររថា ព្រះជាម្ចាស់របស់សាសន៍អ៊ីស្រាអែលនឹងយាងចុះមកប្រទានព្រះគុណដល់អ្នករាល់គ្នាដោយព្រះវត្តមានរបស់ទ្រង់។ អ្នករាល់គ្នាថែមទាំងមិនសូវហ៊ានគិតអំពីរបៀបដែលអ្នកអាចមើលឃើញព្រះជាម្ចាស់លេចមកដោយផ្ទាល់ ដោយបង្ហាញថា អ្នករាល់គ្នាកខ្វក់យ៉ាងខ្លាំងដែលមិនអាចទទួលយកបាន។ អ្នករាល់គ្នាក៏មិនដែលបានគិតពីរបៀបដែលព្រះជាម្ចាស់ អាចយាងចុះមកក្នុងទឹកដីនៃសាសន៍ដទៃដែរ។ ព្រះអង្គគួរតែចុះមកនៅលើភ្នំស៊ីណៃ ឬភ្នំដើមអូលីវ និងលេចមកឯជនជាតិអ៊ីស្រាអែល។ តើពួកសាសន៍ដទៃ (គឺមនុស្សដែលមិនស្ថិតនៅក្នុងទឹកដីអ៊ីស្រាអែល) មិនមែនសុទ្ធតែជារបស់ដែលទ្រង់ស្អប់ខ្ពើមទេឬ? តើព្រះអង្គអាចធ្វើការនៅក្នុងចំណោមពួកគេដោយផ្ទាល់ដូចម្ដេចបាន? ពួកគេទាំងអស់នេះគឺជាប្រជាជាតិដែលបានចាក់ឫសយ៉ាងជ្រៅ ដែលអ្នករាល់គ្នាបានវិវត្តឡើងអស់រយៈពេលជាច្រើនឆ្នាំ។ គោលបំណងនៃការយកឈ្នះលើអ្នករាល់គ្នានៅថ្ងៃនេះ គឺដើម្បីបំបែកគំនិតទាំងនេះរបស់អ្នករាល់គ្នា។ ដូចនេះ អ្នករាល់គ្នាមើលឃើញការលេចមកដោយផ្ទាល់របស់ព្រះជាម្ចាស់នៅក្នុងចំណោមអ្នករាល់គ្នា មិនមែនជាព្រះនៅលើភ្នំស៊ីណៃ ឬភ្នំដើមអូលីវទេ តែគឺនៅក្នុងចំណោមប្រជាជន ដែលព្រះអង្គមិនដែលបានដឹកនាំពីមុនមក។ ក្រោយពេលដែលព្រះជាម្ចាស់ អនុវត្តនូវកិច្ចការពីរដំណាក់កាលរបស់ព្រះអង្គនៅក្នុងទឹកដីអ៊ីស្រាអែល នោះជនជាតិអ៊ីស្រាអែល និងអ្នកដែលមានគំនិតដូចសាសន៍ដទៃទាំងអស់ សុទ្ធតែមានគំនិតថា វាជាការពិតណាស់ដែលព្រះជាម្ចាស់បានបង្កើតរបស់សព្វសារពើ តែទ្រង់សព្វព្រះហឫទ័យ ធ្វើជាព្រះជាម្ចាស់របស់ជនជាតិអ៊ីស្រាអែលប៉ុណ្ណោះ មិនមែនជាព្រះជាម្ចាស់នៃសាសន៍ដទៃទេ។ ជនជាតិអ៊ីស្រាអែលជឿដូចនេះថា៖ ព្រះជាម្ចាស់អាចជាព្រះរបស់យើងតែប៉ុណ្ណោះ មិនមែនជាព្រះជាម្ចាស់របស់អ្នករាល់គ្នាដែលជាសាសន៍ដទៃទេ ហើយដោយសារតែអ្នករាល់គ្នាមិនបានគោរពដល់ព្រះយេហូវ៉ា ដូចនេះព្រះយេហូវ៉ា ដែលជាព្រះជាម្ចាស់របស់យើងស្អប់ខ្ពើមអ្នករាល់គ្នា។ សាសន៍យូដាទាំងនោះក៏ជឿដែរថា៖ ព្រះអម្ចាស់យេស៊ូវបានយករូបអង្គដូចជាពួកយើងដែលជាសាសន៍យូដា និងជាព្រះជាម្ចាស់ដែលមាននូវ

សញ្ញាសម្គាល់របស់សាសន៍យូដា។ ព្រះជាម្ចាស់ធ្វើកិច្ចការនៅក្នុងចំណោមយើង។ រូបអង្គរបស់ព្រះជាម្ចាស់ និងរូបភាពរបស់យើងគឺស្រដៀងគ្នា ហើយរូបភាពរបស់យើងគឺប្រហាក់ប្រហែលនឹងរូបអង្គរបស់ព្រះជាម្ចាស់ខ្លាំងណាស់។ ព្រះអម្ចាស់យេស៊ូវគឺជាស្ដេចរបស់យើងរាល់គ្នាដែលជាសាសន៍យូដា។ ពួកសាសន៍ដទៃមិនមានលក្ខណៈគ្រប់គ្រាន់ ដើម្បីទទួលយកនូវការសង្គ្រោះឡើយ។ ព្រះអម្ចាស់យេស៊ូវគឺជាតង្វាយលោះបាបសម្រាប់យើងដែលជាសាសន៍យូដា។ វាគ្រាន់តែជាមូលដ្ឋាននៃកិច្ចការពីរដំណាក់កាលដែលសាសន៍អ៊ីស្រាអែល និងសាសន៍យូដា បង្កើតនូវសញ្ញាណទាំងនេះប៉ុណ្ណោះ។ ពួកគេទាមទារយកសិទ្ធិកាន់កាប់លើព្រះជាម្ចាស់ ដោយមិនបានព្រមឱ្យព្រះជាម្ចាស់ធ្វើជាព្រះរបស់សាសន៍ដទៃដែរឡើយ។ តាមរបៀបនេះ ព្រះជាម្ចាស់បានក្លាយជាចន្លោះប្រហោងនៅក្នុងដួងចិត្តរបស់សាសន៍ដទៃ។ នេះគឺដោយសារតែគ្រប់គ្នាបានជឿថា ព្រះជាម្ចាស់មិនសព្វព្រះទ័យធ្វើជាព្រះរបស់សាសន៍ដទៃ និងជឿថា ព្រះអង្គចូលចិត្តតែសាសន៍អ៊ីស្រាអែលដែលជារាស្ត្ររើសតាំងរបស់ព្រះជាម្ចាស់ព្រមទាំងសាសន៍យូដា ជាពិសេសពួកសាវ័កដែលបានដើរតាមព្រះអង្គ។ តើអ្នកមិនដឹងថា កិច្ចការដែលព្រះយេហូវ៉ា និងព្រះយេស៊ូវបានធ្វើ គឺសម្រាប់ឱ្យមនុស្សជាតិទាំងអស់មានជីវិតទេឬ? តើពេលនេះអ្នកទទួលស្គាល់ឬទេថា ព្រះជាម្ចាស់គឺជាព្រះរបស់អ្នករាល់គ្នាដែលប្រសូត្រនៅក្រៅប្រទេសអ៊ីស្រាអែល? តើពេលនេះព្រះជាម្ចាស់មិនស្ថិតនៅកណ្ដាលអ្នករាល់គ្នាទេឬ? នេះមិនអាចជាការយល់សប្តិទេ មែនឬ? តើអ្នករាល់គ្នាគេមិនទទួលយកការពិតនេះទេឬ? អ្នករាល់គ្នាមិនហ៊ានជឿលើការពិតនេះ ឬគិតអំពីការពិតនេះឡើយ។ មិនថាអ្នកយល់ឃើញយ៉ាងណា អំពីការពិតនេះនោះទេ តើព្រះជាម្ចាស់មិនគង់នៅទីនេះក្នុងចំណោមអ្នករាល់គ្នាទេឬ? តើអ្នកនៅតែខ្លាចមិនហ៊ានជឿលើពាក្យទាំងនេះទៀតឬ? ចាប់ពីថ្ងៃនេះទៅ តើមនុស្សដែលព្រះជាម្ចាស់បានយកឈ្នះ និងមនុស្សទាំងអស់ដែលប្រាថ្នាចង់ក្លាយជាអ្នកដើរតាមព្រះជាម្ចាស់មិនមែនជារាស្ត្ររើសតាំងរបស់ព្រះជាម្ចាស់ទេឬ? តើអ្នករាល់គ្នា ដែលជាអ្នកដើរតាមព្រះជាម្ចាស់នៅពេលបច្ចុប្បន្ននេះ មិនមែនជារាស្ត្ររើសតាំងរបស់ព្រះជាម្ចាស់ដែល

នៅក្រៅទឹកដីអ៊ីស្រាអែលទេឬ? តើឋានៈរបស់អ្នករាល់គ្នាមិនដូចសាសន៍អ៊ីស្រាអែលទេឬ? តើការទាំងអស់នេះ មិនមែនជាអ្វីដែលអ្នករាល់គ្នាគួរទទួលស្គាល់ទេឬ? តើនេះមិនមែនជាគោលដៅនៃកិច្ចការយកឈ្នះលើអ្នករាល់គ្នាទេឬ? ដោយសារអ្នករាល់គ្នាអាចមើលឃើញព្រះជាម្ចាស់ នោះព្រះអង្គនឹងធ្វើជាព្រះជាម្ចាស់របស់អ្នករាល់គ្នាជារៀងរហូត ចាប់តាំងពីដើមដំបូងមក និងរហូតតទៅអនាគត។ ព្រះអង្គនឹងមិនបោះបង់ចោលអ្នករាល់គ្នាឡើយ ដរាបណាអ្នករាល់គ្នានៅតែសុខចិត្តដើរតាមព្រះអង្គ និងនៅតែបន្តធ្វើជាសត្តនិកររបស់ទ្រង់ដែលស្មោះត្រង់ និងស្តាប់បង្គាប់។

មិនថាមនុស្ស មានចិត្តស្រលាញ់ព្រះជាម្ចាស់ខ្លាំងយ៉ាងណានោះទេ ក៏ជាទូទៅពួកគេបានស្តាប់បង្គាប់ក្នុងការដើរតាមព្រះអង្គរហូតមកដល់ថ្ងៃនេះដែរ។ មិនមែនរហូតដល់ពេលចុងក្រោយនោះទេ គឺនៅពេលដែលដំណាក់កាលនៃកិច្ចការនេះបានចប់ ទើបពួកគេនឹងកែប្រែចិត្តដោយហ្មត់ចត់។ នោះគឺជាពេលដែលមនុស្សនឹងត្រូវបានយកឈ្នះយ៉ាងពិតប្រាកដ។ ពេលនេះ ពួកគេបានត្រឹមតែនៅក្នុងដំណើរការនៃការកំពុងត្រូវបានយកឈ្នះប៉ុណ្ណោះ។ នៅពេលដែលកិច្ចការនេះបានបញ្ចប់ នោះពួកគេនឹងត្រូវបានយកឈ្នះយ៉ាងឆាប់រហ័ស ប៉ុន្តែនោះមិនមែនជាបញ្ហានៅពេលនេះទេ! ទោះបីជាមនុស្សគ្រប់គ្នាត្រូវបានជំរុញចិត្តក៏ដោយ ក៏នោះមិនមានន័យថា ពួកគេត្រូវបានយកឈ្នះយ៉ាងហ្មត់ចត់ដែរ។ នេះគឺដោយសារតែនៅពេលបច្ចុប្បន្ននេះ មនុស្សបានឃើញតែព្រះបន្ទូល និងមិនមែនជាព្រឹត្តិការណ៍ពិតប្រាកដ ហើយពួកគេនៅតែមិនប្រាកដប្រជា មិនថាពួកគេជឿយ៉ាងជ្រាលជ្រៅប៉ុនណានោះទេ។ ដូច្នេះហើយមានតែព្រឹត្តិការណ៍ជាក់ស្តែងចុងក្រោយដែលព្រះបន្ទូលក្លាយជាការពិតទេ នោះទើបមនុស្សនឹងត្រូវបានយកឈ្នះដោយហ្មត់ចត់។ ពេលនេះ មនុស្សទាំងនេះត្រូវបានយកឈ្នះពីព្រោះពួកគេបានស្តាប់ឮរឿងអាថ៌កំបាំងជាច្រើន ដែលមិនធ្លាប់បានឮពីមុនមក។ ប៉ុន្តែនៅក្នុងអាថ៌កំបាំងនីមួយៗនោះ ពួកគេនៅតែស្វែងរក និងរង់ចាំព្រឹត្តិការណ៍ជាក់ស្តែង ដែលអនុញ្ញាតឱ្យពួកគេមើលឃើញគ្រប់ទាំងព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលកំពុងធ្វើឱ្យមានភាពពិតប្រាកដដែរ។ មានតែបែបនោះទេ ទើបគេនឹងត្រូវបាន

ជំរុញចិត្តទាំងស្រុង។ ទីបំផុត មានតែនៅពេលដែលគ្រប់គ្នាបានឃើញនូវការពិតដែលត្រូវបានធ្វើឱ្យជាក់ស្តែង ហើយការពិតទាំងនេះបានបណ្តាលឱ្យពួកគេមានអារម្មណ៍ជឿជាក់ទេ ទើបពួកគេបង្ហាញនូវការជឿជាក់នៅក្នុងដួងចិត្តរបស់ពួកគេ ពាក្យសម្ដីរបស់ពួកគេ និងក្រសែភ្នែករបស់ពួកគេ ព្រមទាំងត្រូវបានជំរុញចិត្តចេញពីជម្រៅបេះដូងរបស់ពួកគេមក។ នេះហើយជាធម្មជាតិរបស់មនុស្ស៖ អ្នកត្រូវតែមើលឃើញថា ព្រះបន្ទូលសុទ្ធតែក្លាយជាការពិត អ្នកត្រូវតែមើលឃើញនូវព្រឹត្តិការណ៍ជាក់ស្តែងមួយចំនួនដែលកំពុងកើតឡើង និងមើលឃើញនូវគ្រោះមហន្តរាយដែលកំពុងធ្លាក់មកលើមនុស្ស ហើយបន្ទាប់មក អ្នករាល់គ្នានឹងត្រូវបានជំរុញចិត្តទាំងស្រុងចេញពីខាងក្នុងមកវិញ។ ដូចជាសាសន៍យូដាដែរ គឺអ្នករាល់គ្នាអំពល់តែចង់មើលឃើញនូវទីសម្គាល់ និងការឫទ្ធិបារមី។ ប៉ុន្តែ អ្នករាល់គ្នានៅតែមើលមិនឃើញទៀតថា មានទីសម្គាល់ និងការឫទ្ធិបារមីជាច្រើន ហើយថាការពិតទាំងនេះកំពុងតែកើតឡើងដើម្បីបើកភ្នែករបស់ឱ្យមើលឃើញច្បាស់។ មិនថាវាជាការដែលមាននរណាម្នាក់ចុះមកពីលើមេឃ ឬក៏មានដុំពពកនិយាយមកកាន់អ្នករាល់គ្នា ឬការដែលខ្ញុំបណ្តេញវិញ្ញាណអារក្សចេញពីម្នាក់ក្នុងចំណោមអ្នករាល់គ្នា ឬព្រះសូរសៀងរបស់ខ្ញុំលាន់ឮដូចជាផ្គរលាន់ក្នុងចំណោមអ្នករាល់គ្នានោះទេ គឺអ្នករាល់គ្នាតែងតែចង់បាន ហើយតែងតែចង់ឃើញព្រឹត្តិការណ៍បែបនេះណាស់។ មនុស្សម្នាក់អាចពោលថា នៅក្នុងការជឿលើព្រះជាម្ចាស់ ក្ដីប្រាថ្នាធំបំផុតរបស់អ្នកគឺចង់ឃើញព្រះជាម្ចាស់យាងមក និងបង្ហាញនូវទីសម្គាល់មួយដល់អ្នករាល់គ្នាដោយផ្ទាល់។ នោះអ្នករាល់គ្នានឹងមានការស្កប់ស្កល់។ ដើម្បីយកឈ្នះលើអ្នករាល់គ្នាដែលជាមនុស្ស ខ្ញុំត្រូវតែសម្តែងកិច្ចការប្រហាក់ប្រហែលនឹងការបង្កើតស្ថានសួគ៌ និងផែនដីដែរ ហើយលើសពីនេះ ខ្ញុំក៏នឹងបង្ហាញអ្នកពីទីសម្គាល់ខ្លះដែរ។ នោះដួងចិត្តរបស់អ្នករាល់គ្នានឹងត្រូវបានយកឈ្នះទាំងស្រុង។

# សេចក្ដីពិតនៅខាងក្នុងអំពីកិច្ចការនៃការយកឈ្នះ (៤)

តើការដែលត្រូវបានប្រោសឲ្យបានគ្រប់លក្ខណ៍ មានន័យដូចម្ដេច? តើការដែលត្រូវបានយកឈ្នះមានន័យដូចម្ដេច? តើត្រូវមានលក្ខណវិនិច្ឆ័យអ្វីខ្លះ ដើម្បីឲ្យមនុស្សត្រូវបានយកឈ្នះ? ទាំងការយកឈ្នះ និងការប្រោសឲ្យបានគ្រប់លក្ខណ៍ គឺជាគោលបំណងនៃការធ្វើឲ្យមនុស្សមាននូវលក្ខណៈពេញលេញ ដើម្បីឲ្យគេអាចត្រូវបានស្ដារទៅរកលក្ខណៈដើមឡើងវិញ និងត្រូវបានរំដោះឲ្យរួចចេញ ពីនិស្ស័យពុករលួយរបស់គេបែបសាតាំង និងឥទ្ធិពលរបស់សាតាំង។ ការត្រូវបានយកឈ្នះនេះបានកើតមកយ៉ាងរួសរាន់នៅក្នុងដំណើរការនៃការធ្វើការលើមនុស្ស។ ពិតណាស់ វាជាជំហានដំបូងនៃកិច្ចការនោះ។ ការប្រោសឲ្យបានគ្រប់លក្ខណ៍ គឺជាជំហានទីពីរ ហើយវាជាកិច្ចការបង្ហើយ។ មនុស្សម្នាក់ៗត្រូវតែឆ្លងកាត់នូវដំណើរការនៃការយកឈ្នះនេះ។ ប្រសិនបើមិនដូច្នេះទេ ពួកគេនឹងមិនមានផ្លូវបានស្គាល់ព្រះជាម្ចាស់ឡើយ ហើយគេក៏នឹងមិនដឹងថាមានព្រះជាម្ចាស់គង់នៅដែរ គឺមានន័យថា ពួកគេមិនអាចទទួលស្គាល់ព្រះជាម្ចាស់បានឡើយ។ ហើយប្រសិនបើមនុស្សមិនទទួលស្គាល់ព្រះជាម្ចាស់ វាក៏មិនអាចឲ្យពួកគេទទួលបានការប្រទានឲ្យមានលក្ខណៈពេញលេញពីព្រះជាម្ចាស់ដែរ ដ្បិតអ្នកមិនបានបំពេញតាមលក្ខណវិនិច្ឆ័យនៃការដែលធ្វើឲ្យពួកគេបានពេញលេញនេះទេ។ ប្រសិនបើអ្នកមិនទទួលស្គាល់ព្រះជាម្ចាស់ទេ នោះតើអ្នកអាចស្គាល់ទ្រង់ម្ដេចបាន? តើអ្នកអាចស្វែងរកព្រះអង្គបានយ៉ាងដូចម្ដេច? អ្នកនឹងមិនអាចធ្វើ បន្ទាល់អំពីទ្រង់បានឡើយ ហើយអ្នកក៏មិនសូវមានជំនឿដើម្បីធ្វើឲ្យព្រះអង្គគាប់ព្រះហឫទ័យដែរ។ ដូចនេះ ចំពោះអស់អ្នកដែលចង់ឲ្យមាន ការប្រទានឲ្យបានពេញលេញ ជំហានដំបូងត្រូវតែឆ្លងកាត់កិច្ចការនៃការយកឈ្នះជាមុនសិន។ នេះគឺជាលក្ខខណ្ឌទីមួយ។ ប៉ុន្ដែ ទាំងការយកឈ្នះ និងការប្រោសឲ្យបានគ្រប់លក្ខណ៍មានលំដាប់លំដោយ ដើម្បីធ្វើការនៅក្នុងមនុស្ស និងដើម្បីផ្លាស់ប្ដូរពួកគេ ហើយចំណុចនីមួយៗគឺជាផ្នែកនៃកិច្ចការគ្រប់គ្រងមនុស្ស។ ជំហានទាំងពីរនេះត្រូវបានតម្រូវក្នុងការធ្វើឲ្យនរណាម្នាក់

បានពេញលេញ ហើយមិនអាចបដិសេធមួយណាបានឡើយ។ វាពិតណាស់ថា «ការត្រូវបានយកឈ្នះ» ស្ដាប់ទៅដូចជាមិនល្អសោះ ប៉ុន្តែតាមពិត ដំណើរការនៃការយកឈ្នះលើនរណាម្នាក់ គឺជាដំណើរការនៃការផ្លាស់ប្ដូរពួកគេ។ នៅពេលដែលអ្នកត្រូវបានយកឈ្នះ នោះនិស្ស័យពុករលួយរបស់អ្នកប្រហែលជាមិនត្រូវបានលុបបំបាត់ចោលទាំងស្រុងទេ ប៉ុន្តែអ្នកនឹងបានស្គាល់ពីវា។ តាមរយៈកិច្ចការនៃការយកឈ្នះនេះ អ្នកនឹងបានស្គាល់នូវភាពជាមនុស្សដែលអន់ថយរបស់អ្នក ព្រមទាំងភាពរឹងទទឹងរបស់អ្នកដែរ។ ទោះបីជាក្នុងរយៈពេលដ៏ខ្លីអ្នកនឹងមិនអាចបោះបង់ចោល ឬផ្លាស់ប្ដូរនូវចំណុចទាំងនេះក៏ដោយ ក៏អ្នកនឹងបានស្គាល់ពីវាដែរ ហើយការនេះនឹងធ្វើជាគ្រឹះសម្រាប់ភាពគ្រប់លក្ខណ៍របស់អ្នក។ ដូចនេះ ទាំងការយកឈ្នះ និងការប្រោសឲ្យបានគ្រប់លក្ខណ៍ ត្រូវបានធ្វើឡើងតាមលំដាប់លំដោយ ដើម្បីផ្លាស់ប្ដូរមនុស្ស ដើម្បីកំចាត់ចោលនូវនិស្ស័យពុករលួយបែបសាតាំងរបស់គេ ដើម្បីឲ្យពួកគេអាចថ្វាយខ្លួនទាំងស្រុងទៅព្រះជាម្ចាស់។ ការត្រូវបានយកឈ្នះ គឺគ្រាន់តែជាជំហានដំបូងនៅក្នុងការផ្លាស់ប្ដូរនិស្ស័យរបស់មនុស្សប៉ុណ្ណោះ ហើយក៏ជាជំហានដំបូងនៅក្នុងការដែលមនុស្សធ្វើការថ្វាយខ្លួនទៅព្រះជាម្ចាស់ទាំងស្រុងដែរ ហើយវានៅទាបជាងជំហាននៃការប្រោសឲ្យបានគ្រប់លក្ខណ៍នោះទេ។ និស្ស័យនៃជីវិតរបស់មនុស្សដែលត្រូវបានយកឈ្នះ មានការផ្លាស់ប្ដូរតិចជាងនិស្ស័យនៃជីវិតរបស់មនុស្ស ដែលត្រូវប្រោសឲ្យបានគ្រប់លក្ខណ៍ឆ្ងាយណាស់។ ការដែលត្រូវបានយកឈ្នះ និងការត្រូវប្រោសឲ្យបានគ្រប់លក្ខណ៍មានការយល់ឃើញខុសពីគ្នា ពីព្រោះចំណុចទាំងពីរនេះស្ថិតនៅក្នុងដំណាក់កាលនៃកិច្ចការខុសគ្នា ហើយក៏ព្រោះតែចំណុចទាំងពីរនេះបាននាំមនុស្សទៅរកស្តង់ដារផ្សេងគ្នាដែរ។ ការយកឈ្នះបាននាំមនុស្សទៅរកស្តង់ដារដែលទន់ទាបជាងមុន រីឯការប្រោសឲ្យបានគ្រប់លក្ខណ៍នាំឲ្យមនុស្សឈានទៅរកស្តង់ដារដែលខ្ពស់ជាងមុន។ មនុស្សដែលត្រូវប្រោសឲ្យបានគ្រប់លក្ខណ៍គឺជាមនុស្សសុចរិត គឺមនុស្សត្រូវបានប្រទានឲ្យបានបរិសុទ្ធ។ ពួកវាជាការកែច្នៃនៃកិច្ចការគ្រប់គ្រងមនុស្ស ឬជាផលិតផលសម្រេច។ ទោះបីជាពួកគេមិនមែនជាមនុស្សគ្រប់លក្ខណ៍ក្ដី ក៏ពួកគេ

ជាមនុស្សដែលស្វែងរកការរស់នៅក្នុង ជីវិតដ៏មានន័យដែរ។ មនុស្សដែលត្រូវបានយកឈ្នះ ទទួលស្គាល់អត្ថិភាពរបស់ព្រះជាម្ចាស់ដោយមាត់របស់ពួកគេតែប៉ុណ្ណោះ ពួកគេទទួលស្គាល់ថា ព្រះជាម្ចាស់បានយកកំណើតជាមនុស្ស ដោយព្រះបន្ទូលបានលេចមកជាសាច់ឈាម ហើយថាព្រះជាម្ចាស់បានយាងមកលើផែនដីនេះ ដើម្បីធ្វើកិច្ចការនៃការជំនុំជម្រះ និងការវាយផ្ចាល។ ពួកគេក៏ទទួលស្គាល់ថាការជំនុំជម្រះ និងការវាយផ្ចាលរបស់ព្រះជាម្ចាស់ ហើយការវាយប្រដៅ និងការបន្សុទ្ធរបស់ព្រះអង្គសុទ្ធតែមានប្រយោជន៍ដល់មនុស្ស។ ពួកគេ ទើបតែចាប់ផ្ដើមមាននូវលក្ខណៈដូចមនុស្សប៉ុណ្ណោះ។ ពួកគេមាននូវការយល់ដឹងជ្រៅជ្រះអំពីជីវិត ប៉ុន្ដែពួកគេនៅតែមានភាពស្រពេចស្រពិលនៅឡើយ។ ម្យ៉ាងទៀត ពួកគេទើបតែចាប់ផ្ដើមមាននូវភាពជាមនុស្សប៉ុណ្ណោះ។ នេះជាឥទ្ធិពលនៃការដែលត្រូវបានយកឈ្នះ។ នៅពេលដែលមនុស្សបានបោះជំហាននៅក្នុងផ្លូវឆ្ពោះទៅរកភាពគ្រប់លក្ខណ៍ និស្ស័យចាស់របស់ពួកគេ អាចមានលទ្ធភាពផ្លាស់ប្ដូរបាន។ លើសពីនេះទៅទៀត ជីវិតរបស់ពួកគេនៅបន្តរីកចម្រើន ហើយជាបន្តបន្ទាប់ ពួកគេក៏ចូលទៅក្នុងសេចក្ដីពិតកាន់តែជ្រៅ។ ពួកគេអាចស្អប់ខ្ពើមលោកិយ និងអស់អ្នកដែលមិនស្វែងរកសេចក្ដីពិត។ ពួកគេស្អប់ខ្លួនឯងជាពិសេស ប៉ុន្ដែលើសពីនេះទៅទៀតនោះ គឺពួកគេស្គាល់ខ្លួនឯងយ៉ាងច្បាស់។ ពួកគេសុខចិត្តរស់នៅដោយសេចក្ដីពិត និងយកវាធ្វើជាគោលដៅក្នុងការស្វែងរកសេចក្ដីពិត។ ពួកគេមិនមានបំណងរស់នៅក្នុងគំនិត ដែលគ្រប់គ្រងដោយខួរក្បាលរបស់ពួកគេទេ ហើយពួកគេមានអារម្មណ៍ថាស្អប់ខ្ពើមចំពោះការរាប់ខ្លួនឯងជាសុចរិតរបស់មនុស្ស ភាពក្រអឺតក្រទម និងអំនួត។ ពួកគេនិយាយដោយស្មារតីរឹងប៉ឹង ដោះស្រាយអ្វីៗដោយវិចារណញ្ញាណ និងប្រកបដោយប្រាជ្ញា និងមានភាពស្មោះត្រង់ ព្រមទាំងស្ដាប់បង្គាប់ព្រះជាម្ចាស់។ ប្រសិនបើពួកគេប្រទះនឹងករណីនៃការវាយផ្ចាល និងការជំនុំជម្រះ ពួកគេមិនត្រឹមតែមិនអសកម្ម ឬខ្សោយឡើយ តែថែមទាំងដឹងគុណចំពោះការវាយផ្ចាល និងការជំនុំជម្រះមកពីព្រះជាម្ចាស់ទៀតផង។ ពួកគេជឿថា ពួកគេមិនអាចគ្មាននូវការវាយផ្ចាល និងការជំនុំជម្រះពីព្រះជាម្ចាស់ទេ ព្រោះការនេះអាចជួយ

ការពារពួកគេបាន។ ពួកគេមិនស្វែករកសេចក្ដីជំនឿនៃសន្តិភាព និងអំណរ ព្រមទាំងការស្វែងរកនូវនំប៉័ង ដើម្បីចម្អែតសេចក្ដីស្រេកឃ្លានដែរ។ ពួកគេក៏មិនស្វែងរកការសប្បាយផ្នែកសាច់ឈាមដែរ។ នេះជាអ្វីដែលកើតឡើងនៅក្នុងមនុស្ស ដែលត្រូវប្រោសឲ្យបានគ្រប់លក្ខណ៍។ ក្រោយពីមនុស្សត្រូវបានយកឈ្នះ ពួកគេទទួលស្គាល់ថា ពិតជាមានព្រះជាម្ចាស់មែន ប៉ុន្តែការទទួលស្គាល់នោះ ត្រូវបានបើកបង្ហាញនៅក្នុងពួកគេក្នុងចំនួននៃរបៀបដែលមានកំណត់។ តើពាក្យថា ព្រះបន្ទូលលេចមកជាសាច់ឈាម មានន័យយ៉ាងណាឲ្យពិតប្រាកដទៅ? តើពាក្យថាយកកំណើតជាមនុស្សមានន័យដូចម្ដេច? តើព្រះជាម្ចាស់ដែលបានយកកំណើតជាមនុស្សបានធ្វើអ្វីខ្លះ? តើអ្វីជាគោលដៅ និងសារៈសំខាន់នៃកិច្ចការរបស់ទ្រង់? ក្រោយពីបានឆ្លងកាត់បទពិសោធពីកិច្ចការជាច្រើនរបស់ទ្រង់ ហើយក្រោយពីមានបទពិសោធពីទង្វើរបស់ទ្រង់នៅក្នុងសាច់ឈាមមក តើអ្នកទទួលបានអ្វីខ្លះ? មានតែក្រោយពេលដែលអ្នកបានយល់ដឹងអំពីការទាំងអស់នេះប៉ុណ្ណោះ ទើបអ្នកនឹងក្លាយជាមនុស្សម្នាក់ ដែលត្រូវបានយកឈ្នះ។ ប្រសិនបើអ្នកគ្រាន់តែពោលថា ខ្លួនទទួលស្គាល់ថាមានព្រះជាម្ចាស់ ប៉ុន្តែមិនបានលះបង់នូវអ្វីដែលអ្នកគួរលះបង់ ហើយបរាជ័យក្នុងការបោះបង់ចោលនូវការសប្បាយផ្នែកសាច់ឈាមដែលអ្នកគួរបោះបង់ចោល ប៉ុន្តែបែជានៅបន្តលោភលន់ចង់បានភាពសុខស្រួលផ្នែកសាច់ឈាម ដូចដែលអ្នកតែងតែមាន ហើយប្រសិនបើអ្នកមិនអាចបោះបង់ចោល នូវការរើសអើងបងប្អូនប្រុសស្រីរបស់អ្នក និងមិនបង់ថ្លៃណាមួយក្នុងការអនុវត្តន៍នូវការប្រតិបត្តិសាមញ្ញជាច្រើនទេនោះ នោះការនេះបញ្ជាក់ថា អ្នកមិនទាន់ត្រូវបានយកឈ្នះនៅឡើយទេ។ ក្នុងករណីនេះ ទោះបើសិនជាអ្នកមានការយល់ដឹងច្រើនក្ដី ក៏វាគ្មានប្រយោជន៍អ្វីដែរ។ មនុស្សដែលត្រូវបានយកឈ្នះគឺជាអ្នកដែលសម្រេចបាននូវការផ្លាស់ប្ដូរដំបូងៗមួយចំនួន និងច្រកចូលដំបូង។ ការមានបទពិសោធអំពីការជំនុំជម្រះ និងការវាយផ្ចាលរបស់ព្រះជាម្ចាស់ ផ្ដល់នូវចំណេះដឹងដំបូងអំពីព្រះជាម្ចាស់ និងការយល់ដឹងដំបូងអំពីសេចក្ដីពិតដល់មនុស្ស។ អ្នកប្រហែលជាមិនអាចចូលទៅដោយពេញលេញ ក្នុងភាពពិតប្រាកដកាន់តែស៊ីជម្រៅ និង

សេចក្ដីពិតដែលមានលក្ខណៈកាន់តែលម្អិតឡើយ ប៉ុន្តែនៅក្នុងជីវិតពិតប្រាកដរបស់អ្នក អ្នកអាចអនុវត្តន៍នូវសេចក្ដីពិតជាមូលដ្ឋានជាច្រើនដូចជា អ្វីៗដែលទាក់ទងនឹងការសប្បាយផ្នែកសាច់ឈាមរបស់អ្នក ឬឋានៈផ្ទាល់ខ្លួនរបស់អ្នកជាដើម។ ការទាំងអស់នេះ គឺជាឥទ្ធិពលដែលទទួលបាននៅក្នុងមនុស្សក្នុងអំឡុងដំណើរការនៃការដែលកំពុងត្រូវបានយកឈ្នះ។ ការផ្លាស់ប្ដូរនិស្ស័យ ក៏អាចមើលឃើញនៅក្នុងមនុស្សដែលត្រូវបានយកឈ្នះដែរ ឧទាហរណ៍ដូចជា របៀបដែលពួកគេស្លៀកពាក់ និងស្ដែងឲ្យឃើញពីខ្លួនឯង ព្រមទាំងរបៀបដែលពួកគេរស់នៅ ទាំងនេះសុទ្ធតែអាចផ្លាស់ប្ដូរទាំងអស់។ ការយល់ឃើញរបស់ពួកគេអំពីជំនឿលើព្រះជាម្ចាស់បានផ្លាស់ប្ដូរ ពួកគេមានភាពច្បាស់លាស់អំពីគោលបំណងនៃការស្វែងរករបស់ខ្លួន ហើយពួកគេមាននូវការប្រាថ្នាខ្ពស់ជាងនេះ។ ក្នុងអំឡុងពេលនៃកិច្ចការយកឈ្នះ ការផ្លាស់ប្ដូរដែលស្របគ្នាក៏កើតឡើងនៅក្នុងនិស្ស័យជីវិតរបស់ពួកគេដែរ។ ការផ្លាស់ប្ដូរនានាបានកើតឡើង ប៉ុន្តែការផ្លាស់ប្ដូរទាំងនេះ រាក់កំភែល កើតឡើងដំបូងៗ ហើយទាបជាងការផ្លាស់ប្ដូរនៅក្នុងនិស្ស័យ និងគោលដៅនៃការស្វែងរករបស់អស់អ្នកដែលត្រូវប្រោសឲ្យបានគ្រប់លក្ខណ៍ទៅទៀត។ នៅក្នុងពេលដែលកំពុងត្រូវបានយកឈ្នះ ប្រសិនបើនិស្ស័យរបស់មនុស្សម្នាក់មិនផ្លាស់ប្ដូរបន្តិចណាសោះ ហើយគេមិនទទួលបានសេចក្ដីពិតណាមួយ នោះមនុស្សម្នាក់នេះគឺដូចជាសម្រាម និងគ្មានប្រយោជន៍សោះឡើយ! មនុស្សដែលមិនត្រូវបានយកឈ្នះ មិនអាចត្រូវប្រោសឲ្យបានគ្រប់លក្ខណ៍ឡើយ! ប្រសិនបើបុគ្គលម្នាក់គ្រាន់តែស្វែងរកនូវការដែលត្រូវបានយកឈ្នះ នោះគេមិនអាចត្រូវបានប្រទានឲ្យបានពេញលេញឡើយ ទោះបីជានិស្ស័យរបស់គេបង្ហាញពីការផ្លាស់ប្ដូរជាក់លាក់ក្នុងអំឡុងពេលនៃកិច្ចការយកឈ្នះនោះក៏ដោយ។ ពួកគេក៏នឹងបាត់បង់ នូវសេចក្ដីពិតពីដំបូងដែលពួកគេបានទទួលដែរ។ ការផ្លាស់ប្ដូរនៅក្នុងនិស្ស័យរបស់មនុស្សដែលត្រូវបានយកឈ្នះ និងមនុស្សដែលត្រូវប្រោសឲ្យបានគ្រប់លក្ខណ៍ មានភាពខុសគ្នាច្រើនណាស់។ ប៉ុន្តែការដែលត្រូវបានយកឈ្នះគឺជាជំហានដំបូងនៅក្នុងការផ្លាស់ប្ដូរ ហើយវាគឺជាមូលដ្ឋានគ្រឹះ។ ការខ្វះនូវការផ្លាស់ប្ដូរដំបូងនេះ គឺបង្ហាញថា បុគ្គលម្នាក់មិនបាន

ស្គាល់ព្រះជាម្ចាស់ទាល់តែសោះ ពីព្រោះចំណេះដឹងនេះ កើតចេញពីការជំនុំជម្រះ ហើយការជំនុំជម្រះនេះ គឺជាផ្នែកធំមួយនៃកិច្ចការយកឈ្នះ។ ដូចនេះ អស់អ្នកដែលត្រូវបានប្រទានពរឲ្យបានគ្រប់លក្ខណ៍ ត្រូវតែត្រូវបានយកឈ្នះជាមុនសិន បើមិនដូច្នេះទេ ពួកគេគ្មានផ្លូវបានទទួលការប្រោសឲ្យបានគ្រប់លក្ខណ៍ទេ។

អ្នកពោលថា អ្នកទទួលស្គាល់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស ហើយអ្នកទទួលស្គាល់ព្រះបន្ទូលដែលលេចមកជាសាច់ឈាម ប៉ុន្តែអ្នកធ្វើនូវរឿងជាក់លាក់មួយចំនួននៅពីក្រោយអង្គទ្រង់ គឺអ្នកធ្វើអ្វីៗដែលទាស់ប្រឆាំងនឹងអ្វីដែលព្រះអង្គបានបង្គាប់ ហើយអ្នកគ្មានសេចក្ដីកោតខ្លាចចំពោះទ្រង់នៅក្នុងចិត្តរបស់អ្នកឡើយ។ តើនេះជាការទទួលស្គាល់ព្រះជាម្ចាស់ដែរឬទេ? អ្នកទទួលស្គាល់ អ្វីដែលព្រះអង្គមានបន្ទូលប៉ុន្តែអ្នកមិនអនុវត្តនូវអ្វីដែលអ្នកអាចធ្វើបានឡើយ ហើយអ្នកក៏មិននៅជាប់នឹងមាគ៌ារបស់ព្រះអង្គដែរ។ តើនេះគឺជាការទទួលស្គាល់ព្រះជាម្ចាស់ដែរឬទេ? ហើយទោះបីជាអ្នកទទួលស្គាល់ទ្រង់ក្ដី ក៏ចិត្តគំនិតរបស់អ្នក គ្រាន់តែជាការប្រុងប្រយ័ត្នចំពោះព្រះអង្គប៉ុណ្ណោះ គឺមិនដែលគោរពឡើយ។ ប្រសិនបើអ្នកបានឃើញ និងទទួលស្គាល់កិច្ចការរបស់ទ្រង់ និងដឹងថាទ្រង់ជាព្រះជាម្ចាស់ ប៉ុន្តែអ្នកនៅតែធ្វើហែអើ ហើយគ្មានការផ្លាស់ប្ដូរទាំងស្រុង នោះអ្នកជាប្រភេទមនុស្សដែលមិនទាន់ត្រូវបានយកឈ្នះនៅឡើយទេ។ អស់អ្នកដែលត្រូវបានយកឈ្នះ ត្រូវតែធ្វើគ្រប់យ៉ាងដែលពួកគេអាចធ្វើបាន ហើយទោះបីជាពួកគេមិនអាចចូលក្នុងសេចក្ដីពិតដែលខ្ពស់ជាងនេះ ហើយទោះបីជាសេចក្ដីពិតទាំងនេះអាចនៅមិនដល់ពួកគេក៏ដោយ ក៏មនុស្សបែបនេះចង់ចូលរួមនឹងសេចក្ដីនេះនៅក្នុងចិត្តរបស់ពួកគេដែរ។ គឺដោយសារតែមាននូវដែនកំណត់ចំពោះអ្វីដែលពួកគេអាចទទួលស្គាល់ថា អ្វីដែលពួកគេអាចអនុវត្តបានគ្មាននូវចំណង និងដែនកំណត់ទេ។ យ៉ាងណាក្ដី យ៉ាងហោចណាស់ពួកគេត្រូវតែធ្វើអ្វីគ្រប់យ៉ាងដែលពួកគេអាចធ្វើបាន ហើយប្រសិនបើអ្នកអាចធ្វើបាន នោះគឺជាឥទ្ធិពលដែលសម្រេចបាន ដោយសារតែកិច្ចការនៃការយកឈ្នះ។ ឧបមាថាអ្នកពោលថា «ដូចមានចែងថា ទ្រង់អាចដាក់ចេញនូវព្រះបន្ទូលជាច្រើនដែលមនុស្ស

មិនអាចធ្វើបាន ប្រសិនបើទ្រង់មិនមែនជាព្រះជាម្ចាស់ទេ តើទ្រង់ជានរណា?» ការគិតបែបនេះមិនមែនមានន័យថាអ្នកទទួលស្គាល់ព្រះជាម្ចាស់ទេ។ ប្រសិនបើអ្នកទទួលស្គាល់ព្រះជាម្ចាស់អ្នកត្រូវតែបង្ហាញវាចេញមកតាមរយៈសកម្មភាពជាក់ស្ដែងរបស់អ្នក។ ប្រសិនបើអ្នកដឹកនាំក្រុមជំនុំ តែមិនអនុវត្តន៍សេចក្ដីសុចរិត ប្រសិនបើអ្នកប្រាថ្នាចង់បានប្រាក់និងទ្រព្យសម្បត្តិ ហើយតែងតែយកប្រាក់មូលនិធិក្រុមជំនុំ ដាក់ចូលហោប៉ៅខ្លួនឯង តើនេះជាការទទួលស្គាល់ថាព្រះជាម្ចាស់មានវត្តមានគង់នៅដែរឬទេ? ព្រះជាម្ចាស់ពេញដោយព្រះចេស្ដា ហើយព្រះអង្គសាកសមនឹងឲ្យគោរព។ តើអ្នកអាចមិនភ័យខ្លាចបានដូចម្ដេច ប្រសិនបើអ្នកពិតជាទទួលស្គាល់ថាមានព្រះជាម្ចាស់? ប្រសិនបើអ្នកអាចប្រព្រឹត្តសកម្មភាពដ៏គួរឲ្យស្អប់ខ្ពើម តើអ្នកទទួលស្គាល់ព្រះអង្គយ៉ាងពិតប្រាកដដូចម្ដេចបាន? តើអ្នកដែលអ្នកជឿនោះ គឺជាព្រះជាម្ចាស់មែនទេ? អ្វីដែលអ្នកជឿលើនោះ គឺជាព្រះដ៏ស្រពេចស្រពិល ហេតុនេះទើបអ្នកមិនភ័យខ្លាច! អស់អ្នកដែលទទួលស្គាល់ និងស្គាល់ព្រះជាម្ចាស់យ៉ាងពិតប្រាកដសុទ្ធតែកោតខ្លាចទ្រង់ ហើយពួកគេមិនហានធ្វើអ្វីដែលទាស់ប្រឆាំងនឹងព្រះអង្គ ឬអ្វីដែលបំពានដល់មនសិការរបស់គេឡើយ។ ពួកគេមានការភ័យខ្លាចជាពិសេស ក្នុងការធ្វើអ្វីមួយដែលពួកគេដឹងថាមានការប្រឆាំងនឹងបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ មានតែបែបនេះទេទើបអាចចាត់ទុកថាជាការទទួលស្គាល់នូវព្រះវត្តមានគង់នៅរបស់ព្រះជាម្ចាស់។ តើអ្នកគួរធ្វើអ្វី នៅពេលដែលឪពុកម្ដាយរបស់អ្នកព្យាយាមបញ្ឈប់អ្នកពីការជឿលើព្រះជាម្ចាស់? តើអ្នកគួរស្រលាញ់ព្រះជាម្ចាស់ដោយរបៀបណានៅពេលដែលប្ដីរបស់អ្នកដែលជាអ្នកមិនជឿប្រព្រឹត្តល្អដាក់អ្នក? ហើយតើអ្នកគួរស្រលាញ់ព្រះជាម្ចាស់ ដោយរបៀបណា នៅពេលបងប្អូនប្រុសស្រីរបស់អ្នកស្អប់ខ្ពើមអ្នក? ប្រសិនបើអ្នកទទួលស្គាល់ទ្រង់ នោះអ្នកនឹងប្រព្រឹត្តយ៉ាងសមរម្យ និងរស់នៅក្នុងសេចក្ដីពិតនៅចំពោះបញ្ហាទាំងនេះ។ ប្រសិនបើអ្នកបរាជ័យក្នុងការឆ្លើយតបដោយរឹងមាំ តែបានត្រឹមតែពោលថា ខ្លួនទទួលស្គាល់នូវព្រះវត្តមានគង់នៅរបស់ព្រះជាម្ចាស់ នោះអ្នកជាមនុស្សនិយាយបានតែមាត់ប៉ុណ្ណោះ! អ្នកពោលថា អ្នកជឿលើទ្រង់ ហើយទទួលស្គាល់ព្រះអង្គ ប៉ុន្តែតើ

អ្នកទទួលស្គាល់ព្រះអង្គតាមរបៀបណា? តើអ្នកជឿលើព្រះអង្គតាមរបៀបណា? តើអ្នកកោតខ្លាចព្រះអង្គដែរឬទេ? តើអ្នកគោរពទ្រង់ដែរឬទេ? តើអ្នកស្រលាញ់ព្រះអង្គអស់ពីជម្រៅចិត្តដែរឬទេ? នៅពេលដែលអ្នកមានទុក្ខព្រួយ ហើយគ្មាននរណាម្នាក់ពឹងផ្អែក នោះអ្នកមានអារម្មណ៍ដឹងពីសេចក្ដីស្រលាញ់របស់ព្រះជាម្ចាស់ ប៉ុន្ដែក្រោយមក អ្នកក៏ភ្លេចការនេះទាំងអស់។ នេះមិនមែនជាការស្រលាញ់ព្រះជាម្ចាស់ទេ ហើយក៏មិនមែនជាការជឿលើព្រះជាម្ចាស់ដែរ! តើអ្វីដែលព្រះជាម្ចាស់ ចង់ឲ្យមនុស្សទទួលបានជាចុងក្រោយ? គ្រប់ទាំងសេចក្ដីដែលខ្ញុំបានរៀបរាប់ ដូចជាអារម្មណ៍ដែលមានការស្ញប់ស្ញែងខ្លាំងចំពោះភាពសំខាន់របស់ខ្លួនឯង ការមានអារម្មណ៍ថាអ្នកឆាប់ចាប់បាន និងឆាប់យល់នូវអ្វីដែលថ្មីៗ ការគ្រប់គ្រងអ្នកដទៃ ការមើលងាយអ្នកដទៃការវិនិច្ឆ័យមនុស្សតែសំបកក្រៅ ការធ្វើបាបមនុស្សដែលស្មោះត្រង់ ចង់បានយកប្រាក់ក្រុមជំនុំ និងការជាច្រើនទៀត។ គឺមានតែនៅពេលដែលនិស្ស័យពុករលួយបែបសាតាំងទាំងនេះត្រូវបានដកចេញពីអ្នករាល់គ្នាជាផ្នែកៗទេ នោះទើបការយកឈ្នះរបស់អ្នកនឹងត្រូវបានស្ដែងចេញមក។

កិច្ចការនៃការយកឈ្នះដែលបានធ្វើលើអ្នករាល់គ្នាដែលជាមនុស្សនេះ គឺមានសារៈសំខាន់យ៉ាងជ្រាលជ្រៅបំផុត៖ នៅក្នុងចំណុចមួយ គោលបំណងនៃកិច្ចការនេះ គឺដើម្បីប្រទានឲ្យមនុស្សមួយក្រុមបានគ្រប់លក្ខណ៍ មានន័យថាធ្វើឲ្យពួកគេបានគ្រប់លក្ខណ៍ ដើម្បីឲ្យពួកគេបានក្លាយជាក្រុមអ្នកឈ្នះមួយក្រុម ជាក្រុមមនុស្សដំបូងដែលត្រូវប្រោសឲ្យបានគ្រប់លក្ខណ៍ មានន័យថាពួកគេជាផលផ្លែដំបូង។ ចំណុចមួយវិញទៀត ការយកឈ្នះនេះត្រូវបានធ្វើឡើង ដើម្បីឲ្យភាវៈទាំងអស់ដែលព្រះបានបង្កើតមក រីករាយនឹងសេចក្ដីស្រលាញ់របស់ព្រះជាម្ចាស់ ទទួលបាននូវសេចក្ដីសង្រ្គោះដ៏ពេញលេញ និងអស្ចារ្យបំផុតរបស់ព្រះជាម្ចាស់ ដើម្បីឲ្យមនុស្សមិនត្រឹមតែរីករាយនឹងសេចក្ដីមេត្ដាករុណា និងសេចក្ដីសប្បុរសដ៏គួរឲ្យស្រលាញ់របស់ព្រះអង្គប៉ុណ្ណោះទេ តែអ្វីដែលសំខាន់ជាងនេះនោះ គឺការវាយផ្ចាល និងការជំនុំជម្រះ។ ចាប់តាំងពីថ្ងៃបង្កើតផែនដីរហូតមកដល់ពេលនេះ អ្វីគ្រប់យ៉ាងដែលព្រះជាម្ចាស់បាន

ធ្វើនៅក្នុងកិច្ចការរបស់ទ្រង់ នោះគឺសេចក្ដីស្រលាញ់ ដោយមិនមានការស្អប់មនុស្សឡើយ។ សូម្បីតែការវាយផ្ចាល និងការជំនុំជម្រះដែលអ្នកបានឃើញនោះ ក៏ជាសេចក្ដីស្រលាញ់ដែរ គឺជាសេចក្ដីស្រលាញ់ដែលពិតជាង និងមានលក្ខណៈប្រាកដជាង ជាសេចក្ដីស្រលាញ់ដែលដឹកនាំមនុស្ស ទៅកាន់មាគ៌ាត្រឹមត្រូវ នៃជីវិតរបស់មនុស្ស។ ប៉ុន្តែ នៅក្នុងចំណុចមួយផ្សេងទៀតនោះ វាជាការធ្វើទីបន្ទាល់នៅចំពោះមុខសាតាំង។ ហើយនៅក្នុងចំណុចមួយផ្សេងទៀត វាជាការធ្វើដើម្បីសង់គ្រឹះសម្រាប់ការផ្សព្វផ្សាយនៃកិច្ចការដំណឹងល្អនាពេលអនាគត។ គ្រប់ទាំងកិច្ចការទាំងអស់ដែលទ្រង់បានធ្វើ គឺមានគោលបំណងដឹកនាំមនុស្សចូលទៅក្នុងមាគ៌ាត្រឹមត្រូវនៃជីវិតមនុស្ស ដើម្បីឲ្យពួកគេរស់នៅជាមនុស្សធម្មតា ប៉ុន្តែសម្រាប់មនុស្សដែលមិនស្គាល់ពីរបៀបរស់នៅ និងរស់នៅដោយគ្មានការណែនាំនេះ គឺអ្នកនឹងរស់នៅក្នុងជីវិតដែលទទេសូន្យប៉ុណ្ណោះ ពីព្រោះជីវិតរបស់អ្នកគ្មានគុណតម្លៃ ឬអត្ថន័យសោះ ហើយអ្នកនឹងមិនអាចក្លាយជាមនុស្សធម្មតាបានឡើយ។ នេះគឺជាសារៈសំខាន់ យ៉ាងជ្រាលជ្រៅបំផុតនៃការយកជ័យជម្នះលើមនុស្ស។ អ្នករាល់គ្នាសុទ្ធតែជាកូនចៅរបស់ម៉ូអាប់។ នៅពេលដែលកិច្ចការនៃការយកឈ្នះ ត្រូវបានអនុវត្តនៅក្នុងអ្នករាល់គ្នា នោះគឺជាសេចក្ដីសង្គ្រោះដ៏អស្ចារ្យបំផុត។ អ្នករាល់គ្នារស់នៅក្នុងទឹកដីនៃអំពើបាប និងខុសឆ្គង ហើយអ្នកសុទ្ធតែខុសឆ្គង និងពេញដោយបាប។ ថ្ងៃនេះ អ្នករាល់គ្នាមិនត្រឹមតែអាចស្ទបស្ទង់ព្រះជាម្ចាស់ទេ តែអ្វីដែលសំខាន់ជាងនេះ អ្នករាល់គ្នាបានទទួលនូវការវាយផ្ចាល និងការជំនុំជម្រះ ហើយអ្នកបានទទួលនូវសេចក្ដីសង្គ្រោះដ៏ជ្រាលជ្រៅយ៉ាងពិតប្រាកដ គឺមានន័យថា អ្នកបានទទួលនូវសេចក្ដីស្រលាញ់ដ៏អស្ចារ្យបំផុតរបស់ព្រះជាម្ចាស់។ គ្រប់ទាំងសេចក្ដីដែលព្រះអង្គបានធ្វើ គឺទ្រង់ពិតជាស្រលាញ់អ្នករាល់គ្នាជាប្រាកដណាស់។ ព្រះអង្គមិនមានចេតនាអាក្រក់ណាមួយឡើយ។ ព្រះអង្គជំនុំជម្រះអ្នករាល់គ្នា ដោយព្រោះតែបាបរបស់អ្នករាល់គ្នា ដើម្បីឲ្យអ្នករាល់គ្នាធ្វើការពិនិត្យពិច័យពីខ្លួនឯង និងទទួលបាននូវសេចក្ដីសង្គ្រោះដ៏អស្ចារ្យនេះ។ សេចក្ដីទាំងអស់នេះ ត្រូវបានធ្វើដោយមានបំណងចង់ធ្វើឲ្យមនុស្សបានពេញលេញ។

ចាប់តាំងពីដើមមករហូតដល់ទីបញ្ចប់ ព្រះជាម្ចាស់បានកំពុងធ្វើការយ៉ាងខ្លាំងក្លាបំផុត ដើម្បីសង្គ្រោះមនុស្ស ហើយទ្រង់ក៏មិនមានព្រះទ័យចង់បំផ្លាញមនុស្សដែលទ្រង់បានបង្កើតដោយផ្ទាល់ព្រះហស្តព្រះអង្គទ្រង់ទាំងស្រុងនោះដែរ។ សព្វថ្ងៃនេះ ព្រះអង្គបានយាងមកនៅក្នុងចំណោមអ្នករាល់គ្នាដើម្បីធ្វើការ តើនេះមិនមែនជាសេចក្ដីសង្គ្រោះបន្ថែមទៀតទេឬ? ប្រសិនបើព្រះអង្គស្អប់អ្នករាល់គ្នា តើព្រះអង្គនៅតែធ្វើកិច្ចការដ៏ឧត្ដុងឧត្ដមនេះ ដើម្បីដឹកនាំអ្នកដោយផ្ទាល់ឬ? ហេតុអ្វីបានជាទ្រង់រងទុក្ខយ៉ាងនេះ? ព្រះជាម្ចាស់មិនបានស្អប់អ្នករាល់គ្នា ឬមានព្រះទ័យមិនល្អចំពោះអ្នកឡើយ។ អ្នកត្រូវដឹងថា សេចក្ដីស្រលាញ់របស់ព្រះជាម្ចាស់ គឺជាក្ដីស្រលាញ់ដ៏ពិតប្រាកដបំផុត។ នេះគឺដោយសារតែមនុស្សមិនស្ដាប់បង្គាប់ ទើបព្រះអង្គត្រូវសង្គ្រោះពួកគេតាមរយៈការជំនុំជម្រះ។ បើមិនធ្វើបែបនេះទេ ការសង្គ្រោះពួកគេនឹងមិនអាចទៅរួចនោះឡើយ។ ពីព្រោះអ្នករាល់គ្នាមិនដឹងពីរបៀបរស់នៅ ហើយមិនជ្រួតជ្រាបពីរបៀបត្រូវរស់នៅ ហើយដោយព្រោះតែអ្នករាល់គ្នា រស់នៅក្នុងទឹកដីដែលខុសឆ្គង និងពេញដោយអំពើបាប ហើយអ្នករាល់គ្នាជាវិញ្ញាណ អាក្រក់ដែលខុសឆ្គង និងកខ្វក់ នោះទ្រង់មិនអាចទ្រាំ ឲ្យអ្នករាល់គ្នាក្លាយជាមនុស្សថោកទាបជាងនេះ ទ្រង់មិនអាចទ្រាំទតឃើញអ្នករាល់គ្នារស់នៅក្នុងទឹកដីកខ្វក់នេះ ដូចដែលអ្នកធ្វើនាពេលនេះដោយត្រូវបានសាតាំងជាន់ឈ្លីតាមអំពើចិត្តនោះទេ ហើយទ្រង់ក៏មិនអាចទ្រាំឲ្យអ្នករាល់គ្នាធ្លាក់ចូលក្នុងស្ថាននរកនោះដែរ។ ព្រះអង្គគ្រាន់តែចង់យកបានមនុស្សក្រុមនេះ និងសង្គ្រោះអ្នករាល់គ្នាដោយហ្មត់ចត់ប៉ុណ្ណោះ។ នេះគឺជាគោលបំណងចម្បងនៃការធ្វើកិច្ចការនៃការយកឈ្នះលើអ្នករាល់គ្នា ពោលគឺវាគ្រាន់តែសម្រាប់សេចក្ដីសង្គ្រោះតែប៉ុណ្ណោះ។ ប្រសិនបើអ្នកមិនអាចឃើញថា គ្រប់យ៉ាងដែលបានធ្វើលើអ្នក គឺជាសេចក្ដីស្រលាញ់ និងសេចក្ដីសង្គ្រោះ ប្រសិនបើអ្នកគិតថា វាគ្រាន់តែជាវិធីសាស្ត្រជារបៀបមួយដើម្បីធ្វើទារុណកម្មមនុស្ស និងជាអ្វីមួយដែលមិនគួរឲ្យទុកចិត្ត នោះអ្នកក៏ប្រហែលជាត្រលប់ទៅកាន់ពិភពរបស់អ្នក ដើម្បីរងនូវការឈឺចាប់ និងភាពលំបាកវិញ! ប្រសិនបើអ្នកសុខចិត្តនៅក្នុងចរន្តនេះ និងរីករាយចំពោះការជំនុំជម្រះនិងសេចក្ដី

សង្គ្រោះដ៏ធំធេងនេះ ដើម្បីរីករាយនឹងព្រះពរទាំងអស់នេះ ជាព្រះពរដែលមិនមាននៅកន្លែងផ្សេងនៅក្នុងពិភពរបស់មនុស្ស និងដើម្បីរីករាយចំពោះសេចក្ដីស្រឡាញ់នេះ នោះជាការល្អហើយ៖ ចូរស្ថិតនៅក្នុងចរន្តនេះដើម្បីទទួលនូវកិច្ចការនៃការយកឈ្នះ ដើម្បីឲ្យអ្នកអាចត្រូវប្រោសឲ្យបានគ្រប់លក្ខណ៍។ ថ្ងៃនេះ អ្នកអាចរងនូវការឈឺចាប់បន្តិចបន្តួច និងការបន្សុទ្ធ ដោយសារតែការជំនុំជម្រះរបស់ព្រះជាម្ចាស់ ប៉ុន្តែការដែលត្រូវរងនូវការឈឺចាប់នេះមាននូវគុណតម្លៃ និងអត្ថន័យ។ ទោះបីជាមនុស្សត្រូវបានបន្សុទ្ធ និងស្ដែងចេញមកដោយគ្មានសេសសល់តាមរយៈការវាយផ្ចាល និងការជំនុំជម្រះរបស់ព្រះជាម្ចាស់ ដែលជាគោលបំណងចង់ដាក់ទោសដល់ពួកគេចំពោះបាបរបស់ពួកគេ ដើម្បីដាក់ទោសផ្នែកសាច់ឈាមរបស់ពួកគេក៏ដោយ ក៏គ្មានការងារណាមួយក្នុងចំណោមការងារនេះមានចេតនាចង់ថ្កោលទោសផ្នែកសាច់ឈាមរបស់ពួកគេឲ្យខូចខាតឡើយ។ ការលាតត្រដាងយ៉ាងធ្ងន់ធ្ងរដោយព្រះបន្ទូល គឺសុទ្ធតែមានគោលបំណងដឹកនាំអ្នកទៅរកមាគ៌ាត្រឹមត្រូវ។ អ្នករាល់គ្នាបានមានបទពិសោធដោយផ្ទាល់ជាច្រើនពីកិច្ចការនេះ ហើយវាច្បាស់ណាស់ថាមិនបាននាំអ្នករាល់គ្នាទៅរកមាគ៌ាអាក្រក់ឡើយ! ទាំងអស់នេះសុទ្ធតែដើម្បីធ្វើឲ្យអ្នករស់នៅក្នុងភាពជាមនុស្សធម្មតា ហើយវាមិនអាចសម្រេចបានតាមរយៈភាពជាមនុស្សធម្មតារបស់អ្នកបានឡើយ។ ជំហាននីមួយៗនៃកិច្ចការរបស់ព្រះជាម្ចាស់ គឺអាស្រ័យលើតម្រូវការរបស់អ្នក យោងទៅតាមភាពកំសោយ និងកម្ពស់ជាក់ស្ដែងរបស់អ្នក ហើយគ្មានបន្ទុកណាមួយដែលហួសពីការទទួលយកបាន ដែលត្រូវបានដាក់លើអ្នករាល់គ្នាឡើយ។ ការនេះមិនច្បាស់លាស់សម្រាប់អ្នកទេនៅថ្ងៃនេះ ហើយអ្នកមានអារម្មណ៍ហាក់ដូចជាខ្ញុំកំពុងតឹងតែងជាមួយអ្នកណាស់ ហើយតាមពិតទៅ អ្នកតែងតែជឿថា មូលហេតុដែលខ្ញុំវាយផ្ចាល ជំនុំជម្រះ និងស្ដីបន្ទោសអ្នកជារៀងរាល់ថ្ងៃគឺដោយសារតែខ្ញុំស្អប់អ្នក។ ប៉ុន្តែ ទោះបីជាការវាយផ្ចាល និងការជំនុំជម្រះដែលអ្នកទទួលរងនោះជាអ្វីក៏ដោយ ក៏តាមពិតទៅនេះជាសេចក្ដីស្រឡាញ់ចំពោះអ្នក ហើយវាជាការការពារដ៏អស្ចារ្យបំផុត។ ប្រសិនបើអ្នកមិនអាចយល់នូវអត្ថន័យដ៏ជ្រាលជ្រៅនៃកិច្ចការនេះទេ វានឹងមិនអាច

ឲ្យអ្នកបន្តមានបទពិសោធពីការនេះទៀតឡើយ។ សេចក្ដីសង្គ្រោះនេះ គួរតែនាំឲ្យអ្នកមានការកម្សាន្តចិត្ត។ មិនត្រូវបដិសេធក្នុងការយកទៅពិចារណាឡើយ។ មកដល់ត្រឹមនេះ សារៈសំខាន់នៃកិច្ចការយកឈ្នះគួរតែមានភាពច្បាស់លាស់ចំពោះអ្នក ហើយអ្នកគួរតែឈប់មានមន្ទិលអំពីការនេះក្នុងរបៀបណាមួយ ឬរបៀបផ្សេងទៀតហើយ!

# តើអ្នកគួរបម្រើបេសកកម្ម នាពេលអនាគតរបស់អ្នកយ៉ាងដូចម្ដេច?

តើអ្នកអាចប្រាប់ពីនិស្ស័យដែលព្រះជាម្ចាស់បានសម្ដែងនៅក្នុងសម័យនីមួយៗឱ្យបានច្បាស់លាស់ ដោយប្រើភាសាដែលអាចពន្យល់ពីសារៈសំខាន់នៃយុគសម័យនេះឱ្យបានត្រឹមត្រូវឬទេ? តើអ្នកដែលបានឆ្លងកាត់នូវកិច្ចការនៃគ្រាចុងក្រោយរបស់ព្រះជាម្ចាស់ អាចពិពណ៌នាពីនិស្ស័យសុចរិត របស់ព្រះជាម្ចាស់បានពិស្ដារឬទេ? តើអ្នកអាចផ្ដល់សក្ខីភាពពីនិស្ស័យរបស់ព្រះជាម្ចាស់បានច្បាស់ និងត្រឹមត្រូវដែរឬទេ? តើអ្នកនឹងប្រាប់បន្តនូវអ្វីដែលបានឃើញ និងបានឆ្លងកាត់ ទៅដល់អ្នកកាន់សាសនាគួរឱ្យសង្វេគ គួរឱ្យអាណិត និងស្មោះត្រង់ ដែលស្រេកឃ្លានសេចក្ដីសុចរិត និងកំពុងរង់ចាំឱ្យអ្នកមកឃ្វាលពួកគេយ៉ាងដូចម្ដេច? តើមនុស្សជំពូកណា កំពុងរង់ចាំឱ្យអ្នកមកឃ្វាលពួកគេ? តើអ្នកអាចស្រមៃបានទេ? តើអ្នកដឹងពីបន្ទុកនៅលើស្មារបស់អ្នក បញ្ជាបេសកកម្មរបស់អ្នក និងទំនួលខុសត្រូវរបស់អ្នកដែរឬទេ? តើស្មារតីយល់ដឹងអំពីបេសកកម្មជាប្រវត្តិសាស្ត្ររបស់អ្នកនៅឯណា? តើអ្នកសមនឹងធ្វើជាចៅហ្វាយនៅយុគសម័យក្រោយបានយ៉ាងដូចម្ដេច? តើអ្នកមានស្មារតីជាចៅហ្វាយខ្លាំងក្លាដែរឬទេ? តើអ្នកនឹងពន្យល់ពីចៅហ្វាយលើអ្វីគ្រប់យ៉ាងយ៉ាងដូចម្ដេច? តើវាពិតជាចៅហ្វាយលើបណ្ដាសត្វមានជីវិត និងវត្ថុដែលមានរូបរាងនៅក្នុងពិភពលោកនេះមែនទេ? តើអ្នកមានផែនការអ្វីខ្លះ សម្រាប់វឌ្ឍនភាពនៃដំណាក់កាលបន្ទាប់នៃកិច្ចការនេះ? តើមានមនុស្សប៉ុន្មានអ្នក កំពុងរង់ចាំឱ្យអ្នកធ្វើជាអ្នកគង្វាលរបស់ពួកគេ? តើវាជាកិច្ចការដ៏ធ្ងន់ធ្ងរ មួយ

សម្រាប់អ្នកឬទេ? ពួកគេក្រីក្រគួរឱ្យសង្វេគ ខ្វាក់ភ្នែក និងវង្វេងផ្លូវ ទាំងកំពុងទ្រហោយំនៅទីងងឹត តើផ្លូវនៅឯណា? ពួកគេចង់បានពន្លឺ ដូចជាទេពច្យុតចុះមកភ្លាមៗ ដើម្បីបណ្ដេញអំណាចនៃភាពអន្ធការ ដែលបានសង្កត់សង្កិនមនុស្សអស់ពេលជាច្រើនឆ្នាំមកហើយ។ តាមដែលដឹងមក តើមានអ្នកណាអាចដឹងថា ពួកគេសង្ឃឹមយ៉ាងអន្ទះសាហើយពួកគេប្រាថ្នាចង់បានការនេះទាំងថ្ងៃទាំងយប់ខ្លាំងប៉ុនណា? សូម្បីនៅពេលថ្ងៃដែលមានពន្លឺជះទៅផុត ក៏មនុស្សកំពុងរងទុក្ខយ៉ាងខ្លាំងទាំងនេះ នៅតែជាប់នៅក្នុងគុកងងឹត ដោយគ្មានសង្ឃឹមពីការដោះលែងឡើយ តើពួកគេនឹងលែងយំតទៅទៀតនៅពេលណា? គ្រោះអកុសលរបស់វិញ្ញាណផុយស្រួយ ដែលមិនធ្លាប់ទទួលការសម្រាកទាំងនេះ គួរឱ្យខ្លាចណាស់ ហើយពួកគេត្រូវចងជាប់នៅក្នុងស្ថានភាពនេះ ដោយចំណងគ្មានមេត្តាធម៌ និងប្រវត្តិសាស្ត្រមិនចេះផ្លាស់ប្ដូរនេះជាយូរមកហើយ។ ចុះតើនរណាធ្លាប់លឺសម្លេងទ្រហោយំរបស់ពួកគេទេ? តើមាននរណាធ្លាប់បានគិតអំពីស្ថានភាពវេទនារបស់ពួកគេទេ? តើអ្នកធ្លាប់គិតទេថា ព្រះជាម្ចាស់មានព្រះហឫទ័យព្រួយ និងសោកសង្រេងប៉ុនណា? តើទ្រង់អាចទ្រាំមើលមនុស្សឥតកំហុស ជាមនុស្សដែលទ្រង់បានបង្កើតដោយព្រះហស្តព្រះអង្គផ្ទាល់ រងទណ្ឌកម្មបែបនេះដូចម្ដេចបាន? សរុបមកមនុស្សជាជនរងគ្រោះដែលត្រូវគេបំពុល។ ហើយបើទោះបីជាមនុស្សជាតិអាចនៅរស់រហូតដល់សព្វថ្ងៃនេះបានក៏ដោយ តើមាននរណាដឹងថាមនុស្សជាតិត្រូវអាកំណាចបំពុលជាយូរមកហើយទេ? តើអ្នកភ្លេចហើយមែនទេថា អ្នកក៏ជាជនរងគ្រោះម្នាក់ដែរ? តើអ្នកគ្មានឆន្ទៈប្រឹងប្រែងជួយសង្គ្រោះអ្នកនៅរស់ទាំងនេះ ដោយទឹកចិត្តស្រឡាញ់របស់អ្នកចំពោះព្រះជាម្ចាស់ទេឬ? តើអ្នកគ្មានឆន្ទៈលះបង់កម្លាំងទាំងអស់របស់ខ្លួនដើម្បីសងគុណដល់ព្រះជាម្ចាស់ ដែលស្រឡាញ់មនុស្សជាតិ ដូចរូបកាយសាច់ឈាមរបស់ទ្រង់ផ្ទាល់ទេឬអី? នៅពេលមានគេនិយាយ និងធ្វើរឿងទាំងអស់នេះហើយ តើអ្នកនឹងបកស្រាយការដែលព្រះជាម្ចាស់ប្រើប្រាស់អ្នកឱ្យរស់នៅក្នុងជីវិតខុសប្លែកពីធម្មតាយ៉ាងដូចម្ដេច? តើអ្នកពិតជាមានការតាំងចិត្ត និងជំនឿចិត្ត ដើម្បីរស់នៅក្នុងជីវិតដ៏មានន័យរបស់បុគ្គលដែលគោរពស្រឡាញ់ និងបម្រើព្រះជាម្ចាស់មែនដែរឬទេ?

# តើអ្នករាល់គ្នាមានការយល់ដឹងអ្វីខ្លះអំពីព្រះពរ?

ទោះបីជាមនុស្សដែលកើតមកនៅក្នុងយុគសម័យនេះ ត្រូវបានពុករលួយដោយសាតាំង និងអារក្សអសោចក៏ដោយ ក៏សេចក្ដីពុករលួយនេះបាននាំពួកគេទៅកាន់សេចក្ដីសង្គ្រោះដ៏ខ្ពស់បំផុត ជាសេចក្ដីសង្គ្រោះមួយដែលធំធេងជាងភ្នំ និងវាលទំនាបរបស់ពពួកសត្វនានា និងទ្រព្យសម្បត្តិដ៏មហាសាលរបស់យ៉ូបទៅទៀត ហើយក៏ធំធេងជាងព្រះពរចេញពីការមើលឃើញព្រះយេហូវ៉ាដែលយ៉ូបបានទទួលក្រោយពេលគាត់បានជួបការល្បងលដែរ។ មានតែក្រោយពេលដែលយ៉ូបបានឆ្លងកាត់ការល្បងលនៃសេចក្ដីស្លាប់ប៉ុណ្ណោះ ទើបគាត់បានឮព្រះយេហូវ៉ាមានបន្ទូល ហើយស្ដាប់ឮព្រះសូរសៀងរបស់ព្រះយេហូវ៉ានៅក្នុងខ្យល់កួច។ ប៉ុន្តែគាត់មិនបានមើលឃើញព្រះភ័ក្ត្ររបស់ព្រះយេហូវ៉ាឡើយ ហើយគាត់ក៏មិនបានស្គាល់និស្ស័យរបស់ទ្រង់នោះដែរ។ អ្វីដែលយ៉ូបទទួលបាន គឺគ្រាន់តែជាទ្រព្យសម្បត្តិដែលផ្ដល់ការសប្បាយដល់រូបកាយ ព្រមទាំងកូនៗដែលមានរូបឆោមដ៏ស្រស់ស្អាតបំផុតនៅក្នុងចំណោមមនុស្សទាំងអស់នៅតាមបណ្ដាក្រុងជុំវិញ ក៏ដូចជាការការពារពីពពួកទេវតានៃស្ថានសួគ៌ប៉ុណ្ណោះ។ គាត់មិនដែលបានឃើញព្រះយេហូវ៉ាឡើយ ហើយទោះបីជាគាត់ត្រូវបានហៅថាជាមនុស្សសុចរិតក៏ដោយ ក៏គាត់មិនដែលបានស្គាល់និស្ស័យរបស់ព្រះយេហូវ៉ានោះដែរ។ គេអាចនិយាយបានថា ទោះបីជាការសប្បាយខាងសម្ភារៈរបស់មនុស្សសព្វថ្ងៃមានកម្រិតតិចតួចបណ្ដោះអាសន្ន ឬបរិយាកាសនៃពិភពខាងក្រៅមានភាពប្រឆាំងក៏ដោយ ក៏ខ្ញុំបង្ហាញនិស្ស័យរបស់ខ្ញុំ ជានិស្ស័យដែលខ្ញុំមិនធ្លាប់បានបើកសម្ដែងដល់មនុស្សតាំងពីបុរាណកាលមក ហើយនិស្ស័យនេះទៀតសោត តែងតែជារឿងលាក់កំបាំង ក៏ដូចជាសេចក្ដីអាថ៌កំបាំងពីអតីតកាលដ៏យូរលង់ចំពោះមនុស្សដ៏ទន់ទាបបំផុតដែរ ប៉ុន្តែខ្ញុំបានប្រទានសេចក្ដីសង្គ្រោះដ៏ធំបំផុតរបស់ខ្ញុំដល់មនុស្សបែបនេះ។ លើសពីនេះទៅទៀត នេះគឺជាលើកដំបូងហើយ ដែលខ្ញុំបានបើកសម្ដែងសេចក្ដីទាំងនេះ ដ្បិតខ្ញុំមិនធ្លាប់បានធ្វើកិច្ចការបែបនេះពីមុនមកឡើយ។ ទោះបីជាអ្នករាល់គ្នា

អន់ជាងយ៉ូបឆ្ងាយយ៉ាងណាក៏ដោយ ក៏អ្វីដែលអ្នករាល់គ្នាទទួលបាន និងអ្វីដែលអ្នកបានឃើញនោះ មានកម្រិតខ្ពស់លើសលប់ជាងគាត់ដែរ។ ទោះបីជាអ្នករាល់គ្នាបានឆ្លងកាត់ទុក្ខលំបាកគ្រប់ប្រភេទ ហើយបានជួបទារុណកម្មសព្វបែបយ៉ាងក៏ដោយ ក៏ទុក្ខលំបាកទាំងនោះមិនអាចប្រៀបស្មើនឹងការល្បងលរបស់យ៉ូបឡើយ។ ផ្ទុយទៅវិញ វាជាការជំនុំជម្រះ និងការវាយផ្ចាលដែលមនុស្សទទួល ដោយសារតែការបះបោររបស់គេ ដោយសារតែការប្រឆាំងរបស់គេ និងដោយសារតែនិស្ស័យដ៏សុចរិតរបស់ខ្ញុំប៉ុណ្ណោះ។ វាជាការជំនុំជម្រះ ការវាយផ្ចាល និងការដាក់បណ្ដាសាដ៏សុចរិត។ នៅក្នុងន័យមួយបែបទៀត យ៉ូបគឺជាមនុស្សសុចរិតនៅក្នុងចំណោមពួកអ៊ីស្រាអែល ដែលបានទទួលសេចក្ដីស្រឡាញ់ និងសេចក្ដីថ្នាក់ថ្នមដ៏អស្ចារ្យបំផុតរបស់ព្រះយេហូវ៉ា។ គាត់មិនបានប្រព្រឹត្តអំពើអាក្រក់ណាមួយ ហើយក៏មិនបានប្រឆាំងនឹងព្រះយេហូវ៉ានោះដែរ ផ្ទុយទៅវិញ គាត់បានស្មោះត្រង់យ៉ាងប្ដូរផ្ដាច់ចំពោះព្រះយេហូវ៉ា។ ដោយសារតែសេចក្ដីសុចរិតរបស់គាត់ គាត់ត្រូវរងការល្បងលហើយគាត់បានឆ្លងកាត់ការល្បងលដ៏ក្ដៅខ្លាំង ដោយសារតែគាត់ ជាអ្នកបម្រើដ៏ស្មោះត្រង់ម្នាក់របស់ព្រះយេហូវ៉ា។ មនុស្សសព្វថ្ងៃត្រូវទទួលការជំនុំជម្រះ និងការដាក់បណ្ដាសារបស់ខ្ញុំ ដោយសារតែសេចក្ដីស្មោកគ្រោក និងសេចក្ដីទុច្ចរិតរបស់ពួកគេ។ ទោះបីជាទុក្ខវេទនារបស់ពួកគេមិនដូចជាអ្វីដែលយ៉ូបបានឆ្លងកាត់ នៅពេលដែលគាត់បានបាត់បង់ហ្វូងសត្វ ទ្រព្យសម្បត្តិ អ្នកបម្រើ កូនៗ ព្រមទាំងមនុស្សជាទីស្រឡាញ់ទាំងអស់របស់គាត់ក៏ដោយ ក៏អ្វីដែលពួកគេរងទុក្ខនេះគឺជាការបន្សុទ្ធ និងការដុតដ៏ក្ដៅខ្លាំងដែរ។ ហើយអ្វីដែលធ្វើឲ្យវាកាន់តែធ្ងន់ធ្ងរជាងអ្វីដែលយ៉ូបបានជួបទៀតនោះគឺថា ការល្បងលបែបនេះមិនត្រូវបានបន្ធូរបន្ថយ ឬដកចេញ ដោយសារតែមនុស្សមានភាព ទន់ខ្សោយនោះឡើយ។ ផ្ទុយទៅវិញ ការល្បងលទាំងនេះនៅស្ថិតស្ថេរជានិច្ច ហើយបន្តមានរហូតដល់ថ្ងៃចុងក្រោយនៃជីវិតរបស់មនុស្ស។ នេះគឺជាការដាក់ទោស ការជំនុំជម្រះ និងការដាក់បណ្ដាសា ដែលកំពុងតែឆេះយ៉ាងឥតសំចៃ ហើយលើសពីនេះទៀតគឺថា វាជា «កេរមរតក» ស្របច្បាប់របស់មនុស្សជាតិ។ វាជាអ្វីដែលមនុស្សសមនឹងទទួល ហើយ

វាជាកន្លែងមួយ ដើម្បីបង្ហាញចេញនូវនិស្ស័យដ៏សុចរិតរបស់ខ្ញុំ។ នេះជាការពិតមួយដែលអ្នកត្រូវដឹង។ ទោះបីជាយ៉ាងណាក៏ដោយ អ្វីដែលមនុស្សបានទទួលយ៉ាងច្រើនសន្ធឹកសន្ធាប់នោះ មានកម្រិតខ្ពស់ជាងទុក្ខលំបាក ដែលពួកគេត្រូវរងទុក្ខនាពេលសព្វថ្ងៃទៅទៀត។ ទុក្ខលំបាកដែលអ្នករាល់គ្នាត្រូវរងទុក្ខ គឺគ្រាន់តែជាឧបសគ្គមួយដែលកើតចេញពីភាពល្ងង់ខ្លៅរបស់អ្នកប៉ុណ្ណោះ ខណៈពេលដែលអ្វីដែលអ្នករាល់គ្នាទទួលបាននោះគឺមានចំនួនមួយរយដង ច្រើនជាងទុក្ខលំបាករបស់អ្នករាល់គ្នាទៅទៀត។ បើស្របតាមក្រឹត្យវិន័យរបស់អ៊ីស្រាអែលនៅក្នុងសញ្ញាចាស់ អស់អ្នកដែលប្រឆាំងនឹងខ្ញុំ អស់អ្នកដែលជំនុំជម្រះខ្ញុំដោយចំហនិងអស់អ្នកដែលមិនដើរតាមផ្លូវរបស់ខ្ញុំ ហើយបែរជាហ៊ានថ្វាយយញ្ញបូជាមិនពិសិដ្ឋដល់ខ្ញុំ អ្នកនោះនឹងប្រាកដជាត្រូវវិនាសដោយភ្លើងនៅក្នុងព្រះវិហារ ឬត្រូវបានពួកអ្នករើសតាំងមួយចំនួនគប់ដុំថ្មសម្លាប់មិនខាន ហើយសូម្បីតែពូជអំបូរ ព្រមទាំងសាច់ញាតិផ្ទាល់ផ្សេងទៀតរបស់ពួកគេក៏នឹងត្រូវរងបណ្ដាសាររបស់ខ្ញុំដែរ។ នៅជីវិតខាងមុខពួកគេនឹងមិនមានសេរីភាពឡើយ ប៉ុន្តែពួកគេនឹងក្លាយជាទាសកររបស់ទាសករខ្ញុំ ហើយខ្ញុំនឹងនិរទេសពួកគេឲ្យចូលទៅក្នុងចំណោមសាសន៍ដទៃ ហើយពួកគេនឹងមិនអាចវិលត្រលប់ទៅកាន់ទឹកដីកំណើតរបស់ពួកគេវិញបានឡើយ។ ដោយអាស្រ័យលើទង្វើ និងឥរិយាបថរបស់ពួកគេ ទុក្ខលំបាកដែលមនុស្សសព្វថ្ងៃជួបប្រទះនេះនៅមិនទាន់ស្មើនឹងទារុណកម្មដ៏ធ្ងន់ធ្ងរ ដែលពួកអ៊ីស្រាអែលបានជួបនោះឡើយ។ ការនិយាយថា អ្វីដែលអ្នករាល់គ្នាកំពុងតែរងទុក្ខនាពេលសព្វថ្ងៃគឺជាកម្មពៀរ នេះមិនមែនជារឿងដែលគ្មានហេតុផលនោះឡើយ ដ្បិតអ្នករាល់គ្នាពិតជាបានឆ្លងកាត់បន្ទាត់ហាមប្រាមមែន។ ប្រសិនបើអ្នករាល់គ្នាបានស្ថិតនៅក្នុងស្រុកអ៊ីស្រាអែល នោះអ្នករាល់គ្នានឹងបានក្លាយជាមនុស្សបាបដ៏អស់កល្បជានិច្ចមិនខាន ហើយអ្នកនឹងត្រូវបានពួកអ៊ីស្រាអែលហែកច្រៀកជាបំណែកៗ និងត្រូវបានឆេះដោយភ្លើងពីស្ថានសួគ៌នៅក្នុងព្រះវិហាររបស់ព្រះយេហូវ៉ាតាំងពីយូរណាស់មកហើយ។ តើសព្វថ្ងៃនេះអ្នករាល់គ្នាទទួលបានអ្វីខ្លះទៅ? តើអ្នករាល់គ្នាបានទទួលអ្វីខ្លះ ហើយអ្នករាល់គ្នាបានរីករាយនឹងអ្វីខ្លះទៅ? ខ្ញុំបានបើក

សម្ដែងអំពីនិស្ស័យដ៏សុចរិតរបស់ខ្ញុំនៅក្នុងអ្នក ប៉ុន្ដែអ្វីដែលសំខាន់បំផុតនោះគឺថា ខ្ញុំបានបើកសម្ដែងព្រះទ័យអត់ធ្មត់របស់ខ្ញុំសម្រាប់ការប្រោសលោះមនុស្សជាតិ។ គេអាចនិយាយបានថា កិច្ចការដែលខ្ញុំបានធ្វើនៅក្នុងអ្នករាល់គ្នាគឺជាកិច្ចការនៃការអត់ធ្មត់ ហើយកិច្ចការនេះ ត្រូវបានធ្វើឡើងសម្រាប់ជាប្រយោជន៍ដល់ការគ្រប់គ្រងរបស់ខ្ញុំ ហើយជាងនេះទៅទៀត វាត្រូវបានធ្វើឡើងសម្រាប់ជាប្រយោជន៍ដល់សេចក្ដីរីករាយរបស់មនុស្សជាតិ។

ទោះបីជាយ៉ូបបានឆ្លងកាត់ការល្បងលរបស់ព្រះយេហូវ៉ាក៏ដោយ ក៏គាត់គ្រាន់តែជាមនុស្សសុចរិតម្នាក់ ដែលបានថ្វាយបង្គំព្រះយេហូវ៉ាប៉ុណ្ណោះ។ ទោះបីកំពុងតែឆ្លងកាត់ការល្បងលទាំងនោះក៏ដោយ ក៏គាត់មិនបានរអ៊ូរទាំ អំពីព្រះយេហូវ៉ាដែរ ហើយគាត់បានឲ្យតម្លៃយ៉ាងខ្លាំងទៅលើជំនួបរបស់គាត់ជាមួយទ្រង់។ មនុស្សសព្វថ្ងៃមិនគ្រាន់តែមិនសាទរចំពោះព្រះវត្តមានរបស់ព្រះយេហូវ៉ាប៉ុណ្ណោះទេ ប៉ុន្ដែពួកគេថែមទាំងបដិសេធ ស្អប់ខ្ពើម រអ៊ូរទាំ និងសើចចំអកចំពោះការលេចមករបស់ទ្រង់ទៀងផង។ តើអ្នករាល់គ្នាមិនទទួលបានច្រើនទេឬ? តើទុក្ខលំបាករបស់អ្នករាល់គ្នាពិតជាធំធេងខ្លាំងមែនឬ? តើអ្នករាល់គ្នាមិនមានសំណាងជាងនាងម៉ារា និងយ៉ាកុបទេឬ? តើការប្រឆាំងរបស់អ្នករាល់គ្នាពិតជាតិចតួចមែនឬ? តើវាអាចដោយសារតែអ្វីដែលខ្ញុំបានទាមទារពីអ្នករាល់គ្នា និងអ្វីដែលខ្ញុំបានសុំពីអ្នកនោះ វាធំខ្លាំងពេក និងច្រើនពេកឬ? សេចក្ដីក្រោធរបស់ខ្ញុំត្រូវបានធ្លាក់ទៅលើពួកអ៊ីស្រាអែលដែលបានប្រឆាំងនឹងខ្ញុំប៉ុណ្ណោះ មិនមែនធ្លាក់ទៅលើអ្នករាល់គ្នាដោយផ្ទាល់ឡើយ ហើយអ្វីដែលអ្នករាល់គ្នាទទួលបាន គ្រាន់តែជាការជំនុំជម្រះដ៏ឃោរឃៅ និងការបើកសម្ដែងរបស់ខ្ញុំ ក៏ដូចជាការបន្សុទ្ធដ៏ក្ដៅខ្លាំងឥតឈប់ឈរប៉ុណ្ណោះ។ ទោះបីជាបែបនេះក៏ដោយ ក៏មនុស្សនៅតែបន្ដប្រឆាំង និងបដិសេធខ្ញុំដដែល ហើយពួកគេធ្វើឡើងដោយគ្មានការចុះចូលសូម្បីតែបន្ដិច។ មានមនុស្សមួយចំនួនទៀតដែលចង់នៅឲ្យឆ្ងាយពីខ្ញុំ និងបដិសេធខ្ញុំ ហើយមនុស្សបែបនេះគ្មានអ្វីប្រសើរជាងបក្សពួករបស់កូរេ និងដាថាន ដែលបានប្រឆាំងនឹងម៉ូសេឡើយ។ ដួងចិត្តរបស់មនុស្សបានរឹងចចេស

ហើយធម្មជាតិរបស់ពួកគេជាមនុស្សក្បាលរឹង។ ពួកគេមិនដែលផ្លាស់ប្ដូរចរិតចាស់របស់ពួកគេឡើយ។ ខ្ញុំមានបន្ទូលថា ពួកគេត្រូវបានបកអាក្រាតយ៉ាងច្បាស់ក្រឡែត គឺដូចជាស្ត្រីពេស្យាដែលលក់ខ្លួននៅពេលថ្ងៃ ហើយព្រះបន្ទូលរបស់ខ្ញុំមិនពិរោះស្ដាប់ឡើយ រហូតដល់ថ្នាក់ធ្វើឲ្យពួកគេ «សង្កៀរត្រចៀក» ដើម្បីលាតត្រដាងពីធម្មជាតិរបស់មនុស្ស ប៉ុន្តែពួកគេគ្រាន់តែងក់ក្បាល សម្រក់ទឹកភ្នែកពីរបីតំណក់ ហើយបង្ខំចិត្តឲ្យមានអារម្មណ៍សោកសៅតែបន្តិចប៉ុណ្ណោះ។ នៅពេលដែលវេលានេះបានកន្លងផុតទៅ ពួកគេក៏មានចរិតកាចសាហាវដូចស្ដេចសត្វព្រៃនៅតាមតំបន់ភ្នំវិញ ហើយពួកគេគ្មានការយល់ដឹងសូម្បីតែបន្តិចសោះឡើយ។ តើមនុស្សដែលមាននិស្ស័យបែបនេះអាចដឹងយ៉ាងដូចម្ដេចទៅថា ពួកគេមានសំណាងជាងយ៉ូបមួយរយដងនោះ? តើពួកគេអាចទទួលស្គាល់យ៉ាងដូចម្ដេចទៅថា អ្វីដែលពួកគេរីករាយនោះគឺជាព្រះពរដែលកម្រនឹងបានឃើញនៅក្នុងយុគសម័យទាំងអស់ និងថាគ្មាននរណាម្នាក់ធ្លាប់បានរីករាយពីមុនមក? តើត្រូវធ្វើដោយរបៀបណាទៅ ដើម្បីឲ្យមនសិការរបស់មនុស្សអាចស្គាល់ពីព្រះពរបែបនេះ ជាព្រះពរដែលមានផ្ទុកនូវការដាក់ទោស? បើនិយាយឲ្យចំទៅ អ្វីគ្រប់យ៉ាងដែលខ្ញុំទាមទារពីអ្នករាល់គ្នា គឺដើម្បីឲ្យអ្នករាល់គ្នាអាចក្លាយជាមនុស្សគំរូសម្រាប់កិច្ចការរបស់ខ្ញុំ ក្លាយជាស្មរបន្ទាល់ សម្រាប់និស្ស័យទាំងស្រុងរបស់ខ្ញុំ និងសម្រាប់គ្រប់ទាំងទង្វើរបស់ខ្ញុំ ព្រមទាំងដើម្បីឲ្យអ្នករាល់គ្នាអាចត្រូវបានរួចខ្លួនពីការធ្វើបាបរបស់សាតាំង។ ប៉ុន្តែ មនុស្សតែងតែស្អប់ខ្ពើមកិច្ចការរបស់ខ្ញុំ ហើយមានបំណងប្រឆាំងនឹងកិច្ចការនេះជានិច្ច។ តើមនុស្សបែបនេះអាចមិនពន្យុះឲ្យខ្ញុំប្រើក្រឹត្យវិន័យរបស់អ៊ីស្រាអែល ហើយទម្លាក់សេចក្ដីក្រោធដែលខ្ញុំបានបញ្ចេញទៅលើអ៊ីស្រាអែល ទៅលើពួកគេយ៉ាងម៉េចកើតទៅ? ទោះបីជាមានមនុស្សជាច្រើននៅក្នុងចំណោមអ្នករាល់គ្នា ដែល «ស្ដាប់បង្គាប់ និងចុះចូល» ចំពោះខ្ញុំក៏ដោយ ក៏នៅមានមនុស្សជាច្រើនទៀតដែលដូចជាបក្សពួកកូរេដែរ។ នៅពេលដែលខ្ញុំបានទទួលសិរីល្អដ៏ពេញលេញរបស់ខ្ញុំរួចហើយ នោះខ្ញុំនឹងប្រើភ្លើងពីស្ថានសួគ៌ ដើម្បីដុតបំផ្លាញពួកគេឲ្យក្លាយជាផេះមិនខាន។ អ្នករាល់គ្នាគួរតែដឹងថា ខ្ញុំនឹងលែងវាយផ្ចាលមនុស្ស

ដោយព្រះបន្ទូលខ្ញុំទៀតហើយ។ ផ្ទុយទៅវិញ មុនពេលធ្វើកិច្ចការរបស់អ៊ីស្រាអែល ខ្ញុំនឹងដុតរំលាយទាំងស្រុងនូវ «បក្សពួកកូរេ» ដែលប្រឆាំងនឹងខ្ញុំ ព្រមទាំងមនុស្សដែលខ្ញុំបានផាត់ចោលតាំងពីយូរលង់ណាស់មកហើយ។ មនុស្សជាតិនឹងលែងមានឱកាសដើម្បីរីករាយនឹងខ្ញុំទៀតហើយ។ ផ្ទុយទៅវិញ គ្រប់យ៉ាងដែលពួកគេមើលឃើញនឹងក្លាយជាសេចក្ដីក្រោធរបស់ខ្ញុំ និងអណ្ដាតភ្លើងដែលធ្លាក់ពីស្ថានសួគ៌។ ខ្ញុំនឹងបើកសម្ដែងលទ្ធផលផ្សេងៗរបស់មនុស្សគ្រប់ប្រភេទ ហើយខ្ញុំនឹងបែងចែកពួកគេទាំងអស់ទៅតាមផ្នែក។ ខ្ញុំនឹងកត់ត្រាទុកគ្រប់ទាំងទង្វើបះបោររបស់ពួកគេ ហើយបន្ទាប់មក បង្ហើយកិច្ចការរបស់ខ្ញុំ ដូច្នេះ លទ្ធផលរបស់មនុស្សនឹងត្រូវបានកំណត់ទុកដោយផ្អែកលើសេចក្ដីសម្រេចរបស់ខ្ញុំ ក្នុងពេលដែលពួកគេរស់នៅលើផែនដី ក៏ដូចជាតាមរយៈអាកប្បកិរិយារបស់ពួកគេដែលមានចំពោះខ្ញុំដែរ។ នៅពេលដែលគ្រានោះមកដល់ វានឹងគ្មានអ្វីមួយអាចផ្លាស់ប្ដូរលទ្ធផលរបស់ពួកគេបានឡើយ។ ចូរឲ្យមនុស្សបើកសម្ដែងពីលទ្ធផលរបស់ពួកគេផ្ទាល់ទៅចុះ! បន្ទាប់មក ខ្ញុំនឹងថ្វាយលទ្ធផលរបស់មនុស្សដល់ព្រះវរបិតាដែលគង់នៅស្ថានសួគ៌។

# តើអ្នកមានការយល់ដឹងយ៉ាងដូចម្ដេចអំពីព្រះជាម្ចាស់?

មនុស្សបានជឿលើព្រះជាម្ចាស់យូរឆ្នាំមកហើយ ប៉ុន្តែ មនុស្សភាគច្រើនមិនយល់អំពីអត្ថន័យនៃពាក្យថា «ព្រះជាម្ចាស់» ឡើយ ហើយគ្រាន់តែដើរតាមទ្រង់ទាំងវង្វេងវង្វាន់ប៉ុណ្ណោះ។ ពួកគេមិនដឹងថា អ្វីជាមូលហេតុដែលនាំឲ្យមនុស្សត្រូវជឿលើព្រះជាម្ចាស់ ឬដឹងថាព្រះជាម្ចាស់ជាអ្វីឡើយ។ ប្រសិនបើមនុស្សគ្រាន់តែចេះជឿ និងចេះដើរតាមព្រះជាម្ចាស់ ប៉ុន្តែមិនដឹងថាព្រះជាម្ចាស់ជាអ្វី ហើយប្រសិនបើពួកគេមិនទាំងស្គាល់ព្រះជាម្ចាស់ផង នោះតើវាមិនមែនជារឿងកំប្លែងពេកទេឬអី? មកដល់ពេលនេះទៅហើយ ទោះបីជាមនុស្សបានឃើញសេចក្ដីលាក់កំបាំងជាច្រើននៃស្ថានសួគ៌ដោយផ្ទាល់ភ្នែក ហើយបានឮអំពីចំណេះដ៏ជ្រាលជ្រៅ ដែលមនុស្ស

មិនធ្លាប់បានយល់ពីមុនក៏ដោយ ក៏ពួកគេនៅមិនស្គាល់ សេចក្ដីជាច្រើននៅក្នុងសេចក្ដីពិតដ៏សាមញ្ញបំផុត ដែលមនុស្សកាលពីមុនមិនធ្លាប់គិតស្រមៃ។ អ្នកខ្លះអាចនិយាយថា «យើងបានជឿលើព្រះជាម្ចាស់ជាច្រើនឆ្នាំមកហើយ។ ម្ដេចបានជាយើងមិនដឹងថា ព្រះជាម្ចាស់គឺជាអ្វី? តើសំណួរនេះមិនមើលងាយយើងពេកទេឬអី?» ប៉ុន្តែតាមការពិត សព្វថ្ងៃនេះទោះបីមនុស្សដើរតាមខ្ញុំក៏ដោយ ក៏ពួកគេមិនដឹងអំពីកិច្ចការរបស់ខ្ញុំនាពេលសព្វថ្ងៃទាល់តែសោះ ហើយសូម្បីតែសំណួរដ៏សាមញ្ញ និងងាយស្រួលបំផុត ក៏គេមិនយល់ផង ចុះទម្រាំតែសំណួរស្មុគស្មាញខ្លាំងអំពីព្រះជាម្ចាស់ នោះគេកាន់តែមិនអាចយល់ទៀតហើយ។ ចូរដឹងថា សំណួរដែលអ្នកមិនខ្វល់ និងមិនស្គាល់ គឺជាសំណួរសំខាន់បំផុតសម្រាប់ឲ្យអ្នកយល់ ព្រោះថាអ្នកចេះតែដើរតាមបណ្ដាជនដោយមិនយកចិត្តទុកដាក់ និងមិនខ្វល់ខ្វាយចំពោះអ្វីដែលអ្នកគួរតែបំពាក់បំប៉នខ្លួននោះឡើយ។ តើអ្នកពិតជាដឹងអំពីហេតុផល ដែលអ្នកគួរតែមានសេចក្ដីជំនឿលើព្រះជាម្ចាស់ដែរឬទេ? តើអ្នកពិតជាស្គាល់អ្វីជាព្រះជាម្ចាស់ដែរឬទេ? តើអ្នកពិតជាស្គាល់អ្វីជាមនុស្សដែរឬទេ? ក្នុងនាមជាមនុស្សម្នាក់ ដែលមានសេចក្ដីជំនឿលើព្រះជាម្ចាស់ ប្រសិនបើអ្នកមិនយល់សំណួរទាំងនេះផង តើអ្នកមិនបាត់បង់សេចក្ដីថ្លៃថ្នូរក្នុងនាមជាអ្នកជឿលើព្រះជាម្ចាស់ទេឬអី? កិច្ចការរបស់ខ្ញុំថ្ងៃនេះគឺៈ ដើម្បីឲ្យមនុស្សយល់អំពីសារជាតិពិតរបស់គេ យល់គ្រប់កិច្ចការទាំងអស់ដែលខ្ញុំធ្វើ និងស្គាល់ព្រះភក្ត្រពិតរបស់ព្រះជាម្ចាស់។ នេះជាការបិទបញ្ចប់ផែនការគ្រប់គ្រងរបស់ខ្ញុំជាដំណាក់កាលចុងក្រោយនៃកិច្ចការរបស់ខ្ញុំ។ ហេតុនេះ បានជាខ្ញុំកំពុងតែប្រាប់អ្នករាល់គ្នាទុកជាមុនអំពីគ្រប់ទាំងសេចក្ដីលាក់កំបាំងនៃជីវិត ដើម្បីឲ្យអ្នករាល់គ្នាអាចទទួលយកសេចក្ដីទាំងនេះពីខ្ញុំ។ ដោយសារនេះជាកិច្ចការនៃយុគសម័យចុងក្រោយ ដូច្នេះខ្ញុំត្រូវតែប្រាប់អ្នករាល់គ្នា នូវគ្រប់ទាំងសេចក្ដីពិតនៃជីវិត ដែលអ្នករាល់គ្នាមិនធ្លាប់បានទទួលពីមុនមក ទោះបីជាអ្នករាល់គ្នាគ្មានសមត្ថភាពនឹងយល់ ឬទ្រាំទ្រសេចក្ដីទាំងនោះ ដោយសារតែសេចក្ដីខ្វះចន្លោះ និងកង្វះគុណសម្បត្តិច្រើនពេកក៏ដោយ។ ខ្ញុំនឹងបញ្ចប់កិច្ចការរបស់ខ្ញុំ។ ខ្ញុំនឹងសម្រេចកិច្ចការដែលខ្ញុំគួរតែធ្វើ ហើយ

ប្រាប់អ្នករាល់គ្នានូវអស់ទាំងសេចក្ដីដែលខ្ញុំបានដាក់បញ្ញាបេសកកម្មដល់អ្នករាល់គ្នា ដើម្បីកុំឲ្យអ្នករាល់គ្នាឃ្លាតចេញ ហើយធ្លាក់ទៅក្នុងផែនការរបស់មេកំណាច ពេលដែលសេចក្ដីងងឹតចុះមក។ មានផ្លូវជាច្រើនដែលអ្នកមិនយល់ មានរឿងជាច្រើនដែលអ្នកមិនដឹង។ អ្នករាល់គ្នាពិតជាល្ងង់ខ្លៅពេកហើយ។ ខ្ញុំស្គាល់យ៉ាងច្បាស់អំពីនិស្ស័យ និងសេចក្ដីខ្វះចន្លោះរបស់អ្នករាល់គ្នា។ ដូច្នេះ ទោះបីមានពាក្យពេចន៍ជាច្រើនដែលអ្នករាល់គ្នាមិនអាចយល់បាន ក៏ខ្ញុំនៅតែព្រមប្រាប់អ្នករាល់គ្នាអំពីសេចក្ដីពិតទាំងអស់ដែលអ្នកមិនធ្លាប់បានយល់ពីមុនមកនេះ ដោយសារតែខ្ញុំចេះតែបារម្ភក្រែងអ្នករាល់គ្នាមិនអាចឈររឹងមាំក្នុងការដែលអ្នករាល់គ្នាធ្វើបន្ទាល់ពីខ្ញុំ តាមគោលជំហររបស់អ្នករាល់គ្នានាពេលបច្ចុប្បន្ន។ ខ្ញុំគិតបែបនេះមិនមែនមានន័យថា អ្នករាល់គ្នាអន់នោះឡើយ ប៉ុន្តែអ្នករាល់គ្នាជាសត្វសាហាវដែលមិនទាន់បានឆ្លងកាត់បង្ហាត់បង្រៀនតាមក្រឹត្យក្រមរបស់ខ្ញុំ ហើយខ្ញុំពិតជាមិនអាចមើលឃើញទំហំសិរីល្អ ដែលមាននៅខាងក្នុងអ្នករាល់គ្នាឡើយ។ ទោះបីខ្ញុំខំចំណាយកម្លាំងច្រើនប៉ុនណាលើអ្នករាល់គ្នា ក៏ធាតុវិជ្ជមាននៅខាងក្នុងអ្នករាល់គ្នាហាក់ដូចជាគ្មានលេចឡើងសោះឡើយ ចំណែកឯធាតុអវិជ្ជមានវិញ បែរជាមានតិចតួច និងទុកសម្រាប់យកមកធ្វើជាបន្ទាល់ ដើម្បីនាំសេចក្ដីអាម៉ាស់មកឱ្យសាតាំងតែប៉ុណ្ណោះ។ ចំណែកឯអ្វីៗផ្សេងទៀតនៅក្នុងអ្នក គឺជាថ្នាំបំពុលរបស់សាតាំង។ អ្នករាល់គ្នាមើលមកខ្ញុំ ដូចជាអ្នកមិនអាចទទួលបានសេចក្ដីសង្គ្រោះអ៊ីចឹង។ ដោយសារតែបែបនេះ ខ្ញុំសម្លឹងមើលសម្ដីសំដៅ និងឫកពាផ្សេងៗរបស់អ្នករាល់គ្នា ហើយទីបំផុត ខ្ញុំក៏ដឹងអំពីកម្ពស់ពិតរបស់អ្នករាល់គ្នា។ នេះជាហេតុផលដែលខ្ញុំតែងតែគិតខ្វល់អំពីអ្នករាល់គ្នាថា៖ បើទុកឲ្យមនុស្សរស់នៅដោយខ្លួនឯង តើជីវិតពួកគេនឹងរស់នៅបានប្រសើរជាងនេះ ឬក៏ដូចគ្នានឹងជីវិតរបស់គេសព្វថ្ងៃ? តើនិស្ស័យជាកូនក្មេងរបស់អ្នករាល់គ្នា មិនធ្វើឲ្យអ្នករសាប់រសល់ទេឬអី? តើអ្នករាល់គ្នាពិតជាអាចធ្វើដូចរាស្ត្ររើសតាំងនៃសាសន៍អ៊ីស្រាអែលដែលស្មោះចំពោះខ្ញុំ គឺចំពោះខ្ញុំតែម្នាក់ជារៀងរហូតបានដែរឬទេ? អ្វីដែលស្តែងចេញនៅក្នុងអ្នករាល់គ្នា មិនមែនជាបំណងប៉ងចង់ធ្វើអាក្រក់របស់ក្មេង ដែលនៅឆ្ងាយពីឪពុកម្ដាយរបស់គេឡើយ

ប៉ុន្តែជាចរិតតិរច្ឆានដែលផុសចេញពីសត្វសាហាវ ដែលនៅឆ្ងាយពីរំពាត់របស់ម្ចាស់វា។ អ្នករាល់គ្នាគួរតែស្គាល់និស្ស័យខ្លួនឯង ជាសេចក្ដីកម្សោយដែលអ្នករាល់គ្នាមានដូចគ្នា វាជាជំងឺទូទៅមួយដែលអ្នករាល់គ្នាមានគ្រប់គ្នា។ ដូច្នេះ ពាក្យដាស់តឿនរបស់ខ្ញុំសម្រាប់អ្នករាល់គ្នានៅថ្ងៃនេះគឺ ចូរឈរមាំក្នុងបន្ទាល់ ដែលអ្នករាល់គ្នាធ្វើសម្រាប់ខ្ញុំ។ ទោះស្ថិតក្រោមកាលៈទេសៈណាក៏ដោយ មិនត្រូវបណ្ដោយឲ្យជំងឺចាស់ផ្ទុះឡើងម្ដងទៀតឡើយ។ ការធ្វើបន្ទាល់ គឺជាកិច្ចការដ៏សំខាន់បំផុត ព្រោះវាជាបេះដូងនៃកិច្ចការរបស់ខ្ញុំ។ អ្នករាល់គ្នាគួរតែទទួលយកពាក្យរបស់ខ្ញុំ ដូចជានាងម៉ារាបានទទួលយកការបើកសម្ដែងរបស់ព្រះយេហូវ៉ា ដែលបានយាងមករកនាងនៅក្នុងសុបិនៈ ទាំងជឿ ហើយបន្ទាប់មកក៏ស្ដាប់បង្គាប់។ នេះហើយជាគុណសម្បត្តិរបស់ស្រីក្រមុំម្នាក់នេះ។ ដ្បិតអ្នករាល់គ្នាជាមនុស្សដែលឮពាក្យរបស់ខ្ញុំច្រើនជាងគេ ជាមនុស្សដែលទទួលព្រះពរពីខ្ញុំច្រើនជាងគេ។ ខ្ញុំបានប្រទានទ្រព្យសម្បត្តិដ៏មានតម្លៃទាំងអស់របស់ខ្ញុំដល់អ្នករាល់គ្នា ខ្ញុំបានប្រទានអ្វីៗគ្រប់យ៉ាងដល់អ្នករាល់គ្នា ប៉ុន្តែអ្នករាល់គ្នាមានស្ថានភាពខុសគ្នាស្រឡះពីប្រជាជនអ៊ីស្រាអែល គឺខុសគ្នាដូចមេឃនិងដីតែម្ដង។ ប៉ុន្តែ ប្រសិនបើធៀបនឹងពួកគេ អ្នករាល់គ្នាបានទទួលច្រើនជាងពួកគេឆ្ងាយណាស់។ ខណៈដែលពួកគេ រង់ចាំការលេចមករបស់ខ្ញុំយ៉ាងអន្ទះសា អំពីអ្នករាល់គ្នាចំណាយជីវិតជាមួយខ្ញុំយ៉ាងរីករាយ ទាំងមានចំណែកទទួលសេចក្ដីសប្បុរសរបស់ខ្ញុំផង។ ផ្អែកលើភាពខុសគ្នានេះ តើអ្វីទៅដែលផ្ដល់ឲ្យអ្នករាល់គ្នាមានសិទ្ធិយំយែក និងទាស់ទែងជាមួយខ្ញុំ ហើយទាមទារឲ្យខ្ញុំចែកទ្រព្យសម្បត្តិរបស់ខ្ញុំជាមួយអ្នករាល់គ្នាដូច្នេះ? តើអ្នករាល់គ្នាមិនបានទទួលច្រើនហើយទេឬអី? ខ្ញុំបានប្រទានដល់អ្នករាល់គ្នាច្រើនណាស់ ប៉ុន្តែអ្វីដែលអ្នករាល់គ្នាតបស្នងមកខ្ញុំវិញ គឺជាភាពសោកសៅយ៉ាងវេទនាចិត្ត និងសេចក្ដីថប់បារម្ភ សេចក្ដីខកចិត្ត និងសេចក្ដីទោមនស្សដែលមិនអាចទប់បាន។ អ្នករាល់គ្នាគួរឲ្យស្អប់ណាស់ ប៉ុន្តែអ្នកក៏គួរឲ្យអាណិតដែរ ដូច្នេះ ខ្ញុំគ្មានជម្រើសណាផ្សេង ក្រៅពីលេបយកសេចក្ដីខកចិត្តទាំងប៉ុន្មានរបស់ខ្ញុំ ហើយពោលពាក្យជំទាស់របស់ខ្ញុំដាក់អ្នករាល់គ្នាម្ដងហើយម្ដងទៀតឡើយ។

សម្រាប់កិច្ចការជាងរាប់ពាន់ឆ្នាំមកនេះ ខ្ញុំមិនធ្លាប់ប្រកែកជាមួយមនុស្សលោកឡើយ ដោយសារតែខ្ញុំបានរកឃើញថា ក្នុងដំណើរវិវឌ្ឍន៍របស់មនុស្សជាតិតាំងពីដើមមកទល់ពេលនេះ គឺមានតែ «សេចក្ដីបញ្ឆោត» នៅក្នុងចំណោមអ្នករាល់គ្នាទេ ដែលបានក្លាយជាចរិតដ៏ពេញនិយមបំផុត ប្រៀបបាននឹងកេរមត៌កដ៏មានតម្លៃ ដែលបុព្វបុរសដ៏ល្បីល្បាញនាសម័យបុរាណ បានបន្សល់ទុកដល់អ្នករាល់គ្នា។ ខ្ញុំពិតជាស្អប់មនុស្សដែលមានចរិតអន់ជាងសត្វទាំងនោះណាស់។ អ្នករាល់គ្នាដូចជាគ្មានមនសិការសោះ! ចរិតរបស់អ្នករាល់គ្នា អន់ខ្លាំងណាស់! ឯដួងចិត្តរបស់អ្នករាល់គ្នារឹងដូចដុំថ្ម! ប្រសិនបើខ្ញុំយកពាក្យនេះទៅប្រើ និងយកកិច្ចការទាំងនេះទៅធ្វើចំពោះពួកអ៊ីស្រាអែលវិញ នោះខ្ញុំនឹងទទួលបានសិរីល្អជាយូរឆ្នាំមកហើយ។ ប៉ុន្តែ នៅក្នុងចំណោមអ្នករាល់គ្នា គឺមិនអាចទៅរួចឡើយ នៅក្នុងចំណោមអ្នករាល់គ្នា មានតែការព្រងើយកន្តើយដ៏ព្រៃផ្សៃ ចរិតរើសអើង និងលេសដោះសារបស់អ្នករាល់គ្នាតែប៉ុណ្ណោះ។ អ្នករាល់គ្នាគ្មានចិត្តមេត្តា និងគ្មានបានការទាល់តែសោះ!

អ្នករាល់គ្នា គួរតែដាក់ចិត្តកាយទាំងអស់របស់អ្នកចំពោះកិច្ចការរបស់ខ្ញុំ។ អ្នកគួរតែធ្វើកិច្ចការណាដែលផ្ដល់ជាប្រយោជន៍ដល់ខ្ញុំ។ ខ្ញុំព្រមពន្យល់ដល់អ្នករាល់គ្នានូវអ្វីគ្រប់យ៉ាងដែលអ្នកមិនយល់ ដើម្បីឲ្យអ្នករាល់គ្នា អាចទទួលបានពីខ្ញុំនូវអ្វីៗដែលអ្នករាល់គ្នាខ្វះ។ ទោះបីសេចក្ដីកម្សោយរបស់អ្នករាល់គ្នាមានច្រើនរាប់មិនអស់ក៏ដោយ ក៏ខ្ញុំព្រមបន្តធ្វើកិច្ចការដែលខ្ញុំគួរតែធ្វើចំពោះអ្នករាល់គ្នា ដោយប្រទានដល់អ្នករាល់គ្នានូវសេចក្ដីមេត្តាករុណាចុងក្រោយរបស់ខ្ញុំ ដើម្បីឲ្យអ្នករាល់គ្នាអាចទទួលបានប្រយោជន៍ពីខ្ញុំ និងទទួលបានសិរីល្អ ដែលអវត្តមាននៅក្នុងអ្នករាល់គ្នា ហើយដែលលោកីយ៍មិនធ្លាប់បានឃើញពីមុនមក។ ខ្ញុំបានធ្វើការ អស់ពេលជាច្រើនឆ្នាំ ប៉ុន្តែគ្មានមនុស្សលោកណាម្នាក់ បានស្គាល់ខ្ញុំឡើយ។ ខ្ញុំចង់ប្រាប់អ្នករាល់គ្នាអំពីសេចក្ដីលាក់កំបាំងដែលខ្ញុំមិនធ្លាប់ប្រាប់នរណាផ្សេងឡើយ។

នៅក្នុងចំណោមមនុស្សលោក ខ្ញុំធ្លាប់ជាព្រះវិញ្ញាណ ដែលពួកគេមិនអាចមើលឃើញ ជាព្រះវិញ្ញាណដែលពួកគេមិនអាចផ្សារភ្ជាប់ជាមួយ។ ដោយព្រោះតែដំណាក់

កាលទាំងបីនៃកិច្ចការរបស់ខ្ញុំនៅលើផែនដី (ការបង្កើតពិភពលោក ការប្រោសលោះ និងការបផ្លិចបំផ្លាញ) ដូច្នេះ ខ្ញុំលេចមកនៅកណ្ដាលចំណោមពួកគេនៅពេលខុសៗគ្នា (មិនដែលជាសាធារណៈ) ដើម្បីធ្វើកិច្ចការរបស់ខ្ញុំនៅកណ្ដាលចំណោមពួកគេ។ លើកទី១ដែលខ្ញុំបានយាងមកកណ្ដាលចំណោមមនុស្ស គឺក្នុងអំឡុងយុគសម័យនៃការប្រោសលោះ។ ពិតមែនហើយ ខ្ញុំបានកើតក្នុងគ្រួសារសាសន៍យូដា ហេតុនេះបានជាសាសន៍យូដា គឺជាក្រុមមនុស្សទី១ដែលមើលឃើញព្រះជាម្ចាស់យាងមកផែនដី។ ហេតុផល ដែលខ្ញុំបានធ្វើកិច្ចការនេះនៅក្នុងរូបកាយជាមនុស្ស គឺមកពីខ្ញុំចង់ប្រើសាច់ឈាមជាមនុស្សរបស់ខ្ញុំ ធ្វើជាតង្វាយលោះបាប នៅក្នុងកិច្ចការនៃការប្រោសលោះរបស់ខ្ញុំ។ ដូច្នេះក្រុមមនុស្សទី១ដែលមើលឃើញខ្ញុំ គឺជាសាសន៍យូដា នៅក្នុងយុគសម័យនៃព្រះគុណ។ នោះជាលើកដំបូងហើយ ដែលខ្ញុំបានធ្វើការនៅក្នុងសាច់ឈាម។ នៅក្នុងយុគសម័យនៃនគរព្រះវិញ កិច្ចការរបស់ខ្ញុំ គឺដើម្បីយកឈ្នះ និងប្រោសឲ្យគ្រប់លក្ខណ៍ ដូច្នេះខ្ញុំក៏ធ្វើកិច្ចការគង្វាលរបស់ខ្ញុំនៅក្នុងសាច់ឈាមសារជាថ្មីម្ដងទៀត។ នេះជាលើកទី២ ដែលខ្ញុំធ្វើការនៅក្នុងសាច់ឈាម។ នៅក្នុងដំណាក់កាលពីរ ចុងក្រោយនៃកិច្ចការនេះ អ្វីដែលមនុស្សមានទំនាក់ទំនងជាមួយ លែងជាព្រះវិញ្ញាណអរូបិយ ដែលមើលមិនឃើញទៀតហើយ ប៉ុន្ដែជាបុគ្គលម្នាក់ដែលជាព្រះវិញ្ញាណយកទម្រង់ជាសាច់ឈាម។ ហេតុនេះ នៅក្នុងភ្នែករបស់មនុស្សលោក ខ្ញុំក្លាយជាមនុស្សសាជាថ្មី ដែលគ្មានរូបរាង ហើយនិងអារម្មណ៍របស់ព្រះជាម្ចាស់ឡើយ។ លើសពីនេះទៅទៀត ព្រះជាម្ចាស់ដែលមនុស្សមើលឃើញ មិនគ្រាន់តែជាបុរសម្នាក់ប៉ុណ្ណោះទេ ប៉ុន្ដែក៏ជាស្ដ្រីម្នាក់ផងដែរ ហើយការនេះធ្វើឲ្យពួកគេមានការស្រឡាំងកាំង និងភ្ញាក់ផ្អើល។ ម្ដងហើយម្ដងទៀត កិច្ចការដ៏មហស្ចារ្យរបស់ខ្ញុំបានកម្ចាត់ចោលជំនឿចាស់ ដែលមានជាច្រើនឆ្នាំមកហើយ។ មនុស្សបានស្រឡាំងកាំង! ព្រះជាម្ចាស់មិនគ្រាន់តែជាព្រះវិញ្ញាណបរិសុទ្ធ ជាព្រះវិញ្ញាណដ៏ខ្លាំងទាំងប្រាំពីរ ឬជាព្រះវិញ្ញាណនៃសព្វសារពើទាំងអស់ប៉ុណ្ណោះទេ ប៉ុន្ដែទ្រង់ក៏ជាមនុស្ស ជាមនុស្សសាមញ្ញម្នាក់ខុសប្លែកពីមនុស្សធម្មតាផងដែរ។ ព្រះអង្គមិនគ្រាន់តែជាបុរស ប៉ុន្ដែទ្រង់ក៏ជាស្ដ្រីផង

ដែរ។ បុគ្គលទាំងពីរដូចគ្នាត្រង់ថា ទាំងពីរអង្គបានកើតមកជាមនុស្សដូចគ្នា ហើយខុសគ្នាត្រង់ថា ម្នាក់ត្រូវបានចាប់កំណើតដោយព្រះវិញ្ញាណបរិសុទ្ធ ហើយម្នាក់ទៀតកើតជាមនុស្សលោក ប៉ុន្តែទាំងពីរអង្គសុទ្ធតែមានកំណើតដោយផ្ទាល់ពីព្រះវិញ្ញាណ។ អង្គទាំងពីរដូចគ្នាត្រង់ថា ទាំងពីរអង្គសុទ្ធតែជាព្រះ ដែលមកយកកំណើតជាសាច់ឈាម មកអនុវត្តកិច្ចការរបស់ព្រះដ៏ជាព្រះវរបិតា ហើយខុសគ្នាត្រង់ថា ម្នាក់បានធ្វើកិច្ចការនៃការប្រោសលោះ ហើយម្នាក់ទៀតធ្វើកិច្ចការនៃការយកឈ្នះ។ ទាំងពីរសុទ្ធតែតំណាងឲ្យព្រះវរបិតា ប៉ុន្តែព្រះមួយអង្គជាព្រះជាម្ចាស់ដ៏ប្រោសលោះ ដែលពេញដោយព្រះទ័យសប្បុរសដែលពេញដោយសេចក្ដីស្រលាញ់ និងក្ដីមេត្តាករុណា ឯមួយអង្គទៀត គឺជាព្រះជាម្ចាស់នៃសេចក្ដីសុចរិត ដែលពេញដោយព្រះពិរោធ និងការជំនុំជម្រះ។ មួយអង្គជាមេទ័ពកំពូលដែលបានផ្ដើមកិច្ចការនៃការប្រោសលោះ ឯមួយអង្គទៀតជាព្រះជាម្ចាស់ដ៏សុចរិតដែលសម្រេចកិច្ចការនៃការយកឈ្នះ។ មួយអង្គជាទីចាប់ផ្ដើម ឯមួយអង្គទៀតជាទីបញ្ចប់។ មួយអង្គជារូបកាយសាច់ឈាមដែលគ្មានបាប ឯមួយអង្គទៀតជារូបកាយសាច់ឈាមដែលសម្រេចការប្រោសលោះ បន្តកិច្ចការ ហើយមិនដែលមានបាបសោះ។ ទាំងពីរអង្គជាព្រះវិញ្ញាណតែមួយ ប៉ុន្តែគង់នៅក្នុងរូបកាយសាច់ឈាមខុសគ្នា និងប្រសូតនៅកន្លែងខុសគ្នា ហើយទ្រង់ត្រូវបានផ្ដាច់ឆ្ងាយពីគ្នាអស់ពេលជាច្រើនពាន់ឆ្នាំ។ យ៉ាងណាមិញ គ្រប់កិច្ចការរបស់ពួកទ្រង់ គឺបំពេញឲ្យគ្នាទៅវិញទៅមក គ្មានវិវាទនឹងគ្នាឡើយ ហើយអាចថ្លែងចេញក្នុងបរិបទដូចគ្នា។ ព្រះអង្គទាំងពីរជាមនុស្ស ប៉ុន្តែម្នាក់ជាទារក ហើយម្នាក់ទៀតជាទារិកា។ អស់រយៈពេលជាច្រើនឆ្នាំមកនេះ អ្វីដែលមនុស្សបានឃើញ គឺមិនគ្រាន់តែជាព្រះវិញ្ញាណ និងមនុស្សប្រុសម្នាក់ប៉ុណ្ណោះទេ ប៉ុន្តែជារឿងជាច្រើនដែលមិនស្របតាមគំនិតរបស់មនុស្សលោកផងដែរ។ ដូច្នេះហើយបានជាមនុស្សលោកមិនអាចយល់ពីខ្ញុំបានទាំងស្រុងនោះទេ។ ពួកគេជឿខ្លះ ហើយសង្ស័យខ្លះពីខ្ញុំ ហាក់ដូចខ្ញុំជាព្រះជាម្ចាស់មែន ប៉ុន្តែក៏សង្ស័យថា ខ្ញុំជាសុបិនបំភាន់ភ្នែកដែរ នេះជាហេតុផលដែលមនុស្សនៅតែមិនស្គាល់ថា ព្រះជាម្ចាស់គឺជាអ្វី ដរាបដល់សព្វថ្ងៃ។ តើអ្នកអាចនិយាយសរុបអំពីខ្ញុំ ដោយប្រើប្រយោគមួយដ៏

សាមញ្ញបានទេ? តើអ្នកពិតជាហ៊ាននិយាយថា «ព្រះយេស៊ូវមិនមែនជានរណាផ្សេងក្រៅពីព្រះជាម្ចាស់ ហើយព្រះជាម្ចាស់ក៏មិនមែនជានរណាផ្សេងក្រៅពីព្រះយេស៊ូវដែរឬទេ?» តើអ្នកពិតជាក្លាហាន ដោយហ៊ាននិយាយថា «ព្រះជាម្ចាស់មិនមែនជានរណាផ្សេងក្រៅពីព្រះវិញ្ញាណ ហើយព្រះវិញ្ញាណក៏មិនមែនជានរណាផ្សេងក្រៅពីព្រះជាម្ចាស់ដែរឬទេ?» តើអ្នកស្រណុកចិត្ត ពេលនិយាយថា «ព្រះជាម្ចាស់គ្រាន់តែជាមនុស្សម្នាក់ ដែលពាក់រូបកាយសាច់ឈាមដែរឬទេ?» តើអ្នកមានចិត្តក្លាហានហ៊ានអះអាងថា «រូបអង្គរបស់ព្រះយេស៊ូវ ជារូបអង្គដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ដែរឬទេ?» តើអ្នកអាចប្រើវោហាសព្ទរបស់អ្នក ដើម្បីបរិយាយពីនិស្ស័យ និងរូបអង្គរបស់ព្រះជាម្ចាស់ឲ្យក្បោះក្បាយបានដែរឬទេ? តើអ្នកពិតជាហ៊ាននិយាយថា «ព្រះជាម្ចាស់បានបង្កើតតែបុរស មិនមែនស្ត្រី ឲ្យមានរូបអង្គដូចទ្រង់ដែរឬទេ?» បើអ្នកហ៊ាននិយាយបែបនេះ ដូច្នេះ ស្ត្រីនឹងមិនស្ថិតនៅក្នុងចំណោមពួកជ្រើសតាំងរបស់ខ្ញុំ ហើយស្ត្រីក៏ទំនងជាគ្មានវណ្ណៈជាមនុស្សលោកដែរ។ ឥឡូវនេះតើអ្នកដឹងថា ព្រះជាម្ចាស់ជាអ្វីឲ្យពិតប្រាកដហើយឬនៅ? តើព្រះជាម្ចាស់ ជាមនុស្សឬ? តើព្រះជាម្ចាស់ជាព្រះវិញ្ញាណឬ? តើព្រះជាម្ចាស់ជាបុរសម្នាក់ឬ? តើមានព្រះយេស៊ូវតែម្នាក់ទេឬ ដែលអាចបំពេញកិច្ចការដែលខ្ញុំត្រូវធ្វើ? បើអ្នកជ្រើសរើសយកចំណុចតែមួយនៅក្នុងចំណោមចំណុចខាងលើ ដើម្បីធ្វើសេចក្ដីសន្និដ្ឋានរួមអំពីសារជាតិពិតរបស់ខ្ញុំ នោះអ្នកជាអ្នកជឿដ៏ស្មោះ ប៉ុន្តែល្ងង់ខ្លៅបំផុតម្នាក់ហើយ។ ប្រសិនបើខ្ញុំធ្លាប់បានធ្វើការ ដោយយកកំណើតជាសាច់ឈាម ហើយបានធ្វើតែម្ដងគត់ តើអ្នករាល់គ្នានឹងកំណត់ព្រំដែនខ្ញុំមែនទេ? តើអ្នកអាចយល់យ៉ាងច្បាស់អំពីខ្ញុំ ដោយគ្រាន់តែមើលតែមួយភ្លែតបានដែរទេ? តើអ្នកអាចធ្វើវិនិច្ឆ័យសរុបគ្រប់យ៉ាងអំពីខ្ញុំ ដោយផ្អែកលើអ្វីដែលអ្នកធ្លាប់មានពិសោធក្នុងជីវិតរបស់អ្នកមែនទេ? ប្រសិនបើខ្ញុំបានធ្វើកិច្ចការស្រដៀងគ្នានៅក្នុងការយកកំណើតជាមនុស្សទាំងពីរលើករបស់ខ្ញុំ តើអ្នករាល់គ្នានឹងយល់ឃើញយ៉ាងដូចម្ដេចដែរចំពោះខ្ញុំ? តើអ្នកនឹងទុកខ្ញុំចោល ឲ្យជាប់ឆ្កាងជារៀងរហូតមែនទេ? តើព្រះជាម្ចាស់អាចមានលក្ខណៈសាមញ្ញ ដូចដែលអ្នកបានអះអាងដែរឬទេ?

ទោះបីអ្នករាល់គ្នាមានសេចក្ដីជំនឿដ៏ស្មោះក៏ដោយ ប៉ុន្តែនៅក្នុងចំណោមអ្នករាល់គ្នា គ្មាននរណាម្នាក់ដែលអាចរ៉ាយរាប់អំពីខ្ញុំបានទាំងស្រុងឡើយ ហើយក៏គ្មាននរណាម្នាក់ អាចធ្វើបន្ទាល់ពេញលេញអំពីគ្រប់ទាំងសេចក្ដីដែលអ្នកមើលឃើញដែរ។ ចូរគិតអំពីការនេះចុះ៖ ថ្ងៃនេះ អ្នករាល់គ្នាភាគច្រើនធ្វេសប្រហែសនឹងភារកិច្ចរបស់ខ្លួន ដោយព្យាយាមដេញតាមសាច់ឈាម ចម្អែតសាច់ឈាម ហើយរីករាយនឹងសាច់ឈាម ទាំងមានចិត្តលោភផង។ អ្នកមានសេចក្ដីពិតតិចតួចណាស់។ ដូច្នេះ តើអ្នកអាចធ្វើបន្ទាល់ អំពីរាល់ទាំងសេចក្ដីដែលអ្នករាល់គ្នាបានឃើញយ៉ាងដូចម្ដេច? តើអ្នករាល់គ្នាពិតជាមានទំនុកចិត្តដែរឬទេថា អ្នកអាចក្លាយជាបន្ទាល់របស់ខ្ញុំ? ប្រសិនបើថ្ងៃមួយមកដល់ ពេលដែលអ្នកមិនអាចធ្វើបន្ទាល់ ពីគ្រប់ទាំងសេចក្ដីដែលអ្នកបានឃើញនៅថ្ងៃនេះ នោះអ្នកនឹងបាត់បង់មុខងារជាមនុស្ស ហើយការដែលអ្នកមានជីវិតនេះ គឺគ្មានន័យទាល់តែសោះ។ អ្នកនឹងមិនសមអ្វីធ្វើជាមនុស្សឡើយ។ អាចនិយាយបានថា អ្នកនឹងមិនមែនជាមនុស្សតែម្ដង! ខ្ញុំបានធ្វើកិច្ចការដ៏ច្រើន សន្ធឹកសន្ធាប់សម្រាប់អ្នករាល់គ្នា ប៉ុន្តែឥឡូវនេះ ដោយសារតែអ្នករាល់គ្នារៀនមិនបានអ្វីសោះ គ្មានដឹងអ្វីទាំងអស់ ហើយការលះបង់របស់អ្នកក៏គ្មានប្រសិទ្ធភាពទៀត ដូច្នេះ នៅពេលដែលខ្ញុំត្រូវពង្រីកកិច្ចការរបស់ខ្ញុំ នោះអ្នកនឹងបានត្រឹមជាមនុស្សម្នាក់ ដែលឈរមើល ទាំងបិទមាត់យ៉ាងជិត ហើយគ្មានប្រយោជន៍អ្វីសោះឡើយ។ តើការនេះ មិនធ្វើឲ្យអ្នកក្លាយជាមនុស្សបាបអស់មួយជីវិតទេឬអី? លុះដល់វេលាកំណត់ តើអ្នកនឹងគ្មានអារម្មណ៍ស្ដាយក្រោយខ្លាំងបំផុតទេឬអី? តើអ្នកនឹងគ្មានអារម្មណ៍សោកសង្រេងទេឬអី? គ្រប់កិច្ចការដែលខ្ញុំធ្វើនាថ្ងៃនេះ មិនត្រូវបានធ្វើឡើងដោយភាពខ្ជិលច្រអូស និងភាពធុញទ្រាន់ឡើយ ប៉ុន្តែដើម្បីចាក់គ្រឹះសម្រាប់កិច្ចការនាពេលអនាគតរបស់ខ្ញុំវិញ។ វាមិនមែនដោយសារតែខ្ញុំអស់ផ្លូវ ហើយត្រូវបង្កើតអ្វីមួយថ្មីឡើយ។ អ្នកគួរតែយល់ពីកិច្ចការដែលខ្ញុំធ្វើ វាមិនមែនជាកិច្ចការដែលត្រូវសម្រេចឡើង ដោយកូនក្មេងលេងដីនៅតាមចិញ្ចើមថ្នល់ឡើយ ប៉ុន្តែវាជាកិច្ចការដែលត្រូវធ្វើឡើង ជាតំណាងឲ្យព្រះវរបិតារបស់ខ្ញុំ។ អ្នករាល់គ្នាគួរតែដឹងថា វាមិនមែនជាខ្ញុំទេ ដែលកំពុងតែធ្វើ

កិច្ចការទាំងអស់នេះតែម្នាក់ឯង ប៉ុន្តែខ្ញុំតំណាងឲ្យព្រះវរបិតាខ្ញុំវិញទេ។ បច្ចុប្បន្ននេះ តួនាទីរបស់អ្នករាល់គ្នាគឺត្រូវដើរតាម ស្ដាប់បង្គាប់ ផ្លាស់ប្ដូរ និងធ្វើបន្ទាល់យ៉ាងតឹងរឹងបំផុត។ អ្វីដែលអ្នករាល់គ្នាគួរតែយល់ គឺជាហេតុផលដែលនាំឲ្យអ្នករាល់គ្នាគួរតែជឿលើខ្ញុំ។ នេះជាសំណួរដ៏សំខាន់បំផុតដែលអ្នករាល់គ្នាម្នាក់ៗត្រូវយល់។ ព្រះវរបិតាខ្ញុំបានដៅអ្នករាល់គ្នាទុកជាមុនសម្រាប់ខ្ញុំ តាំងពីពេលដែលទ្រង់បានបង្កើតពិភពលោកមកម្ល៉េះ សម្រាប់ជាប្រយោជន៍ដល់សិរីល្អទ្រង់។ ព្រះអង្គបានដៅកំណត់អ្នករាល់គ្នាទុកជាមុន សម្រាប់ជាប្រយោជន៍នៃកិច្ចការរបស់ខ្ញុំ និងជាប្រយោជន៍ដល់សិរីល្អរបស់ទ្រង់។ គឺដោយសារតែព្រះវរបិតារបស់ខ្ញុំ ទើបអ្នករាល់គ្នាជឿលើខ្ញុំ។ គឺដោយសារតែការកំណត់ទុកជាមុនរបស់ព្រះបិតាខ្ញុំ ទើបអ្នករាល់គ្នាដើរតាមខ្ញុំ។ គ្មានការណាមួយដែលកើតចេញពីការជ្រើសរើសរបស់អ្នករាល់គ្នាឡើយ។ អ្វីដែលកាន់តែសំខាន់ទៀតនោះគឺថា អ្នករាល់គ្នាយល់ថា អ្នករាល់គ្នាជាមនុស្សដែលព្រះវរបិតាខ្ញុំបានប្រទានដល់ខ្ញុំ សម្រាប់គោលបំណងនៃការធ្វើបន្ទាល់ពីខ្ញុំ។ ដោយសារតែទ្រង់បានប្រទានអ្នករាល់គ្នាដល់ខ្ញុំ នោះអ្នករាល់គ្នាគួរតែនៅជាប់ជាមួយផ្លូវដែលខ្ញុំបានប្រទានដល់អ្នករាល់គ្នា ក៏ដូចជាផ្លូវ និងពាក្យដែលខ្ញុំបង្រៀនដល់អ្នករាល់គ្នាដែរ ព្រោះថាវាជាភារកិច្ចរបស់អ្នករាល់គ្នា ដែលត្រូវនៅជាប់ក្នុងផ្លូវរបស់ខ្ញុំ។ នេះជាគោលបំណងដើមនៃសេចក្ដីជំនឿរបស់អ្នករាល់គ្នាចំពោះខ្ញុំ។ ដូច្នេះ ខ្ញុំប្រាប់អ្នករាល់គ្នាទៅចុះថា៖ អ្នករាល់គ្នាគ្រាន់តែជាមនុស្សដែលព្រះបិតារបស់ខ្ញុំប្រទានមកដល់ខ្ញុំ ដើម្បីឲ្យនៅជាប់ក្នុងផ្លូវរបស់ខ្ញុំប៉ុណ្ណោះ។ យ៉ាងណាមិញ អ្នករាល់គ្នាគ្រាន់តែជឿលើខ្ញុំ អ្នកមិនមែនជារបស់ខ្ញុំ ដោយសារតែអ្នករាល់គ្នាមិនមែនជាក្រុមគ្រួសារអ៊ីស្រាអែល ប៉ុន្តែអ្នកជាប្រភេទតែមួយនៃសត្វពស់ពីបុរាណវិញ។ អ្វីគ្រប់យ៉ាងដែលខ្ញុំកំពុងតែទាមទារឲ្យអ្នករាល់គ្នាធ្វើ គឺត្រូវធ្វើបន្ទាល់សម្រាប់ខ្ញុំ ប៉ុន្តែថ្ងៃនេះអ្នករាល់គ្នាត្រូវតែដើរតាមផ្លូវរបស់ខ្ញុំ។ អ្វីទាំងអស់នេះ គឺសម្រាប់ជាប្រយោជន៍ដល់ទីបន្ទាល់នាពេលអនាគត។ ប្រសិនបើអ្នករាល់គ្នាធ្វើការ ដូចជាមនុស្សដែលគ្រាន់តែស្ដាប់តាមផ្លូវរបស់ខ្ញុំ នោះអ្នកនឹងក្លាយជាមនុស្សគ្មានតម្លៃ ហើយសារៈសំខាន់នៃការដែលព្រះវរបិតាខ្ញុំបានប្រទាន

អ្នករាល់គ្នាមកខ្ញុំ នឹងត្រូវបាត់បង់មិនខាន។ អ្វីដែលខ្ញុំទទូចប្រាប់ដល់អ្នករាល់គ្នាគឺថា៖ អ្នករាល់គ្នាគួរតែដើរតាមផ្លូវរបស់ខ្ញុំ។

## តើក្លាយជាមនុស្សពិតប្រាកដម្នាក់មានន័យដូចម្ដេច

វាជាភារកិច្ចរបស់ខ្ញុំ ដែលត្រូវគ្រប់គ្រងមនុស្ស។ បន្ថែមលើនេះ ការយកឈ្នះលើមនុស្ស គឺជាអ្វីដែលខ្ញុំបានតែងតាំង នៅពេលដែលខ្ញុំបានបង្កើត ពិភពលោកនេះ។ មនុស្សប្រហែលមិនដឹងថា ខ្ញុំនឹងយកឈ្នះលើមនុស្សឲ្យបានទាំងស្រុងនៅគ្រាចុងក្រោយបង្អស់នោះទេ ឬមិនដឹងថា ការយកឈ្នះលើពួកបះបោរនៅក្នុងចំណោមមនុស្ស គឺជាសេចក្ដីសម្អាងនៃជ័យជម្នះរបស់ខ្ញុំលើសាតាំងឡើយ។ ប៉ុន្តែ នៅពេលដែលសត្រូវរបស់ខ្ញុំបានចូលរួមប្រយុទ្ធជាមួយខ្ញុំ ខ្ញុំបានប្រាប់វារួចជាស្រេចហើយថា ខ្ញុំនឹងយកឈ្នះលើអស់អ្នកណា ដែលសាតាំងបានចាប់ជាឈ្លើយ និងធ្វើឲ្យទៅជាកូនចៅរបស់វា ទៅជាបាវបម្រើដ៏ស្មោះត្រង់ដែលនៅចាំការពារផ្ទះរបស់វា។ អត្ថន័យដើមនៃពាក្យយកឈ្នះ គឺការយកឈ្នះ ធ្វើឲ្យរងការអាម៉ាស់មុខ។ នៅក្នុងភាសានៃពួកអ៊ីស្រាអែល ពាក្យនេះមានន័យថា យកឈ្នះឲ្យខានតែបាន បំផ្លាញ និងធ្វើឲ្យគ្មានសមត្ថភាពអាចតស៊ូប្រឆាំងទាស់នឹងខ្ញុំតទៅមុខទៀតបាន។ ប៉ុន្តែ សព្វថ្ងៃនេះ នៅពេលដែលប្រើក្នុងចំណោមអ្នករាល់គ្នា អត្ថន័យនៃពាក្យនេះ គឺយកឈ្នះ។ អ្នករាល់គ្នាគប្បីដឹងថា ចិត្តរបស់ខ្ញុំ គឺតែងតែចង់កម្ចាត់ចោល និងយកឈ្នះឲ្យបានទាំងស្រុងលើមេកំណាចរបស់មនុស្សជាតិ ដើម្បីកុំឲ្យវាអាចបះបោរប្រឆាំងនឹងខ្ញុំបាន និងគ្មានសូម្បីខ្យល់ដង្ហើមដើម្បីរំខាន ឬធ្វើឲ្យរឹករវរដល់កិច្ចការរបស់ខ្ញុំ។ ហេតុនេះ តាមការយល់ដឹងរបស់មនុស្ស ពាក្យនេះបានក្លាយជាមានន័យថា ការយកឈ្នះ។ មិនថាអត្ថន័យបង្កប់នៃពាក្យនេះមានន័យដូចម្ដេចខ្លះទេ កិច្ចការរបស់ខ្ញុំគឺបង្ក្រាបមនុស្សជាតិ។ មួយរយៈមកនេះ វាជាការពិតដែលមនុស្សជាតិ គឺជារបស់បន្ទាប់បន្សំនៃការគ្រប់គ្រងរបស់ខ្ញុំ និយាយឲ្យកាន់តែច្បាស់ទៅ មនុស្សជាតិ គឺគ្មានអ្វីក្រៅពីសត្រូវ របស់ខ្ញុំនោះទេ។

មនុស្សជាតិ គឺជាមនុស្សអាក្រក់ដែលប្រឆាំងទាស់ និងមិនស្ដាប់បង្គាប់ខ្ញុំ។ មនុស្សជាតិ គឺគ្មានអ្វីក្រៅពីកូនចៅ នៃមេកំណាច ដែលខ្ញុំស្អប់ខ្ពើមឡើយ។ មនុស្សជាតិ គឺគ្មានអ្វីក្រៅពីពូជពង្សមហាទេវតា ដែលបានក្បត់ខ្ញុំឡើយ។ មនុស្សជាតិ គឺគ្មានអ្វីក្រៅពីកេរ្ដិ៍ដំណែលនៃមនុស្សអាក្រក់ ដែលខ្ញុំបានបោះបង់ជាយូរមកហើយ និងជាសត្រូវដែលមិនអាចផ្សះផ្សារបានជាមួយនឹងខ្ញុំតាំងពីពេលនោះមក។ ដ្បិតមេឃនៅខាងលើមនុស្សជាតិ គឺខ្មៅ និងងងឹតសូន្យសុង គ្មានពន្លឺមើលច្បាស់សូម្បីបន្តិចសោះឡើយ ហើយពិភពមនុស្សបានធ្លាក់ទៅក្នុងភាពងងឹតសូន្យសុង ដូចនេះ មនុស្សដែលរស់នៅក្នុងពិភពនោះ មិនអាចមើលឃើញដៃរបស់ខ្លួនដែលលាតសន្ធឹងនៅចំពោះមុខខ្លួន ឬឃើញព្រះអាទិត្យ នៅពេលគេងើបក្បាលឡើងលើឡើយ។ ផ្លូវនៅខាងក្រោមជើងរបស់គេ ជាដីភក់ និងសម្បូរទៅដោយគ្រហុក ខ្វាត់ខ្វែង និងក្រវិចក្រវៀន។ ដីទាំងមូលពោរពេញទៅដោយសាកសព។ ជ្រុងដែលងងឹតៗ មានពេញទៅដោយសាកសពនៃអ្នកស្លាប់ ហើយនៅជ្រុងដែលត្រជាក់ និងមានស្រមោលបាំង ពួកវិញ្ញាណកំណាចជាច្រើនបានយកធ្វើជាទីលំនៅ។ ហើយនៅគ្រប់ទីកន្លែងទាំងអស់ នៅក្នុងពិភពមនុស្ស វិញ្ញាណអាក្រក់បានចូលមកទាំងក្រុមៗ។ កូនសត្វគ្រប់ប្រភេទទាំងអស់ ដែលប្រឡាក់ទៅដោយភាពស្មោកគ្រោគ ត្រូវជាប់នៅក្នុងសង្គ្រាមឈ្លានពាន ដែលសំឡេងនៃសង្គ្រាមនោះធ្វើឲ្យមានការភ័យតក់ស្លុតនៅក្នុងចិត្ត។ នៅពេលនោះ ស្ថិតក្នុងពិភពមួយបែបនេះ នៅក្នុង «ស្ថានសួគ៌លោកិយ» មួយបែបនេះ តើមនុស្សទៅស្វែងរកកន្លែងបរមសុខនៅក្នុងជីវិតនៅទីណាបាន? តើមនុស្សអាចទៅស្វែងរកទិសដៅជីវិតរបស់ខ្លួននៅទីណាបាន? ចាប់តាំងពីត្រូវសាតាំងជាន់ឈ្លីនៅក្រោមបាទជើងមក ជាលើកដំបូង ហើយដែលមនុស្សជាតិបានក្លាយធ្វើជាតួអង្គដែលយកតាមរូបកាយរបស់សាតាំង លើសពីនេះ មនុស្សជាតិគឺជាតំណាងរបស់សាតាំង និងធ្វើជាទីសម្អាងដែលធ្វើបន្ទាល់ឲ្យសាតាំង ដោយសំឡេងឮៗ និងច្បាស់ៗ។ តើពូជមនុស្សបែបនេះ ក្រុមមនុស្សថោកទាបគ្មានគុណធម៌បែបនេះ កូនចៅនៃអំបូរមនុស្សពុករលួយបែបនេះ អាចធ្វើទីបន្ទាល់សម្រាប់ព្រះជាម្ចាស់បានដោយរបៀបណា? តើសិរីល្អរបស់ខ្ញុំចូលមកដល់

នៅពេលណា? តើនៅទីណាដែលមនុស្សអាចចាប់ផ្ដើមនិយាយអំពីទីបន្ទាល់របស់ខ្ញុំបាន? ដ្បិតសត្រូវដែលឈរទទឹងទាស់នឹងខ្ញុំ ដែលបានធ្វើឲ្យមនុស្សជាតិពុករលួយ បានដណ្ដើមយកមនុស្សជាតិរួចជាស្រេចទៅហើយ ព្រមទាំងធ្វើឲ្យពួកគេប្រឡាក់អស់ជាមនុស្សជាតិដែលខ្ញុំបានបង្កើតតាំងពីយូរមកហើយ និងបានទទួលនូវសិរីល្អរបស់ខ្ញុំ និងការសម្ដែងចេញរបស់ខ្ញុំ តាមរយៈការរស់នៅ។ វាបានឆក់យកនូវ សិរីល្អរបស់ខ្ញុំ ហើយអ្វីទាំងអស់ដែលវាបានបញ្ជ្រាបចូលទៅក្នុងខ្លួនមនុស្សនោះគឺថ្នាំពុលដែលបានលាយយ៉ាងច្រើននឹងភាពអាក្រក់របស់សាតាំង រួមនឹងទឹកផ្លែឈើពីផ្លែឈើនៃដើមដឹងខុសត្រូវផង។ ការពីដើមឡើយ ខ្ញុំបានបង្កើតមនុស្សជាតិ ពោលគឺខ្ញុំបានបង្កើតដូនតារបស់មនុស្សជាតិមក គឺអ័ដាម។ គាត់ត្រូវបានផ្ដល់ឲ្យនូវទម្រង់ និងរូបអង្គ ដែលពេញប្រៀបទៅដោយថាមពល ពេញប្រៀបទៅដោយភាពក្លៀវក្លា រួមជាមួយនឹងសិរីល្អរបស់ខ្ញុំថែមទៀតផង។ នោះគឺជាថ្ងៃដ៏មានសិរីល្អ នៅពេលដែលខ្ញុំបានបង្កើតមនុស្ស។ ក្រោយមក អេវ៉ា ត្រូវបង្កើតចេញពីរូបកាយរបស់អ័ដាម ហើយនាងក៏ជាជីដូនជីតារបស់មនុស្សដែរ ដូច្នេះ មនុស្សដែលខ្ញុំបានបង្កើតមក ត្រូវបំពេញដោយខ្យល់ដង្ហើមរបស់ខ្ញុំ និងពេញប្រៀបទៅដោយសិរីល្អរបស់ខ្ញុំ។ ដំបូងឡើយ អ័ដាមកើតចេញពីស្នាព្រះហស្តរបស់ខ្ញុំ ហើយជារូបអង្គតំណាងរបស់ខ្ញុំ។ ហេតុនេះ អត្ថន័យដំបូងរបស់ «អ័ដាម» គឺជាភាវៈមួយដែលត្រូវបានបង្កើតឡើងដោយខ្ញុំ ពោរពេញទៅដោយអនុភាពជីវិតរបស់ខ្ញុំ ជ្រួតជ្រាបទៅដោយសិរីល្អរបស់ខ្ញុំ ដោយមានទម្រង់ និងរូបអង្គ ដោយមានព្រលឹង និងខ្យល់ដង្ហើម។ គាត់គឺជាសភាវៈដែលត្រូវបង្កើតមកតែមួយគត់ ដែលមានព្រលឹង មានសមត្ថភាពតំណាងឲ្យខ្ញុំបាន អាចមានរូបអង្គរបស់ខ្ញុំបាន និងអាចទទួលបានខ្យល់ដង្ហើមជីវិតរបស់ខ្ញុំ។ កាលដើមដំបូងឡើយ អេវ៉ា គឺជាមនុស្សទីពីរដែលទទួលបានការផ្ដល់ខ្យល់ដង្ហើមជីវិត ជាស្នាព្រះហស្តដែលខ្ញុំបានបង្កើតឡើង ដូចនេះ អត្ថន័យរបស់ «អេវ៉ា» គឺជាសភាវៈ ដែលត្រូវបង្កើតឡើង ដែលនឹងបន្តសិរីល្អរបស់ខ្ញុំ និងពេញទៅដោយភាពក្លៀវក្លារបស់ខ្ញុំ ព្រមទាំងទទួលបាននូវការផ្ដល់សិរីល្អរបស់ខ្ញុំទៀតផង។ អេវ៉ាកើតចេញពីអ័ដាម ដូចនេះ នាងក៏មានរូបអង្គរបស់ខ្ញុំដែរ ដ្បិតនាងជាមនុស្សទីពីរ

ដែលត្រូវបានបង្កើតឡើងក្នុងរូបអង្គរបស់ខ្ញុំ។ អត្ថន័យដើមរបស់ «អេវ៉ា» គឺជាមនុស្សរស់ ដែលមានព្រលឹង សាច់ឈាម និងឆ្អឹង ជាទីបន្ទាល់ទីពីររបស់ខ្ញុំ ក៏ដូចជារូបអង្គទីពីររបស់ខ្ញុំក្នុងចំណោមមនុស្សជាតិដែរ។ ពួកគេជាជីដូនជីតារបស់មនុស្សជាតិ ជាសម្បត្តិដ៏ល្អបរិសុទ្ធ និងមានតម្លៃរបស់មនុស្ស ហើយពីដំបូងឡើយ ភាវៈមានជីវិត ត្រូវបានផ្ដល់នូវព្រលឹង។ ក៏ប៉ុន្តែ មេកំណាចបានជាន់ឈ្លី និងចាប់កូនចៅនៃជីដូនជីតារបស់មនុស្សជាតិជាឈ្លើយ ដោយទម្លាក់ពិភពមនុស្សទៅក្នុងភាពងងឹតសូន្យសុង និងធ្វើឲ្យពិភពនេះទៅជាបែបនេះ ដើម្បីឲ្យកូនចៅគេលែងជឿលើវត្តមានរបស់ខ្ញុំទៀត។ អ្វីដែលគួរឲ្យស្អប់ខ្ពើមជាងនេះទៀតនោះគឺថា មេកំណាចមិនត្រឹមតែធ្វើឲ្យមនុស្សពុករលួយ និងជាន់ឈ្លីលើពួកគេនោះទេ វាសាហាវឃោឃៅដោយដណ្ដើមយកនូវសិរីល្អរបស់ខ្ញុំ ទីបន្ទាល់របស់ខ្ញុំ សេចក្ដីក្លៀវក្លាដែលខ្ញុំបានផ្ដល់ឲ្យពួកគេ ខ្យល់ដង្ហើម និងជីវិតដែលខ្ញុំបានផ្លុំបញ្ចូលទៅឲ្យពួកគេ គ្រប់សិរីល្អរបស់ខ្ញុំនៅក្នុងពិភពមនុស្ស និងគ្រប់ឈាមនៅក្នុងបេះដូងដែលខ្ញុំបានចំណាយទៅលើមនុស្សជាតិ។ មនុស្សជាតិលែងស្ថិតនៅក្នុងពន្លឺទៀតហើយ មនុស្សបានបាត់បង់នូវអ្វីគ្រប់យ៉ាងដែលខ្ញុំបានផ្ដល់ឲ្យគេ ហើយពួកគេបានលះបង់នូវសិរីល្អដែលខ្ញុំបានផ្ដល់ឲ្យពួកគេ។ តើពួកគេអាចទទួលស្គាល់ថាខ្ញុំជាព្រះអម្ចាស់នៃភាវៈទាំងអស់ ដែលបង្កើតឡើងមកនោះដោយរបៀបណា? តើពួកគេអាចបន្តជឿលើវត្តមានរបស់ខ្ញុំ នៅស្ថានសួគ៌បានដោយរបៀបណា? តើពួកគេអាចស្វែងរកការសម្ដែងឲ្យឃើញនូវសិរីល្អរបស់ខ្ញុំនៅលើផែនដីនេះបានដោយរបៀបណា? តើចៅប្រុស និងចៅស្រីទាំងអស់នេះ អាចទទួលយកព្រះជាម្ចាស់ ដែលជីដូនជីតារបស់ពួកគេគោរពបូជា ជាព្រះអម្ចាស់ដែលបង្កើតគេមកនោះ បានដោយរបៀបណា? ចៅប្រុស និងចៅស្រីដ៏គួរឲ្យអាណិតទាំងអស់នេះ បាន «ផ្ដល់ជូន» ដោយសុទ្ធចិត្តនូវសិរីល្អ រូបអង្គ និងទីបន្ទាល់ដែលខ្ញុំបានផ្ដល់ដល់អ័ដាមនិងអេវ៉ា ក៏ដូចជាជីវិតដែលខ្ញុំបានផ្ដល់ឲ្យមនុស្សជាតិ ដែលពួកគេត្រូវការដើម្បីរស់រាននោះ ទៅឲ្យមេកំណាច។ ហើយពួកគេមិនបានចាប់ភ្លឹកទាល់តែសោះចំពោះវត្តមានរបស់មេកំណាច និងបានផ្ដល់នូវ សិរីល្អទាំងអស់របស់ខ្ញុំ ទៅឲ្យវា។ តើនេះមិនមែនជាប្រភព នៃងារ

«មនុស្សថោកទាប» ទេឬអី? តើមនុស្សបែបនេះ អារក្សកំណាចបែបនេះ សាកសពចេះដើរបែបនេះ រូបតំណាងរបស់សាតាំងបែបនេះ សត្រូវរបស់ខ្ញុំបែបនេះ អាចទទួលបាននូវសិរីល្អរបស់ខ្ញុំដោយរបៀបណា? ខ្ញុំនឹងយកមកវិញនូវសិរីល្អរបស់ខ្ញុំ យកមកវិញនូវទីបន្ទាល់របស់ខ្ញុំដែលមាននៅក្នុងចំណោមមនុស្ស និងអ្វីគ្រប់ទាំងអស់ដែលធ្លាប់ជារបស់ខ្ញុំ និងអ្វីដែលខ្ញុំបានផ្ដល់ទៅឲ្យមនុស្សជាតិជាយូរលង់មកហើយ ខ្ញុំនឹងយកឈ្នះលើមនុស្សជាតិ ឲ្យបានទាំងស្រុង។ ក៏ប៉ុន្តែ អ្នករាល់គ្នាគួរដឹងថា មនុស្សដែលខ្ញុំបានបង្កើតមក គឺជាមនុស្សដែលមានរូបអង្គរបស់ខ្ញុំ និងមានសិរីល្អរបស់ខ្ញុំ។ ពួកគេមិនមែនជាកម្មសិទ្ធិរបស់សាតាំងឡើយ ហើយពួកគេក៏មិនមែនជារបស់ដែលត្រូវឲ្យវាជាន់ឈ្លីដែរ ប៉ុន្តែជាការបើកបង្ហាញដ៏បរិសុទ្ធរបស់ខ្ញុំ ដោយមិនមានដានជាតិពុលរបស់សាតាំងសូម្បីបន្តិច។ អាស្រ័យដូចនេះ ខ្ញុំប្រាប់មនុស្សថា ខ្ញុំគ្រាន់តែចង់បានអ្វីដែលខ្ញុំបានបង្កើតឡើងដោយដៃរបស់ខ្ញុំតែប៉ុណ្ណោះ ជារបស់បរិសុទ្ធដែលខ្ញុំស្រឡាញ់ និងរបស់ដែលមិនមែនជាកម្មសិទ្ធិរបស់អ្នកណាមួយ។ បន្ថែមលើនេះ ខ្ញុំនឹងមានសេចក្ដីរីករាយពីរបស់ទាំងនោះ និងចាត់ទុកវាជាសិរីល្អរបស់ខ្ញុំ។ ក៏ប៉ុន្តែ អ្វីដែលខ្ញុំចង់បាន គឺមិនមែនជាមនុស្សជាតិដែលត្រូវបានសាតាំងធ្វើឲ្យពុករលួយនោះទេ ហើយក៏មិនមែនជាកម្មសិទ្ធិរបស់សាតាំងក្នុងពេលសព្វថ្ងៃនេះដែរ ព្រោះនោះលែងជារបស់ដើមដែលខ្ញុំបានបង្កើតឡើងទៀតហើយ។ ដោយសារខ្ញុំមានបំណងចង់យកមកវិញនូវសិរីល្អរបស់ខ្ញុំដែលមាននៅក្នុងពិភពមនុស្ស ខ្ញុំត្រូវយកឈ្នះលើ អ្នកនៅរស់ក្នុងចំណោមមនុស្សជាតិឲ្យបានទាំងស្រុង ជាសេចក្ដីសម្គាល់នៃសិរីល្អរបស់ខ្ញុំនៅក្នុងការយកឈ្នះលើសាតាំង។ ខ្ញុំគ្រាន់តែធ្វើទីបន្ទាល់របស់ខ្ញុំ ដែលជារូបអង្គដ៏ច្បាស់របស់ខ្ញុំប៉ុណ្ណោះ ជារបស់នៃសេចក្ដីសប្បាយរីករាយរបស់ខ្ញុំ។ នេះគឺជាបំណងចិត្តរបស់ខ្ញុំ។

វាត្រូវការពេលរាប់សិបពាន់ឆ្នាំក្នុងប្រវត្តិសាស្ត្ររបស់មនុស្សជាតិ ដើម្បីចូលមកដល់ពេលបច្ចុប្បន្ននេះ ក៏ប៉ុន្តែ មនុស្សជាតិដែលខ្ញុំបានបង្កើតតាំងពីដើមដំបូងមកបានលិចចូលទៅក្នុងភាពចុះអន់ថយជាយូរលង់មកហើយ។ មនុស្សលែងជាមនុស្សដែលខ្ញុំចង់បានទៀតហើយ ហេតុនេះ នៅក្នុងភ្នែករបស់ខ្ញុំ មនុស្សលែងសមនឹងទទួល

ឈ្មោះជាមនុស្សជាតិទៀតហើយ។ ផ្ទុយទៅវិញ ពួកគេជាមនុស្សជាតិថោកទាបដែលសាតាំងបានចាប់ជាឈ្លើយ ជាសាកសពរលួយស្អុយដែលចេះដើរ ដែលសាតាំងសណ្ឋិតនៅ និងដែលសាតាំងយកធ្វើជាសម្លៀកបំពាក់របស់វា។ មនុស្សពុំមានសេចក្តីទុកចិត្តលើវត្តមានរបស់ខ្ញុំ ហើយពួកគេមិនស្វាគមន៍ចំពោះការត្រឡប់មកវិញរបស់ខ្ញុំឡើយ។ មនុស្សជាតិគ្រាន់តែឆ្លើយតបទៅនឹងសំណើរបស់ខ្ញុំ ដោយសេចក្តីច្រណែនឈ្នានីស ដោយយល់ព្រមជាបណ្តោះអាសន្នចំពោះសំណើទាំងនោះ តែមិនបានរួមសុខទុក្ខជាមួយខ្ញុំនៅក្នុងជីវិតដោយស្មោះត្រង់នោះទេ។ ដោយសារមនុស្សគិតថាខ្ញុំមិនអាចយល់បាន ពួកគេញញឹមដោយសេចក្តីឈ្នានីស អត្តចរិតរបស់ពួកគេត្រេកអរចំពោះអ្នកដែលមានអំណាច ដ្បិតមនុស្សពុំមានចំណេះដឹងអំពីកិច្ចការរបស់ខ្ញុំឡើយ ហើយកាន់តែមិនដឹងអំពីបំណងចិត្តរបស់ខ្ញុំក្នុងពេលសព្វថ្ងៃនេះដែរ។ ខ្ញុំនឹងនិយាយដោយត្រង់ចំពោះអ្នករាល់គ្នា៖ នៅពេលថ្ងៃនោះបានមកដល់ ទុក្ខសោករបស់មនុស្សដែលថ្វាយបង្គំខ្ញុំ នឹងបានធូរស្បើយជាងទុក្ខសោករបស់អ្នករាល់គ្នា។ កម្រិតនៃសេចក្តីជំនឿរបស់អ្នកចំពោះខ្ញុំ តាមពិតទៅ មិនលើសពីសេចក្តីជំនឿរបស់យ៉ូបឡើយ បើទោះបីជាសេចក្តីជំនឿ របស់ពួកផារិស៊ីជាតិយូដា ក៏លើសពីសេចក្តីជំនឿរបស់អ្នករាល់គ្នាដែរ ហើយដូច្នេះ ប្រសិនបើថ្ងៃដែលភ្លើងធ្លាក់មក ទុក្ខសោករបស់អ្នករាល់គ្នានឹងកាន់តែធ្ងន់ធ្ងរជាងទុក្ខសោករបស់ពួកផារិស៊ី នៅពេលដែលព្រះយេស៊ូវ បានស្តីបន្ទោសឲ្យ ហើយក៏ខ្លាំងជាងពួកមេដឹកនាំទាំង ២៥០ នាក់ ដែលប្រឆាំងទាស់នឹងម៉ូសេ និងខ្លាំងជាងក្រុងសូដុមដែលត្រូវបំផ្លិចបំផ្លាញដោយអណ្តាតភ្លើងដែលឆេះរោលរាលនោះទៅទៀត។ នៅពេលដែលម៉ូសេវាយថ្ម នោះទឹកដែលព្រះយេហូវ៉ាបានប្រទានឲ្យក៏ហូរចេញមក នេះគឺដោយសារសេចក្តីជំនឿរបស់គាត់។ នៅពេលដែល ដាវីឌលេងស៊ុងដើម្បីសរសើរតម្កើងខ្ញុំ ដែលជាព្រះយេហូវ៉ា ដោយដួងចិត្តគាត់ពោរពេញដោយសេចក្តីអរសប្បាយ នេះគឺដោយសារសេចក្តីជំនឿរបស់គាត់។ នៅពេលដែលយ៉ូបបាត់បង់សត្វចិញ្ចឹមរបស់គាត់ដែលនៅពេញភ្នំ និងទ្រព្យសម្បត្តិយ៉ាងច្រើនសម្បើម ហើយរាងកាយរបស់គាត់ដែលពេញដោយដំបៅខ្ទុះ នេះគឺដោយសារសេចក្តីជំនឿ

របស់គាត់។ នៅពេលដែលគាត់អាចស្ដាប់ឮព្រះសូរសៀងរបស់ខ្ញុំ ដែលជាព្រះយេហូវ៉ា និងឃើញសិរីល្អរបស់ខ្ញុំដែលជាព្រះយេហូវ៉ា នេះគឺដោយសារសេចក្ដីជំនឿរបស់គាត់។ ការដែលពេត្រុសអាចស្ដាប់បង្គាប់ព្រះយេស៊ូវគ្រីស្ទ គឺដោយសារសេចក្ដីជំនឿរបស់គាត់។ ការដែលគាត់អាចឲ្យគេដំដែកគោលទៅនឹងឈើឆ្កាងក៏ព្រោះតែនាមខ្ញុំ និងធ្វើទីបន្ទាល់ដែលមានសិរីល្អ គឺដោយសារសេចក្ដីជំនឿរបស់គាត់ដែរ។ នៅពេលដែលយ៉ូហានបានឃើញពីរូបអង្គដ៏អស្ចារ្យនៃកូនមនុស្ស នេះគឺដោយសារសេចក្ដីជំនឿរបស់គាត់។ នៅពេលដែលគាត់បានឃើញពីនិមិត្តហេតុនៅគ្រាចុងក្រោយបង្អស់ នេះគឺដោយសារសេចក្ដីជំនឿរបស់គាត់។ មូលហេតុដែលពួកហ្វូងមនុស្សនៅក្នុងប្រទេសនៃពួកជាតិសាសន៍ដទៃ បានទទួលនូវការបើកសម្ដែងរបស់ខ្ញុំ និងបានដឹងថា ខ្ញុំបានត្រឡប់មកជាសាច់ឈាម ដើម្បីបំពេញកិច្ចការរបស់ខ្ញុំក្នុងចំណោមមនុស្ស ក៏ដោយសារសេចក្ដីជំនឿរបស់ពួកគេដែរ។ អស់អ្នកណាដែលលត់ដំដោយសារបន្ទូលមិនពិរោះស្ដាប់របស់ខ្ញុំ ប៉ុន្ដែត្រូវបានធូរស្បើយចិត្ត និងបានសង្គ្រោះដោយបន្ទូលទាំងនោះ តើពួកគេមិនបានធ្វើបែបនេះ ដោយសារសេចក្ដីជំនឿរបស់ពួកគេទេឬអី? អស់អ្នកណាដែលជឿលើខ្ញុំ ប៉ុន្ដែមិនទាន់បានរងទុក្ខខ្លាំង តើពួកគេមិនត្រូវពិភពលោកនេះបដិសេធចោលទេឬអី? អស់អ្នកណាដែលរស់នៅក្រៅព្រះបន្ទូលរបស់ខ្ញុំ ដោយចាកចេញពីការរងទុក្ខនៃការសាកល្បង តើពួកគេមិនកំពុងរសាត់អណ្ដែតនៅក្នុងពិភពលោកនេះទេឬអី? ពួកគេស្រដៀងគ្នានឹងស្លឹកឈើនាសរទរដូវ ដែលបក់វិលចម្ងងទៅនេះ ម្ដងទៅនោះ គ្មានពេលឈប់ ហើយពាក្យរបស់ខ្ញុំក៏មិនអាចឲ្យគេបានធូរស្បើយចិត្តដែរ។ បើទោះបីជាការកាត់ទោស និងការបន្សុទ្ធរបស់ខ្ញុំ ពុំធ្វើតាមពួកគេក្ដី ប៉ុន្ដែតើពួកគេមិនដូចជាអ្នកសុំទាន ដែលរសាត់អណ្ដែតពីកន្លែងមួយទៅកន្លែងមួយ ដោយដើរតាមផ្លូវនានានៅខាងក្រៅនគរស្ថានសួគ៌ទេឬអី? តើពិភពលោកនេះ គឺជាកន្លែងសម្រាប់អ្នកឈប់សម្រាកមែនទេ? តាមរយៈការគេចវេសពីការកាត់ទោសរបស់ខ្ញុំ តើអ្នកពិតជាអាចទទួលបាននូវស្នាមញញឹមនៃការពេញចិត្ត ចំពោះពិភពលោកនេះដែរឬទេ? តើអ្នកពិតជាអាចប្រើប្រាស់នូវសេចក្ដីរីករាយដ៏ខ្លីរបស់អ្នកដើម្បីលាក់បាំងនូវភាពទទេ

ស្អាតនៅក្នុងដួងចិត្តរបស់អ្នក ជាភាពទទេស្អាតដែលមិនអាចលាក់បាំងនេះបានដែរឬទេ? អ្នកអាចបោកបញ្ឆោតមនុស្សគ្រប់គ្នានៅក្នុងគ្រួសាររបស់អ្នកបាន ប៉ុន្តែអ្នកមិនអាចបោកប្រាស់ខ្ញុំបានឡើយ។ ដោយសារសេចក្ដីជំនឿរបស់អ្នកស្ដួចស្ដើងខ្លាំងពេក មកទល់សព្វថ្ងៃនេះ អ្នកនៅតែគ្មានអំណាច ដើម្បីស្វែងរកជីវិតស្រស់បំព្រងដែលគួរមានបានឡើយ។ ខ្ញុំទទូចដល់អ្នកចុះ៖ យកល្អគួរចំណាយពេលពាក់កណ្ដាលជីវិតរបស់អ្នកដោយស្មោះត្រង់ដើម្បីជាប្រយោជន៍ដល់ខ្ញុំ ជាជាងចំណាយពេលពេញមួយជីវិតនៅក្នុងភាពថ្លៃថ្នូរ និងការងាររវល់ដើម្បីតែខាងសាច់ឈាម ដោយតស៊ូឆ្លងកាត់នូវទុក្ខសោកទាំងអស់ដែលមនុស្សកម្រនឹងអាចតស៊ូអត់ទ្រាំបាន។ តើមានគោលបំណងអ្វីដែលត្រូវទុកទ្រព្យសម្បត្តិឲ្យខ្លួនអ្នកច្រើនដល់ម្ល៉េះ និងគេចចេញពីការកាត់ទោសរបស់ខ្ញុំ? តើមានគោលបំណងអ្វី ដែលត្រូវលាក់បាំងខ្លួនអ្នក ពីការកាត់ទោសមួយពេលរបស់ខ្ញុំ ដោយគ្រាន់តែចង់បានការអាម៉ាស់ និងការកាត់ទោសអស់កល្បជានិច្ចនោះវិញ? តាមពិត ខ្ញុំមិនបានបត់បែននរណាម្នាក់ ទៅតាមបំណងចិត្តរបស់ខ្ញុំ នោះឡើយ។ ប្រសិនបើមាននរណាម្នាក់ ពិតជាសុខចិត្តចុះចូលនឹង ផែនការទាំងអស់របស់ខ្ញុំ នោះខ្ញុំនឹងមិនធ្វើដាក់ពួកគេ អាក្រក់ពេកទេ។ ប៉ុន្តែ ខ្ញុំត្រូវការឲ្យមនុស្សទាំងអស់ជឿលើខ្ញុំ ដូចជាយ៉ូបជឿលើខ្ញុំ ដែលជាព្រះយេហូវ៉ាដែរ។ ប្រសិនបើសេចក្ដីជំនឿរបស់អ្នកលើសពីសេចក្ដីជំនឿរបស់ថូម៉ាស់ នោះសេចក្ដីជំនឿរបស់អ្នករាល់គ្នា នឹងទទួលបានការកោតសរសើរអំពីខ្ញុំចំពោះសេចក្ដីស្មោះត្រង់របស់អ្នករាល់គ្នា អ្នកនឹងរកឃើញ នូវសិរីល្អរបស់ខ្ញុំ ហើយអ្នកនឹងប្រាកដជាឃើញនូវសិរីល្អរបស់ខ្ញុំនៅក្នុងសម័យរបស់អ្នករាល់គ្នា។ ក៏ប៉ុន្តែ មនុស្សដែលជឿលើពិភពលោកនេះ និងជឿលើអារក្ស បានធ្វើឲ្យចិត្តរបស់គេរឹងដូចដែក ដូចជាហ្វូងមនុស្សនៃទីក្រុងសូដុម ដែលត្រូវគ្រាប់ខ្សាច់បក់ចូលភ្នែក និងមានគ្រឿងតង្វាយពីពួកអារក្សនៅក្នុងមាត់របស់ពួកគេ ដែលចិត្តគំនិតមោហ៍បាំងរបស់ពួកគេ ត្រូវបានមេកំណាចដែលបានដណ្ដើមពិភពលោកនេះ គ្រប់គ្រងមកជាយូរយកហើយ។ គំនិតរបស់ពួកគេ ស្ទើរតែធ្លាក់ជាឈ្លើយទាំងស្រុងទៅក្នុងដៃរបស់ពួកអារក្សនៃសម័យមុន។ ដូច្នេះហើយ សេចក្ដីជំនឿរបស់មនុស្សជាតិ បាន

រសាត់ទៅបាត់តាមខ្យល់ ហើយពួកគេមិនអាចកត់សម្គាល់សូម្បីតែកិច្ចការរបស់ខ្ញុំ។ អ្វីគ្រប់យ៉ាងដែលពួកគេអាចធ្វើបាន គឺខិតខំប្រឹងប្រែងទាំងឥតកម្លាំងដើម្បីបំពេញកិច្ចការរបស់ខ្ញុំដោយគ្រាន់តែបង្គ្រប់កិច្ច ឬដើម្បីវិភាគវាដោយរដិបរដុប ដ្បិតពួកគេត្រូវជោគជាំដោយថ្នាំពុលរបស់សាតាំងជាយូរមកហើយ។

ខ្ញុំនឹងយកឈ្នះលើមនុស្សជាតិ ដោយសារមនុស្សត្រូវខ្ញុំបង្កើតមក ហើយថែមទាំងបានត្រេកអរសប្បាយនឹងរបស់ជាច្រើនសន្ធឹកសន្ធាប់ដែលខ្ញុំបានបង្កើតមក។ ប៉ុន្តែមនុស្សក៏បានបដិសេធខ្ញុំវិញដែរ។ ខ្ញុំបាត់ចេញពីក្នុងចិត្តរបស់ពួកគេ ហើយពួកគេគិតថាខ្ញុំជាអម្រែកនៅក្នុងការរស់នៅរបស់ពួកគេ សូម្បីតែក្នុងចំណុចមួយដែលពួកគេបានឃើញខ្ញុំដោយពិតប្រាកដក្ដី ក៏ពួកគេនៅតែបដិសេធខ្ញុំដដែល ហើយប្រឹងប្រើខួរក្បាលរបស់ពួកគេ គិតរកវិធីអ្វីដែលអាចយកឈ្នះលើខ្ញុំបាន។ មនុស្សមិនព្រមឲ្យខ្ញុំយកចិត្តទុកដាក់នឹងគេទេ ឬមិនចង់ឲ្យខ្ញុំទាមទារពីពួកគេតឹងតែងពេកនោះទេ ហើយពួកគេ ក៏មិនព្រមឲ្យខ្ញុំវិនិច្ឆ័យ ឬកាត់ទោសសេចក្ដីទុច្ចរិតរបស់ពួកគេដែរ។ ពួកគេបែរជាមិនចាប់អារម្មណ៍លើរឿងនេះ និងគិតថាវាគួរឲ្យធុញទ្រាន់ទៅវិញ។ ហើយកិច្ចការរបស់ខ្ញុំ គឺត្រូវយក និងយកឈ្នះ លើពួកមនុស្សជាតិដែលបរិភោគ ផឹក និងអរសប្បាយជាមួយខ្ញុំ ប៉ុន្តែពុំស្គាល់ខ្ញុំ។ ខ្ញុំនឹងដោះគ្រឿងសាស្ត្រាវុធចេញពីមនុស្ស ហើយបន្ទាប់មកខ្ញុំនឹងនាំយកពួកទេវតារបស់ខ្ញុំ និងសិរីល្អរបស់ខ្ញុំ រួចខ្ញុំនឹងត្រឡប់ទៅកាន់ទីសំណាក់របស់ខ្ញុំវិញ។ ដ្បិតសកម្មភាពរបស់មនុស្ស បានធ្វើឲ្យខ្ញុំខកចិត្តជាយូរមកហើយ ហើយធ្វើឲ្យកិច្ចការរបស់ខ្ញុំបែកខ្ញែកជាចំណែកតូចៗ។ ខ្ញុំមានបំណងចង់យកមកវិញនូវសិរីល្អរបស់ខ្ញុំ ដែលមេកំណាចបានយកទៅជាយូរមកហើយ នៅមុនពេលដែលខ្ញុំដើរចេញដោយដួងចិត្តសប្បាយរីករាយ ដោយអនុញ្ញាតឲ្យមនុស្សបន្តរស់នៅក្នុងជីវិតរបស់ពួកគេ បន្ត «រស់នៅ និងធ្វើការក្នុងសុខសន្តិភាព និងសេចក្ដីសប្បាយរីករាយ» ហើយខ្ញុំនឹងមិនធ្វើអន្តរាគមន៍ លើជីវិតរបស់ពួកគេនោះទេ។ ប៉ុន្តែ សព្វថ្ងៃនេះ ខ្ញុំមានបំណងចង់យកសិរីល្អរបស់ខ្ញុំមកវិញឲ្យបានពេញលេញពីដៃរបស់មេកំណាច យកមកវិញនូវសិរីល្អទាំងស្រុង ដែលបានផ្ដល់ទៅឲ្យមនុស្ស នៅពេលបង្កើតពិភពលោកនេះ។ ខ្ញុំនឹង

មិនផ្ដល់វាជាថ្មីដល់ពូជមនុស្សនៅលើផែនដីឡើយ។ ដ្បិតមនុស្សមិនត្រឹមតែមិនបាន ថែរក្សាសិរីល្អរបស់ខ្ញុំប៉ុណ្ណោះទេ ប៉ុន្តែពួកគេបានផ្លាស់ប្ដូរវាទៅជារូបអង្គរបស់សាតាំង ទៀតផង។ មនុស្សពុំអរសប្បាយ នឹងការមកដល់របស់ខ្ញុំទេ ហើយពួកគេពុំឲ្យតម្លៃលើ ថ្ងៃនៃសិរីល្អរបស់ខ្ញុំឡើយ។ ពួកគេមិនអរសប្បាយនឹងទទួលនូវការកាត់ទោសរបស់ខ្ញុំ ឡើយ ពួកគេក៏មិនសុខចិត្តត្រឡប់មករកសិរីល្អរបស់ខ្ញុំនៅចំពោះខ្ញុំដែរ ហើយពួកគេក៏ មិនសុខចិត្ត បន្សាបនូវថ្នាំពុលរបស់មេកំណាចទេ។ មនុស្សបន្ដបោកបញ្ឆោតខ្ញុំ នៅក្នុង វិធីចាស់ៗដដែល មនុស្សនៅបន្ដពាក់មុខញញឹមពព្រាយ និងសប្បាយរីករាយ ក្នុង របៀបចាស់ៗដដែល។ ពួកគេពុំបានដឹងអំពីជម្រៅនៃភាពងងឹត ដែលនឹងចុះមកលើ មនុស្សជាតិក្រោយពេលសិរីល្អរបស់ខ្ញុំចាកចេញនោះទេ។ ជាពិសេស ពួកគេពុំបានដឹង ថា នៅថ្ងៃដែលខ្ញុំចុះមកក្នុងចំណោមមនុស្សជាតិទាំងមូល នោះវានឹងកាន់តែលំបាក សម្រាប់ពួកគេ ជាងមនុស្សនៅក្នុងសម័យ ណូអេ ទៅទៀត ដ្បិតពួកគេពុំបានដឹងថា តើ ប្រទេសអ៊ីស្រាអែលទៅជាងងឹតដោយបែបណានោះទេ នៅពេលដែលសិរីល្អរបស់ខ្ញុំ បានចេញផុតពីទីនោះ ដ្បិតមនុស្សភ្លេចថាការដើរក្នុងយប់ងងឹតសូន្យសុង នោះពិបាក យ៉ាងណានៅពេលថ្ងៃទើបនឹងរះឡើង។ នៅពេលព្រះអាទិត្យបាត់ទៅវិញជាថ្មីម្ដងទៀត ហើយនៅពេលភាពងងឹតចុះមកលើមនុស្ស គេនឹងទួញសោក និងសង្កៀតធ្មេញជាថ្មី នៅក្នុងភាពងងឹត។ តើអ្នករាល់គ្នាបានភ្លេចថា ពួកសាសន៍អ៊ីស្រាអែលត្រូវរងទុក្ខ ក្នុង សម័យនោះដោយបែបណាហើយមែនទេ នៅពេលដែលសិរីល្អរបស់ខ្ញុំបានចាកចេញ ពីអ៊ីស្រាអែលទៅ? បច្ចុប្បន្ននេះ គឺជាពេលដែលអ្នករាល់គ្នាត្រូវឃើញសិរីល្អរបស់ខ្ញុំ ហើយវាក៏ជាពេលដែលអ្នករាល់គ្នារួមរស់ក្នុងថ្ងៃនៃសិរីល្អរបស់ខ្ញុំដែរ។ មនុស្សនឹងទួញ សោកនៅកណ្ដាលយប់ នៅពេលដែលសិរីល្អរបស់ខ្ញុំចាកចេញពីដីដ៏ស្មោកគ្រោកនេះ។ បច្ចុប្បន្ននេះគឺជាថ្ងៃនៃសិរីល្អ ជាពេលដែលខ្ញុំបំពេញកិច្ចរបស់ខ្ញុំ ហើយវាគឺជាថ្ងៃដែលខ្ញុំ ធ្វើឲ្យមនុស្សជាតិគេចផុតពីការរងទុក្ខវេទនា ដ្បិតខ្ញុំនឹងមិនចែករំលែកពេលវេលាទុក្ខ ទារុណ និងទុក្ខសោកជាមួយពួកគេឡើយ។ ដ្បិតខ្ញុំគ្រាន់តែចង់យកឈ្នះលើមនុស្សជាតិ និងយកឈ្នះលើមេកំណាចរបស់មនុស្សជាតិឲ្យបានទាំងស្រុងប៉ុណ្ណោះ។

# តើអ្នកដឹងអ្វីខ្លះអំពីសេចក្ដីជំនឿ?

នៅក្នុងមនុស្សមានតែពាក្យមិនច្បាស់លាស់អំពីសេចក្ដីជំនឿ ប៉ុន្តែមនុស្សមិនបានដឹងអំពីអ្វីដែលផ្សំគ្នាឡើងឲ្យមានសេចក្ដីជំនឿ និងកាន់តែមិនដឹងពីហេតុផលដែលនាំឲ្យគេមានសេចក្ដីជំនឿនោះឡើយ។ មនុស្សមានការយល់ដឹងតិចតួចណាស់ ហើយមនុស្សខ្លួនឯងផ្ទាល់ក៏កំពុងតែខ្វះខាតច្រើនពេកហើយ ព្រោះថាសេចក្ដីជំនឿរបស់គេចំពោះខ្ញុំ ជាសេចក្ដីជំនឿខ្វះការពិចារណា និងល្ងិតល្ងង់។ ទោះបីជាគេមិនដឹងថាអ្វីជាសេចក្ដីជំនឿ ឬមិនដឹងពីហេតុផលដែលនាំឲ្យគេមានសេចក្ដីជំនឿលើខ្ញុំក៏ដោយ ក៏គេបន្តជឿលើខ្ញុំទាំងគិតមមៃ។ អ្វីដែលខ្ញុំទាមទារពីមនុស្សគឺមិនគ្រាន់តែឲ្យគេអំពាវនាវរកខ្ញុំទាំងមមៃបែបនេះ ឬជឿលើខ្ញុំដោយគ្មានទិសដៅបែបនេះឡើយ ដ្បិតកិច្ចការដែលខ្ញុំធ្វើ គឺដើម្បីឲ្យមនុស្សអាចមើលឃើញ និងស្គាល់ខ្ញុំ មិនមែនឲ្យមនុស្សដក់អារម្មណ៍នឹងខ្ញុំ និងមើលមកខ្ញុំ ដោយទស្សនៈមួយថ្មីនោះឡើយ។ ខ្ញុំធ្លាប់សម្ដែងទីសម្គាល់ ការអស្ចារ្យ និងសម្ដែងឫទ្ធិបារមីជាច្រើន ហើយពួកអ៊ីស្រាអែលនៅសម័យនោះក៏បានបង្ហាញនូវការកោតសរសើរ និងការគោរពស្ញប់ស្ញែងយ៉ាងខ្លាំង ចំពោះសមត្ថភាពដ៏អស្ចារ្យរបស់ខ្ញុំ ក្នុងការប្រោសអ្នកជំងឺឲ្យជា និងការបណ្ដេញអារក្ស។ នៅគ្រានោះ ពួកយូដាបានគិតថា ព្រះចេស្ដាប្រោសឲ្យជារបស់ខ្ញុំ គឺជាកិច្ចការដ៏ប៉ិនប្រសប់អស្ចារ្យ ហើយដោយសារតែទង្វើជាច្រើនរបស់ខ្ញុំ ពួកគេគ្រប់គ្នាបានគោរពចំពោះខ្ញុំ និងមានអារម្មណ៍កោតសរសើរយ៉ាងខ្លាំងចំពោះគ្រប់ទាំងព្រះចេស្ដារបស់ខ្ញុំ។ ដូច្នេះ មនុស្សគ្រប់គ្នាដែលបានឃើញខ្ញុំធ្វើការអស្ចារ្យ បានដើរតាមខ្ញុំយ៉ាងប្រកិត រហូតដល់ថ្នាក់មានមនុស្សរាប់ពាន់នាក់ ដែលបានហ៊ុមព័ទ្ធជុំវិញខ្ញុំ ដើម្បីមើលខ្ញុំប្រោសអ្នកជំងឺឲ្យជា។ ខ្ញុំបានសម្ដែងទីសម្គាល់ និងការអស្ចារ្យជាច្រើន ប៉ុន្តែមនុស្សចាត់ទុកខ្ញុំត្រឹមជាគ្រូពេទ្យដ៏ពូកែម្នាក់ប៉ុណ្ណោះ ហើយខ្ញុំក៏បានចែកចាយសេចក្ដីបង្រៀនជាច្រើនទៅកាន់មនុស្ស នៅសម័យនោះផងដែរ ប៉ុន្តែពួកគេចាត់ទុកខ្ញុំត្រឹមជាបរមគ្រូម្នាក់ចំពោះពួកសិស្សរបស់គាត់តែប៉ុណ្ណោះ។ សូម្បីសព្វថ្ងៃនេះក៏ដោយ ក្រោយពេលមនុស្សបាន

ឃើញកំណត់ត្រាប្រវត្តិសាស្រ្ត នៃកិច្ចការរបស់ខ្ញុំក៏ពួកគេបន្តកាត់ស្រាយថា ខ្ញុំជាគ្រូពេទ្យដ៏ពូកែ ដែលបានប្រោសអ្នកជំងឺឲ្យជា និងជាគ្រូបង្រៀនដល់មនុស្សល្ងិតល្ងង់ ហើយពួកគេបានបរិយាយពីខ្ញុំថា ខ្ញុំជាព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទដែលពេញដោយសេចក្ដីមេត្តាករុណា។ អស់អ្នកដែលកាត់ស្រាយបទគម្ពីរ អាចមានជំនាញពូកែលើសខ្ញុំនៅក្នុងការប្រោសឲ្យជា ឬមួយពេលនេះ គេអាចក្លាយជាសិស្សដែលពូកែលើសគ្រូរបស់គេ ប៉ុន្ដែមនុស្សពូកែដែលមានកិត្តិនាមល្បីរន្ទឺ មានកេរ្តិ៍ឈ្មោះល្បីល្បាញនៅជុំវិញពិភពលោកទាំងនេះ ចាត់ទុកខ្ញុំត្រឹមតែជាគ្រូពេទ្យដ៏តូចទាបម្នាក់ប៉ុណ្ណោះ។ ទង្វើរបស់ខ្ញុំមានចំនួនច្រើនជាងគ្រាប់ខ្សាច់នៅតាមឆ្នេរសមុទ្រ ហើយព្រះប្រាជ្ញាញាណរបស់ខ្ញុំទៀតសោត ក៏ខ្ពង់ខ្ពស់លើសបុត្រាទាំងអស់របស់ព្រះបាទសាឡូម៉ូនផងដែរ ប៉ុន្ដែមនុស្សគិតត្រឹមថា ខ្ញុំជាគ្រូពេទ្យម្នាក់ដែលមិនសូវល្បី និងជាគ្រូបង្រៀនម្នាក់ដែលគ្មានមនុស្សណាស្គាល់សោះ។ មនុស្សជាច្រើនជឿលើខ្ញុំ ដើម្បីឲ្យខ្ញុំប្រោសគេឲ្យជាតែប៉ុណ្ណោះ។ មនុស្សជាច្រើនជឿលើខ្ញុំ ដើម្បីឲ្យខ្ញុំប្រើព្រះចេស្ដាបណ្ដេញវិញ្ញាណស្មោកគ្រោក ចេញពីរូបកាយរបស់គេ ហើយមានមនុស្សជាច្រើនជឿលើខ្ញុំដើម្បីឲ្យតែបានសេចក្ដីសុខសាន្ត និងសេចក្ដីអំណរពីខ្ញុំប៉ុណ្ណោះ។ មនុស្សជាច្រើនជឿលើខ្ញុំ ដើម្បីទាមទារចង់បានទ្រព្យសម្បត្តិកាន់តែច្រើនពីខ្ញុំប៉ុណ្ណោះ។ មនុស្សជាច្រើនជឿលើខ្ញុំ ដើម្បីឲ្យជីវិតនេះអាចរស់នៅយ៉ាងសុខសាន្ត និងមានសុវត្ថិភាពល្អនៅលោកខាងមុខតែប៉ុណ្ណោះ។ មនុស្សជាច្រើនជឿលើខ្ញុំ ដើម្បីឲ្យបានរួចខ្លួនពីទុក្ខវេទនានៃស្ថាននរក និងដើម្បីទទួលបានព្រះពរនៃស្ថានសួគ៌។ មនុស្សជាច្រើនជឿលើខ្ញុំ ដើម្បីភាពស្រោកស្រាន្តមួយរយៈខ្លី ប៉ុន្ដែគេមិនព្យាយាមដើម្បីឲ្យបានអ្វីៗដែលមាននៅលោកខាងមុខឡើយ។ នៅពេលដែលខ្ញុំសម្ដែងព្រះពិរោធមកលើមនុស្ស ហើយដកហូតរាល់ទាំងសេចក្ដីអំណរ និងសេចក្ដីសុខសាន្តដែលគេធ្លាប់មាន នោះមនុស្សចាប់ផ្ដើមមានចិត្តសង្ស័យ។ ពេលដែលខ្ញុំប្រគល់ទុក្ខវេទនានៃស្ថាននរកឲ្យទៅមនុស្ស ហើយយកព្រះពរនៃស្ថានសួគ៌មកវិញ នោះសេចក្ដីអាម៉ាស់របស់មនុស្សប្រែក្លាយជាកំហឹង។ ពេលមនុស្សទូលសុំឲ្យខ្ញុំប្រោសគេឲ្យជា ខ្ញុំមិនស្ដាប់ឡើយ ហើយមានអារម្មណ៍ស្អប់ខ្ពើម

គេយ៉ាងខ្លាំងទៀតផង។ មនុស្សបានចាកចេញពីខ្ញុំ ហើយបែរទៅរកវិធីព្យាបាលតាមផ្លូវងងឹត និងអំពើអាបធ្មប់។ នៅពេលដែលខ្ញុំដកហូតអ្វីៗគ្រប់យ៉ាងដែលមនុស្សបានទាមទារពីខ្ញុំ ស្រាប់តែមនុស្សគ្រប់គ្នាបាត់ស្រមោលឈឹង ទាំងគ្មានបន្សល់ដានអ្វីឡើយ។ បើដូច្នេះ ខ្ញុំអាចនិយាយបានថាមនុស្សមានជំនឿលើខ្ញុំ ដោយសារតែខ្ញុំប្រទានព្រះគុណច្រើនពេក ហើយពួកគេទទួលបានប្រយោជន៍ច្រើនពេក។ ពួកយូដាបានជឿលើខ្ញុំ ដើម្បីបានព្រះគុណរបស់ខ្ញុំ ហើយបានដើរតាមខ្ញុំទៅគ្រប់ទីកន្លែងដែលខ្ញុំបានទៅផង។ មនុស្សល្ងិតល្ងង់ដែលមានចំណេះដឹង និងបទពិសោធដ៏មានកម្រិតទាំងនេះ បានស្វែងរកខ្ញុំ ដើម្បីចង់ឃើញទីសម្គាល់ និងការអស្ចារ្យដែលខ្ញុំបានធ្វើតែប៉ុណ្ណោះ។ ពួកគេបានចាត់ទុកខ្ញុំជាមេគ្រួសាររបស់ពួកយូដាដែលអាចសម្ដែងការឫទ្ធិបារមីដ៏ពូកែបំផុត។ ហើយនៅពេលដែលខ្ញុំបានបណ្ដេញអារក្សចេញពីមនុស្ស វាក៏បានធ្វើឲ្យមានការពិភាក្សាជាច្រើននៅក្នុងចំណោមពួកគេ៖ ពួកគេបាននិយាយថា ខ្ញុំជាអេលីយ៉ា ថាខ្ញុំជាម៉ូសេ ថាខ្ញុំជាហោរាដ៏ចំណាស់បំផុតក្នុងចំណោមពួកហោរាទាំងអស់នាសម័យបុរាណ ឬថាខ្ញុំជាគ្រូពេទ្យដ៏ពូកែជាងគេបំផុត។ ក្រៅពីខ្ញុំផ្ទាល់ដែលមានបន្ទូលថា ខ្ញុំជាជីវិត ជាផ្លូវ និងជាសេចក្ដីពិត គ្មាននរណាម្នាក់អាចស្គាល់អង្គខ្ញុំ ឬអត្តសញ្ញាណរបស់ខ្ញុំបានឡើយ។ ក្រៅពីខ្ញុំផ្ទាល់ដែលមានបន្ទូលថា ស្ថានសួគ៌ជាកន្លែងមួយដែលព្រះវរបិតាខ្ញុំគង់នៅ គ្មាននរណាម្នាក់បានដឹងឡើយថា ខ្ញុំជាព្រះបុត្រានៃព្រះ ហើយក៏ជាព្រះជាម្ចាស់ផ្ទាល់ផងដែរ។ ក្រៅពីខ្ញុំផ្ទាល់ដែលមានបន្ទូលថា ខ្ញុំនឹងនាំសេចក្ដីប្រោសលោះ ទៅឲ្យមនុស្សលោកទាំងអស់ ហើយបង់ថ្លៃលោះយកមនុស្ស គ្មាននរណាម្នាក់បានដឹងថា ខ្ញុំជាព្រះដែលប្រោសលោះមនុស្សលោក ហើយមនុស្សស្គាល់ខ្ញុំ ត្រឹមតែជាមនុស្សម្នាក់ដែលមានចិត្តមេត្តា និងចិត្តក្ដួលអាណិតប៉ុណ្ណោះ។ ហើយក្រៅពីខ្ញុំផ្ទាល់ ដែលអាចពន្យល់គ្រប់ទាំងសេចក្ដីអំពីខ្លួនខ្ញុំ នោះគ្មាននរណាម្នាក់បានស្គាល់ខ្ញុំ ហើយក៏គ្មាននរណាម្នាក់ជឿថា ខ្ញុំជាព្រះរាជបុត្រារបស់ព្រះដ៏មានព្រះជន្មរស់នោះដែរ។ នេះហើយគឺជាសេចក្ដីជំនឿរបស់មនុស្ស ដែលមានចំពោះខ្ញុំ និងជារបៀបដែលគេព្យាយាមបញ្ឆោតខ្ញុំ។ តើពួកគេអាចធ្វើបន្ទាល់អំពីខ្ញុំយ៉ាងដូចម្ដេច

ខណៈពេលដែលគេមានទស្សនៈបែបនេះ ចំពោះខ្ញុំ?

មនុស្សជឿលើខ្ញុំ ប៉ុន្តែពួកគេគ្មានសមត្ថភាពធ្វើបន្ទាល់ពីខ្ញុំ ហើយពួកគេក៏មិនអាចផ្ដល់សក្ខីភាពសម្រាប់ខ្ញុំ មុនពេលខ្ញុំធ្វើឲ្យមនុស្សស្គាល់ខ្ញុំនោះដែរ។ មនុស្សបានត្រឹមមើលឃើញថា ខ្ញុំមានភាពប្រសើរលើសពួកមនុស្សលោក និងមនុស្សបរិសុទ្ធទាំងអស់ ហើយមើលឃើញថា កិច្ចការដែលខ្ញុំធ្វើ មនុស្សមិនអាចធ្វើបានឡើយ។ ដូច្នេះ តាំងពីពួកយូដា រហូតដល់មនុស្សនាពេលសព្វថ្ងៃនេះ មនុស្សគ្រប់គ្នាដែលបានឃើញនូវទង្វើដ៏ពេញដោយសិរីល្អរបស់ខ្ញុំ បានពេញដោយភាពចង់ដឹងចង់ស្គាល់អំពីខ្ញុំ ហើយគ្មានមាត់មនុស្សលោកណាម្នាក់ ដែលអាចធ្វើបន្ទាល់ពីខ្ញុំនោះឡើយ។ មានតែព្រះបិតាខ្ញុំប៉ុណ្ណោះ ដែលអាចធ្វើបន្ទាល់ពីខ្ញុំ និងបានរៀបចំផ្លូវសម្រាប់ខ្ញុំនៅក្នុងចំណោមមនុស្សលោកទាំងអស់។ បើទ្រង់មិនបានធ្វើទេ ទោះបីខ្ញុំខំប្រឹងបែបណា ក៏មនុស្សនឹងគ្មានផ្លូវដឹងថា ខ្ញុំគឺជាព្រះអម្ចាស់នៃសកលលោកនេះដែរ ព្រោះថាមនុស្សដឹងតែចង់បានពីខ្ញុំ ហើយគេគ្មានសេចក្ដីជំនឿលើខ្ញុំ ចេញពីលទ្ធផលនៃកិច្ចការរបស់ខ្ញុំឡើយ។ មនុស្សស្គាល់ខ្ញុំ ដោយសារតែខ្ញុំជាមនុស្សស្លូតត្រង់ និងគ្មានបាបសោះឡើយ។ ពួកគេស្គាល់ខ្ញុំ ដោយសារតែខ្ញុំអាចពន្យល់ពីសេចក្ដីលាក់កំបាំងជាច្រើន ដោយសារតែខ្ញុំ មានឋានៈខ្ពស់ជាងបណ្ដាជន ឬដោយសារតែមនុស្សបានទទួលប្រយោជន៍យ៉ាងច្រើនពីខ្ញុំ ប៉ុន្តែមានមនុស្សតិចតួចណាស់ដែលជឿថា ខ្ញុំជាព្រះអម្ចាស់នៃសកលលោកទាំងមូល។ នេះជាហេតុផលដែលខ្ញុំនិយាយថា មនុស្សមិនដឹងអំពីហេតុផលដែលគេមានជំនឿលើខ្ញុំឡើយ។ គេមិន ដឹងអំពីគោលបំណងឬសារៈសំខាន់នៃសេចក្ដីជំនឿរបស់គេចំពោះខ្ញុំឡើយ។ គេកំពុងតែខ្វះតថភាពជាមនុស្ស ដែលជាហេតុនាំឲ្យគេមិនសក្តិសមនឹងធ្វើបន្ទាល់ ពីខ្ញុំឡើយ។ អ្នករាល់គ្នាមានសេចក្ដីជំនឿដ៏ពិតតិចពេក ហើយក៏បានទទួលតិចពេកផងដែរ ដូច្នេះ អ្នករាល់គ្នាមានសក្ខីភាពតិចពេកហើយ។ លើសពីនេះទៅទៀត អ្នករាល់គ្នាមានការយល់ដឹងតិចពេកនិងនៅខ្វះខាតច្រើនណាស់ ដូច្នេះ អ្នកសឹងតែមិនសមមកធ្វើបន្ទាល់ពីទង្វើរបស់ខ្ញុំផង។ ពិតណាស់ ការតាំងចិត្តរបស់អ្នករាល់គ្នាគួរជាទីពិចារណា ប៉ុន្តែតើអ្នករាល់គ្នាប្រាកដ

ច្បាស់ដែរឬទេថា អ្នកនឹងអាចធ្វើបន្ទាល់ពីលក្ខណៈរបស់ព្រះជាម្ចាស់បានដោយជោគជ័យ? អ្វីដែលអ្នករាល់គ្នាបានពិសោធនិងបានឃើញ គឺប្រសើរជាងពួកបរិសុទ្ធ និងពួកហោរាពីគ្រប់សម័យកាលទៅទៀត ប៉ុន្តែតើអ្នករាល់គ្នាអាចធ្វើទីបន្ទាល់ឲ្យបានប្រសើរជាងពួកបរិសុទ្ធ និងពួកហោរាពីសម័យបុរាណទាំងនេះដែរឬទេ? អ្វីដែលខ្ញុំប្រទានឲ្យអ្នករាល់គ្នាឥឡូវនេះ គឺប្រសើរលើសម៉ូសេ ហើយច្រើនជាងដាវីឌផង ដូច្នេះខ្ញុំក៏សុំឲ្យទីបន្ទាល់របស់អ្នករាល់គ្នាល្អលើសម៉ូសេ ហើយសុំឲ្យពាក្យរបស់អ្នករាល់គ្នាអស្ចារ្យជាងដាវីឌផងដែរ។ ខ្ញុំប្រទានដល់អ្នករាល់គ្នាលើសគេមួយរយដង ដូច្នេះ ខ្ញុំតម្រូវឲ្យអ្នករាល់គ្នាតបស្នងមកខ្ញុំវិញដូចគ្នាផងដែរ។ អ្នកត្រូវតែដឹងថា ខ្ញុំគឺជាព្រះមួយអង្គដែលប្រទានជីវិតដល់មនុស្សលោក គឺជាអ្នករាល់គ្នាហើយដែលទទួលបាននូវជីវិតពីខ្ញុំ និងត្រូវធ្វើបន្ទាល់សម្រាប់ខ្ញុំ។ នេះជាភារកិច្ចដែលខ្ញុំប្រទានដល់អ្នករាល់គ្នា ហើយវាជាអ្វីដែលអ្នករាល់គ្នាគួរតែធ្វើសម្រាប់ខ្ញុំ។ ខ្ញុំបានប្រទាននូវសិរីល្អទាំងអស់របស់ខ្ញុំដល់អ្នករាល់គ្នា ខ្ញុំបានប្រទានដល់អ្នករាល់គ្នានូវជីវិត ដែលពួកអ៊ីស្រាអែលជារាស្ត្ររើសតាំងរបស់ខ្ញុំ មិនធ្លាប់បានទទួលពីមុនឡើយ។ តាមត្រូវ អ្នករាល់គ្នាគួរតែធ្វើបន្ទាល់ពីខ្ញុំ ហើយថ្វាយភាពយុវវ័យរបស់អ្នក និងលះបង់ជីវិតរបស់អ្នកសម្រាប់ខ្ញុំ។ អស់អ្នកណាដែលខ្ញុំប្រទានសិរីល្អខ្ញុំដល់គេ អ្នកនោះនឹងត្រូវធ្វើបន្ទាល់ពីខ្ញុំ និងថ្វាយជីវិតរបស់គេសម្រាប់ខ្ញុំ។ នេះជាសេចក្ដីដែលខ្ញុំបានកំណត់ទុកយូរណាស់មកហើយ។ សំណាងល្អហើយដែលខ្ញុំប្រទានសិរីល្អរបស់ខ្ញុំដល់អ្នករាល់គ្នា ហើយភារកិច្ចរបស់អ្នករាល់គ្នា គឺត្រូវធ្វើបន្ទាល់ពីសិរីល្អរបស់ខ្ញុំ។ បើអ្នករាល់គ្នាជឿលើខ្ញុំ ដោយគ្រាន់តែចង់បានព្រះពរ នោះកិច្ចការរបស់ខ្ញុំនឹងទទួលបាននូវសារៈសំខាន់តិចតួចបំផុត ហើយអ្នករាល់គ្នានឹងមិនបំពេញភារកិច្ចរបស់អ្នករាល់គ្នាឡើយ។ ពួកអ៊ីស្រាអែលបានឃើញតែសេចក្ដីមេត្តា សេចក្ដីស្រឡាញ់ និងភាពធំឧត្ដមរបស់ខ្ញុំប៉ុណ្ណោះ ហើយពួកយូដាបានឃើញព្រះទ័យអត់ធ្មត់ និងការប្រោសលោះរបស់ខ្ញុំផ្ទាល់ភ្នែកដែរ។ ពួកគេបានឃើញកិច្ចការនៃព្រះវិញ្ញាណរបស់ខ្ញុំតិចតួចបំផុត គឺថាពួកគេយល់បានតែមួយភាគមួយម៉ឺននៃអ្វីដែលអ្នករាល់គ្នាបានឮ និងបានឃើញប៉ុណ្ណោះ។ អ្វីដែល

អ្នករាល់គ្នាបានឃើញ គឺប្រសើរជាងពួកសម្តេចសង្ឃដែលស្ថិតនៅក្នុងចំណោមពួកគេទៅទៀត។ សេចក្តីពិតដែលអ្នករាល់គ្នាយល់នាពេលសព្វថ្ងៃ គឺប្រសើរលើសសេចក្តីពិតដែលគេយល់ទៅទៀត។ អ្វីដែលអ្នករាល់គ្នាបានឃើញនាពេលសព្វថ្ងៃ គឺប្រសើរលើសអ្វីដែលគេបានឃើញ នៅក្នុងយុគសម័យនៃក្រឹត្យវិន័យ ក៏ដូចជាយុគសម័យនៃព្រះគុណទៅទៀត ហើយសេចក្តីអ្វីដែលអ្នករាល់គ្នាបានពិសោធ ក៏លើសទាំងម៉ូសេ និងអេលីយ៉ាផងដែរ។ ដ្បិតអ្វីដែលពួកអ៊ីស្រាអែលបានយល់ គឺគ្រាន់តែជាក្រឹត្យវិន័យរបស់ព្រះយេហូវ៉ា ហើយអ្វីដែលពួកគេបានឃើញ គឺគ្រាន់តែជាប្រឹស្ដាង្គរបស់ព្រះយេហូវ៉ាប៉ុណ្ណោះ។ អ្វីដែលពួកយូដាបានយល់ គ្រាន់តែជាការប្រោសលោះរបស់ព្រះយេស៊ូវ។ អ្វីដែលពួកគេបានទទួល គ្រាន់តែជាព្រះគុណដែលព្រះយេស៊ូវបានប្រទានមក ហើយអ្វីដែលពួកគេបានឃើញ គឺគ្រាន់តែជារូបអង្គរបស់ព្រះយេស៊ូវនៅក្នុងផ្ទះរបស់សាសន៍យូដាប៉ុណ្ណោះ។ អ្វីដែលអ្នករាល់គ្នាមើលឃើញសព្វថ្ងៃ គឺជាសិរីល្អរបស់ព្រះយេហូវ៉ា ការប្រោសលោះរបស់ព្រះយេស៊ូវ និងគ្រប់ទាំងទង្វើរបស់ខ្ញុំនៅសម័យនេះ។ ដូច្នេះ អ្នកក៏បានឮអំពីព្រះបន្ទូលនៃព្រះវិញ្ញាណរបស់ខ្ញុំដែរ ហើយបានកោតសរសើរព្រះប្រាជ្ញាញាណរបស់ខ្ញុំ ស្គាល់ពីឫទ្ធិបារមីរបស់ខ្ញុំ និងបានរៀនអំពីនិស្ស័យរបស់ខ្ញុំផង។ ខ្ញុំក៏បានប្រាប់អ្នករាល់គ្នា អំពីផែនការគ្រប់គ្រងទាំងអស់របស់ខ្ញុំដែរ។ អ្វីដែលអ្នករាល់គ្នាបានឃើញ មិនគ្រាន់តែជាព្រះជាម្ចាស់ដ៏ពេញដោយសេចក្តីស្រឡាញ់ និងក្តីមេត្តាប៉ុណ្ណោះទេ ប៉ុន្តែក៏ជាព្រះដ៏ពេញដោយសេចក្តីសុចរិតផងដែរ។ អ្នកបានឃើញកិច្ចការដ៏អស្ចារ្យរបស់ខ្ញុំ និងបានដឹងហើយថា ខ្ញុំពេញពោរដោយព្រះចេស្តា និងសេចក្តីក្រោធ។ លើសពីនេះទៅទៀត អ្នកដឹងថា ខ្ញុំធ្លាប់នាំសេចក្តីក្រោធរបស់ខ្ញុំមកលើពូជពង្សអ៊ីស្រាអែល ហើយដឹងថា នៅថ្ងៃនេះ សេចក្តីក្រោធនេះបានមកដល់អ្នក រាល់គ្នាហើយ។ អ្នករាល់គ្នាយល់អំពីសេចក្តីលាក់កំបាំងរបស់ខ្ញុំនៅឯស្ថានសួគ៌ ច្រើន ជាងអេសាយ និងយ៉ូហានទៅទៀតផង ហើយអ្នករាល់គ្នាក៏ស្គាល់ពីភាពគួរឲ្យ ស្រឡាញ់ និងភាពគួរឲ្យគោរពរបស់ខ្ញុំ ច្រើនជាងពួកបរិសុទ្ធទាំងអស់កាលពីអតីតកាលផងដែរ។ អ្វីដែលអ្នករាល់គ្នាបានទទួល មិនគ្រាន់តែជាសេចក្តីពិត

ជាផ្លូវ និងជាជីវិតរបស់ខ្ញុំប៉ុណ្ណោះទេ ប៉ុន្តែជានិមិត្ត និងការបើកសម្ដែងដែលអស្ចារ្យជាងអ្វីដែលយ៉ូហានបានទទួលទៅទៀត។ អ្នករាល់គ្នាយល់នូវសេចក្ដីលាក់កំបាំងច្រើនលើសនេះទៅទៀត ហើយក៏បានសម្លឹងឃើញព្រះភក្ត្រពិតរបស់ខ្ញុំផងដែរ។ អ្នករាល់គ្នាបានទទួលការជំនុំជម្រះរបស់ខ្ញុំកាន់តែច្រើន ហើយក៏ស្គាល់អំពីនិស្ស័យសុចរិតរបស់ខ្ញុំកាន់តែច្រើនផងដែរ។ ហើយទោះបីជាអ្នករាល់គ្នា បានកើតមកនៅគ្រាចុងក្រោយក៏ដោយ ប៉ុន្តែអ្នកក៏មានការយល់ដឹងបែបចាស់គំរិលពីអតីតកាល ហើយអ្នកក៏បានពិសោធរឿងរ៉ាវសព្វថ្ងៃ ដែលការទាំងអស់នេះ សុទ្ធតែត្រូវបានធ្វើឡើងដោយខ្ញុំផ្ទាល់។ អ្វីដែលខ្ញុំតម្រូវពីអ្នករាល់គ្នា មិនជ្រុលពេកឡើយ ដ្បិតខ្ញុំបានប្រទានដល់អ្នករាល់គ្នាច្រើនណាស់ ហើយអ្នករាល់គ្នាក៏បានឃើញរឿងរ៉ាវជាច្រើន នៅក្នុងខ្ញុំផងដែរ។ ដូច្នេះ ខ្ញុំសុំឲ្យអ្នករាល់គ្នាធ្វើបន្ទាល់ពីខ្ញុំទៅកាន់ពួកបរិសុទ្ធនាសម័យមុន ហើយនេះជាបំណងព្រះហឫទ័យតែមួយគត់របស់ខ្ញុំ។

ព្រះបិតារបស់ខ្ញុំ គឺជាអ្នកទីមួយដែលបានធ្វើបន្ទាល់សម្រាប់ខ្ញុំ ប៉ុន្តែខ្ញុំចង់ទទួលបានសិរីល្អច្រើនជាងនេះ និងចង់ឲ្យមានបន្ទាល់ចេញពីមាត់របស់មនុស្សដែលព្រះបានបង្កើតមក ដូច្នេះ ខ្ញុំប្រទានអ្វីគ្រប់យ៉ាងរបស់ខ្ញុំដល់អ្នករាល់គ្នា ដើម្បីឲ្យអ្នករាល់គ្នាបំពេញភារកិច្ចរបស់ខ្លួន គឺសម្រេចកិច្ចការរបស់ខ្ញុំនៅក្នុងចំណោមមនុស្សលោក។ អ្នករាល់គ្នាគួរតែយល់អំពីហេតុផល ដែលនាំឲ្យអ្នករាល់គ្នាជឿលើខ្ញុំហើយ។ បើអ្នករាល់គ្នាគ្រាន់តែចង់ក្លាយជាសិស្ស ឬជាអ្នកជំងឺរបស់ខ្ញុំ ឬក្លាយជាពួកបរិសុទ្ធម្នាក់ក្នុងចំណោមពួកបរិសុទ្ធរបស់ខ្ញុំនៅឯស្ថានសួគ៌ នោះការដែល អ្នករាល់គ្នាដើរតាមខ្ញុំ នឹងគ្មានន័យឡើយ។ ការដើរតាមខ្ញុំនៅក្នុងឥរិយាបថបែបនេះ គឺជាការខ្ជះខ្ជាយកម្លាំងចោលប៉ុណ្ណោះ។ ការមានសេចក្ដីជំនឿបែបនេះចំពោះខ្ញុំ វាគ្រាន់តែជាការចំណាយពេលឥតប្រយោជន៍ដែលនាំឲ្យខាតបង់ដល់យុវភាពរបស់អ្នកទៀតផង។ ហើយនៅទីបញ្ចប់ អ្នករាល់គ្នានឹងមិនទទួលបានអ្វីសោះឡើយ។ តើនេះវាមិនមែនជាការប្រឹងប្រែង ជាអសារឥតការទេឬ អី? ខ្ញុំបានចាកចេញពីក្នុងចំណោមសាសន៍យូដាជាយូរមកហើយ ហើយក៏លែងជាគ្រូពេទ្យរបស់មនុស្ស ឬក៏ជាឱសថព្យាបាល

មនុស្សទៀតដែរ។ ខ្ញុំលែងធ្វើជាសត្វសម្រាប់ ឲ្យមនុស្សលោកជិះ ឬកាប់យកសាច់តាមតែចិត្តគេចង់ទៀតហើយ។ ផ្ទុយទៅវិញ ខ្ញុំបានមកនៅក្នុងចំណោមមនុស្ស ដើម្បីជំនុំជម្រះ និងវាយផ្ចាលមនុស្សវិញ ដើម្បីឲ្យមនុស្សអាចស្គាល់ខ្ញុំ។ អ្នកគួរតែដឹងថា ខ្ញុំធ្លាប់ធ្វើកិច្ចការនៃការប្រោសលោះ និងដឹងថា ខ្ញុំធ្លាប់ជាព្រះយេស៊ូវ ប៉ុន្តែខ្ញុំមិនអាចបន្តនៅជាព្រះយេស៊ូវរហូតឡើយ គឺដូចជាខ្ញុំធ្លាប់ជាព្រះយេហូវ៉ា ប៉ុន្តែក្រោយមកក៏បានក្លាយជាព្រះយេស៊ូវដូច្នឹងដែរ។ ខ្ញុំជាព្រះជាម្ចាស់របស់មនុស្សលោក ជាព្រះអម្ចាស់នៃសកលលោក ប៉ុន្តែខ្ញុំមិនអាចជាព្រះយេស៊ូវ ឬព្រះយេហូវ៉ាជារៀងរហូតឡើយ។ ខ្ញុំបានក្លាយជាបុគ្គលម្នាក់ដែលមនុស្សចាត់ទុកថាជាគ្រូពេទ្យ ប៉ុន្តែមិនអាចនិយាយបានថា ព្រះជាម្ចាស់គ្រាន់តែជាគ្រូពេទ្យម្នាក់ សម្រាប់មនុស្សលោកឡើយ។ ដូច្នេះ ប្រសិនបើអ្នក ប្រកាន់ខ្ជាប់នូវទស្សនៈចាស់គំរិល នៅក្នុងសេចក្តីជំនឿរបស់អ្នកចំពោះខ្ញុំ នោះអ្នកនឹងមិនទទួលបានអ្វីឡើយ។ បើទោះបីជាអ្នកសរសើរខ្ញុំនៅថ្ងៃនេះថា៖ «ព្រះដ៏ជាមនុស្សគួរឲ្យស្រឡាញ់ណាស់។ ទ្រង់ប្រោសខ្ញុំឲ្យបានជា ហើយប្រទានដល់ខ្ញុំនូវព្រះពរ សេចក្តីសុខសាន្ត និងសេចក្តីអំណរ។ ព្រះអង្គពិតជាល្អចំពោះមនុស្សលោកខ្លាំងណាស់។ ប្រសិនបើខ្ញុំគ្រាន់តែមានជំនឿលើទ្រង់ នោះខ្ញុំមិនចាំបាច់ខ្វល់ខ្វាយអំពីរឿងប្រាក់កាស និងទ្រព្យសម្បត្តិឡើយ...» ក៏ខ្ញុំនៅតែមិនអាចបញ្ឈប់កិច្ចការដើមរបស់ខ្ញុំ បានឡើយ។ បើអ្នកជឿលើខ្ញុំនៅថ្ងៃនេះ នោះអ្នកនឹងទទួលបានតែសិរីល្អរបស់ខ្ញុំ ហើយអ្នកនឹងសក្តិសមធ្វើបន្ទាល់ពីខ្ញុំ ហើយអ្វីៗផ្សេងទៀត នឹងក្លាយជារឿងបន្ទាប់ បន្សំប៉ុណ្ណោះ។ អ្នកត្រូវតែយល់អំពីការនេះឲ្យបានច្បាស់។

ឥឡូវនេះ តើអ្នកដឹងអំពីហេតុផលដែលនាំឲ្យអ្នកជឿលើខ្ញុំ យ៉ាងពិតប្រាកដហើយឬនៅ? តើអ្នកដឹងអំពីគោលបំណង និងសារៈសំខាន់នៃកិច្ចការរបស់ខ្ញុំពិតប្រាកដហើយឬនៅ? តើអ្នកដឹងអំពីភារកិច្ចរបស់អ្នកពិតប្រាកដដែរឬទេ? តើអ្នកស្គាល់ទីបន្ទាល់របស់ខ្ញុំ ពិតប្រាកដដែរឬទេ? ប្រសិនបើអ្នកគ្រាន់តែជឿលើខ្ញុំ ប៉ុន្តែគ្មានសញ្ញាអំពីសិរីល្អ ឬបន្ទាល់របស់ខ្ញុំនៅក្នុងអ្នកទេ នោះខ្ញុំបានផាត់អ្នកចោលតាំងពីយូរណាស់មកហើយ។ សម្រាប់អស់អ្នកដែលចេះអស់ហើយ ពួកគេរឹតតែប្រៀបដូចជាបន្លាដ៏ច្រើននៅក្នុង

ព្រះនេត្រខ្ញុំ ពួកគេគ្មានអ្វីក្រៅតែជាឧបសគ្គរាំងផ្លូវរបស់ខ្ញុំ និងនៅក្នុងដំណាក់របស់ខ្ញុំ ពួកគេជាស្រងែ ដែលត្រូវបានដករំលើងចោលចេញពីកិច្ចការរបស់ខ្ញុំ ព្រោះថា ពួកគេគ្មានប្រយោជន៍ និងគ្មានតម្លៃទាល់តែសោះ ហើយខ្ញុំបានស្អប់ខ្ពើមពួកគេយូរណាស់មកហើយ។ ជារឿយៗ សេចក្ដីក្រោធរបស់ខ្ញុំធ្លាក់ទៅលើអស់អ្នកណាដែលលែងមានទីបន្ទាល់ ហើយដំបងរបស់ខ្ញុំក៏នៅមិនឆ្ងាយពីពួកគេដែរ។ ខ្ញុំមានបំណងចង់ប្រគល់ពួកគេទៅក្នុងដៃរបស់មេកំណាចជាយូរមកហើយ។ ពួកគេលែងមានព្រះពររបស់ខ្ញុំហើយ។ នៅពេលដែលថ្ងៃនោះមកដល់ ការវាយផ្ចាលរបស់គេនឹងគួរឲ្យសោកសង្រេងជាងទោសរបស់ពួកស្ត្រីល្ងង់ខ្លៅទៅទៀត។ ថ្ងៃនេះ ខ្ញុំធ្វើកិច្ចការណាដែលជាភារកិច្ចដែលខ្ញុំត្រូវធ្វើតែប៉ុណ្ណោះ។ ខ្ញុំនឹងចងស្រូវសាលីទាំងអស់ជាកណ្ដាប់ រួមជាមួយស្រងែទាំងនោះផងដែរ។ នេះជាកិច្ចការរបស់ខ្ញុំនៅថ្ងៃនេះ។ ស្រងែទាំងនោះ នឹងត្រូវដករលើងចោលទាំងអស់ នៅក្នុងគ្រានៃការរែញ្ញករបស់ខ្ញុំបន្ទាប់មក គ្រាប់ស្រូវនឹងត្រូវប្រមូលទុកនៅក្នុងឃ្លាំង ហើយស្រងែទាំងប៉ុន្មាន ដែលប្រមូលបាន នឹងត្រូវដុតចោលឲ្យក្លាយជាផេះ។ កិច្ចការរបស់ខ្ញុំនៅថ្ងៃនេះ គឺគ្រាន់តែចងមនុស្សទាំងអស់ជាកណ្ដាប់ មានន័យថា ត្រូវច្បាំងយកជ័យលើពួកគេទាំងស្រុងសិន។ បន្ទាប់មក ខ្ញុំនឹងចាប់ផ្ដើមដំណើរការនៃការរែញ្ញក ដើម្បីបើកសម្ដែងពីគ្រាចុងបញ្ចប់របស់មនុស្សទាំងអស់។ ឥឡូវនេះ អ្នកគួរតែដឹងអំពីរបៀបដែលអ្នកគួរតែបំពេញព្រះទ័យខ្ញុំ និងរបៀបដែល អ្នកគួរតែរៀបចំផ្លូវឲ្យបានត្រឹមត្រូវ នៅក្នុងសេចក្ដីជំនឿរបស់អ្នកចំពោះខ្ញុំហើយ។ អ្វីដែលខ្ញុំចង់បាន គឺជាភក្ដីភាព និងការស្ដាប់បង្គាប់ សេចក្ដីស្រឡាញ់ និងបន្ទាល់របស់អ្នកនៅពេលនេះ។ ទោះបីជាពេលនេះអ្នកមិនដឹងថា អ្វីទៅជាទីបន្ទាល់ ឬអ្វីទៅជាសេចក្ដីស្រឡាញ់ក៏ដោយ ប៉ុន្តែអ្នកគួរតែថ្វាយដល់ខ្ញុំ នូវអ្វីគ្រប់យ៉ាងរបស់អ្នក ហើយប្រគល់ដល់ខ្ញុំនូវទ្រព្យសម្បត្តិតែមួយគត់ដែលអ្នកមានគឺជាភក្ដីភាព និងការស្ដាប់បង្គាប់របស់អ្នក។ អ្នកគួរតែដឹងថា ទីបន្ទាល់អំពីជ័យជម្នះរបស់ខ្ញុំលើអារក្សសាតាំងស្ថិត គឺនៅក្នុងភក្ដីភាព និងការស្ដាប់បង្គាប់របស់មនុស្សហើយក៏ស្ថិតលើទីបន្ទាល់អំពីជ័យជម្នះទាំងស្រុងរបស់ខ្ញុំ ទៅលើមនុស្សផងដែរ។ ភារកិច្ចនៃសេចក្ដីជំនឿរបស់អ្នកចំពោះ

ខ្ញុំ គឺត្រូវធ្វើបន្ទាល់អំពីខ្ញុំ មានភក្ដីភាពចំពោះខ្ញុំតែម្នាក់គត់ ហើយស្ដាប់បង្គាប់ដល់ទីបញ្ចប់។ មុនពេលខ្ញុំចាប់ផ្ដើមជំហានបន្ទាប់នៃកិច្ចការរបស់ខ្ញុំ តើអ្នកនឹងធ្វើបន្ទាល់អំពីខ្ញុំយ៉ាងដូចម្ដេច? តើអ្នកនឹងមានភក្ដីភាព និងស្ដាប់បង្គាប់ចំពោះខ្ញុំដោយរបៀបណា? តើអ្នកដាក់ភក្ដីភាពទាំងស្រុងរបស់អ្នកចំពោះកិច្ចការរបស់អ្នក ឬក៏អ្នកនឹងគ្រាន់តែបោះបង់វាចោល? តើអ្នកនឹងចុះចូលចំពោះគ្រប់ទាំងការរៀបចំរបស់ខ្ញុំ (ទោះបីជាត្រូវស្លាប់ ឬវិនាស) ឬក៏រត់យករួចខ្លួនទាំងពាក់កណ្ដាលទី ដើម្បីគេចវេសពីការវាយផ្ចាលរបស់ខ្ញុំ? ខ្ញុំវាយផ្ចាលអ្នក ដើម្បីឲ្យអ្នកនឹងធ្វើបន្ទាល់ពីខ្ញុំ មានភក្ដីភាព និងស្ដាប់បង្គាប់ចំពោះខ្ញុំ។ លើសពីនេះ ការវាយផ្ចាលនាពេលសព្វថ្ងៃ គឺដើម្បីបើកបង្ហាញពីជំហានបន្ទាប់នៃកិច្ចការរបស់ខ្ញុំ និងអនុញ្ញាតឲ្យកិច្ចការនេះរីវឌ្ឍទៅមុខ ដោយគ្មានការបង្អាក់។ ដូច្នេះ ខ្ញុំសូមដាស់តឿនអ្នកថា អ្នកគួរតែមានប្រាជ្ញា ហើយមិនត្រូវចាត់ទុកជីវិតរបស់អ្នក ក៏ដូចជាសារៈសំខាន់នៃវត្តមានជីវិតអ្នក ដូចជាគ្រាប់ខ្សាច់ដែលគ្មានតម្លៃនោះទេ។ តើអ្នកអាចដឹងថា កិច្ចការនាពេលខាងមុខរបស់ខ្ញុំ នឹងមានលក្ខណៈបែបណាឲ្យប្រាកដដែរឬទេ? តើអ្នកដឹងអំពីរបៀបដែលខ្ញុំនឹងធ្វើ ការនៅថ្ងៃខាងមុខ និងរបៀបដែលកិច្ចការរបស់ខ្ញុំនឹងបើកបង្ហាញដែរឬទេ? អ្នកគួរតែដឹងពីសារៈសំខាន់នៃបទពិសោធរបស់អ្នកអំពីកិច្ចការរបស់ខ្ញុំ ហើយលើសពីនេះទៅទៀត គឺដឹងអំពីសារៈសំខាន់នៃសេចក្ដីជំនឿរបស់អ្នកចំពោះខ្ញុំ។ ខ្ញុំបានធ្វើកិច្ចការជាច្រើនរួចទៅហើយ។ តើខ្ញុំអាចបោះបង់ចោលទាំងពាក់កណ្ដាលទី ដូចអ្នកស្រមើស្រមៃយ៉ាងដូចម្ដេច? ខ្ញុំបានធ្វើការយ៉ាងច្រើនម្ល៉ឹងហើយ តើខ្ញុំអាចបំផ្លាញវាចោលយ៉ាងដូចម្ដេច? តាមពិតទៅ ខ្ញុំបានមកដើម្បីបញ្ចប់យុគសម័យនេះ។ នេះជាសេចក្ដីពិត ប៉ុន្តែលើសពីនេះទៅទៀត អ្នកត្រូវតែដឹងថា ខ្ញុំកំពុងតែចាប់ផ្ដើមយុគសម័យមួយថ្មី ចាប់ផ្ដើមកិច្ចការមួយថ្មី ហើយអ្វីដែលសំខាន់បំផុតនោះគឺដើម្បីផ្សាយដំណឹងល្អអំពីនគរព្រះ។ ដូច្នេះ អ្នកគួរតែដឹងថា កិច្ចការបច្ចុប្បន្ន គឺគ្រាន់តែចាប់ផ្ដើមយុគសម័យមួយ និងចាក់គ្រឹះមូលដ្ឋាន សម្រាប់ការផ្សាយដំណឹងល្អនាពេលខាងមុខ ហើយបញ្ចប់សម័យកាលនេះ នៅពេលអនាគត។ កិច្ចការរបស់ខ្ញុំមិនមែនសាមញ្ញដូចអ្វីដែលអ្នកគិតឡើយ ហើយក៏មិនមែនគ្មានតម្លៃ ឬគ្មានន័យដូច

អ្វីដែលអ្នកជឿដែរ។ ដូច្នេះ ខ្ញុំនៅតែត្រូវនិយាយទៅកាន់អ្នកថា៖ អ្នកគួរតែថ្វាយជីវិតរបស់អ្នកដើម្បីកិច្ចការរបស់ខ្ញុំ ហើយលើសពីនេះ អ្នកគួរតែលះបង់ជីវិតរបស់អ្នកសម្រាប់សិរីល្អរបស់ខ្ញុំ។ ខ្ញុំបានទន្ទឹងរង់ចាំឲ្យអ្នកធ្វើបន្ទាល់ពីខ្ញុំយូរណាស់មកហើយ ហើយខ្ញុំក៏ទន្ទឹងឲ្យអ្នកផ្សាយដំណឹងល្អរបស់ខ្ញុំយូរជាងនេះទៅទៀត។ អ្នកគួរតែយល់អំពីអ្វីដែលមាននៅក្នុងព្រះហឫទ័យរបស់ខ្ញុំ។

# នៅពេលស្លឹកឈើជ្រុះធ្លាក់ទៅគល់វិញ នោះអ្នកនឹងសោកស្ដាយនូវរាល់អំពើអាក្រក់ទាំងអស់ដែលអ្នកបានធ្វើ

អ្នករាល់គ្នាសុទ្ធតែបានឃើញនឹងភ្នែករបស់អ្នកហើយនូវកិច្ចការដែលខ្ញុំបានធ្វើក្នុងចំណោមអ្នករាល់គ្នា អ្នករាល់គ្នាក៏បានស្ដាប់ដោយខ្លួនឯងនូវព្រះបន្ទូលដែលខ្ញុំបានមានបន្ទូលរួចហើយដែរ ហើយអ្នករាល់គ្នាសុទ្ធតែបានដឹងអំពីអាកប្បកិរិយារបស់ខ្ញុំចំពោះអ្នករាល់គ្នាដែរ ដូចនេះ អ្នករាល់គ្នាគួរតែដឹងពីមូលហេតុ ដែលខ្ញុំកំពុងបំពេញកិច្ចការនេះក្នុងចំណោមអ្នករាល់គ្នា។ ខ្ញុំប្រាប់អ្នករាល់គ្នាដោយត្រង់ទៅចុះ អ្នករាល់គ្នាគ្មានអ្វីផ្សេងក្រៅពីជាឧបករណ៍សម្រាប់កិច្ចការនៃការយកឈ្នះរបស់ខ្ញុំនៅក្នុងគ្រាចុងក្រោយឡើយ ជាឧបករណ៍ដើម្បីពង្រីកកិច្ចការរបស់ខ្ញុំក្នុងចំណោមជាតិសាសន៍ដទៃ។ ខ្ញុំមានព្រះបន្ទូលតាមរយៈសេចក្ដីទុច្ចរិត ភាពស្មោកគ្រោក ការរឹងទទឹង និងការបះបោររបស់អ្នករាល់គ្នា ដើម្បីផ្សព្វផ្សាយកិច្ចការរបស់ខ្ញុំឲ្យបានប្រសើរជាងនេះ និងដើម្បីផ្សាយព្រះនាមរបស់ខ្ញុំក្នុងចំណោមជាតិសាសន៍ដទៃ ពោលគឺដើម្បីផ្សាយព្រះនាមរបស់ខ្ញុំក្នុងចំណោមជាតិសាសន៍ផ្សេងនៅក្រៅស្រុកអ៊ីស្រាអែល។ ដោយបែបនេះ ព្រះនាមរបស់ខ្ញុំ ទង្វើរបស់ខ្ញុំ និងព្រះសូរសៀងរបស់ខ្ញុំ អាចផ្សព្វផ្សាយនៅទូទាំងជាតិសាសន៍ដទៃ ហេតុដូច្នេះហើយ គ្រប់ជាតិសាសន៍ទាំងអស់ដែលមិនមែនជាសាសន៍អ៊ីស្រាអែល អាចនឹងត្រូវបានខ្ញុំយកឈ្នះ ហើយអាចនឹងថ្វាយបង្គំខ្ញុំ ដោយ

ក្លាយជាដែនដីបរិសុទ្ធនៅក្រៅទឹកដីអ៊ីស្រាអែល និងអេស៊ីព្ទ។ តាមពិត ការពង្រីកកិច្ចការរបស់ខ្ញុំ គឺជាការពង្រីកកិច្ចការនៃការយកឈ្នះរបស់ខ្ញុំ និងការពង្រីកដែនដីបរិសុទ្ធ ជាការពង្រីកកន្លែងដាក់ព្រះបាទារបស់ខ្ញុំនៅលើផែនដីនេះ។ អ្នករាល់គ្នាគប្បីដឹងឲ្យបានច្បាស់ថា អ្នករាល់គ្នាគឺគ្រាន់តែជាសត្តនិករ ដែលត្រូវបានបង្កើតមកក្នុងចំណោមជាតិសាសន៍ដទៃដែលខ្ញុំយកឈ្នះតែប៉ុណ្ណោះ។ ដំបូងឡើយ អ្នកគ្មានឋានៈ និងគ្មានតម្លៃអ្វីសម្រាប់ប្រើជាការឡើយ ហើយគ្មានបានប្រយោជន៍អ្វីទាំងអស់។ នោះគឺដោយសារតែខ្ញុំបានលើកស្ទួយពពួកសត្វដង្កូវនេះចេញពីគំនរលាមក ឲ្យបានក្លាយជាគំរូនៃការយកឈ្នះរបស់ខ្ញុំលើដែនដីទាំងមូល ដើម្បីឲ្យបានក្លាយជា «របស់សម្អាង» តែមួយគត់សម្រាប់ការយកឈ្នះរបស់ខ្ញុំ លើដែនដីទាំងមូលនេះ ដែលអ្នករាល់គ្នាមានសំណាងបានមកជួបនឹងខ្ញុំ និងបានជួបជុំនុំជាមួយខ្ញុំក្នុងពេលនេះ។ នោះគឺដោយសារតែ ឋានៈដ៏តូចទាបរបស់អ្នករាល់គ្នា ដែលខ្ញុំបានជ្រើសរើសអ្នករាល់គ្នា ដើម្បីឲ្យបានក្លាយជាប្រភេទ និងជាគំរូនៃកិច្ចការនៃការយកឈ្នះរបស់ខ្ញុំ។ នោះគឺដោយសារតែមូលហេតុនេះហើយ ទើបបានជាខ្ញុំបំពេញកិច្ចការ និងមានព្រះបន្ទូលក្នុងចំណោមអ្នករាល់គ្នា ហើយខ្ញុំក៏រួមរស់ និងស្នាក់នៅជាមួយអ្នករាល់គ្នានេះ។ អ្នកគប្បីដឹងថា នោះគឺដោយសារតែការគ្រប់គ្រងរបស់ខ្ញុំប៉ុណ្ណោះ ហើយដោយសារការស្អប់ខ្ពើមយ៉ាងក្រៃលែងរបស់ខ្ញុំចំពោះពពួកសត្វដង្កូវនៅក្នុងគំនរលាមកនេះ ដែលខ្ញុំនឹងមានព្រះបន្ទូលក្នុងចំណោមអ្នករាល់គ្នា។ វាបានឈានដល់ចំណុចមួយដែលធ្វើឲ្យខ្ញុំពិរោធយ៉ាងខ្លាំង។ កិច្ចការរបស់ខ្ញុំក្នុងចំណោមអ្នករាល់គ្នា គឺមិនសុទ្ធតែដូចគ្នានឹងកិច្ចការដែលព្រះយេហូវ៉ាបានបំពេញនៅស្រុកអ៊ីស្រាអែលទាំងអស់ឡើយ ហើយជាពិសេស កិច្ចការនេះ មិនដូចគ្នានឹងកិច្ចការដែលព្រះយេស៊ូវបានធ្វើនៅស្រុកយូដាឡើយ។ ខ្ញុំមានព្រះបន្ទូល និងបំពេញកិច្ចការដោយសេចក្ដីអន់ឱនខ្លាំងបំផុត ហើយខ្ញុំយកឈ្នះលើមនុស្សគ្មានគុណធម៌ទាំងអស់នេះ ដោយកំហឹង និងការជំនុំជម្រះ។ វាគ្មានអ្វីដែលដូចទៅនឹងការដែលព្រះយេហូវ៉ាធ្វើការដឹកនាំរាស្ត្ររបស់ទ្រង់នៅអ៊ីស្រាអែលឡើយ។ កិច្ចការរបស់ទ្រង់នៅអ៊ីស្រាអែល គឺដើម្បីប្រទានអាហារ និងទឹក

រស់ ហើយទ្រង់ពោរពេញដោយមេត្តាធម៌ និងសេចក្ដីស្រឡាញ់ចំពោះរាស្ត្ររបស់ទ្រង់ នៅពេលដែលទ្រង់ប្រទានដល់ពួកគេ។ កិច្ចការនាពេលសព្វថ្ងៃនេះ ត្រូវធ្វើឡើងក្នុងចំណោមជាតិសាសន៍ដែលជាប់បណ្ដាសា ដែលមិនមែនជារាស្ត្រដែលត្រូវបានរើសតាំងឡើយ។ គឺមិនមានអាហារច្រើនបរិបូរណ៍ទេ ហើយក៏គ្មានការបំពេញ សេចក្ដីស្រេកឃ្លានដោយទឹករស់ដែរ ហើយកាន់តែគ្មាន ការផ្គត់ផ្គង់ចំណីអាហារដ៏ច្រើនលើសលប់ដែរ។ មានតែការប្រទាននូវការជំនុំជម្រះ បណ្ដាសា និងការវាយផ្ចាលយ៉ាងច្រើនតែប៉ុណ្ណោះ។ ពពួកសត្វដង្កូវដែលកំពុងរស់នៅក្នុងគំនរលាមកទាំងអស់នេះ គឺគ្មានតម្លៃនឹងទទួលបានភ្នំដែលមានពេញទៅដោយគោក្របី និងចៀមរាប់សិបក្បាល ទ្រព្យសម្បត្តិដ៏ច្រើនមហិមា និងកូនចៅដ៏ស្រស់ស្អាតជាងគេបំផុតនៅលើដែនដីទាំងអស់នេះ ដូចដែលខ្ញុំបានប្រទានដល់អ៊ីស្រាអែលឡើយ។ ប្រទេសអ៊ីស្រាអែលនាពេលសព្វថ្ងៃនេះ បូជានូវតង្វាយជាគោក្របីនិងចៀម និងគ្រឿងមាស គ្រឿងប្រាក់នៅលើទីសក្ការៈបូជា ដែលខ្ញុំចិញ្ចឹមបីបាច់រាស្ត្រនៃប្រទេសនេះ ដែលលើសពីតង្វាយមួយភាគដប់ដែលព្រះយេហូវ៉ាតម្រូវឲ្យយកនៅទៅតាមក្រឹត្យវិន័យកំណត់ ដូច្នេះហើយ ទើបខ្ញុំបានប្រទានរបស់ទាំងអស់នោះកាន់តែច្រើន គឺច្រើនជាងរាប់រយដង ដែលពួកអ៊ីស្រាអែល បានទទួលនៅក្រោមក្រឹត្យវិន័យនោះ។ អ្វីដែលខ្ញុំបានផ្គត់ផ្គង់ដល់អ៊ីស្រាអែលច្រើនលើសអ្វីទាំងអស់ដែលអ័ប្រាហាំបានទទួល និងលើសអ្វីទាំងអស់ដែលអ៊ីសាក់បានទទួល។ ខ្ញុំនឹងធ្វើឲ្យគ្រួសារអ៊ីស្រាអែលបានផលផ្លែ និងស្ម័យគុណ ហើយខ្ញុំនឹងធ្វើឲ្យរាស្ត្រអ៊ីស្រាអែលរបស់ខ្ញុំរីកសាយនៅទូទាំងផែនដីនេះ។ អស់អ្នកណាដែលខ្ញុំប្រទានពរ និងយកព្រះទ័យទុកដាក់ គឺនៅតែជារាស្ត្រអ៊ីស្រាអែលដែលបានជ្រើសរើសដដែល ពោលគឺ ជារាស្ត្រដែលបានលះបង់គ្រប់បែបយ៉ាងថ្វាយដល់ខ្ញុំ និងជាអ្នកដែលបានទទួលបានគ្រប់សព្វបែបយ៉ាងពីខ្ញុំ។ នោះគឺដោយសារពួកគេទុកខ្ញុំនៅក្នុងចិត្តរបស់ពួកគេ ទើបពួកគេបូជានូវកូនគោនិងកូនចៀមទើបនឹងកើត នៅទីសក្ការៈដ៏បរិសុទ្ធរបស់ខ្ញុំ និងថ្វាយសព្វគ្រប់យ៉ាងដែលពួកគេមាននៅចំពោះខ្ញុំ សូម្បីតែកូនទើបកើតថ្មីដែលជាកូនដំបូងរបស់ពួកគេ ដោយសង្ឃឹមចាំការយាងត្រឡប់មកវិញ

របស់ខ្ញុំ។ ហើយចុះចំណែកអ្នករាល់គ្នាវិញ? អ្នកដាស់សេចក្តីក្រោធរបស់ខ្ញុំ ទាមទារពីខ្ញុំ និងលួចតង្វាយរបស់គេដែលបានដាក់ថ្វាយដល់ខ្ញុំ ហើយអ្នកមិនដឹងថាអ្នកកំពុងបំពានដល់ខ្ញុំឡើយ។ ហេតុនេះ អ្វីដែលអ្នករាល់គ្នាទទួលបាន គឺការទួញសោក និងការដាក់ទោសនៅក្នុងភាពងងឹត។ អ្នករាល់គ្នាបានធ្វើឲ្យខ្ញុំក្រោធជាច្រើនសា ហើយខ្ញុំបានធ្វើឲ្យភ្លើងកំពុងឆេះធ្លាក់មកជាភ្លៀង រហូតដល់ចំណុចមួយដែលមានមនុស្សតិចតួចណាស់ធ្លាប់ជួបប្រទះនូវទីបញ្ចប់ដ៏សោកសង្រេងបែបនេះ ហើយផ្ទះដែលសុខុមដុមបានក្លាយជាផ្នូរខ្មោចដ៏សែនកណ្តោចកណ្តែង។ គ្រប់យ៉ាងដែលខ្ញុំមានសម្រាប់ពួកដង្កូវទាំងអស់នេះ គឺជាកំហឹងគ្មានទីបញ្ចប់ ហើយខ្ញុំគ្មានបំណងព្រះហឫទ័យនឹងប្រទានពរដល់ពួកគេឡើយ។ នោះគឺដោយសារតែប្រយោជន៍ដល់កិច្ចការរបស់ខ្ញុំប៉ុណ្ណោះ ទើបខ្ញុំបានធ្វើការលើកលែង និងលើកស្ទួយអ្នករាល់គ្នា ហើយបានស៊ូទ្រាំនឹងការអាម៉ាស់យ៉ាងខ្លាំង និងបានធ្វើការក្នុងចំណោមអ្នករាល់គ្នា។ ប្រសិនបើមិនមែនដើម្បីបំណងព្រះហឫទ័យរបស់ព្រះវរបិតាខ្ញុំទេ តើខ្ញុំអាចរស់នៅក្នុងផ្ទះតែមួយជាមួយសត្វដង្កូវដែលវារនៅជុំវិញគំនរលាមកបានដោយរបៀបណា? ខ្ញុំមានព្រះទ័យស្អប់ខ្ពើមជាខ្លាំងចំពោះទង្វើ និងពាក្យសម្តីរបស់អ្នករាល់គ្នា ហើយទោះបីយ៉ាងនេះក្តី ក៏ខ្ញុំមាន «ប្រយោជន៍» ខ្លះៗពីភាពស្មោកគ្រោក និងការបះបោររបស់អ្នកដែរ ហើយវាបានក្លាយជាការប្រមូលផ្តុំព្រះបន្ទូលរបស់ខ្ញុំយ៉ាងច្រើន។ បើពុំដូច្នេះទេ ខ្ញុំប្រាកដជានឹងមិនបន្តរួមរស់នៅក្នុងចំណោមអ្នករាល់គ្នាអស់ពេលជាយូរយ៉ាងនេះឡើយ។ ហេតុនេះ អ្នករាល់គ្នាគប្បីដឹងថាឥរិយាបថរបស់ខ្ញុំចំពោះអ្នករាល់គ្នា គឺគ្រាន់តែជាសេចក្តីករុណា និងការអាណិតអាសូរប៉ុណ្ណោះ។ ខ្ញុំគ្មានសេចក្តីស្រឡាញ់ ចំពោះអ្នកសូម្បីតែមួយដំណក់។ អ្វីដែលខ្ញុំមានសម្រាប់អ្នករាល់គ្នា គឺគ្រាន់តែជាការអត់ឱនប៉ុណ្ណោះ ដ្បិតខ្ញុំធ្វើបែបនេះ ដើម្បីជាប្រយោជន៍ដល់កិច្ចការរបស់ខ្ញុំប៉ុណ្ណោះ។ ហើយអ្នករាល់គ្នាបានឃើញនូវទង្វើរបស់ខ្ញុំ ក៏ដោយសារតែខ្ញុំបានចាត់ទុកភាពស្មោកគ្រោក និងការបះបោរ ជា «វត្ថុធាតុដើម» ប៉ុណ្ណោះ។ បើពុំដូច្នេះទេ ខ្ញុំប្រាកដជានឹងមិនបើកសម្តែងនូវទង្វើរបស់ខ្ញុំដល់ពួកដង្កូវទាំងនេះឡើយ។ ខ្ញុំធ្វើការក្នុងចំណោមអ្នករាល់គ្នាដោយ

ស្នាក់ស្នើរតែប៉ុណ្ណោះ មិនដូចជាខ្ញុំបានត្រៀមព្រះកាយ និងមានបំណងធ្វើវា ដូចកាល ខ្ញុំបានបំពេញកិច្ចការរបស់ខ្ញុំនៅអ៊ីស្រាអែលឡើយ។ ខ្ញុំទប់កំហឹងរបស់ខ្ញុំ ដោយបាន បង្ខំអង្គខ្ញុំឲ្យមានព្រះបន្ទូលក្នុងចំណោមអ្នករាល់គ្នា។ ប្រសិនបើមិនមែនដើម្បីកិច្ចការ ដ៏អស្ចារ្យរបស់ខ្ញុំទេ តើខ្ញុំអាចអត់ទ្រាំនឹងមើលពួកដង្កូវបែបនេះបានដោយរបៀបណា? ប្រសិនបើមិនមែនដើម្បីព្រះនាមរបស់ខ្ញុំទេ ខ្ញុំនឹងឡើងទៅកាន់ទីខ្ពស់ជាយូរណាស់មក ហើយ ហើយនឹងធ្វើឲ្យពួកដង្កូវទាំងអស់នេះចាប់កំណើតជាមួយនឹងគំនរលាមករបស់ ពួកគេជាមិនខាន! ប្រសិនបើមិនមែនដើម្បីសិរីល្អរបស់ខ្ញុំទេ តើខ្ញុំអាចអនុញ្ញាតឲ្យ អារក្សកំណាចប្រឆាំងទាស់នឹងខ្ញុំដោយបើកចំហ ដោយងក់ក្បាលនៅចំពោះព្រះនេត្រ របស់ខ្ញុំបានដោយរបៀបណា? ប្រសិនបើមិនត្រូវបញ្ចប់កិច្ចការរបស់ខ្ញុំឲ្យបានរលូន ដោយគ្មានការរំខានសូម្បីបន្តិចទេនោះ តើខ្ញុំអាចអនុញ្ញាតឲ្យពួកមនុស្សដូចសត្វដង្កូវ ទាំងអស់នេះធ្វើបាបខ្ញុំដោយគ្មានត្រាប្រណីយ៉ាងដូចម្ដេចបាន? ប្រសិនបើមនុស្សមួយ រយនាក់ នៅក្នុងភូមិមួយនៃស្រុកអ៊ីស្រាអែល ក្រោកឈរប្រឆាំងទាស់នឹងខ្ញុំដូច្នេះ សូម្បីតែពួកគេបានលះបង់ថ្វាយដល់ខ្ញុំក្ដី ក៏ខ្ញុំនឹងនៅតែធ្វើឲ្យពួកគេវិនាសសាបសូន្យ និងទម្លាក់ពួកគេ ចូលទៅក្នុងក្រហែងដី ដើម្បីកុំឲ្យរាស្ត្រនៅក្នុងទីក្រុងផ្សេងទៀត បះបោរជាថ្មីឡើយ។ ខ្ញុំគឺជាព្រះដែលសោយភ្លើង ហើយខ្ញុំនឹងមិនអត់ឱនចំពោះកំហុស ណាមួយឡើយ។ ដោយសារខ្ញុំជាអ្នកបង្កើតមនុស្សទាំងអស់នេះមក ដូច្នេះ អ្វីក៏ដោយ ដែលខ្ញុំមានព្រះបន្ទូលនិងធ្វើ ពួកគេត្រូវតែស្ដាប់តាម ហើយពួកគេមិនអាចបះបោរបាន ឡើយ។ មនុស្សគ្មានសិទ្ធិជ្រៀតជ្រែកក្នុងកិច្ចការរបស់ខ្ញុំឡើយ ហើយពួកគេកាន់តែ គ្មានគុណសម្បត្តិក្នុងការវិភាគថាកិច្ចការរបស់ខ្ញុំ និងព្រះបន្ទូលរបស់ខ្ញុំ មួយណាត្រូវ ឬមួយណាខុសណាស់។ ខ្ញុំគឺជាព្រះអម្ចាស់ដែលបង្កើតសព្វសារពើ ហើយសត្តនិករ ដែលបានបង្កើតមក គប្បីសម្រេចនូវគ្រប់យ៉ាងដែលខ្ញុំតម្រូវចង់បាន ដោយមានដួងចិត្ត កោតខ្លាចចំពោះខ្ញុំ។ ពួកគេមិនគប្បីព្យាយាមដេញដោលរកហេតុផលជាមួយខ្ញុំឡើយ ហើយជាពិសេស ពួកគេមិនគួរប្រឆាំងទាស់នឹងខ្ញុំឡើយ។ ខ្ញុំគ្រប់គ្រងលើរាស្ត្ររបស់ខ្ញុំ ដោយសិទ្ធិអំណាចរបស់ខ្ញុំ ហើយអស់អ្នកណាដែលជាចំណែកនៃការបង្កើតរបស់ខ្ញុំ

គប្បីចុះចូលនឹងសិទ្ធិអំណាចរបស់ខ្ញុំ។ បើទោះបីជាសព្វថ្ងៃនេះ អ្នករាល់គ្នាអង់អាចក្លាហាន និងមិនកោតក្រែងចំពោះខ្ញុំក្ដី បើទោះបីជាអ្នកមិនស្ដាប់បង្គាប់តាមព្រះបន្ទូលដែលខ្ញុំបង្រៀនដល់អ្នករាល់គ្នាក្ដី និងគ្មានការភ័យខ្លាចក្ដី ក៏ខ្ញុំមានត្រឹមតែការអត់ឱនចំពោះការបះបោររបស់អ្នកប៉ុណ្ណោះ។ ខ្ញុំនឹងមិនភ្លាត់ចេញនូវសេចក្ដីក្រោធ និងប៉ះពាល់ដល់កិច្ចការរបស់ខ្ញុំ ដោយសារតែពួកដង្កូវតូចតាច និងគ្មានបានការដែលបានកកូរកកាយដីនៅក្នុងគំនរលាមកឡើយ។ ខ្ញុំអត់ឱនចំពោះការបន្ដជីវិតរស់នៅនៃគ្រប់យ៉ាងដែលខ្ញុំស្អប់ និងគ្រប់សព្វសារពើដែលខ្ញុំមិនចូលចិត្ត ក៏ព្រោះតែបំណងព្រះហឫទ័យនៃព្រះវរបិតារបស់ខ្ញុំដែរ ហើយខ្ញុំនឹងធ្វើបែបនេះឡើយ រហូតទាល់តែព្រះសូរសៀងរបស់ខ្ញុំបានសម្រេចការ រហូតដល់ពេលវេលាចុងក្រោយបំផុតរបស់ខ្ញុំ។ ចូរកុំបារម្ភអី! ខ្ញុំមិនអាចលិចចុះទៅដល់កម្រិតដែលដូចគ្នានឹងសត្វដង្កូវដែលគ្មានឈ្មោះឡើយ ហើយខ្ញុំនឹងមិនប្រៀបធៀបកម្រិតជំនាញរបស់ខ្ញុំជាមួយអ្នកឡើយ។ ខ្ញុំស្អប់អ្នក ប៉ុន្ដែខ្ញុំអាចអត់ទ្រាំបាន។ អ្នកមិនស្ដាប់បង្គាប់ខ្ញុំ ប៉ុន្ដែអ្នកមិនអាចគេចផុតពីថ្ងៃដែលខ្ញុំនឹងវាយផ្ចាលអ្នកឡើយ ដែលព្រះវរបិតាបានសន្យានឹងខ្ញុំ។ តើសត្វដង្កូវដែលបានបង្កើតមកនេះ អាចប្រៀបធៀបនឹងព្រះអម្ចាស់ ដែលបង្កើតសព្វសារពើបានដែរឬទេ? នៅសរទរដូវស្លឹកឈើជ្រុះធ្លាក់ទៅគល់វិញ នោះអ្នកនឹងត្រឡប់ទៅផ្ទះរបស់ «ឪពុក» អ្នកវិញ ហើយខ្ញុំនឹងត្រឡប់ទៅខាងឯព្រះវរបិតារបស់ខ្ញុំវិញ។ នោះខ្ញុំនឹងបានហ៊ុំព័ទ្ធដោយសេចក្ដីស្រឡាញ់ដ៏កក់ក្ដៅពីទ្រង់ ហើយអ្នកនឹងទទួលបាននូវការជាន់ឈ្លីពីឪពុករបស់អ្នក។ ខ្ញុំនឹងមាននូវសិរីល្អរបស់ព្រះវរបិតារបស់ខ្ញុំ ហើយអ្នកនឹងមាននូវភាពអាម៉ាស់របស់ឪពុកអ្នក។ ខ្ញុំនឹងប្រើការវាយផ្ចាលដែលខ្ញុំបានទ្រាំទុកជាយូរមកហើយ ដើម្បីអមដំណើរអ្នក ហើយអ្នកនឹងជួបនូវការវាយផ្ចាលរបស់ខ្ញុំដោយមានក្លិនខារពីខាងសាច់ឈាមដែលត្រូវធ្វើឲ្យពុករលួយអស់រាប់សិបពាន់ឆ្នាំមកហើយ។ ជាមួយនឹងការអត់ឱន ខ្ញុំនឹងបានបញ្ចប់កិច្ចការនៃព្រះបន្ទូលរបស់ខ្ញុំចំពោះអ្នក ហើយអ្នកនឹងចាប់ផ្ដើមបំពេញតួនាទីដោយត្រូវទទួលរងគ្រោះមហន្ដរាយដ៏វេទនាពីព្រះបន្ទូលរបស់ខ្ញុំ។ ខ្ញុំនឹងអរសប្បាយយ៉ាងខ្លាំង និងបំពេញកិច្ចការនៅអ៊ីស្រាអែល។ អ្នកនឹងទួញសោក និងសង្កៀតធ្មេញរបស់អ្នក

ដោយចាប់កំណើត ហើយស្លាប់ទៅវិញនៅក្នុងភក់ជ្រាំ។ ខ្ញុំនឹងយកនូវលក្ខណៈដើមរបស់ខ្ញុំត្រឡប់មកវិញ ហើយនឹងលែងគង់នៅក្នុងភាពស្មោកគ្រោកជាមួយអ្នកទៀតហើយ ចំណែកអ្នកវិញ នឹងទទួលបាននូវសារធាតុអាក្រក់ដែលជាសារជាតិដើមរបស់អ្នកវិញ និងបន្តត្បុលនៅជុំវិញគំនរលាមកនោះ។ នៅពេលកិច្ចការនិងព្រះបន្ទូលរបស់ខ្ញុំបានចប់សព្វគ្រប់ហើយ នោះថ្ងៃនៃអំណរសប្បាយសម្រាប់ខ្ញុំ នឹងចូលមកដល់។ នៅពេលដែលការប្រឆាំងទាស់ និងការបះបោរបានបញ្ចប់ នោះថ្ងៃនៃការទួញសោកសម្រាប់អ្នក នឹងចូលមកដល់។ ខ្ញុំនឹងមិនអាណិតអាសូរដល់អ្នកឡើយ ហើយអ្នកនឹងមិនដែលឃើញខ្ញុំម្ដងទៀតឡើយ។ ខ្ញុំនឹងលែងបានសន្ទនាជាមួយអ្នកទៀត ហើយអ្នកនឹងមិនដែលជួបខ្ញុំម្ដងទៀតឡើយ។ ខ្ញុំនឹងស្អប់ការបះបោររបស់អ្នក ហើយអ្នកនឹងនឹកដល់ភាពគួរឲ្យស្រឡាញ់របស់ខ្ញុំ។ ខ្ញុំនឹងវាយបំបាក់អ្នក ហើយអ្នកនឹងប្រាថ្នាចង់បានខ្ញុំ។ ខ្ញុំនឹងយាងចេញពីអ្នកដោយរីករាយ ហើយអ្នកនឹងដឹងអំពីបំណុលដែលអ្នកជំពាក់ខ្ញុំ។ ខ្ញុំនឹងមិនទតឃើញអ្នកម្ដងទៀតឡើយ ប៉ុន្តែអ្នកនឹងតែងតែសង្ឃឹមចង់ជួបខ្ញុំជានិច្ច។ ខ្ញុំនឹងស្អប់អ្នក ដ្បិតបច្ចុប្បន្ននេះ អ្នកប្រឆាំងទាស់នឹងខ្ញុំ ហើយអ្នកនឹងនឹកដល់ខ្ញុំ ដ្បិតបច្ចុប្បន្ននេះ ខ្ញុំវាយផ្ចាលអ្នក។ ខ្ញុំនឹងមិនអាចរួមរស់ជាមួយអ្នកបានទៀតឡើយ ប៉ុន្តែអ្នកនឹងទន្ទឹងរង់ចាំដោយជូរចត់ ដើម្បីបានរស់នៅជាមួយខ្ញុំ និងទួញសោកអស់កល្បជានិច្ច ដ្បិតអ្នកនឹងសោកស្ដាយ ចំពោះគ្រប់យ៉ាងដែលអ្នកបានធ្វើដាក់ខ្ញុំ។ អ្នកនឹងមានអារម្មណ៍ស្ដាយ ក្រោយចំពោះការបះបោរ និងការប្រឆាំងទាស់របស់អ្នក អ្នកនឹងទម្លាក់មុខចុះទៅដីដោយក្ដីសោកស្ដាយ និងដួលចុះនៅចំពោះខ្ញុំ ហើយស្បថថានឹងមិនដែលឈប់ស្ដាប់បង្គាប់ខ្ញុំទៀតឡើយ។ ក៏ប៉ុន្តែ នៅក្នុងដួងចិត្តរបស់អ្នក អ្នកបានត្រឹមតែស្រឡាញ់ខ្ញុំប៉ុណ្ណោះ ប៉ុន្តែអ្នកនឹងមិនអាចស្ដាប់ឮព្រះសូរសៀងរបស់ខ្ញុំឡើយ។ ខ្ញុំនឹងធ្វើឲ្យអ្នកខ្មាសអៀនចំពោះខ្លួនឯង។

ពេលនេះ ខ្ញុំកំពុងទតមើលសាច់ឈាមដែលមិនមាំទាំរបស់អ្នក ដែលនឹងលួងលោមដល់ខ្ញុំ ហើយខ្ញុំគ្រាន់តែមានការព្រមានតិចតួចដល់អ្នកប៉ុណ្ណោះ បើទោះបីជាខ្ញុំនឹងមិន «ប្រទានទោស» ដល់អ្នកដោយការវាយផ្ចាលក្ដី។ អ្នកគប្បីដឹងថា អ្នកគួរបំពេញតួនាទី

អ្វីនៅក្នុងកិច្ចការរបស់ខ្ញុំ នោះខ្ញុំនឹងបានសព្វព្រះហឫទ័យហើយ។ ចំពោះបញ្ហាផ្សេងពីនេះ ប្រសិនបើអ្នកប្រឆាំងទាស់នឹងខ្ញុំ ឬចាយប្រាក់របស់ខ្ញុំ ឬស៊ីតង្វាយដែលគេថ្វាយដល់ខ្ញុំដែលជាព្រះយេហូវ៉ា ឬប្រសិនបើអ្នករាល់គ្នា ជាសត្វដង្កូវដែលខាំគ្នាទៅវិញទៅមក ឬប្រសិនបើអ្នកជាសត្តនិករដែលដូចនឹងសត្វឆ្កែ មានជម្លោះ ឬបំពានគ្នាទៅវិញទៅមក នោះខ្ញុំនឹងមិនខ្វាយខ្វល់ចំពោះរឿងនេះសោះឡើយ។ អ្នករាល់គ្នាត្រូវដឹងថា អ្នកជាប្រភេទសត្តនិករណា នោះខ្ញុំនឹងបានសព្វព្រះហឫទ័យហើយ។ ក្រៅពីរឿងទាំងអស់នេះ ប្រសិនបើអ្នករាល់គ្នាចង់ដកគ្រឿងសាស្ត្រាវុធដាក់គ្នា ឬវាយច្បាំងគ្នាដោយពាក្យសម្ដី នោះក៏តាមចិត្តចុះ។ ខ្ញុំគ្មានបំណងនឹងជ្រៀតជ្រែកក្នុងរឿងទាំងអស់នេះទេ ហើយខ្ញុំមិនពាក់ព័ន្ធសូម្បីតែបន្តិច នៅក្នុងបញ្ហារបស់មនុស្ស។ នោះមិនមែនដោយសារខ្ញុំមិនយកព្រះទ័យទុកដាក់ចំពោះទំនាស់រវាងអ្នករាល់គ្នានោះទេ។ នោះគឺដោយសារខ្ញុំមិនមែនជាមនុស្សម្នាក់ក្នុងចំណោមអ្នករាល់គ្នាឡើយ ហើយហេតុនេះ ខ្ញុំមិនត្រូវចូលពាក់ព័ន្ធក្នុងបញ្ហារបស់អ្នករាល់គ្នាឡើយ។ ខ្ញុំផ្ទាល់ព្រះអង្គឯងនេះ មិនមែនជាសត្តនិករដែលបានបង្កើតមកទេ ហើយខ្ញុំក៏មិនមែនជាពិភពលោកដែរ ដូចនេះ ខ្ញុំស្អប់ជីវិតមនុស្សដែលរវល់ខ្លាំង និងរញ៉េរញ៉ៃ និងមានទំនាក់ទំនងមិនត្រឹមត្រូវ។ ជាពិសេស ខ្ញុំស្អប់ហ្វូងមនុស្សដែលស្រែកឡូឡាតែរ។ ក៏ប៉ុន្តែខ្ញុំបានជ្រាបដឹងយ៉ាងជ្រៅអំពីភាពមិនបរិសុទ្ធនៅក្នុងដួងចិត្តរបស់សត្តនិករនីមួយៗដែលបានបង្កើតមកនេះ ហើយនៅមុនពេលខ្ញុំបានបង្កើតអ្នករាល់គ្នាមក ខ្ញុំបានដឹងរួចជាស្រេចហើយនូវសេចក្ដីទុច្ចរិតដែលមានយ៉ាងជ្រៅនៅខាងក្នុងដួងចិត្តរបស់មនុស្ស ហើយខ្ញុំបានជ្រាបយ៉ាងច្បាស់នូវរាល់ការបោកបញ្ឆោត និងសេចក្ដីវៀចវេរនៅក្នុងដួងចិត្តមនុស្ស។ ហេតុនេះ បើទោះបីជាគ្មានដានអ្វីទាល់តែសោះ នៅពេលមនុស្សប្រព្រឹត្តអំពើទុច្ចរិត ក៏ខ្ញុំនៅតែជ្រាបថា សេចក្ដីទុច្ចរិតដែលមាននៅក្នុងដួងចិត្តរបស់អ្នករាល់គ្នា មានច្រើនលើសពីរបស់សព្វសារពើទាំងអស់ដែលខ្ញុំបានបង្កើតមក។ មនុស្សគ្រប់គ្នាក្នុងចំណោមអ្នករាល់គ្នា បានត្រដែតឡើងទៅដល់កំពូលនៃហ្វូងមនុស្ស។ អ្នកបានឡើងទៅជាបុព្វបុរសនៃពួកមហាជន។ អ្នករាល់គ្នាពិតជាធ្វើតាមតែ

អំពើចិត្តខ្លាំងណាស់ ហើយអ្នកជ្រួលច្របល់ក្នុងចំណោមពពួកសត្វដង្កូវទាំងអស់នោះ ដោយស្វែងរកកន្លែងសុខស្រួល និងព្យាយាមលេបត្របាក់ពពួកដង្កូវដែលតូចជាងខ្លួនអ្នក។ នៅក្នុងដួចចិត្តអ្នក អ្នកសាហាវឃោរឃៅ និងអាក្រក់ជាងខ្មោចដែលបានលិចដល់បាតសមុទ្រទៅទៀត។ អ្នករស់នៅក្រោមបាតគំនរលាមក ដោយរុកគួនពួកដង្កូវតាំងពីកំពូលទៅបាតក្រោម រហូតដល់ពួកវាគ្មានសេចក្តីស្ងប់សុខ ដោយតយុទ្ធនឹងគ្នាទៅវិញទៅមកអស់មួយរយៈ រួចក៏ស្ងប់ទៅវិញ។ អ្នកមិនស្គាល់កន្លែងរបស់អ្នកឡើយ ប៉ុន្តែអ្នកនៅតែច្បាំងជាមួយគ្នាទៅវិញទៅមក នៅក្នុងគំនរលាមកនោះដដែល។ តើអ្នកអាចទទួលបានអ្វីខ្លះពីការខំពុះពារនេះ? ប្រសិនបើនៅក្នុងដួងចិត្តរបស់អ្នករាល់គ្នាពិតជាមានការកោតខ្លាចចំពោះខ្ញុំមែន តើអ្នកអាចច្បាំងជាមួយគ្នាទៅវិញទៅមកនៅពីក្រោយខ្នងរបស់ខ្ញុំបានដោយរបៀបណា? មិនថាអ្នកមានឋានៈខ្ពស់យ៉ាងណានោះទេ តើអ្នកមិនមែននៅតែជាកូនដង្កូវស្អុយគគ្រក់នៅក្នុងគំនរលាមកទេឬអី? តើអ្នកនឹងអាចដុះស្លាប និងក្លាយជាសត្វព្រាបនៅលើមេឃបានដែរឬទេ? អ្នករាល់គ្នាជាកូនដង្កូវដែលស្អុយគគ្រក់ ដែលលួចតង្វាយពីទីសក្ការៈរបស់ខ្ញុំ ដែលជាព្រះយេហូវ៉ា។ ក្នុងការធ្វើបែបនេះ តើអ្នកអាចរំដោះកេរ្តិ៍ឈ្មោះដែលស្អុយរលួយ និងខូចបង់ ហើយក្លាយជារាស្ត្ររើសតាំងនៃស្រុកអ៊ីស្រាអែលបានដែរឬទេ? អ្នកគឺជាមនុស្សទុច្ចរិតដែលគ្មានការអៀនខ្មាសទាល់តែសោះ! តង្វាយទាំងអស់នៅលើទីសក្ការៈ គឺមនុស្សដាក់ថ្វាយដល់ខ្ញុំ ជាការសម្តែងនូវអារម្មណ៍មេត្តាធម៌របស់អស់អ្នកដែលគោរពកោតខ្លាចខ្ញុំ។ តង្វាយទាំងនោះ គឺសម្រាប់ការគ្រប់គ្រងរបស់ខ្ញុំ និងសម្រាប់ការប្រើប្រាស់របស់ខ្ញុំ ហេតុនេះ តើអ្នកអាចប្លន់យកពីខ្ញុំនូវកូនលលកដែលមនុស្សបានថ្វាយដល់ខ្ញុំនោះដោយរបៀបណា? តើអ្នកមិនខ្លាចថានឹងត្រូវក្លាយជាយូដាសទេឬអី? តើអ្នកមិនខ្លាចថា ដែនដីរបស់អ្នកនឹងក្លាយជាវាលឈាមទេឬអី? អ្នកគឺមិនចេះអៀនខ្មាសទាល់តែសោះ! តើអ្នកគិតថាសត្វដែលមនុស្សបានដាក់ជាតង្វាយ គឺដើម្បីចម្អែតពោះជាសត្វដង្កូវរបស់អ្នកនេះមែនទេ? អ្វីដែលខ្ញុំបានប្រទានដល់អ្នក គឺជាអ្វីដែលខ្ញុំពេញចិត្ត និងសព្វព្រះទ័យនឹងប្រទានដល់អ្នក។ អ្វីដែលខ្ញុំបានប្រទានដល់អ្នកគឺជាអ្វីដែលខ្ញុំមានគ្រប់គ្រាន់។ អ្នកមិនចាំបាច់អីត្រូវ

លួចតង្វាយរបស់ខ្ញុំនោះទេ។ អ្នកដែលធ្វើកិច្ចការ គឺជាអង្គខ្ញុំដែលជាព្រះយេហូវ៉ា ដែលជាព្រះអម្ចាស់ដែលបង្កើតរបស់សព្វសារពើ ហើយមនុស្សដាក់តង្វាយក៏ដង្វិតអង្គខ្ញុំនេះដែរ។ តើអ្នកគិតថា នេះគឺជាការតបស្នងចំពោះការរវល់ដែលអ្នកធ្វើមែនទេ? អ្នកពិតជាឥតអៀនខ្មាសមែន! តើអ្នករវល់ដោយសារនរណា? តើមិនមែនដោយសារខ្លួនឯងទេឬអី? តើហេតុអ្វីបានជាអ្នកលួចតង្វាយរបស់ខ្ញុំ? តើហេតុអ្វីបានជាអ្នកលួចប្រាក់ពីថង់ប្រាក់របស់ខ្ញុំ? តើអ្នកមិនមែនជាកូនរបស់យូដាសអ៊ីស្ការីយ៉ុតទេឬអី? តង្វាយថ្វាយដល់ខ្ញុំ ដែលជាព្រះយេហូវ៉ា គឺដើម្បីដល់ពួកសង្ឃបានអាស្រ័យ។ តើអ្នកជាពួកសង្ឃមែនទេ? អ្នកហ៊ានលួចលាក់ស៊ីតង្វាយរបស់ខ្ញុំ ហើយហ៊ានសូម្បីដាក់ក្រាលតង្វាយនៅលើតុថែមទៀត។ អ្នកគ្មានតម្លៃអ្វីទាល់តែសោះ! អ្នកជាមនុស្សទុច្ចរិតដែលគ្មានតម្លៃទាល់តែសោះ! ភ្លើងរបស់ខ្ញុំ ដែលជាភ្លើងរបស់ព្រះយេហូវ៉ា នឹងដុតកម្ទេចអ្នក!

# គ្មាននរណាម្នាក់ដែលមានសាច់ឈាម<br>អាចគេចផុតពីថ្ងៃនៃសេចក្តីក្រោធបានឡើយ

ថ្ងៃនេះ ខ្ញុំសូមដាស់តឿនអ្នករាល់គ្នា សម្រាប់ជាប្រយោជន៍ដល់ការរស់រានផ្ទាល់របស់អ្នករាល់គ្នា និងដើម្បីឲ្យកិច្ចការរបស់ខ្ញុំរីកចម្រើនទៅដោយរលូន និងដើម្បីឲ្យកិច្ចការដំបូងរបស់ខ្ញុំនៅក្នុងសាកលលោកទាំងមូល អាចត្រូវបានអនុវត្តត្រឹមត្រូវ និងឥតខ្ចោះ ដោយបើកសម្តែងពីព្រះបន្ទូល សិទ្ធិអំណាច ឫទ្ធានុភាព និងការជំនុំជម្រះរបស់ខ្ញុំ ចំពោះមនុស្សនៅគ្រប់ប្រទេស និងគ្រប់ជាតិសាសន៍ទាំងអស់។ កិច្ចការដែលខ្ញុំធ្វើក្នុងចំណោមអ្នករាល់គ្នា គឺជាការចាប់ផ្តើមនៃកិច្ចការរបស់ខ្ញុំនៅក្នុងសាកលលោកទាំងមូល។ ទោះបីជាឥលូវនេះ ដល់ពេលវេលានៃគ្រាចុងក្រោយហើយក៏ដោយ ចូរចាំថា «គ្រាចុងក្រោយ» គឺត្រឹមជាឈ្មោះសម្រាប់យុគសម័យមួយដូចជាយុគសម័យនៃក្រឹត្យវិន័យ និងយុគសម័យនៃព្រះគុណដែរ ហើយវាបង្ហាញពីយុគសម័យទាំងមូល មិនមែនត្រឹមតែពីរបីឆ្នាំ ឬក៏ពីរបីខែចុងក្រោយនោះទេ។ ប៉ុន្តែ

គ្រាចុងក្រោយមិនមានលក្ខណៈដូចគ្នានឹងយុគសម័យនៃព្រះគុណ និងយុគសម័យនៃក្រឹត្យវិន័យទេ។ កិច្ចការនៃគ្រាចុងក្រោយ មិនមែនត្រូវអនុវត្តនៅក្នុងប្រទេសអ៊ីស្រាអែលទេ ប៉ុន្តែនៅក្នុងចំណោមសាសន៍ដទៃវិញ ហើយវាគឺជាជ័យជម្នះរបស់មនុស្សពីគ្រប់ជាតិសាសន៍ និងពីគ្រប់ពូជអំបូរទាំងអស់ដែលនៅក្រៅអ៊ីស្រាអែល នៅចំពោះបល្ល័ង្ករបស់ខ្ញុំ ប្រយោជន៍ឲ្យសិរីល្អរបស់ខ្ញុំនៅលើសាកលលោកទាំងមូលអាចបំពេញចក្រវាឡ និងលំហអាកាសបាន។ យ៉ាងនោះទើបខ្ញុំអាចទទួលបានសិរីល្អកាន់តែច្រើន ប្រយោជន៍ឲ្យជីវិតទាំងអស់នៅលើផែនដី អាចបញ្ជូនសិរីល្អរបស់ខ្ញុំទៅកាន់ជាតិសាសន៍ទាំងអស់ និងទៅដល់មនុស្សគ្រប់ជំនាន់ជារៀងរហូត ហើយឲ្យជីវិតទាំងអស់នៅលើស្ថានសួគ៌ និងនៅលើផែនដី អាចមើលឃើញសិរីល្អដែលខ្ញុំបានទទួលនៅលើផែនដី។ កិច្ចការដែលបានអនុវត្តនៅគ្រាចុងក្រោយ គឺជាកិច្ចការនៃការយកឈ្នះ។ វាមិនមែនជាការណែនាំ ពីជីវិតមនុស្សទាំងអស់នៅលើផែនដីទេ ប៉ុន្តែជាការបញ្ចប់នៃជីវិតដែលរងវេទនាគ្មានទីបញ្ចប់ និងរាប់ពាន់ឆ្នាំនៅលើផែនដី។ ជាលទ្ធផល កិច្ចការនៃគ្រាចុងក្រោយ មិនអាចមានលក្ខណៈដូចជាកិច្ចការរាប់ពាន់ឆ្នាំនៅក្នុងប្រទេសអ៊ីស្រាអែលទេ ហើយក៏មិនអាចមានលក្ខណៈដូចជាកិច្ចការត្រឹមតែប៉ុន្មានឆ្នាំនៅក្នុងស្រុកយូដា ដែលបានបន្តអស់រយៈពេលពីរពាន់ឆ្នាំ រហូតដល់ការមកយកនិស្ស័យជាមនុស្សជាលើកទីពីរ របស់ព្រះជាម្ចាស់នោះដែរ។ មនុស្សនៃគ្រាចុងក្រោយ ជួបប្រទះតែនឹងការលេចមកជាសាច់ឈាមម្ដងទៀតនៃព្រះដ៏ប្រោសលោះប៉ុណ្ណោះ ហើយពួកគេទទួលកិច្ចការ និងព្រះបន្ទូលផ្ទាល់ខ្លួនរបស់ព្រះជាម្ចាស់។ វានឹងមិនដល់ពីរពាន់ឆ្នាំនោះទេ មុនពេលដែលគ្រាចុងក្រោយឈានដល់ទីបញ្ចប់ ព្រោះវាជារយៈពេលមួយខ្លី ដូចកាលដែលព្រះយេស៊ូវបានអនុវត្តកិច្ចការរបស់ទ្រង់នៅយុគសម័យនៃព្រះគុណ ក្នុងស្រុកយូដាដែរ។ នេះគឺដោយសារតែគ្រាចុងក្រោយគឺជាការបញ្ចប់នៃយុគសម័យទាំងមូល។ វាជាការបង្ហើយ និងជាទីបញ្ចប់នៃផែនការគ្រប់គ្រងរបស់ព្រះជាម្ចាស់រយៈពេលប្រាំមួយពាន់ឆ្នាំ ហើយវាក៏បញ្ចប់ដំណើររងទុក្ខនៃជីវិតមនុស្សជាតិដែរ។ វាមិនយកមនុស្សជាតិទាំងអស់ចូលទៅក្នុងយុគសម័យថ្មី

ឬក៏អនុញ្ញាតឲ្យជីវិតរបស់មនុស្សជាតិបន្តទៅទៀតដែរ ព្រោះវាគ្មានសារៈសំខាន់អ្វីសម្រាប់ផែនការគ្រប់គ្រងរបស់ខ្ញុំ ឬក៏សម្រាប់អត្ថិភាពរបស់មនុស្សទេ។ ប្រសិនបើមនុស្សជាតិបន្តធ្វើបែបនេះទៀត នោះមិនយូរមិនឆាប់ ពួកគេនឹងត្រូវបំផ្លាញដោយអារក្ស ហើយព្រលឹងទាំងអស់ដែលជាកម្មសិទ្ធិរបស់ខ្ញុំនឹងត្រូវបំផ្លាញដោយដៃរបស់វាជាមិនខាន។ កិច្ចការរបស់ខ្ញុំមានរយៈពេលប្រាំមួយពាន់ឆ្នាំប៉ុណ្ណោះ ហើយខ្ញុំបានសន្យាថាការគ្រប់គ្រងរបស់អារក្សលើមនុស្សជាតិទាំងមូល ក៏ស្ថិតនៅមិនលើសពីប្រាំមួយពាន់ឆ្នាំដែរ។ ដូច្នេះ ឥលូវនេះដល់ពេលហើយ។ ខ្ញុំនឹងមិនបន្ត ហើយក៏មិនពន្យារពេលតទៅទៀតដែរ៖ ក្នុងអំឡុងពេលគ្រាចុងក្រោយ ខ្ញុំនឹងធ្វើឲ្យសាតាំងវិនាស ខ្ញុំនឹងយកសិរីល្អទាំងអស់របស់ខ្ញុំត្រលប់មកវិញ ហើយខ្ញុំនឹងទាមទារព្រលឹងទាំងអស់ដែលជាកម្មសិទ្ធិរបស់ខ្ញុំនៅលើផែនដីត្រលប់មកវិញ ដើម្បីឲ្យព្រលឹងដែលរងទុក្ខព្រួយទាំងអស់នេះអាចគេចផុតពីសមុទ្រទុក្ខ ដើម្បីឱ្យកិច្ចការទាំងមូលរបស់ខ្ញុំនៅលើផែនដីនឹងត្រូវបញ្ចប់។ ចាប់ពីថ្ងៃនេះតទៅ ខ្ញុំនឹងមិនត្រលប់មកជាសាច់ឈាមនៅលើផែនម្ដងទៀតឡើយ ហើយវិញ្ញាណគ្រប់គ្រងទាំងអស់របស់ខ្ញុំក៏នឹងមិនធ្វើកិច្ចការនៅលើផែនដីម្ដងទៀតដែរ។ ខ្ញុំនឹងមិនធ្វើកិច្ចការអ្វីទៀតឡើយនៅលើផែនដីនេះ ក្រៅតែពីកិច្ចការម៉្យាងគឺ៖ ខ្ញុំនឹងបង្កើតមនុស្សជាតិជាថ្មី ជាមនុស្សជាតិដែលបរិសុទ្ធ និងជាទីក្រុងដ៏ស្មោះត្រង់របស់ខ្ញុំនៅលើផែនដី។ ប៉ុន្តែចូរដឹងថា ខ្ញុំនឹងមិនបំផ្លាញពិភពលោកទាំងមូលឡើយ ហើយខ្ញុំក៏នឹងមិនបំផ្លាញមនុស្សជាតិទាំងមូលដែរ។ ខ្ញុំនឹងរក្សាទុកមនុស្សមួយភាគបី ជាមនុស្សដែលស្រលាញ់ខ្ញុំ និងជាមនុស្សដែលខ្ញុំបានយកឈ្នះដោយហ្មត់ចត់ ហើយខ្ញុំនឹងធ្វើឲ្យមនុស្សមួយភាគបីនេះបង្កើតផលផ្លែ និងចម្រើនកូនចៅឡើងនៅលើផែនដី ដូចជាជនជាតិអ៊ីស្រាអែលបានធ្វើក្រោមក្រឹត្យវិន័យដែរ ដោយប្រទានឲ្យពួកគេមានហ្វូងចៀម គោក្របីជាច្រើន និងទ្រព្យសម្បត្តិទាំងអស់នៅលើផែនដី។ មនុស្សជាតិនេះនឹងនៅជាប់ជាមួយខ្ញុំជារៀងរហូត ប៉ុន្តែមិនមែនជាមនុស្សជាតិដែលកខ្វក់គួរឲ្យស្អប់ខ្ពើមនាពេលសព្វថ្ងៃនេះទេ តែជាមនុស្សជាតិមួយក្រុមដែលខ្ញុំបានទទួលមក។ មនុស្សជាតិប្រភេទនេះនឹងមិនត្រូវបំផ្លាញ រំខាន ឬក៏

ឡើងវិញទាំងស្រុងដោយសាតាំងឡើយ ហើយពួកគេគឺជាមនុស្សជាតិតែមួយក្រុមគត់ដែលរស់នៅលើផែនដីក្រោយពេលដែលខ្ញុំយកជ័យជម្នះលើសាតាំង។ នេះគឺជាមនុស្សជាតិមួយក្រុម ដែលខ្ញុំបានយកឈ្នះនៅថ្ងៃនេះ និងបានទទួលសេចក្ដីសន្យារបស់ខ្ញុំ។ ដូច្នេះហើយ មនុស្សជាតិដែលត្រូវបានយកឈ្នះក្នុងអំឡុងពេលគ្រាចុងក្រោយ ក៏ជាមនុស្សជាតិដែលនឹងនៅរស់រានមានជីវិត និងទទួលព្រះពរដ៏នៅអស់កល្បជានិច្ចរបស់ខ្ញុំដែរ។ វានឹងក្លាយជាភស្ដុតាងតែមួយគត់អំពីជ័យជម្នះរបស់ខ្ញុំលើសាតាំង និងជាជ័យភណ្ឌតែមួយគត់នៃចម្បាំងរបស់ខ្ញុំជាមួយសាតាំង។ ខ្ញុំបានសង្គ្រោះជ័យភណ្ឌទាំងនេះចេញពីការគ្រប់គ្រងរបស់សាតាំង ហើយពួកគេជាការបង្ហាញយ៉ាងច្បាស់ និងជាផលផ្លែតែមួយនៃផែនការគ្រប់គ្រងរយៈពេលប្រាំមួយពាន់ឆ្នាំរបស់ខ្ញុំ។ ពួកគេមកពីគ្រប់ជាតិសាសន៍ និងគ្រប់និកាយ ពីគ្រប់ទីកន្លែង និងគ្រប់ប្រទេសទាំងអស់នៅលើសាកលលោក។ ពួកគេមកពីពូជអំបូរផ្សេងគ្នា មានភាសា ទំនៀមទម្លាប់ និងពណ៌សម្បុរផ្សេងគ្នា ហើយពួកគេបែកខ្ញែកទៅគ្រប់ប្រជាជាតិ និងគ្រប់និកាយទាំងអស់នៅលើសាកលលោក ព្រមទាំងគ្រប់ផ្នែកទាំងអស់នៅលើពិភពលោក។ នៅទីបំផុត ពួកគេនឹងមករួមគ្នាបង្កើតជាមនុស្សជាតិពេញលេញមួយក្រុម គឺជាក្រុមមនុស្សដែលកម្លាំងរបស់សាតាំងមិនអាចឈោងទៅដល់។ ក្នុងចំណោមមនុស្សជាតិទាំងនោះ អស់អ្នកដែលខ្ញុំមិនបានសង្គ្រោះ និងមិនបានយកឈ្នះ នឹងលិចលង់ទៅក្នុងជម្រៅសមុទ្រដោយស្ងាត់ៗ ហើយនឹងត្រូវឆេះដោយភ្លើងសន្ធោសន្ធៅអស់កល្បជានិច្ចរបស់ខ្ញុំ។ ខ្ញុំនឹងបំផ្លាញមនុស្សជាតិចាស់ និងកខ្វក់បំផុតនេះចោល ដូចដែលខ្ញុំបានបំផ្លាញពួកកូនប្រុសច្បងរបស់ជនជាតិអេស៊ីព្ទ និងគោក្របីរបស់ពួកគេដែរ ដោយទុកតែជនជាតិអ៊ីស្រាអែលដែលបានបរិភោគសាច់កូនចៀម និងបានផឹកឈាមកូនចៀម ព្រមទាំងបានលាបឈាមកូនចៀមនៅលើធ្នឹមទ្វាររបស់ពួកគេប៉ុណ្ណោះ។ តើមនុស្សដែលខ្ញុំបានយកឈ្នះ និងមនុស្សដែលនៅក្នុងគ្រួសាររបស់ខ្ញុំ មិនមែនជាមនុស្សដែលបរិភោគសាច់កូនចៀមដែលជារូបខ្ញុំ និងផឹកឈាមកូនចៀមដែលជារូបខ្ញុំ ព្រមទាំងបានប្រោសលោះដោយខ្ញុំ និងថ្វាយបង្គំខ្ញុំទេឬអី? តើសិរីល្អរបស់ខ្ញុំមិននៅជាមួយមនុស្សបែបនេះជានិច្ច

ទេឬអី? តើអ្នករាល់គ្នាដែលគ្មានសាច់កូនចៀមដែលជារូបខ្ញុំ មិនបានលិចលង់នៅក្នុងជម្រៅសមុទ្រដោយស្ងាត់ៗហើយទេឬអី? ថ្ងៃនេះ អ្នករាល់គ្នាជំទាស់នឹងខ្ញុំ ហើយថ្ងៃនេះព្រះបន្ទូលរបស់ខ្ញុំគ្រាន់តែដូចជាព្រះបន្ទូល ដែលព្រះយេហូវ៉ាបានមានបន្ទូលទៅកាន់កូនចៅរបស់អ៊ីស្រាអែលប៉ុណ្ណោះ។ ប៉ុន្តែ ភាពរឹងរូសនៅក្នុងជម្រៅចិត្តរបស់អ្នករាល់គ្នាកំពុងជំរុញឲ្យសេចក្ដីក្រោធរបស់ខ្ញុំឆួលឡើង ដោយនាំការរងទុក្ខវេទនាបន្ថែមទៀតមកលើសាច់ឈាមរបស់អ្នករាល់គ្នា ការជំនុំជម្រះបន្ថែមទៀតមកលើអំពើបាបរបស់អ្នករាល់គ្នា និងសេចក្ដីក្រោធបន្ថែមទៀតមកលើសេចក្ដីទុច្ចរិតរបស់អ្នករាល់គ្នា។ តើនរណាអាចនៅរស់រានមានជីវិតបាននៅថ្ងៃនៃសេចក្ដីក្រោធរបស់ខ្ញុំ នៅពេលដែលអ្នករាល់គ្នាប្រព្រឹត្តចំពោះខ្ញុំដូចថ្ងៃនេះ? តើសេចក្ដីទុច្ចរិតរបស់នរណាដែលអាចគេចផុតពីព្រះនេត្រនៃការវាយផ្ចាលរបស់ខ្ញុំ? តើអំពើបាបរបស់នរណាដែលអាចគេចពីព្រះហស្តរបស់ខ្ញុំ ដែលជាព្រះហស្តដ៏មានគ្រប់ចេស្ដាបាន? ខ្ញុំជាព្រះយេហូវ៉ាមានបន្ទូលដូច្នេះទៅកាន់អ្នករាល់គ្នាដែលជាកូនចៅនៃគ្រួសារសាសន៍ដទៃ ហើយព្រះបន្ទូលដែលខ្ញុំថ្លែងទៅកាន់អ្នករាល់គ្នា លើសពីព្រះសូរសៀងទាំងអស់ដែលខ្ញុំថ្លែងនៅយុគសម័យនៃក្រឹត្យវិន័យ និងយុគសម័យនៃព្រះគុណ ប៉ុន្តែអ្នករាល់គ្នាបែរជារឹងរូសជាងជនជាតិអេស៊ីព្ទទាំងអស់នោះទៅវិញ។ តើអ្នករាល់គ្នាមិនមែនប្រមូលសេចក្ដីក្រោធរបស់ខ្ញុំទុក នៅពេលដែលខ្ញុំសម្រាកធ្វើកិច្ចការរបស់ខ្ញុំទេឬអី? តើអ្នករាល់គ្នាអាចគេចផុតពីទុក្ខទោសនៅថ្ងៃរបស់ខ្ញុំ ដែលជាព្រះដ៏មានគ្រប់ចេស្ដាយ៉ាងដូចម្ដេចបាន?

ខ្ញុំបានធ្វើកិច្ចការ និងបានមានបន្ទូលតាមរបៀបនេះនៅក្នុងចំណោមអ្នករាល់គ្នា ហើយខ្ញុំបានចំណាយកម្លាំង និងការខំប្រឹងប្រែងយ៉ាងច្រើន ប៉ុន្តែតើនៅពេលណាដែលអ្នករាល់គ្នាធ្លាប់ស្ដាប់អ្វីដែលខ្ញុំមានបន្ទូលប្រាប់អ្នករាល់គ្នាយ៉ាងច្បាស់នោះ? តើនៅកន្លែងណាដែលអ្នករាល់គ្នាបានឱនចុះ នៅចំពោះខ្ញុំ ដែលជាព្រះដ៏មានគ្រប់ចេស្ដា។ តើហេតុអ្វីបានជាអ្នករាល់គ្នាប្រព្រឹត្តចំពោះខ្ញុំបែបនេះ? តើហេតុអ្វីបានជាអ្វីៗដែលអ្នករាល់គ្នានិយាយ និងធ្វើជំរុញឲ្យសេចក្ដីក្រោធរបស់ខ្ញុំ ឆួលឡើងបែបនេះ? តើហេតុអ្វីបានជាចិត្តរបស់អ្នករាល់គ្នារឹងរូសដូច្នេះ? តើខ្ញុំធ្លាប់វាយអ្នករាល់គ្នាឬទេ? តើ

ហេតុអ្វីបានជាអ្នករាល់គ្នា មិនធ្វើអ្វីសោះ ក្រៅពីធ្វើឲ្យខ្ញុំព្រួយព្រះទ័យ និងថប់បារម្ភដូច្នេះ? តើអ្នករាល់គ្នាកំពុងរង់ចាំឲ្យថ្ងៃនៃសេចក្ដីក្រោធរបស់ខ្ញុំដែលជាព្រះយេហូវ៉ាធ្លាក់មកលើអ្នករាល់គ្នាឬ? តើអ្នករាល់គ្នាកំពុងរង់ចាំឲ្យខ្ញុំបញ្ជូនសេចក្ដីក្រោធរបស់ខ្ញុំដែលបានឆួលឡើងដោយសារការមិនស្ដាប់បង្គាប់របស់អ្នករាល់គ្នាឬ? តើអ្វីៗគ្រប់យ៉ាងដែលខ្ញុំធ្វើ មិនមែនសម្រាប់អ្នករាល់គ្នាទេឬអី? ប៉ុន្តែជានិច្ចកាល អ្នករាល់គ្នាតែងតែប្រព្រឹត្តចំពោះខ្ញុំដែលជាព្រះយេហូវ៉ាបែបនេះគឺ៖ លួចយញ្ញបូជារបស់ខ្ញុំ យកតង្វាយពីអាសនារបស់ខ្ញុំទៅកាន់ជម្រករបស់ឆ្កែចចក ដើម្បីផ្ដល់ចំណីដល់កូនឆ្កែចចកទាំងអស់នោះ ហើយនិងកូននៃកូនឆ្កែចចកទៀត មនុស្សប្រយុទ្ធប្រឆាំងគ្នាទៅវិញទៅមក ប្រឈមមុខដាក់គ្នាដោយសេចក្ដីក្រេវក្រោធ និងដាវលំពែង បោះចោលព្រះបន្ទូលរបស់ខ្ញុំដែលជាព្រះដ៏មានគ្រប់ចេស្ដា ទៅក្នុងបង្គន់ឲ្យក្លាយទៅជាលាមកដ៏កខ្វក់។ តើឯណាទៅ សុចរិតភាពរបស់អ្នករាល់គ្នា? សារជាតិជាមនុស្សរបស់អ្នករាល់គ្នាបានក្លាយទៅជាសត្វសាហាវ! បេះដូងរបស់អ្នករាល់គ្នាបានក្លាយទៅជាដុំថ្មជាយូរមកហើយ។ តើអ្នករាល់គ្នាមិនដឹងទេឬអីថា នៅពេលដែលថ្ងៃនៃសេចក្ដីក្រោធរបស់ខ្ញុំមកដល់ គឺជាពេលដែលខ្ញុំនឹងជំនុំជម្រះការអាក្រក់ដែលអ្នករាល់គ្នាប្រព្រឹត្តទាស់នឹងខ្ញុំ ដែលជាព្រះដ៏មានគ្រប់ចេស្ដា នៅថ្ងៃនេះ? តើអ្នករាល់គ្នាគិតថាតាមរយៈការបោកបញ្ឆោតខ្ញុំបែបនេះ ការបោះចោលព្រះបន្ទូលរបស់ខ្ញុំទៅក្នុងភក់ជ្រាំ និងមិនស្ដាប់តាមព្រះបន្ទូលទាំងនោះ តើអ្នករាល់គ្នាគិតថាតាមរយៈការធ្វើបែបនេះនៅក្រោយខ្នងខ្ញុំ អ្នករាល់គ្នាអាចគេចផុតពីការឃ្លាំមើលដែលពោរពេញដោយសេចក្ដីក្រោធរបស់ខ្ញុំឬអី? តើអ្នករាល់គ្នាមិនដឹងថាខ្ញុំដែលជាព្រះយេហូវ៉ា បានទតមើលឃើញអ្នករាល់គ្នាដោយព្រះនេត្ររបស់ខ្ញុំហើយទេឬអី នៅពេលដែលអ្នករាល់គ្នាបានលួចយកយញ្ញបូជារបស់ខ្ញុំ និងលោភយកទ្រព្យសម្បត្តិរបស់ខ្ញុំនោះ? តើអ្នករាល់គ្នាមិនដឹងទេឬអីថា នៅពេលដែលអ្នករាល់គ្នាបានលួចយកយញ្ញបូជារបស់ខ្ញុំ គឺអ្នករាល់គ្នាបានប្រព្រឹត្តទង្វើបែបនេះនៅមុខអាសនា ដែលគេបានថ្វាយយញ្ញបូជា? តើអ្នករាល់គ្នាអាចជឿបានយ៉ាងដូចម្ដេចថា ខ្លួនឯងឆ្លាតល្មមនឹងអាចបោកបញ្ឆោតខ្ញុំតាមរបៀបនេះ

បាន? តើសេចក្តីក្រោធរបស់ខ្ញុំអាចឃ្លាតចេញពីអំពើបាបដ៏សាហាវរបស់អ្នករាល់គ្នាយ៉ាងដូចម្តេចកើត? តើសេចក្តីក្រេវក្រោធដ៏លើសលប់របស់ខ្ញុំ អាចរំលងទង្វើអាក្រក់របស់អ្នករាល់គ្នាយ៉ាងដូចម្តេចកើត? ការអាក្រក់ដែលអ្នករាល់គ្នាប្រព្រឹត្តនៅថ្ងៃនេះ មិនមែនបើកផ្លូវចេញសម្រាប់អ្នករាល់គ្នាទេ ប៉ុន្តែគឺសន្សំទោស សម្រាប់អ្នករាល់គ្នានៅថ្ងៃស្អែកវិញ ព្រោះវាជំរុញការវាយផ្ចាល់របស់ខ្ញុំ ដែលជាព្រះដ៏មានគ្រប់ចេស្តាចំពោះអ្នករាល់គ្នា។ តើទង្វើ និងពាក្យសម្តីអាក្រក់ៗរបស់អ្នករាល់គ្នា អាចគេចផុតពីការវាយផ្ចាលរបស់ខ្ញុំយ៉ាងដូចម្តេចកើត? តើសេចក្តីអធិស្ឋានរបស់អ្នករាល់គ្នាអាចទៅដល់ព្រះកាណ៌របស់ខ្ញុំយ៉ាងដូចម្តេចកើត? តើខ្ញុំអាចបើកផ្លូវចេញសម្រាប់សេចក្តីទុច្ចរិតរបស់អ្នករាល់គ្នាយ៉ាងដូចម្តេចកើត? តើខ្ញុំអាចលើកលែងចំពោះទង្វើអាក្រក់របស់អ្នករាល់គ្នាដែលមិនគោរពខ្ញុំយ៉ាងដូចម្តេចកើត? តើខ្ញុំអាចមិនកាត់ផ្តាច់អណ្តាតរបស់អ្នករាល់គ្នា ដែលមានពិសដូចជាអណ្តាតពស់យ៉ាងដូចម្តេចកើត? អ្នករាល់គ្នាមិនអំពាវនាវរកខ្ញុំ សម្រាប់ជាប្រយោជន៍ ដល់សេចក្តីសុចរិតរបស់អ្នករាល់គ្នាទេ ប៉ុន្តែអ្នករាល់គ្នាបែរជាសន្សំសេចក្តីក្រោធរបស់ខ្ញុំទុកដោយសារសេចក្តីទុច្ចរិតរបស់អ្នករាល់គ្នាទៅវិញ។ តើខ្ញុំអាចអត់ទោសឲ្យអ្នករាល់គ្នាយ៉ាងដូចម្តេចកើត? នៅក្នុងព្រះនេត្ររបស់ខ្ញុំដែលជាព្រះដ៏មានគ្រប់ចេស្តា គឺពាក្យសម្តី និងទង្វើរបស់អ្នករាល់គ្នាសុទ្ធតែកខ្វក់។ ព្រះនេត្ររបស់ខ្ញុំដែលជាព្រះដ៏មានគ្រប់ចេស្តា ទតឃើញសេចក្តីទុច្ចរិតរបស់អ្នករាល់គ្នាជាការវាយផ្ចាលដែលគ្មានបន្ធូរ។ តើការវាយផ្ចាល និងការជំនុំជម្រះដ៏សុចរិតរបស់ខ្ញុំ អាចឃ្លាតចេញពីអ្នករាល់គ្នាយ៉ាងដូចម្តេចកើត? ដោយព្រោះអ្នករាល់គ្នាធ្វើបែបនេះចំពោះខ្ញុំ ដោយធ្វើឲ្យខ្ញុំព្រួយព្រះទ័យ និងពេញដោយសេចក្តីក្រោធ តើខ្ញុំអាចបណ្តោយឲ្យអ្នករាល់គ្នាគេចផុតពីព្រះហស្តរបស់ខ្ញុំ និងឃ្លាតចេញពីថ្ងៃដែលខ្ញុំជាព្រះយេហូវ៉ា វាយផ្ចាល និងដាក់បណ្តាសាអ្នករាល់គ្នាយ៉ាងដូចម្តេចកើត? តើអ្នករាល់គ្នាមិនដឹងថាពាក្យសម្តី និងសូរស័ព្ទដ៏អាក្រក់ដែលចេញពីមាត់របស់អ្នករាល់គ្នាបានឮទៅដល់ព្រះកាណ៌ខ្ញុំហើយទេឬអី? តើអ្នករាល់គ្នាមិនដឹងថាសេចក្តីទុច្ចរិតរបស់អ្នករាល់គ្នាបានធ្វើឲ្យប្រឡាក់ព្រះពស្ត្រនៃសេចក្តីសុចរិតរបស់ខ្ញុំហើយ

ទេឬអី? តើអ្នករាល់គ្នាមិនដឹងថាការមិនស្ដាប់បង្គាប់របស់អ្នករាល់គ្នាបានជំរុញឲ្យសេចក្ដីក្រោធដ៏ខ្លាំងក្លារបស់ខ្ញុំឆួលឡើងហើយទេឬអី? តើអ្នករាល់គ្នាមិនដឹងទេឬអីថា អ្នករាល់គ្នាបានទុកខ្ញុំចោលឲ្យខឹងក្រេវក្រោធ និងបានសាកល្បងភាពអត់ធ្មត់របស់ខ្ញុំជាយូរមកហើយ? តើអ្នករាល់គ្នាមិនដឹងទេឬអីថា អ្នករាល់គ្នាបានបំផ្លាញសាច់ឈាមរបស់ខ្ញុំរួចទៅហើយ ដោយកាត់បន្ថយទៅជាចំណិតៗ? ខ្ញុំបានស៊ូទ្រាំរហូតមកដល់ពេលនេះ ទើបខ្ញុំបង្ហាញសេចក្ដីក្រោធរបស់ខ្ញុំចេញទៅ ដោយមិនលើកលែងឲ្យអ្នករាល់គ្នាទៀតឡើយ។ តើរាល់គ្នាមិនដឹងថាព្រះនេត្ររបស់ខ្ញុំបានទតឃើញទង្វើអាក្រក់របស់អ្នករាល់គ្នា ហើយព្រះកន្សែងរបស់ខ្ញុំបានឮទៅដល់ព្រះកាណ៌របស់ព្រះវរបិតាខ្ញុំហើយទេឬអី? តើទ្រង់អាចបណ្ដោយឲ្យអ្នករាល់គ្នាប្រព្រឹត្តចំពោះខ្ញុំបែបនេះយ៉ាងដូចម្ដេចកើត? តើមានកិច្ចការណាមួយដែលខ្ញុំធ្វើនៅក្នុងអ្នករាល់គ្នាដែលមិនមែនជាប្រយោជន៍សម្រាប់អ្នករាល់គ្នា? ប៉ុន្តែ តើនរណាក្នុងចំណោមអ្នករាល់គ្នា បានស្រលាញ់កិច្ចការរបស់ខ្ញុំដែលជាព្រះយេហូវ៉ាកាន់តែខ្លាំង? តើខ្ញុំអាចមិនស្មោះត្រង់ចំពោះព្រះហឫទ័យនៃព្រះវរបិតារបស់ខ្ញុំដោយសារតែខ្ញុំទន់ខ្សោយ និងដោយសារតែខ្ញុំបានរងទុក្ខយ៉ាងដូចម្ដេចកើត? តើអ្នករាល់គ្នាមិនយល់ពីព្រះហឫទ័យរបស់ខ្ញុំទេឬអី? ខ្ញុំមានបន្ទូលទៅកាន់អ្នករាល់គ្នា ដូចដែលព្រះយេហូវ៉ាបានធ្វើ តើខ្ញុំមិនបានបូជាអ្វីច្រើនសម្រាប់អ្នករាល់គ្នាទេឬអី? ទោះបីជាខ្ញុំព្រមទទួលការរងទុក្ខទាំងអស់នេះ សម្រាប់ជាប្រយោជន៍ដល់កិច្ចការនៃព្រះវរបិតារបស់ខ្ញុំក៏ដោយ តើអ្នករាល់គ្នាអាចរួចផុត ពីការវាយផ្ចាលដែលខ្ញុំនាំមកលើអ្នករាល់គ្នា ដោយសារលទ្ធផល នៃការរងទុក្ខរបស់ខ្ញុំយ៉ាងដូចម្ដេចកើត? តើអ្នករាល់គ្នាមិនបានរីករាយយ៉ាងខ្លាំងចំពោះខ្ញុំទេឬអី? ថ្ងៃនេះ ព្រះវរបិតាខ្ញុំបានប្រទានខ្ញុំមកឲ្យអ្នករាល់គ្នា តើអ្នករាល់គ្នាមិនដឹងថា អ្នករាល់គ្នាបានរីករាយយ៉ាងខ្លាំង លើសពីព្រះបន្ទូលដ៏សប្បុរសរបស់ខ្ញុំទេឬអី? តើអ្នករាល់គ្នាមិនដឹងថាជីវិតរបស់ខ្ញុំត្រូវបានប្ដូរដើម្បីជីវិត និងអ្វីៗដែលអ្នករាល់គ្នារីករាយជាមួយទេឬអី? តើអ្នករាល់គ្នាមិនដឹងទេឬអីថា ព្រះវរបិតាខ្ញុំបានប្រើជីវិតរបស់ខ្ញុំ ដើម្បីធ្វើចម្បាំងជាមួយសាតាំង ហើយថាទ្រង់ក៏បានប្រទានជីវិតរបស់ខ្ញុំ

មកឲ្យអ្នករាល់គ្នា ដើម្បីធ្វើឲ្យអ្នករាល់គ្នាទទួលបានជីវិតមួយរយដង និងអនុញ្ញាតឲ្យអ្នករាល់គ្នាជៀសផុតពីសេចក្ដីល្បួងជាច្រើន? តើអ្នករាល់គ្នាមិនដឹងទេឬអីថា មានតែតាមរយៈកិច្ចការរបស់ខ្ញុំប៉ុណ្ណោះ ទើបអ្នករាល់គ្នាបានរួចផុតពីសេចក្ដីល្បួង និងពីការវាយផ្ចាលដ៏ធ្ងន់ធ្ងរជាច្រើន? តើអ្នករាល់គ្នាមិនដឹងទេឬអីថា ដោយសារខ្ញុំតែមួយគត់ ទើបព្រះវរបិតាខ្ញុំអនុញ្ញាតឲ្យអ្នករាល់គ្នារីករាយរហូតមកដល់ពេលនេះ? តើថ្ងៃនេះ អ្នករាល់គ្នាអាចនៅរឹងរូស និងមិនបន្ទន់ចិត្ត ហាក់ដូចជាភាពឃោរឃៅបានរីកចម្រើននៅក្នុងចិត្តរបស់អ្នករាល់គ្នាយ៉ាងដូចម្ដេចកើត? តើការអាក្រក់ដែលអ្នករាល់គ្នាប្រព្រឹត្តនៅថ្ងៃនេះ អាចគេចផុតពីថ្ងៃនៃសេចក្ដីក្រោធ ដែលនឹងកើតឡើងក្រោយពេលដែលខ្ញុំចាកចេញពីផែនដីយ៉ាងដូចម្ដេចកើត? តើខ្ញុំអាចបណ្ដោយឲ្យអស់អ្នកដែលរឹងរូស និងមិនបន្ទន់ចិត្ត គេចផុតពីសេចក្ដីក្រោធរបស់ព្រះយេហូវ៉ាយ៉ាងដូចម្ដេចកើត?

ចូរគិតពីអតីតកាលចុះ៖ តើនៅពេលណាដែលព្រះនេត្ររបស់ខ្ញុំក្រេវក្រោធ ហើយព្រះសូរសៀងរបស់ខ្ញុំទាស់នឹងអ្នករាល់គ្នា? តើនៅពេលណាដែលខ្ញុំបានធ្វើរឿងមិនចាំបាច់ជាមួយអ្នករាល់គ្នា? តើនៅពេលណាដែលខ្ញុំបានស្ដីបន្ទោសអ្នករាល់គ្នាដោយមិនសមហេតុផល? តើនៅពេលណាដែលខ្ញុំបានស្ដីបន្ទោសអ្នករាល់គ្នានៅចំពោះមុខ? តើវាមិនមែនសម្រាប់ជាប្រយោជន៍នៃកិច្ចការរបស់ខ្ញុំទេឬអី ដែលខ្ញុំទូលសុំព្រះវរបិតារបស់ខ្ញុំឲ្យជួយអ្នករាល់គ្នាគេចផុតពីសេចក្ដីល្បួងគ្រប់បែបយ៉ាង? តើហេតុអ្វីបានជាអ្នករាល់គ្នាប្រព្រឹត្តចំពោះខ្ញុំបែបនេះ? តើខ្ញុំធ្លាប់បានប្រើសិទ្ធិអំណាចរបស់ខ្ញុំ ដើម្បីវាយធ្វើបាបសាច់ឈាមរបស់អ្នករាល់គ្នាឬទេ? តើហេតុអ្វីបានជាអ្នករាល់គ្នាសងខ្ញុំវិញបែបនេះ? ក្រោយពេលដែលផ្លាស់ប្ដូរចិត្តចំពោះខ្ញុំយ៉ាងឆាប់រហ័ស អ្នករាល់គ្នាក៏លែងក្ដៅ និងលែងត្រជាក់តទៅទៀត ហើយបន្ទាប់មក អ្នករាល់គ្នាក៏ព្យាយាមបញ្ឆុះបញ្ឆូលខ្ញុំ និងលាក់បាំងអ្វីៗពីខ្ញុំ ហើយមាត់របស់អ្នករាល់គ្នាពេញដោយពាក្យសម្ដីរបស់មនុស្សទុច្ចរិត។ តើអ្នករាល់គ្នា គិតថាអណ្ដាតរបស់អ្នករាល់គ្នាអាចបោកប្រាស់វិញ្ញាណរបស់ខ្ញុំបានឬ? តើអ្នករាល់គ្នា គិតថាអណ្ដាតរបស់អ្នករាល់គ្នាអាចគេចផុតពីសេចក្ដីក្រោធរបស់ខ្ញុំឬ? ទោះជាពួកគេប្រាថ្នាបែបនេះក៏ដោយ តើ

អ្នករាល់គ្នាគិតថាអណ្ដាតរបស់អ្នករាល់គ្នាអាចធ្វើការវិនិច្ឆ័យចំពោះទង្វើរបស់ខ្ញុំ ដែលជាព្រះយេហូវ៉ាបានឬ? តើខ្ញុំគឺជាព្រះជាម្ចាស់ ដែលមនុស្សធ្វើការវិនិច្ឆ័យឬ? តើខ្ញុំអាចបណ្ដោយឲ្យដង្កូវដ៏តូចមួយប្រមាថខ្ញុំបែបនេះឬទេ? តើខ្ញុំអាចដាក់កូនដែលមិនស្ដាប់បង្គាប់បែបនេះនៅក្នុងចំណោមព្រះពរដ៏អស់កល្បជានិច្ចរបស់ខ្ញុំយ៉ាងដូចម្ដេចកើត? ពាក្យសម្ដី និងទង្វើរបស់អ្នករាល់គ្នាបានលាតត្រដាង និងបានថ្កោលទោសអ្នករាល់គ្នាជាយូរមកហើយ។ នៅពេលដែលខ្ញុំលាតសន្ធឹងផ្ទៃមេឃ និងបង្កើតអ្វីៗទាំងអស់មក ខ្ញុំមិនបានបណ្ដោយឲ្យសត្វលោកណាមួយ ចូលរួមតាមដែលពួកគេពេញចិត្តនោះទេ ព្រោះខ្ញុំមិនបណ្ដោយឲ្យអ្វីមករំខានដល់កិច្ចការ និងការគ្រប់គ្រងរបស់ខ្ញុំឡើយ ទោះបីជាពួកគេប្រាថ្នាចង់ធ្វើបែបនេះក៏ដោយ។ ខ្ញុំមិនលើកលែងចំពោះមនុស្សណាម្នាក់ ឬក៏វត្ថុណាមួយឡើយ តើខ្ញុំអាចអនុគ្រោះឲ្យអស់អ្នកដែលឃោរឃៅ និងគ្មានមនុស្សធម៌ចំពោះខ្ញុំយ៉ាងដូចម្ដេចកើត? តើខ្ញុំអាចអត់ទោសដល់អស់អ្នកដែលបះបោរទាស់នឹងព្រះបន្ទូលរបស់ខ្ញុំយ៉ាងដូចម្ដេចកើត? តើខ្ញុំអាចអនុគ្រោះឲ្យអស់អ្នកដែលមិនស្ដាប់បង្គាប់ខ្ញុំយ៉ាងដូចម្ដេចកើត? តើជោគវាសនារបស់មនុស្សមិនស្ថិតនៅក្នុងព្រះហស្ដរបស់ខ្ញុំ ដែលជាព្រះដ៏មានគ្រប់ចេស្ដាទេឬអី? តើខ្ញុំអាចរាប់សេចក្ដីទុច្ចរិត និងការមិនស្ដាប់បង្គាប់របស់អ្នកជាបរិសុទ្ធយ៉ាងដូចម្ដេចកើត? តើអំពើបាបរបស់អ្នកអាចធ្វើឲ្យកខ្វក់ ដល់ភាពបរិសុទ្ធរបស់ខ្ញុំយ៉ាងដូចម្ដេចកើត? ខ្ញុំមិនកខ្វក់ដោយសារភាពមិនបរិសុទ្ធរបស់មនុស្សទុច្ចរិតឡើយ ហើយខ្ញុំក៏មិនរីករាយចំពោះតង្វាយរបស់មនុស្សទុច្ចរិតដែរ។ ប្រសិនបើអ្នកស្មោះត្រង់ចំពោះខ្ញុំដែលជាព្រះយេហូវ៉ា តើអ្នកអាចយកយញ្ញបូជានៅអាសនារបស់ខ្ញុំសម្រាប់ខ្លួនឯងយ៉ាងដូចម្ដេចកើត? តើអ្នកអាចប្រើអណ្ដាតពិសពុលរបស់អ្នកមកប្រមាថព្រះនាមដ៏បរិសុទ្ធរបស់ខ្ញុំឬទេ? តើអ្នកអាចបះបោរទាស់នឹងព្រះបន្ទូលរបស់ខ្ញុំតាមរបៀបនេះឬទេ? តើអ្នកអាចប្រព្រឹត្តចំពោះសិរីល្អ និងព្រះនាមដ៏បរិសុទ្ធរបស់ខ្ញុំ ទុកជាឧបករណ៍មួយដែលបម្រើដល់សាតាំងដែលជាមេកំណាចឬទេ? ជីវិតរបស់ខ្ញុំបានប្រទានមកសម្រាប់ជាការរីករាយរបស់ពួកបរិសុទ្ធ។ តើខ្ញុំអាចអនុញ្ញាតឲ្យអ្នកលេងសើចជាមួយជីវិតរបស់ខ្ញុំតាមដែលអ្នកប្រាថ្នា

និងប្រើប្រាស់ធ្វើជាឧបករណ៍បង្កទំនាស់ នៅក្នុងចំណោមអ្នករាល់គ្នាយ៉ាងដូចម្ដេចកើត? តើអ្នករាល់គ្នាអាចគ្មានចិត្ត និងខ្វះសេចក្ដីល្អចំពោះខ្ញុំយ៉ាងដូចម្ដេចកើត? តើអ្នករាល់គ្នាមិនដឹងថា ខ្ញុំបានកត់ត្រាទង្វើអាក្រក់របស់អ្នករាល់គ្នានៅក្នុងព្រះបន្ទូលនៃជីវិតទាំងនេះទេឬអី? តើអ្នករាល់គ្នាអាចគេចផុតពីថ្ងៃនៃសេចក្ដីក្រោធ នៅពេលដែលខ្ញុំវាយផ្ចាលប្រទេសអេស៊ីព្ទយ៉ាងដូចម្ដេចកើត? តើខ្ញុំអាចបណ្ដោយឲ្យអ្នករាល់គ្នាប្រឆាំង និងបំពានលើខ្ញុំតាមរបៀបនេះម្ដងហើយម្ដងទៀតយ៉ាងដូចម្ដេចកើត? ខ្ញុំសូមប្រាប់អ្នករាល់គ្នាដោយត្រង់ថា នៅពេលដែលថ្ងៃនោះមកដល់ ទោសរបស់អ្នករាល់គ្នានឹងកាន់តែពិបាកទ្រាំជាងទោសរបស់ប្រទេសអេស៊ីព្ទទៅទៀត។ តើអ្នករាល់គ្នាអាចគេចផុតពីថ្ងៃនៃសេចក្ដីក្រោធរបស់ខ្ញុំយ៉ាងដូចម្ដេចបាន? ខ្ញុំសូមប្រាប់អ្នករាល់គ្នាជាប្រាកដថា៖ ការស៊ូទ្រាំរបស់ខ្ញុំត្រូវបានរៀបចំសម្រាប់ទង្វើអាក្រក់របស់អ្នករាល់គ្នា ហើយក៏មានសម្រាប់ការវាយផ្ចាល អ្នករាល់គ្នានៅថ្ងៃនោះដែរ។ នៅពេលដែលការស៊ូទ្រាំរបស់ខ្ញុំដល់ទីបញ្ចប់ តើអ្នករាល់គ្នាមិនមែនជាមនុស្ស ដែលនឹងត្រូវទទួលរងការជំនុំជម្រះដែលពេញដោយសេចក្ដីក្រោធទេឬអី? តើអ្វីៗមិនស្ថិតនៅក្នុងព្រះហស្តរបស់ខ្ញុំដែលជាព្រះដ៏មានគ្រប់ចេស្ដាទេឬអី? នៅក្រោមមេឃនេះ តើខ្ញុំអាចបណ្ដោយឲ្យអ្នករាល់គ្នាមិនស្ដាប់បង្គាប់ខ្ញុំបែបនេះយ៉ាងដូចម្ដេចកើត? ជីវិតអ្នករាល់គ្នានឹងជួបការលំបាកយ៉ាងខ្លាំង ព្រោះអ្នករាល់គ្នាបានជួបជាមួយព្រះមែស្ស៊ីដែលត្រូវបានថ្លែងថា ទ្រង់នឹងយាងមក ប៉ុន្តែបែរជាមិនបានយាងមក។ តើអ្នករាល់គ្នាមិនមែនជាសត្រូវរបស់ទ្រង់ទេឬអី? ព្រះយេស៊ូវបានធ្វើមិត្តសម្លាញ់ជាមួយអ្នករាល់គ្នា ប៉ុន្តែអ្នករាល់គ្នាគឺជាសត្រូវរបស់ព្រះមែស្ស៊ី។ តើអ្នករាល់គ្នាមិនដឹងទេឬអីថា ទោះបីជាអ្នករាល់គ្នាគឺជាមិត្តសម្លាញ់នឹងព្រះយេស៊ូវក៏ដោយ ក៏ទង្វើអាក្រក់របស់អ្នករាល់គ្នាបានបំពេញភាជន៍របស់អស់អ្នកដែលគួរឲ្យស្អប់ខ្ពើមទាំងនោះដែរ? ទោះបីជាអ្នករាល់គ្នាជិតស្និទ្ធយ៉ាងខ្លាំងជាមួយព្រះយេហូវ៉ាក៏ដោយ តើអ្នករាល់គ្នាមិនដឹងថាពាក្យសម្ដីដ៏អាក្រក់របស់អ្នករាល់គ្នាបានឮទៅដល់ព្រះកាណ៌របស់ព្រះយេហូវ៉ា និងបានធ្វើឲ្យសេចក្ដីក្រោធរបស់ទ្រង់ឆួលឡើងហើយទេឬអី? តើទ្រង់អាចជិតស្និទ្ធជាមួយអ្នកយ៉ាងដូចម្ដេចកើត ហើយ

តើទ្រង់អាចមិនដុតបំផ្លាញភាជន៍ទាំងអស់របស់អ្នក ដែលពេញដោយទង្វើអាក្រក់យ៉ាងដូចម្ដេចកើត? តើទ្រង់អាចមិនធ្វើជាសត្រូវរបស់អ្នកយ៉ាងដូចម្ដេចកើត?

## ព្រះអង្គសង្គ្រោះបានយាងត្រឡប់មកវិញហើយ នៅលើ «ពពកស» មួយដុំ

រាប់ពាន់ឆ្នាំមកហើយដែលមនុស្សចង់បានសមត្ថភាពមើលឃើញការយាងមកដល់របស់ព្រះអង្គសង្គ្រោះផ្ទាល់នឹងភ្នែក។ មនុស្សចង់មើលឃើញព្រះយេស៊ូវ ដ៏ជាព្រះអង្គសង្គ្រោះពីចម្ងាយ នៅពេលដែលទ្រង់យាងចុះមក ដោយគង់នៅលើពពកសមួយដុំក្នុងរូបភាពជាមនុស្ស កណ្ដាលចំណោមមនុស្សដែលរង់ចាំទ្រង់ អស់រយៈពេលរាប់ពាន់ឆ្នាំយ៉ាងក្រៀមក្រំ និងដោយអន្ទះសា។ មនុស្សក៏ចង់ឲ្យព្រះអង្គសង្គ្រោះ យាងត្រឡប់មកវិញ និងចង់ឲ្យទ្រង់បានរួបរួមជាមួយនឹងពួកគេដែរ ពោលគឺ ពួកគេចង់ឲ្យព្រះយេស៊ូវដ៏ជាព្រះអង្គសង្គ្រោះ ដែលបានគង់ឆ្ងាយពីពួកគេអស់រយៈពេលរាប់ពាន់ឆ្នាំមកហើយនោះ យាងត្រឡប់មកវិញ និងមកអនុវត្តកិច្ចការនៃការប្រោសលោះដែលទ្រង់បានធ្វើក្នុងចំណោមសាសន៍យូដានោះម្ដងទៀត យាងមកសម្ដែងចិត្តក្ដួលអាណិត និងក្ដីស្រឡាញ់ដល់មនុស្ស យាងមកអត់ទោសបាបមនុស្សលោក និងយកបាបនេះដាក់លើអង្គទ្រង់ ព្រមទាំងស្ពាយយកអស់ទាំងសេចក្ដីរំលងរបស់គេ ហើយប្រោសគេឲ្យរួចពីអំពើបាបផង។ អ្វីដែលមនុស្សចង់បានបំផុត គឺចង់ឲ្យព្រះយេស៊ូវដ៏ជាព្រះអង្គសង្គ្រោះ យាងមកធ្វើដូចគ្រាមុន គឺមកធ្វើជាព្រះអង្គសង្គ្រោះដែលពោរពេញដោយសេចក្ដីស្រឡាញ់ ព្រះទ័យសប្បុរស និងគួរជាទីគោរព ជាព្រះដែលគ្មានសេចក្ដីក្រោធ ចំពោះមនុស្ស ក៏មិនដែលស្ដីបន្ទោសឲ្យគេ គឺមានតែការអត់ទោសនិងដកយកអំពើបាបរបស់មនុស្សទាំងអស់ ហើយថែមទាំងសុគតលើឈើឆ្កាង ជំនួសមនុស្សដូចគ្រាមុនផង។ តាំងពីពេលដែលព្រះយេស៊ូវបានយាងចេញទៅបាត់ ពួកសិស្សដែលដើរតាមទ្រង់ និងពួកបរិសុទ្ធដែលបានសង្គ្រោះដោយនូវព្រះនាមទ្រង់ នាំគ្នា

ស្វែងរកទ្រង់យ៉ាងក្រៀមក្រំ និងកំពុងទន្ទឹងមើលផ្លូវទ្រង់។ អស់អ្នកដែលបានសង្គ្រោះ ដោយសារព្រះគុណរបស់ព្រះយេស៊ូវគ្រីស្ទ ក្នុងយុគសម័យនៃព្រះគុណ ក៏នៅតែ អន្ទះសាចង់ឃើញថ្ងៃជោគជ័យនៅគ្រាចុងក្រោយ ពេលដែលព្រះយេស៊ូវដ៏ជាព្រះអង្គ សង្គ្រោះ យាងចុះមកលើពពក ដើម្បីបង្ហាញព្រះកាយដល់មនុស្សគ្រប់ គ្នា។ ប្រាកដ ណាស់ នេះជាក្ដីប្រាថ្នារួមរបស់មនុស្សគ្រប់គ្នា ដែលទទួលយកព្រះនាមព្រះយេស៊ូវ ជា ព្រះអង្គសង្គ្រោះនៅថ្ងៃនេះ។ គ្រប់ៗគ្នាក្នុងសកលលោក ដែលដឹងពីសេចក្ដីសង្គ្រោះ របស់ព្រះយេស៊ូវ ដ៏ជាព្រះអង្គសង្គ្រោះ គេអន្ទះសាយ៉ាងខ្លាំង ចង់ឲ្យព្រះយេស៊ូវគ្រីស្ទ យាងមកដល់ភ្លាមៗ ដើម្បីសម្រេចនូវអ្វីដែលទ្រង់បានមានបន្ទូលកាលទ្រង់នៅគង់ លើផែនដីថា៖ «ខ្ញុំនឹងត្រឡប់មកវិញ ដូចគ្នានឹងរបៀបដែលខ្ញុំបានចាកចេញទៅដែរ»។ មនុស្សជឿថា បន្ទាប់ពីត្រូវគេឆ្កាង ហើយមានព្រះជន្មរស់ឡើងវិញ ព្រះយេស៊ូវបាន យាងត្រឡប់ទៅស្ថានសួគ៌ដោយគង់នៅលើពពកសមួយដុំ ដើម្បីទៅទទួលតំណែង របស់ទ្រង់ គឺគង់ខាងស្ដាំនៃព្រះដ៏ខ្ពស់បំផុត។ ព្រះយេស៊ូវនឹងយាងចុះមកវិញម្ដងទៀត ដោយគង់នៅលើពពកសមួយដុំក្នុងលក្ខណៈដូចគ្នា (ពពកនេះ គឺសំដៅលើពពកដែល ព្រះយេស៊ូវគង់ ពេលទ្រង់យាងត្រឡប់ទៅស្ថានសួគ៌វិញ) មកក្នុងចំណោមមនុស្សដែល ទន្ទឹងចាំទ្រង់ ដោយក្ដីសង្ឃឹមជាខ្លាំងអស់រយៈពេលរាប់ពាន់ឆ្នាំ ហើយព្រះអង្គនឹងយក សណ្ឋានជាសាសន៍យូដា ព្រមទាំងស្លៀកសម្លៀកបំពាក់សាសន៍យូដាផង។ បន្ទាប់ពី លេចមកឲ្យមនុស្សឃើញ ទ្រង់នឹងប្រទានអាហារឲ្យពួកគេ ហើយធ្វើឲ្យទឹករស់ហូរ យ៉ាងគំហុកមករកគេ ព្រមទាំងរស់នៅកណ្ដាលចំណោមមនុស្ស ពេញដោយព្រះគុណ និងពេញដោយក្ដីស្រឡាញ់ ផូរផង់ និងប្រាកដប្រជា។ ការយល់ឃើញទាំងអស់នេះ ហើយ គឺជាអ្វីដែលមនុស្សជឿ។ ដោយឡែក ព្រះយេស៊ូវដ៏ជាព្រះអង្គសង្គ្រោះ ទ្រង់ មិនបានធ្វើដូច្នេះទេ ទ្រង់ធ្វើផ្ទុយស្រឡះពីអ្វីដែលមនុស្សយល់ឃើញ។ ទ្រង់មិនបាន យាងមកក្នុងចំណោមមនុស្សដែលរង់ចាំការយាងត្រឡប់មកវិញរបស់ទ្រង់ ដោយ សង្ឃឹមនោះទេ ហើយទ្រង់ក៏មិនលេចមកឲ្យមនុស្សគ្រប់ៗគ្នាឃើញ នៅពេលដែល ទ្រង់គង់នៅលើពពកសដែរ។ ទ្រង់បានយាងមកដល់ហើយ ប៉ុន្តែមនុស្សមិនបាន

ដឹងទេ ហើយក៏នៅតែមិនអើពើ។ មនុស្សគ្រាន់តែរង់ចាំទ្រង់ដោយគ្មានបំណង ក៏មិនដឹងថាទ្រង់បានយាងមកដោយគង់នៅលើ «ពពកស» មួយដុំរួចហើយដែរ (ពពកនេះគឺជាព្រះវិញ្ញាណទ្រង់ ព្រះបន្ទូលទ្រង់ និស្ស័យរបស់ទ្រង់ទាំងមូល និងលក្ខណៈទាំងអស់របស់ទ្រង់) ចំណែកពេលនេះ ទ្រង់កំពុងគង់កណ្តាលចំណោមក្រុមមនុស្សដែលមានជ័យជម្នះ ដែលទ្រង់នឹងបង្កើតឡើងនៅគ្រាចុងក្រោយ។ មនុស្សមិនដឹងរឿងមួយ គឺ៖ បើទោះជាព្រះអង្គសង្គ្រោះ ដ៏បរិសុទ្ធ មានសេចក្តីស្រឡាញ់គ្រប់យ៉ាងដល់មនុស្ស តើធ្វើម្តេចឲ្យទ្រង់ធ្វើការនៅក្នុង «ព្រះវិហារ» ដែលមានសុទ្ធតែវិញ្ញាណស្មោកគ្រោក និងមិនបរិសុទ្ធដូច្នេះបាន? ថ្វីដ្បិតថាមនុស្សកំពុងទន្ទឹងរង់ចាំការយាងមកដល់របស់ទ្រង់ តើទ្រង់អាចលេចមកឲ្យអស់អ្នកដែលបរិភោគសាច់ឈាមមនុស្សទុច្ចរិត ផឹកឈាមមនុស្សទុច្ចរិត ហើយស្លៀកសម្លៀកបំពាក់មនុស្សទុច្ចរិត ជាអ្នកដែលជឿដល់ទ្រង់ ប៉ុន្តែមិនស្គាល់ទ្រង់ ហើយក៏ជាអ្នកដែលកំហែងព្រះអង្គរហូតមកបានឃើញយ៉ាងដូចម្តេចកើត? មនុស្សដឹងត្រឹមថា ព្រះយេស៊ូវដ៏ជាព្រះអង្គសង្គ្រោះទ្រង់ពោរពេញដោយក្តីស្រឡាញ់ ហើយមានក្តីមេត្តាករុណាដ៏ហូរហៀរ និងដឹងថា ទ្រង់ជាតង្វាយលោះបាប ពោរពេញដោយការប្រោសលោះ។ យ៉ាងណាមិញ គេពុំដឹងសោះថា ទ្រង់គឺជាព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ ដែលមានពេញដោយភាពសុចរិត ឬទ្ធានុភាព សេចក្តីក្រោធ និងការជំនុំជម្រះ ហើយមានសិទ្ធិអំណាច និងពេញដោយសេចក្តីថ្លៃថ្នូរនោះឡើយ។ ហេតុនេះ ទោះបីជាមនុស្សអន្ទះសារង់ចាំ និងទទូចចង់ឃើញការវិលត្រឡប់របស់ព្រះដ៏ប្រោសលោះយ៉ាងណា ហើយទោះបីជាសេចក្តីអធិដ្ឋានរបស់គេធ្វើឲ្យ «ស្ថានសួគ៌» រង្គើក៏ដោយ ក៏ព្រះយេស៊ូវដ៏ជាព្រះអង្គសង្គ្រោះ មិនលេចមកឲ្យអស់អ្នកដែលជឿលើទ្រង់ តែមិនស្គាល់ព្រះអង្គ បានឃើញនោះដែរ។

«ព្រះយេហូវ៉ា» គឺជានាមដែលខ្ញុំបានប្រើ ក្នុងគ្រាដែលខ្ញុំធ្វើការក្នុងស្រុកអ៊ីស្រាអែល ហើយពាក្យនេះមានន័យថា ព្រះនៃសាសន៍អ៊ីស្រាអែល (រាស្ត្ររើសតាំងរបស់ព្រះជាម្ចាស់) ជាព្រះដែលមានព្រះទ័យអាណិតមេត្តាដល់មនុស្ស ក៏ដាក់បណ្តាសាមនុស្ស ហើយដឹកនាំជីវិតមនុស្សផងដែរ ទ្រង់ជាព្រះដែលមានព្រះចេស្តាដ៏មហិមា

និងពេញដោយព្រះប្រាជ្ញាញាណ។ «ព្រះយេស៊ូវ» គឺអេម៉ាញូអែល ដែលមានន័យថា តង្វាយលោះបាបដែលពោរពេញដោយក្ដីស្រលាញ់ ចិត្តក្ដួលអាណិត និងប្រោសលោះមនុស្ស។ ទ្រង់បានធ្វើការក្នុងយុគសម័យនៃព្រះគុណ ហើយព្រះអង្គក៏ជាតំណាងយុគសម័យនៃព្រះគុណ ព្រមទាំងអាចធ្វើជាតំណាងឲ្យផ្នែកតែមួយគត់នៃកិច្ចការក្នុងផែនការគ្រប់គ្រង។ មានន័យថា មានតែព្រះយេហូវ៉ាទេ ទើបជាព្រះរបស់សាសន៍អ៊ីស្រាអែលដ៏ជារាស្ត្រជ្រើសរើស ជាព្រះរបស់អ័ប្រាហាំ ជាព្រះរបស់អ៊ីសាក ជាព្រះរបស់យ៉ាកុប ជាព្រះរបស់ម៉ូសេ និងជាព្រះរបស់សាសន៍អ៊ីស្រាអែលទាំងមូល។ ហេតុនេះ នៅពេលបច្ចុប្បន្ននេះសាសន៍អ៊ីស្រាអែលទាំងអស់ ក្រៅពីពូជអំបូរយូដា គឺសុទ្ធតែថ្វាយបង្គំព្រះយេហូវ៉ា។ ពួកគេថ្វាយយញ្ញបូជាដល់ទ្រង់លើអាសនា ហើយបម្រើទ្រង់នៅក្នុងព្រះវិហារ ដោយស្លៀកពាក់ជាសង្ឃ។ អ្វីដែលគេសង្ឃឹមនោះ គឺការលេចមករបស់ព្រះយេហូវ៉ា។ គឺមានតែព្រះយេស៊ូវទេ ទើបជាព្រះដ៏ប្រោសលោះនៃមនុស្សជាតិ ហើយទ្រង់ក៏ជាតង្វាយលោះបាបដែលប្រោសលោះមនុស្សពីអំពើបាបដែរ។ មានន័យថា ព្រះនាមព្រះយេស៊ូវកើតចេញពី យុគសម័យនៃព្រះគុណ ហើយមានវត្តមាន ដោយសារតែកិច្ចការប្រោសលោះ នៅក្នុងយុគសម័យនៃព្រះគុណ។ ព្រះនាមព្រះយេស៊ូវ លេចវត្តមានឡើង ដើម្បីឲ្យមនុស្សនៅក្នុងយុគសម័យនៃព្រះគុណបានកើតជាថ្មី ហើយបានសង្គ្រោះ និងជាព្រះនាមដ៏វិសេស សម្រាប់ការប្រោសលោះមនុស្សជាតិទាំងមូល។ ដូច្នេះ ព្រះនាមយេស៊ូវ តំណាងឲ្យកិច្ចការនៃការប្រោសលោះ និងជាសញ្ញាបង្ហាញពីយុគសម័យនៃព្រះគុណ។ ព្រះនាមយេហូវ៉ា ជាព្រះនាមដ៏វិសេសសម្រាប់ប្រជារាស្ត្រអ៊ីស្រាអែល ដែលរស់នៅក្រោមក្រឹត្យវិន័យ។ នៅក្នុងយុគសម័យនីមួយៗ និងនៅក្នុងដំណាក់កាលនៃកិច្ចការនីមួយៗ ព្រះនាមរបស់ខ្ញុំមិនមែនគ្មានមូលដ្ឋានទេ ប៉ុន្តែជាព្រះនាមដែលជាតំណាងដ៏សំខាន់៖ ព្រះនាមនីមួយៗ តំណាងឲ្យយុគសម័យមួយ។ «ព្រះយេហូវ៉ា» តំណាងឲ្យយុគសម័យនៃក្រឹត្យវិន័យ ហើយក៏ជាព្រះកិត្តិនាមដែលសាសន៍អ៊ីស្រាអែលហៅថាជាព្រះជាម្ចាស់ដែលខ្លួនថ្វាយបង្គំដែរ។ «ព្រះយេស៊ូវ» គឺជាព្រះនាមតំណាងឲ្យយុគសម័យនៃព្រះគុណ ហើយជាព្រះនាមនៃ

ព្រះជាម្ចាស់របស់អស់អ្នកដែលត្រូវបានប្រោសលោះក្នុងយុគសម័យនៃព្រះគុណ។ ប្រសិនបើមនុស្សនៅតែប្រាថ្នាចង់ឃើញការយាងមកដល់របស់ព្រះយេស៊ូវដ៏ជាព្រះអង្គសង្គ្រោះនៅគ្រាចុងក្រោយ ហើយនៅតែរំពឹងចង់ឲ្យទ្រង់យាងមក ក្នុងលក្ខណៈដែលទ្រង់បានមកប្រសូតក្នុងស្រុកយូដា នោះផែនការគ្រប់គ្រងរយៈពេល៦ពាន់ឆ្នាំនេះមុខជាត្រូវបញ្ឈប់ត្រឹមយុគសម័យនៃការប្រោសលោះបាត់ទៅហើយ មិនអាចបានបន្តទៅមុខទៀតទេ។ ជាងនេះទៅទៀត គ្រាចុងក្រោយក៏មុខជាមិនមកដល់ ហើយយុគសម័យនោះ ក៏មុខជាមិនបានមកដល់ទីបញ្ចប់ដែរ។ មូលហេតុគឺ នាមព្រះយេស៊ូវដ៏ជាព្រះអង្គសង្គ្រោះ គឺសម្រាប់តែការប្រោសលោះ និងការសង្គ្រោះរបស់មនុស្សប៉ុណ្ណោះ។ ខ្ញុំប្រើនាមព្រះយេស៊ូវ គឺដោយយល់ដល់មនុស្សបាបគ្រប់គ្នា ដែលនៅក្នុងយុគសម័យនៃព្រះគុណប៉ុណ្ណោះ ប៉ុន្ដែព្រះនាមនេះ មិនមែនជាព្រះនាមដែលខ្ញុំប្រើ សម្រាប់នាំមនុស្សទាំងអស់ ទៅរកទីបញ្ចប់ឡើយ។ ថ្វីបើព្រះនាម ព្រះយេហូវ៉ា ព្រះយេស៊ូវ និងព្រះមែស្ស៊ី គឺសុទ្ធតែតំណាងឲ្យវិញ្ញាណរបស់ខ្ញុំក៏ដោយ ក៏ព្រះនាមទាំងនេះ គ្រាន់តែជាសញ្ញាបង្ហាញពីយុគសម័យខុសៗគ្នានៅក្នុងផែនការគ្រប់គ្រងរបស់ខ្ញុំប៉ុណ្ណោះ ហើយក៏មិនតំណាងឲ្យខ្ញុំនៅក្នុងភាពបរិបូររបស់ខ្ញុំដែរ។ ព្រះនាមដែលមនុស្សនៅលើផែនដីហៅរកខ្ញុំ មិនអាចបញ្ជាក់ឲ្យច្បាស់នូវនិស្ស័យ និងលក្ខណៈទាំងអស់របស់ខ្ញុំ បាននោះឡើយ។ ទាំងអស់នេះគ្រាន់តែជាព្រះនាមផ្សេងៗ ដែលគេហៅខ្ញុំនៅក្នុង យុគសម័យខុសៗគ្នាប៉ុណ្ណោះ។ ហេតុនេះ ពេលដែលយុគសម័យចុងក្រោយមកដល់ គឺយុគសម័យនៃគ្រាចុងក្រោយ នោះព្រះនាមរបស់ខ្ញុំនឹងផ្លាស់ប្ដូរម្ដងទៀត។ គេនឹងមិនហៅខ្ញុំថាព្រះយេហូវ៉ា ឬព្រះយេស៊ូវទៀតឡើយ រឹតតែមិនហៅខ្ញុំថា ព្រះមែស្ស៊ីដែរ គេនឹងហៅខ្ញុំថា ព្រះដ៏មានគ្រប់ព្រះចេស្ដាដែលមានពេញដោយឫទ្ធានុភាព ហើយខ្ញុំនឹងបញ្ចប់យុគសម័យទាំងអស់ ដោយនូវព្រះនាមមួយនេះ។ ខ្ញុំធ្លាប់ត្រូវបានស្គាល់ថាជាព្រះយេហូវ៉ា។ គេក៏ធ្លាប់ស្គាល់ខ្ញុំជាព្រះមែស្ស៊ី ហើយមនុស្សក៏ធ្លាប់ហៅខ្ញុំថា ព្រះយេស៊ូវដ៏ជាព្រះអង្គសង្គ្រោះ ដែលពេញដោយសេចក្ដីស្រឡាញ់ និងការគោរព។ យ៉ាងណាមិញ ថ្ងៃនេះ ខ្ញុំលែងជាព្រះយេហូវ៉ា ឬព្រះយេស៊ូវ ដែល

មនុស្សធ្លាប់ស្គាល់កាលពីមុនទៀតហើយ ខ្ញុំគឺជាព្រះជាម្ចាស់ដែលបានយាងត្រលប់មកវិញនៅគ្រាចុងក្រោយ ជាព្រះជាម្ចាស់ដែលនឹងបញ្ចប់នូវយុគសម័យនេះ។ ខ្ញុំគឺជាព្រះជាម្ចាស់ដោយផ្ទាល់ព្រះអង្គ ដែលលេចឡើងពីចុងផែនដី មានពេញដោយនិស្ស័យទាំងអស់របស់ខ្ញុំ និងពេញដោយសិទ្ធិអំណាច កិត្តិយស និងសិរីរុងរឿង។ មនុស្សដែលពុំធ្លាប់មានទំនាក់ទំនងជាមួយខ្ញុំ គេពុំដែលស្គាល់ខ្ញុំសោះ ហើយក៏មិនអើពើនឹងនិស្ស័យរបស់ខ្ញុំរហូតមកដែរ។ តាំងពីកំណើតផែនដីមកទល់សព្វថ្ងៃ គ្មានមនុស្សណាម្នាក់ ធ្លាប់បានឃើញខ្ញុំឡើយ។ នេះគឺជាព្រះជាម្ចាស់ ដែលលេចមកឲ្យមនុស្សនៅគ្រាចុងក្រោយឃើញ តែទ្រង់លាក់ព្រះកាយនៅក្នុងចំណោមមនុស្ស។ ព្រះអង្គគង់នៅក្នុងចំណោមមនុស្សយ៉ាងពិតប្រាកដ ដូចជាព្រះអាទិត្យពេញកម្ដៅ និងអណ្ដាតភ្លើងកំពុងឆេះសន្ធោសន្ធៅ ពេញដោយព្រះចេស្ដា និងដោយសិទ្ធិអំណាច។ ពុំមានអ្វីមួយឬមនុស្សណាសោះ សូម្បីតែម្នាក់ ដែលមិនត្រូវជំនុំជម្រះ ដោយព្រះបន្ទូលរបស់ខ្ញុំឡើយ ក៏ពុំមានអ្វីមួយ ឬមនុស្សណាសោះសូម្បីម្នាក់ដែលមិនត្រូវបន្សុទ្ធដោយភ្លើងដែលកំពុងឆេះសន្ធោសន្ធៅដែរ។ ប្រជាជាតិទាំងអស់ គង់តែបានប្រកបដោយព្រះពរ ដោយសារព្រះបន្ទូលរបស់ខ្ញុំ ហើយក៏ត្រូវខ្ទេចខ្ទីជាបំណែក ដោយសារព្រះបន្ទូលខ្ញុំដូចគ្នា។ គឺវិធីនេះហើយ ដែលធ្វើឲ្យមនុស្សទាំងអស់នៅគ្រាចុងក្រោយដឹងថា ខ្ញុំជាព្រះអង្គសង្គ្រោះដែលបានយាងត្រឡប់មកវិញ ហើយដឹងថា ខ្ញុំជាព្រះដ៏មានគ្រប់ព្រះចេស្ដា ដែលយកឈ្នះលើមនុស្សជាតិទាំងអស់។ ហើយមនុស្សទាំងអស់ នឹងមើលឃើញថា ខ្ញុំធ្លាប់ជាតង្វាយលោះបាបសម្រាប់មនុស្ស ប៉ុន្តែនៅគ្រាចុងក្រោយ ខ្ញុំក៏ក្លាយជាអណ្ដាតភ្លើងនៃព្រះអាទិត្យដែលដុតបន្សុសរបស់សព្វសារពើ ក៏ជាព្រះអាទិត្យនៃសេចក្ដីសុចរិត ដែលបើកសម្ដែងគ្រប់សព្វទាំងអស់ដែរ។ នេះគឺជាកិច្ចការរបស់ខ្ញុំនៅគ្រាចុងក្រោយ។ ខ្ញុំយកព្រះនាមនេះ ហើយខ្ញុំក៏ប្រើនិស្ស័យមួយនេះ ដើម្បីឲ្យមនុស្សទាំងអស់អាចមើលឃើញថា ខ្ញុំជាព្រះជាម្ចាស់ដ៏សុចរិត ជាព្រះអាទិត្យពេញកម្ដៅ ជាអណ្ដាតភ្លើងកំពុងឆេះសន្ធោសន្ធៅ និងដើម្បីឲ្យមនុស្សទាំងអស់អាចថ្វាយបង្គំខ្ញុំជាព្រះជាម្ចាស់ពិតតែមួយ និងដើម្បីឲ្យគេមើលឃើញព្រះភក្ត្រពិតរបស់ខ្ញុំថា៖ ខ្ញុំមិនត្រឹមតែជាព្រះជាម្ចាស់របស់

សាសន៍អ៊ីស្រាអែល និងជាព្រះជាម្ចាស់ដ៏ប្រោសលោះប៉ុណ្ណោះទេ តែខ្ញុំជាព្រះជាម្ចាស់នៃសត្តនិករទាំងអស់ ដែលមានពេញផ្ទៃមេឃ ផែនដីនិងសមុទ្រផង។

ប្រសិនបើព្រះអង្គសង្គ្រោះ យាងមកដល់នៅគ្រាចុងក្រោយ ហើយនៅតែត្រូវគេហៅថា ព្រះយេស៊ូវ ហើយត្រូវប្រសូតម្ដងទៀត ក្នុងស្រុកយូដា ព្រមទាំងធ្វើកិច្ចការរបស់ទ្រង់នៅទីនោះ នេះបញ្ជាក់ថា ខ្ញុំបង្កើតតែសាសន៍អ៊ីស្រាអែល និងប្រោសលោះតែសាសន៍អ៊ីស្រាអែលប៉ុណ្ណោះ ហើយក៏បញ្ជាក់ទៀតថា ខ្ញុំពុំមានអ្វីពាក់ព័ន្ធនឹងសាសន៍ដទៃឡើយ។ តើនេះមិនផ្ទុយនឹងព្រះបន្ទូលខ្ញុំដែលថា «ខ្ញុំជាព្រះអម្ចាស់ដែលបានបង្កើតផ្ទៃមេឃ និងផែនដី ព្រមទាំងរបស់សព្វសាររពើទេឬអី?» ខ្ញុំបានចាកចេញពីស្រុកយូដា ហើយធ្វើកិច្ចការរបស់ខ្ញុំនៅក្នុងចំណោមសាសន៍ដទៃ ដ្បិតខ្ញុំមិនត្រឹមតែជាព្រះរបស់សាសន៍អ៊ីស្រាអែលតែក៏ជាព្រះជាម្ចាស់របស់មនុស្សទាំងអស់ដែរ។ ខ្ញុំលេចមកនៅក្នុងចំណោមសាសន៍ដទៃនៅគ្រាចុងក្រោយ ដ្បិតខ្ញុំមិនត្រឹមតែជាព្រះយេហូវ៉ាជាព្រះជាម្ចាស់របស់សាសន៍អ៊ីស្រាអែលទេ ប៉ុន្តែលើសពីនេះ គឺដោយសារខ្ញុំជាព្រះអាទិករនៃរាស្ត្ររើសតាំងទាំងអស់របស់ខ្ញុំ នៅក្នុងចំណោមសាសន៍ដទៃ។ ខ្ញុំមិនមែនបង្កើតតែសាសន៍អ៊ីស្រាអែល សាសន៍អេស៊ីព្ទ និងពួកលីបង់ឡើយ តែខ្ញុំក៏បានបង្កើតសាសន៍ដទៃទាំងអស់ ក្រៅពីអ៊ីស្រាអែលដែរ។ ដោយហេតុនេះ ទើបខ្ញុំគឺជាព្រះអម្ចាស់នៃមនុស្សទាំងអស់។ ខ្ញុំគ្រាន់តែប្រើអ៊ីស្រាអែល ជាចំណុចចាប់ផ្ដើមសម្រាប់កិច្ចការរបស់ខ្ញុំ ហើយយកស្រុកយូដា និងស្រុកកាលីឡេ ធ្វើជាបន្ទាយនៃកិច្ចការប្រោសលោះរបស់ខ្ញុំប៉ុណ្ណោះ ហើយពេលនេះ ខ្ញុំប្រើសាសន៍ដទៃជាមូលដ្ឋាន ដើម្បីនឹងបញ្ចប់យុគសម័យទាំងមូល។ ខ្ញុំបានធ្វើកិច្ចការពីរដំណាក់កាលនៅក្នុងស្រុកអ៊ីស្រាអែល (កិច្ចការទាំងពីរដំណាក់កាលនេះ គឺយុគសម័យនៃក្រឹត្យវិន័យ និងយុគសម័យនៃព្រះគុណ) ហើយខ្ញុំក៏កំពុងអនុវត្តកិច្ចការពីរដំណាក់កាលបន្តទៀត (យុគសម័យព្រះគុណ និងយុគសម័យនៃនគរព្រះ) ពាសពេញទឹកដី ក្រៅពីស្រុកអ៊ីស្រាអែល។ ខ្ញុំនឹងធ្វើកិច្ចការចម្បាំងនៅក្នុងចំណោមសាសន៍ដទៃ និងដើម្បីបញ្ចប់យុគសម័យនេះ។ ប្រសិនបើមនុស្សហៅខ្ញុំដោយព្រះនាមថា ព្រះយេស៊ូវគ្រីស្ទរហូតមក តែមិនដឹងថា

ខ្ញុំបានចាប់ផ្ដើមយុគសម័យថ្មីមួយនៅគ្រាចុងក្រោយ និងចាប់ផ្ដើមកិច្ចការថ្មីទេ ហើយប្រសិនបើមនុស្សបន្តរង់ចាំការយាងមកដល់របស់ព្រះយេស៊ូវដ៏ជាព្រះអង្គសង្គ្រោះទាំងមមៃ នោះខ្ញុំនឹងហៅមនុស្សទាំងនោះថា ជាអ្នកដែលមិនជឿដល់ខ្ញុំឡើយ ពួកគេជាមនុស្សដែលមិនស្គាល់ខ្ញុំ ហើយជំនឿដែលគេមានចំពោះខ្ញុំ ក៏ជាជំនឿក្លែងក្លាយដែរ។ តើមនុស្សបែបនេះ អាចមើលឃើញការយាងមកដល់របស់ព្រះយេស៊ូវ ដ៏ជាព្រះអង្គសង្គ្រោះពីស្ថានសួគ៌ ដោយផ្ទាល់នឹងភ្នែកយ៉ាងដូចម្ដេច? អ្វីដែលគេរង់ចាំនោះមិនមែនការយាងមកដល់របស់ខ្ញុំទេ ប៉ុន្តែគឺជាការយាងមកដល់របស់ស្ដេចសាសន៍យូដា។ ពួកគេមិនរង់ចាំខ្ញុំឲ្យមករំលាយលោកិយស្មោកគ្រោកនេះទេ តែផ្ទុយទៅវិញគេទន្ទឹងរង់ចាំការយាងមកវិញជាលើកទីពីររបស់ព្រះយេស៊ូវ ដើម្បីឲ្យគេបានប្រោសលោះ។ ពួកគេទន្ទឹងចាំព្រះយេស៊ូវយាងមកម្ដងទៀត មកប្រោសលោះមនុស្សទាំងអស់ពីទឹកដីស្មោកគ្រោក និងទុច្ចរិតនេះវិញ។ ធ្វើម្ដេចឲ្យមនុស្សបែបនេះ អាចក្លាយជាមនុស្សដែលសម្រេចកិច្ចការរបស់ខ្ញុំ នៅគ្រាចុងក្រោយបាន? ក្ដីប្រាថ្នារបស់មនុស្ស គឺមិនអាចនឹងសម្រេចបំណងព្រះហឫទ័យរបស់ខ្ញុំ ឬសម្រេចកិច្ចការរបស់ខ្ញុំបាន ពីព្រោះមនុស្សគ្រាន់តែសរសើរ ឬអរសប្បាយនឹងកិច្ចការដែលខ្ញុំបានធ្វើកាលពីមុន ហើយគេមិនដឹងសោះថា ខ្ញុំនេះហើយ គឺជាព្រះជាម្ចាស់ ដែលថ្មីជានិច្ច មិនដែលចាស់ឡើយ។ មនុស្សដឹងត្រឹមថា ខ្ញុំជាព្រះយេហូវ៉ា និងជាព្រះយេស៊ូវ ហើយគ្មានមន្ទិលអ្វីសោះថា ខ្ញុំគឺជា ជាព្រះនៃគ្រាចុងក្រោយដែលនាំមនុស្សជាតិទៅរកទីបញ្ចប់។ គ្រប់យ៉ាងដែលមនុស្សទន្ទឹងរង់ចាំ ហើយស្គាល់ គឺសុទ្ធតែបានមកពីការយល់ដឹងរបស់គេ ហើយគ្រាន់តែជាអ្វីដែលគេមើលឃើញនឹងភ្នែករបស់គេផ្ទាល់។ ការនេះមិនស្របនឹងកិច្ចការដែលខ្ញុំធ្វើនោះឡើយ គឺខុសស្រឡះតែម្ដង។ ប្រសិនបើកិច្ចការរបស់ខ្ញុំ ត្រូវធ្វើទៅតាមគំនិតរបស់មនុស្ស តើកិច្ចការនោះនឹងត្រូវចប់នៅពេលណា? តើមនុស្សជាតិនឹងបានចូលទៅទីសម្រាកនៅពេលណា? ហើយតើខ្ញុំនឹងអាចចូលទៅថ្ងៃទី៧ដែលជាថ្ងៃសប្ប័ទនៅពេលណា? ខ្ញុំធ្វើកិច្ចការទៅតាមផែនការរបស់ខ្ញុំ និងស្របតាមបំណងព្រះហឫទ័យរបស់ខ្ញុំ មិនមែនធ្វើទៅតាមបំណងរបស់មនុស្សឡើយ។

# កិច្ចការប្រកាសដំណឹងល្អ ក៏ជាកិច្ចការសង្គ្រោះមនុស្សដែរ

មនុស្សគ្រប់គ្នាត្រូវតែយល់ពីគោលបំណងនៃកិច្ចការរបស់ខ្ញុំនៅលើផែនដីនេះ ពោលគឺអ្វី ដែលខ្ញុំសព្វព្រះហឫទ័យចង់ទទួលបាននៅពេលចុងក្រោយបំផុត និង កម្រិតដែលខ្ញុំត្រូវសម្រេចបាននៅក្នុងកិច្ចការនេះ មុនពេលវាត្រូវបញ្ចប់។ បន្ទាប់ពីបាន ដើរជាមួយខ្ញុំរហូតមកដល់ថ្ងៃនេះហើយ ប្រសិនបើមនុស្សនៅតែមិនយល់ពីអ្វីដែលជា កិច្ចការរបស់ខ្ញុំទៀត នោះតើពួកគេមិនមែនដើរជាមួយខ្ញុំដោយឥតប្រយោជន៍ទេឬអី? ប្រសិនបើមនុស្សដើរតាមខ្ញុំ នោះពួកគេគួរតែដឹងពីបំណងព្រះហឫទ័យរបស់ខ្ញុំ។ ខ្ញុំ បានធ្វើការនៅលើផែនដី អស់រយៈពេលរាប់ពាន់ឆ្នាំមកហើយ ហើយរហូតមកដល់ សព្វថ្ងៃនេះ ក៏ខ្ញុំនៅតែបន្តបំពេញកិច្ចការរបស់ខ្ញុំតទៅទៀតដែរ។ ទោះបីជាមាន គម្រោងជាច្រើន នៅក្នុងកិច្ចការរបស់ខ្ញុំក៏ដោយ ក៏គោលបំណងនៃកិច្ចការនោះ មិនផ្លាស់ប្ដូរដែរ ហើយទោះបីជាខ្ញុំពេញដោយការជំនុំជម្រះ និងការដាក់ទោស ចំពោះមនុស្សក៏ដោយ ក៏អ្វីដែលខ្ញុំធ្វើ នៅតែដើម្បីជួយសង្គ្រោះមនុស្ស និងដើម្បី ធ្វើឲ្យដំណឹងល្អរបស់ខ្ញុំ កាន់តែរីកសុសសាយ ព្រមទាំងដើម្បីពង្រីកកិច្ចការរបស់ខ្ញុំ នៅក្នុងចំណោមសាសន៍ដទៃទាំងអស់ដែរ នៅពេលដែលមនុស្សបានជាបរិបូរ។ ដូច្នេះ ទោះបីជានៅពេលដែលមនុស្សជាច្រើនបានលិចលង់ជ្រៅទៅក្នុងសេចក្ដីអស់សង្ឃឹម ជាយូរមកហើយក៏ដោយ ក៏ថ្ងៃនេះខ្ញុំនៅតែបន្តធ្វើកិច្ចការរបស់ខ្ញុំតទៅទៀតដែរ គឺខ្ញុំ បន្តកិច្ចការដែលខ្ញុំត្រូវធ្វើដើម្បីជំនុំជម្រះ និងដាក់ទោសដល់មនុស្សលោក។ ទោះបីជា មនុស្សធុញទ្រាន់នឹងអ្វីដែលខ្ញុំមានបន្ទូល ហើយមិនខ្វល់ខ្វាយចំពោះកិច្ចការរបស់ខ្ញុំ ក៏ដោយ ក៏ខ្ញុំនៅតែបំពេញភារកិច្ចរបស់ខ្ញុំដែរ ព្រោះគោលបំណងនៃកិច្ចការរបស់ខ្ញុំ មិនផ្លាស់ប្ដូរឡើយ ហើយផែនការដើមរបស់ខ្ញុំក៏មិនបានបរាជ័យដែរ។ មុខងារនៃការ ជំនុំជម្រះរបស់ខ្ញុំ គឺដើម្បីជួយឲ្យមនុស្សកាន់តែស្ដាប់បង្គាប់ខ្ញុំ ហើយមុខងារនៃការវាយ ផ្ចាលរបស់ខ្ញុំ គឺដើម្បីឲ្យមនុស្សផ្លាស់ប្ដូរកាន់តែមានប្រសិទ្ធភាព។ ទោះបីជាអ្វីដែល

ខ្ញុំធ្វើ គឺដើម្បីជាប្រយោជន៍ដល់ការគ្រប់គ្រងរបស់ខ្ញុំក៏ដោយ ក៏ខ្ញុំមិនធ្លាប់ធ្វើអ្វីដែលគ្មានប្រយោជន៍ដល់មនុស្សលោកដែរ ព្រោះខ្ញុំសព្វព្រះហឫទ័យចង់ឲ្យជាតិសាសន៍ទាំងអស់ក្រៅពីអ៊ីស្រាអែលស្ដាប់បង្គាប់ខ្ញុំ ដូចជាជនជាតិអ៊ីស្រាអែលដែរ ដើម្បីធ្វើឲ្យពួកគេក្លាយទៅជាមនុស្សពិតប្រាកដ ប្រយោជន៍ឲ្យខ្ញុំអាចមានមូលដ្ឋាននៅលើទឹកដីផ្សេងទៀតក្រៅពីអ៊ីស្រាអែល។ នេះហើយជាការគ្រប់គ្រងរបស់ខ្ញុំ។ វាជាកិច្ចការដែលខ្ញុំកំពុងសម្រេចក្នុងចំណោមសាសន៍ដទៃ។ សូម្បីតែឥឡូវនេះ ក៏នៅតែមានមនុស្សជាច្រើនមិនយល់ពីការគ្រប់គ្រងរបស់ខ្ញុំដែរ ព្រោះពួកគេមិនចាប់អារម្មណ៍ចំពោះរឿងបែបនេះ ហើយពួកគេយកចិត្តទុកដាក់តែចំពោះអនាគត ហើយនិងទិសដៅរបស់ខ្លួនប៉ុណ្ណោះ។ មិនថាខ្ញុំមានបន្ទូលអ្វីក៏ដោយ ក៏ពួកគេនៅតែមិនអើពើចំពោះកិច្ចការដែលខ្ញុំធ្វើដែរ ផ្ទុយទៅវិញ ពួកគេផ្ដោតទាំងស្រុងទៅលើទិសដៅរបស់ពួកគេនៅថ្ងៃស្អែក។ ប្រសិនបើអ្វីៗនៅតែបន្តរបៀបនេះ តើឲ្យកិច្ចការរបស់ខ្ញុំរីកចម្រើនយ៉ាងដូចម្ដេចបាន? តើឲ្យដំណឹងល្អរបស់ខ្ញុំអាចផ្សព្វផ្សាយទៅពាសពេញពិភពលោកយ៉ាងដូចម្ដេចបាន? ចូរដឹងថានៅពេលដែលកិច្ចការរបស់ខ្ញុំរីកចម្រើន នោះខ្ញុំនឹងកម្ទាត់កម្ទាយអ្នករាល់គ្នា ហើយវាយបំបាក់អ្នករាល់គ្នា ដូចជាព្រះយេហូវ៉ាបានវាយបំបាក់ពូជអំបូរអ៊ីស្រាអែលនីមួយៗដែរ។ ការទាំងអស់នេះនឹងកើតឡើង ដើម្បីឲ្យដំណឹងល្អរបស់ខ្ញុំ បានផ្សព្វផ្សាយទៅពាសពេញលើផែនដី និងបានឮទៅដល់សាសន៍ដទៃ ដើម្បីឲ្យទាំងមនុស្សពេញវ័យ និងកុមារបានលើកតម្កើងព្រះនាមខ្ញុំ ហើយដើម្បីឲ្យបបូរមាត់របស់មនុស្សពីគ្រប់ពូជអំបូរ និងគ្រប់ជាតិសាសន៍ទាំងអស់ បានសរសើរដល់ព្រះនាមដ៏បរិសុទ្ធរបស់ខ្ញុំ។ ដូច្នេះ គឺនៅក្នុងយុគសម័យចុងក្រោយនេះហើយ ដែលគេនឹងលើកតម្កើងព្រះនាមរបស់ខ្ញុំនៅក្នុងចំណោមសាសន៍ដទៃ ហើយពួកគេនឹងមើលឃើញការប្រព្រឹត្តរបស់ខ្ញុំ ព្រមទាំងហៅខ្ញុំថាជាព្រះដ៏មានគ្រប់ចេស្ដា ទៅតាមដំណើររឿងនៃការប្រព្រឹត្តរបស់ខ្ញុំ ហើយព្រះបន្ទូលរបស់ខ្ញុំនឹងសម្រេចក្នុងពេលឆាប់ៗនេះ។ ខ្ញុំនឹងធ្វើឲ្យមនុស្សទាំងអស់ដឹងថា ខ្ញុំមិនត្រឹមតែជាព្រះជាម្ចាស់របស់ជនជាតិអ៊ីស្រាអែលប៉ុណ្ណោះទេ ប៉ុន្តែក៏ជាព្រះជាម្ចាស់របស់ជាតិសាសន៍ដទៃទៀតដែរ រួមទាំងអស់អ្នកដែលខ្ញុំបានដាក់បណ្ដាសា

ផង។ ខ្ញុំនឹងឲ្យមនុស្សទាំងអស់ឃើញថា ខ្ញុំគឺជាព្រះជាម្ចាស់នៃអ្វីៗទាំងអស់។ នេះហើយជាកិច្ចការដ៏ធំបំផុតរបស់ខ្ញុំ ជាគោលបំណងនៃផែនការកិច្ចការរបស់ខ្ញុំនៅគ្រាចុងក្រោយ និងជាកិច្ចការតែមួយគត់ដែលត្រូវសម្រេចនៅគ្រាចុងក្រោយ។

មានតែនៅគ្រាចុងក្រោយទេ ទើបកិច្ចការដែលខ្ញុំបាន និងកំពុងគ្រប់គ្រងអស់រយៈពេលរាប់ពាន់ឆ្នាំមកនេះ ត្រូវបានបើកសម្ដែងទាំងស្រុងឲ្យមនុស្សឃើញ។ លើសពីនេះទៅទៀត មានតែនៅគ្រាឥឡូវនេះទេ ដែលខ្ញុំបានបង្ហាញអាថ៌កំបាំងនៃការគ្រប់គ្រងរបស់ខ្ញុំពេញលេញទៅដល់មនុស្ស ហើយមនុស្ស ក៏បានដឹងពីគោលបំណងនៃកិច្ចការរបស់ខ្ញុំដែរ ព្រមទាំងបានយល់ពីអាថ៌កំបាំងទាំងអស់របស់ខ្ញុំផង។ ខ្ញុំបានប្រាប់ដល់មនុស្សរួចហើយ អំពីអ្វីៗគ្រប់យ៉ាងនៃទិសដៅដែលពួកគេខ្វល់ខ្វាយ។ ខ្ញុំបានលាតត្រដាងឲ្យមនុស្សដឹងពីអាថ៌កំបាំងទាំងអស់របស់ខ្ញុំ ជាអាថ៌កំបាំងដែលបានលាក់ទុកជាង៥៩០០ឆ្នាំមកហើយ។ តើព្រះយេហូវ៉ាជានរណា? តើព្រះមែស្ស៊ីជានរណា? តើព្រះយេស៊ូវជានរណា? អ្នករាល់គ្នាគួរតែដឹងពីរឿងទាំងអស់នេះហើយ។ កិច្ចការរបស់ខ្ញុំ គឺផ្ដោតសំខាន់ទៅលើឈ្មោះទាំងនេះ។ តើអ្នករាល់គ្នាបានយល់ពីការនោះដែរឬទេ? តើព្រះនាមដ៏បរិសុទ្ធរបស់ខ្ញុំ គួរតែត្រូវបានគេប្រកាសយ៉ាងដូចម្ដេច? តើព្រះនាមរបស់ខ្ញុំ គួរតែបានឮទៅដល់ជាតិសាសន៍ដែលបានអំពាវនាវរកខ្ញុំ តាមព្រះនាមណាមួយរបស់ខ្ញុំ យ៉ាងដូចម្ដេច? កិច្ចការរបស់ខ្ញុំកំពុងរីកចម្រើន ហើយខ្ញុំនឹងផ្សព្វផ្សាយពីភាពពេញលេញនៃកិច្ចការនេះ ទៅដល់គ្រប់ជាតិសាសន៍ទាំងអស់។ ដោយសារកិច្ចការរបស់ខ្ញុំ ត្រូវបានអនុវត្តតាមរយៈអ្នករាល់គ្នា ខ្ញុំនឹងវាយបំបាក់អ្នករាល់គ្នាដូចជាព្រះយេហូវ៉ាបានវាយបំបាក់អ្នកគង្វាលនៃដំណាក់របស់ដាវីឌនៅក្នុងប្រទេសអ៊ីស្រាអែលដែរ ដោយធ្វើឲ្យអ្នករាល់គ្នាខ្ចាត់ខ្ចាយទៅក្នុងគ្រប់ជាតិសាសន៍ទាំងអស់។ ដ្បិតនៅគ្រាចុងក្រោយ ខ្ញុំនឹងកម្ទេចជាតិសាសន៍ទាំងអស់ ឲ្យទៅជាគំនរបាក់បែក ហើយឲ្យប្រជាជននៃជាតិសាសន៍ទាំងអស់នោះ បែកខ្ញែកគ្នាជាថ្មី។ នៅពេលដែលខ្ញុំត្រឡប់មកវិញ ជាតិសាសន៍ទាំងអស់ត្រូវបានញែកចេញពីគ្នាតាមខ័ណ្ឌសីមាដែលបានកំណត់ដោយអណ្ដាតភ្លើងដ៏សន្ធោសន្ធៅរបស់ខ្ញុំរួចទៅហើយ។ នៅគ្រានោះ ខ្ញុំ

នឹងបង្ហាញខ្លួនឲ្យមនុស្សជាតិឃើញសាជាថ្មី ដូចជាព្រះអាទិត្យដែលកំពុងឆេះយ៉ាងសន្ធោសន្ធៅ ទាំងបង្ហាញខ្លួនខ្ញុំដោយបើកចំហដល់ពួកគេ ក្នុងរូបអង្គជាព្រះដ៏បរិសុទ្ធមួយអង្គ ដែលពួកគេមិនធ្លាប់បានឃើញ ហើយក៏ដើរក្នុងចំណោមប្រជាជាតិជាច្រើន ដូចដែលខ្ញុំបានដើរក្នុងនាមជាព្រះយេហូវ៉ានៅក្នុងចំណោមពូជអំបូរយូដាដែរ។ ចាប់ពីពេលនោះតទៅ ខ្ញុំនឹងដឹកនាំជីវិតមនុស្សជាតិនៅលើផែនដីនេះ។ នៅទីនោះ ពួកគេនឹងមើលឃើញសិរីរុងរឿងរបស់ខ្ញុំ ហើយពួកគេនឹងមើលឃើញបង្គោលពពកមួយនៅក្នុងខ្យល់ ដែលដឹកនាំជីវិតរបស់ពួកគេ ព្រោះខ្ញុំនឹងបង្ហាញខ្លួននៅកន្លែងដែលបរិសុទ្ធ។ មនុស្សនឹងឃើញថ្ងៃនៃសេចក្ដីសុចរិតរបស់ខ្ញុំ ហើយក៏ឃើញការបើកសម្ដែងដ៏រុងរឿងរបស់ខ្ញុំដែរ។ ការនោះកើតឡើងនៅពេលដែលខ្ញុំសោយរាជ្យលើផែនដីទាំងមូល ហើយខ្ញុំនឹងនាំពួកកូនប្រុសជាច្រើនរបស់ខ្ញុំចូលទៅក្នុងសិរីរុងរឿង។ មនុស្សគ្រប់ទីកន្លែងនៅលើផែនដីនឹងឱនក្រាបចុះ ហើយរោងឧបោសថរបស់ខ្ញុំនឹងត្រូវសាងសង់ឡើងយ៉ាងមាំនៅកណ្ដាលមនុស្សជាតិ គឺនៅលើថ្មដានៃកិច្ចការដែលខ្ញុំបំពេញសព្វថ្ងៃនេះ។ មនុស្សក៏នឹងបម្រើខ្ញុំនៅក្នុងព្រះវិហារដែរ។ ខ្ញុំនឹងកម្ទេចអាសនាដែលគ្របដណ្ដប់ដោយរបស់ស្មោកគ្រោក និងគួរឲ្យស្អប់ខ្ពើម ទៅជាបំណែកតូចៗ ហើយសាងសង់ឡើងជាថ្មី។ គេនឹងយកកូនចៀម ព្រមទាំងកូនគោដែលទើបកើតថ្មីៗទៅដាក់នៅលើអាសនាបរិសុទ្ធ។ ខ្ញុំនឹងបំផ្លាញព្រះវិហារសព្វថ្ងៃនេះចោល ហើយសាងសង់ព្រះវិហារថ្មីមួយ។ ព្រះវិហារដែលឈរនៅពេលនេះ ជាព្រះវិហារដែលសម្បូរដោយមនុស្សគួរឲ្យស្អប់ខ្ពើម នឹងត្រូវដួលរលំចុះ ហើយខ្ញុំនឹងសាងសង់ព្រះវិហារថ្មីមួយ ដែលពេញដោយអ្នកបម្រើដែលស្មោះត្រង់ចំពោះខ្ញុំ។ ពួកគេនឹងក្រោកឈរឡើងជាថ្មី ហើយបម្រើដល់ខ្ញុំ សម្រាប់ជាប្រយោជន៍ដល់សិរីរុងរឿងនៃព្រះវិហាររបស់ខ្ញុំ។ អ្នករាល់គ្នានឹងឃើញថ្ងៃដែលខ្ញុំទទួលសិរីរុងរឿងដ៏អស្ចារ្យយ៉ាងពិតប្រាកដ ហើយអ្នករាល់គ្នាក៏នឹងឃើញថ្ងៃដែលខ្ញុំបំផ្លាញព្រះវិហារនេះចោល ហើយសាងសង់ព្រះវិហារថ្មីមួយឡើងវិញ យ៉ាងពិតប្រាកដដែរ។ អ្នករាល់គ្នានឹងឃើញថ្ងៃដែលរោងឧបោសថរបស់ខ្ញុំចូលមកដល់ពិភពលោករបស់មនុស្សយ៉ាងពិតប្រាកដ។ កាលណាខ្ញុំកម្ទេចព្រះវិហារនេះចោល នោះខ្ញុំនឹង

នាំយករោងឧបោសថរបស់ខ្ញុំ ចូលមកក្នុងពិភពលោករបស់មនុស្ស ដូចដែលពួកគេមើលឃើញការយាងមកដល់របស់ខ្ញុំដែរ។ ក្រោយពេលដែលខ្ញុំកម្ទេចជាតិសាសន៍ទាំងអស់ហើយ ខ្ញុំនឹងប្រមូលពួកគេមកជួបជុំគ្នាជាថ្មី ហើយសាងសង់ព្រះវិហារ និងអាសនារបស់ខ្ញុំឡើងវិញ ដើម្បីឲ្យមនុស្សទាំងអស់អាចថ្វាយយញ្ញបូជាដល់ខ្ញុំ បម្រើខ្ញុំនៅក្នុងព្រះវិហារ ព្រមទាំងលះបង់ចំពោះកិច្ចការរបស់ខ្ញុំនៅក្នុងចំណោមសាសន៍ដទៃដោយស្មោះត្រង់។ ពួកគេនឹងបានដូចជនជាតិអ៊ីស្រាអែលនៅពេលបច្ចុប្បន្ន ដែលប្រដាប់កាយដោយសម្លៀកបំពាក់របស់បូជាចារ្យ និងមកុដ មានទាំងសិរីរុងរឿងរបស់ខ្ញុំដែលជាព្រះយេហូវ៉ា នៅកណ្ដាលចំណោមពួកគេផង ហើយឫទ្ធានុភាពរបស់ខ្ញុំក៏នៅរេរាលើពួកគេ និងនៅជាប់ជាមួយពួកគេដែរ។ កិច្ចការរបស់ខ្ញុំនៅក្នុងចំណោមសាសន៍ដទៃ ក៏នឹងអនុវត្តតាមរបៀបដូចគ្នានេះដែរ។ ដែលខ្ញុំអនុវត្តកិច្ចការរបស់ខ្ញុំ នៅក្នុងប្រទេសអ៊ីស្រាអែលជាយ៉ាងណា នោះខ្ញុំក៏នឹងអនុវត្តវា នៅក្នុងចំណោមសាសន៍ដទៃយ៉ាងនោះដែរ ព្រោះខ្ញុំនឹងពង្រីកកិច្ចការរបស់ខ្ញុំនៅក្នុងប្រទេសអ៊ីស្រាអែល ហើយផ្សព្វផ្សាយកិច្ចការនេះទៅដល់សាសន៍ដទៃទាំងអស់។

ឥឡូវនេះ ដល់ពេលដែលព្រះវិញ្ញាណរបស់ខ្ញុំធ្វើកិច្ចការដ៏អស្ចារ្យហើយ ក៏ដល់ពេលដែលខ្ញុំបំពេញកិច្ចការរបស់ខ្ញុំ នៅក្នុងចំណោមសាសន៍ដទៃដែរ។ លើសពីនោះទៅទៀត ដល់ពេលដែលខ្ញុំត្រូវញែកមនុស្សទាំងអស់ទៅតាមប្រភេទនីមួយៗរបស់ពួកគេរៀងៗខ្លួនហើយ ប្រយោជន៍ឲ្យកិច្ចការរបស់ខ្ញុំ ដំណើរការទៅមុខបានលឿន និងមានប្រសិទ្ធភាព។ ដូច្នេះហើយ អ្វីដែលខ្ញុំស្នើសុំពីអ្នករាល់គ្នាគឺឲ្យអ្នកផ្ដល់នូវលក្ខណៈទាំង ដើម្បីកិច្ចការទាំងអស់របស់ខ្ញុំ ហើយលើសពីនេះទៅទៀត គឺឲ្យអ្នកយល់ច្បាស់ពីការងារទាំងអស់ដែលខ្ញុំបានធ្វើនៅក្នុងអ្នក ហើយធ្វើនូវកិច្ចការជាក់លាក់ទាំងអស់នោះ ព្រមទាំងប្រឹងឲ្យអស់ពីកម្លាំងកាយក្នុងការបំពេញកិច្ចការរបស់ខ្ញុំផង ដើម្បីឲ្យកិច្ចការនោះកាន់តែមានប្រសិទ្ធភាព។ នេះហើយជាអ្វីដែលអ្នកត្រូវយល់។ ចូរបោះបង់ការតយុទ្ធគ្នា ទៅវិញទៅមកក្នុងចំណោមអ្នករាល់គ្នា ដើម្បីស្វែងរកផ្លូវត្រឡប់ក្រោយ ឬស្វែងរកការកម្សាន្តចិត្តខាងសាច់ឈាម ដែលនឹងពន្យារពេលកិច្ចការរបស់ខ្ញុំ និងអូស

បន្លាយអនាគតដ៏អស្ចារ្យរបស់អ្នក។ ក្រៅពីមិនអាចការពារអ្នកបាន ការធ្វើដូច្នេះនឹងនាំមកនូវការបំផ្លាញដល់ខ្លួនអ្នក។ តើនេះ មិនមែនជាភាពល្ងង់ខ្លៅរបស់អ្នកទេឬអី? អ្វីៗដែលអ្នករីករាយដោយការលោភលន់នៅថ្ងៃនេះ គឺជាកត្តាដែលកំពុងបំផ្លាញដល់អនាគតរបស់អ្នក តែការឈឺចាប់ដែលអ្នកទទួលរងនៅថ្ងៃនេះ គឺជារនាំងដែលកំពុងការពារអ្នក។ អ្នកត្រូវតែដឹងឲ្យច្បាស់ពីរឿងទាំងអស់នេះ ដើម្បីចៀសវាងពីការធ្លាក់ទៅក្នុងសេចក្ដីល្បួង ដែលអ្នកពិបាកនឹងដកខ្លួនចេញ ហើយគេចពីការវង្វេងចូលទៅក្នុងអ័ព្ទដ៏ក្រាស់ និងមិនអាចរកពន្លឺព្រះអាទិត្យឃើញ។ នៅពេលដែលអ័ព្ទដ៏ក្រាស់នោះរសាត់អស់ទៅ អ្នកនឹងឃើញខ្លួនឯងស្ថិតនៅក្នុងការជំនុំជម្រះនៃថ្ងៃដ៏អស្ចារ្យ។ នៅពេលនោះ ថ្ងៃរបស់ខ្ញុំនឹងចូលមកជិតមនុស្ស។ តើអ្នកនឹងរត់គេចពីការជំនុំជម្រះរបស់ខ្ញុំបានយ៉ាងដូចម្ដេច? តើអ្នកអាចនឹងទ្រាំទ្រនៅក្រោមកម្ដៅព្រះអាទិត្យដែលឆេះយ៉ាងសន្ធោសន្ធៅយ៉ាងដូចម្ដេច? នៅពេលដែលខ្ញុំប្រគល់ភាពបរិបូររបស់ខ្ញុំទៅឲ្យមនុស្ស គេមិនបានឱបវាជាប់នឹងដើមទ្រូងរបស់គេដោយក្ដីស្រឡាញ់ទេ ប៉ុន្តែពួកគេបែរជាបោះវាចោលទៅកន្លែងមួយដែលគ្មានអ្នកណាម្នាក់ចាប់អារម្មណ៍សោះឡើយ។ នៅពេលដែលគ្រារបស់ខ្ញុំធ្លាក់មកលើមនុស្ស គេនឹងមិនអាចរកឃើញភាពបរិបូររបស់ខ្ញុំទៀតឡើយ តែគេនឹងរកឃើញពាក្យដ៏ជូរចត់នៃសេចក្ដីពិត ដែលខ្ញុំបាននិយាយទៅកាន់គេតាំងពីយូរមកហើយ។ គេនឹងស្រែកថ្ងូរ ហើយយំសោក ព្រោះគេបានបាត់បង់ នូវពន្លឺដ៏ត្រចះត្រចង់ ហើយបានធ្លាក់ចូលទៅក្នុងសេចក្ដីងងឹត។ អ្វីដែលអ្នករាល់គ្នាមើលឃើញនៅថ្ងៃនេះ គឺគ្រាន់តែជាដាវមុតស្រួច នៃព្រះឱស្ឋរបស់ខ្ញុំប៉ុណ្ណោះ។ អ្នកមិនទាន់បានឃើញដំបងនៅក្នុងដៃរបស់ខ្ញុំ ឬក៏អណ្ដាតភ្លើងដែលខ្ញុំបញ្ឆេះមនុស្សនៅឡើយទេ ទើបបានជាអ្នកនៅតែព្រហើន និងហួសហេតុនៅចំពោះមុខខ្ញុំ។ ហេតុនោះហើយបានជាអ្នកនៅតែតយុទ្ធជាមួយខ្ញុំនៅក្នុងដំណាក់របស់ខ្ញុំ ដោយប្រើអណ្ដាតមនុស្សរបស់អ្នក មកប្រកែកនឹងអ្វីដែលខ្ញុំបានមានបន្ទូលដោយព្រះឱស្ឋរបស់ខ្ញុំផ្ទាល់។ មនុស្សមិនកោតខ្លាចខ្ញុំទេ ហើយទោះបីជាគេនៅតែបន្តស្អប់ខ្ញុំរហូតដល់សព្វថ្ងៃនេះក៏ដោយ ក៏គេនៅតែគ្មានការកោតខ្លាចអ្វីដែរ។ អ្នករាល់គ្នា

មានអណ្ដាត និងធ្មេញរបស់មនុស្សទុច្ចរិតនៅក្នុងមាត់របស់អ្នករាល់គ្នា។ ពាក្យសម្ដី និងការប្រព្រឹត្តរបស់អ្នករាល់គ្នា ប្រៀបដូចជាទង្វើដែលសត្វពស់បានបោកបញ្ឆោតនាងអេវ៉ាឲ្យធ្វើបាបដែរ។ អ្នករាល់គ្នាទាមទារពីគ្នាទៅវិញទៅមក ដោយយកភ្នែកធួននឹងភ្នែក ហើយយកធ្មេញធួននឹងធ្មេញ ហើយអ្នករាល់គ្នាតស៊ូនៅចំពោះមុខខ្ញុំដើម្បីដណ្ដើមឋានៈ កិត្តិនាម និងផលប្រយោជន៍សម្រាប់ខ្លួនឯង ប៉ុន្តែអ្នករាល់គ្នាមិនដឹងថាខ្ញុំកំពុងឃ្លាំមើលពាក្យសម្ដី និងការប្រព្រឹត្តរបស់អ្នករាល់គ្នាដោយស្ងាត់ៗនោះទេ។ មុនពេលដែលអ្នករាល់គ្នាចូលមកចំពោះមុខខ្ញុំ គឺខ្ញុំបានដឹងពីជម្រៅចិត្តរបស់អ្នករាល់គ្នារួចទៅហើយ។ មនុស្សតែងតែប្រាថ្នាចង់គេចចេញពីកណ្ដាប់ព្រះហស្តរបស់ខ្ញុំ និងបង្វែរការសង្កេតចេញពីព្រះនេត្ររបស់ខ្ញុំ ប៉ុន្តែ ខ្ញុំមិនដែលគេចចេញពីពាក្យសម្ដី និងការប្រព្រឹត្តរបស់គេឡើយ។ ផ្ទុយទៅវិញ ខ្ញុំសព្វព្រះហឫទ័យឲ្យពាក្យសម្ដី និងការប្រព្រឹត្តទាំងនោះ ចូលមកក្នុងព្រះនេត្ររបស់ខ្ញុំ ប្រយោជន៍ឲ្យខ្ញុំអាចដាក់ទោសចំពោះអំពើទុច្ចរិតរបស់មនុស្ស និងជំនុំជម្រះការបះបោររបស់ពួកគេ។ ដូច្នេះ ពាក្យសម្ដី និងការប្រព្រឹត្តដោយអាថ៌កំបាំងរបស់មនុស្ស នៅតែត្រូវលាតត្រដាងចំពោះបល្ល័ង្កជំនុំជម្រះរបស់ខ្ញុំ ហើយការជំនុំជម្រះរបស់ខ្ញុំ មិនដែលចាកចេញពីមនុស្សឡើយ ព្រោះការបះបោររបស់ពួកគេច្រើនពេកហើយ។ កិច្ចការរបស់ខ្ញុំ គឺត្រូវដុតបញ្ឆេះ និងបន្សុទ្ធគ្រប់ទាំងពាក្យសម្ដី និងការប្រព្រឹត្តទាំងអស់របស់មនុស្សដែលបាននិយាយ និងបានធ្វើនៅចំពោះវត្តមាននៃព្រះវិញ្ញាណរបស់ខ្ញុំ។ តាមរយៈការធ្វើបែបនេះ[ក] នៅពេលដែលខ្ញុំចាកចេញពីផែនដីទៅ មនុស្សនឹងនៅតែរក្សាភាពស្មោះត្រង់របស់ខ្លួនចំពោះខ្ញុំ ហើយនឹងនៅតែបម្រើខ្ញុំ ដូចដែលអ្នកបម្រើដ៏បរិសុទ្ធរបស់ខ្ញុំធ្វើការបម្រើនៅក្នុងកិច្ចការរបស់ខ្ញុំដែរ ដោយអនុញ្ញាតឲ្យកិច្ចការរបស់ខ្ញុំនៅលើផែនដីនេះ បន្តរហូតដល់ថ្ងៃដែលវាត្រូវបញ្ចប់។

លេខយោង៖

ក. អត្ថបទដើមមិនមានឃ្លា «តាមរយៈការធ្វើបែបនេះ»។

# កិច្ចការនៅក្នុងយុគសម័យនៃក្រឹត្យវិន័យ

កិច្ចការដែលព្រះយេហូវ៉ាបានធ្វើមកលើជនជាតិអ៊ីស្រាអែល បានបង្កើតឱ្យមានកន្លែងកំណើតរបស់ព្រះជាម្ចាស់នៅលើផែនដី នៅក្នុងចំណោមមនុស្ស ជាកន្លែងពិសិដ្ឋដែលព្រះអង្គគង់នៅ។ ទ្រង់កំណត់កិច្ចការរបស់ទ្រង់ សម្រាប់តែជនជាតិអ៊ីស្រាអែលប៉ុណ្ណោះ។ ដំបូង ព្រះអង្គមិនបានធ្វើកិច្ចការនៅខាងក្រៅស្រុកអ៊ីស្រាអែលទេ តែផ្ទុយទៅវិញ ព្រះអង្គបានជ្រើសរើសមនុស្ស ដែលព្រះអង្គទតឃើញថាសមរម្យ ដើម្បីកំណត់វិសាលភាពនៃកិច្ចការរបស់ទ្រង់។ អ៊ីស្រាអែល ជាកន្លែងដែលព្រះជាម្ចាស់បានបង្កើតអ័ដាម និងអេវ៉ា។ ព្រះយេហូវ៉ាបានសូនមនុស្សចេញពីធូលីដី នៅកន្លែងនោះ។ កន្លែងនោះបានក្លាយជាមូលដ្ឋាននៃកិច្ចការរបស់ទ្រង់នៅលើផែនដី។ ជនជាតិអ៊ីស្រាអែល ដែលជាពូជពង្សរបស់ណូអេ និងជាពូជពង្សរបស់អ័ដាមដែរនោះ ជាគ្រឹះរបស់មនុស្សនៃកិច្ចការរបស់ព្រះយេហូវ៉ានៅលើផែនដី។

ពេលនោះ សារៈសំខាន់ គោលបំណង និងជំហាននៃកិច្ចការរបស់ព្រះយេហូវ៉ាក្នុងស្រុកអ៊ីស្រាអែល គឺដើម្បីចាប់ផ្ដើមកិច្ចការរបស់ទ្រង់នៅលើផែនដីទាំងមូល ដោយយកអ៊ីស្រាអែលធ្វើជាចំណុចកណ្ដាល បន្ទាប់មក រីកសាយបន្តិចម្ដងៗទៅដល់ជាតិសាសន៍ដទៃ។ នេះគឺជាគោលការណ៍អនុលោមទៅតាម កិច្ចការដែលទ្រង់ធ្វើនៅក្នុងចក្រវាឡទាំងមូល ដើម្បីកសាងគំរូមួយ ហើយបន្ទាប់មក ក៏ពង្រីកវារហូតទាល់តែមនុស្សទាំងអស់នៅក្នុងចក្រវាឡបានទទួលដំណឹងល្អរបស់ព្រះអង្គ។ ជនជាតិអ៊ីស្រាអែលដំបូងគេបង្អស់ គឺជាពូជពង្សរបស់ណូអេ។ ដង្ហើមរបស់ព្រះយេហូវ៉ាបានប្រទាននូវជីវិត និងការយល់ដឹងល្មមគ្រប់គ្រាន់ ដល់មនុស្សទាំងនេះ ដើម្បីថែរក្សាមូលដ្ឋានចាំបាច់នៃជីវិត ប៉ុន្តែពួកគេមិនស្គាល់លក្ខណៈរបស់ព្រះយេហូវ៉ាដ៏ជាព្រះ ឬបំណងព្រះហឫទ័យរបស់ទ្រង់សម្រាប់មនុស្សទេ ពួកគេរឹតតែមិនដឹង អំពីរបៀបគោរពកោតខ្លាចដល់ព្រះអម្ចាស់ដែលបង្កើតរបស់សព្វសារពើ។ ដូចនេះ ទោះបីជាមានច្បាប់ និងក្រឹត្យវិន័យ

ដែលត្រូវស្ដាប់តាម[ក] ហើយទោះបីជាមានកិច្ចការដែលមនុស្សត្រូវធ្វើសម្រាប់ព្រះអាទិករក៏ដោយ ក៏ពូជពង្សរបស់អ័ដាមមិនបានដឹងអ្វីសោះដែរ។ អ្វីទាំងអស់ដែលពួកគេបានដឹង គឺ ប្ដីត្រូវតែនឿយហត់ និងធ្វើការដើម្បីផ្គត់ផ្គង់គ្រួសាររបស់គាត់ ហើយភរិយាត្រូវចុះចូលចំពោះប្ដី ព្រមទាំងរក្សាពូជមនុស្សដែលព្រះយេហូវ៉ាបានបង្កើតមកឱ្យគង់វង្ស។ ពោលគឺ មនុស្សដែលមានដង្ហើមរបស់ព្រះយេហូវ៉ា និងជីវិតរបស់ទ្រង់នេះ មិនបានដឹងអំពីរបៀបធ្វើតាមក្រឹត្យវិន័យរបស់ព្រះជាម្ចាស់ ឬដឹងអំពីរបៀបផ្គាប់ព្រះហឫទ័យព្រះអម្ចាស់ ដែលបង្កើតរបស់សព្វសារពើទាល់តែសោះ។ ពួកគេដឹងតិចតួចណាស់។ ដូច្នេះ ទោះបីជាមិនមានអ្វីទុច្ចរិត ឬការបញ្ឆោតនៅក្នុងចិត្តរបស់ពួកគេ មិនមានចិត្តច្រណែន និងកម្រមានការឈ្លោះប្រកែកនៅក្នុងចំណោមពួកគេយ៉ាងណាក៏ដោយ ក៏ពួកគេគ្មានចំណេះដឹងឬការយល់ដឹងអំពីព្រះយេហូវ៉ាជាព្រះអម្ចាស់ ដែលបង្កើតរបស់សព្វសារពើដែរ។ ព្ទយុកោរបស់មនុស្សទាំងនេះបានដឹងត្រឹមតែបរិភោគ និងអរសប្បាយ នឹងរបស់ដែលព្រះយេហូវ៉ាប្រទានប៉ុណ្ណោះទេ ប៉ុន្តែពួកគេមិនបានដឹងអំពីការគោរពកោតខ្លាចដល់ព្រះយេហូវ៉ាទៀតផង។ ពួកគេមិនបានដឹងថា ព្រះយេហូវ៉ាជាអ្នកដែលពួកគេត្រូវថ្វាយបង្គំដោយលុតជង្គង់ឡើយ។ ដូច្នេះ តើឱ្យទ្រង់ហៅពួកគេថាជាមនុស្សដែលទ្រង់បង្កើតដូចម្ដេចបាន? បើដូច្នេះមែន តើពាក្យថា៖ «ព្រះយេហូវ៉ាជាព្រះអម្ចាស់ ដែលបង្កើតរបស់សព្វសារពើ» និង «ទ្រង់បង្កើតមនុស្សមក ដើម្បីឱ្យមនុស្សបង្ហាញពីទ្រង់ថ្វាយសិរីល្អដល់ទ្រង់ និងតំណាងទ្រង់» មិនទៅជាសម្ដី ឥតប្រយោជន៍ទេឬ? តើមនុស្សដែលគ្មានការគោរពកោតខ្លាចដល់ព្រះយេហូវ៉ា ក្លាយជាស្មរបន្ទាល់អំពីសិរីល្អរបស់ទ្រង់ដោយរបៀបណា? តើពួកគេក្លាយជាការសម្ដែងពីសិរីល្អរបស់ទ្រង់ដោយរបៀបណា? តើព្រះបន្ទូលរបស់ព្រះយេហូវ៉ាដែលថា៖ «ខ្ញុំបង្កើតមនុស្ស ឲ្យដូចរូបអង្គរបស់ខ្ញុំ» មិនក្លាយជាអាវុធ

លេខយោង៖

ក. អត្ថបទដើមមិនមានឃ្លា «ស្ដាប់តាម»។

នៅក្នុងដៃរបស់អារក្សសាតាំង ដែលជាមេកំណាចទេឬអី? តើពាក្យទាំងនេះមិនក្លាយជាសញ្ញាសម្គាល់នៃការប្រមាថដល់ការដែលព្រះយេហូវ៉ាបង្កើតមនុស្សមកទេឬអី? ដើម្បីបញ្ចប់ដំណាក់កាលនៃកិច្ចការនោះ គឺបន្ទាប់ពីបានបង្កើតមនុស្សរួចមក ព្រះយេហូវ៉ាមិនបានណែនាំ ឬទូន្មានពួកគេ ចាប់តាំងតែពីជំនាន់អ័ដាមរហូតដល់ជំនាន់លោក ណូអេ។ ផ្ទុយទៅវិញ លុះដល់ក្រោយសម័យទឹកជំនន់បានបំផ្លាញពិភពលោករួចមក ទើបព្រះអង្គចាប់ផ្ដើមទូន្មាន ជនជាតិអ៊ីស្រាអែលជាពូជពង្សរបស់ណូអេ និងអ័ដាមជាផ្លូវការ។ កិច្ចការ និងព្រះបន្ទូលរបស់ទ្រង់នៅក្នុងស្រុកអ៊ីស្រាអែល ផ្ដល់នូវការទូន្មានដល់ប្រជាជនអ៊ីស្រាអែលទាំងអស់ ពេលពួកគេរស់នៅក្នុងជីវិតរបស់ពួកគេនៅលើដែនដីអ៊ីស្រាអែលទាំងមូល។ ការនេះបង្ហាញដល់មនុស្សថា ព្រះយេហូវ៉ាមិនត្រឹមតែអាចផ្លុំខ្យល់ដង្ហើមចូលទៅក្នុងមនុស្ស ដើម្បីឱ្យគេមានជីវិតពីទ្រង់ និងរស់ឡើងចេញពីធូលីដី ទៅជាមនុស្សដែលទ្រង់បង្កើតមកប៉ុណ្ណោះទេ តែទ្រង់ក៏អាចបំផ្លាញមនុស្ស និងដាក់បណ្ដាសាមនុស្ស ព្រមទាំងប្រើព្រនង់របស់ទ្រង់ ដើម្បីគ្រប់គ្រងមនុស្សបាន។ ធ្វើដូច្នេះទើបពួកគេយល់ឃើញថា ព្រះយេហូវ៉ាអាចដឹកនាំជីវិតរបស់មនុស្សនៅលើផែនដី និងមានព្រះបន្ទូល ព្រមទាំងធ្វើការនៅក្នុងចំណោមមនុស្ស ស្របទៅតាមម៉ោងពេលនៃវេលាថ្ងៃ និងយប់ផង។ កិច្ចការដែលព្រះអង្គបានធ្វើ គឺដើម្បីឱ្យមនុស្សដែលទ្រង់បានបង្កើតមកដឹងថាមនុស្សបានកើតមកពីធូលីដី ដែលទ្រង់បានរើស ហើយលើសពីនេះទៀត គឺមនុស្សត្រូវបានបង្កើតឡើងដោយសារទ្រង់។ មិនត្រឹមតែប៉ុណ្ណោះទេ ដំបូងទ្រង់បានធ្វើកិច្ចការរបស់ទ្រង់នៅក្នុងស្រុកអ៊ីស្រាអែល ដើម្បីឱ្យមនុស្ស និងប្រជាជាតិដទៃទៀត (ដែលតាមពិតមិនមែនដាច់ដោយឡែកពីអ៊ីស្រាអែលទេ តែផ្ទុយទៅវិញមានអម្បូរចេញពីជនជាតិអ៊ីស្រាអែល ដែលនៅតែជាតំណវង្សពីអ័ដាម និងអេវ៉ា) អាចទទួលដំណឹងល្អរបស់ព្រះយេហូវ៉ាពីអ៊ីស្រាអែល ដើម្បីឱ្យមនុស្សដែលត្រូវបានបង្កើតមកទាំងអស់នៅក្នុងចក្រវាឡ អាចគោរពកោតខ្លាចដល់ព្រះយេហូវ៉ា និងលើកតម្កើងទ្រង់ជាព្រះដ៏ឧត្ដម។ ព្រះយេហូវ៉ាមិនបានចាប់ផ្ដើមកិច្ចការរបស់ទ្រង់នៅអ៊ីស្រាអែលទេ ប៉ុន្ដែផ្ទុយទៅវិញ បន្ទាប់ពីបានបង្កើតមនុស្សរួច ទ្រង់អនុញ្ញាតឱ្យពួកគេ

រស់នៅក្នុងជីវិតដែលឥតព្រួយខ្វល់អ្វីសោះនៅលើផែនដី ហើយក្នុងករណីនេះ គឺទ្រង់ជាម្ចាស់សណ្ឋានរូបសាច់របស់មនុស្ស (សណ្ឋាននេះមានន័យថា មនុស្សមិនអាចដឹងអំពីអ្វីៗដែលគេមិនអាចមើលឃើញឡើយ មានន័យថា គេមិនដឹងទេថា ព្រះយេហូវ៉ាជាអ្នកបង្កើតមនុស្សមក ហើយរឹតតែមិនអាចដឹងថា ហេតុអ្វីបានជាទ្រង់ធ្វើដូច្នេះទេ) គេមិនអាចដឹងថា ព្រះយេហូវ៉ាជាអ្នកបង្កើតមនុស្ស ឬដឹងថា ទ្រង់ជាព្រះអម្ចាស់ដែលបង្កើតរបស់សព្វសារពើទេ។ ប្រសិនបើព្រះយេហូវ៉ាបាន បង្កើតមនុស្ស និងដាក់គាត់នៅលើផែនដី រួចរលាស់ធូលីដីចេញពីព្រះហស្ដ ហើយចាកចេញទៅដោយមិនបន្ដគង់នៅក្នុងចំណោមមនុស្ស ដើម្បីផ្ដល់ការទូន្មានមួយរយៈឱ្យពួកគេ នោះមនុស្សជាតិទាំងអស់មុខជាត្រឡប់ជាសាបសូន្យមិនខាន។ សូម្បីផ្ទៃមេឃ និងផែនដីព្រមទាំងរបស់ជាច្រើនដែលទ្រង់បានបង្កើតមក និងមនុស្សទាំងអស់ នឹងត្រឡប់ទៅជាឥតប្រយោជន៍ ហើយលើសពីនេះទៀត អារក្សសាតាំងមុខជាជាន់ឈ្លីមិនខាន។ ដូច្នេះ ទើបព្រះយេហូវ៉ាសព្វព្រះទ័យឱ្យមាន «កន្លែងមួយដែលទ្រង់តាំងព្រះវត្តមានជាកន្លែងដ៏បរិសុទ្ធនៅលើផែនដី នៅកណ្ដាលចំណោមមនុស្សជាតិ ដែលទ្រង់បង្កើត» ត្រូវខ្ទេចខ្ទីទៅ។ យ៉ាងនេះទើបព្រះអង្គអាចបន្ដគង់នៅកណ្ដាលចំណោមមនុស្ស ដើម្បីដឹកនាំជីវិតរបស់ពួកគេ និងមានព្រះបន្ទូលទៅពួកគេពីកណ្ដាលចំណោមពួកគេ។ ការទាំងអស់នេះ គឺដើម្បីឱ្យដឹងអំពីបំណងព្រះហឫទ័យ និងដើម្បីសម្រេចផែនការរបស់ព្រះអង្គ។ កិច្ចការដែលទ្រង់បានធ្វើនៅអ៊ីស្រាអែល គឺដើម្បីអនុវត្តផែនការដែលទ្រង់បានគ្រោងទុក មុនពេលទ្រង់បង្កើតរបស់សព្វសារពើប៉ុណ្ណោះ ដូច្នេះ កិច្ចការដំបូងដែលទ្រង់បានធ្វើនៅក្នុងចំណោមជនជាតិអ៊ីស្រាអែល និងរបស់សព្វសារពើដែលទ្រង់បង្កើតមិនខុសពីគ្នាទេ ប៉ុន្ដែកិច្ចការទាំងពីរនេះត្រូវបានធ្វើឡើងសម្រាប់ជាប្រយោជន៍ដល់ការគ្រប់គ្រងរបស់ទ្រង់ ដល់កិច្ចការរបស់ទ្រង់ និងដើម្បីជាសិរីល្អដល់ទ្រង់ ព្រមទាំងត្រូវបានធ្វើឡើងដើម្បីផ្ដល់អត្ថន័យ ឱ្យកាន់តែស៊ីជម្រៅដល់ការដែលទ្រង់បង្កើតមនុស្សមក។ ទ្រង់បានដឹកនាំជីវិតរបស់មនុស្សនៅលើផែនដីអស់រយៈពេលពីរពាន់ឆ្នាំក្រោយសម័យណូអេ ក្នុងអំឡុងពេលនេះ ទ្រង់បានបង្រៀនមនុស្សឱ្យយល់ពីរបៀបគោរព

កោតខ្លាចដល់ព្រះយេហូវ៉ាជាព្រះអម្ចាស់ដែលបង្កើតរបស់សព្វសារពើ បង្រៀនគេឱ្យយល់ពីវិធីប្រព្រឹត្តក្នុងជីវិតរបស់ពួកគេ និងរបៀបរស់នៅបន្ត ហើយអ្វីដែលសំខាន់បំផុតនោះ គឺវិធីធ្វើខ្លួនជាស្មរបន្ទាល់សម្រាប់ព្រះយេហូវ៉ា ទាំងស្ដាប់បង្គាប់ទ្រង់ និងថ្វាយការគោរពកោតខ្លាចដល់ទ្រង់ ហើយសរសើរតម្កើងទ្រង់ដោយតន្ត្រី ដូចដាវីឌ និងពួកសង្ឃរបស់ទ្រង់ដែរ។

ពីរពាន់ឆ្នាំមុន គឺនៅគ្រាដែលព្រះយេហូវ៉ាបំពេញកិច្ចការរបស់ទ្រង់ មនុស្សមិនបានដឹងអ្វីសោះ ហើយមនុស្សស្ទើរតែទាំងអស់ បានធ្លាក់ទៅក្នុងអំពើអាក្រក់ជួជាតិ រហូតដល់មុនពេលពិភពលោកត្រូវបំផ្លាញដោយទឹកជំនន់ ពួកគេបានឈានទៅដល់ជម្រៅមួយនៃភាពស្មោកគ្រោក និងសេចក្ដីពុករលួយ ដែលធ្វើឲ្យចិត្តរបស់ពួកគេ គ្មានព្រះយេហូវ៉ាទាល់តែសោះ ហើយក៏មិនចង់ដើរតាមផ្លូវរបស់ព្រះអង្គដែរ។ ពួកគេពុំធ្លាប់បានយល់អំពីកិច្ចការដែលព្រះយេហូវ៉ាបម្រុងនឹងធ្វើនោះឡើយ។ ពួកគេខ្វះហេតុផល និងមានចំណេះដឹងកាន់តែតិច ហើយប្រៀបបីដូចជាគ្រឿងម៉ាស៊ីនដែលដកដង្ហើម គឺពួកគេល្ងង់ខ្លៅបំផុតមិនយល់អ្វីទាំងអស់អំពីមនុស្ស អំពីព្រះជាម្ចាស់ អំពីលោកិយអំពីជីវិត និងអំពីអ្វីៗផ្សេងទៀត។ នៅលើផែនដី ពួកគេចូលរួមក្នុងការល្បួងលួងលោមជាច្រើន ដូចជាសត្វពស់ ហើយនិយាយពាក្យជាច្រើនដែលប្រមាថដល់ព្រះយេហូវ៉ា ប៉ុន្តែដោយព្រោះពួកគេល្ងង់ខ្លៅ ព្រះយេហូវ៉ាពុំបានស្ដីបន្ទោស ឬដាក់វិន័យពួកគេនោះឡើយ។ ទាល់តែទឹកជំនន់ចប់ គឺនៅគ្រាដែលណូអេមានអាយុ៦០១ឆ្នាំ ទើបព្រះយេហូវ៉ាលេចមកឲ្យណូអេឃើញជាផ្លូវការ ហើយដឹកនាំគាត់គ្រួសាររបស់គាត់ និងដឹកនាំបក្សាបក្សី ព្រមទាំងសត្វនានាដែលបានរួចជីវិតពីទឹកជំនន់ជាមួយណូអេ និងកូនចៅរបស់គាត់ រហូតដល់ចុងបញ្ចប់របស់យុគសម័យនៃក្រឹត្យវិន័យ ដែលមានរយៈពេលសរុប២៥០០ឆ្នាំ។ ទ្រង់បានធ្វើការនៅក្នុងស្រុកអ៊ីស្រាអែលជាផ្លូវការដោយប្រើរយៈពេលសរុប២០០០ឆ្នាំ ហើយក៏ធ្វើការព្រមគ្នា ទាំងក្នុង និងក្រៅស្រុកអ៊ីស្រាអែល រយៈពេល៥០០ឆ្នាំទៀត សរុបទាំងអស់មានរយៈពេល២៥០០ឆ្នាំ។ នៅក្នុងគ្រានោះ ទ្រង់បានណែនាំដល់ជនជាតិអ៊ីស្រាអែលថា ដើម្បីបម្រើដល់ព្រះ

យេហូវ៉ា ពួកគេត្រូវសង់ព្រះវិហារ គ្រងសម្លៀកបំពាក់សង្ឃ និងដើរជើងទទេចូលទៅក្នុងព្រះវិហារ នៅពេលព្រលឹមស្រាងៗ ក្រែងស្បែកជើងរបស់ពួកគេធ្វើឲ្យព្រះវិហារកខ្វក់ ហើយក៏មានភ្លើងទម្លាក់មកលើពួកគេពីកំពូលនៃព្រះវិហារ ដុតពួកគេរហូតដល់ស្លាប់។ ពួកគេបំពេញភារកិច្ចរបស់ខ្លួន ហើយចុះចូលចំពោះផែនការរបស់ព្រះយេហូវ៉ា។ ពួកគេអធិស្ឋានទៅកាន់ព្រះយេហូវ៉ានៅក្នុងព្រះវិហារ បន្ទាប់ពីទទួលបានការបើកសម្ដែងពីព្រះយេហូវ៉ារួច គឺក្រោយពេលដែលព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលរួច ពួកគេក៏ដឹកនាំបណ្ដាជន ហើយបង្រៀនពួកគេថា ពួកគេត្រូវបង្ហាញការកោតខ្លាចដល់ព្រះយេហូវ៉ាដ៏ជាព្រះរបស់ពួកគេ។ ព្រះយេហូវ៉ាមានព្រះបន្ទូលប្រាប់ពួកគេថា ពួកគេត្រូវសង់ព្រះវិហារ និងអាសនា ហើយដល់ពេលដែលព្រះយេហូវ៉ាបានកំណត់ នោះគឺក្នុងអំឡុងពេលបុណ្យរំលង ពួកគេត្រូវរៀបចំកូនគោ និងកូនចៀមដែលទើបនឹងកើត រួចយកមកដាក់នៅលើអាសនា ទុកជាយញ្ញបូជាបម្រើដល់ព្រះយេហូវ៉ា ក៏ដូចជាដើម្បីហាមឃាត់ពួកគេ និងដាក់ការកោតខ្លាចដល់ព្រះយេហូវ៉ានៅក្នុងចិត្តរបស់ពួកគេដែរ។ ទោះបីជាពួកគេស្ដាប់បង្គាប់តាមក្រឹត្យវិន័យហើយក៏ដោយ ក៏ការនេះនឹងក្លាយជារង្វាស់នៃភាពស្មោះត្រង់របស់ពួកគេចំពោះព្រះយេហូវ៉ាដែរ។ ព្រះយេហូវ៉ាក៏បានតាំងឱ្យមានថ្ងៃឈប់សម្រាកសម្រាប់ពួកគេ ដែលជាថ្ងៃទី៧នៃការបង្កើតរបស់ព្រះអង្គ។ ១ថ្ងៃបន្ទាប់ពីថ្ងៃឈប់សម្រាក ព្រះអង្គបង្កើតថ្ងៃទី១ ជាថ្ងៃសម្រាប់ពួកគេសរសើរតម្កើងដល់ព្រះយេហូវ៉ា ថ្វាយយញ្ញបូជា និងលេងតន្ត្រីថ្វាយទ្រង់។ នៅថ្ងៃនេះ ព្រះយេហូវ៉ាបានហៅពួកសង្ឃទាំងអស់ មកបែងចែកយញ្ញបូជា នៅលើអាសនាសម្រាប់បណ្ដាជនបរិភោគ ដើម្បីឱ្យពួកគេអាចអរសប្បាយនឹងយញ្ញបូជា នៅលើអាសនារបស់ព្រះយេហូវ៉ា។ បន្ទាប់មកព្រះយេហូវ៉ាមានព្រះបន្ទូលថា ពួកគេមានព្រះពរហើយ ដែលពួកគេបានរួមចំណែកជាមួយព្រះអង្គ ហើយពួកគេជាប្រជារាស្ត្រដែលព្រះអង្គបានជ្រើសរើស (នេះគឺជាសេចក្ដីសញ្ញារបស់ព្រះយេហូវ៉ាចំពោះជនជាតិអ៊ីស្រាអែល)។ ហេតុនេះហើយបានជារហូតមកដល់សព្វថ្ងៃនេះ ប្រជាជនអ៊ីស្រាអែលនៅតែពោលថា ព្រះយេហូវ៉ាជាព្រះរបស់ពួកគេតែមួយគត់ មិនមែនជាព្រះរបស់សាសន៍ដទៃឡើយ។

ក្នុងអំឡុងយុគសម័យនៃក្រឹត្យវិន័យ ព្រះយេហូវ៉ាបានប្រទានបញ្ញត្តិជាច្រើនដល់ម៉ូសេ ដើម្បីឱ្យលោកផ្ទេរបញ្ញត្តិទាំងអស់នេះឱ្យទៅជនជាតិអ៊ីស្រាអែល ដែលបានដើរតាមលោកចេញពីស្រុកអេស៊ីព្ទ។ បញ្ញត្តិទាំងនេះ ត្រូវបានប្រទានមកដោយព្រះយេហូវ៉ា សម្រាប់ជនជាតិអ៊ីស្រាអែល និងគ្មានទាក់ទងអ្វីជាមួយជនជាតិអេស៊ីព្ទឡើយ គឺដើម្បីដាក់កំហិតដល់ជនជាតិអ៊ីស្រាអែល ហើយទ្រង់ប្រើបញ្ញត្តិទាំងនេះ ដើម្បីឱ្យពួកគេស្ដាប់បង្គាប់។ ទោះបីជាពួកគេប្រតិបត្តិតាមថ្ងៃឈប់សម្រាក ឬអត់ទោះបីជាពួកគេគោរពឪពុកម្ដាយរបស់ពួកគេ ឬអត់ ទោះបីជាពួកគេថ្វាយបង្គំរូបព្រះ និងធ្វើអ្វីៗផ្សេងទៀតឬអត់ ក៏ចំណុចទាំងនេះ គឺជាគោលការណ៍សម្រាប់វិនិច្ឆ័យឱ្យពួកគេមានបាប ឬក៏បានរាប់ជាសុចរិតដែរ។ នៅក្នុងចំណោមពួកគេ មានអ្នកខ្លះត្រូវព្រះយេហូវ៉ាប្រហារដោយភ្លើង អ្នកខ្លះត្រូវគប់សម្លាប់នឹងដុំថ្ម និងអ្នកខ្លះទៀត ទទួលបានព្រះពរពីព្រះយេហូវ៉ា ដោយអាស្រ័យថា ពួកគេស្ដាប់ ឬមិនស្ដាប់តាមបញ្ញត្តិទាំងនេះ។ អស់អ្នកដែលមិនប្រតិបត្តិតាមថ្ងៃឈប់សម្រាក ត្រូវគប់សម្លាប់នឹងដុំថ្ម។ រីឯពួកសង្ឃដែលមិនប្រតិបត្តិតាមថ្ងៃឈប់សម្រាក ត្រូវប្រហារដោយភ្លើងរបស់ព្រះយេហូវ៉ា។ ចំណែកឯអស់អ្នកដែលមិនគោរពដល់ឪពុកម្ដាយរបស់ខ្លួន ក៏ត្រូវគប់សម្លាប់នឹងដុំថ្មដែរ។ នេះគឺជាបញ្ញត្តិទាំងប៉ុន្មានដែលបានមកពីព្រះយេហូវ៉ា។ ព្រះយេហូវ៉ាបង្កើតបញ្ញត្តិ និងក្រឹត្យវិន័យទាំងប៉ុន្មាន ដើម្បីឱ្យបណ្ដាជនស្ដាប់ និងធ្វើតាមព្រះបន្ទូលរបស់ព្រះអង្គ ហើយមិនបះបោរប្រឆាំងនឹងទ្រង់ នៅពេលដែលព្រះអង្គដឹកនាំជីវិតរបស់ពួកគេ។ ទ្រង់ប្រើក្រឹត្យវិន័យទាំងនេះ ដើម្បីរក្សាពូជសាសន៍មនុស្សដែលកើតថ្មីឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ទ្រង់ ហើយចាក់គ្រឹះដែលល្អជាងមុនសម្រាប់កិច្ចការរបស់ព្រះអង្គនាពេលអនាគត។ ដូច្នេះ យោងតាមកិច្ចការដែលព្រះយេហូវ៉ាទ្រង់បានធ្វើគ្រាដំបូងបំផុតនេះ ត្រូវបានហៅថា «យុគសម័យនៃក្រឹត្យវិន័យ»។ ទោះបីជាព្រះយេហូវ៉ាបានមានព្រះបន្ទូល និងបានធ្វើកិច្ចការជាច្រើនក៏ដោយ ក៏ទ្រង់គ្រាន់តែទូន្មានមនុស្សតាមបែបវិជ្ជមាន ដោយបង្រៀនមនុស្សល្ងង់ខ្លៅទាំងអស់នេះឲ្យដឹងពីរបៀបធ្វើជាមនុស្ស ដឹងពីរបៀបរស់នៅ និងដឹងពីរបៀបស្វែងយល់ផ្លូវរបស់ព្រះយេហូវ៉ាតែប៉ុណ្ណោះ។

កិច្ចការភាគច្រើនដែលព្រះអង្គបានធ្វើ គឺដើម្បីនាំមនុស្ស ឲ្យមើលឃើញនូវផ្លូវរបស់ព្រះអង្គ និងធ្វើតាមក្រឹត្យវិន័យរបស់ព្រះអង្គ។ កិច្ចការរបស់ព្រះជាម្ចាស់ ត្រូវបានធ្វើទៅលើមនុស្សពុករលួយ តែកិច្ចការនេះមិនបានឈានទៅដល់ការផ្លាស់ប្រែនិស្ស័យ ឬវឌ្ឍនភាពនៃជីវិតរបស់ពួកគេឡើយ។ ទ្រង់គ្រាន់តែខ្វល់ខ្វាយ អំពីការប្រើប្រាស់ក្រឹត្យវិន័យ ដើម្បីរឹតត្បិត និងគ្រប់គ្រងមនុស្សប៉ុណ្ណោះ។ ចំពោះជនជាតិអ៊ីស្រាអែលនាសម័យនោះ ព្រះយេហូវ៉ាគឺជាព្រះជាម្ចាស់ ដែលគង់នៅក្នុងព្រះវិហារ និងជាព្រះជាម្ចាស់ដែលគង់នៅស្ថានសួគ៌។ ទ្រង់ជាបង្គោលពពក និងជាបង្គោលភ្លើង។ អ្វីៗទាំងអស់ដែលព្រះយេហូវ៉ាតម្រូវឱ្យពួកគេធ្វើ គឺស្ដាប់បង្គាប់តាមអ្វីដែលមនុស្សសព្វថ្ងៃនេះស្គាល់ថាជាក្រឹត្យវិន័យ និងបញ្ញត្តិ អ្នកខ្លះហៅថាច្បាប់ ព្រោះអ្វីដែលព្រះយេហូវ៉ាបានធ្វើ គឺមិនមែនដើម្បីផ្លាស់ប្រែពួកគេទេ តែដើម្បីប្រទានដល់ពួកគេថែមទៀតនូវអ្វីដែលមនុស្សគួរតែមាន និងដើម្បីណែនាំពួកគេចេញពីព្រះឱស្ឋរបស់ទ្រង់ផ្ទាល់ ដ្បិតក្រោយពីព្រះអង្គបានបង្កើតមនុស្សមក នោះមនុស្ស គ្មានអ្វីដែលពួកគេគួរមានជាកម្មសិទ្ធិទេ។ ដូច្នេះ ព្រះយេហូវ៉ាបានប្រទានដល់មនុស្ស នូវអ្វីដែលពួកគេគួរមានជាកម្មសិទ្ធិសម្រាប់ជីវិតពួកគេនៅលើផែនដី ធ្វើឱ្យមនុស្សដែលព្រះអង្គបានដឹកនាំ មានលើសពីឲ្យុកោរបស់ពួកគេ គឺអ័ដាម និងនាងអេវ៉ា ព្រោះអ្វីដែលព្រះយេហូវ៉ាបានប្រទានដល់ពួកគេ វាលើសពីអ្វីដែលព្រះអង្គបានប្រទានដល់អ័ដាម និងនាងអេវ៉ា កាលពីដើមដំបូង។ យ៉ាងណាក្ដីកិច្ចការដែលព្រះយេហូវ៉ាបានធ្វើនៅក្នុងស្រុកអ៊ីស្រាអែល គឺគ្រាន់តែដើម្បីទូន្មានមនុស្ស និងឱ្យពួកគេស្គាល់ព្រះអាទិកររបស់ពួកគេប៉ុណ្ណោះ។ ព្រះអង្គមិនបានយកឈ្នះលើពួកគេ ឬផ្លាស់ប្រែពួកគេទេ គឺព្រះអង្គគ្រាន់តែតម្រង់ផ្លូវពួកគេប៉ុណ្ណោះ។ នេះគឺជាសេចក្ដីសង្ខេបនៃកិច្ចការរបស់ព្រះយេហូវ៉ានៅក្នុងយុគសម័យនៃក្រឹត្យវិន័យ។ សេចក្ដីនេះជាប្រវត្តិ ជារឿងពិត និងជាលក្ខណៈពិសេសនៃកិច្ចការរបស់ព្រះអង្គ នៅក្នុងទឹកដីទាំងមូលរបស់អ៊ីស្រាអែល ព្រមទាំងជាការចាប់ផ្ដើមកិច្ចការរបស់ទ្រង់រយៈពេលប្រាំមួយពាន់ឆ្នាំ ដើម្បីរក្សាមនុស្សឱ្យស្ថិតក្រោមការគ្រប់គ្រងនៃព្រះហស្ដរបស់ព្រះយេហូវ៉ា។ មានកិច្ចការដទៃទៀត បានកើតចេញពីគម្រោងគ្រប់គ្រងរយៈពេលប្រាំមួយពាន់ឆ្នាំនេះដែរ។

# រឿងពិតពីក្រោយកិច្ចការ នាយុគសម័យនៃការប្រោសលោះ

ផែនការគ្រប់គ្រងទាំងមូលរបស់ខ្ញុំ ដែលជាផែនការគ្រប់គ្រងរយៈពេល៦ពាន់ឆ្នាំ មាន៣ដំណាក់កាល ឬ៣យុគសម័យ៖ យុគសម័យនៃក្រឹត្យវិន័យ នាគ្រាដើមដំបូង យុគសម័យនៃព្រះគុណ (ដែលហៅម្យ៉ាងទៀតថាយុគសម័យនៃការប្រោសលោះ) ហើយនិងយុគសម័យនៃនរគព្រះនាគ្រាចុងក្រោយ។ កិច្ចការរបស់ខ្ញុំ នៅក្នុងយុគសម័យទាំងបីនេះ មានខ្លឹមសារខុសគ្នា អាស្រ័យទៅតាមសណ្ឋាននៃយុគសម័យនីមួយៗ ប៉ុន្តែនៅរាល់ដំណាក់កាលនីមួយៗ កិច្ចការនេះផ្ដល់ប្រយោជន៍ដល់តម្រូវការរបស់មនុស្ស ឬបើនិយាយឲ្យចំ គឺត្រូវបានធ្វើឡើង ដោយស្របទៅនឹងល្បិចដែលសាតាំងប្រើនៅក្នុងសង្គ្រាមដែលខ្ញុំប្រយុទ្ធតតាំងជាមួយវា។ គោលបំណងនៃកិច្ចការរបស់ខ្ញុំ គឺដើម្បីផ្ដួលសាតាំងឲ្យបរាជ័យ ដើម្បីសម្ដែងប្រាជ្ញាញាណ និងសព្វានុភាពរបស់ខ្ញុំ ដើម្បីបើកកកាយល្បិចទាំងអស់របស់សាតាំង និងដើម្បីសង្គ្រោះពូជសាសន៍មនុស្សទាំងមូល ដែលរស់នៅក្រោមដែនគ្រប់គ្រងរបស់សាតាំង។ កិច្ចការនេះធ្វើឡើង ដើម្បីបង្ហាញប្រាជ្ញាញាណ និងសព្វានុភាពរបស់ខ្ញុំ និងដើម្បីបង្ហាញពីសេចក្ដីអាក្រក់ដ៏លើសលុបរបស់សាតាំង ហើយលើសពីនេះទៀត គឺដើម្បីឲ្យមនុស្សមើលឃើញភាពខុសគ្នារវាងការល្អ និងការអាក្រក់ ដើម្បីឲ្យគេដឹងថា ខ្ញុំជាអ្នកគ្រប់គ្រងលើរបស់សព្វសារពើ ដើម្បីឲ្យគេមើលឃើញយ៉ាងច្បាស់ថា សាតាំងគឺជាសត្រូវរបស់មនុស្ស ជាវិញ្ញាណអាក្រក់ ជាមេកំណាច ហើយឲ្យមនុស្សអាចប្រាប់ពីភាពខុសគ្នាដោយភាពជាក់លាក់ក្រៃលែងរវាងការល្អ និងការអាក្រក់ សេចក្ដីពិត និងភាពក្លែងក្លាយ ភាពបរិសុទ្ធ និងភាពស្មោកគ្រោក ហើយអ្វីជាភាពអស្ចារ្យ និងអ្វីជាភាពថោកទាប។ ធ្វើបែបនេះ មនុស្សដ៏ល្ងង់ខ្លៅ នឹងអាចមើលឃើញដោយផ្ទាល់ភ្នែកថា ខ្ញុំមិនមែនជាអ្នកដែលធ្វើឲ្យមនុស្សទៅជាពុករលួយទេ ហើយមានតែខ្ញុំដែលជាព្រះអាទិករនេះទេ ទើបអាចសង្គ្រោះមនុស្សបាន អាចប្រទានឲ្យគេនូវអ្វីដែលអាចឲ្យគេរីករាយ ហើយ

គេនឹងដឹងថា ខ្ញុំគឺជាអ្នកគ្រប់គ្រងលើរបស់សព្វសារពើ ចំណែកសាតាំងវិញ គឺគ្រាន់តែជាវិញ្ញាណមួយដែលខ្ញុំបានបង្កើតមក តែបែរជាត្រឡប់មកប្រឆាំងនឹងខ្ញុំវិញប៉ុណ្ណោះ។ ផែនការគ្រប់គ្រងរយៈពេល៦ពាន់ឆ្នាំរបស់ខ្ញុំ ត្រូវបានបែងចែកជា ៣ដំណាក់កាល ហើយខ្ញុំធ្វើបែបនេះ ដើម្បីសម្រេចនូវប្រសិទ្ធភាព ឲ្យមនុស្សធ្វើជាស្មរបន្ទាល់របស់ខ្ញុំ ហើយយល់ពីបំណងចិត្តខ្ញុំ ព្រមទាំងដឹងថា ខ្ញុំជាសេចក្ដីពិត។ ដូច្នេះ ក្នុងគ្រាដំបូងនៃផែនការគ្រប់គ្រងរយៈពេល៦ពាន់ឆ្នាំរបស់ខ្ញុំ គឺខ្ញុំបានអនុវត្តកិច្ចការនៃក្រឹត្យវិន័យ តាមរយៈកិច្ចការនេះហើយ ដែលព្រះយេហូវ៉ាបានដឹកនាំរាស្ត្រទ្រង់។ ដំណាក់កាលទី២បានចាប់ផ្ដើមនៅក្នុងកិច្ចការ ក្នុងយុគសម័យនៃព្រះគុណ នៅតាមភូមិនានាក្នុងស្រុកយូដា។ ព្រះយេស៊ូវ តំណាងឲ្យកិច្ចការក្នុងយុគសម័យនៃព្រះគុណ ទ្រង់បានប្រសូតមកជាសាច់ឈាម ត្រូវបានគេបោះភ្ជាប់នឹងឈើឆ្កាង ហើយទ្រង់ក៏បានចាប់ផ្ដើមយុគសម័យនៃព្រះគុណ។ ទ្រង់ត្រូវបានគេឆ្កាង ដើម្បីសម្រេចកិច្ចការនៃការប្រោសលោះ ដើម្បីបញ្ចប់យុគសម័យនៃក្រឹត្យវិន័យ ហើយចាប់ផ្ដើមយុគសម័យនៃព្រះគុណ ហេតុនេះ ទើបទ្រង់ត្រូវបានគេហៅថា «មេទ័ពកំពូល» «តង្វាយលោះបាប» និង «ព្រះដ៏ប្រោសលោះ»។ ជាលទ្ធផល កិច្ចការរបស់ព្រះយេស៊ូវមានខ្លឹមសារខុសពីកិច្ចការរបស់ព្រះយេហូវ៉ា បើទោះបីជាកិច្ចការទាំង២នេះ មានគោលការណ៍ដូចគ្នាក៏ដោយ។ ព្រះយេហូវ៉ាបានចាប់ផ្ដើមយុគសម័យនៃក្រឹត្យវិន័យ ដោយបង្កើតឱ្យមានមូលដ្ឋានដែលជាចំណុចចាប់ផ្ដើមសម្រាប់កិច្ចការរបស់ព្រះជាម្ចាស់នៅលើផែនដី និងដាក់ចេញនូវក្រឹត្យវិន័យ និងបទបញ្ញត្តិនានា។ ទាំងក្រឹត្យវិន័យ និងបទបញ្ញត្តិនានា គឺជាបំណែកនៃកិច្ចការដែលទ្រង់បានអនុវត្ត ហើយជាតំណាងឲ្យយុគសម័យនៃក្រឹត្យវិន័យ។ កិច្ចការដែលព្រះយេស៊ូវបានធ្វើ នៅក្នុងយុគសម័យនៃព្រះគុណ មិនមែនដើម្បីដាក់ចេញនូវក្រឹត្យវិន័យទេ តែដើម្បីសម្រេចក្រឹត្យវិន័យវិញ ក៏ជាការចាប់ផ្ដើមយុគសម័យនៃព្រះគុណ និងជាការបញ្ចប់យុគសម័យនៃក្រឹត្យវិន័យដែលមានរយៈពេល២ពាន់ឆ្នាំមកហើយដែរ។ ទ្រង់គឺជាអ្នកត្រួសត្រាយ ដែលបានយាងមកដើម្បីចាប់ផ្ដើមយុគសម័យនៃព្រះគុណ ប៉ុន្តែចំណែកដ៏សំខាន់បំផុតនៃកិច្ចការរបស់

ទ្រង់ គឺជាការប្រោសលោះ។ ហេតុនេះ កិច្ចការដែលព្រះអង្គធ្វើ គឺជាកិច្ចការមុខពីរៈ គឺ សម្រេចកិច្ចការនៃការប្រោសលោះតាមរយៈការសុគតលើឈើឆ្កាងរបស់ទ្រង់ និងបើក យុគសម័យមួយថ្មី បន្ទាប់ពីទ្រង់បានចាកចេញទៅ។ ដូច្នេះ នៅពេលដែលយុគសម័យ នៃក្រឹត្យវិន័យបញ្ចប់ទៅ នោះយុគសម័យនៃព្រះគុណក៏ចាប់ផ្ដើមឡើង។

កិច្ចការដែលព្រះយេស៊ូវបានធ្វើ គឺស្របទៅនឹងសេចក្ដីត្រូវការ របស់មនុស្សនៅក្នុង យុគសម័យនោះ។ ភារកិច្ចរបស់ព្រះអង្គ គឺប្រោសលោះមនុស្ស និងអត់ទោសអំពើបាប របស់ពួកគេ ដូច្នេះ ទើបនិស្ស័យរបស់ទ្រង់ មានទាំងការបន្ទាបខ្លួន ការអត់ធ្មត់ សេចក្ដីស្រឡាញ់ ការគោរពកោតខ្លាចព្រះជាម្ចាស់ ការអត់ទ្រាំ សេចក្ដីមេត្តាករុណា និងសេចក្ដីស្រលាញ់អស់ពីព្រះទ័យ។ ព្រះអង្គបាននាំមកនូវព្រះគុណ និងព្រះពរជា បរិបូរដល់មនុស្ស ហើយអ្វីៗគ្រប់យ៉ាងដែលធ្វើឲ្យមនុស្សរស់នៅយ៉ាងរីករាយ ទ្រង់ បានប្រទានសេចក្ដីទាំងអស់នោះដល់គេ សម្រាប់ជាអំណរសប្បាយរបស់គេ ដូចជា សេចក្ដីសុខសាន្ត និងសុភមង្គល សេចក្ដីត្រាប្រណី និងសេចក្ដីស្រឡាញ់របស់ទ្រង់ សេចក្ដីមេត្តាករុណា និងសេចក្ដីស្រលាញ់អស់ពីព្រះទ័យរបស់ទ្រង់។ គ្រានោះ ភាព បរិបូរនៃសព្វសារពើសម្រាប់អំណរសប្បាយដែលមនុស្សធ្លាប់មាន ដូចជា អារម្មណ៍ សុខសាន្ត និងសុខសុវត្ថិភាពនៅក្នុងដួងចិត្តរបស់គេ អារម្មណ៍កក់ក្ដៅនៅក្នុងវិញ្ញាណ របស់គេ និងការពឹងអាងរបស់គេលើព្រះយេស៊ូវដ៏ជាព្រះអង្គសង្គ្រោះ គឺសុទ្ធតែមានក្នុង យុគសម័យដែលគេរស់នៅ។ នៅក្នុងយុគសម័យនៃព្រះគុណ មនុស្សត្រូវបានធ្វើឲ្យ ពុករលួយដោយសារសាតាំងរួចទៅហើយ ដូច្នេះ ដើម្បីសម្រេចកិច្ចការនៃការប្រោស លោះមនុស្សគ្រប់គ្នា តម្រូវឲ្យមានព្រះគុណជាបរិបូរ ការអត់ទ្រាំ និងការអត់ធ្មត់ឥត ដែនកំណត់ ហើយលើសពីនេះទៀត គឺតង្វាយដ៏ស័ក្ដិសមមួយឲ្យធួននឹងបាបរបស់ មនុស្ស ទើបអាចយកជាការបាន។ អ្វីដែលមនុស្សមើលឃើញ នៅក្នុងយុគសម័យ នៃព្រះគុណ គឺគ្រាន់តែជាតង្វាយរបស់ខ្ញុំ សម្រាប់ថ្វាយឲ្យធួននឹងបាបរបស់មនុស្ស ប៉ុណ្ណោះ៖ ព្រះយេស៊ូវ។ គ្រប់យ៉ាងដែលគេដឹងគឺថា ព្រះជាម្ចាស់ច្បាស់មានព្រះទ័យ មេត្តា និងអត់ធ្មត់ ហើយគ្រប់យ៉ាងដែលគេបានឃើញ គឺសេចក្ដីមេត្តាករុណា និង

សេចក្ដីស្រលាញ់អស់ពីព្រះទ័យរបស់ព្រះយេស៊ូវ។ ទាំងអស់នេះ គឺដោយសារតែពួកគេកើតមកក្នុងយុគសម័យនៃព្រះគុណ។ ដូច្នេះហើយ មុនពេលពួកគេអាចត្រូវបានប្រោសលោះ ពួកគេរីករាយនឹងព្រះគុណច្រើនយ៉ាង ដែលព្រះយេស៊ូវបានប្រទានឱ្យគេ ដើម្បីឲ្យបានជាប្រយោជន៍ពីការនោះ។ តាមវិធីនេះ ពួកគេអាចត្រូវបានអត់ទោសពីអំពើបាបរបស់ខ្លួនតាមរយៈអំណររីករាយចំពោះព្រះគុណ ហើយក៏អាចមានឱកាសទទួលបាននូវការប្រោសលោះតាមរយៈការរីករាយនឹងការអត់ទ្រាំ និងក្ដីអំណត់របស់ព្រះយេស៊ូវទៀតផង។ មានតែតាមរយៈការអត់ទ្រាំ និងក្ដីអំណត់របស់ព្រះយេស៊ូវទេ ទើបពួកគេអាចមានសិទ្ធិក្នុងការទទួលបាននូវការអត់ទោស ហើយរីករាយនឹងភាពបរិបូរនៃព្រះគុណដែលព្រះយេស៊ូវប្រទានឲ្យ។ ដូចដែលព្រះយេស៊ូវមានបន្ទូលប្រាប់ថា៖ ខ្ញុំមិនមែនមកប្រោសលោះមនុស្សសុចរិតទេ គឺមកប្រោសលោះមនុស្សបាបវិញ ដើម្បីឱ្យមនុស្សបាបអាចត្រូវបានអត់ទោស ពីអំពើបាបរបស់ខ្លួន។ កាលព្រះយេស៊ូវយាងមកប្រសូតជាសាច់ឈាម ប្រសិនបើទ្រង់យាងមកទាំងយកនិស្ស័យនៃការជំនុំជម្រះ បណ្ដាសា និងព្រះទ័យគុំកួនចំពោះសេចក្ដីរំលងរបស់មនុស្សមកជាមួយ នោះមនុស្សច្បាស់ជាគ្មានឱកាសទទួលបាន ការប្រោសលោះឡើយ ហើយគេប្រាកដជានៅជាប់បាបអស់កល្បជានិច្ចមិនខាន។ បើដូច្នេះមែន ផែនការគ្រប់គ្រងរយៈពេល៦ពាន់ឆ្នាំ ច្បាស់ជាត្រូវផ្អាកត្រឹមយុគសម័យនៃក្រឹត្យវិន័យ ហើយយុគសម័យនៃក្រឹត្យវិន័យ ច្បាស់ជាត្រូវអូសបន្លាយរហូតដល់ទៅ៦ពាន់ឆ្នាំ។ អំពើបាបរបស់មនុស្សច្បាស់ជាកើនឡើងកាន់តែច្រើន និងកាន់តែអាក្រក់ផង ហើយការបង្កើតមនុស្សមក ក៏ប្រែជាសូន្យទទេដែរ។ ត្រឹមតែបម្រើព្រះយេហូវ៉ានៅក្រោមក្រឹត្យវិន័យមនុស្សច្បាស់ជាអាចធ្វើបាន តែអំពើបាបរបស់គេមុខជាលើសលុបជាងមនុស្សដែលត្រូវបានបង្កើតមកតាំងពីគ្រាដំបូងទៅទៀត។ កាលណាព្រះយេស៊ូវកាន់តែស្រឡាញ់មនុស្ស អត់ទោសបាបឲ្យគេ និងនាំគេមកក្នុងក្ដីករុណា និងសេចក្ដីក្ដីមេត្តាករុណាជាបរិបូរ នោះពួកគេក៏រឹតតែក្អេងក្អាងថានឹងបានសង្គ្រោះ ដោយសារព្រះយេស៊ូវដែរ ដើម្បីឲ្យបានហៅថាជាកូនចៀមវង្វេង ដែលព្រះយេស៊ូវបានលោះមកវិញក្នុងតម្លៃដ៏លើសលុប។ សាតាំង

មិនអាចជ្រៀតជ្រែកក្នុងកិច្ចការនេះបានទេ ដ្បិតព្រះយេស៊ូវប្រព្រឹត្តចំពោះអ្នកដែលដើរតាមទ្រង់ ដូចជាម្ដាយដែលពេញដោយក្ដីស្រឡាញ់ កំពុងបីកូនតូចជាប់នឹងទ្រូង។ ទ្រង់មិនបានខឹងក្រោធ ឬមើលងាយពួកគេទេ តែទ្រង់មានពេញដោយការកម្សាន្តចិត្តវិញ។ ទ្រង់មិនដែលបញ្ចេញសេចក្ដីក្រោធចំពោះពួកគេទេ ទ្រង់មានតែទ្រាំទ្រនឹងអំពើបាបគេ ហើយបាំងព្រះនេត្រពីភាពលេលា និងភាពល្ងង់ខ្លៅរបស់គេ ដល់ថ្នាក់មានព្រះបន្ទូលថា «ចូរអត់ទោសដល់អ្នកដទៃ ដល់ទៅ៧ចិតសិបដង»។ នេះហើយជាដួងចិត្តរបស់អស់អ្នក ដែលត្រូវបានបំផ្លាស់បំប្រែតាមព្រះហឫទ័យទ្រង់ ហើយមានតែមនុស្សបែបនេះទេ ទើបអាចទទួលបានការអត់ទោសបាបរបស់ខ្លួន តាមរយៈការទ្រាំទ្ររបស់ទ្រង់។

ទោះបីជាព្រះយេស៊ូវពុំមានចេតនារម្មណ៍អ្វីសោះក្នុងរូបកាយសាច់ឈាមរបស់ទ្រង់ ក៏ទ្រង់តែងតែកម្សាន្តចិត្តសិស្សទ្រង់ ផ្គត់ផ្គង់ពួកគេ ជួយពួកគេ និងឧបត្ថម្ភពួកគេជានិច្ចដែរ។ តែទោះបីទ្រង់ធ្វើកិច្ចការច្រើនយ៉ាងណា ឬទ្រាំទ្រនឹងការលំបាកវេទនាប៉ុនណា ក៏ទ្រង់មិនដែលទាមទារអ្វីលើសលុបពីមនុស្សដែរ តែទ្រង់តែងតែមានព្រះទ័យអំណត់ និងអត់ធ្មត់ចំពោះអំពើបាបរបស់គេជានិច្ច មនុស្សក្នុងយុគសម័យនៃព្រះគុណនេះ បានហៅព្រះនាមទ្រង់ដោយសេចក្ដីស្រឡាញ់ថា «ព្រះយេស៊ូវដ៏ជាព្រះអង្គសង្គ្រោះជាទីស្រឡាញ់»។ ចំពោះមនុស្សនាសម័យនោះ ក៏ដូចជាចំពោះមនុស្សទាំងអស់ អ្វីដែលព្រះយេស៊ូវមាន ហើយជាលក្ខណៈរបស់ទ្រង់ គឺសេចក្ដីមេត្តាករុណា និងសេចក្ដីស្រលាញ់ អស់ពីព្រះទ័យរបស់ព្រះអង្គ។ ព្រះអង្គមិនដែលនឹកចាំពីសេចក្ដីរំលងរបស់មនុស្សឡើយ ហើយការប្រព្រឹត្តដែលទ្រង់មានចំពោះគេ ក៏មិនមែនផ្អែកលើសេចក្ដីរំលងរបស់គេដែរ។ ទ្រង់តែងតែប្រទាន នូវអាហារជាច្រើនដល់មនុស្ស ដើម្បីឱ្យគេបរិភោគឆ្អែត ដ្បិតយុគសម័យនោះ គឺជាយុគសម័យមួយដោយឡែក។ ទ្រង់ប្រព្រឹត្តចំពោះអ្នកដែលដើរតាមទ្រង់ ដោយព្រះគុណ ទាំងប្រោសជំងឺ បណ្ដេញវិញ្ញាណអាក្រក់ ហើយប្រោសមនុស្សស្លាប់ឲ្យរស់ឡើងវិញផង។ ដើម្បីឲ្យមនុស្សជឿដល់ទ្រង់ និងមើលឃើញថា កិច្ចការដែលទ្រង់បានធ្វើ គឺសុទ្ធតែធ្វើឡើងដោយភាព

ស្មោះត្រង់អស់ពីព្រះទ័យនោះ ទ្រង់ថែមទាំងបានប្រោសសាកសពស្អុយរលួយឲ្យរស់ឡើងវិញផង ដើម្បីស្តែងឲ្យគេឃើញថា នៅក្នុងព្រះហស្តទ្រង់ សូម្បីតែមនុស្សស្លាប់ក៏អាចរស់ឡើងវិញបានដែរ។ ព្រះអង្គបានទ្រាំទ្រ និងបានអនុវត្តកិច្ចការប្រោសលោះយ៉ាងស្ងៀមស្ងាត់នៅក្នុងចំណោមពួកគេ តាមវិធីនេះហើយ។ ព្រះយេស៊ូវបានយកអំពើបាបរបស់មនុស្ស មកដាក់លើព្រះកាយទ្រង់ និងបានក្លាយជាតង្វាយលោះបាបសម្រាប់មនុស្ស ទាំងមុនពេលដែលទ្រង់ត្រូវគេដំភ្ជាប់ទៅនឹងឈើឆ្កាងទៅទៀត។ ទ្រង់បានបើកផ្លូវទៅឈើឆ្កាង ដើម្បីសង្គ្រោះមនុស្សតាំងពីមុនពេលដែលទ្រង់ត្រូវគេឆ្កាងម្ល៉េះ។ ទីបំផុត ទ្រង់ក៏ត្រូវគេដំភ្ជាប់នឹងឈើឆ្កាង ទាំងថ្វាយអង្គទ្រង់ដោយយល់ដល់ឈើឆ្កាងនោះ ហើយប្រទានគ្រប់ទាំងសេចក្តីមេត្តាករុណា សេចក្តីស្រលាញ់អស់ពីព្រះទ័យ និងភាពបរិសុទ្ធរបស់ទ្រង់ទៅដល់មនុស្ស។ ចំពោះមនុស្ស គឺព្រះអង្គតែងតែត្រាប្រណី មិនដែលចងគំនុំ អត់ទោសបាបគេ ទូន្មានគេឲ្យប្រែចិត្ត ហើយបង្រៀនគេឲ្យចេះអត់ធ្មត់ ស៊ូទ្រាំ និងចេះស្រឡាញ់ ដើម្បីឲ្យគេដើរតាមលំអានបាទារបស់ទ្រង់ ហើយថ្វាយខ្លួនគេ ដោយយល់ដល់ឈើឆ្កាង។ សេចក្តីស្រឡាញ់របស់ទ្រង់ចំពោះបងប្អូនប្រុសស្រី គឺលើសលុបជាងសេចក្តីស្រឡាញ់ដែលទ្រង់មានចំពោះនាងម៉ារីទៅទៀត។ កិច្ចការដែលទ្រង់បានយកធ្វើជាគោលការណ៍ដ៏សំខាន់ដូចជាប្រោសជំងឺ និងបណ្តេញវិញ្ញាណអាក្រក់ នោះគឺសុទ្ធតែដើម្បីការប្រោសលោះរបស់ទ្រង់។ មិនថាទ្រង់យាងទៅកន្លែងណា ក៏ទ្រង់នៅតែប្រព្រឹត្តចំពោះមនុស្សទាំងអស់ដែលដើរតាមទ្រង់ដោយព្រះគុណដែរ។ ទ្រង់ធ្វើឲ្យអ្នកក្រក្លាយជាមាន ធ្វើឲ្យមនុស្សខ្វិនអាចដើរបាន ធ្វើឲ្យមនុស្សខ្វាក់អាចមើលឃើញ និងធ្វើឲ្យមនុស្សថ្លង់អាចស្តាប់ឮបាន។ ទ្រង់ថែមទាំងបានហៅមនុស្សតូចទាបបំផុត មនុស្សទុរគត មនុស្សមានបាបឲ្យមកអង្គុយនៅរួមតុជាមួយនឹងទ្រង់ ព្រះអង្គមិនដែលគេចពីពួកគេឡើយ តែទ្រង់អត់ធ្មត់ជានិច្ចវិញ ថែមទាំងមានបន្ទូលថា៖ កាលណាអ្នកគង្វាលបាត់ចៀម១ក្បាលនោះ គាត់នឹងទុកចៀម៩៩ក្បាលទៀតចោល ដើម្បីតាមរកចៀម១ដែលបាត់នោះ ហើយនៅពេលដែលគាត់រកវាឃើញ គាត់នឹងអរសប្បាយយ៉ាងក្រៃលែង។ ព្រះអង្គ

ស្រឡាញ់អ្នកដើរតាមទ្រង់ ដូចជាចៀមញីស្រឡាញ់កូនរបស់វា។ ថ្វីបើពួកគេលេលា ហើយល្ងង់ខ្លៅ ព្រមទាំងជាមនុស្សមានបាបនៅចំពោះព្រះនេត្រទ្រង់ ហើយជាងនេះទៅទៀត គេជាសមាជិកដ៏តូចទាបបំផុតនៅក្នុងសង្គម ក៏ទ្រង់នៅតែរាប់មនុស្សមានបាប ដែលអ្នកដទៃមើលងាយនេះ ថាជាកែវព្រះនេត្ររបស់ទ្រង់ដែរ។ ដោយសារទ្រង់សព្វព្រះទ័យនឹងពួកគេ បានជាទ្រង់លះបង់ព្រះជន្មទ្រង់មកធ្វើជាកូនចៀមដែលត្រូវថ្វាយនៅលើអាសនាដើម្បីពួកគេ។ ក្នុងចំណោមពួកគេ ទ្រង់ប្រព្រឹត្តខ្លួនដូចជាអ្នកបម្រើរបស់គេ ទាំងបណ្ដោយឲ្យគេប្រើទ្រង់ ហើយធ្វើគុតទ្រង់ដោយចុះចូលចំពោះពួកគេឥតលក្ខខណ្ឌ។ នៅចំពោះអ្នកដើរតាមទ្រង់ ព្រះអង្គគឺជាព្រះយេស៊ូវដ៏ជាព្រះអង្គសង្គ្រោះជាទីស្រឡាញ់ ប៉ុន្តែចំពោះពួកផារីស៊ីដែលបង្រៀនមនុស្សពីលើវេទិកាវិញ គឺទ្រង់មិនបង្ហាញសេចក្ដីមេត្តាករុណា និងសេចក្ដីស្រលាញ់អស់ពីព្រះទ័យដល់គេឡើយ មានតែបង្ហាញពីការស្អប់ខ្ពើម និងការមិនពេញព្រះទ័យប៉ុណ្ណោះ។ ទ្រង់មិនបានធ្វើកិច្ចការអ្វីច្រើនក្នុងចំណោមពួកផារីស៊ីទេ មានតែបង្រៀន និងស្ដីបន្ទោសពួកគេម្ដងម្កាល ទ្រង់ក៏មិនធ្វើកិច្ចការនៃការប្រោសលោះ ហើយក៏មិនធ្វើទីសម្គាល់ និងការអស្ចារ្យនៅក្នុងចំណោមពួកគេដែរ។ ព្រះអង្គបានប្រទានសេចក្ដីមេត្តាករុណា និងសេចក្ដីស្រលាញ់អស់ពីព្រះទ័យទាំងអស់របស់ទ្រង់ ដល់អ្នកដែលដើរតាមទ្រង់ ទាំងទ្រាំទ្រដោយយល់ដល់មនុស្សមានបាបទាំងអស់នេះ រហូតដល់ទីបំផុត គឺនៅពេលដែលទ្រង់ត្រូវគេដំភ្ជាប់ទៅនឹងឈើឆ្កាង ហើយរងគ្រប់ទាំងការប្រមាថ រហូតដល់ទ្រង់បានប្រោសលោះមនុស្សទាំងអស់ជាបរិបូរ។ នេះហើយគឺជាសេចក្ដីសរុបនៃកិច្ចការរបស់ព្រះអង្គ។

បើគ្មានការប្រោសលោះរបស់ព្រះយេស៊ូវទេ មនុស្សច្បាស់ជានៅរស់ក្នុងអំពើបាប ហើយក្លាយជាពូជពង្សនៃអំពើបាប ជាតំណវង្សរបស់វិញ្ញាណអាក្រក់ អស់កល្បជានិច្ច។ បើនៅតែបន្តបែបនេះ ពិភពលោកទាំងមូលនឹងក្លាយជាទឹកដីដែលសាតាំងបោះទីលំនៅមិនខាន។ យ៉ាងណាមិញ កិច្ចការនៃការប្រោសលោះទាមទារនូវការបង្ហាញសេចក្ដីមេត្តាករុណា និងសេចក្ដី ស្រលាញ់អស់ពីព្រះទ័យចំពោះមនុស្ស គឺមានតែតាមរយៈមធ្យោបាយនេះទេ ទើបមនុស្សអាចទទួលបានការអត់ទោស ហើយ

ចុងក្រោយក៏មានសិទ្ធិទទួលនូវការកែប្រែឲ្យបានបរិបូរ ហើយត្រូវបានទទួលយកពីព្រះជាម្ចាស់យ៉ាងពេញទំហឹង។ ប្រសិនគ្មានកិច្ចការក្នុងដំណាក់កាលនេះទេ ផែនការគ្រប់គ្រងរយៈពេល៦ពាន់ឆ្នាំ មុខជាមិនអាចវិវឌ្ឍទៅមុខបានឡើយ។ ប្រសិនបើព្រះយេស៊ូវពុំត្រូវបានគេឆ្កាង ប្រសិនបើទ្រង់គ្រាន់តែប្រោសជំងឺ និងបណ្ដេញវិញ្ញាណអាក្រក់ ម្ល៉េះមនុស្សច្បាស់ជាមិនអាចទទួលបានការអត់ទោសពីអំពើបាបរបស់គេទាំងស្រុងបានទេ។ ក្នុងរយៈពេល៣ឆ្នាំកន្លះដែលព្រះយេស៊ូវបានចំណាយក្នុងការបំពេញកិច្ចការរបស់ទ្រង់នៅលើផែនដី ទ្រង់បានសម្រេចកិច្ចការនៃការប្រោសលោះរបស់ទ្រង់បានតែពាក់កណ្ដាលទេ បន្ទាប់មក ទ្រង់ក៏សម្រេចកិច្ចការនៃការជាប់ឆ្កាង និងបានធ្វើជាម្ចាស់លើវាសនាមនុស្ស ដោយឲ្យគេដំភ្ជាប់នឹងឈើឆ្កាង ហើយត្រលប់ជាមានភាពដូចគ្នានឹងសាច់ឈាមដែលមានបាប និងតាមរយៈការប្រគល់អង្គទ្រង់ទៅឲ្យមេកំណាច។ នៅពេលដែលទ្រង់ត្រូវបានប្រោសឲ្យរួចពីដៃរបស់សាតាំង ទើបទ្រង់បានប្រោសលោះមនុស្សឲ្យរួចបាន។ សម្រាប់រយៈពេល៣៣ឆ្នាំកន្លះដែលទ្រង់បានរងទុក្ខនៅលើផែនដី ដោយត្រូវគេចំអក ត្រូវគេមួលបង្កាច់ ហើយត្រូវគេបោះបង់ រហូតរកកន្លែងកើយក្បាលដើម្បីនឹងសម្រាកគ្មាន ក្រោយមកទៀតក៏ត្រូវគេឆ្កាង ដំភ្ជាប់នឹងឈើឆ្កាងទៀត ក៏រូបកាយទ្រង់ទាំងមូលនៅតែបរិសុទ្ធគ្មានទោសដែរ។ ទ្រង់បានទ្រាំទ្រគ្រប់ទាំងទុក្ខលំបាក។ ពួកអ្នកមានអំណាចចំអកដាក់ទ្រង់ ហើយវាយទ្រង់នឹងរំពាត់ ចំណែកឯពួកទាហានវិញ ទះកំផ្លៀងទ្រង់ ប៉ុន្តែទ្រង់នៅតែមិនស្ដី ហើយទ្រាំទ្ររហូតដល់ទីបញ្ចប់ ដោយចុះចូលឥតលក្ខខណ្ឌលុះដល់ទីមរណា ជាទីដែលទ្រង់បានប្រោសលោះមនុស្សទាំងអស់។ ទាល់តែដល់ពេលនេះ ទើបទ្រង់ត្រូវបានអនុញ្ញាតឲ្យសម្រាក។ កិច្ចការដែលព្រះយេស៊ូវបានធ្វើ តំណាងត្រឹមតែយុគសម័យនៃព្រះគុណប៉ុណ្ណោះ កិច្ចការនេះមិនតំណាងឲ្យ យុគសម័យនៃក្រឹត្យវិន័យឡើយ ក៏មិនមែនជាកិច្ចការសម្រាប់ជំនួសកិច្ចការនៃគ្រាចុងក្រោយដែរ។ នេះហើយជាសារជាតិនៃកិច្ចការរបស់ព្រះយេស៊ូវនៅក្នុងយុគសម័យនៃព្រះគុណ ជាយុគសម័យទី២ដែលមនុស្សបានឆ្លងកាត់ ជាយុគសម័យនៃការប្រោសលោះ។

# អ្នកគួរតែដឹងពីរបៀប ដែលមនុស្សទាំងអស់បានវិវឌ្ឍមកដល់ពេលបច្ចុប្បន្ន

កិច្ចការទាំងស្រុងដែលត្រូវបានអនុវត្តជាងប្រាំមួយពាន់ឆ្នាំមកនេះ បានផ្លាស់ប្ដូរបន្តិចម្ដងៗ នៅពេលដែលយុគសម័យផ្សេងៗ បានចូលមក និងចប់បាត់ទៅ។ ការផ្លាស់ប្ដូរនៅក្នុងកិច្ចការនេះបានអាស្រ័យលើស្ថានភាពទាំងមូលនៃពិភពលោក និងនិន្នាការនៃការអភិវឌ្ឍន៍របស់មនុស្សទាំងស្រុង ដូច្នេះ កិច្ចការនៃការគ្រប់គ្រងក៏បានផ្លាស់ប្ដូរបន្តិចម្ដងៗ ទៅតាមនោះដែរ។ គ្រប់យ៉ាងមិនត្រូវបានគ្រោងទុក តាំងពីដើមដំបូងនៃកំណើតពិភពលោកមកឡើយ។ មុនពេលពិភពលោកត្រូវបានបង្កើត ឬបន្តិចក្រោយមក ព្រះយេហូវ៉ាមិនទាន់បានគ្រោងទុកនូវដំណាក់កាលទីមួយនៃកិច្ចការ ដែលជាក្រឹត្យវិន័យ និងដំណាក់កាលទីពីរនៃកិច្ចការ ដែលជាដំណាក់កាលនៃព្រះគុណ ព្រមទាំងដំណាក់កាលទីបី ដែលជាដំណាក់កាលនៃការយកឈ្នះ ដែលទ្រង់បានចាប់ផ្ដើមដំបូងឡើយជាមួយពូជពង្សខ្លះរបស់ម៉ូអាប់ ហើយតាមរយៈពូជពង្សនេះ ត្រូវយកឈ្នះលើចក្រវាលទាំងមូល។ ក្រោយការបង្កើតពិភពលោក ទ្រង់មិនដែលធ្លាប់មានបន្ទូលទាំងនេះ ក៏មិនធ្លាប់មានបន្ទូលទាំងនេះ ក្រោយម៉ូអាប់នោះដែរ ហើយតាមពិតទៅ មុនពេលឡុត ទ្រង់ក៏មិនដែលថ្លែងព្រះបន្ទូលទាំងនេះដែរ។ គ្រប់កិច្ចការរបស់ព្រះជាម្ចាស់ត្រូវបានធ្វើឡើង ដោយមិនបានគ្រោងទុកឡើយ។ នេះជារបៀបដែលកិច្ចការគ្រប់គ្រងទាំងស្រុងរយៈពេលប្រាំមួយពាន់ឆ្នាំរបស់ទ្រង់ត្រូវបានបង្កើតឡើង។ មុនពេលបង្កើតពិភពលោក ទ្រង់មិនដែលសរសេរផែនការបែបនេះនៅក្នុងទម្រង់អ្វីមួយ ដូចជា «តារាងសង្ខេបសម្រាប់ការអភិវឌ្ឍរបស់មនុស្ស» នោះឡើយ។ នៅក្នុងកិច្ចការរបស់ព្រះជាម្ចាស់ ទ្រង់បង្ហាញអំពីលក្ខណៈរបស់ទ្រង់ដោយផ្ទាល់។ ទ្រង់មិនបានខំប្រឹងព្រះតម្រិះ ដើម្បីបង្កើតចេញជាផែនការមួយឡើយ។ ពិតណាស់មានហោរាពីរបីនាក់ដែរ ដែលបានថ្លែងទំនាយដ៏អស្ចារ្យជាច្រើន ប៉ុន្តែវានៅតែមិនអាចនិយាយបានដដែលថា កិច្ចការរបស់ព្រះជាម្ចាស់ តែងតែចេញពីផែនការមួយដ៏

ច្បាស់លាស់នោះឡើយ ដ្បិតសេចក្តីទំនាយទាំងនោះត្រូវបានបង្កើតឡើង ស្របតាមកិច្ចការរបស់ព្រះជាម្ចាស់នាពេលនោះប៉ុណ្ណោះ។ គ្រប់កិច្ចការដែលទ្រង់ធ្វើ គឺជាកិច្ចការជាក់ស្ដែងបំផុត។ ទ្រង់អនុវត្តកិច្ចការនោះ ស្របទៅតាមការអភិវឌ្ឍន៍នៃយុគសម័យនីមួយៗ និងអាស្រ័យលើរបៀប ដែលស្ថានការណ៍ផ្លាស់ប្ដូរ។ សម្រាប់ទ្រង់ការអនុវត្តកិច្ចការ គឺប្រៀបដូចជាការចេញវេជ្ជបញ្ជាថ្នាំពេទ្យ ដើម្បីព្យាបាលជំងឺអ្វីចឹង ព្រោះថាក្នុងអំឡុង ពេលដែលទ្រង់កំពុងតែធ្វើកិច្ចការ ទ្រង់សង្កេតមើលបណ្ដើរ ហើយបន្តធ្វើកិច្ចការរបស់ទ្រង់បណ្ដើរ ដោយស្របតាមការសង្កេតរបស់ទ្រង់។ នៅក្នុងគ្រប់ដំណាក់កាលនៃកិច្ចការរបស់ទ្រង់ ព្រះជាម្ចាស់អាចបង្ហាញ ព្រះប្រាជ្ញាញាណ និងសមត្ថភាពដ៏ខ្ពស់លើសលប់របស់ទ្រង់បាន ហើយទ្រង់បើកសម្ដែងពីព្រះប្រាជ្ញាញាណ និងសិទ្ធិអំណាចដ៏ពេញបរិបូណ៌របស់ទ្រង់ ស្របតាមកិច្ចការនៃយុគសម័យជាក់ស្ដែង និងអនុញ្ញាតឲ្យមនុស្ស ដែលទ្រង់បាននាំត្រឡប់មកវិញនៅក្នុងយុគសម័យនោះ មើលឃើញពីនិស្ស័យទាំងអស់របស់ទ្រង់។ ទ្រង់ផ្គត់ផ្គង់ ដល់តម្រូវការរបស់មនុស្ស ស្របតាមកិច្ចការ ដែលត្រូវសម្រេចនៅក្នុងយុគសម័យនីមួយៗ ដោយធ្វើគ្រប់កិច្ចការដែលទ្រង់គួរតែធ្វើ។ ទ្រង់ប្រទានឲ្យមនុស្សមាននូវអ្វីដែលគេត្រូវការ ដោយផ្អែកលើកម្រិតដែលសាតាំងបានធ្វើឲ្យពួកគេពុករលួយ។ វាដូចជារបៀបដែលទ្រង់បានធ្វើ ដើម្បីឲ្យពួកគេបង្ហាញពីព្រះជាម្ចាស់នៅលើផែនដី នៅពេលដែលព្រះយេហូវ៉ាបានបង្កើតអ័ដាម និងអេវ៉ាកាលពីដំបូង ដើម្បីឲ្យពួកគេអាចធ្វើបន្ទាល់ អំពីព្រះជាម្ចាស់នៅក្នុងចំណោមសត្តនិករអ៊ីចឹង។ ទោះបីជាយ៉ាងណា នាងអេវ៉ាបានប្រព្រឹត្តអំពើបាប ក្រោយពេលសត្វពស់បានល្បួងនាង ហើយអ័ដាមបានធ្វើដូចគ្នាដែរ ដោយពួកគេទាំងពីរបានបរិភោគផ្លែឈើចេញពីដើមដឹងខុសត្រូវនៅក្នុងសួន។ ដូច្នេះ ព្រះយេហូវ៉ាមាននូវកិច្ចការបន្ថែមទៀត ដែលត្រូវធ្វើការលើពួកគេ។ ដោយឃើញពីសេចក្តីអាក្រាតរបស់គេ ទ្រង់បានបិទបាំងកាយរបស់គេជាមួយសម្លៀកបំពាក់ ដែលធ្វើពីស្បែកសត្វ។ ក្រោយមក ទ្រង់បានមានបន្ទូលទៅកាន់អ័ដាមថា «ដោយសារអ្នកស្ដាប់តាមសម្ដីប្រពន្ធអ្នក ហើយបានស៊ីផ្លែដឹងខុសត្រូវ ដែលខ្ញុំបានបង្គាប់អ្នកដោយពោលថា អ្នកមិនត្រូវស៊ីផ្លែនោះឡើយ

នោះដីត្រូវបណ្ដាសាដោយសារអ្នក...រហូតដល់អ្នកក្លាយជាដីវិញ។ ដ្បិតអ្នកកើតពីធូលីដី ដូច្នេះអ្នកជាធូលីដី ហើយអ្នកនឹងត្រូវត្រឡប់ទៅជាធូលីដីវិញ»។ ហើយទ្រង់បានមានបន្ទូលទៅកាន់ស្ត្រីថា៖ «ខ្ញុំនឹងចម្រើនទុក្ខព្រួយដល់អ្នកឲ្យច្រើនសន្ធឹក និងធ្វើឲ្យអ្នកពពោះទាំងឈឺចាប់ផង អ្នកនឹងបង្កើតកូនដោយទុក្ខព្រួយ ចំណែកចិត្តអ្នកក៏ប្រាថ្នាចង់បានប្ដី ហើយគេនឹងត្រួតលើអ្នក»។ ចាប់តាំងពីពេលនោះមក ទ្រង់បានបណ្ដេញពួកគេចេញពីសួនអេដែន និងឲ្យពួកគេរស់នៅខាងក្រៅសួន ដូចជាមនុស្សនាសម័យទំនើបបច្ចុប្បន្ន ដែលរស់នៅលើផែនដីដូច្នេះដែរ។ នៅពេលដែលព្រះជាម្ចាស់បានបង្កើតមនុស្សតាំងពីដើមដំបូងបំផុត ទ្រង់គ្មានផែនការឲ្យមនុស្សជួបសេចក្ដីល្បួងរបស់សត្វពស់ ក្រោយពេលទ្រង់បានបង្កើតពួកគេមក ហើយបន្ទាប់មក ដាក់បណ្ដាសាមនុស្ស និងសត្វពស់នោះឡើយ។ តាមពិតទៅ ព្រះអង្គគ្មានផែនការបែបនេះឡើយ គឺវាគ្រាន់តែជារបៀបដែលស្ថានការណ៍បានអភិវឌ្ឍ ដែលនាំឲ្យទ្រង់មានកិច្ចការថ្មីដែលត្រូវធ្វើនៅក្នុងចំណោមសត្តនិកររបស់ទ្រង់ប៉ុណ្ណោះ។ ក្រោយពេលដែលព្រះយេហូវ៉ាបានអនុវត្តកិច្ចការនេះនៅក្នុងចំណោមអ័ដាម និងអេវ៉ានៅលើផែនដីរួចមក មនុស្សបានបន្តអភិវឌ្ឍ អស់រយៈពេលជាច្រើនពាន់ឆ្នាំទៀត រហូតដល់ «ព្រះយេហូវ៉ាបានទតឃើញថា សេចក្ដីអាក្រក់របស់មនុស្សក៏ពោរពេញផែនដី ហើយដួងចិត្តរបស់គេគ្រប់គ្នាគិតស្រមៃឃើញតែការអាក្រក់ជាបន្តបន្ទាប់។ ព្រះយេហូវ៉ាទ្រង់ស្ដាយដែលបានបង្កើតមនុស្សលើផែនដី ហើយទ្រង់ព្រួយ ព្រះទ័យ។ ... តែលោកណូអេ បានប្រកបដោយព្រះគុណនៅចំពោះព្រះនេត្រ ព្រះយេហូវ៉ា»។ នៅគ្រានោះ ព្រះយេហូវ៉ាមានកិច្ចការថ្មីជាច្រើនដែលត្រូវធ្វើ ព្រោះថាមនុស្សដែលទ្រង់បានបង្កើតឡើង បានប្រព្រឹត្តបាបច្រើនពេក ក្រោយពេលដែលសត្វពស់បានល្បួងពួកគេ។ ដោយសារតែ កាលៈទេសៈទាំងនេះ ដែលមាននៅក្នុងចំណោមមនុស្សទាំងអស់ បានជាព្រះយេហូវ៉ាបានជ្រើសរើស ទុកជីវិតឲ្យក្រុមគ្រួសាររបស់ណូអេ ហើយបន្ទាប់មក ទ្រង់បានអនុវត្តកិច្ចការរបស់ទ្រង់ ដែលជាការបំផ្លាញពិភពលោកដោយទឹកជំនន់។ មនុស្សបានបន្តអភិវឌ្ឍនៅក្នុងឥរិយាបថបែបនេះ រហូតមកដល់សម័យបច្ចុប្បន្ន គឺចម្រើនឡើង នៅក្នុងសេចក្ដី

ពុករលួយ ហើយនៅពេលដែលការអភិវឌ្ឍន៍របស់មនុស្សបានឡើងដល់កម្រិតកំពូល នោះវានឹងមានន័យថា ទីបញ្ចប់របស់មនុស្សបានមកដល់ទីបញ្ចប់ហើយ។ ចាប់តាំងពីដើមដំបូងបំផុត រហូតមកដល់ចុងបញ្ចប់នៃពិភពលោក សេចក្ដីពិតខាងក្នុងនៃកិច្ចការរបស់ទ្រង់កាលពីមុនមានលក្ខណៈបែបណាទៅថ្ងៃខាងមុខ វានឹងមានលក្ខណៈបែបនោះដដែល។ របៀបដែលមនុស្សនឹងត្រូវបានចាត់ថ្នាក់ទៅតាមប្រភេទរបស់គេ នឹងនៅតែដដែល ហើយវាមិនដូចការលើកឡើងថា តាំងពីដើមដំបូងបំផុត មនុស្សម្នាក់ៗត្រូវបានកំណត់ទុកជាមុនថាស្ថិតនៅក្នុងប្រភេទជាក់លាក់ណាមួយនោះឡើយ។ ផ្ទុយទៅវិញ មនុស្សគ្រប់គ្នាត្រូវបានចាត់ថ្នាក់បន្តិចម្ដងៗ ក្រោយពេលដែលពួកគេបានឆ្លងកាត់ដំណើរការនៃការអភិវឌ្ឍន៍រួចហើយប៉ុណ្ណោះ។ នៅចុងបញ្ចប់ អស់អ្នកដែលមិនអាចទទួលបានសេចក្ដីសង្គ្រោះដ៏ពេញលេញ នឹងត្រូវត្រឡប់ទៅរក «បុព្វបុរស» របស់គេវិញ។ គ្មានកិច្ចការណាមួយរបស់ព្រះជាម្ចាស់នៅក្នុងចំណោមមនុស្សត្រូវបានរៀបចំរួចជាស្រេច នៅពេលដែលទ្រង់បង្កើតពិភពលោកនោះឡើយ។ ផ្ទុយទៅវិញ វាជាការអភិវឌ្ឍនៃស្ថានការណ៍វិញទេ ដែលបានអនុញ្ញាតឲ្យព្រះជាម្ចាស់ធ្វើកិច្ចការរបស់ទ្រង់នៅក្នុងចំណោមមនុស្សមួយជំហានម្ដងៗ ហើយនិងនៅក្នុងទម្រង់កាន់តែពិតប្រាកដ និងជាក់ស្ដែង។ ឧទាហរណ៍ ព្រះយេហូវ៉ាមិនបានបង្កើតសត្វពស់ ដើម្បីល្បួងស្ត្រីឡើយ។ ទ្រង់គ្មានផែនការបែបនេះទេ ហើយវាក៏មិនមែនជាអ្វីមួយដែលទ្រង់មានគោលបំណងកំណត់ទុកជាមុនដែរ។ គេអាចនិយាយថា នេះជាហេតុការណ៍ដែលកើតឡើង មិនបានរំពឹងទុក។ ដូច្នេះ ដោយសារតែហេតុការណ៍នេះហើយ ទើបព្រះយេហូវ៉ាបានបណ្ដេញអ័ដាម និងអេវ៉ាចេញពីសួនអេដែន ហើយស្បថសច្ចាមិនបង្កើតមនុស្សម្ដងទៀតនោះ។ ទោះបីជាយ៉ាងណា មនុស្សអាចរកឃើញព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់ ចេញពីគ្រឹះមូលដ្ឋាននេះ។ ដូចជាខ្ញុំបានមានបន្ទូល កាលពីដើមដំបូងថា៖ «ខ្ញុំប្រើព្រះប្រាជ្ញាញាណរបស់ខ្ញុំ ស្របតាមគម្រោងការណ៍របស់សាតាំង»។ ទោះមនុស្សមានសេចក្ដីពុករលួយខ្លាំងដល់ណា ឬសត្វពស់ល្បួងពួកគេតាមរបៀបណាក៏ដោយ ក៏ព្រះយេហូវ៉ានៅតែមានព្រះប្រាជ្ញាញាណរបស់ទ្រង់ដដែល

ហើយវាជាព្រះប្រាជ្ញាញាណមួយ ដែលនាំឲ្យទ្រង់ចូលរួមនៅក្នុងកិច្ចការថ្មី តាំងពីពេលដែលទ្រង់បានបង្កើតពិភពលោកមក ហើយគ្មានជំហានណាមួយនៃកិច្ចការនេះបានកើតឡើងដដែលៗនោះឡើយ។ សាតាំងបានបន្តអនុវត្តតាមគម្រោងការណ៍អាក្រក់របស់វា មនុស្សត្រូវបានសាតាំងបន្តធ្វើឱ្យពុករលួយ ហើយព្រះយេហូវ៉ាបានបន្តអនុវត្តកិច្ចការរបស់ទ្រង់ ដែលប្រកបដោយព្រះប្រាជ្ញាញាណ ដោយឥតឈប់ឈរឡើយ។ ព្រះអង្គមិនដែលបរាជ័យ ហើយក៏មិនដែលឈប់ធ្វើការដែរ តាំងពីពិភពលោកត្រូវបានបង្កើតមក។ ក្រោយពេលដែលមនុស្សត្រូវបានសាតាំងធ្វើឱ្យពុករលួយ ទ្រង់បានបន្តធ្វើការនៅក្នុងចំណោមពួកគេ ដើម្បីបង្ក្រាបខ្មាំងសត្រូវ ដែលជាប្រភពនៃសេចក្ដីពុករលួយរបស់ពួកគេ។ សមរភូមិនេះបានកើតឡើងតាំងពីដើមដំបូងមកម្ល៉េះ ហើយវានឹងបន្តរហូតដល់ចុងបញ្ចប់នៃពិភពលោក។ ដើម្បីធ្វើកិច្ចការទាំងអស់នេះ ព្រះយេហូវ៉ាមិនគ្រាន់តែអនុញ្ញាតឲ្យមនុស្ស ដែលត្រូវបានសាតាំងធ្វើឱ្យពុករលួយ ទទួលបានសេចក្ដីសង្គ្រោះដ៏ធំរបស់ទ្រង់ប៉ុណ្ណោះទេ ប៉ុន្តែក៏អនុញ្ញាតឲ្យពួកគេមើលឃើញពីព្រះប្រាជ្ញាញាណ ព្រះចេស្ដា និងសិទ្ធិអំណាចរបស់ទ្រង់ដែរ។ លើសពីនេះទៅទៀត នៅចុងបញ្ចប់ ទ្រង់នឹងអនុញ្ញាតឲ្យពួកគេមើលឃើញពីនិស្ស័យដ៏សុចរិតរបស់ទ្រង់ ដែលដាក់ទោសដល់មនុស្សទុច្ចរិត និងប្រទានរង្វាន់ដល់មនុស្សសុចរិត។ ទ្រង់បានប្រយុទ្ធជាមួយសាតាំងរហូតមកដល់សព្វថ្ងៃ ហើយទ្រង់មិនដែលចាញ់ម្ដងណាឡើយ។ នេះគឺដោយសារតែទ្រង់គឺជាព្រះជាម្ចាស់ប្រកបដោយព្រះប្រាជ្ញាញាណ ហើយទ្រង់ប្រើព្រះប្រាជ្ញាញាណរបស់ទ្រង់ ស្របតាមគម្រោងការណ៍អាក្រក់របស់សាតាំងប៉ុណ្ណោះ។ ដូច្នេះ ព្រះជាម្ចាស់មិនគ្រាន់តែធ្វើឲ្យអ្វីៗទាំងអស់នៅស្ថានសួគ៌ ចុះចូលចំពោះសិទ្ធិអំណាចរបស់ទ្រង់ប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ក៏ដាក់អ្វីៗគ្រប់យ៉ាងនៅលើផែនដី ឲ្យស្ថិតនៅក្រោមព្រះបាទារបស់ទ្រង់ដែរ ហើយយ៉ាងហោចណាស់ ទ្រង់នាំយកមនុស្សទុច្ចរិតដែលឈ្លានពាន និងរុកគួនមនុស្សឲ្យលុតជង្គង់ទទួលការកាត់ទោសរបស់ទ្រង់ដែរ។ លទ្ធផលនៃកិច្ចការទាំងអស់នេះត្រូវបានកើតឡើង ដោយសារតែព្រះប្រាជ្ញាញាណរបស់ទ្រង់។ ទ្រង់មិនដែលបើកសម្ដែងព្រះប្រាជ្ញាញាណរបស់ទ្រង់ មុនអត្ថិភាពរបស់

មនុស្សឡើយ ព្រោះថាទ្រង់គ្មានសត្រូវនៅស្ថានសួគ៌ នៅលើផែនដី ឬនៅគ្រប់ទីកន្លែងក្នុងចក្រវាលនេះឡើយ ហើយក៏គ្មានកម្លាំងឈ្លានពាន នៃសេចក្ដីងងឹតណាមួយនៅក្នុងចំណោមធម្មជាតិនោះដែរ។ ក្រោយមហាទេវតាបានក្បត់ទ្រង់ ព្រះអង្គបានបង្កើតមនុស្សនៅលើផែនដី ហើយដោយសារតែមនុស្សនេះហើយ ទើបទ្រង់បានចាប់ផ្ដើមធ្វើសង្គ្រាមរយៈពេលមួយពាន់ឆ្នាំរបស់ទ្រង់ជាមួយសាតាំង ដែលជាមហាទេវតា ជាសង្គ្រាមមួយដែលកើនកម្ដៅកាន់តែខ្លាំងឡើងៗ នៅក្នុងដំណាក់កាលក្រោយៗ។ ព្រះចេស្ដា និងព្រះប្រាជ្ញាញាណរបស់ទ្រង់ត្រូវបានស្ដែងចេញនៅក្នុងដំណាក់កាលនីមួយៗ។ មានតែបែបនេះទេ ទើបអ្វីៗគ្រប់យ៉ាងនៅលើមេឃ និងនៅលើផែនដី បានឃើញផ្ទាល់ភ្នែកនូវព្រះប្រាជ្ញាញាណព្រះចេស្ដា និងការពិតរបស់ព្រះជាម្ចាស់ ជាពិសេស។ ទ្រង់នៅតែអនុវត្តតាមកិច្ចការរបស់ទ្រង់នៅក្នុងឥរិយាបថពិតជាក់ស្ដែងបែបនេះ រហូតមកដល់ពេលសព្វថ្ងៃ។ លើសពីនេះទៅទៀត នៅពេលដែលទ្រង់អនុវត្តកិច្ចការរបស់ទ្រង់ ព្រះអង្គក៏បើកសម្ដែងពីព្រះប្រាជ្ញាញាណ និងព្រះចេស្ដារបស់ទ្រង់ដែរ។ ទ្រង់អនុញ្ញាតឲ្យអ្នករាល់គ្នា មើលឃើញពីសេចក្ដីពិតខាងក្នុងនៃដំណាក់កាលនីមួយៗនៃកិច្ចការ មើលឃើញយ៉ាងជាក់ច្បាស់ពីរបៀបពន្យល់អំពីព្រះចេស្ដារបស់ព្រះជាម្ចាស់ ហើយលើសពីនេះ គឺមើលឃើញពីសេចក្ដីពន្យល់ដ៏ដាច់ស្រេចអំពីភាពជាក់ស្ដែងរបស់ព្រះជាម្ចាស់ដែរ។

ទាក់ទងនឹងអំពើក្បត់របស់យូដាសចំពោះព្រះយេស៊ូវវិញ មនុស្សខ្លះឆ្ងល់ថា៖ តើទង្វើនេះមិនត្រូវបានគ្រោងទុក មុនពេលកំណើតពិភពលោកទេឬអី? តាមពិតទៅព្រះវិញ្ញាណបរិសុទ្ធបានធ្វើផែនការទាំងនេះ ដោយផ្អែកលើភាពពិតជាក់ស្ដែងនាពេលនោះ។ វាបានកើតឡើងចំពេលដែលមានបុរសម្នាក់ឈ្មោះយូដាសកំពុងតែលួចបន្លំលុយ ដូច្នេះ បុគ្គលម្នាក់នេះត្រូវបានជ្រើសរើសឲ្យដើរតួនេះ ដើម្បីបម្រើដល់កិច្ចការរបស់ទ្រង់តែម្ដងទៅ។ នេះគឺជាឧទាហរណ៍ដ៏ពិតមួយអំពីការប្រើប្រាស់ធនធានក្នុងស្រុក។ ដំបូងឡើយ ព្រះយេស៊ូវមិនបានជ្រាបដឹងអំពីការនេះឡើយ។ ទ្រង់បានជ្រាបដឹងអំពីរឿងនេះ នាពេលក្រោយមកប៉ុណ្ណោះ គឺក្រោយពេលដែលយូដាស

ត្រូវបានលាតត្រដាង។ បើមាននរណាម្នាក់ផ្សេងមានសមត្ថភាពដើរតួនេះ នោះគេនឹងបានធ្វើទង្វើនេះ ជំនួសឲ្យយូដាសមិនខាន។ ការដែលត្រូវបានកំណត់ទុកជាមុនតាមពិតទៅ គឺជាអ្វីមួយដែលព្រះវិញ្ញាណបរិសុទ្ធបានធ្វើនៅក្នុងពេលនោះប៉ុណ្ណោះ។ កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ គឺតែងតែធ្វើឡើងភ្លាមៗ ដោយគ្មានការគ្រោងទុកឡើយ។ ទ្រង់អាចរៀបចំផែនការនៃកិច្ចការរបស់ទ្រង់នៅគ្រប់ពេលវេលាហើយអនុវត្តកិច្ចការនោះនៅគ្រប់ពេលវេលា។ ហេតុអ្វីបានជាខ្ញុំតែងតែមានបន្ទូលថា កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធមានភាពពិតជាក់ស្តែង និងតែងតែថ្មីជានិច្ច មិនដែលចាស់ហើយតែងតែស្រស់ៗ បំផុត? កិច្ចការរបស់ទ្រង់ មិនត្រូវបានគ្រោងទុកឡើយ នៅពេលដែលពិភពលោកត្រូវបានបង្កើតមក ហើយនោះមិនមែនជាអ្វីដែលបានកើតឡើងទាល់តែសោះ! គ្រប់ជំហាននៃកិច្ចការមានប្រសិទ្ធភាពរបស់វាទៅតាមពេលកំណត់របស់វា ហើយជំហានទាំងនេះមិនជ្រៀតជ្រៀកគ្នាឡើយ។ ភាគច្រើន ផែនការដែលអ្នកមាននៅក្នុងគំនិត មិនត្រូវគ្នាជាមួយកិច្ចការដ៏ថ្មីៗបំផុតរបស់ព្រះវិញ្ញាណបរិសុទ្ធឡើយ។ កិច្ចការរបស់ទ្រង់មិនមានលក្ខណៈសាមញ្ញដូចជាការត្រិះរិះពិចារណារបស់មនុស្សឡើយ ហើយក៏មិនមានភាពស្មុគស្មាញដូចការស្រមៃរបស់មនុស្សដែរប៉ុន្តែវាផ្សំឡើងពីការផ្គត់ផ្គង់ដល់មនុស្សនៅគ្រប់ពេល និងគ្រប់ទីកន្លែង ដោយស្របតាមតម្រូវការបច្ចុប្បន្នរបស់គេ។ គ្មាននរណាម្នាក់ស្គាល់ច្បាស់អំពីសារជាតិរបស់មនុស្សជាងទ្រង់នោះឡើយ ហើយដោយសារតែហេតុផលនេះ ទើបគ្មានអ្វីមួយអាចបំពេញតម្រូវការជាក់ស្តែងរបស់មនុស្សបានយ៉ាងល្អ ដូចជាកិច្ចការរបស់ទ្រង់នោះឡើយ។ ដូច្នេះ បើចេញពីទស្សនៈរបស់មនុស្ស កិច្ចការរបស់ទ្រង់ហាក់ដូចជាបានគ្រោងទុករាប់ពាន់ឆ្នាំរួចមកហើយ។ នៅពេលដែលទ្រង់ធ្វើការនៅក្នុងចំណោមអ្នករាល់គ្នានាពេលសព្វថ្ងៃ ទ្រង់នឹងធ្វើការបណ្ដើរ និងមានបន្ទូលបណ្ដើរ នៅពេលដែលទ្រង់ទតឃើញសភាពជាក់ស្តែង ដែលអ្នករាល់គ្នាស្ថិតនៅ ហើយទ្រង់មានព្រះបន្ទូលចំៗស្របតាមសភាពការណ៍នីមួយៗ ដែលត្រូវនឹងអ្វីដែលមនុស្សត្រូវការតែម្តង។ ការបោះជំហានដំបូងនៃកិច្ចការរបស់ទ្រង់៖ ពេលវេលា នៃការវាយផ្ចាល។ ក្រោយមក

ទៀត មនុស្សបានសម្ដែង គ្រប់ទាំងឥរិយាបថរបស់គេ ហើយបានប្រព្រឹត្តបះបោរ នៅក្នុងរបៀបជាក់ស្ដែង ដែលមានទាំងសភាពវិជ្ជមាន និងសភាពអវិជ្ជមាន។ ពួកគេបានឈានដល់កម្រិតមួយ នៅក្នុងភាពអវិជ្ជមានរបស់គេ និងបានបង្ហាញពីដែនកម្រិតដ៏ទាបបំផុតដែលពួកគេនឹងដួលចុះ។ ព្រះជាម្ចាស់បានធ្វើកិច្ចការរបស់ទ្រង់ដោយផ្អែកទៅលើចំណុចទាំងអស់នេះ រួមទាំងប្រើចំណុចទាំងនេះដើម្បីសម្រេចកិច្ចការរបស់ទ្រង់ឲ្យបានផលកាន់តែច្រើន។ នោះមានន័យថា ទ្រង់ធ្វើកិច្ចការទ្រទ្រង់នៅក្នុងចំណោមមនុស្ស ដោយផ្អែកលើសភាពការណ៍បច្ចុប្បន្ន របស់គេនាពេលនោះ។ ទ្រង់អនុវត្តគ្រប់ទាំងជំហាននៃកិច្ចការរបស់ទ្រង់ ស្របទៅតាមសភាពការណ៍ជាក់ស្ដែងរបស់មនុស្ស។ សត្តនិករទាំងអស់ស្ថិតនៅក្នុងព្រះហស្តរបស់ទ្រង់ តើទ្រង់អាចមិនជ្រាបដឹងអំពីពួកគេយ៉ាងដូចម្ដេចទៅ? ព្រះជាម្ចាស់អនុវត្តជំហានបន្ទាប់នៃកិច្ចការដែលគួរតែត្រូវបានធ្វើនៅគ្រប់ពេលវេលា និងគ្រប់ទីកន្លែង ដោយស្របទៅតាមសភាពរបស់មនុស្ស។ កិច្ចការនេះមិនត្រូវបានគ្រោងទុកជាមុនរាប់ពាន់ឆ្នាំនោះឡើយ ដ្បិតនេះជាសញ្ញាណរបស់មនុស្សទេ! ទ្រង់ធ្វើការនៅពេលដែលទ្រង់សង្កេតឃើញផលប៉ះពាល់នៃកិច្ចការរបស់ទ្រង់ ហើយកិច្ចការរបស់ទ្រង់បន្តស៊ីជម្រៅ និងអភិវឌ្ឍទៅមុខ ហើយក្រោយពេលសង្កេតឃើញលទ្ធផលនៃកិច្ចការរបស់ទ្រង់រួចហើយ ទ្រង់តែងតែអនុវត្តជំហានបន្ទាប់នៃកិច្ចការរបស់ទ្រង់ជានិច្ច។ ទ្រង់ប្រើនូវកិច្ចការជាច្រើន ដើម្បីផ្លាស់ប្ដូរបន្តិចម្ដងៗ និងដើម្បីធ្វើឲ្យមនុស្សមើលឃើញពីកិច្ចការថ្មីរបស់ទ្រង់ដែលបានធ្វើកន្លងមក។ ឥរិយាបថនៃការធ្វើការបែបនេះអាចផ្គត់ផ្គង់ដល់តម្រូវការរបស់មនុស្សព្រោះថាព្រះជាម្ចាស់ស្គាល់មនុស្សទាំងអស់យ៉ាងច្បាស់។ នេះជារបៀបដែលទ្រង់អនុវត្តកិច្ចការរបស់ទ្រង់ពីស្ថានសួគ៌។ ដូចគ្នាដែរ ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស ក៏ធ្វើកិច្ចការរបស់ទ្រង់តាមរបៀបនេះដែរ ដោយធ្វើការរៀបចំចាត់ចែង និងធ្វើការក្នុងចំណោមមនុស្ស ស្របតាមកាលៈទេសៈ និងការធ្វើការជាក់ស្ដែង។ គ្មានកិច្ចការណាមួយរបស់ទ្រង់ត្រូវបានរៀបចំមុនពេលដែលពិភពលោកត្រូវបានបង្កើតឡើយ ហើយក៏គ្មានកិច្ចការណាដែលត្រូវបានគ្រោងទុកយ៉ាងល្អិតល្អន់ពីមុនមកដែរ។ ពីរពាន់ឆ្នាំ ក្រោយពេលដែល

ពិភពលោកត្រូវបានបង្កើតមក ព្រះយេហូវ៉ាបានទតឃើញថាមនុស្សបានពុករលួយយ៉ាងខ្លាំង ដែលនាំឲ្យទ្រង់ប្រើប្រាស់មាត់របស់ហោរាអេសាយ ដើម្បីទស្សន៍ទាយថា ក្រោយយុគសម័យនៃក្រឹត្យវិន័យបានបញ្ចប់ ព្រះយេហូវ៉ានឹងអនុវត្តកិច្ចការនៃការប្រោសលោះមនុស្សរបស់ទ្រង់នៅក្នុងយុគសម័យនៃព្រះគុណ។ ជាការពិត នេះជាផែនការរបស់ព្រះយេហូវ៉ា ប៉ុន្តែផែនការនេះក៏ត្រូវបានបង្កើតឡើងស្របតាមកាលៈទេសៈដែលទ្រង់កំពុងតែសង្កេតឃើញនាពេលនោះដែរ។ ច្បាស់ណាស់ ទ្រង់មិនបានព្រះតម្រិះអំពីផែនការនេះភ្លាមៗ ក្រោយពេលដែលទ្រង់បានបង្កើតអ័ដាមនោះឡើយ។ អេសាយគ្រាន់តែថ្លែងទំនាយ ប៉ុន្តែព្រះយេហូវ៉ាមិនបានធ្វើការរៀបចំទុកជាមុនសម្រាប់កិច្ចការនេះនៅក្នុងអំឡុងយុគសម័យនៃក្រឹត្យវិន័យឡើយ ផ្ទុយទៅវិញ ទ្រង់បានអនុវត្តវានៅទីចាប់ផ្ដើមនៃយុគសម័យនៃព្រះគុណ ជាពេលដែលទេវតានាំសារបានលេចឡើងនៅក្នុងសុបិនរបស់យ៉ូសែប ដើម្បីស្រាយបំភ្លឺដល់គាត់ជាមួយសារមួយថា ព្រះជាម្ចាស់នឹងត្រលប់ជាសាច់ឈាម ហើយមានតែបែបនេះទេ ទើបកិច្ចការនៃការយកកំណើតជាមនុស្សរបស់ទ្រង់បានចាប់ផ្ដើមឡើង។ ព្រះជាម្ចាស់មិនបានរៀបចំសម្រាប់កិច្ចការ នៃការយកកំណើតជាមនុស្សរបស់ទ្រង់ភ្លាមៗក្រោយពេលទ្រង់បង្កើតពិភពលោក ដូចអ្វីដែលមនុស្សបានស្រមើស្រមៃនោះឡើយ។ ការនេះត្រូវបានសម្រេច ដោយផ្អែកលើកម្រិតដែលមនុស្សបានអភិវឌ្ឍ និងស្ថានការណ៍នៃការធ្វើសង្គ្រាមរបស់ទ្រង់ទាស់នឹងសាតាំងប៉ុណ្ណោះ។

នៅពេលដែលព្រះជាម្ចាស់ត្រលប់ជាសាច់ឈាម ព្រះវិញ្ញាណរបស់ទ្រង់យាង ចុះមកសណ្ឋិតលើមនុស្ស។ អាចនិយាយម្យ៉ាងទៀតបានថា ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់គ្របដណ្ដប់អង្គទ្រង់ជាមួយរូបកាយជាមនុស្ស។ ទ្រង់យាងមកដើម្បីធ្វើកិច្ចការរបស់ទ្រង់នៅលើផែនដី មិនមែនដើម្បីនាំមកជាមួយទ្រង់នូវជំហានដែលមានដែនកម្រិតឡើយ។ កិច្ចការរបស់ទ្រង់គឺគ្មានដែនកម្រិតឡើយ។ កិច្ចការដែលព្រះវិញ្ញាណបរិសុទ្ធធ្វើនៅក្នុងសាច់ឈាម នៅតែត្រូវបានកំណត់ទុក ដោយលទ្ធផលនៃកិច្ចការរបស់ទ្រង់ ហើយទ្រង់ប្រើប្រាស់លទ្ធផលទាំងនោះ ដើម្បីកំណត់ពីរយៈពេលដែល

ទ្រង់នឹងធ្វើកិច្ចការ ខណៈពេលដែលទ្រង់គង់នៅក្នុងសាច់ឈាម។ ព្រះវិញ្ញាណបរិសុទ្ធបើកសម្ដែងដោយផ្ទាល់នូវជំហាននីមួយៗនៃកិច្ចការរបស់ទ្រង់ ពិនិត្យមើលកិច្ចការរបស់ទ្រង់ នៅពេលដែលទ្រង់ចាប់ផ្ដើមការងារ។ កិច្ចការនេះមិនមានលក្ខណៈបែបអធិធម្មជាតិ ដូចជាការពង្រីកដែនកំណត់នៃការស្រមើស្រមៃរបស់មនុស្សឡើយ។ ការនេះ ដូចជាកិច្ចការរបស់ព្រះយេហូវ៉ា នៅក្នុងការបង្កើតផ្ទៃមេឃនិងផែនដី និងរបស់សព្វសារពើដែរ ហើយទ្រង់បានគ្រោង និងធ្វើការភ្លាមៗតែម្ដង។ ទ្រង់បានញែកពន្លឺចេញពីទីងងឹត ហើយពេលព្រឹកនិងពេលល្ងាចក៏លេចចេញឡើង ដែលការនេះត្រូវការពេលតែមួយថ្ងៃប៉ុណ្ណោះ។ នៅថ្ងៃទីពីរ ទ្រង់បានបង្កើតលំហមួយ ហើយការនេះក៏ត្រូវការពេលតែមួយថ្ងៃដែរ។ បន្ទាប់មក ទ្រង់បានបង្កើតផែនដី សមុទ្រ និងសត្វគ្រប់ប្រភេទដែលមានជីវិតរស់នៅលើដី និងសមុទ្រ ដែលតម្រូវឲ្យប្រើពេលមួយថ្ងៃទៀត។ ការនេះបានបន្តរហូតដល់ថ្ងៃទីប្រាំមួយ នៅពេលដែលព្រះជាម្ចាស់បានបង្កើតបុរសមក ហើយអនុញ្ញាតឲ្យគាត់គ្រប់គ្រងលើអ្វីៗទាំងអស់នៅលើផែនដី។ បន្ទាប់មកនៅថ្ងៃទីប្រាំពីរ នៅពេលដែលទ្រង់បានបញ្ចប់ការបង្កើតអ្វីៗគ្រប់យ៉ាងរួចហើយ ទ្រង់ក៏បានសម្រាក។ ព្រះជាម្ចាស់បានប្រទានពរដល់ថ្ងៃទីប្រាំពីរ ហើយបានកំណត់យកថ្ងៃនោះជាថ្ងៃបរិសុទ្ធ។ ទ្រង់បានសម្រេចកំណត់យកថ្ងៃបរិសុទ្ធនេះ ក្រោយពេលដែលទ្រង់បានបង្កើត របស់សព្វសារពើហើយប៉ុណ្ណោះ មិនមែនក្រោយពេលបង្កើតអ្វីៗទាំងអស់នោះឡើយ។ កិច្ចការនេះក៏ត្រូវបានអនុវត្តភ្លាមៗដែរ ហើយមុនពេលបង្កើតអ្វីៗទាំងនេះ ទ្រង់មិនទាន់បានសម្រេច ព្រះទ័យបង្កើតពិភពលោក នៅក្នុងពេលប្រាំមួយថ្ងៃ ហើយបន្ទាប់មក សម្រាកនៅថ្ងៃទីប្រាំពីរឡើយ ដូច្នេះ ការទាំងនេះមិនស្របជាមួយភាពពិតជាក់ស្ដែងទាល់តែសោះ។ ទ្រង់មិនបានមានបន្ទូលបែបនេះ ឬបានគ្រោងផែនការទុកនោះដែរ។ ទ្រង់មិនដែលមានបន្ទូលថា ការបង្កើតអ្វីៗគ្រប់យ៉ាងនឹងត្រូវសម្រេចនៅថ្ងៃទីប្រាំមួយ និងថាទ្រង់នឹងសម្រាក នៅថ្ងៃទីប្រាំពីរនោះឡើយ។ ផ្ទុយទៅវិញ ទ្រង់បានបង្កើតស្របតាមអ្វី ដែលទ្រង់ទតឃើញថាល្អនាពេលនោះ។ នៅពេលដែលទ្រង់បានបង្កើតអ្វីៗ គ្រប់យ៉ាងចប់សព្វគ្រប់ហើយ វាក៏បានមកដល់ថ្ងៃទីប្រាំមួយតែម្ដង។

ប្រសិនបើវាត្រូវចំថ្ងៃទីប្រាំ នៅពេលដែលទ្រង់បានបញ្ចប់ការបង្កើតអ្វីៗគ្រប់យ៉ាង វិញនោះ ទ្រង់នឹងកំណត់យកថ្ងៃទីប្រាំមួយជាថ្ងៃបរិសុទ្ធមិនខាន។ យ៉ាងណាមិញ ទ្រង់ពិតជាបានបញ្ចប់ការបង្កើតរបស់សព្វសារពើនៅថ្ងៃទីប្រាំមួយ ដូច្នេះ ថ្ងៃទីប្រាំពីរបានក្លាយជាថ្ងៃបរិសុទ្ធ ដែលត្រូវបានបញ្ជូនបន្តរហូតមកដល់ពេលសព្វថ្ងៃ។ ដូច្នេះ កិច្ចការបច្ចុប្បន្នរបស់ទ្រង់កំពុងតែត្រូវបានអនុវត្តនៅក្នុងតរិយាបថដូចគ្នានេះអ្នក។ ទ្រង់មានបន្ទូល និងផ្ដត់ផ្គង់ដល់តម្រូវការរបស់អ្នករាល់គ្នា ដោយស្របតាមស្ថានភាពរបស់អ្នករាល់គ្នា។ នោះជាព្រះវិញ្ញាណដែលមានបន្ទូល និងធ្វើការស្របតាមកាលៈទេសៈរបស់មនុស្ស ហើយទ្រង់បន្តទតមើលពីលើអ្វីៗគ្រប់យ៉ាង ធ្វើការនៅគ្រប់ពេលវេលា និងគ្រប់ទីកន្លែង។ ការដែលខ្ញុំធ្វើមានបន្ទូល និងប្រទានឲ្យដល់អ្នករាល់គ្នា គឺជាការអ្វីដែលអ្នករាល់គ្នាត្រូវការ ដោយគ្មានករណីលើកលែងឡើយ។ ដូច្នេះ គ្មានកិច្ចការណាមួយរបស់ខ្ញុំ ដែលដាច់ចេញពីភាពពិតជាក់ស្ដែងឡើយ ប៉ុន្តែវាជាការពិតជានិច្ច ព្រោះអ្នករាល់គ្នាបានដឹងហើយថា «ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ ទតមើលពីលើមនុស្សគ្រប់គ្នា»។ ប្រសិនបើការនេះត្រូវបានកំណត់ទុកជាមុន តើវាមិនកើតឡើងតាមផែនការគ្រោងទុកពេកទេឬអី? អ្នកគិតថា វាកើតឡើងដូចព្រះជាម្ចាស់បានគ្រោងទុកថានឹងធ្វើរយៈពេលប្រាំមួយពាន់ឆ្នាំទាំងស្រុង ហើយបន្ទាប់មក ដូចបានកំណត់ទុកជាមុន មនុស្សបានបះបោរ ប្រឆាំង វៀចវេរ និងបោកបញ្ឆោត ហើយមានសេចក្ដីពុករលួយខាងសាច់ឈាម មាននិស្ស័យរបស់សាតាំង សេចក្ដីស្រើបស្រាលរបស់ភ្នែក និងការបណ្ដោយខ្លួនរបស់បុគ្គល។ គ្មានចំណុចណាមួយទាំងនេះត្រូវបានកំណត់ទុកជាមុន ដោយព្រះជាម្ចាស់ឡើយ ប៉ុន្តែទាំងអស់នេះបានកើតឡើង ជាលទ្ធផលនៃសេចក្ដីពុករលួយរបស់សាតាំង។ អ្នកខ្លះអាចនិយាយថា៖ «តើសាតាំងមិនស្ថិតនៅក្នុងកណ្ដាប់ព្រះហស្ដរបស់ព្រះជាម្ចាស់ដែរទេឬអី? ព្រះជាម្ចាស់បានកំណត់ទុកជាមុនថា សាតាំងនឹងធ្វើឲ្យមនុស្សពុករលួយ ហើយក្រោយមកព្រះជាម្ចាស់បានអនុវត្តកិច្ចការរបស់ទ្រង់នៅក្នុងចំណោមមនុស្ស»។ តើព្រះជាម្ចាស់ ពិតជាកំណត់ទុកជាមុនឲ្យសាតាំងធ្វើឲ្យមនុស្សពុករលួយឬ? ព្រះជាម្ចាស់ហាក់ដូចជាសព្វព្រះហឫទ័យចង់

ឲ្យមនុស្សរស់នៅតាមបែបសាមញ្ញខ្លាំងពេកហើយ ដូច្នេះ តើទ្រង់ពិតជាជ្រៀតជ្រែកជាមួយជីវិតរបស់ពួកគេឬ? បើបែបនេះ តើការបង្ក្រាបសាតាំង និងការសង្គ្រោះមនុស្ស មិនមែនជាកិច្ចខិតខំប្រឹងប្រែងដែលឥតសារជាតិទេឬអី? តើការបះបោររបស់មនុស្ស អាចត្រូវបានមើលឃើញថា ជាការកំណត់ទុកជាមុនបានដោយរបៀបណា? វាជាអ្វីមួយដែលបានកើតឡើង ដោយសារតែការជ្រៀតជ្រែករបស់សាតាំង ដូច្នេះ តើវាអាចក្លាយជាការកំណត់ទុកជាមុនដោយព្រះជាម្ចាស់បានយ៉ាងដូចម្ដេចទៅ? សាតាំងដែលស្ថិតនៅក្នុងកណ្ដាប់ព្រះហស្តរបស់ព្រះជាម្ចាស់ ដែលអ្នករាល់គ្នាយល់ឃើញនោះ គឺមានលក្ខណៈខុសគ្នាស្រឡះពីសាតាំង ដែលស្ថិតនៅក្នុងកណ្ដាប់ព្រះហស្តរបស់ព្រះជាម្ចាស់ ដែលខ្ញុំមានបន្ទូល។ បើស្របតាមសេចក្ដីថ្លែងការណ៍របស់អ្នករាល់គ្នាថា «ព្រះជាម្ចាស់ជាព្រះដ៏មានគ្រប់ព្រះចេស្ដា ហើយសាតាំងស្ថិតនៅក្នុងកណ្ដាប់ព្រះហស្តរបស់ទ្រង់» ដូច្នេះសាតាំងមិនអាចក្បត់ទ្រង់បានឡើយ។ តើអ្នកមិនបាននិយាយថា ព្រះជាម្ចាស់ជាព្រះដ៏មានគ្រប់ព្រះចេស្ដាទេឬអី? ចំណេះដឹងរបស់អ្នករាល់គ្នា ដូចជាអរូបីពេកហើយ ហើយវាគ្មានការពិតទាល់តែសោះឡើយ។ មនុស្សមិនអាចវាស់ស្ទង់ពីព្រះតម្រិះរបស់ព្រះជាម្ចាស់បានឡើយ ហើយគេក៏មិនអាចយល់ពីព្រះប្រាជ្ញាញាណរបស់ទ្រង់បានដែរ! ព្រះជាម្ចាស់ជាព្រះដ៏មានគ្រប់ព្រះចេស្ដា ហើយនេះមិនមែនជាសេចក្ដីខុសឆ្គងឡើយ។ មហាទេវតាបានក្បត់ព្រះជាម្ចាស់ដោយសារតែដំបូងឡើយ ដ្បិតព្រះជាម្ចាស់បានប្រទានចំណែកមួយនៃសិទ្ធិអំណាចដល់វា។ ពិតណាស់ នេះជាព្រឹត្តិការណ៍មួយដែលមិនបានរំពឹងទុក ដូចជាពេលដែលនាងអេវ៉ាបានធ្លាក់ក្នុងសេចក្ដីល្បួងរបស់សត្វពស់អ៊ីចឹងដែរ។ យ៉ាងណាមិញ មិនថាសាតាំងអនុវត្តអំពើក្បត់របស់វាបែបណានោះទេ ក៏វានៅតែគ្មានអំណាចចេស្ដាដូចជាព្រះជាម្ចាស់នោះដែរ។ ដូចអ្នករាល់គ្នាបាននិយាយហើយថា សាតាំងមានអំណាចខ្លះ ហើយមិនថាវាធ្វើអ្វីនោះឡើយ ក៏សិទ្ធិអំណាចរបស់ព្រះជាម្ចាស់នឹងឈ្នះលើវាជានិច្ចដែរ។ នេះជាអត្ថន័យដ៏ពិតនៅពីក្រោយការនិយាយថា «ព្រះជាម្ចាស់ជាព្រះដ៏មានគ្រប់ព្រះចេស្ដា ហើយសាតាំងស្ថិតក្នុងកណ្ដាប់ព្រះហស្តរបស់ទ្រង់»។ ដូច្នេះ សង្គ្រាមជាមួយសាតាំងត្រូវតែអនុវត្តម្ដង

មួយជំហានៗ។ លើសពីនេះ ព្រះជាម្ចាស់រៀបចំផែនការរបស់ទ្រង់ ជាការឆ្លើយតបចំពោះឧបាយកលរបស់សាតាំង គឺថា ទ្រង់នាំមកនូវសេចក្ដីសង្គ្រោះដល់មនុស្ស និងបើកសម្ដែងពីព្រះចេស្ដា និងព្រះប្រាជ្ញាញាណរបស់ទ្រង់ នៅក្នុងរបៀបមួយដែលស្របតាមយុគសម័យនាពេលនោះ។ ដូចគ្នាដែរ កិច្ចការនៃគ្រាចុងក្រោយមិនត្រូវបានកំណត់ទុកជាមុន នៅមុនយុគសម័យនៃព្រះគុណឡើយ។ ការកំណត់ទុកជាមុន មិនត្រូវបានបង្កើតឡើងនៅក្នុងទម្រង់លំដាប់លំដោយបែបនេះឡើយ៖ ជាដំបូង ជាការធ្វើឲ្យនិស្ស័យខាងក្រៅរបស់មនុស្សផ្លាស់ប្ដូរ។ ទីពីរ ធ្វើឲ្យមនុស្សចុះចូលចំពោះការវាយផ្ចាល និងការល្បងលរបស់ទ្រង់។ ទីបី ជាការធ្វើឲ្យមនុស្សឆ្លងកាត់ទុក្ខលំបាកនៃសេចក្ដីស្លាប់។ ទីបួន ជាការឲ្យមនុស្សឆ្លងកាត់ពេលវេលានៃការស្រឡាញ់ព្រះជាម្ចាស់ និងបង្ហាញចេញនូវការតាំងចិត្តរបស់មនុស្សដែលទ្រង់បានបង្កើត។ ទីប្រាំ ការអនុញ្ញាតឲ្យមនុស្សមើលឃើញទាំងស្រុង ពីព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងស្គាល់ទ្រង់ ហើយចុងបញ្ចប់ ជាការធ្វើឲ្យមនុស្សទៅជាគ្រប់លក្ខណ៍។ ទ្រង់មិនបានគ្រោងកិច្ចការទាំងនេះទុកជាមុន ក្នុងអំឡុងយុគសម័យនៃព្រះគុណឡើយ។ ផ្ទុយទៅវិញ ទ្រង់បានចាប់ផ្ដើមគ្រោងកិច្ចការទាំងនេះនៅក្នុងយុគសម័យបច្ចុប្បន្នប៉ុណ្ណោះ។ សាតាំងកំពុងតែធ្វើការ ដូចជាព្រះជាម្ចាស់ដែរ។ សាតាំងបង្ហាញពីនិស្ស័យដ៏ពុករលួយរបស់វា ខណៈពេលដែលព្រះជាម្ចាស់មានបន្ទូលចំៗ និងបើកសម្ដែងពីកិច្ចការដ៏សំខាន់មួយចំនួន។ នេះជាកិច្ចការដែលកំពុងតែធ្វើនាពេលសព្វថ្ងៃ ហើយវាមាននូវគោលការណ៍ការងារដូចគ្នា ដែលត្រូវបានប្រើជាយូរយារណាស់មកហើយ ក្រោយកំណើតនៃពិភពលោក។

ដំបូង ព្រះជាម្ចាស់បានបង្កើតអ័ដាម និងអេវ៉ា ហើយទ្រង់ក៏បានបង្កើតសត្វពស់ដែរ។ នៅក្នុងចំណោមសត្វទាំងអស់ សត្វពស់នេះ គឺជាសត្វដែលមានពិសបំផុត។ រាងកាយរបស់វាមានផ្ទុកនូវពិស ដែលសាតាំងបានប្រើជាប្រយោជន៍របស់វា។ វាជាសត្វពស់ដែលបានល្បួងនាងអេវ៉ាឲ្យប្រព្រឹត្តអំពើបាប។ អ័ដាមបានប្រព្រឹត្តបាបតាមក្រោយនាងអេវ៉ាបានប្រព្រឹត្ត ហើយបន្ទាប់មក អ្នកទាំងពីរអាចវែកញែករវាងល្អ និងអាក្រក់។ ប្រសិនបើព្រះយេហូវ៉ាបានជ្រាបថា សត្វពស់នឹងល្បួងនាងអេវ៉ា និងជ្រាបថា

អេវ៉ានឹងល្បួងអ័ដាម ចុះហេតុអ្វីបានជាទ្រង់ដាក់ពួកគេទាំងអស់គ្នានៅក្នុងសួនតែមួយដូច្នេះ? ប្រសិនបើទ្រង់អាចទស្សន៍ទាយអំពីហេតុការណ៍ទាំងនេះបាន ចុះហេតុអ្វីបានជាទ្រង់បង្កើតសត្វពស់ ហើយដាក់វានៅក្នុងសួនអេដែនបែបនេះ? ហេតុអ្វីបានជាសួនអេដែនមាននូវដើមឈើដឹងខុសត្រូវដូច្នេះ? តើទ្រង់មានចេតនា ឲ្យពួកគេបរិភោគផ្លែឈើនោះឬ? នៅពេលដែលព្រះយេហូវ៉ាបានយាងមក មិនថាអ័ដាម ឬនាងអេវ៉ាឡើយ គឺពួកគេមិនហ៊ានប្រឈមមុខជាមួយទ្រង់ទេ ហើយមានតែពេលនោះទេ ទើបព្រះយេហូវ៉ាបានជ្រាបដឹងថា ពួកគេបានបរិភោគផ្លែឈើចេញពីដើមឈើដឹងខុសត្រូវ ហើយបានចាញ់កលល្បិចរបស់សត្វពស់។ ចុងបញ្ចប់ ទ្រង់បានដាក់បណ្ដាសាសត្វពស់ ហើយទ្រង់បានដាក់បណ្ដាសាអ័ដាម និងអេវ៉ាដែរ។ នៅពេលដែលពួកគេទាំងពីរនាក់បានបរិភោគផ្លែឈើចេញពីដើមឈើនេះ ព្រះយេហូវ៉ាមិនបានជ្រាបដឹងទាល់ តែសោះអំពីអ្វីដែលពួកគេកំពុងតែធ្វើនោះ។ មនុស្សបានត្រលប់ជាពុករលួយ ដល់កម្រិតមួយដែលអាក្រក់ និងស្រេកឃ្លានកាមគុណថោកទាប រហូតដល់អ្វីៗគ្រប់យ៉ាងដែលពួកគេមាននៅក្នុងចិត្តរបស់គេ សុទ្ធតែអាក្រក់ និងទុច្ចរិត ពោលគឺដួងចិត្តរបស់គេក្លាយជាអាក្រក់ស្មោកគ្រោក។ ដូច្នេះ ព្រះយេហូវ៉ាបានសោកស្ដាយដែលបានបង្កើតមនុស្សមក។ ក្រោយមកទៀត ទ្រង់ក៏បានអនុវត្តកិច្ចការរបស់ទ្រង់ក្នុងការបំផ្លាញពិភពលោកដោយទឹកជំនន់ ប៉ុន្តែណូអេ និងកូនប្រុសរបស់គាត់ទាំងប៉ុន្មាននៅមានជីវិតរស់។ មានកិច្ចការខ្លះមិនបានជឿនលឿន និងមានលក្ខណៈអធិធម្មជាតិ ដូចអ្វីដែលមនុស្សស្រមើស្រមៃឡើយ។ អ្នកខ្លះសួរថា៖ «ដោយសារតែព្រះជាម្ចាស់បានជ្រាបដឹងថា មហាទេវតានឹងក្បត់ទ្រង់ ចុះហេតុអ្វីបានជាទ្រង់បង្កើតវាមក?» ការពិតនោះគឺថា៖ មុនពេលផែនដីបានចេញជារូបរាង មហាទេវតាគឺជាទេវតាដ៏ខ្លាំងបំផុតនៃពួកទេវតានៅឯស្ថានសួគ៌។ វាមានយុត្តាធិការលើពួកទេវតាទាំងអស់នៅស្ថានសួគ៌ ព្រោះនេះជាសិទ្ធិអំណាចដែលព្រះជាម្ចាស់បានប្រទានដល់វា។ ក្រៅពីព្រះជាម្ចាស់ វាជាទេវតាដ៏មានអំណាចបំផុតនៅស្ថានសួគ៌។ បន្ទាប់ពីព្រះជាម្ចាស់បានបង្កើតមនុស្សរួចមក មហាទេវតាបានអនុវត្តអំពើក្បត់កាន់តែធំទាស់នឹងព្រះជាម្ចាស់នៅលើផែនដី។ ខ្ញុំមានបន្ទូល

ថា វាបានក្បត់ព្រះជាម្ចាស់ ដោយសារតែវាចង់គ្រប់គ្រងលើមនុស្ស និងចង់មានសិទ្ធិអំណាចខ្លាំងជាងព្រះជាម្ចាស់។ វាជាមហាទេវតាដែលបានល្បួងនាងអេវ៉ាឲ្យប្រព្រឹត្តអំពើបាប ហើយវាបានធ្វើបែបនេះ ដោយសារតែវាចង់តាំងនគររបស់វាឡើងនៅលើផែនដី និងឲ្យមនុស្សបែរខ្នងរបស់គេដាក់ព្រះជាម្ចាស់ ហើយបែរមកស្ដាប់បង្គាប់វាវិញ។ មហាទេវតាបានឃើញថា មានអ្វីៗជាច្រើនអាចស្ដាប់បង្គាប់វា រួមទាំងពួកទេវតា និងមនុស្សនៅលើផែនដីផង។ សត្វស្លាប និងសត្វព្រៃ ដើមឈើ ព្រៃភ្នំ ទន្លេ និងរបស់សព្វសារពើនៅលើផែនដី គឺស្ថិតនៅក្រោមការមើលថែរបស់មនុស្ស គឺអ័ដាម និងអេវ៉ា ខណៈពេលដែលអ័ដាមនិងអេវ៉ាបានស្ដាប់បង្គាប់តាមមហាទេវតា។ ដូច្នេះ មហាទេវតាមានបំណង ចង់មានសិទ្ធិអំណាចខ្ពស់ជាងព្រះជាម្ចាស់ និងក្បត់ព្រះជាម្ចាស់។ ក្រោយមក វាបានដឹកនាំពួកទេវតាជាច្រើនបះបោរប្រឆាំងនឹងព្រះជាម្ចាស់ ដែលក្រោយមក បានក្លាយជាពួកវិញ្ញាណមិនបរិសុទ្ធទៅតាមប្រភេទផ្សេងៗគ្នា។ តើការអភិវឌ្ឍន៍របស់មនុស្សមកដល់សព្វថ្ងៃនេះ មិនត្រូវបានបង្កឡើងដោយសេចក្ដីពុករលួយរបស់មហាទេវតាទេឬអី? មនុស្សមានលក្ខណៈដូចជាពួកគេនាពេលសព្វថ្ងៃ ដោយសារតែមហាទេវតាបានក្បត់ព្រះជាម្ចាស់ និងបានធ្វើឲ្យមនុស្សពុករលួយ។ កិច្ចការមួយជំហានម្ដងៗនេះមិនមានលក្ខណៈអរូបិយ និងសាមញ្ញ ដូចជាអ្វីដែលមនុស្សស្រមៃនោះឡើយ។ សាតាំងបានអនុវត្តអំពើក្បត់របស់វាសម្រាប់ហេតុផលមួយ ប៉ុន្តែមនុស្ស មិនអាចយល់អំពីការពិតដ៏សាមញ្ញនោះឡើយ។ ហេតុអ្វីបានជាព្រះជាម្ចាស់ដែលបានបង្កើតផ្ទៃមេឃ និងផែនដី ព្រមទាំងរបស់សព្វសារពើនៅលើនោះ បានបង្កើតសាតាំងដែរដូច្នេះ? ដោយសារព្រះជាម្ចាស់ស្អប់សាតាំងយ៉ាងខ្លាំង ហើយសាតាំងជាសត្រូវរបស់ទ្រង់ ហេតុអ្វីបានជាទ្រង់បានបង្កើតវាមក? តាមរយៈការបង្កើតសាតាំង តើទ្រង់មិនមែនកំពុងតែបង្កើតឲ្យមានសត្រូវទេឬអី? តាមពិតទៅ ព្រះជាម្ចាស់មិនបានបង្កើតសត្រូវឡើយ ផ្ទុយទៅវិញ ទ្រង់បានបង្កើតទេវតាមួយរូប ដែលក្រោយមកទេវតានោះបែរជាក្បត់ទ្រង់។ ឋានៈបុណ្យសក្ដិរបស់វាបានឡើងខ្ពស់ពេក រហូតដល់វាចង់ក្បត់ព្រះជាម្ចាស់។ គេអាចនិយាយបានថា វាជាហេតុការណ៍គាប់ជួនប៉ុណ្ណោះ ប៉ុន្តែ

វាក៏ជារឿងមួយ ដែលមិនអាចចៀសផុតដែរ។ វាស្រដៀងគ្នាទៅនឹងរបៀបដែលមនុស្សម្នាក់នឹងត្រូវស្លាប់ ដោយចៀសមិនផុត ក្រោយពេលដែលមានវ័យចំណាស់ដល់ចំណុចមួយអ៊ីចឹងដែរ ដូច្នេះ អ្វីៗក៏បានអភិវឌ្ឍមកដល់ដំណាក់កាលនោះ។ មនុស្សល្ងីល្ងើមិនសមហេតុផលមួយចំនួននិយាយថា «ដោយសារសាតាំងជាសត្រូវរបស់ទ្រង់ ចុះហេតុអ្វីបានជាទ្រង់បានបង្កើតវាមក? តើទ្រង់មិនបានជ្រាបដឹងថា មហាទេវតានឹងក្បត់ទ្រង់ទេឬអី? តើទ្រង់មិនទតឃើញពីភាពអស់កល្បមួយ ទៅភាពអស់កល្បមួយទៀតទេឬអី? តើទ្រង់មិនស្គាល់ពីនិស្ស័យរបស់មហាទេវតាទេឬ? ដោយសារទ្រង់បានជ្រាបដឹងយ៉ាងច្បាស់ថា វានឹងក្បត់ទ្រង់ ហេតុអ្វីបានជាទ្រង់តែងតាំងវាឲ្យក្លាយជាមហាទេវតាទៀត? វាមិនគ្រាន់តែក្បត់ទ្រង់ប៉ុណ្ណោះទេ ប៉ុន្តែ វាក៏បាននាំពួកទេវតាជាច្រើនរូបផ្សេងទៀតឲ្យទៅជាមួយវា ហើយធ្លាក់ទៅកាន់ពិភពលោករបស់មនុស្ស ដើម្បីបង្ខូចមនុស្សដែរ ប៉ុន្តែរហូតមកដល់ពេលបច្ចុប្បន្ននេះ ទ្រង់នៅតែមិនអាចសម្រេចផែនការគ្រប់គ្រង រយៈពេលប្រាំមួយពាន់ឆ្នាំរបស់ទ្រង់ទៀត»។ តើពាក្យទាំងនេះត្រឹមត្រូវដែរឬទេ? នៅពេលដែលអ្នកគិតបែបនេះ តើអ្នកមិនមែនកំពុងតែយកបញ្ហាដាក់ខ្លួនកាន់តែច្រើនទេឬអី? មានអ្នកផ្សេងទៀតដែលនិយាយថា «ប្រសិនបើសាតាំងបានធ្វើឲ្យមនុស្សពុករលួយ រហូតមកដល់ពេលបច្ចុប្បន្ន នោះព្រះជាម្ចាស់ នឹងមិននាំសេចក្ដីសង្គ្រោះមកដល់មនុស្សឡើយ។ បើបែបនេះ ព្រះប្រាជ្ញាញាណ និងព្រះចេស្ដារបស់ព្រះជាម្ចាស់នឹងត្រូវបានលាក់កំបាំងមិនខាន តើព្រះប្រាជ្ញាញាណរបស់ទ្រង់ត្រូវបានបើកសម្ដែងនៅកន្លែងណាទៅ? ដូច្នេះ ព្រះជាម្ចាស់បានបង្កើតពូជសាសន៍មនុស្សមួយសម្រាប់សាតាំង ដើម្បីឲ្យទ្រង់អាចបើកសម្ដែងពីព្រះចេស្ដារបស់ទ្រង់នៅពេលក្រោយ បើមិនដូច្នោះទេ តើមនុស្សអាចរកឃើញនូវព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់បានដោយរបៀបណា? ប្រសិនបើមនុស្សមិនប្រឆាំងនឹងព្រះជាម្ចាស់ ឬបះបោរទាស់នឹងទ្រង់ទេ នោះវានឹងគ្មានភាពចាំបាច់ក្នុងការបើកសម្ដែងអំពីទង្វើរបស់ទ្រង់ឡើយ។ ប្រសិនបើសត្តនិករទាំងអស់ត្រូវថ្វាយបង្គំ និងចុះចូលចំពោះទ្រង់ ដូច្នេះ ព្រះជាម្ចាស់នឹងគ្មានកិច្ចការដែលត្រូវធ្វើឡើយ»។ ការនេះកាន់តែឃ្លាតចាកឆ្ងាយពីការពិតហើយ

ព្រោះថាគ្មានអ្វីមួយស្មោកគ្រោកសោះឡើយអំពីព្រះជាម្ចាស់ ដូច្នេះ ទ្រង់មិនអាចបង្កើតសេចក្តីស្មោកគ្រោកបានឡើយ។ ទ្រង់បើកសម្តែងទង្វើរបស់ទ្រង់ឥឡូវ ដើម្បីបង្ក្រាបខ្មាំងសត្រូវរបស់ទ្រង់ ដើម្បីសង្គ្រោះមនុស្សដែលទ្រង់បានបង្កើត និងដើម្បីបង្ក្រាបពួកអារក្ស និងសាតាំងដែលស្អប់ ក្បត់ និងប្រឆាំងទាស់នឹងព្រះជាម្ចាស់ ហើយដាក់ពួកវាឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទ្រង់ និងដែលជាកម្មសិទ្ធិរបស់ទ្រង់កាលពីដើមដំបូងប៉ុណ្ណោះ។ ព្រះជាម្ចាស់ចង់បង្ក្រាបពួកអារក្សទាំងនេះ ហើយតាមរយៈកិច្ចការបង្ក្រាបនេះ នោះក៏បើកសម្តែងពីព្រះចេស្តារបស់ទ្រង់ទៅកាន់អ្វីៗគ្រប់យ៉ាងដែរ។ មនុស្ស និងរបស់សព្វសារពើនៅលើផែនដីនាពេលសព្វថ្ងៃ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់សាតាំង ហើយសេចក្តីកុហក ស្ថិតនៅក្រោមការគ្រប់គ្រងរបស់មនុស្សអាក្រក់។ ព្រះជាម្ចាស់ ចង់បើកសម្តែងទង្វើរបស់ទ្រង់ទៅកាន់អ្វីៗទាំងអស់ ដើម្បីឲ្យមនុស្សស្គាល់ទ្រង់ និងបង្ក្រាបសាតាំង ហើយលុបបំបាត់ខ្មាំងសត្រូវរបស់ទ្រង់ឲ្យវិនាសសាបសូន្យតែម្តង។ កិច្ចការទាំងអស់នេះត្រូវបានសម្រេច តាមរយៈការបើកសម្តែងពីកិច្ចការរបស់ទ្រង់។ គ្រប់សត្តនិកររបស់ទ្រង់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់សាតាំង ដូច្នេះ ព្រះជាម្ចាស់ចង់បើកសម្តែងពីព្រះចេស្តារបស់ទ្រង់ឲ្យពួកគេឃើញតាមរយៈការបង្ក្រាបសាតាំង។ ប្រសិនបើគ្មានសាតាំងទេ នោះទ្រង់នឹងមិនចាំបាច់ត្រូវបើកសម្តែងពីទង្វើរបស់ទ្រង់នោះឡើយ។ ប្រសិនបើមិនមែនដោយសារតែការរុកគួនរបស់សាតាំងទេ នោះព្រះជាម្ចាស់នឹងមិនបានបង្កើតមនុស្ស ហើយដឹកនាំពួកគេឲ្យរស់នៅក្នុងសួនអេដែនឡើយ។ មុនពេលមានអំពើក្បត់របស់សាតាំង ហេតុអ្វីបានជាព្រះជាម្ចាស់មិនដែលបើកសម្តែងគ្រប់ទាំងទង្វើរបស់ទ្រង់ទៅកាន់ពួកទេវតា ឬមហាទេវតាទៅ? កាលពីដើមដំបូង ប្រសិនបើពួកទេវតាទាំងអស់ និងមហាទេវតាបានស្គាល់ព្រះជាម្ចាស់ ហើយបានចុះចូលចំពោះទ្រង់ នោះព្រះជាម្ចាស់នឹងមិនបានអនុវត្តកិច្ចការដែលគ្មានន័យទាំងនោះឡើយ។ ដោយសារតែអត្ថិភាពរបស់សាតាំង និងពួកអារក្ស មនុស្សក៏បានប្រឆាំងនឹងព្រះជាម្ចាស់ដែរ ហើយពួកគេបានពេញទៅដោយនិស្ស័យដែលបះបោរ។ ដូច្នេះ ព្រះជាម្ចាស់ចង់បើកសម្តែងពីទង្វើរបស់ទ្រង់។ ដោយសារតែ

ទ្រង់ចង់ធ្វើសង្គ្រាមជាមួយសាតាំង ទើបទ្រង់ត្រូវប្រើសិទ្ធិអំណាចផ្ទាល់របស់ទ្រង់ និងគ្រប់ទង្វើរបស់ទ្រង់ ដើម្បីបង្ក្រាបវា ហើយតាមរយៈការធ្វើបែបនេះ នោះកិច្ចការសង្គ្រោះដែលទ្រង់ធ្វើនៅក្នុងចំណោមមនុស្សនឹងអនុញ្ញាតឲ្យពួកគេមើលឃើញពីព្រះប្រាជ្ញាញាណ និងព្រះចេស្ដារបស់ទ្រង់មិនខាន។ កិច្ចការដែលព្រះជាម្ចាស់កំពុងតែធ្វើនាពេលសព្វថ្ងៃ គឺជាកិច្ចការដ៏មានអត្ថន័យ ហើយគ្មានផ្លូវដូចអ្វីដែលមនុស្សមួយចំនួននិយាយថា៖ «តើកិច្ចការដែលទ្រង់ធ្វើមិនប្រឆាំងគ្នាទេឬអី? តើកិច្ចការជាបន្តបន្ទាប់នេះមិនកំពុងតែបង្កបញ្ហាសម្រាប់ទ្រង់ផ្ទាល់ទេឬ? ទ្រង់បានបង្កើតសាតាំង ហើយបន្ទាប់មកអនុញ្ញាតឲ្យវាក្បត់ និងប្រឆាំងនឹងទ្រង់។ ទ្រង់បានបង្កើតមនុស្ស ហើយបន្ទាប់មកប្រគល់ពួកគេទៅឲ្យសាតាំង ដោយអនុញ្ញាតឲ្យអ័ដាម និងអេវ៉ាជួបសេចក្ដីល្បួង។ ដោយសារតែទ្រង់មានចេតនាធ្វើកិច្ចការទាំងអស់នេះ ហេតុអ្វីបានជាទ្រង់នៅតែស្អប់ខ្ពើមមនុស្សទៀត? ហេតុអ្វីបានជាទ្រង់ស្អប់ខ្ពើមសាតាំង? តើពួកគេទាំងនេះមិនចេញមកពីការបង្កើតរបស់ទ្រង់ផ្ទាល់ទេឬអី? តើទ្រង់ស្អប់អ្វីឲ្យប្រាកដទៅ?» មានមនុស្សមិនសមហេតុផលពីរបីនាក់ដែលនិយាយសម្ដីបែបនេះ។ ពួកគេចង់ស្រឡាញ់ព្រះជាម្ចាស់ ប៉ុន្តែខាងក្នុងជម្រៅចិត្ត ពួកគេរអ៊ូរទាំអំពីព្រះជាម្ចាស់។ នេះពិតជាចិត្តផ្សេង មាត់ផ្សឹងមែន! អ្នកមិនយល់អំពីសេចក្ដីពិត អ្នកមានគំនិតបែបអធិធម្មជាតិច្រើនពេក ហើយអ្នកថែមទាំងអះអាងថា ព្រះជាម្ចាស់បានធ្វើខុសទៀត។ អ្នកដូចជាភ្លើពេកហើយ! គឺអ្នកវិញទេតើដែលកំពុងតែបំភ្លៃសេចក្ដីពិតនោះ ព្រោះថាព្រះជាម្ចាស់មិនដែលធ្វើខុសសោះឡើយ! មនុស្សមួយចំនួនថែមទាំងរអ៊ូរទាំដដែលៗថា៖ «គឺទ្រង់ដែលបានបង្កើតសាតាំងមក ហើយគឺទ្រង់ដែលបានបោះទម្លាក់សាតាំងមកក្នុងចំណោមមនុស្ស ហើយប្រគល់ពួកគេទៅឲ្យវា។ នៅពេលដែលមនុស្សមាននិស្ស័យរបស់សាតាំង ទ្រង់មិនបានអត់ទោសឲ្យពួកគេឡើយ ផ្ទុយទៅវិញ ទ្រង់បែរជាស្អប់ពួកគេដល់កម្រិតមួយទៅវិញ។ ជាដំបូង ទ្រង់បានស្រឡាញ់ពួកគេដល់កម្រិតមួយ ប៉ុន្តែឥឡូវនេះ ទ្រង់បែរជាស្អប់ខ្ពើមពួកគេទៅវិញ។ គឺទ្រង់ហើយដែលបានស្អប់មនុស្ស ប៉ុន្តែក៏ជាទ្រង់ដែរ ដែលបានស្រឡាញ់មនុស្ស។ តើមានអ្វីកំពុងតែកើតឡើងទៅ? តើវាមិនមែនជារឿងផ្ទុយគ្នាទេ

ឬអី?» មិនថាអ្នករាល់គ្នាមើលទៅកាន់រឿងនេះក្នុងទិដ្ឋភាពបែបណានោះឡើយ ប៉ុន្តែនេះជាអ្វីដែលបានកើតឡើងនៅស្ថានសួគ៌។ នេះជាឥរិយាបថមួយដែលមហាទេវតាបានក្បត់ព្រះជាម្ចាស់ និងធ្វើឲ្យមនុស្សពុករលួយ ហើយនេះជារបៀបដែលមនុស្សបានបន្តរហូតមកដល់ពេលសព្វថ្ងៃ។ មិនថាអ្នករាល់គ្នាសរសេរវាបែបណាទេ នេះជាសាច់រឿងទាំងមូលហើយ។ យ៉ាងណាមិញ អ្នករាល់គ្នាត្រូវតែយល់ថា គោលបំណងទាំងស្រុងនៅពីក្រោយកិច្ចការដែលព្រះជាម្ចាស់កំពុងតែធ្វើនាពេលសព្វថ្ងៃនេះ គឺដើម្បីសង្គ្រោះអ្នករាល់គ្នា និងបង្ក្រាបសាតាំង។

ដោយសារតែ ពួកទេវតាមានអត្តចរិតទន់ខ្សោយ និងគ្មានសមត្ថភាពក្នុងការនិយាយ ដូច្នេះ ពួកគេមានអំនួតក្អេងក្អាងកាន់តែខ្លាំង នៅពេលដែលពួកគេទទួលបានសិទ្ធិអំណាច។ នេះជាការពិតចំពោះមហាទេវតា ដែលមានឋានៈបុណ្យសក្តិខ្ពស់ជាងពួកទេវតាឯទៀតៗ។ វាដូចជាស្ដេចមួយអង្គនៅក្នុងចំណោមពួកទេវតា វាបានដឹកនាំទេវតារាប់លាននាក់ ដោយនៅក្រោមព្រះយេហូវ៉ាតែមួយប៉ុណ្ណោះ ដូច្នេះ សិទ្ធិអំណាចរបស់វា គឺខ្ពស់ជាងពួកទេវតាទាំងអស់។ វាចង់ធ្វើបែបនេះ និងបែបនោះ ហើយចង់ដឹកនាំពួកទេវតា ចុះមកកណ្ដាលចំណោមមនុស្ស ដើម្បីត្រួតត្រាលើពិភពលោក។ ព្រះជាម្ចាស់បានមានបន្ទូលថា ទ្រង់ជាព្រះដែលគ្រប់គ្រងលើចក្រវាល ប៉ុន្តែមហាទេវតាបានអះអាងថា គឺវាវិញទេតើ ដែលគ្រប់គ្រងលើចក្រវាល ដូច្នេះ តាំងពីពេលនោះមក មហាទេវតាបានក្បត់ព្រះជាម្ចាស់។ ព្រះជាម្ចាស់បានបង្កើតពិភពលោកមួយទៀតនៅស្ថានសួគ៌ ហើយមហាទេវតាចង់ត្រួតត្រាលើពិភពលោកនេះ ហើយវាក៏ចុះមកពិភពរបស់មនុស្ស។ តើព្រះជាម្ចាស់អាចអនុញ្ញាតឲ្យវាធ្វើបែបនេះទេ? ដូច្នេះ ទ្រង់បានវាយប្រហារមហាទេវតា ហើយទម្លាក់វាមកក្នុងលំហអាកាស។ តាំងពីពេលដែលវាបានធ្វើឲ្យមនុស្សពុករលួយមក ព្រះជាម្ចាស់បានធ្វើសង្គ្រាមជាមួយមហាទេវតា ដើម្បីសង្គ្រោះពួកគេ ហើយទ្រង់បានប្រើរយៈពេលប្រាំមួយពាន់ឆ្នាំនេះ ដើម្បីបង្ក្រាបវា។ គំនិតរបស់អ្នករាល់គ្នាអំពីព្រះដ៏មានគ្រប់ព្រះចេស្ដា គឺមិនត្រូវគ្នាជាមួយកិច្ចការដែលព្រះជាម្ចាស់កំពុងតែអនុវត្តនោះឡើយ ដ្បិតគំនិតទាំងនោះមានលក្ខណៈ

ប្រើការមិនបាន និងខុសឆ្គងខ្លាំងពេក! តាមពិតទៅ មានតែក្រោយពេលដែលអំពើក្បត់របស់មហាទេវតាប៉ុណ្ណោះ ទើបព្រះជាម្ចាស់បានប្រកាសថា វាជាខ្មាំងសត្រូវរបស់ទ្រង់។ គឺដោយសារតែអំពើក្បត់របស់វាប៉ុណ្ណោះ ទើបមហាទេវតាមកជាន់ឈ្លីមនុស្ស បន្ទាប់ពីចូលមកក្នុងពិភពរបស់មនុស្ស ហើយដោយសារតែហេតុផលនេះហើយ ទើបមនុស្សបានអភិវឌ្ឍមកដល់ចំណុចនេះ។ ក្រោយហេតុការណ៍នេះ បានកើតឡើង ព្រះជាម្ចាស់បានស្បថសច្ចាចំពោះសាតាំងថា៖ «ខ្ញុំនឹងបង្ក្រាបអ្នក ហើយនាំសេចក្ដីសង្គ្រោះទៅកាន់មនុស្សទាំងអស់ដែលខ្ញុំបានបង្កើតមក»។ ដោយមិនទាន់ជឿកាលពីដំបូង សាតាំងបានតបវិញថា៖ «តើទ្រង់អាចធ្វើអ្វីខ្លះដាក់ទូលបង្គំទៅ? តើទ្រង់អាចវាយប្រហារទូលបង្គំនៅលំហអាកាសដែរឬអី? តើទ្រង់ពិតជាអាចបង្ក្រាបទូលបង្គំបានឬ?» ក្រោយពេលដែលព្រះជាម្ចាស់បានទម្លាក់វាទៅក្នុងលំហអាកាស ទ្រង់លែងយកចិត្តទុកដាក់ចំពោះមហាទេវតាទៀតហើយ ហើយក្រោយមក ទ្រង់ក៏ចាប់ផ្ដើមសង្គ្រោះមនុស្ស និងអនុវត្តកិច្ចការរបស់ទ្រង់ ទោះបីជាសាតាំងចេះតែរំខានដល់កិច្ចការរបស់ទ្រង់ក៏ដោយ។ សាតាំងអាចធ្វើនេះ និងធ្វើនោះបាន គឺដោយសារតែអំណាចនានាដែលព្រះជាម្ចាស់បានប្រទានដល់វាកាលពីមុន។ វាបាននាំយកអំណាចទាំងនេះមកជាមួយវានៅលំហអាកាស ហើយវាបានរក្សាអំណាចទាំងនោះមកដល់សព្វថ្ងៃ។ ពេលទម្លាក់មហាទេវតាចុះមកលំហអាកាស ព្រះជាម្ចាស់មិនបានដកសិទ្ធិអំណាចរបស់វាវិញឡើយ ដូច្នេះ សាតាំងបានបន្តធ្វើឲ្យមនុស្សពុករលួយ។ នៅក្នុងន័យម្យ៉ាងទៀត ព្រះជាម្ចាស់បានចាប់ផ្ដើមសង្គ្រោះមនុស្សដែលសាតាំងបានធ្វើឲ្យពុករលួយ ក្រោយពេលដែលពួកគេត្រូវបានបង្កើតមកមិនយូរប៉ុន្មាន។ ព្រះជាម្ចាស់មិនបានបើកសម្ដែងទង្វើរបស់ទ្រង់ ខណៈពេលដែលទ្រង់គង់នៅលើស្ថានសួគ៌ឡើយ ប៉ុន្តែមុនពេលបង្កើតផែនដី ទ្រង់បានអនុញ្ញាតឲ្យមនុស្ស នៅក្នុងពិភពលោកដែលទ្រង់បានបង្កើតមកនៅលើស្ថានសួគ៌មើលឃើញពីទង្វើរបស់ទ្រង់ ថែមទាំងដឹកនាំមនុស្សទាំងនោះពីស្ថានសួគ៌ផង។ ទ្រង់បានប្រទានឲ្យពួកគេមានប្រាជ្ញា និងបញ្ញាវៃឆ្លាត ហើយបានដឹកនាំមនុស្សទាំងនោះឲ្យរស់នៅក្នុងពិភពលោកនោះ។ តាមធម្មតា នៅក្នុងចំណោម

អ្នករាល់គ្នាគ្មាននរណាម្នាក់ដែលធ្លាប់បានឮអំពីការនេះពីមុនមកឡើយ។ ក្រោយមក បន្ទាប់ពីព្រះជាម្ចាស់បានបង្កើតមនុស្ស មហាទេវតាបានចាប់ផ្ដើមធ្វើឲ្យមនុស្សពុករលួយ ហើយនៅលើផែនដី មនុស្សទាំងអស់ក៏បានធ្លាក់ទៅក្នុងភាពចលាចល។ ចាប់ពីពេលនោះហើយ ដែលព្រះជាម្ចាស់ចាប់ផ្ដើមធ្វើសង្គ្រាមជាមួយសាតាំង ហើយគឺនៅពេលនោះហើយ ដែលមនុស្សចាប់ផ្ដើមមើលឃើញពីទង្វើរបស់ទ្រង់។ កាលពីដើមដំបូង ទង្វើទាំងនេះត្រូវបានលាក់បាំងពីមនុស្ស។ ក្រោយពេលសាតាំងត្រូវបានទម្លាក់ទៅក្នុងលំហអាកាស វាបានធ្វើកិច្ចការរបស់វា ហើយព្រះជាម្ចាស់បានបន្តធ្វើកិច្ចការរបស់ទ្រង់ ដោយបន្តធ្វើសង្គ្រាមជាមួយសាតាំង ចាប់ពីពេលនោះរហូតដល់គ្រាចុងក្រោយ។ ឥឡូវនេះ ដល់ពេលដែលសាតាំងគួរតែត្រូវបានបំផ្លាញហើយ។ កាលពីដើមដំបូង ព្រះជាម្ចាស់បានប្រទាន ឲ្យវាមានសិទ្ធិអំណាច ហើយក្រោយមកទ្រង់បានទម្លាក់វាទៅក្នុងលំហអាកាស ប៉ុន្តែវានៅតែរឹងទទឹង។ ក្រោយមកទៀត វាបានធ្វើឲ្យមនុស្សជាតិនៅលើផែនដីទៅជាពុករលួយ ប៉ុន្តែព្រះជាម្ចាស់បានគង់នៅទីនោះ ដើម្បីគ្រប់គ្រងមនុស្ស។ ព្រះជាម្ចាស់ប្រើការគ្រប់គ្រងមនុស្សរបស់ទ្រង់ ដើម្បីបង្ក្រាបសាតាំង។ តាមរយៈការធ្វើឲ្យមនុស្សពុករលួយ សាតាំងបញ្ចប់ជោគវាសនារបស់ពួកគេ ហើយបង្អាក់ដល់កិច្ចការរបស់ព្រះជាម្ចាស់។ នៅក្នុងន័យម្យ៉ាងទៀត កិច្ចការរបស់ព្រះជាម្ចាស់គឺជាការសង្គ្រោះមនុស្ស។ តើជំហានណាខ្លះនៃកិច្ចការដែលព្រះជាម្ចាស់ធ្វើ ដែលមិនមានន័យក្នុងការសង្គ្រោះមនុស្សទៅ? តើជំហានណាខ្លះដែលមិនមែនជាការលាងជម្រះមនុស្ស និងធ្វើឲ្យពួកគេប្រព្រឹត្តយ៉ាងសុចរិត ហើយរស់នៅតាមរូបភាពនៃមនុស្សដែលអាចទទួលបានសេចក្ដីស្រឡាញ់ទៅ? ទោះជាយ៉ាងណាសាតាំងមិនធ្វើបែបនេះឡើយ។ វាធ្វើឲ្យមនុស្សត្រលប់ជាពុករលួយ។ វាបន្តអនុវត្តកិច្ចការរបស់វា ដោយធ្វើឲ្យមនុស្សនៅក្នុងចក្រវាលទៅជាពុករលួយ។ ជាការពិតព្រះជាម្ចាស់ក៏ធ្វើកិច្ចការរបស់ទ្រង់ផងដែរ ដោយមិនយកចិត្តទុកដាក់ចំពោះសាតាំងឡើយ។ មិនថាសាតាំងមានសិទ្ធិអំណាចច្រើនប៉ុនណា ក៏សិទ្ធិអំណាចនោះនៅតែត្រូវបានប្រទានមកពីព្រះជាម្ចាស់ដែរ។ តាមពិតទៅ ព្រះជាម្ចាស់មិនបានប្រទានសិទ្ធិអំណាចរបស់ទ្រង់

ទាំងអស់ដល់វាឡើយ ដូច្នេះ មិនថាសាតាំងធ្វើអ្វីឡើយ វាមិនអាចខ្លាំងជាងព្រះជាម្ចាស់ ហើយវានឹងនៅក្នុងកណ្ដាប់ព្រះហស្តរបស់ព្រះជាម្ចាស់ជានិច្ច។ ព្រះជាម្ចាស់មិនបាន បើកសម្ដែងទង្វើរបស់ទ្រង់ណាមួយឡើយ ក្នុងពេលនៅស្ថានសួគ៌។ ទ្រង់គ្រាន់តែ ប្រទានឲ្យសាតាំងនូវសិទ្ធិអំណាចមួយក្ដាប់តូច ហើយអនុញ្ញាតឲ្យវាអនុវត្តការត្រួតត្រា លើពួកទេវតាប៉ុណ្ណោះ។ ដូច្នេះ មិនថាសាតាំងធ្វើអ្វីឡើយ វាមិនអាចខ្លាំងលើសសិទ្ធិ អំណាចរបស់ព្រះជាម្ចាស់ឡើយ ដោយសារតែសិទ្ធិអំណាចដែលព្រះជាម្ចាស់បាន ប្រទានដល់វាកាលពីគ្រាដំបូង គឺមានកម្រិត។ នៅពេលដែលព្រះជាម្ចាស់ធ្វើការ សាតាំងព្យាយាមបង្អាក់។ នៅគ្រាចុងក្រោយ ការបង្អាក់របស់វានឹងត្រូវបញ្ចប់។ ដូចគ្នាផងដែរ កិច្ចការរបស់ព្រះជាម្ចាស់ក៏នឹងត្រូវបញ្ចប់ផងដែរ ហើយប្រភេទនៃ មនុស្សលោក ដែលព្រះជាម្ចាស់ចង់ធ្វើឲ្យគ្រប់លក្ខណ៍ នឹងត្រូវសម្រេចជាស្ថាពរ មិនខាន។ ព្រះជាម្ចាស់ដឹកនាំមនុស្សនៅក្នុងផ្លូវវិជ្ជមាន ដ្បិតព្រះជន្មរបស់ទ្រង់គឺជា ទឹករស់ មិនអាចវាស់វែងបាន ហើយក៏គ្មានដែនកំណត់ផងដែរ។ សាតាំងបានធ្វើឲ្យ មនុស្សខូចអាក្រក់ទៅដល់កម្រិតមួយ ប៉ុន្តែ នៅចុងបញ្ចប់ទឹកនៃជីវិតដ៏រស់នឹងធ្វើឲ្យ ពួកគេក្លាយជាគ្រប់លក្ខណ៍ ហើយសាតាំងនឹងមិនអាចជ្រៀតជ្រែក និងអនុវត្តកិច្ចការ របស់វាបានទៀតឡើយ។ ដូច្នេះ ព្រះជាម្ចាស់នឹងអាចទទួលយកមនុស្សទាំងនេះយ៉ាង ពេញលេញ។ សូម្បីតែឥឡូវនេះ សាតាំងនៅតែបដិសេធមិនទទួលស្គាល់ការពិតនេះ ឡើយ ព្រោះវានៅតែបន្ត ទាស់ប្រឆាំងនឹងព្រះជាម្ចាស់ ប៉ុន្តែ ទ្រង់មិនយកចិត្តទុកដាក់ ចំពោះវាឡើយ។ ព្រះជាម្ចាស់បានមានបន្ទូលថា៖ «ខ្ញុំនឹងមានជ័យជម្នះលើកម្លាំងងងឹត របស់សាតាំង និងលើគ្រប់ឥទ្ធិពលខាងផ្លូវងងឹតរបស់វាទាំងអស់»។ នេះជាកិច្ចការ ដែលត្រូវតែសម្រេចនាពេលបច្ចុប្បន្ននៅក្នុងសាច់ឈាម ហើយវាក៏ជាអ្វីដែលធ្វើឲ្យ ការក្លាយជាសាច់ឈាមមានភាពសំខាន់ផងដែរ៖ នោះគឺដើម្បីបញ្ចប់ដំណាក់កាល នៃកិច្ចការបង្ក្រាបសាតាំងនៅគ្រាចុងក្រោយនិងបោសសម្អាតអ្វីៗទាំងអស់ដែលជា កម្មសិទ្ធិរបស់សាតាំង។ ជ័យជម្នះរបស់ព្រះជាម្ចាស់ទៅលើសាតាំង គឺជាអ្វីមួយនឹង កើតឡើងយ៉ាងប្រាកដជាក់! ជាការពិត សាតាំងបានបរាជ័យជាយូរឆ្នាំមកហើយ។

នៅពេលដែលដំណឹងល្អបានចាប់ផ្ដើមរីកសាយភាយនៅទូទាំងទឹកដីរបស់នាគដ៏ធំមានសម្បុរក្រហម នោះជាពេលដែលព្រះដែលយកកំណើតជាមនុស្សបានចាប់ផ្ដើមធ្វើកិច្ចការរបស់ទ្រង់ ហើយកិច្ចការនេះកំពុងតែដំណើរការ សាតាំងបានចាញ់ទាំងស្រុង ព្រោះគោលបំណងចម្បងនៃការយកកំណើតជាមនុស្ស គឺដើម្បីកម្ចាត់សាតាំងឲ្យវិនាសសាបសូន្យតែម្ដង។ នៅពេលដែលសាតាំងបានឃើញថា ព្រះជាម្ចាស់ បានក្លាយជាសាច់ឈាមម្ដងទៀត និងចាប់ផ្ដើមអនុវត្តកិច្ចការរបស់ទ្រង់ ដែលគ្មានកម្លាំងណាមួយអាចបញ្ឈប់បាន ដូច្នេះ វាបានស្រឡាំងកាំងចំពោះកិច្ចការនេះ ហើយមិនហ៊ានបង្កសេចក្ដីអន្តរាយអ្វីផ្សេងទៀតឡើយ។ ជាដំបូង សាតាំងបានគិតថា វាក៏មានប្រាជ្ញាច្រើនផងដែរ ដូច្នេះ វាធ្វើការរំខាន និងរុកគួនដល់កិច្ចការរបស់ព្រះជាម្ចាស់ ប៉ុន្តែវាមិនបានរំពឹងថា ព្រះជាម្ចាស់នឹងក្លាយជាសាច់ឈាមម្ដងទៀត ឬដឹងថា នៅក្នុងកិច្ចការរបស់ទ្រង់ ព្រះជាម្ចាស់នឹងប្រើការបះបោររបស់សាតាំង មកបម្រើជាការបើកសម្ដែង និងការជំនុំជម្រះសម្រាប់មនុស្សជាតិ ក្នុងគោលបំណងទៅយកឈ្នះមនុស្ស និងបង្ក្រាបសាតាំងឡើយ។ ព្រះជាម្ចាស់ មានព្រះប្រាជ្ញាញាណឆ្លាតជាងសាតាំង ហើយកិច្ចការរបស់ទ្រង់ក៏មានអំណាចខ្លាំងជាងវាផងដែរ។ ដូច្នេះ ដូចជាខ្ញុំបានមានបន្ទូលកាលពីមុនថា៖ «កិច្ចការរបស់ខ្ញុំត្រូវបានអនុវត្ត ដើម្បីឆ្លើយតបនឹងឧបាយកលរបស់សាតាំង ហើយនៅចុងបញ្ចប់ ខ្ញុំនឹងបើកសម្ដែងព្រះចេស្ដារបស់ខ្ញុំ និងភាពគ្មានអំណាចរបស់សាតាំង»។ ព្រះជាម្ចាស់នឹងធ្វើកិច្ចការរបស់ទ្រង់នៅជួរមុខ ឯសាតាំងវិញ វានឹងដើរថយក្រោយរហូតដល់ទីបញ្ចប់ វានឹងត្រូវបំផ្លាញទាំងមិនដឹងខ្លួនថា មានអ្វីមួយនឹងបុកវាផង! វានឹងដឹងអំពីសេចក្ដីពិត នៅពេលដែលវាត្រូវបានកម្ទេច និងសង្កត់ឲ្យខ្ទេចខ្ទី ហើយទម្រាំដល់ពេលនោះ វានឹងត្រូវបានដុតរំលាយនៅក្នុងបឹងភ្លើងរួចស្រេចទៅហើយ។ តើវានឹងនៅតែមិនជឿទាំងស្រុងទៀតឬ? ដ្បិតនៅពេលនោះ សាតាំងនឹងគ្មានផែនការណាផ្សេងទៀត ដើម្បីប្រើឡើយ!

គឺកិច្ចការពិតជាក់ស្ដែង មួយជំហានម្ដងៗនេះហើយ ដែលជារឿយៗធ្វើឲ្យព្រះជាម្ចាស់ព្រួយព្រះទ័យចំពោះមនុស្ស ដូច្នេះ ការធ្វើសង្គ្រាមរបស់ទ្រង់ជាមួយសាតាំង

មានរយៈពេលប្រាំមួយពាន់ឆ្នាំ ហើយព្រះជាម្ចាស់បានមានបន្ទូលថា «ខ្ញុំនឹងមិនបង្កើតមនុស្សម្ដងទៀតទេ ហើយក៏មិនប្រទានសិទ្ធិអំណាចដល់ពួកទេវតាម្ដងទៀតដែរ»។ ចាប់ពីពេលនោះមក នៅពេលដែលពួកទេវតាចាប់ផ្ដើមធ្វើការនៅលើផែនដី ពួកគេគ្រាន់តែដើរតាមព្រះជាម្ចាស់ ដើម្បីធ្វើកិច្ចការមួយចំនួនប៉ុណ្ណោះ ហើយទ្រង់មិនបានប្រទានឲ្យពួកគេមានសិទ្ធិអំណាចម្ដងទៀតឡើយ។ តើពួកអ៊ីស្រាអែលបានឃើញពួកទេវតាអនុវត្តកិច្ចការរបស់ពួកគេយ៉ាងដូចម្ដេចទៅ? ពួកគេបានបើកសម្ដែងនៅក្នុងសុបិន ហើយបាននាំព្រះបន្ទូលរបស់ព្រះយេហូវ៉ា។ នៅពេលដែលព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញនៅបីថ្ងៃក្រោយការជាប់ឆ្កាង ពួកទេវតាគឺជាអ្នកដែលបានរុញរំកិលផ្ទាំងថ្មទៅម្ខាង ព្រោះព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ មិនបានធ្វើកិច្ចការនេះដោយផ្ទាល់ទេ។ ពួកទេវតាបានធ្វើកិច្ចការបែបនេះប៉ុណ្ណោះ។ ពួកគេបានដើរតួជាអ្នកជំនួយ ប៉ុន្តែគ្មានសិទ្ធិអំណាចទេឡើយ ដ្បិតព្រះជាម្ចាស់មិនបានប្រទានឲ្យពួកគេមានសិទ្ធិអំណាចអ្វីឡើយ។ ក្រោយធ្វើការបានមួយរយៈ មនុស្សដែលព្រះជាម្ចាស់បានប្រើនៅលើផែនដី បានយកតួនាទីរបស់ព្រះជាម្ចាស់ ហើយនិយាយថា៖ «ខ្ញុំចង់មានឋានៈខ្ពស់ជាងចក្រវាល! ខ្ញុំចង់ឈរនៅស្ថានសួគ៌ជាន់ទីបី! យើងចង់កាន់កាប់អំណាចជាស្ដេចដែលសោយរាជ្យ!» ពួកគេបានមានអំនួតក្អេងក្អាង ក្រោយធ្វើកិច្ចការបានប៉ុន្មានថ្ងៃ ហើយពួកគេចង់មានសិទ្ធិអំណាចជាស្ដេចលើផែនដី ចង់តាំងប្រជាជាតិមួយទៀតឡើង ចង់ដាក់អ្វីៗទាំងអស់នៅក្រោមជើងរបស់គេ និងចង់ឈរនៅស្ថានសួគ៌ជាន់ទីបី។ តើអ្នកមិនដឹងទេឬថា អ្នកគ្រាន់តែជាមនុស្សដែលព្រះជាម្ចាស់ប្រើប៉ុណ្ណោះ? តើអ្នកអាចឡើងស្ថានសួគ៌ជាន់ទីបីបានដោយរបៀបណា? ព្រះជាម្ចាស់យាងមកផែនដីដើម្បីធ្វើការស្ងាត់ៗ មិនស្រែកប្រកាសឡើយ ហើយបន្ទាប់មក ទ្រង់ក៏បានចាកចេញទៅដោយស្ងាត់ៗ ក្រោយពេលបង្ហើយកិច្ចការរបស់ទ្រង់។ ទ្រង់មិនដែលស្រែកក្ដែងៗដូចមនុស្សឡើយ ប៉ុន្តែទ្រង់មានភាពពិតជាក់ស្ដែងនៅក្នុងការអនុវត្តកិច្ចការ របស់ទ្រង់។ ទ្រង់ក៏មិនដែលចូលទៅក្នុងពួកជំនុំ ហើយស្រែកឡើងថា «ខ្ញុំនឹងបោសសម្អាតអ្នករាល់គ្នាចោល! ខ្ញុំនឹងដាក់បណ្ដាសា និងកាត់ទោសអ្នករាល់គ្នាឡើយ!» ទ្រង់

គ្រាន់តែបន្តធ្វើកិច្ចការរបស់ទ្រង់ ហើយចាកចេញទៅ នៅពេលដែលទ្រង់បានធ្វើចប់ប៉ុណ្ណោះ។ គ្រូគង្វាលសាសនាដែលប្រោសអ្នកជំងឺឲ្យជា និងបណ្ដេញអារក្ស បង្រៀនមនុស្សពីលើឆាក អធិប្បាយព្រះបន្ទូលយ៉ាងយូរ និងពេញដោយភាពក្រអឺតក្រទម ហើយពិភាក្សាអំពីកិច្ចការដែលមិនពិតជាក់ស្ដែងទាំងនោះ សុទ្ធតែមានចិត្តក្មេងក្មាងទាំងអស់! ពួកគេជាពូជពង្សរបស់មហាទេវតា!

ក្រោយបានអនុវត្តកិច្ចការ រយៈពេលប្រាំមួយពាន់ឆ្នាំរបស់ទ្រង់ រហូតមកដល់ពេលបច្ចុប្បន្ន ព្រះជាម្ចាស់បានបើកសម្ដែងទង្វើរបស់ទ្រង់ជាច្រើនមកហើយ ហើយគោលបំណងចម្បងរបស់ទ្រង់ គឺដើម្បីបង្ក្រាបសាតាំង និងនាំសេចក្ដីសង្គ្រោះទៅកាន់មនុស្សទាំងអស់។ ទ្រង់កំពុងតែប្រើប្រាស់ឱកាសនេះ ដើម្បីអនុញ្ញាតឲ្យអ្វីៗគ្រប់យ៉ាងនៅលើមេឃ អ្វីៗគ្រប់យ៉ាងនៅលើផែនដី អ្វីៗគ្រប់យ៉ាងនៅក្នុងសមុទ្រ និងគ្រប់វត្ថុចុងក្រោយនៃការបង្កើតរបស់ព្រះជាម្ចាស់ នៅលើផែនដី មើលឃើញពីព្រះចេស្ដា និងគ្រប់ទង្វើរបស់ទ្រង់ដោយផ្ទាល់ភ្នែក។ ទ្រង់កំពុងតែប្រើប្រាស់ឱកាស ចេញពីការបង្ក្រាបរបស់ទ្រង់ទៅលើសាតាំង ដើម្បីបើកសម្ដែងពីគ្រប់ទង្វើរបស់ទ្រង់ ទៅកាន់មនុស្ស និងដើម្បីឲ្យពួកគេសរសើរទ្រង់ ហើយលើកតម្កើងពីព្រះប្រាជ្ញាញាណរបស់ទ្រង់ក្នុងការបង្ក្រាបសាតាំង។ អ្វីៗគ្រប់យ៉ាងនៅលើផែនដី នៅលើមេឃ និងនៅក្នុងសមុទ្រ នឹងថ្វាយសិរីល្អដល់ព្រះជាម្ចាស់ សរសើរពីព្រះចេស្ដារបស់ទ្រង់ សរសើរពីគ្រប់ទង្វើរបស់ទ្រង់ និងស្រែកប្រកាសពីព្រះនាមដ៏វិសុទ្ធរបស់ទ្រង់។ នេះជាភស្ដុតាងដែលបញ្ជាក់អំពីការបង្ក្រាបរបស់ទ្រង់ទៅលើសាតាំង ហើយក៏ជាភស្ដុតាងពីការដែលទ្រង់កម្ចាត់សាតាំងឲ្យវិនាសសាបសូន្យដែរ។ អ្វីដែលកាន់តែសំខាន់ទៀតនោះគឺថា វាជាភស្ដុតាងអំពីសេចក្ដីសង្គ្រោះរបស់ទ្រង់សម្រាប់មនុស្ស។ អ្វីទាំងអស់ដែលព្រះជាម្ចាស់បានបង្កើតមក ថ្វាយសិរីល្អដល់ទ្រង់ សរសើរទ្រង់សម្រាប់ការបង្ក្រាបខ្មាំងសត្រូវរបស់ទ្រង់ និងយាងត្រឡប់មកវិញប្រកបដោយជ័យជម្នះ ហើយលើកតម្កើងទ្រង់ជាស្ដេចដ៏មានជ័យជម្នះបំផុត។ គោលបំណងរបស់ទ្រង់ គឺមិនគ្រាន់តែបង្ក្រាបសាតាំងប៉ុណ្ណោះទេ ហើយនេះជាហេតុផលដែលនាំឲ្យកិច្ចការរបស់ទ្រង់បន្តអស់រយៈពេលប្រាំមួយពាន់

ឆ្នាំមកនេះ។ ទ្រង់ប្រើការបង្ក្រាបលើសាតាំង ដើម្បីសង្គ្រោះមនុស្ស។ ទ្រង់ប្រើការបង្ក្រាបលើសាតាំង ដើម្បីបើកសម្ដែងពីគ្រប់ទាំងទង្វើ និងគ្រប់ទាំងសិរីល្អរបស់ទ្រង់។ ទ្រង់នឹងទទួលបានសិរីល្អ ហើយគ្រប់ពួកទេវតាទាំងអស់នឹងមើលឃើញពីគ្រប់ទាំងសិរីល្អរបស់ទ្រង់។ អ្នកនាំសារនៅស្ថានសួគ៌ មនុស្សនៅលើផែនដី និងគ្រប់ទាំងវត្ថុដែលទ្រង់បានបង្កើតមកនៅលើផែនដី នឹងមើលឃើញពីសិរីល្អរបស់ព្រះអាទិករ។ នេះជាកិច្ចការដែលទ្រង់ធ្វើ។ ការបង្កើតរបស់ទ្រង់នៅស្ថានសួគ៌ និងនៅលើផែនដី នឹងមើលឃើញផ្ទាល់ភ្នែក ពីសិរីល្អរបស់ទ្រង់ ហើយទ្រង់នឹងយាងត្រឡប់មកវិញប្រកបដោយជ័យជម្នះ ក្រោយពេលបង្ក្រាបសាតាំងបានទាំងស្រុង ព្រមទាំងអនុញ្ញាតឲ្យមនុស្សសរសើរទ្រង់ ដូច្នេះ ទ្រង់សម្រេចបានជ័យជម្នះទ្វេដងនៅក្នុងកិច្ចការរបស់ទ្រង់។ នៅចុងបញ្ចប់ មនុស្សទាំងអស់នឹងត្រូវទ្រង់យកឈ្នះ ហើយទ្រង់នឹងបោសសម្អាតមនុស្សទាំងអស់ដែលបះបោរ ឬប្រឆាំងនឹងទ្រង់។ អាចនិយាយម្យ៉ាងទៀតបានថា ទ្រង់នឹងបោសសម្អាតអស់អ្នកណាដែលនៅខាងសាតាំង។ បច្ចុប្បន្ននេះ អ្នកកំពុងតែមើលឃើញដោយផ្ទាល់ភ្នែក អំពីកិច្ចការជាច្រើនរបស់ព្រះជាម្ចាស់ ប៉ុន្តែអ្នកនៅតែប្រឆាំង នៅតែបះបោរ ហើយមិនព្រមចុះចូលទៀត។ អ្នករក្សាទុកនូវរឿងរ៉ាវជាច្រើននៅខាងក្នុងអ្នក ហើយធ្វើទង្វើតាមតែទំនើងចិត្តរបស់អ្នក។ អ្នកធ្វើតាមសេចក្ដីស្រើបស្រាល និងចំណង់ចំណូលចិត្តរបស់អ្នក។ នេះហើយជាការបះបោរ និងជាការប្រឆាំងនោះ។ រាល់ជំនឿលើព្រះជាម្ចាស់ទាំងឡាយណាសម្រាប់ជាប្រយោជន៍ដល់សាច់ឈាម និងសេចក្ដីស្រើបស្រាលរបស់ខ្លួន ក៏ដូចជាសម្រាប់ជាប្រយោជន៍ដល់ការចូលចិត្តរបស់ខ្លួន របស់លោកីយ៍ និងរបស់សាតាំង គឺជាជំនឿដ៏ស្មោកគ្រោក ដ្បិតវាមាននិស្ស័យបែបប្រឆាំង និងបះបោរ។ សព្វថ្ងៃនេះ មានសេចក្ដីជំនឿជាច្រើនប្រភេទខុសៗគ្នា៖ អ្នកខ្លះស្វែងរកទីជម្រកពីគ្រោះមហន្តរាយ ហើយអ្នកផ្សេងទៀតស្វែងរកចង់បានព្រះពរ។ អ្នកខ្លះចង់យល់ពីសេចក្ដីលាក់កំបាំង ហើយអ្នកផ្សេងទៀតនៅតែស្វែងរកលុយកាក់។ ទាំងនេះ សុទ្ធតែជាទម្រង់នៃការប្រឆាំង ហើយវាសុទ្ធតែជាការប្រមាថ! ការនិយាយថា មនុស្សម្នាក់ប្រឆាំង ឬបះបោរ តើវាមិនសំដៅទៅលើ

តវិយាបថបែបនេះទេឬ? មនុស្សជាច្រើននាពេលសព្វថ្ងៃត្អូញត្អែរ រអ៊ូរទាំ ឬចូលចិត្តវិនិច្ឆ័យគេ។ ទាំងអស់នេះ សុទ្ធតែត្រូវបានធ្វើដោយមនុស្សអាក្រក់ ហើយពួកគេជាឧទាហរណ៍អំពីការប្រឆាំង និងការបះបោររបស់មនុស្ស។ មនុស្សបែបនេះត្រូវបានគ្រប់គ្រង និងកាន់កាប់ដោយសាតាំង។ អស់អ្នកណាដែលព្រះជាម្ចាស់ទទួល គឺជាមនុស្សដែលចុះចូលចំពោះទ្រង់ទាំងស្រុង។ ពួកគេជាមនុស្សដែលត្រូវបានសាតាំងធ្វើឲ្យពុករលួយ ប៉ុន្តែត្រូវបានសង្គ្រោះ និងយកឈ្នះ ដោយកិច្ចការបច្ចុប្បន្នរបស់ព្រះជាម្ចាស់ ជាអ្នកដែលបានឆ្លងផុតសេចក្ដីទុក្ខវេទនានៅចុងបញ្ចប់ និងជាអ្នកដែលព្រះជាម្ចាស់ទទួលយកទាំងស្រុង ជាអ្នកដែលលែងរស់នៅក្រោមការគ្រប់គ្រងរបស់សាតាំង ដែលមានសេរីភាពពីសេចក្តីទុច្ចរិត និងជាអ្នកដែលព្រមរស់នៅតាមភាពបរិសុទ្ធ។ មនុស្សបែបនេះគឺជាមនុស្សដែលបរិសុទ្ធបំផុត ពួកគេគឺជាមនុស្សបរិសុទ្ធយ៉ាងពិតប្រាកដ។ ប្រសិនបើទង្វើបច្ចុប្បន្នរបស់អ្នក មិនស្របជាមួយ សូម្បីតែមួយផ្នែកនៃសេចក្តីតម្រូវរបស់ព្រះជាម្ចាស់ផង នោះអ្នកនឹងត្រូវផាត់ចោលមិនខាន។ ការនេះមិនអាចប្រកែកបានឡើយ។ អ្វីៗគ្រប់យ៉ាងអាស្រ័យលើអ្វីដែលកើតឡើងនាពេលបច្ចុប្បន្ន ហើយទោះបីអ្នកត្រូវបានកំណត់ទុកជាមុន និងត្រូវបានជ្រើសរើសក៏ដោយ ក៏ទង្វើរបស់អ្នកនាពេលសព្វថ្ងៃ នឹងនៅតែកំណត់ពីលទ្ធផលរបស់អ្នកដដែល។ ប្រសិនបើអ្នកមិនអាចបន្តប្តេជ្ញាចិត្តបានទេ នោះអ្នកនឹងត្រូវផាត់ចោលមិនខាន។ ប្រសិនបើអ្នកមិនអាចបន្តប្តេជ្ញាចិត្តបានទេ តើអ្នកអាចបន្តតាំងចិត្តនៅពេលក្រោយបានដោយរបៀបណា? ការអស្ចារ្យដ៏ធំមួយបានលេចឡើងនៅមុខអ្នក ប៉ុន្តែអ្នកនៅតែមិនជឿទៀត។ ដូច្នេះ តើអ្នកនឹងជឿលើព្រះជាម្ចាស់នៅពេលក្រោយដោយរបៀបណាទៅ នៅពេលដែលទ្រង់បានបញ្ចប់កិច្ចការរបស់ទ្រង់ ហើយនឹងលែងធ្វើការបែបនេះតទៅទៀត? ទម្រាំដល់ពេលនោះ វានឹងកាន់តែមិនអាចទៅរួច សម្រាប់អ្នកក្នុងការដើរតាមទ្រង់មិនខាន! ក្រោយមក ព្រះជាម្ចាស់នឹងពឹងអាងលើចិត្តគំនិតរបស់អ្នក ចំណេះដឹងរបស់អ្នកចំពោះកិច្ចការរបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស និងបទពិសោធរបស់អ្នកក្នុងការកំណត់ថា តើអ្នកជាមនុស្សមានបាប ឬក៏ជាមនុស្សសុចរិត ឬកំណត់ថាតើអ្នកជា

មនុស្សត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍ ឬក៏ត្រូវបានផាត់ចោល។ អ្នកត្រូវតែមើលឃើញឲ្យច្បាស់ឥឡូវនេះ។ ព្រះវិញ្ញាណបរិសុទ្ធធ្វើការបែបនេះ៖ ទ្រង់កំណត់ពីលទ្ធផលរបស់អ្នក ស្របតាមអាកប្បកិរិយារបស់អ្នកនាពេលសព្វថ្ងៃ។ តើនរណាថ្លែងព្រះបន្ទូលនៅថ្ងៃនេះ? តើនរណាធ្វើកិច្ចការនៅថ្ងៃនេះ? តើនរណាសម្រេចចិត្តថា អ្នកនឹងត្រូវផាត់ចោលនៅថ្ងៃនេះ? តើនរណាសម្រេចចិត្តធ្វើឲ្យអ្នកបានគ្រប់លក្ខណ៍? តើនេះមិនមែនជាអ្វីដែលខ្ញុំធ្វើដោយខ្លួនខ្ញុំទេឬអី? ខ្ញុំជាព្រះដែលថ្លែងនូវព្រះបន្ទូលទាំងនេះ។ ខ្ញុំជាព្រះដែលអនុវត្តកិច្ចការទាំងនេះ។ ការដាក់បណ្ដាសា ការវាយផ្ចាល និងការជំនុំជម្រះមនុស្ស សុទ្ធតែជាចំណែកនៃកិច្ចការរបស់ខ្ញុំ។ នៅចុងបញ្ចប់ វាក៏នឹងអាស្រ័យលើខ្ញុំដែរក្នុងការផាត់អ្នកចោល។ កិច្ចការទាំងអស់នេះ គឺជាកិច្ចការរបស់ខ្ញុំ! ការប្រោសឲ្យអ្នកបានគ្រប់លក្ខណ៍ គឺជាកិច្ចការរបស់ខ្ញុំ ហើយការអនុញ្ញាតឲ្យអ្នករីករាយនឹងព្រះពរ ក៏ជាកិច្ចការរបស់ខ្ញុំដែរ។ នេះសុទ្ធតែជាកិច្ចការដែលខ្ញុំធ្វើ។ លទ្ធផលរបស់អ្នកមិនត្រូវបានកំណត់ទុកជាមុន ដោយព្រះយេហូវ៉ាឡើយ ប៉ុន្តែវាកំពុងតែត្រូវបានកំណត់ដោយព្រះជាម្ចាស់នាពេលសព្វថ្ងៃ។ វាកំពុងតែត្រូវបានកំណត់ក្នុងពេលឥឡូវនេះមិនមែនត្រូវបានកំណត់ទុកជាមុនតាំងពីមុនកំណើតពិភពលោកនោះឡើយ។ មនុស្សមិនសមហេតុផលមួយចំនួននិយាយថា «ប្រហែលភ្នែករបស់អ្នកមានបញ្ហាហើយ ព្រោះអ្នកមើលមិនឃើញខ្ញុំតាមការដែលអ្នកគួរតែមើលឃើញឡើយ។ នៅចុងបញ្ចប់ អ្នកនឹងមើលឃើញដូចអ្វីដែលព្រះវិញ្ញាណបើកសម្ដែងអ៊ីចឹង!» ដំបូងឡើយ ព្រះយេស៊ូវបានជ្រើសរើសយូដាស ជាសិស្សរបស់ទ្រង់។ មនុស្សសួរថា៖ «តើទ្រង់អាចជ្រើសរើសសិស្សម្នាក់ដែលនឹងក្បត់ទ្រង់បានដោយរបៀបណា?» ជាដំបូង យូដាសគ្មានចេតនាចង់ក្បត់ព្រះយេស៊ូវឡើយ វាទើបតែកើតឡើងនៅពេលក្រោយប៉ុណ្ណោះ។ នៅពេលនោះ ព្រះយេស៊ូវបានទតឃើញយូដាសជាមនុស្សម្នាក់គួរជាទីពេញចិត្ត ហើយទ្រង់បានធ្វើឲ្យគាត់ដើរតាមទ្រង់ និងប្រទានឲ្យគាត់មានទំនួលខុសត្រូវលើកិច្ចការហិរញ្ញវត្ថុរបស់ពួកគេ។ ប្រសិនបើព្រះយេស៊ូវបានជ្រាបថា យូដាសនឹងកិបកេងលុយកាក់ នោះទ្រង់នឹងមិនទុកឲ្យគាត់មើលខុសត្រូវលើកិច្ចការមួយនេះឡើយ។ គឺអាចនិយាយបាន

ថា ដំបូងឡើយ ព្រះយេស៊ូវមិនបានជ្រាបដឹងថា បុរសម្នាក់នេះមានចិត្តវៀចវេរ និងបោកបញ្ឆោត ឬជ្រាបថា គាត់នឹងបោកប្រាស់បងប្អូនប្រុសស្រីរបស់គាត់នោះឡើយ។ ក្រោយមកទៀត បន្ទាប់ពីយូដាសបានដើរតាមព្រះយេស៊ូវបានមួយរយៈ ព្រះយេស៊ូវបានទតឃើញថា គាត់និយាយបញ្ឆោរដល់បងប្អូនប្រុសស្រីរបស់គាត់ និងបញ្ឆោរព្រះជាម្ចាស់។ បណ្ដាជនបានរកឃើញថា យូដាសមានទម្លាប់ដកលុយ ចេញពីថង់ប្រាក់ដែរ ហើយបន្ទាប់មក ពួកគេបានប្រាប់ព្រះយេស៊ូវអំពីរឿងនេះ។ គឺមានតែពេលនោះទេ ទើបព្រះយេស៊ូវបានជ្រាបដឹង អំពីអ្វីៗគ្រប់យ៉ាង ដែលកំពុងតែកើតឡើង។ ដោយសារតែព្រះយេស៊ូវត្រូវធ្វើកិច្ចការនៃការជាប់ឆ្កាង និងត្រូវការមនុស្សម្នាក់ដើម្បីក្បត់ទ្រង់ ហើយដោយសារតែយូដាសបានក្លាយជាបុគ្គលដ៏សក្ដិសមក្នុងការបំពេញតួនាទីនេះផងនោះ ទើបព្រះយេស៊ូវបានមានបន្ទូលថា «នឹងមានបុគ្គលម្នាក់នៅក្នុងចំណោមយើងរាល់គ្នាដែលនឹងក្បត់ខ្ញុំ។ បុត្រមនុស្សនឹងប្រើអំពើក្បត់នេះ ដើម្បីជាប់ឆ្កាង ហើយបីថ្ងៃក្រោយមក ទ្រង់នឹងមានព្រះជន្មរស់ឡើងវិញ»។ នៅពេលនោះ ព្រះយេស៊ូវមិនទាន់បានជ្រើសរើសយូដាស ដើម្បីឲ្យក្បត់ទ្រង់នៅឡើយទេ។ ផ្ទុយទៅវិញ ទ្រង់គ្រាន់តែសង្ឃឹមថា យូដាសនឹងក្លាយជាសិស្សដែលមានចិត្តភក្ដីភាពម្នាក់ប៉ុណ្ណោះ។ ដោយខុសពីការរំពឹងទុក យូដាសបានក្លាយជាមនុស្សពុកខូចដ៏លោភលន់ដែលបានក្បត់ព្រះអម្ចាស់ ដូច្នេះ ព្រះយេស៊ូវបានប្រើស្ថានភាពនេះ ដើម្បីជ្រើសរើសយូដាសសម្រាប់កិច្ចការនេះ។ ប្រសិនបើពួកសិស្សទាំងដប់ពីរនាក់របស់ព្រះយេស៊ូវបានស្មោះស្ម័គ្រចំពោះទ្រង់ ហើយគ្មាននរណាម្នាក់ដូចជាយូដាសនៅក្នុងចំណោមពួកគេ នោះទីបំផុត បុគ្គលដែលក្បត់ព្រះយេស៊ូវនឹងក្លាយជាមនុស្សម្នាក់ដែលមិនមែនជាសិស្សរបស់ទ្រង់មិនខាន។ យ៉ាងណាមិញ នៅពេលនោះ វាចៃដន្យដែលម្នាក់នៅក្នុងចំណោមពួកសិស្ស ដែលចូលរួមក្នុងការទទួលសំណូក គឺយូដាស។ ដូច្នេះ ព្រះយេស៊ូវបានប្រើប្រាស់បុរសម្នាក់នេះ ដើម្បីបញ្ចប់កិច្ចការរបស់ទ្រង់។ នេះពិតជាសាមញ្ញមែន! ព្រះយេស៊ូវមិនបានកំណត់ហេតុការណ៍នេះទុកជាមុនតាំងពីដើមដំបូងនៃកិច្ចការរបស់ទ្រង់ឡើយ គឺទ្រង់គ្រាន់តែធ្វើការសម្រេចព្រះទ័យនេះ នៅពេលដែល

ស្ថានការណ៍បានអភិវឌ្ឍ ដល់កម្រិតនេះតែប៉ុណ្ណោះ។ នេះជាការសម្រេចព្រះទ័យរបស់ព្រះយេស៊ូវ ដែលអាចនិយាយបានថា វាជាការសម្រេចព្រះទ័យរបស់ព្រះវិញ្ញាណនៃព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ។ ដំបូងឡើយ ព្រះយេស៊ូវជាអ្នកដែលបានជ្រើសរើសយូដាស ប៉ុន្តែនៅពេលដែលយូដាសបានក្បត់ព្រះយេស៊ូវ គឺព្រះវិញ្ញាណបរិសុទ្ធជាអ្នកដែលបានធ្វើការនេះវិញ ដើម្បីបម្រើដល់គោលបំណងចុងក្រោយរបស់ទ្រង់។ វាជាកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ដែលត្រូវអនុវត្តនៅពេលនោះ។ នៅពេលដែលព្រះយេស៊ូវបានជ្រើសរើសយូដាស ទ្រង់មិនបានជ្រាបដឹងថា យូដាសនឹងក្បត់ទ្រង់ឡើយ។ ទ្រង់គ្រាន់តែជ្រាបដឹងថា បុរសនោះមានឈ្មោះថា យូដាស អ៊ីស្ការីយ៉ុតប៉ុណ្ណោះ។ លទ្ធផលរបស់អ្នករាល់គ្នាក៏ត្រូវបានកំណត់ស្របទៅតាមកម្រិតនៃការចុះចូលរបស់អ្នករាល់គ្នានៅពេលសព្វថ្ងៃ និងស្របតាមកម្រិតនៃការរីកចម្រើននៃជីវិតរបស់អ្នករាល់គ្នាដែរ មិនមែនស្របតាមសញ្ញាណរបស់មនុស្សដែលគិតថា លទ្ធផលរបស់អ្នកត្រូវបានកំណត់ទុកជាមុន តាំងពីកំណើតពិភពលោកមកនោះឡើយ។ អ្នកត្រូវតែយល់អំពីចំណុចទាំងនេះឲ្យបានច្បាស់។ គ្មានកិច្ចការណាមួយបានកើតឡើងតាមរបៀបដែលអ្នកស្រមើស្រមៃនោះឡើយ។

# អំពីងារ និងអត្តសញ្ញាណ

ប្រសិនបើអ្នកចង់មានគុណសម្បត្តិសក្ដិសម ដើម្បីឲ្យព្រះជាម្ចាស់ប្រើ អ្នកត្រូវតែដឹងអំពីកិច្ចការរបស់ព្រះជាម្ចាស់ អ្នកត្រូវតែដឹងអំពីកិច្ចការដែលទ្រង់បានធ្វើកាលពីអតីតកាល (នៅក្នុងព្រះគម្ពីរសញ្ញាថ្មី និងសញ្ញាចាស់) ហើយលើសពីនេះ អ្នកក៏ត្រូវតែដឹងអំពីកិច្ចការរបស់ទ្រង់នាពេលសព្វថ្ងៃផងដែរ។ គឺអាចនិយាយបានថា អ្នកត្រូវតែដឹង អំពីដំណាក់កាលទាំងបីនៃកិច្ចការរបស់ព្រះជាម្ចាស់ ដែលបានធ្វើជាង៦០០០ឆ្នាំកន្លងមកនេះ។ ប្រសិនបើអ្នកត្រូវបានស្នើសុំឲ្យផ្សាយដំណឹងល្អ នោះអ្នកនឹងមិនអាចធ្វើកិច្ចការនេះ ដោយមិនដឹងអំពីកិច្ចការរបស់ព្រះជាម្ចាស់នោះឡើយ។

មនុស្សម្នាក់អាចសួរអ្នកអំពីសេចក្ដីដែលព្រះរបស់អ្នករាល់គ្នាបានមានបន្ទូលទាក់ទង នឹងព្រះគម្ពីរសញ្ញាចាស់ និងអំពីកិច្ចការ ព្រមទាំងព្រះបន្ទូលរបស់ព្រះយេស៊ូវនៅគ្រានោះ។ ប្រសិនបើអ្នកមិនអាចនិយាយចេញពីសាច់រឿងខាងក្នុងព្រះគម្ពីរទេ នោះពួកគេនឹងមិនជឿអ្នកឡើយ។ នៅគ្រានោះ ព្រះយេស៊ូវបានមានបន្ទូលយ៉ាងច្រើនអំពីព្រះគម្ពីរសញ្ញាចាស់ ជាមួយនឹងពួកសិស្សរបស់ទ្រង់។ គ្រប់យ៉ាងដែលពួកគេបានអាន គឺចេញមកពីព្រះគម្ពីរសញ្ញាចាស់ ហើយព្រះគម្ពីរសញ្ញាថ្មីត្រូវបាននិពន្ធឡើងតែប៉ុន្មានទសវត្សរ៍ ក្រោយពេលដែលព្រះយេស៊ូវត្រូវបានជាប់ឆ្កាងប៉ុណ្ណោះ។ ដើម្បីផ្សាយដំណឹងល្អ អ្នករាល់គ្នាគួរតែយល់គោលៗអំពីសេចក្ដីពិតខាងក្នុងព្រះគម្ពីរ និងយល់អំពីកិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងស្រុកអ៊ីស្រាអែល ជាកិច្ចការដែលត្រូវបានធ្វើដោយព្រះយេហូវ៉ា ហើយអ្នកក៏ត្រូវយល់អំពីកិច្ចការដែលត្រូវបានធ្វើដោយព្រះយេស៊ូវផងដែរ។ ទាំងនេះ គឺជាចំណុចដែលមនុស្សទាំងអស់មានការខ្វល់ខ្វាយបំផុត ហើយសាច់រឿងខាងក្នុងដំណាក់កាលនៃកិច្ចការទាំងពីរនោះ គឺជាអ្វីដែលពួកគេមិនធ្លាប់បានឮឡើយ។ នៅពេលផ្សាយដំណឹងល្អ ជាដំបូង ចូរកុំទាន់អាលនិយាយអំពីកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធនាពេលសព្វថ្ងៃនេះ។ ដំណាក់កាលនៃកិច្ចការនេះ គឺលើសពីអ្វីដែលគេអាចយល់បាន ព្រោះអ្វីដែលអ្នករាល់គ្នាដេញតាម គឺជាសេចក្ដីដែលខ្ពង់ខ្ពស់បំផុត ពោលគឺជាចំណេះដឹងអំពីព្រះជាម្ចាស់ និងចំណេះដឹងអំពីកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ហើយគ្មានអ្វីដែលត្រូវបានគេលើកតម្កើងជាងសេចក្ដីទាំងពីរនេះឡើយ។ ប្រសិនបើអ្នករាល់គ្នាចាប់ផ្ដើមនិយាយដំបូងអំពីសេចក្ដីដែលខ្ពង់ខ្ពស់បែបនេះ នោះវានឹងច្រើនពេកហើយសម្រាប់ពួកគេ ព្រោះថាគ្មាននរណាម្នាក់ ធ្លាប់មានបទពិសោធអំពីកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធឡើយ ព្រោះវាមិនធ្លាប់មានពីមុនមកទេ ហើយវាមិនងាយស្រួលសម្រាប់មនុស្សក្នុងការទទួលយកនោះទេ។ បទពិសោធរបស់គេ គឺជាបទពិសោធចាស់ៗពីអតីតកាល ដែលព្រះវិញ្ញាណបរិសុទ្ធធ្វើការម្ដងម្កាល។ អ្វីដែលគេមានបទពិសោធនោះ មិនមែនជាកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធនាពេលសព្វថ្ងៃ ឬបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់នាពេលសព្វថ្ងៃឡើយ។ ពួកគេនៅតែ

ប្រព្រឹត្តតាមទម្លាប់ចាស់ ដោយគ្មានពន្លឺថ្មី និងកិច្ចការថ្មីៗដដែល។

នៅក្នុងយុគសម័យរបស់ព្រះយេស៊ូវ ព្រះវិញ្ញាណបរិសុទ្ធបានធ្វើកិច្ចការរបស់ទ្រង់ជាចម្បងនៅក្នុងព្រះយេស៊ូវ ខណៈពេលដែលអស់អ្នកដែលបម្រើព្រះយេហូវ៉ា ទាំងសម្លៀកបំពាក់ជាបូជាចារ្យនៅក្នុងព្រះវិហារ បានធ្វើកិច្ចការរបស់គេ ដោយចិត្តភក្ដីភាពឥតងាករេ។ ពួកគេក៏មានកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធផងដែរ ប៉ុន្ដែពួកគេមិនអាចយល់អំពីព្រះហឫទ័យបច្ចុប្បន្នរបស់ព្រះជាម្ចាស់ឡើយ គឺគេគ្រាន់តែស្មោះត្រង់ចំពោះព្រះយេហូវ៉ាស្របតាមការអនុវត្តចាស់ៗ ហើយគ្មានការដឹកនាំថ្មីៗនោះឡើយ។ ព្រះយេស៊ូវបានយាងមក ហើយបាននាំមកនូវកិច្ចការថ្មី ប៉ុន្ដែអស់អ្នកដែលបម្រើនៅក្នុងព្រះវិហារមិនមានការដឹកនាំថ្មីៗទេ ហើយពួកគេក៏គ្មាននូវកិច្ចការថ្មីៗដែរ។ ដោយការបម្រើនៅក្នុងព្រះវិហារ ពួកគេគ្រាន់តែអាចប្រកាន់ខ្ជាប់នូវការអនុវត្តចាស់ៗប៉ុណ្ណោះ ហើយដោយគ្មានការចាកចេញពីព្រះវិហារ ពួកគេក៏មិនអាចមាននូវច្រកចូលថ្មីណាមួយដែរ។ កិច្ចការថ្មីត្រូវបាននាំមកដោយព្រះយេស៊ូវ ហើយព្រះយេស៊ូវមិនបានចូលទៅក្នុងព្រះវិហារ ដើម្បីធ្វើកិច្ចការរបស់ទ្រង់ឡើយ។ ទ្រង់គ្រាន់តែធ្វើកិច្ចការរបស់ទ្រង់នៅខាងក្រៅព្រះវិហារប៉ុណ្ណោះ ព្រោះវិសាលភាពនៃកិច្ចការរបស់ព្រះជាម្ចាស់បានផ្លាស់ប្ដូរជាយូរឆ្នាំមកហើយ។ ទ្រង់មិនបានធ្វើកិច្ចការនៅក្នុងព្រះវិហារ ហើយនៅពេលដែលមនុស្សបានបម្រើព្រះជាម្ចាស់នៅទីនោះ វាគ្រាន់តែជាការបម្រើតាមទម្លាប់ប៉ុណ្ណោះ ហើយវាមិនអាចនាំមកនូវកិច្ចការថ្មីនោះឡើយ។ ដូចគ្នាដែរ អ្នកដឹកនាំសាសនានាពេលសព្វថ្ងៃ នៅតែថ្វាយបង្គំព្រះគម្ពីរ។ ប្រសិនបើអ្នកផ្សាយដំណឹងល្អទៅកាន់ពួកគេ នោះពួកគេនឹងបោះសម្ដីមកកាន់អ្នកវិញជាសេចក្ដីលម្អិតគួរសមអំពីព្រះបន្ទូលនៅក្នុងព្រះគម្ពីរ ហើយពួកគេនឹងមានភស្ដុតាងជាច្រើន ដើម្បីធ្វើឲ្យអ្នកស្រឡាំងកាំង និងកប់យោបល់។ បន្ទាប់មក ពួកគេនឹងដាក់ងារឲ្យអ្នក ហើយគិតថាអ្នករាល់គ្នាជាមនុស្សល្ងីល្ងើនៅក្នុងសេចក្ដីជំនឿរបស់អ្នក។ ពួកគេនឹងនិយាយថា៖ «អ្នកមិនទាំងដឹងអំពីព្រះគម្ពីរ ជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ផង តើអ្នកអាចនិយាយថាអ្នកជឿលើព្រះជាម្ចាស់ដូចម្ដេចកើតទៅ?» បន្ទាប់មក គេនឹងមើលងាយអ្នក ហើយ

និយាយថា៖ «ដោយសារតែព្រះមួយអង្គដែលអ្នករាល់គ្នាជឿ គឺជាព្រះជាម្ចាស់ ចុះហេតុអ្វីបានជាទ្រង់មិនមានបន្ទូលប្រាប់អ្នករាល់គ្នា គ្រប់ទាំងសេចក្ដីអំពីព្រះគម្ពីរសញ្ញាចាស់ និងសញ្ញាថ្មី? ដោយសារតែទ្រង់បាននាំសិរីល្អរបស់ទ្រង់ ចេញពីអ៊ីស្រាអែលទៅទិសខាងកើត ហេតុអ្វីបានជាទ្រង់មិនជ្រាបដឹងអំពីកិច្ចការដែលបានធ្វើនៅក្នុងស្រុកអ៊ីស្រាអែល? ហេតុអ្វីបានជាទ្រង់មិនបានជ្រាបដឹងអំពីកិច្ចការរបស់ព្រះយេស៊ូវ? ប្រសិនបើអ្នករាល់គ្នាមិនដឹង នោះបញ្ជាក់ឲ្យឃើញថា ទ្រង់មិនបានមានបន្ទូលប្រាប់អ្នករាល់គ្នា ហើយដោយសារតែទ្រង់ជាព្រះយេស៊ូវដែលយកកំណើតជាមនុស្សលើកទីពីរ តើទ្រង់មិនអាចជ្រាបដឹងអំពីកិច្ចការទាំងនេះ ដូចម្ដេចទៅ? ព្រះយេស៊ូវបានជ្រាបដឹងអំពីកិច្ចការដែលត្រូវបានធ្វើដោយព្រះយេហូវ៉ា តើទ្រង់មិនអាចជ្រាបដឹងយ៉ាងដូចម្ដេចទៅ?» នៅពេលដែលពេលកំណត់បានមកដល់ ពួកគេទាំងអស់គ្នានឹងសួរអ្នកនូវសំណួរទាំងនេះ។ ក្បាលរបស់គេ គឺពេញដោយសេចក្ដីបែបនេះ តើពួកគេអាចមិនសួរនាំយ៉ាងដូចម្ដេចទៅ? ក្នុងចំណោមអ្នករាល់គ្នាដែលស្ថិតនៅក្នុងចរន្តនេះ មិនបានផ្ដោតទៅលើព្រះគម្ពីរឡើយ ដ្បិតអ្នករាល់គ្នាបានបន្តតាមដាននូវកិច្ចការមួយជំហានម្ដងៗ ដែលត្រូវបានធ្វើដោយព្រះជាម្ចាស់នាពេលសព្វថ្ងៃ អ្នករាល់គ្នាបានឃើញផ្ទាល់នឹងភ្នែកអំពីកិច្ចការមួយជំហានម្ដងៗនេះ ហើយអ្នកបានឃើញយ៉ាងច្បាស់អំពីដំណាក់កាលទាំងបីនៃកិច្ចការ ដូច្នេះ អ្នកត្រូវតែទម្លាក់ព្រះគម្ពីរចុះ ហើយផ្អាកការសិក្សាសិន។ ប៉ុន្តែ ពួកគេមិនអាចផ្អាកការសិក្សាបានឡើយព្រោះពួកគេមិនដឹងអំពីកិច្ចការមួយជំហានម្ដងៗនេះឡើយ។ មនុស្សខ្លះនឹងសួរថា «តើអ្វីទៅជាភាពខុសគ្នារវាងកិច្ចការដែលត្រូវបានធ្វើដោយព្រះជាម្ចាស់ និងកិច្ចការរបស់ពួកហោរា និងពួកសាវ័កកាលពីអតីតកាល? ស្ដេចដាវីឌត្រូវបានហៅថា ព្រះអម្ចាស់ ឯព្រះយេស៊ូវក៏ត្រូវបានហៅបែបនេះដែរ ហើយទោះបីជាកិច្ចការ ដែលពួកទ្រង់បានធ្វើខុសគ្នាក៏ដោយ ក៏ពួកទ្រង់ត្រូវបានគេហៅដូចគ្នា។ ចូរប្រាប់ខ្ញុំបន្តិចមើល៍ថា ហេតុអ្វីបានជាអត្តសញ្ញាណរបស់ពួកទ្រង់មិនដូចគ្នា? អ្វីដែលយ៉ូហានបានឃើញ គឺជានិមិត្តមួយ ជានិមិត្តដែលបានមកពីព្រះវិញ្ញាណបរិសុទ្ធដែរ ហើយគាត់អាចនិយាយអំពីសេចក្ដីដែល

ព្រះវិញ្ញាណបរិសុទ្ធចង់មានព្រះបន្ទូលទៀត ដូច្នេះ ហេតុអ្វីបានជាអត្តសញ្ញាណរបស់យ៉ូហានខុសពីអត្តសញ្ញាណរបស់ព្រះយេស៊ូវ?» ព្រះបន្ទូលដែលចេញពីព្រះយេស៊ូវអាចតំណាងឲ្យព្រះជាម្ចាស់យ៉ាងពេញលេញ ហើយព្រះបន្ទូលទាំងនោះបានតំណាងយ៉ាងពេញលេញឲ្យកិច្ចការរបស់ព្រះជាម្ចាស់។ អ្វីដែលយ៉ូហានបានឃើញ គឺជានិមិត្តមួយ ហើយគាត់មិនអាចមានសមត្ថភាពតំណាងឲ្យកិច្ចការរបស់ព្រះជាម្ចាស់យ៉ាងពេញលេញនោះឡើយ។ ហេតុអ្វីបានជាយ៉ូហាន ពេត្រុស និងប៉ុលបានថ្លែងនូវពាក្យជាច្រើន ដូចជាព្រះយេស៊ូវដែរ ប៉ុន្តែពួកគេមិនមានអត្តសញ្ញាណដូចជាព្រះយេស៊ូវ? ជាចម្បង គឺដោយសារតែកិច្ចការដែលពួកគេបានធ្វើ មានលក្ខណៈខុសគ្នា។ ព្រះយេស៊ូវបានតំណាងឲ្យព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ ហើយជាព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ដែលកំពុងតែធ្វើការដោយផ្ទាល់។ ទ្រង់បានធ្វើកិច្ចការនៃយុគសម័យថ្មី ជាកិច្ចការមួយដែលគ្មាននរណាម្នាក់ធ្លាប់បានធ្វើពីមុនមកឡើយ។ ទ្រង់បានរៀបចំផ្លូវមួយថ្មី ទ្រង់បានតំណាងឲ្យព្រះយេហូវ៉ា ហើយទ្រង់បានតំណាងឲ្យព្រះជាម្ចាស់ផ្ទាល់ ចំណែកឯពេត្រុស ប៉ុល និងដាវីឌវិញ មិនថាពួកគេត្រូវបានត្រាស់ហៅឲ្យធ្វើអ្វីនោះឡើយ ពួកគេគ្រាន់តែបានតំណាងឲ្យអត្តសញ្ញាណជាសត្តនិករមួយរបស់ព្រះជាម្ចាស់ប៉ុណ្ណោះ ហើយពួកគេត្រូវបានព្រះយេស៊ូវ ឬព្រះយេហូវ៉ាបញ្ជូនមក។ ដូច្នេះ មិនថាពួកគេធ្វើកិច្ចការបានច្រើនយ៉ាងណា មិនថាពួកគេបានធ្វើការអស្ចារ្យធំៗ បែបណានោះទេ ពួកគេគ្រាន់តែជាសត្តនិកររបស់ព្រះជាម្ចាស់ប៉ុណ្ណោះ ហើយពួកគេគ្មានសមត្ថភាពតំណាងឲ្យព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ឡើយ។ ពួកគេបានធ្វើការនៅក្នុងព្រះនាមរបស់ព្រះជាម្ចាស់ ឬបានធ្វើការ ក្រោយពេលត្រូវបានព្រះជាម្ចាស់បញ្ជូនមកប៉ុណ្ណោះ ហើយលើសពីនេះ ពួកគេបានធ្វើការនៅក្នុងយុគសម័យដែលបានចាប់ផ្ដើមដោយព្រះយេស៊ូវ ឬព្រះយេហូវ៉ា ហើយពួកគេមិនបានធ្វើកិច្ចការណាផ្សេងទៀតឡើយ។ សរុបមក ពួកគេគ្រាន់តែជាសត្តនិកររបស់ព្រះជាម្ចាស់ប៉ុណ្ណោះ។ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ មានហោរាជាច្រើនបានថ្លែងទំនាយ ឬបាននិពន្ធនូវកណ្ឌគម្ពីរទំនាយជាច្រើន។ គ្មាននរណាម្នាក់និយាយថា ពួកគេជាព្រះជាម្ចាស់ឡើយ ប៉ុន្តែពេលដែល

ព្រះយេស៊ូវបានចាប់ផ្ដើមធ្វើកិច្ចការ ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់បានធ្វើបន្ទាល់ថា ទ្រង់ជាព្រះជាម្ចាស់។ តើនោះជាអ្វីទៅ? នៅត្រង់នេះ អ្នកគួរតែបានដឹងរួចហើយ! កាលពីមុន ពួកសាវ័ក និងពួកហោរាបានសរសេរសំបុត្រជាច្រើន ហើយបានថ្លែងទំនាយជាច្រើនដែរ។ ក្រោយមក មនុស្សបានជ្រើសរើសយកសំបុត្រ និងសេចក្ដីទំនាយមួយចំនួនមកដាក់នៅក្នុងព្រះគម្ពីរ ហើយសំបុត្រ និងទំនាយខ្លះទៀតត្រូវបានបាត់បង់។ ដោយសារតែមានមនុស្សដែលនិយាយថា គ្រប់ទាំងសេចក្ដីដែលពួកគេនិយាយ សុទ្ធតែចេញមកពីព្រះវិញ្ញាណបរិសុទ្ធ ដូច្នេះ តើហេតុអ្វីបានជាសេចក្ដីខ្លះត្រូវបានចាត់ទុកថាល្អ ហើយសេចក្ដីខ្លះទៀត ត្រូវបានចាត់ទុកថាអាក្រក់? ហើយហេតុអ្វីបានជាសេចក្ដីខ្លះត្រូវបានជ្រើសរើស ហើយសេចក្ដីខ្លះទៀត មិនត្រូវបានជ្រើសរើសដូច្នេះ? ប្រសិនបើសេចក្ដីទាំងនោះ ពិតជាព្រះបន្ទូលដែលថ្លែងចេញពីព្រះវិញ្ញាណបរិសុទ្ធមែន ហេតុអ្វីបានជាវាចាំបាច់សម្រាប់មនុស្សក្នុងការជ្រើសរើសសេចក្ដីទាំងនោះ? ហេតុអ្វីបានជារឿងរ៉ាវនៃព្រះបន្ទូល ដែលត្រូវបានថ្លែងចេញពីព្រះយេស៊ូវ និងកិច្ចការដែលទ្រង់បានធ្វើ មានលក្ខណៈខុសៗគ្នានៅក្នុងកណ្ឌគម្ពីរនីមួយៗនៃកណ្ឌគម្ពីរដំណឹងល្អទាំងបួនក្បាលបែបនេះ? តើនេះមិនមែនជាកំហុសរបស់មនុស្សដែលបានកត់ត្រាព្រះបន្ទូលទាំងនោះទេឬ? មនុស្សខ្លះនឹងសួរថា៖ «ដោយសារតែសំបុត្រដែលត្រូវបាននិពន្ធដោយប៉ុល និងអ្នកនិពន្ធព្រះគម្ពីរសញ្ញាថ្មីផ្សេងទៀត និងកិច្ចការដែលពួកគេបានធ្វើ មានផ្នែកខ្លះចេញមកពីឆន្ទៈរបស់មនុស្ស ហើយត្រូវបានលាយឡំដោយសញ្ញាណរបស់មនុស្ស ដូច្នេះ តើវាគ្មានភាពមិនបរិសុទ្ធរបស់មនុស្សនៅក្នុងព្រះបន្ទូលដែលទ្រង់ (ព្រះជាម្ចាស់) មានបន្ទូលនាពេលសព្វថ្ងៃទេឬអី? តើព្រះបន្ទូលទាំងនោះ ពិតជាគ្មានផ្ទុកនូវសញ្ញាណរបស់មនុស្សមែនឬ?» ដំណាក់កាលនៃកិច្ចការដែលត្រូវបានធ្វើដោយព្រះជាម្ចាស់នេះ គឺមានលក្ខណៈខុសប្លែកទាំងស្រុងពីដំណាក់កាលដែលត្រូវបានធ្វើដោយប៉ុល ពួកសាវ័ក និងពួកហោរាជាច្រើននាក់។ វាមិនគ្រាន់តែមានភាពខុសគ្នាមួយនៅក្នុងអត្តសញ្ញាណប៉ុណ្ណោះទេ ប៉ុន្ដែតាមគោលការណ៍ វាមាននូវភាពខុសគ្នាមួយនៅក្នុងកិច្ចការដែលត្រូវអនុវត្តផងដែរ។ ក្រោយពេល

ដែលប៉ុលត្រូវបានដួលចុះនៅចំពោះព្រះភ័ក្ត្រព្រះអម្ចាស់ គាត់ត្រូវបានដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធដើម្បីធ្វើការ ហើយគាត់បានក្លាយជាបុគ្គលម្នាក់ដែលត្រូវបានបញ្ជូនឲ្យចេញទៅ។ ដូច្នេះ គាត់បានសរសេរសំបុត្រទៅកាន់ពួកជំនុំ ហើយសំបុត្រទាំងអស់នេះសុទ្ធតែសរសេរឡើងតាមសេចក្ដីបង្រៀនរបស់ព្រះយេស៊ូវ។ ប៉ុលត្រូវបានព្រះអម្ចាស់បញ្ជូនឲ្យទៅធ្វើការ នៅក្នុងព្រះនាមរបស់ព្រះអម្ចាស់យេស៊ូវ ប៉ុន្តែនៅពេលដែលព្រះជាម្ចាស់ផ្ទាល់បានយាងមក ទ្រង់មិនបានធ្វើកិច្ចការនៅក្នុងនាមណាមួយឡើយ ហើយក៏មិនបានតំណាងឲ្យនរណាម្នាក់ដែរ ក្រៅពីព្រះវិញ្ញាណរបស់ព្រះជាម្ចាស់នៅក្នុងកិច្ចការរបស់ទ្រង់នោះ។ ព្រះជាម្ចាស់បានយាងមក ដើម្បីធ្វើកិច្ចការរបស់ទ្រង់ដោយផ្ទាល់៖ ទ្រង់មិនត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍ដោយមនុស្ស ហើយកិច្ចការរបស់ទ្រង់ក៏មិនត្រូវបានអនុវត្តស្របតាមសេចក្ដីបង្រៀនរបស់មនុស្សណាម្នាក់ដែរ។ នៅក្នុងដំណាក់កាលនៃកិច្ចការនេះ ព្រះជាម្ចាស់មិនបានដឹកនាំ ដោយមានបន្ទូលអំពីបទពិសោធផ្ទាល់ខ្លួនរបស់ទ្រង់ឡើយ ប៉ុន្តែផ្ទុយទៅវិញ ទ្រង់អនុវត្តកិច្ចការរបស់ទ្រង់ដោយផ្ទាល់ស្របតាមអ្វីដែលទ្រង់មាន។ ឧទាហរណ៍ ការល្បងលរបស់អ្នកស៊ីឈ្នួល ពេលវេលានៃការវាយផ្ចាល ការល្បងលនៃសេចក្ដីស្លាប់ ពេលវេលានៃការស្រឡាញ់ព្រះជាម្ចាស់...។ ទាំងអស់នេះសុទ្ធតែជាកិច្ចការដែលមិនធ្លាប់ត្រូវបានធ្វើពីមុនមកឡើយ ហើយក៏ជាកិច្ចការដែលចេញពី យុគសម័យបច្ចុប្បន្ន ជាជាងចេញពីបទពិសោធរបស់មនុស្ស។ នៅក្នុងព្រះបន្ទូលដែលខ្ញុំបានថ្លែង តើមានព្រះបន្ទូលណាខ្លះដែលជាបទពិសោធរបស់មនុស្ស? តើព្រះបន្ទូលទាំងអស់នោះ មិនចេញមកដោយផ្ទាល់ពីព្រះវិញ្ញាណទេឬ? តើព្រះបន្ទូលទាំងនោះមិនត្រូវបានថ្លែងចេញមកពីព្រះវិញ្ញាណទេឬ? គឺដោយសារតែគុណសម្បត្តិរបស់អ្នកអន់ពេក ទើបអ្នកគ្មានសមត្ថភាពមើលឃើញសេចក្ដីពិតនោះ! ផ្លូវនៃជីវិតដ៏ជាក់ស្ដែងដែលខ្ញុំថ្លែងនេះ គឺដើម្បីនាំផ្លូវ ហើយផ្លូវនេះមិនធ្លាប់បាននិយាយដោយនរណាម្នាក់ពីមុនមកឡើយ ហើយក៏គ្មាននរណាម្នាក់ធ្លាប់មានបទពិសោធអំពីផ្លូវមួយនេះ ឬបានស្គាល់ពីការពិតនេះដែរ។ មុនពេលខ្ញុំថ្លែងព្រះបន្ទូលទាំងនេះ គ្មាននរណាម្នាក់ធ្លាប់បាននិយាយវាពីមុនមកឡើយ។ គ្មាននរណា

ម្នាក់ធ្លាប់បាននិយាយអំពីបទពិសោធបែបនេះ ហើយក៏មិនធ្លាប់មាននរណានិយាយលម្អិតបែបនេះនោះដែរ ហើយលើសពីនេះទៅទៀត ក៏គ្មាននរណាម្នាក់ធ្លាប់លើកឡើងអំពីសភាពបែបនេះ ដើម្បីបើកសម្ដែងពីសេចក្តីទាំងនេះដែរ។ គ្មាននរណាម្នាក់ធ្លាប់បានដឹកនាំផ្លូវដែលខ្ញុំដឹកនាំនៅថ្ងៃនេះឡើយ ហើយបើវាត្រូវបានដឹកនាំដោយមនុស្សពីមុនមក ដូច្នេះ វាមិនមែនជាផ្លូវថ្មីនោះឡើយ។ សូមយកប៉ុល និងពេត្រុស មកធ្វើជាឧទាហរណ៍ចុះ។ មុនពេលព្រះយេស៊ូវបានដឹកនាំផ្លូវ ពួកគេមិនធ្លាប់មានបទពិសោធផ្ទាល់ខ្លួនរបស់គេឡើយ។ មានតែក្រោយពេលដែលព្រះយេស៊ូវបានដឹកនាំផ្លូវរួចហើយប៉ុណ្ណោះ ទើបពួកគេបានមានបទពិសោធ អំពីព្រះបន្ទូលដែលត្រូវបានថ្លែងដោយព្រះយេស៊ូវ និងផ្លូវដែលត្រូវបានដឹកនាំដោយទ្រង់។ ដោយហេតុនេះ ពួកគេបានទទួលនូវបទពិសោធជាច្រើន ហើយពួកគេក៏បានសរសេរនូវសំបុត្រជាច្រើនដែរ។ ដូច្នេះ បទពិសោធរបស់មនុស្ស មិនដូចជាកិច្ចការរបស់ព្រះជាម្ចាស់ ហើយកិច្ចការរបស់ព្រះជាម្ចាស់ក៏មិនដូចជាចំណេះដឹង ដែលត្រូវបានពណ៌នាដោយសញ្ញាណ និងបទពិសោធរបស់មនុស្សដែរ។ ខ្ញុំបានមានបន្ទូលម្ដងហើយម្ដងទៀតថា នៅថ្ងៃនេះ ខ្ញុំកំពុងតែដឹកនាំផ្លូវមួយថ្មី និងកំពុងតែធ្វើកិច្ចការមួយថ្មី ហើយកិច្ចការនិងព្រះសូរសៀងរបស់ខ្ញុំ មានលក្ខណៈខុសគ្នាពីកិច្ចការ និងសូរសំឡេងរបស់យ៉ូហាន និងពួកហោរាទាំងអស់ផ្សេងទៀត។ ជាដំបូង ខ្ញុំមិនដែលទទួលបានបទពិសោធ ហើយបន្ទាប់មកមានបន្ទូលអំពីបទពិសោធទាំងនោះប្រាប់អ្នករាល់គ្នា គឺខ្ញុំមិនដែលបានធ្វើបែបនេះឡើយ។ បើខ្ញុំធ្វើបែបនេះ តើវានឹងមិនបានពន្យារពេលអ្នករាល់គ្នាកាលពីយូរលង់ណាស់មកហើយទេឬអី? កាលពីអតីតកាល ចំណេះដឹងដែលមនុស្សជាច្រើនបានថ្លែង ក៏ត្រូវបានលើកតម្កើងឡើង ប៉ុន្តែពាក្យទាំងអស់របស់គេគ្រាន់តែជាពាក្យដែលថ្លែងចេញពីមនុស្សដែលត្រូវបានហៅថាជាបុគ្គលអស្ចារ្យខាងវិញ្ញាណប៉ុណ្ណោះ។ ពាក្យទាំងនោះមិនបានដឹកនាំផ្លូវឡើយ ប៉ុន្តែបានចេញមកពីបទពិសោធ ចេញមកពីអ្វីដែលគេបានឃើញ និងចេញមកពីចំណេះដឹងរបស់គេប៉ុណ្ណោះ។ ពាក្យខ្លះចេញមកពីសញ្ញាណរបស់គេ ហើយពាក្យខ្លះទៀតចេញមកពីបទពិសោធដែលពួកគេបានធ្វើការសង្ខេបប៉ុណ្ណោះ។ នៅ

ថ្ងៃនេះ និស្ស័យនៃកិច្ចការរបស់ខ្ញុំ គឺខុសស្រះឡះពីពួកគេ។ ខ្ញុំមិនធ្លាប់មានបទពិសោធឲ្យអ្នកដទៃដឹកនាំ ហើយខ្ញុំក៏មិនធ្លាប់បានទទួលការប្រោសឲ្យគ្រប់លក្ខណ៍ពីអ្នកដទៃដែរ។ លើសពីនេះទៅទៀត រាល់សេចក្ដីដែលខ្ញុំបានថ្លែង និងបានប្រកប គឺមានលក្ខណៈខុសពីសេចក្ដីរបស់អ្នកឯទៀតៗ ហើយក៏ជាសេចក្ដីដែលមិនធ្លាប់មាននរណាម្នាក់បានថ្លែងពីមុនមកដែរ។ នៅថ្ងៃនេះ មិនថាអ្នករាល់គ្នាជានរណាឡើយ គឺកិច្ចការរបស់អ្នកត្រូវតែអនុវត្ត ដោយផ្អែកលើមូលដ្ឋាននៃព្រះបន្ទូលដែលខ្ញុំថ្លែង។ បើគ្មានព្រះសូរសៀង និងកិច្ចការទាំងនេះទេ តើនរណានឹងមានសមត្ថភាពដកពិសោធន៍សេចក្ដីទាំងនេះ (ការល្បងលរបស់ពួកអ្នកស៊ីឈ្នួល ពេលវេលានៃការវាយផ្ចាល...) ហើយតើនរណាអាចនឹងនិយាយពី ចំណេះដឹងបែបនេះបានទៅ? តើអ្នកពិតជាគ្មានសមត្ថភាពមើលឃើញចំណុចនេះមែនឬ? មិនថាជំហាននៃកិច្ចការនោះបែបណាឡើយ គឺនៅពេលដែលព្រះបន្ទូលរបស់ខ្ញុំត្រូវបានថ្លែងចេញទៅ នោះអ្នករាល់គ្នាចាប់ផ្ដើមការប្រកបគ្នាស្របតាមព្រះបន្ទូលរបស់ខ្ញុំ និងធ្វើការស្របតាមព្រះបន្ទូលទាំងនោះ ហើយនេះមិនមែនជាផ្លូវមួយដែលនរណាម្នាក់ក្នុងចំណោមអ្នករាល់គ្នាធ្លាប់បានគិតនោះឡើយ។ ដោយបានមកឆ្ងាយបែបនេះហើយ តើអ្នកគ្មានសមត្ថភាពមើលឃើញសំណួរដ៏ច្បាស់លាស់ និងសាមញ្ញនេះទេឬអី? វាមិនមែនជាផ្លូវមួយដែលមនុស្សម្នាក់ធ្លាប់បានគិតនោះទេ ហើយវាក៏មិនមានមូលដ្ឋានចេញមកពីបុគ្គលអស្ចារ្យខាងវិញ្ញាណណាម្នាក់ដែរ។ វាជាផ្លូវថ្មីមួយ ហើយសូម្បីតែព្រះបន្ទូលជាច្រើនដែលព្រះយេស៊ូវធ្លាប់បានមានបន្ទូល ក៏ប្រើការលែងបានដែរ។ អ្វីដែលខ្ញុំមានបន្ទូល គឺជាកិច្ចការនៃការបើកយុគសម័យថ្មីមួយ ហើយវាជាកិច្ចការដែលឯករាជ្យ ដ្បិតកិច្ចការដែលខ្ញុំធ្វើ និងព្រះបន្ទូលដែលខ្ញុំថ្លែង សុទ្ធតែថ្មីទាំងអស់។ តើនេះមិនមែនជាកិច្ចការថ្មីនាពេលសព្វថ្ងៃទេឬ? កិច្ចការរបស់ព្រះយេស៊ូវ ក៏មានលក្ខណៈបែបនេះផងដែរ។ កិច្ចការរបស់ទ្រង់មានលក្ខណៈខុសប្លែកពីកិច្ចការរបស់មនុស្សនៅក្នុងព្រះវិហារ ខុសពីកិច្ចការរបស់ពួកផារិស៊ី ហើយក៏មិនមានលក្ខណៈស្រដៀងគ្នាទៅនឹងកិច្ចការដែលត្រូវបានធ្វើដោយប្រជាជនអ៊ីស្រាអែលទាំងអស់នោះដែរ។ ក្រោយពីបានឃើញផ្ទាល់ភ្នែកហើយ មនុស្ស

មិនអាចសម្រេចចិត្តបានឡើយថា៖ «វាពិតជាត្រូវបានធ្វើឡើងដោយព្រះជាម្ចាស់ឬ?» ព្រះយេស៊ូវមិនបានកាន់តាមក្រឹត្យវិន័យរបស់ព្រះយេហូវ៉ាឡើយ ហើយនៅពេលដែលទ្រង់បានយាងមកបង្រៀនមនុស្ស រាល់សេចក្ដីដែលទ្រង់បានមានបន្ទូលគឺសុទ្ធតែថ្មី និងមានលក្ខណៈខុសប្លែកពីអ្វីដែលត្រូវបានថ្លែងដោយពួកបរិសុទ្ធ និងពួកហោរាពីបុរាណនៃព្រះគម្ពីរសញ្ញាចាស់ ហើយដោយសារតែការនេះហើយ ទើបមនុស្សនៅតែមិនទាន់ច្បាស់លាស់។ នេះគឺជាអ្វីដែលធ្វើឲ្យមនុស្សពិបាកដោះស្រាយជាមួយ។ មុនពេលទទួលយកដំណាក់កាលថ្មីនៃកិច្ចការនេះ ផ្លូវដែលអ្នករាល់គ្នាភាគច្រើនបានដើរ គឺជាការអនុវត្ត និងការចូលទៅលើគ្រឹះមូលដ្ឋានចេញពីបុគ្គលអស្ចារ្យខាងវិញ្ញាណប៉ុណ្ណោះ។ ប៉ុន្ដែ នៅថ្ងៃនេះ កិច្ចការដែលខ្ញុំធ្វើ មានលក្ខណៈខុសគ្នាយ៉ាងខ្លាំង ដែលជាហេតុនាំឲ្យអ្នករាល់គ្នាមិនអាចសម្រេចចិត្តបានឡើយថា វាត្រឹមត្រូវ ឬក៏ខុសនោះ។ ខ្ញុំមិនខ្វល់អំពីផ្លូវដែលអ្នកបានដើរកាលពីមុននោះឡើយ ហើយក៏មិនចាប់អារម្មណ៍លើ «អាហារ» របស់នរណាដែលអ្នកបានទទួលទាន ឬនរណាដែលអ្នកយកធ្វើជា «ឪពុក» របស់អ្នកនោះដែរ។ ដោយសារតែខ្ញុំបាននាំមកនូវកិច្ចការថ្មី ដើម្បីដឹកនាំមនុស្ស ដូច្នេះ អស់អ្នកណាដែលដើរតាមខ្ញុំ ត្រូវតែប្រព្រឹត្តតាមអ្វីដែលខ្ញុំមានបន្ទូល។ មិនថាអ្នកចេញមកពី «ក្រុមគ្រួសារ» ដែលមានអំណាចប៉ុនណាឡើយ គឺអ្នកត្រូវតែដើរតាមខ្ញុំ អ្នកមិនត្រូវប្រព្រឹត្តស្របតាមទម្លាប់ពីអតីតកាលរបស់អ្នកឡើយ «ឪពុកចិញ្ចឹម» របស់អ្នកគួរតែចុះចេញ ហើយអ្នកគួរតែមកនៅចំពោះព្រះជាម្ចាស់របស់អ្នក ដើម្បីស្វែងរកចំណែកដ៏ស្របច្បាប់របស់អ្នកវិញ។ អ្វីៗទាំងអស់របស់អ្នកស្ថិតនៅក្នុងព្រះហស្តរបស់ខ្ញុំ ហើយអ្នកមិនគួរជឿទាំងងងឹតងងល់ខ្លាំងពេកលើឪពុកចិញ្ចឹមរបស់អ្នកនោះឡើយ ព្រោះថាគេមិនអាចគ្រប់គ្រងលើអ្នកបានទាំងស្រុងឡើយ។ កិច្ចការនាពេលសព្វថ្ងៃ គឺជាកិច្ចការដែលឯករាជ្យ។ គ្រប់យ៉ាងដែលខ្ញុំមានបន្ទូលនៅថ្ងៃនេះ មិនមានមូលដ្ឋានចេញពីអតីតកាលឡើយ។ ហើយវាជាទីចាប់ផ្ដើមថ្មីមួយ ហើយប្រសិនបើអ្នកនិយាយថា វាត្រូវបានបង្កើតឡើងដោយដៃរបស់មនុស្ស នោះអ្នកជាមនុស្សម្នាក់ដែលមានភ្នែកខ្វាក់ងងឹតមើលមិនឃើញ ហើយពិបាកនឹងសង្គ្រោះណាស់!

អេសាយ អេសេគាល ម៉ូសេ ដាវីឌ អ័ប្រាហាំ និងដានីយ៉ែល សុទ្ធតែជាអ្នកដឹកនាំ ឬហោរានៅក្នុងចំណោមរាស្ត្ររើសតាំងរបស់អ៊ីស្រាអែល។ ហេតុអ្វីបានជាពួកគេមិនត្រូវបានហៅថា ព្រះជាម្ចាស់ដូច្នេះ? ហេតុអ្វីបានជាព្រះវិញ្ញាណបរិសុទ្ធមិនធ្វើបន្ទាល់អំពីពួកគេ? ហេតុអ្វីបានជាព្រះវិញ្ញាណបរិសុទ្ធធ្វើបន្ទាល់អំពីព្រះយេស៊ូវ នៅពេលដែលទ្រង់ចាប់ផ្ដើមកិច្ចការរបស់ទ្រង់ និងចាប់ផ្ដើមមានបន្ទូលរបស់ទ្រង់ដូច្នេះ? ហើយហេតុអ្វីបានជាព្រះវិញ្ញាណបរិសុទ្ធ មិនធ្វើបន្ទាល់អំពីអ្នកដទៃ? មនុស្សដែលចេញមកពីសាច់ឈាម ពួកគេត្រូវបានហៅថា «ព្រះអម្ចាស់»។ មិនថាពួកគេត្រូវបានហៅបែបណានោះទេ គឺកិច្ចការរបស់គេតំណាងឲ្យលក្ខណៈ និងសារជាតិរបស់គេ ហើយលក្ខណៈ និងសារជាតិរបស់គេតំណាងឲ្យអត្តសញ្ញាណរបស់គេ។ សារជាតិរបស់គេមិនជាប់ទាក់ទងអ្វីទៅនឹងងាររបស់គេឡើយ ព្រោះថាវាត្រូវបានតំណាងឲ្យអ្វីដែលពួកគេបានបង្ហាញ និងអ្វីដែលពួកគេបានស្ដែងចេញតាមការរស់នៅ។ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ វាគ្មានអ្វីមួយចេញពីមនុស្សសាមញ្ញដែលត្រូវបានហៅថា ព្រះអម្ចាស់នោះទេ ហើយទោះបីជាបុគ្គលម្នាក់អាចត្រូវបានគេហៅតាមរបៀបណាមួយក៏ដោយ ប៉ុន្តែសារជាតិ និងអត្តសញ្ញាណដើមរបស់គេមិនចេះប្រែប្រួលឡើយ។ នៅក្នុងចំណោមព្រះគ្រីស្ទក្លែងក្លាយ ពួកហោរាក្លែងក្លាយ និងពួកបោកបញ្ឆោត តើមិនមានមនុស្សដែលត្រូវបានគេហៅថាជា «ព្រះជាម្ចាស់» ដែរទេឬអី? ចុះហេតុអ្វីបានជាពួកគេមិនមែនជាព្រះជាម្ចាស់ទៅ? នោះគឺដោយសារតែ ពួកគេគ្មានសមត្ថភាពធ្វើកិច្ចការរបស់ព្រះជាម្ចាស់។ តាមឋានៈ ពួកគេគឺជាមនុស្ស ជាពួកបញ្ឆោតមនុស្ស មិនមែនជាព្រះជាម្ចាស់ឡើយ ដូច្នេះ ពួកគេមិនមានអត្តសញ្ញាណរបស់ព្រះជាម្ចាស់ឡើយ។ តើស្ដេចដាវីឌក៏មិនត្រូវបានគេហៅថា ជាព្រះអម្ចាស់នៅក្នុងចំណោមអំបូរទាំងដប់ពីរដែរឬ? ព្រះយេស៊ូវក៏ត្រូវបានគេហៅថាជាព្រះអម្ចាស់ដែរ ចុះហេតុអ្វីបានជាមានតែព្រះយេស៊ូវមួយអង្គ ដែលត្រូវបានគេហៅថា ជាព្រះជាម្ចាស់ ដែលយកកំណើតជាមនុស្ស? តើយេរេមាមិនត្រូវបានគេស្គាល់ថាជាបុត្រមនុស្សទេឬ? ហើយតើព្រះយេស៊ូវក៏មិនត្រូវបានគេស្គាល់ថាជាបុត្រមនុស្សដែរទេឬអី? ចុះហេតុអ្វីបានជាព្រះយេស៊ូវត្រូវ

បានជាប់ឆ្កាង ជំនួសឲ្យព្រះជាម្ចាស់ទៅវិញ? តើនោះមិនមែនដោយសារតែសារជាតិរបស់ទ្រង់មានលក្ខណៈខុសពីគេទេឬ? តើនោះមិនមែនដោយសារតែកិច្ចការដែលទ្រង់បានធ្វើមានលក្ខណៈខុសពីគេទេឬ? តើងារសំខាន់ដែរឬទេ? ទោះបីព្រះយេស៊ូវត្រូវបានហៅថាជាបុត្រមនុស្សក៏ដោយ ក៏ទ្រង់គឺជាការយកកំណើតជាមនុស្សទីមួយរបស់ព្រះជាម្ចាស់ដែរ ហើយទ្រង់បានយាងមក ដើម្បីកាន់កាប់អំណាច និងដើម្បីសម្រេចកិច្ចការនៃការប្រោសលោះ។ ការនេះសបញ្ជាក់ឲ្យឃើញថា អត្តសញ្ញាណនិងសារជាតិរបស់ព្រះយេស៊ូវ មានលក្ខណៈខុសប្លែកពីអ្នកដទៃផ្សេងទៀតដែលត្រូវបានហៅថាជាបុត្រមនុស្សដែរនោះ។ នៅថ្ងៃនេះ តើនរណាខ្លះនៅក្នុងចំណោមអ្នករាល់គ្នាដែលហ៊ាននិយាយថា គ្រប់ទាំងពាក្យដែលត្រូវបានថ្លែងដោយមនុស្សដែលព្រះវិញ្ញាណបរិសុទ្ធប្រើ សុទ្ធតែបានចេញមកពីព្រះវិញ្ញាណបរិសុទ្ធ? តើអ្នកណាខ្លះដែលហ៊ាននិយាយពាក្យបែបនេះទៅ? ប្រសិនបើអ្នកពិតជានិយាយបែបនេះមែន ចុះហេតុអ្វីបានជាកណ្ឌគម្ពីរទំនាយរបស់អែសរ៉ា ត្រូវបានបោះបង់ចោល ហើយហេតុអ្វីបានជារឿងដូចគ្នានេះ ត្រូវបានធ្វើចំពោះកណ្ឌគម្ពីររបស់ពួកបរិសុទ្ធ និងពួកហោរាពីបុរាណទាំងនោះ? ប្រសិនបើពួកគេទាំងអស់នោះ បានមកពីព្រះវិញ្ញាណបរិសុទ្ធមែន ចុះហេតុអ្វីបានជាអ្នករាល់គ្នាហ៊ានធ្វើការជ្រើសរើសដ៏សារ៉ាំបែបនេះ? តើអ្នកមានគុណសម្បត្តិគ្រប់គ្រាន់ក្នុងការជ្រើសរើសកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធដែរឬ? មានសាច់រឿងជាច្រើនចេញពីអ៊ីស្រាអែល ក៏ត្រូវបានបោះបង់ចោលដែរ ហើយប្រសិនបើអ្នកជឿថា សំណេរកាលពីអតីតកាលទាំងនេះ សុទ្ធតែចេញមកពីព្រះវិញ្ញាណបរិសុទ្ធ ដូច្នេះហេតុអ្វីបានជាសៀវភៅមួយចំនួនត្រូវបានបោះបង់ចោលដូច្នេះ? ប្រសិនបើសៀវភៅទាំងអស់នេះ បានមកពីព្រះវិញ្ញាណបរិសុទ្ធ នោះសៀវភៅទាំងនោះគួរតែត្រូវបានរក្សាទុក ហើយផ្ញើទៅកាន់បងប្អូនប្រុសស្រីនៃពួកជំនុំដើម្បីអានបាត់ទៅហើយ។ សៀវភៅទាំងនោះ មិនគួរណាមិនត្រូវបានជ្រើសរើស ឬបោះបង់ចោលដោយឆន្ទៈរបស់មនុស្សឡើយ ដ្បិតការធ្វើបែបនេះ គឺជារឿងខុសហើយ។ ការនិយាយថា បទពិសោធរបស់ប៉ុល និងយ៉ូហាន ត្រូវបានលាយឡំជាមួយគតិជ្រៅជ្រះផ្ទាល់ខ្លួនរបស់

គេ មិនមែនមានន័យថា បទពិសោធ និងចំណេះដឹងរបស់គេ មកពីសាតាំងនោះឡើយ ប៉ុន្តែវាគ្រាន់តែមានន័យថា ពួកគេមាននូវសេចក្ដីដែលចេញមកពីបទពិសោធ និងគតិជ្រៅជ្រះរបស់គេប៉ុណ្ណោះ។ ចំណេះដឹងរបស់គេគឺស្របតាមសាវតារនៃបទពិសោធពិតរបស់គេនៅគ្រានោះ ដូច្នេះ តើនរណាអាចហ៊ាននិយាយទាំងជឿជាក់ថា អ្វីៗទាំងអស់នេះ សុទ្ធតែចេញមកពីព្រះវិញ្ញាណបរិសុទ្ធនោះ? ប្រសិនបើកណ្ឌគម្ពីរដំណឹងល្អទាំងបួនសុទ្ធតែចេញមកពីព្រះវិញ្ញាណបរិសុទ្ធមែន ចុះហេតុអ្វីបានជាកណ្ឌគម្ពីរម៉ាថាយ ម៉ាកុស លូកា និងយ៉ូហាន ចែងខុសៗគ្នាអំពីកិច្ចការរបស់ព្រះយេស៊ូវបែបនេះ? ប្រសិនបើអ្នករាល់គ្នាមិនជឿលើការនេះទេ សាកបើកមើលព្រះគម្ពីរអំពីរបៀបដែលពេត្រុសបដិសេធព្រះអម្ចាស់ចំនួនបីដងទៅមើល៍៖ កណ្ឌគម្ពីរទាំងអស់ចែងខុសៗគ្នា ហើយកណ្ឌគម្ពីរនីមួយៗមាននូវចរិតលក្ខណៈរបស់គេរៀងៗខ្លួន។ មនុស្សដែលល្ងីល្ងើនិយាយថា «ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សក៏ជាមនុស្សផងដែរ ដូច្នេះ តើព្រះបន្ទូលដែលទ្រង់ថ្លែងពិតជាអាចចេញមកពីព្រះវិញ្ញាណបរិសុទ្ធដែរឬទេ? ប្រសិនបើពាក្យរបស់ប៉ុល និងយ៉ូហាន ត្រូវបានលាយឡំជាមួយឆន្ទៈរបស់មនុស្ស តើព្រះបន្ទូលដែលទ្រង់ថ្លែងនោះមិនលាយឡំជាមួយឆន្ទៈរបស់មនុស្សទេឬអី?» មនុស្សដែលនិយាយបែបនេះ គឺជាមនុស្សខ្វាក់ និងល្ងង់ខ្លៅ! ចូរអានកណ្ឌគម្ពីរដំណឹងល្អទាំងបួនដោយយកចិត្តទុកដាក់ចុះ។ ចូរអានអ្វីដែលគេបានកត់ត្រាអំពីកិច្ចការដែលព្រះយេស៊ូវបានធ្វើ និងព្រះបន្ទូលដែលទ្រង់បានថ្លែង។ កណ្ឌគម្ពីរនីមួយៗមានលក្ខណៈខុសៗគ្នា ហើយកណ្ឌគម្ពីរនីមួយៗមាននូវទស្សនៈរបស់វាផ្ទាល់។ ប្រសិនបើសេចក្ដីដែលត្រូវបានសរសេរ ដោយអ្នកនិពន្ធនៃកណ្ឌគម្ពីរទាំងនេះ សុទ្ធតែមកពីព្រះវិញ្ញាណបរិសុទ្ធ នោះវាគួរតែមានភាពដូចគ្នា និងភាពជាប់លាប់មិនខាន។ ចុះហេតុអ្វីបានជាវាមានភាពផ្សេងគ្នាយ៉ាងដូច្នេះ? តើមនុស្សមិនល្ងីល្ងើពេកទេឬអី ដែលមើលមិនឃើញអំពីចំណុចនេះ? ប្រសិនបើអ្នកត្រូវបានសុំឲ្យធ្វើបន្ទាល់អំពីព្រះជាម្ចាស់ តើបន្ទាល់បែបណាទៅដែលអ្នកអាចធ្វើនោះ? តើចំណេះដឹងអំពីព្រះជាម្ចាស់បែបនេះអាចធ្វើបន្ទាល់អំពីទ្រង់បានដែរឬ? ប្រសិនបើអ្នកដទៃសួរអ្នកថា «បើកណ្ឌគម្ពីរយ៉ូហាន

និងលូកាត្រូវបានលាយឡំជាមួយឆន្ទៈរបស់មនុស្ស ដូច្នេះ តើព្រះបន្ទូលដែលត្រូវបានថ្លែង ដោយព្រះជាម្ចាស់របស់អ្នករាល់គ្នា មិនត្រូវបានលាយឡំជាមួយឆន្ទៈរបស់មនុស្សទេឬអី?» តើអ្នកអាចឆ្លើយសំណួរនេះបានយ៉ាងច្បាស់លាស់ដែរឬទេ? ក្រោយពេលលូកា និងម៉ាថាយបានឮអំពីព្រះបន្ទូលរបស់ព្រះយេស៊ូវ និងបានឃើញអំពីកិច្ចការរបស់ព្រះយេស៊ូវហើយ ពួកគេបាននិយាយ ចេញពីចំណេះដឹងផ្ទាល់ខ្លួនរបស់គេ ទៅតាមការចងចាំអំពីកិច្ចការដែលព្រះយេស៊ូវបានធ្វើប៉ុណ្ណោះ។ តើអ្នកអាចនិយាយថា ចំណេះដឹងរបស់គេត្រូវបានបើកសម្ដែងទាំងស្រុង ដោយព្រះវិញ្ញាណបរិសុទ្ធឬ? នៅខាងក្រៅព្រះគម្ពីរមាននូវបុគ្គលអស្ចារ្យខាងវិញ្ញាណជាច្រើនដែលមានចំណេះដឹងខ្ពស់ជាងពួកគេទៅទៀត ចុះហេតុអ្វីបានជាពាក្យរបស់ពួកគេ មិនត្រូវបានចាប់អារម្មណ៍ដោយមនុស្សជំនាន់ក្រោយដូច្នេះ? តើពួកគេមិនត្រូវបានប្រើដោយព្រះវិញ្ញាណបរិសុទ្ធដែរទេឬអី? ចូរដឹងថា នៅក្នុងកិច្ចការនាពេលថ្ងៃនេះ ខ្ញុំមិនមែនកំពុងតែនិយាយអំពីគតិជ្រៅជ្រះរបស់ខ្ញុំ ដោយផ្អែកលើមូលដ្ឋាននៃកិច្ចការរបស់ព្រះយេស៊ូវឡើយ ហើយខ្ញុំក៏មិនកំពុងនិយាយចេញពីចំណេះដឹងផ្ទាល់ខ្លួនរបស់ខ្ញុំទាស់នឹងសាវតារកិច្ចការរបស់ព្រះយេស៊ូវនោះដែរ។ តើព្រះយេស៊ូវ បានធ្វើកិច្ចការអ្វីខ្លះនៅពេលនោះ? តើខ្ញុំកំពុងតែធ្វើកិច្ចការអ្វីខ្លះនាពេលសព្វថ្ងៃ? អ្វីដែលខ្ញុំធ្វើ និងមានបន្ទូលនេះ គ្មានពាក់ព័ន្ធនឹងគ្រាមុនឡើយ។ ផ្លូវដែលខ្ញុំដើរនៅថ្ងៃនេះ មិនធ្លាប់ត្រូវបានដើរកាលពីមុនឡើយ គឺវាមិនធ្លាប់ត្រូវបានដើរដោយមនុស្សជំនាន់មុនៗនោះទេ។ នៅថ្ងៃនេះ វាត្រូវបានផ្ដើមឡើង តើនេះមិនមែនជាកិច្ចការរបស់ព្រះវិញ្ញាណទេឬ? ទោះបីវាជាកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធក៏ដោយ ក៏អ្នកដឹកនាំទាំងអស់កាលពីអតីតកាល សុទ្ធតែបានអនុវត្តកិច្ចការរបស់គេ ដោយផ្អែកលើគ្រឹះមូលដ្ឋាននៃកិច្ចការរបស់អ្នកដទៃ ប៉ុន្តែយ៉ាងណាមិញ កិច្ចការរបស់ព្រះជាម្ចាស់ផ្ទាល់ មានលក្ខណៈខុសពីគេ។ ដំណាក់កាលនៃកិច្ចការរបស់ព្រះយេស៊ូវគឺដូចគ្នា៖ ទ្រង់បានរៀបចំផ្លូវមួយថ្មី។ នៅពេលដែលទ្រង់បានយាងមក ទ្រង់បានប្រកាសដំណឹងល្អអំពីនគរស្ថានសួគ៌ និងបានមានបន្ទូលថា មនុស្សគួរតែប្រែចិត្ត ហើយលន់តួ។ ក្រោយពេលដែលព្រះយេស៊ូវបានបង្ហើយកិច្ចការ

របស់ទ្រង់ ពេត្រុស ប៉ុល និងអ្នកផ្សេងទៀតបានចាប់ផ្ដើមបន្ដកិច្ចការរបស់ព្រះយេស៊ូវ។ ក្រោយពេលដែលព្រះយេស៊ូវត្រូវបានបោះភ្ជាប់នឹងឈើឆ្កាង ហើយយាងឡើងទៅស្ថានសួគ៌ ព្រះវិញ្ញាណក៏បានចាត់ពួកគេឲ្យទៅផ្សាយអំពីផ្លូវនៃឈើឆ្កាង។ ទោះបីជាពាក្យរបស់ប៉ុលត្រូវបានលើកតម្កើងក៏ដោយ ក៏ពាក្យទាំងនោះផ្អែកលើគ្រឹះមូលដ្ឋានដែលត្រូវបានចាក់ដោយសេចក្ដីដែលព្រះយេស៊ូវបានមានបន្ទូលដូចជា ចិត្តអត់ធ្មត់ សេចក្ដីស្រឡាញ់ ការរងទុក្ខលំបាក ការគ្របបាំងក្បាល បុណ្យជ្រមុជទឹក ឬគោលលទ្ធិជាបន្ដបន្ទាប់ផ្សេងទៀតដែរ។ រាល់សេចក្ដីទាំងនេះត្រូវបាននិយាយចេញដោយផ្អែកលើមូលដ្ឋាននៃព្រះបន្ទូលរបស់ព្រះយេស៊ូវ។ ពួកគេគ្មានសមត្ថភាពរៀបចំផ្លូវថ្មីឡើយ ដ្បិតពួកគេគ្រាន់តែជាមនុស្សដែលត្រូវបានព្រះជាម្ចាស់ប្រើប៉ុណ្ណោះ។

ព្រះបន្ទូល និងកិច្ចការរបស់ព្រះយេស៊ូវនៅគ្រានោះ មិនផ្ទុកនូវគោលលទ្ធិឡើយ ហើយទ្រង់ក៏មិនអនុវត្តកិច្ចការរបស់ទ្រង់ ស្របតាមកិច្ចការនៃក្រឹត្យវិន័យរបស់ព្រះគម្ពីរសញ្ញាចាស់នោះដែរ។ វាត្រូវបានអនុវត្តស្របតាមកិច្ចការដែលគួរតែត្រូវបានធ្វើនៅក្នុងយុគសម័យនៃព្រះគុណ។ ទ្រង់បានធ្វើការស្របតាមកិច្ចការដែលទ្រង់បាននាំមក ស្របតាមផែនការរបស់ទ្រង់ និងស្របតាមព័ន្ធកិច្ចរបស់ទ្រង់ ហើយទ្រង់មិនធ្វើការស្របតាមក្រឹត្យវិន័យ នៃព្រះគម្ពីរសញ្ញាចាស់នោះឡើយ។ គ្មានអ្វីមួយដែលទ្រង់បានធ្វើស្របតាមក្រឹត្យវិន័យនៃព្រះគម្ពីរសញ្ញាចាស់ឡើយ ហើយទ្រង់ក៏មិនបានយាងមកធ្វើកិច្ចការ ដើម្បីសម្រេចតាមពាក្យរបស់ពួកហោរានោះដែរ។ ដំណាក់កាលនីមួយៗនៃកិច្ចការរបស់ព្រះជាម្ចាស់ មិនត្រូវបានធ្វើឡើងដើម្បីសម្រេចទំនាយរបស់ពួកហោរាពីបុរាណឡើយ ហើយទ្រង់ក៏មិនបានយាងមកដើម្បីប្រកាន់ខ្ជាប់តាមគោលលទ្ធិ ឬមកសម្រេចតាមទំនាយរបស់ពួកហោរាពីបុរាណនោះដែរ។ ប៉ុន្ដែ សកម្មភាពរបស់ទ្រង់ មិនបានបង្អាក់ដល់សេចក្ដីទំនាយរបស់ពួកហោរាពីបុរាណ ហើយក៏មិនរំខានដល់កិច្ចការដែលទ្រង់បានធ្វើកន្លងមកនោះដែរ។ ចំណុចដ៏លេចធ្លោនៃកិច្ចការរបស់ទ្រង់ មិនមែនជាការកាន់តាមគោលលទ្ធិណាមួយឡើយ ផ្ទុយទៅវិញ ជាការធ្វើកិច្ចការដែលទ្រង់ផ្ទាល់គួរតែធ្វើវិញ។ ទ្រង់មិនមែនជាហោរា ឬព្យាការីឡើយ ប៉ុន្ដែជា

អ្នកអនុវត្តផ្ទាល់ ដែលបានយាងមក ដើម្បីធ្វើកិច្ចការដែលទ្រង់គួរតែធ្វើ ហើយទ្រង់បានយាងមក ដើម្បីចាប់ផ្ដើមនូវយុគសម័យថ្មីរបស់ទ្រង់ និងអនុវត្តតាមកិច្ចការថ្មីរបស់ទ្រង់។ ជាការពិត នៅពេលដែលព្រះយេស៊ូវបានយាងមកធ្វើកិច្ចការរបស់ទ្រង់ ទ្រង់ក៏បានសម្រេចតាមព្រះបន្ទូលជាច្រើនដែលត្រូវបានថ្លែងទុកដោយពួកហោរាពីបុរាណនៅក្នុងព្រះគម្ពីរសញ្ញាចាស់ដែរ។ ដូច្នេះ កិច្ចការនាពេលសព្វថ្ងៃ ក៏បានសម្រេចតាមទំនាយរបស់ពួកហោរាពីបុរាណនៃព្រះគម្ពីរសញ្ញាចាស់ដែរ។ វាគ្រាន់តែខ្ញុំមិនកាន់ «សៀវភៅចំណាស់ពណ៌លឿង» នោះប៉ុណ្ណោះ។ សម្រាប់កិច្ចការជាច្រើនទៀតដែលខ្ញុំត្រូវធ្វើ ខ្ញុំក៏ត្រូវថ្លែងព្រះបន្ទូលជាច្រើនទៀតទៅកាន់អ្នករាល់គ្នាផងដែរ ហើយកិច្ចការ និងពាក្យទាំងនេះ ពិតជាសំខាន់ខ្លាំងណាស់ គឺសំខាន់ជាងសេចក្ដីពន្យល់បទគម្ពីរទៅទៀត ដោយសារតែកិច្ចការបែបនេះមិនសំខាន់ ឬមានតម្លៃអ្វីសម្រាប់អ្នករាល់គ្នាឡើយ ហើយក៏មិនអាចជួយអ្វីដល់អ្នករាល់គ្នា ឬផ្លាស់ប្រែអ្នករាល់គ្នានោះដែរ។ ខ្ញុំចង់ធ្វើកិច្ចការថ្មី មិនមែនសម្រាប់ជាប្រយោជន៍នៃការសម្រេចតាមបទគម្ពីរណាមួយនៅក្នុងព្រះគម្ពីរឡើយ។ ប្រសិនបើព្រះជាម្ចាស់គ្រាន់តែយាងមកកាន់ផែនដីដើម្បីសម្រេចតាមពាក្យរបស់ពួកហោរាពីបុរាណនៅក្នុងព្រះគម្ពីរ នោះតើនរណាទៅដែលមានឋានៈធំជាង ជាព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស ឬក៏ជាពួកហោរាពីបុរាណ? សរុបមក តើពួកហោរាគ្រប់គ្រងលើព្រះជាម្ចាស់ ឬក៏ព្រះជាម្ចាស់គ្រប់គ្រងលើពួកហោរា? តើអ្នកត្រូវពន្យល់អំពីពាក្យទាំងនេះយ៉ាងដូចម្ដេចទៅ?

កាលពីដើមដំបូង នៅពេលដែលព្រះយេស៊ូវមិនទាន់បានចាប់ផ្ដើម ធ្វើព័ន្ធកិច្ចរបស់ទ្រង់ជាផ្លូវការ ពេលខ្លះ ទ្រង់ក៏បានចូលរួមការប្រជុំ និងច្រៀងបទទំនុកតម្កើងថ្វាយការសរសើរ និងអានព្រះគម្ពីរសញ្ញាចាស់នៅក្នុងព្រះវិហារ ដូចពួកសិស្សដែលបានដើរតាមទ្រង់ដែរ។ ក្រោយពេលដែលទ្រង់បានទទួលបុណ្យជ្រមុជទឹក និងងើបឡើងចេញពីទឹក ព្រះវិញ្ញាណបានយាងមកសណ្ឋិតលើទ្រង់ជាផ្លូវការ ហើយទ្រង់បានចាប់ផ្ដើមធ្វើការបើកសម្ដែងអំពីអត្តសញ្ញាណរបស់ទ្រង់ និងព័ន្ធកិច្ចដែលទ្រង់ត្រូវធ្វើ។ មុនពេលនេះ គ្មាននរណាម្នាក់បានដឹងអំពីអត្តសញ្ញាណរបស់ទ្រង់ ហើយក្រៅពីនាង

ម៉ារា សូម្បីតែយ៉ូហានក៏មិនបានដឹងផង។ ព្រះយេស៊ូវ មានព្រះជន្ម២៩ព្រះវស្សា នៅពេលដែលទ្រង់បានទទួលបុណ្យជ្រមុជទឹក។ ក្រោយពេលបុណ្យជ្រមុជទឹករបស់ទ្រង់ត្រូវបានធ្វើរួច ផ្ទៃមេឃបានបើកចំហ ហើយមានសំឡេងមួយពីស្ថានសួគ៌ថា៖ «នេះគឺជាបុត្រស្ងួនភ្ងារបស់ខ្ញុំ ខ្ញុំសព្វព្រះទ័យនឹងទ្រង់ណាស់»។ នៅពេលដែលព្រះយេស៊ូវបានទទួលបុណ្យជ្រមុជទឹក ព្រះវិញ្ញាណបរិសុទ្ធបានចាប់ផ្ដើមធ្វើបន្ទាល់អំពីទ្រង់នៅក្នុងរបៀបនេះ។ មុនពេលដែលទទួលបុណ្យជ្រមុជទឹកនៅវ័យ២៩ព្រះវស្សា ទ្រង់បានរស់នៅក្នុងជីវិតជាមនុស្សសាមញ្ញ សោយអាហារនៅពេលដែលទ្រង់គួរតែសោយ ផ្ទុំ និងគ្រងព្រះពស្រ្តជាមនុស្សសាមញ្ញ ហើយគ្មានអ្វីមួយអំពីទ្រង់ដែលមានលក្ខណៈខុសប្លែកពីអ្នកដទៃឡើយ ហើយពិតណាស់ នេះគ្រាន់តែចំពោះផ្នែកខាងសាច់ឈាមរបស់មនុស្សប៉ុណ្ណោះ។ ពេលខ្លះ ទ្រង់ក៏ទន់ខ្សោយ ហើយពេលខ្លះទៀតទ្រង់ក៏មិនអាចយល់រឿងរ៉ាវផ្សេងៗ ដូចជាមានចែងនៅក្នុងព្រះគម្ពីរថា៖ បញ្ញារបស់ទ្រង់បានចម្រើនឡើងទៅតាមព្រះជន្មរបស់ទ្រង់។ ពាក្យទាំងនេះគ្រាន់តែបង្ហាញថា ទ្រង់មានភាពជាមនុស្សសាមញ្ញធម្មតា និងបង្ហាញទៀតថាទ្រង់មិនមានលក្ខណៈពិសេសអ្វី ពីមនុស្សសាមញ្ញផ្សេងទៀតឡើយ។ ទ្រង់ក៏បានធំធាត់ឡើងជាមនុស្សសាមញ្ញម្នាក់ ហើយគ្មានអ្វីមួយពិសេសអំពីទ្រង់នោះឡើយ។ ប៉ុន្តែ ទ្រង់បានស្ថិតនៅក្រោមការមើលថៃ និងការការពាររបស់ព្រះជាម្ចាស់។ ក្រោយពេលដែលទទួលបុណ្យជ្រមុជទឹកហើយ ទ្រង់បានចាប់ផ្ដើមជួបសេចក្ដីល្បួង បន្ទាប់មកទ្រង់បានចាប់ផ្ដើមធ្វើព័ន្ធកិច្ចរបស់ទ្រង់ ហើយទ្រង់បានពេញដោយឫទ្ធានុភាព ព្រះប្រាជ្ញាញាណ និងសិទ្ធិអំណាច។ នេះមិនមែនមានន័យថា ព្រះវិញ្ញាណបរិសុទ្ធមិនបានធ្វើការនៅក្នុងទ្រង់ មុនពេលបុណ្យជ្រមុជទឹករបស់ទ្រង់ ឬព្រះអង្គមិនបានគង់នៅខាងក្នុងទ្រង់នោះឡើយ។ មុនបុណ្យជ្រមុជទឹករបស់ទ្រង់ ព្រះវិញ្ញាណបរិសុទ្ធក៏បានគង់សណ្ឋិតនៅខាងក្នុងទ្រង់ផងដែរ ប៉ុន្តែទ្រង់មិនទាន់បានចាប់ផ្ដើមធ្វើការជាផ្លូវការឡើយ ព្រោះមិនទាន់ដល់ពេលកំណត់ដែលព្រះជាម្ចាស់ធ្វើកិច្ចការរបស់ទ្រង់ ហើយលើសពីនេះ មនុស្សសាមញ្ញមាននូវដំណើរការសាមញ្ញនៅក្នុងការលូតលាស់។ ព្រះវិញ្ញាណបរិសុទ្ធតែងតែគង់នៅខាង

ក្នុងទ្រង់ជានិច្ច។ នៅពេលដែលព្រះយេស៊ូវប្រសូតមក ទ្រង់មានលក្ខណៈខុសប្លែកពីអ្នកដទៃ ហើយផ្កាយព្រឹកបានលេចឡើង។ មុនកំណើតរបស់ទ្រង់ ទេវតាមួយអង្គបានបង្ហាញខ្លួនឲ្យយ៉ូសែបឃើញនៅក្នុងសុបិន ហើយប្រាប់គាត់ថា ម៉ារាត្រូវផ្ដល់កំណើតដល់ទារកម្នាក់ និងបានប្រាប់ទៀតថា បុត្រនោះកើតមកពីព្រះវិញ្ញាណបរិសុទ្ធទេ។ ក្រោយពេលដែលព្រះយេស៊ូវ បានទទួលបុណ្យជ្រមុជទឹកហើយ ព្រះវិញ្ញាណបរិសុទ្ធបានចាប់ផ្ដើមធ្វើកិច្ចការរបស់ទ្រង់ ប៉ុន្តែការនេះមិនមានន័យថា ព្រះវិញ្ញាណបរិសុទ្ធគ្រាន់តែយាងចុះមកសណ្ឋិត ពីលើព្រះយេស៊ូវនោះឡើយ។ ការដែលនិយាយថា ព្រះវិញ្ញាណបរិសុទ្ធបានយាងចុះមក ដូចជាសត្វព្រាបសណ្ឋិតពីលើទ្រង់ គឺជាការសំដៅទៅលើ ការចាប់ផ្ដើមជាផ្លូវការនៃព័ន្ធកិច្ចរបស់ទ្រង់។ ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់បានគង់នៅក្នុងទ្រង់កាលពីមុន ប៉ុន្តែទ្រង់មិនទាន់បានចាប់ផ្ដើមធ្វើការទេ ដ្បិតពេលកំណត់មិនទាន់បានមកដល់នៅឡើយ ហើយព្រះវិញ្ញាណក៏មិនចាប់ផ្ដើមធ្វើការដោយតក់ក្រហល់នោះដែរ។ ព្រះវិញ្ញាណបានធ្វើបន្ទាល់អំពីទ្រង់ តាមរយៈបុណ្យជ្រមុជទឹក។ នៅពេលដែលទ្រង់ងើបចេញពីទឹក ព្រះវិញ្ញាណក៏បានចាប់ផ្ដើមធ្វើការជាផ្លូវការនៅក្នុងទ្រង់ ដែលជាទីសម្គាល់បង្ហាញថា សាច់ឈាមដែលយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់បានចាប់ផ្ដើមបំពេញព័ន្ធកិច្ចរបស់ទ្រង់ ហើយបានចាប់ផ្ដើមកិច្ចការនៃការប្រោសលោះ ដែលមានន័យថា យុគសម័យនៃព្រះគុណបានចាប់ផ្ដើមជាផ្លូវការហើយ។ ដូច្នេះ វាមាននូវពេលកំណត់មួយសម្រាប់កិច្ចការរបស់ព្រះជាម្ចាស់ មិនថាទ្រង់ធ្វើកិច្ចការអ្វីនោះឡើយ។ ក្រោយបុណ្យជ្រមុជទឹករបស់ទ្រង់ វាមិនទាន់មានការផ្លាស់ប្ដូរជាក់លាក់ណាមួយនៅក្នុងព្រះយេស៊ូវនោះឡើយ ហើយទ្រង់នៅតែគង់នៅក្នុងសាច់ឈាមដើមរបស់ទ្រង់ដដែល។ វាគ្រាន់តែថា ទ្រង់បានចាប់ផ្ដើមកិច្ចការរបស់ទ្រង់ និងបើកសម្ដែងពីអត្តសញ្ញាណរបស់ទ្រង់ ហើយទ្រង់បានពេញដោយសិទ្ធិអំណាច និងឫទ្ធានុភាពប៉ុណ្ណោះ។ នៅក្នុងការនេះ ទ្រង់មានលក្ខណៈខុសពីមុន។ អត្តសញ្ញាណរបស់ទ្រង់មានលក្ខណៈខុសពីមុន គឺអាចនិយាយបានថា វាមាននូវការផ្លាស់ប្ដូរដ៏សំខាន់មួយនៅក្នុងឋានៈរបស់ទ្រង់ ហើយនេះជាទីបន្ទាល់របស់ព្រះវិញ្ញាណ

បរិសុទ្ធ និងមិនមែនជាកិច្ចការដែលត្រូវបានធ្វើដោយមនុស្សឡើយ។ កាលពីដំបូង មនុស្សមិនបានដឹង ហើយពួកគេគ្រាន់តែដឹងតែបន្តិចប៉ុណ្ណោះ នៅពេលដែលព្រះវិញ្ញាណបរិសុទ្ធ បានធ្វើបន្ទាល់អំពីព្រះយេស៊ូវនៅក្នុងរបៀបនោះ។ ប្រសិនបើព្រះយេស៊ូវបានធ្វើកិច្ចការដ៏ធំ មុនពេលព្រះវិញ្ញាណបរិសុទ្ធបានធ្វើបន្ទាល់អំពីទ្រង់ ប៉ុន្តែដោយគ្មានបន្ទាល់អំពីព្រះជាម្ចាស់ផ្ទាល់ នោះទោះបីកិច្ចការរបស់ទ្រង់ធំអស្ចារ្យប៉ុនណាក៏ដោយ ក៏មនុស្សនឹងមិនបានស្គាល់ អំពីអត្តសញ្ញាណរបស់ទ្រង់នោះដែរ ព្រោះថាភ្នែករបស់មនុស្សនឹងគ្មានសមត្ថភាពអ្វីទៅមើលឃើញអំពីអត្តសញ្ញាណនេះឡើយ។ បើគ្មានជំហាននៃការធ្វើបន្ទាល់របស់ព្រះវិញ្ញាណបរិសុទ្ធទេ នោះគ្មាននរណាម្នាក់អាចស្គាល់ទ្រង់ថា ជាព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សឡើយ។ ក្រោយ ពេលព្រះវិញ្ញាណបរិសុទ្ធបានធ្វើបន្ទាល់អំពីទ្រង់រួចហើយ ប្រសិនបើព្រះយេស៊ូវបានបន្តធ្វើការ នៅក្នុងរបៀបដដែលដោយគ្មានភាពខុសប្លែកពីមុនទេ នោះវានឹងគ្មានប្រសិទ្ធភាពឡើយ ហើយនៅក្នុងចំណុចនេះ កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធក៏ត្រូវបានបង្ហាញឲ្យឃើញដែរ។ ក្រោយពេលដែលព្រះវិញ្ញាណបរិសុទ្ធបានធ្វើបន្ទាល់រួចហើយ ព្រះវិញ្ញាណបរិសុទ្ធត្រូវតែបង្ហាញអង្គទ្រង់ ដើម្បីឲ្យអ្នកអាចមើលឃើញយ៉ាងច្បាស់ថា ទ្រង់គឺជាព្រះជាម្ចាស់ មើលឃើញថា មានព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ដែលគង់សណ្ឋិតនៅខាងក្នុងទ្រង់ និងមើលឃើញទៀតថា ទីបន្ទាល់របស់ព្រះជាម្ចាស់មិនមែនជារឿងខុសឡើយ ដូច្នេះ នេះអាចបញ្ជាក់យ៉ាងច្បាស់ថា ទីបន្ទាល់របស់ទ្រង់គឺជារឿងត្រឹមត្រូវ។ ប្រសិនបើកិច្ចការរបស់ទ្រង់ កាលពីមុន និងក្រោយការធ្វើបន្ទាល់របស់ព្រះវិញ្ញាណបរិសុទ្ធ បានកើតឡើងនៅពេលតែមួយ នោះព័ន្ធកិច្ចរបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស និងកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ នឹងមិនត្រូវលេចចេញយ៉ាងច្បាស់ឡើយ ហើយជាលទ្ធផល មនុស្សនឹងគ្មានសមត្ថភាពទទួលស្គាល់កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធបានឡើយ ព្រោះវានឹងគ្មានភាពខុសគ្នាដ៏ច្បាស់លាស់នោះទេ។ បន្ទាប់ពីធ្វើបន្ទាល់រួច ព្រះវិញ្ញាណបរិសុទ្ធត្រូវតែប្រកាន់ខ្ជាប់នឹងទីបន្ទាល់នេះ ដូច្នេះ ទ្រង់ត្រូវតែបើកបង្ហាញពីព្រះប្រាជ្ញាញាណ និងសិទ្ធិអំណាចរបស់

ទ្រង់នៅក្នុងព្រះយេស៊ូវ ដែលមានលក្ខណៈខុសប្លែកពីអតីតកាល។ ជាការពិត នេះមិនមែនជាលទ្ធផលកើតចេញពីបុណ្យជ្រមុជទឹកឡើយ ដ្បិតបុណ្យជ្រមុជទឹកគ្រាន់តែជាពិធីមួយប៉ុណ្ណោះ ហើយបុណ្យជ្រមុជទឹកគ្រាន់តែជាផ្លូវមួយ ដើម្បីបង្ហាញថាវាដល់ពេលក្នុងការធ្វើព័ន្ធកិច្ចរបស់ទ្រង់ប៉ុណ្ណោះ។ កិច្ចការនេះកើតឡើង ដើម្បីឲ្យឃើញជាក់ស្តែងអំពីឫទ្ធានុភាពដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ ឲ្យឃើញជាក់ស្តែងអំពីការធ្វើបន្ទាល់របស់ព្រះវិញ្ញាណបរិសុទ្ធ ហើយព្រះវិញ្ញាណបរិសុទ្ធ នឹងទទួលខុសត្រូវសម្រាប់ការធ្វើបន្ទាល់នេះ រហូតដល់ទីបញ្ចប់។ មុនពេលធ្វើព័ន្ធកិច្ចរបស់ទ្រង់ ព្រះយេស៊ូវក៏បានស្ដាប់សេចក្ដីអធិប្បាយ បានប្រកាស និងផ្សាយដំណឹងល្អនៅតាមកន្លែងផ្សេងៗផងដែរ។ ទ្រង់មិនបានធ្វើកិច្ចការធំដុំណាមួយទេ ដោយសារតែពេលកំណត់ដែលឲ្យទ្រង់ធ្វើព័ន្ធកិច្ចរបស់ទ្រង់ មិនទាន់មកដល់នៅឡើយ ហើយក៏ដោយសារតែព្រះជាម្ចាស់ផ្ទាល់បានលាក់កំបាំងដោយបន្ទាបព្រះអង្គទ្រង់នៅក្នុងសាច់ឈាម និងមិនធ្វើកិច្ចការណាមួយឡើយ រហូតដល់ពេលកំណត់បានមកដល់។ ទ្រង់មិនបានធ្វើការមុនពេលបុណ្យជ្រមុជទឹក ដោយសារហេតុផលពីរយ៉ាង៖ ទីមួយ គឺដោយសារតែព្រះវិញ្ញាណបរិសុទ្ធមិនទាន់យាងចុះមកសណ្ឋិតលើទ្រង់ជាផ្លូវការដើម្បីធ្វើការ (គឺអាចនិយាយបានថា ព្រះវិញ្ញាណបរិសុទ្ធមិនទាន់បានប្រទានព្រះចេស្ដា និងសិទ្ធិអំណាចដល់ព្រះយេស៊ូវ ដើម្បីធ្វើកិច្ចការបែបនេះនៅឡើយ) ហើយទោះបីជាទ្រង់បានស្គាល់ពីអត្តសញ្ញាណរបស់ទ្រង់ហើយក៏ដោយ ក៏ព្រះយេស៊ូវមិនមានសមត្ថភាពធ្វើកិច្ចការដែលទ្រង់ត្រូវធ្វើនៅពេលក្រោយដែរ ដូច្នេះ ទ្រង់ត្រូវតែរង់ចាំរហូតដល់ថ្ងៃបុណ្យជ្រមុជទឹករបស់ទ្រង់។ នេះគឺជាពេលកំណត់របស់ព្រះជាម្ចាស់ ហើយគ្មាននរណាម្នាក់មានសមត្ថភាពល្មើសបានឡើយ រួមទាំងព្រះយេស៊ូវផ្ទាល់ ព្រោះថាព្រះយេស៊ូវផ្ទាល់មិនអាចបង្អាក់ដល់កិច្ចការរបស់ទ្រង់ផ្ទាល់នោះឡើយ។ ជាការពិត នេះគឺជាការបន្ទាបអង្គទ្រង់របស់ព្រះជាម្ចាស់ ហើយក៏ជាក្រឹត្យវិន័យនៃកិច្ចការរបស់ព្រះជាម្ចាស់ផងដែរ ប្រសិនបើព្រះវិញ្ញាណរបស់ព្រះជាម្ចាស់មិនបានធ្វើការទេ នោះក៏គ្មាននរណាម្នាក់អាចធ្វើកិច្ចការរបស់ទ្រង់បានដែរ។ ហេតុផលទីពីរគឺថា មុនពេលដែលទ្រង់បានទទួល

បុណ្យជ្រមុជទឹក ទ្រង់គ្រាន់តែជាមនុស្សសាមញ្ញធម្មតាម្នាក់ប៉ុណ្ណោះ គឺទ្រង់គ្មានលក្ខណៈអ្វីខុសប្លែកពីមនុស្សសាមញ្ញធម្មតាផ្សេងទៀតនោះឡើយ។ នេះជាទិដ្ឋភាពមួយអំពីរបៀបដែលព្រះយកកំណើតជាមនុស្ស មិនមែនជាអធិធម្មជាតិ។ ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស មិនបានបំពានលើការរៀបចំនៃព្រះវិញ្ញាណ របស់ព្រះជាម្ចាស់ឡើយ គឺទ្រង់បានធ្វើការនៅក្នុងរបៀបដែលមានលំដាប់លំដោយ ហើយទ្រង់បានធ្វើការយ៉ាងសាមញ្ញបំផុត។ គឺមានតែក្រោយពេលបុណ្យជ្រមុជទឹកប៉ុណ្ណោះ ទើបកិច្ចការរបស់ទ្រង់មាននូវសិទ្ធិអំណាច និងព្រះចេស្ដា។ គឺអាចនិយាយបានថា ទោះបីទ្រង់ជាព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សក៏ដោយក៏ទ្រង់មិនអនុវត្តកិច្ចការអធិធម្មជាតិណាមួយ ហើយទ្រង់បានធំធាត់ឡើងនៅក្នុងរបៀបសាមញ្ញ ដូចជាមនុស្សផ្សេងទៀតផងដែរ។ ប្រសិនបើព្រះយេស៊ូវបានស្គាល់អត្តសញ្ញាណរបស់ទ្រង់ និងបានធ្វើកិច្ចការដ៏អស្ចារ្យនៅទូទាំងទឹកដី មុនពេលដែលទ្រង់ទទួលបុណ្យជ្រមុជទឹកហើយទ្រង់មានលក្ខណៈខុសប្លែក ពីមនុស្សសាមញ្ញ ព្រមទាំងបង្ហាញអង្គទ្រង់ជាមនុស្សដ៏អស្ចារ្យ នោះយ៉ូហានមិនត្រឹមតែមិនអាចធ្វើកិច្ចការរបស់គាត់ប៉ុណ្ណោះទេ ប៉ុន្តែវាក៏នឹងគ្មានផ្លូវសម្រាប់ព្រះជាម្ចាស់ ដើម្បីចាប់ផ្ដើមជំហានបន្ទាប់នៃកិច្ចការរបស់ទ្រង់ដែរ។ ដូច្នេះ ការនេះនឹងសបញ្ជាក់ឲ្យឃើញថា អ្វីដែលព្រះជាម្ចាស់បានធ្វើ ប្រែទៅជាខុស ហើយចំពោះមនុស្សវិញ វានឹងស្ដែងចេញឲ្យឃើញថា ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ និងព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់មិនបានយាងមកចេញពីប្រភពតែមួយឡើយ។ ដូច្នេះ កិច្ចការរបស់ព្រះយេស៊ូវដែលត្រូវបានកត់ត្រាទុកនៅក្នុងព្រះគម្ពីរ គឺជាកិច្ចការដែលត្រូវបានអនុវត្ត ក្រោយពេលទ្រង់បានទទួលបុណ្យជ្រមុជទឹក ជាកិច្ចការដែលត្រូវបានធ្វើក្នុងពេលបី ឆ្នាំ។ ព្រះគម្ពីរមិនបានកត់ត្រាអ្វីដែលទ្រង់បានធ្វើ មុនពេលទ្រង់បានទទួលបុណ្យជ្រមុជទឹក ដោយសារតែទ្រង់មិនបានធ្វើកិច្ចការនេះ មុនពេលទ្រង់បានទទួលបុណ្យជ្រមុជទឹកឡើយ។ ទ្រង់គ្រាន់តែជាមនុស្សសាមញ្ញ និងតំណាងឲ្យមនុស្សសាមញ្ញម្នាក់ប៉ុណ្ណោះ ហើយមុនពេលព្រះយេស៊ូវបានចាប់ផ្ដើមធ្វើព័ន្ធកិច្ចរបស់ទ្រង់ ទ្រង់ក៏គ្មានលក្ខណៈអ្វីខុសប្លែកពីមនុស្សសាមញ្ញនោះ

ដែរ ហើយអ្នកដទៃក៏មើលមិនឃើញអ្វីប្លែកនៅក្នុងទ្រង់នោះដែរ។ មានតែក្រោយពេលដែលទ្រង់បានចូលដល់ព្រះជន្ម២៩ព្រះវស្សាប៉ុណ្ណោះ ទើបព្រះយេស៊ូវបានជ្រាបថា ទ្រង់បានយាងមកដើម្បីបញ្ចប់ដំណាក់កាលមួយនៃកិច្ចការរបស់ព្រះជាម្ចាស់ ហើយកាលពីមុននោះ ទ្រង់ផ្ទាល់មិនបានដឹងអំពីការនេះ ដ្បិតកិច្ចការដែលត្រូវបានធ្វើដោយព្រះជាម្ចាស់ មិនមែនជាកិច្ចការអធិធម្មជាតិឡើយ។ នៅពេលដែលទ្រង់បានចូលរួមការប្រជុំនៅក្នុងសាលាប្រជុំនៅវ័យ១២ព្រះវស្សា ម៉ារាកំពុងតែតាមស្វែងរកទ្រង់ ហើយទ្រង់គ្រាន់តែមានបន្ទូលតែមួយប្រយោគ ដូចជាក្មេងឯទៀតៗប៉ុណ្ណោះ៖ «អ្នកម្ដាយ! តើលោកមិនជ្រាបទេឬថា ខ្ញុំត្រូវឲ្យតម្លៃខ្ពស់ទៅលើព្រះហឫទ័យរបស់ព្រះវរបិតាជាងអ្វីៗទាំងអស់?» ជាការពិត ដោយសារតែទ្រង់បានចាប់កំណើតដោយព្រះវិញ្ញាណបរិសុទ្ធ តើព្រះយេស៊ូវអាចមិនមានលក្ខណៈពិសេសនៅក្នុងរបៀបណាមួយដែរឬទេ? ប៉ុន្តែភាពពិសេសរបស់ទ្រង់មិនមែនមានន័យថា ទ្រង់ជាមនុស្សអធិធម្មជាតិឡើយ ប៉ុន្តែគ្រាន់តែចង់បង្ហាញថា ទ្រង់ស្រឡាញ់ព្រះជាម្ចាស់លើសក្មេងឯទៀតៗប៉ុណ្ណោះ។ ទោះបីទ្រង់មានរូបរាងជាមនុស្សក៏ដោយ ក៏សារជាតិរបស់ទ្រង់នៅតែពិសេស និងមានលក្ខណៈខុសប្លែកពីអ្នកដទៃ។ មានតែក្រោយពេលបុណ្យជ្រមុជទឹកប៉ុណ្ណោះ ទើបទ្រង់ពិតជាជ្រាបដឹងថា ព្រះវិញ្ញាណបរិសុទ្ធកំពុងធ្វើការនៅក្នុងទ្រង់ជ្រាបដឹងថា ទ្រង់ជាព្រះជាម្ចាស់ផ្ទាល់។ មានតែពេលដែលទ្រង់បានចូលដល់វ័យ៣៣ព្រះវស្សាប៉ុណ្ណោះ ទើបទ្រង់ជ្រាបដឹងយ៉ាងពិតប្រាកដថា ព្រះវិញ្ញាណបរិសុទ្ធមានបំណងអនុវត្តកិច្ចការនៃការជាប់ឆ្កាងតាមរយៈទ្រង់។ នៅវ័យ៣២ព្រះវស្សា ទ្រង់ទើបតែចាប់ផ្ដើមដឹងអំពីសេចក្ដីពិតពីខាងក្នុងមួយចំនួន ដូចជាមានចែងនៅក្នុងកណ្ឌគម្ពីរដំណឹងល្អម៉ាថាយថា៖ «រួចលោកស៊ីម៉ូនពេត្រុសក៏ឆ្លើយថា ទ្រង់គឺជាព្រះគ្រីស្ទ ជាព្រះរាជបុត្រា នៃព្រះដ៏មានព្រះជន្មគង់នៅ។ ... តាំងពីគ្រានោះមក ព្រះយេស៊ូវក៏ចាប់ផ្ដើមបង្ហាញប្រាប់សិស្សទ្រង់ ពីរបៀបដែលទ្រង់ត្រូវយាងចូលក្រុងយេរូសាឡឹម និងរងទុក្ខលំបាកជាច្រើនពីពួកចាស់ទុំ ពួកបូជាចារ្យ និងពួកអាចារ្យ ព្រមទាំងត្រូវគេធ្វើគុត ហើយមានព្រះជន្មរស់ឡើងវិញ នៅថ្ងៃទីបី»។ មុនពេលនោះ ទ្រង់មិនបានជ្រាបដឹងអំពីកិច្ចការដែលទ្រង់ត្រូវ

ធ្វើនោះឡើយ ដ្បិតទ្រង់ដឹងនៅពេលជាក់លាក់មួយប៉ុណ្ណោះ។ ក្រោយពេលដែលទ្រង់បានប្រសូតភ្លាម ទ្រង់មិនបានជ្រាបដឹងទាំងស្រុងឡើយ ហើយព្រះវិញ្ញាណបរិសុទ្ធបានធ្វើការបន្តិចម្ដងៗនៅក្នុងទ្រង់ ហើយវាមាននូវដំណើរការមួយចំពោះកិច្ចការនេះ។ តាំងពីដើមដំបូងមក ប្រសិនបើទ្រង់បានជ្រាបដឹងថា ទ្រង់ជាព្រះជាម្ចាស់ ជាព្រះគ្រីស្ទ និងជាព្រះរាជបុត្រានៃព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស និងជ្រាបទៀតថា ទ្រង់ត្រូវសម្រេចកិច្ចការនៃការជាប់ឆ្កាង ចុះហេតុអ្វីបានជាកាលពីមុន ទ្រង់មិនបានធ្វើការដូច្នេះ? ហេតុអ្វីបានជាក្រោយពេលប្រាប់ដល់ពួកសិស្សរបស់ទ្រង់អំពីព័ន្ធកិច្ចរបស់ទ្រង់ហើយ ទើបព្រះយេស៊ូវមានអារម្មណ៍កើតទុក្ខ និងបានអធិស្ឋានយ៉ាងអស់ពីចិត្តសម្រាប់ការនេះ? ហេតុអ្វីបានជាយ៉ូហានរៀបចំផ្លូវសម្រាប់ទ្រង់ និងធ្វើបុណ្យជ្រមុជទឹកឲ្យទ្រង់មុនពេលទ្រង់ចាប់ផ្ដើមយល់អំពីរឿងជាច្រើនដែលទ្រង់មិនទាន់បានយល់? ការនេះចង់បញ្ជាក់ឲ្យឃើញថា វាជាកិច្ចការរបស់ព្រះដែលត្រូវយកកំណើតជាមនុស្ស នៅក្នុងសាច់ឈាម ហើយដើម្បីឲ្យទ្រង់យល់និងសម្រេចនូវកិច្ចការនោះ វាមាននូវដំណើរការមួយ ព្រោះថាទ្រង់ គឺជាសាច់ឈាមដែលយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់ ហើយកិច្ចការរបស់ទ្រង់ក៏ខុសប្លែកពីកិច្ចការដែលព្រះវិញ្ញាណបានធ្វើដោយផ្ទាល់ដែរ។

គ្រប់ជំហាននៃកិច្ចការរបស់ព្រះជាម្ចាស់ គឺសុទ្ធតែដើរតាមចរន្តតែមួយដូចគ្នាដូច្នេះ នៅក្នុងផែនការគ្រប់គ្រងរយៈពេលប្រាំមួយពាន់ឆ្នាំរបស់ព្រះជាម្ចាស់ ជំហាននីមួយៗបានដើរតាមក្រោយគ្នាយ៉ាងប្រកិត ចាប់តាំងពីពិភពលោកត្រូវបានបង្កើតរហូតមកដល់ពេលសព្វថ្ងៃ។ ប្រសិនបើគ្មាននរណាម្នាក់ជួយរៀបចំផ្លូវទេ នោះនឹងគ្មាននរណាម្នាក់មកតាមក្រោយនោះឡើយ ព្រោះដោយសារតែ មានមនុស្សដែលមកតាមក្រោយដូច្នេះហើយទើបមានមនុស្សដែលបានរៀបចំផ្លូវ។ កិច្ចការត្រូវបានហុចបន្តមួយជំហានម្ដងៗតាមរបៀបនេះ។ ជំហានមួយមកតាមក្រោយជំហានមួយទៀតហើយបើគ្មានមនុស្សម្នាក់រៀបចំផ្លូវទេ នោះក៏មិនអាចនឹងចាប់ផ្ដើមកិច្ចការបានឡើយហើយព្រះជាម្ចាស់ក៏នឹងគ្មានផ្លូវក្នុងការនាំកិច្ចការរបស់ទ្រង់ឆ្ពោះទៅមុខដែរ។ គ្មានជំហានណាមួយ ជាន់ដានជំហានមួយទៀតឡើយ ដ្បិតជំហាននីមួយៗតាមពីក្រោយគ្នា

ទៅតាមលំដាប់លំដោយ ដើម្បីបង្កើតជាចរន្តមួយ ហើយកិច្ចការទាំងអស់នេះ ត្រូវបានធ្វើឡើងដោយព្រះវិញ្ញាណតែមួយ។ ប៉ុន្តែ ទោះបីជាបុគ្គលម្នាក់រៀបចំផ្លូវ ឬអនុវត្តកិច្ចការរបស់បុគ្គលម្នាក់ទៀតក៏ដោយ ក៏ការនេះមិនកំណត់អំពីអត្តសញ្ញាណរបស់គេឡើយ។ តើនេះមិនត្រឹមត្រូវទេឬ? យ៉ូហានបានរៀបចំផ្លូវ ហើយព្រះយេស៊ូវបានបន្តធ្វើកិច្ចការរបស់គាត់ ដូច្នេះ តើការនេះបញ្ជាក់ថា អត្តសញ្ញាណរបស់ព្រះយេស៊ូវមានឋានៈទាបជាងយ៉ូហានឬ? ព្រះយេហូវ៉ាបានអនុវត្តកិច្ចការរបស់ទ្រង់មុនព្រះយេស៊ូវ ដូច្នេះ តើអ្នកអាចនិយាយថា ព្រះយេហូវ៉ាមានឋានៈធំជាងព្រះយេស៊ូវឬ? មិនថាពួកគេបានរៀបចំផ្លូវ ឬបានបន្តធ្វើកិច្ចការរបស់អ្នកដទៃនោះឡើយ វាមិនសំខាន់ទេ ប៉ុន្តែអ្វីដែលសំខាន់បំផុតនោះគឺជាសារជាតិនៃកិច្ចការរបស់ពួកគេ និងអត្តសញ្ញាណដែលវាតំណាងឲ្យ។ តើនេះមិនត្រឹមត្រូវទេឬ? ដោយសារតែព្រះជាម្ចាស់មានគោលបំណងធ្វើការនៅក្នុងចំណោមមនុស្ស ដូច្នេះ ទ្រង់ត្រូវតែជ្រើសតាំងអស់អ្នកដែលអាចធ្វើកិច្ចការនៃការរៀបចំផ្លូវ។ នៅពេលដែលយ៉ូហានទើបតែចាប់ផ្ដើមប្រកាសព្រះបន្ទូល គាត់បានមានប្រសាសន៍ថា៖ «ចូររៀបចំផ្លូវថ្វាយព្រះអម្ចាស់ ចូររៀបផ្លូវឲ្យត្រង់ថ្វាយទ្រង់»។ «ចូរអ្នករាល់គ្នាប្រែចិត្ត ដ្បិតនគរព្រះនៅជិតបង្កើយ»។ គាត់មានប្រសាសន៍បែបនេះ តាំងពីដើមដំបូងមក តើហេតុអ្វីបានជាគាត់អាចនិយាយពាក្យទាំងនេះបាន? ទាក់ទងនឹងលំដាប់លំដោយដែលពាក្យទាំងនេះត្រូវបានថ្លែងចេញជាដំបូង យ៉ូហានបាននិយាយ អំពីដំណឹងល្អនៃនគរស្ថានសួគ៌ ហើយព្រះយេស៊ូវជាអ្នកមានបន្ទូលក្រោយមកទៀត។ យោងតាមសញ្ញាណរបស់មនុស្ស គឺយ៉ូហានទេដែលបានរៀបចំផ្លូវថ្មី ដូច្នេះ យ៉ូហានប្រាកដជាមានឋានៈខ្ពស់ជាងព្រះយេស៊ូវហើយ។ ប៉ុន្តែ យ៉ូហានមិនបាននិយាយថា គាត់ជាព្រះគ្រីស្ទឡើយ ហើយព្រះជាម្ចាស់ក៏មិនបានធ្វើបន្ទាល់អំពីគាត់ថាជាបុត្រស្ងួនភ្ញារបស់ព្រះជាម្ចាស់នោះដែរ ប៉ុន្តែទ្រង់គ្រាន់តែប្រើគាត់ដើម្បីបើក និងរៀបចំផ្លូវសម្រាប់ព្រះអម្ចាស់ប៉ុណ្ណោះ។ គាត់បានរៀបចំផ្លូវសម្រាប់ព្រះយេស៊ូវ ប៉ុន្តែគាត់មិនអាចធ្វើការជំនួសឲ្យព្រះយេស៊ូវបានឡើយ។ គ្រប់កិច្ចការរបស់មនុស្សក៏ត្រូវបានរក្សាដោយព្រះវិញ្ញាណបរិសុទ្ធដែរ។

នៅក្នុងយុគសម័យនៃព្រះគម្ពីរសញ្ញាចាស់ គឺជាព្រះយេហូវ៉ា ដែលបានដឹកនាំផ្លូវ ហើយកិច្ចការរបស់ព្រះយេហូវ៉ា បានតំណាងឲ្យយុគសម័យទាំងមូលនៃព្រះគម្ពីរសញ្ញាចាស់ និងកិច្ចការទាំងអស់ ដែលបានធ្វើនៅក្នុងស្រុកអ៊ីស្រាអែល។ ម៉ូសេគ្រាន់តែកាន់កាប់កិច្ចការនេះនៅលើផែនដីប៉ុណ្ណោះ ហើយការខំប្រឹងរបស់គាត់ត្រូវបានចាត់ទុកជាកិច្ចសហប្រតិបត្តិការ ដែលមនុស្សបានផ្ដល់ឲ្យ។ នៅពេលនោះ គឺព្រះយេហូវ៉ាដែលបានមានបន្ទូលត្រាស់ហៅម៉ូសេ ហើយទ្រង់បានលើកម៉ូសេឡើងនៅក្នុងចំណោមប្រជាជនអ៊ីស្រាអែល និងបានធ្វើឲ្យគាត់ដឹកនាំពួកគេចូលទៅកាន់វាលរហោស្ថាន និងបន្តទៅកាន់ទឹកដីកាណានទៀត។ នេះមិនមែនជាកិច្ចការរបស់ម៉ូសេផ្ទាល់នោះឡើយ ប៉ុន្តែជាកិច្ចការដែលត្រូវបានដឹកនាំដោយផ្ទាល់ ពីសំណាក់ព្រះយេហូវ៉ា ដូច្នេះម៉ូសេ មិនអាចត្រូវបានហៅថាជាព្រះជាម្ចាស់ឡើយ។ ម៉ូសេក៏បានសរសេរនូវក្រឹត្យវិន័យដែរ ប៉ុន្តែក្រឹត្យវិន័យនេះ ត្រូវបានចេញព្រះរាជក្រឹត្យដោយផ្ទាល់ពីព្រះយេហូវ៉ា។ វាគ្រាន់តែទ្រង់ឲ្យម៉ូសេ ជាអ្នកបង្ហាញក្រឹត្យវិន័យនោះប៉ុណ្ណោះ។ ព្រះយេស៊ូវក៏បានបង្កើតនូវបទបញ្ញត្តិផងដែរ ហើយទ្រង់បានលុបបំបាត់នូវក្រឹត្យវិន័យនៃព្រះគម្ពីរសញ្ញាចាស់ និងបានដាក់ចេញនូវបទបញ្ញត្តិសម្រាប់យុគសម័យថ្មី។ ហេតុអ្វីបានជាព្រះយេស៊ូវគឺជាព្រះជាម្ចាស់ផ្ទាល់? គឺដោយសារតែវាមានលក្ខណៈខុសគ្នា។ នៅពេលនោះ កិច្ចការដែលត្រូវបានធ្វើដោយម៉ូសេ មិនតំណាងឲ្យយុគសម័យទេ ហើយក៏មិនបានបើកផ្លូវថ្មីនោះដែរ។ គាត់គ្រាន់តែត្រូវបានដឹកនាំដោយផ្ទាល់ពីសំណាក់ព្រះយេហូវ៉ា និងគ្រាន់តែត្រូវបានព្រះជាម្ចាស់ប្រើប៉ុណ្ណោះ។ នៅពេលដែលព្រះយេស៊ូវបានយាងមក យ៉ូហានបានអនុវត្តជំហានមួយនៃកិច្ចការរៀបចំផ្លូវ ហើយបានចាប់ផ្ដើមផ្សាយដំណឹងល្អអំពីនគរស្ថានសួគ៌ (ព្រះវិញ្ញាណបរិសុទ្ធបានចាប់ផ្ដើមកិច្ចការនេះ)។ នៅពេលដែលព្រះយេស៊ូវបានយាងមក ទ្រង់បានធ្វើកិច្ចការរបស់ទ្រង់ដោយផ្ទាល់ ប៉ុន្តែវាមានភាពខុសគ្នាដ៏ធំមួយ រវាងកិច្ចការរបស់ទ្រង់ និងកិច្ចការរបស់ម៉ូសេ។ អេសាយក៏បានថ្លែងទំនាយជាច្រើនផងដែរ ចុះហេតុអ្វីបានជាគាត់មិនមែនជាព្រះជាម្ចាស់ផ្ទាល់ទៅ? ព្រះយេស៊ូវមិនបានថ្លែងទំនាយ

ជាច្រើនឡើយ ចុះហេតុអ្វីបានជាទ្រង់គឺជាព្រះជាម្ចាស់ផ្ទាល់ដូច្នេះ? គ្មាននរណាម្នាក់ហ៊ាននិយាយថា កិច្ចការរបស់ព្រះយេស៊ូវនៅគ្រានោះ សុទ្ធតែចេញមកពីព្រះវិញ្ញាណបរិសុទ្ធនោះទេ ហើយពួកគេក៏មិនហ៊ានអះអាងថា កិច្ចការរបស់ទ្រង់សុទ្ធតែចេញពីឆន្ទៈរបស់មនុស្សឬក៏និយាយថា វាជាកិច្ចការរបស់ព្រះជាម្ចាស់ផ្ទាល់ទាំងស្រុងនោះដែរ។ មនុស្សគ្មានផ្លូវអាចវិភាគយល់ពីកិច្ចការបែបនេះឡើយ។ គឺអាចនិយាយបានថា អេសាយបានធ្វើកិច្ចការបែបនេះ និងបានថ្លែងទំនាយបែបនេះ ហើយទាំងអស់សុទ្ធតែចេញមកពីព្រះវិញ្ញាណបរិសុទ្ធ ហើយអ្វីៗទាំងនេះ មិនបានចេញមកដោយផ្ទាល់ពីអេសាយឡើយ ប៉ុន្តែវាជាការបើកសម្ដែងមកពីព្រះយេហូវ៉ា។ ព្រះយេស៊ូវមិនបានធ្វើកិច្ចការធំដុំច្រើនឡើយ ហើយក៏មិនបានមានបន្ទូល ឬថ្លែងទំនាយជាច្រើននោះដែរ។ ចំពោះមនុស្ស សេចក្តីអធិប្បាយរបស់ទ្រង់មិនគួរត្រូវបានលើកតម្កើងឡើយ ប៉ុន្តែទ្រង់គឺជាព្រះជាម្ចាស់ផ្ទាល់ ហើយមនុស្សមិនអាចពន្យល់ពីការនេះបានឡើយ។ គ្មាននរណាម្នាក់បានជឿលើ យ៉ូហាន អេសាយ ឬដាវីឌឡើយ ហើយក៏គ្មាននរណាម្នាក់បានហៅពួកគេថាជាព្រះជាម្ចាស់ដូចជា ព្រះជាម្ចាស់ដាវីឌ ឬព្រះជាម្ចាស់យ៉ូហាននោះដែរ។ គ្មាននរណាម្នាក់ធ្លាប់បាននិយាយបែបនេះទេ គឺមានតែព្រះយេស៊ូវតែមួយអង្គប៉ុណ្ណោះ ដែលត្រូវបានគេហៅថាជាព្រះគ្រីស្ទ។ ការចាត់ថ្នាក់នេះត្រូវបានធ្វើឡើងស្របតាមការធ្វើបន្ទាល់របស់ព្រះជាម្ចាស់ កិច្ចការដែលទ្រង់បានធ្វើ និងព័ន្ធកិច្ចដែលទ្រង់បានបំពេញ។ ដោយមានការគោរព ចំពោះវីរបុរសដ៏អស្ចារ្យនៃព្រះគម្ពីរដូចជា អ័ប្រាហាំ ដាវីឌ យ៉ូស្វេ ដានីយ៉ែល អេសាយ យ៉ូហាន និងព្រះយេស៊ូវ តាមរយៈកិច្ចការដែលពួកគេបានធ្វើ នោះអ្នកអាចប្រាប់បានថា នរណាគឺជាព្រះជាម្ចាស់ផ្ទាល់ ហើយមនុស្សប្រភេទណាខ្លះជាពួកហោរា និងជាពួកសាវ័ក។ នរណាដែលព្រះជាម្ចាស់បានប្រើប្រាស់ ហើយនរណាគឺជាព្រះជាម្ចាស់ផ្ទាល់ ត្រូវបានបែងចែក និងកំណត់ដោយសារជាតិ និងប្រភេទនៃកិច្ចការដែលពួកគេបានធ្វើ។ ប្រសិនបើអ្នកមិនអាចប្រាប់ពីភាពខុសគ្នានេះបានទេ នោះវាបញ្ជាក់ឲ្យឃើញថា អ្នកមិនដឹងអំពីអត្ថន័យនៃការជឿលើព្រះជាម្ចាស់ឡើយ។ ព្រះយេស៊ូវជាព្រះជាម្ចាស់ ដោយសារតែទ្រង់បានមាន

បន្ទូលជាច្រើន និងបានធ្វើនូវកិច្ចការជាច្រើន ជាពិសេសគឺការធ្វើការអស្ចារ្យជាច្រើនរបស់ទ្រង់។ យ៉ូហានក៏បានធ្វើនូវកិច្ចការជាច្រើន និងបានមានប្រសាសន៍ជាច្រើន រួមទាំងម៉ូសេផង ចុះហេតុអ្វីបានជាពួកគេមិនត្រូវបានហៅថា ជាព្រះជាម្ចាស់? អ័ដាមត្រូវបានព្រះជាម្ចាស់បង្កើតឡើងដោយផ្ទាល់ ចុះហេតុអ្វីបានជាគាត់មិនត្រូវបានគេហៅថាជាព្រះជាម្ចាស់ ផ្ទុយទៅវិញ គ្រាន់តែត្រូវបានគេហៅថាជាសត្តនិករម្នាក់? ប្រសិនបើមនុស្សម្នាក់និយាយទៅកាន់អ្នកថា «នៅថ្ងៃនេះ ព្រះជាម្ចាស់បានធ្វើកិច្ចការជាច្រើន និងបានមានបន្ទូលជាច្រើនដែរ ដូច្នេះ ទ្រង់គឺជាព្រះជាម្ចាស់ផ្ទាល់។ អ៊ីចឹង ម៉ូសេត្រូវតែជាព្រះជាម្ចាស់ហើយ ព្រោះគាត់ថ្លែងនូវព្រះបន្ទូលជាច្រើន!» អ្នកគួរតែសួរពួកគេវិញថា «នៅគ្រានោះ ហេតុអ្វីបានជាព្រះជាម្ចាស់ធ្វើបន្ទាល់អំពីព្រះយេស៊ូវ ថាជាព្រះជាម្ចាស់ផ្ទាល់ ហើយមិនមែនជាយ៉ូហាន? តើយ៉ូហានមិនបានមកពីព្រះយេស៊ូវទេឬអី? តើមួយណាមានអំណាចជាង កិច្ចការរបស់យ៉ូហាន ឬកិច្ចការរបស់ព្រះយេស៊ូវ? ចំពោះមនុស្ស កិច្ចការរបស់យ៉ូហានមើលទៅដូចជាមានអំណាចជាងកិច្ចការរបស់ព្រះយេស៊ូវ ប៉ុន្ដែហេតុអ្វីបានជាព្រះវិញ្ញាណបរិសុទ្ធធ្វើបន្ទាល់អំពីព្រះយេស៊ូវ ហើយមិនមែនជាយ៉ូហាន?» រឿងដដែលនេះកំពុងតែកើតឡើងនៅពេលសព្វថ្ងៃ! នៅសម័យនោះ នៅពេលដែលម៉ូសេបានដឹកនាំប្រជាជនអ៊ីស្រាអែល ព្រះយេហូវ៉ាបានមានបន្ទូលទៅកាន់គាត់ចេញពីក្នុងពពកមក។ ម៉ូសេមិនបាននិយាយដោយផ្ទាល់ឡើយ ប៉ុន្ដែផ្ទុយទៅវិញ គាត់ត្រូវបានដឹកនាំដោយផ្ទាល់ពីសំណាក់ព្រះយេហូវ៉ា។ នេះគឺជាកិច្ចការរបស់អ៊ីស្រាអែលកាលពីសញ្ញាចាស់។ នៅក្នុងម៉ូសេ គ្មានព្រះវិញ្ញាណឡើយ ហើយក៏គ្មានវត្តមានរបស់ព្រះជាម្ចាស់ដែរ។ គាត់មិនអាចធ្វើកិច្ចការនោះបានឡើយ ដូច្នេះ វាមានភាពខុសគ្នាដ៏ធំមួយរវាងកិច្ចការដែលគាត់បានធ្វើ និងកិច្ចការដែលព្រះយេស៊ូវបានធ្វើ។ ហើយនោះគឺដោយសារតែកិច្ចការដែលពួកគេបានធ្វើ មានលក្ខណៈខុសគ្នា! ដើម្បីដឹងថាមនុស្សម្នាក់ត្រូវបានប្រើដោយព្រះជាម្ចាស់ ឬជាហោរា ជាសាវ័ក ឬក៏ជាព្រះជាម្ចាស់ផ្ទាល់នោះ គឺគេអាចឈ្វេងយល់បានតាមរយៈនិស្ស័យនៃកិច្ចការរបស់គេ ហើយការនេះនឹងជួយឲ្យអ្នកលែងមានមន្ទិលតទៅទៀត។ នៅក្នុងព្រះគម្ពីរ មាន

ចែងទុកមកថា មានតែកូនចៀមប៉ុណ្ណោះដែលអាចបកត្រាទាំងប្រាំពីរបាន។ នៅក្នុងយុគសម័យកាលនានា មានអ្នកកាត់ស្រាយបទគម្ពីរជាច្រើននាក់នៅក្នុងចំណោមបុគ្គលអស្ចារ្យៗជាច្រើន ដូច្នេះ តើអ្នកអាចនិយាយថា ពួកគេទាំងអស់គ្នាសុទ្ធតែជាកូនចៀមឬ? តើអ្នកអាចនិយាយបានថា សេចក្ដីពន្យល់របស់ពួកគេសុទ្ធតែមកពីព្រះជាម្ចាស់ឬ? ពួកគេគ្រាន់តែជាគ្រូអធិប្បាយប៉ុណ្ណោះ ហើយពួកគេគ្មានអត្តសញ្ញាណនៃកូនចៀមទេឡើយ។ តើពួកគេអាចមានតម្លៃសក្ដិសមក្នុងការបកត្រាទាំងប្រាំពីរបានយ៉ាងដូចម្ដេច? នេះគឺជាការពិតដែលថា «មានតែកូនចៀមប៉ុណ្ណោះ ដែលអាចបើកត្រាទាំងប្រាំពីរបាន» ប៉ុន្តែទ្រង់មិនគ្រាន់តែយាងមក ដើម្បីបើកត្រាទាំងប្រាំពីរប៉ុណ្ណោះទេ ដ្បិតកិច្ចការនេះគ្មានភាពចាំបាច់នោះឡើយ ហើយវាត្រូវបានធ្វើឡើងដោយចៃដន្យប៉ុណ្ណោះ។ ទ្រង់ជ្រាបដឹងយ៉ាងច្បាស់អំពីកិច្ចការរបស់ទ្រង់ផ្ទាល់ ដូច្នេះ តើវាចាំបាច់សម្រាប់ទ្រង់ដែរឬទេក្នុងការចំណាយពេលជាច្រើនធ្វើការបកស្រាយបទគម្ពីរនោះ? តើ «យុគសម័យនៃកូនចៀមបកស្រាយបទគម្ពីរ» ត្រូវបូកបន្ថែមទៅក្នុងកិច្ចការរយៈពេលប្រាំមួយពាន់ឆ្នាំឬ? ទ្រង់យាងមកធ្វើកិច្ចការថ្មី ប៉ុន្តែទ្រង់ក៏ប្រទាននូវការបើកសម្ដែងមួយចំនួនអំពីកិច្ចការកាលពីអតីតកាលដែរ ដើម្បីធ្វើឲ្យមនុស្សយល់អំពីសេចក្ដីពិតនៃកិច្ចការរយៈពេលប្រាំមួយពាន់ឆ្នាំ។ ដូច្នេះ វាគ្មានភាពចាំបាច់អ្វីក្នុងការពន្យល់នូវបទគម្ពីរយ៉ាងច្រើនចេញពីព្រះគម្ពីរនោះឡើយ ដ្បិតគឺកិច្ចការនាពេលបច្ចុប្បន្នទេដែលសំខាន់។ អ្នកគួរតែដឹងថា ព្រះជាម្ចាស់មិនបានយាងមកដើម្បីបកត្រាទាំងប្រាំពីរឡើយ ប៉ុន្តែដើម្បីធ្វើកិច្ចការនៃសេចក្ដីសង្គ្រោះវិញ។

អ្នកគ្រាន់តែដឹងថា ព្រះយេស៊ូវនឹងយាងត្រឡប់មកវិញ នៅគ្រាចុងក្រោយ ប៉ុន្តែតើទ្រង់នឹងយាងចុះមកយ៉ាងដូចម្ដេចឲ្យប្រាកដទៅ? មនុស្សមានបាបដូចជាអ្នករាល់គ្នាដែលទើបតែត្រូវបានប្រោសលោះ និងមិនទាន់ត្រូវបានផ្លាស់ប្ដូរ ឬត្រូវបានព្រះជាម្ចាស់ប្រោសឲ្យគ្រប់លក្ខណ៍ តើអ្នកអាចស្របតាមព្រះហឫទ័យ ព្រះជាម្ចាស់ដែរឬទេ? សម្រាប់អ្នក អ្នកនៅតែមាននិស្ស័យចាស់ដដែល ហើយវាជាការពិតដែលអ្នកត្រូវបានសង្គ្រោះដោយព្រះយេស៊ូវ និងមិនត្រូវបានរាប់ថាជាមនុស្សមានបាប ដោយសារ

សេចក្ដីសង្គ្រោះរបស់ព្រះជាម្ចាស់ ប៉ុន្ដែការនេះមិនបញ្ជាក់ថា អ្នកមិនមានបាប និងបរិសុទ្ធនោះឡើយ។ តើអ្នកអាចក្លាយជាពួកបរិសុទ្ធយ៉ាងដូចម្ដេច បើអ្នកមិនត្រូវបានផ្លាស់ប្ដូរផងនោះ? នៅខាងក្នុង អ្នកត្រូវបានហ៊ុមព័ទ្ធដោយភាពមិនបរិសុទ្ធ ភាពអាត្មានិយម និងភាពឃោរឃៅ ប៉ុន្ដែអ្នកនៅតែចង់ឡើងទៅជាមួយព្រះយេស៊ូវ ហើយបើបានបែបនេះមែន អ្នកច្បាស់ជាមនុស្សសំណាងបំផុតហើយ! អ្នកបានខកខានមួយជំហាននៅក្នុងជំនឿរបស់អ្នកលើព្រះជាម្ចាស់៖ អ្នកត្រូវបានប្រោសលោះមែន ប៉ុន្ដែ អ្នកមិនត្រូវបានផ្លាស់ប្ដូរឡើយ។ ដើម្បីឲ្យអ្នកស្របតាមព្រះហឫទ័យ របស់ព្រះជាម្ចាស់ ព្រះជាម្ចាស់ត្រូវតែធ្វើកិច្ចការនៃការផ្លាស់ប្ដូរ និងការបន្សុទ្ធអ្នកដោយផ្ទាល់សិន។ ប្រសិនបើអ្នកគ្រាន់តែត្រូវបានប្រោសលោះ នោះអ្នកនឹងគ្មានសមត្ថភាពទទួលបានការញែកជាបរិសុទ្ធឡើយ។ តាមរបៀបនេះ អ្នកនឹងគ្មានគុណសម្បត្តិអ្វីគ្រប់គ្រាន់ដើម្បីទទួលបានចំណែក ជាព្រះពរដ៏ល្អៗរបស់ព្រះជាម្ចាស់ឡើយ ព្រោះអ្នកបានខកខានមួយជំហាននៅក្នុងកិច្ចការនៃការគ្រប់គ្រងលើមនុស្សរបស់ព្រះជាម្ចាស់ដែលជាជំហានដ៏សំខាន់នៃការផ្លាស់ប្ដូរ និងការប្រោសឲ្យគ្រប់លក្ខណ៍។ ដូច្នេះ អ្នកដែលជាមនុស្សមានបាប ដែលទើបតែត្រូវបានប្រោសលោះនេះ គ្មានសមត្ថភាពក្នុងការស្នងមត៌ករបស់ព្រះជាម្ចាស់ដោយផ្ទាល់ឡើយ។

បើគ្មានការចាប់ផ្ដើមដំណាក់កាលថ្មីនៃកិច្ចការនេះទេ នោះនរណាទៅដឹងទៅថា អ្នករាល់គ្នាដែលជាអ្នកផ្សាយដំណឹងល្អ ជាគ្រូអធិប្បាយ ជាអ្នកកាត់ស្រាយព្រះគម្ពីរ និងជាអ្នកដឹកនាំខាងវិញ្ញាណដ៏អស្ចារ្យ នឹងត្រូវទៅកន្លែងដ៏សែនឆ្ងាយ! បើសិនគ្មានការចាប់ផ្ដើមដំណាក់កាលថ្មីនៃកិច្ចការនេះទេ នោះអ្វីដែលអ្នករាល់គ្នានិយាយនឹងក្លាយជារឿងហួសសម័យមិនខាន! មិនថាអ្វីៗដែលអ្នកនិយាយនោះ ស្ដីពីការឡើងទៅលើបល្ល័ង្ក ឬការរៀបចំឋានៈក្លាយជាស្ដេច មិនថាស្ដីពីការលះកាត់ចិត្តខ្លួនឯង ឬការយកឈ្នះរូបកាយរបស់ខ្លួន ស្ដីពីការធ្វើជាអ្នកជំងឺ ឬការរៀនមេរៀនចេញពីអ្វីៗគ្រប់យ៉ាង និងស្ដីពីការបន្ទាបខ្លួន ឬសេចក្ដីស្រឡាញ់នោះឡើយ។ តើនេះមិនមែនជាការច្រៀងចេញពីតុងចាស់ដូចគ្នាទេឬអី? វាគ្រាន់តែជាការហៅសាច់រឿងតែមួយ

ដោយឈ្មោះផ្សេងគ្នាប៉ុណ្ណោះ! មិនថាជាការគ្របបាំងក្បាល និងការកាត់នំប៉ុង ឬជាការដាក់ដៃអធិស្ឋាន និងការប្រោសអ្នកជំងឺឲ្យជា និងការដេញអារក្សនោះឡើយ។ តើវាអាចមានកិច្ចការថ្មីៗផ្សេងទេ? តើវាអាចមានការអភិវឌ្ឍថ្មីទេ? ប្រសិនបើអ្នកបន្តដឹកនាំតាមរបៀបនេះ នោះអ្នកនឹងដើរតាមគោលលទ្ធិ ឬកាន់តាមទំនៀមទម្លាប់ទាំងងងឹតងងល់មិនខាន។ អ្នករាល់គ្នាជឿថា កិច្ចការរបស់អ្នករាល់គ្នានឹងមានភាពខ្ពង់ខ្ពស់ ក៏ប៉ុន្តែ តើអ្នកមិនដឹងទេឬថា អ្វីៗទាំងអស់ត្រូវបានផ្ទេរ និងបង្រៀនដោយ «មនុស្សចាស់» ទាំងនោះកាលពីសម័យបុរាណ? តើគ្រប់ទាំងសេចក្ដីដែលអ្នករាល់គ្នានិយាយនិងធ្វើ មិនមែនជាពាក្យចុងក្រោយរបស់មនុស្សចាស់ទាំងនោះទេឬ? តើវាមិនមែនជាអ្វីដែលត្រូវបានបង្គាប់មក ដោយមនុស្សចាស់ទាំងនេះ មុនពេលពួកគេបានចែកឋានទេឬអី? តើអ្នកគិតថាទង្វើរបស់អ្នករាល់គ្នាខ្ពស់លើសពីទង្វើរបស់ពួកសាវ័ក និងពួកហោរាកាលពីជំនាន់មុន និងថែមទាំងខ្ពស់លើសគ្រប់ទាំងអស់ឬ? ការចាប់ផ្ដើមដំណាក់កាលនៃកិច្ចការនេះ បានបញ្ចប់ការលើកសរសើររបស់អ្នករាល់គ្នាចំពោះកិច្ចការរបស់វីតណេស លី អំពីការព្យាយាមក្លាយជាស្ដេច និងការឡើងអង្គុយលើបល្ល័ង្ក ហើយវាបានធ្វើឲ្យអ្នកមានសេចក្ដីអំនួតក្អេងក្អាង ដូច្នេះ អ្នកមិនអាចជ្រែកខ្លួនចូលទៅក្នុងដំណាក់កាលនៃកិច្ចការនេះបានឡើយ។ បើគ្មានដំណាក់កាលនេះទេ អ្នករាល់គ្នានឹងត្រូវលិចកាន់តែជ្រៅរហូតដល់លង់ខ្លួនគ្មានថ្ងៃត្រឡប់ក្រោយវិញឡើយ។ នៅក្នុងចំណោមអ្នករាល់គ្នា មានរឿងចាស់ៗច្រើនណាស់! ជាសំណាងល្អកិច្ចការនាថ្ងៃនេះ បាននាំអ្នករាល់គ្នាឲ្យបកក្រោយវិញ បើមិនដូច្នោះទេ នរណាទៅដឹងអំពីទិសដៅដែលអ្នករាល់គ្នានឹងត្រូវទៅ! ដោយសារតែព្រះជាម្ចាស់ជាព្រះដែលតែងតែថ្មី និងមិនដែលចាស់ តើហេតុអ្វីបានជាអ្នកមិនស្វែងរកអ្វីដែលថ្មីៗដូច្នេះ? ហេតុអ្វីបានជាអ្នកតែងតែប្រកាន់ខ្ជាប់នឹងអ្វីចាស់ៗបែបនេះ? ដូច្នេះ ការដឹងអំពីកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធនាពេលសព្វថ្ងៃ ពិតជាសំខាន់ណាស់!

# អ្នកគប្បីទុកព្រះពរនៃឋានៈចោលមួយឡែក រួចឈ្វេងយល់ព្រះហឫទ័យព្រះជាម្ចាស់ ក្នុងការនាំសេចក្ដីសង្គ្រោះ មកឲ្យមនុស្សលោក

តាមទស្សនៈរបស់មនុស្សលោក ពូជពង្សម៉ូអាប់មិនអាចត្រូវបានធ្វើឲ្យបានពេញខ្នាតបានឡើយ ហើយពួកគេក៏ពុំមាននូវលក្ខណសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលការនេះដែរ។ ផ្ទុយទៅវិញ ពូជពង្សហ្លួងដាវីឌមានសង្ឃឹមយ៉ាងប្រាកដ ហើយពិតជាអាចទទួលបានភាពពេញខ្នាត។ ប្រសិនបើនរណាម្នាក់ជាពូជពង្សរបស់ម៉ូអាប់ ពួកគេមិនអាចត្រូវបានធ្វើឲ្យពេញខ្នាតបានឡើយ។ សូម្បីតែឥឡូវនេះ អ្នករាល់គ្នានៅតែមិនដឹងពីសារៈសំខាន់នៃកិច្ចការដែលកំពុងធ្វើនៅក្នុងចំណោមអ្នករាល់គ្នា។ នៅដំណាក់កាលនេះ អ្នករាល់គ្នានៅតែរក្សាក្ដីសង្ឃឹមនាពេលអនាគតរបស់ខ្លួននៅក្នុងដួងចិត្តដដែល ហើយស្ទាក់ស្ទើរ ក្នុងការបោះបង់ចោលក្ដីសង្ឃឹមនោះ។ គ្មាននរណាម្នាក់ខ្វល់ពីមូលហេតុដែលសព្វថ្ងៃនេះ ព្រះជាម្ចាស់ទើបតែជ្រើសរើសធ្វើការកែប្រែក្រុមមនុស្សដែលគ្មានតម្លៃបំផុតដូចអ្នករាល់គ្នានោះទេ។ តើអាចទេថា ទ្រង់បានធ្វើខុសក្នុងកិច្ចការនេះ? តើកិច្ចការនេះ ជាការធ្វេសប្រហែសមួយភ្លែតមែនទេ? តើហេតុអ្វីបានជាព្រះជាម្ចាស់ដែលតែងតែជ្រាបតាំងពីដើមរហូតមកហើយថាអ្នករាល់គ្នាជាកូនចៅរបស់ម៉ូអាប់ យាងចុះមកធ្វើការក្នុងចំណោមអ្នករាល់គ្នា យ៉ាងប្រាកដដូច្នេះ? តើរឿងនេះមិនដែលកើតឡើងចំពោះអ្នករាល់គ្នាទេឬ? តើព្រះជាម្ចាស់មិនដែលព្រះតម្រិះអំពីរឿងនេះទេឬនៅពេលធ្វើកិច្ចការរបស់ទ្រង់? តើទ្រង់ មានឥរិយាបថបែបក្រអឺតក្រទមមែនទេ? តើទ្រង់មិនបានដឹងតាំងពីដំបូងថា អ្នករាល់គ្នាជាពូជពង្សរបស់ម៉ូអាប់មែនទេ? តើអ្នករាល់គ្នាមិនចេះពិចារណាពីរឿងទាំងនេះទេឬ? តើសញ្ញាណរបស់អ្នករាល់គ្នាទៅណាអស់ហើយ? តើការរិះគិតហ្មត់ចត់របស់អ្នករាល់គ្នា វង្វេងអស់ហើយមែនទេ? តើភាពឆ្លាតវៃ និងប្រាជ្ញារបស់អ្នករាល់គ្នា ទៅណាបាត់ហើយ? តើពិតទេថា អ្នករាល់គ្នាមានឫកពាអធ្យាស្រ័យល្អ ដល់ថ្នាក់អ្នកមិនយកចិត្តទុកដាក់លើបញ្ហាតូចតាចមែនទេ?

ចិត្តរបស់អ្នករាល់គ្នាងាយញាប់ញ័របំផុតចំពោះរឿងរ៉ាវផ្សេងៗដូចជា ក្ដីសង្ឃឹមនាពេលអនាគត និងវាសនាផ្ទាល់ខ្លួន ប៉ុន្ដែចំពោះរឿងផ្សេងៗវិញ វាបែរជាស្ពឹក មិនសូវរវាងវៃ និងល្ងង់ខ្លៅមែនទែន។ តើអ្នករាល់គ្នាជឿលើអ្វីទៅនៅលើផែនដីនេះ? ក្ដីសង្ឃឹមនាពេលអនាគត? ឬក៏ព្រះជាម្ចាស់? តើអ្វីគ្រប់យ៉ាងដែលអ្នកជឿ មិនមែនជាទិសដៅដ៏ស្រស់ត្រកាលរបស់អ្នកទេឬអី? តើវាមិនមែនជាក្ដីសង្ឃឹមនាពេលអនាគតរបស់អ្នកទេឬអី? តើពេលនេះ អ្នកយល់ដឹងអំពីផ្លូវជីវិតបានប៉ុនណាហើយ? តើអ្នកទទួលបានប៉ុនណាហើយ? តើអ្នកគិតថា កិច្ចការដែលកំពុងធ្វើទៅលើពូជពង្សរបស់ម៉ូអាប់ឥឡូវនេះ ត្រូវបានធ្វើឡើងដើម្បីបំបាក់មុខអ្នករាល់គ្នាមែនទេ? តើកិច្ចការនេះ ត្រូវបានធ្វើឡើងដោយមានចេតនា បើកឲ្យឃើញភាពអាក្រក់របស់អ្នករាល់គ្នាមែនទេ? តើកិច្ចការនេះត្រូវបានធ្វើឡើងដោយមានបំណងធ្វើឲ្យអ្នករាល់គ្នាទទួលយកការវាយផ្ចាល រួចបោះអ្នករាល់គ្នាចូលក្នុងបឹងភ្លើងមែនទេ? ខ្ញុំមិនធ្លាប់មានបន្ទូលថា អ្នករាល់គ្នាមិនមានក្ដីសង្ឃឹមនាពេលអនាគតទេ ក៏រឹតតែមិនធ្លាប់មានបន្ទូលថា អ្នករាល់គ្នាត្រូវតែរងនូវការបំផ្លាញ ឬទទួលរងសេចក្ដីហិនវិនាសនោះដែរ។ តើខ្ញុំបានប្រកាសអំពីរឿងបែបនេះ ជាសាធារណៈមែនទេ? អ្នកនិយាយថា អ្នកគ្មានសង្ឃឹម ប៉ុន្ដែតើនេះមិនមែនជាការសន្និដ្ឋានដែលអ្នកបានធ្វើដោយខ្លួនឯងទេឬអី? តើនេះមិនមែនជាផលនៃផ្នត់គំនិតផ្ទាល់ខ្លួនរបស់អ្នកទេឬអី? តើការសន្និដ្ឋានផ្ទាល់ខ្លួនរបស់អ្នកយកជាការដែរឬទេ? ប្រសិនបើខ្ញុំមានបន្ទូលថា អ្នករាល់គ្នាមិនទទួលបានព្រះពរទេ នោះអ្នករាល់គ្នានឹងក្លាយជាកម្មវត្ថុនៃការបំផ្លាញជាប្រាកដ ហើយប្រសិនបើខ្ញុំមានបន្ទូលថា អ្នករាល់គ្នាទទួលបានព្រះពរ នោះអ្នករាល់គ្នានឹងមិនទទួលរងការបំផ្លាញជាដាច់ខាត។ ខ្ញុំគ្រាន់តែមានបន្ទូលថា អ្នករាល់គ្នាគឺជាពូជពង្សរបស់ម៉ូអាប់ ខ្ញុំមិនបានមានបន្ទូលថា អ្នករាល់គ្នានឹងត្រូវរងការបំផ្លាញនោះទេ។ ពូជពង្សរបស់ម៉ូអាប់គ្រាន់តែត្រូវបណ្ដាសា និងជាពូជនៃមនុស្សពុករលួយតែប៉ុណ្ណោះ។ អំពើបាបត្រូវបានលើកឡើងមុននេះរួចហើយ តើអ្នករាល់គ្នា មិនមែនសុទ្ធតែមានបាបគ្រប់គ្នាទេឬអី? តើមនុស្សមានបាបទាំងអស់មិនមែនសុទ្ធតែត្រូវបានសាតាំងធ្វើឲ្យពុករលួយទេឬអី? តើមនុស្សមានបាបទាំងអស់

មិនផ្ដើន និងបះបោរប្រឆាំងនឹងព្រះជាម្ចាស់ទេឬអី? តើអ្នកដែលផ្ដើនប្រឆាំងនឹងព្រះជាម្ចាស់ មិនត្រូវបណ្ដាសាទេឬអី? តើមនុស្សមានបាបទាំងអស់មិនមែនសុទ្ធតែត្រូវវិនាសទេឬអី? ចំពោះករណីនោះ ក្នុងចំណោមមនុស្សខាងសាច់ឈាម តើនរណាខ្លះអាចត្រូវបានសង្គ្រោះ? តើអ្នករាល់គ្នា អាចរស់រានរហូតមកដល់ថ្ងៃនេះបានយ៉ាងដូចម្ដេច? អ្នករាល់គ្នាបានដឹងក្ដីបែបអវិជ្ជមាន ព្រោះអ្នកជាពូជពង្សរបស់ម៉ូអាប់ តើអ្នករាល់គ្នាមិនត្រូវរាប់ជាមនុស្សដែលមានបាបនឹងគេដែរទេឬអី? តើអ្នករាល់គ្នារស់នៅរហូតដល់ថ្ងៃនេះ បានយ៉ាងដូចម្ដេច? នៅពេលនិយាយពីភាពគ្រប់លក្ខណ៍ អ្នករាល់គ្នារីករាយណាស់។ បន្ទាប់ពីឮថា អ្នករាល់គ្នាត្រូវតែឆ្លងកាត់នូវមហាទុក្ខវេទនា អ្នករាល់គ្នាបែរជាមានអារម្មណ៍ថា រឿងនេះធ្វើឲ្យអ្នករាល់គ្នា ទទួលបានព្រះពរកាន់តែច្រើនទៅវិញ។ អ្នករាល់គ្នាគិតថា អ្នករាល់គ្នាអាចក្លាយជាអ្នកឈ្នះ ក្រោយពេលឆ្លងផុតពីមហាទុក្ខវេទនា ហើយគិតលើសពីនេះទៅទៀតថា នេះជាព្រះពរដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ និងជាការលើកតម្កើងដ៏ខ្ពង់ខ្ពស់របស់ទ្រង់ចំពោះអ្នករាល់គ្នា។ នៅពេលនិយាយអំពីម៉ូអាប់ នោះចលាចលក៏កើតឡើងក្នុងចំណោមអ្នករាល់គ្នា មនុស្សទាំងចាស់ទាំងក្មេងមានអារម្មណ៍សោកសៅដែលមិនអាចពណ៌នាបានដូចគ្នា ហើយអ្នករាល់គ្នា មិនមានសេចក្ដីអំណរនៅក្នុងដួងចិត្តរបស់ខ្លួនទាល់តែសោះ អ្នករាល់គ្នាក៏សោកស្ដាយដែលបានកើតមក។ អ្នករាល់គ្នាមិនយល់ពីសារៈសំខាន់នៃកិច្ចការនៅក្នុងដំណាក់កាល ដែលកំពុងធ្វើទៅលើពូជពង្សរបស់ម៉ូអាប់នេះទេ អ្នករាល់គ្នាដឹងតែស្វះស្វែងរកមុខតំណែងខ្ពស់ៗតែប៉ុណ្ណោះ ហើយនៅពេលណា អ្នករាល់គ្នាដឹងថាឥតមានសង្ឃឹមទេ អ្នករាល់គ្នាក៏ត្រឡប់ទៅរកជំនឿចាស់វិញ។ នៅពេលនិយាយអំពីភាពគ្រប់លក្ខណ៍ និងទិសដៅអនាគត អ្នករាល់គ្នាមានអារម្មណ៍រីករាយ អ្នករាល់គ្នាដាក់ជំនឿរបស់ខ្លួនឯងលើព្រះជាម្ចាស់ ដើម្បីទទួលបានព្រះពរ និងដើម្បីឲ្យខ្លួនឯងអាចមានទិសដៅដ៏ល្អមួយ។ ឥឡូវនេះ មនុស្សមួយចំនួនមានអារម្មណ៍ភិតភ័យដោយសារតែឋានៈរបស់ពួកគេ។ ដោយសារតែពួកគេពុំសូវគេឲ្យតម្លៃ និងឋានៈតូចទាប ពួកគេមិនចង់ស្វះស្វែងរកឲ្យបានភាពគ្រប់លក្ខណ៍ទេ។ កាលពីដំបូង ភាព

គ្រប់លក្ខណ៍ត្រូវបានលើកមកនិយាយ ហើយបន្ទាប់មកក៏មានការលើកឡើងអំពីពូជពង្សរបស់ម៉ូអាប់ ដូច្នេះមនុស្ស ក៏បានបដិសេធផ្លូវនៃភាពគ្រប់លក្ខណ៍ដែលបានលើកឡើងពីមុន។ នេះក៏ព្រោះតែតាំងពីដើមដល់ចប់ អ្នករាល់គ្នាមិនដែលដឹងពីសារៈសំខាន់នៃកិច្ចការនេះទេ ហើយអ្នករាល់គ្នាក៏មិនខ្វល់ពីសារៈសំខាន់របស់វាដែរ។ អ្នករាល់គ្នាពុំមានកេរ្តិ៍ឈ្មោះនឹងគេ ហើយមិនអាចស៊ូទ្រាំបាន សូម្បីតែការរំខានដ៏តិចតួចបំផុត។ នៅពេលអ្នកយល់ថា ឋានៈខ្លួនឯងទាបខ្លាំងពេក អ្នកក្លាយជាអគតិ ហើយបាត់បង់ទំនុកចិត្តក្នុងការស្វះស្វែងរកបន្តទៀត។ មនុស្សគ្រាន់តែចាត់ទុកការទទួលបានព្រះគុណ និងការរីករាយក្នុងសេចក្តីសុខសាន្ត ជានិមិត្តរូបនៃជំនឿប៉ុណ្ណោះ ហើយគេយល់ថា ការស្វះស្វែងរកព្រះពរទើបជាមូលដ្ឋានសម្រាប់ជំនឿរបស់ពួកគេចំពោះព្រះជាម្ចាស់។ មានមនុស្សតិចតួចណាស់ដែលប្រឹងប្រែងស្គាល់ព្រះជាម្ចាស់ ឬស្វះស្វែងរកការផ្លាស់ប្ដូរនិស្ស័យរបស់ពួកគេ។ ក្នុងជំនឿរបស់ពួកគេ មនុស្សប្រឹងប្រែងធ្វើឲ្យព្រះជាម្ចាស់ផ្ដល់ឲ្យពួកគេនូវទិសដៅដ៏សមរម្យមួយ ព្រមទាំងព្រះគុណទាំងអស់ដែលពួកគេត្រូវការក្នុងជំនឿរបស់ពួកគេ ដើម្បីធ្វើឲ្យទ្រង់ក្លាយជាអ្នកបម្រើរបស់ពួកគេ ដើម្បីឲ្យទ្រង់រក្សាសម្ពន្ធភាពដែលប្រកបដោយភាពសុខសាន្ត និងមេត្រីភាពជាមួយនឹងពួកគេ ហេតុដូច្នេះ មិនថាពេលណានោះទេ ទំនាស់រវាងព្រះជាម្ចាស់ និងពួកគេ នឹងមិនមានជាដរាប។ មានន័យថា ជំនឿរបស់ពួកគេលើព្រះជាម្ចាស់ ទាមទារឲ្យទ្រង់សន្យាធ្វើការបំពេញតាមតម្រូវការទាំងអស់របស់ពួកគេ និងផ្តល់ឲ្យពួកគេនូវអ្វីៗ ដែលពួកគេអធិស្ឋាន សុំជាថ្នូរនឹងការរក្សាព្រះបន្ទូលដែលពួកគេបានអានក្នុងព្រះគម្ពីរថា «ខ្ញុំនឹងស្ដាប់ការអធិស្ឋានទាំងអស់របស់អ្នករាល់គ្នា»។ ពួកគេរំពឹងថា ព្រះជាម្ចាស់នឹងមិនជំនុំជម្រះ ឬដោះស្រាយជាមួយនរណាម្នាក់ឡើយ ដ្បិតទ្រង់គឺជាព្រះយេស៊ូវដ៏ជាព្រះអង្គសង្គ្រោះ ប្រកបដោយសេចក្ដីមេត្តាករុណា ជាព្រះដែលរក្សាទំនាក់ទំនងល្អជាមួយមនុស្សគ្រប់ពេល និងគ្រប់ទីកន្លែងរហូតមក។ នេះជារបៀបដែលមនុស្សជឿលើព្រះជាម្ចាស់៖ ពួកគេធ្វើការទាមទារពីព្រះជាម្ចាស់ ដោយមិនចេះខ្មាសអៀនតែម្ដង ដោយជឿថា មិនថាពួកគេបះបោរ ឬស្ដាប់បង្គាប់នោះទេ ទ្រង់នឹងនៅតែផ្ដល់អ្វី

គ្រប់យ៉ាងឲ្យពួកគេទាំងងងឹតងងល់។ ពួកគេគ្រាន់តែ «ទារបំណុល» ជាបន្តពីព្រះជាម្ចាស់ដោយជឿថា ទ្រង់ត្រូវតែ «បង់សង» ពួកគេដោយគ្មានការតវ៉ា ហើយលើសពីនេះទៅទៀត គឺទ្រង់ត្រូវបង់ទ្វេដង។ ពួកគេគិតថា ទោះបីជាព្រះជាម្ចាស់មិនបានទទួលអ្វីពីពួកគេក៏ដោយ ក៏ពួកគេនៅតែអាចបញ្ជាទ្រង់ដោយឧបាយបានដែរ ហើយទ្រង់មិនអាចចាត់ចែងមនុស្សយ៉ាងហ្មត់ចត់តាមអំពើចិត្តបានដែរ និងកាន់តែមិនអាចបើកសម្ដែងឲ្យមនុស្សស្គាល់ប្រាជ្ញាញាណ និងនិស្ស័យដ៏សុចរិតរបស់ទ្រង់ ដែលត្រូវបានលាក់កំបាំងអស់ជាច្រើនឆ្នាំមកហើយ នៅពេលណាដែលទ្រង់ចង់ឲ្យគេដឹង និងដោយគ្មានការអនុញ្ញាត ពីពួកគេបានឡើយ។ ពួកគេគ្រាន់តែលន់តួបាបរបស់ពួកគេចំពោះព្រះជាម្ចាស់ដោយជឿថា ព្រះជាម្ចាស់នឹងនៅតែលើកលែងទោសបាបឲ្យពួកគេជឿថា ទ្រង់នឹងមិនធុញធុញទ្រាន់នឹងការធ្វើដូច្នោះទេ ហើយជឿថា ការនេះនឹងបន្តទៅបែបនេះជារៀងរហូត។ ពួកគេនៅតែបញ្ជាព្រះជាម្ចាស់ទាំងបង្ខំដោយជឿថា ទ្រង់នឹងនៅតែស្ដាប់តាមពួកគេ ព្រោះក្នុងព្រះគម្ពីរបានចែងថា ព្រះជាម្ចាស់មិនបានយាងមកដើម្បីឲ្យមនុស្សលោកបម្រើទ្រង់ទេ ប៉ុន្តែទ្រង់បានយាងមកដើម្បីបម្រើពួកគេវិញ ហើយទ្រង់គង់ទីនេះ ដើម្បីធ្វើជាអ្នកបម្រើរបស់ពួកគេ។ តើអ្នករាល់គ្នាមិនមែនជឿបែបនេះរហូតមកទេមែនទេ? នៅរាល់ពេលដែលអ្នករាល់គ្នាមិនអាចទទួលបានអ្វីមួយពីព្រះជាម្ចាស់ អ្នករាល់គ្នាចង់រត់ចេញពីទ្រង់នៅពេលអ្នករាល់គ្នាមិនយល់ពីអ្វីមួយ អ្នករាល់គ្នាក៏អាក់អន់ស្រពន់ចិត្តយ៉ាងខ្លាំង ថែមទាំងហ៊ានដល់ថ្នាក់និយាយនូវ សម្ដីត្រគោះបក់បោកសព្វបែបយ៉ាង បំពានទ្រង់ផង។ អ្នករាល់គ្នាមិនព្រមឲ្យព្រះជាម្ចាស់បង្ហាញនូវប្រាជ្ញាញាណ និងភាពអស្ចារ្យរបស់ទ្រង់ឲ្យបានពេញលេញ ដោយផ្ទាល់ព្រះអង្គសោះ ផ្ទុយទៅវិញ អ្នករាល់គ្នាចង់តែសប្បាយនឹងភាពស្រាកស្រាន្ត និងភាពស្រណុកសុខស្រួលបណ្ដោះអាសន្នប៉ុណ្ណោះ។ រហូតមកដល់ពេលនេះ អាកប្បកិរិយានៅក្នុងជំនឿរបស់អ្នករាល់គ្នាចំពោះព្រះជាម្ចាស់ មានត្រឹមតែជាទស្សនៈចាស់គំរិលដដែល។ ប្រសិនបើព្រះជាម្ចាស់ បង្ហាញឲ្យអ្នករាល់គ្នាឃើញឫទ្ធានុភាពតែបន្តិចអ្នករាល់គ្នាមិនសប្បាយចិត្តឡើយ។ តើពេលនេះអ្នករាល់គ្នាឃើញច្បាស់ទេថា ឋានៈ

របស់អ្នករាល់គ្នាធំប៉ុនណា? កុំស្មានថា អ្នករាល់គ្នាសុទ្ធសឹងតែស្មោះត្រង់ចំពោះព្រះជាម្ចាស់នៅពេលដែលការពិតទស្សនៈដ៏ចាស់គំរិលរបស់អ្នករាល់គ្នាមិនបានផ្លាស់ប្តូរសោះនោះ។ នៅពេលគ្មានរឿងអ្វីកើតមានដល់អ្នក អ្នកជឿថាអ្វីគ្រប់យ៉ាងដំណើរការទៅយ៉ាងរលូន ហើយសេចក្តីស្រលាញ់របស់អ្នកចំពោះព្រះជាម្ចាស់ឈានដល់ចំណុចមួយដ៏ខ្ពស់។ នៅពេលរឿងតូចតាចអ្វីមួយកើតឡើងចំពោះអ្នក អ្នកក៏ធ្លាក់ចូលទៅក្នុងស្ថានឃុំព្រលឹង។ តើនេះឬជាការស្មោះត្រង់ចំពោះព្រះជាម្ចាស់?

ប្រសិនបើដំណាក់កាលចុងក្រោយនៃកិច្ចការនៃការយកឈ្នះ ត្រូវចាប់ផ្តើមនៅក្នុងប្រទេសអ៊ីស្រាអែល នោះកិច្ចការនៃការយកឈ្នះនេះនឹងគ្មានន័យទេ។ កិច្ចការនេះមានសារៈសំខាន់បំផុត ពេលត្រូវបានធ្វើនៅក្នុងប្រទេសចិន និងពេលដែលវាធ្វើលើមនុស្សដូចអ្នករាល់គ្នា។ អ្នករាល់គ្នា គឺជាមនុស្សអន់ជាទីបំផុត ជាមនុស្សដែលមានឋានៈតូចទាបបំផុត អ្នករាល់គ្នាគឺជាមនុស្សដែលមានវណ្ណៈតូចទាបបំផុតក្នុងសង្គមនេះ ហើយអ្នកគឺជាមនុស្សដែលស្គាល់ព្រះជាម្ចាស់បានតិចបំផុតតាំងពីដំបូង។ អ្នករាល់គ្នាគឺជាមនុស្សដែលបានវង្វេងចេញឆ្ងាយពីព្រះជាម្ចាស់ជាងគេ ហើយជាមនុស្សដែលរងទុក្ខវេទនាធ្ងន់ធ្ងរបំផុត។ ដោយសារតែកិច្ចការក្នុងដំណាក់កាលនេះ គឺសម្រាប់តែជាប្រយោជន៍ដល់ការធ្វើចម្បាំងប៉ុណ្ណោះ ដែលអ្នករាល់គ្នាទទួលការជ្រើសរើសធ្វើជាស្នារបន្ទាល់នាថ្ងៃអនាគត តើវាមិនស័ក្តិសមបំផុតទេឬអី? ប្រសិនបើជំហានដំបូងនៃកិច្ចការនៃការយកឈ្នះនេះ មិនត្រូវបានធ្វើលើអ្នករាល់គ្នាទេ នោះកិច្ចការនៃការយកឈ្នះដែលនឹងត្រូវមកដល់ មុខជាពិបាកឈានទៅមុខ ដ្បិតកិច្ចការនៃការយកឈ្នះក្រោយៗមកទៀតនឹងសម្រេចបាននូវលទ្ធផល ដោយផ្អែកលើការពិតនៃកិច្ចការដែលកំពុងធ្វើនាពេលសព្វថ្ងៃនេះ។ កិច្ចការនៃការយកឈ្នះនាពេលបច្ចុប្បន្ននេះ គឺគ្រាន់តែជាការចាប់ផ្តើមនៃកិច្ចការនៃការយកឈ្នះទាំងមូលប៉ុណ្ណោះ។ អ្នករាល់គ្នាគឺជាក្រុមមនុស្សដំបូងដែលត្រូវបានយកឈ្នះ។ អ្នករាល់គ្នាគឺជាតំណាងមនុស្សជាតិទាំងអស់គ្នាដែលនឹងត្រូវយកឈ្នះ។ មនុស្សដែលពិតជាមានចំណេះដឹង គេនឹងឃើញថា កិច្ចការទាំងអស់ដែលព្រះជាម្ចាស់ធ្វើនាពេលសព្វថ្ងៃនេះ គឺអស្ចារ្យណាស់ ហើយទ្រង់មិន

ត្រឹមតែធ្វើឲ្យមនុស្សស្គាល់ចរិតបះបោររបស់ខ្លួនឯងផ្ទាល់ប៉ុណ្ណោះទេ តែថែមទាំងបើកសម្ដែងឲ្យគេស្គាល់ឋានៈរបស់ខ្លួនឯងទៀតផង។ គោលបំណង និងអត្ថន័យនៃព្រះបន្ទូលរបស់ទ្រង់ គឺមិនមែនដើម្បីបង្ខូចទឹកចិត្តមនុស្ស ហើយក៏មិនមែនដើម្បីផ្ដួលរំលំពួកគេដែរ។ តែវាគឺសម្រាប់ឲ្យពួកគេទទួលបានការបំភ្លឺ និងសេចក្ដីសង្គ្រោះតាមរយៈព្រះបន្ទូលរបស់ទ្រង់។ វាគឺដើម្បីដាស់ស្មារតីរបស់ពួកគេដោយប្រើព្រះបន្ទូលរបស់ទ្រង់។ ចាប់តាំងពីពេលបង្កើតពិភពលោកមក មនុស្សលោកបានរស់នៅក្រោមដែនត្រួតត្រារបស់សាតាំង ទាំងមិនដឹង និងមិនជឿថា មានព្រះជាម្ចាស់នោះទេ។ ការដែលមនុស្សទាំងអស់នេះអាចត្រូវបានបញ្ចូលទៅក្នុងសេចក្ដីសង្គ្រោះដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ និងអាចត្រូវបានព្រះអង្គលើកតម្កើងយ៉ាងអស្ចារ្យ គឺពិតជាបង្ហាញឲ្យឃើញនូវសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ប្រាកដណាស់។ អស់អ្នកដែលយល់ដឹងពិតប្រាកដ គេនឹងជឿរឿងនេះ។ ចុះចំណែកអស់អ្នកដែលមិនមានចំណេះដឹងបែបនេះវិញ? ពួកគេនឹងនិយាយថា «អា៎! ព្រះជាម្ចាស់មានបន្ទូលថា យើងជាពូជពង្សរបស់ម៉ូអាប់ ទ្រង់មានព្រះបន្ទូលបែបនេះ ដោយព្រះឱស្ឋរបស់ទ្រង់ផ្ទាល់។ តើយើងនៅតែអាចទទួលបានលទ្ធផលល្អដែរឬទេ? តើនរណាឲ្យយើងធ្វើជាពូជពង្សរបស់ម៉ូអាប់? តើនរណាឲ្យយើងរឹងទទឹងនឹងទ្រង់ខ្លាំងដល់ម្ល៉ឹងកាលពីមុន? ព្រះជាម្ចាស់បានយាងមកផ្ដន្ទាទោសយើង។ តើអ្នកមើលមិនឃើញពីវិធីដែលទ្រង់តែងតែកាត់ទោសយើងតាំងពីដំបូងមកម្ល៉េះទេឬអី? ព្រោះតែយើងបានរឹងទទឹងនឹងព្រះជាម្ចាស់ គឺយើងគួរតែត្រូវបានវាយផ្ចាលដោយវិធីនេះ»។ តើពាក្យទាំងនេះត្រឹមត្រូវដែរឬទេ? សព្វថ្ងៃនេះ ព្រះជាម្ចាស់ជំនុំជម្រះអ្នករាល់គ្នា វាយផ្ចាលអ្នករាល់គ្នា និងផ្ដន្ទាទោសអ្នករាល់គ្នាយ៉ាងធ្ងន់ធ្ងរ ប៉ុន្ដែអ្នកត្រូវតែដឹងថា ប្រយោជន៍នៃការផ្ដន្ទាទោសអ្នកនេះ គឺដើម្បីឲ្យអ្នកស្គាល់ខ្លួនឯង។ ទ្រង់ផ្ដន្ទាទោស ដាក់បណ្ដាសា កាត់ទោស និងវាយផ្ចាល ដើម្បីឲ្យអ្នកអាចស្គាល់ខ្លួនឯង ដើម្បីឲ្យនិស្ស័យរបស់អ្នកអាចផ្លាស់ប្ដូរបាន ហើយលើសពីនេះទៅទៀត គឺដើម្បីឲ្យអ្នកអាចស្គាល់តម្លៃរបស់ខ្លួន និងមើលឃើញថា សកម្មភាពទាំងអស់របស់ព្រះជាម្ចាស់ គឺសុទ្ធតែសុចរិត ហើយស្របទៅនឹងនិស្ស័យរបស់ទ្រង់ និងតម្រូវការនៃ

កិច្ចការរបស់ទ្រង់ ឃើញថា ទ្រង់ធ្វើការស្របតាមផែនការរបស់ទ្រង់ ដើម្បីសង្គ្រោះមនុស្សលោក ហើយឃើញថាទ្រង់គឺជាព្រះដ៏សុចរិតដែលស្រឡាញ់ សង្គ្រោះ ជំនុំជម្រះ និងវាយផ្ចាលលើមនុស្សលោក។ ប្រសិនបើអ្នកគ្រាន់តែដឹងថា អ្នកមានឋានៈទាប អ្នកពុករលួយ និងមិនស្ដាប់បង្គាប់ តែមិនដឹងថា ព្រះជាម្ចាស់ចង់សម្ដែងឲ្យអ្នកឃើញច្បាស់នូវសេចក្តីសង្គ្រោះរបស់ទ្រង់តាមរយៈការជំនុំជម្រះ និងការវាយផ្ចាល់ដែលទ្រង់ធ្វើលើអ្នករាល់គ្នានាពេលសព្វថ្ងៃនេះទេ នោះអ្នកគ្មានផ្លូវ ទទួលបានបទពិសោធឡើយ ហើយរឹតតែមិនអាចបន្តទៅមុខទៀតបានឡើយ។ ព្រះជាម្ចាស់មិនបានយាងមកដើម្បីសម្លាប់ ឬបំផ្លាញនោះទេ តែដើម្បីជំនុំជម្រះ ដាក់បណ្ដាសា វាយផ្ចាល និងសង្គ្រោះ។ មុនពេលដែលព្រះជាម្ចាស់បើកសម្ដែងលទ្ធផល សម្រាប់ជំពូកមនុស្សនីមួយៗ កិច្ចការរបស់ទ្រង់នៅលើផែនដី គឺនៅតែធ្វើជាប្រយោជន៍ដល់សេចក្តីសង្គ្រោះដដែល ទាល់តែផែនការរយៈពេល៦០០០ឆ្នាំរបស់ទ្រង់ត្រូវដល់ទីបញ្ចប់ គោលបំណងនៃកិច្ចការនេះ គឺគ្មានអ្វីក្រៅតែពីដើម្បីធ្វើឲ្យអ្នកដែលស្រឡាញ់ទ្រង់បានពេញខ្នាត និងដើម្បីនាំពួកគេឲ្យចុះចូល ក្រោមការត្រួតត្រារបស់ទ្រង់ទាំងស្រុងនោះទេ។ មិនថាព្រះជាម្ចាស់ជួយសង្គ្រោះមនុស្សតាមវិធីណាក៏ដោយ កិច្ចការទាំងអស់នោះត្រូវបានធ្វើឡើងដោយបំបែកពួកគេចេញពីនិស្ស័យសាតាំងចាស់របស់ពួកគេ ពោលគឺ ទ្រង់សង្គ្រោះពួកគេដោយឲ្យពួកគេស្វះស្វែងរកជីវិត។ ប្រសិនបើពួកគេមិនធ្វើដូច្នោះទេ នោះពួកគេនឹងគ្មានផ្លូវទទួលយកសេចក្តីសង្គ្រោះរបស់ព្រះជាម្ចាស់ឡើយ។ សេចក្តីសង្គ្រោះ គឺជាកិច្ចការរបស់ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ រីឯការស្វះស្វែងរកជីវិត គឺជាកិច្ចការដែលមនុស្សលោកត្រូវតែធ្វើ ដើម្បីទទួលយកសេចក្តីសង្គ្រោះ។ នៅក្នុងក្រសែភ្នែករបស់មនុស្សលោក សេចក្តីសង្គ្រោះ គឺជាសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ហើយសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ មិនអាចជាការវាយផ្ចាល ការជំនុំជម្រះ និងការដាក់បណ្ដាសានោះទេ។ សេចក្តីសង្គ្រោះត្រូវតែមានសេចក្តីស្រឡាញ់ សេចក្តីមេត្តាករុណា ហើយលើសពីនេះទៅទៀតគឺ ព្រះបន្ទូលលួងលោម ព្រមទាំងព្រះពរដែលគ្មានព្រំដែន ដែលព្រះជាម្ចាស់ត្រូវប្រទានឲ្យ។ មនុស្សលោកជឿថា នៅពេលព្រះជាម្ចាស់

ជួយសង្គ្រោះមនុស្សលោក ទ្រង់ធ្វើដូច្នោះតាមរយៈការបណ្ដាលចិត្តពួកគេដោយប្រើព្រះពរ និងព្រះគុណរបស់ទ្រង់ ដើម្បីឲ្យពួកគេអាចថ្វាយដួងចិត្តរបស់ពួកគេដល់ព្រះអង្គ។ និយាយឲ្យចំគឺថា ការដែលទ្រង់លូកព្រះហស្តទៅពាល់មនុស្សលោក នោះហើយគឺជាការសង្គ្រោះរបស់ទ្រង់ចំពោះពួកគេ។ សេចក្ដីសង្គ្រោះប្រភេទនេះ ត្រូវបានធ្វើឡើងដោយការដោះដូរគ្នា។ ទាល់តែពេលព្រះជាម្ចាស់ផ្ដល់ឲ្យពួកគេច្រើនរយដង ទើបមនុស្សលោកព្រមចុះចូលចំពោះព្រះនាមព្រះជាម្ចាស់ ហើយព្យាយាមធ្វើឲ្យបានល្អសម្រាប់ទ្រង់ និងថ្វាយសិរីល្អដល់ទ្រង់។ នេះមិនមែនជាអ្វីដែលព្រះជាម្ចាស់ចង់បានសម្រាប់មនុស្សជាតិឡើយ។ ព្រះជាម្ចាស់យាងមកធ្វើការនៅលើផែនដី ដើម្បីជួយសង្គ្រោះមនុស្សលោកដែលពុករលួយ ឥតមានពាក្យមុសានៅក្នុងចេតនានេះទេ។ ប្រសិនបើមានមែន ម្ល៉េះទ្រង់ច្បាស់ជាមិនយាងមកដើម្បីធ្វើកិច្ចការរបស់ទ្រង់ដោយផ្ទាល់នោះឡើយ។ កាលពីមុន មធ្យោបាយនៃសេចក្ដីសង្គ្រោះរបស់ទ្រង់រួមមានទាំងការបង្ហាញនូវសេចក្ដីស្រឡាញ់ និងក្ដីមេត្តាករុណាបំផុត រហូតដល់ថ្នាក់ទ្រង់បានប្រគល់របស់ទ្រង់គ្រប់យ៉ាងទៅឲ្យសាតាំង ជាថ្នូរនឹងមនុស្សជាតិទាំងមូល។ បច្ចុប្បន្ននេះ មិនដូចអតីតកាលទេ៖ សេចក្ដីសង្គ្រោះដែលត្រូវផ្ដល់ឲ្យអ្នករាល់គ្នា សព្វថ្ងៃនេះកើតឡើងនៅគ្រាចុងក្រោយ ក្នុងអំឡុងពេលបែងចែកមនុស្សម្នាក់ៗទៅតាមជំពូក។ មធ្យោបាយក្នុងការសង្គ្រោះអ្នករាល់គ្នា មិនមែនជាសេចក្ដីស្រឡាញ់ ឬក្ដីមេត្តាករុណាទៀតទេ តែជាការវាយផ្ចាល និងការជំនុំជម្រះ ដើម្បីឲ្យមនុស្សលោកអាចត្រូវបានសង្គ្រោះទាំងស្រុងថែមទៀត។ ដូច្នេះ គ្រប់យ៉ាងដែលអ្នករាល់គ្នាទទួលបាន គឺជាការវាយផ្ចាល ការជំនុំជម្រះ និងការវាយផ្ចួលដោយឥតមេត្តា ប៉ុន្តែចូរដឹងថា៖ នៅក្នុងការវាយផ្ចួលដ៏កាចសាហាវនេះ គឺឥតមានការដាក់ទណ្ឌកម្មសូម្បីតែបន្តិចឡើយ។ មិនខ្វល់ថា ព្រះបន្ទូលរបស់ខ្ញុំគ្រោតគ្រាតយ៉ាងណានោះទេ ប៉ុន្តែអ្វីដែលកើតមានដល់អ្នករាល់គ្នា គ្រាន់តែជាព្រះបន្ទូលបន្តិចបន្តួច ដែលហាក់ដូចជាសាហាវមែនទែនចំពោះអ្នករាល់គ្នា ហើយមិនថាខ្ញុំខឹងក្រោធយ៉ាងណានោះទេ អ្វីៗដែលធ្លាក់ស្រោចលើអ្នករាល់គ្នាក៏នៅតែជាពាក្យប្រៀនប្រដៅ ហើយខ្ញុំគ្មានបំណងធ្វើបាបអ្នករាល់គ្នា ឬ

សម្លាប់អ្នករាល់គ្នានោះទេ។ តើទាំងអស់នេះ មិនមែនជាការពិតទេឬអី? ចូរដឹងថា សព្វថ្ងៃនេះ មិនថាការជំនុំជម្រះដ៏សុចរិត ឬជាការបន្សុទ្ធ និងការវាយផ្ចាលដ៏កាចសាហាវនោះទេ គ្រប់យ៉ាងគឺសុទ្ធតែដើម្បី សេចក្ដីសង្គ្រោះ។ មិនខ្វល់ថា សព្វថ្ងៃនេះ មនុស្សម្នាក់ៗដែលត្រូវបានចាត់ថ្នាក់ទៅតាមជំពូកឬលំដាប់ ត្រូវបានលាតត្រដាងអស់ឬអត់ក៏ដោយ គោលបំណងនៃព្រះបន្ទូល និងកិច្ចការទាំងអស់របស់ព្រះជាម្ចាស់ គឺជួយសង្គ្រោះមនុស្សដែលស្រឡាញ់ព្រះអង្គពិតប្រាកដ។ ការកាត់ទោសដ៏សុចរិតត្រូវបាននាំមក ដើម្បីញែកមនុស្សលោកជាបរិសុទ្ធ ឯការបន្សុទ្ធដ៏កាចសាហាវ ត្រូវបានធ្វើឡើងដើម្បីសម្អាតពួកគេ។ ព្រះបន្ទូលដ៏គ្រោតគ្រាត ឬការវាយផ្ចាល គឺសុទ្ធតែត្រូវបានធ្វើឡើងដើម្បីបន្សុទ្ធ និងសម្រាប់ជាប្រយោជន៍ដល់សេចក្ដីសង្គ្រោះ។ ដូច្នេះ វិធីសាស្ត្រអនុវត្តសេចក្ដីសង្គ្រោះសព្វថ្ងៃនេះ គឺមិនដូចកាលពីអតីតកាលទេ។ សព្វថ្ងៃនេះ សេចក្ដីសង្គ្រោះត្រូវបាននាំមកឲ្យអ្នករាល់គ្នា តាមរយៈការជំនុំជម្រះដ៏សុចរិត ហើយនេះគឺជាឧបករណ៍ដ៏ល្អសម្រាប់បែកចែកអ្នករាល់គ្នាម្នាក់ៗទៅតាមជំពូក។ លើសពីនេះទៅទៀត ការវាយប្រដៅដែលគ្មានមេត្តា ដើរតួជាសេចក្ដីសង្គ្រោះដ៏ល្អបំផុតសម្រាប់អ្នករាល់គ្នា ហើយតើអ្នករាល់គ្នាមានអ្វីត្រូវនិយាយនៅចំពោះមុខការវាយផ្ចាល និងការជំនុំជម្រះបែបនេះ? តើអ្នករាល់គ្នាមិនមែនរីករាយនឹងសេចក្ដីសង្គ្រោះតាំងពីដើមរហូតដល់ចប់ទេឬអី? អ្នករាល់គ្នាបានឃើញព្រះជាម្ចាស់ចាប់បដិសន្ធិ និងបានដឹងពីសព្វានុភាព និងប្រាជ្ញារបស់ទ្រង់។ បន្ថែមពីលើនេះ អ្នកបានឆ្លងកាត់ការវាយផ្ចាល និងការលត់ដំម្ដងហើយម្ដងទៀតដែរ។ យ៉ាងណាមិញ តើអ្នករាល់គ្នាមិនបានទទួលព្រះគុណដ៏ខ្ពស់បំផុតដែរទេឬអី? តើព្រះពររបស់អ្នករាល់គ្នា មិនប្រសើរជាងព្រះពររបស់អ្នកដទៃទេឬអី? ព្រះគុណរបស់អ្នករាល់គ្នា គឺច្រើនជាងសិរីល្អ និងភោគទ្រព្យដែលព្រះបាទសាឡូម៉ូនមានទៅទៀត! ចូរគិតមើលទៅថា៖ ប្រសិនបើខ្ញុំមានបំណងយាងមកផ្ដន្ទាទោស និងដាក់ទោសអ្នករាល់គ្នា មិនមែនមកសង្គ្រោះអ្នករាល់គ្នាមែននោះ តើអាយុអ្នករាល់គ្នាអាចនៅយូរដល់ម៉្លឹងទេ? តើអ្នករាល់គ្នាដែលជាមនុស្សខាងសាច់ឈាមពេញដោយអំពើបាប អាចរស់រានរហូតមកដល់សព្វថ្ងៃនេះដែរ

ឬទេ? ប្រសិនបើគោលដៅរបស់ខ្ញុំ គឺដើម្បីតែដាក់ទោសអ្នករាល់គ្នា ចុះហេតុអ្វីបានជាខ្ញុំយកកំណើតជាសាច់ឈាម និងចាប់ផ្ដើមគ្រោងការធំដល់ម្លឹង? តើការដាក់ទោសអ្នករាល់គ្នាដែលជាមនុស្សធម្មតា មិនអាចធ្វើទៅបានដោយគ្រាន់តែបញ្ចេញព្រះបន្ទូលតែមួយម៉ាត់ទេឬអី? តើខ្ញុំនឹងនៅតែត្រូវបំផ្លាញអ្នករាល់គ្នាទៀត បន្ទាប់ពីផ្ដន្ទាទោសអ្នករាល់គ្នាតាមបំណងហើយមែនទេ? តើអ្នករាល់គ្នានៅតែមិនជឿព្រះបន្ទូលរបស់ខ្ញុំនេះទៀតឬអី? តើខ្ញុំអាចសង្គ្រោះមនុស្សលោកបានតែតាមរយៈសេចក្ដីស្រឡាញ់ និងមេត្តាករុណាទេឬអី? ឬមួយក៏ខ្ញុំអាចប្រើតែការជាប់ឆ្កាងទេទើបសង្គ្រោះមនុស្សលោកបាន? តើនិស្ស័យសុចរិតរបស់ខ្ញុំ មិនអំណោយផលដល់ការធ្វើឲ្យមនុស្សលោកស្ដាប់បង្គាប់ទាំងស្រុងទេឬអី? តើនិស្ស័យសុចរិតនេះមិនអាចសង្គ្រោះមនុស្សលោកបានទាំងស្រុងទេឬអី?

ថ្វីបើព្រះបន្ទូលរបស់ខ្ញុំ ប្រហែលជាតឹងតែងក៏ពិតមែន ប៉ុន្តែព្រះបន្ទូលទាំងអស់នោះត្រូវបានថ្លែងដើម្បីសង្គ្រោះមនុស្សលោក ព្រោះខ្ញុំកំពុងថ្លែងត្រឹមព្រះបន្ទូលតែប៉ុណ្ណោះ មិនមែនកំពុងដាក់ទណ្ឌកម្មសាច់ឈាមរបស់មនុស្សលោកទេ ព្រះបន្ទូលទាំងនេះធ្វើឲ្យមនុស្សលោករស់នៅក្នុងពន្លឺ ដឹងថាមានពន្លឺ ដឹងថាពន្លឺនោះមានតម្លៃ ហើយរឹតតែអស្ចារ្យទៀតនោះ គឺការដឹងថា ព្រះបន្ទូលទាំងនេះផ្ដល់ប្រយោជន៍ខ្លាំងយ៉ាងណាដល់ពួកគេ ព្រមទាំងដឹងទៀតថា ព្រះជាម្ចាស់ជាសេចក្ដីសង្គ្រោះ។ ថ្វីបើខ្ញុំបានថ្លែងព្រះបន្ទូលជាច្រើនអំពីការវាយផ្ចាល និងការកាត់ទោសក៏ពិតមែន ប៉ុន្តែអ្វីដែលបានបង្ហាញមកនេះ នៅមិនទាន់កើតឡើងចំពោះអ្នករាល់គ្នាមែនទែនទេ។ ខ្ញុំមកបំពេញកិច្ចការរបស់ខ្ញុំ និងសម្ដែងព្រះបន្ទូលរបស់ខ្ញុំ ហើយថ្វីបើព្រះបន្ទូលរបស់ខ្ញុំប្រហែលជាតឹងរ៉ឹងក៏ពិតមែន ប៉ុន្តែព្រះបន្ទូលទាំងអស់នោះត្រូវបានថ្លែងចេញ ជាការជំនុំជម្រះទង្វើពុករលួយ និងការបះបោររបស់អ្នករាល់គ្នា។ គោលបំណងនៃទង្វើដែលខ្ញុំធ្វើបែបនេះ នៅតែដើម្បីសង្គ្រោះមនុស្សលោកពីដែនត្រួតត្រារបស់សាតាំង ខ្ញុំកំពុងប្រើព្រះបន្ទូលរបស់ខ្ញុំដើម្បីសង្គ្រោះមនុស្សលោក។ គោលបំណងរបស់ខ្ញុំ មិនមែនជាការធ្វើបាបមនុស្សលោក ដោយប្រើព្រះបន្ទូលរបស់ខ្ញុំទេ។ ព្រះបន្ទូលរបស់ខ្ញុំតឹងតែង

គឺដើម្បីសម្រេចបានលទ្ធផលនៅក្នុងកិច្ចការរបស់ខ្ញុំ។ មានតែតាមរយៈកិច្ចការបែបនេះទេ ទើបមនុស្សលោកអាចស្គាល់ខ្លួនឯង និងផ្ដាច់ខ្លួនពីនិស្ស័យបះបោររបស់ពួកគេ។ សារៈសំខាន់ធំបំផុតនៃកិច្ចការនៃព្រះបន្ទូល គឺជាការអនុញ្ញាតឲ្យមនុស្សលោកយកសេចក្ដីពិតទៅអនុវត្ត បន្ទាប់ពីបានយល់សេចក្ដីពិតនេះ ដើម្បីអនុញ្ញាតឲ្យគេសម្រេចបាននូវការផ្លាស់ប្ដូរនិស្ស័យរបស់ពួកគេ និងឲ្យគេស្គាល់ខ្លួនឯង និងស្គាល់កិច្ចការរបស់ព្រះជាម្ចាស់។ មានតែការធ្វើកិច្ចការដោយការថ្លែងព្រះបន្ទូលទេ ទើបអាចធ្វើឲ្យទំនាក់ទំនងរវាងព្រះជាម្ចាស់ និងមនុស្សលោកកើតមានឡើងបាន ហើយមានតែព្រះបន្ទូលប៉ុណ្ណោះ ទើបអាចពន្យល់សេចក្ដីពិតបាន។ ការធ្វើការតាមរបៀបនេះ គឺជាមធ្យោបាយដ៏ល្អបំផុត ក្នុងការយកឈ្នះមនុស្សលោក។ ក្រៅពីការថ្លែងព្រះបន្ទូល គ្មានវិធីណាផ្សេងទៀតដែលអាចផ្ដល់ឲ្យមនុស្សនូវការយល់ដឹងអំពីសេចក្ដីពិត និងកិច្ចការរបស់ព្រះជាម្ចាស់ ឲ្យច្បាស់ជាងនេះឡើយ។ ដូច្នេះ ព្រះជាម្ចាស់មានបន្ទូលទៅកាន់មនុស្សលោក ដើម្បីបើកបង្ហាញដល់ពួកគេនូវសេចក្ដីពិត និងអាថ៌កំបាំងទាំងអស់ដែលពួកគេមិនទាន់យល់ដឹងនៅឡើយ នៅក្នុងដំណាក់កាលចុងក្រោយនៃកិច្ចការរបស់ទ្រង់ដោយអនុញ្ញាតឲ្យពួកគេទទួលបានផ្លូវពិត និងជីវិតពីព្រះជាម្ចាស់ ហើយក៏បំពេញបំណងព្រះហឫទ័យព្រះជាម្ចាស់ដោយព្រោះលទ្ធផលនេះ។ គោលបំណងនៃកិច្ចការរបស់ព្រះជាម្ចាស់ចំពោះមនុស្សលោក គឺជួយឲ្យពួកគេអាចបំពេញតាមបំណងព្រះហឫទ័យព្រះជាម្ចាស់ ហើយកិច្ចការនេះត្រូវបានធ្វើឡើងដើម្បីនាំសេចក្ដីសង្គ្រោះមកឲ្យពួកគេ។ ហេតុដូច្នេះហើយ ពេលទ្រង់ធ្វើកិច្ចការសង្គ្រោះមនុស្សលោក ទ្រង់មិនធ្វើកិច្ចការដាក់ទោសពួកគេឡើយ។ ព្រះជាម្ចាស់ មិនដាក់ទោសមនុស្សអាក្រក់ ឬផ្ដល់រង្វាន់ដល់មនុស្សល្អ ពេលកំពុងនាំសេចក្ដីសង្គ្រោះមកឲ្យមនុស្សលោកទេ ហើយទ្រង់ ក៏មិនបើកឲ្យគេដឹងពីទិសដៅនានារបស់មនុស្សប្រភេទផ្សេងៗគ្នាផងដែរ។ ផ្ទុយទៅវិញ ទាល់តែក្រោយពេលដែលដំណាក់កាលចុងក្រោយ នៃកិច្ចការរបស់ទ្រង់បានចប់សព្វគ្រប់ទើបទ្រង់នឹងធ្វើកិច្ចការដាក់ទណ្ឌកម្មមនុស្សអាក្រក់ និងផ្ដល់រង្វាន់ដល់មនុស្សល្អ ពេលនោះទើបទ្រង់នឹងបើកឲ្យដឹងពីចុងបញ្ចប់នៃមនុស្ស

ប្រភេទផ្សេងៗទាំងអស់គ្នា។ មនុស្សដែលត្រូវរងការដាក់ទោស គឺជាមនុស្សដែលមិនអាចទទួលសេចក្ដីសង្គ្រោះបាន រីឯមនុស្សដែលនឹងត្រូវបានសង្គ្រោះ គឺជាមនុស្សដែលបានទទួលសេចក្ដីសង្គ្រោះរបស់ព្រះជាម្ចាស់ ពេលទ្រង់កំពុងធ្វើកិច្ចការសង្គ្រោះមនុស្សលោក។ ខណៈពេលដែលព្រះជាម្ចាស់កំពុងធ្វើកិច្ចការសង្គ្រោះ បុគ្គលគ្រប់រូបដែលអាចបានសង្គ្រោះ នឹងត្រូវបានសង្គ្រោះ យ៉ាងអស់ពីលទ្ធភាពដែលអាចធ្វើទៅបាន ហើយគ្មាននរណាម្នាក់ត្រូវបានបោះបង់ចោលឡើយ ដ្បិតគោលបំណងនៃកិច្ចការរបស់ព្រះជាម្ចាស់ គឺដើម្បីសង្គ្រោះដល់មនុស្សលោក។ ក្នុងអំឡុងពេលដែលព្រះជាម្ចាស់ធ្វើកិច្ចការសង្គ្រោះមនុស្សលោក មនុស្សណាដែលមិនអាចសម្រេចបាននូវការផ្លាស់ប្ដូរនូវនិស្ស័យរបស់ពួកគេ និងមនុស្សណាដែលមិនអាចចុះចូលចំពោះព្រះជាម្ចាស់បានទាំងស្រុង នឹងក្លាយជាកម្មវត្ថុសម្រាប់ការដាក់ទោស។ កិច្ចការនៃព្រះបន្ទូលដែលជាកិច្ចការក្នុងដំណាក់កាលនេះ នឹងបើកបង្ហាញដល់មនុស្សនូវផ្លូវ និងអាថ៌កំបាំងទាំងអស់ដែលពួកគេមិនយល់ ដើម្បីឲ្យពួកគេអាចយល់ពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងសេចក្ដីតម្រូវដែលព្រះជាម្ចាស់ទាមទារពួកគេ និងដើម្បីឲ្យពួកគេអាចមានលក្ខណៈចាំបាច់ទុកជាមុន សម្រាប់យកព្រះបន្ទូលទៅអនុវត្ត និងសម្រេចបាន ការផ្លាស់ប្ដូរនិស្ស័យរបស់ពួកគេ។ ព្រះជាម្ចាស់ប្រើតែព្រះបន្ទូលប៉ុណ្ណោះ ដើម្បីធ្វើកិច្ចការរបស់ទ្រង់ ហើយមិនដាក់ទោសមនុស្ស ចំពោះការបះបោរតូចតាចទេនេះ ក៏ដោយសារតែឥឡូវនេះជាពេលវេលាធ្វើកិច្ចការសង្គ្រោះ។ បើសិនបើមនុស្សរាល់គ្នាដែលបានប្រព្រឹត្តបែបបះបោរនឹងត្រូវបានដាក់ទោស នោះនឹងគ្មាននរណាម្នាក់ មានឱកាសទទួលបានការសង្គ្រោះឡើយ។ គ្រប់គ្នានឹងត្រូវដាក់ទោស ហើយធ្លាក់ចូលក្នុងស្ថានឃុំព្រលឹង។ គោលបំណងនៃព្រះបន្ទូលដែលជំនុំជម្រះមនុស្សលោក គឺដើម្បីឲ្យពួកគេស្គាល់ខ្លួនឯង ហើយចុះចូលចំពោះព្រះជាម្ចាស់ មិនមែនដើម្បីដាក់ទោសពួកគេដោយការជំនុំជម្រះបែបនោះឡើយ។ ក្នុងអំឡុងពេលធ្វើកិច្ចការនៃព្រះបន្ទូល មនុស្សជាច្រើននឹងសម្ដែងចេញនូវការបះបោរ និងការរឹងទទឹងរបស់ពួកគេ ព្រមទាំងការមិនស្ដាប់បង្គាប់របស់ពួកគេ ចំពោះព្រះជាម្ចាស់ដែលបានយកកំណើតជា

មនុស្ស។ តែទោះយ៉ាងណាក៏ដោយ ទ្រង់នឹងមិនដាក់ទោសមនុស្សទាំងអស់នេះ មកធ្វើជាលទ្ធផលនោះឡើយ ប៉ុន្តែផ្ទុយទៅវិញ ទ្រង់គ្រាន់តែបោះមនុស្សដែលពុករលួយដល់បណ្ដូលចិត្ត និងមនុស្សដែលមិនអាចត្រូវបានសង្គ្រោះ ទុកទៅម្ខាងសិនប៉ុណ្ណោះ។ ទ្រង់នឹងប្រគល់សាច់ឈាមរបស់ពួកគេទៅឲ្យសាតាំង ហើយក្នុងករណីមួយចំនួនតូច ទ្រង់នឹងបញ្ចប់ជីវិតសាច់ឈាមរបស់ពួកគេ។ មនុស្សដែលនៅសល់នឹងបន្តធ្វើតាម និងឆ្លងកាត់នូវការដោះស្រាយ និងការលួសកាត់។ នៅខណៈពេលកំពុងធ្វើតាម ប្រសិនបើមនុស្សទាំងនេះ នៅតែមិនអាចទទួលយកការដោះស្រាយ និងការលួសកាត់បាន ហើយក្លាយជាកាន់តែអាក្រក់ទៅៗ នោះពួកគេនឹងបាត់បង់ឱកាសទទួលបាននូវសេចក្ដីសង្គ្រោះ។ បុគ្គលណាដែលចុះចូលទទួលការយកឈ្នះដោយព្រះបន្ទូលរបស់ព្រះជាម្ចាស់ នឹងមានឱកាសច្រើនសម្រាប់ទទួលបានសេចក្ដីសង្គ្រោះ។ សេចក្ដីសង្គ្រោះរបស់ព្រះជាម្ចាស់ចំពោះមនុស្សម្នាក់ៗ នឹងបង្ហាញពីសេចក្ដីអត់ឱនជាទីបំផុតរបស់ទ្រង់។ ម្យ៉ាងវិញទៀត ពួកគេនឹងឃើញនូវសេចក្ដីត្រាប្រណីបំផុត។ ដរាបណាមនុស្សងាកចេញពីផ្លូវខុសឆ្គង ហើយដរាបណាពួកគេអាចប្រែចិត្ត នោះព្រះជាម្ចាស់នឹងឲ្យពួកគេនូវឱកាសទទួលបានសេចក្ដីសង្គ្រោះពីទ្រង់។ នៅពេលមនុស្សលោកបះបោរប្រឆាំង នឹងព្រះជាម្ចាស់ជាលើកដំបូង ទ្រង់គ្មានបំណងសម្លាប់ពួកគេទេ ផ្ទុយទៅវិញ ទ្រង់ធ្វើសព្វបែបយ៉ាងដែលអាចធ្វើបាន ដើម្បីសង្គ្រោះពួកគេ។ ប្រសិនបើនរណាម្នាក់ពិតជាគ្មានចិត្តចង់បានសេចក្ដីសង្គ្រោះទេ នោះព្រះជាម្ចាស់នឹងបោះចោលពួកគេទៅម្ខាង។ មូលហេតុដែលព្រះជាម្ចាស់ យឺតយ៉ាវក្នុងការដាក់ទណ្ឌកម្មមនុស្សមួយចំនួន គឺដោយសារតែទ្រង់ចង់សង្គ្រោះមនុស្សគ្រប់គ្នាដែលអាចទទួលការសង្គ្រោះបាន។ ទ្រង់ជំនុំជម្រះ ទ្រង់បំភ្លឺ និងណែនាំមនុស្សដោយប្រើតែព្រះបន្ទូលប៉ុណ្ណោះ ហើយទ្រង់ក៏មិនប្រើដំបងមកសម្លាប់ពួកគេដែរ។ ការប្រើព្រះបន្ទូល ដើម្បីនាំសេចក្ដីសង្គ្រោះមកឲ្យមនុស្សលោក គឺជាគោលបំណង និងជាសារៈសំខាន់នៃដំណាក់កាលចុងក្រោយនៃកិច្ចការរបស់ព្រះជាម្ចាស់។

# តើមនុស្សដែលបានដាក់កំហិតព្រះជាម្ចាស់ តាមសញ្ញាណរបស់ខ្លួន អាចទទួលការបើកសម្ដែង ពីព្រះជាម្ចាស់យ៉ាងដូចម្ដេច?

កិច្ចការរបស់ព្រះជាម្ចាស់ វិវឌ្ឍទៅមុខជានិច្ច ហើយទោះបីជាគោលបំណងនៃកិច្ចការរបស់ទ្រង់ មិនប្រែប្រួលក៏ពិតមែន ប៉ុន្តែវិធីសាស្ត្រដែលទ្រង់ធ្វើការ គឺប្រែប្រួលជាដរាប ដែលមានន័យថា អស់អ្នកដែលដើរតាមព្រះជាម្ចាស់ ក៏ប្រែប្រួលជាដរាបដែរ។ កាលណាព្រះជាម្ចាស់ធ្វើកិច្ចការកាន់តែច្រើន នោះចំណេះដឹងដែលគេមានអំពីទ្រង់ ក៏កាន់តែពិស្ដារដែរ។ បម្រែបម្រួលដ៏សមស្រប នៅក្នុងនិស្ស័យរបស់មនុស្ស ក៏កើតមានឡើង អាស្រ័យតាមកិច្ចការរបស់ព្រះជាម្ចាស់ដែរ។ យ៉ាងណាមិញ ដោយសារកិច្ចការរបស់ព្រះជាម្ចាស់ ចេះតែប្រែប្រួលជានិច្ច ទើបអស់អ្នកដែលមិនស្គាល់កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ និងមនុស្សលេលាដែលមិនស្គាល់សេចក្តីពិត ក្លាយជាមនុស្សដែលរឹងទទឹងនឹងព្រះជាម្ចាស់។ កិច្ចការរបស់ព្រះជាម្ចាស់ គឺពុំដែលត្រូវគ្នានឹងការយល់ឃើញរបស់មនុស្សឡើយ ដ្បិតកិច្ចការរបស់ទ្រង់ថ្មីជានិច្ច មិនដែលចាស់ ហើយទ្រង់ក៏មិនដែលយកកិច្ចការចាស់មកធ្វើម្ដងទៀតដែរ តែផ្ទុយទៅវិញ ទ្រង់មានតែវិវឌ្ឍទៅមុខជាមួយនឹងកិច្ចការដែលពុំធ្លាប់ត្រូវបានធ្វើពីមុនមកសោះ។ ដោយសារតែព្រះជាម្ចាស់មិនធ្វើកិច្ចការរបស់ទ្រង់ម្ដងទៀត ហើយមនុស្សក៏ចេះតែវិនិច្ឆ័យកិច្ចការបច្ចុប្បន្នរបស់ទ្រង់ តាមរយៈកិច្ចការដែលទ្រង់បានធ្វើពីអតីតកាល ទើបការដែលទ្រង់អនុវត្តដំណាក់កាលនីមួយៗនៃកិច្ចការក្នុងយុគសម័យថ្មី កាន់តែលំបាកក្រៃលែង។ មនុស្សមានការលំបាកច្រើនពេកហើយ! គំនិតរបស់គេ អភិរក្សនិយមពេកហើយ! គ្មាននរណាម្នាក់ដឹងពីកិច្ចការរបស់ព្រះជាម្ចាស់ឡើយ តែគ្រប់ៗគ្នាបែរជាដាក់កំហិតកិច្ចការនោះវិញ។ កាលណាគេចាកចេញពីព្រះជាម្ចាស់ មនុស្សនឹងបាត់បង់ជីវិត បាត់បង់សេចក្តីពិត និងបាត់បង់ព្រះពរមកពីទ្រង់ស្រាប់ហើយ ប៉ុន្តែកាលណាគេក៏មិនទទួលយកជីវិត ឬសេចក្តីពិត នោះក៏រឹតតែមិនទទួលបានព្រះពរដ៏ធំដែលព្រះប្រទាន

ឲ្យមនុស្សលោកដែរ។ មនុស្សទាំងអស់ចង់បានព្រះជាម្ចាស់ តែពួកគេមិនអាចទ្រាំទ្រនឹងបម្រែបម្រួលណាមួយនៅក្នុងកិច្ចការរបស់ព្រះជាម្ចាស់បានឡើយ។ អស់អ្នកដែលទទួលយកកិច្ចការថ្មីរបស់ព្រះជាម្ចាស់ជឿថា កិច្ចការរបស់ព្រះជាម្ចាស់មិនប្រែប្រួលឡើយ ដោយជឿថាកិច្ចការនោះនៅទ្រឹងរហូត។ នៅក្នុងជំនឿរបស់ពួកគេ តម្រូវការតែមួយគត់ ដើម្បីទទួលបាននូវសេចក្ដីសង្គ្រោះដ៏អស់កល្បជានិច្ចពីព្រះជាម្ចាស់ គឺត្រូវកាន់តាមក្រឹត្យវិន័យ ហើយដរាបណាពួកគេប្រែចិត្ត ហើយលន់តួបាបរបស់ខ្លួន នោះព្រះជាម្ចាស់ក៏នៅតែគាប់ព្រះទ័យជានិច្ចដែរ។ ទាំងនេះ គឺជាគំនិតដែលគិតថា ព្រះជាម្ចាស់អាចធ្វើជាព្រះដែលស្ថិតក្រោមអំណាចក្រឹត្យវិន័យ និងជាព្រះដែលត្រូវគេបោះភ្ជាប់លើឈើឆ្កាងឲ្យសុគតជំនួសមនុស្សលោកប៉ុណ្ណោះ គេក៏គិតក្នុងចិត្តទៀតថា ព្រះជាម្ចាស់មិនគួរ និងមិនអាចធ្វើកិច្ចការលើសពីអ្វីដែលមានចែងក្នុងព្រះគម្ពីរឡើយ។ ប្រាកដណាស់ គឺគំនិតទាំងអស់នេះហើយ ដែលបានចងគេជាប់ទៅនឹងក្រឹត្យវិន័យពីបុរាណ ហើយបោះគេភ្ជាប់នឹងបញ្ញត្តិដែលសាបសូន្យបាត់ទៅហើយ។ មានអ្នកខ្លះថែមទាំងជឿទៀតថា ទោះបីកិច្ចការរបស់ព្រះជាម្ចាស់ថ្មីយ៉ាងណា ក៏កិច្ចការនោះត្រូវតែស្ដែងបញ្ជាក់ដោយបទទំនាយដែរ និងជឿថា នៅក្នុងដំណាក់កាលនីមួយៗនៃកិច្ចការបែបនេះ អស់អ្នកដែលដើរតាមទ្រង់ដោយដួងចិត្ត «ពិត» គឺត្រូវតែមើលឃើញនូវការបើកសម្ដែង។ ពុំនោះទេ កិច្ចការបែបនេះ គឺមិនមែនជាកិច្ចការរបស់ព្រះជាម្ចាស់ឡើយ។ ត្រឹមចូលមករកព្រះជាម្ចាស់ ដើម្បីឱ្យបានស្គាល់ទ្រង់ នោះវាគឺជាកិច្ចការមួយ ដែលមិនងាយស្រួលសម្រាប់មនុស្សលោកស្រេចទៅហើយ។ ទម្រាំឲ្យគេបន្ថែមនូវដួងចិត្តលេលារបស់មនុស្ស ការរាប់ខ្លួនឯងជាសំខាន់ និងការបោកបញ្ឆោតខ្លួនឯងដែលជាចរិតបះបោររបស់គេទៀតនោះ នោះវារឹតតែធ្វើឲ្យគេកាន់តែលំបាកនឹងទទួលយកកិច្ចការថ្មីរបស់ព្រះជាម្ចាស់ទៅទៀត។ មនុស្សមិនបានពិនិត្យពិច័យពីកិច្ចការថ្មីរបស់ព្រះជាម្ចាស់ដោយយកចិត្តទុកដាក់ ហើយក៏មិនអាចទទួលយកកិច្ចការនេះ ដោយការបន្ទាបខ្លួនបានដែរផ្ទុយទៅវិញ គេនឹងប្រើនូវចរិតឆ្មើងឆ្មៃ ខណៈដែលគេកំពុងរង់ចាំការបើកសម្ដែង និងការណែនាំពីព្រះជាម្ចាស់។ តើនេះមិនមែនជាឥរិយាបថ

របស់មនុស្សដែលបះបោរប្រឆាំង និងរឹងទទឹងនឹងព្រះជាម្ចាស់ទេឬអី? តើមនុស្សបែបនេះអាចទទួលបាននូវការសរសើរពីព្រះជាម្ចាស់ដោយរបៀបណា?

ព្រះយេស៊ូវមានព្រះបន្ទូលថា កិច្ចការរបស់ព្រះយេហូវ៉ា មិនបានសម្រេចទាន់វេលាទេក្នុងយុគសម័យនៃព្រះគុណ គឺដូចខ្ញុំថ្លែងនៅថ្ងៃនេះដែរ ដែលកិច្ចការរបស់ព្រះយេស៊ូវសម្រេច ក៏មិនទាន់វេលាដែរ។ ប្រសិនបើមានត្រឹមតែយុគសម័យនៃក្រឹត្យវិន័យ ហើយគ្មានយុគសម័យនៃព្រះគុណ នោះព្រះយេស៊ូវមុខជាមិនត្រូវគេឆ្កាង ហើយក៏ច្បាស់ជាមិនបានប្រោសលោះមនុស្សលោកគ្រប់គ្នាដែរ។ ប្រសិនបើមានតែយុគសម័យនៃក្រឹត្យវិន័យ តើមនុស្សលោកអាចនៅបានយូរដល់ថ្ងៃនេះទេ? ប្រវត្តិសាស្រ្ត រីវឌ្ឍទៅមុខ ហើយចុះប្រវត្តិសាស្រ្តមិនមែនជាច្បាប់ធម្មជាតិនៃកិច្ចការរបស់ព្រះជាម្ចាស់ទេឬអី? តើនេះ មិនមែនជាការបរិយាយពីការដែលទ្រង់គ្រប់គ្រងមនុស្សលោក នៅក្នុងចក្រវាឡពីដើមដល់ចប់ទេឬអី? ប្រវត្តិសាស្រ្ត រីវឌ្ឍទៅមុខ ហើយកិច្ចការរបស់ព្រះជាម្ចាស់ ក៏រីវឌ្ឍទៅមុខដែរ។ បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ប្រែប្រួលជានិច្ច។ ទ្រង់មិនអាចនៅទ្រឹងក្នុងដំណាក់កាលតែមួយនៃកិច្ចការរបស់ទ្រង់អស់រយៈពេល៦ពាន់ឆ្នាំបានឡើយ ដ្បិតគ្រប់គ្នាដឹងថា ព្រះជាម្ចាស់តែងតែថ្មីជានិច្ច ហើយពុំដែលចាស់ឡើយ ហើយព្រះអង្គក៏ទំនងជាមិនបន្តធ្វើកិច្ចការដូចជា ការជាប់ឆ្កាង ដោយឲ្យគេបោះដែកគោលភ្ជាប់នឹងឈើឆ្កាងម្ដង ពីរដង បីដង... នោះដែរ។ ការគិតបែបនេះ គឺគួរឱ្យអស់សំណើចណាស់។ ព្រះជាម្ចាស់មិនបន្តធ្វើនូវកិច្ចការដដែលៗទេ កិច្ចការរបស់ទ្រង់ប្រែប្រួល ហើយថ្មីជានិច្ច ថ្មីរាល់ថ្ងៃ ហើយកាន់តែថ្មីទាំងពេលដែលខ្ញុំកំពុងថ្លែងប្រាប់អ្នករាល់គ្នានេះផងដែរ។ នេះជាកិច្ចការដែលខ្ញុំធ្វើ ហើយគន្លឹះដ៏សំខាន់គឺពាក្យថា «ថ្មី» និង «អស្ចារ្យ»។ «ព្រះជាម្ចាស់មិនប្រែប្រួលឡើយ ហើយទ្រង់ក៏នៅតែជាព្រះជាម្ចាស់ជានិច្ច»៖ សម្ដីមួយឃ្លានេះ គឺជាការពិត។ លក្ខណៈរបស់ព្រះជាម្ចាស់មិនប្រែប្រួលឡើយ ព្រះជាម្ចាស់គឺនៅតែព្រះជាម្ចាស់ជានិច្ច ហើយទ្រង់មិនអាចប្រែក្លាយទៅជាសាតាំងបានឡើយ តែនេះមិនមែនបញ្ជាក់ថា កិច្ចការរបស់ទ្រង់នៅតែដដែលមិនប្រែប្រួល ដូចនឹងលក្ខណៈរបស់ទ្រង់នោះទេ។ អ្នកប្រកាសថា

ព្រះជាម្ចាស់មិនប្រែប្រួល ប៉ុន្តែតើអ្នកអាចពន្យល់ថា ព្រះជាម្ចាស់តែងថ្មីជានិច្ច ហើយមិនដែលចាស់សោះ ដោយរបៀបណា? កិច្ចការរបស់ព្រះជាម្ចាស់ នៅបន្តសាយភាយ ហើយប្រែប្រួលជាដរាប ហើយបំណងព្រះហឫទ័យរបស់ទ្រង់ ក៏នៅតែត្រូវបានសម្ដែងឱ្យមនុស្សលោកបានដឹង នឹងបានស្គាល់ដដែល។ ពេលមនុស្សលោកបានឆ្លងកាត់កិច្ចការរបស់ព្រះជាម្ចាស់ និស្ស័យរបស់គេ នឹងប្រែប្រួលឥតឈប់ឈរ ចំណែកចំណេះដឹងរបស់គេ ក៏ដូចគ្នា។ ដូច្នេះ តើការប្រែប្រួលនេះ កើតឡើងពីពេលណា? តើវាមិនមែនកើតមកពីកិច្ចការរបស់ព្រះជាម្ចាស់ ដែលប្រែប្រួលឥតឈប់ឈរទេឬអី? ប្រសិនបើនិស្ស័យរបស់មនុស្ស អាចប្រែប្រួលបាន ហេតុអ្វីក៏មនុស្សមិនអាចបណ្ដោយឲ្យកិច្ចការរបស់ខ្ញុំ និងព្រះបន្ទូលរបស់ខ្ញុំ បន្តប្រែប្រួលជាមួយគ្នាដែរ? តើយើងត្រូវនៅក្រោមកំហិតរបស់មនុស្សដែរមែនទេ? តើអ្នកមិនមែនកំពុងប្រើប្រាស់ការប្រកែក ដោយបង្ខំ និងហេតុផលបំភ័ន្ត នៅក្នុងគំនិតនេះទេឬអី?

បន្ទាប់ពីព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ ទ្រង់បានបង្ហាញព្រះកាយឱ្យពួកសិស្សបានឃើញ និងមានព្រះបន្ទូលថា «ខ្ញុំចាត់សេចក្ដីសន្យា ពីព្រះវរបិតាឲ្យមកសណ្ឋិតលើអ្នករាល់គ្នា ប៉ុន្តែអ្នករាល់គ្នាត្រូវនៅក្នុងក្រុងយេរូសាឡឹម រហូតដល់អ្នករាល់គ្នាបានគ្របដណ្ដប់ដោយព្រះចេស្ដាពីស្ថានដ៏ខ្ពស់»។ តើអ្នកដឹងទេថា ព្រះបន្ទូលនេះអាចយកទៅបកស្រាយយ៉ាងដូចម្ដេច? ពេលនេះ តើអ្នកមានព្រះចេស្ដាពីទ្រង់មកគ្របដណ្ដប់ ហើយឬនៅ? តើអ្នកយល់ទេថា «ព្រះចេស្ដា» សំដៅលើអ្វី? ព្រះយេស៊ូវបានប្រកាសថា ព្រះវិញ្ញាណនៃសេចក្ដីពិត មុខជាត្រូវបានប្រទានមកឱ្យមនុស្សលោកក្នុងអំឡុងពេលនៃគ្រាចុងក្រោយ។ ពេលនេះ ម៉ោងនេះ គឺជាគ្រាចុងក្រោយហើយ តើអ្នកយល់ពីរបៀបដែលព្រះវិញ្ញាណនៃសេចក្ដីពិត សម្ដែងព្រះបន្ទូលទេ? តើព្រះវិញ្ញាណនៃសេចក្ដីពិតបង្ហាញព្រះកាយ និងធ្វើការនៅកន្លែងណា? នៅក្នុងគម្ពីរទំនាយរបស់ហោរាអេសាយ គ្មានកន្លែងណាមានចែងថា ទារកម្នាក់ឈ្មោះថាយេស៊ូវ នឹងត្រូវប្រសូតនៅក្នុងយុគសម័យនៃសម្ពន្ធមេត្រីថ្មីនោះទេ គឺគ្រាន់តែមានចែងថាមានទារកម្នាក់ឈ្មោះថា អេម៉ាញូអែលនឹងត្រូវប្រសូតមក។ ហេតុអ្វីក៏ឈ្មោះ «យេស៊ូវ» មិនត្រូវ

បានលើកយកមកនិយាយ? នៅក្នុងគម្ពីរសញ្ញាចាស់ ឈ្មោះនេះនៅកន្លែងណាក៏គ្មានដែរ ចុះហេតុអ្វីបានជាអ្នកនៅជឿលើព្រះយេស៊ូវ? ប្រាកដណាស់ អ្នកមិនបានចាប់ផ្ដើមជឿព្រះយេស៊ូវ ត្រឹមពេលដែលអ្នកមើលឃើញទ្រង់ផ្ទាល់នឹងភ្នែកទេមែនទេ? ឬមួយក៏អ្នកចាប់ផ្ដើមជឿនៅពេលដែលអ្នកទទួលបានការបើកសម្ដែង? តើព្រះជាម្ចាស់ពិតជាបង្ហាញព្រះគុណបែបនេះ ដល់អ្នកមែនឬ? តើទ្រង់ប្រទានព្រះពរអស្ចារ្យដល់ម្ល៉ឹងដល់អ្នកមែនទេ? តើអ្វីជាគោលនៃជំនឿដែលអ្នកមានចំពោះព្រះយេស៊ូវ? ហេតុអ្វីបានជាអ្នកមិនជឿថា ព្រះជាម្ចាស់បានក្លាយជាសាច់ឈាមនៅថ្ងៃនេះ? ហេតុអ្វីក៏អ្នកនិយាយថា អវត្តមាននៃការបើកសម្ដែងមកពីព្រះជាម្ចាស់ចំពោះអ្នករាល់គ្នា ស្ដែងឲ្យឃើញថា ទ្រង់មិនបានប្រសូតជាសាច់ឈាមទេ? តើព្រះជាម្ចាស់ត្រូវជម្រាបមនុស្សឲ្យដឹងមុនពេលចាប់ផ្ដើមកិច្ចការរបស់ទ្រង់មែនទេ? តើទ្រង់ត្រូវទទួលការអនុម័តពីពួកគេសិនមែនទេ? ហោរាអេសាយគ្រាន់តែប្រកាសថា ទារកម្នាក់នឹងប្រសូតនៅក្នុងស្នូកសត្វ លោកមិនបានទាយថា នាងម៉ារានឹងផ្ដល់កំណើតដល់ព្រះយេស៊ូវនោះទេ។ តើអ្នកសំអាងលើអ្វីបានជាអ្នកជឿថា ព្រះយេស៊ូវប្រសូតពីនាងម៉ារា? ប្រាកដណាស់ ជំនឿរបស់អ្នកគឺមិនភ័ន្តទេ? អ្នកខ្លះនិយាយថាព្រះនាមរបស់ព្រះជាម្ចាស់មិនប្រែប្រួលទេ។ ចុះហេតុអ្វីក៏ព្រះនាមរបស់ព្រះយេហូវ៉ា ក្លាយជាព្រះយេស៊ូវ? បទទំនាយទាយទុកថា ព្រះមែស្ស៊ីនឹងយាងមក ចុះហេតុអ្វីបានជាមានមនុស្សម្នាក់ឈ្មោះថា យេស៊ូវ មកដល់ទៅវិញ? ហេតុអ្វីបានជាព្រះនាមរបស់ព្រះជាម្ចាស់ប្រែប្រួល? តើកិច្ចការនេះមិនមែនត្រូវបានអនុវត្តជាយូរមកហើយទេឬអី? តើសព្វថ្ងៃនេះព្រះជាម្ចាស់ប្រហែលជាមិនធ្វើកិច្ចការថ្មីជាងនេះទេឬអី? កិច្ចការពីអតីតកាលអាចនឹងត្រូវកែប្រែ ហើយកិច្ចការរបស់ព្រះយេស៊ូវអាចនឹងចាប់ផ្ដើមបន្តពីកិច្ចការរបស់ព្រះយេហូវ៉ា។ ចុះតើកិច្ចការរបស់ព្រះយេស៊ូវ មិនអាចសម្រេចបានដោយកិច្ចការផ្សេងទៀតទេមែនទេ? ប្រសិនបើព្រះនាម «យេហូវ៉ា» អាចប្ដូរមកជាព្រះនាម «យេស៊ូវ» ចុះតើព្រះនាម «យេស៊ូវ» មិនអាចនឹងប្ដូរដែរទេឬអី? រឿងនេះគ្មានអ្វីប្លែកទេ គ្រាន់តែមនុស្សមានគំនិតគិតសាមញ្ញៗពេក។ ព្រះជាម្ចាស់នៅតែជាព្រះជាម្ចាស់រហូត។ ទោះបីជាកិច្ចការរបស់ទ្រង់ ប្រែប្រួលយ៉ាងណា ហើយ

មិនថា ព្រះនាមទ្រង់អាចនឹងប្ដូរទៅជាយ៉ាងណាក៏និស្ស័យ និងព្រះប្រាជ្ញាញាណរបស់ទ្រង់ មិនប្រែប្រួលឡើយ។ ប្រសិនបើអ្នកជឿថាព្រះជាម្ចាស់អាចហៅបានត្រឹមព្រះនាមព្រះយេស៊ូវ នោះចំណេះរបស់អ្នក គឺនៅមានកម្រិតឆ្ងាយណាស់។ តើអ្នកហ៊ានអះអាងថា ព្រះនាម «យេស៊ូវ» នឹងនៅតែជាព្រះនាមរបស់ព្រះជាម្ចាស់រហូតទេ ហ៊ានអះអាងថា ព្រះជាម្ចាស់នឹងនៅតែរក្សាព្រះនាម «យេស៊ូវ» រហូត ហើយអះអាងថា ព្រះនាមនេះនឹងមិនប្រែប្រួលទេមែនទេ? តើអ្នកហ៊ានអះអាងយ៉ាងប្រាកដថា ព្រះនាម «យេស៊ូវ» ដែលបានបញ្ចប់យុគសម័យនៃក្រឹត្យវិន័យ និងបញ្ចប់យុគសម័យចុងក្រោយនេះដែរមែនទេ? តើនរណាអាចពោលថា ព្រះគុណរបស់ព្រះយេស៊ូវ អាចធ្វើឲ្យយុគសម័យចុងក្រោយត្រូវបញ្ចប់បាន? ប្រសិនបើអ្នកខ្វះការយល់ដឹងច្បាស់លាស់អំពីសេចក្ដីពិតទាំងអស់នេះ អ្នកមិនមែនត្រឹមអសមត្ថភាពនឹងផ្សាយដំណឹងល្អទេ តែអ្នកខ្លួនឯង ក៏មិនអាចឈរមាំបានដែរ។ នៅថ្ងៃដែលអ្នកយកឈ្នះអស់ទាំងការលំបាករបស់មនុស្សដែលកាន់តាមសាសនា ហើយបដិសេធជំនឿខុសឆ្គងរបស់ពួកគេ ថ្ងៃនោះនឹងក្លាយជាភស្ដុតាងបញ្ជាក់ថាអ្នកដឹងច្បាស់ប្រាកដអំពីដំណាក់កាលនៃកិច្ចការនេះ ហើយក៏គ្មានមន្ទិលសង្ស័យសូម្បីបន្ដិចសោះ។ ប្រសិនបើអ្នកមិនអាចបដិសេធជំនឿខុសឆ្គងរបស់គេ នោះពួកគេនឹងទម្លាក់កំហុសលើអ្នក ហើយនិយាយបង្ខូចអ្នកជាមិនខាន។ តើនោះមិនមែនជារឿងគួរឲ្យអាម៉ាស់ទេឬអី?

សាសន៍យូដាទាំងអស់ សុទ្ធតែអានគម្ពីរសញ្ញាចាស់ ហើយដឹងពីបទទំនាយរបស់ហោរាអេសាយដែលទាយថា ទារកម្នាក់នឹងប្រសូតក្នុងស្នូកសត្វ។ ចុះហេតុអ្វីបានជាគេនៅតែបៀតបៀនព្រះយេស៊ូវ ទាំងដឹងច្បាស់ឥតចន្លោះអំពីបទទំនាយនេះ? តើមិនមែនដោយសារធម្មជាតិបះបោរ និងកង្វះការយល់ដឹងរបស់គេ អំពីកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធទេឬអី? នៅគ្រានោះ ពួកផារិស៊ីជឿថា កិច្ចការរបស់ព្រះយេស៊ូវខុសពីអ្វីដែលគេដឹងអំពីទារកដែលត្រូវបានទាយទុក ហើយមនុស្សសម័យបច្ចុប្បន្នបដិសេធព្រះជាម្ចាស់ ក៏ដោយសារកិច្ចការរបស់ព្រះដែលប្រសូតជាសាច់ឈាម មិនស្របទៅនឹងព្រះគម្ពីរ។ តើសារជាតិនៃភាពបះបោររបស់គេចំពោះព្រះជាម្ចាស់ មិនមែននៅដដែល

ទេឬអី? តើអ្នកអាចទទួលយកកិច្ចការទាំងអស់របស់ព្រះវិញ្ញាណបរិសុទ្ធ ដោយគ្មានចម្ងល់បានដែរឬទេ? ប្រសិនបើវាជាកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ នោះចរន្តលំហូរនេះ គឺត្រឹមត្រូវហើយ ហើយអ្នកគួរតែទទួលយកកិច្ចការនេះដោយពុំមានការសង្ស័យអ្វីទាំងអស់ អ្នកពុំគួរជ្រើសរើស ឬសម្រេចយកអ្វីដែលត្រូវទទួល ឬមិនទទួលនោះឡើយ។ បើអ្នកកាន់តែមានចំណេះដឹងពីព្រះជាម្ចាស់កាន់តែច្រើន និងមានការប្រុងប្រយ័ត្នចំពោះទ្រង់បន្ថែមទៀត នោះតើវាមិនសមកើតឡើងទេឬ? អ្នកមិនចាំបាច់ស្វែងរកភ័ស្តុតាងបញ្ជាក់បន្ថែមទៀតពីគម្ពីរទេ។ បើវាជាកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធ នោះអ្នកត្រូវទទួលយកវាចុះ ដ្បិតអ្នកជឿលើព្រះជាម្ចាស់ ដើម្បីដើរតាមទ្រង់ ហើយអ្នកពុំគួរស៊ើបអង្កេតពីទ្រង់នោះឡើយ អ្នកពុំគួរស្វះស្វែងរកភស្តុតាងបន្ថែមពីខ្ញុំនោះដើម្បីបញ្ជាក់ថា ខ្ញុំជាព្រះជាម្ចាស់របស់អ្នកនោះឡើយ ប៉ុន្តែអ្នកគួរតែចេះសម្គាល់មើលថា ខ្ញុំមានប្រយោជន៍ដល់អ្នករាល់គ្នាឬអត់ នេះទើបជាកត្តាសំខាន់បំផុត។ បើទោះបីជាអ្នករកឃើញនូវភស្តុតាងដែលមិនអាចប្រកែកបាននៅក្នុងព្រះគម្ពីរ ភស្តុតាងនោះក៏មិនអាចនាំអ្នកឲ្យចូលមកចំពោះខ្ញុំទាំងស្រុងបានដែរ។ អ្នកគ្រាន់តែរស់នៅក្នុងដែនកំណត់នៃព្រះគម្ពីរប៉ុណ្ណោះ មិនមែននៅចំពោះខ្ញុំនោះទេ។ ព្រះគម្ពីរមិនអាចជួយអ្នកឲ្យស្គាល់ខ្ញុំបានទេ ក៏មិនអាចជួយឲ្យសេចក្ដីស្រឡាញ់ដែលអ្នកមានចំពោះខ្ញុំ កាន់តែស៊ីជម្រៅនោះដែរ។ ថ្វីដ្បិតព្រះគម្ពីរបានទាយថា ទារកម្នាក់នឹងត្រូវប្រសូត ក៏គ្មាននរណាអាចដឹងច្បាស់ថា បទទំនាយនឹងសម្រេចដោយសារនរណាដែរ ដ្បិតមនុស្សមិនដឹងពីកិច្ចការរបស់ព្រះជាម្ចាស់ ហើយនេះក៏ជាហេតុបណ្ដាលឲ្យពួកផារិស៊ីប្រឆាំងទាស់នឹងព្រះយេស៊ូវដែរ។ អ្នកខ្លះនិយាយថា កិច្ចការរបស់យើង គឺសម្រាប់ជាប្រយោជន៍ដល់មនុស្ស ប៉ុន្តែពួកគេនៅតែជឿថា ព្រះយេស៊ូវនិងខ្ញុំ គឺជាព្រះពីរអង្គដោយឡែកពីគ្នាទាំងស្រុង ជាព្រះដែលមិនចុះសម្រុងនឹងគ្នាទាល់តែសោះ។ នៅគ្រានោះ ព្រះយេស៊ូវគ្រាន់តែប្រទាននូវសេចក្ដីអធិប្បាយជាច្រើននៅក្នុងយុគសម័យនៃព្រះគុណ ទាក់ទងនឹងប្រធានបទនានាដូចជា វិធីអនុវត្ត វិធីជួបជុំគ្នា វិធីអធិដ្ឋានទូលអង្វរ វិធីប្រព្រឹត្តចំពោះអ្នកដទៃ ។ល។ កិច្ចការដែលទ្រង់បានអនុវត្ត គឺជាកិច្ចការក្នុងយុគសម័យនៃ

ព្រះគុណ ហើយទ្រង់ក៏បកស្រាយតែរបៀបដែលពួកសិស្សទ្រង់ និងអ្នកដែលដើរតាមទ្រង់ គួរអនុវត្តតែប៉ុណ្ណោះ។ ទ្រង់ធ្វើតែកិច្ចការក្នុងយុគសម័យនៃព្រះគុណ និងមិនបានធ្វើកិច្ចការនៃគ្រាចុងក្រោយទាល់តែសោះ។ កាលព្រះយេហូវ៉ាកត់ត្រាក្រឹត្យវិន័យសញ្ញាចាស់ ក្នុងយុគសម័យនៃក្រឹត្យវិន័យ ចុះហេតុអ្វីបានជាទ្រង់មិនធ្វើកិច្ចការក្នុងយុគសម័យនៃព្រះគុណផង? ហេតុអ្វីបានជាទ្រង់មិនបញ្ជាក់ពីកិច្ចការក្នុងយុគសម័យនៃព្រះគុណ ឲ្យច្បាស់ជាមុនផង។ តើការនេះនឹងមិនជួយឲ្យមនុស្សទទួលយកបានទេឬអី? ទ្រង់គ្រាន់តែទាយទុកថា ទារកម្នាក់នឹងប្រសូត ហើយនឹងមានព្រះចេស្ដា ប៉ុន្តែទ្រង់មិនបានអនុវត្តកិច្ចការក្នុងយុគសម័យនៃព្រះគុណ ទុកជាមុននោះឡើយ។ កិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងយុគសម័យនីមួយៗ មានដែនកំណត់ច្បាស់លាស់ ទ្រង់ធ្វើតែកិច្ចការក្នុងយុគសម័យបច្ចុប្បន្ន ហើយមិនដែលអនុវត្តកិច្ចការនៃដំណាក់កាលបន្ទាប់ទុកជាមុនឡើយ។ ទាល់តែបែបនេះ ទើបកិច្ចការតំណាងរបស់ទ្រង់ក្នុងយុគសម័យនីមួយៗ អាចត្រូវបានគេកត់សម្គាល់។ ព្រះយេស៊ូវបានមានព្រះបន្ទូលអំពីទីសម្គាល់នៃគ្រាចុងក្រោយ អំពីរបៀបអត់ធ្មត់ និងធ្វើយ៉ាងណាឲ្យបានសង្គ្រោះ អំពីរបៀបលន់តួបាប និងប្រែចិត្ត និងរបៀបលីឈើឆ្កាង និងទ្រាំរងនូវទុក្ខវេទនាតែប៉ុណ្ណោះ។ ប៉ុន្តែទ្រង់មិនធ្លាប់មានបន្ទូលអំពីរបៀបដែលមនុស្សនៅគ្រាចុងក្រោយសម្រេចបាននូវច្រកចូល ឬអំពីរបៀប ដែលគេគួរផ្គាប់បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ឡើយ។ ដូច្នេះ តើការស្វែងរក កិច្ចការរបស់ព្រះជាម្ចាស់ក្នុងគ្រាចុងក្រោយនៅក្នុងព្រះគម្ពីរ វាគួរឲ្យអស់សំណើចទេ? ដោយគ្រាន់តែប្រកាន់ខ្ជាប់តាមព្រះគម្ពីរ តើអ្នកអាចមើលឃើញអ្វីខ្លះ? រវាងគ្រូអធិប្បាយតាមព្រះគម្ពីរ និងអ្នកប្រកាសដំណឹងល្អ តើនរណាអាចបានឃើញកិច្ចការនាសម័យបច្ចុប្បន្នទុកជាមុន?

«អ្នកណាដែលមានត្រចៀក ចូរស្ដាប់ព្រះបន្ទូលដែលព្រះវិញ្ញាណថ្លែងទៅកាន់ក្រុមជំនុំទាំងអម្បាលម៉ានចុះ»។ ពេលនេះ តើអ្នករាល់គ្នាបានឮព្រះបន្ទូលនៃព្រះវិញ្ញាណបរិសុទ្ធហើយឬនៅ? ព្រះបន្ទូលរបស់ព្រះជាម្ចាស់ បានមកសណ្ឋិតលើអ្នករាល់គ្នាហើយ។ តើអ្នករាល់គ្នាស្ដាប់ឮព្រះបន្ទូលនេះទេ? ព្រះជាម្ចាស់ធ្វើកិច្ចការនៃព្រះបន្ទូល

នៅគ្រាចុងក្រោយ ហើយព្រះបន្ទូលនេះសោត ក៏ជាព្រះបន្ទូលនៃព្រះវិញ្ញាណបរិសុទ្ធដែរ ដ្បិតព្រះជាម្ចាស់ជាព្រះវិញ្ញាណបរិសុទ្ធ ហើយក៏អាចក្លាយជាសាច់ឈាមដែរ ហេតុនេះ ព្រះបន្ទូលនៃព្រះវិញ្ញាណបរិសុទ្ធ ក៏ជាព្រះបន្ទូលព្រះជាម្ចាស់ដែលប្រសូតជាសាច់ឈាមនាពេលបច្ចុប្បន្ន ដូចគេតំណាលពីអតីតកាលដែរ។ មានមនុស្សលេលាជាច្រើនដែលជឿថា ដ្បិតព្រះបន្ទូលនេះ គឺជាព្រះបន្ទូលដែលព្រះវិញ្ញាណបរិសុទ្ធកំពុងមានបន្ទូល ហេតុនេះ ព្រះសូរសៀងរបស់ទ្រង់គួរតែមានបន្ទូលពីស្ថានសួគ៌មក ដើម្បីឲ្យមនុស្សស្ដាប់ឮ។ នរណាដែលគិតបែបនេះ គេមិនស្គាល់កិច្ចការរបស់ព្រះជាម្ចាស់ទេ។ តាមការពិត ព្រះសូរសៀងដែលចេញពីព្រះឱស្ឋរបស់ព្រះវិញ្ញាណបរិសុទ្ធ ក៏ជាព្រះបន្ទូលដែលថ្លែងដោយព្រះជាម្ចាស់ដែលត្រឡប់ជាសាច់ឈាមដែរ។ ព្រះវិញ្ញាណបរិសុទ្ធមិនអាចមានព្រះបន្ទូលមកកាន់មនុស្ស ដោយផ្ទាល់បាននោះទេ សូម្បីតែក្នុងយុគសម័យនៃក្រឹត្យវិន័យ ព្រះយេហូវ៉ាក៏មិនបានមានព្រះបន្ទូលដោយផ្ទាល់ទៅកាន់ពួកបណ្ដាជនដែរ។ ទម្រាំឲ្យទ្រង់ធ្វើបែបនេះ ក្នុងយុគសម័យបច្ចុប្បន្នទៀត គឺរឹតតែមិនទំនងទៅទៀតហើយមែនទេ? ដើម្បីឲ្យព្រះជាម្ចាស់បញ្ចេញព្រះសូរសៀង ដើម្បីអនុវត្តកិច្ចការរបស់ទ្រង់ ទ្រង់ត្រូវក្លាយជាសាច់ឈាម។ ពុំនោះទេ កិច្ចការរបស់ទ្រង់នឹងមិនអាចសម្រេចគោលដៅនៃកិច្ចការនោះបានឡើយ។ អស់អ្នកណាដែលបដិសេធព្រះដែលត្រឡប់ជាសាច់ឈាម គឺជាមនុស្សដែលមិនស្គាល់ព្រះវិញ្ញាណ ឬស្គាល់គោលការណ៍ដែលព្រះជាម្ចាស់ប្រើ សម្រាប់កិច្ចការរបស់ព្រះអង្គ។ អស់អ្នកដែលជឿថា បច្ចុប្បន្ននេះគឺជាយុគសម័យនៃព្រះវិញ្ញាណបរិសុទ្ធ ប៉ុន្តែមិនទទួលកិច្ចការថ្មីរបស់ទ្រង់ គេគឺជាមនុស្សដែលរស់នៅក្នុងជំនឿស្រពេចស្រពិល និងបែបស្រមើស្រមៃ។ មនុស្សបែបនេះនឹងមិនទទួលបាននូវកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធឡើយ។ អស់អ្នកដែលសុំឲ្យតែព្រះវិញ្ញាណបរិសុទ្ធមានព្រះបន្ទូល និងអនុវត្តកិច្ចការរបស់ទ្រង់ដោយផ្ទាល់ ប៉ុន្តែមិនទទួលយកព្រះបន្ទូល ឬកិច្ចការរបស់ព្រះដែលត្រឡប់ជាសាច់ឈាម អ្នកនោះនឹងមិនអាចឈានចូលទៅក្នុងយុគសម័យថ្មី ឬអាចឲ្យព្រះជាម្ចាស់នាំយកសេចក្ដីសង្គ្រោះដ៏ពេញលេញ មកប្រទានឲ្យគេបាននោះឡើយ!

# មានតែអស់អ្នកដែលស្គាល់ព្រះជាម្ចាស់ និងស្គាល់កិច្ចការរបស់ទ្រង់ប៉ុណ្ណោះ ដែលអាចផ្គាប់ព្រះហឫទ័យព្រះជាម្ចាស់បាន

កិច្ចការរបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស មានពីរផ្នែក។ នៅពេលដែលទ្រង់បានត្រលប់ជាសាច់ឈាមជាលើកដំបូង មនុស្សមិនជឿលើទ្រង់ ឬស្គាល់ទ្រង់ឡើយ ហើយពួកគេបានឆ្កាងព្រះយេស៊ូវទៅនឹងឈើឆ្កាង។ បន្ទាប់មក នៅពេលដែលទ្រង់បានត្រលប់ជាសាច់ឈាមជាលើកទីពីរ មនុស្សនៅតែមិនជឿលើទ្រង់និងមិនស្គាល់ទ្រង់ដដែល ហើយពួកគេបានឆ្កាងព្រះគ្រីស្ទទៅនឹងឈើឆ្កាងសារជាថ្មី។ តើមនុស្សមិនមែនជាសត្រូវរបស់ព្រះជាម្ចាស់ទេឬអី? ប្រសិនបើមនុស្សពុំស្គាល់ទ្រង់ទេ តើមនុស្សអាចជិតស្និទ្ធនឹងព្រះជាម្ចាស់បានដោយរបៀបណា? តើគេអាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីធ្វើទីបន្ទាល់អំពីព្រះជាម្ចាស់បានដោយរបៀបណា? ការដែលមនុស្សអះអាងថាស្រឡាញ់ព្រះជាម្ចាស់ បម្រើព្រះជាម្ចាស់ និងថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់ តើវាមិនមែនជាការកុហកបោកប្រាស់ទេឬអី? ប្រសិនបើអ្នកលះបង់ជីវិតរបស់អ្នកចំពោះអ្វីៗដែលមិនពិត មិនជាក់ស្ដែង តើអ្នកមិនខំប្រឹងដោយអសារឥតការទេឬអី? តើអ្នកអាចក្លាយជាមនុស្សជិតស្និទ្ធនឹងព្រះជាម្ចាស់ បានដោយរបៀបណា នៅពេលដែលអ្នកមិនទាំងស្គាល់ថាព្រះជាម្ចាស់ជានរណាផងនោះ? តើការស្វែងរកដោយបែបនេះ មិនស្រពេចស្រពិល និងអរូបីទេឬអី? តើវាមិនមែនជាការបោកបញ្ឆោតទេឬអី? តើមនុស្សម្នាក់អាចជិតស្និទ្ធនឹងព្រះជាម្ចាស់បានដោយរបៀបណា? តើការក្លាយជាមនុស្សជិតស្និទ្ធនឹងព្រះជាម្ចាស់ មានអត្ថន័យជាក់ស្ដែងយ៉ាងណា? តើអ្នកអាចក្លាយជាមនុស្សជិតស្និទ្ធនឹងព្រះវិញ្ញាណនៃព្រះជាម្ចាស់បានដែរឬទេ? តើអ្នកអាចមើលឃើញថាព្រះវិញ្ញាណអស្ចារ្យ និងខ្ពង់ខ្ពស់ប៉ុនណាដែរឬទេ? ដើម្បីក្លាយជាមនុស្សជិតស្និទ្ធនឹងព្រះជាម្ចាស់ ដែលមើលមិនឃើញ និងគ្មានរូបរាង តើវាមិនស្រពេចស្រពិល និងអរូបីទេឬអី? តើអត្ថន័យជាក់ស្ដែងនៃការស្វែងរកបែបនេះគឺជាអ្វីដែរ? តើវាមិនមែន

ជាការកុហកបោកប្រាស់ទាំងស្រុងទេឬអី? អ្វីដែលអ្នកស្វែងរក គឺដើម្បីក្លាយជាមនុស្សជិតស្និទ្ធនឹងព្រះជាម្ចាស់ ប៉ុន្ដែតាមពិតទៅ អ្នកគ្រាន់តែជាកូនចៅរបស់សាតាំងប៉ុណ្ណោះ ដ្បិតអ្នកមិនស្គាល់ព្រះជាម្ចាស់ឡើយ ហើយអ្នកស្វែងរក «ព្រះនៃសព្វសារពើ» ដែលគ្មានអត្ថិភាព ដែលមិនអាចមើលឃើញ គ្មានរូបរាង និងគ្រាន់តែជាព្រះដែលកើតពីសញ្ញាណផ្ទាល់ខ្លួនរបស់អ្នកប៉ុណ្ណោះ។ ដោយនិយាយបែបស្រពេចស្រពិលទៅ «ព្រះ» បែបនេះ គឺជាសាតាំងតែម្ដង ហើយបើនិយាយឲ្យច្បាស់លាស់វិញ ព្រះបែបនេះ គឺជាខ្លួនឯងផ្ទាល់។ អ្នកស្វះស្វែងដើម្បីក្លាយជាមនុស្សជិតស្និទ្ធនឹងខ្លួនឯង ប៉ុន្ដែនៅបន្តនិយាយថា អ្នកស្វែងរកដើម្បីបានក្លាយជាមនុស្សជិតស្និទ្ធនឹងព្រះជាម្ចាស់ តើនេះមិនមែនជាការប្រមាថទេឬអី? តើការស្វែងរកដោយបែបនេះមានតម្លៃអ្វីទៅ? ប្រសិនបើព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ មិនបានត្រលប់ជាសាច់ឈាម នោះសារជាតិរបស់ព្រះជាម្ចាស់ គឺគ្រាន់តែជាព្រះវិញ្ញាណនៃជីវិតដែលមិនអាចមើលឃើញ គ្មានរូបរាង គ្មានទម្រង់ និងគ្មានសណ្ឋាន ជាប្រភេទដែលគ្មានលក្ខណៈរូប ដែលមនុស្សមិនអាចចូលទៅជិតបាន និងមិនអាចយល់បានប៉ុណ្ណោះ។ តើមនុស្សអាចមានភាពជិតស្និទ្ធនឹងព្រះវិញ្ញាណដែលគ្មានរូប អស្ចារ្យ និងមិនអាចវាស់ស្ទង់បាននេះដោយបែបណាទៅ? តើនេះមិនមែនជាការកំប្លែងលេងទេឬអី? ការរកហេតុផលដែលខុសទំនងបែបនេះ គឺមិនត្រឹមត្រូវ និងមិនជាក់ស្ដែងឡើយ។ មនុស្សដែលត្រូវបានបង្កើតមក គឺជាប្រភេទខុសគ្នាពីព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ ដូច្នេះ តើគេទាំងពីរអាចជិតស្និទ្ធនឹងគ្នាបានដោយរបៀបណា? ប្រសិនបើព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ មិនត្រូវបានគេស្គាល់ជាសាច់ឈាមទេ ប្រសិនបើព្រះជាម្ចាសមិនបានត្រលប់ជាសាច់ឈាម និងបន្ទាបព្រះអង្គទ្រង់ តាមរយៈការក្លាយជាមនុស្សទេ មនុស្សដែលបង្កើតមកនេះ នឹងមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងមិនអាចក្លាយជាមនុស្សជិតស្និទ្ធនឹងទ្រង់បានឡើយ ហើយក្រៅតែពីអ្នកដែលជឿលើព្រះជាម្ចាស់ ដែលអាចមានឱកាសក្នុងការក្លាយជាមនុស្សជិតស្និទ្ធនឹងព្រះជាម្ចាស់បាន ក្រោយពីព្រលឹងរបស់ពួកគេ បានចូលទៅក្នុងស្ថានសួគ៌ ក្រៅពីនេះ មនុស្សភាគច្រើននឹងមិនអាចមានភាពជិតស្និទ្ធនឹងព្រះវិញ្ញាណ

របស់ព្រះជាម្ចាស់បានឡើយ។ ហើយប្រសិនបើមនុស្ស ចង់មានភាពជិតស្និទ្ធនឹងព្រះជាម្ចាស់នៅឯស្ថានសួគ៌ ក្រោមការណែនាំរបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស តើពួកគេមិនមែនជាអមនុស្សដែលឆ្កួតលីលាខ្លាំងបំផុតទេឬអី? មនុស្សគ្រាន់តែស្វែងរក «សេចក្ដីស្មោះត្រង់» ចំពោះព្រះដែលមិនអាចមើលឃើញប៉ុណ្ណោះ និងមិនបានយកចិត្តទុកដាក់សូម្បីបន្តិច ចំពោះព្រះជាម្ចាស់ដែលអាចមើលឃើញ ដ្បិតការស្វែងរកព្រះជាម្ចាស់ ដែលមើលមិនឃើញ គឺងាយស្រួលខ្លាំងណាស់។ ទោះបីជាមនុស្សអាចធ្វើអ្វីតាមដែលពួកគេចង់ក៏ដោយ ប៉ុន្តែការស្វែងរកព្រះជាម្ចាស់ដែលអាចមើលឃើញ គឺមិនងាយស្រួលសោះឡើយ។ បុគ្គលដែលស្វែងរកព្រះដ៏ស្រពេចស្រពិល គឺច្បាស់ជាមិនអាចទទួលយកព្រះជាម្ចាស់បានឡើយ ដ្បិតអ្វីៗដែលស្រពេចស្រពិល និងអរូបី គឺមនុស្សនឹកស្រមៃបាន ហើយមនុស្សមិនអាចទទួលបានវាឡើយ។ ប្រសិនបើព្រះជាម្ចាស់ដែលយាងមកក្នុងចំណោមអ្នករាល់គ្នា គឺជាព្រះជាម្ចាស់ដែលខ្ពស់ត្រដែត និងថ្កើងថ្កាន ដែលអ្នករាល់គ្នាមិនអាចចូលទៅជិតបាន នោះតើអ្នករាល់គ្នាអាចយល់ពីបំណងព្រះហឫទ័យរបស់ទ្រង់បានដោយរបៀបណា? ហើយតើអ្នកអាចដឹង និងយល់ពីទ្រង់បានដោយរបៀបណា? ប្រសិនបើទ្រង់គ្រាន់តែបំពេញកិច្ចការរបស់ទ្រង់ និងពុំមានការប្រាស្រ័យទាក់ទងជាធម្មតាជាមួយមនុស្ស ឬពុំមានលក្ខណៈជាមនុស្សធម្មតា និងមិនអាចឲ្យមនុស្សធម្មតា ចូលទៅជិតបាន ដូចនេះ បើទោះបីជាទ្រង់បានបំពេញកិច្ចការយ៉ាងច្រើន សម្រាប់អ្នករាល់គ្នាក៏ដោយ ក៏ប៉ុន្តែអ្នករាល់គ្នាមិនមានការប្រាស្រ័យទាក់ទងជាមួយទ្រង់ និងមិនអាចមើលឃើញទ្រង់បាន តើអ្នកអាចស្គាល់ទ្រង់បានដោយរបៀបណា? ប្រសិនបើមិនមែនដោយសារសាច់ឈាមដែលមនុស្សធម្មតាមាន មនុស្សនឹងគ្មានផ្លូវអាចស្គាល់ព្រះជាម្ចាស់បានឡើយ។ នេះគឺដោយសារការយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់ ទើបមនុស្សមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីក្លាយជាមនុស្សជិតស្និទ្ធនឹងព្រះជាម្ចាស់ខាងសាច់ឈាម។ មនុស្សមានភាពជិតស្និទ្ធនឹងព្រះជាម្ចាស់ ដោយសារពួកគេបានមកជួបទ្រង់ ដោយសារពួកគេរស់នៅជាមួយនឹងទ្រង់ និងអមដំណើរទ្រង់ ហើយដូច្នេះ

ក៏បានស្គាល់ទ្រង់ទៅ។ ប្រសិនបើមិនដូច្នេះទេ តើការស្វែងរករបស់មនុស្សមិនទៅជាអសារឥតការទេឬអី? នោះមានន័យថា មិនមែនដោយសារកិច្ចការទាំងអស់របស់ព្រះជាម្ចាស់ ដែលធ្វើឲ្យមនុស្សអាចមានភាពស្និទ្ធស្នាលនឹងព្រះជាម្ចាស់នោះទេ ប៉ុន្តែដោយសារភាពពិត និងភាពសាមញ្ញរបស់ព្រះដែលយកកំណើតជាមនុស្ស។ ដោយព្រោះព្រះជាម្ចាស់បានត្រលប់ជាសាច់ឈាម ទើបមនុស្សមានឱកាសបំពេញភារកិច្ចរបស់ពួកគេ និងមានឱកាសថ្វាយបង្គំព្រះដ៏ពិត។ តើនេះមិនមែនជាសេចក្ដីពិតដែលប្រាកដ និងជាក់ស្ដែងទេឬអី? សព្វថ្ងៃនេះ តើអ្នកនៅបន្តចង់ក្លាយជាមនុស្សជិតស្និទ្ធនឹងព្រះជាម្ចាស់នៅស្ថានសួគ៌ទៀតដែរឬទេ? មានតែពេលដែលព្រះជាម្ចាស់បន្ទាបព្រះអង្គទ្រង់មកដល់ចំណុចណាមួយប៉ុណ្ណោះ ពោលគឺមានតែពេលដែលព្រះជាម្ចាស់បានត្រលប់ជាសាច់ឈាមប៉ុណ្ណោះ ដែលមនុស្សអាចក្លាយជាមនុស្សជិតស្និទ្ធ និងជាមនុស្សជំនិតរបស់ទ្រង់បាន។ ព្រះជាម្ចាស់គឺជាព្រះវិញ្ញាណ៖ តើមនុស្សអាចមានលក្ខណៈសម្បត្តិធ្វើជាមនុស្សជិតស្និទ្ធនឹងព្រះវិញ្ញាណដែលថ្កុំថ្កើងនិងមិនអាចវាស់ស្ទង់បាននេះ បានដោយរបៀបណា? មានតែពេលដែលព្រះវិញ្ញាណរបស់ព្រះជាម្ចាស់យាងចុះមកយកកំណើតមកខាងសាច់ឈាម និងក្លាយជាសភាវៈដែលមានសម្បកខាងក្រៅដូចជាមនុស្សជាតិតែប៉ុណ្ណោះ ដែលមនុស្សអាចយល់ពីបំណងព្រះហឫទ័យរបស់ទ្រង់បាន និងអាចឲ្យទ្រង់ទទួលយកបានដោយពិតប្រាកដ។ ទ្រង់មានបន្ទូល និងបំពេញកិច្ចការខាងសាច់ឈាម ចែករំលែកសេចក្ដីអរសប្បាយ ទុក្ខសោក និងការឈឺចាប់របស់មនុស្សជាតិ រស់នៅក្នុងពិភពតែមួយជាមួយមនុស្សជាតិ ការពារមនុស្សជាតិ និងណែនាំពួកគេ ហើយតាមរយៈការនេះ ទ្រង់សម្អាតមនុស្សឲ្យបានស្អាត និងអនុញ្ញាតឲ្យពួកគេ ទទួលបាននូវការសង្គ្រោះ និងព្រះពររបស់ទ្រង់។ នៅពេលទទួលបានអ្វីទាំងអស់នេះហើយ មនុស្សពិតជាស្គាល់ពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ហើយមានតែពេលនោះទេ ដែលពួកគេអាចក្លាយជាមនុស្សជិតស្និទ្ធនឹងព្រះជាម្ចាស់បាន។ មានតែចំណុចនេះទេដែលជាក់ស្ដែង។ ប្រសិនបើព្រះជាម្ចាស់ ពិតជាមិនអាចឲ្យមនុស្សមើលឃើញ និងអរូបីមែន នោះតើពួកគេអាចក្លាយជាមនុស្សជិតស្និទ្ធនឹងទ្រង់

បានដោយរបៀបណា? តើនេះមិនមែនជាគោលលទ្ធិដែលទទេសូន្យទេឬអី?

ដោយបានជឿលើព្រះជាម្ចាស់មកទល់បច្ចុប្បន្ននេះក្តី មានមនុស្សជាច្រើននៅបន្តស្វែងរកអ្វីដែលស្រពេចស្រពិលនិងអរូបីដដែល។ ពួកគេពុំបានយល់ពីការពិតនៃកិច្ចការរបស់ព្រះជាម្ចាស់ក្នុងពេលបច្ចុប្បន្ននេះឡើយ ហើយនៅបន្តរស់នៅទៅតាមន័យពាក្យ និងគោលលទ្ធិនានាដដែល។ បន្ថែមលើនេះ មនុស្សជាច្រើនមិនទាន់ចូលទៅក្នុងការពិតនៃដំណាក់កាលថ្មីៗដូចជា «ជំនាន់ថ្មីនៃអ្នក ដែលស្រឡាញ់ដល់ព្រះជាម្ចាស់» «មនុស្សជិតស្និទ្ធនឹងព្រះជាម្ចាស់» «ឧទាហរណ៍ និងគំរូនៃការស្រឡាញ់ព្រះជាម្ចាស់» និង «បែបផែនរបស់ពេត្រុស»។ ផ្ទុយទៅវិញ ការស្វែងរករបស់ពួកគេ គឺនៅតែស្រពេចស្រពិល និងអរូបរីដដែល ពួកគេនៅបន្តរាវរកនៅក្នុងគោលលទ្ធិ ហើយពួកគេគ្មានការយល់ដឹង អំពីការពិតនៃព្រះបន្ទូលទាំងអស់នេះឡើយ។ នៅពេលព្រះវិញ្ញាណនៃព្រះជាម្ចាស់បានត្រលប់ជាសាច់ឈាម អ្នកអាចមើលឃើញ និងអាចប៉ះពាល់កិច្ចការរបស់ទ្រង់នៅក្នុងសាច់ឈាមបាន។ ប៉ុន្តែ ប្រសិនបើអ្នកនៅតែមិនអាចក្លាយជាមនុស្សជិតស្និទ្ធនឹងទ្រង់បានទេ ប្រសិនបើអ្នកនៅតែមិនអាចក្លាយជាមនុស្សជំនិតរបស់ទ្រង់បានទេ នោះតើអ្នកអាចក្លាយជាមនុស្សជំនិតរបស់ព្រះវិញ្ញាណនៃព្រះជាម្ចាស់ បានដោយរបៀបណា? ប្រសិនបើអ្នកមិនស្គាល់ព្រះជាម្ចាស់ក្នុងពេលបច្ចុប្បន្ននេះ តើអ្នកអាចក្លាយជាមនុស្សម្នាក់ ក្នុងចំណោមមនុស្សនៅជំនាន់ថ្មីនៃអស់អ្នកដែលស្រឡាញ់ព្រះជាម្ចាស់បានដោយរបៀបណា? តើដំណាក់កាលទាំងនេះមិនមែនជាន័យពាក្យ និងគោលលទ្ធិដែលគ្មានសារជាតិទេឬអី? តើអ្នកអាចមើលឃើញព្រះវិញ្ញាណ និងយល់ពីព្រះហឫទ័យរបស់ទ្រង់ដែរឬទេ? តើដំណាក់កាលនេះ មិនទទេស្អាតទេឬអី? វាមិនគ្រប់គ្រាន់ទេដែលអ្នកគ្រាន់តែនិយាយពីដំណាក់កាល និងពាក្យសម្ដីទាំងនេះ ហើយអ្នកមិនអាចគាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់តាមរយៈការតាំងចិត្ត តែមួយមុខនោះទេ។ អ្នកពេញចិត្តដោយគ្រាន់តែនិយាយពាក្យទាំងអស់នេះ ហើយអ្នកបានធ្វើបែបនេះ ដើម្បីបំពេញបំណងរបស់ខ្លួនឯងផ្ទាល់ ដើម្បីផ្គាប់តាមគំនិតមិនពិតប្រាកដរបស់អ្នក និងដើម្បីផ្គាប់តាមសញ្ញាណ និងការគិតរបស់អ្នក

ផ្ទាល់។ ប្រសិនបើអ្នកមិនស្គាល់ព្រះជាម្ចាស់បច្ចុប្បន្ននេះទេ នោះមិនថាអ្នកធ្វើអ្វីនោះទេ អ្នកនឹងមិនអាចផ្គាប់ដួងព្រះហឫទ័យរបស់ព្រះជាម្ចាស់បានឡើយ។ តើការដែលក្លាយជាមនុស្សជំនិតរបស់ព្រះជាម្ចាស់មានន័យដូចម្ដេច? តើអ្នកនៅមិនយល់ចំណុចនេះទៀតឬអី? ដោយសារអ្នកជិតស្និទ្ធនឹងព្រះជាម្ចាស់គឺជាមនុស្ស នោះព្រះជាម្ចាស់ក៏ជាមនុស្សដែរ។ នេះមានន័យថាព្រះជាម្ចាស់បានត្រលប់ជាសាច់ឈាម និងក្លាយជាមនុស្សលោក។ មានតែអស់អ្នកដែលមានប្រភេទដូចគ្នាប៉ុណ្ណោះ ទើបអាចហៅគ្នាថាមនុស្សជំនិតបាន ហើយមានតែពេលនោះទេ ដែលពួកគេអាចចាត់ទុកជាមនុស្សជំនិតបាន។ ប្រសិនបើព្រះជាម្ចាស់ គឺជាព្រះវិញ្ញាណ តើមនុស្សដែលបានបង្កើតមកនេះអាចក្លាយជាមនុស្សជិតស្និទ្ធនឹងទ្រង់បានដោយរបៀបណា?

ជំនឿរបស់អ្នកចំពោះព្រះជាម្ចាស់ ការស្វែងរកសេចក្ដីពិតរបស់អ្នក ហើយសូម្បីតែរបៀបដែលអ្នកប្រព្រឹត្ត ក៏ផ្អែកលើការពិតទាំងអស់នេះផងដែរ។ អ្វីគ្រប់យ៉ាងដែលអ្នកធ្វើគប្បីមានលក្ខណៈជាក់ស្ដែង ហើយអ្នកមិនគប្បីស្វែងរកអ្វីដែលមិនពិត និងរវើរវាយនោះទេ។ ការប្រព្រឹត្តដោយបែបនេះ ពុំមានតម្លៃអ្វីឡើយ ហើយក៏គ្មានសារជាតិចំពោះជីវិតបែបនេះដែរ។ ដោយសារការស្វែងរក និងជីវិតរបស់អ្នក មិនបានចំណាយលើអ្វីផ្សេងក្រៅពីភាពក្លែងក្លាយ និងការបោកបញ្ឆោតឡើយ ហើយដោយសារអ្នកមិនស្វែងរកអ្វីដែលមានតម្លៃ និងមានសារជាតិ នោះអ្វីដែលអ្នកទទួលបាន គឺជាហេតុផលដែលខុសទំនង និងគោលលទ្ធិមិនត្រឹមត្រូវ ដែលមិនមែនជាសេចក្ដីពិត។ អ្វីអស់ទាំងនោះ គ្មានទំនាក់ទំនងទៅនឹងតម្លៃ និងសារជាតិនៃវត្តមានរស់នៅរបស់អ្នកឡើយ ហើយគ្រាន់តែអាចនាំអ្នកទៅកាន់ពិភពរាក់កំផែលមួយប៉ុណ្ណោះ។ តាមរយៈការនេះ ជីវិតទាំងមូលរបស់អ្នកនឹងមិនមានតម្លៃ ឬអត្ថន័យអ្វីឡើយ ហើយប្រសិនបើអ្នកមិនស្វែងរកជីវិតមួយដែលមានអត្ថន័យទេ នោះអ្នកអាចរស់នៅបានមួយរយឆ្នាំមែន តែការរស់នៅនោះនឹងគ្មានប្រយោជន៍អ្វីទាំងអស់។ តើជីវិតបែបនេះ អាចហៅថាជាជីវិតរបស់មនុស្សបានដោយរបៀបណា? តាមពិតទៅ តើវាមិនមែនជាជីវិតរបស់សត្វទេឬអី? ដូចគ្នានេះដែរ ប្រសិនបើអ្នករាល់គ្នាព្យាយាមដើរតាមផ្លូវនៃជំនឿលើព្រះជាម្ចាស់

ប៉ុន្តែមិនព្យាយាមដើម្បីស្វែងរកព្រះជាម្ចាស់ដែលអាចមើលឃើញបាន តែបែរជាទៅថ្វាយបង្គំព្រះដែលមើលមិនឃើញ និងអរូបីទៅវិញ នោះតើការស្វែងរកបែបនេះ មិនកាន់តែអសារឥតការទេឬអី? នៅចុងបញ្ចប់ទៅ ការស្វែងរករបស់អ្នកនឹងក្លាយជាគំនរបាក់បែក។ តើការស្វែងរកបែបនេះ មានប្រយោជន៍អ្វីចំពោះអ្នក? បញ្ហាធំបំផុតសម្រាប់មនុស្សគឺថា គេគ្រាន់តែស្រឡាញ់អ្វីដែលគេមិនអាចមើលឃើញឬប៉ះបានប៉ុណ្ណោះ ពោលគឺអ្វីដែលមានអាថ៌កំបាំង និងអស្ចារ្យខ្លាំងបំផុត និងអ្វីដែលមនុស្សមិនអាចស្រមៃបាន ហើយមនុស្សធម្មតាមិនអាចចាំយកបាន។ នៅពេលដែលអ្វីទាំងអស់នេះកាន់តែមិនពិតប្រាកដ នោះមនុស្សកាន់តែវិភាគវាខ្លាំងឡើង ហើយមនុស្សកាន់តែស្វែងរកអ្វីអស់ទាំងនោះដោយមិនប្រុងប្រយ័ត្ន និងព្យាយាមយកអ្វីទាំងនោះឲ្យបាន។ នៅពេលដែលអ្វីទាំងនោះកាន់តែអរូបី មនុស្សកាន់តែពិនិត្យពិច័យនិងវិភាគវាដោយយកចិត្តទុកដាក់ ហើយថែមទាំងធ្វើឲ្យគំនិតអំពីអ្វីអស់ទាំងនោះកាន់តែជ្រាលជ្រៅថែមទៀត។ ផ្ទុយទៅវិញ នៅពេលដែលអ្វីៗកាន់តែជាក់ស្ដែង មនុស្សកាន់តែមិនឲ្យតម្លៃលើវា។ ពួកគេមិនឲ្យតម្លៃលើអ្វីអស់ទាំងនោះ ហើយថែមទាំងមើលងាយវាទៀតផង។ តើនេះមិនមែនជាអាកប្បកិរិយារបស់អ្នករាល់គ្នា ចំពោះកិច្ចការជាក់ស្ដែងដែលខ្ញុំធ្វើក្នុងពេលបច្ចុប្បន្ននេះទេឬអី? នៅពេលអ្វីទាំងអស់នោះ កាន់តែជាក់ស្ដែងឡើងៗ អ្នករាល់គ្នាកាន់តែលម្អៀង ព្រោះស្អប់អ្វីទាំងអស់នោះ។ អ្នកមិនបានចំណាយពេលដើម្បីពិនិត្យមើលវា ហើយបែរជាមិនអើពើនឹងវាទៅវិញ។ អ្នកមើលស្រាលចំពោះលក្ខខណ្ឌតម្រូវដែលជាក់ស្ដែង និងទាបតូចនេះ ហើយបែរជាមានសញ្ញាណច្រើនអំពីព្រះជាម្ចាស់ដែលពិតប្រាកដបំផុតនេះទៅវិញ ថែមទាំងមិនអាចទទួលយកនូវការពិត និងភាពសាមញ្ញរបស់ទ្រង់បានទៀតផង។ តាមរបៀបនេះ តើអ្នករាល់គ្នាមិនមែនកំពុងប្រកាន់តាមជំនឿស្រពេចស្រពិលទេឬអី? អ្នករាល់គ្នាមានសេចក្ដីជំនឿដ៏មុតមាំចំពោះព្រះដ៏ស្រពេចស្រពិលកាលពីអតីតកាល ហើយគ្មានចាប់អារម្មណ៍នឹងព្រះជាម្ចាស់ដ៏ពិតប្រាកដនៃសម័យបច្ចុប្បន្ននេះសោះ។ តើនេះមិនមែនដោយសារព្រះជាម្ចាស់នៃអតីតកាល និងព្រះជាម្ចាស់នៃបច្ចុប្បន្នកាលនេះ មកពីសម័យពីរ

ខុសគ្នាទេឬអី? តើនេះមិនមែនដោយសារព្រះជាម្ចាស់នៃអតីតកាលគឺជាព្រះជាម្ចាស់នៅស្ថានសួគ៌ដែលខ្ពង់ខ្ពស់ ចំណែកឯព្រះជាម្ចាស់នៃបច្ចុប្បន្នកាលនេះ គឺជាមនុស្សតូចទាបនៅលើផែនដីទេឬអី? បន្ថែមលើនេះ តើវាមិនមែនដោយសារព្រះជាម្ចាស់ដែលមនុស្សថ្វាយបង្គំ គឺជាព្រះដែលបង្កើតឡើងនៅក្នុងសញ្ញាណរបស់គេចំណែកឯព្រះជាម្ចាស់នៃបច្ចុប្បន្នកាលនេះ គឺជាព្រះខាងសាច់ឈាមពិតៗ ដែលកើតនៅលើផែនដីនេះទេឬអី? នៅពេលដែលអ្វីគ្រប់យ៉ាងត្រូវបាននិយាយ និងធ្វើរួចរាល់ តើវាមិនមែនដោយសារព្រះជាម្ចាស់នៃបច្ចុប្បន្ននេះ ពិតប្រាកខ្លាំងពេក ទើបធ្វើឲ្យមនុស្សមិនស្វែងរកទ្រង់ទេឬអី? ដ្បិតអ្វីដែលព្រះជាម្ចាស់នៃបច្ចុប្បន្នកាលនេះទាមទារពីមនុស្សគឺច្បាស់ជាអ្វីដែលមនុស្សមិនសុខចិត្តធ្វើតាម និងជាអ្វីដែលធ្វើឲ្យពួកគេមានអារម្មណ៍អាប់មុខ។ តើនេះមិនមែនធ្វើឲ្យមនុស្សកាន់តែលំបាកទេឬអី? តើនេះមិនមែនជាការបើកបង្ហាញស្នាមរបួសរបស់មនុស្សទេឬអី? តាមរបៀបនេះ មនុស្សជាច្រើនមិនស្វះស្វែងរកព្រះជាម្ចាស់ដ៏ពិត ព្រះជាម្ចាស់ដ៏ជាក់ស្ដែង ដូច្នេះហើយ ពួកគេក្លាយជាសត្រូវនឹងព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស ដែលអាចនិយាយបានថាជាពួកទទឹងនឹងព្រះគ្រីស្ទ។ តើនេះមិនមែនជាការពិតច្បាស់ក្រឡែតទេឬអី? កាលពីអតីតកាល នៅពេលដែលព្រះជាម្ចាស់មិនទាន់បានត្រលប់ជាសាច់ឈាមនៅឡើយ អ្នកអាចក្លាយជាមេដឹកនាំសាសនា ឬជាអ្នកជឿដែលកោតខ្លាចព្រះជាម្ចាស់។ បន្ទាប់ពីព្រះជាម្ចាស់បានត្រលប់ជាសាច់ឈាម អ្នកជឿដែលកោតខ្លាចព្រះជាម្ចាស់ជាច្រើនបានក្លាយជាពួកទទឹងនឹងព្រះគ្រីស្ទដោយមិនដឹងខ្លួន។ តើអ្នកដឹងថាមានអ្វីកើតឡើងដែរឬទេ? នៅក្នុងជំនឿរបស់អ្នកលើព្រះជាម្ចាស់ អ្នកមិនបានចាប់អារម្មណ៍លើការពិត ឬស្វែងរក សេចក្ដីពិតនោះទេ តែបែរជាជាប់ជំពាក់យ៉ាងក្រាស់ក្រែល ទៅនឹងភាពក្លែងក្លាយទៅវិញហើយតើនេះមិនមែនជាប្រភពយ៉ាងច្បាស់ក្រឡែតអំពីការប្រឆាំងរបស់អ្នកចំពោះព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សទេឬអី? ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស ត្រូវបានគេហៅថាព្រះគ្រីស្ទ ដូចនេះ តើអ្នកទាំងឡាយដែលមិនជឿលើព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស មិនមែនជាពួកទទឹងទាស់នឹង

ព្រះគ្រីស្ទទេឬអី? ដូច្នេះ តើមនុស្សម្នាក់ដែលអ្នកជឿ និងស្រឡាញ់ ពិតជាព្រះជាម្ចាស់នៅក្នុងសាច់ឈាមមែនទេ? តើព្រះជាម្ចាស់ដែលមានព្រះជន្មរស់ មានដកដង្ហើម គឺជាព្រះដែលពិតប្រាកដជាងគេ និងសាមញ្ញជាងគេមែនទេ? តើគោលបំណងពិតប្រាកដនៃការស្វែងរករបស់អ្នកគឺជាអ្វីដែរ? តើវានៅឯស្ថានសួគ៌ ឬនៅលើផែនដី? តើវាជាសញ្ញាណ ឬជាសេចក្ដីពិត? តើជាព្រះជាម្ចាស់ ឬជាភាវៈអភិធម្មជាតិមួយចំនួន? ជាការពិតណាស់ សេចក្ដីពិតគឺជាសុភាសិតពិតជាងគេបំផុតនៃជីវិត និងជាសុភាសិតដែលខ្ពស់ជាងគេបំផុតក្នុងចំណោមមនុស្សជាតិទាំងអស់។ ដោយសារវាជាសេចក្ដីតម្រូវដែលព្រះជាម្ចាស់តម្រូវឱ្យមនុស្សលោកធ្វើ និងជាកិច្ចការដែលព្រះជាម្ចាស់ធ្វើដោយផ្ទាល់ ហេតុនេះ កិច្ចការនេះហៅថា «ភាសិតនៃជីវិត»។ វាមិនមែនជាភាសិតមួយដែលបង្កើតចេញពីអ្វីមួយឡើយ វាមិនមែនជាសម្រង់សម្ដីពីបុគ្គលដ៏អស្ចារ្យណាមួយនោះទេ។ ផ្ទុយទៅវិញ វាគឺជាសូរសៀងរបស់ម្ចាស់នៃស្ថានសួគ៌និងផែនដី និងម្ចាស់នៃគ្រប់សព្វសារពើទាំងអស់។ វាមិនមែនជាពាក្យបង្កើតចេញពីមនុស្សជាតិនោះទេ ប៉ុន្តែជាជីវិតផ្ទាល់របស់ព្រះជាម្ចាស់។ ហេតុនេះហើយ គេហៅវាថា «ភាសិតនៃជីវិតដែលខ្ពង់ខ្ពស់បំផុត»។ ការស្វែងរករបស់មនុស្សក្នុងការដាក់បញ្ចូលសេចក្ដីពិតទៅក្នុងការអនុវត្ត គឺជាការបំពេញកិច្ចការរបស់ពួកគេពោលគឺវាជាការស្វែងរកការបំពេញតាមសេចក្ដីតម្រូវរបស់ព្រះជាម្ចាស់។ សារជាតិនៃសេចក្ដីតម្រូវនេះ មានលក្ខណៈពិតប្រាកដបំផុតក្នុងចំណោមសេចក្ដីពិតទាំងអស់ ជាជាងគោលលទ្ធិទទេសូន្យដែលគ្មានមនុស្សណាម្នាក់អាចសម្រេចបាន។ ប្រសិនបើការស្វែងរករបស់អ្នក គឺគ្មានអ្វីផ្សេងក្រៅពីគោលលទ្ធិ និងគ្មាននូវការពិតទេ តើអ្នកមិនមែនបះបោរទាស់នឹងសេចក្ដីពិតទេឬអី? តើអ្នកមិនមែនជាមនុស្សម្នាក់ ដែលវាយប្រហារលើសេចក្ដីពិតទេឬអី? តើមនុស្សបែបនេះអាចក្លាយជាមនុស្សម្នាក់ដែលស្វះស្វែងស្រឡាញ់ព្រះជាម្ចាស់ដោយរបៀបណា? មនុស្សដែលគ្មានការពិត គឺជាអ្នកដែលផិតក្បត់នឹងសេចក្ដីពិត ហើយពួកគេជាពួកបះបោរពីកំណើត!

ក្រៅពីនេះ មិនថាអ្នកកំពុងស្វែងរកអ្វីនោះទេ អ្នកត្រូវយល់ពីកិច្ចការដែលព្រះ

ជាម្ចាស់ធ្វើនៅថ្ងៃនេះ ហើយអ្នកត្រូវដឹងពីសារៈសំខាន់នៃកិច្ចការនេះ។ អ្នកត្រូវយល់ និងដឹងពីកិច្ចការដែលព្រះជាម្ចាស់នាំមក នៅពេលដែលទ្រង់យាងមកនៅគ្រាចុងក្រោយ ដឹងពីនិស្ស័យអ្វីដែលទ្រង់នាំមក និងដឹងពីអ្វីដែលទ្រង់ធ្វើឲ្យមនុស្សបានបរិបូរណ៍។ ប្រសិនបើអ្នកមិនដឹង ឬមិនយល់អំពីកិច្ចការដែលទ្រង់បានយាងមក ដើម្បីធ្វើនៅក្នុងសាច់ឈាមទេ នោះតើអ្នកអាចយល់ពីបំណងព្រះហឫទ័យរបស់ទ្រង់បានដោយរបៀបណា ហើយតើអ្នកអាចក្លាយជាមនុស្សជិតស្និទ្ធនឹងទ្រង់បានដោយរបៀបណា? ពិតណាស់ ការក្លាយជាមនុស្សជិតស្និទ្ធនឹងព្រះជាម្ចាស់ គឺមិនសាំញ៉ាំនោះទេ ប៉ុន្តែក៏មិនមែនជារឿងងាយស្រួលដែរ។ ប្រសិនបើមនុស្សអាចយល់ពីវាបានយ៉ាងច្បាស់ និងយកវាទៅអនុវត្ត នោះវាក្លាយជាមិនសាំញ៉ាំឡើយ។ ប្រសិនបើមនុស្សមិនអាចយល់វា បានយ៉ាងច្បាស់ទេនោះ វានឹងក្លាយទៅជាពិបាក ហើយបន្ថែមលើនេះ ពួកគេនឹងនាំឲ្យការស្វែងរករបស់ពួកគេ ដឹកនាំពួកគេទៅក្នុងភាពស្រពេចស្រពិល។ ក្នុងការស្វែងរកព្រះជាម្ចាស់ ប្រសិនបើមនុស្សមិនមានទីតាំងឈរជើងផ្ទាល់ខ្លួនទេ ហើយមិនដឹងថាពួកគេគប្បីប្រកាន់តាមសេចក្ដីពិតដោយបែបណាទេនោះ មានន័យថា ពួកគេពុំមានមូលដ្ឋានគ្រឹះឡើយ ហើយពួកគេនឹងពិបាកក្នុងការឈរឲ្យបានរឹងមាំ។ សព្វថ្ងៃនេះ មានមនុស្សជាច្រើនដែលមិនយល់ពីសេចក្ដីពិត ដែលមិនអាចបែងចែកភាពខុសគ្នារវាងអំពីល្អ និងអំពើអាក្រក់ ឬប្រាប់ថាអ្វីដែលត្រូវស្រឡាញ់ ឬអ្វីដែលត្រូវស្អប់។ មនុស្សបែបនេះ ពិបាកនឹងឈរជើងឲ្យបាននឹងធឹងណាស់។ គន្លឹះសម្រាប់ជំនឿលើព្រះជាម្ចាស់ គឺការដែលអាចយកសេចក្ដីពិតទៅអនុវត្តបាន ដើម្បីគិតគូរអំពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដើម្បីស្គាល់ពីកិច្ចការរបស់ព្រះជាម្ចាស់ចំពោះមនុស្ស នៅពេលទ្រង់បានត្រលប់ជាសាច់ឈាម និងដឹងពីគោលការណ៍ដែលទ្រង់មានព្រះបន្ទូល។ ចូរកុំដើរតាមហ្វូងមនុស្សឡើយ។ អ្នកត្រូវតែមានគោលការណ៍នៅក្នុងអ្វីដែលអ្នកចូលទៅ ហើយអ្នកត្រូវប្រកាន់ខ្ជាប់ទៅនឹងគោលការណ៍ទាំងនោះ។ ការប្រកាន់ខ្ជាប់ខ្ជួនទៅនឹងគោលការណ៍ទាំងនោះនៅក្នុងខ្លួនរបស់អ្នក ដោយការបំភ្លឺរបស់ព្រះជាម្ចាស់ នឹងអាចជួយដល់អ្នកបាន។ ប្រសិនបើអ្នក

មិនធ្វើបែបនេះទេ ថ្ងៃនេះ អ្នកនឹងងាករេចេញពីផ្លូវមួយ ថ្ងៃខានស្អែកអ្នកនឹងត្រូវងាករេចេញពីផ្លូវមួយទៀត ហើយអ្នកមិនអាចទទួលបានអ្វីដែលពិតនោះឡើយ។ ការធ្វើបែបនេះ គឺពុំមានប្រយោជន៍អ្វីដល់ជីវិតផ្ទាល់ខ្លួនរបស់អ្នកឡើយ។ អស់អ្នកណាដែលមិនយល់ពីសេចក្ដីពិត តែងតែដើរតាមអ្នកដទៃ៖ ប្រសិនបើមនុស្សនិយាយថានេះគឺជាកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធ នោះអ្នកនឹងនិយាយថា វាជាកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធដែរ។ ប្រសិនបើមនុស្សនិយាយថា វាជាកិច្ចការរបស់វិញ្ញាណអាក្រក់ នោះអ្នកនឹងទៅជាងឿងឆ្ងល់ ឬក៏និយាយថា វាជាកិច្ចការរបស់វិញ្ញាណអាក្រក់ដូចគេដែរ។ អ្នកតែងតែនិយាយត្រាប់តាមពាក្យរបស់អ្នកដទៃដូចជាសត្វសេក ហើយមិនអាចបែងចែកភាពខុសគ្នាបានដោយខ្លួនឯងនោះទេ ហើយអ្នកក៏មិនអាចគិតសម្រាប់ខ្លួនឯងបានដែរ។ នេះគឺជាមនុស្សម្នាក់ដែលគ្មានទីឈរជើង ជាមនុស្សដែលមិនអាចធ្វើការបែងចែកនូវភាពខុសគ្នាបាន ហើយមនុស្សបែបនោះ គឺជាមនុស្សទុច្ចរិតដែលគ្មានតម្លៃ! អ្នកតែងតែត្រាប់តាមពាក្យសម្ដីរបស់អ្នកដទៃ៖ ថ្ងៃនេះ គេបាននិយាយថា នេះគឺជាកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធ ប៉ុន្តែអាចថា នៅថ្ងៃណាមួយមនុស្សម្នាក់នឹងនិយាយថា វាមិនមែនជាកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធទេ ហើយវាគ្មានអ្វីផ្សេងក្រៅពីទង្វើរបស់មនុស្សឡើយ ប៉ុន្តែអ្នកមិនអាចយល់ពីចំណុចនេះបានឡើយ ហើយនៅពេលដែលអ្នកបានឃើញអ្នកដទៃនិយាយដោយបែបនេះ អ្នកក៏នឹងនិយាយដូចគ្នានេះដែរ។ តាមពិត វាគឺជាកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ប៉ុន្តែអ្នកនិយាយថា វាជាកិច្ចការរបស់មនុស្ស។ តើអ្នកមិនបានក្លាយជាមនុស្សម្នាក់ក្នុងចំណោមមនុស្សដែលប្រមាថដល់កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធទេឬអី? នៅក្នុងចំណុចនេះតើអ្នកមិនបានប្រឆាំងទាស់នឹងព្រះជាម្ចាស់ ដោយសារអ្នកមិនអាចបែងចែកភាពខុសគ្នាបានទេឬអី? ប្រហែលនៅថ្ងៃណាមួយ មនុស្សល្ងង់ខ្លៅមួយចំនួននឹងលេចមកដោយនិយាយថា «នេះគឺជាកិច្ចការរបស់វិញ្ញាណអាក្រក់» ហើយនៅពេលដែលអ្នកឮពាក្យទាំងអស់នេះ អ្នកនឹងវង្វេង ហើយអ្នកនឹងដក់ជាប់ទៅនឹងពាក្យសម្ដីរបស់អ្នកដទៃនោះសារជាថ្មី។ គ្រប់ពេលដែលនរណាម្នាក់បង្កការរំខាន អ្នកមិនអាចក្រោកឈរនៅទីតាំងរបស់ខ្លួនឯងបានឡើយ

នេះគឺដោយសារអ្នកមិនមានសេចក្ដីពិត។ ការជឿលើព្រះជាម្ចាស់ និងការចង់ស្គាល់ព្រះជាម្ចាស់ គឺមិនមែនជារឿងសាមញ្ញនោះទេ។ អ្វីទាំងអស់នេះ មិនអាចសម្រេចទៅបានដោយងាយៗ តាមរយៈការជួបជុំគ្នានិងស្ដាប់ការអធិប្បាយនោះទេ ហើយអ្នកមិនត្រូវបានធ្វើឲ្យគ្រប់លក្ខណ៍ ដោយចិត្តឆេះឆួលតែមួយមុខឡើយ។ អ្នកត្រូវការដកពិសោធន៍ ត្រូវដឹង និងមានគោលការណ៍នៅក្នុងសកម្មភាពរបស់អ្នក និងទទួលនូវកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធ។ នៅពេលដែលអ្នកបានឆ្លងកាត់បទពិសោធជាច្រើន អ្នកនឹងអាចយល់ពីរឿងរ៉ាវជាច្រើនបាន ហើយអ្នកនឹងអាចធ្វើការបែងចែកភាពខុសគ្នារវាងអំពីល្អនិងអំពើអាក្រក់ រវាងសេចក្ដីសុចរិតនិងសេចក្ដីទុច្ចរិត រវាងអ្វីដែលជារបស់ខាងសាច់ឈាមនិងអ្វីដែលជាសេចក្ដីពិត។ អ្នកគួរតែអាចធ្វើការបែងចែករវាងអ្វីៗទាំងនេះ ហើយតាមរយៈការធ្វើបែបនេះ មិនថាកាលៈទេសៈបែបណានោះទេ អ្នកនឹងមិនវង្វេងឡើយ។ មានតែបែបនេះទេដែលជាកម្ពស់ពិតរបស់អ្នក។

ការដែលស្គាល់កិច្ចការរបស់ព្រះជាម្ចាស់ គឺមិនមែនជារឿងសាមញ្ញនោះទេ។ អ្នកគប្បីមានបទដ្ឋាន និងមានគោលបំណងនៅក្នុងការស្វែងរករបស់អ្នក អ្នកគប្បីដឹងពីរបៀបស្វែងរកសេចក្ដីពិត របៀបវាស់វែងថាតើវាជាផ្លូវដ៏ពិតដែរឬទេ និងថាតើវាជាកិច្ចការរបស់ព្រះជាម្ចាស់មែនឬអត់។ តើអ្វីទៅជាគោលការណ៍មូលដ្ឋានគ្រឹះសំខាន់បំផុតក្នុងការស្វែងរកផ្លូវដ៏ពិត? អ្នកត្រូវមើលថា តើមានកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធដែរឬអត់នៅក្នុងផ្លូវនេះ ថាតើពាក្យសម្ដីទាំងអស់នេះ គឺជាការបើកសម្ដែងពីសេចក្ដីពិតដែរឬទេ ថាតើនរណាដែលត្រូវធ្វើទីបន្ទាល់ ហើយតើអាចនាំអ្វីមកដល់អ្នកបាន។ ការបែងចែកភាពខុសគ្នារវាងផ្លូវពិត និងផ្លូវមិនពិត តម្រូវឲ្យមានទិដ្ឋភាពចំណេះដឹងមូលដ្ឋានខ្លះៗ ហើយមូលដ្ឋានគ្រឹះដែលសំខាន់ជាងគេបំផុតនោះគឺ ត្រូវប្រាប់ថាតើកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធមានបង្ហាញនៅក្នុងនោះដែរឬទេ។ សម្រាប់សារជាតិនៃជំនឿរបស់មនុស្សលើព្រះជាម្ចាស់ គឺដោយព្រោះជំនឿលើព្រះវិញ្ញាណនៃព្រះជាម្ចាស់ ហើយសូម្បីតែ ជំនឿលើព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សក៏ដោយព្រោះសាច់ឈាមនេះគឺជាតំណាងនៃព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ដែល

មានន័យថា ជំនឿនោះ គឺនៅតែជាជំនឿលើព្រះវិញ្ញាណដដែល។ មានភាពខុសគ្នារវាងព្រះវិញ្ញាណនិងសាច់ឈាម ប៉ុន្តែដោយសារសាច់ឈាមនេះមកអំពីព្រះវិញ្ញាណ ហើយគឺជាព្រះបន្ទូលដែលបានត្រលប់ជាសាច់ឈាមនោះអ្វីដែលមនុស្សជឿ គឺនៅតែជាលក្ខណៈពីដើមរបស់ព្រះជាម្ចាស់ដដែល។ ដូច្នេះ ក្នុងការបែងចែកភាពខុសគ្នាថា តើវាជាផ្លូវពិត ឬមិនមែននោះ អ្វីដែលសំខាន់គឺអ្នកត្រូវមើលថាតើ វាមានកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធដែរឬអត់ បន្ទាប់មក អ្នកត្រូវមើលថាតើមានសេចក្តីពិតនៅក្នុងនោះដែរឬទេ។ សេចក្តីពិត គឺជានិស្ស័យជីវិតនៃភាពជាមនុស្សធម្មតា ជានិស្ស័យដែលត្រូវការចាំបាច់សម្រាប់មនុស្ស នៅពេលដែលព្រះជាម្ចាស់បានបង្កើតគេមកនៅគ្រាដំបូង ពោលគឺភាពជាមនុស្សធម្មតាក្នុងលក្ខណៈទាំងស្រុងរបស់គេ (រួមទាំងសារជាតិជាមនុស្ស គំនិតយល់ធ្លុះជ្រៅ ប្រាជ្ញាញាណ និងចំណេះដឹងមូលដ្ឋាននៃការធ្វើជាមនុស្ស)។ នោះគឺ អ្នកត្រូវមើលថាតើផ្លូវនេះ អាចនាំមនុស្សទៅក្នុងជីវិតនៃភាពជាមនុស្សធម្មតាឬអត់ ថាតើសេចក្តីពិតដែលគេនិយាយនោះ ស្របតាមការពិតនៃភាពជាមនុស្សធម្មតាដែរឬទេ ថាតើសេចក្តីពិតនេះ ជាក់ស្តែង និងពិតប្រាកដដែរឬទេ ហើយថាតើវាត្រូវតាមសម័យកាលដែរឬទេ។ ប្រសិនបើមានសេចក្តីពិត នោះវាអាចនាំមនុស្សទៅក្នុងបទពិសោធធម្មតា និងជាក់ស្តែងបាន។ បន្ថែមលើនេះ មនុស្សក្លាយជាសាមញ្ញទៅៗ អត្ថន័យជាមនុស្សរបស់ពួកគេកាន់តែពេញបរិបូរណ៍ទៅៗ ជីវិតខាងសាច់ឈាម និងជីវិតខាងព្រលឹងវិញ្ញាណរបស់ពួកគេ ក្លាយជាមានរបៀបរៀបរយទៅៗ ហើយអារម្មណ៍របស់ពួកគេ ក្លាយជាសាមញ្ញទៅៗ។ នេះគឺជាគោលការណ៍ទីពីរ។ មានគោលការណ៍មួយផ្សេងទៀត នោះគឺ មិនថាមនុស្សមានចំណេះដឹងច្រើនប៉ុនណាអំពីព្រះជាម្ចាស់ ហើយមិនថាជួបបទពិសោធនៃការកិច្ចការបែបណានោះទេ សេចក្តីពិតអាចជំរុញសេចក្តីស្រឡាញ់ចំពោះព្រះជាម្ចាស់នៅក្នុងខ្លួនពួកគេ និងនាំពួកគេមកកាន់តែជិតព្រះជាម្ចាស់។ នៅក្នុងចំណុចនេះ យើងអាចធ្វើការវាស់ស្ទង់បានថាតើផ្លូវនេះគឺជាផ្លូវពិតប្រាកដឬយ៉ាងណា។ អ្វីដែលជាមូលដ្ឋានគ្រឹះសំខាន់បំផុតនោះគឺថាតើផ្លូវនេះពិតជាក់ស្តែងជាងអភិធម្មជាតិ មិនថាវាអាចផ្តល់ជីវិតដល់មនុស្ស

បានឬអត់នោះទេ។ ប្រសិនបើវាស្របទៅតាមគោលការណ៍ទាំងនេះ យើងអាចទាញសេចក្ដីសន្និដ្ឋានបានថា ផ្លូវនេះគឺជាផ្លូវដ៏ពិត។ ខ្ញុំមានបន្ទូលទាំងអស់នេះ មិនមែនដើម្បីឲ្យអ្នករាល់គ្នាទទួលយកផ្លូវផ្សេងទៀតនៅក្នុងបទពិសោធនាពេលអនាគតរបស់អ្នកទេ ហើយក៏មិនមែនជាការទស្សន៍ទាយដែលថានឹងមានកិច្ចការនៃសម័យថ្មីមួយក្នុងពេលអនាគតនោះដែរ។ ខ្ញុំមានបន្ទូលទាំងអស់នេះ ដើម្បីឲ្យអ្នករាល់គ្នាអាចច្បាស់ថា ផ្លូវសព្វថ្ងៃនេះ គឺជាផ្លូវពិត ប្រយោជន៍កុំឲ្យអ្នករាល់គ្នាគ្រាន់តែប្រាកដអំពីផ្នែកខ្លះនៅក្នុងជំនឿរបស់អ្នកចំពោះកិច្ចការនៅបច្ចុប្បន្ននេះ និងមិនអាចយល់ដឹងស៊ីជម្រៅអំពីកិច្ចការនោះ។ មានមនុស្សជាច្រើននាក់ ក្រៅពីច្បាស់ក្នុងចិត្តហើយ នៅតែបន្តដើរក្នុងការវង្វេងដដែល។ ភាពច្បាស់លាស់បែបនេះ ពុំមានគោលការណ៍នៅក្នុងនោះទេ ហើយមិនយូរមិនឆាប់ មនុស្សបែបនេះនឹងត្រូវផាត់ចោល។ សូម្បីតែអស់អ្នកដែលក្លៀវក្លានៅក្នុងការដើរតាមរបស់ខ្លួន ក៏មានបីភាគដែលប្រាកដ ហើយប្រាំភាគមិនប្រាកដដែរ ដែលនេះបង្ហាញថា ពួកគេពុំមានមូលដ្ឋានគ្រឹះសោះឡើយ។ ដោយសារគុណសម្បត្តិរបស់អ្នករាល់គ្នាអន់ខ្សោយខ្លាំងពេក ហើយមូលដ្ឋានគ្រឹះរបស់អ្នករាក់កំផែលខ្លាំងពេក នោះអ្នករាល់គ្នាពុំមានការយល់ដឹងអំពីការបែងចែកភាពខុសគ្នាឡើយ។ ព្រះជាម្ចាស់មិនបំពេញកិច្ចការរបស់ទ្រង់ម្ដងទៀតឡើយ ទ្រង់មិនធ្វើកិច្ចការដែលមិនជាក់ស្ដែងឡើយ ទ្រង់មិនទាមទារអ្វីច្រើន ពីមនុស្សឡើយ ហើយទ្រង់ក៏មិនបំពេញកិច្ចការដែលហួសពីអត្ថន័យជាមនុស្សដែរ។ គ្រប់កិច្ចការដែលទ្រង់ធ្វើគឺសុទ្ធតែស្ថិតក្នុងព្រំដែនអត្ថន័យនៃមនុស្សធម្មតា និងមិនលើសពីអត្ថន័យ នៃភាពជាមនុស្សធម្មតាឡើយ ហើយកិច្ចការរបស់ទ្រង់ ត្រូវធ្វើឡើងស្របទៅតាមសេចក្ដីតម្រូវធម្មតារបស់មនុស្ស។ ប្រសិនបើវាជាកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ នោះមនុស្សនឹងកាន់តែមានភាពសាមញ្ញទៅៗ ហើយភាពជាមនុស្សរបស់ពួកគេ ក៏កាន់តែសាមញ្ញទៅៗដែរ។ មនុស្សទទួលបានចំណេះដឹងច្រើនអំពីនិស្ស័យពុករលួយរបស់ពួកគេដែលមកពីសាតាំង និងយល់ពីអត្ថន័យជាមនុស្ស ហើយពួកគេក៏នឹងចង់បានសេចក្ដីពិតកាន់តែធំធេងជាងមុនដែរ។ នេះគឺអាចនេះនិយាយបានថា ជីវិតរបស់មនុស្សធំធាត់

ឡើងៗ ហើយនិស្ស័យពុករលួយរបស់មនុស្សកាន់តែអាចបំផ្លាស់បំប្រែបានច្រើនជាងមុន ដែលគ្រប់ការទាំងអស់នេះ គឺជាអត្ថន័យនៃការដែលព្រះជាម្ចាស់ក្លាយជាជីវិតរបស់មនុស្ស។ ប្រសិនបើផ្លូវមួយ មិនអាចបើកសម្ដែងនូវចំណុចទាំងអស់ ដែលជាអត្ថន័យជាមនុស្សនេះបាន មិនបំផ្លាស់បំប្រែនិស្ស័យរបស់មនុស្សបាន ហើយលើសពីនោះមិនអាចនាំមនុស្សមកចំពោះព្រះជាម្ចាស់បាន ឬផ្ដល់ឲ្យពួកគេនូវការយល់ដឹងដ៏ពិតប្រាកដអំពីព្រះជាម្ចាស់បាន ហើយថែមទាំងបណ្ដាលឲ្យភាពជាមនុស្សរបស់ពួកគេកាន់តែទាបទៅៗ និងធ្វើឲ្យអារម្មណ៍របស់ពួកគេកាន់តែមិនធម្មតាទៅៗ នោះផ្លូវនេះច្បាស់ជាមិនមែនជាផ្លូវដ៏ពិតឡើយ ហើយវាអាចជាកិច្ចការរបស់វិញ្ញាណអាក្រក់ ឬជាផ្លូវចាស់។ និយាយឲ្យខ្លី វាមិនអាចជាកិច្ចការបច្ចុប្បន្នរបស់ព្រះវិញ្ញាណបរិសុទ្ធបានឡើយ។ អ្នករាល់គ្នាបានជឿលើព្រះជាម្ចាស់ក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះ ប៉ុន្តែអ្នកគ្មានចំណេះដឹងបន្តិចសោះអំពីគោលការណ៍សម្រាប់ការបែងចែកភាពខុសគ្នារវាងផ្លូវពិត និងផ្លូវមិនពិត ឬសម្រាប់ស្វែងរកផ្លូវពិត។ មនុស្សភាគច្រើន មិនចាប់អារម្មណ៍លើបញ្ហានេះទេ។ ពួកគេគ្រាន់តែទៅកន្លែងណាដែលមនុស្សភាគច្រើនទៅ និងនិយាយដដែលៗ ពីអ្វីដែលមនុស្សភាគច្រើននិយាយប៉ុណ្ណោះ។ ចុះចំណែកមនុស្សដែលស្វែងរកផ្លូវដ៏ពិតវិញ? ហើយចុះតើមនុស្សបែបនេះអាចស្វែងផ្លូវពិតបានដោយរបៀបណា? ប្រសិនបើអ្នកយល់ពីគោលការណ៍គន្លឹះមួយចំនួននេះបាន មិនថាមានអ្វីកើតឡើងនោះទេ អ្នករាល់គ្នានឹងមិនត្រូវបានគេបោកបញ្ឆោតឡើយ។ បច្ចុប្បន្ននេះ វាសំខាន់ខ្លាំងណាស់ដែលមនុស្សអាចបែងចែកភាពខុសគ្នាបាន។ នេះគឺជាអ្វីដែលមនុស្សធម្មតាគប្បីមាននៅក្នុងខ្លួន ហើយនេះគឺជាអ្វីដែលមនុស្សត្រូវមាននៅក្នុងបទពិសោធរបស់ពួកគេ។ សូម្បីតែបច្ចុប្បន្ននេះ ប្រសិនបើមនុស្សនៅតែមិនអាចបែងចែកភាពខុសគ្នាបាន នៅក្នុងដំណើរការនៃការដើរតាមនេះ ហើយប្រសិនបើការយល់ដឹងរបស់មនុស្សមិនរីកចម្រើនធំធាត់ទេនោះ មនុស្សគឺល្ងង់ខ្លៅខ្លាំងណាស់ ហើយការស្វែងរករបស់ពួកគេ ត្រូវយល់ច្រលំ និងងាករេ។ នៅក្នុងការស្វែងរករបស់អ្នកនាពេលសព្វថ្ងៃនេះ គ្មានការបែងចែកភាពខុសគ្នាសូម្បីបន្តិចសោះឡើយ ហើយវាជា

ការពិត ដែលអ្នកនិយាយថា អ្នកបានរកឃើញនូវផ្លូវដ៏ពិតនេះ ប៉ុន្តែតើអ្នកបានទទួលវាហើយឬនៅ? តើអ្នកអាចបែងចែកភាពខុសគ្នានៃអ្វីមួយបានហើយឬនៅ? តើអ្វីទៅជាសារជាតិនៃផ្លូវពិត? នៅក្នុងផ្លូវពិត អ្នកមិនបានទទួលនូវផ្លូវពិតទេ។ អ្នកមិនបានទទួលនូវអ្វីដែលជាសេចក្ដីពិតឡើយ។ នេះមានន័យថា អ្នកមិនបានសម្រេចនូវចំណុចដែលព្រះជាម្ចាស់តម្រូវឲ្យអ្នកធ្វើនោះទេ ហេតុនេះ សេចក្ដីពុករលួយរបស់អ្នក ពុំបានបំផ្លាស់បំប្រែឡើយ។ ប្រសិនបើអ្នកបន្តស្វែងរកដោយរបៀបនេះ នោះនៅទីបំផុត អ្នកនឹងត្រូវផាត់ចោល។ ការដែលបានដើរតាមរហូតមកដល់ពេលបច្ចុប្បន្ននេះអ្នកគប្បីប្រាកដថា ផ្លូវដែលអ្នកបានជ្រើសរើស គឺជាផ្លូវពិត ហើយពុំគួរមានការងឿងឆ្ងល់អ្វីបន្ថែមទៀតឡើយ។ មនុស្សជាច្រើន តែងតែមិនភាពច្បាស់លាស់ និងឈប់ស្វែងរកសេចក្ដីពិតដោយសារបញ្ហាតូចតាចមួយចំនួន។ មនុស្សបែបនេះ គឺជាមនុស្សដែលគ្មានចំណេះដឹងអំពីកិច្ចការរបស់ព្រះជាម្ចាស់ឡើយ។ ពួកគេជាមនុស្សដែលដើរតាមព្រះជាម្ចាស់ក្នុងសេចក្ដីភាន់ច្រឡំ។ មនុស្សដែលមិនស្គាល់កិច្ចការរបស់ព្រះជាម្ចាស់ មិនអាចក្លាយជាមនុស្សជិតស្និទ្ធនឹងទ្រង់បានឡើយ ឬមិនអាចធ្វើទីបន្ទាល់អំពីទ្រង់បានឡើយ។ ខ្ញុំសូមទូន្មានដល់អស់អ្នកណាដែលគ្រាន់តែស្វែងរកព្រះពរ និងគ្រាន់តែស្វែងរកអ្វីដែលស្រពេចស្រពិល និងអរូបីថា ត្រូវស្វែងរកសេចក្ដីពិតឲ្យបានឆាប់ដើម្បីឲ្យជីវិតរបស់ពួកគេអាចមានន័យ។ ចូរកុំបោកបញ្ឆោតខ្លួនឯងទៀតអី!

# ភាពខុសគ្នារវាងព័ន្ធកិច្ចរបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស និងភារកិច្ចរបស់មនុស្ស

អ្នករាល់គ្នាត្រូវស្គាល់ពីនិមិត្តនៃកិច្ចការរបស់ព្រះជាម្ចាស់ និងត្រូវយល់ពីគោលដៅទូទៅនៃកិច្ចការរបស់ទ្រង់។ នេះគឺជាច្រកចូលវិជ្ជមាន។ នៅពេលណាដែលអ្នកបានយល់ច្បាស់ពីសេចក្ដីពិតនៃនិមិត្តទាំងនោះ ការចូលទៅក្នុងរបស់អ្នក នឹងមាន

សុវត្ថិភាព។ មិនថាកិច្ចការរបស់ព្រះជាម្ចាស់ ផ្លាស់ប្តូរយ៉ាងណានោះទេ នៅក្នុងដួងចិត្តរបស់អ្នក នឹងមិនប្រែប្រួលជាដាច់ខាត ត្រូវមានភាពប្រាកដប្រជាចំពោះនិមិត្តទាំងនោះ និងត្រូវមានគោលដៅមួយសម្រាប់ការចូលទៅក្នុងរបស់អ្នក និងការស្វែងរករបស់អ្នក។ តាមរបៀបនេះ គ្រប់បទពិសោធ និងចំណេះដឹងទាំងអស់នៅក្នុងខ្លួនរបស់អ្នក នឹងកាន់តែស៊ីជម្រៅហើយល្អិតល្អន់ទៅៗ។ នៅពេលណាដែលអ្នកបានចាប់យល់ពីរូបភាពធំនៅក្នុងកិច្ចការនេះទាំងស្រុង អ្នកនឹងលែងជួបប្រទះការបាត់បង់ជីវិតទៀតហើយ ហើយអ្នកក៏នឹងលែងដើរផ្លូវខុសទៀតដែរ។ ប្រសិនបើអ្នកមិនស្គាល់ពីជំហាននៃកិច្ចការទាំងនេះទេ អ្នកនឹងត្រូវបាត់បង់នៅគ្រប់ជំហាននីមួយៗ ហើយអ្នកនឹងត្រូវចំណាយពេលវេលាជាច្រើនថ្ងៃដើម្បីបំផ្លាស់បំប្រែរឿងមួយចំនួនឲ្យមករកភាពល្អប្រសើរវិញ ហើយអ្នកនឹងមិនអាចដើរនៅលើផ្លូវត្រូវឡើយ សូម្បីតែត្រឹមប៉ុន្មានសប្តាហ៍ក៏ដោយ។ តើនេះនឹងមិនធ្វើឲ្យមានការយឺតយ៉ាវទេឬអី? មានច្រកចូលវិជ្ជមាន និងការអនុវត្តជាច្រើន ដែលអ្នករាល់គ្នាត្រូវធ្វើឱ្យបានល្អ។ សម្រាប់និមិត្តនៃកិច្ចការរបស់ព្រះជាម្ចាស់ អ្នកត្រូវចាប់យល់ពីចំណុចខាងក្រោម៖ សារៈសំខាន់នៃកិច្ចការយកឈ្នះរបស់ទ្រង់ ផ្លូវទៅអនាគតដើម្បីត្រូវបានប្រោសឲ្យបានគ្រប់លក្ខណ៍ អ្វីដែលត្រូវសម្រេចឲ្យបានតាមរយៈការដកពិសោធន៍ក្នុងការល្បួងល និងទុក្ខវេទនា សារជាតិសំខាន់នៃការជំនុំជម្រះ និងការវាយផ្ចាល គោលការណ៍នៅពីខាងក្រោយកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ និងគោលការណ៍នៅពីខាងក្រោយការប្រោសឲ្យបានគ្រប់លក្ខណ៍ និងការយកឈ្នះ។ ទាំងអស់នេះ ជាសេចក្តីពិតនៃនិមិត្តទាំងនោះ។ ក្រៅពីនោះ គឺជាដំណាក់កាលទាំងបី នៃកិច្ចការនៅក្នុងយុគសម័យនៃក្រឹត្យវិន័យ យុគសម័យនៃព្រះគុណ និងយុគសម័យនៃនគរព្រះ ក៏ដូចជាការធ្វើទីបន្ទាល់ នាពេលអនាគតដែរ។ កិច្ចការទាំងអស់នេះក៏ជាសេចក្តីពិតនៃនិមិត្តដែរ ហើយកិច្ចការទាំងនេះ ក៏ជាមូលដ្ឋានគ្រឹះសំខាន់ជាងគេ ក៏ដូចជាមានសារៈសំខាន់ជាងគេបំផុតដែរ។ បច្ចុប្បន្ននេះ មានរឿងជាច្រើនដែលអ្នករាល់គ្នាគប្បីចូលរួម និងអនុវត្ត ហើយបច្ចុប្បន្ននេះ វាមានច្រើនស្រទាប់ និងល្អិតល្អន់ជាងមុន។ ប្រសិនបើអ្នកគ្មានចំណេះដឹងអំពីសេចក្តីពិត

ទាំងនេះទេ នេះបញ្ជាក់ថា អ្នកមិនទាន់សម្រេចនូវការចូលទៅក្នុងបានទេ។ ភាគច្រើនចំណេះដឹងរបស់មនុស្ស អំពីសេចក្ដីពិតគឺរាក់កំភែលខ្លាំងណាស់។ ពួកគេមិនអាចអនុវត្តនូវសេចក្ដីពិត ជាមូលដ្ឋានជាក់លាក់ណាមួយ និងមិនដឹងថាតើត្រូវដោះស្រាយយ៉ាងដូចម្ដេចនោះឡើយ សូម្បីតែបញ្ហាបន្តិចបន្តួច។ មូលហេតុដែលមនុស្សមិនអាចអនុវត្តនូវសេចក្ដីពិតបាន គឺដោយសារនិស្ស័យបះបោររបស់ពួកគេ ហើយដោយសារចំណេះដឹងរបស់ពួកគេអំពីកិច្ចការបច្ចុប្បន្ន គឺរាក់កំភែលខ្លាំងពេក និងលម្អៀងទៅតែម្ខាង។ ហេតុនេះ វាមិនមែនជាកិច្ចការងាយស្រួលទេសម្រាប់ឲ្យមនុស្សត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍នោះ។ អ្នកពិតជាបះបោរពេកហើយ ហើយអ្នករក្សានូវធាតុចាស់របស់អ្នកច្រើនពេកហើយ។ អ្នកមិនអាចឈរនៅខាងសេចក្ដីពិតបានទេ ហើយអ្នកមិនអាចអនុវត្តសូម្បីតែសេចក្ដីពិតដែលអាចបញ្ជាក់ដោយខ្លួនឯង។ មនុស្សបែបនេះ មិនអាចត្រូវសង្គ្រោះបានទេ ហើយក៏ជាអស់អ្នកដែលមិនត្រូវបានយកឈ្នះដែរ។ ប្រសិនបើការចូលទៅក្នុងរបស់អ្នកគ្មានភាពល្អិតល្អន់ និងគ្មានគោលដៅទេ នោះការរីកធំធាត់ដែលមកចំពោះអ្នកនឹងត្រូវយឺតយ៉ាវ។ ប្រសិនបើគ្មានភាពពិតសូម្បីបន្តិចចំពោះការចូលទៅក្នុងរបស់អ្នក នោះការស្វែងរករបស់អ្នកនឹងទៅជាអាសារឥតការមិនខាន។ ប្រសិនបើអ្នកមិនដឹងអំពីសារជាតិនៃសេចក្ដីពិតទេ អ្នកនឹងមិនផ្លាស់ប្ដូរជាដាច់ខាត។ ការរីកធំធាត់នៅក្នុងជីវិតមនុស្ស និងការផ្លាស់ប្ដូរនិស្ស័យរបស់គេ គឺសម្រេចទៅបានដោយការចូលទៅក្នុងភាពពិត និងតាមរយៈការចូលទៅក្នុងបទពិសោធល្អិតល្អន់។ ប្រសិនបើអ្នកមានបទពិសោធល្អិតល្អន់ក្នុងអំឡុងពេលនៃការចូលរួមរបស់អ្នក ហើយអ្នកមានចំណេះដឹងជាក់ស្ដែង និងការចូលទៅក្នុង នោះនិស្ស័យរបស់អ្នកនឹងត្រូវបំផ្លាស់បំប្រែយ៉ាងឆាប់រហ័ស។ បច្ចុប្បន្ននេះ សូម្បីតែអ្នកមិនទាន់ច្បាស់ទាំងស្រុងអំពីការអនុវត្តនេះក្ដី ក៏ប៉ុន្តែអ្នកក៏ត្រូវច្បាស់លាស់អំពីនិមិត្តនៃកិច្ចការរបស់ព្រះជាម្ចាស់ដែរ។ ប្រសិនបើមិនដូច្នេះទេ អ្នកនឹងគ្មានសមត្ថភាពចូលទៅបានឡើយ។ ការចូលទៅក្នុងគឺអាចមានបានឲ្យតែអ្នកមានចំណេះដឹងអំពីសេចក្ដីពិត។ ប្រសិនបើព្រះវិញ្ញាណបរិសុទ្ធបំភ្លឺផ្លូវអ្នកតាមរយៈបទពិសោធរបស់អ្នក នោះអ្នកនឹងទទួលបាននូវការយល់

ដឹងស៊ីជម្រៅអំពីសេចក្តីពិត និងការចូលកាន់តែស៊ីជម្រៅ។ អ្នករាល់គ្នាត្រូវស្គាល់ពីកិច្ចការរបស់ព្រះជាម្ចាស់។

នៅគ្រាដំបូងឡើយ ក្រោយការបង្កើតមនុស្សជាតិ នោះគឺពួកសាសន៍អ៊ីស្រាអែលដែលធ្វើជាមូលដ្ឋានគ្រឹះនៃកិច្ចការរបស់ព្រះជាម្ចាស់។ ប្រទេសអ៊ីស្រាអែលទាំងមូលគឺជាមូលដ្ឋាននៃកិច្ចការរបស់ព្រះយេហូវ៉ានៅលើផែនដី។ កិច្ចការរបស់ព្រះយេហូវ៉ាគឺត្រូវដឹកនាំ និងឃ្វាលមនុស្សដោយផ្ទាល់ តាមរយៈការកំណត់ក្រឹត្យវិន័យ ដើម្បីឲ្យមនុស្សអាចរស់នៅក្នុងជីវិតសាមញ្ញធម្មតា និងថ្វាយបង្គំព្រះយេហូវ៉ា នៅក្នុងភាពសាមញ្ញធម្មតានៅលើផែនដីនេះ។ ព្រះជាម្ចាស់ នៅក្នុងយុគសម័យនៃក្រឹត្យវិន័យមិនអាចឲ្យមនុស្សមើលឃើញ និងប៉ះពាល់បានឡើយ។ ដោយសារគ្រប់ការដែលទ្រង់បំពេញ គឺដើម្បីណែនាំមនុស្សកាលពីដើមដំបូងបង្អស់ដែលត្រូវសាតាំងធ្វើឲ្យពុករលួយ ដោយការបង្រៀននិងឃ្វាលពួកគេ ព្រះបន្ទូលរបស់ទ្រង់គ្មានអ្វីផ្សេងក្រៅពីក្រឹត្យវិន័យ បញ្ញត្តិ និងក្បួនខ្នាតនៃឥរិយាបថរបស់មនុស្សឡើយ និងមិនបានផ្តល់ឲ្យពួកគេនូវសេចក្តីពិតនៃជីវិតនោះទេ។ ពួកសាសន៍អ៊ីស្រាអែលស្ថិតក្រោមការដឹកនាំរបស់ទ្រង់ មិនត្រូវបានសាតាំងធ្វើឲ្យពុករលួយដល់ឆ្អឹងបែបនេះទេ។ កិច្ចការនៃក្រឹត្យវិន័យរបស់ទ្រង់ គឺគ្រាន់តែជាដំណាក់កាលដំបូងបង្អស់ នៅក្នុងកិច្ចការនៃការប្រោសលោះប៉ុណ្ណោះ ដែលជាការចាប់ផ្តើមដំបូងនៃកិច្ចការប្រោសលោះ ហើយគ្មានអ្វីផ្សេងក្រៅពីការបំផ្លាស់បំប្រែនិស្ស័យជីវិតរបស់មនុស្សឡើយ។ ហេតុនេះ នៅដើមដំបូងនៃកិច្ចការប្រោសលោះរបស់ទ្រង់នៅក្នុងប្រទេសអ៊ីស្រាអែល ពុំចាំបាច់ត្រូវការឲ្យទ្រង់យកកំណើតជាមនុស្សឡើយ។ នេះហើយជាមូលហេតុ ដែលទ្រង់ត្រូវការមធ្យោបាយដែលជាឧបករណ៍មួយដើម្បីឲ្យទ្រង់អាចភ្ជាប់ទំនាក់ទំនងជាមួយមនុស្សបាន។ ហេតុនេះ នៅក្នុងចំណោមភាវៈដែលបានបង្កើតមក មានលេចមកនូវអស់អ្នកដែលនិយាយ និងធ្វើការជំនួសមុខឲ្យព្រះយេហូវ៉ា ហើយនេះជាមូលហេតុដែលនាំឲ្យកូនមនុស្ស និងពួកហោរាបានមកធ្វើការក្នុងចំណោមមនុស្ស។ កូនមនុស្សបានធ្វើការក្នុងចំណោមមនុស្សជំនួសមុខឲ្យព្រះយេហូវ៉ា។ ដើម្បីឲ្យព្រះយេហូវ៉ាហៅថា «កូន

មនុស្ស» បាន ដែលមានន័យថា មនុស្សបែបនោះ ត្រូវកំណត់ក្រឹត្យវិន័យជំនួសមុខឲ្យព្រះយេហូវ៉ា។ ពួកគេក៏ជាពួកបូជាចារ្យក្នុងចំណោមប្រជាជនអ៊ីស្រាអែលដែរ ជាពួកបូជាចារ្យដែលត្រូវព្រះយេហូវ៉ាទតមើលនិងការពារ និងជាអ្នកដែលព្រះវិញ្ញាណនៃព្រះយេហូវ៉ាសណ្ឋិតនៅ។ ពួកគេគឺជាមេដឹកនាំនៅក្នុងចំណោមមនុស្ស និងបម្រើដល់ព្រះយេហូវ៉ាដោយផ្ទាល់។ ម្យ៉ាងវិញទៀត ពួកហោរាបានថ្វាយខ្លួនក្នុងការនិយាយទៅកាន់មនុស្សនៅគ្រប់ទឹកដី និងពូជអំបូរទាំងអស់ជំនួសមុខឲ្យព្រះយេហូវ៉ា។ ពួកគេក៏បានថ្លែងទំនាយអំពីកិច្ចការរបស់ព្រះយេហូវ៉ាដែរ។ មិនថាពួកគេជាកូនមនុស្ស ឬជាហោរានោះទេ ពួកគេទាំងអស់ត្រូវបានព្រះវិញ្ញាណនៃព្រះយេហូវ៉ាលើកតម្កើងដោយផ្ទាល់ព្រះអង្គ និងត្រូវបានប្រគល់កិច្ចការរបស់ព្រះយេហូវ៉ាឲ្យ។ ក្នុងចំណោមមនុស្ស ពួកគេគឺជាមនុស្សដែលតំណាងព្រះយេហូវ៉ាដោយផ្ទាល់។ ពួកគេបំពេញកិច្ចការរបស់ពួកគេ ក៏ព្រោះតែពួកគេត្រូវបានព្រះយេហូវ៉ាលើកតម្កើង និងមិនមែនដោយព្រោះតែពួកគេជាសាច់ឈាមដែលព្រះវិញ្ញាណបរិសុទ្ធបានមកយកកំណើតជាមនុស្សដោយផ្ទាល់ព្រះអង្គនោះឡើយ។ ហេតុនេះ ទោះបីជាពួកគេនិយាយ និងបំពេញកិច្ចការជំនួសមុខឲ្យព្រះជាម្ចាស់ក្ដី ក៏ពួកកូនមនុស្ស និងពួកហោរានៅក្នុងយុគសម័យនៃក្រឹត្យវិន័យ មិនមែនជាសាច់ឈាមនៃព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សដែរ។ កិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងយុគសម័យនៃព្រះគុណ និងដំណាក់កាលចុងក្រោយគឺផ្ទុយគ្នាស្រឡះ ដ្បិតកិច្ចការនៃការសង្គ្រោះ និងការជំនុំជម្រះលើមនុស្ស ត្រូវបំពេញដោយព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សដោយផ្ទាល់ព្រះអង្គទ្រង់ ហើយដូចនេះពុំត្រូវការឲ្យមានការលើកតម្កើងពួកហោរា និងកូនមនុស្សជាថ្មីម្ដងទៀត ដើម្បីបំពេញកិច្ចការជំនួសមុខឲ្យទ្រង់នោះទេ។ នៅក្នុងភ្នែករបស់មនុស្ស ពុំមានភាពខុសគ្នាពិតប្រាកដរវាងអត្ថន័យនិងវិធីសាស្ត្រនៃកិច្ចការរបស់ពួកគេឡើយ។ ហើយគឺមូលហេតុនេះហើយដែលមនុស្សមានការភ័ន្តច្រឡំមិនចេះចប់អំពីកិច្ចការរបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស និងកិច្ចការរបស់ពួកហោរា និងកូនមនុស្ស។ ការលេចមករបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស គឺមានមូលដ្ឋានដូចគ្នានឹងពួកហោរា និងកូន

មនុស្សដែរ។ ហើយព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស គឺកាន់តែសាមញ្ញ និងកាន់តែជាក់ស្ដែងជាងពួកហោរាទៅទៀត។ ហេតុដូច្នេះ មនុស្សមិនអាចបែងចែកភាពខុសគ្នារវាងពួកគេបានឡើយ។ មនុស្សផ្ដោតសំខាន់តែទៅលើរូបរាងខាងក្រៅ មិនបានដឹងសោះថា សូម្បីតែមនុស្សពីរនាក់ដែលដូចគ្នានៅក្នុងការបំពេញកិច្ចការ និងការនិយាយស្ដី ក៏មានភាពខុសគ្នាដាច់ស្រឡះរវាងពួកគេដែរ។ ដោយសារសមត្ថភាពរបស់មនុស្សក្នុងការបែងចែកភាពខុសគ្នានៅខ្សោយខ្លាំងពេក ទើបគេមិនអាចធ្វើការបែងចែកភាពខុសគ្នារវាងបញ្ហាសាមញ្ញៗបាន ហើយកាន់តែមិនអាចយល់ពីការងារស្មុគ្រស្មាញបានឡើយ។ នៅពេលដែលពួកហោរា និងអស់អ្នកដែលព្រះវិញ្ញាណបរិសុទ្ធបានប្រើ បាននិយាយនិងបំពេញកិច្ចការ នេះគឺដើម្បីអនុវត្តនូវភារកិច្ចរបស់មនុស្ស ពោលគឺដើម្បីបំពេញមុខងាររបស់ភាវៈដែលត្រូវបានបង្កើតមក ហើយវាគឺជាកិច្ចការដែលមនុស្សគួរតែធ្វើ។ ក៏ប៉ុន្តែ ព្រះបន្ទូល និងកិច្ចការរបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស គឺត្រូវបំពេញព័ន្ធកិច្ចរបស់ទ្រង់។ ថ្វីបើទម្រង់ខាងក្រៅរបស់ទ្រង់ គឺជាទម្រង់នៃភាវៈមួយដែលបានបង្កើតមកក៏ពិតមែន ក៏កិច្ចការរបស់ទ្រង់មិនមែនដើម្បីអនុវត្តមុខងាររបស់ទ្រង់នោះទេ ប៉ុន្តែគឺដើម្បីបំពេញព័ន្ធកិច្ចរបស់ទ្រង់វិញ។ ពាក្យថា «ភារកិច្ច» ត្រូវបានប្រើទាក់ទងនឹងភាវៈដែលបានបង្កើតមក រីឯពាក្យ «ព័ន្ធកិច្ច» គឺត្រូវបានប្រើទាក់ទងនឹងខាងសាច់ឈាមនៃព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស។ មានភាពខុសគ្នាយ៉ាងខ្លាំងរវាងពាក្យទាំងពីរនេះ។ ពាក្យទាំងពីរនេះមិនអាចប្រើជំនួសគ្នាបានឡើយ។ កិច្ចការរបស់មនុស្ស គឺគ្រាន់តែត្រូវបំពេញភារកិច្ចរបស់ខ្លួនតែប៉ុណ្ណោះ ចំណែកឯកិច្ចការរបស់ព្រះជាម្ចាស់វិញ គឺត្រូវគ្រប់គ្រង និងត្រូវបំពេញព័ន្ធកិច្ចរបស់ទ្រង់។ ហេតុនេះ ថ្វីបើពួកសាវ័កជាច្រើនត្រូវបានព្រះវិញ្ញាណបរិសុទ្ធប្រើ ហើយពួកហោរាជាច្រើនត្រូវបំពេញដោយទ្រង់ក្ដី ក៏កិច្ចការនិងពាក្យសម្ដីរបស់ពួកគេគឺគ្រាន់តែដើម្បីបំពេញភារកិច្ចរបស់ពួកគេក្នុងនាមជាភាវៈដែលត្រូវបានបង្កើតមកប៉ុណ្ណោះ។ សេចក្ដីទំនាយរបស់ពួកគេ អាចហួសពីមាគ៌ាជីវិតដែលបានមានបន្ទូលដោយព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស ហើយភាពជាមនុស្សរបស់ពួកគេអាច

មានលក្ខណៈខ្ពង់ខ្ពស់ជាងព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស ប៉ុន្តែពួកគេនៅតែបំពេញភារកិច្ចរបស់ពួកគេដដែល និងមិនមែនបំពេញព័ន្ធកិច្ចនោះទេ។ ភារកិច្ចរបស់មនុស្សសំដៅលើមុខងាររបស់មនុស្ស។ វាជាកិច្ចការដែលមនុស្សអាចសម្រេចបាន។ ក៏ប៉ុន្តែ ព័ន្ធកិច្ចដែលបានបំពេញដោយព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស គឺពាក់ព័ន្ធនឹងការគ្រប់គ្រងរបស់ទ្រង់ ហើយកិច្ចការនេះមិនអាចសម្រេចដោយមនុស្សបានទេ។ មិនថាព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សមានបន្ទូល បំពេញការងារ ឬបើកសម្ដែងពីការអស្ចារ្យអ្វីនោះទេ គឺទ្រង់នឹងធ្វើកិច្ចការដ៏អស្ចារ្យក្នុងការគ្រប់គ្រងរបស់ទ្រង់ ហើយកិច្ចការបែបនេះមិនអាចឲ្យមនុស្សធ្វើជំនួសទ្រង់បានឡើយ។ កិច្ចការរបស់មនុស្សគឺគ្រាន់តែបំពេញភារកិច្ចរបស់ខ្លួនក្នុងនាមជាភាវៈមួយដែលបានបង្កើតមកនៅក្នុងដំណាក់កាលណាមួយនៃកិច្ចការគ្រប់គ្រងរបស់ព្រះជាម្ចាស់តែប៉ុណ្ណោះ។ បើគ្មានការគ្រប់គ្រងរបស់ព្រះជាម្ចាស់ទេ ពោលគឺ ប្រសិនបើព័ន្ធកិច្ចរបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សត្រូវបាត់បង់ទៅ នោះភារកិច្ចរបស់ភាវៈមួយដែលបានបង្កើតមកក៏នឹងត្រូវបាត់បងទៅដែរ។ កិច្ចការរបស់ព្រះជាម្ចាស់ក្នុងការបំពេញព័ន្ធកិច្ចរបស់ទ្រង់ គឺត្រូវគ្រប់គ្រងលើមនុស្ស រីឯការបំពេញភារកិច្ចរបស់មនុស្ស គឺជាការបំពេញកាតព្វកិច្ចផ្ទាល់ខ្លួនរបស់ពួកគេដើម្បីបំពេញតាមការចង់បានរបស់ព្រះអាទិករ ហើយគ្មានផ្លូវដែលអាចចាត់ទុកថាជាការបំពេញព័ន្ធកិច្ចរបស់នរណាម្នាក់ឡើយ។ ចំពោះសារជាតិដែលមានស្រាប់របស់ព្រះជាម្ចាស់ ពោលគឺចំពោះព្រះវិញ្ញាណរបស់ទ្រង់ កិច្ចការរបស់ព្រះជាម្ចាស់ គឺជាការគ្រប់គ្រងរបស់ទ្រង់ ប៉ុន្តែចំពោះព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សដែលពាក់ទម្រង់ខាងក្រៅនៃភាវៈមួយដែលត្រូវបានបង្កើតមកវិញ កិច្ចការរបស់ទ្រង់ គឺដើម្បីអនុវត្តព័ន្ធកិច្ចរបស់ទ្រង់។ មិនថាកិច្ចការអ្វីដែលទ្រង់បំពេញនោះទេ គឺសុទ្ធតែដើម្បីអនុវត្តព័ន្ធកិច្ចរបស់ទ្រង់ ហើយគ្រប់ការដែលមនុស្សអាចធ្វើបាន គឺត្រូវផ្តល់នូវអ្វីដែលល្អបំផុតនៅក្នុងទំហំនៃការគ្រប់គ្រងរបស់ព្រះជាម្ចាស់ និងនៅក្រោមការណែនាំរបស់ទ្រង់។

ការបំពេញភារកិច្ចរបស់មនុស្ស តាមពិតទៅ គឺជាការសម្រេចនូវគ្រប់កិច្ចការ

ទាំងអស់ដែលត្រូវធ្វើក្នុងនាមជាមនុស្សដែលនេះមានន័យថា ជាកិច្ចការដែលមនុស្សអាចធ្វើបាន។ គឺនៅពេលនោះហើយដែលគេអាចបំពេញកិច្ចការរបស់គេបាន។ ភាពខ្វះខាតរបស់មនុស្សក្នុងអំឡុងពេលនៃការបម្រើរបស់គេ គឺត្រូវកាត់បន្ថយបន្តិចម្ដងៗ តាមរយៈបទពិសោធជឿនលឿនទៅមុខ និងដំណើរការនៃការឆ្លងកាត់ ការជំនុំជម្រះ។ ពួកគេពុំបង្កការរំខាន ឬប៉ះពាល់ដល់ភារកិច្ចរបស់មនុស្សឡើយ។ អស់អ្នកណាដែលឈប់បម្រើ ឬផ្ដល់ផល និងធ្លាក់ទៅវិញដោយខ្លាចថា អាចនឹងមានកំហុសចំពោះការបម្រើរបស់ពួកគេ គឺជាមនុស្សកំសាកខ្លាំងជាងគេបំផុត។ ប្រសិនបើមនុស្សមិនអាចសម្ដែងឲ្យឃើញនូវអ្វីដែលពួកគេគួរសម្ដែងឲ្យឃើញ ក្នុងអំឡុងពេលនៃការបម្រើ ឬសម្រេចនូវអ្វីដែលមនុស្សអាចធ្វើបានពីកំណើត ហើយផ្ទុយទៅវិញ បែរជាចំណាយពេលវេលាឥតប្រយោជន៍ និងធ្វើឲ្យរួចតែពីដៃ នោះពួកគេបានបាត់បង់មុខងារដែលភាវៈត្រូវបានបង្កើតមក គួរតែមានហើយ។ មនុស្សបែបនេះ គេហៅថា «មនុស្សធុនកណ្ដាល»។ ពួកគេគឺជាកាកសំណល់ដែលគ្មានបានការ។ តើមនុស្សបែបនេះអាចហៅថាជាភាវៈដែលបានបង្កើតមកឲ្យបានត្រឹមត្រូវដោយរបៀបណាទៅ? តើពួកគេមិនមែនជាភាវៈពុករលួយដែលចាំងចែងតែខាងក្រៅ ប៉ុន្តែរលួយខាងក្នុងទេឬអី? ប្រសិនបើមនុស្សហៅខ្លួនឯងថាព្រះជាម្ចាស់ ប៉ុន្តែមិនអាចបើកសម្ដែងនូវភាពជាព្រះ បំពេញកិច្ចការរបស់ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ ឬតំណាងឲ្យព្រះជាម្ចាស់បានទេ នោះមិនបាច់ឆ្ងល់ទេ គេមិនមែនជាព្រះជាម្ចាស់ឡើយ ដ្បិតគេមិនមានសារជាតិរបស់ព្រះជាម្ចាស់ឡើយ ហើយអ្វីដែលព្រះជាម្ចាស់អាចសម្រេចបាន គឺពុំមានពិតនៅក្នុងខ្លួនរបស់គេទេ។ ប្រសិនបើមនុស្សបាត់បង់អ្វីដែលគេអាចទទួលបានពីកំណើតមក គេនឹងមិនអាចហៅថាជាមនុស្សបានទៀតទេ ហើយគេគ្មានតម្លៃដើម្បីឈរក្នុងនាមជាភាវៈមួយដែលបានបង្កើតមក ឬត្រូវមកចំពោះព្រះជាម្ចាស់ និងបម្រើទ្រង់ឡើយ។ បន្ថែមលើនេះ គេមិនមានតម្លៃ ដើម្បីទទួលនូវព្រះគុណរបស់ព្រះជាម្ចាស់ ឬដើម្បីឲ្យព្រះជាម្ចាស់ឃ្លាំមើល ការពារ និងធ្វើឲ្យគេបានគ្រប់លក្ខណ៍ឡើយ។ មនុស្សជាច្រើនដែលបានបាត់បង់ទំនុកចិត្តចំពោះព្រះជាម្ចាស់ ក៏បន្តបាត់បង់ព្រះគុណរបស់ព្រះជាម្ចាស់

ដែរ។ ពួកគេមិនត្រឹមតែមិនស្អប់ខ្ពើមអំពើខុសឆ្គងរបស់ពួកគេទេ ប៉ុន្តែពួកគេថែមទាំងផ្សព្វផ្សាយគំនិតរបស់ពួកគេដោយឥតញញើត ថាផ្លូវរបស់ព្រះជាមិនត្រឹមត្រូវ ហើយពួកបះបោរថែមទាំងបដិសេធអត្ថិភាពរបស់ព្រះជាម្ចាស់ទៀតផង។ តើមនុស្ស ដែលមានការបះបោរបែបនេះ អាចមានសិទ្ធិត្រេកអរសប្បាយ នឹងព្រះគុណរបស់ព្រះជាម្ចាស់បានដោយរបៀបណា? អស់អ្នកណាដែលមិនបំពេញភារកិច្ចរបស់ខ្លួន គឺបះបោរប្រឆាំងនឹងព្រះជាម្ចាស់ ហើយជំពាក់ទ្រង់យ៉ាងច្រើន ប៉ុន្តែពួកគេបែរខ្នង និងស្ដីបន្ទោសខ្លាំងៗថា ព្រះជាម្ចាស់មិនត្រឹមត្រូវ។ តើមនុស្សបែបនេះ អាចមានតម្លៃដើម្បីធ្វើឲ្យបានគ្រប់លក្ខណ៍ដោយរបៀបណាទៅ? តើនេះ មិនមែនជាការនាំឆ្ពោះទៅកាន់ការត្រូវផាត់ចោល និងការដាក់ទោសទេឬអី? មនុស្សមិនបំពេញភារកិច្ចរបស់ពួកគេនៅចំពោះព្រះជាម្ចាស់ គឺមានអារម្មណ៍ខុសឆ្គង់ជាស្រេចនៅក្នុងបទឧក្រិដ្ឋយ៉ាងធ្ងន់ធ្ងរ ដ្បិតសូម្បីតែការដាក់ទោសដល់ស្លាប់ក្ដី ក៏នៅមិនទាន់គ្រប់គ្រាន់ដែរ ប៉ុន្តែពួកគេមានលេសក្នុងការតវ៉ាជាមួយព្រះជាម្ចាស់ និងប្រៀបធៀបខ្លួនពួកគេជាមួយនឹងទ្រង់ទៀតផង។ តើការធ្វើឲ្យមនុស្សបែបនេះបានគ្រប់លក្ខណ៍មានតម្លៃអ្វីទៅ? នៅពេលដែលមនុស្សមិនបានបំពេញភារកិច្ចរបស់ពួកគេ ពួកគេគួរតែមានអារម្មណ៍ដឹងកំហុស និងជាប់ជំពាក់។ ពួកគេគប្បីស្អប់ខ្ពើមចំណុចខ្សោយ និងភាពមិនបានការរបស់ពួកគេ ស្អប់ខ្ពើមការបះបោរ និងសេចក្ដីពុករលួយរបស់ពួកគេ ហើយថែមទាំងត្រូវប្រគល់ជីវិតរបស់ពួកគេថ្វាយដល់ព្រះជាម្ចាស់ទៀតផង។ មានតែពេលនោះប៉ុណ្ណោះដែលពួកគេមានលក្ខណៈជាភាវៈមួយដែលត្រូវបានបង្កើតមក ដែលស្រឡាញ់ព្រះជាម្ចាស់ដោយពិតប្រាកដ ហើយមានតែមនុស្សបែបនេះទេ ដែលមានតម្លៃក្នុងការត្រេកអរសប្បាយនឹងព្រះពរ និងសេចក្ដីសន្យារបស់ព្រះជាម្ចាស់ ហើយអាចឲ្យទ្រង់ប្រោសឲ្យបានគ្រប់លក្ខណ៍។ ហើយចុះភាគច្រើននៃអ្នករាល់គ្នាវិញ? តើអ្នករាល់គ្នាប្រព្រឹត្តដាក់ព្រះជាម្ចាស់ដែលគង់នៅក្នុងចំណោមអ្នករាល់គ្នាដូចម្ដេច? តើអ្នករាល់គ្នាបានបំពេញភារកិច្ចរបស់អ្នករាល់គ្នានៅចំពោះទ្រង់ដោយរបៀបណា? តើអ្នកបានបំពេញគ្រប់ការទាំងអស់ដែលអ្នកត្រូវបានត្រាស់ហៅឲ្យទៅបំពេញ ទោះបីជាត្រូវលះបង់ជីវិតផ្ទាល់ខ្លួនរបស់

អ្នកក្ដីហើយឬនៅ? តើអ្នករាល់គ្នាបានលះបង់អ្វីខ្លះហើយ? តើអ្នករាល់គ្នាមិនបានទទួលច្រើនគ្រប់គ្រាន់ពីខ្ញុំទេឬអី? តើអ្នករាល់គ្នាយល់ដែរឬទេ? តើអ្នករាល់គ្នាស្មោះត្រង់ចំពោះខ្ញុំដល់កម្រិតណា? តើអ្នកបានបម្រើដល់ខ្ញុំដូចម្ដេចខ្លះ? ហើយតើខ្ញុំបានប្រទានអ្វីខ្លះដល់ឲ្យអ្នករាល់គ្នា និងបានធ្វើអ្វីខ្លះសម្រាប់អ្នករាល់គ្នា? តើអ្នករាល់គ្នាបានវាស់ស្ទង់កិច្ចការទាំងអស់នោះហើយឬនៅ? តើអ្នករាល់គ្នាបានវិនិច្ឆ័យ និងប្រៀបធៀបកិច្ចការទាំងអស់នេះ ដោយប្រើមនសិការតិចតួចដែលអ្នកមាននៅក្នុងខ្លួនឯង ហើយឬនៅ? តើពាក្យសម្ដី និងទង្វើរបស់អ្នកអាចមានតម្លៃចំពោះនរណាខ្លះ? តើវាអាចទេដែលការលះបង់តិចតួចរបស់អ្នករាល់គ្នា មានតម្លៃចំពោះគ្រប់អ្វីៗដែលខ្ញុំបានប្រទានដល់អ្នករាល់គ្នានោះ? ខ្ញុំគ្មានជម្រើសអ្វីផ្សេងទៀតឡើយ ហើយខ្ញុំបានលះបង់អស់ពីព្រះហឫទ័យចំពោះអ្នករាល់គ្នា ប៉ុន្តែអ្នករាល់គ្នាវិញនៅជាប់ដោយបំណងអាក្រក់ និងមានការស្ទាក់ស្ទើរចំពោះខ្ញុំ។ នេះគឺជាទំហំនៃភារកិច្ចរបស់អ្នករាល់គ្នា ជាមុខងារតែមួយគត់របស់អ្នករាល់គ្នា។ តើវាមិនមែនបែបនេះទេឬអី? តើអ្នករាល់គ្នាមិនដឹងថាអ្នករាល់គ្នាមិនបានបំពេញភារកិច្ចជាភាវៈមួយ ដែលបានបង្កើតមកនេះទេឬអី? តើអ្នករាល់គ្នាអាចចាត់ទុកជាភាវៈ ដែលបង្កើតមកបានដោយរបៀបណាទៅ? តើអ្នករាល់គ្នាមិនច្បាស់អំពីអ្វី ដែលអ្នករាល់គ្នាកំពុងបើកបង្ហាញ និងកំពុងស្ដែងចេញតាមរយៈការរស់នៅទេឬអី? អ្នករាល់គ្នាមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនឡើយ ប៉ុន្តែអ្នកព្យាយាមចង់បាននូវការអត់ឱន និងព្រះគុណដ៏ច្រើនសន្ធឹកសន្ធាប់របស់ព្រះជាម្ចាស់។ ព្រះគុណបែបនេះមិនធ្លាប់បានរៀបចំសម្រាប់នរណាម្នាក់ដែលគ្មានតម្លៃ និងថោកទាប ដូចជាអ្នករាល់គ្នាទេ ប៉ុន្តែគឺសម្រាប់អស់អ្នកណាដែលមិនស្នើសុំអ្វីសោះ និងជាអ្នកដែលលះបង់ដោយរីករាយ។ មនុស្សដូចជាអ្នករាល់គ្នា មនុស្សធុនកណ្ដាលបែបនេះ គឺគ្មានតម្លៃនឹងអរសប្បាយ ចំពោះព្រះគុណនៃស្ថានសួគ៌សូម្បីតែបន្តិចសោះឡើយ។ មានតែទុក្ខលំបាក និងការដាក់ទោសមិនចេះចប់ មិនចេះហើយប៉ុណ្ណោះ ដែលត្រូវកើតមាននៅសម័យរបស់អ្នករាល់គ្នា! ប្រសិនបើអ្នករាល់គ្នា មិនអាចស្មោះត្រង់ចំពោះខ្ញុំបានទេ នោះវាសនារបស់អ្នករាល់គ្នានឹងត្រូវជាវាសនាមួយដែលរងទុក្ខ

វេទនា។ ប្រសិនបើអ្នកមិនអាចទទួលខុសត្រូវចំពោះព្រះបន្ទូលរបស់ខ្ញុំ និងកិច្ចការរបស់ខ្ញុំបានទេ នោះលទ្ធផលរបស់អ្នករាល់គ្នានឹងទៅជាលទ្ធផលនៃការដាក់ទោស។ គ្រប់ព្រះគុណ ព្រះពរ និងជីវិតដ៏អស្ចារ្យនៃនគរព្រះ គឺគ្មានអ្វីពាក់ព័ន្ធជាមួយនឹងអ្នករាល់គ្នាឡើយ។ នេះគឺជាចុងបញ្ចប់ដែលអ្នករាល់គ្នាត្រូវជួបប្រទះ និងជាលទ្ធផលនៃការប្រព្រឹត្តរបស់អ្នកផ្ទាល់។ ភាពល្ងង់ខ្លៅ និងភាពក្រអឺតក្រទមទាំងអស់នេះ មិនធ្វើឲ្យពួកគេល្អនោះទេ ហើយក៏មិនឲ្យពួកគេបំពេញភារកិច្ចរបស់ពួកគេដែរ ពួកគេលាដៃរបស់ពួកគេសុំព្រះគុណ ហាក់ដូចជាអ្វីដែលពួកគេសុំនោះ គឺសមនឹងឲ្យពួកគេទទួលបានដូច្នោះដែរ។ ហើយប្រសិនបើពួកគេ មិនបានទទួលនូវអ្វីដែលពួកគេស្នើសុំទេ នោះពួកគេនឹងកាន់តែមានភាពស្មោះត្រង់តិចតួចទៅៗ។ តើមនុស្សបែបនេះ អាចត្រូវចាត់ទុកថាមានហេតុផលបានដោយរបៀបណា? អ្នករាល់គ្នាជាអ្នកដែលមានគុណសម្បត្តិអន់ខ្សោយ និងគ្មានហេតុផលសោះ គឺគ្មានសមត្ថភាពទាំងស្រុងក្នុងការបំពេញកាតព្វកិច្ចដែលអ្នករាល់គ្នា គប្បីត្រូវបំពេញក្នុងអំឡុងពេលនៃកិច្ចការការគ្រប់គ្រងនេះ។ តម្លៃរបស់អ្នករាល់គ្នា បានធ្លាក់ចុះយ៉ាងខ្លាំង។ ការដែលអ្នករាល់គ្នាមិនបានតបស្នងមកកាន់រូបខ្ញុំសម្រាប់ការបង្ហាញដល់អ្នករាល់គ្នានូវព្រះគុណបែបនេះ គឺជាអំពើបះបោរយ៉ាងខ្លាំងរួចបាត់ទៅហើយ គឺគ្រប់គ្រាន់ដើម្បីដាក់ទោសដល់អ្នករាល់គ្នា និងបើកឲ្យឃើញនូវភាពកំសាកញី ភាពអសមត្ថភាព ភាពថោកទាប និងភាពគ្មានតម្លៃរបស់អ្នករាល់គ្នា។ តើអ្នកមានសិទ្ធិអ្វីទៅលាដៃរបស់អ្នកចេញមកក្រៅទៀតនោះ? ការដែលអ្នករាល់គ្នាមិនអាចជួយដល់កិច្ចការរបស់ខ្ញុំ មិនអាចស្មោះត្រង់ និងមិនអាចធ្វើទីបន្ទាល់សម្រាប់ខ្ញុំបានសូម្បីបន្តិចនោះ គឺជាអំពើខុសឆ្គង និងការបរាជ័យរបស់អ្នករាល់គ្នា តែផ្ទុយទៅវិញ អ្នករាល់គ្នាវាយប្រហារមកលើខ្ញុំ និយាយមិនពិតអំពីខ្ញុំ និងរអ៊ូរទាំថាខ្ញុំមិនសុចរិត។ តើនេះរាប់បញ្ចូលថាជាសេចក្ដីស្មោះត្រង់របស់អ្នកដែរឬអី? តើនេះរាប់បញ្ចូលថាជាសេចក្ដីស្រឡាញ់របស់អ្នកដែរឬអី? តើមានកិច្ចការអ្វីផ្សេងទៀតដែលអ្នករាល់គ្នាអាចធ្វើបានក្រៅពីនេះ? តើអ្នករាល់គ្នាបានរួមចំណែកដល់កិច្ចការដែលបានបំពេញរួចរាល់ហើយនោះដោយរបៀបណា? តើអ្នកបានលះបង់ច្រើនប៉ុន ណា

ហើយ? ខ្ញុំបានបង្ហាញនូវការអត់ឱនយ៉ាងខ្លាំង ដោយមិនបានស្ដីបន្ទោសដល់អ្នករាល់គ្នាទេ ប៉ុន្តែអ្នករាល់គ្នានៅតែមិនរៀនខ្លាសក្នុងការដោះសារចំពោះខ្ញុំ និងរអ៊ូរទាំអំពីខ្ញុំដោយស្ងាត់កំបាំង។ តើអ្នករាល់គ្នាមានដានជាមនុស្សសូម្បីបន្តិចបន្តួចដែរឬទេ? បើទោះបីជាភារកិច្ចរបស់មនុស្ស ប្រឡាក់ប្រឡូកទៅដោយគំនិតរបស់មនុស្ស និងសញ្ញាណរបស់គេក្ដី ក៏ប៉ុន្តែអ្នកត្រូវតែបំពេញភារកិច្ចរបស់អ្នក និងបង្ហាញពីភាពស្មោះត្រង់របស់អ្នក។ ភាពមិនបរិសុទ្ធនៅក្នុងកិច្ចការរបស់មនុស្ស គឺជាបញ្ហាគុណសម្បត្តិរបស់គេ ផ្ទុយទៅវិញ ប្រសិនបើមនុស្សមិនបានបំពេញភារកិច្ចរបស់ខ្លួនទេ វាបង្ហាញឲ្យឃើញនូវភាពបះបោររបស់គេ។ ភារកិច្ចរបស់មនុស្ស និងការដែលគេត្រូវទទួលបានព្រះពរ ឬបណ្ដាសានោះ គឺពុំមានជាប់ទាក់ទងគ្នាទេ។ ភារកិច្ចគឺជាអ្វីដែលមនុស្សត្រូវបំពេញ។ វាជារបរចិញ្ចឹមជីវិតដែលប្រទានពីស្ថានសួគ៌មក ហើយមិនគប្បីត្រូវពឹងផ្អែកលើការប៉ះប៉ូវ លក្ខខណ្ឌ ឬមូលហេតុអ្វីឡើយ។ មានតែពេលនោះប៉ុណ្ណោះដែលគេនឹងបំពេញភារកិច្ចរបស់គេ។ ការទទួលបានព្រះពរ គឺនៅពេលដែលមនុស្សម្នាក់ត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍ ហើយត្រេកអរសប្បាយនឹងព្រះពររបស់ព្រះជាម្ចាស់ក្រោយពីឆ្លងកាត់ការជំនុំជម្រះរួច។ ការទទួលបណ្ដាសាគឺនៅពេលដែលនិស្ស័យរបស់មនុស្សម្នាក់មិនបានផ្លាស់ប្ដូរ ក្រោយពេលដែលពួកគេឆ្លងកាត់ការជំនុំជម្រះ និងការវាយផ្ចាលរួច គឺនៅពេលដែលពួកមិនបានឆ្លងកាត់នូវការប្រោសឲ្យបានគ្រប់លក្ខណ៍ ប៉ុន្តែត្រូវរងនូវការដាក់ទោសទៅវិញ។ ប៉ុន្តែ មិនថាពួកគេត្រូវទទួលបានព្រះពរ ឬការដាក់បណ្ដាសានោះទេ ភាវៈដែលត្រូវបង្កើតមកគប្បីបំពេញភារកិច្ចរបស់ពួកគេ ធ្វើអ្វីដែលពួកគេត្រូវធ្វើ និងធ្វើអ្វីដែលពួកគេអាចធ្វើបាន។ នេះគឺជាកិច្ចការតិចតួចបំផុតដែលមនុស្សម្នាក់ដែលជាមនុស្សដែលស្វែងរកព្រះជាម្ចាស់ គួរធ្វើ។ អ្នកមិនគួរបំពេញភារកិច្ចរបស់អ្នក ដើម្បីតែការប្រទានពរនោះទេ ហើយអ្នកមិនគួរបដិសេធមិនបំពេញកិច្ចការដោយការភ័យខ្លាចចំពោះការដាក់បណ្ដាសានោះទេ។ ខ្ញុំប្រាប់អ្នករាល់គ្នាពីរឿងមួយនេះចុះ៖ ការបំពេញភារកិច្ចផ្ទាល់ខ្លួនរបស់មនុស្ស គឺជាអ្វីដែលគេត្រូវធ្វើ ហើយប្រសិនបើគេមិនអាចបំពេញភារកិច្ចរបស់គេបានទេ នោះគឺដោយសារតែការបះបោររបស់

ពួកគេ។ គឺតាមរយៈដំណើរការនៃការបំពេញភារកិច្ចរបស់គេនេះហើយដែលមនុស្ស បានបំផ្លាស់បំប្រែបន្ដិចម្ដងៗ ហើយគឺដំណើរការនេះហើយ ដែលគេបានបង្ហាញនូវភាព ស្មោះត្រង់របស់គេ។ ដោយបែបនេះ កាលណាដែលអ្នកអាចបំពេញកិច្ចការរបស់អ្នក បានកាន់តែច្រើន នោះអ្នកនឹងកាន់តែទទួលបានសេចក្ដីពិតកាន់តែច្រើនដែរ ហើយការ បើកបង្ហាញរបស់អ្នក ក៏កាន់តែជាក់ស្ដែងជាងមុនដែរ។ អស់អ្នកណាដែលគ្រាន់តែ ឆ្លងកាត់សកម្មភាពក្នុងការបំពេញកិច្ចការរបស់ពួកគេ និងមិនស្វែងរកសេចក្ដីពិត នឹង ត្រូវផាត់ចោលនៅចុងបំផុត ដ្បិតមនុស្សបែបនេះមិនបំពេញភារកិច្ចរបស់ពួកគេនៅក្នុង ការអនុវត្តសេចក្ដីពិតទេ ហើយក៏មិនអនុវត្តសេចក្ដីពិតនៅក្នុងបំពេញភារកិច្ចរបស់ពួកគេ ឡើយ។ ពួកគេជាមនុស្សដែលមិនព្រមបំផ្លាស់បំប្រែ ហើយនឹងត្រូវបណ្ដាសា។ មិន ត្រឹមតែការបើកបង្ហាញរបស់ពួកគេ មិនបរិសុទ្ធនោះទេ ប៉ុន្ដែគ្រប់យ៉ាងដែលពួកគេ បង្ហាញមក គឺសុទ្ធតែអាក្រក់ទាំងអស់។

នៅក្នុងយុគសម័យនៃព្រះគុណ ព្រះយេស៊ូវក៏បានមានបន្ទូលជាច្រើន និងបាន បំពេញកិច្ចការជាច្រើនដែរ។ តើទ្រង់ខុសគ្នាពីអេសាយយ៉ាងណាខ្លះ? តើទ្រង់ខុសគ្នា ពី ដានីញ៉ែលយ៉ាងណាខ្លះ? តើទ្រង់ជាហោរាម្នាក់មែនទេ? តើហេតុអ្វីបានជាគេហៅ ទ្រង់ថាព្រះគ្រីស្ទ? តើពួកគាត់មានអ្វីខុសគ្នាខ្លះទៅ? ពួកគេជាមនុស្សដែលបាននិយាយ ពីព្រះបន្ទូល ហើយព្រះបន្ទូលរបស់ពួកគេសម្រាប់មនុស្ស គឺគ្មានអ្វីខុសគ្នានោះទេ។ ពួកគេបាននិយាយពីព្រះបន្ទូល និងបានបំពេញកិច្ចការ។ ពួកហោរានៃព្រះគម្ពីរសញ្ញា ចាស់ បាននិយាយអំពីសេចក្ដីទំនាយ ហើយព្រះយេស៊ូវក៏អាចធ្វើស្រដៀងគ្នានេះបាន ដែរ។ តើហេតុអ្វីបានជាដូច្នេះទៅវិញ? ភាពខុសគ្នានៅត្រង់នេះ គឺផ្អែកលើធម្មជាតិ នៃកិច្ចការនោះ។ ដើម្បីអាចស្វែងយល់អំពីបញ្ហានេះបាន អ្នកមិនត្រូវពិចារណាអំពី ធម្មជាតិនៃសាច់ឈាមនោះទេ ហើយអ្នកក៏មិនត្រូវគិតពិចារណាអំពីជម្រៅ ឬភាព រាក់កំភែលនៃសម្ដីរបស់ពួកគេដែរ។ ជានិច្ចកាល អ្នកត្រូវគិតពិចារណាអំពីកិច្ចការ របស់ពួកគេជាមុន ហើយតើកិច្ចការរបស់ពួកគេនោះ ត្រូវសម្រេចជាលទ្ធផលបែប ណាចំពោះមនុស្ស។ ពួកហោរាបាននិយាយ អំពីសេចក្ដីទំនាយនៅពេលមួយដែល

មិនអាចទំនុកបម្រុងដល់ជីវិតរបស់មនុស្សបាន ហើយការជំរុញលើកចិត្តពីមនុស្សមួយចំនួនដូចជា អេសាយ និងដានីយ៉ែល គឺគ្រាន់តែជាសេចក្ដីទំនាយប៉ុណ្ណោះ និងមិនមែនជាមាគ៌ាជីវិតឡើយ។ ប្រសិនបើ មិនមែនជាការបើកសម្ដែងដោយផ្ទាល់ពីព្រះយេហូវ៉ាទេ គ្មាននណាម្នាក់អាចសម្រេចកិច្ចការ នោះបានឡើយ មនុស្សសាមញ្ញធម្មតាមិនអាចធ្វើវាបានឡើយ។ ព្រះយេស៊ូវក៏បានថ្លែងពីព្រះបន្ទូលជាច្រើនដែរ ប៉ុន្ដែព្រះបន្ទូលទាំងអស់នោះ គឺជាមាគ៌ាជីវិតដែលមនុស្សអាចស្វែងរកផ្លូវសម្រាប់ការអនុវត្តបាន។ នេះគឺចង់បានន័យថា ដំបូង ទ្រង់អាចទំនុកបម្រុងដល់ជីវិតមនុស្សបាន ដ្បិតព្រះយេស៊ូវគឺជាជីវិត។ ទីពីរ ទ្រង់អាចកែប្រែភាពវៀចវេររបស់មនុស្សបាន។ ទីបីកិច្ចការរបស់ទ្រង់អាចសម្រេចបាននូវកិច្ចការរបស់ព្រះយេហូវ៉ា ដើម្បីបន្តសម័យកាលនោះតទៅទៀត។ ទីបួន ទ្រង់អាចយល់ពីតម្រូវការនៅក្នុងមនុស្ស និងជ្រាបពីអ្វីដែលមនុស្សខ្វះខាត។ ទីប្រាំ ទ្រង់អាចនាំទៅក្នុងយុគសម័យថ្មីមួយ និងបញ្ចប់យុគសម័យចាស់។ នេះគឺជាមូលហេតុ ដែលទ្រង់ត្រូវបានគេហៅថាព្រះជាម្ចាស់ និងព្រះគ្រីស្ទ។ ទ្រង់មិនត្រឹមតែខុសពីអេសាយប៉ុណ្ណោះទេ ប៉ុន្ដែក៏ខុសគ្នាពីពួកហោរាដទៃទៀតដែរ។ ចូរយកអេសាយមកធ្វើការប្រៀបធៀបអំពីកិច្ចការរបស់ពួកហោរា។ ដំបូង គាត់មិនអាចទំនុកបម្រុងដល់ជីវិតរបស់មនុស្សបានឡើយ។ គាត់មិនអាចចូលទៅក្នុងយុគសម័យថ្មីមួយបានឡើយ។ គាត់បំពេញកិច្ចការនៅក្រោមការដឹកនាំរបស់ព្រះយេហូវ៉ា មិនមែនដើម្បីនាំចូលទៅក្នុងយុគសម័យថ្មីមួយទេ។ ទីបី ព្រះបន្ទូលដែលគាត់បានថ្លែង គឺហួសព្រំដែនរបស់គាត់។ គាត់ទទួលបានការបើកសម្ដែងដោយផ្ទាល់ពីព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ ហើយមនុស្សផ្សេងទៀតនឹងមិនអាចយល់បានឡើយ ទោះបីជាបានស្ដាប់ព្រះបន្ទូលទាំងអស់នោះក្ដី។ ចំណុចទាំងអស់នេះ គឺគ្រប់គ្រាន់សម្រាប់បញ្ជាក់ថា សម្ដីរបស់គាត់ គឺមិនលើសពីសេចក្ដីទំនាយនោះទេ គ្មានអ្វីក្រៅពីទិដ្ឋភាពមួយនៃកិច្ចការដែលបានធ្វើជំនួសព្រះយេហូវ៉ាឡើយ។ ក៏ប៉ុន្ដែ គាត់មិនអាចតំណាងឲ្យព្រះយេហូវ៉ាបានទាំងស្រុងឡើយ។ គាត់គឺជាបាវបម្រើរបស់ព្រះយេហូវ៉ា ជាឧបករណ៍មួយនៅក្នុងកិច្ចការរបស់ព្រះយេហូវ៉ា។ គាត់គ្រាន់តែធ្វើកិច្ចការនៅក្នុងយុគសម័យនៃ

ក្រឹត្យវិន័យ និងនៅក្នុងទំហំនៃកិច្ចការរបស់ព្រះយេហូវ៉ាប៉ុណ្ណោះ។ គាត់មិនបានបំពេញកិច្ចការហួសពីយុគសម័យនៃក្រឹត្យវិន័យឡើយ។ ផ្ទុយទៅវិញ កិច្ចការរបស់ព្រះយេស៊ូវខុសគ្នាពីនេះ។ ទ្រង់បានធ្វើហួសពីទំហំនៃកិច្ចការរបស់ព្រះយេហូវ៉ា។ ទ្រង់បានធ្វើជាព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស និងបានឆ្លងកាត់ការជាប់ឆ្កាង ដើម្បីប្រោសលោះមនុស្សជាតិទាំងអស់។ នេះចង់មានន័យថា ទ្រង់បានបំពេញកិច្ចការថ្មីក្រៅពីកិច្ចការដែលព្រះយេហូវ៉ាបានបំពេញ។ នេះគឺជា ការនាំចូលទៅក្នុងយុគសម័យថ្មីមួយ។ បន្ថែមលើនេះ ទ្រង់អាចមានបន្ទូលអំពីអ្វីដែលមនុស្សមិនអាចសម្រេចទៅដល់បាន។ កិច្ចការរបស់ទ្រង់ គឺជាកិច្ចការនៃការគ្រប់គ្រងរបស់ព្រះជាម្ចាស់ ហើយពាក់ព័ន្ធនឹងមនុស្សជាតិទាំងមូល។ ទ្រង់មិនបានបំពេញកិច្ចការនេះសម្រាប់តែមនុស្សពីរបីនាក់នោះទេ ហើយកិច្ចការរបស់ទ្រង់ គឺជាមធ្យោបាយដើម្បីដឹកនាំមនុស្សនៅក្នុងចំនួនដែលមានកំណត់។ ចំពោះរបៀបដែលព្រះជាម្ចាស់បានយកកំណើតជាមនុស្ស របៀបដែលព្រះវិញ្ញាណបានប្រទាននូវការបើកសម្ដែងនៅពេលនោះ និងរបៀបដែលព្រះវិញ្ញាណបានយាងចុះមកសណ្ឋិតលើមនុស្សម្នាក់ដើម្បីបំពេញកិច្ចការគឺទាំងអស់នេះសុទ្ធតែជាបញ្ហាដែលមនុស្សមិនអាចមើលឃើញ ឬប៉ះបានឡើយ។ សេចក្តីពិតទាំងអស់នេះមិនអាចធ្វើជាសេចក្តីសម្អាងថា ទ្រង់គឺជាព្រះជាម្ចាស់ ដែលយកកំណើតជាមនុស្សបាននោះឡើយ។ ដោយបែបនេះ ភាពប្លែកគ្នាអាចបែងចែកបានតែនៅក្នុងព្រះបន្ទូល និងកិច្ចការរបស់ព្រះជាម្ចាស់ ដែលមានលក្ខណៈរូបីចំពោះមនុស្សប៉ុណ្ណោះ។ មានតែចំណុចនេះប៉ុណ្ណោះដែលជាក់ស្តែង។ នេះគឺដោយសារតែ អ្នកមិនអាចមើលឃើញបញ្ហារបស់ព្រះវិញ្ញាណបានឡើយ ហើយមានតែព្រះជាម្ចាស់ផ្ទាល់ព្រះអង្គប៉ុណ្ណោះដែលជ្រាបអំពីបញ្ហានេះបានច្បាស់លាស់ ហើយសូម្បីតែការយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់ ក៏ខាងសាច់ឈាមមិនដឹងបានគ្រប់គ្នាដែរ។ អ្នកគ្រាន់តែអាចបញ្ជាក់បានថា តើទ្រង់គឺជាព្រះជាម្ចាស់មែនឬអត់ តាមរយៈកិច្ចការដែលទ្រង់បានបំពេញប៉ុណ្ណោះ។ តាមរយៈកិច្ចការរបស់ទ្រង់ គេអាចមើលឃើញថា ទីមួយ គឺទ្រង់អាចចាប់ផ្តើមយុគសម័យថ្មីមួយបាន។ ទីពីរ ទ្រង់អាចទំនុកបម្រុងដល់ជីវិតមនុស្ស

និងអាចបង្ហាញផ្លូវឲ្យមនុស្សដើរតាមបាន។ នេះគឺគ្រប់គ្រាន់ក្នុងការ បញ្ជាក់ថា ទ្រង់គឺជាព្រះជាម្ចាស់ផ្ទាល់ព្រះអង្គទ្រង់តែម្ដង។ យ៉ាងហោចណាស់ កិច្ចការដែលទ្រង់បំពេញអាចតំណាងឲ្យព្រះវិញ្ញាណរបស់ព្រះជាម្ចាស់បានពេញលេញ ហើយតាមរយៈកិច្ចការនេះ គេអាចមើលឃើញថា ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ សណ្ឋិតនៅក្នុងទ្រង់។ ចំពោះកិច្ចការដែលបំពេញដោយព្រះជាម្ចាស់ ដែលយកកំណើតជាមនុស្ស សំខាន់គឺដើម្បីនាំទៅកាន់យុគសម័យថ្មីមួយ ដឹកនាំកិច្ចការថ្មី និងចាប់ផ្ដើមសម័យថ្មី ចំណុចទាំងអស់នេះ គឺគ្រប់គ្រាន់ដើម្បីបញ្ជាក់ថា ទ្រង់គឺជាព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ។ ហេតុនេះ វាអាចបញ្ជាក់ពីភាពខុសគ្នារវាងទ្រង់ និងអេសាយ ដានីយ៉ែល និងពួកហោរាធំៗដទៃទៀត។ អេសាយ ដានីយ៉ែល និងមនុស្សដទៃទៀត គឺជាក្រុមមនុស្សដែលមានការអប់រំ និងមានវប្បធម៌ខ្ពង់ខ្ពស់ ហើយពួកគេគឺជាមនុស្សពិសេស ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ព្រះយេហូវ៉ា។ សាច់ឈាមនៃព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស ក៏មានចំណេះដឹងដែរ និងមិនខ្វះនូវការយល់ដឹងឡើយ ប៉ុន្តែភាពជាមនុស្សរបស់ទ្រង់ គឺមានភាពសាមញ្ញធម្មតាជាពិសេស។ ទ្រង់ជាមនុស្សសាមញ្ញធម្មតា ហើយភ្នែកទទេមិនអាចយល់បានឡើយនូវលក្ខណៈពិសេសនៃភាពជាមនុស្សរបស់ទ្រង់ ឬយល់បានពីអ្វីគ្រប់យ៉ាងនៅក្នុងភាពជាមនុស្សរបស់ទ្រង់ ដែលខុសពីអ្នកដទៃទៀត។ ទ្រង់មិនហួសពីនិស្ស័យធម្មជាតិ ឬពិសេសអ្វីនោះទេ ហើយទ្រង់មិនមានការអប់រំ ចំណេះដឹង ឬទ្រឹស្តីខ្ពង់ខ្ពស់អ្វីឡើយ។ ជីវិតដែលទ្រង់បានមានព្រះបន្ទូល និងផ្លូវដែលទ្រង់ដឹកនាំ មិនអាចសម្រេចបានតាមទ្រឹស្តី តាមចំណេះដឹង តាមបទពិសោធជីវិត ឬតាមរយៈការអប់រំរបស់គ្រួសារឡើយ។ ផ្ទុយទៅវិញ វាជាកិច្ចការផ្ទាល់របស់ព្រះវិញ្ញាណ ដែលជាកិច្ចការនៃការយកកំណើតជាមនុស្ស។ ដោយសារមនុស្សមានសញ្ញាណយ៉ាងច្រើនអំពីព្រះជាម្ចាស់ ហើយជាពិសេសដោយសារសញ្ញាណទាំងអស់ត្រូវបានបង្កើតឡើងដោយធាតុស្រពេចស្រពិល និងហួសពីនិស្ស័យធម្មជាតិ បានជានៅក្នុងភ្នែករបស់មនុស្ស ព្រះជាម្ចាស់ដែលសាមញ្ញធម្មតា ដែលមានចំណុចខ្សោយរបស់មនុស្ស ដែលមិនអាចធ្វើទីសម្គាល់ និងការអស្ចារ្យបាន គឺច្បាស់ណាស់ថាមិនមែន

ជាព្រះជាម្ចាស់ទេ។ តើនេះមិនមែនជាសញ្ញាណខុស របស់មនុស្សទេឬអី? ប្រសិនបើសាច់ឈាមរបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស មិនមែនជាមនុស្សធម្មតាទេ ដូច្នេះតើគេអាចនិយាយថា ទ្រង់បានត្រលប់ជាសាច់ឈាមដោយរបៀបណា? ដើម្បីត្រលប់ជាសាច់ឈាមបាន គឺត្រូវក្លាយជាមនុស្សធម្មតា។ ប្រសិនបើទ្រង់មានលក្ខណៈជាមនុស្សដែលខ្ពង់ខ្ពស់ វិសេសវិសាល នោះទ្រង់នឹងមិនអាចក្លាយជាសាច់ឈាមបានឡើយ។ ដើម្បីបញ្ជាក់ថា ទ្រង់បានត្រលប់ជាសាច់ឈាម ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស ចាំបាច់ត្រូវមានសាច់ឈាមធម្មតា។ នេះគឺដើម្បីបំពេញនូវអត្ថន័យនៃការយកកំណើតជាមនុស្ស។ ក៏ប៉ុន្ដែ នេះមិនមែនជាករណីសម្រាប់ពួកហោរា និងកូនមនុស្សទេ។ ពួកគេគឺជាមនុស្សមានអំណោយទាន ដែលព្រះវិញ្ញាណបរិសុទ្ធបានប្រើ។ នៅក្នុងភ្នែករបស់មនុស្ស ភាពជាមនុស្សរបស់ពួកគេ គឺអស្ចារ្យខ្លាំងណាស់ ហើយពួកគេធ្វើទង្វើជាច្រើនដែលហួសពីសមត្ថភាពរបស់មនុស្សធម្មតា។ ដោយព្រោះហេតុផលនេះ បានជាមនុស្សចាត់ទុកពួកគេជាព្រះជាម្ចាស់។ សព្វថ្ងៃនេះ អ្នករាល់គ្នាត្រូវយល់ពីបញ្ហានេះឲ្យបានច្បាស់ ដ្បិតវាធ្លាប់ជាបញ្ហាដែលមនុស្សនៅជំនាន់មុនងាយនឹងយល់ច្រឡំបំផុត។ បន្ថែមលើនេះ ការយកកំណើតជាមនុស្ស គឺមានអាថ៌កំបាំងលើសរឿងអ្វីទាំងអស់ ហើយព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស គឺពិបាកនឹងឲ្យមនុស្ស ទទួលយកបានខ្លាំងណាស់។ អ្វីដែលខ្ញុំមានបន្ទូលនេះ គឺចាំបាច់ដើម្បីបំពេញមុខងាររបស់អ្នករាល់គ្នា និងសម្រាប់ការយល់ដឹងរបស់អ្នករាល់គ្នាចំពោះអាថ៌កំបាំងនៃការយកកំណើតជាមនុស្សនេះ។ អ្វីទាំងអស់នេះ ពាក់ព័ន្ធនឹងការគ្រប់គ្រងរបស់ព្រះជាម្ចាស់ ពាក់ព័ន្ធនឹងនិមិត្តទាំងនោះ។ ការយល់ដឹងរបស់អ្នករាល់គ្នាអំពីបញ្ហានេះ នឹងកាន់តែមានប្រយោជន៍ចំពោះការទទួលបានចំណេះដឹងអំពីនិមិត្តទាំងនោះ ពោលគឺកិច្ចការនៃការគ្រប់គ្រងរបស់ព្រះជាម្ចាស់។ តាមរបៀបនេះ អ្នករាល់គ្នាក៏ទទួលបាននូវការយល់ដឹងយ៉ាងច្រើនអំពីភារកិច្ចដែលមនុស្សខុសៗគ្នាគួរបំពេញដែរ។ ថ្វីបើព្រះបន្ទូលទាំងអស់នេះ មិនបានបង្ហាញឲ្យអ្នករាល់គ្នាឃើញពីផ្លូវនោះដោយផ្ទាល់ក្ដី ក៏ព្រះបន្ទូលទាំងអស់នេះ នៅតែជាជំនួយយ៉ាងសំខាន់ចំពោះ

ការចូលរួមរបស់អ្នករាល់គ្នាដែរ ដ្បិតអ្នករាល់គ្នារស់នៅក្នុងពេលបច្ចុប្បន្ននេះ មានការខ្វះខាតនូវនិមិត្តទាំងនេះខ្លាំងណាស់ ហើយកង្វះខាតនេះនឹងក្លាយជាឧបសគ្គយ៉ាងធំ ដែលរារាំងការចូលរួមរបស់អ្នករាល់គ្នា។ ប្រសិនបើអ្នករាល់គ្នាមិនអាចយល់ពីបញ្ហាទាំងអស់នេះបានទេ នឹងគ្មានការបណ្ដាលចិត្តណាដែលជំរុញការចូលរួមរបស់អ្នកបានឡើយ។ ហើយតើការស្វែងរកដោយបែបនេះ អាចឲ្យអ្នកបំពេញភារកិច្ចរបស់ខ្លួនបានល្អឥតខ្ចោះយ៉ាងដូចម្ដេចទៅ?

# ព្រះជាម្ចាស់ គឺជាព្រះអម្ចាស់នៃសព្វសាររពើទាំងអស់

ដំណាក់កាលមួយនៃកិច្ចការ ក្នុងយុគសម័យពីមុនចំនួនពីរ ត្រូវបានអនុវត្តនៅអ៊ីស្រាអែល ហើយមួយទៀតត្រូវបានអនុវត្តនៅស្រុកយូដា។ និយាយរួម កិច្ចការនេះគ្មានដំណាក់កាលណាមួយនៅសេសសល់ ក្នុងអ៊ីស្រាអែលទេ ហើយដំណាក់កាលនីមួយៗ ត្រូវបានអនុវត្តលើមនុស្ស ដែលបានជ្រើសរើសដំបូង។ ជាលទ្ធផល ជនជាតិអ៊ីស្រាអែលជឿថាព្រះយេហូវ៉ា គឺជាព្រះតែមួយគត់របស់ជនជាតិអ៊ីស្រាអែល។ ដោយសារព្រះយេស៊ូវបានធ្វើការនៅស្រុកយូដា ជាទីកន្លែងដែលទ្រង់បានបំពេញនូវកិច្ចការជាប់ឆ្កាង ទើបជនជាតិយូដាចាត់ទុកទ្រង់ ជាព្រះដ៏ប្រោសលោះរបស់ជនជាតិយូដា។ ពួកគេយល់ថាទ្រង់ជាស្ដេច របស់ជនជាតិយូដាតែមួយគត់ មិនមែនជាស្ដេចរបស់ជាតិសាសន៍ផ្សេងទៀតទេ គឺទ្រង់មិនមែនជាព្រះអម្ចាស់ដែលប្រោសលោះជនជាតិអង់គ្លេស ក៏មិនមែនជាព្រះអម្ចាស់ដែលប្រោសលោះជនជាតិអាមេរិកាំងនោះដែរ តែទ្រង់ជាព្រះអម្ចាស់ដែលប្រោសលោះជនជាតិអ៊ីស្រាអែល គឺជាជនជាតិយូដា ដែលទ្រង់បានប្រោសលោះនៅអ៊ីស្រាអែល។ តាមពិតទៅ ព្រះជាម្ចាស់គឺជាចៅហ្វាយនៃអ្វីៗទាំងអស់។ ទ្រង់គឺជាព្រះជាម្ចាស់នៃសព្វសាររពើទាំងអស់។ ទ្រង់មិនត្រឹមតែជាព្រះជាម្ចាស់របស់ជនជាតិអ៊ីស្រាអែល និងជនជាតិយូដាប៉ុណ្ណោះទេ ទ្រង់គឺជាព្រះជាម្ចាស់នៃសព្វសាររពើទាំងអស់។ ដំណាក់កាលពីមុនចំនួនពីរអំពីកិច្ចការរបស់

ទ្រង់ បានកើតឡើងនៅអ៊ីស្រាអែល គឺកិច្ចការនេះហើយដែលបានបង្កើតសញ្ញាណជាក់លាក់នៅក្នុងចិត្តមនុស្ស។ ពួកគេជឿថា ព្រះយេហូវ៉ាបានធ្វើកិច្ចការរបស់ទ្រង់នៅអ៊ីស្រាអែល និងជឿថា ព្រះយេស៊ូវផ្ទាល់បានបំពេញកិច្ចការរបស់ទ្រង់នៅស្រុកយូដា ហើយលើសពីនេះទៀត ទ្រង់បានក្លាយជាសាច់ឈាមដើម្បីធ្វើការ និងទោះជាក្នុងករណីណាក៏ដោយ ក៏កិច្ចការនេះមិនលាតសន្ធឹង ហួសពីអ៊ីស្រាអែលដែរ។ ព្រះជាម្ចាស់មិនបានធ្វើការនៅក្នុងជនជាតិអេហ្ស៊ីប ឬជនជាតិឥណ្ឌានោះទេ។ ទ្រង់ធ្វើការក្នុងជនជាតិអ៊ីស្រាអែលមួយប៉ុណ្ណោះ។ ដូច្នេះ មនុស្សបង្កើតនូវសញ្ញាណផ្សេងៗ ហើយកំណត់ព្រំដែននៃកិច្ចការរបស់ព្រះជាម្ចាស់ នៅក្នុងវិសាលភាពជាក់លាក់មួយ។ ពួកគេនិយាយថា នៅពេលព្រះជាម្ចាស់ធ្វើការ ទ្រង់ត្រូវតែធ្វើកិច្ចការនោះក្នុងចំណោមមនុស្សដែលទ្រង់បានជ្រើសរើស និងនៅអ៊ីស្រាអែល ដើម្បីជួយសង្គ្រោះជនជាតិអ៊ីស្រាអែល ព្រះជាម្ចាស់មិនធ្វើការនឹងជនជាតិដទៃឡើយ ហើយកិច្ចការរបស់ទ្រង់ ក៏មិនមានវិសាលភាពធំជាងនេះដែរ។ និយាយដល់ការរក្សាព្រះជាម្ចាស់ដែលត្រលប់ជាសាច់ឈាមឱ្យនៅក្នុងដែនកំណត់ពួកគេ តឹងរឹងជាពិសេសតែម្ដង ហើយមិនអនុញ្ញាតឱ្យទ្រង់ឆ្លងហួសព្រំដែនអ៊ីស្រាអែលឡើយ។ តើទាំងនេះមិនមែនគ្រាន់តែជាសញ្ញាណរបស់មនុស្សទេឬអី? ព្រះជាម្ចាស់បានបង្កើតផ្ទៃមេឃផែនដី និងអ្វីៗទាំងអស់ ទ្រង់បានបង្កើតសព្វសារពើទាំងអស់ ដូច្នេះតើទ្រង់អាចកម្រិតកិច្ចការរបស់ទ្រង់ ត្រឹមតែអ៊ីស្រាអែលបានយ៉ាងដូចម្ដេច? ប្រសិនបើដូច្នោះមែន តើទ្រង់បង្កើតអ្វីៗទាំងអស់មកដើម្បីអ្វី? ទ្រង់បានបង្កើតពិភពលោកទាំងមូល ហើយទ្រង់បានអនុវត្តផែនការគ្រប់គ្រងរយៈពេលប្រាំមួយពាន់ឆ្នាំរបស់ទ្រង់ មិនត្រឹមតែនៅក្នុងប្រទេសអ៊ីស្រាអែលប៉ុណ្ណោះទេ គឺអនុវត្តលើមនុស្សគ្រប់រូប នៅក្នុងសកលលោកទាំងមូលទៀតផង។ បើទោះបីជាពួកគេរស់នៅក្នុងប្រទេសចិន សហរដ្ឋអាមេរិកចក្រភពអង់គ្លេស ឬប្រទេសរុស្ស៊ីក្ដី មនុស្សគ្រប់គ្នាសុទ្ធតែជា ពូជពង្សរបស់អ័ដាម។ ពួកគេទាំងអស់ត្រូវបានបង្កើតឡើងដោយព្រះជាម្ចាស់។ គ្មាននរណាម្នាក់អាចគេចផុតពីព្រំដែននៃការបង្កើតរបស់ព្រះជាម្ចាស់ទេ ហើយក៏គ្មាននរណាម្នាក់អាចផ្ដាច់ខ្លួនពីស្លាកសញ្ញានៃ «ពូជពង្សរបស់

អ័ដាម» ឡើយ។ ពួកគេជាមនុស្សដែលព្រះជាម្ចាស់បង្កើត ពួកគេទាំងអស់សុទ្ធតែជាពូជរបស់អ័ដាម ហើយពួកគេក៏ជាពូជពង្សខូចអាក្រក់របស់អ័ដាម និងអេវ៉ាដែរ។ មនុស្សដែលព្រះជាម្ចាស់បង្កើត មិនមែនមានតែជនជាតិអ៊ីស្រាអែលមួយប៉ុណ្ណោះទេ ប៉ុន្តែជាមនុស្សទាំងអស់វិញ គ្រាន់តែថាអ្នកខ្លះត្រូវបណ្ដាសា ចំណែកអ្នកខ្លះទៀតត្រូវបានព្រះជាម្ចាស់ប្រទានពរ។ មានរឿងរ៉ាវរីករាយជាច្រើនអំពីជនជាតិអ៊ីស្រាអែល។ ព្រះជាម្ចាស់បានធ្វើការឲ្យពួកគេតាំងពីដំបូង ពីព្រោះពួកគេជាមនុស្សដែលពុករលួយតិចតួចជាងគេ។ ជនជាតិចិន មិនមានអ្វីប្រៀបធៀបជាមួយពួកគេបានទេ។ ពួកគេអន់ជាងពួកអ៊ីស្រាអែលឆ្ងាយណាស់។ ដូច្នេះពីដំបូងឡើយ ព្រះជាម្ចាស់បានធ្វើការក្នុងចំណោមប្រជាជនអ៊ីស្រាអែល ហើយដំណាក់កាលទីពីរនៃកិច្ចការរបស់ទ្រង់ ត្រូវបានអនុវត្តនៅតែស្រុកយូដាប៉ុណ្ណោះ ដែលនាំឱ្យមានសញ្ញាណ និងច្បាប់ជាច្រើនក្នុងចំណោមមនុស្ស។ តាមពិត ប្រសិនបើព្រះជាម្ចាស់ធ្វើតាមសញ្ញាណរបស់មនុស្ស ទ្រង់នឹងធ្វើជាព្រះជាម្ចាស់របស់អ៊ីស្រាអែលតែមួយអង្គគត់ ហើយដូច្នេះ ទ្រង់មិនអាចមានសមត្ថភាពពង្រីកកិច្ចការរបស់ទ្រង់ដល់ជាតិសាសន៍ដទៃបានឡើយ ពីព្រោះទ្រង់នឹងធ្វើជាព្រះជាម្ចាស់របស់ជនជាតិអ៊ីស្រាអែលប៉ុណ្ណោះ ហើយមិនមែនជាព្រះជាម្ចាស់របស់មនុស្សលោកទាំងមូលទេ។ ទំនាយជាច្រើនបានទាយថា ព្រះនាមរបស់ព្រះយេហូវ៉ា នឹងត្រូវបានតម្កើងឡើងក្នុងចំណោមជាតិសាសន៍ដទៃ ហើយព្រះនាមរបស់ទ្រង់នឹងសុសសាយដល់ជាតិសាសន៍ដទៃដែរ។ ហេតុអ្វីបានជាមានទំនាយបែបនេះ? ប្រសិនបើព្រះជាម្ចាស់ គឺជាព្រះរបស់ជនជាតិអ៊ីស្រាអែលតែមួយមែននោះ ទ្រង់នឹងធ្វើការនៅក្នុងប្រទេសអ៊ីស្រាអែលតែមួយប៉ុណ្ណោះ។ លើសពីនេះទៀត ទ្រង់នឹងមិនផ្សព្វផ្សាយកិច្ចការនេះទេ ហើយទ្រង់ក៏នឹងមិនធ្វើការទាយទុកបែបនេះដែរ។ ដោយសារទ្រង់បានទាយទុក ដូច្នេះ ទ្រង់ប្រាកដជាពង្រីកកិច្ចការរបស់ទ្រង់ ក្នុងចំណោមជាតិសាសន៍ដទៃ ក្នុងចំណោមប្រជាជាតិនីមួយៗ និងគ្រប់ដែនដីទាំងអស់។ ដោយសារព្រះជាម្ចាស់មានបន្ទូលបែបនេះ ទ្រង់ត្រូវតែធ្វើឱ្យបាន។ នេះគឺជាផែនការរបស់ទ្រង់ ដ្បិតទ្រង់ជាព្រះអម្ចាស់ដែលបានបង្កើតផ្ទៃមេឃ និងផែនដី

និងអ្វីៗសព្វសារពើ ហើយជាព្រះជាម្ចាស់នៃសត្តនិករផងទាំងពួង។ ទោះបីជាទ្រង់ធ្វើការក្នុងចំណោមជនជាតិអ៊ីស្រាអែលក្ដី ធ្វើការពេញស្រុកយូដាទាំងមូលក្ដី ក៏កិច្ចការដែលទ្រង់ធ្វើ គឺជាកិច្ចការនៃសកលលោកទាំងមូល និងជាកិច្ចការរបស់មនុស្សលោកទាំងអស់។ កិច្ចការដែលទ្រង់ធ្វើនាពេលសព្វថ្ងៃនេះ នៅក្នុងប្រទេសនាគដ៏ធំមានសម្បុរក្រហម គឺនៅក្នុងជាតិសាសន៍ដទៃមួយ ក៏នៅតែជាកិច្ចការរបស់មនុស្សលោកទាំងមូលដែរ។ អ៊ីស្រាអែលអាចជាមូលដ្ឋានសម្រាប់កិច្ចការរបស់ទ្រង់ នៅលើផែនដី។ ដូចគ្នាដែរ ប្រទេសចិនក៏អាចជាមូលដ្ឋានសម្រាប់កិច្ចការរបស់ទ្រង់ក្នុងចំណោមជាតិសាសន៍ដទៃដែរ។ ពេលនេះ តើទ្រង់មិនបានសម្រេចទំនាយថា៖ «ព្រះនាមរបស់ព្រះយេហូវ៉ានឹងត្រូវបានលើកតម្កើងក្នុងចំណោមជាតិសាសន៍ដទៃ» ទេ មែនទេ? ជំហានដំបូងនៃកិច្ចការរបស់ទ្រង់ក្នុងចំណោមជាតិសាសន៍ដទៃ គឺកិច្ចការនេះ ហើយជាកិច្ចការដែលទ្រង់បានធ្វើនៅក្នុងប្រទេសនៃនាគដ៏ធំមានសម្បុរក្រហម។ ព្រះជាម្ចាស់ដែលត្រលប់ជាសាច់ឈាមដែលគួរតែធ្វើការនៅក្នុងទឹកដីនេះ ខុសស្រឡះពីសញ្ញាណរបស់មនុស្ស ហើយទ្រង់ធ្វើការក្នុងចំណោមមនុស្សដែលត្រូវបណ្ដាសាទាំងនេះ ពួកគេជាមនុស្សតូចទាបបំផុតក្នុងចំណោមមនុស្សទាំងអស់ ពួកគេគ្មានតម្លៃទាល់តែសោះ ហើយពួកគេត្រូវបានព្រះយេហូវ៉ាបោះបង់ចោលតាំងពីដំបូង។ មនុស្សអាចត្រូវបានមនុស្សផងគ្នាបោះបង់ចោល ប៉ុន្ដែប្រសិនបើពួកគេត្រូវបានព្រះជាម្ចាស់បង់ចោល នោះពុំមាននរណាម្នាក់មានឋានៈទាបជាងគេទៀតឡើយ គ្មាននរណាម្នាក់មានតម្លៃទាបជាងពួកគេទៀតឡើយ។ សម្រាប់មនុស្សដែលព្រះជាម្ចាស់បង្កើត ការដែលត្រូវសាតាំងសណ្ឋិត ឬត្រូវមនុស្សផងគ្នាបោះបង់ចោល គឺជារឿងដែលធ្វើឱ្យគេមានអារម្មណ៍ឈឺចាប់ខ្លាំង ប៉ុន្ដែសម្រាប់មនុស្សដែលត្រូវព្រះជាម្ចាស់បោះបង់ចោល មានន័យថាពួកគេមិនអាចរកឋានៈណាដែលទាបជាងនេះបានទេ។ ពូជពង្សរបស់ម៉ូអាប់ត្រូវបណ្ដាសា ហើយពួកគេក៏បានទៅកើតក្នុងប្រទេសអន់ថយនេះ។ ក្នុងចំណោមមនុស្សទាំងអស់ដែលស្ថិតក្រោមឥទ្ធិពលនៃភាពងងឹត ប្រាកដណាស់ ពូជពង្សរបស់ម៉ូអាប់មានឋានៈទាបជាងគេបំផុត។ ដោយសារមនុស្សទាំងនេះមានឋានៈទាបជាងគេបំផុតតាំងតែពីមុន

មក នោះកិច្ចការដែលធ្វើទៅលើពួកគេអាចបំផ្លាញសញ្ញាណរបស់មនុស្សយ៉ាងប្រសើរបំផុត ហើយវាក៏ជាកិច្ចការដែលមានអត្ថប្រយោជន៍ច្រើនសម្រាប់ផែនការទាំងមូលនៃការគ្រប់គ្រង រយៈពេលប្រាំមួយពាន់ឆ្នាំរបស់ព្រះជាម្ចាស់ដែរ។ ការធ្វើកិច្ចការបែបនេះក្នុងចំណោមជនទាំងនេះ គឺជាវិធីដ៏ល្អបំផុតក្នុងការបំផ្លាញសញ្ញាណរបស់មនុស្ស ហើយព្រះជាម្ចាស់ក៏ចាប់ផ្ដើមសករាជមួយដោយប្រើវិធីនេះ។ ទ្រង់បំផ្លាញសញ្ញាណទាំងអស់របស់មនុស្ស ដោយប្រើសករាជនេះ។ ហើយទ្រង់ក៏បញ្ចប់កិច្ចការក្នុងយុគសម័យនៃព្រះគុណទាំងមូលដោយវិធីនេះដែរ។ កិច្ចការដំបូងរបស់ទ្រង់ ត្រូវបានអនុវត្តនៅស្រុកយូដាក្នុងដែនដីនៃប្រទេសអ៊ីស្រាអែល។ ទ្រង់មិនបានធ្វើកិច្ចការណាមួយ ដើម្បីចាប់ផ្ដើមសករាជថ្មីក្នុងចំណោមសាសន៍ដទៃឡើយ។ ដំណាក់កាលចុងក្រោយនៃកិច្ចការរបស់ព្រះជាម្ចាស់ មិនត្រឹមតែត្រូវបានអនុវត្តក្នុងចំណោមជាតិសាសន៍ដទៃប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវបានអនុវត្តកាន់តែច្រើន ក្នុងចំណោមមនុស្សដែលត្រូវបណ្ដាសាព្រះជាម្ចាស់ផងដែរ។ ចំណុចមួយនេះ គឺជាភស្ដុតាងដែលអាចបន្ទោកបន្ទាបសាតាំងបាន ហើយដូច្នេះព្រះជាម្ចាស់ក៏ «ក្លាយជា» ព្រះជាម្ចាស់នៃរបស់សព្វសារពើនៅក្នុងសកលលោក ជាម្ចាស់នៃអ្វីៗទាំងអស់ ជាកម្មវត្ថុនៃការថ្វាយបង្គំសម្រាប់អ្វីៗទាំងអស់ដែលមានជីវិត។

សព្វថ្ងៃនេះ នៅតែមានមនុស្សដែលនៅតែមិនយល់ពីកិច្ចការថ្មីដែលព្រះជាម្ចាស់បានចាប់ផ្ដើមនៅឡើយ។ ព្រះជាម្ចាស់បានបើកការចាប់ផ្ដើមថ្មីក្នុងចំណោមសាសន៍ដទៃ។ ទ្រង់បានចាប់ផ្ដើមសករាជថ្មី ហើយបានចាប់ផ្ដើមកិច្ចការថ្មី ហើយទ្រង់បំពេញកិច្ចការនេះលើកូនចៅរបស់ម៉ូអាប់។ តើនេះមិនមែនជាកិច្ចការថ្មីបំផុតរបស់ទ្រង់ទេឬអី? នៅក្នុងប្រវត្តិសាស្ត្រទាំងមូល គ្មាននរណាម្នាក់ធ្លាប់មានបទពិសោធអំពីកិច្ចការនេះពីមុនមកទេ។ គ្មានអ្នកណាម្នាក់ធ្លាប់បានឮអំពីរឿងនេះទេ គេឱ្យតម្លៃតិចបំផុតចំពោះកិច្ចការនេះ។ ប្រាជ្ញាញាណ ភាពអស្ចារ្យ ភាពមិនអាចយល់បាន ភាពអស្ចារ្យ និងភាពបរិសុទ្ធរបស់ព្រះជាម្ចាស់ សុទ្ធតែត្រូវបានបង្ហាញ តាមរយៈដំណាក់កាលនៃកិច្ចការនេះ គឺជាកិច្ចការនៃគ្រាចុងក្រោយ។ តើនេះមិនមែនជាកិច្ចការថ្មី កិច្ចការ

ដែលកម្ចាត់កម្ចាយសញ្ញាណរបស់មនុស្សទេឬអី? ក៏មានមនុស្ស ដែលគិតយ៉ាងដូច្នេះថា «ដោយសារព្រះជាម្ចាស់បានដាក់បណ្តាសាពួកម៉ូអាប់ និងបាននិយាយថាទ្រង់នឹងបោះបង់កូនចៅម៉ូអាប់ តើពេលនេះទ្រង់អាចសង្គ្រោះពួកគេដូចម្ដេចបាន?» មនុស្សទាំងអស់នេះ គឺជាសាសន៍ដទៃដែលត្រូវបណ្តាសាពីព្រះជាម្ចាស់ និងត្រូវបណ្តេញចេញពីអ៊ីស្រាអែល។ សាសន៍អ៊ីស្រាអែលហៅពួកគេថា «សុនខសាសន៍ដទៃ»។ នៅក្នុងទស្សនៈរបស់មនុស្សគ្រប់គ្នា ពួកគេមិនគ្រាន់តែជាសុនខសាសន៍ដទៃប៉ុណ្ណោះទេ តែគេអាក្រក់ជាងសុនខទៅទៀត គឺកូននៃសេចក្តីហិនវិនាស មានន័យថាពួកគេមិនមែនជារាស្ត្ររើសតាំងរបស់ព្រះជាម្ចាស់នោះឡើយ។ ពួកគេប្រហែលជាកើតនៅក្នុងទឹកដីអ៊ីស្រាអែល ក៏ប៉ុន្តែពួកគេមិនមែនជាសាសន៍អ៊ីស្រាអែលទេ ហើយត្រូវបណ្តេញឲ្យទៅក្នុងចំណោមសាសន៍ដទៃផង។ ពួកគេ គឺជាមនុស្សតូចទាបជាងគេក្នុងចំណោមមនុស្សទាំងអស់។ ប្រាកដណាស់ ដោយសារតែពួកគេជាមនុស្សតូចទាបជាងគេនៅក្នុងចំណោមមនុស្សដែលព្រះជាម្ចាស់អនុវត្តកិច្ចការរបស់ទ្រង់អំពីការចាប់ផ្តើមយុគសម័យថ្មីនៅក្នុងចំណោមពួកគេ ដ្បិតពួកគេជាតំណាងមនុស្សពុករលួយ។ កិច្ចការរបស់ព្រះជាម្ចាស់ សម្រិតសម្រាំង និងមានគោលដៅច្បាស់លាស់ណាស់ កិច្ចការដែលទ្រង់ធ្វើនៅក្នុងមនុស្សទាំងនេះនៅថ្ងៃនេះ ក៏ជាកិច្ចការដែលត្រូវបានធ្វើឡើងពេលបង្កើតពិភពលោកនេះដែរ។ ណូអេ គឺជាសត្តនិកររបស់ព្រះជាម្ចាស់ ចំណែកឯកូនចៅរបស់គាត់ក៏ដូច្នោះដែរ។ ក្នុងពិភពលោកនេះ នរណាក៏ដោយដែលមានសាច់មានឈាម គឺសុទ្ធតែជាមនុស្សដែលព្រះជាម្ចាស់បង្កើត។ កិច្ចការរបស់ព្រះជាម្ចាស់ គឺសម្រាប់មនុស្សគ្រប់គ្នា មិនមែនផ្អែកលើមនុស្សដែលត្រូវបណ្តាសា ឬក៏មិនត្រូវបណ្តាសា បន្ទាប់ពីពួកគេត្រូវបានបង្កើតមកនោះទេ។ កិច្ចការគ្រប់គ្រងរបស់ទ្រង់ គឺសម្រាប់មនុស្សទាំងអស់ មិនមែនតែមនុស្សជ្រើសរើសដែលមិនត្រូវបណ្តាសានោះដែរ។ ដោយសារព្រះជាម្ចាស់ចង់អនុវត្តកិច្ចការរបស់ទ្រង់នៅក្នុងចំណោមមនុស្សដែលទ្រង់បង្កើតនោះ ទ្រង់នឹងអនុវត្តកិច្ចការនេះឲ្យសម្រេចដោយជោគជ័យ ហើយទ្រង់នឹងធ្វើការក្នុងចំណោមមនុស្សដែលមានប្រយោជន៍ដល់កិច្ចការរបស់ទ្រង់។ ដូច្នេះ

ទ្រង់បំផ្លាញទម្លាប់ទាំងអស់ នៅពេលដែលកិច្ចការរបស់ទ្រង់ក្នុងចំណោមមនុស្ស។ ចំពោះព្រះអង្គ ពាក្យថា «ត្រូវបណ្ដាសា» «ត្រូវវាយផ្ចាល» និង «ត្រូវប្រទានពរ» មិនមានន័យចំពោះទ្រង់ទេ! ជនជាតិយូដា គឺជាមនុស្សល្អ ចំណែកឯជនជាតិអ៊ីស្រាអែលដែលជារាស្ត្ររើសតាំង ក៏ជាមនុស្សល្អដែរ។ ពួកគេគឺជាមនុស្សដែលមានគុណសម្បត្តិល្អ និងមានភាពមនុស្ស។ កាលពីដំបូង ព្រះយេហូវ៉ាបានចាប់ផ្ដើមកិច្ចការរបស់ទ្រង់ ហើយនិងបានបំពេញកិច្ចការដំបូងបំផុតរបស់ទ្រង់ក្នុងចំណោមពួកគេ ប៉ុន្តែការអនុវត្តកិច្ចការយកឈ្នះលើពួកគេនាបច្ចុប្បន្ននេះ គឺគ្មានន័យទេ។ ពួកគេក៏អាចជាផ្នែកមួយនៃការបង្កើតផែនដីនេះដែរ ហើយអាចមានរឿងរ៉ាវវិជ្ជមានអំពីពួកគេជាច្រើនទៀត ប៉ុន្តែការអនុវត្តដំណាក់កាលនៃកិច្ចការនេះក្នុងចំណោមពួកគេ គ្មានប្រយោជន៍ឡើយ។ ព្រះជាម្ចាស់នឹងមិនអាចបង្ក្រាបមនុស្សបានទេ ហើយព្រះអង្គក៏នឹងមិនអាចបញ្ចុះបញ្ចូលមនុស្សទាំងអស់ឱ្យជឿបានដែរ ដែលជាចំណុចជាក់លាក់នៃការបង្វែរកិច្ចការរបស់ទ្រង់ មករកប្រជាជននៃប្រទេសនាគដ៏ធំមានសម្បុរក្រហមនេះ។ កិច្ចការដ៏មានសារៈសំខាន់វិសេសវិសាលបំផុតនៅទីនេះ គឺការចាប់ផ្ដើមសករាជមួយរបស់ទ្រង់ នោះគឺការដែលទ្រង់បំផ្លាញច្បាប់វិន័យ និងសញ្ញាណទាំងអស់របស់មនុស្ស ហើយជាការបញ្ចប់កិច្ចការយុគសម័យនៃព្រះគុណទាំងមូលរបស់ទ្រង់។ ប្រសិនបើកិច្ចការបច្ចុប្បន្នរបស់ទ្រង់ ត្រូវបានអនុវត្តក្នុងចំណោមប្រជាជនអ៊ីស្រាអែលនោះ លុះដល់ពេលដែលផែនការគ្រប់គ្រងរយៈពេលប្រាំមួយពាន់ឆ្នាំរបស់ទ្រង់ដល់ទីបញ្ចប់ មនុស្សគ្រប់គ្នានឹងជឿថាព្រះជាម្ចាស់ គឺជាព្រះជាម្ចាស់ របស់ជនជាតិអ៊ីស្រាអែលតែមួយប៉ុណ្ណោះ មានតែប្រជាជនអ៊ីស្រាអែលមួយប៉ុណ្ណោះ គឺជាមនុស្សដែលព្រះជាម្ចាស់បានជ្រើសរើស មានតែជនជាតិអ៊ីស្រាអែលមួយប៉ុណ្ណោះ ដែលសមនឹងទទួលព្រះពរ និងការសន្យារបស់ព្រះជាម្ចាស់ជាមរតក។ ការយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់ក្នុងអំឡុងពេលនៃគ្រាចុងក្រោយ នៅក្នុងសាសន៍ដទៃ នៃប្រទេសរបស់នាគដ៏ធំមានសម្បុរក្រហម សម្រេចបាននូវកិច្ចការរបស់ព្រះជាម្ចាស់ដែលព្រះជាម្ចាស់នៃសព្វសារពើ។ ទ្រង់បញ្ចប់កិច្ចការគ្រប់គ្រងរបស់ទ្រង់ទាំងមូល និងបញ្ចប់កិច្ចការស្នូល

របស់ព្រះអង្គនៅក្នុងសាសន៍នៃនាគដ៏ធំមានសម្បុរក្រហម។ ចំណុចស្នូលដ៏សំខាន់នៃកិច្ចការទាំងបីដំណាក់កាលនេះ គឺការសង្គ្រោះមនុស្សលោក ពោលគឺការធ្វើឱ្យសព្វសារពើក្នុងសាកលលោក ថ្វាយបង្គំព្រះអាទិករ។ ដូច្នេះ មានអត្ថន័យដ៏ជ្រាលជ្រៅណាស់សម្រាប់ដំណាក់កាលនៃកិច្ចការនីមួយៗ។ ព្រះជាម្ចាស់មិនធ្វើអ្វីដែលគ្មានន័យ ឬគ្មានតម្លៃទេ។ ម្យ៉ាងទៀត ដំណាក់កាលនៃកិច្ចការនេះ គឺជាការចាប់ផ្ដើមសករាជថ្មី និងបញ្ចប់សករាជមុនចំនួនពីរ។ ម្យ៉ាងវិញទៀត កិច្ចការនេះបំផ្លាញចោលនូវសញ្ញាណរបស់មនុស្ស និងរបៀបរបបនៃជំនឿ និងចំណេះដឹងចាស់គំរឹលទាំងអស់របស់មនុស្ស។ កិច្ចការនៃយុគសម័យមុនចំនួនពីរ ត្រូវបានអនុវត្តស្របទៅតាមសញ្ញាណខុសៗគ្នារបស់មនុស្ស។ ប៉ុន្តែដំណាក់កាលនេះ ផាត់ចោលទាំងស្រុងនូវសញ្ញាណរបស់មនុស្ស ដោយយកឈ្នះមនុស្សលោកទាំងស្រុង។ ព្រះជាម្ចាស់នឹងបង្ក្រាបមនុស្សទាំងអស់លើសាកលលោកទាំងមូល តាមរយៈការយកឈ្នះពូជពង្សរបស់ម៉ូអាប់ និងតាមរយៈកិច្ចការ ដែលព្រះជាម្ចាស់បានអនុវត្តក្នុងចំណោមពូជពង្សម៉ូអាប់។ នេះគឺជាសារៈសំខាន់ដ៏ជ្រាលជ្រៅបំផុត នៃកិច្ចការរបស់ព្រះជាម្ចាស់នៅដំណាក់កាលនេះ ហើយវាគឺជាចំណែកដ៏មានតម្លៃបំផុតនៃកិច្ចការរបស់ទ្រង់ ក្នុងដំណាក់កាលនេះ ទោះបីជានៅពេលនេះអ្នកដឹងថា ឋានៈរបស់អ្នកតូចទាប ហើយអ្នកមានតម្លៃតិចតួចក៏ដោយ ក៏អ្នកនៅតែមានអារម្មណ៍ថា អ្នកបានជួបរឿងរីករាយបំផុត៖ អ្នកបានទទួលព្រះពរដ៏ប្រសើរទុកជាមរតក ទទួលបានការសន្យាដ៏ប្រសើរ ហើយអ្នកអាចជួយសម្រេចនូវកិច្ចការដ៏វិសេសវិសាលមួយនេះរបស់ព្រះជាម្ចាស់បាន។ អ្នកបានឃើញនូវព្រះភក្ត្រពិតរបស់ព្រះជាម្ចាស់ អ្នកស្គាល់និស្ស័យពិតរបស់ព្រះជាម្ចាស់ ហើយអ្នកធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ពីរដំណាក់កាលមុន នៃកិច្ចការរបស់ព្រះជាម្ចាស់ ត្រូវបានអនុវត្តនៅអ៊ីស្រាអែល។ ប្រសិនបើដំណាក់កាលនៃកិច្ចការរបស់ទ្រង់នៅគ្រាចុងក្រោយនេះ ក៏ត្រូវបានអនុវត្តនៅក្នុងចំណោមជនជាតិអ៊ីស្រាអែលទៀត នោះសព្វសារពើទាំងអស់ មិនត្រឹមតែជឿថាមានតែជនជាតិអ៊ីស្រាអែលមួយប៉ុណ្ណោះទើបជារាស្ត្ររើសតាំងរបស់ព្រះជាម្ចាស់នោះទេ ប៉ុន្តែគេជឿទៀតថា ផែនការគ្រប់គ្រង

ទាំងមូលរបស់ព្រះជាម្ចាស់ នឹងមិនសម្រេចនូវលទ្ធផល ដូចដែលគេចង់បាននោះឡើយ។ ក្នុងអំឡុងពេលដែលដំណាក់កាលពីរនៃកិច្ចការរបស់ទ្រង់ ត្រូវបានអនុវត្តនៅក្នុងប្រទេសអ៊ីស្រាអែល គ្មានកិច្ចការថ្មី ឬកិច្ចការនៃការបើកសករាជថ្មី ត្រូវបានអនុវត្តក្នុងចំណោមជាតិសាសន៍ដទៃឡើយ។ ដំណាក់កាលនៃកិច្ចការបច្ចុប្បន្ន ពោលគឺកិច្ចការនៃការចាប់ផ្ដើមសករាជថ្មី ត្រូវបានអនុវត្តដំបូងក្នុងចំណោមជាតិសាសន៍ដទៃ ហើយលើសពីនេះទៀត ត្រូវបានអនុវត្តក្នុងចំណោមពូជពង្សរបស់ម៉ូអាប់ពីដំបូងនេះ ហើយជាការចាប់ផ្ដើមនៃសករាជនេះទាំងមូល។ ព្រះជាម្ចាស់បានបំផ្លាញចំណេះដឹងដែលមាននៅក្នុងសញ្ញាណរបស់មនុស្ស មិនឱ្យនៅសេសសល់ឡើយ។ នៅក្នុងកិច្ចការនៃការយកឈ្នះរបស់ទ្រង់ ព្រះជាម្ចាស់បានបំផ្លាញសញ្ញាណរបស់មនុស្ស ដែលជារបៀបរបបចាស់បុរាណនៃចំណេះដឹងរបស់មនុស្សពីដើម។ ទ្រង់អនុញ្ញាតឱ្យមនុស្សឃើញថា ពុំមានច្បាប់ណាអាចយកមកប្រើជាមួយព្រះជាម្ចាស់ គឺថាគ្មានអ្វីចាស់គំរឹលអំពីព្រះជាម្ចាស់ ដោយកិច្ចការដែលទ្រង់ធ្វើ ត្រូវបានបញ្ចេញមកឥតគិតថ្លៃទាំងស្រុង និងឱ្យមនុស្សឃើញថា ទ្រង់ត្រឹមត្រូវក្នុងគ្រប់សព្វសារពើដែលទ្រង់ធ្វើ។ អ្នកត្រូវតែចុះចូលចំពោះកិច្ចការដែលទ្រង់ធ្វើ នៅក្នុងចំណោមសព្វសារពើទាំងអស់ ឱ្យបានពេញលេញ។ កិច្ចការគ្រប់យ៉ាងដែលទ្រង់ធ្វើ មានអត្ថន័យ ហើយត្រូវបានអនុវត្តស្របតាមបំណងព្រះហឫទ័យ និងប្រាជ្ញាញាណរបស់ទ្រង់ផ្ទាល់ ហើយមិនអនុលោមតាមការសម្រេចចិត្ត និងសញ្ញាណរបស់មនុស្សឡើយ។ ប្រសិនបើមានអ្វីមួយដែលមានប្រយោជន៍ដល់កិច្ចការរបស់ទ្រង់ ទ្រង់នឹងធ្វើកិច្ចការនោះ ហើយប្រសិនបើមានអ្វីមួយមិនមានប្រយោជន៍ដល់កិច្ចការរបស់ទ្រង់ នោះទ្រង់មិនធ្វើទេ មិនថាកិច្ចការល្អយ៉ាងណាទេ! ទ្រង់ធ្វើការ និងជ្រើសរើសអ្នកទទួល និងជ្រើសរើសទីតាំងនៃកិច្ចការរបស់ទ្រង់ ស្របតាមអត្ថន័យ និងគោលបំណងនៃកិច្ចការរបស់ទ្រង់។ ទ្រង់មិនប្រកាន់តាមច្បាប់បុរាណឡើយ នៅពេលដែលទ្រង់ធ្វើការ ហើយទ្រង់ក៏មិនធ្វើតាមរូបមន្តចាស់ដែរ។ ផ្ទុយទៅវិញ ទ្រង់អនុវត្តផែនការកិច្ចការរបស់ទ្រង់យោងទៅតាមសារៈសំខាន់នៃកិច្ចការនោះ។ នៅទីបំផុត ទ្រង់នឹងទទួលបានប្រសិទ្ធភាពពិតប្រាកដ និងសម្រេច

គោលដៅដែលបានរំពឹងទុក។ ប្រសិនបើអ្នកមិនយល់ពីកិច្ចការទាំងនេះនៅថ្ងៃនេះទេ កិច្ចការនេះនឹងមិនមានឥទ្ធិពលលើអ្នកឡើយ។

## ជោគជ័យ ឬបរាជ័យ អាស្រ័យលើផ្លូវដែលមនុស្សដើរ

មនុស្សភាគច្រើនជឿលើព្រះជាម្ចាស់ ដើម្បីតែទិសដៅទៅអនាគតរបស់ពួកគេ ឬដើម្បីតែសេចក្ដីអំណរមួយពេលខ្លីប៉ុណ្ណោះ។ សម្រាប់អ្នកដែលមិនបានឆ្លងកាត់ការដោះស្រាយណាមួយ នោះពួកគេជឿលើព្រះជាម្ចាស់ ដើម្បីចូលទៅក្នុងស្ថានសួគ៌ ដើម្បីទទួលបានរង្វាន់។ ពួកគេមិនជឿលើព្រះជាម្ចាស់ដើម្បីឲ្យបានគ្រប់លក្ខណ៍ ឬដើម្បីបំពេញភារកិច្ចក្នុងនាមជាសត្តនិកររបស់ព្រះជាម្ចាស់ឡើយ។ គឺមានន័យថា មនុស្សភាគច្រើនមិនជឿលើព្រះជាម្ចាស់ដើម្បីអនុវត្តការទទួលខុសត្រូវរបស់ពួកគេ ឬដើម្បីបំពេញភារកិច្ចរបស់ពួកគេឡើយ។ មនុស្សកម្រនឹងជឿលើព្រះជាម្ចាស់ដើម្បីដឹកនាំជីវិតដែលមានអត្ថន័យសារជាតិណាស់ ហើយដោយសារមនុស្សនៅមានជីវិត ក៏គ្មានអ្នកដែលជឿថា គេគួរតែស្រឡាញ់ព្រះជាម្ចាស់ ដោយសារនេះជាច្បាប់របស់ស្ថានសួគ៌ និងជាគោលការណ៍របស់ផែនដី និងជារបរចិញ្ចឹមជីវិតរបស់មនុស្សពីកំណើតមកនោះដែរ។ ក្នុងលក្ខណៈនេះ បើទោះបីជាមនុស្សម្នាក់ៗស្វះស្វែងរកគោលដៅរបស់ពួកគេរៀងៗខ្លួនក្ដី ក៏គោលបំណងនៃការស្វះស្វែងរក និងការជំរុញចិត្តពួកគេនៅពីក្រោយការស្វែងរកនេះ គឺសុទ្ធតែដូចគ្នាទាំងអស់ដែរ ហើយបន្ថែមលើនេះរូបចម្លាក់ដែលពួកគេភាគច្រើនថ្វាយបង្គំ គឺកាន់តែដូចគ្នាថែមទៀត។ ក្នុងរយៈពេលប៉ុន្មានពាន់ឆ្នាំមកនេះ អ្នកជឿជាច្រើនបានស្លាប់ ហើយមនុស្សជាច្រើនក៏បានស្លាប់ និងកើតជាថ្មីដែរ។ មិនមែនមានតែមនុស្សម្នាក់ ឬពីរនាក់ដែលស្វែងរកព្រះជាម្ចាស់នោះទេ ហើយក៏មិនមែនមានតែមួយពាន់ ឬពីរពាន់នាក់ដែរ ប៉ុន្តែភាគច្រើននៃមនុស្សទាំងនោះ ស្វែងរកដើម្បីតែក្ដីសង្ឃឹមទៅអនាគតរបស់ពួកគេ ឬដើម្បីតែក្ដីសង្ឃឹមដ៏រុងរឿងរបស់ពួកនាពេលអនាគតតែប៉ុណ្ណោះ។ អ្នកដែលមានភក្ដីភាពចំពោះព្រះគ្រីស្ទ

មិនសូវមានច្រើនប៉ុន្មានទេ។ អ្នកជឿដែលគោរពកោតខ្លាចព្រះយ៉ាងច្រើននៅតែបន្តស្លាប់ ដោយទាក់ជាប់នៅក្នុងសំណាញ់របស់ខ្លួនឯង ហើយបន្ថែមលើនេះ ចំនួនមនុស្សដែលមានជ័យជម្នះ ក៏មានចំនួនតិចតួចណាស់ដែរ។ មកទល់នឹងសព្វថ្ងៃនេះ មនុស្សនៅតែមិនទាន់ដឹងពីមូលហេតុដែលពួកគេបរាជ័យ ឬអាថ៌កំបាំងដែលពួកគេមានជ័យជម្នះនៅឡើយទេ។ អស់អ្នកដែលមានការជាប់រវល់ខ្លាំងក្នុងការស្វែងរកព្រះគ្រីស្ទ នៅតែមិនទាន់មានពេលណាមួយដែលអាចយល់ដឹងជ្រៅជ្រះបានភ្លាមៗនៅឡើយទេ ពួកគេមិនទាន់បានចូលជ្រៅក្នុងក្នុងអាថ៌កំបាំងនេះឡើយ ដោយសារតែពួកគេមិនទាន់បានដឹងអ្វីសោះ។ បើទោះបីជាពួកគេបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងនៅក្នុងការស្វែងរករបស់ពួកគេក្ដី ក៏ផ្លូវដែលពួកគេដើរ គឺជាផ្លូវបរាជ័យ ដែលដូនតារបស់ពួកគេធ្លាប់បានដើររួចម្ដងមកហើយ និងមិនមែនជាផ្លូវជោគជ័យឡើយ។ តាមរបៀបនេះ មិនថាពួកគេស្វែងរកដោយបែបណាឡើយ តើពួកគេមិនមែនដើរនៅលើផ្លូវដែលនាំទៅរកសេចក្ដីងងឹតទេឬអី? តើអ្វីដែលពួកគេទទួលបានមិនមែនជាផ្លែស្លែងទេឬអី? វាពិបាកនឹងទស្សន៍ទាយថាតើមនុស្សដែលដើរតាមអ្នកដែលជោគជ័យកាលពីពេលមុន ចុងក្រោយនឹងទទួលបានសំណាង ឬគ្រោះកាចណាស់។ ចុះចំណែកអ្នកដែលស្វែងរកដោយដើរតាមលំអានរបស់អ្នកដែលបានបរាជ័យវិញ តើឱកាសជួបសំណាងអាក្រក់នោះច្រើនប៉ុនណាទៅ? តើពួកគេមិនកាន់តែងាយនឹងទទួលបរាជ័យទេឬអី? តើផ្លូវដែលពួកគេដើរ មានតម្លៃអ្វីទៅ? តើពួកគេមិនមែនកំពុងចំណាយពេលអសារឥតការទេឬអី? មិនថាមនុស្សជោគជ័យ ឬបរាជ័យនៅក្នុងការស្វែងរករបស់ពួកគេ ឬអត់នោះទេ និយាយរួមពួកគេមានមូលហេតុមួយដែលត្រូវធ្វើបែបនេះ ហើយភាពជោគជ័យ ឬការបរាជ័យរបស់ពួកគេ គឺមិនត្រូវបានកំណត់ដោយដោយការស្វែងរកនូវអ្វីដែលពួកគេស្រឡាញ់ពេញចិត្តនោះទេ។

សេចក្ដីតម្រូវសំខាន់ជាងគេបំផុត នៅក្នុងជំនឿរបស់មនុស្សលើព្រះជាម្ចាស់ គឺឲ្យគេមានដួងចិត្តស្មោះសរ និងឲ្យគេលះបង់ខ្លួនគេទាំងស្រុង និងស្ដាប់បង្គាប់យ៉ាងពិតប្រាកដ។ អ្វីដែលពិបាកខ្លាំងបំផុតសម្រាប់មនុស្ស គឺត្រូវលះបង់ជីវិតរបស់គេ

ទាំងមូលដើម្បីដូរនឹងជំនឿដ៏ពិតប្រាកដ ដែលតាមរយៈជំនឿនេះ គេអាចទទួលបាននូវសេចក្ដីពិតទាំងស្រុង និងអាចបំពេញភារកិច្ចរបស់ខ្លួនក្នុងនាមជាសត្តនិកររបស់ព្រះជាម្ចាស់។ ចំណុចនេះ អ្នកដែលបរាជ័យមិនអាចធ្វើឲ្យសម្រេចបានឡើយ ហើយអ្នកដែលមិនអាចស្វែងរកព្រះគ្រីស្ទបាន គឺកាន់តែមិនអាចសម្រេចបានទៅទៀត។ ដោយសារមនុស្សមិនពូកែក្នុងការលះបង់ខ្លួនគេទាំងស្រុង ថ្វាយដល់ព្រះជាម្ចាស់ ដោយសារមនុស្សមិនសុខចិត្តបំពេញភារកិច្ចរបស់ខ្លួនថ្វាយព្រះអាទិករ ដោយសារមនុស្សបានឃើញសេចក្ដីពិត តែគេចចេញពីសេចក្ដីពិត និងដើរតាមផ្លូវរបស់គេផ្ទាល់ ដោយសារមនុស្សតែងស្វែងរកដោយដើរតាមផ្លូវរបស់អ្នកដែលបានបរាជ័យ ដោយសារមនុស្សតែងតតាំងនឹងស្ថានសួគ៌ ហេតុនេះ មនុស្សតែងតែបរាជ័យ តែងតែជាប់នៅក្នុងឧបាយកលរបស់សាតាំង និងទាក់ជាប់ក្នុងមងរបស់ខ្លួនឯង។ ដោយសារមនុស្សមិនស្គាល់ព្រះគ្រីស្ទ ដោយសារមនុស្សមិនបានសម្របខ្លួនដើម្បីស្គាល់ និងដកពិសោធន៍ពីសេចក្ដីពិត ដោយសារមនុស្សថ្វាយបង្គំប៉ុលខ្លាំងពេក និងលោភលន់ចង់ឡើងស្ថានសួគ៌ខ្លាំងពេក ដោយសារមនុស្សតែងទាមទារឲ្យព្រះគ្រីស្ទស្ដាប់បង្គាប់គេ និងធ្វើការបង្គាប់បញ្ជាព្រះជាម្ចាស់ ហេតុនេះ បុគ្គលអស្ចារ្យទាំងនោះ និងអស់អ្នកដែលធ្លាប់មានបទពិសោធពីដំណើរប្រែប្រួលនៃពិភពលោកនេះ គឺនៅតែជាមនុស្សធម្មតាដដែល និងនៅតែត្រូវស្លាប់នៅក្នុងការវាយផ្ចាលរបស់ព្រះជាម្ចាស់ដដែល។ អ្វីគ្រប់យ៉ាងដែលខ្ញុំអាចមានបន្ទូលបានអំពីមនុស្សបែបនេះ គឺថាពួកគេត្រូវស្លាប់ក្នុងសេចក្ដីស្លាប់ដ៏គួរឲ្យសោកសង្រេង ហើយគ្រោះអាក្រក់ដែលកើតមាន ចំពោះពួកគេដែលជាសេចក្ដីស្លាប់នោះ គឺមិនមែនកើតឡើង ដោយគ្មានហេតុផលនោះឡើយ។ តើបរាជ័យរបស់ពួកគេ មិនកាន់តែមិនអាចអត់ទ្រាំបានចំពោះច្បាប់ស្ថានសួគ៌ទេឬអី? សេចក្ដីពិតចេញមកពីពិភពរបស់មនុស្ស ប៉ុន្តែសេចក្ដីពិតក្នុងចំណោមមនុស្សគឺត្រូវផ្ទេរបន្តដោយព្រះគ្រីស្ទ។ សេចក្ដីពិតចេញមកពីព្រះគ្រីស្ទ ពោលគឺមកអំពី ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ ហើយមនុស្សមិនអាចធ្វើកិច្ចការនេះបាននោះឡើយ។ ក៏ប៉ុន្តែ ព្រះគ្រីស្ទប្រទានត្រឹមតែសេចក្ដីពិតប៉ុណ្ណោះ។ ទ្រង់មិនយាងមកដើម្បីសម្រេចថាតើមនុស្សនឹង

ត្រូវជោគជ័យនៅក្នុងការស្វែងរកសេចក្ដីពិតរបស់គេឡើយ។ ហេតុនេះ ជោគជ័យ ឬបរាជ័យ នៅក្នុងសេចក្ដីពិត គឺសុទ្ធតែស្ថិតនៅលើការស្វែងរក មនុស្សទាំងអស់។ ជោគជ័យ ឬបរាជ័យរបស់មនុស្សនៅក្នុងសេចក្ដីពិត ក៏មិនមានអ្វីពាក់ព័ន្ធនឹងព្រះគ្រីស្ទដែរ តែផ្ទុយទៅវិញ ត្រូវកំណត់ដោយការស្វែងរករបស់គេ។ ទិសដៅរបស់មនុស្ស និង ជោគជ័យ ឬបរាជ័យរបស់គេ មិនអាចប្រមូលដាក់លើព្រះសិរសារបស់ព្រះជាម្ចាស់ ដើម្បីធ្វើឲ្យព្រះជាម្ចាស់ផ្ទាល់ព្រះអង្គទទួលបន្ទុក លើបញ្ហានេះឡើយ ពីព្រោះនេះ មិនមែនជាបញ្ហាមួយសម្រាប់ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គឡើយ ប៉ុន្តែគឺជាប់ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងភារកិច្ចដែលសត្តនិកររបស់ព្រះជាម្ចាស់គប្បីត្រូវបំពេញ។ មនុស្សភាគច្រើនមានចំណេះដឹងបន្តិចបន្តួចអំពីការស្វែងរក និងទិសដៅរបស់ប៉ុល និង ពេត្រុស តែមនុស្សគ្មានដឹងអ្វីផ្សេងក្រៅពីលទ្ធផលរបស់ពេត្រុសនិងប៉ុលឡើយ ហើយពួកគេមិនដឹងពីអាថ៌កំបាំងនៃជោគជ័យរបស់ពេត្រុស ឬភាពខ្វះចន្លោះដែលនាំប៉ុលឲ្យបរាជ័យឡើយ។ ហេតុដូច្នេះ ប្រសិនបើអ្នករាល់គ្នា គ្មានសមត្ថភាពអ្វីសោះក្នុងការមើលឃើញជ្រៅជ្រះនូវសារជាតិនៃការស្វែងរករបស់ពួកគេទេ នោះការស្វែងរករបស់អ្នករាល់គ្នាភាគច្រើន នឹងនៅតែបរាជ័យដដែល ហើយបើទោះបីជាមនុស្សតិចតួចក្នុងចំណោមអ្នករាល់គ្នានឹងទទួលបានជោគជ័យក្ដី ក៏ពួកគេមិនអាចស្មើនឹងពេត្រុសបានដែរ។ ប្រសិនបើផ្លូវនៃការស្វែងរករបស់អ្នក គឺជាផ្លូវត្រូវ នោះអ្នកមានក្ដីសង្ឃឹមនឹងទទួលបាននូវជោគជ័យ។ ប្រសិនបើផ្លូវដែលអ្នកដើរនៅក្នុងការស្វែងរកសេចក្ដីពិត គឺជាផ្លូវខុស នោះអ្នកនឹងមិនទទួលបានជោគជ័យជារៀងរហូត ហើយនឹងជួបប្រទះនូវចុងបញ្ចប់ដូចជារូបប៉ុលដែរ។

ពេត្រុស គឺជាមនុស្សម្នាក់ ដែលត្រូវបានធ្វើឲ្យគ្រប់លក្ខណ៍។ ក្រោយពីបានឆ្លងកាត់ការវាយផ្ចាល និងការជំនុំជម្រះ និងទទួលបានសេចក្ដីស្រឡាញ់ដ៏បរិសុទ្ធចំពោះព្រះជាម្ចាស់ហើយ គាត់ត្រូវបានធ្វើឲ្យគ្រប់លក្ខណ៍ទាំងស្រុង។ ផ្លូវដែលគាត់បានដើរគឺជាផ្លូវដែលត្រូវប្រោសឲ្យគ្រប់លក្ខណ៍។ ដែលនេះមានន័យថា ចាប់តាំងពីដើមដំបូងមក ផ្លូវដែលពេត្រុសបានដើរគឺជាផ្លូវដែលត្រូវ ហើយការជំរុញចិត្តឲ្យគាត់

ជឿលើព្រះជាម្ចាស់ គឺជាការជំរុញចិត្តដែលត្រឹមត្រូវ ហេតុដូច្នេះ គាត់បានក្លាយជាមនុស្សម្នាក់ ដែលត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍ ហើយគាត់បានដើរនៅលើផ្លូវថ្មីមួយដែលមនុស្សមិនធ្លាប់បានដើរពីមុនមកសោះ។ ផ្ទុយទៅវិញ ផ្លូវដែលប៉ុលបានដើរតាំងពីដើមដំបូងមក គឺជាផ្លូវដែលប្រឆាំងទាស់នឹងព្រះគ្រីស្ទ ហើយដោយសារតែព្រះវិញ្ញាណបរិសុទ្ធចង់ប្រើប្រាស់គាត់ និងទាញយកផលពីអំណោយទានរបស់គាត់ និងគុណូបការៈទាំងអស់របស់គាត់សម្រាប់កិច្ចការរបស់ទ្រង់ប៉ុណ្ណោះ ទើបគាត់ធ្វើការសម្រាប់ព្រះគ្រីស្ទ អស់ពេលប៉ុន្មានទសវត្សរ៍បាន។ គាត់គ្រាន់តែជាមនុស្សម្នាក់ដែលត្រូវព្រះវិញ្ញាណបរិសុទ្ធប្រើប៉ុណ្ណោះ ហើយគាត់មិនមែនត្រូវបានប្រើដោយសារតែព្រះយេស៊ូវបានទតមើលដោយពេញព្រះទ័យ ចំពោះភាពជាមនុស្សរបស់គាត់នោះទេ ប៉ុន្តែដោយសារអំណោយទានរបស់គាត់វិញ។ គាត់អាចបំពេញកិច្ចការថ្វាយព្រះយេស៊ូវគ្រីស្ទបាន ដោយសារគាត់ត្រូវវាយផ្ដួល មិនមែនដោយសារគាត់ត្រេកអរនឹងធ្វើបែបនេះឡើយ។ គាត់អាចធ្វើកិច្ចការបែបនេះបានដោយសារការបំភ្លឺ និងការណែនាំពីព្រះវិញ្ញាណបរិសុទ្ធ ហើយកិច្ចការដែលគាត់បានធ្វើ គ្មានអ្វីជាតំណាងដល់ការស្វែងរករបស់គាត់ ឬភាពជាមនុស្សរបស់គាត់ឡើយ។ កិច្ចការរបស់ប៉ុលតំណាងឲ្យកិច្ចការនៃបាវបម្រើ ដែលមានន័យថា គាត់បានបំពេញកិច្ចការក្នុងនាមជាសាវ័កម្នាក់។ ចំណែកពេត្រុសវិញ គឺខុសគ្នាពីគាត់៖ គាត់ក៏បានបំពេញកិច្ចការមួយចំនួនដែរ តែកិច្ចការនោះមិនមែនអស្ចារ្យដូចជាកិច្ចការរបស់ប៉ុលឡើយ ប៉ុន្តែគាត់បានបំពេញកិច្ចការផង និងស្វែងរកច្រកចូលផ្ទាល់ខ្លួនផង ហើយកិច្ចការរបស់គាត់ខុសគ្នា ពីកិច្ចការរបស់ប៉ុល។ កិច្ចការរបស់ពេត្រុស គឺជាការអនុវត្តភារកិច្ច ជាសត្តនិកររបស់ព្រះជាម្ចាស់។ គាត់មិនបានបំពេញកិច្ចការក្នុងនាមជាសាវ័កម្នាក់ឡើយ ប៉ុន្តែគាត់បានបំពេញក្កិការផង និងស្វែងរកសេចក្ដីស្រឡាញ់ចំពោះព្រះជាម្ចាស់ផង។ ដំណើរនៃកិច្ចការរបស់ប៉ុល ក៏មាននូវការស្វែងរកផ្ទាល់ខ្លួនគាត់ដែរ៖ ការស្វះស្វែងរបស់គាត់ គឺគ្មានអ្វីផ្សេងក្រៅពីក្ដីសង្ឃឹមរបស់គាត់ទៅអនាគត និងបំណងប្រាថ្នារបស់គាត់ ដើម្បីទទួលបានទិសដៅល្អមួយឡើយ។ គាត់ពុំបានទទួលយកនូវការ

បន្សុទ្ធក្នុងអំឡុងកិច្ចការរបស់គាត់ឡើយ ហើយគាត់ក៏ពុំបានទទួលយកការលួសកាត់ និងការដោះស្រាយដែរ។ គាត់ជឿថា ឲ្យតែកិច្ចការដែលគាត់បានធ្វើ គាប់តាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ នោះគ្រប់ការទាំងអស់ដែលគាត់បានធ្វើ គឺផ្គាប់ព្រះទ័យព្រះជាម្ចាស់ហើយ ដូច្នេះ នៅទីបំផុតនឹងមានរង្វាន់សម្រាប់ប្រគល់ជូនគាត់។ នៅក្នុងកិច្ចការរបស់គាត់ ពុំមានបទពិសោធផ្ទាល់ខ្លួនឡើយ។ កិច្ចការរបស់គាត់ គឺដើម្បីតែកិច្ចការមិនបានធ្វើឡើងដើម្បីស្វែងរកនូវការផ្លាស់ប្ដូរឡើយ។ អ្វីសព្វគ្រប់បែបយ៉ាងនៅក្នុងកិច្ចការរបស់គាត់ គឺជាការដោះដូរ គ្មានភារកិច្ច ឬការចុះចូលនៃសត្តនិករបស់ព្រះជាម្ចាស់ឡើយ។ ក្នុងអំឡុងពេលនៃកិច្ចការរបស់គាត់ និស្ស័យចាស់របស់ប៉ុលពុំបានផ្លាស់ប្រែឡើយ។ កិច្ចការរបស់គាត់ គឺគ្រាន់តែជាការបម្រើដល់អ្នកដទៃតែប៉ុណ្ណោះ និងមិនអាចនាំមកនូវការបំផ្លាស់បំប្រែនិស្ស័យរបស់គាត់ឡើយ។ ប៉ុលបានបំពេញកិច្ចការរបស់គាត់ដោយផ្ទាល់ ដោយមិនបានធ្វើឲ្យគ្រប់លក្ខណ៍ ឬបានដោះស្រាយជាមួយឡើយ ហើយគាត់ត្រូវបានជំរុញចិត្តដោយរង្វាន់។ ពេត្រុសខុសគ្នាពីគាត់៖ គាត់គឺជាមនុស្សម្នាក់ដែលបានឆ្លងកាត់ការលួសកាត់ និងការដោះស្រាយ និងបានឆ្លងកាត់នូវការបន្សុទ្ធ។ គោលបំណង និងការជំរុញចិត្តនៃកិច្ចការរបស់ពេត្រុស គឺមានភាពខុសគ្នាយ៉ាងខ្លាំងជាមួយនឹងគោលបំណង និងការជំរុញចិត្តរបស់ប៉ុល។ បើទោះបីជាពេត្រុស មិនបានធ្វើកិច្ចការឲ្យបានច្រើនក្ដី ក៏និស្ស័យរបស់គាត់បានឆ្លងកាត់ការបំផ្លាស់បំប្រែជាច្រើនដែរ ហើយអ្វីដែលគាត់បានស្វែងរកនោះ គឺជាសេចក្ដីពិត និងជាការបំផ្លាស់បំប្រែជាក់ស្ដែង។ កិច្ចការរបស់គាត់ មិនមែនគ្រាន់តែធ្វើដើម្បីតែធ្វើកិច្ចការនោះទេ។ បើទោះបីជាប៉ុលបានធ្វើកិច្ចការច្រើនក្ដី ក៏កិច្ចការទាំងនោះសុទ្ធតែជាកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធដែរ ហើយបើទោះបីជាប៉ុលបានពួតដៃគ្នានៅក្នុងកិច្ចការនេះក្ដី ក៏គាត់មិនមានបទពិសោធនៅក្នុងកិច្ចការនេះដែរ។ ការដែលពេត្រុសបានធ្វើកិច្ចការតិចជាង គឺដោយសារតែព្រះវិញ្ញាណបរិសុទ្ធមិនបានបំពេញកិច្ចការច្រើនតាមរយៈគាត់តែប៉ុណ្ណោះ។ បរិមាណនៃកិច្ចការរបស់ពួកគេ ពុំបានកំណត់ថាតើពួកគេត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍ឬអត់នោះទេ ព្រោះការស្វែងរករបស់គេ

ម្នាក់គឺដើម្បីទទួលបានរង្វាន់ ហើយការស្វែងរករបស់គេម្នាក់ទៀត គឺដើម្បីសម្រេចនូវសេចក្តីស្រឡាញ់ដ៏ជ្រាលជ្រៅបំផុតចំពោះព្រះជាម្ចាស់ និងដើម្បីបំពេញភារកិច្ចរបស់គេក្នុងនាមជាសត្តនិកររបស់ព្រះជាម្ចាស់ រហូតដល់កម្រិតមួយដែលគេអាចស្តែងចេញនូវរូបភាពដ៏គួរឲ្យស្រឡាញ់តាមរយៈការរស់នៅ ដើម្បីផ្គាប់តាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ សម្បកក្រៅ ពួកគេខុសគ្នា ហើយសារជាតិរបស់ពួកគេក៏ខុសគ្នាដែរ។ អ្នកមិនអាចកំណត់ថាតើក្នុងចំណោមពួកគេ នរណាមួយត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍ ដោយផ្អែកលើបរិមាណការងារ ដែលពួកគេបានធ្វើនោះទេ។ ពេត្រុសបានព្យាយាមរស់នៅក្នុងរូបភាពជាអ្នកដែលស្រឡាញ់ព្រះជាម្ចាស់ដើម្បីក្លាយជាមនុស្សម្នាក់ដែលស្តាប់បង្គាប់ព្រះជាម្ចាស់ ដើម្បីក្លាយជាមនុស្សម្នាក់ដែលទទួលយកការដោះស្រាយ និងការលួសកាត់ ហើយដើម្បីក្លាយជាមនុស្សម្នាក់ដែលបំពេញភារកិច្ចរបស់ខ្លួនក្នុងនាមជាសត្តនិកររបស់ព្រះជាម្ចាស់។ គាត់អាចលះបង់ខ្លួនគាត់ដើម្បីព្រះជាម្ចាស់បាន អាចលះបង់ខ្លួនគាត់ទាំងស្រុង ថ្វាយទៅក្នុងព្រះហស្តរបស់ព្រះជាម្ចាស់ និងស្តាប់បង្គាប់ទ្រង់រហូតដល់ស្លាប់។ នេះគឺជាអ្វីដែលគាត់តាំងចិត្តធ្វើ ហើយក៏ជាអ្វីដែលគាត់សម្រេចបានដែរ។ នេះគឺជាមូលហេតុសំខាន់ដែលចុងក្រោយទៅ ចុងបញ្ចប់នៃជីវិតរបស់គាត់ ខុសគ្នាពីចុងបញ្ចប់នៃជីវិតរបស់ប៉ុល។ កិច្ចការដែលព្រះវិញ្ញាណបរិសុទ្ធបានបំពេញចំពោះពេត្រុស គឺដើម្បីធ្វើឲ្យគាត់បានគ្រប់លក្ខណ៍ ហើយកិច្ចការដែលព្រះវិញ្ញាណបរិសុទ្ធបានធ្វើនៅក្នុងប៉ុល គឺដើម្បីប្រើគាត់។ នេះគឺដោយសារពួកគេមានលក្ខណៈ និងទស្សនៈចំពោះការស្វែងរកមិនដូចគ្នា។ អ្នកទាំងពីរមានកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ។ ពេត្រុសបានអនុវត្តកិច្ចការនេះ ចំពោះខ្លួនគាត់ ហើយក៏បានចែករំលែកកិច្ចការនោះដល់អ្នកដទៃដែរ។ ចំណែកប៉ុលវិញ គាត់គ្រាន់តែបានចែករំលែកនូវកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធទាំងស្រុងទៅដល់អ្នកដទៃតែប៉ុណ្ណោះ ហើយខ្លួនគាត់ផ្ទាល់ ពុំបានទទួលអ្វីទាំងអស់ពីកិច្ចការនេះ។ តាមរបៀបនេះ បន្ទាប់ពីប៉ុលមានបទពិសោធអំពីកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធអស់រយៈពេលជាច្រើនឆ្នាំមក ស្ទើរតែគ្មានការបំផ្លាស់បំប្រែចំពោះគាត់ទាល់តែសោះ។ គាត់នៅតែ

បន្តស្ថិតក្នុងសភាពដើមរបស់គាត់ដដែល ហើយគាត់នៅតែជាប៉ុលដូចពីមុនដដែល។ គ្រាន់តែថា ក្រោយពេលដែលគាត់បានឆ្លងកាត់ទុក្ខលំបាកក្នុងកិច្ចការអស់រយៈពេលជាច្រើនឆ្នាំមក គាត់បានរៀនពីរបៀប «ធ្វើការ» និងបានរៀនពីការតស៊ូអត់ធ្មត់ប៉ុណ្ណោះ ប៉ុន្តែលក្ខណៈចាស់របស់គាត់ ដែលជាលក្ខណៈប្រកួតប្រជែងខ្ពស់ និងគិតតែពីប្រយោជន៍នោះ នៅតែមានដដែល។ បន្ទាប់ពីបានធ្វើការអស់រយៈពេលជាច្រើនឆ្នាំមក គាត់មិនបានដឹងអំពីនិស្ស័យពុករលួយរបស់គាត់ឡើយ ហើយគាត់ក៏មិនបានរំដោះខ្លួនចេញពីនិស្ស័យចាស់របស់គាត់ដែរ ហើយគេនៅតែអាចមើលឃើញយ៉ាងច្បាស់ អំពីនិស្ស័យនេះនៅក្នុងកិច្ចការរបស់គាត់ដដែល។ នៅក្នុងខ្លួនគាត់ គឺគ្រាន់តែមានបទពិសោធការងារច្រើនតែប៉ុណ្ណោះ ប៉ុន្តែបទពិសោធដ៏តិចតួចតែមួយមុខនេះ មិនអាចបំផ្លាស់បំប្រែគាត់បានឡើយ និងមិនអាចផ្លាស់ប្ដូរទស្សនៈរបស់គាត់ចំពោះអត្ថិភាព និងសារៈសំខាន់នៃការស្វែងរករបស់គាត់បានឡើយ។ បើទោះបីជាគាត់បានបំពេញកិច្ចការជាច្រើនឆ្នាំសម្រាប់ព្រះគ្រីស្ទក្ដី និងមិនដែលបានធ្វើទុក្ខបុកម្នេញព្រះអម្ចាស់យេស៊ូវក្ដី ក៏នៅក្នុងដួងចិត្តរបស់គាត់គ្មានការបំផ្លាស់បំប្រែចំណេះដឹងរបស់គាត់អំពីព្រះជាម្ចាស់ដែរ។ នេះមានន័យថាគាត់មិនបានបំពេញកិច្ចការដើម្បីលះបង់ខ្លួនគាត់ ថ្វាយដល់ព្រះជាម្ចាស់ឡើយប៉ុន្តែផ្ទុយទៅវិញ គាត់ត្រូវបានបង្ខំឲ្យធ្វើការដើម្បីតែទិសដៅទៅអនាគតរបស់គាត់តែប៉ុណ្ណោះ។ ដ្បិតកាលពីដើមដំបូងឡើយ គាត់បានធ្វើទុក្ខបុកម្នេញព្រះគ្រីស្ទ និងមិនបានចុះចូលចំពោះព្រះគ្រីស្ទឡើយ។ គាត់មានសារជាតិជាអ្នកបះបោរពីកំណើត ដែលប្រឆាំងទាស់នឹងព្រះគ្រីស្ទដោយចេតនា និងជាមនុស្សម្នាក់ដែលគ្មានចំណេះដឹងអំពីកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធឡើយ។ នៅពេលដែលកិច្ចការរបស់គាត់ជិតចូលដល់ទីបញ្ចប់ គាត់នៅតែមិនដឹងអំពីកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធដដែល ហើយគាត់គ្រាន់តែធ្វើការផ្ទាល់ខ្លួនរបស់គាត់ ស្របទៅតាមអត្តចរិតរបស់គាត់តែប៉ុណ្ណោះ ដោយពុំបានយកចិត្តទុកដាក់សូម្បីតែបន្តិចចំពោះព្រះហឫទ័យរបស់ព្រះវិញ្ញាណបរិសុទ្ធ។ ហេតុដូច្នេះធម្មជាតិរបស់គាត់ គឺប្រឆាំងនឹងព្រះគ្រីស្ទ និងមិនបានស្ដាប់បង្គាប់តាមសេចក្ដីពិតឡើយ។ មនុស្សម្នាក់

ដែលមានលក្ខណៈដូចនេះ គឺជាមនុស្សដែលត្រូវបានកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធបោះបង់ចោលមនុស្ស ជាមនុស្សដែលមិនស្គាល់កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ និងជាមនុស្សដែលទាស់ទទឹងនឹងព្រះគ្រីស្ទ តើមនុស្សបែបនេះ អាចទទួលបានសេចក្តីសង្គ្រោះដោយរបៀបណា? មនុស្សអាចត្រូវបានសង្គ្រោះឬអត់នោះ ពុំស្ថិតនៅលើបរិមាណនៃកិច្ចការដែលគេធ្វើ ឬទំហំដែលគេបានលះបង់ឡើយ ប៉ុន្តែផ្ទុយទៅវិញ គឺត្រូវកំណត់តាមរយៈថាតើគេស្គាល់កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធដែរឬអត់ ថាតើគេអាចអនុវត្តតាមសេចក្តីពិតបានដែរឬអត់ និងថាតើទស្សនៈរបស់គេចំពោះការស្វែងរកនោះ ស្របទៅតាមសេចក្តីពិតដែរឬអត់។

បើទោះបីជាមានការបើកសម្តែងដោយឯកឯង បានកើតឡើងបន្ទាប់ពីពេត្រុសបានចាប់ផ្តើមដើរតាមព្រះយេស៊ូវក្តី ក៏ក្នុងធម្មជាតិរបស់គាត់តាំងពីដើមដំបូងមកគាត់គឺជាមនុស្សម្នាក់ដែលសុខចិត្តចុះចូលនឹងព្រះវិញ្ញាណបរិសុទ្ធ និងស្វែងរកព្រះគ្រីស្ទដែរ។ ការស្តាប់បង្គាប់របស់គាត់ ចំពោះព្រះវិញ្ញាណបរិសុទ្ធគឺស្អាតបរិសុទ្ធ៖ គាត់មិនបានស្វែងរកកេរ្តិ៍ឈ្មោះ និងសំណាងនោះទេ ប៉ុន្តែផ្ទុយទៅវិញ ត្រូវបានជំរុញទឹកចិត្តតាមរយៈការស្តាប់បង្គាប់ចំពោះសេចក្តីពិត។ បើទោះបីជាពេត្រុសបានធ្វើការបដិសេធ មិនទទួលស្គាល់ព្រះគ្រីស្ទចំនួនបីលើកក្តី ហើយបើទោះបីជាគាត់បានលបញ្ជោតព្រះអម្ចាស់យេស៊ូវក្តី ក៏ភាពអន់ខ្សោយបន្តិចបន្តួចក្នុងនាមមនុស្ស មិនពាក់ព័ន្ធនឹងធម្មជាតិរបស់គាត់ដែរ វាមិនប៉ះពាល់ដល់ការស្វែងរកនាពេលអនាគតរបស់គាត់ឡើយ ហើយវាមិនអាចគ្រប់គ្រាន់ដើម្បីបញ្ជាក់ថា ការបញ្ជោតរបស់គាត់នេះ គឺជាកិច្ចការនៃពួកទទឹងនឹងព្រះគ្រីស្ទបានឡើយ។ ភាពអន់ខ្សោយក្នុងនាមជាមនុស្សធម្មតា គឺជាអ្វីដែលមនុស្សគ្រប់គ្នានៅក្នុងពិភពលោកនេះមាន។ តើអ្នករំពឹងឲ្យពេត្រុស មានភាពខុសគ្នាពីគេមែនទេ? តើមនុស្សមិនប្រកាន់ទស្សនៈណាមួយចំពោះពេត្រុស ដោយព្រោះតែគាត់បានប្រព្រឹត្តកំហុស ឆោតល្ងង់ ជាច្រើនដងទេឬអី? ហើយតើមនុស្សមិនកោតសរសើរចំពោះប៉ុល ដោយព្រោះតែកិច្ចការទាំងអស់ដែលគាត់បានធ្វើ និងគ្រប់សំបុត្រទាំងអស់ដែលគាត់បានសរសេរទេឬអី? តើមនុស្សអាច

មានសមត្ថភាពមើលឃើញពីសារជាតិរបស់មនុស្សបានដោយរបៀបណា? ច្បាស់ណាស់ អស់អ្នកណាដែលមានសតិពិតប្រាកដ អាចមើលឃើញអ្វីឃើញអ្វីមួយដែលមិនសំខាន់។ បើទោះបីជាបទពិសោធឈឺចាប់ជាច្រើនឆ្នាំរបស់ពេត្រុស មិនត្រូវបានកត់ត្រាទុកនៅក្នុងព្រះគម្ពីរក្ដី ក៏នេះមិនបញ្ជាក់ថាពេត្រុស គ្មានបទពិសោធជាក់ស្ដែង ឬថាពេត្រុសមិនត្រូវបានធ្វើឲ្យគ្រប់លក្ខណ៍ដែរ។ តើកិច្ចការរបស់ព្រះជាម្ចាស់ អាចឲ្យមនុស្សលោកយល់បានទាំងស្រុងដូចម្ដេចកើតទៅ? កំណត់ត្រានៅក្នុងព្រះគម្ពីរមិនត្រូវបានព្រះយេស៊ូវជ្រើសរើសដោយផ្ទាល់ឡើយ ប៉ុន្តែត្រូវប្រមូលផ្ដុំចងក្រងនៅពេលក្រោយដោយមនុស្សជំនាន់ក្រោយៗទៀត។ ដោយសារត្រូវធ្វើការចងក្រងបែបនេះ តើគ្រប់ការទាំងអស់ដែលបានកត់ត្រាទុកនៅក្នុងព្រះគម្ពីរ មិនមែនត្រូវបានជ្រើសរើសទៅតាមគំនិតរបស់មនុស្សទេឬអី? បន្ថែមលើនេះ ចុងបញ្ចប់របស់ពេត្រុសនិងប៉ុលមិនត្រូវបានបញ្ជាក់ឲ្យបានច្បាស់នៅក្នុងសំបុត្រទាំងអស់នោះឡើយ ដូច្នេះមនុស្សវិនិច្ឆ័យពេត្រុស និងប៉ុលទៅតាមគំនិតផ្ទាល់ខ្លួនរបស់ពួកគេ និងទៅតាមការចង់បានផ្ទាល់ខ្លួនរបស់ពួកគេ។ ហើយដោយសារប៉ុលបានធ្វើការងារយ៉ាងច្រើន ដោយសារ «ការរួមចំណែក» របស់គាត់ មានទំហំច្រើនក្រាស់ក្រែល ទើបគាត់ទទួលបានការជឿទុកចិត្តពីហ្វូងមនុស្ស។ តើមនុស្សមិនផ្ដោតសំខាន់តែទៅលើរឿងដែលរាក់កំភែលទេឬអី? តើមនុស្សអាចមានសមត្ថភាព មើលឃើញពីសារជាតិរបស់មនុស្សបានដោយរបៀបណា? មិនចាំបាច់និយាយនោះទេ ព្រោះប៉ុលបានក្លាយជាវត្ថុមួយដែលត្រូវគេថ្វាយបង្គំអស់រយៈពេលរាប់ពាន់ឆ្នាំមកហើយ តើមាននរណាដែលហ៊ានបដិសេធកិច្ចការរបស់គាត់ភ្លាមៗនោះ? ពេត្រុសគ្រាន់តែជាអ្នកនេសាទម្នាក់ប៉ុណ្ណោះ ដូច្នេះតើការរួមចំណែករបស់គាត់អាចធំធេងដូចជាប៉ុល បានដោយរបៀបណា? និយាយពីការរួមចំណែកដែលពួកគាត់បានធ្វើ ប៉ុលគួរណាស់តែទទួលបានរង្វាន់មុនពេត្រុសទៅទៀត ហើយគាត់គួរណាស់តែត្រូវក្លាយជាមនុស្សម្នាក់ដែលមានលក្ខណៈសម្បត្តិល្អប្រសើរជាង ក្នុងការទទួលបានការយល់ព្រមពីព្រះជាម្ចាស់។ តើនរណាអាចនឹងស្រមៃដល់ទៅថា នៅក្នុងការប្រព្រឹត្តរបស់ទ្រង់ចំពោះប៉ុល ព្រះជាម្ចាស់គ្រាន់តែធ្វើឲ្យ

គាត់បំពេញកិច្ចការតាមរយៈអំណោយទានរបស់គាត់ប៉ុណ្ណោះ ផ្ទុយទៅវិញព្រះជាម្ចាស់បានធ្វើឲ្យពេត្រុស បានគ្រប់លក្ខណ៍។ គ្មានករណីណាមួយ ដែលថាព្រះអម្ចាស់យេស៊ូវបានបង្កើតផែនការសម្រាប់ពេត្រុស និងប៉ុលតាំងពីដើមដំបូងមកឡើយ។ ផ្ទុយទៅវិញពួកគេត្រូវបានធ្វើឲ្យគ្រប់លក្ខណ៍ ឬត្រូវចាត់ឲ្យបំពេញកិច្ចការស្របទៅតាមលធម្មជាតិពីកំណើតរបស់ពួកគេ។ ហេតុដូច្នេះ អ្វីដែលមនុស្សមើលឃើញ គឺគ្រាន់តែជាការរួមចំណែកពីខាងក្រៅរបស់មនុស្សតែប៉ុណ្ណោះ ចំណែកអ្វីដែលព្រះជាម្ចាស់ទតឃើញ គឺជាសារជាតិរបស់មនុស្ស ក៏ដូចជាផ្លូវដែលមនុស្សស្វែងរកតាំងពីដើមដំបូងមក និងការជំរុញចិត្តពីក្រោយការស្វែងរករបស់មនុស្ស។ មនុស្សវាស់ស្ទង់មនុស្ស គឺស្របទៅតាម សញ្ញាណរបស់ពួកគេ និងស្របទៅតាមការយល់ឃើញផ្ទាល់ខ្លួនរបស់ពួកគេ ក៏ប៉ុន្តែចុងបញ្ចប់របស់មនុស្ស មិនមែនកំណត់ស្របទៅតាមលក្ខណៈខាងក្រៅរបស់គេឡើយ។ ហេតុដូច្នេះ ខ្ញុំមានបន្ទូលថា ប្រសិនបើផ្លូវដែលអ្នកត្រូវដើរតាំងពីដើមដំបូងមក គឺជាផ្លូវជោគជ័យ ហើយទស្សនៈរបស់អ្នកចំពោះការស្វែងរក គឺជាទស្សនៈដែលត្រឹមត្រូវតាំងពីដើមដំបូងមក នោះអ្នកមានលក្ខណៈដូចគ្នានឹងពេត្រុសហើយ។ ប្រសិនបើផ្លូវដែលអ្នកដើរ គឺជាផ្លូវបរាជ័យ នោះមិនថាលះបង់ក្នុងតម្លៃណានោះទេ ចុងបញ្ចប់របស់អ្នកនឹងនៅតែដូចជាចុងបញ្ចប់របស់ប៉ុលដដែល។ មិនថាករណីបែបណា ទិសដៅរបស់អ្នកបែបណា ហើយមិនថាអ្នកជោគជ័យ ឬបរាជ័យនោះទេ គឺទាំងពីរនេះសុទ្ធតែត្រូវកំណត់តាមរយៈថាតើផ្លូវដែលអ្នកស្វែងរក គឺជាផ្លូវត្រឹមត្រូវដែរឬអត់ មិនមែនកំណត់លើភក្តីភាពរបស់អ្នក ឬតម្លៃដែលអ្នកលះបង់នោះទេ។ សារជាតិរបស់ពេត្រុសនិងប៉ុល និងគោលដៅដែលពួកគេស្វែងរក គឺខុសគ្នា។ មនុស្សមិនអាចដឹងពីចំណុចអស់ទាំងនេះបានឡើយ ហើយមានតែព្រះជាម្ចាស់ប៉ុណ្ណោះ ដែលអាចជ្រាបពីកិច្ចការទាំងនេះបានទាំងស្រុង។ ដ្បិតអ្វីដែលព្រះជាម្ចាស់ទតឃើញ គឺជាសារជាតិរបស់មនុស្ស ចំណែកឯមនុស្សវិញ គ្មានដឹងអ្វីសោះអំពីសារជាតិផ្ទាល់ខ្លួនរបស់គេឡើយ។ មនុស្សមិនអាចមើលឃើញពីសារជាតិនៅក្នុងខ្លួនមនុស្ស ឬកម្ពស់ជាក់ស្តែងរបស់គេឡើយ ហេតុដូច្នេះ មនុស្សមិនអាចកំណត់ពីមូលហេតុនៃជោគជ័យ

និងបរាជ័យរបស់ប៉ុល និងពេត្រុសបានឡើយ។ មូលហេតុដែលមនុស្សភាគច្រើនថ្វាយបង្គំប៉ុល និងមិនថ្វាយបង្គំពេត្រុស គឺដោយសារតែពេត្រុសត្រូវប្រើឲ្យធ្វើកិច្ចការសាធារណៈ ហើយមនុស្សអាចសង្កេតឃើញពីកិច្ចការនេះបាន ដូច្នេះ មនុស្សទទួលស្គាល់នូវ «សមិទ្ធផល» របស់ប៉ុល។ ចំណែកឯបទពិសោធរបស់ពេត្រុសវិញ មិនអាចឲ្យមនុស្សមើលឃើញបានឡើយ ហើយអ្វីដែលគាត់ស្វែងរក គឺមិនអាចឲ្យមនុស្សសម្រេចបានឡើយ ដូច្នេះហើយ មនុស្សគ្មានចំណាប់អារម្មណ៍ចំពោះពេត្រុសទេ។

ពេត្រុសត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍តាមរយៈបទពិសោធនៃការដោះស្រាយ និងការបន្សុទ្ធ។ គាត់បាននិយាយថា «ខ្ញុំត្រូវផ្គាប់តាមបំណងព្រះហឫទ័យ របស់ព្រះជាម្ចាស់គ្រប់ពេលទាំងអស់។ គ្រប់ការទាំងអស់ដែលខ្ញុំធ្វើ ខ្ញុំគ្រាន់តែចង់ផ្គាប់តាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់តែប៉ុណ្ណោះ ហើយមិនថាខ្ញុំត្រូវបានវាយផ្ចាល ឬជំនុំជម្រះនោះទេ ក៏ខ្ញុំនៅតែសប្បាយចិត្តនឹងធ្វើបែបនេះដដែល»។ ពេត្រុសបានប្រគល់គ្រប់យ៉ាងរបស់គាត់ថ្វាយដល់ព្រះជាម្ចាស់ ហើយកិច្ចការ ពាក្យសម្ដី និងជីវិតគាត់ទាំងមូល គឺសុទ្ធសឹងតែដើម្បីសេចក្ដីស្រឡាញ់ចំពោះព្រះជាម្ចាស់។ គាត់គឺជាមនុស្សម្នាក់ដែលបានស្វែងរកភាពបរិសុទ្ធ ហើយនៅពេលដែលគាត់មានបទពិសោធកាន់តែច្រើន នោះសេចក្ដីស្រឡាញ់របស់គាត់ចំពោះព្រះជាម្ចាស់ ក៏កាន់តែធំធេង និងជ្រាលជ្រៅនៅក្នុងដួងចិត្តរបស់គាត់ដែរ។ ផ្ទុយទៅវិញ ប៉ុលបានធ្វើតែកិច្ចការខាងក្រៅប៉ុណ្ណោះ ហើយទោះបីជាគាត់បានខំប្រឹងប្រែងធ្វើការយ៉ាងខ្លាំងក្ដី ក៏ការងាររបស់គាត់គឺប្រយោជន៍គ្រាន់តែដើម្បីធ្វើកិច្ចការ របស់គាត់ឲ្យបានត្រឹមត្រូវនិងដើម្បីទទួលបានរង្វាន់តែប៉ុណ្ណោះ។ ប្រសិនបើគាត់បានដឹងជាមុនថា គាត់នឹងមិនទទួលបានរង្វាន់អ្វីទេ នោះគាត់ប្រាកដជាឈប់ធ្វើកិច្ចការរបស់គាត់ជាមិនខាន។ អ្វីដែលពេត្រុសខ្វាយខ្វល់នោះ គឺជាសេចក្ដីស្រឡាញ់ពិតប្រាកដនៅក្នុងដួងចិត្តរបស់គាត់ ហើយជារឿងដែលជាក់ស្ដែង និងអាចសម្រេចបាន។ គាត់មិនបានខ្វាយខ្វល់ថាតើ គាត់នឹងទទួលបានរង្វាន់ឬអត់នោះទេ ប៉ុន្តែគាត់ខ្វាយខ្វល់ថាតើនិស្ស័យរបស់គាត់អាចត្រូវបានបំផ្លាស់បំប្រែដែរឬអត់។ ប៉ុលខ្វាយខ្វល់អំពីការខំប្រឹងប្រែងធ្វើការឲ្យបានកាន់តែខ្លាំងឡើងៗ

គាត់ខ្វល់តែពីកិច្ចការ និងការលះបង់តស៊ូតែសំបកក្រៅ និងខ្វល់តែពីគោលលទ្ធិដែលមនុស្សធម្មតា មិនអាចដកពិសោធន៍បាន។ គាត់មិនខ្វាយខ្វល់អំពីការបំផ្លាស់បំប្រែ ស៊ីជម្រៅនៅក្នុងខ្លួនគាត់ឡើយ ហើយក៏មិនខ្វល់ពីសេចក្ដីស្រឡាញ់ដ៏ពិតចំពោះព្រះជាម្ចាស់ដែរ។ បទពិសោធរបស់ពេត្រុស គឺដើម្បីសម្រេចបាននូវសេចក្ដីស្រឡាញ់ពិតប្រាកដ និងចំណេះដឹងពិតប្រាកដ អំពីព្រះជាម្ចាស់។ បទពិសោធរបស់គាត់ គឺដើម្បីទទួលបានទំនាក់ទំនងជិតស្និទ្ធជាមួយព្រះជាម្ចាស់ និងដើម្បីមានការរស់នៅដែលជាក់ស្ដែង។ កិច្ចការរបស់ប៉ុលត្រូវបានធ្វើឡើង ដោយព្រោះតែព្រះយេស៊ូវបានប្រទានកិច្ចការនោះដល់គាត់ និងដើម្បីសម្រេចបាននូវអ្វីៗដែលគាត់ទន្ទឹងចង់បាន ក៏ប៉ុន្តែកិច្ចការទាំងអស់នេះ មិនពាក់ព័ន្ធនឹងចំណេះដឹងរបស់គាត់អំពីខ្លួនគាត់ និងព្រះជាម្ចាស់ឡើយ។ កិច្ចការរបស់គាត់ គឺប្រយោជន៍គ្រាន់តែដើម្បីគេចចេញពីការវាយផ្ចាល និងការជំនុំជម្រះតែប៉ុណ្ណោះ។ អ្វីដែលពេត្រុសបានស្វែងរកគឺជាសេចក្ដីស្រឡាញ់ដ៏បរិសុទ្ធ ហើយអ្វីដែលប៉ុលបានស្វែងរក គឺជាមកុដនៃសេចក្ដីសុចរិត។ ពេត្រុសធ្លាប់មានបទពិសោធជាច្រើនឆ្នាំនៅក្នុងកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ និងមានចំណេះដឹងជាក់ស្ដែងអំពីព្រះគ្រីស្ទ ក៏ដូចជាចំណេះដឹងជ្រាលជ្រៅអំពីខ្លួនគាត់ដែរ។ ហេតុដូច្នេះ សេចក្ដីស្រឡាញ់របស់គាត់ចំពោះព្រះជាម្ចាស់ គឺបរិសុទ្ធ។ ការបន្សុទ្ធអស់រយៈពេលជាច្រើនឆ្នាំ បានធ្វើឲ្យការយល់ដឹងរបស់គាត់អំពីព្រះយេស៊ូវ និងអំពីជីវិត មានការកើនឡើង ហើយសេចក្ដីស្រឡាញ់របស់ទ្រង់ គឺជាសេចក្ដីស្រឡាញ់ដែលឥតលក្ខខណ្ឌ វាគឺជាសេចក្ដីស្រឡាញ់ដែលឆេះឆួលឡើងដោយឯកអន្ទក ហើយគាត់ពុំបានសុំអ្វីត្រឡប់មកវិញឡើយ ក៏មិនសង្ឃឹមថានឹងទទួលបានប្រយោជន៍អ្វីនោះដែរ។ ប៉ុលបានធ្វើការងារអស់រយៈពេលជាច្រើនឆ្នាំ ប៉ុន្តែគាត់មិនមានចំណេះដឹងច្រើនអំពីព្រះគ្រីស្ទឡើយ ហើយចំណេះដឹងរបស់គាត់អំពីខ្លួនឯង គឺតិចតួចខ្លាំងណាស់។ គាត់គ្មានសេចក្ដីស្រឡាញ់ចំពោះព្រះគ្រីស្ទឡើយ ហើយកិច្ចការរបស់គាត់ និងការរត់ប្រណាំងរបស់គាត់ គឺដើម្បីទទួលបាននូវកិត្តិយសនៅពេលចុងក្រោយប៉ុណ្ណោះ។ អ្វីដែលគាត់ស្វែងរក គឺជាមកុដដ៏ល្អឯក មិនមែនជាសេចក្ដីស្រឡាញ់

ដ៏បរិសុទ្ធនោះទេ។ គាត់មិនបានស្វែងរកដោយសកម្មទេ ប៉ុន្តែដោយអកម្ម។ គាត់មិនបានបំពេញនូវភារកិច្ចរបស់គាត់ឡើយ ប៉ុន្តែបានបង្ខំចិត្តក្នុងការស្វែងរករបស់គាត់ បន្ទាប់ពីត្រូវបានចាប់ចងដោយកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ។ ហេតុដូច្នេះការស្វែងរកគាត់មិនបានបញ្ជាក់ថា គាត់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាសត្តនិកររបស់ព្រះជាម្ចាស់ឡើយ។ គឺជាពេត្រុសនេះឯង ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាសត្តនិកររបស់ព្រះជាម្ចាស់ ដោយបានបំពេញនូវភារកិច្ចរបស់គាត់។ មនុស្សគិតថា អស់អ្នកណាដែលបានរួមចំណែកដល់ព្រះជាម្ចាស់ គួរតែទទួលបានរង្វាន់ ហើយកាលណាការរួមចំណែកកាន់តែច្រើន នោះកាន់តែភ្លេចថា ពួកគេគួរតែទទួលបានការគាប់ព្រះហឫទ័យពីព្រះជាម្ចាស់។ សារជាតិនៃទស្សនៈរបស់មនុស្ស គឺការដោះដូរ ហើយគេពុំបានស្វែងរកដោយសកម្មដើម្បីបំពេញភារកិច្ចរបស់គេក្នុងនាមជាសត្តនិកររបស់ព្រះជាម្ចាស់ឡើយ។ សម្រាប់ព្រះជាម្ចាស់វិញ កាលណាមនុស្សស្វែងរកសេចក្ដីស្រឡាញ់ពិតប្រាកដចំពោះព្រះជាម្ចាស់ និងស្ដាប់បង្គាប់ព្រះជាម្ចាស់ទាំងស្រុង ដែលក៏មានន័យថា ត្រូវបំពេញភារកិច្ចរបស់ពួកគេក្នុងនាមជាសត្តនិកររបស់ព្រះជាម្ចាស់ឲ្យបានកាន់តែច្រើនដែរ នោះពួកគេនឹងកាន់តែអាចទទួលបានការយល់ព្រមពីព្រះជាម្ចាស់។ ទស្សនៈរបស់ព្រះជាម្ចាស់ គឺទាមទារឲ្យមនុស្ស ស្រោចស្រង់នូវភារកិច្ច និងឋានៈដើមរបស់គេត្រឡប់មកវិញ។ មនុស្ស គឺជាសត្តនិកររបស់ព្រះជាម្ចាស់ ដូច្នេះហើយ មនុស្សមិនគប្បីប្រព្រឹត្តខ្លួនឲ្យហួសហេតុដោយទាមទារចង់បានអ្វីពីព្រះជាម្ចាស់ឡើយ ហើយមិនគប្បីធ្វើអ្វីផ្សេងក្រៅពីបំពេញភារកិច្ចរបស់ខ្លួនក្នុងនាមជាសត្តនិកររបស់ព្រះជាម្ចាស់ឡើយ។ ទិសដៅរបស់ប៉ុល និងពេត្រុស ត្រូវវាស់វែងតាមរយៈថាតើពួកគេអាចបំពេញភារកិច្ចរបស់ពួកគេក្នុងនាមជាសត្តនិករបានដែរឬទេ និងមិនមែនកំណត់ទៅតាមទំហំនៃការរួមចំណែករបស់ពួកគេឡើយ។ ទិសដៅរបស់ពួកគេ ត្រូវកំណត់ស្របទៅតាមអ្វីដែលពួកគេស្វែងរកតាំងពីដើមដំបូងមក មិនមែនទៅតាមបរិមាណការងារដែលពួកគេធ្វើ ឬទៅតាមការប៉ាន់ស្មានរបស់អ្នកដទៃចំពោះពួកគេឡើយ។ ហេតុដូច្នេះ ការស្វែងរកដោយសកម្មក្នុងការបំពេញភារកិច្ច របស់

មនុស្សម្នាក់ក្នុងនាមជាសត្តនិកររបស់ព្រះជាម្ចាស់គឺជាផ្លូវទៅកាន់ភាពជោគជ័យ។ ការស្វែងរកផ្លូវនៃសេចក្ដីស្រឡាញ់ដ៏ពិតប្រាកដចំពោះព្រះជាម្ចាស់ គឺជាផ្លូវដ៏ត្រឹមត្រូវជាងគេបំផុត។ ការស្វែងរកការបំផ្លាស់បំប្រែ និស្ស័យចាស់របស់មនុស្សម្នាក់ និងការស្វែងរកសេចក្ដីស្រឡាញ់ដ៏បរិសុទ្ធចំពោះព្រះជាម្ចាស់ គឺជាផ្លូវទៅកាន់ភាពជោគជ័យ។ ផ្លូវទៅកាន់ភាពជោគជ័យ គឺជាផ្លូវនៃការស្រោចស្រង់ភារកិច្ចដើមត្រឡប់មកវិញ ក៏ដូចជារូបកាយដើមនៃសត្តនិកររបស់ព្រះជាម្ចាស់ដែរ។ វាគឺជាផ្លូវនៃការស្រោចស្រង់ ហើយវាក៏ជាគោលដៅនៃកិច្ចការទាំងអស់របស់ព្រះជាម្ចាស់ តាំងពីដើមដំបូងរហូតដល់ចុងបញ្ចប់ដែរ។ ប្រសិនបើការស្វែងរករបស់មនុស្សប្រឡាក់ជាប់ទៅដោយការទាមទារផ្ទាល់ខ្លួនយ៉ាងច្រើន និងការទន្ទឹងរង់ចាំដែលគ្មានហេតុផល នោះផលដែលសម្រេចបាននឹងមិនមែនជាការបំផ្លាស់បំប្រែនិស្ស័យរបស់មនុស្សឡើយ។ ចំណុចនេះ គឺជាមិនស្របគ្នាជាមួយនឹងកិច្ចការនៃការស្រោចស្រង់នោះទេ។ វាច្បាស់ណាស់ថាមិនមែនជាកិច្ចការដែលព្រះវិញ្ញាណបរិសុទ្ធបានបំពេញឡើយ ហេតុដូច្នេះហើយ នេះបញ្ជាក់ថាការស្វែងរកបែបនេះ ព្រះជាម្ចាស់មិនបានអនុញ្ញាតឡើយ។ តើការស្វែងរកដែលព្រះជាម្ចាស់មិនអនុញ្ញាតនោះ មានសារៈសំខាន់អ្វីទៅ?

កិច្ចការដែលប៉ុលបានធ្វើ គឺត្រូវបានដាក់បង្ហាញឲ្យឃើញនៅចំពោះមុខមនុស្ស ប៉ុន្តែថាតើសេចក្ដីស្រឡាញ់របស់គាត់ចំពោះព្រះជាម្ចាស់បរិសុទ្ធប៉ុនណា និងថាតើគាត់ស្រឡាញ់ព្រះជាម្ចាស់ជ្រាលជ្រៅប៉ុនណានៅក្នុងដួងចិត្តរបស់គាត់នោះ មនុស្សពុំអាចមើលឃើញចំណុចទាំងនេះបានឡើយ។ មនុស្សគ្រាន់តែអាចមើលឃើញនូវកិច្ចការដែលគាត់បានធ្វើតែប៉ុណ្ណោះ ដែលតាមរយៈកិច្ចការនោះ មនុស្សដឹងថា គាត់ត្រូវបានព្រះវិញ្ញាណបរិសុទ្ធប្រើយ៉ាងប្រាកដ ដូច្នេះហើយ មនុស្សគិតថា ប៉ុលពូកែជាងពេត្រុស កិច្ចការរបស់គាត់ល្អជាង ដ្បិតគាត់អាចផ្គត់ផ្គង់ដល់ពួកជំនុំបាន។ ពេត្រុសគ្រាន់តែសម្លឹងមើលបទពិសោធផ្ទាល់ខ្លួនរបស់គាត់ និងបានទទួលយកមនុស្សពីរបីនាក់ប៉ុណ្ណោះក្នុងអំឡុងកិច្ចការម្ដងម្កាលរបស់គាត់។ មានសំបុត្រមួយចំនួនដែលមកអំពីគាត់ដែលពុំសូវមានគេដឹង ប៉ុន្តែតើនរណាដឹងថាតើសេចក្ដីស្រឡាញ់របស់គាត់

ចំពោះព្រះជាម្ចាស់ជ្រាលជ្រៅខ្លាំងប៉ុនណានៅក្នុងដួងចិត្តរបស់គាត់? មួយថ្ងៃហើយមួយថ្ងៃទៀត ប៉ុលបានធ្វើការដើម្បីព្រះជាម្ចាស់៖ ឲ្យតែមានការត្រូវធ្វើ គាត់នឹងធ្វើវាមិនខាន។ គាត់មានអារម្មណ៍ថា ការធ្វើបែបនេះ គាត់នឹងអាចទទួលបាននូវមកុដ និងអាចគាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់បាន ប៉ុន្តែគាត់ពុំបានស្វែងរកផ្លូវដើម្បីផ្លាស់ប្ដូរខ្លួនគាត់តាមរយៈកិច្ចការរបស់គាត់ឡើយ។ អ្វីៗនៅក្នុងជីវិតរបស់ពេត្រុស ដែលមិនគាប់តាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ បានធ្វើឲ្យគាត់មានអារម្មណ៍មិនស្រណុកចិត្ត។ ប្រសិនបើ មិនគាប់តាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ទេ នោះគាត់នឹងមានអារម្មណ៍ស្ដាយក្រោយ ហើយនឹងស្វែងរកផ្លូវដែលសមស្របមួយ ដែលគាត់អាចប្រឹងប្រែងដើម្បីផ្គាប់ដួងព្រះហឫទ័យរបស់ព្រះជាម្ចាស់បាន។ សូម្បីចំណែកដ៏តូចបំផុត និងចំណែកដែលមិនសំខាន់ក្នុងជីវិតរបស់គាត់ក្ដី ក៏គាត់នៅតែតម្រូវឲ្យខ្លួនគាត់ ផ្គាប់តាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ដដែល។ និយាយដល់និស្ស័យចាស់របស់គាត់វិញ គាត់មិនបានបន្ធូរបន្ថយឡើយ គឺកាន់តែហ្មត់ចត់ឡើងៗនៅក្នុងសេចក្ដីតម្រូវរបស់គាត់ចំពោះខ្លួនគាត់ ដើម្បីឲ្យយល់កាន់ជ្រៅទៅក្នុងសេចក្ដីពិត។ ប៉ុលស្វែងរកតែកេរ្តិ៍ឈ្មោះ និងឋានៈរាក់កំភែលតែប៉ុណ្ណោះ។ គាត់បានព្យាយាមអួតអាងខ្លួនឯងនៅចំពោះមុខមនុស្ស និងមិនបានព្យាយាមដើម្បីឲ្យបានរីកចម្រើនកាន់តែជ្រៅនៅក្នុងច្រកផ្លូវនៃជីវិតឡើយ។ អ្វីដែលគាត់ខ្វាយខ្វល់នោះ គឺជាគោលលទ្ធិ មិនមែនជាភាពពិតឡើយ។ មនុស្សខ្លះនិយាយថា «ប៉ុលបានធ្វើកិច្ចការយ៉ាងច្រើនថ្វាយព្រះជាម្ចាស់ ហេតុអ្វីបានជាព្រះជាម្ចាស់មិនចងចាំគាត់? ពេត្រុសបានធ្វើការតិចតួចប៉ុណ្ណោះថ្វាយព្រះជាម្ចាស់ និងមិនបានរួមចំណែកអ្វីច្រើនដល់ពួកជំនុំឡើយ តើហេតុដូចម្ដេចបានជាគាត់ត្រូវបានប្រោសឲ្យបានគ្រប់លក្ខណ៍?» ពេត្រុសបានស្រឡាញ់ព្រះជាម្ចាស់ដល់កម្រិតមួយ ដែលជាសេចក្ដីតម្រូវរបស់ព្រះជាម្ចាស់។ មានតែមនុស្សបែបនេះទេ ទើបមានទីបន្ទាល់។ ហើយចុះចំណែកប៉ុលវិញ? តើប៉ុលស្រឡាញ់ព្រះជាម្ចាស់ដល់កម្រិតណាដែរ? តើអ្នកដឹងដែរឬទេ? តើកិច្ចការរបស់ប៉ុលត្រូវបានធ្វើឡើងដើម្បីអ្វី? ហើយតើកិច្ចការរបស់ពេត្រុស ត្រូវបានធ្វើឡើងដើម្បីអ្វី?

ពេត្រុសមិនបានធ្វើការច្រើនប៉ុន្មានទេ ប៉ុន្ដែតើអ្នកដឹងថាមានអ្វីដែលកប់ជ្រៅនៅក្នុងដួងចិត្តរបស់គាត់ទេ? កិច្ចការរបស់ប៉ុលដែលពាក់ព័ន្ធនឹងការផ្គត់ផ្គង់ដល់ពួកជំនុំ និងការគាំទ្រដល់ពួកជំនុំ។ អ្វីដែលពេត្រុសជួបប្រទះ គឺជាការផ្លាស់ប្ដូរនៅក្នុងនិស្ស័យជីវិតរបស់គាត់ ហើយគាត់មានបទពិសោធអំពីការស្រឡាញ់ព្រះជាម្ចាស់។ ដោយសារតឡូវ អ្នកបានដឹងពីភាពខុសគ្នានៃសារជាតិរបស់ពួកគេហើយ នោះអ្នកអាចមើលបានថាតើនៅពេលចុងក្រោយ នរណាដែលពិតជាជឿលើព្រះជាម្ចាស់ដោយពិតប្រាកដ និងនរណាដែលមិនជឿលើព្រះជាម្ចាស់ដោយពិតប្រាកដ។ ក្នុងចំណោមពួកគេមានម្នាក់ដែលស្រឡាញ់ព្រះជាម្ចាស់ ហើយម្នាក់ទៀត មិនបានស្រឡាញ់ព្រះជាម្ចាស់ដោយពិតប្រាកដឡើយ។ ម្នាក់បានឆ្លងកាត់ការផ្លាស់ប្ដូរនិស្ស័យរបស់ខ្លួន ហើយម្នាក់ទៀតមិនបានឆ្លងកាត់ឡើយ។ ម្នាក់បានបម្រើដោយការបន្ទាបខ្លួន និងមិនងាយឲ្យមនុស្សកត់សម្គាល់ឃើញបានឡើយ ហើយម្នាក់ទៀតត្រូវមនុស្សថ្វាយបង្គំ និងមានរូបភាពល្អអស្ចារ្យ។ ម្នាក់បានស្វែងរកសេចក្ដីបរិសុទ្ធ ហើយម្នាក់ទៀតមិនបានស្វែងរកឡើយ ហើយបើទោះបីជាគេមិនបរិសុទ្ធក្ដី ក៏គេមិនមាននូវសេចក្ដីស្រឡាញ់ដ៏បរិសុទ្ធដែរ។ ម្នាក់មានភាពជាមនុស្សពិតប្រាកដ ហើយម្នាក់ទៀតគ្មានឡើយ។ ម្នាក់មាននូវស្មារតីជាសត្តនិកររបស់ព្រះជាម្ចាស់ ហើយម្នាក់ទៀតគ្មានឡើយ។ ទាំងអស់នេះ គឺជាភាពខុសគ្នានៃសារជាតិរបស់ប៉ុល និងពេត្រុស។ ផ្លូវដែលពេត្រុសបានដើរ គឺជាផ្លូវជោគជ័យ ហើយក៏ជាផ្លូវនៃការសម្រេចបាន នូវការស្រោចស្រង់នូវភាពជាមនុស្សសាមញ្ញធម្មតា និងការស្រោចស្រង់ នូវភារកិច្ចក្នុងនាមជាសត្តនិកររបស់ព្រះជាម្ចាស់ត្រឡប់មកវិញផងដែរ។ ពេត្រុសតំណាងឲ្យអ្នកដែលមានជោគជ័យ។ ផ្លូវដែលប៉ុលបានដើរ គឺជាផ្លូវបរាជ័យ ហើយគាត់តំណាងឲ្យអ្នកទាំងឡាយដែលគ្រាន់តែចុះចូល និងលះបង់ខ្លួនសើៗតែប៉ុណ្ណោះ និងមិនបានស្រឡាញ់ព្រះជាម្ចាស់ដោយពិតប្រាកដឡើយ។ ប៉ុលតំណាងឲ្យអ្នកដែលមិនមានសេចក្ដីពិត។ នៅក្នុងជំនឿរបស់គាត់លើព្រះជាម្ចាស់ ពេត្រុសបានព្យាយាមផ្គាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់នៅគ្រប់ការទាំងអស់ ហើយបានព្យាយាមស្ដាប់បង្គាប់នូវគ្រប់ការទាំងអស់ដែលមកអំពី

ព្រះជាម្ចាស់។ គាត់អាចទទួលយកនូវការវាយផ្ចាល និងការជំនុំជម្រះ ក៏ដូចជាការបន្សុទ្ធ ទុក្ខសោក និងការបន្តទៅមុខដោយគ្មានអ្វីសោះនៅក្នុងជីវិតរបស់គាត់ ដោយគ្មានការតវ៉ាសូម្បីតែបន្តិច ហើយគ្មានអ្វីអាចផ្លាស់ប្ដូរសេចក្ដីស្រឡាញ់របស់គាត់ចំពោះព្រះជាម្ចាស់បានឡើយ។ តើនេះមិនមែនជាសេចក្ដីស្រឡាញ់ដ៏ជ្រាលជ្រៅបំផុតចំពោះព្រះជាម្ចាស់ទេឬអី? តើនេះមិនមែនជាការបំពេញភារកិច្ចក្នុងនាមជាសត្តនិកររបស់ព្រះជាម្ចាស់ទេឬអី? មិនថានៅក្នុងការវាយផ្ចាល ការជំនុំជម្រះ ឬទុក្ខសោកនោះទេ អ្នកតែងអាចសម្រេចបាននូវការស្ដាប់បង្គាប់រហូតដល់ស្លាប់បាន ហើយនេះគឺជាអ្វីដែលសត្តនិកររបស់ព្រះជាម្ចាស់គប្បីសម្រេចឲ្យបាន នេះគឺជាភាពស្អាតបរិសុទ្ធនៃសេចក្ដីស្រឡាញ់ចំពោះព្រះជាម្ចាស់។ ប្រសិនបើមនុស្សសម្រេចបានចំណុចនេះបានកាន់តែច្រើន នោះគេនឹងមានលក្ខណៈសម្បត្តិជាសត្តនិកររបស់ព្រះជាម្ចាស់ ហើយគ្មានអ្វីផ្សេងដែលអាចផ្គាប់បំណងព្រះហឫទ័យរបស់ព្រះអាទិករបានប្រសើរជាងនេះឡើយ។ ឧបមាថា អ្នកអាចធ្វើការថ្វាយព្រះជាម្ចាស់បាន ប៉ុន្តែអ្នកមិនស្ដាប់បង្គាប់ព្រះជាម្ចាស់ និងមិនអាចស្រឡាញ់ព្រះជាម្ចាស់ដោយពិតប្រាកដបាន។ តាមរបៀបនេះអ្នកមិនត្រឹមតែនឹងមិនបានបំពេញភារកិច្ច ជាសត្តនិកររបស់ព្រះជាម្ចាស់ប៉ុណ្ណោះទេ ប៉ុន្តែអ្នកក៏នឹងត្រូវព្រះជាម្ចាស់ថ្កោលទោសដែរ ដ្បិតអ្នកគឺជាមនុស្សម្នាក់ដែលមិនមានសេចក្ដីពិត ជាអ្នកដែលមិនអាចស្ដាប់បង្គាប់ព្រះជាម្ចាស់បាន ហើយជាមនុស្សមិនស្ដាប់បង្គាប់ព្រះជាម្ចាស់។ អ្នកគ្រាន់តែខ្វល់អំពីការធ្វើការថ្វាយព្រះជាម្ចាស់ប៉ុណ្ណោះ និងមិនខ្វល់អំពីការប្រតិបត្តិសេចក្ដីពិត ឬស្វែងយល់អំពីខ្លួនឯងឡើយ។ អ្នកពុំយល់ ឬស្គាល់ព្រះអាទិករទេ ហើយអ្នកមិនគោរព ឬស្រឡាញ់ព្រះអាទិករឡើយ។ អ្នកគឺជាមនុស្សម្នាក់ដែលមិនស្ដាប់បង្គាប់ព្រះជាម្ចាស់តាំងពីកំណើតមក ហើយមនុស្សបែបអ្នកនេះ មិនត្រូវបានព្រះអាទិករសព្វព្រះហឫទ័យឡើយ។

មនុស្សខ្លះនិយាយថា «ប៉ុលបានធ្វើការយ៉ាងច្រើន ហើយគាត់បានរែកពន់បន្ទុកយ៉ាងធ្ងន់សម្រាប់ពួកជំនុំ និងបានរួមចំណែកផ្ដល់ដល់ពួកគេយ៉ាងច្រើន។ សំបុត្រទាំងដប់បីរបស់ប៉ុល និយាយពីរឿងរ៉ាវរយៈពេល ២០០០ ឆ្នាំ ក្នុងយុគសម័យនៃព្រះគុណ

និងផ្នែកទីពីររបស់ប៉ុល្លោះ បន្ទាប់ពីដំណឹងល្អទាំងបួន។ តើនរណាអាចប្រៀបធៀបជាមួយនឹងគាត់បាន? គ្មាននរណាម្នាក់ដែលយល់ពីការបើកសម្ដែងរបស់យ៉ូហានបានឡើយ ចំណែកឯសំបុត្ររបស់ប៉ុលវិញ ផ្ដល់នូវជីវិត ហើយកិច្ចការដែលគាត់បានធ្វើ គឺជាប្រយោជន៍ដល់ពួកជំនុំ។ តើនរណាផ្សេងទៀតដែលអាចសម្រេចរឿងបែបនេះបាន? ហើយតើកិច្ចការអ្វីដែលពេត្រុសបានធ្វើ?» នៅពេលដែលមនុស្សវាស់ស្ទង់អ្នកដទៃ គេវាស់ស្ទង់ទៅតាមការរួមចំណែករបស់ពួកគេ។ នៅពេលដែលព្រះជាម្ចាស់វាស់ស្ទង់មនុស្ស ទ្រង់វាស់ស្ទង់ទៅតាមលក្ខណៈរបស់មនុស្ស។ ក្នុងចំណោមអស់អ្នកដែលស្វែងរកជីវិត ប៉ុលគឺជាមនុស្សម្នាក់ដែលមិនបានស្គាល់នូវសារជាតិរបស់ខ្លួន។ គាត់មិនបន្ទាបខ្លួន ឬស្ដាប់បង្គាប់ទាល់តែសោះ ហើយគាត់ក៏មិនដឹងពីសារជាតិរបស់គាត់ ដែលទាស់ទទឹងនឹងព្រះជាម្ចាស់ដែរ។ ហេតុដូច្នេះ គាត់គឺជាមនុស្សម្នាក់ដែលមិនបានឆ្លងកាត់បទពិសោធល្អិតល្អន់ និងជាមនុស្សម្នាក់ដែលមិនបានប្រតិបត្តិតាមសេចក្ដីពិតឡើយ។ ពេត្រុស គឺខុសគ្នា។ គាត់បានដឹងភាពមិនគ្រប់លក្ខណ៍ ចំណុចខ្សោយ និងនិស្ស័យពុករលួយរបស់គាត់ ក្នុងនាមជាសត្តនិកររបស់ព្រះជាម្ចាស់ ហេតុដូច្នេះ គាត់មានផ្លូវអនុវត្តមួយ ដើម្បីផ្លាស់ប្ដូរនូវនិស្ស័យរបស់គាត់។ គាត់មិនមែនជាមនុស្សម្នាក់ក្នុងចំណោមមនុស្សដែលមានតែគោលលទ្ធិ តែគ្មាននូវភាពពិតនោះទេ។ អស់អ្នកដែលបានផ្លាស់ប្រែ គឺជាមនុស្សថ្មីដែលត្រូវបានសង្គ្រោះ ពួកគេគឺជាអ្នកដែលមានលក្ខណៈសម្បត្តិនៅក្នុងការស្វែងរកសេចក្ដីពិត។ មនុស្សដែលមិនបានផ្លាស់ប្ដូរ ជាអ្នកដែលគ្មានសារជាតិតាំងពីដើមមក។ ពួកគេគឺជាអ្នកដែលមិនត្រូវបានសង្គ្រោះឡើយ ពោលគឺជាអ្នកដែលត្រូវព្រះជាម្ចាស់ស្អប់ខ្ពើម និងបដិសេធចោល។ ពួកគេនឹងមិនត្រូវព្រះជាម្ចាស់ចងចាំទុកឡើយ មិនថាកិច្ចការរបស់ពួកគេល្អប៉ុនណាក៏ដោយ។ មិនថាអ្នកជាប្រភេទមនុស្សដូចគ្នាតែមួយនឹងពេត្រុស ឬប៉ុលនោះទេ នៅពេលដែលអ្នកប្រៀបធៀបចំណុចនេះជាមួយនឹងការស្វែងរកផ្ទាល់ខ្លួនរបស់អ្នក នោះអ្នកគួរតែអាចបញ្ជាក់បានដោយខ្លួនឯងហើយ។ ប្រសិនបើក្នុងការស្វែងរករបស់អ្នកគ្មានសេចក្ដីពិតទេ ហើយបើទោះបីជាអ្នកនៅតែក្រអឺតក្រទម និងព្រហើនដូចជាប៉ុល ហើយនៅតែ

និយាយអត់បានការ និងអួតអាងដូចជាគាត់ នោះមិនចាំបាច់ឆ្ងល់ទេអ្នកគឺជាមនុស្ស គ្មានគុណធម៌ម្នាក់ដែលបរាជ័យ។ ប្រសិនបើអ្នកស្វែងរក ដូចគ្នានឹងពេត្រុសដែរ ប្រសិនបើអ្នកស្វែងរកការប្រតិបត្តិ និងការផ្លាស់ប្ដូរដែលពិតប្រាកដ ហើយមិនក្រអឺត ក្រទម ឬតាមតែចិត្តអ្នក ប៉ុន្តែព្យាយាមបំពេញភារកិច្ចរបស់ខ្លួន នោះអ្នកនឹងក្លាយជា សត្តនិកររបស់ព្រះជាម្ចាស់ ដែលអាចសម្រេចនូវជ័យជម្នះបាន។ ប៉ុលពុំបានដឹងអំពី សារជាតិ និងសេចក្ដីពុករលួយរបស់ខ្លួនគាត់ឡើយ គាត់កាន់តែមិនដឹងអំពីការមិន ស្ដាប់បង្គាប់ផ្ទាល់ខ្លួនរបស់គាត់ទៀត។ គាត់មិនដែលនិយាយអំពីការរឹងទទឹងដ៏គួរឲ្យ ស្អប់ខ្ពើមជាមួយព្រះគ្រីស្ទឡើយ ហើយគាត់ក៏មិនមាន ការស្ដាយក្រោយអ្វីសោះដែរ។ គាត់គ្រាន់តែផ្ដល់នូវការពន្យល់ខ្លីៗប៉ុណ្ណោះ ហើយនៅក្នុងដួងចិត្តរបស់គាត់ គាត់ មិនបានចុះចូលទាំងស្រុងចំពោះព្រះជាម្ចាស់ឡើយ។ បើទោះបីជាគាត់បានដួលនៅ លើផ្លូវទៅកាន់ទីក្រុងដាម៉ាសក្ដី ក៏គាត់មិនបានពិនិត្យឲ្យជ្រៅនៅក្នុងខ្លួនរបស់គាត់ ដែរ។ គាត់សប្បាយចិត្ត ដែលត្រូវធ្វើការបន្ដទៀតតែប៉ុណ្ណោះហើយគាត់មិនបាន ពិចារណាស្វែងយល់អំពីខ្លួនឯង និងផ្លាស់ប្ដូរនិស្ស័យចាស់របស់គាត់ ឲ្យក្លាយជាបញ្ហា សំខាន់ជាងគេបំផុតឡើយ។ គាត់ពេញចិត្តដោយបាននិយាយពីសេចក្ដីពិត ដោយបាន ផ្ដល់ដល់អ្នកដទៃក្នុងលក្ខណៈជាការស្រោចស្រង់សតិសម្បជញ្ញៈផ្ទាល់ខ្លួនរបស់គាត់ ហើយលែងមានការធ្វើទុក្ខបុកម្នេញ ចំពោះសិស្សរបស់ព្រះយេស៊ូវ ដើម្បីលួងលោម ចិត្តរបស់គាត់ និងអត់ទោសបាបរបស់គាត់ពីមុនទៀតហើយ។ គោលដៅដែលគាត់ ស្វែងរក គឺគ្មានអ្វីផ្សេងក្រៅពីមកុដទៅអនាគត និងកិច្ចការបណ្ដោះអាសន្នឡើយ គោលដៅដែលគាត់ស្វែងរក គឺជាព្រះគុណដ៏ច្រើន មហិមា។ គាត់ពុំបានស្វែងរក សេចក្ដីពិតឲ្យបានគ្រប់គ្រាន់ឡើយ ហើយគាត់ក៏មិនបានស្វែងរកការយល់ដឹងជ្រាល ជ្រៅទៅក្នុងសេចក្ដីពិត ដែលគាត់មិនធ្លាប់បានយល់ពីមុនមកដែរ។ ហេតុនេះ ចំណេះ ដឹងរបស់គាត់អំពីខ្លួនឯង អាចនិយាយបានថាជាការមិនត្រឹមត្រូវ ហើយគាត់មិនបាន ទទួលយកការវាយផ្ចាល និងការជំនុំជម្រះឡើយ។ ការដែលគាត់អាចបំពេញកិច្ចការ បាន ពុំមានន័យថា គាត់មានចំណេះដឹងអំពីធម្មជាតិ ឬសារជាតិផ្ទាល់របស់គាត់

ឡើយ។ គាត់ផ្ដោតសំខាន់លើការអនុវត្តតែសំបកខាងក្រៅតែប៉ុណ្ណោះ។ បន្ថែមលើនេះ អ្វីដែលគាត់ខំប្រឹងចង់បានមិនមែនជាការផ្លាស់ប្ដូរទេ ប៉ុន្តែជាចំណេះដឹង។ កិច្ចការរបស់គាត់ គឺជាលទ្ធផលទាំងស្រុងនៃការលេចមករបស់ព្រះយេស៊ូវនៅលើផ្លូវទៅកាន់ទីក្រុងដាម៉ាស។ វាមិនមែនជាអ្វីដែលគាត់បានតាំងចិត្តធ្វើពីដើមមកនោះទេ ហើយវាក៏មិនមែនជាកិច្ចការដែលកើតមានក្រោយពីគាត់បានទទួលយកការលួសកាត់និស្ស័យចាស់របស់គាត់ដែរ។ មិនថាគាត់ធ្វើការដោយបែបណានោះទេ និស្ស័យចាស់របស់គាត់មិនបានផ្លាស់ប្ដូរឡើយ ដូច្នេះហើយ កិច្ចការរបស់គាត់មិនទទួលរងនូវបាបពីមុនរបស់គាត់ទេ ប៉ុន្តែគ្រាន់តែបានដើរតួនាទី ក្នុងចំណោមពួកជំនុំនៅពេលនោះតែប៉ុណ្ណោះ។ សម្រាប់មនុស្សដូចគាត់នេះ ដែលនិស្ស័យចាស់របស់ខ្លួនមិនបានផ្លាស់ប្ដូរពោលគឺអស់អ្នកដែលមិនបានទទួលនូវសេចក្ដីសង្គ្រោះ និងគ្មានសេចក្ដីពិតផងនោះពិតជាមិនអាចក្លាយជាមនុស្សម្នាក់ដែលត្រូវព្រះអម្ចាស់យេស៊ូវទទួលយកឡើយ។ គាត់មិនមែនជាមនុស្សម្នាក់ ដែលចាក់បំពេញដោយសេចក្ដីស្រឡាញ់ និងការគោរពកោតខ្លាចចំពោះព្រះយេស៊ូវគ្រីស្ទឡើយហើយគាត់ក៏មិនមែនជាមនុស្សម្នាក់ដែលបានសម្របខ្លួនក្នុងការស្វែងរកសេចក្ដីពិតដែរ ហើយគាត់កាន់តែមិនមែនជាមនុស្សម្នាក់ដែលបានស្វែងរកនូវអាថ៌កំបាំងនៃការយកកំណើតជាមនុស្សដែរ។ គាត់គ្រាន់តែជាមនុស្សម្នាក់ដែលមានជំនាញក្នុងការបោកបញ្ឆោតដ៏ឈ្លាសវៃតែប៉ុណ្ណោះ ហើយគាត់នឹងមិនផ្ដល់ផលផ្លែដល់នរណាម្នាក់ដែលខ្ពស់ជាងគាត់ ឬនរណាដែលមាននូវសេចក្ដីពិតឡើយ។ គាត់បានច្រណែននឹងមនុស្ស ឬច្រណែននឹងសេចក្ដីពិត ដែលផ្ទុយនឹងគាត់ ឬប្រឆាំងនឹងគាត់ ដោយគាត់ចង់បានមនុស្សដែលមានអំណោយទាន ដែលបានបង្ហាញនូវមុខមាត់ដ៏វិសេសវិសាល និងមាននូវចំណេះដឹងដ៏ជ្រាលជ្រៅ។ គាត់មិនចូលចិត្តទាក់ទង ជាមួយមនុស្សអន់ខ្សោយដែលស្វែងរកផ្លូវពិត និងមិនខ្វាយខ្វល់ពីអ្វីផ្សេងក្រៅពីសេចក្ដីពិតឡើយ ហើយផ្ទុយទៅវិញ គាត់ព្រួយបារម្ភខ្លួនគាត់ជាមួយនឹងពួកចាស់ទុំពីស្ថាប័នសាសនា ដែលគ្រាន់តែនិយាយអំពីគោលលទ្ធិ និងជាពួកអ្នកដែលមាននូវចំណេះដឹងយ៉ាងច្រើនអនេក។ គាត់គ្មានសេចក្ដីស្រឡាញ់ចំពោះកិច្ចការថ្មីរបស់

ព្រះវិញ្ញាណបរិសុទ្ធឡើយ និងមិនខ្វាយខ្វល់អំពីការវិវឌ្ឍនៃកិច្ចការថ្មីរបស់ព្រះវិញ្ញាណបរិសុទ្ធដែរ។ ផ្ទុយទៅវិញ គាត់ពេញចិត្តតែច្បាប់ និងគោលលទ្ធិដែលខ្ពស់ជាងសេចក្ដីពិតទូទៅ។ នៅក្នុងសារជាតិពីកំណើតរបស់គាត់ និងលក្ខណៈទាំងស្រុងដែលគាត់ស្វែងរក គឺគាត់ពុំស័ក្ដិសមនឹងត្រូវហៅថាជាគ្រីស្ទបរិស័ទដែលស្វែងរកសេចក្ដីពិតឡើយ រឹតតែមិនអាចហៅថាជាបាវបម្រើដ៏ស្មោះត្រង់នៅក្នុងដំណាក់របស់ព្រះជាម្ចាស់ ដ្បិតការលាក់ពុតរបស់គាត់ ច្រើនក្រាស់ក្រែលខ្លាំងណាស់ ហើយការមិនស្ដាប់បង្គាប់របស់គាត់ពិតជាច្រើនខ្លាំងណាស់។ បើទោះបីជាគាត់ត្រូវបានគេស្គាល់ថា ជាបាវបម្រើរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ក៏គាត់មិនស័ក្ដិសម នឹងចូលទៅកាន់ច្រកទ្វារនៃនគរស្ថានសួគ៌ដែរដ្បិតសកម្មភាពរបស់គាត់តាំងពីដើមដំបូងរហូតដល់ទីបញ្ចប់ មិនអាចរាប់ថាសុចរិតបានឡើយ។ គាត់គ្រាន់តែអាចឲ្យគេមើលឃើញថាជាមនុស្សម្នាក់ដែលលាក់ពុត និងបានប្រព្រឹត្តអំពើទុច្ចរិត តែបែរជាបានធ្វើការថ្វាយព្រះគ្រីស្ទទៅវិញ។ បើទោះបីជាគាត់មិនអាចរាប់ថាជាមនុស្សអាក្រក់ក្ដី ក៏គាត់ស័ក្ដិសមនឹងរាប់ថាជាមនុស្សម្នាក់ដែលបានប្រព្រឹត្តអំពើទុច្ចរិតដែរ។ គាត់បានធ្វើការច្រើនក៏ពិតមែន ក៏ប៉ុន្តែ គាត់មិនគួរត្រូវបានគេវិនិច្ឆ័យដោយសារបរិមាណនៃកិច្ចការដែលគាត់បានធ្វើនោះទេ ប៉ុន្តែត្រូវវិនិច្ឆ័យតែទៅលើគុណភាព និងសារជាតិនៃកិច្ចការនោះប៉ុណ្ណោះ។ មានតែបែបនេះទេ ទើបអាចចូលទៅដល់ដើមហេតុនៃបញ្ហានេះ។ គាត់តែងជឿថា៖ «ខ្ញុំអាចធ្វើការបាន ខ្ញុំជាមនុស្សពូកែជាងមនុស្សភាគច្រើន។ ខ្ញុំជាមនុស្សគិតគូរអំពីអម្រែករបស់ព្រះអម្ចាស់ជាងមនុស្សផងឯទៀត ហើយគ្មាននរណាម្នាក់ប្រែចិត្តយ៉ាងជ្រាលជ្រៅដូចជាខ្ញុំឡើយ ដ្បិតពន្លឺដ៏អស្ចារ្យបានចាំងចែងមកលើខ្ញុំ ហើយខ្ញុំបានឃើញនូវពន្លឺដ៏អស្ចារ្យនោះ ដូច្នេះហើយការប្រែចិត្តរបស់ខ្ញុំជ្រាលជ្រៅជាងអ្នកណាទាំងអស់»។ នេះគឺជាអ្វីដែលគិតនៅក្នុងដួងចិត្តរបស់គាត់នៅពេលនោះ។ នៅចុងបញ្ចប់នៃកិច្ចការរបស់គាត់ ប៉ុលបាននិយាយថា៖ «ខ្ញុំបានតយុទ្ធ ខ្ញុំបានរត់ប្រណាំងជាស្រេច ហើយមានមកុដនៃសេចក្ដីសុចរិតបម្រុងទុកឲ្យខ្ញុំ»។ ការតយុទ្ធ ការធ្វើការ និងការរត់ប្រណាំងរបស់គាត់ គឺសុទ្ធតែដើម្បីមកុដនៃសេចក្ដីសុចរិត ហើយគាត់មិនបានចម្រើនទៅមុខដោយសកម្ម

ឡើយ។ បើទោះបីជាគាត់មិនប្រាកដប្រជានឹងកិច្ចការរបស់គាត់ក្ដី អាចនិយាយបានថា កិច្ចការរបស់គាត់ គឺគ្រាន់តែធ្វើឡើងដើម្បីលុបលាងកំហុសរបស់គាត់តែប៉ុណ្ណោះ ដើម្បីតបស្នងនឹងការចោទប្រកាន់លើសតិសម្បជញ្ញៈរបស់គាត់។ គាត់គ្រាន់តែសង្ឃឹមថា អាចបញ្ចប់កិច្ចការរបស់គាត់ បញ្ចប់ការរត់ប្រណាំងរបស់គាត់ និងការតយុទ្ធនៅក្នុងចម្បាំងរបស់គាត់ឲ្យបានឆាប់ប៉ុណ្ណោះ ដើម្បីឲ្យគាត់អាចទទួលបាននូវមកុដនៃសេចក្ដីសុចរិត ដែលគាត់ទន្ទឹងចង់បានជាយូរមកហើយនោះ ដើម្បីឲ្យបានកាន់តែឆាប់។ អ្វីដែលគាត់ទន្ទឹងចង់បាន គឺមិនមែនដើម្បីជួបព្រះអម្ចាស់យេស៊ូវដោយបទពិសោធ និងចំណេះដឹងពិតប្រាកដរបស់គាត់ឡើយ ប៉ុន្ដែដើម្បីបញ្ចប់កិច្ចការឲ្យបានឆាប់ ដើម្បីឲ្យគាត់នឹងទទួលបាននូវរង្វាន់ដែលគួរទទួលបានពីកិច្ចការដែលគាត់បានបំពេញ នៅពេលដែលគាត់បានជួបជាមួយព្រះអម្ចាស់យេស៊ូវ។ គាត់បានប្រើកិច្ចការរបស់គាត់ដើម្បីលួងលោមខ្លួនឯង និងដើម្បីធ្វើការចរចាដោះដូរនូវមកុដនៃអនាគត។ អ្វីដែលគាត់បានស្វែងរក គឺមិនមែនជាសេចក្ដីពិត ឬព្រះជាម្ចាស់ឡើយ ប៉ុន្ដែគឺគ្រាន់តែជាមកុដប៉ុណ្ណោះ។ តើការស្វែងរកដោយបែបនេះត្រឹមត្រូវតាមក្បួនខ្នាតដែរឬទេ? ការជំរុញចិត្តរបស់គាត់ កិច្ចការរបស់គាត់ និងតម្លៃដែលគាត់លះបង់ និងគ្រប់កិច្ចខិតខំប្រឹងប្រែងទាំងអស់របស់គាត់ ត្រូវបានគំនិតរវើរវាយអស្ចារ្យរបស់គាត់ជ្រួតជ្រាបលើទាំងអស់ ហើយគាត់បានធ្វើការទាំងស្រុងទៅតាមបំណងប្រាថ្នាផ្ទាល់ខ្លួនរបស់គាត់។ នៅក្នុងកិច្ចការរបស់គាត់ទាំងមូល គ្មានឆន្ទៈសូម្បីតែបន្ដិចនៅក្នុងតម្លៃដែលគាត់បានលះបង់។ គាត់គ្រាន់តែបានចូលរួមក្នុងការចរចាដោះដូរតែប៉ុណ្ណោះ។ កិច្ចខិតខំប្រឹងប្រែងរបស់គាត់ មិនបានធ្វើឡើងដោយឆន្ទៈ ដើម្បីបំពេញភារកិច្ចរបស់គាត់ឡើយ ប៉ុន្ដែត្រូវបង្កើតឡើងដោយឆន្ទៈដើម្បីសម្រេចនូវគោលបំណងនៃការចរចាដោះដូរប៉ុណ្ណោះ។ តើមានតម្លៃណាមួយចំពោះការខំប្រឹងប្រែងដោយបែបនេះដែរឬទេ? តើនរណានឹងកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់គាត់ដែលមិនបរិសុទ្ធនេះ? តើនរណាដែលមានផលប្រយោជន៍ពីការខំប្រឹងប្រែងនេះ? កិច្ចការរបស់គាត់ពោរពេញទៅដោយសេចក្ដីស្រមៃសម្រាប់អនាគត ពោរពេញទៅដោយផែនការដ៏អស្ចារ្យ និងគ្មានផ្លូវណាដែលអាចបំផ្លាស់បំប្រែ

និស្ស័យមនុស្សបានឡើយ។ ភាគច្រើននៃចិត្តមេត្តារបស់គាត់ គឺជាការធ្វើពុត។ កិច្ចការរបស់គាត់មិនបានផ្ដល់នូវជីវិតឡើយ ប៉ុន្តែជាការបញ្ឆោតដោយសេចក្ដីគួរសម។ វាគឺជាការបង្កើតការចរចាដោះដូរ។ តើកិច្ចការបែបនេះ អាចនាំមនុស្សទៅកាន់ផ្លូវនៃការស្រោចស្រង់ភារកិច្ចដើមរបស់គេត្រឡប់មកវិញបានដោយរបៀបណា?

គ្រប់ការទាំងអស់ ដែលពេត្រុសបានស្វែងរក គឺទៅតាមដួងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ គាត់បានព្យាយាមបំពេញតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ហើយមិនថាមានទុក្ខវេទនា និងការលំបាកនោះទេ គឺគាត់នៅតែសុខចិត្តគាប់បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ដដែល។ គ្មានការស្វែងរករបស់អ្នកជឿលើព្រះជាម្ចាស់ណាម្នាក់ដែលអស្ចារ្យជាងគេនោះឡើយ។ អ្វីដែលប៉ុលបានស្វែងរក ប្រឡាក់ប្រឡូសទៅដោយសាច់ឈាមផ្ទាល់ខ្លួន ដោយសញ្ញាណផ្ទាល់ខ្លួន និងដោយផែនការ ព្រមទាំងគ្រោងការផ្ទាល់ខ្លួនរបស់គាត់។ គាត់គ្មានអ្វីដែលមានលក្ខណៈសម្បត្តិជាសត្តនិករបស់ព្រះជាម្ចាស់ទេ គឺមិនមែនជាមនុស្សម្នាក់ដែលបានព្យាយាមបំពេញបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ឡើយ។ ពេត្រុសបានព្យាយាមចុះចូលនឹងការចាត់ចែងរបស់ព្រះជាម្ចាស់ ហើយបើទោះបីជាកិច្ចការដែលគាត់បានធ្វើមិនអស្ចារ្យក្ដី ក៏ការជំរុញចិត្តនៅពីក្រោយការស្វែងរករបស់គាត់ និងផ្លូវដែលគាត់បានដើរ គឺជាការស្វែងរក និងជាផ្លូវដែលត្រឹមត្រូវដែរ។ បើទោះបីជាគាត់មិនអាចទទួលយកមនុស្សឲ្យបានច្រើនក្ដី ក៏គាត់អាចស្វែងរកផ្លូវនៃសេចក្ដីពិតបានដែរ។ ដោយសារចំណុចនេះ អាចនិយាយបានថា គាត់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាសត្តនិកររបស់ព្រះជាម្ចាស់។ សព្វថ្ងៃនេះ បើទោះជាអ្នកមិនមែនជាបាវបម្រើក្ដី ក៏អ្នកគប្បីអាចបំពេញភារកិច្ចជាសត្តនិកររបស់ព្រះជាម្ចាស់ និងព្យាយាមចុះចូលនឹងការចាត់ចែងគ្រប់យ៉ាងរបស់ព្រះជាម្ចាស់ដែរ។ អ្នកគប្បីអាចស្ដាប់បង្គាប់គ្រប់ការដែលព្រះជាម្ចាស់មានព្រះបន្ទូល និងបទពិសោធនៃទុក្ខលំបាក ព្រមទាំងការបន្សុទ្ធសព្វគ្រប់បែបយ៉ាង ហើយបើទោះបីជាអ្នកអន់ខ្សោយក្ដី ក៏នៅក្នុងដួងចិត្តរបស់អ្នក គប្បីអាចស្រឡាញ់ព្រះជាម្ចាស់បានដដែល។ អស់អ្នកដែលមានទំនួលខុសត្រូវចំពោះជីវិតផ្ទាល់ខ្លួនរបស់ពួកគេ គឺមានឆន្ទៈបំពេញភារកិច្ច

ជាសត្តនិកររបស់ព្រះជាម្ចាស់ ហើយទស្សនៈរបស់មនុស្សអំពីការស្វែងរកបែបនេះ គឺជាទស្សនៈដ៏ត្រឹមត្រូវ។ អ្នកទាំងអស់នេះ គឺជាមនុស្សដែលព្រះជាម្ចាស់ត្រូវការ។ ប្រសិនបើអ្នកធ្វើការងារច្រើន ហើយអ្នកដទៃទទួលបានការបង្រៀនរបស់អ្នក ប៉ុន្តែខ្លួនឯងមិនបានផ្លាស់ប្ដូរ និងមិនបានធ្វើទីបន្ទាល់ណាមួយ ឬមានបទពិសោធពិតប្រាកដនោះការងារបែបនេះនៅចុងបញ្ចប់នៃជីវិតរបស់អ្នក គឺនៅតែគ្មានអ្វីដែលអ្នកបានធ្វើដើម្បីជាទីបន្ទាល់ឡើយ ដូច្នេះ តើអ្នកជាមនុស្សម្នាក់ដែលបានផ្លាស់ប្ដូរមែនទេ? តើអ្នកជាមនុស្សម្នាក់ដែលស្វែងរកសេចក្តីពិតមែនទេ? នៅពេលមួយ ព្រះវិញ្ញាណបរិសុទ្ធបានប្រើអ្នក ប៉ុន្តែនៅពេលដែលទ្រង់បានប្រើអ្នក ទ្រង់បានប្រើចំណែករបស់អ្នកដែលអាចប្រើបានដើម្បីបំពេញកិច្ចការ ហើយទ្រង់មិនបានប្រើចំណែកនៃខ្លួនឯងដែលមិនអាចប្រើប្រាស់បាននោះទេ។ ប្រសិនបើអ្នកបានព្យាយាមដើម្បីផ្លាស់ប្ដូរ នោះអ្នកនឹងត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍នៅចុងបំផុត ក្នុងអំឡុងពេលនៃដំណើរការនៃការប្រើប្រាស់។ ប៉ុន្តែ ព្រះវិញ្ញាណបរិសុទ្ធមិនទទួលខុសត្រូវ ថាតើអ្នកនឹងត្រូវទទួលយកនៅចុងបំផុតទៅដែរឬអត់នោះទេ ហើយកិច្ចការនេះអាស្រ័យលើលក្ខណៈនៃការស្វែងរករបស់អ្នក។ ប្រសិនបើគ្មានការផ្លាស់ប្ដូរនិស្ស័យផ្ទាល់ខ្លួនរបស់អ្នកទេនោះ គឺដោយសារតែទស្សនៈនៃការស្វែងរករបស់អ្នកនោះមិនត្រឹមត្រូវ។ ប្រសិនបើអ្នកមិនត្រូវបានប្រទាននូវរង្វាន់អ្វីទេ នោះវាគឺជាបញ្ហាផ្ទាល់ខ្លួនរបស់អ្នក ហើយដោយសារខ្លួនអ្នកមិនបានប្រតិបត្តិតាមសេចក្តីពិត និងមិនអាចបំពេញតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ហេតុដូច្នេះ គ្មានអ្វីដែលសំខាន់ជាងបទពិសោធផ្ទាល់ខ្លួនរបស់អ្នកឡើយ ហើយគ្មានអ្វីដែលសំខាន់ជាងច្រកចូលផ្ទាល់ខ្លួនរបស់អ្នកឡើយ។ មនុស្សខ្លះនឹងនិយាយថា «ខ្ញុំបានធ្វើកិច្ចការជាច្រើនសម្រាប់ទ្រង់ ហើយបើទោះបីជាខ្ញុំមិនអាចសម្រេចនូវសមិទ្ធផលដែលគួរសាទរក្តី ក៏ខ្ញុំនៅតែបន្តមានការព្យាយាមនៅក្នុងកិច្ចការរបស់ខ្ញុំដដែល។ តើទ្រង់មិនអាចត្រឹមអនុញ្ញាតឲ្យខ្ញុំចូលទៅស្ថានសួគ៌ដើម្បីទទួលទានផ្លែឈើនៃជីវិតទេឬ?» អ្នកត្រូវដឹងថា ខ្ញុំចង់បានមនុស្សប្រភេទណា។ អស់អ្នកដែលមិនបរិសុទ្ធ មិនត្រូវបានអនុញ្ញាតឲ្យចូលក្នុង នគរព្រះឡើយ អស់អ្នកដែលមិនបរិសុទ្ធ

មិនត្រូវបានអនុញ្ញាតឲ្យប្រឡូកប្រឡាក់ទីធ្លាដែលបរិសុទ្ធឡើយ។ បើទោះបីជាអ្នកអាចបានធ្វើកិច្ចការយ៉ាងច្រើនក្ដី និងបានធ្វើការជាច្រើនឆ្នាំមកហើយក្ដី ក៏នៅទីបញ្ចប់ ប្រសិនបើអ្នកនៅតែស្មោកគ្រោកគួរឲ្យស្អប់ខ្ពើម នោះច្បាប់របស់ស្ថានសួគ៌ នឹងមិនអាចទទួលយកបានឡើយ ដែលអ្នកចង់ចូលទៅក្នុងនគររបស់ខ្ញុំនោះ! ចាប់តាំងពីគ្រឹះនៃពិភពលោករហូតមកដល់សព្វថ្ងៃនេះ ខ្ញុំមិនដែលអនុញ្ញាតឲ្យអស់អ្នកណាដែលនិយាយបញ្ចើចបញ្ចើខ្ញុំ បានចូលទៅក្នុងនគររបស់ខ្ញុំដោយងាយឡើយ។ នេះគឺជាក្រឹត្យក្រមរបស់ស្ថានសួគ៌ ហើយគ្មាននរណាម្នាក់អាចបំពានបានឡើយ! អ្នកត្រូវតែស្វែងរកជីវិត។ សព្វថ្ងៃនេះ អស់អ្នកដែលនឹងត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍ គឺជាមនុស្សដូចគ្នានឹងពេត្រុសដែរ៖ ពួកគេគឺជាអ្នក ដែលស្វែងរកការផ្លាស់ប្ដូរនិស្ស័យផ្ទាល់ខ្លួនរបស់ពួកគេ និងជាអ្នកដែលសុខចិត្តធ្វើទីបន្ទាល់អំពីព្រះជាម្ចាស់ និងបំពេញមុខងាររបស់ពួកគេក្នុងនាមជាសត្តនិកររបស់ព្រះជាម្ចាស់។ មានតែមនុស្សបែបនេះទេ ដែលនឹងត្រូវប្រោសឲ្យបានគ្រប់លក្ខណ៍។ ប្រសិនបើអ្នកគ្រាន់តែព្យាយាមដើម្បីទទួលបានរង្វាន់ និងមិនបានស្វែងរកនូវការផ្លាស់ប្ដូរនិស្ស័យជីវិតផ្ទាល់ខ្លួនរបស់អ្នក នោះកិច្ចខិតខំប្រឹងប្រែងទាំងអស់របស់អ្នក នឹងក្លាយជាអសារឥតការ។ នេះគឺជាសេចក្ដីពិតដែលមិនអាចកែប្រែបានឡើយ!

រាប់ចាប់តាំងពីភាពខុសគ្នានៃសារជាតិរបស់ពេត្រុស និងប៉ុល អ្នកគប្បីយល់ថា អស់អ្នកដែលមិនស្វែងរកជីវិត នឹងធ្វើការដោយអសារឥតការ! អ្នកជឿលើព្រះជាម្ចាស់ និងដើរតាមព្រះជាម្ចាស់ ហេតុដូច្នេះ នៅក្នុងដួងចិត្តរបស់អ្នក អ្នកត្រូវតែស្រឡាញ់ព្រះជាម្ចាស់។ អ្នកត្រូវតែកម្ចាត់ចោល នូវនិស្ស័យពុករលួយរបស់អ្នក អ្នកត្រូវតែព្យាយាមបំពេញ តាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ហើយអ្នកត្រូវតែបំពេញភារកិច្ច ក្នុងនាមជាសត្តនិកររបស់ព្រះជាម្ចាស់។ ដោយសារអ្នកជឿ និងដើរតាមព្រះជាម្ចាស់ អ្នកគប្បីថ្វាយអ្វីគ្រប់យ៉ាងដល់ទ្រង់ ហើយមិនគប្បីធ្វើការសម្រេចចិត្ត ឬការទាមទារផ្ទាល់ខ្លួនឡើយ ហើយអ្នកគប្បីសម្រេចឲ្យបាននូវការបំពេញបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ដោយសារអ្នកត្រូវបានបង្កើតមក

អ្នកគប្បីស្ដាប់បង្គាប់ព្រះអម្ចាស់ដែលបានបង្កើតអ្នកមក ដ្បិតអ្នកកើតមកគ្មានអំណាចត្រួតត្រាលើខ្លួនឯង និងគ្មានសមត្ថភាពដើម្បីគ្រប់គ្រងលើវាសនាផ្ទាល់ខ្លួនរបស់អ្នកឡើយ។ ដោយសារអ្នកជាមនុស្សម្នាក់ដែលជឿលើព្រះជាម្ចាស់ អ្នកគប្បីស្វែងរកភាពបរិសុទ្ធ និងការផ្លាស់ប្ដូរ។ ដោយសារអ្នកជាសត្តនិកររបស់ព្រះជាម្ចាស់ អ្នកគប្បីធ្វើតាមភារកិច្ចរបស់អ្នក និងត្រូវរក្សាទីកន្លែងរបស់អ្នក ហើយអ្នកមិនត្រូវប្រព្រឹត្តឲ្យហួសពីភារកិច្ចរបស់អ្នកឡើយ។ នេះគឺមិនមែនដើម្បីឃុំឃាំងអ្នក ឬដើម្បីគាបសង្កត់លើអ្នកតាមរយៈគោលលទ្ធិឡើយ ប៉ុន្តែផ្ទុយទៅវិញ គឺជាផ្លូវដែលអ្នកអាចបំពេញភារកិច្ចរបស់អ្នកបាន ហើយជាផ្លូវដែលអាចសម្រេចបាន (និងគប្បីសម្រេចឲ្យបាន) ដោយអស់អ្នកដែលប្រព្រឹត្តតាមសេចក្ដីសុចរិត។ ប្រសិនបើអ្នកប្រៀបធៀបសារជាតិរបស់ពេត្រុស និងប៉ុល នោះអ្នកនឹងដឹងថាតើអ្នកត្រូវស្វែងរកដោយរបៀបណា។ ក្នុងចំណោមផ្លូវដែលពេត្រុស និងប៉ុលបានដើរ ផ្លូវមួយគឺជាផ្លូវនៃការប្រោសឲ្យគ្រប់លក្ខណ៍ ហើយផ្លូវមួយទៀត គឺជាផ្លូវនៃការផាត់ចោល។ ពេត្រុស និងប៉ុល តំណាងឲ្យផ្លូវពីរខុសគ្នា។ បើទោះបីជាមនុស្សម្នាក់ៗទទួលបានកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធក្ដី ហើយគេម្នាក់ៗបានទទួលនូវការបំភ្លឺ និងការបង្ហាញរបស់ព្រះវិញ្ញាណបរិសុទ្ធក្ដី ក៏គេម្នាក់ៗបានទទួលកិច្ចការដែលបានប្រគល់ទៅឲ្យពួកគេដោយព្រះអម្ចាស់យេស៊ូវដែរ ផលផ្លែដែលកើតចេញពីគេម្នាក់ៗ មិនដូចគ្នានោះទេ៖ គឺម្នាក់បានបង្កើតផលផ្លែពិតប្រាកដ ហើយម្នាក់ទៀតគ្មានឡើយ។ តាមរយៈសារជាតិរបស់ពួកគេ កិច្ចការដែលពួកគេបានធ្វើ ដែលត្រូវបានបង្ហាញឲ្យឃើញពីខាងក្រៅ និងចុងបញ្ចប់របស់ពួកគេ នោះអ្នកគួរដឹងថាផ្លូវមួយណាដែលអ្នកគួរយក ផ្លូវមួយណាដែលអ្នកគួរជ្រើសរើសដើរហើយ។ ពួកគេបានដើរលើផ្លូវពីរដែលខុសគ្នាស្រឡះ។ ប៉ុល និងពេត្រុស ពួកគេគឺជាឧទាហរណ៍ដ៏ល្អបំផុតអំពីផ្លូវនីមួយៗ ដូច្នេះហើយ ចាប់តាំងពីដើមដំបូងមក ពួកគេត្រូវបានលើកយកមកដើម្បីសម្គាល់អំពីផ្លូវទាំងពីរនេះ។ តើអ្វីទៅជាចំណុចគន្លឹះនៃបទពិសោធរបស់ប៉ុល ហើយហេតុអ្វីបានជាគាត់មិនអាចធ្វើវាបាន? តើអ្វីទៅជាចំណុចគន្លឹះនៃបទពិសោធរបស់ពេត្រុស ហើយតើគាត់បានទទួលបទពិសោធនៃការប្រោសឲ្យគ្រប់លក្ខណ៍

ដោយរបៀបណា? ប្រសិនបើអ្នកប្រៀបធៀបអ្វីដែលពួកគេខ្វាយខ្វល់ នោះអ្នកនឹងដឹងថា តើមនុស្សប្រភេទណាដែលព្រះជាម្ចាស់សព្វព្រះហឫទ័យចង់បានអ្វីជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ អ្វីជានិស្ស័យរបស់ព្រះជាម្ចាស់ អ្វីជាប្រភេទមនុស្សដែលនឹងត្រូវប្រោសឲ្យបានគ្រប់លក្ខណ៍នៅទីចុងបំផុត និងថាតើប្រភេទមនុស្សបែបណាដែលមិនត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍។ អ្នកនឹងដឹងថាតើអ្វីជានិស្ស័យរបស់អ្នកដែលត្រូវប្រោសឲ្យគ្រប់លក្ខណ៍ និងអ្វីជានិស្ស័យរបស់អស់អ្នកដែលនឹងមិនត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍។ បញ្ហាទាំងអស់នេះអំពីសារជាតិអាចមើលឃើញបាននៅក្នុងបទពិសោធរបស់ពេត្រុស និងប៉ុល។ ព្រះជាម្ចាស់បានបង្កើតរបស់សព្វសារពើ ហេតុដូច្នេះ ទ្រង់បានបង្កើតរបស់សព្វសារពើ ដែលស្ថិតនៅក្រោមអំណាចត្រួតត្រារបស់ទ្រង់ និងចុះចូលចំពោះអំណាចត្រួតត្រារបស់ទ្រង់ ហើយទ្រង់នឹងបញ្ជាលើរបស់សព្វសារពើ ដើម្បីឲ្យរបស់សព្វសារពើទាំងនោះ ស្ថិតនៅក្នុងព្រះហស្តរបស់ទ្រង់។ របស់សព្វសារពើដែលព្រះបានបង្កើតមក រួមទាំងសត្វ រុក្ខជាតិ មនុស្សជាតិ ភ្នំ ទន្លេ និងបឹងបួរ គឺទាំងអស់នេះត្រូវស្ថិតនៅក្រោមអំណាចត្រួតត្រារបស់ទ្រង់។ របស់សព្វសារពើនៅលើផ្ទៃមេឃ និងនៅលើដី ត្រូវតែមកនៅក្រោមអំណាចត្រួតត្រារបស់ទ្រង់។ ពួកគេមិនអាចមានជម្រើសអ្វីផ្សេងឡើយ ហើយត្រូវតែចុះចូលចំពោះការចាត់ចែងរបស់ទ្រង់គ្រប់យ៉ាង។ នេះគឺជាបញ្ញត្តិរបស់ព្រះជាម្ចាស់ ហើយវាគឺជាសិទ្ធិអំណាចរបស់ព្រះជាម្ចាស់។ ព្រះជាម្ចាស់ បញ្ជាលើអ្វីៗគ្រប់យ៉ាង និងរៀបចំហើយចាត់ថ្នាក់របស់សព្វសារពើ ដោយចាត់ថ្នាក់របស់នីមួយៗទៅតាមប្រភេទរបស់វា និងបែងចែងតួនាទីរបស់ពួកគេ ស្របទៅតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។ មិនថាមានអ្វីដែលធំមហិមាប៉ុនណានោះទេ គឺគ្មានអ្វីដែលអាចលើសព្រះជាម្ចាស់បានឡើយ របស់សព្វសារពើទាំងអស់ត្រូវបម្រើដល់មនុស្សជាតិដែលព្រះជាម្ចាស់បានបង្កើតមក និងគ្មានអ្វីដែលហ៊ានមិនស្ដាប់បង្គាប់ព្រះជាម្ចាស់ ឬទាមទារអ្វីពីព្រះជាម្ចាស់ឡើយ។ ហេតុនេះ ក្នុងនាមជាសត្តនិកររបស់ព្រះជាម្ចាស់ មនុស្សក៏ត្រូវបំពេញភារកិច្ចរបស់មនុស្សដែរ។ មិនថាគេជាពួកចៅហ្វាយ ឬជាអ្នកមើលថែគ្រប់ការ

ទាំងអស់ មិនថាឋានៈរបស់គេខ្ពស់ប៉ុនណាក្នុងចំណោមមនុស្សទេ ក៏គេនៅតែជាមនុស្សតូចទាប ដែលស្ថិតនៅក្រោមអំណាចត្រួតត្រារបស់ព្រះជាម្ចាស់ដដែល ហើយគេគ្មានអ្វីលើសពីមនុស្សដែលគ្មានសារៈសំខាន់ដែលជាសត្តនិកររបស់ព្រះជាម្ចាស់នោះឡើយ ហើយគេនឹងមិនអាចខ្ពស់ជាងព្រះជាម្ចាស់បានឡើយ។ ក្នុងនាមជាសត្តនិកររបស់ព្រះជាម្ចាស់ មនុស្សគប្បីព្យាយាមបំពេញភារកិច្ចក្នុងនាមជាសត្តនិកររបស់ព្រះជាម្ចាស់ និងព្យាយាមស្រឡាញ់ព្រះជាម្ចាស់ ដោយគ្មានបង្កើតជម្រើសអ្វីផ្សេងទៀតឡើយ ដ្បិតព្រះជាម្ចាស់មានតម្លៃសមនឹងទទួលបាន សេចក្ដីស្រឡាញ់របស់មនុស្ស។ អស់អ្នកដែលព្យាយាមស្រឡាញ់ព្រះជាម្ចាស់ មិនគួរណាត្រូវស្វែងរកប្រយោជន៍ផ្ទាល់ខ្លួន ឬស្វែងរកអ្វីដែលពួកគេទន្ទឹងរង់ចាំផ្ទាល់ខ្លួនជាយូរមកហើយនោះដែរ។ នេះគឺជាមធ្យោបាយនៃការស្វែងរកដ៏ត្រឹមត្រូវ។ ប្រសិនបើអ្វីដែលអ្នកស្វែងរក គឺជាសេចក្ដីពិតប្រសិនបើអ្វីដែលអ្នកប្រតិបត្តិតាម គឺជាសេចក្ដីពិត ហើយប្រសិនបើអ្នកបានទទួលនូវការផ្លាស់ប្ដូរនិស្ស័យរបស់អ្នក នោះផ្លូវដែលអ្នកត្រូវដើរ គឺជាផ្លូវដ៏ត្រឹមត្រូវហើយ។ ប្រសិនបើអ្វីដែលអ្នកស្វែងរក គឺជាព្រះពរខាងសាច់ឈាម ហើយអ្វីដែលអ្នកប្រតិបត្តិតាម គឺជាសេចក្ដីពិតនៃសញ្ញាណផ្ទាល់ខ្លួនរបស់អ្នក ហើយប្រសិនបើគ្មានការផ្លាស់ប្ដូរនិស្ស័យរបស់អ្នក ហើយអ្នករាល់គ្នាសុទ្ធតែមិនស្ដាប់បង្គាប់ព្រះជាម្ចាស់នៅខាងសាច់ឈាម ព្រមទាំងបន្តរស់នៅក្នុងភាពស្រពេចស្រពិល នោះអ្វីដែលអ្នកស្វែងរកច្បាស់ណាស់ នឹងនាំអ្នកទៅកាន់ស្ថាននរក ដ្បិតផ្លូវដែលអ្នកដើរ គឺជាផ្លូវបរាជ័យ។ អ្នកនឹងត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍ ឬត្រូវផាត់ចោល ឬអត់នោះ គឺអាស្រ័យលើការស្វែងរករបស់អ្នកផ្ទាល់ ដែលនេះក៏អាចនិយាយបានថា ជោគជ័យ ឬបរាជ័យ គឺអាស្រ័យលើផ្លូវដែលមនុស្សដើរ។

# កិច្ចការរបស់ព្រះជាម្ចាស់ និងកិច្ចការរបស់មនុស្ស

តើកិច្ចការរបស់មនុស្សច្រើនប៉ុនណាជាកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ហើយបទពិសោធរបស់មនុស្សច្រើនប៉ុនណា? អាចនិយាយបានថា មនុស្សនៅមិនទាន់យល់ពីសំណួរទាំងនេះ និងហេតុផលដែលពួកគេមិនយល់ពីគោលការណ៍នៃកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ។ ពេលខ្ញុំនិយាយថា «កិច្ចការរបស់មនុស្ស» ពិតណាស់ ខ្ញុំចង់សំដៅដល់កិច្ចការរបស់មនុស្សដែលមានកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ឬមនុស្សដែលព្រះវិញ្ញាណបរិសុទ្ធប្រើ។ ខ្ញុំមិនមែនសំដៅលើកិច្ចការដែលកើតមកពីឆន្ទៈរបស់មនុស្សទេ ប៉ុន្តែសំដៅលើកិច្ចការរបស់ពួកសាវ័កអ្នកបម្រើការងារ ឬបងប្អូនប្រុសស្រីទូទៅ ដែលស្ថិតនៅក្នុងវិសាលភាពនៃកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ។ «កិច្ចការរបស់មនុស្ស» ក្នុងអត្ថបទនេះ មិនមែនសំដៅលើកិច្ចការរបស់ព្រះដែលយកកំណើតជាមនុស្សទេ ប៉ុន្តែសំដៅលើវិសាលភាព និងគោលការណ៍នៃកិច្ចការដែលព្រះវិញ្ញាណអនុវត្តលើមនុស្ស។ ខណៈពេលដែលគោលការណ៍ទាំងនេះ គឺជាគោលការណ៍ និងជាវិសាលភាពនៃកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ នោះគោលការណ៍ទាំងអស់នេះមិនដូចគោលការណ៍ និងវិសាលភាពនៃកិច្ចការរបស់ព្រះដែលយកកំណើតជាមនុស្សទេ។ កិច្ចការរបស់មនុស្សមាននូវលក្ខណៈ និងគោលការណ៍របស់មនុស្ស ឯកិច្ចការរបស់ព្រះជាម្ចាស់មានលក្ខណៈ និងមានគោលការណ៍របស់ព្រះជាម្ចាស់។

កិច្ចការនៅក្នុងលំហូររបស់ព្រះវិញ្ញាណបរិសុទ្ធ បើទោះបីជា កិច្ចការរបស់ព្រះជាម្ចាស់ផ្ទាល់ ឬក៏ជាកិច្ចការដែលទ្រង់ប្រើមនុស្សឲ្យធ្វើ សុទ្ធតែជាកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ។ លក្ខណៈសំខាន់របស់ព្រះជាម្ចាស់ គឺព្រះអង្គផ្ទាល់ជាវិញ្ញាណដែលអាចហៅថា ព្រះវិញ្ញាណបរិសុទ្ធ ឬវិញ្ញាណដ៏ខ្លាំងក្លាទាំងប្រាំពីរ។ ជារួមទាំងអស់នេះសុទ្ធតែជាព្រះវិញ្ញាណនៃព្រះ បើទោះបីជាព្រះវិញ្ញាណនៃព្រះជាម្ចាស់ មានឈ្មោះផ្សេងៗពីគ្នាក្នុងយុគសម័យខុសៗគ្នាក៏ដោយ។ លក្ខណៈរបស់ព្រះវិញ្ញាណទាំងនេះគឺដូចគ្នាដដែល។ ដូច្នេះ កិច្ចការរបស់ព្រះជាម្ចាស់ផ្ទាល់ ក៏ជាកិច្ចការរបស់ព្រះវិញ្ញាណ

បរិសុទ្ធដែរ ចំណែកឯកិច្ចការរបស់ព្រះដែលយកកំណើតជាសាច់ឈាម ក៏មិនខុស ព្រះវិញ្ញាណបរិសុទ្ធដែលកំពុងធ្វើការនោះដែរ។ កិច្ចការរបស់មនុស្សដែលព្រះជាម្ចាស់ប្រើ ក៏ជាកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធដែរ។ ដោយឡែកកិច្ចការរបស់ព្រះជាម្ចាស់ ជាការស្ដែងបង្ហាញចេញមកទាំងស្រុងរបស់ព្រះវិញ្ញាណបរិសុទ្ធ ចំណែកឯកិច្ចការរបស់មនុស្សដែលព្រះជាម្ចាស់កំពុងប្រើវិញ មានចម្រុះទាំងកិច្ចការរបស់មនុស្ស និងពុំមែនជាការបង្ហាញផ្ទាល់របស់ព្រះវិញ្ញាណបរិសុទ្ធ ក៏រឹតតែមិនមែនជាការបង្ហាញចេញមកទាំងអស់របស់ទ្រង់ដែរ នេះជាការពិតទាំងស្រុង។ កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ មានភាពខុសគ្នា និងមិនត្រូវបានកំណត់ ដោយលក្ខខណ្ឌណាទាំងអស់។ កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ មានភាពខុសគ្នានៅក្នុងមនុស្សខុសៗគ្នា។ លក្ខណៈនេះស្ដែងចេញនូវលក្ខណៈខុសគ្នា ហើយខុសពីគ្នាទៅតាមសម័យកាល និងខុសគ្នាទៅតាមប្រទេស។ ពិតណាស់ បើទោះបីជាព្រះវិញ្ញាណបរិសុទ្ធធ្វើការតាមវិធីខុសៗគ្នាជាច្រើន និងយោងទៅតាមគោលការណ៍ច្រើនក្ដី មិនថាកិច្ចការនោះត្រូវបានធ្វើឡើងដោយវិធីណា ឬធ្វើទៅលើមនុស្សបែបណាក៏ដោយ ក៏សារជាតិនៃកិច្ចការនេះខុសៗគ្នាជានិច្ចដែរ។ កិច្ចការទាំងអស់ដែលបានធ្វើចំពោះមនុស្សខុសៗគ្នា សុទ្ធតែមានគោលការណ៍របស់វា ហើយគោលការណ៍ទាំងអស់នោះគឺសុទ្ធតែអាចតំណាងឲ្យសារជាតិនៃគោលបំណងកិច្ចការនោះ។ ដោយសារកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធគឺជាកិច្ចការ ដែលមានវិសាលភាពជាក់លាក់ ហើយមានវិធានការច្រើនគួរសម។ កិច្ចការដែលត្រូវបានធ្វើឡើងនៅក្នុងសាច់ឈាម របស់ព្រះដែលយកកំណើតជាមនុស្ស មិនដូចគ្នានឹងកិច្ចការដែលត្រូវបានធ្វើចំពោះមនុស្សឡើយ ហើយកិច្ចការនេះក៏ខុសគ្នាតាមគុណសម្បត្តិនៃមនុស្សដែលកិច្ចការនេះបានធ្វើចំពោះ។ កិច្ចការដែលត្រូវបានធ្វើនៅក្នុងសាច់ឈាមនៃព្រះដែលយកកំណើតជាមនុស្ស មិនត្រូវបានធ្វើចំពោះមនុស្សទេ ហើយក៏មិនដូចគ្នានឹងកិច្ចការដែលត្រូវបានធ្វើចំពោះមនុស្សដែរ។ និយាយឲ្យខ្លី ទោះបីជាកិច្ចការនោះត្រូវបានធ្វើឡើងច្រើនប៉ុនណាក៏កិច្ចការដែលត្រូវបានធ្វើឡើងក្នុងគោលបំណងផ្សេងគ្នា មិនដូចគ្នាសោះ ហើយគោលការណ៍ដែល

ព្រះអង្គធ្វើការ ក៏ខុសគ្នាតាមសភាព និងលក្ខណៈខុសៗគ្នានៃមនុស្សដែលទទួលនូវឥទ្ធិពលពីកិច្ចការនោះដែរ។ ព្រះវិញ្ញាណបរិសុទ្ធធ្វើការចំពោះមនុស្សខុសគ្នា ផ្អែកលើចរិតពិតពីកំណើតរបស់គេ និងមិនតម្រូវឲ្យគេមានលើសពីចរិតពិតឡើយ ហើយទ្រង់ក៏មិនធ្វើការចំពោះគេ លើសលក្ខណៈនៃកិរិយាពីកំណើតរបស់គេដែរ។ ហេតុនេះ កិច្ចការដែលព្រះវិញ្ញាណបរិសុទ្ធធ្វើចំពោះមនុស្ស ជួយឲ្យពួកគេអាចមើលឃើញពីសារជាតិ នៃគោលបំណងកិច្ចការនោះ។ លក្ខណៈពីកំណើតរបស់មនុស្ស មិនប្រែប្រួលឡើយ។ លក្ខណៈពីកំណើតរបស់គេ មានកម្រិត។ ព្រះវិញ្ញាណបរិសុទ្ធ ប្រើមនុស្ស ឬធ្វើការចំពោះពួកគេ ស្របទៅតាមការកំណត់នៃលក្ខណៈរបស់គេ ដើម្បីឲ្យពួកគេអាចទទួលបាននូវអត្ថប្រយោជន៍ពីការនេះ។ ពេលព្រះវិញ្ញាណបរិសុទ្ធធ្វើការលើមនុស្សដែលព្រះកំពុងប្រើទេពកោសល្យ ហើយនិងលក្ខណៈពីកំណើតរបស់គេក៏ត្រូវបញ្ចេញមកឲ្យឃើញមិនមែនត្រូវបង្ខាំងទុកនោះឡើយ។ លក្ខណៈពីកំណើតរបស់គេ ត្រូវបានប្រើប្រាស់ក្នុងការបម្រើនូវកិច្ចការរបស់ព្រះ។ អាចនិយាយបានថា ព្រះអង្គប្រើប្រាស់ចំណែកដែលអាចប្រើបានរបស់មនុស្សលោក នៅក្នុងកិច្ចការរបស់ទ្រង់ ដើម្បីសម្រេចនូវលទ្ធផលនៅក្នុងកិច្ចការនោះ។ ផ្ទុយមកវិញ កិច្ចការដែលបានធ្វើរួចនៅក្នុងរូបកាយសាច់ឈាមនៃព្រះដែលយកកំណើតជាមនុស្ស បង្ហាញឲ្យឃើញពីកិច្ចការនៃព្រះវិញ្ញាណដោយផ្ទាល់ ហើយមិនត្រូវបានបង្អាក់ដោយគំនិតនិងតម្រិះរបស់មនុស្សលោកនោះឡើយ ក៏ពុំមានអំណោយទាន បទពិសោធ ឬនិស្ស័យកំណើតរបស់មនុស្ស អាចឈានទៅសម្រេចកិច្ចការនោះបានដែរ។ កិច្ចការច្រើនអនេករបស់ព្រះវិញ្ញាណ គឺតម្រូវមកដើម្បីផ្ដល់ប្រយោជន៍ និងដើម្បីបង្រៀនមនុស្ស។ ដោយឡែកមនុស្សខ្លះអាចត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍ តែអ្នកខ្លះវិញ ពុំធ្វើតាមលក្ខខណ្ឌសម្រាប់ឲ្យបានគ្រប់លក្ខណ៍ឡើយ មានន័យថា ពួកគេមិនអាចបានសង្គ្រោះឡើយ ហើយបើទោះបីជាពួកគេ ប្រហែលជាធ្លាប់មានកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធក៏ដោយ ក៏ចុងក្រោយពួកគេនឹងត្រូវផាត់ចោលដែរ។ នេះមានន័យថា ទោះបីជាកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ គឺដើម្បីបង្រៀនមនុស្សក៏ពិតមែន ក៏ពុំមាននរណាអាច

ពោលថា អស់អ្នកណាដែលធ្លាប់មានកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ គេនឹងត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍ទាំងស្រុងនោះឡើយ ដ្បិតផ្លូវដែលមនុស្សជាច្រើនដើរតាម ក្នុងការព្យាយាមឲ្យបានរបស់គេនោះមិនមែនជាផ្លូវនៃការទទួលបាននូវការប្រោសឲ្យបានគ្រប់លក្ខណ៍នោះទេ។ ពួកគេមានកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ បែបឯកតោភាគី ប៉ុន្ដែមិនមានការរួមចំណែកពីមនុស្ស ដោយមិនលម្អៀង និងគ្មានការព្យាយាមឲ្យបានដ៏ត្រឹមត្រូវរបស់មនុស្សនោះឡើយ។ ហេតុនេះ កិច្ចការរបស់ព្រះវិញ្ញាណដែលស្ថិតលើមនុស្សទាំងនោះ គឺមកបម្រើអស់អ្នកដែលកំពុងត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍។ មនុស្សមិនអាចមើលឃើញកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធដោយផ្ទាល់នោះឡើយ ចំណែកឯមនុស្សខ្លួនឯងផ្ទាល់ទៀតសោត ក៏ពុំអាចប៉ះពាល់កិច្ចនោះដោយផ្ទាល់បានដែរ។ ទាល់តែមនុស្ស ដែលមានអំណោយទានក្នុងកិច្ចការនោះ ទើបអាចស្ដែងឲ្យឃើញកិច្ចការនោះបាន មានន័យថាកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ត្រូវបានប្រទានដល់អ្នកដើរតាមទ្រង់ តាមរយៈការបង្ហាញចេញមករបស់គេ។

កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធត្រូវសម្រេច និងបញ្ចប់ជាបរិបូរ តាមរយៈប្រភេទមនុស្ស និងលក្ខខណ្ឌខុសៗគ្នាជាច្រើន។ ថ្វីបើកិច្ចការរបស់ព្រះដែលមកយកកំណើតជាសាច់ឈាម អាចតំណាងឲ្យកិច្ចការនៃយុគសម័យមួយទាំងមូល និងអាចតំណាងឲ្យច្រកចូលដែល មនុស្សចូលទៅកាន់យុគសម័យទាំងមូល ក៏កិច្ចការស្ដីអំពីសេចក្ដីពិស្ដារនៃច្រកចូលរបស់មនុស្ស នៅតែត្រូវធ្វើឡើងដោយមនុស្សដែលត្រូវបានប្រើដោយព្រះវិញ្ញាណបរិសុទ្ធ មិនមែនដោយព្រះដែលយកកំណើតជាមនុស្សឡើយ។ ដូចនេះ កិច្ចការរបស់ព្រះជាម្ចាស់ ឬព័ន្ធកិច្ចរបស់ព្រះជាម្ចាស់ផ្ទាល់ គឺជាកិច្ចការរបស់ព្រះដែលយកកំណើតជាមនុស្ស ដ្បិតមនុស្សមិនអាចធ្វើជំនួសទ្រង់បានឡើយ។ កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធបានបញ្ចប់សព្វគ្រប់ តាមរយៈមនុស្សជាច្រើនប្រភេទខុសៗគ្នា គ្មានមនុស្សណាម្នាក់អាចសម្រេចកិច្ចការនេះទាំងស្រុង តែម្នាក់ឯងនោះឡើយ ហើយក៏គ្មានមនុស្សណាម្នាក់ អាចស្ដែងចេញនូវកិច្ចការនេះទាំងស្រុងម្នាក់ឯងនោះដែរ។ អស់អ្នកដែលដឹកនាំពួកជំនុំ ក៏មិនអាចធ្វើជាតំណាងឲ្យកិច្ចការរបស់ព្រះវិញ្ញាណ

បរិសុទ្ធបានទាំងស្រុងដែរ។ ពួកគេ អាចធ្វើបានត្រឹមកិច្ចការដឹកនាំខ្លះៗប៉ុណ្ណោះ។ ហេតុនេះកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធអាចត្រូវចែកចេញជាបីផ្នែកគឺ កិច្ចការរបស់ព្រះជាម្ចាស់ផ្ទាល់ កិច្ចការរបស់មនុស្សដែលព្រះប្រើ និងកិច្ចការរបស់មនុស្សដែលនៅក្នុងលំហូររបស់ព្រះវិញ្ញាណបរិសុទ្ធ។ កិច្ចការរបស់ព្រះជាម្ចាស់ផ្ទាល់ គឺដើម្បីដឹកនាំយុគសម័យទាំងមូល។ កិច្ចការរបស់មនុស្សដែលព្រះទ្រង់ប្រើប្រាស់ គឺដឹកនាំមនុស្សទាំងអស់ដែលដើរតាមព្រះជាម្ចាស់ និងមនុស្សដែលសហការជាមួយនឹងកិច្ចការរបស់ព្រះជាម្ចាស់ ដោយព្រះចាត់ឲ្យទៅ ឬក៏ទទួលបញ្ញើបេសកកម្មពីព្រះជាម្ចាស់ បន្ទាប់ពីព្រះអង្គបានធ្វើកិច្ចការរបស់ទ្រង់រួច។ កិច្ចការដែលធ្វើឡើងដោយព្រះវិញ្ញាណបរិសុទ្ធចំពោះមនុស្សដែលស្ថិតក្នុងលំហូរនេះ គឺដើម្បីរក្សាការគ្រប់គ្រងទាំងមូលរបស់ព្រះអង្គ និងរក្សាទីបន្ទាល់ទ្រង់ ទាំងកំពុងប្រោសមនុស្សដែលអាចប្រោសឲ្យបានគ្រប់លក្ខណ៍ឲ្យទៅជាគ្រប់លក្ខណ៍ក្នុងពេលជាមួយគ្នា។ កិច្ចការទាំងបីផ្នែកនេះរួមគ្នា គឺជាកិច្ចការដ៏ពេញលេញរបស់ព្រះវិញ្ញាណបរិសុទ្ធ ប៉ុន្តែប្រសិនបើគ្មានកិច្ចការរបស់ព្រះជាម្ចាស់ផ្ទាល់ទេ នោះកិច្ចការគ្រប់គ្រងនឹងនៅទ្រឹងទាំងស្រុងតែម្តង។ កិច្ចការរបស់ព្រះជាម្ចាស់ផ្ទាល់មានការពាក់ព័ន្ធនឹងកិច្ចការរបស់មនុស្សលោកទាំងអស់ ហើយក៏តំណាងឲ្យកិច្ចការនៃយុគសម័យទាំងមូលដែរ មានន័យថា កិច្ចការរបស់ព្រះជាម្ចាស់ផ្ទាល់តំណាងឲ្យថាមពល និងទំនោរនៃកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ចំណែកកិច្ចការរបស់ពួកសាវ័ក កើតក្រោយពីកិច្ចការរបស់ព្រះជាម្ចាស់ផ្ទាល់ រួចបន្តពីកិច្ចការរបស់ទ្រង់ ហើយកិច្ចការរបស់សាវ័កមិនបានដឹកនាំយុគសម័យទេ ក៏មិនតំណាងឲ្យទំនោរនៃកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធក្នុងយុគសម័យទាំងមូលដែរ។ ពួកគេធ្វើបានត្រឹមកិច្ចការដែលមនុស្សគួរធ្វើ គ្មានអ្វីពាក់ព័ន្ធកិច្ចការគ្រប់គ្រងទាល់តែសោះ។ កិច្ចការដែលព្រះជាម្ចាស់ធ្វើដោយផ្ទាល់ គឺជាគម្រោងមួយក្នុង កិច្ចការគ្រប់គ្រង។ កិច្ចការរបស់មនុស្ស គឺគ្រាន់តែជាកតព្វកិច្ចមួយ ដែលមនុស្សដែលត្រូវព្រះប្រើដែលត្រូវបំពេញហើយគ្មានអ្វីពាក់ព័ន្ធនឹងកិច្ចការគ្រប់គ្រងនោះឡើយ។ បើទោះបីជាការពិតដែលថាកិច្ចការទាំងពីរនេះ សុទ្ធតែជាកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធក៏ដោយ ក៏រវាង

កិច្ចការរបស់ព្រះជាម្ចាស់ និងកិច្ចការរបស់មនុស្ស មាននូវលក្ខណៈខុសគ្នាដ៏សំខាន់ជាច្រើន ដោយសារតែភាពខុសគ្នាខាងអត្តសញ្ញាណ និងសេចក្តីតំណាងនៃកិច្ចការ។ ជាងនេះទៅទៀត វិសាលភាពនៃកិច្ចការដែលត្រូវបានធ្វើឡើងដោយព្រះវិញ្ញាណបរិសុទ្ធ ខុសគ្នាតាមកម្មវត្ថុដែលមានអត្តសញ្ញាណខុសៗគ្នា។ ទាំងនេះ សុទ្ធតែជាគោលការណ៍ និងទំហំនៃកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ។

កិច្ចការរបស់មនុស្សប្រាប់ឲ្យដឹង អំពីបទពិសោធ និងភាពជាមនុស្សរបស់គេ។ អ្វីៗដែលមនុស្សផ្ដល់ជូន និងកិច្ចការដែលគេធ្វើ គឺតំណាងរូបគេតែម្ដង។ តម្រិះរបស់មនុស្ស ការបកស្រាយរកហេតុផលរបស់មនុស្ស កត្តវិទ្យារបស់មនុស្ស និងការស្រមើស្រមៃសម្បូរបែប សុទ្ធតែរាប់បញ្ចូលនៅក្នុងកិច្ចការរបស់គេទាំងអស់។ បទពិសោធរបស់មនុស្ស អាចប្រាប់អំពីកិច្ចការរបស់គេជាពិសេស ហើយបទពិសោធរបស់បុគ្គលម្នាក់ ក៏ក្លាយជាធាតុផ្សំនៃកិច្ចការរបស់គេ។ កិច្ចការរបស់មនុស្សអាចស្ដែងចេញនូវបទពិសោធរបស់គេ។ ពេលមនុស្សខ្លះ ទទួលបទពិសោធអវិជ្ជមាន នោះសម្ដីភាគច្រើននៃការរួមប្រកបរបស់គេ ក៏នឹងមានចំណុចអវិជ្ជមានដែរ។ ប្រសិនបើបទ ពិសោធមួយគ្រារបស់គេ មានលក្ខណៈវិជ្ជមាន នោះពួកគេក៏មានផ្លូវមួយជាពិសេសក្នុងចំណុចវិជ្ជមាន ការប្រកបគ្នារបស់គេ ក៏ប្រកបដោយការលើកទឹកចិត្ត ហើយមនុស្សក៏អាចទទួលបានការផ្ដល់ជូនដ៏វិជ្ជមានពីពួកគេដែរ។ ប្រសិនបើអ្នកបម្រើការម្នាក់ទៅជាអវិជ្ជមានមួយគ្រា នោះការប្រកបគ្នារបស់គេ នឹងបន្តមានចំណុចអវិជ្ជមានរហូត។ ការប្រកបគ្នាបែបនេះ មានតែការបាក់ទឹកចិត្ត ហើយអ្នកដទៃក៏ទៅជាបាក់ទឹកចិត្តទាំងមិនដឹងខ្លួនបន្ទាប់ពីបាន ចូលរួមប្រកបជាមួយគេ។ ស្ថានភាពរបស់អ្នកដើរតាម គឺប្រែប្រួលទៅតាមស្ថានភាពរបស់អ្នកដឹកនាំ។ អ្នកធ្វើការមានស្ថានភាពក្នុងចិត្តយ៉ាងណា គេនឹងស្ដែងចេញស្ថានភាពនោះមក រីឯកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធរមែងប្រែប្រួលតាមសភាពរបស់មនុស្ស។ ព្រះអង្គធ្វើ ការទៅតាមបទពិសោធរបស់មនុស្ស ហើយមិនបង្ខំពួកគេទេ ប៉ុន្ដែទ្រង់តម្រូវពីមនុស្ស ទៅតាមលំហូរទូទៅនៃបទពិសោធរបស់គេ។ មានន័យថា ការប្រកបគ្នារបស់មនុស្ស ខុសគ្នាពីព្រះបន្ទូលរបស់ព្រះជាម្ចាស់។ អ្វីដែល

មនុស្សប្រកបគ្នា បង្ហាញឲ្យឃើញនូវបទពិសោធ និងតម្រិះរបស់បុគ្គលម្នាក់ៗ ទាំងស្ដែងពីបទពិសោធ និងតម្រិះរបស់គេចំពោះមូលដ្ឋានកិច្ចការរបស់ព្រះទៀតផង។ ទំនួលខុសត្រូវរបស់គេ គឺត្រូវស្វែងរកនូវអ្វីដែលពួកគេគួរអនុវត្ត ឬចូលទៅក្នុងសេចក្ដីនោះ បន្ទាប់ពីព្រះជាម្ចាស់ធ្វើការ ឬមានបន្ទូលរួចយកសេចក្ដីទាំងនេះ ទៅប្រាប់អ្នកដើរតាម។ ដូច្នេះ កិច្ចការរបស់មនុស្សតំណាងឲ្យច្រកទ្វារនិងការអនុវត្តរបស់គេ។ ពិតណាស់ កិច្ចការនេះ លាយបញ្ចូលគ្នាទាំងមេរៀន និងបទពិសោធរបស់មនុស្ស ឬគំនិតខ្លះរបស់គេ។ ដោយឡែក ទោះបីជាព្រះវិញ្ញាណបរិសុទ្ធធ្វើការ ទាំងចំពោះមនុស្ស ឬនៅក្នុងព្រះដែលយកកំណើតជាសាច់ឈាម ក៏អ្នកបម្រើការអាចបង្ហាញឲ្យដឹងថា កិច្ចការនោះជាអ្វីដែរ។ បើទោះបីព្រះ វិញ្ញាណបរិសុទ្ធជាអ្នកធ្វើកិច្ចការក៏ដោយ ក៏កិច្ចការនេះត្រូវបានសង់លើគ្រឹះនៃអត្តសញ្ញាណដែលមនុស្សមានពីកំណើត ពីព្រោះព្រះវិញ្ញាណបរិសុទ្ធ មិនធ្វើការដោយគ្មានមូលដ្ឋានគ្រឹះឡើយ។ ម្យ៉ាងទៀត គឺកិច្ចការនេះមិនមែនកើតមានឡើងដោយទទេសូន្យ ប៉ុន្តែវាមែងត្រូវបានធ្វើឡើងស្របតាមស្ថានការណ៍ជាក់ស្ដែង និងលក្ខខណ្ឌពិត។ គឺមានតែតាមវិធីនេះទេ ទើបនិស្ស័យរបស់មនុស្សត្រូវបានបំផ្លាស់បំប្រែ ហើយសញ្ញាណនិងគំនិតចាស់គំរិលរបស់គេត្រូវបានផ្លាស់ប្រែ។ អ្វីដែលមនុស្សស្ដែងចេញមក ជាអ្វីដែលគេមើលឃើញ អ្វីដែលគេទទួលជាបទពិសោធ និងជាអ្វីដែលគេអាចស្រមៃដល់ ហើយក៏ជាអ្វីដែលគំនិតរបស់មនុស្សអាចគិតយល់ដែរ បើទោះការនេះគឺជាគោលលទ្ធិ ឬមួយជាសញ្ញាណក៏ដោយ។ កិច្ចការរបស់មនុស្ស ពុំអាចលើសពីទំហំបទពិសោធរបស់គេ ក៏មិនមែនជាអ្វីដែលមនុស្សមើលឃើញ មិនមែនជាអ្វីដែលមនុស្សអាចស្រមើស្រមៃ ឬគិតស្មានដល់ បើទោះបីជាកិច្ចការនោះធំយ៉ាងណាក៏ដោយ។ គ្រប់យ៉ាងដែលព្រះជាម្ចាស់ស្ដែងចេញមកឲ្យឃើញ គឺជាអង្គទ្រង់ផ្ទាល់តែម្ដង ហើយការនេះមនុស្សមិនអាចសម្រេចបាននោះឡើយ ដ្បិតវាលើសពីការគិតរបស់មនុស្ស។ ទ្រង់បង្ហាញឲ្យឃើញអំពីកិច្ចការដឹកនាំមនុស្សលោកទាំងអស់ ហើយកិច្ចការនេះមិនពាក់ព័ន្ធនឹងសេចក្ដីពិស្ដារនៃបទពិសោធរបស់មនុស្សទេ ប៉ុន្តែវាពាក់ព័ន្ធនឹងការគ្រប់គ្រងរបស់ទ្រង់ផ្ទាល់វិញ។ អ្វីដែលមនុស្សបង្ហាញឲ្យ

ឃើញ គឺជាបទពិសោធរបស់គេ រីឯអ្វីដែលព្រះជាម្ចាស់បង្ហាញឲ្យឃើញ គឺជាលក្ខណៈរបស់ទ្រង់ដែលជានិស្ស័យដែលទ្រង់មានរហូតមក ហើយវាលើសពីការយល់របស់មនុស្សផង។ បទពិសោធរបស់មនុស្ស គឺជាការយល់ឃើញនិងចំណេះដឹងដែលគេទទួលបាន ផ្អែកទៅលើមូលដ្ឋាននៃការស្ដែងឲ្យឃើញអំពីលក្ខណៈរបស់ព្រះជាម្ចាស់វិញ។ តម្រិះនិងចំណេះដឹងទាំងនេះ ត្រូវបានហៅថាជាលក្ខណៈរបស់មនុស្ស និងជាគ្រឹះនៃការស្ដែងចេញឲ្យឃើញនូវនិស្ស័យពីកំណើត និងគុណសម្បត្តិពីកំណើតរបស់មនុស្ស ហេតុនេះទើបទើបចំណុចទាំងនេះត្រូវបានហៅថាជាលក្ខណៈរបស់មនុស្ស។ មនុស្សអាចប្រកបនឹងអ្វីដែលគេទទួលជាបទពិសោធ និងមើលឃើញ។ គ្មាននរណាអាចប្រកបនឹងអ្វីដែលគេមិនធ្លាប់មានបទពិសោធ មិនធ្លាប់មើលឃើញ ឬគំនិតគេយល់មិនដល់ទេ ពួកគេពុំមានលក្ខណៈទាំងអស់នេះនៅក្នុងពួកគេនោះឡើយ។ ប្រសិនបើអ្វីដែលមនុស្សបង្ហាញឲ្យឃើញ មិនមែនកើតពីបទពិសោធរបស់គេ ការនោះគឺជាការស្រមើស្រមៃ ឬជាគោលលទ្ធិហើយ។ និយាយឲ្យស្រួលយល់ គឺគ្មានទេភាពជាក់ស្ដែងនៅក្នុងពាក្យសម្ដីរបស់គេ។ ប្រសិនបើអ្នកមិនដែលប្រឡូកជាមួយនឹងរឿងរ៉ាវសង្គមសោះ អ្នកមុខជាមិនអាចជជែកអំពីសម្ពន្ធភាពសាំញ៉ាំក្នុងសង្គមឲ្យបានច្បាស់ដែរ។ ប្រសិនបើអ្នកគ្មានគ្រួសារ នៅពេលអ្នកដទៃជជែកគ្នាអំពីបញ្ហាគ្រួសារ អ្នកមុខជាមិនយល់អំពីសម្ដីភាគច្រើនដែលគេជជែកនោះឡើយ។ ហេតុដូច្នេះ អ្វីដែលមនុស្សជជែកគ្នា និងកិច្ចការដែលគេធ្វើ តំណាងឲ្យលក្ខណៈសម្ងាត់របស់គេ។ ប្រសិនបើមនុស្សម្នាក់ជជែកអំពីការយល់ដឹងរបស់គេ ចំពោះការវាយផ្ចាល និងការជំនុំជម្រះ ប៉ុន្តែអ្នកគ្មានបទពិសោធអំពីការនោះសោះ អ្នកមុខជាមិនហ៊ានបដិសេធការយល់ដឹងរបស់គេទេ ក៏រឹតតែមិនហ៊ានជឿអ្វីដែលគេនិយាយមួយរយភាគរយដែរ។ នេះគឺមកពីការប្រកបគ្នារបស់គេ គឺជារឿងដែលអ្នកមិនធ្លាប់មានបទពិសោធ ជារឿងដែលអ្នកមិនធ្លាប់បានដឹង ហើយគំនិតរបស់អ្នកស្រមៃមិនដល់។ តាមការចេះដឹងរបស់គេគ្រប់យ៉ាងដែលអ្នកអាចយកបាន គឺវិធីមួយដែលត្រូវឆ្លងកាត់ការវាយផ្ចាល និងការជំនុំជម្រះនៅពេលអនាគត។ ប៉ុន្តែ វិធីនេះគ្រាន់តែអាចជាចំណេះដឹងខាងគោលលទ្ធិ

តែប៉ុណ្ណោះ វាមិនអាចជំនួសការយល់ដឹងផ្ទាល់របស់អ្នកបានឡើយ រីតតែមិនជំនួសបទពិសោធរបស់អ្នកទៀតផង។ ប្រហែលជាអ្នកគិតថា អ្វីដែលគេនិយាយក៏ត្រឹមត្រូវដែរ ប៉ុន្តែតាមពិសោធរបស់អ្នកផ្ទាល់ អ្នកយល់ថា សេចក្តីទាំងនោះមិនអាចអនុវត្តបានតាមវិធីជាច្រើន។ ប្រហែលជាអ្នកមានអារម្មណ៍ថា រឿងខ្លះដែលអ្នកស្តាប់ឮ គឺមិនអាចអនុវត្តបានទាំងស្រុង ពេលនោះអ្នកក៏កើតមានសញ្ញាណពីរឿងនេះ ហើយទោះបីអ្នកទទួលយករឿងនេះ ក៏អ្នកទទួលយកទាំងទើសទាល់ប៉ុណ្ណោះ។ ប៉ុន្តែ តាមបទពិសោធរបស់អ្នកផ្ទាល់ ការចេះដឹងដែលអ្នកទាញបានជាសញ្ញាណ ក្លាយជាវិធីអនុវត្តរបស់អ្នក ហើយកាលណាអ្នកកាន់តែអនុវត្ត អ្នកក៏កាន់តែយល់ពីគុណតម្លៃពិតនៃពាក្យសម្តីដែលអ្នកបានស្តាប់។ បន្ទាប់ពីមានបទពិសោធខ្លួនឯងផ្ទាល់ នោះអ្នកនឹងអាចជំរែកពីចំណេះដឹងដែលអ្នកគួរទទួលបានពីអ្វីដែលអ្នកបានឆ្លងកាត់។ ក្រៅពីនេះ អ្នកអាចបែងចែកថា ចំណេះដឹងរបស់នរណា គឺជាចំណេះដឹងពិត និងជាក់ស្តែង ហើយចំណេះដឹងរបស់នរណា គឺជាចំណេះដឹងដែលផ្អែកលើគោលលទ្ធិ ហើយគ្មានតម្លៃ។ ដូច្នេះ មិនថាចំណេះដឹងដែលអ្នកអះអាងស្របនឹងសេចក្តីពិត ឬក៏អត់ គឺវាភាគច្រើនអាស្រ័យត្រង់ថា អ្នកមានបទពិសោធជាក់ស្តែងទាក់ទងនឹងចំណេះដឹងពិត ឬក៏អត់។ ទីណាដែលមានសេចក្តីពិតនៅក្នុងបទពិសោធរបស់អ្នក នោះចំណេះដឹងរបស់អ្នកនឹងក្លាយជាបទពិសោធជាក់ស្តែង ហើយមានតម្លៃ។ តាមរយៈបទពិសោធរបស់អ្នក អ្នកក៏អាចទទួលបានការវិនិច្ឆ័យល្អអាក្រក់ និងគំនិតស៊ីជម្រៅ ធ្វើឲ្យចំណេះដឹងរបស់អ្នកកាន់តែជ្រាលជ្រៅ ហើយបង្កើនប្រាជ្ញា និងសុភវិនិច្ឆ័យទាក់ទងនឹងរបៀបដែលអ្នកគួរសម្តែងនូវចរិតមារយាទរបស់ខ្លួនឯងផង។ ចំណេះដឹងដែលត្រូវបានស្តែងចេញមកពីមនុស្សដែលគ្មានសេចក្តីពិត គឺជាគោលលទ្ធិ ទោះបីជាចំណេះដឹងនោះខ្ពង់ខ្ពស់ប៉ុនណាក៏ដោយ។ មនុស្សប្រភេទនេះ អាចជាមនុស្សដែលវាងវៃខ្លាំងចំពោះរឿងសាច់ឈាម តែមិនអាចបែងចែកនូវភាពខុសគ្នាចំពោះរឿងព្រលឹងវិញ្ញាណ។ នេះក៏មកពីមនុស្សបែបនេះគ្មានបទពិសោធនឹងកិច្ចការខាងព្រលឹងវិញ្ញាណទាល់តែសោះ។ មនុស្សទាំងនេះ ជាមនុស្សដែលមិនត្រូវបានស្រាយបំភ្លឺ ក្នុងកិច្ចការខាងវិញ្ញាណ

ហើយមិនយល់ពីរឿងរ៉ាវខាងព្រលឹងវិញ្ញាណ។ ទោះបីជាអ្នកស្ដែងចេញនូវចំណេះដឹងបែបណាក៏ដោយ ដរាបណាវាជាលក្ខណៈរបស់អ្នក នោះវាជាបទពិសោធផ្ទាល់របស់អ្នក គឺជាចំណេះដឹងពិតរបស់អ្នកហើយ។ មនុស្សដែលនិយាយតែពីគោលលទ្ធិ គឺជាមនុស្សដែលគ្មានទាំងសេចក្ដីពិត គ្មានទាំងភាពជាក់ស្ដែង អ្វីដែលគេពិភាក្សាក៏អាចរាប់ថាជាលក្ខណៈរបស់គេបានដែរ ដ្បិតដែលគេឈានដល់គោលលទ្ធិកម្រិតនេះ នោះក៏ដោយសារតែតាមរយៈការត្រិះរិះ និងការសញ្ជឹងគិតដ៏ស៊ីជម្រៅរបស់គេប៉ុណ្ណោះដែរ។ ប៉ុន្តែវាគ្រាន់តែជាគោលលទ្ធិ វាមិនខុសពីការស្រមើស្រមៃនោះទេ! បទពិសោធរបស់មនុស្សគ្រប់ប្រភេទ តំណាងឲ្យអ្វីៗដែលមាននៅក្នុងគេ។ មនុស្សណាដែលគ្មានបទពិសោធខាងព្រលឹងវិញ្ញាណ មិនអាចនិយាយពីចំណេះ ដឹងនៃសេចក្ដីពិត ក៏មិនអាចនិយាយអំពីចំណេះដឹងដ៏ត្រឹមត្រូវ ទាក់ទងនឹងរឿងរ៉ាវខាងព្រលឹងវិញ្ញាណទេ។ ប្រាកដណាស់ អ្វីដែលមនុស្សស្ដែងចេញគឺជាលក្ខណៈដែលមាននៅក្នុងគេ។ ប្រសិនបើនរណាម្នាក់ ចង់បានចំណេះដឹងខាងឯព្រលឹងវិញ្ញាណ និងចំណេះដឹងខាងឯសេចក្ដីពិត គេត្រូវតែមានបទពិសោធជាក់ស្ដែង។ ប្រសិនបើអ្នកមិនអាចនិយាយច្បាស់អំពីសុភវិនិច្ឆ័យនៅក្នុងជីវិតមនុស្ស អ្នកក៏កាន់តែមិនអាចនិយាយអំពីកិច្ចការខាងឯព្រលឹងវិញ្ញាណយ៉ាងដូច្នោះដែរ? មនុស្សដែលអាចដឹកនាំពួកជំនុំ ចិញ្ចឹមជីវិតមនុស្ស ហើយធ្វើជាសាវ័កដល់អ្នកដទៃ ត្រូវតែមានបទពិសោធពិត។ ពួកគេត្រូវតែមានការយល់ដឹងដ៏ត្រឹមត្រូវអំពីរឿងរ៉ាវខាងព្រលឹងវិញ្ញាណ និងការឲ្យតម្លៃ និងបទពិសោធដ៏ត្រឹមត្រូវអំពីសេចក្ដីពិត។ គឺទាល់តែមនុស្សបែបនេះទេ ទើបមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នឹងធ្វើជាអ្នកធ្វើការ ឬជាពួកសាវ័កដែលដឹកនាំពួកជំនុំបាន។ ពុំនោះទេ ពួកគេអាចបានត្រឹមតែដើរតាមប៉ុណ្ណោះ មិនអាចដឹកនាំបានទេ ក៏រឹតតែមិនអាចធ្វើជាសាវ័កដែលអាចផ្ដល់ជីវិតដល់អ្នកដទៃឡើយ។ នេះ គឺមកពីតួនាទីរបស់សាវ័ក គឺមិនមែនរត់ទៅរត់មក ឬក៏តយុទ្ធនោះឡើយ តួនាទីនេះគឺធ្វើកិច្ចការផ្ដល់ជីវិត និងដឹកនាំអ្នកដទៃក្នុងការបំផ្លាស់បំប្រែនិស្ស័យរបស់គេ។ មនុស្សដែលបំពេញតួនាទីនេះ ត្រូវបានដាក់បញ្ជាបេសកកម្មឱ្យស្ពាយទំនួលខុសត្រូវដ៏ធ្ងន់ធ្ងរមួយ ជាទំនួលខុសត្រូវដែលមិនមែននរណា

ក៏អាចស្ដាយបាននោះដែរ។ កិច្ចការប្រភេទនេះ ទាល់តែមនុស្សដែលមានលក្ខណៈជីវិត ជាមនុស្សដែលមានបទពិសោធពីសេចក្ដីពិត ទើបអាចធ្វើបាន។ កិច្ចការនេះពុំអាចធ្វើឡើង ដោយមនុស្សដែលអាចត្រឹមតែលះបង់មនុស្សដែលអាចរត់ទៅមក ឬមនុស្សដែលព្រមលះបង់ខ្លួនឯងនោះឡើយ។ មនុស្សដែលពុំមានបទពិសោធពីសេចក្ដីពិត មនុស្សដែលមិនធ្លាប់ត្រូវបានកែតម្រូវ ឬវិនិច្ឆ័យពុំអាចធ្វើកិច្ចការប្រភេទនេះបានទេ។ មនុស្សគ្មានបទពិសោធ គឺជាមនុស្សដែលគ្មានភាពជាក់ស្ដែង ពុំអាចមើលឃើញតថភាពច្បាស់ឡើយ ពីព្រោះពួកគេផ្ទាល់គ្មានលក្ខណៈបែបនេះទេ។ ដូច្នេះមនុស្សប្រភេទនេះមិនត្រឹមតែមិនអាចធ្វើកិច្ចការដឹកនាំប៉ុណ្ណោះទេ តែប្រសិនបើពួកគេនៅតែគ្មានសេចក្ដីពិតយូរតទៅទៀត ពួកគេនឹងក្លាយជាកម្មវត្ថុនៃការផាត់ចោលហើយ។ តម្រិះដែលអ្នកបង្ហាញចេញមក អាចធ្វើជាភស្តុតាងនៃទុក្ខវេទនាដែលអ្នកបានឆ្លងកាត់នៅក្នុងជីវិត ជាអ្វីដែលនាំឲ្យអ្នកត្រូវបានវាយផ្ចាល និងជាបញ្ហាដែលនាំឲ្យអ្នកត្រូវជំនុំជម្រះ។ នេះក៏ជារឿងពិតចំពោះការល្បងលដូចគ្នា៖ កន្លែងដែលជាចំណុចខ្សោយកន្លែងនោះហើយត្រូវបន្សុទ្ធ នេះជាបញ្ហាដែលមនុស្សត្រូវមានបទពិសោធទុកជាវិធីអនុវត្ត។ ឧទាហរណ៍ ប្រសិនបើមនុស្សម្នាក់រសាយចិត្តក្នុងជីវិតអាពាហ៍ពិពាហ៍ ពួកគេត្រូវប្រកបគ្នាដោយពាក្យថា «អរព្រះគុណព្រះជាម្ចាស់ សរសើរតម្កើង ព្រះជាម្ចាស់ ទូលបង្គំត្រូវតែបំពេញតាមព្រះទ័យចង់បានរបស់ព្រះជាម្ចាស់ ហើយថ្វាយជីវិតទូលបង្គំទាំងមូលដល់ទ្រង់ ហើយទូលបង្គំត្រូវយកជីវិតអាពាហ៍ពិពាហ៍របស់ទូលបង្គំទាំងមូលទៅដាក់ក្នុងព្រះហស្តរបស់ព្រះជាម្ចាស់។ ទូលបង្គំព្រមថ្វាយជីវិតទូលបង្គំទាំងមូលដល់ព្រះជាម្ចាស់។» គ្រប់យ៉ាងដែលមាននៅក្នុងជីវិតមនុស្ស អាចបង្ហាញអំពីលក្ខណៈរបស់គេ តាមរយៈការប្រកបគ្នា។ សន្ទុះនៃការនិយាយរបស់បុគ្គលម្នាក់ មិនថាគេនិយាយឮខ្លាំង ឬស្ងាត់នោះឡើយ បញ្ហានេះមិនមែនជាបញ្ហាបទពិសោធ និងមិនអាចធ្វើជាតំណាងលក្ខណៈដែលគេមាន និងលក្ខណៈរបស់គេបានឡើយ។ ការទាំងនេះគ្រាន់តែអាចប្រាប់បានថា សន្ដានកំណើតរបស់គេល្អ ឬអាក្រក់ប៉ុណ្ណោះ ប៉ុន្តែពួកគេមិនអាចចាត់ទុកស្មើនឹងមនុស្សម្នាក់ដែលមាន ឬគ្មានបទពិសោធនោះឡើយ។ សមត្ថភាព

សម្ដែងពីមនុស្សម្នាក់ពេលនិយាយ ឬជំនាញ ឬល្បឿននៃសម្ដីរបស់គេ គ្រាន់តែជាបញ្ហាទាក់ទងនឹងទម្លាប់តែប៉ុណ្ណោះ មិនអាចយកមកជំនួសបទពិសោធរបស់មនុស្សបានឡើយ។ កាលណាអ្នកនិយាយអំពីបទពិសោធរៀងខ្លួនរបស់អ្នក អ្នកប្រកបឃើញនូវអ្វីដែលអ្នកយល់ថាសំខាន់ និងប្រកបឃើញគ្រប់យ៉ាងដែលមាននៅក្នុងអ្នក។ សម្ដីរបស់ខ្ញុំតំណាងឲ្យលក្ខណៈរបស់ខ្ញុំ ប៉ុន្តែអ្វីដែលខ្ញុំនិយាយ វាហួសពីគំនិតគិតដល់របស់មនុស្ស។ អ្វីដែលខ្ញុំនិយាយ មិនមែនជារឿងដែល មនុស្សមានពិសោធនោះទេ ហើយក៏មិនមែនជាអ្វីដែល មនុស្សអាចមើលឃើញនោះដែរ ហើយវាក៏មិនមែនជារបស់ដែលមនុស្សអាចពាល់បានដែរ តែវាគឺជាលក្ខណៈរបស់ខ្ញុំ។ មនុស្សខ្លះទទួលស្គាល់តែត្រឹមថា អ្វីដែលខ្ញុំនិយាយប្រាប់ គឺជាអ្វីដែលខ្ញុំមានពិសោធ ប៉ុន្តែពួកគេមិនទទួលស្គាល់ថា វាគឺជាការសម្ដែងចេញដោយផ្ទាល់របស់ព្រះវិញ្ញាណ។ ប្រាកដណាស់ អ្វីដែលខ្ញុំនិយាយគឺជាអ្វីដែលខ្ញុំមានពិសោធ។ ខ្ញុំនេះហើយជាអ្នកដែលបានធ្វើការងារគ្រប់គ្រងអស់រយៈពេលប្រាំមួយពាន់ឆ្នាំមកនេះ។ ខ្ញុំបានមានពិសោធនូវអ្វីៗគ្រប់យ៉ាងតាំងតែពីដើមកំណើតរបស់មនុស្សលោក មកទល់នឹងបច្ចុប្បន្ននេះ។ ម្ដេចក៏ខ្ញុំមិនអាចពិភាក្សាអំពីរឿងនេះបាន? កាលណានិយាយអំពីសន្ដានកំណើតរបស់មនុស្ស ខ្ញុំបានឃើញច្បាស់ណាស់ ដ្បិតខ្ញុំបានសង្កេតតាំងពីយូរណាស់មកហើយ។ ម្ដេចក៏ខ្ញុំមិនអាចជជែកអំពីរឿងនេះ ឲ្យច្បាស់លាស់បាន? ដោយសារតែខ្ញុំបានមើលឃើញលក្ខណៈរបស់មនុស្សច្បាស់ ខ្ញុំក៏មានលក្ខណសម្បត្តិគ្រប់គ្រាន់ នឹងដាក់ទោសមនុស្ស ហើយជំនុំជម្រះគេផង ពីព្រោះមនុស្សលោកទាំងអស់កើតពីខ្ញុំមក ប៉ុន្តែគេត្រូវបង្ខូចឲ្យទៅជាអាក្រក់ដោយសារសាតាំង។ ពិតណាស់ ខ្ញុំក៏មានលក្ខណៈសម្បត្តិគ្រាប់គ្រាន់ដើម្បីនឹងវាយតម្លៃកិច្ចការដែលខ្ញុំបានធ្វើដែរ។ បើទោះបីជាកិច្ចការនេះ ពុំមែនត្រូវបានធ្វើឡើងដោយសាច់ឈាមរបស់ខ្ញុំមែន តែវាគឺជាការស្ដែងចេញដោយផ្ទាល់ពីព្រះវិញ្ញាញ ហើយនេះគឺជាលក្ខណៈដែលខ្ញុំមាន និងជាលក្ខណៈរបស់ខ្ញុំ។ ដូច្នេះ ខ្ញុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការបង្ហាញ និងធ្វើកិច្ចការដែលខ្ញុំគួរធ្វើ។ អ្វីដែលមនុស្សនិយាយ គឺជាអ្វីដែលគេមានបទពិសោធ។ វាជាអ្វីដែលគេបានឃើញ ជាអ្វីដែលគំនិតរបស់គេអាច

គិតដល់ ហើយជាអ្វីដែលញាណរបស់គេអាចចាប់បាន។ នោះជាអ្វីដែលគេអាចជជែកប្រាប់បាន។ ព្រះបន្ទូលដែលថ្លែងដោយសាច់ឈាមនៃព្រះដែលយកកំណើតជាមនុស្សជាការបង្ហាញដោយផ្ទាល់ពីព្រះវិញ្ញាណ គឺជារឿងដែលសាច់ ឈាមមិនធ្លាប់មានបទពិសោធ ឬមើលឃើញ ប៉ុន្តែទ្រង់នៅតែអាចបង្ហាញលក្ខណៈរបស់ទ្រង់ដដែល ដ្បិតលក្ខណៈនៃសាច់ឈាមរបស់ទ្រង់ជាវិញ្ញាណ ហើយទ្រង់បង្ហាញនូវកិច្ចការនៃព្រះវិញ្ញាណ។ កិច្ចការនេះ ជាកិច្ចការដែលត្រូវបានធ្វើរួចជាស្រេចដោយព្រះវិញ្ញាណ បើទោះបីជាកិច្ចការនោះ វាហួសពីការឈានដល់នៃសាច់ឈាមក៏ដោយ។ បន្ទាប់ពីការយកកំណើតជាសាច់ឈាម តាមរយៈការបង្ហាញនៃសាច់ឈាម ព្រះអង្គអាចធ្វើឲ្យមនុស្សស្គាល់ លក្ខណៈរបស់ព្រះជាម្ចាស់ ឲ្យមនុស្សមើលឃើញនិស្ស័យរបស់ព្រះជាម្ចាស់ និងកិច្ចការដែលព្រះអង្គបានធ្វើ។ កិច្ចការរបស់មនុស្សផ្តល់នូវភាពច្បាស់លាស់អំពីអ្វីដែលគេគួរប្រកាន់ខ្ជាប់ និងអ្វីដែលគេគួរតែយល់កិច្ចការពាក់ព័ន្ធ ទាំងការដឹកនាំមនុស្សឆ្ពោះទៅរកការយល់ដឹង និងការទទួលបទពិសោធនូវសេចក្តីពិត។ កិច្ចការរបស់មនុស្ស គឺដើម្បីគាំទ្រមនុស្ស។ កិច្ចការរបស់ព្រះជាម្ចាស់ គឺដើម្បីបើកផ្លូវ និងយុគសម័យថ្មីៗ សម្រាប់មនុស្សលោក និងដើម្បីបង្ហាញឲ្យមនុស្សស្គាល់ពីកិច្ចការដែលមនុស្សមិនធ្លាប់ស្គាល់ ដោយឲ្យគេអាចស្គាល់និស្ស័យរបស់ទ្រង់។ រីឯកិច្ចការរបស់ព្រះជាម្ចាស់ គឺដើម្បីដឹកនាំមនុស្សជាតិទាំងអស់។

កិច្ចការទាំងអស់របស់ព្រះវិញ្ញាណបរិសុទ្ធត្រូវបានអនុវត្ត ដើម្បីផ្តល់ប្រយោជន៍ដល់មនុស្ស។ កិច្ចការទាំងអស់ គឺដើម្បីតែបង្រៀនមនុស្ស ពុំមានកិច្ចការណាដែលមិនផ្តល់ប្រយោជន៍ដល់មនុស្សឡើយ។ ទោះបីជាសេចក្តីពិតស៊ីជម្រៅ ឬរាក់កំភែល ហើយបើទោះបីជាមនុស្សដែលទទួលសេចក្តីពិតមានគុណសម្បត្តិយ៉ាងណាក៏កិច្ចការដែលព្រះវិញ្ញាណបរិសុទ្ធធ្វើ ផ្តល់ប្រយោជន៍ដល់មនុស្សដែរ។ ប៉ុន្តែកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធមិនអាចត្រូវបានធ្វើឡើងដោយផ្ទាល់ឡើយ កិច្ចការនេះត្រូវតែបង្ហាញចេញមកតាមរយៈមនុស្សដែលប្រាស្រ័យទាក់ទងជាមួយទ្រង់។ គឺទាល់តែបែបនេះ ទើបកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធអាចសម្រេចបាន។ ពិតមែនហើយកាលណាព្រះវិញ្ញាណ

បរិសុទ្ធធ្វើការដោយផ្ទាល់ កិច្ចការនោះមិនច្របូកច្របល់ទាល់តែសោះ ប៉ុន្តែកាលណាព្រះវិញ្ញាណបរិសុទ្ធ ធ្វើការតាមរយៈមនុស្ស កិច្ចការនោះក៏ក្លាយជាច្របូកច្របល់ ហើយមិនមែនជាកិច្ចការដើមរបស់ព្រះវិញ្ញាណបរិសុទ្ធនោះឡើយ។ ដោយហេតុនេះ សេចក្ដីពិតក៏ប្រែប្រួលទៅរកការញែកកម្រិតខុសៗគ្នាដែរ។ អ្នកដើរតាម មិនទទួលបាននូវចេតនាដើមរបស់ព្រះវិញ្ញាណបរិសុទ្ធទេ ប៉ុន្តែជាការរួមបញ្ចូលគ្នានៃកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ព្រមទាំងបទពិសោធ និងចំណេះដឹងរបស់មនុស្សវិញ។ ត្រឹមត្រូវហើយចំណែកការដែលអ្នកដើរតាមទទួលនោះ គឺជាកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ឯបទពិសោធ និងចំណេះដឹងរបស់មនុស្សដែលគេទទួលវិញវាខុសៗគ្នា ដ្បិតអ្នកធ្វើការសុទ្ធតែខុសគ្នា។ អ្នកធ្វើការដែលមានការស្រាយបំភ្លឺ និងការដឹកនាំរបស់ព្រះវិញ្ញាណបរិសុទ្ធ នឹងបន្តទទួលបានបទពិសោធផ្អែកទៅលើការស្រាយបំភ្លឺ និងការដឹកនាំនេះ។ ក្នុងបទពិសោធនេះ បានរួមបញ្ចូលគ្នាទាំងគំនិត និងបទពិសោធរបស់មនុស្ស ក៏ដូចជាសភាវៈនៃមនុស្សជាតិ ហើយបន្ទាប់មក ពួកគេក៏ទទួលបានចំណេះដឹងនិងតម្រិះដែលពួកគេគួរមាន។ នេះជាវិធីអនុវត្តរបស់មនុស្ស បន្ទាប់ពីពួកគេបានមានបទពិសោធអំពីសេចក្ដីពិត។ វិធីអនុវត្តនេះ មិនមែនដូចគ្នារហូតទេ ដ្បិតមនុស្សមានពិសោធខុសគ្នា ហើយកិច្ចការដែលគេមានបទពិសោធ ក៏មានភាពខុសៗគ្នាដែរ។ តាមវិធីនេះ ការស្រាយបំភ្លឺដដែលរបស់ព្រះវិញ្ញាណបរិសុទ្ធ នាំមកនូវចំណេះដឹង និងការអនុវត្តខុសៗគ្នា ដ្បិតមនុស្សដែលទទួលនូវការស្រាយបំភ្លឺនេះមាននូវភាពខុសៗគ្នា។ មនុស្សខ្លះ ប្រព្រឹត្តខុសតិចតួចក្នុងពេលអនុវត្ត ខណៈដែលមនុស្សខ្លះទៀតប្រព្រឹត្ត ធ្ងន់ធ្ងរ ហើយមនុស្សខ្លះទៀតប្រព្រឹត្តខុសទាំងស្រុងតែម្ដង។ នេះគឺមកពីមនុស្សមានសមត្ថភាពយល់ដឹងខុសគ្នា ហើយក៏ដោយសារតែគុណសម្បត្តិពីកំណើតរបស់គេខុសៗពីគ្នាដែរ។ មនុស្សខ្លះ មានការយល់តែមួយប្រភេទទេ ក្រោយពេលស្ដាប់ឮសារមួយ ឯមនុស្សខ្លះទៀត មានការយល់ដឹងផ្សេងបន្ទាប់ពីបានឮសេចក្ដីពិត។ មនុស្សខ្លះយល់លម្អៀងតែបន្តិចទេ ប៉ុន្តែអ្នកខ្លះទៀតវិញ មិនយល់ពីអត្ថន័យពិតនៃសេចក្ដីពិតសោះតែម្ដង។ ដូច្នេះ ការយល់ដឹងរបស់មនុស្សម្នាក់ៗ ជះឥទ្ធិពលដល់

វិធីដែលគេដឹកនាំអ្នកដទៃ។ ជាការពិតប្រាកដណាស់ដ្បិតកិច្ចការរបស់មនុស្សម្នាក់ គឺបានត្រឹមតែ ជាការបង្ហាញនូវលក្ខណៈរបស់គេប៉ុណ្ណោះ។ មនុស្សដែលត្រូវបាន ដឹកនាំដោយមនុស្សដែលមានការយល់ដឹងដ៏ត្រឹមត្រូវចំពោះសេចក្តីពិត គេក៏មានការ យល់ដឹងដ៏ត្រឹមត្រូវចំពោះសេចក្តីពិតដូចគ្នាដែរ។ បើទោះបីជាមានមនុស្សខ្លះ មានការ យល់ខុសតិចតួច ក៏មនុស្សទាំងនោះមានចំនួនតិចតួចដែរ មិនមែនគ្រប់គ្នាសុទ្ធតែយល់ ខុសនោះទេ។ ប្រសិនបើមនុស្សម្នាក់មានការយល់ដឹងខុសចំពោះសេចក្តីពិត អ្នកដែល ដើរតាមគាត់ក៏ប្រាកដជាខុសដែរ ហើយមនុស្សទាំងនេះនឹងយល់ខុសលើន័យពាក្យ គ្រប់ម៉ាត់។ កម្រិតយល់ដឹងអំពីសេចក្តីពិតរបស់អ្នកដែលដើរតាម ភាគច្រើនគឺអាស្រ័យ លើអ្នកធ្វើការ។ ពិតណាស់ សេចក្តីពិតដែលមកពីព្រះជាម្ចាស់ គឺត្រឹមត្រូវ ហើយឥត ខុសត្រង់ណា ព្រមទាំងប្រាកដច្បាស់ផង។ យ៉ាងណាមិញ អ្នកធ្វើការមិនមែនត្រឹមត្រូវ ទាំងស្រុង ហើយក៏មិនអាចនិយាយថា ជឿជាក់បានទាំងស្រុងដែរ។ ប្រសិនបើ អ្នកធ្វើការអាចមានវិធីជាក់ស្តែងដើម្បីយកសេចក្តីពិតទៅអនុវត្ត នោះអ្នកដឹកនាំក៏ មានវិធីអនុវត្តដែរ។ ប្រសិនបើអ្នកធ្វើការ ពុំមានវិធីអនុវត្តសេចក្តីពិត មានតែគោល លទ្ធិ នោះអ្នកដើរតាម ក៏មិនមានភាពជាក់ស្តែងដែរ។ គុណសម្បត្តិ និងនិស្ស័យរបស់ អ្នកដើរតាម ត្រូវបានកំណត់ពីកំណើត គ្មានអ្វីពាក់ព័ន្ធនឹងអ្នកធ្វើការទេ ប៉ុន្តែទំហំនៃ ការយល់ដឹងនូវសេចក្តីពិត និងការដែលអ្នកដើរតាមស្គាល់ព្រះជាម្ចាស់ គឺអាស្រ័យ ទៅលើអ្នកធ្វើការ (នេះក៏ចំពោះតែមនុស្សខ្លះដែរទេ)។ អ្នកធ្វើការមានលក្ខណៈបែប ណា នោះអ្នកដើរតាមដែលគេដឹកនាំនោះ ក៏បែបនោះដែរ។ អ្វីដែលធ្វើការស្តែងចេញ មក ជាលក្ខណៈរបស់គេផ្ទាល់ ដោយមិនបាច់ព្រៀង។ ការទាមទារដែលគេតម្រូវពីអ្នក ដែលដើរតាមគេ គឺជាអ្វីដែលខ្លួនគេផ្ទាល់យល់ព្រម ឬអាចសម្រេចបាន។ អ្នកធ្វើការ ភាគច្រើន ប្រើប្រាស់អ្វីដែលធ្វើខ្លួនឯង មកធ្វើជាមូលដ្ឋាន ដើម្បីតម្រូវពីមនុស្សដែល ដើរតាមពួកគេ បើទោះបីជាមានកិច្ចការជាច្រើនដែលអ្នកដើរតាមពួកគេ មិនអាច សម្រេចសោះ ហើយកិច្ចការដែលពួកគេមិនអាចសម្រេចបាននោះ ក៏ក្លាយជាឧបសគ្គ ដល់ការចូលទៅក្នុងការអនុវត្តរបស់គេទៅវិញ។

ក្នុងកិច្ចការរបស់អ្នកដែលបានឆ្លងកាត់ការលួសកាត់ ការដោះស្រាយជាមួយ ការជំនុំជម្រះ និងការវាយផ្ចាល មានការបង្វែរចាកតិចតួចបំផុត រីឯការបង្ហាញអំពីកិច្ចការរបស់គេក៏រឹតតែសុក្រឹតទៀតផង។ មនុស្សដែលសម្អាងលើលក្ខណៈធម្មជាតិរបស់គេដើម្បីធ្វើការប្រព្រឹត្តកំហុសធ្ងន់ណាស់។ កិច្ចការរបស់មនុស្សដែលមិនបានគ្រប់លក្ខណ៍ បង្ហាញចេញនូវលក្ខណៈធម្មជាតិរបស់គេច្រើនពេក ដែលបង្កើតឲ្យមានឧបសគ្គដ៏ធំដល់កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ។ ដោយឡែក ទោះបីជាគុណសម្បត្តិរបស់មនុស្សល្អយ៉ាងណា ក៏គេនៅតែត្រូវឆ្លងកាត់ការលួសកាត់ ការដោះស្រាយជាមួយ និងការជំនុំជម្រះដែរ មុនពេលដែលគេអាចធ្វើកិច្ចការនៃបញ្ញាបេសកកម្មរបស់ព្រះជាម្ចាស់បាន។ ប្រសិនបើពួកគេមិនឆ្លងកាត់ ការជំនុំជម្រះបែបនេះទេ កិច្ចការរបស់ពួកគេ ទោះបីជាសម្រេចបានល្អយ៉ាងណា ក៏មិនអាចស្របនឹងគោលការណ៍នៃសេចក្ដីពិតបានឡើយ ហើយនៅតែជាផលដែលកើតចេញពីលក្ខណៈធម្មជាតិ និងសេចក្ដីល្អរបស់មនុស្សដដែល។ កិច្ចការរបស់មនុស្សដែលបានឆ្លងកាត់នូវការលួសកាត់ ការដោះស្រាយជាមួយ និង ការជំនុំជម្រះ កាន់តែសុក្រឹតជាងកិច្ចការរបស់មនុស្សដែលមិនឆ្លងកាត់ការលួសកាត់ ការដោះស្រាយជាមួយ និងការជំនុំជម្រះទៅទៀត។ មនុស្សដែលមិនបានឆ្លង កាត់ការជំនុំជម្រះ មិនបង្ហាញនូវអ្វីក្រៅតែពីសាច់ឈាម និងគំនិតរបស់មនុស្សលោក បូករួមទាំងបញ្ញា និងទេពកោសល្យពីកំណើតរបស់មនុស្សលោកប៉ុណ្ណោះ។ នេះមិនមែនជាបង្ហាញអំពីកិច្ចការរបស់ព្រះជាម្ចាស់ ដោយសុក្រឹតរបស់មនុស្សឡើយ។ អ្នកដែលដើរតាមមនុស្សបែបនេះ ត្រូវបាននាំមកចំពោះព្រះជាម្ចាស់ ដោយសារលក្ខណៈពីកំណើតរបស់គេ។ ដោយសារគេបង្ហាញនូវតម្រិះនិងបទពិសោធរបស់មនុស្សខ្លាំងពេក ដែលស្ទើរតែដាច់ចេញពីចេតនាដើមរបស់ព្រះជាម្ចាស់ និងល្មៀងឆ្ងាយពេក ទើបកិច្ចការរបស់មនុស្សបែបនេះ មិនអាចនាំមនុស្សមកចំពោះព្រះជាម្ចាស់ តែផ្ទុយទៅវិញបែរជា នាំគេមកចំពោះមនុស្សលោកវិញ។ ហេតុនេះ អស់អ្នកដែលមិនបានឆ្លងកាត់ការជំនុំជម្រះ និងការដាក់ទោសពុំមានលក្ខណៈសម្បត្តិនឹងអនុវត្តកិច្ចការនៃបញ្ញាបេសកកម្មរបស់ព្រះជាម្ចាស់នោះឡើយ។

កិច្ចការរបស់អ្នកធ្វើការដែលមានលក្ខណសម្បត្តិ អាចនាំមនុស្សមកក្នុងផ្លូវត្រឹមត្រូវ ហើយផ្ដល់ឲ្យពួកគេនូវការប្រកាន់ខ្ជាប់តាមសេចក្ដីពិតដែលកាន់តែអស្ចារ្យ។ កិច្ចការរបស់គេ អាចនាំមនុស្សមកចំពោះព្រះជាម្ចាស់បាន។ លើសពីនេះកិច្ចការដែលគេធ្វើ អាចខុសគ្នាពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ និងមិនត្រូវដាក់កំហិតដោយក្រឹត្យក្រមនោះឡើយ ទាំងអនុញ្ញាតឲ្យមនុស្សមានសិទ្ធិ និងសេរីភាព ហើយឲ្យសមត្ថភាពពួកគេលូតលាស់ក្នុងជីវិតបន្តិចម្ដងៗ និងឲ្យគេមាននូវការប្រកាន់ខ្ជាប់តាមសេចក្ដីពិត ដែលកាន់តែជ្រាលជ្រៅ។ កិច្ចការរបស់អ្នកធ្វើការដែលពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នៅមានចំណុចខ្វះខាតច្រើនណាស់។ កិច្ចការរបស់គេ គឺចោលម្សៀត។ គេបានត្រឹមនាំមនុស្សឲ្យស្គាល់ក្រឹត្យក្រម ហើយអ្វីដែលគេទាមទារពីមនុស្ស មិនខុសគ្នាពីបុគ្គលម្នាក់ទៅបុគ្គលទៀតទេ។ គេមិនធ្វើការឲ្យស្របទៅនឹងសេចក្ដីត្រូវការជាក់ស្ដែងរបស់មនុស្សនោះឡើយ។ ក្នុងកិច្ចការប្រភេទនេះ មាននូវក្រឹត្យក្រម និងមានគោលលទ្ធិច្រើនណាស់ ហើយវាមិនអាចនាំមនុស្សចូលមកក្នុងភាពជាក់ស្ដែងនោះទេ ក៏មិននាំគេមកក្នុងការអនុវត្ត នៃការលូតលាស់ជាធម្មតានៅក្នុងជីវិតនោះឡើយ។ វាបានត្រឹមតែអាចឲ្យមនុស្ស អាចប្រកាន់តាមក្រឹត្យក្រមឥតបានការ មួយចំនួនតូចតែប៉ុណ្ណោះ។ ការដឹកនាំបែបនេះ បានត្រឹមតែនាំមនុស្សឲ្យវង្វេងតែប៉ុណ្ណោះ។ គេដឹកនាំអ្នកឲ្យក្លាយជាមនុស្សដូចគេ គេអាចនាំអ្នកឲ្យមានចរិតលក្ខណៈ និងលក្ខណៈដូចនឹងអ្វីដែលគេមាន។ ដើម្បីឲ្យអ្នកដើរតាមមើលដឹងថា អ្នកដឹកនាំមាន ឬគ្មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ កត្តាសំខាន់ គឺសម្លឹងមើលផ្លូវដែលគេដឹកនាំ និងលទ្ធផលនៃកិច្ចការរបស់គេ ហើយមើលថា អ្នកដែលដើរតាមទទួលបាននូវគោលការណ៍ស្របទៅនឹងសេចក្ដីពិតដែរ ឬអត់ ហើយមើលថា ពួកគេទទួលបានវិធីអនុវត្តត្រូវនឹងការបំផ្លាស់បំប្រែរបស់គេដែរ ឬអត់។ អ្នកគួរបែងចែកឲ្យបានរវាងកិច្ចការខុសគ្នារបស់ប្រភេទមនុស្សខុសគ្នា អ្នកមិនគប្បីធ្វើជាអ្នកដើរតាមដ៏ល្ងង់ខ្លៅនោះឡើយ។ កត្តានេះពាក់ព័ន្ធនឹងបញ្ហា នៃការប្រកាន់ខ្ជាប់របស់មនុស្ស។ ប្រសិនបើអ្នកមិនអាចបែងចែកថា ការដឹកនាំរបស់មនុស្សណាមួយមានផ្លូវ ហើយណាមួយគ្មានផ្លូវ នោះអ្នកនឹងត្រូវ

គេបញ្ឆោតបានយ៉ាងងាយ។ ចំណុចទាំងនេះ ជះឥទ្ធិពលដោយផ្ទាល់លើជីវិតរបស់អ្នកផ្ទាល់។ ក្នុងកិច្ចការរបស់មនុស្សដែលពុំបានគ្រប់លក្ខណ៍ មានចរិតពីកំណើតច្រើនពេក កិច្ចការនេះលាយឡំនឹងឆន្ទៈរបស់មនុស្សច្រើនជ្រុល។ លក្ខណៈរបស់គេ គឺជាចរិតកំណើតរបស់គេ ជាលក្ខណៈដែលគេមានតាំងពីពេលគេកើតមក។ វាមិនមែនជាជីវិតដែលគេមាន បន្ទាប់ពីត្រូវបានដោះស្រាយជាមួយ ឬជាភាពជាក់ស្ដែងដែលគេមាន បន្ទាប់ពីគេត្រូវបំផ្លាស់បំប្រែនោះឡើយ។ តើបុគ្គលបែបនេះអាចគាំទ្រមនុស្សដែលកំពុងព្យាយាមឲ្យបានជីវិតដោយវិធីណា? ជីវិតដែលមនុស្សមានតាំងពីដើមមក គឺបញ្ញា និងទេពកោសល្យដែលគេមានពីកំណើត។ បញ្ញា ឬទេពកោសល្យប្រភេទនេះ គឺខុសឆ្ងាយពីសេចក្ដីតម្រូវពិតប្រាកដរបស់ព្រះជាម្ចាស់ ចំពោះមនុស្សលោកណាស់។ ប្រសិនបើមនុស្សពុំត្រូវបានប្រោសឲ្យបានគ្រប់លក្ខណ៍ទេ ហើយនិស្ស័យពុករលួយរបស់គេពុំត្រូវបានលួសកាត់ និងពុំត្រូវបានដោះស្រាយជាមួយទេ នោះចន្លោះរវាងអ្វីដែលគេបង្ហាញចេញ និងសេចក្ដីពិត គឺធំណាស់។ អ្វីដែលគេបង្ហាញចេញមក វាមានលាយឡំជាមួយនឹងកត្តាស្រពេចស្រពិល ដូចជាការស្រមើស្រមៃ និងបទពិសោធតែម្ខាងរបស់គេ។ ជាងនេះទៅទៀត បើទោះបីជាគេធ្វើការយ៉ាងណាក៏មនុស្សមានអារម្មណ៍ថា គ្មានគោលដៅទូទៅ និងគ្មានសេចក្ដីពិតដែលស័ក្ដិសមដើម្បីឲ្យមនុស្សទាំងអស់ប្រកាន់ខ្ជាប់ដែរ។ ភាគច្រើននៃអ្វីដែលទាមទារពីមនុស្ស គឺហួសពីសមត្ថភាពគេ ពួកគេប្រៀបដូចជាសត្វទាដែលត្រូវគេបង្ខំឲ្យទៅទំលើទ្រនំ។ នេះជាកិច្ចការដែលកើតពីឆន្ទៈរបស់មនុស្ស។ និស្ស័យពុករលួយរបស់មនុស្ស គំនិត និងសញ្ញាណរបស់គេ ជ្រួតជ្រាបទៅគ្រប់អវយវៈទាំងអស់នៅក្នុងរាងកាយរបស់គេ។ មនុស្សមិនមែនកើតមកទាំងមាននូវសភាវគតិក្នុងការអនុវត្តសេចក្ដីពិតមកជាមួយនោះទេ គេក៏មិនមានសភាវគតិក្នុងការស្វែងយល់ពីសេចក្ដីពិតដោយផ្ទាល់នោះដែរ។ បន្ថែមពីលើនិស្ស័យពុករលួយរបស់មនុស្ស កាលណាមនុស្សដែលមានចរិតកំណើតបែបនេះធ្វើការ តើវាមិនបង្កឲ្យមានការបន្ទុចបង្អាក់ទេឬអី? ចំណែកមនុស្សដែលបានគ្រប់លក្ខណ៍វិញ គេបានទាំងបទពិសោធសេចក្ដីពិតដែលមនុស្សយល់ និងស្គាល់

នូវនិស្ស័យពុករលួយរបស់ពួកគេ ដើម្បីឲ្យរឿងដ៏ស្រពេចស្រពិល និងកត្តាដែលមិនច្បាស់លាស់ក្នុងកិច្ចការរបស់គេ នឹងថមថយទៅបន្តិចម្ដងៗ ភាពស្មោកគ្រោករបស់របស់មនុស្ស ក៏កាន់តែតិចទៅៗ ហើយកិច្ចការ និងការបម្រើរបស់គេក៏កាន់តែកៀកទៅនឹងបទដ្ឋានដែលព្រះជាម្ចាស់តម្រូវដែរ។ ដូច្នេះ កិច្ចការរបស់គេបានចូលទៅក្នុងភាពជាក់ស្ដែងនៃសេចក្ដីពិត ហើយកិច្ចការនោះក៏បានក្លាយជាភាពប្រាកដនិយម។ ការរិះគិតនៅក្នុងគំនិតរបស់មនុស្ស រារាំងដល់កិច្ចការ របស់ព្រះវិញ្ញាណបរិសុទ្ធជាពិសេស។ មនុស្សសម្បូរការស្រមើស្រម៉ៃ ហើយមានសុភវិនិច្ឆ័យដ៏សមហេតុផលច្រើន គេក៏មានបទពិសោធដោះស្រាយការងារយូរផងដែរ។ ប្រសិនបើលក្ខណៈរបស់មនុស្សទាំងនេះ មិនឆ្លងកាត់នូវការលួសកាត់ និងការកែតម្រូវទេ លក្ខណៈទាំងនេះនឹងក្លាយជាឧបសគ្គដល់កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ។ ដូច្នេះ កិច្ចការរបស់មនុស្សមិនអាចសម្រេចបានកម្រិតធំបំផុតនៃភាពត្រឹមត្រូវបានឡើយ ជាពិសេស គឺកិច្ចការរបស់មនុស្សដែលមិនបានគ្រប់លក្ខណ៍។

កិច្ចការរបស់មនុស្សស្ថិតតែក្នុងក្រុមមួយ និងមាននូវដែនកំណត់។ មនុស្សម្នាក់អាចត្រឹមតែធ្វើកិច្ចការនៅក្នុងដំណាក់កាលមួយ និងមិនអាចធ្វើការក្នុងយុគសម័យទាំងមូលបានឡើយ ពុំនោះទេ គេមុខជាដឹកនាំមនុស្សឲ្យលង់ ក្នុងក្រឹត្យក្រមជាមិនខាន។ កិច្ចការរបស់មនុស្ស អាចប្រើការបានត្រឹមតែមួយគ្រា ឬមួយដំណាក់កាលជាក់លាក់ប៉ុណ្ណោះ។ នេះគឺដោយសារបទពិសោធរបស់មនុស្ស មានវិសាលភាពរបស់វា។ គេពុំអាចប្រៀបធៀបនឹងកិច្ចការរបស់មនុស្សជាមួយនឹងកិច្ចការរបស់ព្រះជាម្ចាស់បានទេ។ វិធីអនុវត្ត និងចំណេះដឹងអំពីសេចក្ដីពិតរបស់មនុស្ស អាចប្រើការបានក្នុងវិសាលភាពមួយជាក់លាក់។ អ្នកពុំអាចនិយាយថា ផ្លូវដែលមនុស្សដើរគឺជាបំណងព្រះហឫទ័យរបស់ព្រះវិញ្ញាណបរិសុទ្ធទាំងស្រុងនោះឡើយ ដ្បិតមនុស្សមិនត្រឹមតែអាចទទួលនូវការស្រាយបំភ្លឺពីព្រះវិញ្ញាណបរិសុទ្ធនោះឡើយ ប៉ុន្តែគេក៏មិនអាចត្រូវបំពេញដោយព្រះវិញ្ញាណទាំងស្រុងនោះដែរ។ កិច្ចការដែលមនុស្សអាចមានពិសោធបាន គឺសុទ្ធតែមាននៅក្នុងវិសាលភាពនៃភាពជាមនុស្សធម្មតា និងពុំអាចហួសពីដែនកំណត់នៃ

ការរិះគិត នៅក្នុងគំនិតរបស់មនុស្សធម្មតានោះឡើយ។ មនុស្សដែលអាចស្វែងនូវភាពជាក់ស្ដែងនៃសេចក្ដីពិតក្នុងជីវិតរបស់គេ គឺសុទ្ធតែមានបទពិសោធនៅក្នុងដែនកំណត់នេះ។ កាលណាពួកគេមានបទពិសោធនឹងសេចក្ដីពិត នោះវានឹងតែងតែជាបទពិសោធនៃជីវិតមនុស្សធម្មតា ដែលត្រូវបានស្រាយបំភ្លឺដោយព្រះវិញ្ញាណបរិសុទ្ធជានិច្ច។ វិធីទទួលបានបទពិសោធ មិនមែនជាកត្តាដែលបញ្ចៀសចេញពីជីវិតធម្មតារបស់មនុស្សឡើយ។ ពួកគេមានបទពិសោធអំពីសេចក្ដីពិតដែលត្រូវបានស្រាយបំភ្លឺដោយព្រះវិញ្ញាណបរិសុទ្ធ ស្ដីអំពីគ្រឹះនៃការរស់នៅរបស់ពួកគេក្នុងជីវិតជាមនុស្ស។ ជាងនេះទៀត សេចក្ដីពិតនេះ គឺមានលក្ខណៈខុសៗគ្នាពីមនុស្សម្នាក់ទៅកាន់មនុស្សម្នាក់ ហើយភាពជ្រាលជ្រៅរបស់វាទាក់ទងនឹងសភាវៈរបស់មនុស្សម្នាក់នោះ។ មនុស្សមិនអាចនិយាយត្រឹមថា ផ្លូវដែលគេដើរ គឺជាជីវិតជាមនុស្សធម្មតារបស់បុគ្គលម្នាក់ដែលកំពុងព្យាយាមឲ្យបានសេចក្ដីពិតឡើយ ហើយផ្លូវនេះក៏មិនត្រូវបានហៅថាជាផ្លូវដែលមនុស្សធម្មតាម្នាក់ដែលត្រូវបានស្រាយបំភ្លឺដោយព្រះវិញ្ញាណបរិសុទ្ធដើរនោះឡើយ។ គ្មាននរណាម្នាក់អាចនិយាយថា ផ្លូវដែលគេដើរជាផ្លូវដែលព្រះវិញ្ញាណបរិសុទ្ធដើរនោះឡើយ។ នៅក្នុងបទពិសោធរបស់មនុស្សធម្មតាៗ កិច្ចការរបស់ព្រះវិញ្ញាណរបស់បរិសុទ្ធក៏មិនដូចគ្នាដែរ ដ្បិតមនុស្សដែលព្យាយាមឲ្យបានសេចក្ដីពិតមិនដូចគ្នាទេ។ ជាងនេះទៀត ដោយសារមជ្ឈដ្ឋានដែលមនុស្សឆ្លងកាត់ និងកម្រិតបទពិសោធរបស់មនុស្សមិនដូចគ្នា ហើយក៏ដោយសារការរួមបញ្ចូលគ្នានៃគំនិត និងការរិះគិតរបស់គេបទពិសោធរបស់គេ លាយបញ្ចូលគ្នានៅក្នុងកម្រិតខុសៗគ្នាផងដែរ។ មនុស្សម្នាក់ៗ យល់អំពីសេចក្ដីពិតមួយ យោងទៅតាមសណ្ឋានខុសគ្នារៀងៗខ្លួន របស់គេដែរ។ ការយល់ដឹងអំពីអត្ថន័យពិតនៃសេចក្ដីពិតរបស់គេមិនពេញលេញ ហើយយល់តែមួយចំណុច ឬបីបួនចំណុចប៉ុណ្ណោះ។ ទំហំនៃសេចក្ដីពិតដែលមនុស្សមានបទពិសោធខុសៗគ្នាពីមនុស្សម្នាក់ទៅមនុស្សម្នាក់ ស្របតាមស្ថានភាពរបស់បុគ្គលម្នាក់ៗ។ ដូច្នេះចំណេះដឹងអំពីសេចក្ដីពិតដូចគ្នា ដែលត្រូវបានបង្ហាញដោយមនុស្សខុសៗគ្នា គឺមិនដូចគ្នាទេ។ មានន័យថា បទពិសោធរបស់មនុស្សមានកម្រិត និងមិន

អាចតំណាងឲ្យព្រះហឫទ័យនៃព្រះវិញ្ញាណបរិសុទ្ធទាំងស្រុងបានឡើយ ចំណែកឯកិច្ចការរបស់មនុស្ស ក៏មិនអាចរាប់ជាកិច្ចការរបស់ព្រះជាម្ចាស់បានដែរ បើទោះបីអ្វីដែលមនុស្សបង្ហាញចេញមកមានលក្ខណៈស្រដៀងនឹងព្រះហឫទ័យព្រះជាម្ចាស់ខ្លាំងក៏ដោយហើយទោះបីជាបទពិសោធរបស់មនុស្សហៀបត្រូវគ្នានឹងកិច្ចការប្រោសឲ្យបានគ្រប់លក្ខណ៍ដែលព្រះវិញ្ញាណបរិសុទ្ធធ្វើក៏ដោយ។ ទាល់តែមនុស្សធ្វើកិច្ចការដែលព្រះជាម្ចាស់ប្រទានឲ្យគេ ទើបគេអាចក្លាយខ្លួនជាអ្នកបម្រើរបស់ព្រះអង្គបាន។ មនុស្សអាចបង្ហាញត្រឹមចំណេះដឹងដែលត្រូវបានស្រាយបំភ្លឺដោយព្រះវិញ្ញាណបរិសុទ្ធ និងសេចក្ដីពិតដែលគេបានពីបទពិសោធផ្ទាល់របស់គេ។ មនុស្សគ្មានលក្ខណៈសម្បត្តិ និងមិនបំពេញតាមលក្ខខណ្ឌ ដើម្បីធ្វើជាមធ្យោបាយនៃព្រះវិញ្ញាណបរិសុទ្ធទេ។ គេពុំមានសិទ្ធិនិយាយថា កិច្ចការរបស់គេ ជាកិច្ចការរបស់ព្រះជាម្ចាស់នោះឡើយ។ មនុស្សមាន គោលការណ៍អនុវត្តកិច្ចការរបស់គេ ហើយមនុស្សទាំងអស់មានបទពិសោធខុសគ្នា និងមានស្ថានភាពដោយឡែកៗពីគ្នា។ កិច្ចការរបស់មនុស្ស រួមបញ្ចូលទាំងបទពិសោធទាំងអស់របស់គេ ស្ថិតនៅក្រោមការស្រាយបំភ្លឺរបស់ព្រះវិញ្ញាណបរិសុទ្ធ។ បទពិសោធទាំងនេះអាចត្រឹមជាតំណាងលក្ខណៈរបស់មនុស្ស និងមិនតំណាងលក្ខណៈរបស់ព្រះជាម្ចាស់ ឬតំណាងឲ្យព្រះហឫទ័យរបស់ព្រះវិញ្ញាណបរិសុទ្ធឡើយ។ ដូច្នេះ ផ្លូវដែលមនុស្សដើរ មិនអាចរាប់ជាផ្លូវដែលព្រះវិញ្ញាណបរិសុទ្ធដើរនោះឡើយ ដ្បិតកិច្ចការរបស់មនុស្សមិនតំណាងឲ្យកិច្ចការរបស់ព្រះជាម្ចាស់ឡើយ ហើយកិច្ចការ និងបទពិសោធរបស់មនុស្ស ក៏មិនមែនជាព្រះហឫទ័យដ៏ពេញលេញរបស់ព្រះវិញ្ញាណបរិសុទ្ធដែរ។ កិច្ចការរបស់មនុស្សងាយនឹងធ្លាក់ទៅក្នុងក្រឹត្យក្រមណាស់ ហើយទ្រឹស្ដីកិច្ចការរបស់គេក៏ងាយនឹងត្រូវបង្ខាំងក្នុងវិសាលភាពមានកម្រិតផងដែរ ព្រមទាំងមិនអាចដឹកនាំមនុស្សទៅរកផ្លូវ ដែលមានសេរីភាពទៀតផង។ អ្នកដើរតាមភាគច្រើនរស់នៅក្នុង វិសាលភាពមានកម្រិត ហើយវិធីដកពិសោធន៍របស់គេក៏មានកម្រិត ក្នុងវិសាលភាពរបស់វាដែរ។ បទពិសោធរបស់មនុស្សរមែងមានកម្រិត ទ្រឹស្ដីនៃកិច្ចការរបស់គេក៏មានកម្រិតទៅតាមប្រភេទមួយចំនួនតូច ហើយក៏មិនអាចធៀបទៅនឹងកិច្ច

ការរបស់ព្រះវិញ្ញាណបរិសុទ្ធ ឬក៏កិច្ចការរបស់ព្រះជាម្ចាស់ផ្ទាល់ដែរ។ នៅទីបំផុត នេះគឺដោយសារតែបទពិសោធរបស់មនុស្សនៅមានកម្រិត។ ព្រះជាម្ចាស់ធ្វើកិច្ចការរបស់ទ្រង់យ៉ាងណា កិច្ចការរបស់ទ្រង់នឹងសម្រេចយ៉ាងនោះ កិច្ចការនោះមិនត្រូវកំហិតដោយក្រឹត្យក្រមឡើយ ក៏មិនត្រូវកំណត់ដោយទ្រឹស្ដីណាមួយដែរ។ កិច្ចការរបស់ព្រះជាម្ចាស់ពុំមានក្រឹត្យក្រមអ្វីទាំងអស់ កិច្ចការទាំងអស់របស់ទ្រង់ត្រូវបានផ្សាយទៅនិងឥតដែនកំណត់។ មិនថាមនុស្ស ប្រើពេលវេលាដើរតាមទ្រង់យូរប៉ុនណានោះទេ គេមិនអាចព្រាងចេញជាក្រឹត្យក្រមណាមួយ មកគ្រប់គ្រងវិធីធ្វើការរបស់ព្រះជាម្ចាស់បានឡើយ។ ទោះបីជាកិច្ចការរបស់ទ្រង់ ផ្អែកលើគោលការណ៍ ក៏កិច្ចការនេះតែងត្រូវបានធ្វើឡើងតាមវិធីថ្មីៗ និងមានការអភិវឌ្ឍន៍ថ្មីជានិច្ច ហើយលើសពីគំនិតគិតដល់របស់មនុស្សទៀតផង។ ក្នុងរយៈពេលតែមួយគ្រា ព្រះជាម្ចាស់អាចមានកិច្ចការច្រើនប្រភេទខុសៗគ្នា និងមានវិធីដឹកនាំមនុស្សខុសៗគ្នាផងដែរ ធ្វើបែបនេះដើម្បីឲ្យមនុស្សមានច្រកទ្វារ និងការប្រែប្រួលថ្មីៗ។ អ្នកមិនអាចយល់ពីក្រឹត្យក្រមនៃកិច្ចការរបស់ទ្រង់ឡើយ ដ្បិតទ្រង់តែងធ្វើការតាមវិធីថ្មី ហើយទាល់តែយ៉ាងនេះ ទើបអ្នកដើរតាមព្រះជាម្ចាស់ មិនត្រូវបានកំហិតដោយក្រឹត្យក្រម។ កិច្ចការរបស់ព្រះជាម្ចាស់ផ្ទាល់រមែងចៀសឆ្ងាយពីសញ្ញាណរបស់មនុស្ស ហើយផ្ទុយពីពួកគេ។ មានតែមនុស្សដែលដើរតាម និងព្យាយាមឲ្យបានទ្រង់ដោយដួងចិត្តពិត ទើបធ្វើឲ្យនិស្ស័យរបស់គេត្រូវបំផ្លាស់បំប្រែ ហើយអាចរស់នៅដោយមានសេរីភាព មិនស្ថិតក្រោមក្រឹត្យក្រមណាមួយ ឬមួយក៏ត្រូវបង្ខាំងដោយសញ្ញាណសាសនានោះឡើយ។ កិច្ចការរបស់មនុស្សធ្វើការទាមទារពីមនុស្ស ដោយសម្អាងលើបទពិសោធរបស់គេផ្ទាល់ និងសម្អាងលើអ្វីដែលខ្លួនគេផ្ទាល់ អាចសម្រេចបាន។ បទដ្ឋាននៃលក្ខខណ្ឌទាំងនេះ ត្រូវបានកំហិតនៅក្នុងវិសាលភាពមួយជាក់លាក់ ចំណែកឯទ្រឹស្ដីនៃការអនុវត្តនានា ក៏មានតិចតួចណាស់ដែរ។ ដូច្នេះ អ្នកដើរតាមក៏រស់ក្នុងវិសាលភាពក្នុងកម្រិតនេះ ទាំងមិនដឹងខ្លួន។ លុះមួយរយៈក្រោយមក ទម្លាប់នេះក៏ក្លាយទៅជាក្រឹត្យក្រម និងជាទម្លាប់នៃការប្រារព្ធផ្សេងៗ។ ប្រសិនបើកិច្ចការក្នុងគ្រាមួយ ត្រូវបានដឹកនាំដោយមនុស្សម្នាក់ ដែល

មិនបានឆ្លង កាត់នូវការប្រោសឲ្យបានគ្រប់លក្ខណ៍ដោយព្រះជាម្ចាស់ផ្ទាល់ និងពុំបានទទួលនូវការជំនុំជម្រះ នោះអ្នកដើរតាមទ្រង់ទាំងអស់នឹងក្លាយជាសាសនិក និងជាអ្នកឯកទេសខាងប្រឆាំងទាស់នឹងព្រះជាម្ចាស់។ ដូច្នេះ ប្រសិនបើនរណាម្នាក់ជាអ្នកដឹកនាំដែលមានលក្ខណៈសម្បត្តិ បុគ្គលនោះត្រូវតែបានឆ្លងកាត់នូវការជំនុំជម្រះ និងបានទទួលនូវការប្រោសឲ្យបានគ្រប់លក្ខណ៍។ មនុស្សដែលមិនបានឆ្លងកាត់នូវការជំនុំជម្រះទោះបីជាពួកគេមានកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ក៏គេបង្ហាញត្រឹមតែកិច្ចការស្រពេចស្រពិល និងមិនប្រាកដប្រជាប៉ុណ្ណោះ។ យូរៗទៅ ពួកគេនឹងដឹកនាំមនុស្សទៅក្នុងក្រឹត្យក្រមស្រពេចស្រពិល និងហួសនិស្ស័យធម្មជាតិ។ កិច្ចការដែលព្រះជាម្ចាស់ធ្វើ គឺមិនសម្របនឹងសាច់ឈាមរបស់មនុស្សទេ។ កិច្ចការនេះសោត ក៏មិនសម្របនឹងការរិះគិតរបស់មនុស្សដែរ គឺមានតែផ្ទុយទៅនឹងសញ្ញាណរបស់មនុស្សវិញ កិច្ចការនេះមិនប្រឡាក់ប្រឡូសទៅនឹងការលាបពណ៌នៃសាសនាដ៏ស្រពេចស្រពិលនោះឡើយ។ លទ្ធផលកិច្ចការរបស់ព្រះជាម្ចាស់ មិនអាចសម្រេចបានដោយមនុស្សដែលពុំត្រូវបានប្រោសឲ្យបានគ្រប់លក្ខណ៍ដោយសារព្រះអង្គនោះឡើយ។ លទ្ធផលទាំងនេះ ហួសពីគំនិតគិតដល់របស់មនុស្សឆ្ងាយណាស់។

កិច្ចការនៅក្នុងគំនិតរបស់មនុស្ស ងាយស្រួលនឹងឲ្យមនុស្សសម្រេចបាន។ ឧទាហរណ៍ដូចជា គ្រូគង្វាល អ្នកដឹកនាំនៅក្នុងចង្កោមសាសនា សុទ្ធតែពឹងផ្អែកលើអំណោយទាន និងតួនាទីរបស់គេក្នុងការអនុវត្តកិច្ចការរបស់ខ្លួន។ មនុស្សដែលដើរតាមពួកគេយូរហើយនោះ គឺច្បាស់ជាត្រូវបណ្ដាលចិត្តដោយអំណោយទានរបស់ពួកគេ និងរងឥទ្ធិពលពីលក្ខណៈខ្លះរបស់គេមិនខាន។ ពួកគេផ្ដោតលើអំណោយទាន សមត្ថភាព និងចំណេះដឹងរបស់មនុស្ស ហើយពួកគេយកចិត្តទុកដាក់ចំពោះរឿងរ៉ាវដែលហួសវិស្ស័យធម្មជាតិ និងគោលលទ្ធិដែលជ្រាលជ្រៅ មិនប្រាកដប្រជា (ពិតណាស់ គោលលទ្ធិជ្រាលជ្រៅទាំងអស់នេះ គឺសុទ្ធតែរកយល់មិនដល់)។ ពួកគេមិនផ្ដោតលើការផ្លាស់ប្ដូរនិស្ស័យរបស់មនុស្សទេ ផ្ទុយទៅវិញ គេផ្ដោតតែលើការបណ្ដុះបណ្ដាលមនុស្សឲ្យចេះអធិប្បាយ និងចេះធ្វើការ ដោយបង្កើនចំណេះដឹងនិង

គោលលទ្ធិសាសនាដ៏សម្បូរបែបរបស់គេវិញ។ ពួកគេផ្ដោតទៅលើទំហំនិស្ស័យ ដែលត្រូវបានផ្លាស់ប្ដូររបស់មនុស្ស មិនផ្ដោតទៅលើទំហំនៃការយល់ដឹងរបស់មនុស្សចំពោះសេចក្ដីពិតនោះឡើយ។ ពួកគេមិនយកចិត្តគិតខ្វល់អំពីលក្ខណៈរបស់មនុស្សហើយ ពួកគេរឹតតែមិនព្យាយាមស្គាល់ពីសភាពធម្មតា និងមិនធម្មតារបស់មនុស្សឡើយ។ ពួកគេមិនប្រឆាំងនឹងសញ្ញាណរបស់មនុស្សឡើយ ហើយក៏មិនបង្ហាញសញ្ញាណរបស់គេដែរ កាន់តែលុបបំបាត់ចំណុចខ្វះខាត ឬសេចក្ដីពុករលួយរបស់មនុស្សដែរ។ មនុស្សភាគច្រើនដែលដើរតាមពួកគេ គេបម្រើដោយអំណោយទានហើយគ្រប់អ្វីដែលគេផ្សាយទៅ គឺសុទ្ធតែជាសញ្ញាណសាសនា និងទ្រឹស្ដីទេវសាស្ត្រ ដែលឆ្ងាយពីភាពជាក់ស្ដែង និងមិនផ្ដល់ឲ្យមនុស្សមានជីវិតផង។ តាមពិត លក្ខណៈនៃកិច្ចការរបស់ពួកគេគឺបណ្ដុះទេពកោសល្យ បណ្ដុះមនុស្សដែលគ្មានអ្វីសោះឲ្យក្លាយទៅជានិស្សិតសាលាព្រះគម្ពីរដែលមានទេពកោសល្យ ក្រោយមក ក៏បន្តទៅធ្វើកិច្ចការ រួចដឹកនាំ។ តើអ្នកអាចមើលឃើញនូវក្រឹត្យវិន័យណាមួយ ក្នុងកិច្ចការប្រាំមួយពាន់ឆ្នាំរបស់ព្រះជាម្ចាស់ដែរឬទេ? មានក្រឹត្យក្រម និងបម្រាមជាច្រើននៅក្នុងកិច្ចការដែលមនុស្សធ្វើ ហើយខួរក្បាលរបស់មនុស្សមានតាមសេចក្ដីជំនឿជ្រុល។ ដូច្នេះអ្វីដែលមនុស្សបង្ហាញចេញ គឺជាចំណេះដឹង និងការទទួលស្គាល់ ដែលស្ថិតក្នុងវិសាលភាពនៃបទពិសោធរបស់គេ។ មនុស្សមិនអាចបង្ហាញអ្វីផ្សេងពីនេះឡើយ។ បទពិសោធ និងចំណេះដឹងរបស់មនុស្ស មិនមែនកើតចេញពីអំណោយទានពីកំណើត ឬសភាវគតិរបស់គេឡើយ កត្តាទាំងនេះកើតឡើងដោយសារតែការដឹកនាំ និងការមើលថែដោយផ្ទាល់របស់ព្រះជាម្ចាស់។ មនុស្សមានតែញាណសតិទទួលយកនូវការ មើលថែនេះ និងគ្មានញាណសតិដែលអាចបង្ហាញឲ្យឃើញផ្ទាល់ថា អ្វីទៅជាទេវភាព។ មនុស្សពុំអាចធ្វើជាប្រភពទឹកបានឡើយ គេត្រឹមតែអាចធ្វើជាភាជនៈដែលទទួលយកទឹកមកពីប្រភពទឹកប៉ុណ្ណោះ។ នេះហើយជាសភាវគតិរបស់មនុស្ស ជាញាណសតិដែលមនុស្សគួរមាន ក្នុងនាមជាមនុស្ស។ ប្រសិនបើមនុស្សម្នាក់បាត់បង់ញាណសតិ ដែលទទួលយកព្រះបន្ទូលព្រះជាម្ចាស់ ហើយបាត់បង់សភាវគតិរបស់មនុស្ស មនុស្សម្នាក់

នោះ ក៏បាត់បង់នូវអ្វីដែលមានតម្លៃបំផុត ហើយបាត់បង់នូវភារកិច្ចជាមនុស្សដែលព្រះបង្កើត។ ប្រសិនបើបុគ្គលម្នាក់គ្មានចំណេះដឹង ឬបទពិសោធអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ ឬកិច្ចការរបស់ទ្រង់ បុគ្គលម្នាក់នោះក៏បាត់បង់ភារកិច្ចរបស់ខ្លួន ជាភារកិច្ចដែលគេគួរបំពេញក្នុងនាមជាមនុស្សដែលព្រះបង្កើត ព្រមទាំងបាត់បង់នូវសេចក្ដីថ្លៃថ្នូរក្នុងនាមជាមនុស្សដែលព្រះបង្កើតដែរ។ នេះជាសភាវគតិរបស់ព្រះជាម្ចាស់ ក្នុងការបង្ហាញថា អ្វីទៅជាទេវភាព មិនថាជាការបង្ហាញឲ្យឃើញតាមសាច់ឈាម ឬបង្ហាញដោយព្រះវិញ្ញាណបរិសុទ្ធផ្ទាល់។ នេះជាព័ន្ធកិច្ចរបស់ព្រះជាម្ចាស់។ មនុស្សបង្ហាញឲ្យឃើញ បទពិសោធ ឬចំណេះដឹងរបស់គេផ្ទាល់ (គឺបង្ហាញនូវ លក្ខណៈរបស់គេ) ក្នុងពេលព្រះជាម្ចាស់កំពុងធ្វើការ ឬក្រោយពេលទ្រង់ធ្វើការរួច។ នេះគឺជាសភាវគតិរបស់មនុស្ស និងជាសភាវគតិរបស់គេ ហើយគឺជាលទ្ធផលដែលមនុស្សគួរសម្រេចឲ្យបានដែរ។ ទោះបីការបង្ហាញឲ្យឃើញរបស់មនុស្ស ខុសឆ្ងាយពីអ្វីដែលព្រះជាម្ចាស់បង្ហាញឲ្យឃើញ ហើយទោះបីការបង្ហាញរបស់មនុស្ស ត្រូវកំហិតដោយក្រឹត្យក្រមច្រើនក៏ដោយ ក៏មនុស្សត្រូវបំពេញភារកិច្ចដែលគេគួរបំពេញ ហើយធ្វើអ្វីដែលគេត្រូវធ្វើ។ មនុស្សគប្បីធ្វើគ្រប់យ៉ាងដែលមនុស្សអាចធ្វើបាន ដើម្បីបំពេញភារកិច្ចរបស់គេ ហើយគេពុំគួរមានចិត្តស្ទាក់ស្ទើរ សូម្បីតែបន្តិច។

បន្ទាប់ពីធ្វើការអស់ជាច្រើនឆ្នាំ មនុស្សនឹងសង្ខេបបទពិសោធការងារជាច្រើនឆ្នាំរបស់គេ ព្រមទាំងបញ្ញា និងក្រឹត្យក្រមដែលគេទទួលបាន។ មនុស្សដែលបានធ្វើការយូរមកហើយ គេចេះពីវិធីជ្រាបដឹងនូវចលនាកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធគេដឹងថាព្រះវិញ្ញាណបរិសុទ្ធធ្វើការនៅពេលណា ហើយមិនធ្វើការនៅពេលណា។ គេចេះពីវិធីប្រកបគ្នា ពេលកំពុងស្ពាយបន្ទុក ហើយគេដឹងពីសភាពធម្មតានៃកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ និងសភាពធម្មតានៃការលូតលាស់របស់មនុស្សនៅក្នុងជីវិត។ បុគ្គលបែបនេះ ជាបុគ្គលដែលធ្វើការរាប់សិបឆ្នាំ ហើយស្គាល់កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ។ មនុស្សដែលបានធ្វើការយូរឆ្នាំ និយាយស្ដីដោយភាពជឿជាក់ និងមិនប្រញាប់ប្រញាល់ សូម្បីតែពេលដែលគេគ្មានអ្វីនិយាយសោះ ក៏គេមានចរិត

ស្រគត់ស្រគំដែរ។ ពួកគេអាចបន្តអធិស្ឋានស្វែងរកកិច្ចការព្រះវិញ្ញាណបរិសុទ្ធនៅក្នុងចិត្តរបស់គេ។ ពួកគេថ្មឹកនឹងការធ្វើកិច្ចការ។ បុគ្គលម្នាក់ដែលធ្លាប់ធ្វើការយូរ បុគ្គលដែលមានបទពិសោធច្រើន ហើយបានរៀនមេរៀនច្រើន នៅក្នុងចិត្តគេមានឧបសគ្គច្រើនណាស់ ដែលរារាំងដល់កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ។ នេះជាគុណវិបត្តិនៃកិច្ចការរយៈពេលវែងរបស់គេ។ បុគ្គលម្នាក់ដែលទើបចាប់ផ្ដើមធ្វើការ គេមិនត្រូវបង្វែរដោយមេរៀន ឬបទពិសោធរបស់មនុស្សទេ ហើយជាពិសេស គឺគេក៏មិនដឹងអំពីរបៀបដែលព្រះវិញ្ញាណបរិសុទ្ធធ្វើការដែរ។ យ៉ាងណាមិញ ក្នុងអំឡុងពេលកំពុងតែធ្វើការ គេក៏រៀនសម្គាល់កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ និងសម្គាល់កិច្ចការដែលត្រូវធ្វើ ដើម្បីទទួលបានកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ជាកិច្ចការដែលត្រូវធ្វើ ដើម្បីចាក់ឲ្យចំភាពងាយរងគ្រោះរបស់អ្នកដទៃ និងចំណេះដឹងទូទៅដទៃផ្សេងទៀត ដែលអ្នកធ្វើការគួរតែមាន។ លុះយូរទៅ គេក៏ចាប់ផ្ដើមស្គាល់ប្រាជ្ញា និងចំណេះដឹងទូទៅនៃកិច្ចការទាំងអស់នេះ ដូចខ្នងដៃរបស់គេ ហើយគេក៏ដូចជាប្រើប្រាស់កត្តាទាំងអស់នេះ បានយ៉ាងងាយ ពេលកំពុងធ្វើការ។ ដោយឡែក ពេលដែលព្រះវិញ្ញាណបរិសុទ្ធផ្លាស់ប្ដូរវិធីដែលមនុស្សធ្វើការ គេក៏នៅតែប្រកាន់ខ្ជាប់នូវចំណេះដឹង និងក្រឹត្យក្រមនៃកិច្ចការចាស់គំរិល ហើយមិនសូវស្គាល់ពីឪណាមិកថ្មីៗនៃកិច្ចការនោះឡើយ។ រយៈពេលរាប់សិបឆ្នាំនៃកិច្ចការ និងការពេញដោយវត្តមាន ហើយនិងការដឹកនាំនៃព្រះវិញ្ញាណបរិសុទ្ធ ផ្ដល់ឲ្យគេនូវមេរៀនស្ដីអំពីកិច្ចការនេះ និងផ្ដល់បទពិសោធដល់គេកាន់តែច្រើន។ កត្តានេះធ្វើឲ្យគេមានពេញដោយភាពជឿជាក់លើខ្លួនឯង មិនមែនជាអំណួតឡើយ។ និយាយបានម្យ៉ាងទៀតថា គេពេញចិត្តនឹងកិច្ចការរបស់គេផ្ទាល់ណាស់ ហើយស្កប់ចិត្តនឹងចំណេះដឹងទូទៅដែលគេបានទទួលស្ដីពីកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធផងដែរ។ ជាពិសេស ក្រោយពេលគេបានទទួល ឬបានស្គាល់នូវសេចក្ដីដែលអ្នកដទៃមិនបានស្គាល់ ក៏ផ្ដល់ឲ្យគេនូវភាពជឿជាក់លើខ្លួនឯងកាន់តែច្រើន។ មើលទៅកិច្ចការដែលព្រះវិញ្ញាណបរិសុទ្ធមាននៅក្នុងគេ ហាក់បីដូចជាមិនអាចពន្លត់បានឡើយ ខណៈដែលអ្នកផ្សេងទៀត គេគ្មានលក្ខណៈសម្បត្តិនឹងទទួលប្រព្រឹត្តកម្មពិសេសនេះ

ឡើយ។ មានតែមនុស្សប្រភេទនេះ គឺជាមនុស្សដែលបានធ្វើការរាប់ឆ្នាំ ហើយការប្រើពួកគេមានតម្លៃគួរពិចារណា ទើបមានលក្ខណៈសម្បត្តិនឹងអាស្រ័យផលប្រព្រឹត្តកម្មនេះបាន។ សេចក្ដីទាំងនេះក៏ក្លាយជាឧបសគ្គដ៏ធំមួយចំពោះការដែលគេទទួលកិច្ចការថ្មីរបស់ព្រះវិញ្ញាណបរិសុទ្ធដែរ។ បើទោះបីជាគេអាចទទួលកិច្ចការថ្មី ក៏គេមិនអាចធ្វើដូច្នេះបាន តែក្នុងរយៈពេលមួយយប់ដែរ។ គេមុខជាត្រូវឆ្លងកាត់នូវការបត់បែន និងការប្រែប្រួលមួយចំនួនធំ មុនពេលទទួលកិច្ចការថ្មីនេះ។ ស្ថានភាពអាចនឹងបញ្ច្រាសវិញសន្សឹមៗបាន លុះត្រាតែសញ្ញាណចាស់គំរិលរបស់គេត្រូវបានដោះស្រាយហើយ និស្ស័យចាស់របស់គេត្រូវបានជំនុំជម្រះ។ បើគ្មានការឆ្លងកាត់ដំណាក់កាលទាំងនេះទេ គេក៏បោះបង់ទម្លាប់ចាស់ ហើយទទួលយកនូវសេចក្ដីបង្រៀន និងកិច្ចការថ្មីៗដែលមិនស្របទៅនឹងសញ្ញាណចាស់គំរិលរបស់គេដែរ។ នេះជារឿងលំបាកដោះស្រាយជាមួយបំផុតនៅក្នុងជីវិតមនុស្ស ហើយក៏មិនងាយនឹងផ្លាស់ប្ដូរដែរ។ ក្នុងនាមជាអ្នកធ្វើការម្នាក់ ប្រសិនបើមិនអាចសម្រេចបានការយល់ដឹងអំពីកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ និងធ្វើការសង្ខេបនូវសក្ដានុពលនៃកិច្ចការនោះភ្លាមៗ ហើយប្រសិនបើគេអាចនៅក្រៅកំហិតបទពិសោធនៃកិច្ចការរបស់គេ ហើយអាចទទួលកិច្ចការថ្មី ដោយសារកិច្ចការចាស់ នោះគេគឺជាមនុស្សឈ្លាសវៃ ហើយជាអ្នកធ្វើការដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ហើយ។ មនុស្សរមែងមានលក្ខណៈដូច្នេះ៖ ពួកគេធ្វើការបីបួនឆ្នាំ ទាំងមិនអាចសង្ខេបបទពិសោធកិច្ចការរបស់គេ បន្ទាប់ពីសង្ខេបនូវបទពិសោធ និងប្រាជ្ញារបស់គេ ទាក់ទងនឹងកិច្ចការ ឬក៏ពួកគេត្រូវរារាំងមិនឲ្យទទួលកិច្ចការថ្មី និងមិនអាចយល់ដឹងឲ្យបានត្រឹមត្រូវ ឬមិនអាចប្រព្រឹត្តចំពោះកិច្ចការ និងកិច្ចការថ្មីឲ្យបានត្រឹមត្រូវឡើយ។ មនុស្សពិតជាពិបាកគ្រប់គ្រងណាស់! អ្នករាល់គ្នាភាគច្រើន គឺសុទ្ធតែបែបនេះ។ មនុស្សដែលបានឆ្លងកាត់នឹងកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធរាប់សិបឆ្នាំ ពិបាកទទួលកិច្ចការថ្មី ហើយពួកគេរមែងសម្បូរដោយសញ្ញាណដែលគេមិនអាចបោះបង់ចោលបាន ខណៈមនុស្សដែលទើបតែចាប់ផ្ដើមធ្វើការ គេខ្វះចំណេះដឹងទូទៅ ហើយមិនទាំងដឹងពីវិធីដោះស្រាយបញ្ហាងាយៗមួយចំនួនផង។ មនុស្សដូចជាអ្នករាល់គ្នា ពិតជាពិបាក

ណាស់! មនុស្សដែលមានវ័យចាស់ មានអំនួតជ្រុល ទាំងអួតថាពួកគេបានភ្លេចថាពួកគេមកពីណាហើយ។ ពួកគេតែងមើលងាយមនុស្សដែលមានវ័យក្មេងជាងខ្លួន ប៉ុន្តែពួកគេមិនអាចទទួលកិច្ចការថ្មី និងមិនអាចបោះបង់ចោលសញ្ញាណដែលបានប្រមូល និងរក្សាទុកជាច្រើនឆ្នាំមកនេះ។ ចំពោះយុវវ័យល្ងង់ខ្លៅទាំងនេះ អាចទទួលកិច្ចការថ្មីរបស់ព្រះវិញ្ញាណបរិសុទ្ធបានតិចតួច និងមានចិត្តឆេះឆួលខ្លាំងក៏ដោយក៏ពួកគេតែងតែច្រឡំ និងមិនដឹងជាត្រូវធ្វើអ្វី នៅពេលដែលមានបញ្ហាកើតឡើង។ ពួកគេមានចិត្តឆេះឆួលតែល្ងង់ខ្លៅ។ ពួកគេមានការយល់ដឹងតិចតួច អំពីកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ហើយមិនអាចប្រើការយល់ដឹងនេះនៅក្នុងជីវិតរបស់គេនោះឡើយ។ ការយល់ដឹងនោះ គឺជាគោលលទ្ធិឥតប្រយោជន៍ទាំងស្រុងតែម្ដង។ មានមនុស្សច្រើនណាស់ដែលមានលក្ខណៈដូចជាអ្នករាល់គ្នា។ តើមនុស្សប៉ុន្មាននាក់ស័ក្តិសមសម្រាប់ប្រើប្រាស់? តើមានមនុស្សប៉ុន្មាននាក់ ដែលអាចស្ដាប់តាមការស្រាយបំភ្លឺរបស់ព្រះវិញ្ញាណបរិសុទ្ធ ហើយព្យាយាមស្របតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់? តាមមើលទៅ អ្នកខ្លះនៅក្នុងចំណោមអ្នករាល់គ្នាដែលធ្លាប់ធ្វើជាអ្នកដើរតាមរហូតមកទល់ពេលនេះ សុទ្ធតែជាមនុស្សស្ដាប់បង្គាប់រហូតមក តែតាមពិតអ្នកមិនបានបោះបង់ចោលនូវសញ្ញាណរបស់អ្នករាល់គ្នាសោះ អ្នកនៅតែស្វែងរកក្នុងព្រះគម្ពីរ ជឿលើភាពស្រពេចស្រពិល ឬវិលវល់នៅក្នុងសញ្ញាណទាំងនោះ។ ពុំមានអ្នកណាស្រាវជ្រាវកិច្ចការជាក់ស្ដែងនាពេលសព្វថ្ងៃនេះ ដោយយកចិត្តទុកដាក់ឬសិក្សាអំពីកិច្ចការនេះស៊ីជម្រៅឡើយ។ អ្នករាល់គ្នាកំពុងទទួលយកកិច្ចការសព្វថ្ងៃជាមួយសញ្ញាណចាស់របស់អ្នក។ ជាមួយនឹងជំនឿបែបនេះ តើអ្នករាល់គ្នាទទួលបានអ្វី? អាចនិយាយបានថា នៅក្នុងអ្នករាល់គ្នាមានបង្កប់នូវសញ្ញាណជាច្រើនដែលមិនត្រូវបានបើកសម្ដែង ហើយអ្នករាល់គ្នាក៏កំពុងប្រឹងប្រែងជាខ្លាំង ដើម្បីលាក់កំបាំងសញ្ញាណទាំងនេះ ដោយមិនបង្ហាញវាចេញមកងាយៗនោះឡើយ។ អ្នករាល់គ្នាមិនទទួលកិច្ចការថ្មីដោយចិត្តស្មោះត្រង់ ហើយអ្នកមិនគ្រោងបោះបង់សញ្ញាណចាស់របស់ខ្លួននោះដែរ អ្នករាល់គ្នាមានទស្សនវិជ្ជាច្រើនពេកសម្រាប់ការរស់នៅ ហើយទស្សនវិជ្ជាទាំងនោះសំខាន់ជ្រុល។ អ្នករាល់គ្នាមិនបោះបង់ចោល

សញ្ញាណចាស់របស់ខ្លួន ហើយអ្នកដោះស្រាយជាមួយកិច្ចការថ្មីទាំងស្ទាក់ស្ទើរ។ ចិត្តរបស់អ្នកអាក្រក់ ហើយអ្នកមិននឹកចាំជំហានកិច្ចការថ្មី ក្នុងចិត្តរបស់អ្នកតែម្តង។ តើមនុស្សខ្ជីខ្ជាដូចជាអ្នករាល់គ្នា អាចធ្វើកិច្ចការផ្សាយដំណឹងល្អបានដែរឬទេ? តើអ្នកអាចអនុវត្តកិច្ចការផ្សាយដំណឹងល្អ ទៅកាន់សកលលោកទាំងមូលបានដែរឬទេ? ការអនុវត្តរបស់អ្នករាល់គ្នានេះ កំពុងតែបង្ខាំងអ្នករាល់គ្នា ពីការបំផ្លាស់បំប្រែនិស្ស័យរបស់អ្នករាល់គ្នា និងមិនឲ្យអ្នករាល់គ្នាស្គាល់ព្រះជាម្ចាស់។ ប្រសិនបើអ្នករាល់គ្នានៅតែបែបនេះ អ្នកនឹងត្រូវផាត់ចោលមិនខាន។

អ្នករាល់គ្នាត្រូវដឹងពីវិធីវែកញែកកិច្ចការរបស់ព្រះជាម្ចាស់ ចេញពីកិច្ចការរបស់មនុស្ស។ តើអ្នកអាចមើលឃើញអ្វីខ្លះ នៅក្នុងកិច្ចការរបស់មនុស្ស? មានចំណុចសំខាន់ៗជាច្រើនក្នុងបទពិសោធរបស់មនុស្ស ក្នុងកិច្ចការរបស់គេ អ្វីដែលគេបង្ហាញចេញមក គឺជាលក្ខណៈរបស់គេ។ កិច្ចការរបស់ព្រះជាម្ចាស់ផ្ទាល់ក៏បង្ហាញលក្ខណៈរបស់ទ្រង់ដែរ តែលក្ខណៈរបស់ទ្រង់ ខុសគ្នាពីលក្ខណៈរបស់មនុស្ស។ លក្ខណៈរបស់មនុស្សតំណាងឲ្យបទពិសោធ និងជីវិតរបស់គេ (អ្វីៗដែលមនុស្សមានបទពិសោធ ឬជួបប្រទះនៅក្នុងជីវិតរបស់គេ ឬជាទស្សនវិជ្ជា ដែលគេមានសម្រាប់ការរស់នៅ) ហើយមនុស្សដែលកំពុងរស់នៅក្នុងបរិយាកាសខុសៗគ្នាក៏បង្ហាញចេញនូវលក្ខណៈខុសៗគ្នាដែរ។ ទោះបីជាអ្នក មានបទពិសោធច្រើនទាក់ទងនឹងសង្គម និងរបៀបដែលអ្នករាល់គ្នារស់នៅជាក់ស្តែង នៅក្នុងគ្រួសាររបស់អ្នក ហើយមានបទពិសោធក្នុងគ្រួសារ នេះក៏អាចត្រូវបានមើលឃើញក្នុងអ្វីដែលអ្នកបង្ហាញចេញឲ្យឃើញ ប៉ុន្តែអ្នកមិនអាចមើលឃើញក្នុងកិច្ចការនៃព្រះដែលយកកំណើតជាសាច់ឈាមឡើយ ទោះបីជាទ្រង់មានបទពិសោធក្នុងសង្គមក៏ដោយ។ ទ្រង់ជ្រាបច្បាស់អំពីសារៈសំខាន់របស់មនុស្ស ហើយអាចសម្តែងចេញនូវការអនុវត្តគ្រប់យ៉ាង ទាក់ទងនឹងមនុស្សគ្រប់ប្រភេទទាំងអស់។ ព្រះអង្គរឹតតែពូកែខាងបើកបង្ហាញអំពីនិស្ស័យពុករលួយ និងឥរិយាបថបះបោររបស់មនុស្ស។ ព្រះអង្គមិនរស់នៅក្នុងចំណោមមនុស្សលោកនេះទេ តែទ្រង់ជ្រាបអំពីសន្តានរបស់មនុស្ស និងចរិតពុករលួយរបស់មនុស្សលោកដែរ។

នេះហើយគឺជាលក្ខណៈរបស់ព្រះអង្គ។ ទោះបីជាព្រះអង្គមិនដោះស្រាយជាមួយនឹងលោកិយ ក៏ទ្រង់ជ្រាបអំពីក្រឹត្យក្រមនៃការដោះស្រាយជាមួយលោកិយ ដ្បិតទ្រង់យល់ពីសន្ដានរបស់មនុស្សយ៉ាងពេញលេញ។ ព្រះអង្គជ្រាបអំពីកិច្ចការរបស់ព្រះវិញ្ញាណថា ភ្នែករបស់មនុស្សពុំអាចមើលឃើញ ហើយត្រចៀករបស់មនុស្សក៏មិនអាចស្ដាប់ឮទាំងកិច្ចការក្នុងពេលបច្ចុប្បន្ន និងកិច្ចការពីអតីតកាល។ កត្ដានេះបូករួមទាំងប្រាជ្ញាដែលមិនមែនជាទស្សនវិជ្ជា សម្រាប់ការរស់នៅ និងការអស្ចារ្យដែលមនុស្សពិបាកនឹងយល់។ នេះជាលក្ខណៈរបស់ទ្រង់ បើកទូលាយដល់មនុស្ស តែក៏លាក់កំបាំងពីមនុស្សដែរ។ អ្វីដែលទ្រង់បង្ហាញចេញ មិនមែនជាលក្ខណៈនៃបុគ្គលអស្ចារ្យនោះទេ តែគឺជាលក្ខណៈដែលទ្រង់មានតាំងតែពីដើម និងលក្ខណៈជាព្រះវិញ្ញាណ។ ព្រះអង្គមិនយាងជុំវិញផែនដីទេតែទ្រង់ជ្រាបគ្រប់យ៉ាងអំពីផែនដី។ ទ្រង់ទាក់ទង «មនុស្ស» ដែលគ្មានចំណេះដឹង ឬតម្រិះ ប៉ុន្ដែទ្រង់បើកសម្ដែងនូវព្រះបន្ទូលដែលឧត្ដុង្គឧត្ដមជាងចំណេះដឹង ហើយខ្ពស់លើសមនុស្សអស្ចារ្យផង។ ព្រះអង្គគង់នៅក្នុងចំណោមមនុស្សខ្សោយបញ្ញា និងមនុស្សទំរន់ ជាមនុស្សដែលពុំមានភាពជាមនុស្ស ហើយក៏មិនយល់ពីទម្លាប់ និងជីវិតរបស់មនុស្សជាតិ ប៉ុន្ដែទ្រង់អាចបង្គាប់ឲ្យមនុស្សជាតិស្ដែងចេញមកនូវភាពជាមនុស្សធម្មតា តាមការរស់នៅរបស់គេ ទាំងបង្ហាញពីមូលដ្ឋាន និងភាពជាមនុស្សតូចទាបរបស់មនុស្សជាតិ ក្នុងពេលជាមួយគ្នាដែរ។ ទាំងអស់នេះសុទ្ធតែជាលក្ខណៈរបស់ទ្រង់ ជាលក្ខណៈដែលខ្ពង់ខ្ពស់ជាងលក្ខណៈរបស់មនុស្សគ្រប់ៗគ្នា ដែលមានសាច់និងឈាម។ ចំពោះព្រះអង្គ ការទទួលបានបទពិសោធជីវិតសង្គមដ៏ស្មុគស្មាញ លំបាកលំបិន និង គួរស្អប់ខ្ពើម ដើម្បីធ្វើកិច្ចការដែលទ្រង់ត្រូវធ្វើ និងដើម្បីបើកសម្ដែងអំពីសារៈសំខាន់នៃចរិតពុករលួយរបស់មនុស្សឲ្យបានហ្មត់ចត់នោះ គឺវាមិនចាំបាច់ទេ។ ជីវិតសង្គមគួរឲ្យស្អប់ មិនទូន្មានសាច់ឈាមរបស់ទ្រង់បានឡើយ។ កិច្ចការ និងព្រះបន្ទូលរបស់ទ្រង់ បើកសម្ដែងត្រឹមតែភាពរឹងចចេសរបស់មនុស្ស និងមិនផ្ដល់នូវបទពិសោធ និងមេរៀនសម្រាប់ការដោះស្រាយនឹងលោកិយនេះឡើយ។ ព្រះអង្គមិនចាំបាច់ស្រាវជ្រាវអំពីសង្គម ឬគ្រួសាររបស់មនុស្សនៅពេល

ដែលទ្រង់ប្រទាននូវជីវិតដល់មនុស្សឡើយ។ ការលាតត្រដាង និងការជំនុំជម្រះមនុស្ស ពុំមែនជាការបង្ហាញអំពីបទពិសោធខាងសាច់ឈាមរបស់ទ្រង់ទេ វាជាការបើកសម្ដែងអំពីភាពទុច្ចរិតរបស់មនុស្ស បន្ទាប់ពីបានស្គាល់ចរិតរឹងចចេសរបស់គេយូរមកហើយ និងជាការស្អប់ខ្ពើមចរិតពុករលួយរបស់មនុស្សជាតិ។ កិច្ចការគ្រប់យ៉ាងដែលទ្រង់ធ្វើ គឺសុទ្ធតែដើម្បីបង្ហាញអំពីនិស្ស័យរបស់ទ្រង់ដល់មនុស្សលោក និងដើម្បីបង្ហាញអំពីលក្ខណៈរបស់ទ្រង់។ មានតែទ្រង់ទេទើបអាចធ្វើកិច្ចការនេះបាន កិច្ចការនេះមិនមែនជាកិច្ចការដែលមនុស្សសាច់ឈាមអាចសម្រេចបាននោះទេ។ តាមរយៈកិច្ចការរបស់ទ្រង់ មនុស្សមិនអាចប្រាប់បានទេថា ទ្រង់ជាបុគ្គលបែបណា។ មនុស្សក៏មិនអាចចាត់ថ្នាក់ទ្រង់ថាជាមនុស្សដែលត្រូវបានបង្កើត ដោយសម្អាងលើកិច្ចការរបស់ទ្រង់ដែរ។ លក្ខណៈរបស់ទ្រង់ក៏ធ្វើឲ្យគេមិនអាចចាត់ថ្នាក់ទ្រង់ជាមនុស្សដែលត្រូវបានបង្កើតមកឡើយ។ មនុស្សអាចត្រឹមចាត់ទុកព្រះអង្គជាជីវិតមួយដែលមិនមែនជាមនុស្ស ប៉ុន្តែមិនដឹងចាត់ថ្នាក់ ទ្រង់ក្នុងប្រភេទមួយណាឡើយ ដូច្នេះមនុស្សត្រូវបង្ខំចាត់ថ្នាក់ព្រះអង្គនៅក្នុងក្រុមអាទិទេពវិញ។ ការដែលមនុស្សធ្វើដូច្នេះ ក៏មិនមែនមិនសមហេតុផលដែរ ដ្បិតព្រះជាម្ចាស់បានធ្វើកិច្ចការជាច្រើនក្នុងចំណោមមនុស្ស ដែលសុទ្ធតែជាកិច្ចការដែលមនុស្សមិនអាចធ្វើបាន។

កិច្ចការដែលព្រះជាម្ចាស់ធ្វើ មិនមែនជាតំណាងឲ្យបទពិសោធនៃសាច់ឈាមរបស់ទ្រង់ទេ កិច្ចការដែលមនុស្សធ្វើជាតំណាងឲ្យបទពិសោធរបស់គេ។ គ្រប់គ្នាសុទ្ធតែជជែកអំពីបទពិសោធផ្ទាល់ខ្លួន។ ព្រះជាម្ចាស់អាចបង្ហាញនូវសេចក្ដីពិតដោយផ្ទាល់ ចំណែកមនុស្សវិញអាចត្រឹមបង្ហាញបទពិសោធ ដែលស្របនឹងសេចក្ដីពិតដែលគេមានពិសោធវិញ។ កិច្ចការរបស់ព្រះគ្មានក្រឹត្យក្រម ហើយក៏មិនចំណុះនឹងពេលវេលា និងកំហិតភូមិសាស្ត្រដែរ។ ទ្រង់អាចបង្ហាញពីលក្ខណៈរបស់ទ្រង់បានគ្រប់ពេលវេលា គ្រប់ទីកន្លែង។ ទ្រង់ធ្វើការតាមតែទ្រង់សព្វព្រះទ័យ។ កិច្ចការរបស់មនុស្សមានលក្ខខណ្ឌ និងបរិបទ ប្រសិនបើគ្មានវា ពួកគេក៏មុខជាមិនអាចធ្វើការ និងមិនអាចបង្ហាញចំណេះដឹងរបស់គេចំពោះព្រះជាម្ចាស់ ឬបទពិសោធរបស់គេចំពោះសេចក្ដីពិតបានឡើយ។

ដើម្បីប្រាប់ថា កិច្ចការនោះជាកិច្ចការរបស់ព្រះជាម្ចាស់ផ្ទាល់ ឬកិច្ចការរបស់មនុស្ស គឺអ្នកត្រូវតែប្រៀបធៀបពីភាពខុសគ្នារវាងកិច្ចការទាំងពីរនេះ។ ប្រសិនបើពុំមានកិច្ចការណាមួយត្រូវបានធ្វើដោយព្រះជាម្ចាស់ផ្ទាល់ទេ និងមានតែកិច្ចការរបស់មនុស្ស អ្នកនឹងដឹងយ៉ាងងាយថា សេចក្តីបង្រៀនរបស់មនុស្សមានកម្រិតខ្ពស់លើស សមត្ថភាពរបស់មនុស្សផ្សេងៗទៀត សូរសម្តីរបស់គេ គោលការណ៍ដោះស្រាយការងាររបស់គេ និងបទពិសោធ ព្រមទាំងឥរិយាបថនឹងនរបស់គេក្នុងការធ្វើការងារ គឺលេចធ្លោជាងអ្នកដទៃ។ អ្នករាល់គ្នា គឺសុទ្ធតែស្ញប់ស្ញែងមនុស្ស ដែលមានគុណសម្បត្តិល្អ និងមានចំណេះដឹងខ្ពង់ខ្ពស់ទាំងអស់នេះ ប៉ុន្តែតាមកិច្ចការ និងព្រះបន្ទូលរបស់ព្រះជាម្ចាស់ អ្នកមិនអាចមើលឃើញថា នរភាពរបស់ទ្រង់ឧត្តុង្គឧត្តមយ៉ាងណានោះឡើយ។ ផ្ទុយទៅវិញ ទ្រង់គឺមានភាពសាមញ្ញហើយពេលកំពុងធ្វើការ ទ្រង់ជាមនុស្សធម្មតា និងជាមនុស្សពិតម្នាក់ តែទ្រង់ក៏ជាបុគ្គលដែលមនុស្សទូទៅមិនអាចវាស់ស្ទង់បានដែរ កត្តានេះហើយដែលធ្វើឲ្យមនុស្សមានអារម្មណ៍កោតខ្លាចចំពោះទ្រង់ខ្លះដែរ។ ប្រហែលជាបទពិសោធនៅក្នុងកិច្ចការរបស់មនុស្សម្នាក់ឈានមុខគេជាពិសេស ឬការស្រមើស្រមៃ និងការរិះរកឈានមុខគេជាពិសេស ចំណែកឯភាពជាមនុស្សរបស់គេ ក៏ល្អជាពិសេសដែរ។ លក្ខណៈសម្បត្តិបែបនេះអាចទទួលបានត្រឹមការសរសើររបស់មនុស្ស ប៉ុណ្ណោះ ប៉ុន្តែមិនជំរុញឲ្យមាននូវការស្ញប់ស្ញែង និងការ កោតខ្លាចនោះទេ។ មនុស្សទាំងអស់សរសើរអស់អ្នកដែលធ្វើការបានល្អ អ្នកដែលមានបទពិសោធស៊ីជម្រៅជាពិសេស និងអស់អ្នកដែលអាចអនុវត្តសេចក្តីពិត តែមនុស្សបែបនេះ មិនអាចទទួលបានការស្ញប់ស្ញែងសោះ មានតែការសរសើរ និងការច្រណែនប៉ុណ្ណោះ។ ដោយឡែក មនុស្សដែលបានមានបទពិសោធអំពីកិច្ចការរបស់ព្រះជាម្ចាស់ ពួកគេមិនសរសើរព្រះជាម្ចាស់នោះទេ ផ្ទុយទៅវិញ ពួកគេគិតថា កិច្ចការរបស់ទ្រង់ មនុស្សឈោងមិនដល់ និងរកគិតមិនយល់ផង ដ្បិតកិច្ចការនោះថ្មីស្រឡាង ហើយអស្ចារ្យផង។ កាលណាមនុស្សមានបទពិសោធអំពីកិច្ចការរបស់ព្រះជាម្ចាស់ ចំណេះដឹងទីមួយដែលគេមានចំពោះព្រះអង្គ គឺទ្រង់ជាព្រះដែលយល់មិនបានឈ្លាសវៃ និងអស្ចារ្យ ហើយពួកគេកោតខ្លាច

ទ្រង់ទាំងមិនដឹងខ្លួន ហើយដឹងអំពីអាថ៌កំបាំងនៃកិច្ចការដែលទ្រង់ធ្វើ ជាកិច្ចការដែលហួសពីការយល់ដឹងនៃគំនិតរបស់មនុស្ស។ មនុស្សចង់ត្រឹមអាចបំពេញសេចក្តីតម្រូវរបស់ទ្រង់ ចង់ផ្តាប់តាមព្រះទ័យចង់បានរបស់ទ្រង់ ពួកគេមិនចង់ឲ្យលើសព្រះអង្គឡើយ ដ្បិតកិច្ចការដែលមនុស្សធ្វើ ហើសពីការគិត និងការស្រមើស្រមៃរបស់មនុស្ស ហើយក៏ពុំមានមនុស្សណាអាចធ្វើជំនួសទ្រង់បានដែរ។ សូម្បីមនុស្សខ្លួនឯង ក៏មិនស្គាល់សេចក្តីកម្សោយរបស់ខ្លួនផង ប៉ុន្តែព្រះបានបង្កើតផ្លូវថ្មីមួយ ហើយមានយាងមកនាំមនុស្សទៅក្នុងពិភពមួយថ្មី និងស្រស់ស្អាតជាងមុន ដូច្នេះមនុស្សជាតិបានបង្កើតនូវវឌ្ឍនភាពថ្មី ហើយមានការចាប់ផ្តើមមួយថ្មីផងដែរ។ អ្វីដែលមនុស្សគិតចំពោះព្រះជាម្ចាស់គឺមិនមែនជាការសរសើរទេ ម្យ៉ាងទៀត វាក៏មិនមែនត្រឹមតែជាការសរសើរដែរ។ បទពិសោធដ៏ស៊ីជម្រៅបំផុតរបស់គេ គឺ ការស្ញប់ស្ញែង និងសេចក្តីស្រឡាញ់។ អារម្មណ៍ដែលគេមានគឺ ព្រះជាម្ចាស់ពិតជាអស្ចារ្យខ្លាំងណាស់។ ទ្រង់ធ្វើកិច្ចការដែលមនុស្សមិនអាចធ្វើបាន ហើយមានបន្ទូលនូវសេចក្តីដែលមនុស្សមិនអាចនិយាយបាន។ មនុស្សដែលបានស្គាល់កិច្ចការរបស់ព្រះជាម្ចាស់ តែងតែមានអារម្មណ៍ដែលពុំអាចបរិយាយបាន។ មនុស្សដែលមានបទពិសោធស៊ីជម្រៅគួរសម អាចយល់អំពីក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ពួកគេអាចមិនដឹងពីលក្ខណៈគួរឲ្យស្រឡាញ់របស់ទ្រង់បានថា កិច្ចការរបស់ទ្រង់វាងវៃ និងអស្ចារ្យណាស់ ហើយមានព្រះចេស្តាដ៏ឥតព្រំដែន កើតឡើងក្នុងកិច្ចការរបស់ទ្រង់ដែរ។ នេះមិនមែនជាភាពភ័យខ្លាច ឬសេចក្តីស្រឡាញ់ និងការគោរពមួយគ្រាៗនោះដែរ តែជាញាណយល់ដឹងដ៏ស៊ីជម្រៅអំពីសេចក្តីមេត្តាករុណា ដែលព្រះជាម្ចាស់មានចំពោះមនុស្សលោក និងព្រះទ័យអធ្យាស្រ័យរបស់ព្រះអង្គ។ យ៉ាងណាមិញ មនុស្សដែលមានបទពិសោធនូវការវាយផ្ចាល និងការជំនុំជម្រះ ដឹងពីតេជានុភាពរបស់ទ្រង់ និងដឹងថាទ្រង់មិនអធ្យាស្រ័យសេចក្តីល្មើសនោះឡើយ។ សូម្បីតែមនុស្ស ដែលបានស្គាល់នូវកិច្ចការជាច្រើនរបស់ព្រះអង្គ ក៏មិនអាចយល់ពីព្រះអង្គដែរ។ មនុស្សទាំងអស់ដែលគោរពកោតខ្លាចព្រះអង្គពិតប្រាកដ ដឹងថាកិច្ចការរបស់ទ្រង់មិនស្របនឹងសញ្ញាណរបស់មនុស្សទេ គឺ

តែងតែទាស់នឹងសញ្ញាណរបស់គេវិញ។ ទ្រង់មិនត្រូវការឲ្យមនុស្សសរសើរទ្រង់ ឬបង្ហាញពីការចុះចូលចំពោះព្រះអង្គទាំងស្រុងដែរ ផ្ទុយទៅវិញ ពួកគេគប្បីមាននូវការកោតខ្លាច និងការចុះចូលពិតប្រាកដ។ មនុស្សណាដែលមានបទពិសោធពិត មានអារម្មណ៍កោតខ្លាចព្រះអង្គ ខ្លាំងជាងការសរសើរតម្កើងទ្រង់ នៅក្នុងកិច្ចការជាច្រើនរបស់ព្រះអង្គ។ មនុស្សធ្លាប់ឃើញនិស្ស័យរបស់ទ្រង់ ដោយសារកិច្ចការនាំការវាយផ្ចាល និងការជំនុំជម្រះរបស់ទ្រង់ ដូច្នេះហើយ ពួកគេគោរពកោតខ្លាចទ្រង់ក្នុងចិត្តរបស់គេ។ ព្រះជាម្ចាស់ គឺជាព្រះសម្រាប់ឲ្យមនុស្សកោតខ្លាច និងស្ដាប់បង្គាប់ ដ្បិតលក្ខណៈ និងនិស្ស័យរបស់ទ្រង់ មិនដូចនឹងមនុស្សដែលត្រូវបានបង្កើតមកឡើយ ហើយខ្ពង់ខ្ពស់ជាងអ្វីៗដែលត្រូវបានបង្កើតមកដែរ។ ព្រះជាម្ចាស់មានវត្តមានគង់នៅដោយអង្គឯង និងអស់កល្បជានិច្ច ទ្រង់ពុំមែនជាសភាវៈដែលត្រូវបានបង្កើតមកឡើយ ហើយមានតែព្រះជាម្ចាស់ទេ ដែលស័ក្តិសមទទួលនូវការគោរពកោតខ្លាច និងស្ដាប់បង្គាប់។ មនុស្សមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ចំពោះសេចក្ដីនេះទេ។ ដូច្នេះ អស់អ្នកដែលបានស្គាល់កិច្ចការរបស់ទ្រង់ ហើយស្គាល់ទ្រង់ពិត ពួកគេមានចិត្តគោរពកោតខ្លាចចំពោះទ្រង់។ យ៉ាងណាមិញ អស់អ្នកដែលមិនបោះបង់ចោលសញ្ញាណដែលមានចំពោះព្រះអង្គ គឺអស់អ្នកដែលមិនរាប់ព្រះអង្គថាជាព្រះ គេពុំមានការគោរពកោតខ្លាចចំពោះព្រះអង្គឡើយ ហើយទោះបីជាពួកគេដើរតាមទ្រង់ ក៏ពួកគេមិនមែនត្រូវបានយកឈ្នះដែរ ពួកគេជាមនុស្សរឹងចចេសពីកំណើតមក។ កិច្ចការដែលទ្រង់ចង់សម្រេចឲ្យបានតាមរយៈកិច្ចការនេះ គឺដើម្បីឲ្យមនុស្សគ្រប់ៗគ្នាដែលត្រូវបានបង្កើតមក មានដួងចិត្តគោរពកោតខ្លាចព្រះអាទិករ ថ្វាយបង្គំទ្រង់ និងចុះចូលចំពោះអំណាចគ្រប់គ្រងរបស់ទ្រង់ ដោយគ្មានលក្ខខណ្ឌ។ នេះគឺជាលទ្ធផលចុងក្រោយដែលកិច្ចការរបស់ព្រះអង្គចង់សម្រេចឲ្យបាន។ ប្រសិនបើមនុស្សដែលបានឆ្លងកាត់កិច្ចការនេះហើយ មិនគោរពកោតខ្លាចព្រះជាម្ចាស់សូម្បីតែបន្តិច ហើយប្រសិនបើចរិតរឹងចចេសរបស់គេពុំផ្លាស់ប្ដូរសោះ នោះពួកគេប្រាកដជាត្រូវផាត់ចោលមិនខាន។ ប្រសិនបើអាកប្បកិរិយាដែលមនុស្សម្នាក់មានចំពោះព្រះជាម្ចាស់ មានត្រឹមតែការសរសើរទ្រង់

ឬបង្ហាញការគោរពដល់ទ្រង់ពីចម្ងាយ និងមិនស្រឡាញ់ទ្រង់បន្តិចសោះ នោះវាជាលទ្ធផលដែលបុគ្គលគ្មានដួងចិត្តស្រឡាញ់ព្រះជាម្ចាស់នឹងមកដល់ ហើយបុគ្គលនោះក៏ពុំមានលក្ខខណ្ឌ ដើម្បីឲ្យបានគ្រប់លក្ខណ៍ឡើយ។ ប្រសិនបើកិច្ចការជាច្រើនក៏មិនអាចទទួលបានសេចក្តីស្រឡាញ់ពិតពីមនុស្ស នោះគេក៏មិនទទួលបានព្រះជាម្ចាស់ ហើយគេក៏មិនព្យាយាមឲ្យបានសេចក្តីពិត យ៉ាងពិតប្រាកដដែរ។ បុគ្គលដែលមិនស្រឡាញ់ព្រះជាម្ចាស់ មិនស្រឡាញ់សេចក្តីពិតទេ ដូច្នេះគេមិនអាចទទួលបានព្រះជាម្ចាស់ឡើយ ហើយក៏កាន់តែមិនទទួលបានការសរសើរ ពីព្រះជាម្ចាស់ដែរ។ មនុស្សបែបនេះ បើទោះបីជាពួកគេស្គាល់កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ហើយបើទោះបីជាពួកគេឆ្លងកាត់ការជំនុំជម្រះ ក៏គេមិនអាចកោតខ្លាចព្រះជាម្ចាស់ដែរ។ មនុស្សទាំងនេះ គឺសុទ្ធតែជាមនុស្សដែលមានសន្តានមិនប្រែប្រួល ហើយជាមនុស្សដែលមាននិស្ស័យអាក្រក់ហួសហេតុ។ មនុស្សទាំងអស់ដែលមិនកោតខ្លាចព្រះជាម្ចាស់នឹងត្រូវផាត់ចោល គឺជាវត្ថុបំណងនៃទណ្ឌកម្ម និងត្រូវទទួលទោសដូចមនុស្សអាក្រក់ គឺត្រូវរងទុក្ខខ្លាំងជាងមនុស្សដែលបានប្រព្រឹត្តអំពើទុច្ចរិតផង។

# ការស្គាល់ដំណាក់កាលទាំងបី<br>នៃកិច្ចការរបស់ព្រះជាម្ចាស់<br>គឺជាផ្លូវនាំទៅរកការស្គាល់ព្រះជាម្ចាស់

កិច្ចការគ្រប់គ្រងមនុស្សជាតិ ត្រូវបានបែងចែកជាបីដំណាក់កាល មានន័យថាកិច្ចការសង្គ្រោះមនុស្សជាតិ ក៏ត្រូវបានបែងចែកជាបីដំណាក់ដែរ។ កិច្ចការទាំងបីដំណាក់កាលនេះ មិនរាប់បញ្ចូលកិច្ចការបង្កើតផែនដីទេ ផ្ទុយទៅវិញ កិច្ចការទាំងបីដំណាក់កាលនេះគឺកិច្ចការក្នុងយុគសម័យនៃក្រឹត្យវិន័យ យុគសម័យនៃព្រះគុណ និងយុគសម័យនៃនគរព្រះ។ កិច្ចការនៃការបង្កើតផែនដី គឺជាកិច្ចការបង្កើតមនុស្សជាតិទាំងមូល។ កិច្ចការនេះមិនមែនជាកិច្ចការសង្គ្រោះមនុស្សជាតិទេ ហើយគ្មានពាក់ព័ន្ធ

អ្វីនឹងកិច្ចការសង្គ្រោះមនុស្សជាតិដែរ ពីព្រោះពេលដែលផែនដីនេះត្រូវបានបង្កើតមក មនុស្សជាតិមិនទាន់ត្រូវបានបង្ខូចឲ្យទៅជាអាក្រក់ ដោយសារសាតាំងឡើយ ដូច្នេះហើយ ពុំចាំបាច់ត្រូវអនុវត្តនូវកិច្ចការសង្គ្រោះមនុស្សជាតិនោះទេ។ កិច្ចការនៃការគ្រប់គ្រងមនុស្សជាតិ ក៏ទើបតែចាប់ផ្ដើមនៅពេលមនុស្សជាតិត្រូវបង្ខូចឲ្យទៅជាអាក្រក់ប៉ុណ្ណោះ។ ពោលគឺ ការដែលព្រះជាម្ចាស់គ្រប់គ្រងមនុស្សជាតិ គឺជាលទ្ធផលកើតចេញពីកិច្ចការសង្គ្រោះ មនុស្សជាតិ ហើយមិនមែនកើតចេញពីកិច្ចការបង្កើតផែនដីនោះទេ។ ទាល់តែពេលមនុស្សជាតិមាននិស្ស័យខូចអាក្រក់ ទើបកិច្ចការគ្រប់គ្រងមនុស្សជាតិ មានវត្តមានឡើង ដូច្នេះហើយ កិច្ចការគ្រប់គ្រងមនុស្សជាតិរួមមានបីផ្នែក មិនមែនបួនដំណាក់កាល ឬបួនយុគសម័យនោះទេ។ នេះគឺជាវិធីត្រឹមត្រូវតែមួយគត់ សម្រាប់និយាយសំដៅលើកិច្ចការគ្រប់គ្រងមនុស្សជាតិរបស់ព្រះជាម្ចាស់។ ពេលយុគសម័យចុងក្រោយឈានដល់ទីបញ្ចប់ កិច្ចការគ្រប់គ្រងមនុស្សជាតិ នឹងឈានមកដល់ទីបញ្ចប់ទាំងស្រុងដែរ។ ការសម្រេចកិច្ចការគ្រប់គ្រង មានន័យថា កិច្ចការនៃការសង្គ្រោះមនុស្សជាតិទាំងអស់ នឹងត្រូវបញ្ចប់ទាំងស្រុង ហើយថា ជំហាននេះនឹងបានបញ្ចប់សម្រាប់មនុស្ស។ ប្រសិនបើមិនមានកិច្ចការសង្គ្រោះមនុស្សជាតិទាំងអស់ទេ កិច្ចការគ្រប់គ្រងមនុស្សជាតិ ក៏មុខជាមិនមានវត្តមាន ឬគ្មានកិច្ចការទាំងបីដំណាក់កាលដែរ។ ប្រាកដណាស់ គឺដោយសារសេចក្ដីអាក្រក់របស់របស់មនុស្ស និងដោយសារតែមនុស្សត្រូវការសេចក្ដីសង្គ្រោះបន្ទាន់ពេក ទើបព្រះយេហូវ៉ាបញ្ចប់កិច្ចការបង្កើតផែនដីហើយក៏បានចាប់ផ្ដើមកិច្ចការយុគសម័យនៃក្រឹត្យវិន័យ។ មានតែគ្រានោះឯងទើបកិច្ចការគ្រប់គ្រងមនុស្សជាតិចាប់ផ្ដើមនេះមានន័យថា មានតែពេលនោះ ទើបកិច្ចការសង្គ្រោះមនុស្សជាតិចាប់ផ្ដើម។ «ការគ្រប់គ្រងមនុស្សជាតិ» មិនមែនជាការដឹកនាំជីវិតរបស់មនុស្សជាតិដែលទើបតែត្រូវបានបង្កើតមកថ្មីៗនៅលើផែនដីនេះទេ (ពោលគឺ មនុស្សជាតិមិនទាន់ត្រូវបានបង្ខូចឲ្យទៅជាអាក្រក់ទេ)។ ផ្ទុយទៅវិញ វាជាសេចក្ដីសង្គ្រោះរបស់មនុស្សជាតិដែលត្រូវសាតាំងបង្ខូចឲ្យទៅជាអាក្រក់ ពោលគឺជាការបំផ្លាស់បំប្រែមនុស្សជាតិដ៏ខូចអាក្រក់នេះ។ នេះជាអត្ថន័យ

នៃ «ការគ្រប់គ្រងមនុស្សជាតិ»។ កិច្ចការសង្គ្រោះមនុស្សជាតិ មិនរាប់បញ្ចូលកិច្ចការនៃការបង្កើតផែនដីនេះទេ ដូច្នេះហើយ កិច្ចការគ្រប់គ្រងមនុស្សជាតិ ក៏មិនរាប់បញ្ចូលកិច្ចការនៃការបង្កើតផែនដីនេះដែរ ដោយឡែក កិច្ចការនេះរួមបញ្ចូលតែកិច្ចការទាំងបីដំណាក់កាលដែលដាច់ដោយឡែកពីកិច្ចការបង្កើតផែនដី។ ដើម្បីយល់អំពីកិច្ចការគ្រប់គ្រងមនុស្សជាតិចាំបាច់ត្រូវដឹងអំពីប្រវត្តិនៃកិច្ចការទាំងបីដំណាក់កាលសិន នេះគឺជាសេចក្ដីដែលគ្រប់គ្នាត្រូវតែដឹង ដើម្បីឲ្យបានសង្គ្រោះ។ ក្នុងនាមជាសត្តនិករដែលព្រះជាម្ចាស់បានបង្កើត អ្នកគួរដឹងថា មនុស្សត្រូវបានព្រះជាម្ចាស់បង្កើតមក ហើយអ្នកគួរដឹងពីប្រភពនៃសេចក្ដីខូចអាក្រក់របស់មនុស្ស ហើយនិងដំណើរនៃសេចក្ដីសង្គ្រោះរបស់មនុស្សថែមទៀតផង។ ប្រសិនបើអ្នករាល់គ្នាដឹងត្រឹមវិធីប្រព្រឹត្ត ស្របតាមគោលលទ្ធិ ដើម្បីព្យាយាមទទួលបានការសព្វព្រះទ័យពីព្រះជាម្ចាស់ ប៉ុន្តែគ្មានគំនិតគិតដល់របៀបដែលព្រះជាម្ចាស់សង្គ្រោះមនុស្សជាតិ ឬប្រភពដើមនៃសេចក្ដីខូចអាក្រក់ របស់មនុស្សជាតិ នេះហើយជាសេចក្ដីដែលអ្នកគ្មាន ក្នុងនាមជាសត្តនិករដែលព្រះបង្កើត។ អ្នកមិនគួរស្កប់ចិត្តត្រឹមតែមានការយល់ដឹងអំពីសេចក្ដីដែលអាចយកទៅអនុវត្ត ទាំងនៅល្ងង់ខ្លៅមិនដឹងពីវិសាលភាពដ៏ធំធេងនៃកិច្ចការគ្រប់គ្រងរបស់ព្រះជាម្ចាស់នោះឡើយ ប្រសិនបើដូច្នេះមែន នោះអ្នកជាមនុស្សមានះជ្រុលហើយ។ កិច្ចការទាំងបីដំណាក់កាលនេះ គឺជារឿងអាថ៌កំបាំងនៃការគ្រប់គ្រងរបស់ព្រះជាម្ចាស់ចំពោះមនុស្សជាតិ ការមកដល់នៃដំណឹងល្អរបស់ពិភពលោកទាំងមូល ជារឿងអាថ៌កំបាំងធំបំផុតនៅក្នុងចំណោមមនុស្សជាតិទាំងអស់ ហើយសេចក្ដីទាំងអស់នេះក៏ ជាគ្រឹះនៃការផ្សាយដំណឹងល្អដែរ។ ប្រសិនបើអ្នកផ្ដោតតែលើការយល់ដឹងសេចក្ដីពិតងាយៗដែលទាក់ទងនឹងជីវិតរបស់អ្នក ហើយមិនដឹងអ្វីសោះ ទាក់ទងនឹងសេចក្ដីអាថ៌កំបាំងនិងនិមិត្តដ៏អស្ចារ្យជាងគេនេះ នោះតើជីវិតរបស់អ្នក មិនដូចគ្នាទៅនឹងផលិតផលអន់គុណភាពគ្មានប្រយោជន៍ បានត្រឹមតាំងលម្អទេឬអី?

ប្រសិនបើមនុស្សយកចិត្តទុកដាក់តែលើការអនុវត្ត និងមើលឃើញថា កិច្ចការរបស់ព្រះជាម្ចាស់ និងអ្វីដែលមនុស្សគួរដឹង ថាជារឿងបន្ទាប់បន្សំ តើគេមិនមែនជា

មនុស្សគិតតែរឿងតូចតាច និងភ្លេចគិតរឿងធំដុំទេឬអី? អ្នកត្រូវតែដឹងរឿងដែល អ្នកត្រូវដឹង អ្នកក៏ត្រូវតែយកទៅអនុវត្តកិច្ចការដែលអ្នកយកទៅអនុវត្តដែរ។ ទាល់តែបែបនោះ ទើបអ្នកក្លាយជាមនុស្សម្នាក់ដែលដឹងអំពីវិធីព្យាយាមយកឲ្យបានសេចក្តីពិត។ លុះដល់ថ្ងៃដែលអ្នកត្រូវផ្សាយដំណឹងល្អ ប្រសិនបើអ្នកអាចនិយាយបានថា ព្រះជាម្ចាស់ ជាព្រះដ៏មហិមា ហើយសុចរិត អាចនិយាយថា ទ្រង់ជាព្រះដ៏ខ្ពង់ខ្ពស់បំផុត ជាព្រះដែលគ្មានមនុស្សអស្ចារ្យណាម្នាក់អាចប្រៀបនឹងទ្រង់បាន និងអាចនិយាយថា ទ្រង់គឺជាព្រះដែលគ្មាននរណាម្នាក់ខ្ពស់ជាងទ្រង់ឡើយ... ប្រសិនបើអ្នកអាចនិយាយត្រឹមពាក្យសម្តីដែលមិនទាក់ទង ហើយរាក់កំផែលទាំងអស់នេះ ដោយមិនអាចនិយាយពាក្យពេចន៍សំខាន់ៗ និងមានសារជាតិទាល់តែសោះ ប្រសិនបើអ្នកគ្មានអ្វីត្រូវនិយាយ ទាក់ទងនឹងការស្គាល់ព្រះជាម្ចាស់ឬទាក់ទងនឹងកិច្ចការរបស់ព្រះជាម្ចាស់ ហើយជាងនេះទៅទៀត អ្នកមិនអាចពន្យល់សេចក្តីពិត ឬផ្តល់អ្វីដែលមនុស្សខ្វះខាតទេ នោះមនុស្សដូចជាអ្នក ក៏មិនអាចអនុវត្តកាតព្វកិច្ចរបស់ខ្លួនឲ្យបានល្អដែរ។ ការធ្វើបន្ទាល់អំពីព្រះជាម្ចាស់ និងការផ្សាយដំណឹងល្អអំពីនគរព្រះ គឺមិនមែនជារឿងងាយទេ។ ជាដំបូង អ្នកត្រូវតែប្រដាប់ខ្លួនដោយសេចក្តីពិត និងប្រដាប់ខ្លួននូវនិមិត្តដែលអាចយល់បាន។ កាលណាអ្នកយល់ច្បាស់ពីនិមិត្ត និងសេចក្តីពិតទាក់ទងនឹងកត្តាខុសគ្នានៃកិច្ចការរបស់ព្រះជាម្ចាស់ ហើយអ្នកនឹងចាប់ផ្តើមស្គាល់ពីកិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងដួងចិត្តរបស់ខ្លួន ហើយទោះបីព្រះជាម្ចាស់ធ្វើអ្វីក៏ដោយ មិនថាជាការជំនុំជម្រះដ៏សុចរិត ឬការបន្សុទ្ធមនុស្ស ក៏អ្នកនៅតែមាននិមិត្តដ៏ធំបំផុតជាមូលដ្ឋានគ្រឹះរបស់អ្នក ហើយអ្នកក៏មានសេចក្តីពិតដ៏ត្រឹមត្រូវ ដើម្បីយកមកអនុវត្តដែរ រួចអ្នកក៏នឹងអាចដើរតាមព្រះជាម្ចាស់ រហូតដល់ទីបញ្ចប់ដែរ។ អ្នកត្រូវដឹងថា បើទោះបីជាព្រះអង្គធ្វើការអ្វីក៏ដោយ ក៏គោលដៅនៃកិច្ចការរបស់ទ្រង់មិនប្រែប្រួល សារជាតិស្នូលនៃកិច្ចការរបស់ទ្រង់ ក៏មិនប្រែប្រួល ហើយព្រះហឫទ័យដែលទ្រង់មានចំពោះមនុស្សជាតិ ក៏មិនប្រែប្រួលដែរ។ ទោះបីជាព្រះបន្ទូលទ្រង់ម៉ឺងម៉ាត់យ៉ាងណា ទោះបីជាបរិយាកាសមិនអនុគ្រោះយ៉ាងណា ក៏គោលការណ៍នៃកិច្ចការរបស់ទ្រង់

មិនប្រែប្រួល ហើយចេតនាដែលទ្រង់ចង់សង្គ្រោះមនុស្សជាតិ ក៏មិនប្រែប្រួលដែរ។ ដោយថានេះមិនមែនជាកិច្ចការនៃការបើកសម្ដែងពីទីបញ្ចប់ ឬគោលដៅរបស់មនុស្ស និងមិនមែនជាកិច្ចការ ក្នុងដំណាក់កាលចុងក្រោយ ឬក៏ជាការបញ្ចប់ផែនការគ្រប់គ្រងទាំងមូលរបស់ព្រះជាម្ចាស់ឡើយ មានន័យថា ចំណុចសំខាន់នៃកិច្ចការនេះ គឺជាគ្រាដែលទ្រង់ប្រើមនុស្ស នោះចំណុចស្នូលនៃកិច្ចការរបស់ព្រះអង្គនឹងមិនប្រែប្រួល។ វានឹងនៅតែជាការសង្គ្រោះមនុស្សជាតិជានិច្ច។ សេចក្ដីនេះគួរតែជាគ្រឹះនៃជំនឿរបស់អ្នកចំពោះព្រះជាម្ចាស់។ គោលបំណងនៃកិច្ចការទាំងបីដំណាក់កាលគឺជាសេចក្ដីសង្គ្រោះសម្រាប់មនុស្សជាតិទាំងអស់ គឺជាការសង្គ្រោះមនុស្សជាតិ ឲ្យរួចផុត ពីអំណាចគ្រប់គ្រងរបស់សាតាំងទាំងស្រុង។ ទោះបីជាដំណាក់កាលនីមួយៗក្នុងកិច្ចការនេះមានវត្ថុបំណង និងមានសារៈសំខាន់ខុសគ្នា ក៏ដំណាក់កាលនីមួយៗជាចំណែកនៃកិច្ចការសង្គ្រោះមនុស្សជាតិ ហើយដំណាក់កាលនីមួយៗ គឺជាកិច្ចការដោយឡែកពីគ្នានៅក្នុងសេចក្ដីសង្គ្រោះ ដែលត្រូវបានអនុវត្តស្របទៅនឹងសេចក្ដីតម្រូវរបស់មនុស្សជាតិ។ កាលណាអ្នកដឹង អំពីគោលបំណងនៃកិច្ចការទាំងបីដំណាក់កាលនេះហើយ នោះអ្នកនឹងដឹងពីវិធីឲ្យតម្លៃសារៈសំខាន់ នៃកិច្ចការក្នុងដំណាក់កាលនីមួយៗ ព្រមទាំងដឹងពីវិធីបំពេញមុខងារដើម្បីផ្គាប់ព្រះទ័យចង់បានរបស់ព្រះជាម្ចាស់ផង។ ប្រសិនបើអ្នកអាចឈានដល់ចំណុចនេះ នោះនិមិត្តដ៏អស្ចារ្យជាងគេបំផុតនេះនឹងក្លាយទៅជាគ្រឹះនៃជំនឿដែលអ្នកមានចំពោះព្រះជាម្ចាស់។ អ្នកមិនគួរស្វែងរកតែវិធីអនុវត្តងាយៗ ឬសេចក្ដីស៊ីជម្រៅនោះទេ ប៉ុន្តែអ្នកគួរផ្សារភ្ជាប់និមិត្តជាមួយនឹងការអនុវត្ត ដើម្បីឲ្យមានទាំងសេចក្ដីពិតដែលអាចយកទៅអនុវត្តបាន ព្រមទាំងមានចំណេះដឹងដែលផ្អែកលើនិមិត្តទាំងអស់នោះ។ មានតែធ្វើបែបនេះទេទើបអ្នកក្លាយជាមនុស្សម្នាក់ដែលព្យាយាមឲ្យបានសេចក្ដីពិតយ៉ាងពេញលេញ។

កិច្ចការទាំងបីដំណាក់កាលនេះ ជាស្នូលនៃកិច្ចការគ្រប់គ្រង ទាំងមូលរបស់ព្រះជាម្ចាស់ ហើយនិស្ស័យ និងលក្ខណៈរបស់ទ្រង់ ក៏ត្រូវបានបង្ហាញចេញមកនៅក្នុងកិច្ចការទាំងបីដំណាក់កាលនេះដែរ។ មនុស្សដែលមិនដឹង អំពីដំណាក់កាលទាំង

បីនៃកិច្ចការរបស់ព្រះជាម្ចាស់ គ្មានសមត្ថភាពស្គាល់វិធី ដែលព្រះជាម្ចាស់បង្ហាញនូវនិស្ស័យរបស់ទ្រង់បានឡើយ ហើយក៏មិនស្គាល់ អំពីប្រាជ្ញាញាណនៃកិច្ចការរបស់ព្រះជាម្ចាស់ដែរ។ ពួកគេក៏នៅតែមិនដឹងពីវិធីនានា ដែលព្រះជាម្ចាស់សង្គ្រោះមនុស្សជាតិ និងមិនដឹងពីព្រះហឫទ័យដែលទ្រង់មាន សម្រាប់មនុស្សជាតិទាំងមូលដែរ។ កិច្ចការទាំងបីដំណាក់កាល មានពេញដោយការបង្ហាញឲ្យឃើញពីកិច្ចការនៃការសង្គ្រោះមនុស្សជាតិ។ មនុស្សដែលពុំដឹងពីកិច្ចការទាំងបីដំណាក់កាល គេក៏ពុំដឹងអំពីទ្រឹស្ដី និងគោលការណ៍នានានៃកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធដែរ ហើយអស់អ្នកដែលមានៈកាន់តាមគោលលទ្ធិដែលនៅសល់ពីដំណាក់កាលនៃកិច្ចការណាមួយ អ្នកនោះគឺជាមនុស្សដែលកំហិតព្រះជាម្ចាស់ទៅតាមគោលលទ្ធិ ហើយជំនឿរបស់គេចំពោះព្រះជាម្ចាស់ ជាជំនឿស្រពេចស្រពិល និងមិនច្បាស់លាស់។ មនុស្សបែបនេះ នឹងមិនទទួលបានសេចក្ដីសង្គ្រោះរបស់ព្រះជាម្ចាស់ឡើយ។ មានតែកិច្ចការទាំងបីដំណាក់កាលនេះទេ ទើបអាចបង្ហាញឲ្យឃើញ នូវនិស្ស័យទាំងអស់របស់ព្រះជាម្ចាស់យ៉ាងពេញលេញ ព្រមទាំងបង្ហាញពីដំណើរទាំងអស់ នៃសេចក្ដីសង្គ្រោះរបស់មនុស្សជាតិ។ នេះជាភ័ស្តុតាងបង្ហាញថា ទ្រង់បានយកឈ្នះសាតាំង និងទទួលបានមនុស្សជាតិ ក៏ជាភ័ស្តុតាងបញ្ជាក់អំពីជ័យជម្នះរបស់ព្រះជាម្ចាស់ និងជាការបង្ហាញពីនិស្ស័យទាំងអស់របស់ព្រះជាម្ចាស់ដែរ។ មនុស្សដែលយល់អំពីកិច្ចការរបស់ព្រះជាម្ចាស់ត្រឹមមួយដំណាក់កាល គេស្គាល់និស្ស័យរបស់ព្រះជាម្ចាស់ត្រឹមតែមួយចំណែកប៉ុណ្ណោះ។ នៅក្នុងសញ្ញាណរបស់មនុស្ស កិច្ចការតែមួយដំណាក់កាលនេះ ងាយនឹងក្លាយទៅជាគោលលទ្ធិណាស់ ហើយមនុស្សក៏ងាយនឹងបង្កើតបានជាក្រឹត្យក្រម ដ៏តឹងរ៉ឹងអំពីព្រះជាម្ចាស់ ព្រមទាំងប្រើនិស្ស័យតែមួយចំណែករបស់ព្រះជាម្ចាស់ យកមកធ្វើជាតំណាងនិស្ស័យទាំងអស់របស់ព្រះជាម្ចាស់។ ជាងនេះទៅទៀត ភាគច្រើននៃការស្រមើស្រមៃរបស់មនុស្ស មានលាយឡំក្នុងដួងចិត្តរបស់គេ មនុស្សបែបនេះ គេដាក់កំហិតយ៉ាងតឹងរ៉ឹងចំពោះនិស្ស័យ លក្ខណៈ និងប្រាជ្ញាញាណក៏ដូចជា គោលការណ៍នៃកិច្ចការរបស់ព្រះជាម្ចាស់ នៅក្នុងព្រំដែនដែលបានកំណត់

ដោយជឿថា ប្រសិនបើព្រះជាម្ចាស់ធ្លាប់មានលក្ខណៈបែបនេះម្ដងហើយ នោះទ្រង់នឹងនៅតែដដែលគ្រប់ពេលវេលា ហើយមិនប្រែប្រួលឡើយ។ មានតែមនុស្សដែលស្គាល់ និងឲ្យតម្លៃកិច្ចការទាំងបីដំណាក់កាល ទើបអាចស្គាល់ព្រះជាម្ចាស់ពេញលេញ និងច្បាស់លាស់បាន។ យ៉ាងហោចណាស់ ពួកគេមិនកំណត់និយមន័យព្រះជាម្ចាស់ ថាជាព្រះនៃសាសន៍អ៊ីស្រាអែល ឬសាសន៍យូដា ហើយមិនចាត់ទុកទ្រង់គឺ ជាព្រះដែលនៅជាប់លើឈើឆ្កាងជានិរន្ត៍ ដើម្បីប្រយោជន៍មនុស្សនោះឡើយ។ ប្រសិនបើបុគ្គលម្នាក់ចាប់ផ្ដើមស្គាល់ព្រះជាម្ចាស់តែពីដំណាក់កាលមួយនៃកិច្ចការរបស់ទ្រង់ នោះចំណេះដឹងរបស់គេ គឺតិចតួចណាស់ ហើយប្រៀបមិនស្មើនឹងទឹកមួយដំណក់ស្រក់ក្នុងមហាសមុទ្រផង។ បើមិនដូច្នោះទេ ហេតុអ្វីក៏ឆ្មាំសាសនាចាស់ៗទាំងអស់នោះ ដំព្រះជាម្ចាស់ឆ្កាងទាំងរស់? តើមិនមែនដោយសារមនុស្សកំហិតព្រះជាម្ចាស់ ឲ្យនៅក្នុងព្រះដែនជាក់លាក់ទេឬអី? តើមនុស្សជាច្រើនមិនប្រឆាំងទាស់នឹងព្រះជាម្ចាស់ និងបង្អាក់ដល់កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ដោយសារតែគេមិនស្គាល់កិច្ចការដែលមានបម្រែបម្រួល និងខុសប្លែកពីគ្នារបស់ព្រះជាម្ចាស់ ហើយ លើសពីនេះទៀត ដោយសារពួកគេមានតែចំណេះដឹង និងគោលលទ្ធិតិចតួច យកមកវាស់ស្ទង់កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធទេឬអី? យ៉ាងណាមិញ បទពិសោធមនុស្សបែបនេះ ជាបទពិសោធរាក់កំផែល ពួកគេក្រអឺតក្រទម និងមានសន្ដានបណ្ដែតបណ្ដោយហើយពួកគេមិនឲ្យតម្លៃកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធទេ ហើយជាងនេះទៅទៀត ពួកគេប្រើការជជែកវែកញែកដ៏ចាស់គំរិលរាក់កំផែលរបស់គេមក «អះអាង» ពីកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ។ ពួកគេក៏ធ្វើពុតជាសម្ដែង ហើយជឿស្លុងលើការរៀនសូត្រនិងចំណេះវិជ្ជាជ្រៅជ្រះរបស់គេ ហើយជឿថា ពួកគេអាចធ្វើដំណើរជុំវិញពិភពលោកបាន។ តើមនុស្សបែបនេះ មិនមែនជាមនុស្សដែលត្រូវព្រះវិញ្ញាណបរិសុទ្ធស្អប់ និងបដិសេធ ហើយពួកគេមិនត្រូវផាត់ចោលក្នុងយុគសម័យថ្មីទេឬអី? តើអ្នកទាំងនោះមិនមែនជាមនុស្សដែលចូលមកចំពោះព្រះជាម្ចាស់ ហើយប្រឆាំងទាស់នឹងទ្រង់ទាំងបើកចំហរ ជាមនុស្សគួរឱ្យស្អប់ដែលក្រអឺតក្រទម និងខ្វះព័ត៌មាន ក៏ជាមនុស្សដែល

គ្រាន់តែខិតខំបង្អួតថា ពួកគេចំណានយ៉ាងណាទេឬអី? ពួកគេព្យាយាមធ្វើកុបកម្ម ចូលទៅក្នុង «មជ្ឈដ្ឋានអប់រំ» របស់លោកិយ ដោយប្រើចំណេះដឹងដ៏តិចតួចរបស់គេ ហើយជាមួយគោលលទ្ធិរាក់កំផែលដែលគេយកទៅបង្រៀនមនុស្ស ពួកគេព្យាយាម បង្វែរកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ហើយព្យាយាមធ្វើឲ្យកិច្ចការនោះ នៅវិលវល់ ជុំវិញដំណើរនៃគម្រិះរបស់គេ។ ពួកគេមើលឃើញមិនច្បាស់យ៉ាងណា ក៏ពួកគេ ព្យាយាមមើលកិច្ចការរយៈពេល៦០០០ឆ្នាំរបស់ព្រះជាម្ចាស់ឲ្យឃើញ អស់ត្រឹមតែ មួយកន្ទុយភ្នែកយ៉ាងនោះដែរ។ ពួកមនុស្សទាំងនោះ ពុំមានញាណសតិដែលសមនឹង លើកយកមកនិយាយឡើយ! តាមការពិតមនុស្សដែលស្គាល់ព្រះជាម្ចាស់រឹតតែខ្លាំង គេ រឹតតែយឺតក្នុងការវិនិច្ឆ័យកិច្ចការរបស់ព្រះជាម្ចាស់។ ជាងនេះទៀត ពួកគេនិយាយតែពី ចំណេះដឹងដ៏តិចតួច ទាក់ទងនឹងកិច្ចការរបស់ព្រះជាម្ចាស់នាពេលសព្វថ្ងៃ ប៉ុន្តែពួកគេ មិនរួសរាន់ក្នុងការវិនិច្ឆ័យរបស់គេនោះទេ។ មនុស្សដែលស្គាល់ព្រះជាម្ចាស់កាន់តែតិច ពួកគេកាន់តែក្រអឺតក្រទម និងកាន់តែជឿជាក់លើខ្លួនឯង ហើយពួកគេរឹតតែប្រកាស អំពីអត្តភាពរបស់ព្រះជាម្ចាស់ដោយមិនសំចៃ ប៉ុន្តែពួកគេនិយាយតែពីទ្រឹស្ដី និងមិន ផ្ដល់ភ័ស្ដុតាងជាក់ស្ដែងសោះ។ មនុស្សបែបនេះ គឺជាមនុស្សពុំមានតម្លៃអ្វីទាំងអស់។ អ្នកដែលចាត់ទុកកិច្ចការ ព្រះវិញ្ញាណបរិសុទ្ធថាជាការកម្សាន្ត គឺជាមនុស្សល្ងីល្ងើ! មនុស្សដែលមិនប្រយ័ត្ន ពេលគេជួបប្រទះកិច្ចការថ្មីរបស់ព្រះវិញ្ញាណបរិសុទ្ធ គឺជា មនុស្សនិយាយមិនចេះគិត ប្រញាប់វិនិច្ឆ័យ ជាមនុស្សដែលបញ្ចេញលក្ខណៈសម្បត្តិ តាមទំនើងចិត្តក្នុងការបដិសេធភាពត្រឹមត្រូវនៃកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ហើយ ថែមទាំងមើលងាយ និងប្រមាថកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធទៀតផង តើមនុស្ស ឈ្លើយបែបនេះមិនមែនជាមនុស្សល្ងង់មិនស្គាល់កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ទេឬអី? ជាងនេះទៅទៀត តើពួកគេមិនមែនជាមនុស្សក្រអឺតក្រទមខ្លាំង ជាមនុស្ស ដែលមានអំណួត និងមិនអាចគ្រប់គ្រងបានតាំងពីកំណើតទេឬអី? បើទោះបីថ្ងៃមួយ មកដល់ នៅពេលដែលមនុស្សបែបនេះទទួលយកកិច្ចការថ្មីរបស់ព្រះវិញ្ញាណបរិសុទ្ធក៏ ព្រះជាម្ចាស់នៅតែមិនអធ្យាស្រ័យឲ្យពួកគេដែរ។ ពួកគេមិនត្រឹមតែមើលងាយអស់អ្នក

ដែលធ្វើការថ្វាយព្រះជាម្ចាស់ប៉ុណ្ណោះទេ ប៉ុន្តែពួកគេក៏ប្រមាថព្រះជាម្ចាស់ផ្ទាល់ព្រះអង្គដែរ។ មនុស្សហួសហេតុបែបនេះ នឹងមិនត្រូវបានអត់ទោសឲ្យឡើយ ទោះបីក្នុងយុគសម័យនេះ ឬយុគសម័យដែលនឹងត្រូវមកដល់ក្តី ហើយពួកគេនឹងត្រូវវិនាសនៅឯស្ថាននរក! មនុស្សឈ្លើយ ហើយទន់ខ្សោយដូចជាពួកគេ កំពុងធ្វើពុតជាជឿលើព្រះជាម្ចាស់ ហើយកាលណាមនុស្សកាន់តែមានចរិតបែបនេះ ពួកគេក៏កាន់តែងាយប្រព្រឹត្តល្មើសបញ្ញត្តិរដ្ឋបាលរបស់ព្រះជាម្ចាស់ទៀតផង។ តើមនុស្សក្រអឺតក្រទមដែលជាមនុស្សមិនចេះប្រយ័ត្នមាត់ពីកំណើត និងមនុស្សដែលមិនស្ដាប់បង្គាប់នរណាសោះសុទ្ធតែដើរលើផ្លូវនេះឬ? តើពួកគេមិនមែនប្រឆាំងទាស់នឹងព្រះជាម្ចាស់ ជាព្រះដែលថ្មីជានិច្ច និងមិនចេះចាស់ពីមួយថ្ងៃទៅមួយថ្ងៃទេឬអី? សព្វថ្ងៃនេះ អ្នករាល់គ្នាគប្បីយល់ពីហេតុផលដែលអ្នករាល់គ្នាត្រូវដឹងពីសារៈសំខាន់នៃដំណាក់កាលទាំងបីក្នុងកិច្ចការរបស់ព្រះជាម្ចាស់។ ព្រះបន្ទូលដែលខ្ញុំថ្លែង គឺជាប្រយោជន៍ដល់អ្នករាល់គ្នានិងមិនមែនគ្រាន់តែជាពាក្យសម្ដីគ្មានប្រយោជន៍នោះឡើយ។ ប្រសិនបើ អ្នករាល់គ្នាគ្រាន់តែអានព្រះបន្ទូលនេះ ដូចកំពុងសរសើរសម្រស់ផ្កាទាំងកំពុងបំផាយលើខ្នងសេះ តើកិច្ចការទាំងអស់របស់ខ្ញុំមិនទៅជាអសារឥតការទេឬអី? អ្នករាល់គ្នាគួរស្គាល់សន្ដានពីកំណើតរបស់ខ្លួនឯងផ្ទាល់។ ភាគច្រើន នៅក្នុងចំណោមអ្នករាល់គ្នាជំនាញខាងជជែកតវ៉ាចម្លើយឆ្លើយនឹងសំណួរទ្រឹស្ដី ហូរចេញពីមាត់របស់អ្នកមិនចេះអស់ ប៉ុន្តែអ្នករាល់គ្នាពុំមានអ្វីនិយាយពាក់ព័ន្ធនឹងន័យ ជាក់ស្ដែងបន្តិចសោះ។ សូម្បីសព្វថ្ងៃនេះ អ្នករាល់គ្នានៅតែបណ្ដោយខ្លួនតាមការសន្ទនាឥតប្រយោជន៍ មិនអាចផ្លាស់ប្ដូរនិស្ស័យចាស់របស់ខ្លួន ហើយភាគច្រើនក្នុងចំណោមអ្នករាល់គ្នា ពុំមានចេតនាចង់ផ្លាស់ប្ដូរវិធីដែលអ្នកព្យាយាមឲ្យបានសេចក្ដីពិត ដើម្បីសម្រេចសេចក្ដីពិតដែលឧត្ដុង្គឧត្ដមជាងនេះឡើយ តែផ្ទុយទៅវិញ អ្នករស់នៅក្នុងជីវិតស្មោះត្រង់តែពាក់កណ្ដាលប៉ុណ្ណោះ។ តើមនុស្សដូច ជាអ្នកនេះ អាចដើរតាមព្រះជាម្ចាស់រហូតដល់ទីបញ្ចប់ដែរឬទេ? បើទោះបីជាអ្នកអាចដើរដល់ទីបញ្ចប់នៃផ្លូវនេះ តើមានប្រយោជន៍ អ្វីដល់អ្នករាល់គ្នាទៅ? យកល្អគួរផ្លាស់ប្ដូរគំនិតរបស់អ្នកឲ្យហើយទៅ កុំឲ្យហួសពេល អាចជាការព្យាយាមឲ្យបាន

ពិតប្រាកដ ពុំនោះទេចូរដកខ្លួនឲ្យបានឆាប់ទៅ។ លុះយូរទៅ អ្នកនឹងក្លាយជាមនុស្ស បញ្ចើក្អែកដែលចាំជំហាមគេប៉ុណ្ណោះ តើអ្នកព្រមបំពេញតួនាទីដ៏តូចតាច និងថោកទាប បែបនេះដែរឬអី?

កិច្ចការទាំងបីដំណាក់កាលនេះ គឺជាកំណត់ត្រានៃកិច្ចការ ទាំងមូលរបស់ព្រះជាម្ចាស់។ កិច្ចការនេះ គឺជាកំណត់ត្រាអំពីសេចក្តីសង្គ្រោះរបស់ព្រះជាម្ចាស់ សម្រាប់មនុស្សជាតិ ហើយក៏មិនមែនជារឿងស្រមើស្រមៃដែរ។ ប្រសិនបើអ្នករាល់គ្នាពិតជាចង់ស្វែងរកការយល់ដឹងអំពីនិស្ស័យទាំងអស់របស់ព្រះជាម្ចាស់ នោះអ្នកត្រូវតែដឹងអំពីកិច្ចការទាំងបីដំណាក់កាល ដែលត្រូវបានអនុវត្តដោយព្រះជាម្ចាស់ ហើយជាងនេះទៀត អ្នកមិនត្រូវរំលងដំណាក់កាលណាមួយនោះឡើយ។ នេះគឺជាកម្រិតទាបបំផុតដែលត្រូវសម្រេចបានដោយមនុស្សដែលព្យាយាមស្គាល់ព្រះជាម្ចាស់។ មនុស្សខ្លួនឯងផ្ទាល់ពុំអាចបង្កើតចំណេះដឹងពិតអំពីព្រះជាម្ចាស់បានឡើយ។ នេះមិនមែនជារឿងដែលមនុស្សខ្លួនឯងអាចស្រមៃបាន ក៏មិនមែនជាផលនៃព្រះហឫទ័យអនុគ្រោះពិសេសរបស់ព្រះវិញ្ញាណបរិសុទ្ធ ដែលទ្រង់ប្រទានដល់មនុស្ស ណាម្នាក់ឡើយ។ ផ្ទុយទៅវិញ នេះគឺជាចំណេះដឹងដែលបានមក បន្ទាប់ពីមនុស្សបានស្គាល់នូវកិច្ចការរបស់ព្រះជាម្ចាស់ និងជាចំណេះដឹងអំពីព្រះ ដែលបានមកលុះត្រាតែគេបានស្គាល់ពីការពិតនានា នៅក្នុងកិច្ចការរបស់ព្រះជាម្ចាស់។ ចំណេះដឹងបែបនេះ មិនអាចទទួលបានដោយរួចរាល់បានឡើយ ហើយក៏មិនមែនជាមេរៀនដែលអាចបង្រៀនបានដែរ។ ចំណេះដឹងនេះ ពាក់ព័ន្ធទាំងស្រុងទៅនឹងបទពិសោធផ្ទាល់ខ្លួន។ សេចក្តីសង្គ្រោះរបស់ព្រះជាម្ចាស់ម្រាប់មនុស្សជាតិ គឺជាស្នូលនៃកិច្ចការទាំងបីដំណាក់កាលនេះ ប៉ុន្តែមានទ្រឹស្តីនៃការអនុវត្តកិច្ចការ និងមធ្យោបាយជាច្រើនដែលព្រះជាម្ចាស់បង្ហាញពីនិស្ស័យរបស់ទ្រង់ ត្រូវបានបញ្ចូលនៅក្នុងកិច្ចការនៃសេចក្តីសង្គ្រោះ។ នេះគឺជាកត្តាដែលមនុស្សពិបាកសម្គាល់ ហើយវាក៏ជាកត្តាដែលមនុស្ស ពិបាកយល់ដែរ។ ការបែងចែកយុគសម័យ ការផ្លាស់ប្តូរកិច្ចការរបស់ព្រះជាម្ចាស់ ការផ្លាស់ប្តូរទីតាំងនៃកិច្ចការ ការផ្លាស់ប្តូរអ្នកទទួលកិច្ចការនេះ ។ល។ ទាំងអស់នេះសុទ្ធតែត្រូវ

បានបញ្ចូលនៅក្នុងកិច្ចការទាំងបីដំណាក់កាល។ ជាពិសេស ភាពខុសគ្នានៅក្នុងវិធីធ្វើការរបស់ព្រះវិញ្ញាណបរិសុទ្ធ និងការបំប្លែងនិស្ស័យ រូបអង្គ ព្រះនាមអត្តសញ្ញាណរបស់ព្រះជាម្ចាស់ និងការផ្លាស់ប្ដូរផ្សេងៗទៀត គឺសុទ្ធតែជាចំណែកនៃកិច្ចការទាំងបីដំណាក់កាលនេះ។ កិច្ចការមួយដំណាក់កាល អាចតំណាងបានតែមួយចំណែកគត់ ហើយត្រូវកំហិតនៅក្នុងវិសាលភាពមួយជាក់លាក់។ កិច្ចការនេះពុំមានពាក់ព័ន្ធនឹងការបែងចែកយុគសម័យ ឬការផ្លាស់ប្ដូរកិច្ចការរបស់ព្រះជាម្ចាស់ទេ រឹតតែមិនពាក់ព័ន្ធនឹងចំណុចដទៃទៀតដែរ។ នេះជាការពិតជាក់ស្ដែងណាស់។ កិច្ចការទាំងបីដំណាក់កាល ជាកិច្ចការទាំងមូលរបស់ព្រះជាម្ចាស់ ក្នុងការសង្គ្រោះមនុស្សជាតិ។ មនុស្សត្រូវស្គាល់កិច្ចការរបស់ព្រះជាម្ចាស់ និងនិស្ស័យរបស់ទ្រង់នៅក្នុងកិច្ចការនៃសេចក្ដីសង្គ្រោះ។ ប្រសិនបើគ្មានការពិតនេះទេ ចំណេះដឹងដែលអ្នកមានចំពោះព្រះជាម្ចាស់ គ្មានអ្វីទាំងអស់ក្រៅតែពីពាក្យពេចន៍ អត់ប្រយោជន៍គ្មានអ្វីក្រៅតែពីការនិយាយអួតតែពីខ្លួនឯងឡើយ។ ចំណេះដឹងបែបនេះ មិនអាចនិយាយឲ្យមនុស្សជឿ ហើយក៏មិនអាចយកឈ្នះមនុស្សបានដែរ។ វាខុសផ្សេងពីតថភាព ហើយក៏ពុំមែនជាសេចក្ដីពិតដែរ។ វាអាចថាមានចំនួនច្រើន និងពីរោះស្ដាប់ដល់ត្រចៀក ប៉ុន្តែប្រសិនបើវាខុសពីនិស្ស័យដែលព្រះជាម្ចាស់មានជាស្រេច នោះទ្រង់នឹងមិនសំចៃអ្នកនោះឡើយ។ ទ្រង់មិនត្រឹមតែមិនសរសើរចំណេះដឹងរបស់អ្នកទេ តែទ្រង់ក៏នឹងផ្ដន្ទាទោសអ្នក ដោយព្រោះតែអ្នកគឺជាមនុស្សមានបាបដែលបានប្រមាថទ្រង់ទៀតផង។ ពាក្យពេចន៍ដែលបញ្ជាក់អំពីការស្គាល់ព្រះជាម្ចាស់ មិនមែនចេះតែនិយាយចេញមកងាយៗនោះទេ។ ថ្វីបើអ្នកប្រហែលជាពូកែនិយាយបញ្ចុះបញ្ចូល និងពូកែនិយាយឲ្យគេជឿ ហើយបើទោះបីសម្ដីរបស់អ្នក វាងវៃរហូតអ្នកអាចនិយាយឲ្យខ្មៅជាស រួចឲ្យសទៅជាខ្មៅក៏ដោយ ក៏សម្ដីរបស់អ្នកនៅតែពុំមានភាពជ្រាលជ្រៅ ពេលនិយាយអំពីចំណេះដឹងអំពីព្រះជាម្ចាស់។ ព្រះជាម្ចាស់ ពុំមែនជាបុគ្គលដែលអ្នកអាចប៉ាន់ប្រមាណដោយរួសរាន់ ឬសរសើរម្ដងម្កាល ឬនិយាយមើលងាយម្ដងហើយម្ដងទៀតបានឡើយ។ នរណាក៏អ្នកសរសើរ ហើយសរសើរមនុស្សគ្រប់គ្នាផង ប៉ុន្តែអ្នកពិបាករកពាក្យសម្ដីត្រឹមត្រូវមក

ពណ៌នាអំពីព្រះគុណដ៏មហិមារបស់ព្រះជាម្ចាស់ នេះជាលក្ខណៈដែលមនុស្សបាត់បង់គ្រប់គ្នា ចាប់ផ្ដើមទទួលស្គាល់។ បើទោះបីជាមានអ្នកជំនាញខាងភាសាជាច្រើន ដែលអាចរៀបរាប់ពីព្រះជាម្ចាស់ ក៏សុក្រឹតភាពនៃអ្វីដែលពួកគេរៀបរាប់ វាគ្រាន់តែជាមួយភាគក្នុងមួយរយនៃសេចក្ដីពិតដែលថ្លែងដោយប្រជារាស្ត្រដែលជាកម្មសិទ្ធិរបស់ព្រះអង្គ ថ្វីបើគេជាមនុស្សមិនសូវសម្បូរវាចារ តែពួកគេមានបទពិសោធជាច្រើនដែលពួកគេអាចយកមកប្រើបាន។ ដូច្នេះ អាចមើលឃើញថា ចំណេះដឹងអំពីព្រះជាម្ចាស់ ស្ថិតនៅលើសុក្រឹតភាព និងភាពពិតជាក់ស្ដែង ហើយមិនមែនស្ថិតលើការប្រើប្រាស់ពាក្យសម្ដីដ៏ឈ្លាសវៃ ឬវាក្យវោហារសព្ទអ្វីទេ ហើយមើលឃើញថា ចំណេះដឹងរបស់មនុស្ស និងចំណេះដឹងអំពីព្រះជាម្ចាស់ គឺពុំមានពាក់ព័ន្ធគ្នាទាំងស្រុង។ មេរៀនអំពីការស្គាល់ព្រះជាម្ចាស់ ខ្ពង់ខ្ពស់ជាងវិទ្យាសាស្ត្រធម្មជាតិរបស់មនុស្សជាតិទៅទៀត។ វាជាមេរៀនដែលមានមនុស្សតិចតួចបំផុត ដែលព្យាយាមស្វែងរកព្រះជាម្ចាស់ ទើបអាចសម្រេចបាន ហើយប្រសិនបើត្រឹមតែជាបុគ្គលម្នាក់ដែលមានទេពកោសល្យ ក៏មិនអាចសម្រេចបានដែរ។ ដូច្នេះអ្នករាល់គ្នាមិនត្រូវចាត់ទុកថា ការស្គាល់ព្រះជាម្ចាស់ និងការព្យាយាមឲ្យបានសេចក្ដីពិតប្រៀបបីដូចជាកិច្ចការដែលសូម្បីតែក្មេងក៏អាចសម្រេចបាននោះដែរ។ ប្រហែលជាអ្នក មានជោគជ័យទាំងស្រុងក្នុងជីវិតគ្រួសាររបស់អ្នក ឬអាជីពការងាររបស់អ្នក ឬជីវិតអាពាហ៍ពិពាហ៍របស់អ្នក តែពេលនិយាយដល់សេចក្ដីពិត និងមេរៀនពីការស្គាល់ព្រះជាម្ចាស់ អ្នកគ្មានអ្វីបង្ហាញសម្រាប់ខ្លួនឯង ហើយមិនសម្រេចបានអ្វីទាំងអស់ដែរ។ ការយកសេចក្ដីពិតទៅអនុវត្ត អាចនិយាយបានថា គឺជាការពិបាកបំផុតសម្រាប់អ្នករាល់គ្នា ហើយការស្គាល់ព្រះជាម្ចាស់ ក៏កាន់តែជាបញ្ហាធំជាងមុនទៅទៀត។ នេះគឺជាការលំបាករបស់អ្នករាល់គ្នា ហើយនេះជាការលំបាក ដែលមនុស្សជាតិទាំងមូលប្រឈមផងដែរ។ នៅក្នុងចំណោមមនុស្សដែលមានស្នាដៃខ្លះ ក្នុងការដែលបណ្ដាលឱ្យគេស្គាល់ព្រះជាម្ចាស់ គឺពុំមានមនុស្សណាម្នាក់ដែលត្រូវតាមបទដ្ឋាននោះទេ។ មនុស្សមិនដឹងថា ការស្គាល់ព្រះជាម្ចាស់ មានអត្ថន័យយ៉ាងណាទេឬក៏មិនដឹងថា មនុស្សត្រូវឈានដល់កម្រិតណា ទើបស្គាល់ព្រះជាម្ចាស់

នោះឡើយ។ នេះគឺជារឿងដែលធ្វើឲ្យមនុស្សទាល់គំនិតបំផុត ហើយនិយាយឲ្យខ្លី គឺជាប្រស្នាធំបំផុតដែលមនុស្សប្រឈម គ្មាននរណាម្នាក់អាចឆ្លើយនឹងសំណួរនេះទេ ក៏គ្មាននរណាម្នាក់ព្រមឆ្លើយនឹងសំណួរនេះដែរ ដ្បិតរហូតមកទល់សព្វថ្ងៃនេះ នៅក្នុងចំណោមមនុស្សជាតិ ពុំមាននរណាម្នាក់ ទទួលបាននូវជោគជ័យណាមួយ នៅក្នុងការសិក្សាអំពីកិច្ចការនេះឡើយ។ ប្រហែលជាពេលដែលប្រស្នាអំពីកិច្ចការទាំងបីដំណាក់កាលត្រូវបានសម្រាយឲ្យមនុស្សជាតិដឹង នោះនឹងមានមនុស្សមានទេពកោសល្យមួយក្រុមដែលស្គាល់ព្រះជាម្ចាស់ លេចមកបន្តកិច្ចការនេះ។ ប្រាកដណាស់ ខ្ញុំសង្ឃឹមដំណើររឿងនឹង ទៅជាបែបនេះ ហើយជាងនេះទៀត ខ្ញុំកំពុងស្ថិតនៅក្នុងដំណើរ ការនៃការអនុវត្តកិច្ចការនេះ ហើយខ្ញុំសង្ឃឹមថានឹងមើលឃើញមនុស្ស មានទេពកោសល្យបែបនេះលេចមកជាច្រើនទៀត នៅថ្ងៃអនាគតដ៏ខ្លីខាងមុខ។ ពួកគេនឹងក្លាយជាមនុស្សដែលធ្វើបន្ទាល់ពីការពិតនៃកិច្ចការទាំងបីដំណាក់កាលនេះ ហើយពិតណាស់ ពួកគេក៏នឹងក្លាយជាមនុស្សដំបូងដែលធ្វើបន្ទាល់ពីកិច្ចការទាំងបីដំណាក់កាលនេះផងដែរ។ ប៉ុន្តែ ប្រសិនបើមនុស្សមានទេពកោសល្យបែបនេះ មិនលេចឡើងនៅថ្ងៃដែលកិច្ចការរបស់ព្រះជាម្ចាស់ដល់ទីបញ្ចប់ ឬប្រសិនបើមានតែមនុស្សបែបនេះតែម្នាក់ ឬពីរនាក់ បានទទួលការប្រោសឲ្យបានគ្រប់លក្ខណ៍ពីព្រះជាម្ចាស់ដោយផ្ទាល់ គ្មានអ្វីតឹងចិត្ត និងគួរឲ្យស្ដាយជាងនេះឡើយ។ យ៉ាងណាមិញ នេះគ្រាន់តែជាលទ្ធផលដ៏ល្អបំផុតដែលអាចកើតឡើង។ បើទោះបីជា អាចមានករណីបែបណាក៏ដោយ ខ្ញុំនៅតែសង្ឃឹមថា អស់អ្នកដែលព្យាយាមពិតប្រាកដ អាចទទួលបានព្រះពរនេះ។ តាំងពីដើមដំបូងមក គឺមិនធ្លាប់មានកិច្ចការបែបនេះឡើយ។ កិច្ចការបែបនេះ មិនធ្លាប់កើតមាននៅក្នុងប្រវត្តិសាស្ត្រនៃការបង្កើតមនុស្សជាតិឡើយ។ ប្រសិនបើអ្នកពិតជាអាចក្លាយជាមនុស្សម្នាក់ ក្នុងចំណោមមនុស្សដំបូងដែលស្គាល់ព្រះជាម្ចាស់ តើនេះមិនក្លាយជាកិត្តិយសដ៏ខ្ពង់ខ្ពស់បំផុត នៅក្នុងចំណោមសត្តនិករទាំងអស់ទេឬអី? នៅក្នុងចំណោមមនុស្សជាតិ តើមានសត្តនិករណាមួយដែលត្រូវបានព្រះជាម្ចាស់សរសើរជាងនេះទេ? កិច្ចការបែបនេះ មិនងាយសម្រេចបានឡើយ ប៉ុន្តែនៅទីបំផុត

នឹងច្រូតផលរង្វាន់។ នៅទីបញ្ចប់ មនុស្សដែលអាចសម្រេចបាននូវចំណេះដឹងអំពីព្រះជាម្ចាស់ គេក៏ទទួលបានកិត្តិយសដ៏ធំបំផុតរបស់ព្រះជាម្ចាស់ ហើយនឹងក្លាយជាមនុស្សមួយក្រុមគត់ដែលមានសិទ្ធិអំណាចរបស់ព្រះជាម្ចាស់ជាកម្មសិទ្ធ ទោះបីជាគេមានភេទអ្វី ឬមានសញ្ជាតិអ្វីក៏ដោយ។ នេះជាកិច្ចការបច្ចុប្បន្ន ហើយក៏ជាកិច្ចការនៅថ្ងៃអនាគតដែរ នេះជាកិច្ចការចុងក្រោយ និងជាកិច្ចការដ៏ខ្ពង់ខ្ពស់បំផុតដែលត្រូវសម្រេចឲ្យបាន ក្នុងកិច្ចការរយៈពេល៦០០០ឆ្នាំនេះ ហើយវាគឺជារបៀបធ្វើការដែលបង្ហាញអំពីជំពូកមនុស្សនីមួយៗ។ តាមរយៈកិច្ចការនៃការបណ្ដាលឲ្យមនុស្សជាតិស្គាល់ព្រះជាម្ចាស់ ឋានៈរបស់មនុស្សត្រូវបានបើកសម្ដែង៖ អស់អ្នកណាដែលស្គាល់ព្រះជាម្ចាស់ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ទទួលបានព្រះពររបស់ព្រះជាម្ចាស់ ហើយទទួលបាននូវសេចក្ដីសន្យារបស់ទ្រង់ ឯមនុស្សដែលមិនស្គាល់ព្រះជាម្ចាស់ គ្មានលក្ខណៈសម្បត្តិទទួលបានព្រះពររបស់ព្រះជាម្ចាស់ ហើយមិនទទួលបាននូវសេចក្ដីសន្យារបស់ទ្រង់ឡើយ។ អស់អ្នកណាដែលស្គាល់ព្រះជាម្ចាស់ គឺជាសម្លាញ់របស់ព្រះជាម្ចាស់ ហើយអស់អ្នកណាដែលមិនស្គាល់ព្រះជាម្ចាស់ គឺមិនអាចហៅជាមិត្តសម្លាញ់របស់ព្រះជាម្ចាស់ឡើយ មិត្តសម្លាញ់របស់ព្រះជាម្ចាស់ អាចទទួលព្រះពរណាក៏បានពីព្រះជាម្ចាស់ ចំណែកឯមនុស្សដែលមិនមែនជាសម្លាញ់របស់ទ្រង់វិញ គឺគេមិនសមទទួលកិច្ចការណាមួយរបស់ទ្រង់ឡើយ។ ទោះបីមហាវេទនាការបន្សុទ្ធ ឬការជំនុំជម្រះ កិច្ចការទាំងអស់នេះ គឺសុទ្ធតែជាប្រយោជន៍ ដើម្បីឲ្យមនុស្សសម្រេចបាននូវការស្គាល់ព្រះជាម្ចាស់នៅទីបំផុត ហើយដើម្បីឲ្យមនុស្សអាចចុះចូលនឹងព្រះជាម្ចាស់។ នេះគ្រាន់តែជាផល ដែលសម្រេចបាននៅទីបំផុត។ ក្នុងកិច្ចការទាំងបីដំណាក់កាល ពុំមានអ្វីលាក់កំបាំងទេ ហើយនេះជាគុណប្រយោជន៍ដល់ការដែលមនុស្សស្គាល់ព្រះជាម្ចាស់ ហើយជាជំនួយឲ្យមនុស្សទទួលបាននូវការស្គាល់ព្រះជាម្ចាស់យ៉ាងពេញលេញ ហើយហ្មត់ ចត់។ កិច្ចការអស់ទាំងនេះ គឺសុទ្ធតែមានអត្ថប្រយោជន៍ដល់មនុស្សជាតិ។

កិច្ចការរបស់ព្រះជាម្ចាស់ផ្ទាល់ គឺជានិមិត្តដែលមនុស្សត្រូវតែស្គាល់ ដ្បិតកិច្ចការ

របស់ព្រះជាម្ចាស់ គឺមិនអាចសម្រេចបាន ដោយសារមនុស្ស ហើយមនុស្សមិនអាចយកធ្វើជាកម្មសិទ្ធិបានឡើយ។ កិច្ចការទាំងបីដំណាក់នេះ ជាការគ្រប់គ្រងរបស់ព្រះជាម្ចាស់ទាំងស្រុង និងគ្មាននិមិត្តណាធំជាងនេះដែលគួរឲ្យមនុស្ស ត្រូវស្គាល់នោះឡើយ។ ប្រសិនបើមនុស្សមិនស្គាល់និមិត្តដ៏មានឫទ្ធានុភាពនេះទេ នោះគេមិនងាយនឹងស្គាល់ព្រះជាម្ចាស់ ក៏មិនងាយនឹងយល់ពីព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែរ ហើយជាងនេះទៅទៀត ផ្លូវដែលមនុស្សដើរ នឹងរឹតតែពិបាកឡើងៗ។ ប្រសិនបើគ្មាននិមិត្តនេះ មនុស្សមុខជាមិនអាចមកដល់ឆ្ងាយ ដល់ថ្នាក់នេះឡើយ។ នេះគឺជានិមិត្តដែលបានឃុំគ្រងមនុស្សរហូតមកទល់សព្វថ្ងៃ ហើយក៏ជានិមិត្តដែលបានផ្ដល់នូវការការពារដ៏ធំបំផុតដល់មនុស្សដែរ។ នៅថ្ងៃអនាគត ចំណេះដឹងរបស់អ្នកត្រូវតែស៊ីជម្រៅ ហើយអ្នកត្រូវតែចាប់ផ្ដើមស្គាល់ព្រះហឫទ័យរបស់ព្រះអង្គទាំងស្រុង និងលក្ខណៈសំខាន់នៃកិច្ចការដ៏ឈ្លាសវៃរបស់ព្រះអង្គ នៅក្នុងកិច្ចការទាំងបីដំណាក់កាល។ នេះទើបជាកេរ្តិ៍ឈ្មោះដ៏ពិតប្រាកដរបស់អ្នក។ កិច្ចការដំណាក់កាលចុងក្រោយ មិនមែនខុសគេនោះទេ ប៉ុន្តែវាជាចំណែកមួយនៃកិច្ចការទាំងមូល ដែលរួមនឹងកិច្ចការនៅក្នុងដំណាក់កាលពីរមុន មានន័យថា កិច្ចការនៃសេចក្ដីសង្គ្រោះទាំងមូលមិនអាចសម្រេចបាន ដោយគ្រាន់តែសម្រេចនូវកិច្ចការតែមួយ ក្នុងចំណោមកិច្ចការទាំងបីដំណាក់កាលឡើយ។ បើទោះបីជាកិច្ចការដំណាក់កាលចុងក្រោយ អាចសង្គ្រោះមនុស្សយ៉ាងពេញលេញមែន នេះមិនមែនមានន័យថា ចាំបាច់ត្រូវតែអនុវត្ត កិច្ចការតែមួយដំណាក់កាលនេះតែឯងនោះទេ និងមាន ន័យថា ការសង្គ្រោះមនុស្សពីឥទ្ធិពលរបស់សាតាំងមិនត្រូវការនូវកិច្ចការពីរដំណាក់កាលមុននោះឡើយ។ ក្នុងដំណាក់កាលទាំងបី គ្មានដំណាក់កាលមួយណា ត្រូវបានរាប់ជានិមិត្តតែមួយគត់ ដែលមនុស្សជាតិទាំងអស់ត្រូវដឹងនោះឡើយ ដ្បិតកិច្ចការនៃសេចក្ដីសង្គ្រោះទាំងមូលជាកិច្ចការទាំងបីដំណាក់កាល មិនមែនកិច្ចការតែមួយដំណាក់កាល ក្នុងចំណោមកិច្ចការទាំងបីដំណាក់កាលនេះឡើយ។ ដរាបណាកិច្ចការនៃសេចក្ដីសង្គ្រោះមិនទាន់បានសម្រេច ការគ្រប់គ្រងរបស់ព្រះជាម្ចាស់មិនអាចឈានមកដល់ទីបញ្ចប់ទាំងស្រុងបានឡើយ។ លក្ខណៈរបស់

ព្រះជាម្ចាស់ និស្ស័យរបស់ទ្រង់ និងប្រាជ្ញាញាណរបស់ទ្រង់ សុទ្ធតែត្រូវបានបង្ហាញក្នុងភាពពេញលេញនៃកិច្ចការនៃសេចក្ដីសង្រ្គោះ។ កិច្ចការទាំងនេះ មិនត្រូវបានបើកសម្ដែងឲ្យមនុស្សឃើញនៅគ្រាដើមដំបូងនោះឡើយ តែត្រូវបានបង្ហាញមកបន្ដិចម្ដងតាមរយៈកិច្ចការនៃសេចក្ដីសង្រ្គោះ។ ដំណាក់កាលនីមួយៗ ក្នុងកិច្ចការនៃសេចក្ដីសង្រ្គោះ បង្ហាញចំណែកមួយនៃនិស្ស័យរបស់ព្រះជាម្ចាស់ និងចំណែកមួយនៃអត្តភាពរបស់ព្រះអង្គ គ្មានដំណាក់កាលមួយនៃកិច្ចការនេះ អាចបង្ហាញអត្ថិភាពទាំងស្រុងរបស់ព្រះជាម្ចាស់ផ្ទាល់ និងពេញលេញបានឡើយ។ ដូច្នេះ កិច្ចការនៃសេចក្ដីសង្រ្គោះអាចបញ្ចប់ទៅយ៉ាងពេញលេញ លុះត្រាតែកិច្ចការទាំងបីដំណាក់កាលត្រូវបានបញ្ចប់ដូច្នេះហើយ ចំណេះដឹងរបស់មនុស្សទាក់ទងនឹងភាពពេញលេញរបស់ព្រះជាម្ចាស់ គឺមិនអាចកាត់ផ្ដាច់ចេញ ពីដំណាក់កាលទាំងបី នៃកិច្ចការរបស់ព្រះជាម្ចាស់។ ផលដែលមនុស្សទទួលបានពីកិច្ចការក្នុងដំណាក់កាលមួយ គឺគ្រាន់តែជានិស្ស័យរបស់ព្រះជាម្ចាស់ ដែលត្រូវបានបង្ហាញចេញមក នៅក្នុងដំណាក់កាលមួយនៃកិច្ចការរបស់ទ្រង់ប៉ុណ្ណោះ។ វាមិនអាចតំណាងនិស្ស័យ និងអត្ថិភាពដែលត្រូវបានបង្ហាញចេញមក នៅក្នុងដំណាក់កាលមុន ឬដំណាក់កាលក្រោយបានឡើយ។ នោះគឺមកពីកិច្ចការសង្រ្គោះមនុស្សជាតិ មិនអាចបញ្ចប់ភ្លាមៗក្នុងពេលមួយគ្រា ឬក្នុងទីតាំងតែមួយឡើយ ប៉ុន្ដែកាន់តែស៊ីជម្រៅបន្ដិចម្ដងៗ ទៅតាមកម្រិតនៃការអភិវឌ្ឍរបស់មនុស្ស នៅក្នុងរយៈពេល និងទីកន្លែងខុសៗគ្នា។ នេះគឺជាកិច្ចការ ដែលត្រូវបានអនុវត្តជាដំណាក់កាលៗ ហើយមិនត្រូវបញ្ចប់ តែក្នុងមួយដំណាក់កាលបានឡើយ។ ដូច្នេះ ប្រាជ្ញាញាណទាំងស្រុងរបស់ព្រះជាម្ចាស់ ត្រូវបានស្ដែងចេញមករឹតតែច្បាស់ ក្នុងដំណាក់កាលទាំងបី មិនមែនតែនៅក្នុងមួយដំណាក់កាលទេ។ លក្ខណៈ និងប្រាជ្ញាញាណទាំងស្រុងរបស់ព្រះអង្គត្រូវបានលាតសន្ធឹងនៅក្នុងដំណាក់កាលទាំងបីនេះ ហើយដំណាក់កាលនីមួយៗសុទ្ធតែមានលក្ខណៈរបស់ទ្រង់ ហើយដំណាក់កាលនីមួយៗ គឺជាកំណត់ត្រាអំពីប្រាជ្ញានៃកិច្ចការរបស់ទ្រង់។ មនុស្សគប្បីស្គាល់និស្ស័យទាំងអស់ ដែលព្រះជាម្ចាស់បានបង្ហាញចេញមក នៅក្នុងដំណាក់កាលទាំងបី។ លក្ខណៈទាំងអស់របស់ទ្រង់ មាន

សារៈសំខាន់ខ្លាំងណាស់ ដល់មនុស្សជាតិគ្រប់ៗគ្នា ហើយប្រសិនបើមនុស្សគ្មានចំណេះដឹងនេះ ពេលគេថ្វាយបង្គំព្រះជាម្ចាស់ នោះពួកគេមិនខុសអីពីមនុស្សដែលថ្វាយបង្គំព្រះពុទ្ធអង្គនោះឡើយ។ កិច្ចការរបស់ព្រះជាម្ចាស់ក្នុងចំណោមមនុស្សជាតិមិនត្រូវបានលាក់កំបាំងពីមនុស្សជាតិឡើយ ហើយមនុស្សជាតិ ទាំងអស់ដែលថ្វាយបង្គំព្រះជាម្ចាស់ គួរណាស់ស្គាល់កិច្ចការនេះ។ ដ្បិតព្រះជាម្ចាស់បានអនុវត្តកិច្ចការទាំងបីដំណាក់កាលនៃសេចក្ដីសង្គ្រោះក្នុងចំណោមមនុស្សជាតិរួចហើយ ដូច្នេះ មនុស្សក៏គួរតែស្គាល់នូវការបង្ហាញពីកម្មសិទ្ធិ និងអត្តសញ្ញាណរបស់ទ្រង់ នៅក្នុងកិច្ចការទាំងបីដំណាក់កាលនេះដែរ។ នេះជាកិច្ចការដែលមនុស្ស ត្រូវតែធ្វើ។ ព្រះជាម្ចាស់លាក់កំបាំងតែកិច្ចការណាដែលមនុស្សពុំសម្រេចបាន និងកិច្ចការណាដែលមនុស្សមិនគួរដឹងទេ ចំណែកឯកិច្ចការដែលទ្រង់បង្ហាញឲ្យមនុស្សជាតិឃើញ គឺជាកិច្ចការដែលមនុស្សគួរដឹង ហើយជាកិច្ចការដែលមនុស្សគួរមានជាកម្មសិទ្ធិ។ ដំណាក់កាលនីមួយៗនៅក្នុងកិច្ចការទាំងបីដំណាក់កាល ត្រូវបានអនុវត្តលើមូលដ្ឋានគ្រឹះនៃដំណាក់កាលមុន។ កិច្ចការនោះ មិនត្រូវបានអនុវត្តដោយឯករាជ្យ ដោយឡែកពីកិច្ចការនៃសេចក្ដីសង្គ្រោះនោះឡើយ។ បើទោះបីជាមានភាពខុសគ្នាជាខ្លាំងក្នុងយុគសម័យ និងកិច្ចការដែលត្រូវបានអនុវត្តក្ដី ក៏ស្នូលនៃកិច្ចការនេះ គឺនៅតែជាសេចក្ដីសង្គ្រោះសម្រាប់មនុស្សជាតិដដែល រីឯដំណាក់កាលនីមួយៗក្នុងកិច្ចការនៃសេចក្ដីសង្គ្រោះ ក៏កាន់តែស៊ីជម្រៅទៅដែរ។ ដំណាក់កាលនៃកិច្ចការនីមួយៗ បន្តលើគ្រឹះនៃដំណាក់កាលចុងក្រោយ ជាគ្រឹះដែលមិនត្រូវបាន រំលើងចោលឡើយ។ តាមវិធីនេះ ព្រះជាម្ចាស់នៅតែបង្ហាញចំណុចៗនៃនិស្ស័យរបស់ទ្រង់ ដែលមិនធ្លាប់ត្រូវបានបង្ហាញដល់មនុស្សណាសោះ តាមរយៈកិច្ចការរបស់ទ្រង់ដែលតែងតែថ្មីជានិច្ច មិនដែលចាស់ ហើយសូម្បីតែអ្នកកាន់សាសនាដ៏ចាស់គំរិល ក៏ប្រឹងអស់ពីលទ្ធភាពដើម្បីតតាំងនឹងសេចក្ដីនេះដែរ ហើយប្រឆាំងទាស់នឹងសេចក្ដីនេះដោយបើកចំហផង ដោយឡែកព្រះជាម្ចាស់តែងធ្វើកិច្ចការថ្មីដែលទ្រង់ចង់ធ្វើជានិច្ច។ កិច្ចការរបស់ទ្រង់ផ្លាស់ប្ដូរជានិច្ច ហើយដោយព្រោះមូលហេតុនេះ ទើបកិច្ចការរបស់ទ្រង់ តែងតែពើបប្រទះនឹងការប្រឆាំងទាស់របស់

មនុស្សរហូត។ ដូច្នេះ និស្ស័យរបស់ព្រះអង្គ ក៏ផ្លាស់ប្ដូរដូចគ្នានឹងយុគសម័យ និងអ្នកទទួលនូវកិច្ចការរបស់ទ្រង់ដែរ។ ជាងនេះទៅទៀត ទ្រង់តែងតែធ្វើកិច្ចការដែលពុំធ្លាប់មានគេធ្វើពីមុនមកសោះ ថែមទាំងអនុវត្តកិច្ចការដែលមនុស្សមើលទៅផ្ទុយស្រឡះពីកិច្ចការ ដែលធ្លាប់មានគេធ្វើពីមុន ដើម្បីឲ្យបញ្ញាសគេ។ មនុស្សបានត្រឹមតែអាចទទួលកិច្ចការតែមួយប្រភេទ ឬក៏វិធីអនុវត្តតែមួយប៉ុណ្ណោះ ហើយវាពិបាកនឹងឲ្យមនុស្សទទួលយកកិច្ចការ ឬវិធីអនុវត្តដែលផ្ទុយ ពីគេ ឬខ្ពង់ខ្ពស់ជាងពួកគេណាស់។ ប៉ុន្តែ ព្រះវិញ្ញាណបរិសុទ្ធតែងតែធ្វើកិច្ចការថ្មីជានិច្ច ដូច្នេះ អ្នកជំនាញខាងសាសនាដែលប្រឆាំងទាស់នឹងកិច្ចការថ្មីរបស់ព្រះជាម្ចាស់ ក៏ចេះតែមានមួយក្រុមហើយមួយក្រុមទៀត។ មនុស្សទាំងអស់នេះ ក៏បានក្លាយជាអ្នកជំនាញយ៉ាងច្បាស់ ដោយសារមកពីមនុស្សមិនដឹងថា ព្រះជាម្ចាស់ថ្មីរហូតមិនចេះចាស់ ហើយគេមិនដឹងអំពីគោលការណ៍នៃកិច្ចការរបស់ព្រះជាម្ចាស់ ហើយជាងនេះទៅទៀត គឺមិនដឹងអំពីវិធីជាច្រើនដែលព្រះជាម្ចាស់ប្រើ ដើម្បីសង្គ្រោះមនុស្សជាតិនោះឡើយ។ ដូច្នេះ មនុស្សមិនអាចប្រាប់បានទេថា មួយណាជាកិច្ចការដែលមកពីព្រះវិញ្ញាណបរិសុទ្ធ ហើយមួយណាជាកិច្ចការរបស់ព្រះជាម្ចាស់ដោយផ្ទាល់ព្រះអង្គ។ មនុស្សជាច្រើន ប្រកាន់ខ្ជាប់អាកប្បកិរិយាមួយថា ប្រសិនបើអ្វីម៉្យាងឆ្លើយតបទៅនឹងព្រះបន្ទូលពីមុន នោះពួកគេនឹងទទួលយក ហើយប្រសិនបើមានភាពខុសប្លែកនឹងកិច្ចការក្នុងអតីតកាល នោះពួកគេនឹងប្រឆាំង ហើយបដិសេធកិច្ចការនោះផង។ សព្វថ្ងៃ តើអ្នករាល់គ្នាមិនប្រកាន់ខ្ជាប់ តាមគោលការណ៍បែបនេះទេឬអី? កិច្ចការទាំងបីដំណាក់កាលនៃសេចក្ដីសង្គ្រោះ ពុំមានឥទ្ធិពលអ្វីធំដុំលើអ្នករាល់គ្នាទេ ក៏មានអ្នកខ្លះទៀតជឿថា កិច្ចការពីរដំណាក់មុន គ្រាន់តែជាបន្ទុកមួយ ដែលពួកគេមិនត្រូវការដឹងឮប៉ុណ្ណោះ។ ពួកគេគិតថា ដំណាក់កាលទាំងអស់នេះមិនគួរយកទៅប្រកាសប្រាប់មហាជន និងមិនគួរដកយកមកវិញយ៉ាងឆាប់ពេកនោះដែរ ដើម្បីកុំឲ្យមនុស្សមានអារម្មណ៍រំភើពជ្រុល ដោយសារតែដំណាក់កាលចំនួនពីរក្នុងគ្រាមុន ដែលនៅក្នុង ចំណោមកិច្ចការទាំងបីដំណាក់កាល។ មនុស្សភាគច្រើនជឿថាការប្រកាសប្រាប់ពីកិច្ចការពីរដំណាក់កាលមុន គឺជាជំហានមួយ ដែលហួសហេតុ

ហើយក៏មិនមាន ប្រយោជន៍ក្នុងការស្គាល់ព្រះជាម្ចាស់ដែរ នេះជាអ្វីដែលអ្នករាល់គ្នាគិត។ សព្វថ្ងៃនេះ អ្នករាល់គ្នាជឿថា ការប្រព្រឹត្តបែបនេះគឺជាទង្វើដ៏ត្រឹមត្រូវ ប៉ុន្តែថ្ងៃមួយមកដល់ នោះអ្នករាល់គ្នានឹងទទួលស្គាល់កិច្ចការរបស់ខ្ញុំ៖ ចូរដឹងថា ខ្ញុំមិនធ្វើកិច្ចការណាដែលពុំមានសារៈសំខាន់ឡើយ។ ដ្បិតខ្ញុំកំពុងប្រកាស ពីកិច្ចការទាំងបីដំណាក់កាលប្រាប់អ្នករាល់គ្នា កិច្ចការនោះត្រូវតែមានប្រយោជន៍ដល់អ្នករាល់គ្នា ដ្បិតកិច្ចការទាំងបីដំណាក់កាលនេះ គឺជាចំណុចដ៏សំខាន់បំផុតនៃកិច្ចការគ្រប់គ្រងរបស់ព្រះជាម្ចាស់ កិច្ចការទាំងនេះក៏ក្លាយជាចំណុចដ៏គួរយកចិត្តទុកដាក់ពីមនុស្សគ្រប់គ្នាក្នុងសកលលោកទាំងមូល។ ថ្ងៃមួយ អ្នករាល់គ្នានឹងទទួលស្គាល់សារៈសំខាន់នៃកិច្ចការនេះ។ ចូរដឹងថា អ្នករាល់គ្នាប្រឆាំងទាស់នឹងកិច្ចការរបស់ព្រះជាម្ចាស់ ឬប្រើប្រាស់សញ្ញាណរបស់ខ្លួនឯងផ្ទាល់ មកវាស់ស្ទង់គោលការណ៍នៃកិច្ចការរបស់ព្រះជាម្ចាស់សព្វថ្ងៃ ដ្បិតអ្នករាល់គ្នាពុំស្គាល់ គោលការណ៍នៃកិច្ចការរបស់ព្រះជាម្ចាស់ ហើយដោយសារការបដិបត្តិរបស់អ្នករាល់គ្នាចំពោះកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ។ ការដែលអ្នករាល់គ្នាប្រឆាំងទាស់នឹងព្រះជាម្ចាស់ និងការរារាំងដល់កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ គឺសុទ្ធតែត្រូវបានបង្កឡើងដោយសញ្ញាណ និងភាពក្រអឺតក្រទមពីកំណើតរបស់អ្នករាល់គ្នា។ នេះមិនមែនមកពីកិច្ចការរបស់ព្រះជាម្ចាស់ខុសនោះទេ តែគឺមកពីអ្នករាល់គ្នារឹងចចេសពេក តាំងពីកំណើត។ បន្ទាប់ពីពួកគេរកឃើញសេចក្ដីជំនឿរបស់ពួកគេ ចំពោះព្រះជាម្ចាស់ មនុស្សខ្លះមិនទាំងអាចនិយាយដោយភាពជឿជាក់ថា មនុស្សមកពីណាផង ប៉ុន្តែពួកគេហ៊ាននិយាយវាយតម្លៃភាពខុសត្រូវនៃកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ជាសាធារណៈ។ ពួកគេថែមទាំងបង្រៀនពួកសាវ័ក ដែលមានកិច្ចការថ្មីរបស់ព្រះវិញ្ញាណបរិសុទ្ធ ដោយផ្ដល់មូលវាចារ និង និយាយចេញមកទាំងដែលខ្លួនគ្មានសិទ្ធិអំណាចអ្វីសោះ។ ភាពជាមនុស្សរបស់គេ នៅទាបណាស់ ហើយពួកគេ ពុំមានសតិនៅក្នុងខ្លួនសូម្បីតែបន្តិច។ តើថ្ងៃដែលមនុស្សត្រូវបានបដិសេធដោយកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ និងត្រូវដុតដោយភ្លើងស្ថាននរក នឹងមិនមកដល់ទេឬអី? ពួកគេមិនស្គាល់កិច្ចការរបស់ព្រះជាម្ចាស់ទេ តែពួកគេបែរជា

ទិតៀនកិច្ចការរបស់ទ្រង់ ហើយព្យាយាមណែនាំទ្រង់ពីរបៀបធ្វើការទៀតផង។ តើមនុស្សឥតហេតុផលបែបនេះ ស្គាល់ព្រះជាម្ចាស់ដូចម្ដេចទៅ? មនុស្សចាប់ផ្ដើមស្គាល់ព្រះជាម្ចាស់ ក្នុងពេលកំពុងស្វែងរក និងកំពុងដកពិសោធន៍ មិនមែនតាមការទិតៀនតាមទំនើងចិត្តថា មនុស្សចាប់ផ្ដើមស្គាល់ព្រះជាម្ចាស់ តាមរយៈការស្រាយបំភ្លឺពីព្រះវិញ្ញាណបរិសុទ្ធឡើយ។ កាលណាមនុស្សស្គាល់ព្រះជាម្ចាស់រឹតតែច្បាស់ នោះគេរឹតតែលែងប្រឆាំងទាស់នឹងទ្រង់។ ផ្ទុយទៅវិញ កាលណាកាន់តែមិនស្គាល់ព្រះជាម្ចាស់ នោះពួកគេក៏រឹតតែប្រឆាំងទាស់នឹងទ្រង់ដែរ។ សញ្ញាណរបស់អ្នក សន្ដានចាស់របស់អ្នក ភាពជាមនុស្សរបស់អ្នក ចរិត និងទស្សនៈខាងសីលធម៌របស់អ្នក គឺជា ដើមទុនដែលអ្នកយកមកតតាំងនឹងព្រះជាម្ចាស់ ហើយកាលណាសីលធម៌ គុណសម្បត្តិរបស់អ្នកកាន់តែគួរឱ្យស្អប់ ហើយភាពជាមនុស្សរបស់អ្នកកាន់តែអន់ថយ នោះអ្នកជាខ្មាំងសត្រូវរបស់ព្រះជាម្ចាស់ហើយ។ មនុស្សណាដែលមាន សញ្ញាណខ្លាំងក្លា និងមនុស្សដែលមាននិស្ស័យស្វ័យសុចរិត រឹតតែជាខ្មាំងសត្រូវនឹងព្រះដែលយកកំណើតជាសាច់ឈាមផង។ មនុស្សបែបនេះគឺជាពួកទទឹងនឹងព្រះគ្រីស្ទ។ ប្រសិនបើសញ្ញាណរបស់អ្នកមិនត្រូវបានកែតម្រង់ទេ នោះពួកគេនឹងប្រឆាំងទាស់នឹងព្រះជា ម្ចាស់រហូត។ អ្នកនឹងមិនបានស្រុះនឹងព្រះជាម្ចាស់ឡើយ ហើយអ្នកនឹង នៅឆ្ងាយពីទ្រង់ជានិច្ច។

មានតែការបោះបង់សញ្ញាណចាស់របស់អ្នកទេ ទើបអាចឲ្យ អ្នកទទួលបានចំណេះដឹងថ្មីបាន តែចំណេះដឹងចាស់មិនចាំឲ្យស្មើ នឹងសញ្ញាណចាស់នោះដែរ។ «សញ្ញាណ» សំដៅលើរឿងរ៉ាវដែល មនុស្សស្រមៃ ហើយមានលក្ខណៈខុសពីភាពជាក់ស្ដែង។ ប្រសិនបើចំណេះដឹងចាស់ បានផុតកំណត់ក្នុងយុគសម័យចាស់ ហើយបានបង្អាក់មនុស្សមិនឲ្យចូលទៅក្នុងកិច្ចការថ្មី នោះចំណេះដឹងបែបនេះក៏ជាសញ្ញាណមួយដែរ។ ប្រសិនបើមនុស្សមិនអាចតម្រង់ឆ្ពោះទៅរកចំណេះដឹងនេះឲ្យបានត្រឹមត្រូវ ហើយអាចចាប់ផ្ដើមស្គាល់ព្រះជាម្ចាស់ តាមរយៈកត្តាជាច្រើនខុសៗគ្នា ដោយរួមបញ្ចូលទាំងចំណេះដឹងចាស់និងថ្មី នោះចំណេះដឹងចាស់នឹងក្លាយជាជំនួយដល់មនុស្ស និងក្លាយជាគោលការណ៍គ្រឹះ សម្រាប់ឲ្យមនុស្សចូលទៅក្នុងយុគសម័យថ្មីជាមិនខាន។

មេរៀនអំពីការស្គាល់ព្រះជាម្ចាស់ ទាមទារឲ្យអ្នកស្គាល់ច្បាស់នូវគោលការណ៍ជាច្រើន ដូចជា៖ វិធីចូលទៅក្នុងមាគ៌ាដើម្បីឲ្យបានស្គាល់ព្រះជាម្ចាស់ សេចក្ដីពិតណាខ្លះដែលអ្នកត្រូវតែយល់ ដើម្បីឲ្យបានស្គាល់ព្រះជាម្ចាស់ និងវិធីកម្ចាត់ចោលនូវសញ្ញាណ ហើយនិងនិស្ស័យចាស់របស់អ្នក ដើម្បីឲ្យអ្នកអាចចុះចូលចំពោះការចាត់ចែងទាំងអស់នៅក្នុងកិច្ចការថ្មីរបស់ព្រះជាម្ចាស់។ ប្រសិនបើអ្នកប្រើគោលការណ៍ទាំងនេះ ធ្វើជាមូលដ្ឋានគ្រឹះ សម្រាប់ការចូលទៅក្នុងមេរៀនអំពីការស្គាល់ព្រះជាម្ចាស់ នោះចំណេះដឹងរបស់អ្នកនឹងកាន់តែស៊ីជម្រៅទៅៗ។ ប្រសិនបើអ្នកមានចំណេះដឹងច្បាស់ អំពីកិច្ចការទាំងបីដំណាក់កាល ពោលគឺផែនការនៃការគ្រប់គ្រងរបស់ព្រះជាម្ចាស់ទាំងមូល ហើយប្រសិនបើអ្នកអាចផ្សារភ្ជាប់ដំណាក់កាលពីមុននៃកិច្ចការរបស់ព្រះជាម្ចាស់ជាមួយនឹងដំណាក់កាលបច្ចុប្បន្ន ហើយមើលឃើញថា នេះគឺជាកិច្ចការដែលត្រូវបានធ្វើដោយព្រះតែមួយ នោះអ្នកនឹងមានគ្រឹះមួយដ៏រឹងមាំ គ្មានអ្វីប្រៀបបាន។ កិច្ចការទាំងបីដំណាក់កាល ត្រូវបានធ្វើឡើងដោយ ព្រះតែមួយអង្គប៉ុណ្ណោះ។ នេះគឺជានិមិត្តមួយដ៏អស្ចារ្យបំផុត ហើយនេះគឺជាមាគ៌ាតែមួយគត់ឆ្ពោះទៅរកការស្គាល់ព្រះជាម្ចាស់។ កិច្ចការទាំងបីដំណាក់កាល គឺមានតែព្រះជាម្ចាស់ផ្ទាល់ទេទើបអាចសម្រេចបាន ក៏ពុំមាននរណាម្នាក់អាចធ្វើកិច្ចការនេះជំនួសទ្រង់បានដែរ មានន័យថា គឺមានតែព្រះជាម្ចាស់ផ្ទាល់ទេ ទើបអាចសម្រេចកិច្ចការរបស់ទ្រង់ផ្ទាល់ តាំងពីគ្រាដើមដំបូង រហូតមកទល់សព្វថ្ងៃនេះ។ ទោះបីកិច្ចការទាំងបី ដំណាក់កាលត្រូវបានអនុវត្តរួចនៅក្នុងយុគសម័យ និងតាមកន្លែងខុសៗគ្នា ហើយទោះបីកិច្ចការនីមួយៗខុសគ្នា ក៏កិច្ចការទាំងអស់ត្រូវបានធ្វើឡើង ដោយព្រះតែមួយអង្គគត់។ នៅក្នុងចំណោមនិមិត្តទាំងអស់នេះជានិមិត្តធំបំផុតដែលមនុស្សគួរដឹង ហើយប្រសិនបើមនុស្សអាចយល់ពីនិមិត្តនេះទាំងស្រុង នោះគេនឹងអាចឈរជាប់។ សព្វថ្ងៃនេះ បញ្ហាដ៏ធំបំផុតដែលកំពុងតែប្រឈមនឹងសាសនា និងនិកាយផ្សេងៗនោះគឺ ពួកគេមិនស្គាល់កិច្ចការរបស់ព្រះវិញ្ញាណដ៏បរិសុទ្ធ និងមិនអាចបែងចែករវាងកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ និងកិច្ចការដែលមិនមែនជា របស់ព្រះវិញ្ញាណបរិសុទ្ធ ដោយព្រោះហេតុនេះ ពួកគេមិន

អាចប្រាប់បានទេថា កិច្ចការក្នុងដំណាក់កាលនេះក៏ត្រូវបានធ្វើឡើងដោយព្រះយេហូវ៉ាដ៏ជាព្រះ ដូចកិច្ចការនៅក្នុងដំណាក់កាលពីរក្នុងគ្រាមុនដែរ។ ទោះបីមនុស្សដើរតាមព្រះជាម្ចាស់ ក៏ពួកគេភាគច្រើន នៅតែមិនអាចប្រាប់បានថា ផ្លូវមួយណាជាផ្លូវត្រឹមត្រូវនោះដែរ។ មនុស្សខ្វល់ថា ផ្លូវនេះជាផ្លូវដែលព្រះជាម្ចាស់ដឹកនាំដោយផ្ទាល់ ឬមិនមែន ហើយខ្វល់ថា រូបកាយសាច់ឈាមរបស់ព្រះជាម្ចាស់ គឺជាការពិត ឬមិនមែន ហើយមនុស្សភាគច្រើននៅតែមិនដឹងអំពីវិធីសម្គាល់សេចក្ដីបែបនេះឡើយ។ មនុស្សដែលដើរតាមព្រះជាម្ចាស់មិនអាចកំណត់ផ្លូវនេះ ដូចនេះសារដែលត្រូវថ្លែង គឺមានឥទ្ធិពលតែមួយចំណែក នៅក្នុងចំណោមមនុស្សទាំងនេះ និងមិនអាចមានប្រសិទ្ធភាពទាំងស្រុងនោះឡើយ ហេតុនេះ ហើយកត្តានេះក៏ជះឥទ្ធិពលដល់ផ្លូវជីវិតនៃមនុស្សបែបនេះដែរ។ ប្រសិនបើមនុស្សអាចមើលឃើញក្នុងកិច្ចការទាំងបីដំណាក់កាលថា កិច្ចការទាំងនេះត្រូវបានអនុវត្តដោយព្រះជាម្ចាស់ផ្ទាល់ នៅក្នុងពេលវេលាខុសគ្នា ក្នុងទីកន្លែងខុសគ្នា និងនៅក្នុងមនុស្សខុសគ្នា ប្រសិនបើមនុស្សអាចមើលឃើញថា ទោះបីជាកិច្ចការនេះខុសគ្នា ក៏កិច្ចការទាំងអស់ ត្រូវបានធ្វើឡើងដោយព្រះតែមួយ ហើយមើលឃើញថា ដោយសារកិច្ចការនេះត្រូវបានធ្វើឡើងដោយព្រះតែមួយនោះ កិច្ចការនោះត្រូវតែជាកិច្ចការត្រឹមត្រូវ និងពុំមានខុសឡើយ ហើយបើទោះបីជាកិច្ចការនេះខុសគ្នាពីសញ្ញាណរបស់មនុស្ស ក៏ពុំមានការបដិសេធថា កិច្ចការនេះ គឺជាកិច្ចការរបស់ព្រះតែមួយដែរ ប្រសិនបើមនុស្សអាចនិយាយដោយប្រាកដច្បាស់ថា កិច្ចការនេះគឺជាកិច្ចការរបស់ព្រះតែមួយ នោះសញ្ញាណរបស់មនុស្សនឹងត្រូវ បន្ថយមកត្រឹមតែជាការលេងសើច មិនសមលើកមកនិយាយទេ។ ដោយសារតែនិមិត្តរបស់មនុស្សមិនច្បាស់លាស់ ហើយដោយសារតែមនុស្សដឹងតែត្រឹមថា ព្រះយេហូវ៉ា គឺជាព្រះ និងដឹងត្រឹមថា ព្រះយេស៊ូវ គឺជាព្រះអម្ចាស់និងមានគំនិតពីរចំពោះព្រះដែលយកកំណើតជាសាច់ឈាមនាពេលសព្វថ្ងៃ ក៏មានមនុស្សជាច្រើននៅតែលះបង់ចំពោះកិច្ចការរបស់ព្រះយេហូវ៉ា និងព្រះយេស៊ូវដែរ ហើយត្រូវរំខានឥតឈប់ឈរ ដោយសញ្ញាណចំពោះកិច្ចការនាពេលបច្ចុប្បន្ន មនុស្សភាគច្រើនតែងសង្ស័យ និងមិនយកចិត្តទុកដាក់ចំពោះ

កិច្ចការបច្ចុប្បន្ននេះទេ។ មនុស្សគ្មានសញ្ញាណ ចំពោះកិច្ចការពីរដំណាក់កាលចុងក្រោយ ដែលមើលមិនឃើញនេះទេ។ នោះគឺមកពីមនុស្សពុំយល់ពីការពិតនៃកិច្ចការពីរដំណាក់កាលចុងក្រោយ និងមិនបានមើលឃើញកិច្ចការនេះផ្ទាល់នឹងភ្នែករបស់គេ។ ព្រោះតែកិច្ចការនៅក្នុងដំណាក់កាលនេះ មើលមិនឃើញ ដូចនឹងការដែលមនុស្សស្រមៃ ទោះបីជាគេស្រមៃចេញមកយ៉ាងណាក៏ដោយ ក៏គ្មានការពិតអ្វីមកបញ្ជាក់ការស្រមើស្រមៃនេះបានឡើយហើយគ្មាននរណាម្នាក់កែតម្រូវការស្រមៃនោះបានឡើយ។ មនុស្សបណ្ដោយខ្លួនតាមលក្ខណៈឆេវឆាវរបស់ខ្លួន ដោយមិនខ្វល់ថាលទ្ធផលនឹងទៅជាយ៉ាងណា ហើយបណ្ដោយឲ្យគំនិតគេស្រមើស្រមៃដោយសេរីដោយគ្មានការពិតណាមកបញ្ជាក់ ពីការស្រមើស្រមៃរបស់គេទេ ដូច្នេះហើយការស្រមើស្រមៃរបស់មនុស្សក៏ក្លាយជា «ការពិត» ទោះបីជាមាន ឬគ្មានភ័ស្តុតាងបញ្ជាក់ពីការស្រមើស្រមៃនោះ ក៏ដោយ។ ហេតុនេះ មនុស្សជឿលើការ ស្រមើស្រមៃដែលគេមានចំពោះព្រះជាម្ចាស់ នៅក្នុងគំនិតរបស់គេ ហើយមិនព្យាយាមស្វែងរកព្រះនៃភាពជាក់ស្ដែងទេ។ ប្រសិនបើបុគ្គលម្នាក់មានជំនឿបែបនេះ នោះក្នុងចំណោមមនុស្សមួយរយនាក់ នោះប្រាកដជាមានជំនឿមួយរយប្រភេទមិនខានឡើយ។ មនុស្សស៊ប់ជាមួយនឹងជំនឿបែបនេះ ដោយសារគេមើលមិនឃើញពីការពិតនៃកិច្ចការរបស់ព្រះជាម្ចាស់ ដោយសារគេបានត្រឹមតែឮពីការនេះ ដោយត្រចៀករបស់គេ ហើយមិនបានមើលឃើញនឹងភ្នែករបស់គេ។ មនុស្សបានឮប្រវត្តិ និងរឿងរ៉ាវពីបុរាណ តែគេកម្រឮពីចំណេះដឹងពីការពិតពាក់ព័ន្ធនឹងកិច្ចការរបស់ព្រះជាម្ចាស់។ ដូច្នេះ បានជាមនុស្សដែលទើបជឿព្រះបានមួយឆ្នាំ ចាប់ផ្ដើមជឿលើព្រះជាម្ចាស់ តាមរយៈសញ្ញាណរបស់គេផ្ទាល់។ ការនេះក៏ពិតចំពោះអស់អ្នកដែលបានជឿព្រះជា ម្ចាស់មួយជីវិតហើយដែរ។ មនុស្សណាដែលមិនអាចមើលឃើញការពិត នឹងមិនអាចគេចផុតពីជំនឿដែលបានមកពីសញ្ញាណ ដែលគេមានចំពោះព្រះជាម្ចាស់ឡើយ។ មនុស្សជឿថា គេបានដោះខ្លួនឯងឲ្យរួចពីចំណងនៃសញ្ញាណចាស់របស់ខ្លួន ហើយបានចូលក្នុងតំបន់ត្រួតត្រាថ្មីផង។ តើមនុស្សមិនដឹងទេថា ចំណេះដឹងរបស់មនុស្សដែលមើលមិនឃើញព្រះភក្ត្រ

ពិតរបស់ព្រះជាម្ចាស់ គឺគ្រាន់តែជាសញ្ញាណ ហើយគ្រាន់តែជាពាក្យចចាមអារ៉ាម ប៉ុណ្ណោះ? មនុស្សគិតថា សញ្ញាណរបស់គេត្រឹមត្រូវ ហើយគ្មានកំហុសទេ រួចគេគិតថា សញ្ញាណទាំងនេះមកពីព្រះជាម្ចាស់។ សព្វថ្ងៃនេះ កាលណាមនុស្សមើលឃើញ កិច្ចការរបស់ព្រះជាម្ចាស់ផ្ទាល់នឹងភ្នែកគេ ក៏បោះបង់សញ្ញាណដែលគេបង្គរទុករាប់ សិបឆ្នាំនោះចោល។ ការស្រមើស្រមៃ និងគំនិតអតីតកាល បានក្លាយជារនាំងរាំងស្ទះ កិច្ចការនៅក្នុងដំណាក់កាលនេះ និងពិបាកឲ្យមនុស្សបោះបង់សញ្ញាណបែបនេះ ហើយពិបាកជំទាស់នឹងគំនិតបែបនេះណាស់។ សញ្ញាណចំពោះកិច្ចការមួយជំហានៗ របស់មនុស្សដែលបានដើរតាមព្រះជាម្ចាស់មកទល់សព្វថ្ងៃរឹតតែធ្ងន់ធ្ងរទៅៗ ហើយ មនុស្សទាំងនេះ ក៏បានក្លាយខ្លួនជាសត្រូវក្បាលរឹងចំពោះព្រះដែលយកកំណើតជា មនុស្សបន្តិចម្ដងៗ។ ប្រភពនៃសេចក្ដីសម្អប់នេះ ស្ថិតនៅលើសញ្ញាណ និងការស្រមើ ស្រមៃរបស់មនុស្ស ដែលបានក្លាយជាសត្រូវនៃកិច្ចការរបស់ព្រះសព្វថ្ងៃ ជាកិច្ចការ ដែលខុសគ្នាពីសញ្ញាណរបស់មនុស្ស។ រឿងនេះកើតឡើងយ៉ាងច្បាស់ ពីព្រោះ ការពិត មិនអនុញ្ញាតឲ្យមនុស្សស្រមើស្រមៃតាមតែអំពើចិត្ត ហើយជាងនេះទៅទៀត ក៏មិនអាចឲ្យមនុស្សបដិសេធដោយស្រួលៗដែរ ហើយសញ្ញាណ និងការស្រមើស្រមៃ របស់មនុស្សមិនប្រើវត្តមាននៃការពិត ដ្បិតមនុស្សមិនគិតគូរដល់ភាពត្រឹមត្រូវ និងការ ប្រកាន់ខ្ជាប់នូវការពិត ជាងនេះទៅទៀត គេក៏បោះបង់សញ្ញាណរបស់ខ្លួន ហើយ ប្រើប្រាស់ការស្រមើស្រមៃរបស់គេ ដោយដួងចិត្តស្មោះត្រង់ប៉ុណ្ណោះ។ សេចក្ដីនេះ និយាយបានត្រឹមថាជាកំហុសនៃសញ្ញាណរបស់មនុស្ស និងមិនអាចនិយាយថាជា កំហុសនៃកិច្ចការរបស់ព្រះជាម្ចាស់ឡើយ។ មនុស្សអាចស្រមៃអ្វីក៏បានតាមតែចិត្តគេ ចង់ តែគេមិនអាចចោទសួរកិច្ចការក្នុងដំណាក់កាលណាមួយ ឬចំណែកណាមួយ នៃ កិច្ចការនោះ ដោយសេរីបានទេ។ ការពិតអំពីកិច្ចការរបស់ព្រះជាម្ចាស់ គឺមនុស្សមិន អាចប្រព្រឹត្តល្មើសនឹងកិច្ចការនេះបានឡើយ។ អ្នកអាចនឹងបណ្ដោយខ្លួនឲ្យស្រមើ ស្រមៃដោយសេរី ហើយអ្នកថែមទាំងអាចចងក្រងរឿងរ៉ាវល្អៗ អំពីកិច្ចការរបស់ព្រះ យេហូវ៉ានិងកិច្ចការរបស់ព្រះយេស៊ូវ ប៉ុន្តែអ្នកប្រហែលជាមិនអាច ជំទាស់នឹងការពិត

នៃកិច្ចការក្នុងដំណាក់កាលនីមួយរបស់ព្រះយេហូវ៉ា និងព្រះយេស៊ូវណាស់។ នេះជាគោលការណ៍មួយ និងជាបញ្ញត្តិរដ្ឋបាលមួយដែរ ហើយអ្នកគួរតែយល់ពីសារៈសំខាន់នៃរឿងរ៉ាវទាំងនេះ។ មនុស្សជឿថា កិច្ចការដំណាក់នេះមិនស្របទៅនឹង សញ្ញាណរបស់មនុស្សទេ និងជឿថា នេះពុំមែនជាករណីសម្រាប់កិច្ចការពីរដំណាក់កាលមុនឡើយ។ នៅក្នុងការស្រមើស្រមៃរបស់មនុស្ស គេជឿថា កិច្ចការពីរដំណាក់កាលមុនច្បាស់ជាមិនដូចគ្នានឹងកិច្ចការបច្ចុប្បន្ននេះទេ ប៉ុន្តែ តើអ្នកធ្លាប់បានពិចារណាដែរឬទេថា គោលការណ៍នៃកិច្ចការ របស់ព្រះជាម្ចាស់ គឺសុទ្ធតែដូចគ្នាទាំងអស់ ពិចារណាថា កិច្ចការរបស់ទ្រង់តែងតែ មានប្រយោជន៍ជានិច្ច ហើយពិចារណាថា ទោះបីយុគសម័យណាក៏មានមនុស្សជាច្រើន តែងមកតតាំង ហើយប្រឆាំងនឹងការពិតនៃកិច្ចការរបស់ទ្រង់? មនុស្សទាំងអស់ដែលតតាំង និងប្រឆាំងនឹងកិច្ចការដំណាក់កាល បច្ចុប្បន្ននេះ មុខជាបានប្រឆាំងនឹងព្រះជាម្ចាស់តាំងពីអតីតកាលដោយមិនបាច់សង្ស័យទេ ដ្បិតមនុស្សបែបនេះ នឹងនៅតែជាសត្រូវរបស់ព្រះជាម្ចាស់ជានិច្ច។ មនុស្សដែលស្គាល់ការពិតអំពីកិច្ចការរបស់ព្រះជាម្ចាស់ នឹងមើលឃើញថា កិច្ចការទាំងបីដំណាក់កាល គឺជាកិច្ចការរបស់ព្រះតែមួយ ព្រមទាំងបោះបង់សញ្ញាណរបស់គេចោលទៀតផង។ អ្នកទាំងនេះគឺជាមនុស្សដែលស្គាល់ព្រះជាម្ចាស់ ហើយមនុស្សបែបនេះ គឺជាមនុស្សដែលដើរតាមព្រះជាម្ចាស់យ៉ាងពិតប្រាកដ។ ពេលដែលការគ្រប់គ្រងទាំងមូលរបស់ព្រះជាម្ចាស់ កំពុងខិតទៅរកទីបញ្ចប់ ព្រះជាម្ចាស់នឹងបែងចែករបស់សព្វសារពើទៅតាមជំពូករបស់វា។ មនុស្សត្រូវបានបង្កើតឡើងដោយព្រះហស្តរបស់ព្រះអាទិករ ហើយនៅទីបញ្ចប់ ទ្រង់នឹងឲ្យមនុស្សត្រឡប់ទៅនៅក្រោមអំណាចគ្រប់គ្រងរបស់ទ្រង់វិញ នេះជាទីបញ្ចប់នៃកិច្ចការទាំងបីដំណាក់កាល។ កិច្ចការដំណាក់កាលនៃគ្រាចុងក្រោយ និងកិច្ចការពីរដំណាក់កាលមុន ដែលស្ថិតនៅក្នុងស្រុកអ៊ីស្រាអែល និងស្រុកយូដា គឺសុទ្ធតែជាផែនការនៃការគ្រប់គ្រងរបស់ព្រះជា ម្ចាស់ក្នុងសកលលោកទាំងមូល។ ពុំមាននរណាម្នាក់អាចបដិសេធរឿងនេះឡើយ ហើយវាគឺជាការពិតនៃកិច្ចការរបស់ព្រះជាម្ចាស់។ ថ្វីបើមនុស្សមិនមានបទពិសោធ ឬឃើញកិច្ចការនេះច្រើន

ផ្ទាល់នឹងភ្នែក ក៏ការពិតនៅតែជាការពិត ហើយរឿងនេះគ្មានមនុស្សណាម្នាក់អាចបដិសេធបានទេ។ មនុស្សដែលជឿលើព្រះជាម្ចាស់ នៅគ្រប់បណ្ដាប្រទេសក្នុងសកលលោក នឹងទទួលកិច្ចការទាំងបីដំណាក់កាលទាំងអស់គ្នា។ ប្រសិនបើអ្នកស្គាល់កិច្ចការក្នុងដំណាក់កាលមួយជាក់លាក់ ហើយមិនស្គាល់កិច្ចការក្នុងដំណាក់ កាលពីរទៀត មិន ស្គាល់កិច្ចការរបស់ព្រះជាម្ចាស់ពីអតីតកាល នោះអ្នកមិនអាចថ្លែង ពីសេចក្ដីពិតទាំងស្រុង ទាក់ទងទៅនឹងផែនការគ្រប់គ្រងទាំងមូលរបស់ព្រះជាម្ចាស់បានឡើយ ហើយចំណេះដឹងដែលអ្នកមានអំពី ព្រះជាម្ចាស់ គឺជាចំណេះដឹងដែលលម្អៀងទៅតែម្ខាង ដ្បិតនៅក្នុង ជំនឿដែលអ្នកមានចំពោះព្រះជា ម្ចាស់ អ្នកមិនស្គាល់ ឬយល់ដឹងពីទ្រង់ឡើយ ដូច្នេះ អ្នកមិនសមនឹងធ្វើបន្ទាល់ពីព្រះជាម្ចាស់ឡើយ។ បើទោះបីជាចំណេះដឹងបច្ចុប្បន្នរបស់អ្នកចំពោះកិច្ចការទាំងអស់នេះ មានលក្ខណៈជ្រាលជ្រៅ ឬរាក់កំផែល នោះនៅទីបញ្ចប់ អ្នកក៏ត្រូវតែមានចំណេះដឹង និងត្រូវជឿទុកចិត្តយ៉ាងម៉ត់ចត់ ហើយមនុស្សទាំងអស់នឹងឃើញភាពពេញលេញនៃកិច្ចការរបស់ព្រះជាម្ចាស់ ហើយចុះចូលនៅក្រោមអំណាចគ្រប់គ្រងរបស់ព្រះជា ម្ចាស់ទៀតផង។ នៅទីបញ្ចប់នៃកិច្ចការនេះ សាសនាទាំងអស់នឹងរួបរួមគ្នាមកតែមួយ សត្តនិករទាំងអស់នឹងថ្វាយបង្គំព្រះដ៏ពិតតែមួយអង្គ ហើយសាសនាដ៏អាក្រក់ទាំងអស់នឹងរលាយបាត់ ដោយមិនលេចមកទៀតឡើយ។

ហេតុអ្វីក៏អត្ថបទនេះចេះតែលើកយកកិច្ចការទាំងបីដំណាក់កាលមកនិយាយម្ដងហើយម្ដងទៀតដូច្នេះ? ដំណើរឆ្លងកាត់យុគសម័យនៃការអភិវឌ្ឍសង្គម និងការផ្លាស់ប្ដូរមុខមាត់ធម្មជាតិ សុទ្ធតែធ្វើទៅតាមការប្រែប្រួល ក្នុងកិច្ចការទាំងបីដំណាក់កាល។ មនុស្សជាតិប្រែប្រួលទៅតាមពេលវេលា ជាមួយនឹងកិច្ចការរបស់ព្រះជាម្ចាស់ ហើយមិនវិវដ្ដឯកឯងឡើយ។ កិច្ចការទាំងបីដំណាក់កាលរបស់ព្រះជាម្ចាស់ ត្រូវបានលើកយកមកនិយាយ ដើម្បីនាំយកសត្តនិករទាំងអស់ និងមនុស្សទាំងអស់ ពីគ្រប់សាសនា និងនិកាយ ឲ្យមកនៅក្រោមអំណាចគ្រប់គ្រងរបស់ព្រះជាម្ចាស់តែមួយ។ មិនថា អ្នកជាអ្នកកាន់សាសនាណាក៏ដោយ ចុងក្រោយអ្នកទាំងអស់នឹងចុះចូលនៅក្រោមអំណាច

គ្រប់គ្រងរបស់ព្រះជាម្ចាស់ដែរ។ គឺមានតែព្រះជាម្ចាស់ផ្ទាល់ទេ ដែលអាចអនុវត្ត កិច្ចការនេះបាន កិច្ចការនេះ មិនអាចធ្វើឡើងដោយប្រមុខសាសនាណាមួយនោះ ឡើយ។ មានសាសនាធំៗជាច្រើន នៅក្នុងពិភពលោក ហើយសាសនានីមួយៗ គឺ សុទ្ធតែមានប្រមុខ ឬអ្នកដឹកនាំរបស់ខ្លួន ហើយអ្នកដើរតាមមានពាសពេញ តាមបណ្ដា ប្រទេស និងសាសនាជាច្រើនខុសៗគ្នា នៅទូទាំងពិភព លោក។ ស្ទើរតែគ្រប់ប្រទេស មិនថា ប្រទេសតូច ឬប្រទេសធំ សុទ្ធតែមានសាសនាក្នុងប្រទេសនោះ។ យ៉ាងណាមិញ ទោះបីជាក្នុងពិភពលោកនេះមានសាសនាច្រើនប៉ុនណា ក៏នៅទីបំផុតមនុស្សទាំងអស់ ក្នុងសកលលោកនេះ ក៏នៅតែមានវត្តមានជីវិតក្រោមការដឹកនាំរបស់ព្រះតែមួយ ឯ វត្តមានជីវិតរបស់គេក៏មិនត្រូវបានដឹកនាំដោយប្រមុខ ឬអ្នកដឹកនាំសាសនាដែរ។ នេះ មានន័យថា មនុស្សជាតិពុំមែនត្រូវបានដឹកនាំដោយប្រមុខ ឬអ្នកដឹកនាំសាសនាម្នាក់ ណាឡើយ ផ្ទុយទៅវិញ មនុស្សជាតិទាំងមូលត្រូវបានដឹកនាំដោយព្រះអាទិករ ដែល បានបង្កើតផ្ទៃមេឃ ផែនដី និងរបស់សព្វសារពើវិញ ហើយជាព្រះដែលបានបង្កើត មនុស្សជាតិវិញ នេះជាការពិត។ ទោះជាពិភពលោកនេះមានសាសនាធំៗច្រើនក៏ ពិតមែន តែទោះបីជាសាសនាទាំងនោះធំប៉ុនណា ពួកគេសុទ្ធតែនៅក្រោមអំណាច គ្រប់គ្រងរបស់ព្រះអាទិករ ហើយមិនមានសាសនាណាមួយអាចធំ លើសវិសាលភាព នៃអំណាច គ្រប់គ្រងនេះបានឡើយ។ ការវិវដ្ដរបស់មនុស្សជាតិ ការចូលមកជំនួសនៃ សង្គម ការបង្កើតវិទ្យាសាស្ត្រធម្មជាតិ សុទ្ធតែមិនអាចផ្ដាច់ពីការចាត់ចែងរបស់ព្រះ អាទិករ ហើយកិច្ចការនេះ ពុំមែនជាកិច្ចការដែលអាចធ្វើឡើងដោយប្រមុខសាសនា ណាម្នាក់ដែលបានលើកឡើងនោះឡើយ។ ប្រមុខសាសនាម្នាក់ គឺត្រឹមតែជាអ្នកដឹកនាំ សាសនាជាក់លាក់ណាមួយ ហើយមិនអាចតំណាងព្រះជាម្ចាស់បានឡើយ និងមិន អាចតំណាងព្រះជាម្ចាស់ ដែលបានបង្កើតផ្ទៃមេឃ ផែនដី និងរបស់សព្វសារពើបាន ឡើយ។ ប្រមុខសាសនាម្នាក់ អាចដឹកនាំមនុស្សទាំងអស់ដែលនៅក្នុងសាសនា ទាំងមូល ប៉ុន្តែពួកគេមិនអាចបញ្ជាសត្វនិករទាំងអស់ ដែលនៅក្រោមមេឃនេះបានទេ នេះគឺជាការពិតមួយដែលត្រូវបានទទួលស្គាល់ជាសកល។ ប្រមុខសាសនាម្នាក់ គឺ

ត្រឹមតែជាអ្នកដឹកនាំម្នាក់ និងមិនអាចឈរស្មើព្រះជាម្ចាស់ (ជាព្រះអាទិករ) បានឡើយ។ សព្វសារពើសុទ្ធតែនៅក្នុងព្រះហស្តរបស់ព្រះអាទិករ ហើយនៅទីបញ្ចប់ ពួកគេទាំងអស់នឹងត្រឡប់ទៅក្នុងព្រះហស្តព្រះអាទិករវិញ។ ដើមឡើយ មនុស្សត្រូវបានព្រះជាម្ចាស់បង្កើតឡើង ហើយមនុស្សគ្រប់គ្នានឹងត្រូវត្រលប់ទៅក្រោមអំណាចគ្រប់គ្រងរបស់ព្រះជាម្ចាស់ ទោះបីជាគេកាន់សាសនាអ្វីក៏ដោយ នេះជារឿងពិតដែលចៀសមិនរួច។ មានតែព្រះជាម្ចាស់ទេ ដែលជាព្រះដ៏ខ្ពង់ខ្ពស់បំផុត ក្នុងបណ្ដាសព្វសារពើ ហើយជាអ្នកគ្រប់គ្រងដ៏ខ្ពង់ខ្ពស់បំផុត ក្នុងបណ្ដាសត្តនិករទាំងអស់ ក៏ត្រូវតែត្រឡប់មក នៅក្រោមអំណាចគ្រប់គ្រងរបស់ព្រះអង្គដែរ។ ទោះបីមនុស្សមានឋានៈខ្ពង់ខ្ពស់យ៉ាងណា ម្នាក់នោះក៏មិនអាចនាំមនុស្ស ទៅរកគោលដៅសមស្របណាមួយឡើយ ហើយក៏គ្មាននរណាម្នាក់អាចបែងចែក របស់សព្វសារពើតាមជំពូកដែរ។ ព្រះយេហូវ៉ាផ្ទាល់បានបង្កើតមនុស្សជាតិ និងបានបែងចែកមនុស្សម្នាក់ៗទៅតាមជំពូក ហើយនៅពេលដែលគ្រាចុងក្រោយមកដល់ ព្រះអង្គនឹងនៅតែធ្វើកិច្ចការរបស់ទ្រង់ដោយអង្គឯង ទាំងបែងចែករបស់សព្វសារពើតាមជំពូកផង កិច្ចការនេះពុំអាចធ្វើឡើងដោយមនុស្សណាផ្សេង ក្រៅពីព្រះជាម្ចាស់ឡើយ។ កិច្ចការទាំងបីដំណាក់កាល គឺត្រូវបានអនុវត្តដោយព្រះតែមួយ។ ការពិតអំពីកិច្ចការទាំងបីដំណាក់កាល គឺជាការពិតអំពីភាពជាអ្នកដឹកនាំរបស់ព្រះជាម្ចាស់ ដល់មនុស្សជាតិគ្រប់គ្នា ជាការពិតមួយដែលគ្មាននរណាម្នាក់ អាចបដិសេធបាន។ នៅទីបញ្ចប់នៃកិច្ចការទាំងបីដំណាក់កាល សព្វសារពើនឹងត្រូវបែងចែកតាមជំពូក ហើយត្រឡប់ទៅនៅ ក្រោមអំណាចគ្រប់គ្រងរបស់ព្រះតែមួយវិញ ព្រោះនៅក្នុងសកលលោកទាំងមូលគឺមានតែព្រះមួយអង្គនេះគត់ គ្មានសាសនាផ្សេងទៀតឡើយ។ ព្រះណាដែលគ្មានសមត្ថភាពបង្កើតពិភពលោកនេះ ក៏គ្មានសមត្ថភាពបញ្ចប់លោកនេះដែរ ចំណែកឯព្រះណាដែលបានបង្កើតពិភពលោកនេះ មុខជាអាចនាំពិភពលោកនេះទៅរកទីបញ្ចប់ទៅបានជាប្រាកដ។ ដូច្នេះ ប្រសិនបើមនុស្សណាម្នាក់មិនអាចធ្វើឲ្យយុគសម័យមួយបញ្ចប់ និងបានត្រឹមតែអាចជួយឲ្យមនុស្សបណ្ដុះគំនិតរបស់គេ អ្នកនោះប្រាកដជាមិនមែនជាព្រះទេ ហើយក៏ច្បាស់ជា

មិនមែនជាព្រះអម្ចាស់នៃមនុស្សជាតិដែរ។ គេពុំអាចធ្វើកិច្ចការអស្ចារ្យបែបនេះបានទេ មានតែមនុស្សម្នាក់គត់អាចអនុវត្តកិច្ចការបែបនេះបាន ហើយមនុស្សទាំងអស់ដែលពុំអាចធ្វើកិច្ចការនេះ គឺសុទ្ធតែជាសត្រូវ ហើយមិនមែនជាព្រះជាម្ចាស់ទេ។ សាសនាអាក្រក់ទាំងអស់ គឺសុទ្ធតែមិនចុះសម្រុងនឹងព្រះជាម្ចាស់ ហើយដោយសារពួកគេមិនចុះសម្រុងនឹងព្រះជាម្ចាស់ ពួកគេសុទ្ធតែជាសត្រូវរបស់ព្រះជាម្ចាស់។ កិច្ចការទាំងអស់សុទ្ធតែត្រូវបានធ្វើឡើងដោយព្រះដ៏ពិតមួយអង្គនេះ ហើយសកលលោកទាំងមូល ក៏ត្រូវបានបង្គាប់ដោយព្រះមួយអង្គនេះដែរ។ ទោះបីជានេះជាកិច្ចការរបស់ទ្រង់នៅស្រុកអ៊ីស្រាអែល ឬនៅប្រទេសចិន ទោះបីជាកិច្ចការនេះ ត្រូវបានអនុវត្តឡើងដោយព្រះវិញ្ញាណ ឬដោយសាច់ឈាម ក៏កិច្ចការទាំងអស់ត្រូវបានធ្វើឡើងដោយព្រះជាម្ចាស់ផ្ទាល់ ហើយមិនអាចធ្វើឡើងដោយនរណាផ្សេងឡើយ។ ច្បាស់ណាស់ ដោយទ្រង់គឺជាព្រះជាម្ចាស់មនុស្សជាតិគ្រប់គ្នា ទើបទ្រង់អាចធ្វើកិច្ចការដោយសេរី គ្មានការបង្ខិតបង្ខំដោយលក្ខខណ្ឌណាមួយឡើយ នេះគឺជានិមិត្តដ៏ធំបំផុតក្នុងបណ្ដានិមិត្តទាំងអស់។ ក្នុងនាមជាមនុស្សដែលព្រះបង្កើតមក ប្រសិនបើអ្នកចង់បំពេញភារៈជាមនុស្សដែលព្រះបង្កើត និងយល់ពីព្រះហឫទ័យរបស់ព្រះជាម្ចាស់ អ្នកត្រូវតែយល់អំពីកិច្ចការរបស់ព្រះជាម្ចាស់ អ្នកត្រូវតែយល់ពី ព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់មនុស្សទាំងអស់ អ្នកត្រូវតែយល់អំពីផែនការនៃការគ្រប់គ្រងរបស់ទ្រង់ ហើយអ្នកត្រូវតែយល់អំពីសារៈសំខាន់ទាំងអស់នៃកិច្ចការដែលទ្រង់ធ្វើ។ មនុស្សដែលមិនយល់ពីសេចក្ដីនេះ មិនមែនជាសត្តនិកររបស់ព្រះជាម្ចាស់ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ឡើយ! ក្នុងនាមជាមនុស្សដែលព្រះបង្កើត ប្រសិនបើអ្នកពុំដឹងថា អ្នកមកពីណា មិនយល់អំពីប្រវត្តិសាស្ត្ររបស់មនុស្សជាតិ និងកិច្ចការទាំងអស់ ដែលត្រូវបានធ្វើឡើងដោយព្រះជាម្ចាស់ ហើយលើសពីនេះ មិនយល់ពីរបៀបដែលមនុស្សបានវិវដ្តឡើងមកទល់សព្វថ្ងៃនេះ ហើយមិនដឹងថា នរណាជាអ្នកបង្គាប់បញ្ជាមនុស្សជាតិទាំងអស់នោះអ្នកពុំអាចបំពេញភារកិច្ចរបស់ខ្លួនបានឡើយ។ ព្រះជាម្ចាស់បានដឹកនាំមនុស្សជាតិរហូតដល់សព្វថ្ងៃ ហើយតាំងតែពីគ្រាដែលទ្រង់បានបង្កើតមនុស្សនៅលើផែនដី

នេះ ទ្រង់មិនដែលចាកចោលគេឡើយ។ ព្រះវិញ្ញាណបរិសុទ្ធមិនដែលឈប់ធ្វើការទាល់តែសោះ ក៏មិនដែលឈប់ដឹកនាំមនុស្សជាតិ ហើយក៏មិនដែលចាកចេញពីមនុស្សជាតិដែរ។ ប៉ុន្តែ មនុស្សជាតិមិនដឹងថាមានព្រះទេ ក៏រឹតតែមិនស្គាល់ព្រះជាម្ចាស់ផង។ ចំពោះមនុស្សទាំងអស់ដែលព្រះបានបង្កើត តើមានអ្វីដែលគួរឲ្យអាម៉ាស់ជាងនេះទេ? ព្រះជាម្ចាស់ដឹក នាំមនុស្សដោយអង្គឯង ប៉ុន្តែមនុស្សមិនដឹងអំពីកិច្ចការរបស់ព្រះជាម្ចាស់ទេ។ អ្នកគឺជាមនុស្សម្នាក់ដែលព្រះបានបង្កើត ប៉ុន្តែអ្នកពុំដឹងពីប្រវត្តិខ្លួនឯង ហើយក៏មិនដឹងថា អ្នកណាដឹកនាំអ្នកនៅលើដំណើរជីវិតនេះរហូតមកដែរ អ្នកមិនស្គាល់កិច្ចការដែលធ្វើឡើង ដោយព្រះជាម្ចាស់ ដូច្នេះ អ្នកមិនអាចស្គាល់ព្រះជាម្ចាស់ឡើយ។ ប្រសិនបើពេលនេះ អ្នកនៅតែមិនដឹង នោះអ្នកពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ធ្វើបន្ទាល់ពីព្រះជាម្ចាស់ដែរ។ សព្វថ្ងៃនេះ ព្រះអាទិករដឹកនាំមនុស្សទាំងអស់ដោយអង្គឯងម្ដងទៀត រួចធ្វើឲ្យមនុស្សទាំងអស់មើលឃើញប្រាជ្ញាញាណ ឫទ្ធានុភាពដ៏លើសលុប សេចក្ដីសង្គ្រោះ និងភាពមហស្ចារ្យរបស់ព្រះអង្គ។ ប៉ុន្តែអ្នកក៏នៅតែមិនដឹង ឬមិនយល់ដដែល ដូច្នេះ តើអ្នកមិនមែនជាមនុស្សដែលមិនទទួលនូវសេចក្ដីសង្គ្រោះទេឬអី? មនុស្សដែលជាកម្មសិទ្ធរបស់សាតាំង មិនយល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ទេ ឯមនុស្សដែលជាកម្មសិទ្ធិរបស់ព្រះ ជាម្ចាស់ អាចស្ដាប់ឮព្រះសូរសៀងរបស់ទ្រង់បាន។ មនុស្សគ្រប់ៗគ្នាដែលដឹង និងយល់ពាក្យពេចន៍ដែលខ្ញុំមានបន្ទូល ជាមនុស្សដែលនឹងត្រូវបានសង្គ្រោះ និងធ្វើបន្ទាល់ពីព្រះជាម្ចាស់ផង មនុស្សទាំងអស់ដែលមិនយល់បន្ទូលដែលខ្ញុំថ្លែងចេញមក មិនអាចធ្វើបន្ទាល់ពីព្រះជាម្ចាស់ ហើយជាមនុស្សដែលនឹងត្រូវផាត់ចោល។ មនុស្សណាដែលមិនយល់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងមិនស្គាល់កិច្ចការរបស់ព្រះជាម្ចាស់ មិនអាចសម្រេចបានចំណេះដឹងអំពីព្រះជាម្ចាស់ឡើយ ហើយមនុស្សបែបនេះក៏មិនអាចធ្វើបន្ទាល់ពីព្រះជាម្ចាស់ដែរ។ ប្រសិនបើអ្នកចង់ធ្វើបន្ទាល់ពីព្រះជាម្ចាស់នោះ អ្នកត្រូវតែស្គាល់ព្រះជាម្ចាស់។ ចំណេះដឹងអំពីព្រះជាម្ចាស់ គឺត្រូវសម្រេចបានតាមរយៈកិច្ចការរបស់ព្រះជាម្ចាស់។ សរុបសេចក្ដីមក ប្រសិនបើអ្នកចង់ស្គាល់ព្រះជាម្ចាស់ នោះអ្នកត្រូវតែស្គាល់កិច្ចការរបស់

ព្រះជាម្ចាស់៖ ការស្គាល់កិច្ចការរបស់ព្រះជាម្ចាស់ គឺជាកត្តាដ៏មានសារៈសំខាន់បំផុត។ កាលណាកិច្ចការទាំងបីដំណាក់កាលឈានមកដល់ទីបញ្ចប់ មនុស្សមួយក្រុមដែលនឹងធ្វើបន្ទាល់ពីព្រះជាម្ចាស់ ជាមនុស្សមួយក្រុមដែលស្គាល់ព្រះជាម្ចាស់ នឹងត្រូវបានបង្កើតឡើងមក។ មនុស្សទាំងអស់នេះនឹងស្គាល់ព្រះជាម្ចាស់ និងអាចយកសេចក្ដីពិតមកអនុវត្ត។ ពួកគេមានភាពជាមនុស្ស និងមានសតិ ហើយគេនឹងស្គាល់អស់ទាំងកិច្ចការទាំងបីដំណាក់កាលនៃសេចក្ដីសង្គ្រោះទៀតផង។ នេះគឺជាកិច្ចការដែលនឹងត្រូវសម្រេចនៅគ្រាចុងក្រោយ ហើយមនុស្សទាំងអស់នេះជាការសម្ដែងឲ្យឃើញច្បាស់ពីកិច្ចការនៃការគ្រប់គ្រងរយៈពេល៦០០០ឆ្នាំ និងជាស្មរបន្ទាល់ដ៏មានអានុភាពបំផុតដើម្បីបរាមុខសាតាំងដល់ទីបំផុត។ មនុស្សដែលធ្វើបន្ទាល់ពីព្រះជាម្ចាស់នឹងអាចទទួលបានសេចក្ដីសន្យា និងព្រះពររបស់ព្រះជាម្ចាស់ ហើយនឹងក្លាយជាក្រុមមនុស្ស ដែលស្ថិតនៅដល់ទីបញ្ចប់ ជាក្រុមមនុស្សដែលមានសិទ្ធិអំណាចរបស់ព្រះជាម្ចាស់ ហើយធ្វើបន្ទាល់ពីព្រះជាម្ចាស់ផង។ ប្រហែលជាមានម្នាក់ ឬមួយចំនួនតូច ឬពាក់ កណ្ដាលក្នុងចំណោមអ្នករាល់គ្នា អាចក្លាយជាសមាជិកក្នុងក្រុមនេះ គឺវាអាស្រ័យនៅលើឆន្ទៈរបស់អ្នករាល់គ្នា និងអាស្រ័យនៅលើការព្យាយាមឲ្យបានរបស់អ្នករាល់គ្នាដែរ។

## មនុស្សជាតិដ៏ពុករលួយកាន់តែត្រូវការសេចក្ដីសង្គ្រោះរបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស

ព្រះជាម្ចាស់បានត្រលប់ជាសាច់ឈាម ដោយសារតែកម្មវត្ថុនៃកិច្ចការរបស់ទ្រង់ មិនមែនជាវិញ្ញាណរបស់សាតាំង ឬអ្វីមួយអរូបិយឡើយ ប៉ុន្តែជាមនុស្សដែលចេញមកពីសាច់ឈាម ហើយត្រូវបានសាតាំងធ្វើឲ្យពុករលួយ។ ដោយសារតែសាច់ឈាមរបស់មនុស្សត្រូវបានពុករលួយនោះហើយ ទើបព្រះជាម្ចាស់បានដាក់មនុស្សខាងសាច់ឈាមជាកម្មវត្ថុនៃកិច្ចការរបស់ទ្រង់ ហើយលើសពីនេះ ដោយសារតែមនុស្សជាកម្មវត្ថុនៃសេចក្ដីពុករលួយ ព្រះជាម្ចាស់បានជ្រើសរើសយកមនុស្ស ដើម្បីក្លាយជា

កម្មវត្ថុតែមួយគត់នៃកិច្ចការរបស់ទ្រង់នៅក្នុងដំណាក់កាលទាំងអស់នៃកិច្ចការសង្គ្រោះរបស់ទ្រង់។ មនុស្សជាភាវៈដែលរមែងស្លាប់ ជាភាវៈដែលមានសាច់និងឈាម ហើយព្រះជាម្ចាស់ ជាព្រះតែមួយគត់ដែលអាចសង្គ្រោះមនុស្សបាន។ តាមរបៀបនេះ ព្រះជាម្ចាស់ ត្រូវតែត្រលប់ជាសាច់ឈាម ដែលមានលក្ខណៈដូចគ្នានឹងមនុស្សដើម្បីធ្វើកិច្ចការរបស់ទ្រង់ ដើម្បីឲ្យកិច្ចការរបស់ទ្រង់អាចទទួលបានលទ្ធផលដ៏ប្រសើរ។ ព្រះជាម្ចាស់ត្រូវតែត្រលប់ជាសាច់ឈាម ដើម្បីធ្វើកិច្ចការរបស់ទ្រង់ឲ្យបានត្រឹមត្រូវ ដោយសារតែមនុស្សនៅខាងសាច់ឈាម ហើយគេគ្មានសមត្ថភាពយកឈ្នះលើបាប ឬដកខ្លួនចេញពីសាច់ឈាមនោះឡើយ។ ទោះបីសារជាតិ និងអត្តសញ្ញាណរបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សខុសគ្នាស្រឡះពីសារជាតិនិងអត្តសញ្ញាណរបស់មនុស្សក៏ដោយ ក៏រូបរាងរបស់ទ្រង់មានលក្ខណៈដូចគ្នាទៅនឹងរូបរាងរបស់មនុស្សដែរ។ ទ្រង់មានរូបរាងជាមនុស្សសាមញ្ញ និងរស់នៅជីវិតជាមនុស្សសាមញ្ញ ហើយអស់អ្នកដែលឃើញទ្រង់ មិនអាចដឹងពីភាពខុសគ្នារវាងទ្រង់និងមនុស្សសាមញ្ញម្នាក់នោះឡើយ។ រូបរាងដ៏សាមញ្ញ និងភាពជាមនុស្សសាមញ្ញនេះគឺគ្រប់គ្រាន់សម្រាប់ទ្រង់ដើម្បីធ្វើកិច្ចការជាព្រះរបស់ទ្រង់នៅក្នុងភាពជាមនុស្សសាមញ្ញ។ សាច់ឈាមរបស់ទ្រង់អនុញ្ញាតឲ្យទ្រង់ធ្វើកិច្ចការរបស់ទ្រង់នៅក្នុងភាពជាមនុស្សសាមញ្ញ និងជួយឲ្យទ្រង់ធ្វើកិច្ចការរបស់ទ្រង់នៅក្នុងចំណោមមនុស្ស ហើយលើសពីនេះ ភាពជាមនុស្សសាមញ្ញរបស់ទ្រង់ ក៏ជួយឲ្យទ្រង់អនុវត្តកិច្ចការនៃសេចក្ដីសង្គ្រោះនៅក្នុងចំណោមមនុស្សដែរ។ ទោះបីភាពជាមនុស្សសាមញ្ញរបស់ទ្រង់ បានបង្កឲ្យមានភាពជ្រួលច្របល់ជាច្រើននៅក្នុងចំណោមមនុស្សក៏ដោយ ក៏ភាពជ្រួលច្របល់ទាំងនេះ មិនបានជះឥទ្ធិពលទៅលើលទ្ធផលនៃកិច្ចការរបស់ទ្រង់ឡើយ។ សរុបមក កិច្ចការនៃសាច់ឈាមសាមញ្ញរបស់ទ្រង់ ពិតជាមានអត្ថប្រយោជន៍យ៉ាងខ្លាំងចំពោះមនុស្ស។ ទោះបីមនុស្សភាគច្រើនមិនទទួលយកភាពជាមនុស្សសាមញ្ញរបស់ទ្រង់ក៏ដោយ ក៏កិច្ចការរបស់ទ្រង់នៅតែអាចទទួលបានលទ្ធផល ហើយលទ្ធផលទាំងនេះអាចសម្រេចបានដោយសារតែភាពជាមនុស្សសាមញ្ញរបស់ទ្រង់។ ដូច្នេះ វាគ្មានអ្វីដែលត្រូវសង្ស័យឡើយអំពីរឿងនេះ។

តាមរយៈកិច្ចការរបស់ទ្រង់នៅក្នុងសាច់ឈាម មនុស្សទទួលបានលទ្ធផលដប់ ឬដប់ពីរដងច្រើនជាងសញ្ញាណដែលមាននៅក្នុងមនុស្សអំពីភាពជាមនុស្សសាមញ្ញរបស់ទ្រង់ទៅទៀត ហើយនៅទីបំផុតសញ្ញាណទាំងនេះ នឹងត្រូវរលាយបាត់ដោយសារតែកិច្ចការរបស់ទ្រង់មិនខាន។ ហើយលទ្ធផលដែលកើតចេញពីកិច្ចការរបស់ទ្រង់ គឺអាចនិយាយបានថា ចំណេះដឹងដែលមនុស្សមានចំពោះទ្រង់ មានកម្រិតខុសគ្នាឆ្ងាយពីសញ្ញាណរបស់មនុស្សអំពីទ្រង់។ មនុស្សមិនអាចស្រមៃ ឬវាស់វែងកិច្ចការដែលទ្រង់ធ្វើនៅក្នុងសាច់ឈាមបានឡើយ ព្រោះកិច្ចការរបស់ទ្រង់ ខុសប្លែកពីកិច្ចការរបស់មនុស្ស។ ទោះបីជាសំបកក្រៅដូចគ្នាមែន ក៏សារជាតិមិនដូចគ្នាឡើយ។ សាច់ឈាមរបស់ទ្រង់បង្កើតនូវសញ្ញាណជាច្រើន នៅក្នុងចំណោមមនុស្សអំពីព្រះជាម្ចាស់ ប៉ុន្តែសាច់ឈាមរបស់ទ្រង់ក៏អាចអនុញ្ញាតឲ្យមនុស្សទទួលបាននូវចំណេះដឹងជាច្រើន ហើយថែមទាំងអាចយកឈ្នះមនុស្សណាដែលមានសំបកក្រៅស្រដៀងគ្នាទៀតផង។ ទ្រង់មិនគ្រាន់តែជាមនុស្សប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ក៏ជាព្រះជាម្ចាស់ដែលមានសំបកក្រៅជាមនុស្សដែរ ហើយគ្មាននរណាម្នាក់អាចវាស់ស្ទង់ ឬយល់អំពីទ្រង់បានទាំងស្រុងឡើយ។ មនុស្សទាំងអស់ស្រឡាញ់ និងស្វាគមន៍ព្រះជាម្ចាស់ដែលអរូបិយ និងគ្មានរូបរាង។ ប្រសិនបើព្រះជាម្ចាស់គ្រាន់តែជាព្រះវិញ្ញាណមួយដែលមនុស្សមើលមិនឃើញ នោះមនុស្សនឹងងាយជឿលើព្រះជាម្ចាស់ជាង។ មនុស្សអាចស្រមើស្រមៃគ្រប់បែបយ៉ាង អាចជ្រើសរើសរូបអង្គណាក៏បានដែលពួកគេចូលចិត្ត ទុកដូចជារូបអង្គរបស់ព្រះជាម្ចាស់ដើម្បីផ្គាប់ចិត្តខ្លួន និងធ្វើឲ្យខ្លួនពួកគេមានអារម្មណ៍សប្បាយចិត្ត។ តាមរបៀបនេះ មនុស្សអាចធ្វើអ្វីៗគ្រប់យ៉ាងដែលព្រះរបស់គេភាគច្រើនចូលចិត្ត និងចង់ឲ្យពួកគេធ្វើដោយគ្មានការអល់អែកនោះឡើយ។ លើសពីនេះទៀត មនុស្សជឿថា គ្មាននរណាម្នាក់មានស្វាមីភក្តិ និងស្មោះស្ម័គ្រចំពោះព្រះជាម្ចាស់ជាងពួកគេនោះឡើយ ហើយអ្នកផ្សេងទៀតគ្រាន់តែជាសុនខនៃសាសន៍ដទៃ ដែលគ្មានស្វាមីភក្តិចំពោះព្រះជាម្ចាស់ប៉ុណ្ណោះ។ គឺអាចនិយាយបានថា នេះគឺជាអ្វីដែលត្រូវបានស្វែងរកដោយអស់អ្នកដែលមានជំនឿលើព្រះជាម្ចាស់នៅក្នុងភាពស្រពេចស្រពិល និងឈរលើគោលលទ្ធិ ប៉ុន្តែអ្វីដែលពួកគេ

ស្វែងរកនោះ ភាគច្រើនមានលក្ខណៈដូចគ្នា គឺមានភាពខុសគ្នាតិចតួចណាស់។ អ្វីដែលខុសគ្នា គឺជារូបអង្គនៃព្រះជាម្ចាស់នៅក្នុងការស្រមើស្រមៃរបស់គេ ប៉ុន្តែសារជាតិរបស់គេវិញ គឺដូចគ្នាតែម្ដង។

មនុស្សស្ងប់ចិត្តដោយជំនឿដ៏ឥតខ្វល់របស់គេទៅលើព្រះជាម្ចាស់ និងជឿលើព្រះជាម្ចាស់តាមការចូលចិត្ត។ នេះជា «សិទ្ធិ និងសេរីភាពរបស់មនុស្ស» ដែលគ្មាននរណាម្នាក់អាចជ្រៀតជ្រែងបានឡើយ ព្រោះមនុស្សជឿលើព្រះរបស់គេ មិនមែនជាព្រះជាម្ចាស់របស់នរណាម្នាក់ឡើយ។ នេះជាទ្រព្យសម្បត្តិឯកជនរបស់គេ ហើយសឹងតែមនុស្សគ្រប់គ្នា មានទ្រព្យសម្បត្តិឯកជនប្រភេទនេះ។ មនុស្សចាត់ទុកទ្រព្យសម្បត្តិនេះ ជាកំណប់ដ៏មានតម្លៃមួយ ប៉ុន្តែចំពោះព្រះជាម្ចាស់វិញ គេចាត់ទុកទ្រង់ដូចជាទន់ទាប ឬគ្មានតម្លៃសោះ ដូច្នេះ វាគ្មានសញ្ញានៃការប្រឆាំងណាចំពោះព្រះជាម្ចាស់ដែលច្បាស់ជាងទ្រព្យសម្បត្តិឯកជនរបស់មនុស្សនេះឡើយ។ នេះគឺដោយសារតែកិច្ចការរបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សនេះហើយ ទើបព្រះជាម្ចាស់ត្រលប់ជាសាច់ឈាមក្នុងទម្រង់រូបិយ ដើម្បីឲ្យមនុស្សអាចមើលឃើញ និងប៉ះពាល់បាន។ ទ្រង់មិនមែនជាព្រះវិញ្ញាណដែលគ្មានរូបរាងនោះឡើយ ប៉ុន្តែជាសាច់ឈាមមួយដែលអាចមើលឃើញ និងមានទំនាក់ទំនងជាមួយបាន។ យ៉ាងណាមិញ ព្រះភាគច្រើនដែលមនុស្សជឿ គឺជាព្រះនានាដែលគ្មានសាច់ឈាម គ្មានរូបរាង ហើយក៏ជាទម្រង់មួយដែលគាប់ចិត្តគេដែរ។ តាមរបៀបនេះ ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សបានក្លាយជាសត្រូវ របស់មនុស្សភាគច្រើនដែលជឿលើព្រះជាម្ចាស់ ហើយអស់អ្នកដែលមិនអាចទទួលយកការពិត នៃការយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់ ក៏ក្លាយជាខ្មាំងសត្រូវរបស់ព្រះជាម្ចាស់ដែរ។ មនុស្សមានសញ្ញាណផ្សេងៗ មិនមែនដោយសារតែរបៀបគិតរបស់គេ ឬដោយសារតែការបះបោររបស់គេនោះឡើយ ប៉ុន្តែគឺដោយសារតែទ្រព្យសម្បត្តិឯកជនរបស់មនុស្សនេះវិញ។ ដោយសារតែទ្រព្យសម្បត្តិនេះហើយដែលនាំឲ្យមនុស្សភាគច្រើនស្លាប់ និងដោយសារតែព្រះដ៏ស្រពេចស្រពិលដែលប៉ះពាល់មិនកើត មើលមិនឃើញ និងគ្មានរូបជាក់ច្បាស់នេះ

ហើយដែលបំផ្លាញដល់ជីវិតរបស់មនុស្ស។ ជីវិតរបស់មនុស្សត្រូវបានបាត់បង់ មិនមែនដោយសារតែព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សនោះឡើយ ហើយក៏មិនមែនដោយសារព្រះជាម្ចាស់នៃស្ថានសួគ៌នោះដែរ ប៉ុន្តែដោយសារតែព្រះនៃការស្រមើស្រមៃរបស់មនុស្សវិញ។ ហេតុផលតែមួយគត់ដែលនាំឲ្យព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សត្រលប់ជាសាច់ឈាម គឺដោយសារតែតម្រូវការរបស់មនុស្សដ៏ពុករលួយ។ វាដោយសារតែតម្រូវការរបស់មនុស្ស មិនមែនតម្រូវការរបស់ព្រះជាម្ចាស់ទេ ហើយគ្រប់ទាំងការលះបង់ និងទុក្ខវេទនារបស់ទ្រង់ត្រូវបានធ្វើឡើងសម្រាប់ជាប្រយោជន៍របស់មនុស្សជាតិ មិនមែនសម្រាប់ជាប្រយោជន៍របស់ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គឡើយ។ សម្រាប់ព្រះជាម្ចាស់ វាគ្មានគុណសម្បត្តិ គុណវិបត្តិ ឬរង្វាន់តបស្នងអ្វីនោះទេ ហើយទ្រង់នឹងមិនច្រូតផលសម្រាប់ថ្ងៃអនាគតនោះឡើយ ប៉ុន្តែនោះជាអ្វីដែលមនុស្សត្រូវជំពាក់ដល់ទ្រង់។ គ្រប់យ៉ាងដែលទ្រង់ធ្វើ និងលះបង់សម្រាប់មនុស្សជាតិ គឺមិនមែនដើម្បីឲ្យទ្រង់ទទួលបានរង្វាន់ដ៏ធំឡើយ ប៉ុន្តែសម្រាប់ជាប្រយោជន៍របស់មនុស្សជាតិសុទ្ធសាធតែម្ដង។ ទោះបីកិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងសាច់ឈាម មាននូវទុក្ខលំបាកដែលនឹកស្មានមិនដល់ជាច្រើនក៏ដោយ ប៉ុន្តែលទ្ធផលដែលកិច្ចការនោះសម្រេចបាននៅទីបំផុត គឺខ្ពស់ជាងកិច្ចការដែលត្រូវបានធ្វើដោយផ្ទាល់ ដោយព្រះវិញ្ញាណឆ្ងាយណាស់។ កិច្ចការនៃសាច់ឈាមតម្រូវឲ្យមានទុក្ខលំបាកជាច្រើន ហើយសាច់ឈាមមិនអាចមានអត្តសញ្ញាណដ៏ធំអស្ចារ្យ ដូចជាព្រះវិញ្ញាណឡើយ។ ទ្រង់មិនអាចអនុវត្តកិច្ចការអធិធម្មជាតិ ដូចជាព្រះវិញ្ញាណ ហើយក៏រឹតតែមិនអាចមានសិទ្ធិអំណាចដូចជាព្រះវិញ្ញាណនោះដែរ។ ប៉ុន្តែ សារជាតិនៃកិច្ចការដែលត្រូវបានធ្វើដោយសាច់ឈាមដ៏សាមញ្ញនេះមានភាពសំខាន់ខ្ពស់ជាងកិច្ចការដែលព្រះវិញ្ញាណធ្វើដោយផ្ទាល់ ហើយសាច់ឈាមនេះ គឺជាចម្លើយចំពោះតម្រូវការរបស់មនុស្សជាតិគ្រប់រូប។ សម្រាប់អស់អ្នកដែលត្រូវបានសង្គ្រោះ តម្លៃនៃការប្រើប្រាស់របស់ព្រះវិញ្ញាណ មានកម្រិតទាបជាងតម្លៃនៃការប្រើប្រាស់សាច់ឈាម៖ កិច្ចការរបស់ព្រះវិញ្ញាណ អាចគ្របបាំងចក្រវាលទាំងមូល ភ្នំ ទន្លេ បឹងបួ និងមហាសមុទ្របាន ប៉ុន្តែកិច្ចការនៃសាច់ឈាម

មានទំនាក់ទំនងជាមួយមនុស្សគ្រប់រូបដែលទ្រង់មានទំនាក់ទំនងជាមួយ ប្រកបដោយប្រសិទ្ធភាពជាង។ លើសពីនេះ សាច់ឈាមរបស់ព្រះជាម្ចាស់ជាមួយទម្រង់រូបិយ អាចធ្វើឲ្យមនុស្សកាន់តែយល់ និងកាន់តែទុកចិត្ត ហើយអាចធ្វើឲ្យចំណេះដឹងរបស់មនុស្សអំពីព្រះជាម្ចាស់កាន់តែស៊ីជម្រៅ និងអាចនាំឲ្យមនុស្សមានអារម្មណ៍ដក់ជាប់កាន់តែជ្រាលជ្រៅ អំពីទង្វើដ៏ពិតរបស់ព្រះជាម្ចាស់។ កិច្ចការរបស់ព្រះវិញ្ញាណ ត្រូវបានលាក់កំបាំងនៅក្នុងភាពអាថ៌កំបាំង។ វាពិបាកសម្រាប់មនុស្សដែលរមែងនឹងស្លាប់នេះក្នុងការវាស់ស្ទង់ ហើយពួកគេក៏កាន់តែពិបាកនឹងមើលឃើញដែរ ដូច្នេះ ពួកគេអាចពឹងអាងលើការស្រមើស្រមៃដែលប្រហោងក្នុងរបស់គេតែមួយប៉ុណ្ណោះ។ យ៉ាងណាមិញ កិច្ចការនៃសាច់ឈាម ជាកិច្ចការសាមញ្ញ និងមានមូលដ្ឋានលើតថភាពជាក់ស្ដែង ព្រមទាំងពេញដោយព្រះប្រាជ្ញាញាណ ហើយតាមពិតទៅ កិច្ចការនេះអាចត្រូវបានមើលឃើញដោយភ្នែករបស់មនុស្ស ដូច្នេះ មនុស្សអាចដកពិសោធន៍ដោយផ្ទាល់នូវព្រះប្រាជ្ញាញាណនៃកិច្ចការរបស់ព្រះជាម្ចាស់ ហើយគេមិនចាំបាច់ប្រើការស្រមើស្រមៃដ៏ច្រើនរបស់គេឡើយ។ នេះជាសុក្រឹត្យភាព និងតម្លៃពិតនៃកិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងសាច់ឈាម។ ព្រះវិញ្ញាណអាចធ្វើកិច្ចការដែលមនុស្សមើលមិនឃើញ និងពិបាកស្រមើស្រមៃប៉ុណ្ណោះ ឧទាហរណ៍ ដូចជាការបំភ្លឺរបស់ព្រះវិញ្ញាណ ការធ្វើចលនារបស់ព្រះវិញ្ញាណ និងការដឹកនាំរបស់ព្រះវិញ្ញាណ ប៉ុន្ដែ សម្រាប់មនុស្សដែលមានគំនិត កិច្ចការទាំងនេះមិនផ្ដល់នូវអត្ថន័យដ៏ច្បាស់លាស់ឡើយ។ កិច្ចការទាំងនេះគ្រាន់តែផ្ដល់នូវការរំជួលចិត្ត ឬអត្ថន័យទូលំទូលាយប៉ុណ្ណោះ ប៉ុន្ដែវាមិនអាចផ្ដល់ជាពាក្យណែនាំឡើយ។ យ៉ាងណាមិញ កិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងសាច់ឈាម មានលក្ខណៈខុសគ្នាច្រើនណាស់៖ កិច្ចការនេះពាក់ព័ន្ធនឹងការចង្អុលបង្ហាញយ៉ាងសុក្រឹត្យអំពីព្រះបន្ទូល ហើយវាមានឆន្ទៈ និងគោលដៅច្បាស់លាស់។ ដូច្នេះ មនុស្សមិនចាំបាច់ប្រើអារម្មណ៍ ឬការស្រមើស្រមៃរបស់ខ្លួនឡើយ ហើយក៏មិនចាំបាច់ប្រើការស្មានព្រាវៗនោះដែរ។ នេះជាភាពច្បាស់លាស់នៃកិច្ចការនៅក្នុងសាច់ឈាម និងជាភាពខុសគ្នាដ៏ធំពីកិច្ចការរបស់ព្រះវិញ្ញាណ។ កិច្ចការរបស់ព្រះវិញ្ញាណសក្ដិសមសម្រាប់វិសាលភាព

ដែលមានដែនកំណត់ប៉ុណ្ណោះ ហើយកិច្ចការនេះ មិនអាចប្រើជំនួសកិច្ចការរបស់សាច់ឈាមនោះឡើយ។ កិច្ចការរបស់សាច់ឈាមផ្ដល់ឲ្យមនុស្សនូវគោលដៅចំៗ និងចាំបាច់ ព្រមទាំងចំណេះដឹងដ៏ពិត និងមានតម្លៃជាងកិច្ចការរបស់ព្រះវិញ្ញាណ។ កិច្ចការដែលមានតម្លៃដ៏ធំធេងបំផុត ចំពោះមនុស្សដ៏ពុករលួយនេះ គឺជាកិច្ចការដែលផ្ដល់នូវព្រះបន្ទូលដ៏សុក្រឹត្យ ផ្ដល់នូវគោលដៅច្បាស់ៗដើម្បីស្វែងរក ហើយអាចមើលឃើញ និងប៉ះពាល់បាន។ មានតែកិច្ចការប្រាកដនិយម និងការចង្អុលបង្ហាញទាន់ពេលប៉ុណ្ណោះ ដែលសក្ដិសមនឹងរសជាតិរបស់មនុស្ស ហើយមានតែកិច្ចការពិតៗប៉ុណ្ណោះ ដែលអាចសង្គ្រោះមនុស្សពីនិស្ស័យដ៏ពុករលួយ និងដ៏អាក្រក់របស់គេបាន។ ការនេះអាចសម្រេចបានតាមរយៈព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សតែប៉ុណ្ណោះ គឺមានតែព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សប៉ុណ្ណោះ ដែលអាចសង្គ្រោះមនុស្សពីនិស្ស័យចាស់ដ៏ពុករលួយនិងអាក្រក់របស់គេ។ ទោះបីព្រះវិញ្ញាណជាសារជាតិរបស់ព្រះជាម្ចាស់ដែលជាប់មានមកជាមួយក៏ដោយ ក៏កិច្ចការបែបនេះ អាចសម្រេចបានតាមរយៈតែសាច់ឈាមរបស់ទ្រង់ប៉ុណ្ណោះ។ បើព្រះវិញ្ញាណបានធ្វើការតែអង្គទ្រង់ នោះកិច្ចការរបស់ទ្រង់នឹងមិនអាចទទួលបានលទ្ធផលឡើយ។ នេះជាសេចក្ដីពិតដ៏ច្បាស់លាស់មួយ។ ទោះបីមនុស្សភាគច្រើនបានក្លាយជាសត្រូវរបស់ព្រះជាម្ចាស់ដោយសារតែសាច់ឈាមនេះក៏ដោយ នៅពេលដែលទ្រង់បញ្ចប់កិច្ចការរបស់ទ្រង់ អស់អ្នកដែលប្រឆាំងនឹងទ្រង់នឹងមិនគ្រាន់តែឈប់ក្លាយជាខ្មាំងសត្រូវរបស់ទ្រង់ប៉ុណ្ណោះទេ ប៉ុន្ដែផ្ទុយទៅវិញ គេនឹងក្លាយជាបន្ទាល់របស់ទ្រង់ថែមទៀតផង។ ពួកគេនឹងក្លាយជាស្មរបន្ទាល់ដែលទ្រង់បានយកឈ្នះ ជាស្មរបន្ទាល់ដែលចុះសម្រុងជាមួយទ្រង់ និងមិនអាចដាច់ចេញពីទ្រង់បានឡើយ។ ព្រះអង្គនឹងធ្វើឲ្យមនុស្សដឹងអំពីសារៈសំខាន់នៃកិច្ចការរបស់ទ្រង់នៅក្នុងសាច់ឈាមចំពោះមនុស្ស ហើយមនុស្សនឹងដឹងអំពីសារៈសំខាន់នៃសាច់ឈាមនេះចំពោះអត្ថន័យនៃអត្ថិភាពរបស់គេ គេនឹងដឹងអំពីតម្លៃដ៏ពិតចំពោះការចម្រើនឡើងនៃជីវិតរបស់មនុស្ស ហើយលើសពីនេះ គេនឹងដឹងថាសាច់ឈាមនេះនឹងក្លាយទៅជាប្រភពទឹកដ៏រស់នៃជីវិត ដែលមនុស្សមិនអាចដាច់ចេញ

ឆ្ងាយបានឡើយ។ ទោះបីសាច់ឈាមដែលយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់ មិនអាចប្រៀបផ្ទឹមទៅនឹងអត្តសញ្ញាណ និងមុខតំណែងរបស់ព្រះជាម្ចាស់ ហើយចំពោះមនុស្ស វាហាក់ដូចជាមិនស្របជាមួយឋានៈដ៏ពិតរបស់ទ្រង់ក៏ដោយ ក៏សាច់ឈាមដែលមិនមានរូបអង្គដ៏ពិតរបស់ព្រះជាម្ចាស់ ឬអត្តសញ្ញាណដ៏ពិតរបស់ព្រះជាម្ចាស់នេះ អាចធ្វើកិច្ចការដែលព្រះវិញ្ញាណរបស់ព្រះជាម្ចាស់មិនអាចធ្វើបានដោយផ្ទាល់ដែរ។ នេះគឺជាភាពសំខាន់ និងតម្លៃដ៏ពិតនៃការយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់ ហើយមនុស្សមិនអាចយល់ និងទទួលស្គាល់ពីភាពសំខាន់ និងតម្លៃនេះឡើយ។ ទោះបីមនុស្សជាតិទាំងអស់ស្ញប់ស្ញែងចំពោះព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ និងមើលងាយចំពោះសាច់ឈាមរបស់ព្រះជាម្ចាស់ក៏ដោយ ហើយមិនថាពួកគេមានទស្សនៈ ឬគំនិតបែបណានោះទេ ក៏សារៈសំខាន់ និងតម្លៃដ៏ពិតនៃសាច់ឈាម មានកម្រិតខ្ពស់ជាងខាងព្រះវិញ្ញាណដែរ។ ជាការពិត តម្លៃនេះគឺសម្រាប់តែមនុស្សជាតិដ៏ពុករលួយប៉ុណ្ណោះ។ សម្រាប់អស់អ្នកណាដែលស្វែងរកសេចក្តីពិត ហើយទន្ទឹងរង់ចាំការលេចមករបស់ព្រះជាម្ចាស់ នោះកិច្ចការរបស់ព្រះវិញ្ញាណអាចប្រទាននូវការរំជួលចិត្ត ឬការបណ្ដាលចិត្ត និងអារម្មណ៍ប្លែកចិត្តដែលកិច្ចការនេះហួសពីសេចក្តីពន្យល់ និងការស្រមើស្រមៃ ព្រមទាំងអារម្មណ៍ដ៏អស្ចារ្យ គិតមិនដល់ និងគួរឲ្យស្ងើចសរសើរ ប៉ុន្តែមនុស្សទាំងអស់មិនអាចទទួលបាន និងយល់បានឡើយ។ មនុស្ស និងព្រះវិញ្ញាណរបស់ព្រះជាម្ចាស់អាចសម្លឹងមើលគ្នាពីចម្ងាយតែប៉ុណ្ណោះ ប្រៀបដូចជាមានគម្លាតដ៏ធំមួយនៅចន្លោះពួកគេ ហើយពួកគេគ្មានថ្ងៃនឹងដូចគ្នាឡើយ គឺដូចជាមនុស្ស និងព្រះជាម្ចាស់ ត្រូវបានដាច់ចេញពីគ្នា ដោយរនាំងខណ្ឌចែកអរូបិយមួយអ៊ីចឹង។ តាមពិតទៅ នេះគឺជាដំណើរបំភាន់មួយដែលព្រះវិញ្ញាណប្រទានដល់មនុស្ស ដោយសារតែព្រះវិញ្ញាណ និងមនុស្សមិនអាចមានលក្ខណៈដូចគ្នាឡើយ ហើយពួកគេក៏មិនអាចរួមរស់ជាមួយគ្នានៅក្នុងពិភពលោកតែមួយបាននោះដែរ និងដោយសារតែព្រះវិញ្ញាណគ្មានលក្ខណៈរបស់មនុស្សសោះឡើយ។ ដូច្នេះ មនុស្សមិនមានតម្រូវការពីព្រះវិញ្ញាណទេ ព្រោះព្រះវិញ្ញាណមិនអាចធ្វើកិច្ចការដែលមនុស្សត្រូវការបំផុតដោយ

អង្គទ្រង់ផ្ទាល់បានឡើយ។ កិច្ចការនៃសាច់ឈាមផ្តល់ឲ្យមនុស្សនូវគោលបំណងដ៏ពិត ដើម្បីដេញតាម ផ្តល់ជាព្រះបន្ទូលច្បាស់ៗ និងផ្តល់នូវអារម្មណ៍ថា ទ្រង់ពិតប្រាកដ ហើយទ្រង់ជាមនុស្សសាមញ្ញ ព្រមទាំងផ្តល់ជាអារម្មណ៍ថា ទ្រង់បន្ទាបអង្គទ្រង់ និងជាមនុស្សធម្មតាម្នាក់។ ទោះបីមនុស្ស អាចមានអារម្មណ៍កោតខ្លាចទ្រង់ក៏ដោយ ក៏សម្រាប់មនុស្សភាគច្រើន ទ្រង់ងាយស្រួលក្នុងការទំនាក់ទំនងជាមួយដែរ៖ មនុស្សអាចមើលឃើញព្រះភ័ក្ត្រទ្រង់ ស្តាប់ឮព្រះសូរសៀងទ្រង់ ហើយគេមិនចាំបាច់សម្លឹងទៅកាន់ទ្រង់ពីចម្ងាយនោះឡើយ។ សាច់ឈាមនេះធ្វើឲ្យមនុស្សមានអារម្មណ៍ថា គេអាចចូលទៅរកទ្រង់បាន។ គេមិនមានអារម្មណ៍ថា ទ្រង់នៅសែនឆ្ងាយ ឬមិនអាចវាស់ស្ទង់បាននោះឡើយ ប៉ុន្តែគេអាចមើលឃើញ និងប៉ះពាល់ទ្រង់បាន ព្រោះសាច់ឈាមនេះស្ថិតនៅក្នុងពិភពលោកដែលមនុស្សរស់នៅ។

សម្រាប់អស់អ្នកណាដែលរស់នៅក្នុងសាច់ឈាម ការផ្លាស់ប្តូរនិស្ស័យរបស់គេតម្រូវឲ្យមានគោលដៅ ដើម្បីដេញតាម ហើយការស្គាល់ព្រះជាម្ចាស់តម្រូវឲ្យមានការឃើញផ្ទាល់នឹងភ្នែកនូវទង្វើដ៏ពិត និងមើលឃើញព្រះភ័ក្ត្រដ៏ពិតរបស់ព្រះជាម្ចាស់។ កិច្ចការទាំងពីរនេះអាចសម្រេចទៅបានតែតាមរយៈសាច់ឈាមដែលយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់ប៉ុណ្ណោះ ហើយកិច្ចការទាំងពីរនេះ អាចសម្រេចបានតាមរយៈសាច់ឈាមដ៏សាមញ្ញ និងពិតប្រាកដតែប៉ុណ្ណោះ។ នេះជាហេតុផលដែលនាំឲ្យការយកកំណើតជាមនុស្ស មានភាពសំខាន់ចាំបាច់ និងជាហេតុផលដែលញ៉ាំងឲ្យមនុស្សជាតិដ៏ពុករលួយទាំងអស់ត្រូវការជាចាំបាច់។ ដោយសារតែមនុស្សត្រូវបានតម្រូវឲ្យស្គាល់ព្រះជាម្ចាស់ ដូច្នេះ រូបអង្គអំពីព្រះដ៏ស្រពេចស្រពិល និងអធិធម្មជាតិ ត្រូវតែលុបបំបាត់ចេញពីដួងចិត្តរបស់គេ ហើយដោយសារតែពួកគេត្រូវបានតម្រូវឲ្យកម្ចាត់ចោលនិស្ស័យដ៏ពុករលួយរបស់គេ ដូច្នេះ ជាដំបូង ពួកគេត្រូវដឹងអំពីនិស្ស័យដ៏ពុករលួយរបស់គេជាមុនសិន។ បើមនុស្សធ្វើកិច្ចការនៃការលុបចោលរូបអង្គព្រះដ៏ស្រពេចស្រពិលចេញពីដួងចិត្តរបស់មនុស្ស នោះគេនឹងមិនអាចទទួលបាននូវលទ្ធផលដ៏សមរម្យឡើយ។ រូបអង្គនៃព្រះដ៏ស្រពេចស្រពិលនៅក្នុងដួងចិត្ត

របស់មនុស្សមិនអាចត្រូវបានលុបចោល កម្ចាត់ចេញ ឬលុបបំបាត់ទាំងស្រុង ដោយពាក្យសម្ដីតែម្យ៉ាងឡើយ។ បើធ្វើបែបនេះនៅទីបំផុត វានឹងនៅតែមិនអាចដកចោលរូបអង្គដែលចាក់ឫសយ៉ាងជ្រៅទាំងនេះ ចេញពីមនុស្សបានឡើយ។ មានតែតាមរយៈការជំនួសរូបដ៏ស្រពេចស្រពិល និងអធិធម្មជាតិទាំងនេះ ដោយព្រះជាម្ចាស់ដ៏ពិត និងរូបអង្គដ៏ពិតរបស់ព្រះជាម្ចាស់ និងធ្វើឲ្យមនុស្សស្គាល់ពីរូបអង្គទាំងនោះ បន្តិចម្ដងៗប៉ុណ្ណោះ ទើបវាអាចទទួលបានលទ្ធផល។ មនុស្សទទួលស្គាល់ថាព្រះជាម្ចាស់ដែលគេស្វែងរកពីអតីតកាល គឺជាព្រះដ៏ស្រពេចស្រពិល និងអធិធម្មជាតិ។ ការដឹកនាំដោយផ្ទាល់ពីព្រះវិញ្ញាណ និងសេចក្ដីបង្រៀនរបស់មនុស្ស មិនអាចជួយទៅសម្រេចការនេះបានឡើយ គឺមានតែព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សប៉ុណ្ណោះដែលអាចជួយបាន។ សញ្ញាណរបស់មនុស្សត្រូវបានលាតត្រដាងឲ្យឃើញនៅពេលដែល ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស ធ្វើកិច្ចការរបស់ទ្រង់ជាផ្លូវការ ពីព្រោះភាពសាមញ្ញ និងតថភាពពិតនៃព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស មានសភាពផ្ទុយគ្នាទៅនឹងព្រះដ៏ស្រពេចស្រពិល និងអធិធម្មជាតិនៅក្នុងការស្រមើស្រមៃរបស់មនុស្ស។ សញ្ញាណដើមរបស់មនុស្សអាចត្រូវបានបើកសម្ដែងឲ្យឃើញ នៅពេលដែលធ្វើការប្រៀបធៀបជាមួយនឹងព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស។ បើគ្មានការប្រៀបធៀបទៅនឹងព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សទេ នោះសញ្ញាណរបស់មនុស្សមិនអាចត្រូវបានបើកសម្ដែងឲ្យឃើញនោះឡើយ ហើយនៅក្នុងន័យម្យ៉ាងទៀត បើគ្មានតថភាពពិតជាគ្រឿងបន្ទាប់បន្សំទេ នោះរូបភាពដ៏ស្រពេចស្រពិល មិនអាចត្រូវបានបើកសម្ដែងឲ្យឃើញឡើយ។ គ្មាននរណាម្នាក់មានសមត្ថភាពប្រើប្រាស់ពាក្យសម្ដី ដើម្បីធ្វើកិច្ចការនេះឡើយ ហើយក៏គ្មាននរណាម្នាក់អាចបរិយាយអំពីកិច្ចការនេះ ដោយប្រើវោហារសព្ទជាពាក្យពេចន៍នោះដែរ។ មានតែព្រះជាម្ចាស់ផ្ទាល់ព្រះអង្គប៉ុណ្ណោះ ដែលអាចធ្វើកិច្ចការរបស់ទ្រង់បាន ហើយគ្មានអ្នកណាផ្សេងអាចធ្វើកិច្ចការនេះ ជំនួសទ្រង់បានឡើយ។ ទោះបីមនុស្ស មានសំនួនវោហារសព្ទសម្បូរបែបយ៉ាងណា ក៏គេគ្មានសមត្ថភាពបរិយាយអំពីតថភាព

ពិត និងភាពសាមញ្ញរបស់ព្រះជាម្ចាស់បានដែរ។ មនុស្សអាចស្គាល់ព្រះជាម្ចាស់កាន់តែជាក់ស្ដែង និងអាចមើលឃើញទ្រង់កាន់តែច្បាស់ លុះត្រាតែទ្រង់ធ្វើការដោយផ្ទាល់នៅក្នុងចំណោមមនុស្ស ហើយបង្ហាញភាពជាទ្រង់ និងរូបអង្គរបស់ទ្រង់ឲ្យគេឃើញទាំងស្រុងប៉ុណ្ណោះ។ លទ្ធផលនេះមិនអាចសម្រេចបាន ដោយមនុស្សខាងសាច់ឈាមណាម្នាក់ឡើយ។ ជាការពិត ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ក៏គ្មានសមត្ថភាពសម្រេចលទ្ធផលនេះបានដែរ។ ព្រះជាម្ចាស់អាចសង្គ្រោះមនុស្សដ៏ពុករលួយពីឥទ្ធិពលរបស់សាតាំងបាន ប៉ុន្តែកិច្ចការនេះមិនអាចត្រូវបានសម្រេចដោយផ្ទាល់ពីព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ឡើយផ្ទុយទៅវិញ កិច្ចការនេះអាចសម្រេចបានតាមរយៈសាច់ឈាម ដែលព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ចូលសណ្ឋិត ឬដោយសាច់ឈាមដែលយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់តែប៉ុណ្ណោះ។ សាច់ឈាមនេះ គឺជាមនុស្ស ហើយក៏ជាព្រះជាម្ចាស់ដែរ។ សាច់ឈាមនេះ គឺជាមនុស្សដែលមានភាពជាមនុស្សសាមញ្ញ ហើយក៏ជាព្រះជាម្ចាស់ដែលមានភាពជាព្រះដ៏ពេញលេញផងដែរ។ ដូច្នេះ ទោះបីសាច់ឈាមនេះមិនមែនជាព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ និងមានលក្ខណៈខុសគ្នាយ៉ាងខ្លាំងពីព្រះវិញ្ញាណក៏ដោយ ក៏នៅតែជាព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ ដែលយកកំណើតជាមនុស្សដដែលដែលសង្គ្រោះមនុស្ស ហើយព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សនេះ ជាព្រះវិញ្ញាណផង និងជាសាច់ឈាមផង។ មិនថាមនុស្សហៅទ្រង់បែបណានោះឡើយ ទីបំផុត គឺនៅតែជាព្រះជាម្ចាស់ផ្ទាល់ព្រះអង្គដដែល ដែលសង្គ្រោះមនុស្សជាតិ។ ដោយសារតែព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ដែលមិនអាចដាច់ចេញពីសាច់ឈាម ហើយកិច្ចការនៃសាច់ឈាម ក៏ជាកិច្ចការនៃព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ដែរនោះ ទើបកិច្ចការនេះ មិនគ្រាន់តែត្រូវបានធ្វើដោយប្រើអត្តសញ្ញាណរបស់ព្រះវិញ្ញាណប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវបានធ្វើដោយប្រើអត្តសញ្ញាណរបស់សាច់ឈាមដែរ។ កិច្ចការដែលព្រះវិញ្ញាណត្រូវធ្វើដោយផ្ទាល់ មិនតម្រូវឲ្យមានការយកកំណើតជាមនុស្សឡើយហើយកិច្ចការដែលតម្រូវឲ្យសាច់ឈាមធ្វើ ក៏មិនអាចធ្វើដោយផ្ទាល់ពីព្រះវិញ្ញាណដែរ ប៉ុន្តែអាចត្រូវបានធ្វើដោយព្រះជាម្ចាស់

ដែលយកកំណើតជាមនុស្សប៉ុណ្ណោះ។ នេះជាអ្វីដែលតម្រូវឲ្យមានសម្រាប់កិច្ចការនេះ ហើយវាជាអ្វីដែលមនុស្សជាតិដ៏ពុករលួយត្រូវការជាចាំបាច់។ នៅក្នុងដំណាក់កាលទាំងបីនៃកិច្ចការរបស់ព្រះជាម្ចាស់ មានតែដំណាក់កាលមួយប៉ុណ្ណោះ ដែលត្រូវបានអនុវត្តដោយផ្ទាល់ពីព្រះវិញ្ញាណ ហើយដំណាក់កាលពីរផ្សេងទៀតត្រូវបានអនុវត្តដោយព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស មិនមែនដោយព្រះវិញ្ញាណដោយផ្ទាល់ទេ។ កិច្ចការនៅយុគសម័យនៃក្រឹត្យវិន័យដែលត្រូវបានធ្វើដោយព្រះវិញ្ញាណ មិនបានពាក់ព័ន្ធនឹងការផ្លាស់ប្ដូរនិស្ស័យដ៏ពុករលួយរបស់មនុស្សឡើយ ហើយវាក៏គ្មានទាក់ទងអ្វីនឹងចំណេះដឹងរបស់មនុស្សអំពីព្រះជាម្ចាស់ដែរ។ យ៉ាងណាមិញ កិច្ចការនៃសាច់ឈាមរបស់ព្រះជាម្ចាស់ នៅក្នុងយុគសម័យនៃព្រះគុណ និងយុគសម័យនៃនគរព្រះ ពាក់ព័ន្ធនឹងនិស្ស័យពុករលួយរបស់មនុស្ស និងចំណេះដឹងរបស់គេអំពីព្រះជាម្ចាស់ ហើយវាជាផ្នែកដ៏សំខាន់និងចាំបាច់ចំពោះកិច្ចការនៃសេចក្ដីសង្គ្រោះ។ ដូច្នេះ មនុស្សជាតិដ៏ពុករលួយ កាន់តែត្រូវការសេចក្ដីសង្គ្រោះរបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស ហើយគេកាន់តែត្រូវការកិច្ចការដោយផ្ទាល់របស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស។ មនុស្សជាតិត្រូវការព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស ចាំមើលថែគេ ចាំជួយគាំទ្រគេ ចាំប្រទានឲ្យទឹកគេ ចាំប្រទានអាហារដល់គេ ជំនុំជម្រះ និងវាយផ្ចាលគេ ហើយគេត្រូវការព្រះគុណកាន់តែច្រើន និងការប្រោសលោះកាន់តែខ្លាំង ពីព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស។ មានតែព្រះជាម្ចាស់ដែលគង់នៅក្នុងសាច់ឈាមប៉ុណ្ណោះ ដែលអាចក្លាយជាបុគ្គលជំនិតរបស់មនុស្ស ជាគង្វាលរបស់មនុស្ស ជាជំនួយគ្រប់ពេលរបស់មនុស្ស ហើយអ្វីៗទាំងអស់នេះគឺជាភាពចាំបាច់នៃការយកកំណើតជាមនុស្ស ទាំងពេលសព្វថ្ងៃ និងពីអតីតកាល។

មនុស្សត្រូវបានសាតាំងធ្វើឲ្យពុករលួយ ហើយមនុស្សជាភាវៈដ៏ខ្ពស់បំផុតនៅក្នុងចំណោមសត្តនិករទាំងអស់របស់ព្រះជាម្ចាស់ ដូច្នេះ មនុស្សត្រូវការសេចក្ដីសង្គ្រោះរបស់ព្រះជាម្ចាស់។ កម្មវត្ថុនៃសេចក្ដីសង្គ្រោះរបស់ព្រះជាម្ចាស់ គឺជាមនុស្ស មិនមែនសាតាំងឡើយ ហើយអ្វីដែលនឹងត្រូវទទួលការសង្គ្រោះ គឺជាសាច់ឈាម និងព្រលឹង

របស់មនុស្ស មិនមែនជាអារក្សនោះឡើយ។ កម្មវត្ថុរបស់ព្រះជាម្ចាស់ចំពោះសាតាំង គឺជាការវិនាសសាបសូន្យ ហើយកម្មវត្ថុរបស់ព្រះជាម្ចាស់សម្រាប់មនុស្ស គឺជាសេចក្ដីសង្គ្រោះ។ សាច់ឈាមរបស់មនុស្សត្រូវបានសាតាំងធ្វើឲ្យពុករលួយ ដូច្នេះ រឿងទីមួយដែលត្រូវសង្គ្រោះ គឺត្រូវតែជាសាច់ឈាមរបស់មនុស្ស។ សាច់ឈាមរបស់មនុស្សត្រូវបានធ្វើឲ្យពុករលួយយ៉ាងជ្រាលជ្រៅបំផុត ហើយវាបានក្លាយជាអ្វីមួយដែលប្រឆាំងនឹងព្រះជាម្ចាស់ ដល់ថ្នាក់ប្រឆាំងនិងបដិសេធចំពោះអត្ថិភាពរបស់ព្រះជាម្ចាស់ទាំងបើកចំហ។ សាច់ឈាមដ៏ពុករលួយនេះចចេសរឹងរូស ហើយគ្មានអ្វីមួយដែលពិបាកដោះស្រាយ ឬពិបាកផ្លាស់ប្ដូរ ជាងនិស្ស័យដ៏ពុករលួយរបស់សាច់ឈាមនោះឡើយ។ សាតាំងចូលក្នុងសាច់ឈាមរបស់មនុស្ស ដើម្បីបង្កឲ្យមានភាពចលាចល ហើយវាប្រើសាច់ឈាមរបស់មនុស្ស ដើម្បីបង្អាក់ដល់កិច្ចការរបស់ព្រះជាម្ចាស់ និងបំផ្លាញផែនការរបស់ព្រះជាម្ចាស់ ដូច្នេះ មនុស្សបានក្លាយជាសាតាំង និងក្លាយជាសត្រូវរបស់ព្រះជាម្ចាស់។ ដើម្បីឲ្យមនុស្សបានសង្គ្រោះ នោះគេត្រូវតែត្រូវបានយកឈ្នះជាមុនសិន។ ដោយសារតែហេតុផលនេះហើយ ទើបព្រះជាម្ចាស់ឆ្លើយតបចំពោះបញ្ហា ហើយយាងចូលទៅក្នុងសាច់ឈាម ដើម្បីធ្វើកិច្ចការដែលទ្រង់ត្រូវធ្វើ និងច្បាំងជាមួយសាតាំង។ គោលបំណងរបស់ទ្រង់ គឺដើម្បីសង្គ្រោះមនុស្សដែលត្រូវបានធ្វើឲ្យពុករលួយ ព្រមទាំងយកឈ្នះលើសាតាំងដែលបះបោរនឹងទ្រង់ និងធ្វើឲ្យវាវិនាសសាបសូន្យ។ ទ្រង់យកឈ្នះលើសាតាំងតាមរយៈកិច្ចការរបស់ទ្រង់អំពីការយកឈ្នះលើមនុស្ស ខណៈពេលដូចគ្នានោះ ទ្រង់សង្គ្រោះមនុស្សជាតិដ៏ពុករលួយ។ ដូច្នេះ នេះជាកិច្ចការមួយដែលសម្រេចបានគោលបំណងពីរក្នុងពេលតែមួយ។ ទ្រង់ធ្វើការនៅក្នុងសាច់ឈាម និងមានបន្ទូលនៅក្នុងសាច់ឈាម ហើយធ្វើគ្រប់កិច្ចការនៅក្នុងសាច់ឈាម ដើម្បីមានទំនាក់ទំនងកាន់តែប្រសើរជាមួយមនុស្ស និងយកឈ្នះលើមនុស្សឲ្យបានកាន់តែប្រសើរ។ ពេលចុងក្រោយដែលព្រះជាម្ចាស់ត្រលប់ជាសាច់ឈាម កិច្ចការរបស់ទ្រង់នៅគ្រាចុងក្រោយ នឹងត្រូវបញ្ចប់នៅក្នុងសាច់ឈាម។ ទ្រង់នឹងចាត់ថ្នាក់មនុស្សទាំងអស់ទៅតាមប្រភេទរបស់គេ បញ្ចប់ការគ្រប់គ្រងទាំងអស់របស់ទ្រង់ ហើយក៏

បញ្ចប់កិច្ចការរបស់ទ្រង់ទាំងអស់ នៅក្នុងសាច់ឈាមដែរ។ ក្រោយពេលកិច្ចការទាំងអស់របស់ទ្រង់នៅលើផែនដីត្រូវបានបញ្ចប់ ទ្រង់នឹងមានជ័យជម្នះទាំងស្រុង។ តាមរយៈការធ្វើការនៅក្នុងសាច់ឈាម ព្រះជាម្ចាស់នឹងយកឈ្នះទាំងស្រុងលើមនុស្សជាតិ ហើយទ្រង់នឹងទទួលបានមនុស្សជាតិទាំងស្រុង។ តើនេះមិនមានន័យថា ការគ្រប់គ្រងទាំងស្រុងរបស់ទ្រង់នឹងត្រូវបញ្ចប់ទេឬអី? នៅពេលដែលព្រះជាម្ចាស់បញ្ចប់កិច្ចការរបស់ទ្រង់នៅក្នុងសាច់ឈាម នៅពេលដែលទ្រង់បានច្បាំងឈ្នះសាតាំង និងមានជ័យជម្នះទាំងស្រុង នោះសាតាំងនឹងគ្មានឱកាស ដើម្បីធ្វើឲ្យមនុស្សពុករលួយទៀតឡើយ។ កិច្ចការនៃការយកកំណើតជាមនុស្សលើកទីមួយរបស់ព្រះជាម្ចាស់ គឺជាការប្រោសលោះ និងការអត់ទោសដល់បាបរបស់មនុស្ស។ ឥឡូវនេះ វាជាកិច្ចការនៃការយកឈ្នះ និងការទទួលបានមនុស្សជាតិទាំងស្រុង ដូច្នេះសាតាំងនឹងលែងមានផ្លូវដើម្បីធ្វើកិច្ចការរបស់វាតទៅទៀត។ វានឹងត្រូវបានចាញ់ទាំងស្រុងតែម្ដង ហើយព្រះជាម្ចាស់នឹងមានជ័យជម្នះទាំងស្រុងតែម្ដង។ នេះគឺជាកិច្ចការនៃសាច់ឈាម និងជាកិច្ចការដែលត្រូវបានធ្វើដោយព្រះជាម្ចាស់ផ្ទាល់។ កិច្ចការដំបូងនៃដំណាក់កាលទាំងបីនៃកិច្ចការរបស់ព្រះជាម្ចាស់ ត្រូវបានធ្វើដោយផ្ទាល់ដោយព្រះវិញ្ញាណ មិនមែនដោយសាច់ឈាមឡើយ។ យ៉ាងណាមិញ កិច្ចការចុងក្រោយនៃដំណាក់កាលទាំងបីនៃកិច្ចការរបស់ព្រះជាម្ចាស់ត្រូវបានធ្វើដោយព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស មិនមែនដោយព្រះវិញ្ញាណផ្ទាល់ឡើយ។ កិច្ចការនៃការប្រោសលោះនៅដំណាក់កាលកណ្ដាល ក៏ត្រូវបានធ្វើឡើងដោយព្រះជាម្ចាស់នៅក្នុងសាច់ឈាមដែរ។ នៅក្នុងចំណោមកិច្ចការនៃការគ្រប់គ្រងទាំងមូល កិច្ចការដ៏សំខាន់បំផុត គឺជាការសង្គ្រោះមនុស្សពីឥទ្ធិពលរបស់សាតាំង។ កិច្ចការដ៏សំខាន់ គឺជាការយកឈ្នះទាំងស្រុងលើមនុស្សដ៏ពុករលួយ ដូចនេះការស្ដារឲ្យមានការគោរពជាដំបូងចំពោះព្រះជាម្ចាស់នៅក្នុងដួងចិត្តរបស់មនុស្សដែលត្រូវបានយកឈ្នះ និងដើម្បីអនុញ្ញាតឲ្យគេទទួលបានជីវិតសាមញ្ញ ដែលជាជីវិតសាមញ្ញនៃសត្តនិកររបស់ព្រះជាម្ចាស់។ កិច្ចការនេះពិតជាសំខាន់ ហើយវាជាចំណុចស្នូលនៃកិច្ចការគ្រប់គ្រង។ នៅក្នុងដំណាក់កាលទាំងបីនៃ

កិច្ចការសង្គ្រោះ ដំណាក់កាលទីមួយនៃកិច្ចការដែលជាយុគសម័យនៃក្រឹត្យវិន័យ គឺស្ថិតនៅឆ្ងាយពីចំណុចស្នូលនៃកិច្ចការគ្រប់គ្រង។ វាគ្រាន់តែមានការលេចមកតិចតួចអំពីកិច្ចការសង្គ្រោះ ហើយវាមិនមែនជាទីចាប់ផ្ដើមនៃកិច្ចការរបស់ព្រះជាម្ចាស់ក្នុងការសង្គ្រោះមនុស្សពីដែនគ្រប់គ្រងរបស់សាតាំងឡើយ។ ដំណាក់កាលទីមួយនៃកិច្ចការគឺព្រះវិញ្ញាណជាអ្នកធ្វើដោយផ្ទាល់ ពីព្រោះនៅពេលដែលស្ថិតនៅក្រោមក្រឹត្យវិន័យ មនុស្សដឹងតែកាន់តាមក្រឹត្យវិន័យប៉ុណ្ណោះ ហើយមនុស្សមិនមានសេចក្ដីពិតជាច្រើនទេ ហើយដោយសារតែកិច្ចការនៅក្នុងយុគសម័យនៃក្រឹត្យវិន័យ មិនសូវពាក់ព័ន្ធនឹងការផ្លាស់ប្ដូរនៅក្នុងនិស្ស័យរបស់មនុស្ស ក៏មិនសូវពាក់ព័ន្ធនឹងកិច្ចការនៃការសង្គ្រោះមនុស្សពីដែនគ្រប់គ្រងរបស់សាតាំងដែរ។ ដូច្នេះ ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់បានបញ្ចប់ដំណាក់កាលនៃកិច្ចការដ៏សាមញ្ញ និងខ្លង់ខ្ពស់នេះ ដែលមិនទាក់ទងនឹងនិស្ស័យដ៏ពុករលួយរបស់មនុស្សឡើយ។ ដំណាក់កាលនៃកិច្ចការនេះមានទំនាក់ទំនងតិចតួចណាស់ទៅនឹងចំណុចស្នូលនៃការគ្រប់គ្រង ហើយវាគ្មានទំនាក់ទំនងអ្វីធំដុំទៅនឹងកិច្ចការជាផ្លូវការនៃការសង្គ្រោះមនុស្ស ហើយវាក៏មិនបានតម្រូវឲ្យព្រះជាម្ចាស់ត្រលប់ជាសាច់ឈាមដោយផ្ទាល់ ដើម្បីធ្វើកិច្ចការរបស់ទ្រង់នោះដែរ។ កិច្ចការដែលត្រូវបានធ្វើដោយព្រះវិញ្ញាណគឺជាកិច្ចការដោយប្រយោល និងមិនអាចវាស់ស្ទង់បាន ហើយកិច្ចការនោះធ្វើឲ្យមនុស្សភ័យខ្លាច និងមិនអាចចូលទៅជិតបានឡើយ។ ព្រះវិញ្ញាណមិនសក្ដិសមនឹងធ្វើកិច្ចការសង្គ្រោះដោយផ្ទាល់ឡើយ ហើយក៏មិនសក្ដិសមប្រទានជីវិតដល់មនុស្សដោយផ្ទាល់នោះដែរ។ កិច្ចការដ៏សក្ដិសមបំផុតសម្រាប់មនុស្ស គឺជាការផ្លាស់ប្ដូរកិច្ចការរបស់ព្រះវិញ្ញាណ ឲ្យក្លាយជាវិធីសាស្ត្រមួយដែលស្និទ្ធស្នាលចំពោះមនុស្ស គឺអាចនិយាយបានថា អ្វីដែលសក្ដិសមបំផុតសម្រាប់មនុស្ស គឺជាការដែលព្រះជាម្ចាស់ក្លាយជាមនុស្សសាមញ្ញធម្មតា ដើម្បីធ្វើកិច្ចការរបស់ទ្រង់។ ការនេះតម្រូវឲ្យព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស មកជំនួសកន្លែងរបស់ព្រះវិញ្ញាណនៅក្នុងកិច្ចការរបស់ទ្រង់ ហើយសម្រាប់មនុស្ស វាគ្មានផ្លូវណាផ្សេងទៀតដែលសក្ដិសមសម្រាប់ព្រះជាម្ចាស់ធ្វើការនោះឡើយ។ នៅក្នុងចំណោមដំណាក់កាលទាំងបីនៃ

កិច្ចការទាំងនេះ ដំណាក់កាលពីរត្រូវបានអនុវត្តដោយសាច់ឈាម ហើយដំណាក់កាលទាំងពីរនេះ គឺជាដំណាក់កាលដ៏សំខាន់នៃកិច្ចការគ្រប់គ្រង។ ការយកកំណើតជាមនុស្សទាំងពីរលើក គឺជាការបំពេញឲ្យគ្នាទៅវិញទៅមក ហើយដំណាក់កាលទាំងពីរនេះបំពេញឲ្យគ្នាយ៉ាងល្អឥតខ្ចោះ។ ដំណាក់កាលទីមួយនៃការយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់បានចាក់គ្រឹះមូលដ្ឋានសម្រាប់ដំណាក់កាលទីពីរ ហើយវាអាចនិយាយបានថា ការយកកំណើតជាមនុស្សទាំងពីរលើករបស់ព្រះជាម្ចាស់បង្កើតឲ្យមានភាពពេញលេញមួយ ហើយវាគ្មានការមិនចុះសម្រុងនឹងគ្នានោះឡើយ។ ដំណាក់កាលទាំងពីរនៃកិច្ចការរបស់ព្រះជាម្ចាស់នេះ ត្រូវបានអនុវត្តដោយព្រះជាម្ចាស់នៅក្នុងអត្តសញ្ញាណនៃព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស ដោយសារតែដំណាក់កាលទាំងពីរនេះពិតជាសំខាន់ណាស់ចំពោះកិច្ចការទាំងស្រុងនៃការគ្រប់គ្រង។ គេសឹងតែអាចនិយាយបានថា បើគ្មានកិច្ចការនៃការយកកំណើតជាមនុស្សទាំងពីរលើករបស់ព្រះជាម្ចាស់ទេ នោះកិច្ចការគ្រប់គ្រងទាំងស្រុងនឹងត្រូវបញ្ឈប់ ហើយកិច្ចការនៃការសង្គ្រោះមនុស្សជាតិនឹងគ្មានន័យអ្វីក្រៅពីការនិយាយចោលនោះឡើយ។ កិច្ចការនេះសំខាន់ ឬមិនសំខាន់ គឺអាស្រ័យលើតម្រូវការរបស់មនុស្សជាតិ អាស្រ័យលើតថភាពជាក់ស្ដែងនៃភាពពុករលួយរបស់មនុស្សជាតិ និងអាស្រ័យលើភាពធ្ងន់ធ្ងរនៃការមិនស្ដាប់បង្គាប់របស់សាតាំង និងការរំខានរបស់វាចំពោះកិច្ចការ។ បុគ្គលដែលមានគុណសម្បត្តិសក្តិសមនឹងការងារ ត្រូវអាស្រ័យលើធម្មជាតិនៃការងារដែលត្រូវបានធ្វើដោយអ្នកធ្វើ និងសារៈសំខាន់នៃការងារ។ នៅពេលដែលនិយាយអំពីចំណុចសំខាន់នៃកិច្ចការនេះ ទាក់ទងនឹងវិធីសាស្ត្រធ្វើការបែបណាដែលត្រូវប្រើ ថាតើកិច្ចការនោះត្រូវធ្វើដោយផ្ទាល់ ដោយព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ ដោយព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស ឬក៏តាមរយៈមនុស្ស ជំហានដំបូងដែលត្រូវផាត់ចោលនោះ គឺជាកិច្ចការដែលត្រូវធ្វើតាមរយៈមនុស្ស ហើយបើផ្អែកលើធម្មជាតិនៃការងារ និងធម្មជាតិនៃកិច្ចការរបស់ព្រះវិញ្ញាណ ទល់នឹងធម្មជាតិនៃសាច់ឈាមវិញ ទីបំផុត គេអាចសម្រេចចិត្តបានថា កិច្ចការដែលត្រូវបានធ្វើដោយសាច់ឈាម មានប្រយោជន៍ចំពោះ

មនុស្សខ្លាំងជាងកិច្ចការដែលត្រូវបានធ្វើដោយផ្ទាល់ដោយព្រះវិញ្ញាណ ហើយគេអាចសម្រេចចិត្តបានទៀតថា វាផ្ដល់នូវគុណប្រយោជន៍ច្រើនជាង។ នេះជាព្រះតម្រិះរបស់ព្រះជាម្ចាស់នៅគ្រានោះ នៅពេលដែលទ្រង់សម្រេចព្រះទ័យថាតើកិច្ចការនេះត្រូវធ្វើដោយព្រះ វិញ្ញាណ ឬក៏ដោយសាច់ឈាម។ វាមានសារៈសំខាន់ និងមូលដ្ឋានរបស់វាចំពោះដំណាក់កាលនីមួយៗនៃកិច្ចការ។ វាមិនមែនជាការស្រមើស្រមៃ ដែលគ្មានមូលដ្ឋាន និងត្រូវបានអនុវត្តតាមតែអំពើចិត្តនោះទេ ប៉ុន្តែដំណាក់កាលទាំងនេះត្រូវបានធ្វើប្រកបដោយព្រះប្រាជ្ញាញាណ។ នេះគឺជាសេចក្ដីពិតមួយ ដែលស្ថិតនៅពីក្រោយគ្រប់កិច្ចការទាំងអស់របស់ព្រះជាម្ចាស់។ ជាពិសេស នៅក្នុងកិច្ចការដ៏ធំនោះ វាមានផែនការជាច្រើនរបស់ព្រះជាម្ចាស់ នៅពេលដែលព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស ធ្វើការដោយផ្ទាល់នៅក្នុងចំណោមមនុស្ស។ ដូច្នេះ ព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់ និងភាពទាំងស្រុងនៃអង្គទ្រង់ ត្រូវបានឆ្លុះបញ្ចាំងឲ្យឃើញនៅក្នុងគ្រប់សកម្មភាព គ្រប់ព្រះតម្រិះ និងគ្រប់យោបល់នៃកិច្ចការរបស់ទ្រង់ ហើយនេះគឺជាលក្ខណៈកាន់តែរឹងមាំ និងជាប្រព័ន្ធរបស់ព្រះជាម្ចាស់។ ព្រះតម្រិះ និងយោបល់ដ៏ល្អិតល្អន់ទាំងនេះពិតជាពិបាកឲ្យមនុស្សស្រមើស្រមៃ និងពិបាកឲ្យមនុស្សជឿ ហើយលើសពីនេះ គឺពិបាកឲ្យមនុស្សដឹង។ កិច្ចការដែលត្រូវបានធ្វើដោយមនុស្ស គឺធ្វើឡើងស្របតាមគោលការណ៍ទូទៅ ជាគោលការណ៍ដែលមនុស្សពេញចិត្តខ្លាំង។ ប៉ុន្តែ បើធៀបជាមួយកិច្ចការរបស់ព្រះជាម្ចាស់វិញ វាហាក់ដូចជាមានភាពខុសគ្នាដ៏ធំមួយ។ ទោះបីទង្វើរបស់ព្រះជាម្ចាស់ធំធេងអស្ចារ្យ ហើយកិច្ចការរបស់ព្រះជាម្ចាស់មានវិសាលភាពប្រសើរក្រៃលែងយ៉ាងណាក៏ដោយ ក៏នៅពីក្រោយកិច្ចការទាំងនោះ មាននូវការចំណាយពេលរាប់ម៉ោងធ្វើផែនការ និងការចាត់ចែងដ៏ច្បាស់លាស់ ដែលមនុស្សមិនអាចស្រមៃដល់នោះឡើយ។ ដំណាក់កាលនីមួយៗនៃកិច្ចការរបស់ទ្រង់ មិនគ្រាន់តែត្រូវបានធ្វើស្របតាមគោលការណ៍ប៉ុណ្ណោះទេ ប៉ុន្តែដំណាក់កាលនីមួយៗក៏មានផ្ទុកនូវចំណុចជាច្រើនដែលមិនអាចបរិយាយដោយភាសារបស់មនុស្សដែរ ហើយទាំងនេះគឺជារឿងដែលមនុស្សមើលមិនឃើញឡើយ។ មិនថាវាជាកិច្ចការរបស់ព្រះវិញ្ញាណ ឬ

ក៏ជាកិច្ចការរបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សនោះឡើយ កិច្ចការនីមួយៗ សុទ្ធតែមាននូវផែនការនៃកិច្ចការរបស់ទ្រង់។ ទ្រង់មិនធ្វើការដោយគ្មានមូលដ្ឋានច្បាស់លាស់ទេ ហើយក៏មិនធ្វើកិច្ចការណាដែលមិនសំខាន់នោះដែរ។ នៅពេលដែលព្រះវិញ្ញាណធ្វើការដោយផ្ទាល់ ទ្រង់ធ្វើការដោយមានគោលដៅរបស់ទ្រង់ ហើយនៅពេលដែលទ្រង់ក្លាយជាមនុស្ស (អាចនិយាយបានថា នៅពេលដែលទ្រង់បំផ្លាស់បំប្រែសំបកក្រៅរបស់ទ្រង់) ដើម្បីធ្វើការ គឺទ្រង់កាន់តែធ្វើការពាក់ព័ន្ធនឹងគោលបំណងរបស់ទ្រង់។ តើហេតុអ្វីបានជាទ្រង់ត្រូវផ្លាស់ប្ដូរអត្តសញ្ញាណរបស់ទ្រង់យ៉ាងស្រួលដូច្នេះ? ហេតុអ្វីបានជាទ្រង់ត្រូវក្លាយជាមនុស្សដែលត្រូវបានគេចាត់ទុកជាអ្នកទន់ទាប និងជួបការបៀតបៀនយ៉ាងស្រួលបែបនេះ?

កិច្ចការរបស់ទ្រង់នៅក្នុងសាច់ឈាមមានសារៈសំខាន់បំផុត ហើយកិច្ចការនេះត្រូវបានថ្លែងឡើងពាក់ព័ន្ធនឹងកិច្ចការ ហើយព្រះមួយអង្គដែលនៅទីបញ្ចប់នឹងត្រូវបញ្ចប់កិច្ចការ គឺព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស មិនមែនជាព្រះវិញ្ញាណឡើយ។ អ្នកខ្លះជឿថា ព្រះជាម្ចាស់អាចយាងមកកាន់ផែនដី ហើយបង្ហាញអង្គទ្រង់ឲ្យមនុស្សឃើញនៅពេលមិនប្រាកដណាមួយ ហើយខណៈពេលនោះ ទ្រង់នឹងជំនុំជម្រះមនុស្សជាតិទាំងអស់ដោយផ្ទាល់ ដោយល្បងលពួកគេម្ដងម្នាក់ៗដោយគ្មាននរណាម្នាក់អាចរួចខ្លួនឡើយ។ អស់អ្នកដែលគិតបែបនេះ មិនដឹងអំពីដំណាក់កាលនៃកិច្ចការរបស់ព្រះជា ម្ចាស់ដែលយកកំណើតជាមនុស្សឡើយ។ ព្រះជាម្ចាស់មិនជំនុំជម្រះមនុស្សម្នាក់ម្ដងៗទេ ហើយទ្រង់ក៏មិនល្បងលមនុស្សម្នាក់ម្ដងៗនោះដែរ ព្រោះថាបើធ្វើបែបនេះ វានឹងមិនមែនជាកិច្ចការនៃការជំនុំជម្រះនោះឡើយ។ តើមិនមែនសេចក្ដីពុករលួយរបស់មនុស្សជាតិទាំងអស់សុទ្ធតែដូចគ្នាទេឬអី? តើមិនមែនសារជាតិរបស់មនុស្សទាំងអស់សុទ្ធតែដូចគ្នាទេឬអី? អ្វីដែលត្រូវជំនុំជម្រះ គឺជាសារជាតិដ៏ពុករលួយរបស់មនុស្សជាតិ ជាសារជាតិរបស់មនុស្សដែលត្រូវបានសាតាំងធ្វើឲ្យពុករលួយ ហើយនិងបាបទាំងអស់របស់មនុស្ស។ ព្រះជាម្ចាស់មិនជំនុំជម្រះកំហុសដ៏កំប៉ិកកំប៉ុក និងមិនសំខាន់របស់មនុស្សឡើយ។ កិច្ចការនៃការជំនុំជម្រះ គឺជាកិច្ចការតំណាង ហើយវាមិនត្រូវបាន

អនុវត្តជាពិសេសសម្រាប់មនុស្សជាក់លាក់ណាម្នាក់ឡើយ។ ផ្ទុយទៅវិញ វាជាកិច្ចការដែលមនុស្សមួយក្រុមត្រូវបានជំនុំជម្រះ ដើម្បីតំណាងឲ្យការជំនុំជម្រះរបស់មនុស្សជាតិទាំងអស់។ តាមរយៈការអនុវត្តកិច្ចការរបស់ទ្រង់ដោយផ្ទាល់ទៅលើមនុស្សមួយក្រុម ព្រះជាម្ចាស់នៅក្នុងសាច់ឈាមប្រើប្រាស់កិច្ចការរបស់ទ្រង់ ដើម្បីតំណាងឲ្យកិច្ចការរបស់មនុស្សជាតិទាំងអស់ ក្រោយពេលកិច្ចការនោះត្រូវបានផ្សព្វផ្សាយបន្តិចម្តងៗ។ នេះក៏ជារបៀបនៃកិច្ចការជំនុំជម្រះដែរ។ ព្រះជាម្ចាស់មិនជំនុំជម្រះមនុស្សមួយប្រភេទ ឬមនុស្សមួយក្រុមជាក់លាក់ឡើយ ប៉ុន្តែផ្ទុយទៅវិញ ទ្រង់ជំនុំជម្រះសេចក្តីទុច្ចរិតរបស់មនុស្សជាតិទាំងមូល ឧទាហរណ៍ដូចជា ការប្រឆាំងរបស់មនុស្សចំពោះព្រះជាម្ចាស់ ការមិនគោរពរបស់មនុស្សចំពោះទ្រង់ ឬការរំខានរបស់មនុស្សចំពោះកិច្ចការរបស់ព្រះជាម្ចាស់ជាដើម។ អ្វីដែលត្រូវជំនុំជម្រះ គឺជាសារជាតិនៃការប្រឆាំងរបស់មនុស្សជាតិចំពោះព្រះជាម្ចាស់ ហើយកិច្ចការនេះក៏ជាកិច្ចការនៃការយកឈ្នះនៅគ្រាចុងក្រោយដែរ។ កិច្ចការ និងព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សដែលមនុស្សបានឃើញផ្ទាល់ភ្នែក គឺជាកិច្ចការនៃការជំនុំជម្រះនៅមុខបល្ល័ង្កពណ៌សដ៏ធំក្នុងអំឡុងពេលនៃគ្រាចុងក្រោយដែលមនុស្សបានមើលឃើញកាលពីអតីតកាល។ កិច្ចការដែលកំពុងតែធ្វើក្នុងពេលបច្ចុប្បន្ន ដោយព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស និយាយឲ្យចំទៅ គឺជាការជំនុំជម្រះនៅមុខបល្ល័ង្កពណ៌សដ៏ធំនោះហើយ។ ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សនាពេលសព្វថ្ងៃ គឺជាព្រះជាម្ចាស់ដែលជំនុំជម្រះមនុស្សជាតិទាំងមូលក្នុងអំឡុងពេលនៃគ្រាចុងក្រោយ។ សាច់ឈាមនេះ និងកិច្ចការរបស់ទ្រង់ ព្រះបន្ទូលរបស់ទ្រង់ និងនិស្ស័យទាំងស្រុងរបស់ទ្រង់ គឺជាភាពទាំងស្រុងរបស់ទ្រង់។ ទោះបីវិសាលភាពនៃកិច្ចការរបស់ទ្រង់នៅមានកម្រិត ហើយទ្រង់មិនបានពាក់ព័ន្ធដោយផ្ទាល់ នឹងចក្រវាលទាំងមូលក៏ដោយ ក៏សារជាតិនៃកិច្ចការជំនុំជម្រះ គឺជាការជំនុំជម្រះដោយផ្ទាល់ ទៅលើមនុស្សជាតិទាំងអស់ គឺមិនមែនសម្រាប់ជាប្រយោជន៍ដល់ពួកជ្រើសតាំងនៃប្រទេសចិន ឬសម្រាប់ជាប្រយោជន៍ដល់មនុស្សមួយក្រុមតូចនោះឡើយ។ ក្នុងអំឡុងពេលនៃកិច្ចការរបស់

ព្រះជាម្ចាស់នៅក្នុងសាច់ឈាម ទោះបីវិសាលភាពនៃកិច្ចការនេះ មិនពាក់ព័ន្ធនឹងចក្រវាលទាំងមូលក៏ដោយ ក៏វាតំណាងឲ្យកិច្ចការនៃចក្រវាលទាំងមូលដែរ ហើយបន្ទាប់ពីទ្រង់បញ្ចប់កិច្ចការដែលស្ថិតក្នុងវិសាលភាពនៃកិច្ចការខាងសាច់ឈាមរបស់ទ្រង់រួច ភ្លាមៗនោះ ទ្រង់នឹងពង្រីកកិច្ចការនេះទៅកាន់ចក្រវាលទាំងមូល នៅក្នុងរបៀបដូចគ្នាដែលដំណឹងល្អរបស់ព្រះយេស៊ូវបានរីកសាយភាយនៅទូទាំងចក្រវាល ក្រោយពេលដែលទ្រង់មានព្រះជន្មរស់ឡើងវិញ និងយាងឡើងទៅស្ថានសួគ៌។ មិនថាជាកិច្ចការនៃព្រះវិញ្ញាណ ឬជាកិច្ចការនៃសាច់ឈាមនោះឡើយ វាគឺជាកិច្ចការមួយដែលត្រូវបានអនុវត្តនៅក្នុងវិសាលភាពមួយមានកម្រិត ប៉ុន្តែវាតំណាងឲ្យកិច្ចការនៃចក្រវាលទាំងមូល។ ក្នុងអំឡុងពេលនៃគ្រាចុងក្រោយ ព្រះជាម្ចាស់ធ្វើកិច្ចការរបស់ទ្រង់ ដោយបង្ហាញអង្គទ្រង់នៅក្នុងអត្តសញ្ញាណនៃព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស ហើយព្រះជាម្ចាស់នៅក្នុងសាច់ឈាម គឺជាព្រះជាម្ចាស់ដែលជំនុំជម្រះមនុស្សនៅមុខបល្ល័ង្កពណ៌សដ៏ធំ។ មិនថាទ្រង់ជាព្រះវិញ្ញាណ ឬជាសាច់ឈាមនោះឡើយ ព្រះអង្គដែលធ្វើកិច្ចការនៃការជំនុំជម្រះ គឺជាព្រះជាម្ចាស់ដែលជំនុំជម្រះមនុស្សជាតិក្នុងអំឡុងពេលនៃគ្រាចុងក្រោយ។ ការនេះត្រូវបានកំណត់ទុកដោយផ្អែកលើកិច្ចការរបស់ទ្រង់ ហើយវាមិនត្រូវបានកំណត់ទុកស្របតាមរូបរាងខាងក្រៅរបស់ទ្រង់ ឬកត្តាជាច្រើនផ្សេងទៀតនោះឡើយ។ ទោះបីជាមនុស្ស មានសញ្ញាណអំពីព្រះបន្ទូលទាំងនេះក៏ដោយ ក៏គ្មាននរណាម្នាក់អាចបដិសេធការពិតអំពីការជំនុំជម្រះ និងការយកឈ្នះលើមនុស្សជាតិទាំងអស់របស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សបានដែរ។ មិនថាមនុស្សគិតអំពីវាបែបណាឡើយ ការពិតគឺនៅតែជាការពិត។ គ្មាននរណាម្នាក់អាចនិយាយថា «កិច្ចការត្រូវបានធ្វើដោយព្រះជាម្ចាស់ ប៉ុន្តែសាច់ឈាមមិនមែនជាព្រះជាម្ចាស់» នោះឡើយ។ នេះជារឿងគ្មានន័យសោះឡើយ ព្រោះថាកិច្ចការនេះមិនអាចត្រូវបានធ្វើដោយនរណាផ្សេង ក្រៅពីព្រះជាម្ចាស់នៅក្នុងសាច់ឈាមឡើយ។ ដោយសារតែកិច្ចការនេះត្រូវបានបញ្ចប់រួចហើយ ដូច្នេះ កិច្ចការបន្ទាប់ទៀត គឺជាកិច្ចការជំនុំជម្រះរបស់ព្រះជាម្ចាស់ចំពោះមនុស្ស ដែលនឹងមិនលេចមកជាលើកទីពីរ

ឡើយ ព្រោះព្រះជាម្ចាស់នៅក្នុងការយកកំណើតជាមនុស្សលើកទីពីររបស់ទ្រង់បានបញ្ចប់កិច្ចការនៃការគ្រប់គ្រងទាំងអស់រួចហើយ ហើយវានឹងគ្មានដំណាក់កាលលើកទីបួននៃកិច្ចការរបស់ព្រះជាម្ចាស់នោះឡើយ។ ដោយសារតែអ្នកដែលត្រូវទទួលការជំនុំជម្រះ គឺជាមនុស្ស ពោលគឺជាមនុស្សដែលមកពីសាច់ឈាម និងត្រូវបានពុករលួយ ហើយមិនមែនវិញ្ញាណរបស់សាតាំងទេដែលត្រូវទទួលការជំនុំជម្រះដោយផ្ទាល់នោះ ដូច្នេះ កិច្ចការនៃការជំនុំជម្រះមិនត្រូវបានអនុវត្តនៅក្នុងពិភពខាងវិញ្ញាណឡើយ ប៉ុន្តែត្រូវបានធ្វើនៅក្នុងចំណោមមនុស្សវិញ។ គ្មាននរណាម្នាក់សក្ដិសម និងមានគុណសម្បត្តិគ្រប់គ្រាន់ជាងព្រះជាម្ចាស់នៅក្នុងសាច់ឈាមនោះទេ សម្រាប់កិច្ចការជំនុំជម្រះសេចក្ដីពុករលួយនៃសាច់ឈាមរបស់មនុស្ស។ ប្រសិនបើការជំនុំជម្រះត្រូវបានធ្វើដោយផ្ទាល់ ដោយព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ នោះវានឹងមិនគ្របដណ្ដប់មនុស្សទាំងអស់ឡើយ។ លើសពីនេះទៀត កិច្ចការបែបនេះនឹងពិបាកឲ្យមនុស្សទទួលយក ព្រោះព្រះវិញ្ញាណមិនអាចយាងមកនៅមុខទល់នឹងមុខជាមួយនឹងមនុស្សឡើយ។ ដោយសារតែហេតុផលនេះ វានឹងមិនទទួលបានលទ្ធផលមួយរំពេចឡើយ ហើយមនុស្សក៏មិនអាចមើលឃើញនិស្ស័យដែលមិនអាចប្រកែកបានរបស់ព្រះជាម្ចាស់កាន់តែច្បាស់នោះដែរ។ សាតាំងអាចចាញ់ទាំងស្រុងបាន លុះត្រាតែព្រះជាម្ចាស់នៅក្នុងសាច់ឈាម ធ្វើការជំនុំជម្រះសេចក្ដីពុករលួយរបស់មនុស្សជាតិ។ ដោយមានលក្ខណៈដូចមនុស្ស ដែលមានភាពជាមនុស្សសាមញ្ញ ព្រះជាម្ចាស់នៅក្នុងសាច់ឈាមអាចជំនុំជម្រះដោយផ្ទាល់លើសេចក្ដីទុច្ចរិតរបស់មនុស្ស។ នេះគឺជាសញ្ញាមួយអំពីភាពបរិសុទ្ធពីដើមរបស់ទ្រង់ និងអំពីភាពអស្ចារ្យរបស់ទ្រង់។ មានតែព្រះជាម្ចាស់មួយប៉ុណ្ណោះដែលមានគុណសម្បត្តិគ្រប់គ្រាន់ និងអាចកាន់មុខតំណែងជំនុំជម្រះមនុស្ស ព្រោះថាទ្រង់មានសេចក្ដីពិត និងសេចក្ដីសុចរិត ដូច្នេះ ទ្រង់អាចជំនុំជម្រះមនុស្សបាន។ អស់អ្នកដែលគ្មានសេចក្ដីពិត និងសេចក្ដីសុចរិត មិនសក្ដិសមក្នុងការជំនុំជម្រះអ្នកដទៃឡើយ។ បើសិនកិច្ចការនេះត្រូវបានធ្វើដោយព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ នោះវានឹងមិនមានន័យថា ជាជ័យជម្នះលើសាតាំងឡើយ។ ព្រះវិញ្ញាណត្រូវទទួល

បានការលើកតម្កើងខ្លាំង ជាងមនុស្សដែលរមែងនឹងស្លាប់ ហើយព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ជាព្រះដ៏បរិសុទ្ធ និងមានជ័យជម្នះលើសាច់ឈាម។ ប្រសិនបើព្រះវិញ្ញាណបានធ្វើកិច្ចការនេះដោយអង្គទ្រង់ផ្ទាល់ នោះទ្រង់នឹងមិនអាចជំនុំជម្រះការមិនស្ដាប់បង្គាប់របស់មនុស្សទាំងអស់បានឡើយ ហើយទ្រង់ក៏មិនអាចបើកសម្ដែងពីគ្រប់ទាំងអំពើទុច្ចរិតរបស់មនុស្សទាំងអស់បានដែរ។ សម្រាប់កិច្ចការនៃការជំនុំជម្រះ ក៏ត្រូវអនុវត្តតាមរយៈសញ្ញាណរបស់មនុស្សអំពីព្រះជាម្ចាស់ដែរ ហើយមនុស្សមិនដែលមានសញ្ញាណណាមួយអំពីព្រះវិញ្ញាណទេ ដូច្នេះ ព្រះវិញ្ញាណគ្មានសមត្ថភាពបើកសម្ដែងបានយ៉ាងប្រសើរអំពីសេចក្ដីទុច្ចរិតរបស់មនុស្ស ហើយក៏មិនអាចលាតត្រដាងទាំងស្រុងអំពីសេចក្ដីទុច្ចរិតនោះដែរ។ ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស គឺជាខ្មាំងសត្រូវរបស់អស់អ្នកដែលមិនស្គាល់ទ្រង់។ តាមរយៈការជំនុំជម្រះសញ្ញាណ និងការប្រឆាំងរបស់មនុស្សដែលមានចំពោះទ្រង់ នោះព្រះអង្គនឹងធ្វើការលាតត្រដាងរាល់ការមិនស្ដាប់បង្គាប់របស់មនុស្សជាតិទាំងអស់។ លទ្ធផលនៃកិច្ចការរបស់ទ្រង់នៅក្នុងសាច់ឈាម គឺស្ដែងចេញឲ្យឃើញច្បាស់ជាងលទ្ធផលនៃកិច្ចការរបស់ព្រះវិញ្ញាណទៅទៀត។ ដូច្នេះ ការជំនុំជម្រះមនុស្សជាតិទាំងអស់មិនត្រូវបានអនុវត្តដោយផ្ទាល់ដោយព្រះវិញ្ញាណឡើយ ប៉ុន្តែវាជាកិច្ចការរបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សវិញទេ។ ចំពោះព្រះជាម្ចាស់នៅក្នុងសាច់ឈាម មនុស្សអាចមើលឃើញ និងអាចប៉ះពាល់បាន ដូច្នេះ ព្រះជាម្ចាស់នៅក្នុងសាច់ឈាមអាចយកឈ្នះលើមនុស្សបានទាំងស្រុង។ នៅក្នុងទំនាក់ទំនងរបស់គេ ជាមួយព្រះជាម្ចាស់នៅក្នុងសាច់ឈាម មនុស្សវិវឌ្ឍពីការប្រឆាំងទៅជាការស្ដាប់បង្គាប់ វិវឌ្ឍពីការបៀតបៀនទៅជាការទទួលយក វិវឌ្ឍពីសញ្ញាណទៅជាចំណេះដឹង និងពីការបដិសេធទៅជាសេចក្ដីស្រឡាញ់ ហើយការទាំងអស់នេះគឺជាលទ្ធផលនៃកិច្ចការរបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស។ មនុស្សបានសង្គ្រោះតាមរយៈការទទួលយកការជំនុំជម្រះរបស់ទ្រង់ប៉ុណ្ណោះ មនុស្សចាប់ផ្ដើមស្គាល់ទ្រង់បន្តិចម្ដងៗតាមរយៈព្រះបន្ទូលដែលចេញពីព្រះឱស្ឋរបស់ទ្រង់ប៉ុណ្ណោះ មនុស្សត្រូវបានទ្រង់យកឈ្នះក្នុង អំឡុងពេលដែលគេប្រឆាំងនឹងទ្រង់

ហើយគេទទួលបានការផ្គត់ផ្គង់សម្រាប់ជីវិតពីទ្រង់ក្នុងអំឡុងពេលនៃការទទួលយកការវាយផ្ចាលរបស់ទ្រង់។ កិច្ចការទាំងអស់នេះ គឺជាកិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងសាច់ឈាម មិនមែនជាកិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងអត្តសញ្ញាណរបស់ទ្រង់ ដែលជាព្រះវិញ្ញាណនោះឡើយ។ កិច្ចការដែលត្រូវបានធ្វើដោយព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស គឺជាកិច្ចការដ៏ធំធេងបំផុត ដ៏ជ្រាលជ្រៅបំផុត ហើយផ្នែកដ៏សំខាន់មួយនៃដំណាក់កាលទាំងបីនៃកិច្ចការរបស់ព្រះជាម្ចាស់ គឺជាដំណាក់កាលទាំងពីរនៃកិច្ចការរបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស។ សេចក្ដីពុករលួយដ៏ជ្រាលជ្រៅរបស់មនុស្ស គឺជាឧបសគ្គដ៏ធំមួយចំពោះកិច្ចការរបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស។ ជាពិសេស កិច្ចការដែលត្រូវបានអនុវត្តទៅលើមនុស្សនៅគ្រាចុងក្រោយពិតជាសំខាន់ណាស់ ហើយបរិយាកាសពេញដោយការប្រឆាំង ឯគុណសម្បត្តិរបស់មនុស្សគ្រប់ប្រភេទវិញ គឺទន់ខ្សោយណាស់។ ប៉ុន្តែ នៅចុងបញ្ចប់នៃកិច្ចការនេះ វានឹងនៅតែសម្រេចបានលទ្ធផលដ៏ល្អ ដោយគ្មានកំហុសណាមួយឡើយ ដ្បិតនេះជាលទ្ធផលនៃកិច្ចការខាងសាច់ឈាម ហើយលទ្ធផលនេះគួរឲ្យជឿជាក់ ជាងលទ្ធផលចេញពីកិច្ចការរបស់ព្រះវិញ្ញាណទៅទៀត។ ដំណាក់កាលទាំងបីនៃកិច្ចការរបស់ព្រះជាម្ចាស់នឹងត្រូវបញ្ចប់នៅក្នុងសាច់ឈាម ហើយកិច្ចការទាំងនេះត្រូវតែបញ្ចប់ដោយព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស។ កិច្ចការដ៏សំខាន់បំផុតត្រូវបានធ្វើនៅក្នុងសាច់ឈាម ហើយសេចក្ដីសង្គ្រោះរបស់មនុស្ស ត្រូវបានអនុវត្តដោយផ្ទាល់ដោយព្រះជាម្ចាស់នៅក្នុងសាច់ឈាម។ ទោះបីមនុស្សជាតិទាំងអស់មានអារម្មណ៍ថា ព្រះជាម្ចាស់នៅក្នុងសាច់ឈាមហាក់ដូចជាគ្មានពាក់ព័ន្ធអ្វីជាមួយមនុស្សក៏ដោយ ក៏ការពិតសាច់ឈាមនេះខ្វល់ខ្វាយពីគោលដៅ និងអត្ថិភាពរបស់មនុស្សជាតិទាំងមូល។

គ្រប់ដំណាក់កាលនៃកិច្ចការរបស់ព្រះជាម្ចាស់ គឺត្រូវបានអនុវត្ត សម្រាប់ជាប្រយោជន៍ដល់មនុស្សជាតិទាំងអស់ និងផ្ដោតលើមនុស្សជាតិទាំងអស់តែម្ដង។ ថ្វីបើវាជាកិច្ចការរបស់ទ្រង់នៅក្នុងសាច់ឈាមក៏ដោយ ក៏វានៅតែផ្ដោតទៅលើមនុស្សជាតិទាំងអស់ដដែល។ ទ្រង់ជាព្រះជាម្ចាស់នៃមនុស្សជាតិទាំងអស់ ហើយទ្រង់ជាព្រះជា

ម្ចាស់នៃអ្វីគ្រប់យ៉ាងដែលត្រូវបានបង្កើតមក និងមិនបានបង្កើតមក។ ទោះបីកិច្ចការរបស់ទ្រង់នៅក្នុងសាច់ឈាម ស្ថិតនៅក្នុងវិសាលភាពមានកម្រិត ហើយកម្មវត្ថុនៃកិច្ចការនេះមានកម្រិតក៏ដោយ ក៏គ្រប់ពេលដែលទ្រង់ត្រលប់ជាសាច់ឈាម ដើម្បីធ្វើកិច្ចការនេះ ទ្រង់ជ្រើសរើសកម្មវត្ថុមួយនៃកិច្ចការរបស់ទ្រង់ដែលជាអ្នកតំណាងដ៏ខ្ពស់បំផុតដែរ។ ទ្រង់មិនជ្រើសរើសមនុស្សមួយក្រុមដែលសាមញ្ញ និងធម្មតា ដើម្បីធ្វើការឡើយ ប៉ុន្តែផ្ទុយទៅវិញ ទ្រង់ជ្រើសរើសមនុស្សមួយក្រុមដែលមានសមត្ថភាពជាកម្មវត្ថុនៃកិច្ចការរបស់ទ្រង់ ដើម្បីឲ្យគេក្លាយជាអ្នកតំណាងសម្រាប់កិច្ចការរបស់ទ្រង់នៅក្នុងសាច់ឈាម។ មនុស្សមួយក្រុមនេះ ត្រូវបានជ្រើសរើសដោយសារតែវិសាលភាពនៃកិច្ចការរបស់ទ្រង់នៅក្នុងសាច់ឈាមមានកម្រិត ហើយត្រូវបានរៀបចំជាពិសេសសម្រាប់សាច់ឈាមដែលយកកំណើតជាមនុស្សរបស់ទ្រង់ និងត្រូវបានជ្រើសរើសជាពិសេសសម្រាប់កិច្ចការរបស់ទ្រង់នៅក្នុងសាច់ឈាម។ ការជ្រើសរើសរបស់ព្រះជាម្ចាស់ទៅលើកម្មវត្ថុនៃកិច្ចការរបស់ទ្រង់ មិនមែនគ្មានមូលដ្ឋាននោះឡើយ ប៉ុន្តែត្រូវបានធ្វើឡើងស្របទៅតាមគោលការណ៍៖ កម្មវត្ថុនៃកិច្ចការត្រូវតែផ្ដល់ជាប្រយោជន៍ដល់កិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងសាច់ឈាម និងត្រូវតែអាចតំណាងឲ្យមនុស្សជាតិទាំងមូល។ ឧទាហរណ៍ សាសន៍យូដាអាចតំណាងឲ្យមនុស្សជាតិទាំងមូលនៅក្នុងការទទួលយកព្រះយេស៊ូវដែលជាព្រះប្រោសលោះ ហើយជនជាតិចិនអាចតំណាងឲ្យមនុស្សជាតិទាំងមូលក្នុងការទទួលយក ការយកឈ្នះផ្ទាល់ខ្លួនរបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស។ វាមាននូវមូលដ្ឋានមួយ សម្រាប់ការតំណាងរបស់សាសន៍យូដាចំពោះមនុស្សជាតិទាំងមូល ហើយវាក៏មានមូលដ្ឋានសម្រាប់ការតំណាងរបស់ប្រជាជនចិនចំពោះមនុស្សជាតិទាំងមូលនៅក្នុងការទទួលយកការយកឈ្នះផ្ទាល់ខ្លួនរបស់ព្រះជាម្ចាស់ដែរ។ គ្មានអ្វីមួយបើកសម្ដែងអំពីសារៈសំខាន់នៃការប្រោសលោះ ច្រើនជាងកិច្ចការនៃការប្រោសលោះដែលត្រូវបានធ្វើនៅក្នុងចំណោមសាសន៍យូដាឡើយ ហើយក៏គ្មានអ្វីមួយដែលបើកសម្ដែងអំពីភាពហ្មត់ចត់ និងភាពជោគជ័យនៃកិច្ចការយកឈ្នះ ច្រើនជាងកិច្ចការនៃការយកឈ្នះដែល

ត្រូវបានធ្វើឡើងនៅក្នុងចំណោមប្រជាជនចិននោះដែរ។ កិច្ចការ និងព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស លេចមកដោយផ្ដោតទៅលើតែមនុស្សមួយក្រុមតូចប៉ុណ្ណោះ ប៉ុន្តែជាការពិត កិច្ចការរបស់ទ្រង់នៅក្នុងចំណោមមនុស្សមួយក្រុមតូចនេះ គឺជាកិច្ចការនៃចក្រវាលទាំងមូល ហើយព្រះបន្ទូលរបស់ទ្រង់ត្រូវបានថ្លែងទៅកាន់មនុស្សជាតិទាំងមូល។ ក្រោយពេលដែល កិច្ចការរបស់ទ្រង់នៅក្នុងសាច់ឈាមត្រូវបានបញ្ចប់ អស់អ្នកដែលដើរតាមទ្រង់នឹងចាប់ផ្ដើមផ្សព្វផ្សាយអំពីកិច្ចការដែលទ្រង់បានធ្វើនៅក្នុងចំណោមពួកគេ។ រឿងដ៏ល្អបំផុតអំពីកិច្ចការរបស់ទ្រង់នៅក្នុងសាច់ឈាមគឺថា ទ្រង់អាចបន្សល់ទុកនូវព្រះបន្ទូល និងសេចក្ដីជាស់តឿនដ៏សុក្រឹត្យព្រមទាំងព្រះហឫទ័យដ៏ជាក់លាក់របស់ទ្រង់សម្រាប់មនុស្សជាតិសម្រាប់អស់អ្នកដែលដើរតាមទ្រង់ ដើម្បីឲ្យក្រោយមក អ្នកដើរតាមទ្រង់អាចផ្ទេរកាន់តែសុក្រឹត្យ និងកាន់តែច្បាស់លាស់អំពីគ្រប់កិច្ចការរបស់ទ្រង់នៅក្នុងសាច់ឈាមនិងព្រះហឫទ័យរបស់ទ្រង់សម្រាប់មនុស្សជាតិ ទៅកាន់អស់អ្នកដែលទទួលយក។ មានតែកិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងសាច់ឈាមក្នុងចំណោមមនុស្សប៉ុណ្ណោះ ដែលនាំទៅសម្រេចចេញជាការពិតនៃព្រះជន្ម និងការរស់នៅរបស់ព្រះជាម្ចាស់ជាមួយមនុស្ស។ មានតែកិច្ចការនេះប៉ុណ្ណោះ ទើបបំពេញបំណងប្រាថ្នារបស់មនុស្ស ដែលចង់ឃើញព្រះភ័ក្ត្ររបស់ព្រះជាម្ចាស់ ចង់ឃើញផ្ទាល់ភ្នែកនូវកិច្ចការរបស់ព្រះជាម្ចាស់ និងចង់ឮព្រះបន្ទូលរបស់ព្រះជាម្ចាស់ដោយផ្ទាល់។ ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សបញ្ចប់នូវយុគសម័យមួយ នៅពេលដែលព្រះយេហូវ៉ាបែរព្រះប្រឹស្ដាង្គ (ខ្នង) របស់ទ្រង់ទៅកាន់មនុស្សជាតិ ហើយទ្រង់ក៏បញ្ចប់យុគសម័យនៃជំនឿរបស់មនុស្សជាតិទៅលើព្រះដ៏ស្រពេចស្រពិលដែរ។ ជាពិសេស កិច្ចការចុងក្រោយរបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស គឺនាំមនុស្សជាតិទាំងអស់ ចូលទៅក្នុងយុគសម័យមួយដែលប្រាកដនិយមជាង ជាក់ស្ដែងជាង និងស្រស់ស្អាតជាង។ ទ្រង់មិនគ្រាន់តែបញ្ចប់យុគសម័យនៃក្រឹត្យវិន័យ និងគោលលទ្ធិប៉ុណ្ណោះទេ ប៉ុន្តែអ្វីដែលកាន់តែសំខាន់នោះគឺ ទ្រង់បើកសម្ដែងទៅកាន់មនុស្សជាតិអំពីព្រះជាម្ចាស់មួយអង្គដែលជា

ព្រះពិតនិងសាមញ្ញ ជាព្រះដែលសុចរិត និងបរិសុទ្ធ ជាព្រះដែលសម្រេចកិច្ចការនៃផែនការគ្រប់គ្រង និងជាព្រះដែលបង្ហាញពីសេចក្ដីលាក់កំបាំង និងគោលដៅរបស់មនុស្ស ជាព្រះដែលបានបង្កើតមនុស្សជាតិ និងបញ្ចប់កិច្ចការនៃការគ្រប់គ្រង និងជាព្រះដែលបានបន្តលាក់ព្រះភ័ក្ត្រអស់រយៈពេលជាច្រើនពាន់ឆ្នាំ។ ព្រះអង្គបញ្ចប់ទាំងស្រុង នូវយុគសម័យនៃភាពស្រពេចស្រពិល ដែលជាយុគសម័យមួយដែលមនុស្សជាតិទាំងអស់ចង់ស្វែងរកព្រះភ័ក្ត្ររបស់ព្រះជាម្ចាស់ ប៉ុន្តែមិនអាចមើលឃើញ ទ្រង់បញ្ចប់យុគសម័យមួយដែលមនុស្សជាតិទាំងអស់បានបម្រើសាតាំង ហើយទ្រង់ដឹកនាំមនុស្សជាតិទាំងអស់ចូលទៅក្នុងយុគសម័យមួយដែលថ្មីស្រឡាង។ កិច្ចការទាំងអស់នេះ គឺជាលទ្ធផលនៃកិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងសាច់ឈាម ដែលធ្វើការជំនួសឲ្យព្រះវិញ្ញាណរបស់ព្រះជាម្ចាស់។ នៅពេលដែលព្រះជាម្ចាស់ធ្វើការនៅក្នុងសាច់ឈាមរបស់ទ្រង់ អស់អ្នកដែលដើរតាមទ្រង់លែងស្វែងរក និងព្យាយាមស្រវាចាប់អ្វីៗដែលហាក់ដូចជាមាន និងមិនមាន ហើយពួកគេលែងស្មានព្រាវៗអំពីព្រះហឫទ័យរបស់ព្រះដ៏ស្រពេចស្រពិលទៀតហើយ។ នៅពេលដែលព្រះជាម្ចាស់ផ្សព្វផ្សាយកិច្ចការរបស់ទ្រង់នៅក្នុងសាច់ឈាម អស់អ្នកដែលដើរតាមទ្រង់នឹងផ្ទេរកិច្ចការដែលទ្រង់បានធ្វើនៅក្នុងសាច់ឈាមទៅកាន់គ្រប់សាសនា និងគ្រប់និកាយ ហើយពួកគេនឹងប្រាស្រ័យទាក់ទងគ្រប់ទាំងព្រះបន្ទូលរបស់ទ្រង់ ទៅកាន់ត្រចៀករបស់មនុស្សជាតិទាំងអស់។ អស់អ្នកដែលបានឮ ហើយទទួលយកដំណឹងល្អរបស់ទ្រង់ នឹងក្លាយជាការពិតនៃកិច្ចការរបស់ទ្រង់ នឹងក្លាយជាបុគ្គលដែលមនុស្សអាចមើលឃើញ និងស្ដាប់ឮ ព្រមទាំងក្លាយជាការពិត មិនមែនជាពាក្យ ចចាមអារ៉ាមឡើយ។ ការពិតទាំងនេះគឺជាភស្តុតាងដែលទ្រង់ផ្សព្វផ្សាយកិច្ចការ ហើយពួកគេក៏ជាឧបករណ៍ដែលទ្រង់ប្រើប្រាស់ ដើម្បីផ្សព្វផ្សាយអំពីកិច្ចការដែរ។ បើគ្មានអត្ថិភាពនៃការពិតទេ នោះដំណឹងល្អរបស់ទ្រង់នឹងមិនរីកសាយភាយទៅគ្រប់ប្រទេស និងទៅគ្រប់ទីកន្លែងឡើយ។ បើគ្មានការពិត ហើយមានតែការស្រមើស្រមៃរបស់មនុស្សនោះ ទ្រង់នឹងមិនអាចធ្វើកិច្ចការនៃការយកឈ្នះលើចក្រវាលទាំងមូលបានឡើយ។ មនុស្ស

មិនអាចយល់ និងមើលមិនឃើញព្រះវិញ្ញាណឡើយ ហើយកិច្ចការរបស់ព្រះវិញ្ញាណក៏គ្មានសមត្ថភាពបន្សល់ទុកនូវភស្តុតាង ឬការពិតបន្ថែមអំពីកិច្ចការរបស់ព្រះជាម្ចាស់សម្រាប់មនុស្សដែរ។ មនុស្សនឹងមិនអាចមើលឃើញព្រះភ័ក្ត្រដ៏ពិតរបស់ព្រះជាម្ចាស់ឡើយ ហើយគេនឹងតែងតែជឿលើព្រះដ៏ស្រពេចស្រពិលដែលគ្មានពិតប្រាកដនោះ។ មនុស្សនឹងមើលមិនឃើញព្រះភ័ក្ត្ររបស់ព្រះជាម្ចាស់ហើយក៏ស្ដាប់មិនឮព្រះបន្ទូលដែលព្រះជាម្ចាស់បានថ្លែងដោយផ្ទាល់ដែរ។ ទីបំផុត ការស្រមើស្រមៃរបស់មនុស្សគឺគ្មានន័យ ហើយមិនអាចជំនួសឲ្យព្រះភ័ក្ត្រដ៏ពិត របស់ព្រះជាម្ចាស់បានឡើយ។ និស្ស័យដើមរបស់ព្រះជាម្ចាស់ និងកិច្ចការរបស់ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ មិនអាចត្រូវបានបន្លំដោយមនុស្សបានទេ។ ព្រះជាម្ចាស់អរូបិយដែលគង់នៅស្ថានសួគ៌ និងកិច្ចការរបស់ទ្រង់ អាចត្រូវបាននាំមកកាន់ផែនដី បានតាមរយៈព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សដែលធ្វើកិច្ចការរបស់ទ្រង់ដោយផ្ទាល់នៅក្នុងចំណោមមនុស្ស។ នេះជាផ្លូវដ៏វិសេសបំផុតសម្រាប់ព្រះជាម្ចាស់ ដើម្បីបង្ហាញអង្គទ្រង់ឲ្យមនុស្សឃើញ គឺឲ្យគេអាចមើលឃើញព្រះជាម្ចាស់ និងស្គាល់ពីព្រះភ័ក្ត្រ ដ៏ពិតរបស់ព្រះជាម្ចាស់ ហើយកិច្ចការនេះមិនអាចត្រូវបានសម្រេចដោយព្រះជាម្ចាស់ដែលមិនយកកំណើតជាមនុស្សបានឡើយ។ ដោយបានអនុវត្តកិច្ចការរបស់ទ្រង់មកដល់ដំណាក់កាលនេះ កិច្ចការរបស់ព្រះជាម្ចាស់ បានសម្រេចលទ្ធផលខ្ពស់បំផុត ហើយបានទទួលជោគជ័យទាំងស្រុង។ កិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងសាច់ឈាម សម្រេចបានកៅសិបភាគរយ នៃកិច្ចការគ្រប់គ្រងទាំងស្រុងរបស់ទ្រង់។ សាច់ឈាមនេះបានផ្ដល់ជាទីចាប់ផ្ដើមដ៏ប្រសើរទៅកាន់កិច្ចការទាំងអស់របស់ទ្រង់ផ្ដល់ជាសេចក្ដីសង្ខេបសម្រាប់គ្រប់កិច្ចការរបស់ទ្រង់ និងបានប្រកាសឲ្យប្រើគ្រប់កិច្ចការរបស់ទ្រង់ ព្រមទាំងបានធ្វើការបំពេញបន្ថែមដ៏ហ្មត់ចត់ចុងក្រោយ ទៅកាន់គ្រប់កិច្ចការនេះ។ ដូច្នេះ នឹងគ្មានព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សមួយទៀត ដើម្បីធ្វើដំណាក់កាលទីបួននៃកិច្ចការរបស់ព្រះជាម្ចាស់ឡើយ ហើយក៏នឹងគ្មានកិច្ចការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សលើកទីបីនោះដែរ។

ដំណាក់កាលនីមួយៗនៃកិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងសាច់ឈាម តំណាងឲ្យកិច្ចការរបស់ទ្រង់នៅក្នុងយុគសម័យទាំងមូល ហើយវាមិនតំណាងឲ្យអំឡុងពេលជាក់លាក់ណាមួយ និងកិច្ចការរបស់មនុស្សឡើយ។ ដូច្នេះ ចុងបញ្ចប់នៃកិច្ចការយកកំណើតជាមនុស្សចុងក្រោយរបស់ទ្រង់ មិនមានន័យថា កិច្ចការរបស់ទ្រង់បានមកដល់ទីបញ្ចប់នោះទេ ព្រោះថាកិច្ចការរបស់ទ្រង់នៅក្នុងសាច់ឈាម តំណាងឲ្យយុគសម័យទាំងមូល ហើយមិនគ្រាន់តែតំណាងឲ្យ អំឡុងពេលមួយដែលទ្រង់ធ្វើកិច្ចការរបស់ទ្រង់នៅក្នុងសាច់ឈាមនោះឡើយ។ វាគ្រាន់តែទ្រង់បញ្ចប់កិច្ចការរបស់ទ្រង់នៅក្នុងយុគសម័យទាំងមូលក្នុងអំឡុងពេលដែលទ្រង់គង់នៅក្នុងសាច់ឈាមក្រោយពេលកិច្ចការនេះ ផ្សព្វផ្សាយទៅកាន់គ្រប់ទីកន្លែងប៉ុណ្ណោះ។ ក្រោយពេលព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សបំពេញព័ន្ធកិច្ចរបស់ទ្រង់រួចហើយ ទ្រង់នឹងផ្ទុកផ្ដាក់កិច្ចការអនាគតរបស់ទ្រង់ ទៅកាន់អស់អ្នកដែលដើរតាមទ្រង់។ ដោយធ្វើបែបនេះ កិច្ចការនៅយុគសម័យទាំងមូលរបស់ទ្រង់ នឹងត្រូវបន្តដោយគ្មានអាក់ខានឡើយ។ កិច្ចការនៅយុគសម័យទាំងមូល នៃការយកកំណើតជាមនុស្ស នឹងត្រូវបានចាត់ទុកថាបញ្ចប់ នៅពេលដែលកិច្ចការនេះ បានផ្សព្វផ្សាយទៅកាន់ចក្រវាលទាំងមូល។ កិច្ចការរបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស ចាប់ផ្ដើមនូវយុគសម័យថ្មី ហើយអស់អ្នកដែលបន្តកិច្ចការរបស់ទ្រង់ គឺជាមនុស្សដែលត្រូវបានទ្រង់ប្រើប្រាស់។ កិច្ចការដែលត្រូវបានធ្វើដោយមនុស្ស គឺជាកិច្ចការដែលស្ថិតនៅក្នុងព័ន្ធកិច្ចរបស់ព្រះជាម្ចាស់ក្នុងសាច់ឈាម ហើយកិច្ចការនេះគ្មានសមត្ថភាពទៅហួសវិសាលភាពនេះឡើយ។ ប្រសិនបើព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស មិនយាងមកធ្វើកិច្ចការរបស់ទ្រង់ទេ នោះមនុស្សនឹងមិនអាចចូលទៅក្នុងយុគសម័យថ្មីបានឡើយ។ កិច្ចការដែលត្រូវបានធ្វើដោយមនុស្ស គ្រាន់តែស្ថិតនៅក្នុងដែនភារកិច្ចរបស់គេ ដែលអាចធ្វើបានដោយមនុស្ស ហើយវាមិនតំណាងឲ្យកិច្ចការរបស់ព្រះជាម្ចាស់ឡើយ។ មានតែព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សប៉ុណ្ណោះ ដែលអាចយាងមកដើម្បីបញ្ចប់កិច្ចការដែលទ្រង់គួរតែធ្វើ ហើយក្រៅពីទ្រង់ នោះគ្មាន

នរណាម្នាក់អាចធ្វើកិច្ចការនេះជំនួសទ្រង់បានឡើយ។ ពិតមែនហើយ អ្វីដែលខ្ញុំមានបន្ទូលនេះគឺទាក់ទងនឹងកិច្ចការយកកំណើតជាមនុស្ស។ ជាដំបូង ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស អនុវត្តជំហានទីមួយនៃកិច្ចការដែលមិនស្របតាមសញ្ញាណរបស់មនុស្សឡើយ ក្រោយពេលទ្រង់ធ្វើកិច្ចការជាច្រើនដែលមិនស្របតាមសញ្ញាណរបស់មនុស្ស។ គោលបំណងនៃកិច្ចការ គឺជាការយកឈ្នះលើមនុស្ស។ នៅក្នុងន័យម្យ៉ាង ការយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់ មិនស្របតាមសញ្ញាណរបស់មនុស្ស ដោយបន្ថែមពីលើការដែលទ្រង់ធ្វើកិច្ចការជាច្រើន ដែលមិនស្របទៅតាមសញ្ញាណរបស់មនុស្ស ទើបធ្វើឲ្យមនុស្សមានទស្សនៈកាន់តែច្រើនអំពីទ្រង់។ ទ្រង់គ្រាន់តែធ្វើកិច្ចការនៃការយកឈ្នះនៅក្នុងចំណោមមនុស្ស ដែលមានសញ្ញាណដ៏ច្រើនអនេកអំពីទ្រង់។ ទោះបីពួកគេប្រព្រឹត្តចំពោះទ្រង់បែបណានៅពេលដែលទ្រង់បានបញ្ចប់ព័ន្ធកិច្ចរបស់ទ្រង់ នោះមនុស្សទាំងអស់ នឹងស្ថិតនៅក្រោមការត្រួតត្រារបស់ទ្រង់មិនខាន។ ការពិតគឺថា កិច្ចការនេះមិនគ្រាន់តែឆ្លុះបញ្ចាំងនៅក្នុងចំណោមប្រជាជនចិនប៉ុណ្ណោះទេ ប៉ុន្តែវាក៏តំណាងឲ្យរបៀបដែលមនុស្សជាតិទាំងមូលនឹងត្រូវបានយកឈ្នះដែរ។ លទ្ធផលដែលត្រូវសម្រេចបានលើមនុស្សទាំងនេះ គឺជាប្រផ្នូលមួយចំពោះលទ្ធផលដែលនឹងត្រូវសម្រេចបាននៅលើមនុស្សជាតិទាំងមូល ហើយលទ្ធផលនៃកិច្ចការដែលទ្រង់ធ្វើនៅក្នុងពេលអនាគត ក៏នឹងមានកម្រិតកាន់តែខ្ពស់ជាងលទ្ធផលទៅលើមនុស្សទាំងនេះដែរ។ កិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងសាច់ឈាមមិនរួមបញ្ចូលសំឡេងត្រែដ៏លាន់រំពង ហើយក៏គ្មានការបំពាក់កម្រងផ្កានៅក្នុងភាពមិនច្បាស់លាស់នោះដែរ។ វាជាកិច្ចការដ៏ពិត និងជាក់ស្ដែង ហើយវាជាកិច្ចការដែលមួយបូកមួយស្មើនឹងពីរ។ កិច្ចការនេះមិនត្រូវបានលាក់បាំងពីនរណាម្នាក់ឡើយ ហើយវាក៏មិនបោកបញ្ឆោតនរណាម្នាក់នោះដែរ។ អ្វីដែលមនុស្សមើលឃើញ គឺជារឿងពិត និងឥតក្លែងបន្លំ ហើយអ្វីដែលមនុស្សទទួលបាន គឺជាសេចក្ដីពិត និងចំណេះដឹងដ៏ពិត។ នៅពេលដែលកិច្ចការត្រូវបានបញ្ចប់ នោះមនុស្សនឹងមានចំណេះដឹងថ្មីអំពីទ្រង់ ហើយអស់អ្នកដែលដេញតាមយ៉ាងពិតប្រាកដ នឹងលែងមានសញ្ញាណអំពីទ្រង់តទៅទៀត។

នេះមិនគ្រាន់តែជាលទ្ធផលនៃកិច្ចការរបស់ទ្រង់ទៅលើជនជាតិចិននោះទេ ប៉ុន្តែវាក៏តំណាងឲ្យលទ្ធផលនៃកិច្ចការរបស់ទ្រង់នៅក្នុងការយកឈ្នះលើមនុស្សជាតិទាំងមូលដែរ ព្រោះថាគ្មានអ្វីមួយមានប្រយោជន៍ចំពោះកិច្ចការនៃការយកឈ្នះលើមនុស្សជាតិទាំងមូលខ្លាំងជាងសាច់ឈាមនេះ កិច្ចការនៃសាច់ឈាមនេះ និងអ្វីៗគ្រប់យ៉ាងនៃសាច់ឈាមនេះឡើយ។ ការទាំងនេះមានប្រយោជន៍ ចំពោះកិច្ចការរបស់ទ្រង់នៅថ្ងៃនេះ និងមានប្រយោជន៍ចំពោះកិច្ចការរបស់ទ្រង់នាពេលអនាគត។ សាច់ឈាមនេះនឹងយកឈ្នះមនុស្សជាតិទាំងមូល ព្រមទាំងទទួលបានមនុស្សជាតិទាំងមូល។ គ្មានកិច្ចការណាដែលប្រសើរជាងកិច្ចការនេះ ដើម្បីឲ្យមនុស្សជាតិទាំងមូលនឹងមើលឃើញព្រះជាម្ចាស់ ស្ដាប់បង្គាប់ព្រះជាម្ចាស់ និងស្គាល់ព្រះជាម្ចាស់នោះឡើយ។ កិច្ចការដែលត្រូវបានធ្វើដោយមនុស្ស គ្រាន់តែតំណាងឲ្យវិសាលភាពដែលមានកម្រិតមួយ ហើយនៅពេលដែលព្រះជាម្ចាស់ធ្វើកិច្ចការរបស់ទ្រង់ ព្រះអង្គមិនមានបន្ទូលទៅកាន់បុគ្គលជាក់លាក់ណាម្នាក់ឡើយ ប៉ុន្តែទ្រង់មានបន្ទូលទៅកាន់មនុស្សជាតិទាំងមូល និងអស់អ្នកដែលទទួលយកព្រះបន្ទូលរបស់ទ្រង់។ ចុងបញ្ចប់ ដែលទ្រង់ប្រកាសគឺជាចុងបញ្ចប់នៃមនុស្សជាតិទាំងអស់ មិនមែនគ្រាន់តែជាចុងបញ្ចប់នៃបុគ្គលម្នាក់ឡើយ។ ទ្រង់មិនប្រព្រឹត្តជាពិសេសទៅកាន់បុគ្គលណាម្នាក់ឡើយ ហើយក៏មិនធ្វើឲ្យនរណាម្នាក់ក្លាយជាជនរងគ្រោះនោះដែរ ប៉ុន្តែទ្រង់ធ្វើការ និងមានបន្ទូលទៅកាន់មនុស្សជាតិទាំងមូល។ ដូច្នេះ ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សនេះ បានធ្វើការចាត់ថ្នាក់មនុស្សជាតិទាំងមូលស្របទៅតាមប្រភេទរបស់គេរួចទៅហើយ ទ្រង់បានជំនុំជម្រះមនុស្សជាតិទាំងមូលរួចទៅហើយ ហើយទ្រង់បានរៀបចំគោលដៅដ៏សមរម្យមួយសម្រាប់មនុស្សជាតិទាំងមូលរួចទៅហើយ។ ទោះបីព្រះជាម្ចាស់ធ្វើតែកិច្ចការរបស់ទ្រង់នៅក្នុងប្រទេសចិនក៏ដោយ ប៉ុន្តែតាមពិតទៅ ទ្រង់បានសម្រេចកិច្ចការនៃចក្រវាលទាំងមូលរួចស្រេចទៅហើយ។ ទ្រង់មិនអាចរង់ចាំរហូតដល់កិច្ចការរបស់ទ្រង់បានផ្សព្វផ្សាយនៅក្នុងចំណោមមនុស្សជាតិ មុនពេលដែលទ្រង់ថ្លែងព្រះសូរសៀង និងធ្វើការរៀបចំមួយជំហានម្ដងៗនោះឡើយ។ បើធ្វើបែបនេះ តើវាមិនយឺតពេល

ពេកទេឬអី? ឥឡូវនេះ ទ្រង់អាចសម្រេចកិច្ចការនាពេលអនាគត បានទាំងស្រុងជាមុន។ ដោយសារតែព្រះជាម្ចាស់ដែលកំពុងតែធ្វើការ គឺជាព្រះជាម្ចាស់នៅក្នុងសាច់ឈាម ដូច្នេះ ទ្រង់កំពុងតែធ្វើកិច្ចការដ៏គ្មានដែនកំណត់ នៅក្នុងវិសាលភាពមួយដែលមានកម្រិត ហើយក្រោយមកទៀត ទ្រង់នឹងធ្វើឲ្យមនុស្សបំពេញភារកិច្ចដែលមនុស្សគួរតែធ្វើ។ នេះហើយជាគោលការណ៍នៃកិច្ចការរបស់ទ្រង់នោះ។ ទ្រង់អាចមានព្រះជន្មរស់នៅជាមួយមនុស្សក្នុងពេលមួយប៉ុណ្ណោះ ហើយទ្រង់មិនអាចរួមដំណើរជាមួយមនុស្ស រហូតដល់កិច្ចការនៃយុគសម័យទាំងមូលត្រូវបានបញ្ចប់នោះឡើយ។ ដោយសារតែទ្រង់ជាព្រះជាម្ចាស់ ទើបទ្រង់ទតឃើញជាមុនអំពីកិច្ចការនាពេលអនាគតរបស់ទ្រង់បែបនេះ។ ក្រោយមក ទ្រង់នឹងធ្វើការចាត់ថ្នាក់មនុស្សជាតិទាំងអស់ស្របតាមប្រភេទរបស់គេ ដោយព្រះបន្ទូលរបស់ទ្រង់ ហើយមនុស្សជាតិនឹងចូលទៅក្នុងកិច្ចការរបស់ទ្រង់មួយជំហានម្ដងៗ ស្របទៅតាមព្រះបន្ទូលរបស់ទ្រង់។ គ្មាននរណាម្នាក់នឹងរួចខ្លួនឡើយ ហើយមនុស្សទាំងអស់ត្រូវតែអនុវត្តស្របតាមការនេះ។ ដូច្នេះ នៅពេលអនាគត យុគសម័យនឹងត្រូវបានដឹកនាំដោយព្រះបន្ទូលរបស់ទ្រង់ មិនមែនដឹកនាំដោយព្រះវិញ្ញាណនោះឡើយ។

កិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងសាច់ឈាម ត្រូវតែធ្វើឡើងនៅក្នុងសាច់ឈាម។ បើវាត្រូវបានធ្វើដោយផ្ទាល់ ដោយព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ នោះវានឹងគ្មានបាន លទ្ធផលឡើយ។ ទោះបីវាត្រូវបានធ្វើដោយព្រះវិញ្ញាណក៏ដោយ ក៏កិច្ចការនោះនឹងគ្មានសារៈសំខាន់ធំដុំទេ ហើយនៅទីបំផុត វានឹងមិនគួរឲ្យជឿជាក់បានឡើយ។ សត្តនិករទាំងអស់ចង់ដឹងថា តើកិច្ចការរបស់ព្រះអាទិករមានសារៈសំខាន់ ឬអត់ កិច្ចការនោះតំណាងឲ្យអ្វី ហើយវាត្រូវបានធ្វើទៅជាប្រយោជន៍សម្រាប់អ្វី និងចង់ដឹងថាតើកិច្ចការរបស់ព្រះជាម្ចាស់ពេញដោយសិទ្ធិអំណាច និងព្រះប្រាជ្ញាញាណ និងជាកិច្ចការដែលមានតម្លៃ និងសារៈសំខាន់បំផុតឬអត់។ កិច្ចការដែលទ្រង់ធ្វើ ត្រូវបានធ្វើសម្រាប់ជាសេចក្ដីសង្គ្រោះរបស់មនុស្សជាតិទាំងមូល សម្រាប់ជាប្រយោជន៍នៃការយកលើឈ្នះសាតាំង និងសម្រាប់ជាការធ្វើបន្ទាល់អំពីអង្គទ្រង់នៅក្នុងចំណោមរបស់

សព្វសារពើ។ ដូច្នេះ កិច្ចការដែលទ្រង់ធ្វើ ប្រាកដជាមានសារៈសំខាន់ធំធេងណាស់។ សាច់ឈាមរបស់មនុស្ស ត្រូវបានសាតាំងធ្វើឲ្យពុករលួយ ហើយវាត្រូវបានខ្វាក់ និងខូចខាតយ៉ាងជ្រាលជ្រៅបំផុត។ ហេតុផលដ៏សំខាន់បំផុត ដែលព្រះជាម្ចាស់ធ្វើការដោយផ្ទាល់នៅក្នុងសាច់ឈាម គឺដោយសារតែកម្មវត្ថុនៃសេចក្ដីសង្គ្រោះរបស់ទ្រង់ គឺជាមនុស្សដែលមកពីសាច់ឈាម និងដោយសារតែសាតាំងប្រើប្រាស់សាច់ឈាមរបស់មនុស្ស ដើម្បីបង្អាក់ដល់កិច្ចការរបស់ព្រះជាម្ចាស់។ សមរភូមិជាមួយសាតាំងតាមពិតទៅ ជាកិច្ចការនៃការយកឈ្នះលើមនុស្ស ហើយស្របពេលជាមួយគ្នានោះ មនុស្សក៏ជាកម្មវត្ថុនៃសេចក្ដីសង្គ្រោះរបស់ព្រះជាម្ចាស់ដែរ។ ដោយឃើញបែបនេះ កិច្ចការរបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស ពិតជាសំខាន់ខ្លាំងណាស់។ សាតាំងបានធ្វើឲ្យសាច់ឈាមរបស់មនុស្សពុករលួយ ហើយមនុស្សបានក្លាយជាតំណាងរបស់សាតាំង និងបានក្លាយជាកម្មវត្ថុមួយដែលព្រះជាម្ចាស់ត្រូវយកឈ្នះ។ នៅក្នុងន័យនេះ គឺកិច្ចការនៃការប្រយុទ្ធជាមួយសាតាំង និងការសង្គ្រោះមនុស្សជាតិត្រូវតែកើតឡើងនៅលើផែនដី ហើយព្រះជាម្ចាស់ត្រូវតែក្លាយជាមនុស្ស ដើម្បីប្រយុទ្ធជាមួយសាតាំង។ នេះជាកិច្ចការនៃភាពជាក់ស្ដែងបំផុត។ នៅពេលដែលព្រះជាម្ចាស់កំពុងតែធ្វើការនៅក្នុងសាច់ឈាម តាមពិតទៅ ទ្រង់កំពុងតែប្រយុទ្ធជាមួយសាតាំងនៅក្នុងសាច់ឈាម។ នៅពេលដែលទ្រង់ធ្វើការនៅក្នុងសាច់ឈាម ទ្រង់កំពុងតែធ្វើការរបស់ទ្រង់នៅក្នុងពិភពខាងវិញ្ញាណ ហើយទ្រង់ធ្វើឲ្យកិច្ចការទាំងអស់របស់ទ្រង់នៅក្នុងពិភពខាងវិញ្ញាណ ក្លាយជាការពិតនៅលើផែនដី។ បុគ្គលដែលទ្រង់ត្រូវយកឈ្នះ គឺជាមនុស្ស ជាមនុស្សដែលមិនស្ដាប់បង្គាប់ទ្រង់ ហើយម្នាក់ដែលត្រូវយកឈ្នះ គឺជាអ្នកតំណាងរបស់សាតាំង (ពិតណាស់ នេះក៏ជាមនុស្សដែរ) ដែលជាពួកទទឹងនឹងទ្រង់ហើយអ្នកដែលត្រូវទទួលសេចក្ដីសង្គ្រោះនៅទីបំផុត ក៏ជាមនុស្សដែរ។ នៅក្នុងន័យនេះ វាកាន់តែចាំបាច់សម្រាប់ព្រះជាម្ចាស់ ដើម្បីក្លាយជាមនុស្សដែលមានសំបកក្រៅជាសត្តនិករម្នាក់ ដើម្បីឲ្យទ្រង់អាចចូលសមរភូមិពិតប្រយុទ្ធទាស់នឹងសាតាំងដើម្បីយកឈ្នះលើមនុស្ស ដែលមិនស្ដាប់បង្គាប់ទ្រង់ និងមានសំបកខាងក្រៅ

ដូចជាទ្រង់ និងដើម្បីសង្គ្រោះមនុស្ស ដែលមានសំបកក្រៅដូចទ្រង់ ហើយត្រូវបានបំផ្លាញដោយសាតាំង។ ខ្មាំងសត្រូវរបស់ទ្រង់ គឺជាមនុស្ស កម្មវត្ថុនៃការយកឈ្នះរបស់ទ្រង់គឺជាមនុស្ស ហើយកម្មវត្ថុនៃសេចក្ដីសង្គ្រោះរបស់ទ្រង់ ក៏ជាមនុស្សដែលត្រូវបានបង្កើតឡើងដោយទ្រង់ដែរ។ ដូច្នេះ ទ្រង់ត្រូវតែក្លាយជាមនុស្ស ហើយតាមរបៀបនេះ កិច្ចការរបស់ទ្រង់កាន់តែងាយស្រួលខ្លាំង។ ទ្រង់អាចបង្ក្រាបសាតាំង និងយកឈ្នះលើមនុស្សជាតិ ហើយលើសពីនេះ ទ្រង់អាចសង្គ្រោះមនុស្សជាតិ។ ទោះបីសាច់ឈាមនេះមានភាពសាមញ្ញ និងពិតក៏ដោយ ក៏ទ្រង់មិនមែនជាសាច់ឈាមដែលសាមញ្ញនោះដែរ៖ ទ្រង់មិនមែនជាសាច់ឈាមមួយដែលគ្រាន់តែជាមនុស្សនោះឡើយ ប៉ុន្តែទ្រង់ក៏ជាសាច់ឈាមមួយដែលមានលក្ខណៈជាមនុស្សផង និងជាព្រះជាម្ចាស់ផងដែរ។ នេះជាភាពខុសគ្នារវាងទ្រង់និងមនុស្ស ហើយវាក៏ជាសញ្ញាសម្គាល់អំពីអត្តសញ្ញាណរបស់ព្រះជាម្ចាស់ដែរ។ មានតែសាច់ឈាមបែបនេះទេ ទើបអាចធ្វើកិច្ចការដែលទ្រង់ចង់ធ្វើ និងបំពេញព័ន្ធកិច្ចរបស់ព្រះជាម្ចាស់នៅក្នុងសាច់ឈាម ហើយសម្រេចកិច្ចការរបស់ទ្រង់នៅក្នុងចំណោមមនុស្សបានយ៉ាងពេញលេញ។ បើមិនដូច្នេះទេ កិច្ចការរបស់ទ្រង់នៅក្នុងចំណោមមនុស្សនឹងតែងតែគ្មានន័យ ហើយមានកំហុសជានិច្ច។ ទោះបីព្រះជាម្ចាស់អាចប្រយុទ្ធជាមួយវិញ្ញាណរបស់សាតាំង ហើយមានជ័យជម្នះក៏ដោយ ក៏ធម្មជាតិដើមរបស់មនុស្សដ៏ពុករលួយមិនត្រូវបានដោះស្រាយ ហើយអស់អ្នកដែលមិនស្ដាប់បង្គាប់ព្រះជាម្ចាស់ និងប្រឆាំងទ្រង់មិនអាចក្លាយជាចំណុះនៅក្រោមការត្រួតត្រារបស់ទ្រង់យ៉ាងពិតប្រាកដឡើយ គឺអាចនិយាយបានថា ទ្រង់មិនដែលយកឈ្នះលើមនុស្សជាតិ ហើយមិនដែលទទួលបានមនុស្សជាតិទាំងមូលឡើយ។ បើកិច្ចការរបស់ទ្រង់នៅលើផែនដីមិនត្រូវបានសម្រេចទេ នោះការគ្រប់គ្រងរបស់ទ្រង់នឹងមិនដែលត្រូវបានបញ្ចប់ ហើយមនុស្សជាតិទាំងមូល នឹងមិនអាចចូលសម្រាកបានឡើយ។ ប្រសិនបើព្រះជាម្ចាស់មិនអាចចូលសម្រាកជាមួយសត្តនិករទាំងអស់របស់ទ្រង់ទេ នោះកិច្ចការគ្រប់គ្រងរបស់ទ្រង់នឹងគ្មានលទ្ធផលឡើយ ដូច្នេះសិរីល្អរបស់ព្រះជាម្ចាស់នឹងរលាយបាត់មិនខាន។ ទោះបីសាច់ឈាមរបស់ទ្រង់គ្មានសិទ្ធិអំណាចក៏ដោយ ក៏

កិច្ចការដែលទ្រង់ធ្វើ នឹងទទួលបានលទ្ធផលមិនខាន។ នេះគឺជាគោលដៅដែលចៀសមិនផុតនៃកិច្ចការរបស់ទ្រង់។ ទោះបីសាច់ឈាមរបស់ទ្រង់មានសិទ្ធិអំណាច ឬក៏អត់ ដរាបណាទ្រង់មានសមត្ថភាពធ្វើកិច្ចការរបស់ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ នោះទ្រង់ជាព្រះជាម្ចាស់ ផ្ទាល់ព្រះអង្គហើយ។ ទោះបីសាច់ឈាមនេះមានលក្ខណៈសាមញ្ញ និងធម្មតាបែបណាក៏ដោយ ក៏ទ្រង់អាចធ្វើកិច្ចការដែលទ្រង់គួរតែធ្វើដែរ ព្រោះសាច់ឈាមនេះគឺជាព្រះជាម្ចាស់ និងមិនគ្រាន់តែជាមនុស្សឡើយ។ ហេតុផលដែលសាច់ឈាមនេះអាចធ្វើកិច្ចការដែលមនុស្សមិនអាចធ្វើបានគឺដោយសារតែសារជាតិខាងក្នុងរបស់ទ្រង់ ខុសពីសារជាតិរបស់មនុស្ស ហើយហេតុផលដែលទ្រង់អាចសង្គ្រោះមនុស្សបាន គឺដោយសារតែអត្តសញ្ញាណរបស់ទ្រង់មានលក្ខណៈខុសប្លែកពីអត្តសញ្ញាណរបស់មនុស្ស។ សាច់ឈាមនេះសំខាន់ខ្លាំងណាស់ចំពោះមនុស្សជាតិ ដោយសារតែទ្រង់ជាមនុស្ស ហើយលើសពីនេះទៀត គឺទ្រង់ជាព្រះជាម្ចាស់ ដោយសារតែទ្រង់អាចធ្វើកិច្ចការដែលគ្មានមនុស្សខាងសាច់ឈាមសាមញ្ញណាមួយអាចធ្វើបានឡើយ និងដោយសារតែទ្រង់អាចសង្គ្រោះមនុស្សដ៏ពុករលួយ ដែលរស់នៅជាមួយទ្រង់នៅលើផែនដី។ ទោះបីទ្រង់មានលក្ខណៈដូចមនុស្សក៏ដោយ ក៏ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សមានសារៈសំខាន់ចំពោះមនុស្សជាតិជាងបុគ្គលដ៏មានតម្លៃណាទៅទៀត ព្រោះថាទ្រង់អាចធ្វើកិច្ចការដែលព្រះវិញ្ញាណរបស់ព្រះជាម្ចាស់មិនអាចធ្វើបាន ទ្រង់អាចធ្វើបន្ទាល់អំពីព្រះជាម្ចាស់ផ្ទាល់ព្រះអង្គច្រើនជាងព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ ហើយទ្រង់អាចទទួលបានមនុស្សជាតិទាំងស្រុង ច្រើនជាងព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ទៅទៀត។ ជាលទ្ធផល ទោះបីសាច់ឈាមនេះមានលក្ខណៈសាមញ្ញ និងធម្មតាក៏ដោយ ក៏ការចូលរួមចំណែករបស់ទ្រង់ចំពោះមនុស្សជាតិ និងសារៈសំខាន់របស់ទ្រង់ចំពោះជីវិតរបស់មនុស្សជាតិធ្វើឲ្យទ្រង់មានតម្លៃយ៉ាងខ្លាំងដែរ ហើយតម្លៃ និងសារៈសំខាន់ពិតរបស់សាច់ឈាមនេះ គ្មានមនុស្សណាម្នាក់អាចវាស់វែងបានឡើយ។ ទោះបីសាច់ឈាមនេះមិនអាចបំផ្លាញសាតាំងបានដោយផ្ទាល់ក៏ដោយ ក៏ទ្រង់អាចប្រើប្រាស់កិច្ចការរបស់ទ្រង់ ដើម្បីយកឈ្នះលើមនុស្សជាតិ និងបង្ក្រាប

សាតាំង ព្រមទាំងធ្វើឲ្យសាតាំងចុះចូលទាំងស្រុងចំពោះការត្រួតត្រា របស់ទ្រង់ដែរ។ គឺដោយសារតែ ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សនេះហើយ ទើបទ្រង់អាចបង្ក្រាបសាតាំង និងអាចសង្គ្រោះមនុស្សជាតិបាន។ ទ្រង់មិនបំផ្លាញសាតាំង ដោយផ្ទាល់ឡើយ ប៉ុន្តែផ្ទុយទៅវិញ ទ្រង់ត្រលប់ជាសាច់ឈាមដើម្បីធ្វើកិច្ចការដែលយកឈ្នះលើមនុស្សជាតិ ដែលត្រូវបានសាតាំងធ្វើឲ្យពុករលួយ។ តាមរបៀបនេះ ទ្រង់អាចធ្វើបន្ទាល់កាន់តែប្រសើរអំពីអង្គទ្រង់នៅក្នុងចំណោមសត្តនិកររបស់ទ្រង់ ហើយទ្រង់អាចសង្គ្រោះមនុស្សដ៏ពុករលួយបានកាន់តែប្រសើរ។ ការដែលព្រះជាម្ចាស់យកកំណើតជាមនុស្សបង្ក្រាបសាតាំងធ្វើបន្ទាល់កាន់តែធំ និងកាន់តែគួរឲ្យជឿជាក់ខ្លាំងជាងការដែលព្រះវិញ្ញាណរបស់ព្រះជាម្ចាស់បំផ្លាញសាតាំងដោយផ្ទាល់ទៅទៀត។ ព្រះជាម្ចាស់នៅក្នុងសាច់ឈាមអាចជួយឲ្យមនុស្សស្គាល់ព្រះអាទិករកាន់តែប្រសើរ និងអាចធ្វើបន្ទាល់កាន់តែប្រសើរអំពីអង្គទ្រង់នៅក្នុងចំណោមសត្តនិកររបស់ទ្រង់។

## សារជាតិនៃសាច់ឈាមដែលព្រះជាម្ចាស់គង់សណ្ឋិត

នៅក្នុងការយកកំណើតជាមនុស្សលើកដំបូង ព្រះជាម្ចាស់បានរស់នៅលើផែនដីអស់រយៈពេលសាមសិបបីឆ្នាំកន្លះ ហើយក្នុងពេលប៉ុន្មានឆ្នាំនោះ ទ្រង់បានធ្វើព័ន្ធកិច្ចរបស់ទ្រង់តែបីឆ្នាំកន្លះប៉ុណ្ណោះ។ ទាំងក្នុងពេល និងមុនពេលដែលទ្រង់ចាប់ផ្ដើមកិច្ចការរបស់ទ្រង់ ទ្រង់មានភាពជាមនុស្សសាមញ្ញ ទ្រង់បានគង់សណ្ឋិតក្នុងភាពជាមនុស្សសាមញ្ញរបស់ទ្រង់ អស់រយៈពេលសាមសិបបីឆ្នាំកន្លះ។ នៅក្នុងរយៈពេលបីឆ្នាំកន្លះចុងក្រោយ ទ្រង់បានបើកសម្ដែងអង្គទ្រង់ ជាព្រះដែលយកកំណើតជាមនុស្ស។ មុនពេលទ្រង់ចាប់ផ្ដើមធ្វើព័ន្ធកិច្ច ទ្រង់បានបង្ហាញអង្គទ្រង់ជាមួយភាពជាមនុស្សសាមញ្ញធម្មតា ដោយមិនបានធ្វើទីសម្គាល់នៃភាពជាព្រះរបស់ទ្រង់ឡើយ គឺមានតែក្រោយពេលដែលទ្រង់ចាប់ផ្ដើមធ្វើព័ន្ធកិច្ចរបស់ទ្រង់ជាផ្លូវការប៉ុណ្ណោះ ទើបភាពជាព្រះរបស់ទ្រង់ ត្រូវបានបង្ហាញចេញមក។ ព្រះជន្ម និងកិច្ចការរបស់ទ្រង់

នៅក្នុងអំឡុងពេលម្ភៃប្រាំបួនឆ្នាំដំបូងនោះបានបង្ហាញថា ទ្រង់ជាមនុស្សសុទ្ធសាធ ជាកូនមនុស្ស និងជារូបកាយខាងសាច់ឈាម ព្រោះថា ព័ន្ធកិច្ចរបស់ទ្រង់បានចាប់ផ្ដើមឡើងដល់កម្រិតខ្លាំងបំផុត ក្រោយពេលទ្រង់ មានព្រះជន្មម្ភៃប្រាំបួនឆ្នាំនេះហើយ។ «ការយកកំណើតជាមនុស្ស» គឺជាការលេចមករបស់ព្រះជាម្ចាស់នៅក្នុងសាច់ឈាម ហើយព្រះជាម្ចាស់ធ្វើការនៅក្នុងចំណោមមនុស្សជាតិ នៅក្នុងរូបអង្គជាសាច់ឈាម។ ដូច្នេះ ដើម្បីឲ្យព្រះជាម្ចាស់យកកំណើតជាមនុស្សបាន ជាដំបូង ទ្រង់ត្រូវតែក្លាយជាសាច់ឈាម ជាសាច់ឈាមដែលមានភាពជាមនុស្សសាមញ្ញ ដ្បិតនេះគឺជាលក្ខខណ្ឌតម្រូវទុកជាមុនដ៏ចាំបាច់បំផុត។ តាមពិតទៅ ការយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់ចង់មានន័យថា ព្រះជាម្ចាស់មានព្រះជន្មគង់នៅ និងធ្វើការនៅក្នុងសាច់ឈាម ហើយមានន័យថា ព្រះជាម្ចាស់ត្រលប់ជាសាច់ឈាម គឺត្រលប់ជាមនុស្សនៅក្នុងសារជាតិដើមរបស់ទ្រង់។ ព្រះជន្ម និងកិច្ចការនៃការយកកំណើតជាមនុស្សរបស់ទ្រង់ អាចត្រូវបានបែងចែកជាពីរដំណាក់កាល។ ដំណាក់កាលទីមួយ គឺជាព្រះជន្មដែលទ្រង់រស់នៅ មុនពេលទ្រង់ធ្វើព័ន្ធកិច្ចរបស់ទ្រង់។ ទ្រង់រស់នៅក្នុងគ្រួសារសាមញ្ញមួយ នៅក្នុងភាពជាមនុស្សសាមញ្ញបំផុត គោរពតាមសីលធម៌និងវិន័យសាមញ្ញនៃការរស់នៅក្នុងជីវិតជាមនុស្ស ហើយទ្រង់ក៏មានតម្រូវការជាមនុស្ស (អាហារ សម្លៀកបំពាក់ ការគេង ជម្រក) មានចំណុចខ្សោយ និងអារម្មណ៍ជាមនុស្សសាមញ្ញផងដែរ។ នៅក្នុងន័យម្យ៉ាងទៀត ក្នុងអំឡុងនៃដំណាក់កាលដំបូងនេះទ្រង់រស់នៅក្នុងភាពមិនមែនជាព្រះ គឺរស់នៅក្នុងភាពជាមនុស្សសាមញ្ញទាំងស្រុងដោយចូលរួមនៅក្នុងគ្រប់សកម្មភាពជាមនុស្សសាមញ្ញតែម្ដង។ ដំណាក់កាលទីពីរ គឺជាព្រះជន្មដែលទ្រង់រស់នៅ បន្ទាប់ពីការចាប់ផ្ដើមធ្វើព័ន្ធកិច្ចរបស់ទ្រង់។ ទ្រង់នៅតែគង់សណ្ឋិតនៅក្នុងភាពជាមនុស្សសាមញ្ញ ជាមួយសំបកកាយជាមនុស្សសាមញ្ញដោយមិនបង្ហាញសញ្ញាខាងក្រៅអំពីកិច្ចការអធិធម្មជាតិឡើយ។ ប៉ុន្ដែ ទ្រង់រស់នៅសម្រាប់ជាប្រយោជន៍ដល់ព័ន្ធកិច្ចរបស់ទ្រង់សុទ្ធសាធ ហើយក្នុងអំឡុងពេលនេះ ភាពជាមនុស្សសាមញ្ញរបស់ទ្រង់ នៅមានទាំងស្រុង ដើម្បីទ្រទ្រង់ដល់កិច្ចការសាមញ្ញនៃភាពជាព្រះរបស់

ទ្រង់ ដ្បិតនៅពេលនោះ ភាពជាមនុស្សសាមញ្ញរបស់ទ្រង់បានចម្រើនពេញវ័យ ដល់កម្រិតមួយដែលអាចធ្វើព័ន្ធកិច្ចរបស់ទ្រង់បាន។ ដូច្នេះ ដំណាក់កាលទីពីរនៃព្រះជន្មរបស់ទ្រង់ គឺដើម្បីធ្វើព័ន្ធកិច្ចរបស់ទ្រង់នៅក្នុងភាពជាមនុស្សសាមញ្ញរបស់ទ្រង់ ជាពេលដែលជីវិតមួយមានទាំងភាពជាមនុស្សសាមញ្ញផង និងភាពជាព្រះទាំងស្រុងផង។ ក្នុងអំឡុងដំណាក់កាលទីមួយនៃព្រះជន្មរបស់ទ្រង់ ហេតុផលដែលនាំឲ្យទ្រង់រស់នៅ ក្នុងភាពជាមនុស្សសាមញ្ញទាំងស្រុង គឺដោយសារតែភាពជាមនុស្សរបស់ទ្រង់មិនទាន់អាចទ្រទ្រង់កិច្ចការរបស់ព្រះបានទាំងស្រុង ព្រោះភាពជាមនុស្សនេះមិនទាន់ចាស់ចិត្តគំនិតនៅឡើយ ទាល់តែក្រោយពេល ដែលភាពជាមនុស្សរបស់ទ្រង់ចាស់ចិត្តគំនិត មានសមត្ថភាពរ៉ាប់រងព័ន្ធកិច្ចរបស់ទ្រង់ ទើបទ្រង់អាចអាចចាប់ផ្ដើមធ្វើព័ន្ធកិច្ចដែលទ្រង់គួរតែធ្វើ។ ដោយសារតែទ្រង់ត្រូវការលូតលាស់ និងចាស់ចិត្តគំនិត ក្នុងនាមជាសាច់ឈាម ដូច្នេះ ដំណាក់កាលដំបូងនៃព្រះជន្មទ្រង់ គឺត្រូវតែជាព្រះជន្មនៃភាពជាមនុស្សសាមញ្ញ ខណៈដែលនៅក្នុងដំណាក់កាលទីពីរ ដោយសារតែភាពជាមនុស្សរបស់ទ្រង់ មានសមត្ថភាពអាចធ្វើកិច្ចការ និងធ្វើព័ន្ធកិច្ចរបស់ទ្រង់បាន ដូច្នេះ ព្រះជន្មនៃព្រះដែលយកកំណើតជាមនុស្សគង់នៅ ក្នុងពេលកំពុងធ្វើព័ន្ធកិច្ចរបស់ទ្រង់ គឺជាព្រះជន្មមួយដែលមានទាំងភាពជាមនុស្សផង និងភាពជាព្រះទាំងស្រុងផង។ ប្រសិនបើព្រះដែលយកកំណើតជាមនុស្ស បានចាប់ផ្ដើមព័ន្ធកិច្ចរបស់ទ្រង់ក្នុងកម្រិតខ្ពស់ ដោយធ្វើទីសម្គាល់អស្ចារ្យនិងឫទ្ធិបារមី ចាប់តាំងពីពេលដែលទ្រង់ប្រសូតមក នោះទ្រង់នឹងគ្មានសារជាតិជារូបកាយសាច់ឈាមឡើយ។ ដូច្នេះ ភាពជាមនុស្សរបស់ទ្រង់កើតមានឡើងសម្រាប់ជាប្រយោជន៍ដល់សារជាតិជារូបកាយសាច់ឈាមរបស់ទ្រង់ ដ្បិតភាពជាមនុស្ស មិនអាចគ្មានសាច់ឈាមនោះឡើយ ហើយមនុស្សម្នាក់ដែលគ្មានភាពជាមនុស្ស ក៏មិនមែនជាមនុស្សដែរ។ នៅក្នុងន័យដូចគ្នានេះ ភាពជាមនុស្សខាងសាច់ឈាមរបស់ព្រះជាម្ចាស់ គឺជាទ្រព្យសម្បត្តិពីដើម នៃសាច់ឈាមជាមនុស្សរបស់ព្រះជាម្ចាស់។ ការនិយាយថា «នៅពេលដែលព្រះជាម្ចាស់ត្រលប់ជាសាច់ឈាម នោះទ្រង់ជាព្រះទាំងស្រុង ហើយមិនមែន

ជាមនុស្សសោះ» គឺជាការប្រមាថដល់ព្រះហើយ ដ្បិតសម្ដីមួយឃ្លានេះ មិនអាចកើតឡើងបានឡើយ ហើយវាក៏បំពានដល់គោលការណ៍ នៃការយកកំណើតជាមនុស្សផងដែរ។ សូម្បីតែ ក្រោយពេលទ្រង់ចាប់ផ្តើមធ្វើព័ន្ធកិច្ចរបស់ទ្រង់ក៏ដោយ ក៏ទ្រង់នៅតែរស់នៅក្នុងភាពជាព្រះរបស់ទ្រង់ ជាមួយសំបកកាយខាងក្រៅជាមនុស្សដដែល នៅពេលដែលទ្រង់ធ្វើកិច្ចការរបស់ទ្រង់។ គ្រាន់តែថា នៅពេលនោះ ភាពជាមនុស្សរបស់ទ្រង់បំពេញគោលបំណងនៃការអនុញ្ញាតឲ្យភាពជាព្រះរបស់ទ្រង់ធ្វើការនៅក្នុងសាច់ឈាមសាមញ្ញតែម៉្យាងគត់។ ដូច្នេះ ភ្នាក់ងារនៃកិច្ចការ គឺភាពជាព្រះដែលកំពុងតែគង់សណ្ឋិតនៅក្នុងភាពជាមនុស្សរបស់ទ្រង់។ ភាពជាព្រះរបស់ទ្រង់វិញទេដែលកំពុងធ្វើការ មិនមែនភាពជាមនុស្សរបស់ទ្រង់ឡើយ ប៉ុន្តែគ្រាន់តែភាពជាព្រះនេះ ត្រូវបានលាក់កំបាំងនៅខាងក្នុងភាពជាមនុស្សរបស់ទ្រង់ប៉ុណ្ណោះ និយាយឲ្យខ្លី កិច្ចការរបស់ទ្រង់ត្រូវបានធ្វើឡើងដោយភាពជាព្រះរបស់ទ្រង់ទាំងស្រុង មិនមែនដោយភាពជាមនុស្សរបស់ទ្រង់ឡើយ។ ដោយឡែក អ្នកប្រតិបត្តិកិច្ចការ គឺជាសាច់ឈាមរបស់ទ្រង់។ គេអាចនិយាយថា ទ្រង់ជាមនុស្សផង និងជាព្រះជាម្ចាស់ផង ដ្បិតព្រះជាម្ចាស់ក្លាយជាព្រះដែលកំពុងរស់នៅក្នុងសាច់ឈាម ជាមួយសំបកកាយជាមនុស្ស និងសារជាតិជាមនុស្ស តែក៏មានសារជាតិជាព្រះផងដែរ។ ដោយសារតែទ្រង់ជាមនុស្ស ដែលមានសារជាតិជាព្រះជាម្ចាស់ នោះទ្រង់ខ្ពង់ខ្ពស់ជាងមនុស្សលោកទាំងអស់ ខ្ពស់ជាងមនុស្សទាំងឡាយណាដែលអាចធ្វើកិច្ចការរបស់ព្រះជាម្ចាស់បាន។ ដូច្នេះហើយ នៅក្នុងចំណោមមនុស្សទាំងអស់ដែលមានសំបកកាយជាមនុស្សដូចទ្រង់ ក្នុងចំណោមមនុស្សទាំងអស់ ដែលមានភាពជាមនុស្ស គឺមានតែទ្រង់ម្នាក់ប៉ុណ្ណោះ ទើបជាព្រះជាម្ចាស់ផ្ទាល់ដែលយកកំណើតជាមនុស្ស ហើយអ្នកឯទៀតទាំងអស់ នោះគ្រាន់តែជាមនុស្សលោកប៉ុណ្ណោះ។ ទោះបីពួកគេទាំងអស់គ្នាមានភាពជាមនុស្សក៏ដោយ ក៏មនុស្សលោកគ្មានអ្វីក្រៅពីភាពជាមនុស្សនោះឡើយ ខណៈឯព្រះដែលយកកំណើតជាមនុស្សវិញ ទ្រង់មានលក្ខណៈខុសពីគេ៖ ព្រះអង្គមិនគ្រាន់តែមានភាពជាមនុស្ស នៅក្នុងសាច់ឈាមរបស់ទ្រង់ប៉ុណ្ណោះទេ ប៉ុន្តែអ្វីដែលសំខាន់ជាង

នេះទៅទៀត ទ្រង់ក៏មានភាពជាព្រះផងដែរ។ ភាពជាមនុស្សរបស់ទ្រង់អាចត្រូវបានមើលឃើញនៅក្នុងរូបរាងខាងក្រៅនៃសាច់ឈាមរបស់ទ្រង់ និងនៅក្នុងជីវិតប្រចាំថ្ងៃរបស់ទ្រង់ ប៉ុន្តែភាពជាព្រះរបស់ទ្រង់ គឺពិបាកនឹងយល់ណាស់។ ដោយសារតែភាពជាព្រះរបស់ទ្រង់ ត្រូវបានស្តែងចេញតែនៅពេលដែលទ្រង់មានភាពជាមនុស្ស ហើយក៏មិនមានលក្ខណៈអធិធម្មជាតិ ដូចអ្វីដែលមនុស្សស្រមៃដែរ ដូច្នេះ វាមានការពិបាកខ្លាំងណាស់ សម្រាប់ឲ្យមនុស្សមើលឃើញ។ សូម្បីតែសព្វថ្ងៃ មនុស្សមានភាពលំបាកក្នុងការយល់អំពីសារជាតិដ៏ពិតរបស់ព្រះដែលយកកំណើតជាមនុស្សខ្លាំងបំផុត។ ទោះបីក្រោយពេលខ្ញុំបាននិយាយអំពីរឿងនេះយូរបន្តិចហើយក៏ដោយ ក៏ខ្ញុំរំពឹងថា រឿងនេះនៅតែជារឿងអាថ៌កំបាំងចំពោះអ្នករាល់គ្នាភាគច្រើនដដែល។ តាមពិតទៅ រឿងនេះងាយយល់ណាស់៖ ដោយសារតែព្រះជាម្ចាស់ក្លាយជាសាច់ឈាម ដូច្នេះ សារជាតិរបស់ទ្រង់ គឺជាបន្សំនៃភាពជាមនុស្ស និងភាពជាព្រះ។ បន្សំនេះត្រូវបានហៅថាជាព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ ជាព្រះជាម្ចាស់ផ្ទាល់ដែលគង់នៅលើផែនដី។

ព្រះជន្មដែលព្រះយេស៊ូវបានរស់នៅលើផែនដី គឺជាព្រះជន្មដ៏សាមញ្ញនៃសាច់ឈាម។ ទ្រង់បានរស់នៅក្នុងភាពជាមនុស្សសាមញ្ញនៃសាច់ឈាមរបស់ទ្រង់។ សិទ្ធិអំណាចរបស់ទ្រង់ សម្រាប់ការធ្វើកិច្ចការរបស់ទ្រង់ និងថ្លែងព្រះបន្ទូលរបស់ទ្រង់ ឬប្រោសអ្នកជំងឺឲ្យជា និងបណ្ដេញអារក្ស ធ្វើកិច្ចការអស្ចារ្យទាំងនេះ ភាគច្រើនគឺមិនបានស្ដែងចេញឡើយ រហូតដល់ទ្រង់ចាប់ផ្ដើមព័ន្ធកិច្ចរបស់ទ្រង់។ ព្រះជន្មរបស់ទ្រង់មុនគម្រប់ព្រះជន្មម្ភៃប្រាំបួនឆ្នាំ មុនពេលទ្រង់បានធ្វើព័ន្ធកិច្ចរបស់ទ្រង់ គឺជាភស្តុតាងគ្រប់គ្រាន់ដែលបញ្ជាក់ថា ទ្រង់គ្រាន់តែជារូបកាយខាងសាច់ឈាមសាមញ្ញប៉ុណ្ណោះ។ ដោយសារហេតុផលនេះ និងដោយសារតែទ្រង់មិនទាន់បានចាប់ផ្ដើមធ្វើព័ន្ធកិច្ចរបស់ទ្រង់ នោះមនុស្សមិនបានឃើញភាពជាព្រះអ្វីសោះនៅក្នុងទ្រង់ មើលមិនឃើញអ្វីផ្សេងលើសពីភាពជាមនុស្សធម្មតាម្នាក់ គឺជាមនុស្សសាមញ្ញម្នាក់ឡើយ ដ្បិតនៅពេលនោះ មនុស្សខ្លះបានជឿថា ទ្រង់ជាកូនប្រុសរបស់យ៉ូសែបតែប៉ុណ្ណោះ។ មនុស្សបានគិតថា ទ្រង់ជាកូនប្រុសរបស់មនុស្សសាមញ្ញម្នាក់ ពួកគេគ្មានវិធីប្រាប់ថា

ទ្រង់ជាព្រះដែលយកកំណើតជាមនុស្សឡើយ ហើយសូម្បីក្នុងពេលដែលព្រះអង្គបានធ្វើការអស្ចារ្យជាច្រើន គឺក្នុងពេលដែលព្រះអង្គកំពុងធ្វើព័ន្ធកិច្ចរបស់ទ្រង់ ក៏មនុស្សភាគច្រើននៅតែនិយាយថា ទ្រង់ជាកូនប្រុសរបស់យ៉ូសែបដែរ ដ្បិតទ្រង់ជាព្រះគ្រីស្ទដែលមានសំបកកាយខាងក្រៅនៃភាពជាមនុស្សសាមញ្ញ។ ភាពជាមនុស្សសាមញ្ញរបស់ទ្រង់ និងកិច្ចការរបស់ទ្រង់បានកើតឡើង ដើម្បីបំពេញសារៈសំខាន់នៃការយកកំណើតជាមនុស្សលើកទីមួយ ដើម្បីបញ្ជាក់ថា ព្រះជាម្ចាស់បានយាងមកសណ្ឋិតក្នុងសាច់ឈាមទាំងស្រុង និងបញ្ជាក់ថា ទ្រង់បានក្លាយជាមនុស្សសាមញ្ញទាំងស្រុង។ ភាពជាមនុស្សសាមញ្ញរបស់ទ្រង់ មុនពេលទ្រង់បានធ្វើកិច្ចការរបស់ទ្រង់ គឺជាភស្តុតាងបញ្ជាក់ថា ទ្រង់ជាសាច់ឈាមសាមញ្ញម្នាក់ ហើយការដែលទ្រង់បានធ្វើការនាពេលក្រោយមកទៀត ក៏បញ្ជាក់ថា ទ្រង់ជាសាច់ឈាមសាមញ្ញម្នាក់ផងដែរ ដ្បិតទ្រង់បានធ្វើទីសម្គាល់និងឫទ្ធិបារមី ប្រោសអ្នកជំងឺឲ្យជា និងបណ្ដេញអារក្សនៅក្នុងសាច់ឈាមដោយប្រើភាពជាមនុស្សសាមញ្ញ។ ហេតុផលដែលទ្រង់អាចធ្វើការអស្ចារ្យបាន គឺដោយសារតែសាច់ឈាមរបស់ទ្រង់មានសិទ្ធិអំណាចរបស់ព្រះជាម្ចាស់ ជាសាច់ឈាមដែលគង់សណ្ឋិតដោយព្រះវិញ្ញាណបរិសុទ្ធ។ ទ្រង់មានសិទ្ធិអំណាចនេះ ដោយសារតែព្រះវិញ្ញាណនៃព្រះ ហើយនេះមិនមែនមានន័យថា ទ្រង់មិនមែនជាសាច់ឈាមនោះឡើយ។ ការប្រោសអ្នកជំងឺឲ្យជា និងការបណ្ដេញអារក្ស គឺជាកិច្ចការដែលទ្រង់ត្រូវធ្វើនៅក្នុងព័ន្ធកិច្ចរបស់ទ្រង់ វាជាការស្ដែងចេញនូវភាពជាព្រះរបស់ទ្រង់ ដែលលាក់ទុកនៅក្នុងភាពជាមនុស្សរបស់ទ្រង់ ហើយមិនថា ទ្រង់បានបង្ហាញទីសម្គាល់អ្វី ឬបានសម្ដែងសិទ្ធិអំណាចរបស់ទ្រង់ដោយរបៀបណានោះឡើយ ក៏ទ្រង់នៅតែរស់នៅក្នុងភាពជាមនុស្សសាមញ្ញ និងនៅតែជាសាច់ឈាមសាមញ្ញម្នាក់ដដែល។ ទ្រង់បានគង់សណ្ឋិតនៅក្នុងសាច់ឈាមសាមញ្ញ រហូតដល់ពេលដែលទ្រង់បានមានព្រះជន្មរស់ឡើងវិញ បន្ទាប់ពីការសុគតនៅលើឈើឆ្កាង។ ការប្រទានព្រះគុណ ការប្រោសអ្នកជំងឺឲ្យជា និងការបណ្ដេញអារក្ស សុទ្ធតែជាផ្នែកមួយនៃព័ន្ធកិច្ចរបស់ទ្រង់ ហើយទាំងអស់នេះគឺជាកិច្ចការដែលទ្រង់បានធ្វើនៅក្នុងសាច់ឈាមសាមញ្ញរបស់ទ្រង់។ មុនពេល

ទ្រង់បានយាងទៅឈើឆ្កាង ទ្រង់មិនដែលចាកចេញពីសាច់ឈាមជាមនុស្សសាមញ្ញរបស់ទ្រង់ឡើយ មិនថាទ្រង់កំពុងតែធ្វើអ្វីនោះឡើយ។ ទ្រង់ជាព្រះជាម្ចាស់ផ្ទាល់ ដែលកំពុងតែធ្វើកិច្ចការរបស់ព្រះជាម្ចាស់ផ្ទាល់ ប៉ុន្តែដោយសារតែទ្រង់ជាព្រះដែលយកកំណើតជាមនុស្ស នោះទើបទ្រង់ទទួលទានអាហារ និងស្លៀកពាក់ខោអាវ មានតម្រូវការជាមនុស្សសាមញ្ញ មានការត្រិះរិះពិចារណាជាមនុស្សសាមញ្ញ និងមានគំនិតជាមនុស្សសាមញ្ញ។ ទាំងអស់នេះគឺជាភស្តុតាងបញ្ជាក់ថា ទ្រង់ជាមនុស្សសាមញ្ញម្នាក់ ហើយវាក៏បញ្ជាក់ដែរថា ព្រះដែលយកកំណើតជាមនុស្ស គឺជាសាច់ឈាមមួយដែលមានភាពជាមនុស្សសាមញ្ញ មិនមែនជាភាពអធិធម្មជាតិនោះឡើយ។ កិច្ចការរបស់ទ្រង់ គឺដើម្បីបញ្ចប់កិច្ចការនៃការយកកំណើតជាមនុស្សលើកទីមួយរបស់ព្រះជាម្ចាស់ ជាការសម្រេចព័ន្ធកិច្ចនៃព្រះដែលយកកំណើតជាមនុស្សជាលើកទីមួយគួរតែធ្វើ។ សារៈសំខាន់នៃការយកកំណើតជាមនុស្សគឺថា មនុស្សសាមញ្ញធម្មតាម្នាក់ធ្វើកិច្ចការរបស់ព្រះជាម្ចាស់ផ្ទាល់ ហើយការដែលព្រះជាម្ចាស់ធ្វើកិច្ចការនៃព្រះរបស់ទ្រង់នៅក្នុងភាពជាមនុស្សនោះ គឺដើម្បីផ្ចាញ់សាតាំង។ ការយកកំណើតជាមនុស្សមានន័យថា ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ត្រលប់ជាសាច់ឈាម ពោលគឺ ព្រះជាម្ចាស់ដែលត្រលប់ជាសាច់ឈាម និងកិច្ចការដែលសាច់ឈាមនោះធ្វើ គឺជាកិច្ចការនៃព្រះវិញ្ញាណ ដែលត្រូវសម្រេចជារូបរាងនៅក្នុងសាច់ឈាម និងស្ដែងចេញតាមរយៈសាច់ឈាម។ ក្រៅពីសាច់ឈាមរបស់ព្រះជាម្ចាស់ គ្មាននរណាម្នាក់អាចបំពេញព័ន្ធកិច្ចរបស់ព្រះដែលយកកំណើតជាមនុស្សបានឡើយ។ ពោលគឺ មានតែសាច់ឈាមជាមនុស្សរបស់ព្រះជាម្ចាស់ គឺភាពជាមនុស្សសាមញ្ញនេះប៉ុណ្ណោះទេ ទើបអាចធ្វើកិច្ចការរបស់ព្រះជាម្ចាស់បាន គ្មាននរណាផ្សេងអាចធ្វើបានឡើយ។ ក្នុងអំឡុងពេលនៃការយាងមកជាលើកដំបូងរបស់ទ្រង់ ប្រសិនបើព្រះជាម្ចាស់មិនមានភាពជាមនុស្សសាមញ្ញ មុនពេលទ្រង់មានព្រះជន្មម្ភៃប្រាំបួនឆ្នាំទេ ប្រសិនបើពេលដែលទ្រង់ប្រសូតមកភ្លាម ទ្រង់អាចធ្វើការអស្ចារ្យភ្លាម ប្រសិនបើពេលទ្រង់រៀននិយាយភ្លាម ទ្រង់អាចនិយាយភាសាស្ថានសួគ៌បានភ្លាម ប្រសិនបើពេលដែលទ្រង់ដាក់ព្រះបាទាជាលើកដំបូង នៅលើ

ផែនដីភ្លាម ស្រាប់តែទ្រង់អាចយល់គ្រប់ទាំងរឿងខាងលោកីយ៍ យល់គ្រប់ទាំងគំនិត និងចេតនារបស់មនុស្ស នោះមនុស្សបែបនេះ គឺមិនអាចនឹងត្រូវបានហៅថាជាមនុស្សសាមញ្ញម្នាក់បានឡើយ ហើយសាច់ឈាមបែបនេះក៏មិនអាចត្រូវបានហៅថាជាសាច់ឈាមជាមនុស្សនោះដែរ។ ប្រសិនបើព្រះគ្រីស្ទស្ថិតនៅក្នុងករណីបែបនេះ នោះអត្ថន័យ និងសារជាតិនៃការយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់នឹងត្រូវបាត់បង់មិនខាន។ ការដែលទ្រង់មានភាពជាមនុស្សសាមញ្ញបញ្ជាក់ថា ទ្រង់ជាព្រះជាម្ចាស់ដែលយកកំណើតនៅក្នុងសាច់ឈាម ហើយការពិតដែលទ្រង់ត្រូវឆ្លងកាត់ដំណើរការលូតលាស់ជាមនុស្សសាមញ្ញ ក៏កាន់តែបង្ហាញថា ទ្រង់ជាសាច់ឈាមធម្មតាម្នាក់ផងដែរ។ លើសពីនេះទៅទៀត កិច្ចការរបស់ទ្រង់ក៏ជាភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ទ្រង់ជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ជាព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ ដែលក្លាយជាសាច់ឈាម។ ព្រះជាម្ចាស់ក្លាយជាសាច់ឈាម ដោយសារតែតម្រូវការនៃកិច្ចការរបស់ទ្រង់។ នៅក្នុងន័យម្យ៉ាងទៀត ដំណាក់កាលនៃកិច្ចការនេះត្រូវតែសម្រេចនៅក្នុងសាច់ឈាម វាត្រូវតែធ្វើការនៅក្នុងភាពជាមនុស្សសាមញ្ញ។ នេះគឺជាលក្ខខណ្ឌតម្រូវមួយសម្រាប់ «ព្រះបន្ទូលក្លាយជាសាច់ឈាម» សម្រាប់ «ការលេចចេញរបស់ព្រះបន្ទូលនៅក្នុងសាច់ឈាម» ហើយវាជាសាច់រឿងពិតមួយ នៅពីក្រោយការយកកំណើតជាមនុស្សទាំងពីររបស់ព្រះជាម្ចាស់។ មនុស្សអាចជឿថា ព្រះយេស៊ូវបានធ្វើការអស្ចារ្យពេញមួយជីវិតរបស់ទ្រង់ ជឿថា ទ្រង់មិនបានបង្ហាញសញ្ញានៃភាពជាមនុស្សឡើយ រហូតដល់កិច្ចការរបស់ទ្រង់នៅលើផែនដីត្រូវបានបញ្ចប់ និងជឿទៀតថា ទ្រង់មិនមានតម្រូវការ សេចក្ដីកម្សោយ ឬអារម្មណ៍ជាមនុស្សសាមញ្ញ ហើយទ្រង់ក៏មិនត្រូវការតម្រូវការចាំបាច់សម្រាប់ជីវិត ឬមានគំនិតជាមនុស្សសាមញ្ញឡើយ។ ពួកគេគិតស្រមៃថា ទ្រង់មានគំនិតអធិធម្មជាតិ និងមានភាពជាមនុស្សដ៏មហស្ចារ្យ។ ពួកគេជឿថា ដោយសារតែទ្រង់ជាព្រះជាម្ចាស់ ដូច្នេះ ទ្រង់មិនគួរគិត និងរស់នៅដូចជាមនុស្សសាមញ្ញឡើយ ហើយជឿថា មានតែមនុស្សសាមញ្ញ គឺជាមនុស្សសាមញ្ញសុទ្ធសាធប៉ុណ្ណោះ ទើបអាចគិតដូចមនុស្សធម្មតា និងរស់នៅជីវិតជាមនុស្សធម្មតាបាន។

ទាំងអស់នេះគឺជាគំនិត និងសញ្ញាណរបស់មនុស្ស ហើយសញ្ញាណទាំងនេះប្រឆាំងនឹងព្រះហឫទ័យដើមដំបូងនៃកិច្ចការរបស់ព្រះជាម្ចាស់។ ការគិតបែបមនុស្សសាមញ្ញជួយទ្រទ្រង់ដល់ការត្រិះរិះពិចារណាជាមនុស្សសាមញ្ញ និងភាពជាមនុស្សសាមញ្ញ។ ភាពជាមនុស្សសាមញ្ញជួយទ្រទ្រង់ ដល់មុខងារសាមញ្ញនៃសាច់ឈាម ហើយមុខងារសាមញ្ញនៃសាច់ឈាម ជួយឲ្យមានជីវិតសាមញ្ញខាងសាច់ឈាមទាំងមូលផងបាន។ មានតែតាមរយៈ ការធ្វើការនៅក្នុងសាច់ឈាមបែបនេះទេ ទើបព្រះជាម្ចាស់អាចសម្រេចគោលបំណងនៃការយកកំណើតជាមនុស្សរបស់ទ្រង់បាន។ ប្រសិនបើព្រះដែលយកកំណើតជាមនុស្សមានតែសំបកក្រៅជាសាច់ឈាម ប៉ុន្តែមិនគិតដូចជាមនុស្សសាមញ្ញ ដូច្នេះ សាច់ឈាមនេះនឹងមិនមានការត្រិះរិះពិចារណាជាមនុស្សឡើយ ក៏រឹតតែគ្មាននូវភាពជាមនុស្សសុទ្ធសាធនោះដែរ។ តើសាច់ឈាមដែលគ្មានភាពជាមនុស្សបែបនេះ អាចសម្រេចព័ន្ធកិច្ចដែលព្រះយក កំណើតជាមនុស្សគួរតែធ្វើបានយ៉ាងដូចម្ដេច? គំនិតសាមញ្ញជួយទ្រទ្រង់ដល់គ្រប់ផ្នែកនៃជីវិតរបស់មនុស្ស ហើយបើគ្មានគំនិតសាមញ្ញទេ នោះគេនឹងមិនមែនជាមនុស្សឡើយ។ នៅក្នុងន័យម្យ៉ាងទៀត មនុស្សម្នាក់ដែលមិនគិតបែបសាមញ្ញ គឺជាអ្នកមានជំងឺផ្លូវចិត្ត ហើយព្រះគ្រីស្ទដែលគ្មានភាពជាមនុស្ស ប៉ុន្តែមានតែភាពជាព្រះ ក៏មិនអាចហៅថាជាព្រះដែលយកកំណើតជាមនុស្សនោះដែរ។ ដូច្នេះ តើសាច់ឈាមជាមនុស្សរបស់ព្រះជាម្ចាស់ អាចគ្មានភាពជាមនុស្សសាមញ្ញបានដោយរបៀបណាទៅ? តើការនិយាយថា ព្រះគ្រីស្ទគ្មានភាពជាមនុស្ស មិនមែនជាការប្រមាថព្រះទេឬអី? គ្រប់សកម្មភាពដែលមនុស្សសាមញ្ញធ្វើ ត្រូវពឹងអាងលើមុខងារនៃការគិត របស់មនុស្ស សាមញ្ញ។ បើគ្មានវាទេ នោះមនុស្សនឹងប្រព្រឹត្តបែបចម្លែកៗមិនខាន។ ពួកគេនឹងថែមទាំងមិនអាចបែងចែកពីភាពខុសគ្នារវាងខ្មៅ និងស ល្អ និងអាក្រក់ទៀតផង ហើយពួកគេនឹងគ្មានក្រមសីលធម៌ជាមនុស្ស និងគោលការណ៍ខាងសីលធម៌នោះឡើយ។ ដូចគ្នាផងដែរ ប្រសិនបើព្រះដែលយកកំណើតជាមនុស្ស មិនគិតដូចជាមនុស្សសាមញ្ញ នោះទ្រង់នឹងមិនមែនជាសាច់ឈាមដ៏ពិត ជាមនុស្សសាមញ្ញឡើយ។ សាច់ឈាមដែលគ្មានការគិតបែបនេះ នឹងមិន

អាចទទួលនូវកិច្ចការរបស់ព្រះបានឡើយ។ ទ្រង់នឹងមិនអាចធ្វើសកម្មភាពរបស់សាច់ឈាមសាមញ្ញ ហើយរឹតតែមិនអាចរស់នៅរួមគ្នាជាមួយមនុស្សលោកនៅលើផែនដីនេះបានដែរ។ ដូច្នេះ សារៈសំខាន់នៃការយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់ ដែលជាសារជាតិដើមនៃការយាងមករបស់ព្រះជាម្ចាស់ចូលក្នុងសាច់ឈាម នឹងត្រូវបាត់បង់មិនខាន។ ភាពជាមនុស្សរបស់ព្រះដែលយកកំណើតជាមនុស្ស កើតមានដើម្បីបន្តថែរក្សាកិច្ចការសាមញ្ញរបស់ព្រះនៅក្នុងសាច់ឈាម ហើយការគិតតាមបែបមនុស្សសាមញ្ញរបស់ទ្រង់ ជួយទ្រទ្រង់ដល់ភាពជាមនុស្សសាមញ្ញរបស់ទ្រង់ និងគ្រប់សកម្មភាពខាងសាច់ឈាមរបស់ទ្រង់។ គេអាចនិយាយបានថា ការគិតតាមបែបមនុស្សសាមញ្ញរបស់ទ្រង់កើតមានបាន គឺដើម្បីជួយទ្រទ្រង់ដល់គ្រប់កិច្ចការរបស់ព្រះជាម្ចាស់ នៅក្នុងសាច់ឈាម។ ប្រសិនបើសាច់ឈាមនេះមិនមានគំនិតតាមបែបមនុស្សសាមញ្ញទេ នោះព្រះជាម្ចាស់ មិនអាចធ្វើការនៅក្នុងសាច់ឈាមបានឡើយ ហើយអ្វីដែលទ្រង់ត្រូវធ្វើនៅក្នុងសាច់ឈាម ក៏មិនអាចសម្រេចបាននោះដែរ។ ទោះបីព្រះដែលយកកំណើតជាមនុស្ស មានគំនិតតាមបែបមនុស្សសាមញ្ញក៏ដោយ ប៉ុន្តែកិច្ចការរបស់ទ្រង់ មិនត្រូវបានលាយឡំដោយគំនិតរបស់មនុស្សឡើយ។ ទ្រង់ធ្វើកិច្ចការនៅក្នុងភាពជាមនុស្ស ជាមួយគំនិតសាមញ្ញ ក្រោមលក្ខខណ្ឌតម្រូវជាមុននៃការមានគំនិតតាមបែបភាពជាមនុស្ស មិនមែនដោយការអនុវត្តតាមគំនិតមនុស្សសាមញ្ញនោះឡើយ។ មិនថាគំនិតខាងសាច់ឈាមរបស់ទ្រង់វិសេសវិសាលប៉ុនណា ក៏កិច្ចការរបស់ទ្រង់មិនត្រូវបានប្រឡាក់ប្រឡូកជាមួយតក្កៈ ឬការគិតដែរ។ នៅក្នុងន័យម្យ៉ាងទៀត កិច្ចការរបស់ទ្រង់មិនត្រូវបានយល់ ដោយគំនិតខាងសាច់ឈាមរបស់ទ្រង់ឡើយ ប៉ុន្តែជាការស្ដែងចេញដោយផ្ទាល់ នូវកិច្ចការរបស់ព្រះនៅក្នុងភាពជាមនុស្សរបស់ទ្រង់។ គ្រប់កិច្ចការទាំងអស់របស់ទ្រង់ គឺជាព័ន្ធកិច្ចដែលទ្រង់ត្រូវតែសម្រេច ហើយគ្មានកិច្ចការណាមួយដែលត្រូវបានយល់ដោយខួរក្បាលរបស់ទ្រង់ឡើយ។ ឧទាហរណ៍ ការប្រោសអ្នកជំងឺឲ្យជា ការបណ្ដេញអារក្ស និងការជាប់ឆ្កាង មិនមែនកើតចេញពីគំនិតតាមបែបមនុស្សរបស់ទ្រង់ឡើយ ហើយក៏មិនអាចត្រូវបានសម្រេចដោយមនុស្ស

ណាម្នាក់ ដែលមានគំនិតជាមនុស្សដែរ។ ដូចគ្នាផងដែរ កិច្ចការនៃការយកឈ្នះនាពេលសព្វថ្ងៃ គឺជាព័ន្ធកិច្ចមួយដែលត្រូវតែធ្វើដោយព្រះដែលយកកំណើតជាមនុស្ស ប៉ុន្តែវាមិនមែនជាកិច្ចការចេញពីឆន្ទៈរបស់មនុស្សឡើយ វាជាកិច្ចការដែលភាពជាព្រះរបស់ទ្រង់គួរតែធ្វើ ជាកិច្ចការដែលគ្មានមនុស្សខាងសាច់ឈាមណា អាចធ្វើបានឡើយ។ ដូច្នេះ ព្រះដែលយកកំណើតជាមនុស្ស ត្រូវតែមានគំនិតបែបមនុស្សសាមញ្ញ ត្រូវតែមានភាពជាមនុស្សសាមញ្ញ ដ្បិតទ្រង់ត្រូវតែធ្វើកិច្ចការរបស់ទ្រង់នៅក្នុងភាពជាមនុស្ស ដែលមានគំនិតសាមញ្ញ។ នេះជាសារជាតិ នៃកិច្ចការរបស់ព្រះដែលយកកំណើតជាមនុស្ស ជាសារជាតិដើមរបស់ព្រះដែលយកកំណើតជាមនុស្ស។

មុនពេលដែលព្រះយេស៊ូវចាប់ផ្តើមធ្វើការ គឺទ្រង់គ្រាន់តែរស់នៅ ក្នុងភាពជាមនុស្សសាមញ្ញរបស់ទ្រង់ប៉ុណ្ណោះ។ គ្មាននរណាម្នាក់អាចប្រាប់បានឡើយថា ទ្រង់ជាព្រះជាម្ចាស់ គ្មាននរណាអាចរកឃើញឡើយថា ទ្រង់ជាព្រះដែលយកកំណើតជាមនុស្ស ហើយមនុស្សគ្រាន់តែដឹងថា ទ្រង់ជាមនុស្សសាមញ្ញទាំងស្រុងម្នាក់ប៉ុណ្ណោះ។ ភាពជាមនុស្សសាមញ្ញធម្មតាទាំងស្រុងរបស់ទ្រង់ គឺជាភស្តុតាងបង្ហាញថាព្រះជាម្ចាស់យកកំណើតជាមនុស្សនៅក្នុងសាច់ឈាម និងបញ្ជាក់ថា យុគសម័យនៃព្រះគុណ គឺជាយុគសម័យនៃកិច្ចការរបស់ព្រះដែលយកកំណើតជាមនុស្សមិនមែនជាយុគសម័យនៃកិច្ចការរបស់ព្រះវិញ្ញាណឡើយ។ វាជាភស្តុតាងដែលបង្ហាញថាព្រះវិញ្ញាណនៃព្រះត្រូវបានលេចជារូបរាងទាំងស្រុងនៅក្នុងសាច់ឈាម ហើយនៅក្នុងយុគសម័យនៃការយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់ សាច់ឈាមរបស់ទ្រង់នឹងធ្វើគ្រប់ទាំងកិច្ចការរបស់ព្រះវិញ្ញាណ។ ព្រះគ្រីស្ទជាមួយភាពជាមនុស្សសាមញ្ញ គឺជាសាច់ឈាមដែលព្រះវិញ្ញាណបានលេចជារូបរាង ហើយត្រូវបានកាន់កាប់ដោយភាពជាមនុស្សសាមញ្ញ ញាណសាមញ្ញ និងគំនិតជាមនុស្ស។ «ការលេចចេញជារូបរាង» មានន័យថា ព្រះជាម្ចាស់ក្លាយជាមនុស្ស ព្រះវិញ្ញាណក្លាយជាសាច់ឈាមហើយបើនិយាយឲ្យកាន់តែច្បាស់ វាជាពេលមួយដែលព្រះជាម្ចាស់ផ្ទាល់ គង់សណ្ឋិតក្នុងសាច់ឈាមជាមួយភាពជាមនុស្សសាមញ្ញ ហើយស្តែងចេញអំពីកិច្ចការនៃព្រះរបស់ទ្រង់ តាមរយៈភាពជា

មនុស្សនេះ។ នេះហើយជាអត្ថន័យនៃពាក្យ លេចចេញជារូបរាង ឬយកកំណើតជាមនុស្សនោះ។ ក្នុងអំឡុងពេលនៃការយកកំណើតជាមនុស្សលើកទីមួយរបស់ទ្រង់ ការប្រោសអ្នកជំងឺឲ្យជា និងការបណ្ដេញអារក្ស គឺជាកិច្ចការចាំបាច់សម្រាប់ព្រះជាម្ចាស់ ដោយសារតែកិច្ចការរបស់ទ្រង់ គឺជាការប្រោសលោះ។ ដើម្បីប្រោសលោះមនុស្សជាតិទាំងមូល ទ្រង់ត្រូវតែមានចិត្តក្តួលអាណិត និងការអត់ទោស។ កិច្ចការដែលទ្រង់បានធ្វើ មុនពេលទ្រង់បានជាប់ឆ្កាង គឺជាការប្រោសអ្នកជំងឺឲ្យជា និងការបណ្តេញអារក្ស ដែលប្រាប់ជាមុនអំពីកិច្ចការសង្គ្រោះមនុស្សរបស់ទ្រង់ឲ្យរួចពីអំពើបាប និងសេចក្តីស្មោកគ្រោក។ ដោយសារតែវាជាយុគសម័យនៃព្រះគុណ នោះការប្រោសអ្នកជំងឺឲ្យជា បង្ហាញទីសម្គាល់ និងឫទ្ធិបារមី ដែលជាសេចក្តីតំណាងនៃព្រះគុណនៅក្នុងយុគសម័យនោះ គឺជាកិច្ចការចាំបាច់សម្រាប់ទ្រង់ ដ្បិតយុគសម័យនៃព្រះគុណផ្តោតសំខាន់ទៅលើការប្រទានព្រះគុណ ដែលមានសញ្ញាសម្គាល់ជាសេចក្តីសុខសាន្ត អំណរ និងព្រះពរខាងសម្ភារៈ ហើយទាំងអស់នេះជានិមិត្តរូបនៃសេចក្តីជំនឿរបស់មនុស្សនៅក្នុងព្រះយេស៊ូវ។ មានន័យថា ការប្រោសអ្នកជំងឺឲ្យជា ការបណ្ដេញអារក្ស និងការប្រទានព្រះគុណគឺជាសមត្ថភាពពីកំណើតខាងសាច់ឈាមរបស់ព្រះយេស៊ូវ នៅក្នុងយុគសម័យនៃព្រះគុណ ហើយការទាំងនេះ គឺជាកិច្ចការរបស់ព្រះវិញ្ញាណ ដែលត្រូវបានសម្រេចនៅក្នុងសាច់ឈាម។ ប៉ុន្តែ កាលទ្រង់កំពុងតែធ្វើកិច្ចការបែបនេះ គឺទ្រង់កំពុងតែរស់នៅក្នុងសាច់ឈាម ហើយមិនលើសកម្រិតសមត្ថភាពនៃសាច់ឈាមឡើយ។ មិនថាទ្រង់បានធ្វើការប្រោសឲ្យជានូវជំងឺអ្វីខ្លះនោះឡើយ ទ្រង់នៅតែមានភាពជាមនុស្សសាមញ្ញ នៅតែរស់នៅក្នុងជីវិតជាមនុស្សសាមញ្ញដដែល។ ហេតុផលដែលខ្ញុំនិយាយថា ក្នុងអំឡុងយុគសម័យនៃការយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់ ដែលសាច់ឈាមធ្វើគ្រប់កិច្ចការរបស់ព្រះវិញ្ញាណនោះគឺថា មិនថា ទ្រង់បានធ្វើកិច្ចការអ្វីទេ ទ្រង់បានធ្វើវានៅក្នុងសាច់ឈាម។ ប៉ុន្តែ ដោយសារតែកិច្ចការរបស់ទ្រង់ មនុស្សមិនបានចាត់ទុកសាច់ឈាមរបស់ទ្រង់ថា មានសារជាតិខាងសាច់ឈាមទាំងស្រុងឡើយ ដ្បិតសាច់ឈាមនេះអាចធ្វើការអស្ចារ្យ ហើយក៏អាចធ្វើកិច្ចការ

ដែលហួសពីសមត្ថភាពនៃសាច់ឈាមផងដែរ។ ពិតប្រាកដណាស់ គ្រប់ហេតុការណ៍ទាំងអស់នេះបានកើតឡើង ក្រោយពេលទ្រង់បានចាប់ផ្ដើមព័ន្ធកិច្ចរបស់ទ្រង់ ដូចជាការដែលទ្រង់ជួបសេចក្ដីល្បួងលរយៈពេលសែសិបថ្ងៃ ឬការដែលទ្រង់ប្រែព្រះភ័ក្ត្រភ្លឺចាំងដូចពន្លឺថ្ងៃនៅលើភ្នំ។ ដូច្នេះ ជាមួយព្រះយេស៊ូវ អត្ថន័យនៃការយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់ មិនទាន់បានពេញលេញនៅឡើយទេ ប៉ុន្តែទ្រង់សម្រេចបានតែផ្នែកខ្លះប៉ុណ្ណោះ។ ព្រះជន្មដែលទ្រង់បានរស់នៅក្នុងសាច់ឈាម មុនពេលចាប់ផ្ដើមកិច្ចការរបស់ទ្រង់ គឺជាព្រះជន្មមួយ ដែលមានលក្ខណៈសាមញ្ញទាំងស្រុងនៅគ្រប់ផ្នែកតែម្ដង។ ក្រោយពេលទ្រង់បានចាប់ផ្ដើមធ្វើកិច្ចការ ទ្រង់រក្សាទុកតែសំបកខាងក្រៅនៃសាច់ឈាមរបស់ទ្រង់ប៉ុណ្ណោះ។ ដោយសារតែកិច្ចការរបស់ទ្រង់គឺជាការសម្ដែងចេញនូវភាពជាព្រះ ដូច្នេះ វាបានទៅលើសកម្រិតមុខងារសាមញ្ញនៃសាច់ឈាម។ ចុងបញ្ចប់ សាច់ឈាមជាមនុស្សរបស់ព្រះជាម្ចាស់ មានលក្ខណៈខុសគ្នាពីមនុស្សខាងរូបសាច់ និងឈាម។ ពិតណាស់ នៅក្នុងជីវិតប្រចាំថ្ងៃរបស់ទ្រង់ ព្រះអង្គត្រូវការអាហារ សម្លៀកបំពាក់ ការគេង និងទីជម្រក។ ទ្រង់ត្រូវការតម្រូវការដ៏ចាំបាច់សាមញ្ញទាំងអស់នេះ ហើយទ្រង់មានអារម្មណ៍ និងគិតដូចជាមនុស្សសាមញ្ញដែរ។ មនុស្សនៅតែគិតថា ទ្រង់ជាមនុស្សសាមញ្ញ លើកលែងតែកិច្ចការដែលទ្រង់បានធ្វើ ជាកិច្ចការអធិធម្មជាតិប៉ុណ្ណោះ។ តាមពិតទៅ មិនថាទ្រង់បានធ្វើអ្វីឡើយ ទ្រង់បានរស់នៅក្នុងភាពជាមនុស្សធម្មតា និងសាមញ្ញម្នាក់ ហើយទោះបីជាទ្រង់បានធ្វើកិច្ចការបែបនេះក៏ដោយក៏ញាណរបស់ទ្រង់មានភាពសាមញ្ញ គំនិតរបស់ទ្រង់មានភាពច្បាស់លាស់ពិសេស លើសពីមនុស្សសាមញ្ញផ្សេងទៀតផង។ ការដែលត្រូវមានគំនិត និងញាណបែបនេះវាចាំបាច់សម្រាប់ព្រះដែលយកកំណើតជាមនុស្ស ដ្បិតកិច្ចការនៃព្រះត្រូវតែស្ដែងចេញតាមរយៈសាច់ឈាមដែលមានញាណសាមញ្ញបំផុត និងគំនិតច្បាស់លាស់បំផុត ហើយទាល់តែធ្វើបែបនេះ ទើបសាច់ឈាមរបស់ទ្រង់អាចសម្ដែងចេញនូវកិច្ចការនៃព្រះបាន។ នៅក្នុងរយៈពេលសាមសិបបីឆ្នាំកន្លះដែលព្រះយេស៊ូវបានរស់នៅលើផែនដី ទ្រង់បានរក្សាភាពជាមនុស្សសាមញ្ញរបស់ទ្រង់ ប៉ុន្តែដោយសារតែ

កិច្ចការរបស់ទ្រង់ ក្នុងអំឡុងពេលនៃព័ន្ធកិច្ចបីឆ្នាំកន្លះរបស់ទ្រង់ មនុស្សបានគិតថា ទ្រង់មានអំណាចខ្ពង់ខ្ពស់លើសមនុស្សសាមញ្ញ និងគិតទៀតថា ទ្រង់មានលក្ខណៈអធិធម្មជាតិជាងពេលមុនៗ។ តាមពិតទៅ ភាពជាមនុស្សសាមញ្ញរបស់ទ្រង់បានបន្តមិនផ្លាស់ប្រែឡើយ ទាំងមុននិងក្រោយដែលទ្រង់ចាប់ផ្ដើមធ្វើព័ន្ធកិច្ចរបស់ទ្រង់។ ភាពជាមនុស្សរបស់ទ្រង់នៅតែដដែលជានិច្ច ប៉ុន្តែដោយសារតែភាពខុសគ្នា នៅមុន និងក្រោយពេលទ្រង់បានចាប់ផ្ដើមធ្វើព័ន្ធកិច្ចរបស់ទ្រង់ ដូច្នេះ ទស្សនៈខុសគ្នាទាំងពីរនេះបានលេចឡើង ទាក់ទងនឹងសាច់ឈាមរបស់ទ្រង់។ មិនថាមនុស្សបានគិតបែបណានោះឡើយ ព្រះដែលយកកំណើតជាមនុស្សនៅតែរក្សាភាពជាមនុស្សសាមញ្ញដើមរបស់ទ្រង់នៅគ្រប់ពេលវេលា ដ្បិតតាំងពីព្រះជាម្ចាស់បានយកកំណើតជាមនុស្ស ទ្រង់បានរស់នៅក្នុងសាច់ឈាមនេះ ជាសាច់ឈាមដែលមានភាពជាមនុស្សសាមញ្ញនេះឯង។ ទោះបីជាទ្រង់មិនធ្វើព័ន្ធកិច្ចរបស់ទ្រង់ក៏ដោយ ក៏ភាពជាមនុស្សសាមញ្ញនៃសាច់ឈាមរបស់ទ្រង់ មិនអាចត្រូវបានលុបចោលនោះឡើយ ដ្បិតភាពជាមនុស្ស គឺជាសារជាតិមូលដ្ឋានខាងសាច់ឈាម។ មុនពេលព្រះយេស៊ូវបានធ្វើព័ន្ធកិច្ចរបស់ទ្រង់ សាច់ឈាមរបស់ទ្រង់ បានបន្តនៅសាមញ្ញទាំងស្រុង ដោយចូលរួមនៅក្នុងគ្រប់ទាំងសកម្មភាពរបស់មនុស្សសាមញ្ញ។ ទ្រង់មិនបានលេចចេញនៅក្នុងទម្រង់អធិធម្មជាតិសូម្បីបន្តិច ហើយក៏មិនបានបង្ហាញទីសម្គាល់អស្ចារ្យអ្វីដែរ។ នៅពេលនោះ ទ្រង់គ្រាន់តែជាមនុស្សសាមញ្ញម្នាក់ ដែលថ្វាយបង្គំព្រះជាម្ចាស់ ទោះបីជាការព្យាយាមឲ្យបានរបស់ទ្រង់មានភាពទៀងត្រង់ និងស្មោះត្រង់ជាងមនុស្សផ្សេងទៀតក៏ដោយ។ នេះគឺជារបៀប ដែលភាពជាមនុស្សសាមញ្ញទាំងស្រុងរបស់ទ្រង់ បានស្ដែងចេញមកដោយឯកឯង។ ដោយសារតែទ្រង់មិនបានធ្វើការទាល់តែសោះ មុនពេលទ្រង់ចាប់ផ្ដើមធ្វើព័ន្ធកិច្ចរបស់ទ្រង់ ទើបគ្មានមនុស្សណាម្នាក់ដឹងអំពីអត្តសញ្ញាណរបស់ទ្រង់ ក៏គ្មាននរណាម្នាក់អាចដឹងថា សាច់ឈាមរបស់ទ្រង់ខុសប្លែកពីអ្នកផ្សេងទៀតដែរ ដ្បិតទ្រង់មិនបានធ្វើការអស្ចារ្យ និងមិនធ្វើកិច្ចការរបស់ព្រះជាម្ចាស់ សូម្បីតែបន្តិចនោះឡើយ។ យ៉ាងណាមិញ ក្រោយពេលទ្រង់បានចាប់ផ្ដើមធ្វើព័ន្ធកិច្ចរបស់ទ្រង់ ទ្រង់បាន

រក្សាសំបកខាងក្រៅនៃភាពជាមនុស្សសាមញ្ញ ហើយនៅតែរស់នៅជាមួយការត្រិះរិះពិចារណាជាមនុស្សសាមញ្ញដដែល ប៉ុន្តែដោយសារតែទ្រង់បានចាប់ផ្ដើមធ្វើកិច្ចការរបស់ព្រះជាម្ចាស់ផ្ទាល់ ធ្វើព័ន្ធកិច្ចរបស់ព្រះគ្រីស្ទ ហើយធ្វើកិច្ចការដែលមនុស្សខាងសាច់និងឈាមគ្មានសមត្ថភាពអាចធ្វើបាន ទើបមនុស្សបានសន្មតថា ទ្រង់មិនមានភាពជាមនុស្សសាមញ្ញ ហើយទ្រង់មិនមែនជាសាច់ឈាមសាមញ្ញទាំងស្រុងឡើយ ប៉ុន្តែជាសាច់ឈាមមិនពេញលេញវិញ។ ដោយសារតែកិច្ចការ ដែលទ្រង់បានធ្វើ ទើបមនុស្សបាននិយាយថា ទ្រង់ជាព្រះជាម្ចាស់គង់នៅក្នុងសាច់ឈាមដែលមិនមានភាពជាមនុស្សសាមញ្ញ។ ការយល់ដឹងបែបនេះ គឺជារឿងភាន់ច្រឡំហើយ ដ្បិតមនុស្សមិនយល់អំពីសារៈសំខាន់នៃការយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់ឡើយ។ ការយល់ច្រឡំនេះបានកើតឡើងចេញពីការពិតដែលថាកិច្ចការដែលស្ដែងចេញដោយព្រះជាម្ចាស់នៅក្នុងសាច់ឈាម គឺជាកិច្ចការរបស់ព្រះដែលស្ដែងចេញនៅក្នុងសាច់ឈាមមួយដែលមានភាពជាមនុស្សសាមញ្ញ។ ព្រះជាម្ចាស់ត្រូវបានគ្របដណ្ដប់ដោយសាច់ឈាម ទ្រង់បានគង់សណ្ឋិតនៅក្នុងសាច់ឈាម ហើយកិច្ចការរបស់ទ្រង់នៅក្នុងភាពជាមនុស្សរបស់ទ្រង់ បានធ្វើឲ្យភាពជាមនុស្សសាមញ្ញរបស់ទ្រង់មានភាពស្រពេចស្រពិល។ ដោយសារតែហេតុផលនេះហើយ ទើបមនុស្សជឿថា ព្រះជាម្ចាស់មិនមានភាពជាមនុស្សឡើយ គឺមានតែភាពជាព្រះតែប៉ុណ្ណោះ។

នៅក្នុងការយកកំណើតជាមនុស្សលើកទីមួយរបស់ព្រះជាម្ចាស់ ទ្រង់មិនបានបង្ហើយកិច្ចការនៃការយកកំណើតជាមនុស្សឡើយ ប៉ុន្តែ ទ្រង់គ្រាន់តែបានបង្ហើយជំហានទីមួយនៃកិច្ចការដែលព្រះជាម្ចាស់ ចាំបាច់ត្រូវធ្វើការនៅក្នុងសាច់ឈាមតែប៉ុណ្ណោះ។ ដូច្នេះ ដើម្បីបង្ហើយកិច្ចការនៃការយកកំណើតជាមនុស្ស ព្រះជាម្ចាស់បានយាងត្រឡប់មកខាងសាច់ឈាមម្ដងទៀត រស់នៅក្នុងភាពសាមញ្ញ និងការពិតនៃសាច់ឈាម ពោលគឺធ្វើឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់ស្ដែងចេញនៅក្នុងសាច់ឈាមដ៏សាមញ្ញធម្មតាបំផុត ក្នុងគោលបំណងបញ្ចប់កិច្ចការដែលទ្រង់មិនទាន់បានសម្រេចនៅក្នុងសាច់ឈាម។ ជាទូទៅ ការយកកំណើតខាងសាច់ឈាមជាលើកទីពីរ គឺ

ដូចជាលើកទីមួយដែរ គ្រាន់តែវាមានលក្ខណៈប្រាកដ និងសាមញ្ញជាងលើកទីមួយប៉ុណ្ណោះ។ ជាលទ្ធផល ទុក្ខវេទនាដែលសាច់ឈាមយកកំណើតលើកទីពីរត្រូវទទួលក៏មានទំហំធំជាងលើកទីមួយផងដែរ ប៉ុន្តែទុក្ខវេទនានេះគឺជាលទ្ធផលកើតចេញពីព័ន្ធកិច្ចរបស់ទ្រង់នៅក្នុងសាច់ឈាម ដែលមានលក្ខណៈខុសពីទុក្ខវេទនារបស់មនុស្សដែលពុករលួយ។ វាក៏មានឫសគល់ចេញពីភាពសាមញ្ញ និងការពិតនៃសាច់ឈាមរបស់ទ្រង់ផងដែរ។ ដោយសារតែទ្រង់ធ្វើព័ន្ធកិច្ចរបស់ទ្រង់ នៅក្នុងសាច់ឈាមសាមញ្ញ និងពិតប្រាកដទាំងស្រុង នោះសាច់ឈាមត្រូវតែរងទុក្ខលំបាកយ៉ាងខ្លាំង។ បើសាច់ឈាមនេះ មានលក្ខណៈសាមញ្ញ និងពិតប្រាកដកាន់តែច្រើន នោះទ្រង់នឹងរងទុក្ខលំបាក នៅក្នុងការធ្វើព័ន្ធកិច្ចរបស់ទ្រង់កាន់តែខ្លាំង។ កិច្ចការរបស់ព្រះជាម្ចាស់ត្រូវបានស្ដែងចេញនៅក្នុងសាច់ឈាមបែបសាមញ្ញបំផុត ជាសាច់ឈាមដែលមិនមានលក្ខណៈអធិធម្មជាតិទាល់តែសោះ។ ដោយសារតែសាច់ឈាមរបស់ទ្រង់មានលក្ខណៈសាមញ្ញ ហើយក៏ត្រូវរែកពន់កិច្ចការនៃការសង្គ្រោះមនុស្ស ផងនោះដូច្នេះទ្រង់ត្រូវតែរងទុក្ខនៅក្នុងកម្រិតកាន់តែធ្ងន់ជាងសាច់ឈាមបែបអធិធម្មជាតិ ហើយទុក្ខវេទនាទាំងអស់នេះមានប្រភពចេញពីការពិតនិងភាពសាមញ្ញនៃសាច់ឈាមរបស់ទ្រង់។ ខណៈពេលដែលព្រះអង្គទាំងពីរ កំពុងតែធ្វើព័ន្ធកិច្ចរបស់ទ្រង់មនុស្សអាចមើលឃើញ អំពីសារជាតិនៃសាច់ឈាមជាមនុស្ស តាមរយៈទុក្ខវេទនាដែលសាច់ឈាមយកកំណើតជាមនុស្សទាំងពីរបានរងទុក្ខ។ បើសាច់ឈាមកាន់តែមានលក្ខណៈសាមញ្ញ នោះទ្រង់ត្រូវតែរងទុក្ខលំបាកកាន់តែខ្លាំងក្នុងពេលធ្វើកិច្ចការ។ បើសាច់ឈាមដែលធ្វើកិច្ចការមានលក្ខណៈកាន់តែពិត នោះមនុស្សនឹងមានសញ្ញាណកាន់តែឃោរឃៅ ហើយគ្រោះថ្នាក់ដែលទំនងជាធ្លាក់លើទ្រង់ ក៏កាន់តែច្រើនផងដែរ។ ប៉ុន្តែ បើសាច់ឈាមមានលក្ខណៈកាន់តែពិតច្រើន ហើយបើសាច់ឈាមមានតម្រូវការនិងការយល់ដឹងពេញលេញ អំពីមនុស្សលោកសាមញ្ញកាន់តែច្រើន នោះទ្រង់មានសមត្ថភាពក្នុងការធ្វើកិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងសាច់ឈាមកាន់តែខ្លាំង។ គឺសាច់ឈាមរបស់ព្រះយេស៊ូវហើយ ដែលត្រូវបានដំដែកគោលជាប់នឹងឈើឆ្កាង ជា

សាច់ឈាមរបស់ទ្រង់ហើយដែលព្រះអង្គបានលះបង់ជាតង្វាយលោះបាប។ គឺតាមរយៈមធ្យោបាយខាងសាច់ឈាមដែលមានភាពជាមនុស្សសាមញ្ញនេះហើយ ដែលទ្រង់បានបំបាក់អារក្សសាតាំង និងសង្គ្រោះមនុស្សបានទាំងស្រុងពីឈើឆ្កាង។ ហើយវាក៏ជាសាច់ឈាមទាំងស្រុងនេះដែរ ដែលព្រះជាម្ចាស់ធ្វើកិច្ចការ នៃការយកឈ្នះ និងបង្ក្រាបអារក្សសាតាំង នៅក្នុងការយាងមក យកកំណើតជាមនុស្សលើកទីពីររបស់ទ្រង់។ មានតែសាច់ឈាមមួយដែលមានលក្ខណៈសាមញ្ញ និងពិតទាំងស្រុងប៉ុណ្ណោះ ដែលអាចធ្វើកិច្ចការនៃការយកឈ្នះនៅក្នុងភាពពេញលេញរបស់វានិងអាចធ្វើបន្ទាល់ដ៏ពេញដោយអនុភាពបាន។ មានន័យថា ការយកឈ្នះរបស់មនុស្សត្រូវបានធ្វើឲ្យមានប្រសិទ្ធភាព តាមរយៈការពិតនិងភាពសាមញ្ញរបស់ព្រះជាម្ចាស់នៅក្នុងសាច់ឈាម មិនមែនតាមរយៈការអស្ចារ្យនិងការបើកសម្ដែងបែបអធិធម្មជាតិឡើយ។ ព័ន្ធកិច្ចរបស់ព្រះដែលយកកំណើតជាមនុស្សនេះ គឺដើម្បីមានបន្ទូល យកឈ្នះ និងធ្វើឲ្យមនុស្សក្លាយជាគ្រប់លក្ខណ៍។ នៅក្នុងន័យម្យ៉ាងទៀត កិច្ចការនៃព្រះវិញ្ញាណត្រូវបានសម្រេចនៅក្នុងសាច់ឈាម ដែលជាភារកិច្ចរបស់សាច់ឈាម គឺដើម្បីមានបន្ទូល ក៏ដូចជាយកឈ្នះ បើកសម្ដែង ប្រោសឲ្យគ្រប់លក្ខណ៍ និងផាត់ចោលមនុស្សទាំងស្រុង។ ដូច្នេះ កិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងសាច់ឈាមនឹងត្រូវបានសម្រេចយ៉ាងពេញលេញ តាមរយៈកិច្ចការនៃការយកឈ្នះនេះហើយ។ កិច្ចការដំបូងនៃការប្រោសលោះ គឺគ្រាន់តែជាទីចាប់ផ្ដើមនៃកិច្ចការយកកំណើតជាមនុស្សប៉ុណ្ណោះ ប៉ុន្តែសាច់ឈាមដែលធ្វើកិច្ចការច្បាំងយកជ័យ នឹងបង្ហើយកិច្ចការទាំងស្រុងនៃការយកកំណើតជាមនុស្ស។ ទាក់ទងនឹងភេទវិញ ម្នាក់ជាបុរស ហើយម្នាក់ទៀតជាស្ត្រី ដើម្បីបង្ហើយសារៈសំខាន់នៃការយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់ផង និងដើម្បីលុបបំបាត់ចោលសញ្ញាណរបស់មនុស្ស អំពីព្រះជាម្ចាស់ផង៖ ព្រះជាម្ចាស់អាចក្លាយជាបុរសផង និងស្ត្រីផង ហើយជាទូទៅ ព្រះដែលយកកំណើតជាមនុស្សមិនមានភេទឡើយ។ ទ្រង់បានបង្កើតទាំងបុរសនិងស្ត្រី ហើយចំពោះទ្រង់ គ្មានការបែងចែករវាងភេទឡើយ។ នៅក្នុងដំណាក់កាលនៃកិច្ចការនេះ ព្រះជាម្ចាស់មិនធ្វើទីសម្គាល់និង

ឫទ្ធិបារមីឡើយ ដូច្នេះ កិច្ចការនឹងសម្រេចជាលទ្ធផល តាមរយៈមធ្យោបាយនៃការថ្លែងព្រះបន្ទូល។ លើសពីនេះទៅទៀត ហេតុផលសម្រាប់ការនេះ គឺដោយសារតែកិច្ចការរបស់ព្រះដែលយកកំណើតជាមនុស្សនៅលើកនេះ មិនមែនដើម្បីប្រោសអ្នកជំងឺឲ្យជានិងបណ្ដេញអារក្សឡើយ ប៉ុន្តែដើម្បីយកឈ្នះមនុស្ស តាមរយៈការមានបន្ទូលវិញ មានន័យថា សមត្ថភាពដើមដែលសាច់ឈាមជាមនុស្សរបស់ព្រះជាម្ចាស់នេះមាន គឺថ្លែងព្រះបន្ទូល និងយកឈ្នះមនុស្ស មិនមែនប្រោសអ្នកជំងឺឲ្យជា និងបណ្ដេញអារក្សឡើយ។ កិច្ចការរបស់ទ្រង់នៅក្នុងភាពជាមនុស្សសាមញ្ញមិនមែនធ្វើការអស្ចារ្យ មិនមែនប្រោសអ្នកជំងឺឲ្យជា និងបណ្ដេញអារក្សឡើយ ប៉ុន្តែគឺថ្លែងព្រះបន្ទូលដូច្នេះ មហាជនមើលឃើញថា សាច់ឈាមជាមនុស្ស លើកទីពីរហាក់ដូចជាមានលក្ខណៈជាមនុស្សសាមញ្ញ កាន់តែច្រើនជាងលើកទីមួយរបស់ទ្រង់។ មនុស្សមើលឃើញថា ការយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់មិនមែនជាសេចក្ដីកុហកឡើយ ប៉ុន្តែព្រះដែលយកកំណើតជាមនុស្សលើកនេះ មានលក្ខណៈខុសប្លែកពីព្រះយេស៊ូវដែលយកកំណើតជាមនុស្ស ហើយទោះបីព្រះទាំងពីរអង្គ ជាព្រះជាម្ចាស់យកកំណើតជាមនុស្សក៏ដោយ ប៉ុន្តែព្រះអង្គទាំងពីរ មិនមានលក្ខណៈដូចគ្នាទាំងស្រុងឡើយ។ ព្រះយេស៊ូវមានភាពជាមនុស្សសាមញ្ញ ភាពជាមនុស្សធម្មតា ប៉ុន្តែទ្រង់ក៏មានអមមកជាមួយនូវទីសម្គាល់ និងឫទ្ធិបារមីជាច្រើនផងដែរ។ នៅក្នុងព្រះដែលយកកំណើតជាមនុស្សនេះ ភ្នែករបស់មនុស្សនឹងមើលមិនឃើញពីទីសម្គាល់ ការអស្ចារ្យ ការប្រោសអ្នកជំងឺឲ្យជា ការបណ្ដេញអារក្ស ការយាងដើរលើទឹក ឬការតមអាហាររយៈពេលសែសិបថ្ងៃនោះទេ...។ ជាទូទៅទ្រង់មិនធ្វើកិច្ចការដដែលដែលព្រះយេស៊ូវបានធ្វើនោះឡើយ មិនមែនដោយសារតែសាច់ឈាមរបស់ទ្រង់មានលក្ខណៈខុសប្លែកពីសាច់ឈាមរបស់ព្រះយេស៊ូវនោះទេ ប៉ុន្តែគឺដោយសារតែការប្រោសអ្នកជំងឺឲ្យជា និងការបណ្ដេញអារក្ស មិនមែនជាព័ន្ធកិច្ចរបស់ទ្រង់ទេ។ ទ្រង់មិនបំផ្លាញកិច្ចការរបស់ទ្រង់ផ្ទាល់ ឬរំខានកិច្ចការរបស់ទ្រង់ផ្ទាល់នោះឡើយ។ ដោយសារតែទ្រង់ យកឈ្នះមនុស្ស តាមរយៈព្រះបន្ទូលដ៏ពិតរបស់ទ្រង់ ដូច្នេះវា មិនចាំបាច់អ្វីដែលត្រូវយកឈ្នះ

លើគេ ដោយការអស្ចារ្យឡើយ ដ្បិតដំណាក់កាលនេះ គឺជាការបញ្ចប់កិច្ចការនៃការយកកំណើតជាមនុស្ស។ ព្រះដែលយកកំណើតជាមនុស្ស ដែលអ្នកមើលឃើញនាពេលសព្វថ្ងៃ មានលក្ខណៈសាច់ឈាមទាំងស្រុង ហើយទ្រង់គ្មានសោះឡើយនូវលក្ខណៈបែបអធិធម្មជាតិនោះ។ ទ្រង់ចេះឈឺដូចជាមនុស្សផ្សេងទៀត ទ្រង់ត្រូវការអាហារ និងសម្លៀកបំពាក់ដូចជាអ្នកឯទៀតៗ គឺទ្រង់ជាសាច់ឈាមទាំងស្រុងតែម្ដង។ សម្រាប់លើកនេះ ប្រសិនបើព្រះដែលយកកំណើតជាមនុស្សបានធ្វើទីសម្គាល់ និងឫទ្ធិបារមីដ៏អស្ចារ្យ ប្រសិនបើទ្រង់ប្រោសអ្នកជំងឺឲ្យជា បណ្ដេញអារក្ស ឬធ្វើឃាតដោយពាក្យតែមួយម៉ាត់ តើកិច្ចការនៃការច្បាំងយកជ័យអាចត្រូវបានអនុវត្តយ៉ាងដូចម្ដេចទៅ? តើកិច្ចការអាចត្រូវផ្សាយទៅ នៅក្នុងចំណោមប្រជាជាតិនៃសាសន៍ដទៃបានដោយរបៀបណា? ការប្រោសអ្នកជំងឺឲ្យជា និងការបណ្ដេញអារក្ស គឺជាកិច្ចការនៅយុគសម័យនៃព្រះគុណ វាជាជំហានដំបូងនៅក្នុងកិច្ចការប្រោសលោះ ហើយឥឡូវនេះ ព្រះជាម្ចាស់បានសង្គ្រោះមនុស្ស ពីឈើឆ្កាងរួចហើយ ដូច្នេះ ព្រះជាម្ចាស់លែងធ្វើកិច្ចការនេះទៀតហើយ។ ក្នុងអំឡុងពេលនៃគ្រាចុងក្រោយ ប្រសិនបើ «ព្រះជាម្ចាស់» មានលក្ខណៈ ដូចកាលព្រះយេស៊ូវបានលេចមក ជាព្រះដែលបានប្រោសអ្នកជំងឺឲ្យជា បណ្ដេញអារក្ស និងជាប់ឆ្កាងជួសមនុស្ស ដូច្នេះ «ព្រះជាម្ចាស់» នោះ ទោះបីមានលក្ខណៈដូចគ្នាទៅនឹងសេចក្ដីពណ៌នាអំពីព្រះជាម្ចាស់នៅក្នុងព្រះគម្ពីរ ហើយមានភាពងាយស្រួល សម្រាប់មនុស្សក្នុងការទទួលយកក៏ដោយ ប៉ុន្ដែនៅក្នុងសារជាតិជាព្រះ ទ្រង់មិនមែនជាសាច់ឈាម ដែលត្រូវបានសណ្ឋិតដោយព្រះវិញ្ញាណនៃព្រះឡើយ ប៉ុន្ដែសណ្ឋិតដោយវិញ្ញាណអាក្រក់វិញ។ ដ្បិតគោលការណ៍នៃកិច្ចការរបស់ព្រះជាម្ចាស់នោះគឺថា ទ្រង់មិនធ្វើកិច្ចការដែលទ្រង់បានធ្វើហើយម្ដងទៀតឡើយ។ ដូច្នេះ កិច្ចការនៃការយកកំណើតជាមនុស្សលើកទីពីររបស់ព្រះជាម្ចាស់ មានលក្ខណៈខុសប្លែកពីកិច្ចការនៅលើកទីមួយ។ នៅគ្រាចុងក្រោយ ព្រះជាម្ចាស់សម្រេចកិច្ចការនៃការយកឈ្នះនៅក្នុងសាច់ឈាមសាមញ្ញធម្មតា។ ទ្រង់មិនប្រោសអ្នកជំងឺឲ្យជា ហើយក៏មិនជាប់ឆ្កាងជួសមនុស្សដែរ ប៉ុន្ដែទ្រង់គ្រាន់តែមានបន្ទូលនៅក្នុងសាច់ឈាម

ហើយយកឈ្មោះមនុស្សនៅក្នុងសាច់ឈាមប៉ុណ្ណោះ។ មានតែសាច់ឈាមបែបនេះទេ ទើបជាសាច់ឈាម ជាមនុស្សរបស់ព្រះជាម្ចាស់។ មានតែសាច់ឈាមបែបនេះប៉ុណ្ណោះ ទើបកិច្ចការរបស់ព្រះជាម្ចាស់អាចបញ្ចប់បាននៅក្នុងសាច់ឈាម។

មិនថានៅក្នុងដំណាក់កាលនេះ ព្រះដែលយកកំណើតជាមនុស្សកំពុងតែរងទុក្ខលំបាក ឬធ្វើព័ន្ធកិច្ចរបស់ទ្រង់ក៏ដោយ ក៏ទ្រង់ធ្វើបែបនេះ ដើម្បីបង្គ្រប់អត្ថន័យនៃការយកកំណើតជាមនុស្ស ដ្បិតនេះជាការយកកំណើតជាមនុស្សចុងក្រោយរបស់ព្រះជាម្ចាស់។ ព្រះជាម្ចាស់អាចយកកំណើតជាមនុស្ស បានតែពីរដងប៉ុណ្ណោះ។ វាមិនអាចមានលើកទីបីឡើយ។ ការយកកំណើតជាមនុស្សលើកទីមួយ គឺជាបុរស ឯលើកទីពីរ គឺជាស្ត្រី ដូច្នេះ រូបអង្គអំពីសាច់ឈាមរបស់ព្រះជាម្ចាស់ ត្រូវបានបំពេញនៅក្នុងគំនិតរបស់មនុស្ស។ លើសពីនេះទៅទៀត ការយកកំណើតជាមនុស្សទាំងពីរនេះបានបញ្ចប់កិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងសាច់ឈាមរួចហើយ។ លើកទីមួយ ព្រះដែលយកកំណើតជាមនុស្ស មានភាពជាមនុស្សសាមញ្ញ ដើម្បីបង្គ្រប់អត្ថន័យនៃការយកកំណើតជាមនុស្ស។ លើកនេះ ទ្រង់ក៏មានភាពជាមនុស្សសាមញ្ញដែរ ប៉ុន្តែអត្ថន័យនៃការយកកំណើតជាមនុស្សលើកនេះមានលក្ខណៈខុសគ្នា៖ វាមានភាពស៊ីជម្រៅជាង ហើយកិច្ចការរបស់ទ្រង់ក៏ពេញដោយសារៈសំខាន់ខ្លាំងជាងផងដែរ។ ហេតុផលដែលព្រះជាម្ចាស់បានក្លាយជាសាច់ឈាមម្ដងទៀត គឺដើម្បីបង្គ្រប់អត្ថន័យនៃការយកកំណើតជាមនុស្ស។ នៅពេលដែលព្រះជាម្ចាស់ បានបញ្ចប់ទាំងស្រុងនូវដំណាក់កាលនៃកិច្ចការរបស់ទ្រង់ អត្ថន័យទាំងស្រុងនៃការយកកំណើតជាមនុស្ស ពោលគឺកិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងសាច់ឈាមនោះ នឹងត្រូវបានបំពេញដែរ ហើយនឹងគ្មានកិច្ចការដែលត្រូវសម្រេច នៅក្នុងសាច់ឈាមតទៅទៀតឡើយ។ មានន័យថា ចាប់ពីពេលនេះតទៅ ព្រះជាម្ចាស់នឹងមិនយាងមកនៅក្នុងសាច់ឈាម ដើម្បីធ្វើកិច្ចការរបស់ទ្រង់ទៀតឡើយ។ ព្រះជាម្ចាស់ ធ្វើតែកិច្ចការនៃការយកកំណើតជាមនុស្ស តាមរយៈការសង្គ្រោះ ហើយនិងការប្រោសមនុស្សឲ្យបានគ្រប់លក្ខណ៍តែប៉ុណ្ណោះ។ នៅក្នុងន័យម្យ៉ាងទៀត ព្រះជាម្ចាស់មិនចាំបាច់អ្វីត្រូវ

យាងមកក្នុងសាច់ឈាមនោះឡើយ លើកលែងតែសម្រាប់ជាប្រយោជន៍ដល់កិច្ចការរបស់ទ្រង់តែប៉ុណ្ណោះ។ តាមរយៈការយាងមកនៅក្នុងសាច់ឈាមដើម្បីធ្វើការ ទ្រង់បង្ហាញទៅកាន់អារក្សសាតាំងថា ព្រះជាម្ចាស់ជាសាច់ឈាម ជាមនុស្សសាមញ្ញម្នាក់ ជាមនុស្សធម្មតាម្នាក់ ប៉ុន្តែទ្រង់នៅតែអាចសោយរាជ្យលើលោកីយ៍ប្រកបដោយជ័យជម្នះ នៅតែអាចបង្ក្រាបអារក្សសាតាំង នៅតែអាចប្រោសលោះមនុស្សជាតិ និងនៅតែអាចយកឈ្នះមនុស្សជាតិបានដដែល! គោលដៅនៃកិច្ចការរបស់សាតាំងគឺដើម្បីធ្វើឲ្យមនុស្សជាតិទៅជាពុករលួយ ខណៈគោលដៅរបស់ព្រះជាម្ចាស់វិញ គឺ ដើម្បីសង្គ្រោះមនុស្សជាតិ។ សាតាំងដាក់អន្ទាក់មនុស្សនៅក្នុងជង្ហុកដ៏ធំ ប៉ុន្តែព្រះជាម្ចាស់ជួយសង្គ្រោះពួកគេឲ្យរួចវិញ។ សាតាំងបង្ខំមនុស្សទាំងអស់ឲ្យថ្វាយបង្គំវា ចំណែកឯព្រះជាម្ចាស់ ធ្វើឲ្យពួកគេនៅចំណុះក្រោមការគ្រប់គ្រងរបស់ទ្រង់ ដ្បិតទ្រង់ជាព្រះអម្ចាស់នៃសត្តនិករ។ គ្រប់កិច្ចការទាំងអស់នេះត្រូវបានសម្រេច តាមរយៈការយកកំណើតជាមនុស្ស ទាំងពីរលើករបស់ព្រះជាម្ចាស់។ ជាទូទៅ សាច់ឈាមរបស់ទ្រង់ គឺជាការរួមគ្នារវាងភាពជាមនុស្សនិងភាពជាព្រះ ហើយសណ្ឋិតក្នុងភាពជាមនុស្សសាមញ្ញ។ ដូច្នេះ បើគ្មានសាច់ឈាមជាមនុស្សរបស់ព្រះជាម្ចាស់ទេ នោះព្រះជាម្ចាស់មិនអាចសម្រេចបានលទ្ធផល នៃការសង្គ្រោះមនុស្សជាតិបានឡើយ ហើយបើគ្មានភាពជាមនុស្សសាមញ្ញនៃសាច់ឈាមរបស់ទ្រង់នោះទេ នោះកិច្ចការរបស់ទ្រង់នៅក្នុងសាច់ឈាម នៅតែមិនអាចសម្រេចលទ្ធផលទាំងនេះបានដែរ។ សារជាតិនៃការយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់គឺថា ទ្រង់ត្រូវតែមានភាពជាមនុស្សសាមញ្ញ ដ្បិតបើពុំនោះទេ ការនេះនឹងប្រឆាំងនឹងចេតនាដើមរបស់ព្រះជាម្ចាស់ក្នុងការយកកំណើតជាមនុស្សមិនខាន។

ហេតុអ្វីបានជាខ្ញុំនិយាយថា អត្ថន័យនៃការយកកំណើតជាមនុស្ស មិនត្រូវបានបង្គ្រប់នៅក្នុងកិច្ចការរបស់ព្រះយេស៊ូវ? គឺដោយសារតែព្រះបន្ទូល មិនបានក្លាយជាសាច់ឈាមទាំងស្រុងឡើយ។ អ្វីដែលព្រះយេស៊ូវបានធ្វើ គឺគ្រាន់តែជាផ្នែកមួយនៃកិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងសាច់ឈាមតែប៉ុណ្ណោះ។ ទ្រង់គ្រាន់តែធ្វើកិច្ចការនៃ

ការប្រោសលោះ ហើយទ្រង់ មិនបានធ្វើកិច្ចការនៃការទទួលបានមនុស្សទាំងស្រុងឡើយ។ ដោយសារតែហេតុផលនេះ ព្រះជាម្ចាស់បានក្លាយជាមនុស្សម្ដងទៀតនៅគ្រាចុងក្រោយ។ ដំណាក់កាលនៃកិច្ចការនេះ ក៏ត្រូវបានសម្រេចនៅក្នុងសាច់ឈាមសាមញ្ញផងដែរ។ កិច្ចការនេះត្រូវបានធ្វើដោយមនុស្សសាមញ្ញបំផុត ជាភាពជាមនុស្សរបស់បុគ្គលម្នាក់ដែលគ្មានភាពអធិធម្មជាតិសោះឡើយ សូម្បីតែបន្តិចក៏គ្មានផង។ នៅក្នុងន័យម្យ៉ាងទៀត ព្រះជាម្ចាស់បានក្លាយជាមនុស្សទាំងស្រុង ហើយទ្រង់ជាមនុស្សម្នាក់ ដែលមានអត្តសញ្ញាណមកពីព្រះជាម្ចាស់ ជាមនុស្សទាំងស្រុង ជាសាច់ឈាមទាំងស្រុង និងជាព្រះដែលកំពុងតែធ្វើកិច្ចការ។ ភ្នែករបស់មនុស្សមើលឃើញរូបកាយខាងសាច់ឈាមមួយ ដែលគ្មានលក្ខណៈអធិធម្មជាតិសោះឡើយ ជាមនុស្សសាមញ្ញបំផុតដែលអាចនិយាយភាសាស្ថានសួគ៌ មិនធ្វើទីសម្គាល់ មិនធ្វើការអស្ចារ្យ ក៏រឹតតែមិនបង្ហាញសេចក្ដីពិតខាងក្នុងអំពីសាសនា នៅតាមសាលាប្រជុំធំៗផងដែរ។ ចំពោះមនុស្ស កិច្ចការនៃសាច់ឈាមជាមនុស្សលើកទីពីរ ហាក់ដូចជាផ្ទុយស្រឡះពីលើកទីមួយ គឺដល់ថ្នាក់គ្មានភាពដូចគ្នាសោះឡើយ ហើយក៏គ្មានកិច្ចការនៅលើកទីមួយ ដែលអាចមើលឃើញនៅលើកនេះផងដែរ។ ទោះបីកិច្ចការនៃសាច់ឈាមជាមនុស្សលើកទីពីរ មានលក្ខណៈខុសគ្នាពីលើកទីមួយក៏ដោយ ប៉ុន្តែវាមិនបានបញ្ជាក់ឡើយថា ប្រភពនៃព្រះទាំងពីរអង្គមិនមែនចេញពីប្រភពតែមួយ និងដូចគ្នានោះឡើយ។ ប្រភពរបស់ពួកទ្រង់ដូច ឬមិនដូចគ្នា គឺអាស្រ័យលើលក្ខណៈនៃកិច្ចការដែលត្រូវបានធ្វើឡើង ដោយសាច់ឈាម មិនមែនដោយសំបកខាងក្រៅរបស់ពួកទ្រង់ឡើយ។ ក្នុងអំឡុងពេលនៃដំណាក់កាលទាំងបីនៃកិច្ចការរបស់ទ្រង់ ព្រះជាម្ចាស់បានយកកំណើតជាមនុស្សចំនួនពីរលើក ហើយទាំងពីរលើកនេះ កិច្ចការរបស់ព្រះដែលយកកំណើតជាមនុស្ស ចាប់ផ្ដើមនូវយុគសម័យថ្មី គឺនាំមកនូវកិច្ចការមួយថ្មីដូច្នេះ ការយកកំណើតជាមនុស្សទាំងនេះជួយបំពេញគ្នាទៅវិញទៅមក។ ភ្នែកមនុស្សមិនអាចប្រាប់បានឡើយថា សាច់ឈាមទាំងពីរចេញមកពីប្រភពតែមួយនោះ។ វាស្ដែងឲ្យឃើញយ៉ាងច្បាស់ថា ការនេះលើសពីសមត្ថភាពនៃភ្នែក ឬគំនិតរបស់មនុស្ស

ទៅទៀត។ ប៉ុន្តែ នៅក្នុងសារជាតិរបស់ពួកទ្រង់ ពួកទ្រង់គឺដូចគ្នា ដ្បិតកិច្ចការរបស់ពួកទ្រង់មានប្រភពចេញពីព្រះវិញ្ញាណដូចគ្នា។ ទោះបីសាច់ឈាមជាមនុស្សទាំងពីរនេះចេញមកពីប្រភពដូចគ្នាក៏ដោយ ប៉ុន្តែវាមិនអាចត្រូវបានវិនិច្ឆ័យដោយយុគសម័យ និងទីកន្លែងដែលពួកទ្រង់បានប្រសូត ឬដោយកត្តាបែបនេះឡើយ ប៉ុន្តែត្រូវវិនិច្ឆ័យដោយកិច្ចការរបស់ព្រះដែលបានស្ដែងចេញតាមរយៈពួកទ្រង់វិញ។ សាច់ឈាមជាមនុស្សលើកទីពីរ មិនធ្វើកិច្ចការណាមួយដែលព្រះយេស៊ូវបានធ្វើរួចឡើយ ព្រោះកិច្ចការរបស់ព្រះជាម្ចាស់មិនប្រកាន់ខ្ជាប់តាមកិច្ចព្រមព្រៀងឡើយ ប៉ុន្តែបើកផ្លូវមួយថ្មីនៅគ្រប់ពេលវិញ។ សាច់ឈាម ជាមនុស្សលើកទីពីរមិនមានគោលបំណងធ្វើឲ្យការសម្ដែងចេញនៃសាច់ឈាមលើកទីមួយកាន់ស៊ីជម្រៅ ឬរឹងមាំនៅក្នុងគំនិតរបស់មនុស្សឡើយ ប៉ុន្តែ ដើម្បីបំពេញបន្ថែម និងធ្វើឲ្យវាគ្រប់លក្ខណ៍គឺដើម្បីឲ្យចំណេះដឹងរបស់មនុស្សអំពីព្រះជាម្ចាស់ កាន់តែស៊ីជម្រៅ ដើម្បីកាត់ផ្ដាច់រាល់ច្បាប់វិន័យ ដែលមាននៅក្នុងដួងចិត្តរបស់មនុស្ស និងដើម្បីបោសសម្អាតរូបអង្គបំភាន់អំពីព្រះជាម្ចាស់នៅក្នុងដួងចិត្តរបស់ពួកគេ។ គឺអាចនិយាយបានថា គ្មានដំណាក់កាលណាមួយនៃកិច្ចការរបស់ព្រះជាម្ចាស់ផ្ទាល់ អាចផ្ដល់ឲ្យមនុស្សមានចំណេះដឹងពេញលេញអំពីទ្រង់ឡើយ ប៉ុន្តែដំណាក់កាលនីមួយៗ ជួយផ្ដល់នូវចំណែកខ្លះតែប៉ុណ្ណោះមិនមែនចំណែកពេញលេញឡើយ។ ទោះបីជាព្រះជាម្ចាស់បានសម្ដែងនិស្ស័យរបស់ទ្រង់យ៉ាងពេញលេញក៏ដោយ ប៉ុន្តែដោយសារតែការយល់ដឹងរបស់មនុស្សមានកម្រិត ដូច្នេះចំណេះដឹងរបស់គេអំពីព្រះជាម្ចាស់នៅតែបន្តមិនពេញលេញដដែល។ ការប្រើប្រាស់ភាសាមនុស្សលោក គឺមិនអាចពន្យល់អំពីនិស្ស័យរបស់ព្រះជាម្ចាស់ទាំងស្រុងបាននោះឡើយ។ លើសពីនេះទៅទៀត តើដំណាក់កាលតែមួយនៃកិច្ចការរបស់ទ្រង់ អាចសម្ដែងអំពីព្រះជាម្ចាស់យ៉ាងពេញលេញបានយ៉ាងដូចម្ដេចទៅ? ទ្រង់ធ្វើការនៅក្នុងសាច់ឈាម ក្រោមការគ្របបាំងនៃភាពជាមនុស្សសាមញ្ញរបស់ទ្រង់ ហើយមនុស្សអាចស្គាល់ទ្រង់បាន តាមរយៈការសម្ដែងចេញនៃភាពជាព្រះរបស់ទ្រង់ប៉ុណ្ណោះ មិនមែនតាមរយៈសំបកកាយរបស់ទ្រង់នោះឡើយ។ ព្រះជាម្ចាស់យាងមកនៅក្នុងសាច់ឈាម

ដើម្បីអនុញ្ញាតឲ្យមនុស្សស្គាល់ទ្រង់ តាមរយៈវិធីផ្សេងៗក្នុងកិច្ចការរបស់ទ្រង់ ហើយដំណាក់កាលទាំងពីរនៃកិច្ចការរបស់ទ្រង់ មិនមានលក្ខណៈដូចគ្នានោះឡើយ។ មានតែធ្វើបែបនេះទេ ទើបមនុស្សអាចមានចំណេះដឹងពេញលេញអំពីកិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងសាច់ឈាម មិនមែនកម្រិតត្រឹមរបៀបតែមួយនោះឡើយ។ ទោះបីកិច្ចការនៃសាច់ឈាមជាមនុស្សទាំងពីរ មានលក្ខណៈខុសគ្នាក៏ដោយ ក៏សារជាតិនៃសាច់ឈាម និងប្រភពនៃកិច្ចការរបស់ពួកទ្រង់ មានលក្ខណៈដូចគ្នាដែរ។ អាចនិយាយបានថា ពួកទ្រង់យាងមក ដើម្បីធ្វើដំណាក់កាលនៃកិច្ចការពីរផ្សេងគ្នា ហើយលេចឡើងនៅក្នុងយុគសម័យពីរខុសគ្នា។ មិនថាបែបណានោះឡើយ សាច់ឈាមជាមនុស្សរបស់ព្រះជាម្ចាស់មានសារជាតិដូចគ្នា និងប្រភពដើមដូចគ្នា។ នេះជាសេចក្ដីពិតមួយដែលគ្មាននរណាម្នាក់អាចបដិសេធបានឡើយ។

## កិច្ចការរបស់ព្រះជាម្ចាស់ និងការអនុវត្តរបស់មនុស្ស

កិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងចំណោមមនុស្ស មិនអាចដាច់ចេញពីមនុស្សបានឡើយ ព្រោះថាមនុស្សគឺជាដើមហេតុនៃកិច្ចការនេះ និងជាសត្តនិករតែមួយគត់ដែលត្រូវបានបង្កើតឡើងដោយព្រះជាម្ចាស់ ដែលអាចធ្វើទីបន្ទាល់អំពីព្រះជាម្ចាស់បាន។ ជីវិតរបស់មនុស្ស និងគ្រប់សកម្មភាពរបស់មនុស្សមិនអាចដាច់ចេញពីព្រះជាម្ចាស់បានទេ ហើយអ្វីៗគ្រប់យ៉ាង ត្រូវបានគ្រប់គ្រងដោយព្រះហស្តរបស់ព្រះជាម្ចាស់ ដូច្នេះ អាចនិយាយបានថា គ្មានមនុស្សណាម្នាក់អាចរស់នៅដោយឯករាជ្យពីព្រះជាម្ចាស់នោះឡើយ។ គ្មាននរណាម្នាក់អាចបដិសេធចំណុចនេះបានទេ ព្រោះថាវាជាការពិត។ គ្រប់កិច្ចការដែលព្រះជាម្ចាស់ធ្វើ គឺសម្រាប់ជាប្រយោជន៍ដល់មនុស្សជាតិ និងដើម្បីប្រឆាំងនឹងផែនការអាក្រក់របស់សាតាំង។ អ្វីគ្រប់យ៉ាងដែលមនុស្សត្រូវការគឺចេញមកពីព្រះជាម្ចាស់ ហើយព្រះជាម្ចាស់ ជាប្រភពនៃជីវិតរបស់មនុស្ស។ ដូច្នេះមនុស្សមិនអាចឃ្លាតឆ្ងាយចេញពីព្រះជាម្ចាស់បានឡើយ។ លើស

ពីនេះទៅទៀត ព្រះជាម្ចាស់ក៏មិនដែលមានព្រះហឫទ័យចង់ឃ្លាតចេញពីមនុស្សនោះដែរ។ កិច្ចការដែលព្រះជាម្ចាស់ធ្វើ គឺសម្រាប់ជាប្រយោជន៍ដល់មនុស្សជាតិទាំងពួង ហើយព្រះតម្រិះរបស់ទ្រង់តែងតែសប្បុរសជានិច្ច។ សម្រាប់មនុស្ស កិច្ចការ និងព្រះតម្រិះរបស់ព្រះជាម្ចាស់ (ដែលជាព្រះហឫទ័យរបស់ព្រះជាម្ចាស់) គឺជា «និមិត្ត» ដែលមនុស្សគួរតែដឹង។ និមិត្តទាំងនេះក៏ជាការគ្រប់គ្រងរបស់ព្រះជាម្ចាស់ដែរ ហើយវាជាកិច្ចការដែលមនុស្សគ្មានសមត្ថភាពនឹងធ្វើឡើយ។ សេចក្តីតម្រូវរបស់ព្រះជាម្ចាស់សម្រាប់មនុស្សក្នុងអំឡុងពេលនៃកិច្ចការរបស់ទ្រង់នាពេលបច្ចុប្បន្នត្រូវបានហៅថាជា «ការអនុវត្ត» របស់មនុស្ស។ និមិត្តគឺជាកិច្ចការរបស់ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ ជាព្រះហឫទ័យរបស់ទ្រង់សម្រាប់មនុស្សជាតិ ឬជាគោលបំណង និងភាពសំខាន់នៃកិច្ចការរបស់ទ្រង់។ និមិត្តក៏អាចត្រូវបានហៅថាជាផ្នែកមួយនៃការគ្រប់គ្រងដែរ ព្រោះការគ្រប់គ្រងនេះជាកិច្ចការរបស់ព្រះជាម្ចាស់ និងផ្តោតសំខាន់លើមនុស្សដូច្នេះ នេះជាកិច្ចការដែលព្រះជាម្ចាស់ធ្វើនៅក្នុងចំណោមមនុស្ស។ កិច្ចការនេះគឺជាភស្តុតាង និងជាផ្លូវមួយដែលមនុស្សត្រូវឆ្លងកាត់ដើម្បីស្គាល់ព្រះជាម្ចាស់ ហើយវាពិតជាសំខាន់ណាស់សម្រាប់មនុស្ស។ ប្រសិនបើមនុស្សគ្រាន់តែយកចិត្តទុកដាក់ ចំពោះគោលលទ្ធិនៃជំនឿលើព្រះជាម្ចាស់ ឬចំពោះសេចក្តីលម្អិតដែលមិនសំខាន់ ជាជាងយកចិត្តទុកដាក់ ចំពោះចំណេះដឹងអំពីកិច្ចការរបស់ព្រះជាម្ចាស់ នោះពួកគេនឹងមិនស្គាល់ព្រះជាម្ចាស់ទេ ហើយលើសពីនេះទៅទៀត ពួកគេនឹងមិនអាចក្លាយជាមនុស្សដែលស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់បានឡើយ។ កិច្ចការរបស់ព្រះជាម្ចាស់ដែលមានប្រយោជន៍ដ៏លើសលប់ដល់ចំណេះដឹងរបស់មនុស្សអំពីព្រះជាម្ចាស់ ត្រូវបានហៅថាជានិមិត្ត។ និមិត្តទាំងនេះគឺជាកិច្ចការរបស់ព្រះជាម្ចាស់ ជាព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងជាគោលបំណង ព្រមទាំងជាភាពសំខាន់នៃកិច្ចការរបស់ព្រះជាម្ចាស់ ហើយវាសុទ្ធតែមានប្រយោជន៍ចំពោះមនុស្ស។ ការអនុវត្តសំដៅទៅលើកិច្ចការដែលមនុស្សគួរតែធ្វើ ជាកិច្ចការដែលគួរតែធ្វើដោយសត្តនិករដែលដើរតាមព្រះជាម្ចាស់ ហើយក៏ជាភារកិច្ចរបស់មនុស្សដែរ។ អ្វីដែលមនុស្សគួរតែធ្វើ មិនមែនជាសេចក្តីដែល

មនុស្សកាលពីដើមដំបូងបានយល់នោះឡើយ ប៉ុន្តែវាជាសេចក្ដីតម្រូវរបស់ព្រះជាម្ចាស់ សម្រាប់មនុស្សក្នុងអំឡុងពេលនៃកិច្ចការរបស់ទ្រង់។ សេចក្ដីតម្រូវទាំងនេះកាន់តែជ្រាលជ្រៅ និងសង់ឡើងពីលើគ្នាបន្តិចម្ដងៗ នៅពេលដែលព្រះជាម្ចាស់ធ្វើការ។ ឧទាហរណ៍ ក្នុងអំឡុងយុគសម័យនៃក្រឹត្យវិន័យ មនុស្សត្រូវកាន់តាមក្រឹត្យវិន័យ ហើយក្នុងអំឡុងយុគសម័យនៃព្រះគុណ មនុស្សត្រូវលីឈើឆ្កាង។ យុគសម័យនៃនគរព្រះមានលក្ខណៈខុសពីនេះ៖ សេចក្ដីតម្រូវចំពោះមនុស្ស មានកម្រិតខ្ពស់ជាងសេចក្ដីតម្រូវនៅក្នុងអំឡុងយុគសម័យនៃក្រឹត្យវិន័យ និងយុគសម័យនៃព្រះគុណ។ នៅពេលដែលនិមិត្តកាន់តែលើកខ្ពស់ នោះសេចក្ដីតម្រូវចំពោះមនុស្សក៏ឡើងកាន់តែខ្ពស់ កាន់តែច្បាស់ និងកាន់តែពិតដែរ។ ដូច្នេះ និមិត្តក៏កាន់តែពិតផងដែរ។ និមិត្តដ៏ពិតជាច្រើនទាំងនេះ មិនគ្រាន់តែជាលទ្ធផលកើតចេញពីការស្ដាប់បង្គាប់របស់មនុស្សចំពោះព្រះជាម្ចាស់ប៉ុណ្ណោះទេ ប៉ុន្តែលើសពីនេះ វាក៏កើតចេញពីចំណេះដឹងរបស់គេអំពីព្រះជាម្ចាស់ដែរ។

បើប្រៀបធៀបនឹងយុគសម័យមុនៗ កិច្ចការរបស់ព្រះជាម្ចាស់ក្នុងអំឡុងយុគសម័យនៃនគរព្រះ សម្រាប់អស់អ្នកដែលដើរតាមទ្រង់ នឹងកាន់តែមានលក្ខណៈជាក់ស្ដែង កាន់តែផ្ដោតលើលក្ខណៈសំខាន់ និងការផ្លាស់ប្ដូររបស់មនុស្សនៅក្នុងនិស្ស័យរបស់គេ និងកាន់តែអាចធ្វើទីបន្ទាល់អំពីព្រះជាម្ចាស់ផ្ទាល់។ អាចនិយាយម្យ៉ាងទៀតបានថា ក្នុងអំឡុងយុគសម័យនៃនគរព្រះ នៅពេលដែលទ្រង់ធ្វើការ ព្រះជាម្ចាស់ក៏បង្ហាញអង្គទ្រង់ទៅកាន់មនុស្សច្រើនជាងពេលណាៗកាលពីអតីតកាលដែរ ដូច្នេះនិមិត្តដែលមនុស្សគួរតែដឹង នឹងមានកម្រិតខ្ពស់ជាងយុគសម័យមុនៗ។ ដោយសារតែកិច្ចការរបស់ព្រះជាម្ចាស់ នៅក្នុងចំណោមមនុស្សបានចូលទៅក្នុងដែនដីមួយដែលមិនធ្លាប់មានកាលពីមុន នោះនិមិត្តដែលមនុស្សត្រូវដឹងក្នុងអំឡុងយុគសម័យនៃនគរព្រះ ក៏មានកម្រិតខ្ពស់បំផុត នៅក្នុងចំណោមគ្រប់កិច្ចការនៃការគ្រប់គ្រងដែរ។ កិច្ចការរបស់ព្រះជាម្ចាស់ បានចូលក្នុងដែនដីមួយដែលមិនធ្លាប់មានពីមុនមក ហើយនិមិត្តដែលមនុស្សត្រូវដឹង ក៏ក្លាយជាកម្រិតដ៏ខ្ពស់បំផុតនៅក្នុង

ចំណោមនិមិត្តទាំងអស់ ហើយលទ្ធផលនៃការអនុវត្តរបស់មនុស្ស ក៏ខ្ពស់ជាងយុគសម័យមុនៗដែរ ដ្បិតការអនុវត្តរបស់មនុស្សផ្លាស់ប្ដូរទៅតាមនិមិត្ត ហើយភាពសម្រេចនៃនិមិត្តក៏គូសបញ្ជាក់ពីភាពគ្រប់លក្ខណ៍នៃសេចក្ដីតម្រូវរបស់មនុស្សដែរ។ ពេលណាគ្រប់កិច្ចការនៃការគ្រប់គ្រងរបស់ព្រះជាម្ចាស់ត្រូវបានផ្អាក នោះការអនុវត្តរបស់មនុស្សក៏ត្រូវផ្អាកដែរ ហើយបើគ្មានកិច្ចការរបស់ព្រះជាម្ចាស់ទេ នោះមនុស្សនឹងគ្មានជម្រើសអ្វីក្រៅពីបន្តកាន់តាមគោលលទ្ធិពីអតីតកាលឡើយ បើមិនដូច្នោះទេ ពួកគេនឹងគ្មានកន្លែងដែលត្រូវទៅនោះទេ។ បើគ្មាននិមិត្តថ្មីៗទេ នោះមនុស្សក៏នឹងគ្មានការអនុវត្តថ្មីៗដែរ។ បើគ្មាននិមិត្តដ៏គ្រប់លក្ខណ៍ទេ នោះមនុស្សនឹងគ្មានការអនុវត្តដ៏គ្រប់លក្ខណ៍ឡើយ។ ហើយបើគ្មាននិមិត្តកាន់តែខ្ពស់ទេ នោះមនុស្សក៏នឹងគ្មានការអនុវត្តកាន់តែខ្ពស់ដែរ។ ការអនុវត្តរបស់មនុស្សផ្លាស់ប្ដូរទៅតាមជំហានព្រះបាទារបស់ព្រះជាម្ចាស់ ហើយចំណេះដឹង និងបទពិសោធរបស់មនុស្ស ក៏ផ្លាស់ប្ដូរទៅតាមកិច្ចការរបស់ព្រះជាម្ចាស់ដែរ។ មិនថាមនុស្សមានសមត្ថភាពកម្រិតណា ក៏គេនៅតែមិនអាចដាច់ចេញពីព្រះជាម្ចាស់បានដែរ ហើយប្រសិនបើព្រះជាម្ចាស់ ឈប់ធ្វើការតែមួយភ្លែត មនុស្សនឹងត្រូវស្លាប់ភ្លាមដោយសារតែសេចក្ដីក្រោធរបស់ទ្រង់ជាក់ជាមិនខាន។ មនុស្សគ្មានអ្វីដែលត្រូវអួតឡើយ មិនថាសព្វថ្ងៃនេះ ពួកគេមានចំណេះដឹងខ្ពង់ខ្ពស់កម្រិតណា មិនថាពួកគេមានបទពិសោធច្រើនប៉ុនណា ក៏គេមិនអាចដាច់ចេញពីកិច្ចការរបស់ព្រះជាម្ចាស់បានដែរ ព្រោះការអនុវត្តរបស់មនុស្ស និងការដែលគេគួរតែស្វែងរកព្រះជាម្ចាស់ នៅក្នុងសេចក្ដីជំនឿរបស់គេ គឺមិនអាចដាច់ចេញពីនិមិត្តបានឡើយ។ នៅក្នុងគ្រប់ហេតុការណ៍នៃកិច្ចការរបស់ព្រះជាម្ចាស់ វាមាននូវនិមិត្តដែលមនុស្សគួរតែដឹង និងមាននូវសេចក្ដីតម្រូវដ៏សមស្រប ដែលមនុស្សត្រូវធ្វើតាម។ បើសិនគ្មាននិមិត្តដែលជាគ្រឹះមូលដ្ឋានទាំងនេះទេ នោះមនុស្សនឹងគ្មានសមត្ថភាពក្នុងការអនុវត្ត ហើយមនុស្សក៏មិនអាចដើរតាមព្រះជាម្ចាស់ដោយមិនងាករេបានដែរ។ ប្រសិនបើមនុស្សមិនស្គាល់ព្រះជាម្ចាស់ ឬមិនយល់អំពីព្រះហឫទ័យរបស់ព្រះជាម្ចាស់ទេ នោះគ្រប់កិច្ចការដែលមនុស្សធ្វើ គឺជារឿងឥតប្រយោជន៍ ហើយមិន

អាចឲ្យព្រះជាម្ចាស់ទទួលយកបានឡើយ។ មិនថាមនុស្សមានអំណោយទានច្រើនប៉ុនណានោះទេ ក៏គេមិនអាចដាច់ចេញពីកិច្ចការ និងការដឹកនាំរបស់ព្រះជាម្ចាស់នោះដែរ។ មិនថាទង្វើដែលគេប្រព្រឹត្តល្អយ៉ាងណា ឬគេបានធ្វើសកម្មភាពជាច្រើនបែបណានោះឡើយ ប៉ុន្ដែទង្វើទាំងនោះនៅតែមិនអាចជំនួសឲ្យកិច្ចការរបស់ព្រះជាម្ចាស់បានដដែល។ ដូច្នេះ ទោះស្ថិតក្នុងកាលៈទេសៈអ្វីក៏ដោយ ក៏ការអនុវត្តរបស់មនុស្សមិនអាចដាច់ចេញពីនិមិត្តបានដែរ។ អស់អ្នកណាដែលមិនទទួលបាននិមិត្តថ្មីៗ ក៏គ្មានការអនុវត្តថ្មីៗដែរ។ ការអនុវត្តរបស់គេគ្មានទាក់ទងទៅនឹងសេចក្ដីពិតទេ ព្រោះពួកគេកាន់តាមគោលលទ្ធិ និងគោរពតាមក្រឹត្យវិន័យដែលស្លាប់ ហើយពួកគេគ្មាននិមិត្តថ្មីៗទាល់តែសោះ ដូច្នេះ ជាលទ្ធផល ពួកគេមិនបានអនុវត្តតាមអ្វីមួយចេញពីយុគសម័យថ្មីនោះឡើយ។ ពួកគេបានបាត់បង់និមិត្ត ហើយដោយសារតែការនេះពួកគេក៏បានបាត់បង់កិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធ និងបាត់បង់សេចក្ដីពិតដែរ។ រាល់សេចក្ដីទាំងឡាយណាដែលគ្មានសេចក្ដីពិត គឺជាគំនិតចោលម្សៀត ហើយវាជាគំនិតរបស់សាតាំង។ មិនថាមនុស្សម្នាក់មានលក្ខណៈបែបណានោះទេ ពួកគេមិនអាចគ្មាននិមិត្តអំពីកិច្ចការរបស់ព្រះជាម្ចាស់ ព្រមទាំងមិនអាចគ្មានព្រះវត្តមានរបស់ព្រះវិញ្ញាណបរិសុទ្ធបានឡើយ ព្រោះថានៅពេលណាដែលគេបាត់បង់និមិត្តភ្លាមៗ នោះគេនឹងធ្លាក់ចូលទៅក្នុងស្ថានឃុំព្រលឹង ហើយរស់នៅក្នុងសេចក្ដីងងឹតជាក់ជាមិនខាន។ មនុស្សដែលគ្មាននិមិត្ត គឺជាអស់អ្នកណាដែលដើរតាមព្រះជាម្ចាស់ទាំងល្ងិតល្ងង់ ពួកគេជាមនុស្ស ដែលគ្មានកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធ ហើយពួកគេកំពុងតែរស់នៅក្នុងស្ថាននរក។ មនុស្សបែបនេះមិនដេញតាមសេចក្ដីពិតបានឡើយ ផ្ទុយទៅវិញពួកគេព្យួរព្រះនាមរបស់ព្រះជាម្ចាស់ដូចជាផ្ទាំងឃោសនាអ៊ីចឹង។ អស់អ្នកណាដែលមិនដឹងអំពីកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធ មិនស្គាល់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស មិនដឹងអំពីដំណាក់កាលទាំងបីនៃកិច្ចការនៅក្នុងការគ្រប់គ្រងទាំងមូលរបស់ព្រះជាម្ចាស់ ពួកគេទាំងនោះក៏មិនដឹងអំពីនិមិត្ត និងគ្មានសេចក្ដីពិតដែរ។ តើមនុស្សទាំងឡាយណាដែលគ្មានសេចក្ដីពិត មិនមែនសុទ្ធតែជាមនុស្សទុច្ចរិតទេឬអី? អស់អ្នក

ណាដែលព្រមអនុវត្តតាមសេចក្ដីពិត ព្រមស្វែងរកចំណេះដឹងអំពីព្រះជាម្ចាស់ និងព្រមសហការជាមួយព្រះជាម្ចាស់យ៉ាងពិតប្រាកដ គឺជាមនុស្សដែលយកនិមិត្តធ្វើជាគ្រឹះមូលដ្ឋាន។ ព្រះជាម្ចាស់នឹងទទួលយកពួកគេ ព្រោះពួកគេសហការជាមួយទ្រង់ ហើយគឺកិច្ចសហប្រតិបត្តិការនេះហើយដែលមនុស្សគួរតែយកទៅអនុវត្ត។

នៅក្នុងនិមិត្ត វាមាននូវមាគ៌ាជាច្រើនដែលត្រូវអនុវត្ត។ ការទាមទារជាក់ស្ដែងដែលមនុស្សត្រូវធ្វើ ក៏មាននៅក្នុងនិមិត្តដែរ ហើយវាជាកិច្ចការដែលមនុស្សគួរតែដឹង។ កាលពីអតីតកាល ក្នុងអំឡុងពេលនៃកិច្ចប្រជុំដ៏ពិសេស ឬការប្រជុំធំៗដែលត្រូវធ្វើឡើងនៅតាមទីកន្លែងផ្សេងៗ វាមានតែទិដ្ឋភាពមួយអំពីមាគ៌ានៃការអនុវត្តប៉ុណ្ណោះដែលត្រូវបានលើកឡើង។ ការអនុវត្តបែបនេះ គឺជាកិច្ចការដែលត្រូវយកទៅអនុវត្តនៅក្នុងអំឡុងយុគសម័យនៃព្រះគុណ ហើយកម្រមានការពាក់ព័ន្ធនឹងចំណេះដឹងអំពីព្រះជាម្ចាស់ណាស់ ព្រោះថានិមិត្តអំពីយុគសម័យនៃព្រះគុណ គ្រាន់តែជានិមិត្តអំពីការជាប់ឆ្កាងរបស់ព្រះយេស៊ូវប៉ុណ្ណោះ ហើយវាគ្មាននិមិត្តអ្វីដែលធំអស្ចារ្យជាងនេះទៀតឡើយ។ មនុស្សគួរតែមានចំណេះដឹងលើសពីកិច្ចការប្រោសលោះមនុស្សជាតិរបស់ទ្រង់តាមរយៈការជាប់ឆ្កាង ហើយក្នុងអំឡុងយុគសម័យនៃព្រះគុណ វាគ្មាននិមិត្តអ្វីផ្សេងដែលមនុស្សត្រូវដឹងនោះឡើយ។ បើបែបនេះ មនុស្សមានចំណេះដឹងមិនគ្រប់គ្រាន់អំពីព្រះជាម្ចាស់នោះទេ ហើយក្រៅពីចំណេះដឹងអំពីសេចក្ដីស្រឡាញ់ និងសេចក្ដីមេត្តាករុណារបស់ព្រះយេស៊ូវ វាមាននូវរឿងដ៏សាមញ្ញៗ និងគួរឲ្យអាណិតតិចតួចបំផុតដែលមនុស្សអាចយកទៅអនុវត្ត ហើយក៏មានលក្ខណៈខុសប្លែកឆ្ងាយពីពេលបច្ចុប្បន្ននេះដែរ។ កាលពីអតីតកាល មិនថាពួកជំនុំដែលគេចូលរួមមានទម្រង់បែបណា ក៏មនុស្សគ្មានសមត្ថភាពក្នុងការនិយាយអំពីចំណេះដឹងជាក់ស្ដែងទាក់ទងនឹងកិច្ចការរបស់ព្រះជាម្ចាស់ដែរ ហើយក៏គ្មាននរណាម្នាក់អាចនិយាយច្បាស់ៗអំពីផ្លូវនៃការអនុវត្តដ៏សក្ដិសមបំផុតសម្រាប់មនុស្ស ដើម្បីចាប់ផ្ដើមនោះដែរ។ មនុស្សគ្រាន់តែបន្ថែមសេចក្ដីលម្អិតដ៏សាមញ្ញចំនួនពីរបីទៅក្នុងគ្រឹះមូលដ្ឋាននៃការអត់ទ្រាំ និងការអត់ធ្មត់ប៉ុណ្ណោះ ប៉ុន្តែវាគ្មាននូវការផ្លាស់ប្ដូរនៅក្នុងលក្ខណៈសំខាន់នៃការអនុវត្ត

របស់គេទេ ព្រោះថានៅក្នុងយុគសម័យដដែលនោះ ព្រះជាម្ចាស់មិនបានធ្វើកិច្ចការថ្មីៗនោះឡើយ ហើយសេចក្ដីតម្រូវតែមួយគត់របស់ទ្រង់សម្រាប់មនុស្ស គឺជាការអត់ទ្រាំ និងការអត់ធ្មត់ ឬការលីឈើឆ្កាង។ ក្រៅពីការអនុវត្តទាំងនេះ វាគ្មាននិមិត្តណាមួយដែលខ្ពស់ជាងការជាប់ឆ្កាង របស់ព្រះយេស៊ូវឡើយ។ កាលពីអតីតកាល វាគ្មានការលើកឡើងអំពីនិមិត្តណាផ្សេងឡើយ ដោយសារតែព្រះជាម្ចាស់មិនបានធ្វើកិច្ចការដ៏អស្ចារ្យ និងដោយសារតែទ្រង់មានការទាមទារដ៏មានកម្រិតពីមនុស្ស។ ដោយហេតុផលនេះ មិនថាមនុស្សបានធ្វើអ្វីនោះឡើយ ក៏គេគ្មានសមត្ថភាពបំពានព្រំដែនទាំងនេះដែរ ទោះបីព្រំដែនទាំងនោះជាចំណុចសាមញ្ញៗ និងរាក់កំភែលចំនួនពីរបី ដែលមនុស្សត្រូវយកទៅអនុវត្តក៏ដោយ។ នៅថ្ងៃនេះ យើងចង់និយាយអំពីនិមិត្តផ្សេងទៀត ដោយសារតែកិច្ចការនាពេលសព្វថ្ងៃមានចំនួនលើសជាងកិច្ចការជាច្រើនដែលបានសម្រេចនៅក្នុងយុគសម័យនៃក្រឹត្យវិន័យ និងយុគសម័យនៃព្រះគុណ។ សេចក្ដីតម្រូវរបស់មនុស្ស ក៏មានកម្រិតខ្ពស់ជាង នៅក្នុងយុគសម័យពីអតីតកាលជាច្រើនដងដែរ។ ប្រសិនបើមនុស្សគ្មានសមត្ថភាពដឹងទាំងស្រុងអំពីកិច្ចការបែបនេះទេ កិច្ចការនោះនឹងគ្មានភាពសំខាន់ខ្លាំងឡើយ។ គឺអាចនិយាយបានថា មនុស្សនឹងមានការពិបាកក្នុងការដឹងយ៉ាងពេញលេញអំពីកិច្ចការបែបនេះប្រសិនបើគេមិនដាក់ចិត្តដាក់កាយខំប្រឹងប្រែងធ្វើកិច្ចការនេះពេញមួយជីវិតនោះទេ។ នៅក្នុងកិច្ចការនៃការយកឈ្នះ ការគ្រាន់តែនិយាយអំពីមាគ៌ានៃការអនុវត្ត នឹងធ្វើឲ្យការយកឈ្នះលើមនុស្សមិនអាចសម្រេចបាននោះឡើយ។ ការគ្រាន់តែនិយាយអំពីនិមិត្ត ដោយគ្មានសេចក្ដីតម្រូវតម្រូវសម្រាប់មនុស្ស ក៏នឹងធ្វើឲ្យកិច្ចការយកឈ្នះលើមនុស្សមិនអាចសម្រេចបានដែរ។ ប្រសិនបើមិននិយាយអ្វីផ្សេងក្រៅពីមាគ៌ានៃការអនុវត្តទេ នោះវានឹងមិនអាចទៅរួចឡើយក្នុងការតទល់ជាមួយទុក្ខវេទនារបស់មនុស្ស ឬលុបបំបាត់សញ្ញាណរបស់មនុស្ស ហើយវាក៏នឹងមិនអាចទៅរួច ក្នុងការយកឈ្នះលើមនុស្សបានទាំងស្រុងនោះដែរ។ និមិត្តគឺជាឧបករណ៍ដ៏សំខាន់នៃការយកឈ្នះលើមនុស្ស ប៉ុន្តែប្រសិនបើវាគ្មានមាគ៌ានៃការអនុវត្តចេញពីនិមិត្តទេ នោះមនុស្សនឹងគ្មានផ្លូវក្នុង

ការដើរតាមឡើយ បើដូច្នេះ គេគ្មានផ្លូវចូលទៅបានឡើយ។ ការនេះបានក្លាយជាគោលការណ៍មួយនៃកិច្ចការរបស់ព្រះជាម្ចាស់ តាំងពីដើមដំបូង រហូតដល់ទីបញ្ចប់៖ នៅក្នុងនិមិត្ត មាននូវកិច្ចការដែលអាចយកទៅអនុវត្ត ហើយក៏មាននិមិត្តបូកជាមួយការអនុវត្តដែរ។ កម្រិតនៃការផ្លាស់ប្ដូរនៅក្នុងជីវិត និងនិស្ស័យរបស់មនុស្ស ត្រូវតែដើរទន្ទឹមគ្នាជាមួយនឹងការផ្លាស់ប្ដូរនៅក្នុងនិមិត្ត។ ប្រសិនបើមនុស្សពឹងអាងទៅលើតែកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន នោះគេនឹងមិនអាចសម្រេចឲ្យមានការផ្លាស់ប្ដូរនៅកម្រិតដ៏ធំបានឡើយ។ និមិត្តថ្លែងអំពីកិច្ចការ និងការគ្រប់គ្រងរបស់ព្រះជាម្ចាស់។ ការអនុវត្ត គឺសំដៅទៅលើមាគ៌ានៃការអនុវត្តរបស់មនុស្ស និងផ្លូវនៃអត្ថិភាពរបស់មនុស្ស ដូច្នេះ នៅក្នុងការគ្រប់គ្រងទាំងអស់របស់ព្រះជាម្ចាស់ ទំនាក់ទំនងរវាងនិមិត្ត និងការអនុវត្ត គឺជាទំនាក់ទំនងរវាងព្រះជាម្ចាស់ និងមនុស្ស។ ប្រសិនបើនិមិត្តត្រូវបានដកចេញ ឬប្រសិនបើនិមិត្តទាំងនោះត្រូវបានថ្លែងចេញដោយមិនបាននិយាយអំពីការអនុវត្ត ឬប្រសិនបើមានតែនិមិត្ត ហើយការអនុវត្តរបស់មនុស្សត្រូវបានបំបាត់ចោល នោះអ្វីៗទាំងនេះមិនអាចត្រូវបានចាត់ទុកថាជាការគ្រប់គ្រងរបស់ព្រះជាម្ចាស់ឡើយ ហើយក៏មិនអាចនិយាយបានថា កិច្ចការរបស់ព្រះជាម្ចាស់ត្រូវបានសម្រេចសម្រាប់ជាប្រយោជន៍ដល់មនុស្សជាតិនោះដែរ។ នៅក្នុងន័យនេះ វាមិនគ្រាន់តែជាភារកិច្ចរបស់មនុស្ស ដែលត្រូវបានដកចោលប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាការបដិសេធចំពោះគោលបំណងនៃកិច្ចការរបស់ព្រះជាម្ចាស់ដែរ។ តាំងពីដើមដំបូង រហូតមកដល់ទីបញ្ចប់ ប្រសិនបើមនុស្សគ្រាន់តែត្រូវបានតម្រូវឲ្យអនុវត្ត ដោយគ្មានការពាក់ព័ន្ធនឹងកិច្ចការរបស់ព្រះជាម្ចាស់ ហើយលើសពីនេះ ប្រសិនបើមនុស្សមិនត្រូវបានតម្រូវឲ្យដឹងអំពីកិច្ចការរបស់ព្រះជាម្ចាស់ទេ នោះកិច្ចការទាំងនេះមិនអាចមានសិទ្ធិហៅថាជាការគ្រប់គ្រងរបស់ព្រះជាម្ចាស់ឡើយ។ ប្រសិនបើមនុស្សមិនស្គាល់ព្រះជាម្ចាស់ហើយមិនដឹងអំពីព្រះហឫទ័យរបស់ព្រះជាម្ចាស់ ព្រមទាំងអនុវត្តទាំងងងឹតងងល់នៅក្នុងផ្លូវដ៏ស្រពេចស្រពិល និងមិនច្បាស់លាស់ នោះគេនឹងមិនអាចក្លាយជាសត្តនិករដែលមានគុណសម្បត្តិដ៏ពេញលេញនោះឡើយ។ ដូច្នេះ កិច្ចការទាំងពីរនេះពិតជាសំខាន់

ខ្លាំងណាស់។ ប្រសិនបើមានតែកិច្ចការរបស់ព្រះជាម្ចាស់ ឬអាចនិយាយបានថា ប្រសិនបើមានតែនិមិត្ត ហើយគ្មានកិច្ចសហប្រតិបត្តិការ ឬការអនុវត្តពីមនុស្សទេនោះ កិច្ចការទាំងនេះ មិនអាចត្រូវបានហៅថាជាការគ្រប់គ្រង របស់ព្រះជាម្ចាស់ឡើយ។ ប្រសិនបើមានតែការអនុវត្ត និងច្រកចូលរបស់មនុស្ស នោះទោះបីជាមាគ៌ាដែលមនុស្សបានចាប់ផ្ដើមនោះខ្ពង់ខ្ពស់យ៉ាងណា ក៏វានឹងមិនអាចទទួលយកបានដែរ។ ច្រកចូលរបស់មនុស្សត្រូវតែផ្លាស់ប្ដូរបន្តិចម្ដងៗ ឲ្យស្របជាមួយកិច្ចការ និងនិមិត្ត ហើយវាមិនអាចផ្លាស់ប្ដូរ ក្នុងពេលតែមួយប៉ប្រិចភ្នែកនោះឡើយ។ គោលការណ៍នៃការអនុវត្តរបស់មនុស្ស មិនមែនធ្វើតាមចិត្តចង់ ហើយគ្មានព្រំដែនកំណត់នោះឡើយ ប៉ុន្តែត្រូវបានកំណត់ ដោយស្ថិតនៅក្នុងព្រំដែនជាក់លាក់។ គោលការណ៍បែបនេះផ្លាស់ប្ដូរស្របទៅតាមនិមិត្តនៃកិច្ចការ។ ដូច្នេះ ចុងបញ្ចប់ ការគ្រប់គ្រងរបស់ព្រះជាម្ចាស់ពាក់ព័ន្ធនឹងកិច្ចការរបស់ព្រះជាម្ចាស់ និងការអនុវត្តរបស់មនុស្ស។

កិច្ចការនៃការគ្រប់គ្រងបានកើតឡើងដោយសារតែមនុស្សជាតិប៉ុណ្ណោះ ដែលមានន័យថា វាបានចេញមកដោយសារតែអត្ថិភាពរបស់មនុស្សជាតិ។ នៅមុនមនុស្សជាតិឬកាលពីដើមដំបូង នៅពេលដែលផ្ទៃមេឃនិងផែនដី ព្រមទាំងរបស់សព្វសារពើត្រូវបានបង្កើតមក វាអត់ទាន់មានការគ្រប់គ្រងនៅឡើយទេ។ នៅក្នុងគ្រប់កិច្ចការរបស់ព្រះជាម្ចាស់ ប្រសិនបើគ្មានការអនុវត្តដែលមានប្រយោជន៍ចំពោះមនុស្សទេ គឺអាចនិយាយបានថា ប្រសិនបើព្រះជាម្ចាស់មិនបានបង្កើតសេចក្ដីតម្រូវដ៏សក្តិសមចំពោះមនុស្សជាតិដែលពុករលួយទេ (នៅក្នុងកិច្ចការដែលព្រះជាម្ចាស់ធ្វើ ប្រសិនបើគ្មានផ្លូវដ៏សមរម្យសម្រាប់ការអនុវត្តរបស់មនុស្ស) នោះកិច្ចការនេះមិនអាចត្រូវបានហៅថាជាការគ្រប់គ្រងរបស់ព្រះជាម្ចាស់ឡើយ។ ប្រសិនបើភាពពេញលេញនៃកិច្ចការរបស់ព្រះជាម្ចាស់ពាក់ព័ន្ធជាមួយតែការប្រាប់មនុស្សជាតិដ៏ពុករលួយអំពីរបៀបដែលពួកគេត្រូវអនុវត្ត ហើយព្រះជាម្ចាស់មិនបានផ្ដើមធ្វើគម្រោងណាមួយរបស់ទ្រង់ និងមិនបានបង្ហាញចេញនូវសព្វានុភាព ឬព្រះប្រាជ្ញាញាណរបស់ទ្រង់ សូម្បីតែបន្តិចទេ នោះមិនថាសេចក្ដីតម្រូវរបស់ព្រះជាម្ចាស់ចំពោះមនុស្សមានកម្រិតខ្ពស់ប៉ុនណា ហើយមិនថា

ព្រះជាម្ចាស់បានរស់នៅក្នុងចំណោមមនុស្សបានយូរយ៉ាងណានោះទេ ក៏មនុស្សនឹងមិនដឹងអំពីនិស្ស័យរបស់ព្រះជាម្ចាស់ឡើយ។ ប្រសិនបើករណីនេះកើតឡើង នោះកិច្ចការបែបនេះ នឹងមិនសក្តិសមក្នុងការហៅថាជាការគ្រប់គ្រងរបស់ព្រះជាម្ចាស់ឡើយ។ និយាយដោយងាយគឺថា កិច្ចការនៃការគ្រប់គ្រងរបស់ព្រះជាម្ចាស់ គឺជាកិច្ចការដែលត្រូវធ្វើដោយព្រះជាម្ចាស់ និងគ្រប់កិច្ចការដែលត្រូវបានអនុវត្តដោយមនុស្ស ដែលព្រះជាម្ចាស់បានទទួលយកក្រោមការដឹកនាំរបស់ព្រះជាម្ចាស់។ កិច្ចការបែបនេះហើយ ទើបអាចសង្ខេបថាជាការគ្រប់គ្រង។ អាចនិយាយម៉្យាងទៀតបានថា កិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងចំណោមមនុស្សក៏ដូចជាកិច្ចសហប្រតិបត្តិការជាមួយទ្រង់ពីសំណាក់មនុស្សដែលដើរតាមទ្រង់ ជារួមមកត្រូវបានហៅថា ការគ្រប់គ្រង។ នៅត្រង់នេះ កិច្ចការរបស់ព្រះជាម្ចាស់ត្រូវបានហៅថាជានិមិត្ត ហើយកិច្ចសហប្រតិបត្តិការរបស់មនុស្ស ត្រូវបានហៅថាជាការអនុវត្ត។ បើកិច្ចការរបស់ព្រះជាម្ចាស់មានកាន់តែខ្ពស់ (បើនិមិត្តមានកាន់តែខ្ពស់) នោះនិស្ស័យរបស់ព្រះជាម្ចាស់ នឹងត្រូវបើកសម្ដែងឲ្យមនុស្សឃើញកាន់តែច្បាស់ ហើយវាកាន់តែផ្ទុយគ្នាច្រើនពីសញ្ញាណរបស់មនុស្ស ហើយការអនុវត្ត និងកិច្ចសហប្រតិបត្តិការរបស់មនុស្ស ក៏មានកាន់តែខ្ពស់ដែរ។ បើសេចក្ដីតម្រូវសម្រាប់មនុស្ស មានកាន់តែខ្ពស់ នោះកិច្ចការរបស់ព្រះជាម្ចាស់នឹងកាន់តែផ្ទុយគ្នាច្រើនពីសញ្ញាណរបស់មនុស្ស ដែលជាលទ្ធផលកើតចេញពីទុក្ខវេទនារបស់មនុស្ស ហើយបទដ្ឋានដែលមនុស្សតម្រូវឲ្យបំពេញ ក៏មានកាន់តែខ្ពស់ដែរ។ សម្រាប់សេចក្ដីសន្និដ្ឋានអំពីកិច្ចការនេះ គ្រប់និមិត្តទាំងអស់នឹងត្រូវបានធ្វើឲ្យពេញខ្នាត ហើយកិច្ចការដែលមនុស្សតម្រូវឲ្យអនុវត្ត នឹងបានឡើងទៅដល់កម្រិតខ្ពស់បំផុតនៃភាពគ្រប់លក្ខណ៍។ ការនេះក៏នឹងក្លាយជាពេលវេលាមួយដែលបុគ្គលម្នាក់ៗត្រូវបានចាត់ថ្នាក់ទៅតាមប្រភេទផ្សេងៗដែរ ព្រោះថាសេចក្ដីដែលមនុស្សត្រូវបានតម្រូវឲ្យដឹង នឹងត្រូវបានបង្ហាញដល់គេ។ ដូច្នេះ នៅពេលដែលនិមិត្តឡើងដល់កម្រិតកំពូលរបស់វា នោះកិច្ចការនឹងមកដល់ទីបញ្ចប់ទៅតាមនោះ ហើយការអនុវត្តរបស់មនុស្សក៏នឹងបានឡើងដល់ទីកំពូលរបស់វាដែរ។ ការអនុវត្តរបស់មនុស្សត្រូវពឹងផ្អែក

លើកិច្ចការរបស់ព្រះជាម្ចាស់ ហើយការគ្រប់គ្រងរបស់ព្រះជាម្ចាស់ ត្រូវបានបង្ហាញចេញយ៉ាងពេញលេញតាមរយៈការអនុវត្ត និងកិច្ចសហប្រតិបត្តិការរបស់មនុស្សប៉ុណ្ណោះ។ មនុស្សគឺជាស្នាព្រះហស្តនៃកិច្ចការរបស់ព្រះជាម្ចាស់ និងជាកម្មវត្ថុនៃកិច្ចការគ្រប់គ្រងទាំងអស់របស់ព្រះជាម្ចាស់ ហើយក៏ជាផលិតផលនៃការគ្រប់គ្រងទាំងអស់របស់ព្រះជាម្ចាស់ដែរ។ ប្រសិនបើព្រះជាម្ចាស់ធ្វើការតែអង្គទ្រង់ ដោយគ្មានកិច្ចសហប្រតិបត្តិការរបស់មនុស្ស នោះវានឹងគ្មានអ្វីមួយដែលអាចបម្រើជារូបតំណាងអំពីកិច្ចការទាំងស្រុងរបស់ទ្រង់ឡើយ ហើយបើដូច្នេះ វានឹងគ្មានភាពសំខាន់សូម្បីតែបន្តិច ចំពោះការគ្រប់គ្រងរបស់ព្រះជាម្ចាស់។ ក្រៅពីកិច្ចការរបស់ព្រះជាម្ចាស់ មានតែតាមរយៈព្រះជាម្ចាស់ជ្រើសរើសកម្មវត្ថុដ៏សក្តិសម ដើម្បីបង្ហាញពីកិច្ចការរបស់ទ្រង់ និងបញ្ជាក់ពីសព្វានុភាព និងព្រះប្រាជ្ញាញាណរបស់ទ្រង់ប៉ុណ្ណោះ ទើបព្រះជាម្ចាស់អាចសម្រេចគោលបំណងនៃការគ្រប់គ្រងរបស់ទ្រង់ និងសម្រេចពីគោលបំណងនៃការប្រើប្រាស់អ្វីៗគ្រប់យ៉ាងនៃកិច្ចការនេះ ដើម្បីបង្ក្រាបសាតាំងបានទាំងស្រុង។ ដូច្នេះ មនុស្សគឺជាផ្នែកមួយដ៏សំខាន់នៃកិច្ចការគ្រប់គ្រងរបស់ព្រះជាម្ចាស់ ហើយមនុស្សគឺជាបុគ្គលតែម្នាក់គត់ដែលអាចធ្វើឲ្យការគ្រប់គ្រងរបស់ព្រះជាម្ចាស់បង្កើតជាផលផ្លែ និងសម្រេចគោលបំណងចុងក្រោយនៃកិច្ចការគ្រប់គ្រងនេះ។ ក្រៅពីមនុស្ស គ្មានទម្រង់ជីវិតណាផ្សេងដែលអាចរ៉ាប់រងនូវតួនាទីនេះបានឡើយ។ ប្រសិនបើមនុស្សត្រូវក្លាយជារូបតំណាងដ៏ពិតនៃកិច្ចការគ្រប់គ្រងរបស់ព្រះជាម្ចាស់ នោះការមិនស្ដាប់បង្គាប់របស់មនុស្សជាតិដ៏ពុករលួយត្រូវតែកម្ចាត់ចោលទាំងស្រុង។ ការនេះតម្រូវឲ្យមនុស្សទទួលបានការអនុវត្តដែលសក្តិសមសម្រាប់ពេលវេលាខុសៗគ្នា និងតម្រូវឲ្យព្រះជាម្ចាស់អនុវត្តនូវកិច្ចការដែលស្របគ្នានេះនៅក្នុងចំណោមមនុស្ស។ មានតែបែបនេះទេ ទើបចុងបញ្ចប់នឹងទទួលបានមនុស្សមួយក្រុមដែលជារូបតំណាងនៃកិច្ចការគ្រប់គ្រងរបស់ព្រះជាម្ចាស់។ កិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងចំណោមមនុស្សមិនអាចធ្វើទីបន្ទាល់អំពីព្រះជាម្ចាស់ផ្ទាល់តាមរយៈកិច្ចការរបស់ព្រះជាម្ចាស់តែម្យ៉ាងនោះឡើយ ប៉ុន្តែដើម្បីសម្រេចបានទីបន្ទាល់បែបនេះក៏តម្រូវឲ្យមានមនុស្សដ៏សកម្មដែលសក្តិសមសម្រាប់

កិច្ចការរបស់ទ្រង់ដែរ។ ជាដំបូងព្រះជាម្ចាស់នឹងធ្វើការនៅក្នុងមនុស្សទាំងនេះ ហើយតាមរយៈពួកគេកិច្ចការរបស់ទ្រង់ នឹងត្រូវបានស្ដែងចេញមក ដូច្នេះការធ្វើទីបន្ទាល់អំពីកិច្ចការរបស់ទ្រង់នឹងត្រូវកើតមាននៅក្នុងចំណោមសត្តនិករ ហើយតាមរបៀបនេះ ព្រះជាម្ចាស់នឹងបានសម្រេចគោលបំណងនៃកិច្ចការរបស់ទ្រង់។ ព្រះជាម្ចាស់មិនធ្វើការតែម្នាក់ឯងដើម្បីបង្រ្កាបសាតាំងឡើយ ដោយសារតែទ្រង់មិនអាចធ្វើទីបន្ទាល់ដោយផ្ទាល់អំពីអង្គទ្រង់នៅក្នុងចំណោមសត្តនិករទាំងអស់បានឡើយ។ ប្រសិនបើទ្រង់ត្រូវធ្វើបែបនេះ នោះវាមិនអាចទៅរួចឡើយក្នុងការបញ្ចុះបញ្ចូលឲ្យមនុស្សជឿទាំងស្រុង ដូច្នេះព្រះជាម្ចាស់ ត្រូវតែធ្វើការលើមនុស្សដើម្បីយកឈ្នះលើគេ ហើយមានតែបែបនេះទេ ទើបទ្រង់អាចទទួលបានទីបន្ទាល់មួយនៅក្នុងចំណោមសត្តនិករទាំងអស់។ ប្រសិនបើព្រះជាម្ចាស់ធ្វើការតែអង្គទ្រង់ ដោយគ្មានកិច្ចសហប្រតិបត្តិការរបស់មនុស្ស ឬប្រសិនបើមនុស្សមិនតម្រូវឲ្យចូលរួមសហការទេ នោះមនុស្សនឹងមិនអាចស្គាល់ពីនិស្ស័យរបស់ព្រះជាម្ចាស់បានឡើយ ហើយគេនឹងមិនដឹងជារៀងរហូតអំពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ បើដូច្នេះ កិច្ចការរបស់ព្រះជាម្ចាស់មិនអាចត្រូវបានហៅថាជាកិច្ចការគ្រប់គ្រងរបស់ព្រះជាម្ចាស់នោះឡើយ។ ប្រសិនបើមនុស្សខំប្រឹង ខំស្វែងរក និងខំធ្វើការដោយខ្លួនឯង ដោយមិនយល់អំពីកិច្ចការរបស់ព្រះជាម្ចាស់ នោះមនុស្សកំពុងតែលេងកំប្លែងហើយ។ បើគ្មានកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធទេ នោះអ្វីដែលមនុស្សធ្វើ គឺមកពីសាតាំង ហើយគាត់ជាមនុស្សបះបោរ និងជាមនុស្សទុច្ចរិត។ សាតាំងត្រូវបានស្ដែងចេញនៅក្នុងគ្រប់កិច្ចការដែលមនុស្សជាតិដ៏ពុករលួយបានធ្វើ ហើយវាគ្មានអ្វីមួយដែលស្របតាមព្រះជាម្ចាស់ឡើយ ដូច្នេះគ្រប់កិច្ចការដែលមនុស្សធ្វើ គឺជាការស្ដែងចេញអំពីសាតាំង។ នៅក្នុងរាល់សេចក្ដីដែលត្រូវបានលើកឡើង គ្មានអ្វីមួយដែលមានភាពពាក់ព័ន្ធនឹងនិមិត្ត និងការអនុវត្តនោះឡើយ។ ពីលើគ្រឹះមូលដ្ឋាននៃនិមិត្ត មនុស្សរកឃើញការអនុវត្ត និងមាគ៌ានៃការស្ដាប់បង្គាប់ ដើម្បីឲ្យគេអាចលះបង់ចោលសញ្ញាណរបស់គេ ហើយទទួលយកសេចក្ដីដែលគេមិនធ្លាប់មានកាលពីអតីតកាល។ ព្រះជាម្ចាស់តម្រូវឲ្យមនុស្សសហការជាមួយ

ទ្រង់ តម្រូវឲ្យមនុស្សចុះចូលទាំងស្រុងចំពោះសេចក្ដីតម្រូវរបស់ទ្រង់ និងតម្រូវឲ្យមនុស្សមើលឃើញកិច្ចការដែលត្រូវបានធ្វើដោយព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ មានបទពិសោធពីព្រះចេស្ដារបស់ព្រះជាម្ចាស់ និងស្គាល់ពីនិស្ស័យរបស់ព្រះជាម្ចាស់។ ជារួមមក ទាំងនេះគឺជាការគ្រប់គ្រងរបស់ព្រះជាម្ចាស់។ ការរួបរួមរបស់ព្រះជាម្ចាស់ជាមួយមនុស្ស គឺជាការគ្រប់គ្រង ហើយនោះគឺជាការគ្រប់គ្រងដ៏ធំបំផុត។

កិច្ចការដែលពាក់ព័ន្ធនឹងនិមិត្ត ជាចម្បងសំដៅទៅលើកិច្ចការរបស់ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ ហើយកិច្ចការដែលពាក់ព័ន្ធនឹងការអនុវត្ត គឺជាកិច្ចការដែលមនុស្សគួរតែធ្វើ ហើយវាមិនទាក់ទងអ្វីនឹងព្រះជាម្ចាស់ឡើយ។ កិច្ចការរបស់ព្រះជាម្ចាស់ត្រូវតែធ្វើដោយព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ ហើយការអនុវត្តរបស់មនុស្សត្រូវតែធ្វើដោយមនុស្សផ្ទាល់។ កិច្ចការដែលគួរតែធ្វើដោយព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ មិនចាំបាច់ឲ្យមនុស្សធ្វើឡើយ ហើយកិច្ចការដែលមនុស្សគួរតែអនុវត្ត ក៏មិនទាក់ទងនឹងព្រះជាម្ចាស់ដែរ។ កិច្ចការរបស់ព្រះជាម្ចាស់ គឺជាព័ន្ធកិច្ចរបស់ទ្រង់ផ្ទាល់ ហើយមិនទាក់ទងនឹងមនុស្សឡើយ។ កិច្ចការនេះមិនត្រូវការឲ្យមនុស្សធ្វើទេ ហើយលើសពីនេះ មនុស្សនឹងគ្មានសមត្ថភាពធ្វើកិច្ចការដែលត្រូវធ្វើដោយព្រះជាម្ចាស់ឡើយ។ កិច្ចការដែលតម្រូវឲ្យមនុស្សអនុវត្ត ត្រូវតែសម្រេចដោយមនុស្ស មិនថាវាជាការពលីជីវិតរបស់គេ ឬជាការប្រគល់ខ្លួនទៅឲ្យសាតាំង ដើម្បីឈរមាំចំពោះទីបន្ទាល់នោះឡើយ ដ្បិតការទាំងនេះត្រូវតែសម្រេចដោយមនុស្សផ្ទាល់។ ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គសម្រេចកិច្ចការទាំងអស់ដែលទ្រង់គួរតែធ្វើ ហើយកិច្ចការដែលមនុស្សគួរតែធ្វើ ត្រូវបានបង្ហាញឲ្យមនុស្សមើលឃើញ ហើយអ្វីដែលនៅសេសសល់ គឺជាកិច្ចការដែលមនុស្សត្រូវធ្វើ។ ព្រះជាម្ចាស់មិនធ្វើកិច្ចការបន្ថែមឡើយ។ ទ្រង់គ្រាន់តែធ្វើកិច្ចការដែលស្ថិតនៅក្នុងព័ន្ធកិច្ចរបស់ទ្រង់ និងបង្ហាញដល់មនុស្សអំពីផ្លូវ និងធ្វើកិច្ចការនៃការបើកផ្លូវប៉ុណ្ណោះ ហើយទ្រង់មិនធ្វើកិច្ចការនៃការឈូសឆាយផ្លូវឡើយ ព្រោះថាមនុស្សទាំងអស់គួរតែយល់អំពីការនេះហើយ។ ការយកសេចក្ដីពិតទៅអនុវត្ត មានន័យថា ជាការយកព្រះបន្ទូល របស់ព្រះជាម្ចាស់ទៅអនុវត្ត ហើយការទាំងអស់នេះ គឺជា

ភារកិច្ចរបស់មនុស្ស ជាកិច្ចការដែលមនុស្សគួរតែធ្វើ ហើយវាគ្មានអ្វីពាក់ព័ន្ធជាមួយព្រះជាម្ចាស់ឡើយ។ ប្រសិនបើមនុស្សទាមទារឱ្យព្រះជាម្ចាស់ត្រូវរងទារុណកម្ម និងឆ្លងកាត់ការបន្សុទ្ធនៅក្នុងសេចក្តីពិត ដូចជាមនុស្សដែរ នោះមនុស្សកំពុងតែមិនស្តាប់បង្គាប់ហើយ។ កិច្ចការរបស់ព្រះជាម្ចាស់គឺត្រូវធ្វើព័ន្ធកិច្ចរបស់ទ្រង់ ហើយភារកិច្ចរបស់មនុស្សគឺត្រូវស្តាប់បង្គាប់តាមការដឹកនាំទាំងអស់របស់ព្រះជាម្ចាស់ដោយគ្មានការជំទាស់អ្វីនោះឡើយ។ មនុស្សត្រូវតែសម្រេចកិច្ចការដ៏ចាំបាច់ដែលគេត្រូវសម្រេច មិនថាព្រះជាម្ចាស់ធ្វើការ ឬរស់នៅបែបណានោះឡើយ។ មានតែព្រះជាម្ចាស់ផ្ទាល់ព្រះអង្គប៉ុណ្ណោះដែលអាចដាក់សេចក្តីតម្រូវដល់មនុស្ស គឺអាចនិយាយបានថា មានតែព្រះជាម្ចាស់ផ្ទាល់ព្រះអង្គប៉ុណ្ណោះដែលសក្តិសមក្នុងការដាក់សេចក្តីតម្រូវសម្រាប់មនុស្ស។ មនុស្សមិនគួរមានជម្រើសណាផ្សេង ហើយក៏មិនគួរធ្វើអ្វីផ្សេងក្រៅពីការចុះចូលទាំងស្រុង និងការអនុវត្តនោះឡើយ ព្រោះថានេះគឺជាការយល់ដឹងមួយដែលមនុស្សគួរតែមាន។ នៅពេលដែលកិច្ចការដែលព្រះជាម្ចាស់គួរតែធ្វើ ត្រូវបានសម្រេច នោះមនុស្សនឹងតម្រូវឲ្យមានបទពិសោធ អំពីកិច្ចការនោះមួយជំហានម្តងៗ។ នៅចុងបញ្ចប់ ពេលដែលគ្រប់ការគ្រប់គ្រងរបស់ព្រះជាម្ចាស់ត្រូវបានសម្រេច ប្រសិនបើមនុស្សនៅតែមិនបានធ្វើកិច្ចការដែលព្រះជាម្ចាស់បានតម្រូវទុកទៀត នោះមនុស្សគួរតែទទួលទោស។ ប្រសិនបើមនុស្សមិនបំពេញតាមសេចក្តីតម្រូវរបស់ព្រះជាម្ចាស់ទេ នោះគឺដោយសារតែមនុស្សមិនបានស្តាប់បង្គាប់ហើយ ដូច្នេះ វាមិនមានន័យថាព្រះជាម្ចាស់មិនបានធ្វើការហ្មត់ចត់គ្រប់គ្រាន់នៅក្នុងកិច្ចការរបស់ទ្រង់នោះឡើយ។ អស់អ្នកណាដែលមិនអាចយកព្រះបន្ទូលរបស់ព្រះជាម្ចាស់ទៅអនុវត្ត អស់អ្នកណាដែលមិនអាចបំពេញតាមសេចក្តីតម្រូវរបស់ព្រះជាម្ចាស់ និងអស់អ្នកណាដែលមិនអាចមានចិត្តភក្តីភាព និងមិនអាចបំពេញភារកិច្ចរបស់ពួកគេបានទេ នោះពួកគេនឹងត្រូវទទួលទោសមិនខាន។ សព្វថ្ងៃនេះ អ្វីដែលអ្នករាល់គ្នាតម្រូវឲ្យសម្រេច មិនមែនជាការទាមទារបន្ថែមឡើយ ប៉ុន្តែវាជាភារកិច្ចរបស់មនុស្ស និងជាកិច្ចការដែលមនុស្សទាំងអស់គួរតែធ្វើប៉ុណ្ណោះ។ ប្រសិនបើអ្នករាល់គ្នាគ្មានសមត្ថភាពក្នុងការធ្វើភារកិច្ច

របស់អ្នករាល់គ្នា ឬធ្វើវាឲ្យបានល្អផង តើអ្នកមិនមែនកំពុងតែនាំបញ្ហាដាក់ខ្លួនទេឬអី? តើអ្នកមិនមែនកំពុងប្រថុយនឹងគ្រោះថ្នាក់ទេឬអី? តើអ្នកអាចនៅតែរំពឹងចង់មានអនាគតល្អ និងភាពជោគជ័យដោយរបៀបណាទៅ? កិច្ចការរបស់ព្រះជាម្ចាស់ត្រូវបានធ្វើសម្រាប់ជាប្រយោជន៍ដល់មនុស្សជាតិ ហើយកិច្ចសហប្រតិបត្តិការរបស់មនុស្ស ត្រូវបានផ្ដល់ជូនសម្រាប់ជាប្រយោជន៍ដល់ការគ្រប់គ្រងរបស់ព្រះជាម្ចាស់។ ក្រោយពេលដែលព្រះជាម្ចាស់ បានធ្វើគ្រប់កិច្ចការដែលទ្រង់គួរតែធ្វើរួចហើយ មនុស្សតម្រូវឲ្យអនុវត្តកិច្ចការរបស់ខ្លួនដោយគ្មានការដាក់កម្រិត និងសហការជាមួយព្រះជាម្ចាស់។ នៅក្នុងកិច្ចការរបស់ព្រះជាម្ចាស់ មនុស្សមិនគួរធ្វើការឲ្យតែរួចពីដៃឡើយ ប៉ុន្ដែគួរតែធ្វើយ៉ាងអស់ពីចិត្តរបស់ខ្លួន ហើយមិនគួរអណ្ដែតអណ្ដូងនៅក្នុងសញ្ញាណជាច្រើន ឬអង្គុយនៅស្ងៀមរង់ចាំសេចក្ដីស្លាប់នោះឡើយ។ ព្រះជាម្ចាស់អាចលះបង់អង្គទ្រង់សម្រាប់មនុស្សបាន ចុះហេតុអ្វីបានជាមនុស្សមិនអាចថ្វាយចិត្តភក្ដីភាពរបស់គេដល់ព្រះជាម្ចាស់វិញបាន? ព្រះជាម្ចាស់យកព្រះទ័យទុកដាក់ចំពោះមនុស្សយ៉ាងខ្លាំង ចុះហេតុអ្វីបានជាមនុស្សមិនអាចផ្ដល់កិច្ចសហប្រតិបត្តិការសូម្បីតែបន្តិច? ព្រះជាម្ចាស់ធ្វើការសម្រាប់មនុស្សជាតិ ហេតុអ្វីបានជាមនុស្សមិនអាចបំពេញភារកិច្ចខ្លះរបស់គេសម្រាប់ជាប្រយោជន៍ដល់ការគ្រប់គ្រងរបស់ព្រះជាម្ចាស់? កិច្ចការរបស់ព្រះជាម្ចាស់បានមកដល់ឆ្ងាយហើយ ប៉ុន្ដែអ្នករាល់គ្នានៅតែអង្គុយមើល មិនព្រមធ្វើសកម្មភាព ហើយអ្នកនៅតែស្ដាប់ តែមិនព្រមធ្វើចលនាទៅវិញ។ តើមនុស្សបែបនេះមិនមែនជាកម្មវត្ថុដែលត្រូវធ្លាក់នរកទេឬអី? ព្រះជាម្ចាស់បានប្រទានអ្វីៗគ្រប់យ៉ាងរបស់ទ្រង់ដល់មនុស្សរួចហើយ ដូច្នេះ ហេតុអ្វីបានជាមនុស្សនាពេលសព្វថ្ងៃនេះគ្មានសមត្ថភាពបំពេញភារកិច្ចរបស់ខ្លួនយ៉ាងអស់ពីចិត្ត? សម្រាប់ព្រះជាម្ចាស់ កិច្ចការរបស់ទ្រង់គឺជាអាទិភាពទីមួយរបស់ទ្រង់ ហើយកិច្ចការគ្រប់គ្រងរបស់ទ្រង់ ពិតជាសំខាន់បំផុត។ សម្រាប់មនុស្សវិញ ការយកព្រះបន្ទូលរបស់ព្រះជាម្ចាស់ទៅអនុវត្ត និងការបំពេញតាមសេចក្ដីតម្រូវរបស់ព្រះជាម្ចាស់ គឺជាអាទិភាពទីមួយរបស់គេ។ នេះហើយជាចំណុចដែលអ្នករាល់គ្នាគួរតែយល់។ ព្រះបន្ទូលដែលបានថ្លែងទៅកាន់អ្នករាល់គ្នា

បានដល់កម្រិតស្ទួល នៃសារជាតិរបស់អ្នករាល់គ្នារួចហើយ ហើយកិច្ចការរបស់ព្រះជាម្ចាស់បានចូលដល់ដែនដីដែលមិនធ្លាប់បានចូលពីមុនមកឡើយ។ មនុស្សជាច្រើននៅតែមិនយល់អំពីសេចក្ដីពិត ឬសេចក្ដីមិនពិតទៀត ហើយពួកគេនៅតែរង់ចាំមើលដោយមិនបំពេញភារកិច្ចរបស់ពួកគេទេ។ ផ្ទុយទៅវិញ ពួកគេពិនិត្យពិច័យគ្រប់ទាំងព្រះបន្ទូល និងគ្រប់ទាំងទង្វើរបស់ព្រះជាម្ចាស់ ពួកគេផ្ដោតទៅលើអ្វីដែលទ្រង់សោយ និងស្លៀកពាក់ ហើយសញ្ញាណរបស់គេកាន់តែធ្ងន់ធ្ងរខ្លាំងឡើងៗ។ តើមនុស្សបែបនេះមិនកំពុងតែខឹងសម្បារ និងព្រួយបារម្ភខ្លាំងពេកទៅលើរឿងដែលគ្មានបានការទេឬអី? តើមនុស្សបែបនេះ អាចក្លាយជាអ្នកដែលស្វែងរកព្រះជាម្ចាស់ដោយរបៀបណា? តើពួកគេអាចក្លាយជាមនុស្ស ដែលមានចេតនាក្នុងការចុះចូលចំពោះព្រះជាម្ចាស់យ៉ាងដូចម្ដេច? ពួកគេមិនសូវគិតច្រើនអំពីចិត្តភក្ដីភាព និងភារកិច្ចរបស់គេឡើយ ផ្ទុយទៅវិញ ពួកគេបែរជាផ្ដោតទៅលើទីកន្លែងដែលព្រះជាម្ចាស់ស្ថិតនៅទៅវិញ។ ពួកគេកំពុងតែប្រមាថយ៉ាងធ្ងន់ធ្ងរណាស់! ប្រសិនបើមនុស្សបានយល់គ្រប់ទាំងសេចក្ដីដែលគេគួរតែយល់ ហើយបានអនុវត្ត គ្រប់ទាំងសេចក្ដីដែលគេគួរតែអនុវត្ត នោះព្រះជាម្ចាស់នឹងប្រាកដជាប្រទានព្រះពររបស់ទ្រង់ ដល់គេមិនខាន ព្រោះថាកិច្ចការដែលទ្រង់ទាមទារពីមនុស្ស គឺជាភារកិច្ចរបស់មនុស្ស និងជាកិច្ចការដែលមនុស្សគួរតែធ្វើប៉ុណ្ណោះ។ ប្រសិនបើមនុស្សគ្មានសមត្ថភាពយល់អំពីអ្វីដែលគេគួរតែយល់ និងគ្មានសមត្ថភាពអនុវត្តតាមអ្វីដែលគេគួរតែអនុវត្តផង នោះមនុស្សនឹងត្រូវទទួលទោសមិនខាន។ អស់អ្នកណា ដែលមិនសហការជាមួយព្រះជាម្ចាស់ គឺទាស់ទទឹងនឹងព្រះជាម្ចាស់ អស់អ្នកណាដែលមិនទទួលយកកិច្ចការថ្មី គឺប្រឆាំងនឹងកិច្ចការថ្មីនេះ ហើយបើមនុស្សបែបនេះគ្មានធ្វើអ្វីសោះ នោះវាស្ដែងចេញឲ្យឃើញថា គេកំពុងតែប្រឆាំងនឹងកិច្ចការរបស់ទ្រង់ហើយ។ អស់អ្នកណាដែលមិនអនុវត្តតាមសេចក្ដីពិតតាមការតម្រូវរបស់ព្រះជាម្ចាស់ទេ ពួកគេជាមនុស្សមានចេតនាប្រឆាំង ហើយមិនស្ដាប់បង្គាប់តាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ឡើយ បើដូច្នេះ មនុស្សបែបនេះក៏មិនយកចិត្តទុកដាក់យ៉ាងពិសេសចំពោះកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធនោះ

ដែរ។ មនុស្សដែលមិនស្ដាប់បង្គាប់ តាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងចុះចូលចំពោះព្រះជាម្ចាស់ គឺជាមនុស្សបះបោរ ហើយពួកគេកំពុងតែប្រឆាំងនឹងព្រះជាម្ចាស់ហើយ។ មនុស្សដែលមិនបំពេញភារកិច្ចរបស់ខ្លួន គឺជាមនុស្សដែលមិនសហការជាមួយព្រះជាម្ចាស់ ហើយមនុស្សដែលមិនសហការជាមួយព្រះជាម្ចាស់ទាំងនេះ គឺជាមនុស្សដែលមិនទទួលបានកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធឡើយ។

នៅពេលដែលកិច្ចការរបស់ព្រះជាម្ចាស់ឡើងដល់កម្រិតមួយ ហើយការគ្រប់គ្រងរបស់ទ្រង់ឡើងដល់កម្រិតមួយ នោះមនុស្សសំណព្វរបស់ទ្រង់គ្រប់រូប ត្រូវតែមានសមត្ថភាព បំពេញតាមសេចក្ដីតម្រូវរបស់ទ្រង់។ ព្រះជាម្ចាស់បង្កើតសេចក្ដីតម្រូវសម្រាប់មនុស្ស ស្របតាមបទដ្ឋានរបស់ទ្រង់ និងស្របតាមកិច្ចការដែលមនុស្សអាចមានសមត្ថភាពសម្រេចបាន។ ខណៈពេលដែលកំពុងនិយាយអំពីការគ្រប់គ្រងរបស់ទ្រង់ ព្រះអង្គក៏ចង្អុលបង្ហាញផ្លូវដល់មនុស្ស និងប្រទានឲ្យមនុស្សមានផ្លូវរស់ដែរ។ ការគ្រប់គ្រងរបស់ព្រះជាម្ចាស់ និងការអនុវត្តរបស់មនុស្ស គឺជាដំណាក់កាលនៃកិច្ចការដូចគ្នា ហើយត្រូវអនុវត្តទៅដំណាលគ្នា។ ការនិយាយអំពីការគ្រប់គ្រងរបស់ព្រះជាម្ចាស់ ទាក់ទងទៅនឹងការផ្លាស់ប្ដូរនៅក្នុងនិស្ស័យរបស់មនុស្ស ហើយការនិយាយអំពីកិច្ចការដែលមនុស្សគួរតែធ្វើ និងការផ្លាស់ប្ដូរនៅក្នុងនិស្ស័យរបស់មនុស្ស វាទាក់ទងទៅនឹងកិច្ចការរបស់ព្រះជាម្ចាស់ ដូច្នេះ វាគ្មានពេលណាមួយដែលកិច្ចការទាំងពីរនេះត្រូវដាច់ចេញពីគ្នាឡើយ។ ការអនុវត្តរបស់មនុស្សកំពុងតែផ្លាស់ប្ដូរមួយជំហានម្ដងៗ។ នោះគឺដោយសារតែសេចក្ដីតម្រូវ របស់ព្រះជាម្ចាស់សម្រាប់មនុស្សកំពុងតែផ្លាស់ប្ដូរ និងដោយសារតែកិច្ចការរបស់ព្រះជាម្ចាស់តែងតែផ្លាស់ប្ដូរ និងវិវឌ្ឍទៅមុខជានិច្ច។ ប្រសិនបើការអនុវត្តរបស់មនុស្ស តែងតែជាប់នៅក្នុងគោលលទ្ធិនោះវាបញ្ជាក់ឲ្យឃើញថា គេគ្មានកិច្ចការ និងការដឹកនាំរបស់ព្រះជាម្ចាស់ឡើយ។ ប្រសិនបើការអនុវត្តរបស់មនុស្ស មិនដែលផ្លាស់ប្ដូរ ឬមិនដែលស៊ីជម្រៅជាងមុនទេ នោះវាបញ្ជាក់ឲ្យឃើញថា ការអនុវត្តរបស់មនុស្សត្រូវបានធ្វើឡើងស្របតាមឆន្ទៈរបស់មនុស្ស ហើយវាមិនមែនជាការអនុវត្តនៃសេចក្ដីពិត

ឡើយ។ ប្រសិនបើមនុស្សគ្មានផ្លូវដែលត្រូវដើរទេ នោះគេបានធ្លាក់ទៅក្នុងដៃរបស់សាតាំងរួចទៅហើយ ហើយត្រូវបានគ្រប់គ្រងដោយសាតាំង ដែលនេះមានន័យថាគេត្រូវបានគ្រប់គ្រងដោយពួកវិញ្ញាណអាក្រក់។ ប្រសិនបើការអនុវត្តរបស់មនុស្សមិនកាន់តែស៊ីជម្រៅទេ នោះកិច្ចការរបស់ព្រះជាម្ចាស់នឹងមិនអភិវឌ្ឍឡើយ ហើយប្រសិនបើវាគ្មានការផ្លាស់ប្ដូរនៅក្នុងកិច្ចការរបស់ព្រះជាម្ចាស់ទេ នោះច្រកចូលរបស់មនុស្សនឹងត្រូវបង្អាក់មិនខាន ហើយការនេះមិនអាចចៀសរួចឡើយ។ នៅក្នុងគ្រប់កិច្ចការទាំងអស់របស់ព្រះជាម្ចាស់ ប្រសិនបើមនុស្សត្រូវកាន់តាមក្រឹត្យវិន័យរបស់ព្រះយេហូវ៉ាជានិច្ចនោះកិច្ចការរបស់ព្រះជាម្ចាស់មិនអាចវិវឌ្ឍទៅមុខ ហើយក៏មិនអាចនាំការបិទបញ្ចប់ដល់យុគសម័យទាំងមូលដែរ។ ប្រសិនបើមនុស្សតែងតែប្រកាន់ខ្ជាប់នឹងឈើឆ្កាងហើយបានអនុវត្តការអត់ធ្មត់ និងការបន្ទាបខ្លួន នោះវានឹងមិនអាចទៅរួចឡើយដើម្បីឲ្យកិច្ចការរបស់ព្រះជាម្ចាស់បន្តវិវឌ្ឍទៅមុខនោះ។ ការគ្រប់គ្រងរយៈពេលប្រាំមួយពាន់ឆ្នាំ មិនអាចដល់ទីបញ្ចប់នៅក្នុងចំណោមមនុស្សដែលកាន់តាមតែក្រឹត្យវិន័យ ឬប្រកាន់ខ្ជាប់នឹងឈើឆ្កាង ព្រមទាំងអនុវត្តនូវការអត់ធ្មត់និងការបន្ទាបខ្លួននោះឡើយ។ ផ្ទុយទៅវិញ កិច្ចការទាំងមូលនៃការគ្រប់គ្រងរបស់ព្រះជាម្ចាស់ ត្រូវបានបិទបញ្ចប់នៅក្នុងចំណោមមនុស្សនៅគ្រាចុងក្រោយ ជាអ្នកដែលស្គាល់ព្រះជាម្ចាស់ ជាអ្នកដែលត្រូវបានយកចេញ ពីក្រញាំដៃរបស់សាតាំង និងជាអ្នកដែល បានដកខ្លួនទាំងស្រុងចេញពីឥទ្ធិពលរបស់សាតាំង។ នេះហើយគឺជាគោលដៅមួយនៃកិច្ចការរបស់ព្រះជាម្ចាស់ ដែលមិនអាចចៀសរួចនោះឡើយ។ ហេតុអ្វីបានជាគេនិយាយថា ការអនុវត្តរបស់មនុស្សនៅក្នុងពួកជំនុំសាសនា គឺជារឿងហួសសម័យកាល? នោះគឺដោយសារតែអ្វីដែលគេអនុវត្ត ដាច់ចេញពីកិច្ចការពេលសព្វថ្ងៃ។ នៅក្នុងយុគសម័យនៃព្រះគុណ អ្វីដែលពួកគេអនុវត្តគឺត្រឹមត្រូវ ប៉ុន្តែនៅពេលដែលយុគសម័យនោះ បានកន្លងផុតទៅ ហើយកិច្ចការរបស់ព្រះជាម្ចាស់បានផ្លាស់ប្ដូរ នោះការអនុវត្តរបស់ពួកគេក៏ប្រែក្លាយទៅជាហួសសម័យកាលបន្តិចម្ដងៗ។ ពួកគេបានភ្លេចអំពីកិច្ចការថ្មី និងពន្លឺថ្មី។ ដោយផ្អែកលើគ្រឹះមូលដ្ឋានដើម

របស់វា កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធបានបោះជំហានកាន់តែស៊ីជម្រៅទៅមុខ។ ប៉ុន្តែ មនុស្សទាំងនោះនៅតែបន្តប្រកាន់ខ្ជាប់នឹងដំណាក់កាលដើមនៃកិច្ចការរបស់ព្រះជាម្ចាស់ និងនៅតែជាប់ចិត្តនឹងការអនុវត្តចាស់ៗ និងពន្លឺចាស់ដដែល។ កិច្ចការរបស់ព្រះជាម្ចាស់អាចផ្លាស់ប្ដូរយ៉ាងខ្លាំងនៅក្នុងពេលបី ឬប្រាំឆ្នាំ ដូច្នេះ តើវានឹងមិនមានការផ្លាស់ប្ដូរកាន់តែធំកើតឡើងទេឬអី នៅក្នុងរយៈពេលជាង២០០០ឆ្នាំនោះ? ប្រសិនបើមនុស្សគ្មានពន្លឺ ឬការអនុវត្តថ្មីទេ នោះវាមានន័យថា គេមិនបានតាមទាន់កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធឡើយ។ នេះគឺជាការបរាជ័យរបស់មនុស្ស។ វត្តមាននៃកិច្ចការថ្មីរបស់ព្រះជាម្ចាស់មិនអាចបដិសេធបានឡើយ ដោយសារតែសព្វថ្ងៃនេះ អស់អ្នកដែលធ្លាប់មានកិច្ចការនៃព្រះវិញ្ញាណកាលពីអតីតកាល នៅតែប្រកាន់ខ្ជាប់នូវការអនុវត្តដែលហួសសម័យកាល។ កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ តែងតែធ្វើចលនាទៅមុខជានិច្ច ហើយអស់អ្នកដែលស្ថិតនៅក្នុងចរន្តនៃព្រះវិញ្ញាណបរិសុទ្ធ ក៏គួរតែកំពុងតែវិវឌ្ឍទៅមុខកាន់តែស៊ីជម្រៅ និងផ្លាស់ប្ដូរមួយជំហានម្ដងៗដែរ។ ពួកគេមិនគួរឈប់នៅក្នុងដំណាក់កាលមួយឡើយ។ មានតែមនុស្សដែលមិនដឹងអំពីកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធទេ ដែលនឹងជាប់គាំងនៅក្នុងចំណោមកិច្ចការដើមរបស់ទ្រង់ ហើយមិនទទួលយកកិច្ចការថ្មីរបស់ព្រះវិញ្ញាណបរិសុទ្ធនោះ។ មានតែមនុស្សដែលមិនស្ដាប់បង្គាប់ទេ ដែលគ្មានសមត្ថភាពទទួលយកកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធនោះ។ ប្រសិនបើការអនុវត្តរបស់មនុស្សមិនមានល្បឿនតាមទាន់កិច្ចការថ្មីនៃព្រះវិញ្ញាណបរិសុទ្ធទេ នោះការអនុវត្តរបស់មនុស្សប្រាកដជាដាច់ចេញពីកិច្ចការនាពេលសព្វថ្ងៃនេះ ហើយប្រាកដជាមិនស្របតាមកិច្ចការ នាពេលសព្វថ្ងៃនេះមិនខាន។ មនុស្សហួសសម័យកាលទាំងនេះ គ្មានសមត្ថភាពក្នុងការសម្រេចតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ហើយក៏មិនអាចក្លាយជាមនុស្ស ដែលនឹងឈរធ្វើទីបន្ទាល់អំពីព្រះជាម្ចាស់នាពេលចុងបញ្ចប់នោះដែរ។ លើសពីនេះទៅទៀត កិច្ចការគ្រប់គ្រងទាំងមូលមិនអាចបិទបញ្ចប់នៅក្នុងចំណោមក្រុមមនុស្សបែបនេះបានឡើយ។ សម្រាប់មនុស្សដែលធ្លាប់ប្រកាន់ខ្ជាប់តាមក្រឹត្យវិន័យរបស់ព្រះយេហូវ៉ា និងមនុស្សដែលធ្លាប់

រងទុក្ខសម្រាប់ឈើឆ្កាង ប្រសិនបើពួកគេមិនអាចទទួលយកដំណាក់កាលនៃកិច្ចការនៅគ្រាចុងក្រោយទេ នោះអ្វីគ្រប់យ៉ាងដែលពួកគេបានធ្វើ នឹងក្លាយជាឥតប្រយោជន៍ ហើយគ្មានន័យ។ ការស្ដែងចេញដ៏ច្បាស់បំផុតអំពីកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ គឺស្ថិតនៅក្នុងការទទួលយកពេលបច្ចុប្បន្ន មិនមែនជាការជាប់ចិត្ត នឹងអតីតកាលឡើយ។ អស់អ្នកណាដែលមិនបានតាមទាន់នឹងកិច្ចការនាពេលសព្វថ្ងៃ និងអ្នកដែលបានដាច់ចេញពីការអនុវត្តនាពេលសព្វថ្ងៃ គឺជាមនុស្សដែលប្រឆាំង និងមិនទទួលយកកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធឡើយ។ មនុស្សបែបនេះមិនស្ដាប់បង្គាប់តាមកិច្ចការរបស់ព្រះជាម្ចាស់នាពេលបច្ចុប្បន្នទេ។ ទោះបីពួកគេប្រកាន់ខ្ជាប់នឹងពន្លឺកាលពីអតីតកាលក៏ដោយ ក៏វាមិនអាចបដិសេធបានដែរថា ពួកគេមិនដឹងអំពីកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធនោះដែរ។ ហេតុអ្វីបានជាមានការនិយាយ សព្វបែបយ៉ាងអំពីការផ្លាស់ប្ដូរនៅក្នុងការអនុវត្តរបស់មនុស្សអំពីការផ្លាស់ប្ដូរនៅក្នុងការអនុវត្តរវាងអតីតកាល និងពេលបច្ចុប្បន្ន អំពីរបៀបដែលការអនុវត្តត្រូវបានប្រព្រឹត្តនៅក្នុងអំឡុងយុគសម័យមុន និងអំពីរបៀបដែលវាត្រូវបានធ្វើនាពេលសព្វថ្ងៃ? ការបែងចែកនៅក្នុងការអនុវត្តរបស់មនុស្សបែបនេះ តែងតែត្រូវបានលើកឡើង ដោយសារតែកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ចេះតែបន្តឆ្ពោះទៅមុខ ហើយការអនុវត្តរបស់មនុស្សតម្រូវឲ្យមានការផ្លាស់ប្ដូរជានិច្ច។ ប្រសិនបើមនុស្ស នៅតែបន្តជាប់នៅក្នុងដំណាក់កាលមួយ នោះវាបញ្ជាក់ឲ្យឃើញថា គេគ្មានសមត្ថភាពតាមទាន់កិច្ចការថ្មី និងពន្លឺថ្មីរបស់ព្រះជាម្ចាស់ឡើយ ហើយការនេះមិនបញ្ជាក់ថា ផែនការគ្រប់គ្រងរបស់ព្រះជាម្ចាស់មិនបានផ្លាស់ប្ដូរនោះទេ។ អស់អ្នកដែលស្ថិតនៅក្រៅចរន្តនៃព្រះវិញ្ញាណបរិសុទ្ធ តែងតែគិតថា ពួកគេត្រឹមត្រូវជានិច្ច ប៉ុន្តែការពិតនោះគឺថា ព្រះជាម្ចាស់ឈប់ធ្វើការនៅក្នុងពួកគេយូរយារណាស់មកហើយ ហើយកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ក៏លែងធ្វើការជាមួយពួកគេដែរ។ កិច្ចការរបស់ព្រះជាម្ចាស់បានកើតឡើងជាយូរណាស់មកហើយ តាំងពីទ្រង់បានផ្ទេរទៅកាន់ក្រុមមនុស្សមួយទៀត ជាក្រុមមួយដែលទ្រង់មានបំណងសម្រេចកិច្ចការថ្មីរបស់ទ្រង់។ ដោយសារតែអស់អ្នកដែលស្ថិតនៅក្នុង

សាសនាគ្មានសមត្ថភាព ទទួលយកកិច្ចការថ្មីរបស់ព្រះជាម្ចាស់ឡើយ ហើយគេប្រកាន់ខ្ជាប់ តែកិច្ចការចាស់ពីអតីតកាលប៉ុណ្ណោះ ដូច្នេះ ព្រះជាម្ចាស់បានបំភ្លេចមនុស្សទាំងនេះចោល ហើយធ្វើកិច្ចការថ្មីរបស់ទ្រង់នៅលើមនុស្សដែលទទួលយកកិច្ចការថ្មីនេះប៉ុណ្ណោះ។ មនុស្សទាំងនេះជាមនុស្សដែលសហការនៅក្នុងកិច្ចការថ្មីរបស់ទ្រង់ ហើយមានតែបែបនេះទេ ទើបការគ្រប់គ្រងរបស់ទ្រង់អាចសម្រេចបាន។ ការគ្រប់គ្រងរបស់ព្រះជាម្ចាស់តែងតែធ្វើចលនាទៅមុខជានិច្ច ហើយការអនុវត្តរបស់មនុស្ស តែងតែឡើងទៅដល់កម្រិតកាន់តែខ្ពស់ជានិច្ច។ ព្រះជាម្ចាស់កំពុងតែធ្វើការ ហើយមនុស្សតែងតែមានតម្រូវការជានិច្ច គឺត្រូវសម្រេចដល់កម្រិតកំពូលរបស់ខ្លួន ហើយព្រះជាម្ចាស់ និងមនុស្សសម្រេចបានការបង្រួបបង្រួមដ៏ពេញលេញ។ នេះគឺជាការស្ដែងចេញអំពីសមិទ្ធផលនៃកិច្ចការរបស់ព្រះជាម្ចាស់ ហើយវាជាលទ្ធផលចុងក្រោយនៃការគ្រប់គ្រងទាំងស្រុងរបស់ព្រះជាម្ចាស់។

នៅក្នុងដំណាក់កាលនីមួយៗនៃកិច្ចការរបស់ព្រះជាម្ចាស់ វាក៏មានសេចក្ដីតម្រូវសមស្របនីមួយៗសម្រាប់មនុស្សដែរ។ អស់អ្នកណា ដែលស្ថិតនៅក្នុងចរន្តរបស់ព្រះវិញ្ញាណបរិសុទ្ធ គឺមានព្រះវត្តមាននិងការប្រៀនប្រដៅរបស់ព្រះវិញ្ញាណបរិសុទ្ធ ហើយអស់អ្នកណា ដែលមិនស្ថិតនៅក្នុងចរន្តនៃព្រះវិញ្ញាណបរិសុទ្ធ គឺស្ថិតនៅក្រោមបញ្ជារបស់សាតាំង ហើយគ្មានកិច្ចការណាមួយ របស់ព្រះវិញ្ញាណបរិសុទ្ធឡើយ។ មនុស្សដែលស្ថិតនៅក្នុងចរន្ត របស់ព្រះវិញ្ញាណបរិសុទ្ធ គឺជាអ្នកដែលទទួលយកនូវកិច្ចការថ្មីរបស់ព្រះជាម្ចាស់ និងជាអ្នកដែលសហការនៅក្នុងកិច្ចការថ្មីរបស់ព្រះជាម្ចាស់។ ប្រសិនបើអស់អ្នកដែលស្ថិតនៅក្នុងចរន្តនេះ គ្មានសមត្ថភាពក្នុងការសហការ ហើយមិនអាចអនុវត្តតាមសេចក្ដីពិតដែលព្រះជាម្ចាស់បានតម្រូវក្នុងអំឡុងពេលនេះទេ នោះពួកគេនឹងត្រូវទទួលពិន័យ ហើយបើអាក្រក់បំផុត ពួកគេនឹងត្រូវព្រះវិញ្ញាណបរិសុទ្ធបោះបង់ចោលតែម្ដង។ អស់អ្នកណាដែលទទួលយកកិច្ចការថ្មីនៃព្រះវិញ្ញាណបរិសុទ្ធ នឹងរស់នៅក្នុងចរន្តនៃព្រះវិញ្ញាណបរិសុទ្ធ ហើយពួកគេនឹងទទួលបានការមើលថែ និងការការពារពីព្រះវិញ្ញាណបរិសុទ្ធ។ អស់អ្នកណា

ដែលព្រមអនុវត្តតាមសេចក្តីពិត ត្រូវបានព្រះវិញ្ញាណបរិសុទ្ធបំភ្លឺ ហើយអស់អ្នកណាដែលមិនព្រមអនុវត្តតាមសេចក្តីពិត ត្រូវទទួលពិន័យពីព្រះវិញ្ញាណបរិសុទ្ធ ព្រមទាំងអាចទទួលទោសពៃរ៍ទៀតផង។ មិនថាពួកគេជាមនុស្សប្រភេទណានោះឡើយបើពួកគេស្ថិតនៅក្នុងចរន្តនៃព្រះវិញ្ញាណបរិសុទ្ធ នោះព្រះជាម្ចាស់នឹងទទួលខុសត្រូវចំពោះមនុស្សទាំងអស់ដែលទទួលយកកិច្ចការថ្មីរបស់ទ្រង់ សម្រាប់ជាប្រយោជន៍ដល់ព្រះនាមទ្រង់។ អស់អ្នកណាដែលថ្វាយសិរីល្អដល់ព្រះនាមទ្រង់ ហើយព្រមអនុវត្តតាមព្រះបន្ទូលរបស់ទ្រង់ នឹងទទួលបានព្រះពររបស់ទ្រង់ ហើយអស់អ្នកណាដែលមិនស្តាប់បង្គាប់តាមទ្រង់ និងមិនអនុវត្តតាមព្រះបន្ទូលរបស់ទ្រង់ទេ នោះនឹងទទួលទោសរបស់ទ្រង់មិនខាន។ មនុស្សដែលស្ថិតនៅក្នុងចរន្តនៃព្រះវិញ្ញាណបរិសុទ្ធគឺជាមនុស្សដែលទទួលយកកិច្ចការថ្មី ហើយដោយសារតែពួកគេបានទទួលយកកិច្ចការថ្មី ដូច្នេះពួកគេ គួរតែសហការឲ្យបានសមគួរជាមួយព្រះជាម្ចាស់ ហើយគេមិនគួរប្រព្រឹត្តដូចជាពួកបះបោរ ដែលមិនបំពេញតាមភារកិច្ចរបស់ខ្លួននោះឡើយ។ នេះជាសេចក្តីតម្រូវតែមួយគត់របស់ព្រះជាម្ចាស់ដែលមានចំពោះមនុស្ស។ សម្រាប់មនុស្សដែលមិនទទួលយកកិច្ចការថ្មី៖ ពួកគេស្ថិតនៅខាងក្រៅចរន្តនៃព្រះវិញ្ញាណបរិសុទ្ធ ហើយការប្រៀនប្រដៅ និងការលលត់ដំរបស់ព្រះវិញ្ញាណបរិសុទ្ធមិនអនុវត្តចំពោះពួកគេឡើយ។ ពេញមួយថ្ងៃ មនុស្សទាំងនេះរស់នៅក្នុងសាច់ឈាម ពួកគេរស់នៅតាមគំនិតរបស់ពួកគេ ហើយគ្រប់កិច្ចការដែលពួកគេធ្វើ គឺស្របតាមគោលលទ្ធិ ដែលបង្កើតឡើងដោយការវិភាគ និងការស្រាវជ្រាវចេញពីខួរក្បាលរបស់ពួកគេផ្ទាល់។ នេះមិនមែនជាសេចក្តីតម្រូវសម្រាប់កិច្ចការថ្មីរបស់ព្រះវិញ្ញាណបរិសុទ្ធឡើយហើយក៏មិនមែនជាកិច្ចសហប្រតិបត្តិការជាមួយព្រះជាម្ចាស់នោះដែរ។ អស់អ្នកណាដែលមិនទទួលយកកិច្ចការថ្មីរបស់ព្រះជាម្ចាស់ ក៏គ្មានព្រះវត្តមានរបស់ព្រះជាម្ចាស់ហើយលើសពីនេះ ក៏គ្មានព្រះពរ និងការការពារពីព្រះជាម្ចាស់នោះដែរ។ ពាក្យសម្ដីនិងទង្វើភាគច្រើនរបស់ពួកគេប្រកាន់ខ្ជាប់តាមសេចក្តីតម្រូវពីអតីតកាលនៃកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ដែលជាគោលលទ្ធិ មិនមែនជាសេចក្តីពិតនោះឡើយ។ គោល

លទ្ធិ និងបទបញ្ញាទាំងនេះ គឺគ្រប់គ្រាន់ក្នុងការបញ្ជាក់ថា ការប្រជុំរបស់មនុស្សទាំងនេះ គឺគ្មានអ្វីក្រៅពីសាសនានោះឡើយ ហើយពួកគេមិនមែនជាពូជជ្រើសរើសឬជាវត្ថុនៃកិច្ចការរបស់ព្រះជាម្ចាស់នោះឡើយ។ ការជួបជុំរបស់អ្នកទាំងនោះ អាចត្រូវបានហៅថាជាការប្រជុំដ៏ធំបែបសាសនាប៉ុណ្ណោះ ហើយវាមិនត្រូវបានហៅថាជាពួកជំនុំឡើយ។ នេះជាការពិតមួយដែលមិនអាចប្រកែកបានឡើយ។ ពួកគេមិនមានកិច្ចការថ្មីរបស់ព្រះវិញ្ញាណបរិសុទ្ធឡើយ។ អ្វីដែលពួកគេធ្វើ ហាក់ដូចជាក្លិននៃសាសនា អ្វីដែលគេរស់នៅ ហាក់ដូចជាពោរពេញដោយសាសនា ដូច្នេះ ពួកគេគ្មានព្រះវត្តមាន និងកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ហើយក៏គ្មានសិទ្ធិទទួលការប្រៀនប្រដៅ ឬការបំភ្លឺពីព្រះវិញ្ញាណបរិសុទ្ធនោះដែរ។ មនុស្សទាំងនេះដូចជាសាកសព និងដង្កូវដែលគ្មានវិញ្ញាណឡើយ។ ពួកគេគ្មានចំណេះដឹងអំពីការបះបោរ និងការប្រឆាំងរបស់មនុស្ស គ្មានចំណេះដឹងអំពីទង្វើអាក្រក់របស់មនុស្ស ហើយក៏មិនដឹងអំពីគ្រប់កិច្ចការរបស់ព្រះជាម្ចាស់ និងបំណងព្រះហឫទ័យនាពេលបច្ចុប្បន្នរបស់ព្រះជាម្ចាស់នោះដែរ។ ពួកគេជាមនុស្សល្ងង់ខ្លៅ និងអាក្រក់ ហើយពួកគេជាមនុស្សស្មោកគ្រោកដែលមិនសក្ដិសមហៅថាជាអ្នកជឿនោះឡើយ! គ្មានកិច្ចការណាមួយដែលពួកគេធ្វើ ជាប់ពាក់ព័ន្ធទៅនឹងការគ្រប់គ្រងរបស់ព្រះជាម្ចាស់ ហើយក៏ធ្វើឲ្យខូចខាតដល់ផែនការរបស់ព្រះជាម្ចាស់ទៀតផង។ ពាក្យសម្ដី និងទង្វើរបស់ពួកគេពិតជាគួរឲ្យខ្ពើមរអើមណាស់ គួរឲ្យអាណិតណាស់ និងគ្មានតម្លៃអ្វីដែលត្រូវលើកឡើងនោះឡើយ។ គ្មានកិច្ចការណាមួយដែលត្រូវបានធ្វើឡើងដោយមនុស្សដែលមិនស្ថិតនៅក្នុងចរន្តរបស់ព្រះវិញ្ញាណបរិសុទ្ធ ជាប់ពាក់ព័ន្ធជាមួយនឹងកិច្ចការថ្មីរបស់ព្រះវិញ្ញាណបរិសុទ្ធនោះឡើយ។ ដោយសារតែហេតុផលនេះ មិនថាពួកគេធ្វើអ្វីទេ ពួកគេគ្មានការប្រដៅពីព្រះវិញ្ញាណបរិសុទ្ធឡើយ ហើយលើសពីនេះទៅទៀត ក៏គ្មានការបំភ្លឺរបស់ព្រះវិញ្ញាណបរិសុទ្ធនោះដែរ។ ព្រោះថាពួកគេជាមនុស្សដែលគ្មានសេចក្ដីស្រឡាញ់ដ៏ពិតចំពោះសេចក្ដីពិត និងជាមនុស្សដែលត្រូវបានព្រះវិញ្ញាណបរិសុទ្ធស្អប់ខ្ពើម និងបដិសេធរួចទៅហើយ។ ពួកគេត្រូវបានហៅថាជាមនុស្សទុច្ចរិត ដោយសារតែពួកគេ

ដើរនៅក្នុងសាច់ឈាម និងធ្វើតាមអ្វីៗដែលផ្គាប់ចិត្តពួកគេ ដោយស្ថិតនៅក្រោមផ្ទាំងឃោសនារបស់ព្រះជាម្ចាស់។ ខណៈពេលដែលព្រះជាម្ចាស់ធ្វើការ ពួកគេបែរជាមានចេតនាប្រឆាំងនឹងទ្រង់ ហើយរត់ទៅគោលដៅផ្ទុយពីទ្រង់ទៅវិញ។ ការបរាជ័យរបស់មនុស្សក្នុងការសហការជាមួយព្រះជាម្ចាស់ គឺជាការបះបោរដ៏ខ្ពស់បំផុតរបស់ពួកគេ តើមនុស្សដែលមានចេតនាប្រឆាំងនឹងព្រះជាម្ចាស់ នឹងមិនទទួលការផ្ដន្ទាទោសដ៏យុត្តិធម៌របស់ខ្លួនទេឬអី? នៅពេលដែលលើកឡើងពីទង្វើអាក្រក់របស់មនុស្សទាំងនេះ អ្នកខ្លះនឹងចង់ជេរប្រទេចផ្ដាសាពួកគេ ប៉ុន្តែព្រះជាម្ចាស់មិនអើពើចំពោះពួកគេទេ។ ចំពោះមនុស្ស វាហាក់ដូចជាទង្វើរបស់ពួកគេទាក់ទងនឹងព្រះនាមរបស់ព្រះជាម្ចាស់ ប៉ុន្តែចំពោះព្រះជាម្ចាស់វិញ តាមពិតទៅ ទង្វើរបស់ពួកគេគ្មានអ្វីពាក់ព័ន្ធនឹងព្រះនាមរបស់ទ្រង់ ឬទីបន្ទាល់ពីទ្រង់នោះឡើយ។ មិនថាមនុស្សទាំងនេះធ្វើអ្វីនោះឡើយ វាមិនទាក់ទងអ្វីនឹងព្រះជាម្ចាស់ឡើយ៖ វាមិនទាក់ទងនឹងព្រះនាមទ្រង់ និងកិច្ចការនាពេលបច្ចុប្បន្នរបស់ទ្រង់ឡើយ។ មនុស្សទាំងនេះបំបាក់មុខខ្លួនឯង ហើយស្ដែងចេញឲ្យឃើញពីសាតាំង ព្រោះពួកគេជាមនុស្សទុច្ចរិតដែលកំពុងតែប្រមូលទុកសម្រាប់ថ្ងៃនៃសេចក្ដីក្រោធ។ ថ្ងៃនេះ មិនថាទង្វើរបស់ពួកគេបែបណា ហើយប្រសិនបើពួកគេមិនរាំងស្ទះដល់ការគ្រប់គ្រងរបស់ព្រះជាម្ចាស់ និងមិនពាក់ព័ន្ធជាមួយកិច្ចការថ្មីរបស់ព្រះជាម្ចាស់ទេ នោះមនុស្សបែបនេះនឹងមិនត្រូវទទួលការផ្ដន្ទាទោសឡើយ ដ្បិតថ្ងៃនៃសេចក្ដីក្រោធមិនទាន់បានមកដល់នៅឡើយទេ។ មាននូវរឿងជាច្រើនដែលមនុស្សជឿថា ព្រះជាម្ចាស់គួរតែបានដោះស្រាយឲ្យបានដាច់ស្រេច ហើយពួកគេគិតថា មនុស្សទុច្ចរិតទាំងនោះ គួរតែទទួលការផ្ដន្ទាទោសឲ្យកាន់តែឆាប់កាន់តែល្អ។ ប៉ុន្តែ ដោយសារតែកិច្ចការនៃការគ្រប់គ្រងរបស់ព្រះជាម្ចាស់មិនទាន់បានដល់ទីបញ្ចប់ ហើយថ្ងៃនៃសេចក្ដីក្រោធក៏មិនទាន់បានមកដល់ ដូច្នេះ មនុស្សទុច្ចរិតនៅតែបន្តធ្វើទង្វើទុច្ចរិតរបស់ពួកគេតទៅទៀត។ អ្នកខ្លះនិយាយថា «អស់អ្នកដែលនៅក្នុងសាសនា គ្មានព្រះវត្តមាន ឬកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធទេ ហើយពួកគេនាំមកនូវភាពអាម៉ាស់ដល់ព្រះនាមរបស់ព្រះជាម្ចាស់។ ដូច្នេះ ហេតុអ្វីបានជាព្រះជាម្ចាស់

មិនបំផ្លាញពួកគេទៅ ជាជាងទុកឲ្យពួកគេបន្ត នូវឥរិយាបថតាមទំនើងចិត្តដោយឥតបង្រៀនបែបនេះ?» មនុស្សដែលជារូបតំណាងឲ្យសាតាំង និងដែលស្ដែងចេញពីសាច់ឈាមទាំងនេះ គឺជាមនុស្សល្ងិតល្ងង់ និងថោកទាប ដ្បិតពួកគេជាមនុស្សគ្មានហេតុផលឡើយ។ ពួកគេនឹងមិនឃើញ ពីការមកដល់នៃសេចក្ដីក្រោធរបស់ព្រះជាម្ចាស់ មុនពេលដែលពួកគេចាប់ផ្ដើមយល់អំពីរបៀបដែលព្រះជាម្ចាស់ធ្វើកិច្ចការរបស់ទ្រង់នៅក្នុងចំណោមមនុស្សឡើយ ហើយនៅពេលដែលព្រះជាម្ចាស់បានយកឈ្នះពួកគេទាំងស្រុងហើយ មនុស្សទុច្ចរិតទាំងនេះ នឹងត្រូវទទួលការផ្ដន្ទាទោសរបស់ពួកគេ ហើយគ្មាននរណាម្នាក់នឹងអាចរួចខ្លួនពីថ្ងៃនៃសេចក្ដីក្រោធបាននោះឡើយ។ ឥឡូវនេះមិនទាន់ដល់ពេលសម្រាប់ការដាក់ទោសមនុស្សនៅឡើយទេ ប៉ុន្តែវាជាពេលដែលត្រូវអនុវត្តតាមកិច្ចការនៃការយកឈ្នះ លុះត្រាតែមានមនុស្សដែលបំផ្លាញដល់ការគ្រប់គ្រងរបស់ព្រះជាម្ចាស់ ទើបពួកគេនឹងត្រូវទទួលទោសដោយផ្អែកលើភាពធ្ងន់ធ្ងរនៃទង្វើរបស់ពួកគេ។ ក្នុងអំឡុងពេលនៃការគ្រប់គ្រងមនុស្សជាតិរបស់ព្រះជាម្ចាស់ អស់អ្នកណាដែលស្ថិតនៅក្នុងចរន្តនៃព្រះវិញ្ញាណបរិសុទ្ធ ត្រូវមានការទាក់ទងជាមួយព្រះជាម្ចាស់។ អស់អ្នកណាដែលត្រូវបានព្រះវិញ្ញាណបរិសុទ្ធស្អប់ខ្ពើម និងបដិសេធ គឺជាអ្នកដែលរស់នៅក្រោមឥទ្ធិពលរបស់សាតាំង ហើយអ្វីដែលគេយកទៅអនុវត្ត គ្មានទំនាក់ទំនងអ្វីជាមួយព្រះជាម្ចាស់ឡើយ។ មានតែអ្នកដែលទទួលយកកិច្ចការថ្មីរបស់ព្រះជាម្ចាស់ និងសហការជាមួយព្រះជាម្ចាស់ទេ ទើបមានទំនាក់ទំនងជាមួយព្រះជាម្ចាស់ ដ្បិតកិច្ចការរបស់ព្រះជាម្ចាស់មានគោលបំណងចំពោះតែមនុស្សទាំងឡាយណាដែលទទួលយកកិច្ចការរបស់ទ្រង់ប៉ុណ្ណោះ ហើយវាមិនមានគោលបំណងសំដៅទៅលើមនុស្សគ្រប់គ្នាឡើយ មិនថាពួកគេទទួលយកវាឬក៏អត់នោះទេ។ កិច្ចការដែលព្រះជាម្ចាស់បានធ្វើតែងតែមានកម្មវត្ថុរបស់ទ្រង់ ហើយមិនត្រូវបានធ្វើឡើង ដោយគ្មានហេតុផលនោះឡើយ។ មនុស្សដែលពាក់ព័ន្ធជាមួយសាតាំង មិនសក្ដិសមក្នុងការធ្វើបន្ទាល់អំពីព្រះជាម្ចាស់ឡើយ ហើយក៏មិនសក្ដិសមសហការជាមួយព្រះជាម្ចាស់ដែរ។

ដំណាក់កាលនីមួយៗនៃកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ក៏តម្រូវឲ្យមានការធ្វើទីបន្ទាល់របស់មនុស្សដែរ។ ដំណាក់កាលនីមួយៗនៃកិច្ចការ គឺជាសមរភូមិរវាងព្រះជាម្ចាស់ និងសាតាំង ហើយគោលដៅនៃចម្បាំងនេះគឺជាសាតាំង ខណៈពេលអ្នកដែលនឹងត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍ តាមរយៈកិច្ចការនេះ គឺជាមនុស្ស។ កិច្ចការរបស់ព្រះជាម្ចាស់អាចបង្កើតផលផ្លែបានឬមិនបាន គឺអាស្រ័យលើឥរិយាបថនៃការធ្វើទីបន្ទាល់របស់មនុស្សអំពីព្រះជាម្ចាស់។ ការធ្វើទីបន្ទាល់នេះ គឺជាអ្វីដែលព្រះជាម្ចាស់ទាមទារពីមនុស្សដែលដើរតាមទ្រង់ ហើយវាជាការធ្វើបន្ទាល់នៅមុខសាតាំង ហើយក៏ជាភស្តុតាង ដែលបង្ហាញអំពីការជះឥទ្ធិពលចេញពីកិច្ចការរបស់ទ្រង់ដែរ។ ការគ្រប់គ្រងទាំងមូលរបស់ព្រះជាម្ចាស់ ត្រូវបានបែងចែកជាបីដំណាក់កាល ហើយនៅក្នុងដំណាក់កាលនីមួយៗ វាមានសេចក្តីតម្រូវដែលតម្រូវឲ្យមនុស្សធ្វើ។ លើសពីនេះទៅទៀត នៅពេលដែលយុគសម័យកន្លងផុត ហើយវិវឌ្ឍទៅមុខ នោះសេចក្តីតម្រូវរបស់ព្រះជាម្ចាស់សម្រាប់មនុស្សជាតិទាំងអស់ ក៏កាន់តែខ្ពស់ជាងមុនដែរ។ ដូច្នេះ កិច្ចការនៃការគ្រប់គ្រងរបស់ព្រះជាម្ចាស់នេះ ឡើងដល់កម្រិតកំពូលរបស់វាមួយជំហានម្តងៗ រហូតដល់មនុស្សមើលឃើញតថភាពពិតអំពី «ការលេចមកនៃព្រះបន្ទូលនៅក្នុងសាច់ឈាម» ហើយតាមរបៀបនេះ សេចក្តីតម្រូវរបស់មនុស្សក៏កាន់តែខ្ពស់ ឯសេចក្តីតម្រូវ ដែលឲ្យមនុស្សធ្វើទីបន្ទាល់ក៏ខ្ពស់ដូចគ្នាដែរ។ ប្រសិនបើមនុស្សមានសមត្ថភាពកាន់តែច្រើនក្នុងការសហការជាមួយព្រះជាម្ចាស់យ៉ាងពិតប្រាកដ នោះព្រះជាម្ចាស់នឹងទទួលបានសិរីល្អកាន់តែច្រើនដែរ។ កិច្ចសហប្រតិបត្តិការរបស់មនុស្ស គឺជាការធ្វើទីបន្ទាល់ដែលតម្រូវឲ្យគេធ្វើ ហើយទីបន្ទាល់ដែលគេធ្វើ គឺជាការអនុវត្តរបស់មនុស្ស។ ដូច្នេះ កិច្ចការរបស់ព្រះជាម្ចាស់អាចមានការជះឥទ្ធិពលឬគ្មាន ហើយមានទីបន្ទាល់ដ៏ពិតឬក៏អត់ គឺត្រូវបានផ្សារភ្ជាប់យ៉ាងស្អិតរមួតទៅនឹងកិច្ចសហប្រតិបត្តិការ និងទីបន្ទាល់របស់មនុស្សនេះហើយ។ នៅពេលដែលកិច្ចការត្រូវបានបញ្ចប់ គឺអាចនិយាយបានថា នៅពេលដែលការគ្រប់គ្រងទាំងអស់របស់ព្រះជាម្ចាស់បានមកដល់ទីបញ្ចប់ នោះមនុស្សនឹងតម្រូវឲ្យធ្វើទីបន្ទាល់កាន់តែខ្ពស់ ហើយនៅពេលដែលកិច្ចការ

របស់ព្រះជាម្ចាស់មកដល់ទីបញ្ចប់ នោះការអនុវត្ត និងច្រកចូលរបស់មនុស្សក៏នឹងឡើងដល់កម្រិតកំពូលរបស់វាដែរ។ កាលពីអតីតកាល មនុស្សតម្រូវឲ្យកាន់តាមក្រឹត្យវិន័យ និងបទបញ្ញត្តិ ហើយគេតម្រូវឲ្យមានចិត្តអត់ធ្មត់ និងការបន្ទាបខ្លួន។ សព្វថ្ងៃនេះ មនុស្សតម្រូវឲ្យស្ដាប់បង្គាប់តាមគ្រប់ការរៀបចំរបស់ព្រះជាម្ចាស់ និងមានសេចក្ដីស្រឡាញ់សម្រាប់ព្រះជាម្ចាស់ឲ្យបានខ្ពស់បំផុត ហើយចុងបញ្ចប់ គេតម្រូវឲ្យនៅតែស្រឡាញ់ព្រះជាម្ចាស់ដដែល ទោះបីជាស្ថិត នៅក្នុងទុក្ខវេទនាក៏ដោយ។ ដំណាក់កាលទាំងបីនេះ គឺជាសេចក្ដីតម្រូវដែលព្រះជាម្ចាស់កំណត់ទុកសម្រាប់មនុស្សមួយជំហានម្ដងៗ នៅទូទាំងការគ្រប់គ្រងទាំងអស់របស់ទ្រង់។ ដំណាក់កាលនីមួយៗនៃកិច្ចការរបស់ព្រះជាម្ចាស់កាន់តែស៊ីជម្រៅជាងដំណាក់កាលមុនៗ ហើយនៅក្នុងដំណាក់កាលនីមួយៗ សេចក្ដីតម្រូវសម្រាប់មនុស្សក៏កាន់តែមានភាពជ្រាលជ្រៅជាងលើកមុនដែរ ហើយតាមរបៀបនេះ ការគ្រប់គ្រងទាំងអស់របស់ព្រះជាម្ចាស់នឹងលេចជារូបរាងបន្តិចម្ដងៗ។ វាកើតឡើងបែបនេះ ដោយសារតែសេចក្ដីតម្រូវសម្រាប់មនុស្សមានកាន់តែខ្ពស់ ដែលនាំឲ្យនិស្ស័យរបស់មនុស្សកាន់តែដូច ទៅនឹងបទដ្ឋានដែលព្រះជាម្ចាស់បានតម្រូវទុក ហើយមានតែបែបនេះទេ ទើបមនុស្សជាតិទាំងមូលចាប់ផ្ដើមចាកចេញបន្តិចម្ដងៗពីឥទ្ធិពលរបស់សាតាំង។ នៅពេលដែលកាលកំណត់នោះមកដល់ កិច្ចការរបស់ព្រះជាម្ចាស់នឹងបានមកដល់ទីបញ្ចប់ ហើយកិច្ចសហប្រតិបត្តិការរបស់មនុស្សជាមួយព្រះជាម្ចាស់ ដើម្បីសម្រេចឲ្យបានការផ្លាស់ប្ដូរនៅក្នុងនិស្ស័យរបស់គេ នឹងលែងមាន ហើយមនុស្សជាតិទាំងអស់នឹងរស់នៅក្នុងពន្លឺរបស់ព្រះជាម្ចាស់ ហើយចាប់ពីពេលនោះតទៅ នឹងគ្មានការបះបោរឬការប្រឆាំងចំពោះព្រះជាម្ចាស់ទៀតឡើយ។ ព្រះជាម្ចាស់ក៏នឹងលែងទាមទារពីមនុស្សទៀតដែរ ហើយនឹងមានកិច្ចសហប្រតិបត្តិការចុះសម្រុងកាន់តែច្រើនរវាងមនុស្សនិងព្រះជាម្ចាស់ ជាកិច្ចសហប្រតិបត្តិការមួយដែលនឹងមានជីវិតរួមគ្នារវាងមនុស្សនិងព្រះជាម្ចាស់ ជាជីវិតដែលកើតចេញ ក្រោយការគ្រប់គ្រងរបស់ព្រះជាម្ចាស់ត្រូវបានបញ្ចប់ទាំងស្រុង និងក្រោយពេលដែលមនុស្សត្រូវបានព្រះជាម្ចាស់សង្គ្រោះយ៉ាងពេញលេញ ចេញពីក្រញាំ

ដៃរបស់សាតាំង។ អស់អ្នកណាដែលមិនអាចដើរប្រកៀកតាមជំហានព្រះបាទារបស់ព្រះជាម្ចាស់ គេនឹងគ្មានសមត្ថភាពទទួលបានជីវិតបែបនេះឡើយ។ ពួកគេនឹងទម្លាក់ខ្លួនឯងទៅក្នុងសេចក្ដីងងឹត ជាកន្លែងដែលពួកគេនឹងយំសោក ហើយសង្កៀតធ្មេញ ព្រោះពួកគេជាមនុស្សដែលជឿលើព្រះជាម្ចាស់ ប៉ុន្ដែមិនដើរតាមទ្រង់ ជាអ្នកដែលជឿលើព្រះជាម្ចាស់ ប៉ុន្ដែមិនស្ដាប់បង្គាប់តាមគ្រប់កិច្ចការរបស់ទ្រង់។ ដោយសារតែមនុស្សជឿលើព្រះជាម្ចាស់ ដូច្នេះ គេត្រូវតែដើរតាមយ៉ាងប្រកៀកនឹងជំហានព្រះបាទារបស់ព្រះជាម្ចាស់មួយជំហានម្ដងៗ ហើយគេគួរតែ «ដើរតាមកូនចៀមនៅគ្រប់ទីកន្លែងដែលទ្រង់យាងទៅ»។ មានតែមនុស្សបែបនេះប៉ុណ្ណោះ ដែលជាមនុស្សស្វែងរកផ្លូវដ៏ពិត និងជាម្នាក់ដែលស្គាល់ពីកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ។ មនុស្សដែលដើរតាមន័យពាក្យ និងគោលលទ្ធិយ៉ាងរឹងរូស គឺជាមនុស្សដែលត្រូវបានផាត់ចោលដោយកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ។ នៅក្នុងអំឡុងពេលនីមួយៗ ព្រះជាម្ចាស់នឹងចាប់ផ្ដើមកិច្ចការថ្មី ហើយនៅក្នុងអំឡុងពេលនីមួយៗ នឹងមានការចាប់ផ្ដើមថ្មីនៅក្នុងចំណោមមនុស្ស។ ប្រសិនបើមនុស្សកាន់តាមសេចក្ដីពិតដែលថែងថា «ព្រះយេហូវ៉ាគឺជាព្រះជាម្ចាស់» ហើយ «ព្រះយេស៊ូវជាព្រះគ្រីស្ទ» ជាសេចក្ដីពិតដែលអនុវត្តតែនៅក្នុងយុគសម័យនីមួយៗ នោះមនុស្សនឹងមិនតាមទាន់កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ហើយគេនឹងគ្មានសមត្ថភាពទទួលបានកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធជារៀងរហូតឡើយ។ មិនថាព្រះជាម្ចាស់ធ្វើការតាមរបៀបណាឡើយ មនុស្សដើរតាមដោយគ្មានចិត្តសង្ស័យសូម្បីតែបន្ដិច ហើយគេដើរតាមទ្រង់យ៉ាងប្រកៀក។ តាមរបៀបនេះ តើមនុស្សអាចត្រូវបានផាត់ចោលដោយព្រះវិញ្ញាណបរិសុទ្ធយ៉ាងដូចម្ដេចទៅ? មិនថាព្រះជាម្ចាស់ធ្វើអ្វីឡើយ ដរាបណាមនុស្សនៅតែប្រាកដច្បាស់ថា វាជាកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ហើយសហការនៅក្នុងកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធដោយគ្មានមន្ទិល ព្រមទាំងព្យាយាមបំពេញតាមសេចក្ដីតម្រូវរបស់ព្រះជាម្ចាស់ តើគេអាចទទួលទោសយ៉ាងដូចម្ដេចកើត? កិច្ចការរបស់ព្រះជាម្ចាស់មិនដែលឈប់ឡើយ ជំហានព្រះបាទារបស់ទ្រង់ក៏មិនដែលឈប់ដែរ ហើយមុនពេលបញ្ចប់កិច្ចការគ្រប់គ្រង

របស់ទ្រង់ ព្រះអង្គតែងតែមមាញឹក ហើយមិនដែលឈប់សម្រាកឡើយ។ ប៉ុន្តែ មនុស្ស មានលក្ខណៈខុសពីនេះ៖ ដោយទទួលបានចំនួនតិចតួចនៃកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ គេចាត់ទុកកិច្ចការរបស់ទ្រង់ថានឹងមិនដែលផ្លាស់ប្ដូរឡើយ។ ដោយទទួលបានចំណេះដឹងតិចតួច គេមិនបានបន្តដើរតាមជំហានព្រះបាទានៃកិច្ចការថ្មីៗ របស់ព្រះជាម្ចាស់ឡើយ។ ដោយមើលឃើញកិច្ចការរបស់ព្រះជាម្ចាស់បានតិចតួច គេក៏កំណត់ភ្លាមៗថា ព្រះជាម្ចាស់ដូចជារូបសំណាក់ធ្វើពីឈើ ហើយជឿថា ព្រះជាម្ចាស់នឹងតែងតែបន្តនៅក្នុងទម្រង់ដែលគេមើលឃើញនៅចំពោះមុខរបស់គេបែបនេះ ព្រមទាំងជឿថា ព្រះអង្គកាលពីអតីតកាលបែបណា នៅថ្ងៃអនាគត ទ្រង់នឹងនៅតែបែបនោះដដែល។ ដោយទទួលបានចំណេះដឹងបន្តិចបន្តួច មនុស្សអួតខ្លួនយ៉ាងខ្លាំងថា គេភ្លេចខ្លួន ហើយចាប់ផ្ដើមប្រកាសដោយឥតសំចៃមាត់អំពីនិស្ស័យ និងរូបអង្គរបស់ព្រះជាម្ចាស់ដែលគ្មានពិតនោះឡើយ។ ហើយដោយប្រាកដច្បាស់អំពីដំណាក់កាលមួយនៃកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ មិនថាអ្នកដែលប្រកាសអំពីកិច្ចការថ្មីរបស់ព្រះជាម្ចាស់នោះជាមនុស្សប្រភេទណាឡើយ គឺមនុស្សមិនទទួលយកទេ។ ពួកគេគឺជាមនុស្សដែលមិនអាចទទួលយកកិច្ចការថ្មីនៃព្រះវិញ្ញាណបរិសុទ្ធឡើយ ព្រោះពួកគេជាមនុស្សអភិរក្សជ្រុល ហើយគ្មានសមត្ថភាពទទួលយកកិច្ចការថ្មីៗឡើយ។ មនុស្សបែបនេះជាអ្នកដែលជឿលើព្រះជាម្ចាស់ ប៉ុន្តែក៏បដិសេធព្រះជាម្ចាស់ដែរ។ មនុស្សជឿថា ពួកអ៊ីស្រាអែលខុសហើយ ដែល «គ្រាន់តែជឿលើព្រះយេហូវ៉ា ហើយមិនព្រមជឿលើព្រះយេស៊ូវ» ប៉ុន្តែ មនុស្សភាគច្រើនប្រព្រឹត្តដូចជាពួកគេ «គ្រាន់តែជឿលើព្រះយេហូវ៉ា ហើយបដិសេធព្រះយេស៊ូវ» និង «ទន្ទឹងរង់ចាំការយាងត្រលប់របស់ព្រះមែស៊ី ប៉ុន្តែប្រឆាំងនឹងព្រះមែស៊ីដែលត្រូវបានហៅថាជាព្រះយេស៊ូវ»។ ដូច្នេះ វាគ្មានអ្វីដែលត្រូវឆ្ងល់ឡើយថា មនុស្សនៅតែរស់នៅក្រោមការគ្រប់គ្រងរបស់សាតាំង ក្រោយការទទួលយកដំណាក់កាលមួយនៃកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ហើយនៅតែមិនទទួលបានព្រះពររបស់ព្រះជាម្ចាស់។ តើនេះមិនមែនជាលទ្ធផលនៃការបះបោររបស់មនុស្សទេឬអី? គ្រីស្ទបរិស័ទនៅទូទាំងពិភពលោកដែលមិនបានតាមទាន់កិច្ចការថ្មីនា

ពេលសព្វថ្ងៃ សុទ្ធតែប្រកាន់ខ្ជាប់នឹងជំនឿថា ពួកគេជាមនុស្សមានសំណាង ព្រមទាំងជឿថា ព្រះជាម្ចាស់នឹងសម្រេចតាមបំណងប្រាថ្នានីមួយៗរបស់ពួកគេមិនខាន។ ប៉ុន្តែពួកគេមិនអាចនិយាយឲ្យបានច្បាស់អំពីហេតុផលដែលព្រះជាម្ចាស់នឹងនាំយកពួកគេឡើងទៅស្ថានសួគ៌ជាន់ទីបី ឬមិនច្បាស់អំពីរបៀបដែលព្រះយេស៊ូវនឹងយាងមកទទួលពួកគេគង់នៅលើពពកសមួយដុំនោះឡើយ ហើយពួកគេក៏មិនអាចនិយាយដោយចិត្តជឿជាក់ថា ព្រះយេស៊ូវនឹងពិតជាយាងត្រលប់មកវិញនៅលើពពកសមួយដុំនៅថ្ងៃដែលគេស្រមើស្រមៃនោះដែរ។ ពួកគេគ្រប់គ្នាមានចិត្តខ្វល់ខ្វាយ និងមិនច្បាស់ឡើយ។ ពួកគេថែមទាំងមិនដឹងថាតើព្រះជាម្ចាស់នឹងចាប់អារម្មណ៍លើពួកគេម្នាក់ៗដែលជាមនុស្សមួយក្តាប់តូចផ្សេងៗគ្នាចេញមកពីគ្រប់និកាយនោះឡើយ។ កិច្ចការដែលព្រះជាម្ចាស់ធ្វើនាពេលសព្វថ្ងៃ ពោលគឺនៅក្នុងយុគសម័យបច្ចុប្បន្ន ដែលជាព្រះហឫទ័យរបស់ព្រះជាម្ចាស់នោះ គឺពួកគេមិនយល់អំពីកិច្ចការទាំងនេះឡើយ ហើយពួកគេមិនអាចធ្វើអ្វីសោះ ក្រៅពីអង្គុយរាប់ថ្ងៃនៅលើម្រាមដៃរបស់ពួកគេ។ មានតែអស់អ្នក ដែលដើរតាមជំហានព្រះបាទារបស់កូនចៀមដល់ទីចុងបញ្ចប់ទេ ទើបចុងបញ្ចប់ អាចទទួលបានព្រះពរ របស់ព្រះជាម្ចាស់ រីឯ «មនុស្សឆ្លាត» ទាំងនោះ ដែលមិនអាចដើរតាមដល់ទីបញ្ចប់ ប៉ុន្តែជឿថាពួកគេបានទទួលអ្វីៗគ្រប់យ៉ាង គឺគ្មានសមត្ថភាពមើលឃើញផ្ទាល់ភ្នែកអំពីការលេចមករបស់ព្រះជាម្ចាស់ឡើយ។ ពួកគេម្នាក់ៗជឿថាពួកគេជាមនុស្សដ៏ឆ្លាតបំផុតនៅលើផែនដី ហើយពួកគេកាត់ចោលការបន្តអភិវឌ្ឍន៍នៃកិច្ចការរបស់ព្រះជា ម្ចាស់ដោយគ្មានហេតុផលទាល់តែសោះ ហើយហាក់ដូចជាជឿយ៉ាងច្បាស់ថា ព្រះ ជាម្ចាស់នឹងនាំពួកគេឡើងទៅឯស្ថានសួគ៌ ព្រមទាំងជឿថាពួកគេ «មានចិត្តភក្តីភាពបំផុតចំពោះព្រះជាម្ចាស់ ដើរតាមព្រះជាម្ចាស់ និងកាន់តាមព្រះបន្ទូលរបស់ព្រះជាម្ចាស់»។ ទោះបីជាពួកគេមាន «ចិត្តភក្តីភាពបំផុត» ចំពោះព្រះបន្ទូលដែលព្រះជាម្ចាស់បានថ្លែងក៏ដោយ ប៉ុន្តែពាក្យសម្តី និងទង្វើរបស់ពួកគេនៅតែគួរឲ្យស្អប់ខ្ពើមបំផុតដដែល ដោយសារតែពួកគេប្រឆាំងនឹងកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ហើយប្រព្រឹត្តរឿងបោកបញ្ឆោត និងអាក្រក់។ អស់អ្នកណាដែលដើរតាមមិនដល់ទី

បញ្ចប់ មិនតាមទាន់កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ និងប្រកាន់ខ្ជាប់ចំពោះកិច្ចការចាស់ នោះពួកគេមិនគ្រាន់តែគ្មានចិត្តភក្តីភាពចំពោះព្រះជាម្ចាស់ប៉ុណ្ណោះទេ ប៉ុន្តែផ្ទុយទៅវិញ ពួកគេបានក្លាយជាមនុស្សដែលប្រឆាំងនឹងព្រះជាម្ចាស់ បានក្លាយជាមនុស្សដែលត្រូវបានបដិសេធដោយយុគសម័យថ្មី ហើយពួកគេនឹងត្រូវទទួលទោសមិនខាន។ តើមានមនុស្សណាដែលគួរឲ្យសង្វេគជាងពួកគេដែរឬទេ? មនុស្សជាច្រើនថែមទាំងជឿថា អស់អ្នកណាដែលបដិសេធក្រឹត្យវិន័យចាស់ ហើយទទួលយកកិច្ចការថ្មី គឺជាមនុស្សគ្មានមនសិការឡើយ។ មនុស្សដែលនិយាយអំពី «មនសិការ» ទាំងនេះ ហើយមិនបានដឹងអំពីកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ចុងបញ្ចប់នឹងត្រូវបាត់បង់អនាគតរបស់ខ្លួនតាមរយៈមនសិការរបស់គេមិនខាន។ កិច្ចការរបស់ព្រះជាម្ចាស់មិនគោរពតាមគោលលទ្ធិទេ ហើយទោះបីវាអាចជាកិច្ចការរបស់ទ្រង់ផ្ទាល់ក៏ដោយ ក៏ព្រះជាម្ចាស់មិនប្រកាន់ខ្ជាប់នឹងវាដែរ។ អ្វីដែលគួរតែបដិសេធ ត្រូវបានបដិសេធ ហើយអ្វីដែលគួរតែផាត់ចោល ត្រូវបានផាត់ចោល។ ប៉ុន្តែ មនុស្សតាំងខ្លួនជាខ្មាំងសត្រូវនឹងព្រះជាម្ចាស់តាមរយៈការប្រកាន់ខ្ជាប់នឹងផ្នែកដ៏តូចមួយនៃកិច្ចការគ្រប់គ្រងរបស់ព្រះជាម្ចាស់។ តើនេះមិនមែនជារឿងមិនសមហេតុផលរបស់មនុស្សទេឬអី? តើនេះមិនមែនជាភាពល្ងីល្ងើរបស់មនុស្សទេឬ? បើមនុស្សកាន់តែកំសាក និងប្រយ័ត្នជ្រុលដោយសារតែពួកគេខ្លាចមិនទទួលបានព្រះពររបស់ព្រះជាម្ចាស់ នោះពួកគេកាន់តែគ្មានសមត្ថភាពក្នុងការទទួលបានព្រះពរកាន់តែធំ និងគ្មានសមត្ថភាពក្នុងការទទួលបានព្រះពរនាពេលចុងក្រោយឡើយ។ អស់អ្នកណាដែលខ្ជះខ្ជាយកាន់តាមក្រឹត្យវិន័យសុទ្ធតែបង្ហាញ ពីចិត្តភក្តីភាពទាំងស្រុងចំពោះក្រឹត្យវិន័យ ហើយបើពួកគេបង្ហាញចិត្តភក្តីភាពបែបនេះចំពោះក្រឹត្យវិន័យ នោះពួកគេកាន់តែក្លាយជាជនបះបោរដែលប្រឆាំងនឹងព្រះជាម្ចាស់។ សម្រាប់ពេលបច្ចុប្បន្ន គឺជាយុគសម័យនៃនគរព្រះ ហើយវាមិនមែនជាយុគសម័យនៃក្រឹត្យវិន័យទេ ហើយកិច្ចការនាពេលបច្ចុប្បន្ន និងកិច្ចការកាលពីអតីតកាល មិនអាចត្រូវបានលើកឡើងនៅក្នុងបរិបទដូចគ្នានោះឡើយ ហើយកិច្ចការកាលពីអតីតកាល ក៏មិនអាចយកមកប្រៀបធៀបជាមួយកិច្ចការ នាពេល

បច្ចុប្បន្នបានដែរ។ កិច្ចការរបស់ព្រះជាម្ចាស់បានផ្លាស់ប្ដូរ ហើយការអនុវត្តរបស់មនុស្សក៏បានផ្លាស់ប្ដូរដែរ ហើយវាមិនប្រកាន់ខ្ជាប់នឹងក្រឹត្យវិន័យ ឬឈើឆ្កាងទេ ដូច្នេះ ចិត្តភក្ដីភាពរបស់មនុស្សចំពោះក្រឹត្យវិន័យ និងឈើឆ្កាងនឹងមិនទទួលបានការយល់ព្រមពីព្រះជាម្ចាស់ឡើយ។

មនុស្សនឹងត្រូវបានប្រោសឲ្យបានគ្រប់លក្ខណ៍ទាំងស្រុង នៅក្នុងយុគសម័យនៃនគរព្រះ។ ក្រោយកិច្ចការនៃការយកឈ្នះ មនុស្សនឹងត្រូវទទួលការបន្សុទ្ធ និងទុក្ខវេទនា។ អស់អ្នកណាដែលអាចយកឈ្នះ និងឈរធ្វើទីបន្ទាល់ក្នុងអំឡុងពេលនៃទុក្ខវេទនានេះ គឺជាមនុស្សដែលនឹងត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍នៅទីចុងបញ្ចប់ ហើយពួកគេគឺជាអ្នកមានជ័យជម្នះ។ ក្នុងអំឡុងពេលនៃទុក្ខវេទនានេះ មនុស្សតម្រូវឲ្យទទួលយកការបន្សុទ្ធនេះ ហើយការបន្សុទ្ធនេះ គឺជាហេតុការណ៍ចុងក្រោយនៃកិច្ចការរបស់ព្រះជាម្ចាស់។ វាជាពេលចុងក្រោយដែលមនុស្សនឹងត្រូវបន្សុទ្ធ មុនពេលធ្វើការបូកសរុបកិច្ចការទាំងអស់នៃការគ្រប់គ្រងរបស់ព្រះជាម្ចាស់ ហើយអស់អ្នកណាដែលដើរតាមព្រះជាម្ចាស់ ត្រូវទទួលយកការសាកល្បងចុងក្រោយនេះ ហើយពួកគេត្រូវទទួលយកការបន្សុទ្ធចុងក្រោយនេះ។ អស់អ្នកណាដែលត្រូវបានរុកគួនដោយទុក្ខវេទនា គឺគ្មានកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ និងការដឹកនាំរបស់ព្រះជាម្ចាស់ឡើយ ប៉ុន្ដែអស់អ្នក ដែលត្រូវបានព្រះជាម្ចាស់យកឈ្នះដោយពិតប្រាកដ ហើយពិតជាស្វែងរកព្រះជាម្ចាស់ នោះពួកគេនឹងឈររឹងមាំនៅចុងបញ្ចប់ ហើយពួកគេជាម្នាក់ដែលមានភាពជាមនុស្ស និងជាអ្នកដែលស្រឡាញ់ដល់ព្រះជាម្ចាស់ យ៉ាងពិតប្រាកដ។ មិនថាព្រះជាម្ចាស់ធ្វើអ្វីនោះឡើយ មនុស្សដ៏មានជ័យទាំងនេះ នឹងមិនបាត់និមិត្តឡើយ ហើយគេនឹងនៅតែអនុវត្តតាមសេចក្ដីពិតដោយមិនបរាជ័យនៅក្នុងទីបន្ទាល់របស់ពួកគេនោះឡើយ។ ពួកគេជាម្នាក់ដែលនឹងងើបឡើងចេញពីទុក្ខវេទនាដ៏ធំនៅគ្រាចុងក្រោយ។ បើអ្នកដែលកេងចំណេញពីកាលៈទេសៈជ្រួលច្របល់ នៅតែអាចកេងចំណេញនាពេលសព្វថ្ងៃដដែល ដូច្នេះ គ្មាននរណាម្នាក់អាចគេចផុតពីទុក្ខវេទនាចុងក្រោយ ហើយគ្មាននរណាម្នាក់អាចគេចផុតពីការសាកល្បងចុងក្រោយ

ឡើយ។ សម្រាប់មនុស្សដែលត្រូវបានយកឈ្នះ ទុក្ខវេទនាបែបនេះគឺជាការបន្សុទ្ធដ៏ធំបំផុតមួយ ប៉ុន្តែសម្រាប់មនុស្សដែលកេងចំណេញពីកាលៈទេសៈជ្រួលច្របល់ វាជាកិច្ចការនៃការផាត់ចោលទាំងស្រុង។ មិនថាពួកគេត្រូវបានសាកល្បងបែបណាឡើយ ចិត្តភក្ដីភាពរបស់អស់អ្នកដែលមានព្រះជាម្ចាស់នៅក្នុងដួងចិត្តរបស់ពួកគេនៅតែមិនផ្លាស់ប្ដូរដដែល ប៉ុន្តែសម្រាប់អស់អ្នកដែលមិនមានព្រះជាម្ចាស់នៅក្នុងដួងចិត្តរបស់ពួកគេវិញ នៅពេលដែលកិច្ចការរបស់ព្រះជាម្ចាស់មិនមានប្រយោជន៍សម្រាប់សាច់ឈាមរបស់ពួកគេ នោះពួកគេប្រាកដជាផ្លាស់ប្ដូរទស្សនៈរបស់ពួកគេអំពីព្រះជាម្ចាស់ ហើយថែមទាំងឃ្លាតឆ្ងាយចេញពីព្រះជាម្ចាស់ទៀតផង។ មនុស្សបែបនេះនឹងមិនឈររឹងមាំនៅក្នុងគ្រាចុងក្រោយឡើយ ដ្បិតពួកគេជាមនុស្សស្វែងរកតែព្រះពររបស់ព្រះជាម្ចាស់ ហើយគ្មានបំណងចង់លះបង់ខ្លួនសម្រាប់ព្រះជាម្ចាស់និងថ្វាយខ្លួនទាំងស្រុងដល់ទ្រង់ឡើយ។ មនុស្សគ្មានតម្លៃបែបនេះ នឹងត្រូវបណ្ដេញចេញទាំងអស់ នៅពេលដែលកិច្ចការរបស់ព្រះជាម្ចាស់មកដល់ទីបញ្ចប់ហើយពួកគេមិនសក្ដិសមនឹងឲ្យអាណិតឡើយ។ អស់អ្នកណាដែលគ្មានភាពជាមនុស្ស នឹងគ្មានសមត្ថភាពស្រឡាញ់ព្រះជាម្ចាស់យ៉ាងពិតប្រាកដឡើយ។ នៅពេលដែលបរិយាកាសមានសុវត្ថិភាព និងសន្តិសុខល្អ ឬមានប្រយោជន៍ដល់ពួកគេ ពួកគេក៏ស្ដាប់បង្គាប់ព្រះជាម្ចាស់ទាំងស្រុង ប៉ុន្តែពេលដែលការប៉ងប្រាថ្នារបស់គេត្រូវបានចរចា ឬជំទាស់នៅចុងបញ្ចប់ភ្លាមៗ នោះពួកគេក៏បះបោរ។ ទោះបីជានៅក្នុងពេលតែមួយយប់ក៏ដោយក៏ពួកគេអាចប្រែប្រួលពីមនុស្សម្នាក់ដែលញញឹមញញែម «ចិត្តល្អ» ទៅក្លាយជាឃាតកមុខអាក្រក់ និងកាចសាហាវម្នាក់ដែរ ដោយចាត់ទុកអ្នកមានគុណរបស់ពួកគេកាលពីអតីតកាល ជាខ្មាំងសត្រូវស្លាប់រស់របស់ពួកគេតែមួយប៉ប្រិចភ្នែកប៉ុណ្ណោះ។ ប្រសិនបើពួកអារក្សទាំងនេះមិនត្រូវបានបណ្ដេញចេញទេ នោះពួកវានឹងសម្លាប់មនុស្សដោយគ្មានចិត្តអល់អែកនោះឡើយ ដូច្នេះ តើពួកវានឹងមិនក្លាយជាគ្រោះថ្នាក់កំបាំងមុខទេឬអី? កិច្ចការនៃការសង្គ្រោះមនុស្ស មិនត្រូវបានសម្រេច ក្រោយការសម្រេចនៃកិច្ចការយកឈ្នះនោះឡើយ។ ទោះបីជាកិច្ចការនៃការយកឈ្នះបានមកដល់ទីបញ្ចប់

ក៏ដោយ ប៉ុន្តែកិច្ចការបន្សុទ្ធមនុស្សឲ្យបរិសុទ្ធមិនទាន់បានចប់នៅឡើយទេ។ កិច្ចការបែបនេះនឹងត្រូវសម្រេចបាន លុះត្រាតែមនុស្សត្រូវបានញែកជាបរិសុទ្ធទាំងស្រុង លុះត្រាតែមនុស្សដែលបានចុះចូលចំពោះព្រះជាម្ចាស់យ៉ាងពិតប្រាកដ ត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍ និងលុះត្រាតែមនុស្សក្លែងបន្លំដែលគ្មានព្រះជាម្ចាស់នៅក្នុងដួងចិត្តរបស់ពួកគេទាំងនោះ ត្រូវបានកម្ចាត់ចោលឲ្យស្អាតសិន។ អស់អ្នកណាដែលមិនបំពេញតាមព្រះទ័យរបស់ព្រះជាម្ចាស់នៅក្នុងដំណាក់កាលចុងក្រោយនៃកិច្ចការរបស់ទ្រង់ នឹងត្រូវផាត់ចោលទាំងស្រុង ហើយអស់អ្នកណាដែលត្រូវផាត់ចោល គឺសុទ្ធតែមកពីអារក្ស។ នៅពេលដែលពួកគេ គ្មានសមត្ថភាពបំពេញតាមព្រះទ័យព្រះជាម្ចាស់ ពួកគេបះបោរប្រឆាំងនឹងព្រះជាម្ចាស់ ហើយទោះបីជាមនុស្សទាំងនេះដើរតាមព្រះជាម្ចាស់នាពេលសព្វថ្ងៃក៏ដោយ ក៏វាមិនបញ្ជាក់បានថា ពួកគេជាមនុស្សដែលនឹងបន្តដើរតាមទ្រង់រហូតដល់ចុងក្រោយនោះដែរ។ នៅក្នុងឃ្លាថា «អស់អ្នកដែលដើរតាមព្រះជាម្ចាស់ដល់ទីចុងបញ្ចប់នឹងទទួលបានសេចក្ដីសង្គ្រោះ» អត្ថន័យនៃពាក្យថា «ដើរតាម» គឺជាការឈររឹងមាំនៅក្នុងពេលជួបទុក្ខវេទនា។ សព្វថ្ងៃនេះមនុស្សជាច្រើនជឿថា ការដើរតាមព្រះជាម្ចាស់ គឺជារឿងងាយស្រួល ប៉ុន្តែនៅពេលដែលកិច្ចការរបស់ព្រះជាម្ចាស់ជិតមកដល់ទីបញ្ចប់ នោះអ្នកនឹងដឹងអំពីអត្ថន័យដ៏ពិតនៃពាក្យថា «ដើរតាម» មិនខាន។ ដោយគ្រាន់តែអ្នកនៅតែអាចដើរតាមព្រះជាម្ចាស់នាពេលសព្វថ្ងៃ ក្រោយត្រូវបានទ្រង់យកឈ្នះ ការនេះមិនបញ្ជាក់បានថា អ្នកជាម្នាក់នៅក្នុងចំណោមមនុស្សដែលនឹងត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍នោះឡើយ។ អស់អ្នកណាដែលមិនអាចទ្រាំទ្រនឹងការសាកល្បង ជាអ្នកដែលគ្មានសមត្ថភាពមានជ័យជម្នះនៅក្នុងពេលជួបទុក្ខវេទនានាពេលចុងបញ្ចប់ គេនឹងគ្មានសមត្ថភាពឈររឹងមាំ ហើយគេនឹងមិនអាចដើរតាមព្រះជាម្ចាស់រហូតដល់ទីបញ្ចប់នោះឡើយ។ អស់អ្នកណាដែលដើរតាមព្រះជាម្ចាស់យ៉ាងពិតប្រាកដ អាចឈរមាំនឹងការសាកល្បងនៃកិច្ចការរបស់ពួកគេ ខណៈមនុស្សដែលមិនដើរតាមព្រះជាម្ចាស់យ៉ាងពិតប្រាកដ នឹងគ្មានសមត្ថភាពឈរមាំនឹងការសាកល្បងណាមួយរបស់ព្រះជាម្ចាស់ឡើយ។ មិនយូរមិនឆាប់ ពួកគេ

នឹងត្រូវបណ្ដេញចេញ ខណៈពេលដែលពួកអ្នកមានជ័យជម្នះ នឹងបន្តនៅក្នុងនគរព្រះ។ មនុស្សម្នាក់ស្វែងរកព្រះជាម្ចាស់យ៉ាងពិតប្រាកដឬយ៉ាងណា គឺត្រូវកំណត់ដោយការសាកល្បងនៃកិច្ចការរបស់គេ ដែលជាការល្បងលរបស់ព្រះជាម្ចាស់ ហើយវាគ្មានទាក់ទងអ្វីជាមួយនឹងការសម្រេចចិត្តដែលមនុស្សធ្វើនោះឡើយ។ ព្រះជាម្ចាស់មិនបដិសេធបុគ្គលណាម្នាក់ដោយឥតហេតុផលឡើយ ហើយគ្រប់កិច្ចការដែលទ្រង់ធ្វើអាចធ្វើឲ្យមនុស្សជឿជាក់ទាំងស្រុង។ ទ្រង់មិនធ្វើអ្វីមួយដែលមនុស្សមើលមិនឃើញ ឬធ្វើកិច្ចការណាមួយដែលមិនអាចធ្វើឲ្យមនុស្សជឿនោះទេ។ បើចង់ដឹងថា សេចក្តីជំនឿរបស់មនុស្សពិត ឬក្លែងក្លាយ គឺត្រូវបញ្ជាក់ដោយការពិត ហើយវាមិនអាចត្រូវបានសម្រេចចិត្តដោយមនុស្សឡើយ។ «ស្រូវមិនអាចធ្វើឲ្យក្លាយជាស្រងែបានឡើយ ហើយស្រងែក៏មិនអាចធ្វើឲ្យក្លាយជាស្រូវបានដែរ» នេះជាចំណុចមួយដែលគ្មានអ្វីគួរឲ្យសង្ស័យឡើយ។ អស់អ្នកណាដែលស្រឡាញ់ព្រះជាម្ចាស់យ៉ាងពិតប្រាកដ ចុងបញ្ចប់គេនឹងបន្តនៅក្នុងនគរព្រះ ហើយព្រះជាម្ចាស់នឹងមិនធ្វើបាបនរណាម្នាក់ដែលស្រឡាញ់ទ្រង់យ៉ាងពិតប្រាកដឡើយ។ ដោយផ្អែកលើមុខងារ និងទីបន្ទាល់ផ្សេងៗរបស់ពួកគេ ពួកអ្នកមានជ័យជម្នះនៅក្នុងនគរព្រះ នឹងបម្រើក្នុងមុខងារជាសង្ឃ ឬជាអ្នកដើរតាម ហើយអស់អ្នកដែលមានជ័យជម្នះនៅក្នុងពេលជួបទុក្ខវេទនា នឹងក្លាយជាសមាជិកនៃគណៈសង្ឃនៅក្នុងនគរព្រះ។ គណៈសង្ឃ នឹងត្រូវបង្កើតឡើងនៅពេលដែលកិច្ចការនៃដំណឹងល្អនៅទូទាំងសកលលោកបានមកដល់ទីបញ្ចប់។ នៅពេលដែលគ្រានោះមកដល់ ការដែលមនុស្សគួរតែធ្វើនឹងក្លាយជាការបំពេញតាមភារកិច្ចរបស់គេនៅក្នុងនគររបស់ព្រះជាម្ចាស់ និងរស់នៅជាមួយព្រះជាម្ចាស់នៅក្នុងនគរព្រះ។ នៅក្នុងគណៈបូជាចារ្យ វានឹងមានមហាបូជាចារ្យ និងពួកបូជាចារ្យ ហើយអ្នកផ្សេងទៀតនឹងក្លាយជាពួកកូនប្រុស និងប្រជារាស្ត្ររបស់ព្រះជាម្ចាស់។ ការនេះត្រូវបានកំណត់ដោយទីបន្ទាល់របស់ពួកគេអំពីព្រះជាម្ចាស់ក្នុងអំឡុងពេលនៃទុក្ខវេទនា ហើយទាំងនេះមិនមែនជាងារដែលត្រូវបានផ្ដល់ជូនទាំងឥតហេតុផលនោះឡើយ។ នៅពេលដែលឋានៈរបស់មនុស្សត្រូវបានតាំងឡើង នោះកិច្ចការរបស់ព្រះជាម្ចាស់នឹងត្រូវឈប់ ដ្បិតមនុស្សម្នាក់ៗត្រូវ

បានចាត់ថ្នាក់ទៅតាមប្រភេទ និងត្រលប់ទៅកាន់មុខងារដើមរបស់គេ ហើយនេះគឺជាសញ្ញានៃការសម្រេចកិច្ចការរបស់ព្រះជាម្ចាស់ វាជាលទ្ធផលចុងក្រោយនៃកិច្ចការរបស់ព្រះជាម្ចាស់ និងការអនុវត្តរបស់មនុស្ស ហើយវាជារូបតំណាងឲ្យនិមិត្តនៃកិច្ចការរបស់ព្រះជាម្ចាស់ និងកិច្ចសហប្រតិបត្តិការរបស់មនុស្ស។ ចុងបញ្ចប់ មនុស្សនឹងរកឃើញសេចក្ដីស្ងប់សុខនៅក្នុងនគរព្រះ ហើយព្រះជាម្ចាស់ក៏នឹងយាងត្រលប់ទៅកាន់ព្រះដំណាក់របស់ទ្រង់ ដើម្បីសម្រាកដែរ។ ការនេះនឹងបានជាលទ្ធផលចុងក្រោយនៃកិច្ចសហប្រតិបត្តិការរយៈពេល៦០០០ឆ្នាំ រវាងព្រះជាម្ចាស់និងមនុស្ស។

# សារជាតិរបស់ព្រះគ្រីស្ទ គឺជាការស្ដាប់បង្គាប់តាមព្រះហឫទ័យរបស់ព្រះវរបិតា ដែលគង់នៅស្ថានសួគ៌

ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស ត្រូវបានហៅថាជាព្រះគ្រីស្ទ ហើយព្រះគ្រីស្ទក៏ជាសាច់ឈាម ដែលត្រូវបានបំពាក់ដោយព្រះវិញ្ញាណនៃព្រះជាម្ចាស់ផងដែរ។ សាច់ឈាមនេះមិនដូចមនុស្សណាផ្សេងដែលកើតចេញពីសាច់ឈាមទេ។ ភាពខុសគ្នាគឺថា ព្រះគ្រីស្ទមិនបានប្រសូត្រមកពីសាច់ និងឈាមឡើយ ប៉ុន្តែទ្រង់គឺជាការយកកំណើតរបស់ព្រះវិញ្ញាណវិញ។ ព្រះអង្គមានទាំងភាពជាមនុស្សសាមញ្ញ និងភាពជាព្រះដ៏ពេញលេញ។ ភាពជាព្រះរបស់ទ្រង់ មិនត្រូវបានកាន់កាប់ដោយមនុស្សណាម្នាក់ឡើយ។ ភាពជាមនុស្សសាមញ្ញរបស់ទ្រង់ ជួយទ្រទ្រង់នូវសកម្មភាពសាមញ្ញទាំងអស់របស់ទ្រង់នៅក្នុងសាច់ឈាម ចំណែកឯភាពជាព្រះរបស់ទ្រង់វិញ ជួយប្រតិបត្តិកិច្ចការរបស់ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ។ មិនថាព្រះអង្គនៅក្នុងភាពជាមនុស្ស ឬភាពជាព្រះឡើយ ទ្រង់តែងតែចុះចូលតាមព្រះហឫទ័យរបស់ព្រះវរបិតាដែលគង់នៅស្ថានសួគ៌ជានិច្ច។ សារជាតិរបស់ព្រះគ្រីស្ទ គឺជាព្រះវិញ្ញាណដែលជាភាពជាព្រះ។ ដូច្នេះ សារជាតិរបស់ទ្រង់ គឺមកពីព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ។ សារជាតិ

នេះ នឹងមិនរំខានដល់កិច្ចការរបស់ទ្រង់ផ្ទាល់ ហើយទ្រង់មិនអាចធ្វើអ្វីមួយដែលបំផ្លាញដល់កិច្ចការរបស់ទ្រង់ផ្ទាល់ ឬក៏នឹងមានបន្ទូលអ្វីមួយដែលទាស់ប្រឆាំងនឹងព្រះហឫទ័យរបស់ទ្រង់ផ្ទាល់ឡើយ។ ដូច្នេះ ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សនឹងមិនអាចធ្វើកិច្ចការណាមួយដែលរំខានដល់ការគ្រប់គ្រងរបស់ទ្រង់ផ្ទាល់ទេ។ នេះជាអ្វីដែលមនុស្សគ្រប់គ្នាគួរតែយល់។ កិច្ចការដ៏ចម្បងរបស់ព្រះវិញ្ញាណបរិសុទ្ធ គឺជាការសង្គ្រោះមនុស្ស និងជាប្រយោជន៍ដល់ការគ្រប់គ្រងផ្ទាល់របស់ព្រះជាម្ចាស់។ ដូចគ្នាដែរ កិច្ចការរបស់ព្រះគ្រីស្ទក៏ជាការសង្គ្រោះមនុស្ស និងជាប្រយោជន៍ដល់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែរ។ ដោយសារតែព្រះជាម្ចាស់ត្រលប់ជាសាច់ឈាម ទ្រង់ទទួលស្គាល់សារជាតិរបស់ទ្រង់ដែលស្ថិតនៅក្នុងសាច់ឈាមរបស់ទ្រង់ ដែលថាសាច់ឈាមរបស់ទ្រង់ គឺគ្រប់គ្រាន់ ដើម្បីធ្វើកិច្ចការរបស់ទ្រង់។ ដូច្នេះ គ្រប់កិច្ចការរបស់ព្រះវិញ្ញាណនៃព្រះជាម្ចាស់ ត្រូវបានជំនួសដោយកិច្ចការរបស់ព្រះគ្រីស្ទ ក្នុងអំឡុងពេលនៃការយកកំណើតជាមនុស្ស ហើយគោលបំណងស្នូលនៃគ្រប់កិច្ចការនៅក្នុងអំឡុងពេលនៃការយកកំណើតជាមនុស្សនេះ គឺជាកិច្ចការរបស់ព្រះគ្រីស្ទ។ វាមិនអាចត្រូវបានលាយឡំជាមួយកិច្ចការពីសម័យកាលផ្សេងៗឡើយ។ ហើយដោយសារតែព្រះជាម្ចាស់ត្រលប់ជាសាច់ឈាម ដូច្នេះ ទ្រង់ធ្វើការនៅក្នុងអត្តសញ្ញាណនៃសាច់ឈាមរបស់ទ្រង់។ ដោយសារតែទ្រង់យាងមកនៅក្នុងសាច់ឈាម ដូច្នេះ ទ្រង់នឹងបញ្ចប់កិច្ចការនៅក្នុងសាច់ឈាមដែលទ្រង់គួរតែធ្វើ។ មិនថាជាព្រះវិញ្ញាណនៃព្រះជាម្ចាស់ ឬជាព្រះគ្រីស្ទឡើយព្រះអង្គទាំងពីរ សុទ្ធតែជាព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ ហើយទ្រង់ធ្វើកិច្ចការ និងព័ន្ធកិច្ចដែលទ្រង់គួរតែធ្វើ។

សារជាតិដើមរបស់ព្រះជាម្ចាស់ផ្ទាល់ មាននូវសិទ្ធិអំណាច ប៉ុន្តែទ្រង់អាចចុះចូលទាំងស្រុងចំពោះសិទ្ធិអំណាចដែលមកពីទ្រង់។ មិនថាជាកិច្ចការនៃព្រះវិញ្ញាណ ឬជាកិច្ចការខាងសាច់ឈាមឡើយ កិច្ចការទាំងពីរនេះ មិនដែលមានជម្លោះនឹងគ្នាទេ។ ព្រះវិញ្ញាណ របស់ព្រះជាម្ចាស់ គឺជាសិទ្ធិអំណាចមួយលើការបង្កើតទាំងអស់។ សាច់ឈាម ដែលមានសារជាតិនៃព្រះជាម្ចាស់ ក៏មាននូវសិទ្ធិអំណាចដែរ ប៉ុន្តែ

ព្រះជាម្ចាស់នៅខាងក្នុងសាច់ឈាម អាចធ្វើគ្រប់កិច្ចការ ដែលស្ដាប់បង្គាប់តាមព្រះហឫទ័យរបស់ព្រះវរបិតាដែលគង់នៅស្ថានសួគ៌។ មនុស្សណាផ្សេង មិនអាចទទួល ឬចាប់កំណើតដោយសិទ្ធិអំណាចនេះបានឡើយ។ ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គគឺជាសិទ្ធិអំណាច ប៉ុន្តែសាច់ឈាមរបស់ទ្រង់អាចចុះចូលចំពោះសិទ្ធិអំណាចរបស់ទ្រង់។ នេះជាអត្ថន័យរបស់វា នៅពេលដែលគេនិយាយថា «ព្រះគ្រីស្ទស្ដាប់បង្គាប់តាមព្រះហឫទ័យរបស់ព្រះវរបិតា»។ ព្រះជាម្ចាស់ជាព្រះវិញ្ញាណ ហើយទ្រង់អាចធ្វើកិច្ចការនៃសេចក្ដីសង្គ្រោះ ដូចដែលព្រះជាម្ចាស់អាចក្លាយជាមនុស្សដែរ។ ទោះជាយ៉ាងណា ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ ធ្វើកិច្ចការរបស់ទ្រង់។ ទ្រង់មិនរំខាន មិនជ្រៀតជ្រែក ហើយក៏មិនធ្វើកិច្ចការទាំងឡាយណាដែលផ្ទុយនោះដែរ ដ្បិតសារជាតិនៃកិច្ចការដែលត្រូវសម្រេចដោយព្រះវិញ្ញាណ និងសាច់ឈាម គឺជាកិច្ចការតែមួយ។ មិនថាជាព្រះវិញ្ញាណ ឬជាសាច់ឈាមឡើយ ព្រះអង្គទាំងពីរធ្វើការ ដើម្បីសម្រេចព្រះហឫទ័យតែមួយ និងគ្រប់គ្រងកិច្ចការដូចគ្នា។ ទោះបីព្រះវិញ្ញាណ និងសាច់ឈាមមានគុណសម្បត្តិពីរខុសគ្នាស្រឡះក៏ដោយ ប៉ុន្តែសារជាតិរបស់ព្រះអង្គទាំងពីរ គឺដូចគ្នា។ ព្រះអង្គទាំងពីរ មានសារជាតិជាព្រះ និងអត្តសញ្ញាណរបស់ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ។ ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ គ្មានសមាសធាតុនៃការមិនស្ដាប់បង្គាប់ឡើយ។ សារជាតិរបស់ទ្រង់ គឺល្អ។ ទ្រង់ជាការសម្ដែងចេញនៃគ្រប់ទាំងភាពស្រស់ស្អាត និងសេចក្ដីល្អ ក៏ដូចជារាល់សេចក្ដីស្រឡាញ់ដែរ។ សូម្បីតែនៅក្នុងសាច់ឈាម ព្រះជាម្ចាស់មិនបានធ្វើអ្វីមួយដែលបំផ្លាញដល់ព្រះវរបិតាឡើយ។ សូម្បីតែពេល នៃការបូជាព្រះជន្មរបស់ទ្រង់ ក៏ទ្រង់ព្រមធ្វើតាមយ៉ាងអស់ពីចិត្ត ហើយទ្រង់នឹងមិនជ្រើសយកជម្រើសណាផ្សេងឡើយ។ ព្រះជាម្ចាស់គ្មានសមាសធាតុនៃការរាប់ខ្លួនឯងជាសុចរិត ការរាប់ខ្លួនឯងជា សំខាន់ ឬសមាសធាតុនៃសេចក្ដីអួត និងសេចក្ដីក្អេងក្អាងឡើយ ហើយសមាសធាតុនៃសេចក្ដីវៀចវេរ ក៏ទ្រង់គ្មានដែរ។ អ្វីគ្រប់យ៉ាងដែលមិនស្ដាប់បង្គាប់ព្រះជាម្ចាស់ សុទ្ធតែមកពីអារក្សសាតាំង ព្រោះថាសាតាំងជាប្រភពនៃគ្រប់ទាំងសេចក្ដីស្មោកគ្រោក និងសេចក្ដីអាក្រក់។ ហេតុផលដែលមនុស្សមានលក្ខណៈ

សម្បត្តិស្រដៀងគ្នាទៅនឹងអារក្សសាតាំង គឺដោយសារតែមនុស្សត្រូវបានពុករលួយ និងកែខៃដោយអារក្សសាតាំង។ ព្រះគ្រីស្ទមិនត្រូវបានពុករលួយ ដោយអារក្សសាតាំងឡើយ ដូច្នេះ ទ្រង់មានចរិតលក្ខណៈរបស់ព្រះជាម្ចាស់តែម្ដង ហើយគ្មានសូម្បីតែបន្តិចនូវចរិតលក្ខណៈរបស់អារក្សសាតាំង។ មិនថាកិច្ចការពិបាកខ្លាំងប៉ុនណា ឬសាច់ឈាមទន់ខ្សោយយ៉ាងណា ក្នុងពេលដែលព្រះជាម្ចាស់រស់នៅក្នុងសាច់ឈាម ក៏ទ្រង់នឹងមិនដែលធ្វើអ្វីមួយដែលរំខានដល់កិច្ចការរបស់ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គដែរ រួមទាំងការបោះបង់ចោល និងការមិនស្ដាប់បង្គាប់តាមព្រះហឫទ័យរបស់ព្រះវរបិតាផង។ ផ្ទុយទៅវិញ ព្រះអង្គនឹងព្រមទទួលយកការឈឺចាប់ខាងសាច់ឈាម ជាជាងក្បត់ចំពោះព្រះហឫទ័យរបស់ព្រះវរបិតា។ វាដូចអ្វីដែលព្រះយេស៊ូវបានអធិស្ឋានថា៖ «ឱព្រះវរបិតាអើយ! ប្រសិនបើអាច សូមឲ្យពែងនេះរំលងពីទូលបង្គំទៅ សូមកុំតាមចិត្តទូលបង្គំឡើយ តែសូមតាមបំណងព្រះហឫទ័យរបស់ទ្រង់វិញ»។ មនុស្សធ្វើតាមជម្រើសរបស់គេ ប៉ុន្តែ ព្រះគ្រីស្ទមិនធ្វើបែបនេះឡើយ។ ទោះបីទ្រង់មានអត្តសញ្ញាណរបស់ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គក៏ដោយ ប៉ុន្តែ ទ្រង់នៅតែស្វែងរកព្រះហឫទ័យរបស់ព្រះវរបិតា និងបំពេញកិច្ចការដែលព្រះវរបិតាបានប្រទានដល់ទ្រង់ ដោយចេញពីទិដ្ឋភាពខាងសាច់ឈាម។ នេះជាអ្វីមួយដែលមនុស្សមិនអាចយល់បាន។ អ្វីដែលមកពីអារក្សសាតាំង មិនអាចមានសារជាតិរបស់ព្រះជាម្ចាស់ឡើយ។ សារជាតិតែមួយគត់របស់វាគឺជាការមិនស្ដាប់បង្គាប់ និងការប្រឆាំងចំពោះព្រះជាម្ចាស់។ វាមិនអាចស្ដាប់បង្គាប់ព្រះជាម្ចាស់បានពេញលេញ ហើយក៏មិនព្រមស្ដាប់បង្គាប់តាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែរ។ មនុស្សទាំងអស់ ដែលនៅដាច់ចេញពីព្រះគ្រីស្ទ អាចធ្វើកិច្ចការដែលប្រឆាំងនឹងព្រះជាម្ចាស់ ហើយគ្មានមនុស្សណាម្នាក់ អាចធ្វើកិច្ចការដែលព្រះជាម្ចាស់បានផ្ទុកផ្ដាក់ដល់ពួកគេដោយផ្ទាល់ឡើយ។ គ្មាននរណាម្នាក់អាចចាត់ទុកការគ្រប់គ្រងរបស់ព្រះជាម្ចាស់ ជាភារកិច្ចមួយដែលគេត្រូវធ្វើដោយផ្ទាល់ឡើយ។ សារជាតិរបស់ព្រះគ្រីស្ទ គឺជាការចុះចូលតាមព្រះហឫទ័យរបស់ព្រះវរបិតា។ ចំណែកឯការមិនស្ដាប់បង្គាប់ទាស់នឹងព្រះជាម្ចាស់ គឺជាចរិតលក្ខណៈរបស់អារក្ស

សាតាំង។ គុណសម្បត្តិទាំងពីរនេះគឺមិនស៊ីគ្នាទេ ហើយអស់អ្នកណាដែលមានគុណសម្បត្តិរបស់អារក្សសាតាំង មិនអាចត្រូវបានហៅថាជាព្រះគ្រីស្ទឡើយ។ ហេតុផលដែលមនុស្សមិនអាចធ្វើកិច្ចការរបស់ព្រះជាម្ចាស់ជំនួសទ្រង់បាន គឺដោយសារតែមនុស្សមិនមានសារជាតិណាមួយរបស់ព្រះជាម្ចាស់ឡើយ។ មនុស្សធ្វើការសម្រាប់ព្រះជាម្ចាស់ សម្រាប់ជាផលប្រយោជន៍ផ្ទាល់ខ្លួន និងអនាគតរបស់គេប៉ុណ្ណោះ ប៉ុន្តែព្រះគ្រីស្ទធ្វើការ ដើម្បីបំពេញតាមព្រះហឫទ័យរបស់ព្រះវរបិតា។

ភាពជាមនុស្សរបស់ព្រះគ្រីស្ទ ត្រូវបានគ្រប់គ្រងដោយភាពជាព្រះរបស់ទ្រង់។ ទោះបីទ្រង់រស់នៅក្នុងសាច់ឈាមក៏ដោយ ក៏ភាពជាមនុស្សរបស់ទ្រង់ខុសស្រឡះពីមនុស្សខាងសាច់ឈាម។ ទ្រង់មានអត្តចរិតវិសេសខុសគេ ហើយការនេះក៏ត្រូវបានគ្រប់គ្រង ដោយភាពជាព្រះរបស់ទ្រង់ផងដែរ។ ភាពជាព្រះរបស់ទ្រង់ គ្មានភាពកម្សោយឡើយ។ ភាពកម្សោយរបស់ព្រះគ្រីស្ទ សំដៅទៅលើភាពជាមនុស្សរបស់ទ្រង់។ ដោយនៅកម្រិតណាមួយ ភាពកម្សោយនេះរាំងខ្ទប់ភាពជាព្រះរបស់ទ្រង់ ប៉ុន្តែវាមានកម្រិតនៅក្នុងផ្នែកវិសាលភាព ពេលវេលា និងដែនកំណត់ជាក់លាក់ណាមួយប៉ុណ្ណោះ។ នៅពេលដែលការប្រតិបត្តិកិច្ចការនៃភាពជាព្រះរបស់ទ្រង់មកដល់ នោះវាត្រូវបានសម្រេច ដោយមិនគិតពីភាពជាមនុស្សរបស់ទ្រង់ឡើយ។ ភាពជាមនុស្សរបស់ព្រះគ្រីស្ទត្រូវបានដឹកនាំទាំងស្រុង ដោយភាពជាព្រះរបស់ទ្រង់។ ក្រៅពីជីវិតសាមញ្ញនៃភាពជាមនុស្សរបស់ទ្រង់ សកម្មភាពដទៃផ្សេងទៀតនៃភាពជាមនុស្សរបស់ទ្រង់ត្រូវរងឥទ្ធិពល ប៉ះពាល់ និងដឹកនាំដោយភាពជាព្រះរបស់ទ្រង់។ ទោះបីព្រះគ្រីស្ទមានភាពជាមនុស្សក៏ដោយ ក៏វាមិនបង្អាក់ដល់កិច្ចការនៃភាពជាព្រះរបស់ទ្រង់ឡើយ ហើយវាកើតឡើងបែបនេះ ដោយសារតែភាពជាមនុស្សរបស់ព្រះគ្រីស្ទ ត្រូវបានដឹកនាំដោយភាពជាព្រះរបស់ទ្រង់។ ទោះបីភាពជាមនុស្សរបស់ទ្រង់មិនទាន់ចាស់ទុំនៅក្នុងរបៀបប្រតិបត្តិខ្លួនជាមួយអ្នកដទៃក៏ដោយ ក៏វាមិនជះឥទ្ធិពលដល់កិច្ចការសាមញ្ញនៃភាពជាព្រះរបស់ទ្រង់ឡើយ។ នៅពេលដែលខ្ញុំនិយាយថា ភាពជាមនុស្សរបស់ទ្រង់មិនត្រូវបានពុករលួយ ខ្ញុំចង់មានន័យថា ភាពជាមនុស្សរបស់ព្រះគ្រីស្ទ អាចត្រូវបាន

បញ្ហាដោយផ្ទាល់ពីភាពជាព្រះរបស់ទ្រង់ ហើយចង់មានន័យថា ទ្រង់មានញាណយល់ដឹងខ្ពស់ជាងមនុស្សសាមញ្ញ។ ភាពជាមនុស្សរបស់ទ្រង់គឺសក្ដិសមបំផុត ដែលត្រូវបានដឹកនាំដោយភាពជាព្រះនៅក្នុងកិច្ចការរបស់ទ្រង់។ ភាពជាមនុស្សរបស់ទ្រង់អាចបង្ហាញចេញបានល្អបំផុតអំពីកិច្ចការនៃភាពជាព្រះ និងអាចចុះចូលបានល្អបំផុតចំពោះកិច្ចការមួយនេះ។ នៅពេលដែលព្រះជាម្ចាស់ធ្វើការនៅក្នុងសាច់ឈាម ទ្រង់មិនដែលខកខាននឹងភារកិច្ចដែលមនុស្សនៅក្នុងសាច់ឈាមគួរតែបំពេញនោះឡើយ។ ទ្រង់អាចថ្វាយបង្គំព្រះជាម្ចាស់នៅស្ថានសួគ៌ ដោយចេញពីដួងចិត្តដ៏ពិត។ ទ្រង់មានសារជាតិរបស់ព្រះ ហើយអត្តសញ្ញាណរបស់ទ្រង់ គឺមកពីព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ។ ដោយសារតែទ្រង់បានយាងមកផែនដី ដើម្បីក្លាយជាមនុស្ស ដោយមានសំបកខាងក្រៅជាមនុស្ស ទើបឥឡូវនេះ ព្រះអង្គកាន់កាប់ភាពជាមនុស្ស ដែលទ្រង់មិនមានពីមុនមក។ ទ្រង់អាចថ្វាយបង្គំព្រះជាម្ចាស់នៅស្ថានសួគ៌។ នេះជាលក្ខណៈរបស់ព្រះជាម្ចាស់ផ្ទាល់ ហើយមនុស្សមិនអាចត្រាប់តាមបានឡើយ។ អត្តសញ្ញាណរបស់ទ្រង់ គឺជាព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ។ វាចេញពីទិដ្ឋភាពខាងសាច់ឈាមថាទ្រង់ថ្វាយបង្គំព្រះជាម្ចាស់។ ដូច្នេះពាក្យដែលថា «ព្រះគ្រីស្ទថ្វាយបង្គំព្រះជាម្ចាស់នៅស្ថានសួគ៌» គឺគ្មានអ្វីខុសឡើយ។ អ្វីដែលទ្រង់ស្នើសុំពីមនុស្ស គឺជាអង្គទ្រង់ដោយផ្ទាល់តែម្ដង។ ទ្រង់បានសម្រេចគ្រប់កិច្ចការដែលទ្រង់ស្នើសុំពីមនុស្ស មុនពេលទ្រង់បានសុំពីពួកគេទៅទៀត។ បើព្រះអង្គផ្ទាល់មិនទាន់មានសេរីភាពពីសេចក្ដីទាំងនេះទេ នោះទ្រង់នឹងមិនទាមទារវាពីមនុស្សឡើយ ព្រោះថាសេចក្ដីទាំងអស់នេះផ្សំគ្នាឡើងជាអង្គរបស់ទ្រង់។ មិនថាទ្រង់ប្រតិបត្តិកិច្ចការរបស់ទ្រង់បែបណា ទ្រង់នឹងមិនប្រព្រឹត្តនៅក្នុងឥរិយាបថណាមួយដែលមិនស្ដាប់បង្គាប់ដល់ព្រះជាម្ចាស់ឡើយ។ មិនថាទ្រង់ស្នើសុំអ្វីពីមនុស្ស ទ្រង់នឹងមិនទាមទារលើសពីអ្វីដែលមនុស្សអាចទទួលនោះឡើយ។ រាល់អ្វីៗដែលទ្រង់ធ្វើ គឺធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងជាប្រយោជន៍សម្រាប់ការគ្រប់គ្រងរបស់ទ្រង់។ ភាពជាព្រះរបស់ព្រះគ្រីស្ទ គឺខ្ពង់ខ្ពស់លើសមនុស្សទាំងអស់។ ដូច្នេះ ទ្រង់គឺជាសិទ្ធិអំណាចដ៏ខ្ពស់បំផុតលើអ្វីទាំងអស់

ដែលបានបង្កើតមក។ សិទ្ធិអំណាចនេះគឺជាភាពជាព្រះរបស់ទ្រង់ ដែលជានិស្ស័យ និងលក្ខណៈព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ ដែលកំណត់ពីអត្តសញ្ញាណរបស់ទ្រង់។ ដូច្នេះ មិនថាភាពជាមនុស្សរបស់ទ្រង់សាមញ្ញាប៉ុនណា ប៉ុន្ដែ វាមិនអាចប្រកែកបានឡើយថា ទ្រង់មានអត្តសញ្ញាណរបស់ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ។ មិនថាទ្រង់មានបន្ទូលចេញពីទស្សនៈបែបណា ឬស្ដាប់បង្គាប់តាមព្រះហឫទ័យរបស់ព្រះជាម្ចាស់យ៉ាងណា ក៏គេមិនអាចនិយាយថា ទ្រង់មិនមែនជាព្រះជាម្ចាស់ផ្ទាល់ព្រះអង្គនោះឡើយ។ ជារឿយៗ មានតែមនុស្សល្ងីល្ងើ និងល្ងង់ខ្លៅប៉ុណ្ណោះដែលចាត់ទុកភាពជាមនុស្សសាមញ្ញរបស់ព្រះគ្រីស្ទ គឺជាកំហុសមួយ។ ទោះជាទ្រង់បង្ហាញចេញ និងបើកសម្ដែងពីលក្ខណៈនៃភាពជាព្រះរបស់ទ្រង់បែបណា មនុស្សមិនអាចដឹងថា ទ្រង់ជាព្រះគ្រីស្ទឡើយ។ ហើយបើព្រះគ្រីស្ទបង្ហាញចេញពីការស្ដាប់បង្គាប់ និងការបន្ទាបខ្លួនរបស់ទ្រង់កាន់តែច្រើន នោះមនុស្សដ៏ល្ងីល្ងើនឹងមើលស្រាលចំពោះព្រះគ្រីស្ទមិនខាន។ មនុស្សខ្លះប្រកាន់នូវអាកប្បកិរិយាបែបបដិសេធ និងមើលងាយចំពោះទ្រង់ ប៉ុន្ដែបែរជាដាក់រូបថត «មនុស្សឆ្នើមអស្ចារ្យ» ទាំងនោះនៅលើតុ ដើម្បីថ្វាយបង្គំទៅវិញ។ ការប្រឆាំង និងការមិនស្ដាប់បង្គាប់របស់មនុស្សចំពោះព្រះជាម្ចាស់ ចេញមកពីការពិតថា សារជាតិរបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សចុះចូលតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ក៏ដូចជាចេញពីភាពជាមនុស្សសាមញ្ញរបស់ព្រះគ្រីស្ទ ដូច្នេះ នេះហើយគឺជាប្រភពនៃការប្រឆាំង និងការមិនស្ដាប់បង្គាប់របស់មនុស្សចំពោះព្រះជាម្ចាស់។ បើព្រះគ្រីស្ទគ្មានសំបកក្រៅនៃភាពជាមនុស្សរបស់ទ្រង់ ឬមិនស្វែងរកព្រះហឫទ័យរបស់ព្រះវរបិតាដោយចេញពីទិដ្ឋភាពជាមនុស្ស ប៉ុន្ដែ ចេញពីភាពជាមនុស្សដ៏ធំអស្ចារ្យវិញ នោះនៅក្នុងចំណោមមនុស្សនឹងទំនងជាគ្មានការមិនស្ដាប់បង្គាប់ឡើយ។ ហេតុផលដែលមនុស្សតែងតែជឿលើព្រះជាម្ចាស់ដែលមើលពុំឃើញនៅស្ថានសួគ៌ គឺដោយសារតែព្រះជាម្ចាស់ដែលនៅស្ថានសួគ៌គ្មានភាពជាមនុស្ស ហើយក៏គ្មានគុណសម្បត្តិរបស់មនុស្សសោះឡើយ។ ដូច្នេះ មនុស្សតែងតែប្រព្រឹត្តចំពោះទ្រង់ ដោយការគោរពបំផុត ប៉ុន្ដែបែរជាប្រកាន់នូវឥរិយាបថបែបមើលងាយចំពោះព្រះគ្រីស្ទទៅវិញ។

ទោះបីព្រះគ្រីស្ទនៅលើផែនដី អាចធ្វើការជំនួសឲ្យព្រះជាម្ចាស់ផ្ទាល់ព្រះអង្គក៏ដោយ ក៏ទ្រង់មិនយាងមកជាមួយបំណងចង់បង្ហាញដល់មនុស្សទាំងអស់អំពីរូបអង្គរបស់ទ្រង់នៅក្នុងសាច់ឈាមឡើយ។ ទ្រង់មិនបានយាងមកដើម្បីឲ្យមនុស្សទាំងអស់មើលឃើញទ្រង់ទេ ប៉ុន្តែទ្រង់យាងមកដើម្បីអនុញ្ញាតឲ្យមនុស្សត្រូវបានដឹកនាំដោយព្រះហស្តទ្រង់ និងឲ្យមនុស្សចូលទៅក្នុងយុគសម័យមួយថ្មី។ មុខងារនៃសាច់ឈាមរបស់ព្រះគ្រីស្ទ គឺសម្រាប់កិច្ចការរបស់ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គនៅក្នុងសាច់ឈាម ប៉ុន្តែមិនមែននាំមនុស្សឲ្យយល់ទាំងស្រុងអំពីសារជាតិនៃសាច់ឈាមរបស់ទ្រង់ឡើយ។ មិនថាទ្រង់ធ្វើការដោយរបៀបណា គឺគ្មានអ្វីមួយដែលទ្រង់ធ្វើខ្ពស់ហួសពីអ្វីដែលសាច់ឈាមបានទទួលនោះឡើយ។ មិនថាទ្រង់ធ្វើការបែបណា ទ្រង់ធ្វើការនោះនៅក្នុងសាច់ឈាមជាមួយភាពជាមនុស្សសាមញ្ញ ហើយមិនបានបើកសម្ដែងទាំងស្រុង ទៅកាន់មនុស្សអំពីទឹកមុខដ៏ពិតរបស់ព្រះជាម្ចាស់ឡើយ។ លើសពីនេះទៅទៀត កិច្ចការរបស់ទ្រង់នៅក្នុងសាច់ឈាម មិនដែលជាកិច្ចការហួសពីនិស្ស័យធម្មជាតិ ឬលើសលប់ ដែលមនុស្សយល់មិនដល់នោះទេ។ ទោះបីជាព្រះគ្រីស្ទតំណាងឲ្យព្រះជាម្ចាស់ផ្ទាល់ព្រះអង្គនៅក្នុងសាច់ឈាម និងអនុវត្តនៅក្នុងអង្គជាមនុស្ស ដោយធ្វើកិច្ចការដែលព្រះជាម្ចាស់ផ្ទាល់ព្រះអង្គគួរតែធ្វើក៏ដោយ ក៏ទ្រង់មិនបដិសេធចំពោះអត្ថិភាពរបស់ព្រះជាម្ចាស់នៅស្ថានសួគ៌ ហើយក៏មិនប្រកាសពីទង្វើផ្ទាល់ខ្លួនរបស់ទ្រង់យ៉ាងរំភើបនោះដែរ។ ផ្ទុយទៅវិញ ទ្រង់បន្តលាក់មុខបន្ទាបខ្លួននៅក្នុងសាច់ឈាមរបស់ទ្រង់។ ក្រៅពីព្រះគ្រីស្ទ អស់អ្នកដែលបន្លំ ដោយអះអាងថាខ្លួនជាព្រះគ្រីស្ទ គ្មានគុណសម្បត្តិរបស់ទ្រង់ឡើយ។ នៅពេលដែលដាក់ក្បែរនិស្ស័យដ៏ក្អេងក្អាង និងតម្កើងខ្លួនរបស់ពួកព្រះគ្រីស្ទក្លែងក្លាយទាំងនោះ វាស្ដែងចេញឲ្យឃើញយ៉ាងច្បាស់អំពីឥរិយាបថខាងសាច់ឈាមរបស់ព្រះគ្រីស្ទដ៏ពិត។ បើពួកគេក្លែងបន្លំកាន់តែច្រើន នោះចរិតសម្ញែងអំពីព្រះគ្រីស្ទក្លែងក្លាយរបស់គេ នឹងស្ដែងចេញឲ្យឃើញកាន់តែច្បាស់ ហើយពួកគេនឹងធ្វើទីសម្គាល់ និងការអស្ចារ្យកាន់តែច្រើន ដើម្បីបោកបញ្ឆោតមនុស្ស។ ព្រះគ្រីស្ទក្លែងក្លាយមិនមានគុណសម្បត្តិរបស់ព្រះជាម្ចាស់

ឡើយ។ ព្រះគ្រីស្ទមិនត្រូវបានសៅហ្មង ដោយសមាសធាតុណាមួយ ដែលពួកព្រះគ្រីស្ទក្លែងក្លាយទាំងនោះមានឡើយ។ ព្រះជាម្ចាស់ត្រលប់ជាសាច់ឈាម ដើម្បីបំពេញកិច្ចការខាងសាច់ឈាមប៉ុណ្ណោះ មិនមែនដើម្បីអនុញ្ញាតឲ្យមនុស្សមើលឃើញទ្រង់នោះទេ។ ផ្ទុយទៅវិញ ទ្រង់អនុញ្ញាតឲ្យកិច្ចការរបស់ទ្រង់ មកបញ្ជាក់ពីអត្តសញ្ញាណរបស់ទ្រង់ និងអនុញ្ញាតឲ្យអ្វីដែលទ្រង់បើកសម្ដែង បញ្ជាក់ពីសារជាតិរបស់ទ្រង់។ សារជាតិរបស់ទ្រង់មិនមែនគ្មានមូលដ្ឋានឡើយ ប៉ុន្តែអត្តសញ្ញាណរបស់ទ្រង់មិនត្រូវបានក្ដោបក្ដាប់ដោយព្រះហស្តរបស់ទ្រង់ឡើយ ប៉ុន្តែវាត្រូវបានកំណត់ដោយកិច្ចការ និងសារជាតិរបស់ទ្រង់។ ទោះបីទ្រង់មានសារជាតិរបស់ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ និងមានសមត្ថភាពធ្វើកិច្ចការរបស់ព្រះជាម្ចាស់ដោយផ្ទាល់ក៏ដោយ ក៏ទ្រង់នៅតែជាសាច់ឈាម មិនមែនជាព្រះវិញ្ញាណឡើយ។ ទ្រង់មិនមែនជាព្រះជាម្ចាស់ដែលមានគុណសម្បត្តិនៃព្រះវិញ្ញាណឡើយ។ ទ្រង់ជាព្រះជាម្ចាស់ ដែលមានសំបកកាយជាសាច់ឈាម។ ដូច្នេះ មិនថាទ្រង់សាមញ្ញ និងទន់ខ្សោយប៉ុនណា ហើយទោះជាទ្រង់ស្វែងរកព្រះហឫទ័យរបស់ព្រះវរបិតាក៏ដោយ ប៉ុន្តែភាពជាព្រះរបស់ទ្រង់មិនអាចប្រកែកបានឡើយ។ នៅក្នុងព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស មិនគ្រាន់តែភាពជាមនុស្សសាមញ្ញ និងភាពកម្សោយប៉ុណ្ណោះទេ ប៉ុន្តែក៏មានភាពអស្ចារ្យ និងភាពមិនអាចស្ទង់បាននៃភាពជាព្រះរបស់ទ្រង់ ក៏ដូចជាគ្រប់ទង្វើរបស់ទ្រង់ នៅក្នុងសាច់ឈាមដែរ។ ដូច្នេះ ទាំងភាពជាមនុស្ស និងភាពជាព្រះមាននៅក្នុងព្រះគ្រីស្ទពិតៗ និងជាក់ស្ដែងតែម្ដង។ នេះមិនមែននៅក្នុងអ្វីមួយអន់បំផុត ឬហួសពីនិស្ស័យធម្មជាតិឡើយ។ ទ្រង់យាងមកកាន់ផែនដី ដោយមានគោលដៅដ៏ចម្បងមួយ គឺជាការប្រតិបត្តិកិច្ចការ។ វាជាការសំខាន់ដែលត្រូវមានភាពជាមនុស្សសាមញ្ញ ដើម្បីប្រតិបត្តិការងារនៅលើផែនដី ហើយទោះបីព្រះចេស្ដានៃភាពជាព្រះរបស់ទ្រង់ខ្លាំងប៉ុនណាក៏ដោយ ក៏វាមិនអាចយកទៅអនុវត្តជាប្រយោជន៍នៅក្នុងមុខងារដើមរបស់វាឡើយ។ ទោះបីភាពជាមនុស្សរបស់ទ្រង់មានភាពសំខាន់ខ្លាំងក៏ដោយ ក៏វាមិនមែនជាសារជាតិរបស់ទ្រង់ឡើយ។ សារជាតិរបស់ទ្រង់គឺជាភាពជាព្រះ។ ដូច្នេះ ចាប់ពីពេលដែលទ្រង់ផ្ដើម

ធ្វើព័ន្ធកិច្ចរបស់ទ្រង់នៅលើផែនដី នោះក៏ជាពេលដែលទ្រង់ចាប់ផ្ដើមបង្ហាញចេញពីលក្ខណៈនៃភាពជាព្រះរបស់ទ្រង់ដែរ។ ភាពជាមនុស្សរបស់ទ្រង់កើតមានឡើងគ្រាន់តែជួយទ្រទ្រង់ដល់ព្រះជន្មដ៏សាមញ្ញនៃសាច់ឈាមរបស់ទ្រង់ ដើម្បីឲ្យភាពជាព្រះរបស់ទ្រង់អាចអនុវត្តការងារបានជាធម្មតា នៅក្នុងសាច់ឈាមតែប៉ុណ្ណោះ។ គឺភាពជាព្រះដែលចង្អុលបង្ហាញកិច្ចការរបស់ទ្រង់ទាំងស្រុង។ នៅពេលដែលទ្រង់បញ្ចប់កិច្ចការរបស់ទ្រង់ នោះព្រះអង្គក៏នឹងបញ្ចប់ព័ន្ធកិច្ចរបស់ទ្រង់ដែរ។ អ្វីដែលមនុស្សគួរតែដឹង គឺជាលក្ខណៈទាំងស្រុងនៃកិច្ចការរបស់ទ្រង់ ហើយតាមរយៈកិច្ចការរបស់ទ្រង់នេះហើយ ដែលទ្រង់ជួយឲ្យមនុស្សស្គាល់ពីទ្រង់។ ក្នុងអំឡុងពេលនៃកិច្ចការរបស់ទ្រង់ ព្រះអង្គដូចជាបង្ហាញចេញយ៉ាងពេញលេញពីលក្ខណៈនៃភាពជាព្រះរបស់ទ្រង់ដែលមិនមែនជានិស្ស័យដែលត្រូវបានប្រឡាក់ស្មោកគ្រោកដោយភាពជាមនុស្ស ឬជាលក្ខណៈដែលប្រឡាក់ខូចដោយគំនិត និងឥរិយាបថរបស់មនុស្សឡើយ។ នៅពេលដែលគ្រានោះមកដល់ ជាពេលដែលព័ន្ធកិច្ចទាំងអស់របស់ទ្រង់បានមកដល់ទីបញ្ចប់ ទ្រង់នឹងបានសម្ដែងចេញយ៉ាងគ្រប់លក្ខណ៍ និងយ៉ាងពេញលេញអំពីនិស្ស័យដែលទ្រង់គួរតែបានបង្ហាញចេញរួចមកហើយ។ កិច្ចការរបស់ទ្រង់ មិនត្រូវបានដឹកនាំដោយសេចក្ដីបង្រៀនរបស់មនុស្សណាម្នាក់ឡើយ។ ការសម្ដែងចេញនូវនិស្ស័យរបស់ទ្រង់គឺដោយសេរី ហើយមិនត្រូវបានគ្រប់គ្រង ឬកាន់កាប់ដោយការគិតឡើយប៉ុន្តែ ត្រូវបានបើកសម្ដែងដោយឯកឯងវិញ។ នេះជាអ្វីមួយដែលគ្មានមនុស្សណាម្នាក់អាចធ្វើបានឡើយ។ ទោះបីជាមជ្ឈដ្ឋានជុំវិញ មានភាពឃោរឃៅ ឬមានលក្ខខណ្ឌមិនអំណោយផលក្ដី ក៏ទ្រង់អាចសម្ដែង អំពីនិស្ស័យរបស់ទ្រង់ ក្នុងពេលសមរម្យបានដដែល។ ម្នាក់ដែលជាព្រះគ្រីស្ទ សម្ដែងលក្ខណៈរបស់ព្រះគ្រីស្ទ ខណៈអ្នកដែលមិនមែនជាព្រះគ្រីស្ទ គឺគេគ្មាននិស្ស័យរបស់ព្រះគ្រីស្ទឡើយ។ ដូច្នេះ ទោះបីជាមនុស្ស គ្រប់គ្នា ប្រឆាំងនឹងទ្រង់ ឬមានសញ្ញាណអំពីទ្រង់ក៏ដោយ ក៏គ្មាននរណាម្នាក់អាចបដិសេធ ចំពោះមូលដ្ឋាននៃសញ្ញាណរបស់មនុស្សថា និស្ស័យដែលត្រូវបានសម្ដែងចេញដោយព្រះគ្រីស្ទនោះ គឺមកពីព្រះជាម្ចាស់ដែរ។ អស់អ្នកដែលដេញតាម

ព្រះគ្រីស្ទជាមួយដួងចិត្តដ៏ពិត ឬស្វែងរកព្រះជាម្ចាស់ដោយស្មោះ នឹងទទួលស្គាល់ថា ទ្រង់ជាព្រះគ្រីស្ទ ដោយផ្អែកលើការសម្ដែងចេញនៃភាពជាព្រះរបស់ទ្រង់។ ពួកគេនឹងមិនបដិសេធព្រះគ្រីស្ទ ដោយផ្អែកលើទិដ្ឋភាពណាមួយរបស់ទ្រង់ ដែលមិនអនុលោមតាមសញ្ញាណរបស់មនុស្សឡើយ។ ទោះបីមនុស្សមានភាពល្ងីល្ងើខ្លាំងក៏ដោយ ប៉ុន្តែមនុស្សទាំងអស់ ដឹងយ៉ាងច្បាស់អំពីអ្វីទៅជាឆន្ទៈរបស់មនុស្ស និងអ្វីទៅដែលមានប្រភពមកពីព្រះជាម្ចាស់។ វាគ្រាន់តែថា មនុស្សជាច្រើនប្រឆាំងនឹងព្រះគ្រីស្ទ ដោយចេញពីចេតនារបស់គេ។ បើមិនមែនហេតុផលនេះទេ នោះនឹងគ្មានមនុស្សណាម្នាក់មានហេតុផលបដិសេធពីអត្ថិភាពរបស់ព្រះគ្រីស្ទបានឡើយ ដ្បិតភាពជាព្រះដែលព្រះគ្រីស្ទបានសម្ដែងចេញមក គឺពិតជាមានជាប្រាកដមែន ហើយកិច្ចការរបស់ទ្រង់ទៀតសោត គឺអាចមើលឃើញដោយភ្នែកទទេតែម្ដង។

កិច្ចការ និងការសម្ដែងចេញមករបស់ព្រះគ្រីស្ទ គឺកំណត់អំពីសារជាតិរបស់ផងទ្រង់។ ទ្រង់អាចបញ្ចប់កិច្ចការដែលទ្រង់បានទទួល ដោយចេញពីចិត្តដ៏ពិត។ ទ្រង់អាចថ្វាយបង្គំព្រះជាម្ចាស់ដែលគង់នៅស្ថានសួគ៌យ៉ាងអស់ពីចិត្តដ៏ពិត ហើយទ្រង់ស្វែងរកព្រះហឫទ័យរបស់ព្រះវរបិតាយ៉ាងអស់ពីចិត្តដ៏ពិត។ ការទាំងអស់នេះត្រូវបានកំណត់ដោយសារជាតិរបស់ទ្រង់។ ហើយការនេះក៏ជាការបើកសម្ដែងដោយឯកឯងរបស់ទ្រង់ដែលត្រូវបានកំណត់ទុកដោយសារជាតិរបស់ទ្រង់ដែរ។ ហេតុផលដែលខ្ញុំហៅការនេះថា «ការបើកសម្ដែងដោយឯកឯង» របស់ទ្រង់ គឺដោយសារតែការបើកសម្ដែងរបស់ទ្រង់មិនមែនជាការត្រាប់តាម ឬជាលទ្ធផលចេញពីការដែលមនុស្សខិតខំរៀនសូត្រ ឬខំអភិវឌ្ឍខ្លួនជាច្រើនឆ្នាំនោះឡើយ។ ទ្រង់មិនបានរៀន ឬតាក់តែងអង្គទ្រង់ជាមួយការនេះឡើយ ផ្ទុយទៅវិញ វាបានមកជាប់ជាមួយទ្រង់ពីកំណើតតែម្ដង។ មនុស្សអាចបដិសេធកិច្ចការរបស់ទ្រង់ ការសម្ដែងចេញរបស់ទ្រង់ ភាពជាមនុស្សរបស់ទ្រង់ និងជីវិតទាំងស្រុង នៃភាពជាមនុស្សសាមញ្ញរបស់ទ្រង់បាន ប៉ុន្តែគ្មាននរណាម្នាក់អាចបដិសេធបានឡើយថា ទ្រង់ថ្វាយបង្គំព្រះជាម្ចាស់ដែលគង់នៅស្ថានសួគ៌យ៉ាងអស់ពីចិត្តដ៏ពិត។ គ្មាននរណាម្នាក់អាចបដិសេធបានឡើយថា ទ្រង់បានយាងមក

ដើម្បីបំពេញតាមព្រះហឫទ័យ នៃព្រះវរបិតាដែលគង់នៅស្ថានសួគ៌ ហើយក៏គ្មាននរណាម្នាក់អាចបដិសេធពីភាពស្មោះសរក្នុងការដែលទ្រង់ស្វែងរកព្រះវរបិតានោះដែរ។ ទោះបីរូបអង្គរបស់ទ្រង់មិនគាប់ភ្នែករបស់គេ សេចក្ដីអត្ថាធិប្បាយរបស់ទ្រង់មិនចូលត្រចៀកគេ ហើយកិច្ចការរបស់ទ្រង់ មិនធ្វើឲ្យកក្រើកមេឃរញ្ជួយដី ដូចអ្វីដែលមនុស្សស្រមើស្រមៃក៏ដោយ ប៉ុន្តែទ្រង់គឺជាព្រះគ្រីស្ទដ៏ពិតប្រាកដ ដែលសម្រេចតាមព្រះហឫទ័យរបស់ព្រះវរបិតា ដែលគង់នៅស្ថានសួគ៌យ៉ាងអស់ពីចិត្តដ៏ពិត ចុះចូលទាំងស្រុងចំពោះព្រះវរបិតាដែលគង់នៅស្ថានសួគ៌ ហើយស្ដាប់បង្គាប់តាមទ្រង់លុះក្ស័យព្រះជន្ម។ នេះគឺដោយសារតែសារជាតិរបស់ទ្រង់ គឺជាសារជាតិរបស់ព្រះគ្រីស្ទ។ សេចក្ដីពិតនេះពិបាកនឹងជឿសម្រាប់មនុស្ស ប៉ុន្តែវាជាការពិត។ នៅពេលដែលព័ន្ធកិច្ចរបស់ព្រះគ្រីស្ទត្រូវបានសម្រេចយ៉ាងពេញលេញ នោះមនុស្សនឹងអាចមើលឃើញចេញពីកិច្ចការរបស់ទ្រង់ថា និស្ស័យ និងលក្ខណៈរបស់ទ្រង់តំណាងឲ្យនិស្ស័យ និងលក្ខណៈរបស់ព្រះជាម្ចាស់ដែលគង់នៅស្ថានសួគ៌។ នៅពេលនោះ សេចក្ដីសង្ខេបនៃគ្រប់កិច្ចការរបស់ទ្រង់ អាចបញ្ជាក់បានថា ទ្រង់ពិតជាព្រះបន្ទូលដែលត្រលប់ជាសាច់ឈាម ហើយទ្រង់មិនដូចជាសាច់ឈាមរបស់មនុស្សឡើយ។ គ្រប់ជំហាននៃកិច្ចការរបស់ព្រះគ្រីស្ទនៅលើផែនដី មានភាពតំណាងដ៏សំខាន់របស់វា ប៉ុន្តែមនុស្សដែលមានបទពិសោធនូវកិច្ចការដ៏ពិតនៃជំហាននីមួយៗ មិនអាចយល់អំពីភាពសំខាន់នៃកិច្ចការរបស់ទ្រង់នោះឡើយ។ ជាពិសេស គឺសម្រាប់ជំហានជាច្រើននៃកិច្ចការដែលព្រះជាម្ចាស់ត្រូវអនុវត្តនៅក្នុងការយកកំណើតជាលើកទីពីររបស់ទ្រង់។ មនុស្សភាគច្រើនដែលគ្រាន់តែស្ដាប់ឮ ឬមើលឃើញព្រះបន្ទូលរបស់ព្រះគ្រីស្ទ ប៉ុន្តែមិនដែលឃើញទ្រង់ដោយផ្ទាល់ នឹងគ្មានសញ្ញាណអំពីកិច្ចការរបស់ទ្រង់ឡើយ។ អស់អ្នកណាដែលបានមើលឃើញព្រះគ្រីស្ទ និងបានស្ដាប់ឮព្រះបន្ទូលរបស់ទ្រង់ ក៏ដូចជាមានបទពិសោធពីកិច្ចការរបស់ទ្រង់ មានការពិបាកក្នុងការទទួលយកកិច្ចការរបស់ទ្រង់។ តើវាមិនមែនដោយសារតែការបង្ហាញអង្គទ្រង់ និងភាពជាមនុស្សសាមញ្ញរបស់ព្រះគ្រីស្ទ ធ្វើឲ្យមនុស្សគ្មានសមត្ថភាពនឹងស្គាល់រសជាតិទេឬ? អស់អ្នកដែល

ទទួលយកកិច្ចការរបស់ទ្រង់ ក្រោយពេលព្រះគ្រីស្ទបានចេញផុតទៅ នឹងមិនមានការលំបាកបែបនេះឡើយ ព្រោះថាពួកគេគ្រាន់តែទទួលយកកិច្ចការរបស់ទ្រង់ ហើយគេមិនមានទំនាក់ទំនងជាមួយភាពជាមនុស្សសាមញ្ញរបស់ព្រះគ្រីស្ទឡើយ។ មនុស្សមិនអាចទម្លាក់ចោលសញ្ញាណរបស់គេអំពីព្រះជាម្ចាស់ ហើយបែរមកពិចារណាយ៉ាងហ្មត់ចត់ អំពីទ្រង់នោះឡើយ។ នេះគឺដោយសារតែការពិតដែលថា មនុស្សផ្តោតទៅលើតែការលេចមករបស់ទ្រង់ ហើយគេមិនអាចទទួលស្គាល់ពីសារជាតិរបស់ទ្រង់ដោយផ្អែកលើកិច្ចការ និងព្រះបន្ទូលរបស់ទ្រង់។ បើមនុស្សបិទភ្នែកមើលមិនឃើញនូវចំពោះការលេចមករបស់ព្រះគ្រីស្ទ ឬក៏គេចវេះមិនចង់ពិភាក្សាអំពីភាពជាមនុស្សរបស់ព្រះគ្រីស្ទ និងនិយាយតែអំពីភាពជាព្រះរបស់ទ្រង់ដែលជាកិច្ចការ និងព្រះបន្ទូលរបស់ទ្រង់ដែលមនុស្សមិនអាចយល់បាន ដូច្នេះសញ្ញាណរបស់មនុស្សនឹងថមថយមកពាក់កណ្តាលអាចទៅដល់កម្រិតមួយដែលនាំឲ្យទុក្ខលំបាកទាំងអស់របស់មនុស្សនឹងត្រូវបានដោះស្រាយ។ ក្នុងអំឡុងពេលនៃកិច្ចការរបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស មនុស្សមិនអាចអត់ទ្រាំនឹងទ្រង់ ហើយគេពោរពេញដោយសញ្ញាណជាច្រើនអំពីទ្រង់ និងការប្រឆាំង ឯការមិនស្តាប់បង្គាប់របស់គេ ក៏កើតមានជាច្រើនដែរ។ មនុស្សមិនអាចអត់ទ្រាំនឹងអត្ថិភាពរបស់ព្រះជាម្ចាស់ មិនអាចបង្ហាញការអត់ឱនចំពោះការបន្ទាបខ្លួន និងភាពលាក់កំបាំង របស់ព្រះគ្រីស្ទ ឬអត់ទោស ចំពោះសារជាតិរបស់ព្រះគ្រីស្ទ ដែលស្តាប់បង្គាប់តាមព្រះវរបិតាដែលគង់នៅស្ថានសួគ៌ឡើយ។ ដូច្នេះ ទ្រង់មិនអាចនៅជាមួយមនុស្សបានជារៀងរហូត ក្រោយពេលដែលទ្រង់បញ្ចប់កិច្ចការរបស់ទ្រង់នោះឡើយ ព្រោះថាមនុស្សមិនមានឆន្ទៈអនុញ្ញាតឲ្យទ្រង់រស់នៅរួមជាមួយពួកគេឡើយ។ បើមនុស្សមិនអាចបង្ហាញពីការអត់ធ្មត់ចំពោះទ្រង់ក្នុងអំឡុងពេលនៃកិច្ចការរបស់ទ្រង់ផង តើពួកគេអាចអត់ធ្មត់ចំពោះទ្រង់ ដែលទ្រង់កំពុងតែរស់នៅជាមួយពួកគេក្រោយពេលដែលទ្រង់បានបញ្ចប់ព័ន្ធកិច្ចរបស់ទ្រង់ ដូចកាលទ្រង់ទតឃើញពួកគេមានបទពិសោធបន្តិចម្តងៗ អំពីព្រះបន្ទូលរបស់ទ្រង់បានដោយរបៀបណាទៅ? តើមនុស្សជាច្រើនមិនបានធ្លាក់ចុះដោយសារតែទ្រង់ទេឬ? មនុស្សគ្រាន់តែអនុញ្ញាតឲ្យ

ទ្រង់ធ្វើការនៅលើផែនដីប៉ុណ្ណោះ ហើយនេះ ជាវិសាលភាពធំបំផុតនៃភាពអត់ធ្មត់របស់មនុស្ស។ បើមិនមែនសម្រាប់កិច្ចការរបស់ទ្រង់ទេ នោះមនុស្សនឹងបណ្ដេញទ្រង់ចេញពីផែនដីជាយូរយារណាស់មកហើយ ដូច្នេះតើពួកគេនឹងបង្ហាញការអត់ធ្មត់កាន់តែតិចបែបណាទៅ នៅពេលដែលកិច្ចការរបស់ទ្រង់ត្រូវបានបញ្ចប់នោះ? ដូច្នេះតើមនុស្សនឹងមិនធ្វើគុតទ្រង់ និងធ្វើទារុណកម្មទ្រង់រហូតដល់សុគតទេឬអី? បើទ្រង់មិនត្រូវបានហៅថាព្រះគ្រីស្ទទេ នោះទ្រង់នឹងមិនអាចធ្វើការ នៅក្នុងចំណោមមនុស្សបានឡើយ។ បើទ្រង់មិនបានធ្វើការ ជាមួយអត្តសញ្ញាណរបស់ព្រះជាម្ចាស់ផ្ទាល់ទេ ហើយបែរជាធ្វើការក្នុងនាមជាមនុស្សសាមញ្ញម្នាក់ នោះមនុស្សនឹងមិនអត់ទ្រាំស្ដាប់ព្រះបន្ទូលរបស់ទ្រង់សូម្បីតែមួយម៉ាត់ ហើយក៏មិនអត់ទ្រាំសូម្បីតែបន្តិចចំពោះកិច្ចការរបស់ទ្រង់។ ដូច្នេះ ទ្រង់អាចនាំយកអត្តសញ្ញាណនេះមកជាមួយទ្រង់ នៅក្នុងកិច្ចការរបស់ទ្រង់តែប៉ុណ្ណោះ។ តាមរបៀបនេះ កិច្ចការរបស់ទ្រង់មានអំណាចខ្លាំងជាងពេលដែលទ្រង់មិនទាន់បានធ្វើទៅទៀត ព្រោះថាមនុស្សទាំងអស់មានឆន្ទៈចង់ស្ដាប់តាមអត្តសញ្ញាណដ៏លេចធ្លោ និងអស្ចារ្យតែប៉ុណ្ណោះ។ បើទ្រង់មិនបាននាំយកអត្តសញ្ញាណរបស់ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ នៅពេលដែលទ្រង់បានធ្វើការ ឬលេចមកជាព្រះជាម្ចាស់ផ្ទាល់ព្រះអង្គទេ នោះទ្រង់នឹងមិនមានឱកាសដើម្បីធ្វើការបានសោះឡើយ។ ទោះបើទ្រង់មានសារជាតិរបស់ព្រះ និងលក្ខណៈរបស់ព្រះគ្រីស្ទក៏ដោយ ក៏មនុស្សនឹងមិនបន្ធូរបន្ថយដៃ ហើយអនុញ្ញាតឲ្យទ្រង់ធ្វើកិច្ចការដោយងាយស្រួលនៅក្នុងចំណោមមនុស្សឡើយ។ ទ្រង់នាំយកអត្តសញ្ញាណរបស់ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គនៅក្នុងកិច្ចការរបស់ទ្រង់។ ទោះបីកិច្ចការបែបនេះមានអំណាចខ្លាំងរាប់សិបដង ជាងការសម្រេចកិច្ចការ ដោយគ្មានអត្តសញ្ញាណក៏ដោយ ប៉ុន្តែមនុស្សនៅតែមិនស្ដាប់បង្គាប់ទ្រង់ទាំងស្រុងដដែល ព្រោះថា មនុស្សចុះចូលចំពោះតែភាពលេចធ្លោរបស់ទ្រង់ប៉ុណ្ណោះ ហើយមិនចុះចូលចំពោះសារជាតិរបស់ទ្រង់ឡើយ។ ដូច្នេះបើមានថ្ងៃមួយ ព្រះគ្រីស្ទចុះចេញពីមុខតំណែងរបស់ទ្រង់ តើមនុស្សអាចអនុញ្ញាតឲ្យទ្រង់បន្តមានព្រះជន្មរស់ សូម្បីតែមួយថ្ងៃដែរឬទេ? ព្រះជាម្ចាស់មានព្រះទ័យចង់រស់នៅលើ

ផែនដីជាមួយមនុស្ស ដើម្បីឲ្យទ្រង់អាចមើលឃើញពីឥទ្ធិពលដែលកើតឡើង ចេញពីកិច្ចការ នៃព្រះហស្តរបស់ទ្រង់នៅឆ្នាំក្រោយៗ។ យ៉ាងណាមិញ មនុស្សមិនអាចអត់ទ្រាំនឹងព្រះវត្តមានរបស់ទ្រង់បានឡើយសូម្បីតែមួយថ្ងៃ ដូច្នេះ ទ្រង់មានតែលះបង់ចោលតែប៉ុណ្ណោះ។ វាជាវិសាលភាពដ៏ខ្ពស់បំផុតនៃការអត់ធ្មត់ និងការអនុគ្រោះរបស់មនុស្សរួចទៅហើយ ដែលអនុញ្ញាតឲ្យព្រះជាម្ចាស់ ធ្វើកិច្ចការដែលទ្រង់គួរតែធ្វើនៅក្នុងចំណោមមនុស្ស និងសម្រេចព័ន្ធកិច្ចរបស់ទ្រង់។ ទោះបីជាមនុស្ស ដែលត្រូវបានទ្រង់យកឈ្នះ រួចហើយក៏ដោយ ក៏បង្ហាញដល់ទ្រង់នូវការយោគយល់បែបនេះដែរ គឺថាពួកគេគ្រាន់តែអនុញ្ញាតឲ្យទ្រង់ បន្តស្នាក់នៅរហូតដល់កិច្ចការរបស់ទ្រង់បានបញ្ចប់តែប៉ុណ្ណោះ គឺគ្មានលើសពីនេះឡើយ។ បើមនុស្សដែលព្រះជាម្ចាស់បានយកឈ្នះ ធ្វើបែបនេះចំពោះទ្រង់ទៅហើយ ចុះទំរាំតែមនុស្សដែលទ្រង់មិនបានយកឈ្នះ តើពួកគេនឹងធ្វើដាក់ទ្រង់បែបណាទៀតទៅ? តើមនុស្សប្រព្រឹត្តចំពោះព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សនៅក្នុងរបៀបបែបនេះមិនមែនដោយសារតែទ្រង់ជាព្រះគ្រីស្ទ ជាមួយសំបកកាយជាមនុស្សធម្មតាទេឬអី? បើទ្រង់មានភាពជាព្រះតែម៉្យាង ហើយគ្មានភាពជាមនុស្សសាមញ្ញ តើភាពពិបាករបស់មនុស្សនឹងមិនត្រូវបានដោះស្រាយដោយងាយស្រួលបំផុតទេឬអី? ដោយចិត្តឈ្នានីស មនុស្សទទួលស្គាល់ភាពជាព្រះរបស់ទ្រង់ ហើយគ្មានចាប់អារម្មណ៍ទាល់តែសោះ ទៅលើសំបកកាយជាមនុស្សសាមញ្ញរបស់ទ្រង់ ទោះបីជាសារជាតិរបស់ទ្រង់គឺមកពីព្រះគ្រីស្ទ ដែលចុះចូលធ្វើតាមព្រះហឫទ័យរបស់ព្រះវរបិតា ដែលគង់នៅស្ថានសួគ៌ក៏ដោយ។ ជាលទ្ធផល ទ្រង់មានតែលុបចោលកិច្ចការ នៃការរស់នៅរបស់ទ្រង់ក្នុងចំណោមមនុស្ស ដើម្បីចែករំលែកជាមួយពួកគេ ទាំងសេចក្ដីអំណរ និងទុក្ខព្រួយ ព្រោះថាមនុស្សលែងអត់ទ្រាំនឹងព្រះវត្តមានរបស់ទ្រង់បានទៀតហើយ។

# ការស្រោចស្រង់ជីវិតធម្មតារបស់មនុស្សត្រឡប់មកវិញ និងការនាំមនុស្សទៅកាន់ទិសដៅដ៏អស្ចារ្យមួយ

មនុស្សយល់ដឹងបានតិចពីកិច្ចការសព្វថ្ងៃ និងកិច្ចការទៅអនាគត ប៉ុន្តែគេមិនយល់ពីទិសដៅ ដែលមនុស្សជាតិនឹងចូលទៅដល់នោះទេ។ ក្នុងនាមជាសត្តនិករមួយ មនុស្សគប្បីបំពេញភារកិច្ចរបស់សត្តនិករនោះ៖ មនុស្សគប្បីធ្វើតាមអ្វីគ្រប់យ៉ាងដែលព្រះជាម្ចាស់ទ្រង់ធ្វើ។ អ្នករាល់គ្នាគប្បីបន្តនៅក្នុងផ្លូវដែលខ្ញុំប្រាប់អ្នករាល់គ្នា។ អ្នកគ្មានវិធីគ្រប់គ្រង លើអ្វីៗដោយខ្លួនឯងឡើយ ហើយអ្នកក៏គ្មានភាពម្ចាស់ការលើខ្លួនឯងដែរ។ គ្រប់ការទាំងអស់ត្រូវស្ថិតក្រោមការចាត់ចែងរបស់ព្រះជាម្ចាស់ ហើយគ្រប់ការទាំងអស់ត្រូវស្ថិតនៅក្រោមព្រះហស្តរបស់ទ្រង់។ ប្រសិនបើកិច្ចការរបស់ព្រះជាម្ចាស់ផ្ដល់ទីបញ្ចប់មួយដល់មនុស្សនៅមុនកាលកំណត់ដែលជាគោលដៅដ៏អស្ចារ្យណាមួយ ហើយប្រសិនបើព្រះជាម្ចាស់បានប្រើប្រាស់ចំណុចនេះដើម្បីល្បួងមនុស្ស និងធ្វើឲ្យមនុស្សដើរតាមទ្រង់ ប្រសិនបើទ្រង់បានព្រមព្រៀងដោយបែបនេះជាមួយមនុស្ស នោះការនេះមិនមែនជាការយកឈ្នះទេ ហើយវាក៏មិនមែនជាការគិតគូរដល់ជីវិតរបស់មនុស្សដែរ។ ប្រសិនបើព្រះជាម្ចាស់ប្រើចុងបញ្ចប់របស់មនុស្សដើម្បីគ្រប់គ្រងលើគេ និងដើម្បីទទួលបានដួងចិត្តរបស់គេ នោះទ្រង់នឹងមិនប្រោសឲ្យមនុស្សបានគ្រប់លក្ខណ៍នោះទេ ហើយទ្រង់ក៏មិនអាចទទួលយកមនុស្សបានដែរ តែផ្ទុយទៅវិញ ទ្រង់នឹងប្រើគោលដៅនេះដើម្បីគ្រប់គ្រងលើគេ។ មនុស្សមិនខ្វាយខ្វល់នឹងអ្វីផ្សេង ក្រៅពីចុងបញ្ចប់នៃអនាគត ដែលជាគោលដៅចុងក្រោយបង្អស់នោះឡើយ និងមិនខ្វល់ថាតើមានអ្វីល្អៗដើម្បីសង្ឃឹមទុកដែរឬអត់នោះទេ។ ប្រសិនបើមនុស្សត្រូវបានប្រទាននូវក្ដីសង្ឃឹមមួយដ៏ស្រស់បំព្រងក្នុងអំឡុងពេលនៃកិច្ចការនៃការយកឈ្នះ ហើយនៅមុនពេលនៃការយកឈ្នះលើមនុស្ស បើមនុស្សត្រូវប្រាប់អំពីទិសដៅដ៏ត្រឹមត្រូវមួយដើម្បីស្វែងរក នោះការយកឈ្នះលើមនុស្ស មិនត្រឹមតែមិន

អាចសម្រេចផលបាននោះទេ ប៉ុន្តែលទ្ធផលនៃកិច្ចការយកឈ្នះនោះ ក៏មិនមានឥទ្ធិពលអ្វីដែរ។ នេះបានន័យថា កិច្ចការនៃការយកឈ្នះនេះ សម្រេចផលទៅបានតាមរយៈការដកចេញនូវវាសនា និងសេចក្តីសង្ឃឹមទៅអនាគតរបស់មនុស្ស និងតាមរយៈការជំនុំជម្រះ និងការវាយផ្ចាលលើនិស្ស័យបះបោររបស់មនុស្ស។ កិច្ចការនេះមិនអាចសម្រេចទៅបានតាមរយៈការព្រមព្រៀងគ្នាជាមួយមនុស្សទេ ពោលគឺមិនមែនតាមរយៈការផ្តល់ព្រះពរ និងព្រះគុណដល់មនុស្សទេ តែផ្ទុយទៅវិញ គឺតាមរយៈការបើកឲ្យឃើញនូវភាពស្មោះត្រង់របស់មនុស្ស តាមរយៈការដកយកនូវ «សេរីភាព» របស់គេ និងការលុបបំបាត់នូវក្តីសេចក្តីសង្ឃឹមទៅអនាគតរបស់គេ។ នេះហើយគឺជាសារជាតិនៃកិច្ចការនៃកាយកឈ្នះ។ ប្រសិនបើមនុស្សត្រូវប្រទានឲ្យនូវសេចក្តីសង្ឃឹមដ៏ស្រស់បំព្រងមួយតាំងពីដើមដំបូងមក ហើយកិច្ចការនៃការវាយផ្ចាល និងការជំនុំជម្រះ ត្រូវធ្វើឡើងនៅពេលក្រោយ ដូច្នេះ មនុស្សនឹងទទួលនូវការវាយផ្ចាល និងការជំនុំជម្រះនេះ ដោយផ្អែកលើមូលដ្ឋានដែលគេមានក្តីសង្ឃឹមទៅអនាគត ហើយនៅទីបញ្ចប់ ការស្តាប់បង្គាប់ និងការថ្វាយបង្គំព្រះអាទិករដោយឥតលក្ខខណ្ឌពីសត្តនិករទាំងអស់របស់ទ្រង់ នឹងមិនអាចសម្រេចទៅបានឡើយ ហើយនឹងមានតែការស្តាប់បង្គាប់ដែលងងឹតងងល់ និងល្ងង់ខ្លៅប៉ុណ្ណោះ ឬបើមិនដូច្នេះទេ មនុស្សនឹងទាមទារដោយងងឹតងងល់ពីព្រះជាម្ចាស់ ហើយវានឹងមិនអាចយកឈ្នះលើដួងចិត្តរបស់មនុស្សបានទាំងស្រុងឡើយ។ ដោយហេតុនេះ កិច្ចការនៃការយកឈ្នះនឹងមិនអាចទទួលបានមនុស្ស ឬមិនអាចធ្វើទីបន្ទាល់អំពីព្រះជាម្ចាស់បានឡើយ។ សត្តនិករបែបនេះ នឹងមិនអាចបំពេញភារកិច្ចរបស់ពួកគេបានឡើយ និងគ្រាន់តែទាមទារចង់ចរចាជាមួយព្រះជាម្ចាស់ប៉ុណ្ណោះ ហើយនេះមិនមែនជាការយកឈ្នះទេ ប៉ុន្តែជាសេចក្តីមេត្តាករុណា និងជាព្រះពរ។ បញ្ហាធំបំផុតសម្រាប់មនុស្សគឺថា គេមិនគិតអ្វីក្រៅពីវាសនា និងក្តីសង្ឃឹមទៅអនាគតរបស់គេឡើយ និងយករឿងទាំងនេះជានិមិត្តរូប។ មនុស្សស្វែងរកព្រះជាម្ចាស់ក៏ព្រោះតែវាសនា និងក្តីសង្ឃឹមទៅអនាគតរបស់ពួកគេដែរ។ គេមិនថ្វាយបង្គំព្រះជាម្ចាស់ ដោយព្រោះគេស្រឡាញ់ទ្រង់នោះទេ។

ហេតុនេះហើយ នៅក្នុងការយកឈ្នះលើមនុស្ស ភាពអត្មានិយមរបស់មនុស្សសេចក្ដីលោភលន់ និងអ្វីៗដែលរារាំងខ្លាំងបំផុតដល់ការថ្វាយបង្គំរបស់គេចំពោះព្រះជាម្ចាស់ គឺត្រូវតែគិតគូរ និងត្រូវផាត់ចោល។ តាមរយៈការធ្វើបែបនេះ នោះឥទ្ធិពលនៃការយកឈ្នះលើមនុស្ស នឹងអាចសម្រេចទៅបាន។ ជាលទ្ធផល នៅក្នុងដំណាក់កាលដំបូងនៃការយកឈ្នះលើមនុស្ស វាចាំបាច់ក្នុងការបោសសម្អាតនូវសេចក្ដីប្រាថ្នាដ៏ច្រើនលើសលប់ និងចំណុចខ្សោយដែលចេះស្លាប់របស់មនុស្ស ហើយតាមរយៈនេះត្រូវបើកបង្ហាញនូវសេចក្ដីស្រឡាញ់របស់មនុស្សចំពោះព្រះជាម្ចាស់ និងត្រូវបំផ្លាស់បំប្រែចំណេះដឹងអំពីជីវិតមនុស្ស ទស្សនៈរបស់គេអំពីព្រះជាម្ចាស់ និងអត្ថន័យនៃការរស់នៅរបស់គេ។ តាមរបៀបនេះ សេចក្ដីស្រឡាញ់របស់មនុស្សចំពោះព្រះជាម្ចាស់ត្រូវបានបន្សុទ្ធ ពោលគឺ ដួងចិត្តរបស់មនុស្សត្រូវបានយកឈ្នះ។ ប៉ុន្តែ តាមរយៈអាកប្បកិរិយារបស់ព្រះជាម្ចាស់ចំពោះសត្តនិករទាំងអស់ ព្រះជាម្ចាស់មិនគ្រាន់តែយកឈ្នះដើម្បីតែការយកឈ្នះប៉ុណ្ណោះទេ។ តែផ្ទុយទៅវិញ ទ្រង់យកឈ្នះដើម្បីទទួលយកមនុស្សសម្រាប់សិរីល្អរបស់ទ្រង់ និងដើម្បីស្រោចស្រង់លក្ខណៈដើម និងដំបូងបង្អស់របស់មនុស្សត្រឡប់មកវិញ។ បើទ្រង់គ្រាន់តែយកឈ្នះដើម្បីតែការយកឈ្នះនោះនោះអត្ថន័យនៃកិច្ចការនៃការយកឈ្នះនឹងត្រូវបាត់បង់។ នេះគឺបានន័យថា ប្រសិនបើព្រះជាម្ចាស់បានលាងសម្អាតព្រះហស្ត ឈប់ពាក់ព័ន្ធនឹងមនុស្ស និងលែងយកព្រះហឫទ័យទុកដាក់ចំពោះការស្លាប់រស់របស់មនុស្ស បន្ទាប់ពីការយកឈ្នះលើមនុស្ស នោះវាមិនមែនជាកិច្ចការ នៃការគ្រប់គ្រងមនុស្សជាតិឡើយ ហើយការយកឈ្នះលើមនុស្ស នឹងគ្រាន់តែដើម្បីជាការប្រោសលោះរបស់ទ្រង់ប៉ុណ្ណោះ។ មានតែការទទួលបានមនុស្សក្រោយពេលការយកឈ្នះលើពួកគេ និងការដែលមនុស្សមកដល់ទិសដៅដ៏អស្ចារ្យនៅទីបំផុតប៉ុណ្ណោះ ដែលជាចំណុចសំខាន់នៃគ្រប់កិច្ចការនៃសេចក្ដីសង្គ្រោះ ហើយមានតែបែបនេះទេដែលគោលបំណងនៃសេចក្ដីសង្គ្រោះអាចសម្រេចទៅបាន។ ម្យ៉ាងវិញទៀត មានតែការមកដល់របស់មនុស្សនៅទិសដៅដ៏ស្រស់ស្អាត និងច្រកចូលទៅកាន់សេចក្ដីសម្រាករបស់គេប៉ុណ្ណោះ ដែលជាក្ដីសង្ឃឹមទៅអនាគត

ដែលសត្តនិករទាំងអស់ប្រាថ្នាចង់បាន និងកិច្ចការដែលព្រះអាទិករគប្បីបំពេញ។ ប្រសិនបើមនុស្សត្រូវធ្វើកិច្ចការនេះ នោះវានឹងមានដែនកំណត់ខ្លាំងណាស់៖ កិច្ចការនេះ អាចនាំមនុស្សទៅកាន់ចំណុចណាមួយ ប៉ុន្តែវាមិនអាចនាំមនុស្សទៅកាន់ទិសដៅដ៏អស់កល្បជានិច្ចបានឡើយ។ មនុស្សមិនអាចសម្រេចចិត្តលើវាសនារបស់មនុស្សបាននោះទេ ហើយជាងនេះទៅទៀត គេមិនអាចធានានូវក្តីសង្ឃឹមទៅអនាគត និងទិសដៅទៅអនាគតរបស់មនុស្សបានឡើយ។ ក៏ប៉ុន្តែ កិច្ចការដែលព្រះជាម្ចាស់បំពេញគឺខុសគ្នា។ ដោយសារទ្រង់បានបង្កើតមនុស្ស ទើបទ្រង់ដឹកនាំពួកគេ។ ដោយសារទ្រង់សង្គ្រោះមនុស្ស ទើបទ្រង់នឹងសង្គ្រោះគេដោយហ្មត់ចត់ និងទទួលយកគេទាំងស្រុង។ ដោយសារទ្រង់ដឹកនាំមនុស្ស ទើបទ្រង់នឹងនាំគេទៅកាន់ទិសដៅ ដែលត្រឹមត្រូវ។ ហើយដោយសារទ្រង់បានបង្កើត និងគ្រប់គ្រងលើមនុស្ស ទើបទ្រង់ត្រូវតែទទួលខុសត្រូវលើវាសនា និងក្តីសង្ឃឹមទៅអនាគតរបស់មនុស្សលោក។ កិច្ចការនេះហើយ គឺជាកិច្ចការដែលព្រះអាទិករបានបំពេញ។ ថ្វីបើកិច្ចការនៃការយកឈ្នះសម្រេចទៅបានតាមរយៈការបោសសម្អាតក្តីសង្ឃឹមទៅអនាគតរបស់មនុស្សក្តី ក៏នៅទីបំផុតមនុស្សត្រូវនាំទៅក្នុងទិសដៅដែលត្រឹមត្រូវដែលព្រះជាម្ចាស់បានរៀបចំសម្រាប់គេដដែល។ ច្បាស់ណាស់ នេះគឺដោយសារព្រះជាម្ចាស់គិតគូរពីមនុស្ស ទើបមនុស្សទទួលបានការធានាចំពោះគោលដៅ និងវាសនារបស់គេ។ ត្រង់ចំណុចនេះ ទិសដៅដែលសមស្របដែលសំដៅដល់នោះ គឺមិនមែនជាការសង្ឃឹម និងសេចក្តីសង្ឃឹមទៅអនាគតរបស់មនុស្ស ដែលបានបោសសម្អាតកាលពីពេលកន្លងមកទេ។ ចំណុចទាំងពីរនេះមានលក្ខណៈខុសគ្នា។ អ្វីអស់ទាំងដែលមនុស្សសង្ឃឹមចង់បាន និងស្វែងរក គឺជាការស្រេកឃ្លានដែលកើតចេញពីការស្វែងរកចំណង់ហួសប្រមាណខាងសាច់ឈាម ជាជាងទិសដៅដែលមនុស្សត្រូវស្វែងរក។ អ្វីដែលព្រះជាម្ចាស់បានត្រៀមរៀបចំសម្រាប់មនុស្ស គឺជាព្រះពរ និងការសន្យាដែលត្រូវប្រទានដល់មនុស្ស នៅពេលដែលមនុស្សត្រូវបានប្រោសឲ្យបរិសុទ្ធ ដែលព្រះជាម្ចាស់បានរៀបចំសម្រាប់មនុស្សក្រោយពីបង្កើតពិភពលោកនេះ ហើយមិនមានជាប់ជំពាក់នឹងជម្រើស សញ្ញាណ ការ

ស្រមៃ ឬសាច់ឈាមរបស់មនុស្សឡើយ។ ទិសដៅនេះមិនបានត្រៀមរៀបចំសម្រាប់មនុស្សជាក់លាក់ណាមួយឡើយ ប៉ុន្ដែវាជាកន្លែងសម្រាករបស់មនុស្សជាតិទាំងមូល។ ហេតុដូចនេះ ទិសដៅនេះ គឺជាទិសដៅស័ក្ដិសមបំផុតសម្រាប់មនុស្សលោក។

ព្រះអាទិករមានគោលបំណងចាត់ចែងលើរបស់សព្វសារពើទាំងអស់ដែលបានបង្កើតមក។ អ្នកមិនត្រូវលះបង់ ឬមិនស្ដាប់បង្គាប់តាមអ្វីគ្រប់យ៉ាងដែលទ្រង់ធ្វើនោះឡើយ ហើយអ្នកក៏មិនត្រូវបះបោរទាស់នឹងទ្រង់ដែរ។ នៅពេលកិច្ចការដែលទ្រង់បំពេញ សម្រេចតាមព្រះរាជបំណងរបស់ទ្រង់ នោះទ្រង់នឹងទទួលបានសិរីរុងរឿងតាមរយៈការនេះ។ សព្វថ្ងៃនេះ ហេតុអ្វីបានជាគេមិនថា អ្នកជាកូនចៅរបស់ពួកសាសន៍ម៉ូអាប់ ឬជាកូននៃនាគដ៏ធំមានសម្បុរក្រហម? ហេតុអ្វីបានជាគ្មានការនិយាយពីរាស្ដ្ររើសតាំង និងមានតែការនិយាយពីសត្តនិករដែលបង្កើតមកទៅវិញ? សត្តនិករដែលបានបង្កើតមក នេះគឺជាងារដំបូងរបស់មនុស្ស ហើយវាជាអត្តសញ្ញាណនៅជាប់នឹងខ្លួនគេ។ ឈ្មោះខុសគ្នាដោយសារតែអាយុ និងសម័យកាលនៃកិច្ចការខុសគ្នាប៉ុណ្ណោះ។ ការពិត មនុស្សជាសត្តនិករធម្មតាមួយ។ សត្តនិករទាំងអស់ មិនថាពួកគេពុករលួយខ្លាំងយ៉ាងណា ឬបរិសុទ្ធយ៉ាងណានោះទេ គឺត្រូវតែបំពេញភារកិច្ចរបស់ខ្លួនដែលជាភារៈដែលត្រូវបានបង្កើតមកនេះ។ នៅពេលព្រះជាម្ចាស់បំពេញកិច្ចការនៃការយកឈ្នះ ទ្រង់មិនគ្រប់គ្រងលើអ្នកដោយប្រើក្ដីសង្ឃឹមទៅអនាគត វាសនា ឬទិសដៅរបស់អ្នកឡើយ។ តាមពិតទៅ ពុំចាំបាច់ត្រូវធ្វើកិច្ចការដោយបែបនេះទេ។ គោលបំណងនៃកិច្ចការនៃការយកឈ្នះ គឺដើម្បីធ្វើឲ្យមនុស្សបំពេញភារកិច្ចរបស់ខ្លួនដែលបានបង្កើតមក ដើម្បីធ្វើឲ្យគេថ្វាយបង្គំព្រះអាទិករ។ មានតែក្រោយពេលនោះទេ ទើបមនុស្សអាចចូលទៅក្នុងទិសដៅដ៏អស្ចារ្យនោះបាន។ វាសនារបស់មនុស្សត្រូវគ្រប់គ្រងនៅក្នុងព្រះហស្ដរបស់ព្រះជាម្ចាស់។ អ្នកមិនមានសមត្ថភាពគ្រប់គ្រងលើខ្លួនឯងឡើយ៖ បើទោះបីជាមនុស្សតែងតែមានការប្រញាប់ប្រញាល់ និងរវល់នឹងរឿងផ្សេងៗរបស់ខ្លួនឯងក៏ដោយ ក៏គេនៅតែគ្មានសមត្ថភាពនៅក្នុងការគ្រប់គ្រងខ្លួនឯងដដែល។ ប្រសិនបើអ្នកអាចស្គាល់ពីក្ដីសង្ឃឹមទៅអនាគតរបស់ខ្លួនឯង ប្រសិនបើអ្នក

អាចគ្រប់គ្រងលើវាសនារបស់ខ្លួនឯងបាន តើអ្នកនៅតែជាសត្តនិករដែលបានបង្កើតមកទៀតឬអី? និយាយឲ្យខ្លី មិនថាព្រះជាម្ចាស់បំពេញកិច្ចការដោយបែបណានោះទេ គ្រប់កិច្ចការទាំងអស់របស់ទ្រង់ គឺសុទ្ធតែដើម្បីជាប្រយោជន៍ដល់មនុស្ស។ ឧទាហរណ៍ ស្ថានសួគ៌ និងផែនដី និងរបស់សព្វសាររពើទាំងអស់ដែលព្រះជាម្ចាស់បានបង្កើតមកដើម្បីបម្រើដល់មនុស្ស៖ ព្រះចន្ទ ព្រះអាទិត្យ និងដួងតារា ដែលទ្រង់បានបង្កើតមកសម្រាប់មនុស្ស សត្វ និងរុក្ខជាតិ រដូវផ្ការីក រដូវក្ដៅ រដូវលំហើយ និងរដូវរងា ព្រមទាំងអ្វីៗផ្សេងទៀត ពោលគឺទាំងអស់នេះសុទ្ធតែត្រូវបានបង្កើតឡើងសម្រាប់អត្ថិភាពរបស់មនុស្ស។ ដូច្នេះហើយ មិនថាព្រះជាម្ចាស់ដាក់ទោស និងជំនុំជម្រះមនុស្សដោយបែបណានោះទេ អ្វីទាំងអស់នេះ គឺសុទ្ធតែដើម្បីជាជាប្រយោជន៍ដល់សេចក្ដីសង្គ្រោះរបស់មនុស្ស។ បើទោះបីជាទ្រង់ដកយកក្ដីសង្ឃឹមខាងសាច់ឈាមរបស់គេក៏ពិតមែន នោះក៏ដើម្បីតែការបន្សុទ្ធមនុស្សតែប៉ុណ្ណោះ ហើយការបន្សុទ្ធមនុស្សនេះ គឺធ្វើឡើងដើម្បីឲ្យមនុស្សអាចរួចផុតពីការស្លាប់បាន។ ទិសដៅរបស់មនុស្សស្ថិតក្នុងព្រះហស្តរបស់ព្រះអាទិករ ដូច្នេះ តើមនុស្សអាចគ្រប់គ្រងខ្លួនឯងបានដោយរបៀបណាទៅ?

នៅពេលដែលកិច្ចការនៃការយកឈ្នះត្រូវបានបញ្ចប់ជាស្ថាពរ មនុស្សនឹងត្រូវនាំទៅកាន់ពិភពលោកមួយដ៏ស្រស់បំព្រង។ ជាការពិតណាស់ ជីវិតនេះនឹងមាននៅលើផែនដី ប៉ុន្តែវានឹងខុសគ្នាទាំងស្រុងពីជីវិតរបស់មនុស្សក្នុងពេលបច្ចុប្បន្ននេះ។ វាគឺជាជីវិតដែលមនុស្សនឹងត្រូវមាន ក្រោយពីមនុស្សជាតិទាំងមូលត្រូវបានយកឈ្នះ វានឹងក្លាយជាការចាប់ផ្ដើមជាថ្មីសម្រាប់មនុស្សនៅលើផែនដី ហើយការដែលធ្វើឲ្យមនុស្សមានជីវិតមួយបែបនេះ នឹងក្លាយជាសេចក្ដីសំអាងដែលបញ្ជាក់ថាមនុស្សបានចូលទៅក្នុងពិភពថ្មីមួយដែលស្រស់បំព្រង។ វានឹងក្លាយជាការចាប់ផ្ដើមនៃជីវិតរបស់មនុស្ស និងព្រះជាម្ចាស់នៅលើផែនដី។ ការលើកឡើងសម្រាប់ជីវិតដ៏ស្រស់បំព្រងក្រោយពីមនុស្សត្រូវបានបន្សុទ្ធ និងយកឈ្នះរួចមក គឺគេនឹងត្រូវចុះចូលនៅចំពោះព្រះអាទិករ។ ហេតុនេះហើយ កិច្ចការនៃការយកឈ្នះ គឺជាដំណាក់កាលចុងក្រោយនៃកិច្ចការរបស់ព្រះជាម្ចាស់ នៅមុនពេលដែលមនុស្សចូលទៅក្នុងគោលដៅដ៏អស្ចារ្យ

នេះ។ ជីវិតបែបនេះ គឺជាជីវិតរបស់មនុស្សនៅលើផែនដីនាពេលអនាគត ជាជីវិតដ៏ស្រស់បំព្រងនៅលើផែនដី ជាជីវិតដែលមនុស្សទន្ទឹងចង់បាន ជាប្រភេទនៃជីវិតដែលមនុស្សមិនធ្លាប់ឈានដល់នៅក្នុងប្រវត្តិសាស្ត្រពិភពលោកឡើយ។ វាគឺជាលទ្ធផលចុងក្រោយនៃកិច្ចការគ្រប់គ្រងរយៈពេល៦០០០ឆ្នាំ។ វាគឺជាអ្វីដែលមនុស្សស្រេកឃ្លានចង់បានបំផុត ហើយវាក៏ជាការសន្យារបស់ព្រះជាម្ចាស់ចំពោះមនុស្សផងដែរ។ ប៉ុន្ដែ ការសន្យានេះ មិនអាចចូលមកដល់ភ្លាមៗនោះទេ។ មនុស្សនឹងចូលទៅក្នុងទិសដៅអនាគត នៅពេលណាដែលកិច្ចការនៃគ្រាចុងក្រោយបង្អស់ ត្រូវបានបញ្ចប់រួចរាល់ និងពេលដែលមនុស្សត្រូវបានយកឈ្នះរួចទាំងស្រុងតែប៉ុណ្ណោះ ពោលគឺនៅពេលណាដែលសាតាំងត្រូវបានយកឈ្នះទាំងស្រុង។ បន្ទាប់ពីមនុស្សត្រូវបានបន្សុទ្ធរួច គេនឹងលែងមានធម្មជាតិដែលមានបាបទៀតហើយ ដ្បិតព្រះជាម្ចាស់បានយកឈ្នះលើសាតាំងជាស្រេចហើយ មានន័យថា នឹងគ្មានការឈ្លានពានដោយកម្លាំងកម្រោល ហើយគ្មានកម្លាំងណាមួយដែលអាចវាយប្រហារលើសាច់ឈាមរបស់មនុស្សបានឡើយ។ ដូចនេះហើយ មនុស្សនឹងត្រូវដោះលែងឲ្យមានសេរីភាព និងបានបរិសុទ្ធ គេនឹងបានចូលទៅក្នុងភាពអស់កល្បជានិច្ច។ ទាល់តែអំណាចទទឹងនៃភាពងងឹតត្រូវបានដាក់ជាបាវបម្រើ ទើបមនុស្សអាចត្រូវបានដោះលែងឲ្យមានសេរីភាពនៅគ្រប់ទីកន្លែងដែលមនុស្សទៅដល់បាន ហេតុដូច្នេះ គេនឹងគ្មានការបះបោរ ឬការប្រឆាំងទាស់ឡើយ។ សាតាំងគ្មានអ្វីក្រៅតែពីត្រូវចាប់ធ្វើជាបាវបម្រើទេ ហើយអ្វីគ្រប់យ៉ាងនឹងត្រូវល្អប្រសើរសម្រាប់មនុស្ស។ ស្ថានភាពបច្ចុប្បន្ន កើតមានដោយសារសាតាំងនៅបន្តបង្កបញ្ហានៅគ្រប់ទីកន្លែងនៅលើផែនដី ហើយដោយសារកិច្ចការនៃការគ្រប់គ្រងរបស់ព្រះជាម្ចាស់ទាំងមូល មិនទាន់សម្រេចដល់ទីបញ្ចប់នៅឡើយ។ នៅពេលដែលសាតាំងត្រូវបានយកឈ្នះរួច មនុស្សនឹងត្រូវដោះលែង ឲ្យមានសេរីភាពទាំងស្រុង នៅពេលមនុស្សទទួលយកព្រះជាម្ចាស់ និងចេញផុតពីដែនត្រួតត្រារបស់សាតាំង នោះគេនឹងអាចឃើញព្រះអាទិត្យនៃសេចក្ដីសុចរិត។ ជីវិតជាមនុស្សធម្មតានឹងត្រូវទទួលបានជាថ្មី។ គ្រប់ការទាំងអស់ដែលត្រូវគ្រប់គ្រងដោយមនុស្សធម្មតា ដូចជា

សមត្ថភាពក្នុងការយល់ដឹងពីអំពើល្អ និងអំពើអាក្រក់ និងការយល់ដឹងអំពីរបៀបទទួលទាន និងស្លៀកពាក់ដោយខ្លួនឯង ព្រមទាំងសមត្ថភាពក្នុងការរស់នៅដោយសាមញ្ញ អ្វីៗគ្រប់សព្វបែបយ៉ាងនេះនឹងត្រូវទទួលបានជាថ្មី។ ប្រសិនបើអេវ៉ាមិនត្រូវបានសត្វពស់ល្បួងទេ មនុស្សគួរតែមានជីវិតធម្មតាបែបនេះ ក្រោយដែលគេត្រូវបានបង្កើតឡើងនៅគ្រាដំបូង។ មនុស្សគួរតែចេះហូបចុក និងស្លៀកពាក់ ហើយនិងដឹកនាំជីវិតមនុស្សធម្មតានៅផែនដីនេះ។ ប៉ុន្តែ ក្រោយពេលមនុស្សត្រូវបានដកសិទ្ធិ ជីវិតមួយនេះក្លាយជាការស្រមើស្រមៃដែលមិនអាចសម្រេចបាន ហើយសូម្បីតែសព្វថ្ងៃនេះក៏មនុស្សមិនហ៊ានស្រមៃអំពីរឿងបែបនោះផង។ ការពិត ជីវិតដ៏ស្រស់បំព្រងដែលមនុស្សទន្ទឹងចង់បាននោះ គឺចាំបាច់ខ្លាំងណាស់។ ប្រសិនបើមនុស្សគ្មានទិសដៅបែបនោះទេ ជីវិតដែលខ្វះខាតនៅលើផែនដីនេះ នឹងមិនបញ្ចប់ឡើយ ហើយប្រសិនបើពុំមានជីវិតដ៏ស្រស់បំព្រងទេ នោះនឹងគ្មានការបញ្ចប់វាសនារបស់សាតាំង ឬសម័យដែលសាតាំងក្ដោបក្ដាប់អំណាចនៅលើផែនដីនេះឡើយ។ មនុស្សត្រូវចូលមកដល់ពិភពមួយដែលមិនអាចទៅដល់បានតាមអំណាចនៃភាពងងឹត ហើយនៅពេលដែលមនុស្សធ្វើបែបនេះបង្ហាញថា សាតាំងត្រូវបានយកឈ្នះហើយ។ ដោយបែបនេះ នៅពេលដែលគ្មានការរំខានដោយសាតាំង ព្រះជាម្ចាស់នឹងគ្រប់គ្រងលើមនុស្សដោយផ្ទាល់ព្រះអង្គ ហើយទ្រង់នឹងបញ្ជា និងគ្រប់គ្រងលើជីវិតមនុស្សទាំងមូល។ មានតែពេលនោះទេ ទើបសាតាំងត្រូវបានយកឈ្នះដោយពិតប្រាកដ។ ជីវិតរបស់មនុស្សសព្វថ្ងៃនេះ គឺជាជីវិតដែលស្មោកគ្រោក ជាជីវិតដែលរងរុក្ខវេទនា និងទុក្ខលំបាក។ កិច្ចការនេះ មិនអាចហៅថា ការបង្ក្រាបសាតាំងនោះទេ។ មនុស្សមិនទាន់បានគេចចេញពីសមុទ្រទុក្ខនៅឡើយទេ ហើយមិនទាន់បានគេចចេញពីទុក្ខលំបាកនៃជីវិតរបស់មនុស្ស ឬឥទ្ធិពលរបស់សាតាំងនៅឡើយទេ ហើយគេនៅតែមានចំណេះតិចតួចបំផុតអំពីព្រះជាម្ចាស់។ គ្រប់ទុក្ខលំបាករបស់មនុស្ស ត្រូវបានបង្កើតឡើងដោយសាតាំង។ គឺសាតាំងនេះហើយ ដែលនាំទុក្ខវេទនាចូលមកក្នុងជីវិតមនុស្ស ហើយមានតែការដែលសាតាំងត្រូវបានធ្វើឲ្យទៅជាបាវបម្រើប៉ុណ្ណោះ ទើបមនុស្សអាចគេចផុតពីសមុទ្រទុក្ខ

បានទាំងស្រុង។ ក៏ប៉ុន្ដែ ការឲ្យសាតាំងធ្វើជាបាវបម្រើ គឺអាចសម្រេចទៅបានតាមរយៈការយកឈ្នះ និងការទទួលយកដួងចិត្តមនុស្ស តាមរយៈការធ្វើឲ្យមនុស្សក្លាយជារបីបនៅក្នុងសង្គ្រាមជាមួយសាតាំង។

សព្វថ្ងៃ ការដែលមនុស្សស្វែងរកដើម្បីក្លាយជាអ្នកដែលមានជ័យជម្នះ និងដើម្បីឲ្យបានគ្រប់លក្ខណ៍ គឺជាអ្វីដែលគេស្វែងរក នៅមុនពេលដែលគេមានជីវិតធម្មតានៅលើផែនដី ហើយអ្វីទាំងអស់នេះ គឺជាវត្ថុបំណងដែលគេស្វែងរក មុនពេលដែលសាតាំងត្រូវបានដាក់ឱ្យជាប់ចំណង។ ជាមូលដ្ឋាន ការដែលមនុស្សស្វែងរកដើម្បីក្លាយជាអ្នកដែលមានជ័យជម្នះ និងដើម្បីធ្វើឲ្យបានគ្រប់លក្ខណ៍ ឬដើម្បីឲ្យបានប្រើការល្អ គឺត្រូវគេចចេញពីឥទ្ធិពលរបស់សាតាំង៖ ការស្វែងរករបស់មនុស្ស គឺដើម្បីក្លាយជាអ្នកដែលមានជ័យជម្នះ ប៉ុន្ដែលទ្ធផលចុងក្រោយ គឺជាការគេចចេញពីឥទ្ធិពលរបស់សាតាំង។ មានតែការគេចចេញពីឥទ្ធិពលរបស់សាតាំងប៉ុណ្ណោះដែលអាចឲ្យមនុស្សដឹកនាំជីវិតធម្មតានៅលើផែនដីនេះបាន ជាជីវិតដែលថ្វាយបង្គំព្រះជាម្ចាស់។ សព្វថ្ងៃនេះ ការដែលមនុស្សស្វែងរកដើម្បីក្លាយជាអ្នកដែលមានជ័យជម្នះ និងដើម្បីឲ្យបានគ្រប់លក្ខណ៍ គឺជារឿងដែលត្រូវស្វែងរក នៅពេលមានជីវិតធម្មតានៅលើផែនដី។ គេស្វែងរកចំណុចទាំងនេះ សំខាន់គឺដើម្បីបានបន្សុទ្ធឲ្យស្អាត និងដើម្បីប្រតិបត្តិតាមសេចក្ដីពិត និងដើម្បីថ្វាយបង្គំព្រះអាទិករ។ ប្រសិនបើមនុស្សមានជីវិតធម្មតានៅលើផែនដី ជាជីវិតមួយដែលគ្មានការលំបាក និងទុក្ខវេទនា នោះមនុស្សនឹងមិនចូលពាក់ព័ន្ធនៅក្នុងការស្វែងរក ដើម្បីឲ្យក្លាយជាអ្នកដែលមានជ័យជម្នះឡើយ។ «ការក្លាយជាអ្នកដែលមានជ័យជម្នះ» និង «ការប្រោសឲ្យបានគ្រប់លក្ខណ៍» គឺជាវត្ថុបំណងដែលព្រះជាម្ចាស់ប្រទានឲ្យមនុស្សស្វែងរក ហើយតាមរយៈការស្វែងរកគោលដៅទាំងនេះ ទ្រង់ធ្វើឲ្យមនុស្សប្រតិបត្តិតាមសេចក្ដីពិត និងរស់នៅក្នុងជីវិតមួយដែលមានន័យ។ វត្ថុបំណងនេះ គឺដើម្បីធ្វើឲ្យមនុស្សបានបរិបូរ និងដើម្បីទទួលយកគេ ហើយការស្វែងរកដើម្បីបានក្លាយជាអ្នកដែលមានជ័យជម្នះ និងដើម្បីត្រូវបានប្រោសឲ្យបានគ្រប់លក្ខណ៍ គឺគ្រាន់តែជាមធ្យោបាយមួយប៉ុណ្ណោះ។ ប្រសិនបើទៅថ្ងៃអនាគត មនុស្ស

ចូលទៅក្នុងទិសដៅដ៏អស្ចារ្យនេះ នោះនឹងលែងមានការសម្អាងដើម្បីបានក្លាយជាអ្នកដែលមានជ័យជម្នះ និងដើម្បីត្រូវបានប្រោសឲ្យបានគ្រប់លក្ខណ៍ទៀតហើយ គឺមានត្រឹមតែសត្តនិករដែលបានបង្កើតមក ដែលបំពេញភារកិច្ចរៀងៗខ្លួនតែប៉ុណ្ណោះ។ សព្វថ្ងៃនេះ មនុស្សត្រូវបានត្រាស់ឲ្យស្វែងរកចំណុចទាំងអស់នេះ គឺគ្រាន់តែដើម្បីកំណត់ពីទំហំកិច្ចការសម្រាប់មនុស្សប៉ុណ្ណោះ ដើម្បីឲ្យការស្វែងរករបស់មនុស្ស កាន់តែមានគោលដៅ និងជាក់ស្ដែងជាងមុន។ បើពុំដូច្នោះទេ មនុស្សនឹងត្រូវរស់នៅក្នុងភាពអរូបីបែបស្រពេចស្រពិល និងស្វែងរកច្រកចូលទៅក្នុងជីវិតដ៏អស់កល្បជានិច្ច ហើយប្រសិនបើបែបនេះមែន តើមនុស្សមិនគួរឲ្យសង្វេគកាន់តែខ្លាំងជាងមុនទេឬអី? ការបន្តស្វែងរកនៅក្នុងផ្លូវនេះ ដោយគ្មានគោលដៅ ឬគ្មានគោលការណ៍ តើនេះមិនមែនជាការបោកបញ្ឆោតខ្លួនឯងទេឬអី? ចុងក្រោយ ការស្វែងរកបែបនេះ នឹងគ្មានផលផ្លែអ្វីឡើយ។ នៅទីបំផុត មនុស្សនឹងនៅតែរស់នៅក្រោមដែនត្រួតត្រារបស់សាតាំងដដែល និងមិនអាចរំដោះខ្លួនចេញពីដែនត្រួតត្រានេះបានឡើយ។ ហេតុអ្វីបានជាត្រូវដាក់ខ្លួនឯងទៅក្នុងការស្វែងរកដែលគ្មានគោលដៅបែបនេះ? នៅពេលមនុស្សចូលទៅក្នុងទិសដៅដ៏អស់កល្បជានិច្ច នោះមនុស្សនឹងថ្វាយបង្គំព្រះអាទិករ ហើយដ្បិតមនុស្ស បានទទួលនូវសេចក្ដីសង្គ្រោះ និងបានចូលក្នុងភាពអស់កល្បជានិច្ច នោះមនុស្សនឹងមិនស្វែងរកវត្ថុបំណងណាមួយឡើយ ហើយបន្ថែមលើនេះ គេក៏នឹងមិនត្រូវការព្រួយបារម្ភ ចំពោះការឡោមព័ទ្ធពីសំណាក់សាតាំងដែរ។ នៅពេលនេះ មនុស្សនឹងដឹងពីកន្លែងរបស់គេ ហើយនឹងបំពេញភារកិច្ចរបស់គេ ហើយបើទោះបីជាពួកគេមិនត្រូវបានវាយផ្ចាល ឬជំនុំជម្រះក្ដី ក៏មនុស្សម្នាក់ៗនឹងត្រូវបំពេញភារកិច្ចរបស់ពួកគេដែរ។ នៅពេលនោះ មនុស្សនឹងមានទាំងអត្តសញ្ញាណនិងឋានៈជាសត្តនិករ។ នឹងលែងមានភាពខុសគ្នារវាងខ្ពស់និងទាប។ មនុស្សម្នាក់ៗ នឹងគ្រាន់តែត្រូវបំពេញមុខងារផ្សេងៗគ្នាតែប៉ុណ្ណោះ។ បែបនេះក្ដី ក៏មនុស្សនៅតែបន្តរស់នៅក្នុងទិសដៅដែលត្រឹមត្រូវ និងសមស្របសម្រាប់មនុស្សជាតិ។ មនុស្សនឹងបំពេញភារកិច្ចរបស់ខ្លួនដើម្បីបានថ្វាយបង្គំព្រះអាទិករ ហើយគឺមនុស្សជាតិនេះហើយ ដែលនឹងត្រូវ

ក្លាយជាមនុស្សជាតិអស់កល្បជានិច្ច។ នៅពេលនោះ មនុស្សនឹងបានទទួលនូវជីវិតមួយដែលព្រះជាម្ចាស់បានបំភ្លឺ ជាជីវិតមួយដែលស្ថិតក្រោមការបីបាច់ និងការការពារពីព្រះជាម្ចាស់ ជាជីវិតមួយសមប្រកបជាមួយព្រះជាម្ចាស់។ មនុស្សជាតិនឹងដឹកនាំជីវិតធម្មតាមួយនៅលើផែនដី ហើយមនុស្សទាំងអស់នឹងចូលទៅក្នុងផ្លូវដែលត្រឹមត្រូវ។ នៅទីបំផុត ផែនការនៃការគ្រប់គ្រងរយៈពេល៦០០០ឆ្នាំ នឹងបានបង្ក្រាបលើសាតាំង ដែលមានន័យថា ព្រះជាម្ចាស់នឹងបានស្រោចស្រង់នូវរូបភាពដើមរបស់មនុស្ស ដែលទ្រង់បានបង្កើតមក យ៉ាងនោះ ទើបបំណងព្រះហឫទ័យដើមរបស់ព្រះជាម្ចាស់ នឹងបានសម្រេចជោគជ័យ។ កាលដើមដំបូងឡើយ មុនពេលដែលមនុស្សជាតិត្រូវបានសាតាំងធ្វើឲ្យពុករលួយ មនុស្សជាតិបានដឹកនាំជីវិតធម្មតានៅលើផែនដី។ ក្រោយមកនៅពេលដែលមនុស្សត្រូវបានសាតាំងធ្វើឲ្យពុករលួយ មនុស្សបាត់បង់នូវជីវិតធម្មតានេះ ហេតុដូច្នេះហើយ ទើបចាប់ផ្ដើមមានកិច្ចការនៃការគ្រប់គ្រងរបស់ព្រះជាម្ចាស់ និងចម្បាំងជាមួយសាតាំង ដើម្បីស្រោចស្រង់ជីវិតធម្មតារបស់មនុស្សត្រឡប់មកវិញ។ មានតែពេលដែលកិច្ចការនៃការគ្រប់គ្រងរយៈពេល៦០០០ឆ្នាំរបស់ព្រះជាម្ចាស់ឈានដល់ទីបញ្ចប់ប៉ុណ្ណោះ ទើបជីវិតរបស់មនុស្សជាតិទាំងមូល នឹងចាប់ផ្ដើមនៅលើផែនដីជាផ្លូវការ។ មានតែបែបនេះប៉ុណ្ណោះ ដែលមនុស្សនឹងមានជីវិតដ៏អស្ចារ្យ ហើយព្រះជាម្ចាស់នឹងស្រោចស្រង់បំណងព្រះហឫទ័យរបស់ទ្រង់នៅក្នុងការបង្កើតមនុស្សកាលពីដើមដំបូង ក៏ដូចជាលក្ខណៈជាមនុស្សដើមត្រឡប់មកវិញ។ ហេតុដូច្នេះ ពេលណាដែលមនុស្សមានជីវិតធម្មតានៅលើផែនដី មនុស្សនឹងមិនស្វែងរកដើម្បីក្លាយជាអ្នកដែលមានជ័យជម្នះ ឬដើម្បីឲ្យបានគ្រប់លក្ខណ៍ឡើយ ដ្បិតមនុស្សនឹងត្រលប់ជាបរិសុទ្ធ។ «អ្នកដែលមានជ័យជម្នះ» និង «ការធ្វើឲ្យបានគ្រប់លក្ខណ៍» ដែលមនុស្សនិយាយមកនេះ គឺជាគោលដៅដែលប្រទានឲ្យមនុស្សស្វែងរកក្នុងអំឡុងចម្បាំងរវាងព្រះជាម្ចាស់និងសាតាំង ហើយចំណុចទាំងនេះកើតមានដោយសារមនុស្សត្រូវបានធ្វើឲ្យពុករលួយប៉ុណ្ណោះ។ តាមរយៈការប្រទាននូវគោលដៅ និងការជំរុញឲ្យអ្នកស្វែងរកគោលដៅនេះហើយដែលសាតាំងនឹងត្រូវបរាជ័យ។ ការសុំឲ្យអ្នកក្លាយជា

អ្នកដែលមានជ័យជម្នះ ឬឲ្យបានគ្រប់លក្ខណ៍ ឬឲ្យអាចប្រើការបាននោះ គឺតម្រូវឲ្យអ្នកធ្វើទីបន្ទាល់ ដើម្បីឲ្យសាតាំងអាម៉ាស់មុខ។ នៅទីបំផុត មនុស្សនឹងដឹកនាំជីវិតធម្មតានៅលើផែនដី ហើយមនុស្សនឹងក្លាយជាបរិសុទ្ធ។ នៅពេលការនេះកើតឡើង តើមនុស្សនឹងនៅតែស្វែងរកដើម្បីក្លាយជាអ្នកដែលមានជ័យជម្នះទៀតដែរឬទេ? តើពួកគេមិនមែនសុទ្ធតែជាសត្តនិករនៃការបង្កើតទេឬអី? ការនិយាយអំពីការក្លាយជាអ្នកដែលមានជ័យជម្នះ និងការធ្វើឲ្យបានគ្រប់លក្ខណ៍ ពាក្យសម្ដីទាំងអស់នេះគឺសុទ្ធតែតម្រង់ទៅរកសាតាំង និងទៅរកភាពស្មោកគ្រោករបស់មនុស្ស។ តើពាក្យថា «អ្នកដែលមានជ័យជម្នះ» មិនមែននិយាយសំដៅទៅលើជ័យជម្នះលើសាតាំង និងអំណាចទទឹងទេឬ? នៅពេលអ្នកនិយាយថា អ្នកត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍ តើមានអ្វីខ្លះនៅក្នុងខ្លួនឯងដែលត្រូវបានធ្វើឲ្យគ្រប់លក្ខណ៍? តើវាមិនមែនជាការដែលអ្នកលះបង់ចេញពីក្នុងខ្លួនឯងនូវនិស្ស័យពុករលួយរបស់សាតាំង ដើម្បីឲ្យអ្នកអាចសម្រេចនូវសេចក្ដីស្រឡាញ់ដ៏មហិមាចំពោះព្រះជាម្ចាស់ទេឬ? គេបាននិយាយថា ចំណុចបែបនេះមានទំនាក់ទំនងជាមួយរឿងស្មោកគ្រោកនៅក្នុងខ្លួនមនុស្ស និងជាប់ពាក់ព័ន្ធជាមួយសាតាំងមិនមែននិយាយពាក់ព័ន្ធនឹងព្រះជាម្ចាស់ឡើយ។

ប្រសិនបើអ្នកពុំបានស្វែងរក ដើម្បីក្លាយជាអ្នកដែលមានជ័យជម្នះ និងដើម្បីឲ្យបានគ្រប់លក្ខណ៍នៅក្នុងពេលនេះទេ នោះនៅពេលដែល មនុស្សជាតិដឹកនាំជីវិតមួយដែលធម្មតា នៅលើផែនដីនាពេលអនាគត នឹងលែងមានឱកាសសម្រាប់ការស្វែងរកបែបនេះទៀតហើយ។ នៅពេលនោះ ចុងបញ្ចប់របស់មនុស្សគ្រប់រូបនឹងត្រូវបើកសម្ដែងឲ្យបានឃើញ។ នៅពេលនោះ នឹងបង្ហាញឲ្យឃើញច្បាស់ថាអ្នកជាមនុស្សប្រភេទណា ហើយប្រសិនបើអ្នកចង់ក្លាយជាអ្នកដែលមានជ័យជម្នះ ឬចង់ឲ្យបានគ្រប់លក្ខណ៍ នោះវាមិនអាចទៅរួចនោះទេ។ ដោយសារការបះបោររបស់គេ មនុស្សនឹងត្រូវដាក់ទោស ក្រោយពីត្រូវបានបើកសម្ដែងឲ្យឃើញ គឺគ្មានអ្វីផ្សេងទៀតឡើយ។ នៅពេលនោះ ការស្វែងរករបស់មនុស្សនឹងលែងជាឋានៈខ្ពង់ខ្ពស់ជាងអ្នកដទៃទៀតហើយ ដ្បិតមនុស្សខ្លះត្រូវក្លាយជាអ្នកដែលមានជ័យជម្នះ ហើយមនុស្ស

ខ្លះទៀត ត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍ ឬមនុស្សខ្លះត្រូវក្លាយជាពួកកូនប្រុសច្បង របស់ព្រះជាម្ចាស់ ហើយអ្នកខ្លះទៀត ត្រូវក្លាយពួកកូនប្រុសរបស់ព្រះជាម្ចាស់។ ពួកគេនឹងមិនស្វែងរកអ្វីទាំងនេះឡើយ។ មនុស្សទាំងអស់នឹងក្លាយជាសត្តនិកររបស់ព្រះជាម្ចាស់ ហើយមនុស្សទាំងអស់នឹងរស់នៅលើផែនដី ហើយមនុស្សទាំងអស់នឹងរស់នៅជាមួយព្រះជាម្ចាស់នៅលើផែនដី។ សព្វថ្ងៃនេះ គឺជាពេលនៃចម្បាំងរវាងព្រះជាម្ចាស់និងសាតាំង ជាពេលមួយដែលចម្បាំងនេះមិនទាន់បានបញ្ចប់នៅឡើយ ជាពេលមួយដែលមនុស្សមិនទាន់ត្រូវបានទទួលយកទាំងស្រុងនៅឡើយ ព្រោះវាគឺជាអំឡុងពេលអន្តរកាល។ ហេតុដូច្នេះ មនុស្សត្រូវការស្វែងរកដើម្បីក្លាយជាអ្នកដែលមានជ័យជម្នះ ឬដើម្បីក្លាយជារាស្ត្ររបស់ព្រះជាម្ចាស់។ សព្វថ្ងៃនេះ មានភាពខុសគ្នាខាងឋានៈបុណ្យស័ក្តិ ប៉ុន្តែនៅពេលនោះចូលមកដល់ នឹងលែងមានភាពខុសគ្នាបែបនេះទៀតហើយ៖ ឋានៈរបស់អស់អ្នកដែលបានទទួលជ័យជម្នះ នឹងដូចៗគ្នា ពួកគេនឹងក្លាយជាសមាជិកនៃមនុស្សជាតិ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ហើយនឹងរស់នៅដោយស្មើភាពគ្នានៅលើផែនដី ដែលមានន័យថា ពួកគេនឹងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាសត្តនិករ ដែលទ្រង់បានបង្កើតមក ហើយមនុស្សគ្រប់គ្នា នឹងទទួលបានដូចៗគ្នា។ ដោយសារសម័យកាលនៃកិច្ចការរបស់ព្រះជាម្ចាស់ ខុសគ្នាហើយគោលដៅនៃកិច្ចការរបស់ទ្រង់ក៏ខុសគ្នាដែរនោះ ប្រសិនបើកិច្ចការនេះ ធ្វើ ចំពោះអ្នករាល់គ្នា នោះអ្នករាល់គ្នាមានសិទ្ធិទទួលបានការធ្វើឲ្យបានគ្រប់លក្ខណ៍និងក្លាយជាអ្នកដែលមានជ័យជម្នះ។ ប្រសិនបើកិច្ចការនេះធ្វើឡើងនៅក្រៅប្រទេសនោះមនុស្សនៅទីនោះនឹងមានសិទ្ធិក្លាយជាក្រុមមនុស្សដំបូងគេដែលត្រូវយកឈ្នះ ហើយជាក្រុមមនុស្សដំបូងគេដែលត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍។ សព្វថ្ងៃនេះ កិច្ចការនេះ មិនត្រូវបានធ្វើនៅក្រៅប្រទេសឡើយ ដូច្នេះ មនុស្សនៅប្រទេសដទៃផ្សេងទៀត មិនមានសិទ្ធិទទួលបានការធ្វើឲ្យបានគ្រប់លក្ខណ៍ និងក្លាយជាអ្នកដែលមានជ័យជម្នះឡើយហើយពួកគេមិនអាចក្លាយជាក្រុមមនុស្សដំបូងគេបានទេ។ ដោយសារគោលដៅនៃកិច្ចការរបស់ព្រះជាម្ចាស់ខុសគ្នា សម័យកាលនៃកិច្ចការ របស់

ព្រះជាម្ចាស់ខុសគ្នាហើយទំហំនៃកិច្ចការនោះក៏ខុសៗគ្នា ទើបមានក្រុមដំបូង ដែលជាក្រុមអ្នកដែលមានជ័យជម្នះ ហើយក៏នឹងមានក្រុមទីពីរផងដែរ ដែលជាក្រុមត្រូវបានធ្វើឲ្យបានគ្រប់លក្ខណ៍។ នៅពេលណាដែលមានក្រុមដំបូងគេ ដែលត្រូវបានធ្វើឲ្យគ្រប់លក្ខណ៍រួចហើយ នោះនឹងមានប្រភេទ និងគំរូមួយ ហេតុដូច្នេះហើយ ទៅពេលអនាគតនឹងមានក្រុមទីពីរ និងក្រុមទីបីទៀត ដែលត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍ ប៉ុន្តែនៅក្នុងភាពអស់កល្បជានិច្ច ពួកគេនឹងមានលក្ខណៈដូចគ្នាទាំងអស់ ហើយនឹងលែងមានការបែងចែកឋានៈអ្វីទៀតហើយ។ ពួកគេនឹងគ្រាន់តែត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍នៅក្នុងពេលខុសៗគ្នាប៉ុណ្ណោះ ហើយនឹងគ្មានភាពខុសគ្នាខាងឋានៈណាមួយឡើយ។ នៅពេលដែលពេលវេលានោះមកដល់ មនុស្សម្នាក់ៗនឹងត្រូវបានធ្វើឲ្យពេញខ្នាត ហើយកិច្ចការនៃសាកលលោកទាំងមូលក៏ត្រូវបានបញ្ចប់ ពេលនោះនឹងលែងមានភាពខុសគ្នាខាងឋានៈបុណ្យស័ក្តិអ្វីទៀតហើយ ហើយមនុស្សគ្រប់គ្នានឹងមានឋានៈដូចៗគ្នា។ សព្វថ្ងៃ កិច្ចការនេះត្រូវធ្វើឡើងនៅក្នុងចំណោមអ្នករាល់គ្នា ដើម្បីឲ្យអ្នករាល់នឹងគ្នាក្លាយទៅជាអ្នកដែលមានជ័យជម្នះ។ ប្រសិនបើកិច្ចការនោះត្រូវធ្វើនៅចក្រភពអង់គ្លេស នោះចក្រភពអង់គ្លេសនឹងមានក្រុមដំបូងគេ គឺដូចគ្នាដែលអ្នកនឹងក្លាយជាក្រុមដំបូងគេដែរ។ គ្រាន់តែថា អ្នកធ្លាប់បានទទួលការប្រទានពរជាពិសេស ដែលប្រកបដោយព្រះគុណ ទៅតាមលក្ខណៈនៃការអនុវត្តកិច្ចការនៅក្នុងចំណោមអ្នករាល់គ្នានាពេលបច្ចុប្បន្ននេះ ហើយប្រសិនបើកិច្ចការនេះមិនត្រូវបានធ្វើឡើងក្នុងចំណោមអ្នករាល់គ្នាទេ នោះអ្នកអាចនឹងក្លាយជាក្រុមទីពីរ ឬទីបី ឬបួន ឬក៏ទីប្រាំ។ នេះគឺគ្រាន់តែដោយសារភាពខុសគ្នា នៃលំដាប់លំដោយកិច្ចការប៉ុណ្ណោះ។ ក្រុមទីមួយ និងក្រុមទីពីរ ពុំកំណត់ន័យថា ក្រុមមួយខ្ពស់ជាង ឬទាបជាងក្រុមមួយទៀតឡើយ។ វាគ្រាន់តែចង់សំដៅលើលំដាប់លំដោយដែលមនុស្សទាំងអស់នេះត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍តែប៉ុណ្ណោះ។ សព្វថ្ងៃ អ្នករាល់គ្នាប្រាស្រ័យទាក់ទងដោយព្រះបន្ទូលទាំងអស់នេះ ប៉ុន្តែហេតុអ្វីបានជាអ្នករាល់គ្នាមិនបានដឹងតាំងពីដំបូងមក? ដ្បិតបើគ្មានដំណើរការណាមួយទេ មនុស្សមានទំនោរទៅរកភាពជ្រុលនិយម

ហួស។ ឧទាហរណ៍ ព្រះគ្រីស្ទបានមានព្រះបន្ទូលក្នុងសម័យរបស់ទ្រង់ថា៖ «ដ្បិតខ្ញុំបានចាកចេញ នោះខ្ញុំនឹងយាងត្រឡប់មកវិញ»។ សព្វថ្ងៃនេះ មនុស្សជ្រួលជ្រើមដោយសារព្រះបន្ទូលទាំងអស់នេះ ហើយពួកគេគ្រាន់តែចង់ពាក់អាវសវែង និងរង់ចាំការលើកទៅកាន់ស្ថានសួគ៌។ ហេតុនេះ មានព្រះបន្ទូលជាច្រើនដែលមិនអាចប្រាប់បានពីដើមដំបូងពេកឡើយ។ ប្រសិនបើព្រះបន្ទូលទាំងនោះ ត្រូវបានថ្លែងប្រាប់តាំងពីដើមដំបូងមក មនុស្សនឹងមានទំនោរទៅរកភាពជ្រុលនិយម។ កម្ពស់របស់មនុស្ស គឺតូចទាបខ្លាំងណាស់ ហើយគេមិនអាចមើលធ្លុះនូវសេចក្ដីពិតនៃព្រះបន្ទូលទាំងអស់នោះបានឡើយ។

នៅពេលមនុស្ស សម្រេចជីវិតជាមនុស្សពិតនៅលើផែនដី ហើយអំណាចទាំងស្រុងរបស់សាតាំងត្រូវបានដាក់ជាបាវបម្រើ នោះមនុស្សនឹងរស់នៅលើផែនដីបានងាយស្រួល។ រឿងរ៉ាវនានានឹងមិនស្មុគស្មាញ ដូចជាពេលសព្វថ្ងៃនេះទេ៖ ទំនាក់ទំនងរបស់មនុស្ស ទំនាក់ទំនងសង្គម ទំនាក់ទំនងគ្រួសារដែលស្មុគស្មាញ នាំមកនូវបញ្ហាជាច្រើន នាំមកនូវការឈឺចាប់យ៉ាងក្រៃលែង! ជីវិតរបស់មនុស្សនៅទីនេះ គឺវេទនាខ្លាំងណាស់! នៅពេលណាដែលមនុស្សត្រូវបានយកឈ្នះរួចហើយ ដួងចិត្ត និងចិត្តគំនិតរបស់គេ នឹងត្រូវបំផ្លាស់បំប្រែ៖ គេនឹងមានដួងចិត្តមួយដែលគោរពកោតខ្លាច និងស្រឡាញ់ព្រះជាម្ចាស់។ នៅពេលណាដែលអស់អ្នកទាំងឡាយដែលស្ថិតក្នុងសាកលលោកនេះ ដែលស្វះស្វែងដើម្បីស្រឡាញ់ព្រះជាម្ចាស់ ត្រូវបានយកឈ្នះរួចហើយ ពោលគឺនៅពេលដែលសាតាំងត្រូវបានបង្ក្រាបរួចហើយ ហើយនៅពេលដែលសាតាំង ពោលគឺគ្រប់អំណាចនៃភាពងងឹតទាំងអស់ ត្រូវបានដាក់ឲ្យជាប់ចំណងរួច នោះជីវិតរបស់មនុស្សនៅលើផែនដីនឹងលែងមានបញ្ហាទៀត ហើយគេនឹងអាចរស់នៅនៅលើផែនដីបានដោយសេរី។ ប្រសិនបើជីវិតរបស់មនុស្សមិនមានទំនាក់ទំនងខាងសាច់ឈាម និងគ្មានភាពស្មុគស្មាញខាងសាច់ឈាមទេ នោះជីវិតនេះនឹងកាន់តែមានភាពងាយស្រួលជាងមុន។ ទំនាក់ទំនងរបស់មនុស្សខាងសាច់ឈាមមានភាពស្មុគស្មាញយ៉ាងខ្លាំង ហើយការដែលមនុស្សមានអ្វីទាំងអស់ទាំងនេះ គឺជា

សេចក្តីសម្អាងដែលបញ្ជាក់ថា គេមិនទាន់បានរំដោះខ្លួនចេញផុតពីឥទ្ធិពលរបស់សាតាំងឡើយ។ ប្រសិនបើអ្នកមានទំនាក់ទំនងដូចគ្នាជាមួយបងប្អូនប្រុស និងបងប្អូនស្រីរបស់អ្នក ប្រសិនបើអ្នកមានទំនាក់ទំនងដូចគ្នា ជាមួយសមាជិកគ្រួសាររបស់អ្នក នោះអ្នកនឹងគ្មានក្តីកង្វល់ និងមិនចាំបាច់ត្រូវព្រួយបារម្ភអំពីនរណាម្នាក់ឡើយ។ គ្មានអ្វីល្អប្រសើរជាងនេះឡើយ ហើយបែបនេះ មនុស្សនឹងត្រូវសម្រាលការឈឺចាប់របស់គេបានពាក់កណ្តាល។ ការរស់នៅក្នុងជីវិតមនុស្សដែលធម្មតានៅលើផែនដី មនុស្សនឹងមានលក្ខណៈស្រដៀងគ្នាទៅនឹងពួកទេវតា។ ថ្វីបីគេនៅជាសាច់ឈាមនៅឡើយ តែគេនឹងកាន់តែមានលក្ខណៈដូចទេវតាមួយអង្គដែរ។ នេះគឺជាការសន្យាចុងក្រោយ ជាការសន្យាចុងបង្អស់ដែលបានប្រទានមកឲ្យមនុស្ស។ សព្វថ្ងៃនេះ មនុស្សរងនូវការវាយផ្ចាល និងការជំនុំជម្រះ។ តើអ្នកគិតថា ជីវិតរបស់មនុស្សដែលជួបប្រទះនូវរឿងបែបនេះ គឺឥតន័យខ្លឹមសារមែនទេ? តើកិច្ចការនៃការវាយផ្ចាល និងការជំនុំជម្រះអាចត្រូវធ្វើឡើងដោយគ្មានហេតុផលឬ? កាលពីមុន មានការនិយាយថា ដើម្បីវាយផ្ចាលនិងជំនុំជម្រះមនុស្ស គឺត្រូវដាក់មនុស្សទៅក្នុងជង្ហុកធំ ដែលមានន័យថាត្រូវដកចេញនូវវាសនា និងក្តីសង្ឃឹមទៅអនាគតរបស់គេ។ ការនេះគឺដើម្បីតែរឿងមួយប៉ុណ្ណោះ៖ ការបន្សុទ្ធមនុស្សឲ្យបានបរិសុទ្ធ។ ក្រោយពេលដែលព្រះជាម្ចាស់បានលាងសម្អាតព្រះហស្តរបស់ទ្រង់រួច មនុស្សមិនត្រូវដាក់ទៅក្នុងជង្ហុកធំដោយចេតនានោះទេ។ ផ្ទុយទៅវិញ ការធ្វើបែបនេះ គឺដើម្បីជម្រះនូវការបះបោរនៅក្នុងខ្លួនមនុស្សប្រយោជន៍ឲ្យនៅចុងបំផុតទៅ អ្វីៗដែលនៅក្នុងខ្លួនមនុស្សនឹងត្រូវសម្អាតឲ្យបានស្អាត ដើម្បីឲ្យគេអាចមានចំណេះដឹងពិតប្រាកដអំពីព្រះជាម្ចាស់ និងមានលក្ខណៈដូចជាបុគ្គលបរិសុទ្ធមួយរូបដែរ។ ប្រសិនបើកិច្ចការនេះត្រូវធ្វើមែន នោះគ្រប់ការទាំងអស់នឹងត្រូវសម្រេចជោគជ័យ។ ជាការពិតណាស់ នៅពេលដែលអ្វីៗទាំងអស់នៅក្នុងខ្លួនមនុស្សដែលតម្រូវឲ្យមានការដោះស្រាយ ត្រូវបានដោះស្រាយរួចរាល់ ហើយមនុស្សធ្វើទីបន្ទាល់លាន់ឮកងរំពង នោះសាតាំងក៏នឹងត្រូវបានយកឈ្នះដែរ ហើយបើទោះបីជា អាចនៅមាននិស្ស័យដើមខ្លះៗក្នុងខ្លួនមនុស្ស ដែលមិនទាន់ត្រូវបាន

បន្សុទ្ធឲ្យបានបរិសុទ្ធទាំងស្រុងក្ដី ក៏នៅពេលដែលសាតាំងត្រូវបានយកឈ្នះហើយ នោះ វានឹងលែងបង្កបញ្ហាអ្វីទៀតដែរ ហើយនៅពេលនោះ មនុស្សនឹងត្រូវបានបន្សុទ្ធឲ្យបានបរិសុទ្ធទាំងស្រុង។ មនុស្សពុំធ្លាប់ជួបប្រទះជីវិតបែបនេះឡើយ ប៉ុន្តែនៅពេលដែលសាតាំងត្រូវបានយកឈ្នះហើយ នោះគ្រប់ការទាំងអស់នឹងត្រូវបានដោះស្រាយ ហើយរឿងរ៉ាវកំប៉ិកកំប៉ុកនៅក្នុងខ្លួនមនុស្សនឹងត្រូវដោះស្រាយ ហើយនៅពេលណាដែលបញ្ហាធំត្រូវបានដោះស្រាយរួច នោះគ្រប់បញ្ហាដទៃផ្សេងទៀតនឹងត្រូវបញ្ចប់។ ក្នុងអំឡុងពេលនៃការយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់នៅលើផែនដី នៅពេលដែលទ្រង់បំពេញកិច្ចការដោយផ្ទាល់ព្រះអង្គគង់ក្នុងចំណោមមនុស្ស គ្រប់កិច្ចការដែលទ្រង់បំពេញគឺត្រូវធ្វើដើម្បីយកឈ្នះលើសាតាំង ហើយទ្រង់នឹងយកឈ្នះលើសាតាំងតាមរយៈការយកឈ្នះលើមនុស្ស និងតាមរយៈការធ្វើឲ្យអ្នករាល់គ្នាបានពេញខ្នាត។ នៅពេលអ្នករាល់គ្នាធ្វើទីបន្ទាល់លាន់ឮកងរំពង ចំណុចនេះក៏ជាសញ្ញាពីការយកឈ្នះលើសាតាំងផងដែរ។ ដំបូង ត្រូវយកឈ្នះលើមនុស្ស ហើយចុងក្រោយ ត្រូវធ្វើឲ្យមនុស្សបានគ្រប់លក្ខណ៍ ដើម្បីយកឈ្នះលើសាតាំង។ ក៏ប៉ុន្តែ រួមជាមួយនឹងការយកឈ្នះលើសាតាំង នេះក៏ជាសេចក្តីសង្គ្រោះរបស់មនុស្សជាតិទាំងអស់ចេញផុតពីសមុទ្រទុក្ខដែលគ្មានន័យខ្លឹមសារនេះផងដែរ។ មិនខ្វល់ថាតើកិច្ចការនេះ ត្រូវបំពេញនៅទូទាំងសាកលលោកទាំងមូល ឬនៅប្រទេសចិននោះទេ គ្រប់ការទាំងអស់ គឺដើម្បីយកឈ្នះលើសាតាំង និងនាំមកនូវសេចក្តីសង្គ្រោះដល់មនុស្សជាតិទាំងមូល ដើម្បីឲ្យមនុស្សអាចចូលទៅក្នុងសេចក្តីសម្រាកបាន។ ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស (ជាសាច់ឈាមធម្មតានេះ) ច្បាស់ណាស់ គឺដើម្បីយកឈ្នះលើសាតាំង។ កិច្ចការរបស់ព្រះជាម្ចាស់នៅខាងសាច់ឈាម គឺប្រើដើម្បីនាំមកនូវសេចក្តីសង្គ្រោះដល់អស់អ្នកដែលស្ថិតក្រោមស្ថានសួគ៌ដែលស្រឡាញ់ព្រះជាម្ចាស់ កិច្ចការនេះគឺដើម្បីយកឈ្នះលើមនុស្សជាតិទាំងអស់ និងដើម្បីយកឈ្នះលើសាតាំងផងដែរ។ ចំណុចស្នូលនៃគ្រប់កិច្ចការគ្រប់គ្រងទាំងអស់របស់ព្រះជាម្ចាស់ គឺមិនអាចកាត់ផ្ដាច់ចេញពីការយកឈ្នះលើសាតាំង ដើម្បីនាំមកនូវសេចក្តីសង្គ្រោះដល់មនុស្សជាតិឡើយ។ ហេតុអ្វីភាគច្រើន

នៃកិច្ចការនេះ តែងមានការនិយាយអំពីការដែលឲ្យអ្នករាល់គ្នាធ្វើទីបន្ទាល់? ហើយតើការធ្វើទីបន្ទាល់នេះតម្រង់ទៅរកអ្នកណា? តើវាមិនមែនតម្រង់ទៅរកសាតាំងទេឬអី? ការធ្វើទីបន្ទាល់នេះ គឺធ្វើឡើងអំពីព្រះជាម្ចាស់ ហើយធ្វើឡើងដើម្បីធ្វើទីបន្ទាល់ថា កិច្ចការរបស់ព្រះជាម្ចាស់ បានសម្រេចផលហើយ។ ការធ្វើទីបន្ទាល់ គឺពាក់ព័ន្ធនឹងកិច្ចការនៃការយកឈ្នះលើសាតាំង។ ប្រសិនបើគ្មានចម្បាំងណាមួយជាមួយសាតាំងទេ នោះមនុស្សនឹងមិនតម្រូវឲ្យធ្វើទីបន្ទាល់ឡើយ។ ដោយសារសាតាំងត្រូវតែបរាជ័យ ក្នុងពេលជាមួយគ្នានឹងការសង្គ្រោះមនុស្ស ទើបព្រះជាម្ចាស់ ត្រូវការឲ្យមនុស្សធ្វើទីបន្ទាល់អំពីទ្រង់នៅចំពោះមុខសាតាំង ដែលទ្រង់ប្រើវិធីនេះ ដើម្បីសង្គ្រោះមនុស្ស និងធ្វើចម្បាំងជាមួយសាតាំង។ ជាលទ្ធផល មនុស្សគឺជាកម្មវត្ថុនៃសេចក្តីសង្គ្រោះ និងជាមធ្យោបាយនៅក្នុងការយកឈ្នះលើសាតាំង ហេតុដូច្នេះមនុស្សគឺជាចំណុចស្នូលនៃកិច្ចការគ្រប់គ្រងទាំងស្រុងរបស់ព្រះជាម្ចាស់ ចំណែកឯសាតាំងគឺគ្រាន់តែជាកម្មវត្ថុនៃការបំផ្លិចបំផ្លាញ និងជាសត្រូវប៉ុណ្ណោះ។ អ្នកអាចមានអារម្មណ៍ថា អ្នកពុំបានធ្វើអ្វីទាល់តែសោះ ប៉ុន្តែដោយសារការបំផ្លាស់បំប្រែនិស្ស័យរបស់អ្នក នោះក៏ចាប់កកើតមាននូវទីបន្ទាល់ឡើង ហើយការធ្វើទីបន្ទាល់នេះគឺតម្រង់ទៅរកសាតាំង និងមិនមែនធ្វើសំដៅលើមនុស្សឡើយ។ មនុស្សមិនស័ក្តិសមនឹងត្រេកអរសប្បាយជាមួយទីបន្ទាល់បែបនេះឡើយ។ តើគេអាចយល់ ពីកិច្ចការដែលព្រះជាម្ចាស់បំពេញបានដោយរបៀបណា? កម្មវត្ថុនៃចម្បាំងរបស់ព្រះជាម្ចាស់ គឺសាតាំង។ ចំណែកឯមនុស្ស គឺគ្រាន់តែជាកម្មវត្ថុនៃសេចក្តីសង្គ្រោះប៉ុណ្ណោះ។ មនុស្សមាននិស្ស័យពុករលួយរបស់សាតាំង ហើយគ្មានសមត្ថភាពក្នុងការយល់ដឹងពីកិច្ចការនេះទេ។ នេះគឺដោយសារសេចក្តីពុករលួយរបស់សាតាំង ហើយនិស្ស័យនេះ មិនបានផ្ទេរទៅឲ្យមនុស្សទេ ប៉ុន្តែត្រូវដឹកនាំដោយសាតាំង។ សព្វថ្ងៃនេះ កិច្ចការចម្បងរបស់ព្រះជាម្ចាស់ គឺដើម្បីយកឈ្នះលើសាតាំង ពោលគឺដើម្បីយកឈ្នះលើមនុស្សឲ្យបានទាំងស្រុង ដើម្បីឲ្យមនុស្សអាចធ្វើទីបន្ទាល់ជាលើកចុងក្រោយ អំពីព្រះជាម្ចាស់នៅចំពោះមុខសាតាំងបាន។ តាមរបៀបនេះ គ្រប់ការទាំងអស់នឹងសម្រេចបានជោគជ័យ។ ក្នុងករណី

ជាច្រើន នៅនឹងភ្នែកទទេរបស់អ្នក ហាក់ដូចជាគ្មានកិច្ចការអ្វីដែលបានធ្វើឡើយ ប៉ុន្តែតាមការពិតកិច្ចការនេះបានបញ្ចប់រួចស្រេចទៅហើយ។ មនុស្សចង់មើលឃើញកិច្ចការទាំងអស់ចប់សព្វគ្រប់ ក៏ប៉ុន្តែខ្ញុំបានបញ្ចប់កិច្ចការរបស់ខ្ញុំរួចជាស្រេចដោយពុំបានឲ្យអ្នកមើលឃើញឡើយ ដ្បិតសាតាំងបានចុះចាញ់រួចទៅហើយ ដែលមានន័យថា សាតាំងត្រូវបានយកឈ្នះទាំងស្រុង ដោយគ្រប់ទាំងព្រះប្រាជ្ញាញាណ ព្រះចេស្ដា និងសិទ្ធិអំណាចទាំងអស់របស់ព្រះជាម្ចាស់បានធ្វើឲ្យសាតាំងបរាជ័យទៅហើយ។ ច្បាស់ណាស់ នេះគឺជាទីបន្ទាល់ដែលត្រូវកើតមាន ហើយបើទោះបីជាវាគ្មានការបើកសម្ដែងឲ្យបានច្បាស់ចំពោះមនុស្សក្ដី ទោះបីវាមិនអាចមើលឃើញដោយភ្នែកទទេក្ដី ក៏សាតាំងត្រូវបានយកឈ្នះរួចជាស្រេចទៅហើយ។ កិច្ចការនេះទាំងមូល គឺតម្រង់ទៅរកសាតាំង និងត្រូវអនុវត្តតាមរយៈចម្បាំងជាមួយសាតាំង។ ហេតុដូចនេះ មានរឿងជាច្រើនដែលមនុស្សពុំបានឃើញថាបានសម្រេចជោគជ័យរួចហើយនោះទេ ប៉ុន្តែនៅក្នុងព្រះនេត្ររបស់ព្រះជាម្ចាស់កិច្ចការនោះបានបញ្ចប់រួចរាល់ជាយូរណាស់មកហើយ។ នេះគឺជាសេចក្ដីពិតមួយក្នុងចំណោមសេចក្ដីពិតដ៏ជ្រាលជ្រៅនៃកិច្ចការរបស់ព្រះជាម្ចាស់។

នៅពេលណាដែលសាតាំងត្រូវបានយកឈ្នះរួចហើយ ពោលគឺ នៅពេលណាដែលមនុស្សត្រូវបានយកឈ្នះ នោះមនុស្សនឹងយល់ដឹងស៊ីជម្រៅថា គ្រប់កិច្ចការទាំងអស់នេះ គឺដើម្បីសេចក្ដីសង្គ្រោះ ហើយមធ្យោបាយនៃសេចក្ដីសង្គ្រោះនេះគឺដើម្បីដណ្ដើមយកមនុស្សពីដៃរបស់សាតាំងមកវិញ។ កិច្ចការនៃការគ្រប់គ្រងរយៈពេល៦០០០ឆ្នាំរបស់ព្រះជាម្ចាស់ ត្រូវបែងចែកជាបីដំណាក់កាល៖ យុគសម័យនៃក្រឹត្យវិន័យ យុគសម័យនៃព្រះគុណ និងយុគសម័យនៃនគរព្រះ។ ដំណាក់កាលទាំងបីនៃកិច្ចការនេះ គឺដើម្បីសេចក្ដីសង្គ្រោះដល់មនុស្សជាតិ ពោលគឺដំណាក់កាលទាំងនេះ គឺដើម្បីជាប្រយោជន៍ដល់សេចក្ដីសង្គ្រោះរបស់មនុស្សជាតិដែលត្រូវបានសាតាំងធ្វើឲ្យពុករលួយដល់ឆ្អឹង។ ក៏ប៉ុន្តែ ក្នុងពេលជាមួយគ្នានោះដែរ ដំណាក់កាលទាំងនេះ ក៏ដើម្បីឲ្យព្រះជាម្ចាស់អាចតយុទ្ធជាមួយសាតាំងបានផងដែរ។ ហេតុនេះ

កិច្ចការនៃសេចក្ដីសង្គ្រោះ ត្រូវបានបែងចែកជាបីដំណាក់កាល ហើយចម្បាំងជាមួយសាតាំងក៏ត្រូវបានបែងចែកជាបីដំណាក់កាលដែរ ហើយផ្នែកទាំងពីរនៃកិច្ចការរបស់ព្រះជាម្ចាស់ គឺត្រូវធ្វើឡើងក្នុងពេលជាមួយគ្នា។ ចម្បាំងជាមួយសាតាំង តាមពិតគឺដើម្បីជាប្រយោជន៍ដល់សេចក្ដីសង្គ្រោះមនុស្សជាតិ ហើយដោយសារកិច្ចការនៃសេចក្ដីសង្គ្រោះរបស់មនុស្សជាតិនេះ មិនមែនជាកិច្ចការដែលអាចសម្រេចជោគជ័យបាននៅក្នុងដំណាក់កាលតែមួយ នោះចម្បាំងជាមួយសាតាំង ក៏ត្រូវបែងចែកទៅជាដំណាក់កាល និងសម័យកាលដែរ ហើយចម្បាំងដែលប្រកាសធ្វើជាមួយសាតាំងគឺស្របទៅតាមតម្រូវការរបស់មនុស្ស និងទៅតាមទំហំនៃសេចក្ដីពុករលួយរបស់សាតាំងចំពោះមនុស្ស។ ប្រហែលជា នៅក្នុងក្ដីស្រមៃរបស់មនុស្ស គេជឿថា នៅក្នុងចម្បាំងនេះ ព្រះជាម្ចាស់នឹងចាប់យកគ្រឿងសាស្ត្រាវុធតតាំងនឹងសាតាំង ក្នុងលក្ខណៈដូចគ្នាដែលកងទ័ពពីរក្រុមនឹងត្រូវច្បាំងគ្នាដែរ។ នេះគឺគ្រាន់តែអ្វីដែលប្រាជ្ញារបស់មនុស្សអាចនឹងស្រមៃដល់បានតែប៉ុណ្ណោះ។ វាគឺជាគំនិតដ៏សែនស្រពេចស្រពិល និងមិនប្រាកដប្រជា ក៏ប៉ុន្តែវាគឺជាគំនិតដែលមនុស្សជឿ។ ហើយដោយសារខ្ញុំមានព្រះបន្ទូលនៅទីនេះថា សេចក្ដីសង្គ្រោះរបស់មនុស្ស គឺតាមរយៈចម្បាំងជាមួយសាតាំង មនុស្សស្រមៃថា នេះគឺជារបៀបដែលត្រូវធ្វើចម្បាំង។ មានដំណាក់កាលចំនួនបីនៃកិច្ចការសម្រាប់សេចក្ដីសង្គ្រោះរបស់មនុស្ស ពោលគឺ ចម្បាំងជាមួយសាតាំងត្រូវបំបែកទៅជាបីដំណាក់កាលដើម្បីយកឈ្នះលើសាតាំងមួយដងជាសម្រេច។ ក៏ប៉ុន្តែសេចក្ដីពិតខាងក្នុងនៃកិច្ចការចម្បាំងទាំងមូលជាមួយសាតាំង គឺថាឥទ្ធិពលនៃចម្បាំងនេះ អាចសម្រេចទៅបានតាមរយៈដំណាក់កាលនៃកិច្ចការជាច្រើន៖ ការប្រទានព្រះគុណដល់មនុស្ស ការក្លាយជាតង្វាយលោះបាបរបស់មនុស្ស ការអត់ទោសបាបរបស់មនុស្ស ការយកឈ្នះលើមនុស្ស និងការប្រោសឲ្យមនុស្សបានគ្រប់លក្ខណ៍។ តាមពិតទៅ ចម្បាំងជាមួយសាតាំង គឺមិនមែនជាការចាប់យកគ្រឿងសាស្ត្រាវុធតតាំងនឹងសាតាំងឡើយប៉ុន្តែជាសេចក្ដីសង្គ្រោះរបស់មនុស្ស ជាការកែខៃដល់ជីវិតមនុស្ស និងការបំផ្លាស់បំប្រែនិស្ស័យរបស់មនុស្ស ដើម្បីឲ្យគេអាចធ្វើទីបន្ទាល់អំពីព្រះជាម្ចាស់បាន។ នេះជាការ

ដែលត្រូវបានយកឈ្នះសាតាំង។ ត្រូវបានយកឈ្នះសាតាំង តាមរយៈការបំផ្លាស់បំប្រែនិស្ស័យពុករលួយរបស់មនុស្ស។ នៅពេលដែល ត្រូវបានយកឈ្នះសាតាំងរួចហើយ ពោលគឺ នៅពេលដែលមនុស្សត្រូវបានសង្គ្រោះទាំងស្រុង នោះសាតាំងដែលរងភាពអាម៉ាស់ នឹងត្រូវចាប់ចងទាំងស្រុង ហើយតាមរយៈការនេះ មនុស្សនឹងត្រូវបានសង្គ្រោះទាំងស្រុង។ ហេតុនេះ សារជាតិនៃសេចក្ដីសង្គ្រោះរបស់មនុស្សគឺជាចម្បាំងជាមួយនឹងសាតាំង ហើយចម្បាំងនេះគឺសំខាន់ត្រូវឆ្លុះបញ្ចាំងតាមរយៈសេចក្ដីសង្គ្រោះរបស់មនុស្ស។ ដំណាក់កាលនៃគ្រាចុងក្រោយដែលមនុស្សត្រូវបានយកឈ្នះ គឺជាដំណាក់កាលចុងក្រោយនៅក្នុងការធ្វើចម្បាំងជាមួយសាតាំង ហើយវាក៏ជាកិច្ចការនៃសេចក្ដីសង្គ្រោះដ៏ពេញលេញរបស់មនុស្សចេញពីដែនត្រួតត្រារបស់សាតាំងផងដែរ។ អត្ថន័យបង្កប់ នៃការយកឈ្នះលើមនុស្សលោកគឺជាការប្រគល់រូបតំណាងរបស់សាតាំង (មនុស្សដែលត្រូវសាតាំងធ្វើឲ្យពុករលួយ) ត្រឡប់មកព្រះអាទិករវិញក្រោយពេលនៃការយកឈ្នះរបស់ទ្រង់ដែលតាមរយៈការនេះ មនុស្សនឹងត្រូវបោះបង់សាតាំងចោល ហើយត្រឡប់មករកព្រះជាម្ចាស់វិញទាំងស្រុង។ តាមរបៀបនេះ មនុស្សនឹងត្រូវបានសង្គ្រោះទាំងស្រុង។ ហេតុដូច្នេះហើយ កិច្ចការនៃការយកឈ្នះ គឺជាកិច្ចការចុងក្រោយនៅក្នុងចម្បាំងជាមួយសាតាំង និងជាដំណាក់កាលចុងក្រោយនៃការគ្រប់គ្រងរបស់ព្រះជាម្ចាស់ដើម្បីការយកឈ្នះលើសាតាំង។ បើគ្មានកិច្ចការនេះទេ សេចក្ដីសង្គ្រោះទាំងស្រុងរបស់មនុស្ស នឹងមិនអាចសម្រេចទៅបាននោះទេ ការយកឈ្នះទាំងស្រុងលើសាតាំង ក៏នឹងមិនអាចធ្វើទៅបានដែរ ហើយមនុស្សជាតិនឹងមិនអាចចូលទៅក្នុងគោលដៅដ៏អស្ចារ្យ ឬរួចផុតពីឥទ្ធិពលរបស់សាតាំងបាននោះឡើយ។ ហេតុនេះ កិច្ចការនៃសេចក្ដីសង្គ្រោះរបស់មនុស្ស មិនអាចបញ្ចប់ទៅបាននៅមុនពេលដែលចម្បាំងជាមួយសាតាំងត្រូវបានបញ្ចប់ឡើយ ដ្បិតចំណុចស្នូលនៃកិច្ចការគ្រប់គ្រងរបស់ព្រះជាម្ចាស់ គឺដើម្បីសេចក្ដីសង្គ្រោះរបស់មនុស្ស។ មនុស្សជាតិកាលពីដើមដំបូងឡើយ គឺស្ថិតនៅក្នុងព្រះហស្តរបស់ព្រះជាម្ចាស់ ប៉ុន្តែដោយសារការល្បួង និងសេចក្ដីពុករលួយរបស់សាតាំង មនុស្សត្រូវបានសាតាំងចាប់ចង និងធ្លាក់ទៅក្នុងដៃរបស់មេ

កំណាចនេះ។ ហេតុនេះ សាតាំងបានក្លាយទៅជាកម្មវត្ថុដែលត្រូវតែយកឈ្នះនៅក្នុងកិច្ចការនៃការគ្រប់គ្រងរបស់ព្រះជាម្ចាស់។ ដោយសារសាតាំងគ្រប់គ្រងលើមនុស្ស ហើយដោយសារមនុស្សជាធនធានដែលព្រះជាម្ចាស់ប្រើដើម្បីអនុវត្តការគ្រប់គ្រងទាំងអស់ ប្រសិនបើមនុស្សត្រូវទទួលបាននូវការសង្គ្រោះមែននោះត្រូវតែកញ្ឆក់យកមនុស្ស ចេញពីក្នុងដៃរបស់សាតាំងមកវិញ ពោលគឺត្រូវយកមនុស្សដែលត្រូវសាតាំងចាប់ធ្វើជាឈ្លើយនោះត្រឡប់មកវិញ។ ហេតុនេះ ត្រូវតែបង្ក្រាបសាតាំងឲ្យបានតាមរយៈការបំផ្លាស់បំប្រែនិស្ស័យចាស់របស់មនុស្ស ជាការបំផ្លាស់បំប្រែដែលស្រោចស្រង់នូវស្មារតីដឹងខុសត្រូវរបស់មនុស្សពីមុនត្រឡប់មកវិញ។ តាមរបៀបនេះ មនុស្សដែលត្រូវបានចាប់ជាឈ្លើយ អាចត្រូវឆក់យកពីដៃរបស់សាតាំងត្រឡប់មកវិញបាន។ ប្រសិនបើមនុស្សត្រូវបានដោះលែងពីឥទ្ធិពល និងចំណងរបស់សាតាំង នោះសាតាំងនឹងត្រូវអាម៉ាស់មុខ មនុស្សនឹងត្រូវយកត្រឡប់មកវិញនៅចុងបំផុត ហើយសាតាំងនឹងត្រូវបរាជ័យ។ ហើយដោយសារមនុស្សត្រូវបានដោះលែងពីឥទ្ធិពលខ្មៅងងឹតរបស់សាតាំង មនុស្សនឹងក្លាយជារបឹបនៃចម្បាំងនេះទាំងមូល ហើយសាតាំងនឹងក្លាយជាកម្មវត្ថុដែលត្រូវដាក់ទោស នៅពេលណាដែលចម្បាំងនេះត្រូវបានបញ្ចប់។ ក្រោយពីចម្បាំងនេះទៅ កិច្ចការនៃសេចក្ដីសង្គ្រោះរបស់មនុស្សទាំងមូល នឹងត្រូវបានបញ្ចប់សព្វគ្រប់។

ព្រះជាម្ចាស់ ពុំមានការព្យាបាទដល់សត្តនិករដែលបានបង្កើតមកទេ។ ទ្រង់មានបំណងព្រះហឫទ័យយកឈ្នះតែលើសាតាំងតែប៉ុណ្ណោះ។ គ្រប់កិច្ចការទាំងអស់របស់ទ្រង់ ពោលគឺមិនថាជាការវាយផ្ចាល ឬការជំនុំជម្រះនោះទេ គឺសុទ្ធតែតម្រង់ទៅរកសាតាំង។ កិច្ចការនោះ ត្រូវធ្វើឡើងដើម្បីជាប្រយោជន៍ដល់សេចក្ដីសង្គ្រោះរបស់មនុស្សជាតិ ហើយគ្រប់ការទាំងអស់ គឺដើម្បីយកឈ្នះលើសាតាំង ហើយវាមានគោលបំណងតែមួយ៖ គឺដើម្បីធ្វើចម្បាំងជាមួយសាតាំង រហូតដល់ទីបញ្ចប់។ ព្រះជាម្ចាស់ នឹងមិនសម្រាកនោះទេ រហូតទាល់តែទ្រង់មានជ័យជម្នះលើសាតាំង! ទ្រង់នឹងសម្រាកតែនៅពេលណាដែលទ្រង់បានយកឈ្នះលើសាតាំងតែប៉ុណ្ណោះ។ ដោយសារ

គ្រប់កិច្ចការទាំងអស់ដែលព្រះជាម្ចាស់បានបំពេញ គឺសុទ្ធតែតម្រង់ទៅរកសាតាំង ហើយដោយសារអស់អ្នកណាដែលត្រូវបានសាតាំងធ្វើឲ្យពុករលួយ គឺស្ថិតនៅក្រោមដែនត្រួតត្រារបស់សាតាំង ហើយគ្រប់ជីវិតដែលនៅក្រោមដែនត្រួតត្រារបស់សាតាំងដែលមិនធ្វើចម្បាំងជាមួយសាតាំង និងមិនបានចែកផ្លូវជាមួយវា នោះសាតាំងនឹងមិនព្រមឈប់ក្ដោបក្ដាប់មនុស្សទាំងនេះទេ ហើយព្រះជាម្ចាស់មិនអាចទទួលបានមនុស្សទាំងនេះឡើយ។ ប្រសិនបើព្រះជាម្ចាស់មិនទទួលបានពួកគេទេ វាបញ្ជាក់ថាសាតាំងមិនទាន់ត្រូវបង្ក្រាបបាននៅឡើយទេ គឺថាវាមិនទាន់ត្រូវបានយកឈ្នះនៅឡើយទេ។ ហេតុដូចនេះ នៅក្នុងផែនការនៃការគ្រប់គ្រងរយៈពេល៦០០០ឆ្នាំ នេះនៅក្នុងអំឡុងដំណាក់កាលដំបូងទ្រង់បានបំពេញកិច្ចការនៃក្រឹត្យវិន័យ នៅក្នុងអំឡុងដំណាក់កាលទីពីរទ្រង់បានបំពេញកិច្ចការនៃយុគសម័យព្រះគុណ ពោលគឺកិច្ចការនៃការជាប់ឆ្កាង និងក្នុងអំឡុងដំណាក់កាលទីបី គឺទ្រង់បំពេញកិច្ចការនៃការយកឈ្នះលើមនុស្សជាតិ។ គ្រប់កិច្ចការទាំងអស់នេះ គឺសុទ្ធតែតម្រង់ទៅរកទំហំដែលសាតាំងបានធ្វើឲ្យមនុស្សជាតិពុករលួយ និងដើម្បីយកឈ្នះសាតាំង ហើយដំណាក់កាលនីមួយៗគឺសុទ្ធតែ ដើម្បីជាប្រយោជន៍ដល់ការយកឈ្នះលើសាតាំង។ សារជាតិនៃកិច្ចការគ្រប់គ្រងរយៈពេល៦០០០ឆ្នាំរបស់ព្រះជាម្ចាស់ គឺជាចម្បាំងតតាំងនឹងនាគដ៏ធំមានសម្បុរក្រហម ហើយកិច្ចការនៃការគ្រប់គ្រងមនុស្សជាតិ ក៏ជាកិច្ចការនៃការយកឈ្នះលើសាតាំងផងដែរ គឺជាកិច្ចការនៃការធ្វើចម្បាំងជាមួយសាតាំង។ ព្រះជាម្ចាស់បានធ្វើចម្បាំងអស់រយៈពេល៦០០០ឆ្នាំមកហើយ ហេតុដូចនេះ ទ្រង់បានបំពេញកិច្ចការអស់រយៈពេល៦០០០ឆ្នាំហើយ ដើម្បីនាំមនុស្សទៅកាន់ពិភពមួយថ្មីនៅទីចុងបំផុត។ នៅពេលសាតាំងត្រូវបានយកឈ្នះរួច មនុស្សនឹងត្រូវដោះលែងឲ្យមានសេរីភាពទាំងស្រុង។ តើនេះមិនមែនជាគោលដៅនៃកិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងពេលសព្វថ្ងៃនេះទេឬអី? ច្បាស់ណាស់ នេះគឺជាគោលដៅនៃកិច្ចការក្នុងពេលសព្វថ្ងៃនេះ៖ ការដោះលែងមនុស្សឲ្យមានសេរីភាព និងស្រាយចំណងរបស់មនុស្សទាំងស្រុង ដើម្បីកុំឲ្យគេត្រូវជាប់ក្រឹត្យវិន័យណាមួយ ឬជាប់ការកំហិតដោយកាតព្វកិច្ច ឬការរឹតត្បិត

ណាមួយឡើយ។ គ្រប់កិច្ចការទាំងអស់ គឺត្រូវធ្វើឡើងស្របទៅតាមកម្ពស់របស់អ្នករាល់គ្នា និងស្របទៅតាមតម្រូវការរបស់អ្នករាល់គ្នា មានន័យថា អ្នកត្រូវបានប្រទានឲ្យនូវអ្វីៗដែលអ្នករាល់គ្នាអាចសម្រេចបាន។ វាមិនមែនជាករណីនៃ «ការដេញទាឲ្យឡើងទ្រនំ» ដោយដាក់កម្រិតអ្វីមួយលើអ្នករាល់គ្នានោះទេ។ ផ្ទុយទៅវិញ គ្រប់កិច្ចការទាំងអស់ សុទ្ធតែអនុវត្តស្របទៅតាមតម្រូវការជាក់ស្ដែងរបស់អ្នករាល់គ្នា។ ដំណាក់កាលនៃកិច្ចការនីមួយៗ ត្រូវអនុវត្តស្របទៅតាមតម្រូវការជាក់ស្ដែង និងសេចក្ដីតម្រូវរបស់មនុស្ស។ ដំណាក់កាលនៃកិច្ចការនីមួយៗ គឺដើម្បីបង្ក្រាបសាតាំង។ ជាការពិតណាស់ កាលពីដំបូងឡើយ ពុំមានឧបសគ្គរវាងព្រះអាទិករ និងសត្តនិករបស់ទ្រង់ឡើយ។ ឧបសគ្គទាំងអស់នេះ គឺបង្កើតឡើងដោយសាតាំង។ មនុស្សបានប្រែជាអសមត្ថភាពមិនអាចមើលឃើញ ឬប៉ះពាល់អ្វីបាន ដោយសារសាតាំងបានរំខាន និងធ្វើឲ្យមនុស្សពុករលួយ។ មនុស្សគឺជាជនរងគ្រោះ ជាអ្នកដែលត្រូវបានគេបោកបញ្ឆោត។ នៅពេលដែលសាតាំងត្រូវបានយកឈ្នះរួចហើយ សត្តនិករដែលបានបង្កើតមកនឹងមើលឃើញព្រះអាទិករ ហើយព្រះអាទិករនឹងទតមើលសត្តនិករដែលបានបង្កើតមក ហើយទ្រង់នឹងអាចដឹកនាំពួកគេដោយផ្ទាល់ព្រះអង្គឯងបាន។ មនុស្សគប្បីមានត្រឹមតែជីវិតបែបនេះប៉ុណ្ណោះនៅលើផែនដី។ ហេតុដូចនេះ កិច្ចការរបស់ព្រះជាម្ចាស់ ជាចម្បងគឺដើម្បីយកឈ្នះលើសាតាំង ហើយនៅពេលដែលសាតាំងត្រូវបានយកឈ្នះរួចហើយ គ្រប់ការទាំងអស់នឹងត្រូវដោះស្រាយបាន។ សព្វថ្ងៃនេះ អ្នកបានឃើញហើយថា ការដែលព្រះជាម្ចាស់ត្រូវយាងមកក្នុងចំណោមមនុស្ស គឺមិនមែនជារឿងធម្មតាទេ។ ទ្រង់មិនយាងមកដើម្បីចំណាយពេលមួយថ្ងៃៗ តាមចាប់កំហុសអ្នករាល់គ្នា ដើម្បីមានបន្ទូលពីនេះពីនោះ ឬគ្រាន់តែដើម្បីអនុញ្ញាតឲ្យអ្នករាល់គ្នាមើលឃើញថាតើទ្រង់មានរូបអង្គបែបណា និងថាតើទ្រង់មានព្រះបន្ទូលបែបណា និងរស់នៅដោយបែបណានោះទេ។ ព្រះជាម្ចាស់មិនបានត្រឡប់មកជាសាច់ឈាមវិញ ដោយគ្រាន់តែដើម្បីអនុញ្ញាតឲ្យអ្នករាល់គ្នាសម្លឹងមើលទ្រង់ ឬដើម្បីបើកភ្នែករបស់អ្នករាល់គ្នា ឬដើម្បីអនុញ្ញាតឲ្យអ្នករាល់គ្នាស្ដាប់ឮនូវអាថ៌កំបាំងនានាដែលទ្រង់បាន

មានព្រះបន្ទូល និងអំពីត្រាទាំងប្រាំពីរដែលទ្រង់បានបើកនោះទេ។ ផ្ទុយទៅវិញ ទ្រង់បានត្រឡប់មកជាសាច់ឈាមវិញ ដើម្បីយកឈ្នះលើសាតាំង។ ទ្រង់បានយាងមកក្នុងចំណោមមនុស្សដោយផ្ទាល់ព្រះអង្គនៅក្នុងលក្ខណៈជាសាច់ឈាម ដើម្បីសង្គ្រោះមនុស្ស និងដើម្បីធ្វើចម្បាំងជាមួយសាតាំង។ នេះគឺជាសារជាតិសំខាន់នៃការយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់។ ប្រសិនបើមិនមែនដើម្បីយកឈ្នះលើសាតាំងទេ នោះទ្រង់នឹងមិនបំពេញកិច្ចការនេះដោយផ្ទាល់ព្រះអង្គឡើយ។ ព្រះជាម្ចាស់បានយាងយកកាន់ផែនដីដើម្បីបំពេញកិច្ចការរបស់ទ្រង់ក្នុងចំណោមមនុស្ស ដើម្បីបើកបង្ហាញពីអង្គទ្រង់ឲ្យមនុស្សបានឃើញដោយផ្ទាល់ និងដើម្បីអនុញ្ញាតឲ្យមនុស្សមើលឃើញទ្រង់។ តើនេះជារឿងតូចតាចមែនទេ? វាមិនមែនជារឿងធម្មតានោះទេ! វាមិនដូចជាការស្រមៃរបស់មនុស្សឡើយៈ ថាព្រះជាម្ចាស់បានយាងមកដើម្បីឲ្យមនុស្សអាចមើលឃើញទ្រង់បាន ដើម្បីឲ្យមនុស្សអាចយល់ថា ព្រះជាម្ចាស់គឺពិតជាក់ស្ដែង និងមិនស្រពេចស្រពិល ឬរាក់កំភែលឡើយ ហើយថាព្រះជាម្ចាស់គឺឧត្ដុង្គឧត្ដម ប៉ុន្តែក៏បន្ទាបអង្គទ្រង់ផងដែរ។ តើវាអាចជារឿងធម្មតាបានដែរឬអី? ច្បាស់ណាស់ គឺដោយសារ សាតាំងបានធ្វើឲ្យខាងសាច់ឈាមរបស់មនុស្សពុករលួយ ហើយមនុស្សគឺជាអ្នកដែលព្រះជាម្ចាស់មានបំណងព្រះហឫទ័យចង់សង្គ្រោះ ហេតុនេះ ព្រះជាម្ចាស់ត្រូវត្រលប់ជាសាច់ឈាម ដើម្បីធ្វើចម្បាំងជាមួយសាតាំង និងដើម្បីឃ្វាលលមនុស្សដោយផ្ទាល់ព្រះអង្គ។ មានតែចំណុចនេះទេ ទើបមានប្រយោជន៍ចំពោះកិច្ចការរបស់ទ្រង់។ ការយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់បានកើតមានឡើងចំនួនពីរលើកដើម្បីយកឈ្នះលើសាតាំងនិងដើម្បីសង្គ្រោះមនុស្សឲ្យបានប្រសើរជាងមុនផងដែរ។ នេះគឺដោយសារអ្នកដែលធ្វើចម្បាំងជាមួយសាតាំង គឺមានតែព្រះជាម្ចាស់ប៉ុណ្ណោះ មិនថាជាព្រះវិញ្ញាណនៃព្រះជាម្ចាស់ ឬសាច់ឈាមដែលយកកំណើតជាមនុស្ស របស់ព្រះជាម្ចាស់នោះទេ។ សរុបមក ពួកទេវតាមិនអាចធ្វើចម្បាំងជាមួយសាតាំងបានឡើយ ហើយមនុស្សកាន់តែមិនអាចធ្វើចម្បាំងជាមួយវាបាន ដ្បិតមនុស្សត្រូវបានសាតាំងធ្វើឲ្យពុករលួយទៅហើយ។ ពួកទេវតាគ្មានឫទ្ធិអំណាចក្នុងការធ្វើចម្បាំងមួយនេះទេ

ហើយមនុស្សកាន់តែគ្មានអំណាចថែមទៀតហើយ។ ដូចនេះ ប្រសិនបើព្រះជាម្ចាស់ចង់កែខៃជីវិតរបស់មនុស្ស ប្រសិន បើទ្រង់ចង់យាងត្រឡប់មកកាន់ផែនដីនេះដោយផ្ទាល់ព្រះអង្គដើម្បីសង្គ្រោះមនុស្ស គឺទ្រង់ត្រូវតែត្រឡប់មកជាសាច់ឈាមដោយផ្ទាល់ព្រះអង្គ ពោលគឺទ្រង់ត្រូវតែយកកំណើតជាមនុស្សដោយផ្ទាល់ យាងមកក្នុងចំណោមមនុស្ស និងសង្គ្រោះមនុស្សដោយផ្ទាល់ព្រះអង្គ តាមរយៈអត្តសញ្ញាណពីកំណើតរបស់ទ្រង់ និងកិច្ចការដែលទ្រង់ត្រូវបំពេញ។ ប្រសិនបើមិនដូច្នេះទេ ប្រសិនបើព្រះវិញ្ញាណនៃព្រះជាម្ចាស់ ឬមនុស្សជាអ្នកធ្វើកិច្ចការនេះវិញ នោះចម្បាំងនេះ នឹងគ្មានលេចចេញជាផលផ្លែអ្វីឡើយ ហើយវានឹងមិនអាចបញ្ចប់ទៅវិញបានទេ។ មានតែពេលដែលព្រះជាម្ចាស់ត្រឡប់មកជាសាច់ឈាមដើម្បីទៅធ្វើចម្បាំងដោយផ្ទាល់ព្រះអង្គជាមួយសាតាំងប៉ុណ្ណោះ ទើបមនុស្សមានឱកាសទទួលបានសេចក្ដីសង្គ្រោះ។ បន្ថែមលើនេះ មានតែពេលនោះទេដែលសាតាំងរងការអាម៉ាស់ និងត្រូវចាកចេញដោយគ្មានឱកាសបំផ្លាញ ឬមានផែនការត្រូវធ្វើទៀតនោះទេ។ កិច្ចការដែលបានបំពេញដោយព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស គឺមិនអាចសម្រេចទៅបានតាមរយៈព្រះវិញ្ញាណនៃព្រះជាម្ចាស់បានឡើយ ហើយកិច្ចការនឹងកាន់តែមិនអាចឲ្យមនុស្សខាងសាច់ឈាមណាម្នាក់បំពេញជំនួសព្រះជាម្ចាស់បានឡើយ ដ្បិតកិច្ចការដែលទ្រង់ធ្វើ គឺដើម្បីជីវិតរបស់មនុស្ស និងដើម្បីបំផ្លាស់បំប្រែនិស្ស័យពុករលួយរបស់មនុស្ស។ ប្រសិនបើមនុស្សត្រូវចូលរួមក្នុងចម្បាំងនេះពិតមែន គេនឹងរត់ចោលជួរទាំងប្របូកប្របល់យ៉ាងសែនវេទនា ហើយនឹងមិនអាចបំផ្លាស់បំប្រែនិស្ស័យពុករលួយរបស់គេបានឡើយ។ ទ្រង់នឹងមិនអាចសង្គ្រោះមនុស្សតាមរយៈឈើឆ្កាង ឬយកឈ្នះលើមនុស្សជាតិដែលបះបោរទាំងអស់បានទេ ប៉ុន្តែអាចត្រឹមធ្វើកិច្ចការចាស់ៗបន្តិចបន្តួច ដោយមិនទៅឆ្ងាយពីគោលការណ៍ផ្សេងៗឡើយ ឬបើពុំដូច្នោះទេ អាចធ្វើត្រឹមកិច្ចការផ្សេងដែលមិនពាក់ព័ន្ធនឹងការយកឈ្នះលើសាតាំងប៉ុណ្ណោះ។ ដូច្នេះ ហេតុអ្វីចាំបាច់ត្រូវខ្វាយខ្វល់? តើកិច្ចការដែលមិនអាចទទួលបានមនុស្ស និងមិនអាចយកឈ្នះលើសាតាំងបាននោះ មានសារៈសំខាន់អ្វីទៅ? ហេតុដូច្នេះ ចម្បាំងជាមួយសាតាំងមានតែព្រះជាម្ចាស់ផ្ទាល់

ព្រះអង្គប៉ុណ្ណោះដែលអាចធ្វើបាន ហើយមនុស្សមិនអាចធ្វើសង្គ្រាមនេះបានឡើយ។ ភារកិច្ចរបស់មនុស្ស គឺត្រូវស្ដាប់បង្គាប់ និងដើរតាម ដ្បិតមនុស្សមិនអាចធ្វើកិច្ចការស្រដៀងគ្នានឹងការបង្កើតផ្ទៃមេឃ និងផែនដីបានឡើយ ហើយបន្ថែមលើនេះ គេមិនអាចបំពេញកិច្ចការនៃការធ្វើចម្បាំងជាមួយសាតាំងបានឡើយ។ មនុស្សអាចត្រឹមផ្គាប់ព្រះហឫទ័យព្រះអាទិករ ស្ថិតក្រោមការដឹកនាំរបស់ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គប៉ុណ្ណោះ ដែលតាមរយៈការនេះ សាតាំងត្រូវបានយកឈ្នះ។ នេះគឺជារឿងតែមួយគត់ដែលមនុស្សអាចធ្វើបាន។ ហេតុដូចនេះ គ្រប់ពេលដែលចាប់ផ្ដើមធ្វើចម្បាំងថ្មីមួយ ពោលគឺគ្រប់ពេលដែលកិច្ចការនៃសម័យថ្មីចាប់ផ្ដើម កិច្ចការនេះត្រូវព្រះជាម្ចាស់បំពេញដោយផ្ទាល់ព្រះអង្គតែម្ដង ដែលតាមរយៈការនេះ ទ្រង់ត្រូវដឹកនាំសម័យកាលទាំងមូល និងចាប់ផ្ដើមផ្លូវថ្មីសម្រាប់មនុស្សជាតិទាំងមូល។ ការចាប់ផ្ដើមយុគសម័យថ្មីនីមួយៗ គឺជាការចាប់ផ្ដើមចម្បាំងថ្មីជាមួយសាតាំង ដែលតាមរយៈការនេះ មនុស្សត្រូវចូលទៅក្នុងពិភពមួយកាន់តែថ្មី និងស្រស់ស្អាតជាងមុន និងជាយុគសម័យថ្មីមួយដែលព្រះជាម្ចាស់ដឹកនាំដោយផ្ទាល់ព្រះអង្គតែម្ដង។ មនុស្សគឺជាម្ចាស់នៃរបស់សព្វសារពើ ប៉ុន្តែអ្នកណាដែលត្រូវបានទទួលយក នឹងក្លាយជាផលផ្លែនៃគ្រប់ចម្បាំងជាមួយសាតាំង។ សាតាំងគឺជាអ្នកធ្វើឲ្យគ្រប់របស់សព្វសារពើពុករលួយ វាត្រូវបរាជ័យនៅពេលចម្បាំងទាំងអស់បញ្ចប់ ហើយវាក៏ជាអ្នកដែលត្រូវដាក់ទោសក្រោយចម្បាំងទាំងអស់នេះផងដែរ។ រវាងព្រះជាម្ចាស់មនុស្សនិងសាតាំង គឺមានតែសាតាំងប៉ុណ្ណោះដែលនឹងត្រូវស្អប់ខ្ពើម និងបដិសេធចោល។ អស់អ្នកដែលត្រូវសាតាំងទទួលយក ប៉ុន្តែមិនត្រូវបានព្រះជាម្ចាស់យកត្រឡប់មកវិញនឹងក្លាយជាមនុស្សដែលនឹងត្រូវទទួលទោសជំនួសសាតាំង។ ក្នុងចំណោមដំណាក់កាលទាំងបីនេះ មានតែព្រះជាម្ចាស់ប៉ុណ្ណោះដែលនឹងត្រូវគ្រប់របស់សព្វសារពើទាំងអស់ថ្វាយបង្គំ។ អស់អ្នកដែលត្រូវបានសាតាំងធ្វើឲ្យពុករលួយ តែត្រូវព្រះជាម្ចាស់យកត្រឡប់មកវិញ ហើយជាអ្នកដែលដើរតាមផ្លូវរបស់ព្រះជាម្ចាស់នឹងក្លាយជាអ្នកដែលត្រូវទទួលនូវការសន្យារបស់ព្រះជាម្ចាស់ និងត្រូវជំនុំជម្រះមេកំណាចជំនួសព្រះជាម្ចាស់។ ព្រះជាម្ចាស់ច្បាស់ជានឹងមានជ័យជម្នះ ហើយសាតាំង

ច្បាស់ជានឹងត្រូវបរាជ័យ ប៉ុន្តែក្នុងចំណោមមនុស្ស ក៏មានអ្នកដែលនឹងត្រូវមានជ័យជម្នះ និងអ្នកដែលនឹងត្រូវបរាជ័យដែរ។ អ្នកដែលឈ្នះនឹងក្លាយជាក្រុមនៃអ្នកដែលមានជ័យជម្នះ ហើយអ្នកដែលចាញ់នឹងស្ថិតក្នុងក្រុមអ្នកចាញ់។ នេះគឺជាការធ្វើចំណាត់ថ្នាក់មនុស្សម្នាក់ៗទៅតាមប្រភេទរបស់គេហើយវាគឺជាទីបញ្ចប់នៃកិច្ចការរបស់ព្រះជាម្ចាស់។ វាក៏ជាគោលបំណងនៃកិច្ចការរបស់ព្រះជាម្ចាស់ផងដែរ ហើយវានឹងមិនផ្លាស់ប្ដូរឡើយ។ ចំណុចស្នូលនៃកិច្ចការចម្បង នៃផែនការគ្រប់គ្រងរបស់ព្រះជាម្ចាស់ គឺផ្ដោតជាសំខាន់ទៅលើសេចក្ដីសង្គ្រោះរបស់មនុស្ស ហើយព្រះជាម្ចាស់ត្រឡប់មកជាសាច់ឈាម សំខាន់គឺដើម្បីចំណុចស្នូលនេះ ដើម្បីកិច្ចការនេះ និងដើម្បីយកឈ្នះលើសាតាំងនេះឯង។ លើកដំបូង ដែលព្រះជាម្ចាស់បានត្រឡប់មកជាសាច់ឈាម ក៏ដើម្បីយកឈ្នះលើសាតាំងផងដែរៈ ទ្រង់ត្រឡប់មកជាសាច់ឈាមដោយផ្ទាល់ព្រះអង្គវិញ និងត្រូវជាប់ឆ្កាងដោយផ្ទាល់ព្រះអង្គ ក៏ដើម្បីបញ្ចប់កិច្ចការនៃចម្បាំងទីមួយ ដែលជាកិច្ចការនៃការប្រោសលោះមនុស្សជាតិដែរ។ ដូចគ្នានេះដែរ ដំណាក់កាលនៃកិច្ចការនេះ ក៏ត្រូវបំពេញដោយព្រះជាម្ចាស់ផ្ទាល់ព្រះអង្គដែរ ដែលទ្រង់បានត្រឡប់មកជាសាច់ឈាមវិញដើម្បីបំពេញកិច្ចការរបស់ទ្រង់ក្នុងចំណោមមនុស្ស ដើម្បីថ្លែងនូវព្រះបន្ទូលរបស់ទ្រង់ដោយផ្ទាល់ និងដើម្បីអនុញ្ញាតឲ្យមនុស្សមើលឃើញទ្រង់។ ជាការពិតណាស់ វាមិនអាចជៀសផុតទេដែលទ្រង់ត្រូវបំពេញកិច្ចការផ្សេងៗទៀតក្នុងពេលដំណាលគ្នានេះដែរ ប៉ុន្តែមូលហេតុចម្បងដែលទ្រង់បំពេញកិច្ចការរបស់ទ្រង់ដោយផ្ទាល់ គឺដើម្បីយកឈ្នះលើសាតាំង ដើម្បីយកឈ្នះលើមនុស្សជាតិទាំងមូល និងដើម្បីទទួលបានមនុស្សទាំងអស់នេះ។ ដូច្នេះ កិច្ចការនៃការយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់ គឺមិនធម្មតាឡើយ។ ប្រសិនបើបំណងព្រះហឫទ័យរបស់ទ្រង់ គឺគ្រាន់តែចង់បង្ហាញដល់មនុស្សថា ព្រះជាម្ចាស់បន្ទាបអង្គទ្រង់ និងលាក់កំបាំង ហើយថាព្រះជាម្ចាស់មានពិត ប្រសិនបើគ្រាន់តែដើម្បីបំពេញកិច្ចការទាំងនេះទេ នោះពុំចាំបាច់ត្រូវត្រឡប់មកជាសាច់ឈាមវិញឡើយ។ បើទោះបីជាព្រះជាម្ចាស់ពុំបានត្រឡប់មកជាសាច់ឈាមក្តី ក៏ទ្រង់អាចបង្ហាញពីការបន្ទាបអង្គទ្រង់

និងការលាក់កំបាំង ព្រះចេស្ដា និងភាពបរិសុទ្ធរបស់ទ្រង់ចំពោះមនុស្សដោយផ្ទាល់បានដែរ ប៉ុន្តែអ្វីទាំងអស់នេះ គ្មានពាក់ព័ន្ធនឹងកិច្ចការនៃការគ្រប់គ្រងមនុស្សជាតិឡើយ។ កិច្ចការទាំងនេះ មិនអាចសង្គ្រោះមនុស្ស និងធ្វើឲ្យគេបានពេញខ្នាតឡើយ ហើយកិច្ចការទាំងនេះ មិនអាចយកឈ្នះលើសាតាំងបានឡើយ។ ប្រសិនបើការយកឈ្នះលើសាតាំង គឺមានពាក់ព័ន្ធតែនឹងព្រះវិញ្ញាណ ដែលធ្វើចម្បាំងតតាំងនឹងវិញ្ញាណមួយទៀត នោះកិច្ចការបែបនេះ នឹងមានតម្លៃជាក់ស្ដែងកាន់តែតិចតួច។ កិច្ចការបែបនេះនឹងមិនអាចទទួលបានមនុស្សឡើយ ហើយវានឹងបំផ្លាញវាសនា និងក្ដីសង្ឃឹមទៅអនាគតរបស់មនុស្ស។ ហេតុដូចនេះ កិច្ចការរបស់ព្រះជាម្ចាស់នាពេលសព្វថ្ងៃ គឺមានសារៈសំខាន់យ៉ាងខ្លាំង។ វាមិនគ្រាន់តែដើម្បីឲ្យមនុស្សអាចមើលឃើញទ្រង់ ឬដើម្បីបើកភ្នែកមនុស្សឲ្យមើលឃើញ ឬដើម្បីផ្ដល់នូវស្មារតីដឹងញាណតិចតួចដល់មនុស្សដែលបានបណ្ដាលចិត្ត និងជំរុញលើកទឹកចិត្តគេនោះទេ ព្រោះកិច្ចការបែបនេះគ្មានសារៈសំខាន់អ្វីឡើយ។ ប្រសិនបើអ្នកអាចត្រឹមតែនិយាយអំពីចំណេះដឹងប្រភេទនេះ នោះវាបញ្ជាក់ថា អ្នកមិនដឹងពីសារៈសំខាន់ពិតប្រាកដនៃការយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់ឡើយ។

កិច្ចការនៃផែនការគ្រប់គ្រងទាំងស្រុងរបស់ព្រះជាម្ចាស់ គឺត្រូវបំពេញដោយព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ។ ដំណាក់កាលដំបូង ពោលគឺដំណាក់កាលនៃការបង្កើតពិភពលោកនេះ ត្រូវបានព្រះជាម្ចាស់បំពេញដោយផ្ទាល់ព្រះអង្គ ហើយប្រសិនបើមិនដូច្នេះទេ នោះគ្មាននរណាម្នាក់ អាចមានសមត្ថភាពបង្កើតមនុស្សជាតិបានឡើយ។ ដំណាក់កាលទីពីរ គឺជាសេចក្ដីសង្គ្រោះរបស់មនុស្សជាតិទាំងមូល ហើយព្រះជាម្ចាស់ក៏បានបំពេញកិច្ចការនេះដោយផ្ទាល់ព្រះអង្គដែរ។ ដំណាក់កាលទីបី គឺកាន់តែជាក់ស្ដែងថែមទៀត៖ មានតម្រូវការកាន់តែច្រើនជាងមុនផងដែរ ដើម្បីឲ្យព្រះជាម្ចាស់បានបំពេញកិច្ចការនៅទីចុងបញ្ចប់ដោយផ្ទាល់ព្រះអង្គ។ កិច្ចការនៃការប្រោសលោះ ការយកឈ្នះ ការទទួលយក និងការប្រោសឲ្យមនុស្សជាតិទាំងមូលបានគ្រប់លក្ខណ៍ គឺជាកិច្ចការដែលត្រូវបំពេញ ដោយព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ។ ប្រសិនបើទ្រង់មិនបាន

បំពេញកិច្ចការដោយផ្ទាល់ព្រះអង្គទេ នោះមនុស្សមិនអាចជំនួសអត្តសញ្ញាណរបស់ទ្រង់បានឡើយ ហើយមនុស្សក៏មិនអាចធ្វើកិច្ចការរបស់ទ្រង់បានដែរ។ ដើម្បីយកឈ្នះលើសាតាំង ដើម្បីទទួលបានមនុស្ស និងដើម្បីប្រទានឲ្យមនុស្សនូវជីវិតធម្មតានៅលើផែនដី ទ្រង់ត្រូវដឹកនាំមនុស្សដោយផ្ទាល់ និងបំពេញកិច្ចការក្នុងចំណោមមនុស្សដោយផ្ទាល់ ហើយសម្រាប់ជា ប្រយោជន៍ដល់កិច្ចការនៃផែនការគ្រប់គ្រងទាំងស្រុងរបស់ទ្រង់ និងសម្រាប់គ្រប់កិច្ចការទាំងអស់របស់ទ្រង់ គឺទ្រង់ត្រូវតែបំពេញកិច្ចការទាំងនោះដោយផ្ទាល់ព្រះអង្គ។ ប្រសិនបើមនុស្សគ្រាន់តែជឿថា ព្រះជាម្ចាស់បានយាងមកដើម្បីឲ្យមនុស្សអាចឃើញទ្រង់បាន គឺគ្រាន់តែដើម្បីឲ្យមនុស្សបានសប្បាយចិត្ត នោះជំនឿបែបនេះ គឺគ្មានតម្លៃ គ្មានសារៈសំខាន់អ្វីឡើយ។ ការយល់ដឹងរបស់មនុស្ស គឺនៅរាក់កំភែលខ្លាំងណាស់! មានតែការអនុវត្តកិច្ចការដោយផ្ទាល់ព្រះអង្គប៉ុណ្ណោះ ទើបព្រះជាម្ចាស់បំពេញកិច្ចការដោយហ្មត់ចត់ និងពេញលេញបាន។ មនុស្សគ្មានសមត្ថភាពក្នុងការធ្វើកិច្ចការជំនួសព្រះជាម្ចាស់បាននោះឡើយ។ ដោយសារមនុស្សពុំមានអត្តសញ្ញាណរបស់ព្រះជាម្ចាស់ ឬលក្ខណៈរបស់ទ្រង់ នោះគេមិនអាចបំពេញកិច្ចការរបស់ព្រះជាម្ចាស់បានឡើយ ហើយបើទោះបីជាមនុស្សធ្វើការនេះមែនក្ដី ក៏វានឹងគ្មានបានផលអ្វីដែរ។ លើកដំបូងដែលព្រះជាម្ចាស់បានត្រឡប់មកជាសាច់ឈាម គឺដើម្បីសេចក្ដីប្រោសលោះ ដើម្បីប្រោសលោះមនុស្សជាតិទាំងអស់ ឲ្យរួចពីបាប ដើម្បីឲ្យមនុស្សអាចទទួលបានការបន្សុទ្ធ និងអាចអត់ទោសចំពោះបាបរបស់គេ។ កិច្ចការនៃការយកឈ្នះក៏ត្រូវបំពេញដោយព្រះជាម្ចាស់ផ្ទាល់ក្នុងចំណោមមនុស្សដែរ។ ប្រសិនបើក្នុងអំឡុងដំណាក់កាលនេះ ព្រះជាម្ចាស់គ្រាន់តែមានព្រះបន្ទូលពីសេចក្ដីទំនាយ នោះពួកហោរា ឬអ្នកណាម្នាក់ដែលមានអំណោយទាន ក៏អាចជំនួសទ្រង់បានដែរ។ ប្រសិនបើវាគ្រាន់តែជាការមានព្រះបន្ទូលអំពីសេចក្ដីទំនាយ នោះមនុស្សអាចជំនួសព្រះជាម្ចាស់បានហើយ។ ក៏ប៉ុន្តែ ប្រសិនបើមនុស្សព្យាយាមបំពេញកិច្ចរបស់ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គដោយខ្លួនឯង និងព្យាយាមកែខៃជីវិតរបស់មនុស្ស នោះមនុស្សមិនអាចធ្វើកិច្ចការនេះបានឡើយ។ កិច្ចការនេះ ត្រូវបំពេញដោយព្រះជាម្ចាស់

ផ្ទាល់ព្រះអង្គតែម្ដង។ ព្រះជាម្ចាស់ ត្រូវត្រឡប់មកជាសាច់ឈាមវិញ ដើម្បីបំពេញកិច្ចការនេះ។ នៅក្នុងយុគសម័យនៃព្រះបន្ទូល ប្រសិនបើមានគេនិយាយពីសេចក្ដីទំនាយនោះអេសាយ ឬអេលីយ៉ាដែលជាពួកហោរា អាចបំពេញកិច្ចការនេះបាន ហើយពុំចាំបាច់ឲ្យព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ បំពេញកិច្ចការនេះដោយផ្ទាល់ឡើយ។ ដោយសារកិច្ចការដែលបានធ្វើនៅដំណាក់កាលនេះ គឺមិនគ្រាន់តែជាការនិយាយអំពីសេចក្ដីទំនាយប៉ុណ្ណោះទេ ហើយដោយសារកិច្ចការនេះមានសារៈសំខាន់ខ្លាំងជាងមុនដែលត្រូវប្រើកិច្ចការនៃព្រះបន្ទូល ដើម្បីយកឈ្នះលើមនុស្ស និងយកឈ្នះលើសាតាំងគឺមនុស្សមិនអាចឲ្យធ្វើកិច្ចការនេះបានឡើយ ហើយព្រះជាម្ចាស់ត្រូវបំពេញកិច្ចការនេះដោយផ្ទាល់ព្រះអង្គ។ នៅក្នុងយុគសម័យនៃក្រឹត្យវិន័យ ព្រះយេហូវ៉ាបានបំពេញផ្នែកនៃកិច្ចការរបស់ទ្រង់ ក្រោយពីទ្រង់បានបានមានព្រះបន្ទូលមួយចំនួន និងបានបំពេញកិច្ចការខ្លះៗតាមរយៈពួកពួកហោរា។ នេះគឺដោយសារមនុស្ស អាចជំនួសព្រះយេហូវ៉ានៅក្នុងកិច្ចការរបស់ទ្រង់បាន ហើយអ្នកដែលបានមើលឃើញ អាចនិយាយប្រាប់អំពីរឿងរ៉ាវ និងកាត់ស្រាយអំពីសុបិន្តមួយចំនួនជំនួសទ្រង់បាន។ កិច្ចការដែលត្រូវធ្វើនៅដើមដំបូង មិនមែនជាកិច្ចការនៃការបំផ្លាស់បំប្រែនិស្ស័យរបស់មនុស្សដោយផ្ទាល់នោះទេ ក៏គ្មានពាក់ព័ន្ធនឹងបាបរបស់មនុស្សឡើយ ហើយមនុស្សគ្រាន់តម្រូវឲ្យគោរពតាមក្រឹត្យវិន័យតែប៉ុណ្ណោះ។ ដូចនេះ ព្រះយេហូវ៉ាមិនបានត្រឡប់មកជាសាច់ឈាម និងបើកសម្ដែងអង្គទ្រង់ដល់មនុស្សឡើយ។ តែផ្ទុយទៅវិញ ទ្រង់បានមានព្រះបន្ទូលដោយផ្ទាល់ជាមួយម៉ូសេ និងអ្នកដទៃទៀត ដោយបានឲ្យពួកគេនិយាយ និងធ្វើកិច្ចការជំនួសទ្រង់ ហើយឲ្យពួកគេធ្វើការដោយផ្ទាល់ក្នុងចំណោមមនុស្សជាតិ។ ដំណាក់កាលដំបូងនៃកិច្ចការរបស់ព្រះជាម្ចាស់ គឺជាការដឹកនាំមនុស្ស។ វាជាការចាប់ផ្ដើមនូវចម្បាំងជាមួយសាតាំង ប៉ុន្តែចម្បាំងនេះមិនទាន់ចាប់ផ្ដើមជាផ្លូវការនៅឡើយទេ។ ចម្បាំងផ្លូវការជាមួយសាតាំងបានចាប់ផ្ដើមដោយការយកកំណើតជាមនុស្សលើកដំបូងរបស់ព្រះជាម្ចាស់ ហើយវាបានបន្តរហូតមកទល់នឹងបច្ចុប្បន្ននេះ។ ចម្បាំងដំបូងនៃសង្គ្រាមនេះ គឺនៅពេលព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស ត្រូវបានគេបោះដែកគោល

ភ្ជាប់ទៅនឹងឈើឆ្កាង។ ការជាប់ឆ្កាងរបស់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស បានយកឈ្នះលើសាតាំង ហើយវាគឺជាដំណាក់កាលជោគជ័យលើកដំបូង នៅក្នុងសង្គ្រាមនេះ។ នៅពេលព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សបានចាប់ផ្ដើមកែខៃជីវិតមនុស្សដោយផ្ទាល់ នេះគឺជាការចាប់ផ្ដើមជាផ្លូវការនៃកិច្ចការទទួលបានមនុស្សយកមក ហើយដោយសារវាគឺជាកិច្ចការនៃការបំផ្លាស់បំប្រែនិស្ស័យចាស់របស់មនុស្សនោះ វាគឺជាកិច្ចការនៃការធ្វើចម្បាំងជាមួយសាតាំង។ ដំណាក់កាលនៃកិច្ចការដែលព្រះយេហូវ៉ាបានបំពេញនៅដើមដំបូង គឺគ្រាន់តែជាការដឹកនាំជីវិតមនុស្សនៅលើផែនដីប៉ុណ្ណោះ។ វាគឺជាការចាប់ផ្ដើមនៃកិច្ចការរបស់ព្រះជាម្ចាស់ ហើយបើទោះបីជាវាមិនមានពាក់ព័ន្ធនឹងចម្បាំងណាមួយ ឬពាក់ព័ន្ធនឹងកិច្ចការណាមួយក្តី ក៏ប៉ុន្តែវាបានចាក់គ្រឹះសម្រាប់កិច្ចការនៃចម្បាំងនៅពេលខាងមុខ។ ក្រោយមកទៀត ដំណាក់កាលទីពីរនៃកិច្ចការក្នុងអំឡុងពេលយុគសម័យនៃព្រះគុណ ពាក់ព័ន្ធនឹងការបំផ្លាស់បំប្រែនិស្ស័យចាស់របស់មនុស្ស ដែលមានន័យថា ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គធ្វើការកែប្រែជីវិតរបស់មនុស្ស។ កិច្ចការនេះត្រូវបំពេញដោយព្រះជាម្ចាស់ដោយផ្ទាល់៖ កិច្ចការនេះតម្រូវឲ្យព្រះជាម្ចាស់ត្រឡប់មកជាសាច់ឈាមដោយផ្ទាល់។ ប្រសិនបើទ្រង់មិនបានត្រឡប់មកជាសាច់ឈាមទេ នោះគ្មាននរណាម្នាក់ផ្សេងទៀតដែលអាចជំនួសទ្រង់នៅក្នុងដំណាក់កាលនៃកិច្ចការនេះបានឡើយ ដ្បិតវាតំណាងឲ្យ កិច្ចការនៃការធ្វើចម្បាំងជាមួយនឹងសាតាំង។ ប្រសិនបើមនុស្សបានបំពេញកិច្ចការនេះជំនួសឲ្យព្រះជាម្ចាស់ នៅពេលដែលមនុស្សឈរនៅចំពោះមុខសាតាំង នោះសាតាំងនឹងមិនបានចុះចាញ់ឡើយ ហើយវានឹងមិនអាចយកឈ្នះលើសាតាំងបានឡើយ។ ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សនេះហើយ ដែលបានយាងមកយកឈ្នះលើវា ដ្បិតលក្ខណៈនៃព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស គឺនៅតែជាព្រះជាម្ចាស់ដដែល ទ្រង់គឺនៅតែជាជីវិតរបស់មនុស្ស ហើយទ្រង់គឺនៅតែជាព្រះអាទិករដដែល។ មិនថាមានអ្វីកើតឡើងនោះទេ អត្តសញ្ញាណ និងលក្ខណៈរបស់ទ្រង់ នឹងមិនផ្លាស់ប្ដូរឡើយ។ ហេតុដូច្នេះ ទ្រង់បានត្រលប់ជាសាច់ឈាម និងបំពេញកិច្ចការនេះដើម្បីឲ្យសាតាំង

បានចុះចាញ់ទាំងស្រុង។ ក្នុងអំឡុងដំណាក់កាល នៃកិច្ចការនៅគ្រាចុងក្រោយ ប្រសិនបើមនុស្សត្រូវធ្វើកិច្ចការនេះ និងត្រូវឲ្យនិយាយពីព្រះបន្ទូលដោយផ្ទាល់ នោះគេនឹងមិនអាចនិយាយព្រះបន្ទូលបានឡើយ ហើយប្រសិនបើត្រូវនិយាយពីសេចក្ដីទំនាយ នោះសេចក្ដីទំនាយនេះនឹងមិនអាចយកឈ្នះលើមនុស្សបានឡើយ។ តាមរយៈការត្រលប់ជាសាច់ឈាម ព្រះជាម្ចាស់យាងមកដើម្បីយកឈ្នះលើសាតាំង និងធ្វើឲ្យវាចុះចាញ់ទាំងស្រុង។ នៅពេលទ្រង់យកឈ្នះលើសាតាំងបានទាំងស្រុងហើយ បានយកឈ្នះលើមនុស្សទាំងអស់ហើយ និងទទួលបានមនុស្សទាំងមូលហើយ នោះដំណាក់កាលនេះនឹងអាចបញ្ចប់ ហើយសម្រេចជោគជ័យបាន។ នៅក្នុងការគ្រប់គ្រងរបស់ព្រះជាម្ចាស់ មនុស្សមិនអាចជំនួសព្រះជាម្ចាស់បានឡើយ។ ជាពិសេស កិច្ចការនៃការដឹកនាំយុគសម័យ និងការចាប់ផ្ដើមកិច្ចការថ្មី គឺមានតម្រូវការកាន់តែច្រើនដែលឲ្យព្រះជាម្ចាស់បំពេញកិច្ចការដោយផ្ទាល់ព្រះអង្គ។ ការប្រទាននូវការបើកសម្ដែង និងសេចក្ដីទំនាយដល់មនុស្ស អាចឲ្យមនុស្សធ្វើបាន ប៉ុន្តែប្រសិនបើវាជាកិច្ចការដែលត្រូវធ្វើដោយព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ ជាកិច្ចការនៃចម្បាំងរវាងព្រះជាម្ចាស់ផ្ទាល់ព្រះអង្គជាមួយនឹងសាតាំង នោះកិច្ចការនេះមិនអាចឲ្យមនុស្សធ្វើបានឡើយ។ ក្នុងអំឡុងដំណាក់កាលទីមួយនៃកិច្ចការនេះ នៅពេលដែលគ្មានចម្បាំងជាមួយសាតាំង ព្រះយេហូវ៉ាបានដឹកនាំសាសន៍អ៊ីស្រាអែលដោយផ្ទាល់ ដោយប្រើសេចក្ដីទំនាយដែលពួកហោរាបានថ្លែង។ បន្ទាប់ពីនោះមក ដំណាក់កាលទីពីរនៃកិច្ចការនេះ គឺជាចម្បាំងជាមួយសាតាំង ហើយព្រះជាម្ចាស់ផ្ទាល់ព្រះអង្គបានត្រឡប់មកជាសាច់ឈាមដោយផ្ទាល់ និងបានត្រឡប់មកជាសាច់ឈាមដើម្បីបំពេញកិច្ចការនេះ។ អ្វីៗដែលពាក់ព័ន្ធនឹងចម្បាំងជាមួយនឹងសាតាំង ក៏មានពាក់ព័ន្ធនឹងការការយកកំណើតជាមនុស្សរបស់ព្រះជាម្ចាស់ដែរ ដែលមានន័យថា ចម្បាំងនេះមិនអាចឲ្យមនុស្សប្រកាសធ្វើចម្បាំងបានឡើយ។ ប្រសិនបើមនុស្សត្រូវធ្វើចម្បាំងមែន គេនឹងគ្មានសមត្ថភាពយកឈ្នះលើសាតាំងឡើយ។ តើគេអាចមានកម្លាំងឯណាដើម្បីច្បាំងជាមួយវាបាន នៅពេលដែលមនុស្សស្ថិតនៅក្រោម ដែនត្រួតត្រារបស់វានៅឡើយ? មនុស្សគឺស្ថិតនៅចំកណ្ដាលៈ

ប្រសិនបើអ្នកលូនក្រាបទៅរកសាតាំង នោះអ្នកជាកម្មសិទ្ធិរបស់សាតាំង ប៉ុន្តែប្រសិនបើអ្នកគាប់ព្រះហឫទ័យព្រះជាម្ចាស់ នោះអ្នកជាកម្មសិទ្ធិរបស់ព្រះជាម្ចាស់។ ប្រសិនបើមនុស្សល្បងល និងជំនួសព្រះជាម្ចាស់នៅក្នុងកិច្ចការនៃចម្បាំងមួយនេះ តើមនុស្សអាចធ្វើបានដែរឬទេ? ប្រសិនបើមនុស្សធ្វើបែបនេះ តើគេនឹងមិនត្រូវវិនាសជាយូរណាស់មកហើយទេឬអី? តើគេនឹងមិនបានចូលទៅក្នុងពិភពអន់ថយជាយូរមកហើយទេឬអី? ដូច្នេះ មនុស្សគឺមិនអាចជំនួសព្រះជាម្ចាស់នៅក្នុងកិច្ចការរបស់ទ្រង់បានឡើយ ដែលមានន័យថា មនុស្សគឺមិនមានលក្ខណៈរបស់ព្រះជាម្ចាស់ឡើយ ហើយប្រសិនបើអ្នកធ្វើចម្បាំងជាមួយសាតាំង អ្នកនឹងមិនអាចយកឈ្នះលើសាតាំងបានឡើយ។ មនុស្សអាចគ្រាន់តែ ធ្វើកិច្ចការខ្លះប៉ុណ្ណោះ។ គេអាចយកឈ្នះលើមនុស្សមួយចំនួនបាន ប៉ុន្តែគេមិនអាច ជំនួសព្រះជាម្ចាស់នៅក្នុងកិច្ចការរបស់ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គបានឡើយ។ តើមនុស្សអាចធ្វើចម្បាំងជាមួយសាតាំងបានដោយរបៀបណា? សាតាំងនឹងចាប់អ្នក ធ្វើជាឈ្លើយ ទាំងមុនពេលដែលអ្នកបានចាប់ផ្ដើមទៅទៀត។ មានតែព្រះជាម្ចាស់ផ្ទាល់ព្រះអង្គប៉ុណ្ណោះ ដែលអាចធ្វើចម្បាំងជាមួយសាតាំងបាន ហើយមនុស្សត្រូវដើរតាម និងស្ដាប់បង្គាប់តាមលំអាននេះ ទើបមនុស្សអាចត្រូវព្រះជាម្ចាស់ទទួលបាន និងរួចផុតពីចំណងរបស់សាតាំង។ រឿងដែលមនុស្ស អាចសម្រេចទៅបានតាមប្រាជ្ញា និងសមត្ថភាពរបស់គេ គឺនៅមានកម្រិតនៅឡើយ។ គេមិនមានសមត្ថភាពក្នុងការធ្វើឲ្យមនុស្សបានពេញខ្នាត ដឹកនាំមនុស្ស និងយកឈ្នះលើសាតាំងបានឡើយ។ ភាពឈ្លាសវៃ និងប្រាជ្ញារបស់មនុស្ស មិនអាចប្រឆាំងនឹងគ្រោងការរបស់សាតាំងបានឡើយ តើមនុស្សអាចតយុទ្ធនឹងវាបានយ៉ាងដូចម្ដេច?

អស់អ្នកណា ដែលសុខចិត្តទទួលយកការធ្វើឲ្យបានគ្រប់លក្ខណ៍ មានឱកាសក្នុងការត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍ ដូច្នេះមនុស្សគ្រប់គ្នា នឹងបានធូរស្បើយ៖ នៅពេលអនាគត អ្នកនឹងសុទ្ធតែចូលទៅកាន់ទិសដៅមួយ។ ប៉ុន្តែ ប្រសិនបើអ្នកមិនព្រមទទួលយកការត្រូវបានប្រោសឲ្យបានគ្រប់លក្ខណ៍ និងមិនអាចចូលទៅក្នុងពិភពដ៏អស្ចារ្យទេ នោះវាគឺជាបញ្ហាផ្ទាល់ខ្លួនរបស់អ្នក។ អស់អ្នកណាដែលសុខចិត្ត

ទទួលយកការប្រោសឲ្យគ្រប់លក្ខណ៍ និងស្មោះត្រង់ចំពោះព្រះជាម្ចាស់ អស់អ្នកដែលស្ដាប់បង្គាប់ និងអស់អ្នកដែលបំពេញនូវមុខងាររបស់ខ្លួនប្រកបដោយសេចក្ដីជំនឿ មនុស្សទាំងអស់នោះអាចត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍។ សព្វថ្ងៃនេះ អស់អ្នកណាដែលមិនបំពេញភារកិច្ចរបស់ខ្លួនដោយស្មោះត្រង់អស់អ្នកណាដែលមិនស្មោះត្រង់ចំពោះព្រះជាម្ចាស់ អស់អ្នកណាដែលមិនចុះចូលនឹងព្រះជាម្ចាស់ ជាពិសេស អស់អ្នកណាដែលបានទទួលការបំភ្លឺ និងការបង្ហាញពីព្រះវិញ្ញាណបរិសុទ្ធ ប៉ុន្តែមិនបានយកទៅអនុវត្ត មនុស្សបែបនេះមិនអាចត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍នោះទេ។ អស់អ្នកណាដែលសុខចិត្តមានចិត្តស្មោះត្រង់ និងស្ដាប់បង្គាប់ព្រះជាម្ចាស់ អាចត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍ បើទោះបីជាពួកគេក្រអឺតក្រទមតិចតួចក្ដី ហើយអស់អ្នកណាដែលសុខចិត្តស្វែងរក នោះអាចត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍។ មិនត្រូវព្រួយបារម្ភអំពីបញ្ហានេះឡើយ។ ឲ្យតែអ្នកសុខចិត្តស្វែងរកនៅក្នុងទិសដៅនេះ អ្នកនឹងអាចត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍។ ខ្ញុំមិនអាចលះបង់ ឬផាត់ចោលនរណាម្នាក់ក្នុងចំណោមអ្នករាល់គ្នាបានទេ ប៉ុន្តែប្រសិនបើមនុស្សពុំខិតខំប្រឹងប្រែងធ្វើឲ្យបានល្អទេ នោះអ្នកកំពុងបំផ្លាញខ្លួនឯងហើយ។ មិនមែនខ្ញុំជាអ្នកផាត់អ្នកចោលទេ ប៉ុន្តែគឺខ្លួនឯងផ្ទាល់តែម្ដង។ ប្រសិនបើអ្នកខ្លួនឯងពុំបានខិតខំប្រឹងប្រែងធ្វើឲ្យបានល្អទេ ប្រសិនបើអ្នកខ្ជិលច្រអូស ឬមិនចង់បំពេញភារកិច្ចរបស់អ្នក ឬមិនស្មោះត្រង់ ឬមិនស្វែងរកសេចក្ដីពិត និងតែងតែធ្វើតាមចិត្តចង់ ប្រសិនបើអ្នកធ្វើអ្វីដោយខ្ជីខ្ជា ច្បាំងដើម្បីតែកេរ្ដិ៍ឈ្មោះ និងលាភសម្ការៈផ្ទាល់ខ្លួន និងមិនច្បាស់លាស់ក្នុងការដោះស្រាយជាមួយភេទផ្ទុយគ្នា នោះអ្នកនឹងត្រូវរែកពន្ធបន្ទុកនៃបាបរបស់អ្នកផ្ទាល់។ អ្នកគ្មានតម្លៃ សមនឹងទទួលបានការអាណិតអាសូរពីនរណាម្នាក់ឡើយ។ បំណងព្រះហឫទ័យរបស់ខ្ញុំ គឺដើម្បីធ្វើឲ្យអ្នករាល់គ្នា បានគ្រប់លក្ខណ៍ ហើយយ៉ាងហោចណាស់ ត្រូវបានយកឈ្នះ ដើម្បីឲ្យដំណាក់កាលនៃកិច្ចការនេះអាចបញ្ចប់ទៅបានដោយជោគជ័យ។ ព្រះជាម្ចាស់សព្វព្រះហឫទ័យចង់ឲ្យមនុស្សគ្រប់គ្នាបានគ្រប់លក្ខណ៍ ឲ្យទ្រង់ទទួលបានមនុស្សគ្រប់គ្នានៅទីបំផុត ឲ្យមនុស្សគ្រប់គ្នាត្រូវបានសម្អាតដោយសារទ្រង់ និងឲ្យគេក្លាយជាមនុស្សដែលទ្រង់

សព្វព្រះហឫទ័យ។ បញ្ហាវាមិនមែនថា តើខ្ញុំមានព្រះបន្ទូលថាអ្នករាល់គ្នាអន់ថយ ឬក៏មានគុណសម្បត្តិទាបនោះទេ។ នេះគឺជាតថភាពទាំងស្រុង។ ព្រះបន្ទូលរបស់ខ្ញុំបែបនេះ ពុំបញ្ជាក់ថាខ្ញុំចង់បោះបង់អ្នករាល់គ្នាចោល ថាខ្ញុំបានបាត់បង់សេចក្តីសង្ឃឹមចំពោះអ្នករាល់គ្នានោះទេ ក៏មិនមែនថាខ្ញុំមិនអាចសង្គ្រោះអ្នករាល់គ្នាបាននោះដែរ។ សព្វថ្ងៃនេះ ខ្ញុំបានយាងមកបំពេញកិច្ចការនៃសេចក្តីសង្គ្រោះរបស់អ្នករាល់គ្នា ដែលមានន័យថា កិច្ចការដែលខ្ញុំធ្វើ គឺជាការបន្តកិច្ចការនៃសេចក្តីសង្គ្រោះ។ មនុស្សគ្រប់គ្នាមានឱកាសក្នុងការត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍៖ ប្រសិនបើអ្នកសុខចិត្ត ប្រសិនបើអ្នកស្វែងរក នៅទីបំផុតអ្នកនឹងអាចសម្រេចបានលទ្ធផលនេះ ហើយគ្មាននរណាម្នាក់ក្នុងចំណោមអ្នក នឹងត្រូវបោះបង់ចោលឡើយ។ ប្រសិនបើអ្នកមានគុណសម្បត្តិទាប នោះសេចក្តីតម្រូវរបស់ខ្ញុំចំពោះអ្នកនឹងស្របទៅតាមគុណសម្បត្តិអន់ខ្សោយរបស់អ្នកដែរ។ ប្រសិនបើអ្នកមានគុណសម្បត្តិខ្ពស់ នោះសេចក្តីតម្រូវរបស់ខ្ញុំចំពោះអ្នកនឹងស្របទៅតាមគុណសម្បត្តិខ្ពស់របស់អ្នកដែរ។ ប្រសិនបើអ្នកល្ងង់ខ្លៅ និងអវិជ្ជា នោះសេចក្តីតម្រូវរបស់ខ្ញុំចំពោះអ្នកនឹងស្របទៅតាមភាពអវិជ្ជារបស់អ្នក។ ប្រសិនបើអ្នកចេះដឹង នោះសេចក្តីតម្រូវរបស់ខ្ញុំចំពោះអ្នកនឹងស្របទៅតាមការចេះដឹងរបស់អ្នកដែរ។ ប្រសិនបើអ្នកចាស់ទុំ នោះសេចក្តីតម្រូវរបស់ខ្ញុំចំពោះអ្នក នឹងស្របទៅតាមវ័យរបស់អ្នកដែរ។ ប្រសិនបើអ្នកអាចផ្តល់បដិសណ្ឋារកិច្ចបាន នោះសេចក្តីតម្រូវរបស់ខ្ញុំចំពោះអ្នកនឹងស្របទៅតាមសមត្ថភាពនេះដែរ។ ប្រសិនបើអ្នកនិយាយថា អ្នកមិនអាចផ្តល់បដិសណ្ឋារកិច្ចបាន និងអាចបំពេញត្រឹមមុខងារជាក់លាក់ណាមួយ មិនថាវាជាការផ្សាយដំណឹងល្អ ឬមើលថែទាំពួកជំនុំ ឬក៏ចូលរួមក្នុងកិច្ចការទូទៅរបស់អ្នកដទៃនោះទេ ការប្រោសអ្នកឲ្យបានគ្រប់លក្ខណ៍ នឹងស្របទៅតាមមុខងារដែលអ្នកធ្វើ។ ការដែលស្មោះត្រង់ ការដែលស្តាប់បង្គាប់រហូតដល់ទីបញ្ចប់ និងការដែលស្វែងរកដើម្បីមានសេចក្តីស្រឡាញ់ដ៏អស្ចារ្យចំពោះព្រះជាម្ចាស់ ទាំងនេះគឺជាកិច្ចការដែលអ្នកត្រូវសម្រេចឲ្យបាន ហើយពុំមានការអនុវត្តណាដែលល្អប្រសើរជាងកិច្ចការទាំងបីនេះទេ។ ចុងក្រោយ មនុស្សត្រូវតម្រូវឲ្យសម្រេចនូវចំណុចទាំងបីនេះ ហើយប្រសិនបើ

គេអាចសម្រេចកិច្ចការទាំងនេះបាន នោះគេនឹងត្រូវធ្វើឲ្យបានគ្រប់លក្ខណ៍។ ក៏ប៉ុន្តែក្រៅពីនេះ អ្នកត្រូវស្វែងរកដោយពិតប្រាកដ អ្នកត្រូវស្វែងរកសេចក្ដីខាងមុខទៀត និងសេចក្ដីដែលប្រសើរជាងនេះដោយសកម្ម និងមិនត្រូវអកម្មនៅក្នុងកិច្ចការទាំងនេះឡើយ។ ខ្ញុំបានមានព្រះបន្ទូលហើយថា មនុស្សគ្រប់រូបសុទ្ធតែមានឱកាសដើម្បីទទួលបានការប្រោសឲ្យបានគ្រប់លក្ខណ៍ និងមានលទ្ធភាពអាចត្រូវត្រូវបានប្រោសឲ្យបានគ្រប់លក្ខណ៍ ហើយនេះជាការពិត ប៉ុន្តែអ្នកមិនព្យាយាមចង់ធ្វើឲ្យបានល្អនៅក្នុងការស្វែងរករបស់អ្នកផ្ទាល់ឡើយ។ ប្រសិនបើអ្នកមិនសម្រេចនូវលក្ខខណ្ឌទាំងបីនេះទេ នោះនៅទីបំផុត អ្នកនឹងត្រូវផាត់ចោលជាមិនខាន។ ខ្ញុំចង់ឲ្យមនុស្សគ្រប់គ្នាដេញតាមឲ្យទាន់ ខ្ញុំចង់ឲ្យមនុស្សគ្រប់គ្នាមានកិច្ចការ និងការបំភ្លឺពីព្រះវិញ្ញាណបរិសុទ្ធ និងអាចស្ដាប់បង្គាប់បានរហូតដល់ទីបញ្ចប់ ដ្បិតនេះគឺជាភារកិច្ចដែលអ្នករាល់គ្នាគប្បីធ្វើ។ នៅពេលដែលអ្នករាល់គ្នាបានបំពេញភារកិច្ចរបស់អ្នករាល់គ្នាហើយ នោះអ្នករាល់គ្នានឹងត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍ ហើយអ្នកក៏នឹងមាននូវទីបន្ទាល់លាន់ឮកងរំពងផងដែរ។ អស់អ្នកដែលមានទីបន្ទាល់ គឺជាអស់អ្នកដែលបានទទួលជ័យជម្នះលើសាតាំង និងទទួលបានការសន្យារបស់ព្រះជាម្ចាស់ ហើយពួកគេគឺជាមនុស្សដែលនឹងត្រូវបន្តរស់នៅក្នុងទិសដៅដ៏អស្ចារ្យនេះ។

# ព្រះជាម្ចាស់ និងមនុស្សលោក នឹងចូលទៅក្នុងសេចក្ដីសម្រាករួមគ្នា

កាលដើមដំបូងឡើយ ព្រះជាម្ចាស់បានគង់ក្នុងសេចក្ដីសម្រាក។ នៅពេលនោះ ពុំមានមនុស្សលោក ឬអ្វីផ្សេងទៀតនៅលើផែនដីនេះទេ ហើយព្រះជាម្ចាស់ក៏មិនទាន់បានបំពេញកិច្ចការអ្វីនៅឡើយដែរ។ ទ្រង់ទើបតែបានចាប់ផ្ដើមកិច្ចការគ្រប់គ្រងរបស់ទ្រង់ នៅពេលដែលចាប់ផ្ដើមមានមនុស្សជាតិ និងបន្ទាប់ពីមនុស្សជាតិត្រូវបានធ្វើឲ្យពុករលួយប៉ុណ្ណោះ។ ចាប់ពីពេលនោះមក ទ្រង់លែងបានសម្រាកទៀតហើយ តែ

បែរជាចាប់ផ្ដើមរស់ជាមួយមនុស្សជាតិដោយផ្ទាល់ព្រះអង្គទ្រង់វិញ។ នេះគឺដោយសារសេចក្ដីពុករលួយរបស់មនុស្សជាតិ និងដោយសារការបះបោររបស់មហាទេវតានេះហើយ ទើបព្រះជាម្ចាស់បាត់បង់សេចក្ដីសម្រាករបស់ទ្រង់។ ប្រសិនបើព្រះជាម្ចាស់ពុំយកឈ្នះលើសាតាំង និងសង្គ្រោះមនុស្សជាតិដែលបានពុករលួយទេ នោះទ្រង់នឹងមិនអាចយាងចូលទៅក្នុងសេចក្ដីសម្រាកសារជាថ្មីបានឡើយ។ ដោយសារមនុស្សខ្វះនូវសេចក្ដីសម្រាក ដូច្នេះព្រះជាម្ចាស់ក៏ខ្វះនូវសេចក្ដីសម្រាកដែរ ហើយនៅពេលទ្រង់ចូលទៅក្នុងសេចក្ដីសម្រាកម្ដងទៀត នោះមនុស្សលោកក៏នឹងបានសម្រាកម្ដងទៀតដែរ។ ការរស់នៅក្នុងសេចក្ដីសម្រាក សំដៅលើជីវិតមួយដែលគ្មានចម្បាំង គ្មានភាពស្មោកគ្រោក និងគ្មានការតតាំងជាមួយសេចក្ដីទុច្ចរិត។ មានន័យថា ជីវិតនេះ គឺជាជីវិតមួយដែលគ្មានការរំខានពីសាតាំង (ក្នុងន័យនេះ «សាតាំង» សំដៅលើអំណាចសត្រូវ) និងសេចក្ដីពុករលួយរបស់សាតាំង ហើយជីវិតនេះនឹងមិនរងនូវការឈ្លានពានពីអំណាចណាមួយដែលប្រឆាំងទាស់នឹងព្រះជាម្ចាស់ឡើយ។ គឺជាជីវិតមួយដែលគ្រប់សព្វសារពើទាំងអស់ ដើរតាមប្រភេទរៀងៗខ្លួន និងអាចថ្វាយបង្គំព្រះអម្ចាស់ដែលបង្កើតសព្វសារពើបាន ហើយស្ថានសួគ៌និងផែនដី មានសភាពស្ងប់ស្ងាត់ទាំងស្រុង។ នេះគឺជាអត្ថន័យពាក្យថា «ជីវិតស្រាកស្រាន្តរបស់មនុស្ស»។ នៅពេលដែលព្រះជាម្ចាស់សម្រាក សេចក្ដីទុច្ចរិតនឹងលែងមាននៅលើផែនដីនេះទៀតហើយ ហើយក៏លែងមានការឈ្លានពានបន្ថែមទៀតពីអំណាចសត្រូវដែរ ហើយមនុស្សជាតិនឹងចូលទៅក្នុងពិភពថ្មីមួយ គេលែងជាមនុស្សជាតិដែលត្រូវសាតាំងធ្វើឲ្យពុករលួយទៀតហើយ ប៉ុន្តែផ្ទុយទៅវិញ ជាមនុស្សជាតិដែលត្រូវបានសង្គ្រោះក្រោយពីត្រូវបានសាតាំងធ្វើឲ្យពុករលួយ។ ថ្ងៃសម្រាករបស់មនុស្សជាតិ ក៏នឹងក្លាយជាថ្ងៃសម្រាករបស់ព្រះជាម្ចាស់ដែរ។ ព្រះជាម្ចាស់បានបាត់បង់សេចក្ដីសម្រាករបស់ទ្រង់ដោយសារមនុស្សជាតិមិនអាចចូលទៅក្នុងសេចក្ដីសម្រាកបាន មិនមែនដោយសារទ្រង់មិនអាចចូលទៅក្នុងសេចក្ដីសម្រាកបានតាំងពីដើមមកនោះទេ។ ការចូលទៅក្នុងសេចក្ដីសម្រាកពុំមានន័យថា អ្វីគ្រប់សព្វសារពើឈប់កម្រើក ឬឈប់វិវឌ្ឍនោះ

ទេ ហើយវាក៏មិនមានន័យថា ព្រះជាម្ចាស់ឈប់បំពេញកិច្ចការ ឬមានន័យថា មនុស្ស ឈប់រស់នៅដែរ។ ទីសម្គាល់នៃការចូលទៅក្នុងសេចក្ដីសម្រាក គឺនៅពេលដែល សាតាំងត្រូវបានបំផ្លាញ នៅពេលដែលមនុស្សទុច្ចរិតដែលចូលដៃជើងក្នុងការប្រព្រឹត្ត អំពើអាក្រក់របស់វា ត្រូវបានដាក់ទោស និងត្រូវកម្ចាត់ចោល និងនៅពេលដែលគ្រប់ អំណាចទាំងអស់ដែលទទឹងនឹងព្រះជាម្ចាស់លែងកើតមាន។ ព្រះជាម្ចាស់ដែលយាង ចូលទៅក្នុងសេចក្ដីសម្រាក សំដៅលើថា ទ្រង់នឹងលែងបំពេញកិច្ចការរបស់ទ្រង់ ក្នុងសេចក្ដីសង្គ្រោះមនុស្សលោកទៀត។ មនុស្សជាតិចូលទៅក្នុងសេចក្ដីសម្រាក មានន័យថា មនុស្សជាតិទាំងមូលនឹងរស់នៅក្នុងពន្លឺរបស់ព្រះជាម្ចាស់ និងរស់នៅ ក្រោមព្រះពររបស់ទ្រង់ គ្មានសេចក្ដីពុករលួយរបស់សាតាំង ហើយសេចក្ដីទុច្ចរិតក៏នឹង លែងកើតមានទៀត។ ស្ថិតក្រោមការថែទាំរបស់ព្រះជាម្ចាស់ មនុស្សលោកនឹងរស់នៅ តាមធម្មតានៅលើផែនដី។ នៅពេលដែលព្រះជាម្ចាស់ និងមនុស្សជាតិចូលទៅក្នុង សេចក្ដីសម្រាករួមគ្នា មានន័យថា មនុស្សជាតិត្រូវបានសង្គ្រោះ ហើយសាតាំងត្រូវបាន បំផ្លាញ ហើយកិច្ចការរបស់ព្រះជាម្ចាស់ចំពោះមនុស្ស គឺមានលក្ខណៈពេញលេញ ទាំងស្រុង។ ព្រះជាម្ចាស់នឹងលែងបន្តបំពេញកិច្ចការចំពោះមនុស្សលោក ហើយពួកគេ នឹងលែងរស់នៅក្រោមដែនត្រួតត្រារបស់សាតាំងទៀត។ ដូច្នេះ ព្រះជាម្ចាស់នឹងលែង ជាប់រវល់ទៀត ហើយមនុស្សនឹងលែងត្រូវដើរតតឈប់ទៀតហើយ។ ព្រះជាម្ចាស់និង មនុស្សជាតិ នឹងចូលទៅក្នុងសេចក្ដីសម្រាកក្នុងពេលជាមួយគ្នា។ ព្រះជាម្ចាស់នឹង ត្រឡប់ទៅកាន់កន្លែងដើមរបស់ទ្រង់វិញ ហើយមនុស្សម្នាក់ៗនឹងត្រូវត្រឡប់ទៅកន្លែង របស់គេរៀងៗខ្លួនវិញ។ ទាំងអស់នេះ គឺជាទិសដៅដែលព្រះជាម្ចាស់និងមនុស្សលោក នឹងត្រូវរស់នៅ នៅពេលការគ្រប់គ្រងទាំងស្រុងរបស់ព្រះជាម្ចាស់ត្រូវបានបញ្ចប់។ ព្រះជាម្ចាស់មានទិសដៅរបស់ទ្រង់ ហើយមនុស្សជាតិមានទិសដៅរបស់មនុស្សជាតិ។ នៅពេលកំពុងសម្រាក ព្រះជាម្ចាស់នឹងបន្តដឹកនាំមនុស្សលោកទាំងអស់នៅក្នុងជីវិត រស់នៅរបស់ពួកគេនៅលើផែនដី ហើយនៅពេលស្ថិតក្នុងពន្លឺរបស់ទ្រង់ពួកគេនឹង ថ្វាយបង្គំព្រះជាម្ចាស់ដ៏ពិតតែមួយអង្គគត់នៅលើស្ថានសួគ៌។ ព្រះជាម្ចាស់នឹងលែង

រស់នៅក្នុងចំណោមមនុស្សលោក ហើយមនុស្សលោកក៏នឹងលែងអាចរស់នៅជាមួយព្រះជាម្ចាស់នៅក្នុងទិសដៅរបស់ទ្រង់ទៀតបានដែរ។ ព្រះជាម្ចាស់និងមនុស្សលោក មិនអាចរស់នៅក្នុងពិភពដូចគ្នាបានទេ ក៏ប៉ុន្តែទាំងព្រះជាម្ចាស់និងមនុស្សលោក មានលក្ខណៈនៃការរស់នៅរៀងៗខ្លួន។ ព្រះជាម្ចាស់ គឺជាព្រះដែលដឹកនាំមនុស្សជាតិទាំងអស់ ហើយគ្រប់មនុស្សជាតិទាំងអស់ គឺជាការបង្ហាញឲ្យឃើញច្បាស់អំពីកិច្ចការគ្រប់គ្រងរបស់ព្រះជាម្ចាស់។ មនុស្សលោក គឺជាមនុស្សដែលត្រូវព្រះជាម្ចាស់ដឹកនាំ និងគ្មានសារជាតិដូចព្រះជាម្ចាស់ឡើយ។ «សម្រាក» មានន័យថា ត្រឡប់ទៅកាន់កន្លែងដើមរៀងៗខ្លួនវិញ។ ហេតុនេះ នៅពេលដែលព្រះជាម្ចាស់យាងចូលទៅក្នុងសេចក្ដីសម្រាក មានន័យថា ទ្រង់បានយាងត្រឡប់ទៅកាន់កន្លែងដើមរបស់ទ្រង់វិញហើយ។ ទ្រង់នឹងលែងរស់នៅលើផែនដីនេះ ឬគង់ក្នុងចំណោមមនុស្សជាតិ ដើម្បីរួមចំណែកក្នុងភាពសប្បាយរីករាយ និងទុក្ខសោករបស់ពួកគេទៀតហើយ។ នៅពេលដែលមនុស្សចូលទៅក្នុងសេចក្ដីសម្រាក មានន័យថា ពួកគេបានក្លាយជារបស់ពិតប្រាកដនៃការបង្កើតសព្វសារពើមក។ ពួកគេនឹងថ្វាយបង្គំព្រះជាម្ចាស់ពីផែនដីនេះ និងរស់នៅក្នុងជីវិតជាមនុស្សសាមញ្ញធម្មតា។ មនុស្សនឹងលែងរឹងចចេសនឹងព្រះជាម្ចាស់ ឬលែងប្រឆាំងនឹងទ្រង់ទៀតហើយ ហើយគេនឹងត្រូវត្រឡប់ទៅកាន់ជីវិតដើមរបស់អ័ដាម និងអេវ៉ាវិញ។ ទាំងអស់នេះ នឹងក្លាយជាជីវិត និងជាទិសដៅរៀងៗខ្លួនរបស់ព្រះជាម្ចាស់និងមនុស្សលោក បន្ទាប់ពីព្រះជាម្ចាស់និងមនុស្សលោកចូលទៅក្នុងសេចក្ដីសម្រាក។ ការបរាជ័យរបស់សាតាំង គឺជារឿងដែលមិនអាចគេចផុតបាន នៅក្នុងសង្គ្រាមរវាងសាតាំងនឹងព្រះជាម្ចាស់។ ដូច្នេះ ការចូលទៅក្នុងសេចក្ដីសម្រាករបស់ព្រះជាម្ចាស់ ក្រោយពីបញ្ចប់កិច្ចការគ្រប់គ្រងរបស់ទ្រង់ និងបញ្ចប់ការសង្គ្រោះមនុស្សជាតិទាំងស្រុង រួចចូលទៅក្នុងសេចក្ដីសម្រាក ក៏បានក្លាយជារឿងដែលមិនអាចគេចផុតដូចគ្នាដែរ។ កន្លែងសម្រាករបស់មនុស្សជាតិគឺនៅលើផែនដី ហើយកន្លែងសម្រាករបស់ព្រះជាម្ចាស់ គឺនៅឯស្ថានសួគ៌។ ពេលមនុស្សលោកថ្វាយបង្គំព្រះជាម្ចាស់ក្នុងសេចក្ដីសម្រាក ពួកគេនឹងរស់នៅលើផែនដីនេះ ហើយ

ពេលព្រះជាម្ចាស់ដឹកនាំមនុស្សជាតិ ដែលនៅសេសសល់ក្នុងសេចក្ដីសម្រាក ទ្រង់នឹងដឹកនាំពួកគេពីស្ថានសួគ៌ មិនមែនពីផែនដីឡើយ។ ព្រះជាម្ចាស់នឹងនៅតែជាព្រះវិញ្ញាណដដែល ចំណែកមនុស្សនឹងនៅតែជាសាច់ឈាមដដែល។ ព្រះជាម្ចាស់ និងមនុស្សលោក សម្រាកក្នុងលក្ខណៈខុសគ្នា។ នៅពេលដែលព្រះជាម្ចាស់សម្រាក ទ្រង់នឹងយាងយក ហើយលេចឡើងក្នុងចំណោមមនុស្សលោក។ នៅពេលដែលមនុស្សលោកសម្រាក ព្រះជាម្ចាស់នឹងដឹកនាំពួកគេទៅលេងស្ថានសួគ៌ក៏ដូចជាទៅត្រើកអរ សប្បាយនឹងជីវិតនៅទីនោះផងដែរ។ បន្ទាប់ពីព្រះជាម្ចាស់ និងមនុស្សជាតិចូលទៅក្នុងសេចក្ដីសម្រាក សាតាំងនឹងលែងកើតមានទៀតហើយ។ ដូចគ្នានេះដែរ មនុស្សទុច្ចរិតទាំងនោះ ក៏នឹងលែងមានវត្តមាននៅលើផែនដីនេះទៀតដែរ។ នៅមុនពេលដែលព្រះជាម្ចាស់ និងមនុស្សជាតិសម្រាក មនុស្សទុច្ចរិតដែលធ្លាប់បានបៀតបៀនព្រះជាម្ចាស់នៅលើផែនដី ក៏ដូចជាសត្រូវដែលរឹងចចេសនឹងទ្រង់នៅលើផែនដីនេះ នឹងត្រូវបានបំផ្លាញរួចជាស្រេចហើយ។ ពួកគេនឹងត្រូវកម្ទាត់ចោលដោយគ្រោះមហន្តរាយយ៉ាងធំក្រៃលែងនៅគ្រាចុងក្រោយ។ នៅពេលដែលមនុស្សទុច្ចរិតទាំងនោះត្រូវវិនាសសាបសូន្យទាំងស្រុង ផែនដីនឹងលែងស្គាល់នូវការយាយីរបស់សាតាំងជាថ្មីទៀតហើយ។ ទាល់តែពេលនោះ ទើបមនុស្សជាតិនឹងទទួលបាននូវសេចក្ដីសង្គ្រោះទាំងស្រុង ហើយកិច្ចការរបស់ព្រះជាម្ចាស់ ក៏នឹងត្រូវបញ្ចប់ដោយទាំងស្រុងផងដែរ។ ទាំងនេះ គឺជាលក្ខខណ្ឌតម្រូវទុកមុន សម្រាប់ឲ្យព្រះជាម្ចាស់ និងមនុស្សជាតិ ចូលទៅក្នុងសេចក្ដីសម្រាក។

ការខិតចូលទៅរកទីបញ្ចប់នៃគ្រប់សារពើទាំងអស់ បង្ហាញពីការបង្ហើយកិច្ចការរបស់ព្រះជាម្ចាស់ ក៏ដូចជាទីបញ្ចប់នៃការវិវឌ្ឍរបស់មនុស្សជាតិដែរ។ នេះមានន័យថា មនុស្សដែលត្រូវសាតាំងធ្វើឲ្យខូចអាក្រក់ នឹងបានឈានចូលដល់ដំណាក់កាលវិវឌ្ឍចុងក្រោយបង្អស់របស់ពួកគេ ហើយកូនចៅរបស់អ័ដាម និងអេវ៉ា នឹងត្រូវបានបញ្ចប់ការបន្តពូជពង្សរបស់ពួកគេដែរ។ វាក៏មានន័យថា មនុស្សជាតិដែលត្រូវបានសាតាំងធ្វើឲ្យពុករលួយបែបនេះ នឹងមិនអាចបន្តការវិវឌ្ឍទៅមុខទៀតបានឡើយ។ កាល

ដើមដំបូងឡើយ អ័ដាមនិងអេវ៉ា មិនត្រូវបានធ្វើឲ្យពុករលួយនោះទេ ប៉ុន្ដែអ័ដាមនិងអេវ៉ា ដែលត្រូវបណ្ដេញចេញពីសួនច្បារអេដែន ត្រូវបានសាតាំងធ្វើឲ្យពុករលួយ។ នៅពេលដែលព្រះជាម្ចាស់និងមនុស្សលោក ចូលទៅក្នុងសេចក្ដីសម្រាករួមគ្នា ចុងក្រោយ អ័ដាមនិងអេវ៉ា (ដែលត្រូវបានបណ្ដេញចេញសួនច្បារអេដែន) និងកូនចៅរបស់ពួកគេ នឹងចូលមកដល់ទីបញ្ចប់។ មនុស្សជាតិនាថ្ងៃអនាគត នឹងនៅតែមានកូនចៅរបស់អ័ដាមនិងអេវ៉ាដដែល ប៉ុន្ដែពួកគេនឹងមិនមែនជាមនុស្សដែលរស់នៅក្រោមដែនត្រួតត្រា របស់សាតាំងទៀតឡើយ។ ផ្ទុយទៅវិញ ពួកគេនឹងក្លាយជាមនុស្សដែលត្រូវបានសង្គ្រោះ និងបន្សុទ្ធវិញ។ គេនឹងក្លាយជាមនុស្សជាតិ ដែលត្រូវបានជំនុំជម្រះ និងវាយផ្ចាល ហើយជាមនុស្សដែលបរិសុទ្ធ។ មនុស្សទាំងអស់នេះនឹងមិនមែនជាអំបូរមនុស្ស ដូចកាលពីដើមដំបូងឡើយ។ សឹងតែអាចនិយាយបានថា ពួកគេនឹងខុសគ្នាទាំងស្រុង ពីប្រភេទមនុស្សជាតិនៃអំបូររបស់អ័ដាម និងអេវ៉ាកាលពីដើមដំបូង។ មនុស្សទាំងនេះ នឹងត្រូវបានជ្រើសរើសចេញពីក្នុងចំណោមអ្នកដែលត្រូវបានសាតាំងធ្វើឲ្យពុករលួយ ហើយពួកគេនឹងក្លាយជាមនុស្សដែលឈរមាំដល់ទីបញ្ចប់ ក្នុងអំឡុងពេលនៃការជំនុំជម្រះ និងការវាយផ្ចាលរបស់ព្រះជាម្ចាស់។ ពួកគេនឹងក្លាយជាក្រុមមនុស្សដែលនៅសេសសល់ចុងក្រោយគេបង្អស់ ក្នុងចំណោមមនុស្សជាតិដែលពុករលួយ។ មានតែមនុស្សទាំងនេះទេ ដែលនឹងអាចចូលទៅក្នុងសេចក្ដីសម្រាក នៅពេលចុងក្រោយជាមួយព្រះជាម្ចាស់។ អ្នកណាដែលអាចឈរមាំដល់ទីបញ្ចប់ក្នុងអំឡុងពេលនៃកិច្ចការជំនុំជម្រះ និងកិច្ចការនៃការវាយផ្ចាលរបស់ព្រះជាម្ចាស់ ក្នុងអំឡុងគ្រាចុងក្រោយ ពោលគឺ ក្នុងអំឡុងកិច្ចការនៃការបន្សុទ្ធលើកចុងក្រោយ នឹងក្លាយជាមនុស្សដែលនឹងត្រូវចូលទៅក្នុងសេចក្ដីសម្រាកចុងក្រោយជាមួយព្រះជាម្ចាស់។ ដូច្នេះ អ្នកណាដែលចូលទៅក្នុងសេចក្ដីសម្រាក នឹងត្រូវផ្ដាច់ចេញពីឥទ្ធិពលរបស់សាតាំង ហើយត្រូវព្រះជាម្ចាស់ទទួលយក បន្ទាប់ពីបានឆ្លងកាត់កិច្ចការនៃការបន្សុទ្ធលើកចុងក្រោយរបស់ទ្រង់។ មនុស្សលោកទាំងអស់នេះ ដែលចុងក្រោយត្រូវព្រះជាម្ចាស់ទទួលយកនោះ នឹងចូលទៅក្នុងសេចក្ដីសម្រាក

ចុងក្រោយ។ គោលបំណងនៃកិច្ចការវាយផ្ចាល និងកិច្ចការជំនុំជម្រះរបស់ព្រះជាម្ចាស់ គឺមានន័យសំខាន់ដើម្បីបន្សុទ្ធមនុស្សជាតិ ដើម្បីជាប្រយោជន៍នៃការសម្រាកនៅទីចុងបំផុត។ គ្មានមនុស្សជាតិណាម្នាក់អាចត្រូវបានចាត់ថ្នាក់ទៅតាមប្រភេទខុសៗគ្នា ឬចូលទៅក្នុងសេចក្ដីសម្រាក ដោយគ្មានការសម្អាតឲ្យបានស្អាតបែបនេះបានឡើយ។ កិច្ចការនេះ គឺជាផ្លូវតែមួយគត់ សម្រាប់ឲ្យមនុស្សជាតិចូលទៅក្នុងសេចក្ដីសម្រាកបាន។ មានតែកិច្ចការនៃការបន្សុទ្ធរបស់ព្រះជាម្ចាស់ប៉ុណ្ណោះ ទើបបន្សុទ្ធសេចក្ដីទុច្ចរិតរបស់មនុស្សលោកឲ្យបានស្អាត ហើយមានតែកិច្ចការនៃការវាយផ្ចាល និងកិច្ចការការជំនុំជម្រះរបស់ទ្រង់ប៉ុណ្ណោះ ទើបនាំពន្លឺទៅដល់មនុស្សជាតិដែលមានចរិតរឹងចចេសបាន ដោយញែកអ្នកដែលអាចត្រូវបានសង្គ្រោះ ចេញពីអ្នកដែលមិនអាចត្រូវបានសង្គ្រោះ ហើយញែកអ្នកដែលនឹងត្រូវបន្តរស់នៅ ចេញពីអ្នកដែលនឹងមិនត្រូវបន្តរស់នៅ។ នៅពេលដែលកិច្ចការនេះត្រូវបានបញ្ចប់ អស់អ្នកណាដែលត្រូវអនុញ្ញាតឲ្យបន្តរស់នៅ នឹងត្រូវបន្សុទ្ធ និងចូលទៅក្នុងសភាពកាន់តែឧត្ដុង្គឧត្ដមរបស់មនុស្សជាតិ ដែលឲ្យពួកគេត្រេកអរសប្បាយនឹងជីវិតទីពីរដ៏អស្ចារ្យរបស់មនុស្សលោក នៅលើផែនដីនេះ។ និយាយឲ្យចំទៅ ពួកគេនឹងចាប់ផ្ដើមថ្ងៃសម្រាករបស់មនុស្សលោក និងរស់នៅព្រមគ្នាជាមួយព្រះជាម្ចាស់។ ក្រោយពេលដែលអស់អ្នកដែលមិនត្រូវអនុញ្ញាតឲ្យបន្តរស់នៅ ត្រូវបានវាយផ្ចាល និងជំនុំជម្រះរួច ចរិតពិតប្រាកដរបស់ពួកគេនឹងត្រូវបង្ហាញឲ្យឃើញទាំងស្រុង ក្រោយពីនោះមក ពួកគេនឹងត្រូវបំផ្លាញចោល ហើយពួកគេនឹងលែងទទួលបានការអនុញ្ញាតឲ្យរស់នៅលើផែនដីនេះតទៅទៀត ដូចសាតាំងដែរ។ មនុស្សជាតិនាពេលអនាគត នឹងលែងរាប់បញ្ចូលមនុស្សប្រភេទនេះទៀតហើយ។ មនុស្សបែបនេះ មិនស័ក្ដិសមចូលទៅក្នុងទឹកដីនៃសេចក្ដីសម្រាកចុងក្រោយឡើយ ហើយពួកគេក៏មិនស័ក្ដិសម នឹងមានថ្ងៃសម្រាកដែលព្រះជាម្ចាស់ និងមនុស្សជាតិត្រូវមានរួមគ្នាដែរ ដ្បិតពួកគេជាគោលដៅនៃការដាក់ទោស និងជាមនុស្សអាក្រក់មនុស្សទុច្ចរិត។ ពួកគេត្រូវបានប្រោសលោះម្ដងរួចមកហើយ ហើយពួកគេក៏ធ្លាប់ត្រូវបានជំនុំជម្រះ និងវាយផ្ចាលរួចផងដែរ។ ពួកគេក៏ធ្លាប់បានបម្រើព្រះជាម្ចាស់ពីមុន

មកទៀតផង។ ក៏ប៉ុន្តែ នៅពេលដែលគ្រាចុងក្រោយបានចូលមកដល់ ពួកគេនឹងត្រូវផាត់ចោល និងបំផ្លាញចោល ដោយសារសេចក្ដីអាក្រក់ និងចរិតរឹងចចេសរបស់ពួកគេ និងដោយសារពួកគេគ្មានសមត្ថភាពទទួលបាននូវការប្រោសលោះ។ ពួកគេនឹងលែងអាចមកចាប់ជាតិជាថ្មី នៅក្នុងពិភពលោកនាពេលអនាគត ហើយនឹងលែងបានរស់នៅក្នុងចំណោមអំបូរមនុស្សនាពេលអនាគតទៀតហើយ។ អ្នកប្រព្រឹត្តអាក្រក់ទាំងអស់ និងអស់អ្នកណាដែលមិនត្រូវបានសង្គ្រោះនឹងត្រូវបំផ្លាញចោល នៅពេលដែលពួកបរិសុទ្ធនៅក្នុងចំណោមមនុស្សលោក បានចូលទៅក្នុងសេចក្ដីសម្រាក ទោះបីពួកគេជាវិញ្ញាណរបស់មនុស្សស្លាប់ ឬជាមនុស្សដែលកំពុងរស់នៅជាសាច់ឈាមនៅឡើយក៏ដោយ។ និយាយពីវិញ្ញាណអាក្រក់ និងមនុស្សលោកដែលប្រព្រឹត្តអំពើអាក្រក់ ឬវិញ្ញាណនៃមនុស្សសុចរិត និងមនុស្សដែលប្រព្រឹត្តអំពើសុចរិត មិនថាពួកគេរស់នៅក្នុងយុគសម័យណានោះទេ អ្នកណាដែលប្រព្រឹត្តអាក្រក់ ចុងក្រោយនឹងត្រូវបំផ្លាញចោល ហើយអ្នកណាដែលសុចរិតនឹងនៅរស់រាន។ បុគ្គលម្នាក់ ឬវិញ្ញាណមួយ អាចនឹងទទួលបាននូវសេចក្ដីសង្គ្រោះ ឬអត់នោះ គឺមិនមែនសម្រេចទាំងស្រុងលើមូលដ្ឋាននៃកិច្ចការនៅយុគសម័យចុងក្រោយឡើយ។ ផ្ទុយទៅវិញ គឺត្រូវកំណត់ត្រង់ថា តើពួកគេបានប្រឆាំង ឬធ្លាប់រឹងចចេសដាក់ព្រះជាម្ចាស់ដែរឬអត់។ មនុស្សកាលពីសម័យមុន ដែលបានប្រព្រឹត្តអំពើបាប និងមិនអាចទទួលបាននូវសេចក្ដីសង្គ្រោះ នឹងក្លាយជាគោលដៅនៃការដាក់ទោសច្បាស់ណាស់ ហើយមនុស្សនៅក្នុងសម័យបច្ចុប្បន្ន ដែលប្រព្រឹត្តអាក្រក់ និងមិនអាចទទួលបានការសង្គ្រោះ ក៏នឹងក្លាយជាគោលដៅនៃការដាក់ទោសយ៉ាងប្រាកដដែរ។ មនុស្សលោកត្រូវបានបែងចែកប្រភេទទៅតាមមូលដ្ឋាននៃអំពើល្អ និងអាក្រក់ មិនមែនទៅតាមសម័យកាលដែលពួកគេរស់នៅឡើយ។ នៅពេលណាដែលពួកគេត្រូវបានចាត់ថ្នាក់ក្នុងលក្ខណៈនេះរួចហើយ ពួកគេនឹងមិនត្រូវដាក់ទោស ឬប្រទានរង្វាន់ភ្លាមៗនោះទេ។ ផ្ទុយទៅវិញ ព្រះជាម្ចាស់នឹងគ្រាន់តែបំពេញកិច្ចការរបស់ទ្រង់ក្នុងការដាក់ទោសអំពើអាក្រក់ និងប្រទានរង្វាន់ដល់អំពើល្អ បន្ទាប់ពីទ្រង់បានបញ្ចប់ការបំពេញកិច្ចការនៃការបង្រ្កាបរបស់ទ្រង់នៅគ្រាចុងក្រោយប៉ុណ្ណោះ។

តាមពិត ទ្រង់បានញែកមនុស្សជាល្អនិងអាក្រក់ តាំងពីទ្រង់បានចាប់ផ្ដើមបំពេញកិច្ចការរបស់ទ្រង់អំពីការសង្គ្រោះមនុស្សលោកមកម្ល៉េះ។ គ្រាន់តែថា ទ្រង់នឹងប្រទានរង្វាន់ដល់មនុស្សសុចរិត និងដាក់ទោសចំពោះមនុស្សទុច្ចរិត នៅពេលដែលកិច្ចការរបស់ទ្រង់បានឈានដល់ទីបញ្ចប់ប៉ុណ្ណោះ។ គ្រាន់តែមិនមែនថា ទ្រង់នឹងញែកពួកគេទៅតាមប្រភេទ នៅពេលបញ្ចប់កិច្ចការរបស់ទ្រង់ ហើយបន្ទាប់មក ចាប់ផ្ដើមកិច្ចការនៃការដាក់ទោសមនុស្សអាក្រក់ និងប្រទានរង្វាន់ដល់មនុស្សល្អភ្លាមៗប៉ុណ្ណោះ។ ផ្ទុយទៅវិញ កិច្ចការនេះនឹងត្រូវសម្រេចបាន លុះត្រាតែកិច្ចការរបស់ទ្រង់ត្រូវបានបញ្ចប់ទាំងស្រុងប៉ុណ្ណោះ។ គោលបំណងទាំងស្រុងនៃកិច្ចការចុងក្រោយរបស់ព្រះជាម្ចាស់ក្នុងការដាក់ទោសលើមនុស្សអាក្រក់ និងប្រទានរង្វាន់ដល់មនុស្សល្អ គឺដើម្បីបន្សុទ្ធមនុស្សលោកទាំងអស់ឲ្យបានបរិសុទ្ធម៉ត់ហ្មង ដើម្បីឲ្យទ្រង់អាចនាំមនុស្សជាតិដែលបរិសុទ្ធម៉ត់ហ្មងនេះ ទៅក្នុងសេចក្ដីសម្រាកដ៏អស់កល្បជានិច្ច។ ដំណាក់កាលនៃកិច្ចការរបស់ទ្រង់នេះ មានសារៈសំខាន់ខ្លាំងបំផុត។ វាគឺជាដំណាក់កាលចុងក្រោយនៃកិច្ចការគ្រប់គ្រងទាំងស្រុងរបស់ព្រះជាម្ចាស់។ ប្រសិនបើព្រះជាម្ចាស់មិនបានបំផ្លាញមនុស្សទុច្ចរិត តែបែរជាអនុញ្ញាតឲ្យពួកគេបន្តរស់នៅវិញ នោះមនុស្សលោកទាំងមូលនឹងនៅតែមិនអាចចូលទៅក្នុងសេចក្ដីសម្រាកបានដដែល ហើយព្រះជាម្ចាស់នឹងមិនអាចនាំមនុស្សជាតិ ទៅក្នុងពិភពមួយដែលល្អប្រសើរជាងនេះបានឡើយ។ កិច្ចការបែបនេះ នឹងមិនអាចបង្ហើយបានឡើយ។ នៅពេលដែលកិច្ចការរបស់ទ្រង់ត្រូវបានបញ្ចប់ មនុស្សជាតិទាំងមូលនឹងក្លាយជាបរិសុទ្ធទាំងស្រុង។ ទាល់តែបែបនេះ ទើបព្រះជាម្ចាស់អាចគង់ក្នុងសេចក្ដីសម្រាកបានដោយស្ងប់ព្រះទ័យ។

បច្ចុប្បន្ននេះ មនុស្សនៅតែមិនអាចដោះលែងអ្វីគ្រប់យ៉ាងខាងសាច់ឈាមបានដដែល។ ពួកគេមិនអាចលះបង់ ការសប្បាយខាងសាច់ឈាម ខាងលោកិយ ប្រាក់កាស ឬនិស្ស័យពុករលួយរបស់ពួកគេបានឡើយ។ មនុស្សភាគច្រើនបន្តការព្យាយាមឲ្យបានរបស់ពួកគេក្នុងលក្ខណៈច្បោលៗ មិនប្រាកដប្រជា។ តាមពិតមនុស្សទាំងអស់នេះ មិនបានយកព្រះជាម្ចាស់ដាក់ក្នុងចិត្តរបស់ពួកគេឡើយ ហើយពួកគេថែមទាំង

មិនកោតខ្លាចព្រះជាម្ចាស់ទៀតផង។ ពួកគេគ្មានព្រះជាម្ចាស់នៅក្នុងចិត្តរបស់ពួកគេឡើយ ហេតុដូច្នេះ ពួកគេមិនអាចយល់ពីអ្វីដែលព្រះជាម្ចាស់ធ្វើឡើយ ពួកគេកាន់តែគ្មានសមត្ថភាពជឿលើព្រះបន្ទូលដែលទ្រង់មានព្រះសូរសៀងមកថែមទៀតហើយ។ មនុស្សបែបនេះ ជាប់ជំពាក់ខាងសាច់ឈាមយ៉ាងក្រាស់ក្រែល។ ពួកគេត្រូវបានធ្វើឲ្យពុករលួយដល់ឆ្អឹង និងគ្មានសេចក្ដីពិតអ្វីបន្តិចសោះ។ លើសពីនេះ ពួកគេមិនជឿថា ព្រះជាម្ចាស់អាចត្រឡប់មកជាសាច់ឈាមបានឡើយ។ អ្នកណាដែលមិនជឿលើព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស ពោលគឺអ្នកណា ដែលមិនជឿលើព្រះជាម្ចាស់ដែលអាចមើលឃើញ ឬមិនជឿលើកិច្ចការនិងព្រះបន្ទូលរបស់ទ្រង់ តែបែរជាថ្វាយបង្គំព្រះជាម្ចាស់នៅឯស្ថានសួគ៌ដែលមើលពុំឃើញវិញ គឺជាមនុស្សម្នាក់ដែលមិនមានព្រះជាម្ចាស់នៅក្នុងដួងចិត្តរបស់ពួកគេឡើយ។ មនុស្សបែបនេះ គឺជាពួកបះបោរ ហើយទទឹងទាស់នឹងព្រះជាម្ចាស់។ ពួកគេខ្វះភាពជាមនុស្ស និងខ្វះហេតុផល ពោលគឺគ្មានសេចក្ដីពិតសោះ។ ជាងនេះទៅទៀត ចំពោះមនុស្សទាំងអស់នេះ កាលណាព្រះជាម្ចាស់កាន់តែអាចមើលឃើញ និងកាន់តែរូបី ពួកគេនឹងកាន់តែលែងជឿ ហើយពួកគេចាត់ទុកព្រះជាម្ចាស់ដែលមិនអាចមើលឃើញ និងអរូបី ជាព្រះដែលគួរទុកចិត្ត និងគួរត្រេកអរខ្លាំងបំផុត។ អ្វីដែលពួកគេស្វែងរក គឺមិនមែនជាសេចក្ដីពិតជាក់ស្ដែងនោះទេ ក៏មិនមែនជាសារជាតិនៃជីវិតពិតប្រាកដដែរ ហើយរឹតតែមិនមែនជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់នោះដែរ។ ផ្ទុយទៅវិញ ពួកគេស្វែងរកសេចក្ដីសប្បាយរីករាយ។ មិនចាំបាច់ឆ្ងល់នោះទេ អ្វីដែលពួកគេជឿ និងអ្វីដែលពួកគេស្វែងរក គឺជាអ្វីដែលអាចបំពេញតាមចំណង់ចិត្តផ្ទាល់ខ្លួនរបស់ពួកគេបាន។ ពួកគេជឿលើព្រះជាម្ចាស់ គឺគ្រាន់តែដើម្បីបំពេញចំណង់ចិត្តផ្ទាល់ខ្លួនរបស់ពួកគេឲ្យស្កប់ស្កល់តែប៉ុណ្ណោះ មិនមែនដើម្បីស្វែងរកសេចក្ដីពិតឡើយ។ តើមនុស្សបែបនេះ មិនមែនជាអ្នកប្រព្រឹត្តអាក្រក់ទេឬអី? ពួកគេទុកចិត្តលើខ្លួនឯងជាខ្លាំង ហើយពួកគេមិនជឿថា ព្រះជាម្ចាស់ដែលគង់នៅឯស្ថានសួគ៌ នឹងបំផ្លាញ «មនុស្សល្អ» ដូចជាពួកគេនេះទាល់តែសោះ។ ផ្ទុយទៅវិញ ពួកគេជឿថា ព្រះជាម្ចាស់នឹង

អនុញ្ញាតឲ្យពួកគេបន្តរស់នៅ ហើយនឹងប្រទានរង្វាន់ដល់ពួកគេឲ្យបានស័ក្ដិសមថែមទៀត ដ្បិតពួកគេបានធ្វើរឿងជាច្រើនថ្វាយព្រះជាម្ចាស់ និងបានបង្ហាញនូវ «ភាពស្មោះត្រង់» យ៉ាងច្រើនចំពោះទ្រង់។ ប្រសិនបើពួកគេត្រូវស្វែងរកព្រះជាម្ចាស់ដែលអាចមើលឃើញ នៅពេលណាដែលបំណងចិត្តរបស់ពួកគេមិនត្រូវបានបំពេញតាម ពួកគេនឹងវាយបកមកព្រះជាម្ចាស់វិញ ឬចាប់ផ្ដើមខឹងសម្បារភ្លាមៗតែម្ដង។ ពួកគេបង្ហាញថា ខ្លួនឯងជាមនុស្សទុរយសថោកទាប ដែលព្យាយាមផ្គាប់តែបំណងចិត្តរបស់ខ្លួនឯងប៉ុណ្ណោះ។ ពួកគេមិនមែនជាមនុស្សដែលមានសេចក្ដីស្មោះត្រង់ក្នុងការព្យាយាមឲ្យបានសេចក្ដីពិតនោះឡើយ។ មនុស្សបែបនេះត្រូវបានហៅថា មនុស្សទុច្ចរិតដែលដើរតាមព្រះគ្រីស្ទ។ អស់អ្នកណាដែលមិនស្វែងរកសេចក្ដីពិត គេមិនអាចជឿលើសេចក្ដីពិតបានឡើយ ហើយក៏មិនអាចសម្រេចបាននូវលទ្ធផលនាពេលអនាគតរបស់មនុស្សជាតិបានដែរ ដ្បិតពួកគេមិនជឿលើកិច្ចការ និងព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលអាចមើលឃើញឡើយ ហើយសេចក្ដីនេះរាប់បញ្ចូលទាំងការមិនជឿលើទិសដៅអនាគតរបស់មនុស្សជាតិដែរ។ ហេតុនេះ បើទោះបីជាពួកគេដើរតាមព្រះជាម្ចាស់ដែលអាចមើលឃើញក្ដី ក៏ពួកគេនៅតែបន្តប្រព្រឹត្តអំពើអាក្រក់ និងមិនបានស្វែងរកសេចក្ដីពិតសោះឡើយ ហើយពួកគេ ក៏មិនបានអនុវត្តនូវសេចក្ដីពិតដែលខ្ញុំចង់បានដែរ។ ផ្ទុយទៅវិញ មនុស្សទាំងអស់នោះដែលមិនជឿថា ពួកគេនឹងត្រូវបំផ្លាញ នឹងក្លាយជាមនុស្សដែលនឹងត្រូវបំផ្លាញចោលវិញ។ ពួកគេគ្រប់គ្នាសុទ្ធតែជឿថា ខ្លួនគេជាមនុស្សឈ្លាសវៃណាស់ ហើយពួកគេគិតថា ពួកគេនោះជាមនុស្សដែលអនុវត្តសេចក្ដីពិត។ ពួកគេចាត់ទុកការប្រព្រឹត្តអាក្រក់របស់ខ្លួនជាសេចក្ដីពិត ហើយអរសប្បាយនឹងអំពើនោះ។ មនុស្សទុច្ចរិតបែបនេះ គឺជាមនុស្សដែលជឿជាក់លើខ្លួនឯងខ្លាំងបំផុត។ ពួកគេចាត់ទុកសេចក្ដីពិតជាគោលលទ្ធិ និងចាត់ទុកទង្វើអាក្រក់របស់ខ្លួនជាសេចក្ដីពិត ប៉ុន្តែចុងបញ្ចប់ទៅ ពួកគេបានត្រឹមតែច្រូតផលនៃទង្វើដែលពួកគេបានសាបព្រោះប៉ុណ្ណោះ។ នៅពេលណាដែលមនុស្សកាន់តែមានទំនុកចិត្តខ្លាំងលើខ្លួនឯង ហើយនៅពេលដែលពួកគេកាន់តែក្រអឺតក្រទមខ្លាំង ពួកគេ

នឹងកាន់តែមិនអាចទទួលបាននូវសេចក្ដីពិត។ នៅពេលណា ដែលមនុស្សកាន់តែជឿលើព្រះជាម្ចាស់ដែលគង់នៅស្ថានសួគ៌ នោះពួកគេនឹងកាន់តែប្រឆាំងទាស់នឹងព្រះជាម្ចាស់។ មនុស្សទាំងអស់នេះ គឺជាមនុស្សដែលនឹងត្រូវដាក់ទោស។ នៅមុនពេលដែលមនុស្សជាតិចូលទៅក្នុងសេចក្ដីសម្រាក ទោះបីជាជំពូកបុគ្គលនីមួយៗត្រូវទទួលទោសឬត្រូវទទួលរង្វាន់ នឹងត្រូវកំណត់លើលក្ខណៈថា តើពួកគេបានស្វែងរកសេចក្ដីពិតដែរឬអត់ ពួកគេស្គាល់ព្រះជាម្ចាស់ដែរឬអត់ ហើយពួកគេអាចចុះចូលចំពោះព្រះជាម្ចាស់ដែលអាចមើលឃើញដែរឬអត់។ អស់អ្នកណាដែលបានបម្រើដល់ព្រះជាម្ចាស់ដែលអាចមើលឃើញបាន ក៏ប៉ុន្ដែមិនបានស្គាល់ទ្រង់ និងមិនបានចុះចូលនឹងទ្រង់ គឺខ្វះនូវសេចក្ដីពិត។ មនុស្សបែបនេះ គឺជាអ្នកប្រព្រឹត្តអំពើអាក្រក់ ហើយអ្នកប្រព្រឹត្តអំពើអាក្រក់ ច្បាស់ជានឹងក្លាយជារបស់ដែលត្រូវដាក់ទោស។ បន្ថែមលើនេះ ពួកគេនឹងត្រូវដាក់ទោសស្របទៅតាមទង្វើទុច្ចរិតរបស់ពួកគេ។ ព្រះជាម្ចាស់ គឺសម្រាប់ឲ្យមនុស្សលោកជឿតាម ហើយទ្រង់ក៏មានតម្លៃឲ្យពួកគេស្ដាប់បង្គាប់តាមដែរ។ អស់អ្នកណាដែលត្រឹមតែមានសេចក្ដីជំនឿ ចំពោះព្រះជាម្ចាស់ដែលស្រពេចស្រពិល និងមិនអាចមើលឃើញ គឺជាអ្នកដែលពុំជឿលើព្រះជាម្ចាស់ និងមិនអាចចុះចូលនឹងព្រះជាម្ចាស់បានឡើយ។ ប្រសិនបើមនុស្សទាំងអស់នេះ នៅតែមិនអាចជឿលើព្រះជាម្ចាស់ដែលអាចមើលឃើញ ពេលដែលកិច្ចការនៃការយកឈ្នះរបស់ទ្រង់បានបញ្ចប់ និងបន្ដមិនស្ដាប់បង្គាប់ ហើយប្រឆាំងទាស់នឹងព្រះជាម្ចាស់ដែលអាចមើលឃើញនៅខាងសាច់ឈាម នោះច្បាស់ណាស់ថា «មនុស្សដែលជឿលើព្រះជាម្ចាស់ដែលស្រពេចស្រពិល» នឹងក្លាយជារបស់ដែលត្រូវបំផ្លាញ។ ដូចគ្នាដែរ មនុស្សមួយចំនួនក្នុងចំណោមអ្នករាល់គ្នា គឺជាមនុស្សដែលទទួលស្គាល់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សត្រឹមតែបបូរមាត់ ប៉ុន្ដែមិនអាចអនុវត្តសេចក្ដីពិតនៃការចុះចូល នឹងព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សបាន ចុងក្រោយនឹងក្លាយជារបស់ដែលត្រូវផាត់ចោល និងត្រូវបំផ្លាញចោល។ បន្ថែមលើនេះ នរណាម្នាក់ដែលទទួលស្គាល់ព្រះជាម្ចាស់ដែលអាចមើលឃើញ តាមបបូរមាត់របស់ពួកគេ ដោយហូប

និងផឹកនូវសេចក្តីពិតដែលទ្រង់បើកសម្តែង ហើយក៏ស្វែងរកព្រះជាម្ចាស់ដ៏ស្រពេចស្រពិល និងមិនអាចមើលឃើញដែរនោះ ប្រាកដជានឹងក្លាយជាកម្មវត្ថុនៃការបំផ្លាញចោលមិនខាន។ ក្នុងចំណោមមនុស្សទាំងអស់នេះ គ្មាននរណាម្នាក់នឹងអាចបន្តរស់នៅរហូតដល់ពេលសម្រាកដែលនឹងត្រូវចូលមកដល់ ក្រោយពេលដែលកិច្ចការរបស់ព្រះជាម្ចាស់បានបញ្ចប់ឡើយ ហើយក៏គ្មាននរណាម្នាក់ស្រដៀងនឹងមនុស្សបែបនេះដែលអាចបន្តរស់នៅក្នុងពេលវេលានៃសេចក្តីសម្រាកបានឡើយ។ មនុស្សអាក្រក់គឺជាមនុស្សដែលមិនអនុវត្តសេចក្តីពិត។ សារជាតិរបស់គេ គឺប្រឆាំងទាស់ ហើយរឹងចចេសនឹងព្រះជាម្ចាស់ ហើយពួកគេមិនមានបំណងចុះចូលនឹងទ្រង់សូម្បីបន្តិចសោះឡើយ។ មនុស្សបែបនេះ នឹងត្រូវបំផ្លាញចោលទាំងអស់។ ការដែលអ្នកមានសេចក្តីពិតឬអត់ ហើយអ្នកប្រឆាំងទាស់នឹងព្រះជាម្ចាស់ឬអត់នោះ គឺអាស្រ័យលើសារជាតិរបស់អ្នក មិនមែនអាស្រ័យលើរូបកាយខាងក្រៅរបស់អ្នកឡើយ ក៏មិនមែនស្ថិតនៅលើរបៀបដែលអ្នកត្រូវនិយាយ ឬប្រព្រឹត្តរបស់ខ្លួនឯងម្តងម្កាលនោះទេ។ បុគ្គលណាមួយនឹងត្រូវបំផ្លាញចោល ឬអត់នោះ គឺត្រូវកំណត់ទៅតាមសារជាតិរបស់មនុស្សម្នាក់ៗ។ គឺត្រូវសម្រេចទៅតាមសារជាតិដែលត្រូវបានបង្ហាញឲ្យឃើញតាមឥរិយាបថ និងតាមការព្យាយាមឲ្យបានសេចក្តីពិតរបស់មនុស្សម្នាក់ៗ។ ក្នុងចំណោមមនុស្សដែលកំពុងបំពេញកិច្ចការដូចគ្នានឹងអ្នកដទៃទៀត និងអ្នកដែលធ្វើកិច្ចការក្នុងចំនួនដូចគ្នា ជាមនុស្សដែលមានសារជាតិជាមនុស្សល្អ និងជាអ្នកដែលមានសេចក្តីពិត គេនឹងនឹងត្រូវអនុញ្ញាតឲ្យបន្តរស់នៅទៀត ចំណែកឯអ្នកដែលមានសារជាតិជាមនុស្សអាក្រក់ ហើយអ្នកដែលមិនស្តាប់បង្គាប់ព្រះជាម្ចាស់ដែលអាចមើលឃើញ គឺជាអ្នកដែលនឹងត្រូវក្លាយរបស់ដែលត្រូវបំផ្លាញចោល។ គ្រប់កិច្ចការ និងព្រះបន្ទូលទាំង់អស់របស់ព្រះជាម្ចាស់ដែលពាក់ព័ន្ធនឹងទិសដៅរបស់មនុស្សជាតិ នឹងត្រូវដោះស្រាយជាមួយមនុស្សឲ្យបានស័ក្តិសមទៅតាមសារជាតិរបស់បុគ្គលម្នាក់ៗ ហើយសូម្បីកំហុសបន្តិចបន្តួច ក៏នឹងមិនអាចកើតមានដែរ ហើយក៏នឹងគ្មានកំហុសឆ្គងសូម្បីបន្តិចសោះឡើយ។ ទាល់តែពេលដែលមនុស្សបំពេញកិច្ចការ ទើបអារម្មណ៍និងអត្ថន័យជាមនុស្ស ច្របល់បញ្ចូលគ្នា។

កិច្ចការដែលព្រះជាម្ចាស់បំពេញ គឺស័ក្ដិសមបំផុត។ ទ្រង់ដាច់ខាតមិនក្លែងទាមទារសំណងពីសត្តនិករណាមួយឡើយ។ បច្ចុប្បន្ននេះ មានមនុស្សជាច្រើនដែលមិនអាចយល់ អំពីទិសដៅអនាគតរបស់មនុស្សជាតិបាន ហើយជាមនុស្សដែលមិនជឿលើព្រះបន្ទូលដែលខ្ញុំថ្លែង។ មនុស្សគ្រប់គ្នាដែលមិនជឿ ក៏ដូចជាអ្នកដែលមិនអនុវត្តសេចក្ដីពិត គឺសុទ្ធតែជាពួកអារក្ស!

បច្ចុប្បន្ននេះ អ្នកដែលស្វែងរក និងអ្នកដែលមិនស្វែងរក គឺជាមនុស្សពីរប្រភេទដែលខុសគ្នាស្រឡះ ហើយទិសដៅរបស់ពួកគេ ក៏ខុសគ្នាយ៉ាងខ្លាំងផងដែរ។ អស់អ្នកដែលស្វែងរកចំណេះដឹងអំពីសេចក្ដីពិត និងអនុវត្តនូវសេចក្ដីពិត គឺមនុស្សដែលព្រះជាម្ចាស់ នឹងប្រទានសេចក្ដីសង្គ្រោះដល់គេ។ អស់អ្នកណាដែលមិនដឹងអំពីផ្លូវពិត គឺសុទ្ធតែជាពួកអារក្ស និងជាពួកសត្រូវ។ ពួកគេជាកូនចៅនៃមហាទេវតា ហើយនឹងក្លាយជារបស់ដែលត្រូវបំផ្លាញចោល។ សូម្បីតែអស់អ្នកណាដែលជឿស៊ប់លើព្រះជាម្ចាស់ដែលស្រពេចស្រពិល តើពួកគេមិនមែនជាពួកអារក្សទេឬអី? មនុស្សដែលមានសតិសម្បជញ្ញៈល្អ ប៉ុន្តែពុំទទួលយកផ្លូវពិត គឺសុទ្ធតែពួកជាអារក្ស។ សារជាតិរបស់ពួកគេ គឺជាមនុស្សដែលប្រឆាំងទាស់នឹងព្រះជាម្ចាស់។ អ្នកណាដែលមិនទទួលយកផ្លូវត្រូវ គឺជាអ្នកដែលប្រឆាំងទាស់នឹងព្រះជាម្ចាស់ ហើយទោះបីជាមនុស្សបែបនេះ ទទួលរងនូវទុក្ខលំបាកក្ដី ក៏ពួកគេនឹងនៅតែត្រូវបំផ្លាញចោលដដែល។ អស់អ្នកណាដែលមិនសុខចិត្តលះបង់លោកិយនេះ អស់អ្នកណាដែលមិនអាចអត់ទ្រាំបែកចេញពីឪពុកម្ដាយរបស់ពួកគេបាន និងអស់អ្នកណាដែលមិនអាចលះបង់នូវការសប្បាយរីករាយខាងសាច់ឈាមបាន គឺសុទ្ធតែជាមនុស្សរឹងចចេសនឹងព្រះជាម្ចាស់ ហើយអ្នកទាំងអស់នេះ នឹងក្លាយជារបស់ដែលត្រូវបំផ្លាញចោល។ ជាងនេះទៅទៀត នរណាម្នាក់ដែលមិនជឿលើព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស គឺជាពួកអារក្ស ហើយនឹងត្រូវបំផ្លាញចោល។ អស់អ្នកណាដែលមានសេចក្ដីជំនឿ ប៉ុន្តែមិនបានអនុវត្តតាមសេចក្ដីពិត អស់អ្នកណាដែលមិនជឿលើព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស និងអស់អ្នកណាដែលមិនជឿលើអត្ថិភាពរបស់ព្រះជាម្ចាស់

ក៏នឹងក្លាយទៅជារបស់ដែលត្រូវបំផ្លាញចោលផងដែរ។ អ្នកទាំងឡាយណាដែលនឹងត្រូវអនុញ្ញាតឲ្យបន្តរស់នៅ គឺសុទ្ធតែជាមនុស្សដែលបានឆ្លងកាត់នូវទុក្ខវេទនានៃការបន្សុទ្ធ និងប្រកាន់ខ្ជាប់នូវជំហរយ៉ាងរឹងមាំ។ មនុស្សទាំងអស់នេះ គឺជាមនុស្សដែលបានឆ្លងកាត់ការល្បងលយ៉ាងពិតប្រាកដ។ នរណាម្នាក់ដែលមិនទទួលស្គាល់ព្រះជាម្ចាស់ គឺជាសត្រូវ ពោលគឺ នរណាម្នាក់ដែលមិនទទួលស្គាល់ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស (មិនថា ពួកគេនៅក្នុង ឬនៅក្រៅកិច្ចការបម្រើទេ) គឺសុទ្ធតែជាពួកទទឹងនឹងព្រះគ្រីស្ទ។ តើសាតាំងជានរណា តើអារក្សជានរណា ហើយតើសត្រូវរបស់ព្រះជាម្ចាស់ជានរណា ប្រសិនបើមិនមែនជាពួកតតាំងដែលមិនជឿលើព្រះជាម្ចាស់នោះ? តើពួកគេមិនមែនជាមនុស្សដែលរឹងទទឹងនឹងព្រះជាម្ចាស់ទេឬអី? តើពួកគេមិនជាមនុស្សដែលអះអាងថា ខ្លួនមានសេចក្ដីជំនឿ តែខ្វះនូវសេចក្ដីពិតទេឬអី? តើពួកគេមិនមែនជាពួកដែលគ្រាន់តែព្យាយាមចង់បានព្រះពរ តែមិនអាចធ្វើបន្ទាល់សម្រាប់ព្រះជាម្ចាស់ទេឬអី? សព្វថ្ងៃនេះ អ្នកនៅលាយឡំជាមួយនឹងពួកអារក្ស ទាំងមានសតិសម្បជញ្ញៈ និងសេចក្ដីស្រឡាញ់ចំពោះពួកវា ប៉ុន្ដែ ក្នុងករណីនេះ តើអ្នកមិនកំពុងបន្ថែមសមានចិត្តចំពោះសាតាំងទេឬអី? តើអ្នកមិនមែននៅក្នុងក្រុមជាមួយនឹងពួកអារក្សទេឬអី? ប្រសិនបើមនុស្សសម័យនេះ នៅតែមិនអាចបែងចែកភាពខុសគ្នា រវាងអ្វីល្អនិងអ្វីអាក្រក់ទេ ហើយបន្តធ្វើជាមនុស្សគួរឲ្យស្រឡាញ់ និងមានមេត្តាធម៌ទាំងងងឹតងងល់ ដោយគ្មានបំណងចង់ឈ្វេងយល់ពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ឬអាចដាក់បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ទៅក្នុងចិត្តរបស់ខ្លួនដោយវិធីណាមួយបាន នោះចុងបញ្ចប់របស់ពួកគេរាល់គ្នានឹងកាន់អាក្រក់ទៅៗ។ អ្នកណាមួយដែលមិនជឿលើព្រះជាម្ចាស់ដែលសណ្ឋិតក្នុងសាច់ឈាម គឺជាសត្រូវរបស់ព្រះជាម្ចាស់។ ប្រសិនបើអ្នកអាចមានសតិសម្បជញ្ញៈ និងក្ដីស្រឡាញ់ចំពោះសត្រូវ តើអ្នកមិនមែនខ្វះស្មារតីនៃសេចក្ដីសុចរិតទេឬអី? ប្រសិនបើអ្នកចុះសម្រុងនឹងអស់អ្នកដែលខ្ញុំស្អប់ខ្ពើម និងអស់អ្នកដែលខ្ញុំមិនយល់ស្របនោះ ហើយនៅតែមានសេចក្ដីស្រឡាញ់ និងអារម្មណ៍ផ្ទាល់ខ្លួនដក់ជាប់ចំពោះពួកគេ ដូច្នេះ តើអ្នកមិនមែន

ជាមនុស្សរឹងចចេសទេឬអី? តើអ្នកមិនមែនកំពុងប្រឆាំងនឹងព្រះជាម្ចាស់ដោយចេតនាទេឬអី? តើមនុស្សបែបនេះ មានសេចក្ដីពិតដែរឬទេ? ប្រសិនបើមនុស្សដែលមានសតិសម្បជញ្ញៈចំពោះសត្រូវ មានសេចក្ដីស្រឡាញ់ចំពោះពួកអារក្ស និងមានសេចក្ដីសន្ដោសប្រណីចំពោះសាតាំង ដូច្នេះ តើពួកគេមិនមែនកំពុងតែរំខានដល់កិច្ចការរបស់ព្រះជាម្ចាស់ដោយចេតនាទេឬអី? អស់អ្នកណាដែលជឿតែលើព្រះយេស៊ូវគ្រីស្ទនិងមិនជឿលើព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សក្នុងគ្រាចុងក្រោយ ក៏ដូចជាអស់អ្នកដែលអះអាងដោយបបូរមាត់ថា គេជឿលើព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស តែប្រព្រឹត្តអំពើអាក្រក់ គឺសុទ្ធតែជាពួកទទឹងនឹងព្រះគ្រីស្ទ ដោយមិនចាំបាច់និយាយដល់អ្នកណាដែលមិនបានជឿលើព្រះជាម្ចាស់ឡើយ។ មនុស្សអស់ទាំងនេះ នឹងក្លាយជារបស់ដែលត្រូវបំផ្លាញចោល។ ក្បួនខ្នាតដែលមនុស្សលោកវិនិច្ឆ័យអ្នកដទៃ គឺផ្អែកលើឥរិយាបថរបស់ពួកគេ។ អស់អ្នកណាដែលប្រព្រឹត្តអំពើល្អ គឺជាមនុស្សសុចរិត រីឯអស់អ្នកណាប្រព្រឹត្តអំពើគួរឲ្យស្អប់ខ្ពើម គឺជាមនុស្សទុច្ចរិត។ ក្បួនខ្នាតដែលព្រះជាម្ចាស់ជំនុំជម្រះមនុស្សលោក គឺផ្អែកលើថា តើសារជាតិរបស់ពួកគេ ចុះចូលនឹងទ្រង់ដែរឬអត់។ នរណាម្នាក់ដែលចុះចូលនឹងព្រះជាម្ចាស់ គឺជាមនុស្សសុចរិត រីឯនរណាម្នាក់ដែលមិនចុះចូល គឺជាសត្រូវ និងជាមនុស្សទុច្ចរិត ទោះបីជាអាកប្បកិរិយារបស់មនុស្សម្នាក់នោះល្អឬអាក្រក់ ហើយទោះបីជាសម្ដីរបស់ពួកគេត្រឹមត្រូវ ឬមិនត្រូវឡើយ។ មនុស្សមួយចំនួនចង់ប្រើប្រាស់អំពើល្អ ដើម្បីទទួលបានទិសដៅល្អនាពេលអនាគត ហើយមនុស្សខ្លះទៀតចង់ប្រើប្រាស់សម្ដីល្អៗ ដើម្បីទទួលបានទិសដៅល្អមួយ។ មនុស្សគ្រប់គ្នាជឿទាំងខុសឆ្គងថា ព្រះជាម្ចាស់កំណត់លទ្ធផលរបស់មនុស្សក្រោយពីទ្រង់បានទតឃើញអាកប្បកិរិយារបស់ពួកគេឬក្រោយពីទ្រង់បានស្ដាប់ឮសម្ដីរបស់ពួកគេ។ ហេតុនេះ មនុស្សភាគច្រើនចង់ទាញយកផលចំណេញពីចំណុចនេះ ដើម្បីបោកបញ្ឆោតព្រះជាម្ចាស់ឲ្យប្រទាននូវការអនុគ្រោះដល់ពួកគេបានមួយគ្រា។ នៅពេលអនាគត មនុស្សដែលនឹងនៅរស់រានក្នុងសភាពនៃការសម្រាក សុទ្ធតែនឹងត្រូវឆ្លងកាត់នូវគ្រារងទុក្ខវេទនា ហើយក៏នឹងត្រូវធ្វើទីបន្ទាល់សម្រាប់ព្រះជាម្ចាស់

ផងដែរ។ ពួកគេនឹងក្លាយជាមនុស្សដែលបានបំពេញភារកិច្ចរបស់ខ្លួន និងជាអ្នកដែលបានចុះចូលនឹងព្រះជាម្ចាស់ ដោយចេតនាពិត។ អស់អ្នកណាដែលគ្រាន់តែចង់ប្រើឱកាសនេះ មកបម្រើដោយមានចេតនាគេចវេសពីការអនុវត្តនូវសេចក្តីពិត នឹងមិនត្រូវអនុញ្ញាតឲ្យបន្តរស់នៅទៀតឡើយ។ ព្រះជាម្ចាស់ មានក្បួនខ្នាតសមស្រប សម្រាប់ការរៀបចំលទ្ធផលរបស់បុគ្គលម្នាក់ៗ។ ទ្រង់មិនមែនគ្រាន់តែសម្រេចព្រះទ័យលើការទាំងអស់នេះ ស្របទៅតាមសម្ដី និងទង្វើរបស់មនុស្សម្នាក់ៗនោះឡើយ ហើយទ្រង់ក៏មិនសម្រេចព្រះទ័យផ្អែកតាមទង្វើរបស់មនុស្សម្នាក់ក្នុងអំឡុងពេលតែមួយគ្រានោះដែរ។ ទ្រង់នឹងមិនអត់ឱនជាដាច់ខាតចំពោះទង្វើអាក្រក់របស់មនុស្សណាម្នាក់ ដោយសារតែពួកគេបានបម្រើដល់ទ្រង់កាលពីមុនមកឡើយ ហើយទ្រង់ក៏នឹងមិនលើកលែងដល់នរណាម្នាក់ឲ្យរួចផុតពីសេចក្ដីស្លាប់ ដោយសារការលះបង់របស់ពួកគេ ចំពោះព្រះជាម្ចាស់តែមួយគ្រានោះឡើយ។ គ្មាននរណាម្នាក់អាចគេចផុតពីទុក្ខវេទនាសម្រាប់អំពើអាក្រក់របស់គេឡើយ ហើយគ្មាននរណាម្នាក់អាចគ្របបាំងអាកប្បកិរិយាអាក្រក់របស់ពួកគេ ហើយគេចចេញពីទុក្ខវេទនា នៃសេចក្តីអន្តរាយបានទេ។ ប្រសិនបើមនុស្ស អាចបំពេញភារកិច្ចរបស់ពួកគេបានដោយពិតប្រាកដ នោះមានន័យថា ពួកគេស្មោះត្រង់ជានិច្ចចំពោះព្រះជាម្ចាស់ និងមិនព្យាយាមចង់បានរង្វាន់នោះទេ ទោះបីជាពួកគេទទួលបានព្រះពរ ឬទទួលសំណាងអាក្រក់ក៏ដោយ។ ប្រសិនបើមនុស្សស្មោះត្រង់ចំពោះព្រះជាម្ចាស់ នៅពេលដែលពួកគេឃើញព្រះពរ ប៉ុន្តែបាត់បង់ភាពស្មោះត្រង់របស់ពួកគេ នៅពេលដែលពួកគេមិនអាចមើលឃើញព្រះពរ ហើយនៅចុងបញ្ចប់ ប្រសិនបើពួកគេនៅតែមិនអាចធ្វើទីបន្ទាល់សម្រាប់ព្រះជាម្ចាស់ ឬបំពេញភារកិច្ចដែលត្រូវបានប្រគល់ជូនពួកគេ នោះពួកគេនឹងនៅតែជារបស់ដែលត្រូវបំផ្លាញចោលដដែល ទោះបីជាពួកគេធ្លាប់បានបម្រើព្រះជាម្ចាស់ដោយស្មោះត្រង់កាលពីមុនមក ឬក៏អត់ក្តី។ និយាយឲ្យខ្លី មនុស្សទុច្ចរិតមិនអាចរស់រាននៅបានរហូតអស់កល្បជានិច្ចឡើយ ហើយពួកគេក៏មិនអាចចូលទៅក្នុងសេចក្ដីសម្រាកបានដែរ។ មានតែមនុស្សសុចរិតប៉ុណ្ណោះ ទើបជាម្ចាស់នៃសេចក្តីសម្រាក។ នៅពេល

ណាដែលមនុស្សជាតិស្ថិតនៅលើផ្លូវត្រូវ មនុស្សនឹងមានជីវិតជាមនុស្សលោកសាមញ្ញធម្មតា។ ពួកគេរាល់គ្នានឹងបំពេញភារកិច្ចរបស់ពួកគេរៀងៗខ្លួន ហើយមានភាពស្មោះត្រង់ចំពោះព្រះជាម្ចាស់យ៉ាងក្រៃលែង។ ចុងក្រោយ ពួកគេនឹងបាត់បង់ចរិតរឹងចចេស និងនិស្ស័យពុករលួយរបស់ខ្លួន ហើយពួកគេនឹងរស់នៅសម្រាប់ព្រះជាម្ចាស់ និងដោយព្រោះព្រះជាម្ចាស់ ដោយគ្មានទាំងចរិតរឹងចចេស និងការចរិតរឹងទទឹងផង។ ពួកគេទាំងអស់នឹងអាចចុះចូលនឹងព្រះជាម្ចាស់ទាំងស្រុង។ នេះនឹងក្លាយជាជីវិតរបស់ព្រះជាម្ចាស់ និងមនុស្សជាតិ។ វានឹងក្លាយជាជីវិតនៃនគរស្ថានសួគ៌ ហើយវានឹងក្លាយជាជីវិតនៃសេចក្តីសម្រាក។

អស់អ្នកណា ដែលអូសទាញកូនចៅ និងសាច់ញាតិរបស់ពួកគេដែលមិនជឿទាល់តែសោះទៅក្នុងព្រះវិហារ គឺជាមនុស្សអាត្មានិយមយ៉ាងក្រៃលែង ហើយពួកគេគ្រាន់តែបង្ហាញនូវចិត្តសប្បុរសតែប៉ុណ្ណោះ។ មនុស្សទាំងអស់នេះ គ្រាន់តែផ្តោតទៅលើការធ្វើខ្លួនជាមនុស្សគួរឲ្យស្រឡាញ់ប៉ុណ្ណោះ ទោះបីជាពួកគេជឿ ឬមិនជឿ ហើយទោះបីវាគឺជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ឬអត់ក៏ដោយ។ អ្នកខ្លះនាំប្រពន្ធរបស់គេមកចំពោះព្រះជាម្ចាស់ ឬអូសទាញឪពុកម្តាយរបស់ពួកគេមកចំពោះព្រះជាម្ចាស់ ហើយទោះបីជាព្រះវិញ្ញាញបរិសុទ្ធយល់ស្របចំពោះរឿងនេះឬអត់ ឬទ្រង់កំពុងធ្វើការនៅក្នុងពួកគេឬអត់នោះ ក៏ពួកគេបន្ត «ជ្រើសរើសមនុស្សដែលមានសមត្ថភាព» សម្រាប់ព្រះជាម្ចាស់ទាំងងងឹតងងល់ដែរ។ តើការសន្ធឹងសេចក្តីសប្បុរសចំពោះអ្នកមិនជឿទាំងអស់នេះ អាចទទួលបានអ្វីមកវិញ? បើទោះបីជាមនុស្សដែលគ្មានវត្តមានរបស់ព្រះវិញ្ញាណបរិសុទ្ធគង់ជាមួយ ខិតខំប្រឹងប្រែងដើរតាមព្រះជាម្ចាស់ ក៏ពួកគេនៅតែ មិនអាចត្រូវបានសង្គ្រោះដូចជាមនុស្សដែលជឿដែរ។ អស់អ្នកណាដែលមិនទទួលបានសេចក្តីសង្គ្រោះ គឺពិតជាមិនងាយស្រួលនឹងទទួលយកនោះទេ។ មនុស្សដែលមិនបានឆ្លងកាត់កិច្ចការ និងការល្បងលរបស់ព្រះវិញ្ញាណបរិសុទ្ធ ហើយមិនត្រូវបាន ព្រះជាម្ចាស់ដែលយកកំណើតជាមនុស្សប្រោសឲ្យគ្រប់លក្ខណ៍ គេច្បាស់ជាមិនអាចត្រូវបានធ្វើឲ្យពេញខ្នាតឡើយ។ ហេតុនេះ ចាប់តាំងពីពេលដែល

ពួកគេចាប់ផ្ដើមដើរតាមទ្រង់ត្រឹមតែឈ្មោះមក មនុស្សទាំងអស់នោះពុំមានវត្តមានរបស់ព្រះវិញ្ញាណបរិសុទ្ធគង់ជាមួយឡើយ។ ចំពោះរឿងលក្ខខណ្ឌ និងស្ថានភាពជាក់ស្ដែងរបស់ពួកគេ ពួកគេមិនអាចត្រូវបានធ្វើឲ្យពេញខ្នាតឡើយ។ ដូច្នេះ ព្រះវិញ្ញាណបរិសុទ្ធសម្រេចព្រះទ័យមិនចំណាយកម្លាំងឲ្យច្រើនលើពួកគេនោះទេ ហើយទ្រង់ក៏មិនប្រទាននូវការបំភ្លឺ ឬការណែនាំដល់ពួកគេ ដោយវិធីណាមួយដែរ។ ទ្រង់គ្រាន់តែអនុញ្ញាតឲ្យពួកគេដើរតាម ហើយនៅចុងបំផុត ទ្រង់ក៏បង្ហាញនូវលទ្ធផលរបស់ពួកគេ។ តែប៉ុណ្ណេះ គឺគ្រប់គ្រាន់ហើយ។ ចិត្តសាទរនិងបំណងរបស់មនុស្សជាតិកើតចេញមកពីសាតាំង ហើយគ្មានផ្លូវណាដែលសេចក្ដីទាំងអស់នេះ អាចបំពេញកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធបានឡើយ។ មិនថាមនុស្សមានលក្ខណៈបែបណានោះទេ ពួកគេត្រូវមានកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ។ តើមនុស្សលោកអាចធ្វើឲ្យមនុស្សលោកបានពេញខ្នាតដែរឬទេ? ហេតុអ្វីបានជាប្ដីស្រឡាញ់ប្រពន្ធ? ហេតុអ្វីបានប្រពន្ធស្រឡាញ់ប្ដី? ហេតុអ្វីបានជាកូនត្រូវមានកាតព្វកិច្ច ចំពោះឪពុកម្ដាយរបស់ពួកគេ? ហេតុអ្វីបានជាឪពុកម្ដាយផ្ដោតការស្រឡាញ់លើកូនៗរបស់ពួកគេ? តើមនុស្សមានបំណងបែបណានៅក្នុងចិត្តរបស់ពួកគេឲ្យប្រាកដ? តើបំណងរបស់ពួកគេ មិនមែនដើម្បីសម្រេចផែនការផ្ទាល់ខ្លួន ឬបំពេញចំណង់ចិត្តអាត្មានិយមរបស់ខ្លួនគេផ្ទាល់ទេមែនទេ? តើពួកគេពិតជាចង់ធ្វើការ ដើម្បីជាប្រយោជន៍ដល់ផែនការគ្រប់គ្រងរបស់ព្រះជាម្ចាស់មែនទេ? តើពួកគេពិតជាកំពុងធ្វើការ ដើម្បីជាប្រយោជន៍ដល់កិច្ចការរបស់ព្រះជាម្ចាស់មែនទេ? តើបំណងរបស់ពួកគេ គឺដើម្បីសម្រេចភារកិច្ចក្នុងនាមជាសត្តនិករដែលព្រះបានបង្កើតមកមែនទេ? អស់អ្នកណាដែលមិនអាចទទួលបាននូវវត្តមានរបស់ព្រះវិញ្ញាណបរិសុទ្ធ ចាប់តាំងពីពេលដែលពួកគេចាប់ផ្ដើមជឿលើព្រះជាម្ចាស់ នឹងមិនអាចទទួលបានកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធឡើយ។ មនុស្សទាំងនេះ ត្រូវបានសម្រេចថា ជារបស់ដែលត្រូវបំផ្លាញចោល។ ទោះបីមនុស្សម្នាក់មានសេចក្ដីស្រឡាញ់ចំពោះពួកគេខ្លាំងប៉ុនណា ក៏វាមិនអាចជំនួសនូវកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធបានឡើយ។ សេចក្ដីអរសប្បាយនិងសេចក្ដីស្រឡាញ់របស់មនុស្ស តំណាងឲ្យ

បំណងរបស់មនុស្ស ប៉ុន្តែមិនអាចតំណាងឲ្យបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់បានឡើយ ហើយសេចក្តីទាំងនេះក៏មិនអាចជំនួសកិច្ចការរបស់ព្រះជាម្ចាស់បានដែរ។ បើទោះបីជាមនុស្សណាម្នាក់លាតសន្ធឹងសេចក្តីស្រឡាញ់ ឬសេចក្តីករុណាយ៉ាងច្រើនលើសលប់តាមដែលគេមានចំពោះមនុស្សដែលគ្រាន់តែជឿលើព្រះជាម្ចាស់ត្រឹមតែឈ្មោះ និងធ្វើពុតជាដើរតាមទ្រង់ដោយគ្មានដឹងសោះថា ការជឿលើព្រះជាម្ចាស់មានន័យដូចម្តេច នោះពួកគេនឹងនៅតែមិនអាចទទួលបាននូវសេចក្តីអាណិតអាសូររបស់ព្រះជាម្ចាស់ ហើយពួកគេ ក៏នឹងមិនអាចទទួលបានកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធដែរ។ ទោះបីជាមនុស្សដែលដើរតាមព្រះជាម្ចាស់ដោយចិត្តស្មោះ មានគុណសម្បត្តិអន់ខ្សោយ និងមិនអាចយល់ពីសេចក្តីពិតបានច្រើនយ៉ាងណាក្តី ក៏ពួកគេនៅតែអាចទទួលបាននូវកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធម្តងម្កាលដែរ។ ដោយឡែក អ្នកដែលត្រូវបានចាត់ទុកថាមានគុណសម្បត្តិល្អគួរសម ប៉ុន្តែមិនជឿដោយចិត្តស្មោះ គឺមិនអាចទទួលបានវត្តមានរបស់ព្រះវិញ្ញាណបរិសុទ្ធសោះឡើយ។ មនុស្សបែបនេះ គ្មានលទ្ធភាពនឹងទទួលបាន សេចក្តីសង្គ្រោះទាល់តែសោះ។ បើទោះបីជាពួកគេអានព្រះបន្ទូលរបស់ព្រះជាម្ចាស់ ឬស្តាប់ការអធិប្បាយអំពីព្រះគម្ពីរម្តងម្កាល ឬសូម្បីតែច្រៀងសរសើរតម្កើងដល់ព្រះជាម្ចាស់ក្តី នៅទីបំផុត ពួកគេក៏នៅតែមិនអាចនៅរស់រានបាន រហូតដល់ពេលវេលានៃសេចក្តីសម្រាកបានដែរ។ ការដែលមនុស្សស្វែងរកដោយចិត្តស្មោះ ឬអត់នោះ មិនមែនកំណត់តាមការដែលមនុស្សដទៃវិនិច្ឆ័យពួកគេយ៉ាងណា ឬតាមការដែលមនុស្សនៅជុំវិញពួកគេ គិតពីពួកគេយ៉ាងណានោះទេ ប៉ុន្តែគឺត្រូវបានកំណត់តាមការដែលព្រះវិញ្ញាណបរិសុទ្ធបំពេញកិច្ចការយ៉ាងណាចំពោះពួកគេនិងតាមការដែលពួកគេបានទទួលនូវវត្តមានរបស់ព្រះវិញ្ញាណបរិសុទ្ធដែរឬមួយក៏អត់។ បន្ថែមលើនេះ វាអាស្រ័យលើថា តើនិស្ស័យរបស់ពួកគេបានបំផ្លាស់បំប្រែដែរឬអត់ ហើយតើពួកគេបានទទួលនូវចំណេះដឹងអំពីព្រះជាម្ចាស់ បន្ទាប់ពីឆ្លងកាត់កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ក្នុងរយៈពេលជាក់លាក់ណាមួយដែរឬអត់។ ប្រសិនបើព្រះវិញ្ញាណបរិសុទ្ធកែខែមនុស្សណាម្នាក់ និស្ស័យរបស់បុគ្គលនោះនឹងត្រូវ

បំផ្លាស់បំប្រែបន្តិចម្ដងៗ ហើយទស្សនៈរបស់ពួកគេចំពោះការជឿលើព្រះជាម្ចាស់ នឹងកាន់តែបរិសុទ្ធបន្តិចម្ដងៗដែរ។ មិនថាមនុស្សដើរតាមព្រះជាម្ចាស់យូរប៉ុនណានោះទេ ឲ្យតែពួកគេបានបំផ្លាស់បំប្រែ នោះមានន័យថា ព្រះវិញ្ញាណបរិសុទ្ធកំពុងកែខៃពួកគេហើយ។ ប្រសិនបើពួកគេមិនបានបំផ្លាស់បំប្រែទេ នោះមានន័យថា ព្រះវិញ្ញាណបរិសុទ្ធមិនមែនកំពុងកែខៃពួកគេឡើយ។ បើទោះបីជាពួកគេបានបម្រើកិច្ចការខ្លះក្ដី អ្វីដែលជំរុញឲ្យពួកគេធ្វើបែបនេះ គឺចំណង់ចិត្តចង់ទទួលបាននូវព្រះពរ។ ត្រឹមតែការបម្រើកិច្ចការម្ដងម្កាល មិនអាចជំនួសការឆ្លងកាត់នូវការបំផ្លាស់បំប្រែនិស្ស័យរបស់ពួកគេឡើយ។ ចុងបញ្ចប់ ពួកគេនឹងត្រូវបំផ្លាញចោល ដ្បិតនៅក្នុងនគរស្ថានសួគ៌ នឹងលែងត្រូវការអ្នកបម្រើទៀតហើយ ហើយក៏លែងត្រូវការមនុស្ស ដែលមិនទាន់បានបំផ្លាស់បំប្រែនិស្ស័យរបស់ពួកគេ ឲ្យមកបម្រើដល់អស់អ្នកដែលត្រូវបានប្រោសឲ្យគ្រប់លក្ខណ៍ និងអស់អ្នកដែលស្មោះត្រង់ចំពោះព្រះជាម្ចាស់ដែរ។ ព្រះបន្ទូលដែលថ្លែងកាលពីអតីតកាលថា «នៅពេលមនុស្សម្នាក់ជឿលើព្រះអម្ចាស់ ភ័ព្វសំណាងញញឹមស្វាគមន៍គ្រួសារគេទាំងមូល» គឺសមស្របសម្រាប់សម័យព្រះគុណ ប៉ុន្តែមិនជាប់ពាក់ព័ន្ធ នឹងទិសដៅរបស់មនុស្សជាតិឡើយ។ ព្រះបន្ទូលទាំងនេះ ស័ក្តិសមសម្រាប់ដំណាក់កាលមួយក្នុងសម័យព្រះគុណតែប៉ុណ្ណោះ។ អត្ថន័យនៃព្រះបន្ទូលទាំងអស់នេះ ត្រូវបានតម្រង់ទៅរកភាពសុខសាន្ត និងព្រះពរខាងរូបកាយដែលមនុស្សចូលចិត្ត។ ព្រះបន្ទូលទាំងនេះ ពុំមែនមានន័យថា គ្រួសារទាំងមូលរបស់អ្នកដែលជឿលើព្រះអម្ចាស់ នឹងត្រូវបានសង្គ្រោះឡើយ ហើយព្រះបន្ទូលនេះក៏មិនមែនមានន័យថា នៅពេលនរណាម្នាក់ទទួលបានព្រះពរ នោះគ្រួសាររបស់គេទាំងមូលក៏អាចត្រូវនាំទៅកាន់សេចក្ដីសម្រាកបាននោះដែរ។ ការដែលនរណាម្នាក់ទទួលបានព្រះពរ ឬទទួលរងសំណាងអាក្រក់ឬអត់នោះ គឺត្រូវកំណត់ទៅតាមសារជាតិរបស់គេ មិនមែនទៅតាមសារជាតិទូទៅដែលមនុស្សម្នាក់អាចមានដូចគ្នានឹងអ្នកដទៃនោះទេ។ ព្រះបន្ទូលដែលពោលបែបនេះ ឬក្បួនខ្នាតបែបនេះ មិនមានសោះឡើយនៅនគរស្ថានសួគ៌។ ចុងក្រោយ ប្រសិនបើមនុស្សម្នាក់អាចរួចជីវិតបាន នោះគឺដោយសារពួកគេបានបំពេញ

តាមសេចក្ដីតម្រូវរបស់ព្រះជាម្ចាស់ ហើយចុងក្រោយ ប្រសិនបើពួកគេមិនអាចបន្តរស់នៅបានរហូតដល់ពេលសម្រាក នោះគឺដោយសារពួកគេរឹងចចេស ចំពោះព្រះជាម្ចាស់ ហើយមិនបានបំពេញតាមសេចក្ដីតម្រូវរបស់ព្រះជាម្ចាស់។ មនុស្សគ្រប់គ្នាមានទិសដៅសមស្របមួយ។ ទិសដៅទាំងអស់នេះត្រូវបានកំណត់ទៅតាមសារជាតិរបស់បុគ្គលម្នាក់ៗ និងគ្មានអ្វីដែលពាក់ព័ន្ធនឹងមនុស្សដទៃទាល់តែសោះ។ ឥរិយាបថអាក្រក់របស់កូនមិនអាចផ្ទេរទៅឲ្យឪពុកម្ដាយបានឡើយ ហើយសេចក្ដីសុចរិតរបស់កូន ក៏មិនអាចចែករំលែកជាមួយឪពុកម្ដាយរបស់ពួកគេបានដែរ។ ឥរិយាបថអាក្រក់របស់ឪពុកម្ដាយ មិនអាចផ្ទេរទៅឲ្យកូនចៅបានឡើយ ហើយសេចក្ដីសុចរិតរបស់ឪពុកម្ដាយ ក៏មិនអាចចែករំលែកជាមួយកូនចៅរបស់ពួកគេបានដែរ។ មនុស្សគ្រប់គ្នាមានបាបរៀងៗខ្លួន ហើយមនុស្សគ្រប់គ្នា ត្រេកអរសប្បាយនឹងព្រះពររបស់ពួកគេរៀងៗខ្លួន។ គ្មាននរណាម្នាក់អាចជំនួសបុគ្គលណាម្នាក់បានឡើយ។ នេះគឺជាសេចក្ដីសុចរិត។ តាមទស្សនៈរបស់មនុស្ស ប្រសិនបើឪពុកម្ដាយទទួលបានព្រះពរ នោះកូនចៅរបស់ពួកគេ គប្បីអាចទទួលបានភ័ព្វសំណាងដែរ ហើយប្រសិនបើកូនចៅប្រព្រឹត្តអាក្រក់ នោះឪពុកម្ដាយរបស់ពួកគេ ក៏ត្រូវតែទទួលរងបាបទាំងនោះដែរ។ នេះគឺជាទស្សនៈរបស់មនុស្សលោក និងជារបៀបដែលមនុស្សលោកប្រព្រឹត្តអំពើផ្សេងៗ។ វាមិនមែនជាទស្សនៈរបស់ព្រះជាម្ចាស់ឡើយ។ លទ្ធផលរបស់មនុស្សម្នាក់ ត្រូវកំណត់ទៅតាមសារជាតិដែលចេញមកពីទង្វើរបស់ពួកគេ ហើយលទ្ធផលនេះ តែងត្រូវកំណត់យ៉ាងសមស្របបំផុត។ គ្មាននរណាម្នាក់អាចរ៉ាប់រងបាបរបស់នរណាផ្សេងទៀតបានឡើយ ហើយបើទោះបីជាដូច្នេះក្ដី ក៏គ្មាននរណាម្នាក់អាចទទួលទណ្ឌកម្មជំនួសនរណាម្នាក់ទៀតបានដែរ។ ចំណុចនេះ គឺដាច់ខាតណាស់។ ការដែលឪពុកម្ដាយស្រឡាញ់ថែទាំកូនចៅរបស់ពួកគេ ពុំបង្ហាញថា ពួកគេអាចបំពេញអំពើសុចរិតជំនួសឲ្យកូនចៅរបស់ពួកគេបានឡើយ ហើយកាតព្វកិច្ចដែលកូនចៅត្រូវស្រឡាញ់ចំពោះឪពុកម្ដាយរបស់ពួកគេ ក៏មិនមានន័យថា ពួកគេអាចបំពេញអំពើសុចរិតជំនួសឪពុកម្ដាយរបស់ពួកគេដែរ។ នេះគឺជាអត្ថន័យពិតប្រាកដនៃព្រះបន្ទូលដែលថា «មានមនុស្សពីរនាក់នៅ

ឯវាល ម្នាក់នឹងត្រូវយកទៅ ហើយម្នាក់នឹងត្រូវទុកឲ្យនៅ។ មានស្រ្ដីពីរនាក់កំពុងកិនម្សៅ ម្នាក់នឹងត្រូវយកទៅ ម្នាក់នឹងត្រូវទុកឲ្យនៅ»។ មនុស្សមិនអាចយកកូនចៅរបស់ពួកគេដែលប្រព្រឹត្តអំពើអាក្រក់ទៅក្នុងសេចក្ដីសម្រាក ដោយសំអាងលើសេចក្ដីស្រឡាញ់ដ៏ជ្រាលជ្រៅរបស់ពួកគេ ចំពោះកូនចៅគេឡើយ ហើយគ្មាននរណាម្នាក់អាចយកប្រពន្ធ (ប្ដី) ទៅក្នុងសេចក្ដីសម្រាក ដោយសំអាងលើអំពើសុចរិតផ្ទាល់ខ្លួនរបស់ពួកគេបានដែរ។ នេះគឺជាបទបញ្ញត្តិគ្រប់គ្រងមួយ គឺគ្មានការលើកលែងចំពោះនរណាម្នាក់ឡើយ។ នៅចុងបញ្ចប់ អ្នកប្រព្រឹត្តអំពើសុចរិត គឺជាអ្នកប្រព្រឹត្តអំពើសុចរិត ហើយអ្នកប្រព្រឹត្តអំពើអាក្រក់ គឺជាអ្នកប្រព្រឹត្តអំពើអាក្រក់។ នៅទីបំផុត ពួកសុចរិតគង់នឹងត្រូវអនុញ្ញាតឲ្យរស់រានបន្ដ រីឯអ្នកប្រព្រឹត្តអាក្រក់ នឹងត្រូវបំផ្លាញចោល។ មនុស្សបរិសុទ្ធមាននូវភាពបរិសុទ្ធ។ ពួកគេមិនស្មោកគ្រោកនោះទេ។ មនុស្សស្មោកគ្រោក មាននូវភាពស្មោកគ្រោក ហើយគ្មានចំណែកណាមួយរបស់ពួកគេដែលបរិសុទ្ធឡើយ។ មនុស្សដែលនឹងត្រូវបំផ្លាញចោល គឺជាមនុស្សទុច្ចរិត ហើយមនុស្សដែលអាចរស់រានបន្ដបានគឺជាមនុស្សសុចរិត បើទោះបីជាកូនចៅរបស់មនុស្សទុច្ចរិតធ្វើនូវអំពើសុចរិត ហើយបើទោះបីជាឪពុកម្ដាយរបស់មនុស្សសុចរិត ប្រព្រឹត្តអំពើអាក្រក់ក៏ដោយ។ ប្ដីជឿ ប្រពន្ធមិនជឿ គ្មានអ្វីទាក់ទងគ្នាទេ ហើយកូនជឿនិងឪពុកម្ដាយមិនជឿ ក៏គ្មានអ្វីទាក់ទងគ្នាដែរ។ មនុស្សពីរប្រភេទនេះ គឺមិនចុះសម្រុងនឹងគ្នាទាល់តែសោះ។ នៅមុនពេលចូលទៅក្នុងសេចក្ដីសម្រាក មនុស្សមានសាច់ញាតិខាងរូបកាយ ប៉ុន្ដែនៅពេលដែលមនុស្សបានចូលទៅក្នុងសេចក្ដីសម្រាកហើយ គេនឹងលែងមានសាច់ញាតិខាងរូបកាយដែលត្រូវរំពុកនឹកដល់ទៀតហើយ។ អស់អ្នកណាដែលបំពេញភារកិច្ចរបស់ខ្លួន គឺជាសត្រូវរបស់អស់អ្នកដែលមិនបំពេញភារកិច្ចរបស់ខ្លួន។ អស់អ្នកណាដែលស្រឡាញ់ព្រះជាម្ចាស់ និងអ្នកដែលស្អប់ទ្រង់ ប្រឆាំងទាស់នឹងគ្នាទៅវិញទៅមក។ អស់អ្នកណាដែលនឹងចូលទៅក្នុងសេចក្ដីសម្រាក និងអ្នកដែលនឹងត្រូវបំផ្លាញ គឺជាសត្តនិករពីរប្រភេទដែលមិនចុះសម្រុងនឹងគ្នាឡើយ។ សត្តនិករដែលបំពេញភារកិច្ចរបស់ខ្លួន នឹងអាចរួចជីវិតបាន ចំណែកឯសត្តនិករដែលមិនបានបំពេញភារកិច្ចរបស់ខ្លួន នឹងក្លាយជារបស់ដែលត្រូវ

បំផ្លាញចោល ជាងនេះទៅទៀត វានឹងត្រូវបន្តរហូតដល់ អស់កល្បជានិច្ច។ តើអ្នកស្រឡាញ់ប្ដីរបស់អ្នក ដើម្បីបំពេញភារកិច្ចរបស់អ្នក ក្នុងនាមជាសត្តនិករដែលបានបង្កើតមកមែនទេ? តើអ្នកស្រឡាញ់ប្រពន្ធរបស់អ្នក ដើម្បីបំពេញភារកិច្ចរបស់អ្នក ក្នុងនាមជាសត្តនិករ ដែលបានបង្កើតមកមែនទេ? តើអ្នកមានកាតព្វកិច្ចចំពោះឪពុកម្ដាយអ្នកដែលមិនជឿ ដើម្បីបំពេញភារកិច្ចរបស់អ្នក ក្នុងនាមជាសត្តនិករដែលបានបង្កើតមកមែនទេ? តើទស្សនៈរបស់មនុស្សចំពោះការជឿលើព្រះជាម្ចាស់នោះ ខុសឬក៏ត្រូវ? តើហេតុអ្វីបានជាអ្នកជឿលើព្រះជាម្ចាស់? តើអ្នកចង់បានអ្វី? តើអ្នកស្រឡាញ់ព្រះជាម្ចាស់ដល់កម្រិតណា? អស់អ្នកណាដែលមិនអាចបំពេញភារកិច្ចរបស់ខ្លួនបានក្នុងនាមជាសត្តនិករដែលបានបង្កើតមក និងអ្នកដែលមិនអាចខិតខំប្រឹងប្រែងឲ្យអស់ពីចិត្តបាននោះ នឹងក្លាយជារបស់ដែលត្រូវបំផ្លាញចោល។ មានសម្ពន្ធភាពខាងរូបកាយជាច្រើន កើតមានឡើងរវាងមនុស្សនាពេលសព្វថ្ងៃ ព្រមទាំងមានសម្ពន្ធភាពជាសាច់សាលោហិតផងដែរ ប៉ុន្តែនៅពេលអនាគត សម្ពន្ធភាពទាំងអស់នេះ នឹងត្រូវបែកខ្ទាត់ខ្ទាយអស់។ អ្នកជឿនិងអ្នកមិនជឿ មិនអាចនឹងចុះសម្រុងគ្នាបានទេ តែផ្ទុយទៅវិញ ពួកគេប្រឆាំងគ្នាទៅវិញទៅមក។ អស់អ្នកណាដែលស្ថិតក្នុងសេចក្ដីសម្រាកនឹងជឿថា មានព្រះជាម្ចាស់មួយអង្គ ហើយគេនឹងចុះចូលនឹងព្រះជាម្ចាស់ ចំណែកឯអ្នកដែលរឹងចចេសនឹងព្រះជាម្ចាស់ សុទ្ធតែនឹងត្រូវបំផ្លាញចោលទាំងអស់។ នឹងលែងមានក្រុមគ្រួសារ នៅលើផែនដីនេះតទៅទៀតហើយ។ តើអាចនឹងមានសម្ពន្ធភាពជាឪពុកម្ដាយ ឬកូនចៅ ឬប្ដីប្រពន្ធទៀត ដោយរបៀបណា? ភាពមិនចុះសម្រុងគ្នាខ្លាំងនៃជំនឿ និងអជំនឿ នឹងធ្វើឲ្យសម្ពន្ធភាពខាងរូបកាយ មានភាពខុសគ្នាយ៉ាងខ្លាំង!

ដំបូងឡើយ ក្នុងចំណោមមនុស្សជាតិ គ្មានក្រុមគ្រួសារឡើយ។ មានតែមនុស្សប្រុស និងមនុស្សស្រីតែប៉ុណ្ណោះ ជាមនុស្សពីរប្រភេទផ្សេងគ្នា។ ពុំមានប្រទេស ពុំមានក្រុមគ្រួសារអ្វីឡើយ ប៉ុន្តែដោយសារសេចក្ដីពុករលួយរបស់មនុស្ស មនុស្សគ្រប់ប្រភេទទាំងអស់បានរៀបចំខ្លួនគេជាក្រុមបក្ខពួក ហើយក្រោយមកក៏បង្កើតជាប្រទេស និងក្រុមជនជាតិនានា។ ប្រទេស និងក្រុមជនជាតិទាំងអស់នេះ រួមមានក្រុមគ្រួសារតូចៗ

ហើយក្នុងលក្ខណៈនេះ មនុស្សគ្រប់ប្រភេទទាំងអស់ ត្រូវបានបែងចែកក្នុងចំណោមជាតិសាសន៍ជាច្រើន ផ្អែកតាមភាពខុសគ្នាខាងភាសា និងព្រំប្រទល់។ តាមពិតទៅ មិនថាមានជាតិសាសន៍ច្រើនប៉ុនណានៅក្នុងពិភពលោកនោះទេ មនុស្សមានបុព្វបុរសតែមួយប៉ុណ្ណោះ។ កាលដើមដំបូងឡើយ មានមនុស្សតែពីរប្រភេទតែប៉ុណ្ណោះ ហើយមនុស្សទាំងពីរប្រភេទនេះ គឺមនុស្សប្រុស និងមនុស្សស្រី។ ក៏ប៉ុន្តែ ដោយសារការវិវឌ្ឍន៍នៃកិច្ចការរបស់ព្រះជាម្ចាស់ ដោយសារចលនាប្រវត្តិសាស្ត្រ និងដោយសារការប្រែប្រួលទីតាំងភូមិសាស្ត្រក្នុងកម្រិតផ្សេងៗគ្នា មនុស្សទាំងពីរប្រភេទនេះ ក៏បានអភិវឌ្ឍទៅជាមនុស្សកាន់តែច្រើនប្រភេទថែមទៀត។ ជាធម្មតា មិនថាមនុស្សមានចម្រុះទៅដោយជាតិសាសន៍ច្រើនប៉ុនណានោះទេ មនុស្សទាំងអស់ នៅតែជាសត្តនិករដែលព្រះជាម្ចាស់បានបង្កើតមកដដែល។ មិនថាមនុស្សស្ថិតក្នុងជាតិសាសន៍ណាមួយឡើយ ពួកគេគឺជាសត្តនិកររបស់ទ្រង់។ ពួកគេទាំងអស់គ្នា គឺជាកូនចៅរបស់អ័ដាម និងអេវ៉ា។ ថ្វីបើពួកគេមិនត្រូវបានព្រះជាម្ចាស់បង្កើតមកដោយផ្ទាល់ព្រះហស្តទ្រង់ក្ដី ក៏ពួកគេនៅតែជាកូនចៅរបស់អ័ដាមនិងអេវ៉ា ដែលព្រះជាម្ចាស់បានបង្កើតមកដោយផ្ទាល់ដដែល។ មិនថាមនុស្សស្ថិតនៅក្នុងប្រភេទមនុស្សបែបណានោះទេ ពួកគេទាំងអស់គឺជាសត្តនិកររបស់ទ្រង់។ ដោយសារពួកគេជាមនុស្សដែលព្រះជាម្ចាស់បានបង្កើតមក នោះទិសដៅរបស់ពួកគេ គឺជាទិសដៅដែលមនុស្សគប្បីមាន ហើយពួកគេត្រូវបានញែកពីគ្នា ទៅតាមក្រឹត្យក្រមសម្រាប់រៀបចំមនុស្សលោក។ នេះមានន័យថា ទីបំផុត អ្នកប្រព្រឹត្តអាក្រក់ និងអ្នកសុចរិតទាំងអស់ គឺសុទ្ធតែជាសត្តនិករទាំងអស់។ សត្តនិករដែលប្រព្រឹត្តអាក្រក់ ចុងក្រោយនឹងត្រូវបំផ្លាញចោល ហើយសត្តនិករដែលប្រព្រឹត្តសុចរិត នឹងត្រូវរួចជីវិត។ នេះគឺជាការរៀបចំដ៏សមស្របបំផុតសម្រាប់សត្តនិករទាំងពីរប្រភេទនេះ។ ដោយសារការមិនស្ដាប់បង្គាប់របស់ពួកគេ ទោះបីជាពួកគេជាសន្តនិករដែលព្រះបានបង្កើតមកក្ដី ក៏អ្នកប្រព្រឹត្តអាក្រក់មិនអាចប្រកែកបានឡើយថា សាតាំងបានចាប់ចងពួកគេឡើយ ហើយដោយហេតុនេះ មិនអាចទទួលបានសេចក្ដីសង្គ្រោះឡើយ។ ផ្អែកតាមការពិតដែលថាពួកគេនឹងត្រូវរួចជីវិតនោះ សត្តនិករដែល

ប្រព្រឹត្តខ្លួនដោយសុចរិត មិនអាចបដិសេធបានឡើយថា ព្រះជាម្ចាស់បានបង្កើតពួកគេឡើងមក តែនៅមិនទាន់ទទួលបាននូវសេចក្តីសង្គ្រោះ បន្ទាប់ពីត្រូវបានសាតាំងធ្វើឲ្យពុករលួយ។ អ្នកប្រព្រឹត្តអាក្រក់ គឺជាអ្នកដែលមិនស្តាប់បង្គាប់ព្រះជាម្ចាស់។ ពួកគេគឺជាសត្តនិករដែលមិនអាចទទួលបានសេចក្តីសង្គ្រោះ ហើយត្រូវបានសាតាំងចាប់ទុកជាយូរណាស់មកហើយ។ មនុស្សដែលប្រព្រឹត្តអាក្រក់ក៏ជាមនុស្សដែរ។ ពួកគេជាមនុស្សដែលត្រូវបានធ្វើឲ្យពុករលួយដល់ឆ្អឹង និងមិនអាចទទួលសេចក្តីសង្គ្រោះបានឡើយ។ មនុស្សដែលប្រព្រឹត្តសុចរិត ក៏ត្រូវបានធ្វើឲ្យពុករលួយដូចជាសត្តនិករផ្សេងដែរ ប៉ុន្តែពួកគេជាមនុស្សដែលអាចផ្តាច់ខ្លួនចេញពីនិស្ស័យពុករលួយរបស់ពួកគេបាន និងមានសមត្ថភាពចុះចូលនឹងព្រះជាម្ចាស់បាន។ មនុស្សដែលប្រព្រឹត្តិសុចរិត មិនពេញប្រៀបទៅដោយសេចក្តីសុចរិតនោះទេ។ តែផ្ទុយទៅវិញ ពួកគេបានទទួលនូវសេចក្តីសង្គ្រោះ និងបានផ្តាច់ចេញពីនិស្ស័យពុករលួយរបស់ពួកគេ។ ពួកគេអាចចុះចូលនឹងព្រះជាម្ចាស់បាន។ ពួកគេនឹងប្រកាន់ខ្ជាប់ដោយបែបនេះរហូតដល់ទីបញ្ចប់ បើទោះបីមិនចាំបាច់និយាយថា ពួកគេមិនធ្លាប់ត្រូវបានសាតាំងធ្វើឲ្យពុករលួយក៏ដោយ។ ក្រោយពីកិច្ចការរបស់ព្រះជាម្ចាស់បានបញ្ចប់ ក្នុងចំណោមសត្តនិករទាំងអស់របស់ទ្រង់ នឹងមានអ្នកដែលនឹងត្រូវបំផ្លាញចោល និងអ្នកដែលនឹងត្រូវរួចខ្លួន។ នេះគឺជានិន្នាការដែលមិនអាចជៀសផុតបានឡើយនៅក្នុងកិច្ចការគ្រប់គ្រងរបស់ទ្រង់។ គ្មាននរណាម្នាក់អាចបដិសេធកិច្ចការនេះបានឡើយ។ អ្នកធ្វើអាក្រក់ នឹងមិនត្រូវអនុញ្ញាតឲ្យរួចខ្លួនបានឡើយ។ អ្នកដែលចុះចូល និងដើរតាមព្រះជាម្ចាស់រហូតដល់ទីបញ្ចប់ ប្រាកដជានឹងបាននៅរស់រាន។ ដោយសារកិច្ចការនេះ គឺជាកិច្ចការនៃការគ្រប់គ្រងរបស់មនុស្ស នោះនឹងមានអ្នកដែលត្រូវនៅ និងអ្នកដែលត្រូវផាត់ចោល។ ទាំងអស់នេះ គឺជាលទ្ធផលខុសៗគ្នាសម្រាប់មនុស្សពីរប្រភេទផ្សេងគ្នានេះ ហើយពួកគេគឺជាការរៀបចំដ៏ស័ក្តិសមបំផុតសម្រាប់សត្តនិកររបស់ព្រះជាម្ចាស់។ ការរៀបចំចុងក្រោយបង្អស់របស់ព្រះជាម្ចាស់សម្រាប់មនុស្ស គឺដើម្បីញែកពួកគេ ដោយបំបែកក្រុមគ្រួសារ កម្ទេចក្រុមជនជាតិ និងរំលាយព្រំប្រទល់ប្រទេស នៅក្នុងការរៀបចំមួយ

ដែលគ្មានក្រុមគ្រួសារ ឬព្រំប្រទល់ប្រទេសអ្វីឡើយ ដ្បិតក្រោយពីនោះមក មនុស្សគឺជាកូនចៅដែលចេញពីដូនតាតែមួយ និងជាស្នាព្រះហស្ដបង្កើតឡើងដោយព្រះជាម្ចាស់។ សរុបមក សត្តនិករដែលប្រព្រឹត្តិអាក្រក់នឹងត្រូវបានបំផ្លាញចោល ហើយសត្តនិករដែលស្ដាប់បង្គាប់ព្រះជាម្ចាស់ នឹងត្រូវរួចផុតជីវិត។ ក្នុងលក្ខណៈនេះ នឹងលែងមានក្រុមគ្រួសារ លែងមានប្រទេស ជាពិសេស គ្មានក្រុមជនជាតិនៅក្នុងគ្រានៃសេចក្ដីសម្រាកដែលនឹងចូលមកដល់នោះឡើយ។ មនុស្សទាំងពីរប្រភេទនេះ នឹងក្លាយជាប្រភេទមនុស្សដែលបរិសុទ្ធជាងគេបំផុត។ កាលដើមដំបូងឡើយ អ័ដាម និងអេវ៉ាត្រូវបានបង្កើតមក ដើម្បីឲ្យមនុស្សអាចមើលថែសព្វសារពើទាំងអស់នៅលើផែនដីនេះបាន។ កាលពីដើម មនុស្សលោក គឺជាម្ចាស់នៃសព្វសារពើទាំងអស់។ បំណងព្រះហឫទ័យរបស់ព្រះយេហូវ៉ានៅក្នុងការបង្កើតមនុស្សលោក គឺដើម្បីឲ្យពួកគេរស់នៅលើផែនដីនេះ និងដើម្បីមើលថែទាំ គ្រប់សារពើទាំងអស់ដែលនៅលើផែនដី ដ្បិតមនុស្សកាលពីដើមដំបូងឡើយ មិនត្រូវបានធ្វើឲ្យពុករលួយ និងមិនអាចប្រព្រឹត្តអំពើអាក្រក់បានឡើយ។ យ៉ាងណាក៏ដោយ ក្រោយពេលដែលមនុស្សត្រូវបានធ្វើឲ្យពុករលួយរួចហើយ ពួកគេលែងក្លាយជាអ្នកមើលថែគ្រប់សព្វសារពើទៀតហើយ។ គោលបំណងនៃសេចក្ដីសង្គ្រោះរបស់ព្រះជាម្ចាស់ គឺដើម្បីស្រោចស្រង់មុខងាររបស់មនុស្សមកវិញ ដើម្បីស្រោចស្រង់នូវមូលហេតុដើម និងការស្ដាប់បង្គាប់ពីដើមរបស់មនុស្ស ត្រឡប់មកវិញ។ ការដែលមនុស្សស្ថិតក្នុងសេចក្ដីសម្រាក នឹងក្លាយជាការតំណាងឲ្យលទ្ធផលដែលព្រះជាម្ចាស់សង្ឃឹមសម្រេចបាន នៅក្នុងកិច្ចការនៃសេចក្ដីសង្គ្រោះរបស់ទ្រង់។ បើទោះបីជាជីវិតនេះលែងជាជីវិតមួយដូចជាជីវិតនៅក្នុងសួនច្បារអេដែនក្ដី ក៏សារជាតិរបស់ពួកគេនៅដូចគ្នាដដែល។ មនុស្សនឹងលែងក្លាយជាមនុស្សនៅដើមដំបូង ដែលមិនមានការពុករលួយ ប៉ុន្តែផ្ទុយទៅវិញ នឹងក្លាយជាមនុស្សជាតិដែលបានពុករលួយ និងក្រោយមកក៏ទទួលបាននូវសេចក្ដីសង្គ្រោះ។ មនុស្សទាំងអស់ដែលបានទទួលនូវសេចក្ដីសង្គ្រោះ ចុងក្រោយ (ពោលគឺ បន្ទាប់ពីកិច្ចការរបស់ព្រះជាម្ចាស់បានបំពេញរួច) នឹងចូលទៅក្នុងសេចក្ដីសម្រាក។ ដូចគ្នានេះដែរ លទ្ធផលនៃអ្នកដែលនឹងត្រូវទទួល

ទោស ក៏នឹងត្រូវបើកសម្ដែងឲ្យឃើញទាំងស្រុងនៅទីចុងបំផុតដែរ ហើយពួកគេនឹងត្រូវបំផ្លាញចោល បន្ទាប់ពីកិច្ចការរបស់ព្រះជាម្ចាស់ត្រូវបានបញ្ចប់។ ម្យ៉ាងវិញទៀត ក្រោយពេលកិច្ចការរបស់ទ្រង់ត្រូវបានបញ្ចប់ អ្នកប្រព្រឹត្តអាក្រក់ទាំងអស់នោះ ព្រមទាំងអ្នកដែលត្រូវបានសង្គ្រោះ នឹងសុទ្ធតែត្រូវបើកបង្ហាញឲ្យឃើញទាំងអស់ ដ្បិតកិច្ចការ នៃការបើកសម្ដែងគ្រប់ប្រភេទទាំងអស់របស់មនុស្ស (មិនថាពួកគេជាអ្នកប្រព្រឹត្តអាក្រក់ ឬក្នុងចំណោមអ្នកដែលត្រូវបានសង្គ្រោះឡើយ) នឹងត្រូវអនុវត្តចំពោះមនុស្សគ្រប់គ្នា ក្នុងពេលតែមួយ។ អ្នកប្រព្រឹត្តអំពើអាក្រក់នឹងត្រូវផាត់ចោល ហើយអ្នកដែលត្រូវបានអនុញ្ញាតឲ្យបន្តរស់នៅ នឹងត្រូវបើកបង្ហាញនៅក្នុងពេលជាមួយគ្នានោះដែរ។ ហេតុនេះ លទ្ធផលរបស់មនុស្សគ្រប់ប្រភេទទាំងអស់ នឹងត្រូវបើកសម្ដែងនៅក្នុងពេលជាមួយគ្នានោះដែរ។ ព្រះជាម្ចាស់នឹងមិនអនុញ្ញាតឲ្យមនុស្សមួយក្រុមណា ដែលមិនទទួលបានសេចក្ដីសង្គ្រោះ ចូលទៅក្នុងសេចក្ដីសម្រាកនៅមុនពេលញែកអ្នកប្រព្រឹត្តអាក្រក់ទុកមួយឡែក និងជំនុំជម្រះ និងដាក់ទោសលើពួកគេបន្តិចម្ដងៗនោះទេ។ កិច្ចការបែបនេះនឹងមិនស្របគ្នាជាមួយនឹងការពិតឡើយ។ នៅពេលអ្នកប្រព្រឹត្តអាក្រក់ត្រូវបានបំផ្លាញ ហើយពេលដែលអ្នករួចខ្លួន ចូលទៅក្នុងសេចក្ដីសម្រាក នោះកិច្ចការរបស់ព្រះជាម្ចាស់នៅទូទាំងសាកលលោកទាំងមូល នឹងត្រូវបញ្ចប់។ នឹងលែងមានលំដាប់លំដោយអាទិភាពក្នុងចំណោមមនុស្សដែលទទួលបានព្រះពរ និងអ្នកដែលទទួលរងសំណាងអាក្រក់ទៀតហើយ។ អ្នកដែលទទួលបានព្រះពរនឹងរស់នៅជារៀងរហូត ចំណែកឯអ្នកដែលទទួលរងសំណាងអាក្រក់ នឹងត្រូវវិនាសហិនហោចអស់កល្បជានិច្ច។ ដំណាក់កាលទាំងពីរនៃកិច្ចការនេះ នឹងត្រូវបញ្ចប់ក្នុងពេលដំណាលគ្នា។ ច្បាស់ណាស់ គឺដោយសារការកើតមាននូវមនុស្សដែលមិនស្ដាប់បង្គាប់នេះហើយ ទើបត្រូវបើកសម្ដែងឲ្យឃើញនូវសេចក្ដីសុចរិតរបស់អ្នកដែលចុះចូល ហើយច្បាស់ណាស់ គឺដោយសារមានអ្នកដែលទទួលបាននូវព្រះពរនេះហើយ ទើបត្រូវបើកសម្ដែងពីសំណាងអាក្រក់ ដែលអ្នកដែលមានឥរិយាបថអាក្រក់ទទួលរង។ ប្រសិនបើព្រះជាម្ចាស់ មិនលាតត្រដាងពីអ្នកប្រព្រឹត្តអាក្រក់ទេ នោះមនុស្សដែលចុះចូលនឹងព្រះ

ជាម្ចាស់ដោយចិត្តស្មោះ នឹងមិនដែលឃើញព្រះអាទិត្យឡើយ។ ប្រសិនបើព្រះជាម្ចាស់ ពុំបាននាំយកអ្នកដែលចុះចូលនឹងទ្រង់ ទៅកាន់ទិសដៅសមស្របណាមួយទេ នោះ មនុស្សដែលមិនស្ដាប់បង្គាប់ព្រះជាម្ចាស់ នឹងមិនអាចទទួលបាននូវការដាក់ទោស ដែលពួកគេ សមនឹងទទួលបានឡើយ។ នេះគឺជាដំណើរការ នៃកិច្ចការរបស់ព្រះ ជាម្ចាស់។ ប្រសិនបើទ្រង់មិនបានបំពេញកិច្ចការនៃការដាក់ទោសអំពើអាក្រក់ ហើយ ប្រទានរង្វាន់ដល់អំពើល្អទេ នោះសត្តនិកររបស់ទ្រង់ នឹងមិនអាចចូលទៅក្នុងទិសដៅ រៀងៗខ្លួនរបស់ពួកគេបានឡើយ។ នៅពេលដែលមនុស្សបានចូលទៅក្នុងសេចក្ដី សម្រាករួចហើយ អ្នកប្រព្រឹត្តអាក្រក់នឹងត្រូវបានបំផ្លាញចោលហើយមនុស្សជាតិ ទាំងអស់ នឹងបានដើរនៅលើផ្លូវត្រូវ។ មនុស្សគ្រប់ប្រភេទទាំងអស់ នឹងបានចូលទៅ ក្នុងប្រភេទរៀងៗខ្លួន ស្របទៅតាមមុខងារដែលពួកគេគប្បីបំពេញ។ មានតែបែបនេះ ទេ ទើបជាថ្ងៃសម្រាករបស់មនុស្ស វានឹងក្លាយជារឿងដែលមិនអាចជៀសផុតបាន សម្រាប់ការវិវឌ្ឍន៍របស់មនុស្ស ហើយមានតែពេលដែលមនុស្សជាតិ ចូលទៅក្នុង សេចក្ដីសម្រាកប៉ុណ្ណោះ ទើបសមិទ្ធផលដ៏អស្ចារ្យនិងសមិទ្ធផលចុងក្រោយបង្អស់ របស់ព្រះជាម្ចាស់ បានចូលដល់ទីបញ្ចប់។ នេះគឺជាផ្នែកចុងបញ្ចប់នៃកិច្ចការរបស់ ទ្រង់។ កិច្ចការនេះនឹងត្រូវបញ្ចប់នូវជីវិតដុនដាបរបស់មនុស្សនៅខាងសាច់ឈាម ក៏ដូចជាជីវិតរបស់មនុស្សដែលពុករលួយផងដែរ។ ចាប់ពេលនោះតទៅ មនុស្សលោក នឹងត្រូវចូលទៅក្នុងពិភពថ្មីមួយ។ បើទោះជាមនុស្សទាំងអស់ នឹងរស់នៅខាងសាច់ ឈាមក្ដី ក៏សារជាតិនៃជីវិតនេះ និងជីវិតរបស់មនុស្សពុករលួយ នឹងមានភាពខុសគ្នា យ៉ាងខ្លាំងដែរ។ សារជាតិសំខាន់នៃការរស់នៅនេះ និងសារជាតិនៃវត្តមានរបស់ មនុស្សដែលពុករលួយ ក៏ខុសគ្នាផងដែរ។ បើទោះជាជីវិតនេះនឹងមិនមែនជាជីវិតរបស់ មនុស្សប្រភេទថ្មីក្ដី ក៏អាចនិយាយបានថា ជាជីវិតនៃមនុស្សដែលបានទទួលនូវសេចក្ដី សង្គ្រោះ ក៏ដូចជាជីវិតមួយដែលមនុស្សនិងវិចារណញាណ ទទួលបានមកវិញ។ មនុស្សទាំងអស់នេះ គឺជាមនុស្សដែលធ្លាប់មិនស្ដាប់បង្គាប់ព្រះជាម្ចាស់ ជាមនុស្ស ដែលត្រូវបានព្រះជាម្ចាស់បង្ក្រាប ហើយបន្ទាប់មកត្រូវបានទ្រង់សង្គ្រោះដោយសារ

ទ្រង់។ មនុស្សទាំងអស់នេះ គឺជាមនុស្សដែលមិនគោរពព្រះជាម្ចាស់ ហើយក្រោយមក បានធ្វើទីបន្ទាល់សម្រាប់ទ្រង់។ ក្រោយពីពួកគេបានឆ្លងកាត់ និងបានរួចផុតពីការសាកល្បងរបស់ទ្រង់ វត្តមានរបស់ពួកគេ នឹងក្លាយជាវត្តមានដែលមានអត្ថន័យបំផុត។ ពួកគេគឺជាមនុស្សដែលធ្វើទីបន្ទាល់អំពីព្រះជាម្ចាស់នៅចំពោះមុខសាតាំង ហើយគឺជាមនុស្សលោកដែលស័ក្តិសមនឹងរស់នៅ។ អ្នកដែលនឹងត្រូវបំផ្លាញចោល គឺជាអ្នកដែលមិនអាចធ្វើទីបន្ទាល់ចំពោះព្រះជាម្ចាស់បាន និងមិនស័ក្តិសមនឹងបន្តរស់នៅឡើយ។ ការបំផ្លាញលើពួកគេ នឹងមកពីលទ្ធផលនៃអាកប្បកិរិយាអាក្រក់របស់ពួកគេ ហើយការធ្វើឲ្យពួកគេវិនាសសាបសូន្យបែបនេះ គឺជាទិសដៅល្អបំផុត។ នៅពេលអនាគត នៅពេលដែលមនុស្សជាតិចូលទៅក្នុងពិភពដ៏ស្រស់ស្អាត នោះនឹងលែងមានទំនាក់ទំនងរវាងប្ដីនិងប្រពន្ធ ទំនាក់ទំនងរវាងឪពុក និងកូនស្រី ឬទំនាក់ទំនងរវាងម្ដាយនិងកូនប្រុសទៀតហើយ ដែលមនុស្សស្រមៃថា ពួកគេនឹងអាចរកឃើញ។ នៅពេលនោះ មនុស្សម្នាក់ៗនឹងដើរតាមប្រភេទរៀងៗខ្លួន ហើយក្រុមគ្រួសារនឹងត្រូវបែកខ្ញែកពីគ្នា។ ដោយរងបរាជ័យទាំងស្រុងបែបនេះ សាតាំងនឹងមិនរំខានមនុស្សជាតិជាថ្មីទៀតឡើយ ហើយមនុស្សលោកនឹងលែងមាននិស្ស័យពុករលួយរបស់សាតាំងទៀតដែរ។ មនុស្សដែលមិនស្ដាប់បង្គាប់ នឹងត្រូវបានបំផ្លាញចោល ហើយមានតែមនុស្សដែលចុះចូលប៉ុណ្ណោះ ដែលនឹងបន្តរស់នៅបាន។ ដូច្នេះ មានក្រុមគ្រួសារតិចតួចណាស់ដែលនឹងរួចផុតពីភាពហ្មងសៅនេះ។ តើទំនាក់ទំនងខាងរូបកាយ អាចបន្តកើតមានបានដោយរបៀបណា? ជីវិតខាងសាច់ឈាមរបស់មនុស្សពីមុន នឹងត្រូវហាមឃាត់ជាដាច់ខាត។ តើទំនាក់ទំនងខាងរូបកាយអាចកើតមានក្នុងចំណោមមនុស្សបានដោយរបៀបណា? បើគ្មាននិស្ស័យពុករលួយរបស់សាតាំងទេ ជីវិតរបស់មនុស្សលោកនឹងលែងជាជីវិតចាស់ នៅក្នុងពេលអតីតកាលទៀតហើយ ប៉ុន្តែជាជីវិតថ្មីមួយ។ ឪពុកម្ដាយនឹងបាត់បង់កូនចៅ ហើយកូនចៅនឹងបាត់បង់ឪពុកម្ដាយ។ ប្ដីនឹងបាត់បង់ប្រពន្ធ ហើយប្រពន្ធនឹងបាត់បង់ប្ដី។ បច្ចុប្បន្ន ទំនាក់ទំនងខាងរូបកាយ កើតមានក្នុងចំណោមមនុស្សលោក ប៉ុន្តែពួកគេនឹងលែងកើតមានទៀតឡើយ នៅពេលដែលមនុស្សគ្រប់គ្នាបានចូលទៅ

ក្នុងសេចក្ដីសម្រាក។ មានតែមនុស្សជាតិប្រភេទនេះទេ ទើបមាននូវសេចក្ដីសុចរិតនិងភាពបរិសុទ្ធ។ មានតែមនុស្សជាតិប្រភេទនេះទេ ទើបអាចថ្វាយបង្គំព្រះជាម្ចាស់បាន។

ព្រះជាម្ចាស់បានបង្កើតមនុស្សលោក និងដាក់ពួកគេនៅលើផែនដី ហើយទ្រង់បានដឹកនាំពួកគេចាប់តាំងពីពេលនោះមក។ ក្រោយមក ទ្រង់ក៏បានសង្គ្រោះពួកគេ និងធ្វើជាតង្វាយលោះបាបសម្រាប់មនុស្សជាតិ។ នៅទីបំផុត ទ្រង់នៅតែត្រូវយកឈ្នះលើមនុស្សជាតិ សង្គ្រោះមនុស្សលោកទាំងមូល និងស្រោចស្រង់ពួកគេទៅរកលក្ខណៈដើមរបស់ពួកគេវិញ។ នេះគឺជាកិច្ចការដែលទ្រង់បានចូលរួមធ្វើ ចាប់តាំងពីគ្រាដំបូងមកម្ល៉េះ ជាការស្រោចស្រង់មនុស្សទៅរករូបអង្គ និងលក្ខណៈដើមរបស់ពួកគេវិញ។ ព្រះជាម្ចាស់នឹងបង្កើតនគរស្ថានសួគ៌របស់ទ្រង់ និងស្រោចស្រង់លក្ខណៈដើមរបស់មនុស្សជាតិត្រឡប់មកវិញ ដែលមានន័យថា ព្រះជាម្ចាស់នឹងស្រោចស្រង់នូវសិទ្ធិអំណាចរបស់ទ្រង់នៅលើផែនដី និងក្នុងចំណោមសត្តនិករទាំងអស់ត្រឡប់មកវិញ។ មនុស្សជាតិបានបាត់បង់នូវចិត្ត ដែលកោតខ្លាចព្រះជាម្ចាស់ ក៏ដូចជាមុខងារដែលប្រគល់ឲ្យសត្តនិកររបស់ព្រះជាម្ចាស់ ក្រោយពីត្រូវសាតាំងធ្វើឲ្យពុករលួយ ហើយបានក្លាយជាសត្រូវមិនស្ដាប់បង្គាប់ព្រះជាម្ចាស់។ ក្រោយមកទៀត មនុស្សជាតិរស់នៅក្រោមដែនត្រួតត្រារបស់សាតាំង និងបានដើរតាមការបញ្ជារបស់សាតាំង។ ហេតុនេះ ព្រះជាម្ចាស់គ្មានផ្លូវណាត្រូវបំពេញកិច្ចការក្នុងចំណោមសត្តនិកររបស់ទ្រង់ឡើយ ហើយកាន់តែមិនអាចយកឈ្នះលើការគោរពកោតខ្លាចដែលពោរពេញដោយការខ្លាចរអារនោះទេ។ មនុស្សលោកត្រូវបានព្រះជាម្ចាស់បង្កើតមក ហើយត្រូវថ្វាយបង្គំព្រះជាម្ចាស់ ប៉ុន្តែពួកគេទៅជាបែរខ្នងដាក់ទ្រង់ និងថ្វាយបង្គំសាតាំងទៅវិញ។ សាតាំងបានក្លាយជាព្រះក្លែងក្លាយនៅក្នុងដួងចិត្តរបស់ពួកគេ។ ហេតុនេះ ព្រះជាម្ចាស់បានបាត់បង់នូវកន្លែងរបស់ទ្រង់នៅក្នុងដួងចិត្តរបស់ពួកគេ ដែលមានន័យថា ទ្រង់បានបាត់បង់នូវអត្ថន័យនៅពីក្រោយការបង្កើតមនុស្សជាតិរបស់ទ្រង់។ ហេតុនេះ ដើម្បីស្រោចស្រង់នូវអត្ថន័យនៅពីក្រោយការបង្កើតមនុស្សជាតិរបស់ទ្រង់ត្រឡប់មកវិញ ទ្រង់ត្រូវតែស្រោចស្រង់នូវភាពជាមនុស្សដើមរបស់ពួកគេត្រឡប់មកវិញ និងបំផ្លាស់

បំប្រែនិស្ស័យពុករលួយរបស់ពួកគេចេញ។ ដើម្បីទាមទារយកមនុស្សពីសាតាំងវិញ ទ្រង់ត្រូវសង្គ្រោះពួកគេឲ្យរួចពីបាបសិន។ មានតែតាមរបៀបនេះទេ ទើបព្រះជាម្ចាស់អាចស្រោចស្រង់លក្ខណៈដើម និងមុខងាររបស់ពួកគេត្រឡប់មកវិញ ហើយចុងក្រោយ ក៏ស្រោចស្រង់នូវនគរស្ថានសួគ៌របស់ទ្រង់ត្រឡប់មកវិញ។ ការបំផ្លាញជាចុងក្រោយបង្អស់លើកូនដែលមិនស្ដាប់បង្គាប់ទាំងនោះ ក៏នឹងត្រូវអនុវត្តដើម្បីឲ្យមនុស្សបានថ្វាយបង្គំព្រះជាម្ចាស់ប្រសើរជាងមុនដែរ ហើយនឹងរស់នៅលើផែនដីនេះបានប្រសើរជាងមុន។ ដោយសារព្រះជាម្ចាស់បានបង្កើតមនុស្សលោកមក ទើបទ្រង់ត្រូវធ្វើឲ្យពួកគេថ្វាយបង្គំទ្រង់។ ដោយសារទ្រង់ចង់ស្រោចស្រង់មុខងារដើម របស់មនុស្សជាតិត្រឡប់មកវិញ ទើបទ្រង់ត្រូវស្រោចស្រង់មុខងារនោះឲ្យបានទាំងស្រុងដោយគ្មានការធិតក្បត់ឡើយ។ ការស្រោចស្រង់សិទ្ធិអំណាចរបស់ទ្រង់មានន័យថាការធ្វើឲ្យមនុស្សថ្វាយបង្គំទ្រង់ និងចុះចូលចំពោះទ្រង់។ វាមានន័យថាព្រះជាម្ចាស់នឹងធ្វើឲ្យមនុស្សជាតិរស់នៅដោយសារទ្រង់ និងធ្វើឲ្យសត្រូវរបស់ទ្រង់វិនាសហិនហោចដោយសារសិទ្ធិអំណាចរបស់ទ្រង់។ វាមានន័យថា ព្រះជាម្ចាស់នឹងធ្វើឲ្យសព្វសារពើររបស់ទ្រង់បន្តស្ថិតនៅក្នុងចំពោះមនុស្សជាតិ ដោយគ្មានការប្រឆាំងទាស់ពីនរណាម្នាក់ឡើយ។ នគរស្ថានសួគ៌ដែលព្រះជាម្ចាស់ចង់បង្កើត គឺជានគរស្ថានសួគ៌របស់ទ្រង់ផ្ទាល់។ មនុស្សជាតិដែលទ្រង់ចង់បាន គឺជាមនុស្សដែលនឹងថ្វាយបង្គំទ្រង់ ជាមនុស្សដែលនឹងចុះចូលចំពោះទ្រង់ទាំងស្រុង និងផ្សាយនូវសិរីល្អរបស់ទ្រង់។ ប្រសិនបើព្រះជាម្ចាស់ពុំបានសង្គ្រោះមនុស្សជាតិដែលពុករលួយទេ នោះអត្ថន័យពីក្រោយការបង្កើតមនុស្សជាតិរបស់ទ្រង់ នឹងត្រូវបាត់បង់។ ទ្រង់នឹងមិនមានសិទ្ធិអំណាចកាន់តែច្រើនក្នុងចំណោមមនុស្សជាតិ ហើយនគរស្ថានសួគ៌របស់ទ្រង់ នឹងលែងអាចកើតមាននៅលើផែនដីនេះទៀតហើយ។ ប្រសិនបើព្រះជាម្ចាស់ពុំបានបំផ្លាញសត្រូវទាំងនោះដែលមិនស្ដាប់បង្គាប់ទ្រង់ទេ ទ្រង់នឹងមិនអាចទទួលបាននូវសិរីល្អពេញលេញរបស់ទ្រង់បានឡើយ ហើយទ្រង់ក៏នឹងមិនអាចបង្កើតនគរស្ថានសួគ៌របស់ទ្រង់នៅលើផែនដីនេះបានដែរ។ ទាំងអស់នេះ នឹងក្លាយជាទីសម្គាល់នៃការបញ្ចប់

កិច្ចការរបស់ទ្រង់ និងជាជោគជ័យដ៏អស្ចារ្យរបស់ទ្រង់៖ ក្នុងការបំផ្លាញដល់អ្នកដែលនៅស្ថិតក្នុងចំណោម មនុស្សជាតិដែលមិនស្ដាប់បង្គាប់ទ្រង់ និងក្នុងការនាំអ្នកដែលបានធ្វើឲ្យពេញខ្នាតចូលទៅក្នុងសេចក្ដីសម្រាក។ នៅពេលដែលមនុស្សលោកត្រូវបានស្រោចស្រង់មកជាលក្ខណៈដើមរបស់ពួកគេវិញ ហើយនៅពេលដែលពួកគេអាចបំពេញភារកិច្ចរៀងៗខ្លួន រក្សាទីតាំងត្រឹមត្រូវរបស់ខ្លួន និងចុះចូលនឹងការរៀបចំទាំងអស់របស់ព្រះជាម្ចាស់បាន នោះព្រះជាម្ចាស់នឹង ទទួលយកមនុស្សមួយក្រុមនៅលើផែនដីដែលថ្វាយបង្គំទ្រង់ ហើយទ្រង់ក៏នឹងបានបង្កើតនគរមួយនៅលើផែនដីដែលថ្វាយបង្គំទ្រង់ផងដែរ។ ទ្រង់នឹងមានជ័យជម្នះជាអស់កល្បជានិច្ចនៅលើផែនដីនេះ ហើយអ្នកដែលប្រឆាំងនឹងទ្រង់ នឹងត្រូវវិនាសហិនហោចជាអស់កល្បជានិច្ច។ កិច្ចការនេះនឹងស្រោចស្រង់នូវបំណងព្រះហឫទ័យដើមរបស់ទ្រង់នៅក្នុងការបង្កើតមនុស្សជាតិនេះត្រឡប់មកវិញ។ វានឹងស្រោចស្រង់ នូវបំណងព្រះហឫទ័យរបស់ទ្រង់ក្នុងការបង្កើតគ្រប់សព្វសារពើ ហើយក៏នឹងស្រោចស្រង់នូវសិទ្ធិអំណាចរបស់ទ្រង់នៅលើផែនដី ក្នុងចំណោមគ្រប់សព្វសារពើ និងក្នុងចំណោមសត្រូវរបស់ទ្រង់ត្រឡប់មកវិញផងដែរ។ ទាំងអស់នេះ នឹងក្លាយជានិមិត្តរូបនៃជ័យជម្នះទាំងស្រុងរបស់ទ្រង់។ ចាប់ពីពេលនោះមក មនុស្សជាតិនឹងចូលទៅក្នុងសេចក្ដីសម្រាក និងចាប់ផ្ដើមជីវិតមួយដែលស្ថិតនៅលើផ្លូវត្រូវ។ ព្រះជាម្ចាស់ ក៏នឹងចូលទៅក្នុងសេចក្ដីសម្រាកជាអស់កល្បជានិច្ចជាមួយមនុស្សជាតិផងដែរ និងចាប់ផ្ដើមជីវិតដ៏អស់កល្បជានិច្ច រួមគ្នាដោយទ្រង់ផ្ទាល់ព្រះអង្គ និងដោយមនុស្សលោក។ ភាពស្មោកគ្រោក និងការមិនស្ដាប់បង្គាប់នៅលើផែនដី នឹងត្រូវបាត់អស់ ហើយអ្នកស្រែកទ្ងូញថ្ងូរ នឹងបានរសាយចិត្ត ហើយគ្រប់សព្វសារពើទាំងអស់នៅក្នុងពិភពលោកនេះ ដែលប្រឆាំងទាស់នឹងព្រះជាម្ចាស់ នឹងត្រូវឈប់កើតមានទៀត។ មានតែព្រះជាម្ចាស់ និងអ្នកដែលទទួលបាននូវសេចក្ដីសង្គ្រោះរបស់ទ្រង់ប៉ុណ្ណោះ ដែលនឹងនៅបន្តទៀត។ មានតែសព្វសារពើដែលទ្រង់បង្កើតមកប៉ុណ្ណោះ ដែលនឹងត្រូវនៅបន្តទៀត។

# ទម្រាំដល់ពេលដែលអ្នក បានឃើញព្រះកាយខាងវិញ្ញាណ របស់ព្រះយេស៊ូវពីចម្ងាយ នោះព្រះជាម្ចាស់បានបង្កើតឋានសួគ៌ និងផែនដីថ្មីរួចស្រេចបាត់ទៅហើយ

តើអ្នកចង់ឃើញព្រះយេស៊ូវ ដែរឬទេ? តើអ្នកចង់រស់នៅជាមួយព្រះយេស៊ូវដែរឬទេ? តើអ្នកចង់ឮព្រះបន្ទូលដែលចេញមកពីព្រះឱស្ឋ ព្រះយេស៊ូវដែរឬទេ? ប្រសិនបើអ្នកចង់ តើអ្នកនឹងត្រូវស្វាគមន៍ការយាងត្រឡប់មកវិញរបស់ព្រះយេស៊ូវ ដោយវិធីណា? តើអ្នកបានប្រុងប្រៀបស្រេចហើយឬនៅ? តើអ្នកនឹងស្វាគមន៍ការយាងត្រឡប់មកវិញរបស់ព្រះយេស៊ូវ ដោយឥរិយាបថបែបណា? ខ្ញុំគិតថា បងប្អូនប្រុសស្រីគ្រប់គ្នាដែលដើរតាមព្រះយេស៊ូវ ចង់ទទួលស្វាគមន៍ទ្រង់ឲ្យបានល្អ។ ប៉ុន្តែ តើអ្នករាល់គ្នាបានពិចារណាចំណុចនេះទេថា៖ នៅពេលដែលទ្រង់យាងត្រឡប់មកវិញ តើអ្នកនឹងស្គាល់ព្រះយេស៊ូវពិតប្រាកដដែរឬទេ? តើអ្នករាល់គ្នានឹងយល់អ្វីៗគ្រប់យ៉ាង ដែលទ្រង់មានព្រះបន្ទូលពិតប្រាកដដែរឬទេ? តើអ្នករាល់គ្នានឹងទទួលយកកិច្ចការទាំងអស់ ដែលទ្រង់ធ្វើដោយឥតលក្ខខណ្ឌ ពិតប្រាកដដែរឬទេ? អស់អ្នកដែលបានអានព្រះគម្ពីរ គឺសុទ្ធតែដឹងអំពីការយាងត្រឡប់មកវិញរបស់ព្រះយេស៊ូវ ហើយអស់អ្នកដែលបានអានព្រះគម្ពីរ ក៏សុទ្ធតែទន្ទឹងរង់ចាំការយាងត្រឡប់មកវិញរបស់ទ្រង់ដោយចិត្តស្មោះត្រង់ដែរ។ អ្នករាល់គ្នាសុទ្ធតែខ្វាយខ្វល់ក្នុងចិត្ត ចំពោះការមកដល់នៃគ្រានោះ ហើយភាពស្មោះត្រង់របស់អ្នករាល់គ្នា ពិតជាគួរឲ្យកោតស្ញប់ស្ញែង ជំនឿរបស់អ្នករាល់គ្នាពិតជាល្អគួរឲ្យច្រណែន ប៉ុន្តែ តើអ្នករាល់គ្នាដឹងទេថា អ្នករាល់គ្នាបានប្រព្រឹត្តនូវកំហុសមួយយ៉ាងធ្ងន់? តើព្រះយេស៊ូវនឹងយាងត្រឡប់មកវិញក្នុងលក្ខណៈដូចម្តេច? អ្នករាល់គ្នាជឿថា ព្រះយេស៊ូវនឹងយាងត្រឡប់មកវិញនៅលើដុំពពកស ប៉ុន្តែខ្ញុំសូមសួរអ្នករាល់គ្នាថាតើដុំពពកសមួយនេះសំដៅលើអ្វី? មានអ្នកដើរតាមព្រះយេស៊ូវច្រើនណាស់ កំពុងទន្ទឹងរង់ចាំការយាងត្រឡប់មកវិញរបស់ទ្រង់ តើទ្រង់នឹងយាងចុះមកវិញក្នុងចំណោម

ក្រុមមនុស្សណាមួយ? ប្រសិនបើអ្នករាល់គ្នាស្ថិតក្នុងចំណោមក្រុមមនុស្សដំបូងគេដែលព្រះយេស៊ូវយាងចុះមក តើអ្នកដទៃទៀតនឹងមិនយល់ថា នេះគឺជាអំពើអយុត្តិធម៌ដែលមិនអាចទទួលយកបានទេឬអី? ខ្ញុំដឹងថា អ្នករាល់គ្នាមានភាពស្មោះត្រង់ និងមានភក្ដីភាពចំពោះព្រះយេស៊ូវខ្លាំងណាស់ ប៉ុន្តែ តើអ្នករាល់គ្នាធ្លាប់ជួបព្រះយេស៊ូវដែរឬទេ? តើអ្នករាល់គ្នាស្គាល់និស្ស័យរបស់ទ្រង់ដែរឬទេ? តើអ្នករាល់គ្នាធ្លាប់រស់នៅជាមួយទ្រង់ដែរឬទេ? តើអ្នករាល់គ្នាយល់ពីទ្រង់ច្បាស់ប៉ុនណា? អ្នកខ្លះមុខជានិយាយថា សម្ដីទាំងនេះធ្វើឲ្យពួកគេស្ថិតក្នុងស្ថានការណ៍មួយដ៏អាម៉ាស់។ ពួកគេមុខជានិយាយថា «ខ្ញុំបានអានព្រះគម្ពីរពីដើមដល់ចប់ ជាច្រើនលើកច្រើនសា។ ម្ដេចក៏ថាខ្ញុំមិនយល់ពីព្រះយេស៊ូវ? កុំថាដល់និស្ស័យរបស់ព្រះយេស៊ូវ សូម្បីតែពណ៌សម្លៀកបំពាក់ដែលទ្រង់សព្វព្រះហឫទ័យ ក៏ខ្ញុំដឹងដែរ។ នៅពេលដែលអ្នកនិយាយថា ខ្ញុំមិនយល់អំពីទ្រង់ តើអ្នកមិនមែនកំពុងតែមើលងាយខ្ញុំទេឬអី?» ខ្ញុំសូមទូន្មានអ្នកទៅចុះថា កុំទៅប្រកែកគ្នាពីរឿងទាំងនេះអី យកល្អគួរធ្វើចិត្តឲ្យស្ងប់ រួចជុំគ្នាជជែកអំពីសំណួរដូចតទៅនេះវិញ៖ ទីមួយ តើអ្នកដឹងទេថា អ្វីទៅជាភាពជាក់ស្ដែង ហើយអ្វីទៅជាទ្រឹស្ដី? ទីពីរ តើអ្នកដឹងទេថា អ្វីទៅជាការសន្មត ហើយអ្វីទៅជាសេចក្ដីពិត? ទីបី តើអ្នកដឹងទេថា អ្វីទៅជាការស្រមើស្រមៃ ហើយអ្វីទៅជាការពិត?

មនុស្សខ្លះបដិសេធការពិតដែលថា ពួកគេមិនស្គាល់ព្រះយេស៊ូវ។ ហើយខ្ញុំនៅតែនិយាយថា អ្នករាល់គ្នាមិនយល់ពីទ្រង់សូម្បីតែបន្តិច ហើយក៏មិនយល់ពីព្រះបន្ទូលរបស់ព្រះយេស៊ូវសូម្បីមួយម៉ាត់ដែរ។ នេះមកពីអ្នករាល់គ្នាដើរតាមទ្រង់ ដោយសារកំណត់ហេតុក្នុងព្រះគម្ពីរ និងដោយសារអ្វីដែលអ្នកដទៃបាននិយាយ។ អ្នករាល់គ្នាមិនធ្លាប់ឃើញព្រះយេស៊ូវសោះ ក៏រឹតតែមិនធ្លាប់រស់នៅជាមួយនឹងទ្រង់ ហើយអ្នកក៏មិនធ្លាប់បានប្រកបជាមួយទ្រង់ដែរ សូម្បីតែមួយរយៈពេលខ្លី។ ដូច្នេះ តើការយល់ដឹងរបស់អ្នកអំពីព្រះយេស៊ូវ មិនមែនគ្រាន់តែជាទ្រឹស្ដីទេឬអី? តើវាមិនមែនជាការយល់ដឹងដែលគ្មានការពិតទេឬអី? អ្នកខ្លះក៏ប្រហែលជាធ្លាប់បានឃើញរូបគំនូរព្រះយេស៊ូវ ឬអ្នកខ្លះទៀតប្រហែលធ្លាប់បានទៅលេងទឹកដីកំណើតរបស់ព្រះយេស៊ូវ។ អ្នកខ្លះទៀត

ក៏ប្រហែលជាធ្លាប់បានប៉ះសម្លៀកបំពាក់របស់ព្រះយេស៊ូវផង។ ប៉ុន្តែ ការយល់ដឹងរបស់អ្នកអំពីទ្រង់ នៅតែជាទ្រឹស្តីនៅឡើយ មិនមែនជាភាពជាក់ស្ដែងនោះទេ បើទោះបីជាខ្លួនឯងផ្ទាល់ ធ្លាប់បានភ្លក់អាហារ ដែលព្រះយេស៊ូវធ្លាប់បានសោយក៏ដោយ។ ទោះក្នុងករណីបែបណាក៏ដោយ ក៏អ្នកមិនធ្លាប់បានឃើញព្រះយេស៊ូវដែរ ហើយមិនធ្លាប់បានប្រកបជាមួយនឹងទ្រង់ នៅក្នុងសណ្ឋានជាសាច់ឈាមនោះដែរ ហេតុនេះការយល់ដឹងរបស់អ្នកអំពីព្រះយេស៊ូវ នឹងនៅតែជាទ្រឹស្តីទទេស្អាត ដែលគ្មានជាក់ស្ដែងបន្តិចសោះ។ ប្រហែលជាព្រះបន្ទូលរបស់ខ្ញុំ មិនធ្វើឲ្យអ្នកចាប់អារម្មណ៍ប៉ុន្មានទេ ប៉ុន្តែខ្ញុំសូមសួរអ្នកនូវសំណួរមួយនេះថា៖ ថ្វីបើ អ្នកបានអានស្នាដៃជាច្រើនរបស់អ្នកនិពន្ធដែលអ្នកស្ញើចសរសើរបំផុតក៏ដោយ ប៉ុន្តែតើអ្នកអាចយល់ អំពីគាត់បានទាំងស្រុងដោយមិនចំណាយពេលជាមួយគាត់បានទេ? តើអ្នកដឹងថា គាត់មានបុគ្គលិកលក្ខណៈបែបណាទេ? តើអ្នកដឹងថា គាត់សម្រេចចិត្តក្នុងជីវិតបែបណាទេ? តើអ្នកដឹងអ្វីខ្លះពីអារម្មណ៍ពិតរបស់គាត់ទេ? សូម្បីតែមនុស្សដែលអ្នកកោតសរសើរ ក៏អ្នកមិនអាចយល់អំពីគេអស់ផង ចុះទម្រាំព្រះយេស៊ូវគ្រីស្ទវិញ តើអ្នកអាចយល់ពីទ្រង់បានដោយវិធីណា? គ្រប់យ៉ាងដែលអ្នកយល់ពីព្រះយេស៊ូវ គឺពោរពេញដោយការស្រមើស្រមៃ និងការសន្មត ហើយគ្មានសេចក្ដីពិត ឬភាពជាក់ស្ដែងឡើយ។ ការយល់ដឹងរបស់អ្នក គឺមានតែក្លិនអសោច និងពោរពេញទៅដោយសាច់ឈាមប៉ុណ្ណោះ។ តើការយល់ដឹងបែបនេះនឹងអាចឲ្យអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីស្វាគមន៍ការយាងត្រឡប់មកវិញរបស់ព្រះយេស៊ូវដូចម្ដេចបាន? ព្រះយេស៊ូវ នឹងមិនទទួលយកមនុស្សណាដែលមានពេញដោយគំនិតស្រមើស្រមៃ និងការសន្មតបែបសាច់ឈាមនោះឡើយ។ តើមនុស្សដែលមិនយល់ពីព្រះយេស៊ូវ សមនឹងធ្វើជាអ្នកជឿដល់ទ្រង់បានដោយរបៀបណា?

តើអ្នករាល់គ្នា ចង់ដឹងអំពីឫសគល់នៃមូលហេតុ ដែលពួកផារិស៊ីប្រឆាំងទាស់ជាមួយព្រះយេស៊ូវដែរឬទេ? តើអ្នករាល់គ្នា ចង់ដឹងពីសារជាតិរបស់ពួកផារិស៊ីទេ? ពួកគេពោរពេញដោយ ការស្រមើស្រមៃអំពីព្រះមែស្ស៊ី។ ជាងនេះទៅទៀត ពួកគេជឿត្រឹមថា ព្រះមែស្ស៊ីនឹងយាងមក ប៉ុន្តែពួកគេមិនបានដេញតាមសេចក្ដីពិតនៃជីវិត

ឡើយ។ ហេតុនេះ សូម្បីសព្វថ្ងៃនេះ ក៏ពួកគេនៅតែទន្ទឹងរង់ចាំព្រះមែស្ស៊ីដែរ ដ្បិតពួកគេមិនស្គាល់ផ្លូវនៃជីវិត ហើយក៏មិនដឹងថា ផ្លូវនៃសេចក្ដីពិតនោះជាអ្វីដែរ។ តើមនុស្សល្ងីល្ងើ ចចេសរឹងរូស និងល្ងង់ខ្លៅដូចជាអ្នករាល់គ្នា អាចទទួលបានព្រះពរពីព្រះជាម្ចាស់បានដោយវិធីណា? តើពួកគេអាចមើលឃើញព្រះមែស្ស៊ីបានដោយរបៀបណា? ពួកគេប្រឆាំងទាស់នឹងព្រះយេស៊ូវ ព្រោះពួកគេមិនស្គាល់គោលដៅនៃកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ព្រោះពួកគេមិនស្គាល់ផ្លូវនៃសេចក្ដីពិតដែលព្រះយេស៊ូវមានបន្ទូលប្រាប់ ហើយលើសនេះទៅទៀត គឺមកពីពួកគេមិនយល់អំពីព្រះមែស្ស៊ី។ ហើយដោយសារតែពួកគេមិនធ្លាប់បានឃើញព្រះមែស្ស៊ី និងមិនធ្លាប់បានប្រកបជាមួយនឹងព្រះមែស្ស៊ី ទើបពួកគេបានប្រព្រឹត្តកំហុសមួយ គឺប្រកាន់ខ្ជាប់ត្រឹមតែព្រះនាមរបស់ព្រះមែស្ស៊ី ទាំងដែលពួកគេកំពុងប្រឆាំងទាស់នឹងនិស្ស័យពិតរបស់ព្រះមែស្ស៊ី អស់ពីលទ្ធភាពដែលគេមាន។ សារជាតិនៃពួកផារិស៊ីនេះ គឺចចេសរឹងរូស ក្រអឺតក្រទម ហើយមិនស្ដាប់បង្គាប់តាមសេចក្ដីពិតឡើយ។ គោលការណ៍នៃសេចក្ដីជំនឿរបស់ពួកគេចំពោះព្រះជាម្ចាស់គឺ៖ បើទោះបីសេចក្ដីបង្រៀនរបស់អ្នកជ្រៅជ្រះយ៉ាងណា ទោះបីជាសិទ្ធិអំណាចរបស់អ្នកខ្ពង់ខ្ពស់យ៉ាងណា ក៏អ្នកមិនមែនជាព្រះគ្រីស្ទដែរ លុះត្រាតែគេហៅថា ព្រះមែស្ស៊ី។ តើជំនឿនេះមិនគួរឲ្យអស់សំណើចនិងខុសទំនងទេឬអី? ខ្ញុំសូមសួរអ្នករាល់គ្នាទៀតចុះថា៖ អ្នករាល់គ្នាគ្មានការយល់ដឹងអំពីព្រះយេស៊ូវ សូម្បីតែបន្តិច តើការប្រព្រឹត្តកំហុសដូចនឹងពួកផារិស៊ីសម័យដើម វាមិនងាយស្រួលជ្រុលពេក សម្រាប់អ្នករាល់គ្នាទេឬអី? តើអ្នកអាចស្គាល់ផ្លូវនៃសេចក្ដីពិត បានដែរឬទេ? តើអ្នកពិតជាអាចធានាបានថា អ្នកនឹងមិនប្រឆាំងទាស់នឹងព្រះគ្រីស្ទបានដែរឬទេ? តើអ្នកអាចធ្វើតាមកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ បានដែរឬទេ? ប្រសិនបើអ្នកមិនដឹងថា អ្នកនឹងប្រឆាំងទាស់នឹងព្រះគ្រីស្ទ ឬក៏អត់នោះ ខ្ញុំសូមប្រាប់ថា អ្នកកំពុងរស់ក្បែរមាត់ច្រកនៃសេចក្ដីស្លាប់ហើយ។ អស់អ្នកណាដែលមិនស្គាល់ព្រះមែស្ស៊ី គឺសុទ្ធតែអាចប្រឆាំងទាស់នឹងព្រះយេស៊ូវ អាចបដិសេធព្រះយេស៊ូវ ហើយក៏អាចនិយាយបង្កាច់បង្ខូចទ្រង់បានដែរ។ មនុស្សដែលមិនស្គាល់ព្រះយេស៊ូវ

សុទ្ធតែអាចបដិសេធទ្រង់ និងអាចជេរប្រមាថទ្រង់បាន។ ជាងនេះទៀត ពួកគេអាចយល់ឃើញថា ការយាងត្រឡប់មកវិញរបស់ព្រះយេស៊ូវ គឺជាការបោកបញ្ឆោតរបស់សាតាំងទៅវិញ ហើយមនុស្សកាន់តែច្រើន នឹងផ្ដន្ទាទោសព្រះយេស៊ូវដែលបានត្រឡប់មកជាសាច់ឈាមវិញ។ តើកត្តាអស់ទាំងនេះ មិនធ្វើឲ្យអ្នករាល់គ្នាខ្លាចរអារទេឬអី? អ្វីដែលអ្នករាល់គ្នាជួបប្រទះ គឺជាការប្រមាថដល់ព្រះវិញ្ញាណបរិសុទ្ធ គឺជាការបំផ្លាញព្រះបន្ទូលនៃព្រះវិញ្ញាណបរិសុទ្ធទៅកាន់ពួកជំនុំនិងជាការច្រានចោលអស់ទាំងសេចក្ដីដែលសម្ដែងឲ្យឃើញ តាមរយៈព្រះយេស៊ូវ។ ប្រសិនបើអ្នករាល់គ្នាវង្វេងវង្វាន់យ៉ាងនេះ តើអ្នកអាចទទួលបានអ្វីខ្លះពីព្រះយេស៊ូវ? ប្រសិនបើអ្នករាល់គ្នា មានះបដិសេធមិនព្រមទទួលស្គាល់កំហុសខ្លួន ពេលទ្រង់យាងត្រឡប់ជាសាច់ឈាមវិញ នៅលើពពកស តើអ្នករាល់គ្នាអាចយល់ពីកិច្ចការរបស់ព្រះយេស៊ូវ បានដោយវិធីណា? ខ្ញុំសូមប្រាប់អ្នករាល់គ្នាដូច្នេះថា៖ មនុស្សដែលមិនទទួលបានសេចក្ដីពិត ហើយនៅទន្ទឹងចាំការយាងត្រឡប់មកវិញរបស់ព្រះយេស៊ូវ នៅលើពពកស ទាំងងងឹតងងល់ គេច្បាស់ជាប្រមាថដល់ព្រះវិញ្ញាណបរិសុទ្ធជាក់ជាមិនខាន ហើយពួកគេគឺជាក្រុមមនុស្សដែលនឹងត្រូវវិនាសទៅ។ អ្នករាល់គ្នា គ្រាន់តែជាចង់បានព្រះគុណរបស់ព្រះយេស៊ូវ និងគ្រាន់តែចង់ត្រេកអរ សប្បាយនឹងនគរស្ថានសួគ៌ដ៏មានសិរីរុងរឿង ប៉ុន្តែអ្នកមិនបានស្ដាប់បង្គាប់ តាមព្រះបន្ទូលរបស់ព្រះយេស៊ូវ និងមិនបានទទួលសេចក្ដីពិត ដែលព្រះយេស៊ូវបើកសម្ដែងពេលទ្រង់យាងត្រឡប់ជាសាច់ឈាមវិញឡើយ។ តើអ្នកនឹងប្រកាន់ខ្ជាប់នូវរបស់អ្វីខ្លះដើម្បីប្ដូរជាមួយសេចក្ដីពិតនៃការយាងត្រឡប់មកវិញរបស់ព្រះយេស៊ូវនៅលើពពកស? តើការដែលអ្នករមែងប្រព្រឹត្តអំពើបាបដដែលៗ រួចលន់តួបាបម្ដងហើយម្ដងទៀតនោះ វាជាភាពស្មោះត្រង់ដែរឬទេ? តើអ្នករាល់គ្នានឹងថ្វាយអ្វីខ្លះ ជាតង្វាយដល់ព្រះយេស៊ូវដែលយាងត្រឡប់មកវិញនៅលើពពកស? តើវាជាកិច្ចការរាប់សិបឆ្នាំ ដែលអ្នកអួតសរសើរដល់ខ្លួនឯងនោះមែនទេ? តើអ្នកនឹងប្រកាន់ខ្ជាប់អ្វីខ្លះ ដើម្បីធ្វើឲ្យព្រះយេស៊ូវដែលយាងត្រឡប់មកវិញនោះ មានព្រះហឫទ័យទុកចិត្តចំពោះអ្នក? តើជាសារជាតិក្រអឺតក្រទមរបស់អ្នករាល់គ្នា ដែលមិនព្រមស្ដាប់ បង្គាប់តាមសេចក្ដីពិតនោះមែនទេ?

ភក្ដីភាពរបស់អ្នករាល់គ្នា គឺមានតែលើបបូរមាត់ប៉ុណ្ណោះ រីឯចំណេះដឹងរបស់អ្នករាល់គ្នា ក៏គ្រាន់តែជាចំណេះដឹងផ្នែកបញ្ញា និងគំនិតតែប៉ុណ្ណោះ ការអនុវត្តកិច្ចការរបស់អ្នករាល់គ្នា គឺដើម្បីឲ្យបានទទួលនូវព្រះពរពីស្ថានសួគ៌ប៉ុណ្ណោះ បើដូច្នេះតើអ្នករាល់គ្នាត្រូវមានជំនឿបែបណា? សូម្បីសព្វថ្ងៃ អ្នករាល់គ្នាក៏នៅតែខ្ទប់ត្រចៀកមិនព្រមស្ដាប់ព្រះបន្ទូលនៃសេចក្ដីពិត មួយម៉ាត់ណាឡើយ។ អ្នករាល់គ្នាមិនដឹងថាព្រះជាម្ចាស់ជាអ្វី មិនដឹងថាព្រះគ្រីស្ទជាអ្វី ក៏មិនដឹងពីរបៀបគោរពកោតខ្លាចព្រះយេហូវ៉ា មិនដឹងថាត្រូវចូលទៅក្នុងកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធដោយរបៀបណា ហើយក៏មិនដឹងពីវិធីបែងចែកភាពខុសគ្នា រវាងកិច្ចការផ្ទាល់របស់ព្រះជាម្ចាស់ និងការបោកបញ្ឆោតរបស់មនុស្សផង។ អ្នកដឹងត្រឹមតែថ្កោលទោសព្រះបន្ទូលនៃសេចក្ដីពិត ដែលព្រះជាម្ចាស់សម្ដែងចេញមក ជាសេចក្ដីពិតដែលមិនត្រូវគំនិតផ្ទាល់ខ្លួនរបស់អ្នកប៉ុណ្ណោះ។ តើឯណាទៅការបន្ទាបខ្លួនរបស់អ្នក? តើឯណាទៅការស្ដាប់បង្គាប់របស់អ្នក? តើឯណាទៅភក្ដីភាពរបស់អ្នក? តើឯណាទៅសេចក្ដីប្រាថ្នាចង់ស្វែងរកសេចក្ដីពិតរបស់អ្នក? តើឯណាទៅការគោរពរបស់អ្នក ចំពោះព្រះជាម្ចាស់? ខ្ញុំប្រាប់អ្នករាល់គ្នាចុះ មនុស្សដែលជឿលើព្រះជាម្ចាស់ ដោយសារទីសម្គាល់ គឺច្បាស់ជាប្រភេទមនុស្សដែលនឹងត្រូវបំផ្លាញជាក់ជាពុំខាន។ អស់អ្នកដែលមិនអាចទទួល ព្រះបន្ទូលរបស់ព្រះយេស៊ូវដែលបានយាងត្រឡប់មកជាសាច់ឈាមវិញ គឺច្បាស់ជាពូជពង្សនរក ជាកូនចៅមហាទេវតា ជាប្រភេទមនុស្សដែលត្រូវវិនាសអស់កល្បជានិច្ច។ មនុស្សជាច្រើនអាចនឹងមិនខ្វាយខ្វល់ចំពោះព្រះបន្ទូលរបស់ខ្ញុំទេ ប៉ុន្តែខ្ញុំនៅតែចង់មានបន្ទូលប្រាប់អ្នកដើរតាមព្រះយេស៊ូវ ជាអ្នកដែលហៅខ្លួនឯងជាពួកបរិសុទ្ធថា កាលណាអ្នកឃើញព្រះយេស៊ូវ យាងចុះពីស្ថានសួគ៌ផ្ទាល់នឹងភ្នែកលើដុំពពកស នេះហើយជាការលេចមកជាសាធារណៈរបស់ព្រះអាទិត្យនៃសេចក្ដីសុចរិត។ គ្រានោះ អាចជាគ្រាអរសប្បាយយ៉ាងក្រៃលែងសម្រាប់អ្នក ប៉ុន្តែអ្នកតោងដឹងថា គ្រាដែលអ្នកមើលឃើញព្រះយេស៊ូវយាងចុះពីស្ថានសួគ៌ ក៏ជាគ្រាដែលអ្នកត្រូវចុះទៅស្ថាននរកដើម្បីទទួលទុក្ខទោសដែរ។ គ្រានោះនឹងក្លាយជាគ្រាចុងក្រោយនៃផែនការគ្រប់គ្រងរបស់

ព្រះជាម្ចាស់ ហើយក៏ជាគ្រា ដែលព្រះជាម្ចាស់ប្រទានរង្វាន់ដល់មនុស្សល្អ ហើយដាក់ទោសមនុស្សអាក្រក់ដែរ។ ដ្បិតការជំនុំជម្រះរបស់ព្រះជាម្ចាស់ នឹងត្រូវបញ្ចប់ទៅ មុនពេលមនុស្សមើលឃើញទីសម្គាល់ គឺជាពេលដែលមានតែការបើកសម្ដែងអំពីសេចក្ដីពិតតែប៉ុណ្ណោះ។ អស់អ្នកណាដែលទទួលយកសេចក្ដីពិត មិនស្វែងរកទីសម្គាល់ ហើយត្រូវបានបន្សុទ្ធ នឹងត្រូវត្រឡប់មកចំពោះបល្ល័ង្កនៃព្រះជាម្ចាស់ រួចត្រូវចូលទៅក្នុងការឱបក្រសោបពីសំណាក់ព្រះអាទិករ។ មានតែមនុស្សដែលមានះជឿថា «ព្រះយេស៊ូវដែលមិនយាងចុះមកដោយជិះលើពពកស ជាព្រះគ្រីស្ទក្លែងក្លាយ» ប៉ុណ្ណោះ ដែលនឹងត្រូវទទួលទោសអស់កល្បជានិច្ច ដ្បិតពួកគេជឿតែលើព្រះយេស៊ូវដែលបង្ហាញទីសម្គាល់ តែមិនទទួលស្គាល់ព្រះយេស៊ូវដែលប្រកាសពីការជំនុំជម្រះដ៏ធ្ងន់ធ្ងរ និងបង្ហើបប្រាប់ពីផ្លូវពិត និងជីវិត។ ដូច្នេះ គឺមានតែព្រះយេស៊ូវទេ ទើបអាចចាត់ការពួកគេបាន នៅពេលទ្រង់យាងត្រឡប់មកវិញដោយបើកចំហ នៅលើពពកស។ ពួកគេចចេសរឹងរូស មានភាពជឿជាក់លើខ្លួនឯង និងក្រអឺតក្រទមណាស់។ តើមនុស្សអាក្រក់បែបនេះ អាចនឹងទទួលរង្វាន់ពីព្រះយេស៊ូវដូចម្ដេចបាន? ការយាងត្រឡប់មកវិញរបស់ព្រះយេស៊ូវ គឺជាសេចក្ដីសង្គ្រោះដ៏មហិមា ដល់អស់អ្នកណាដែលអាចទទួលយកសេចក្ដីពិតបាន ប៉ុន្ដែការយាងត្រឡប់មកវិញរបស់ទ្រង់ គឺជាទីសម្គាល់នៃការដាក់ទោសដល់អស់អ្នកណាដែលមិនអាចទទួលយកសេចក្ដីពិតបាន។ អ្នករាល់គ្នាតោងជ្រើសរើសផ្លូវរបស់ខ្លួន និងមិនគប្បីប្រមាថដល់ព្រះវិញ្ញាណបរិសុទ្ធ និងបដិសេធសេចក្ដីពិតឡើយ។ អ្នកមិនគួរធ្វើជាមនុស្សក្រអឺតក្រទម និងក្អេងក្អាងនោះឡើយ ប៉ុន្ដែ ត្រូវធ្វើជាមនុស្សម្នាក់ដែលស្ដាប់បង្គាប់តាមការដឹកនាំរបស់ព្រះវិញ្ញាណបរិសុទ្ធ ហើយសង្វាត និងខ្នះខ្នែងរកសេចក្ដីពិត។ គឺទាល់តែបែបនេះ ទើបអ្នកនឹងទទួលបានប្រយោជន៍។ ខ្ញុំសូមទូន្មានអ្នករាល់គ្នាឲ្យដើរតាមផ្លូវនៃសេចក្ដីជំនឿក្នុងព្រះជាម្ចាស់ដោយយកចិត្តទុកដាក់។ ចូរកុំប្រញាប់សន្និដ្ឋានពេក ហើយសូមកុំឲ្យជំនឿដែលអ្នកមានចំពោះព្រះជាម្ចាស់ ក្លាយជាជំនឿមួយគ្រាៗ ហើយខ្វះការពិចារណានោះឡើយ។ អ្នករាល់គ្នាតោងដឹងថា យ៉ាងហោចណាស់អស់អ្នកណា

ដែលជឿលើព្រះជាម្ចាស់ គួរតែបន្ទាបខ្លួន និងចេះគោរពកោតខ្លាចដល់ព្រះជាម្ចាស់។ អស់អ្នកណាដែលបានស្ដាប់ឮសេចក្ដីពិត តែបដិសេធមិនទទួលយកសេចក្ដីពិតនេះ គឺល្ងីល្ងើ និងល្ងង់ខ្លៅណាស់។ អស់អ្នកណាដែលបានស្ដាប់ឮសេចក្ដីពិត ប៉ុន្តែគេបែរជាប្រញាប់សន្និដ្ឋានដោយធ្វេសប្រហែស ឬប្រមាថសេចក្ដីពិតនោះចោល គេគឺជាមនុស្សដែលរងទុក្ខដោយភាពក្រអឺតក្រទម។ គ្មាននរណាម្នាក់ដែលជឿព្រះយេស៊ូវ មានសិទ្ធិជេរប្រមាថ ឬមួយក៏ថ្កោលទោសអ្នកដទៃឡើយ។ អ្នករាល់គ្នាគប្បីធ្វើជាមនុស្សដែលមានការយល់ដឹង ហើយទទួលយកនូវសេចក្ដីពិត។ ប្រហែលជាការដែលបានស្ដាប់ឮអំពីផ្លូវនៃសេចក្ដីពិត និងការដែលបានអានព្រះបន្ទូលនៃជីវិតនេះហើយ បានជាអ្នកជឿថា ក្នុងចំណោមពាក្យសម្ដី១ម៉ឺនម៉ាត់នេះ គឺមានតែ១ម៉ាត់គត់ដែលស្របទៅនឹងជំនឿរបស់អ្នក ហើយស្របទៅនឹងព្រះគម្ពីរ ដូច្នេះ អ្នកគួរបន្តស្វែងរកផ្លូវនៃសេចក្ដីពិត និងព្រះបន្ទូលនៃជីវិត នៅក្នុងពាក្យសម្ដី១ម៉ឺនម៉ាត់នេះចុះ។ ខ្ញុំក៏នៅតែទូន្មានឲ្យអ្នកចេះបន្ទាបខ្លួន កុំឲ្យជឿជាក់ខ្លួនឯងជ្រុលពេក និងមិនត្រូវតម្កើងខ្លួនឯងឲ្យខ្ពស់ពេកដែរ។ អ្នកនឹងទទួលបាននូវពន្លឺ កាន់តែត្រចះត្រចង់ថែមទៀត តាមរយៈដួងចិត្តដ៏តូចទាបដែលប្រកាន់ខ្ជាប់ការគោរពកោតខ្លាចព្រះជាម្ចាស់។ ប្រសិនបើអ្នកពិនិត្យពិច័យនូវពាក្យសម្ដីទាំងនេះដោយយកចិត្តទុកដាក់ រួចថ្លឹងថ្លែងពិចារណាពាក្យសម្ដីទាំងនេះម្ដងហើយម្ដងទៀត នោះអ្នកនឹងដឹងថា តើពាក្យសម្ដីទាំងនោះ គឺជាសេចក្ដីពិត ឬក៏មិនមែន និងដឹងថា ពាក្យសម្ដីទាំងនោះ គឺជាជីវិត ឬក៏មិនមែន។ ប្រហែលជាអ្នកខ្លះគ្រាន់តែបានអានពីរបីប្រយោគ រួចក៏ថ្កោលទោសព្រះបន្ទូលទាំងនេះទាំងងងឹតងងល់ ដោយនិយាយថា «នេះគ្មានអ្វីផ្សេងក្រៅពីការស្រាយបំភ្លឺពីព្រះវិញ្ញាណបរិសុទ្ធទេ» ឬនិយាយថា «នេះគឺជាព្រះគ្រីស្ទក្លែងក្លាយ ដែលបោកបញ្ឆោតមនុស្សតែប៉ុណ្ណោះ»។ អស់អ្នកដែលនិយាយដូច្នេះ ជាមនុស្សដែលខ្វាក់ភ្នែក ដោយសារតែភាពល្ងង់ខ្លៅ! អ្នកយល់ដឹងពីកិច្ចការ និងព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់តិចតួចណាស់ ហើយខ្ញុំសុំទូន្មានឲ្យអ្នករាល់គ្នា ចាប់ផ្ដើមសាជាថ្មីពីចំណុចសូន្យវិញ! អ្នករាល់គ្នាមិនត្រូវប្រមាថព្រះបន្ទូលដែលព្រះជាម្ចាស់បង្ហាញប្រាប់ ទាំងងងឹតងងល់ ដោយសារ

ការបង្ហាញខ្លួន របស់ព្រះគ្រីស្ទក្លែងក្លាយនៅគ្រាចុងក្រោយនោះទេ ហើយអ្នកក៏មិនត្រូវធ្វើជាមនុស្សដែលប្រមាថដល់ព្រះវិញ្ញាណបរិសុទ្ធ ដោយសារខ្លាចរអារការបោកបញ្ឆោតនោះដែរ។ តើនេះវាមិនគួរឲ្យអាណិតពេកទេឬអី? បន្ទាប់ពីពិនិត្យពិច័យល្អិតល្អន់ហើយ ប្រសិនបើអ្នកនៅតែជឿថា ព្រះបន្ទូលទាំងនេះ វាមិនមែនជាសេចក្ដីពិត មិនមែនជាផ្លូវ និងមិនមែនជាការបើកសម្ដែងពីព្រះជាម្ចាស់ទេ នៅទីបំផុត អ្នកនឹងត្រូវទទួលទោស ហើយអ្នកនឹងមិនទទួលបានព្រះពរនោះឡើយ។ ប្រសិនបើអ្នកមិនអាចទទួលសេចក្ដីពិតដែលថ្លែងដោយត្រង់ៗ និងច្បាស់លាស់បែបនេះបានទេ តើអ្នកស័ក្ដិសមនឹងទទួលសេចក្ដីសង្គ្រោះពីព្រះជាម្ចាស់ដែរឬអី? តើអ្នកមិនមែនជាមនុស្សដែលមិនទទួលបានព្រះពរគ្រប់គ្រាន់ នឹងអាចចូលទៅចំពោះបល្ល័ង្កនៃព្រះទេឬអី? សូមពិចារណាមើលចុះ! ចូរកុំប្រញាប់ប្រញាល់ និងច្រឡោតពេក ហើយសូមកុំចាត់ទុកសេចក្ដីជំនឿក្នុងព្រះជាម្ចាស់ជាល្បែងលេងសើចឲ្យសោះ។ ចូរត្រៀមខ្លួនធ្វើអំពើល្អឲ្យបានគ្រប់គ្រាន់សម្រាប់ទិសដៅរបស់អ្នក សម្រាប់ជាប្រយោជន៍ ដល់ក្ដីសង្ឃឹមរបស់អ្នក ជាប្រយោជន៍ដល់ជីវិតរបស់អ្នក ហើយកុំលេងសើចនឹងខ្លួនឯងឲ្យសោះ។ តើអ្នកអាចទទួលយកព្រះបន្ទូលទាំងអស់នេះបានដែរឬទេ?

# មនុស្សដែលមិនចុះសម្រុងនឹងព្រះគ្រីស្ទ គឺជាសត្រូវព្រះជាម្ចាស់ប្រាកដណាស់

មនុស្សទាំងអស់ សុទ្ធតែប្រាថ្នាចង់ឃើញព្រះភ័ក្ត្រពិតរបស់ព្រះយេស៊ូវ ហើយគ្រប់គ្នាចង់រស់នៅជាមួយទ្រង់។ ខ្ញុំគិតថា គ្មានបងប្អូនប្រុសស្រីណាម្នាក់ពោលថាខ្លួនមិនប្រាថ្នាចង់ឃើញ ឬរស់នៅជាមួយព្រះយេស៊ូវឡើយ។ មុនពេលអ្នករាល់គ្នាបានឃើញព្រះយេស៊ូវ មុនពេលអ្នករាល់គ្នាបានឃើញព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស នោះអ្នករាល់គ្នាទំនងជាចៅរ៉ៅនឹងគំនិតគ្រប់ប្រភេទ ដូចជា ឧទាហរណ៍ អំពីការលេចមករបស់ព្រះយេស៊ូវ របៀបដែលទ្រង់មានបន្ទូល របៀបរស់នៅរបស់

ទ្រង់ និងចំណុចជាច្រើនផ្សេងទៀត។ ប៉ុន្តែ នៅពេលដែលអ្នករាល់គ្នាពិតជាបានឃើញទ្រង់ គំនិតរបស់អ្នករាល់គ្នានឹងផ្លាស់ប្ដូរយ៉ាងឆាប់រហ័ស។ តើហេតុអ្វីបានជាដូច្នេះ? តើអ្នករាល់គ្នាចង់ដឹងដែរឬទេ? ជាការពិតណាស់ គេមិនអាចមើលរំលងគំនិតរបស់មនុស្សឡើយ ប៉ុន្តែលើសពីនេះទៅទៀត មនុស្សក៏មិនត្រូវធ្វើការកែប្រែសារជាតិរបស់ព្រះគ្រីស្ទដែរ។ អ្នករាល់គ្នាគិតថា ព្រះគ្រីស្ទជាមនុស្សអមតៈ ឬជាអ្នកប្រាជ្ញ ប៉ុន្តែគ្មាននរណាម្នាក់ចាត់ទុកទ្រង់ ជាមនុស្សសាមញ្ញម្នាក់ ដែលមានសារជាតិរបស់ព្រះឡើយ។ តាមពិតទៅមនុស្សជាច្រើន ដែលទន្ទឹងចង់ឃើញព្រះជាម្ចាស់ទាំងយប់ទាំងថ្ងៃនោះ តាមពិតគឺជាសត្រូវរបស់ព្រះជាម្ចាស់ ហើយមិនចុះសម្រុងជាមួយនឹងទ្រង់ទៀតផង។ តើនេះ មិនមែនជាចំណែកមួយនៃកំហុសរបស់មនុស្សទេឬអី? សូម្បីពេលនេះក្ដី អ្នករាល់គ្នានៅតែគិតថា ជំនឿ និងភាពស្មោះត្រង់របស់អ្នករាល់គ្នា គឺគ្រប់គ្រាន់ធ្វើឲ្យអ្នករាល់គ្នាសក្ដិសមនឹងមើលឃើញព្រះភ័ក្ត្ររបស់ព្រះគ្រីស្ទ ប៉ុន្តែខ្ញុំសូមដាស់តឿនថា ចូរប្រដាប់ខ្លួនរបស់អ្នកជាមួយនឹងអ្វីដែលមានប្រយោជន៍ជាច្រើនទៀត! ដ្បិតមនុស្សជាច្រើននាក់ ដែលបានស្គាល់ព្រះគ្រីស្ទនៅអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល បានបរាជ័យ ឬនឹងបរាជ័យជាមិនខាន ពួកគេគ្រប់គ្នាបានប្រតិបត្តិខ្លួន ដូចជាពួកផារិស៊ី។ ចុះបរាជ័យរបស់អ្នករាល់គ្នាវិញ តើបណ្ដាលមកពីអ្វីដែរ? ប្រាកដណាស់ ដ្បិតក្នុងគំនិតរបស់អ្នករាល់គ្នាគិតថា ព្រះជាម្ចាស់ជាព្រះខ្ពង់ខ្ពស់ និងគួរឲ្យកោតសរសើរបំផុត។ ប៉ុន្តែ សេចក្ដីពិតវិញ មិនដូចអ្វីដែលមនុស្សចង់បានទេ។ ព្រះគ្រីស្ទ មិនត្រឹមតែមិនខ្ពង់ខ្ពស់ទេ តែទ្រង់ថែមទាំងតូចទាបផង ទ្រង់មិនត្រឹមតែជាមនុស្សទេ តែទ្រង់ជាមនុស្សធម្មតាទៀតផង ទ្រង់មិនត្រឹមតែមិនអាចយាងទៅស្ថានសួគ៌ទេ តែទ្រង់ថែមទាំងមិនអាចដើរ ដោយសេរីនៅលើផែនដីទៀតផង។ ហើយដោយហេតុនេះ មនុស្សបានប្រតិបត្តិចំពោះទ្រង់ ដូចជាការប្រតិបត្តិចំពោះមនុស្សធម្មតាដែរ ពួកគេប្រព្រឹត្តចំពោះទ្រង់ជាធម្មតា នៅពេលដែលពួកគេនៅជាមួយទ្រង់ ហើយក៏និយាយទៅកាន់ព្រះអង្គដោយមិនសូវយកចិត្តទុកដាក់ដែរ ដោយគ្រប់គ្នា នៅតែរង់ចាំការយាងមករបស់ «ព្រះគ្រីស្ទពិត»។ អ្នករាល់គ្នាបានទទួលយកព្រះគ្រីស្ទដែលបានយាងមករួចហើយ

សម្រាប់មនុស្សធម្មតា ហើយព្រះបន្ទូលរបស់ទ្រង់ សម្រាប់មនុស្សធម្មតាដែរ។ ដោយបុព្វហេតុនេះ អ្នករាល់គ្នាមិនទាន់ទទួលបានអ្វីពីព្រះគ្រីស្ទនៅឡើយទេ ហើយបែរជាបានលាតត្រដាងទាំងស្រុង នូវភាពអាក្រក់របស់ខ្លួននៅចំពោះពន្លឺវិញ។

មុននឹងមានទំនាក់ទំនងជាមួយនឹងព្រះគ្រីស្ទ អ្នកអាចជឿលើនិស្ស័យរបស់អ្នក ដើម្បីទទួលបានការផ្លាស់ប្រែទាំងស្រុង ដែលអ្នកជាអ្នកដើរតាមព្រះគ្រីស្ទដ៏ស្មោះត្រង់ម្នាក់ ដែលគ្មាននរណាសក្ដិសម នឹងទទួលនូវព្រះពររបស់ព្រះគ្រីស្ទជាងអ្នកឡើយ ហើយគិតថា ខ្លួនបានឆ្លងកាត់រឿងរ៉ាវជាច្រើន បានធ្វើកិច្ចការជាច្រើន ហើយបានបង្កើតផលផ្លែជាច្រើនដែរ នោះអ្នកច្បាស់ណាស់ថានឹងក្លាយជា ម្នាក់ក្នុងចំណោមអស់អ្នកដែលនឹងទទួលបានមកុដ។ ប៉ុន្តែ មានសេចក្ដីពិតមួយ ដែលអ្នកប្រហែលជាមិនស្គាល់៖ និស្ស័យពុករលួយរបស់មនុស្ស និងភាពបះបោរ ព្រមទាំងការជំទាស់របស់គេ នឹងត្រូវបានលាតត្រដាង ពេលគេបានជួបនឹងព្រះគ្រីស្ទ ហើយភាពបះបោរ និងការជំទាស់របស់មនុស្សដែលបានលាតត្រដាងនៅពេលនេះ គឺកាន់តែច្បាស់លាស់ និងបង្ហាញយ៉ាងច្បាស់ ជាងពេលណាៗទាំងអស់។ ដោយព្រោះតែព្រះគ្រីស្ទជាបុត្រមនុស្ស ពោលគឺបុត្រមនុស្សដែលមាននូវភាពជាមនុស្សធម្មតា ជាបុត្រមនុស្សដែលមិនទទួលបានការលើកតម្កើង និងការគោរព។ នេះដោយសារតែព្រះជាម្ចាស់រស់នៅក្នុងសាច់ឈាម ដែលការបះបោររបស់មនុស្ស ត្រូវបានលាតត្រដាងយ៉ាងច្បាស់ ហើយហ្មត់ចត់ផង។ ដូចនេះ ខ្ញុំសូមនិយាយថា ការយាងមករបស់ព្រះគ្រីស្ទ បានលាតត្រដាងនូវការបះបោររបស់មនុស្សជាតិទាំងអស់ ហើយក៏បានធ្វើឲ្យលក្ខណៈដើមនៃមនុស្សជាតិ បានប្រសើរឡើងដែរ។ ការនេះត្រូវបានហៅថា «ព្រលែងខ្លាឲ្យចុះពីភ្នំ» និង «ព្រលែងចចកចេញពីរូង»។ តើអ្នកហ៊ានសន្និដ្ឋានថា ខ្លួនស្មោះត្រង់ចំពោះព្រះជាម្ចាស់ដែរឬទេ? តើអ្នកនៅតែសន្មតថា ខ្លួនបានស្ដាប់បង្គាប់ព្រះជាម្ចាស់ទាំងស្រុងទេ? តើអ្នកនៅតែសន្មតថា ខ្លួនមិនបានបះបោរដែរឬទេ? មនុស្សខ្លះពោលថា៖ «នៅពេលព្រះជាម្ចាស់ បានប្រទាននូវបរិយាកាសថ្មីមកខ្ញុំ នោះខ្ញុំនឹងធ្វើតាមឲ្យខាងតែបាន ដោយមិនរអ៊ូរទាំ ហើយលើសពីនេះទៅទៀត ខ្ញុំក៏មិនមានយោបល់

អ្វីចំពោះព្រះជាម្ចាស់ឡើយ»។ មនុស្សខ្លះទៀតក៏ពោលថា៖ «នៅពេលព្រះជាម្ចាស់ប្រគល់កិច្ចការមកឲ្យខ្ញុំ នោះខ្ញុំនឹងធ្វើឲ្យអស់ពីសមត្ថភាព ហើយមិនឲ្យខកខានឡើយ»។ ក្នុងករណីនេះ ខ្ញុំសុំសួរអ្នករាល់គ្នាដូច្នេះថា៖ នៅពេលអ្នករាល់គ្នារស់នៅជាមួយព្រះគ្រីស្ទ តើអ្នករាល់គ្នាអាចចុះសម្រុងនឹងទ្រង់ដែរឬទេ? តើអ្នករាល់គ្នាអាចចុះសម្រុងនឹងទ្រង់ បានយូរប៉ុនណាដែរ? មួយថ្ងៃ? ពីរថ្ងៃ? មួយម៉ោង? ពីរម៉ោង? សេចក្ដីជំនឿរបស់អ្នករាល់គ្នាអាចនឹងគួរឲ្យសរសើរ ប៉ុន្តែ អ្នករាល់គ្នាមិនមានការស៊ូទ្រាំច្រើននៅឡើយ។ នៅពេលដែលអ្នករាល់គ្នាពិតជាបានរស់នៅជាមួយព្រះគ្រីស្ទ នោះការរាប់ខ្លួនឯងជាសុចរិត និងការទុកខ្លួនជាសំខាន់របស់អ្នក នឹងត្រូវបានលាតត្រដាងចេញមកតាមរយៈពាក្យសម្ដី និងសកម្មភាពរបស់អ្នក ហើយបំណងប្រាថ្នាដ៏ហួសហេតុរបស់អ្នក ផ្នត់គំនិតមិនស្ដាប់បង្គាប់ និងមិនពេញចិត្តរបស់អ្នក នឹងត្រូវបានលាតត្រដាងបន្តិចម្ដងៗ។ ជាចុងក្រោយ ចរិតក្រអឺតក្រទមរបស់ខ្លួន នឹងលេចចេញមកកាន់តែខ្លាំងឡើងៗ រហូតដល់អ្នកខុសឆ្ងាយពីព្រះគ្រីស្ទដូចមេឃនឹងដី ហើយលក្ខណៈដើមរបស់អ្នក នឹងលេចចេញមកទាំងស្រុង។ ពេលនោះអ្នកមិនអាចគ្របបាំងសញ្ញាណរបស់អ្នកបានទៀតឡើយ ហើយក៏មិនអាចលាក់បាំងការរអ៊ូរទាំរបស់ខ្លួនដែរ ដោយវានឹងលេចចេញមកដោយឯកឯង ហើយភាពអន់ថយខាងមនុស្សជាតិរបស់អ្នក ក៏បានលាតត្រដាងឡើងទាំងស្រុងដែរ។ យ៉ាងណាក្ដីអ្នកនៅតែបដិសេធមិនទទួលស្គាល់នូវការបះបោររបស់ខ្លួន ដោយបែរមកជឿថាព្រះគ្រីស្ទមួយអង្គនេះ មិនងាយស្រួលឲ្យមនុស្សទទួលយកឡើយ ដោយទ្រង់មានលក្ខណៈដូចមនុស្សខ្លាំងពេក ហើយអ្នករាល់គ្នានឹងចុះចូលទាំងស្រុង ប្រសិនបើទ្រង់ជាព្រះគ្រីស្ទ ដែលមានសេចក្ដីសប្បុរសជាងនេះ។ អ្នករាល់គ្នាជឿថា ការបះបោររបស់អ្នករាល់គ្នាត្រឹមត្រូវ គឺអ្នករាល់គ្នាគ្រាន់តែជំទាស់នឹងទ្រង់ នៅពេលដែលទ្រង់ជំរុញអ្នករាល់គ្នាខ្លាំងពេកតែប៉ុណ្ណោះ។ អ្នករាល់គ្នាមិនដែលពិចារណាថា ខ្លួនមិនបានចាត់ទុកព្រះគ្រីស្ទជាព្រះទេ បានជាអ្នកខ្វះនូវចេតនាស្ដាប់បង្គាប់ទ្រង់។ ផ្ទុយទៅវិញអ្នករាល់គ្នាចចេសរឹងរូសថា ព្រះគ្រីស្ទធ្វើការដោយស្របតាមបំណងប្រាថ្នារបស់អ្នក ហើយនៅពេលដែលទ្រង់ធ្វើអ្វីមួយ

ដែលខុសប្លែកពីការគិតរបស់ខ្លួន អ្នកបែជាជឿថាទ្រង់មិនមែនជាព្រះឡើយ គឺទ្រង់ជាមនុស្សវិញ។ តើមាននរណាម្នាក់ក្នុងចំណោមអ្នករាល់គ្នា ទាស់នឹងទ្រង់របៀបនេះ? ដូចនេះ តើអ្នករាល់គ្នាជឿលើនរណាវិញ? ហើយតើអ្នករាល់គ្នាស្វែងរកព្រះជាម្ចាស់ដោយរបៀបណា?

អ្នករាល់គ្នាតែងតែប្រាថ្នាចង់ឃើញព្រះគ្រីស្ទ ប៉ុន្តែ ខ្ញុំសូមអង្វរអ្នករាល់គ្នា កុំឲ្យតម្លើខ្លួនឯងខ្លាំងពេក នរណាក៏អាចនឹងឃើញព្រះគ្រីស្ទដែរ ប៉ុន្តែ ខ្ញុំសូមនិយាយថា គ្មាននរណាម្នាក់សក្ដិសម នឹងបានឃើញព្រះគ្រីស្ទឡើយ។ ដ្បិតធម្មជាតិរបស់មនុស្ស ពោរពេញដោយអំពើអាក្រក់ ក្រអឺតក្រទម និងបះបោរ នៅពេលដែលអ្នកបានឃើញព្រះគ្រីស្ទភ្លាម នោះលក្ខណៈដើមរបស់អ្នករាល់គ្នា នឹងបំផ្លាញអ្នក ព្រមទាំងថ្កោលទោសអ្នកដល់ស្លាប់ផង។ ការចូលរួមជាមួយបងប្អូនប្រុសស្រីរបស់អ្នក អាចនឹងមិនបង្ហាញលក្ខណៈជាច្រើនរបស់អ្នករាល់គ្នាទេ ប៉ុន្តែ ការដែលអ្នកមានទំនាក់ទំនងជាមួយព្រះគ្រីស្ទ នោះមិនមែនជារឿងសាមញ្ញឡើយ។ គ្រប់ពេលវេលាទាំងអស់សញ្ញាណរបស់អ្នកអាចនឹងចាក់ឫសគល់ ភាពក្រអឺតក្រទមរបស់អ្នក ក៏ចាប់ផ្ដើមដុះពន្លកមក ហើយការបះបោររបស់អ្នកក៏ផ្ដល់ផល ជាផ្លែល្វាមកដែរ។ តើអ្នកដែលមានលក្ខណៈជាមនុស្សជាតិ អាចសក្ដិសមនឹងមានទំនាក់ទំនងជាមួយព្រះគ្រីស្ទបានយ៉ាងដូចម្ដេច? តើអ្នកពិតជាអាចប្រព្រឹត្តចំពោះទ្រង់ ក្នុងនាមទ្រង់ជាព្រះជាម្ចាស់បានរាល់ថ្ងៃដែរឬទេ? តើអ្នកពិតជាមានការចុះចូលនឹងព្រះជាម្ចាស់ ពិតប្រាកដដែរឬទេ? អ្នករាល់គ្នាថ្វាយបង្គំព្រះដ៏ខ្ពង់ខ្ពស់នៅក្នុងចិត្ត ដូចជាព្រះយេហូវ៉ា ខណៈពេលដែលចាត់ទុកព្រះគ្រីស្ទ ដែលអាចមើលឃើញថាជាមនុស្ស។ សញ្ញាណរបស់អ្នករាល់គ្នាហាក់តូចពេកហើយ ចំណែកសារជាតិជាមនុស្សរបស់អ្នកក៏អន់ពេកដែរ! អ្នករាល់គ្នាមិនមានសមត្ថភាព ក្នុងការលើកតម្កើងព្រះគ្រីស្ទជាព្រះជារៀងរហូតឡើយ គឺធ្វើបានតែម្ដងម្កាលប៉ុណ្ណោះ។ អ្នកក៏ឱបក្រសោបទ្រង់ និងថ្វាយបង្គំទ្រង់ជាព្រះជាម្ចាស់នៅពេលដែលអ្នកចូលចិត្តប៉ុណ្ណោះ។ ហេតុនេះ ទើបខ្ញុំនិយាយថា អ្នករាល់គ្នាមិនមែនជាអ្នកជឿលើព្រះជាម្ចាស់ឡើយ ប៉ុន្តែ អ្នករាល់គ្នាមានលក្ខណៈប្រឆាំងជំទាស់នឹង

ព្រះគ្រីស្ទ។ សូម្បី មនុស្សដែលមានចិត្តសប្បុរសចំពោះអ្នកដទៃ ក៏ទទួលបានការតបស្នងដែរ ប៉ុន្ដែ ព្រះគ្រីស្ទដែលបានធ្វើកិច្ចការជាច្រើនក្នុងចំណោមអ្នករាល់គ្នា បែរជាមិនបានទទួលសេចក្ដីស្រលាញ់របស់មនុស្ស និងការប៉ះប៉ូវ ព្រមទាំងការចុះចូលទៅវិញ។ តើនេះមិនមែនជាការគួរឲ្យខូចចិត្តទេឬអី?

គេអាចថា នៅក្នុងរយៈពេលជាច្រើនឆ្នាំនៃសេចក្ដីជំនឿរបស់អ្នកលើព្រះជាម្ចាស់ អ្នកមិនដែលដាក់បណ្ដាសានរណាម្នាក់ ឬក៏មិនបានប្រព្រឹត្តអំពើអាក្រក់ឡើយ ប៉ុន្ដែ នៅក្នុងទំនាក់ទំនងជាមួយព្រះគ្រីស្ទវិញ អ្នកមិនអាចនិយាយសេចក្ដីពិត មិនអាចបញ្ចេញនូវភាពស្មោះត្រង់ ឬស្ដាប់បង្គាប់ព្រះបន្ទូលរបស់ព្រះគ្រីស្ទឡើយ ក្នុងករណីនេះ ខ្ញុំសូមប្រាប់ថា អ្នករាល់គ្នាជាមនុស្សសាហាវ និងអាក្រក់បំផុតក្នុងលោក។ អ្នកអាចមានលក្ខណៈគួរឲ្យស្រឡាញ់ និងគោរពពីសាច់ញាតិ មិត្តភក្ដិ ប្ដី ឬប្រពន្ធ កូនប្រុសស្រី និងឪពុកម្ដាយ ហើយមិនដែលយកចំណេញពីគ្នាឡើយ ប៉ុន្ដែ ប្រសិនបើអ្នកមិនអាចមានលក្ខណៈចុះសម្រុងនឹងព្រះគ្រីស្ទ ហើយប្រសិនបើអ្នកមិនអាចមានទំនាក់ទំនងល្អប្រសើរទៅវិញទៅមកជាមួយទ្រង់នោះទេ ហើយទោះបីជាអ្នកចំណាយគ្រប់យ៉ាងសម្រាប់អ្នកជិតខាង ឬអ្នកថែរក្សាឪពុកម្ដាយ និងសមាជិកក្នុងគ្រួសារអ្នកបានយ៉ាងល្អិតល្អន់ក្ដី ក៏ខ្ញុំនៅតែនិយាយថា អ្នកជាមនុស្សអាក្រក់ ហើយថែមទាំងជាមនុស្សដែលពោរពេញដោយ អំពើពុតត្បុតយ៉ាងអាក្រក់ផង។ ចូរកុំចាត់ទុកខ្លួនឯងចុះសម្រុងនឹងព្រះគ្រីស្ទយ៉ាងងាយស្រួល ដោយព្រោះអ្នកចុះសម្រុងនឹងអ្នកផ្សេងទៀត ឬធ្វើអំពើល្អបានតិចតួចឲ្យសោះ។ តើអ្នកគិតថា ចេតនាសប្បុរសរបស់អ្នក អាចទទួលបានព្រះពរពីស្ថានសួគ៌ឬ? តើអ្នកគិតថាការធ្វើអំពើល្អបន្ដិចបន្ដួច អាចយកមកជំនួសការស្ដាប់បង្គាប់របស់អ្នកហើយមែនទេ? គ្មាននរណាម្នាក់ ក្នុងចំណោមអ្នករាល់គ្នាអាចទទួលយកការដោះស្រាយ និងកាត់ចេញបានឡើយ ហើយអ្នករាល់គ្នាក៏មានការលំបាកក្នុងការទទួលយកភាពជាមនុស្សរបស់ព្រះគ្រីស្ទដែរ ទោះបីអ្នករាល់គ្នាជាមនុស្សមិនស្ដាប់បង្គាប់ព្រះជាម្ចាស់ក៏ដោយ។ សេចក្ដីជំនឿរបស់អ្នករាល់គ្នាបែបនេះនឹងនាំមកនូវការថ្កោលទោសយ៉ាងសមរម្យមួយ។ អ្នករាល់គ្នាត្រូវបញ្ឈប់ការបំភាន់ និង

ការប្រាថ្នាចង់ឃើញព្រះគ្រីស្ទ ដ្បិតអ្នករាល់គ្នានៅតូចទាបណាស់ ហើយអ្នករាល់គ្នាមិនសក្ដិសមនឹងបានឃើញទ្រង់ឡើយ។ នៅពេលដែលអ្នកបានលុបបំបាត់នូវការបះបោររបស់អ្នកបានទាំងស្រុងរួចរាល់ ហើយអាចមានការចុះសម្រុងនឹងព្រះគ្រីស្ទ យ៉ាងរីករាយផង គឺនៅគ្រានោះហើយ ដែលព្រះជាម្ចាស់នឹងលេចមកនៅចំពោះអ្នកជាមិនខាន។ ប្រសិនបើអ្នកមើលទៅព្រះជាម្ចាស់ដោយមិនបានឆ្លងកាត់ការកាត់ចេញឬការជំនុំជម្រះទេនោះ ប្រាកដណាស់ថា អ្នកនឹងក្លាយជាសត្រូវរបស់ព្រះជាម្ចាស់ហើយត្រូវកំណត់សម្រាប់ការបំផ្លិចបំផ្លាញផង។ លក្ខណៈធម្មជាតិរបស់មនុស្ស គឺនៅជាប់ជាសត្រូវនឹងព្រះជាម្ចាស់ ដ្បិតមនុស្សទាំងអស់បានទទួលនូវសេចក្ដីពុករលួយរបស់សាតាំង។ ប្រសិនបើមនុស្សម្នាក់ព្យាយាមទំនាក់ទំនងជាមួយព្រះជាម្ចាស់ ចេញពីចំណុចកណ្ដាលនៃអំពើអាក្រក់របស់ខ្លួន នោះប្រាកដណាស់ថា គ្មានអ្វីល្អអាចកើតចេញពីទំនាក់ទំនងនេះបានឡើយ ទង្វើ និងពាក្យសម្ដីរបស់គេ នឹងលាតត្រដាងនូវសេចក្ដីពុករលួយរបស់ខ្លួន គ្រប់ពេលទាំងអស់ ហើយចំពោះការមានទំនាក់ទំនងជាមួយព្រះជាម្ចាស់ នោះការបះបោររបស់គេនឹងត្រូវលាតត្រដាងចេញមកនូវគ្រប់រូបភាពទាំងអស់។ មនុស្សចេញមកប្រឆាំងនឹងព្រះគ្រីស្ទទាំងមិនដឹងខ្លួន គេក្បត់នឹងព្រះគ្រីស្ទ ហើយបោះបង់ទ្រង់ចោលទៀតផង នៅពេលដែលការនេះកើតឡើង នោះមនុស្សនឹងស្ថិតក្នុងសភាពមិនទៀងទាត់ជាងមុនទៅទៀត ហើយបើការនេះនៅតែបន្តទៀត នោះគេនឹងត្រូវទទួលការកាត់ទោសជាមិនខាន។

មនុស្សមួយចំនួនអាចនឹងជឿថា ប្រសិនបើការមានទំនាក់ទំនងជាមួយព្រះជាម្ចាស់មានគ្រោះថ្នាក់ខ្លាំងយ៉ាងនេះ នោះវាជារឿងល្អក្នុងការនៅឲ្យឆ្ងាយពីព្រះជាម្ចាស់។ តើមនុស្សបែបនេះអាចទទួលបានអ្វីខ្លះ? តើពួកគេអាចស្មោះត្រង់ ចំពោះព្រះជាម្ចាស់ដែរឬទេ? ប្រាកដណាស់ ការមានទំនាក់ទំនងជាមួយព្រះជាម្ចាស់ ពិតជាលំបាកណាស់ ប៉ុន្ដែ នេះក៏ព្រោះតែមនុស្សមានត្រូវបានធ្វើឲ្យពុករលួយ មិនមែនដោយសារតែព្រះជាម្ចាស់ មិនអាចមានទំនាក់ទំនងជាមួយគេនោះឡើយ។ សម្រាប់អ្នករាល់គ្នា វាជារឿងល្អក្នុងការលះបង់ការខិតខំកាន់តែខ្លាំង ចំពោះសេចក្ដីពិត នៃការស្គាល់នូវ

ខ្លួនឯង។ ហេតុអ្វីបានជាអ្នករាល់គ្នា មិនអាចរកឃើញនូវការសព្វព្រះហឫទ័យពីព្រះជាម្ចាស់? តើហេតុអ្វីបានជានិស្ស័យរបស់អ្នករាល់គ្នាចំពោះទ្រង់ គួរឲ្យស្អប់ខ្ពើមយ៉ាងនេះ? ហេតុអ្វីបានជាពាក្យសម្ដីរបស់អ្នករាល់គ្នា ធ្វើឲ្យទ្រង់ស្អប់ខ្ពើម? ដរាបណាអ្នករាល់គ្នាបានបង្ហាញនូវភាពស្មោះត្រង់តែបន្តិច នោះអ្នកអាចច្រៀងសរសើរ និងទាមទាររង្វាន់សម្រាប់ការចូលរួមចំណែកបន្តិចបន្តួចនោះបាន អ្នកបានមាក់ងាយអ្នកដទៃនៅពេលដែលបានបង្ហាញគំរូ នៃការស្ដាប់បង្គាប់ ហើយបានមើលងាយដល់ព្រះជាម្ចាស់នៅពេលបានសម្រេចកិច្ចការបន្តិចបន្តួច។ ដ្បិតក្នុងការដែលយាងព្រះជាម្ចាស់មកក្នុងជីវិតអ្នក អ្នករាល់គ្នាក៏ទូលសុំមាសប្រាក់ អំណោយ និងសមិទ្ធផលនានា។ វាធ្វើឲ្យអ្នកខូចចិត្តក្នុងការថ្វាយប្រាក់មួយកាក់ ឬពីរកាក់ទៅវិញ នៅពេលដែលអ្នកថ្វាយដប់រៀល នោះអ្នកក៏ប្រាថ្នាសុំព្រះពរមកវិញ ហើយចង់បានការប្រព្រឹត្តដាក់ខ្លួនខុសពីគេផង។ លក្ខណៈជាមនុស្សជាតិរបស់អ្នក ដូចជាការចង់បានរបស់អ្នកគឺមិនគួរនិយាយ ឬមិនគួរឮឡើយ។ តើនៅក្នុងពាក្យសម្ដី និងទង្វើរបស់អ្នករាល់គ្នាមានអ្វីដែលគួរឲ្យសរសើរដែរឬទេ? អស់អ្នកដែលប្រតិបត្តិ តាមកាតព្វកិច្ចរបស់ខ្លួន និងអស់អ្នកដែលមិនប្រតិបត្តិ អស់អ្នកដែលដឹកនាំ និងអស់អ្នកដែលដើរតាមអស់អ្នកដែលបានបរិច្ចាគ និងអស់អ្នកដែលមិនបានចូលរួមបរិច្ចាគ អស់អ្នកដែលអធិប្បាយព្រះបន្ទូល និងអស់អ្នកដែលទទួលស្ដាប់នូវព្រះបន្ទូល និងមនុស្សជាច្រើន ប្រភេទទៀត៖ គឺមនុស្សទាំងអស់សុទ្ធតែកោតសរសើរខ្លួនឯង។ តើអ្នករាល់គ្នាមិនយល់ថាការនេះគួរឲ្យចង់សើចទេឬអី? ទោះជាយ៉ាងណាក្ដី អ្នករាល់គ្នាមិនអាចចុះសម្រុងនឹងព្រះជាម្ចាស់ ដោយការដែលដឹងច្បាស់ថា អ្នកជឿលើព្រះជាម្ចាស់ឡើយ។ ការដែលដឹងច្បាស់ថា អ្នករាល់គ្នាមិនសក្ដិសមនឹងគួរឲ្យសរសើរ នោះអ្នកនៅតែអួតបំប៉ោងដដែលៗ។ តើអ្នករាល់គ្នាមិនយល់ថា គំនិតរបស់អ្នកបានធ្លាក់ដុនដាប ដល់ចំណុចដែលគ្រប់គ្រងលែងបានទេឬ? ក្នុងករណីដែលគំនិតរបស់អ្នកស្ថិតក្នុងសភាពបែបនេះ តើអ្នករាល់គ្នាមិនការភ័យខ្លាចក្នុងគ្រាដែលខ្លួនកំពុងស្ថិតក្នុងផ្លូវបំបែកនេះទេឬ? និស្ស័យរបស់អ្នករាល់គ្នាបានធ្លាក់ដុនដាប ដល់ចំណុចដែលអ្នកមិនអាចចុះសម្រុង

នឹងព្រះជាម្ចាស់។ នៅក្នុងសេចក្ដីនេះ តើសេចក្ដីជំនឿរបស់អ្នករាល់គ្នាមិនគួរឲ្យចង់សើចទេឬអី? តើសេចក្ដីជំនឿរបស់អ្នករាល់គ្នា មិនមែនជាការចំអកឡកឡឺយទេឬអី? តើអ្នកឈានទៅសម្រេចអនាគតរបស់អ្នក បានយ៉ាងដូចម្ដេច? តើអ្នករាល់គ្នាសម្រេចចិត្តជ្រើសរើសយកផ្លូវណាមួយ យ៉ាងដូចម្ដេច?

## មនុស្សជាច្រើនត្រូវបានត្រាស់ហៅ<br>តែមានមនុស្សតិចណាស់ដែលត្រូវបានជ្រើសរើស

ខ្ញុំបានស្វែងរកមនុស្សជាច្រើននៅលើផែនដី ដើម្បីឲ្យគេធ្វើជាអ្នកដើរតាមខ្ញុំ។ ក្នុងចំណោមអ្នកដើរតាមទាំងអស់នេះ មានអ្នកខ្លះបម្រើការងារជាពួកសង្ឃ អ្នកខ្លះជាអ្នកដឹកនាំ អ្នកខ្លះជាពួកកូនប្រុសរបស់ព្រះជាម្ចាស់ អ្នកខ្លះជារាស្ត្ររបស់ព្រះជាម្ចាស់ ហើយអ្នកខ្លះទៀតធ្វើការបម្រើព័ន្ធកិច្ច។ ខ្ញុំបែងចែកពួកគេទៅតាមភាពស្មោះត្រង់ដែលពួកគេបង្ហាញចំពោះខ្ញុំ។ នៅពេលមនុស្សទាំងអស់ ត្រូវបានបែងចែកទៅតាមជំពូករួចហើយ ពោលគឺនៅពេលដែលលក្ខណៈនៃជំពូកមនុស្សម្នាក់ៗ ត្រូវបានបែងចែកច្បាស់លាស់អស់ហើយ នោះខ្ញុំនឹងដាក់លេខរៀងពួកគេម្នាក់ៗ ទៅក្នុងជំពូកដ៏ត្រឹមត្រូវរបស់គេ រួចដាក់ជំពូកមនុស្សនីមួយៗ ទៅក្នុងកន្លែងដែលស័ក្ដិសមសម្រាប់ពួកគេ ដើម្បីសម្រេចបាននូវគោលដៅនៃសេចក្ដីសង្គ្រោះរបស់ខ្ញុំ សម្រាប់មនុស្សលោក។ ខ្ញុំត្រាស់ហៅអស់អ្នកដែលខ្ញុំចង់ប្រោសលោះ នៅក្នុងដំណាក់របស់ខ្ញុំជាក្រុមៗ ហើយបន្ទាប់មក ឲ្យពួកគេរាល់គ្នាទទួលយកកិច្ចការរបស់ខ្ញុំនៅថ្ងៃចុងក្រោយ។ ក្នុងពេលនោះដែរ ខ្ញុំបែងចែកពួកគេទៅតាមជំពូក បន្ទាប់មកផ្ដល់រង្វាន់ ឬដាក់ទោសពួកគេម្នាក់ៗ ទៅតាមទង្វើរបស់ពួកគេ។ នេះហើយ គឺជាដំណាក់កាលនៅក្នុងកិច្ចការរបស់ខ្ញុំ។

សព្វថ្ងៃនេះ ខ្ញុំរស់នៅលើផែនដី ហើយខ្ញុំរស់នៅក្នុងចំណោមមនុស្សលោក។ មនុស្សមានបទពិសោធពីកិច្ចការរបស់ខ្ញុំ និងចាំផ្ទៀងស្ដាប់សូរសៀងរបស់ខ្ញុំ ហើយ

ជាមួយគ្នានេះ ខ្ញុំក៏ប្រទានសេចក្ដីពិតទាំងអស់ទៅដល់មនុស្សរាល់គ្នា ដែលដើរតាមខ្ញុំ ដើម្បីពួកគេអាចទទួលបានជីវិតពីខ្ញុំ ហើយក៏ទទួលបានផ្លូវមួយដែលពួកគេអាចដើរបាន។ ដ្បិតខ្ញុំជាព្រះជាម្ចាស់ ជាអ្នកប្រទានជីវិត។ អំឡុងពេលជាច្រើនឆ្នាំក្នុងការបំពេញកិច្ចការរបស់ខ្ញុំ មនុស្សបានទទួលក៏ច្រើន ហើយបោះបង់ចោលក៏ច្រើន ប៉ុន្ដែខ្ញុំនៅតែពោលថា ពួកគេនៅមិនទាន់ជឿលើខ្ញុំដោយពិតប្រាកដឡើយ។ ដ្បិតមនុស្សលោកគ្រាន់តែទទួលស្គាល់ថា ខ្ញុំជាព្រះជាម្ចាស់ដោយមាត់របស់ពួកគេ ប៉ុន្ដែពួកគេមិនយល់ស្របនឹងសេចក្ដីពិតដែលខ្ញុំមានបន្ទូលនោះទេ ហើយជាងនេះទៅទៀតពួកគេមិនអនុវត្តតាមសេចក្ដីពិតដែលខ្ញុំបង្គាប់ពីពួកគេនោះឡើយ។ នោះមានន័យថាមនុស្សទទួលស្គាល់ត្រឹមថា មានព្រះជាម្ចាស់ ប៉ុន្ដែមិនទទួលស្គាល់ថាមានសេចក្ដីពិតនោះទេ។ មនុស្សទទួលស្គាល់ត្រឹមថាមានព្រះជាម្ចាស់ ប៉ុន្ដែមិនទទួលស្គាល់ថា មានជីវិតនោះទេ។ មនុស្សទទួលស្គាល់ត្រឹមព្រះនាមរបស់ព្រះជាម្ចាស់ ប៉ុន្ដែមិនទទួលស្គាល់លក្ខណៈរបស់ទ្រង់នោះទេ។ ខ្ញុំស្អប់ពួកគេ ដោយសារតែចិត្តងប់ងល់របស់ពួកគេ ដ្បិតពួកគេគ្រាន់តែប្រើពាក្យសម្ដីពិរោះៗដើម្បីបោកប្រាស់ខ្ញុំប៉ុណ្ណោះ។ គ្មាននរណាម្នាក់ក្នុងចំណោមពួកគេថ្វាយបង្គំខ្ញុំដោយពិតប្រាកដនោះទេ។ ពាក្យសម្ដីរបស់អ្នករាល់គ្នា មានបង្កប់នូវសេចក្ដីល្បួងរបស់សត្វពស់ ហើយជាសម្ដីអួតខ្លាំងជាទីបំផុត ជាសេចក្ដីប្រកាសដ៏ពិតប្រាកដដោយមហាទេវតា។ ជាងនេះទៅទៀតទង្វើរបស់អ្នករាល់គ្នាត្រូវបានបំផ្លាញខ្ទេចខ្ទីដល់កម្រិតមួយយ៉ាងអាម៉ាស់។ ក្ដីប្រាថ្នាច្រើនហួសប្រមាណ និងបំណងលោភលន់របស់អ្នករាល់គ្នា គឺទាស់ត្រចៀកខ្លាំងណាស់។ អ្នករាល់គ្នាបានក្លាយជាសត្វខ្មូត នៅក្នុងដំណាក់របស់ខ្ញុំ ជាវត្ថុដែលត្រូវបោះចោលដោយសារសេចក្ដីសម្អប់។ ដ្បិតគ្មាននរណាម្នាក់ក្នុងចំណោមអ្នករាល់គ្នាស្រឡាញ់សេចក្ដីពិតនោះទេ។ ផ្ទុយទៅវិញ អ្នកប្រាថ្នាចង់ទទួលបានព្រះពរ ចង់បានទៅឋានសួគ៌ ចង់មើលឃើញទិដ្ឋភាពដ៏អស្ចារ្យរបស់ព្រះគ្រីស្ទដែលទ្រង់សម្ដែងឫទ្ធានុភាពរបស់ទ្រង់នៅលើផែនដីនេះ។ ប៉ុន្ដែ តើអ្នករាល់គ្នាធ្លាប់គិតទេថា មនុស្សដូចជាអ្នករាល់គ្នា មនុស្សដែលពុករលួយយ៉ាងខ្លាំង ជាមនុស្សដែលមិនដឹងថាព្រះ

ជាម្ចាស់ជាអ្វីផងនោះ ស័ក្តិសមនឹងដើរតាមព្រះជាម្ចាស់ដូចម្ដេចបាន? តើអ្នកអាចទៅឋានសួគ៌បានដូចម្ដេចទៅ? តើអ្នកស័ក្តិសមនឹងមើលឃើញទិដ្ឋភាពដ៏អស្ចារ្យ ជាទិដ្ឋភាពដ៏ល្អត្រចះត្រចង់ មិនដែលធ្លាប់មានពីមុនមកនោះ បានដោយរបៀបណា? មាត់របស់អ្នក ពោរពេញដោយពាក្យសម្ដីបោកប្រាស់ និងពាក្យស្មោកគ្រោក ពាក្យមិនស្មោះត្រង់ និងពាក្យក្រអឺតក្រទម។ អ្នកមិនដែលនិយាយពាក្យស្មោះត្រង់ចំពោះខ្ញុំឡើយ គ្មានពាក្យបរិសុទ្ធ គ្មានពាក្យចុះចូលចំពោះខ្ញុំ នៅពេលស្ដាប់ព្រះបន្ទូលរបស់ខ្ញុំឡើយ។ នៅទីបំផុត តើជំនឿរបស់អ្នកមានលក្ខណៈបែបណាទៅ? នៅក្នុងចិត្តរបស់អ្នករាល់គ្នា គ្មានអ្វីក្រៅពីសេចក្ដីប៉ងប្រាថ្នា និងប្រាក់កាសឡើយ ហើយនៅក្នុងគំនិតរបស់អ្នករាល់គ្នា ក៏គ្មានអ្វីក្រៅពីទ្រព្យសម្បត្តិដែរ។ រៀងរាល់ថ្ងៃ អ្នកត្រិះរិះថា ត្រូវធ្វើបែបណាដើម្បីទទួលបានអ្វីមួយពីខ្ញុំ។ រៀងរាល់ថ្ងៃ អ្នករាប់ចំនួនទ្រព្យសម្បត្តិ និងចំនួនរបស់ទ្រព្យដែលអ្នកបានទទួលពីខ្ញុំ។ រៀងរាល់ថ្ងៃ អ្នកទន្ទឹងរង់ចាំឲ្យព្រះពរធ្លាក់មករកអ្នករាល់គ្នាទៀត ដើម្បីឲ្យអ្នករាល់គ្នាអាចត្រេកអរសប្បាយនឹងរបស់ទ្រព្យគួរជាទីត្រេកអរសប្បាយ ដែលមានចំនួនកាន់តែច្រើន និងមានក្បួនខ្នាតកាន់តែខ្ពស់ជាងមុន។ នៅគ្រប់ពេលទាំងអស់ នៅក្នុងគំនិតរបស់អ្នកពុំមានរូបខ្ញុំឡើយ ក៏មិនមានសេចក្ដីពិតដែលមកអំពីខ្ញុំដែរ តែផ្ទុយទៅវិញ គំនិតរបស់អ្នក មានតែប្ដី ឬប្រពន្ធ កូនប្រុស កូនស្រីរបស់អ្នករាល់គ្នា និងគ្រឿងបរិភោគ ព្រមទាំងសម្លៀកបំពាក់របស់អ្នករាល់គ្នាតែប៉ុណ្ណោះ។ អ្នកគិតថា តើត្រូវធ្វើដូចម្ដេច ទើបអ្នកអាចទទួលបានភាពរីករាយកាន់តែច្រើន និងកាន់តែខ្លាំងជាងនេះ។ ប៉ុន្តែ បើទោះបីជាពេលដែលអ្នកបានចម្អែតក្រពះរបស់អ្នករាល់គ្នារហូតដល់ផ្ទុះពោះក្ដី តើអ្នកនៅតែមិនមែនជាសាកសពទេឬអី? សូម្បីតែពេលដែលអ្នកតុបតែងខ្លួនឯងពីខាងក្រៅ ដោយសម្លៀកបំពាក់ស្អាតៗបែបនេះក្ដី តើអ្នករាល់គ្នាមិនមែនជាសាកសពចេះដើរ ដែលគ្មានជីវិតទេឬអី? អ្នករាល់គ្នា ខំធ្វើការនឿយហត់ព្រោះតែក្រពះ រហូតដល់សក់ក្បាលប្រែទៅជាស្កូវ តែគ្មាននរណាលះបង់សក់មួយសរសៃដើម្បីកិច្ចការរបស់ខ្ញុំទេ។ អ្នករាល់គ្នាកំពុងទៅមុខឥតឈប់ឈរ ដោយប្រើកម្លាំងកាយ និងញាំញីខួរក្បាល ដើម្បីជាប្រយោជន៍ដល់ខាង

សាច់ឈាមរបស់អ្នកផ្ទាល់ និងសម្រាប់កូនប្រុសស្រីរបស់អ្នក ប៉ុន្តែគ្មាននរណាម្នាក់ក្នុងចំណោមអ្នករាល់គ្នា បង្ហាញការព្រួយបារម្ភ ឬក្ដីកង្វល់អំពីបំណងហឫទ័យរបស់ខ្ញុំឡើយ។ តើនៅមានអ្វីខ្លះទៀតដែលអ្នករាល់គ្នាសង្ឃឹមថានឹងទទួលបានពីខ្ញុំ?

នៅពេលខ្ញុំធ្វើការ ខ្ញុំមិនដែលប្រញាប់ប្រញាល់នោះទេ។ មិនខ្វល់ថាមនុស្សដើរតាមខ្ញុំដោយរបៀបណានោះទេ ខ្ញុំធ្វើកិច្ចការរបស់ខ្ញុំស្របទៅតាមជំហាននីមួយៗស្របទៅតាមផែនការរបស់ខ្ញុំ។ ដូចនេះ មិនថាអ្នករាល់គ្នាបះបោរនឹងខ្ញុំយ៉ាងណានោះទេ ក៏ខ្ញុំនៅតែបន្តធ្វើការឥតឈប់ដែរ ហើយខ្ញុំនៅតែបន្តនិយាយពាក្យពេចន៍ដែលខ្ញុំត្រូវនិយាយ។ ខ្ញុំត្រាស់ហៅអស់អ្នកដែលខ្ញុំបានដៅទុកជាមុនឲ្យមកដំណាក់របស់ខ្ញុំ ដើម្បីឲ្យពួកគេអាចស្ដាប់បន្ទូលរបស់ខ្ញុំបាន។ ខ្ញុំនឹងនាំយកអស់អ្នកណាដែលចុះចូលនឹងបន្ទូលរបស់ខ្ញុំ អ្នកដែលស្រេកឃ្លានចង់បានបន្ទូលរបស់ខ្ញុំ មកចំពោះបល្ល័ង្ករបស់ខ្ញុំ។ អស់អ្នកណាដែលបែរខ្នងដាក់បន្ទូលរបស់ខ្ញុំ អ្នកដែលមិនស្ដាប់បង្គាប់ខ្ញុំ និងបំពានមកលើខ្ញុំដោយបើកចំហ ខ្ញុំនឹងទុកពួកគេចោលមួយឡែកដើម្បីរង់ចាំការដាក់ទោសចុងក្រោយរបស់គេ។ មនុស្សទាំងអស់ សុទ្ធតែរស់នៅក្នុងសេចក្ដីពុករលួយ និងស្ថិតនៅក្រោមដៃរបស់មេកំណាច ដូច្នេះហើយ អ្នកដើរតាមខ្ញុំពុំសូវមានអ្នកដែលមានចិត្តប្រាថ្នាចង់បានសេចក្ដីពិតនោះទេ។ មានន័យថា ពួកគេភាគច្រើនមិនថ្វាយបង្គំខ្ញុំដោយពិតប្រាកដទេ។ ពួកគេមិនថ្វាយបង្គំខ្ញុំដោយសេចក្ដីពិតទេ ប៉ុន្តែពួកគេព្យាយាមទទួលបានការជឿជាក់ពីខ្ញុំ តាមរយៈសេចក្ដីពុករលួយ និងការបះបោរដោយមធ្យោបាយបោកបញ្ឆោត។ ហេតុដូច្នេះហើយ ទើបខ្ញុំនិយាយថា៖ មនុស្សជាច្រើនត្រូវបានត្រាស់ហៅ តែមានមនុស្សតិចណាស់ដែលត្រូវបានជ្រើសរើស។ មនុស្សដែលត្រូវបានត្រាស់ហៅ ពុករលួយខ្លាំងណាស់ ហើយទាំងអស់គ្នាសុទ្ធតែរស់នៅក្នុងយុគសម័យតែមួយ ប៉ុន្តែមនុស្សដែលត្រូវបានជ្រើសរើសគឺជាចំណែកមួយក្នុងចំណោមពួកគេ ពួកគេគឺជាអ្នកជឿ និងទទួលស្គាល់សេចក្ដីពិតហើយជាអ្នកអនុវត្តតាមសេចក្ដីពិតនេះ។ មនុស្សទាំងអស់នេះ គ្រាន់តែជាចំណែកដ៏តូចមួយ ក្នុងចំណោមពួកគេ ហើយខ្ញុំនឹងទទួលបានសិរីល្អថែមទៀតពីក្នុងចំណោម

ពួកគេនេះ។ បើប្រៀបធៀបទៅនឹងពាក្យសម្ដីទាំងនេះ តើអ្នកដឹងទេថា អ្នករាល់គ្នាស្ថិតនៅក្នុងចំណោមមនុស្សដែលត្រូវជ្រើសដែរឬទេ? តើចុងបញ្ចប់របស់អ្នករាល់គ្នានឹងមានលក្ខណៈដូចម្ដេច?

ដូចខ្ញុំមានបន្ទូលហើយថា អ្នកដែលដើរតាមខ្ញុំ គឺមានច្រើនណាស់ ប៉ុន្តែអ្នកដែលស្រឡាញ់ខ្ញុំដោយពិតប្រាកដនោះ គឺមានតិចណាស់។ ប្រហែលអ្នកខ្លះអាចសួរថា «បើទូលបង្គំមិនស្រឡាញ់ទ្រង់ទេ តើទូលបង្គំអាចទទួលបានការឲ្យតម្លៃធំធេងដល់ម្លឹងទេ? បើទូលបង្គំមិនបានស្រឡាញ់ទ្រង់ទេ តើទូលបង្គំដើរតាមទ្រង់រហូតដល់ពេលនេះម្ដេចកើត?» ប្រាកដណាស់ អ្នកមានហេតុផលជាច្រើន ហើយក្ដីស្រឡាញ់របស់អ្នក គឺធំធេងប្រាកដណាស់ ប៉ុន្តែតើអ្វីទៅជាសារជាតិនៃសេចក្ដីស្រឡាញ់របស់អ្នកចំពោះខ្ញុំ? តាមនិយមន័យ «សេចក្ដីស្រឡាញ់» គឺសំដៅលើមនោសញ្ចេតនាដ៏បរិសុទ្ធ និងឥតសៅហ្មង ជាទីដែលអ្នកប្រើដួងចិត្តរបស់អ្នកដើម្បីស្រឡាញ់ ដើម្បីសម្ដែងអារម្មណ៍ និងដើម្បីគិតពិចារណា។ នៅក្នុងសេចក្ដីស្រឡាញ់ គ្មានលក្ខខណ្ឌ គ្មានរនាំងខណ្ឌចែក និងគ្មានគម្លាតនោះទេ។ នៅក្នុងសេចក្ដីស្រឡាញ់ គ្មានមន្ទិលសង្ស័យគ្មានការបោកបញ្ឆោត និងគ្មានកលល្បិចនោះទេ។ នៅក្នុងសេចក្ដីស្រឡាញ់ គ្មានទេគម្លាតពីគ្នា និងគ្មានភាពមន្ទិលសៅហ្មងឡើយ។ បើអ្នកស្រឡាញ់ នោះអ្នកនឹងមិនបោកបញ្ឆោត ត្អូញត្អែរ ផិតក្បត់ បះបោរ ទាមទារ ឬស្វែងរកផលប្រយោជន៍អ្វីមួយ ឬដើម្បីទទួលបានលាភសក្ការៈក្នុងចំនួនណាមួយឡើយ។ បើអ្នកស្រឡាញ់ នោះអ្នកនឹងលះបង់ខ្លួនឯងដោយក្ដីរីករាយ សុខចិត្តរងការលំបាក ដោយក្ដីរីករាយ អ្នកនឹងមានការចុះសម្រុងជាមួយនឹងខ្ញុំ អ្នកនឹងបោះបង់ចោលអ្វីទាំងអស់ដែលអ្នកមានដើម្បីខ្ញុំ អ្នកនឹងលះបង់គ្រួសាររបស់អ្នក អនាគតរបស់អ្នក យុវភាពរបស់អ្នក និងជីវិតអាពាហ៍ពិពាហ៍របស់អ្នក។ ពុំនោះសោត ក្ដីស្រឡាញ់របស់អ្នក នឹងមិនមែនជាក្ដីស្រឡាញ់ដែលពិតប្រាកដនោះទេ គ្រាន់តែជាការបោកបញ្ឆោត និងការផិតក្បត់ប៉ុណ្ណោះ! តើក្ដីស្រឡាញ់របស់អ្នក គឺជាក្ដីស្រឡាញ់ប្រភេទណា? តើវាជាក្ដីស្រឡាញ់ពិតប្រាកដមែនដែរឬទេ? ឬមួយក្លែងក្លាយ? តើអ្នកបានលះបង់ច្រើនប៉ុនណាហើយ? តើអ្នកបាន

ថ្វាយច្រើនប៉ុនណាហើយ? តើខ្ញុំទទួលបានក្ដីស្រឡាញ់អ្នក ច្រើនប៉ុនណាហើយ? តើអ្នកដឹងដែរឬទេ? ដួងចិត្តរបស់អ្នកពោរពេញទៅដោយសេចក្ដីអាក្រក់ អំពើក្បត់ និងការបោកបញ្ឆោត ហើយបើបែបនេះ តើក្ដីស្រឡាញ់របស់អ្នកស្មោកគ្រោកខ្លាំងប៉ុនណា? អ្នករាល់គ្នាគិតថា អ្នកបានលះបង់ច្រើនគ្រប់គ្រាន់ហើយសម្រាប់ខ្ញុំ។ អ្នករាល់គ្នាគិតថាក្ដីស្រឡាញ់របស់អ្នករាល់គ្នាចំពោះខ្ញុំ វាច្រើនគ្រប់គ្រាន់ហើយ។ បើដូច្នោះមែន តើហេតុអ្វីបានជាពាក្យសម្ដី និងទង្វើរបស់អ្នករាល់គ្នា តែងតែបះបោរ និងបោកបញ្ឆោតទៅវិញ? អ្នករាល់គ្នាដើរតាមខ្ញុំ ប៉ុន្តែអ្នកមិនទទួលស្គាល់បន្ទូលរបស់ខ្ញុំឡើយ។ តើនេះចាត់ទុកជាក្ដីស្រឡាញ់បានដែរឬទេ? អ្នករាល់គ្នាដើរតាមខ្ញុំ ប៉ុន្តែបែរជាទុកខ្ញុំចោលទៅវិញ។ តើនេះចាត់ទុកជាក្ដីស្រឡាញ់ដែរឬទេ? អ្នករាល់គ្នាដើរតាមខ្ញុំ ប៉ុន្តែអ្នករាល់គ្នាមិនទុកចិត្តខ្ញុំ។ តើនេះចាត់ទុកជាក្ដីស្រឡាញ់ដែរឬទេ? អ្នករាល់គ្នាដើរតាមខ្ញុំ ប៉ុន្តែអ្នករាល់គ្នាមិនអាចទទួលថាខ្ញុំមានពិតនោះទេ។ តើនេះចាត់ទុកជាក្ដីស្រឡាញ់បានដែរឬទេ? អ្នករាល់គ្នាដើរតាមខ្ញុំ ប៉ុន្តែអ្នករាល់គ្នាមិនប្រព្រឹត្តនឹងខ្ញុំឲ្យស័ក្ដិសមឋានៈរបស់ខ្ញុំទេ ហើយអ្នកតែងធ្វើឲ្យខ្ញុំមានការពិបាកជានិច្ច។ តើនេះចាត់ទុកជាក្ដីស្រឡាញ់បានដែរឬទេ? អ្នករាល់គ្នាដើរតាមខ្ញុំ ប៉ុន្តែអ្នករាល់ព្យាយាមបន្លំខ្ញុំ និងបោកបញ្ឆោតខ្ញុំគ្រប់រឿងទាំងអស់។ តើនេះចាត់ទុកជាក្ដីស្រឡាញ់បានទេ? អ្នករាល់គ្នាបម្រើខ្ញុំ ប៉ុន្តែអ្នករាល់គ្នាមិនខ្លាចរអាចំពោះខ្ញុំសោះឡើយ។ តើនេះចាត់ទុកជាក្ដីស្រឡាញ់បានទេ? អ្នករាល់គ្នាទាស់ទទឹងនឹងខ្ញុំសព្វគ្រប់បែបយ៉ាងទាំងអស់។ តើទាំងអស់នេះ ចាត់ទុកជាក្ដីស្រឡាញ់បានដែរឬទេ? អ្នករាល់គ្នាបានលះបង់ជាច្រើន វាជាការពិត ប៉ុន្តែអ្នករាល់គ្នាមិនដែលបានអនុវត្តទៅតាមអ្វីដែលខ្ញុំតម្រូវឲ្យអ្នកធ្វើនោះទេ។ តើនេះអាចចាត់ទុកជាក្ដីស្រឡាញ់បានទេ? តាមការគិតពិចារណាដោយយកចិត្តទុកដាក់ បង្ហាញថា នៅក្នុងចិត្តរបស់អ្នករាល់គ្នា គ្មានសេចក្ដីស្រឡាញ់ចំពោះខ្ញុំសូម្បីបន្តិចសោះឡើយ។ បន្ទាប់ពីបំពេញកិច្ចការអស់ពេលជាច្រើនឆ្នាំ និងតាមរយៈពាក្យសម្ដីជាច្រើនដែលខ្ញុំមានបន្ទូល តើអ្នករាល់គ្នា ទទួលបានច្រើនប៉ុនណាហើយ? តើការនេះមិនសមនឹងពិចារណាឡើងវិញដោយយកចិត្តទុកដាក់ទេឬអី? ខ្ញុំសូមទូន្មានអ្នករាល់គ្នាថា៖ មនុស្សដែលខ្ញុំត្រាស់

ហៅឲ្យមកឯខ្ញុំ ជាមនុស្សដែលពុំធ្លាប់ពុករលួយពីមុនមកនោះទេ ផ្ទុយទៅវិញ មនុស្សដែលខ្ញុំជ្រើសយក គឺជាមនុស្សដែលស្រឡាញ់ខ្ញុំដោយពិតប្រាកដ។ ហេតុដូច្នេះ អ្នករាល់គ្នា ត្រូវតែមានការប្រុងប្រយ័ត្នចំពោះពាក្យសម្ដី និងទង្វើរបស់ខ្លួន ហើយពិនិត្យមើលបំណង និងគំនិតរបស់ខ្លួន ដើម្បីកុំឲ្យវាជ្រុលជ្រួសហួសកំណត់។ នៅគ្រាចុងក្រោយ ចូរខំប្រឹងថ្វាយសេចក្ដីស្រឡាញ់របស់អ្នករាល់គ្នាមកខ្ញុំឲ្យអស់ពីចិត្ត ក្រែងសេចក្ដីក្រោធរបស់ខ្ញុំ មិនរសាយចេញពីអ្នករាល់គ្នាសោះ!

# អ្នកគួរតែស្វះស្វែងរកវិធីដែលស្របនឹងព្រះគ្រីស្ទ

ខ្ញុំបានធ្វើកិច្ចការជាច្រើនក្នុងចំណោមមនុស្សលោក ក្នុងពេលដែលខ្ញុំបានសម្ដែងចេញនូវព្រះបន្ទូលជាច្រើនដែរ។ បន្ទូលទាំងនោះសុទ្ធតែដើម្បីសេចក្ដីសង្គ្រោះរបស់មនុស្សលោក ហើយត្រូវបានថ្លែង ដើម្បីឱ្យមនុស្សបានចុះសម្រុងនឹងខ្ញុំ។ ប៉ុន្តែខ្ញុំបានទទួលមនុស្សលើផែនដីតិចតួចណាស់ ដែលចុះសម្រុងជាមួយនឹងខ្ញុំ ដូច្នេះបានជាខ្ញុំនិយាយថា មនុស្សមិនឱ្យតម្លៃបន្ទូលរបស់ខ្ញុំទេ ដ្បិតមនុស្សមិនចុះសម្រុងជាមួយខ្ញុំ។ តាមរបៀបនេះ កិច្ចការដែលខ្ញុំធ្វើមិនគ្រាន់តែដើម្បីឱ្យមនុស្សអាចថ្វាយបង្គំខ្ញុំទេ អ្វីដែលសំខាន់ជាងនេះគឺថា មនុស្សអាចស្របនឹងខ្ញុំ។ មនុស្សបានក្លាយជាខូចអាក្រក់ និងរស់នៅក្នុងអន្ទាក់សាតាំង។ មនុស្សទាំងអស់រស់នៅតាមសាច់ឈាម រស់នៅតាមចំណង់ចិត្តអាត្មានិយម ហើយក៏គ្មាននរណាម្នាក់ក្នុងចំណោមពួកគេស្របនឹងខ្ញុំឡើយ។ មានមនុស្សមួយចំនួននិយាយថា ពួកគេចុះសម្រុងនឹងខ្ញុំតែមនុស្សទាំងនោះសុទ្ធតែថ្វាយបង្គំព្រះក្លែងក្លាយគ្រប់គ្នា។ បើទោះបីជាពួកគេ ទទួលស្គាល់នាមខ្ញុំថាបរិសុទ្ធ តែពួកគេដើរតាមផ្លូវបញ្ច្រាសពីខ្ញុំ ហើយពាក្យសម្ដីពួកគេ ពោរពេញដោយភាពក្អេងក្អាង និងការជឿជាក់លើខ្លួនឯង។ នេះដោយសារតែពួកគេប្រឆាំងទាស់នឹងខ្ញុំ ហើយនៅមិនស្របនឹងខ្ញុំ តាំងពីក្នុងជម្រៅចិត្តរបស់គេមក។ រៀងរាល់ថ្ងៃ ពួកគេស្វែងរកដានរបស់ខ្ញុំនៅក្នុងព្រះគម្ពីរ ហើយបានឃើញសារ «ស័ក្តិសម» ដោយចៃដន្យ ជាសារ

ដែលពួកគេអានមិនចេះចប់មិនចេះហើយ និងទន្ទេញដូចគម្ពីរ។ ពួកគេមិនដឹងពីវិធីចុះសម្រុងនឹងខ្ញុំទេ ហើយក៏មិនដឹងថា ការទាស់ទទឹងនឹងខ្ញុំ គឺជាអ្វីដែរ។ ពួកគេគ្រាន់តែអានគម្ពីរទាំងងងឹតងងល់។ នៅក្នុងព្រះគម្ពីរពួកគេដាក់កំហិតព្រះដ៏ស្រពេចស្រពិលដែលពួកគេមិនធ្លាប់បានជួបសោះ និងគ្មានសមត្ថភាព អាចមើលឃើញបាន ហើយយកគម្ពីរមកមើលពេលទំនេរ។ ពួកគេជឿថា វត្តមានខ្ញុំមានតែនៅក្នុងវិសាលភាពនៃព្រះគម្ពីរ ហើយពួកគេចាត់ទុកខ្ញុំស្មើនឹងព្រះគម្ពីរ ពោលគឺ គ្មានព្រះគម្ពីរ គឺគ្មានខ្ញុំ ហើយគ្មានខ្ញុំគឺគ្មានព្រះគម្ពីរ។ ពួកគេព្រងើយកន្ដើយចំពោះវត្តមាន និងសកម្មភាពខ្ញុំ ផ្ទុយទៅវិញពួកគេយកចិត្តទុកដាក់ជ្រុល និងជាពិសេស លើគ្រប់ពាក្យពេចន៍ក្នុងបទគម្ពីរ។ មនុស្សច្រើនជាងនេះទៀត ជឿថាខ្ញុំមិនគួរធ្វើអ្វីដែលខ្ញុំចង់ធ្វើទេ លុះត្រាតែមានការទាយទុកក្នុងបទគម្ពីរ។ ពួកគេផ្ដល់សារៈសំខាន់ខ្លាំងពេកដល់បទគម្ពីរ។ អាចនិយាយបានថា ពួកគេផ្ដល់សារៈសំខាន់ដល់ពាក្យពេចន៍ និងសំនួនសំណេរខ្លាំងពេកដល់ថ្នាក់ពួកគេប្រើខគម្ពីរ ដើម្បីវាស់ស្ទង់ព្រះបន្ទូលដែលខ្ញុំថ្លែង រួចថ្កោលទោសខ្ញុំ។ អ្វីដែលពួកគេស្វែងរក មិនមែនជាវិធីដែលស្របនឹងខ្ញុំ ឬវិធីដែលស្របនឹងសេចក្ដីពិតនោះទេ ប៉ុន្តែជាការចុះសម្រុងនឹងពាក្យពេចន៍ក្នុងគម្ពីរ ហើយពួកគេជឿថា អ្វីដែលមិនស្របនឹងព្រះគម្ពីរ មិនមែនជាកិច្ចការរបស់ខ្ញុំទេ មិនថាមួយណាក៏ដោយ។ តើមនុស្សបែបនោះ មិនមែនជាពូជពង្សដ៏ស្មោះត្រង់របស់ពួកផារិស៊ីទេឬអី? ពួកផារិស៊ីជនជាតិយូដាបានប្រើក្រឹត្យវិន័យម៉ូសេមកដាក់ទោសព្រះយេស៊ូវ។ ពួកគេមិនស្វែងរកការចុះសម្រុងជាមួយនឹងព្រះយេស៊ូវនាពេលនោះទេ ប៉ុន្តែបានធ្វើតាមន័យពាក្យក្នុងក្រឹត្យវិន័យយ៉ាងខ្ជាប់ខ្ជួន រហូតដល់ថ្នាក់ដំព្រះយេស៊ូវដែលឥតទោស ភ្ជាប់នឹងឈើឆ្កាង នៅទីបំផុតបន្ទាប់ពីពួកគេបានចោទព្រះយេស៊ូវថា មិនធ្វើតាមក្រឹត្យវិន័យនៃគម្ពីរសញ្ញាចាស់ និងមិនមែនជាព្រះមែស្ស៊ីទេ។ តើពួកគេមានលក្ខណៈអ្វី? តើមិនមែនមកពីពួកគេមិនបានស្វែងរកវិធីដែលស្របនឹងសេចក្ដីពិតទេឬអី? ពួកគេងប់នឹងពាក្យពេចន៍គ្រប់ម៉ាត់ក្នុងបទគម្ពីរ តែមិនធ្វើព្រងើយនឹងបំណងព្រះហឫទ័យរបស់ខ្ញុំ ហើយថែមទាំងមិនខ្វល់ពីជំហាន និងវិធីសាស្ត្រអនុវត្តកិច្ចការរបស់ខ្ញុំឡើយ។ ពួកគេមិនមែនជាមនុស្សដែល

ស្វែងរកសេចក្តីពិតទេ ប៉ុន្តែជាមនុស្សដែលប្រកាន់ខ្ជាប់នឹងពាក្យពេចន៍ជាខ្លាំង។ ពួកគេមិនមែនជាមនុស្សដែលជឿលើព្រះជាម្ចាស់ទេ ប៉ុន្តែជាមនុស្សដែលជឿលើព្រះគម្ពីរ។ សំខាន់បំផុត គឺពួកគេជាអ្នកចាំដានព្រះគម្ពីរ។ ដើម្បីរក្សាប្រយោជន៍នៃព្រះគម្ពីរ ដើម្បីរក្សាកិត្តិយសនៃព្រះគម្ពីរ និងដើម្បីការពារកេរ្តិ៍ឈ្មោះនៃព្រះគម្ពីរ ពួកគេដល់ថ្នាក់ឆ្កាងព្រះយេស៊ូវ ដែលពេញព្រះទ័យមេត្តាករុណានៅលើឈើឆ្កាង។ ពួកគេធ្វើបែបនេះគ្រាន់តែដើម្បីការពារព្រះគម្ពីរ និងដើម្បីរក្សាសារៈសំខាន់នៃពាក្យពេចន៍គ្រប់ម៉ាត់នៃព្រះគម្ពីរនៅក្នុងចិត្តមនុស្ស។ ដូចនេះបានជាពួកគេបោះបង់អនាគតរបស់ខ្លួន និងតង្វាយលោះបាប ដើម្បីថ្កោលទោសព្រះយេស៊ូវ ដែលមិនសម្រុបតាមគោលលទ្ធិនៃព្រះគម្ពីរ រហូតដល់សុគត។ តើពួកគេទាំងអស់គ្នា មិនមែនជាកញ្ជះនៃពាក្យពេចន៍គ្រប់ម៉ាត់ក្នុងបទគម្ពីរទេឬអី?

ចុះមនុស្សសព្វថ្ងៃ យ៉ាងដូចម្តេចដែរ? ព្រះគ្រីស្ទបានយាងមក ដើម្បីបង្ហាញសេចក្តីពិត តែពួកគេបែរជាកម្ចាត់ទ្រង់ចេញពីពិភពលោកនេះ ដើម្បីឱ្យពួកគេអាចទទួលបានសិទ្ធចូលទៅកាន់ស្ថានសួគ៌ និងទទួលព្រះគុណទៅវិញ។ ពួកគេចង់បដិសេធការមកដល់នៃសេចក្តីពិតទាំងស្រុង ដើម្បីរក្សាប្រយោជន៍នៃព្រះគម្ពីរ ហើយពួកគេមុខជាចង់ដំដែកគោលឆ្កាងព្រះគ្រីស្ទ ដែលយាងមកជាសាច់ឈាមទៅនឹងឈើឆ្កាងម្តងទៀតដើម្បីជានាវត្តមានដ៏គង់វង្សរបស់ព្រះគម្ពីរ។ តើមនុស្សអាចទទួលសេចក្តីសង្គ្រោះរបស់ខ្ញុំម្តេចបាន បើដួងចិត្តពួកគេព្រៃផ្សៃ ហើយសន្តានពួកគេប្រឆាំងទាស់នឹងខ្ញុំដល់ម្លឹង? ខ្ញុំរស់នៅក្នុងចំណោមមនុស្ស តែមនុស្សមិនដឹងពីវត្តមានខ្ញុំសោះ។ នៅពេលខ្ញុំជះពន្លឺរបស់ខ្ញុំទៅលើមនុស្ស ក៏គេនៅតែមិនអើពើពីវត្តមានខ្ញុំដែរ។ នៅពេលខ្ញុំបញ្ចេញសេចក្តីក្រោធលើគេ គេកាន់តែបដិសេធវត្តមានខ្ញុំខ្លាំងឡើង។ មនុស្សស្វែងរកការចុះសម្រុងនឹងពាក្យពេចន៍ និងស្របនឹងព្រះគម្ពីរ ប៉ុន្តែមិនមាននរណាម្នាក់មកចំពោះមុខខ្ញុំ ដើម្បីស្វែងរកវិធីដែលស្របនឹងសេចក្តីពិតឡើយ។ មនុស្សសម្លឹងមើលមកខ្ញុំនៅស្ថានសួគ៌ ហើយបានថ្វាយក្តីបារម្ភជាពិសេសចំពោះវត្តមានខ្ញុំនៅស្ថានសួគ៌ ប៉ុន្តែគ្មាននរណាម្នាក់យកចិត្តទុកដាក់ចំពោះខ្ញុំ ជាសាច់ឈាមឡើយ ដ្បិតខ្ញុំដែល

រស់នៅក្នុងចំណោមមនុស្ស គ្មានសារៈសំខាន់ឡើយ។ អស់អ្នកណាដែលគ្រាន់តែស្វែងរកការចុះសម្រុងនឹងបន្ទូលក្នុងព្រះគម្ពីរ និងអ្នកដែលស្វែងរកការចុះសម្រុងនឹងព្រះដ៏ស្រពេចស្រពិល គឺជាទិដ្ឋភាពដ៏អាក្រក់ដល់ខ្ញុំ។ នោះគឺដោយសារអ្វីដែលពួកគេថ្វាយបង្គំ គឺជាពាក្យពេចន៍សោះកក្រោះ និងព្រះជាម្ចាស់ដែលមានសមត្ថភាពប្រទានឱ្យពួកគេនូវទ្រព្យសម្បត្តិដែលមិនអាចបរិយាយបាន អ្វីដែលពួកគេថ្វាយបង្គំ គឺជាព្រះដែលដាក់ខ្លួនឲ្យនៅក្រោមការគ្រប់គ្រងរបស់មនុស្សទាំងស្រុង ពោលគឺជាព្រះដែលមិនមានលើលោក។ ដូច្នេះ តើមនុស្សទាំងនោះ អាចទទួលបានអ្វីខ្លះពីខ្ញុំ? មនុស្សថោកទាបដល់ថ្នាក់គ្មានពាក្យបរិយាយទេ។ អស់អ្នកណាដែលប្រឆាំងទាស់នឹងខ្ញុំ អស់អ្នកណាដែលទាមទារពីខ្ញុំមិនចេះអស់មិនចេះហើយ អស់អ្នកណាដែលគ្មានសេចក្ដីស្រឡាញ់ចំពោះសេចក្ដីពិត អស់អ្នកណាដែលបះបោរប្រឆាំងនឹងខ្ញុំ តើពួកគេអាចស្របនឹងខ្ញុំយ៉ាងដូចម្ដេច?

អស់អ្នកណាដែលប្រឆាំងនឹងខ្ញុំ អ្នកនោះហើយ ដែលមិនចុះសម្រុងនឹងខ្ញុំ។ អស់អ្នកណាដែលមិនស្រឡាញ់សេចក្ដីពិត ក៏ដូចគ្នាដែរ។ អស់អ្នកណាដែលបះបោរនឹងខ្ញុំ រឹតតែប្រឆាំងនឹងខ្ញុំ ហើយមិនស្របនឹងខ្ញុំទៀតផង។ អស់អ្នកណាដែលមិនស្របនឹងខ្ញុំ ខ្ញុំប្រគល់អ្នកនោះទៅក្នុងដៃអាកំណាច ហើយខ្ញុំបោះបង់ពួកគេទៅក្នុងសេចក្ដីខូចអាក្រក់របស់អាកំណាច ទុកឲ្យពួកគេបានបង្ហាញសេចក្ដីអាក្រក់របស់ខ្លួនដោយសេរី ហើយចុងបញ្ចប់ ក៏ប្រគល់ពួកគេទៅឲ្យអាកំណាចបំផ្លាញចោល។ ខ្ញុំមិនខ្វល់ថា មានមនុស្សប៉ុន្មាននាក់ថ្វាយបង្គំខ្ញុំទេ ដែលអាចនិយាយបានថា ខ្ញុំមិនខ្វល់ថា មានមនុស្សប៉ុន្មាននាក់ជឿខ្ញុំទេ។ អ្វីដែលខ្ញុំខ្វល់ខ្វាយនោះគឺ តើមានមនុស្សប៉ុន្មាននាក់ដែលស្របនឹងខ្ញុំ។ នោះគឺដោយសារតែអស់អ្នកដែលមិនស្របនឹងខ្ញុំ គឺជាមនុស្សអាក្រក់ដែលក្បត់នឹងខ្ញុំ ពួកគេជាសត្រូវរបស់ខ្ញុំ ហើយខ្ញុំនឹងមិន «រក្សាទុក» ពួកសត្រូវរបស់ខ្ញុំនៅក្នុងដំណាក់ខ្ញុំឡើយ។ អស់អ្នកណាដែលចុះសម្រុងនឹងខ្ញុំ គេនឹងបម្រើខ្ញុំ នៅក្នុងដំណាក់របស់ខ្ញុំជារៀងដរាបតទៅ ហើយអស់អ្នកណាដែលប្រឆាំងនឹងខ្ញុំ គេនឹងរងនូវការដាក់ទោសរបស់ខ្ញុំជារៀងរហូត។ អស់អ្នកណា ដែលខ្វល់តែពីពាក្យនៅក្នុង

គម្ពីរ ហើយមិនរវល់នឹងសេចក្ដីពិត ក៏មិនរវល់នឹងការស្វែងរកដានជើងរបស់ខ្ញុំ នោះគឺពួកគេប្រឆាំងនឹងខ្ញុំហើយ ព្រោះពួកគេកំណត់ខ្ញុំតាមព្រះគម្ពីរ កំហិតខ្ញុំត្រឹមក្នុងគម្ពីរ ហើយថែមទាំងប្រមាថខ្ញុំយ៉ាងក្រៃលែងផង។ តើមនុស្សបែបនោះ អាចមកនៅចំពោះព្រះភ័ក្ត្រខ្ញុំយ៉ាងដូចម្ដេច? ពួកគេមិនយកចិត្តទុកដាក់ចំពោះទង្វើល្អរបស់ខ្ញុំ ក៏មិនយកចិត្តទុកដាក់ចំពោះបំណងព្រះហឫទ័យរបស់ខ្ញុំ ឬសេចក្ដីពិតទេ តែផ្ទុយទៅវិញ គេបែរជាឈ្លក់វង្វេងនឹងន័យពាក្យ គឺន័យពាក្យដែលធ្វើឲ្យស្លាប់។ តើមនុស្សបែបនេះអាចចុះសម្រុងនឹងខ្ញុំដោយរបៀបណា?

ខ្ញុំបានសម្ដែងចេញនូវព្រះបន្ទូលយ៉ាងច្រើន ហើយក៏បានបង្ហាញពីព្រះហឫទ័យ និងនិស្ស័យរបស់ខ្ញុំផង បើទោះជាដូច្នេះក្ដី ក៏មនុស្សនៅតែមិនអាចស្គាល់ខ្ញុំ ហើយជឿលើខ្ញុំដែរ។ ឬក៏អាចនិយាយបានម្យ៉ាងទៀតថា មនុស្សនៅតែមិនអាចស្ដាប់បង្គាប់ខ្ញុំ។ អស់អ្នកដែលរស់នៅក្នុងគម្ពីរ អស់អ្នកដែលរស់នៅក្នុងក្រឹត្យវិន័យ អស់អ្នកដែលរស់នៅលើឈើឆ្កាង អស់អ្នកដែលរស់នៅស្របតាមសេចក្ដីបង្រៀន អស់អ្នកដែលរស់នៅក្នុងកិច្ចការដែលខ្ញុំធ្វើសព្វថ្ងៃនេះ ក្នុងចំណោមពួកគេទាំងនេះ តើនរណាទៅដែលស្របនឹងខ្ញុំ? អ្នករាល់គ្នាគិតតែពីការទទួលព្រះពរ និងរង្វាន់ តែមិនដែលលៃទុកគំនិតគិតថា ធ្វើរបៀបណាដើម្បីឲ្យបានចុះសម្រុងនឹងខ្ញុំយ៉ាងពិតប្រាកដ ឬក៏ពីរបៀបបង្ការខ្លួនឯងពីការប្រឆាំងនឹងខ្ញុំ។ ខ្ញុំខកព្រះហឫទ័យនឹងអ្នករាល់គ្នាណាស់ ព្រោះខ្ញុំបានប្រទានដល់អ្នករាល់គ្នាយ៉ាងច្រើន តែខ្ញុំទទួលបានពីអ្នករាល់គ្នាវិញ តិចតួចជាទីបំផុត។ ការឆបោក ភាពក្រអឺតក្រទម ភាពលោភលន់ សេចក្ដីប្រាថ្នាហួសល្បត់ ការក្បត់ ការមិនស្ដាប់បង្គាប់របស់អ្នករាល់គ្នា ក្នុងចំណោមទង្វើទាំងអស់នេះ តើទង្វើណាមួយ ដែលអាចគេចពីការកត់ចំណាំរបស់ខ្ញុំបាន? អ្នករាល់គ្នាព្រងើយកន្តើយនឹងខ្ញុំ អ្នករាល់គ្នាបោកបញ្ឆោតខ្ញុំ អ្នករាល់គ្នាប្រមាថខ្ញុំ អ្នករាល់គ្នាបញ្ឆោរខ្ញុំ អ្នករាល់គ្នាទារឲ្យខ្ញុំសង ហើយជំរិតទារតង្វាយខ្ញុំ តើសេចក្ដីអាក្រក់របៀបនេះ អាចនឹងគេចរួចពីការដាក់ទោសរបស់ខ្ញុំដោយរបៀបបណា? ការប្រព្រឹត្តអាក្រក់ទាំងអស់នេះ ជាភ័ស្តុតាងបញ្ជាក់ពីភាពជាសត្រូវរបស់អ្នករាល់គ្នាចំពោះខ្ញុំ ហើយជាភ័ស្តុតាងបញ្ជាក់ពីភាព

មិនចុះសម្រុងរបស់អ្នករាល់គ្នានឹងខ្ញុំ។ ពួកអ្នកម្នាក់ៗ ជឿលើខ្លួនឯងថា ចុះសម្រុងនឹងខ្ញុំណាស់ ប៉ុន្តែប្រសិនជាបែបនោះមែន តើភ័ស្តុតាងដែលមិនអាចប្រកែកបាននេះត្រូវប្រើចំពោះនរណាខ្លះ? អ្នករាល់គ្នាជឿលើខ្លួនឯងថា មានសេចក្ដីស្មោះត្រង់ និងភក្តីភាព យ៉ាងច្រើនអនេកចំពោះខ្ញុំ។ អ្នករាល់គ្នាគិតថា ខ្លួនឯងមានចិត្តសប្បុរសខ្លាំងណាស់ មានមេត្តាខ្លាំងណាស់ ហើយស្រឡាញ់ខ្ញុំជាខ្លាំង។ អ្នករាល់គ្នាគិតថា ខ្លួនបានធ្វើលើសពីគ្រប់គ្រាន់ហើយដើម្បីខ្ញុំ។ ក៏ប៉ុន្តែ តើអ្នករាល់គ្នាមានដែលផ្ទៀបផ្ទៀងនឹងនេះ ទៅនឹងសកម្មភាពរបស់ខ្លួនឯងដែរឬទេ? ខ្ញុំមានបន្ទូលថា អ្នករាល់គ្នាក្រអឺតក្រទមខ្លាំង លោភលន់ខ្លាំង ធ្វេសប្រហែសខ្លាំង ល្បិចដែលអ្នករាល់គ្នាបោកខ្ញុំ គឺពិតជាឆ្លាតវៃណាស់ អ្នកមានចេតនា និងវិធីសាស្ត្រថោកទាបច្រើនណាស់។ ភក្តីភាពរបស់អ្នករាល់គ្នា តិចតួចណាស់ សេចក្ដីស្មោះត្រង់របស់អ្នករាល់គ្នាវិញ ក៏ស្ដួចស្ដើងហើយសតិសម្បជញ្ញៈរបស់អ្នក រឹតតែខ្វះខាតទៅទៀត។ ក្នុងដួងចិត្តអ្នករាល់គ្នា គឺមានតែការព្យាបាទច្រើនពេក ហើយមិនមាននរណាម្នាក់ រួចផុតពីការព្យាបាទរបស់អ្នកឡើយសូម្បីតែខ្ញុំ។ អ្នករាល់គ្នាបិទទ្វារចោលខ្ញុំ ដើម្បីតែកូនៗខ្លួនឯង ឬក៏ប្ដីអ្នករាល់គ្នា ឬដើម្បីតែការពារខ្លួនឯង។ ជំនួសឲ្យការយកចិត្តទុកដាក់នឹងខ្ញុំ អ្នកយកចិត្តទុកដាក់នឹងគ្រួសារកូនៗ ឋានៈ អនាគត និងក្ដីសុខរបស់អ្នករាល់គ្នាជាង។ តើពេលណាទៅដែលអ្នកធ្លាប់បានគិតពីខ្ញុំ ខណៈពេលអ្នករាល់គ្នានិយាយ ឬប្រព្រឹត្តនោះ? នៅថ្ងៃដែលត្រជាក់ខ្លាំងគំនិតរបស់អ្នករាល់គ្នា រិះគិតតែអំពីកូនៗ ប្ដីប្រពន្ធ ឬឪពុកម្ដាយរបស់អ្នករាល់គ្នា។ នៅថ្ងៃដែលក្ដៅហែង អ្នកក៏មិនដែលគិតដល់ខ្ញុំដែរ។ ពេលអ្នករាល់គ្នាបំពេញភារកិច្ចរបស់ខ្លួន អ្នកកំពុងគិតពីផលប្រយោជន៍ សុវត្ថិភាពផ្ទាល់ខ្លួន និងសមាជិកគ្រួសាររបស់អ្នក។ តើអ្វីទៅដែលអ្នកធ្លាប់ធ្វើដើម្បីខ្ញុំនោះ? តើពេលណាទៅដែលអ្នកធ្លាប់គិតពីខ្ញុំ? តើពេលណាទៅ ដែលអ្នកធ្លាប់ថ្វាយខ្លួនឯងដល់ខ្ញុំ និងកិច្ចការរបស់ខ្ញុំ ទោះត្រូវលះបង់អ្វីក៏ដោយនោះ? ឯណាទៅភ័ស្តុតាង បញ្ជាក់ពីការចុះសម្រុងរបស់អ្នកនឹងខ្ញុំនោះ? ឯណាទៅតថភាពនៃភក្តីភាពរបស់អ្នកចំពោះខ្ញុំនោះ? ឯណាទៅតថភាពនៃការស្ដាប់បង្គាប់របស់អ្នកចំពោះខ្ញុំនោះ? ពេលណាទៅ ដែលអ្នកគ្មានចេតនា

ចង់បានព្រះពរពីខ្ញុំ? អ្នករាល់គ្នាបោកប្រាស់ និងបញ្ឆោតខ្ញុំ អ្នករាល់គ្នាលេងនឹងសេចក្តីពិត អ្នកបិទបាំងវត្តមាននៃសេចក្តីពិត ហើយក្បត់នឹងសារជាតិនៃសេចក្តីពិត។ តាមរយៈការទាស់ទទឹងនឹងខ្ញុំបែបនេះ នាំឲ្យមានលទ្ធផលអ្វីខ្លះ ដែលកំពុងតែរង់ចាំអ្នករាល់គ្នានៅថ្ងៃខាងមុខ? អ្នករាល់គ្នាគ្រាន់តែព្យាយាមចុះសម្រុងនឹងព្រះដ៏ស្រពេចស្រពិល ហើយស្វែងរកតែជំនឿស្រពេចស្រពិល ប៉ុន្តែអ្នកមិនស្របនឹងព្រះគ្រីស្ទទេ។ តើសេចក្តីអាក្រក់របស់អ្នក នឹងមិនទទួលការដាក់ទោស ដូចគ្នានឹងទោសដែលមនុស្សអាក្រក់សមនឹងទទួលទេឬអី? នៅពេលនោះ អ្នករាល់គ្នានឹងបានដឹងថា អ្នកដែលមិនចុះសម្រុងនឹងព្រះគ្រីស្ទ គ្មាននរណាម្នាក់អាចគេចផុតពីថ្ងៃនៃសេចក្តីក្រោធបានទេ ហើយអ្នករាល់គ្នានឹងបានដឹងថា តើការដាក់ទោសប្រភេទណានឹងកើតមានចំពោះអស់អ្នក ដែលប្រឆាំងនឹងព្រះគ្រីស្ទ។ ពេលថ្ងៃនោះមកដល់ ក្តីសុបិនថានឹងបានទទួលពរ ដោយសារតែជំនឿរបស់អ្នករាល់គ្នាចំពោះព្រះជាម្ចាស់ និងក្តីសុបិនថានឹងបានចូលទៅកាន់ស្ថានសួគ៌ នឹងត្រូវរលាយបាត់ទាំងស្រុង។ យ៉ាងណាមិញ សម្រាប់អស់អ្នកដែលចុះសម្រុងនឹងព្រះគ្រីស្ទ នឹងមិនមែនបែបនោះទេ។ បើទោះជាពួកគេបានបាត់បង់ច្រើនប៉ុនណា បើទោះជាពួកគេរងទុក្ខលំបាកច្រើនប៉ុនណា ពួកគេនឹងទទួលបានមរតកទាំងអស់ ដែលខ្ញុំចែកឲ្យមនុស្សលោក។ នៅចុងបញ្ចប់ អ្នករាល់គ្នានឹងយល់ថា ខ្ញុំតែមួយអង្គគត់ ទើបជាព្រះដ៏សុចរិត ហើយខ្ញុំតែមួយអង្គគត់ ទើបមានសមត្ថភាពអាចនាំមនុស្សទៅកាន់ទិសដៅដ៏ស្រស់ត្រកាលរបស់ពួកគេបាន។

## តើអ្នកជាអ្នកជឿលើព្រះជាម្ចាស់ដ៏ពិតប្រាកដមែនទេ?

ប្រហែលជាអ្នកបានដើរនៅលើផ្លូវនៃសេចក្តីជំនឿដល់ព្រះជាម្ចាស់ជាងមួយឆ្នាំ ឬពីរឆ្នាំហើយ ហើយក្នុងពេលប៉ុន្មានឆ្នាំនេះ អ្នកប្រហែលជារងទុក្ខលំបាកជាច្រើននៅក្នុងជីវិតរបស់អ្នក ឬមួយក៏អ្នកមិនបានរងទុក្ខលំបាកច្រើនឡើយ ប៉ុន្តែអ្នកទទួលបានព្រះគុណច្រើនវិញ។ អ្នកក៏ប្រហែលជាមិនបានទាំងរងទុក្ខ ហើយក៏មិនបាន

ទាំងព្រះគុណដែរ ប៉ុន្តែរស់នៅក្នុងជីវិតមួយដែលសាមញ្ញៗ។ យ៉ាងណាក៏អ្នកនៅតែជាអ្នកដើរតាមព្រះជាម្ចាស់ ដូច្នេះ ចូរយើងប្រកបគ្នាអំពីប្រធានបទនៃការដើរតាមព្រះជាម្ចាស់វិញ។ យ៉ាងណាមិញ យើងត្រូវតែរំឭកមនុស្សទាំងអស់ដែលអានពាក្យទាំងនេះថា ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ត្រូវបានប្រទានដល់អ្នកដែលទទួលស្គាល់ និងដើរតាមទ្រង់ មិនមែនសម្រាប់មនុស្សទាំងអស់ឡើយ មិនថាគេទទួលស្គាល់ទ្រង់ ឬក៏អត់នោះឡើយ។ ប្រសិនបើអ្នកជឿថា ព្រះជាម្ចាស់មានបន្ទូលទៅកាន់មហាជនទៅកាន់មនុស្សទាំងអស់នៅក្នុងពិភពលោក ដូច្នេះ ព្រះបន្ទូលរបស់ព្រះជាម្ចាស់នឹងគ្មានឥទ្ធិពលទៅលើអ្នកឡើយ។ ដូច្នេះ អ្នកគួរតែចងចាំពាក្យទាំងនេះនៅក្នុងដួងចិត្តរបស់អ្នក ហើយមិនត្រូវដកចិត្តអ្នកចេញពីពាក្យទាំងនេះឡើយ។ យ៉ាងណាក៏ដោយ ចូរយើងនិយាយអំពីអ្វីដែលកំពុងតែកើតឡើងនៅក្នុងផ្ទះរបស់យើង។

ឥឡូវ អ្នករាល់គ្នាគួរតែយល់អំពីអត្ថន័យដ៏ពិត នៃសេចក្ដីជំនឿលើព្រះជាម្ចាស់ហើយ។ អត្ថន័យនៃសេចក្ដីជំនឿលើព្រះជាម្ចាស់ ដែលខ្ញុំធ្លាប់មានបន្ទូលកាលពីមុនទាក់ទងជាមួយនឹងផ្លូវចូលវិជ្ជមានរបស់អ្នករាល់គ្នា។ ថ្ងៃនេះ គឺខុសពីមុន៖ ថ្ងៃនេះ ខ្ញុំចង់វិភាគអំពីសារជាតិនៃសេចក្ដីជំនឿរបស់អ្នករាល់គ្នា ចំពោះព្រះជាម្ចាស់។ ប្រាកដណាស់ ការនេះគឺថាជាការចេញពីទិដ្ឋភាពអវិជ្ជមានដើម្បីដឹកនាំអ្នករាល់គ្នា។ ប្រសិនបើខ្ញុំមិនបានធ្វើបែបនេះទេ នោះអ្នករាល់គ្នានឹងមិនស្គាល់ពីមុខមាត់ពិតរបស់ខ្លួន ហើយនៅតែបន្តអួតអាងពីការគោរពប្រណិប័តន៍ដល់ព្រះជាម្ចាស់ និងសេចក្ដីស្មោះត្រង់របស់ខ្លួនជារៀងរហូត។ វាជាការសមគួរដែលនិយាយថា ប្រសិនបើខ្ញុំមិនលាតត្រដាងពីសេចក្ដីស្មោកគ្រោកនៅក្នុងជម្រៅចិត្តរបស់អ្នករាល់គ្នាទេ នោះម្នាក់ៗនឹងពាក់មកុដលើក្បាលរបស់ខ្លួន ហើយទទួលយកគ្រប់ទាំងសិរីល្អសម្រាប់ខ្លួនឯងមិនខាន។ និស្ស័យអំនួត និងភាពក្អេងក្អាងរបស់អ្នករាល់គ្នា គឺជាកត្តាដែលជំរុញឲ្យអ្នករាល់គ្នាក្បត់សម្បជញ្ញៈរបស់ខ្លួន ឲ្យអ្នកបះបោរទាស់ទទឹងនឹងព្រះគ្រីស្ទ និងបើកឱ្យដឹងពីសេចក្ដីស្មោកគ្រោក ចេតនា សញ្ញាណ សេចក្ដីប៉ងប្រាថ្នាហួសប្រមាណ និងកែវភ្នែកដែលពោរពេញទៅដោយភាពលោភលន់របស់អ្នករាល់គ្នា ដោយយកវាមកដាក់នៅ

ទីភ្លឺ។ ប៉ុន្តែអ្នករាល់គ្នានៅតែបន្តនិយាយប៉ប៉ាច់ប៉ប៉ោចពីបំណងចិត្តចង់ធ្វើការថ្វាយព្រះគ្រីស្ទរហូតមួយជីវិតរបស់អ្នក ហើយនិយាយដដែលៗពីសេចក្តីពិតដែលព្រះគ្រីស្ទមានព្រះបន្ទូលកាលពីយូរលង់ណាស់មកហើយ។ នេះជា «សេចក្តីជំនឿ» របស់អ្នករាល់គ្នា ជា «សេចក្តីជំនឿឥតសៅហ្មង»។ យើងបានដាក់បទដ្ឋានដ៏តឹងរឹងមួយឲ្យមនុស្សកាន់តាមពេញមួយជីវិត។ បើចិត្តភក្តីភាពរបស់អ្នកមានភ្ជាប់ជាមួយចេតនា និងលក្ខខណ្ឌនានា នោះយើងមិនចង់បានចិត្តភក្តីភាពរបស់អ្នកឡើយ ព្រោះថា យើងស្អប់ណាស់អ្នកណាដែលបោកបញ្ឆោតយើងដោយចេតនារបស់គេ ហើយមកកំហែងយើងដោយលក្ខខណ្ឌរបស់គេនេះ។ យើងចង់បានតែមនុស្សដែលស្មោះត្រង់ពិតប្រាកដចំពោះយើង ហើយហ៊ានធ្វើអ្វីគ្រប់យ៉ាង ដើម្បីបញ្ជាក់ និងជាប្រយោជន៍ដល់សេចក្តីជំនឿ។ យើងស្អប់ណាស់ពាក្យអែបអបដែលអ្នករាល់គ្នាប្រើ ដើម្បីព្យាយាមធ្វើឲ្យយើងអរសប្បាយ ដ្បិតកន្លងមក យើងតែងតែប្រព្រឹត្តចំពោះអ្នករាល់គ្នា ដោយព្រះទ័យស្មោះសរ ហើយយើងសង្ឃឹមថាអ្នករាល់គ្នាក៏ប្រព្រឹត្តចំពោះយើង ដោយសេចក្តីជំនឿដ៏ពិតវិញផងដែរ។ នៅពេលនិយាយដល់សេចក្តីជំនឿ មនុស្សជាច្រើនគិតថា ពួកគេដើរតាមព្រះ ដោយសារតែគេមានសេចក្តីជំនឿ ដូច្នេះ គេនឹងមិនរងទុក្ខវេទនាឡើយ។ ហេតុនេះ យើងសូមសួរអ្នករាល់គ្នាដូច្នេះថា៖ បើអ្នកជឿថាពិតជាមានព្រះជាម្ចាស់មែន ហេតុអ្វីបានជាអ្នកមិនគោរពប្រណិប័តន៍ទ្រង់? បើអ្នកជឿថាមានព្រះជាម្ចាស់មែន ហេតុអ្វីបានជាអ្នកគ្មានការគោរពកោតខ្លាចដល់ទ្រង់សូម្បីតែបន្តិច នៅក្នុងដួងចិត្តរបស់អ្នកដូច្នេះ? អ្នកទទួលស្គាល់ថាព្រះគ្រីស្ទជាព្រះជាម្ចាស់ដែលយកកំណើតជាមនុស្ស ចុះហេតុអ្វី បានជាអ្នកខ្វះការគោរពចំពោះទ្រង់? ហេតុអ្វីបានជាអ្នកប្រព្រឹត្តចំពោះទ្រង់ ដោយខ្វះការគោរពបែបនេះ? ហេតុអ្វីបានជាអ្នកវិនិច្ឆ័យទ្រង់ ដោយបើកចំហរ? ហេតុអ្វីបានជាអ្នកចេះតែលបយកការណ៍ ពីដំណើរទៅមករបស់ទ្រង់? ហេតុអ្វីបានជាអ្នកមិនចុះចូលចំពោះការរៀបចំរបស់ទ្រង់? ហេតុអ្វីបានជាអ្នកមិនប្រព្រឹត្តស្របតាមព្រះបន្ទូលរបស់ទ្រង់? ហេតុអ្វីបានជាអ្នកព្យាយាមកំហែង និងលួចតង្វាយរបស់ទ្រង់? ហេតុអ្វីបានជាអ្នកនិយាយជំនួសព្រះគ្រីស្ទ? ហេតុអ្វីបានជាអ្នកហ៊ានវិនិច្ឆ័យថា

កិច្ចការ និងព្រះបន្ទូលរបស់ទ្រង់ ត្រូវ ឬខុស? ហេតុអ្វីបានជាអ្នកថ្លើមធំ ហ៊ានប្រមាថដល់ទ្រង់ ពីក្រោយខ្នងដូច្នេះ? តើសេចក្ដីពណ៌នាទាំងនេះ ជាធាតុផ្សំនៃសេចក្ដីជំនឿរបស់អ្នករាល់គ្នាមែនទេ?

ធាតុផ្សំចិត្តមិនជឿរបស់អ្នករាល់គ្នាចំពោះព្រះគ្រីស្ទ ត្រូវបានស្ដែងចេញមកតាមរយៈពាក្យសម្ដី និងឥរិយាបថរបស់អ្នករាល់គ្នា។ ចិត្តមិនជឿបញ្ជ្រាបទៅដល់ទាំងបំណង និងគោលដៅនៃកិច្ចការដែលអ្នកធ្វើ។ សូម្បីតែអត្តចរិតនៃការសំឡក់សម្លឹងរបស់អ្នករាល់គ្នា ក៏មានចិត្តមិនជឿលើព្រះគ្រីស្ទនៅក្នុងនោះដែរ។ គឺអាចនិយាយបានថា ពីមួយនាទីទៅមួយនាទី អ្នករាល់គ្នាម្នាក់ៗ ក្រសោបយកធាតុផ្សំនៃចិត្តមិនជឿរហូត។ នេះមានន័យថា អ្នករាល់គ្នាស្ថិតក្នុងគ្រោះថ្នាក់នៃការក្បត់ព្រះគ្រីស្ទ នៅគ្រប់ពេលតែម្ដង ព្រោះថាឈាមដែលហូរកាត់រាងកាយរបស់អ្នក ត្រូវបានបញ្ចូលជាមួយនឹងចិត្តមិនជឿលើព្រះដែលយកកំណើតជាមនុស្ស។ ដូច្នេះ ខ្ញុំសូមប្រាប់ទៅចុះថា ដានជើងដែលអ្នករាល់គ្នាបន្សល់ទុកនៅលើមាគ៌ានៃសេចក្ដីជំនឿលើព្រះជាម្ចាស់ មិនមែនជាដានជើងពិតឡើយ។ ពេលដែលអ្នករាល់គ្នាដើរនៅលើផ្លូវនៃសេចក្ដីជំនឿលើព្រះជាម្ចាស់ អ្នកមិនដាក់ជើងយ៉ាងមាំទៅលើដីឡើយ គឺអ្នកគ្រាន់តែធ្វើតាមតែបញ្ញាទាំងចិត្តមិនចង់ប៉ុណ្ណោះ។ អ្នករាល់គ្នាមិនដែលជឿលើព្រះបន្ទូលរបស់ព្រះគ្រីស្ទយ៉ាងអស់ពីចិត្តឡើយ ហើយក៏គ្មានសមត្ថភាពយកព្រះបន្ទូលនោះទៅអនុវត្តភ្លាមៗដែរ។ នេះជាហេតុផលដែលអ្នករាល់គ្នាមិនមានសេចក្ដីជំនឿលើព្រះគ្រីស្ទ។ ដែលអ្នករាល់គ្នាតែងតែមានគំនិតបែបនេះបែបនោះអំពីទ្រង់ ក៏ជាហេតុផលមួយទៀត ដែលនាំឲ្យអ្នករាល់គ្នា មិនមានសេចក្ដីជំនឿចំពោះទ្រង់ដែរ។ ខាងក្រោមនេះ គឺជាធាតុផ្សំផ្សេងទៀត ដែលនាំឲ្យអ្នកមិនមានជំនឿនៅក្នុងចិត្ត ដូចជា ការសង្ស័យអំពីកិច្ចការរបស់ព្រះគ្រីស្ទឥតល្ហែ ការបណ្ដោយឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់ធ្លាក់ទៅលើត្រចៀកថ្លង់ ការមានទស្សនៈបែបនេះបែបនោះចំពោះកិច្ចការដែលព្រះគ្រីស្ទបានធ្វើ ហើយមិនយល់អំពីកិច្ចការនោះឲ្យបានត្រឹមត្រូវ ការពិបាកបោះបង់សញ្ញាណរបស់អ្នកដោយឡែក មិនថាអ្នកទទួលបានសេចក្ដីពន្យល់បែបណា និងហេតុផលផ្សេងទៀត

យ៉ាងណាក៏ដោយ។ ទោះអ្នករាល់គ្នាអនុវត្តតាមកិច្ចការរបស់ព្រះគ្រីស្ទ ហើយមិនដែលរយាលក៏ដោយ ប៉ុន្តែអ្នកមានការបះបោរច្រើនពេកហើយ ដែលច្របូកច្របល់នៅក្នុងដួងចិត្តរបស់អ្នករាល់គ្នា។ ការបះបោរនេះ គឺជាភាពសៅហ្មងនៅក្នុងជំនឿរបស់អ្នករាល់គ្នាចំពោះព្រះជាម្ចាស់។ ប្រហែលអ្នករាល់គ្នាមិនបានគិតបែបនេះឡើយ ប៉ុន្តែប្រសិនបើអ្នកគ្មានសមត្ថភាពស្គាល់ពីចេតនារបស់ខ្លួន តាមរយៈការនេះទេ នោះអ្នកត្រូវជាប់នៅក្នុងចំណោមមនុស្សដែលត្រូវវិនាស ដ្បិតទាល់តែមនុស្សដែលជឿពិតលើព្រះជាម្ចាស់ ទើបទ្រង់ប្រោសគេឲ្យបានគ្រប់លក្ខណ៍ មិនមែនមនុស្សដែលមានចិត្តសង្ស័យចំពោះទ្រង់ ហើយក៏មិនមែនមនុស្សដែលមានចិត្តអល់អែក ក្នុងការដើរតាមទ្រង់ ទាំងមិនធ្លាប់ជឿថា ទ្រង់ជាព្រះជាម្ចាស់នោះឡើយ។

មនុស្សមួយចំនួនមិនអរសប្បាយនៅក្នុងសេចក្តីពិតទេ ក៏រឹតតែមិនអរសប្បាយនឹងការជំនុំជម្រះដែរ។ ផ្ទុយទៅវិញ គេបែរជាអរសប្បាយនៅក្នុងអំណាច និងភាពមានបានទៅវិញ។ មនុស្សបែបនេះគេហៅថា អ្នកស្វែងរកអំណាច។ ពួកគេស្វែងរកតែនិកាយទាំងឡាយណា ដែលមានឥទ្ធិពលនៅក្នុងពិភពលោក ហើយរកតែគ្រូគង្វាល និងគ្រូបង្រៀន ដែលចេញមកពីសាលាព្រះគម្ពីរ។ ទោះពួកគេបានទទួលយកផ្លូវនៃសេចក្តីពិតក៏ដោយ ក៏ពួកគេមានជំនឿតែពាក់កណ្តាលប៉ុណ្ណោះ។ ពួកគេមិនអាចថ្វាយដួងចិត្ត និងគំនិតរបស់គេទាំងអស់ដល់ព្រះបានឡើយ ហើយទោះបីជាមាត់របស់គេនិយាយអំពីការលះបង់ខ្លួនឯងថ្វាយព្រះជាម្ចាស់ក៏ដោយ ប៉ុន្តែភ្នែករបស់គេផ្តោតទៅលើតែគ្រូគង្វាល និងគ្រូបង្រៀនល្បីៗប៉ុណ្ណោះ ហើយមិនសម្លឹងមើលទៅព្រះគ្រីស្ទសូម្បីមួយវិនាទីឡើយ។ ដួងចិត្តរបស់គេវក់ទៅនឹងការចង់បានតែកិត្តិនាម ទ្រព្យសម្បត្តិ និងសិរីល្អ។ ដោយព្រោះតែចម្ងល់មួយថា ម្តេចបានជាមនុស្សតូចទាបបែបនេះ មានសមត្ថភាពអាចយកឈ្នះមនុស្សជាច្រើនបាន ទើបពួកគេគិតថា មនុស្សដ៏សាមញ្ញនេះអាចប្រោសមនុស្សលោកឲ្យឥតខ្ចោះបាន។ ពួកគេគិត ដោយសារតែគេឆ្ងល់ថា ម្តេចក៏មនុស្សថោកទាបបាតសង្គមទាំងនេះ គឺជារាស្ត្រដែលព្រះជាម្ចាស់ជ្រើសរើសទៅវិញ។ ពួកគេជឿថា ប្រសិនបើមនុស្សបែបនេះជាវត្ថុបំណងនៃសេចក្តីសង្គ្រោះរបស់

ព្រះជាម្ចាស់ នោះផ្ទៃមេឃនិងផែនដីនឹងក្រឡាប់ចក្រ ហើយមនុស្សទាំងអស់នឹងសើច មិនខានចំអកខ្លាំងជាមិនខាន។ ពួកគេជឿថា ប្រសិនបើព្រះជាម្ចាស់បានជ្រើសរើស មនុស្សសំរាមទាំងនេះ ឲ្យក្លាយជាគ្រប់លក្ខណ៍ ដូច្នេះ មនុស្សអស្ចារ្យទាំងនោះ នឹង ក្លាយជាព្រះជាម្ចាស់ផ្ទាល់ព្រះអង្គហើយ។ ទស្សនៈរបស់គេត្រូវសៅហ្មងដោយចិត្តមិន ជឿ ពួកគេមិនត្រឹមតែមិនជឿទេ ពួកគេគឺដូចជាសត្វតិរច្ឆានដល្ងង់ខ្លៅតែម្ដង។ ពួកគេ គោរពតែពួកជំនុំ និងនិកាយធំៗប៉ុណ្ណោះ ព្រោះថា ពួកគេឲ្យតម្លៃតែលើឋានៈ បុណ្យសក្តិ និងអំណាចប៉ុណ្ណោះ។ ពួកគេគ្មានការគោរពចំពោះមនុស្សដែលព្រះគ្រីស្ទដឹកនាំសោះ ឡើយ សូម្បីតែបន្តិចក៏គ្មានផង។ មែនទែនទៅ ពួកគេគ្រាន់តែជាជនក្បត់ ដែលបាន បែរខ្នងដាក់ព្រះគ្រីស្ទ បែរខ្នងដាក់សេចក្តីពិត និងបែរខ្នងដាក់ជីវិតតែប៉ុណ្ណោះ។

អ្វីដែលអ្នកគោរពសរសើរ មិនមែនជាការបន្ទាបខ្លួនរបស់ព្រះគ្រីស្ទឡើយ ប៉ុន្តែ ជាពួកគង្វាលក្លែងក្លាយដែលមានកិត្តិនាមលេចធ្លោទៅវិញ។ អ្នកមិនសរសើរចំពោះ ភាពគួរឲ្យស្រឡាញ់ ឬព្រះប្រាជ្ញាញាណរបស់ព្រះគ្រីស្ទឡើយ ប៉ុន្តែបែរជាសរសើរពួក ខិលខូចដែលលង់នៅក្នុងសេចក្តីស្មោកគ្រោកនៃលោកីយ៍ទៅវិញ។ អ្នកសើចចំអក ចំពោះការឈឺចាប់របស់ព្រះគ្រីស្ទ ទាំងដែលទ្រង់គ្មានកន្លែងសម្រាប់កើយព្រះសិរសា ទ្រង់ ប៉ុន្តែបែរជាសរសើរសាកសពដែលតាមប្រមាញ់តង្វាយ ហើយរស់នៅក្នុងអំពើ ឧបាយមុខទៅវិញ។ អ្នកមិនព្រមរងទុក្ខរួមជាមួយព្រះគ្រីស្ទទេ ប៉ុន្តែអ្នកបែរជារីករាយ នឹងប្រគល់ខ្លួន ទៅក្នុងដៃរបស់ពួកទទឹងព្រះគ្រីស្ទទាំងកំព្រើល ទោះពួកគេឲ្យអ្នក បានតែសាច់ឈាម ពាក្យសម្ដី និងការត្រួតត្រាក៏ដោយ។ សូម្បីតែពេលនេះ ដួងចិត្ត របស់អ្នក នៅតែបែរទៅរកពួកគេ បែរទៅរកកេរ្តិ៍ឈ្មោះរបស់គេ បែរទៅរកឋានៈរបស់ គេ និងបែរទៅរកឥទ្ធិពលរបស់គេ។ ហើយអ្នកនៅតែបន្តប្រកាន់ខ្ជាប់នូវអាកប្បកិរិយា មួយ ដោយអ្នកគិតថាកិច្ចការរបស់ព្រះគ្រីស្ទពិបាកទទួលយកណាស់ ហើយអ្នកក៏ មិនព្រមទទួលយកកិច្ចការនេះដែរ។ នេះជាហេតុផលដែលខ្ញុំហ៊ាននិយាយថា អ្នកខ្វះ សេចក្តីជំនឿក្នុងការទទួលស្គាល់ព្រះគ្រីស្ទ។ ហេតុផលដែលនាំឲ្យអ្នកបានដើរតាម ទ្រង់មកដល់សព្វថ្ងៃគឺដោយសារតែអ្នកគ្មានជម្រើសផ្សេងប៉ុណ្ណោះ។ នៅក្នុងដួងចិត្ត

របស់អ្នក ចេះតែលេចឡើងនូវរូបភាពបុគ្គលខ្ពង់ខ្ពស់ជាច្រើន។ ពាក្យសម្ដី ទង្វើ និងស្នាដៃដ៏មានឥទ្ធិពលរបស់គេ ដក់ជាប់នៅក្នុងគំនិតរបស់អ្នកជានិច្ច។ នៅក្នុងចិត្តរបស់អ្នករាល់គ្នា ពួកគេជាបុគ្គលដ៏ខ្ពស់ឧត្ដម និងជាវីរបុរសក្នុងចិត្តរបស់អ្នកជារៀងរហូត។ ប៉ុន្តែ សព្វថ្ងៃនេះអ្នកមិនបានគិតបែបនេះ ចំពោះព្រះគ្រីស្ទឡើយ។ នៅក្នុងដួងចិត្តរបស់អ្នក ទ្រង់គ្មានសារៈសំខាន់ ហើយមិនសក្ដិសមទទួលបានការគោរពស្រឡាញ់របស់អ្នកជារៀងរហូត។ ដ្បិតទ្រង់ជាមនុស្សសាមញ្ញពេក មានឥទ្ធិពលតិចតួចពេក និងរឹតតែគ្មានឋានៈ យសសក្ដិ ខ្ពង់ខ្ពស់អ្វីឡើយ។

ទោះយ៉ាងណា ក៏ខ្ញុំអាចនិយាយបានថា មនុស្សទាំងអស់ដែលមិនឲ្យតម្លៃចំពោះសេចក្ដីពិត សុទ្ធតែជាអ្នកមិនជឿ ហើយគេជាជនក្បត់ចំពោះសេចក្ដីពិតដែរ។ មនុស្សបែបនេះនឹងមិនទទួលបានការសរសើរពីព្រះគ្រីស្ទឡើយ។ ឥឡូវនេះ តើអ្នកបានដឹងពីទំហំចិត្តមិនជឿនៅក្នុងជីវិតរបស់អ្នក ហើយដឹងពីទំហំចិត្តក្បត់ ដែលអ្នកមានចំពោះព្រះគ្រីស្ទហើយឬនៅ? ខ្ញុំសូមដាស់តឿនដល់អ្នកដូច្នេះថា៖ ដោយសារតែអ្នកបានជ្រើសរើសផ្លូវនៃសេចក្ដីពិត នោះអ្នកគួរតែថ្វាយជីវិតរបស់អ្នកទាំងស្រុងដល់ទ្រង់ចុះ កុំធ្វើជាមនុស្សស្ទាក់ស្ទើរ ឬមនុស្សដែលនិយាយខុសពីចិត្តនោះឡើយ។ អ្នកគួរតែយល់ថា ព្រះជាម្ចាស់មិនមែនជាកម្មសិទ្ធិនៃលោកីយ៍ ឬជារបស់នរណាម្នាក់ឡើយ ប៉ុន្តែទ្រង់ជាកម្មសិទ្ធិរបស់មនុស្សទាំងអស់ ដែលជឿលើទ្រង់យ៉ាងពិតប្រាកដ ជាអ្នកដែលថ្វាយបង្គំទ្រង់ ជាមនុស្សប្ដូរផ្ដាច់ ហើយស្មោះត្រង់ចំពោះទ្រង់។

ថ្ងៃនេះ ចិត្តមិនជឿរបស់អ្នកនៅតែមានច្រើននៅក្នុងជីវិតរបស់អ្នក។ ចូរប្រឹងសម្លឹងមើលជីវិតរបស់អ្នករាល់គ្នាទៅមើល៍ នោះអ្នកនឹងរកឃើញចម្លើយរបស់អ្នកជាប្រាកដ។ ពេលដែលអ្នករកឃើញចម្លើយពិត នោះអ្នកនឹងទទួលស្គាល់ថា អ្នកមិនមែនជាអ្នកជឿលើព្រះជាម្ចាស់ឡើយ ប៉ុន្តែជាមនុស្សដែលបញ្ឆោត ប្រមាថ ហើយក្បត់ទ្រង់ ព្រមទាំងជាមនុស្សដែលគ្មានចិត្តស្មោះចំពោះទ្រង់ឡើយ។ បន្ទាប់មក អ្នកនឹងទទួលស្គាល់ថា ព្រះគ្រីស្ទមិនគ្រាន់តែជាមនុស្សប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ក៏ជាព្រះជាម្ចាស់ដែរ។ ពេលដែលគ្រានោះមកដល់ អ្នកនឹងគោរពកោតខ្លាច និងស្រឡាញ់ព្រះគ្រីស្ទយ៉ាងពិត

ប្រាកដ។ ឥឡូវនេះ ដួងចិត្តរបស់អ្នកមានតែសាមសិបភាគរយប៉ុណ្ណោះ ដែលមានពេញដោយសេចក្ដីជំនឿ ចំណែកឯចិតសិបភាគរយទៀត មានពេញដោយសេចក្ដីសង្ស័យ។ គ្រប់យ៉ាងដែលព្រះគ្រីស្ទធ្វើ និងមានបន្ទូល មុខជាធ្វើឲ្យអ្នករាល់គ្នាមានគំនិត និងទស្សនៈចំពោះទ្រង់ ជាគំនិតនិងទស្សនៈដែលមានឫសគល់ ចេញពីចិត្តមិនជឿទាំងស្រុងរបស់អ្នកចំពោះទ្រង់។ អ្នករាល់គ្នាគោរពសរសើរ និងកោតខ្លាចតែព្រះដែលមើលមិនឃើញ ដែលគង់នៅស្ថានសួគ៌ប៉ុណ្ណោះ ប៉ុន្តែអ្នកគ្មានការគោរពចំពោះព្រះគ្រីស្ទដ៏មានព្រះជន្មរស់នៅលើផែនដីនេះឡើយ។ តើនេះមិនមែនជាចិត្តមិនជឿរបស់អ្នករាល់គ្នាទេឬអី? អ្នករាល់គ្នាស្រេកឃ្លានចង់បានតែព្រះជាម្ចាស់ ដែលបានធ្វើការពីអតីតកាល ប៉ុន្តែមិនព្រមសម្លឹងទៅរកព្រះគ្រីស្ទ នាពេលសព្វថ្ងៃឡើយ។ ទាំងអស់នេះគឺជា «សេចក្ដីជំនឿ» ដែលត្រូវបានលាយឡំជានិច្ច នៅក្នុងដួងចិត្តរបស់អ្នក ជាសេចក្ដីជំនឿដែលមិនជឿលើព្រះគ្រីស្ទនាពេលសព្វថ្ងៃឡើយ។ ខ្ញុំមិនមែនមើលងាយអ្នករាល់គ្នា ដោយសារតែអ្នករាល់គ្នាមានចិត្តមិនជឿច្រើនពេក នៅក្នុងជីវិតរបស់ខ្លួន ទាំងមានភាពសៅហ្មងច្រើនពេក នៅក្នុងចិត្តដែលត្រូវយកមកវិភាគវែកញែកនោះទេ។ ភាពសៅហ្មងទាំងនេះ គឺជាសញ្ញាមួយដែលបង្ហាញថា អ្នករាល់គ្នាគ្មានជំនឿទាល់តែសោះ ជាសញ្ញាដែលបង្ហាញថា អ្នករាល់គ្នាបានបោះបង់ចោលព្រះគ្រីស្ទ និងជាសញ្ញាដៅសម្គាល់អ្នករាល់គ្នាថា គេជាជនក្បត់ព្រះគ្រីស្ទផងដែរ។ វាជាស្បៃដែលមិនឲ្យអ្នករាល់គ្នាស្គាល់ព្រះគ្រីស្ទ ជារនាំងដែលនាំឲ្យព្រះគ្រីស្ទមិនទទួលយកអ្នករាល់គ្នា ជាឧបសគ្គចំពោះភាពចុះសម្រុងរបស់អ្នករាល់គ្នាជាមួយព្រះគ្រីស្ទ និងជាភស្តុតាងដែលនាំឲ្យព្រះគ្រីស្ទមិនទទួលយកអ្នករាល់គ្នា។ ឥឡូវនេះដល់ពេលដែលអ្នករាល់គ្នាត្រូវពិនិត្យមើលគ្រប់ផ្នែកនៃជីវិតរបស់ខ្លួនហើយ! ការធ្វើបែបនេះ វានឹងផ្ដល់ប្រយោជន៍ដល់អ្នករាល់គ្នា ដោយស្មានមិនដល់!

# ព្រះគ្រីស្ទធ្វើកិច្ចការជំនុំជម្រះ ដោយសេចក្តីពិត

កិច្ចការនៅគ្រាចុងក្រោយ គឺដើម្បីញែកមនុស្សមនុស្សទាំងអស់ទៅតាមជំពូករបស់ពួកគេ ហើយបញ្ចប់ផែនការគ្រប់គ្រងរបស់ព្រះជាម្ចាស់ ដ្បិតពេលវេលាកាន់តែកៀក ហើយថ្ងៃរបស់ព្រះជាម្ចាស់ក៏មកដល់ហើយដែរ។ ព្រះជាម្ចាស់ នាំមនុស្សទាំងអស់ដែលមានភក្តីភាពចំពោះទ្រង់រហូតដល់ទីបញ្ចប់ ចូលទៅក្នុងនគររបស់ទ្រង់ គឺចូលទៅក្នុងយុគសម័យនៃព្រះជាម្ចាស់ផ្ទាល់។ ប៉ុន្តែមុនយុគសម័យនៃព្រះជាម្ចាស់ចូលមកដល់ កិច្ចការរបស់ព្រះជាម្ចាស់ គឺមិនមែនឃ្លាំចាំមើលការប្រព្រឹត្តរបស់មនុស្ស ឬសើបសួរពីជីវិតមនុស្សទេ ប៉ុន្តែគឺមកជំនុំជម្រះភាពមិនស្ដាប់បង្គាប់របស់មនុស្សវិញ ដ្បិតព្រះជាម្ចាស់នឹងបន្សុទ្ធមនុស្សទាំងអស់ ដែលចូលមកចំពោះបល្ល័ង្ករបស់ទ្រង់។ មនុស្សទាំងអស់ដែលបានដើរតាមគន្លងព្រះបាទារបស់ព្រះជាម្ចាស់រហូតដល់ថ្ងៃនេះ គឺអស់អ្នកដែលចូលមកចំពោះបល្ល័ង្ករបស់ព្រះជាម្ចាស់ ហើយហេតុនេះបុគ្គលគ្រប់ៗរូប ដែលទទួលយកកិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងដំណាក់កាលចុងក្រោយនេះ គេគឺជាកម្មវត្ថុនៃការបន្សុទ្ធរបស់ព្រះជាម្ចាស់ហើយ។ អាចនិយាយម្យ៉ាងទៀតបានថា គ្រប់ៗគ្នាដែលទទួលយកកិច្ចការរបស់ព្រះជាម្ចាស់ក្នុងដំណាក់កាលចុងក្រោយនេះ គេគឺជាកម្មវត្ថុនៃការជំនុំជម្រះរបស់ព្រះជាម្ចាស់។

នៅក្នុងការជំនុំជម្រះដែលចាប់ផ្ដើមនៅក្នុងដំណាក់របស់ព្រះជាម្ចាស់ ដែលគេតំណាលពីអតីតកាល គឺជា «ការជំនុំជម្រះ» ដែលសំដៅលើការជំនុំជម្រះដែលព្រះជាម្ចាស់ទ្រង់ធ្វើឡើងនៅថ្ងៃនេះ ចំពោះអស់អ្នកដែលចូលមកចំពោះបល្ល័ង្ករបស់ទ្រង់នៅគ្រាចុងក្រោយ។ ប្រហែលជាមានអ្នកខ្លះ ជឿលើការស្រមើស្រមៃដ៏មហស្ចារ្យយ៉ាងនេះដែលថា នៅពេលគ្រាចុងក្រោយបានមកដល់ ព្រះជាម្ចាស់នឹងតម្លើងតុមួយយ៉ាងធំនៅឯស្ថានសួគ៌ ហើយនៅលើតុនោះមានកម្រាលតុពណ៌សមួយ ហើយព្រះជាម្ចាស់នឹងបើកសម្ដែងអស់ទាំងអំពើបាបរបស់មនុស្សម្នាក់ៗ ខណៈដែលទ្រង់គង់លើបល្ល័ង្កធំមួយ ហើយមនុស្សទាំងអស់លុតជង្គង់នៅលើដី រួចទ្រង់នឹងកំណត់

ថា ត្រូវឲ្យគេឡើងស្ថានសួគ៌ ឬបញ្ជូនគេចុះទៅក្នុងបឹងភ្លើង និងស្ពាន់ធ័រ។ ទោះបីជាមនុស្សខំស្រមៃយ៉ាងណា ក៏មិនអាចកែប្រែសារជាតិនៃកិច្ចការរបស់ព្រះជាម្ចាស់ដែរ។ ការស្រមើស្រមៃរបស់មនុស្សមិនមែនជាអ្វីទាំងអស់ ក្រៅតែពីគំនិតដែលគេស្អាងឡើង ហើយគំនិតទាំងអស់នេះ កើតចេញពីខួរក្បាលរបស់មនុស្ស ដោយប្រមូលផ្ដុំ ហើយផ្គុំចូលគ្នាទៅតាមអ្វីដែលមនុស្សមើលឃើញ និងស្ដាប់ឮ។ ហេតុនេះ ខ្ញុំសូមប្រាប់ថា ទោះបីជារូបភាពដែលគេនឹកស្រមៃនោះអស្ចារ្យយ៉ាងណា ក៏វាគ្រាន់តែជាគំនូរបែបជីវចល និងមិនអាចយកមកជំនួសផែនការនៃកិច្ចការរបស់ព្រះជាម្ចាស់បានឡើយ។ ទីបំផុត មនុស្សក៏ទៅជាខូចអាក្រក់ដោយសារសាតាំង ដូច្នេះ តើគេអាចវាស់ស្ទង់ព្រះតម្រិះរបស់ព្រះជាម្ចាស់យ៉ាងដូចម្ដេចបាន? មនុស្សស្រមៃយល់ថា កិច្ចការជំនុំជម្រះរបស់ព្រះជាម្ចាស់ គឺជារឿងដ៏អស្ចារ្យ។ ដោយសារអ្នកដែលធ្វើកិច្ចការជំនុំជម្រះ គឺព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ ហេតុនេះគេជឿថា កិច្ចការនេះ គឺច្បាស់ជាកិច្ចការមហិមាអស្ចារ្យក្រៃលែង ក៏រកយល់មិនបានដល់មនុស្សដែលមានរូបកាយតែងតែស្លាប់នេះ ហើយលាន់រំពងខ្ទរខ្ទារពេញផ្ទៃមេឃ និងផែនដី ពុំនោះទេ កិច្ចការនេះអាចរាប់ជាកិច្ចការជំនុំជម្រះ របស់ព្រះជាម្ចាស់យ៉ាងដូចម្ដេចបាន? ដោយព្រោះកិច្ចការនេះជាកិច្ចការជំនុំជម្រះ ហេតុនេះគេជឿថា ព្រះជាម្ចាស់ប្រាកដជាធ្វើការដោយរឹតត្បិត និងដោយតេជានុភាព ហើយអស់អ្នកដែលត្រូវជំនុំជម្រះ ប្រាកដជាទ្រហោយំ និងលត់ជង្គង់អង្វរសុំក្ដីមេត្តាជាមិនខាន។ ទិដ្ឋភាពនេះ គឺច្បាស់ជាអស្ចារ្យ និងគួរឲ្យអាណិតខ្លាំងទៀតផង...។ មនុស្សគ្រប់គ្នាស្រមៃថា កិច្ចការជំនុំជម្រះរបស់ព្រះជាម្ចាស់គឺជាកិច្ចការដ៏អស្ចារ្យ។ ប៉ុន្ដែតើអ្នកមានដឹងទេថា ចាប់តាំងពីគ្រាដែលព្រះជាម្ចាស់បានចាប់ផ្ដើមកិច្ចការជំនុំជម្រះរបស់ទ្រង់នៅក្នុងចំណោមមនុស្ស អ្នកនៅជាប់ក្នុងការបណ្ដែតបណ្ដោយយ៉ាងសុខសាន្តនៅឡើយ? ទម្រាំដល់ពេលដែលអ្នកគិតថា កិច្ចការជំនុំជម្រះរបស់ព្រះជាម្ចាស់បានចាប់ផ្ដើមជាផ្លូវការ ព្រះជាម្ចាស់ប្រាកដជាបានបង្កើតផ្ទៃមេឃ និងផែនដីថ្មីរួចបាត់ទៅហើយទេដឹង? នៅគ្រានោះ អ្នកប្រហែលជាទើបចាប់ផ្ដើមយល់ពីអត្ថន័យនៃជីវិតប៉ុណ្ណោះ ប៉ុន្ដែកិច្ចការដាក់ទណ្ឌកម្ម ឥតមេត្តារបស់

ព្រះជាម្ចាស់ នឹងនាំអ្នកទៅកាន់ស្ថាននរក ពេលដែលអ្នកនៅលង់លក់ក្នុងដំណេក នៅឡើយផង។ ដល់ពេលនោះ ទើបអ្នកភ្ញាក់ដឹងខ្លួនមួយរំពេចថា កិច្ចការជំនុំជម្រះរបស់ព្រះជាម្ចាស់បានបញ្ចប់ទៅហើយ។

ចូរយើងកុំខ្ជះខ្ជាយពេលវេលាដ៏មានតម្លៃរបស់យើង ហើយឈប់ជជែកពីប្រធានបទស្មោកគ្រោក និងគួរឲ្យស្អប់ទៀតទៅ។ ចូរយើងមកជជែកអំពីកត្តាដែលនាំឲ្យមានការជំនុំជម្រះជំនួសវិញ។ ពេលលើកឡើងនូវពាក្យថា «ជំនុំជម្រះ» មកនិយាយ អ្នកប្រហែលជាគិតដល់ពាក្យពេចន៍ដែលព្រះយេហូវ៉ាមានបន្ទូលបង្គាប់បង្រៀនមនុស្សក្នុងគ្រប់តំបន់ និងពាក្យពេចន៍ ដែលព្រះយេស៊ូវមានបន្ទូលស្ដីបន្ទោសទៅកាន់ពួកផារិស៊ី។ ទោះបីជាមានភាពធ្ងន់ធ្ងរក៏ដោយ ក៏ពាក្យពេចន៍ទាំងនេះ មិនមែនជាការជំនុំជម្រះ របស់ព្រះជាម្ចាស់មកលើមនុស្សលោកទេ ពាក្យពេចន៍ទាំងនេះ គឺគ្រាន់តែជាពាក្យពេចន៍ដែលព្រះជាម្ចាស់មានបន្ទូលក្នុងបរិយាកាសខុសៗគ្នា និងនៅក្នុងបរិបទផ្សេងគ្នាតែប៉ុណ្ណោះ។ ពាក្យពេចន៍ទាំងនេះ ខុសពីពាក្យពេចន៍ដែលព្រះគ្រីស្ទនៃគ្រាចុងក្រោយមានបន្ទូលពេលទ្រង់ជំនុំជម្រះមនុស្សលោក។ ព្រះគ្រីស្ទនៃគ្រាចុងក្រោយ ប្រើនូវសេចក្ដីពិតជាច្រើន មកបង្រៀនមនុស្ស មកលាតត្រដាងពីលក្ខណៈរបស់មនុស្ស និងមកវិភាគពីពាក្យសម្ដី និងទង្វើរបស់មនុស្ស។ ព្រះបន្ទូលទាំងនេះមានរួមបញ្ចូលនូវសេចក្ដីពិតជាច្រើនខុសៗគ្នា ដូចជា ភារកិច្ចរបស់មនុស្ស របៀបដែលគេគួរស្ដាប់ បង្គាប់ព្រះជាម្ចាស់ របៀបរក្សាភក្ដីភាពថ្វាយព្រះជាម្ចាស់ របៀបដែលមនុស្សគួរស្ដែងចេញនូវសភាពជាមនុស្សសាមញ្ញ ក៏ដូចជាព្រះប្រាជ្ញាញាណ និងនិស្ស័យរបស់ព្រះជាម្ចាស់ផងដែរ ។ល។ ពាក្យពេចន៍ទាំងអស់នេះសំដៅទៅលើសារៈសំខាន់របស់មនុស្ស និងនិស្ស័យពុករលួយរបស់គេ។ ជាពិសេស ព្រះបន្ទូលដែលលាតត្រដាងពីរបៀបដែលមនុស្សបដិសេធព្រះជាម្ចាស់ បានលើកឡើងទាក់ទងនឹងវិធីដែលមនុស្សក្លាយជាតំណាងរបស់អារក្សសាតាំង និងជាកម្លាំងសត្រូវ មកទាស់ទទឹងនឹងព្រះជាម្ចាស់។ នៅក្នុងការអនុវត្តការងារជំនុំជម្រះរបស់ព្រះជាម្ចាស់ ព្រះអង្គមិនមែនយកតែព្រះបន្ទូលពីរបីម៉ាត់ មកបញ្ជាក់អំពីសន្ដានរបស់មនុស្សនោះទេ តែ

ទ្រង់នឹងលាតត្រដាង ដោះស្រាយជាមួយ និងលួសកាត់ក្នុងរយៈពេលដ៏យូរអង្វែង។ វិធីសាស្ត្រ ផ្សេងៗទាំងនេះអំពីការលាតត្រដាង ការដោះស្រាយ និងការលួសកាត់ មិនអាចធ្វើឡើងដោយពាក្យពេចន៍ធម្មតាៗបានឡើយ ទាល់តែសេចក្ដីពិត ដែលធ្វើឲ្យមនុស្សអស់សង្ឃឹមទាំងស្រុង ទើបជំនួសបាន។ មានតែវិធីបែបនេះទេ ទើបអាចហៅបានថាជាការជំនុំជម្រះ ហើយមានតែតាមរយៈការជំនុំជម្រះបែបនេះទេ ទើបអាចបង្ក្រាបមនុស្ស និងត្រូវបញ្ចុះបញ្ចូលយ៉ាងច្បាស់អំពីព្រះជាម្ចាស់ ព្រមទាំងស្គាល់ដល់ព្រះជាម្ចាស់ពិតប្រាកដទៀតផង។ លទ្ធផលដែលកិច្ចការជំនុំជម្រះបាននាំមក គឺឲ្យមនុស្សបានស្គាល់ព្រះភក្ត្រព្រះជាម្ចាស់ពិត និងស្គាល់សេចក្ដីពិតអំពីការបះបោររបស់ខ្លួនគេផ្ទាល់។ កិច្ចការនៃការជំនុំជម្រះ ធ្វើឲ្យមនុស្សទទួលបាននូវការយល់ដឹងច្រើនអំពីបំណងព្រះហឫទ័យនៃព្រះជាម្ចាស់ អំពីគោលបំណងនៃកិច្ចការរបស់ព្រះជាម្ចាស់ និងអំពីអាថ៌កំបាំងដែលគេមិនអាចយល់បាន។ កិច្ចការនេះ ក៏អនុញ្ញាតឲ្យមនុស្សទទួលស្គាល់ និងដឹងអំពីសារជាតិពុករលួយ និងឫសគល់នៃសេចក្ដីពុករលួយរបស់ខ្លួន ព្រមទាំងរកឃើញភាពស្មោកគ្រោករបស់មនុស្សផងដែរ។ លទ្ធផលទាំងអស់នេះ សុទ្ធតែបានមកពីកិច្ចការជំនុំជម្រះ ដ្បិតលក្ខណៈសម្បត្តិនៃកិច្ចការនេះ ការពិតគឺជាកិច្ចការបើកបង្ហាញអំពីសេចក្ដីពិត អំពីផ្លូវ និងអំពីជីវិតរបស់ព្រះជាម្ចាស់ ដល់អស់អ្នកណាដែលមានសេចក្ដីជំនឿលើទ្រង់។ កិច្ចការនេះ គឺជាកិច្ចការជំនុំជម្រះដែលត្រូវបានធ្វើឡើងដោយព្រះជាម្ចាស់។ ប្រសិនបើអ្នកមិនរាប់សេចក្ដីពិតទាំងអស់នេះជារឿងសំខាន់ ប្រសិនបើអ្នកមិនពិចារណាអ្វីសោះ ក្រៅតែពីរិះរកវិធីគេចវេសពីសេចក្ដីពិតនេះ ឬរិះរកដំណោះស្រាយដែលមិនឲ្យពាក់ព័ន្ធនឹងរឿងទាំងអស់នេះ នោះខ្ញុំសុំប្រាប់ថា អ្នកជាមនុស្សបាបដែលសោកសៅបំផុត។ ប្រសិនបើអ្នកមានសេចក្ដីជំនឿលើព្រះជាម្ចាស់ ប៉ុន្តែអ្នកមិនស្វះស្វែងរកសេចក្ដីពិត ឬស្វែងយល់អំពីបំណងព្រះហឫទ័យព្រះជាម្ចាស់ ក៏មិនស្រឡាញ់ចូលចិត្តផ្លូវ ដែលនាំឲ្យអ្នកចូលមកកៀកនឹងព្រះជាម្ចាស់ នោះខ្ញុំសុំប្រាប់អ្នកថា អ្នកគឺជាមនុស្សដែលកំពុងព្យាយាមគេចវេសពីការជំនុំជម្រះ ហើយអ្នកក៏ជាអាយ៉ង និងជាជនក្បត់ ដែលគេចពីបល្ល័ង្កសដ៏ធំដែរ។ ព្រះជាម្ចាស់មិន

ទុកឲ្យមនុស្សបះបោរដែលរត់គេចពីព្រះនេត្រទ្រង់ បានរួចខ្លួនឡើយ។ មនុស្សបែបនេះ នឹងត្រូវទទួលទោសរឹតតែធ្ងន់។ អស់អ្នកដែលមកឯចំពោះព្រះជាម្ចាស់ដើម្បីទទួលការវិនិច្ឆ័យ ព្រមទាំងត្រូវបន្សុទ្ធកាន់តែខ្លាំង ទើបអាចរស់នៅក្នុងនគរព្រះអស់កល្បជានិច្ចបាន។ ប្រាកដណាស់ រឿងនេះគឺជារឿងអនាគតកាល។

កិច្ចការជំនុំជម្រះ គឺជាកិច្ចការរបស់ព្រះជាម្ចាស់ផ្ទាល់ ដូច្នេះ តាមធម្មតា កិច្ចការនេះ គឺត្រូវតែអនុវត្តដោយព្រះជាម្ចាស់ផ្ទាល់ មិនអាចឲ្យមនុស្សមកធ្វើជំនួសទ្រង់បានឡើយ។ ដ្បិតការជំនុំជម្រះ គឺជាការប្រើប្រាស់នូវសេចក្តីពិត ដើម្បីយកឈ្នះមនុស្សលោក ដូច្នេះ គ្មានទេចម្ងល់ដែលថា ព្រះជាម្ចាស់មុខជាសម្តែងរូបអង្គទ្រង់លេចមកជាសាច់ឈាម ដើម្បីអនុវត្តកិច្ចការនេះ នៅក្នុងចំណោមមនុស្សលោក។ ពោលគឺ ព្រះគ្រីស្ទនៃគ្រាចុងក្រោយ នឹងប្រើនូវសេចក្តីពិតដើម្បីបង្រៀនមនុស្សទូទាំងពិភពលោក នឹងឲ្យពួកគេបានស្គាល់សេចក្តីពិតគ្រប់យ៉ាងទាំងអស់។ នេះហើយជាកិច្ចការជំនុំជម្រះរបស់ព្រះជាម្ចាស់។ មនុស្សជាច្រើនមានអារម្មណ៍មិនល្អចំពោះការយកកំណើតជាមនុស្សជាលើកទីពីររបស់ព្រះជាម្ចាស់ ដ្បិតមនុស្សទាំងនោះពិបាកនឹងជឿថា ព្រះជាម្ចាស់នឹងប្រសូតមកជាសាច់ឈាម ដើម្បីធ្វើកិច្ចការជំនុំជម្រះ។ តែទោះជាយ៉ាងណាក៏ដោយ ខ្ញុំត្រូវតែប្រាប់អ្នកថា កិច្ចការរបស់ព្រះជាម្ចាស់ រមែងហួសពីការរំពឹងគិតរបស់មនុស្ស ហើយពិបាកនឹងឲ្យគំនិតរបស់គេទទួលយកបានផង។ ដ្បិតមនុស្សគ្រាន់តែជាដង្កូវនៅលើផែនដី ចំណែកឯព្រះជាម្ចាស់ ទ្រង់ជាព្រះដ៏ឧត្តុង្គឧត្តមដែលបំពេញចក្រវាឡនេះ គំនិតរបស់មនុស្សប្រៀបបាននឹងអណ្តូងទឹកកខ្វក់ ដែលនាំឲ្យកើតជាដង្កូវតែប៉ុណ្ណោះ ចំណែកឯដំណាក់កាលនីមួយៗនៃកិច្ចការដែលត្រូវបានដឹកនាំដោយព្រះតម្រិះរបស់ព្រះជាម្ចាស់វិញ គឺជាលទ្ធផលដែលបានមកពីព្រះប្រាជ្ញាញាណរបស់ទ្រង់។ មនុស្សតែងតែព្យាយាមទាស់ទទឹងជាមួយព្រះជាម្ចាស់ ដែលខ្ញុំចាត់ទុកជាភ័ស្តុតាងបញ្ជាក់ដោយខ្លួនឯងថា នៅទីបំផុត គឺគេនឹងខាតបង់ដោយព្រោះតែជាទង្វើរបស់គេ។ ខ្ញុំសូមទូន្មានអ្នកទៅចុះថា សូមកុំគិតថាអ្នកមានតម្លៃជាងមាស។ ប្រសិនបើអ្នកដទៃអាចទទួលយកការជំនុំជម្រះពីព្រះជាម្ចាស់បាន

ហេតុអ្វីបានជាអ្នកទទួលមិនបាន? តើអ្នកមានឋានៈធំជាងគេប៉ុនណាទៅ? ប្រសិនបើអ្នកដទៃអាចឱនក្បាលរបស់គេចុះចូលចំពោះសេចក្ដីពិត ហេតុអ្វីបានជាអ្នកមិនអាចធ្វើដូចគេបាន? កិច្ចការរបស់ព្រះជាម្ចាស់ មានកម្លាំងចលករមួយដែលមិនអាចបញ្ឈប់បាន។ ទ្រង់នឹងមិនធ្វើកិច្ចការជំនុំជម្រះម្ដងទៀត ដោយសារតែ «ភាគទាន» ដែលអ្នកបានធ្វើនោះទេ ហើយអ្នកក៏នឹងមានវិប្បដិសារីជាខ្លាំងចំពោះការបណ្ដោយឲ្យឱកាសដ៏ល្អនេះកន្លងផុតទៅ។ ប្រសិនបើអ្នកមិនជឿសម្ដីខ្ញុំទេ ចូររង់ចាំមើលបល្ល័ង្កធំសនៅលើមេឃ ដែលនឹងមកជំនុំជម្រះអ្នកចុះ! អ្នកត្រូវដឹងថា ជនជាតិអ៊ីស្រាអែលទាំងអស់សុទ្ធតែបានបដិសេធ និងមិនទទួលស្គាល់ព្រះយេស៊ូវ ប៉ុន្ដែការពិតស្ដីអំពីការប្រោសលោះរបស់ព្រះយេស៊ូវសម្រាប់មនុស្សលោក បានផ្សព្វផ្សាយពេញចក្រវាឡទាំងមូល និងរហូតដល់ចុងបំផុតនៃផែនដីផង។ តើនេះមិនមែនជាការពិតដែលព្រះជាម្ចាស់ ទ្រង់បានធ្វើឡើងតាំងពីយូរណាស់មកហើយទេឬអី? ប្រសិនបើអ្នកនៅកំពុងទន្ទឹងរង់ចាំព្រះយេស៊ូវ មកនាំអ្នកឡើងទៅស្ថានសួគ៌ នោះខ្ញុំសូមប្រាប់ថា មនុស្សដូចអ្នក គឺជាឈើងាប់មួយដុំដ៏រឹងរូស។[ក] អ្នកជឿក្លែងក្លាយដែលគ្មានភក្ដីភាពចំពោះសេចក្ដីពិត និងស្វែងរកតែព្រះពរដូចជាអ្នក គឺព្រះយេស៊ូវមិនទទួលស្គាល់ទេ។ ផ្ទុយទៅវិញ ទ្រង់នឹងបោះអ្នកចូលទៅក្នុងបឹងភ្លើងឲ្យឆេះរយៈពេលរាប់ម៉ឺនឆ្នាំដោយគ្មានមេត្ដាឡើយ។

ពេលនេះ តើអ្នកយល់ហើយឬនៅថា អ្វីទៅជាការជំនុំជម្រះ ហើយអ្វីទៅជាសេចក្ដីពិត? ប្រសិនបើអ្នកយល់ហើយ នោះខ្ញុំសូមដាស់តឿនឲ្យអ្នកចុះចូលចំពោះការជំនុំជម្រះដោយស្ដាប់បង្គាប់ ពុំនោះទេ អ្នកនឹងគ្មានឱកាសទទួលបានការសរសើរពីព្រះជាម្ចាស់ ឬត្រូវបានព្រះអង្គនាំចូលទៅក្នុងនគររបស់ទ្រង់ឡើយ។ អស់អ្នកដែលទទួលយកតែការជំនុំជម្រះ ប៉ុន្ដែមិនធ្លាប់ត្រូវបានបន្សុទ្ធសោះ នោះព្រះជាម្ចាស់នឹងមិនសព្វព្រះហឫទ័យចំពោះពួកគេឡើយ ហើយទ្រង់ក៏នឹងបដិសេធពួកគេដែរ ដ្បិតពួកគេ

---

លេខយោង៖

ក. ឈើងាប់មួយដុំ៖ ជាគ្រាមភាសាក្នុងភាសាចិន ដែលមានន័យថា «ជួយមិនបាន»។

ជាអ្នករត់គេចពីកិច្ចការជំនុំជម្រះ។ អំពើបាបរបស់ពួកគេ កើនច្រើនឡើងៗ និងកាន់តែអាក្រក់ជាងពួកផារិស៊ីទៅទៀត ដ្បិតពួកគេបានក្បត់ព្រះជាម្ចាស់ ហើយបះបោរទាស់ទទឹងនឹងទ្រង់ផង។ ជាងនេះទៅទៀត មនុស្សបែបនេះមិនសមនឹងធ្វើការបម្រើផង ពួកគេនឹងទទួលបាននូវការដាក់ទោសដែលកាន់តែធ្ងន់ធ្ងរ ជាការដាក់ទោសដ៏អស់កល្បជានិច្ច។ ព្រះជាម្ចាស់នឹងមិនទុកជនក្បត់ណាម្នាក់ដែលធ្លាប់បង្ហាញភក្ដីភាពចំពោះព្រះបន្ទូល តែក្រោយមក បែរជាក្បត់ទ្រង់វិញនោះឡើយ។ មនុស្សបែបនេះ នឹងទទួលបាននូវការផ្ដន្ទាទោស តាមរយៈទណ្ឌកម្ម ដល់វិញ្ញាណ ព្រលឹង និងរូបកាយ។ តើនេះមិនមែនជាការបើកសម្ដែងពីនិស្ស័យដ៏សុចរិតរបស់ព្រះជាម្ចាស់ទេឬអី? តើនេះមិនមែនជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ក្នុងការជំនុំជម្រះមនុស្ស និងបកអាក្រាតគេទេឬអី? ក្នុងពេលជំនុំជម្រះ ព្រះជាម្ចាស់បញ្ជូនអស់អ្នកណាដែលប្រព្រឹត្តទង្វើអាក្រក់គ្រប់ប្រភេទ ទៅកាន់កន្លែងដែលពោរពេញដោយវិញ្ញាណអាក្រក់ ហើយបណ្ដោយឲ្យវិញ្ញាណអាក្រក់ទាំងអស់នេះ បំផ្លាញរូបកាយខាងសាច់ឈាមរបស់ពួកគេទៅតាមទង្វើចិត្តរបស់វា ហើយរូបកាយរបស់អ្នកទាំងនេះ បញ្ចេញជាក្លិនគំរង់សពមនុស្ស។ នេះហើយជាការផ្ដន្ទាទោសដ៏ស័ក្ដិសមសម្រាប់ពួកគេ។ ព្រះជាម្ចាស់ កត់ត្រាពីអំពើបាបរបស់អ្នកជឿក្លែងក្លាយដែលគ្មានភាពស្មោះត្រង់ សាវ័កក្លែងក្លាយ និងអ្នកធ្វើការក្លែងក្លាយក្នុងសៀវភៅកំណត់ត្រារបស់គេ។ ក្រោយមក លុះដល់វេលាត្រឹមត្រូវ ព្រះអង្គក៏បណ្ដេញពួកគេឲ្យទៅក្នុងចំណោមវិញ្ញាណស្មោកគ្រោក ទុកឲ្យវិញ្ញាណស្មោកគ្រោកទាំងអស់នេះ បង្ខូចរូបកាយរបស់គេទាំងមូលតាមចិត្ត ដើម្បីកុំឲ្យគេកើតមកវិញ និងមិនឲ្យឃើញពន្លឺថ្ងៃម្ដងទៀតឡើយ។ មនុស្សកំពុតដែលធ្វើកិច្ចការបម្រើបានមួយគ្រា តែគ្មានសមត្ថភាពរក្សាភាពស្មោះត្រង់រហូតដល់ទីបញ្ចប់ ត្រូវបានព្រះជាម្ចាស់រាប់បញ្ចូលទៅក្នុងជំពូកមនុស្សអាក្រក់ ដើម្បីឲ្យគេធ្លាក់ចូលក្នុងបក្សពួកមនុស្សអាក្រក់ និងក្លាយជាចំណែកមួយនៃក្រុមមនុស្សគ្មានសណ្ដាប់ធ្នាប់របស់គេ។ ទីបំផុត ព្រះជាម្ចាស់នឹងធ្វើឲ្យពួកគេសាបសូន្យទៅ។ ព្រះជាម្ចាស់បណ្ដេញអស់អ្នកដែលពុំធ្លាប់មានភក្ដីភាពចំពោះព្រះគ្រីស្ទ ឬពុំធ្លាប់រួមចំណែកជាកម្លាំងអ្វីសោះចេញ ហើយក៏មិនខ្វល់ពីពួកគេដែរ លុះ

នៅពេលប្ដូរសម័យកាល ទ្រង់នឹងធ្វើឲ្យគេសាបសូន្យទៅ។ ពួកគេលែងមានវត្តមានលើផែនដី ហើយក៏មិនបានធ្វើដំណើរចូលទៅក្នុងនគរព្រះដែរ។ អស់អ្នកដែលមិនធ្លាប់ស្មោះត្រង់ចំពោះព្រះជាម្ចាស់ ប៉ុន្តែត្រូវកាលៈទេសៈបង្ខំឲ្យគេមានទំនាក់ទំនងជាមួយទ្រង់ដោយគ្រាន់តែបង្គ្រប់កិច្ច អ្នកនោះត្រូវបានរាប់បញ្ចូលទៅក្នុងអស់អ្នកដែលបម្រើរាស្ត្ររបស់ទ្រង់។ មនុស្សបែបនេះមានចំនួនតិចតួចណាស់ដែលនៅរស់រានមានជីវិត ខណៈដែលភាគច្រើនសុទ្ធតែត្រូវវិនាសទៅជាមួយនឹងអស់អ្នកដែលផ្ដល់ការបម្រើដែលមិនត្រូវនឹងបទដ្ឋាន។ ចុងក្រោយបំផុត ព្រះជាម្ចាស់នឹងនាំអស់អ្នកដែលមានគំនិតដូចព្រះជាម្ចាស់ ពោលគឺជារាស្ត្រ និងពួកកូនប្រុសរបស់ព្រះជាម្ចាស់ ព្រមទាំងអស់អ្នកដែលទ្រង់កំណត់ឲ្យធ្វើជាសង្ឃ ចូលទៅក្នុងនគររបស់ព្រះអង្គ។ ពួកគេនឹងក្លាយជាផលចម្រាញ់នៃកិច្ចការរបស់ព្រះជាម្ចាស់។ ចំពោះអស់អ្នកដែលមិនអាចរាប់បញ្ចូលក្នុងប្រភេទមនុស្សដែលព្រះជាម្ចាស់បានកំណត់ ពួកគេនឹងត្រូវរាប់បញ្ចូលជាមួយអ្នកមិនជឿ ហើយអ្នករាល់គ្នាប្រាកដជាអាចស្រមៃបានហើយថា លទ្ធផលរបស់ពួកគេនឹងទៅជាយ៉ាងណា។ អ្វីៗគ្រប់យ៉ាងដែលខ្ញុំគួរនិយាយ គឺខ្ញុំបាននិយាយប្រាប់អ្នករាល់គ្នារួចហើយ។ ផ្លូវដែលអ្នករាល់គ្នាជ្រើសរើស គឺជាជម្រើសផ្ទាល់ខ្លួនរបស់អ្នកតែម្នាក់ឯងប៉ុណ្ណោះ។ អ្វីដែលអ្នករាល់គ្នាគួរយល់គឺ កិច្ចការរបស់ព្រះជាម្ចាស់ មិនដែលរង់ចាំអ្នកណាម្នាក់ដែលមិនអាចដើរតាមលំអានរបស់ទ្រង់ទាន់នោះឡើយ ហើយនិស្ស័យសុចរិតរបស់ព្រះជាម្ចាស់ មិនបង្ហាញក្ដីសន្ដោសដល់មនុស្សម្នាក់ណាឡើយ។

# តើអ្នកដឹងទេ? ព្រះជាម្ចាស់បានធ្វើការដ៏អស្ចារ្យមួយនៅក្នុងចំណោមមនុស្សលោក

យុគសម័យចាស់បានកន្លងផុតទៅ ហើយយុគសម័យថ្មីក៏បានចូលមកដល់។ ពីមួយឆ្នាំទៅមួយឆ្នាំ ហើយពីមួយថ្ងៃទៅមួយថ្ងៃ ព្រះជាម្ចាស់បានធ្វើកិច្ចការជាច្រើន។ ទ្រង់បានយាងមកក្នុងលោកិយ ហើយបន្ទាប់មកក៏បានចាកចេញទៅ។ វដ្ដនេះបានកើតឡើង

ម្ដងហើយម្ដងទៀត ឆ្លងកាត់ជាច្រើនជំនាន់។ សព្វថ្ងៃនេះ ព្រះជាម្ចាស់បន្តធ្វើកិច្ចការដែលទ្រង់ត្រូវតែធ្វើដូចកាលពីមុនទៀត ជាកិច្ចការដែលទ្រង់មិនទាន់បានសម្រេចនៅឡើយ ដ្បិតរហូតមកដល់សព្វថ្ងៃនេះ ទ្រង់មិនទាន់ចូលសម្រាកនៅឡើយទេ។ ចាប់តាំងពីពេលបង្កើតអ្វីៗរហូតដល់សព្វថ្ងៃនេះ ព្រះជាម្ចាស់បានធ្វើកិច្ចការជាច្រើន។ ប៉ុន្តែ តើអ្នកដឹងទេថា សព្វថ្ងៃនេះព្រះជាម្ចាស់ធ្វើកិច្ចការច្រើនជាងពីមុនឆ្ងាយណាស់ ហើយទំហំនៃកិច្ចការរបស់ទ្រង់ក៏ច្រើនជាងពីមុនដែរ? ដូច្នេះហើយបានជាខ្ញុំនិយាយថា ព្រះជាម្ចាស់បានធ្វើកិច្ចការដ៏អស្ចារ្យមួយនៅក្នុងចំណោមមនុស្សលោក។ កិច្ចការទាំងអស់របស់ព្រះជាម្ចាស់មានសារៈសំខាន់ណាស់ ចំពោះមនុស្សលោក ឬចំពោះព្រះជាម្ចាស់ផ្ទាល់ ដ្បិតគ្រប់កិច្ចការទាំងអស់របស់ទ្រង់ សុទ្ធតែជាប់ទាក់ទងនឹងមនុស្ស។

ដោយព្រោះកិច្ចការរបស់ព្រះជាម្ចាស់ ជាកិច្ចការដែលមើលមិនឃើញ ក៏មិនអាចប៉ះបាន ហើយលោកិយក៏រឹតមិនអាចមើលឃើញទៀតនោះ តើកិច្ចការនេះអាចជាកិច្ចការមួយដ៏អស្ចារ្យយ៉ាងដូចម្ដេច? តើកិច្ចការប្រភេទអ្វី ដែលនឹងត្រូវបានគេចាត់ទុកថាជាកិច្ចការអស្ចារ្យ? ប្រាកដណាស់ កិច្ចការណាដែលព្រះជាម្ចាស់ធ្វើ គឺគ្មានអ្នកណាម្នាក់អាចបដិសេធឡើយ វាអាចមើលទៅថាអស្ចារ្យ ប៉ុន្តែហេតុអ្វីបានជាខ្ញុំនិយាយថា កិច្ចការដែលព្រះជាម្ចាស់ធ្វើសព្វថ្ងៃ គឺជាកិច្ចការដែលអស្ចារ្យ? នៅពេលដែលខ្ញុំនិយាយថា ព្រះជាម្ចាស់បានធ្វើកិច្ចការដ៏អស្ចារ្យមួយ នោះវាច្បាស់ជាទាក់ទងនឹងអាថ៌កំបាំងជាច្រើនដែលមនុស្សមិនទាន់យល់។ ចូរយើងនិយាយពីអាថ៌កំបាំងទាំងនោះនៅពេលឥលូវនេះ។

ព្រះយេស៊ូវបានប្រសូត្រមកនៅក្នុងស្នូកសត្វ នៅយុគសម័យមួយ ដែលមិនអាចទទួលយកព្រះវត្តមានគង់នៅរបស់ទ្រង់បាន ប៉ុន្តែទោះបីជាយ៉ាងនេះក្តី ក៏លោកិយមិនអាចរាំងផ្លូវទ្រង់បានដែរ ហើយទ្រង់បានរស់នៅជាមួយមនុស្សលោក អស់រយៈពេល៣៣ឆ្នាំ ក្រោមការថែរក្សារបស់ព្រះជាម្ចាស់។ ក្នុងការរស់នៅរយៈពេលជាច្រើនឆ្នាំនេះ ទ្រង់បានឆ្លងកាត់ភាពល្វីងជូរចត់របស់លោកិយ និងបានភ្លក់រសជាតិជីវិតវេទនានៅលើផែនដីផង។ ទ្រង់បានរែកពន់បន្ទុកដ៏ធ្ងន់ដោយការជាប់ឆ្កាង ដើម្បីប្រោសលោះ

មនុស្សលោកទាំងអស់។ ទ្រង់បានលោះមនុស្សមានបាបទាំងអស់ដែលបានរស់នៅក្រោមការគ្រប់គ្រងរបស់សាតាំង ហើយចុងក្រោយ រូបកាយដែលរស់ឡើងវិញរបស់ទ្រង់ ក៏បានត្រលប់ទៅកាន់កន្លែងសម្រាករបស់ទ្រង់វិញ។ ឥលូវនេះ កិច្ចការថ្មីរបស់ព្រះជាម្ចាស់បានចាប់ផ្តើមហើយ ហើយវាក៏ជាការចាប់ផ្តើមនៃយុគសម័យថ្មីមួយដែរ។ ព្រះជាម្ចាស់នាំអស់អ្នកដែលទទួលបានការប្រោសលោះចូលទៅក្នុងដំណាក់របស់ទ្រង់ ដើម្បីចាប់ផ្តើមកិច្ចការថ្មីនៃសេចក្តីសង្គ្រោះរបស់ទ្រង់។ ពេលនេះ កិច្ចការនៃសេចក្តីសង្គ្រោះមានភាពហ្មត់ចត់ជាងកាលពីអតីតកាល។ ព្រះវិញ្ញាណបរិសុទ្ធមិនមែនជាអ្នកដែលធ្វើការនៅក្នុងមនុស្ស ដើម្បីជំរុញឲ្យគេផ្លាស់ប្តូរដោយខ្លួនឯងទៀតហើយ ក៏មិនមែនជារូបកាយរបស់ព្រះយេស៊ូវដែលលេចមកឲ្យមនុស្សលោកឃើញ ដើម្បីធ្វើកិច្ចការនេះដែរ តែយ៉ាងហោចណាស់កិច្ចការនេះត្រូវបានធ្វើឡើងតាមវិធីផ្សេងទៀត។ ផ្ទុយទៅវិញ គឺព្រះជាម្ចាស់ដែលយកនិស្ស័យជាមនុស្សមកធ្វើកិច្ចការនេះ និងណែនាំឲ្យធ្វើកិច្ចការនេះដោយអង្គឯង។ ទ្រង់ធ្វើវាតាមរបៀបនេះ ដើម្បីដឹកនាំមនុស្សចូលទៅក្នុងកិច្ចការថ្មី។ តើនេះមិនមែនជាកិច្ចការមួយដ៏អស្ចារ្យទេឬអី? ព្រះជាម្ចាស់មិនធ្វើកិច្ចការនេះតាមរយៈក្រុមមនុស្សលោកណាមួយ ឬតាមរយៈការថ្លែងទំនាយទេ ផ្ទុយទៅវិញ ព្រះជាម្ចាស់ធ្វើកិច្ចការនេះដោយអង្គឯង។ មនុស្សមួយចំនួនប្រហែលជានិយាយថា នេះមិនមែនជាកិច្ចការមួយដ៏អស្ចារ្យទេ ហើយថា វាក៏មិនអាចនាំភាពរំជើបរំជួលមកឲ្យមនុស្សដែរ។ ប៉ុន្តែ ខ្ញុំសូមនិយាយប្រាប់អ្នកថា កិច្ចការរបស់ព្រះជាម្ចាស់មិនមែនត្រឹមប៉ុននេះទេ ប៉ុន្តែជាកិច្ចការមួយដែលអស្ចារ្យជាងនេះឆ្ងាយណាស់។

នៅសម័យនេះ ព្រះជាម្ចាស់មិនយាងមកធ្វើកិច្ចការក្នុងរូបកាយខាងព្រលឹងវិញ្ញាណទេ ប៉ុន្តែគឺក្នុងរូបកាយដ៏សាមញ្ញមួយវិញ។ លើសពីនេះទៅទៀត វាមិនត្រឹមតែជារូបកាយរបស់ព្រះជាម្ចាស់ ដែលមកយកនិស្ស័យជាមនុស្សជាលើកទីពីរប៉ុណ្ណោះទេ តែក៏ជារូបកាយដែលព្រះជាម្ចាស់ត្រលប់មកជាសាច់ឈាមវិញដែរ។ វាជាសាច់ឈាមដ៏សាមញ្ញមួយ។ អ្នកមិនអាចមើលឃើញអ្វីៗ ដែលធ្វើឲ្យទ្រង់លេចធ្លោជាងអ្នកដទៃទេ ប៉ុន្តែអ្នកអាចទទួលបានពីទ្រង់នូវសេចក្តីពិតដែលមិនធ្លាប់ឮពីមុនមក។ រូបកាយ

សាច់ឈាមដ៏សំខាន់នេះ តំណាងអស់ទាំងព្រះបន្ទូលនៃសេចក្ដីពិតដែលមកពីព្រះជាម្ចាស់ ក៏អនុវត្តកិច្ចការរបស់ព្រះជាម្ចាស់នៅគ្រាចុងក្រោយ និងបង្ហាញពីនិស្ស័យរបស់ព្រះជាម្ចាស់ឲ្យមនុស្សបានយល់ទៀតផង។ តើអ្នកមិនប្រាថ្នាចង់ឃើញព្រះជាម្ចាស់នៅលើស្ថានសួគ៌ជាខ្លាំងទេឬអី? តើអ្នកមិនប្រាថ្នាចង់យល់ពីព្រះជាម្ចាស់នៅលើស្ថានសួគ៌ជាខ្លាំងទេឬអី? តើអ្នកមិនប្រាថ្នាចង់ឃើញទិសដៅរបស់មនុស្សលោកជាខ្លាំងទេឬអី? ទ្រង់នឹងប្រាប់អ្នក អំពីអាថ៌កំបាំងទាំងអស់នេះ ជាអាថ៌កំបាំងដែលគ្មានមនុស្សណាអាចប្រាប់អ្នកបានឡើយ ហើយទ្រង់ក៏នឹងប្រាប់អ្នកអំពីសេចក្ដីពិតដែលអ្នកមិនយល់ដែរ។ ទ្រង់ជាក្លោងទ្វាររបស់អ្នក សម្រាប់ចូលទៅក្នុងនគរស្ថានសួគ៌ និងជាមគ្គុទេសក៏របស់អ្នក សម្រាប់ចូលទៅក្នុងយុគសម័យថ្មី។ រូបកាយសាច់ឈាមដ៏សាមញ្ញមួយនេះ ផ្ទុកនូវអាថ៌កំបាំងជាច្រើនដែលមិនអាចយល់បាន។ ទង្វើរបស់ទ្រង់អាចនឹងពិបាកយល់សម្រាប់អ្នក ប៉ុន្ដែគោលដៅទាំងមូលនៃកិច្ចការដែលទ្រង់ធ្វើ ល្មមគ្រប់គ្រាន់នឹងឲ្យអ្នកមើលឃើញថា ទ្រង់មិនមែនជារូបកាយសាច់ឈាមធម្មតាមួយដូចដែលមនុស្សជឿនោះទេ។ ដ្បិតទ្រង់តំណាងឲ្យព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងការថែរក្សាដែលព្រះជាម្ចាស់បានបង្ហាញ ចំពោះមនុស្សលោកនៅគ្រាចុងក្រោយ។ ទោះបីជាអ្នកមិនអាចស្ដាប់ឮព្រះបន្ទូលរបស់ទ្រង់ដែលហាក់ដូចជាអង្រួនឲ្យផ្ទៃមេឃ និងផែនដីរញ្ជួយ ទោះបីជាអ្នក មិនអាចមើលឃើញព្រះនេត្ររបស់ទ្រង់ ថាជាអណ្ដាតភ្លើងឆេះសន្ធោរសន្ធៅ ហើយទោះបីជា អ្នកមិនអាចទទួលការដាក់វិន័យដោយដំបងដែករបស់ទ្រង់ក៏ដោយ ក៏អ្នកអាចស្ដាប់ឮពីព្រះបន្ទូលរបស់ទ្រង់ថា ព្រះជាម្ចាស់ទ្រង់ព្រះពិរោធ ហើយដឹងថា ព្រះជាម្ចាស់កំពុងបង្ហាញព្រះហឫទ័យក្ដួលអាណិតចំពោះមនុស្សលោកដែរ។ អ្នកអាចមើលឃើញនិស្ស័យដ៏សុចរិតរបស់ព្រះជាម្ចាស់ និងព្រះប្រាជ្ញាញាណរបស់ទ្រង់ ហើយលើសពីនេះទៀត អ្នកក៏អាចដឹងពីការយកព្រះហឫទ័យទុកដាក់របស់ព្រះជាម្ចាស់សម្រាប់មនុស្សលោកទាំងអស់ដែរ។ កិច្ចការរបស់ព្រះជាម្ចាស់នៅគ្រាចុងក្រោយ គឺដើម្បីឲ្យមនុស្សមើលឃើញព្រះជាម្ចាស់ដែលគង់នៅស្ថានសួគ៌កំពុងរស់នៅជាមួយមនុស្សលោកលើផែនដី និងដើម្បីជួយឲ្យមនុស្សអាចស្គាល់ ស្ដាប់បង្គាប់

គោរព និងស្រលាញ់ព្រះជាម្ចាស់។ នេះហើយជាមូលហេតុដែលទ្រង់បានយាងត្រលប់មកយកនិស្ស័យសាច់ឈាមជាលើកទីពីរ។ ទោះបីជាអ្វីដែលមនុស្សមើលឃើញសព្វថ្ងៃនេះ គឺជាព្រះមួយអង្គដែលមានលក្ខណៈដូចមនុស្ស ជាព្រះដែលមានច្រមុះមួយនិងភ្នែកពីរ និងជាព្រះមួយអង្គដែលមិនគួរឲ្យកត់សម្គាល់ក៏ដោយ ក៏នៅទីបញ្ចប់ ព្រះជាម្ចាស់នឹងបង្ហាញឲ្យអ្នករាល់គ្នាឃើញថា ប្រសិនបើគ្មានព្រះមួយអង្គនេះទេ នោះផ្ទៃមេឃ និងផែនដីនឹងមានការផ្លាស់ប្ដូរយ៉ាងខ្លាំង។ ប្រសិនបើគ្មានព្រះមួយអង្គនេះទេ នោះផ្ទៃមេឃនឹងប្រែជាស្រអាប់ ផែនដីនឹងធ្លាក់ទៅក្នុងភាពវឹកវរ ហើយមនុស្សជាតិទាំងអស់នឹងរស់នៅក្នុងភាពទុរ្ភិក្ស និងគ្រោះកាចនានាផង។ ទ្រង់នឹងបង្ហាញឲ្យអ្នករាល់គ្នាឃើញថា ប្រសិនព្រះជាម្ចាស់មិនបានយកនិស្ស័យជាមនុស្សមកជួយសង្គ្រោះអ្នករាល់គ្នានៅគ្រាចុងក្រោយទេ នោះព្រះជាម្ចាស់ច្បាស់ជាបំផ្លាញមនុស្សលោកទាំងអស់ ទៅក្នុងស្ថាននរកជាយូរមកហើយ។ ប្រសិនបើគ្មានរូបកាយសាច់ឈាមនេះទេ នោះអ្នករាល់គ្នានឹងក្លាយទៅជាមនុស្សមានបាបយ៉ាងធំ ហើយក្លាយទៅជាសាកសពជារៀងរហូតដែរ។ អ្នករាល់គ្នាគួរតែដឹងថា ប្រសិនបើគ្មានរូបកាយសាច់ឈាមនេះទេ មនុស្សលោកទាំងអស់នឹងជួបនូវគ្រោះមហន្តរាយមួយដែលចៀសមិនរួច និងរឹតតែឃើញថា មិនអាចគេចផុតពីទណ្ឌកម្មដ៏ធ្ងន់ធ្ងរដែលព្រះជាម្ចាស់ដាក់ចំពោះមនុស្សលោកនៅគ្រាចុងក្រោយដែរ។ ប្រសិនបើរូបកាយសាច់ឈាមធម្មតានេះមិនបានកើតមកទេ នោះអ្នករាល់គ្នានឹងស្ថិតនៅក្នុងសភាពមួយដែលអ្នករាល់គ្នាអង្វរសុំជីវិតដែលមិនអាចរស់នៅបាន និងអធិស្ឋានសុំសេចក្ដីស្លាប់ដែលមិនអាចស្លាប់បាន ហើយប្រសិនបើរូបកាយសាច់ឈាមនេះមិនបានកើតមកទេ នោះអ្នករាល់គ្នានឹងមិនអាចទទួលបានសេចក្ដីពិត និងមិនអាចចូលមកចំពោះបល្ល័ង្ករបស់ព្រះជាម្ចាស់នៅថ្ងៃនេះបានឡើយ ប៉ុន្តែផ្ទុយទៅវិញ អ្នកនឹងត្រូវព្រះជាម្ចាស់ដាក់ទោសដោយព្រោះបាបដ៏ធ្ងន់ធ្ងររបស់អ្នក។ តើអ្នករាល់គ្នាបានដឹងទេថា ប្រសិនបើព្រះជាម្ចាស់មិនបានត្រលប់មកយកនិស្ស័យជាមនុស្សទេ នោះគ្មានអ្នកណាម្នាក់មានឱកាសទទួលបានសេចក្ដីសង្គ្រោះឡើយ ហើយប្រសិនបើមិនមែនដោយសារការមកដល់នៃរូបកាយសាច់ឈាមនេះទេ នោះព្រះជាម្ចាស់ច្បាស់ជាបញ្ចប់

យុគសម័យចាស់ជាយូរមកហើយ? ដូច្នេះ តើអ្នករាល់គ្នានៅតែអាចបដិសេធចំពោះការមកយកនិស្ស័យជាមនុស្សជាលើកទីពីររបស់ព្រះជាម្ចាស់បានដែរឬអី? ដោយព្រោះអ្នករាល់គ្នាអាចទាញយកអត្ថប្រយោជន៍ជាច្រើន ចេញពីមនុស្សធម្មតាម្នាក់នេះ តើហេតុអ្វីបានជាអ្នករាល់គ្នាមិនទទួលយកទ្រង់ដោយរីករាយ?

កិច្ចការរបស់ព្រះជាម្ចាស់ គឺជាអ្វីមួយដែលអ្នកមិនអាចយល់បាន។ ប្រសិនបើអ្នកមិនអាចយល់ច្បាស់ទាំងស្រុងថា ជម្រើសរបស់អ្នកត្រឹមត្រូវឬអត់ ក៏មិនអាចដឹងថាកិច្ចការរបស់ព្រះជាម្ចាស់អាចជោគជ័យឬអត់ ហេតុអ្វីក៏មិនផ្សងសំណាងរបស់អ្នកហើយមើលថា តើមនុស្សធម្មតាម្នាក់នេះអាចជាជំនួយដល់អ្នកច្រើនប៉ុនណា ហើយថាព្រះជាម្ចាស់ពិតជាបានធ្វើកិច្ចការដ៏អស្ចារ្យមែនឬអត់? ប៉ុន្តែ ខ្ញុំត្រូវតែប្រាប់អ្នកថា នៅជំនាន់ណូអេមនុស្សបានផឹកស៊ី និងរៀបអាពាហ៍ពិពាហ៍ក្នុងកម្រិតមួយដែលព្រះជាម្ចាស់មិនអាចទ្រាំទតមើលបាន ដូច្នេះទ្រង់ក៏បានបញ្ជូនទឹកជំនន់ដ៏ធំមកបំផ្លាញមនុស្សជាតិដោយទុកតែគ្រួសាររបស់ណូអេចំនួន៨នាក់ និងសត្វគ្រប់ប្រភេទប៉ុណ្ណោះ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ នៅគ្រាចុងក្រោយ អស់អ្នកដែលព្រះជាម្ចាស់បានរក្សាទុក គឺជាអស់អ្នកដែលស្មោះត្រង់ចំពោះទ្រង់រហូតដល់ទីបញ្ចប់។ ទោះបីជាសម័យកាលទាំងពីរជាពេលដែលមានសេចក្តីពុករលួយយ៉ាងខ្លាំងបំផុតដែលព្រះជាម្ចាស់មិនអាចទ្រាំទតមើល ហើយមនុស្សជាតិក្នុងយុគសម័យទាំងពីរ បានត្រលប់ជាពុករលួយយ៉ាងខ្លាំង ហើយបដិសេធថាព្រះជាម្ចាស់មិនមែនជាព្រះអម្ចាស់របស់ពួកគេក៏ដោយ ក៏ព្រះជាម្ចាស់បានបំផ្លាញតែមនុស្ស ដែលនៅជំនាន់ណូអេប៉ុណ្ណោះ។ មនុស្សលោកក្នុងយុគសម័យទាំងពីរ បានធ្វើឲ្យព្រះជាម្ចាស់ព្រួយព្រះហឫទ័យយ៉ាងខ្លាំង ប៉ុន្តែព្រះជាម្ចាស់នៅតែអត់ធ្មត់ ចំពោះមនុស្សលោកនៅគ្រាចុងក្រោយ រហូតមកដល់ឥលូវនេះ។ តើហេតុអ្វីបានជាបែបនេះ? តើអ្នករាល់គ្នាមិនដែលឆ្ងល់ថាហេតុអ្វីទេឬ? ប្រសិនអ្នករាល់គ្នាពិតជាមិនដឹងមែន ចាំយើងប្រាប់អ្នករាល់គ្នាទៅចុះ។ មូលហេតុដែលព្រះជាម្ចាស់អាចសម្តែងព្រះគុណចំពោះមនុស្សនៅគ្រាចុងក្រោយនេះ មិនមែនដោយសារតែពួកគេពុករលួយតិចជាងមនុស្សនៅជំនាន់ណូអេ ឬដោយសារពួកគេ

បានបង្ហាញការប្រែចិត្តចំពោះព្រះជាម្ចាស់ឡើយ ហើយក៏រឹតតែមិនមែនដោយសារបច្ចេកវិទ្យានៅគ្រាចុងក្រោយនេះទំនើបរហូតដល់ព្រះជាម្ចាស់មិនអាចមកបំផ្លាញពួកគេបាននោះដែរ។ ផ្ទុយទៅវិញ គឺថាព្រះជាម្ចាស់មានកិច្ចការដែលត្រូវធ្វើនៅក្នុងមនុស្សមួយក្រុមនៅគ្រាចុងក្រោយនេះ ហើយគឺថាព្រះជាម្ចាស់ នឹងធ្វើកិច្ចការនេះដោយព្រះអង្គទ្រង់ផ្ទាល់ តាមរយៈការយកនិស្ស័យជាមនុស្សរបស់ទ្រង់។ លើសពីនេះទៅទៀត ព្រះជាម្ចាស់នឹងជ្រើសរើសមួយផ្នែកនៃមនុស្សមួយក្រុមនេះឲ្យធ្វើជាកម្មវត្ថុនៃសេចក្ដីសង្គ្រោះរបស់ទ្រង់ និងជាផលផ្លែនៃផែនការគ្រប់គ្រងរបស់ទ្រង់ ព្រមទាំងនាំមនុស្សទាំងអស់នេះ ចូលទៅក្នុងយុគសម័យបន្ទាប់។ ដូច្នេះទោះបីជាយ៉ាងណាក៏ដោយ ក៏តម្លៃដែលព្រះជាម្ចាស់បានបង់នេះ ត្រូវបានបម្រុងទុកជាស្រេចសម្រាប់កិច្ចការ ដែលរូបកាយសាច់ឈាមរបស់ទ្រង់ នឹងធ្វើនៅគ្រាចុងក្រោយដែរ។ ការពិតដែលអ្នករាល់គ្នាបានមកដល់សព្វថ្ងៃនេះ គឺត្រូវអរគុណដល់រូបកាយសាច់ឈាមនេះហើយ។ ដោយសារព្រះជាម្ចាស់គង់នៅក្នុងរូបកាយសាច់ឈាមនេះ ទើបអ្នករាល់គ្នា មានឱកាសរស់រានមានជីវិត។ សំណាងល្អទាំងអស់នេះបានមកដោយសារមនុស្សសាមញ្ញម្នាក់នេះហើយ។ មិនត្រឹមតែប៉ុននេះទេ ប៉ុន្តែនៅទីបញ្ចប់ គ្រប់ជាតិសាសន៍ទាំងអស់នឹងថ្វាយបង្គំមនុស្សសាមញ្ញម្នាក់នេះ ហើយស្ដាប់បង្គាប់ ក៏ដូចជាអរគុណមនុស្សសាមញ្ញម្នាក់នេះដែរ ពីព្រោះដោយសារសេចក្ដីពិត ជីវិត និងផ្លូវដែលទ្រង់បាននាំមកនេះហើយ ដែលបានជួយសង្គ្រោះមនុស្សលោកទាំងអស់ និងបានដោះស្រាយទំនាស់រវាងមនុស្សនិងព្រះជាម្ចាស់ ពង្រួញគម្លាតរវាងមនុស្ស និងទ្រង់ ព្រមទាំងបើកឲ្យមានការផ្សារភ្ជាប់មួយរវាងព្រះតម្រិះរបស់ព្រះជាម្ចាស់និងគំនិតមនុស្ស។ គឺទ្រង់នេះហើយដែលបានទទួលសិរីរុងរឿងរឹតតែអស្ចារ្យ សម្រាប់ថ្វាយដល់ព្រះជាម្ចាស់។ តើមនុស្សសាមញ្ញម្នាក់នេះ មិនស័ក្ដិសមនឹងទទួលបានការទុកចិត្ត និងការគោរពស្រឡាញ់របស់អ្នកទេឬអី? តើរូបកាយសាច់ឈាមដ៏សាមញ្ញមួយនេះមិនសមនឹងហៅថា ព្រះគ្រីស្ទទេឬអី? តើមនុស្សម្នាក់ដ៏សាមញ្ញបែបនេះមិនអាចក្លាយជាការសម្ដែងឲ្យស្គាល់ពីព្រះជាម្ចាស់ នៅក្នុងចំណោមមនុស្សទេឬអី? តើ

មនុស្សដែលជួយសង្គ្រោះមនុស្សលោកឲ្យរួចពីគ្រោះមហន្តរាយបែបនេះ មិនសមនឹងឲ្យអ្នករាល់គ្នាស្រឡាញ់ ហើយប្រាថ្នាឱបទ្រង់ជាប់ទេឬអី? ប្រសិនបើអ្នករាល់គ្នាបដិសេធសេចក្ដីពិតដែលចេញពីព្រះឱស្ឋទ្រង់ ហើយស្អប់ខ្ពើមការដែលទ្រង់គង់នៅក្នុងចំណោមអ្នករាល់គ្នា នោះតើអ្នករាល់គ្នានឹងក្លាយទៅជាអ្វីនៅទីបញ្ចប់?

គ្រប់កិច្ចការទាំងអស់របស់ព្រះជាម្ចាស់នៅគ្រាចុងក្រោយ សុទ្ធតែបានសម្រេចតាមរយៈមនុស្សសាមញ្ញម្នាក់នេះ។ ទ្រង់នឹងប្រទានអ្វីៗគ្រប់យ៉ាងមកឲ្យអ្នក ហើយលើសពីនោះទៅទៀត ទ្រង់អាចនឹងសម្រេចអ្វីៗគ្រប់យ៉ាងដែលទាក់ទងនឹងអ្នក។ តើមនុស្សប្រភេទនេះអាចជាអ្វីដែលអ្នករាល់គ្នាជឿអំពីទ្រង់ឬទេថា៖ ទ្រង់ជាមនុស្សម្នាក់ដែលសាមញ្ញ មិនស័ក្ដិសមនឹងរំឭកនោះ? តើសេចក្ដីពិតរបស់ទ្រង់ មិនគ្រប់គ្រាន់នឹងបញ្ចុះបញ្ចូលឲ្យអ្នករាល់គ្នាជឿទេឬអី? តើស្នាមបន្ទាល់អំពីទង្វើរបស់ទ្រង់ មិនគ្រប់គ្រាន់នឹងបញ្ចុះបញ្ចូល ឲ្យអ្នករាល់គ្នាជឿទេឬអី? ឬថា ផ្លូវដែលទ្រង់នាំទៅមិនស័ក្ដិសម នឹងឲ្យអ្នករាល់គ្នាដើរលើវាទេឬអី? នៅពេលដែលអ្វីៗគ្រប់យ៉ាងត្រូវបានគេនិយាយ និងបានធ្វើ តើអ្វីទៅដែលជំរុញឲ្យអ្នករាល់គ្នាស្អប់ខ្ពើមទ្រង់ និងបោះបង់ទ្រង់ចោលព្រមទាំងបណ្ដេញទ្រង់ទៅឆ្ងាយ? គឺមនុស្សម្នាក់នេះហើយ ដែលបង្ហាញនូវសេចក្ដីពិត គឺមនុស្សម្នាក់នេះហើយដែលផ្ដល់សេចក្ដីពិត ហើយគឺមនុស្សម្នាក់នេះហើយដែលផ្ដល់ផ្លូវមួយឲ្យអ្នករាល់គ្នាដើរតាម។ តើអ្នករាល់គ្នានៅតែមិនអាចរកឃើញដាននៃកិច្ចការរបស់ព្រះជាម្ចាស់ នៅក្នុងសេចក្ដីពិតទាំងនេះទៀតឬអី? បើគ្មានកិច្ចការរបស់ព្រះយេស៊ូវទេ មនុស្សលោកមិនអាចចុះពីឈើឆ្កាងបានទេ ប៉ុន្តែបើគ្មានការយកនិស្ស័យជាមនុស្សនៅសម័យនេះ នោះអស់អ្នកដែលបានចុះពីឈើឆ្កាង ក៏មិនអាចទទួលបានការអនុញ្ញាតរបស់ព្រះជាម្ចាស់ ឬក៏ចូលទៅក្នុងយុគសម័យថ្មីបានឡើយ។ បើគ្មានការមកដល់នៃមនុស្សសាមញ្ញម្នាក់នេះទេ អ្នករាល់គ្នានឹងគ្មានឱកាសមើលឃើញព្រះភក្ត្រពិតប្រាកដរបស់ព្រះជាម្ចាស់ឡើយ ហើយអ្នករាល់គ្នាក៏មិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែរ ដ្បិតអ្នករាល់គ្នាគឺជាកម្មវត្ថុដែលគួរតែត្រូវបានបំផ្លាញចោលជាយូរមកហើយ។ ដោយសារការមកដល់ នៃការយកនិស្ស័យជាមនុស្សជា

លើកទីពីររបស់ព្រះជាម្ចាស់ ព្រះជាម្ចាស់បានអត់ទោសឲ្យអ្នករាល់គ្នា ហើយបានបង្ហាញសេចក្ដីមេត្តាករុណាដល់អ្នករាល់គ្នា។ មិនថាយ៉ាងណានោះទេ ព្រះបន្ទូលដែលខ្ញុំត្រូវទុកនៅជាមួយអ្នករាល់គ្នានៅទីបញ្ចប់ គឺនៅតែជាព្រះបន្ទូលទាំងនេះដដែល គឺថា៖ មនុស្សសាមញ្ញម្នាក់នេះ ជាព្រះដែលយកកំណើតជាមនុស្ស ហើយទ្រង់មានសារៈសំខាន់ណាស់សម្រាប់អ្នករាល់គ្នា។ នេះគឺជាកិច្ចការដ៏អស្ចារ្យដែលព្រះជាម្ចាស់បានធ្វើក្នុងចំណោមមនុស្សលោករួចហើយ។

## មានតែព្រះគ្រីស្ទ<br>នៃគ្រាចុងក្រោយទេ ទើបអាចប្រទានមាគ៌ា<br>ជីវិតអស់កល្បជានិច្ចដល់មនុស្សបាន

មាគ៌ាជីវិតមិនមែនជាអ្វីម្យ៉ាងដែលនរណាៗក៏អាចកាន់កាប់បាននោះទេ ក៏មិនមែនជាអ្វីម្យ៉ាង ដែលនរណាៗក៏អាចយកបានយ៉ាងស្រួលនោះដែរ។ មូលហេតុគឺនៅត្រង់ថា ជីវិតបានមកតែពីព្រះជាម្ចាស់ប៉ុណ្ណោះ ដែលមានន័យថា មានតែព្រះជាម្ចាស់ផ្ទាល់ទេ ជាម្ចាស់កម្មសិទ្ធិរូបធាតុនៃជីវិត ហើយមានតែព្រះជាម្ចាស់ផ្ទាល់ទេ ទើបមានមាគ៌ានៃជីវិត។ ហេតុនេះហើយ គឺមានតែព្រះជាម្ចាស់ផ្ទាល់ទេ ទើបជាប្រភពនៃជីវិត ជាប្រភពទឹករស់នៃជីវិត ដែលហូរចេញមកឥតស្រាកស្រាន្ត។ ចាប់តាំងពីគ្រាដែលព្រះជាម្ចាស់បានបង្កើតពិភពលោកមក ទ្រង់បានធ្វើកិច្ចការជាច្រើនពាក់ព័ន្ធនឹងភាពស្រស់បស់នៃជីវិត ទ្រង់បានធ្វើកិច្ចការជាច្រើន ដើម្បីនាំយកជីវិតមកឲ្យមនុស្ស ហើយបានបង់ថ្លៃលោះដ៏មហិមា ដើម្បីឲ្យមនុស្សលោកមានជីវិត។ ដោយសារព្រះជាម្ចាស់ផ្ទាល់ គឺជាជីវិតអស់កល្បជានិច្ច ហើយទ្រង់ផ្ទាល់ គឺជាផ្លូវដែលប្រោសឲ្យមនុស្សលោកបានរស់ឡើងវិញ។ ព្រះជាម្ចាស់មិនដែលអវត្តមានពីដួងចិត្តរបស់មនុស្សឡើយ ហើយទ្រង់ក៏គង់នៅកណ្ដាលចំណោមមនុស្សគ្រប់ពេលវេលាដែរ។ ព្រះអង្គគឺជាកម្លាំងជំរុញដល់ការរស់នៅរបស់មនុស្សតាំងតែពីដើមមកទល់នឹងពេលនេះ ជាឫសគល់នៃវត្តមាន

ជីវិតរបស់មនុស្ស និងជាទ្រព្យតម្កល់ដ៏បរិបូរ សម្រាប់វត្ថុមានជីវិតរបស់មនុស្ស បន្ទាប់ពីពួកគេចាប់កំណើត។ ទ្រង់ធ្វើឲ្យមនុស្សបានកើតជាថ្មី ហើយជួយឲ្យគេអាចរស់នៅក្នុងគ្រប់តួនាទីរបស់គេ ដោយការតស៊ូយ៉ាងមោះមុត។ សូមអរព្រះគុណចំពោះព្រះចេស្ដា និងអានុភាពជីវិតដ៏គង់វង់របស់ព្រះអង្គ ដែលអានុភាពជីវិតរបស់ព្រះជាម្ចាស់ បានក្លាយជាគ្រឹះដ៏រឹងមាំនៃវត្ថុមានជីវិតរបស់មនុស្សតាំងតែពីដើមមក មនុស្សលោកអាចរស់បានពីមួយជំនាន់ទៅមួយជំនាន់ ហើយព្រះជាម្ចាស់បានបង់ថ្លៃលោះមួយដែលគ្មានសាមញ្ញជនណាម្នាក់ ធ្លាប់បានបង់ពីមុនមកសោះ ក៏ដោយសារតែអានុភាពនៃជីវិតរបស់ទ្រង់នេះដែរ។ អានុភាពជីវិតរបស់ព្រះជាម្ចាស់ អាចឈ្នះលើអំណាចគ្រប់យ៉ាងទាំងអស់ លើសពីនេះ អំណាចណាក៏ខ្លាំងពុំស្មើដែរ។ ជីវិតរបស់ទ្រង់អស់កល្បជានិច្ច ព្រះចេស្ដារបស់ទ្រង់ខ្លាំងពូកែអស្ចារ្យ ហើយក៏គ្មានមនុស្សណា ឬខ្មាំងសត្រូវណាអាចយកឈ្នះអានុភាពជីវិតរបស់ទ្រង់បានឡើយ។ អានុភាពជីវិតរបស់ព្រះជាម្ចាស់ឋិតថេរ ហើយបញ្ចេញពន្លឺដ៏ត្រចះត្រចង់របស់ខ្លួន ទោះបីជានៅពេលណា ឬកន្លែងណាក៏ដោយ។ ផ្ទៃមេឃ និងផែនដីអាចឆ្លងកាត់នូវបម្រែបម្រួលជាខ្លាំង ប៉ុន្តែជីវិតរបស់ព្រះជាម្ចាស់ គឺនៅតែដដែលអស់កល្បជានិច្ច។ គ្រប់សព្វសារពើ អាចនឹងកន្លងបាត់ទៅ ប៉ុន្តែជីវិតរបស់ព្រះជាម្ចាស់ឋិតថេរនៅជានិរន្ដ ដ្បិតព្រះជាម្ចាស់ជាប្រភពនៃវត្ថុមានជីវិតសព្វសារពើទាំងអស់ ហើយជាឫសគល់នៃវត្ថុមានជីវិតរបស់គេផង។ ជីវិតរបស់មនុស្ស កើតមកពីព្រះជាម្ចាស់ វត្ថុមានផ្ទៃមេឃ កើតមកពីព្រះជាម្ចាស់ វត្ថុមានផែនដីក៏កើតចេញមកពីព្រះចេស្ដានៃជីវិតរបស់ព្រះជាម្ចាស់ដែរ។ គ្មានសភាវៈមានជីវិតណាអាចខ្ពស់ស្មើអធិបតេយ្យភាពរបស់ព្រះជាម្ចាស់ឡើយ ហើយក៏គ្មានសភាវៈណា មានអនុភាពអាចគេចផុតពីដែនគ្រប់គ្រងនៃសិទ្ធិអំណាចរបស់ព្រះជាម្ចាស់ដែរ។ តាមវិធីនេះ បើទោះបីជាពួកគេជានរណាក៏ដោយ ក៏ពួកគេគ្រប់គ្នាត្រូវតែចុះចូលក្រោមអំណាចគ្រប់គ្រងរបស់ព្រះជាម្ចាស់ គ្រប់គ្នាត្រូវតែរស់នៅក្រោមសេចក្ដីបង្គាប់របស់ព្រះជាម្ចាស់ ហើយក៏គ្មាននរណាម្នាក់អាចគេចផុតពីព្រះហស្ដរបស់ទ្រង់ដែរ។

ប្រហែលជាពេលនេះ ក្ដីប្រាថ្នារបស់អ្នករាល់គ្នា គឺប្រាថ្នាឲ្យបានជីវិត ឬក៏អ្នករាល់គ្នា

ប្រាថ្នាចង់បានសេចក្ដីពិត។ ទោះជាបែបណាក៏ដោយ អ្នកចង់ស្វែងរកព្រះជាម្ចាស់ជាព្រះដែលអ្នកអាចពឹងអាងបាន ហើយជាព្រះដែលប្រទាននូវជីវិតអស់កល្បជានិច្ចដល់អ្នក។ ប្រសិនបើអ្នកចង់បានជីវិតអស់កល្បជានិច្ច អ្នកត្រូវតែយល់ពីប្រភពនៃជីវិតអស់កល្បជានិច្ច និងស្គាល់កន្លែងដែលព្រះជាម្ចាស់គង់នៅជាមុនសិន។ ខ្ញុំបាននិយាយរួចហើយថា មានតែព្រះជាម្ចាស់ទេ ទើបជាជីវិតឥតប្រួលប្រែ ហើយមានតែព្រះជាម្ចាស់ទេ ទើបមានមាគ៌ាជីវិតជាកម្មសិទ្ធិ។ ដោយសារតែព្រះជាម្ចាស់ គឺជាជីវិតដែលមិនចេះប្រែប្រួល នោះទ្រង់ជាជីវិតដែលអស់កល្បជានិច្ច។ ដោយសារទ្រង់តែមួយ គឺជាមាគ៌ាជីវិត ដូច្នេះ ទ្រង់ផ្ទាល់ក៏ជាមាគ៌ាជីវិតដ៏អស់កល្បជានិច្ចដែរ។ ដូច្នេះ ជាដំបូង អ្នកគួរដឹងអំពីកន្លែងដែលទ្រង់គង់នៅជាមុនសិន រួចត្រូវដឹងអំពីវិធីធ្វើយ៉ាងណា ដើម្បីឲ្យបានមាគ៌ាចូលទៅឯជីវិតអស់កល្បជានិច្ចនេះ។ ឥឡូវនេះ ចូរយើងមកប្រកបគ្នាអំពីរឿងពីរយ៉ាងនេះដោយឡែកពីគ្នាសិន។

ប្រសិនបើអ្នកពិតជាចង់បានមាគ៌ាជីវិតដ៏អស់កល្បជានិច្ចមែន ហើយប្រសិនបើអ្នកមិនស្កប់ចិត្តនឹងការដែលអ្នកស្វះស្វែងរកមាគ៌ានេះមែន ជាដំបូងអ្នកត្រូវតែឆ្លើយនឹងសំណួរនេះសិនថា៖ សព្វថ្ងៃនេះ តើព្រះជាម្ចាស់គង់នៅកន្លែងណា? អ្នកប្រហែលជាឆ្លើយថា «ព្រះជាម្ចាស់កំពុងតែគង់នៅស្ថានសួគ៌ ប្រាកដណាស់ព្រះអង្គ មិនមែនកំពុងគង់ក្នុងផ្ទះរបស់អ្នកទេមែនទេ?» អ្នកក៏ប្រហែលជាពោលថា ព្រះជាម្ចាស់គង់ក្នុងសព្វសារពើច្បាស់ណាស់។ អ្នកក៏ប្រហែលជាពោលទៀតថា ព្រះជាម្ចាស់គង់ក្នុងដួងចិត្តមនុស្សរាល់គ្នា ឬពោលថា ព្រះជាម្ចាស់គង់នៅក្នុងភពខាងវិញ្ញាណ។ ខ្ញុំមិនបដិសេធចម្លើយណាមួយទេ ប៉ុន្តែខ្ញុំត្រូវតែបញ្ជាក់ពីរឿងនេះឲ្យបានច្បាស់។ ការនិយាយថា ព្រះជាម្ចាស់គង់នៅក្នុងដួងចិត្តរបស់មនុស្ស ថាត្រូវទាំងអស់ក៏មិនមែនថាខុសទាំងអស់ក៏មិនមែនដែរ។ មូលហេតុគឺនៅត្រង់ថា ក្នុងចំណោមអ្នកជឿលើព្រះជាម្ចាស់ មានមួយចំនួនដែលមានជំនឿពិតប្រាកដ ហើយក៏មានមួយចំនួនដែលមានជំនឿក្លែងក្លាយដែរ មានមួយចំនួនដែលព្រះអង្គទទួលស្គាល់ ហើយក៏មានមនុស្សមួយចំនួនដែលព្រះអង្គមិនទទួលស្គាល់ដែរ មានមនុស្សមួយចំនួនដែលព្រះអង្គ

សព្វព្រះហឫទ័យ ហើយក៏មានមនុស្សមួយចំនួន ដែលព្រះអង្គមិនសព្វព្រះហឫទ័យដែរ មានមនុស្សមួយចំនួន ដែលព្រះអង្គកែឲ្យបានគ្រប់លក្ខណ៍ ហើយក៏មានមនុស្សមួយចំនួនដែលព្រះអង្គផាត់ចោលដែរ។ ហេតុនេះទើបខ្ញុំនិយាយថា ព្រះជាម្ចាស់គង់នៅក្នុងដួងចិត្តមនុស្សមួយចំនួនតូចប៉ុណ្ណោះ ហើយមនុស្សទាំងនេះ ពួកគេជាមនុស្សដែលជឿលើព្រះជាម្ចាស់ពិតឥតសង្ស័យឡើយ ហើយក៏ជាមនុស្សដែលទ្រង់កែឲ្យបានគ្រប់លក្ខណ៍ដែរ។ ពួកគេជាមនុស្សដែលព្រះជាម្ចាស់ដឹកនាំ។ ដោយសារពួកគេ គឺជាមនុស្សដែលព្រះជាម្ចាស់ដឹកនាំ ទើបពួកគេក៏ជាមនុស្សដែលធ្លាប់បានស្ដាប់ឮ និងធ្លាប់បានឃើញមាគ៌ាជីវិតអស់កល្បជានិច្ចរបស់ព្រះជាម្ចាស់ដែរ។ មនុស្សដែលមានជំនឿក្លែងក្លាយ ពួកគេជាមនុស្ស ដែលព្រះជាម្ចាស់មិនទទួលយកឡើយ ពួកគេគឺជាមនុស្សដែលព្រះអង្គស្អប់ខ្ពើម ជាមនុស្សដែលព្រះអង្គផាត់ចោល ពួកគេនឹងត្រូវព្រះអង្គបដិសេធ ត្រូវនៅដោយគ្មានមាគ៌ាជីវិត ហើយត្រូវនៅទាំងមិនដឹងថាព្រះជាម្ចាស់គង់នៅកន្លែងណា។ ផ្ទុយមកវិញ មនុស្សដែលមានព្រះជាម្ចាស់គង់នៅក្នុងចិត្តរបស់គេដឹងថា ព្រះជាម្ចាស់គង់នៅកន្លែងណា។ ពួកគេគឺជាមនុស្សដែលព្រះជាម្ចាស់ប្រទានជីវិតអស់កល្បជានិច្ចឲ្យ ហើយពួកគេក៏ជាមនុស្សដែលដើរតាមព្រះជាម្ចាស់ដែរ។ ពេលនេះ តើអ្នកដឹងហើយឬនៅថា ព្រះជាម្ចាស់គង់នៅកន្លែងណា? ព្រះជាម្ចាស់គង់ទាំងក្នុងដួងចិត្តរបស់មនុស្ស ហើយគង់នៅក្បែរគេទៀតផង។ ទ្រង់មិនមែនគង់នៅតែក្នុងភពខាងវិញ្ញាណ ហើយគង់ខ្ពស់ផុតសព្វសារពើទាំងអស់នោះដែរ ប៉ុន្តែទ្រង់ក៏គង់ទាំងនៅលើផែនដី ដែលមនុស្សមានវត្តមានដែរ។ ហេតុនេះហើយការមកដល់នៃគ្រាចុងក្រោយ បាននាំជំហាននៃកិច្ចការរបស់ព្រះជាម្ចាស់ ឲ្យចូលទៅក្នុងតំបន់ត្រួតត្រាថ្មី។ ព្រះជាម្ចាស់មានអធិបតេយ្យភាពលើគ្រប់សព្វសារពើទាំងអស់ក្នុងចំណោមរបស់គ្រប់យ៉ាង ហើយទ្រង់ក៏ជាគ្រឹះដ៏រឹងមាំនៅក្នុងដួងចិត្តរបស់មនុស្សដែរ ហើយលើសពីនេះ ទ្រង់មានវត្តមានគង់នៅកណ្ដាលចំណោមមនុស្សលោកទៀតផង។ ទាល់តែធ្វើបែបនេះ ទើបទ្រង់អាចនាំមាគ៌ាជីវិតមកប្រទានឲ្យមនុស្សលោក ហើយនាំមនុស្សលោក ទៅក្នុងមាគ៌ាជីវិតបាន។ ព្រះជាម្ចាស់បានយាងមកផែនដី

នេះ ហើយគង់នៅកណ្ដាលចំណោមមនុស្ស ដើម្បីឲ្យមនុស្សមានមាគ៌ាជីវិត ហើយដើម្បីឲ្យមនុស្សអាចមានជីវិតគង់វង្សបាន។ ក្នុងពេលជាមួយគ្នានោះ ព្រះជាម្ចាស់ក៏បង្គាប់បញ្ជារបស់សព្វសារពើនៅក្នុងចំណោមគ្រប់យ៉ាង ដើម្បីសម្របសម្រួលការសហការជាមួយនឹងការគ្រប់គ្រងដែលទ្រង់ធ្វើក្នុងចំណោមមនុស្សលោក។ ហេតុនេះហើយ ប្រសិនបើអ្នកគ្រាន់តែស្គាល់សេចក្ដីបង្រៀនថា ព្រះជាម្ចាស់គង់នៅក្នុងនគរស្ថានសួគ៌ និងគង់ក្នុងដួងចិត្តរបស់មនុស្ស ប៉ុន្តែមិនស្គាល់សេចក្ដីពិតអំពីព្រះវត្តមានរបស់ព្រះជាម្ចាស់នៅក្នុងចំណោមមនុស្សលោក នោះអ្នកនឹងមិនទទួលបាននូវជីវិតឡើយ ហើយក៏មិនទទួលបានមាគ៌ានៃសេចក្ដីពិតដែរ។

ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ គឺជាជីវិត ជាសេចក្ដីពិត ហើយជីវិតនិងសេចក្ដីពិតរបស់ទ្រង់ មានវត្តមានព្រមគ្នា។ មនុស្សដែលពុំមានសមត្ថភាពនឹងទទួលសេចក្ដីពិត ក៏មិនទទួលបានជីវិតដែរ។ ប្រសិនបើគ្មានការដឹកនាំ ការជ្រោមជ្រែង និងការប្រទាននូវសេចក្ដីពិតទេ នោះអ្នកនឹងទទួលបានតែត្រឹមតែន័យពាក្យ គោលលទ្ធិ ហើយអ្វីដែលសំខាន់ជាងគេនោះគឺសេចក្ដីស្លាប់តែប៉ុណ្ណោះ។ ជីវិតរបស់ព្រះជាម្ចាស់ មានវត្តមានជានិរន្តន៍ ហើយសេចក្ដីពិត និងជីវិតរបស់ទ្រង់ មានវត្តមានព្រមគ្នា។ ប្រសិនបើអ្នកមិនអាចរកឃើញប្រភពនៃសេចក្ដីពិតទេ នោះអ្នកក៏មិនទទួលបាន ការចិញ្ចឹមជីវិតដែរ ប្រសិនបើអ្នកមិនអាចទទួលបានការចិញ្ចឹមជីវិតទេ នោះអ្នកក៏ច្បាស់ជាគ្មានសេចក្ដីពិតដែរ ហើយគ្មានអ្វីក្រៅតែពីការស្រមើស្រមៃ និងការយល់ដឹងលំៗប៉ុណ្ណោះ ហើយរូបកាយទាំងមូលរបស់អ្នកគ្មានអ្វីទាំងអស់ ក្រៅតែពីសាច់ឈាម គឺជាសាច់ឈាមដ៏អសោចរបស់អ្នកតែប៉ុណ្ណោះ។ ចូរដឹងថា ពាក្យពេចន៍ក្នុងសៀវភៅមិនរាប់ជាជីវិតទេ កំណត់ត្រាប្រវត្តិសាស្ត្រ ក៏មិនអាចត្រូវគោរពថ្វាយបង្គំថាជាសេចក្ដីពិតដែរ ហើយបញ្ញត្តិពីបុរាណក៏មិនអាចដើរតួជាសេចក្ដីអធិប្បាយអំពីព្រះបន្ទូលដែលព្រះជាម្ចាស់ថ្លែងនាពេលបច្ចុប្បន្ននេះដែរ។ មានតែព្រះបន្ទូលដែលព្រះជាម្ចាស់ថ្លែងពេលព្រះអង្គយាងមកផែនដី ហើយរស់នៅក្នុងចំណោមមនុស្សលោកប៉ុណ្ណោះ ទើបជាសេចក្ដីពិត ជាជីវិត ជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ហើយជាវិធីអនុវត្តកិច្ចការបច្ចុប្បន្នរបស់

ទ្រង់។ ប្រសិនបើអ្នកយកកំណត់ត្រាព្រះបន្ទូលដែលព្រះជាម្ចាស់ថ្លែងកាលពីអតីតកាលមកអនុវត្តនៅពេលបច្ចុប្បន្ន ទង្វើនេះធ្វើឲ្យអ្នកក្លាយជាបុរាណវិទូហើយ ហើយងារដ៏ល្អបំផុតសម្រាប់បរិយាយពីអ្នក គឺអ្នកឯកទេសបេតិកភណ្ឌប្រវត្តិសាស្ត្រ។ នេះមកពីអ្នកតែងតែជឿលើតឹកតាងនៃកិច្ចការដែលព្រះជាម្ចាស់បានធ្វើពីអតីតកាលជឿតែលើស្រមោលដែលព្រះជាម្ចាស់បានបន្សល់ទុក កាលដែលទ្រង់បានធ្វើការនៅក្នុងចំណោមមនុស្ស ហើយជឿតែលើមាគ៌ា ដែលព្រះជាម្ចាស់បានប្រទានឲ្យពួកសិស្សរបស់ទ្រង់ពីអតីតកាល។ អ្នកមិនជឿលើគោលដៅនៃកិច្ចការរបស់ព្រះជាម្ចាស់នាពេលបច្ចុប្បន្ននេះទេ ក៏មិនជឿលើព្រះភក្ត្រដែលពេញដោយសិរីរុងរឿងរបស់ព្រះជាម្ចាស់នាពេលបច្ចុប្បន្ននេះ ហើយមិនជឿលើមាគ៌ានៃសេចក្តីពិតដែលព្រះជាម្ចាស់បានបង្ហាញឲ្យគេស្គាល់នាពេលបច្ចុប្បន្ននេះដែរ។ ហេតុនេះ អ្នកគឺជាមនុស្សរវើរវាយ ដែលនៅដាច់ឆ្ងាយពីភាពជាក់ស្តែងទាំងស្រុង ដោយគ្មានអ្វីប្រកែកឡើយ។ ពេលនេះ ប្រសិនបើអ្នកនៅតែប្រកាន់ខ្ជាប់តាមពាក្យពេចន៍ដែលមិនអាចប្រទានជីវិតឲ្យមនុស្សបាន នោះអ្នកជាមនុស្សដូចឈើងាប់មួយដុំដែលអស់សង្ឃឹម[ក] ដ្បិតអ្នករាល់គ្នាមានគំនិតអភិរក្សជ្រុលនិយម ពិបាកទូន្មានជ្រុល ហើយរឹងរូសជ្រុល មិនទទួលហេតុផលសោះ!

ព្រះជាម្ចាស់ដែលបានប្រសូតជាសាច់ឈាម មានព្រះនាមថាព្រះគ្រីស្ទ ហើយព្រះគ្រីស្ទដែលអាចប្រទានឲ្យមនុស្សមានសេចក្តីពិតនេះ ហៅថាព្រះជាម្ចាស់។ គ្មានអ្វីលើសពីនេះទេ ដ្បិតព្រះគ្រីស្ទមានលក្ខណៈរបស់ព្រះជាម្ចាស់ មានទាំងនិស្ស័យរបស់ព្រះជាម្ចាស់ ហើយព្រះប្រាជ្ញាញាណដែលទ្រង់មានក្នុងការអនុវត្ត កិច្ចការរបស់ទ្រង់ជាប្រាជ្ញាញាណ ដែលមនុស្សរកយល់មិនដល់ឡើយ។ អស់អ្នកដែលហៅខ្លួនឯងថាព្រះគ្រីស្ទ ប៉ុន្តែមិនអាចធ្វើកិច្ចការរបស់ព្រះជាម្ចាស់បាន គឺជាមនុស្សបោកប្រាស់ហើយ។ ព្រះគ្រីស្ទមិនមែនត្រឹមតែជាការបង្ហាញព្រះកាយរបស់ព្រះជាម្ចាស់នៅលើ

---

លេខយោង៖

ក. ឈើងាប់មួយដុំ៖ ជាគ្រាមភាសាក្នុងភាសាចិន ដែលមានន័យថា «ជួយមិនបាន»។

ផែនដីនេះទេ តែជារូបកាយសាច់ឈាមដ៏វិសេសវិសាល ដែលព្រះជាម្ចាស់សណ្ឋិតពេលទ្រង់អនុវត្ត និងសម្រេចកិច្ចការរបស់ទ្រង់ នៅកណ្ដាលចំណោមមនុស្ស។ សាច់ឈាមនេះមិនមែនមនុស្សណាក៏សុទ្ធតែអាចជំនួសបាននោះទេ ប៉ុន្តែជារូបកាយសាច់ឈាមមួយ ដែលអាចទ្រាំទ្រកិច្ចការរបស់ព្រះជាម្ចាស់នៅលើផែនដីនេះបានយ៉ាងមានប្រសិទ្ធភាព ក៏ស្ដែងនូវនិស្ស័យរបស់ព្រះជាម្ចាស់ ទាំងតំណាងឲ្យព្រះជាម្ចាស់បានយ៉ាងល្អ ហើយប្រទានឲ្យមនុស្សមានជីវិតផង។ មិនយូរមិនឆាប់ មនុស្សដែលក្លែងធ្វើជាព្រះគ្រីស្ទ នឹងត្រូវដួលចុះ ថ្វីបើពួកគេប្រកាសខ្លួនឯងថាជាព្រះគ្រីស្ទក៏ពិតមែន ប៉ុន្តែពួកគេគ្មានលក្ខណៈរបស់ព្រះគ្រីស្ទឡើយ សូម្បីតែមួយ។ ហេតុនេះ ខ្ញុំប្រាប់ឲ្យដឹងទៅចុះថា យថាភាពរបស់ព្រះគ្រីស្ទ គ្មានមនុស្សណាកំណត់និយមន័យបានឡើយ គឺមានតែព្រះជាម្ចាស់ផ្ទាល់ព្រះអង្គប៉ុណ្ណោះ ទើបអាចឆ្លើយ និងសម្រេចបាន។ តាមវិធីនេះ ប្រសិនបើអ្នកពិតជាចង់ស្វែងរកមាគ៌ានៃជីវិត គឺអ្នកត្រូវតែដឹងជាមុនសិនថា ព្រះអង្គប្រទានមាគ៌ាជីវិតដល់មនុស្ស តាមរយៈការយាងមកផែនដី ហើយអ្នកត្រូវតែដឹងថា ទ្រង់យាងមកផែនដី ដើម្បីប្រទានមាគ៌ាជីវិតដល់មនុស្សក្នុងអំឡុងពេលនៃគ្រាចុងក្រោយ។ ពេលនេះ មិនមែនអតីតកាលទេ រឿងនេះកំពុងតែកើតឡើងនាពេលបច្ចុប្បន្ន។

ព្រះគ្រីស្ទនៃគ្រាចុងក្រោយ នាំយកទាំងជីវិត ហើយនាំយកទាំងមាគ៌ានៃសេចក្ដីពិតដ៏ឋិតថេរ និងអស់កល្បជានិច្ចមកជាមួយ។ សេចក្ដីពិតនេះ ជាផ្លូវដែលមនុស្សទទួលបានជីវិត និងជាផ្លូវតែមួយគត់ ដែលឲ្យមនុស្សបានស្គាល់ព្រះជាម្ចាស់ ហើយត្រូវបានព្រះជាម្ចាស់ទទួលយក។ ប្រសិនបើអ្នកមិនស្វែងរកមាគ៌ានៃជីវិតដែលព្រះគ្រីស្ទនៃគ្រាចុងក្រោយប្រទានឲ្យទេ នោះអ្នកនឹងមិនទទួលបានការទទួលយកពីព្រះយេស៊ូវ និងគ្មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីចូលទៅតាមទ្វារនគរស្ថានសួគ៌ដែរ ដ្បិតអ្នកគឺជាអាយ៉ង និងជាអ្នកជាប់ឃុំក្នុងប្រវត្តិសាស្ត្រ។ មនុស្សដែលត្រូវត្រួតត្រាដោយបញ្ញត្តិដោយន័យពាក្យនានា ហើយជាប់ខ្នោះឃ្នាងប្រវត្តិសាស្ត្រ អ្នកនោះនឹងមិនអាចទទួលបានជីវិត ហើយក៏មិនទទួលបាននូវមាគ៌ាជីវិតដ៏គង់វង្សបានឡើយ។ ដោយសារអ្វីៗគ្រប់យ៉ាងដែលគេមាន សុទ្ធតែជាភក់ដែលស្អិតជាប់រាប់ពាន់ឆ្នាំមកហើយ មិនមែន

ជាទឹកនៃជីវិតដែលហូរចេញពីបល្ល័ង្ករបស់ព្រះជាម្ចាស់ទេ។ មនុស្សដែលមិនមែនរស់ដោយសារទឹកនៃជីវិត នឹងនៅជាសាកសព ជារបស់លេងរបស់សាតាំង និងជាកូននរករហូតអស់កល្បជានិច្ច។ ចុះម្ដេចបានជាពួកគេអាចមើលឃើញព្រះជាម្ចាស់ពីចម្ងាយ? ប្រសិនបើអ្នកគ្រាន់តែព្យាយាមឱបក្រសោបអតីតកាល គ្រាន់តែព្យាយាមបណ្ដោយឲ្យអ្វីៗ ទៅតាមដំណើរដោយនៅឈរទ្រឹង ហើយមិនព្យាយាមផ្លាស់ប្ដូរស្ថានភាពបច្ចុប្បន្ន ព្រមទាំងបោះបង់អតីតកាលចោលទេ តើអ្នកមិននៅតែទាស់ទទឹងនឹងព្រះជាម្ចាស់រហូតទេឬអី? ជំហានកិច្ចការរបស់ព្រះជាម្ចាស់ ទាំងល្វឹងល្វើយ ទាំងខ្លាំងពូកែ ប្រៀបបានទៅនឹងទឹករលកកំពុងខ្ទោលឡើង និងសំឡេងផ្គររន្ទះផ្ទុងផ្ទាំង ប៉ុន្ដែអ្នកបែរជាអង្គុយរង់ចាំឲ្យសេចក្ដីវិនាសមកដល់ ទាំងឱបជាប់ភាពលេលា ហើយមិនធ្វើអ្វីទាល់តែសោះ។ បើនៅតែបែបនេះ តើឲ្យព្រះជាម្ចាស់រាប់អ្នកជាអ្នកដើរតាមលំអាននៃកូនចៀមយ៉ាងដូចម្ដេច? តើអ្នកអាចបញ្ជាក់ហេតុផលថាព្រះជាម្ចាស់ដែលអ្នកជឿតាមនេះ គឺជាព្រះជាម្ចាស់ដែលថ្មីជានិច្ច មិនដែលចាស់គំរិលយ៉ាងដូចម្ដេច? ហើយធ្វើយ៉ាងណា ឲ្យពាក្យពេចន៍ក្នុងសៀវភៅលឿងរបស់អ្នក នាំអ្នកឆ្លងទៅក្នុងយុគសម័យថ្មីបាន? តើធ្វើយ៉ាងណាឲ្យពាក្យពេចន៍ទាំងនេះ នាំអ្នកស្វែងរកជំហាននៃកិច្ចការរបស់ព្រះជាម្ចាស់បាន? ហើយធ្វើយ៉ាងណាឲ្យពាក្យពេចន៍ទាំងនេះ នាំអ្នកឡើងទៅស្ថានសួគ៌បាន? អ្វីដែលអ្នកកាន់នៅនឹងដៃ គឺជាន័យពាក្យដែលអាចផ្ដល់ជូនត្រឹមតែជាសេចក្ដីស្រាកស្រាន្ដក្នុងចិត្តបណ្ដោះអាសន្នប៉ុណ្ណោះ មិនមែនផ្ដល់សេចក្ដីពិតដែលអាចផ្ដល់នូវជីវិតនោះឡើយ។ បទគម្ពីរដែលអ្នកអាន គ្រាន់តែអាចបង្កើនវោហារសព្ទដល់អណ្ដាតរបស់អ្នក និងមិនមែនជាពាក្យពេចន៍នៃទស្សនៈវិជ្ជា ដែលអាចជួយឲ្យអ្នកស្គាល់ជីវិតមនុស្ស ក៏រឹតតែមិនមែនជាផ្លូវ ដែលអាចនាំអ្នកទៅរកភាពគ្រប់លក្ខណ៍បានឡើយ។ តើភាពខុសគ្នានេះមិនផ្ដល់ជាបុព្វហេតុ សម្រាប់ឲ្យអ្នកសញ្ជឹងគិតទេឬអី? តើវាមិនធ្វើឲ្យអ្នកស្គាល់នូវអាថ៌កំបាំង ដែលមាននៅក្នុងភាពខុសគ្នានេះទេឬអី? តើអ្នកមានសមត្ថភាពនឹងនាំខ្លួនឯងចូលទៅឯស្ថានសួគ៌ ដើម្បីជួបនឹងព្រះជាម្ចាស់ដោយខ្លួនឯងបានដែរឬទេ? ប្រសិនបើគ្មានការយាងមករបស់ព្រះជាម្ចាស់ទេ តើអ្នក

អាចនាំខ្លួនឯងចូលទៅឯស្ថានសួគ៌ ដើម្បីរស់នៅយ៉ាងរីករាយនឹងសុភមង្គលគ្រួសារជាមួយនឹងព្រះជាម្ចាស់បានដែរឬទេ? តើអ្នកនៅកំពុងយល់សុបិនទៀតទេ? ខ្ញុំសូមទូន្មានអ្នកទៅចុះថា ចូរឈប់សុបិនទៅ ហើយសម្លឹងមើលវិញថា នរណាកំពុងធ្វើកិច្ចការនៅពេលនេះ ពេលនេះនរណាកំពុងអនុវត្ត កិច្ចការសង្គ្រោះមនុស្សលោកក្នុងអំឡុងពេលនៃគ្រាចុងក្រោយ។ ប្រសិនបើអ្នកមិនសម្លឹងមើលទេ នោះអ្នកនឹងមិនទទួលបានសេចក្ដីពិត ហើយមិនទទួលបានជីវិតនោះឡើយ។

អស់អ្នកណាដែលចង់បានជីវិត ដោយមិនពឹងលើសេចក្ដីពិតដែលព្រះគ្រីស្ទមានបន្ទូលប្រាប់ ជាមនុស្សដែលគួរឲ្យអស់សំណើចបំផុតនៅលើផែនដី ហើយមនុស្សដែលមិនទទួលមាគ៌ាជីវិតដែលព្រះគ្រីស្ទយកមកប្រទានឲ្យ គឺជាមនុស្សដែលវង្វេងក្នុងភាពស្រមើស្រមៃរបស់ខ្លួនហើយ។ ដូច្នេះ ខ្ញុំប្រាប់អ្នករាល់គ្នាទៅចុះថា មនុស្សដែលមិនទទួលព្រះគ្រីស្ទនៃគ្រាចុងក្រោយ នឹងត្រូវព្រះជាម្ចាស់ស្អប់រហូតអស់កល្បជានិច្ច។ ព្រះគ្រីស្ទ គឺជាច្រកទ្វារចូលទៅកាន់នគរព្រះនៅគ្រាចុងក្រោយ ហើយគ្មាននរណាម្នាក់អាចទៅក្បែរព្រះអង្គបានឡើយ។ ប្រសិនបើមិនមែនដោយសារព្រះគ្រីស្ទ នោះគ្មាននរណាម្នាក់ដែលត្រូវបានព្រះជាម្ចាស់ប្រោសឱ្យបានគ្រប់លក្ខណ៍នោះឡើយ។ អ្នកជឿលើព្រះជាម្ចាស់ ហេតុនេះហើយ អ្នកក៏ត្រូវតែទទួលយកព្រះបន្ទូលទ្រង់ ហើយស្ដាប់តាមមាគ៌ារបស់ទ្រង់ផងដែរ។ អ្នកមិនអាចគិតតែពីការទទួលបានព្រះពរ ខណៈដែលអ្នកមិនអាចទទួលយកសេចក្ដីពិត ហើយមិនអាចទទួលយកការប្រទានជីវិតនោះឡើយ។ ព្រះគ្រីស្ទយាងមកក្នុងអំឡុងពេលនៃគ្រាចុងក្រោយ ដើម្បីឲ្យអស់អ្នកដែលជឿដល់ទ្រង់ពិត អាចទទួលបានជីវិត។ កិច្ចការរបស់ទ្រង់ គឺដើម្បីបញ្ចប់យុគសម័យចាស់ រួចចូលទៅក្នុងយុគសម័យថ្មី ហើយកិច្ចការរបស់ទ្រង់ គឺជាផ្លូវមួយដែលមនុស្សចូលទៅក្នុងយុគសម័យថ្មីត្រូវដើរ។ ប្រសិនបើអ្នកមិនអាចទទួលស្គាល់ទ្រង់ តែបែរជាថ្កោលទោស ប្រមាថ ឬបៀតបៀនទ្រង់ នោះអ្នកនឹងត្រូវដុតបញ្ឆេះរហូតអស់កល្បជានិច្ច ហើយនឹងមិនអាចចូលទៅក្នុងនគរព្រះបានឡើយ។ ដ្បិតព្រះគ្រីស្ទផ្ទាល់ព្រះអង្គ ជាការសម្ដែងឲ្យស្គាល់ព្រះវិញ្ញាណបរិសុទ្ធ និងជាការសម្ដែង

ឲ្យស្គាល់ព្រះជាម្ចាស់ ហើយទ្រង់ជាព្រះមួយអង្គដែលព្រះជាម្ចាស់បានផ្ទុកផ្ដាក់ឲ្យធ្វើកិច្ចការរបស់ទ្រង់ នៅលើផែនដី។ ហើយហេតុនេះ ខ្ញុំប្រាប់អ្នករាល់គ្នាទៅចុះថា ប្រសិនបើអ្នកមិនអាចទទួលកិច្ចការទាំងអស់ដែលព្រះគ្រីស្ទទ្រង់នៃគ្រាចុងក្រោយធ្វើទេ នោះអ្នករាល់គ្នា ប្រមាថព្រះវិញ្ញាណបរិសុទ្ធហើយ។ មហាទុក្ខវេទនា ដែលមនុស្សប្រមាថព្រះវិញ្ញាណបរិសុទ្ធត្រូវទទួល គឺជាភស្តុតាងបញ្ជាក់ដល់មនុស្សទាំងអស់។ ខ្ញុំសូមប្រាប់អ្នករាល់គ្នាទៀតចុះថា ប្រសិនបើអ្នកតតាំងនឹងព្រះគ្រីស្ទនៃគ្រាចុងក្រោយ ហើយប្រសិនបើអ្នកបដិសេធព្រះគ្រីស្ទនៃគ្រាចុងក្រោយ នោះគ្មាននរណាមកទ្រាំរងលទ្ធផលជំនួសអ្នករាល់គ្នាទៀតឡើយ។ ជាងនេះទៅទៀត ចាប់ពីថ្ងៃនេះទៅ អ្នកនឹងគ្មានឱកាសទទួលបានការទទួលយកពីព្រះជាម្ចាស់ឡើយ បើទោះបីជាអ្នកព្យាយាមរំដោះខ្លួនយ៉ាងណាក៏ដោយ អ្នកនឹងមើលមិនឃើញព្រះភក្ត្រព្រះជាម្ចាស់ពីចម្ងាយម្ដងទៀតឡើយ។ ដ្បិតអ្វីដែលអ្នកតតាំងជាមួយនោះ មិនមែនជាមនុស្សទេ អ្វីដែលអ្នកបដិសេធនោះ ក៏មិនមែនជាសភាវៈទន់ខ្សោយនោះដែរ ប៉ុន្តែជាព្រះគ្រីស្ទវិញ។ តើអ្នកដឹងទេថា លទ្ធផលនៃទង្វើនេះគឺជាអ្វី? កំហុសដែលអ្នកនឹងប្រព្រឹត្តឡើងមកនេះ មិនមែនជាកំហុសតូចតាចទេ តែជាទោសដ៏សាហាវដែលប្រព្រឹត្តដោយចេតនាវិញ។ ដូច្នេះហើយ ខ្ញុំសូមទូន្មានអ្នករាល់គ្នាកុំឲ្យសំញែងកំហឹងចំពោះសេចក្ដីពិតឲ្យសោះ ក៏មិនត្រូវធ្វើការទិតៀនដោយធ្វេសប្រហែសនោះដែរ ដ្បិតមានតែសេចក្ដីពិតទេ ទើបអាចនាំយកជីវិតមកឲ្យអ្នកបាន ហើយក៏គ្មានអ្វីអាចឲ្យអ្នកបានកើតជាថ្មី ហើយមើលឃើញព្រះភក្ត្រព្រះជាម្ចាស់ពីចម្ងាយម្ដងទៀតបានដែរ មានតែសេចក្ដីពិតប៉ុណ្ណោះ។

# ចូរត្រៀមខ្លួនធ្វើអំពើល្អឲ្យបានគ្រប់គ្រាន់ សម្រាប់ទិសដៅរបស់អ្នក

ប្រាកដណាស់ ខ្ញុំបានធ្វើកិច្ចការជាច្រើនក្នុងចំណោមអ្នករាល់គ្នា និងបាននិយាយពាក្យពេចន៍មួយចំនួនផងដែរ។ តែទោះយ៉ាងនេះក្ដី ខ្ញុំមិនអាចជួយឲ្យមានអារម្មណ៍ថា បន្ទូលនិងកិច្ចការរបស់ខ្ញុំ មិនបានបំពេញបំណងនៃកិច្ចការរបស់ខ្ញុំនៅគ្រាចុងក្រោយនេះទាំងស្រុងឡើយ។ សម្រាប់គ្រាចុងក្រោយនេះ កិច្ចការរបស់ខ្ញុំគឺមិនមែនសម្រាប់ជាប្រយោជន៍ដល់បុគ្គលណាម្នាក់ ឬមនុស្សមួយចំនួននោះទេ ប៉ុន្តែគឺដើម្បីបង្ហាញពីនិស្ស័យរបស់ខ្ញុំវិញ។ ប៉ុន្តែ ដោយសារហេតុផលដ៏ច្រើនអនេក ប្រហែលដោយសារតែការខ្វះពេលវេលា ឬមមាញឹកនឹងការងារខ្លាំងពេក មនុស្សមិនបានស្គាល់ខ្ញុំតាមរយៈនិស្ស័យរបស់ខ្ញុំនោះទេ។ ដូច្នេះខ្ញុំចាប់ផ្ដើមផែនការថ្មីរបស់ខ្ញុំ ដែលជាកិច្ចការចុងក្រោយរបស់ខ្ញុំ ហើយបើកទំព័រថ្មីនៅក្នុងកិច្ចការរបស់ខ្ញុំ ដើម្បីឲ្យអស់អ្នកដែលឃើញខ្ញុំ ពួកគេនឹងញាប់ញ័រដួងចិត្ត ស្រក់ទឹកភ្នែក និងស្រែកយំឥតឈប់ឈរចំពោះអត្ថិភាពរបស់ខ្ញុំ។ នេះក៏ព្រោះតែខ្ញុំនាំមកឲ្យពិភពលោក នូវទីបញ្ចប់របស់មនុស្សជាតិហើយ ចាប់ពីពេលនេះតទៅ ខ្ញុំលាតត្រដាងនិស្ស័យទាំងមូលរបស់ខ្ញុំ ចំពោះមុខមនុស្សជាតិ ដើម្បីឲ្យអស់អ្នកដែលស្គាល់ខ្ញុំ និងអស់អ្នកដែលមិនស្គាល់ អាចសប្បាយភ្នែកដែលឃើញថា ខ្ញុំពិតជាបានមកកាន់ពិភពមនុស្ស គឺបានមកកាន់ផែនដី ជាកន្លែងដែលអ្វីៗគ្រប់យ៉ាងពហុគុណឡើង។ នេះជាផែនការរបស់ខ្ញុំ និងជា «ការសារភាព» តែមួយគត់របស់ខ្ញុំ ចាប់តាំងពីពេលដែលខ្ញុំបង្កើតមនុស្សជាតិមក។ សូមឲ្យអ្នករាល់គ្នាយកចិត្តទុកដាក់ទាំងស្រុងចំពោះរាល់ចលនារបស់ខ្ញុំ ដ្បិតដំបងរបស់ខ្ញុំសង្កត់ជិតដល់មនុស្សជាតិម្ដងទៀតហើយ គឺជិតដល់អស់អ្នកដែលប្រឆាំងនឹងខ្ញុំ។

ខ្ញុំចាប់ផ្ដើមកិច្ចការដែលខ្ញុំត្រូវធ្វើរួមជាមួយស្ថានសួគ៌។ ដូច្នេះហើយ បានជាខ្ញុំប្រជ្រៀតផ្លូវទៅមុខ ឆ្លងកាត់ហ្វូងមនុស្សច្រើនតំណ ហើយធ្វើដំណើរចុះឡើងរវាងស្ថានសួគ៌និងផែនដី ដោយគ្មាននរណាម្នាក់ដឹងពីចលនារបស់ខ្ញុំ ឬក៏ចាប់អារម្មណ៍

អំពីបន្ទូលរបស់ខ្ញុំឡើយ។ ហេតុដូចនេះ ផែនការរបស់ខ្ញុំនៅតែបន្តជឿនលឿនទៅមុខដោយរលូន។ វាគ្រាន់តែថា ញាណទាំងអស់របស់អ្នករាល់គ្នាបានប្រែទៅជាស្ពឹកខ្លាំងរហូតដល់ថ្នាក់មិនចាប់ភ្លឹកនឹងជំហាននៃកិច្ចការរបស់ខ្ញុំប៉ុណ្ណោះ។ ប៉ុន្តែ ប្រាកដជានឹងមានថ្ងៃមួយដែលអ្នករាល់គ្នានឹងដឹងពីចេតនារបស់ខ្ញុំ។ ថ្ងៃនេះ ខ្ញុំរស់នៅរួមជាមួយអ្នករាល់គ្នា និងរងទុក្ខរួមជាមួយអ្នករាល់គ្នា ហើយខ្ញុំបានយល់ដឹងតាំងពីយូរយារមកហើយអំពីអាកប្បកិរិយា ដែលមនុស្សជាតិមានចំពោះខ្ញុំ។ ខ្ញុំមិនចង់និយាយពីរឿងនេះបន្ថែមទៀតទេ ហើយខ្ញុំពិតជាមិនចង់ធ្វើឲ្យអ្នករាល់គ្នាអាម៉ាស់មុខ តាមរយៈការលើកយកឧទាហរណ៍បន្ថែមទៀត អំពីប្រធានបទដ៏ឈឺចាប់នេះមកនិយាយឡើយ។ ខ្ញុំសង្ឃឹមតែម្យ៉ាងគត់ថា អ្នករាល់គ្នាចងចាំទុកក្នុងចិត្ត នូវអ្វីៗទាំងអស់ដែលខ្លួនបានធ្វើ ដើម្បីឲ្យយើងទាំងអស់គ្នាអាចបញ្ចូលរឿងរ៉ាវរបស់ខ្លួនជាមួយគ្នា នៅថ្ងៃដែលយើងទាំងអស់គ្នាជួបគ្នាម្ដងទៀត។ ខ្ញុំមិនចង់ចោទប្រកាន់ខុសទៅលើអ្នកណាម្នាក់ក្នុងចំណោមអ្នករាល់គ្នាឡើយ ដ្បិតខ្ញុំតែងតែប្រព្រឹត្តដោយយុត្តិធម៌ មិនលំអៀង និងប្រកបដោយកិត្តិយស។ ពិតមែនហើយ ខ្ញុំក៏សង្ឃឹមដែរថា អ្នករាល់គ្នាអាចទៀងត្រង់ ហើយមិនធ្វើអ្វីដែលប្រឆាំងនឹងស្ថានសួគ៌ និងផែនដី ឬមនសិការផ្ទាល់ខ្លួនឡើយ។ នេះជាបញ្ហាតែមួយគត់ ដែលខ្ញុំសួរអំពីអ្នករាល់គ្នា។ មនុស្សជាច្រើនមានអារម្មណ៍រសាប់រសល់ និងងាយឈឺចាប់ ព្រោះពួកគេបានប្រព្រឹត្តខុសធ្ងន់ធ្ងរពេក ហើយមនុស្សជាច្រើនមានអារម្មណ៍ខ្មាសខ្លួនឯង ពីព្រោះពួកគេមិនធ្លាប់ធ្វើអំពើល្អអ្វីមួយសោះ។ តែទោះជាយ៉ាងនេះក្ដី ក៏មានមនុស្សជាច្រើនដែលគ្មានអារម្មណ៍អាម៉ាស់មុខចំពោះអំពើបាបរបស់ខ្លួនដែរ ដោយប្រែក្លាយពីអាក្រក់ទៅជាកាន់តែអាក្រក់ ដោយហែកចេញអស់របាំងមុខដែលបិទបាំងលក្ខណៈគួរឲ្យខ្ពើមរបស់ពួកគេដែលមិនទាន់ត្រូវបានលាតត្រដាងពេញលេញដើម្បីសាកល្បងនិស្ស័យរបស់ខ្ញុំ។ ខ្ញុំមិនខ្វល់ និងមិនយកចិត្តទុកដាក់ចំពោះសកម្មភាពរបស់នរណាម្នាក់ឡើយ។ ផ្ទុយទៅវិញ ខ្ញុំធ្វើកិច្ចការដែលខ្ញុំគួរតែធ្វើដូចជា ប្រមូលព័ត៌មាន ឬធ្វើដំណើរជុំវិញផែនដី ឬធ្វើអ្វីមួយដែលខ្ញុំចាប់អារម្មណ៍។ នៅសម័យកាលដែលសំខាន់ៗ ខ្ញុំបន្តធ្វើកិច្ចការរបស់ខ្ញុំនៅ

ក្នុងចំណោមមនុស្ស តាមផែនការដូចដើម មិនយឺតពេក ហើយក៏មិនឆាប់ពេក និងដោយងាយស្រួល ព្រមទាំងមានប្រសិទ្ធភាពលឿន។ ទោះយ៉ាងណាក៏ដោយនៅវាល់ជំហាននៃកិច្ចការរបស់ខ្ញុំ អ្នកខ្លះត្រូវបានបោះចោលទៅម្ខាង ដ្បិតខ្ញុំស្អប់ការបញ្ឆោររបស់ពួកគេ និងការស្ដាប់បង្គាប់ក្លែងក្លាយរបស់ពួកគេ។ អ្នកទាំងនោះដែលគួរឲ្យស្អប់ខ្ពើមចំពោះខ្ញុំ ប្រាកដជានឹងត្រូវបានបោះបង់ចោល ទោះមានចេតនា ឬអចេតនាក៏ដោយ។ សរុបសេចក្ដីមក ខ្ញុំចង់ឲ្យអ្នកដែលខ្ញុំស្អប់នៅឆ្ងាយពីខ្ញុំ។ មិនចាំបាច់និយាយទេ ខ្ញុំនឹងមិនប្រណីដល់មនុស្សអាក្រក់ ដែលបន្តនៅក្នុងដំណាក់របស់ខ្ញុំឡើយ។ ដោយសារតែថ្ងៃដាក់ទោសមនុស្សជិតមកដល់ហើយ នោះខ្ញុំមិនបាច់ប្រញាប់បណ្ដេញអស់អ្នកដែលគួរឲ្យស្អប់ទាំងនោះចេញពីផ្ទះរបស់ខ្ញុំទេ ដ្បិតខ្ញុំមានផែនការផ្ទាល់ខ្លួនខ្ញុំហើយ។

ឥឡូវនេះ គឺជាពេលដែលខ្ញុំកំណត់លទ្ធផលចុងក្រោយ សម្រាប់មនុស្សម្នាក់ៗ មិនមែនជាដំណាក់កាល ដែលខ្ញុំចាប់ផ្ដើមកែខៃមនុស្សទេ។ ខ្ញុំសរសេរនៅក្នុងសៀវភៅកំណត់ត្រារបស់ខ្ញុំម្ដងមួយៗ នូវពាក្យសំដី និងអំពើរបស់មនុស្សម្នាក់ៗ បែបបទដែលពួកគេបានដើរតាមខ្ញុំ ចរិតលក្ខណៈជាប់នឹងខ្លួនរបស់ពួកគេ ហើយនិងអាកប្បកិរិយាដែលពួកគេបានប្រកាន់យកចុងក្រោយ។ តាមវិធីនេះ មិនថាពួកគេជាមនុស្សប្រភេទណាក៏ដោយ គ្មាននរណាម្នាក់អាចរត់គេចពីព្រះហស្តរបស់ខ្ញុំបានទេ ហើយមនុស្សទាំងអស់នឹងនៅតាមប្រភេទរបស់ខ្លួនដូចដែលខ្ញុំចាត់ចែង។ ខ្ញុំកំណត់ទិសដៅរបស់មនុស្សម្នាក់ៗដោយមិនផ្អែកលើអាយុ អតីតភាព ទំហំនៃការរងទុក្ខ និងជាពិសេស កម្រិតដែលពួកគេសុំឲ្យមានក្ដីអាណិតទេ ប៉ុន្តែយោងទៅលើថាតើពួកគេមានសេចក្ដីពិត ឬអត់។ មិនមានជម្រើសផ្សេងក្រៅពីនេះទេ។ អ្នករាល់គ្នាត្រូវដឹងថា អស់អ្នកដែលមិនធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ក៏នឹងត្រូវទទួលទណ្ឌកម្មផងដែរ។ នេះគឺជាការពិតដែលមិនអាចផ្លាស់ប្ដូរបាន។ ហេតុដូចនេះ អស់អ្នកដែលទទួលទណ្ឌកម្មទាំងនោះ ត្រូវទទួលទណ្ឌកម្មយ៉ាងខ្លាំងសម្រាប់សេចក្ដីសុចរិតរបស់ព្រះជាម្ចាស់ និងជាសំណងសម្រាប់អំពើទុច្ចរិតយ៉ាងច្រើនរបស់ពួកគេ។

ខ្ញុំមិនបានធ្វើការកែប្រែអ្វីមួយឡើយចំពោះផែនការរបស់ខ្ញុំតាំងពីពេលវាចាប់ផ្ដើមមកម្ល៉េះ។ វាគ្រាន់តែថា តាមការគិតរបស់មនុស្ស អ្នកដែលខ្ញុំណែនាំបន្ទូលរបស់ខ្ញុំទាំងអស់នោះ ហាក់ដូចជាកំពុងថយចំនួនចុះ គឺដូចជាអ្នកដែលខ្ញុំពិតជាយល់ព្រម។ ទោះយ៉ាងណាក៏ដោយ ខ្ញុំនៅតែរក្សាផែនការរបស់ខ្ញុំ មិនឲ្យផ្លាស់ប្ដូរដាច់ខាត។ ផ្ទុយទៅវិញ វាគឺជាជំនឿ និងសេចក្ដីស្រឡាញ់របស់មនុស្សទេដែលកំពុងតែផ្លាស់ប្ដូរជានិច្ច កំពុងតែថយចុះជានិច្ច រហូតដល់កម្រិតដែលវាអាចធ្វើឲ្យមនុស្សម្នាក់ៗបែរចេញពីការលុតក្រាបចំពោះខ្ញុំ ទៅជាព្រងើយកន្ដើយចំពោះខ្ញុំ ហើយថែមទាំងបណ្ដេញខ្ញុំចេញទៀត។ អាកប្បកិរិយារបស់ខ្ញុំចំពោះអ្នករាល់គ្នានឹងមិនក្ដៅ ហើយក៏មិនត្រជាក់ដែរ រហូតដល់ខ្ញុំមានអារម្មណ៍ខ្ពើមរអើម និងស្អប់ខ្ពើមខ្លាំង ទើបទីបំផុតដាក់ចេញនូវការដាក់ទោស។ ទោះយ៉ាងណាក៏ដោយ នៅថ្ងៃដាក់ទោសអ្នករាល់គ្នា ខ្ញុំក៏នឹងនៅតែមើលឃើញអ្នករាល់គ្នាដែរ ប៉ុន្ដែអ្នករាល់គ្នានឹងមិនអាចមើលឃើញខ្ញុំទៀតទេ។ ដោយសារតែជីវិតក្នុងចំណោមអ្នករាល់គ្នាបានក្លាយជាគួរឲ្យធុញទ្រាន់ និងល្អក់កករចំពោះខ្ញុំ ដូច្នេះមិនចាំបាច់និយាយអ្វីទេ ខ្ញុំបានជ្រើសរើសកន្លែងផ្សេងទៀតដើម្បីគង់នៅ ដែលល្អប្រសើរជាងមុន ដើម្បីចៀសផុតពីការឈឺចាប់ដោយសារពាក្យសំដីព្យាបាទរបស់អ្នករាល់គ្នា និងគេចផុតពីឥរិយាបថដ៏ថោកទាបដែលមិនអាចទ្រាំបានរបស់អ្នករាល់គ្នា ដែលអ្នករាល់គ្នាលែងអាចបំភាន់ខ្ញុំ ឬប្រព្រឹត្តចំពោះខ្ញុំតាមបែបបង្គ្រប់កិច្ចទៀតហើយ។ មុនពេលខ្ញុំចាកចេញពីអ្នករាល់គ្នាខ្ញុំនៅតែត្រូវដាស់តឿនអ្នករាល់គ្នាឲ្យចៀសវាងធ្វើអ្វីមួយដែលមិនស្របតាមសេចក្ដីពិត។ ផ្ទុយទៅវិញ គួរតែធ្វើនូវអ្វីដែលគាប់ចិត្តទាំងអស់គ្នា ដែលផ្ដល់ប្រយោជន៍ដល់ទាំងអស់គ្នា និងដែលមានប្រយោជន៍ដល់ទិសដៅផ្ទាល់ខ្លួនរបស់អ្នក បើមិនដូច្នេះទេ អ្នកដែលរងទុក្ខនៅក្នុងគ្រោះមហន្ដរាយ នឹងមិនមែនជានរណាផ្សេងក្រៅពីអ្នកឡើយ។

ខ្ញុំបានបង្ហាញសេចក្ដីមេត្ដាករុណាដល់អស់អ្នកដែលស្រឡាញ់ខ្ញុំ និងបដិសេធខ្លួនឯង។ ទន្ទឹមនឹងនេះ ទណ្ឌកម្មដែលដាក់ទៅលើមនុស្សអាក្រក់ គឺជាភស្ដុតាងយ៉ាងច្បាស់អំពីនិស្ស័យដ៏សុចរិតរបស់ខ្ញុំ ហើយថែមទាំងជាទីបន្ទាល់អំពីសេចក្ដីក្រោធរបស់ខ្ញុំ

ផង។ ពេលមហន្តរាយមកដល់ អស់អ្នកដែលប្រឆាំងនឹងខ្ញុំ ពួកគេនឹងស្រក់ទឹកភ្នែក ព្រោះពួកគេរងទុក្ខដោយសារភាពអត់ឃ្លាន និងគ្រោះកាចសាហាវ។ រីឯអស់អ្នកដែលបានប្រព្រឹត្តអំពើអាក្រក់គ្រប់បែបយ៉ាង ប៉ុន្តែបានដើរតាមខ្ញុំអស់រយៈពេលជាច្រើនឆ្នាំ ពួកគេក៏នឹងមិនរួចផុតពីការសងថ្លៃចំពោះអំពើបាបរបស់ពួកគេឡើយ ហើយពួកគេក៏នឹងត្រូវធ្លាក់ចូលក្នុងមហន្តរាយផងដែរ រឿងដូចគ្នានេះធ្លាប់បានកើតឡើងយូរៗម្ដងក្នុងរយៈពេលរាប់លានឆ្នាំមកនេះ ហើយពួកគេនឹងរស់នៅក្នុងស្ថានភាពស្លន់ស្លោ និងភ័យខ្លាចជានិច្ច។ ដោយឡែក អ្នកដើរតាមខ្ញុំទាំងអស់ដែលមានភក្ដីភាពចំពោះខ្ញុំ នឹងរីករាយ ហើយត្រេកអរនឹងអានុភាពរបស់ខ្ញុំ។ ពួកគេនឹងទទួលនូវភាពស្កប់ស្កល់ដែលមិនអាចពិពណ៌នាបាន ហើយរស់នៅក្នុងភាពរីករាយដែលខ្ញុំមិនធ្លាប់ផ្ដល់ឲ្យមនុស្សជាតិកាលពីមុនឡើយ។ ដ្បិតខ្ញុំឲ្យតម្លៃខ្លាំងទៅលើអំពើល្អរបស់មនុស្ស ហើយស្អប់ខ្ពើមខ្លាំងចំពោះអំពើអាក្រក់របស់ពួកគេ។ តាំងពីពេលដែលខ្ញុំចាប់ផ្ដើមដឹកនាំមនុស្សជាតិមក ខ្ញុំមានសេចក្ដីសង្ឃឹមយ៉ាងខ្លាំងក្នុងការទទួលបានមនុស្សមួយក្រុមដែលមានចិត្តគំនិតដូចខ្ញុំ។ ទន្ទឹមនឹងនេះ ខ្ញុំមិនដែលភ្លេចឡើយនូវអស់អ្នកដែលគ្មានចិត្តគំនិតដូចខ្ញុំ។ ខ្ញុំមិនដែលចូលចិត្តពួកគេឡើយនៅក្នុងព្រះហឫទ័យរបស់ខ្ញុំ ហើយខ្ញុំរង់ចាំឱកាសដើម្បីផ្ដន្ទាទោសពួកគេឲ្យសប្បាយភ្នែកម្ដង។ ឥឡូវនេះ នៅទីបំផុត ថ្ងៃរបស់ខ្ញុំបានមកដល់ហើយ ហើយខ្ញុំមិនចាំបាច់រង់ចាំទៀតទេ!

កិច្ចការចុងក្រោយរបស់ខ្ញុំ គឺមិនត្រឹមតែសម្រាប់ជាប្រយោជន៍ដល់ការដាក់ទោសមនុស្សប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់ជាប្រយោជន៍ដល់ការរៀបចំទិសដៅរបស់មនុស្សផងដែរ។ លើសពីនេះទៅទៀត គឺដើម្បីឲ្យមនុស្សទាំងអស់អាចស្គាល់ពីអំពើ និងសកម្មភាពរបស់ខ្ញុំ។ ខ្ញុំចង់ឲ្យមនុស្សរាល់គ្នាឃើញថា គ្រប់យ៉ាងដែលខ្ញុំបានធ្វើ គឺត្រឹមត្រូវ ហើយគ្រប់យ៉ាងដែលខ្ញុំបានធ្វើ គឺជាការបង្ហាញពីនិស្ស័យរបស់ខ្ញុំ។ វាមិនមែនជាទង្វើរបស់មនុស្ស និងធម្មជាតិដាច់ខាត ដែលបានធ្វើឲ្យកើតមានមនុស្សជាតិឡើងមក ប៉ុន្តែខ្ញុំទេ ដែលជាអ្នកដែលចិញ្ចឹមបីបាច់រាល់ភាវរស់ទាំងអស់ដែលត្រូវបានបង្កើតមក។ បើគ្មានអត្ថិភាពរបស់ខ្ញុំទេ មនុស្សជាតិនឹងត្រូវវិនាស ហើយទទួលរងនូវ

ទុក្ខទោសជាមិនខាន។ គ្មានមនុស្សណាម្នាក់នឹងបានឃើញព្រះអាទិត្យ និងព្រះចន្ទដ៏សែនស្អាត ឬពិភពលោកដ៏ស្រស់បំព្រងម្ដងទៀតឡើយ មនុស្សជាតិនឹងជួបប្រទះតែរាត្រីដ៏ត្រជាក់ និងស្រមោលនៃសេចក្ដីស្លាប់ដែលមិនអាចទប់ទល់បាន។ ខ្ញុំជាសេចក្ដីសង្គ្រោះតែមួយគត់របស់មនុស្សជាតិ។ ខ្ញុំជាសេចក្ដីសង្ឃឹមតែមួយគត់របស់មនុស្សជាតិ ហើយជាងនេះទៅទៀត ខ្ញុំជាព្រះដែលទ្រទ្រង់អត្ថិភាពនៃមនុស្សជាតិទាំងអស់។ បើគ្មានខ្ញុំទេ មនុស្សជាតិនឹងឈានដល់ភាពនៅទ្រឹងយ៉ាងឆាប់រហ័ស។ បើគ្មានខ្ញុំទេ មនុស្សជាតិនឹងរងគ្រោះមហន្តរាយ ហើយត្រូវពួកខ្មោចគ្រប់បែបយ៉ាងជាន់ឈ្លីក្រោមជើង ទោះបីជាគ្មាននរណាម្នាក់យកចិត្តទុកដាក់ចំពោះខ្ញុំក្ដី។ ខ្ញុំបានធ្វើកិច្ចការដែលគ្មានអ្នកណាម្នាក់អាចធ្វើបាន ហើយខ្ញុំគ្រាន់តែសង្ឃឹមថា មនុស្សអាចតបស្នងខ្ញុំវិញដោយការធ្វើអំពើល្អខ្លះៗតែប៉ុណ្ណោះ។ ទោះបីជាមានតែមនុស្សតិចតួចអាចតបស្នងខ្ញុំវិញក៏ដោយ ក៏ខ្ញុំនៅតែបញ្ចប់ដំណើររបស់ខ្ញុំ នៅក្នុងពិភពមនុស្សដដែល ហើយចាប់ផ្ដើមជំហានបន្ទាប់នៃកិច្ចការដែលខ្ញុំកំពុងបង្ហាញឲ្យឃើញ ព្រោះការប្រញាប់ប្រញាល់ទាំងអម្បាលម៉ានរបស់ខ្ញុំនៅក្នុងចំណោមមនុស្ស ក្នុងរយៈពេលជាច្រើនឆ្នាំមកនេះ ទទួលបានផ្លែផ្កា ហើយខ្ញុំក៏សព្វព្រះហឫទ័យណាស់ដែរ។ អ្វីដែលខ្ញុំយកចិត្តទុកដាក់មិនមែនជាចំនួនមនុស្សទេ តែផ្ទុយទៅវិញ គឺជាអំពើល្អរបស់ពួកគេ។ ទោះក្នុងករណីណាក៏ដោយ ខ្ញុំសង្ឃឹមថា អ្នករាល់គ្នាត្រៀមខ្លួនធ្វើអំពើល្អឲ្យបានគ្រប់គ្រាន់សម្រាប់ទិសដៅរបស់ខ្លួនឯងផ្ទាល់។ ពេលនោះខ្ញុំនឹងសព្វព្រះហឫទ័យ បើមិនដូច្នោះទេគ្មាននរណាម្នាក់អាចរួចផុតពីមហន្តរាយដែលនឹងកើតឡើងឡើយ។ មហន្តរាយនេះកើតចេញពីខ្ញុំ ហើយប្រាកដណាស់ថា ខ្ញុំក៏ជាអ្នកចាត់ចែងវាយ៉ាងហ្មត់ចត់ដែរ។ បើអ្នករាល់គ្នាមិនអាចធ្វើខ្លួនឲ្យល្អ ក្នុងព្រះនេត្ររបស់ខ្ញុំទេ នោះអ្នករាល់គ្នានឹងគេចមិនផុតពីការរងទុក្ខដោយសារមហន្តរាយឡើយ។ ក្នុងអំឡុងពេលរងទុក្ខខ្លាំង សកម្មភាព និងអំពើរបស់អ្នករាល់គ្នា មិនត្រូវបានចាត់ទុកថាសមស្របទាំងស្រុងឡើយ ដ្បិតសេចក្ដីជំនឿ និងសេចក្ដីស្រឡាញ់របស់អ្នករាល់គ្នាប្រហោងក្នុង ហើយវាគ្រាន់តែបង្ហាញថាអ្នករាល់គ្នាជាមនុស្សកំសាក ឬរឹងរូសប៉ុណ្ណោះ។ ចំពោះ

បញ្ហានេះ ខ្ញុំនឹងធ្វើការវិនិច្ឆ័យតែទៅលើសេចក្ដីល្អ ឬសេចក្ដីអាក្រក់ប៉ុណ្ណោះ។ ខ្ញុំនៅតែបារម្ភអំពីរបៀបដែលអ្នករាល់គ្នាប្រព្រឹត្ត និងសម្ដែងអំពីខ្លួនឯង ហើយខ្ញុំនឹងកំណត់ទីបញ្ចប់របស់អ្នករាល់គ្នា ដោយផ្អែកលើមូលដ្ឋាននេះ។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំត្រូវតែធ្វើការនេះឲ្យបានច្បាស់លាស់៖ ចំពោះអស់អ្នកដែលបង្ហាញខ្ញុំថាគ្មានភក្ដីភាពទាល់តែសោះ ក្នុងអំឡុងពេលរងទុក្ខខ្លាំង ខ្ញុំនឹងមិនប្រោសប្រណីទៀតឡើយ ដ្បិតសេចក្ដីមេត្តាករុណារបស់ខ្ញុំលាតសន្ធឹងដល់ត្រឹមនេះតែប៉ុណ្ណោះ។ ជាងនេះទៅទៀត ខ្ញុំគ្មានចំណូលចិត្ត ចំពោះអ្នកណាដែលធ្លាប់ក្បត់ខ្ញុំម្ដងហើយនោះទេ ហើយខ្ញុំពិតជាមិនចូលចិត្តសេពគប់ជាមួយអ្នកណាដែលលក់ផលប្រយោជន៍មិត្តភក្ដិរបស់ខ្លួនឡើយ។ មិនខ្វល់ថាបុគ្គលនោះជាអ្វីនោះទេ នេះជានិស្ស័យរបស់ខ្ញុំ។ ខ្ញុំត្រូវតែប្រាប់អ្នករាល់គ្នាដូចនេះថា៖ អ្នកណាដែលធ្វើឲ្យខ្ញុំខូចចិត្ត ពួកគេនឹងមិនទទួលបានការប្រោសប្រណីពីខ្ញុំជាលើកទីពីរឡើយ ចំណែកឯអ្នកណាដែលស្មោះត្រង់ចំពោះខ្ញុំ ពួកគេនឹងស្ថិតនៅក្នុងដួងព្រះហឫទ័យរបស់ខ្ញុំជារៀងរហូត។

## តើអ្នកស្មោះត្រង់ចំពោះអ្នកណា?

ជីវិតដែលអ្នករាល់គ្នារស់នៅរាល់ថ្ងៃនេះ មានសារៈសំខាន់ណាស់ ហើយវាសំខាន់ខ្លាំងបំផុតចំពោះទិសដៅចុងក្រោយ និងជោគវាសនារបស់អ្នករាល់គ្នា ដូច្នេះអ្នករាល់គ្នាត្រូវតែស្រឡាញ់អ្វីៗគ្រប់យ៉ាងដែលអ្នករាល់គ្នាមាននៅថ្ងៃនេះ ហើយឲ្យតម្លៃគ្រប់នាទីដែលកន្លងទៅ។ អ្នកត្រូវតែលៃលកពេលវេលាឲ្យបានច្រើន តាមដែលអ្នកអាចធ្វើបានដើម្បីផ្ដល់ផលប្រយោជន៍ច្រើនបំផុតដល់ខ្លួនឯង ទើបអ្នកមិនចំណាយជីវិតនេះជាអាសារឥតការ។ អ្នករាល់គ្នាប្រហែលជាមានអារម្មណ៍ភ័ន្តភាំង ចំពោះមូលហេតុដែលខ្ញុំពោលពាក្យបែបនេះ។ និយាយឲ្យត្រង់ទៅ ខ្ញុំមិនពេញចិត្តនឹងឥរិយាបថរបស់នរណាម្នាក់ក្នុងចំណោមអ្នករាល់គ្នាទេ ពីព្រោះក្ដីសង្ឃឹមដែលខ្ញុំមានចំពោះអ្នករាល់គ្នា វាមិនដូចអ្នករាល់គ្នាសព្វថ្ងៃនេះទេ។ ដូច្នេះខ្ញុំអាចនិយាយបានថា៖

អ្នករាល់គ្នាម្នាក់ៗកំពុងស្ថិតក្នុងគ្រោះថ្នាក់ ហើយសម្រែកអំពាវនាវរកជំនួយរបស់អ្នករាល់គ្នានៅពេលនេះ និងបំណងប្រាថ្នាពីអតីតកាល ដើម្បីស្វែងរកសេចក្ដីពិត និងស្វែងរកពន្លឺ ក៏កំពុងតែឈានដល់ទីបញ្ចប់ហើយ។ នេះគឺជាការបង្ហាញនូវការតបស្នងចុងក្រោយរបស់អ្នករាល់គ្នា ហើយវាគឺជាអ្វីដែលខ្ញុំមិនដែលរំពឹងទុកឡើយ។ ខ្ញុំមិនចង់និយាយផ្ទុយពីការពិតទេ ព្រោះអ្នករាល់គ្នាបានធ្វើឲ្យខ្ញុំខកព្រះទ័យយ៉ាងខ្លាំង។ ប្រហែលជាអ្នកមិនចង់ប្រឈមសម្ដីរឿងនេះទេ ដោយសារអ្នកមិនចង់ប្រឈមមុខនឹងការពិត ប៉ុន្តែខ្ញុំត្រូវតែសួរអ្នករាល់គ្នាពីរឿងនេះយ៉ាងម៉ឺងម៉ាត់ថា៖ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ តើមានអ្វីខ្លះមកបំពេញចិត្តអ្នករាល់គ្នាឱ្យពិតប្រាកដទៅ? តើចិត្តអ្នករាល់គ្នាស្មោះត្រង់ចំពោះអ្នកណា? ចូរកុំនិយាយថា សំណួរទាំងនេះមិនដឹងជាមកពីណា ហើយកុំសួរខ្ញុំថា ហេតុអ្វីបានជាខ្ញុំសួររឿងបែបនេះ។ ចូរដឹងថា៖ មកពីខ្ញុំស្គាល់អ្នករាល់គ្នាច្បាស់ ខ្វាយខ្វល់ពីអ្នករាល់គ្នាណាស់ ហើយយកព្រះទ័យទុកដាក់ខ្លាំងចំពោះកិរិយា និងការប្រព្រឹត្តរបស់អ្នករាល់គ្នា ទើបខ្ញុំប្រឈមសម្ដីនឹងអ្នករាល់គ្នាឥតឈប់ឈរ និងមិនគិតពីការលំបាកដ៏ជូរចត់។ ប៉ុន្តែ អ្នករាល់គ្នាមិនបានតបសងអ្វីដល់ខ្ញុំវិញសោះ ក្រៅតែពីការព្រងើយកន្តើយ និងការបំភ្លេចចោលដែលមិនអាចទ្រាំទ្របានទៅវិញ។ អ្នករាល់គ្នាធ្វេសប្រហែសនឹងខ្ញុំណាស់។ តើវាអាចទៅរួចទេថាខ្ញុំមិនដឹងអ្វីទាំងអស់នោះ? ប្រសិនបើនេះជាអ្វីដែលអ្នករាល់គ្នាជឿ វាបញ្ជាក់បន្ថែមនូវការពិតថា អ្នករាល់គ្នាមិនប្រព្រឹត្តចំពោះខ្ញុំ ដោយចិត្តសប្បុរសយ៉ាងពិតប្រាកដនោះទេ។ ដូច្នេះខ្ញុំប្រាប់អ្នករាល់គ្នាទៅចុះថា អ្នករាល់គ្នាកំពុងបដិសេធមិនទទួលយកការពិតហើយ។ អ្នករាល់គ្នាសុទ្ធតែជាមនុស្សឆ្លាត ទើបមិនដឹងថាខ្លួនឯងកំពុងធ្វើអ្វី ដូច្នេះ តើអ្នកនឹងយកអ្វីមកប្រឈមសម្ដីឆ្លើយតបនឹងខ្ញុំ?

សំណួរដែលធ្វើឲ្យព្រះទ័យខ្ញុំខ្វល់បំផុតគឺ តើចិត្តរបស់អ្នករាល់គ្នាស្មោះត្រង់ចំពោះអ្នកណាឱ្យពិតប្រាកដ។ ខ្ញុំក៏សង្ឃឹមដែរថា អ្នករាល់គ្នាម្នាក់ៗនឹងព្យាយាមរៀបចំគំនិតរបស់ខ្លួនឲ្យបានត្រឹមត្រូវ ហើយសួរខ្លួនឯងថា តើអ្នកស្មោះត្រង់នឹងនរណា ហើយអ្នករស់នៅដើម្បីនរណា។ ប្រហែលជាអ្នករាល់គ្នាមិនដែលបានពិចារណាសំណួរទាំងនេះ

ដោយយកចិត្តទុកដាក់ទេ ដូច្នេះ ប្រសិនបើខ្ញុំបង្ហាញចម្លើយដល់អ្នករាល់គ្នាវិញ តើអ្នករាល់គ្នាយល់យ៉ាងណាដែរ?

អ្នកណាដែលមានការចងចាំ នឹងទទួលស្គាល់ការពិតនេះថា៖ មនុស្សរស់នៅសម្រាប់ខ្លួនឯង ហើយស្មោះត្រង់ចំពោះខ្លួនឯង។ ខ្ញុំមិនជឿថា ចម្លើយអ្នករាល់គ្នាពិតជាត្រឹមត្រូវទាំងអស់នោះទេ ដ្បិតអ្នករាល់គ្នាម្នាក់ៗមានជីវិតរៀងៗខ្លួន ហើយម្នាក់ៗ កំពុងតែជាប់គាំងនឹងទុក្ខវេទនាផ្ទាល់ខ្លួនដែរ។ ដូច្នេះ អ្នករាល់គ្នាស្មោះត្រង់នឹងមនុស្សដែលអ្នករាល់គ្នាស្រឡាញ់ ហើយស្មោះត្រង់នឹងអ្វីដែលគាប់ចិត្តអ្នករាល់គ្នា។ អ្នករាល់គ្នា មិនស្មោះត្រង់នឹងខ្លួនឯងទាំងស្រុងនោះទេ។ ដោយសារតែអ្នករាល់គ្នាម្នាក់ៗ ទទួលឥទ្ធិពលពីមនុស្ស ពីព្រឹត្តិការណ៍ និងពីរឿងរ៉ាវជុំវិញខ្លួនអ្នករាល់គ្នា ហើយមិនស្មោះត្រង់នឹងខ្លួនឯងទេ។ ខ្ញុំនិយាយពាក្យទាំងនេះ មិនមែនដើម្បីគាំទ្រភាពស្មោះត្រង់ចំពោះខ្លួនឯងទេ ប៉ុន្តែដើម្បីបង្ហាញភាពស្មោះត្រង់របស់អ្នករាល់គ្នាចំពោះអ្វីមួយវិញ ដ្បិតអស់រយៈពេលជាច្រើនឆ្នាំមកនេះ គឺខ្ញុំមិនដែលទទួលបានភាពស្មោះត្រង់ពីនរណាម្នាក់ក្នុងចំណោមអ្នករាល់គ្នាឡើយ។ អ្នករាល់គ្នាបានដើរតាមខ្ញុំអស់រយៈពេលជាច្រើនឆ្នាំមកហើយ ប៉ុន្តែអ្នករាល់គ្នាមិនដែលតបស្នងដល់ខ្ញុំនូវភាពស្មោះត្រង់វិញ សូម្បីតែបន្តិច។ ផ្ទុយទៅវិញ អ្នករាល់គ្នាបានវិលវល់ជុំវិញមនុស្សដែលអ្នករាល់គ្នាស្រឡាញ់ និងអ្វីៗដែលគាប់ចិត្តអ្នករាល់គ្នាដល់ថ្នាក់មិនថានៅពេលណា មិនថាអ្នករាល់គ្នាទៅទីណា ក៏អ្នករាល់គ្នារក្សាវានៅជាប់នឹងចិត្តអ្នករាល់គ្នា ហើយមិនដែលបោះបង់ចោលវាម្ដងណាឡើយ។ រាល់ពេលដែលអ្នករាល់គ្នាចង់ធ្វើ ឬងប់ងល់នឹងរឿងណាមួយដែលអ្នករាល់គ្នាស្រឡាញ់ ការនេះកើតឡើងនៅពេលដែលអ្នករាល់គ្នាកំពុងដើរតាមខ្ញុំ ឬសូម្បីតែពេលអ្នករាល់គ្នាកំពុងស្ដាប់ពាក្យរបស់ខ្ញុំ។ ដូច្នេះ ខ្ញុំប្រាប់អ្នករាល់គ្នាទៅចុះថា អ្នករាល់គ្នាកំពុងប្រើប្រាស់ភាពស្មោះត្រង់ដែលខ្ញុំតម្រូវពីអ្នករាល់គ្នា មកស្មោះត្រង់នឹងសេចក្ដីស្រឡាញ់ «វត្ថុកំណាន់» របស់អ្នករាល់គ្នាជំនួសវិញ។ ទោះបីអ្នករាល់គ្នាលះបង់កិច្ចការមួយ ឬពីរ សម្រាប់ខ្ញុំក៏ដោយ ក៏វាមិនបង្ហាញនូវកិច្ចការទាំងអស់របស់អ្នករាល់គ្នា ហើយក៏មិនបង្ហាញថា អ្នករាល់គ្នាពិតជាស្មោះត្រង់

ចំពោះខ្ញុំដែរ។ អ្នករាល់គ្នាបានបញ្ចូលខ្លួនឯងទៅក្នុងការអនុវត្តកិច្ចការដែលអ្នករាល់គ្នាចង់ធ្វើពិតប្រាកដគឺ៖ មនុស្សខ្លះស្មោះត្រង់នឹងកូនប្រុសស្រី អ្នកខ្លះទៀតស្មោះនឹងប្ដី ប្រពន្ធ ទ្រព្យសម្បត្តិ ការងារចៅហ្វាយនាយ ឋានៈ ឬស្ត្រី។ អ្នករាល់គ្នាមិនដែលមានអារម្មណ៍នឿយណាយ ឬធុញទ្រាន់ ចំពោះអ្វីដែលអ្នករាល់គ្នាស្មោះត្រង់ចំពោះនោះទេ ផ្ទុយទៅវិញ អ្នករាល់គ្នារឹតតែចង់បានរបស់ទាំងនេះមកធ្វើជាកម្មសិទ្ធិកាន់តែច្រើន ទាំងបរិមាណ និងគុណភាព ហើយអ្នករាល់គ្នាមិនដែលបោះបង់វាឡើយ។ ទាំងខ្ញុំ និងព្រះបន្ទូលរបស់ខ្ញុំ តែងតែត្រូវបានគេរុញច្រានឲ្យទៅនៅពីក្រោយអ្វីដែលអ្នករាល់គ្នាពេញចិត្តពិត ប្រាកដ។ ហើយអ្នកគ្មានជម្រើសអ្វី ក្រៅពីដាក់ចំណាត់ថ្នាក់វានៅចុងក្រោយគេទេ។ មានអ្នកខ្លះទៀត សូម្បីតែកន្លែងចុងក្រោយនេះ ក៏គេទុកសម្រាប់អ្វីដែលពួកគេស្មោះត្រង់ចំពោះហើយ តែពួកគេមិនទាន់បានរកឃើញ។ ក្នុងចិត្តគេ សូម្បីតែដានបន្តិចបន្តួចពីខ្ញុំ ក៏មិនដែលមានដែរ។ អ្នករាល់គ្នាប្រហែលជាគិតថា ខ្ញុំទាមទារពីអ្នករាល់គ្នាច្រើនពេក ឬចោទប្រកាន់អ្នករាល់គ្នាខុស ប៉ុន្តែតើអ្នករាល់គ្នាធ្លាប់គិតទេថាពេលដែលអ្នករីករាយនឹងចំណាយពេលជាមួយគ្រួសារអ្នករាល់គ្នា នោះអ្នករាល់គ្នាមិនធ្លាប់ស្មោះត្រង់នឹងខ្ញុំសោះ សូម្បីម្ដង? នៅពេលវេលាបែបនេះ តើវាមិនធ្វើឲ្យអ្នករាល់គ្នាឈឺចាប់ទេឬ? នៅពេលដួងចិត្តរបស់អ្នករាល់គ្នាបានពេញដោយអំណរ ហើយអ្នករាល់គ្នាទទួលបានរង្វាន់សម្រាប់ការនឿយហត់របស់ខ្លួន តើអ្នករាល់គ្នា មិនមានអារម្មណ៍នឿយណាយ ដែលមិនបានផ្គត់ផ្គង់ខ្លួនឯងដោយសេចក្ដីពិតគ្រប់គ្រាន់ទេឬអី? តើនៅពេលណាដែលអ្នករាល់គ្នាបានយំ ដោយមិនបានទទួលការសរសើរពីខ្ញុំ? អ្នករាល់គ្នាបានខំប្រឹងគិត ហើយទទួលនូវការឈឺចាប់យ៉ាងខ្លាំងដើម្បីជាប្រយោជន៍ដល់កូនប្រុសស្រីរបស់អ្នករាល់គ្នា ប៉ុន្តែអ្នករាល់គ្នានៅតែមិនពេញចិត្ត ហើយអ្នករាល់គ្នានៅតែជឿជាក់ថា អ្នកមិនបានខំប្រឹងជំនួសពួកគេទេ ហើយជឿថាអ្នកមិនបានធ្វើអ្វីគ្រប់យ៉ាងឲ្យអស់ពីលទ្ធភាពសម្រាប់ពួកគេទេ។ យ៉ាងណាមិញអ្នករាល់គ្នាតែងព្រងើយកន្តើយ និងមិនយកចិត្តទុកដាក់ចំពោះខ្ញុំរហូត។ ខ្ញុំមានតែក្នុងការចងចាំរបស់អ្នករាល់គ្នាប៉ុណ្ណោះ តែខ្ញុំមិននៅក្នុងចិត្តអ្នករាល់គ្នាឡើយ។ អ្នករាល់គ្នា

មិនបានដឹងពីព្រះទ័យស្មោះត្រង់ និងការខិតខំប្រឹងប្រែងរបស់ខ្ញុំជារៀងដរាប ហើយអ្នករាល់គ្នា ក៏មិនដែលមានការកោតសរសើរពីការទាំងនោះដែរ។ អ្នកគ្រាន់តែចូលរួមក្នុងការសញ្ជឹងគិតបន្តិចបបន្តួច ហើយជឿថាវានឹងគ្រប់គ្រាន់។ «ភាពស្មោះត្រង់» បែបនេះ មិនមែនជាអ្វីដែលខ្ញុំចង់បានជាយូរមកហើយនោះទេ ប៉ុន្តែជាអ្វីដែលខ្ញុំមិនសព្វព្រះទ័យវិញ។ ហេតុនេះហើយមិនថាខ្ញុំនិយាយអ្វីនោះទេ ក៏អ្នករាល់គ្នានៅតែបន្តទទួលស្គាល់រឿងមួយ ឬពីរប៉ុណ្ណោះ អ្នកមិនអាចទទួលយកសេចក្ដីនេះបានទាំងស្រុងទេ ពីព្រោះអ្នកទាំងអស់គ្នាមាន «ភាពជឿជាក់» ខ្លាំង ហើយអ្នករាល់គ្នាតែងតែជ្រើសរើស និងសម្រេចយកអ្វីដែលត្រូវទទួលពីពាក្យដែលខ្ញុំបាននិយាយ។ ប្រសិនបើអ្នករាល់គ្នានៅតែដូចសព្វថ្ងៃនេះ ខ្ញុំមានវិធីសាស្ត្រមួយចំនួនសម្រាប់កម្ចាត់ភាពជឿជាក់លើខ្លួនឯងរបស់អ្នករាល់គ្នា ហើយលើសពីនេះទៅទៀតខ្ញុំនឹងធ្វើឱ្យអ្នករាល់គ្នាទទួលស្គាល់ថា ពាក្យរបស់ខ្ញុំទាំងអស់ គឺសុទ្ធតែជាពាក្យពិត ហើយគ្មានពាក្យណាមួយបំភ្លៃការពិតឡើយ។

ប្រសិនបើខ្ញុំដាក់លុយខ្លះនៅចំពោះមុខអ្នករាល់គ្នាឥឡូវនេះ ហើយផ្ដល់សេរីភាពឲ្យអ្នករាល់គ្នាជ្រើសរើស ហើយប្រសិនបើខ្ញុំមិនថ្កោលទោសអ្នករាល់គ្នាដោយព្រោះតែការសម្រេចចិត្តរបស់អ្នករាល់គ្នាទេនោះ អ្នករាល់គ្នាភាគច្រើននឹងជ្រើសរើសយកលុយ ហើយបោះបង់សេចក្ដីពិត។ ក្នុងចំណោមអ្នករាល់គ្នា អ្នកដែលប្រសើរជាងគេនឹងលះបង់លុយកាក់ ហើយជ្រើសរើសសេចក្ដីពិតទាំងស្ទាក់ស្ទើរ ក៏មានអ្នកខ្លះចាក់ខ្សែ ដៃម្ខាងយកលុយ ដៃម្ខាងទៀតយកសេចក្ដីពិត។ ដូច្នេះ តើសន្ដានពិតរបស់អ្នករាល់គ្នា មិនក្លាយជាភស្ដុតាងបញ្ជាក់ដោយខ្លួនឯងទេឬអី? កាលណាត្រូវជ្រើសរើសរវាងសេចក្ដីពិត និងអ្វីៗដែលអ្នករាល់គ្នាងប់ងល់ចង់បាននោះ អ្នករាល់គ្នានឹងជ្រើសរើសយកជម្រើសនេះ ហើយអាកប្បកិរិយារបស់អ្នករាល់គ្នា នឹងនៅដដែល។ តើវាដូច្នោះមែន ឬមិនមែន? ក្នុងចំណោមអ្នករាល់គ្នា តើមិនមានគ្នាច្រើនទេឬ ដែលនៅចាក់ខ្សែ ចំកណ្ដាលរវាងភាពខុសឆ្គង និងភាពត្រឹមត្រូវ? នៅក្នុងការជជែកវែកញែករវាងភាពវិជ្ជមាន និងភាពអវិជ្ជមាន ខ្មៅ និងស អ្នករាល់គ្នាច្បាស់ជាដឹងអំពីជម្រើស

ដែលអ្នករាល់គ្នាបានជ្រើសរវាងគ្រួសារ និងព្រះជាម្ចាស់ រវាងកូនៗ និងព្រះជាម្ចាស់ រវាងភាពសុខសាន្ត និងការរំខាន រវាងភាពសម្បូរសប្បាយ និងភាពក្រីក្រ រវាងភាពខ្ពង់ខ្ពស់ និងភាពសាមញ្ញ រវាងការដែលត្រូវបានគេជ្រោមជ្រែង និងការដែលត្រូវគេបោះបង់ចោល ។ល។ រវាងគ្រួសារសុខសាន្ត និងគ្រួសារបែកបាក់ គឺអ្នករាល់គ្នាបានជ្រើសរើសយកជម្រើសទីមួយ ហើយអ្នកធ្វើដូច្នេះដោយគ្មានការស្ទាក់ស្ទើរ រវាងទ្រព្យសម្បត្តិ និងភារកិច្ច ជាថ្មីម្ដងទៀតអ្នករាល់គ្នាបានជ្រើសរើសជម្រើសទីមួយ បើទោះជាខ្វះឆន្ទៈត្រឡប់ទៅច្រាំងវិញក៏ដោយ។[ក] រវាងភាពប្រណីត និងភាពក្រីក្រ អ្នករាល់គ្នាបានជ្រើសរើសជម្រើសទីមួយ។ នៅពេលជ្រើសរើសរវាងកូនប្រុស កូនស្រី ប្រពន្ធ និងស្វាមីរបស់អ្នក ហើយនិងខ្ញុំ អ្នករាល់គ្នាបានជ្រើសរើសយកជម្រើសទីមួយ ហើយរវាងគំនិត និងសេចក្ដីពិត អ្នកបានជ្រើសរើសយកជម្រើសទីមួយជាថ្មីម្ដងទៀត។ ខ្ញុំបានបាត់បង់ជំនឿលើអ្នករាល់គ្នាដោយសារអ្នករាល់គ្នាប្រឈមមុខនឹងអំពើអាក្រក់គ្រប់បែបយ៉ាង។ បញ្ហានេះធ្វើឱ្យខ្ញុំភ្ញាក់ផ្អើលជាខ្លាំង ដ្បិតចិត្តរបស់អ្នករាល់គ្នា ពិតជាពិបាកកែប្រែណាស់។ តាមរយៈការលះបង់ និងការខិតខំអស់រយៈពេលជាច្រើនឆ្នាំមកនេះ ពិតជាមិនបាននាំអ្វីមកឱ្យខ្ញុំសោះ ក្រៅពីការបោះបង់ចោល និងភាពអស់សង្ឃឹមរបស់អ្នករាល់គ្នានោះទេ ប៉ុន្ដែក្ដីសង្ឃឹមរបស់ខ្ញុំសម្រាប់អ្នករាល់គ្នា គឺចេះ តែចម្រើនឡើងជាមួយនឹងពេលវេលាដែលកន្លងផុតទៅរាល់ថ្ងៃ ដ្បិតពេលវេលាកំណត់របស់ខ្ញុំត្រូវបានបង្ហាញដល់មនុស្សគ្រប់គ្នា។ ប៉ុន្ដែ អ្នករាល់គ្នានៅតែព្យាយាមស្វែងរកភាពងងឹត និងការអាក្រក់នានា ហើយបដិសេធមិនព្រមបោះបង់វាចោលឡើយ។ ដូច្នេះ តើលទ្ធផលរបស់អ្នករាល់គ្នានឹងទៅជាយ៉ាងណា? តើអ្នករាល់គ្នាធ្លាប់បានគិតពិចារណា ដោយយកចិត្តទុកដាក់ចំពោះបញ្ហានេះទេ? ប្រសិនបើគេឲ្យអ្នករាល់គ្នាជ្រើសរើសម្ដងទៀត តើអ្វីជាគោលជំហររបស់អ្នករាល់គ្នា? តើវានៅតែជា

---

លេខយោង៖

ក. ត្រឡប់ទៅច្រាំងវិញ៖ សំនួនវោហារចិនមានន័យថា «ងាកចេញពីផ្លូវអាក្រក់របស់ខ្លួន»។

ជម្រើសទីមួយ ដដែលមែនទេ? តើអ្នករាល់គ្នានៅតែធ្វើឱ្យខ្ញុំខកចិត្ត និងសោកសៅបន្តទៀតទេ? តើដួងចិត្តអ្នករាល់គ្នា នៅតែស្ទើរក្ដៅស្ទើរត្រជាក់ដដែលមែនទេ? តើអ្នករាល់គ្នានៅតែមិនដឹងពីអ្វីដែលត្រូវធ្វើ ដើម្បីកម្សាន្តព្រះហឫទ័យខ្ញុំទេឬអី? នៅខណៈនេះ តើអ្នករាល់គ្នាជ្រើសរើសយកអ្វី? តើអ្នករាល់គ្នានឹងចុះចូលនឹងពាក្យរបស់ខ្ញុំ ឬធុញទ្រាន់នឹងពាក្យទាំងអស់នេះ? ពេលវេលារបស់ខ្ញុំ បានបង្ហាញផ្ទាល់នឹងភ្នែករបស់អ្នករាល់គ្នា ហើយអ្វីដែលអ្នករាល់គ្នាប្រឈម គឺជាជីវិតថ្មី និងជាចំណុចចាប់ផ្ដើមថ្មី។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំត្រូវតែប្រាប់អ្នករាល់គ្នាថាចំណុចចាប់ផ្ដើមនេះ មិនមែនជាការចាប់ផ្ដើមនៃការងារថ្មីពីអតីតកាលទេ ប៉ុន្តែជាការបញ្ចប់ការងារចាស់។ មានន័យថា នេះគឺជាសកម្មភាពចុងក្រោយ។ ខ្ញុំគិតថា អ្នកទាំងអស់គ្នាអាចយល់ពីអ្វីដែលមិនប្រក្រតីអំពីចំណុចចាប់ផ្ដើមនេះ។ ទោះយ៉ាងណានៅថ្ងៃណាមួយឆាប់ៗនេះ អ្នករាល់គ្នានឹងយល់អត្ថន័យពិតនៃចំណុចចាប់ផ្ដើមនេះដូច្នេះ ខ្ញុំនឹងបញ្ចប់កិច្ចការនេះរួមគ្នា ហើយស្វាគមន៍លទ្ធផលចុងក្រោយ ដែលនឹងត្រូវកើតឡើង។ យ៉ាងណាមិញ អ្វីដែលនៅតែធ្វើឲ្យខ្ញុំព្រួយបារម្ភអំពីអ្នករាល់គ្នានោះ គឺនៅពេលដែលអ្នករាល់គ្នាប្រឈមមុខនឹងភាពអយុត្តិធម៌ និងភាពយុត្តិធម៌ អ្នករាល់គ្នាតែងតែជ្រើសរើសយក ជម្រើសទីមួយដដែល។ នោះគ្រាន់តែជា អតីតកាលរបស់អ្នករាល់គ្នាប៉ុណ្ណោះ។ ខ្ញុំក៏សង្ឃឹមថានឹងអាចបំភ្លេចអ្វីៗទាំងអស់ពីអតីតកាលរបស់អ្នករាល់គ្នា ទោះបីវាពិបាកធ្វើក៏ដោយ។ ដូច្នេះខ្ញុំមានវិធីល្អក្នុងការដោះស្រាយបញ្ហានេះគឺ៖ យកអនាគតមកជំនួសអតីតកាល ហើយបណ្ដោយឱ្យស្រមោលអតីតកាលរបស់អ្នករាល់គ្នា ត្រូវបណ្ដេញចេញ ជាថ្នូរប្ដូរយកអត្តិភាពពិតរបស់អ្នករាល់គ្នានាពេលបច្ចុប្បន្ននេះវិញ។ ដូច្នេះខ្ញុំត្រូវតែរំអុកអ្នករាល់គ្នាឲ្យសម្រេចចិត្តជ្រើសរើសម្ដងទៀត៖ តើអ្នករាល់គ្នាស្មោះត្រង់នឹងអ្នកណាឱ្យប្រាកដ?

# អំពីទិសដៅ

នៅពេលដែលនិយាយអំពីទិសដៅ អ្នករាល់គ្នាចាត់ទុកវាថា ជារឿងដ៏ធ្ងន់ធ្ងរមួយ។ លើសពីនេះទៅទៀត វាគឺជាអ្វីមួយដែលអ្នករាល់គ្នាងាយនឹងដឹងបំផុត។ មនុស្សខ្លះមិនអាចរង់ចាំ ក្នុងការដាក់ក្បាលពួកគេទៅនឹងដី ដោយឱនក្រាបនៅចំពោះព្រះជាម្ចាស់ ដើម្បីទទួលបានទិសដៅល្អនោះទេ។ ខ្ញុំអាចកំណត់បាននូវភាពចង់បានរបស់អ្នករាល់គ្នាដោយមិនចាំបាច់អ្នកនិយាយចេញជាពាក្យសំដីនោះឡើយ។ ក្រៅពីនេះ អ្នករាល់គ្នាមិនចង់ឲ្យសាច់ឈាមរបស់អ្នកធ្លាក់ក្នុងគ្រោះមហន្តរាយ ហើយអ្នកនៅតែចង់ធ្លាក់ខ្លួនក្នុងការដាក់ទោសជារៀងរហូត នាពេលអនាគត។ អ្នករាល់គ្នាគ្រាន់តែសង្ឃឹមថា នឹងអនុញ្ញាតឲ្យខ្លួនឯងរស់នៅ ដោយសេរីជាងនេះបន្តិច ហើយកាន់តែងាយស្រួលប៉ុណ្ណោះ។ ដូច្នេះហើយអ្នករាល់គ្នាមានអារម្មណ៍រំជើបរំជួល ជាពិសេសនៅពេលនិយាយអំពីទិសដៅ ដោយភ័យខ្លាចជាខ្លាំងចំពោះវាសនា ហើយប្រសិនបើអ្នករាល់គ្នា មិនបានយកចិត្តទុកដាក់គ្រប់គ្រាន់ទេនោះ អ្នករាល់គ្នាអាចនឹងធ្វើឲ្យព្រះជាម្ចាស់អាក់អន់ព្រះទ័យ ដូច្នេះហើយអ្នករាល់គ្នានឹងត្រូវទទួលទោស ដែលអ្នកសមនឹងទទួល។ អ្នករាល់គ្នាមិនបានស្ទាក់ស្ទើរក្នុងការសម្រុះសម្រួល ដើម្បីជាប្រយោជន៍ដល់ទិសដៅរបស់អ្នកនោះទេ ហើយសូម្បីតែអ្នករាល់គ្នាភាគច្រើនដែលធ្លាប់ជាមនុស្សវង្វេង និងព្រហើន ក៏ស្រាប់តែក្លាយទៅជាសុភាពរាបសានិងស្មោះត្រង់មួយរំពេច។ លក្ខណៈនៃភាពស្មោះត្រង់របស់អ្នក ធ្វើអោយមនុស្សមានការភ្ញាក់ផ្អើលជាខ្លាំង។ ទោះយ៉ាងណាអ្នករាល់គ្នាសុទ្ធតែមានដួងចិត្តស្មោះត្រង់ ហើយអ្នកបានបើកចំហនៅចំពោះខ្ញុំ នូវអាថ៌កំបាំងក្នុងដួងចិត្តរបស់អ្នករាល់គ្នាជាប់ជានិច្ច ដោយមិនរក្សាទុកអ្វីទាំងអស់ ទោះបីវាជាការសោកសៅ ការបោកបញ្ឆោត ឬការលះបង់ក៏ដោយ។ សរុបមកអ្នករាល់គ្នាបាន «លន់តួ» យ៉ាងស្មោះត្រង់ចំពោះខ្ញុំ នូវរឿងរ៉ាវដែលស្ថិតនៅក្នុងការសម្រាកដ៏ស៊ីជម្រៅបំផុត នៃធម្មជាតិខាងក្នុងរបស់អ្នករាល់គ្នា។ ជាការពិត ខ្ញុំមិនដែលសសៀរជុំវិញរឿងរ៉ាវបែបនេះទេ សម្រាប់ខ្ញុំ រឿងរ៉ាវទាំងនេះធ្លាប់ស្គាល់ច្បាស់ហើយ។ អ្នករាល់គ្នាគួរតែ

ចូលទៅក្នុងសមុទ្រភ្លើង ដើម្បីជាប្រយោជន៍ដល់ទិសដៅចុងក្រោយរបស់អ្នក ជាជាងការបាត់បង់សក់តែមួយសរសៃដើម្បីទទួលការយល់ព្រមពីព្រះជាម្ចាស់។ វាមិនមែនថាខ្ញុំកំពុងម៉ឺងម៉ាត់នឹងអ្នករាល់គ្នាពេកនោះទេ។ គឺថា អ្នករាល់គ្នាកំពុងតែខ្វះខាតនូវភាពលះបង់នៅក្នុងចិត្ត ដើម្បីមកប្រឈមនឹងអ្វីដែលខ្ញុំបានធ្វើ។ អ្នករាល់គ្នាប្រហែលជាមិនយល់ពីអ្វីដែលខ្ញុំទើបតែមានព្រះបន្ទូលដូច្នេះខ្ញុំសូមផ្ដល់ឲ្យអ្នកនូវការពន្យល់ដ៏សាមញ្ញមួយ៖ អ្វីដែលអ្នករាល់គ្នាត្រូវការ មិនមែនជាសេចក្ដីពិត និងជីវិតនោះទេ ហើយក៏មិនមែនជាគោលការណ៍អំពីរបៀបនៃការប្រតិបត្តិខ្លួនឯងដែរ ក៏កាន់តែមិនមែនជាកិច្ចការធ្វើយ៉ាងផ្ចិតផ្ចង់របស់ខ្ញុំដែរ។ ផ្ទុយទៅវិញ អ្វីដែលអ្នកត្រូវការ គឺអ្វីគ្រប់យ៉ាងដែលអ្នករាល់គ្នាមាននៅក្នុងសាច់ឈាមទៅវិញទេ ដូចជាទ្រព្យសម្បត្តិ ស្ថានភាពគ្រួសារអាពាហ៍ពិពាហ៍ជាដើម។ អ្នករាល់គ្នាច្រានចោលនូវព្រះបន្ទូល និងកិច្ចការរបស់ខ្ញុំទាំងស្រុង ដូច្នេះខ្ញុំអាចសរុបសេចក្ដីជំនឿរបស់អ្នករាល់គ្នា ដោយព្រះបន្ទូលមួយម៉ាត់ថា៖ ធ្វើដើម្បីតែបង្គ្រប់កិច្ច។ អ្នករាល់គ្នានឹងប្រឹងប្រែងដើម្បីសម្រេចនូវអ្វីដែលអ្នករាល់គ្នាបានលះបង់ពិតប្រាកដប៉ុណ្ណោះ ប៉ុន្តែខ្ញុំបានរកឃើញថា អ្នករាល់គ្នានឹងមិនធ្វើដូចគ្នា ដើម្បីជាប្រយោជន៍នៃរឿងរ៉ាវដែលទាក់ទងនឹងជំនឿរបស់អ្នកលើព្រះជាម្ចាស់ទេ។ ផ្ទុយទៅវិញអ្នកមានភក្ដីភាព និងភាពស្មោះអស់ពីចិត្ត ដែលមិនជាក់លាក់។ នោះហើយជាមូលហេតុដែលខ្ញុំមានព្រះបន្ទូលថា អស់អ្នកដែលខ្វះដួងចិត្តស្មោះត្រង់បំផុត គឺជាអ្នកដែលបរាជ័យ ក្នុងជំនឿរបស់ខ្លួនលើព្រះជាម្ចាស់។ ចូរគិតឲ្យបានល្អិតល្អន់ តើមានអ្នកបរាជ័យច្រើនទេ ក្នុងចំណោមអ្នករាល់គ្នា?

អ្នកគប្បីដឹងថា ភាពជោគជ័យក្នុងជំនឿលើព្រះជាម្ចាស់ គឺសម្រេចបានដោយសារសកម្មភាពរបស់មនុស្សផ្ទាល់។ នៅពេលដែលមនុស្សមិនទទួលបានជោគជ័យ ប៉ុន្តែផ្ទុយទៅវិញបែរជាបរាជ័យ នោះក៏ដោយសារតែ សកម្មភាពរបស់ពួកគេផ្ទាល់ដែរ ហើយមិនមានកត្តាផ្សេងទៀតជះឥទ្ធិពលទៅលើសកម្មភាពទាំងនេះឡើយ។ ខ្ញុំជឿថា អ្នករាល់គ្នានឹងធ្វើអ្វីគ្រប់យ៉ាងដែលត្រូវការដើម្បីសម្រេចបាននូវអ្វីដែលកាន់តែលំបាក និងតម្រូវឲ្យរងទុក្ខកាន់តែច្រើនជាងការជឿលើព្រះជាម្ចាស់ ហើយថាអ្នករាល់គ្នានឹងធ្វើ

វាយ៉ាងខ្ជាប់ខ្ជួន ដូច្នេះអ្នកនឹងមិនបណ្ដោយឲ្យមានកំហុសណាមួយឡើយ។ ទាំងនេះគឺជាប្រភេទនៃការខិតខំប្រឹងប្រែងដោយមិនបន្ធូរ ដែលអ្នករាល់គ្នាបានធ្វើនៅក្នុងជីវិតរបស់អ្នក។ អ្នករាល់គ្នាថែមទាំងអាចបញ្ឆោតសាច់ឈាមរបស់ខ្ញុំ ក្នុងកាលៈទេសៈដែលអ្នកនឹងមិនបោកបញ្ឆោតសមាជិកណាម្នាក់នៃគ្រួសាររបស់អ្នកផ្ទាល់នោះ ឡើយ។ នេះគឺជាឥរិយាបទជាប់លាប់របស់អ្នករាល់គ្នា និងគោលការណ៍ ដែលអ្នករាល់គ្នារស់នៅ។ តើអ្នករាល់គ្នានៅតែមិនមានគម្រោងការខុសឆ្គងដោយបញ្ឆោតខ្ញុំដើម្បីជាប្រយោជន៍ដល់ទិសដៅរបស់អ្នករាល់គ្នា ដើម្បីឲ្យទិសដៅរបស់អ្នករាល់គ្នាបានស្រស់ស្អាត និងទៅតាមអ្វីដែលអ្នកចង់បានទេឬ? ខ្ញុំដឹងថាការលះបង់របស់អ្នកគឺដូចជាភាពស្មោះត្រង់របស់អ្នកគឺគ្រាន់តែជាបណ្ដោះអាសន្នប៉ុណ្ណោះ។ តើដំណោះស្រាយរបស់អ្នករាល់គ្នា និងតម្លៃដែលអ្នករាល់គ្នាត្រូវលះបង់ សម្រាប់តែប្រយោជន៍ពេលបច្ចុប្បន្ន និងមិនមែនសម្រាប់អនាគតទេឬអី? អ្នករាល់គ្នាគ្រាន់តែខិតខំប្រឹងប្រែងចុងក្រោយ ដើម្បីទទួលបានទិសដៅដ៏ស្រស់បំព្រង ដោយមានគោលបំណងតែធ្វើការដោះដូរប៉ុណ្ណោះ។ អ្នកមិនបានខិតខំប្រឹងប្រែងដើម្បីចៀសវាងជំពាក់នឹងសេចក្ដីពិតទេ ហើយកាន់តែមិនមែនដើម្បីជាការតបស្នងដល់ខ្ញុំ ចំពោះតម្លៃដែលខ្ញុំបានបង់នោះដែរ។ សរុបមក អ្នកមានបំណងបានត្រឹមតែប្រើល្បិចកលដ៏វៃឆ្លាតដើម្បីទទួលបានអ្វីដែលអ្នកចង់បានប៉ុណ្ណោះ ប៉ុន្តែមិនធ្វើសង្គ្រាមដោយបើកចំហសម្រាប់ការទាំងនោះទេ។ តើនេះមិនមែនជាក្ដីប្រាថ្នាចេញពីចិត្តរបស់អ្នករាល់គ្នាទេឬ? អ្នករាល់គ្នាមិនត្រូវបន្លំខ្លួនឯងហើយមិនត្រូវខំប្រឹងគិតខ្លាំងអំពីទិសដៅរបស់អ្នក រហូតដល់អ្នកមិនអាចបរិភោគ ឬគេងបាននោះឡើយ។ តើវាមិនពិតទេដែលថា លទ្ធផលរបស់អ្នកនឹងត្រូវបានកំណត់រួចជាស្រេចហើយ នៅចុងបញ្ចប់នោះ? អ្នករាល់គ្នានីមួយៗ គប្បីបំពេញភារកិច្ចផ្ទាល់ខ្លួនឲ្យអស់ពីសមត្ថភាពរបស់អ្នក ដោយដួងចិត្តបើកចំហ និងស្មោះត្រង់ ហើយមានឆន្ទៈក្នុងការបង់ថ្លៃនូវអ្វីដែលចាំបាច់។ ដូចដែលអ្នករាល់បាននិយាយហើយថានៅពេលថ្ងៃនោះមកដល់ ព្រះជាម្ចាស់នឹងមិនមានការធ្វេសប្រហែស ចំពោះនរណាម្នាក់ដែលបានរងទុក្ខ ឬបង់ថ្លៃដល់ទ្រង់នោះឡើយ។ ជំនឿដ៏មុតមាំបែបនេះ គឺគួរប្រកាន់ខ្ជាប់ ហើយ

វាជាការត្រឹមត្រូវដែលអ្នករាល់គ្នាមិនភ្លេចនូវជំនឿនេះ។ មានតែតាមវិធីនេះទេ ដែលខ្ញុំអាចលែងមានការព្រួយបារម្ភអំពីអ្នករាល់គ្នាទៀតបាន។ បើមិនដូច្នោះទេ អ្នករាល់គ្នានឹងក្លាយជាមនុស្សដែលខ្ញុំត្រូវព្រួយបារម្ភជារៀងរហូត ហើយអ្នកនឹងក្លាយជាវត្ថុនៃការស្អប់ខ្ពើមរបស់ខ្ញុំជារៀងរហូត។ ប្រសិនបើអ្នករាល់គ្នាអាចធ្វើតាមមនសិការរបស់អ្នក ហើយប្រគល់អ្វីៗទាំងអស់របស់អ្នកសម្រាប់ខ្ញុំ ធ្វើអ្វីតាមតែអាចធ្វើទៅបានសម្រាប់កិច្ចការរបស់ខ្ញុំ និងលះបង់ថាមពលពេញមួយជីវិតសម្រាប់កិច្ចការដំណឹងល្អរបស់ខ្ញុំ នោះតើព្រះហឫទ័យរបស់ខ្ញុំមិនមានការរីករាយជារឿយៗ ចំពោះអ្នករាល់គ្នាទេឬអី? តាមវិធីនេះ ខ្ញុំអាចនឹងលែងមានការព្រួយបារម្ភទាំងស្រុងចំពោះអ្នករាល់គ្នាទៀត តើអីចឹងមែនទេ? វាជាការអាម៉ាស់មួយ ដែលអ្វីដែលអ្នករាល់គ្នាអាចធ្វើបាន គឺគ្រាន់តែជាផ្នែកតូចមួយនៃអ្វីដែលខ្ញុំរំពឹងចង់បាននោះ។ បើសិនជាអីចឹងមែន តើអ្នករាល់គ្នាអាចស្វែងរកពីខ្ញុំ នូវអ្វីដែលអ្នករាល់គ្នាសង្ឃឹមចង់បានយ៉ាងដូចម្ដេចទៅ?

ទិសដៅ និងវាសនារបស់អ្នក មានសារៈសំខាន់ណាស់សម្រាប់អ្នករាល់គ្នា គឺវាសំខាន់ខ្លាំង។ អ្នករាល់គ្នាជឿថា ប្រសិនបើអ្នកមិនធ្វើអ្វីដោយយកចិត្តទុកដាក់ខ្ពស់ទេ វានឹងមានន័យថា អ្នកឈប់មានទិសដៅ ហើយថា អ្នកបានបំផ្លាញវាសនារបស់អ្នកហើយ។ ប៉ុន្តែតើវាធ្លាប់កើតឡើងចំពោះអ្នករាល់គ្នាទេ ដែលថាមនុស្សដែលខិតខំប្រឹងប្រែងដើម្បីតែទិសដៅរបស់ពួកគេ គឺកំពុងធ្វើការដោយឥតប្រយោជន៍នោះ? ការខិតខំបែបនេះមិនមានភាពពិតប្រាកដទេ ជាការខិតខំក្លែងក្លាយ និងបោកបញ្ឆោត។ ប្រសិនបើដូច្នោះមែន នោះអ្នកដែលធ្វើការដើម្បីតែទិសដៅរបស់ពួកគេ គឺស្ថិតនៅក្នុងកម្រិតនៃការបរាជ័យចុងក្រោយរបស់ពួកគេ ដ្បិតបរាជ័យក្នុងជំនឿរបស់មនុស្សម្នាក់ទៅលើព្រះជាម្ចាស់ គឺបណ្ដាលមកពីការបោកបញ្ឆោត។ ខ្ញុំធ្លាប់បានព្រះបន្ទូលពីមុនហើយថា ខ្ញុំមិនចូលចិត្តមានការអែបអប ឬលុតក្រាប ឬប្រព្រឹត្តចំពោះខ្ញុំដោយភាពស្ញើចសរសើរនោះទេ។ ខ្ញុំសព្វព្រះទ័យចំពោះមនុស្សស្មោះត្រង់ ដើម្បីទទួលនូវសេចក្ដីពិត និងការរំពឹងទុករបស់ខ្ញុំ។ លើសពីនេះទៅទៀត ខ្ញុំសព្វព្រះទ័យនៅពេលដែលមនុស្សអាចបង្ហាញការយកចិត្តទុកដាក់ និងការគិតពិចារណាខ្លាំងបំផុតចំពោះ

ដួងព្រះហឫទ័យរបស់ខ្ញុំ ហើយនិងពេលដែលពួកគេថែមទាំងអាចលះបង់អ្វីគ្រប់យ៉ាង ដើម្បីជាប្រយោជន៍ដល់ខ្ញុំ។ មានតែវិធីនេះទេ ដែលអាចធ្វើឲ្យដួងព្រះហឫទ័យខ្ញុំបាន ធូរស្បើយ។ ឥឡូវនេះ តើមានរឿងរ៉ាវប៉ុន្មានរបស់អ្នករាល់គ្នា ដែលខ្ញុំមិនសព្វព្រះទ័យ? តើមានរឿងរ៉ាវប៉ុន្មានរបស់អ្នករាល់គ្នា ដែលខ្ញុំសព្វព្រះទ័យ? តើអាចទេថា គ្មាននរណាម្នាក់ក្នុងចំណោមអ្នករាល់គ្នា បានដឹងពីការបើកសម្ដែងផ្សេងៗទាំងអស់ពីការអាក្រក់ ដែលអ្នករាល់គ្នាបានធ្វើ ដើម្បីជាប្រយោជន៍ដល់ទិសដៅរបស់អ្នក?

ក្នុងចិត្តខ្ញុំ ខ្ញុំមិនចង់ធ្វើឲ្យឈឺចាប់ដល់ដួងចិត្តនរណាម្នាក់ ដែលមានភាពវិជ្ជមាន និងសេចក្ដីប្រាថ្នាចង់បាន ហើយខ្ញុំកាន់តែមិនចង់ឲ្យថាមពលរបស់នរណាម្នាក់ ដែលបំពេញកាតព្វកិច្ចរបស់ខ្លួនដោយស្មោះត្រង់ មានការធ្លាក់ចុះនោះឡើយ។ ទោះយ៉ាងណា ខ្ញុំត្រូវតែរំលឹកអ្នករាល់គ្នាម្នាក់ៗពីភាពមិនគ្រប់គ្រាន់របស់អ្នក និងពីព្រលឹងដែលស្មោកគ្រោក ដែលស្ថិតនៅក្នុងជម្រៅជ្រៅបំផុតនៃដួងចិត្តរបស់អ្នករាល់គ្នា។ ខ្ញុំធ្វើដូច្នេះ ដោយសង្ឃឹមថាអ្នករាល់គ្នានឹងអាចថ្វាយនូវដួងចិត្តដ៏ពិតរបស់អ្នក ក្នុងការចូលមកកាន់ព្រះបន្ទូលរបស់ខ្ញុំដោយផ្ទាល់ ព្រោះអ្វីដែលខ្ញុំស្អប់បំផុត គឺការបោកបញ្ឆោតរបស់មនុស្សចំពោះខ្ញុំ។ ខ្ញុំគ្រាន់តែសង្ឃឹមថា ក្នុងដំណាក់កាលចុងក្រោយនៃកិច្ចការរបស់ខ្ញុំ អ្នករាល់គ្នានឹងអាចផ្ដល់ឲ្យនូវស្នាដៃដ៏លេចធ្លោបំផុតរបស់អ្នក ហើយអ្នកនឹងលះបង់ខ្លួនឯងអស់ពីដួងចិត្ត ហើយលែងមានបេះដូងមួយចំហៀងទៀតហើយ។ ជាការពិត ខ្ញុំក៏សង្ឃឹមថាអ្នករាល់គ្នា អាចមានទិសដៅល្អទាំងអស់គ្នា។ ទោះយ៉ាងណា ខ្ញុំនៅតែមានសេចក្ដីតម្រូវរបស់ខ្ញុំ ដែលសម្រាប់អ្នករាល់គ្នាធ្វើការសម្រេចចិត្តដ៏ល្អបំផុត ក្នុងការថ្វាយដល់ខ្ញុំ នូវការលះបង់តែមួយ និងចុងក្រោយរបស់អ្នក។ ប្រសិនបើនរណាម្នាក់ មិនមានការលះបង់តែមួយនោះទេ នោះគេប្រាកដជាជាកម្មសិទ្ធិរបស់សាតាំងហើយខ្ញុំនឹងមិនទុកគេប្រើទៀតទេ ប៉ុន្តែនឹងបញ្ជូនគេទៅផ្ទះ ដើម្បីទទួលការមើលថែពីសំណាក់ឪពុកម្ដាយរបស់គេ។ កិច្ចការរបស់ខ្ញុំ គឺជាជំនួយដ៏អស្ចារ្យដល់អ្នករាល់គ្នា។ អ្វីដែលខ្ញុំសង្ឃឹមថា នឹងទទួលបានពីអ្នករាល់គ្នា គឺជាដួងចិត្តដែលស្មោះត្រង់ ហើយប្រាថ្នាខ្ពស់ ប៉ុន្តែរហូតមកដល់ពេលនេះ ព្រះហស្តរបស់ខ្ញុំនៅទំនេរនៅឡើយ។ ចូរគិតអំពីការនេះ៖

ប្រសិនបើថ្ងៃណាមួយខ្ញុំនៅតែមានការសោកសៅខ្លាំងហួសពីកម្រិតនៃពាក្យដែលត្រូវរៀបរាប់ តើពេលនោះអាកប្បកិរិយារបស់ខ្ញុំចំពោះអ្នករាល់គ្នានឹងទៅជាយ៉ាងណា? តើនៅពេលនោះ ខ្ញុំគួរឲ្យគោរពនៅចំពោះអ្នក ដូចពេលឥឡូវនេះដែរឬទេ? តើនៅពេលនោះ ព្រះហឫទ័យខ្ញុំ នឹងស្ងប់ស្ងាត់ដូចពេលឥឡូវនេះទេ? តើអ្នករាល់គ្នាយល់ពីអារម្មណ៍របស់មនុស្សម្នាក់ដែលបានភ្ជួររាស់ដីយ៉ាងផ្ចិតផ្ចង់ ដោយមិនបានប្រមូលផលសូម្បីតែមួយគ្រាប់ទេ? តើអ្នកដឹងទេថាតើដួងចិត្តរបស់មនុស្សម្នាក់ត្រូវបានរងរបួសយ៉ាងដូចម្ដេច នៅពេលដែលគេត្រូវបានគេធ្វើបាបយ៉ាងខ្លាំងនោះ? តើអ្នករាល់គ្នាអាចភ្លក្សរសជាតិជូរចត់របស់មនុស្សម្នាក់បានទេ នៅពេលដែលគេពោរពេញដោយក្ដីសង្ឃឹម តើអ្នកណាដែលនៅចំណែកដែលមិនល្អទៅ? តើអ្នករាល់គ្នាបានឃើញនូវកំហឹង ចេញពីមនុស្សម្នាក់ដែលត្រូវបានគេធ្វើឲ្យខឹងដែរឬទេ? តើអ្នករាល់គ្នាអាចដឹងពីការចង់សងសឹករបស់មនុស្សម្នាក់ ដែលត្រូវបានធ្វើបាបដោយខ្មាំងសត្រូវ និងការបោកបញ្ឆោតទេ? ប្រសិនបើអ្នករាល់គ្នា យល់ពីចិត្តគំនិតរបស់មនុស្សទាំងនេះ នោះខ្ញុំគិតថាវាមិនគួរពិបាកសម្រាប់អ្នករាល់គ្នា ដើម្បីស្រមៃមើលអាកប្បកិរិយាដែលព្រះជាម្ចាស់នឹងមាន នៅពេលនៃការដាក់ទោសរបស់ទ្រង់នោះទេ! ជាចុងបញ្ចប់ ខ្ញុំសង្ឃឹមថាអ្នករាល់គ្នាខិតខំប្រឹងប្រែងយ៉ាងខ្លាំងដើម្បីជាប្រយោជន៍ដល់ទិសដៅរបស់អ្នកផ្ទាល់ ទោះបីអ្នកមិនបានប្រើមធ្យោបាយបោកបញ្ឆោតក្នុងកិច្ចប្រឹងប្រែងរបស់អ្នកក៏ដោយ បើមិនដូច្នេះទេ ខ្ញុំនឹងនៅតែខកព្រះទ័យនឹងអ្នករាល់គ្នានៅក្នុងព្រះហឫទ័យរបស់ខ្ញុំ។ ហើយតើការខកចិត្តបែបនេះ នាំឲ្យមាន អ្វី? តើអ្នករាល់គ្នាមិនបំភាន់ខ្លួនឯងទេឬអី? អស់អ្នកណាដែលគិតដល់ទិសដៅរបស់ខ្លួន តែបំផ្លាញវា គឺជាមនុស្សដែលមិនអាចបានសង្គ្រោះឡើយ។ ទោះបីគេមានការខឹង និងអន់ចិត្តក៏ដោយ តើនរណានឹងអាណិតដល់មនុស្សបែបនេះ? សរុបសេចក្ដីមក ខ្ញុំនៅតែចង់ឲ្យអ្នករាល់គ្នាមានទិសដៅទាំងសមរម្យផង ទាំងល្អផង ហើយលើសពីនេះ ខ្ញុំសង្ឃឹមថាគ្មានអ្នកណាម្នាក់ក្នុងចំណោមអ្នករាល់គ្នានឹងធ្លាក់ទៅក្នុងគ្រោះមហន្តរាយឡើយ។

# សេចក្ដីដាស់តឿនទាំងបី

ក្នុងនាមជាអ្នកជឿលើព្រះជាម្ចាស់ អ្នកគប្បីត្រូវមានភក្ដីភាព ចំពោះព្រះជាម្ចាស់តែមួយអង្គគត់នៅក្នុងកិច្ចការគ្រប់យ៉ាង ហើយស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ នៅក្នុងកិច្ចការគ្រប់យ៉ាងទាំងនោះ។ យ៉ាងណាក៏ដោយ ទោះបីជាមនុស្សគ្រប់រូប យល់ពីសារនេះក៏ដោយ ដោយសារតែ ភាពលំបាកផ្សេងៗរបស់មនុស្ស ភាពអវិជ្ជាភាពល្ងង់ខ្លៅ និងសេចក្ដីពុករលួយជាដើម ទើបសេចក្ដីពិតទាំងនេះ ដែលងាយនឹងមើលឃើញបំផុត និងជាមូលដ្ឋានចាំបាច់នៃកិច្ចការគ្រប់យ៉ាង មិនឃើញមាននៅក្នុងខ្លួនពួកគេទាំងស្រុងឡើយ។ ហេតុដូច្នេះ មុននឹងទីបញ្ចប់របស់អ្នករាល់គ្នាត្រូវបានកំណត់ ខ្ញុំគួរតែប្រាប់អ្នករាល់គ្នានូវរឿងមួយចំនួន ដែលមានសារៈសំខាន់បំផុតចំពោះអ្នករាល់គ្នាជាមុនសិន។ មុននឹងខ្ញុំបន្ត អ្នករាល់គ្នា គប្បីត្រូវយល់អំពីសេចក្ដីនេះសិន គឺថាអ្វីដែលខ្ញុំនិយាយ គឺជាសេចក្ដីពិតដែលសំដៅលើមនុស្សជាតិគ្រប់រូប។ ពាក្យសម្ដីទាំងនេះ មិនសំដៅទៅលើតែចំពោះបុគ្គល ឬប្រភេទនៃមនុស្សជាក់លាក់ណាមួយនោះទេ។ ដូច្នេះ អ្នករាល់គ្នា គប្បីត្រូវផ្ដោតការយល់ដឹងលើពាក្យសម្ដីរបស់ខ្ញុំ តាមទស្សនៈនៃសេចក្ដីពិត ហើយត្រូវតែមានអាកប្បកិរិយា ដែលមានការយកចិត្តទុកដាក់មិនបែងចែក និង មានភាពស្មោះត្រង់។ ហេតុនេះហើយ កុំព្រងើយកន្ដើយនឹងពាក្យសម្ដី ឬសេចក្ដីពិតដែលខ្ញុំនិយាយសូម្បីមួយពាក្យឡើយ ហើយមិនត្រូវមើលស្រាលលើរាល់ពាក្យសម្ដីទាំងអស់ ដែលខ្ញុំនិយាយឡើយ។ នៅក្នុងជីវិតរបស់អ្នករាល់គ្នា ខ្ញុំឃើញថាអ្នករាល់គ្នាបានធ្វើអ្វីៗជាច្រើន ដែលមិនទាក់ទងនឹងសេចក្ដីពិត ហេតុដូច្នេះខ្ញុំសូមស្នើយ៉ាងជាក់លាក់ ឱ្យអ្នករាល់គ្នាក្លាយជាអ្នកបម្រើនៃសេចក្ដីពិត ស្នើឲ្យអ្នកកុំឲ្យភាពកំណាច និងសេចក្ដីអាក្រក់គ្រប់គ្រងលើអ្នកបាន និងដើម្បីកុំឲ្យអ្នកជាន់ឈ្លីលើសេចក្ដីពិត ឬប្រមាថជ្រុងណាមួយនៃព្រះដំណាក់របស់ព្រះជាម្ចាស់ឡើយ។ នេះជាសេចក្ដីក្រើនរំលឹករបស់ខ្ញុំចំពោះអ្នករាល់គ្នា។ ឥឡូវនេះ ខ្ញុំនឹងនិយាយ អំពីប្រធានបទនៃសេចក្ដីពិតទាំងនេះ។

ទីមួយ ដើម្បីជាប្រយោជន៍នៃគោលដៅរបស់អ្នករាល់គ្នា នោះអ្នករាល់គ្នាគប្បីត្រូវស្វែងរកការយល់ព្រម ពីព្រះជាម្ចាស់។ នេះគឺមានន័យថា ដោយសារអ្នករាល់គ្នាទទួលស្គាល់ថា អ្នកជាសមាជិកម្នាក់នៃព្រះដំណាក់របស់ព្រះជាម្ចាស់ នោះអ្នករាល់គ្នាគប្បីធ្វើឲ្យព្រះហឫទ័យរបស់ព្រះជាម្ចាស់ ស្ងប់សុខ ហើយបំពេញតាមព្រះហឫទ័យទ្រង់ នៅក្នុងគ្រប់កិច្ចការទាំងអស់។ អាចនិយាយម្យ៉ាងទៀតបានថាអ្នកត្រូវតែមានគោលការណ៍ក្នុងគ្រប់ទង្វើរបស់អ្នក ហើយអនុលោមតាមសេចក្ដីពិត នៅក្នុងទង្វើទាំងនោះ។ ប្រសិនបើអ្នកធ្វើរឿងនេះមិនបាន នោះអ្នកនឹងត្រូវព្រះជាម្ចាស់ស្អប់ខ្ពើម និងបដិសេធចោល ហើយនឹងត្រូវមនុស្សគ្រប់រូបច្រានចេញមិនខាន។ នៅពេលដែលអ្នក បានធ្លាក់ចូលទៅក្នុងស្ថានភាពលំបាកបែបនេះ អ្នកមិនអាចត្រូវបានរាប់បញ្ចូលចូលជាសមាជិកក្នុងដំណាក់របស់ព្រះជាម្ចាស់បានទេ ដែលនេះជាអត្ថន័យនៃការដែលមិនទទួលបានការយល់ព្រមពីព្រះជាម្ចាស់។

ទីពីរ អ្នករាល់គ្នាត្រូវដឹងថាព្រះជាម្ចាស់ សព្វព្រះហឫទ័យនឹងមនុស្សទៀងត្រង់។ ធាតុពិត ព្រះជាម្ចាស់គឺស្មោះត្រង់ ហេតុដូច្នេះ ព្រះបន្ទូលរបស់ព្រះអង្គតែងតែអាចទុកចិត្តបានជានិច្ច។ លើសពីនេះទៅទៀត ទង្វើរបស់ព្រះជាម្ចាស់គឺគ្មានកំហុស និងមិនអាចប្រកែកបានឡើយ ដែលនេះជាមូលហេតុនាំឱ្យព្រះជាម្ចាស់ សព្វព្រះហឫទ័យនឹងមនុស្សទាំងឡាយ ដែលស្មោះត្រង់នឹងទ្រង់។ ភាពស្មោះត្រង់ គឺមានន័យថាអ្នកប្រគល់ដួងចិត្តរបស់អ្នកថ្វាយដល់ព្រះជាម្ចាស់ មានភាពស្មោះត្រង់ពិតប្រាកដចំពោះព្រះជាម្ចាស់ ក្នុងកិច្ចការគ្រប់យ៉ាងមិនលាក់បាំងសេចក្ដីពិត មិនព្យាយាមបោកបញ្ឆោតអ្នកដែលនៅខាងលើ និងខាងក្រោមអ្នក ហើយមិនធ្វើអ្វីដែលគ្រាន់តែដើម្បីចង់បានការគាំទ្រពីព្រះជាម្ចាស់។ សរុបសេចក្ដីមក ដើម្បីមានភាពស្មោះត្រង់គឺត្រូវមានភាពបរិសុទ្ធនៅក្នុងទង្វើ និងពាក្យសម្ដីរបស់អ្នក ហើយក៏មិនបោកបញ្ឆោតព្រះជាម្ចាស់ និងមនុស្សទាំងឡាយដែរ។ អ្វីដែលខ្ញុំនិយាយ គឺងាយស្រួលណាស់ ប៉ុន្តែចំពោះអ្នកវិញ វាពិបាកក្រៃលែង ព្រោះមនុស្សជាច្រើនសុខចិត្តឲ្យគេដាក់ទោសទៅកាន់ឋាននរកជាជាងនិយាយ និងប្រព្រឹត្តិដោយស្មោះត្រង់។ គ្មានអ្វីប្លែកទេដែលខ្ញុំ

មានការតបស្នងផ្សេងទៀតនៅក្នុងដៃរបស់អ្នកដែលមិនស្មោះត្រង់។ ជាការពិត ខ្ញុំដឹងយ៉ាងច្បាស់ថាវាពិបាកយ៉ាងណាសម្រាប់អ្នករាល់គ្នា ដើម្បីឲ្យមាន ភាពស្មោះ ត្រង់។ ដោយសារតែអ្នករាល់គ្នាមានភាពឆ្លាតវៃទាំងអស់គ្នា ហេតុដូច្នេះ អ្នករាល់គ្នាពូកែខាង ការវាស់ស្ទង់មនុស្ស ដោយប្រើគោលការណ៍ថ្នាក់ទាបផ្ទាល់ខ្លួន របស់អ្នករាល់គ្នា ដែលនេះធ្វើឱ្យការងាររបស់ខ្ញុំមានភាពសាមញ្ញច្រើន។ ហើយចាប់តាំងពីអ្នករាល់គ្នាឱបអាថ៌កំបាំងរបស់ខ្លួននៅក្នុងដើមទ្រូងរបស់អ្នករាល់គ្នា នោះខ្ញុំនឹងបញ្ជូនអ្នករាល់គ្នាម្ដងមួយៗចូលទៅក្នុងគ្រោះមហន្តរាយ ដើម្បីឲ្យទទួលបាន «ការអប់រំ» ដោយភ្លើង ដើម្បីឲ្យក្រោយមក អ្នករាល់គ្នាអាចនឹងស្លាប់ចិត្តនៅក្នុងជំនឿលើពាក្យសម្ដីរបស់ខ្ញុំ។ នៅទីបំផុត ខ្ញុំនឹងឮពាក្យសម្ដីចេញពីមាត់របស់អ្នករាល់គ្នាថា «ព្រះជាម្ចាស់ជាព្រះដ៏ស្មោះត្រង់» ដែលអ្នករាល់គ្នានឹងទះទ្រូង និងវាចាដោយកំសត់ថា «ភាពពុតត្បុត គឺជាបេះដូងរបស់មនុស្ស!»។ តើអ្វីទៅជាសណ្ឋាននៃចិត្តរបស់អ្នករាល់គ្នានៅពេលនេះ? ខ្ញុំនឹកស្រម៉ៃថា អ្នករាល់គ្នា នឹងមិនមានភាពជោគជ័យដូចនៅពេលឥឡូវនេះទេ។ ហើយអ្នកនឹងមិនសូវមាន «ភាពជ្រាលជ្រៅ និងភាពងងឹតងងល់» ដូចអ្នកនៅពេលឥឡូវនេះទេ។ ក្រោមវត្តមាននៃព្រះជាម្ចាស់ មនុស្សមួយចំនួនសុទ្ធតែមានលក្ខណៈសមសួន និងត្រឹមត្រូវ។ ពួកគេទទួលរងការឈឺចាប់ដើម្បីមាន «អាកប្បកិរិយាល្អ» ប៉ុន្តែពួកគេហ៊ានយកចង្កូម និងប្រើក្រញាំរបស់ពួកគេនៅចំពោះវត្តមាននៃព្រះវិញ្ញាណ។ តើអ្នកនឹងរាប់បញ្ចូលមនុស្សបែបនេះ ក្នុងចំណោម ជួរនៃមនុស្សស្មោះត្រង់បានដែរឬទេ? ប្រសិនបើអ្នករាល់គ្នា ជាមនុស្សលាក់ពុតដែលមានជំនាញក្នុង «ទំនាក់ទំនងរវាងបុគ្គល» នោះខ្ញុំនិយាយថា អ្នកពិតជាមនុស្សម្នាក់ដែលព្យាយាមលេងសើចនឹងព្រះជាម្ចាស់។ ប្រសិនបើពាក្យសម្ដីរបស់អ្នករអាក់រអួលជាមួយនឹងការដោះសារ និងយុត្តិកម្មដែលគ្មានតម្លៃ នោះខ្ញុំនិយាយថាអ្នកជាមនុស្សដែលស្អប់ខ្ពើមក្នុងការអនុវត្តសេចក្ដីពិត។ ប្រសិនបើអ្នកមានការសម្ងាត់ច្រើនដែលមិនចង់ចែករំលែកប្រសិនបើអ្នកមិនពេញចិត្តក្នុងការលាតត្រដាងអាថ៌កំបាំងរបស់អ្នក ការលំបាករបស់អ្នកចំពោះមុខអ្នកដទៃ ដើម្បីស្វែងរកផ្លូវនៃពន្លឺទេ នោះខ្ញុំនិយាយថាអ្នកជាមនុស្សដែលមិនទទួល

បានការសង្គ្រោះដោយងាយទេ ហើយនឹងមិនងាយចេញផុតពីភាពងងឹតបានឡើយ។ ប្រសិនបើការស្វែងរកផ្លូវនៃសេចក្ដីពិត ធ្វើឲ្យអ្នកពេញចិត្ត នោះអ្នកជាមនុស្សម្នាក់ដែលតែងតែរស់នៅក្នុងពន្លឺជានិច្ច។ ប្រសិនបើអ្នកសប្បាយចិត្តខ្លាំង នៅពេលដែលបានធ្វើជាអ្នកបម្រើនៅក្នុងដំណាក់នៃព្រះជាម្ចាស់ បំពេញការងារដោយភាពឧស្សាហ៍ព្យាយាម និងមានមនសិការនៅក្នុងភាពងងឹត តែងតែផ្ដល់និងមិនដែលទទួលយកវិញ នោះខ្ញុំនិយាយថាអ្នកជាបុគ្គលបរិសុទ្ធដោយភក្ដីភាពពីព្រោះអ្នកមិនស្វែងរករង្វាន់តបស្នង ហើយនិយាយដោយសាមញ្ញ ជាមនុស្សម្នាក់ដែលស្មោះត្រង់។ ប្រសិនបើអ្នកមានឆន្ទៈក្នុងការនិយាយដោយស្មោះត្រង់ ប្រសិនបើអ្នកមានឆន្ទៈក្នុងការចំណាយអ្វីៗទាំងអស់របស់អ្នក ប្រសិនបើអ្នកអាចបូជាជីវិតរបស់អ្នកសម្រាប់ព្រះជាម្ចាស់ និងឈរយ៉ាងរឹងមាំក្នុងទីបន្ទាល់របស់អ្នក ប្រសិនបើអ្នកមានភាពស្មោះត្រង់ក្នុងកម្រិតដែលអ្នកត្រឹមតែដឹងថា ដើម្បីបំពេញតាមព្រះហឫទ័យព្រះជាម្ចាស់ និងមិនគិតអំពីខ្លួនឯង ឬទាមទារយកសម្រាប់ខ្លួនឯងនោះឡើយ នោះខ្ញុំនិយាយថាមនុស្សបែបនេះគឺជាមនុស្សដែលត្រូវបានចិញ្ចឹមដោយពន្លឺ និងជាមនុស្សដែលត្រូវរស់នៅជារៀងរហូតក្នុងនគរព្រះ។ អ្នកគប្បីដឹងថាតើមានសេចក្ដីជំនឿពិត និងភក្ដីភាពពិតនៅក្នុងខ្លួនរបស់អ្នកដែរឬទេ តើអ្នកមានកំណត់ត្រានៃការរងទុក្ខ ដើម្បីព្រះជាម្ចាស់ដែរឬទេ និងថាតើអ្នកបានប្រគល់ខ្លួនទាំងមូលដល់ព្រះជាម្ចាស់ដែរឬទេ។ ប្រសិនបើអ្នកខ្វះខាតនូវរបស់ទាំងនេះ នោះនៅក្នុងខ្លួនអ្នកមានតែការមិនស្ដាប់បង្គាប់ ការបោកប្រាស់ ការលោភលន់ និងការស្ដីបន្ទោសប៉ុណ្ណោះ។ ដោយសារចិត្តរបស់អ្នកនៅឆ្ងាយពីភាពស្មោះត្រង់ អ្នកមិនដែលបានការទទួលស្គាល់ជាវិជ្ជមានពីព្រះជាម្ចាស់ឡើយ និងមិនដែលបានរស់នៅក្នុងពន្លឺនោះទេ។ ជោគវាសនារបស់មនុស្សម្នាក់នឹងក្លាយទៅជាយ៉ាងណានៅទីបញ្ចប់ ក្រោយពេលដែលពួកគេមានចិត្តស្មោះត្រង់ និងឈាមក្រហម និងក្រោយពេលដែលពួកគេមានដួងព្រលឹងបរិសុទ្ធ។ ប្រសិនបើអ្នកជាមនុស្សម្នាក់ដែលគ្មានភាពស្មោះត្រង់ខ្លាំង ជាមនុស្សដែលមានចិត្តនៃការព្យាបាទ ជាមនុស្សដែលមាន ដួងព្រលឹងមិនស្អាត នោះអ្នកប្រាកដជា ត្រូវបញ្ចប់ នៅទីកន្លែងដែលមនុស្សត្រូវបានដាក់ទណ្ឌកម្មទៅតាម

អំពើដែលត្រូវបានកត់ត្រា ក្នុងកំណត់ត្រានៃជោគវាសនារបស់អ្នក។ ប្រសិនបើអ្នកអះអាងថា អ្នកជាមនុស្សស្មោះត្រង់ណាស់ ប៉ុន្តែ មិនរៀបចំការប្រព្រឹត្តិទៅតាមសេចក្ដីពិត ឬនិយាយពាក្យសម្ដីទៅតាមសេចក្ដីពិតនោះទេ តើអ្នកនៅតែរង់ចាំព្រះជាម្ចាស់ប្រទានរង្វាន់ដល់អ្នកមែនទេ? តើអ្នកនៅតែសង្ឃឹមថា ព្រះជាម្ចាស់ចាត់ទុកអ្នកជាវត្ថុសំខាន់ ក្នុងកែវព្រះនេត្ររបស់ព្រះជាម្ចាស់មែនទេ? តើការគិតបែបនេះ គឺមិនសមហេតុផលទេ មែនទេ? អ្នកបំភ័ន្តព្រះជាម្ចាស់ក្នុងកិច្ចការគ្រប់យ៉ាងទាំងអស់ តើព្រះដំណាក់នៃព្រះជាម្ចាស់អាចផ្ដល់ជាកន្លែងស្នាក់អាស្រ័យដល់បុគ្គលដូចជាអ្នកដែលមានដៃកខ្វក់បែបហ្នឹងដូចម្ដេចបាន?

រឿងទីបីដែលខ្ញុំចង់ប្រាប់អ្នករាល់គ្នាគឺដូច្នេះ៖ នៅក្នុងដំណើរជីវិតនៃការរស់នៅរបស់មនុស្សគ្រប់រូប ដែលមានសេចក្ដីជំនឿលើព្រះជាម្ចាស់ ពួកគេបានធ្វើកិច្ចការដែលប្រឆាំង និងបោកបញ្ឆោតព្រះជាម្ចាស់។ អំពើអាក្រក់ខ្លះ គឺមិនចាំបាច់កត់ត្រាថាជាបទល្មើសទេ ប៉ុន្តែ ខ្លះទៀតមិនអាចលើកលែងទោសបានឡើយ។ មានអំពើជាច្រើនដែលរំលោភបញ្ញត្តិរដ្ឋបាលដែលនេះជាការប្រមាថដល់និស្ស័យរបស់ព្រះជាម្ចាស់។ មនុស្សជាច្រើនដែលព្រួយបារម្ភ អំពីជោគវាសនារបស់ពួកគេផ្ទាល់ អាចចោទសួរថា តើអំពើទាំងនោះមានអ្វីខ្លះ។ អ្នករាល់គ្នាគប្បីដឹងថា អ្នករាល់គ្នាជាមនុស្សក្រអឺតក្រទម និងឆ្មើងឆ្មៃពីកំណើតមក និងមិនមានឆន្ទៈក្នុងការប្រគល់ខ្លួនចំពោះសេចក្ដីពិតទេ។ ក្នុងហេតុផលនេះ ខ្ញុំនឹងប្រាប់អ្នករាល់គ្នាបន្តិចម្ដងៗ បន្ទាប់ពីអ្នករាល់គ្នាបានឆ្លុះបញ្ចាំងឃើញដោយខ្លួនឯង។ ខ្ញុំសូមដាស់តឿនអ្នករាល់គ្នា ឲ្យបានយល់ច្បាស់អំពីសារជាតិនៃបញ្ញត្តិរដ្ឋបាល និងឱ្យខិតខំប្រឹងប្រែងដើម្បីយល់ដឹងអំពីនិស្ស័យរបស់ព្រះជាម្ចាស់។ បើមិនដូច្នោះទេ អ្នករាល់គ្នានឹងពិបាកក្នុងការរក្សាបបូរមាត់ឲ្យបិទជិតអណ្ដាតរបស់អ្នករាល់គ្នានឹងគ្រលាស់ដោយសេរីជាមួយនឹងការនិយាយដោយបន្លឺសំឡេងខ្លាំងៗ ហើយអ្នករាល់គ្នានឹងបំពានចំពោះនិស្ស័យរបស់ព្រះជាម្ចាស់ដោយមិនដឹងខ្លួន ព្រមទាំងធ្លាក់ចូលទៅក្នុងភាពងងឹត បាត់បង់វត្តមាននៃព្រះវិញ្ញាណបរិសុទ្ធ និងពន្លឺផង។ ដោយសារតែអ្នករាល់គ្នា គ្មានគោលការណ៍នៅក្នុងសកម្មភាពរបស់ខ្លួន

ដោយសារតែអ្នកធ្វើ និងនិយាយអ្វីដែលអ្នកមិនគួរធ្វើ អ្នកនឹងទទួលការដាក់ទោសវិញ ដោយសក្ដិសម។ អ្នកគប្បីដឹងថា ទោះបីជាអ្នកគ្មានគោលការណ៍នៅក្នុងពាក្យសម្ដី និងការប្រព្រឹត្តិក៏ដោយ តែព្រះជាម្ចាស់មានគោលការណ៍ខ្ពស់នៅក្នុងកិច្ចការទាំងពីរយ៉ាងនេះ។ មូលហេតុដែលអ្នកទទួលការដាក់ទោសនេះ គឺដោយសារតែអ្នកបានល្មើសនឹងព្រះជាម្ចាស់ មិនមែនបុគ្គលណាម្នាក់ទេ។ ប្រសិនបើនៅក្នុងជីវិតរបស់អ្នក អ្នកប្រព្រឹត្តអំពើល្មើសច្រើនប្រឆាំងនឹងនិស្ស័យរបស់ព្រះជាម្ចាស់ នោះអ្នកត្រូវបានចងភ្ជាប់ទៅក្នុងការក្លាយខ្លួនជាកូននៃនរក។ ចំពោះមនុស្ស វាអាចលេចឡើងថាអ្នកបានប្រព្រឹត្តិអំពើមួយចំនួនតូចដែលខុសឆ្គងនឹងសេចក្ដីពិត និងគ្មានអ្វីលើសពីនេះទៀតទេ។ ថ្វីបើបែបនេះក៏ដោយ តើអ្នកដឹងទេថានៅក្នុងព្រះនេត្ររបស់ព្រះជាម្ចាស់ អ្នកបានក្លាយខ្លួនជាមនុស្សម្នាក់ ដែលបានរួចពីអំពើបាបហើយ? ដោយសារតែអ្នកបានរំលោភបញ្ញត្តិរដ្ឋបាលរបស់ព្រះជាម្ចាស់ច្រើនជាងមួយដង ហើយលើសពីនេះទៅទៀតអ្នកមិនបានបង្ហាញពីសញ្ញានៃការសោកស្ដាយឡើយ ហេតុដូច្នេះ គ្មានអ្វីជាគ្រឿងពឹងអាស្រ័យផ្សេងសម្រាប់អ្នកឡើយ គឺមានតែត្រូវធ្លាក់ចូលទៅក្នុងឋាននរក ដែលជាទីកន្លែង សម្រាប់ព្រះជាម្ចាស់ដាក់ទោសមនុស្សតែប៉ុណ្ណោះ។ មនុស្សមួយចំនួនតូចដែលដើរតាមព្រះជាម្ចាស់ បានប្រព្រឹត្តអំពើមួយចំនួន ដែលរំលោភនឹងគោលការណ៍ ប៉ុន្ដែបន្ទាប់ពីបានដោះស្រាយ និងផ្ដល់ការណែនាំដល់ពួកគេ ពួកគេបានរកឃើញបន្តិចម្ដងៗ នូវសេចក្ដីពុករលួយផ្ទាល់ខ្លួនរបស់ពួកគេ ហើយបន្ទាប់មកទៀត បានដើរលើផ្លូវត្រូវនៃភាពពិត ហើយពួកគេរក្សាបាននូវជំហររឹងមាំដូចសព្វថ្ងៃនេះ។ មនុស្សបែបនេះ គឺជាបុគ្គលដែលនឹងត្រូវបន្តរស់នៅដល់ទីបញ្ចប់។ ទោះបីជាយ៉ាងនេះក៏ដោយ វាជាភាពស្មោះត្រង់ដែលខ្ញុំស្វែងរក។ ប្រសិនបើអ្នកជាមនុស្សស្មោះត្រង់ និងជាមនុស្សម្នាក់ដែលប្រព្រឹត្តតាមគោលការណ៍ នោះអ្នកអាចក្លាយជាមនុស្សជំនិតរបស់ព្រះជាម្ចាស់។ ប្រសិនបើនៅក្នុងសកម្មភាពរបស់អ្នក អ្នកមិនប្រាសចាកពីនិស្ស័យរបស់ព្រះជាម្ចាស់ទេ ហើយស្វែងយល់ពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងមានចិត្តគោរពចុះចូលចំពោះព្រះជាម្ចាស់យ៉ាងអស់ពីចិត្ត នោះ

សេចក្ដីជំនឿរបស់អ្នក មានលក្ខណៈឈានដល់កម្រិតបទដ្ឋាន។ អ្នកណាដែលមិនគោរពព្រះជាម្ចាស់ និងមិនមានចិត្ត កោតខ្លាចដោយញាប់ញ័រទេនោះ គឺអាចនឹងរំលោភបញ្ញត្តិរដ្ឋបាលរបស់ព្រះជាម្ចាស់។ មនុស្សជាច្រើន ដែលបម្រើព្រះជាម្ចាស់ដោយអំណាច នៃចំណង់ចំណូលចិត្តរបស់ពួកគេ ប៉ុន្តែពួកគេមិនបានយល់ដឹងអំពីបញ្ញត្តិរដ្ឋបាលរបស់ព្រះជាម្ចាស់នោះទេ ដូច្នេះនៅតែមានកម្រិតយល់ដឹងទាបអំពីអត្ថន័យនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ដដែល។ ហេតុដូច្នេះ តាមរយៈចេតនាល្អរបស់ពួកគេ ពួកគេជាញឹកញាប់ធ្វើអ្វីៗដែលបង្កជាផលរំខាន ដល់ការរៀបចំរបស់ព្រះជាម្ចាស់ទៅវិញ។ ក្នុងករណីធ្ងន់ធ្ងរ ពួកគេត្រូវបានបណ្ដេញចេញ មិនត្រូវបានផ្ដល់ឱកាសជាថ្មីទៀតក្នុងការដើរតាមព្រះជាម្ចាស់ឡើយ ហើយត្រូវបានបោះចូលទៅក្នុងឋាននរកដែលទាំងអស់នេះជាប់ទាក់ទងនឹងដំណាក់នៃព្រះជាម្ចាស់នៅទីបញ្ចប់។ មនុស្សទាំងនេះធ្វើការនៅក្នុងដំណាក់នៃព្រះជាម្ចាស់ដោយកំលាំងចេតនាល្អនៃភាពល្ងង់ខ្លៅរបស់ពួកគេ ហើយបញ្ចប់ដោយការខឹងក្រោធនឹងនិស្ស័យរបស់ព្រះជាម្ចាស់។ មនុស្សនាំយករបៀបនៃការបម្រើជាសាមីជន និងជាម្ចាស់របស់ពួកគេទៅក្នុងដំណាក់នៃព្រះជាម្ចាស់ និងព្យាយាមដាក់ខ្លួនរបស់ពួកគេឲ្យសកម្មដោយការគិតឥតប្រយោជន៍ថា ចេតនាទាំងនោះអាចត្រូវបានអនុវត្តនៅទីនេះដោយងាយស្រួល គ្មានការខិតខំប្រឹងប្រែង។ ពួកគេមិនដែលនឹកស្រម៉ៃថាព្រះជាម្ចាស់ មិនមែនមាននិស្ស័យជាកូនចៀមទេ ប៉ុន្តែ មាននិស្ស័យជាសត្វតោទៅវិញ។ ហេតុដូច្នេះ អ្នកដែលពាក់ព័ន្ធនឹងព្រះជាម្ចាស់ជាលើកដំបូង គឺមិនអាចធ្វើការទំនាក់ទំនងជាមួយព្រះអង្គបានទេព្រោះព្រះហឫទ័យព្រះជាម្ចាស់ មិនដូចនឹងចិត្តមនុស្សទេ។ មានតែក្រោយពីអ្នកបានយល់អំពីសេចក្ដីពិតច្រើនឡើងៗ ទើបអ្នកអាចបន្តការស្វែងយល់ អំពីព្រះជាម្ចាស់បាន។ ចំណេះដឹងនេះមិនត្រូវបានបង្កើតឡើងដោយពាក្យ និងគោលលទ្ធិទេ ប៉ុន្តែអាចត្រូវបានប្រើជាកំណប់ទ្រព្យតាមរយៈមធ្យោបាយដែលអ្នកមានភាពជឿជាក់កាន់តែខ្លាំងចំពោះព្រះជាម្ចាស់ និងដោយភស្តុតាងបង្ហាញថា ព្រះជាម្ចាស់សព្វព្រះហឫទ័យនឹងអ្នក។ ប្រសិនបើអ្នកខ្វះខាតភាពពិតនៃចំណេះដឹង និងមិនដឹងពីសេចក្ដីពិត នោះ

ការបម្រើការងារដោយភាពងប់ងល់របស់អ្នកអាចនាំមកនូវភាពគួរឱ្យស្អប់ខ្ពើម និងការខ្ពើមរអើមដល់ព្រះជាម្ចាស់វិញ។ ឥឡូវនេះ អ្នកគួរតែបានស្វែងយល់ហើយថា ជំនឿលើព្រះជាម្ចាស់គឺគ្មានអ្វីដូចទៅនឹងការសិក្សាអំពីទេវវិទ្យានោះទេ។

ទោះបីជាពាក្យសម្ដីដែលខ្ញុំដាស់តឿនអ្នករាល់គ្នានេះ ជាសេចក្ដីសង្ខេបក៏ដោយ អ្វីដែលខ្ញុំបានបរិយាយមកនេះ គឺជាអ្វីដែលអ្នករាល់គ្នាខ្វះខាតបំផុតនៅក្នុងខ្លួនរបស់អ្នក។ អ្នករាល់គ្នាគប្បីដឹងថា អ្វីដែលខ្ញុំនិយាយនៅពេលនេះគឺដើម្បីជាប្រយោជន៍ដល់ការងារចុងក្រោយរបស់ខ្ញុំសម្រាប់មនុស្ស ដើម្បីជាប្រយោជន៍ដល់ការកំណត់ទីបញ្ចប់របស់មនុស្ស។ ខ្ញុំមិនមានបំណងចង់ធ្វើកិច្ចការច្រើនផ្សេងទៀតដែលគ្មានគោលបំណងនោះទេ ឬក៏បន្តណែនាំមនុស្សដែលអស់សង្ឃឹម ដូចជាឈើពុកនោះដែរ ហើយនឹងមិនបន្តដឹកនាំមនុស្ស ដែលមានចេតនាអាក្រក់យ៉ាងសម្ងាត់នោះ ឡើយ។ ប្រហែលជាថ្ងៃណាមួយ អ្នករាល់គ្នា នឹងយល់ពីចេតនាដ៏ស្មោះត្រង់នៅពីក្រោយពាក្យសម្ដីរបស់ខ្ញុំ និងការលះបង់ដែលខ្ញុំបានធ្វើ សម្រាប់មនុស្សជាតិ។ ប្រហែលជាថ្ងៃណាមួយ អ្នករាល់គ្នានឹងយល់អំពីសារនេះ ដែលអាចឱ្យអ្នករាល់គ្នាសម្រេចចិត្តអំពីទីបញ្ចប់របស់ខ្លួនឯងបាន។

# អំពើរំលងនឹងនាំមនុស្សទៅកាន់ស្ថាននរក

ខ្ញុំបានផ្ដល់ការព្រមានជាច្រើនដល់អ្នករាល់គ្នា ហើយបានផ្ដល់ឲ្យអ្នករាល់គ្នានូវសេចក្ដីពិតជាច្រើន ក្នុងគោលបំណងយកឈ្នះអ្នករាល់គ្នា។ មកដល់ឥឡូវនេះ អ្នករាល់គ្នាមានអារម្មណ៍ថាមានការលូតលាស់ច្រើនខ្លាំងជាងកាលដែលអ្នកបានធ្វើពីមុន ដោយអ្នកបានយល់ពីគោលការណ៍ជាច្រើននៃរបៀបដែលមនុស្សម្នាក់គប្បីមាន ហើយអ្នកបានក្លាយជាមនុស្សដែលមានសុភវិនិច្ឆ័យជាច្រើន ដែលមនុស្សស្មោះត្រង់គប្បីមាន។ ទាំងអស់នេះ គឺជាផលដែលអ្នករាល់គ្នាប្រមូលបានក្នុងរយៈពេលជាច្រើនឆ្នាំមកនេះ។ ខ្ញុំមិនបដិសេធនូវសមិទ្ធផលរបស់អ្នករាល់គ្នាទេ ប៉ុន្តែខ្ញុំក៏ត្រូវមានព្រះបន្ទូល

ដោយត្រង់ៗផងដែរថា ខ្ញុំក៏មិនបដិសេធចំពោះការមិនគោរព និងការបះបោរជាច្រើន ដែលអ្នករាល់គ្នាបានធ្វើទាស់នឹងខ្ញុំក្នុងរយៈពេលច្រើនឆ្នាំនេះផងដែរ ដ្បិតគ្មាននរណាម្នាក់បរិសុទ្ធក្នុងចំណោមអ្នករាល់គ្នាទេ។ ដោយគ្មានការលើកលែង អ្នកគឺជាមនុស្សដែលត្រូវបានសាតាំងធ្វើឲ្យពុករលួយ។ អ្នកគឺជាសត្រូវរបស់ព្រះគ្រីស្ទ។ មកដល់ពេលបច្ចុប្បន្ន អំពើរំលង និងការមិនស្ដាប់បង្គាប់របស់អ្នករាល់គ្នា មានចំនួនច្រើនខ្លាំងណាស់ ដែលមិនអាចរាប់បាន ដូច្នេះវាសឹងតែមិនអាចចាត់ទុកថា ជាការចម្លែកនោះឡើយ ដែលខ្ញុំតែងតែធ្វើទុក្ខបុកម្នេញអ្នកនោះ។ ខ្ញុំមិនចង់រួមរស់ជាមួយអ្នករាល់គ្នាតាមរបៀបនេះទេ ប៉ុន្តែដើម្បីជាប្រយោជន៍នៃអនាគតរបស់អ្នករាល់គ្នា ដើម្បីជាប្រយោជន៍នៃទិសដៅរបស់អ្នករាល់គ្នា ខ្ញុំឥឡូវនេះ ខ្ញុំមានព្រះបន្ទូលម្ដងទៀតនូវអ្វីដែលខ្ញុំបានមានព្រះបន្ទូលរួចហើយ។ ខ្ញុំសង្ឃឹមថាអ្នករាល់គ្នានឹងព្រមតាមខ្ញុំ ហើយលើសពីនេះទៀត អ្នករាល់គ្នានឹងអាចជឿនូវរាល់ព្រះបន្ទូលរបស់ខ្ញុំ ហើយពិចារណាអំពីផលប៉ះពាល់ដ៏ស៊ីជម្រៅចេញពីព្រះបន្ទូលរបស់ខ្ញុំ។ ចូរកុំសង្ស័យនូវអ្វីដែលខ្ញុំមានព្រះបន្ទូល ចូរកុំជ្រើសយកព្រះបន្ទូលរបស់ខ្ញុំតាមដែលអ្នកចង់បាន ហើយបោះព្រះបន្ទូលចោល ទៅតាមឆន្ទៈរបស់អ្នកនោះឡើយ។ បើធ្វើបែបនេះ ខ្ញុំនឹងមិនអាចអត់ឱនឲ្យនោះឡើយ។ ចូរកុំវិនិច្ឆ័យព្រះបន្ទូលរបស់ខ្ញុំ ហើយជាងនេះទៅទៀត អ្នកក៏មិនគួរមើលស្រាយព្រះបន្ទូលរបស់ខ្ញុំខ្លាំងពេកនោះដែរ ឬក៏និយាយថាខ្ញុំតែងតែល្បងអ្នករាល់គ្នាជានិច្ច ឬកាន់តែអាក្រក់ជាងនេះ ថាអ្វីដែលខ្ញុំបានមានព្រះបន្ទូលប្រាប់អ្នក គឺមិនមានភាពត្រឹមត្រូវនោះឡើយ។ ការទាំងនេះក៏ខ្ញុំមិនអាចអត់ទ្រាំបានឡើយ។ ដោយសារតែអ្នករាល់គ្នាប្រព្រឹត្តចំពោះខ្ញុំ និងអ្វីដែលខ្ញុំមានព្រះបន្ទូលដោយមានការមន្ទិលបែបនេះ ដោយអ្នកមិនបានយកព្រះបន្ទូលរបស់ខ្ញុំមកគិតពិចារណា និងព្រងើយកន្ដើយនឹងខ្ញុំ ខ្ញុំសូមប្រាប់អ្នករាល់គ្នាម្នាក់ៗ ដោយភាពប្រាកដប្រជាថា៖ ចូរកុំផ្សារភ្ជាប់នូវអ្វីដែលខ្ញុំមានព្រះបន្ទូលទៅនឹងទស្សនវិជ្ជាឡើយ។ ចូរកុំផ្សារភ្ជាប់ព្រះបន្ទូលរបស់ខ្ញុំទៅនឹងការកុហក របស់មនុស្សបោកប្រាស់នោះដែរ។ អ្នកក៏ពុំគួរឆ្លើយតបនឹងព្រះបន្ទូលរបស់ខ្ញុំដោយការមិនស្ដាប់បង្គាប់នោះឡើយ។ ប្រហែលជាគ្មាននរណាម្នាក់នាពេល

អនាគត អាចប្រាប់អ្នករាល់គ្នានូវអ្វីដែលខ្ញុំកំពុងមានព្រះបន្ទូលប្រាប់អ្នក ឬមានព្រះបន្ទូលទៅកាន់អ្នករាល់គ្នាដោយក្ដីសប្បុរស ឬក៏នាំអ្នករាល់គ្នាដើរឆ្លងកាត់ចំណុចទាំងនេះដោយអត់ធ្មត់បានឡើយ។ អ្នកនឹងលះបង់ពេលប៉ុន្មានថ្ងៃនោះ ដើម្បីរំឭកឡើងវិញនូវពេលវេលាល្អៗ ឬយំខ្លាំងៗ ឬស្រែកថ្ងូរដោយឈឺចាប់ ឬអ្នករាល់គ្នានឹងរស់នៅក្នុងភាពងងឹតដោយគ្មានការផ្ដល់នូវសេចក្ដីពិត ឬជីវិត ឬគ្រាន់តែរង់ចាំដោយគ្មានសង្ឃឹម ឬរស់នៅក្នុងភាពសោកស្ដាយដ៏ជូរចត់ ដែលអ្នករាល់គ្នាបាត់បង់គ្រប់ទាំងវិចារណញ្ញាណទាំងអស់...។ ជាក់ស្ដែង គ្មាននរណាម្នាក់ក្នុងចំណោមអ្នករាល់គ្នាអាចគេចផុតពីភាពដែលអាចកើតមានទាំងនេះបានទេ។ ដោយសារតែគ្មាននរណាម្នាក់ក្នុងចំណោមអ្នករាល់គ្នា យកបាននូវកន្លែងមួយដែលអ្នករាល់គ្នាអាចថ្វាយបង្គំព្រះជាម្ចាស់ដ៏ពិតប្រាកដ ប៉ុន្តែជ្រមុជខ្លួនឯងចូលទៅក្នុងពិភពនៃភាពអសីលធម៌ និងការអាក្រក់ ដោយលាយបញ្ចូលទៅក្នុងជំនឿរបស់អ្នករាល់គ្នា ចូលទៅក្នុងវិញ្ញាណព្រលឹង និងរូបកាយរបស់អ្នករាល់គ្នា នោះមានរឿងរ៉ាវជាច្រើនដែលមិនទាក់ទងនឹងជីវិត និងសេចក្ដីពិត ហើយដែលតាមពិតទៅ គឺផ្ទុយទៅនឹងរឿងរ៉ាវទាំងនោះវិញ។ ដូច្នេះហើយ អ្វីដែលខ្ញុំសង្ឃឹមចំពោះអ្នករាល់គ្នាគឺថាអ្នករាល់គ្នាអាចនឹងត្រូវនាំទៅកាន់ផ្លូវនៃពន្លឺបាន។ ក្ដីសង្ឃឹមតែមួយគត់របស់ខ្ញុំគឺថា អ្នករាល់គ្នាអាចមានសមត្ថភាពយកចិត្តទុកដាក់លើខ្លួនឯង ថែទាំខ្លួនឯង ហើយថាអ្នកនឹងមិនផ្ដោតសំខាន់លើទិសដៅរបស់អ្នកខ្លាំងពេក ខណៈពេលដែលកំពុងមើលទៅលើឥរិយាបថ និងអំពើរំលងរបស់អ្នកដោយភាពព្រងើយកន្តើយនោះឡើយ។

អស់រយៈពេលជាយូរមកហើយ មនុស្សដែលជឿលើព្រះជាម្ចាស់ សុទ្ធតែបានសង្ឃឹមយ៉ាងមុតមាំក្នុងការទទួលបាននូវទិសដៅដ៏ស្រស់បំព្រងមួយ ហើយគ្រប់ទាំងអ្នកជឿព្រះជាម្ចាស់ទាំងអស់សង្ឃឹមថា សំណាងល្អនឹងមកដល់ពួកគេភ្លាមៗ។ ពួកគេទាំងអស់សង្ឃឹមថា មុនពេលដែលពួកគេដឹងពីទិសដៅ ពួកគេនឹងបានអង្គុយដោយសេចក្ដីសុខសាន្ត នៅកន្លែងមួយ ឬកន្លែងផ្សេងទៀតនៅឯស្ថានសួគ៌។ ជាមួយនឹងគំនិតដ៏ល្អរបស់ពួកគេ ប៉ុន្តែខ្ញុំមានបន្ទូលថា មនុស្សទាំងនេះមិនដែលដឹងថាតើពួកគេមាន

លក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលបាននូវសំណាងល្អបែបនេះដែលធ្លាក់ពីលើមេឃ ឬសូម្បីតែអង្គុយលើកៅអីនៅទីនោះឡើយ។ នាពេលបច្ចុប្បន្ន អ្នករាល់គ្នាមានចំណេះដឹងល្អអំពីខ្លួនឯង តែអ្នករាល់គ្នានៅតែសង្ឃឹមថា នឹងរួចផុតពីគ្រោះមហន្តរាយនៃគ្រាចុងក្រោយ និងព្រះហស្តនៃព្រះដ៏មានគ្រប់ព្រះចេស្ដា នៅពេលដែលទ្រង់ដាក់ទោសមនុស្សអាក្រក់ទាំងឡាយ។ វាហាក់ដូចជាមានក្ដីសុបិនដ៏ល្អ និងចង់បានអ្វីដែលពួកគេចូលចិត្តជាលក្ខណៈទូទៅរបស់មនុស្សទាំងអស់ដែលសាតាំងបានធ្វើឲ្យពុករលួយ ហើយមិនមែនជាគំនិតដ៏ឈ្លាសវៃរបស់មនុស្សណាម្នាក់នោះទេ។ ទោះបីយ៉ាងនេះក្ដី ខ្ញុំនៅតែចង់បញ្ចប់នូវសេចក្ដីប្រាថ្នាផ្ដេសផ្ដាសទាំងនេះរបស់អ្នករាល់គ្នា ក៏ដូចជាភាពចង់បានរបស់អ្នករាល់គ្នា ដើម្បីទទួលបាននូវព្រះពរ។ ដោយសារអំពើរំលងរបស់អ្នកមានចំនួនច្រើន ហើយការពិតនៃភាពបះបោររបស់អ្នករាល់គ្នាកាន់តែចម្រើនឡើង តើរឿងទាំងនេះអាចសមនឹងប្លង់មេដ៏គួរឲ្យស្រឡាញ់របស់អ្នករាល់គ្នាសម្រាប់អនាគតយ៉ាងដូចម្ដេចទៅ? ប្រសិនបើអ្នកចង់បន្តទៅតាមអ្វីដែលអ្នកពេញចិត្ត នៅតែធ្វើខុសដោយមិនមានអ្វីបញ្ឈប់អ្នក តែក្នុងពេលជាមួយគ្នានេះអ្នកនៅតែចង់ឲ្យក្ដីសុបិនរបស់អ្នកក្លាយជាការពិត នោះខ្ញុំជំរុញឲ្យអ្នកបន្តនៅក្នុងភាពល្ងង់ខ្លៅរបស់អ្នកចុះ ហើយកុំភ្ញាក់ឡើយ ដ្បិតអីក្ដីសុបិនរបស់អ្នក គឺជាក្ដីសុបិនទទេ ហើយនៅចំពោះព្រះវត្តមានរបស់ព្រះជាម្ចាស់ដ៏សុចរិត ទ្រង់នឹងមិនលើកលែងដល់អ្នកនោះឡើយ។ ប្រសិនបើអ្នកចង់ឲ្យក្ដីសុបិនរបស់អ្នកក្លាយជាការពិត ចូរកុំសុបិនអី។ ផ្ទុយទៅវិញ ត្រូវប្រឈមមុខនឹងសេចក្ដីពិត និងការពិតជារៀងរហូតវិញ។ នេះគឺជាមធ្យោបាយតែមួយគត់ ដែលអ្នកអាចត្រូវបានសង្គ្រោះ។ បើនិយាយឲ្យចំទៅ តើវិធីសាស្ត្រនេះមានជំហានអ្វីខ្លះ?

ជាដំបូង ត្រូវពិនិត្យមើលរាល់អំពើរំលងរបស់អ្នក ហើយពិនិត្យមើលឥរិយាបថ និងគំនិតណាមួយដែលអ្នកមាន ដែលមិនស្របទៅនឹងសេចក្ដីពិត។

នេះគឺជារឿងមួយដែលអ្នកអាចធ្វើបានយ៉ាងងាយស្រួល ហើយខ្ញុំជឿជាក់ថាគ្រប់មនុស្សវៃឆ្លាតទាំងអស់អាចធ្វើបាន។ ទោះយ៉ាងណាក៏ដោយ លើកលែងតែអ្នកដែលមិនធ្លាប់ដឹងអំពីអត្ថន័យនៃអំពើរំលង និងសេចក្ដីពិតប៉ុណ្ណោះ ដែលមិនអាចធ្វើបាន

ពីព្រោះនៅក្នុងកម្រិតមូលដ្ឋាន ពួកគេមិនមែនជាមនុស្សឆ្លាតវៃនោះទេ។ ខ្ញុំកំពុងមានព្រះបន្ទូលអំពីមនុស្សដែលត្រូវបានព្រះជាម្ចាស់ទទួលស្គាល់ ជាមនុស្សស្មោះត្រង់ មិនបានបំពានធ្ងន់ធ្ងរលើបញ្ញត្តិរដ្ឋបាលណាមួយ ហើយអាចងាយយល់ពីអំពើរំលងរបស់ខ្លួន។ ទោះបីរឿងមួយនេះខ្ញុំតម្រូវពីអ្នករាល់គ្នា ហើយងាយស្រួលនឹងសម្រេចបានក៏ដោយ ក៏នេះមិនមែនជារឿងតែមួយ ដែលខ្ញុំតម្រូវពីអ្នករាល់គ្នានោះឡើយ។ មិនថាមានបញ្ហាអ្វីក៏ដោយ ខ្ញុំសង្ឃឹមថាអ្នករាល់គ្នានឹងមិនសើចចំអកដោយសម្ងាត់ចំពោះសេចក្តីតម្រូវនេះទេ ហើយជាពិសេសអ្នកនឹងមិនមើលងាយ ឬមើលស្រាលចំពោះសេចក្តីតម្រូវនោះឡើយ។ អ្នកគប្បីធ្វើឲ្យបានម៉ឺងម៉ាត់ ហើយកុំបោះបង់សេចក្តីតម្រូវចោលឡើយ។

ទីពីរ ចំពោះអំពើរំលង និងការមិនស្តាប់បង្គាប់នីមួយៗរបស់អ្នក អ្នកគប្បីរកមើលសេចក្តីពិតដែលត្រូវគ្នា ហើយបន្ទាប់មកប្រើសេចក្តីពិតទាំងនេះ ដើម្បីដោះស្រាយបញ្ហាទាំងនោះ។ បន្ទាប់ពីនោះមក ចូរជំនួសអំពើរំលង និងគំនិតដែលមិនស្តាប់បង្គាប់ ហើយនិងការប្រព្រឹត្ត ដោយការអនុវត្តនៃសេចក្តីពិតវិញ។

ទីបី អ្នកគប្បីជាមនុស្សដែលស្មោះត្រង់ មិនមែនជាមនុស្សដែលតែងតែឆ្លាតជ្រុល និងតែងតែបោកប្រាស់ជានិច្ចនោះឡើយ។ (ត្រង់ចំណុចនេះ ខ្ញុំស្នើដល់អ្នករាល់គ្នាម្តងទៀត ឲ្យធ្វើជាមនុស្សស្មោះត្រង់)។

ប្រសិនបើអ្នកអាចសម្រេចនូវកិច្ចការទាំងបីនេះបាន នោះអ្នកគឺជាមនុស្សម្នាក់ក្នុងចំណោមអ្នកដែលមានសំណាង ជាមនុស្សដែលសុបិនក្លាយជាការពិត និងទទួលបានសំណាងល្អ។ ប្រហែលជាអ្នករាល់គ្នា នឹងធ្វើនូវសេចក្តីតម្រូវទាំងបីដែលមិនទាក់ទាញទាំងនេះដោយម៉ឺងម៉ាត់នោះទេ ឬប្រហែលជាអ្នកនឹងធ្វើនូវសេចក្តីតម្រូវទាំងនោះដោយគ្មានការទទួលខុសត្រូវដែរ។ ទោះជាមួយណាក៏ដោយ គោលបំណងរបស់ខ្ញុំ គឺបំពេញនូវក្តីសុបិនរបស់អ្នករាល់គ្នា ហើយដាក់ឧត្តមគតិរបស់អ្នករាល់គ្នាទៅជាការអនុវត្តន៍ ដោយមិនសើចចំអកដាក់អ្នករាល់គ្នា ឬក៏ធ្វើចាត់ទុកអ្នកដូចជាមនុស្សល្ងីល្ងើនោះឡើយ។

ការទាមទាររបស់ខ្ញុំអាចមានលក្ខណៈសាមញ្ញ ប៉ុន្តែអ្វីដែលខ្ញុំកំពុងមានព្រះបន្ទូលប្រាប់អ្នករាល់គ្នា មិនមានលក្ខណៈសាមញ្ញ ដូចជាមួយបូកមួយស្មើពីរនោះទេ។ ប្រសិនបើអ្វីដែលអ្នករាល់គ្នាធ្វើទាំងអស់ ជាការដែលនិយាយបែបធម្មតាអំពីការនេះ ឬនិយាយមិនច្បាស់លាស់ឥតប្រយោជន៍ និងថ្លែងសេចក្តីដោយមិនស្មោះត្រង់នោះប្លង់មេរបស់អ្នករាល់គ្នា និងបំណងប្រាថ្នារបស់អ្នករាល់គ្នា នឹងនៅតែមិនអាចកើតឡើងនោះឡើយ។ ខ្ញុំនឹងមិនមានអារម្មណ៍អាណិតដល់អ្នករាល់គ្នាដែលរងទុក្ខអស់រយៈពេលជាច្រើនឆ្នាំ ហើយខំធ្វើការយ៉ាងខ្លាំងតែគ្មានចេញជាផលផ្លែនោះឡើយ។ ផ្ទុយទៅវិញខ្ញុំនឹងប្រព្រឹត្តចំពោះអ្នកដែលមិនបានបំពេញតាមការទាមទាររបស់ខ្ញុំ តាមរយៈការដាក់ទោស មិនមែនផ្តល់រង្វាន់ទេ ហើយមិនមែនជាក្តីអាណិតអាសូរដែរ។ អ្នករាល់គ្នាប្រហែលជាស្រមៃគិតថា ដោយបានធ្វើជាអ្នកដើរតាមទ្រង់អស់រយៈពេលជាច្រើនឆ្នាំ អ្នកបានខិតខំធ្វើការមិនថាជាអ្វីទេ ហើយអ្នកគួរទទួលបានបាយមួយចាននៅក្នុងដំណាក់របស់ព្រះជាម្ចាស់ ក្នុងនាមតែជាអ្នកស៊ីឈ្នួលប៉ុណ្ណោះ។ ខ្ញុំចង់មានបន្ទូលប្រាប់ថា ភាគច្រើននៃអ្នករាល់គ្នាគិតតាមរបៀបនេះ ដ្បិតអ្នករាល់គ្នាតែងតែស្វែងរកនូវគោលការណ៍ ពីរបៀបទាញយកប្រយោជន៍ ហើយមិនឲ្យមានការទាញយកប្រយោជន៍ពីខ្លួនឡើយ។ ដូច្នេះ ខ្ញុំប្រាប់អ្នករាល់គ្នាឥឡូវនេះដោយភាពម៉ឺងម៉ាត់ទាំងអស់ថា៖ ខ្ញុំមិនខ្វល់ថាកិច្ចខិតខំប្រឹងប្រែងរបស់អ្នកគួរឲ្យស្ងើចយ៉ាងណា សមត្ថភាពរបស់អ្នកខ្លាំងប៉ុនណា អ្នកធ្វើតាមខ្ញុំបានជាប់ប៉ុនណា កិត្តិនាមល្បីល្បាញប៉ុនណា ឬអាកប្បកិរិយារបស់អ្នកមានភាពប្រសើរប៉ុនណានោះទេ ដរាបណាអ្នកមិនបានបំពេញតាមការទាមទាររបស់ខ្ញុំ នោះអ្នកនឹងមិនអាចទទួលបាននូវការសរសើរពីខ្ញុំនោះឡើយ។ ចូរសរសេរចេញនូវគំនិត និងការគណនាទាំងនោះទាំងអស់របស់អ្នករាល់គ្នាឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន ហើយចាប់ផ្តើមធ្វើតាមសេចក្តីតម្រូវរបស់ខ្ញុំយ៉ាងហ្មត់ចត់។ បើមិនដូច្នោះទេ ខ្ញុំនឹងធ្វើឲ្យមនុស្សទាំងអស់ទៅជាផេះផង់ ដើម្បីបញ្ចប់នូវកិច្ចការរបស់ខ្ញុំ ហើយដែលអាក្រក់បំផុតនោះ គឺធ្វើឱ្យឆ្នាំនៃកិច្ចការនិងការរងទុក្ខទាំងប៉ុន្មានរបស់ខ្ញុំត្រឡប់ទៅជាឥតប្រយោជន៍ ដ្បិតខ្ញុំមិនអាចយកខ្មាំងសត្រូវ និងមនុស្សដែលធ្វើការ

អាក្រក់ទាំងនោះ ហើយដែលមានរូបរាងរបស់សាតាំង ឲ្យចូលមកក្នុងនគររបស់ខ្ញុំ ឬយកចូលទៅក្នុងយុគសម័យបន្ទាប់បាននោះឡើយ។

ខ្ញុំមានសង្ឃឹមច្រើនណាស់។ ខ្ញុំសង្ឃឹមថាអ្នករាល់គ្នាអាចប្រព្រឹត្តដោយខ្លួនឯងនូវឥរិយាបថសមរម្យ និងត្រឹមត្រូវ ដោយបំពេញកាតព្វកិច្ចរបស់អ្នកដោយស្មោះត្រង់ មានសេចក្ដីពិត និងភាពជាមនុស្ស ជាមនុស្សដែលអាចលះបង់អ្វីគ្រប់យ៉ាងដែលខ្លួនមាន និងសូម្បីតែជីវិតសម្រាប់ព្រះជាម្ចាស់ ហើយនិងអ្វីៗផ្សេងទៀត។ ក្ដីសង្ឃឹមទាំងអស់នេះបានមកពីភាពមិនគ្រប់គ្រាន់របស់អ្នករាល់គ្នា ហើយនិងការពុករលួយ និងការមិនស្ដាប់បង្គាប់របស់អ្នក។ ប្រសិនបើការសន្ទនាណាមួយដែលខ្ញុំមានជាមួយអ្នករាល់គ្នា មិនគ្រប់គ្រាន់ដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់អ្នករាល់គ្នាទេ នោះទំនងជាអ្វី ដែលខ្ញុំអាចធ្វើបាននៅពេលនេះ គឺខ្ញុំលែងមានព្រះបន្ទូលតទៅទៀត។ ទោះយ៉ាងណាក៏ដោយ អ្នករាល់គ្នាយល់នូវអ្វីជាលទ្ធផលដែលនឹងទៅជាយ៉ាងណា។ ខ្ញុំមិនដែលសម្រាកញឹកញាប់នោះទេ ដូច្នេះប្រសិនបើខ្ញុំមិនមានបន្ទូល ខ្ញុំនឹងធ្វើអ្វីម៉្យាងដើម្បីឲ្យមនុស្សមើល។ ខ្ញុំអាចធ្វើឲ្យអណ្ដាតរបស់នរណាម្នាក់ ទៅជារលួយ ឬធ្វើឲ្យនរណាម្នាក់ស្លាប់បែកជាបំណែក ឬធ្វើឲ្យមនុស្សមានភាពមិនធម្មតាផ្នែកសរសៃប្រសាទ និងធ្វើឲ្យពួកគេមើលទៅគួរឲ្យស្អប់តាមវិធីជាច្រើនយ៉ាង។ បន្ទាប់មកទៀត ខ្ញុំអាចធ្វើឲ្យមនុស្សរងនឹងទារុណកម្ម ដែលខ្ញុំបានបង្កើតជាពិសេសសម្រាប់ពួកគេ។ តាមវិធីនេះ ខ្ញុំនឹងមានអារម្មណ៍រីករាយ សប្បាយជាខ្លាំង និងពេញចិត្តយ៉ាងខ្លាំងផងដែរ។ មានពាក្យដែលគេតែងតែលើកឡើងថា «ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់» ចុះឥឡូវ ហេតុអ្វីបានជាមិនអ៊ីចឹង? ប្រសិនបើអ្នកមានបំណងជំទាស់នឹងខ្ញុំ ហើយធ្វើការជំនុំជម្រះចំពោះខ្ញុំ នោះខ្ញុំនឹងធ្វើឲ្យមាត់អ្នករលួយ ហើយនោះនឹងធ្វើឲ្យខ្ញុំរីករាយមិនឈប់ឈរនោះឡើយ។ នេះក៏ព្រោះតែទីបំផុត អ្វីដែលអ្នកបានធ្វើ មិនមែនជាសេចក្ដីពិត ហើយក៏មិនទាក់ទងនឹងជីវិតផងដែរ ដ្បិតអ្វីគ្រប់យ៉ាងដែលខ្ញុំធ្វើគឺជាសេចក្ដីពិត។ រាល់សកម្មភាពរបស់ខ្ញុំ គឺពាក់ព័ន្ធនឹងគោលការណ៍នៃកិច្ចការរបស់ខ្ញុំ និងបញ្ញត្តិរដ្ឋបាលដែលខ្ញុំបានដាក់ចេញ។ ហេតុដូច្នេះហើយ ខ្ញុំជំរុញឲ្យអ្នករាល់គ្នា

ម្នាក់ៗបង្កើននូវគុណធម៌ខ្លះៗឈប់ធ្វើអំពើអាក្រក់ច្រើនពេក ហើយធ្វើតាមការទាមទាររបស់ខ្ញុំក្នុងពេលទំនេររបស់អ្នក។ ពេលនោះខ្ញុំនឹងមានអារម្មណ៍រីករាយ។ ប្រសិនបើអ្នករាល់គ្នាត្រូវចែករំលែក (ឬបរិច្ចាគ) ទៅចំពោះសេចក្ដីពិតសូម្បីតែមួយភាគមួយពាន់នៃការខិតខំប្រឹងប្រែងដែលអ្នកធ្វើក្នុងសាច់ឈាមនោះ ខ្ញុំអាចមានព្រះបន្ទូលថាអ្នកនឹងមិនប្រព្រឹត្តនូវអំពើរំលង និងមានមាត់ដែលរលួយជាញឹកញាប់នោះឡើយ។ តើនេះមិនច្បាស់ទេឬអី?

បើអ្នកប្រព្រឹត្តនូវអំពើរំលងកាន់តែច្រើន នោះឱកាសរបស់អ្នកក្នុងការទទួលបាននូវទិសដៅល្អ គឺកាន់តែតិចដែរ។ ផ្ទុយទៅវិញ បើអ្នកប្រព្រឹត្តអំពើរំលងកាន់តែតិចនោះអ្នកកាន់តែមានឱកាសច្រើនក្នុងការទទួលបាននូវការសរសើរពីព្រះជាម្ចាស់។ ប្រសិនបើអំពើរំលងរបស់អ្នកកើនឡើង ដល់ចំណុចដែលខ្ញុំមិនអាចអភ័យទោសឲ្យអ្នកបាននោះអ្នកនឹងត្រូវបាត់បង់ទាំងស្រុងនូវឱកាសនៃការដែលត្រូវអត់ទោស។ ដូច្នេះទិសដៅរបស់អ្នកនឹងមិននៅខាងលើទេ ប៉ុន្តែនៅខាងក្រោមវិញ។ ប្រសិនបើអ្នកមិនជឿខ្ញុំទេ ចូរអ្នកក្លាហាន ហើយប្រព្រឹត្តខុសចុះ នោះអ្នកនឹងឃើញនូវអ្វីដែលអ្នកត្រូវទទួលបាន។ ប្រសិនបើអ្នកជាមនុស្សដែលមានចិត្តស្មោះត្រង់ ដែលអនុវត្តនូវសេចក្ដីពិត នោះអ្នកប្រាកដជានឹងមានឱកាសទទួលបានការលើកលែងទោស ចំពោះអំពើរំលងរបស់អ្នក ហើយអ្នកនឹងមិនស្ដាប់បង្គាប់កាន់តែតិចទៅៗ។ ប្រសិនបើអ្នកជាមនុស្សម្នាក់ដែលការអនុវត្តសេចក្ដីពិតរបស់ខ្លួន មានលក្ខណៈស្មោះអស់ពីចិត្តយ៉ាងខ្លាំង នោះអំពើរំលងរបស់អ្នកនៅចំពោះព្រះជាម្ចាស់ច្បាស់ជាកើនឡើង ហើយអ្នកនឹងមិនស្ដាប់បង្គាប់កាន់តែច្រើនឡើងៗ រហូតដល់អ្នកឈានដល់កម្រិត ដែលនឹងជាពេលនៃការបំផ្លាញជាសរុបចំពោះអ្នកតែម្ដង។ នេះជាពេលដែលសុបិនដ៏រីករាយនៃការទទួលបាននូវព្រះពររបស់អ្នកនឹងត្រូវវិនាស។ កុំចាត់ទុកអំពើរំលងរបស់អ្នក ថាគ្រាន់តែជាកំហុសរបស់មនុស្សដែលមិនទាន់គ្រប់អាយុ ឬមនុស្សល្ងីល្ងើនោះឡើយ។ ចូរកុំប្រើលេសដែលអ្នកមិនបានអនុវត្តនូវសេចក្ដីពិត ពីព្រោះតែលក្ខណៈសម្បត្តិមិនល្អរបស់អ្នក ដែលធ្វើឲ្យអ្នកមិនអាចធ្វើបាននោះឡើយ។ លើសពីនេះទៅទៀត មិនត្រូវចាត់ទុកអំពើរំលង

ដែលអ្នកបានប្រព្រឹត្ត ថាជាអំពើរបស់នរណាម្នាក់ផ្សេងនោះឡើយ។ ប្រសិនបើអ្នកពូកែក្នុងការអភ័យទោសឲ្យខ្លួនឯង និងប្រព្រឹត្តចំពោះខ្លួនឯងដោយសន្ដោសប្រណី នោះខ្ញុំសូមមានព្រះបន្ទូលថា អ្នកជាមនុស្សកំសាក ដែលមិនដែលទទួលបាននូវសេចក្ដីពិត ហើយអំពើរំលងរបស់អ្នកក៏មិនដែលឈប់ក្នុងការតាមលងអ្នកដែរ។ អំពើរំលងរបស់អ្នកនឹងទាសអ្នកចេញ មិនឲ្យទទួលបាននូវតម្រូវការនៃសេចក្ដីពិត ហើយធ្វើឲ្យអ្នកនៅតែជាដៃគូស្មោះត្រង់របស់សាតាំងជានិច្ច។ ឱវាទរបស់ខ្ញុំចំពោះអ្នកនៅតែមានដូច្នេះ៖ ចូរកុំយកចិត្តទុកដាក់តែលើទិសដៅរបស់អ្នក ដោយមិនអាចកត់សម្គាល់ពីអំពើរំលងដែលលាក់កំបាំងរបស់អ្នកនោះឡើយ តែចូរប្រកាន់ខ្ជាប់នូវអំពើរំលងយ៉ាងម៉ឺងម៉ាត់ ហើយកុំមើលរំលងនូវអំពើរំលងទាំងនោះ ក្រៅពីការព្រួយបារម្ភចង់បានទិសដៅរបស់អ្នកឡើយ។

# ការយល់ដឹងអំពីនិស្ស័យរបស់ព្រះជាម្ចាស់ ពិតជាសំខាន់ក្រៃលែង

មានសេចក្ដីជាច្រើនដែលខ្ញុំរំពឹងឲ្យអ្នករាល់គ្នាសម្រេចឲ្យបាន តែមិនមែនគ្រប់សកម្មភាពទាំងអស់របស់អ្នករាល់គ្នា មិនមែនគ្រប់យ៉ាងទាំងអស់ក្នុងជីវិតអ្នករាល់គ្នាសុទ្ធតែអាចសម្រេចនូវអ្វីដែលខ្ញុំបង្គាប់ពីអ្នករាល់គ្នាឡើយ ហេតុនេះខ្ញុំក៏គ្មានជម្រើសដែរ ក្រៅតែពីមានបន្ទូលឲ្យចំចំណុច ហើយពន្យល់ប្រាប់អ្នករាល់គ្នាពីបំណងព្រះហឫទ័យរបស់ខ្ញុំ។ ដោយយល់ថា ញាណយល់ដឹងរបស់អ្នករាល់គ្នាខ្សោយ ចំណែកការដឹងគុណរបស់អ្នករាល់គ្នាក៏ខ្សោយ អ្នករាល់គ្នាក៏ស្ទើរតែមិនដឹងអ្វីសោះ អំពីនិស្ស័យ និងសារជាតិរបស់ខ្ញុំ ហេតុនេះ ខ្ញុំត្រូវតែប្រញាប់មានបន្ទូលប្រាប់អ្នករាល់គ្នាអំពីសេចក្ដីទាំងនេះ។ ទោះបីជាពីមុនមក អ្នករាល់គ្នាធ្លាប់យល់ដឹងយ៉ាងណា ទោះបីជាអ្នករាល់គ្នាមិនចង់យល់ដឹងពីរឿងទាំងអស់នេះ ក៏ខ្ញុំនៅតែត្រូវពន្យល់ប្រាប់សេចក្ដីទាំងនេះ ដល់អ្នករាល់គ្នាយ៉ាងពិស្ដារដែរ។ រឿងទាំងនេះ ក៏មិនមែនជារឿងប្លែក

ទាំងស្រុងដល់អ្នករាល់គ្នាដែរ ប៉ុន្តែអ្នករាល់គ្នាខ្វះការយល់ដឹងច្រើន ខ្វះការយល់ច្បាស់ច្រើន ទាក់ទងនឹងអត្ថន័យដែលមាននៅក្នុង សេចក្ដីទាំងនេះ។ មនុស្សជាច្រើនក្នុងចំណោមអ្នករាល់គ្នា មានត្រឹមការយល់ដឹងស្រពេចស្រពិល ហើយជាការយល់ដឹងត្រឹមមួយផ្នែក និងមិនពេញលេញទាល់តែសោះ។ ដើម្បីជួយឲ្យអ្នករាល់គ្នាអនុវត្តសេចក្ដីពិតបានកាន់តែប្រសើរ គឺអនុវត្តតាមព្រះបន្ទូលរបស់ខ្ញុំបានកាន់តែប្រសើរ ខ្ញុំព្រះតម្រិះឃើញថា សេចក្ដីទាំងនេះ គឺជារឿងសំខាន់បំផុតដែលអ្នករាល់គ្នាត្រូវដឹង។ ពុំនោះទេ សេចក្ដីជំនឿរបស់អ្នករាល់គ្នាគឺនៅតែស្រពេចស្រពិល ពុតត្បុត និងពោរពេញទៅដោយអន្ទាក់នៃសាសនា។ ប្រសិនបើអ្នករាល់គ្នាមិនយល់អំពីនិស្ស័យរបស់ព្រះជាម្ចាស់ នោះអ្នកមិនអាចធ្វើកិច្ចការដែលអ្នកគួរធ្វើថ្វាយទ្រង់បានឡើយ។ ប្រសិនបើអ្នករាល់គ្នាមិនស្គាល់សារជាតិរបស់ព្រះជាម្ចាស់ នោះអ្នករាល់គ្នាមិនអាចគោរពប្រណិបតន៍ និងកោតខ្លាចទ្រង់បានឡើយ ផ្ទុយទៅវិញ គឺមានតែទង្វើធ្វើឲ្យតែបានរួចពីដៃដោយគ្មានការប្រុងប្រយ័ត្ន និងការកុហកបោកប្រាស់តែប៉ុណ្ណោះ ហើយលើសពីនេះ គឺមានតែការប្រមាថដែលគ្មានអ្វីអាចទូន្មានបាន។ ថ្វីបើការយល់ដឹងអំពីនិស្ស័យរបស់ព្រះជាម្ចាស់ ពិតជាសំខាន់ ហើយការស្គាល់សារជាតិរបស់ព្រះជាម្ចាស់ក៏មិនអាចមើលរំលងបានមែន ក៏គ្មាននរណាម្នាក់បានពិនិត្យពិច័យ ឬក៏ជជីកវែកញែកសេចក្ដីទាំងនេះឲ្យបានហ្មត់ចត់នោះដែរ។ អ្នករាល់គ្នាបានច្រានចោលបញ្ញត្តិគ្រប់គ្រងនានាដែលខ្ញុំបានដាក់ចេញយ៉ាងច្បាស់ណាស់។ ប្រសិនបើអ្នករាល់គ្នាមិនយល់អំពីនិស្ស័យរបស់ព្រះជាម្ចាស់នោះអ្នកក៏ងាយនឹងប្រព្រឹត្តទាស់នឹងនិស្ស័យរបស់ទ្រង់ដែរ។ ការប្រព្រឹត្តទាស់នឹងនិស្ស័យរបស់ព្រះជាម្ចាស់ គឺដូចគ្នានឹងការជំរុញឲ្យព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ ទ្រង់មានសេចក្ដីក្រោធ ហើយក្នុងករណីនេះ ផលចុងក្រោយនៃទង្វើរបស់អ្នក គឺការបំពានបញ្ញត្តិគ្រប់គ្រងនោះហើយ។ ពេលនេះ អ្នកគប្បីទទួលស្គាល់ហើយថា កាលណាអ្នកស្គាល់សារជាតិរបស់ព្រះជាម្ចាស់ នោះអ្នកក៏អាចយល់អំពីនិស្ស័យរបស់ទ្រង់បានដែរ ហើយកាលណាអ្នកយល់អំពីនិស្ស័យរបស់ទ្រង់ នោះអ្នកក៏នឹងបានយល់អំពីបញ្ញត្តិរដ្ឋបាលនោះដែរ។ មិនចាំបាច់និយាយច្រើនទេ សារជាតិភាគច្រើននៅក្នុង

បញ្ញត្តិរដ្ឋបាលនោះ សុទ្ធតែនិយាយអំពីនិស្ស័យរបស់ព្រះជាម្ចាស់ ប៉ុន្តែមិនមែនគ្រប់និស្ស័យទាំងអស់របស់ទ្រង់ សុទ្ធតែមាននៅក្នុងបញ្ញត្តិរដ្ឋបាលនោះទេ ហើយអំណេះតទៅ អ្នករាល់គ្នាត្រូវបង្កើនការយល់ដឹងរបស់ខ្លួន ទាក់ទងនឹងនិស្ស័យរបស់ព្រះជាម្ចាស់ ឲ្យកាន់តែស៊ីជម្រៅជាងនេះ។

ខ្ញុំមានបន្ទូលជាមួយអ្នករាល់គ្នាថ្ងៃនេះ មិនមែនជាការសន្ទនាបែបធម្មតាៗនោះទេ ដើម្បីឲ្យបានជាប្រយោជន៍ដល់អ្នករាល់គ្នា ក្នុងការខិតចូលមកជិតព្រះបន្ទូលរបស់ខ្ញុំដោយការយកចិត្តទុកដាក់ ហើយលើសពីនេះ គឺដើម្បីសញ្ជឹងគិតពីព្រះបន្ទូលឲ្យស៊ីជម្រៅ។ ន័យដែលខ្ញុំមានបន្ទូលនេះគឺថា អ្នករាល់គ្នាបានខិតខំតិចតួចណាស់ចំពោះព្រះបន្ទូលដែលខ្ញុំបានថ្លែង។ អ្នករាល់គ្នា ក៏មិនសូវចូលចិត្តគិតពិចារណាពីនិស្ស័យរបស់ព្រះជាម្ចាស់ដែរ ក៏មិនសូវមាននរណាម្នាក់ខំប្រឹងប្រែងផង។ ដោយព្រោះហេតុផលនេះហើយបានជាខ្ញុំមានបន្ទូលថា សេចក្ដីជំនឿរបស់អ្នករាល់គ្នាគ្មានអ្វីក្រៅពីការសម្ដែងវោហារសាស្ត្រនោះទេ។ សូម្បីតែពេលនេះ ក៏ក្នុងចំណោមអ្នករាល់គ្នា គ្មាននរណាម្នាក់ខំប្រឹងប្រែងយ៉ាងខ្លាំងដើម្បីសេចក្ដីកម្សោយបំផុតរបស់អ្នករាល់គ្នាដែរ។ អ្នករាល់គ្នាបានធ្វើឲ្យខ្ញុំខកព្រះទ័យ បន្ទាប់ពីខ្ញុំបានទទួលយកអស់ទាំងការឈឺចាប់ជំនួសអ្នករាល់គ្នារួច។ ដូច្នេះហើយទើបអ្នករាល់គ្នាមិនខ្វល់ពីព្រះជាម្ចាស់ ហើយជីវិតរបស់អ្នករាល់គ្នាទៀតសោត ក៏គ្មានសេចក្ដីពិតដែរ។ ធ្វើម្ដេចអាចឲ្យមនុស្សបែបនេះរាប់ជាពួកបរិសុទ្ធបាន? វិន័យឋានសួគ៌ មិនបណ្ដោតបណ្ដោយចំពោះរឿងបែបនេះទេ! ដោយព្រោះអ្នករាល់គ្នាមានការយល់ដឹងតិចតួចអំពីរឿងនេះ ខ្ញុំគ្មានជម្រើសទេ មានតែប្រើខ្យល់ដង្ហើមទៀតប៉ុណ្ណោះ។

និស្ស័យរបស់ព្រះជាម្ចាស់ គឺជាប្រធានបទមួយ ដែលហាក់ដូចជាពិបាកយល់ចំពោះមនុស្សគ្រប់គ្នា ហើយជាងនេះទៅទៀត នេះក៏ជាប្រធានបទមួយដែលមិនងាយឲ្យមនុស្សគ្រប់គ្នាទទួលយកបានដែរ ដ្បិតនិស្ស័យរបស់ទ្រង់ ខុសពីបុគ្គលិកលក្ខណៈរបស់មនុស្ស។ ព្រះជាម្ចាស់ផ្ទាល់ក៏មានអារម្មណ៍ត្រេកអរ ខ្ញាល់ សោកសង្រេង និងរីករាយដូចគ្នាដែរ ប៉ុន្តែអារម្មណ៍ទាំងអស់នេះ គឺខុសគ្នាពីអារម្មណ៍របស់មនុស្ស។

ព្រះជាម្ចាស់ មាននូវអ្វីដែលជាលក្ខណៈរបស់ទ្រង់ ហើយទ្រង់មាននូវអ្វីដែលជាកម្មសិទ្ធិរបស់ទ្រង់។ គ្រប់យ៉ាងដែលទ្រង់បញ្ចេញ និងបើកសម្ដែងឲ្យឃើញ គឺសុទ្ធតែជាតំណាងនៃសារជាតិ និងអត្តសញ្ញាណរបស់ទ្រង់។ លក្ខណៈ និងកម្មសិទ្ធិរបស់ទ្រង់ ក៏ដូចជាលក្ខណៈសំខាន់ និងអត្តសញ្ញាណរបស់ទ្រង់ គឺជាសេចក្ដីដែលមិនអាចយកមនុស្សណាម្នាក់មកជំនួសបានឡើយ។ និស្ស័យរបស់ទ្រង់ គឺរាប់បញ្ចូលទាំងសេចក្ដីស្រឡាញ់របស់ទ្រង់ចំពោះមនុស្សជាតិ ភាពស្រាកស្រាន្តរបស់មនុស្សជាតិ សេចក្ដីសម្អប់ចំពោះមនុស្សជាតិ ហើយជាងនេះទៅទៀតគឺ ការយល់ដឹងយ៉ាងហ្មត់ចត់អំពីមនុស្សជាតិ។ យ៉ាងណាមិញ បុគ្គលិកលក្ខណៈរបស់មនុស្សអាចមានលក្ខណៈសុទិដ្ឋិនិយម រស់រវើក និងគ្មានមេត្តា។ និស្ស័យរបស់ព្រះជាម្ចាស់ គឺជានិស្ស័យដែលជាកម្មសិទ្ធិរបស់អ្នកគ្រប់គ្រងលើរបស់សព្វសារពើទាំងអស់ រួមទាំងសភាវៈមានជីវិតផងជាកម្មសិទ្ធិរបស់ព្រះអម្ចាស់នៃអ្វីៗទាំងអស់ដែលបានបង្កើតមក។ និស្ស័យរបស់ទ្រង់តំណាងឲ្យកិត្តិយស ព្រះចេស្ដា ភាពប្រសើរថ្លៃថ្លា ភាពមហិមា ហើយសំខាន់ជាងគេគឺ ភាពឧត្ដុង្គឧត្ដម។ និស្ស័យរបស់ទ្រង់ គឺជានិមិត្តរូបនៃសិទ្ធិអំណាច ជានិមិត្តរូបនៃគ្រប់អំពើសុចរិត ក៏ជានិមិត្តរូបនៃសោភណភាព និងភាពល្អប្រពៃគ្រប់យ៉ាងដែរ។ លើសពីនេះ និស្ស័យនេះ គឺជានិមិត្តរូបនៃព្រះដែលមិនអាច[ក] ឲ្យភាពអន្ធការ និងពួកខ្មាំងសត្រូវណាមួយមកយកឈ្នះ ឬឈ្លានពានបានឡើយ ហើយជានិមិត្តរូបនៃព្រះដែលមិនអាចឲ្យភាវៈណាមួយដែលទ្រង់បានបង្កើតមកបំពានដែរ[ខ] (ព្រះអង្គក៏មិនបណ្ដោយឲ្យគេបំពានទ្រង់ដែរ)។ និស្ស័យរបស់ទ្រង់ គឺជានិមិត្តរូបនៃព្រះចេស្ដាដ៏ខ្ពស់បំផុត។ គ្មានបុគ្គលណាអាចមករំខានកិច្ចការរបស់ទ្រង់ ឬនិស្ស័យរបស់ទ្រង់បាន

លេខយោង៖

ក. អត្ថបទដើមសរសេរថា «វាជានិមិត្តរូបនៃកង្វះសមត្ថភាព»។

ខ. អត្ថបទដើមសរសេរថា «ក៏ជានិមិត្តរូបនៃការដែលមិនអាចត្រូវគេបំពាន (និងមិនប្រណីចំពោះការដែលត្រូវគេបំពាន)»។

ឡើយ។ ដោយឡែក បុគ្គលិកលក្ខណៈរបស់មនុស្ស ក៏មិនមែនគ្រាន់តែជានិមិត្តរូបនៃឧត្ដមភាពដែលមនុស្សមានលើសសត្វបន្ដិចបន្ដួចនោះដែរ។ មនុស្សផ្ទាល់ ពុំមានសិទ្ធិអំណាច ពុំមានស្វ័យភាព ក៏ពុំមានសមត្ថភាពអ្វីនឹងលើកតម្កើងខ្លួនឯងដែរ ប៉ុន្តែនៅក្នុងសារជាតិរបស់ខ្លួន មនុស្សម្នាក់ស្ថិតក្រោមការគ្រប់គ្រងនៃរបៀបរបស់មនុស្ស ព្រឹត្តិការណ៍ និងអ្វីៗជាច្រើនទៀត។ អំណររបស់ព្រះជាម្ចាស់ កើតមកពីអត្ថិភាព និងការលេចឡើងនៃភាពសុចរិត និងពន្លឺ ក៏ដោយសារតែក្ដីវិនាសនៃភាពអន្ធការ និងការអាក្រក់ដែរ។ ទ្រង់សព្វព្រះហឫទ័យក្នុងការនាំយកពន្លឺ និងជីវិតដ៏ល្អប្រពៃមកឲ្យមនុស្សជាតិ។ អំណររបស់ទ្រង់ គឺជាអំណរដ៏សុចរិត ជានិមិត្តរូបនៃអត្ថិភាពនៃអ្វីៗគ្រប់យ៉ាងដែលវិជ្ជមាន ហើយលើសពីនេះ អំណរនេះជានិមិត្តរូបនៃភ័ព្វដ៏ប្រសើរ។ សេចក្ដីក្រោធរបស់ព្រះជាម្ចាស់កើតមកពីភាពអន្តរាយដែលធ្លាក់មកលើមនុស្សជាតិ ដោយសារតែអត្ថិភាព និងការរំខាននៃអំពើអយុត្តិធម៌ ដោយសារតែអត្ថិភាពនៃសេចក្ដីអាក្រក់ និងភាពអន្ធការ ដោយសារតែអត្ថិភាពនៃកត្តានានាដែលបណ្ដេញសេចក្ដីពិតឲ្យចេញទៅឆ្ងាយ ហើយលើសពីនេះ គឺដោយសារតែអត្ថិភាពនៃកត្តានានាដែលប្រឆាំងទាស់នឹងសេចក្ដីល្អ និងភាពស្រស់បំព្រង។ សេចក្ដីក្រោធរបស់ទ្រង់ គឺជានិមិត្តរូបបញ្ជាក់ប្រាប់ថា គ្រប់យ៉ាងដែលអវិជ្ជមាន លែងមានទៀតហើយ លើសពីនេះទៀតគឺបញ្ជាក់ថា សេចក្ដីក្រោធនេះ គឺជានិមិត្តរូបនៃភាពបរិសុទ្ធរបស់ទ្រង់។ សេចក្ដីទុក្ខសោករបស់ទ្រង់កើតមកពីមនុស្ស ជាអ្នកដែលទ្រង់មានក្ដីសង្ឃឹម ប៉ុន្តែគេបែរជាធ្លាក់ក្នុងភាពអន្ធការវិញ ពីព្រោះកិច្ចការដែលទ្រង់ធ្វើចំពោះមនុស្ស មិនបានផ្ដល់ផលសមនឹងក្ដីរំពឹងរបស់ទ្រង់ ក៏ដោយសារតែមនុស្សទាំងអស់ដែលទ្រង់ស្រឡាញ់ មិនអាចរស់នៅក្នុងពន្លឺបាន។ ទ្រង់មានអារម្មណ៍សោយសោក ចំពោះមនុស្សឥតទោស ចំពោះមនុស្សស្មោះត្រង់ តែល្ងីល្ងើ និងចំពោះមនុស្សល្អ តែគ្មានអ្វីជាទស្សនៈផ្ទាល់ខ្លួនឯងសោះ។ សេចក្ដីទុក្ខសោករបស់ទ្រង់ គឺជានិមិត្តរូបនៃសេចក្ដីល្អ និងសេចក្ដីមេត្តាករុណារបស់ទ្រង់ ជានិមិត្តរូបនៃសោភណភាព និងសេចក្ដីសប្បុរសរបស់ទ្រង់។ ព្រះទ័យរីករាយរបស់ទ្រង់ប្រាកដណាស់ គឺបានមកពីការយកឈ្នះលើ

ខ្មាំងសត្រូវរបស់ទ្រង់ និងទទួលបានភាពស្មោះត្រង់ពីមនុស្ស។ ជាងនេះទៅទៀត ព្រះទ័យរីករាយរបស់ទ្រង់ កើតចេញពីការបណ្ដេញ និងការបំផ្លិចបំផ្លាញពួកខ្មាំងសត្រូវ ហើយដោយសារតែមនុស្សជាតិទទួលបានជីវិតមួយដ៏ល្អប្រពៃ និងប្រកបដោយសេចក្ដីសុខសាន្ត។ សេចក្ដីរីករាយរបស់ព្រះជាម្ចាស់ ខុសពីអំណរសប្បាយរបស់មនុស្ស។ ម្យ៉ាងទៀត សេចក្ដីរីករាយនេះ ជាអារម្មណ៍រីករាយ ដូចនៅពេលប្រមូលផលដាក់ជង្រុក គឺជាអារម្មណ៍រីករាយខ្លាំងក្លាជាងអំណរធម្មតា។ ព្រះទ័យរីករាយរបស់ទ្រង់ គឺជានិមិត្តរូបនៃការដែលមនុស្សជាតិរើខ្លួនរួចពីទុក្ខលំបាកចាប់ពីពេលនេះតទៅ និងជានិមិត្តរូបនៃការដែលមនុស្សជាតិឈានចូលក្នុងពិភពនៃពន្លឺ។ ម្យ៉ាងវិញទៀត អារម្មណ៍របស់មនុស្សជាតិ គឺសុទ្ធតែកើតឡើងដើម្បីជាប្រយោជន៍សម្រាប់ពួកគេផ្ទាល់ មិនមែនដើម្បីភាពសុចរិត មិនមែនដើម្បីពន្លឺ ក៏មិនមែនដើម្បីភាពស្រស់បំព្រង ហើយក៏រឹតតែមិនមែនដើម្បីព្រះគុណ ដែលត្រូវបានប្រទានមកពីស្ថានសួគ៌ដែរ។ អារម្មណ៍របស់មនុស្សជាតិ គឺជាអារម្មណ៍អាត្មានិយម ហើយជាកម្មសិទ្ធិនៃពិភពងងឹត។ អារម្មណ៍ទាំងនេះ មិនមែនកើតឡើងដើម្បីព្រះហឫទ័យរបស់ព្រះជាម្ចាស់ទេ ក៏រឹតតែមិនមែនដើម្បីផែនការរបស់ព្រះជាម្ចាស់ដែរ ហេតុនេះហើយ មនុស្ស និងព្រះជាម្ចាស់ មិនអាចយកសម្ដីពីខ្យល់ដង្ហើមតែមួយមកនិយាយឲ្យយល់បាននោះឡើយ។ ព្រះជាម្ចាស់ឧត្ដុង្គឧត្ដម និងខ្ពង់ខ្ពស់ជានិច្ច ចំណែកឯមនុស្សវិញ តូចទាប គ្មានតម្លៃរហូត។ នេះគឺមកពីព្រះជាម្ចាស់ទ្រង់តែងថ្វាយអង្គទ្រង់ជាយញ្ញបូជា ហើយលះបង់ដើម្បីមនុស្សជាតិរហូត។ ចំណែកឯមនុស្សវិញ គឺចេះតែយក និងខិតខំដើម្បីតែខ្លួនឯងប៉ុណ្ណោះ។ ព្រះជាម្ចាស់ទ្រាំរងនូវការឈឺចាប់ដើម្បីឲ្យមនុស្សជាតិមានជីវិតរស់រានរហូត ចំណែកមនុស្សវិញ ពុំដែលរួមចំណែកអ្វីដល់ពន្លឺ ឬដើម្បីសេចក្ដីសុចរិតឡើយ។ បើទោះបីជាមនុស្សខំប្រឹងយ៉ាងណាក៏ដោយ ក៏មិនអាចធន់នឹងការវាយប្រហារបានសូម្បីតែមួយលើក ដ្បិតការខិតខំរបស់មនុស្ស រមែងធ្វើឡើងដើម្បីប្រយោជន៍ផ្ទាល់ខ្លួនតែប៉ុណ្ណោះ មិនមែនដើម្បីប្រយោជន៍អ្នកដទៃឡើយ។ មនុស្សរមែងមានចិត្តអាត្មានិយម ចំណែកឯព្រះជាម្ចាស់វិញ ព្រះអង្គលះបង់ជានិច្ច។ ព្រះជាម្ចាស់ជាប្រភពនៃភាពសុចរិត ភាពល្អ

ប្រពៃ និងភាពស្រស់បំព្រងគ្រប់យ៉ាង ចំណែកមនុស្សវិញ គេបានជោគជ័យ ហើយស្ដែងឲ្យឃើញភាពស្មោកគ្រោក និងការអាក្រក់គ្រប់យ៉ាងទាំងអស់។ ព្រះជាម្ចាស់នឹងមិនកែប្រែសារជាតិនៃភាពសុចរិត និងសោភណភាពរបស់ទ្រង់ឡើយ ចំណែកឯមនុស្សវិញ ទោះជានៅទីណា ពេលណា ក៏គេមានសមត្ថភាពឥតខ្ចោះ ក្នុងការក្បត់ភាពសុចរិត ហើយគេចចេញពីព្រះជាម្ចាស់ផង។

គ្រប់ប្រយោគដែលខ្ញុំបានថ្លែងប្រាប់ សុទ្ធតែបង្កប់នូវនិស្ស័យរបស់ព្រះជាម្ចាស់។ អ្នករាល់គ្នាគួរខំប្រឹងសញ្ជឹងគិតអំពីព្រះបន្ទូលរបស់ខ្ញុំដោយយកចិត្តទុកដាក់ នោះអ្នករាល់គ្នា នឹងទទួលផលពីព្រះបន្ទូលនេះជាប្រាកដ។ សារជាតិរបស់ព្រះជាម្ចាស់ពិបាកនឹងយល់ណាស់ ប៉ុន្តែខ្ញុំជឿជាក់ថា យ៉ាងហោចណាស់អ្នករាល់គ្នានឹងបានដឹងខ្លះអំពីនិស្ស័យរបស់ព្រះជាម្ចាស់ដែរ។ ពេលនោះខ្ញុំសង្ឃឹមថា អ្នកនឹងមានអ្វីបន្ថែមទៀតឲ្យខ្ញុំឃើញពីរឿងរ៉ាវដែលអ្នកបានធ្វើ ដែលមិនបំពានដល់និស្ស័យរបស់ព្រះជាម្ចាស់។ ពេលនោះ ខ្ញុំនឹងរឹតតែមានទំនុកចិត្ត។ ឧទាហរណ៍ដូចជាឲ្យព្រះជាម្ចាស់គង់ក្នុងចិត្តអ្នករាល់គ្នាគ្រប់ពេលវេលា។ កាលណាអ្នកធ្វើអ្វីមួយ ចូរធ្វើការនោះឲ្យស្របទៅនឹងព្រះបន្ទូលរបស់ទ្រង់។ ចូរឈ្វេងយល់ពីបំណងព្រះហឫទ័យរបស់ទ្រង់ ក្នុងគ្រប់កិច្ចការទាំងអស់ ហើយរក្សាខ្លួនពីការប្រព្រឹត្តនូវទង្វើទាំងឡាយណា ដែលនាំឲ្យគេមើលងាយ និងបង្អាប់ដល់ព្រះជាម្ចាស់។ អ្នកក៏រឹតតែពុំគួរដកព្រះជាម្ចាស់ចេញពីគំនិតរបស់អ្នក ដើម្បីបំពេញអនាគតដែលនៅចន្លោះក្នុងចិត្តរបស់អ្នកដែរ។ ប្រសិនបើអ្នកធ្វើដូច្នេះ អ្នកមុខជាបំពាននិស្ស័យរបស់ព្រះជាម្ចាស់ហើយ។ ឧបមាថា អ្នកពុំដែលនិយាយប្រមាថ ឬរអ៊ូរទាំទាស់នឹងព្រះជាម្ចាស់សោះក្នុងមួយជីវិតរបស់អ្នក ហើយឧបមាទៀតថា អ្នកអាចបោះបង់ទ្រព្យសម្បត្តិគ្រប់យ៉ាង ដែលទ្រង់បានប្រទានមកឲ្យអ្នក ហើយអាចចុះចូលចំពោះព្រះបន្ទូលទាំងអស់របស់ទ្រង់ពេញមួយជីវិតរបស់អ្នក ពេលនោះ អ្នកនឹងបានចៀសផុតពីសេចក្ដីរំលង ដែលប្រព្រឹត្តទាស់នឹងបញ្ញត្តិគ្រប់គ្រងនោះហើយ។ ឧទាហរណ៍ ប្រសិនបើអ្នកធ្លាប់និយាយថា «ហេតុអ្វីបានជាខ្ញុំមិនគិតសោះថា ទ្រង់ជាព្រះជាម្ចាស់?» «ខ្ញុំគិតថា ព្រះបន្ទូលទាំងអស់នេះ គ្មានន័យ

អ្វីទេ គ្រាន់តែជាការបំភ្លឺពីព្រះវិញ្ញាណបរិសុទ្ធតែប៉ុណ្ណោះ» «ចំពោះគំនិតរបស់ខ្ញុំវិញ ខ្ញុំគិតថា មិនមែនគ្រប់យ៉ាងដែលព្រះជាម្ចាស់ទ្រង់ធ្វើសុទ្ធតែត្រូវរហូតនោះទេ» «ភាពជាមនុស្សរបស់ព្រះជាម្ចាស់ មិនប្រសើរជាងខ្ញុំនោះទេ» «ព្រះបន្ទូលរបស់ព្រះជាម្ចាស់គ្មានអ្វីគួរឲ្យជឿទេ» ឬក៏ធ្លាប់និយាយសម្ដីវិនិច្ឆ័យដទៃទៀត នោះខ្ញុំទូន្មានអ្នករាល់គ្នាឲ្យលន់តួ ហើយប្រែចិត្តពីអំពើបាបរបស់ខ្លួនឲ្យបានរឿយៗជាងនេះ។ ពុំនោះទេអ្នកនឹងគ្មានឱកាសទទួលបានការអត់ទោសសោះឡើយ ដ្បិតអ្នកមិនមែនបំពានមនុស្សទេ តែបំពានព្រះជាម្ចាស់ផ្ទាល់ព្រះអង្គវិញ។ អ្នកប្រហែលជាគិតថា អ្នកកំពុងវិនិច្ឆ័យមនុស្ស ប៉ុន្តែព្រះវិញ្ញាណនៃព្រះជាម្ចាស់ មិនមានព្រះតម្រិះដូច្នេះឡើយ។ ការដែលអ្នកប្រមាថសាច់ឈាមរបស់ទ្រង់ គឺស្មើនឹងប្រមាថដល់ទ្រង់ហើយ។ ដូច្នេះ អ្នកមិនបានបំពាននិស្ស័យរបស់ព្រះជាម្ចាស់ទេ មែនទេ? អ្នកត្រូវចងចាំថា គ្រប់កិច្ចការដែលបានធ្វើឡើងដោយព្រះវិញ្ញាណនៃព្រះជាម្ចាស់ គឺត្រូវបានធ្វើឡើង ដើម្បីរក្សាការពារកិច្ចការរបស់ព្រះអង្គនៅក្នុងសាច់ឈាម និងដើម្បីឲ្យកិច្ចការនោះសម្រេចបានយ៉ាងប្រសើរ។ ប្រសិនបើអ្នកមិនអើពើចំពោះរឿងនេះ នោះខ្ញុំសូមមានបន្ទូលប្រាប់អ្នករាល់គ្នាឲ្យដឹងថា អ្នកជាមនុស្សដែលពុំអាចទទួលបានជោគជ័យ ក្នុងការជឿលើព្រះជាម្ចាស់ឡើយ។ ដោយព្រោះអ្នករាល់គ្នាបានជំរុញសេចក្ដីក្រោធរបស់ព្រះជាម្ចាស់ ហេតុដូច្នេះហើយទ្រង់នឹងប្រើទណ្ឌកម្មដ៏សក្តិសម មកបង្រៀនមេរៀនមួយដល់អ្នកវិញ។

ការស្គាល់ពីសារជាតិរបស់ព្រះជាម្ចាស់ មិនមែនជារឿងឥតបានការទេ។ អ្នករាល់គ្នាត្រូវតែយល់អំពីនិស្ស័យរបស់ទ្រង់។ តាមវិធីនេះ អ្នកនឹងបានស្គាល់ពីសារជាតិរបស់ព្រះជាម្ចាស់បន្តិចម្ដងៗ ទាំងមិនដឹងខ្លួន។ កាលណាអ្នកបានដឹងអំពីរឿងនេះហើយ អ្នកប្រាកដជាឃើញខ្លួនឯងកំពុងឈានជើងចូលក្នុងសភាពដែលខ្ពង់ខ្ពស់ជាងមុន និងស្រស់បំព្រងជាងមុន។ ទីបំផុត អ្នកនឹងមានអារម្មណ៍ខ្មាសចំពោះព្រលឹងដ៏អាក្រក់របស់អ្នក ហើយលើសពីនេះ អ្នកនឹងមានអារម្មណ៍ថា គ្មានកន្លែងណាដើម្បីលាក់ពីភាពអាម៉ាស់របស់អ្នកបានឡើយ។ គ្រានោះ អ្នកនឹងកាន់តែលែងប្រព្រឹត្តទង្វើដែលបំពានដល់និស្ស័យរបស់ព្រះជាម្ចាស់តទៅទៀត ដួងចិត្តរបស់អ្នកនឹងចូលទៅកាន់

តែកៀកនឹងព្រះជាម្ចាស់ ហើយសេចក្ដីស្រឡាញ់របស់អ្នកចំពោះព្រះអង្គ ក៏កាន់តែចម្រើនឡើងនៅក្នុងដួងចិត្តរបស់អ្នកដែរ។ នេះហើយជាសញ្ញារបស់មនុស្សជាតិដែលកំពុងចូលទៅក្នុងសភាពស្រស់បំព្រង។ ដោយឡែក អ្នករាល់គ្នាមិនទាន់សម្រេចរឿងនេះបាននៅឡើយទេ។ កាលណាអ្នករាល់គ្នាប្រញាប់ប្រញាល់សម្រេចជោគវាសនារបស់ខ្លួន តើនរណាខ្លះមានចិត្តចង់ព្យាយាមស្គាល់ពីសារជាតិរបស់ព្រះជាម្ចាស់? បើនៅតែបែបនេះ អ្នករាល់គ្នានឹងប្រព្រឹត្តរំលងទាស់នឹងបញ្ញត្តិគ្រប់គ្រងទាំងមិនដឹងខ្លួន ដ្បិតអ្នករាល់គ្នាយល់ដឹងអំពីនិស្ស័យរបស់ព្រះជាម្ចាស់បានតិចតួចណាស់។ ដូច្នេះតើកិច្ចការដែលអ្នករាល់គ្នាធ្វើពេលនេះ មិនមែនកំពុងចាក់គ្រឹះសម្រាប់ការប្រព្រឹត្តទាស់នឹងនិស្ស័យរបស់ព្រះជាម្ចាស់ទេឬអី? ថាខ្ញុំបង្គាប់ឲ្យអ្នករាល់គ្នាយល់អំពីនិស្ស័យរបស់ព្រះជាម្ចាស់ គឺមិនដាច់ចេញពីកិច្ចការរបស់ខ្ញុំទេ។ ដ្បិតប្រសិនបើអ្នករាល់គ្នាប្រព្រឹត្តរំលងនឹងបញ្ញត្តិគ្រប់គ្រងជារឿយៗ តើមាននរណាក្នុងចំណោមអ្នករាល់គ្នា ដែលនឹងគេចផុតពីទណ្ឌកម្មបាន? តើពេលនោះ កិច្ចការរបស់ខ្ញុំនឹងទៅជាអសារឥតការទាំងស្រុងទៅហើយមែនទេ? ហេតុនេះ ខ្ញុំនៅតែបង្គាប់ឲ្យអ្នករាល់គ្នាប្រុងប្រយ័ត្នចំពោះជំហានដែលអ្នកដើរ បន្ថែមទៅលើការពិនិត្យពិច័យ ការប្រព្រឹត្តរបស់អ្នកផ្ទាល់។ នេះគឺជាសេចក្ដីបង្គាប់ដ៏ឧត្តមដែលខ្ញុំបង្គាប់ពីអ្នករាល់គ្នា ហើយខ្ញុំសង្ឃឹមថាអ្នករាល់គ្នានឹងពិចារណាពីសេចក្ដីបង្គាប់នេះដោយយកចិត្តទុកដាក់ ហើយគិតគូរអំពីសេចក្ដីបង្គាប់នេះដោយស្មោះអស់ពីចិត្ត។ គង់មានថ្ងៃមួយមកដល់ គឺជាពេលដែលទង្វើរបស់អ្នករាល់គ្នា ជំរុញឲ្យខ្ញុំមានសេចក្ដីក្រោធយ៉ាងខ្លាំងក្លា នោះលទ្ធផលដែលត្រូវពិចារណា គឺជារបស់អ្នករាល់គ្នាសុទ្ធសាធ ហើយគ្មាននរណាផ្សេងទៀត មកទទួលទណ្ឌកម្មជួសអ្នករាល់គ្នាឡើយ។

# វិធីស្គាល់ព្រះដែលគង់នៅលើផែនដី

អ្នករាល់គ្នាប្រាថ្នាចង់ទទួលបានរង្វាន់នៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់ និងចង់ឲ្យព្រះជាម្ចាស់សព្វព្រះហឫទ័យនឹងអ្នករាល់គ្នា ព្រោះមនុស្សគ្រប់គ្នាសង្ឃឹមចង់បានរឿងបែបនេះ នៅពេលពួកគេចាប់ផ្ដើមជឿលើព្រះជាម្ចាស់ ព្រោះគ្រប់គ្នាវក់នឹងការដេញតាមភាពខ្ពង់ខ្ពស់ ហើយគ្មានមនុស្សណាចង់នៅក្រោមអ្នកដទៃនោះទេ។ មនុស្សគឺបែបនេះហើយ។ ច្បាស់ណាស់ ដោយសារហេតុផលនេះ ក្នុងចំណោមអ្នករាល់គ្នាមានមនុស្សជាច្រើនតែងតែប្រឹងប្រែង ដើម្បីទទួលបានការគាំទ្រពីព្រះជាម្ចាស់ដែលគង់នៅស្ថានសួគ៌ ប៉ុន្តែតាមការពិត ភក្តីភាព និងភាពទៀងត្រង់របស់អ្នករាល់គ្នាចំពោះព្រះជាម្ចាស់ គឺតិចជាងភក្តីភាព និងភាពទៀងត្រង់ចំពោះខ្លួនអ្នកឆ្ងាយណាស់។ ហេតុអ្វីបានជាខ្ញុំនិយាយបែបនេះ? ព្រោះខ្ញុំមិនទទួលស្គាល់ភក្តីភាពរបស់អ្នករាល់គ្នាចំពោះព្រះជាម្ចាស់សោះឡើយ ហើយជាងនេះទៀត ព្រោះខ្ញុំហ៊ានប្រកែកថាដួងចិត្តរបស់អ្នករាល់គ្នាគ្មានព្រះជាម្ចាស់ឡើយ។ មានន័យថា ព្រះជាម្ចាស់ដែលអ្នករាល់គ្នាថ្វាយបង្គំ គឺព្រះជាម្ចាស់ដ៏ស្រពេចស្រពិលដែលអ្នករាល់គ្នាលើកសរសើរតម្កើងនោះគ្មានវត្តមានសោះឡើយ។ ហេតុផលដែលខ្ញុំអាចនិយាយបាន យ៉ាងច្បាស់ដូច្នេះ ព្រោះអ្នករាល់គ្នានៅឆ្ងាយពីព្រះដ៏ពិតខ្លាំងពេក។ ហេតុផលសម្រាប់ភក្តីភាពរបស់អ្នករាល់គ្នា គឺរូបព្រះដែលស្ថិតនៅក្នុងចិត្តរបស់អ្នករាល់គ្នា ហើយនៅពេលនេះ ចំពោះខ្ញុំវិញ អ្នករាល់គ្នាគ្រាន់តែទទួលស្គាល់ព្រះជាម្ចាស់ដែលអ្នករាល់គ្នាគិតថាមិនធំ ក៏មិនតូចតាមពាក្យសម្ដីប៉ុណ្ណោះ។ នៅពេលខ្ញុំនិយាយថា អ្នករាល់គ្នានៅឆ្ងាយពីព្រះជាម្ចាស់នោះ គឺខ្ញុំចង់មានន័យថា អ្នករាល់គ្នាឃ្លាតឆ្ងាយពីព្រះដ៏ពិត ខណៈដែលព្រះដ៏ស្រពេចស្រពិលនោះហាក់ដូចជាស្ថិតនៅក្បែរខ្លួនអ្នករាល់គ្នាទៅវិញ។ នៅពេលខ្ញុំនិយាយថា «មិនធំ» នោះគឺខ្ញុំចង់សំដៅលើព្រះដែលអ្នករាល់គ្នាជឿសព្វថ្ងៃនេះ ទំនងគ្រាន់តែជាបុគ្គលមួយរូបដែលគ្មានសមត្ថភាពអស្ចារ្យអ្វីនោះទេ គឺជាបុគ្គលដែលមិនមានភាពខ្ពង់ខ្ពស់អ្វីឡើយ។ ហើយនៅពេលខ្ញុំនិយាយថា «មិនតូច» ខ្ញុំចង់មានន័យថាទោះបីជា

បុគ្គលនេះមិនអាចហៅខ្យល់ហៅភ្លៀងបានក៏ដោយ ប៉ុន្តែទ្រង់អាចហៅព្រះវិញ្ញាណរបស់ព្រះជាម្ចាស់មកធ្វើកិច្ចការដែលធ្វើឲ្យស្ថានសួគ៌ និងផែនដីញ័ររញ្ជួយបាន ដែលនឹងធ្វើឲ្យមនុស្សស្រឡាំងកាំង។ មើលពីខាងក្រៅ អ្នករាល់គ្នាហាក់ដូចជាស្ដាប់បង្គាប់ចំពោះព្រះគ្រីស្ទដែលគង់នៅលើផែនដី ប៉ុន្តែតាមពិត អ្នករាល់គ្នាមិនមានសេចក្ដីជំនឿលើទ្រង់ឡើយ ហើយក៏មិនស្រឡាញ់ទ្រង់ដែរ។ នេះមានន័យថា ព្រះដែលអ្នករាល់គ្នាជឿយ៉ាងពិតប្រាកដ គឺគ្រាន់តែជាព្រះដ៏ស្រពេចស្រពិល នៅក្នុងអារម្មណ៍ផ្ទាល់ខ្លួនរបស់អ្នករាល់គ្នាប៉ុណ្ណោះ ហើយព្រះដែលអ្នករាល់គ្នាស្រឡាញ់យ៉ាងពិតប្រាកដ ដែលអ្នករាល់គ្នាចង់បានយ៉ាងខ្លាំងទាំងថ្ងៃទាំងយប់ គឺអ្នករាល់គ្នាមិនដែលបានឃើញទ្រង់ផ្ទាល់សោះឡើយ។ ចំពោះព្រះគ្រីស្ទ សេចក្ដីជំនឿរបស់អ្នករាល់គ្នា គឺមានតិចតួចប៉ុណ្ណោះ ចំណែកក្ដីស្រឡាញ់របស់អ្នករាល់គ្នាវិញគឺគ្មានសោះឡើយ។ សេចក្ដីជំនឿមានន័យថា ការជឿ និងការទុកចិត្ត ចំណែកក្ដីស្រឡាញ់វិញមានន័យថាការចូលចិត្តយ៉ាងខ្លាំង និងការលើកសរសើរនៅក្នុងដួងចិត្តរបស់នរណាម្នាក់ និងមិនអាចបំបែកពីគ្នាបានឡើយ។ ប៉ុន្តែសេចក្ដីជំនឿ និងក្ដីស្រឡាញ់របស់អ្នករាល់គ្នាចំពោះព្រះគ្រីស្ទនៅសព្វថ្ងៃនេះ មិនទាន់គ្រប់គ្រាន់នៅឡើយទេ។ នៅពេលនិយាយដល់សេចក្ដីជំនឿ តើអ្នករាល់គ្នាមានសេចក្ដីជំនឿលើទ្រង់យ៉ាងដូចម្ដេច? នៅពេលនិយាយដល់ក្ដីស្រឡាញ់ តើអ្នករាល់គ្នាស្រឡាញ់ទ្រង់តាមរបៀបណា? អ្នករាល់គ្នាមិនមានការយល់ដឹងពីនិស្ស័យរបស់ទ្រង់ទាល់តែសោះ កុំថាឡើយអ្នករាល់គ្នាស្គាល់ពីសារជាតិរបស់ទ្រង់ ដូចនេះតើអ្នករាល់គ្នាមានសេចក្ដីជំនឿលើទ្រង់បានយ៉ាងដូចម្ដេច? តើការពិតនៃសេចក្ដីជំនឿរបស់អ្នករាល់គ្នាចំពោះទ្រង់ស្ថិតនៅកន្លែងណា? តើអ្នករាល់គ្នាស្រឡាញ់ទ្រង់យ៉ាងដូចម្ដេច? តើការពិតនៃក្ដីស្រឡាញ់របស់អ្នករាល់គ្នាចំពោះទ្រង់ស្ថិតនៅកន្លែងណា?

មនុស្សជាច្រើនបានដើរតាមខ្ញុំដោយគ្មានការស្ទាក់ស្ទើរមកទល់សព្វថ្ងៃនេះ។ ដូច្នេះ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ អ្នករាល់គ្នាក៏បានទទួលរងការនឿយហត់ជាច្រើនផងដែរ។ ខ្ញុំបានយល់យ៉ាងច្បាស់ពីចរិតពីកំណើត និងទម្លាប់របស់អ្នករាល់គ្នា ហើយការទាក់ទងជាមួយអ្នករាល់គ្នាក៏មានភាពលំបាកក្រៃលែងដែរ។ អ្វីដែលគួរឲ្យ

សោកស្ដាយនោះគឺថា ទោះបីជាខ្ញុំបានយល់ច្រើនពីអ្នករាល់គ្នាក៏ដោយ ក៏អ្នករាល់គ្នាមិនបានយល់អ្វីសោះពីខ្ញុំ។ គេមិនបាច់ឆ្ងល់ទេដែលមានមនុស្សនិយាយថា អ្នករាល់គ្នាជឿលើល្បិចកលរបស់នរណាម្នាក់ នៅអំឡុងពេលនៃការភាន់ច្រលំនោះ។ តាមពិតអ្នករាល់គ្នាមិនយល់អ្វីសោះពីនិស្ស័យរបស់ខ្ញុំ កុំថាឡើយអ្នករាល់គ្នាអាចយល់បានពីអ្វីដែលមាននៅក្នុងចិត្តរបស់យើងនោះ។ សព្វថ្ងៃនេះ ការយល់ខុសរបស់អ្នករាល់គ្នាអំពីខ្ញុំ គឺកំពុងកើនឡើងយ៉ាងរហ័ស ហើយសេចក្ដីជំនឿរបស់អ្នករាល់គ្នាចំពោះខ្ញុំ ក៏នៅតែជាសេចក្ដីជំនឿដែលភាន់ច្រលំដដែល។ គួរតែនិយាយថា អ្នករាល់គ្នាកំពុងព្យាយាមយកព្រះហឫទ័យខ្ញុំ និងអែបអបខ្ញុំវិញ ជាជាងនិយាយថាអ្នករាល់គ្នាមានសេចក្ដីជំនឿលើខ្ញុំ បំណងរបស់អ្នករាល់គ្នាសាមញ្ញខ្លាំងណាស់គឺ៖ ខ្ញុំចង់ដើរតាមនរណាដែលអាចផ្ដល់រង្វាន់ដល់ខ្ញុំ ហើយខ្ញុំនឹងជឿលើអ្នកណាដែលអាចឲ្យខ្ញុំគេចផុតពីមហន្តរាយដ៏ធំធេងនេះ មិនថាអ្នកនោះជាព្រះជាម្ចាស់ ឬជាព្រះណាមួយនោះទេ គឺខ្ញុំមិនខ្វល់ឡើយ។ មានមនុស្សជំពូកនេះច្រើនណាស់ក្នុងចំណោមអ្នករាល់គ្នាហើយស្ថានភាពនេះមានភាពធ្ងន់ធ្ងរណាស់។ ថ្ងៃណាមួយ ប្រសិនបើមានការសាកល្បងថាមានមនុស្សប៉ុន្មានអ្នកក្នុងចំណោមអ្នករាល់គ្នាមានសេចក្ដីជំនឿលើព្រះគ្រីស្ទដោយសារតែការជ្រួតជ្រាបអំពីព្រះវិញ្ញាណរបស់ព្រះអង្គ នោះខ្ញុំខ្លាចថាគ្មានអ្នកណាម្នាក់នៅក្នុងចំណោមអ្នករាល់គ្នានឹងធ្វើឲ្យខ្ញុំសព្វព្រះហឫទ័យឡើយ។ ដូច្នេះ សម្រាប់អ្នករាល់គ្នា ការពិចារណាលើសំណួរនេះ គឺមិនបង្កការឈឺចាប់អ្វីឡើយព្រោះថាព្រះដែលអ្នករាល់គ្នាជឿគឺខុសឆ្ងាយពីខ្ញុំខ្លាំងណាស់ ហើយបើដូច្នោះមែន តើចំណុចសំខាន់នៃសេចក្ដីជំនឿរបស់អ្នករាល់គ្នាចំពោះព្រះជាម្ចាស់គឺជាអ្វី? នៅពេលអ្នករាល់គ្នាកាន់តែជឿលើបុគ្គលដែលអ្នករាល់គ្នាហៅថាជាព្រះ នោះអ្នករាល់គ្នានឹងកាន់តែឃ្លាតឆ្ងាយពីខ្ញុំ។ ដូចនោះ តើចំណុចសំខាន់នៃបញ្ហានេះគឺជាអ្វី? វាច្បាស់ណាស់ថា គ្មាននរណាម្នាក់ក្នុងចំណោមអ្នករាល់គ្នាធ្លាប់ពិចារណាសំណួរនេះទេ ប៉ុន្តែតើចំណុចសំខាន់នៃសំណួរនេះធ្លាប់បានកើតឡើងចំពោះអ្នករាល់គ្នាឬទេ? តើអ្នករាល់គ្នាធ្លាប់បានគិតពីផលវិបាកនៃការបន្តជឿតាមរបៀបនេះឬទេ?

សព្វថ្ងៃនេះ អ្នករាល់គ្នាប្រឈមនឹងបញ្ហាជាច្រើន ហើយគ្មាននរណាម្នាក់ក្នុងចំណោមអ្នករាល់គ្នាមានជំនាញខាងដោះស្រាយបញ្ហានោះទេ។ ប្រសិនបើស្ថានភាពនេះនៅតែបន្ត អ្នកដែលអាចខាតបង់ គឺមានតែខ្លួនអ្នករាល់គ្នាប៉ុណ្ណោះ។ យើងនឹងជួយអ្នករាល់គ្នាឲ្យមើលស្គាល់បញ្ហាទាំងនេះ ប៉ុន្តែការដោះស្រាយ គឺអាស្រ័យលើអ្នករាល់គ្នាប៉ុណ្ណោះ។

យើងសព្វព្រះហឫទ័យចំពោះអស់អ្នកដែលមិនសង្ស័យលើអ្នកដទៃ ហើយយើងចូលចិត្តអស់អ្នក ដែលសុខចិត្តទទួលយកសេចក្ដីពិត ព្រោះយើងបង្ហាញការយកព្រះទ័យទុកដាក់យ៉ាងខ្លាំង ចំពោះមនុស្សទាំងពីរប្រភេទនេះ ដ្បិតពួកគេជាមនុស្សស្មោះត្រង់នៅក្នុងព្រះនេត្ររបស់យើង។ ប្រសិនបើអ្នកមានគំនិតបោកប្រាស់គេ នោះអ្នកនឹងមានការប្រុងប្រយ័ត្នខ្លួន ហើយមានការសង្ស័យចំពោះមនុស្សគ្រប់គ្នា និងគ្រប់បញ្ហា ហេតុនេះហើយ សេចក្ដីជំនឿរបស់អ្នកចំពោះយើង នឹងកើតឡើងពីមូលដ្ឋានគ្រឹះនៃការសង្ស័យ។ យើងមិនអាចទទួលស្គាល់សេចក្ដីជំនឿបែបនេះបានទេ។ ដោយសារគ្មានសេចក្ដីជំនឿពិតប្រាកដ នោះអ្នកនឹងកាន់តែមិនមានក្ដីស្រឡាញ់ពិតប្រាកដ។ ហើយប្រសិនបើអ្នកអាចមានមន្ទិលសង្ស័យចំពោះព្រះជាម្ចាស់ និងទាយពីព្រះម្ចាស់តាមតែអំពើចិត្តរបស់អ្នក នោះអ្នកគឺជាជនបោកប្រាស់ខ្លាំងជាងគេបំផុត មិនចាំបាច់បកស្រាយអ្វីទេ។ អ្នកទាយថា ព្រះជាម្ចាស់អាចដូចជាមនុស្សបែបនេះថា៖ មានអំពើបាបដែលមិនអាចលើកលែងឲ្យបាន មានចរិតថោកទាប គ្មានភាពយុត្តិធម៌ និងហេតុផល គ្មានញាណដឹងពីសេចក្ដីយុត្តិធម៌ តែងតែមានកលល្បិចកាចសាហាវ ជាមនុស្សលាក់ពុត និងខូច សព្វហឫទ័យនឹងអំពើអាក្រក់ និងអំពើខ្មៅងងឹតជាដើម ។ល។ តើហេតុផលដែលមនុស្សមានគំនិតបែបនេះ មិនមែនដោយសារតែពួកគេមិនបានយល់ដឹងអ្វីទាល់តែសោះ ពីព្រះជាម្ចាស់ឬ? សេចក្ដីជំនឿបែបនេះ គឺគ្មានអ្វីក្រៅពីអំពើបាបនោះទេ! មានមនុស្សខ្លះទៀតថែមទាំងជឿថា អ្នកដែលអាចផ្គាប់ចិត្តយើងបាន គឺជាអ្នកដែលចេះបញ្ចោរ និងចេះលត់ក្រាប ហើយថាអ្នកដែលមិនមានជំនាញបែបនេះ នឹងមិនត្រូវបានស្វាគមន៍មកកាន់ដំណាក់របស់ព្រះជាម្ចាស់នោះទេ ហើយក៏

នឹងបាត់បង់កន្លែងរបស់ខ្លួននៅទីនោះដែរ។ តើនេះជាចំណេះដឹងតែមួយគត់ ដែលអ្នករាល់គ្នាទទួលបានក្នុងរយៈពេលច្រើនឆ្នាំមកនេះឬ? តើនេះជាអ្វីដែលអ្នករាល់គ្នាបានទទួលឬ? ហើយការយល់ខុសរបស់អ្នករាល់គ្នា ចំពោះយើងមិនបានឈប់ត្រឹងហ្នឹងនោះទេ ព្រោះថា អាក្រក់ជាងនេះទៀតនោះ គឺអ្នករាល់គ្នាបានប្រមាថព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ និងនិយាយអាក្រក់ពីស្ថានសួគ៌។ ដូច្នេះហើយបានជាយើងនិយាយថា សេចក្ដីជំនឿរបស់អ្នករាល់គ្នាបែបនេះ បានត្រឹមតែធ្វើឲ្យអ្នករាល់គ្នាឃ្លាតកាន់តែឆ្ងាយពីយើង និងកាន់តែប្រឆាំងនឹងយើងខ្លាំងថែមទៀតប៉ុណ្ណោះ។ តាមរយៈការងារជាច្រើនឆ្នាំ អ្នករាល់គ្នាបានមើលឃើញសេចក្ដីពិតជាច្រើន ប៉ុន្តែតើអ្នករាល់គ្នាមានបានដឹងពីអ្វី ដែលត្រចៀករបស់យើងបានស្ដាប់លឺទេ? តើក្នុងចំណោមអ្នករាល់គ្នាមានប៉ុន្មានអ្នក ដែលសុខចិត្តទទួលយកសេចក្ដីពិតនេះ? អ្នករាល់គ្នាសុទ្ធតែជឿថាអ្នករាល់គ្នាសុខចិត្តបង់នូវតម្លៃដើម្បីប្ដូរយកសេចក្ដីពិត ប៉ុន្តែក្នុងចំណោមអ្នករាល់គ្នាតើមានប៉ុន្មានអ្នកបានរងទុក្ខយ៉ាងពិតប្រាកដ ដើម្បីប្ដូរយកសេចក្ដីពិតនោះ? គ្មានអ្វីក្រៅពីសេចក្ដីទុច្ចរិតនៅក្នុងចិត្តរបស់អ្នករាល់គ្នាឡើយ ដែលធ្វើឲ្យអ្នករាល់គ្នាគិតថាគ្រប់គ្នាសុទ្ធតែមានគំនិតបោកប្រាស់ និងវៀចវេរដូចគ្នា មិនថាគេជានរណានោះទេ ហើយអ្នករាល់គ្នាថែមទាំងជឿបែបនេះទៀតថា ការត្រលប់ជាសាច់ឈាមរបស់ព្រះជាម្ចាស់ អាចមានលក្ខណៈដូចជាមនុស្សធម្មតា គឺគ្មានដួងចិត្តដែលសប្បុរស និងសេចក្ដីស្រឡាញ់ដែលប្រកបដោយមេត្ដាធម៌។ លើសពីនេះទៅទៀត អ្នករាល់គ្នាជឿថាចរិតដ៏ខ្ពង់ខ្ពស់ និងនិស្ស័យមេត្ដាធម៌ ព្រមទាំងអាណិតអាសូរ កើតមានតែនៅក្នុងព្រះជាម្ចាស់ ដែលគង់នៅស្ថានសួគ៌ប៉ុណ្ណោះ។ អ្នករាល់គ្នាជឿថា មនុស្សបរិសុទ្ធបែបនេះមិនមាននៅលើលោកនេះទេ គឺមានតែអំពើខ្មៅងងឹត និងអំពើអាក្រក់ប៉ុណ្ណោះ ចំណែកព្រះជាម្ចាស់វិញ គឺគ្រាន់តែជារបស់ដែលមនុស្សដាក់ក្ដីប្រាថ្នារបស់ពួកគេចង់ឲ្យបានល្អ និងស្រស់ស្អាត តាមតួអង្គនៅរឿងព្រេងនិទានដែលពួកគេបានប្រឌិតឡើងប៉ុណ្ណោះ។ នៅក្នុងចិត្តគំនិតរបស់អ្នករាល់គ្នា ព្រះជាម្ចាស់ដែលគង់នៅស្ថានសួគ៌ គឺទៀងត្រង់ សុចរិត និង អស្ចារ្យ ដែលស័ក្ដិសមនឹងការគោរពបូជា និង ការលើកសរសើរ

ប៉ុន្ដែចំណែកព្រះជាម្ចាស់ដែលគង់នៅលើផែនដីវិញ គឺគ្រាន់តែជាអ្នកជំនួស និងជាឧបករណ៍របស់ព្រះជាម្ចាស់ដែលគង់នៅស្ថានសួគ៌ប៉ុណ្ណោះ។ អ្នកជឿថាព្រះជាម្ចាស់អង្គនេះមិនអាចប្រៀបស្មើនឹងព្រះជាម្ចាស់ដែលគង់ស្ថានសួគ៌បានទេ កុំថាឡើយយកមកប្រៀបធៀបនឹងទ្រង់នោះ។ នៅពេលនិយាយពីភាពអស្ចារ្យ និង កិត្ដិយសរបស់ព្រះជាម្ចាស់វិញ ទាំងនោះគឺ ជាផ្នែកមួយនៃសិរីរុងរឿងរបស់ព្រះម្ចាស់ដែលគង់នៅស្ថានសួគ៌ ប៉ុន្ដែនៅពេលនិយាយដល់និស្ស័យ និងការខូចអាក្រក់របស់មនុស្សវិញ ទាំងនោះគឺជាលក្ខណៈដែលជាប់មកជាមួយនឹងព្រះជាម្ចាស់ដែលគង់នៅលើផែនដី។ ព្រះជាម្ចាស់ដែលគង់នៅស្ថានសួគ៌ គឺមានភាពខ្ពង់ខ្ពស់ជានិច្ច ចំណែកព្រះជាម្ចាស់ដែលគង់នៅលើផែនដីវិញ គឺមិនសំខាន់ ទន់ខ្សោយ និងគ្មានសមត្ថភាពជារៀងរហូត ព្រះជាម្ចាស់ដែលគង់នៅស្ថានសួគ៌មិនមានមនោសញ្ចេតនានោះទេ គឺមានតែសេចក្ដីសុចរិតប៉ុណ្ណោះ ចំណែកព្រះជាម្ចាស់ដែលគង់នៅលើផែនដីវិញ គឺមានតែហេតុផលអត្មានិយម និងគ្មានភាពយុត្ដិធម៌ ឬហេតុផលនោះទេ។ ព្រះជាម្ចាស់ដែលគង់នៅស្ថានសួគ៌ មិនវៀចវេរសោះឡើយ និងមានភាពស្មោះត្រង់ជានិច្ច ចំណែកព្រះជាម្ចាស់ដែលគង់នៅលើផែនដី គឺតែងតែគ្មានភាពទៀងត្រង់។ ព្រះជាម្ចាស់ដែលគង់នៅស្ថានសួគ៌ ស្រឡាញ់មនុស្សខ្លាំងណាស់ ចំណែកព្រះជាម្ចាស់ដែលគង់នៅលើផែនដីវិញ បង្ហាញការយកចិត្ដទុកដាក់ចំពោះមនុស្សមិនគ្រប់គ្រាន់ និងថែមទាំងមិនអើពើនឹងពួកគេទៀតផង។ ការយល់ដឹងខុសឆ្គងនេះ បានស្ថិតនៅក្នុងចិត្ដរបស់អ្នករាល់គ្នាជាយូរមកហើយ ហើយក៏អាចបន្ដទៅអនាគតបានថែមទៀតផង។ អ្នករាល់គ្នាគិតដល់ទង្វើរបស់ព្រះគ្រីស្ទតាមទស្សនៈរបស់ពួកទុច្ចរិត និងវាយតម្លៃគ្រប់ការងារទាំងអស់របស់ទ្រង់ ព្រមទាំងអត្ដសញ្ញាណ និងព្រះវិញ្ញាណរបស់ទ្រង់តាមទស្សនៈរបស់ពួកមនុស្សអាក្រក់។ អ្នករាល់គ្នាបានបង្កើតកំហុសដ៏ធ្ងន់ធ្ងរ និងបានធ្វើរឿងដែល មិនធ្លាប់មាននរណាបានធ្វើពីមុនមកទេ។ បានន័យថា អ្នករាល់គ្នាបម្រើតែព្រះដែលខ្ពង់ខ្ពស់ដែលគង់នៅស្ថានសួគ៌ ដែលមានមកុដនៅលើព្រសិរសារបស់ទ្រង់ប៉ុណ្ណោះ និងមិនបម្រើព្រះដែលអ្នករាល់គ្នាគិតថាមិនសំខាន់សោះរហូតដល់មើលមិនឃើញទ្រង់។ តើ

នេះមិនមែនអំពើបាបរបស់អ្នករាល់គ្នាទេឬ? តើនេះមិនមែនជាឧទាហរណ៍ទូទៅដែលបង្ហាញពីការប្រមាថនិស្ស័យរបស់ព្រះរបស់អ្នករាល់គ្នាទេឬ? អ្នករាល់គ្នាចូលចិត្តរូបអង្គដ៏ខ្ពង់ខ្ពស់ និងឲ្យតម្លៃដល់អ្នកដែលចំណានខាងវោហាស័ព្ទបញ្ចុះបញ្ចូល។ អ្នករីករាយនឹងទទួលបញ្ជាពីព្រះជាម្ចាស់ដែលបានញាត់មាសប្រាក់ពេញដៃរបស់អ្នក និងចង់បានព្រះជាម្ចាស់ដែលអាចបំពេញគ្រប់សេចក្ដីប្រាថ្នារបស់អ្នក។ ព្រះមួយអង្គដែលអ្នកមិនថ្វាយបង្គំ គឺជាព្រះជាម្ចាស់ដែលគ្មានភាពខ្ពស់ខ្ពស់ ហើយរឿងតែមួយគត់ដែលអ្នកស្អប់ គឺទាក់ទងនឹងព្រះជាម្ចាស់ ដែលគ្មានមនុស្សណាគោរព។ រឿងតែមួយគត់ដែលអ្នកមិនសុខចិត្តធ្វើ គឺបម្រើព្រះជាម្ចាស់ដែលមិនដែលផ្ដល់ប្រាក់សូម្បីមួយសេនដល់អ្នក ហើយព្រះមួយអង្គដែលមិនអាចធ្វើឲ្យអ្នកចង់បានទ្រង់ គឺព្រះជាម្ចាស់ដែលមិនគួរឲ្យស្រឡាញ់នេះហើយ។ ព្រះជាម្ចាស់នេះ មិនអាចធ្វើឲ្យអ្នកពង្រីកចំណេះដឹងរបស់អ្នកបាន ហើយមិនអាចឲ្យអ្នកមានអារម្មណ៍ដូចជាអ្នករកបានកំណប់នោះទេ កុំថាឡើយបំពេញតាមសេចក្ដីប្រាថ្នារបស់អ្នក។ ដូចនោះ ហេតុអ្វីបានជាអ្នកដើរតាមទ្រង់? តើអ្នកធ្លាប់បានគិតដល់សំណួរបែបនេះទេ? អ្វីដែលអ្នកធ្វើមិនត្រឹមតែប្រមាថដល់ព្រះគ្រីស្ទនោះទេ សំខាន់ជាងនេះទៀតនោះ គឺវាថែមទាំងប្រមាថដល់ព្រះជាម្ចាស់ដែលគង់នៅស្ថានសួគ៌ថែមទៀតផង។ ខ្ញុំគិតថា នេះមិនមែនជាគោលបំណងនៃសេចក្ដីជំនឿរបស់អ្នករាល់គ្នាចំពោះព្រះជាម្ចាស់ទេ!

អ្នករាល់គ្នាចង់ឲ្យព្រះជាម្ចាស់សព្វព្រះហឫទ័យនឹងអ្នករាល់គ្នា ប៉ុន្តែអ្នករាល់គ្នាស្ថិតនៅឆ្ងាយពីព្រះម្ចាស់។ តើអ្វីជាបញ្ហានៅទីនេះ? អ្នករាល់គ្នាទទួលតែព្រះបន្ទូលរបស់ទ្រង់ ប៉ុន្តែមិនទទួលយកការដោះស្រាយ និងការលួសកាត់របស់ទ្រង់ កុំថាឡើយអ្នកអាចទទួលយក គ្រប់ការរៀបចំរបស់ទ្រង់ ដើម្បីមានជំនឿពេញលេញចំពោះទ្រង់។ ដូចនោះ តើអ្វីជាបញ្ហានៅទីនេះ? នៅក្នុងការវិភាគចុងក្រោយ សេចក្ដីជំនឿរបស់អ្នករាល់គ្នា គឺជាសម្បកស៊ុតទទេមួយ ដែលមិនអាចញាស់ជាកូនមាន់បានទេ។ ព្រោះសេចក្ដីជំនឿរបស់អ្នករាល់គ្នាមិនបាននាំសេចក្ដីពិតមកដល់អ្នករាល់គ្នាឬក៏ផ្ដល់ជីវិតដល់អ្នក ប៉ុន្តែផ្ទុយមកវិញ បានផ្ដល់ឲ្យអ្នករាល់គ្នានូវញាណបំភាន់ភ្នែកអំពីការ

ទ្រទ្រង់ជីវិត និងក្ដីសង្ឃឹម។ គឺញាណនៃកាទ្រទ្រង់ជីវិត និងក្ដីសង្ឃឹមនេះហើយ ដែលជាគោលបំណងរបស់អ្នករាល់គ្នា ក្នុងការជឿលើព្រះជាម្ចាស់ គឺមិនមែនជាសេចក្ដីពិត និងជីវិតនោះទេ។ ហេតុនេះហើយទើបខ្ញុំនិយាយថា រយៈពេលនៃសេចក្ដីជំនឿរបស់អ្នករាល់គ្នាចំពោះព្រះជាម្ចាស់ គ្មានអ្វីក្រៅពីការព្យាយាមដើម្បីទទួលបានការគាំទ្រពីព្រះជាម្ចាស់ តាមរយៈទាសភាព និងភាពឥតអៀនខ្មាសនោះទេ ហើយក៏មិនអាចចាត់ទុកថាជាសេចក្ដីជំនឿពិតប្រាកបានដែរ។ តើកូនមាន់អាចកើតចេញពីសេចក្ដីជំនឿបែបនេះបានយ៉ាងដូចម្ដេច? អាចនិយាយម្យ៉ាងទៀតបានថាតើសេចក្ដីជំនឿបែបនេះអាចសម្រេចបានអ្វីខ្លះ? គោលបំណងនៃសេចក្ដីជំនឿរបស់អ្នករាល់គ្នាចំពោះព្រះជាម្ចាស់ គឺប្រើប្រាស់ទ្រង់ ដើម្បីសម្រេចគោលបំណងរបស់ខ្លួន។ តើនេះមិនមែនជាការប្រមាថរបស់អ្នករាល់គ្នាចំពោះនិស្ស័យរបស់ព្រះជាម្ចាស់ទេឬ? អ្នករាល់គ្នាជឿថា ព្រះជាម្ចាស់ដែលគង់នៅលើស្ថានសួគ៌ មានពិតប្រាកដមែន និងបដិសេធថាព្រះជាម្ចាស់ដែលគង់នៅលើផែនដី មិនមានពិតប្រាកដទេ ប៉ុន្ដែយើងមិនទទួលស្គាល់ទស្សនៈរបស់អ្នករាល់គ្នាទេ ព្រោះយើងលើកសរសើរតែអ្នកណាដែលដាក់ជើងរបស់ខ្លួននៅលើដី ហើយបម្រើព្រះជាម្ចាស់ដែលគង់នៅលើផែនដីប៉ុណ្ណោះ ប៉ុន្ដែមិនសរសើរអ្នកណាដែលមិនទទួលស្គាល់ព្រះគ្រីស្ទដែលគង់នៅលើផែនដីនោះទេ។ មិនថាមនុស្សបែបនេះមានភក្ដីភាពចំពោះព្រះជាម្ចាស់ដែលគង់នៅស្ថានសួគ៌យ៉ាងណានោះទេ នៅទីបំផុត ពួកគេមិនអាចគេចផុតពីព្រះហស្ដរបស់យើងដែលនឹងដាក់ទោសមនុស្សអាក្រក់បានឡើយ។ មនុស្សទាំងនេះសុទ្ធតែជាមនុស្សអាក្រក់ ព្រោះពួកគេគឺជាមនុស្សធ្វើអំពើអាក្រក់ដែលប្រឆាំងនឹងព្រះជាម្ចាស់ និងមិនដែលបានស្ដាប់បង្គាប់ព្រះគ្រីស្ទដោយក្ដីរីករាយឡើយ។ ពិតណាស់ ចំនួនរបស់ពួកគេរាប់បញ្ចូលទាំងអស់អ្នកដែលមិនស្គាល់ព្រះគ្រីស្ទ និងជាងនេះទៀត មិនទទួលស្គាល់ព្រះគ្រីស្ទ។ ដរាបណាអ្នកមានភក្ដីភាពចំពោះព្រះជាម្ចាស់ដែលគង់នៅស្ថានសួគ៌ តើអ្នកជឿថាអ្នកអាចធ្វើអ្វីបានតាមចិត្តខ្លួនចំពោះព្រះគ្រីស្ទឬ? ខុសហើយ! ការមិនអើពើរបស់អ្នកចំពោះព្រះគ្រីស្ទ គឺជាការមិនអើចំពោះព្រះជាម្ចាស់ដែលគង់នៅស្ថានសួគ៌។

មិនថាអ្នកមានភក្ដីភាពចំពោះព្រះជាម្ចាស់ដែលគង់នៅស្ថានសួគ៌យ៉ាងណានោះទេ វាគ្រាន់តែជាសម្ដីដែលគ្មានន័យ និងការធ្វើពើប៉ុណ្ណោះ ព្រោះព្រះជាម្ចាស់ដែលគង់នៅលើផែនដី មិនគ្រាន់តែជាមធ្យោបាយសម្រាប់ឲ្យមនុស្សទទួលបានសេចក្ដីពិត និងចំណេះដឹងដ៏ជ្រៅជ្រះប៉ុណ្ណោះទេ ប៉ុន្តែលើសពីនេះទៅទៀត ទ្រង់គឺជាមធ្យោបាយក្នុងការថ្កោលទោសមនុស្ស និងបន្ទាប់មកជាមធ្យោបាយក្នុងការយកការពិតមកដាក់ទោសមនុស្សអាក្រក់។ តើអ្នកបានយល់ ពីលទ្ធផលដែលផ្ដល់ផលប្រយោជន៍ និងផលអាក្រក់នៅទីនេះឬទេ? តើអ្នកធ្លាប់ឆ្លងកាត់លទ្ធផលទាំងនេះឬទេ? យើងសូមជូនពរឲ្យអ្នករាល់គ្នាយល់ពីសេចក្ដីពិតនេះនៅថ្ងៃណាមួយឆាប់ៗនេះ ដែលថា ដើម្បីស្គាល់ព្រះជាម្ចាស់ អ្នកមិនត្រឹមតែត្រូវស្គាល់ព្រះជាម្ចាស់ដែលគង់នៅស្ថានសួគ៌ប៉ុណ្ណោះទេ ប៉ុន្តែសំខាន់ជាងនេះទៅទៀតនោះ គឺអ្នកត្រូវស្គាល់ព្រះជាម្ចាស់ដែលគង់នៅលើផែនដីផងដែរ។ ចូរកុំច្រលំពីរឿងអាទិភាពរបស់អ្នក ឬអនុញ្ញាតឲ្យរឿងបន្ទាប់បន្សំជំនួសរឿងសំខាន់ឡើយ។ មានតែតាមវិធីនេះទេ ទើបអ្នកអាចកសាងទំនាក់ទំនងល្អជាមួយព្រះជាម្ចាស់បានពិតប្រាកដ និងកាន់តែខិតជិតព្រះជាម្ចាស់ ព្រមទាំងនាំយកដួងចិត្តរបស់អ្នកឲ្យកាន់តែខិតជិតទ្រង់។ ប្រសិនបើអ្នកមានសេចក្ដីជំនឿជាច្រើនឆ្នាំមកហើយ ហើយមានទំនាក់ទំនងជាមួយ យើងយូរមកហើយ ប៉ុន្តែនៅតែឃ្លាតឆ្ងាយពីយើង នោះយើងអាចនិយាយថា គឺប្រាកដជាអ្នកនេះហើយដែលតែងតែប្រមាថដល់និស្ស័យរបស់ព្រះជាម្ចាស់ ហើយទីបញ្ចប់របស់អ្នក នឹងពិបាករកគិតពុំយល់។ ប្រសិនបើការទាក់ទងនឹងខ្ញុំជាច្រើនឆ្នាំមកនេះមិនបានផ្លាស់ប្ដូរអ្នកឲ្យទៅជាបុគ្គលម្នាក់ដែលមានភាពជាមនុស្ស និងសេចក្ដីពិតទេ ប៉ុន្តែផ្ទុយទៅវិញបានធ្វើឲ្យផ្លូវអាក្រក់របស់អ្នកជ្រួតជ្រាបចូលក្នុងនិស្ស័យរបស់អ្នកទៅវិញ ហើយភាពក្អេងក្អាងរបស់អ្នកមិនត្រឹមតែកើនឡើងលើសមុនទ្វេរដងទេ ប៉ុន្តែការយល់ខុសរបស់អ្នកអំពីយើង ក៏បានកើនឡើងច្រើនដងផងដែរ រហូតដល់អ្នកចាប់ផ្ដើមគិតថាយើងជាមិត្តភក្ដិដ៏តូចតាចរបស់អ្នក នោះយើងអាចនិយាយថា ទុក្ខវេទនារបស់អ្នកលែងស្ថិតនៅត្រឹមស្បែករបស់អ្នកទៀតហើយ ប៉ុន្តែវាបានជ្រៀតចូលដល់ឆ្អឹងរបស់អ្នកតែម្ដង។ គ្រប់យ៉ាងដែលនៅសល់ គឺរង់ចាំឲ្យ

គេរៀបចំបុណ្យសពសម្រាប់អ្នកប៉ុណ្ណោះ។ ដល់ពេលនោះ អ្នកមិនចាំបាច់អង្វរករឲ្យខ្ញុំធ្វើជាព្រះជាម្ចាស់របស់អ្នកទេ ព្រោះអ្នកបានប្រព្រឹត្តិអំពើបាបដែលស័ក្ដិសមនឹងសេចក្ដីស្លាប់ ជាអំពើបាបដែលមិនអាចអត់ឱនឲ្យបាន។ ទោះបីជាខ្ញុំអាចមានក្ដីអាណិតអាសូរដល់អ្នកក៏ដោយ ក៏ព្រះជាម្ចាស់ដែលគង់នៅស្ថានសួគ៌នឹងទទួចចង់យកជីវិតរបស់អ្នកដែរ ព្រោះការប្រមាថរបស់អ្នកដល់និស្ស័យរបស់ព្រះជាម្ចាស់ គឺមិនមែនជាបញ្ហាធម្មតានោះទេ ប៉ុន្តែជាបញ្ហាធ្ងន់ធ្ងរខ្លាំងណាស់។ នៅពេលដែលពេលវេលាមកដល់ សូមកុំបន្ទោសយើងថាមិនបានប្រាប់អ្នកជាមុនឲ្យសោះ។ អ្វីដែលសំខាន់ គឺស្ថិតនៅលើរឿងទាំងអស់នេះហើយ គឺនៅពេលដែលអ្នកមានទំនាក់ទំនងជាមួយព្រះគ្រីស្ទដែលជាព្រះជាម្ចាស់នៅលើផែនដីក្នុងនាមជាមនុស្សធម្មតាម្នាក់ គឺនៅពេលនោះហើយដែលអ្នកជឿថា ព្រះជាម្ចាស់គ្មានអ្វីក្រៅតែពីជាមនុស្សម្នាក់នោះទេ គឺនៅពេលនោះហើយអ្នកនឹងត្រូវវិនាស។ នេះគ្រាន់តែជាការក្រើនរំលឹកដល់អ្នករាល់គ្នាប៉ុណ្ណោះ។

## បញ្ហាដ៏ធ្ងន់ធ្ងរមួយ៖ អំពើក្បត់ (១)

កិច្ចការរបស់ខ្ញុំនឹងត្រូវបានបញ្ចប់ឆាប់ៗនេះ ហើយរយៈពេលជាច្រើនឆ្នាំជាមួយគ្នានេះ បានក្លាយជាការចងចាំដែលមិនអាចទ្រាំទ្របាន។ ខ្ញុំបាននិយាយបន្ទូលរបស់ខ្ញុំដដែលៗឥតឈប់ឈរ ហើយបានលាតត្រដាងកិច្ចការថ្មីរបស់ខ្ញុំជានិច្ច។ ពិតណាស់ដំបូន្មានរបស់ខ្ញុំ គឺជាធាតុផ្សំដ៏ចាំបាច់នៃចំណែកកិច្ចការនីមួយៗដែលខ្ញុំធ្វើ។ ដោយគ្មានពាក្យទូន្មានរបស់ខ្ញុំ អ្នករាល់គ្នាមុខជាបែកឆ្វេង ថែមទាំងយល់ឃើញថា ខ្លួនឯងវង្វេងទាំងស្រុងផង។ កិច្ចការរបស់ខ្ញុំពេលនេះ គឺជិតនឹងបញ្ចប់ហើយ ក៏ស្ថិតនៅក្នុងដំណាក់កាលចុងក្រោយដែរ។ ខ្ញុំនៅតែចង់ធ្វើកិច្ចការនៃការផ្ដល់ដំបូន្មាន ពោលគឺ ផ្ដល់នូវពាក្យទូន្មានសម្រាប់ឲ្យអ្នករាល់គ្នាស្ដាប់។ ខ្ញុំគ្រាន់តែសង្ឃឹមថា អ្នករាល់គ្នាមិនអាចបណ្ដោយឲ្យការឈឺចាប់ដែលខ្ញុំបានទទួលយកនេះ នឹងទៅជាអសារបង់នោះទេហើយជាងនេះទៅទៀត ខ្ញុំសង្ឃឹមថា អ្នកអាចយល់ពីការយកទុកដាក់ដ៏ប្រិតប្រៀនដែល

ខ្ញុំមាន និងចាត់ទុកបន្ទូលរបស់ខ្ញុំជាគ្រឿះសម្រាប់របៀបដែលអ្នកប្រព្រឹត្តខ្លួនក្នុងនាមជាមនុស្ស។ ទោះបីជាព្រះបន្ទូលនេះ មិនមែនជាប្រភេទបន្ទូលដែលអ្នករាល់គ្នាព្រមស្ដាប់ ទោះបីជាអ្នករាល់គ្នាមិនពេញចិត្តនឹងការទទួលយកព្រះបន្ទូលទាំងនេះ ឬអាចទទួលបន្ទូលនេះបានទាំងមិនស្រណុកចិត្ត ក៏អ្នករាល់គ្នាត្រូវតែចាត់ទុកបន្ទូលទាំងនេះជាព្រះបន្ទូលដ៏សំខាន់ដែរ។ ពុំនោះទេ និស្ស័យ និងចរិយាឥតព្រៀងនិងឥតខ្វល់ខ្វាយរបស់អ្នករាល់គ្នា នឹងធ្វើឲ្យខ្ញុំព្រួយចិត្តជាខ្លាំង ហើយស្អប់ខ្ពើមខ្ញុំខ្លាំងទៀតផង។ ខ្ញុំសង្ឃឹមជាខ្លាំងថា អ្នករាល់គ្នាអាចអានព្រះបន្ទូលខ្ញុំម្ដងហើយម្ដងទៀតរាប់ពាន់ដង និងសង្ឃឹមថា អ្នករាល់គ្នាថែមទាំងអាចចាំព្រះបន្ទូលទាំងនេះទុកក្នុងចិត្ត។ មានតែវិធីនេះទេ ទើបអ្នកមិនអាចធ្វើឲ្យខកខុសពីការរំពឹងរបស់ខ្ញុំចំពោះអ្នករាល់គ្នាបាន។ យ៉ាងណាមិញ ពេលនេះ គ្មាននរណាម្នាក់ក្នុងចំណោមអ្នករាល់គ្នាកំពុងរស់ក្នុងសភាពនេះទេ។ ផ្ទុយទៅវិញ អ្នករាល់គ្នាសុទ្ធតែលង់ក្នុងជីវិតដែលខុសគន្លងធម៌ ជាជីវិតនៃការផឹកស៊ីតាមទំនើងចិត្ត ហើយគ្មាននរណាម្នាក់ក្នុងចំណោមអ្នករាល់គ្នាប្រើព្រះបន្ទូលរបស់ខ្ញុំចម្រើនដួងចិត្ត និងព្រលឹងរបស់អ្នកឡើយ។ ដោយព្រោះហេតុនេះហើយ ទើបខ្ញុំចាប់ផ្ដើមសន្និដ្ឋានអំពីមុខមាត់ពិតរបស់មនុស្សជាតិថា៖ មនុស្សអាចក្បត់ខ្ញុំពេលណាក៏បាន ហើយគ្មាននរណាម្នាក់ស្មោះត្រង់នឹងព្រះបន្ទូលរបស់ខ្ញុំទាំងស្រុងឡើយ។

«មនុស្សត្រូវសាតាំងធ្វើឲ្យពុករលួយ រហូតដល់ថ្នាក់គេលែងមានអាការៈខាងក្រៅជាមនុស្សទៀតហើយ»។ ពេលនេះ មនុស្សភាគច្រើនទទួលស្គាល់សម្ដីមួយឃ្លានេះយ៉ាងទូលំទូលាយ។ ខ្ញុំនិយាយដូច្នេះ ពីព្រោះ «ការទទួលស្គាល់» ដែលខ្ញុំនិយាយនេះ គឺគ្រាន់តែជាការទទួលស្គាល់លំៗ ដែលផ្ទុយនឹងចំណេះដឹងពិតតែប៉ុណ្ណោះ។ ដោយសារគ្មាននរណាម្នាក់ក្នុងចំណោមអ្នករាល់គ្នា អាចវាយតម្លៃខ្លួនឯងបានសុក្រឹត្យ ឬវិភាគខ្លួនឯងឲ្យបានហ្មត់ចត់ ទើបអ្នករាល់គ្នានៅតែសង្ស័យលើព្រះបន្ទូលរបស់ខ្ញុំ។ តែពេលនេះ ខ្ញុំកំពុងប្រើហេតុពិតមកពន្យល់ ពីបញ្ហាដ៏ធ្ងន់ធ្ងរមួយដែលមាននៅក្នុងអ្នករាល់គ្នា។ បញ្ហានោះ គឺអំពើក្បត់។ អ្នកទាំងអស់គ្នាសុទ្ធតែស្គាល់ពាក្យថា «អំពើក្បត់» ដ្បិតមនុស្សភាគច្រើនសុទ្ធតែធ្វើនូវទង្វើខ្លះដែលក្បត់នឹងអ្នកដទៃ ដូចជាប្ដីក្បត់

ប្រពន្ធរបស់ខ្លួន ប្រពន្ធក្បត់ប្ដីរបស់ខ្លួន កូនប្រុសក្បត់ឪពុករបស់ខ្លួន កូនស្រីក្បត់ម្ដាយរបស់ខ្លួន ទាសករក្បត់ចៅហ្វាយរបស់ខ្លួន មិត្តភក្ដិក្បត់គ្នាទៅវិញទៅមក សាច់ញាតិក្បត់គ្នាទៅវិញទៅមក អ្នកលក់ក្បត់អ្នកទិញ ។ល។ ឧទាហរណ៍ទាំងអស់នេះ សុទ្ធតែមានសារជាតិនៃអំពើក្បត់។ និយាយឲ្យខ្លី អំពើក្បត់គឺជាទម្រង់នៃអកប្បកិរិយាដែលបំពានសន្យា ល្មើសនឹងគោលការណ៍សីលធម៌ ឬទង្វើផ្ទុយទៅនឹងក្រមសីលធម៌របស់មនុស្ស ដោយបង្ហាញនូវការបាត់បង់ភាពជាមនុស្ស។ និយាយជារួម ក្នុងនាមជាមនុស្សដែលកើតមកក្នុងលោកនេះ អ្នកនឹងបានធ្វើនូវទង្វើដែលបង្កើតបានជាអំពើក្បត់នឹងសេចក្ដីពិត បើទោះបីជាអ្នកនឹកចាំពីការដែលអ្នកធ្លាប់ប្រព្រឹត្តអំពើក្បត់នឹងនរណាម្នាក់ផ្សេងទៀត ឬអ្នកធ្លាប់ក្បត់អ្នកដទៃពីមុនមកច្រើនដងក៏ដោយ។ ដោយព្រោះអ្នកអាចក្បត់ទាំងឪពុកម្ដាយ ឬមិត្តភក្ដិរបស់អ្នក នោះអ្នកក៏អាចក្បត់អ្នកដទៃបានដែរ ហើយជាងនេះទៀត អ្នកក៏អាចក្បត់ខ្ញុំ ហើយប្រព្រឹត្តនូវទង្វើដែលខ្ញុំស្អប់ទៀតផង។ អាចនិយាយម្យ៉ាងទៀតបានថា អំពើក្បត់គឺមិនគ្រាន់តែជាឥរិយាបថអសីលធម៌បែបលំៗនោះទេ តែវាជាទង្វើដែល ផ្ទុយនឹងសេចក្ដីពិត។ ប្រាកដណាស់ នេះគឺជាប្រភពនៃការតតាំង និងចរិតរឹងចចេសរបស់មនុស្សជាតិចំពោះខ្ញុំ។ ដូច្នេះហើយទើបខ្ញុំសង្ខេបជាសម្ដីយ៉ាងខ្លីដូចតទៅថា៖ អំពើក្បត់គឺជាធម្មជាតិរបស់មនុស្ស ហើយធម្មជាតិនេះ គឺជាខ្មាំងនៃភាពចុះសម្រុងដែលបុគ្គលម្នាក់ៗមានចំពោះខ្ញុំ។

ឥរិយាបថដែលមិនអាចស្ដាប់បង្គាប់ខ្ញុំទាំងស្រុង គឺជាអំពើក្បត់ហើយ។ ឥរិយាបថដែលមិនអាចស្មោះត្រង់នឹងខ្ញុំ គឺជាអំពើក្បត់ហើយ។ ការបោកប្រាស់ខ្ញុំ និងការប្រើពាក្យកុហកដើម្បីបោកប្រាស់ខ្ញុំ គឺជាអំពើក្បត់ហើយ។ ការលាក់ទុកនូវសញ្ញាណជាច្រើន ហើយផ្សព្វផ្សាយពីសញ្ញាណនោះទៅគ្រប់ទីកន្លែង គឺជាអំពើក្បត់ហើយ។ ការដែលមិនអាចកាន់ខ្ជាប់តាមទីបន្ទាល់ និងផលប្រយោជន៍របស់ខ្ញុំ គឺជាអំពើក្បត់ហើយ។ ការផ្ដល់នូវស្នាមញញឹមក្លែងក្លាយ ពេលដែលដួងចិត្តនៅឆ្ងាយពីខ្ញុំ នោះក៏ជាអំពើក្បត់ដែរ។ ទាំងអស់នេះ សុទ្ធតែជាអំពើក្បត់ដែលអ្នករាល់គ្នាតែងតែអាចធ្វើទៅរួច ហើយទង្វើនេះ គឺជារឿងធម្មតានៅក្នុងចំណោមអ្នករាល់គ្នា។ គ្មាននរណា

ម្នាក់ក្នុងចំណោមអ្នករាល់គ្នាអាចនឹងគិតថា ទង្វើនេះគឺជាបញ្ហានោះឡើយ ប៉ុន្តែនោះមិនមែនជាអ្វីដែលខ្ញុំគិតនោះទេ។ ខ្ញុំមិនអាចចាត់ទុកអំពើក្បត់របស់បុគ្គលណាម្នាក់គឺជារឿងលេងសើចនោះឡើយ ហើយខ្ញុំក៏ប្រាកដជាមិនអាចព្រងើយកន្តើយនឹងរឿងនេះដែរ។ បច្ចុប្បន្ននេះ កាលខ្ញុំកំពុងធ្វើការក្នុងចំណោមអ្នករាល់គ្នា អ្នករាល់គ្នាមានកិរិយាបែបនេះ ប្រសិនបើថ្ងៃនោះមកដល់ ពេលគ្មាននរណាឃ្លាំមើលអ្នករាល់គ្នា តើអ្នករាល់គ្នាមិនប្រៀបបានទៅនឹងចោរដែលបានប្រកាសថា ខ្លួនឯងជាស្តេចនៃភ្នំតូចៗរបស់ពួកគេទេឬអី? នៅពេលដែលរឿងនោះកើតឡើង ហើយអ្នករាល់គ្នាបានបង្កនូវចលាចល តើនរណាជាអ្នកដោះស្រាយបញ្ហានេះបន្ទាប់ពីអ្នក? អ្នករាល់គ្នាគិតថា អំពើក្បត់ខ្លះគ្រាន់តែជារឿងហេតុចៃដន្យម្តងម្កាល មិនមែនជាឥរិយាបថអចិន្ត្រៃយ៍របស់អ្នករាល់គ្នាទេ ហើយក៏មិនសមនឹងយកមកពិភាក្សាដោយភាពតឹងរ៉ឹងថ្នាក់ហ្នឹង គឺដល់ថ្នាក់ត្រូវបង្ខូចដល់សេចក្តីអំណួតរបស់អ្នករាល់គ្នាដែរ។ ប្រសិនបើអ្នករាល់គ្នាពិតជាគិតដូច្នេះ នោះអ្នករាល់គ្នាខ្វះសតិហើយ។ ការគិតដូច្នេះ គឺធ្វើជាសំណាក និងជាគំរូនៃការបះបោរហើយ។ ធម្មជាតិរបស់មនុស្ស គឺជាជីវិតរបស់គេ វាគឺជាគោលការណ៍មូលដែលគេពឹងអាង ដើម្បីរក្សាជីវិត ហើយគេមិនអាចផ្លាស់ប្តូរវាបានឡើយ។ ចូរយកធម្មជាតិនៃអំពើក្បត់ធ្វើជាឧទាហរណ៍។ ប្រសិនបើអ្នកអាចធ្វើរឿងអ្វីម្យ៉ាង ដើម្បីក្បត់សាច់ញាតិ ឬមិត្តភក្តិនោះបង្ហាញថា វាជាផ្នែកមួយនៃជីវិតរបស់អ្នករាល់គ្នា និងជាធម្មជាតិមួយ ដែលអ្នកមានស្រាប់តាំងពីកំណើតមក។ នេះគឺជារឿងមួយដែលគ្មាននរណាម្នាក់ អាចបដិសេធបានឡើយ។ ឧទាហរណ៍ ប្រសិនបើបុគ្គលម្នាក់សប្បាយនឹងលួចគេ នោះ ភាពរីករាយនឹងការលួចនេះ គឺជាផ្នែកមួយនៃជីវិតរបស់គេ ទោះបីជាគេលួចរបស់អ្វី ឬមិនលួចរបស់អ្វីក៏ដោយ។ ទោះបីជាគេលួច ឬមិនលួច ក៏វាមិនអាចបញ្ជាក់ថា ទង្វើលួចរបស់គេនេះ គ្រាន់តែជាឥរិយាបថមួយប្រភេទរបស់គេបានឡើយ។ ផ្ទុយទៅវិញ វាបញ្ជាក់ថា វាគឺជាចំណែកមួយនៃជីវិតរបស់គេ ពោលគឺជាធម្មជាតិរបស់គេតែម្តង។ អ្នកខ្លះនឹងសួរថា៖ ដោយសារវាជាធម្មជាតិរបស់គេ ចុះហេតុអ្វីក៏នៅពេលដែលពួកគេឃើញរបស់ល្អៗ ពេលខ្លះពួកគេមិនព្រមលួច? ចម្លើយគឺ

សាមញ្ញបំផុត។ មានហេតុផលជាច្រើនដែលគេមិនលួច។ ពួកគេអាចនឹងមិនលួចរបស់ខ្លះ ដោយសារតែរបស់ដែលត្រូវលួចនោះធំពេក លាក់មិនជិតភ្នែកដែលចាំឃ្លាំមើល ឬមកពីគ្មានពេលវេលាសមស្របនឹងលួច ឬរបស់នោះថ្លៃពេក គេឃ្លាំមើលតឹងរ៉ឹងពេក ឬប្រហែលមកពីពួកគេគ្មានចំណាប់អារម្មណ៍អ្វីពិសេសចំពោះរបស់នោះ ឬមួយគេមើលមិនឃើញថារបស់នោះមានប្រយោជន៍អ្វីសម្រាប់ពួកគេ ។ល។ ហេតុផលទាំងអស់នេះសុទ្ធតែជាហេតុផលដែលអាចទៅរួច។ តែទោះជាហេតុផលអ្វីក៏ដោយ ទោះបីជាពួកគេលួច ឬមិនលួចរបស់ក៏ដោយ ក៏មិនអាចបញ្ជាក់ថា គំនិតនេះគ្រាន់តែជាគំនិតដែលមានឡើងមួយឆាវ ដូចភ្លើងហ្វាជែងនោះដែរ។ ផ្ទុយទៅវិញ វាជាចំណែកមួយនៃធម្មជាតិរបស់គេ ដែលពិបាកកែប្រែឲ្យប្រសើរឡើង។ មនុស្សបែបនេះ លួចម្ដងគឺមិនស្កប់ចិត្តទេ គំនិតដែលគិតទាមទារកម្មសិទ្ធិរបស់គេមកធ្វើជាកម្មសិទ្ធិរបស់ខ្លួនបែបនេះ កើតឡើងនៅពេលណាដែលពួកគេប្រទះឃើញរបស់ល្អ ឬស្ថិតក្នុងស្ថានភាពសមប្រកបមួយ។ នេះហើយជាមូលហេតុដែលខ្ញុំនិយាយថា ប្រភពដើមនៃគំនិតគិតដូច្នេះ មិនមែនជាឥរិយាបថដែលគេមានម្ដងម្កាលនោះឡើយ តែវាជាចរិតដែលមាននៅក្នុងធម្មជាតិរបស់បុគ្គលម្នាក់នេះតែម្ដង។

នរណាៗក៏អាចប្រើពាក្យសម្ដី និងសកម្មភាពរបស់ពួកគេផ្ទាល់ មកបង្ហាញពីមុខមាត់ពិតរបស់ពួកគេបានដែរ។ ពិតណាស់ មុខមាត់ពិតនេះ គឺជាធម្មជាតិរបស់ពួកគេនោះឯង។ ប្រសិនបើអ្នកគឺជាមនុស្សម្នាក់ដែលនិយាយស្ដីវៀចវេរ នោះអ្នកមានធម្មជាតិវៀចវេរ។ ប្រសិនបើធម្មជាតិរបស់អ្នកប្រកបដោយល្បិចកល នោះអ្នកនឹងប្រព្រឹត្តតាមបែបមានល្បិច ហើយអ្នកនឹងធ្វើយ៉ាងណា ឲ្យអ្នកដទៃងាយលង់នឹងល្បិចកលរបស់អ្នក។ ប្រសិនបើធម្មជាតិរបស់អ្នកចង្រៃឧត្បាត នោះសម្ដីរបស់អ្នកអាចនឹងពីរោះស្ដាប់ តែទង្វើរបស់អ្នកមិនអាចលាក់បាំងល្បិចកលឧត្បាតរបស់អ្នកបានឡើយ។ ប្រសិនបើធម្មជាតិរបស់អ្នកខ្ជិលច្រអូស នោះគ្រប់យ៉ាងដែលអ្នករាល់គ្នានិយាយ ក៏ដើម្បីគេចវេសពីទំនួលខុសត្រូវចំពោះការបង្អង់កិច្ច និងភាពខ្ជិលច្រអូសរបស់អ្នករាល់គ្នា ចំណែកសកម្មភាពរបស់អ្នករាល់គ្នាទៀតសោតក៏យឺតយ៉ាវ និង

បង្គ្រប់កិច្ច ហើយប៉ុនប្រសប់ខាងលាក់បំបាំងសេចក្តីពិតផង។ ប្រសិនបើធម្មជាតិរបស់អ្នករាល់គ្នាចេះយល់ចិត្ត នោះសម្ដីរបស់អ្នករាល់គ្នានឹងមានហេតុផល ហើយសកម្មភាពរបស់អ្នករាល់គ្នា ក៏អនុលោមគ្នាយ៉ាងត្រសងនឹងសេចក្តីពិតដែរ។ ប្រសិនបើធម្មជាតិរបស់អ្នករាល់គ្នាស្មោះត្រង់ នោះពាក្យសម្ដីរបស់អ្នករាល់គ្នា ក៏ប្រាកដជាស្មោះត្រង់ ហើយវិធីដែលអ្នកប្រព្រឹត្តក៏សាមញ្ញ មិនមានអ្វីដែលអាចធ្វើឲ្យថៅហ្វាយរបស់អ្នកទើសទាល់នោះឡើយ។ ប្រសិនបើធម្មជាតិរបស់អ្នកពេញដោយចំណង់ ឬលោភលន់ចង់បានប្រាក់ នោះដួងចិត្តរបស់អ្នកក៏ពោរពេញដោយសេចក្តីទាំងនេះ ហើយអ្នកនឹងប្រព្រឹត្តទាំងមិនដឹងខ្លួន នូវទង្វើខុសគេ និងទង្វើអសីលធម៌ ដែលមនុស្សនឹងមិនបំភ្លេចបានងាយៗ និងធ្វើឲ្យគេខ្ពើមរអើមទៀតផង។ ដូចខ្ញុំបាននិយាយរួចហើយថា ប្រសិនបើអ្នកមានធម្មជាតិនៃអំពើក្បត់ នោះអ្នកមិនងាយនឹងអាចរើខ្លួនពីវាបានឡើយ។ ចូរកុំទុកចិត្តព្រេងសំណាងដែលថា ប្រសិនបើអ្នកមិនបានប្រព្រឹត្តខុសនឹងអ្នកដទៃ នោះអ្នកគ្មានធម្មជាតិនៃអំពើក្បត់នោះឡើយ។ ប្រសិនបើនោះជាអ្វីដែលអ្នកគិត នោះអ្នកពិតជាកំពុងបះបោរប្រឆាំងហើយ។ រាល់ពេលដែលខ្ញុំថ្លែងបន្ទូលទាំងអស់របស់ខ្ញុំ គឺសុទ្ធតែតម្រង់ឆ្ពោះទៅរកមនុស្សទាំងអស់ មិនមែនតម្រង់ទៅរកបុគ្គលតែម្នាក់ ឬក៏បុគ្គលតែមួយប្រភេទនោះឡើយ។ ដោយព្រោះតែអ្នកមិនបានក្បត់ខ្ញុំនៅក្នុងរឿងមួយ មិនមែនបញ្ជាក់ថា អ្នកមិនអាចក្បត់ខ្ញុំនៅក្នុងរឿងណាមួយនោះឡើយ។ មនុស្សខ្លះនៅពេលមានឧបសគ្គនៅក្នុងអាពាហ៍ពិពាហ៍របស់ពួកគេ គឺបាត់បង់ជំនឿចិត្តរបស់ខ្លួនក្នុងការស្វែងរកសេចក្តីពិត។ មនុស្សខ្លះបោះបង់កាតព្វកិច្ចរបស់ខ្លួនក្នុងការធ្វើជាមនុស្សស្មោះត្រង់ចំពោះខ្ញុំ នៅពេលបែកបាក់គ្រួសារ។ មនុស្សខ្លះបោះបង់ខ្ញុំចោល ដើម្បីស្វះស្វែងរកឱកាសសប្បាយ និងរីករាយ។ មនុស្សខ្លះសុខចិត្តធ្លាក់ទៅក្នុងជ្រោះងងឹត ក៏មិនសុខចិត្តរស់នៅក្នុងពន្លឺ និងទទួលបាននូវភាពរីករាយនៃកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធដែរ។ មនុស្សខ្លះមិនអើពើនឹងដំបូន្មានរបស់មិត្តភក្តិ ដើម្បីបំពេញចំណង់លោភលន់ចង់បានទ្រព្យសម្បត្តិរបស់គេ ហើយសូម្បីតែពេលនេះ ក៏ពួកគេមិនអាចទាំងទទួលស្គាល់កំហុសរបស់ខ្លួន ហើយកែប្រែទង្វើរបស់ខ្លួនផង។ មនុស្ស

ខ្លះ រស់នៅក្រោមឈ្មោះរបស់ខ្ញុំបានតែមួយគ្រា ដើម្បីទទួលនូវការការពាររបស់ខ្ញុំ ខណៈដែលមនុស្សខ្លះទៀត ប្ដូរផ្ដាច់តែបន្ដិចចំពោះការបង្គាប់បញ្ជារបស់ខ្ញុំប៉ុណ្ណោះ ដោយសារតែពួកគេតោងទាមជីវិត និងភ័យខ្លាចស្លាប់។ លើសពីនេះ តើទង្វើទាំងអស់នេះ និងទង្វើអសីលធម៌ដែលគ្មានសេចក្ដីថ្លៃថ្នូរ មិនគ្រាន់តែជាឥរិយាបថដែលមនុស្សបានក្បត់នឹងខ្ញុំយ៉ាងជ្រាលជ្រៅនៅក្នុងចិត្តរបស់ពួកគេ ជាយូរមកហើយទេឬអី? ពិតណាស់ ខ្ញុំដឹងថា មនុស្សគ្មានផែនការក្បត់ខ្ញុំជាមុននោះទេ ហើយក៏គ្មាននរណាសប្បាយចិត្តដែរ ដ្បិតពួកគេបានធ្វើអ្វីម្យ៉ាងក្បត់នឹងខ្ញុំ។ ផ្ទុយទៅវិញ ពួកគេញាប់ញ័រដោយភាពខ្លាច តើមែនទេ? ដូច្នេះ តើអ្នករាល់គ្នាកំពុងគិតរកវិធីលោះអំពើក្បត់ទាំងនេះ និងគិតរកវិធីផ្លាស់ប្ដូរស្ថានភាពបច្ចុប្បន្ននេះដែរឬទេ?

## បញ្ហាដ៏ធ្ងន់ធ្ងរមួយ៖ អំពើក្បត់ (២)

ធម្មជាតិរបស់មនុស្ស ខុសគ្នាពីសារជាតិរបស់ខ្ញុំឆ្ងាយណាស់ ដ្បិតធម្មជាតិពុករលួយរបស់មនុស្សកើតចេញមកទាំងស្រុងពីសាតាំង។ ធម្មជាតិរបស់មនុស្សត្រូវបានកែច្នៃ និងត្រូវធ្វើឲ្យពុករលួយដោយសាតាំង។ ពោលគឺ មនុស្សរស់នៅក្រោមឥទ្ធិពលនៃសេចក្ដីអាក្រក់ និងភាពគួរឲ្យស្អប់ខ្ពើមរបស់វា។ មនុស្សមិនលូតលាស់នៅក្នុងពិភពនៃសេចក្ដីពិត ឬក្នុងមជ្ឈដ្ឋានដ៏បរិសុទ្ធនោះទេ និងរឹតតែមិនរស់នៅក្នុងពន្លឺ។ ដូច្នេះ ការដែលមនុស្សណាម្នាក់មានសេចក្ដីពិតនៅក្នុងធម្មជាតិរបស់ពួកគេ តាំងពីពេលដែលគេកើតមក គឺវាមិនអាចទៅរួចនោះឡើយ ហើយរឹតតែគ្មាននរណាម្នាក់អាចកើតមកដោយមានសារជាតិដែលកោតខ្លាច និងស្ដាប់បង្គាប់ព្រះជាម្ចាស់ទៅទៀត។ មនុស្សមានធម្មជាតិមួយដែលតតាំងនឹងព្រះជាម្ចាស់ មិនស្ដាប់បង្គាប់ព្រះជាម្ចាស់ ហើយគ្មានសេចក្ដីស្រឡាញ់ចំពោះសេចក្ដីពិតឡើយ។ ធម្មជាតិនេះ គឺជាបញ្ហាដែលខ្ញុំចង់ពិភាក្សា ហើយវាគឺជាអំពើក្បត់។ អំពើក្បត់ គឺជាប្រភពនៃការតតាំងរបស់មនុស្សម្នាក់ៗចំពោះព្រះជាម្ចាស់។ នេះគឺជាបញ្ហាមួយ ដែលមានតែនៅក្នុង

មនុស្សប៉ុណ្ណោះ និងគ្មាននៅក្នុងខ្ញុំទេ។ អ្នកខ្លះនឹងសួរថា៖ ដោយសារមនុស្សទាំងអស់សុទ្ធតែរស់នៅក្នុងលោកីយ៍ដូចព្រះគ្រីស្ទដែរ ហេតុអ្វីបានមនុស្សទាំងអស់មានធម្មជាតិដែលក្បត់នឹងព្រះជាម្ចាស់ តែព្រះគ្រីស្ទមិនក្បត់នឹងព្រះជាម្ចាស់ដូច្នេះ? នេះគឺជាបញ្ហាមួយដែលត្រូវតែយកមកបកស្រាយប្រាប់អ្នករាល់គ្នាឲ្យបានច្បាស់។

មូលដ្ឋាននៃអត្ថិភាពរបស់មនុស្សជាតិ ការចាប់កំណើតខាងព្រលឹងម្តងទៀត។ អាចនិយាយម្យ៉ាងទៀតបានថា មនុស្សគ្រប់ៗរូបទទួលបានជីវិតជាមនុស្សនៅក្នុងសាច់ឈាម នៅពេលដែលព្រលឹងរបស់គេចាប់កំណើតឡើងវិញ។ បន្ទាប់ពីរូបកាយរបស់មនុស្សបានកើតមក ជីវិតរបស់គេក៏បន្តរហូតទាល់តែសាច់ឈាមនេះឈានដល់ដែនកំណត់ចុងក្រោយបំផុតរបស់វា គឺជាពេលដែលព្រលឹងចាកចេញពីសំបកកាយរបស់គេ។ ដំណើរការនេះ កើតឡើងដដែលៗ ម្តងហើយម្តងទៀត ដោយព្រលឹងមនុស្សម្នាក់ទៅមកៗ ម្តងហើយម្តងទៀត ដូច្នេះហើយទើបអត្ថិភាពរបស់មនុស្សក៏ត្រូវបានរក្សាទុក។ ជីវិតនៃសាច់ឈាមនេះ ក៏ជាជីវិតនៃព្រលឹងរបស់មនុស្សដែរ ហើយព្រលឹងរបស់មនុស្សទ្រទ្រង់ដល់អត្ថិភាពនៃសាច់ឈាមរបស់មនុស្ស។ មានន័យថាជីវិតរបស់បុគ្គលម្នាក់ៗកើតចេញពីព្រលឹងរបស់ពួកគេ ហើយជីវិតនេះមិនមែនជាប់ជាមួយនឹងសាច់ឈាមឡើយ។ ដូច្នេះ ធម្មជាតិរបស់មនុស្សកើតចេញមកពីព្រលឹង មិនមែនពីសាច់ឈាមនោះទេ។ មានតែព្រលឹងរបស់មនុស្សម្នាក់ៗទេ ទើបដឹងថាគេបានឆ្លងកាត់ការល្បួង ទុក្ខវេទនា និងសេចក្តីពុករលួយរបស់សាតាំងដោយរបៀបណា។ សាច់ឈាមរបស់មនុស្សមិនអាចដឹងពីសេចក្តីទាំងនេះបានឡើយ។ ដូច្នេះ មនុស្សជាតិក៏កាន់តែងងឹតងងល់ កាន់តែស្មោកគ្រោក និងកាន់តែអាក្រក់ទៅៗទាំងមិនដឹងខ្លួន ខណៈដែលគម្លាតរវាងមនុស្សនិងខ្លួនខ្ញុំផ្ទាល់ ក៏កាន់តែឆ្ងាយទៅៗ ហើយជីវិតក៏កាន់តែងងឹតទៅៗសម្រាប់មនុស្សជាតិ។ សាតាំងក្រសោបព្រលឹងរបស់មនុស្សនៅក្នុងកណ្តាប់ដៃរបស់វា ដូច្នេះ សាច់ឈាមរបស់មនុស្សពិតជាត្រូវសាតាំងកាន់កាប់មែន។ តើសាច់ឈាមបែបនេះ និងមនុស្សបែបនេះ អាចមិនតតាំងនឹងព្រះជាម្ចាស់យ៉ាងដូចម្តេចកើត? តើពួកគេអាចស្របគ្នាជាមួយដោយរបៀបណា?

ហេតុផល ដែលខ្ញុំបណ្ដេញសាតាំងឲ្យចុះមកកណ្ដាលអាកាស គឺដោយសារតែវាក្បត់ខ្ញុំ។ ហើយចុះតើមនុស្សអាចរួចពីចំណងពាក់ព័ន្ធរបស់ពួកគេដោយរបៀបណា? ហេតុនេះទើបអំពើក្បត់ គឺជាធម្មជាតិរបស់មនុស្ស។ ខ្ញុំទុកចិត្តថា កាលណាអ្នករាល់គ្នាយល់ពីការលើកហេតុផលនេះហើយ អ្នករាល់គ្នាក៏គួរតែមានមាត្រដ្ឋាននៃខ្លះៗអំពីជំនឿលើសារជាតិរបស់ព្រះគ្រីស្ទដែរ។ សាច់ឈាមដែលព្រះវិញ្ញាណនៃព្រះជាម្ចាស់សណ្ឋិត គឺជាសាច់ឈាមរបស់ព្រះជាម្ចាស់ផ្ទាល់។ ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ឧត្តុង្គឧត្តមណាស់។ ទ្រង់ប្រកបដោយព្រះចេស្ដា ទ្រង់បរិសុទ្ធ ហើយសុចរិតផង។ ដូចគ្នាដែរ សាច់ឈាមរបស់ទ្រង់ក៏ឧត្តុង្គឧត្តមប្រកបដោយព្រះចេស្ដា បរិសុទ្ធ និងសុចរិតដែរ។ សាច់ឈាមបែបនេះ អាចធ្វើបានតែកិច្ចការណាដែលសុចរិត និងមានប្រយោជន៍ដល់មនុស្សជាតិប៉ុណ្ណោះ គឺជាកិច្ចការដែលបរិសុទ្ធ ប្រកបដោយសិរីល្អ និងប្រកបដោយព្រះចេស្ដា។ ទ្រង់មិនអាចធ្វើកិច្ចការដែលបំពានសេចក្ដីពិត បំពានសីលធម៌ និងភាពយុត្តិធម៌ ហើយរឹតតែមិនអាចធ្វើកិច្ចការដែលក្បត់នឹងវិញ្ញាណរបស់ព្រះជាម្ចាស់បានឡើយ។ ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់បរិសុទ្ធ ដូច្នេះសាច់ឈាមរបស់ទ្រង់ក៏សាតាំងមិនអាចធ្វើឲ្យពុករលួយបានដែរ។ សាច់ឈាមរបស់ទ្រង់ជាសាច់ឈាមដែលមានសារជាតិខុសពីសាច់ឈាមរបស់មនុស្ស។ ដ្បិតនេះជាមនុស្សដែលត្រូវសាតាំងធ្វើឲ្យពុករលួយ មិនមែនជាព្រះជាម្ចាស់ឡើយ។ សាតាំងមិនអាចធ្វើឲ្យសាច់ឈាមរបស់ព្រះជាម្ចាស់ពុករលួយបានឡើយ។ ហេតុនេះ ទោះបីជាមនុស្ស និងព្រះគ្រីស្ទស្ថិតនៅក្នុងកន្លែងតែមួយដូចគ្នា ក៏មានតែមនុស្សទេទើបត្រូវបានកាន់កាប់ ប្រើប្រាស់ និងជាប់អន្ទាក់សាតាំង។ ផ្ទុយទៅវិញ ព្រះគ្រីស្ទមិនរញ្ជួយដោយសារសេចក្ដីពុករលួយរបស់សាតាំងជានិរន្តន៍ ពីព្រោះសាតាំងមិនអាចទឡើងទៅស្ថានដ៏ខ្ពស់បំផុត ហើយមិនអាចចូលមកកៀកនឹងព្រះជាម្ចាស់ឡើយ។ សព្វថ្ងៃនេះ អ្នករាល់គ្នាគប្បីដឹងថា គឺមានតែមនុស្សជាតិដែលត្រូវបានពុករលួយដោយសាតាំងទេ ទើបក្បត់ខ្ញុំ។ អំពើក្បត់មិនមែនជាបញ្ហាដែលពាក់ព័ន្ធនឹងព្រះគ្រីស្ទបន្តិចឡើយ។

ព្រលឹងទាំងអស់ដែលសាតាំងបានធ្វើឲ្យពុករលួយ សុទ្ធតែជាទាសករនៅក្នុងដែន

ត្រួតត្រារបស់សាតាំង។ មានតែអស់អ្នកដែលជឿលើព្រះគ្រីស្ទប៉ុណ្ណោះ ដែលត្រូវបានញែកដាច់ដោយឡែក និងបានសង្គ្រោះចេញពីជុំរុំរបស់សាតាំង ព្រមទាំងនាំចូលទៅក្នុងនគរព្រះនាពេលសព្វថ្ងៃនេះ។ មនុស្សទាំងអស់នេះលែងរស់នៅក្រោមឥទ្ធិពលរបស់សាតាំងទៀតហើយ។ ទោះបីជាដូច្នេះក៏ដោយ ក៏ធម្មជាតិរបស់មនុស្សនៅតែចាក់ឫសក្នុងសាច់ឈាមរបស់មនុស្សដែរ ពោលគឺទោះបីជាព្រលឹងរបស់អ្នករាល់គ្នាបានសង្គ្រោះហើយក៏ដោយ ក៏ធម្មជាតិរបស់អ្នករាល់គ្នានៅតែដូចមុនដែរ ហើយឱកាសដែលអ្នករាល់គ្នានឹងក្បត់ខ្ញុំក៏នៅមួយរយភាគរយដែរ។ នេះហើយជាមូលហេតុដែលកិច្ចការរបស់ខ្ញុំស្ថិតនៅយូរអង្វែង ដូចដែលធម្មជាតិរបស់អ្នករាល់គ្នាអាចយល់បាន។ ឥលូវនេះ អ្នករាល់គ្នាសុទ្ធតែកំពុងឆ្លងកាត់ការលំបាកអស់ពីសមត្ថភាពរបស់អ្នក នៅពេលដែលអ្នកបំពេញភារកិច្ចរបស់ខ្លួន ប៉ុន្តែម្នាក់ៗក្នុងចំណោមអ្នករាល់គ្នាសុទ្ធតែអាចក្បត់ខ្ញុំ ហើយត្រលប់ទៅរកដែនត្រួតត្រារបស់សាតាំង ទៅរកជុំរុំរបស់វា និងត្រលប់ទៅរកជីវិតចាស់របស់អ្នករាល់គ្នាវិញ ហើយនេះគឺជាការពិតមួយដែលមិនអាចបដិសេធបាន។ នៅពេលនោះ អ្នករាល់គ្នាមិនអាចនឹងបង្ហាញពីចំណែកណាមួយនៃភាពជាមនុស្ស ឬក៏លក្ខណៈជាមនុស្ស ដូចដែលអ្នកបង្ហាញនៅពេលឥលូវនេះឡើយ។ ក្នុងករណីធ្ងន់ធ្ងរ អ្នកនឹងត្រូវបំផ្លាញចោល ហើយលើសពីនោះទៀត អ្នកនឹងត្រូវផ្ដន្ទាទោសជារៀងរហូត ដាក់ទោសយ៉ាងធ្ងន់ធ្ងរ និងមិនបានចាប់កំណើតម្ដងទៀតឡើយ។ នេះគឺជាបញ្ហាដែលបានលាតត្រដាងនៅចំពោះមុខអ្នករាល់គ្នា។ ជាដំបូង ខ្ញុំសូមរំឭកអ្នករាល់គ្នាតាមរបៀបនេះ ដើម្បីកុំឲ្យកិច្ចការរបស់ខ្ញុំក្លាយជាអសារឥតការ ហើយបន្ទាប់មកទៀត គឺដើម្បីឲ្យអ្នករាល់គ្នាអាចរស់នៅក្នុងគ្រានៃពន្លឺ។ តាមពិតទៅ ទោះបីជាកិច្ចការរបស់ខ្ញុំក្លាយជាអសារឥតការ ក៏មិនមែនជាបញ្ហាធំដុំអ្វីដែរ។ អ្វីដែលសំខាន់នោះគឺ អ្នករាល់គ្នាមានជីវិតរីករាយ និងមានអនាគតមួយដ៏ត្រចះត្រចង់។ កិច្ចការរបស់ខ្ញុំ គឺជាកិច្ចការនៃការសង្គ្រោះព្រលឹងមនុស្ស។ ប្រសិនបើព្រលឹងរបស់អ្នកធ្លាក់ទៅក្នុងដៃរបស់សាតាំង រូបកាយរបស់អ្នកនឹងមិនរស់នៅក្នុងសន្តិភាពឡើយ។ ប្រសិនបើខ្ញុំការពាររូបកាយរបស់អ្នក ព្រលឹងរបស់អ្នកក៏ប្រាកដជានឹងស្ថិតនៅក្រោម

ការថែទាំរបស់ខ្ញុំដែរ។ ប្រសិនបើខ្ញុំពិតជាស្អប់អ្នក នោះរូបកាយ និងព្រលឹងរបស់អ្នក នឹងធ្លាក់ទៅក្នុងដៃរបស់សាតាំងភ្លាម។ ដូច្នេះ តើអ្នកអាចស្រមៃពីស្ថានភាពរបស់អ្នក បានទេ? ប្រសិនបើនៅថ្ងៃណាមួយ ព្រះបន្ទូលរបស់ខ្ញុំត្រូវបាត់បង់ដោយសារអ្នក នោះខ្ញុំនឹងប្រគល់អ្នករាល់គ្នាទៅឲ្យសាតាំង ដែលនឹងធ្វើទារុណកម្មអ្នករាល់គ្នាយ៉ាងខ្លាំង រហូតដល់កំហឹងរបស់ខ្ញុំបានរលាយបាត់ទាំងស្រុង ឬក៏ខ្ញុំនឹងដាក់ទោសអ្នករាល់គ្នាជាមនុស្សដែលមិនអាចលើកលែងឲ្យបាននេះដោយផ្ទាល់ ដ្បិតចិត្តរបស់អ្នករាល់គ្នាដែលក្បត់ខ្ញុំ នឹងមិនដែលផ្លាស់ប្ដូរឡើយ។

ឥលូវនេះ អ្នករាល់គ្នាគ្នាគួរតែព្យាយាមស្គាល់ខ្លួនឯងឲ្យបានឆាប់ តាមដែលអ្នកអាចធ្វើបាន ដើម្បីមើលឲ្យដឹងថា អំពើក្បត់ចំពោះខ្ញុំដែលនៅក្នុងអ្នករាល់គ្នា មានច្រើនយ៉ាងណា។ ខ្ញុំកំពុងរង់ចាំការឆ្លើយតបរបស់អ្នករាល់គ្នាយ៉ាងអន្ទះសា។ ចូរកុំដោះស្រាយជាមួយនឹងខ្ញុំ ដើម្បីបង្គ្រប់កិច្ចនោះឡើយ។ ខ្ញុំមិនលេងសើចជាមួយនឹងមនុស្សទេ។ ប្រសិនបើខ្ញុំនិយាយថា ខ្ញុំនឹងធ្វើអ្វីម៉្យាង នោះខ្ញុំប្រាកដជានឹងធ្វើការនោះមែន។ ខ្ញុំសង្ឃឹមថា អ្នករាល់គ្នាម្នាក់ៗនឹងធ្វើជាមនុស្សម្នាក់ដែលផ្ដល់សារៈសំខាន់ដល់ព្រះបន្ទូលរបស់ខ្ញុំ ហើយមិនគិតថា បន្ទូលទាំងនេះគ្រាន់តែជារឿងប្រឌិតខាងវិទ្យាសាស្ត្រនោះឡើយ។ អ្វីដែលខ្ញុំចង់បាន គឺសកម្មភាពដ៏ជាក់លាក់ពីអ្នករាល់គ្នា មិនមែនជាការស្រមើស្រមៃរបស់អ្នករាល់គ្នានោះទេ។ បន្ទាប់មក អ្នករាល់គ្នាត្រូវតែឆ្លើយនឹងសំណួររបស់ខ្ញុំ ដែលមានដូចតទៅ៖ ១. ប្រសិនបើអ្នក គឺពិតជាអ្នកស៊ីឈ្នួលមែន តើអ្នកអាចបម្រើដល់ខ្ញុំដោយស្មោះត្រង់ ដោយគ្មានភាពធូររលុង និងភាពអវិជ្ជមានបានទេ? ២. ប្រសិនបើអ្នករកឃើញថា ខ្ញុំមិនធ្លាប់ឲ្យតម្លៃអ្នកសោះ តើអ្នកនឹងនៅតែអាចនៅនឹងខ្ញុំ ហើយបម្រើខ្ញុំអស់មួយជីវិតទេ? ៣. ប្រសិនបើខ្ញុំនៅតែសោះកក្រោះនឹងអ្នករាល់ បើទោះបីជាអ្នកបានលះបង់នូវការប្រឹងប្រែងជាច្រើនហើយក្ដី តើអ្នកនឹងអាចបន្តធ្វើការឲ្យខ្ញុំ ដោយងងឹតងងល់បានដែរឬទេ? ៤. បន្ទាប់ពីអ្នកបានធ្វើការ លះបង់សម្រាប់ខ្ញុំហើយ ប្រសិនបើខ្ញុំមិនពេញចិត្តនឹងការទាមទារកំប៉ិកកំប៉ុករបស់អ្នក តើអ្នកនឹងទៅជានឿយណាយ ហើយខកចិត្តនឹងខ្ញុំ ឬកាន់តែខឹងក្រេវក្រោធ ហើយគំហក

មើលងាយដែរឬទេ? ៥. ប្រសិនបើអ្នកតែងតែស្មោះត្រង់រហូតមក ដោយមានទាំងសេចក្ដីស្រឡាញ់យ៉ាងច្រើនចំពោះខ្ញុំ តែអ្នករងនូវទណ្ឌកម្មជាជំងឺ ភាពក្រខ្សត់ និងការបោះបង់ចោលពីមិត្តភក្តិ និងសាច់ញាតិ ឬប្រសិនបើអ្នកទ្រាំទ្រនឹងគ្រោះអកុសលផ្សេងៗក្នុងជីវិត តើភាពស្មោះត្រង់ និងសេចក្ដីស្រឡាញ់របស់អ្នករាល់គ្នាចំពោះខ្ញុំនៅតែបន្តដែរឬទេ? ៦. ប្រសិនបើ អ្វីដែលអ្នករាល់គ្នាស្រមៃក្នុងចិត្តរបស់អ្នករាល់គ្នាគ្មានអ្វីមួយត្រូវគ្នានឹងកិច្ចការដែលខ្ញុំបានធ្វើ តើអ្នកនឹងដើរលើមាគ៌ាអនាគតរបស់ខ្លួនយ៉ាងដូចម្ដេច? ៧. ប្រសិនបើអ្នក មិនទទួលបាននូវសេចក្ដី ដែលអ្នកសង្ឃឹមថានឹងបាន តើអ្នកអាចបន្តធ្វើជាអ្នកដើរតាមខ្ញុំដែរឬទេ? ៨. ប្រសិនបើអ្នកពុំធ្លាប់បានយល់ពីគោលបំណង និងសារៈសំខាន់នៃកិច្ចការរបស់ខ្ញុំ តើអ្នកអាចធ្វើជាមនុស្សស្ដាប់បង្គាប់ម្នាក់ដែលមិនធ្វើការវិនិច្ឆ័យ និងធ្វើការសន្និដ្ឋាន តាមទំនើងចិត្តរបស់ខ្លួនដែរឬទេ? ៩. តើអ្នកអាចផ្ដល់តម្លៃដល់ព្រះបន្ទូលគ្រប់យ៉ាងដែលខ្ញុំបានថ្លែង និងកិច្ចការគ្រប់យ៉ាងដែលខ្ញុំបានធ្វើ កាលដែលខ្ញុំនៅជាមួយមនុស្សជាតិបានដែរឬទេ? ១០. តើអ្នកអាចធ្វើជាអ្នកដើរតាមដ៏ស្មោះត្រង់របស់ខ្ញុំ ទាំងស៊ូរងទ្រាំងនូវទុក្ខលំបាកពេញមួយជីវិតដើម្បីខ្ញុំ ទាំងដែលអ្នកមិនទទួលបានអ្វីសោះដែរឬទេ? ១១. ដោយយល់ដល់ខ្ញុំ តើអ្នកអាចបណ្ដោយឲ្យការពិចារណា ការគ្រោងទុក ឬការរៀបចំសម្រាប់មាគ៌ាអនាគតនៃការរក្សាជីវិតរបស់អ្នកកន្លងទៅដែរឬទេ? ទាំងអស់នេះគឺជាសំណួរដែលបង្ហាញអំពីសេចក្ដីតម្រូវជាចុងក្រោយរបស់ខ្ញុំពីអ្នករាល់គ្នា ហើយខ្ញុំសង្ឃឹមថា អ្នករាល់គ្នាអាចផ្ដល់ចម្លើយឲ្យខ្ញុំបាន។ ប្រសិនបើអ្នកបានសម្រេចនូវកិច្ចការម្យ៉ាង ឬពីរយ៉ាង ដែលសំណួរនេះសុំពីអ្នក នោះអ្នកត្រូវតែបន្តព្យាយាមថែមទៀត។ ប្រសិនបើអ្នកមិនអាចសម្រេចបាននូវសេចក្ដីតម្រូវណាមួយ ពីក្នុងសេចក្ដីតម្រូវទាំងនេះ នោះអ្នកមុខជាប្រភេទមនុស្សដែលនឹងត្រូវបោះទៅក្នុងស្ថាននរកហើយ។ ចំពោះមនុស្សបែបនេះ ខ្ញុំមិនចាំបាច់និយាយអ្វីទៀតទេ ដ្បិតពួកគេប្រាកដជា មិនមែនមនុស្សដែលអាចចុះសម្រុងនឹងខ្ញុំនោះឡើយ។ តើឲ្យខ្ញុំអាចទុកមនុស្សម្នាក់ដែលអាចក្បត់ខ្ញុំក្នុងគ្រប់កាលៈទេសៈឲ្យនៅក្នុងផ្ទះរបស់ខ្ញុំដូចម្ដេចបាន? ហើយចំពោះអស់អ្នកណាដែលនៅតែអាចក្បត់ខ្ញុំ ស្ទើរគ្រប់

កាលៈទេសៈនោះ ខ្ញុំនឹងសង្កេតមើលលំនាំនៃការអនុវត្តរបស់គេ មុនពេលធ្វើការរៀបចំដទៃទៀត។ យ៉ាងណាមិញ អស់អ្នកណាដែលអាចក្បត់ខ្ញុំ ទោះបីស្ថិតនៅក្នុងស្ថានភាពណាក៏ដោយ ខ្ញុំនឹងមិនបំភ្លេចឡើយ ខ្ញុំនឹងនឹកចាំពីពួកគេក្នុងចិត្តរបស់ខ្ញុំ ហើយទន្ទឹងចាំឱកាសតបស្នងនឹងទង្វើរបស់គេវិញជាមិនខាន។ សេចក្ដីតម្រូវដែលខ្ញុំបានលើកឡើង គឺសុទ្ធតែជាបញ្ហាដែលអ្នករាល់គ្នាត្រូវតែពិនិត្យពិច័យនៅក្នុងខ្លួនអ្នករាល់គ្នា។ ខ្ញុំសង្ឃឹមថា អ្នករាល់គ្នា អាចពិចារណាពីរឿងនេះយ៉ាងយកចិត្តទុកដាក់ ហើយមិនដោះស្រាយជាមួយខ្ញុំ ដោយបង្គ្រប់កិច្ចនោះទេ។ នៅក្នុងអនាគតដ៏ខ្លីខាងមុខ ខ្ញុំនឹងពិនិត្យមើលចម្លើយដែលអ្នករាល់គ្នាបានផ្ដល់ធៀបទៅនឹងសេចក្ដីតម្រូវរបស់ខ្ញុំ។ នៅពេលនោះ ខ្ញុំនឹងមិនតម្រូវអ្វីពីអ្នករាល់គ្នាទេ ហើយខ្ញុំក៏មិនផ្ដល់នូវការក្រើនរម្លឹកដ៏ស្មោះត្រង់ដល់អ្នកទៀតដែរ។ ផ្ទុយទៅវិញ ខ្ញុំនឹងប្រើប្រាស់សិទ្ធិអំណាចរបស់ខ្ញុំ។ អស់អ្នកណាដែលគួរត្រូវរក្សាទុក នឹងត្រូវបានរក្សាទុក អស់អ្នកណាដែលគួរត្រូវផ្ដល់រង្វាន់ នឹងទទួលបានរង្វាន់ អស់អ្នកណាដែលគួរត្រូវប្រគល់ទៅឲ្យសាតាំង នឹងត្រូវប្រគល់ទៅឲ្យសាតាំង អស់អ្នកណាដែលគួរត្រូវដាក់ទោសយ៉ាងធ្ងន់ធ្ងរ នឹងត្រូវដាក់ទោសយ៉ាងធ្ងន់ធ្ងរ ហើយអស់អ្នកណាដែលគួរវិនាសទៅនោះ ក៏នឹងត្រូវបំផ្លាញចោលដែរ។ ដូច្នេះ នឹងគ្មាននរណាមករំខានដល់ខ្ញុំ ក្នុងគ្រាដែលខ្ញុំកំពុងនៅរស់បានឡើយ។ តើអ្នកជឿលើព្រះបន្ទូលរបស់ខ្ញុំទេ? តើអ្នកជឿលើការដាក់ទោសឬទេ? តើអ្នកជឿថា ខ្ញុំនឹងដាក់ទោសដល់មនុស្សអាក្រក់ ដែលបោកប្រាស់ និងក្បត់ខ្ញុំដែរឬទេ? តើអ្នកសង្ឃឹមចង់ឲ្យថ្ងៃនោះមកដល់ឆាប់ៗ ឬឲ្យវាមកដល់នៅពេលក្រោយ? តើអ្នកជាមនុស្សដែលខ្លាចការដាក់ទោស ឬជាមនុស្សដែលតតាំងនឹងខ្ញុំ ទោះបីជាគេត្រូវទទួលការដាក់ទោស? នៅពេលដែលថ្ងៃនោះមកដល់ តើអ្នកអាចស្រមៃបានទេថា អ្នកនឹងរស់ក្នុងសំណើច និងភាពក្អាកក្អាយ ឬក៏អ្នកនឹងត្រូវយំ ហើយសង្កៀតធ្មេញវិញ? តើអ្នកសង្ឃឹមចង់ពើបប្រទះនឹងទីបញ្ចប់ប្រភេទណា? តើអ្នកធ្លាប់បានពិចារណា យ៉ាងយកចិត្តទុកដាក់ទេថា អ្នកជឿលើខ្ញុំមួយរយភាគរយ ឬសង្ស័យខ្ញុំមួយរយភាគរយ? តើអ្នកធ្លាប់បានពិចារណាពីប្រភេទនៃផលវិបាក និងលទ្ធផលដែលសកម្មភាព និងឥរិយាបថរបស់អ្នកផ្ដល់ជូនអ្នកដែរ

ឬទេ? តើអ្នកពិតជាសង្ឃឹមថា ព្រះបន្ទូលរបស់ខ្ញុំនឹងត្រូវបានសម្រេចម្ដងមួយៗ ឬអ្នកភ័យខ្លាចថា ព្រះបន្ទូលរបស់ខ្ញុំនឹងត្រូវសម្រេចម្ដងមួយៗ? ប្រសិនបើអ្នកសង្ឃឹមថា ខ្ញុំនឹងចាកចេញទៅឆាប់ៗ ដើម្បីសម្រេចព្រះបន្ទូលរបស់ខ្ញុំ តើអ្នកនឹងប្រព្រឹត្តចំពោះពាក្យសម្ដី និងសកម្មភាពរបស់អ្នកយ៉ាងដូចម្ដេច? ប្រសិនបើអ្នកសង្ឃឹមថា ខ្ញុំនឹងចាកចេញទៅឆាប់ៗ ដើម្បីសម្រេចព្រះបន្ទូលរបស់ខ្ញុំ តើអ្នកគួរប្រព្រឹត្តចំពោះពាក្យសម្ដី និងសកម្មភាពរបស់ខ្លួនឯងដោយរបៀបណា? ប្រសិនបើអ្នកមិនទន្ទឹងចាំការចាកចេញរបស់ខ្ញុំ និងមិនសង្ឃឹម ឲ្យព្រះបន្ទូលទាំងអស់របស់ខ្ញុំបានសម្រេចភ្លាមទេ ហេតុអ្វីក៏អ្នកជឿលើខ្ញុំដល់ម្ល៉ឹង? តើអ្នកពិតជាដឹងមែនទេថា ហេតុអ្វីបានជាអ្នកកំពុងដើរតាមខ្ញុំ? ប្រសិនបើហេតុផលរបស់អ្នកគ្រាន់តែដើម្បីពង្រីកចំណេះដឹងរបស់ខ្លួន នោះមិនចាំបាច់ឲ្យខ្ញុំបង្កបញ្ហាដល់ខ្លួនអ្នកម្ល៉ឹងទេ។ ប្រសិនបើការធ្វើឡើងដើម្បីឲ្យបានព្រះពរ និងគេចចេញពីគ្រោះមហន្តរាយដែលនឹងមកដល់ ហេតុអ្វីបានជាអ្នកមិនខ្វល់ខ្វាយនឹងកិរិយាផ្ទាល់ខ្លួនរបស់អ្នក? ហេតុអ្វីបានជាអ្នកមិនសួរខ្លួនឯងមើលថា តើអ្នកអាចបំពេញសេចក្ដីតម្រូវរបស់ខ្ញុំដែរឬទេ? ហេតុអ្វីបានអ្នកមិនសួរខ្លួនឯងមើលថា អ្នកមាន ឬគ្មានលក្ខណសម្បត្តិទទួលនូវព្រះពរដែលនឹងត្រូវមកដល់ដូច្នេះ?

# អ្នករាល់គ្នាត្រូវតែពិចារណានូវទង្វើរបស់ខ្លួន

គ្រប់អំពើ និងសកម្មភាពរបស់អ្នករាល់គ្នានៅក្នុងជីវិត បង្ហាញថា អ្នករាល់គ្នាត្រូវការទទួលយក ព្រះបន្ទូលមួយចំនួនរបស់ខ្ញុំរាល់ថ្ងៃ ដើម្បីបំពេញអ្នករាល់គ្នាឡើងវិញ ដ្បិតអ្នករាល់គ្នាខ្វះខាតខ្លាំងណាស់ ហើយចំណេះដឹង និងសមត្ថភាពទទួលយករបស់អ្នករាល់គ្នា មានតិចតួចណាស់។ នៅក្នុងជីវិតប្រចាំថ្ងៃ អ្នករាល់គ្នារស់នៅក្នុងបរិយាកាស និងបរិស្ថានដែលគ្មានការពិត ឬបញ្ញាញាណល្អ។ អ្នករាល់គ្នាខ្វះដើមទុនក្នុងការរស់រាន ហើយគ្មានគ្រឹះក្នុងការស្គាល់ខ្ញុំ ឬការពិតទេ។ ជំនឿរបស់អ្នករាល់គ្នាត្រូវបានបង្កើតឡើងនៅលើភាពទទេសូន្យ មានតែជំនឿមិនច្បាស់លាស់ និងអរូបី ឬជា

ចំណោះដឹងបែបមានះខ្លាំង ហើយជាពិធីសាសនាផង។ ជារៀងរាល់ថ្ងៃ ខ្ញុំសង្កេតមើលចលនារបស់អ្នករាល់គ្នា ដោយពិនិត្យមើលចេតនា និងផលអាក្រក់របស់អ្នករាល់គ្នា ហើយខ្ញុំមិនដែលឃើញមនុស្សណាម្នាក់ដែលពិតជាដាក់ដួងចិត្ត និងវិញ្ញាណរបស់ពួកគេនៅលើអាសនៈដែលមិនចេះប្រែប្រួលរបស់ខ្ញុំសោះ។ ដូច្នេះខ្ញុំមិនចង់ខាតពេលក្នុងការបញ្ចេញព្រះបន្ទូលទាំងអស់ដែលខ្ញុំចង់បង្ហាញដល់មនុស្សជាតិប្រភេទនេះទេ ផែនការតែមួយគត់នៅក្នុងព្រះហឫទ័យរបស់ខ្ញុំ គឺសម្រាប់កិច្ចការដែលមិនទាន់បញ្ចប់របស់ខ្ញុំ និងសម្រាប់មនុស្សលោកទាំងឡាយណា ដែលខ្ញុំមិនទាន់បានសង្គ្រោះនៅឡើយ។ ដូច្នេះ ខ្ញុំចង់ឲ្យអស់អ្នកដែលដើរតាមខ្ញុំ ទទួលបានសេចក្តីសង្គ្រោះរបស់ខ្ញុំ និងសេចក្តីពិតដែលព្រះបន្ទូលរបស់ខ្ញុំប្រទានឲ្យមនុស្សលោក។ ខ្ញុំសង្ឃឹមថានៅថ្ងៃណាមួយ ពេលដែលអ្នកបិទភ្នែក អ្នកនឹងឃើញពិភពមួយដែលមានក្លិនក្រអូបពេញខ្យល់ និងមានអូរទឹករស់ហូរ មិនមែនជាពិភពអាប់អួ ឬសោកក្រោះ និងជាកន្លែងដែលពពកខ្មៅបាំងជិតផ្ទៃមេឃ និងមានសំឡេងស្រែកថ្ងូរមិនចេះឈប់នោះឡើយ។

ជារៀងរាល់ថ្ងៃ អំពើ និងគំនិតរបស់មនុស្សម្នាក់ៗ ត្រូវបានទតឃើញដោយព្រះនេត្ររបស់ព្រះដ៏ពិតតែមួយអង្គ ហើយក៏ជាការត្រៀមសម្រាប់ថ្ងៃស្អែកផ្ទាល់ខ្លួនរបស់ពួកគេ ក្នុងពេលជាមួយគ្នានេះដែរ។ នេះគឺជាផ្លូវដែលត្រូវតែដើរដោយអស់អ្នកដែលកំពុងរស់នៅ វាគឺជាផ្លូវដែលខ្ញុំបានកំណត់ទុកមុនសម្រាប់គ្រប់គ្នា ហើយគ្មាននរណាម្នាក់អាចគេចផុត ឬត្រូវបានលើកលែងឡើយ។ ព្រះបន្ទូលដែលខ្ញុំបានថ្លែង គ្មានចំនួនកំណត់ទេ ហើយលើសពីនេះទៅទៀត កិច្ចការដែលខ្ញុំធ្វើ គឺមិនអាចវាស់ស្ទង់បានទេ។ តាមធម្មតា រៀងរាល់ថ្ងៃខ្ញុំទតមើលមនុស្សម្នាក់ៗអនុវត្តការងារទាំងអស់ដែលពួកគេធ្វើ អាស្រ័យតាមចរិតកំណើតរបស់ពួកគេ និងការវិវឌ្ឍនៃធម្មជាតិរបស់ពួកគេ។ មនុស្សជាច្រើន បានស្ថិតនៅលើ «ផ្លូវត្រូវ» ដែលខ្ញុំបានកំណត់ ដើម្បីពន្យល់ពីជំពូកមនុស្សខុសៗគ្នា ដោយមិនដឹងខ្លួន។ មនុស្សជំពូកខុសៗគ្នាទាំងនេះ ខ្ញុំបានដាក់ពួកគេនៅក្នុងបរិស្ថានខុសគ្នា តាំងពីយូរមកហើយ ហើយម្នាក់ៗបានបង្ហាញលក្ខណៈពីកំណើតរបស់គេ តាមកន្លែងរៀងៗខ្លួនរបស់គេដែរ។ គ្មានអ្នកណាចងពួកគេទេ ហើយក៏គ្មាន

អ្នកណាបោកបញ្ឆោតពួកគេដែរ។ ពួកគេមានសេរីភាពពេញលេញទាំងស្រុង ហើយកិរិយាដែលពួកគេស្ដែងចេញ គឺចេញមកតាមលក្ខណៈធម្មជាតិ។ មានតែវត្ថុមួយប៉ុណ្ណោះដែលរក្សាពួកគេឲ្យស្ថិតក្នុងការត្រួតពិនិត្យគឺ៖ ព្រះបន្ទូលរបស់ខ្ញុំ។ ដូច្នេះ មនុស្សមួយចំនួនពិតជាបានអានព្រះបន្ទូលរបស់ខ្ញុំទាំងមិនពេញចិត្ត ទាំងមិនដែលអនុវត្តតាមព្រះបន្ទូលខ្ញុំឡើយ តែគេធ្វើដូច្នោះដើម្បីចៀសវាងពីសេចក្តីស្លាប់ប៉ុណ្ណោះ ទន្ទឹមនឹងនេះ អ្នកផ្សេងទៀតពិបាកទ្រាំរស់ណាស់ បើថ្ងៃណាគ្មានព្រះបន្ទូលរបស់ខ្ញុំមកណែនាំ និងផ្គត់ផ្គង់ពួកគេទេ ដូច្នេះហើយ ពួកគេជាធម្មតាកាន់តាមព្រះបន្ទូលរបស់ខ្ញុំគ្រប់ពេលវេលា។ ពេលវេលាចេះតែកន្លងទៅ ពួកគេរកឃើញអាថ៌កំបាំងនៃជីវិតមនុស្ស ទិសដៅរបស់មនុស្សលោក និងតម្លៃជីវិតជាមនុស្ស។ នេះគ្រាន់តែជាសភាពដែលមនុស្សជាតិ ស្ថិតក្នុងវត្តមាននៃព្រះបន្ទូលរបស់ខ្ញុំ ហើយខ្ញុំគ្រាន់តែអនុញ្ញាតឲ្យរឿងរ៉ាវកើតឡើង តាមដំណើររបស់ពួកវា។ ខ្ញុំមិនធ្វើកិច្ចការណាមួយដែលបង្ខំមនុស្សឲ្យយកព្រះបន្ទូលរបស់ខ្ញុំធ្វើជាគ្រឹះនៃអត្ថិភាពរបស់ពួកគេនោះទេ។ ដូច្នេះ មនុស្សដែលមិនធ្លាប់មានមនសិការ និងដែលអត្ថិភាពរបស់ពួកគេ មិនធ្លាប់មានគុណតម្លៃអ្វីសោះ ហ៊ានបោះចោលព្រះបន្ទូលរបស់ខ្ញុំទៅម្ខាង ហើយធ្វើតាមចំណង់របស់ពួកគេ ក្រោយពេលអង្កេតមើលរឿងរ៉ាវកើតឡើងយ៉ាងស្ងៀមស្ងាត់។ ពួកគេចាប់ផ្ដើមធុញទ្រាន់នឹងសេចក្តីពិត និងគ្រប់យ៉ាងដែលចេញមកពីខ្ញុំ។ លើសពីនេះទៅទៀត ពួកគេធុញទ្រាន់នឹងការស្នាក់នៅក្នុងដំណាក់របស់ខ្ញុំ។ មនុស្សទាំងនេះ ស្នាក់នៅក្នុងដំណាក់របស់ខ្ញុំមួយរយៈ សម្រាប់ជាប្រយោជន៍ដល់គោលដៅរបស់ពួកគេ និងដើម្បីរួចផុតពីការដាក់ទណ្ឌកម្ម ទោះបីជាពួកគេកំពុងបម្រើព័ន្ធកិច្ចក៏ដោយ។ ដោយឡែកចេតនា និងសកម្មភាពរបស់ពួកគេ មិនដែលផ្លាស់ប្ដូរឡើយ។ ទង្វើនេះបង្កើនសេចក្ដីប្រាថ្នារបស់ពួកគេចំពោះព្រះពរ និងបង្កើនសេចក្តីប្រាថ្នារបស់ពួកគេក្នុងការចូលទៅនគរព្រះតែមួយដង ហើយស្ថិតនៅទីនោះជារៀងរហូតតទៅ ទាំងចូលក្នុងស្ថានសួគ៌ដ៏អស់កល្ប។ កាលណាពួកគេរឹតតែចង់ឲ្យថ្ងៃរបស់ខ្ញុំឆាប់មកដល់ ពួកគេកាន់តែមានអារម្មណ៍ថា សេចក្តីពិតក្លាយជាឧបសគ្គ ជាថ្មជំពប់ដល់ផ្លូវរបស់ពួកគេ។ ពួកគេស្ទើរតែ

មិនអាចរង់ចាំឈានជើងចូលក្នុងនគរព្រះ ដើម្បីទទួលបានព្រះពរពីនគរស្ថានសួគ៌ជារៀងរហូត ដោយមិនចាំបាច់តាមរកសេចក្ដីពិត ឬទទួលយកការជំនុំជម្រះ និងការដាក់ទោសអ្វីទាំងអស់ ហើយសំខាន់ជាងគេ គឺមិនចាំបាច់លុតក្រាបនៅក្នុងដំណាក់ខ្ញុំ និងធ្វើតាមខ្ញុំបញ្ជា។ មនុស្សទាំងនេះចូលក្នុងដំណាក់ខ្ញុំ មិនមែនដើម្បីបំពេញសេចក្ដីប្រាថ្នារបស់គេ ក្នុងការស្វែងរកសេចក្ដីពិត ឬសហការជាមួយការគ្រប់គ្រងរបស់ខ្ញុំទេ គោលបំណងរបស់ពួកគេ គឺគ្រាន់តែឲ្យបានស្ថិតក្នុងចំណោមមនុស្សដែលមិនរងសេចក្ដីវិនាសនៅក្នុងយុគសម័យដែលនឹងមកដល់។ ហេតុដូច្នេះ ដួងចិត្តរបស់ពួកគេមិនដែលស្គាល់អ្វីទៅជាសេចក្ដីពិត ឬធ្វើដូចម្ដេចទើបទទួលបានសេចក្ដីពិតឡើយ។ នេះជាមូលហេតុដែលមនុស្សបែបនេះ មិនដែលអនុវត្តសេចក្ដីពិត ឬដឹងពីជម្រៅនៃសេចក្ដីពុករលួយរបស់ពួកគេ ហើយនៅតែរស់នៅក្នុងដំណាក់របស់ខ្ញុំ ក្នុងនាមជា «អ្នកបម្រើ» រហូត។ ពួកគេរង់ចាំថ្ងៃរបស់ខ្ញុំមកដល់ «ទាំងអត់ធ្មត់» ហើយក៏មិនចេះនឿយហត់ ខណៈពេលដែលពួកគេត្រូវបានរុញទៅរុញមកដោយលក្ខណៈនៃកិច្ចការរបស់ខ្ញុំ។ ប៉ុន្តែមិនថាពួកគេខិតខំប្រឹងប្រែងខ្លាំងយ៉ាងណា ឬពួកគេបង់សងក្នុងតម្លៃណានោះទេ ក៏គ្មាននរណាម្នាក់ធ្លាប់ឃើញពួកគេរងទុក្ខដើម្បីសេចក្ដីពិតទេ ឬក៏ផ្ដល់អ្វីមួយ សម្រាប់ជាប្រយោជន៍ដល់ខ្ញុំដែរ។ ក្នុងដួងចិត្តរបស់ពួកគេ កំពុងតែរសាប់រសល់ចង់ឃើញថ្ងៃដែលខ្ញុំបញ្ចប់យុគសម័យចាស់ ហើយលើសពីនេះទៅទៀត គេមិនអាចទ្រាំចាំមើលភាពអស្ចារ្យនៃព្រះចេស្ដា និងសិទ្ធិអំណាចរបស់ខ្ញុំឡើយ។ រឿងដែលពួកគេមិនដែលរួសរាន់ធ្វើសោះនោះ គឺការកែខ្លួន និងតាមរកសេចក្ដីពិត។ ពួកគេស្រឡាញ់អ្វីៗដែលខ្ញុំធុញទ្រាន់ ប៉ុន្តែពួកគេធុញទ្រាន់នឹងអ្វីៗដែលខ្ញុំស្រឡាញ់។ ពួកគេចង់បានយ៉ាងខ្លាំងនូវអ្វីៗដែលខ្ញុំស្អប់ ហើយពួកគេខ្លាចបាត់បង់អ្វីៗដែលខ្ញុំស្អប់ខ្ពើមខ្លាំង។ ពួកគេរស់នៅក្នុងលោកិយដ៏អាក្រក់នេះ មិនដែលស្អប់ខ្ពើមវា ហើយបែរជាខ្លាចខ្ញុំបំផ្លាញវាចោលយ៉ាងខ្លាំងទៅវិញ។ ក្នុងចេតនាផ្ទុយគ្នារបស់ពួកគេ ពួកគេស្រឡាញ់លោកិយដែលខ្ញុំស្អប់ខ្ពើមនេះ ប៉ុន្តែពួកគេក៏ចង់ឲ្យខ្ញុំបំផ្លាញវាយ៉ាងរួសរាន់ ដើម្បីឲ្យពួកគេអាចរួចជីវិតពីការរងទុក្ខដោយក្ដីអន្តរាយ ហើយក្លាយទៅជាចៅហ្វាយនៃយុគសម័យបន្ទាប់

មុនពេលពួកគេងាកចេញពីផ្លូវពិត។ នេះក៏ព្រោះតែ ពួកគេមិនស្រឡាញ់សេចក្ដីពិត ហើយក៏ធុញទ្រាន់នឹងគ្រប់យ៉ាងដែលចេញមកពីខ្ញុំ។ ពួកគេអាចក្លាយជា «មនុស្សដែលស្ដាប់បង្គាប់» ក្នុងរយៈពេលខ្លី ដើម្បីកុំឲ្យបាត់បង់ព្រះពរ ប៉ុន្តែភាពអន្ទះសាររបស់ពួកគេក្នុងការទទួលបានព្រះពរ ព្រមទាំងការភ័យខ្លាចការវិនាស និងការចូលក្នុងបឹងភ្លើង មិនអាចបិទបាំងបានរហូតនោះទេ។ នៅពេលដែលថ្ងៃរបស់យើលជិតមកដល់ សេចក្តីប្រាថ្នារបស់ពួកគេ ក៏ដុះដាលខ្លាំងឡើងជាលំដាប់។ ហើយពេលមហន្តរាយកាន់តែខ្លាំង វាកាន់តែធ្វើឲ្យពួកគេគ្មានទីពឹង ទាំងមិនដឹងថា ត្រូវចាប់ផ្ដើមពីកន្លែងណា ដើម្បីធ្វើឲ្យខ្ញុំរីករាយព្រះទ័យ និងចៀសវាងការបាត់បង់ព្រះពរដែលពួកគេចង់បានយ៉ាងខ្លាំងជាយូរមកហើយ។ មនុស្សបែបនេះ ទទូចចង់ធ្វើសកម្មភាពបម្រើការជាទ័ពស្រួចឲ្យបានទាន់ពេលដែលដៃរបស់ខ្ញុំចាប់ផ្ដើមធ្វើការ។ ពួកគេគិតតែពីការកញ្ជ្រោលឡើងទៅជួរមុខបំផុតរបស់កងទ័ព ដោយខ្លាចខ្ញុំមើលមិនឃើញពួកគេយ៉ាងខ្លាំង។ ពួកគេធ្វើ និងនិយាយនូវអ្វីដែលពួកគេគិតថាត្រឹមត្រូវ ដោយមិនដែលដឹងថា អំពើ និងសកម្មភាពរបស់ពួកគេ មិនទាក់ទងនឹងសេចក្ដីពិតទាល់តែសោះ ហើយអំពើរបស់ពួកគេបានត្រឹមតែរំខាន និងបង្អាក់ផែនការរបស់ខ្ញុំប៉ុណ្ណោះ។ ពួកគេប្រហែលជាបានប្រឹងប្រែងយ៉ាងខ្លាំង ហើយអាចជាមានឆន្ទៈ និងចេតនាស្មោះត្រង់ពិត ក្នុងការស៊ូទ្រាំនឹងភាពលំបាក ប៉ុន្តែពួកគេមិនបានធ្វើអ្វីសោះដែលទាក់ទងនឹងខ្ញុំ ដ្បិតខ្ញុំមិនដែលឃើញថាអំពើរបស់ពួកគេចេញមកពីចេតនាល្អសោះ ហើយខ្ញុំរឹតតែមិនធ្លាប់ឃើញពួកគេថ្វាយអ្វីមួយនៅលើអាសនៈរបស់ខ្ញុំដែរ។ ទាំងនេះ គឺជាអំពើដែលពួកគេបាន និងកំពុងធ្វើនៅចំពោះមុខខ្ញុំអស់រយៈពេលជាច្រើនឆ្នាំកន្លងមកនេះ។

កាលពីដើម ខ្ញុំធ្លាប់ចង់ផ្ដត់ផ្ដង់ដល់អ្នករាល់គ្នានូវសេចក្ដីពិតច្រើនជាងនេះ ប៉ុន្តែខ្ញុំត្រូវតែអត់ធ្មត់ មិនផ្ដល់ឲ្យច្រើនទៀតទេ ព្រោះអាកប្បកិរិយារបស់អ្នករាល់គ្នាចំពោះសេចក្ដីពិត គឺសោះកក្រោះ និងតោះតើយពេកហើយ ខ្ញុំមិនចង់ឱ្យការខំប្រឹងប្រែងរបស់ខ្ញុំត្រូវចោលទទេ ហើយខ្ញុំក៏មិនចង់ឃើញមនុស្សដែលកាន់តាមព្រះបន្ទូលរបស់ខ្ញុំបែរជាធ្វើគ្រប់បែបយ៉ាងដែលប្រឆាំងនឹងខ្ញុំ បង្ខូចខ្ញុំ និងប្រមាថខ្ញុំដែរ។ ដោយសារតែ

អាកប្បកិរិយា និងភាពជាមនុស្សរបស់អ្នករាល់គ្នា ទើបខ្ញុំគ្រាន់តែផ្ដត់ផ្គង់ដល់អ្នករាល់គ្នានូវចំណែកដ៏តិចតួច និងសំខាន់បំផុតនៃព្រះបន្ទូលរបស់ខ្ញុំ ដែលជាកិច្ចការសាកល្បងរបស់ខ្ញុំក្នុងចំណោមមនុស្សជាតិ សម្រាប់អ្នករាល់គ្នា។ មានតែឥឡូវនេះទេ ដែលខ្ញុំបានបញ្ជាក់យ៉ាងពិតប្រាកដថា ការសម្រេចចិត្ត និងផែនការដែលខ្ញុំបានធ្វើ គឺសក្ដិសមនឹងសេចក្ដីត្រូវការរបស់អ្នករាល់គ្នា ហើយជាងនេះទៅទៀត អាកប្បកិរិយារបស់ខ្ញុំចំពោះមនុស្សជាតិ គឺជាឥរិយាបថដ៏ត្រឹមត្រូវ។ អាកប្បកិរិយាជាច្រើនឆ្នាំរបស់អ្នករាល់គ្នានៅចំពោះមុខខ្ញុំ បានផ្ដល់ឲ្យខ្ញុំនូវចម្លើយដែលមិនធ្លាប់មានពីមុនមក ហើយសំណួរចំពោះចម្លើយនេះគឺ៖ «តើមនុស្សមានអាកប្បកិរិយាបែបណា នៅចំពោះមុខសេចក្ដីពិត និងព្រះដ៏ពិត?» ការប្រឹងប្រែង ដែលខ្ញុំបានបូជាចំពោះមនុស្ស គឺបញ្ជាក់ពីទម្ងន់នៃសេចក្ដីស្រឡាញ់របស់ខ្ញុំចំពោះមនុស្ស ហើយរាល់សកម្មភាពរបស់មនុស្សនៅចំពោះមុខខ្ញុំ បញ្ជាក់ពីទម្ងន់ នៃការស្អប់ខ្ពើមរបស់ពួកគេចំពោះសេចក្ដីពិត ហើយទាស់ទទឹងនឹងខ្ញុំ។ គ្រប់ពេលវេលា ខ្ញុំបារម្ភពីអស់អ្នកដែលដើរតាមខ្ញុំ ប៉ុន្តែគ្មានពេលណាមួយដែលអ្នកដើរតាមខ្ញុំទាំងនោះអាចទទួលយកព្រះបន្ទូលរបស់ខ្ញុំទេ ពួកគេមិនអាចទទួលយកសូម្បីតែការទូន្មានរបស់ខ្ញុំ។ នេះជារឿងដែលធ្វើឲ្យខ្ញុំក្រៀមក្រំបំផុត។ គ្មានអ្នកណាម្នាក់អាចយល់ពីខ្ញុំសោះ ហើយជាងនេះទៅទៀតក៏គ្មានអ្នកណាម្នាក់អាចទទួលយកខ្ញុំ ទោះបីជាអាកប្បកិរិយាខ្ញុំស្មោះត្រង់ ហើយព្រះបន្ទូលខ្ញុំទន់ភ្លន់ក៏ដោយ។ គ្រប់គ្នាព្យាយាមធ្វើកិច្ចការដែលខ្ញុំបានប្រគល់ឲ្យ តាមគំនិតផ្ទាល់ខ្លួនរបស់គេ ពួកគេមិនស្វះស្វែងរកហឫទ័យរបស់ខ្ញុំឡើយ កុំថាឡើយសួរពីអ្វីដែលខ្ញុំទាមទារពីពួកគេ។ ពួកគេនៅតែអះអាងថា បម្រើខ្ញុំដោយស្មោះត្រង់ ខណៈដែលពួកគេបះបោរប្រឆាំងនឹងខ្ញុំគ្រប់ពេល។ មនុស្សជាច្រើនជឿថា សេចក្ដីពិតដែលពួកគេមិន អាចទទួលយក ឬដែលពួកគេមិនអាចអនុវត្តបាន គឺមិនមែនជាសេចក្ដីពិតទេ។ ចំពោះមនុស្សបែបនេះ សេចក្ដីពិតរបស់ខ្ញុំក្លាយជារបស់ដែលត្រូវបានបដិសេធ និងបោះចោលទៅម្ខាង។ ក្នុងពេលជាមួយគ្នានោះ មនុស្សទទួលស្គាល់ខ្ញុំថាជាព្រះជាម្ចាស់ ត្រឹមតែពាក្យសម្ដី ក៏ជឿថាខ្ញុំជាអ្នកក្រៅ ដែលមិនមែនជាសេចក្ដី

ពិត មិនមែនជាផ្លូវ ឬមិនមែនជាជីវិតផងដែរ។ គ្មានអ្នកណាស្គាល់សេចក្តីពិតនេះទេ៖ ព្រះបន្ទូលរបស់ខ្ញុំ គឺជាសេចក្តីពិត ដែលមិនប្រែប្រួលរហូត។ ខ្ញុំជាអ្នកផ្គត់ផ្គង់ជីវិតដល់មនុស្ស និងជាមគ្គុទេសក៍តែមួយគត់សម្រាប់មនុស្សជាតិ។ តម្លៃ និងអត្ថន័យនៃព្រះបន្ទូលរបស់ខ្ញុំ មិនត្រូវបានកំណត់ត្រង់ថាមនុស្សលោកទទួលស្គាល់ ឬទទួលយក ឬក៏អត់នោះទេ ប៉ុន្តែសារជាតិនៃព្រះបន្ទូលទេ ដែលជាអ្នកកំណត់ដោយខ្លួនឯង។ ទោះបីជាគ្មានមនុស្សណាម្នាក់នៅលើផែនដីនេះអាចទទួលយកព្រះបន្ទូលរបស់ខ្ញុំបានក៏ដោយ ក៏គុណតម្លៃ និងជំនួយនៃព្រះបន្ទូលរបស់ខ្ញុំចំពោះមនុស្សលោក គឺមិនអាចគណនាបានទេ ចំពោះមនុស្សណាក៏ដោយ។ ហេតុដូច្នេះហើយ នៅពេលប្រឈមមុខជាមួយមនុស្សជាច្រើនដែលបះបោរប្រឆាំង ឆ្លើយបដិសេធ ឬមើលងាយយ៉ាងខ្លាំងចំពោះព្រះបន្ទូលរបស់ខ្ញុំ ជំហររបស់ខ្ញុំគឺមានតែ៖ ទុកឲ្យពេលវេលា និងហេតុការណ៍ធ្វើជាសាក្សីរបស់ខ្ញុំ ព្រមទាំងបង្ហាញថា ព្រះបន្ទូលរបស់ខ្ញុំគឺជាសេចក្តីពិត ជាផ្លូវ និងជាជីវិត។ ទុកឲ្យពួកវាបង្ហាញថា អ្វីដែលខ្ញុំបានថ្លែងគឺសុទ្ធតែត្រឹមត្រូវ ជាព្រះបន្ទូលដែលដែលមនុស្សគួរប្រដាប់ឲ្យជាប់ខ្លួន ហើយជាងនេះទៅទៀត ជាអ្វីដែលមនុស្សគួរតែទទួលយក។ ខ្ញុំនឹងឲ្យអស់អ្នកដែលដើរតាមខ្ញុំ ដឹងពីហេតុការណ៍នេះ៖ អ្នកដែលមិនអាចទទួលយកព្រះបន្ទូលរបស់ខ្ញុំបានពេញលេញ អ្នកដែលមិនអាចអនុវត្តតាមព្រះបន្ទូលរបស់ខ្ញុំ អ្នកដែលមិនអាចរកឃើញពីគោលបំណងនៅក្នុងព្រះបន្ទូលរបស់ខ្ញុំ និងអ្នកដែលមិនអាចទទួលសេចក្តីសង្គ្រោះដោយសារព្រះបន្ទូលរបស់ខ្ញុំ សុទ្ធតែជាអ្នកដែលត្រូវទទួលការផ្តន្ទាទោសដោយព្រះបន្ទូលរបស់ខ្ញុំ ហើយជាងនេះទៅទៀត ពួកគេបានបាត់បង់សេចក្តីសង្គ្រោះរបស់ខ្ញុំ ហើយដំបងរបស់ខ្ញុំក៏នឹងមិនដែលងាកចេញពីពួកគេដែរ។

ថ្ងៃទី១៦ ខែមេសា ឆ្នាំ២០០៣

# ព្រះជាម្ចាស់ គឺជាប្រភពនៃជីវិតមនុស្ស

ចាប់តាំងពីពេលដែលអ្នកស្រែកយំចូលមកក្នុងពិភពលោកនេះ គឺអ្នកចាប់ផ្ដើមបំពេញភារកិច្ចរបស់ខ្លួនហើយ។ អ្នកបំពេញតួនាទី និងចាប់ផ្ដើមដំណើរជីវិតរបស់ខ្លួនសម្រាប់ផែនការរបស់ព្រះជាម្ចាស់ និងការរៀបចំរបស់ទ្រង់។ មិនថាអ្នកមានប្រវត្តិបែបណា ហើយដំណើរដែលនៅខាងមុខអ្នកយ៉ាងណានោះទេ គឺគ្មាននរណាម្នាក់អាចគេចផុតពីការរៀបចំ និងការចាត់ចែងរបស់ស្ថានសួគ៌បានឡើយ ហើយគ្មាននរណាម្នាក់អាចគ្រប់គ្រងជោគវាសនារបស់ខ្លួនបានទេ ដ្បិតមានតែទ្រង់ដែលគ្រប់គ្រងលើអ្វីៗទាំងអស់ប៉ុណ្ណោះ ដែលអាចធ្វើកិច្ចការបែបនេះបាន។ ចាប់តាំងពីថ្ងៃដែលមនុស្សបានកើតមក ព្រះជាម្ចាស់បានធ្វើកិច្ចការនេះរួចទៅហើយ ដោយទ្រង់គ្រប់គ្រងលើចក្រវាឡទាំងមូល ដឹកនាំច្បាប់នៃការផ្លាស់ប្ដូរសម្រាប់អ្វីៗទាំងអស់ និងគន្លងចលនានៃរបស់ទាំងអស់នោះ។ មនុស្ស ក៏ដូចជាអ្វីៗទាំងអស់ដែរ គឺត្រូវបានចិញ្ចឹមបីបាច់ដោយស្ងៀមស្ងាត់ និងដោយមិនដឹងខ្លួន តាមរយៈភាពផ្អែមល្ហែម និងទឹកភ្លៀងព្រមទាំងទឹកសន្សើមដែលមកពីព្រះជាម្ចាស់ ហើយមនុស្សក៏រស់នៅក្រោមការរៀបចំនៃព្រះហស្តរបស់ព្រះជាម្ចាស់ទាំងមិនដឹងខ្លួនដែរ។ ព្រះជាម្ចាស់ក្រសោបដួងចិត្ត និងវិញ្ញាណរបស់មនុស្សនៅក្នុងព្រះហស្តទ្រង់ ហើយគ្រប់យ៉ាងនៅក្នុងជីវិតរបស់មនុស្សសុទ្ធតែត្រូវបានមើលឃើញនៅក្នុងព្រះនេត្ររបស់ព្រះជាម្ចាស់។ មិនថាអ្នកជឿ ឬក៏មិនជឿនោះទេ អ្វីៗគ្រប់យ៉ាងទាំងអស់ ទាំងរបស់មានជីវិត និងគ្មានជីវិត នឹងផ្លាស់វេនផ្លាស់ប្ដូរ ផ្លាស់ជាថ្មី ព្រមទាំងបាត់ទៅវិញតាមព្រះតម្រិះរបស់ព្រះជាម្ចាស់។ នេះជារបៀបដែលព្រះជាម្ចាស់គ្រប់គ្រងលើអ្វីៗទាំងអស់។

នៅពេលដែលពេលរាត្រីចូលមកដល់យ៉ាងស្ងៀមស្ងាត់ មនុស្សមិនដឹងខ្លួននោះទេ ព្រោះដួងចិត្តរបស់មនុស្សមិនអាចដឹងថា ពេលរាត្រីចូលមកដល់ដោយរបៀបណា ហើយក៏មិនដឹងថាវាមកដល់នៅពេលណាដែរ។ នៅពេលដែលពេលរាត្រីរសាត់បាត់ទៅដោយស្ងៀមស្ងាត់ មនុស្សក៏ស្វាគមន៍ចំពោះការមកដល់នៃពន្លឺថ្ងៃ ប៉ុន្តែថាពន្លឺបាន

មកដល់នៅពេលណា ហើយថាវាបានដេញភាពងងឹតនៃពេលរាត្រីចេញទៅដោយរបៀបណា នោះមនុស្សដឹងតិចតួចណាស់ ហើយក៏មិនសូវដឹងដែរ។ ភាពឆ្លាស់គ្នាដដែលៗនៃពេលថ្ងៃ និងពេលយប់ នាំមនុស្សឆ្លងកាត់ពីរយៈពេលមួយទៅរយៈពេលមួយទៀត ពីបរិបទប្រវត្តិសាស្រ្តមួយទៅបរិបទប្រវត្តិសាស្រ្តមួយទៀត ខណៈដែលមានការធានាថា កិច្ចការរបស់ព្រះជាម្ចាស់ក្នុងគ្រប់ពេល និងផែនការរបស់ទ្រង់គ្រប់សម័យកាលទាំងអស់ ត្រូវបានអនុវត្ត។ មនុស្សបានដើរឆ្លងកាត់រយៈពេលទាំងអស់នេះជាមួយព្រះជាម្ចាស់ ប៉ុន្តែមិនដឹងថា ព្រះជាម្ចាស់គ្រប់គ្រងលើគោលដៅនៃរបស់សព្វសារពើ និងសត្វមានជីវិតទាំងអស់នោះទេ ហើយក៏មិនដឹងថាព្រះជាម្ចាស់រៀបចំ និងដឹកនាំអ្វីៗទាំងអស់យ៉ាងដូចម្ដេចដែរ។ មនុស្សមិនបានយល់អំពីការនេះ តាំងពីយូរយារណាស់មកហើយ រហូតមកដល់សព្វថ្ងៃនេះ។ ចំពោះមូលហេតុ គឺមិនមែនដោយសារតែកិច្ចការរបស់ព្រះជាម្ចាស់លាក់កំបាំងពេក ឬដោយសារផែនការរបស់ព្រះជាម្ចាស់មិនទាន់ត្រូវបានគេដឹងនៅឡើយនោះទេ ប៉ុន្តែ គឺដោយសារតែដួងចិត្ត និងវិញ្ញាណរបស់មនុស្សនៅឆ្ងាយពីព្រះជាម្ចាស់រហូតដល់ចំណុចមួយដែលគាត់ស្ថិតនៅក្នុងការបម្រើរបស់អារក្សសាតាំង ទោះបីជាគាត់ដើរតាមព្រះជាម្ចាស់ក៏ដោយ ក៏គាត់នៅតែមិនដឹងដែរ។ គ្មាននរណាម្នាក់ស្វែងរកយ៉ាងសកម្ម នូវស្នាមព្រះបាទារបស់ព្រះជាម្ចាស់ និងការបង្ហាញអង្គទ្រង់របស់ព្រះជាម្ចាស់នោះទេ ហើយគ្មាននរណាម្នាក់មានឆន្ទៈចង់ស្ថិតនៅក្នុងការយកព្រះទ័យទុកដាក់ និងការថែរក្សារបស់ព្រះជាម្ចាស់ដែរ។ ផ្ទុយទៅវិញ ពួកគេប្រាថ្នាចង់ពឹងផ្អែកលើភាពពុកផុយរបស់អារក្សសាតាំងដែលជាមេកំណាច ដើម្បីសម្របខ្លួនទៅនឹងពិភពលោកនេះ និងច្បាប់ជីវិតដែលមនុស្សអាក្រក់អនុវត្តតាម។ ត្រង់ចំណុចនេះ ដួងចិត្ត និងវិញ្ញាណរបស់មនុស្សបានក្លាយទៅជាសួយសារអាករ និងជាចំណីរបស់អារក្សសាតាំង។ ជាងនេះទៅទៀត ដួងចិត្ត និងវិញ្ញាណរបស់មនុស្សបានក្លាយទៅជាកន្លែងមួយដែលអារក្សសាតាំងអាចរស់នៅ និងជាកន្លែងលេងរបស់វា។ ដូច្នេះ មនុស្សបាត់បង់ការយល់ដឹងរបស់ខ្លួនអំពីគោលការណ៍នៃភាពជាមនុស្ស និងគុណតម្លៃ ព្រមទាំងអត្ថន័យនៃជីវិតមនុស្ស ទាំងមិនដឹងខ្លួន។

ក្រឹត្យវិន័យរបស់ព្រះជាម្ចាស់ និងសម្ព័ន្ធមេត្រីរវាងព្រះជាម្ចាស់ និងមនុស្ស បានរលាយចេញពីដួងចិត្តរបស់មនុស្សបន្តិចម្ដងៗ ហើយគេក៏ឈប់ស្វែងរក ឬក៏លែងយកចិត្តទុកដាក់ចំពោះព្រះជាម្ចាស់។ តាមរយៈការឆ្លងកាត់ពេលវេលា មនុស្សលែងយល់ពីមូលហេតុដែលព្រះជាម្ចាស់បានបង្កើតខ្លួនមក ហើយក៏មិនយល់ពីព្រះបន្ទូលដែលចេញពីព្រះឱស្ឋរបស់ព្រះជាម្ចាស់ និងអ្វីៗគ្រប់យ៉ាងដែលមកពីព្រះជាម្ចាស់ដែរ។ ដូច្នេះ មនុស្សក៏ចាប់ផ្ដើមប្រឆាំងចំពោះក្រឹត្យវិន័យ និងព្រះរាជក្រឹត្យរបស់ព្រះជាម្ចាស់ ហើយដួងចិត្ត និងវិញ្ញាណរបស់គេក៏បានស្លាប់...។ ព្រះជាម្ចាស់បាត់បង់មនុស្សដែលទ្រង់បានបង្កើតពីដំបូងមក ហើយមនុស្សបាត់បង់ឫសគល់ដែលមានពីដើមកំណើតរបស់ខ្លួនមក៖ នេះគឺជាទុក្ខព្រួយនៃពូជមនុស្ស។ តាមពិតទៅ តាំងពីដើមដំបូងមកដល់ពេលនេះ ព្រះជាម្ចាស់បានរៀបចំសោកនាដកម្មមួយសម្រាប់មនុស្សជាតិ ជាសោកនាដកម្មដែលមនុស្សគឺជាអ្នកបង្កហេតុផង និងជាជនរងគ្រោះផង ហើយគ្មាននរណាម្នាក់អាចឆ្លើយបានថា អ្នកដឹកនាំនៃសោកនាដកម្មនេះជានរណាឡើយ។

នៅក្នុងពិភពលោកដ៏ធំល្វឹងល្វើយ មហាសមុទ្រនាំដីល្បាប់ចូលទៅក្នុងស្រែចំការចម្ការ ហើយស្រែចម្ការជន់ទឹកឡើងចូលទៅក្នុងមហាសមុទ្រម្ដងហើយម្ដងទៀត។ ក្រៅពីព្រះអង្គដែលគ្រប់គ្រងលើអ្វីៗទាំងអស់ ក្នុងចំណោមរបស់សព្វសារពើ នោះគ្មាននរណាម្នាក់អាចដឹកនាំ និងណែនាំពូជមនុស្សនេះបានឡើយ។ គ្មាននរណាម្នាក់ខ្លាំងពូកែដែលធ្វើការងារ ឬក៏ធ្វើការរៀបចំសម្រាប់ពូជមនុស្សនេះទេ ព្រោះមានមនុស្សតិចតួចណាស់ដែលអាចដឹកនាំពូជមនុស្សនេះឆ្ពោះទៅកាន់ទិសដៅនៃពន្លឺ និងរំដោះពួកគេពីភាពអយុត្តិធម៌នៅលើផែនដីនេះ។ ព្រះជាម្ចាស់សោយសោកចំពោះអនាគតរបស់មនុស្ស ទ្រង់ព្រួយព្រះហឫទ័យនៅពេលដែលមនុស្សធ្លាក់ចុះ ហើយទ្រង់ឈឺព្រះហឫទ័យដែលមនុស្សដើរមួយជំហានម្ដងៗទៅរកភាពពុករលួយ និងផ្លូវដែលមិនអាចត្រលប់ក្រោយវិញបាន។ គ្មាននរណាម្នាក់ធ្លាប់បានគិតថា តើគោលដៅមួយណាដែលមនុស្សបានធ្វើឲ្យព្រះហឫទ័យរបស់ព្រះជាម្ចាស់ខ្ទេចខ្ទាំ និងបានបោះបង់ចោលទ្រង់ទៅស្វែងរកមេកំណាចដែលអាចត្រូវបាននាំទៅ។ ប្រាកដណាស់ថា គឺដោយសារ

មូលហេតុនេះហើយបានជាគ្មាននរណាម្នាក់មានអារម្មណ៍ដឹងពីសេចក្ដីក្រោធរបស់ព្រះជាម្ចាស់ ហើយគ្មាននរណាម្នាក់ ស្វែងរកវិធីដើម្បីផ្គាប់ដល់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ ឬក៏ព្យាយាមចូលទៅជិតព្រះជាម្ចាស់ទេ ហើយលើសពីនោះទៅទៀត ដោយសារមូលហេតុនេះហើយ បានជាគ្មាននរណាម្នាក់យល់ច្បាស់ពីការព្រួយព្រះហឫទ័យ និងការឈឺចាប់របស់ព្រះជាម្ចាស់។ ទោះបីជាក្រោយពេលដែលស្ដាប់ឮព្រះសូរសៀងរបស់ព្រះជាម្ចាស់ហើយក៏ដោយ ក៏មនុស្សនៅតែបន្តដើរលើផ្លូវរបស់ខ្លួន នៅតែបន្តវង្វេងចេញពីព្រះជាម្ចាស់ ដោយការគេចចេញពីព្រះគុណ និងការយកព្រះហឫទ័យទុកដាក់របស់ព្រះជាម្ចាស់ ព្រមទាំងគេចចេញពីសេចក្ដីពិតរបស់ទ្រង់ ដោយព្រមលក់ខ្លួនទៅឲ្យអារក្សសាតាំង ដែលជាខ្មាំងសត្រូវរបស់ព្រះជាម្ចាស់។ បើមនុស្សនៅក្បាលរឹងបែបនេះ តើព្រះជាម្ចាស់នឹងប្រព្រឹត្តយ៉ាងណាចំពោះមនុស្សដែលបានបោះបង់ទ្រង់ចោល ដោយគ្មានងាកក្រោយសូម្បីតែបន្តិច? គ្មាននរណាម្នាក់ដឹងឡើយថា មូលហេតុដែលនាំឲ្យទ្រង់រំឭក និងដាស់តឿនម្ដងហើយម្ដងទៀត នោះគឺដោយសារទ្រង់បានរៀបចំគ្រោះមហន្តរាយមួយដែលមិនធ្លាប់មានពីមុនមកនៅក្នុងព្រះហស្តទ្រង់ ជាគ្រោះមហន្តរាយមួយដែលសាច់ឈាម និងព្រលឹងរបស់មនុស្សមិនអាចទ្រាំទ្របាននោះទេ។ គ្រោះមហន្តរាយនេះ មិនមែនគ្រាន់តែជាទណ្ឌកម្មនៃសាច់ឈាមប៉ុណ្ណោះទេ ប៉ុន្តែក៏ជាទណ្ឌកម្មនៃព្រលឹងដែរ។ អ្នកត្រូវដឹងពីចំណុចនេះ៖ នៅពេលដែលផែនការរបស់ព្រះជាម្ចាស់បរាជ័យ ហើយនៅពេលដែលការរំឭក និងការដាស់តឿនរបស់ទ្រង់មិនត្រូវបានតបស្នង តើទ្រង់នឹងសម្ដែងសេចក្ដីក្រោធប្រភេទណាទៅ? គឺសេចក្ដីក្រោធដែលមិនធ្លាប់មានអ្នកជួបប្រទះ ឬក៏ធ្លាប់ឮពីមុនមកទេ។ ដូច្នេះហើយបានជាខ្ញុំនិយាយថា គ្រោះមហន្តរាយនេះមិនធ្លាប់មានពីមុនមកទេ ហើយក៏នឹងមិនកើតឡើងម្ដងទៀតដែរ។ ដ្បិតផែនការរបស់ព្រះជាម្ចាស់ គឺបង្កើតមនុស្សជាតិតែមួយដង និងសង្គ្រោះមនុស្សជាតិតែមួយដងនេះប៉ុណ្ណោះ។ នេះគឺជាលើកដំបូង ហើយក៏ជាលើកចុងក្រោយដែរ។ ដូច្នេះហើយ គ្មាននរណាម្នាក់អាចយល់ពីបំណងព្រះហឫទ័យក្នុងការទទួលយកការឈឺចាប់ និងការគិតទុកជាមុនដ៏ក្លៀវក្លា

ដែលព្រះជាម្ចាស់ជួយសង្គ្រោះមនុស្សនៅគ្រានេះទេ។

ព្រះជាម្ចាស់បានបង្កើតពិភពលោកនេះ ហើយបាននាំមនុស្សដែលជាសភាវមានជីវិតមួយ ដែលទ្រង់បានប្រទានឲ្យមានជីវិត ចូលមកក្នុងពិភពលោកនេះ។ បន្ទាប់មក មនុស្សក៏ចាប់ផ្ដើមមានឪពុកម្ដាយ និងសាច់ញាតិ ហើយក៏លែងឯកាទៀត។ ចាប់តាំងពីពេលដែលមនុស្សបានសម្លឹងមើលពិភពលោកខាង សម្ភារៈនេះជាលើកដំបូង គឺគេត្រូវបានកំណត់ឲ្យរស់នៅក្នុងការចាត់តាំងរបស់ទ្រង់ទៅហើយ។ ខ្យល់ដង្ហើមជីវិតដែលចេញមកពីព្រះជាម្ចាស់ ទ្រទ្រង់សភាវមានជីវិតទាំងឡាយឲ្យលូតលាស់រហូតដល់ពេញវ័យ។ ក្នុងអំឡុងពេលនៃដំណើរការនេះ គ្មាននរណាម្នាក់មានអារម្មណ៍ថាមនុស្សធំធាត់ឡើង ក្រោមការយកព្រះហឫទ័យទុកដាក់របស់ព្រះជាម្ចាស់ទេ ផ្ទុយទៅវិញ ពួកគេជឿថា មនុស្សធំធាត់ឡើងក្រោមការយកចិត្តទុកដាក់ប្រកបដោយក្ដីស្រលាញ់របស់ឪពុកម្ដាយខ្លួន ហើយជឿថាសភាវគតិនៃជីវិតរបស់គេ គឺជាអ្វីដែលជម្រុញដល់ការធំធាត់របស់ពួកគេ។ នេះគឺដោយសារតែមនុស្សមិនស្គាល់អ្នកដែលបានផ្ដល់ជីវិតរបស់ខ្លួនមក ឬមិនដឹងថាជីវិតរបស់ខ្លួនបានមកពីណា ពោលគឺមិនដឹងពីរបៀបដែលសភាវគតិនៃជីវិតបង្កើតការអស្ចារ្យ។ គេដឹងត្រឹមតែថា ចំណីអាហារគឺជាមូលដ្ឋានដែលធ្វើឲ្យជីវិតរបស់គេបន្តរស់នៅតទៅទៀត និងថាភាពតស៊ូគឺជាប្រភពនៃការរស់នៅរបស់គេ ព្រមទាំងថាជំនឿនៅក្នុងគំនិតរបស់គេ គឺជាដើមទុនដែលការរស់នៅរបស់គេត្រូវពឹងផ្អែកលើ។ មនុស្សភ្លេចទាំងស្រុងនូវព្រះគុណ និងការផ្គត់ផ្គង់របស់ព្រះជាម្ចាស់ ដូច្នេះហើយបានជាគេមិនខ្វល់ពីជីវិតដែលព្រះជាម្ចាស់បានប្រទានដល់គេ...។ គ្មានមនុស្សណាម្នាក់ដែលព្រះជាម្ចាស់យកព្រះហឫទ័យទុកដាក់ទាំងយប់ទាំងថ្ងៃ យកខ្លួនគេមកថ្វាយបង្គំទ្រង់ឡើយ។ ព្រះជាម្ចាស់បន្តដោះស្រាយជាមួយមនុស្ស ដូចដែលទ្រង់បានគ្រោងទុក ទោះបីជាទ្រង់មិនបានរំពឹងទុកអ្វីពីគេក៏ដោយ។ ទ្រង់ធ្វើដូច្នេះ ព្រោះសង្ឃឹមថា ថ្ងៃណាមួយមនុស្សនឹងភ្ញាក់ពីសុបិនរបស់ខ្លួន ហើយចាប់ផ្ដើមទទួលស្គាល់ភ្លាមៗនូវគុណតម្លៃ និងអត្ថន័យនៃជីវិត និងតម្លៃដែលព្រះជាម្ចាស់បានបង់សម្រាប់អ្វីៗទាំងអស់ដែលទ្រង់បានប្រទានដល់គេ ព្រមទាំងភាពអន្ទះសាដែលព្រះជាម្ចាស់

រង់ចាំឲ្យមនុស្សវិលត្រលប់មករកទ្រង់វិញ។ គ្មាននរណាម្នាក់ធ្លាប់សម្លឹងមើលទៅអាថ៌កំបាំងដែលគ្រប់គ្រងលើដើមកំណើត និងការបន្តនៃជីវិតរបស់មនុស្សទេ។ មានតែព្រះជាម្ចាស់ប៉ុណ្ណោះ ដែលយល់ពីការទាំងអស់នេះ ហើយទ្រាំទ្រយ៉ាងស្ងៀមស្ងាត់ចំពោះការឈឺចាប់ និងការវាយប្រហារដែលមនុស្សផ្ដល់ឲ្យទ្រង់ គឺជាមនុស្សដែលបានទទួលអ្វីៗគ្រប់យ៉ាងពីព្រះជាម្ចាស់ ប៉ុន្តែមិនចេះដឹងគុណទ្រង់ឡើយ។ ដូចគ្នាផងដែរ មនុស្សរីករាយចំពោះអ្វីៗដែលកើតមានតាមសភាពធម្មតា ហើយដូចគ្នានេះដែរ វាជា «រឿងធម្មតា» ទេ ដែលព្រះជាម្ចាស់ត្រូវបានមនុស្សក្បត់ បំភ្លេច និងគំរាមកំហែង។ តើវាអាចទេដែលថា ផែនការរបស់ព្រះជាម្ចាស់ពិតជាមានសារៈសំខាន់បែបនេះ? តើវាអាចទេដែលថា មនុស្សដែលជាសភាវមានជីវិតដែលចេញមកពីព្រះហស្តរបស់ព្រះជាម្ចាស់ពិតជាមានសារៈសំខាន់បែបនេះ? ផែនការរបស់ព្រះជាម្ចាស់ ពិតជាមានសារៈសំខាន់ណាស់ ប៉ុន្តែសភាវមានជីវិតដែលបានកើតមកដោយសារព្រះហស្តរបស់ព្រះជាម្ចាស់រស់នៅសម្រាប់ជាប្រយោជន៍ដល់ផែនការរបស់ទ្រង់។ ដូច្នេះហើយ ព្រះជាម្ចាស់មិនអាចបោះបង់ផែនការរបស់ទ្រង់ចោល ដោយសារតែសេចក្ដីស្អប់ចំពោះពូជមនុស្សនេះឡើយ។ ព្រះជាម្ចាស់ទ្រាំទទួលទារុណកម្មគ្រប់យ៉ាងសម្រាប់ជាប្រយោជន៍ដល់ផែនការរបស់ទ្រង់ និងខ្យល់ដង្ហើមដែលទ្រង់បានផ្លុំចេញមក មិនមែនសម្រាប់ជាប្រយោជន៍ដល់សាច់ឈាមរបស់មនុស្សទេ ប៉ុន្តែសម្រាប់ជាប្រយោជន៍ដល់ជីវិតរបស់មនុស្សវិញ។ ទ្រង់ធ្វើដូច្នេះដើម្បីយកជីវិតដែលទ្រង់បានផ្លុំចេញ ឲ្យត្រលប់មកវិញ មិនមែនដើម្បីយកសាច់ឈាមរបស់មនុស្សទេ។ នេះគឺជាផែនការរបស់ទ្រង់។

មនុស្សគ្រប់គ្នាដែលចូលមកក្នុងលោកិយនេះ ត្រូវតែឆ្លងកាត់ជីវិត និងសេចក្ដីស្លាប់ ហើយភាគច្រើនក្នុងចំណោមពួកគេ បានឆ្លងកាត់វដ្តនៃសេចក្ដីស្លាប់ និងការកើតម្ដងទៀត។ អស់អ្នកដែលកំពុងនៅរស់ មិនយូរទេគេនឹងស្លាប់ទៅ ហើយអ្នកដែលបានស្លាប់ទៅហើយ មិនយូរទេគេនឹងត្រលប់ទៅកើតម្ដងទៀត។ ទាំងអស់នេះជាដំណើរជីវិតដែលព្រះជាម្ចាស់បានរៀបចំសម្រាប់សភាវៈមានជីវិតនីមួយៗ។ ដោយឡែកដំណើរជីវិត និងវដ្តជីវិតនេះ គឺគ្រាន់តែជាសេចក្ដីពិតដែលព្រះជាម្ចាស់ចង់ឲ្យមនុស្ស

ប្រកាន់ខ្ជាប់ថា៖ ជីវិតដែលព្រះជាម្ចាស់បានប្រទានដល់មនុស្ស គឺឥតដែនកំណត់ឡើយ មិនមែនជាប់ឃុំក្នុងរាងកាយ ពេលវេលា ឬក្នុងលំហនោះទេ។ នេះហើយជាអាថ៌កំបាំងនៃជីវិត ដែលព្រះជាម្ចាស់បានប្រទានដល់មនុស្ស និងជាភ័ស្ដុតាងបញ្ជាក់ថា ជីវិតកើតមកពីព្រះអង្គ។ ថ្វីបើមនុស្សជាច្រើនមិនជឿថា ជីវិតកើតមកពីព្រះជាម្ចាស់ក៏ដោយ ក៏មនុស្សនៅតែរីករាយនឹងគ្រប់យ៉ាងដែលកើតមកពីទ្រង់ ដោយចៀសមិនរួច ទោះបីជាគេមិនជឿ ឬបដិសេធព្រះវត្តមានរបស់ទ្រង់ក៏ដោយ។ គង់មានថ្ងៃមួយ ព្រះជាម្ចាស់ទ្រង់ប្ដូរព្រះទ័យ ហើយចង់ទាមទារមកវិញនូវអ្វីៗសព្វសារពើដែលមានវត្តមានក្នុងលោកិយនេះ ព្រមទាំងទារយកជីវិតដែលទ្រង់បានប្រទាន នោះគ្រប់ទាំងអស់នឹងលែងមានទៀតហើយ។ ព្រះជាម្ចាស់ប្រើប្រាស់ព្រះជន្មទ្រង់ ដើម្បីផ្គត់ផ្គង់ដល់អ្វីៗសព្វសារពើ ទាំងមានជីវិត និងគ្មានជីវិត ទាំងនាំមកនូវសណ្ដាប់ធ្នាប់ល្អ តាមរយៈគុណធម៌នៃព្រះចេស្ដា និងសិទ្ធិអំណាចរបស់ទ្រង់។ នេះជាសេចក្ដីពិតមួយដែលគ្មាននរណាម្នាក់អាចយល់បាន ហើយសេចក្ដីពិតដ៏មិនអាចយល់បាននេះគឺជាការបើកសម្ដែង និងជាបន្ទាល់នៃថាមពលជីវិតរបស់ព្រះជាម្ចាស់។ ខ្ញុំសូមប្រាប់អាថ៌កំបាំងមួយដល់អ្នកថា៖ ឧត្ដមភាពនៃជីវិតរបស់ព្រះជាម្ចាស់ និងព្រះចេស្ដានៃព្រះជន្មរបស់ទ្រង់ គឺគ្មានមនុស្សណាម្នាក់អាចយល់បានឡើយ។ ពេលនេះក៏បែបនេះ ពីមុនក៏បែបនេះ ហើយនឹងនៅតែបែបនេះរហូតតទៅអនាគត។ អាថ៌កំបាំងទីពីរដែលខ្ញុំចង់ប្រាប់គឺ៖ ប្រភពនៃជីវិតសម្រាប់គ្រប់សភាវៈទាំងអស់មានកំណើតមកពីព្រះជាម្ចាស់ បើទោះបីជាពួកគេមានទម្រង់ជីវិត ឬលក្ខណៈខុសគ្នាយ៉ាងណាក៏ដោយ។ មិនថាអ្នកជាសភាវៈមានជីវិតបែបណា ក៏អ្នកមិនអាចទាស់ទទឹងនឹងគន្លងជីវិតដែលព្រះជាម្ចាស់បានកំណត់ទុកដែរ។ ទោះក្នុងករណីណាក៏ដោយ គ្រប់យ៉ាងដែលខ្ញុំប្រាថ្នា គឺឲ្យមនុស្សយល់ដូច្នេះថា ប្រសិនបើគ្មានការបីបាច់ ថែរក្សា និងការផ្គត់ផ្គង់របស់ព្រះជាម្ចាស់ទេ នោះមនុស្សមិនអាចទទួលបានគ្រប់យ៉ាងដែលគេត្រូវទទួលបានឡើយ បើទោះបីជាខំប្រឹងព្យាយាម ឬខ្នះខ្នែង តស៊ូយ៉ាងណាក៏ដោយ។ ប្រសិនបើគ្មានការប្រទានជីវិតមកពីព្រះជាម្ចាស់ទេ មនុស្សបាត់បង់គុណតម្លៃក្នុងការរស់នៅ

និងបាត់បង់អត្ថន័យនៃជីវិត។ តើព្រះជាម្ចាស់ អនុញ្ញាតឲ្យមនុស្សដែលខ្ជះខ្ជាយតម្លៃជីវិតជាអសារឥតការ អាចរស់នៅដោយមិនខ្វល់បែបនេះដូចម្ដេចបាន? ដូចខ្ញុំបាននិយាយរួចហើយថា សូមកុំភ្លេចឲ្យសោះថា ព្រះជាម្ចាស់គឺជាប្រភពនៃជីវិតរបស់អ្នក។ ប្រសិនបើមនុស្ស មិនពេញចិត្តនឹងអ្វីគ្រប់យ៉ាងដែលព្រះជាម្ចាស់បានប្រទានឲ្យដល់គេទេ នោះទ្រង់មិនត្រឹមតែដកយកនូវអ្វីដែលទ្រង់បានប្រទានឲ្យតាំងតែពីដើមមកវិញប៉ុណ្ណោះទេ តែទ្រង់ក៏នឹងតម្រូវឲ្យមនុស្សសងមកវិញទ្វេដងនូវតម្លៃនៃរបស់គ្រប់យ៉ាងដែលទ្រង់បានប្រទានឲ្យដល់គេផងដែរ។

ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៣

# ខ្យល់ដង្ហើមនៃព្រះដ៏មានគ្រប់ចេស្ដា

នៅក្នុងចិត្តរបស់អ្នក មានរឿងរ៉ាវអាថ៌កំបាំងជាច្រើនដែលអ្នកមិនធ្លាប់ដឹងសោះ ដ្បិតអ្នកកំពុងរស់នៅក្នុងពិភពមួយដែលគ្មានពន្លឺ។ ដួងចិត្ត និងវិញ្ញាណរបស់អ្នក ត្រូវបានមេកំណាចចាប់យកទៅ។ ភ្នែករបស់អ្នកស្រអាប់ដោយសារភាពងងឹត ហើយអ្នកមិនអាចមើលឃើញព្រះអាទិត្យនៅលើមេឃ ឬផ្កាយភ្លឺព្រិចៗនៅពេលយប់ឡើយ។ ត្រចៀករបស់អ្នកត្រូវបិទជិត ដោយពាក្យកុហកបោកប្រាស់ ហើយអ្នកស្ដាប់មិនឮព្រះសូរសៀងរបស់ព្រះយេហូវ៉ា ដែលលាន់ឮដូចផ្គរលាន់ និងមិនឮសំឡេងទឹកហូរមកពីបល្ល័ង្កទ្រង់ទេ។ អ្នកបានបាត់បង់អ្វីគ្រប់យ៉ាងដែលជាកម្មសិទ្ធិស្របច្បាប់របស់អ្នក អ្វីគ្រប់យ៉ាងដែលព្រះដ៏មានគ្រប់ចេស្ដាបានប្រទានមកឱ្យអ្នក។ អ្នកបានចូលមកក្នុងសមុទ្រទុក្ខដែលគ្មានទីបញ្ចប់ ដោយគ្មានកម្លាំងដើម្បីសង្គ្រោះខ្លួនឯង គ្មានសង្ឃឹមថានឹងអាចរួចជីវិតបានឡើយ ហើយអ្វីទាំងអស់ដែលអ្នកធ្វើនោះ គឺការពុះពារជម្នះ និងការគេចចេញយ៉ាងប្រញាប់ប្រញាល់...។ ចាប់តាំងពីពេលនោះមក អ្នកត្រូវទទួលគ្រោះកម្មឱ្យរងទុក្ខវេទនាដោយមេកំណាច ដោយឃ្លាតឆ្ងាយពីព្រះពររបស់ព្រះដ៏មានគ្រប់ចេស្ដា នៅឆ្ងាយផុតពីការទំនុកបម្រុងរបស់ព្រះដ៏មានគ្រប់ចេស្ដា ដោយដើរនៅលើផ្លូវ

ដែលគ្មានថ្ងៃត្រឡប់ក្រោយ។ សម្រែកដង្ហោយរាប់សិបលានដង ក៏មិនអាចដាស់ចិត្តនិង វិញ្ញាណអ្នកឱ្យភ្ញាក់ដឹងខ្លួនបានឡើយ។ អ្នកដេកលក់យ៉ាងស្កប់ស្កល់នៅក្នុងដៃរបស់មេកំណាចដែលបានល្បួងអ្នកទៅក្នុងពិភពមួយដែលគ្មានព្រំដែន គ្មានគោលដៅ ឬកន្លែងឈប់សំចតឡើយ។ ហេតុនេះ អ្នកបាត់បង់ចិត្តស្លូតត្រង់ និងចិត្តបរិសុទ្ធដើមរបស់អ្នក ហើយចាប់ផ្ដើមគេចចេញពីការយកព្រះទ័យទុកដាក់របស់ព្រះដ៏មានគ្រប់ចេស្ដា។ នៅក្នុងចិត្តរបស់អ្នក មេកំណាចកាច់ចង្កូតជីវិតអ្នកលើគ្រប់បញ្ហាទាំងអស់ ហើយវាបានក្លាយជាជីវិតរបស់អ្នកទៀតផង។ អ្នកលែងខ្លាចវា លែងគេចចេញពីវា និងលែងសង្ស័យវាហើយ ផ្ទុយទៅវិញ អ្នកចាត់ទុកវាជាព្រះនៅក្នុងចិត្តរបស់អ្នក។ អ្នកចាប់ផ្ដើមធ្វើទីតម្កល់ និងថ្វាយបង្គំវា ហើយទាំងអ្នក និងមេកំណាច ក៏បានក្លាយជារូបកាយ និងស្រមោលដែលមិនអាចបំបែកពីគ្នាបាន ដោយប្ដេជ្ញាស្លាប់រស់ជាមួយគ្នា។ អ្នកមិនដឹងថា អ្នកបានមកដល់ពីពេលណា ហេតុអ្វីក៏អ្នកចាប់កំណើត ឬហេតុអ្វីក៏អ្នកស្លាប់នោះទេ។ អ្នកសម្លឹងមើលព្រះដ៏មានគ្រប់ចេស្ដាថាជាបុគ្គលចម្លែកម្នាក់។ អ្នកពុំបានដឹងអំពីដើមកំណើតរបស់ទ្រង់ឡើយ ហើយអ្នកកាន់តែមិនដឹងថា ទ្រង់បានធ្វើអ្វីខ្លះសម្រាប់អ្នកនោះទេ។ អ្វីគ្រប់យ៉ាងដែលមកអំពីទ្រង់ បានក្លាយជាសេចក្ដីសម្អប់ចំពោះអ្នក។ អ្នកមិនបានត្រេកអរសប្បាយនឹងសេចក្ដីទាំងនេះឡើយ ហើយក៏មិនបានដឹងអំពីតម្លៃរបស់វាដែរ។ អ្នករួមដំណើរជាមួយមេកំណាច ចាប់តាំងពីថ្ងៃដែលអ្នកបានទទួលការទំនុកបម្រុងអំពីព្រះដ៏មានគ្រប់ចេស្ដា។ អ្នកបានឆ្លងកាត់ភាពស្មុគស្មាញ និងព្យុះជីវិតរាប់សិបពាន់ឆ្នាំមកហើយជាមួយនឹងមេកំណាច ហើយអ្នកឈរនៅជាមួយនឹងវា ដើម្បីទាស់នឹងព្រះជាម្ចាស់ ដែលជាប្រភពនៃជីវិតរបស់អ្នក។ អ្នកមិនដឹងអំពីការប្រែចិត្តទាល់តែសោះ ហើយអ្នកក៏រឹតតែមិនដឹងទៀតថា អ្នកបានខិតមកជិតសេចក្ដីវិនាស។ អ្នកភ្លេចហើយថាមេកំណាចបានបោកប្រាស់ និងធ្វើឱ្យអ្នករងទុក្ខវេទនា អ្នកភ្លេចទីចាប់ផ្ដើមរបស់ខ្លួនហើយ។ ហេតុនេះហើយ ទើបមេកំណាចបោកប្រាស់អ្នកនៅគ្រប់ជំហាន តាំងពីដើមរហូតដល់ពេលនេះ។ ដួងចិត្ត និងវិញ្ញាណរបស់អ្នក ត្រូវបានធ្វើឱ្យស្ពឹកស្រពន់ និងពុកផុយ។ អ្នកឈប់រអ៊ូរទាំនឹងទុក្ខលំបាកនៃពិភពមនុស្សទៀតហើយ

អ្នកលែងជឿហើយថា ពិភពលោកនេះគ្មានយុត្តិធម៌។ អ្នករឹតតែលែងខ្វល់ថា ព្រះដ៏មានគ្រប់ចេស្តា ពិតជាមានវត្តមានមែន។ នេះគឺដោយសារ អ្នកចាត់ទុកមេកំណាចជាឪពុកដ៏ពិតប្រាកដរបស់អ្នក តាំងពីយូរយារណាស់មកហើយ ហើយក៏មិនអាចឃ្លាតចេញឆ្ងាយពីវាបានដែរ។ នេះហើយ គឺជាអាថ៌កំបាំងនៅក្នុងចិត្តរបស់អ្នក។

ពេលព្រលឹមស្រាងៗបានចូលមកដល់ ផ្កាយព្រឹកក៏ចាប់ផ្ដើមរះនៅទិសខាងកើត។ ផ្កាយនេះមិនធ្លាប់រះត្រង់ទិសនោះទេពីមុនមក ហើយវារះបំភ្លឺផ្ទៃមេឃដែលស្ងប់ស្ងាត់ និងមានពន្លឺព្រិចៗ ធ្វើឱ្យពន្លឺក្នុងចិត្តមនុស្សដែលបានរលត់បាត់ទៅហើយនោះ ឆេះឆួលឡើងវិញ។ មនុស្សលែងនៅឯកាទៀតហើយ ដោយសារតែពន្លឺដែលរះចែងចាំងមកលើអ្នក និងមនុស្សឯទៀត។ ប៉ុន្តែ អ្នកបែរជាបន្តគេងលង់លក់ក្នុងយប់ងងឹតនោះទៅវិញ។ អ្នកមិនបានស្ដាប់ឮ ក៏មិនបានឃើញពន្លឺអ្វីសោះឡើយ។ អ្នកមិនបានដឹងអំពីការមកដល់នៃផ្ទៃមេឃ និងផែនដីថ្មី និងយុគសម័យថ្មីឡើយ ដ្បិតឪពុករបស់អ្នកប្រាប់អ្នកថា «កូនអើយ! កុំទាន់ក្រោកអី មេឃមិនទាន់ភ្លឺច្បាស់នៅឡើយទេ។ អាកាសធាតុត្រជាក់ណាស់ ចូរកុំចេញទៅក្រៅឱ្យសោះ ក្រែងភ្នែកកូននឹងត្រូវចាក់ដោយផ្លែដាវ និងលំពែង»។ អ្នកជឿតែពាក្យដាស់តឿនរបស់ឪពុកអ្នកប៉ុណ្ណោះពីព្រោះអ្នកជឿថា មានតែឪពុកអ្នកទេដែលនិយាយត្រូវ ដ្បិតឪពុកអ្នកមានវ័យចាស់ជាងអ្នក ហើយគាត់ស្រលាញ់អ្នកជាខ្លាំង។ ការដាស់តឿន និងសេចក្ដីស្រលាញ់នេះ ធ្វើឱ្យអ្នកលែងជឿលើរឿងដែលគេដំណាលថា មានពន្លឺនៅក្នុងលោកិយនេះ វាក៏ធ្វើឱ្យអ្នកលែងខ្វាយខ្វល់ថា នៅក្នុងលោកិយនេះមាន ឬគ្មានសេចក្ដីពិតទៀតហើយ។ អ្នកលែងហ៊ានសង្ឃឹមលើការសង្គ្រោះពីព្រះដ៏មានគ្រប់ចេស្តា។ អ្នកពេញចិត្តនឹងស្ថានភាពបច្ចុប្បន្ននេះ អ្នកលែងទន្ទឹងរង់ចាំការមកដល់នៃពន្លឺ លែងទន្ទឹងចាំមើលការយាងមកដល់នៃព្រះដ៏មានគ្រប់ចេស្តា ដូចដែលគេបាននិទានក្នុងរឿងដំណាល។ តាមអ្វីដែលអ្នកបានដឹង អ្វីៗដែលស្រស់ស្អាត មិនអាចត្រលប់មកដូចដើមវិញទេ គឺគ្មានសោះឡើយ។ នៅក្នុងភ្នែករបស់អ្នក អនាគតរបស់មនុស្សបានរលាយបាត់បង់ទៅហើយ។ អ្នកប្រឹងតោងសម្លៀកបំពាក់ឪពុករបស់អ្នក តាមកម្លាំងដែលអ្នកមាន ដោយសុខចិត្តចែករំលែកការលំបាករបស់

គាត់ ដោយភ័យខ្លាចបាត់បង់ដៃគូរួមដំណើរ ហើយវង្វេងគោលដៅនៃការធ្វើដំណើរដ៏វែងឆ្ងាយរបស់អ្នក។ ពិភពលោកដ៏ធំធេង និងស្រពេចស្រពិលនេះ បានបង្កើតមនុស្សជាច្រើនដូចជាអ្នក ជាមនុស្សអង់អាចក្លាហាន និងមោះមុតក្នុងការបំពេញតួនាទីផ្សេងៗនៅក្នុងលោកិយនេះ។ វាបានបង្កើត «អ្នកចម្បាំង» ជាច្រើន ដែលមិនខ្លាចរអារនឹងសេចក្ដីស្លាប់។ លើសពីនេះ ពិភពលោកនេះក៏បានបង្កើតមនុស្សមួយក្រុមហើយមួយក្រុមទៀតដែលជាពពួកមនុស្សខ្វាក់ និងខ្វិន ដែលមិនដឹងពីបុព្វហេតុនៃការបង្កើតពួកគេមកឡើយ។ ព្រះនេត្ររបស់ព្រះដ៏មានគ្រប់ចេស្ដា ទ្រង់ទតរំពៃបុគ្គលម្នាក់ៗក្នុងចំណោមមនុស្សដែលរងទុក្ខវេទនាយ៉ាងខ្លាំង។ អ្វីដែលទ្រង់ស្ដាប់ឮ គឺសម្រែកយំសោករបស់មនុស្សដែលកំពុងរងការឈឺចាប់ អ្វីដែលទ្រង់ទតឃើញ គឺភាពឥតខ្មាសរបស់មនុស្សដែលរងទុក្ខវេទនា ហើយអ្វីដែលទ្រង់មានព្រះទ័យអាណិតអាសូរនោះ គឺសេចក្ដីអស់សង្ឃឹម និងភាពភ័យខ្លាចរបស់មនុស្សដែលបាត់បង់ព្រះគុណនៃសេចក្ដីសង្គ្រោះ។ មនុស្សបដិសេធការយកព្រះទ័យទុកដាក់របស់ទ្រង់ ដោយបានជ្រើសយកផ្លូវដើរដោយខ្លួនឯង និងព្យាយាមគេចចេញពីខ្សែព្រះនេត្រឃ្លាំមើលរបស់ទ្រង់ ដោយក្រេបរសជាតិប្រៃល្វីងនៃសមុទ្រដ៏ជ្រៅជាមួយនឹងសត្រូវរបស់ទ្រង់រហូតដល់ដំណាក់ចុងក្រោយ។ ខ្យល់ដង្ហើមនៃព្រះដ៏មានគ្រប់ចេស្ដា ដែលមនុស្សធ្លាប់ស្ដាប់ឮ ក៏លែងមាន ព្រះហស្តនៃព្រះដ៏មានគ្រប់ចេស្ដាដែលស៊ូនៅបបោសអង្អែលមនុស្សវេទនានេះក៏លែងមានដែរ។ ទ្រង់ក្រសោបគេមកវិញម្ដងហើយម្ដងទៀត ហើយទ្រង់ក៏បរាជ័យម្ដងហើយម្ដងទៀតដែរ ដូច្នេះ ទើបកិច្ចការរបស់ទ្រង់ត្រូវធ្វើដដែលជាដដែល។ តាំងពីពេលនោះមក ទ្រង់ចាប់ផ្ដើមស្រងាកព្រះទ័យ មានអារម្មណ៍ល្វើយ ហើយទ្រង់ឈប់ធ្វើកិច្ចការដែលមានក្នុងព្រះហស្តទ្រង់ ហើយក៏លែងយាងទៅមកក្នុងចំណោមមនុស្សដែរ...។ មនុស្ស មិនបានដឹងអំពីការផ្លាស់ប្ដូរទាំងអស់នេះទេ មិនដឹងអំពីការមកដល់ និងការត្រឡប់ទៅវិញនៃព្រះដ៏មានគ្រប់ចេស្ដា ក៏មិនដឹងអំពីព្រះទ័យទុក្ខព្រួយ និងភាពសោកសង្រេងរបស់ទ្រង់ដែរ។

អ្វីៗគ្រប់យ៉ាងនៅក្នុងពិភពលោកនេះ ប្រែប្រួលយ៉ាងឆាប់រហ័សតាមព្រះតម្រិះ

របស់ព្រះដ៏មានគ្រប់ចេស្ដា និងនៅក្រោមព្រះនេត្រឃ្លាំមើលរបស់ទ្រង់។ អ្វីៗដែលមនុស្សពុំធ្លាប់បានស្ដាប់ឮ បានមកដល់យ៉ាងឆាប់រហ័ស តែផ្ទុយទៅវិញ អ្វីៗដែលមនុស្សមានជាយូរមកហើយនោះ បានបាត់បង់ទៅវិញដោយមិនដឹងខ្លួន។ គ្មាននរណាម្នាក់អាចយល់បានពីទីសំចតរបស់ព្រះដ៏មានគ្រប់ចេស្ដាឡើយ ហើយមនុស្សម្នាក់ៗរឹតតែមិនយល់ពីឧត្តមភាព និងភាពមហិមានៃថាមពលជីវិតរបស់ព្រះដ៏មានគ្រប់ចេស្ដា។ ទ្រង់ឧត្តុង្គឧត្តមត្រង់ថា ទ្រង់អាចជ្រាបនូវអ្វី ដែលមនុស្សមិនអាចដឹង បាន។ ទ្រង់មហិមាត្រង់ថា ទ្រង់ជាព្រះតែមួយអង្គគត់ដែលត្រូវមនុស្សបោះបង់ចោល តែបែរជាមកសង្គ្រោះមនុស្សទៅវិញ។ ទ្រង់ជ្រាបពីអត្ថន័យជីវិត និងសេចក្ដីស្លាប់ ហើយលើសពីនេះ ទ្រង់ជ្រាបពីច្បាប់កកើតឡើង ដែលមនុស្សដែលជាអ្នកដែលត្រូវបានបង្កើតឡើង គួរតែធ្វើតាម។ ទ្រង់គឺជាគ្រឹះនៃការរស់នៅរបស់មនុស្ស ហើយទ្រង់ជាព្រះដ៏ប្រោសលោះ ដែលប្រោសមនុស្សឱ្យរស់ឡើងវិញ។ ទ្រង់បន្ធូរចិត្តរីករាយ ដោយភាពសោកសង្រេង ហើយលើកតម្កើងចិត្តសោកសង្រេងដោយចិត្តរីករាយវិញ ទាំងអស់គឺដើម្បីជាប្រយោជន៍ដល់កិច្ចការរបស់ទ្រង់ ដើម្បីជាប្រយោជន៍ដល់ផែនការរបស់ទ្រង់។

មនុស្សមិនដឹងអំពីគោលបំណងនៃអត្ថិភាពរបស់គេទេ ដ្បិតគេបានបែរចេញពីការផ្គត់ផ្គង់ជីវិតរបស់ព្រះដ៏មានគ្រប់ចេស្ដា តែយ៉ាងណា ក៏គេនៅតែខ្លាចសេចក្ដីស្លាប់ដែរ។ ពួកគេគ្មានការជួយ ឬការជ្រោមជ្រែងអ្វីឡើយ តែនៅស្ទាក់ស្ទើរមិនព្រមបិទភ្នែករបស់ពួកគេ ហើយពួកគេនៅតែបង្ខំខ្លួនឯងឲ្យបន្តរស់នៅក្នុងជីវិតដ៏ថោកទាបក្នុងពិភពលោកនេះ ជាសំបកខាងសាច់ឈាមដែលមិនដឹងអ្វីសោះអំពីព្រលឹងរបស់ខ្លួន។ អ្នករស់នៅមិនខុសពីអ្នកដទៃទេ គឺគ្មានក្ដីសង្ឃឹម និងគ្មានគោលដៅឡើយ។ មានតែព្រះដ៏បរិសុទ្ធនៅក្នុងរឿងតំណាលតែមួយអង្គគត់ ដែលនឹងសង្គ្រោះមនុស្សដែលទន្ទឹងរង់ចាំការមកដល់របស់ទ្រង់ ទាំងកំពុងស្រែកថ្ងូរក្នុងទុក្ខវេទនារបស់ពួកគេ។ មកទល់នឹងពេលនេះ ក្នុងចំណោមមនុស្សដែលខ្វះបញ្ញាចិត្ត គឺគ្មាននរណាស្គាល់ជំនឿបែបនេះឡើយ។ ទោះបែបនេះក្ដី ក៏មនុស្សនៅតែចង់បានជីវិតដោយបែបនេះដដែល។ ព្រះដ៏មានគ្រប់ចេស្ដា មានសេចក្ដីមេត្តាករុណាចំពោះមនុស្សដែលរងទុក្ខវេទនាយ៉ាង

ក្រៃលែង ហើយស្របពេលនោះដែរ ទ្រង់ហត់នឿយនឹងអ្នកដែលខ្វះបញ្ញាចិត្ត ដ្បិតទ្រង់បានរង់ចាំចម្លើយពីមនុស្សជាយូរមកហើយ។ ទ្រង់មានព្រះទ័យស្វះស្វែងរកដួងចិត្ត និងវិញ្ញាណរបស់អ្នក ព្យាយាមយកអាហារ និងទឹកមកឲ្យអ្នក ហើយដាស់អ្នកឲ្យភ្ញាក់ ដើម្បីកុំឲ្យអ្នកនៅស្រេកឃ្លានតទៅទៀត។ នៅពេលដែលអ្នកនឿយហត់ អស់កម្លាំង និងនៅពេលដែលអ្នកចាប់ផ្ដើមមានអារម្មណ៍ថា នៅក្នុងពិភពលោកនេះមានអ្វីមួយត្រូវវិនាសហិនហោច ចូរកុំវង្វេងឡើយ ចូរកុំទួញសោកឡើយ។ ព្រះដ៏មានគ្រប់ព្រះចេស្ដាជាព្រះដ៏ចាំយាម ទ្រង់នឹងទទួលយកការមកដល់របស់អ្នក គ្រប់ពេលវេលាទាំងអស់។ ទ្រង់កំពុងចាំយាមនៅក្បែរអ្នកជានិច្ច រង់ចាំឱ្យអ្នកវិលត្រឡប់មកវិញ។ ទ្រង់កំពុងរង់ចាំថ្ងៃដែលអ្នកមានការចងចាំដូចដើមវិញភ្លាមៈ នៅពេលអ្នកដឹងខ្លួនថា អ្នកមកអំពីព្រះជាម្ចាស់ ដឹងថាអ្នកបានវង្វេងគោលដៅរបស់អ្នក នៅពេលណាមួយ ដឹងថាអ្នកវង្វេងស្មារតីរបស់អ្នកនៅតាមផ្លូវ ហើយនៅពេលណាមួយអ្នកក៏រកបាន «ឪពុក» ម្នាក់នោះអ្នកនឹងដឹងថា ព្រះដ៏មានគ្រប់ចេស្ដាកំពុងឃ្លាំមើល និងកំពុងរង់ចាំការវិលត្រឡប់មកវិញរបស់អ្នកនៅទីនោះ អស់ពេលជាយូរណាស់មកហើយ។ ទ្រង់កំពុងរង់ចាំដោយក្ដីអន្ទះសា រង់ចាំការឆ្លើយតបដែលគ្មានចម្លើយ។ ការចាំយាម និងការរង់ចាំរបស់ទ្រង់មានតម្លៃហួសប្រមាណ ហើយការចាំយាមនេះ គឺដើម្បីជាប្រយោជន៍ដល់ដួងចិត្ត និងវិញ្ញាណរបស់មនុស្ស។ ប្រហែលជាការចាំយាម និងការរង់ចាំរបស់ទ្រង់គ្មានដែនកំណត់ឡើយ ហើយទាំងនេះក៏ប្រហែលជាជិតដល់ទីបញ្ចប់ដែរ។ តែពេលនេះ អ្នកគប្បីដឹងថា ដួងចិត្ត និងវិញ្ញាណរបស់អ្នកស្ថិតនៅទីណា។

ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៣

# ការលេចមករបស់ព្រះជាម្ចាស់ បានចាប់ផ្ដើមក្នុងយុគសម័យថ្មីមួយ

ផែនការគ្រប់គ្រងរយៈពេលប្រាំមួយពាន់ឆ្នាំរបស់ព្រះជាម្ចាស់ កំពុងខិតទៅរកទីបញ្ចប់ ហើយច្រកទ្វារនគរព្រះជាម្ចាស់បានបើកជាស្រេចសម្រាប់អស់អ្នកដែលស្វែងរកការលេចមករបស់ទ្រង់។ បងប្អូនប្រុសស្រីអើយ តើអ្នករាល់គ្នាកំពុងរង់ចាំអ្វីទៀត? តើអ្នករាល់គ្នាកំពុងស្វែងរកអ្វី? តើអ្នករាល់គ្នាកំពុងរង់ចាំ ឲ្យព្រះជាម្ចាស់លេចមកមែនទេ? តើអ្នកកំពុងរកមើលស្នាមព្រះបាទារបស់ទ្រង់មែនទេ? ពិតជាចង់ឃើញការលេចមករបស់ព្រះជាម្ចាស់ខ្លាំងណាស់! ហើយការស្វែងរកស្នាមព្រះបាទារបស់ព្រះជាម្ចាស់ អីក៏លំបាកដល់ម្ល៉េះ! នៅក្នុងយុគសម័យបែបនេះ នៅក្នុងពិភពមួយបែបនេះ តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីអាចមើលឃើញថ្ងៃដែលព្រះជាម្ចាស់លេចមក? តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីដើរឲ្យទាន់លំអាននៃព្រះបាទារបស់ព្រះជាម្ចាស់? អស់អ្នកដែលរង់ចាំព្រះជាម្ចាស់លេចមក តែងមានសំណួរបែបនេះ។ អ្នករាល់គ្នាគិតពិចារណាអំពីសំណួរទាំងនេះជាច្រើនលើកច្រើនសា ប៉ុន្តែតើបានលទ្ធផលអ្វីខ្លះហើយ? តើព្រះជាម្ចាស់លេចមកនៅទីណា? តើស្នាមព្រះបាទារបស់ព្រះជាម្ចាស់នៅទីណា? តើអ្នករាល់គ្នាមានចម្លើយហើយឬនៅ? មនុស្សជាច្រើននឹងឆ្លើយបែបនេះថា៖ «ព្រះជាម្ចាស់លេចមកនៅក្នុងចំណោមអ្នកទាំងឡាយដែលដើរតាមទ្រង់ ហើយស្នាមព្រះបាទារបស់ទ្រង់គឺនៅក្នុងចំណោមយើងរាល់គ្នា។ ចម្លើយគឺងាយស្រួលបែបនេះឯង!» នរណាក៏អាចផ្ដល់ចម្លើយដែលមានជាលំនាំស្រាប់បានដែរ ប៉ុន្តែតើអ្នករាល់គ្នាយល់ពីអត្ថន័យនៃការលេចមករបស់ព្រះជាម្ចាស់ ឬស្នាមព្រះបាទារបស់ទ្រង់ដែរឬទេ? ការលេចមករបស់ព្រះជាម្ចាស់ សំដៅលើការយាងមកកាន់ផែនដីរបស់ទ្រង់ ដើម្បីបំពេញកិច្ចការរបស់ទ្រង់ដោយផ្ទាល់។ ទ្រង់នឹងយាងចុះមកក្នុងចំណោមមនុស្សជាតិដើម្បីបំពេញកិច្ចការនៃការបង្កើតយុគសម័យមួយ និងបញ្ចប់យុគសម័យមួយដែរ ដោយប្រើអត្តសញ្ញាណ និងនិស្ស័យរបស់ទ្រង់ផ្ទាល់ និងតាមវិធីដែលទ្រង់មានស្រាប់។ ការលេចមកប្រភេទ

នេះ គឺមិនមែនជាទម្រង់នៃពិធីណាមួយឡើយ។ វាមិនមែនជាទីសម្គាល់ ជារូបភាព ជាការអស្ចារ្យ ឬជានិមិត្តដ៏ធំអស្ចារ្យអ្វីនោះទេ ហើយវាក៏មិនមែនជាដំណើរនៃកិច្ចការសាសនាអ្វីដែរ។ វាគឺជាសេចក្ដីពិត និងជាតថភាពជាក់ស្ដែង ដែលមនុស្សអាចប៉ះបាន និងអាចមើលឃើញបាន។ ការលេចមកប្រភេទនេះ គឺមិនមែនគ្រាន់តែធ្វើឲ្យតែបាន ឬសម្រាប់ជាការសន្យារយៈពេលខ្លីនោះទេ ផ្ទុយទៅវិញ វាជាផ្នែកមួយនៃកិច្ចការនៅក្នុងផែនការគ្រប់គ្រងរបស់ទ្រង់ទេ។ ការលេចមករបស់ព្រះជាម្ចាស់ គឺសុទ្ធតែមានអត្ថន័យសារជាតិជានិច្ច និងតែងមានទំនាក់ទំនងខ្លះៗទៅនឹងផែនការគ្រប់គ្រងរបស់ទ្រង់។ អ្វីដែលហៅថា ការលេចមក នៅទីនេះ គឺខុសគ្នាទាំងស្រុងពី «ការលេចមក» ផ្សេងទៀត ដែលព្រះជាម្ចាស់ណែនាំ ដឹកនាំ និងបំភ្លឺដល់មនុស្ស។ ព្រះជាម្ចាស់បំពេញកិច្ចការដ៏វិសេសរបស់ទ្រង់ក្នុងចំណែកណាមួយ រៀងរាល់ពេលដែលទ្រង់ លេចមកដោយផ្ទាល់។ កិច្ចការនេះគឺខុសគ្នាពីកិច្ចការនៃយុគសម័យផ្សេងទៀត។ កិច្ចការនេះ មនុស្សមិនអាចស្រមៃនឹកដល់ និងមិនដែលធ្លាប់បានជួបប្រទះពីមុនមកឡើយ។ វាជាកិច្ចការដែលចាប់ផ្ដើមនូវយុគសម័យថ្មីមួយ និងបញ្ចប់ទៅវិញនូវយុគសម័យមុន ហើយវាគឺជាទម្រង់នៃកិច្ចការថ្មីដែលបានកែលម្អរួច សម្រាប់ជាការសង្គ្រោះដល់មនុស្សលោក។ បន្ថែមលើនេះ វាគឺជាកិច្ចការដែលនាំមនុស្សទៅកាន់យុគសម័យថ្មីមួយទៀត។ នេះហើយគឺជាអត្ថន័យនៃការលេចមករបស់ព្រះជាម្ចាស់។

នៅពេលណាដែលអ្នករាល់គ្នា បានយល់អំពីអត្ថន័យនៃការលេចមករបស់ព្រះជាម្ចាស់ តើអ្នករាល់គ្នាគប្បីត្រូវស្វែងរកស្នាមព្រះបាទារបស់ព្រះជាម្ចាស់ដោយរបៀបណា? សំណួរនេះមិនពិបាកពន្យល់នោះទេ៖ នៅទីណាដែល ព្រះជាម្ចាស់លេចមក នៅទីនោះហើយដែលអ្នកនឹងឃើញស្នាមព្រះបាទារបស់ទ្រង់។ ការពន្យល់បែបនេះ ស្ដាប់ទៅដូចជាត្រង់ៗពេក ប៉ុន្តែមិនងាយស្រួលនឹងអនុវត្តនោះទេ ដ្បិតមនុស្សជាច្រើនពុំបានដឹងថាព្រះជាម្ចាស់លេចមកនៅទីណានោះទេ កាន់តែមិនដឹងថា ទ្រង់អាចនឹងលេចមកនៅទីណា ឬទ្រង់គួរលេចមកនៅទីណាឡើយ។ មនុស្សខ្លះជឿទាំងមិនបានគិតថា នៅទីណាដែលព្រះវិញ្ញាណបរិសុទ្ធកំពុងបំពេញកិច្ចការ នៅទីនោះហើយដែល

ព្រះជាម្ចាស់លេចមក។ ឬម៉្យាងទៀត ពួកគេជឿថា នៅទីណាដែលមានបុគ្គលខាងវិញ្ញាណ នៅទីនោះហើយដែលព្រះជាម្ចាស់លេចមក។ ឬម៉្យាងទៀតពួកគេជឿថា នៅទីណាដែលមានបុគ្គលមានកេរ្តិ៍ឈ្មោះល្បី នៅទីនោះហើយដែលព្រះជាម្ចាស់លេចមក។ ក្នុងពេលនេះ ចូរយើងទុករឿងដែលថាជំនឿបែបនេះត្រឹមត្រូវឬខុសនោះមួយឡែកសិន។ ដើម្បីពន្យល់សំណួរបែបនេះយើងត្រូវមានគោលដៅច្បាស់លាស់ជាមុនសិន។ យើងកំពុងស្វែងរក ស្នាមព្រះបាទារបស់ព្រះជាម្ចាស់។ យើងមិនមែនកំពុងស្វែងរកបុគ្គលខាងវិញ្ញាណនោះទេ ហើយយើងក៏មិនបានកំពុងស្វែងរកមនុស្សដែលមានកេរ្តិ៍ឈ្មោះល្បីដែរ គឺយើងកំពុងស្វែងរកស្នាមព្រះបាទារបស់ព្រះជាម្ចាស់។ ក្នុងហេតុផលនេះ ដោយសារយើងកំពុងស្វែងរកស្នាមព្រះបាទារបស់ព្រះជាម្ចាស់ វាជាការចាំបាច់ណាស់ ដែលយើងត្រូវស្វែងយល់ពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ពីព្រះបន្ទូលរបស់ព្រះជាម្ចាស់និងពីព្រះសូរសៀងរបស់ព្រះជាម្ចាស់ ព្រោះនៅទីណាដែលព្រះជាម្ចាស់ទ្រង់ថ្លែងនូវព្រះបន្ទូលថ្មីៗ នោះព្រះសូរសៀងរបស់ព្រះជាម្ចាស់គឺនៅទីនោះឯង ហើយនៅទីណាដែលមានស្នាមព្រះបាទារបស់ព្រះជាម្ចាស់ នៅទីនោះមានសកម្មភាពរបស់ព្រះជាម្ចាស់។ នៅទីណាដែលមានការសម្ដែងចេញអំពីព្រះជាម្ចាស់ នៅទីនោះព្រះជាម្ចាស់លេចមក ហើយនៅទីណាដែលព្រះជាម្ចាស់លេចមក នៅទីនោះមានសេចក្តីពិត មានផ្លូវ ហើយជីវិតក៏កើតមានដែរ។ អ្នករាល់គ្នាបានព្រងើយកន្តើយចំពោះពាក្យថា «ព្រះជាម្ចាស់គឺជាសេចក្ដីពិត ជាផ្លូវ និងជាជីវិត» ក្នុងការស្វែងរកស្នាមព្រះបាទារបស់ព្រះជាម្ចាស់។ ហេតុដូចនេះ មានមនុស្សជាច្រើនពុំជឿថា ពួកគេបានរកឃើញស្នាមព្រះបាទារបស់ព្រះជាម្ចាស់ទេ ហើយរឹតតែមិនទទួលស្គាល់នូវការលេចមករបស់ព្រះជាម្ចាស់ទៀត ទោះបីជាពួកគេទទួលបានសេចក្តីពិតក៏ដោយ។ នេះ គឺជាកំហុសដ៏ធ្ងន់ធ្ងរខ្លាំងណាស់! ការលេចមករបស់ព្រះជាម្ចាស់ មិនអាចត្រូវទៅនឹងសញ្ញាណរបស់មនុស្សបានទេ ហើយទ្រង់រឹតតែមិនអាចលេចមកតាមបង្គាប់របស់មនុស្សបានដែរ។ ព្រះជាម្ចាស់ សម្រេចព្រះហឫទ័យនិងធ្វើផែនការរបស់ទ្រង់ដោយព្រះអង្គឯង នៅពេលទ្រង់បំពេញកិច្ចការរបស់ទ្រង់។ បន្ថែមលើនេះ ទ្រង់មាន

គោលដៅ និងវិធីសាស្រ្តផ្ទាល់របស់ព្រះអង្គ។ មិនថាកិច្ចការអ្វីដែលទ្រង់ធ្វើនោះទេ ទ្រង់ពុំចាំបាច់ត្រូវការពិភាក្សាជាមួយមនុស្ស ឬស្នើសុំយោបល់ពីពួកគេឡើយ និងមិនចាំបាច់ប្រាប់ឲ្យមនុស្សរាល់គ្នាដឹងអំពីកិច្ចការរបស់ទ្រង់ដែរ។ លើសពីនេះទៅទៀត នេះគឺជានិស្ស័យរបស់ព្រះជាម្ចាស់ ដែលមនុស្សគ្រប់រូបគប្បីត្រូវសម្គាល់។ ប្រសិនបើអ្នករាល់គ្នាមានបំណងចង់ធ្វើបន្ទាល់អំពីការលេចមករបស់ព្រះជាម្ចាស់ ចង់ដើរតាមស្នាមព្រះបាទារបស់ព្រះជាម្ចាស់ នោះអ្នកត្រូវដើរចេញពីសញ្ញាណផ្ទាល់ខ្លួនរបស់អ្នកជាមុនសិន។ អ្នកមិនត្រូវទាមទារឲ្យព្រះជាម្ចាស់ធ្វើនេះ ឬធ្វើនោះទេ ហើយអ្នកមិនត្រូវដាក់ទ្រង់នៅក្នុងការឃុំឃាំងរបស់ខ្លួន និងកំណត់ព្រំដែនទ្រង់ នៅក្នុងសញ្ញាណផ្ទាល់ខ្លួនរបស់អ្នកឡើយ។ ផ្ទុយទៅវិញ អ្នករាល់គ្នាគប្បីទាមទារពីខ្លួនអ្នករាល់គ្នានូវវិធីដែលអ្នកគួរស្វែងរកស្នាមព្រះបាទាទ្រង់ វិធីដែលអ្នកគួរទទួលយកការលេចមករបស់ព្រះជាម្ចាស់ និងវិធីដែលអ្នកគួរចុះចូលទៅក្នុងកិច្ចការថ្មីរបស់ព្រះជាម្ចាស់៖ នេះគឺជាអ្វីដែលមនុស្សគប្បីត្រូវធ្វើ។ ដោយសារមនុស្សមិនមែនជាសេចក្ដីពិត និងមិនមានសេចក្ដីពិត នោះគេគប្បីស្វែងរក ទទួលយក និងស្ដាប់បង្គាប់តាមទ្រង់។

មិនថាអ្នកជាជនជាតិអាមេរិក អង់គ្លេស ឬជាតិសាសន៍ដទៃនោះទេ អ្នកគប្បីដើរចេញពីរនាំងជាតិសាសន៍ផ្ទាល់ខ្លួនរបស់អ្នក ដោយបន្ទាបខ្លួន និងគិតពីកិច្ចការរបស់ព្រះជាម្ចាស់តាមទីស្ថានរបស់សត្តនិករដែលត្រូវបានបង្កើតឡើងមក។ តាមរបៀបនេះ អ្នកនឹងមិនដាក់ព្រំដែនចំពោះស្នាមព្រះបាទារបស់ព្រះជាម្ចាស់ឡើយ។ នេះគឺដោយសារបច្ចុប្បន្ននេះ មានមនុស្សជាច្រើនយល់ថាវាមិនអាចទៅរួចនោះទេដែលព្រះជាម្ចាស់នឹងលេចមកនៅក្នុងជាតិសាសន៍ណាមួយ ឬក្នុងចំណោមក្រុមមនុស្សណាមួយ។ កិច្ចការរបស់ព្រះជាម្ចាស់ ពិតជាមានអត្ថន័យជ្រាលជ្រៅ ហើយការលេចមករបស់ព្រះជាម្ចាស់ពិតជាមានសារៈសំខាន់ណាស់! តើសញ្ញាណនិងគំនិតរបស់មនុស្សអាចធ្វើការវាស់ស្ទង់បានដោយរបៀបណា? ហេតុនេះហើយបានជាខ្ញុំមានបន្ទូលថា អ្នកគប្បីទម្លុះនូវសញ្ញាណជាតិសាសន៍ និងពូជសាសន៍ដើម្បីស្វែងរកការលេចមករបស់ព្រះជាម្ចាស់។ មានតែការធ្វើបែបនេះទេ ទើបអ្នកនឹងមិនត្រូវកំហិតដោយសញ្ញាណផ្ទាល់ខ្លួនរបស់

អ្នក។ ហើយមានតែការធ្វើបែបនេះទេ ទើបអ្នកនឹងមានគុណសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលស្វាគមន៍ការលេចមករបស់ព្រះជាម្ចាស់។ បើពុំដូច្នោះទេ អ្នកនឹងស្ថិតក្នុងភាពងងឹតជាដរាប និងមិនអាចទទួលបានការសព្វព្រះហឫទ័យពីព្រះជាម្ចាស់ឡើយ។

ព្រះជាម្ចាស់ គឺជាព្រះនៃមនុស្សគ្រប់ជាតិសាសន៍ទាំងមូល។ ទ្រង់ពុំចាត់ទុកអង្គទ្រង់ ជាទ្រព្យសម្បត្តិផ្ទាល់ខ្លួននៃជាតិសាសន៍ ឬមនុស្សមួយក្រុមណាឡើយ ប៉ុន្តែទ្រង់ផ្ដើមបំពេញកិច្ចការរបស់ទ្រង់ ដូចដែលទ្រង់បានគ្រោងទុក ដោយពុំមានការបង្ខាំង ដោយទម្រង់ណាមួយចំពោះសាសន៍ណាមួយ ឬចំពោះក្រុមមនុស្សណាមួយឡើយ។ ប្រហែលជាអាចមកពីអ្នក ពុំធ្លាប់ស្រមៃដល់ទម្រង់នេះ ឬមកពីអ្នកមានអាកប្បកិរិយា បដិសេធទម្រង់នេះ ឬមកពីប្រជាជាតិដែលព្រះជាម្ចាស់សម្ដែងអង្គទ្រង់ និងបណ្ដាមនុស្សដែលទ្រង់លេចមកក្នុងចំណោមពួកគេ ជាមនុស្សដែលគេគ្រប់គ្នារើសអើង ហើយជាមនុស្ស ដែលអន់ខ្សោយបំផុតនៅលើផែនដី។ តែព្រះជាម្ចាស់ មានព្រះប្រាជ្ញាញាណរបស់ទ្រង់។ ព្រះអង្គ ពិតជាទទួលបានក្រុមមនុស្សដែលមានគំនិតដូចទ្រង់ ហើយជាក្រុមមនុស្ស ដែលទ្រង់ចង់កែច្នៃឲ្យបានបរិបូរ ជាក្រុមមនុស្សដែលទ្រង់បានយកឈ្នះដោយព្រះចេស្ដាដ៏មហិមា និងដោយសេចក្ដីពិត ព្រមទាំងនិស្ស័យដ៏អង់អាចរបស់ទ្រង់ ជាក្រុមមនុស្សដែលបានទ្រាំទ្រទុក្ខលំបាក សេចក្ដីវេទនា និងការបៀតបៀនគ្រប់យ៉ាង ហើយនៅតែអាចដើរតាមទ្រង់រហូតដល់ទីបញ្ចប់។ គោលបំណងនៃការលេចមករបស់ព្រះជាម្ចាស់ គឺដើម្បីឲ្យទ្រង់អាចបំពេញកិច្ចការរបស់ទ្រង់បានទៅតាមអ្វីដែលទ្រង់បានគ្រោងទុក ដោយពុំមានដាក់ដែនកំណត់ក្នុងលក្ខណៈណាមួយ ឬដោយសាសន៍ណាមួយឡើយ។ នេះគឺដូចកាលដែលព្រះជាម្ចាស់បានត្រលប់ជាសាច់ឈាមនៅស្រុកយូដាដែរ៖ គោលបំណងរបស់ទ្រង់ គឺដើម្បីបញ្ចប់កិច្ចការនៃការត្រូវឆ្កាងដើម្បីប្រោសលោះមនុស្សទាំងមូល។ ក៏ប៉ុន្តែសាសន៍យូដាបានជឿថា ព្រះជាម្ចាស់មិនអាចធ្វើរឿងបែបនេះបានទេ ហើយពួកគេបានគិតថា ព្រះជាម្ចាស់មិនអាចត្រលប់ជាសាច់ឈាម និងក្លាយជារូបអង្គនៃព្រះអម្ចាស់យេស៊ូវបានឡើយ។ គំនិត «មិនអាចទៅរួច» របស់ពួកគេ បានក្លាយជា

មូលដ្ឋានដែលពួកគេថ្កោលទោស និងបដិសេធព្រះជាម្ចាស់ ហើយចុងក្រោយនាំទៅដល់ការបំផ្លិចបំផ្លាញស្រុកអ៊ីស្រាអែល។ សព្វថ្ងៃនេះ មនុស្សជាច្រើនបានប្រព្រឹត្តកំហុសស្រដៀងគ្នានេះដែរ។ ពួកគេប្រកាសប្រាប់ ពីការលេចមករបស់ព្រះជាម្ចាស់ដែលនឹងជិតមកដល់ អស់ពីកម្លាំងរបស់ពួកគេ តែក្នុងពេលដំណាលគ្នានោះ គេបែរជាថ្កោលទោស ចំពោះការលេចមករបស់ទ្រង់វិញ។ គំនិត «មិនអាចទៅរួច» របស់ពួកគេ ដាក់កំហិតម្ដងទៀតលើការលេចមករបស់ព្រះជាម្ចាស់នៅក្នុងព្រំដែននៃការស្រមើស្រមៃរបស់ពួកគេ។ ហេតុនេះ ខ្ញុំបានឃើញមនុស្សជាច្រើនផ្ទុះសំណើចក្អាកក្អាយ និងកងរំពង ក្រោយជួបព្រះបន្ទូលរបស់ព្រះជាម្ចាស់ដោយចៃដន្យ។ ប៉ុន្តែតើសំណើចនេះខុសគ្នាពីការថ្កោលទោស និងការប្រមាថរបស់សាសន៍យូដាដែរទេ? អ្នករាល់គ្នាពុំមានការគោរពចំពោះវត្តមាននៃសេចក្ដីពិតទេ ហើយអ្នកមិនមានអាកប្បកិរិយាស្រេកឃ្លានសេចក្ដីពិតដែរ។ អ្វីទាំងអស់ដែលអ្នកធ្វើ គឺសិក្សាស្វែងយល់ដោយមិនរើសមុខ និងរង់ចាំដោយត្រេកអរសប្បាយ គ្មានការខ្វល់ខ្វាយសោះឡើយ។ តើអ្នកអាចទទួលបានអ្វីខ្លះ ពីការសិក្សាស្វែងយល់ និងការរង់ចាំបែបនេះ? តើអ្នកគិតថា អ្នកនឹងទទួលបានការដឹកនាំពីព្រះជាម្ចាស់ដោយផ្ទាល់ដែរឬទេ? ប្រសិនបើអ្នកមិនអាចយល់ពីសូរសៀងរបស់ព្រះជាម្ចាស់ តើអ្នកមានលក្ខណសម្បត្តិបែបណា ដើម្បីអាចធ្វើបន្ទាល់អំពីការលេចមករបស់ព្រះជាម្ចាស់បាន? នៅទីណាដែលព្រះជាម្ចាស់លេចមក នៅទីនោះមានការបើកសម្ដែងអំពីសេចក្ដីពិត ហើយនៅទីនោះមានសូរសៀងរបស់ព្រះជាម្ចាស់។ មានតែអ្នកដែលអាចទទួលយកនូវសេចក្ដីពិតនេះប៉ុណ្ណោះ ដែលនឹងអាចស្ដាប់ឮ ព្រះសូរសៀងរបស់ព្រះជាម្ចាស់បាន ហើយមានតែមនុស្សជំពូកនេះទេ ដែលមានលក្ខណសម្បត្តិធ្វើបន្ទាល់ពីការលេចមករបស់ព្រះជាម្ចាស់។ ត្រូវជម្រុះចោលនូវសញ្ញាណរបស់អ្នកចេញ! ចូររក្សាភាពស្ងប់ស្ងៀម និងអានព្រះបន្ទូលទាំងនេះដោយយកចិត្តទុកដាក់។ បើអ្នកចង់ឃើញសេចក្ដីពិត នោះព្រះជាម្ចាស់នឹងបំភ្លឺអ្នក ហើយអ្នកនឹងយល់ពីបំណងព្រះហឫទ័យ និងព្រះបន្ទូលរបស់ទ្រង់។ ត្រូវជម្រុះចោលនូវទស្សនៈរបស់អ្នករាល់គ្នាចំពោះគំនិតថា «មិនអាចទៅរួច» នេះចេញ!

នៅពេលដែលមនុស្សជឿកាន់តែខ្លាំងថា អ្វីមួយមិនអាចទៅរួច នោះវានឹងកាន់តែអាចកើតមានឡើង ដោយសារព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់ អណ្ដែតឡើងខ្ពស់ជាងឋានសួគ៌ ព្រះតម្រិះរបស់ព្រះជាម្ចាស់ ខ្ពស់ជាងគំនិតរបស់មនុស្ស ហើយកិច្ចការរបស់ព្រះជាម្ចាស់ ក៏ហួសព្រំដែននៃការគិត និងសញ្ញាណរបស់មនុស្សដែរ។ នៅពេលអ្វីមួយកាន់តែមិនអាចទៅរួច នោះវាមានសេចក្ដីពិតកាន់តែច្រើនដែលអាចស្វែងរកបាន។ នៅពេលអ្វីមួយស្ថិតនៅហួសពីសញ្ញាណ និងការស្រមៃរបស់មនុស្ស នោះវាមានពេញទៅដោយព្រះហឫទ័យរបស់ព្រះជាម្ចាស់កាន់តែច្រើនដែរ។ ដ្បិតទោះបីជាព្រះអង្គបង្ហាញអង្គទ្រង់នៅទីណា ក៏ទ្រង់នៅតែជាព្រះជាម្ចាស់ ហើយនិស្ស័យពិតរបស់ទ្រង់ ក៏មិនប្រែប្រួលតាមទីកន្លែង ឬលក្ខណៈនៃការលេចមករបស់ទ្រង់ដែរ។ និស្ស័យរបស់ព្រះជាម្ចាស់ នៅរក្សាដូចដើមដដែល មិនថាស្នាមព្រះបាទារបស់ទ្រង់នៅទីណានោះទេ ហើយមិនថាទីណាដែលមានស្នាមព្រះបាទារបស់ព្រះជាម្ចាស់នោះទេ ទ្រង់គឺជាម្ចាស់នៃមនុស្សជាតិទាំងអស់ គឺដូចជាព្រះអម្ចាស់យេស៊ូវ ដែលមិនមែនគ្រាន់តែជាព្រះជាម្ចាស់នៃពួកសាសន៍អ៊ីស្រាអែលឡើយ ប៉ុន្ដែជាព្រះជាម្ចាស់នៃមនុស្សគ្រប់គ្នា មិនថាជាតិសាសន៍អាស៊ី អឺរ៉ុប និងអាមេរិក និងជាតិសាសន៍ដទៃទៀតឡើយ ទ្រង់គឺជាព្រះជាម្ចាស់តែមួយ និងមួយអង្គគត់នៅក្នុងសាកលលោកទាំងមូលនេះ។ ដូចនេះ ចូរយើងស្វែងយល់ពីព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងស្វែងរកការលេចមករបស់ទ្រង់នៅក្នុងព្រះសូរសៀងរបស់ទ្រង់ និងត្រូវដើរឲ្យទាន់លំអាននៃស្នាមព្រះបាទារបស់ទ្រង់! ព្រះជាម្ចាស់គឺជាសេចក្ដីពិត ជាផ្លូវ និងជាជីវិត។ ព្រះបន្ទូលរបស់ទ្រង់ និងការលេចមករបស់ទ្រង់កើតឡើងដំណាលគ្នា ហើយនិស្ស័យនិងស្នាមព្រះបាទារបស់ទ្រង់ បើកចំហចំពោះមនុស្សជាតិនៅគ្រប់ពេលវេលាទាំងអស់។ បងប្អូនប្រុសស្រីអើយ ខ្ញុំសង្ឃឹមថាអ្នករាល់គ្នាអាចមើលឃើញពីការលេចមករបស់ព្រះជាម្ចាស់នៅក្នុងព្រះបន្ទូលទាំងនេះ និងចាប់ផ្ដើមដើរតាមលំអាននៃស្នាមព្រះបាទារបស់ទ្រង់នៅពេលអ្នកបោះជំហានទៅមុខ ទៅក្នុងយុគសម័យថ្មីមួយ និងចូលទៅក្នុងឋានសួគ៌និងផែនដីថ្មីដ៏ស្រស់ស្អាតដែលព្រះជាម្ចាស់បានរៀបចំសម្រាប់អស់អ្នកដែលរង់ចាំការលេចមករបស់ទ្រង់!

# ព្រះជាម្ចាស់គ្រប់គ្រងលើវាសនា របស់មនុស្សលោកទាំងអស់

ក្នុងនាមជាសមាជិកនៃអម្បូរមនុស្សលោក និងជាគ្រីស្ទបរិស័ទដែលគោរពកោតខ្លាចព្រះជាម្ចាស់ ការលះបង់ចិត្តគំនិត និងរូបកាយរបស់យើង ដើម្បីបំពេញបញ្ជាបេសកកម្មរបស់ព្រះជាម្ចាស់ គឺជាទំនួលខុសត្រូវ និងជាកាតព្វកិច្ចរបស់យើងរាល់គ្នា ដ្បិតជីវិតយើងទាំងមូលបានមកពីព្រះជាម្ចាស់ ហើយវាកើតមានមកបាន ក៏ដោយសារអំណាចគ្រប់គ្រងរបស់ព្រះជាម្ចាស់ដែរ។ ប្រសិនបើចិត្តគំនិត និងរូបកាយរបស់យើង មិនមែនសម្រាប់បញ្ជាបេសកកម្មរបស់ព្រះជាម្ចាស់ និងមិនមែនសម្រាប់បុព្វហេតុសុចរិតរបស់មនុស្សទេ នោះព្រលឹងរបស់យើង នឹងមានអារម្មណ៍ថាមិនសមនឹងតម្លៃរបស់អស់អ្នកដែលសុខចិត្តរងទុក្ខដើម្បីបញ្ជាបេសកកម្មរបស់ព្រះជាម្ចាស់ឡើយ ហើយកាន់តែគ្មានតម្លៃសមនឹងព្រះជាម្ចាស់ ជាព្រះដែលបានប្រទាននូវអ្វីៗគ្រប់យ៉ាងមកដល់យើងដែរ។

ព្រះជាម្ចាស់បានបង្កើតពិភពលោកនេះ ទ្រង់បានបង្កើតមនុស្សលោក ហើយជាងនេះទៅទៀត ទ្រង់ជាស្ថាបត្យករនៃវប្បធម៌ក្រិកបុរាណ និងអរិយធម៌មនុស្សលោកទៀតផង។ មានតែព្រះជាម្ចាស់ប៉ុណ្ណោះ ដែលអាចលួងលោមចិត្តមនុស្សលោកបាន ហើយមានតែព្រះជាម្ចាស់ប៉ុណ្ណោះ ដែលយកព្រះទ័យទុកដាក់ចំពោះមនុស្សលោកទាំងយប់ទាំងថ្ងៃ។ ការអភិវឌ្ឍ និងការរីកចម្រើនរបស់មនុស្សលោក មិនអាចកាត់ផ្ដាច់ចេញពីអំណាចគ្រប់គ្រងរបស់ព្រះជាម្ចាស់បានឡើយ ហើយប្រវត្តិសាស្ត្រ និងវប្បធម៌របស់មនុស្សលោក មិនអាចកែប្រែឲ្យខុសពីគម្រោងការរបស់ព្រះជាម្ចាស់បាននោះទេ។ ប្រសិនបើអ្នកជាគ្រីស្ទបរិស័ទពិត នោះអ្នកប្រាកដជាជឿថា ការងើបឡើង និងការធ្លាក់ចុះរបស់ប្រទេស ឬជាតិសាសន៍មួយ កើតឡើងស្របទៅតាមគ្រោងការរបស់ព្រះជាម្ចាស់។ មានតែព្រះជាម្ចាស់តែមួយអង្គប៉ុណ្ណោះ ដែលជ្រាបអំពីវាសនារបស់ប្រទេស ឬជាតិសាសន៍មួយបាន ហើយមានតែព្រះជាម្ចាស់តែមួយអង្គប៉ុណ្ណោះ ដែល

គ្រប់គ្រងដំណើរជីវិតរបស់មនុស្សនេះ។ ប្រសិនបើមនុស្សលោកចង់មានវាសនាល្អ ប្រសិនបើប្រទេសមួយចង់មានវាសនាល្អ នោះមនុស្សត្រូវតែក្រាបចុះ ថ្វាយបង្គំព្រះជាម្ចាស់ ហើយប្រែចិត្ត និងលន់តួបាបនៅចំពោះព្រះជាម្ចាស់ ពុំនោះទេ វាសនា និងទិសដៅរបស់មនុស្សលោក នឹងជួបគ្រោះមហន្តរាយដោយចៀសមិនរួចទេ។

ចូរត្រឡប់ទៅមើលសម័យដែលណូអេសាងសង់ទូកធំ៖ មនុស្សលោកពុករលួយខ្លាំងណាស់ គេបានវង្វេងចេញពីព្រះពររបស់ព្រះជាម្ចាស់ ព្រះជាម្ចាស់ក៏លែងយកព្រះទ័យទុកដាក់ចំពោះគេ រួចគេក៏បានបាត់បង់សេចក្ដីសន្យារបស់ព្រះជាម្ចាស់ផងដែរ។ ពួកគេរស់នៅក្នុងភាពងងឹត ដោយគ្មានពន្លឺរបស់ព្រះជាម្ចាស់។ ក្រោយមកពួកគេបានប្រាសចាកសីលធម៌ពីកំណើត និងបណ្ដោយខ្លួនឲ្យទៅក្នុងអំពើអគុណធម៌គួរឲ្យខ្ពើមរអើម។ មនុស្សបែបនេះ លែងអាចទទួលសេចក្ដីសន្យារបស់ព្រះជាម្ចាស់ទៀតហើយ។ ពួកគេមិនស័ក្ដិសមនឹងមើលឃើញព្រះភ័ក្ត្ររបស់ព្រះជាម្ចាស់ ឬស្ដាប់ឮព្រះសូរសៀងរបស់ព្រះជាម្ចាស់ឡើយ ដ្បិតពួកគេបានបោះបង់ចោលព្រះជាម្ចាស់ បានបោះបង់ចោលគ្រប់អ្វីៗទាំងអស់ ដែលទ្រង់បានប្រទានឲ្យពួកគេ និងបានបំភ្លេចសេចក្ដីបង្រៀនរបស់ព្រះជាម្ចាស់ទៀតផង។ ដួងចិត្តរបស់ពួកគេបានវង្វេងចេញពីព្រះជាម្ចាស់កាន់តែឆ្ងាយទៅៗ ហេតុនេះ ទើបពួកគេក្លាយទៅជាមនុស្សអសីលធម៌ហួសល្បត់ ជាមនុស្សអមនុស្សធម៌ និងកាន់តែអាក្រក់ទៅៗ។ បន្ទាប់មក ពួកគេបានដើរខិតកាន់តែជិតទៅរកសេចក្ដីស្លាប់ និងធ្លាក់ក្រោមសេចក្ដីក្រោធ និងការដាក់ទោសរបស់ព្រះជាម្ចាស់។ មានតែណូអេទេ ដែលថ្វាយបង្គំព្រះជាម្ចាស់ និងអាចជៀសចេញពីអំពើអាក្រក់បាន ហេតុដូច្នេះ ទើបគាត់អាចស្ដាប់ឮព្រះសូរសៀងរបស់ព្រះជាម្ចាស់ និងអាចស្ដាប់ឮការណែនាំរបស់ទ្រង់បាន។ គាត់បានសាងសង់ទូកធំនោះ ទៅតាមការណែនាំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយបានប្រមូលផ្ដុំគ្រប់សត្វមានជីវិតទាំងអស់នៅទីនោះ។ យ៉ាងនេះ ទើបព្រះជាម្ចាស់បញ្ជេញវិនាសកម្មមកលើពិភពលោកនេះ នៅពេលគ្រប់យ៉ាងបានរៀបចំរួចជាស្រេច។ មានតែណូអេ និងសមាជិកគ្រួសាររបស់គាត់ទាំងប្រាំពីររូបប៉ុណ្ណោះ ដែលរួចជីវិតពីគ្រោះមហន្តរាយនេះ

ដ្បិតណូអេថ្វាយបង្គំព្រះយេហូវ៉ា និងជៀសចេញពីអំពើអាក្រក់។
ឥឡូវ ចូរមើលសម័យបច្ចុប្បន្ននេះ៖ មនុស្សសុចរិតដូចជា ណូអេដែលអាចថ្វាយបង្គំព្រះជាម្ចាស់ និងជៀសចេញពីអំពើអាក្រក់លែងកើតទៀតហើយ។ ក៏ប៉ុន្តែនៅក្នុងសម័យចុងក្រោយនេះ ព្រះជាម្ចាស់នៅតែមានព្រះទ័យសន្ដោសប្រណី ចំពោះមនុស្ស និងនៅតែអត់ទោសដល់ពួកគេដដែល។ ព្រះជាម្ចាស់ស្វែងរកអស់អ្នកណាដែលទន្ទឹងរង់ចាំទ្រង់លេចមក។ ទ្រង់ស្វែងរកអស់អ្នកណាដែលអាចស្ដាប់ព្រះបន្ទូលរបស់ទ្រង់ ស្វែងរកអស់អ្នកណា ដែលមិនដែលបំភ្លេចបញ្ញត្តិរបស់ទ្រង់ ហើយលះបង់ដួងចិត្ត និងរូបកាយរបស់ពួកគេថ្វាយដល់ទ្រង់។ ទ្រង់ស្វែងរកអស់អ្នកណាដែលស្ដាប់បង្គាប់ទ្រង់ ដូចជាកូនតូច និងមិនប្រឆាំងទាស់នឹងទ្រង់។ ប្រសិនបើអ្នកលះបង់ខ្លួនឯងថ្វាយដល់ព្រះជាម្ចាស់ ដោយមិនមានការរារាំងពីអំណាច ឬពីអនុភាពណាមួយ នោះព្រះជាម្ចាស់នឹងទតមើលអ្នកដោយក្ដីអនុគ្រោះ ហើយប្រទានព្រះពររបស់ទ្រង់ដល់អ្នក។ ប្រសិនបើអ្នកមានឋានៈខ្ពស់ មានកេរ្តិ៍ឈ្មោះកិត្តិយស មានចំណេះដឹងខ្ពង់ខ្ពស់ ជាម្ចាស់ទ្រព្យសម្បត្តិច្រើនសន្ធឹកសន្ធាប់ និងមានមនុស្សជាច្រើនគាំទ្រអ្នក ប៉ុន្តែកត្តាទាំងអស់នេះ ពុំបានរារាំងអ្នកមិនឲ្យមករកព្រះជាម្ចាស់ ដើម្បីទទួលយកការត្រាស់ហៅរបស់ទ្រង់ និងទទួលយកបញ្ញត្តិរបស់ទ្រង់ និងដើម្បីធ្វើអ្វីដែលព្រះបង្គាប់ឲ្យអ្នកធ្វើ នោះអ្វីៗគ្រប់យ៉ាងដែលអ្នកធ្វើ នឹងក្លាយជាបុព្វហេតុដ៏មានន័យ ជាងគេបំផុតនៅលើផែនដីនេះ និងជាកិច្ចការសុចរិតជាងគេសម្រាប់មនុស្សលោក។ ប្រសិនបើអ្នក បដិសេធការត្រាស់ហៅរបស់ព្រះជាម្ចាស់ ដោយសារឋានៈ និងគោលដៅផ្ទាល់ខ្លួនរបស់អ្នក នោះអ្វីគ្រប់យ៉ាងដែលអ្នកធ្វើ នឹងត្រូវព្រះជាម្ចាស់ដាក់បណ្ដាសា និងស្អប់ខ្ពើម។ អ្នកអាចជាប្រធានាធិបតី ជាអ្នកវិទ្យាសាស្ត្រ ជាគ្រូគង្វាល ឬជាចាស់ទុំម្នាក់ ប៉ុន្តែមិនថាតួនាទីរបស់អ្នកខ្ពង់ខ្ពស់ប៉ុនណានោះទេ ប្រសិនបើអ្នកពឹងផ្អែកលើចំណេះដឹង និងសមត្ថភាពរបស់អ្នកនៅក្នុងកិច្ចការរបស់ខ្លួន នោះអ្នកនឹងក្លាយជាមនុស្សបរាជ័យជាដរាប ហើយអ្នកនឹងមិនទទួលបានព្រះពរពីព្រះជាម្ចាស់ឡើយ ដ្បិតព្រះជាម្ចាស់មិនទទួលយកអ្វីដែលអ្នកធ្វើឡើយ ហើយទ្រង់

ពុំចាត់ទុកកិច្ចការរបស់អ្នក ជាកិច្ចការសុចរិត ឬទទួលស្គាល់ថា អ្នកកំពុងធ្វើការដើម្បីជាប្រយោជន៍ដល់មនុស្សលោកឡើយ។ ទ្រង់នឹងមានបន្ទូលថា អ្វីគ្រប់យ៉ាងដែលអ្នកធ្វើ គឺធ្វើដើម្បីប្រើចំណេះដឹង និងកម្លាំងរបស់មនុស្ស ដើម្បីរុញច្រានការការពាររបស់ព្រះជាម្ចាស់ចេញពីមនុស្ស ហើយវាត្រូវបានធ្វើឡើងដើម្បីបដិសេធព្រះពររបស់ព្រះជាម្ចាស់។ ទ្រង់នឹងមានបន្ទូលថា អ្នកកំពុងដឹកនាំមនុស្សទៅរកភាពងងឹត ទៅរកសេចក្ដីស្លាប់ និងទៅរកការចាប់ផ្ដើមជីវិតដែលគ្មានដែនកំណត់ ដែលមនុស្សបានបាត់បង់ព្រះជាម្ចាស់ និងព្រះពររបស់ទ្រង់។

ដោយសារតែការបង្កើតវិទ្យាសាស្ត្រសង្គមរបស់មនុស្ស ទើបគំនិតរបស់គេត្រូវពង្វក់ដោយវិទ្យាសាស្ត្រ និងចំណេះដឹង។ ក្រោយមក វិទ្យាសាស្ត្រ និងចំណេះដឹងក៏បានក្លាយជាឧបករណ៍ សម្រាប់គ្រប់គ្រងមនុស្សលោក ហើយលែងមានចន្លោះគ្រប់គ្រាន់សម្រាប់ឲ្យមនុស្សថ្វាយបង្គំព្រះជាម្ចាស់ និងលែងមានលក្ខខណ្ឌអនុគ្រោះសម្រាប់ការថ្វាយបង្គំព្រះជាម្ចាស់ទៀតដែរ។ ឋានៈរបស់ព្រះជាម្ចាស់ បានធ្លាក់ចុះកាន់តែទាបនៅក្នុងចិត្តមនុស្ស។ បើគ្មានព្រះជាម្ចាស់នៅក្នុងចិត្តទេ ពិភពខាងក្នុងរបស់មនុស្សនឹងងងឹត អស់សង្ឃឹម និងទទេសូន្យ។ ក្រោយៗមកទៀត អ្នកវិទ្យាសាស្ត្រសង្គម អ្នកប្រវត្តិសាស្ត្រ និងអ្នកនយោបាយជាច្រើន បានក្លាយជាអ្នកនាំមុខគេ ក្នុងការបង្ហាញពីទ្រឹស្ដីវិទ្យាសាស្ត្រសង្គម ទ្រឹស្ដីនៃការវិវត្តរបស់មនុស្សលោក និងទ្រឹស្ដីផ្សេងៗទៀតដែលផ្ទុយទៅនឹងសេចក្ដីពិតដែលព្រះជាម្ចាស់បានបង្កើតមនុស្សលោក ដើម្បីបំពេញតាមចិត្ត និងគំនិតរបស់មនុស្សលោក។ ដោយសារតែបែបនេះ ទើបមនុស្សដែលជឿថាព្រះជាម្ចាស់បានបង្កើតអ្វីៗគ្រប់យ៉ាង មានកាន់តែតិចទៅៗ ហើយមនុស្សដែលជឿលើទ្រឹស្ដីនៃការវិវត្ត នោះក៏កាន់តែមានចំនួនច្រើនឡើងៗ។ មនុស្សកាន់តែច្រើនឡើងចាត់ទុកកំណត់ត្រានៃកិច្ចការរបស់ព្រះជាម្ចាស់ និងបន្ទូលរបស់ទ្រង់ក្នុងសម័យនៃព្រះគម្ពីរសញ្ញាចាស់ ជាទេវកថា និងជារឿងព្រេងនិទាន។ នៅក្នុងដួងចិត្តរបស់ពួកគេ មនុស្សលែងអើពើចំពោះភាពថ្លៃថ្នូរ និងភាពមហិមារបស់ព្រះជាម្ចាស់ទៀតហើយ គេលែងអើពើចំពោះគោលជំនឿថា ព្រះជាម្ចាស់មានពិត និងមានអំណាចត្រួតត្រាលើគ្រប់

អ្វីៗទាំងអស់។ ការរស់រានរបស់មនុស្សលោក និងវាសនាប្រទេស និងជាតិសាសន៍នានា លែងសំខាន់ចំពោះពួកគេទៀតហើយ ហើយមនុស្សរស់នៅក្នុងពិភពដែលគ្មានសារជាតិ ដែលខ្វល់ខ្វាយតែនឹងរឿងហូបចុក ស៊ីផឹក និងរឿងសប្បាយ។ ... មានមនុស្សតិចណាស់ដែលគិតថា ខ្លួនមានកាតព្វកិច្ច ក្នុងការស្វែងរកទីកន្លែងដែលព្រះជាម្ចាស់បំពេញកិច្ចការរបស់ទ្រង់នាពេលសព្វថ្ងៃនេះ ឬព្យាយាមស្វែងយល់ពីរបៀបដែលទ្រង់គ្រប់គ្រង និងរៀបចំទិសដៅរបស់មនុស្សលោក។ ហើយដោយបែបនេះ ទើបអរិយធម៌របស់មនុស្ស កាន់តែមិនអាចត្រួសត្រាយក្ដីប្រាថ្នារបស់មនុស្សលោកបាន ក៏លែងមានមនុស្សស្គាល់ ហើយខណៈកំពុងរស់នៅក្នុងពិភពបែបនេះ ទើបមនុស្សច្រើនណាស់មានអារម្មណ៍ថា ពួកគេសប្បាយចិត្ត តិចជាងមនុស្សដែលបានស្លាប់ទៅហើយ។ សូម្បីតែប្រជាជននៃប្រទេសដែលធ្លាប់មានអរិយធម៌ថ្កុំថ្កើង ក៏ជួបនឹងទុក្ខព្រួយបែបនេះដែរ។ មិនថា មេដឹកនាំ និងអ្នកប្រាជ្ញសង្គមវិទ្យា ខំប្រឹងប្រើខួរក្បាលរបស់ពួកគេ ដើម្បីថែរក្សាអរិយធម៌របស់មនុស្សលោកយ៉ាងណាក៏ដោយ ក៏វាគ្មានបានការអ្វីដែរ ដ្បិតគ្មានការដឹកនាំរបស់ព្រះជាម្ចាស់។ គ្មាននរណាម្នាក់អាចបំពេញដួងចិត្តទទេស្អាតរបស់មនុស្សលោកបានទេ ដ្បិតគ្មាននរណាម្នាក់ អាចធ្វើជាជីវិតរបស់មនុស្សលោកបានឡើយ ហើយគ្មានទ្រឹស្ដីសង្គមណាមួយ អាចរំដោះមនុស្សចេញពីភាពទទេស្អាត ដែលធ្វើឲ្យគេរងទុក្ខវេទនាបានដែរ។ វិទ្យាសាស្ត្រ ចំណេះដឹង សេរីភាព លទ្ធិប្រជាធិបតេយ្យ ការកម្សាន្ត ភាពស្រោកស្រាន្ត កត្តាទាំងអស់នេះ អាចលួងលោមចិត្តមនុស្សបានបណ្ដោះអាសន្នប៉ុណ្ណោះ។ ទោះបីជាមានកត្តាទាំងអស់នេះក្ដី ក៏មនុស្សនៅតែប្រព្រឹត្តបាប និងទួញសោកចំពោះអំពើអយុត្តិធម៌ក្នុងសង្គម ដោយជៀសមិនផុតដែរ។ ចំណុចទាំងអស់នេះ មិនអាចហាមឃាត់ចំណង់ និងសេចក្ដីប្រាថ្នារបស់មនុស្ស ដើម្បីរុករកអ្វីថ្មីៗបានឡើយ។ នេះគឺដោយសារព្រះជាម្ចាស់បង្កើតមនុស្សលោកមក ហើយការលះបង់ និងការរុករកឥតន័យខ្លឹមសាររបស់មនុស្ស អាចត្រឹមនាំទៅរកសេចក្ដីទុក្ខព្រួយកាន់តែខ្លាំងឡើង និងធ្វើឲ្យមនុស្សរស់នៅក្នុងអារម្មណ៍ភ័យខ្លាចឥតឈប់តែប៉ុណ្ណោះ ទាំងមិនដឹងថា ត្រូវប្រឈមមុខចំពោះអនាគតរបស់មនុស្សលោកដោយរបៀបណា ឬ

ត្រូវប្រឈមមុខនឹងផ្លូវនៅខាងមុខនោះដោយបែបណាឡើយ។ មនុស្សកាន់តែមានការកោតខ្លាចចំពោះវិទ្យាសាស្ត្រ និងចំណេះដឹង និងកាន់តែភ័យខ្លាចចំពោះអារម្មណ៍ទទេស្អូន្យ។ នៅក្នុងពិភពលោកនេះ មិនថាអ្នករស់នៅក្នុងប្រទេសសេរី ឬប្រទេសដែលគ្មានសិទ្ធិមនុស្សឡើយ អ្នកគ្មានសមត្ថភាពគេចចេញពីវាសនារបស់មនុស្សលោកបានទេ។ មិនថា អ្នកជាមេដឹកនាំ ឬត្រូវគេដឹកនាំនោះទេ ទីបំផុត អ្នកនៅតែគ្មានសមត្ថភាពគេចពីចំណង់ក្នុងការរុករកវាសនា សេចក្ដីអាថ៌កំបាំង និងទិសដៅរបស់មនុស្សលោកបានឡើយ ហើយអ្នកកាន់តែគ្មានសមត្ថភាពគេចចេញពីគំនិតវិលវល់នៃអារម្មណ៍ទទេស្អូន្យនេះដែរ។ បាតុភូតបែបនេះ កើតមានជាទូទៅចំពោះមនុស្សគ្រប់រូប ហើយត្រូវអ្នកសង្គមវិទ្យាហៅថាបាតុភូតសង្គម ប៉ុន្តែគ្មានមនុស្សអស្ចារ្យណាម្នាក់ ដែលអាចមកដោះស្រាយបញ្ហាបែបនេះបានឡើយ។ ចុងក្រោយទៅ មនុស្សនៅតែជាមនុស្ស ហើយគ្មានមនុស្សណាម្នាក់ ដែលអាចជំនួសឋានៈ និងព្រះជន្មរបស់ព្រះជាម្ចាស់បានឡើយ។ មនុស្សលោកមិនត្រឹមតែត្រូវការសង្គមមួយដែលមានយុត្តិធម៌ ដែលមនុស្សគ្រប់គ្នាមានអាហារគ្រប់គ្រាន់ រស់នៅស្មើភាពគ្នា និងមានសេរីភាពនោះទេ តែអ្វីដែលមនុស្សលោកត្រូវការ គឺសេចក្ដីសង្គ្រោះរបស់ព្រះជាម្ចាស់ និងការប្រទានជីវិតពីទ្រង់ដល់ពួកគេ។ ទាល់តែមនុស្សទទួលបានការប្រទានជីវិតពីព្រះជាម្ចាស់ និងការសង្គ្រោះរបស់ទ្រង់ ពេលនោះទើបសេចក្ដីត្រូវការ ការស្រេកឃ្លានក្នុងការរុករក និងភាពទទេស្អាតនៃវិញ្ញាណរបស់មនុស្ស អាចដោះស្រាយបាន។ ប្រសិនបើប្រជាជននៃប្រទេស ឬជាតិសាសន៍មួយ មិនអាចទទួលបានសេចក្ដីសង្គ្រោះ និងព្រះទ័យទុកដាក់ពីព្រះជាម្ចាស់ទេ ដូច្នេះ ប្រទេស ឬជាតិសាសន៍នោះ នឹងធ្វើដំណើរលើផ្លូវនៃការធ្លាក់ចុះឆ្ពោះទៅរកភាពងងឹត និងត្រូវព្រះជាម្ចាស់ធ្វើឲ្យវិនាសសាបសូន្យ។

ប្រហែលបច្ចុប្បន្ននេះ ប្រទេសរបស់អ្នកកំពុងរីកចម្រើន ប៉ុន្តែប្រសិនបើអ្នកអនុញ្ញាតឲ្យប្រជាជនអ្នកវង្វេងចេញពីព្រះជាម្ចាស់ ដូច្នេះប្រទេសនោះនឹងត្រូវឃ្លាតឆ្ងាយពីព្រះពររបស់ព្រះជាម្ចាស់។ អរិយធម៌នៃប្រទេសរបស់អ្នក នឹងត្រូវគេជាន់ឈ្លីកាន់តែច្រើនឡើង មិនយូរប៉ុន្មាន មនុស្សនឹងក្រោកឡើងទាស់ទទឹងនឹងព្រះជាម្ចាស់

និងដាក់បណ្ដាសាស្ថានសួគ៌ជាមិនខាន។ ដូច្នេះហើយ វាសនានៃប្រទេសនោះនឹងត្រូវវិនាសហិនហោចទាំងមិនឲ្យមនុស្សដឹង។ ព្រះជាម្ចាស់ នឹងលើកប្រទេសដែលមានអំណាចឲ្យខ្ពស់ឡើង ដើម្បីប្រឈមមុខជាមួយប្រទេសនានាដែលព្រះជាម្ចាស់បានដាក់បណ្ដាសា ហើយអាចនឹងកម្ចាត់ប្រទេសទាំងនោះឲ្យអស់ពីផែនដីផង។ ការងើបឡើង និងការធ្លាក់ចុះនៃប្រទេស ឬជាតិសាសន៍មួយ គឺអាស្រ័យត្រង់ថា មេដឹកនាំប្រទេសនោះ ថ្វាយបង្គំព្រះជាម្ចាស់ដែរឬអត់ ហើយពួកគេដឹកនាំប្រជាជនរបស់ពួកគេឲ្យមានភាពស្និទ្ធស្នាលជាមួយព្រះជាម្ចាស់ និងថ្វាយបង្គំទ្រង់ ដែរឬអត់។ ក៏ប៉ុន្ដែ នៅក្នុងសម័យចុងក្រោយនេះ ដោយសារមនុស្សដែលស្វែងរក និងថ្វាយបង្គំព្រះជាម្ចាស់ពិតប្រាកដ កាន់តែកម្រ ទើបព្រះជាម្ចាស់ប្រទានការអនុគ្រោះពិសេស ចំពោះប្រទេសនានាដែលយកគ្រីស្ទសាសនា ជាសាសនារបស់រដ្ឋ។ ទ្រង់ប្រមូលផ្ដុំប្រទេសទាំងនោះបញ្ចូលគ្នា ដើម្បីបង្កើតជាជំរុំសុចរិតបណ្ដោះអាសន្នរបស់ពិភពលោក ចំណែកប្រទេសដែលមិនជឿលើព្រះជាម្ចាស់ និងអស់អ្នកណាដែលមិនថ្វាយបង្គំព្រះជាម្ចាស់ដ៏ពិត នឹងក្លាយជាសត្រូវនៃជំរុំសុចរិតនេះ។ ដោយបែបនេះ ព្រះជាម្ចាស់មិនត្រឹមតែមានកន្លែងមួយនៅក្នុងចំណោមមនុស្សលោក ដើម្បីបំពេញកិច្ចការរបស់ទ្រង់ប៉ុណ្ណោះទេ ប៉ុន្ដែក៏ទទួលបាន នូវបណ្ដាប្រទេសដែលអាចអនុវត្តសិទ្ធិអំណាចសុចរិត ដោយអនុញ្ញាតឲ្យមានការដាក់ទណ្ឌកម្ម និងការដាក់កំហិតលើប្រទេសដែលប្រឆាំងទាស់នឹងទ្រង់។ បើទោះបីជាបែបនេះក្ដី ក៏មានមនុស្សតិចតួចណាស់ ដែលមកថ្វាយបង្គំព្រះជាម្ចាស់ ដ្បិតមនុស្សលោកបានវង្វេងឆ្ងាយខ្លាំងពីទ្រង់ រួចមនុស្សបានបំភ្លេចព្រះជាម្ចាស់ជាយូរមកហើយ។ មានតែប្រទេសដែលអនុវត្តតាមសេចក្ដីសុចរិត និងប្រឆាំងទាស់នឹងសេចក្ដីទុច្ចរិតទេ ទើបនៅមានវត្តមានលើផែនដី។ ប៉ុន្ដែ ការនេះនៅឆ្ងាយពីព្រះទ័យចង់បានរបស់ព្រះជាម្ចាស់ណាស់ ដ្បិតគ្មានមេដឹកនាំប្រទេសណា នឹងអនុញ្ញាតឲ្យព្រះជាម្ចាស់គ្រប់គ្រងលើប្រជាជនរបស់ពួកគេឡើយ និងគ្មានគណបក្សនយោបាយណាមួយ ដែលនឹងប្រមូលផ្ដុំប្រជាជនរបស់ខ្លួន ដើម្បីថ្វាយបង្គំព្រះជាម្ចាស់ឡើយ។ ព្រះជាម្ចាស់ បានបាត់បង់ឋានៈពេញសិទ្ធិរបស់ទ្រង់

នៅក្នុងដួងចិត្តនៃគ្រប់បណ្ដាប្រទេស ជាតិសាសន៍ គណបក្សកាន់អំណាចទាំងអស់ និងសូម្បីតែក្នុងដួងចិត្តនៃមនុស្សគ្រប់រូប។ ថ្វីបើអំណាចដ៏សុចរិត មានពិតនៅក្នុងពិភពលោកនេះ តែប្រភេទអំណាចដ៏ផុយស្រួយ ដែលធ្វើឲ្យព្រះគង់ក្នុងដួងចិត្តរបស់គេមិនបាន គឺនៅតែមាន។ ដោយគ្មានព្រះពរពីព្រះជាម្ចាស់ទេ សង្វៀននយោបាយត្រូវធ្លាក់ក្នុងភាពច្របូកច្របល់ និងប្រែជាមិនអាចទប់ទល់នឹងការវាយប្រហារសូម្បីតែមួយ។ សម្រាប់មនុស្សលោក ការដែលគ្មានព្រះពរពីព្រះជាម្ចាស់ គឺដូចជាការដែលគ្មានព្រះអាទិត្យដូច្នោះដែរ។ មិនថាមេដឹកនាំ រួមចំណែកដល់ប្រជាជនរបស់ពួកគេដោយយកចិត្តទុកដាក់យ៉ាងណា មិនថាមនុស្សមានការជួបជុំប្រកបដោយភាពសុចរិតប៉ុន្មានដងនោះទេ ក៏ក្នុងនោះ គ្មានអ្វីនឹងអាចផ្លាស់ប្ដូរកាលៈទេសៈ ឬផ្លាស់ប្ដូរវាសនារបស់មនុស្សជាតិបានដែរ។ មនុស្សជឿថា ប្រទេសមួយដែលប្រជាជនមានចំណីអាហារ និងសម្លៀកបំពាក់ នៅក្នុងប្រទេសដែលពួកគេអាចរស់នៅរួមគ្នាដោយសុខសាន្ត ហើយមានអ្នកដឹកនាំល្អ គឺជាប្រទេសល្អ។ ប៉ុន្តែ ព្រះជាម្ចាស់ពុំបានគិតដូច្នេះឡើយ។ ទ្រង់ជឿថា ប្រទេសមួយដែលគ្មាននរណាថ្វាយបង្គំទ្រង់ គឺជាប្រទេសដែលទ្រង់ត្រូវធ្វើឲ្យវិនាសហិនហោច។ របៀបគិតគូររបស់មនុស្សលោក គឺខុសគ្នាស្រឡះពីការគិតរបស់ព្រះជាម្ចាស់។ ដូច្នេះ ប្រសិនបើអ្នកដឹកនាំប្រទេសមួយ ពុំថ្វាយបង្គំព្រះជាម្ចាស់ ដូច្នេះ វាសនារបស់ប្រទេសនោះ នឹងត្រូវជួបគ្រោះមហន្តរាយ ហើយប្រទេសនោះនឹងគ្មានទិសដៅច្បាស់លាស់ទេ។

ព្រះជាម្ចាស់ពុំចូលរួមក្នុងរឿងនយោបាយរបស់មនុស្សលោកឡើយ តែវាសនារបស់ប្រទេស ឬជាតិសាសន៍មួយ គឺព្រះជាម្ចាស់ជាអ្នកគ្រប់គ្រង។ ព្រះជាម្ចាស់គ្រប់គ្រងពិភពលោកនេះ និងសាកលលោកទាំងមូល។ វាសនារបស់មនុស្សលោក និងផែនការរបស់ព្រះជាម្ចាស់ មានការជាប់ពាក់ព័ន្ធគ្នាយ៉ាងជិតស្និទ្ធ ហើយគ្មានមនុស្ស គ្មានប្រទេស ឬជាតិសាសន៍ណាមួយត្រូវបានលើកលែងចេញពីអំណាចគ្រប់គ្រងរបស់ព្រះជាម្ចាស់ឡើយ។ ប្រសិនបើមនុស្សចង់ដឹងពីវាសនារបស់ខ្លួន នោះគេត្រូវមកចំពោះព្រះជាម្ចាស់។ ព្រះជាម្ចាស់ ត្រូវធ្វើឲ្យអស់អ្នកណាដែលដើរតាម និងថ្វាយបង្គំទ្រង់ និង

ថ្វាយបង្គំ ទ្រង់បានរីកចម្រើន និងធ្វើឲ្យអស់អ្នកណាដែលប្រឆាំងទាស់ និងបដិសេធទ្រង់ ជួបការអន់ថយ និងវិនាសហិនហោច។

ចូរនឹកចាំពីដំណើររឿងនៅក្នុងព្រះគម្ពីរ កាលដែលព្រះជាម្ចាស់បំផ្លាញក្រុងសូដុម និងគិតអំពីការដែលប្រពន្ធរបស់ឡុត ក្លាយទៅជាបង្គោលអំបិល។ ចូរត្រឡប់ទៅគិតពីការដែលប្រជាជននៃក្រុងនីនីវេប្រែចិត្តចេញពីអំពើបាបរបស់ខ្លួន ដោយស្លៀកសំពត់ធ្មៃរួចអង្គុយក្នុងផេះ ហើយនឹកឃើញដល់រឿងរ៉ាវដែលបានកើតឡើង ក្រោយពេលពួកយូដា ជំភ្ជាប់ព្រះយេស៊ូវទៅនឹងឈើឆ្កាងកាលពី២០០០ឆ្នាំមុន។ ពួកយូដាត្រូវបានបណ្ដេញចេញពីអ៊ីស្រាអែល និងភៀសខ្លួនទៅប្រទេសជាច្រើន នៅជុំវិញពិភពលោក។ មនុស្សជាច្រើនត្រូវបានកាប់សម្លាប់ ហើយជាតិសាសន៍យូដាទាំងមូលត្រូវស្ថិតក្រោមការឈឺចាប់ចំពោះការសាបសូន្យនៃប្រទេសរបស់ខ្លួនដោយឥតព្រៀងទុក។ ពួកគេបានឆ្កាងព្រះជាម្ចាស់នៅលើឈើឆ្កាង គឺបានប្រព្រឹត្តអំពើបាបយ៉ាងសាហាវយង់ឃ្នង និងបានញុះញង់ ឲ្យមានការដាក់ទោសព្រះជាម្ចាស់។ ពួកគេត្រូវបានបង្កើតឡើង ដើម្បីតបស្នងនូវអ្វីដែលពួកគេបានធ្វើ និងត្រូវបានបង្កើតឡើង ដើម្បីទទួលលទ្ធផលនៃការប្រព្រឹត្តរបស់ពួកគេ។ ពួកគេថ្កោលទោសព្រះជាម្ចាស់ បដិសេធព្រះជាម្ចាស់ ហេតុដូច្នេះ វាសនារបស់ពួកគេមានតែមួយគត់ គឺត្រូវព្រះជាម្ចាស់ដាក់ទោស។ នេះជាលទ្ធផលដ៏ជូរចត់ និងជាសោកនាដកម្មដែលមេដឹកនាំរបស់ពួកគេបានបង្កមកលើជាតិសាសន៍ និងប្រទេសរបស់ពួកគេ។

សព្វថ្ងៃនេះព្រះជាម្ចាស់បានយាងត្រឡប់មកលោកិយវិញ ដើម្បីបំពេញកិច្ចការរបស់ទ្រង់។ ទីសំចតដំបូងរបស់ទ្រង់ គឺជាទីគំរូនៃការត្រួតត្រាបែបផ្ដាច់ការ៖ ប្រទេសចិនជាកំពែងការពារ ដ៏រឹងមាំរបស់ពួកមិនជឿលើព្រះជាម្ចាស់។ ព្រះជាម្ចាស់ទទួលយកមនុស្សមួយក្រុមដោយព្រះប្រាជ្ញាញាណ និងព្រះចេស្ដារបស់ទ្រង់។ ក្នុងអំឡុងពេលនេះ ទ្រង់ត្រូវបានគណបក្សកាន់អំណាចរបស់ចិន កំពុងតាមប្រម៉ាញ់ដោយប្រើគ្រប់មធ្យោបាយទាំងអស់ ហើយទ្រង់ត្រូវរងទុក្ខយ៉ាងខ្លាំង និងគ្មានកន្លែងឲ្យទ្រង់ដាក់ព្រះកេសផ្ទំបាន ហើយមិនអាចស្វែងរកទីជម្រកបាន។ ថ្វីបើបែបនេះក្ដី ក៏

ព្រះជាម្ចាស់នៅតែបន្តកិច្ចការ ដែលទ្រង់មានបំណងចង់ធ្វើដដែលៈ ទ្រង់បញ្ចេញព្រះសូរសៀងរបស់ទ្រង់ និងផ្សាយដំណឹងល្អ។ គ្មាននរណាម្នាក់ អាចយល់ពីឫទ្ធានុភាពរបស់ព្រះជាម្ចាស់បានឡើយ។ ព្រះជាម្ចាស់មិនដែលបញ្ឈប់កិច្ចការរបស់ទ្រង់ នៅក្នុងប្រទេសចិន ជាប្រទេសដែលចាត់ទុកព្រះជាម្ចាស់ជាសត្រូវនោះឡើយ។ ផ្ទុយទៅវិញ មនុស្សកាន់តែច្រើនឡើងៗ ទទួលយកកិច្ចការ និងព្រះបន្ទូលរបស់ទ្រង់ ដ្បិតព្រះជាម្ចាស់បំពេញគ្រប់កិច្ចការដែលទ្រង់អាចធ្វើបាន ដើម្បីសង្គ្រោះមនុស្សលោកគ្រប់គ្នា។ យើងជឿថា គ្មានប្រទេស ឬមហាអំណាចណាមួយដែលអាចឈររាំងកិច្ចការដែលព្រះជាម្ចាស់ចង់សម្រេចឲ្យបាននោះឡើយ។ អស់អ្នកដែលរារាំងកិច្ចការរបស់ព្រះជាម្ចាស់ តតាំងនឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយរំខាន និងធ្វើឲ្យខូចផែនការរបស់ព្រះជាម្ចាស់ ចុងក្រោយនឹងត្រូវព្រះជាម្ចាស់ដាក់ទោស។ អ្នកណាដែលប្រឆាំងនឹងកិច្ចការរបស់ព្រះជាម្ចាស់ នឹងត្រូវបញ្ជូនទៅស្ថាននរក។ ប្រទេសណាដែលប្រឆាំងនឹងកិច្ចការរបស់ព្រះជាម្ចាស់ នឹងត្រូវរងនូវការបំផ្លិចបំផ្លាញ។ ជាតិសាសន៍ណាដែលក្រោកឡើងប្រឆាំងទាស់នឹងកិច្ចការរបស់ព្រះជាម្ចាស់ នឹងត្រូវកម្ចាត់ចេញពីផែនដីនេះ និងលែងមានទៀត។ ខ្ញុំអង្វរដល់គ្រប់ជាតិសាសន៍ទាំងអស់ គ្រប់ប្រទេសទាំងអស់ និងគ្រប់ឧស្សាហកម្មទាំងអស់ ឲ្យស្ដាប់តាមព្រះសូរសៀងរបស់ព្រះជាម្ចាស់ ឲ្យសម្លឹងមើលកិច្ចការរបស់ព្រះជាម្ចាស់ និងឲ្យយកចិត្តទុកដាក់លើវាសនារបស់មនុស្សលោក ដើម្បីធ្វើឲ្យព្រះជាម្ចាស់បានបរិសុទ្ធ មានព្រះកិត្តិយសបំផុត ខ្ពង់ខ្ពស់បំផុត និងជាព្រះជាម្ចាស់តែមួយអង្គគត់ដែលមនុស្សថ្វាយបង្គំ និងដើម្បីឲ្យមនុស្សលោកទាំងមូលរស់នៅប្រកបដោយព្រះពររបស់ព្រះជាម្ចាស់ ដូចជាពូជពង្សរបស់អ័ប្រាហាំ ដែលបានរស់នៅក្រោមការសន្យារបស់ព្រះយេហូវ៉ា និងដូចជា អ័ដាម និងអេវ៉ា ជាមនុស្សដែលព្រះជាម្ចាស់បានបង្កើតមកដំបូងគេ និងបានរស់នៅក្នុងសួនច្បារអេដែន។

កិច្ចការរបស់ព្រះជាម្ចាស់បាចសាចទៅមុខ ប្រៀបដូចជាទឹករលកដ៏ធំសម្បើម។ គ្មាននរណាម្នាក់អាចឃាត់ឃាំងទ្រង់បានឡើយ ហើយក៏គ្មាននរណាម្នាក់អាចបញ្ឈប់ដំណើររបស់ទ្រង់បានដែរ។ មានតែអស់អ្នកណាដែលស្ដាប់បន្ទូលរបស់ទ្រង់ដោយ

យកចិត្តទុកដាក់ និងអស់អ្នកដែលស្វែងរក ហើយស្រេកឃ្លានចង់បានទ្រង់ប៉ុណ្ណោះ ទើបអាចដើរតាមស្នាមព្រះបាទារបស់ទ្រង់ និងទទួលសេចក្ដីសន្យារបស់ទ្រង់បាន។ អ្នកដែលមិនស្ដាប់តាមទ្រង់ នឹងត្រូវជួបគ្រោះមហន្តរាយយ៉ាងច្រើនសន្ធឹក និងត្រូវទទួលទោសដែលស័ក្តិសមបំផុត។

## ការស្គាល់ព្រះជាម្ចាស់ គឺជាផ្លូវឆ្ពោះទៅរក ការកោតខ្លាចព្រះជាម្ចាស់ និងការគេចចេញពីសេចក្ដីអាក្រក់

អ្នករាល់គ្នាម្នាក់ៗ គួរពិនិត្យពិច័យម្ដងទៀតអំពីរបៀបដែលអ្នករាល់គ្នាជឿលើព្រះជាម្ចាស់ក្នុងជីវិតរបស់អ្នកពីដើមមក ដើម្បីឲ្យអ្នករាល់គ្នាអាចមើលឃើញថា អ្នកពិតជាបានយល់ដឹង ពិតជាបានយល់ច្បាស់ និងពិតជាចាប់ផ្ដើមស្គាល់ព្រះជាម្ចាស់មែន ឬមិនមែននៅក្នុងដំណើរការដើរតាមព្រះជាម្ចាស់ មើលឃើញថា អ្នកពិតជាស្គាល់អាកប្បកិរិយាអ្វីខ្លះដែលព្រះជាម្ចាស់ដាក់ក្នុងជំពូកមនុស្សខុសៗគ្នាមែន ឬមិនមែនមើលឃើញថា អ្នកពិតជាយល់ពីកិច្ចការដែលព្រះជាម្ចាស់កំពុងធ្វើលើអ្នក ហើយពិតជាយល់អំពីវិធី ដែលព្រះជាម្ចាស់កំណត់គ្រប់ទង្វើរបស់អ្នកមែន ឬមិនមែន។ ព្រះជាម្ចាស់អង្គនេះ ជាព្រះដែលគង់នៅក្បែរអ្នក កំពុងតែដឹកនាំទិសដៅនៃការវិវឌ្ឍន៍របស់អ្នក កំពុងគ្រប់គ្រងវាសនារបស់អ្នក ហើយកំពុងផ្គត់ផ្គង់សេចក្ដីត្រូវការរបស់អ្នក តើអ្នកយល់ពីព្រះជាម្ចាស់អង្គនេះកម្រិតណា នៅពេលដែលគ្រប់យ៉ាងត្រូវបាននិយាយរួច ហើយត្រូវបានធ្វើរួច។ តើអ្នកពិតជាស្គាល់ព្រះជាម្ចាស់អង្គនេះកម្រិតណា? តើអ្នកស្គាល់កិច្ចការដែលទ្រង់ប្រគល់ឲ្យអ្នករៀងរាល់ថ្ងៃនេះទេ? តើអ្នកស្គាល់គោលការណ៍ និងគោលបំណងនានាដែលទ្រង់ប្រើជាគ្រឹះនៃគ្រប់សកម្មភាពរបស់ទ្រង់ទេ? តើអ្នកដឹងពីរបៀបដែលទ្រង់ដឹកនាំអ្នកទេ? តើអ្នកដឹងពីមធ្យោបាយដែលទ្រង់ផ្គត់ផ្គង់សម្រាប់អ្នកទេ? តើអ្នកស្គាល់ទ្រឹស្ដីដែលទ្រង់ដឹកនាំអ្នកទេ? តើអ្នកស្គាល់អ្វីដែលទ្រង់ចង់ទទួល

បានពីអ្នក និងដឹងពីអ្វីដែលទ្រង់ចង់សម្រេចនៅក្នុងអ្នកទេ? តើអ្នកស្គាល់ឥរិយាបថដែលព្រះជាម្ចាស់ប្រកាន់ខ្ជាប់ចំពោះរបៀបនានាដែលអ្នកបញ្ចេញកិរិយាទេ? តើអ្នកដឹងថា អ្នកជាមនុស្សម្នាក់ដែលទ្រង់សព្វព្រះទ័យមែន ឬមិនមែន? តើអ្នកដឹងអំពីប្រភពដើមនៃសេចក្ដីអំណរ ព្រះពិរោធ ទុក្ខសោក និងព្រះហឫទ័យដ៏រីករាយរបស់ទ្រង់ រួមទាំងព្រះតម្រិះ និងយោបល់ដែលនៅពីក្រោយលក្ខណៈទាំងអស់នេះ ព្រមទាំងឥរិយាបទពិតរបស់ទ្រង់ដែរឬទេ? ចុងក្រោយ តើអ្នកដឹងទេថា ព្រះជាម្ចាស់ដែលអ្នកជឿអង្គនេះជាព្រះជាម្ចាស់ប្រភេទណា? តើសំណួរទាំងនេះ និងសំណួរផ្សេងទៀត សុទ្ធតែជាសំណួរដែលអ្នកមិនធ្លាប់យល់ ឬមិនធ្លាប់គិតដល់មែនទេ? ក្នុងការព្យាយាមឲ្យបាននៅក្នុងជំនឿរបស់អ្នកលើព្រះជាម្ចាស់ តើអ្នកបានកម្ចាត់ការយល់ខុស របស់អ្នកចំពោះទ្រង់ តាមរយៈការថ្លែងអំណរគុណពិតប្រាកដ និងតាមរយៈបទពិសោធនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែរ ឬទេ? បន្ទាប់ពីទទួលការដាក់វិន័យ និងការវាយផ្ចាលពីព្រះជាម្ចាស់ តើអ្នកទទួលបានការស្ដាប់បង្គាប់ និងការមើលថែដ៏ពិតហើយឬនៅ? ក្នុងគ្រាដែលកំពុងទទួលការវាយផ្ចាល និងការជំនុំជម្រះរបស់ព្រះជាម្ចាស់ តើអ្នកបានចាប់ផ្ដើមស្គាល់ ចរិតបះបោរ និងធម្មជាតិជាសាតាំងរបស់មនុស្ស និងទទួលបានការយល់ដឹងបន្តិចបន្តួចអំពីភាពបរិសុទ្ធរបស់ព្រះជាម្ចាស់ហើយ ឬនៅ? ក្រោមការដឹកនាំ និងការបំភ្លឺនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ តើអ្នកបានចាប់ផ្ដើមមានទស្សនៈថ្មីចំពោះជីវិតហើយឬនៅ? ក្នុងគ្រាកំពុងត្រូវឆ្លងកាត់នូវការល្បងលដែលព្រះជាម្ចាស់ចាត់ឲ្យមក តើអ្នកបានស្គាល់ពីការមិនលើលែងរបស់ទ្រង់ ចំពោះសេចក្ដីល្មើសរបស់មនុស្ស ក៏ដូចជាអ្វីដែលទ្រង់តម្រូវពីអ្នក និងរបៀបដែលទ្រង់កំពុងសង្គ្រោះអ្នកហើយឬនៅ? ប្រសិនបើអ្នកមិនដឹងថា ការយល់ខុសចំពោះព្រះជាម្ចាស់គឺជាអ្វី ឬមិនដឹងពីរបៀបបំបាត់ការយល់ខុសនេះ នោះគេអាចនិយាយបានថា អ្នកមិនធ្លាប់មានទំនាក់ទំនងពិតជាមួយនឹងព្រះជាម្ចាស់ និងមិនធ្លាប់យល់ពីព្រះជាម្ចាស់ ឬយ៉ាងហោចណាស់ក៏គេអាចនិយាយបានថា អ្នកមិនដែលប្រាថ្នាចង់យល់អំពីព្រះអង្គឡើយ។ ប្រសិនអ្នកមិនដឹងថា អ្វីទៅជាការដាក់វិន័យ និងការវាយផ្ចាលរបស់ព្រះជាម្ចាស់ នោះអ្នក

ប្រាកដជាមិនស្គាល់អ្វីទៅជាការស្ដាប់បង្គាប់ ឬយ៉ាងហោចណាស់ក៏អ្នកមិនធ្លាប់ស្ដាប់បង្គាប់ ឬខ្វល់ខ្វាយនឹងព្រះជាម្ចាស់ពិតប្រាកដឡើយ។ ប្រសិនបើអ្នកមិនធ្លាប់ឆ្លងកាត់ការវាយផ្ចាល និងការជំនុំជម្រះរបស់ព្រះជាម្ចាស់ នោះអ្នកច្បាស់ជាមិនស្គាល់អ្វីទៅជាភាពបរិសុទ្ធរបស់ទ្រង់ ហើយអ្នកក៏រឹតតែមិនច្បាស់ពីអ្វីដែលជាការបះបោររបស់មនុស្សឡើយ។ ប្រសិនបើអ្នកមិនធ្លាប់មានទស្សនៈត្រឹមត្រូវចំពោះជីវិតដ៏ពិតប្រាកដ ឬគោលបំណងត្រឹមត្រូវមួយក្នុងជីវិត ប៉ុន្តែអ្នកនៅតែមានសភាពយល់ច្រឡំ និងអល់អែកចំពោះផ្លូវអនាគតរបស់អ្នកក្នុងជីវិតដល់ថ្នាក់រារែកក្នុងការបន្តដំណើរទៅមុខ គឺច្បាស់ណាស់ថា អ្នកមិនធ្លាប់បានទទួលការបំភ្លឺ និងការដឹកនាំរបស់ព្រះជាម្ចាស់ឡើយ។ ក៏គ្មាននរណាអាចនិយាយបានថា អ្នកមិនធ្លាប់ត្រូវបានផ្គត់ផ្គង់ ឬត្រូវបានបំពេញដោយព្រះបន្ទូលរបស់ព្រះជាម្ចាស់ឡើយ។ ប្រសិនបើអ្នកមិនទាន់បានឆ្លងកាត់ការល្បងលរបស់ព្រះជាម្ចាស់ទេ មិនចាំបាច់និយាយក៏ដឹងដែរថា អ្នកច្បាស់ជាមិនស្គាល់ការមិនលើកលែងរបស់ព្រះជាម្ចាស់ចំពោះសេចក្ដីល្មើសរបស់មនុស្សឡើយ ហើយអ្នកក៏មុខជាមិនយល់អ្វីដែលព្រះជាម្ចាស់តម្រូវពីអ្នកជាចុងក្រោយដែរ ហើយនៅទីបំផុត អ្នករឹតតែមិនយល់ថា អ្វីទៅជាកិច្ចការគ្រប់គ្រង និងកិច្ចការសង្គ្រោះមនុស្សរបស់ទ្រង់ឡើយ។ មិនថាបុគ្គលម្នាក់បានជឿលើព្រះជាម្ចាស់ប៉ុន្មានឆ្នាំហើយក៏ដោយ ប្រសិនបើពួកគេមិនធ្លាប់បានស្គាល់ ឬមិនដឹងអ្វីសោះអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ នោះពួកគេក៏ច្បាស់ជាមិនមែនកំពុងដើរតាមផ្លូវ ឆ្ពោះទៅរកសេចក្ដីសង្គ្រោះឡើយ សេចក្ដីជំនឿរបស់គេចំពោះព្រះជាម្ចាស់ ក៏ប្រាកដជាគ្មានសារជាតិជាក់ស្ដែង ចំណេះដឹងរបស់គេអំពីព្រះជាម្ចាស់ក៏ច្បាស់គ្មានដែរ ហើយមិនចាំបាច់និយាយក៏ដឹងដែរថា ពួកគេមិនដឹងសោះថា អ្វីទៅគឺជាការគោរពកោតខ្លាចព្រះជាម្ចាស់។

កម្មសិទ្ធិ និងភាវៈរបស់ព្រះជាម្ចាស់ សារជាតិរបស់ព្រះជាម្ចាស់ និស្ស័យរបស់ព្រះជាម្ចាស់ គឺសុទ្ធតែត្រូវបានបើកសម្ដែង ឲ្យមនុស្សស្គាល់តាមរយៈព្រះបន្ទូលរបស់ទ្រង់។ កាលណាមនុស្សស្គាល់ព្រះបន្ទូលរបស់ទ្រង់ គេនឹងចាប់ផ្ដើមយល់ពីគោលបំណងដែលនៅពីក្រោយព្រះបន្ទូល ដែលព្រះជាម្ចាស់ថ្លែង និងយល់ពីប្រភព

ព្រមទាំងសាវតារនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ រួចយល់ និងអរគុណដល់ឥទ្ធិពលដែលបានគ្រោងទុកនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅក្នុងដំណើរការនៃការយកព្រះបន្ទូលទាំងនេះទៅអនុវត្ត។ សម្រាប់មនុស្សទាំងអស់នេះ ជាសេចក្ដីគ្រប់យ៉ាងដែលមនុស្សត្រូវតែឆ្លងកាត់ ត្រូវតែយល់ និងត្រូវតែទទួលឲ្យបាន ដើម្បីទទួលបានសេចក្ដីពិត និងជីវិត យល់ពីបំណងរបស់ព្រះជាម្ចាស់ បានបំផ្លាស់បំប្រែនិស្ស័យរបស់ខ្លួន ហើយអាចស្ដាប់ បង្គាប់អធិបតេយ្យភាព និងការចាត់ចែងរបស់ព្រះជាម្ចាស់។ ក្នុងពេលជាមួយគ្នា មនុស្សដែលឆ្លងកាត់ យល់ដឹង ហើយទទួលបានសេចក្ដីទាំងនេះ នោះគេនឹងទទួលបានការយល់ដឹងអំពីព្រះជាម្ចាស់បន្តិចម្ដងៗ ហើយនៅពេលនេះ គេក៏នឹងបានទទួលកម្រិតខុសគ្នានៃចំណេះដឹងអំពីព្រះអង្គដែរ។ ការយល់ដឹង និងចំណេះដឹងនេះ មិនមែនកើតចេញមកពីអ្វីម្យ៉ាងដែលមនុស្សធ្លាប់ស្រមៃ ឬប្រឌិតឡើងទេ ប៉ុន្តែកើតចេញពីអ្វីដែលគេឲ្យតម្លៃ គេឆ្លងកាត់ គេដឹង និងបញ្ជាក់ក្នុងខ្លួនគេផ្ទាល់។ លុះត្រាតែគេឲ្យតម្លៃ ស្គាល់ ដឹង និងបញ្ជាក់ពីសេចក្ដីទាំងនេះ ទើបចំណេះដឹងរបស់មនុស្សចំពោះព្រះជាម្ចាស់ទទួលបាននូវខ្លឹមសារ។ មានតែចំណេះដឹងដែលមនុស្សម្នាក់នោះទទួលបាននៅពេលនេះប៉ុណ្ណោះ ទើបជាចំណេះដឹងជាក់ស្ដែង ពិតប្រាកដ និងត្រឹមត្រូវ ហើយដំណើរការនៃការទទួលបានការយល់ដឹង និងចំណេះដឹងពិតប្រាកដអំពីព្រះជាម្ចាស់តាមរយៈការឲ្យតម្លៃ ការឆ្លងកាត់ ការដឹង និងការបញ្ជាក់ពីព្រះបន្ទូលរបស់ទ្រង់នេះ មិនមែនជាអ្វីផ្សេងក្រៅពីការប្រាស្រ័យគ្នាពិតប្រាកដរវាងមនុស្សនិងព្រះជាម្ចាស់នោះឡើយ។ ក្នុងទំនាក់ទំនងបែបនេះ មនុស្សគឺពិតជាដឹង និងចាប់ផ្ដើមយល់ពីចេតនារបស់ព្រះជាម្ចាស់ ពិតជាចាប់ផ្ដើមយល់ និងស្គាល់ពីកម្មសិទ្ធិ និងភាវៈរបស់ព្រះជាម្ចាស់ ពិតជាចាប់ផ្ដើមយល់ និងស្គាល់ពីសារជាតិរបស់ព្រះជាម្ចាស់ ចាប់ផ្ដើមយល់ និងស្គាល់អំពីនិស្ស័យរបស់ព្រះជាម្ចាស់យ៉ាងពិតប្រាកដ ឈានដល់ការជឿជាក់យ៉ាងពិតប្រាកដព្រមទាំងនិយមន័យដ៏ត្រឹមត្រូវអំពីការពិតនៃអំណាចគ្រប់គ្រងរបស់ព្រះជាម្ចាស់លើសត្តនិករទាំងអស់ និងទទួលបានការអត់ធ្មត់ដ៏សំខាន់ និងចំណេះដឹងពីអត្តសញ្ញាណ និងឋានៈរបស់ព្រះជាម្ចាស់។ នៅក្នុងទំនាក់ទំនងប្រភេទនេះ មនុស្សផ្លាស់ប្ដូរគំនិតរបស់គេ

ចំពោះព្រះជាម្ចាស់ លែងស្រមៃពីទ្រង់ដោយពុំមានអ្វីសោះ ឬសង្ស័យចំពោះព្រះអង្គតាមទំនើងចិត្ត ឬយល់ខុសចំពោះទ្រង់ ឬថ្កោលទោសទ្រង់ ឬទិតៀនទ្រង់ ឬសង្ស័យទ្រង់បន្តិចម្ដងៗទៀតហើយ។ ដូច្នេះ មនុស្សនឹងមានការជំទាស់ជាមួយព្រះជាម្ចាស់រឹតតែតិចទៅៗ គេនឹងមានជម្លោះជាមួយនឹងព្រះជាម្ចាស់រឹតតែតិច ហើយឱកាសដែលមនុស្សបះបោរទាស់នឹងព្រះជាម្ចាស់ ក៏មានរឹតតែតិចទៅដែរ។ ផ្ទុយទៅវិញ ការយកចិត្តទុកដាក់របស់មនុស្ស និងការស្ដាប់បង្គាប់របស់គេចំពោះព្រះជាម្ចាស់ នឹងកើនឡើងកាន់តែខ្លាំង ហើយការកោតខ្លាចរបស់គេចំពោះព្រះជាម្ចាស់ ក៏កាន់តែពិតប្រាកដហើយជ្រាលជ្រៅដែរ។ នៅក្នុងការប្រាស្រ័យបែបនេះ មនុស្សនឹងទទួលបានត្រឹមតែការផ្ដល់ជូននូវសេចក្ដីពិត និងពិធីបុណ្យជ្រមុជនៃជីវិតប៉ុណ្ណោះ ប៉ុន្តែក្នុងពេលជាមួយគ្នា គេក៏នឹងទទួលបាននូវចំណេះដឹងពិតប្រាកដអំពីព្រះជាម្ចាស់ដែរ។ នៅក្នុងទំនាក់ទំនងបែបនេះ មនុស្សនឹងមិនត្រឹមតែបានបំផ្លាស់បំប្រែនិស្ស័យរបស់គេ ហើយទទួលបានសេចក្ដីសង្គ្រោះនោះទេ តែក្នុងពេលជាមួយគ្នា គេក៏ទទួលបាននូវការគោរពកោតខ្លាច និងការថ្វាយបង្គំដ៏ពិតប្រាកដដែលមនុស្សមានចំពោះព្រះជាម្ចាស់ដែរ។ ដោយសារការមានទំនាក់ទំនងបែបនេះ សេចក្ដីជំនឿដែលមនុស្សមានចំពោះព្រះជាម្ចាស់នឹងលែងជាក្រដាសទទេ ឬជាសេចក្ដីសន្យាដែលផ្ដល់ជូនត្រឹមបបូរមាត់ ឬជាទម្រង់នៃការព្យាយាមឲ្យបាន និងការគោរពស្រឡាញ់ទាំងងងឹតងងល់ទៀតហើយ។ មានតែទំនាក់ទំនងបែបនេះទេ ទើបជីវិតរបស់មនុស្សលូតលាស់ទៅរកភាពចាស់ទុំពីមួយថ្ងៃទៅមួយថ្ងៃ ហើយមានតែពេលនេះទេ ទើបនិស្ស័យរបស់គេនឹងត្រូវបំផ្លាស់បំប្រែបន្តិចម្ដងៗ ហើយសេចក្ដីជំនឿរបស់គេលើព្រះជាម្ចាស់ នឹងប្ដូរពីសេចក្ដីជំនឿដ៏ស្រពេចស្រពិល និងមិនច្បាស់លាស់ ទៅជាការស្ដាប់បង្គាប់ និងការយកចិត្តទុកដាក់ពិតប្រាកដ ទៅជាការគោរពកោតខ្លាចដ៏ពិតបន្តិចម្ដងៗ ហើយមនុស្សក៏នឹងវិវឌ្ឍពីជំហារអសកម្មទៅជាជំហារសកម្ម ពីជំហារអវិជ្ជមានទៅជាជំហារវិជ្ជមានសន្សឹមៗនៅក្នុងដំណើរការនៃការដើរតាមព្រះជាម្ចាស់។ គឺមានតែទំនាក់ទំនងបែបនេះទេ ទើបមនុស្សឈានដល់ការស្គាល់ និងការយល់ពីព្រះជាម្ចាស់ពិតប្រាកដ ជាចំណេះដឹងពិតប្រាកដ

អំពីព្រះជាម្ចាស់។ ដោយសារមនុស្សភាគច្រើនមិនធ្លាប់មានទំនាក់ទំនងពិតប្រាកដជាមួយព្រះជាម្ចាស់ ចំណេះដឹងរបស់គេអំពីព្រះជាម្ចាស់ ឈប់ទ្រឹង ត្រឹមកម្រិតទ្រឹស្តី គឺត្រឹមកម្រិតន័យពាក្យ និងគោលលទ្ធិ។ មានន័យថា មនុស្សមួយចំនួនធំ ទោះបីជាពួកគេជឿលើព្រះជាម្ចាស់ច្រើនឆ្នាំយ៉ាងណា ឲ្យតែនិយាយដល់ការស្គាល់ព្រះជាម្ចាស់ គឺនៅតែដដែលដូចពេលដែលគេចាប់ផ្តើម គឺនៅទ្រឹងក្នុងមូលដ្ឋាននៃការគោរពបែបប្រពៃណី ដោយប្រើអបិយជំនឿពីបុរាណ និងស្លាកស្នាមអណ្តែតអណ្តូង ដែលគេធ្លាប់មានពីមុនមក។ ចំណេះដឹងអំពីព្រះជាម្ចាស់របស់មនុស្សម្នាក់នោះ គួរតែនៅទ្រឹងត្រឹមចំណុចចាប់ផ្តើមរបស់វា មានន័យថា តាមជាក់ស្តែង ចំណេះដឹងនេះគឺគ្មានវត្តមានទេ។ ក្រៅពីការបញ្ជាក់របស់មនុស្សអំពីនិស្ស័យ និងអត្តសញ្ញាណរបស់ព្រះជាម្ចាស់ សេចក្តីជំនឿរបស់មនុស្សចំពោះព្រះជាម្ចាស់ គឺនៅតែស្ថិតក្នុងភាពមិនប្រាកដប្រជាដ៏ស្រពេចស្រពិលដដែលដែរ។ ជាលទ្ធផល តើមនុស្សអាចប្រកាន់ខ្ជាប់ចំពោះការគោរពកោតខ្លាចដ៏ពិតប្រាកដចំពោះព្រះជាម្ចាស់បានប៉ុនណា?

ទោះបីជាអ្នកជឿ ទៅលើអត្ថិភាពរបស់ព្រះជាម្ចាស់ខ្ជាប់ខ្ជួនយ៉ាងណា ក៏ជំនឿនេះមិនអាចជំនួសចំណេះដឹងរបស់អ្នកអំពីព្រះជាម្ចាស់បានឡើយ ក៏មិនអាចជំនួសការគោរព ការកោតខ្លាចរបស់អ្នកចំពោះព្រះជាម្ចាស់ដែរ។ ទោះបីជាអ្នកបានរីករាយនឹងអំណរ និងព្រះគុណរបស់ទ្រង់ប៉ុនណាក៏ដោយ ក៏ការ រីករាយនេះមិនអាចជំនួសចំណេះដឹងរបស់អ្នកអំពីព្រះជាម្ចាស់បានឡើយ។ ទោះបីជាអ្នកព្រមបូជាគ្រប់យ៉ាងដែលអ្នកមាន និងលះបង់គ្រប់យ៉ាង ដែលអ្នកមានដោយយល់ដល់ព្រះនាមទ្រង់ក៏ដោយ ការនេះក៏មិនអាចជំនួសចំណេះដឹងរបស់អ្នក អំពីព្រះជាម្ចាស់បានដែរ។ ប្រហែលជាអ្នកកាន់តែស្គាល់ព្រះបន្ទូលដែលព្រះជាម្ចាស់បានថ្លែង ឬអ្នកថែមទាំងចងចាំព្រះបន្ទូលទាំងនោះក្នុងចិត្ត ហើយអាចសូត្រយ៉ាងចាំមាត់ទៀតផង ប៉ុន្តែការនេះមិនអាចជំនួសចំណេះដឹងរបស់អ្នក អំពីព្រះជាម្ចាស់បានឡើយ។ ទោះបីជាមនុស្សអាចនឹងកំពុងដើរតាមព្រះជាម្ចាស់ដោយចេតនាបែបណាក៏ដោយ ប្រសិនបើគេមិនដែលធ្លាប់មានទំនាក់ទំនងពិតជាមួយព្រះជាម្ចាស់ ឬមិនធ្លាប់មានបទពិសោធ

ពិតអំពីព្រះបន្ទូលព្រះជាម្ចាស់ នោះចំណេះដឹងគេអំពីព្រះជាម្ចាស់ គឺទទេស្អាត ឬគំនិតរវើរវាយដែលគ្មានទីបញ្ចប់ ដ្បិតអ្វីគ្រប់យ៉ាងដែលអ្នកប្រហែលជាមាន បានទង្គិចស្មាជាមួយព្រះជាម្ចាស់ ក្នុងការឆ្លងកាត់គ្នា ឬជួបជាមួយទ្រង់មុខនិងមុខ ចំណេះដឹងរបស់អ្នកចំពោះព្រះជាម្ចាស់នឹងនៅតែសូន្យទទេ ហើយការគោរពកោតខ្លាចរបស់អ្នកចំពោះព្រះជាម្ចាស់ក៏គ្មានអ្វីលើសពីពាក្យសម្ដីដែលធ្វើឲ្យគេចាប់អារម្មណ៍ ឬជាទស្សនៈដែលត្រូវតាមឧត្ដមគតិប៉ុណ្ណោះ។

មនុស្សជាច្រើនកាន់ខ្ជាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ដើម្បីអានរៀងរាល់ថ្ងៃ រហូតដល់ថ្នាក់តាំងចិត្តទន្ទេញបទគម្ពីរក្នុងព្រះបន្ទូលបុរាណទាំងនោះយ៉ាងយកចិត្តទុកដាក់ ដូចជាសម្បត្តិដ៏មានតម្លៃបំផុតរបស់គេ ហើយជាងនេះទៅទៀត គេក៏ផ្សាយព្រះបន្ទូលទៅគ្រប់ទីកន្លែងទាំងផ្គត់ផ្គង់ និងជួយដល់អ្នកដទៃ ដោយព្រះបន្ទូលរបស់ព្រះជាម្ចាស់ទៀតផង។ ពួកគេគិតថា ការធ្វើបែបនេះ គឺដើម្បីធ្វើបន្ទាល់ពីព្រះជាម្ចាស់ ធ្វើបន្ទាល់ពីព្រះបន្ទូលរបស់ទ្រង់ គិតថាការធ្វើបែបនេះ គឺជាការដើរតាមផ្លូវរបស់ព្រះជាម្ចាស់ ពួកគេគិតថា ការធ្វើបែបនេះ គឺជាការរស់នៅតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ គិតថាការធ្វើបែបនេះ គឺជាការនាំយកព្រះបន្ទូលរបស់ទ្រង់មកដាក់ក្នុងជីវិតរស់នៅផ្ទាល់របស់គេ គិតថាការធ្វើបែបនេះនឹងអាចឲ្យគេទទួលបានការសរសើរពីព្រះជាម្ចាស់ ហើយដើម្បីឲ្យបានសង្គ្រោះ និងបានប្រោសឲ្យគ្រប់លក្ខណ៍។ ប៉ុន្តែសូម្បីតែពេលដែលពួកគេផ្សាយព្រះបន្ទូលព្រះជាម្ចាស់ ក៏ពួកគេមិនធ្លាប់ប្រព្រឹត្តតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅក្នុងការអនុវត្ត ឬព្យាយាមប្រៀបធៀបខ្លួនឯងទៅនឹងអ្វីដែលត្រូវបានបើកសម្ដែងនៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែរ។ ផ្ទុយទៅវិញ ពួកគេប្រើព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីទទួលបាននូវការស្រឡាញ់ និងការទុកចិត្តអ្នកដទៃដោយប្រើល្បិច ដើម្បីចូលទៅក្នុងការគ្រប់គ្រងរបស់ពួកគេផ្ទាល់ និងដើម្បីបន្លំនិងលួចយកសិរីល្អរបស់ព្រះជាម្ចាស់។ ពួកគេសង្ឃឹមកេងយកឱកាសដែលបានមកពីការផ្សាយព្រះបន្ទូលទាំងមិនបានការ ដើម្បីឲ្យបានកិច្ចការរបស់ព្រះជាម្ចាស់ និងការសរសើររបស់ទ្រង់ជារង្វាន់។ ប៉ុន្មានឆ្នាំបានកន្លងផុតទៅហើយ ប៉ុន្តែមនុស្សទាំងនេះ

មិនត្រឹមតែមិនអាចទទួលបានការសរសើររបស់ព្រះជាម្ចាស់នៅក្នុងដំណើរការនៃការផ្សាយព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយពួកគេក៏មិនត្រឹមតែមិនអាចស្វែងរកផ្លូវដែលពួកគេគួរដើរតាមនៅក្នុងដំណើរការនៃការធ្វើបន្ទាល់ពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយពួកគេមិនត្រឹមតែមិនបានជួយ ឬផ្គត់ផ្គង់សម្រាប់ខ្លួនឯងនៅក្នុងដំណើរការនៃការជួយ និងការផ្គត់ផ្គង់អ្នកដទៃដោយព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយពួកគេមិនត្រឹមតែមិនអាចស្គាល់ព្រះជាម្ចាស់ ឬដាស់ខ្លួនឯងឲ្យមានការគោរពកោតខ្លាចពិតប្រាកដចំពោះព្រះជាម្ចាស់នៅក្នុងដំណើរការនៃការធ្វើកិច្ចការទាំងអស់នេះប៉ុណ្ណោះទេ ប៉ុន្តែផ្ទុយទៅវិញ ការយល់ខុសរបស់គេចំពោះព្រះជាម្ចាស់ គឺកាន់តែជ្រៅទៅៗ ការសង្ស័យរបស់គេក៏កាន់តែធ្ងន់ធ្ងរទៅៗ ហើយគំនិតរវើរវាយរបស់គេចំពោះទ្រង់ ក៏កាន់តែខុសឆ្ងាយពីការពិតទៅទៀតផង។ ដោយត្រូវបានផ្គត់ផ្គង់ ហើយដឹកនាំដោយទ្រឹស្ដីរបស់គេចំពោះព្រះបន្ទូលរបស់ព្រះជាម្ចាស់ ពួកគេហាក់ដូចជាកំពុងប្រើជំនាញរបស់គេយ៉ាងងាយស្រួលដោយមិនបាច់ប្រឹង ពួកគេហាក់ដូចជាបានរកឃើញគោលបំណងរបស់គេក្នុងជីវិតបេសកកម្មរបស់គេ ហើយពួកគេក៏ហាក់ដូចជារកបានជីវិតថ្មី និងហាក់ដូចជាបានសង្គ្រោះដោយមានព្រះបន្ទូលរបស់ព្រះជាម្ចាស់ហូរចេញមកម៉ាត់ៗ តាមការរ៉ាយរ៉ាប់ដោយអណ្ដាតរបស់គេដែរ ពួកគេបានទទួលនូវសេចក្ដីពិត និង បានយល់ពីចេតនារបស់ព្រះជាម្ចាស់ ហើយហាក់ដូចជាបានរកឃើញផ្លូវឆ្ពោះទៅរកការស្គាល់ព្រះជាម្ចាស់ នៅក្នុងដំណើរការនៃការផ្សាយព្រះបន្ទូលរបស់ព្រះជាម្ចាស់ ពួកគេច្រើនតែមករកព្រះជាម្ចាស់ ដោយមុខទល់នឹងមុខ។ ពួកគេក៏ឧស្សាហ៍ត្រូវបាន «បណ្ដាលចិត្ត» ឲ្យដាក់វេនគ្នាយំ និងរមែងត្រូវបាននាំដោយ «ព្រះជាម្ចាស់» នៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ពួកគេក៏ហាក់ដូចជាកំពុងយល់ពីក្ដីកង្វល់ដ៏ស្មោះត្រង់ និងចេតនាដ៏សប្បុរសរបស់ទ្រង់ឥតឈប់ឈរដែរ ហើយក្នុងពេលជាមួយគ្នា គេហាក់ដូចជាបានយល់ពីសេចក្ដីសង្គ្រោះរបស់ព្រះជាម្ចាស់ សម្រាប់មនុស្សជាតិ និងការគ្រប់គ្រងរបស់ទ្រង់ ហាក់ដូចជាចាប់ផ្ដើមស្គាល់ពីសារជាតិរបស់ទ្រង់ និងហាក់ដូចជាបានយល់ពីនិស្ស័យសុចរិតរបស់ទ្រង់ដែរ។ ផ្អែកលើមូលដ្ឋាន

គ្រឹះនេះ ពួកគេហាក់ដូចជាជឿលើអត្ថិភាពរបស់ព្រះជាម្ចាស់ កាន់តែខ្លាំងជាងមុន កាន់តែដឹងអំពីសភាពរុងរឿងរបស់ទ្រង់ជាងមុន ព្រមទាំងដឹងអំពីភាពមហស្ចារ្យ និងឧត្តមភាពរបស់ទ្រង់ កាន់តែស៊ីជម្រៅ។ ដោយបានផុងជ្រៅក្នុងចំណេះដឹងលំៗរបស់គេអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ សេចក្ដីជំនឿរបស់គេ ហាក់ដូចជាបានចម្រើនឡើង ការតាំងចិត្តរបស់គេក្នុងការទ្រាំទ្រនឹងទុក្ខលំបាក ក៏កាន់តែរឹងមាំ ហើយចំណេះ ដឹងរបស់គេអំពីព្រះជាម្ចាស់ ក៏កាន់តែជ្រាលជ្រៅដែរ។ ពួកគេសឹងតែមិនដឹងសោះថា ចំណេះដឹងគ្រប់យ៉ាងរបស់គេអំពីព្រះជាម្ចាស់ និងគំនិតរបស់គេអំពីព្រះអង្គ គឺសុទ្ធតែកើតពីគំនិតរវើរវាយ និងការគិតស្មានរបស់គេផ្ទាល់តាមចិត្តដែលគេប្រាថ្នា។ សេចក្ដីជំនឿរបស់គេមុខជាមិនបានបង្ហាញថាបានឆ្លងកាត់នូវការល្បងលណាមួយពីព្រះជាម្ចាស់ ជីវិតខាងព្រលឹងវិញ្ញាណ និងឋានៈដែលគេអួតនោះ មុខជាមិនបង្ហាញថាបានឆ្លងកាត់នូវការល្បងល ឬការពិនិត្យពិច័យរបស់ព្រះជាម្ចាស់ឡើយ ហើយការតាំងចិត្តរបស់គេ គ្រាន់តែជាប្រាសាទដែលធ្វើពីដីខ្សាច់ ហើយចំណេះដឹងរបស់គេអំពីព្រះជាម្ចាស់ ក៏គ្រាន់តែជាការប្រឌិតនៃគំនិតរវើរវាយរបស់គេប៉ុណ្ណោះ។ តាមពិតមនុស្សទាំងនេះ ធ្លាប់យកចិត្តទុកដាក់ខ្លាំងចំពោះព្រះបន្ទូលរបស់ព្រះជាម្ចាស់ តែមិនធ្លាប់បានដឹងសោះថា អ្វីទៅជាជំនឿពិត អ្វីទៅជាការស្ដាប់បង្គាប់ពិត អ្វីទៅជាការយកចិត្តទុកដាក់ពិត ឬក៏អ្វីទៅជាចំណេះដឹងពិតអំពីព្រះជាម្ចាស់។ ពួកគេយកទ្រឹស្ដី ការស្រមើស្រមៃ ចំណេះដឹង អំណោយទាន ប្រពៃណី អបិយជំនឿ ហើយនិងគុណតម្លៃសីលធម៌របស់មនុស្ស រួចក៏យកសេចក្ដីទាំងនេះមកធ្វើជា «មូលធន» និងជា «អាវុធ» សម្រាប់ការជឿលើព្រះជាម្ចាស់ និងការដើរតាមទ្រង់ ថែមទាំងធ្វើឲ្យសេចក្ដីទាំងនេះក្លាយជាគ្រឹះនៃជំនឿរបស់គេលើព្រះជាម្ចាស់ និងការដែលគេដើរតាមព្រះអង្គថែមទៀតផង។ នៅក្នុងពេលជាមួយគ្នា ពួកគេក៏យកមូលធន និងអាវុធនេះមកប្រែក្លាយជាវត្ថុស័ក្ដិសិទ្ធមានវេទមន្ត ដែលធ្វើឲ្យគេស្គាល់ព្រះជាម្ចាស់សម្រាប់ការប្រឈម និងការដោះស្រាយជាមួយការពិនិត្យពិច័យ ការល្បងល ការវាយផ្ចាល និងការជំនុំជម្រះរបស់ព្រះជាម្ចាស់។ នៅទីបញ្ចប់ ពួកគេមិនទទួលបានអ្វីសោះ ក្រៅតែពី

ការសន្និដ្ឋានចំពោះព្រះជាម្ចាស់ ដែលផុងជ្រៅក្នុងន័យលាក់កំបាំងខាងសាសនា ក្នុងអបិយជំនឿហួសសម័យ និងក្នុងអ្វីៗគ្រប់យ៉ាងដែលនាំឲ្យរំជួលចិត្ត ប្លែកក្នុងចិត្ត និងជាអាថ៌កំបាំង។ មាគ៌ានៃការស្គាល់ និងការដែលគេកំណត់និយមន័យព្រះជាម្ចាស់ត្រូវបានដៅជាប់នៅក្នុងពុម្ពតែមួយ ជាមួយនឹងមនុស្សដែលជឿតែត្រឹមថា ស្ថានសួគ៌នៅខាងលើ ឬបុរសចំណាស់នៅលើមេឃ ខណៈដែលភាពពិតជាក់ស្ដែងរបស់ព្រះជាម្ចាស់ សារជាតិរបស់ទ្រង់ និស្ស័យរបស់ទ្រង់ កម្មសិទ្ធិ និងអត្ថិភាពរបស់ទ្រង់ ។ល។ គ្រប់យ៉ាងដែលទាក់ទងនឹងព្រះជាម្ចាស់ដ៏ពិតផ្ទាល់ព្រះអង្គ គឺសុទ្ធតែជាសេចក្ដីដែលចំណេះដឹងរបស់គេយល់មិនដល់ ជាសេចក្ដីដែលចំណេះដឹងរបស់គេត្រូវបានផ្ដាច់ចេញស្រឡះ ហើយថែមទាំងនៅឆ្ងាយពីគ្នាស្រឡះ ដូចពីប៉ូលខាងជើងទៅប៉ូលខាងត្បូង។ តាមរបៀបនេះ ទោះបីជាមនុស្សទាំងអស់នេះរស់នៅក្រោមការផ្គត់ផ្គង់ និងការទំនុកបម្រុងនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ក៏ដោយ ក៏ពួកគេនៅតែមិនអាចដើរលើមាគ៌ានៃការកោតខ្លាចព្រះជាម្ចាស់ ហើយគេចចេញពីសេចក្ដីអាក្រក់យ៉ាងពិតប្រាកដដែរ។ ហេតុផលពិតចំពោះរឿងនេះ គឺពួកគេមិនធ្លាប់បានស្គាល់ព្រះជាម្ចាស់ទាល់តែសោះ ហើយពួកគេក៏មិនធ្លាប់មានទំនាក់ទំនង ឬប្រាស្រ័យជាមួយព្រះអង្គដែរ ដូច្នេះហើយ ពួកគេមិនអាចឈានដល់ការយោគយល់គ្នាទៅវិញទៅមកជាមួយនឹងព្រះជាម្ចាស់ ឬដាស់ជំនឿពិតដែលគេមានក្នុងខ្លួនពួកគេ ការដើរតាម ឬការថ្វាយបង្គំសម្រាប់ព្រះជាម្ចាស់ឡើយ។ ដែលពួកគេគួរគិតបែបនេះ ចំពោះព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលពួកគេគួរគិតបែបនេះចំពោះព្រះជាម្ចាស់ ទស្សនៈ និងអាកប្បកិរិយានេះបានបំផ្លាញពួកគេ ឲ្យត្រឡប់ពីការប្រឹងប្រែងរបស់គេដោយដៃទទេ បានបំផ្លាញពួកគេមិនឲ្យពួកគេអាចដើរលើមាគ៌ានៃការកោតខ្លាចព្រះជាម្ចាស់ ហើយគេចចេញពីសេចក្ដីអាក្រក់បាន រហូតអស់កល្បជានិច្ច។ គោលដៅដែលពួកគេកំពុងតម្រង់ឆ្ពោះ និងទិសដៅដែលគេកំពុងទៅ បង្ហាញថាពួកគេជាខ្មាំងសត្រូវរបស់ព្រះជាម្ចាស់អស់កល្បជានិច្ច និងបញ្ជាក់ថាពួកគេនឹងមិនអាចទទួលបានសេចក្ដីសង្គ្រោះអស់កល្បជានិច្ចឡើយ។

ប្រសិនបើក្នុងករណីដែលបុគ្គលម្នាក់បានដើរតាមព្រះ ជាម្ចាស់ជាច្រើនឆ្នាំ ហើយបានអាស្រ័យផលពីការផ្គត់ផ្គង់នៃព្រះបន្ទូលទ្រង់ជាច្រើនឆ្នាំហើយ និយមន័យរបស់គេអំពីព្រះជាម្ចាស់ គឺដូចគ្នានឹងនិយមន័យរបស់មនុស្ស ដែលដាក់ខ្លួនក្រាបបង្គំចំពោះរូបព្រះខ្លាំងណាស់ ហើយសេចក្ដីនេះនឹងបញ្ជាក់បានថា បុគ្គលម្នាក់នេះមិនបានទទួលនូវតថភាពនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់នោះទេ។ នេះគឺមកពីពួកគេមិនបានចូលទៅក្នុងតថភាពនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់សោះតែម្ដង ហើយដោយព្រោះហេតុផលនេះ តថភាព សេចក្ដីពិត ចេតនា និងការទាមទារពីមនុស្ស គ្រប់យ៉ាងដែលមាននៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ពុំមានពាក់ព័ន្ធអ្វីសោះនឹងបុគ្គលម្នាក់នោះ។ មានន័យថា ទោះបីជាបុគ្គលម្នាក់ខំប្រឹងរៀនអំពីផ្ទៃខាងក្រៅនៃអត្ថន័យព្រះបន្ទូលរបស់ព្រះជាម្ចាស់ខ្លាំងប៉ុនណាក៏ដោយ ក៏សេចក្ដីទាំងអស់នេះសុទ្ធតែឥតបានការដែរ៖ ដ្បិតអ្វីដែលពួកគេព្យាយាមឲ្យបាន គឺត្រឹមតែជាពាក្យសម្ដី ហើយអ្វីដែលគេទទួលបាន ក៏ត្រឹមតែជាពាក្យសម្ដីចាំបាច់ដែរ។ ទោះបីជាព្រះបន្ទូលដែលព្រះជាម្ចាស់ថ្លែង មានន័យត្រង់ ឬន័យជ្រាលជ្រៅបើមើលតាមសម្បកក្រៅទៅក៏ដោយ ក៏ព្រះបន្ទូលទាំងនោះសុទ្ធតែជាសេចក្ដីពិត ដែលសំខាន់ចំពោះមនុស្សដែរ នៅពេលដែលគេចូលទៅក្នុងជីវិត។ ព្រះបន្ទូលទាំងនោះ គឺជាប្រភពទឹករស់ដែលអាចឲ្យមនុស្សរស់រានទាំងនៅក្នុងវិញ្ញាណ និងសាច់ឈាម។ ព្រះបន្ទូលនេះផ្ដល់នូវអ្វីដែលមនុស្សត្រូវការ ដើម្បីរក្សាជីវិតឲ្យនៅរស់រាន ជាគោលការណ៍ និងគោលជំនឿសម្រាប់ការប្រតិបត្តិជីវិតប្រចាំថ្ងៃរបស់គេ ជាផ្លូវដែលគេត្រូវតែទទួលយក ដើម្បីទទួលបានសេចក្ដីសង្គ្រោះ ព្រមទាំងគោលដៅ និងទិសដៅផងដែរ ជាសេចក្ដីពិតសព្វបែបយ៉ាង ដែលគេគួរមាន ក្នុងនាមជាភាវៈដែលត្រូវបានបង្កើត នៅចំពោះព្រះជាម្ចាស់ និងជាសេចក្ដីពិតគ្រប់យ៉ាងដែលទាក់ទងនឹងវិធីដែលមនុស្សស្ដាប់បង្គាប់ និងថ្វាយបង្គំព្រះជាម្ចាស់។ ព្រះបន្ទូលទាំងនេះជាការធានា ដែលធានានូវការរស់រានមានជីវិតរបស់មនុស្ស ជានំម៉ាន៉ាប្រចាំថ្ងៃរបស់មនុស្ស ហើយក៏ជាជំនួយដ៏រឹងមាំ ដែលជួយឲ្យមនុស្សមានកម្លាំងខ្លាំងក្លា ហើយអាចក្រោកឈរបានដែរ។ ព្រះបន្ទូលទាំងនេះសម្បូរទៅដោយ ភាពពិតនៃសេចក្ដីពិត

ដែលត្រូវបានបង្កើតមក ដើម្បីឲ្យមនុស្សបានរស់នៅជាមនុស្សសាមញ្ញ សម្បូរដោយសេចក្ដីពិតដែលជួយមនុស្សជាតិឲ្យរួចពីសេចក្ដីពុករលួយ និងគេចផុតពីអន្ទាក់របស់សាតាំង សម្បូរដោយសេចក្ដីបង្រៀន ការទូន្មាន និងការលើកទឹកចិត្ត ឥតនឿយហត់ និងភាពធូរស្បើយដែលព្រះអាទិករប្រទានឲ្យមនុស្សដែលត្រូវបានបង្កើតមក។ ព្រះបន្ទូលទាំងនេះគឺជាចង្កៀងដែលដឹកនាំ និងបំភ្លឺមនុស្សឲ្យយល់សេចក្ដីគ្រប់យ៉ាងដែលវិជ្ជមាន ជាការធានាដែលធានាបានថា មនុស្សនឹងស្ដែងចេញតាមរយៈការរស់នៅរបស់គេ ហើយចាប់ផ្ដើមមានគ្រប់យ៉ាងដែលសុចរិត និងល្អប្រពៃ ជាលក្ខណវិនិច្ឆ័យដែលវាស់ស្ទង់មនុស្ស ព្រឹត្តិការណ៍ និងវត្ថុទាំងអស់ ហើយជាសញ្ញាសម្គាល់ទិសដែលនាំមនុស្សទៅរកសេចក្ដីសង្គ្រោះ និងមាគ៌ានៃពន្លឺ។ មានតែនៅក្នុងបទពិសោធជាក់ស្ដែងពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ទេ ទើបអាចប្រទានឲ្យមនុស្សមានសេចក្ដីពិត និងជីវិតបាន ហើយមានតែនៅក្នុងព្រះបន្ទូលនេះទេ ទើបមនុស្សអាចចាប់ផ្ដើមយល់ថា អ្វីទៅជាភាពជាមនុស្សធម្មតា អ្វីទៅជាជីវិតដ៏មានន័យ អ្វីទៅជាមនុស្សពិត អ្វីទៅជាការស្ដាប់បង្គាប់ដ៏ពិតប្រាកដចំពោះព្រះជាម្ចាស់ ហើយមានតែនៅក្នុងព្រះបន្ទូលនេះទេទើបមនុស្សអាចចាបផ្ដើមយល់ពីវិធីដែលគេគួរយកចិត្តទុកដាក់ចំពោះព្រះជាម្ចាស់ យល់អំពីវិធីដែលគេគួរមានភាពដូចគ្នារបស់មនុស្សពិត មានតែនៅក្នុងព្រះបន្ទូលនេះទេ ទើបមនុស្សអាចចាប់ផ្ដើមយល់ពីអត្ថន័យនៃសេចក្ដីជំនឿពិត និងការថ្វាយបង្គំពិត មានតែនៅក្នុងព្រះបន្ទូលនេះទេ ទើបមនុស្សចាប់ផ្ដើមយល់ថានរណាជាអ្នកគ្រប់គ្រងស្ថានសួគ៌ និងផែនដី និងរបស់សព្វសារពើ មានតែនៅក្នុងព្រះបន្ទូលនេះទេ ទើបមនុស្សអាចយល់ពីមធ្យោបាយ ដែលព្រះដ៏ជាចៅហ្វាយលើសព្វសារពើ ទ្រង់គ្រប់គ្រង ដឹកនាំ និងផ្គត់ផ្គង់ដល់អ្វីៗទាំងអស់ដែលទ្រង់បានបង្កើតមក ហើយមានតែនៅក្នុងព្រះបន្ទូលរបស់ទ្រង់ទេ ទើបមនុស្សអាចចាប់ផ្ដើមដឹង និងយល់ពីមធ្យោបាយដែលព្រះដ៏ជាចៅហ្វាយលើរបស់ទាំងអស់ដែលទ្រង់បានបង្កើតមក មានអត្ថិភាព សម្ដែងអង្គទ្រង់ ហើយនិងធ្វើការ។ ដោយត្រូវបានកាត់ផ្ដាច់ពីបទពិសោធពិតនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ មនុស្សពុំមានចំណេះដឹងពិត ឬការយល់ដឹងជ្រៅជ្រះខាងព្រះបន្ទូលរបស់

ព្រះជាម្ចាស់ និងសេចក្តីពិតទេ។ មនុស្សបែបនេះ គឺជាសាកសពមានជីវិតដ៏ពិតប្រាកដ ជាសម្បកស្នូកសុទ្ធសាធ ហើយចំណេះដឹងទាំងអស់ទាក់ទងនឹងព្រះអាទិករ គឺគ្មានអ្វីពាក់ព័ន្ធនឹងគេសោះ។ នៅចំពោះព្រះនេត្ររបស់ព្រះជាម្ចាស់ មនុស្សបែបនេះមិនបានជឿលើទ្រង់សោះឡើយ ក៏មិនធ្លាប់ដើរតាមព្រះអង្គដែរ ដូច្នេះហើយ ព្រះជាម្ចាស់ក៏មិនទទួលស្គាល់គេថាជាអ្នកជឿលើព្រះអង្គ ឬជាអ្នកដើរតាមទ្រង់នោះដែរ រឹតតែមិនមែនជាភាវៈដែលទ្រង់បានបង្កើតពិតប្រាកដផង។

ភាវៈដែលព្រះបានបង្កើតពិតប្រាកដ ត្រូវដឹងថា ព្រះអាទិករជានរណា មនុស្សកើតមកដើម្បីអ្វី ត្រូវបំពេញទំនួលខុសត្រូវជាមនុស្សដោយរបៀបណា ហើយត្រូវថ្វាយបង្គំព្រះអម្ចាស់នៃអ្វីៗទាំងអស់ដែលបានបង្កើតមក ត្រូវដឹង ត្រូវយល់ ត្រូវស្គាល់ និងយកចិត្តទុកដាក់ចំពោះចេតនា បំណងព្រះហឫទ័យ និងការ ទាមទាររបស់ព្រះអាទិករ ហើយត្រូវប្រព្រឹត្តស្របតាមផ្លូវរបស់ព្រះអាទិករ គឺកោតខ្លាចព្រះជាម្ចាស់ ហើយគេចចេញពីសេចក្តីអាក្រក់។

តើការកោតខ្លាចព្រះជាម្ចាស់គឺជាអ្វី? ហើយតើមនុស្ស អាចគេចពីសេចក្តីអាក្រក់យ៉ាងដូចម្តេច?

«កោតខ្លាចព្រះជាម្ចាស់» មិនមែនជាការភិតភ័យ និងរន្ធត់បែបអនាមិក ក៏មិនមែនជាការគេចចេញទៅឲ្យឆ្ងាយ ក៏មិនមែនជាការថ្វាយបង្គំរូបព្រះ ឬអបិយជំនឿនោះដែរ។ ផ្ទុយទៅវិញ វាគឺជាការស្ញើចសរសើរ ការគោរព ការជឿទុកចិត្ត ការយល់ដឹង ការយកចិត្តទុកដាក់ ការស្តាប់បង្គាប់ ការញែកជាបរិសុទ្ធ ក្តីស្រឡាញ់ ក៏ដូចជាការថ្វាយបង្គំ ការតបស្នង និងការចុះចូលឥតលក្ខខណ្ឌ ព្រមទាំងគ្មានការរអ៊ូរទាំ។ គ្មានចំណេះដឹងពិតប្រាកដអំពីព្រះជាម្ចាស់ នោះមនុស្សក៏មិនមានការស្ញើចសរសើរ ការជឿទុកចិត្ត ការយល់ដឹង ការយកចិត្តទុកដាក់ ឬការស្តាប់បង្គាប់ដ៏ពិតប្រាកដដែរ មានតែការយល់ដឹង និងការគេចចេញគួរឲ្យខ្លាច មានតែការសង្ស័យ និងការគេចមុខប៉ុណ្ណោះ។ បើគ្មានចំណេះដឹងពិតអំពីព្រះជាម្ចាស់ មនុស្សនឹងគ្មានការញែកជាបរិសុទ្ធ និងការតបស្នងពិតប្រាកដឡើយ។ បើគ្មានចំណេះពិតអំពីព្រះជាម្ចាស់ មនុស្សនឹង

គ្មានការថ្វាយបង្គំ និងការចុះចូលពិតប្រាកដឡើយ មានតែការថ្វាយបង្គំរូបព្រះ និងអបិយជំនឿដ៏ងងឹតងងល់ប៉ុណ្ណោះ។ បើគ្មានចំណេះដឹងពិតអំពីព្រះជាម្ចាស់ មនុស្សមិនអាចប្រព្រឹត្តស្របទៅនឹងមាគ៌ារបស់ព្រះជាម្ចាស់ ឬកោតខ្លាចព្រះជាម្ចាស់ ឬគេចចេញពីសេចក្ដីអាក្រក់ឡើយ។ ផ្ទុយទៅវិញ គ្រប់សកម្មភាព និងឥរិយាបថដែលមនុស្សពាក់ព័ន្ធនឹងពោរពេញទៅដោយការបះបោរ និងការរឹងទទឹង ពេញដោយការចោទប្រកាន់ដោយការមួលបង្កាច់ និងការវិនិច្ឆ័យអគតិចំពោះទ្រង់ និងពេញដោយកិរិយាអាក្រក់ ដែលកំពុងតែដំណើរការផ្ទុយនឹងសេចក្ដីពិត និងអត្ថន័យពិតនៃព្រះបន្ទូល របស់ព្រះជាម្ចាស់។

នៅពេលដែលមនុស្ស មានទំនុកចិត្តពិតលើព្រះជាម្ចាស់ ពួកគេនឹងដើរតាមព្រះជាម្ចាស់ ហើយពឹងអាងលើទ្រង់ពិតប្រាកដ។ មានតែទំនុកចិត្ត និងការពឹងអាងពិតប្រាកដលើព្រះជាម្ចាស់ទេ ទើបមនុស្សអាចមានការយល់ដឹង និងការជ្រួតជ្រាបដ៏ពិតប្រាកដ។ ការជ្រួតជ្រាបពីព្រះជាម្ចាស់ពិតប្រាកដ មកជាមួយនឹងការយកចិត្តទុកដាក់ចំពោះព្រះអង្គពិតប្រាកដ។ ទាល់តែមានការយកចិត្តទុកដាក់ពិតប្រាកដចំពោះព្រះជាម្ចាស់ ទើបមនុស្សអាចមានការស្ដាប់បង្គាប់ពិតប្រាកដ។ ទាល់តែមានការស្ដាប់បង្គាប់ពិតប្រាកដ ទើបមនុស្សអាចមានការញែកជាបរិសុទ្ធពិតប្រាកដ។ ទាល់តែមានការញែកជាបរិសុទ្ធពិតប្រាកដ ទើបមនុស្សអាចមានការតបស្នងឥតលក្ខខណ្ឌ និងគ្មានការរអ៊ូរទាំ។ ទាល់តែមានការជឿទុកចិត្ត និងការពឹងអាងពិតប្រាកដ មានការយល់ដឹង និងការយកចិត្តទុកដាក់ពិតប្រាកដ មានការស្ដាប់បង្គាប់ពិតប្រាកដ មានការញែកជាបរិសុទ្ធ និងមានការតបស្នងពិតប្រាកដ ទើបមនុស្សអាចចាប់ផ្ដើមស្គាល់ពិតប្រាកដនូវអត្តសញ្ញាណរបស់ព្រះអាទិករ។ ទាល់តែពួកគេចាប់ផ្ដើមស្គាល់ព្រះអាទិករពិតប្រាកដ ទើបមនុស្សអាចបង្កើតឲ្យមានការថ្វាយបង្គំ និងការចុះចូលពិតប្រាកដ នៅក្នុងខ្លួនគេផ្ទាល់បាន។ ទាល់តែមនុស្សមានការថ្វាយបង្គំ និងការចុះចូលពិតប្រាកដចំពោះព្រះអាទិករ ទើបពួកគេពិតជាអាចលះបង់ផ្លូវអាក្រក់របស់គេ ពោលគឺគេចចេញពីសេចក្ដីអាក្រក់។

ការនេះបង្កើតនូវដំណើរការទាំងមូលនៃ «ការកោតខ្លាចព្រះជាម្ចាស់ និងការគេចចេញពីសេចក្ដីអាក្រក់» ហើយក៏ជាសារជាតិនៃភាពពេញលេញនៃដំណើរការនៃការកោតខ្លាចព្រះជាម្ចាស់ ហើយគេចចេញពីសេចក្ដីអាក្រក់ដែរ។ នេះជាផ្លូវដែលត្រូវតែឆ្លងកាត់ ដើម្បីទទួលបាននូវការកោតខ្លាចព្រះជាម្ចាស់ និងការគេចចេញពីសេចក្ដីអាក្រក់។

«ការកោតខ្លាចព្រះជាម្ចាស់ និងការគេចចេញពីសេចក្ដីអាក្រក់» និងការស្គាល់ព្រះជាម្ចាស់ ត្រូវបានផ្សារភ្ជាប់គ្នាឥតដាច់ដោយតំណជាច្រើន ហើយការផ្សារភ្ជាប់រវាងសេចក្ដីទាំងនេះបញ្ជាក់ចេញមកយ៉ាងច្បាស់ ដោយមិនបាច់ពន្យល់។ ប្រសិនបើមនុស្សម្នាក់ចង់ទទួលបានការគេចចេញពីសេចក្ដីអាក្រក់ ដំបូងគេត្រូវមានការកោតខ្លាចពិតចំពោះព្រះជាម្ចាស់ ប្រសិនបើគេចង់ទទួលបានការកោតខ្លាចពិត ចំពោះព្រះជាម្ចាស់ ដំបូងគេត្រូវតែមានចំណេះដឹងពិតអំពីព្រះជាម្ចាស់ ប្រសិនបើគេចង់ទទួលបានចំណេះដឹងពិតអំពីព្រះជាម្ចាស់ ដំបូងគេត្រូវឆ្លងកាត់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ចូលទៅក្នុងតថភាពនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ ឆ្លងកាត់ការវាយផ្ចាល និងការជំនុំជម្រះរបស់ទ្រង់ ប្រសិនបើមនុស្សចង់ឆ្លងកាត់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដំបូងគេត្រូវប្រឈមនឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់ដោយមុខទល់នឹងមុខ ប្រឈមនឹងព្រះជាម្ចាស់ដោយមុខទល់នឹងមុខ និងទូលសុំព្រះជាម្ចាស់ឲ្យប្រទានឱកាសឆ្លងកាត់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ក្នុងគ្រប់សណ្ឋាន គ្រប់ប្រភេទនៃបរិយាកាសទាក់ទងនឹងមនុស្ស ព្រឹត្តិការណ៍ និងវត្ថុបំណង ហើយប្រសិនបើគេចង់ប្រឈមជាមួយព្រះជាម្ចាស់ និងព្រះបន្ទូលរបស់ទ្រង់ដោយមុខទល់នឹងមុខ ដំបូងគេត្រូវមានចិត្តសាមញ្ញ និងស្មោះត្រង់ មានការត្រៀមខ្លួនទទួលសេចក្ដីពិត និងមានឆន្ទៈក្នុងការទ្រាំទ្រទុក្ខលំបាក មានការតាំងចិត្ត និងភាពក្លាហានក្នុងការគេចចេញពីសេចក្ដីអាក្រក់ និងមានមហិច្ឆតាចង់ក្លាយជាមនុស្សដែលត្រូវបានបង្កើតពិតប្រាកដ...។ តាមវិធីនេះ អ្នកនឹងចូលទៅកៀកព្រះជាម្ចាស់ ដោយឆ្ពោះទៅមុខមួយជំហានម្ដងៗ ដួងចិត្តរបស់អ្នកនឹងរឹតតែស្អាតបរិសុទ្ធ ហើយជីវិត និងគុណតម្លៃនៃការរស់រានរបស់អ្នក នឹងកាន់តែមានន័យ

ក្នុងការដែលអ្នកចាប់ផ្ដើមស្គាល់ព្រះជាម្ចាស់ កាន់តែមានន័យ និងកាន់តែមានរស្មី។ លុះដល់ថ្ងៃមួយ អ្នកនឹងដឹងថា ព្រះ អាទិករលែងជាប្រស្នាទៀតហើយ ដឹងថាព្រះអាទិករមិនធ្លាប់លាក់បំពួនពីអ្នកឡើយ ដឹងថាព្រះអាទិករមិនធ្លាប់លាក់ព្រះភក្ត្រពីអ្នក ដឹងថាព្រះអាទិករនៅមិនឆ្ងាយពីអ្នក ដឹងថាព្រះអាទិករលែងជាព្រះដែលអ្នកចង់បានជាដរាប ក្នុងគំនិតរបស់អ្នកទៀតហើយ ប៉ុន្ដែជាព្រះដែលអ្នកមិនអាចឈោងដល់ដោយអារម្មណ៍របស់អ្នក ដឹងថាទ្រង់ពិតជា និងប្រាកដជាកំពុងឈរការពារអ្នកពីខាងឆ្វេងដល់ខាងស្ដាំអ្នក ទាំងផ្គត់ផ្គង់ជីវិតអ្នក ហើយគ្រប់គ្រងជោគវាសនារបស់អ្នកផង។ ទ្រង់មិនមែននៅជើងមេឃសន្លឹម ក៏មិនបានលាក់បំពួនអង្គទ្រង់យ៉ាងខ្ពស់នៅក្នុងពពកដែរ។ ទ្រង់នៅក្បែរអ្នកបង្កើយ ដោយគង់ជាម្ចាស់លើគ្រប់យ៉ាងជារបស់អ្នក ទ្រង់ជាអ្វីៗគ្រប់យ៉ាងដែលអ្នកមាន ហើយទ្រង់ជារបស់តែមួយគត់ដែលអ្នកមាន។ ព្រះជាម្ចាស់បែបនេះ អនុញ្ញាតឲ្យអ្នកស្រឡាញ់ទ្រង់ចេញពីចិត្ត ប្រតោងទ្រង់ឲ្យជាប់ ប្រទាញទ្រង់ឲ្យកៀក ស្ងើចសរសើរទ្រង់ ខ្លាចបាត់បង់ទ្រង់ ហើយមិនព្រមបោះបង់ទ្រង់តទៅទៀត លែងរឹងចចេសនឹងទ្រង់ ឬលែងគេចពីទ្រង់ ឬនៅឆ្ងាយពីទ្រង់។ គ្រប់យ៉ាងដែលអ្នកចង់បានគឺយកចិត្តទុកដាក់នឹងទ្រង់ តបស្នងគ្រប់យ៉ាងដែលទ្រង់ប្រទានឲ្យអ្នក ហើយចុះចូលនឹងអំណាចគ្រប់គ្រងរបស់ទ្រង់។ អ្នកលែងបដិសេធមិនឲ្យទ្រង់ដឹងនាំ មិនឲ្យទ្រង់ផ្គត់ផ្គង់ មិនឲ្យទ្រង់ការពារ និងមិនឲ្យទ្រង់ថែរក្សា លែងបដិសេធនូវអ្វីដែលទ្រង់បង្គាប់ និងបញ្ជាឲ្យអ្នកធ្វើទៀតហើយ។ គ្រប់យ៉ាងដែលអ្នកចង់បានគឺដើរតាមទ្រង់នៅជិតទ្រង់ដោយសហការនឹងទ្រង់ គ្រប់យ៉ាងដែលអ្នកចង់បានគឺទទួលទ្រង់ធ្វើជាជីវិតតែមួយគត់របស់អ្នក ទទួលទ្រង់ធ្វើជាព្រះអម្ចាស់តែមួយគត់របស់អ្នក និងជាព្រះជាម្ចាស់តែមួយគត់របស់អ្នក។

ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៤

# ការមើលឃើញការលេចមករបស់ព្រះជាម្ចាស់ នៅក្នុងការជំនុំជម្រះ និងការវាយផ្ចាលរបស់ទ្រង់

យើងគោរពតាមក្រឹត្យវិន័យ និងបញ្ញត្តិនានានៅក្នុងព្រះគម្ពីរ រីករាយចំពោះព្រះគុណដ៏បរិបូររបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ហើយរួមគ្នាអធិស្ឋាន សរសើរតម្កើង និងបម្រើដោយនូវព្រះនាមរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ដូចជាមនុស្សរាប់រាយលាននាក់ផ្សេងទៀតដែរ ហើយកិច្ចការដែលយើងធ្វើទាំងអស់នេះសុទ្ធតែស្ថិតក្រោមការថែរក្សា និងការការពាររបស់ព្រះអម្ចាស់។ យើងតែងទន់ខ្សោយជារឿយៗ ហើយក៏រឹងមាំជារឿយៗដែរ។ យើងជឿថា សកម្មភាពទាំងអស់របស់យើងសុទ្ធតែស្របតាមសេចក្ដីបង្រៀនរបស់ព្រះអម្ចាស់។ ដូច្នេះមិនចាំបាច់និយាយអ្វីទេ យើងក៏ជឿថាខ្លួនយើងស្ថិតនៅលើវិថីនៃការធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះវរបិតាដែលគង់នៅស្ថានសួគ៌ដែរ។ យើងទន្ទឹងរង់ចាំការយាងត្រលប់មកវិញរបស់ព្រះអម្ចាស់យេស៊ូវ រង់ចាំការយាងចុះមកប្រកបដោយសិរីរុងរឿងរបស់ទ្រង់ រង់ចាំទីបញ្ចប់នៃជីវិតរបស់យើងនៅលើផែនដី រង់ចាំការលេចមកនៃនគរព្រះ និងរង់ចាំអ្វីៗទាំងអស់ដូចដែលបានចែងទុកជាមុននៅក្នុងកណ្ឌគម្ពីរវិវរណៈថា៖ ព្រះអម្ចាស់យាងមកដល់ ទ្រង់នាំយកគ្រោះមហន្តរាយមក ទ្រង់ប្រទានរង្វាន់ដល់មនុស្សល្អ និងដាក់ទណ្ឌកម្មមនុស្សអាក្រក់ ហើយទ្រង់យកអស់អ្នកដែលដើរតាមទ្រង់ និងស្វាគមន៍ការយាងត្រលប់មកវិញរបស់ទ្រង់ ទៅជួបជាមួយទ្រង់នៅលើអាកាស។ រាល់ពេលដែលយើងគិតអំពីរឿងនេះ យើងមិនអាចធ្វើអ្វីបានឡើយ ក្រៅតែពីត្រូវយកឈ្នះដោយអារម្មណ៍ ពេញដោយអំណរដែលយើងបានកើតមកនៅគ្រាចុងក្រោយ និងមានសំណាងធ្វើជាស្មរបន្ទាល់ពីការយាងមករបស់ព្រះអម្ចាស់។ ទោះបីជាយើងបានទទួលរងការបៀតបៀនក៏ដោយ ក៏យើងបានទទួលមកវិញនូវ «សិរីរុងរឿងយ៉ាងច្រើនលើសលុប អស់កល្បជានិច្ច»។ នេះគឺជាព្រះពរដ៏អស្ចារ្យមួយ! រាល់ការចង់បានទាំងអស់នេះ និងព្រះគុណដែលព្រះអម្ចាស់បានប្រទានមកយើង ធ្វើឲ្យយើងមានស្មារតីអធិស្ឋានជាប់ជានិច្ច និងធ្វើឲ្យយើង

កាន់តែឧស្សាហ៍ក្នុងការប្រមូលផ្ដុំគ្នា។ ប្រហែលជាឆ្នាំក្រោយ ប្រហែលជាថ្ងៃស្អែក និង ប្រហែលជាក្នុងចន្លោះពេលវេលាមួយដែលខ្លីជាងអ្វីដែលមនុស្សអាចយល់បាន នោះ ព្រះអម្ចាស់នឹងយាងចុះមកភ្លាម ដោយលេចមកក្នុងចំណោមមនុស្សមួយក្រុមដែល បានរង់ចាំទ្រង់ដោយយកចិត្តទុកដាក់យ៉ាងខ្លាំង។ យើងប្រញាប់ប្រញាល់ទៅខាងមុខ គេ គ្មាននរណាម្នាក់ចង់នៅក្រោយគេឡើយ ហើយទាំងអស់នេះគឺដើម្បីឲ្យបានស្ថិតនៅ ក្នុងចំណោមក្រុមមនុស្សដំបូងគេ ដែលមើលឃើញការលេចមករបស់ព្រះអម្ចាស់ គឺ ក្នុងចំណោមអស់អ្នក ដែលត្រូវបានលើកឡើងទៅលើអាកាស។ ដើម្បីការមកដល់ នៃថ្ងៃនេះ យើងបានប្រគល់អ្វីៗគ្រប់យ៉ាងដោយមិនខ្វល់ពីការខាតបង់ឡើយ ដោយ អ្នកខ្លះទុកការងាររបស់ខ្លួនចោល អ្នកខ្លះបោះបង់គ្រួសាររបស់ខ្លួន អ្នកខ្លះផ្ដាច់ចំណង អាពាហ៍ពិពាហ៍ចោល ហើយអ្នកខ្លះទៀតថែមទាំងបរិច្ចាគប្រាក់សន្សំទាំងអស់របស់ ខ្លួនទៀតផង។ នេះជាការលះបង់ដ៏អស្ចារ្យដោយមិនគិតពីខ្លួនឯង! ភាពស្មោះត្រង់ និងភក្ដីភាពបែបនេះ ប្រាកដជាលើសពីពួកបរិសុទ្ធកាលពីសម័យមុនទៅទៀត! ដោយ ព្រោះព្រះអម្ចាស់ប្រទានព្រះគុណ និងសម្ដែងសេចក្ដីមេត្តាករុណាដល់អស់អ្នកណា ដែលទ្រង់សព្វព្រះហឫទ័យ យើងជឿថាព្រះនេត្ររបស់ទ្រង់បានទតឃើញភាពស្មោះ ត្រង់ និងការលះបង់របស់យើង តាំងពីយូរមកហើយ។ ដូច្នេះ ការអធិស្ឋានអស់ពី ដួងចិត្តរបស់យើង ក៏បានឮទៅដល់ព្រះកាណ៌របស់ទ្រង់ដែរ ហើយយើងជឿជាក់ ថា ព្រះអម្ចាស់នឹងប្រទានការតបស្នងចំពោះការលះបង់របស់យើង។ លើសពីនេះ ទៀត ព្រះជាម្ចាស់បានបង្ហាញព្រះគុណចំពោះយើងមុនពេលដែលទ្រង់បានបង្កើត ពិភពលោកមក ហើយព្រះពរ និងសេចក្ដីសន្យាដែលទ្រង់បានប្រទានដល់យើង គ្មាន នរណាម្នាក់អាចដកចេញបានឡើយ។ យើងទាំងអស់គ្នាសុទ្ធតែកំពុងរៀបចំផែនការ សម្រាប់ពេលអនាគត ហើយតាមធម្មតាបានដាក់ការតាំងចិត្តនិងការលះបង់របស់ យើងជាប្រាក់ដើម ឬទុនដើម្បីដោះដូរនឹងការលើកឡើងទៅជួបជាមួយព្រះអម្ចាស់នៅ លើអាកាស។ បន្ថែមលើនេះទៀត យើងបានដាក់ខ្លួនយើងនៅលើបល្ល័ង្កនៃអនាគត ដោយមិនស្ទាក់ស្ទើរបន្តិចឡើយ ដើម្បីបានធ្វើជាអធិបតីលើជាតិសាសន៍ និងមនុស្ស

ទាំងអស់ ឬដើម្បីសោយរាជ្យធ្វើជាស្ដេច។ យើងរាប់អ្វីៗទាំងអស់នេះទុកដូចជាការប្រទានឲ្យ ជាអ្វីម៉្យាងដែលយើងបានរំពឹងទុក។

យើងមាក់ងាយអស់អ្នកដែលទាស់ប្រឆាំងនឹងព្រះអម្ចាស់យេស៊ូវ។ ទីបញ្ចប់របស់ពួកគេទាំងអស់គ្នាគឺការវិនាសសាបសូន្យ។ តើនរណាដែលបានប្រាប់ពួកគេមិនឲ្យជឿថាព្រះអម្ចាស់យេស៊ូវដែលជាព្រះអង្គសង្គ្រោះ? ប្រាកដណាស់ មានពេលវេលាជាច្រើនដងដែលយើងត្រាប់តាមព្រះអម្ចាស់យេស៊ូវ ក្នុងការបង្ហាញចិត្តក្ដួលអាណិតចំពោះមនុស្សនៅក្នុងលោកិយ ដ្បិតពួកគេមិនយល់ ហើយវាជារឿងត្រឹមត្រូវដែលលើកលែងហើយអត់ទោសដល់ពួកគេ។ អ្វីៗគ្រប់យ៉ាងដែលយើងធ្វើ សុទ្ធតែស្របតាមព្រះបន្ទូលនៅក្នុងព្រះគម្ពីរ ដ្បិតអ្វីៗដែលមិនស្របនឹងបទគម្ពីរ សុទ្ធតែជាសេចក្ដីបង្រៀនក្លែងក្លាយ និងខុសឆ្គង។ ជំនឿប្រភេទនេះបានចាក់ឫសយ៉ាងជ្រៅនៅក្នុងចិត្តគំនិតរបស់យើងម្នាក់ៗ។ ព្រះអម្ចាស់របស់យើងនៅក្នុងព្រះគម្ពីរ ហើយប្រសិនបើយើងមិនឃ្លាតឆ្ងាយពីព្រះគម្ពីរទេ នោះយើងក៏នឹងមិនឃ្លាតឆ្ងាយពីព្រះអម្ចាស់ឡើយ ហើយប្រសិនបើយើង នៅជាប់នឹងគោលការណ៍នេះ នោះយើងនឹងទទួលបានសេចក្ដីសង្គ្រោះ។ យើងជំរុញគ្នាទៅវិញទៅមក គាំទ្រគ្នាទៅវិញទៅមក ហើយគ្រប់ពេលដែលយើងជួបជុំគ្នា គឺយើងសង្ឃឹមថាអ្វីៗដែលយើងនិយាយ និងធ្វើ សុទ្ធតែស្របតាមបំណងព្រះហឫទ័យរបស់ព្រះអម្ចាស់ ហើយព្រះអម្ចាស់នឹងទទួលយក។ ទោះបីជាបរិយាកាសរបស់យើងមានភាពប្រទូស្តរ៉ាយយ៉ាងខ្លាំងក៏ដោយ ក៏ដួងចិត្តរបស់យើងពេញដោយក្ដីរីករាយដែរ។ នៅពេលដែលយើងគិតអំពីព្រះពរដែលងាយនឹងទទួលយកបែបនេះ តើមានអ្វីដែលយើងមិនអាចទុកចោលឬទេ? តើមានអ្វីដែលយើងស្ទាក់ស្ទើរក្នុងការចូលរួមឬទេ? ទាំងអស់នេះ គឺមិនបាច់និយាយនោះទេ ហើយអ្វីៗទាំងអស់នេះសុទ្ធតែស្ថិតក្រោមការឃ្លាំមើលរបស់ព្រះជាម្ចាស់។ យើងទាំងអស់គ្នាជាមនុស្សខ្វះខាតមួយក្ដាប់តូច ដែលត្រូវបានលើកចេញពីគំនរលាមកសត្វមក ហើយយើងក៏ដូចជាអ្នកដើរតាមធម្មតាទាំងអស់របស់ព្រះអម្ចាស់យេស៊ូវដែរ គឺយើងសុបិនថានឹងត្រូវលើកឡើងទៅលើអាកាស ទទួលបានព្រះពរ និងគ្រួតត្រាលើជាតិសាសន៍

ទាំងអស់។ ភាពពុករលួយរបស់យើង ត្រូវបានលាតត្រដាងដោយចំហនៅចំពោះព្រះនេត្ររបស់ព្រះជាម្ចាស់ ហើយបំណងប្រាថ្នា និងការលោភលន់របស់យើងក៏ត្រូវបានថ្កោលទោស នៅចំពោះព្រះនេត្ររបស់ព្រះជាម្ចាស់ដែរ។ ទោះជាយ៉ាងណាក៏ដោយ អ្វីៗទាំងអស់នេះកើតឡើងជាធម្មតា និងសមហេតុផលបំផុត បានជាគ្មាននរណាម្នាក់ក្នុងចំណោមយើងរាល់គ្នាឆ្ងល់ថាការចង់បានរបស់យើងត្រឹមត្រូវ ឬក៏អត់នោះទេ ហើយមានមនុស្សតិចណាស់ក្នុងចំណោមយើងរាល់គ្នាដែលសង្ស័យពីភាពត្រឹមត្រូវនៃអ្វីៗ ដែលយើងប្រកាន់ខ្ជាប់។ តើនរណាអាចដឹងពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់? យើងមិនដឹងថាត្រូវស្វែងរក ឬក៏ស្រាវជ្រាវរកឲ្យដឹងច្បាស់ថា ផ្លូវដែលមនុស្សដើរជាផ្លូវប្រភេទណាឲ្យពិតប្រាកដទេ ហើយយើងក៏មិនចាប់អារម្មណ៍ចង់សាកសួរអ្វីដែរ។ ដ្បិតយើងខ្វល់ខ្វាយតែចំណុចដែលថា យើងអាចត្រូវបានលើកឡើងទៅលើអាកាសឬអត់ យើងអាចទទួលបានព្រះពរឬអត់ មានកន្លែងសម្រាប់យើងនៅលើនគរស្ថានសួគ៌ឬអត់ ហើយថាយើងនឹងមានចំណែកពីទឹកនៃទន្លេជីវិត និងផលផ្លែពីដើមជីវិតឬអត់ប៉ុណ្ណោះ។ តើមិនមែន ដើម្បីឲ្យបានរបស់ទាំងអស់នេះទេឬអីដែលយើងជឿលើព្រះអម្ចាស់ និងក្លាយជាអ្នកដើរតាមទ្រង់? បាបរបស់យើងត្រូវបានអត់ទោសឲ្យ យើងបានប្រែចិត្ត យើងបានផឹកពីពែងស្រាទំពាំងបាយជូរដ៏ល្វីង ហើយយើងបានដាក់ឈើឆ្កាងលើខ្នងរបស់យើង។ តើនរណាអាចនិយាយថា ព្រះអម្ចាស់នឹងមិនទទួលយកតម្លៃដែលយើងបានបង់? តើនរណាអាចនិយាយថា យើងមិនបានរៀបចំប្រេងគ្រប់គ្រាន់? យើងមិនចង់ធ្វើជាស្ត្រីព្រហ្មចារីដ៏ល្ងង់ទាំងនោះ ឬក៏ធ្វើជានរណាម្នាក់ក្នុងចំណោមមនុស្ស ដែលត្រូវបានគេបោះបង់ចោលនោះទេ។ លើសពីនេះទៀត យើងអធិស្ឋានឥតឈប់ឈរ ដោយទូលសុំព្រះអម្ចាស់ឲ្យការពារយើងពីការបោកបញ្ឆោតដោយព្រះគ្រីស្ទក្លែងក្លាយ ដ្បិតព្រះគម្ពីរបានចែងថា៖ «ហើយប្រសិនបើមានមនុស្សនិយាយប្រាប់អ្នករាល់គ្នាថា មើលណ៎! ព្រះគ្រីស្ទនៅទីនេះ ឬទីនោះ ចូរកុំជឿឲ្យសោះ។ ដ្បិតនឹងមានព្រះគ្រីស្ទក្លែងក្លាយ និងហោរាក្លែងក្លាយ ហើយសម្ដែងទីសម្គាល់ និងការអស្ចារ្យជាច្រើនផង ដើម្បីបញ្ឆោតពួកជ្រើសតាំង ប្រសិនបើអាច»

(ម៉ាថាយ ២៤:២៣-២៤)។ យើងទាំងអស់គ្នាប្ដេជ្ញាចិត្តទន្ទេញខព្រះគម្ពីរទាំងនេះ យើងចងចាំខព្រះគម្ពីរទាំងនេះរត់មាត់ ហើយយើងរាប់ខព្រះគម្ពីរទាំងនេះថាជាទ្រព្យសម្បត្តិដ៏មានតម្លៃ ជាជីវិត និងជាលិខិតសរសើរមួយ ដែលសម្រេចថាយើងអាចបានសង្គ្រោះ ឬអាចត្រូវលើកឡើងទៅលើអាកាសឬអត់ ...

រាប់ពាន់ឆ្នាំមកហើយ មនុស្សរស់បានស្លាប់ទៅ ដោយនាំយកការចង់បាន និងក្ដីសុបិនរបស់ខ្លួនទៅជាមួយ ប៉ុន្តែថាតើពួកគេបានទៅនគរស្ថានសួគ៌ឬអត់នោះ គឺគ្មាននរណាម្នាក់ដឹងច្បាស់ឡើយ។ មនុស្សស្លាប់ត្រលប់មកវិញ ដោយភ្លេចរឿងរ៉ាវទាំងអស់ដែលបានកើតឡើង ហើយពួកគេនៅតែអនុវត្តតាមសេចក្ដីបង្រៀន និងដើរតាមផ្លូវរបស់ពួកព្ឋយុកោ។ ហើយនៅពេលដែលពេលវេលាកន្លងផុតទៅបែបនេះច្រើនឆ្នាំច្រើនថ្ងៃ នោះគ្មាននរណាម្នាក់ដឹងថា ព្រះអម្ចាស់យេស៊ូវដ៏ជាព្រះជាម្ចាស់នៃយើង ពិតជាទទួលយកអ្វីៗទាំងអស់ដែលយើងធ្វើឬក៏អត់នោះទេ។ អ្វីដែលយើងអាចធ្វើបាន គឺរង់ចាំទទួលលទ្ធផល និងប៉ាន់ស្មានអំពីអ្វីៗដែលនឹងកើតឡើង។ ប៉ុន្តែ ព្រះជាម្ចាស់បានរក្សាភាពស្ងៀមស្ងាត់នៅគ្រប់ទីកន្លែង មិនដែលលេចមកឲ្យយើងឃើញឡើយក៏មិនដែលមានបន្ទូលមកកាន់យើងដែរ។ ដូច្នេះហើយ ការអនុវត្តតាមព្រះគម្ពីរ និងតាមទីសម្គាល់បញ្ជាក់ថាយើងមានបំណងធ្វើការវិនិច្ឆ័យអំពីបំណងព្រះហឫទ័យ និងនិស្ស័យរបស់ព្រះជាម្ចាស់។ យើងបានស៊ាំនឹងភាពស្ងៀមស្ងាត់របស់ព្រះជាម្ចាស់ យើងបានស៊ាំនឹងការវាស់ស្ទង់លើការប្រព្រឹត្តរបស់ខ្លួនថាត្រូវ និងខុស តាមតែគំនិតផ្ទាល់ខ្លួនរបស់យើង យើងបានស៊ាំនឹងការពឹងផ្អែកលើចំណេះដឹង សញ្ញាណ និងក្រមសីលធម៌របស់យើង ដែលព្រះជាម្ចាស់តម្រូវពីយើង យើងបានស៊ាំនឹងការរីករាយចំពោះព្រះគុណរបស់ព្រះជាម្ចាស់ យើងបានស៊ាំនឹងការមានព្រះជាម្ចាស់ចាំប្រទានជំនួយនៅពេលដែលយើងត្រូវការ យើងបានស៊ាំនឹងការលូកដៃទៅរកព្រះជាម្ចាស់ និងបញ្ជាទ្រង់គ្រប់រឿង យើងក៏បានស៊ាំនឹងអនុលោមតាមបទបញ្ជាដែរ តែមិនយកចិត្តទុកដាក់ចំពោះរបៀបដែលព្រះវិញ្ញាណបរិសុទ្ធដឹកនាំយើងទេ ហើយលើសពីនោះទៀត យើងក៏ស៊ាំនឹងសភាពសព្វថ្ងៃដែលយើងធ្វើជាចៅហ្វាយលើខ្លួនឯងដែរ។ យើងជឿលើព្រះមួយ

អង្គ ដែលយើងមិនធ្លាប់ជួបមុខទល់នឹងមុខសោះ។ សំណួរដូចជា តើទ្រង់មាននិស្ស័យបែបណា តើទ្រង់មានលក្ខណៈបែបណា ហើយមានអ្វីខ្លះ តើរូបអង្គទ្រង់មានលក្ខណៈបែបណា តើយើងស្គាល់ទ្រង់ឬអត់នៅពេលដែលទ្រង់យាងមក និងសំណួរផ្សេងៗទៀត គឺសុទ្ធតែគ្មានអ្វីសំខាន់នោះទេ។ អ្វីដែលសំខាន់នោះ គឺទ្រង់គង់នៅក្នុងចិត្តរបស់យើង ហើយថាយើងទាំងអស់គ្នាសុទ្ធតែរង់ចាំទ្រង់ ហើយវាល្មមនឹងអាចឲ្យយើងស្រម៉ៃថាទ្រង់បែបនេះ ឬក៏បែបនោះ។ យើងសរសើរពីសេចក្ដីជំនឿរបស់យើង ហើយឲ្យតម្លៃទៅលើជីវិតខាងព្រលឹងវិញ្ញាណរបស់យើង។ យើងមើលទៅអ្វីៗទាំងអស់ដូចជាលាមក ហើយជាន់ឈ្លីអ្វីៗទាំងអស់នៅក្រោមជើង។ ដោយព្រោះយើងជាអ្នកជឿលើព្រះអម្ចាស់ដ៏មានសិរីល្អ មិនថាដំណើរនោះវែងឆ្ងាយ ហើយតឹងតែងប៉ុនណា មិនថាការលំបាក និងគ្រោះថ្នាក់កើតឡើងចំពោះយើងយ៉ាងណាក៏ដោយក៏គ្មានអ្វីដែលអាចបញ្ឈប់ជំហានជើងរបស់យើងបានដែរ នៅពេលដែលយើងដើរតាមព្រះអម្ចាស់។ «ទន្លេជីវិតដ៏បរិសុទ្ធមួយ ថ្លាដូចកែវចរណៃ ហូរចេញពីបល្ល័ង្ករបស់ព្រះជាម្ចាស់ និងកូនចៀម។ នៅសងខាងទន្លេនេះ មានដើមជីវិតដែលបង្កើតផ្លែដប់ពីរដង គឺរៀងរាល់ខែ ឯស្លឹករបស់វា គឺសម្រាប់ប្រោសប្រជាជាតិនានាឲ្យជា។ នឹងគ្មានបណ្ដាសាទៀតឡើយ គឺមានតែបល្ល័ង្ករបស់ព្រះ និងកូនចៀមនៅទីនោះវិញ ហើយអ្នកបម្រើទ្រង់ នឹងនៅបម្រើទ្រង់ ពួកគេនឹងមើលឃើញព្រះភក្ត្រទ្រង់ ហើយព្រះនាមទ្រង់ នឹងឆ្លាក់នៅជាប់នឹងថ្ងាសរបស់គេ។ នៅទីនោះគ្មានពេលយប់ទេ ហើយពួកគេក៏មិនត្រូវការទៀន ឬត្រូវការពន្លឺព្រះអាទិត្យដែរ ដ្បិតព្រះអម្ចាស់ដ៏ជាព្រះ ប្រទានពន្លឺដល់គេ ហើយពួកគេនឹងគ្រងរាជ្យដរាបអស់កល្បជានិច្ច» (វិវរណៈ ២២:១-៥)។ រាល់ពេលដែលយើងច្រៀងពាក្យពេចន៍ទាំងនេះ ចិត្តរបស់យើងពោរពេញទៅដោយអំណរ និងការពេញចិត្តឥតព្រំដែន ហើយទឹកភ្នែកក៏ហូរចេញពីភ្នែករបស់យើងមក។ សូមអរព្រះគុណដល់ព្រះអម្ចាស់ ដែលជ្រើសរើសយើង សូមអរព្រះគុណព្រះអម្ចាស់ចំពោះព្រះគុណរបស់ទ្រង់។ ទ្រង់បានប្រទានដល់យើងមួយរយដងនៅក្នុងជីវិតនេះ ហើយទ្រង់បានប្រទានជីវិតអស់កល្បជានិច្ចដល់យើងនៅលោកខាងមុខ។ ប្រសិនបើទ្រង់ឲ្យយើងស្លាប់ឥលូវនេះ យើងនឹង

ធ្វើតាមភ្លាមដោយមិនត្អូញត្អែរអ្វីបន្តិចឡើយ។ ឱព្រះអម្ចាស់អើយ សូមទ្រង់មេត្តាឆាប់យាងមក! សូមទ្រង់ពិចារណាមើល យើងខ្ញុំត្រូវការទ្រង់ខ្លាំងណាស់ ហើយយើងបានលះបង់អ្វីៗគ្រប់យ៉ាងថ្វាយទ្រង់ សូមទ្រង់កុំពន្យារពេលទៀតឡើយ សូម្បីតែមួយនាទីឬក៏មួយវិនាទី។

ព្រះជាម្ចាស់នៅស្ងៀម ហើយទ្រង់មិនដែលលេចមកឲ្យយើងឃើញឡើយ ប៉ុន្តែកិច្ចការរបស់ទ្រង់មិនដែលឈប់ឡើយ។ ទ្រង់ស្ទង់មើលផែនដីទាំងមូល ហើយបញ្ជាអ្វីៗទាំងអស់ ព្រមទាំងទតមើលពាក្យសម្ដី និងការប្រព្រឹត្តទាំងអស់របស់មនុស្ស។ ទ្រង់អនុវត្តការគ្រប់គ្រងរបស់ទ្រង់តាមជំហានដ៏ល្អិតល្អន់ និងទៅតាមផែនការរបស់ទ្រង់ដោយសម្ងាត់ និងគ្មានឥទ្ធិពលអស្ចារ្យអ្វីនោះទេ ប៉ុន្តែជំហានព្រះបាទារបស់ទ្រង់ឆ្ពោះទៅមុខមួយជំហានម្ដងៗ ខិតទៅកាន់តែជិតមនុស្សជាតិ ហើយបល្ល័ង្កជំនុំជម្រះរបស់ទ្រង់បានសម្ដែងនៅលើសកលលោកទាំងមូលលឿនដូចជាផ្លេកបន្ទោរ បន្ទាប់ពីបល្ល័ង្ករបស់ទ្រង់ ចុះមកកណ្ដាលចំណោមយើងភ្លាមៗ។ នោះគឺជាទស្សនីយភាពមួយដ៏អស្ចារ្យ ជាទិដ្ឋភាពដ៏វិសេសវិសាល និងឱឡារិកមួយ។ ព្រះវិញ្ញាណយាងចុះមកកណ្ដាលយើងប្រៀបដូចជាសត្វព្រាបមួយក្បាល និងសឹង្ហមួយក្បាលដែលកំពុងគ្រហឹម។ ទ្រង់គឺជាប្រាជ្ញា ជាសេចក្ដីបរិសុទ្ធ និងជាអានុភាពដ៏អស្ចារ្យ ហើយទ្រង់យាងចុះមកកណ្ដាលចំណោមយើងដោយស្ងាត់ៗ ដោយសិទ្ធិអំណាចគ្រប់គ្រង និងពេញដោយសេចក្ដីស្រលាញ់ ព្រមទាំងសេចក្ដីមេត្តាករុណា។ គ្មាននរណាម្នាក់ដឹងពីការយាងមកដល់របស់ទ្រង់ឡើយ គ្មាននរណាម្នាក់ស្វាគមន៍ការយាងមកដល់របស់ទ្រង់ឡើង ហើយលើសពីនោះទៀតគឺគ្មាននរណាម្នាក់ដឹងពីអ្វីគ្រប់យ៉ាងដែលទ្រង់រៀបនឹងធ្វើឡើយ។ ជីវិតរបស់មនុស្សបន្តទៅដូចកាលពីមុន ដួងចិត្តរបស់ពួកគេមិនខុសប្លែកអ្វីឡើយ ហើយថ្ងៃក៏កន្លងផុតទៅដូចធម្មតាដែរ។ ព្រះជាម្ចាស់គង់នៅកណ្ដាលចំណោមយើង ក្នុងលក្ខណៈជាមនុស្សម្នាក់ដូចជាមនុស្សផ្សេងទៀតដែរ គឺជាមនុស្សម្នាក់ដែលសំខាន់បំផុតក្នុងចំណោមអ្នកដើរតាម និងជាអ្នកជឿធម្មតាម្នាក់។ ទ្រង់មានការស្វែងរកផ្ទាល់ខ្លួន ទ្រង់មានគោលដៅផ្ទាល់ខ្លួន ហើយលើសពីនោះទៀត

ទ្រង់មានភាពជាព្រះដែលមនុស្សធម្មតាមិនមានឡើយ។ គ្មាននរណាម្នាក់កត់សម្គាល់ពីអត្ថិភាពនៃភាពជាព្រះរបស់ទ្រង់ឡើង ហើយគ្មាននរណាម្នាក់បានយល់ដឹងអំពីភាពខុសគ្នារវាងលក្ខណៈរបស់ទ្រង់ និងភាពជាមនុស្សរបស់ទ្រង់នោះឡើយ។ យើងរស់នៅជាមួយទ្រង់ ដោយមិនគ្មានការបង្ខិតបង្ខំ និងគ្មានខ្លាចអ្វីឡើយ ដ្បិតនៅក្នុងភ្នែករបស់យើង ទ្រង់គឺជាអ្នកជឿម្នាក់ដែលមិនសំខាន់។ ទ្រង់ទតមើលគ្រប់ដំណើរផ្លាស់ប្ដូររបស់យើង ហើយគំនិតនិងយោបល់របស់យើងទាំងប៉ុន្មានសុទ្ធតែត្រូវបានលាតត្រដាងនៅចំពោះទ្រង់។ គ្មាននរណាម្នាក់ចាប់អារម្មណ៍ចំពោះអត្ថិភាពរបស់ទ្រង់ឡើយ គ្មាននរណាម្នាក់ នឹកឃើញដល់មុខងាររបស់ទ្រង់ឡើយ ហើយលើសពីនោះទៀត គ្មាននរណាម្នាក់សង្ស័យអ្វីបន្តិចអំពីអត្តសញ្ញាណរបស់ទ្រង់ឡើយ។ អ្វីៗដែលយើងធ្វើគឺបន្តការស្វែងរករបស់ខ្លួន ហាក់ដូចជាទ្រង់គ្មានជាប់ទាក់ទងអ្វីនឹងយើងបន្តិចឡើយ ...

ថ្ងៃដន្យ ព្រះវិញ្ញាណបរិសុទ្ធសម្ដែងអត្ថបទព្រះបន្ទូល «តាមរយៈ» ទ្រង់ ហើយទោះបីវាមានអារម្មណ៍ហាក់ដូចជាស្មានមិនដល់ក៏ដោយ ក៏យើងទទួលស្គាល់ថា វាជាព្រះបន្ទូលដែលមកចេញពីព្រះជាម្ចាស់ និងទទួលយកពីព្រះជាម្ចាស់យ៉ាងងាយស្រួលដែរ។ នោះគឺដោយសារថា ដរាបណាព្រះបន្ទូលទាំងនោះមកពីព្រះវិញ្ញាណបរិសុទ្ធនោះយើងគួរតែទទួលយក មិនត្រូវបដិសេធឡើយ ទោះបីជានរណាសម្ដែងព្រះបន្ទូលទាំងនេះក៏ដោយ។ ព្រះសូរសៀងបន្ទាប់ទៀត អាចមកតាមរយៈខ្ញុំ ឬក៏តាមរយៈអ្នក ឬមួយក៏តាមរយៈនរណាម្នាក់ផ្សេងទៀត។ មិនថាបុគ្គលនោះជានរណាទេ ទាំងនេះគឺជាព្រះគុណរបស់ព្រះជាម្ចាស់។ ប៉ុន្តែ មិនថាបុគ្គលនោះជានរណាទេ យើងមិនអាចថ្វាយបង្គំបានឡើយ ដ្បិតមិនថាយ៉ាងណាទេ បុគ្គលនេះមិនអាចជាព្រះជាម្ចាស់បានឡើយ ហើយយើងក៏មិនត្រូវជ្រើសរើសមនុស្សដ៏សាមញ្ញធម្មតាបែបនេះមកធ្វើជាព្រះជាម្ចាស់របស់យើងដែរ ទោះជាតាមវិធីណាក៏ដោយ។ ព្រះជាម្ចាស់របស់យើងធំមហិមា និងគួរឲ្យលើកតម្កើង តើមនុស្សដែលមិនសំខាន់បែបនេះអាចឈរជំនួសកន្លែងរបស់ទ្រង់យ៉ាងដូចម្ដេចកើត? អ្វីដែលលើសពីនេះទៀត គឺយើងកំពុងរង់ចាំព្រះជាម្ចាស់យាងមក ហើយនាំយើងត្រលប់ទៅនរគរស្ថានសួគ៌វិញ ដូច្នេះតើបុគ្គល

ម្នាក់ដែលមិនសំខាន់បែបនេះ អាចធ្វើកិច្ចការមួយដ៏សំខាន់ និងលំបាកបែបនេះបានយ៉ាងដូចម្ដេចកើត? ប្រសិនបើព្រះអម្ចាស់យាងមកម្ដងទៀត គឺត្រូវតែយាងមកនៅលើពពកពណ៌សមួយដុំ ដើម្បីឲ្យហ្វូងមនុស្សទាំងអស់អាចមើលឃើញ។ នោះគឺជារឿងដែលប្រកបដោយសិរីល្អ! តើទ្រង់អាចលាក់ខ្លួនស្ងាត់ៗក្នុងចំណោមក្រុមមនុស្សដ៏សាមញ្ញធម្មតាយ៉ាងដូចម្ដេចកើត?

ហើយបុគ្គលធម្មតា ដែលបានលាក់កំបាំង នៅកណ្ដាលចំណោមមនុស្សនេះ ហើយជាអ្នក ដែលកំពុងធ្វើកិច្ចការថ្មីនៃការសង្គ្រោះយើង។ ទ្រង់មិនពន្យល់ប្រាប់យើងទេ ហើយទ្រង់ក៏មិនមានបន្ទូលប្រាប់យើងពីមូលហេតុដែលទ្រង់បានយាងមកដែរ ប៉ុន្តែទ្រង់ធ្វើកិច្ចការដែលទ្រង់សព្វព្រះហឫទ័យចង់ធ្វើយ៉ាងសាមញ្ញ តាមជំហានដ៏ល្អិតល្អន់ និងទៅតាមផែនការរបស់ទ្រង់។ ព្រះបន្ទូល និងព្រះសូរសៀងរបស់ទ្រង់បានសម្ដែងចេញមកកាន់តែញឹកញាប់។ ពីការលួងលោម ការដាស់តឿន ការរំឭកនិងការព្រមាន ទៅដល់កាបន្ទោស និងការដាក់វិន័យ ហើយពីសូរសៀងទន់ភ្លន់ និងសុភាពរាបសារ ទៅដល់ព្រះបន្ទូលដ៏កាចសាហាវ និងប្រកបដោយអនុភាព ហើយទាំងអស់នេះសុទ្ធតែផ្ដល់នូវសេចក្ដីមេត្តាករុណាដល់មនុស្ស និងបណ្ដុះភាពភ័យខ្លាចនៅក្នុងគេ។ គ្រប់យ៉ាងដែលទ្រង់មានបន្ទូល សុទ្ធតែត្រូវចំអាថ៌កំបាំងដែលលាក់ទុកយ៉ាងជ្រៅនៅក្នុងខ្លួនយើង ព្រះបន្ទូលរបស់ទ្រង់ចាក់ដោតដួងចិត្តយើង ចាក់ដោតព្រលឹងវិញ្ញាណយើង ហើយធ្វើឲ្យយើងមានភាពអាម៉ាស់ដែលមិនអាចទ្រាំទ្របាន ទាំងមិនដឹងថាត្រូវលាក់ខ្លួននៅកន្លែងណា។ យើងចាប់ផ្ដើមងឿងឆ្ងល់ថា តើព្រះជាម្ចាស់ដែលគង់នៅក្នុងដួងចិត្តរបស់បុគ្គលនេះ ពិតជាស្រលាញ់យើងមែនឬអត់ ហើយតើទ្រង់ព្រះតម្រិះពីអ្វីឲ្យពិតប្រាកដ។ ប្រហែលជាយើងអាចត្រូវបានលើកឡើងទៅលើអាកាស ក្រោយពេលស៊ូទ្រាំនឹងការរងទុក្ខទាំងអស់នេះទេដឹង? នៅក្នុងខួរក្បាលរបស់យើង គឺយើងកំពុងគន់គូរ... អំពីទិសដៅខាងមុខ និងជោគវាសនាអនាគតរបស់យើង។ ប៉ុន្តែ វានៅតែដូចកាលពីមុនដដែល គឺគ្មាននរណាម្នាក់នៅក្នុងចំណោមយើងរាល់គ្នាជឿថាព្រះជាម្ចាស់ បានយាងមកយកនិស្ស័យជាសាច់ឈាម ដើម្បីធ្វើកិច្ចការនៅ

កណ្ដាលចំណោមយើងរួចទៅហើយនោះទេ។ ទោះបីជាទ្រង់បានអមដំណើរជាមួយយើងអស់រយៈពេលយ៉ាងយូរបែបនេះហើយក៏ដោយ ហើយទោះបីជាទ្រង់បានមានបន្ទូលយ៉ាងច្រើនជាមួយយើងដោយមុខទល់នឹងមុខក៏ដោយ ក៏យើងនៅតែមិនព្រមទទួលយកបុគ្គលដ៏សាមញ្ញធម្មតាបែបនេះធ្វើជាព្រះជាម្ចាស់នៃអនាគតរបស់យើងដដែល ហើយយើងនៅតែមិនព្រមប្រគល់ការគ្រប់គ្រងលើអនគត និងជោគវាសនារបស់យើងទៅបុគ្គលដែលមិនសំខាន់បែបនេះដែរ។ តាមរយៈទ្រង់ យើងរីករាយចំពោះការផ្គត់ផ្គង់ទឹករស់ដែលមិនចេះរីងស្ងួត ហើយតាមរយៈទ្រង់ យើងរស់នៅមុខទល់នឹងមុខជាមួយព្រះជាម្ចាស់។ ប៉ុន្តែ យើងអរគុណតែចំពោះព្រះគុណរបស់ព្រះអម្ចាស់យេស៊ូវ ដែលគង់នៅស្ថានសួគ៌ប៉ុណ្ណោះ ហើយយើងមិនដែលយកចិត្តទុកដាក់ ចំពោះអារម្មណ៍របស់បុគ្គលដ៏សាមញ្ញម្នាក់នេះ ដែលមានភាពជាព្រះនោះទេ។ ទ្រង់នៅតែធ្វើកិច្ចការរបស់ទ្រង់ ទាំងបន្ទាបព្រះអង្គទ្រង់យ៉ាងលាក់កំបាំងនៅក្នុងសាច់ឈាមដូចកាលពីមុនដដែល ដើម្បីបង្ហាញពីព្រះហឫទ័យដ៏ជ្រាលជ្រៅរបស់ទ្រង់ចំពោះមនុស្ស ទាំងអត់ទោសចំពោះភាពផ្ដេសផ្ដាសដូចជាកូនក្មេង និងភាពល្ងង់ខ្លៅរបស់មនុស្សជរាបអស់កល្បជានិច្ច ហើយក៏អត់ឱនចំពោះអាកប្បកិរិយាឆ្គាំឆ្គងរបស់មនុស្សចំពោះទ្រង់ ដោយហាក់ដូចជាមិនខ្វល់នឹងការបដិសេធរបស់ពួកគេចំពោះទ្រង់សោះឡើយ។

បុគ្គលដែលមិនសំខាន់ម្នាក់នេះ បានដឹកនាំយើងចូលទៅក្នុងកិច្ចការរបស់ព្រះជាម្ចាស់មួយជំហានម្ដងៗ ទាំងដែលយើងមិនដឹងខ្លួនសោះ។ យើងឆ្លងកាត់នូវទុក្ខលំបាករាប់មិនអស់ ទទួលទោសជាច្រើន និងត្រូវបានល្បងលដោយសេចក្ដីស្លាប់។ យើងរៀនសូត្រអំពីនិស្ស័យដ៏សុចរិត និងប្រកបដោយតេជានុភាពរបស់ព្រះជាម្ចាស់ ក៏រីករាយចំពោះសេចក្ដីស្រលាញ់ និងសេចក្ដីមេត្តាករុណារបស់ទ្រង់ ព្រមទាំងចាប់ផ្ដើមកោតសរសើរអំពីព្រះចេស្ដា និងព្រះប្រាជ្ញាញាណដ៏អស្ចារ្យរបស់ទ្រង់ ធ្វើបន្ទាល់ពីសេចក្ដីស្រលាញ់របស់ព្រះជាម្ចាស់ និងសម្លឹងមើលព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែលចង់ជួយសង្គ្រោះមនុស្ស។ តាមរយៈពាក្យសម្ដីរបស់បុគ្គលធម្មតាម្នាក់នេះ យើង

ចាប់ផ្ដើមស្គាល់អំពីនិស្ស័យ និងលក្ខណៈរបស់ព្រះជាម្ចាស់ ចាប់ផ្ដើមយល់ពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ស្គាល់និស្ស័យ និងលក្ខណៈរបស់មនុស្ស ព្រមទាំងមើលឃើញផ្លូវទៅកាន់សេចក្ដីសង្គ្រោះ និងភាពគ្រប់លក្ខណ៍ផងដែរ។ ព្រះបន្ទូលរបស់ទ្រង់បណ្ដាលឲ្យយើង «ស្លាប់» ហើយព្រះបន្ទូលទាំងនោះក៏បណ្ដាលឲ្យយើង «កើតជាថ្មី» ដែរ។ ព្រះបន្ទូលរបស់ទ្រង់នាំយកមកនូវការកំសាន្ដចិត្តដល់យើង ប៉ុន្តែក៏នាំមកនូវការឈឺចាប់គ្មានព្រំដែនដែរ។ ពេលខ្លះ យើងដូចជាកូនចៀមដែលយកទៅសម្លាប់នៅក្នុងព្រះហស្តទ្រង់ ពេលខ្លះយើងប្រៀបបីដូចជាប្រស្រីព្រះនេត្ររបស់ទ្រង់ និងរីករាយចំពោះសេចក្ដីស្រលាញ់ដ៏ផ្អែមល្ហែមរបស់ទ្រង់ ពេលខ្លះទៀតយើងប្រៀបបីដូចជាខ្មាំងសត្រូវរបស់ទ្រង់ ហើយស្ថិតក្រោមការឃ្លាំមើលរបស់ទ្រង់ក៏ប្រែក្លាយទៅជាផេះ ដោយសារសេចក្ដីក្រោធរបស់ទ្រង់។ យើងគឺជាពូជមនុស្សដែលបានសង្គ្រោះដោយសារទ្រង់ យើងគឺជាដង្កូវនៅក្នុងព្រះនេត្រទ្រង់ ហើយយើងគឺជាកូនចៀមវង្វេង ដែលទ្រង់បានបន្ទាបព្រះអង្គទ្រង់តាមរកទាំងយប់ទាំងថ្ងៃ។ ទ្រង់ពេញដោយសេចក្ដីមេត្តាករុណាចំពោះយើង ទ្រង់ស្អប់យើង ទ្រង់លើកយើងឡើង ទ្រង់កំសាន្ដចិត្តយើង ហើយណែនាំយើង ទ្រង់ដឹកនាំយើង ទ្រង់បំភ្លឺយើង ទ្រង់វាយផ្ចាល និងដាក់វិន័យយើង ហើយទ្រង់ក៏ដាក់បណ្ដាសាយើងដែរ។ ទាំងយប់ទាំងថ្ងៃ ទ្រង់មិនដែលឈប់បារម្ភពីយើងឡើយ ហើយទ្រង់ការពារ និងថែរក្សាយើងទាំងយប់ទាំងថ្ងៃ ដោយមិនមិនឃ្លាតឆ្ងាយពីយើងឡើយ ប៉ុន្តែទ្រង់បានបង្ហូរព្រះលោហិតពីបេះដូងរបស់ទ្រង់សម្រាប់ជាប្រយោជន៍ដល់យើង និងបង់តម្លៃគ្រប់យ៉ាងជំនួសយើង។ នៅក្នុងព្រះបន្ទូលនៃរូបកាយជាសាច់ឈាមដ៏តូច និងធម្មតានេះ យើងក៏បានរីករាយនឹងភាពពេញលេញរបស់ព្រះជាម្ចាស់ ព្រមទាំងបានមើលឃើញទិសដៅដែលព្រះជាម្ចាស់បានប្រទានដល់យើងទៀតផង។ ទោះជាយ៉ាងនេះក្ដី ភាពឥតប្រយោជន៍នៅតែបង្កបញ្ហានៅក្នុងដួងចិត្តរបស់យើងដដែល ហើយយើងនៅតែមិនព្រមទទួលយកបុគ្គលបែបនេះមកធ្វើជាព្រះជាម្ចាស់របស់យើងដដែល។ ទោះបីជាទ្រង់បានប្រទាននំម៉ាណាជាច្រើនដល់យើង ដើម្បីឲ្យយើងរីករាយច្រើនប៉ុនណាក៏ដោយ ក៏គ្មានអ្វីមួយក្នុងចំណោមនេះ

អាចជំនួសកន្លែងរបស់ព្រះអម្ចាស់នៅក្នុងដួងចិត្តយើងបានដែរ។ យើងលើកតម្កើងអត្តសញ្ញាណ និងឋានៈដ៏ពិសេសរបស់បុគ្គលម្នាក់នេះ ត្រឹមតែដោយភាពស្ងាក់ស្ទើរខ្លាំងប៉ុណ្ណោះ។ ដរាបណាទ្រង់មិនបើកព្រះឱស្ឋរបស់ទ្រង់ប្រាប់ឲ្យយើងទទួលស្គាល់ថាទ្រង់គឺជាព្រះជាម្ចាស់ទេ នោះយើងប្រាកដជានឹងមិនទទួលស្គាល់ទ្រង់ដោយខ្លួនឯងថាព្រះអង្គគឺជាព្រះជាម្ចាស់ដែលត្រូវយាងមកក្នុងពេលឆាប់ៗ និងបានកំពុងតែធ្វើកិច្ចការក្នុងចំណោមយើងរាល់គ្នាជាយូរមកហើយនោះឡើយ។

ព្រះជាម្ចាស់បន្តព្រះសូរសៀងរបស់ទ្រង់ដោយប្រើវិធីសាស្ត្រ និងទស្សនៈផ្សេងៗជាច្រើន ដើម្បីដាស់តឿនយើងអំពីអ្វីដែលយើងគួរធ្វើ ខណៈដែលក្នុងពេលជាមួយគ្នាថ្វាយសម្លេងដល់ដួងព្រះហឫទ័យរបស់ទ្រង់។ ព្រះបន្ទូលរបស់ទ្រង់ មានអំណាចចេស្ដាលើជីវិត បង្ហាញផ្លូវដែលយើងគួរដើរ និងជួយឲ្យយើងអាចយល់ពីអ្វីដែលជាសេចក្ដីពិត។ យើងចាប់ផ្ដើមត្រូវបានទាក់ទាញដោយព្រះបន្ទូលរបស់ទ្រង់ យើងចាប់ផ្ដើមផ្ដោតសំខាន់ទៅលើកម្រិតសម្លេង និងលក្ខណៈនៃការមានបន្ទូលរបស់ទ្រង់ ហើយយើងចាប់ផ្ដើមចាប់អារម្មណ៍ដោយមិនដឹងខ្លួន ចំពោះអារម្មណ៍ដ៏ជ្រាលជ្រៅបំផុតរបស់បុគ្គលដ៏សាមញ្ញម្នាក់នេះ។ ទ្រង់បង្ហូរព្រះលោហិតចេញពីដួងព្រះហឫទ័យរបស់ទ្រង់ជំនួសយើង ផ្ទុំពុំលក់ និងសោយអាហារពុំបានដោយសាររឿងរបស់យើង ព្រះកន្សែងជំនួសយើង នឿយដើម្បីយើង ស្រែកថ្ងូរដោយសារជំងឺជំនួសយើង រងភាពអាម៉ាស់ដើម្បីជាប្រយោជន៍ដល់ទិសដៅ និងសេចក្ដីសង្គ្រោះរបស់យើង ហើយភាពស្ពឹកស្រពន់ និងការបះបោររបស់យើង បានធ្វើឲ្យទឹកភ្នែក និងព្រះលោហិតហូរចេញពីដួងព្រះហឫទ័យរបស់ទ្រង់មក។ ព្រះហឫទ័យបែបនេះមិនមែនជាកម្មសិទ្ធិរបស់មនុស្សសាមញ្ញធម្មតាណាម្នាក់ឡើយ ហើយក៏គ្មានមនុស្សពុករលួយណាម្នាក់អាចកាន់កាប់ ឬក៏ទទួលបាននោះដែរ។ ទ្រង់បង្ហាញការអត់ឱន និងការអត់ធ្មត់ដែលគ្មានមនុស្សសាមញ្ញធម្មតាណាម្នាក់មានឡើយ ហើយសេចក្ដីស្រលាញ់របស់ទ្រង់មិនមែនជាអ្វីម៉្យាងដែលជីវិតផងទាំងពួងដ៏ជាស្នាព្រះហស្ដរបស់ទ្រង់ បានទទួលជាទេយ្យទាននោះទេ។ ក្រៅពីទ្រង់ គ្មាននរណាម្នាក់អាចដឹងពីអ្វីៗគ្រប់យ៉ាងនៅក្នុង

គំនិតរបស់យើង ឬក៏យល់ច្បាស់ទាំងស្រុងអំពីលក្ខណៈ និងសារជាតិរបស់យើង ឬក៏វិនិច្ឆ័យទៅលើការបះបោរ និងភាពពុករលួយរបស់មនុស្សជាតិ ឬក៏និយាយមកកាន់យើង និងចាត់ចែងយើងបែបនេះ ជំនួសព្រះជាម្ចាស់ដែលគង់នៅស្ថានសួគ៌ឡើយ។ ក្រៅពីទ្រង់ គ្មាននរណាម្នាក់បានទទួលសិទ្ធិអំណាច ប្រាជ្ញាញាណ និងសេចក្ដីថ្លៃថ្នូររបស់ព្រះជាម្ចាស់ឡើយ ហើយនិស្ស័យរបស់ព្រះជាម្ចាស់ កម្មសិទ្ធិ និងលក្ខណៈរបស់ព្រះជាម្ចាស់បានបង្ហាញពីភាពពេញលេញរបស់ខ្លួននៅក្នុងទ្រង់។ ក្រៅពីទ្រង់ គ្មាននរណាម្នាក់អាចបង្ហាញផ្លូវដល់យើង និងនាំពន្លឺមកដល់យើងឡើយ។ ក្រៅពីទ្រង់ គ្មាននរណាម្នាក់អាចបើកសម្ដែងពីអាថ៌កំបាំងដែលព្រះជាម្ចាស់បានបង្ហាញចាប់តាំងពីការបង្កបង្កើត រហូតមកដល់សព្វថ្ងៃនេះឡើយ។ ក្រៅពីទ្រង់ គ្មាននរណាម្នាក់អាចសង្គ្រោះយើងពីចំណងសាតាំង និងនិស្ស័យពុករលួយរបស់យើងឡើយ។ ទ្រង់តំណាងឲ្យព្រះជាម្ចាស់។ ទ្រង់សម្ដែងអំពីដួងព្រះហឫទ័យដ៏ជ្រាលជ្រៅបំផុតរបស់ព្រះជាម្ចាស់ ការដាស់តឿនរបស់ព្រះជាម្ចាស់ និងព្រះបន្ទូលជំនុំជម្រះរបស់ព្រះជាម្ចាស់ចំពោះមនុស្សជាតិទាំងអស់។ ទ្រង់បានចាប់ផ្ដើមយុគសម័យថ្មីមួយ និងបាននាំផ្លូវនៅក្នុងផ្ទៃមេឃ ផែនដីថ្មី ព្រមទាំងកិច្ចការថ្មី ហើយទ្រង់បាននាំសេចក្ដីសង្ឃឹមមកដល់យើង ដោយបញ្ចប់ជីវិត ដែលយើងបានដឹកនាំក្នុងភាពស្រពេចស្រពិល ព្រមទាំងធ្វើឲ្យរូបកាយទាំងមូលរបស់យើងមើលឃើញផ្លូវទៅកាន់សេចក្ដីសង្គ្រោះច្បាស់លាស់។ ទ្រង់បានយកឈ្នះលើរូបកាយរបស់យើងទាំងមូល និងទទួលបានដួងចិត្តរបស់យើង។ ចាប់ពីពេលនោះមក ចិត្តគំនិតរបស់យើងបានភ្ញាក់ដឹងខ្លួន ហើយវិញ្ញាណរបស់យើងក៏ហាក់ដូចជាបានរស់ឡើងវិញដែរ៖ តើបុគ្គលដ៏សាមញ្ញធម្មតា និងមិនសំខាន់ដែលរស់នៅក្នុងចំណោមយើង និងត្រូវបានយើងបដិសេធជាយូរមកហើយនោះ មិនមែនជាព្រះអម្ចាស់យេស៊ូវដែលនៅក្នុងចិត្តយើង ដែលយើងទន្ទឹងរង់ចាំទាំងយប់ទាំងថ្ងៃ ទាំងភ្ញាក់ ទាំងគេងទេឬអី? គឺទ្រង់នេះហើយ! គឺពិតជាទ្រង់នេះហើយ! ទ្រង់គឺជាព្រះជាម្ចាស់របស់យើង! ទ្រង់គឺជាផ្លូវ ជាសេចក្ដីពិត និងជាជីវិត! ទ្រង់បានជួយឲ្យយើងអាចរស់នៅជាថ្មីម្ដងទៀត និងអាចឃើញពន្លឺជាថ្មី ព្រមទាំងបានបញ្ឈប់ដួងចិត្តរបស់យើងកុំឲ្យ

វង្វេង។ យើងបានវិលត្រលប់ទៅកាន់ដំណាក់របស់ព្រះជាម្ចាស់វិញ យើងបានវិលត្រលប់មកនៅមុខបល្ល័ង្ករបស់ទ្រង់វិញ យើងនៅជាមួយទ្រង់ដោយមុខទល់នឹងមុខ យើងបានធ្វើបន្ទាល់អំពីការអនុញ្ញាតរបស់ទ្រង់ ហើយយើងបានមើលឃើញផ្លូវដែលនៅខាងមុខ។ នៅពេលនោះ ទ្រង់បានយកឈ្នះលើដួងចិត្តរបស់យើងទាំងស្រុង យើងលែងសង្ស័យថាទ្រង់ជានរណាទៀតហើយ យើងលែងប្រឆាំងនឹងកិច្ចការរបស់ទ្រង់ ព្រមទាំងព្រះបន្ទូលទៀតហើយ ហើយយើងក៏ក្រាបថ្វាយបង្គំនៅចំពោះទ្រង់ដែរ។ យើងមិនប្រាថ្នាចង់បានអ្វីក្រៅពីដើរតាមស្នាមព្រះបាទារបស់ទ្រង់អស់មួយជីវិតរបស់យើង និងបានគ្រប់លក្ខណ៍ដោយសារទ្រង់ តបស្នងចំពោះព្រះគុណ និងសេចក្ដីស្រលាញ់របស់ទ្រង់ចំពោះយើង ហើយស្ដាប់តាមការចាត់ចែង និងការរៀបចំរបស់ទ្រង់ ព្រមទាំងសហការជាមួយកិច្ចការរបស់ទ្រង់ និងធ្វើអ្វីៗដែលយើងអាចធ្វើបាន ដើម្បីបំពេញនូវអ្វីដែលទ្រង់ផ្ទុកដាក់នឹងយើង។

ការដែលត្រូវបានយកឈ្នះដោយព្រះជាម្ចាស់ គឺប្រៀបដូចជាការប្រកួតក្បាច់គុណមួយ។

ព្រះបន្ទូលនីមួយៗរបស់ព្រះជាម្ចាស់ សុទ្ធតែវាយចំចំណុចស្លាប់របស់យើង ដោយធ្វើឲ្យយើងរងរបួស និងពេញដោយភាពភ័យខ្លាច។ ទ្រង់លាតត្រដាងសញ្ញាណរបស់យើង ការស្រមើស្រមៃរបស់យើង និងនិស្ស័យពុករលួយរបស់យើង។ ចាប់ពីអ្វីៗគ្រប់យ៉ាងដែលយើងនិយាយ និងអ្វីៗគ្រប់យ៉ាងដែលយើងធ្វើ រហូតទៅដល់គំនិតនិងយោបល់គ្រប់យ៉ាងរបស់យើង ធម្មជាតិនិងសារជាតិរបស់យើង គឺសុទ្ធតែត្រូវបានបើកសម្ដែងឲ្យឃើញតាមរយៈព្រះបន្ទូលទ្រង់ ដែលធ្វើឲ្យយើងស្ថិតក្នុងសភាពភ័យខ្លាច និងញាប់ញ័រ ដោយគ្មានកន្លែងដើម្បីលាក់បាំងភាពអាម៉ាស់របស់ខ្លួន។ ទ្រង់មានបន្ទូលប្រាប់យើងអំពីសកម្មភាព គោលបំណង និងចេតនារបស់យើងម្ដងមួយៗ សូម្បីតែនិស្ស័យពុករលួយរបស់យើង ដែលយើងខ្លួនឯងមិនធ្លាប់ដឹងក៏ដោយ ដែលធ្វើឲ្យយើងមានអារម្មណ៍ថាភាពមិនគ្រប់លក្ខណ៍ដ៏អាក្រក់របស់យើងត្រូវបានលាតត្រដាងឲ្យគេឃើញ និងត្រូវបានយកឈ្នះទាំងស្រុង។ ទ្រង់ជំនុំជម្រះយើងដោយព្រោះការ

ប្រឆាំងនឹងទ្រង់ ហើយវាយផ្ចាលយើងដោយព្រោះការប្រមាថ និងការថ្កោលទោសទ្រង់ ព្រមទាំងធ្វើឲ្យយើងមានអារម្មណ៍ថា នៅក្នុងព្រះនេត្រទ្រង់ យើងគ្មានលក្ខណៈដែលសមនឹងការប្រោសលោះសូម្បីតែមួយ ដ្បិតយើងគឺជាសាតាំងដែលមានជីវិត។ សេចក្ដីសង្ឃឹមរបស់យើងត្រូវរលាយសាបសូន្យអស់ យើងលែងហ៊ានធ្វើការទាមទារដោយមិនសមហេតុផលពីទ្រង់ ឬក៏រក្សាការរៀបចំណាមួយចំពោះទ្រង់ទៀត ហើយសូម្បីតែក្ដីសុបិនរបស់យើងក៏រលាយបាត់ទៅក្នុងពេលមួយយប់ដែរ។ នេះហើយជាការពិតដែលគ្មាននរណាម្នាក់ក្នុងចំណោមយើងអាចស្រមៃគិតដល់ ហើយគ្មាននរណាម្នាក់ក្នុងចំណោមយើងអាចទទួលយកបានឡើយ។ នៅក្នុងខណៈពេលនេះយើងបាត់បង់លំនឹងខាងក្នុងរបស់យើង ហើយមិនដឹងថាត្រូវបន្តដំណើរនៅលើផ្លូវដែលនៅខាងមុខ ឬបន្តជំនឿរបស់យើងដោយរបៀបណាឡើយ។ វាហាក់ដូចជាសេចក្ដីជំនឿរបស់យើងបានត្រលប់ទៅជាផ្រុងការ៉េមួយ ហើយហាក់ដូចជាយើងមិនដែលជួបជាមួយព្រះអម្ចាស់យេស៊ូវ ឬក៏មិនធ្លាប់ស្គាល់ទ្រង់សោះ។ អ្វីៗគ្រប់យ៉ាងដែលនៅមុខភ្នែកយើង ធ្វើឲ្យយើងមានភាពអល់អែក និងរារែកមិនដាច់ស្រេច។ យើងមានការស្រងាកចិត្ត យើងខកចិត្ត ហើយនៅក្នុងជម្រៅចិត្តយើងមានកំហឹងនិងសេចក្ដីស្អប់ខ្ពើមដែលមិនអាចកែប្រែបាន។ យើងព្យាយាមបន្ធូរអារម្មណ៍ និងរកផ្លូវចេញ ហើយលើសពីនោះទៀត គឺបន្តរង់ចាំព្រះយេស៊ូវដ៏ជាព្រះអង្គសង្គ្រោះនៃយើង ដែលយើងអាចចាក់បង្ហូរដួងចិត្តរបស់យើងទៅកាន់ទ្រង់បាន។ ទោះបីជាមានពេលខ្លះ នៅពេលដែលយើងបង្ហាញខ្លួននៅខាងក្រៅថាយើងគឺជាមនុស្សពូកែ មិនក្រអឺតក្រទម និងបន្ទាបខ្លួនក៏ដោយ ក៏ក្នុងដួងចិត្តរបស់យើងបានទទួលរងនូវអារម្មណ៍បាត់បង់ម្យ៉ាងដែលយើងមិនធ្លាប់មានពីមុនមកដែរ។ ទោះបីជាពេលខ្លះ យើងហាក់ដូចស្ងប់ស្ងាត់ខុសពីធម្មតានៅផ្នែកខាងក្រៅក៏ដោយ ក៏ចិត្តគំនិតរបស់យើងកំពុងគ្រហឹមដោយទារុណកម្មដូចជាសមុទ្រដែលមានព្យុះ។ ការជំនុំជម្រះ និងការវាយផ្ចាលរបស់ទ្រង់ បានធ្វើឲ្យយើងបាត់បង់ក្ដីសង្ឃឹម និងក្ដីសុបិនទាំងអស់របស់យើង ដោយបញ្ចប់ក្ដីប៉ងប្រាថ្នាដ៏ខ្ពង់ខ្ពស់របស់យើង ហើយធ្វើឲ្យយើងមិនព្រមជឿថាទ្រង់គឺជាព្រះអង្គសង្គ្រោះរបស់យើង និង

មានសមត្ថភាពអាចជួយសង្គ្រោះយើងបាន។ ការជំនុំជម្រះ និងការវាយផ្ចាលរបស់ទ្រង់ ធ្វើឲ្យមានជ្រលងដ៏ជ្រៅមួយនៅចន្លោះយើង និងទ្រង់ ដែលគ្មាននរណាម្នាក់ហ៊ានឆ្លងកាត់ឡើយ។ ការជំនុំជម្រះ និងការវាយផ្ចាលរបស់ទ្រង់ គឺជាលើកដំបូងដែលយើងបានជួបនូវឧបសគ្គ និងភាពអាម៉ាស់ដ៏ធំធេងបែបនេះនៅក្នុងជីវិតរបស់យើង។ ការជំនុំជម្រះ និងការវាយផ្ចាលរបស់ទ្រង់ ពិតជាធ្វើឲ្យយើងកោតសរសើរពីព្រះកិត្តិនាមរបស់ព្រះជាម្ចាស់ និងការមិនអត់ឱនរបស់ទ្រង់ចំពោះកំហុសរបស់មនុស្ស ធៀបទៅនឹងអ្វីដែលយើងផ្អែកធ្វើជាមូលដ្ឋាន គឺមិនបរិសុទ្ធនោះឡើយ។ ការជំនុំជម្រះ និងការវាយផ្ចាលរបស់ទ្រង់ធ្វើឲ្យយើងដឹងជាលើកដំបូងថាយើងក្រអឺតក្រទម និងឆ្មើងឆ្មៃប៉ុនណា និងដឹងថាមនុស្សមិនស្មើនឹងព្រះជាម្ចាស់ ឬក៏មិនអាចប្រៀបនឹងព្រះជាម្ចាស់បានឡើយ។ ការជំនុំជម្រះ និងការវាយផ្ចាលរបស់ទ្រង់ ធ្វើឲ្យយើងលែងចង់រស់នៅក្នុងនិស្ស័យពុករលួយបែបនេះតទៅទៀត និងចង់ឲ្យខ្លួនយើងរួចផុតពីលក្ខណៈធម្មជាតិ និងសារជាតិបែបនេះក្នុងពេលឆាប់ៗតាមដែលអាចធ្វើទៅបាន ព្រមទាំងបញ្ឈប់ភាពកខ្វក់ និងភាពគួរឲ្យស្អប់ខ្ពើមចំពោះទ្រង់។ ការជំនុំជម្រះ និងការវាយផ្ចាលរបស់ទ្រង់ ធ្វើឲ្យយើងរីករាយក្នុងការស្ដាប់បង្គាប់តាមព្រះបន្ទូលរបស់ទ្រង់ លែងបះបោរទាស់នឹងការរៀបចំ និងការចាត់ចែងរបស់ទ្រង់តទៅទៀត។ ការជំនុំជម្រះ និងការវាយផ្ចាលរបស់ទ្រង់ ប្រទានឲ្យយើងនូវបំណងប្រាថ្នាដែលចង់រស់រានមានជីវិតនិងធ្វើឲ្យយើងរីករាយក្នុងការទទួលទ្រង់ជាព្រះអង្គសង្គ្រោះរបស់យើង...។ យើងបានបោះជំហានចេញពីកិច្ចការនៃការយកឈ្នះពីស្ថាននរក និងពីជ្រលងស្រមោលនៃសេចក្តីស្លាប់...។ ព្រះដ៏មានគ្រប់ព្រះចេស្ដាបានទទួលយើងដែលជាមនុស្សមួយក្រុមនេះ! ទ្រង់បានយកឈ្នះលើសាតាំង និងបានយកឈ្នះលើខ្មាំងសត្រូវរបស់ទ្រង់ជាច្រើន!

យើងគ្រាន់តែជាក្រុមមនុស្សធម្មតា ដែលមាននិស្ស័យពុករលួយបែបសាតាំងប៉ុណ្ណោះ ជាអ្នកដែលព្រះជាម្ចាស់បានតម្រូវទុកតាំងពីមុនពេលមានយុគសម័យមកម្ល៉េះ និងជាអ្នកខ្វះខាតដែលព្រះជាម្ចាស់បានលើកចេញពីរណ្ដៅលាមកមក។ យើងធ្លាប់បានបដិសេធ និងថ្កោលទោសព្រះជាម្ចាស់ ប៉ុន្តែយើងមិនត្រូវបានយកឈ្នះដោយ

ទ្រង់ឡើយ។ យើងបានទទួលជីវិតពីព្រះជាម្ចាស់ ជាផ្លូវទៅកាន់ជីវិតអស់កល្បជានិច្ច។ មិនថាយើងនៅកន្លែងណានៅលើផែនដីនេះ ហើយមិនថាយើងរងទ្រាំការបៀតបៀន និងទុក្ខវេទនាយ៉ាងណាក៏ដោយ ក៏យើងមិនអាចដាច់ចេញពីសេចក្ដីសង្គ្រោះនៃព្រះដ៏មានគ្រប់ព្រះចេស្ដាបានដែរ។ ដ្បិតទ្រង់គឺជាព្រះអាទិកររបស់យើង និងជាសេចក្ដីប្រោសលោះរបស់យើងតែមួយគត់!

សេចក្ដីស្រលាញ់របស់ព្រះជាម្ចាស់សន្ធឹងទៅមុខដូចជាទឹកដែលហូរចេញពីប្រភពទឹក ហើយសេចក្ដីស្រលាញ់នេះបានប្រទានមកដល់អ្នក ដល់ខ្ញុំ និងអ្នកដទៃទៀត ព្រមទាំងអស់អ្នកដែលស្វែងរកសេចក្ដីពិត និងរងចាំការលេចមករបស់ព្រះជាម្ចាស់ពិតប្រាកដ។

ដូចជាព្រះអាទិត្យ និងព្រះចន្ទដើរតាមព្រះអាទិត្យឆ្លាស់វេនគ្នាឥតឈប់ឈរជាយ៉ាងណា កិច្ចការរបស់ព្រះជាម្ចាស់ក៏មិនដែលឈប់ឡើយ ហើយនឹងត្រូវអនុវត្តលើអ្នក លើខ្ញុំ លើអ្នកដទៃទៀត និងលើអស់អ្នកដែលដើរតាមស្នាមព្រះបាទារបស់ព្រះជាម្ចាស់ ព្រមទាំងទទួលយកការជំនុំជម្រះ និងការវាយផ្ចាលរបស់ទ្រង់។

ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០

ពួកជំនុំនៃព្រះដ៏មានគ្រប់ព្រះចេស្តា

# គេហទំព័រដំណឹងល្អ

https://km.kingdomsalvation.org

គេហទំព័ររបស់ពួកយើង

ការទាញយកតាមកម្មវិធី App

**YouTube:** https://l.kingdomsalvation.org/km/video

**Facebook:** https://l.kingdomsalvation.org/km/facebook

**Email:** contact.km@kingdomsalvation.org